

សៀវភៅមគ្គុទេសន៍ការសិក្សា

# គោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ

## សម្រាប់សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ

# សៀវភៅមគ្គុទេសក៍ការសិក្សាគោលលទ្ធិ
# និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ
# សម្រាប់សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ

បោះពុម្ពដោយ
សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ
ទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍

សូមថ្លែងអំណរគុណចំពោះយោបល់ និងការកែលម្អ ។ សូមផ្ញើទៅកាន់ ៖
Seminaries and Institutes of Religion Curriculum Services
៥០ E North Temple Street
Salt Lake City, UT ៨៤១៥០–០០០៨ USA
អ៊ីម៉ែល ៖ ces–manuals@ldschurch.org

សូមសរសេរឈ្មោះពេញ អាសយដ្ឋានរបស់ វួដ និងស្តេករបស់អ្នក ។

សូមកុំភ្លេចសរសេរចំណងជើងសៀវភៅសិក្សានោះ ។ បន្ទាប់មក សូមផ្តល់មតិយោបល់របស់អ្នក ។
© ២០១៣, ២០១៧ by Intellectual Reserve, Inc.
All rights reserved.
បោះពុម្ពនៅសហរដ្ឋអាមេរិក
កំណែថ្មីទី ២ ៨/១៧

អនុមតិជាភាសាអង់គ្លេស ៖ ៨/១២
អនុមតិការបកប្រែ ៖ ៨/១២
ការបកប្រែនៃ *Doctrine and Covenants and Church History Study Guide for Home–Study Seminary Students*
Cambodian
10589 258

# មាតិកា


សេចក្ដីណែនាំស្ដីពីកម្មវិធីថ្នាក់សិក្ខាសាលាដែលសិក្សានៅតាមផ្ទះ . . . ix

តារាងការអានគោលលទ្ធិ និងសេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ . . . xi

សូមស្វាគមន៍មកកាន់គោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ . . . xvi

កាលប្រវត្តិនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ . . . xviii

សេចក្ដីណែនាំស្ដីពីចំណេះចំណានខគម្ពីរ . . . xix

វគ្គចំណេះចំណានខគម្ពីរទាំង ១០០ . . . xx

សេចក្ដីណែនាំអំពីគោលលទ្ធិគ្រឹះ . . . xxi

គោលលទ្ធិគ្រឹះ . . . xxii

ផែនការនៃសេចក្ដីសង្គ្រោះ . . . ១

ការក្បត់សាសនាដ៏ធំ . . . ៥

គោលលទ្ធិ និង សេចក្ដីសញ្ញា ១ . . . ១០

ការសិក្សាព្រះគម្ពីរ . . . ១៥

យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១–២០ . . . ២០

យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២១–២៦ . . . ២៤

យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៧–៥៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ២ . . . ២៨

យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៥–៦៥ . . . ៣៣

គោលលទ្ធិ និង សេចក្ដីសញ្ញា ៣; ១០ . . . ៣៧

គោលលទ្ធិ និង សេចក្ដីសញ្ញា ៤ . . . ៤២

គោលលទ្ធិ និង សេចក្ដីសញ្ញា ៥ . . . ៤៦

យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៦–៦៧; គោលលទ្ធិ និង សេចក្ដីសញ្ញា ៦–៧ . . . ៤៩

គោលលទ្ធិ និង សេចក្ដីសញ្ញា ៨–៩ . . . ៥៣

គោលលទ្ធិ និង សេចក្ដីសញ្ញា ១១–១២ . . . ៥៧

យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៨–៧៥ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣ . . . ៦១

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤–១៦ . . . ៦៥

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧ . . . ៦៩

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨ . . . ៧៤

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១–២២ . . . ៨១

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៣–៤១ . . . ៨៥

គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១–៣៦ . . . ៨៩

គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៨–៦៧ . . . ៩៣

គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧, ៦៨–៨៤ . . . ៩៨

គោលលទ្ធិ និង សេចក្ដីសញ្ញា ២១–២៣ . . . ១០៣

គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤–២៦ . . . ១០៨

គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧ . . . . . . . . . . ១១៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨ . . . . . . . . . . ១១៦
គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១–៣០ . . . . . . . . . . ១២០
គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣១–៥០ . . . . . . . . . . ១២៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០–៣២ . . . . . . . . . . ១២៨
គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣–៣៤ . . . . . . . . . . ១៣៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥ . . . . . . . . . . ១៣៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦–៣៧ . . . . . . . . . . ១៤១
គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨ . . . . . . . . . . ១៤៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩–៤០ . . . . . . . . . . ១៤៩
នៅរដ្ឋ អូហៃអូ . . . . . . . . . . ១៥៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១ . . . . . . . . . . ១៥៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១–២៩ . . . . . . . . . . ១៦១
គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣០–៩៣ . . . . . . . . . . ១៦៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣–៤៤ . . . . . . . . . . ១៦៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១–១៥ . . . . . . . . . . ១៧៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១៦–៧៥ . . . . . . . . . . ១៧៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦ . . . . . . . . . . ១៨៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧–៤៨ . . . . . . . . . . ១៨៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩ . . . . . . . . . . ១៩១
គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០ . . . . . . . . . . ១៩៤
គោលលទ្ធិ និង សេចក្ដីសញ្ញា ៥១–៥២ . . . . . . . . . . ១៩៨
គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣–៥៦ . . . . . . . . . . ២០១
កន្លែងកណ្ដាលនៃក្រុងស៊ីយ៉ូន . . . . . . . . . . ២០៦
គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧ . . . . . . . . . . ២១១
គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨ . . . . . . . . . . ២១៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩ . . . . . . . . . . ២១៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦២ . . . . . . . . . . ២២៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣ . . . . . . . . . . ២២៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១–១៩ . . . . . . . . . . ២៣១
មេរៀនទី ១៤ ៖ ថ្ងៃទី ៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០–៤៣ . . . . . . . . . . ២៣៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥–៦៦ . . . . . . . . . . ២៣៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧ . . . . . . . . . . ២៤៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨ . . . . . . . . . . ២៤៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩–៧១ . . . . . . . . . . ២៥១

គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២–៧៤ . . . ២៥៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥ . . . ២៦០
គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១–៤៩ . . . ២៦៤
គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០–៨០ . . . ២៦៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–១១៩; ៧៧ . . . ២៧៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨–៨០ . . . ២៧៨
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១ . . . ២៨២
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២–៨៣ . . . ២៨៦
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១–៤២ . . . ២៩០
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៣–១២០ . . . ២៩៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥–៨៦ . . . ២៩៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧ . . . ៣០៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១–៤០ . . . ៣០៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤១–៦៩ . . . ៣១២
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧០–១៤១ . . . ៣១៦
គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩ . . . ៣២១
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០–៩២ . . . ៣២៦
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣ . . . ៣៣១
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤–៩៦ . . . ៣៣៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧ . . . ៣៤១
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨ . . . ៣៤៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩–១០០ . . . ៣៥០
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១–១៦ . . . ៣៥៤
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១៧–៤២ . . . ៣៥៨
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–១០១; ១០២ . . . ៣៦២
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣ . . . ៣៦៦
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤ . . . ៣៧០
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥ . . . ៣៧៤
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦; ១០៧:១–២០ . . . ៣៧៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២១–៣៨ . . . ៣៨៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩–១០០; ១០៨ . . . ៣៩០
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧ . . . ៣៩៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩ . . . ៣៩៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០ . . . ៤០៦
គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១ . . . ៤១១

គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤១៥
សាសនាចក្រប្ដូរទៅរដ្ឋមិសសួរីភាគខាងជើង . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤១៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣–១៤ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤២៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥–១៦ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤២៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧–២០ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៣៤
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១–១០; ១២២ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៣៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១១–៣៣. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៤៤
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤–៤៦ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៤៨
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣; ការស្ថាបនាទីក្រុងណៅវូ . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៥២
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១–៨៣ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៥៦
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤–១៤៥; ១២៥–២៦ . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៦០
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧; ១២៨:១–១១ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៦៥
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១២–២៥ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៦៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩; ១៣០:១–១១, ២២–២៣ . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៧៤
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១២–២១ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៧៩
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៨៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១–៣៣ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៨៧
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១–៣៥ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៩២
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៣៦–៧៤ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤៩៦
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥០០
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥០៤
ការស្នងតំណែងនៅក្នុងគណៈប្រធានទីមួយ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥០៩
មេរៀនទី ៣០ ៖ ថ្ងៃទី ២ ការចាកចេញពីទីក្រុង ណៅវូ ការធ្វើដំណើរឆ្លងកាត់រដ្ឋ
អៃអូវ៉ា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១–១៨. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥១៦
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១៩–៤២ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥២២
ក្រុមអ្នកត្រួតត្រាយរទេះអូស ឆ្នាំ ១៨៥៦–៦០ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥២៦
សង្គ្រាមនៅរដ្ឋ យូថាហ៍ និង ការសម្លាប់រង្គាលនៅភ្នំម៉េដូ. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៣២
ការលេចចេញមកនៃព្រះគម្ពីរមុក្ដាដ៏មានតម្លៃមហិមា . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៣៨
សេចក្ដីប្រកាសជាផ្លូវការទី ១និង ការអភិវឌ្ឍកិច្ចការព្រះវិហារបរិសុទ្ធជាបន្តបន្ទាប់ . . . . . . . . . . . . . . . . . . . . ៥៤៣
គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥៤៨
កម្មវិធី និង អង្គការសាសនាចក្រ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៥២
សេចក្ដីប្រកាសជាផ្លូវការទី ២ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៥៧
ការពន្លឿនកិច្ចការនៃសេចក្ដីសង្គ្រោះ. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៦២
ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៦៧

# សេចក្ដីណែនាំស្ដីពីកម្មវិធីថ្នាក់សិក្ខាសាលាដែលសិក្សានៅតាមផ្ទះ

កម្មវិធីថ្នាក់សិក្ខាសាលាដែលសិក្សានៅតាមផ្ទះ ត្រូវបានរៀបរៀងឡើង ដើម្បីជួយអ្នកឲ្យពង្រឹងការយល់ដឹងរបស់អ្នកអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយអនុវត្តការបង្រៀននៃដំណឹងល្អនៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក តាមរយៈការសិក្សាព្រះគម្ពីរនានា ។ សម្រាប់ការសិក្សារបស់អ្នកនៅក្នុងឆ្នាំសិក្សានេះ ដំបូង អ្នកនឹងបញ្ចប់កិច្ចការអាន ចេញពីព្រះគម្ពីរនៃវគ្គសិក្សានេះ—គឺព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា —ហើយបន្ទាប់មក អ្នកនឹងបញ្ចប់មេរៀននីមួយៗ ។ អ្នកនឹងជួបជាមួយគ្រូថ្នាក់សិក្ខាសាលាក្នុងមួយសប្ដាហ៍ម្ដង ដើម្បីដាក់ជូននូវកិច្ចការ និង ការចូលរួមរបស់អ្នក នៅក្នុងមេរៀនប្រចាំសប្ដាហ៍ ។



ថ្នាក់សិក្ខាសាលា គឺជាកម្មវិធីអប់រំខាងសាសនាប្រចាំថ្ងៃ ។ ការសិក្សាព្រះគម្ពីរទាំងឡាយរបស់អ្នកប្រកបដោយការអធិស្ឋាន គប្បីជាទម្លាប់មួយជាប្រចាំថ្ងៃ ។ អ្នកនឹងត្រូវធ្វើកិច្ចការថ្នាក់សិក្ខាសាលារបស់អ្នករាល់ថ្ងៃទៅរៀន ទោះបីអ្នកមិនចូលរួមនៅថ្នាក់សិក្ខាសាលារាល់ថ្ងៃក៏ដោយ ។ មាន ៣២ មេរៀន ដែលត្រូវបញ្ចប់នៅអំឡុងវគ្គសិក្សានេះ ។ តារាងការអានបង្ហាញពីអ្វីដែលអ្នកគប្បីសិក្សាសម្រាប់មេរៀននីមួយៗ ។ គ្រូរបស់អ្នកនឹងជួយអ្នកឲ្យយល់ថាពេលណាដែលមេរៀននីមួយៗត្រូវដល់ពេលប្រមូល ។ ចំណាយពេលប្រហែល ៣០ នាទី ដើម្បីបញ្ចប់មេរៀននីមួយៗនៃមេរៀនទាំងឡាយនៅក្នុងសៀវភៅមគ្គុទេសក៍ការសិក្សានេះ បន្ថែមលើការសិក្សាព្រះគម្ពីរប្រចាំថ្ងៃរបស់អ្នក ។

ក្រៅពីកំណត់ហេតុផ្ទាល់ខ្លួនរបស់អ្នក អ្នកគប្បីមានសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរពីរ ( ឬ សៀវភៅសរសេរពីរក្បាល ) ដែលអ្នកនឹងសរសេរកិច្ចការទាំងឡាយចេញពីសកម្មភាពក្នុងសៀវភៅមគ្គុទេសក៍ការសិក្សា ។ រាល់សប្ដាហ៍ដែលអ្នកជួបជាមួយគ្រូរបស់អ្នក អ្នកគប្បីប្រគល់សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ដែលមាននូវកិច្ចការទាំងឡាយដែលបានបញ្ចប់ ចេញពីសកម្មភាពក្នុងសៀវភៅមគ្គុទេសក៍ការសិក្សា ដែលអ្នកបានបញ្ចប់សម្រាប់សប្ដាហ៍នោះ ។ គ្រូរបស់អ្នកនឹងអាន ហើយឆ្លើយតបចំពោះកិច្ចការទាំងនោះ ហើយប្រគល់សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរដល់អ្នកវិញ នៅសប្ដាហ៍បន្ទាប់ ។ អ្នកក៏អាចសរសេរចម្លើយរបស់អ្នកនៅលើក្រដាសសៀវភៅដែលអាចដកហូតចេញចូលបាន ហើយប្រគល់ក្រដាសកិច្ចការទាំងឡាយដែលអ្នកបានធ្វើនៅសប្ដាហ៍នោះ ។
ហើយនៅពេលដែលគ្រូអ្នកប្រគល់ក្រដាសទាំងនោះត្រឡប់មកវិញ នោះអ្នកអាចដាក់វាចូលក្នុងសៀវភៅវិញ ។

## ការប្រើប្រាស់សៀវភៅសិក្សានេះ នៅក្នុងកម្មវិធីថ្នាក់សិក្ខាសាលាប្រចាំថ្ងៃ

សៀវភៅសិក្សានេះអាចត្រូវបានប្រើប្រាស់ដោយគ្រូ និង សិស្ស នៅក្នុងកម្មវិធីថ្នាក់សិក្ខាសាលាប្រចាំថ្ងៃ ដើម្បីធ្វើឲ្យមេរៀនកាន់តែប្រសើរឡើង ឬ សម្រាប់ធ្វើកិច្ចការសងវិញ ។ ទោះយ៉ាងណា គឺមិនមានបំណងប្រគល់ឲ្យសិស្សថ្នាក់សិក្ខាសាលាប្រចាំថ្ងៃទាំងអស់គ្នានោះទេ ។ បើសិស្សម្នាក់ត្រូវការធ្វើមេរៀនសងមួយដើម្បីបានពិន្ទុ នោះគ្រូអាចដាក់កិច្ចការឲ្យគាត់បញ្ចប់មេរៀនដែលសិក្សានៅតាមផ្ទះ ដែលត្រូវគ្នានឹងមេរៀនដែលគាត់មិនបានមករៀននោះ ។

## ការប្រើប្រាស់សៀវភៅមគ្គុទេសន៍ការសិក្សាសម្រាប់សិស្សដែលសិក្សានៅតាមផ្ទះ

### សេចក្ដីណែនាំស្ដីពីអត្ថបទព្រះគម្ពីរ

សេចក្ដីណែនាំផ្ដល់នូវព័ត៌មានសាវតាមួយចំនួន ព្រមទាំងសេចក្ដីសង្ខេបអត្ថបទគម្ពីរសម្រាប់មេរៀននីមួយៗ ។

### ក្រុមខគម្ពីរ និង សេចក្ដីសង្ខេបមាតិការឿង

ក្រុមខគម្ពីរ ឆ្លុះបង្ហាញពីការផ្អាក នៅកន្លែងដែលមានការផ្លាស់ប្ដូរសកម្មភាព ឬ ប្រធានបទ ។ ក្រុមខគម្ពីរនីមួយៗមានសេចក្ដីសង្ខេបពីព្រឹត្តិការណ៍ ឬ ការបង្រៀននៅក្នុងខគម្ពីរទាំងនោះ ។

## គោលលទ្ធិ និង គោលការណ៍ទាំងឡាយ

ពេលដែលគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អលេចចេញមកពីអត្ថបទគម្ពីរ នោះគោលលទ្ធិ និង គោលការណ៍ទាំងនោះ ត្រូវបានបោះពុម្ពជាអក្សរដិត នៅក្នុងមេរៀន ដើម្បីជួយអ្នកឃើញវាច្បាស់ ។

## ជំនួយការសិក្សា

ជំនួយការសិក្សាផ្ដល់នូវការយល់ដឹង និង ពន្យល់ពីការអនុវត្ត ដែលអាចពង្រីកដល់ការសិក្សា និង ការយល់ដឹងរបស់អ្នកអំពីបទគម្ពីរ ។

## ចំណេះចំណានខគម្ពីរ

ចំណេះចំណានខគម្ពីរនីមួយៗក្នុងចំណោមចំណេះចំណានខគម្ពីរទាំង ២៥ ដែលមានក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ត្រូវបានប្រើប្រាស់ដោយឡែកៗពីគ្នា ដែលចំណេះចំណានខគម្ពីរទាំងនោះមាននៅក្នុងមេរៀន ដើម្បីជួយអ្នកធ្វើឲ្យចំណេះចំណានរបស់អ្នកកាន់តែស៊ីជម្រៅ ។

## ការកត់ត្រាចម្លើយក្នុងសៀវភៅសិក្សា

ពេលខ្លះ អ្នកនឹងត្រូវបានស្នើឲ្យសរសេរចម្លើយនៅក្នុងសៀវភៅសិក្សា នៅបន្ទាត់ចន្លោះ ឬ នៅក្នុងតារាងមួយ ។

## កិច្ចការក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ

កិច្ចការក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ គឺត្រូវបានសរសេរ និង ប្រគល់ទៅគ្រូរបស់អ្នករាល់សប្ដាហ៍ ដើម្បីបានមតិកែតម្រូវមកវិញ ។ ការផ្ដល់នូវគំនិតយ៉ាងយកចិត្តទុកដាក់ដល់ចម្លើយរបស់អ្នក នឹងជួយអ្នកទទួលបានបទពិសោធន៍ដ៏មានអត្ថន័យពេលអ្នករៀន និង អនុវត្តសេចក្ដីពិតទាំងឡាយចេញពីបទគម្ពីរ ។

# តារាងការអានគោលលទ្ធិ និងសេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ

| លេខមេរៀន | ជំពូកដែលត្រូវចាត់ឲ្យខ្ញុំអានសប្ដាហ៍នេះ | ថ្ងៃដែលខ្ញុំអានព្រះគម្ពីរ | | | | | | |
|---|---|---|---|---|---|---|---|---|
| ១ | បុព្វកថាព្រះគម្ពីរ គោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ<br>គ. និង ស.១ | អា | ច | អ | ព | ព្រ | សុ | ស |
| ២ | យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១–៦៥<br>គ. និង ស.២ | អា | ច | អ | ព | ព្រ | សុ | ស |
| ៣ | គ. និង ស.៣<br>១០<br>៤<br>៥<br>៦<br>៧<br>យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៦–៦៧ | អា | ច | អ | ព | ព្រ | សុ | ស |
| ៤ | គ. និង ស. ៨<br>៩<br>១១<br>១២<br>១៣<br>១៤<br>១៥<br>១៦ | អា | ច | អ | ព | ព្រ | សុ | ស |
| ៥ | គ. និង ស. ១៧<br>១៨<br>១៩ | អា | ច | អ | ព | ព្រ | សុ | ស |
| ៦ | គ. និង ស. ២០<br>២១<br>២២<br>២៣ | អា | ច | អ | ព | ព្រ | សុ | ស |
| ៧ | គ. និង ស.២៤<br>២៤<br>២៦<br>២៧<br>២៨<br>២៩:១–២៩ | អា | ច | អ | ព | ព្រ | សុ | ស |

| លេខមេរៀន | ជំពូកដែលត្រូវចាត់ឲ្យខ្ញុំអានសប្ដាហ៍នេះ | ថ្ងៃដែលខ្ញុំអានព្រះគម្ពីរ | | | | | | |
|---|---|---|---|---|---|---|---|---|
| ៨ | គ និង ស ២៩:៣០–៥០<br>៣០<br>៣១<br>៣២<br>៣៣<br>៣៤<br>៣៥ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ៩ | គ. និង ស. ៣៦<br>៣៧<br>៣៨<br>៣៩<br>៤០ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ១០ | គ. និង ស. ៤១<br>៤២<br>៤៣<br>៤៤ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ១១ | គ. និង ស. ៤៥<br>៤៦<br>៤៧<br>៤៨ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ១២ | គ. និង ស. ៤៩<br>៥០<br>៥១<br>៥២<br>៥៣<br>៥៤<br>៥៥<br>៥៦ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ១៣ | គ. និង ស. ៥៧<br>៥៨<br>៥៩ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ១៤ | គ. និង ស. ៦០<br>៦១<br>៦២<br>៦៣<br>៦៤ | អា | ច | អ | ពុ | ព្រ | សុ | ស |

| លេខមេរៀន | ជំពូកដែលត្រូវចាត់ឲ្យខ្ញុំអានសប្ដាហ៍នេះ | ថ្ងៃដែលខ្ញុំអានព្រះគម្ពីរ | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៥ | គ. និង ស. ៦៥<br>៦៦<br>៦៧<br>៦៨<br>៦៩<br>៧០<br>៧១ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ១៦ | គ. និង ស. ៧២<br>៧៣<br>៧៤<br>៧៥<br>៧៦:១–៨០ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ១៧ | គ. និង ស. ៧៦:៨១–១១៩<br>៧៧<br>៧៨<br>៧៩<br>៨០<br>៨១<br>៨២<br>៨៣ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ១៨ | គ. និង ស. ៨៤<br>៨៥<br>៨៦<br>៨៧ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ១៩ | គ. និង ស. ៨៨<br>៨៩ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ២០ | គ. និង ស. ៩០<br>៩១<br>៩២<br>៩៣<br>៩៤<br>៩៥<br>៩៦<br>៩៧ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ២១ | គ. និង ស. ៩៨<br>៩៩<br>១០០<br>១០១:១–៤២ | អា | ច | អ | ពុ | ព្រ | សុ | ស |

| លេខមេរៀន | ជំពូកដែលត្រូវចាត់ឲ្យខ្ញុំអានសប្ដាហ៍នេះ | ថ្ងៃដែលខ្ញុំអានព្រះគម្ពីរ | | | | | | |
|---|---|---|---|---|---|---|---|---|
| ២២ | គ. និង ស. ១០១:៤៣–១០១<br>១០២<br>១០៣<br>១០៤<br>១០៥ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ២៣ | គ. និង ស. ១០៦<br>១០៧<br>១០៨<br>១៣៧ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ២៤ | គ. និង ស. ១០៩<br>១១០<br>១១១<br>១១២ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ២៥ | គ. និង ស. ១១៣<br>១១៤<br>១១៥<br>១១៦<br>១១៧<br>១១៨<br>១១៩<br>១២០ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ២៦ | គ. និង ស. ១២១<br>១២២<br>១២៣ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ២៧ | គ. និង ស. ១២៤<br>១២៥<br>១២៦<br>១២៧<br>១២៨ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ២៨ | គ. និង ស. ១២៩<br>១៣០<br>១៣១<br>១៣២ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ២៩ | គ. និង ស. ១៣៣<br>១៣៤<br>១៣៥ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ៣០ | គ. និង ស.១៣៦ | អា | ច | អ | ពុ | ព្រ | សុ | ស |

| លេខមេរៀន | ជំពូកដែលត្រូវចាត់ឲ្យខ្ញុំអានសប្ដាហ៍នេះ | ថ្ងៃដែលខ្ញុំអានព្រះគម្ពីរ | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣១ | គ. និង ស.១៣៨<br>សេចក្ដីប្រកាសជាផ្លូវការទី ១<br>បុព្វកថានៃព្រះគម្ពីរ មុក្ខារដ៏មានតម្លៃមហិមា<br>មាត្រានៃសេចក្ដីជំនឿ | អា | ច | អ | ពុ | ព្រ | សុ | ស |
| ៣២ | សេចក្ដីប្រកាសជាផ្លូវការទី ២<br>« ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » | អា | ច | អ | ពុ | ព្រ | សុ | ស |

# សូមស្វាគមន៍មកកាន់គោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ

## តើគោលលទ្ធិ និងសេចក្ដីសញ្ញាគឺជាអ្វី ?

គោលលទ្ធិ និងសេចក្តីសញ្ញា គឺជាគម្ពីរ ហើយមាននូវការប្រមូលផ្តុំនៃវិវរណៈរបស់ព្រះ និងសេចក្តីប្រកាសដ៏បំផុសគំនិតទាំងឡាយ ដែលផ្តល់នូវការណែនាំដល់អ្នកដឹកនាំសាសនាចក្រ សមាជិកសាសនាចក្រ និងប្រជាជនទាំងអស់នៅលើផែនដីក្នុងជំនាន់របស់យើង ។ វាគឺជាវិវរណៈសម័យទំនើប ហើយឈរទន្ទឹមគ្នាជាមួយព្រះគម្ពីរប៊ីប ព្រះគម្ពីរមរមន និងមុក្តាដ៏មានតម្លៃមហិមា ក្នុងនាមជាគម្ពីរជាបទដ្ឋានមួយនៃគម្ពីរជាបទដ្ឋានទាំងបួនរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។



ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានពន្យល់អំពីតម្លៃនៃគោលលទ្ធិ និងសេចក្តីសញ្ញាចំពោះយើង ៖ « គោលលទ្ធិ និងសេចក្ដីសញ្ញានេះ មាននូវព្រះបន្ទូលនៃព្រះដល់អស់អ្នកទាំងឡាយណា ដែលរស់នៅក្នុងពេលឥឡូវនេះ » ។ វាគឺជាព្រះគម្ពីររបស់យើង ។ វាជារបស់ផងនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ព្យាការី [ យ៉ូសែប ស្ម៊ីធ ] បានមានប្រសាសន៍ថាវាមានតម្លៃថ្លៃជាងមាស ដែលយើងគប្បីរក្សាទុកច្រើនជាងរបស់ទ្រព្យនានានៃលោកិយនេះទាំងមូល » (*Doctrines of Salvation* comp. Bruce R. McConkie 3 vols. [១៩៥៤–៥៦] ៣:១៩៨ ) ។

## ហេតុអ្វីក៏ការសិក្សាគោលលទ្ធិ និងសេចក្តីសញ្ញា និងប្រវត្តិសាស្ត្រនៃសាសនាចក្រសំខាន់ចំពោះខ្ញុំ ?

ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទផ្ទាល់ បានប្រទាននូវការទទួលខុសត្រូវមួយដល់អ្នកទាំងឡាយណាដែលទទួលបានគោលលទ្ធិ និងសេចក្តីសញ្ញា ៖

« ចូរពិចារណាមើលព្រះបញ្ញត្តិទាំងនេះចុះ ដ្បិតព្រះបញ្ញត្តិទាំងនេះពិត ហើយស្មោះត្រង់ ហើយសេចក្តីព្យាករណ៍ និងសេចក្តីសន្យា ដែលមានទាំងប៉ុន្មាននៅក្នុងនោះ នោះនឹងបានសម្រេចទាំងអស់ ។

« អ្វីដែលយើងជាព្រះអម្ចាស់បានមានបន្ទូល នោះយើងបានមានបន្ទូលហើយ ហើយយើងពុំកែដោះសារខ្លួនឡើយ ហើយទោះជាផ្ទៃមេឃហើយផែនដី នឹងកន្លងបាត់ទៅក៏ដោយ គង់តែពាក្យរបស់យើង នឹងមិនកន្លងបាត់ដែរ ប៉ុន្តែពាក្យទាំងអស់នឹងបានសម្រេច ទោះជាដោយសំឡេងរបស់យើងផ្ទាល់ ឬក៏ដោយសំឡេងនៃពួកអ្នកបម្រើរបស់យើងក្តី គឺដូចតែគ្នា » (គ និង ស ១:៣៧–៣៨) ។

ប្រធាន ហ្គរដុន ប៊ី. ហ៊ិងគ្លី បានពន្យល់ថា



« ព្រះគម្ពីរគោលលទ្ធិ និងសេចក្តីសញ្ញា គឺពិសេសនៅក្នុងចំណោមព្រះគម្ពីរទាំងឡាយរបស់យើង ។ វាគឺជារដ្ឋធម្មនុញ្ញរបស់សាសនាចក្រ។ ខណៈដែលគោលលទ្ធិ និងសេចក្តីសញ្ញាដាក់បញ្ចូលនូវការសរសេរ និងសេចក្តីថ្លែងការអំពីច្បាប់ដើមផ្សេងៗក្តី ក៏វាជាគម្ពីរនៃវិវរណៈដែលបានប្រទានដល់ព្យាការីដ៏សំខាន់មួយនៃគ្រាកាន់កាប់ត្រួតត្រានេះដែរ ។

« វិវរណៈទាំងនេះចាប់ផ្តើមជាមួយនឹងការប្រកាសដ៏ខ្ទរខ្ទាំងអំពីគោលបំណងរបស់ព្រះនៅជុំវិញនៃការស្តារឡើងវិញនៃកិច្ចការថ្ងៃចុងក្រោយដ៏មហិមារបស់ទ្រង់ ៖

« ‹ ចូរប្រុងស្តាប់ចុះ ឱប្រជារាស្ត្រនៃសាសនាចក្រយើងអើយ សំឡេងនៃព្រះដែលគង់នៅលើ ហើយដែលមានព្រះនេត្រទតមកលើមនុស្សទាំងអស់ ទ្រង់មានព្រះបន្ទូលថា ដូច្នោះ ប្រាកដមែន យើងប្រាប់ជាប្រាកដថា ៖ ចូរប្រុងស្តាប់ចុះ ឱប្រជាជាតិទាំងប៉ុន្មានដែលនៅឆ្ងាយអើយ និងអ្នករាល់គ្នាដែលនៅលើកោះក្នុងសមុទ្រអើយ ចូរស្តាប់ព្រមគ្នាចុះ ។

« ‹ ដ្បិតសំឡេងនៃព្រះអម្ចាស់ប្រាកដជាប្រាប់ដល់មនុស្សទាំងអស់ មែនហើយគ្មាននរណានឹងគេចបានឡើយ ហើយគ្មានភ្នែកណាដែលនឹងមិនបានឃើញ ឬគ្មានត្រចៀកណាដែលនឹងមិនបានឮ ឬគ្មានដួងចិត្តណាដែលនឹងមិនធ្លុះបានឡើយ › ។ ( គ និង ស ១:១–២ ) ។

« ចេញមកពីការចាប់ផ្ដើមដ៏សំខាន់ នោះភាពទូលំទូលាយខាងគោលលទ្ធិដ៏អស្ចារ្យបើកបង្ហាញឡើង ដែលកើតចេញមកពីគ្រឹះនៃសេចក្ដីពិតដ៏អស់កល្បជានិច្ច ។ រឿងមួយចំនួនគឺជាវិវរណៈ ដែលព្រះអម្ចាស់បានបង្គាប់ដល់ព្យាការីរបស់ទ្រង់ដោយផ្ទាល់ ។ នេះគឺជាភាសាមួយចំនួនរបស់យ៉ូសែប ស្ម៊ីធ សរសេរ ឬនិយាយ នៅពេលលោកត្រូវបានសណ្ឋិតដោយព្រះវិញ្ញាណបរិសុទ្ធ ។ ក៏មានបញ្ចូលនូវព្រឹត្តការណ៍និទានកថារបស់លោក ដែលបានកើតឡើងនៅក្នុងស្ថានភាពផ្សេងៗផងដែរ ។ អ្វីៗទាំងអស់ត្រូវបានប្រមូលផ្ដុំគ្នា ដែលវាបង្កើតបានជាខ្នាតដ៏ត្រឹមត្រូវចំពោះគោលលទ្ធិ និងការអនុវត្តទាំងឡាយក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។. . .

« បញ្ហាផ្សេងៗដែលគម្ពីរមាន គឺអស្ចារ្យណាស់ ។ វាមានរួមបញ្ចូលទាំងគោលការណ៍ និងទម្រង់ការទាំងឡាយអំពីការគ្រប់គ្រងសាសនាចក្រ ។ ច្បាប់សុខភាពដ៏ពិសេស និងអស្ចារ្យ មាននូវការសន្យាជាច្រើនទាំងខាងរូបកាយ និងខាងវិញ្ញាណ ។ សេចក្ដីសញ្ញានៃបព្វជិតភាពដ៏អស់កល្បជានិច្ច ត្រូវបានរៀបរាប់នៅក្នុងលក្ខណៈមួយដែលរកមិនឃើញនៅកន្លែងផ្សេងឡើយក្នុងព្រះគម្ពីរ ។ ឯកសិទ្ធិ និងពរជ័យទាំងឡាយ–ព្រមទាំងព្រំដែន និងឱកាសទាំងឡាយ–នៃកម្រិតសិរីល្អទាំងបី ត្រូវបានប្រកាស ស្ថាបនានៅលើសេចក្ដីថ្លែងដោយសង្ខេបរបស់ប៉ុលអំពីសិរីល្អនៃព្រះអាទិត្យ និងនៃព្រះចន្ទ និងនៃតារាទាំងឡាយ ។ ការប្រែចិត្តត្រូវបានប្រកាសឡើងដោយភាសាច្បាស់ៗ និងដាក់កំហិត។ គំរូនៃពិធីបុណ្យជ្រមុជទឹកត្រឹមត្រូវ ត្រូវបានផ្ដល់ឲ្យ ។ លក្ខណៈនៃក្រុមព្រះ ដែលទេវវិទូធ្លាប់មានបញ្ហាអស់ជាច្រើនសតវត្សរ៍ ឥឡូវត្រូវបានពិពណ៌នាជាភាសាដែលអាចយល់បានសម្រាប់មនុស្សទូទៅ ។ ក្រឹត្យវិន័យខាងហិរញ្ញវត្ថុរបស់ព្រះអម្ចាស់ ត្រូវបានប្រកាសជាលិខិតប្រគល់សិទ្ធិ អំពីរបៀបដែលមូលនិធិប្រតិបត្តិការសាសនាចក្រ គឺត្រូវទទួលបាន និងត្រូវបានចំណាយ ។ កិច្ចការសម្រាប់មរណជន គឺត្រូវបានបើកសម្ដែងដើម្បីប្រទានពរដល់បុត្រា និងបុត្រីនៃព្រះនៅគ្រប់ជំនាន់ » (« The Order and Will of God » *Ensign* ខែ មករា ឆ្នាំ ១៩៨៩ ទំព័រ ២, ៤ ) ។

នៅពេលអ្នកសិក្សាគោលលទ្ធិ និងសេចក្ដីសញ្ញា អ្នកអាចបានកាន់តែស្គាល់សំឡេងនៃព្រះយេស៊ូវ គ្រីស្ទ ( សូមមើល គ. និងស. ១៨:៣៣–៣៦) និងទំនាក់ទំនងមកពីព្រះវិញ្ញាណបរិសុទ្ធ ( សូមមើល គ. និង ស. ៨:២–៣) ។

## អំពីគោលលទ្ធិ និងសេចក្ដីសញ្ញា

គោលលទ្ធិ និងសេចក្ដីសញ្ញាត្រូវបានដាក់បញ្ចូលគ្នាជា១៣៨ កណ្ឌ និងសេចក្ដីប្រកាសជាផ្លូវការពីរ ។ វិវរណៈជាច្រើនទាំងនេះត្រូវបានបោះពុម្ពជាលើកដំបូងនៅក្នុងទម្រង់ជាសៀវភៅ ដូចជាព្រះគម្ពីរនៃព្រះបញ្ញត្តិ នៅឆ្នាំ ១៨៣៣ ។ នៅក្រោមការដឹកនាំរបស់គណៈប្រធានទីមួយ នៅក្នុងការបោះពុម្ពបន្តបន្ទាប់នៃគោលលទ្ធិ និង សេចក្ដីសញ្ញា វិវរណៈបន្ថែម ឬបញ្ហាផ្សេងទៀតនៃកំណត់ត្រាត្រូវបានបន្ថែមចូលបន្ទាប់ពីដាក់ជូន និងទទួលយកដោយសមាជិកនៃសាសនាចក្រអំឡុងសន្និសីទនៃសាសនាចក្រ ។

នៅក្នុងការបោះពុម្ពឆ្នាំ ១៨៧៦ បានរៀបចំដោយអែលឌើរ អូរសុន ប្រាត្ត នៅក្រោមការដឹកនាំរបស់ប្រធាន ព្រិកហាំ យ៉ង់ បានរៀបចំវិវរណៈតាមកាលប្បវត្តិ ហើយផ្ដល់នូវក្បាលកណ្ឌថ្មីដោយមានការណែនាំអំពីប្រវត្តិ ។

នៅក្នុងការបោះពុម្ព នៃគោលលទ្ធិ និងសេចក្ដីសញ្ញាឆ្នាំ ១៩៨១ ឯកសារចំនួនបីច្បាប់ត្រូវបានដាក់បញ្ចូលជាលើកទីមួយ ។ ទាំងនេះគឺជា កណ្ឌ ១៣៧ និង ១៣៨ ដាក់ជាគ្រឹះនៃសេចក្ដីសង្គ្រោះសម្រាប់មរណជន និង សេចក្ដីប្រកាសជាផ្លូវការទី ២។

នៅក្នុងការបោះពុម្ពនៃព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញាឆ្នាំ ២០១៣ មានដាក់បញ្ចូលទាំងកំណែថ្មីដើម្បីជាជំនួយដល់ការសិក្សា រួបថតថ្មី ផែនទីដែលបានធ្វើបច្ចុប្បន្នភាព និងការកែសម្រួលសេចក្ដីផ្ដើមកណ្ឌ ។ ការកែសម្រួលបន្តិចបន្តួចចំពោះសេចក្ដីណែនាំ គឺមានបំណងដើម្បីផ្ដល់នូវបរិបទកាន់តែច្បាស់ និងកាន់តែត្រឹមត្រូវចំពោះបទគម្ពីរទាំងឡាយ ។

## The Joseph Smith Papers ( គម្រោងឯកសាររបស់ យ៉ូសែប ស្ម៊ីធ )

ព័ត៌មានប្រវត្តិសាស្ត្រភាគច្រើននៅក្នុងសៀវភៅសិក្សានេះបានដកស្រង់ចេញពី *History of the Church* និង Joseph Smith Papers Project ( គម្រោងឯកសាររបស់យ៉ូសែប ស្ម៊ីធ ) ។ ជាពិសេសគឺភាគទី ១ និង ២នៃ Documents series of *The Joseph Smith Papers ( គម្រោងឯកសាររបស់យ៉ូសែប ស្ម៊ីធ )* ដែលបានបោះពុម្ពដោយការិយាល័យប្រវត្តិសាស្ត្ររបស់សាសនាចក្រ ( ការបោះពុម្ពនៃនាយកដ្ឋានប្រវត្តិសាស្ត្រសាសនាចក្រនៃ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ) ។ ដើម្បីមើលរូបភាពឌីជីថល និងអានឯកសារសរសេរដោយដៃនៃឯកសារច្បាប់ដើមនៅក្នុង The Joseph Smith Papers ( គម្រោងឯកសាររបស់យ៉ូសែប ស្ម៊ីធ ) សូមចូលទស្សនានៅ josephsmithpapers.org ។

# កាលប្រវត្តិនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ



# សេចក្ដីណែនាំស្ដីពីចំណេះចំណានខគម្ពីរ

ថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថានសាសនាបានជ្រើសរើសវគ្គចំណេះចំណានខគម្ពីរចំនួន ២៥ សម្រាប់ថ្នាក់សិក្ខាសាលានីមួយៗនៃវគ្គសិក្សាថ្នាក់សិក្ខាសាលាទាំងបួនវគ្គ ។ វគ្គខគម្ពីរទាំង ១០០ ផ្ដល់សារៈសំខាន់ជាមូលដ្ឋានគ្រឹះមួយខាងបទគម្ពីរសម្រាប់ការយល់ដឹង និង ការចែកចាយដំណឹងល្អព្រមទាំង សម្រាប់ការពង្រឹងដល់សេចក្ដីជំនឿ ។

អ្នកត្រូវបានលើកទឹកចិត្តឲ្យទន្ទេញចាំចំណេះចំណានខគម្ពីរទាំងនេះ ។ ការទន្ទេញចាំចំណេះចំណានខគម្ពីររួមមានដូចតទៅ ៖

- ការរកឃើញទីតាំង ខគម្ពីរទាំងឡាយដោយការដឹងពី សេចក្ដីយោងព្រះគម្ពីរដែលទាក់ទងគ្នា
- ការយល់ពីបរិបទ និង មាតិកានៃវគ្គបទគម្ពីរ
- ការអនុវត្តន៍តាម គោលការណ៍ និង គោលលទ្ធិទាំងឡាយនៃដំណឹងល្អ ដែលបានបង្រៀននៅក្នុងវគ្គបទគម្ពីរនោះ
- ការទន្ទេញចាំនូវវគ្គបទគម្ពីរទាំងឡាយ

នៅក្នុងសេចក្ដីណែនាំការសិក្សាទាំងនេះ អ្នកនឹងសិក្សាអំពីចំណានខគម្ពីរចំនួន ២៥ ខណៈដែលលេចឡើងនៅក្នុងវគ្គសិក្សាគោលលទ្ធិ និង សេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ ។ ការទន្ទេញចាំនូវវគ្គបទគម្ពីរទាំងឡាយ តម្រូវឲ្យមានការប្រឹងប្រែង ។ ការប្រព្រឹត្តដោយទៀងទាត់ និង ដដែលៗក្នុងការរៀនចំណេះចំណានខគម្ពីរ នឹងជួយអ្នកឲ្យចងចាំសេចក្ដីពិតនានាបានយ៉ាងយូរទៅពេលខាងមុខ ។ អ្នកអាចសម្រេចចិត្តចំណាយពេលពីរបីនាទីរាល់ថ្ងៃ សិក្សាវគ្គចំណេះចំណានខគម្ពីរ ។ សូមស្វែងរកឱកាសប្រើ ចំណេះចំណានខគម្ពីរទាំងនោះ នៅពេលអ្នកពន្យល់អំពីគោលលទ្ធិគ្រឹះនៃដំណឹងល្អទៅដល់មនុស្សទូទៅ ។

# វគ្គចំណេះចំណានខគម្ពីរទាំង១០០

**ខាងក្រោមនេះ គឺជាបញ្ជីនៃវគ្គចំណេះចំណានខគម្ពីរទាំង ១០០ ៖**

| ព្រះគម្ពីរសញ្ញាចាស់ | ព្រះគម្ពីរសញ្ញាថ្មី | ព្រះគម្ពីរមរមន | គោលលទ្ធិ និង សេចក្ដីសញ្ញា |
|---|---|---|---|
| ម៉ូសេ ១:៣៩ | ម៉ាថាយ ៥:១៤–១៦ | នីហ្វៃទី១ ៣:៧ | ប្រ.— ឃ.ស. ១:១៥–២០ |
| ម៉ូសេ ៧:១៨ | ម៉ាថាយ ១១:២៨–៣០ | នីហ្វៃទី២ ២:២៥ | គ. និង ស. ១:៣៧–៣៨ |
| អ័ប្រាហាំ ៣:២២–២៣ | ម៉ាថាយ ១៦:១៥–១៩ | នីហ្វៃទី២ ២:២៧ | គ. និង ស. ៦:៣៦ |
| លោកុប្បត្តិ១:២៦–២៧ | ម៉ាថាយ ២២:៣៦–៣៩ | នីហ្វៃទី ២ ៩:២៨–២៩ | គ. និង ស. ៨:២–៣ |
| លោកុប្បត្តិ ២:២៤ | ម៉ាថាយ ២៨:១៩–២០ | នីហ្វៃ ទី ២ ២៥:២៣, ២៦ | គ. និងស. ១០:៥ |
| លោកុប្បត្តិ ៣៩:៩ | លូកា ២៤:៣៦–៣៩ | ហ្វៃទី២ ២៨:៧–៩ | គ. និងស. ១៣:១ |
| និក្ខមនំ ១៩:៥–៦ | យ៉ូហាន ៣:៥ | នីហ្វៃទី២ ៣១:១៩–២០ | គ. និង ស. ១៨:១០–១១ |
| និក្ខមនំ ២០:៣–១៧ | យ៉ូហាន ១៤:៦ | នីហ្វៃទី ២ ៣២:៣ | គ. និង ស. ១៨:១៥–១៦ |
| យ៉ូស្វេ ២៤:១៥ | យ៉ូហាន ១៤:១៥ | នីហ្វៃទី ២ ៣២:៨–៩ | គ. និង ស. ១៩:១៦–១៩ |
| សាំយ៉ូអែលទី១ ១៦:៧ | យ៉ូហាន ១៧:៣ | ម៉ូសាយ ២:១៧ | គ. និង ស. ១៩:២៣ |
| ទំនុកតម្កើង ២៤:៣–៤ | កិច្ចការ ២:៣៦–៣៨ | ម៉ូសាយ ៣:១៩ | គ. និងស. ២៥:១៣ |
| ទំនុកតម្កើង ១១៩:១០៥ | កិច្ចការ ៣:១៩–២១ | ម៉ូសាយ ៤:៣០ | គ. និងស. ៤៦:៣៣ |
| ទំនុកតម្កើង ១២៧:៣ | កូរិនថូសទី១ ៦:១៩–២០ | អាលម៉ា ៧:១១–១៣ | គ. និងស. ៥៨:២៧ |
| សុភាសិត៣:៥–៦ | កូរិនថូសទី១ ១៥:២០–២២ | អាលម៉ា ៣២:២១ | គ. និង ស. ៥៨:៤២–៤៣ |
| អេសាយ ១:១៨ | កូរិនថូសទី១ ១៥:៤០–៤២ | អាលម៉ា ៣៧:៣៥ | គ. និង ស. ៦៤:៩–១១ |
| អេសាយ ៥:២០ | កាឡាទី ៥:២២–២៣ | អាលម៉ា ៣៩:៩ | គ. និង ស. ៧៦:២២–២៤ |
| អេសាយ ២៩:១៣–១៤ | អេភេសូរ ៤:១១–១៤ | អាលម៉ា ៤១:១០ | គ. និង ស. ៧៦:៤០–៤១ |
| អេសាយ ៥៣:៣–៥ | ភីលីព ៤:១៣ | ហេលេមិន ៥:១២ | គ. និងស. ៧៨:១៩ |
| អេសាយ ៥៨:៦–៧ | ថែស្សាឡូនីចទី ២ ២:១–៣ | នីហ្វៃទី៣ ១២:៤៨ | គ. និងស. ៨២:១០ |
| អេសាយ ៥៨:១៣–១៤ | ធីម៉ូថេទី២ ៣:១៥–១៧ | នីហ្វៃទី៣ ១៨:១៥, ២០–២១ | គ. និងស. ៨៨:១២៤ |
| យេរេមា ១:៤–៥ | ហេព្រើរ ១២:៩ | អេធើរ ១២:៦ | គ. និង ស. ៨៩:១៨–២១ |
| អេសេគាល ៣៧:១៥–១៧ | យ៉ាកុប ១:៥–៦ | អេធើរ ១២:២៧ | គ. និង ស. ១០៧:៨ |
| អេម៉ុស ៣:៧ | យ៉ាកុប ២:១៧–១៨ | មរ៉ូណៃ ៧:៤១ | គ. និង ស. ១២១:៣៦, ៤១–៤២ |
| ម៉ាឡាគី ៣:៨–១០ | ពេត្រុសទី១ ៤:៦ | មរ៉ូណៃ ៧:៤៥, ៤៧–៤៨ | គ. និង ស. ១៣០:២២–២៣ |
| ម៉ាឡាគី ៤:៥–៦ | វិវរណៈ ២០:១២ | មរ៉ូណៃ ១០:៤–៥ | គ. និង ស. ១៣១:១–៤ |

# សេចក្ដីណែនាំអំពីគោលលទ្ធិគ្រឹះ

ខាងក្រោមនេះគឺជាបញ្ជីគោលលទ្ធិគ្រឹះនៃដំណឹងល្អ ៖

- ក្រុមព្រះ
- ផែនការនៃសេចក្ដីសង្គ្រោះ
- ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ
- គ្រាកាន់កាប់ត្រួតត្រា ការក្បត់សាសនា និង ការស្ដារឡើងវិញ
- ពួកព្យាការី និង វិវរណៈ
- បព្វជិតភាព និង កូនសោនៃបព្វជិតភាព
- ពិធីបរិសុទ្ធ និង សេចក្ដីសញ្ញា
- អាពាហ៍ពិពាហ៍ និង គ្រួសារ
- ព្រះបញ្ញត្តិទាំងឡាយ

នៅពេលអ្នកសិក្សាព្រះគម្ពីរ សូមស្វែងរក ឲ្យយល់ ជឿ ពន្យល់ ហើយអនុវត្តគោលលទ្ធិគ្រឹះនៃដំណឹងល្អទាំងនេះ ។ ការធ្វើដូច្នោះនឹងជួយអ្នកពង្រឹងទីបន្ទាល់ ហើយបង្កើនអំណរគុណរបស់អ្នក ចំពោះដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ។ ការរៀនគោលលទ្ធិគ្រឹះ នឹងជួយអ្នករៀបចំខ្លួនកាន់តែប្រសើរ ដើម្បីរស់នៅតាមដំណឹងល្អ និងបង្រៀនអំពីសារៈសំខាន់នៃសេចក្ដីពិតទាំងនេះដល់មនុស្សទូទៅផងដែរ ។ គោលលទ្ធិសំខាន់ៗដទៃទៀតនៃដំណឹងល្អ ក៏នឹងបានគូសបញ្ជាក់នៅក្នុងសៀវភៅសិក្សានេះផងដែរ ទោះជាមិនត្រូវបានចុះនៅក្នុងបញ្ជីនៃគោលលទ្ធិគ្រឹះទាំងនេះក្ដី ។

# គោលលទ្ធិគ្រឹះ

គោលលទ្ធិគ្រឹះគួរតែត្រូវបានបង្ហាញទាំងនៅក្នុងថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាន ។ គ្រូបង្រៀនទាំងឡាយត្រូវជួយសិស្សឲ្យស្គាល់ យល់ ជឿ ពន្យល់ ហើយអនុវត្តគោលលទ្ធិគ្រឹះនៃដំណឹងល្អទាំងនេះ ។ ការធ្វើដូច្នោះនឹងជួយសិស្សឲ្យពង្រឹងទីបន្ទាល់ទាំងឡាយ ហើយបង្កើនអំណរគុណរបស់ពួកគេ ចំពោះដំណឹងល្អដែលបានស្តារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ ការសិក្សាគោលលទ្ធិគ្រឹះទាំងនេះ ក៏នឹងជួយសិស្សឲ្យរៀបចំបានយ៉ាងប្រសើរ ដើម្បីបង្រៀនពីសារៈសំខាន់នៃសេចក្ដីពិតទាំងនេះដល់អ្នកដទៃទៀតផងដែរ ។

ភាគច្រើននៃវគ្គចំណេះចំណានខគម្ពីរទាំង ១០០ ដែលបានជ្រើសរើសដោយថ្នាក់សិក្ខាសាលា និងវិទ្យាស្ថានសាសនាគឺត្រូវបានជ្រើសរើស ដើម្បីជាជំនួយដល់ការយល់ដឹងពីគោលលទ្ធិគ្រឹះរបស់សិស្សទាំងឡាយ ។ សេចក្ដីយោងបទគម្ពីរភាគច្រើនដែលមានក្នុងឯកសារនេះសំដៅទៅវគ្គចំណេះចំណានខគម្ពីរ ។ វគ្គចំណេះចំណានខគម្ពីរទាំងនេះ ត្រូវបានដាក់បញ្ចូលដើម្បីបង្ហាញពីរបៀប ដែលខទាំងនោះទាក់ទងទៅនឹងគោលលទ្ធិគ្រឹះទាំងឡាយ ។

## ១.ក្រុមព្រះ

មានតួអង្គបីអង្គ ដែលមានរូបអង្គដាច់ដោយឡែកពីគ្នានៅក្នុងក្រុមព្រះ ៖ ព្រះជាព្រះវរបិតាដ៏អស់កល្ប ព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ និង ព្រះវិញ្ញាណបរិសុទ្ធ (សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ៖ ១:១៥—២០) ។ ព្រះវរបិតា និង ព្រះរាជបុត្រាមាននូវរូបកាយជាសាច់ និងឆ្អឹងពិត ហើយព្រះវិញ្ញាណបរិសុទ្ធគឺជាតួអង្គនៃវិញ្ញាណ (សូមមើល គ. និង ស. ១៣០:២២–២៣) ។ ទ្រង់ទាំងបីអង្គមានព្រះរាជបំណង និងគោលលទ្ធិតែមួយ ។ ទ្រង់ទាំងបីអង្គរួមសាមគ្គីគ្នាយ៉ាងល្អឥតខ្ចោះក្នុងការនាំមកនូវផែនការនៃសេចក្ដីសង្គ្រោះដ៏ទេវភាពរបស់ព្រះវរបិតា ។

### ព្រះជាព្រះវរបិតា

ព្រះវរបិតាគឺជាអង្គគ្រប់គ្រងដ៏ខ្ពស់បំផុតនៃសាកលលោកនេះ ។ ទ្រង់គឺជាបិតានៃវិញ្ញាណរបស់យើង ( សូមមើល ហេព្រើរ ១២:៩) ។ ទ្រង់ល្អឥតខ្ចោះ មានគ្រប់ទាំងព្រះចេស្ដា និងជ្រាបដឹងនូវគ្រប់ការណ៍ទាំងអស់ ។ ទ្រង់ក៏ជាព្រះនៃក្ដីមេត្តាករុណាសណ្ដោសប្រណី និងក្ដីសប្បុរសដ៏ឥតខ្ចោះផងដែរ ។

### ព្រះយេស៊ូវគ្រីស្ទ

ព្រះយេស៊ូវគ្រីស្ទគឺជាបុត្រច្បងរបស់ព្រះវរបិតាខាងវិញ្ញាណ ហើយជាព្រះរាជបុត្របង្កើតតែមួយគត់របស់ព្រះវរបិតាខាងសាច់ឈាម ។ ទ្រង់គឺជាព្រះយេហូវ៉ានៃព្រះគម្ពីរសញ្ញាចាស់ និងជាព្រះមែស៊ីនៃគម្ពីរសញ្ញាថ្មី ។

ព្រះយេស៊ូវគ្រីស្ទបានរស់នៅក្នុងជីវិតដែលគ្មានអំពើបាប និងបានធ្វើដង្វាយធួនដ៏ល្អឥតខ្ចោះសម្រាប់បាបនៃមនុស្សលោកទាំងអស់ ( សូមមើល អាលម៉ា ៧:១១–១៣ ) ។ ជីវិតរបស់ទ្រង់គឺជាគំរូដ៏ឥតខ្ចោះ អំពីរបៀបដែលមនុស្សទាំងអស់គួររស់នៅតាម ( សូមមើល យ៉ូហាន ១៤:៦, នីហ្វៃទី៣ ១២:៤៨ ) ។ ទ្រង់គឺជាមនុស្សដំបូងគេបង្អស់ ដែលបានរស់ឡើងវិញនៅលើផែនដីនេះ ( សូមមើល កូរិនថូសទី១ ១៥:២០–២២) ។ ទ្រង់នឹងយាងមកម្ដងទៀតដោយព្រះចេស្ដា និងភាពរុងរឿង ហើយនឹងគ្រងលើផែនដីនេះក្នុងអំឡុងពេលសហស្សវត្សរ៍ ។

ការអធិស្ឋាន ពរជ័យ និង ពិធីបរិសុទ្ធនៃបព្វជិតភាពទាំងឡាយ ត្រូវបានធ្វើឡើងដោយ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ( សូមមើល នីហ្វៃទី៣ ១៨:១៥, ២០–២១ ) ។

ខគម្ពីរយោងដែលទាក់ទង ៖ ហេលេមិន ៥:១២, គ. និង ស. ១៩:២៣, គ. និង ស. ៧៦:២២–២៤

### ព្រះវិញ្ញាណបរិសុទ្ធ

ព្រះវិញ្ញាណបរិសុទ្ធគឺជាសមាជិកទីបីនៃក្រុមព្រះ ។ ទ្រង់គឺជាតួអង្គនៃវិញ្ញាណដោយគ្មានរូបកាយជាសាច់ និងឆ្អឹងទេ ។ ជាទូទៅ ទ្រង់ត្រូវបានគេស្គាល់ថាជាព្រះវិញ្ញាណ ជាព្រះវិញ្ញាណបរិសុទ្ធ ជាព្រះវិញ្ញាណនៃព្រះ ជាព្រះវិញ្ញាណនៃព្រះអម្ចាស់ និង ជាអង្គលួងលោម ។

ព្រះវិញ្ញាណបរិសុទ្ធថ្លែងទីបន្ទាល់អំពីព្រះវរបិតា និងព្រះរាជបុត្រា សម្ដែងសេចក្ដីពិតនៃការណ៍គ្រប់យ៉ាង និងញែកអ្នកទាំងឡាយណាដែលបានប្រែចិត្ត និងទទួលបុណ្យជ្រមុជទឹកឲ្យបានបរិសុទ្ធ ( សូមមើល ម៉ូរ៉ូណៃ ១០:៤–៥ ) ។

ឯកសារយោងដែលទាក់ទង ៖ កាឡាទី ៥:២២–២៣; គ. និង ស. ៨:២–៣

## ២.ផែនការនៃសេចក្តីសង្គ្រោះ

នៅក្នុងជីវិតមុនផែនដីនេះ ព្រះវរបិតាបានណែនាំផែនការមួយដើម្បីជួយយើងឲ្យប្រែក្លាយទៅដូចជាទ្រង់ និង ទទួលបានជីវិតអមត និង ជីវិតដ៏នៅអស់កល្បជានិច្ច ( សូមមើល ម៉ូសេ ១:៣៩ ) ។ ព្រះគម្ពីរជាច្រើនបាននិយាយអំពីផែនការនេះថាជាផែនការនៃសេចក្តីសង្គ្រោះ ផែនការនៃសុភមង្គលដ៏មហិមា ផែនការនៃសេចក្តីប្រោសលោះ និង ផែនការនៃក្តីមេត្តាករុណា ។

ផែនការនៃសេចក្តីសង្គ្រោះរួមមានការបង្កបង្កើត ការធ្លាក់ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និង ក្រឹត្យវិន័យទាំងអស់ ពិធីបរិសុទ្ធទាំងឡាយ និង គោលលទ្ធិទាំងឡាយនៃដំណឹងល្អ ។ សិទ្ធិជ្រើសរើស—គឺជាលទ្ធភាពដើម្បីជ្រើសរើស និង ប្រព្រឹត្តចំពោះខ្លួនយើងផ្ទាល់— គឺជាផ្នែកដ៏សំខាន់នៅក្នុងផែនការនៃព្រះវរបិតាផងដែរ ( សូមមើល នីហ្វៃទី២ ២:២៧) ។ ដោយសារផែនការនេះ នោះយើងអាចត្រូវបានធ្វើឲ្យល្អឥតខ្ចោះតាមរយៈដង្វាយធួន ទទួលបានក្តីអំណរដ៏ពេញលេញ ហើយរស់នៅជារៀងរហូតនៅក្នុងវត្តមាននៃព្រះ ( សូមមើល នីហ្វៃទី៣ ១២:៤៨) ។ ទំនាក់ទំនងគ្រួសាររបស់យើងអាចមានរហូតដល់អស់កល្បជានិច្ច ។

ខគម្ពីរយោងដែលទាក់ទង ៖ យ៉ូហាន ១៧:៣, គ. និង ស. ៥៨:២៧

### ជីវិតមុនឆាកជីវិតនេះ

ពីមុនយើងបានកើតមកលើផែនដីនេះ យើងបានរស់នៅក្នុងវត្តមាននៃព្រះវរបិតាសួគ៌របស់យើងក្នុងនាមជាកូនចៅវិញ្ញាណរបស់ទ្រង់ ( សូមមើល អ័ប្រាហាំ ៣:២២–២៣ ) ។ នៅក្នុងជីវិតមុនផែនដី យើងបានចូលរួមនៅក្នុងក្រុមប្រឹក្សាមួយជាមួយនឹងកូនចៅវិញ្ញាណផ្សេងទៀតរបស់ព្រះវរបិតាសួគ៌ ។ ក្នុងអំឡុងពេលប្រជុំក្រុមប្រឹក្សានោះ ព្រះវរបិតាសួគ៌បានបង្ហាញដល់យើងនូវផែនការរបស់ទ្រង់ ហើយព្រះយេស៊ូវគ្រីស្ទពីមុនជីវិតលើផែនដីនេះបានធ្វើសេចក្តីសញ្ញាដើម្បីធ្វើជាអង្គសង្គ្រោះ ។

យើងបានប្រើប្រាស់សិទ្ធិជ្រើសរើសរបស់យើង ដើម្បីធ្វើតាមផែនការព្រះវរបិតាសួគ៌ ។ យើងបានរៀបចំខ្លួនដើម្បីមកកាន់ផែនដីនេះ ជាទីកន្លែងដែលយើងអាចបន្តរីកចម្រើន ។

អស់អ្នកណាដែលបានធ្វើតាមព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទត្រូវបានអនុញ្ញាតឲ្យមកកាន់ផែនដីនេះ ដើម្បីទទួលបទពិសោធន៍នៃជីវិតរមែងស្លាប់ និង ហើយរីកចម្រើនទៅរកជីវិតដ៏នៅអស់កល្បជានិច្ច ។ លូស៊ីហ្វើរ ជាកូនវិញ្ញាណនៃព្រះម្នាក់ទៀតដែលបានជំទាស់ប្រឆាំងនឹងផែនការនេះ ។ វាបានក្លាយទៅជាសាតាំង ហើយវា និងពួកពលបរិវារទាំងឡាយរបស់វាត្រូវបានបណ្តេញចេញពីស្ថានសួគ៌ ហើយមិនបានទទួលឯកសិទ្ធិនៃការទទួលបានរូបកាយ និង បទពិសោធន៍នៃជីវិតរមែងស្លាប់ឡើយ ។

ខគម្ពីរយោងដែលទាក់ទង ៖ យេរេមា ១:៤–៥

### ការបង្កបង្កើត

ព្រះយេស៊ូវគ្រីស្ទបានបង្កើតស្ថានសួគ៌ និង ផែនដីក្រោមការដឹកនាំរបស់ព្រះវរបិតា ។ ផែនដីមិនមែនបង្កើតឡើងពីភាពទទេនោះទេ គឺវាត្រូវបានបង្កើតឡើងពីអ្វីៗដែលមានរួចហើយ ។ ព្រះយេស៊ូវបានបង្កើតពិភពដ៏ច្រើនឥតគណនា ( សូមមើល គ. និង ស. ៧៦:២២–២៤) ។

ការបង្កើតផែនដីគឺជាផ្នែកមួយដ៏សំខាន់នៃផែនការរបស់ព្រះ ។ ផែនដីផ្តល់ឲ្យយើងនូវកន្លែងដែលយើងអាចទទួលបានរូបកាយ ត្រូវបានសាកល្បង និង ទទួលបទពិសោធន៍ ព្រមទាំងអភិវឌ្ឍនូវឥរិយាបថដ៏ទេវភាព ។

យើងត្រូវតែប្រើប្រាស់នូវធនធានលើផែនដីនេះដោយឈ្លាសវៃ សុភវិនិច្ឆ័យ និង អំណរគុណ ( សូមមើល គ. និង ស. ៥៨:១៩ ) ។

អ័ដាមគឺជាមនុស្សដំបូងគេ ដែលត្រូវបានបង្កើតនៅលើផែនដីនេះ ។ ព្រះបានបង្កើត អ័ដាម និង អេវ៉ា តាមរូបរាងរបស់អង្គទ្រង់ផ្ទាល់ ។ គ្រប់មនុស្សលោកទាំងអស់—ទាំងប្រុស ទាំងស្រី—ត្រូវបានបង្កើតតាមរូបរាងរបស់ព្រះ ( សូមមើល លោកុប្បត្តិ ១:២៦–២៧ ) ។

### ការធ្លាក់

នៅក្នុងសួនច្បារអេដែន ព្រះបានបញ្ជាដល់អ័ដាម និង អេវ៉ា ថាមិនត្រូវបរិភោគផ្លែឈើដឹងខុស និង ត្រូវឡើយ ព្រោះលទ្ធផលនៃការធ្វើដូច្នោះគឺនឹងត្រូវស្លាប់ខាងវិញ្ញាណ និង ខាងរូបកាយ ។ សេចក្តីស្លាប់ខាងវិញ្ញាណគឺជាការបែកចេញពីព្រះ ។ សេចក្តីស្លាប់ខាងរូបកាយគឺជាការបែកចេញរវាងវិញ្ញាណ និងរូបកាយរមែងស្លាប់ ។ ដោយសារតែអ័ដាម និង អេវ៉ា បានរំលងនូវបញ្ញត្តិរបស់ព្រះ នោះពួកគេត្រូវបានបណ្តេញចេញពីវត្តមានរបស់ទ្រង់ ហើយបានក្លាយទៅជាជីវិតរមែងស្លាប់ ។ ការរំលងរបស់ អ័ដាម និង អេវ៉ា ព្រមទាំងលទ្ធផលនៃការផ្លាស់ប្តូរដែលពួកគេបានដកពិសោធន៍ រួមទាំងសេចក្តីស្លាប់ខាងវិញ្ញាណ និង សេចក្តីស្លាប់ខាងរូបកាយ ត្រូវបានហៅថាការធ្លាក់ ។

ដោយសារលទ្ធផលនៃការធ្លាក់ នោះអ័ដាម និង អេវ៉ា និង ពូជពង្សរបស់ពួកគេអាចទទួលបាននូវភាពរីករាយ និង ទុក្ខព្រួយ ដឹងខុស និង ត្រូវ ហើយមានកូនចៅ ( សូមមើល នីហ្វៃទី២ ២:២៥) ។ ក្នុងនាមជាកូនចៅរបស់ អ័ដាម និង អេវ៉ា នោះយើងទទួលបាននូវលក្ខខណ្ឌនៃការធ្លាក់ក្នុងអំឡុងពេលជីវិតរមែងស្លាប់នេះ ។ យើងត្រូវបានបែកចេញពីវត្តមាននៃព្រះអម្ចាស់ ហើយត្រូវស្លាប់ខាងរូបកាយ ។ យើងក៏ត្រូវបានសាកល្បងដោយភាពលំបាកនៃជីវិត និង ការល្បួងនៃមារសត្រូវផងដែរ ។ ( សូមមើល ម៉ូសាយ ៣:១៩ ) ។

ការធ្លាក់គឺជាផ្នែកមួយដ៏សំខាន់នៃផែនការសង្គ្រោះរបស់ព្រះវរបិតាសួគ៌ទាំងមូល ។ វាមានទិសដៅពីរ—ចុះក្រោម ប៉ុន្តែទៅមុខ ។ ក្រៅពីនាំឲ្យមានការស្លាប់ខាងរូបកាយ និង វិញ្ញាណ ការធ្លាក់បានផ្តល់ឲ្យយើងនូវឱកាសដើម្បីកើតមកលើផែនដីនេះដើម្បីរៀន និង រីកចម្រើន ។

## ជីវិតរមែងស្លាប់

ជីវិតរមែងស្លាប់គឺជាពេលវេលានៃការរៀនសូត្រ នៅពេលយើងអាចរៀបចំសម្រាប់ជីវិតដ៏នៅអស់កល្ប និង ដើម្បីបង្ហាញថា យើងនឹងប្រើប្រាស់នូវសិទ្ធិជ្រើសរើសរបស់យើង ដើម្បីធ្វើអ្វីៗទាំងអស់ដែលព្រះអម្ចាស់បានបញ្ជា ។ ក្នុងអំឡុងពេលនៃជីវិតរមែងស្លាប់នេះ យើងត្រូវតែស្រឡាញ់ និង បម្រើគ្នាទៅវិញទៅមក ( សូមមើល ម៉ូសាយ ២:១៧, មរ៉ូណៃ ៧:៤៥, ៤៧–៤៨) ។

នៅក្នុងជីវិតរមែងស្លាប់ វិញ្ញាណរបស់យើងត្រូវបានរួមគ្នាជាមួយនឹងរូបកាយរបស់យើង ដោយផ្តល់ឲ្យយើងនូវឱកាសដើម្បីរីកចម្រើន និង អភិវឌ្ឍតាមវិធីជាច្រើនដែលមិនអាចកើតមានបានឡើយនៅក្នុងជីវិតមុនផែនដីនេះ ។ រូបកាយរបស់យើងគឺជាផ្នែកមួយដ៏សំខាន់នៃផែនការនៃសេចក្តីសង្គ្រោះ ហើយថារូបកាយនេះគួរតែត្រូវបានគោរពដោយយកចិត្តទុកដាក់ ថាជាអំណោយមួយមកពីព្រះវរបិតាសួគ៌របស់យើង ( សូមមើល កូរិនថូសទី ១ ៦:១៩–២០) ។

ខគម្ពីរយោងដែលទាក់ទង ៖ យ៉ូស្វេ ២៤:១៥, ម៉ាថាយ២២:៣៦–៣៩, នីហ្វៃទី ២ ២៨:៧–៩, អាលម៉ា ៤១:១០, គ. និង ស. ៥៨:២៧

## ជីវិតក្រោយសេចក្តីស្លាប់

នៅពេលយើងស្លាប់ វិញ្ញាណរបស់យើងចូលទៅក្នុងពិភពវិញ្ញាណ ហើយរង់ចាំការរស់ឡើងវិញ ។ វិញ្ញាណនៃពួកសុចរិតត្រូវបានទទួលចូលទៅក្នុងស្ថានភាពនៃសុភមង្គល ដែលត្រូវបានហៅថាស្ថានបរមសុខ ។ មានពួកអ្នកស្មោះត្រង់ជាច្រើននឹងផ្សាយដំណឹងល្អទៅកាន់អ្នកទាំងនោះនៅក្នុងស្ថានឃុំព្រលឹង ។

ស្ថានឃុំព្រលឹងគឺជាកន្លែងបណ្តោះអាសន្ន នៅក្នុងពិភពក្រោយពីជីវិតរមែងស្លាប់សម្រាប់អ្នកទាំងឡាយណាដែលស្លាប់ទៅដោយមិនបានដឹងអំពីសេចក្តីពិត និង សម្រាប់អ្នកទាំងឡាយណាដែលមិនបានគោរពប្រតិបត្តិនៅក្នុងជីវិតរមែងស្លាប់ ។ នៅទីនោះ វិញ្ញាណទាំងឡាយត្រូវបានបង្រៀនដំណឹងល្អ ហើយមានឱកាសដើម្បីប្រែចិត្ត និងទទួលពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះ ដែលត្រូវបានធ្វើឡើងសម្រាប់ពួកគេនៅក្នុងព្រះវិហារបរិសុទ្ធ ( សូមមើល ពេត្រុសទី១ ៤:៦) ។ អ្នកទាំងឡាយណាដែលទទួលយកដំណឹងល្អ នឹងរស់នៅក្នុងស្ថានបរមសុខរហូតដល់ការរស់ឡើងវិញ ។

ការរស់ឡើងវិញគឺជាការរួមបញ្ចូលគ្នាវិញនៃរូបកាយជាវិញ្ញាណរបស់យើង ជាមួយនឹងរូបកាយជាសាច់ និងឆ្អឹងរបស់យើង ( សូមមើល លូកា ២៤:៣៦–៣៩ ) ។ ក្រោយពីការរស់ឡើងវិញ វិញ្ញាណ និង រូបកាយនឹងមិនបែកចេញពីគ្នាទៀតឡើយ ហើយយើងនឹងក្លាយទៅជាអមតៈ ។ មនុស្សគ្រប់រូបកើតមកលើផែនដីនឹងត្រូវបានរស់ឡើងវិញ ពីព្រោះព្រះយេស៊ូវគ្រីស្ទបានយកឈ្នះលើសេចក្តីស្លាប់ ( សូមមើល កូរិនថូសទី ១ ១៥:២០–២២) ។ ពួកសុចរិតនឹងរស់ឡើងវិញមុនពួកទុច្ចរិត ហើយពួកគេរស់ឡើងវិញនៅក្នុងដំណើររស់ឡើងវិញទីមួយ ។

សេចក្តីជំនុំជម្រះចុងក្រោយ នឹងកើតឡើងបន្ទាប់ពីការរស់ឡើងវិញ ។ ព្រះយេស៊ូវគ្រីស្ទនឹងកាត់សេចក្តីមនុស្សគ្រប់រូប ដើម្បីកំណត់នូវសេចក្តីរុងរឿងដ៏អស់កល្បដែលបុគ្គលនោះនឹងទទួលបាន ។ ការកាត់សេចក្តីនេះនឹងផ្អែកទៅលើការគោរពប្រតិបត្តិរបស់បុគ្គលម្នាក់ៗតាមព្រះបញ្ញត្តិរបស់ព្រះ ( សូមមើល វិវរណៈ ២០:១២, ម៉ូសាយ ៤:៣០) ។

មាននគរនៃសិរីល្អបី ( សូមមើល កូរិនថូសទី ១ ១៥:៤០–៤២) ។ នគរដែលខ្ពស់ជាងគេនោះគឺនគរសេឡេស្ទាល ។ អ្នកទាំងឡាយណាដែលមានសេចក្តីក្លាហានក្នុងការថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និង គោរពប្រតិបត្តិតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ នឹងរស់នៅក្នុងនគរសេឡេស្ទាលក្នុងវត្តមាននៃព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ( សូមមើល គ. និង ស. ១៣១:១–៤) ។

នគរទីពីរនៃនគរសិរីល្អទាំងបីគឺនគរទេរេសទ្រាល ។ អ្នកទាំងឡាយណាដែលរស់នៅក្នុងនគរនេះនឹងជាបុរស និង ស្ត្រីណាដែលរស់នៅដោយសុចរិតទៀងត្រង់ តែមិនមានសេចក្តីក្លាហានក្នុងការថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវ ។

នគរទេឡេស្ទាលគឺជានគរដែលទាបបំផុតក្នុងចំណោមនគរនៃសិរីល្អទាំងបី ។ អ្នកទាំងឡាយណាដែលទទួលបាននគរនេះនឹងជាអស់អ្នកដែលជ្រើសរើសសេចក្តីទុច្ចរិតជាជាងជ្រើសរើសសេចក្តីសុចរិត កាលរស់នៅក្នុងជីវិតរមែងស្លាប់របស់ពួកគេ ។ បុគ្គលទាំងនេះនឹងទទួលសិរីល្អរបស់ពួកគេ បន្ទាប់ពីត្រូវបានសង្គ្រោះពីស្ថានឃុំព្រលឹង ។

ឯកសារយោងដែលទាក់ទង ៖ យ៉ូហាន ១៧:៣

## ៣.ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ

ការធ្វើឲ្យធួនគឺរងទារុណកម្មនៃអំពើបាប ហេតុដូច្នេះហើយ តាមរយៈការណ៍នេះ វាដកចេញនូវឥទ្ធិពលនៃអំពើបាបចេញពីអ្នកប្រែចិត្តពីអំពើបាប និងអនុញ្ញាតឲ្យបុគ្គលនោះត្រូវបានផ្សះផ្សារឡើងវិញជាមួយនឹងព្រះ ។ មានតែព្រះយេស៊ូវគ្រីស្ទមួយអង្គគត់ដែលមានសមត្ថភាពធ្វើដង្វាយធួនដ៏ឥតខ្ចោះសម្រាប់មនុស្សលោកទាំងអស់ ។ ដង្វាយធួនរបស់ទ្រង់គឺរួមមាន ការរងទុក្ខរបស់ទ្រង់ក្នុងសួនច្បារគែតសេម៉ានី សម្រាប់អំពើបាបនៃមនុស្សលោកទាំងអស់ ការបង្ហូរព្រះលោហិតរបស់ទ្រង់ ការរងការឈឺចាប់ និង ការសុគតរបស់ទ្រង់នៅលើឈើឆ្កាង និង ការរស់ឡើងវិញពីផ្នូររបស់ទ្រង់ ( សូមមើល លូកា ២៤:៣៦–៣៩, គ. និង ស. ១៩:១៦–១៩) ។ ព្រះអង្គសង្គ្រោះមានសមត្ថភាពធ្វើដង្វាយធួននេះ ពីព្រោះទ្រង់បានរក្សាអង្គទ្រង់ចៀសពីអំពើបាប និងមានអំណាចឈ្នះលើសេចក្ដីស្លាប់ ។ ដោយសារទ្រង់មានមាតាដែលមានជីវិតរមែងស្លាប់ នោះទ្រង់ទទួលមរតកនៃសេចក្ដីស្លាប់ ។ ដោយសារទ្រង់មានបិតាដែលមានជីវិតអមត នោះទ្រង់មានអំណាចដើម្បីនឹងយកព្រះជន្មរបស់ទ្រង់មកវិញម្ដងទៀត ។

តាមរយៈព្រះគុណ នោះដង្វាយធួនរបស់ព្រះអង្គសង្គ្រោះធ្វើឲ្យមនុស្សទាំងអស់នឹងរស់ឡើងវិញ ហើយទទួលបាននូវជីវិតអមតៈ ។ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទក៏អាចធ្វើឲ្យយើងទទួលបាននូវជីវិតដ៏អស់កល្បជានិច្ចផងដែរ ( សូមមើល ម៉ូរ៉ូណៃ ៧:៤១ ) ។ ដើម្បីទទួលបាននូវអំណោយទាននេះ យើងត្រូវតែរស់នៅតាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ដែលរួមមាន ការមានសេចក្ដីជំនឿលើទ្រង់ ការប្រែចិត្តពីអំពើបាបរបស់យើង ការទទួលបុណ្យជ្រមុជទឹក ការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ និង ប្រកាន់ខ្ជាប់ដោយស្មោះត្រង់រហូតដល់ទីបំផុត ( សូមមើល យ៉ូហាន ៣:៥) ។

ក្នុងផ្នែកនៃដង្វាយធួនរបស់ទ្រង់ នោះព្រះយេស៊ូវគ្រីស្ទ មិនត្រឹមតែរងទុក្ខសម្រាប់អំពើបាបរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកមកដាក់លើខ្លួនព្រះអង្គនូវការឈឺចាប់ ជំងឺ និង រោគាទាំងឡាយរបស់មនុស្សទៀតផង ( សូមមើល អាលម៉ា ៧:១១–១៣ ) ។ ទ្រង់យល់អំពីការឈឺចាប់របស់យើង ពីព្រោះទ្រង់បានទទួលនូវបទពិសោធន៍នៃការឈឺចាប់នោះ ។ ព្រះគុណ ឬអំណាចដែលអាចធ្វើទៅបានរបស់ទ្រង់ ពង្រឹងយើងដើម្បីអាចរងនូវបន្ទុក និង សម្រេចបានកិច្ចការមួយចំនួន ដែលយើងមិនអាចធ្វើដោយខ្លួនយើងផ្ទាល់ ( សូមមើល ម៉ាថាយ ១១:២៨–៣០, ភីលីព ៤:១៣, អេធើរ ១២:២៧ ) ។

ខគម្ពីរយោងដែលទាក់ទង ៖ យ៉ូហាន ៣:៥, កិច្ចការ ៣:១៩–២១

### សេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ

សេចក្ដីជំនឿគឺជា « សេចក្ដីសង្ឃឹមទៅលើអ្វីៗដែលមើលមិនឃើញ ហើយដែលពិត » ( អាលម៉ា ៣២:២១, សូមមើលផងដែរ អេធើរ ១២:៦ ) ។ វាជាអំណោយទានពីព្រះ ។

សេចក្ដីជំនឿត្រូវតែផ្ដោតទៅលើព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យសេចក្ដីជំនឿនោះដឹកនាំបុគ្គលនោះទៅរកសេចក្ដីសង្គ្រោះ ។ ការមានសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទមានន័យថា ការពឹងផ្អែកទាំងស្រុងទៅលើទ្រង់ និង ទុកចិត្តលើដង្វាយធួន អំណាច និង សេចក្ដីស្រឡាញ់ដ៏គ្មានដែនកំណត់របស់ទ្រង់ ។ វារួមទាំងការជឿលើការបង្រៀនរបស់ទ្រង់ និង ការជឿមួយសូម្បីតែយើងមិនយល់អំពីអ្វីៗទាំងអស់ដែលទ្រង់ធ្វើក៏ដោយ ( សូមមើល សុភាសិត ៣:៥–៦, គ. និង ស. ៦:៣៦) ។

សេចក្ដីជំនឿត្រូវបង្ហាញតាមរបៀបដែលយើងរស់នៅ ជាជាងសេចក្ដីជំនឿដែលគ្មានការប្រព្រឹត្ត ( សូមមើល យ៉ាកុប ២:១៧–១៨ ) ។ សេចក្ដីជំនឿអាចរីកចម្រើនឡើង នៅពេលយើងអធិស្ឋាន សិក្សាព្រះគម្ពីរ និងគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ។

ពួកបរិសុទ្ធថ្ងៃចុងក្រោយក៏មានសេចក្ដីជំនឿលើព្រះវរបិតា ព្រះវិញ្ញាណបរិសុទ្ធ និងអំណាចបព្វជិតភាព ព្រមទាំងចំណុចសំខាន់ៗដទៃទៀតនៃដំណឹងល្អ ដែលបានស្ដារឡើងវិញផងដែរ ។ សេចក្ដីជំនឿជួយយើងឲ្យទទួលបាននូវការព្យាបាលខាងវិញ្ញាណ និងខាងរូបកាយ ដើម្បីឈានទៅមុខ ប្រឈមមុខនឹងការលំបាករបស់យើង និង យកឈ្នះទៅលើសេចក្ដីល្បួង ( សូមមើល នីហ្វៃទី២ ៣១:១៩–២០) ។ ព្រះអម្ចាស់នឹងសម្ដែងនូវអព្ភូតហេតុដ៏អស្ចារ្យនៅក្នុងជីវិតរបស់យើងស្របតាមសេចក្ដីជំនឿរបស់យើង ។

តាមរយៈសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ នោះបុគ្គលម្នាក់អាចទទួលបាននូវការផ្ដាច់បាប ហើយនៅទីបំផុតអាចនឹងរស់នៅក្នុងវត្តមានរបស់ព្រះ ។

ខគម្ពីរយោងដែលទាក់ទង ៖ ម៉ាថាយ ១១:២៨–៣០

### ការប្រែចិត្ត

ការប្រែចិត្តគឺជាការផ្លាស់ប្ដូរនៃគំនិត និង ចិត្តដែលផ្ដល់ដល់យើងនូវទិដ្ឋភាពថ្មីអំពីព្រះ អំពីខ្លួនរបស់យើងផ្ទាល់ និង អំពីពិភពលោកនេះ ។ វារួមមានការបែរចេញពីអំពើបាប ហើយបែរទៅរកព្រះដើម្បីទទួលបានការអត់ទោស ។ វាត្រូវបានទាក់ទាញទឹកចិត្តដោយសេចក្ដីស្រឡាញ់ចំពោះព្រះ និងបំណងប្រាថ្នាដ៏ពិតប្រាកដដើម្បីគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

អំពើបាបរបស់យើងធ្វើឲ្យយើងមិនស្អាតស្អំ—មិនសក្ដិសមដើម្បីត្រឡប់ទៅ និង រស់នៅក្នុងវត្តមាននៃព្រះវរបិតាសួគ៌របស់យើងវិញ ។ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ នោះព្រះវរបិតាដែលគង់នៅឋានសួគ៌របស់យើងបានប្រទាននូវវិធីតែមួយគត់ដល់យើង ដើម្បីទទួលបានការអភ័យបាប ( សូមមើល អេសាយ ១:១៨ ) ។

ការប្រែចិត្តរួមមានទាំងអារម្មណ៍នៃការសោកស្ដាយសម្រាប់ការប្រព្រឹត្តអំពើបាប សារភាពទៅកាន់ព្រះវរបិតាសួគ៌របស់យើង និង ទៅកាន់អ្នកដទៃទៀតដែលចាំបាច់ លះបង់ចោលអំពើបាប ស្វែងរកការស្ដារឡើងវិញតាមដែលអាចធ្វើទៅបានចំពោះអ្វីៗដែលបានខូចខាតដោយសារអំពើបាបរបស់នរណាម្នាក់ និង រស់នៅដោយគោរពតាមព្រះបញ្ញត្តិរបស់ព្រះ ( សូមមើល គ. និង ស. ៥៨:៤២–៤៣ ) ។

ខគម្ពីរយោងដែលទាក់ទង ៖ អេសាយ ៥៣:៣–៥; យ៉ូហាន ១៤:៦; នីហ្វៃទី ២ ២៥:២៣, ២៦; គ. និង ស. ១៨:១០–១១; គ. និង ស. ១៩:២៣; គ. និង ស. ៧៦:៤០–៤១

## ៤.គ្រាកាន់កាប់ត្រួតត្រា ការក្បត់សាសនា និង ការស្ដារឡើងវិញ

### គ្រាកាន់កាប់ត្រួតត្រា

គ្រាកាន់កាប់ត្រួតត្រា គឺជាអំឡុងពេលដែលព្រះអម្ចាស់ត្រាស់សម្ដែងគោលលទ្ធិ ពិធីបរិសុទ្ធនានា និង បព្វជិតភាពរបស់ទ្រង់ ។ វាគឺជាអំឡុងពេលមួយ ដែលយ៉ាងហោចណាស់ ព្រះអម្ចាស់មានអ្នកបម្រើដែលបានទទួលសិទ្ធិអំណាចម្នាក់នៅលើផែនដី ដែលកាន់បព្វជិតភាពបរិសុទ្ធ និង ជាអ្នកដែលមាននូវការអនុញ្ញាតពីព្រះដើម្បីចែកចាយដំណឹងល្អ និង ដើម្បីចាត់ចែងពិធីបរិសុទ្ធដែលមានក្នុងដំណឹងល្អនោះ ។ សព្វថ្ងៃនេះ យើងកំពុងរស់នៅក្នុងគ្រាកាន់កាប់ត្រួតត្រាចុងក្រោយ—ជាគ្រាកាន់កាប់ត្រួតត្រាដែលពេញកំណត់ ដែលបានចាប់ផ្ដើមជាមួយនឹងវិវរណៈនៃដំណឹងល្អទៅកាន់យ៉ូសែប ស្ម៊ីធ ។

គ្រាកាន់កាប់ត្រួតត្រាមុនៗត្រូវបានគេស្គាល់ថាជាគ្រាកាន់កាប់ត្រួតត្រាជាមួយ អ័ដាម ណូអេ អ័ប្រាហាំ ម៉ូសេ និង ព្រះយេស៊ូវគ្រីស្ទ ។ លើសពីនេះ មាននូវគ្រាកាន់កាប់ត្រួតត្រាដទៃផ្សេងទៀតជាច្រើន រួមមាននូវគ្រាកាន់កាប់ត្រួតត្រាក្នុងចំណោមសាសន៍នីហ្វៃ និង សាសន៍យ៉ារេឌ ។ ផែនការនៃសេចក្ដីសង្គ្រោះ និងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ត្រូវបានបើកសម្ដែង និងបង្រៀននៅក្នុងគ្រប់គ្រាកាន់កាប់ត្រួតត្រាទាំងអស់ ។

### ការក្បត់សាសនា

នៅពេលមនុស្សបែរចេញពីគោលការណ៍នៃដំណឹងល្អ និងមិនមានកូនសោនៃបព្វជិតភាពទេនោះ
ពួកគេស្ថិតនៅក្នុងការក្បត់សាសនា ។

ពេលវេលាការក្បត់សាសនាទូទៅ បានកើតឡើងពេញអស់ទាំងប្រវត្តិសាស្ត្រនៃពិភពលោក ។ ឧទាហរណ៍មួយគឺការក្បត់សាសនាដ៏ធំ ដែលបានកើតឡើងបន្ទាប់ពីព្រះអង្គសង្គ្រោះបានស្ថាបនាសាសនាចក្ររបស់ទ្រង់ ( សូមមើល ថែស្សាឡូនិចទី ២ ២:១–៣ ) ។ បន្ទាប់ពីការស្លាប់នៃពួកសាវករបស់ព្រះអង្គសង្គ្រោះ គោលការណ៍ទាំងឡាយនៃដំណឹងល្អត្រូវបានខូចបង់ ហើយការផ្លាស់ប្ដូរដែលគ្មានការអនុញ្ញាតបានកើតឡើងនៅក្នុងអង្គការសាសនាចក្រ និង ពិធីបរិសុទ្ធទាំងឡាយនៃបព្វជិតភាព ។ ដោយសារការរីករាលដាលនៃភាពទុច្ចរិតនោះ ព្រះអម្ចាស់បានដកយកសិទ្ធិអំណាច និង កូនសោទាំងឡាយនៃបព្វជិតភាពចេញពីផែនដី ។

ក្នុងអំឡុងពេលនៃការក្បត់សាសនាដ៏ធំនេះ គឺមនុស្សរស់នៅ ដោយគ្មាននូវការដឹកនាំពីព្រះតាមរយៈព្យាការីនៅរស់នោះទេ ។ មានព្រះវិហារជាច្រើនត្រូវបានស្ថាបនាឡើង ប៉ុន្តែពួកគេគ្មាននូវសិទ្ធិអំណាចដើម្បីប្រគល់នូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ឬ ធ្វើពិធីបរិសុទ្ធនៃបព្វជិតភាពផ្សេងៗទៀតបានឡើយ ។ ផ្នែកមួយចំនួននៃព្រះគម្ពីរបរិសុទ្ធត្រូវបានខូច និងបាត់បង់ ហើយមនុស្សលែងមាននូវភាពត្រឹមត្រូវនៃការយល់ដឹងពីព្រះទៀតហើយ ។

ការក្បត់សាសនានេះបានកើតឡើងរហូតដល់ពេលព្រះវរបិតាសួគ៌ និង ព្រះរាជបុត្រាសំណព្វទ្រង់បានយាងមកជួប យ៉ូសែប ស្ម៊ីធ និង បានចាប់ផ្ដើមការស្ដារភាពពេញលេញនៃដំណឹងល្អឡើងវិញ ។

### ការស្ដារឡើងវិញ

ការស្ដារឡើងវិញគឺជាការការស្ថាបនាឡើងវិញរបស់ព្រះនៃសេចក្ដីពិត និង ពិធីបរិសុទ្ធនៃដំណឹងល្អរបស់ទ្រង់ក្នុងចំណោមកូនចៅរបស់ទ្រង់នៅលើផែនដីនេះ ( សូមមើល កិច្ចការ៣:១៩–២១ ) ។

នៅក្នុងការរៀបចំសម្រាប់ការស្ដារឡើងវិញ ព្រះអម្ចាស់បានលើកពួកបុរសសុចរិតឡើងក្នុងអំឡុងពេលមួយដែលគេហៅថា ការសាងឡើងវិញ ។ ពួកគេបានមានបំណងដើម្បីបែរទៅរកគោលលទ្ធិ ការអនុវត្ត និងការរៀបចំសាសនាទៅតាមរបៀបដែលព្រះអង្គសង្គ្រោះបានស្ថាបនាឡើង ។ ទោះជាយ៉ាងនោះក្ដី ពួកគេពុំមានបព្វជិតភាព ឬភាពពេញលេញនៃដំណឹងល្អនោះទេ ។

ការស្ដារឡើងវិញបានចាប់ផ្ដើមនៅក្នុងឆ្នាំ ១៨២០ នៅពេលព្រះជាព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទបានបង្ហាញអង្គទ្រង់ដល់ យ៉ូសែប ស្ម៊ីធ ក្នុងការឆ្លើយតបចំពោះការអធិស្ឋានរបស់លោក ( សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៥–២០ ) ។ ព្រឹត្តិការណ៍សំខាន់ៗមួយចំនួននៃការស្ដារឡើងវិញ គឺការបកប្រែព្រះគម្ពីរមរមន ការស្ដារឡើងវិញនៃបព្វជិតភាពអើរ៉ុន និង មិលគីស្សាដែក និង ការរៀបចំសាសនាចក្រនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០ ។

បព្វជិតភាពអើរ៉ុនត្រូវបានស្ដារឡើងវិញដល់យ៉ូសែប ស៊្មីធ និង អូលីវើរ ខៅឌើរី ដោយ យ៉ូហាន បាទីស្ទ នៅថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៨២៩ ។ បព្វជិតភាពមិលគីស្សាដែក និង កូនសោទាំងឡាយនៃនគរត្រូវបានស្ដារឡើងវិញនៅក្នុងឆ្នាំ ១៨២៩ នៅពេលដែលសាវក ពេត្រុស យ៉ាកុប និង យ៉ូហាន បានប្រគល់កូនសោទាំងនោះដល់ យ៉ូសែប ស៊្មីធ និង អូលីវើរ ខៅឌើរី ។

ភាពពេញលេញនៃដំណឹងល្អត្រូវបានស្ដារឡើងវិញ ហើយសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺជា « សាសនាចក្រតែមួយដែលពិត ហើយសកម្មនៅលើផ្ទៃផែនដីទាំងមូល » (គ. និង ស. ១:៣០ ) ។ នៅទីបំផុត សាសនាចក្រ នឹងមានពាសពេញផ្ទៃផែនដី និងឈរឡើងជារៀងរហូត ។

ឯកសារយោងដែលទាក់ទង ៖ អេសាយ ២៩:១៣–១៤; អេសេគាល ៣៧:១៥–១៧; អេភេសូ ៤:១១–១៤; យ៉ាកុប ១:៥–៦

## ៥.ព្យាការី និង វិវរណៈ

ព្យាការីគឺជាមនុស្សម្នាក់ដែលត្រូវបានហៅដោយព្រះ ដើម្បីនិយាយជំនួសទ្រង់ ( សូមមើល អេម៉ុស ៣:៧) ។ ពួកព្យាការី ទាំងឡាយថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និងបង្រៀនដំណឹងល្អរបស់ទ្រង់ ។ ពួកលោកបង្ហាញឲ្យស្គាល់នូវព្រះហឫទ័យ និង ចរិតលក្ខណៈពិតរបស់ព្រះ ។ ពួកលោកប្រាប់អំពីអំពើបាប និងព្រមានអំពីផលវិបាកនៃអំពើបាប ។ ជួនកាល ពួកលោកបាន ព្យាករពីព្រឹត្តិការណ៍នាពេលអនាគត ( សូមមើល គ. និង ស. ១:៣៧–៣៨) ។ ការបង្រៀនជាច្រើនរបស់ព្យាការីគឺមាននៅ ក្នុងព្រះគម្ពីរនានា ។ នៅពេលយើងសិក្សាប្រសាសន៍របស់ព្យាការី នោះយើងអាចរៀនសេចក្ដីពិត និងទទួលបាននូវការណែនាំ ( សូមមើល នីហ្វៃទី២ ៣២:៣) ។

យើងគាំទ្រប្រធាននៃសាសនាចក្រជា ព្យាការី អ្នកមើលឆុត និង ជាអ្នកទទួលវិវរណៈ និង ជាបុរសតែម្នាក់គាត់នៅលើផែនដី ដែលទទួលបានវិវរណៈដើម្បីដឹកនាំសាសនាចក្រនេះទាំងមូល ។ យើងក៏គាំទ្រដល់ទីប្រឹក្សាទាំងឡាយនៅក្នុងគណៈប្រធានទី មួយ និង សមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ជាព្យាការី អ្នកមើលឆុត និង ជាអ្នកទទួលវិវរណៈផងដែរ ។

វិវរណៈគឺជាទំនាក់ទំនងរវាងព្រះទៅកាន់កូនចៅរបស់ទ្រង់ ។ នៅពេលព្រះអម្ចាស់បើកសម្ដែងព្រះឆន្ទៈរបស់ទ្រង់ទៅកាន់ សាសនាចក្រ នោះទ្រង់មានព្រះបន្ទូលតាមរយៈព្យាការីរបស់ទ្រង់ ។ ព្រះគម្ពីរនានា—ព្រះគម្ពីរបរិសុទ្ធ ព្រះគម្ពីរមរមន គោលលទ្ធិ និង សេចក្ដីសញ្ញា និង មុក្ដាដ៏មានតម្លៃមហិមា—មាននូវវិវរណៈទាំងឡាយ ដែលបានផ្ដល់ឲ្យតាមរយៈព្យាការី ពីបុរាណ និង ព្យាការីថ្ងៃចុងក្រោយ ។ ប្រធាននៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជាព្យាការីរបស់ ព្រះនៅលើផែនដីនាសព្វថ្ងៃនេះ ។

បុគ្គលម្នាក់ៗអាចទទួលវិវរណៈដើម្បីជួយពួកគេជាមួយនឹងសេចក្ដីត្រូវការ ការទទួលខុសត្រូវ និង សំណួរជាក់លាក់ទាំងឡាយ របស់ពួកគេ និង ដើម្បីជួយពង្រឹងទីបន្ទាល់របស់ពួកគេ ។ វិវរណៈដែលកើតមានចំពោះពួកអ្នកដឹកនាំ និងសមាជិកសាសនាចក្រ ភាគច្រើនកើតឡើងតាមរយៈចំណាប់អារម្មណ៍ និង គំនិតទាំងឡាយដែលបានមកពីព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះវិញ្ញាណបរិសុទ្ធ មានបន្ទូលទៅកាន់គំនិត និង ដួងចិត្តរបស់យើងជាសំឡេងដ៏តូចរហៀង ( សូមមើល គ. និង ស. ៨:២–៣ ) ។ វិវរណៈអាច កើតមានតាមរយៈការនិមិត្ត សុបិន និង ការយាងមកជួបពីពួកទេវតាផងដែរ ។

ខគម្ពីរយោងដែលទាក់ទង ៖ ទំនុកដំកើង ១១៩:១០៥, អេភេសូ ៤:១១–១៤, ធីម៉ូថេទី២ ៣:១៥–១៧, យ៉ាកុប១:៥–៦, មរ៉ូណៃ ១០:៤–៥

## ៦.បព្វជិតភាព និង កូនសោទាំងឡាយនៃបព្វជិតភាព

បព្វជិតភាពគឺជាអំណាច និង ជាសិទ្ធិអំណាចដ៏អស់កល្បរបស់ព្រះ ។ តាមរយៈបព្វជិតភាព ព្រះបានបង្កើត និង គ្រប់គ្រង ស្ថានសួគ៌ព្រមទាំងផែនដីផងដែរ ។ តាមរយៈអំណាចនេះ នោះទ្រង់បានប្រោសលោះ និងតម្កើងកូនចៅរបស់ទ្រង់ ដើម្បីនាំឲ្យ មាន « អមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » (ម៉ូសេ ១:៣៩) ។

ព្រះប្រទានសិទ្ធិអំណាចបព្វជិតភាពដល់បុរសជាសមាជិកនៃសាសនាចក្រដែលសក្ដិសម ដូច្នេះពួកគេអាចធ្វើកិច្ចការក្នុងនាម របស់ទ្រង់ សម្រាប់សេចក្ដីសង្គ្រោះដល់កូនចៅទាំងឡាយរបស់ទ្រង់ ។ កូនសោនៃបព្វជិតភាពគឺជាសិទ្ធិនៃគណៈប្រធាន ឬជា អំណាចដែលត្រូវបានផ្ដល់ឲ្យដល់ពួកបុរសដោយព្រះដើម្បីគ្រប់គ្រង និង ដឹកនាំនគរព្រះនៅលើផែនដីនេះ ( សូមមើល ម៉ាថាយ ១៦:១៥–១៩) ។ តាមរយៈកូនសោទាំងនេះ អ្នកកាន់អំណាចបព្វជិតភាពអាចទទួលបាននូវការអនុញ្ញាតដើម្បីផ្សាយដំណឹង ល្អ និង ចាត់ចែងពិធីបរិសុទ្ធទាំងឡាយនៃសេចក្ដីសង្គ្រោះ ។ ចំពោះអស់អ្នកទាំងឡាយណាដែលបម្រើនៅក្នុងសាសនាចក្រ គឺ ត្រូវបានហៅក្រោមការដឹកនាំរបស់បុគ្គលម្នាក់ដែលកាន់កូនសោបព្វជិតភាព ។ ដូច្នេះ ពួកគេមានសិទ្ធិទទួលបានអំណាចដែល ចាំបាច់ដើម្បីបម្រើ និងបំពេញការទទួលខុសត្រូវទាំងឡាយនៃការហៅរបស់ពួកគេ ។

ខគម្ពីរយោងដែលទាក់ទង ៖ គ. និង ស. ១២១:៣៦, ៤១–៤២

### បព្វជិតភាពអើរ៉ុន

ជាទូទៅបព្វជិតភាពអើរ៉ុនត្រូវបានហៅថាជាបព្វជិតភាពបម្រុង ។ មុខតំណែងនៃបព្វជិតភាពអើរ៉ុនមាន ឌីកុន គ្រូ សង្ឃ និង ប៊ីស្សព ។ នៅក្នុងសាសនាចក្រសព្វថ្ងៃនេះ សមាជិកប្រុសៗដែលសក្ដិសមអាចចាប់ផ្ដើមទទួលបព្វជិតភាពអើរ៉ុននៅអាយុ ១២ឆ្នាំ ។

បព្វជិតភាពអើរ៉ុន « កាន់កូនសោទាំងឡាយអំពីការបម្រើនៃពួកទេវតា និង អំពីដំណឹងល្អនៃការប្រែចិត្ត និង អំពីបុណ្យជ្រមុជទឹក » ( គ. និង ស. ១៣:១ ) ។

### បព្វជិតភាពមិលគីស្សាដែក

បព្វជិតភាពមិលគីស្សាដែកជាបព្វជិតភាពខ្ពស់ជាង ឬធំជាង និងដើម្បីចាត់ចែងការណ៍ទាំងឡាយខាងវិញ្ញាណ ( សូមមើល គ. និង ស. ១០៧:៨ ) ។ បព្វជិតភាពដ៏ប្រសើរជាងនេះត្រូវបានផ្ដល់ឲ្យដល់អ័ដាម ហើយមាននៅលើផែនដី នៅពេលណាដែលព្រះអម្ចាស់បានបើកសម្ដែងដំណឹងល្អរបស់ទ្រង់ ។

ដំបូងបព្វជិតភាពនេះត្រូវបានហៅថាជា « បព្វជិតភាពដ៏បរិសុទ្ធ តាមរបៀបនៃព្រះរាជបុត្រានៃព្រះ »( គ. និង ស. ១០៧:៣ ) ។ ក្រោយមកបព្វជិតភាពនេះត្រូវបានស្គាល់ថា ជា បព្វជិតភាពមិលគីស្សាដែក ដែលត្រូវបានដាក់ឈ្មោះតាមសង្ឃជាន់ខ្ពស់ដ៏អស្ចារ្យម្នាក់ ដែលបានរស់នៅក្នុងអំឡុងពេលនៃជំនាន់ព្យាការីអ័ប្រាហាំ ។

នៅក្នុងបព្វជិតភាពមិលគីស្សាដែកមាននូវមុខតំណែងដូចជា អែលឌើរ សង្ឃជាន់ខ្ពស់ លោកអយ្យកោ ពួកចិតសិបនាក់ និង សាវក ។ ប្រធាននៃបព្វជិតភាពមិលគីស្សាដែកគឺជាប្រធានសាសនាចក្រ ។

ឯកសារយោងដែលទាក់ទង ៖ អេភេសូ ៤:១១–១៤

## ៧. ពិធីបរិសុទ្ធ និង សេចក្ដីសញ្ញាទាំងឡាយ

### ពិធីបរិសុទ្ធ

នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ពិធីបរិសុទ្ធគឺពិសិដ្ឋ ហើយជាពិធីផ្លូវការដែលមានអត្ថន័យខាងវិញ្ញាណ ។ ពិធីបរិសុទ្ធនីមួយៗត្រូវបានបង្កើតឡើងដោយព្រះដើម្បីបង្រៀនពីសេចក្ដីពិតនានាខាងវិញ្ញាណ ។ ពិធីបរិសុទ្ធទាំងឡាយនៃសេចក្ដីសង្គ្រោះ ត្រូវបានធ្វើឡើងដោយសិទ្ធិអំណាចនៃបព្វជិតភាព និងក្រោមការដឹកនាំនៃអស់អ្នកដែលកាន់កូនសោបព្វជិតភាព ។ ពិធីបរិសុទ្ធមួយចំនួនគឺសំខាន់ចំពោះភាពលើកតម្កើង និងត្រូវបានគេហៅថាជា ពិធិបរិសុទ្ធសម្រាប់ការសង្គ្រោះ ។

ពិធីបរិសុទ្ធសម្រាប់ការសង្គ្រោះដំបូងគេនៃដំណឹងល្អគឺ ពិធីបុណ្យជ្រមុជទឹកដោយការជ្រមុជទៅក្នុងទឹកដោយអ្នកមានសិទ្ធិអំណាច ។ បុណ្យជ្រមុជទឹកគឺចាំបាច់សម្រាប់បុគ្គលម្នាក់ៗ ដើម្បីក្លាយជាសមាជិកនៃសាសនាចក្រ ដើម្បីចូលទៅក្នុងនគរសេឡេស្ទាល ( សូមមើល យ៉ូហាន ៣:៥ ) ។

ពាក្យថា *បុណ្យជ្រមុជទឹក* មកពីភាសាក្រិក មានន័យថា ជ្រលក់ ឬជ្រមុជ ។ ការជ្រមុជគឺជានិមិត្តរូបនៃសេចក្ដីស្លាប់នៃជីវិតដែលមានអំពើបាបរបស់មនុស្សម្នាក់ និងការកើតជាថ្មីក្នុងជីវិតខាងវិញ្ញាណ ដែលបានឧទ្ទិសដល់ការបម្រើព្រះ និងកូនចៅទាំងឡាយរបស់ទ្រង់ ។ វាក៏ជានិមិត្តរូបនៃសេចក្ដីស្លាប់ និងការរស់ឡើងវិញផងដែរ ។

បន្ទាប់ពីមនុស្សម្នាក់ត្រូវបានជ្រមុជទឹកហើយ នោះអ្នកកាន់បព្វជិតភាពមិលគីស្សាដែកម្នាក់ ឬច្រើននាក់នឹងដាក់ដៃលើក្បាលបុគ្គលនោះ ហើយបញ្ជាក់គាត់ថាជាសមាជិកនៃសាសនាចក្រនេះ ។ ជាផ្នែកនៃពិធីបរិសុទ្ធនេះ ដែលត្រូវបានហៅថា ពិធីបញ្ជាក់ បុគ្គលនោះត្រូវបានគេផ្ដល់ឲ្យនូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។

អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ គឺខុសពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។ ពីមុនការជ្រមុជទឹក បុគ្គលម្នាក់អាចទទួលអារម្មណ៍នៃឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធម្ដងម្កាល ហើយតាមរយៈឥទ្ធិពលនោះ នោះបុគ្គលម្នាក់នោះអាចទទួលបាននូវទីបន្ទាល់នៃសេចក្ដីពិតមួយ ( សូមមើល ម៉ូរ៉ូណៃ ១០:៤–៥ ) ។ បើសិនបុគ្គលនោះកាន់តាមព្រះបញ្ញត្តិទាំងឡាយ បន្ទាប់ពីទទួលបានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធនោះ បុគ្គលនោះមានសិទ្ធិដើម្បីមានភាពជាដៃគូដ៏ជាប់លាប់របស់ទ្រង់ ។

ពិធីបរិសុទ្ធសម្រាប់ការសង្គ្រោះផ្សេងទៀតរួមមាន ការតែងតាំងបព្វជិតភាពមិលគីស្សាដែក ( សម្រាប់បុរស ) អំណោយទានពិសិដ្ឋក្នុងព្រះវិហារបរិសុទ្ធនិង អាពាហ៍ពិពាហ៍នៃការផ្សារភ្ជាប់ ( សូមមើល គ. និង ស. ១៣១:១–៤ ) ។ គ្រប់ពិធីបរិសុទ្ធសម្រាប់ការសង្គ្រោះនៃបព្វជិតភាពទាំងអស់គឺមានសេចក្ដីសញ្ញា ។ នៅក្នុងព្រះវិហារបរិសុទ្ធ ពិធីបរិសុទ្ធសម្រាប់ការសង្គ្រោះទាំងនេះអាចនឹងត្រូវបានធ្វើឡើងជំនួសមរណជន ។ ពិធីបរិសុទ្ធជំនួសអាចមានប្រសិទ្ធភាពបាន លុះត្រាតែបុគ្គលដែលបានស្លាប់នោះទទួលយកពិធីទាំងនេះនៅក្នុងពិភពវិញ្ញាណ ហើយគោរពតាមសេចក្ដីសញ្ញាដែលមានពាក់ព័ន្ធតែប៉ុណ្ណោះ ។

ពិធីបរិសុទ្ធដទៃទៀតដូចជា ការប្រសិទ្ធពរអ្នកឈឺ និង ការដាក់ឈ្មោះ និង ការប្រសិទ្ធពរកុមារ ក៏ជាកិច្ចការសំខាន់ផងដែរ សម្រាប់ការអភិវឌ្ឍខាងវិញ្ញាណរបស់យើង ។

ខគម្ពីរយោងដែលទាក់ទង ៖ កិច្ចការ ២:៣៦–៣៨

### សេចក្ដីសញ្ញា

សេចក្ដីសញ្ញាគឺជាកិច្ចព្រមព្រៀងដ៏ពិសិដ្ឋមួយរវាងព្រះ និងមនុស្ស ។ ព្រះប្រទានលក្ខខណ្ឌទាំងឡាយសម្រាប់សេចក្ដីសញ្ញា ហើយយើងយល់ព្រមដើម្បីធ្វើនូវអ្វីដែលទ្រង់ប្រាប់ឲ្យយើងធ្វើ បន្ទាប់មកព្រះសន្យាដល់យើងនូវពរជ័យជាក់លាក់មួយចំនួន នៅពេលយើងគោរពប្រតិបត្តិតាម ( សូមមើល គ. និង ស. ៨២:១០ ) ។

រាល់ពិធីបរិសុទ្ធសម្រាប់សេចក្ដីសង្គ្រោះនៃបព្វជិតភាព គឺមានសេចក្ដីសញ្ញា ។ យើងចុះសេចក្ដីសញ្ញាជាមួយនឹងព្រះអម្ចាស់ នៅពេលធ្វើបុណ្យជ្រមុជទឹក និង រំឭកសេចក្ដីសញ្ញាទាំងនោះឡើងវិញ ដោយការទទួលទានសាក្រាម៉ង់ ។ បងប្អូនប្រុសដែលទទួលបព្វជិតភាពមិលគីស្សាដែកនឹងបានចូលទៅក្នុងសម្បថ និង សេចក្ដីសញ្ញានៃបព្វជិតភាព ។ យើងបានធ្វើសេចក្ដីសញ្ញាបន្ថែមទៀតនៅក្នុងព្រះវិហារបរិសុទ្ធ ។

ខគម្ពីរយោងដែលទាក់ទង ៖ និក្ខមនំ ១៩:៥–៦,ទំនុកតម្កើង ២៤:៣–៤, នីហ្វៃទី២ ៣១:១៩–២០, គ. និង ស. ២៥:១៣

## ៨.អាពាហ៍ពិពាហ៍ និង គ្រួសារ

អាពាហ៍ពិពាហ៍រវាងបុរស និង ស្ត្រី គឺត្រូវបានតែងតាំងឡើងដោយព្រះ ហើយគ្រួសារគឺជាស្នូលសំខាន់ចំពោះផែនការសង្គ្រោះ និង សុភមង្គលរបស់យើង ។ សុភមង្គលនៅក្នុងជីវិតគ្រួសារអាចកើតឡើងបាន នៅពេលយើងធ្វើតាមការបង្រៀនរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។

អំណាចដ៏ពិសិដ្ឋនៃការបង្កើតកូនចៅ ប្រើបានសម្រាប់តែប្រុស និង ស្រីដែលបានរៀបអាពាហ៍ពិពាហ៍ពេញច្បាប់ជាប្ដីប្រពន្ធតែប៉ុណ្ណោះ ។ ឪពុកម្ដាយត្រូវបង្កើតកូនឲ្យចម្រើនជាច្រើនឡើងឲ្យមានពេញពាសលើផែនដី ចិញ្ចឹមបីបាច់កូនចៅរបស់ពួកគេដោយសេចក្ដីស្រឡាញ់ និង សេចក្ដីសុចរិត និង ផ្ដល់នូវសេចក្ដីត្រូវការខាងរូបកាយ និង ខាងវិញ្ញាណដល់កូនចៅរបស់ពួកគេ ។

ស្វាមី និង ភរិយាមាននូវការទទួលខុសត្រូវដ៏ឱឡារិកដើម្បីស្រឡាញ់ និង ថែរក្សាគ្នាទៅវិញទៅមក ។ ឪពុកជាអ្នកដឹកនាំក្នុងក្រុមគ្រួសាររបស់ពួកគេប្រកបដោយសេចក្ដីស្រឡាញ់ និង សេចក្ដីសុចរិត និង ផ្ដល់នូវសេចក្ដីត្រូវការដ៏ចាំបាច់នានាសម្រាប់ជីវិត ។ ម្ដាយមានភារកិច្ចសំខាន់ ដើម្បីថែរក្សាបីបាច់កូនចៅរបស់ខ្លួន ។ នៅក្នុងការទទួលខុសត្រូវដ៏ពិសិដ្ឋទាំងនេះឪពុក និង ម្ដាយមានកាតព្វកិច្ចដើម្បីជួយគ្នាទៅវិញទៅមកជាដៃគូស្មើគ្នា ។

ផែនការនៃសុភមង្គលដ៏ទេវភាពនេះផ្ដល់លទ្ធភាពដល់ទំនាក់ទំនងក្រុមគ្រួសារឲ្យបន្តតទៅហួសពីសេចក្ដីស្លាប់ ។ ផែនដីត្រូវបានបង្កើតឡើង ហើយដំណឹងល្អត្រូវបានបើកសម្ដែង ដូច្នេះក្រុមគ្រួសារត្រូវបានបង្កើតឡើង ត្រូវបានផ្សារភ្ជាប់ និង ត្រូវបានតម្កើងឡើងដ៏អស់កល្បជានិច្ច ។ ( កែសម្រួលពី The Family: A Proclamation to the World » *Ensign* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២៩, សូមមើលផងដែរនៅគេហទំព័រ LDS.org/topics/family–proclamation) ។

ឯកសារយោងដែលទាក់ទង ៖ លោកុប្បត្តិ ២:២៤; ទំនុកដំកើង១២៧:៣; ម៉ាឡាគី ៤:៥–៦; គ. និង ស. ១៣១:១–៤

## ៩.ព្រះបញ្ញត្តិទាំងឡាយ

ព្រះបញ្ញត្តិទាំងឡាយគឺជាក្រឹត្យវិន័យ និងជាតម្រូវការដែលព្រះបានប្រទានដល់មនុស្សលោក ។ យើងបង្ហាញសេចក្ដីស្រឡាញ់របស់យើងចំពោះទ្រង់ដោយការគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ ( សូមមើល យ៉ូហាន ១៤:១៥) ។ ការរក្សានូវបទបញ្ញត្តិទាំងឡាយនឹងនាំមកនូវពរជ័យពីព្រះអម្ចាស់ ( សូមមើល គ. និង ស. ៨២:១០) ។

បទបញ្ញត្តិគ្រឹះពីរដ៏សំខាន់បំផុតគឺ « ស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងឲ្យអស់ពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង ។. . . ហើយ. . . ស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង » (ម៉ាថាយ ២២:៣៦–៣៩) ។

ក្រឹត្យវិន័យទាំងដប់ប្រការគឺជាផ្នែកមួយដ៏សំខាន់នៃដំណឹងល្អ ហើយជាគោលការណ៍ដ៏នៅអស់កល្បដែលចាំបាច់សម្រាប់ភាពតម្កើងឡើងរបស់យើង ( សូមមើល និក្ខមនំ ២០:៣–១៧ ) ។ ព្រះម្ចាស់បានបង្ហាញក្រឹត្យវិន័យទាំងនោះដល់ ម៉ូសេកាលពីសម័យបុរាណ ហើយទ្រង់បានលើកឡើងម្ដងទៀតនៅក្នុងវិវរណៈថ្ងៃចុងក្រោយ ។

ព្រះបញ្ញត្តិផ្សេងទៀត រួមមាន ការអធិស្ឋានប្រចាំថ្ងៃ ( សូមមើល នីហ្វៃទី ២ ៣២:៨–៩), ការបង្រៀនដំណឹងល្អដល់អ្នកដទៃ ( សូមមើល ម៉ាថាយ ២៨:១៩–២០), ការកាន់តាមច្បាប់ព្រហ្មចារីយភាព ( សូមមើល គ. និង ស. ៤៦:៣៣), ការបង់ដង្វាយមួយភាគដប់ពេញលេញ ( សូមមើល ម៉ាឡាគី ៣:៨–១០), ការតមអាហារ ( សូមមើល អេសាយ ៥៨:៦–៧), ការអភ័យទោសដល់អ្នកដទៃ ( សូមមើល គ. និង ស. ៦៤:៩–១១), ការមានវិញ្ញាណនៃសេចក្ដីអំណរគុណ ( សូមមើល គ. និង ស. ៧៨:១៩), និង ការធ្វើតាមពាក្យសម្ដី នៃប្រាជ្ញាវាងវៃ ( សូមមើល គ. និង ស. ៨៩:១៨–២១) ។

ខគម្ពីរយោងដែលទាក់ទង ៖ លោកុប្បត្តិ ៣៩:៩;អេសាយ ៥៨:១៣–១៤; នីហ្វៃទី១ ៣:៧; ម៉ូសាយ ៤:៣០; អាលម៉ា ៣៧:៣៥; អាលម៉ា ៣៩:៩; គ. និង ស. ១៨:១៥–១៦; គ. និង ស. ៨៨:១២៤

សម្រាប់ព័ត៌មានបន្ថែមអំពីប្រធានបទទាំងនេះ សូមចូលទៅ LDS.org, Teachings, Gospel Topics ឬ សូមមើល *ពិតចំពោះសេចក្ដីជំនឿ ៖ សេចក្ដីយោងនៃដំណឹងល្អ* ( ឆ្នាំ ២០០៤ ) ។



មេរៀនទី ១ ៖ ថ្ងៃទី ១

# ផែនការនៃសេចក្តីសង្គ្រោះ

## សេចក្តីផ្តើម

តើអ្នកធ្លាប់ចូលពីមូលហេតុដែលព្រះទ្រង់ត្រាស់បញ្ជាឲ្យយើងធ្វើកិច្ចការមួយចំនួន និងមួយចំនួនទៀតទ្រង់ហាមមិនឲ្យធ្វើដែរឬទេ ? ទស្សនទូទៅនៃផែនការរបស់ព្រះវរបិតាសួគ៌សម្រាប់សេចក្តីសង្គ្រោះរបស់យើង ដែលពេលខ្លះត្រូវបានហៅថាជាផែនការនៃសុភមង្គល អាចជួយយើងឲ្យយល់ដឹងកាន់តែច្បាស់ពីគោលបំណងនៃព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ ប្រធាន បិយដ៏ ឃេ ផាកកឺ ជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា « ចំណេះដឹងអំពីផែនការនៃសុភមង្គល ទោះជាក្នុងទម្រង់ក្រៅ ក៏អាចផ្តល់ជាពាក្យថា ‹ ហេតុអ្វី › ដល់អ្នកដែលមានគំនិតក្មេងខ្ចីដែរ » ( « The Great Plan of Happiness » [ address to CES religious educators ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៣ ] ទំព័រ ៣ si.lds.org ) ។

មេរៀននេះផ្តល់ជាទិដ្ឋភាពទូទៅសង្ខេបមួយអំពី ផែនការនៃសេចក្តីសង្គ្រោះ ។ ដូចអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា វាផ្តោតសំខាន់ទៅលើដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទដែល « ជាសេចក្តីពិតដ៏សំខាន់បំផុត គ្រឹះដ៏សំខាន់ក្រៃលែង និងជាគោលការណ៍ចម្បងនៃផែនការនៃសេចក្តីសង្គ្រោះដ៏មហិមា និងអស់កល្បជានិច្ច » ( «កិច្ចការផ្សព្វផ្សាយសាសនា និង ដង្វាយធួន » *Ensign* ខែ មីនា ឆ្នាំ ២០០១ ទំព័រ ៨ ) ។

### ផែនការរបស់ព្រះវរបិតាសួគ៌សម្រាប់សុភមង្គលរបស់យើង

ព្រះបានបើកសម្តែងគោលបំណងអំពីផែនការនៃសេចក្តីសង្គ្រោះរបស់ទ្រង់ទៅដល់ម៉ូសេ កាលទ្រង់បានជួបលោកដោយផ្ទាល់នៅលើភ្នំ ។ សូមអាន ម៉ូសេ ១:៣៩ រួចស្វែងរកអ្វីដែលព្រះបានមានព្រះបន្ទូលថាជាព្រះរាជបំណងរបស់ទ្រង់ ។

តើអ្នកស្គាល់ពីភាពខុសគ្នារវាង « អមតភាព » និង « ជីវិតអស់កល្ប » ដែរឬទេ ? អមតភាព គឺជាជីវិតដែលអាចរស់នៅដោយនិរន្តរ៍ក្នុងស្ថានភាពដែលបានរស់ឡើងវិញ ។ តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ មនុស្សទាំងអស់ដែលមកចាប់កំណើតនៅលើផែនដីនេះដើម្បីទទួលរូបកាយខាងសាច់ឈាម នឹងទទួលបានអំណោយទានមួយនេះ ។ ជីវិតដ៏នៅអស់កល្បជានិច្ច ឬភាពតម្កើងឡើង គឺជាជីវិតរស់នៅដោយនិរន្តរ៍ជាក្រុមគ្រួសារក្នុងវត្តមានរបស់ព្រះ ។ អំណោយទានមួយនេះក៏កើតមានតាមរយៈដង្វាយធួនដែរ ប៉ុន្តែគឺសម្រាប់តែអស់អ្នកណាដែលមានគុណសម្បត្តិសមនឹងទទួលតែប៉ុណ្ណោះ ។

អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ថា ៖ « ដូចដែលបានប្រើក្នុងព្រះគម្ពីរ *ជីវិតដ៏នៅអស់កល្បជានិច្ច* គឺជាឈ្មោះដែលត្រូវបានដាក់ឲ្យដល់ជីវិតដែលព្រះវរបិតាដ៏អស់កល្បជានិច្ចទ្រង់កំពុងមានព្រះជន្មរស់ ។. . . *ជីវិតរបស់ព្រះគឺជាជីវិតដ៏នៅអស់កល្បជានិច្ច ជីវិតដ៏នៅអស់កល្បជានិច្ចគឺជាជីវិតរបស់ព្រះ*—វោហារសព្ទទាំងនេះមានន័យដូចគ្នា » (*Mormon Doctrine* ការបោះពុម្ពលើកទីពីរ [ ឆ្នាំ ១៩៦៦ ] ទំព័រ ២៣៧ ) ។

អែលឌើរ យ៉ូសែប ប៊ី វ៉ឺតលីន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖



« អមតភាពគិតអំពីបរិមាណ ។ ជីវិតអស់កល្បជានិច្ច គឺគិតអំពីគុណភាព ។. . .

« ជីវិតដ៏នៅអស់កល្បជានិច្ច គឺជាចំណុចខ្ពស់បំផុតនៃជីវិត ។ ក្នុងនាមជាកូនចៅខាងវិញ្ញាណរបស់ព្រះ បងប្អូន និងខ្ញុំ គឺជាអ្នកទទួលមតកចំពោះជោគវាសនាដែលពុំអាចកាត់ថ្លៃបាននេះ ជាអ្នកផ្តល់ប្រយោជន៍ចំពោះអនាគតដ៏រុងរឿងមួយ ជាអ្នកទទួលព្រះគុណ ។

« បើជីវិតអមតៈ គឺជាកិច្ចការរបស់ព្រះ នោះជីវិតដ៏នៅអស់កល្បជានិច្ច គឺជាសិល្បៈរបស់ព្រះ » (« តើជីវិតអមតៈ និង ជីវិតអស់កល្បជានិច្ចខុសគ្នាយ៉ាងដូចម្តេច ? *New Era* ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ៨ ) ។

ជីវិតដ៏នៅអស់កល្បជានិច្ច រួមមានទាំងការរស់នៅក្នុងវត្តមានរបស់ព្រះ ការប្រែក្លាយដូចជាទ្រង់ខាងរូបកាយ និងលក្ខណៈសម្បត្តិ និងការទទួលបានអ្វីៗគ្រប់យ៉ាងដែលទ្រង់មាន រួមមានក្រុមគ្រួសារអស់កល្បជានិច្ច ។

ចេញពីអ្វីដែលអ្នកបានរៀនក្នុង ម៉ូសេ ១:៣៩ សូមបំពេញសេចក្តីថ្លែងការណ៍ខាងគោលលទ្ធិចំពោះផែនការរបស់ព្រះវរបិតាសួគ៌ដូចតទៅនេះ ៖ **គោលបំណងនៃផែនការរបស់ព្រះវរបិតាសួគ៌គឺដើម្បីឲ្យយើងអាចទទួលបាន។**

ក្នុងជីវិតមុនជីវិតនេះ យើងបានរស់នៅជាវិញ្ញាណក្នុងវត្តមានរបស់ព្រះវរបិតាសួគ៌ ។ នៅទីនោះយើងបានយល់ដឹងអំពីផែនការទ្រង់សម្រាប់សុភមង្គលរបស់យើង និងរបៀបដែលការធ្វើតាមផែនការនោះនឹងជួយយើងឲ្យបំពេញគោលបំណងទ្រង់ដែលមានសម្រាប់យើង ។ ( សូមមើល គ. និង ស. ១៣៨:៥៥–៥៦ អ័ប្រាហាំ ៣:២២–២៨ ។ )

### សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ

ក្នុងអំឡុងពេលអ្នកសិក្សានៅផ្ទះនោះអ្នកនឹងមានឱកាសឆ្លើយសំណួរទាំងឡាយ ហើយចែកចាយការយល់ដឹងជាមួយគ្រូរបស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ។ ការសរសេរទុកពីគំនិត និង អារម្មណ៍ទាំងឡាយរបស់អ្នក ព្រមទាំងសរសេរចម្លើយចំពោះសំណួរដែលមានក្នុងសៀវភៅសិក្សានេះ អាចអញ្ជើញឲ្យមានវិវរណៈ ។ អែលឌើរ រីឆាដ ជី ស្កត ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖ « ចំណេះដឹងដែលបានកត់ត្រាទុកដោយយកចិត្តទុកដាក់ គឺជាចំណេះដឹងដែលអាចប្រើប្រាស់បាន នៅចំពេលដែលចាំបាច់ ។ ព័ត៌មានដែលងាយរញ្ជួយខាងវិញ្ញាណ គួរតែត្រូវបានរក្សាទុកនៅក្នុងកន្លែងពិសិដ្ឋមួយ ដែលមានទំនាក់ទំនងជាមួយព្រះអម្ចាស់ អំពីរបៀបដែលអ្នកឲ្យតម្លៃវា ។ ការអនុវត្តបែបនោះបង្កើននូវសក្ដានុពលរបស់អ្នកក្នុងការទទួលបានពន្លឺបន្ថែមទៀត » ( «Acquiring Spiritual Knowledge, » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ទំព័រ ៨៦ ) ។ សូមយកសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកទៅកាន់ថ្នាក់រៀនការសិក្សានៅផ្ទះប្រចាំសប្ដាហ៍របស់អ្នក ការធ្វើដូច្នេះ អ្នកនឹងត្រូវបានត្រៀមខ្លួនជាស្រេចដើម្បីពិភាក្សាអំពីអ្វីដែលអ្នកបានរៀន ហើយបង្ហាញដល់គ្រូរបស់អ្នកនូវកិច្ចការដែលអ្នកបានធ្វើ ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តាមការយល់ដឹងរបស់អ្នក តើយើងមានសភាពខុសប្លែកពីព្រះវរបិតាសួគ៌របស់យើងយ៉ាងដូចម្ដេចក្នុងជីវិតមុនផែនដី ?

ខ. តើព្រះវរបិតាសួគ៌បានបង្ហាញ ហើយប្រទានអ្វីដល់យើងដើម្បីជួយយើងឲ្យប្រែក្លាយដូចជាទ្រង់ ?

២. ផែនការរបស់ព្រះវរបិតាសួគ៌យើងតម្រូវឲ្យយើងចាកចេញពីវត្តមានទ្រង់ ហើយមកដកពិសោធន៍ក្នុងជីវិតលើផែនដី ។ ជីវិតរបស់យើងនៅលើផែនដី នេះជាញឹកញាប់ត្រូវបានហៅថា ជីវិតរមែងស្លាប់ ។ សូមពិចារណាមួយស្របក់ពីមូលហេតុដែលយើងត្រូវចាកចេញពីវត្តមានរបស់ព្រះ និងពីរបៀបដែលជីវិតរមែងស្លាប់ជួយយើងឲ្យរីកចម្រើន ហើយប្រែក្លាយកាន់តែដូចជាព្រះវរបិតាសួគ៌របស់យើង ។ សូមសរសេរគំនិតរបស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

ប្រធាន ស្ពែនសើរ ដបុលយូ឴ ឃីមប៊ល បានមានប្រសាសន៍ពីជីវិតរមែងស្លាប់របស់យើងលើផែនដីនេះថា ៖ « ព្រះបានប្រទានដល់យើងនូវផែនការមួយ ។ **ទ្រង់បានបញ្ជូនយើងទាំងអស់គ្នាមកលើផែនដីនេះដើម្បីទទួលបានរូបកាយ និងដើម្បីដកពិសោធន៍ ហើយរីកចម្រើន** » ( *The Teachings of Spencer W. Kimball,* បានបោះពុម្ពដោយ Edward L. Kimball [ ឆ្នាំ ១៩៨២ ] ទំព័រ ២៥ ការសង្កត់ន័យត្រូវបានបន្ថែម ) ។ តើការទទួលបានរូបកាយសាច់ឈាម និងការដកពិសោធន៍លើផែនដីជួយយើងឲ្យប្រែក្លាយកាន់តែដូចជាព្រះវរបិតាសួគ៌យ៉ាងដូចម្ដេច ? តើឧបសគ្គនានាមានដូចជាការល្បួង ជំងឺ ទុក្ខព្រួយ ការឈឺចាប់ ការបាក់ទឹកចិត្ត អសមត្ថភាព ថែមទាំងទុក្ខលំបាកក្នុងជីវិតរមែងស្លាប់ដទៃទៀត មានតួនាទីដូចម្ដេចក្នុងការខិតខំរបស់យើងដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ហើយប្រែក្លាយកាន់តែដូចជាព្រះវរបិតាសួគ៌ ?

ឧបសគ្គធំមួយដែលយើងប្រឈមមុខក្នុងជីវិតរមែងស្លាប់គឺ អំពើបាប ។ **អំពើបាបរារាំងយើងពីការប្រែក្លាយដូចជាព្រះវរបិតាសួគ៌ និងការត្រឡប់ទៅរស់នៅជាមួយនឹងទ្រង់វិញ** ( សូមមើល គ. និង ស. ២០:១៨–២០; ម៉ូសេ ៦:៥៧ ) ។ អំពើបាបពុំគ្រាន់តែធ្វើឲ្យយើងពុំស្អាតស្អំនោះទេ ប៉ុន្តែ កាលយើងប្រព្រឹត្តបាបក៏ជួយទៅនឹងនិស្ស័យនៃព្រះដែរ—យើងពុំអាចបន្តប្រព្រឹត្តបាប ហើយនៅតែអាចចាប់យកគោលដៅនៃការប្រែក្លាយដូចជាព្រះវរបិតាសួគ៌បានឡើយ ( សូមមើល អាលម៉ា ៤១:១០–១១ ) ។



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៤០–៤២ រួចគូសចំណាំពីរបៀបដែលព្រះវរបិតាសួគ៌បានប្រទានឲ្យដើម្បីយកឈ្នះលើអំពើបាប ។

ភាពពិតដែល **ព្រះយេស៊ូវគ្រីស្ទបានរងឈឺចាប់ ហើយត្រូវគេឆ្កាងជំនួសអំពើបាបនៃមនុស្សទាំងអស់** គឺជាគោលលទ្ធិសំខាន់ក្នុងផែនការរបស់ព្រះវរបិតាសួគ៌សម្រាប់យើង ហើយអាចផ្ដល់ជាសេចក្ដីសង្ឃឹមដល់កូនចៅព្រះវរបិតាសួគ៌ទាំងអស់គ្នា ។ សូមយកពេលមួយស្របក់សញ្ជឹងគិតពីអ្វីដែលពលិកម្មរបស់ព្រះអង្គសង្គ្រោះមានន័យចំពោះអ្នក ។



ទោះជាព្រះយេស៊ូវគ្រីស្ទទទួលទោសជំនួសអំពើបាបរបស់យើងយ៉ាងណាក្ដី ក៏ទ្រង់ពុំដកយកការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់យើងដែរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:២២–២៣; ២៥:១៣, ១៥ ហើយស្វែងរកអ្វីដែលតម្រូវឲ្យយើងធ្វើដើម្បីទទួលបានអំណាចនៃការលាងសម្អាតរបស់ដង្វាយធួន ហើយដើម្បីត្រឡប់ទៅរស់នៅក្នុងវត្តមានព្រះវរបិតាសួគ៌វិញ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

៣. យោងទៅតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:២២-២៣; ២៥:១៣, ១៥ តើយើងត្រូវតែធ្វើអ្វីខ្លះ ដើម្បីមករកព្រះយេស៊ូវគ្រីស្ទ ហើយទទួលបានពរជ័យនៃពលិកម្មដ៏ធួនរបស់ទ្រង់ ? សូមសរសេរចម្លើយរបស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

**ប្រសិនបើយើងគោរពប្រតិបត្តិតាមគោលការណ៍ និងពិធីបរិសុទ្ធនានានៃដំណឹងល្អ យើងអាចយកឈ្នះលើអំពើបាបតាមរយៈព្រះគុណ និងដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទបាន** ( សូមមើល ម៉ូរ៉ូណៃ ១០:៣២-៣៣ ) ។ ដោយសារតែដង្វាយធួន ទើបនៅពេលយើងរក្សាសេចក្ដីសញ្ញាដែលយើងធ្វើនៅពេលទទួលបុណ្យជ្រមុជទឹក នោះយើងអាចប្រែចិត្ត ហើយត្រូវបានអភ័យទោសពីអំពើបាបរបស់យើង ហើយទទួលបានការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធដើម្បីនាំយើងដើរតាមមាគ៌ាឆ្ពោះទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច ។

ក្រៅពីអំពើបាប មានឧបសគ្គមួយទៀតដែលយើងត្រូវតែយកឈ្នះឲ្យបានដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។ សូមអាន អាលម៉ា ១២:២៤ រួចប្រាប់ឧបសគ្គនោះ ។

នៅពេលយើងស្លាប់ នោះវិញ្ញាណ និង រូបកាយរបស់យើងបែកចេញពីគ្នា ។ ប្រសិនបើវិញ្ញាណ និងរូបកាយរបស់យើងបែកចេញពីគ្នាជារៀងរហូត នោះវានឹងមិនអាចទៅរួចឡើយដើម្បីប្រែក្លាយឲ្យដូចជាព្រះនោះ ។ **យើងពុំអាចប្រែក្លាយដូចជាព្រះវរបិតាសួគ៌ដោយគ្មានរូបកាយនៃសាច់ និងឆ្អឹងបានឡើយ**( សូមមើល គ. និង ស. ៩៣:៣៣-៣៤; ១៣០:២២) ។

សូមអាន អាលម៉ា ១១:៤២-៤៥ រួចស្វែងរកថាតើការបែកចេញពីគ្នានៃវិញ្ញាណ និងរូបកាយរបស់យើង ដែលកើតឡើងនៅពេលយើងស្លាប់នោះត្រូវបានយកឈ្នះដោយរបៀបណា ។

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីបានជាការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទគឺជាដំណឹងល្អសម្រាប់មនុស្សគ្រប់រូប ?

ខ. តើសេចក្ដីសង្ឃឹមនៃដំណើររស់ឡើងវិញនាំមកនូវសេចក្ដីអំណរដល់អ្នកយ៉ាងដូចម្ដេច ?



ដូចដែលអ្នកបានអានមុននេះថា អមតភាពគឺជាអំណោយទាននៃដង្វាយធួនព្រះយេស៊ូវគ្រីស្ទដែលមនុស្សគ្រប់រូបនឹងទទួលបាន ដោយមិនគិតថាពួកគេបានប្រព្រឹត្តល្អ ឬអាក្រក់កាលកំពុងរស់ក្នុងជីវិតរមែងស្លាប់នោះឡើយ ( សូមមើល អាលម៉ា ១១:៤២-៤៥; គ. និង ស. ១៣៨:១៤-១៧ ) ។ **ដោយសារតែការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទនេះហើយ ទើបមនុស្សលោកទាំងអស់នឹងរស់ឡើងវិញ ហើយរស់នៅជានិរន្តរ៍** ។ ទោះជាយ៉ាងណាក៏ដោយ ជីវិតដ៏នៅអស់កល្បជានិច្ចគឺជាអំណោយទានពីព្រះទៅដល់តែអស់អ្នកដែលគោរពប្រតិបត្តិតាមច្បាប់ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អរបស់ទ្រង់ប៉ុណ្ណោះ ( សូមមើល គ. និង ស. ១៤:៧ ) ។

**ផែនការនៃសេចក្ដីសង្គ្រោះ**




៥. សូមសង្ខេបនូវអ្វីដែលអ្នកបានរៀនអំពីផែនការរបស់ព្រះវរបិតាសួគ៌សម្រាប់សុភមង្គលរបស់យើងនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមញែកពេលវេលាមួយដើម្បីបង្រៀនពីអ្វីដែលអ្នកបានរៀនអំពីផែនការរបស់ព្រះវរបិតាសួគ៌សម្រាប់សេចក្ដីសង្គ្រោះរបស់យើង ទៅកាន់សមាជិកគ្រួសារម្នាក់ ឬមិត្តម្នាក់ដោយផ្ទាល់ ។ នៅពេលអ្នកពន្យល់ពីអ្វីដែលអ្នកបានរៀននោះ អ្នកអាចគូរឌីយ៉ាក្រាមដើម្បីធ្វើជាជំនួយ ។ សូមប្រុងប្រៀបជាស្រេចដើម្បីចែកចាយបទពិសោធន៍ជាមួយគ្រូរបស់អ្នក ។

មេរៀននេះបានផ្ដល់តែការពន្យល់សង្ខេបនៃផែនការនៃសេចក្ដីសង្គ្រោះតែប៉ុណ្ណោះ ។ ក្នុងការសិក្សារបស់អ្នកអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា នៅឆ្នាំនេះ អ្នកនឹងរៀនពីសេចក្ដីពិតជាច្រើនបន្ថែមទៀតដែលទាក់ទងទៅនឹងផែនការនៃសេចក្ដីសង្គ្រោះ ។ នៅពេលអ្នករៀនបន្ថែមពីផែនការនេះ សូមស្វែងរកអ្វីដែលព្រះទ្រង់បានធ្វើសម្រាប់អ្នក ហើយទោរទន់ទៅរកការបំផុសគំនិតរបស់ព្រះវិញ្ញាណអំពីអ្វីដែលអ្នកត្រូវធ្វើដើម្បីទទួលបានពរជ័យពេញលេញដែលព្រះវរបិតាសួគ៌ប្រទានឲ្យ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សាមេរៀនអំពី « ផែនការនៃសេចក្ដីសង្គ្រោះ » ហើយបានបញ្ចប់វានៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែមដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# ការក្បត់សាសនាដ៏ធំ

## សេចក្ដីផ្ដើម

ព្រះយេស៊ូវគ្រីស្ទបានស្ថាបនាសាសនាចក្រទ្រង់ឡើងកាលទ្រង់ធ្វើការបម្រើនៅលើផែនដី ។ ប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយបានពន្យល់ថា ៖ « បន្ទាប់ពីការយាងឡើងទៅស្ថានសួគ៌វិញរបស់ព្រះគ្រីស្ទ ពួកសាវកបានបន្តប្រើប្រាស់កូនសោដែលទ្រង់បានបន្សល់ទុកនៅនឹងពួកលោក ។ ប៉ុន្តែដោយសារតែការមិនគោរពប្រតិបត្តិ និងការបាត់បង់សេចក្ដីជំនឿពីសំណាក់សមាជិក នោះពួកសាវកបានចែកឋានទៅដោយគ្មានអ្នកទទួលកាន់កូនសោបន្តឡើយ ។ យើងហៅព្រឹត្តិការណ៍សោកនាដកម្មនោះថា ‹ ការក្បត់សាសនា › » («The True and Living Church, » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ២១ ) ។ ដោយសារតែការក្បត់សាសនាដែលរីករាលដាលនេះហើយ ទើបសិទ្ធិអំណាចបព្វជិតភាពត្រូវបានបាត់បង់ពីចំណោមមនុស្សលោក ។ ការយល់ដឹងពីការក្បត់សាសនាដ៏ធំជួយយើងឲ្យយល់កាន់តែច្បាស់ពីតម្រូវការឲ្យមានការស្ដារឡើងវិញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទនៅថ្ងៃចុងក្រោយនេះ ។

## ព្រះយេស៊ូវគ្រីស្ទបានស្ថាបនាសាសនាចក្រទ្រង់ឡើងកាលទ្រង់គង់នៅលើផែនដីនេះ

ក្នុងតារាងខាងក្រោម សូមផ្គូផ្គងគ្រឿងឧបករណ៍ជាមួយនឹងម៉ាស៊ីន ឬចំណែកនៃបរិក្ខារដែលត្រូវនឹងវា ៖








តើម៉ាស៊ីនទាំងនេះមានអត្ថប្រយោជន៍ដូចម្ដេច ប្រសិនបើគ្មានឧបករណ៍ដែលអ្នកបានផ្គូរផ្គងទេនោះ ? សូមប្រៀបធៀបការណ៍នេះទៅនឹងសាសនាចក្ររបស់ព្រះអម្ចាស់ ។ តើមានផ្នែកចាំបាច់អ្វីខ្លះ ដែលប្រសិនបើវាត្រូវបានដកចេញពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនោះសាសនាចក្រនឹងពុំអាចដំណើរការបាន ឬ មិនអាចសូម្បីតែមានរូបរាងនោះ ?

១. សូមសរសេរចំណងជើងក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកថា *ធាតុចំបាច់នានានៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ* ។ នៅពេលអ្នករកឃើញធាតុផ្សេង ៗអំឡុងពេលសិក្សាមេរៀននេះ សូមសរសេរវានៅក្រោមចំណងជើងនេះ ។

សូមអាន អេភេសូរ ២:១៩–២២ រួចគូសចំណាំពីគ្រឹះដែលព្រះយេស៊ូវគ្រីស្ទបានស្ថាបនាសាសនាចក្រទ្រង់នៅលើ អំឡុងពេលការបម្រើរបស់ទ្រង់ក្នុងជីវិតរមែងស្លាប់ ។ តើអ្នកគិតថាហេតុអ្វីបានជាពួកសាវក និងពួកព្យាការីត្រូវបានចាត់ទុកថាជា « គ្រឹះ » នៃសាសនាចក្រ ? តើនរណាជាថ្មជ្រុងយ៉ាងឯក ?

សូមសរសេរសេចក្ដីពិតតទៅនេះក្នុងបញ្ជីធាតុចាំបាច់នានានៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកថា ៖**ពួកសាវក និងពួកព្យាការី បង្កើតបានជាគ្រឹះនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។**

តើមានអ្វីកើតឡើងក្នុងរូបភាពខាងក្រោមនេះ ?



សូមអាន យ៉ូហាន ១៥:១៦ រួចស្វែងរកធាតុមួយទៀតនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទដែលចាំបាច់សម្រាប់សេចក្ដីសង្គ្រោះនៃកូនចៅរបស់ព្រះ ។

ពីមុនព្រះអង្គសង្គ្រោះបានយាងឡើងទៅឯស្ថានសួគ៌វិញ ទ្រង់បានប្រទានដល់ពួកសាវកទ្រង់នូវសិទ្ធិអំណាចដើម្បីដឹកនាំសាសនាចក្រទ្រង់ ហើយប្រព្រឹត្តនៅក្នុងព្រះនាមនៃព្រះដើម្បីឲ្យមានសេចក្ដីសង្គ្រោះដល់កូនចៅទ្រង់ ។ សិទ្ធិអំណាចបព្វជិតភាពនេះរួមមានកូនសោបព្វជិតភាព ឬសិទ្ធិ ដើម្បីដឹកនាំសាសនាចក្រ ហើយធ្វើពិធីបរិសុទ្ធទាំងឡាយដែលចាំបាច់ដល់សេចក្ដីសង្គ្រោះ ។ សូមសរសេរបញ្ចូលសេចក្ដីពិតតទៅនេះ ទៅក្នុងបញ្ជីក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកថា ៖ **សិទ្ធិអំណាចបព្វជិតភាពគឺចាំបាច់ដើម្បីទទួលសេចក្ដីសញ្ញា និងពិធីបរិសុទ្ធទាំងឡាយនៃសេចក្ដីសង្គ្រោះ ។**



អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបកស្រាយពីធាតុចាំបាច់មួយទៀតនៃសាសនាចក្រដ៏ពិតថា ៖ « សេចក្ដីពិត និងគោលលទ្ធិ ដែលយើងបានទទួល បានមក ហើយនឹងបន្តមានមកតាមរយៈវិវរណៈរបស់ព្រះ ។ នៅក្នុងទំនៀមទម្លាប់ជំនឿមួយចំនួន. . .បញ្ហាខាងគោលលទ្ធិអាចក្លាយជាការខ្វែងមតិយោបល់គ្នា ។. . . យើងឲ្យតម្លៃដល់ចំណេះវិជ្ជាដែលពង្រីកការយល់ដឹងប៉ុន្តែនៅក្នុងសាសនាចក្រសព្វថ្ងៃ ក៏ដូចជាជំនាន់បុរាណ ការស្ថាបនាគោលលទ្ធិនៃព្រះគ្រីស្ទ ឬការកែតំរិតកំនុំច្រឡំខាងគោលលទ្ធិ គឺជារឿងមួយនៃវិវរណៈរបស់ព្រះចំពោះអ្នកទាំងឡាយណាដែលព្រះអម្ចាស់បានប្រគល់ឲ្យនូវសិទ្ធិអំណាចជាសាវក » (« The Doctrine of Christ, » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ៨៦ ) ។

ស្របតាមអែលឌើរ គ្រីស្តូហ្វឺសិន តើតួនាទីសំខាន់មួយរបស់ព្យាការី និងពួកសាវកគឺជាអ្វី ?

គោលលទ្ធិមួយគឺជាសេចក្ដីពិតគ្រឹះដ៏អស់កល្បអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ តើអ្នកគិតថាហេតុអ្វីបានជាវាសំខាន់ថាគោលលទ្ធិពិត ត្រូវបានបង្រៀន ហើយយល់ត្រឹមត្រូវនៅក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ដូច្នេះ ?

សូមសរសេរបញ្ចូលសេចក្ដីពិតដូចតទៅនេះ ទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកថា ៖ **ពួកសាវកនិងពួកព្យាការីស្ថាបនាគោលលទ្ធិដ៏ត្រឹមត្រូវតាមរយៈវិវរណៈដ៏ទេវភាព ។**

ទោះបីជាមានគោលលទ្ធិជាច្រើននៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទយ៉ាងណាក៏ដោយ ក៏អ្នកត្រូវបានលើកទឹកចិត្តឲ្យបង្កើនការយល់ដឹងឲ្យបានកាន់តែជ្រាលជ្រៅពីគោលលទ្ធិគ្រឹះទាំងឡាយខាងក្រោមពេញមួយការសិក្សាថ្នាក់សិក្ខាសាលារបស់អ្នក ។ ដោយធ្វើដូច្នេះ វានឹងជួយអ្នកឲ្យពង្រឹងទីបន្ទាល់ខ្លួន ហើយរៀបចំអ្នកឲ្យបង្រៀនដំណឹងល្អដល់មនុស្សដទៃ ។

- ក្រុមព្រះ
- ផែនការនៃសេចក្ដីសង្គ្រោះ
- ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ
- គ្រាកាន់កាប់ត្រួតត្រា ការក្បត់សាសនា និង ការស្ដារឡើងវិញ
- ព្យាការី និង វិវរណៈ

- បព្វជិតភាព និង កូនសោនៃបព្វជិតភាព
- ពិធីបរិសុទ្ធ និងសេចក្តីសញ្ញា
- អាពាហ៍ពិពាហ៍ និង គ្រួសារ
- ព្រះបញ្ញត្តិ

២. សូមជ្រើសរើសយកគោលលទ្ធិគ្រឹះមួយខាងលើនេះ ។ សូមសរសេរការបកស្រាយនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ពីមូលហេតុដែលគោលលទ្ធិនោះមានអត្ថន័យសម្រាប់អ្នក ។

សូមស្វែងរកគោលលទ្ធិទាំងនេះពេញមួយការសិក្សាគោលលទ្ធិ និង សេចក្តីសញ្ញារបស់អ្នកនៅឆ្នាំនេះ ហើយព្យាយាមពង្រីកចំណេះដឹង និងការយល់ដឹងរបស់អ្នកឲ្យបានជ្រៅជ្រះអំពីគោលការណ៍ទាំងនោះ ។

ដើម្បីជួយអ្នកឲ្យស្គាល់ពីធាតុចំបាច់មួយទៀតនៃសាសនាចក្រនៃព្រះអម្ចាស់ សូមមើលទៅរូបភាពទាំងឡាយខាងក្រោមនេះ ហើយគិតពីអ្វីដែលរូបភាពទាំងនេះមានដូចគ្នា ។



ពិធីបរិសុទ្ធគឺជាការប្រព្រឹត្តដ៏ពិសិដ្ឋជាផ្លូវការដែលធ្វើឡើងដោយមនុស្សដែលមានសិទ្ធិអំណាចបព្វជិតភាពត្រឹមត្រូវ និងការអនុញ្ញាតដើម្បីធ្វើពិធីបរិសុទ្ធនោះ ។ តើអ្នកគិតថាហេតុអ្វីបានជាពិធីបរិសុទ្ធទាំងឡាយជាផ្នែកដ៏ចាំបាច់ក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ? ( ដើម្បីជួយអ្នកឆ្លើយនឹងសំណួរនេះ សូមអាន យ៉ូហាន ៣:៥ ។ ក្រោយមកសូមគិតអំពីអ្វីដែលនឹងកើតឡើង ប្រសិនបើអ្នកពុំអាចទទួលបានពិធីបរិសុទ្ធនៃបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ និងទទួលព្រះវិញ្ញាណបរិសុទ្ធទេនោះ ) ។

សេចក្តីសញ្ញាគឺជា « កិច្ចព្រមព្រៀងរវាងព្រះ និងមនុស្ស ប៉ុន្តែភាគីទាំងសងខាងពុំចាំបាច់ប្រព្រឹត្តដោយស្មើភាពក្នុងកិច្ចព្រមព្រៀងនេះឡើយ ។ ព្រះដាក់លក្ខខណ្ឌទាំងឡាយសម្រាប់សេចក្តីសញ្ញា ហើយមនុស្សយល់ព្រមធ្វើតាមអ្វីដែលទ្រង់សុំឲ្យពួកគេធ្វើ ។ បន្ទាប់មក ព្រះសន្យានឹងមនុស្សនូវពរជ័យជាក់លាក់ទាំងឡាយសម្រាប់ការគោរពប្រតិបត្តិរបស់ពួកគេ » ( សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សេចក្តីសញ្ញា » scriptures.lds.org) ។ ពិធីបរិសុទ្ធគឺជាមធ្យោបាយដែលយើងបង្កើតសេចក្តីសញ្ញាជាមួយព្រះ ហើយពរជ័យទាំងឡាយកើតមានពីការរក្សាសេចក្តីសញ្ញាទាំងនោះ ។

គ្រប់ពិធីបរិសុទ្ធនៃការសង្គ្រោះនៃបព្វជិតភាពទាំងអស់ សុទ្ធតែអមមកជាមួយសេចក្តីសញ្ញា ដែលជាកិច្ចព្រមព្រៀងពិសិដ្ឋជាមួយព្រះ ។ សូមសរសេរបញ្ចូលសេចក្តីពិតតទៅនេះ ទៅក្នុងបញ្ជីក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់អ្នកថា ៖ **ក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ យើងអាចទទួលបានពិធីបរិសុទ្ធទាំងឡាយដែលចាំបាច់ដល់សេចក្តីសង្គ្រោះរបស់យើង ។**

កាលទ្រង់គង់នៅលើផែនដីនេះ ព្រះយេស៊ូវគ្រីស្ទបានស្ថាបនាធាតុនីមួយៗដែលអ្នកបានសិក្សាជាផ្នែកចាំបាច់របស់សាសនាចក្រទ្រង់ ។ បន្ទាប់ពីទ្រង់បានសុគត បានមានព្រះជន្មរស់ឡើងវិញ ហើយបានយាងឡើងទៅស្ថានសួគ៌វិញ នោះទ្រង់បានបន្តដឹកនាំ ហើយបង្រៀនពួកសាវកទ្រង់តាមរយៈវិវរណៈ ។ នៅក្រោមការដឹកនាំរបស់ពួកសាវក នោះសាសនាចក្រពីបុរាណបានរីកដុះដាលយ៉ាងរហ័ស ហើយមនុស្សរាប់ពាន់នាក់បានទទួលបុណ្យជ្រមុជទឹក ។ ក្រុមជំនុំទាំងឡាយនៃពួកបរិសុទ្ធត្រូវបានបង្កើតឡើងពេញមួយចំណែកធំនៃចក្រភព រ៉ូម ( រួមមានពួកអេស៊្បាញ ទួគី ក្រិក អ៊ីតាលី ស៊ីរី និងផ្នែកដទៃទៀតនៅប៉ែកអឺរ៉ុប អាស៊ី និង អាហ្វ្រិកនៅសម័យទំនើបនេះ ) ។ អែលឌើរ ប៊ីស្សព ឌីកុន សង្ឃ គ្រូ និងអ្នកបង្រៀនដំណឹងល្អ ( ពួកអយ្យកោ ) ត្រូវបានហៅ ហើយផ្តល់សិទ្ធិអំណាចបព្វជិតភាពត្រឹមត្រូវដោយពួកសាវក ។

## ការក្បត់សាសនាដ៏ធំកើតឡើងនៅប៉ុន្មានសតវត្សរ៍ក្រោយពីការបម្រើរបស់ព្រះអម្ចាស់ក្នុងជីវិតរមែងស្លាប់

ទោះជាមានការខិតខំពីសំណាក់ពួកសាវកយ៉ាងណាក្តី ក៏សាសនាចក្រកាលពីបុរាណបានប្រឈមមុខនឹងការគំរាមកំហែងទាំងក្នុង និងក្រៅសាសនាចក្រដែរ ។ សូមអានការដកស្រង់បទគម្ពីរខាងក្រោម រួចស្វែងរកការគំរាមកំហែងទាំងនេះ ៖

កិច្ចការ ១២:១–៣

កិច្ចការ ២០:២៩–៣០

ធីម៉ូថេ ទី ២ ៤:១–៤

ពេត្រុស ទី២ ២:១–២

៣. តើអ្នកគិតថាហេតុអ្វីបានជាការគំរាមកំហែងទាំងនេះគ្រោះថ្នាក់ដល់សាសនាចក្រ ? សូមសរសេរគំនិតរបស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

ប្រធាន ប៊ យដ៍ ឃេ ផាកកឺ ប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ពីការបាត់បង់ដ៏ធំដែលសាសនាចក្រក្នុងសញ្ញាថ្មីបានជួបប្រទះអំឡុងពេលនោះថា ៖



« យ៉ាកុបត្រូវបានសម្លាប់នៅក្រុងយេរូសាឡិមដោយស្តេចហេរ៉ូឌ ។ ពេត្រុស និងប៉ុល ស្លាប់នៅក្រុងរ៉ូម ។ ទំនៀមទម្លាប់បានប្រាប់ថា ភីលីព បានចេញទៅភាគខាងកើត ។ មានរឿងជាច្រើនទៀតដែលយើងពុំដឹង ។

« ពួកលោកបានបំបែកគ្នា ពួកលោកបានបង្រៀន ថ្លែងទីបន្ទាល់ ហើយបានស្ថាបនាសាសនាចក្រឡើង ។ ហើយពួកគេបានស្លាប់ដើម្បីជំនឿរបស់ពួកគេ ហើយដោយការស្លាប់របស់ពួកគេ នោះកើតមាននូវភាពងងឹតនៃការក្បត់សាសនាជាច្រើនសតវត្សន៍ » ( ពួកដប់ពីរនាក់ » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៨, ទំព័រ ៨៤ ) ។

តើរចនាសម្ព័ន្ធនឹងទៅជាយ៉ាងណាប្រសិនបើគ្រឹះត្រូវបានដកចេញទៅហើយនោះ ?

ការធ្លាក់នៃសាសនាចក្រកាលពីបុរាណត្រូវបានហៅថា ការក្បត់សាសនាដ៏ធំ ។ **ការក្បត់សាសនាកើតឡើងនៅពេលមនុស្សបែរចេញឆ្ងាយពីសេចក្តីពិតនៃដំណឹងល្អ ហើយបដិសេធចោលពួកអ្នកបម្រើដែលមានសិទ្ធិអំណាចពីព្រះអម្ចាស់ ។**



ប្រធាន ផាកកឺ បានពន្យល់បន្ថែមពីការបាត់បង់ដ៏ធំផងជាងគេដែលជាលទ្ធផលពីការក្បត់សាសនាដ៏ធំនោះថា ៖ « របស់ដ៏មានតម្លៃបំផុតដែលបានបាត់បង់នៅក្នុងការក្បត់សាសនា គឺសិទ្ធិអំណាចដែលពួកដប់ពីរនាក់កាន់–គឺកូនសោបព្វជិតភាព ។ ដើម្បីឲ្យសាសនាចក្រនេះ ជាសាសនាចក្រ*របស់ទ្រង់* សាសនាចក្រនេះត្រូវតែមានកូរ៉ុមមួយនៃពួកសាវកដប់ពីរនាក់ ដែលកាន់កូនសោទាំងឡាយនៃបព្វជិតភាព ហើយប្រគល់វាទៅដល់មនុស្សដទៃទៀត » («The Twelves » ទំព័រ ៨៤) ។

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការបាត់បង់សិទ្ធិអំណាចបព្វជិតភាពមានផលប៉ះពាល់ដល់ធាតុចាំបាច់ដទៃទៀតនៃសាសនាចក្រយ៉ាងដូចម្តេច ?

ខ. ហេតុអ្វីបានជាពុំមានមធ្យោបាយដើម្បីកែលម្អសាសនាចក្រឡើងវិញ ប្រសិនបើគ្មានពួកព្យាការី និងពួកសាវកសិទ្ធិអំណាចបព្វជិតភាព និងចំណេះដឹងដ៏ត្រឹមត្រូវពីគោលលទ្ធិនៃព្រះយេស៊ូវគ្រីស្ទទេនោះ ?



ប្រធាន ផាកកឺ បានមានប្រសាសន៍ពីគ្រានោះក្នុងប្រវត្តិសាស្ត្រថា ៖ « នៅពេលជាច្រើនសតវត្សន៍បានកន្លងផុតទៅ នោះអណ្ដាតភ្លើងនៃគោលលទ្ធិបានភ្លឺព្រឹមៗ រួចងងឹតសូន្យសុង ។ ពិធីបរិសុទ្ធទាំងឡាយត្រូវបានកែប្រែ ឬបោះបង់ចោល ។ ខ្សែតំណរត្រូវបានផ្ដាច់ ហើយសិទ្ធិអំណាចដើម្បីប្រគល់ព្រះវិញ្ញាណបរិសុទ្ធ ដែលជាអំណោយទានមួយ ត្រូវបានបាត់ ។ យុគសម័យដ៏ខ្មៅងងឹតនៃការក្បត់សាសនា បានរីកសាយពេញលើពិភពលោក » (The Cloven Tongues of Fire » *Ensign* ខែ ឧសភា ឆ្នាំ ២០០២,ទំព័រ ៨ ) ។

៥. សូមឆ្លើយសំណួរដូចតទៅនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថាហេតុអ្វីបានជាវាមានសារៈសំខាន់ដែលត្រូវយល់ពីការក្បត់សាសនាដ៏ធំ និងផលវិបាករបស់វា ?

នៅពេលអ្នកសិក្សាពីគោលលទ្ធិ និង សេចក្ដីសញ្ញា និង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ អំឡុងពេលវគ្គសិក្សាថ្នាក់សិក្ខាសាលាឆ្នាំនេះ អ្នកនឹងយល់ដឹងថា **ការស្ដារឡើងវិញនៃសេចក្ដីពិត និង សិទ្ធិអំណាចបព្វជិតភាពមានភាពចាំបាច់ដើម្បីយកឈ្នះលើឥទ្ធិពលនៃការក្បត់សាសនាដ៏ធំ ។** ការស្ដារឡើងវិញគឺជា « ការបង្កើតឡើងវិញរបស់ព្រះនូវសេចក្ដីពិត និង ពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អរបស់ទ្រង់ក្នុងចំណោមកូនចៅមនុស្សនៅលើផែនដី ។ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទបានបាត់បង់ពីផែនដីដោយសារការក្បត់សាសនា ដែលបានកើតមាននៅបន្ទាប់ពីការបម្រើនៃពួកសាវករបស់ព្រះយេស៊ូវគ្រីស្ទនៅលើផែនដីនេះ ។ ការក្បត់សាសនានោះបានធ្វើឲ្យមានភាពចាំបាច់ចំពោះការស្ដារឡើងវិញនៃដំណឹងល្អ » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ការស្ដារឡើងវិញនៃដំណឹងល្អ » scriptures.lds.org) ។

នៅពេលអ្នកសិក្សា អ្នកនឹងស្គាល់ពីរបៀបដែលធាតុចាំបាច់នានានៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទត្រូវបានស្ដារឡើងវិញនៅលើផែនដីតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ។ ព្រះអម្ចាស់បានស្ថាបនាសាសនាចក្រទ្រង់ឡើងសាជាថ្មី ក្នុងគោលបំណងឲ្យមានសេចក្ដីសង្គ្រោះដល់ពិភពលោក ។

៦. សូមពន្យល់ទៅកាន់សមាជិកគ្រួសារម្នាក់ ឬ មិត្តម្នាក់ ( ដោយផ្ទាល់ ) អំពីធាតុចាំបាច់នានានៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ និងពីរបៀបដែលធាតុទាំងនេះត្រូវបានបាត់បង់ពីសាសនាចក្រកាលពីបុរាណ ។ សូមពន្យល់ពីមូលហេតុដែលវាចាំបាច់ដែលត្រូវយល់ពីការក្បត់សាសនាដ៏ធំនេះ ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកពីរបៀបដែលការពិភាក្សារបស់អ្នកបានប្រព្រឹត្តទៅ និងពីរបៀបដែលសមាជិកគ្រួសារឬមិត្តរបស់អ្នកបានឆ្លើយតបមកវិញ ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សាមេរៀនអំពី « ការក្បត់សាសនាដ៏ធំ » ហើយបានបញ្ចប់វានៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១

## សេចក្ដីផ្ដើម

គិតមកដល់ត្រឹមខែ វិច្ឆិកា ឆ្នាំ ១៨៣១ ព្យាការី យ៉ូសែប ស្ម៊ីធ បានកត់ត្រាវិវរណៈជាង ៦០ វិវរណៈ ។ យ៉ាងណាក៏ដោយសមាជិកសាសនាចក្រភាគច្រើនពុំអាចទទួលបានច្បាប់ចម្លងទាំងនោះឡើយ ។ ព្យាការីបានកោះហៅប្រជុំសន្និសីទមួយក្នុងទីក្រុង ហៃរ៉ាំ រដ្ឋ អូហៃអូ ដើម្បីពិភាក្សាពីការបោះពុម្ពវិវរណៈទាំងនោះនៅក្នុងសៀវភៅមួយក្បាលដែលនឹងត្រូវបានហៅថាព្រះគម្ពីរនៃព្រះបញ្ញត្តិ ។ គណៈកម្មការនៃពួកអែលឌើរបានសរសេរសេចក្ដីព្រៀងអារម្ភកថានៃព្រះគម្ពីរនេះ ។ ដោយពុំពេញចិត្តនឹងការពង្រាងនេះ អ្នកទាំងឡាយដែលចូលរួមក្នុងសន្និសីទ បានស្នើរសុំឲ្យយ៉ូសែប ស្ម៊ីធ សួរដល់ព្រះអម្ចាស់សុំបុព្វកថាមួយ ។ បន្ទាប់ពីបានទូលសូមដល់ព្រះអម្ចាស់ក្នុងការអធិស្ឋាន យ៉ូសែបបានទទួលអារម្ភកថាមួយតាមរយៈវិវរណៈ ។ អារម្ភកថារបស់ព្រះអម្ចាស់ចំពោះព្រះគម្ពីរនៃព្រះបញ្ញត្តិសព្វថ្ងៃនេះគឺកណ្ឌទី ១ នៃគោលលទ្ធិ និង សេចក្ដីសញ្ញា ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១–១៦

*ព្រះអម្ចាស់ដាស់តឿនពីការជំនុំជម្រះដែលនឹងប្រព្រឹត្តទៅចំពោះមនុស្សដែលបះបោរនៅពេលការយាងមកជាលើកទីពីរ*



សូមពិចារណាពីបទពិសោធន៍ខាងក្រោមអំពីបងប្អូនប្រុសបីនាក់ ដែលត្រូវបានការពារឲ្យផុតពីគ្រោះថ្នាក់ ដោយព្រោះតែគេបានស្ដាប់តាមការតាស់តឿនពីឪពុកខ្លួន ៖

« មែក និងប្អូនប្រុសរបស់គាត់ អែរិក និង ថម ចូលចិត្តឡើងភ្នំជាមួយឪពុករបស់ពួកគេ ។ ឪពុកតែងនិយាយថា គាត់ស្គាល់ភ្នំជាច្រើនច្បាស់ដូចថ្ងៃអញ្ចឹង ។ គាត់បានធំដឹងក្ដីឡើងដោយបានដើរតាមផ្លូវដដែល ៗជាមួយឪពុកគាត់ដែលជាអ្នកមើលថែហ្វូងចៀម ។. . .

« . . .ថ្ងៃមួយនៅរដូវក្ដៅ [ ក្មេងប្រុសទាំងនោះ ] មានសេចក្ដីរំភើបដើម្បីទៅដល់ទិសដៅចុងក្រោយ—ជាវាលស្មៅខ្ពស់ពេញទៅដោយស្មៅពណ៌បៃតងស្រស់បំព្រង និងបុប្ផាចម្រុះពណ៌ ។ ដូច្នេះពួកគេបានរត់កាត់ព្រៃព្រឹក្សាដោយល្បឿនលឿនបំផុតទោះជាពួកគេមានការនឿយហត់ពីការឡើងភ្នំនាពេលព្រឹករួចហើយក្ដី ។ ពួកគេចង់រត់ចូលទៅវាលស្មៅនោះដូចជាសត្វទន្សាយ ។

ឪពុកបានស្រែកប្រាប់ពីក្រោយថា « ‹ នៅពេលកូន ៗទៅដល់វាលស្មៅ ឈប់នៅទីនោះសិនហើយ ។ ‹ ចាំជួបគ្នានៅទីនោះ › ។ ពួកគេបានរត់ទៅមុន ម្នាក់ ៗព្យាយាមរត់ឲ្យបានមុនអ្នកដទៃ ។. . .

« [ ពួកគេបានភ្លេច ] បណ្ដាំឪពុកខ្លួន ។ ពួកគេបានរត់ជារង្វង់កាត់ស្មៅក្រាស់ ៗ ដោយលោតឆ្លោះ ស្រែកខ្លាំង ៗ ហ៊ោកញ្ជ្រៀវ និងប្រទ្បេងគ្នា ។. . .

« ក្រោយមក អែរិក មានគំនិតមួយ ។ ‹ តោះយើងនាំគ្នារត់ប្រណាំងកាត់វាលស្មៅនេះតែម្ដងទៅ › ! ថម បានរុញរា ។ ពួកគេពុំអាចមើលឃើញត្រើយដ៏ឆ្ងាយនៃទីវាលនោះទេ ព្រោះទីទួលដែលមានស្មៅដុះពេញបានបាំងភ្នែករបស់ពួកគេ ។ ប៉ុន្តែ មែក ពុំខ្វល់ឡើយ ។ គាត់បានអះអាងទៅកាន់បងប្អូនប្រុសគាត់ថា ‹ បងគិតថានេះគឺជាវាលតែមួយដែលយើងបានមកកាលពីរដូវក្ដៅមុន › ។

« ពួកគេបានប្រជុំគ្នានៅក្រោមដើមឈើ ។ « រួចហើយ » ។ អែរិក បានស្រែក ។ ‹ រួចហើយ ! តោះទៅ ! › ខ្យល់បរិសុទ្ធ និងត្រជាក់បានបក់ប៉ះមុខ និងសក់របស់គាត់ ហើយដរាបណាគាត់រត់កាន់តែលឿន នោះខ្យល់បក់មកលើគាត់កាន់តែខ្លាំង ។ មិនយូរប៉ុន្មាន គាត់បានរត់នាំមុខគេ ។ គាត់មានអារម្មណ៍ថាគាត់អាចរត់រហូតមិនចេះហត់ ។

មានសំឡេងមួយស្រែកឡើងលាន់ឮដូចរន្ទះពីក្រោយពួកគេថា « ‹ ឈប់ ! › ភ្លាមនោះក្មេងប្រុសទាំងបីនាក់បានឈប់មួយរំពេច ។ ពួកគេបានងាកក្រោយ ហើយឃើញឪពុកកំពុងតែរត់មកកាន់ពួកគេពីជ្រុងម្ខាងនៃវាលស្មៅនោះ ។ ឪពុករូបនោះបានស្រែកហៅម្ដងទៀតដោយសំឡេងស្រទន់ជាងមុនថា ‹ នាំគ្នាមកនេះ មកក្បែរប៉ា › ។ ក្មេងប្រុសទាំងនោះបានស្ដាប់តាមបង្គាប់ ។ . . [ ក្រោយមក ] ពួកគេបានដើរឆ្លងកាត់វាលស្មៅនោះទាំងអស់គ្នា ។ នៅពេលពួកគេបានឡើងទៅលើទីទួលតូចមួយហើយ ភ្លាមនោះឪពុកបានឈប់ ។

« នៅតែពីរបីជំហានខាងមុខទៀតប៉ុណ្ណោះ មានច្រាំងចោតមួយដែលមានកម្ពស់យ៉ាងហោចណាស់ ៦ ឬ ៩ ម៉ែត្រ ។ ប្រសិនបើពួកគេកំពុងតែរត់ នោះគ្មានផ្លូវឡើយដែលពួកគេអាចឃើញច្រាំងចោត ហើយឈប់ទាន់ពេលវេលានោះ ។. . .

« . . . មែក ពោលតិចៗថា ‹ យើងអាចនឹងស្លាប់បាន ›

« ‹ មែនហើយ អាចជាអញ្ចឹង ។ ប៉ារីករាយណាស់ដែលកូនៗបានឈប់រត់ ទោះជាប៉ាពុំមានពេលពន្យល់ពីមូលហេតុយ៉ាងណាក្ដី ។ ពេលខ្លះ យើងត្រូវគោរពប្រតិបត្តិជាមុនសិន ទើបសួរសំណួរតាមក្រោយ ! ›

« មែក ពោលថា ‹ ជាពិសេស នៅពេលអ្នកណាម្នាក់ដឹងថាកំពុងមានអ្វីកើតឡើង ហើយអ្នកមិនដឹង › » ( Ana Nelson Shaw, « Stop ! » ខែ មិថុនា ឆ្នាំ ២០០៥ ទំព័រ ៤៧–៤៨ ) ។



សូមគិតពីគ្រាមួយដែលមនុស្សម្នាក់ព្យាយាមធ្វើឲ្យអ្នកយកចិត្តទុកដាក់ ហើយដាស់តឿនអ្នកពីអ្វីមួយ ។ តើអ្នកឆ្លើយតបយ៉ាងដូចម្ដេច ? តើអ្នកមានអំណរគុណចំពោះកិច្ចខិតខំរបស់បុគ្គលនោះក្នុងការដាស់តឿនអ្នកដែរឬទេ ? ហេតុអ្វីមានអំណរគុណ ឬ ហេតុអ្វីមិនមានអំណរគុណ ?

ក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ព្រះអម្ចាស់បានប្រទានការដាស់តឿន ព្រះបញ្ញត្តិ និងការណែនាំនានាដែលមានសារៈសំខាន់ខ្លាំងណាស់ចំពោះសុភមង្គល និងសេចក្ដីសង្គ្រោះរបស់យើង ។ ដូចបានពន្យល់ខាងលើ ព្រះអម្ចាស់បានបើកសម្ដែងកណ្ឌទី ១ ជាអារម្ភកថាចំពោះវិវរណៈដទៃទៀតក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ។ អារម្ភកថារៀបចំសម្រាប់អ្នកអានសម្រាប់មាតិកានៃសៀវភៅមួយ ដោយការសង្ខេបសារលិខិត និងគោលបំណងនៃអ្នកនិពន្ធ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១–៣ រួចស្វែងរកពាក្យ ឬ ឃ្លាដែលព្រះអម្ចាស់បានប្រើប្រាស់ដើម្បីទាញយកការចាប់អារម្មណ៍របស់អ្នកអាន ។ ( វាអាចនឹងជួយដល់យើងក្នុងការស្គាល់ថាពាក្យ *ចូរប្រុងស្ដាប់ចុះ* មានន័យថា ស្ដាប់ដោយយកចិត្តទុកដាក់ ហើយគោរពប្រតិបត្តិតាម ) ។ សូមឆ្លើយនឹងសំណួរខាងក្រោមក្នុងចន្លោះដែលមាន ៖

- តើនៅក្នុងខគម្ពីរទាំងនេះ ព្រះអម្ចាស់កំពុងមានព្រះបន្ទូលទៅកាន់នរណា ?
- តើអ្នកគិតថាឃ្លា « សេចក្ដីទុច្ចរិតរបស់ពួកគេនឹងត្រូវថ្លែងប្រាប់ពីលើដំបូលផ្ទះ ហើយអំពើស្ងាត់កំបាំងរបស់ពួកគេនឹងត្រូវបើកសម្ដែងមកឲ្យឃើញ » ( គ. និង ស. ១:៣) មានន័យដូចម្ដេច ?

១. សូមពន្យល់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ពីមូលហេតុដែលអ្នកគិតថាវាជាការសំខាន់ដែលត្រូវដាស់តឿនដល់ប្រជាជនថា អំពើបាបដែលបានប្រព្រឹត្តដោយស្ងាត់កំបាំងនឹងត្រូវសម្ដែងមកឲ្យឃើញ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៤–៧ រួចស្វែងរកបៀបដែលព្រះអម្ចាស់នឹងប្រទានការព្រមានរបស់ទ្រង់ទៅកាន់ប្រជាជនទាំងអស់ ។

**ព្រះអម្ចាស់មានព្រះបន្ទូលព្រមានទៅកាន់ប្រជាជនទាំងអស់តាមរយៈពួកសិស្សទ្រង់ដែលបានជ្រើសតាំង ។** ព្រះអម្ចាស់ប្រទានការព្រមានតាមរយៈពួកអ្នកបម្រើទ្រង់ និងតាមរយៈព្រះគម្ពីរ ។ សូមរំឮកឡើងវិញពីសុន្ទរកថាសន្និសីទទូទៅចុងក្រោយបង្អស់ពីគណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ តើដំបូន្មាន ឬការព្រមានណាខ្លះដែលអ្នកធ្លាប់បានឮពីពួកសាវក និងព្យាការីរបស់ព្រះអម្ចាស់ ដែលបានផ្ដល់ឲ្យក្នុងពេលថ្មីៗនេះ ?

ការព្រមានមួយដែលព្រះអម្ចាស់ប្រទានឲ្យក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៨–១០ គឺថាទ្រង់នឹងជំនុំជម្រះប្រជាជនស្រប ទៅតាមទង្វើរបស់ខ្លួន និងរបៀបដែលពួកគេប្រព្រឹត្តចំពោះមនុស្សដទៃ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១១–១៤ រួចស្វែងរកការព្រមានបន្ថែមដែលព្រះអម្ចាស់បានប្រទានឲ្យ ។ នៅពេលអ្នកមើលក្នុងសេចក្ដីយោងនៃ Topical Guide ក្នុងលេខយោង ១២ ខ សូមពិចារណាថា ព្រឹត្តិការណ៍អ្វីដែលព្រះអម្ចាស់សំដៅដល់ក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១២ ។

២. សូមឆ្លើយនឹងសំណួរបន្ទាប់នេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថា ការព្រមានរបស់ព្រះអម្ចាស់ដែលថា អស់អ្នកដែលពុំស្ដាប់តាមព្យាការី « នឹងត្រូវកាត់ចេញពីចំណោមប្រជាជន » ( គ. និង ស. ១:១៤) មានន័យដូចម្ដេច ?

ដោយសារតែសេចក្ដីទុច្ចរិត និងការក្បត់សាសនាមានពាសពេញពិភពលោក ទើបការព្រមានរបស់ព្រះអម្ចាស់គឺជាការចាំបាច់ណាស់ ។ អស់អ្នកណាដែលពុំស្ដាប់តាមប្រសាសន៍នៃព្យាការីរបស់ទ្រង់នឹងត្រូវបានដកចេញពីពួកសុចរិត ហើយបាត់បង់ពរជ័យដែលមានតាមរយៈពិធីបរិសុទ្ធ និង សេចក្ដីសញ្ញានានានៃដំណឹងល្អ ។

៣. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១៥–១៦ ។ សូមធ្វើបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីពាក្យ ឬឃ្លាណាដែលប្រាប់ពីសេចក្ដីទុច្ចរិត ឬការក្បត់សាសនាដែលព្រះអម្ចាស់បានមានព្រះបន្ទូលថានឹងកើតឡើងនៅថ្ងៃចុងក្រោយ ។ រួចសូមឆ្លើយនឹងសំណួរបន្ទាប់នេះ ៖ តើប្រជាជនក្នុងជំនាន់យើងនេះដើរ « តាមផ្លូវ [ របស់ខ្លួនគេ ] ផ្ទាល់ ហើយតាមរូបភាពនៃព្រះ [ របស់ខ្លួនគេ ] ផ្ទាល់ » តាមរបៀបណា ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១៧–៣៣

*ដំណឹងល្អត្រូវបានស្ដារឡើងវិញតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ នៅពីមុនគ្រោះមហន្តរាយដែលនឹងមកដល់*

សូមស្វែងរកពាក្យដែលព្រះអម្ចាស់បានប្រើក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១៧ ដែលសំដៅទៅលើលទ្ធផលនៃអំពើទុច្ចរិត ការក្បត់សាសនា និងការបំផ្លិចបំផ្លាញដែលនឹងកើតឡើងក្នុងចំណោមប្រជាជនលើផែនដីនៅថ្ងៃចុងក្រោយ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ១:១៧–៣៣ មាននូវដំណោះស្រាយរបស់ព្រះអម្ចាស់ដើម្បីជួយយើងឲ្យឆ្លងកាត់គ្រោះមហន្តរាយនាថ្ងៃចុងក្រោយ ។ សូមបំពេញតារាងខាងក្រោមដោយអានបទគម្ពីរយោងដែលមាននៅប្រអប់ខាងឆ្វេង រួចស្វែងរកដំណោះស្រាយរបស់ព្រះអម្ចាស់ដើម្បីជួយយើងឲ្យឆ្លងកាត់គ្រោះមហន្តរាយនាថ្ងៃចុងក្រោយ ។ នៅក្នុងប្រអប់កណ្ដាល សូមសរសេរការពិពណ៌នា ឬ គូររូបភាពនៃអ្វីដែលអ្នកស្វែងរកបានក្នុងបទគម្ពីរយោង ។ អ្នកអាចគិតពីការគូររូបភាពនៃការពិពណ៌នាទាំងនេះនៅលើទំព័រនៃសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ នៅក្នុងប្រអប់ខាងស្ដាំ សូមសរសេរការពន្យល់សង្ខេបពីរបៀបដែលដំណោះស្រាយរបស់ព្រះអម្ចាស់ជួយយើងជាមួយនឹងគ្រោះមហន្តរាយនាថ្ងៃចុងក្រោយ ។

| បទគម្ពីរយោង | តើដំណោះស្រាយដូចម្ដេចដែលព្រះអម្ចាស់ប្រទានឲ្យសម្រាប់គ្រោះមហន្តរាយដែលនឹងកើតមានលើផែនដី ? | តើដំណោះស្រាយនេះ ជួយយើងប្រឈមមុខនឹងគ្រោះមហន្តរាយនៃថ្ងៃចុងក្រោយយ៉ាងដូចម្ដេច? |
|---|---|---|
| គ និង ស ១:១៧ | | |
| គ និង ស ១:១៨–២៣ | | |
| គ និង ស ១:២៩ | | |
| គ. និង ស. ១:៣០ | | |

ដើម្បីជួយអ្នកឲ្យគិតបន្ថែមពីការប្រកាសរបស់ព្រះអម្ចាស់ក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣០ សូមគូសចំណាំពាក្យក្នុងខគម្ពីរនេះដោយផ្ដាត់ពណ៌លើសេចក្ដីពិតដែលថា **សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជាសាសនាចក្រតែមួយដែលពិត ហើយសកម្មនៅលើផែនដីនេះ ។**

៤. សូមឆ្លើយនឹងសំណួរតទៅនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ ដោយរំឭកឡើងវិញពីអ្វីដែលអ្នកបានសិក្សាកាលពីមេរៀនមុនអំពីការក្បត់សាសនាដ៏ធំ តើអ្នកនឹងពន្យល់ទៅកាន់នរណាម្នាក់ពីមូលហេតុដែល សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺជាសាសនាចក្រតែមួយដែលពិត និងសកម្មនៅលើផែនដីនេះយ៉ាងដូចម្ដេច ?



អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ពីអត្ថន័យនៃការធ្វើជាចំណែកមួយនៃសាសនាចក្រ « សកម្ម » ៖ « សាសនាចក្រដែលបានស្ដារឡើងវិញនេះ គឺពិត ព្រោះវាជាសាសនាចក្ររបស់ព្រះអង្គសង្គ្រោះ ដ្បិតទ្រង់ជា ‹ ផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត › ( យ៉ូហាន ១៤:៦ ) ។ ហើយវាជាសាសនាចក្រដ៏សកម្មដោយសារតែកិច្ចការ និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ យើងមានពរម្ល៉េះទេដែលបានរស់នៅក្នុងជំនាន់ដែលបព្វជិតភាពមាននៅលើផែនដី ហើយយើងអាចទទួលបានព្រះវិញ្ញាណបរិសុទ្ធ » ( "Receive the Holy Ghost," *Ensign* ឬ *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ៩៧ ) ។

តាមរយៈអំណោយទានព្រះវិញ្ញាណបរិសុទ្ធ នោះព្រះអម្ចាស់អាចដឹកនាំសាសនាចក្រទ្រង់ដោយវិវរណៈដែលមិនចេះរីងស្ងួត ។ វិវរណៈដែលមានជាបន្តបន្ទាប់នេះជាគំរូមួយនៃរបៀបដែលសាសនាចក្រគឺជាសាសនាចក្រសកម្ម ។

៥. សូមឆ្លើយសំណួរមួយ ឬ សំណួរទាំងពីរខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីបានជាវាមានសារៈសំខាន់សម្រាប់អ្នកដើម្បីដឹងថាអ្នកជាកម្មសិទ្ធិនៃសាសនាចក្រពិត ហើយសកម្មតែមួយគត់នៅលើផែនដីនេះ ?

ខ. តើអ្នកគិតថាវាមានន័យដូចម្ដេចក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣០ កាលព្រះអម្ចាស់បានមានព្រះបន្ទូលថា ទ្រង់សព្វព្រះហឫទ័យនឹងសាសនាចក្រ « ទាំងស្រុង ហើយមិនមែននីមួយៗ » ទេ ?

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣១–៣៣ រួចផ្គូផ្គងអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលអំពីអំពើបាប និងការប្រែចិត្តជាមួយនឹងសំណួរសមស្របក្នុងតារាងខាងក្រោម ។

| | |
|---|---|
| _____១. តើព្រះអម្ចាស់ពុំអាចទតមើលអំពើបាបយ៉ាងដូចម្ដេច ? | ក. ពន្លឺ និង ព្រះវិញ្ញាណទ្រង់នឹងត្រូវបានដកយក |
| _____២. តើអ្នកអាចបានអត់ទោសតាមរបៀបណា ? | ខ. សូម្បីតែបន្តិចបន្តួច |
| _____៣. តើមានអ្វីកើតឡើងចំពោះអ្នកដែលពុំប្រែចិត្ត ? | គ. ប្រែចិត្ត ហើយរក្សាព្រះបញ្ញត្តិទាំងឡាយ |

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៤–៣៩

*ព្រះអម្ចាស់ណែនាំយើងឲ្យស្វែងយល់ពីវិវរណៈ និងព្រះបញ្ញត្តិទាំងឡាយដែលទ្រង់បានប្រទានឲ្យ*

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៤–៣៦ រួចកត់ត្រាការដាស់តឿនរបស់ព្រះអម្ចាស់ទៅកាន់មនុស្សទាំងអស់ឲ្យត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៧–៣៩ រួចស្វែងរកសេចក្ដីពិតដែលព្រះអម្ចាស់បានគូសបញ្ជាក់នៅចុងបញ្ចប់នៃអារម្ភកថារបស់ទ្រង់ទៅកាន់គោលលទ្ធិ និង សេចក្ដីសញ្ញា ។ ( គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៧–៣៨ គឺជាចំណេះចំណាននខគម្ពីរមួយ ) ។

ប្រសិនបើអ្នកពុំទាន់បានធ្វើដូច្នេះទេ នោះអ្នកអាចគូសចំណាំពាក្យ ឬ ឃ្លាដែលបង្រៀនពីសេចក្ដីពិតដូចតទៅនេះ ៖ **យើងត្រូវស្វែងយល់ពីព្រះបញ្ញត្តិទាំងឡាយដែលព្រះអម្ចាស់បានប្រទានឲ្យ ។ ព្រះបន្ទូលរបស់ព្រះអម្ចាស់នឹងត្រូវបានបំពេញ ។ ព្រះបន្ទូលរបស់ព្រះអម្ចាស់សុទ្ធតែពិត ទោះជាថ្លែងចេញដោយទ្រង់ ឬដោយពួកអ្នកបម្រើទ្រង់ក្ដី ។**

៦. យោងតាមអ្វីដែលអ្នកបានសិក្សាថ្ងៃនេះ តើអ្នកអាចបានពរយ៉ាងដូចម្ដេច ប្រសិនបើអ្នកស្វែងយល់ពីព្រះបញ្ញត្តិ និងវិវរណៈទាំងឡាយដែលព្រះអម្ចាស់បានប្រទានឲ្យក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ? សូមសរសេរគំនិតរបស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

៧. សូមសរសេរគោលដៅមួយក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ដើម្បីសិក្សាពីគោលលទ្ធិ និងសេចក្ដីសញ្ញា ជារៀងរាល់ថ្ងៃអំឡុងពេលឆ្នាំសិក្សា ។ សូមពិចារណាពីពេលវេលា ទីកន្លែង និងរយៈពេល ឬ ចំនួនទំព័រដែលអ្នកនឹងសិក្សាជារៀងរាល់ថ្ងៃ ជាចំណែកក្នុងគោលដៅរបស់អ្នក ។

## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៧–៣៨

ដើម្បីជួយអ្នកឲ្យទន្ទេញ គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៧ សូមសរសេរតួអក្សរដំបូងគេនៃពាក្យនីមួយៗនៅលើក្រដាសមួយសន្លឹក ។ សូត្រ គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៧ ( ដោយប្រើព្រះគម្ពីររបស់អ្នកប្រសិនបើចាំបាច់ ) ដរាបដល់អ្នកអាចសូត្រខគម្ពីរទាំងស្រុងដោយប្រើតែតួអក្សរដំបូង ។ ក្រោយមកសូមលុប ឬបិទតួអក្សរមួយចំនួន ហើយសូត្រខគម្ពីរម្ដងទៀត ។ សូមបន្តដំណើរការនេះ រហូតដល់តួអក្សរទាំងអស់ត្រូវបានលុបចេញ ហើយអ្នកអាចទន្ទេញចាំខគម្ពីរទាំងមូលដោយការចងចាំ ។ សូមអនុវត្តដំណើរការនេះឡើងវិញជាមួយនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៨ ។

៨. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១ ៖ ថ្ងៃទី ៤

# ការសិក្សាព្រះគម្ពីរ

## សេចក្ដីផ្ដើម

មេរៀននេះនឹងជួយអ្នកឲ្យរៀនពីរបៀបយល់ដឹងព្រះគម្ពីរបានកាន់តែប្រសើរ ស្វែងរកគោលលទ្ធិ និង គោលការណ៍នៃដំណឹងល្អដែលមានក្នុងព្រះគម្ពីរទាំងឡាយ ហើយអនុវត្តសេចក្ដីពិតទាំងនោះក្នុងជីវិតរបស់អ្នក ។ នៅពេលអ្នកធ្វើដូចនេះ ព្រះគម្ពីរនឹងក្លាយជាធនធានដឹកនាំ និងវិវរណៈកាន់តែប្រសើរនៅក្នុងជីវិតរបស់អ្នក ។

## ការសិក្សាព្រះគម្ពីរក្នុងថ្នាក់សិក្ខាសាលា

តើអ្នកធ្លាប់ជួយនរណាម្នាក់ស្វែងរកវត្ថុដែលបានបាត់ដែរឬទេ ? ពីមុនអ្នកចាប់ផ្ដើមស្វែងរក តើអ្នកស្គាល់ពីទ្រង់ទ្រាយវត្ថុដែលអ្នកកំពុងតែស្វែងរកនោះដែរឬទេ ? ប្រសិនបើអ្នកពុំស្គាល់ពីវត្ថុដែលអ្នកកំពុងតែស្វែងរកទេនោះ តើការស្វែងរករបស់អ្នកទទួលបានជោគជ័យប៉ុណ្ណាដែរ ឬ តើអ្នកគិតថា ការស្វែងរករបស់អ្នកនោះនឹងទទួលបានជោគជ័យដល់កម្រិតណា ?



តាមរបៀបដូចគ្នានេះដែរ ការសិក្សាព្រះគម្ពីររបស់អ្នកអាចកាន់តែមានអត្ថន័យ កាលអ្នកស្គាល់ពីអ្វីដែលអ្នកស្វែងរកនៅពេលអ្នកសិក្សា ។

១. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកនូវអ្វីដែលអ្នកសង្ឃឹមថានឹងទទួលបាននៅពេលអ្នកសិក្សាព្រះគម្ពីរ ។



ប្រធាន ម៉ារ៉ុន ជី រ៉មនី ក្នុងគណៈប្រធានទីមួយ បានបង្រៀនអំពីមូលហេតុមួយដែលព្រះគម្ពីរត្រូវបានចងក្រងឡើង ដែលអាចជួយអ្នកឲ្យស្គាល់ពីអ្វីដែលត្រូវស្វែងរកនៅពេលអ្នកសិក្សាព្រះគម្ពីរថា ៖ « មនុស្សម្នាក់ពុំអាចសិក្សាបទគម្ពីរដោយស្មោះ ដោយពុំរៀនគោលការណ៍នានានៃដំណឹងល្អទេ ដោយសារតែបទគម្ពីរ ត្រូវបានសរសេរទុក ដើម្បីរក្សាគោលការណ៍នានានោះទុកជាប្រយោជន៍ដល់យើង » ( « The Message of the Old Testament » [ សុន្ទរកថាថ្លែងទៅកាន់អ្នកអប់រំសាសនា ស៊ី.អ៊ី.អេស ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៧៩ ] ទំព័រ ៣ si.lds.org ) ។

យោងតាមប្រធាន រ៉មនី ហេតុអ្វីបានជាព្រះគម្ពីរត្រូវបានចងក្រងឡើង ?

ដូច្នេះ តើយើងស្វែងរកអ្វីនៅពេលយើងសិក្សាព្រះគម្ពីរ ដើម្បីឲ្យបានប្រសើរជាងការគ្រាន់តែស្គាល់ពីសាច់រឿងលម្អិតអំពីព្រឹត្តិការណ៍នានា និងតួអង្គដែលនៅក្នុងព្រះគម្ពីរនោះ ? យើងគួរតែព្យាយាមស្វែងរកសេចក្ដីពិតនៃដំណឹងល្អដែលពួកព្យាការីជំនាន់បុរាណបានថែរក្សាទុកដែលបានមកពីព្រឹត្តិការណ៍ ទេសនកថា និងវិវរណៈនានាដែលពួកលោកបានកត់ត្រាទុកក្នុងព្រះគម្ពីរ ។ សេចក្ដីពិតទាំងនេះត្រូវបានហៅថាគោលលទ្ធិ និង គោលការណ៍ ។

គោលលទ្ធិគឺជាគ្រឹះ ជាសេចក្ដីពិតនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលពុំប្រែប្រួល ដូចជា *ព្រះវរបិតាសួគ៌មានព្រះកាយជាសាច់ និង ឆ្អឹង* ។ គោលការណ៍គឺជាសេចក្ដីពិត ឬ ច្បាប់ដ៏ខ្ជាប់ខ្ជួន ដែលយើងអាចប្រើដើម្បីដឹកនាំយើងក្នុងការធ្វើការសម្រេចចិត្ត និងការអនុវត្តគោលលទ្ធិទាំងឡាយនៅក្នុងជីវិតយើង ។ អែលឌើរ រីឆាដ ជី ស្កុត ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពិពណ៌នាអំពីរបៀបដែលគោលការណ៍នៃដំណឹងល្អអាចផ្ដល់ជាអត្ថប្រយោជន៍ដល់យើងថា ៖ « គោលការណ៍គឺជាសេចក្ដីពិតដ៏បរិសុទ្ធ

ដែលត្រូវបានរៀបចំឡើងឲ្យអនុវត្តក្នុងគ្រប់កាលៈទេសៈ ។ គោលការណ៍ពិត ធ្វើឲ្យការសម្រេចចិត្តច្បាស់លាស់ ទោះជាស្ថិតនៅក្រោមស្ថានភាពច្របូកច្របល់ និងការបង្ខិតបង្ខំដ៏ខ្លាំងបំផុតក្ដី » ( Acquiring Spiritual Knowledge » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៣, ទំព័រ ៨៦ ) ។

យោងតាមអែលឌើរ ស្កត តើគោលការណ៍គឺជាអ្វី ?

ឧទាហរណ៍នៃគោលការណ៍មួយដែលបានបង្រៀននៅក្នុងព្រះគម្ពីរ មានចែងនៅក្នុងការនិមិត្តដំបូងរបស់ យ៉ូសែប ស៊្មីធ ។ ចេញពីបទពិសោធន៍របស់ យ៉ូសែប យើងស្វែងយល់ថា **ព្រះទ្រង់ឮ ហើយឆ្លើយតបការអធិស្ឋាន ។**


២. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកនូវគោលលទ្ធិ ឬ គោលការណ៍មួយដែលអ្នកបានស្វែងយល់ដោយការសិក្សាព្រះគម្ពីរ ។

## ការយល់ដឹងអំពីបរិបទ និង មាតិកាបទគម្ពីរ

សូមស្រមៃពីរូបភាពនៃផ្លែឈើដែលមានសំបក ឬ ស្រទាប់ក្រៅដូចជា ផ្លែចេក ឬ ផ្លែក្រូច ។



តើផ្នែកណាមួយនៃផ្លែឈើដែលមានអត្ថប្រយោជន៍ជាងគេ ? តើអ្នកត្រូវតែធ្វើដូចម្ដេចពីមុនអ្នកអាចបរិភោគផ្លែឈើនោះបាន ?

ប្រសិនបើផ្នែកដែលមានសារៈសំខាន់ និង អត្ថប្រយោជន៍បំផុតនៃផ្លែឈើស្ថិតនៅខាងក្នុង តើសំបកផ្នែកខាងក្រៅមានតួនាទីអ្វី ?

ផ្លែឈើមានសំបក ដែលយើងបរិភោគឲ្យមានថាមពល និង សារជាតុចិញ្ចឹម អាចប្រៀបធៀបទៅនឹងគោលលទ្ធិ និង គោលការណ៍នានាដែលមានចែងនៅក្នុងព្រះគម្ពីរ ។ សំបកដែលនៅពីក្រៅផ្លែឈើអាចប្រៀបធៀបទៅនឹងព្រឹត្តិការណ៍ និងតួអង្គទាំងឡាយនៅក្នុងព្រះគម្ពីរ ។ គឺដូចជាសំបកខាងក្រៅដែលការពារ និងជួយដល់សាច់ផ្លែឈើផ្នែកខាងក្នុងដែរ ដំណើររឿងក្នុងព្រះគម្ពីរទាំងនេះមាន ហើយនាំមកឲ្យយើងនូវគោលលទ្ធិ និង គោលការណ៍នៃដំណឹងល្អតាមរបៀបដែលជួយយើងឲ្យយល់ ចងចាំ ហើយអនុវត្តក្នុងជីវិតរបស់យើង ។



ប្រសិនបើអ្នកមានផ្លែឈើមួយចំណិត សូមចិត/បកសំបកចេញដើម្បីអ្នកអាចឃើញសាច់ផ្លែឈើខាងក្នុង ( ឬគិតពីមធ្យោបាយផ្សេង ៗគ្នាដែលអ្នកអាចបានសាច់ផ្លែចេក ឬផ្លែក្រូច ) ។ សកម្មភាពដែលត្រូវបក/ចិតសំបកខាងក្រៅ ហើយបង្ហាញសាច់ផ្លែឈើខាងក្នុងគឺស្រដៀងគ្នាទៅនឹងអ្វីដែលយើងត្រូវតែធ្វើដើម្បីបើក ឬដកយកនូវវគ្គបទគម្ពីរ ។ ដើម្បីបកសំបកបើកព្រះគម្ពីរ ហើយបង្ហាញសាច់ផ្លែឈើខាងក្នុង យើងត្រូវយល់ពីទិដ្ឋភាពជាប្រវត្តិសាស្ត្រនៃវិវរណៈ ហើយក៏ត្រូវព្យាយាមស្វែងយល់ពីព្រឹត្តិការណ៍ តួអង្គ និងអត្ថន័យនៃសម្ដីទាំងឡាយ ។ នៅពេលយើងធ្វើដូច្នេះ គោលលទ្ធិ និង គោលការណ៍ទាំងឡាយដែលមានក្នុងដំណើររឿងព្រះគម្ពីរនឹងកាន់តែមានភាពងាយស្រួលអាន និងយល់ ។

ចំណុចខាងក្រោមនេះគឺជាវិធីសាស្ត្រ និងជំនាញសំខាន់ៗដើម្បីជួយអ្នកយល់កាន់តែប្រសើរពីបទគម្ពីរនៅពេលអ្នកសិក្សាពីវា ។ នៅចុងបញ្ចប់នៃមេរៀននេះ អ្នកនឹងរកឃើញជំនាញ និងវិធីសាស្ត្របន្ថែមអំពីការសិក្សាព្រះគម្ពីរ ។

**ទិដ្ឋភាពជាប្រវត្តិសាស្ត្រ ៖** កណ្ឌនីមួយៗនៃគោលលទ្ធិ និង សេចក្ដីសញ្ញា មាននូវសេចក្ដីណែនាំអំពីកណ្ឌ ដែលជាញឹកញាប់ប្រាប់ពីកង្វល់ សំណួរ ឬ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដែលបង្កើតបានជាវិវរណៈក្នុងកណ្ឌមួយនោះ ។ ការស្គាល់ពីសេចក្ដីលម្អិតទាំងនេះអាចជួយអ្នកឲ្យយល់ពីវិវរណៈ ។


៣. ដើម្បីឃើញពីរបៀបដែលការស្គាល់ទិដ្ឋភាពជាប្រវត្តិសាស្ត្រអាចបង្កើនការយល់ដឹងពីវិវរណៈ សូមអាន សេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១ និង ខ ១–៨ ។ សូមពិពណ៌នានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបដែលការដឹងថា ព្យាការីយ៉ូសែប ស៊្មីធ ត្រូវបានឃុំខ្លួនក្នុងគុក

លីបើធីអស់រយៈពេលបីបួនខែ បន្ថែមអត្ថន័យទៅក្នុងការអធិស្ឋានរបស់លោក និងចម្លើយរបស់ព្រះអម្ចាស់នៅក្នុងខគម្ពីរទាំងនេះ ។

**និយមន័យពាក្យ** ៖ ពាក្យមួយចំនួនដែលត្រូវបានប្រើក្នុងព្រះគម្ពីរអាចជាពាក្យពិបាកយល់ ។ Bible Dictionary សេចក្ដីណែនាំដល់បទគម្ពីរ លេខយោងបទគម្ពីរ និងវចនានុក្រមធម្មតាអាចជួយអ្នកឲ្យយល់ពីអត្ថន័យនៃពាក្យទាំងនោះ ។

ឧទាហរណ៍ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១,៤ ។ ពាក្យ *ព្រះពន្លា* សំដៅលើត្រសាល ឬ សំណង់ការពារ ។ តើការស្គាល់បែបនេះជួយអ្នកឲ្យយល់កាន់តែច្បាស់ពីខគម្ពីរទាំងនេះយ៉ាងដូចម្ដេច ?

**បទគម្ពីរយោង** ៖ ជាញឹកញាប់ វគ្គបទគម្ពីរមួយអាចជួយពន្យល់ ឬបកស្រាយអត្ថន័យនៃឃ្លា ឬ គំនិតដែលមានក្នុងវគ្គបទគម្ពីរមួយទៀត ។ ឧទាហរណ៍ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៥៥ ។ ខគម្ពីរនេះទំនងជាបង្ហាញថា ការណ៍តែមួយគត់ដែលតម្រូវឲ្យមានដើម្បីគ្រងនគរសេឡេស្ទាលគឺត្រូវធ្វើជាសមាជិកសាសនាចក្រ ។ ឥឡូវនេះ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៦៧ រួចកត់ចំណាំពីអ្វីដែលវាបង្រៀនអំពីការធ្វើជាសមាជិកសាសនាចក្រ ។

4. សូមពន្យល់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកពីរបៀបដែល គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧ ជួយអ្នកយល់ពីអត្ថន័យនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៥៥ និង ១០:៦៧ ។ អ្នកអាចចង់សរសេរ *គ. និង ស. ១០:៦៧; ២០:៣៧* នៅគែមទំព័រក្បែរនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៥៥ ជាបទគម្ពីរយោង ។

## ស្គាល់ពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយ

នៅពេលអ្នកបង្កើនការយល់ដឹងពីប្រវត្តិ ពាក្យសម្ដី តួអង្គ និងព្រឹត្តិការណ៍នានាដែលមានចែងក្នុងព្រះគម្ពីរ គឺអ្នកបានត្រៀមខ្លួនកាន់តែប្រសើរដើម្បីស្គាល់សេចក្ដីពិតនៃដំណឹងល្អដែលមានក្នុងអ្វីទាំងអស់នេះ ។

គោលលទ្ធិ និង គោលការណ៍នៃដំណឹងល្អមួយចំនួនគឺស្រួលស្គាល់ ដោយសារវាត្រូវបានថ្លែងត្រង់ៗនៅក្នុងគម្ពីរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២២ រួចគូសចំណាំគោលលទ្ធិ និង គោលការណ៍ទាំងឡាយដែលត្រូវបានថ្លែងត្រង់ៗក្នុងខគម្ពីរនេះ ។ ក្នុងចំណោមគោលលទ្ធិដែលបានប្រកាសក្នុងខគម្ពីរនេះគឺសេចក្ដីពិតដែលថា **ព្រះវរបិតា និង ព្រះរាជបុត្រាមានព្រះកាយជាសាច់ និង ឆ្អឹងដែលជាក់ស្ដែងដូចជារូបកាយមនុស្ស** ហើយ **ព្រះវិញ្ញាណបរិសុទ្ធគឺជាតួអង្គវិញ្ញាណ ។**

មានគោលលទ្ធិ និង គោលការណ៍ជាច្រើនដែលពុំបានថ្លែងដោយត្រង់ៗក្នុងព្រះគម្ពីរទេ ប៉ុន្តែ ត្រូវបានបង្ហាញ ឬ ពិពណ៌នាពេញទាំងបីបួនខគម្ពីរ ។ ដើម្បីស្គាល់គោលលទ្ធិ និង គោលការណ៍ទាំងនេះ យើងត្រូវស្គាល់សេចក្ដីពិតដែលត្រូវបានបង្ហាញនៅក្នុងវគ្គបទគម្ពីរ ហើយក្រោយមកថ្លែងសេចក្ដីពិតទាំងនោះឲ្យបានច្បាស់ ហើយងាយយល់ ។ ជាញឹកញាប់ការណ៍នេះត្រូវការពេលវេលា និង ការគិតដោយប្រុងប្រយ័ត្ន ។



អែលឌើរ រីឆាដ ជី ស្កុត បានផ្ដល់ដំបូន្មានដូចនេះថា ៖ « នៅពេលអ្នកស្វែងរកចំណេះដឹងខាងវិញ្ញាណ ចូរស្វែងរកគោលការណ៍នានា ។ សូមបែងចែកវាចេញពីព័ត៌មានលម្អិត ដែលបានប្រើដើម្បីពន្យល់វានោះដោយប្រុងប្រយ័ត្ន › » ។ . . . វាសក្ដិសមនឹងកិច្ចខិតខំដ៏មហិមាដើម្បីរៀបចំសេចក្ដីពិតដែលយើងប្រមូលផ្ដុំដើម្បីបង្កើតសេចក្ដីថ្លែងការណ៍សាមញ្ញអំពីគោលការណ៍ »(«Acquiring Spiritual Knowledge » ទំព័រ ៨៦ )។

នៅពេលអ្នករៀនពីរបៀបស្គាល់គោលលទ្ធិ និង គោលការណ៍ទាំងឡាយដែលពុំត្រូវបានថ្លែងដោយត្រង់ៗ នោះអ្នកអាចនឹងសួរសំណួរដូចជា ៖ ហេតុអ្វីបានជាព័ត៌មាននេះត្រូវបានកត់ត្រាទុកក្នុងបទគម្ពីរនេះ ? តើអ្នកនិពន្ធចង់ឲ្យអ្នកអានរៀន ហើយយល់ដឹងពីអ្វី ? តើខ្ញុំអាចរៀនអ្វីពីការណ៍នេះ ដែលអាចជួយខ្ញុំក្នុងជីវិតបាន ? តើខ្ញុំអាចរៀនអ្វីពីការណ៍នេះ ដែលអាចជួយខ្ញុំក្នុងការចែកចាយដំណឹងល្អជាមួយមនុស្សដទៃបាន ?

5. សូមអនុវត្តការស្គាល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយដោយរំឭក គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១–៨ រួចសួរខ្លួនឯងនូវសំណួរពីមុននេះមួយចំនួន ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកនូវសេចក្ដីពិតចំនួនមួយ ឬពីរដែលអ្នករៀនពីការអធិស្ឋានរបស់ព្យាការី យ៉ូសែប ស្ម៊ីធ និង ចម្លើយរបស់ព្រះអម្ចាស់ចំពោះការអធិស្ឋាននោះ ។

## អនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៅក្នុងជីវិតអ្នក

សូមគិតម្ដងទៀតពីផ្លែឈើដែលបានពិភាក្សានៅដើមមេរៀន ។ តើផ្លែឈើនោះនឹងមានតម្លៃអ្វីទៅ ប្រសិនបើវាត្រូវបានបក/ចិតសំបកចេញ ហើយពុំត្រូវបានប្រើអ្វីសោះនោះ ?

ប្រសិនបើយើងប្រៀបធៀបសាច់ផ្លែឈើក្នុងសំបកនោះទៅនឹងគោលលទ្ធិ និង គោលការណ៍ទាំងឡាយដែលយើងស្គាល់ក្នុងព្រះគម្ពីរ តើយើងគួរធ្វើដូចម្ដេចជាមួយនឹងសេចក្ដីពិតទាំងនេះនៅពេលយើងរកវាឃើញហើយនោះ ?

គុណប្រយោជន៍នៃកិច្ចការដែលយើងធ្វើដើម្បីចិត/បកសំបកចេញនោះ គឺជាសារធាតុចិញ្ចឹម និងថាមពលដែលយើងទទួលបានពីសាច់ផ្លែឈើខាងក្នុង ។ តាមរបៀបដូចគ្នានេះដែរ គុណប្រយោជន៍នៃការសិក្សាព្រះគម្ពីរកើតមាននៅពេលយើងយកគោលលទ្ធិ និង គោលការណ៍ទាំងឡាយដែលយើងស្គាល់មក ហើយអនុវត្តក្នុងជីវិតរបស់យើង ។ វិវរណៈជាច្រើននៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញាត្រូវបានប្រទានដល់បុគ្គលជាច្រើនដែលមានសំណួរ ឬ កង្វល់នានា ប៉ុន្តែ យើងអាចអនុវត្តដំបូន្មាន និងការបង្រៀនទាំងឡាយនៅក្នុងជីវិតផ្ទាល់ខ្លួនបានផងដែរ ។ ទោះជាកណ្ឌភាគច្រើនសំដៅទៅលើសមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយយ៉ាងណាក្ដី ក៏សារលិខិត ការព្រមាន និងការក្រើនរំឭកនានាផ្ដល់ជាគុណប្រយោជន៍ដល់មនុស្សគ្រប់គ្នាផងដែរ ។

៦. សូមគិតពីឧទាហរណ៍មួយនៃសេចក្ដីពិតនៃដំណឹងល្អដែលអ្នកបានសិក្សាចេញពីបទគម្ពីរ និង ពីរបៀបដែលវាផ្ដល់ពរដល់ជីវិតអ្នកនៅពេលអ្នកបានអនុវត្តវា ។ សូមកត់ត្រាបទពិសោធន៍របស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។



ប្រធាន បិយដ៍ យេ ផាកកឺ ជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានផ្ដល់ជាការសន្យាទៅកាន់អស់អ្នកដែលសិក្សាព្រះគម្ពីរ ហើយអនុវត្តសេចក្ដីពិតដែលវាមានដូចនេះថា ៖ « បើ [ អ្នក ] បានស្គាល់វិវរណៈ នោះអ្នកគ្មានការសង្ស័យទេ–ទោះជាផ្ទាល់ខ្លួន ជាសង្គម ឬនយោបាយ ឬវិជ្ជាជីវៈក្ដី– ដែលពុំចាំបាច់មានចម្លើយទេ ។ វាមាននូវភាពពោរពេញនៃដំណឹងល្អដ៏អស់កល្បជានិច្ច ។ នៅក្នុងនោះ យើងរកឃើញគោលការណ៍នៃសេចក្ដីពិត ដែលនឹងដោះស្រាយរាល់ការច្របូកច្របល់ និងរាល់បញ្ហា និងរាល់ទុក្ខគ្រោះ ដែលនឹងប្រឈមមុខចំពោះគ្រួសារមនុស្ស ឬបុគ្គលម្នាក់ៗនោះ » ( « Teach the Scriptures » [ address to CES religious educators ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៧៧ ] ទំព័រ ៣–៤ si.lds.org) ។

អ្នកអាចនឹងចង់គូសចំណាំផ្នែកនានានៃការសន្យារបស់លោក ដែលមានអត្ថន័យចំពោះអ្នក ។

សូមគិតពីការដាក់គោលដៅមួយដើម្បីជួយអ្នកឲ្យអនុវត្តសេចក្ដីពិតមួយដែលអ្នកបានរៀនអំឡុងពេលការសិក្សាព្រះគម្ពីររបស់អ្នកនៅថ្ងៃនេះ ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សាមេរៀនអំពី « ការសិក្សាព្រះគម្ពីរ » ហើយបានបញ្ចប់វានៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែមដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

## ជំនាញ និង វិធីសាស្ត្របន្ថែមនៃការសិក្សាព្រះគម្ពីរ

**ការប្រើឈ្មោះជំនួស** ៖ ដើម្បីជួយអ្នកឲ្យអនុវត្តគោលការណ៍ទាំងឡាយចេញពីព្រះគម្ពីរនៅក្នុងជីវិតអ្នក សូមប្រើឈ្មោះរបស់អ្នកជំនួសឈ្មោះដែលមានក្នុងព្រះគម្ពីរ ។ សូមសាកល្បងដំណើរការនេះជាមួយនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:២០ ។

**បុព្វហេតុ និង លទ្ធផល** ៖ ដើម្បីជួយអ្នកឲ្យស្គាល់គោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អក្នុងព្រះគម្ពីរ សូមស្វែងរកទំនាក់ទំនងនៃពាក្យ បើសិនជា–នោះ/ខណៈនោះ និង មកពី/ពីព្រោះ–ហេតុដូច្នេះហើយ ។ សូមសាកល្បងដំណើរការនេះជាមួយនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:២៤ ។

**ពាក្យគន្លឹះ** ៖ ពាក្យ និង ឃ្លាដូចជា « មើលចុះ » « ហេតុដូច្នេះហើយ » « ពីព្រោះ/មកពី » « ហេតុដូច្នោះហើយ » « ទោះជាយ៉ាងណាក៏ដោយ » ឬ « ដូច្នេះយើងឃើញថា » សុទ្ធតែជាការអញ្ជើញឲ្យឈប់ ហើយស្វែងរកសារលិខិតជាក់លាក់ផ្សេងៗ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:២៦ រួចកត់ចំណាំពីរបៀបដែលពាក្យគន្លឹះអាចជួយអ្នកឲ្យស្គាល់គោលលទ្ធិ និង គោលការណ៍ទាំងឡាយ ។

**បញ្ជីបទគម្ពីរ** ៖ ជាញឹកញាប់មាននូវបញ្ជីនានាដូចជាបញ្ជីលក្ខណៈសម្បត្តិអាកប្បកិរិយា សេចក្ដីណែនាំ ឬ ការព្រមាន ។ នៅពេលអ្នករកឃើញបញ្ជី សូមគិតពីការចុះលេខលើចំណុចនីមួយៗ ។ សូមសាកល្បងដំណើរការនេះជាមួយនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៥–៦ ។

**ភាពផ្ទុយ** ៖ បទគម្ពីរជាញឹកញាប់បង្ហាញពីភាពផ្ទុយក្នុងគំនិត ព្រឹត្តិការណ៍ និងតួអង្គ ។ ភាពផ្ទុយទាំងនេះគូសបញ្ជាក់ពីគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ សូមស្វែងរកភាពផ្ទុយក្នុងខគម្ពីរនីមួយៗក្នុងជំពូក និងពេញមួយជំពូក និងពេញមួយព្រះគម្ពីរ ។ សូមសាកល្បងដំណើរការនេះជាមួយនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:២៣–២៥ ។

**ការស្រមៃ** ៖ សូមស្វែងរកការពិពណ៌នាសេចក្ដីលម្អិតដែលអាចជួយអ្នកឲ្យបង្កើតរូបភាពក្នុងគំនិតនូវអ្វីដែលអ្នកអាន ។ សូមស្រមៃថាអ្នកកំពុងមានវត្តមានក្នុងព្រឹត្តការណ៍ជាក់លាក់នានា ។ ការធ្វើដូចនេះនឹងជួយពង្រឹងទីបន្ទាល់របស់អ្នកអំពីភាពពិតនៃអ្វីដែលអ្នកអានក្នុងព្រះគម្ពីរ ។ សូមសាកល្បងដំណើរការនេះជាមួយនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៤៤–៤៦ ។

**និមិត្តសញ្ញា** ៖ ពាក្យ និង ឃ្លាមានដូចជា « ដូច » « ដូចជា » ឬ « ប្រៀបប្រដូចទៅនឹង » អាចជួយអ្នកស្គាល់ពីនិមិត្តសញ្ញានានា ។ សម្លឹងមើលឲ្យហួសពីនិមិត្តសញ្ញាមួយដោយស្រាវជ្រាវពីលក្ខណៈធម្មជាតិ ហើយគិតពីឥរិយាបថរបស់វា ។ លេខយោង Bible Dictionary និង សេចក្ដីណែនាំដល់បទគម្ពីរ អាចជួយអ្នកឲ្យបកស្រាយពីនិមិត្តសញ្ញាមួយចំនួនបាន ។ សូមសាកល្បងដំណើរការនេះជាមួយនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤៦, ៥១–៦១ ។

**ការសញ្ជឹងគិត** ៖ ការពិចារណារួមមាន ការគិត ការស្ញឹងស្ញាធ ការសួរសំណួរ ហើយនិងការវាយតម្លៃនូវអ្វីៗដែលអ្នកដឹង និងអ្វីៗដែលអ្នកបានរៀន ។ ជាញឹកញាប់ ការពិចារណា ជួយយើងឲ្យយល់ពីអ្វីដែលយើងត្រូវធ្វើ ដើម្បីយកគោលការណ៍នានានៃដំណឹងល្អមកអនុវត្ត ។ ប្រធាន ដេវីឌ អូ មិកឃេ បានបង្រៀនថា « ការស្ញឹងស្ញាធគឺជាច្រកចូលដ៏អាថ៌កំបាំង និងពិសិដ្ឋបំផុតមួយ ដែលយើងដើរចូលទៅកាន់វត្តមានរបស់ព្រះអម្ចាស់បាន » (*Teachings of Presidents of the Church: David O. McKay* [ ឆ្នាំ ២០០៣ ] ទំព័រ ៣២) ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១–៤ ស្វែងរកគំរូនៃមនុស្សដែលប្រើដំណើរការមួយនេះ ។

មេរៀនទី ២ ៖ ថ្ងៃទី ១

# យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១–២០

## សេចក្ដីផ្ដើម

នៅឆ្នាំ ១៨៣៨ យ៉ូសែប ស្ម៊ីធ បានចាប់ផ្ដើមធ្វើការអំពីប្រវត្តិនៃគ្រួសារលោកជាផ្លូវការ ។ ក្នុងនោះលោកបានសរសេរប្រាប់ពីក្រុមគ្រួសារ និងទីកន្លែងផ្សេងៗដែលពួកលោកបានរស់នៅ ។ លោកក៏បានប្រាប់ផងដែរអំពី « ការរំភើបខុសប្រក្រតី » អំពីវិស័យសាសនាដែលរីកសុះសាយពេញរដ្ឋនូវយ៉ោកភាគខាងលិចក្នុងឆ្នាំ ១៨២០ ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥ ) ។ សេចក្ដីរំភើបដ៏ធំនេះបាននាំឲ្យលោក « មានគំនិតគិតពិចារណាដ៏ជ្រាលជ្រៅ ហើយមានចិត្តខ្វល់ខ្វាយជាខ្លាំង » ដោយសារតែ « ការរំជួល និងការឈ្លោះប្រកែកគ្នាជាខ្លាំងក្នុងចំណោមបក្សពួកផ្សេងៗ » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៨ ) ។

កាលកំពុងស្រាវជ្រាវព្រះគម្ពីរ យ៉ូសែប បានអាននៅក្នុងគម្ពីរ យ៉ាកុប ១:៥ ( សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១១ ) ដែលទូន្មានដល់អស់អ្នកដែលត្រូវការប្រាជ្ញាឲ្យ « សូមដល់ព្រះ » ។ យ៉ូសែប បានសរសេរថា ៖ « ពុំដែលមានបទគម្ពីរណាមួយ ដែលមានប្រសិទ្ធិភាពទៅលើចិត្តមនុស្ស ដូចជាបទគម្ពីរនេះមានប្រសិទ្ធិភាពមកលើចិត្តខ្ញុំឡើយ ។ មើលទៅហាក់បីដូចជាចូលមកពេញដួងចិត្តដោយឥទ្ធិពលដ៏មហិមា ។ ខ្ញុំតែងតែពិចារណាគិតអំពីរឿងនោះម្ដងហើយម្ដងទៀត ដោយដឹងថា បើមានអ្នកណាមួយដែលត្រូវការប្រាជ្ញាពីព្រះ គឺខ្លួនខ្ញុំនេះហើយ តែនឹងធ្វើណានោះខ្ញុំមិនដឹងទេ ហើយលើកលែងតែខ្ញុំអាចមានប្រាជ្ញាលើសជាងដែលខ្ញុំមាន នោះខ្ញុំនឹងមិនដឹងសោះ ដ្បិតពួកគ្រូបង្រៀនសាសនាពីបក្សពួកផ្សេងៗគេយល់បទគម្ពីរតែមួយខុសឆ្ងាយពីគ្នា ធ្វើយ៉ាងនេះដូចជាបំផ្លាញនូវការទុកចិត្តទាំងអស់ បើចង់បានការដោះស្រាយនូវសំណួរនេះដោយពឹងផ្អែកទៅលើព្រះគម្ពីរប៊ីប » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១២ ) ។ លោកក៏បានសម្រេចចិត្តថានឹងសូមដល់ព្រះនៅក្នុងការអធិស្ឋានដើម្បីទទួលបានចម្លើយចំពោះសំណួររបស់លោក ។ ក្នុងការឆ្លើយតបដល់ការអធិស្ឋានរបស់លោក ព្រះជាព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ បានបង្ហាញព្រះកាយមកឲ្យលោកឃើញ ។

### យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១–៤

*យ៉ូសែប ស្ម៊ីធ ចាប់ផ្ដើមសរសេរជីវប្រវត្តិរបស់លោក*

ប្រធាន ថូម៉ាស អេស ម៉នសុន ដែលបានបម្រើជាប្រធានបេសកកម្មប្រទេសកាណាដា បានចែកចាយបទពិសោធន៍របស់អ្នកពួកផ្សព្វផ្សាយសាសនាពីររូបរបស់លោកថា ៖



« [ អ្នកផ្សព្វផ្សាយសាសនា ] ពីរនាក់ត្រូវបានហៅនៅផ្ទះរបស់លោក អ៊ីមើរ ផូឡាដ ហើយគាត់ដោយក្ដីអាណិតអាសូរដល់អ្នកផ្សព្វផ្សាយសាសនាដែលស្ទើរតែរងារកកខ្លួន នោះលោកបានអញ្ជើញពួកគេឲ្យចូលផ្ទះ ។ ពួកគេបានបង្ហាញសារលិខិតរបស់ពួកគេ ហើយសួរគាត់ បើគាត់នឹងចូលរួមក្នុងការអធិស្ឋានជាមួយពួកគេ ។ គាត់បានយល់ព្រម តែទាល់តែគាត់ជាអ្នកធ្វើការអធិស្ឋាន ។

« ការអធិស្ឋានរបស់គាត់ បានធ្វើឲ្យអ្នកផ្សព្វផ្សាយសាសនាមានការភ្ញាក់ផ្អើលជាខ្លាំង ។ គាត់អធិស្ឋានថា ‹ ព្រះវរបិតាសួគ៌អើយ សូមប្រទានពរដល់អ្នកផ្សព្វផ្សាយសាសនាដ៏អភ័ព្វ និងល្ងិតល្ងង់ពីរនាក់នេះផង ដើម្បីពួកគេអាចត្រឡប់ទៅផ្ទះវិញ ហើយកុំខ្ជះខ្ជាយពេលវេលាដើរនិយាយប្រាប់ប្រជាជនកាណាដា អំពីសារលិខិត ដែលមិនគួរឲ្យជឿនេះ ហើយដែលពួកគេចេះតែបន្តិចបន្តួចនេះឡើយ › ។

« នៅពេលពួកគេក្រោកឡើង នោះលោក ផូឡាត បានសុំឲ្យអ្នកផ្សព្វផ្សាយសាសនាកុំត្រឡប់មកផ្ទះគាត់ទៀតឡើយ ។ នៅពេលពួកគេចាកចេញទៅ គាត់បាននិយាយចំអកដាក់ពួកគេ ‹ អ្នកមិនអាចទាំងប្រាប់ខ្ញុំថា អ្នកពិតជាជឿថា យ៉ូសែប ស្ម៊ីធ ជាព្យាការីម្នាក់របស់ព្រះផងហ្នឹង ណាស់ហើយចុះ › ហើយគាត់បានរុញទ្វាបិទទៅ » ( «The Prophet Joseph Smith: Teacher by Example, » *Ensign* ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ៦៩ ) ។

ប្រសិនបើអ្នកគឺជាម្នាក់ក្នុងចំណោមអ្នកផ្សព្វផ្សាយសាសនាទាំងនោះ តើអ្នកនឹងថ្លែងដូចម្ដេចទៅកាន់លោក ផូឡឹដ អំពីព្យាការី យ៉ូសែប ស្ម៊ីធ ?

ព្យាការី យ៉ូសែប ស្ម៊ីធ បានសរសេរពីដំណើរជីវិតរបស់លោកដែលមានចែងក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ក្នុងឆ្នាំ ១៨៣៨ ក្នុងគោលបំណងបោះពុម្ពជាប្រវត្តិផ្លូវការរបស់សាសនាចក្រ ។ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១–២ រួចស្វែងរកមូលហេតុដែល យ៉ូសែប ស្ម៊ីធ បានផ្ដល់ឲ្យក្នុងការសរសេរពីប្រវត្តិជាផ្លូវការនេះ ។

យ៉ូសែប ស្ម៊ីធ—ប្រវត្តិ រួមមាននូវដំណើររឿងផ្ទាល់ខ្លួននៃការនិមិត្តដំបូងរបស់ព្យាការី ។ មានដំណើររឿងនៃការនិមិត្តដំបូងដែលគេស្គាល់មួយចំនួន—បួនត្រូវបានសរសេរ ឬហៅឲ្យសរសេរតាមដោយយ៉ូសែប ស្ម៊ីធ និងផ្សេងទៀតត្រូវបានសរសេរដោយអ្នក

ដែលបានរំពុកឡើងវិញពីបទពិសោធន៍របស់យ៉ូសែប ស្ម៊ីធ ដោយសម្ដីផ្ទាល់របស់គេ ។ ដំណើររឿងទាំងនេះត្រូវបានរៀបរៀងឡើងនៅពេលខុស ៗគ្នា សម្រាប់អ្នកអានខុសគ្នា និង គោលបំណងផ្សេងគ្នា ។ ដំណើររឿងទាំងនេះរៀបរៀងឡើងដោយយល់ស្របគ្នាចំពោះសេចក្ដីពិតដ៏ចាំបាច់ដែលថា យ៉ូសែប ស្ម៊ីធ ពិតជាបានធ្វើឲ្យស្ថានសួគ៌បើកចំហដល់លោក ហើយឃើញសារទូតសួគ៌ា ដែលរួមមានទាំងព្រះជាព្រះវរបិតា និង ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។ ដោយសារតែដំណើររឿងក្នុងឆ្នាំ ១៨៣៨ គឺជាផ្នែកនៃប្រវត្តិជាផ្លូវការរបស់យ៉ូសែប ស្ម៊ីធ និងជាទីបន្ទាល់ទៅកាន់ពិភពលោក ទើបវាត្រូវបានបញ្ចូលទៅក្នុងគម្ពីរមុក្តាដ៏មានតម្លៃមហិមា ។

## យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥–១៣

*ស្ថិតនៅក្នុងការវង្វេលខាងសាសនានេះ យ៉ូសែប ស្ម៊ីធ ប្ដេជ្ញាចិត្តសូមដល់ព្រះថាតើសាសនាចក្រមួយណាត្រឹមត្រូវ*

យ៉ូសែប ស្ម៊ីធ បានរស់នៅអំឡុងពេលមានការចាប់អារម្មណ៍ និង ការរំភើបដ៏ធំអំពីសាសនា ។ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥–៧ រួចស្វែងរកពាក្យ ឬឃ្លាដែលពិពណ៌នាអំពីស្ថានភាពដែល យ៉ូសែប បានប្រឈមមុខ ។ អ្នកអាចនឹងចង់គូសចំណាំពាក្យទាំងនេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។ ពេលអ្នកបញ្ចប់ការស្វែងរក សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៨, ១០ ដោយស្វែងរកការពិពណ៌នារបស់យ៉ូសែប ស្ម៊ីធ ថាតើលោកបានមានអារម្មណ៍យ៉ាងណាក្នុងពេលនោះ ។

១. សូមសង្ខេបក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកពី យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥–៧ ដោយស្រមៃថាខ្លួនអ្នកត្រូវពន្យល់ពីស្ថានភាព និងគ្រាលំបាករបស់យ៉ូសែប ទៅកាន់នរណាម្នាក់ដែលពុំដែលបានឮពី យ៉ូសែប ស្ម៊ីធ ។ សូមសរសេរបញ្ចូលគំនិតឲ្យបានយ៉ាងហោចណាស់បីដែលអ្នកគិតថាគួរលើកឡើងពីយ៉ូសែប ស្ម៊ីធ ។

សូមគិតអំពីស្ថានភាពដែលបណ្ដាលឲ្យអ្នកសួរសំណួរមួយចំនួន ហើយពិចារណាពីអ្វីដែលអ្នកបានធ្វើដើម្បីដោះស្រាយកង្វល់ផ្ទាល់ខ្លួន ។ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១១ រួចស្វែងរកទីកន្លែងដែលយ៉ូសែប ស្ម៊ីធ បានទទួលចម្លើយចំពោះសំណួររបស់លោក ។ សូមយកពេលបន្តិច ហើយសូត្រឡើងវិញ ឬ ទន្ទេញឮៗ យ៉ាកុប ១:៥ ដែលបានដកស្រង់ក្នុង ខទី ១១ ។

គោលការណ៍មួយដែលមានក្នុង យ៉ាកុប ១:៥ ដែលបានជួយដល់យ៉ូសែប ស្ម៊ីធ ស្វែងរកចម្លើយចំពោះសំណួររបស់លោកគឺ **ប្រសិនបើយើងសូមដល់ព្រះក្នុងសេចក្ដីជំនឿ នោះទ្រង់នឹងឆ្លើយតបការអធិស្ឋានរបស់យើង** ។ សូមគូសចំណាំពាក្យ ឬ ឃ្លាដែលបង្រៀនពីគោលការណ៍នេះនៅក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១១ ។ ដោយយល់ថា ព្រះនឹងឆ្លើយតបការអធិស្ឋានរបស់យើងតាមកាលវេលា និងរបៀបរបស់ទ្រង់ នោះសូមពិចារណាពីរបៀបដែលអ្នកឃើញថាគោលការណ៍នេះពិតក្នុងជីវិតផ្ទាល់របស់អ្នក ។

យ៉ូសែប បានប្រាប់ពីរបៀបដែលវគ្គបទគម្ពីរនេះបានមានអានុភាពលើរូបលោក ។ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១២–១៣ រួចស្វែងរកឃ្លាដែលពិពណ៌នាពីបទពិសោធន៍របស់យ៉ូសែប ស្ម៊ីធ ហើយសូមឆ្លើយបន្ទាប់ពីអាន យ៉ាកុប ១:៥ ចប់ ។ តើធ្លាប់មានខគម្ពីរណាដែលបានធ្វើឲ្យអ្នករំជួលចិត្តដោយព្រះចេស្ដាដែរឬទេ ? យោងតាម យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៣ តើយ៉ូសែប ស្ម៊ីធ ចង់យកឈ្នះលើអ្វី ? តើលោកបានសម្រេចចិត្តថានឹងត្រូវធ្វើអ្វី ?

## យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៤–២០

*យ៉ូសែប ស្ម៊ីធ ឃើញព្រះជាព្រះវរបិតា និង ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ*

យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៥–២០ គឺជាចំណោះចំណានខគម្ពីរ ។ អ្នកអាចនឹងចង់គូសចំណាំវានៅក្នុងរបៀបមួយដែលងាយស្រួលរកឃើញ ។

ប្រសិនបើអ្នកអាចចូលទៅកាន់ LDS hymnbook បាន សូមអានទំនុកបទ « Joseph Smith's First Prayer » (*Hymns* no. ២៦) ។ បន្ទាប់មកសូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៤–១៥ ។

តើអ្នកគិតថាហេតុអ្វីសាតាំងព្យាយាមបញ្ឈប់យ៉ូសែប ស្ម៊ីធ ពីការអធិស្ឋាន ? ដើម្បីរកឃើញអ្វីដែលយ៉ូសែប ស្ម៊ីធ បានធ្វើកាលលោកត្រូវប្រឈមមុខនឹង « ឥទ្ធិពលយ៉ាងអស្ចារ្យ » នេះ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៦ ។ តើអ្នកគិតថាពាក្យការីចង់មានន័យដូចម្ដេចកាលលោកបានមានប្រសាសន៍ថា លោកបានប្រឹងប្រែង « អស់ពីសមត្ថភាព [ របស់លោក ] ដើម្បីអំពាវនាវដល់ព្រះ » ? សូមពិចារណាពីអ្វីដែលគំរូរបស់យ៉ូសែប ស្ម៊ីធ អាចបង្រៀនអ្នកអំពីរបៀបឆ្លើយតប កាលអ្នកត្រូវបានបំភាន់ដោយនូវស្ថានភាពលំបាក ឬ ការល្បួងរបស់សាតាំងនោះ ។

ព្រឹត្តិការណ៍សំខាន់បំផុតក្នុងប្រវត្តិសាស្ត្រមនុស្សលោកត្រូវបានកត់ត្រាក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៧ ។ នៅពេលអ្នកអានខគម្ពីរនេះ សូមព្យាយាមស្រមៃពីព្រឹត្តិការណ៍ដ៏ពិសិដ្ឋនេះ ។ សេចក្ដីពិតសំខាន់មួយដែលយើងរៀនចេញពីខគម្ពីរនេះគឺ **យ៉ូសែប ស្ម៊ីធ បានឃើញព្រះជាព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ** ។ លោកក៏បានទូលជាមួយទ្រង់ទាំងពីរអង្គ ហើយទទួលបានការណែនាំផងដែរ ។ ការនិមិត្តដំបូងរបស់យ៉ូសែប ស្ម៊ីធ គឺជាព្រឹត្តិការណ៍គ្រឹះនៃការស្ដារឡើងវិញនៃដំណឹងល្អនាថ្ងៃចុងក្រោយ ។



២. សូមសរសេរនៅក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ពីមូលហេតុដែលអ្នកគិតថាវាមានសារៈសំខាន់សម្រាប់អ្នក និងសមាជិកសាសនាចក្រគ្រប់រូបត្រូវមានទីបន្ទាល់ថា យ៉ូសែប ស្ម៊ីធ បានឃើញព្រះជាព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ។

សូមរំឭក យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៥–១៧ រួចស្វែងរកសេចក្ដីពិតដែលយើងអាចរៀនចេញពីដំណើររឿងនៃការបង្ហាញព្រះកាយរបស់ព្រះវរបិតា និងព្រះរាជបុត្រាទៅដល់យ៉ូសែប ស្ម៊ីធ ។

ជួនកាល ការល្បួង ឬ ការសាកល្បងអាចកើតឡើងពីមុន ឬបន្ទាប់ពីបទពិសោធន៍ខាងវិញ្ញាណ ។ យ៉ូសែប ស្ម៊ីធ បានមានបទពិសោធន៍ពីការសាកល្បងមួយពីមុនការនិមិត្តដំបូង ។ សម្រាប់ម៉ូសេ ការសាកល្បងបានកើតឡើងបន្ទាប់ពីលោកបានទូលជាមួយព្រះ ( សូមមើល ម៉ូសេ ១:៩–១២ ) ។ យ៉ូសែប ស្ម៊ីធ បានស្វែងយល់ឃើញថា **ប្រសិនបើយើងស្វែងរកជំនួយពីព្រះដោយស្មោះត្រង់ កាលសាតាំងព្យាយាមបំបាក់ទឹកចិត្តយើង នោះព្រះអាចជួយរំដោះយើងបាន ។**

៣. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើការដឹងថាយើងអាចទទួលបានជំនួយពីព្រះដើម្បីយកឈ្នះលើភាពលំបាក និងការបាក់ទឹកចិត្តបាន ជួយអ្នកបានយ៉ាងដូចម្ដេច ?

ខ. តើមានគោលការណ៍ផ្សេងណាទៀតដែលអ្នកអាចរៀនពីបទពិសោធន៍របស់យ៉ូសែប ស្ម៊ីធ នៅក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៥–១៦ ដែលអាចជួយអ្នកឲ្យយកឈ្នះលើការល្បួងបាន ?

៤. តើយើងអាចរៀនអ្វីខ្លះអំពីក្រុមព្រះចេញពី យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៥–១៧ ? សូមសរសេរចម្លើយរបស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ។

គោលលទ្ធិមួយចំនួនអំពីក្រុមព្រះដែលមានចែងនៅក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៥–១៧ មាន ៖ **ព្រះជាព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ ។ ព្រះវរបិតាសួគ៌ និង ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ជាជាអង្គផ្សេង និងដាច់ដោយឡែកពីគ្នា ។**

យ៉ូសែប ស្ម៊ីធ បានទូលសួរដល់ព្រះអម្ចាស់ដើម្បីដឹងថា សាសនាចក្រណាមួយដែលលោកគួរចូលរួម ។ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៨–២០ រួចគូសចំណាំពីចម្លើយដែលយ៉ូសែប បានទទួលចំពោះសំណួរនេះ ។

តើអ្នកចងចាំពីដំណើររឿងនៃពួកអ្នកផ្សព្វផ្សាយសាសនាដែលត្រូវបានចែកចាយនៅពេលចាប់ផ្ដើមមេរៀនដែរឬទេ ? ប្រធាន ម៉នសុន បានមានប្រសាសន៍ប្រាប់ពីអ្វីដែលពួកអ្នកផ្សព្វផ្សាយសាសនាបានធ្វើបន្ទាប់ពីបុរសរូបនោះបានបិទទ្វារឰសួរក្ដាំងនៅចំពោះមុខគេថា ៖



« ពួកអ្នកផ្សព្វផ្សាយសាសនាដើរបានតែប៉ុន្មានជំហាន ស្រាប់តែដៃគូជុញ្ញ័របន្លឺថា ‹ អែលឌើរ យើងពុំទាន់បានឆ្លើយនឹងសំណួររបស់លោក ផូឡាត នៅឡើយទេ › ។

« ដៃគូច្បងបានឆ្លើយថា ៖ ‹ យើងត្រូវគេបដិសេធហើយ ។ តោះយើងបន្តទៅមុខទៀត › ។

« ទោះជាយ៉ាងក៏ដោយ អ្នកផ្សព្វផ្សាយសាសនាវ័យក្មេងរូបនោះបានជំនះរហូតដល់អ្នកទាំងពីរត្រឡប់ទៅមាត់ទ្វារផ្ទះរបស់លោក ផូឡាត វិញ ។ លោកផូឡាត បានបើកទ្វាទាំងខឹង រួចនិយាយថា ‹ ខ្ញុំគិតថាខ្ញុំបានប្រាប់យុវជនឯងហើយ ថាកុំឲ្យត្រឡប់មកវិញទៀត ! ›

> « ដៃគូជុញ្ជ័រ ពេលនោះបាននិយាយដោយភាពក្លាហានរបស់ខ្លួនថា ‹ លោក ផូឡាត នៅពេលដែលយើងបានដើរចេញពីទ្វាផ្ទះលោក លោកបាននិយាយថា យើងពុំបានជឿពិតថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីម្នាក់របស់ព្រះ ។ ខ្ញុំចង់ថ្លែងទីបន្ទាល់ទៅ លោក ផូឡាត ថា ខ្ញុំ *ដឹង* ថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីម្នាក់របស់ព្រះ ថាតាមរយៈការបំផុសគំនិតលោកបានបកប្រែកំណត់ត្រាពិសិដ្ឋ ដែលស្គាល់ថាជាព្រះគម្ពីរមរមន ថាលោកបានឃើញព្រះជាព្រះវរបិតា និងព្រះយេស៊ូវ ជាព្រះរាជបុត្រា › ។ រួចហើយពួកអ្នកផ្សព្វផ្សាយសាសនាក៏បានដើរចេញពីមាត់ទ្វាទៅ ។
>
> « [ ក្រោយមក លោក ផូឡា បានថ្លែងទីបន្ទាល់ថា ] ‹ នាល្ងាចនោះ ខ្ញុំគេងពុំលក់សោះ ។ ខ្ញុំប្រែខ្លួនចុះឡើងរហូត ។ ខ្ញុំបានឮពាក្យសម្ដីដែលថា « យ៉ូសែប ស្ម៊ីធ គឺជាព្យាការីម្នាក់របស់ព្រះ ម្ដងហើយម្ដងទៀតក្នុងគំនិតរហូត ។ ខ្ញុំដឹងពីរឿងនេះ ។. . . ខ្ញុំដឹងពីរឿងនេះ ។. . . ខ្ញុំដឹងយ៉ាងដូច្នេះ » ។. . . ខ្ញុំបានអន្ទះសាចង់ឲ្យពេលព្រឹកមកដល់ឆាប់ៗ ។ ខ្ញុំបានទូរសព្ទទៅកាន់អ្នកផ្សព្វផ្សាយសាសនាទាំងនោះ តាមលេខដែលមានសរសេរនៅលើប័ណ្ណតូចមួយនៃមាត្រានៃសេចក្ដីជំនឿ ។ ពួកគេបានត្រឡប់មកវិញ ហើយគ្រានេះ ភរិយាខ្ញុំ គ្រួសារខ្ញុំ និងខ្ញុំ បានចូលរួមក្នុងការពិភាក្សា ក្នុងនាមជាអ្នកស្វែងរកសេចក្ដីពិតដោយអស់ពីចិត្ត ។ ជាលទ្ធផល ពួកយើងទាំងអស់គ្នាបានឱបក្រសោបយកដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ » ( «The Prophet Joseph Smith, » ទំព័រ ៦៩ ) ។

ប្រសិនបើអ្នកពុំទាន់បានធ្វើដូច្នេះទេនោះ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ដោយខ្លួនឯង ហើយសូមដល់ព្រះវរបិតាសួគ៌ដើម្បីជួយអ្នកដឹងថាដំណើររឿងនៃការនិមិត្តដំបូងរបស់យ៉ូសែប ស្ម៊ីធ គឺជារឿងពិត ឬ ដើម្បីពង្រឹងជំនឿរបស់អ្នកថារឿងនេះគឺពិត ។ អ្នកក៏អាចនឹងចង់ស្វែងរកឱកាសចែកចាយសារលិខិតនៃការនិមិត្តដំបូងនេះជាមួយនឹងមនុស្សដទៃផងដែរ ។

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកនូវអារម្មណ៍ ឬ ទីបន្ទាល់របស់អ្នកអំពីព្យាការីយ៉ូសែប ស្ម៊ីធ ។

## ចំណេះចំណានខគម្ពីរ—យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៥–២០

សូមញែកពេលដើម្បីព្យាយាម ហើយទន្ទេញវគ្គចំណេះចំណានខគម្ពីរនេះ ។ ប្រសិនបើអ្នកមានអារម្មណ៍ថាពុំអាចទន្ទេញខគម្ពីរទាំងអស់ទេ នោះអ្នកអាចនឹងចង់បែកចែកខគម្ពីរជាចំណែកតូចៗ ឬ ទន្ទេញ ខទី ១៦–១៧ ឬ គ្រាន់តែការសង្ខេបខ្លីៗនៃខគម្ពីរទាំងនេះក៏បាន ។ នេះគឺជាវិធីសាស្ត្រមួយដើម្បីជួយអ្នកឲ្យទន្ទេញចាំខគម្ពីរទាំងនេះបាន ៖ អានឃ្លាមួយម្ដងហើយម្ដងទៀតដរាបដល់អ្នកអាចថាឃ្លានោះបានដោយមិនបាច់មើល ។ បញ្ចូលឃ្លាទីពីរ ហើយអានឃ្លានោះម្ដងហើយម្ដងទៀតដរាបដល់អ្នកអាចសូត្រឃ្លាទាំងពីរបាន ។ បញ្ចូលឃ្លាទីបីទៀត រួចបន្តធ្វើដូចនេះ ។ អ្នកអាចសូត្រឃ្លាដែលអ្នកបានទន្ទេញចាំហើយនោះយ៉ាងលឿន ហើយសូត្រឃ្លាថ្មីដោយយឺតៗ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១–២០ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២ ៖ ថ្ងៃទី ២

# យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:២១–២៦

## បុព្វកថា

បន្ទាប់ពីយ៉ូសែប ស៊្មីធ បានទទួលការនិមិត្តដំបូងក្នុងឆ្នាំ ១៨២០ ហើយ លោកបានចែកចាយពីបទពិសោធន៍នោះទៅកាន់គ្រូបង្រៀនសាសនាម្នាក់ ប៉ុន្តែគាត់បានប្រានចោលទីបន្ទាល់របស់លោក ។ មនុស្សដទៃទៀតក្នុងសហគមន៍ក៏បានបដិសេធ ហើយបៀតបៀនដល់យ៉ូសែបជំវ័យក្មេងនេះដែរ ។ ជនមានឋានៈខ្ពង់ខ្ពស់ក្នុងសង្គមជាច្រើននាក់បានខិតខំរិះគន់លោកដល់សាធារណជន ។ ទោះជាមានការប្រឆាំងយ៉ាងនេះក្តី យ៉ូសែប ស៊្មីធ នៅតែបន្តស្មោះត្រង់ចំពោះទីបន្ទាល់របស់លោកដដែល ។

## យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:២១–២៣

*សេចក្តីបៀតបៀនប្រឆាំងនឹងយ៉ូសែប ស៊្មីធ បានរីករាលដាលឡើង*

ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានចែកចាយពីបទពិសោធន៍ដែលលោកបានមានក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាវ័យក្មេងមួយរូបនៅទីក្រុង ឡុងដ៍ ប្រទេស អង់គ្លេស ។ នៅពេលអ្នកអានពីដំណើររឿងរបស់លោក សូមពិចារណាពីអ្វីដែលអ្នកអាចនឹងធ្វើប្រសិនបើអ្នកស្ថិតក្នុងស្ថានភាពដូចយុវជនរូបនេះ ។



« [ យុវជនម្នាក់បានមក ] ដល់ផ្ទះរបស់ពួកយើងដោយដើរកាត់ភ្លៀងនាពេលរាត្រីមួយ ។ គាត់បានគោះទ្វារផ្ទះរបស់យើង ហើយខ្ញុំបានអញ្ជើញគាត់ឲ្យចូលក្នុង ។

« គាត់ប្រាប់ថា ‹ ខ្ញុំត្រូវការនិយាយជាមួយនឹងនរណាម្នាក់ ។ ខ្ញុំឯកោណាស់. . . › ។

« រួចខ្ញុំពោលថា ‹ តើប្អូនមានបញ្ហាអ្វី ? ›

« រួចគាត់និយាយថា ‹ នៅពេលខ្ញុំចូលរួមក្នុងព្រះវិហារមិនបានមួយឆ្នាំផង នោះឪពុកខ្ញុំបានដេញខ្ញុំចេញពីផ្ទះរបស់គាត់ និងឲ្យត្រឡប់ទៅវិញឡើយ › ។ ហើយខ្ញុំពុំដែលបានទៅវិញទេ ›។

« គាត់បានបន្តថា ‹ ប៉ុន្មានខែក្រោយមក ក្រុមកីឡាក្រិកខិត ដែលខ្ញុំជាសមាជិក បានដកខ្ញុំចេញពីក្រុម រារាំងខ្ញុំមិនឲ្យមានទំនាក់ទំនងនឹងយុវជនដែលខ្ញុំបានធំឡើងជាមួយ និងពីមិត្តភក្តិជិតស្និតរបស់ខ្ញុំ ›។

« រួចគាត់និយាយថា ‹ កាលពីខែមុន ថៅហ្វាយខ្ញុំបានបណ្តេញខ្ញុំចេញ ដោយសារតែខ្ញុំជាសមាជិកនៃព្រះវិហារនេះ ហើយខ្ញុំពុំអាចរកការងារផ្សេងធ្វើបានទេ › ។. . .

« ‹ ហើយយប់មិញនេះ នារីដែលខ្ញុំបានស្គាល់អស់រយៈពេលមួយឆ្នាំកន្លះ បានប្រាប់ខ្ញុំថា នាងពុំរៀបការជាមួយខ្ញុំឡើយ ដោយសារតែខ្ញុំជាពួកមរមន › » ( «The Loneliness of Leadership » [ ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៦៩ ] ទំព័រ ៣ speeches.byu.edu) ។

តើអ្នកធ្លាប់បានទទួលអារម្មណ៍ថាអ្នកត្រូវគេប្រព្រឹត្តមិនល្អដាក់ ឬ រិះគន់ដោយសារតែជំនឿសាសនារបស់អ្នកដែរឬទេ ? តើអ្នកមានអារម្មណ៍ដូចម្តេចនៅពេលនោះ ?

ទោះជា យ៉ូសែប ស្ម៊ីធ បានទទួលពរយ៉ាងអស្ចារ្យដោយសារតែលោកនៅតែបន្តស្មោះត្រង់ចំពោះទីបន្ទាល់នៃការនិមិត្តដំបូងរបស់លោកយ៉ាងណាក៏ដោយ ក៏លោកត្រូវបានសាកល្បងជាទម្ងន់ដែរ ។ នៅពេលអ្នកសិក្សានៅថ្ងៃនេះ សូមពិចារណាពីអ្វីដែលអ្នកអាចនឹងរៀនពីរបៀបដែលយ៉ូសែប ស្ម៊ីធ បានឆ្លើយតបទៅនឹងការប្រឆាំងចំពោះទីបន្ទាល់របស់លោក ដែលអាចជួយអ្នកឲ្យស៊ូទ្រាំនឹងការប្រឆាំងដែលអ្នកអាចនឹងប្រឈមមុខនាពេលបច្ចុប្បន្ន ឬ នៅថ្ងៃណាមួយនាពេលអនាគត ។



ក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ព្យាការីបានប្រាប់ពីការប្រឆាំងដែលលោកបានប្រឈមមុខដោយសារតែទីបន្ទាល់របស់លោក ។ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២១–២៣ ដោយរកមើលពាក្យ ឬ ឃ្លាដែលជួយអ្នកឲ្យយល់ពីអ្វីដែលលោកបានមានបទពិសោធន៍ ។ យោងតាម ខទី ២២ តើនរណាដែលរួមចំណែកធំជាងគេក្នុងការបៀតបៀនដល់យ៉ូសែប ស្ម៊ីធ ? កាលអ្នកគិតពីវ័យរបស់យ៉ូសែប ស្ម៊ីធ និងស្ថានភាពនៃជីវិតលោក តើអ្នកគិតថាហេតុអ្វីបានជាការបៀតបៀនចេញពីមនុស្សទាំងនេះអាចក្លាយជាការលំបាកដ៏ធំសម្រាប់លោក ?

សូមកត់ចំណាំឃ្លាដែលនៅជិតចុងបញ្ចប់នៃ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២០ ដែលចាប់ផ្ដើមដោយពាក្យ « មើលទៅហាក់បីដូចជា. . . » ។ ដោយចាប់ផ្ដើមជាមួយនឹងពាក្យទាំងនេះ សូមអានខគម្ពីរនេះដល់ចប់ ដោយរកមើលមូលហេតុដែលបណ្ដាលឲ្យយ៉ូសែប ស្ម៊ីធ ទទួលការបៀតបៀននេះ ។ យោងតាមយ៉ូសែប ហេតុអ្វីបានជាលោកត្រូវទទួលបទពិសោធន៍នៃការបៀតបៀនដ៏ធំនោះនៅវ័យដ៏ក្មេងបែបនេះ ?

## យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៤–២៦

*ទោះជាយ៉ូសែប ស្ម៊ីធ ត្រូវបានគេស្អប់ និងបៀតបៀនយ៉ាងណាក្ដី ក៏លោកនៅតែបន្តស្មោះត្រង់ចំពោះទីបន្ទាល់របស់លោកដែរ*

សូមគិតពីដំណើររឿងជាច្រើនអំពីសេចក្ដីជំនឿ និងទីបន្ទាល់ខុសប្លែកពីគ្នាដែលមាននៅក្នុងព្រះគម្ពីរ ។ តើមានតួអង្គណាមួយផ្សេងទៀតនៅក្នុងព្រះគម្ពីរដែលមានលក្ខណៈសម្បត្តិ ឬ ភាពរឹងមាំនៃសេចក្ដីជំនឿដែលអ្នកកោតសរសើរជាខ្លាំងដែរឬទេ ?

១. សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៤ រួចស្វែងរកតួអង្គម្នាក់នៅក្នុងព្រះគម្ពីរដែលយ៉ូសែប ស្ម៊ីធ កោតសរសើរ ហើយលើកឡើងដោយសារតែការបៀតបៀនដែលលោកបានជួបប្រទះ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរខាងក្រោមនេះ ៖

   ក. តើអ្នកគិតថាវាអាចនឹងមានគុណប្រយោជន៍ដូចម្ដេចសម្រាប់យ៉ូសែប ស្ម៊ីធ ដែលបានឃើញរឿងដែលលោកមានដែលដូចគ្នាទៅនឹងរឿងរបស់សាវកប៉ុល ?

   ខ. តើយើងអាចរៀនមេរៀនអ្វីអំពីរបៀបដោះស្រាយឧបសគ្គលំបាក ៗពីគំរូរបស់យ៉ូសែប ស្ម៊ីធ ដែលបានសិក្សាហើយពិចារណាអំពីបទពិសោធន៍របស់ប៉ុល ?

មេរៀនមួយដែលយើងអាចរៀនគឺ **នៅអំឡុងពេលលំបាក យើងអាចទាញយកភាពរឹងមាំចេញពីគំរូនៃតួអង្គស្មោះត្រង់ជាច្រើនដែលមាននៅក្នុងព្រះគម្ពីរ ។** ( អ្នកអាចនឹងចង់សរសេរគោលការណ៍នេះនៅគែមព្រះគម្ពីររបស់អ្នកក្បែរ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៤ ) ។

*ការស្វែងរកគោលការណ៍*

គោលការណ៍គឺជាសេចក្តីពិតស្ថិតស្ថេរ ឬ ជាច្បាប់ដែលយើងអាចយកមកដើម្បីដឹកនាំយើងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ។ ការស្វែងរកគោលការណ៍នៅពេលអ្នកសិក្សាព្រះគម្ពីរ អាចជួយអ្នកឲ្យអនុវត្តបទគម្ពីរទាំងឡាយនៅក្នុងជីវិតរបស់អ្នក ។

២. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគ្រាដែលអ្នកធ្លាប់ត្រូវបានពង្រឹងដោយការសិក្សាពីបទពិសោធន៍របស់តួអង្គស្មោះត្រង់ដែលមាននៅក្នុងព្រះគម្ពីរ ។

ក្នុងការសិក្សាគោលលទ្ធិ និង សេចក្តីសញ្ញារបស់អ្នកនៅឆ្នាំនេះ អ្នកនឹងជួបប្រទះតួអង្គជាច្រើនដែលអ្នកអាចរកឃើញ និងជាតួអង្គមានបទពិសោធន៍ដែលអ្នកអាចទាញយកភាពរឹងមាំដែលអ្នកត្រូវការបាន ។

សូមពិចារណាឃ្លានេះចេញពីទីបន្ទាល់របស់ព្យាការីក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៥ ៖ « ខ្ញុំបានឃើញការនិមិត្ត ខ្ញុំដឹងថាខ្ញុំបានឃើញការនិមិត្ត ហើយខ្ញុំដឹងថា ព្រះទ្រង់ក៏ដឹងថាខ្ញុំបានឃើញការនិមិត្ត ហើយខ្ញុំពុំអាចបដិសេធរឿងនេះ » ។

៣. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរមួយ ឬ ទាំងពីរនៃសំណួរខាងក្រោមនេះ ៖

ក. តើឃ្លានៅក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៥ បង្រៀនអ្នកដូចម្តេចអំពីទីបន្ទាល់នៃការនិមិត្តដំបូងរបស់យ៉ូសែប ស្ម៊ីធ ?

ខ. តើអ្នកអាចពង្រឹងទីបន្ទាល់របស់អ្នកអំពីការនិមិត្តដំបូងបានយ៉ាងដូចម្តេច ?

៤. សូមរំឭក យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៤ រួចសិក្សា ខទី ២៥ ដោយស្វែងរកគោលលទ្ធិ និង គោលការណ៍បន្ថែមដែលអាចជួយអ្នកពេលអ្នកប្រឈមមុខនឹងការផ្ទុយ ឬ អារម្មណ៍ដែលត្រូវបានល្បួងឲ្យរារែកនឹងទីបន្ទាល់របស់អ្នក ។ សូមសរសេរសេចក្តីពិតបន្ថែមទាំងនេះដែលអ្នករកឃើញនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

*ការកត់ត្រាគោលលទ្ធិ និង គោលការណ៍ទាំងឡាយ*

ការរៀនពីរបៀបស្គាល់គោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អដែលមាននៅក្នុងព្រះគម្ពីរ តម្រូវឲ្យមានកិច្ចខិតខំ និង ការអនុវត្ត ។ ការសរសេរគោលលទ្ធិ និងគោលការណ៍ទាំងនោះនៅគែមព្រះគម្ពីរ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអាចជួយរំឭកអ្នកនៅពេលក្រោយ ។

៥. សូមជ្រើសរើសសេចក្តីពិតមួយដែលអ្នកបានរកឃើញចេញពី យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៤–២៥ ។ សូមឆ្លើយនឹងសំណួរខាងក្រោមនេះដោយផ្អែកទៅលើសេចក្តីពិតដែលអ្នកបានជ្រើសរើសដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

ក. តើព្យាការីយ៉ូសែប ស្ម៊ីធ បានបង្ហាញភស្តុតាងនៃសេចក្តីពិតនេះក្នុងជីវិតរបស់លោកយ៉ាងដូចម្តេច ?

ខ. តើសេចក្តីពិតនេះអាចនឹងមានគុណប្រយោជន៍យ៉ាងដូចម្តេចចំពោះអ្នក ?

គ. តើការរស់នៅតាមសេចក្តីពិតនេះនឹងមានឥទ្ធិពលលើជម្រើសរបស់អ្នកយ៉ាងដូចម្តេច ឬតើការរស់នៅតាមសេចក្តីពិតនេះបានមានឥទ្ធិពលលើជីវិតរបស់អ្នកហើយឬនៅ ?

គោលលទ្ធិ និង គោលការណ៍បន្ថែមមួយចំនួនដែលអ្នកអាចរកឃើញក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៤–២៥ គឺ ៖ **ចំណេះដឹងដែលយើងទទួលបានពីព្រះគឺជាចំណេះដឹងពិត ទោះជាលោកិយបដិសេធចំណេះដឹងនោះយ៉ាងណាក៏ដោយ ។ យើងគប្បីខ្វាយខ្វល់ពីអ្វីដែលព្រះទ្រង់មានព្រះទ័យរំពឹងពីយើងជាងអ្វីដែលមនុស្សរំពឹងពីយើង ។ ទោះជាយើងត្រូវគេស្អប់ ហើយបៀតបៀនដោយសារទីបន្ទាល់របស់យើងយ៉ាងណាក្តី ក៏យើងត្រូវតែបន្តស្មោះត្រង់ចំពោះទីបន្ទាល់របស់យើងដែរ ។**

សូមគិតអំពីដំណើររឿងដែលប្រធាន ហ៊ិងគ្លី បានមានប្រសាសន៍ប្រាប់អំពីយុវជនម្នាក់នៅទីក្រុង ឡុងដ៍ ប្រទេស អង់គ្លេស ដែលបានប្រឈមមុខនឹងការប្រឆាំងមួយដ៏ធំដោយសារតែជំនឿសាសនារបស់គាត់ ។ ប្រធាន ហ៊ិងគ្លី បានបន្តតំណាលរឿងរបស់លោកថា ៖



« ខ្ញុំបាននិយាយថា ‹ បើរឿងនេះ ធ្វើឲ្យអ្នកត្រូវបាត់បង់ច្រើនយ៉ាងនេះ ហេតុអ្វីក៏អ្នកមិនចាកចេញពីសាសនាចក្រនេះ ហើយត្រឡប់ទៅផ្ទះរកឪពុកអ្នកវិញ ទៅរកក្រុមកីឡាក្រិកខិតរបស់អ្នក និងទៅរកកន្លែងការងារ ដែលមានន័យយ៉ាងខ្លាំងចំពោះអ្នក និង ទៅរកមិត្តស្រី ដែលអ្នកគិតថាអ្នកស្រឡាញ់នោះវិញទៅ ? ›

« គាត់ពុំបាននិយាយអ្វីជាយូរ ។ រួចហើយគាត់យកដៃអោបក្បាលចុះ គាត់យំខ្សឹកខ្សួលយ៉ាងខ្លាំង ។ ទីបំផុត គាត់បានងើបឡើងវិញនិយាយទាំងទឹកភ្នែកថា ‹ ខ្ញុំមិនអាចធ្វើដូច្នោះបានទេ ។ ខ្ញុំដឹងថា សាសនាចក្រនេះពិត ហើយបើវាត្រូវចំណាយទាំងជីវិតខ្ញុំក្តី ក៏ខ្ញុំពុំអាចលះបង់វាចោលឡើយ ។

« គាត់បានយកមួកសើមរបស់គាត់ ហើយបានដើរសំដៅទៅទ្វារ ហើយបានចេញទៅទាំងភ្លៀង តែម្នាក់ឯង ទាំងរងារ និងភ័យខ្លាច ប៉ុន្តែមានការតាំងចិត្តដ៏មុតមាំ ។ នៅពេលដែលខ្ញុំបានឃើញគាត់ដូច្នេះ ខ្ញុំបានគិតដល់ភាពឯកោនៃសតិសម្បជញ្ញៈ ភាពឯកោនៃទីបន្ទាល់ និងភាពឯកោនៃសេចក្តីជំនឿ ថែមទាំងភាពរឹងមាំ និងការលួងលោមចិត្តពីព្រះវិញ្ញាណនៃព្រះ » ( «The Loneliness of Leadership, » ទំព័រ ៣–៤ ) ។

សូមជ្រើសរើសសេចក្ដីពិតមួយដែលអ្នករាយក្នុងបញ្ជី រួចដាក់គោលដៅដើម្បីអនុវត្តសេចក្ដីពិតនោះនៅក្នុងជីវិតអ្នក ។ ( អ្នកអាចនឹងចង់សរសេរគោលការណ៍នេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ) ។

ដើម្បីបញ្ចប់ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៦ រួចស្វែងរកគោលការណ៍តទៅនេះដែលយ៉ូសែប ស្ម៊ីធ បានបង្រៀន ៖ **ដោយការប្រព្រឹត្តតាមគោលការណ៍ទាំងឡាយដែលបានបង្រៀននៅក្នុងព្រះគម្ពីរ នោះយើងអាចបង្កើនទីបន្ទាល់នៃសេចក្ដីពិតរបស់គោលការណ៍ទាំងនោះបាន ។** នៅពេលអ្នកប្រព្រឹត្តតាមគោលលទ្ធិ ឬ គោលការណ៍ដែលអ្នកបានសរសេរ នោះទីបន្ទាល់របស់អ្នកនឹងត្រូវបានពង្រឹង ហើយអ្នកនឹងអាចមានជោគជ័យលើការផ្ទុយ ឬឧបសគ្គនានាដែលអ្នកអាចនឹងជួបប្រទះ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២១–២៦ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២ ៖ ថ្ងៃទី ៣

# យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៧–៥៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ២

## បុព្វកថា

យុវជន យ៉ូសែប ស្ម៊ីធ បានបន្តបញ្ជាក់អះអាងថា លោកបានឃើញការនិមិត្តមួយ ហើយលោកត្រូវបានបៀតបៀនជាបន្តបន្ទាប់ដោយសារតែការណ៍នោះ ។ កាលលោកមានអាយុ ១៧ ឆ្នាំ នារាត្រីមួយពេលយ៉ូសែបកំពុងអធិស្ឋាន មានទេវតាមួយអង្គ នាម ម៉ូរ៉ូណៃ បានលេចមក ហើយបានប្រកាសថា ព្រះមានកិច្ចការមួយសម្រាប់យ៉ូសែបធ្វើ រួមមានទាំងការបកប្រែបញ្ជីកំណត់ត្រាបុរាណមួយ នៅលើផ្ទាំងមាស ។ ខណៈដែលកំពុងតែពន្យល់អំពីតួនាទីរបស់ យ៉ូសែប នៅក្នុងការស្ដារឡើងវិញនៃដំណឹងល្អ នោះ ម៉ូរ៉ូណៃ បានដកស្រង់ពាក្យព្យាករណ៍មួយចំនួនមកពីព្រះគម្ពីរប៊ីប រួមទាំងការព្យាការណ៍អំពីការត្រឡប់មកវិញរបស់អេលីយ៉ា ។ នៅថ្ងៃបន្ទាប់ យ៉ូសែប ស្ម៊ីធ បានចេញទៅកូនភ្នំ ដែល ម៉ូរ៉ូណៃ បានប្រាប់ថា ផ្ទាំងមាសត្រូវបានកប់ទុកនោះ ។ លោកបានទទួលការណែនាំបន្ថែមពីម៉ូរ៉ូណៃនៅទីនោះ ។

### យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៧-២៩

*យ៉ូសែប ស្ម៊ីធ អធិស្ឋានដើម្បីបានការអភ័យទោសចំពោះអំពើបាបទាំងឡាយរបស់លោក*

ក្នុងមេរៀននៅថ្ងៃនេះ អ្នកនឹងរៀនបន្ថែមពីយ៉ូសែប ស្ម៊ីធ ដ៏ក្មេង ។ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៧–២៩ រួចប្រៀបប្រដូចបទគម្ពីរទាំងនេះទៅនឹងខ្លួនអ្នក ។

*ការប្រៀបប្រដូចបទគម្ពីរទៅនឹងខ្លួនអ្នក*

ដើម្បីប្រៀបប្រដូចបទគម្ពីរ គឺត្រូវប្រៀបធៀបវាទៅនឹងជីវិតផ្ទាល់ខ្លួនអ្នក ។ អ្នកអាចសួរថា « តើខ្ញុំមានលក្ខណៈដូចនឹងតួអង្គដែលខ្ញុំកំពុងសិក្សានៅក្នុងព្រះគម្ពីរដល់កម្រិតណា » ? នៅពេលអ្នកឃើញថាមានភាពប្រហាក់ប្រហែលគ្នារវាងបទពិសោធន៍របស់អ្នក និងតួអង្គដែលនៅក្នុងព្រះគម្ពីរ នោះមានន័យថាអ្នកអាចស្គាល់គោលលទ្ធិ និង គោលការណ៍បានកាន់តែច្បាស់ ហើយទទួលបានវិវរណៈអំពីរបៀបដែលអ្នកអាចអនុវត្តសេចក្ដីពិតទាំងនោះក្នុងជីវិតផ្ទាល់ខ្លួនអ្នក ។

សូមពិចារណាពីស្ថានភាព និងអារម្មណ៍ដែលយ៉ូសែប ស្ម៊ីធ បានមានកាលនៅជាយុវវ័យ ។ តើវាមានលក្ខណៈស្រដៀងគ្នាទៅនឹងស្ថានភាព និងអារម្មណ៍ដែលអ្នកមានយ៉ាងដូចម្ដេច ?

នៅក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៨ យ៉ូសែប បានសរសេរថា ខណៈដែលលោកពុំមានធ្វើខុសអំពើបាបធ្ងន់ធ្ងរណាមួយក្ដី ក៏លោកពុំតែងតែមានចរិយា ដូចជាអ្នកដែលត្រូវបានហៅដោយព្រះ គួរធ្វើជានិច្ចនោះដែរ ។ យើងអាចរៀនមេរៀនដ៏សំខាន់ចេញពីអ្វីដែលយ៉ូសែប ស្ម៊ីធ បានធ្វើក្នុងការឆ្លើយតបទៅនឹងអ្វីដែលលោកបានប្រព្រឹត្តខុសឆ្គង ។

១. សូមរំឭកផ្នែកចុងបញ្ចប់នៃ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៨ រួចសូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកនូវអ្វីដែលយ៉ូសែប ស្ម៊ីធ បានធ្វើក្នុងការឆ្លើយតបទៅនឹងអ្វីដែលលោកបានប្រព្រឹត្តខុសឆ្គង ។ បន្ថែមពីនេះ សូមសរសេរគោលការណ៍មួយ ឬពីរដែលអ្នករៀនចេញពីគំរូរបស់យ៉ូសែប ។

សេចក្ដីពិតមួយចំនួនដែលយើងអាចរៀនចេញពី យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៨ គឺ ៖ **ពេលយើងទទួលស្គាល់អំពើបាបយើង ហើយសោកស្ដាយដែលបានប្រព្រឹត្តអំពើបាបទាំងនោះ យើងអាចអធិស្ឋានសុំការអភ័យទោសពីព្រះវរបិតាសួគ៌ ។ យើងអាចអធិស្ឋានដើម្បីស្គាល់ពីគោលជំហររបស់យើងចំពោះព្រះ ។**

២. សូមឆ្លើយសំណួរតទៅនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការអធិស្ឋានដើម្បីស្គាល់ពីគោលជំហររបស់អ្នកចំពោះព្រះ អាចជួយអ្នកយ៉ាងដូចម្ដេច ?

សូមអានសេចក្ដីណែនាំខាងក្រោមពីអែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដើម្បីយល់កាន់តែច្បាស់ពីរបៀបដែលការអធិស្ឋានអាចជួយយើងឲ្យស្គាល់ពីគោលជំហររបស់យើងចំពោះព្រះ ហើយស្គាល់ការផ្លាស់ប្ដូរដែលទ្រង់អាចតម្រូវឲ្យយើងធ្វើ ៖



« តើយើងសម្រេចថាការប្រែចិត្តរបស់យើងគួរតែផ្ដោតទៅលើអ្វីមួយតាមរបៀបណា ?. . . « [ យើងអាច ] ទូលអង្វរដល់ព្រះអម្ចាស់ដោយរាបសារ ៖ ‹ ព្រះវរបិតាអើយ តើទ្រង់សព្វព្រះទ័យចង់ឲ្យទូលបង្គំធ្វើអ្វីខ្លះ ? › ចម្លើយបានមក ។ យើងស្គាល់ពីការផ្លាស់ប្ដូរដែលយើងត្រូវធ្វើ ។ ព្រះអម្ចាស់មានបន្ទូលប្រាប់នៅក្នុងគំនិតរបស់យើង និងនៅក្នុងចិត្តរបស់យើង ។

« ភ្លាមនោះយើងត្រូវបានអនុញ្ញាតឲ្យជ្រើសរើសថា ៖ យើងនឹងប្រែចិត្ត ឬ យើងនឹងទាញយកស្រមោលខ្មៅមកបិទបាំងបង្អួចដែលបើកនាំយើងទៅឯស្ថានសួគ៌នោះវិញ » ? ( «ប្រែចិត្ត . . . ដើម្បីឲ្យយើងអាចព្យាបាលអ្នក » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤១ ) ។

ចូរចងចាំថា ព្រះវរបិតាសួគ៌មានព្រះទ័យអភ័យទោសដល់យើងនៅពេលយើងអនុវត្តសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ ហើយធ្វើនូវអ្វីដែលជាការចាំបាច់ដើម្បីប្រែចិត្តពីអំពើបាបរបស់យើង ។

## យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៣០–៣៥

*ទេវតាមរ៉ូណៃបង្ហាញព្រះកាយដល់ យ៉ូសែប ស្ម៊ីធ*

ខណៈដែល យ៉ូសែប ស្ម៊ីធ កំពុងតែអធិស្ឋានសុំអភ័យទោស នោះទេវតាមរ៉ូណៃបានបង្ហាញព្រះកាយមកឲ្យលោកឃើញ ។ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៣០–៣២ រួចព្យាយាមស្រមៃថាតើបទពិសោធន៍នេះមានសភាពដូចម្ដេច ។



សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៣៣ រួចស្វែងរកសារលិខិតដែលមរ៉ូណៃបានប្រទានដល់យ៉ូសែប ស្ម៊ីធ ។ អ្នកអាចគូសចំណាំពាក្យ ឬឃ្លាដែលបង្ហាញថា **ព្រះមានកិច្ចការឲ្យយ៉ូសែប ស្ម៊ីធ ធ្វើ ។** សូមពិចារណាអំពីអ្វីដែលយ៉ូសែបអាចទទួលអារម្មណ៍ពេលលោកបានដឹងអំពីអ្វីដែលព្រះអម្ចាស់នឹងធ្វើតាមរយៈលោក ។

៣. មរ៉ូណៃបានព្យាករថា ឈ្មោះយ៉ូសែប ស្ម៊ីធ នឹងត្រូវនិយាយដល់ដោយ « ទាំងសេចក្ដីល្អ និងសេចក្ដីអាក្រក់នៅក្នុងចំណោមបណ្ដាជនទាំងអស់ » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៣៣ ) ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីភស្តុតាងដែលអ្នកបានឃើញដែលបង្ហាញថាការព្យាការណ៍នេះកំពុងតែត្រូវបានបំពេញ ។

មរ៉ូណៃក៏បានបង្រៀនដល់យ៉ូសែប ស្ម៊ីធ អំពីកិច្ចការដែលលោកនឹងធ្វើផងដែរ ។ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៣៤–៣៥ រួចសូមស្វែងរកថាតើកិច្ចការនោះគឺជាអ្វី ?

## យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៣៦–៤៩ គោលលទ្ធិ និង សេចក្ដីសញ្ញា ២

*មរ៉ូណៃណែនាំ ហើយដាស់តឿនដល់យ៉ូសែប ស្ម៊ីធ*

នៅក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៣៦–៤២ ចែងថា មរ៉ូណៃ បានដកស្រង់ការព្យាការណ៍ជាច្រើនចេញពីព្រះគម្ពីរប៊ីបដើម្បីពន្យល់ថា ការស្ដារឡើងវិញនៃដំណឹងល្អគឺហៀបនឹងចាប់ផ្ដើមហើយ ។ នៅពេលអ្នកអានខគម្ពីរទាំងនេះ អ្នកអាចនឹងចង់គូសចំណាំសេចក្ដីយោងចំពោះវគ្គខគម្ពីរទាំងនេះដែលត្រូវបានលើកឡើង ។

សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៣៨–៣៩ ។ ក្នុងឆ្នាំ ១៨៧៦ ព្រិកហាំ យ៉ង់ បានបង្គាប់ឲ្យដាក់បញ្ចូលបន្ទូលរបស់មរ៉ូណៃដែលមានក្នុងខគម្ពីរទាំងនេះទៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ជាកណ្ឌទី ២ ។ ការព្យាករណ៍អំពីការត្រឡប់មកវិញនៃអេលីយ៉ានេះ គឺជាវិវរណៈដំបូងគេមួយដែលត្រូវបានប្រទានឲ្យក្នុងគ្រាកាន់កាប់ត្រួតត្រានេះ ហើយមានសារៈសំខាន់ដែលថាវាក៏មានចែងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ដែរ ( ម៉ាឡាគី ៤:៥–៦) ព្រះគម្ពីរសញ្ញាថ្មី ( លូកា ១:១៧) និង ព្រះគម្ពីរមរមន ( នីហ្វៃទី ៣ ២៥:៥–៦) ។ អ្នកអាចចង់សរសេរបទគម្ពីរយោងទាំងនេះនៅក្បែរ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៣៨–៣៩ និង គោលលទ្ធិ និង សេចក្ដីសញ្ញា ២ ។



ប្រធាន ហិនរី ប៊ី អាវរិង ក្នុងគណៈប្រធានទីមួយ បានមានប្រសាសន៍ពីអេលីយ៉ា និងអំណាចបព្វជិតភាពដែលលោកនឹងស្ដារឡើងវិញដូចនេះថា ៖ « វាមានសារៈសំខាន់ដើម្បីដឹងពីមូលហេតុដែលព្រះអម្ចាស់បានសន្យាថា នឹងបញ្ជូនអេលីយ៉ាមក ។ អេលីយ៉ា គឺជាព្យាការីដ៏អស្ចារ្យម្នាក់ ដែលមាននូវអំណាចដ៏មហិមាដែលប្រទានមកពីព្រះ ។ លោកបានកាន់អំណាចដ៏មហិមាបំផុតដែលព្រះប្រទានដល់កូនចៅរបស់ទ្រង់ ៖ លោកបានកាន់អំណាចផ្សារភ្ជាប់ ជាអំណាចដែលចងទុកអ្វីៗនៅផែនដី នោះនឹងត្រូវចងទុកនៅស្ថានសួគ៌ដែរ ។ ( «Hearts Bound Together, » *Ensign* ខែ ឧសភា ឆ្នាំ ២០០៥ ទំព័រ ៧៨ ) ។

ដោយមានការពន្យល់របស់ប្រធាន អាវរិង ដើម្បីជួយដល់អ្នក សូមសង្ខេបអត្ថន័យនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ២:១ ដោយប្រើពាក្យផ្ទាល់ខ្លួនរបស់អ្នក ៖

គោលលទ្ធិ និង សេចក្ដីសញ្ញា ២:២ សំដៅទៅលើការសន្យាដែលបានធ្វើជាមួយពួកឪពុក ។ អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃីក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបញ្ជាក់ប្រាប់ថានរណាជាពួកឪពុកទាំងនេះ និងការសន្យាអ្វីខ្លះដែលត្រូវបានធ្វើជាមួយពួកលោកថា ៖ « តើពួកឪពុកទាំងនេះជានរណា ? ពួកលោកគឺអ័ប្រាហាំ អ៊ីសាក និង យ៉ាកុប ជាពួកឪពុកដែលព្រះបានសន្យាជាមួយ ។ តើការសន្យានោះមានអ្វីខ្លះ ? វាជាការសន្យានៃការបន្តពូជពង្សក្រុមគ្រួសារនៅក្នុងភាពដ៏អស់កល្បជានិច្ច » ( *The Millennial Messiah: The Second Coming of the Son of Man* [ ឆ្នាំ ១៩៨២ ] ទំព័រ ២៦៧ ) ។



បន្ថែមលើការសំដៅទៅលើពួកព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់មានដូចជា អ័ប្រាហាំ អ៊ីសាក និង យ៉ាកុប ពាក្យ « ពួកឪពុក » ក៏សំដៅទៅលើមនុស្សផ្សេងៗទៀតផងដែរ ដោយយោងតាមប្រសាសន៍របស់ប្រធាន យ៉ូសែប ហ្វីលឌិង ស្ម៊ីធ បានមានប្រសាសន៍ថា ៖ « *ពួកឪពុក* គឺជាបុព្វការីជនយើងដែលបានចែកឋានទៅដោយពុំបានមានឱកាសទទួលយកដំណឹងល្អ ប៉ុន្តែ ពួកលោកត្រូវបានសន្យាថា នឹងមានពេលដែលនឹងមកដល់កាលឱកាសនោះនឹងត្រូវបានប្រទានដល់ពួកលោក ។ ពាក្យ *កូនចៅ* គឺជាអស់អ្នកដែលមានជីវិតរស់នៅសព្វថ្ងៃ ដែលកំពុងរៀបចំទិន្នន័យពង្សាវតា និងជាអ្នកដែលធ្វើពិធីបរិសុទ្ធនានានៅក្នុងព្រះវិហារបរិសុទ្ធ » ( *Doctrines of Salvation,* ការបោះពុម្ព ប្រ៊ូស អ័រ ម៉ាក់ខន់ឃី វ៉ុល ៣ [ ឆ្នាំ ១៩៥៤–៥៦ ] ២:១២៧ ) ។

ដោយប្រើការពន្យល់របស់ប្រធាន អាវរិង នៅខាងលើ សូមសង្ខេបអត្ថន័យនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ២:២ ដោយប្រើពាក្យផ្ទាល់ខ្លួនរបស់អ្នក ៖

គោលលទ្ធិ និង សេចក្ដីសញ្ញា ២:៣ ថ្លែងថា ផែនដីទាំងមូលនឹងត្រូវកំទេចចោលសូន្យឈឹងប្រសិនបើអេលីយ៉ាពុំត្រឡប់មកវិញទេនោះ ។ ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានពន្យល់ពីមូលហេតុដែលការណ៍នេះនឹងកើតឡើងថា ៖ « ហេតុអ្វីបានជាផែនដីទាំងមូលត្រូវកំទេចចោលសូន្យឈឹងដូច្នេះ ? ប្រាកដណាស់ព្រោះបើគ្មានតំណភ្ជាប់គ្នារវាងពួកឪពុក និងកូនចៅ—ដែលជាកិច្ចការសម្រាប់មនុស្សស្លាប់ទេ—នោះយើងទាំងអស់គ្នានឹងត្រូវកំទេចចោល ហើយកិច្ចការរបស់ព្រះទាំងមូលនឹងបរាជ័យ និងត្រូវកំទេចចោលសូន្យឈឹង » ( *Doctrines of Salvation,* ២:១២២ សូមមើលផងដែរ គ. និង ស. ១២៨:១៧–១៨ ) ។

ដោយប្រើការពន្យល់នេះ សូមសង្ខេបអត្ថន័យនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ២:៣ ដោយប្រើពាក្យផ្ទាល់ខ្លួនរបស់អ្នក ៖

ចំណុចខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួនអំពីសេចក្ដីពិតដែលអ្នកអាចរកឃើញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២:១–៣ ។ សូមផ្គូផ្គងសេចក្ដីពិតទៅនឹងខគម្ពីរត្រឹមត្រូវដែលវាត្រូវបានបង្រៀន ។

| | |
|---|---|
| _____១. ព្រះនឹងបញ្ជូនអេលីយ៉ាឲ្យទៅស្ដារអំណាចនៃការផ្សារភ្ជាប់ឡើងវិញនៅលើផែនដីពីមុនការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ | ក. គ. និង ស. ២:១ |
| _____២. ដួងចិត្តយើងអាចត្រូវបានបង្វែរទៅរកសមាជិកគ្រួសារយើង ហើយយើងអាចធ្វើពិធីបរិសុទ្ធទាំងឡាយដែលអាចផ្សារភ្ជាប់យើងជាមួយពួកគេដ៏អស់កល្បជានិច្ច ។ | ខ. គ. និង ស. ២:២ |
| _____៣. ប្រសិនបើក្រុមគ្រួសារពុំត្រូវបានផ្សារភ្ជាប់តាមរយៈអំណាចនៃការផ្សារភ្ជាប់ទេ នោះផែនដីទាំងមូលនឹងត្រូវកំទេចចោលសូន្យឈឹងនៅពេលការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ | គ. គ. និង ស. ២:៣ |

៤. ដោយផ្អែកទៅលើអ្វីដែលអ្នកបានរៀនពី គោលលទ្ធិ និង សេចក្ដីសញ្ញា ២ សូមកត់ត្រានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកនូវប្រយោគមួយចំនួនដែលពន្យល់ប្រាប់ពីអារម្មណ៍របស់អ្នកចំពោះសារៈសំខាន់នៃត្រឡប់មកវិញរបស់អេលីយ៉ា ។

ក្នុងការសិក្សារបស់អ្នកអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០ នៅពេលខាងមុខក្នុងឆ្នាំនេះ អ្នកនឹងរៀនពីរបៀបដែលការព្យាការណ៍នេះត្រូវបានបំពេញ នៅពេលអេលីយ៉ាបានត្រឡប់មកវិញ ហើយបានប្រគល់អំណាចនៃការផ្សារភ្ជាប់ទៅដល់ព្យាការី យ៉ូសែប ស្ម៊ីធ ។

បន្ទាប់ពីម៉ូរ៉ូណៃ បានបង្រៀនយ៉ូសែប ស្ម៊ីធ អំពីការត្រឡប់មកវិញរបស់អេលីយ៉ា បានដកស្រង់នូវការព្យាករណ៍ទាំងឡាយអំពីការស្ដារឡើងវិញ ហើយបានណែនាំបន្ថែមអំពីផ្ទាំងចំណារមាសរួចហើយ នោះទ្រង់ក៏បានយាងចាកចេញទៅ ( សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៤២–៤៣) ។ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៤៤–៤៥ រួចស្វែងរកថាតើមានអ្វីបានកើតឡើងបន្ទាប់ពីម៉ូរ៉ូណៃបានយាងចាកចេញទៅ ។

សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៤៦–៤៩ រួចស្វែងរកថាតើម៉ូរ៉ូណៃបានមានបន្ទូលឡើងវិញពីសារលិខិតរបស់ទ្រង់ទៅកាន់ យ៉ូសែប ស្ម៊ីធ ចំនួនប៉ុន្មានលើក ។ សរុបសេចក្ដីមក តើម៉ូរ៉ូណៃបានចែកចាយសារលិខិតរបស់ទ្រង់ទៅដល់យ៉ូសែប ស្ម៊ីធ ចំនួនប៉ុន្មានលើក ?

សេចក្ដីពិតមួយដែលយើងរៀនពីការណ៍នេះគឺ **ព្រះអម្ចាស់ និងពួកអ្នកបម្រើទ្រង់តែងតែលើកឡើងពីការបង្រៀនដែលសំខាន់មកបង្រៀនម្ដងហើយម្ដងទៀត ។**

សូមសញ្ជឹងគិតពីការអធិស្ឋានប្រសិទ្ធពរសាក្រាម៉ង់ ។ ហេតុអ្វីបានជាគេសូត្រការអធិស្ឋាននោះដោយច្បាស់ៗជារៀងរាល់សប្ដាហ៍ដូចនេះ ? សូមគិតអំពីការបង្រៀនដែលអ្នកបានឮ ដែលមានលើកឡើងម្ដងហើយម្ដងទៀតនៅក្នុងព្រះគម្ពីរ និងអំឡុងពេលសន្និសីទទូទៅ ។

៥. សូមធ្វើបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកនូវឧទាហរណ៍មួយចំនួននៃការបង្រៀននានាដែលអ្នកបានឮលើកឡើងម្ដងហើយម្ដងទៀត ក្រោយមកពន្យល់ពីមូលហេតុដែលអ្នកគិតថាព្រះអម្ចាស់ និងពួកអ្នកបម្រើទ្រង់តែងតែលើកឡើងពីការបង្រៀនរបស់ខ្លួនមកបង្រៀនម្ដងហើយម្ដងទៀត ។ សូមប្រាកដថាអ្នករៀបរាប់ពីរបៀបដែលអ្នកអាចអនុវត្តសេចក្ដីពិតនេះនៅឆ្នាំនេះ ។

## យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥០–៥៤

*យ៉ូសែប បានឡើងទៅលើភ្នំ ហើយបានដកយកបញ្ជីប្រវត្តិ យូរីម និង ធូមីម និង ប្រដាប់បាំងទ្រូង*

យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥០–៥១ ពន្យល់ថា បន្ទាប់ពីលោកបានប្រាប់ដល់ឪពុកលោកអំពីការយាងមករបស់ម៉ូរ៉ូណៃហើយ នោះលោកក៏បានឡើងទៅលើភ្នំដែលផ្ទាំងចំណារមាសត្រូវបានកប់លាក់ទុក ។

៦. សូមស្រមៃថាតើអ្នកនឹងមានអារម្មណ៍ដូចម្ដេច ប្រសិនបើអ្នកជាម៉ូរ៉ូណៃ ហើយបានយាងមកជួបនឹងយ៉ូសែប ស្ម៊ីធ បន្ទាប់ពីបានរង់ចាំអស់រយៈពេលជាង ១៤០០ ឆ្នាំមកហើយនោះ ដើម្បីឲ្យផ្ទាំងទាំងនេះត្រូវបានដកចេញមក ហើយបានបកប្រែ ។ នៅពេលអ្នកស្រមៃដូចនេះ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥២–៥៤ រួចក្រោយមកសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សារបស់អ្នកនូវរបៀបដែលអ្នកអាចមានអារម្មណ៍អំឡុងពេលមានបទពិសោធន៍នេះ ។

នៅមេរៀនបន្ទាប់ អ្នកនឹងដឹងពីអ្វីដែលបានកើតឡើងនៅបំណាច់ឆ្នាំទីបួននៃការរង់ចាំ ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៧–៥៤ និង គោលលទ្ធិ និង សេចក្ដីសញ្ញា ២ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២ ៖ ថ្ងៃទី ៤

# យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៥–៦៥

## សេចក្ដីផ្ដើម

បន្ទាប់ពីបានទទួលការណែនាំពីទេវតាមរ៉ូណៃអស់រយៈពេលបួនឆ្នាំហើយ យ៉ូសែប ស្ម៊ីធ បានទទួលខុសត្រូវលើផ្ទាំងចំណារមាស ហើយលោកបានចាប់ផ្ដើមបកប្រែព្រះគម្ពីរមរមន ។ លោកម៉ាទិន ហារីស ត្រូវបានអនុញ្ញាតឲ្យបង្ហាញតួអក្សរដែលបានចម្លងចេញពីផ្ទាំងទាំងនោះ និងការបកប្រែចេញពីផ្ទាំងទាំងនោះទៅដល់សាស្ត្រាចារ្យនៅទីក្រុង នូវ យ៉ោក ។ សូមកត់ចំណាំពីរបៀបដែលយ៉ូសែប ស្ម៊ីធ ទទួលខុសត្រូវលើផ្ទាំងទាំងនោះដោយយកចិត្តទុកដាក់ ។

### យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៥–៥៨

*យ៉ូសែប ទទួលបទពិសោធន៍នៃព្រឹត្តិការណ៍សំខាន់ៗកាលលោកចាប់ផ្ដើមឈានចូលក្នុងមជ្ឈិមវ័យ*

សូមគិតអំពីព្រឹត្តិការណ៍សំខាន់ៗដែលបានកើតឡើងក្នុងជីវិតរបស់យុវវ័យដែលអ្នកស្គាល់ ។ ( វារួមបញ្ចូលទាំងពររបស់លោកអយ្យកោ ការងារ ការអប់រំ ការផ្លាស់ប្ដូរស្ថានភាពគ្រួសារ ឬ មរណភាពរបស់មនុស្សជាទីស្រឡាញ់ ) ។ តើមានព្រឹត្តិការណ៍សំខាន់ៗអ្វីខ្លះដែលបានកើតឡើងចំពោះអ្នកនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ? តើអ្នកដឹងថាព្រឹត្តិការណ៍នេះបានមានឥទ្ធិពលលើលក្ខណៈសម្បត្តិ និងអនាគតរបស់អ្នកយ៉ាងដូចម្ដេច ?

សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៥–៥៨ រួចស្វែងរកព្រឹត្តិការណ៍សំខាន់ៗក្នុងជីវិតរបស់យ៉ូសែប ស្ម៊ីធ ដែលបានកើតឡើងនៅពីមុនពេលដែលលោកទទួលបានផ្ទាំងមាសពីទេវតាមរ៉ូណៃ ។

វាជាការសំខាន់ដែលត្រូវដឹងថា នៅអំឡុងពេលនោះបងប្រុសរបស់យ៉ូសែប គឺ អាលវិន បានទទួលមរណភាព ។ ព្រឹត្តិការណ៍នេះបានដើរតួយ៉ាងសំខាន់ក្នុងវិវរណៈនាពេលអនាគតដែលអ្នកនឹងដឹងនៅពេលក្រោយនៅឆ្នាំនេះ ( សូមមើល គ. និង ស. ១៣៧:១–៦ ) ។

ព្រឹត្តិការណ៍សំខាន់មួយទៀតក្នុងជីវិតរបស់លោកនៅគ្រានោះគឺអាពាហ៍ពិពាហ៍របស់លោកជាមួយនឹង អិមម៉ា ហេល ។ ម្ដាយរបស់ព្យាការីគឺ លូស៊ី ម៉ាក ស្ម៊ីធ បានកត់ត្រាអំពីអាពាហ៍ពិពាហ៍របស់កូនប្រុសគាត់ជាមួយនឹង អិមម៉ា ថា ៖ « យើងមានក្ដីរីករាយយ៉ាងខ្លាំងចំពោះការជ្រើសរើសរបស់គាត់ ហើយពុំគ្រាន់តែយល់ព្រមចំពោះការរៀបការរបស់គាត់នឹងនាងទេ ប៉ុន្តែបានស្នើរសុំឲ្យគាត់នាំនាងមកផ្ទះ ហើយរស់នៅនឹងយើងទៀតផង » (*History of Joseph Smith by His Mother,* បានបោះពុម្ពដោយ. Preston Nibley [ ឆ្នាំ ១៩៥៨ ] ទំព័រ ៩៣ ) ។

### យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៩–៦២

*យ៉ូសែប ទទួលបានផ្ទាំងទាំងនោះ ហើយចាប់ផ្ដើមបកប្រែ*

សូមស្រមៃថា ឪពុកអ្នកបានប្រគល់ច្បាប់ចម្លងមួយនៃការបោះពុម្ពដំបូងរបស់ព្រះគម្ពីរមរមន ( ដែលសព្វថ្ងៃនេះមានតម្លៃជិត ១៨០,០០០ ដុល្លា ) ។ តើអ្នកនឹងថែរក្សាសៀវភៅនោះយ៉ាងដូចម្ដេច ប្រសិនបើអ្នកស្គាល់ពីតម្លៃខាងសាច់ប្រាក់របស់វាហើយនោះ ? តើអ្នកនឹងថែរក្សាវាយ៉ាងដូចម្ដេច ប្រសិនបើអ្នកបានដឹងថា វាគឺជាច្បាប់ចម្លងដើមចុងក្រោយតែមួយគត់នៃព្រះគម្ពីរមរមនដែលមានលើផែនដីនេះ ?

យ៉ូសែប ស្ម៊ីធ ត្រូវបានប្រទានឲ្យនូវវត្ថុដ៏មានតម្លៃពន់ពេក ។ សូមពិចារណាពីអ្វីដែលអ្នកអាចរៀនពីគំរូរបស់លោកកាលអ្នកសិក្សាពីដំណើររឿងរបស់លោក ។ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៩ រួចស្វែងរកវត្ថុដ៏មានតម្លៃដែលទេវតាមរ៉ូណៃបានប្រគល់ដល់យ៉ូសែប ( សូមគិតពីការគូសចំណាំវត្ថុទាំងនេះនៅក្នុងព្រះគម្ពីររបស់អ្នក ) ។

តើការទទួលខុសត្រូវអ្វីខ្លះដែលយ៉ូសែបមានចំពោះវត្ថុទាំងនេះ ? សូមបំពេញគោលការណ៍តទៅនេះដោយផ្អែកទៅលើអ្វីដែលមរ៉ូណៃបានសន្យាដល់យ៉ូសែប ដូចមានកត់ត្រានៅក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៩ ៖ **ដរាបណាខ្ញុំទទួលខុសត្រូវចំពោះ ហើយថែរក្សាវត្ថុដែលព្រះអម្ចាស់បានប្រទានដល់ខ្ញុំនោះ ទ្រង់** នឹង។

អ្នកអាចបំពេញគោលការណ៍នេះថា « ប្រទានការការពារ និងជំនួយ » ។

សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦០ រួចស្វែងរកអ្វីដែលបានកើតឡើងនៅពេលយ៉ូសែបកាន់កាប់ផ្ទាំងចំណារមាសទាំងនោះ ។ នៅពេលអ្នកអាន សូមកត់ចំណាំពីរបៀបដែលព្រះអម្ចាស់បំពេញការសន្យារបស់ទ្រង់ដរាបណាយ៉ូសែបស្មោះត្រង់ចំពោះការទទួលខុសត្រូវដែលលោកបានទទួល ។



បន្ទាប់ពីយ៉ូសែប ស្ម៊ីធ បានទទួលផ្ទាំងទាំងនោះពីមរ៉ូណៃហើយដំបូងឡើយលោកបានលាក់វាទុកនៅក្នុងកំណាត់ឈើហុបដែលពុកផុយមួយប្រមាណប្រាំគីឡូម៉ែតពីផ្ទះរបស់លោក ។ ដើម្បីយល់ពីរបៀបដែលព្រះអម្ចាស់ប្រទានការការពារ និងជំនួយ នៅពេលយ៉ូសែប ស្ម៊ីធ បានខិតខំអស់សមត្ថភាពដើម្បីទទួលខុសត្រូវចំពោះផ្ទាំងចំណារមាសទាំងនោះ សូមអានការបកស្រាយរបស់ម្ដាយយ៉ូសែប ស្ម៊ីធ អំពីអ្វីដែលបានកើតឡើងនៅមិនយូរប៉ុន្មានបន្ទាប់ពីលោកទទួលបានផ្ទាំងទាំងនោះពីមរ៉ូណៃនៅលើភ្នំគូម៉ូរ៉ា ៖



« យ៉ូសែប ស្ម៊ីធ បានទៅ ហើយបានយកចេញពីកន្លែងសម្ងាត់មក ហើយបានរុំវានៅក្នុងក្រណាត់អាវរងារ ដាក់វាក្លៀតនៅនឹងដៃ រួចដើរមកផ្ទះ ។

« បន្ទាប់ពីដើរបានបន្តិចមក លោកបានគិតថា វានឹងមានសុវត្ថិភាពជាងដើម្បីកុំដើរតាមផ្លូវ ហើយទៅដើរកាត់តាមព្រៃវិញ ។ បន្ទាប់ពីដើរចុះពីផ្លូវ បានបន្តិចមក នោះលោកបានទៅជួបនឹងខ្យល់បក់យ៉ាងខ្លាំងមួយ ហើយពេលលោកលោតរំលងគល់ឈើមួយ នោះមានមនុស្សម្នាក់បានលេចចេញមកពីក្រោយ ហើយបានវាយលោកយ៉ាងខ្លាំងនឹងកាំភ្លើង។ យ៉ូសែប បានងាកក្រោយ ហើយវាយមនុស្សម្នាក់នោះដួល រួចរត់យ៉ាងលឿនបំផុតតាមដែលលោកអាចធ្វើបាន ។ ពេលទៅបានប្រហែលជាកន្លះម៉ាយល៍ទៀត លោកត្រូវបានគេវាយប្រហារម្ដងទៀតតាមរបៀបដូចមុនដែរ លោកបានវាយមនុស្សនោះដួល ដូចមុន ហើយក៏បានរត់ម្ដងទៀត ហើយពីមុនលោកបានទៅដល់ផ្ទះ នោះលោកត្រូវបានគេវាយជាលើកទីបី ។ នៅក្នុងការវាយប្រហារចុងក្រោយនេះ លោកបានភ្លាត់ឆ្អឹងមេដៃ តែទោះជាយ៉ាងណា លោកពុំបានដឹងទេ រហូតទាល់តែលោកបានមកជិតដល់ផ្ទះ ពេលលោកបានទម្លាក់ខ្លួនចុះនៅជិតនឹងកាច់ជ្រុងរបងផ្ទះ ដើម្បីឈប់ឲ្យបាត់ហត់។ ពេលលោកមានកម្លាំងភ្លាម នោះលោកបានក្រោកឡើង ហើយចូលទៅក្នុងផ្ទះ ។ លោកនៅតែពុំទាន់អាចនិយាយបានទេ ដោយសារតែការវាយប្រហារ និងការហត់មកពីការរត់នោះ » (*History of Joseph Smith by His Mother,* ទំព័រ ១០៨ ) ។

ទោះជាការការពារផ្ទាំងចំណារមាសពុំមានភាពងាយស្រួលទាល់តែសោះសម្រាប់យ៉ូសែប ស្ម៊ីធ សូមកត់ចំណាំពីរបៀបដែលព្រះបានប្រទានពរ ហើយពង្រឹងលោកឲ្យមានលទ្ធភាពបំពេញការទទួលខុសត្រូវរបស់លោក ។ អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានផ្ដល់ដំបូន្មានអំពីការទុកព្រះទ័យដ៏ពិសិដ្ឋដែលព្រះអម្ចាស់បានប្រទានដល់អ្នកថា ៖



« ចូរឈ្លាសវៃជាមួយអ្វីដែលព្រះអម្ចាស់បានប្រទានដល់អ្នក។ វាគឺជាទំនុកចិត្តមួយ ។ . . .

« ជាជាងធ្លាក់ចុះទៅក្នុងភាពធ្វេសប្រហែស សូមឲ្យជីវិតរបស់អ្នក ធ្វើជាមនុស្សម្នាក់ដែលបង្កើនភាពត្រឹមត្រូវច្បាស់លាស់ក្នុងការគោរពប្រតិបត្តិ ។ ខ្ញុំសង្ឃឹមថា អ្នកនឹងគិត ទទួលអារម្មណ៍ ស្លៀកពាក់ និងធ្វើសកម្មភាពតាមរបៀប ដែលបង្ហាញគារវភាព និងការគោរពដល់វត្ថុពិសិដ្ឋ កន្លែងពិសិដ្ឋ ឱកាសពិសិដ្ឋ » («A Sense of the Sacred, »*New Era* ខែ មិថុនា ឆ្នាំ ២០០៦ ទំព័រ ៣១ ) ។

សូមគិតអំពីការទុកព្រះទ័យដ៏ពិសិដ្ឋដែលព្រះវរបិតាសួគ៌បានប្រទានដល់យើង មានដូចជា ការប្រព្រឹត្តចំពោះរូបកាយដោយគារវភាព សេចក្ដីសញ្ញាពិធីបុណ្យជ្រមុជទឹក និង នៃព្រះវិហារបរិសុទ្ធ សិទ្ធិអំណាច និងករណីយកិច្ចបព្វជិតភាព ការហៅបម្រើក្នុងសាសនាចក្រ ការទទួលខុសត្រូវខាងការចិញ្ចឹមបីបាច់ដល់គំនិត និងវិញ្ញាណរបស់យើង ការទទួលខុសត្រូវ និង ទំនាក់ទំនង

ក្នុងគ្រួសារ និងការក្រើនរំឭកឲ្យចែកចាយដំណឹងល្អ ។ សូមវាយតម្លៃថាតើអ្នកកំពុងធ្វេសប្រហែស និង មិនយកចិត្តទុកដាក់ ឬក៏កំពុងទទួលខុសត្រូវចំពោះអ្វីៗដែលបានប្រទានដល់អ្នក ។ សូមពិចារណាពីពរជ័យទាំងឡាយដែលអាចកើតមានក្នុងជីវិតអ្នក ពេលអ្នកព្យាយាមប្រព្រឹត្តដោយការយកចិត្តទុកដាក់ខ្លាំងបំផុតចំពោះការទុកព្រះទ័យដែលព្រះមានចំពោះអ្នក ។

១. សូមកត់ត្រានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកពីការទុកព្រះទ័យដ៏ពិសិដ្ឋដែលអ្នកដឹងថាត្រូវបានប្រទានឲ្យ និងពីពរជ័យដែលអាចកើតមានចំពោះអ្នកនៅពេលអ្នកប្រព្រឹត្តដោយការយកចិត្តទុកដាក់ចំពោះការទុកព្រះទ័យទាំងនោះ ។

ដើម្បីឃើញពីរបៀបដែលព្រះអម្ចាស់បានបន្តប្រទានពរដល់យ៉ូសែប និង អិមម៉ា ស៊្មីធ សម្រាប់ការស្មោះត្រង់របស់ពួកលោក សូមអាន យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:៦១–៦២ ។ តើព្រះអម្ចាស់បានប្រទានពរដល់ព្យាការី និង ភរិយារបស់លោកនៅគ្រានេះតាមរបៀបណា ?

## យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:៦៣–៦៥

*ម៉ាទិន ហារីស បង្ហាញតួអក្សរចេញពីផ្ទាំងទាំងនោះទៅដល់សាស្ត្រាចារ្យនៅទីក្រុង នូវ យ៉ោក*

សូមស្រមៃថាអ្នកត្រូវបានអនុញ្ញាតឲ្យចម្លងតួអក្សរពិតប្រាកដមួយចំនួនចេញពីផ្ទាំងមាស ។ តើអ្នកនឹងធ្វើយ៉ាងណាចំពោះច្បាប់ចម្លងនោះ ? តើអ្នកនឹងធ្វើយ៉ាងណាប្រសិនបើអ្នកចង់បង្ហាញភស្តុតាងទៅដល់មិត្តម្នាក់ថា ផ្ទាំងចំណារមាសពិតជាមានដើមកំណើតពីបុរាណ ដូចជាអ្វីដែលអ្នកតែងតែថ្លែងមកនោះ ?




រូបភាពខាងលើនេះគឺជាគំរូមួយនៃតួអក្សរទាំងឡាយដែលបានចែងនៅលើផ្ទាំងចំណារមាស ។ ក្នុងឆ្នាំ ១៨២៧ យ៉ូសែប ស៊្មីធ បានចម្លងតួអក្សរមួយចំនួនទៅក្នុងក្រដាសមួយផ្ទាំង ។ ម៉ាទិន ហារីស បានសួរថាតើគាត់អាចបង្ហាញតួអក្សរទាំងនោះទៅដល់សាស្ត្រាចារ្យដែលមានឯកទេសខាងភាសា និង អារ្យធម៌ពីបុរាណបានដែរឬទេ ។ ម៉ាទីន អាចគិតថា លិខិតបញ្ជាក់ពីតួអក្សរទាំងនោះអាចជួយដល់ភរិយាគាត់ ដែលពុំយល់ស្របនឹងម៉ាទីនក្នុងការជួយដល់យ៉ូសែប ស៊្មីធ ក្នុងដំណើរការបកប្រែនេះ ។ ម៉ាទិន ហារីស ក៏អាចសង្ឃឹមដែរថា លិខិតបញ្ជាក់ពីភាពជាក់ស្តែងនៃតួអក្សរទាំងនោះអាចជួយគាត់រៃអង្គាសប្រាក់ដើម្បីចំណាយលើការបោះពុម្ពព្រះគម្ពីរមរមន ។ យើងពុំដឹងទេថាតើច្បាប់ចម្លងដែលបង្ហាញនៅទីនេះដូចគ្នានឹងច្បាប់ចម្លងដែលម៉ាទីន ហារីស បានបង្ហាញទៅដល់ពួកសាស្ត្រាចារ្យនោះឬទេ ព្រោះច្បាប់ចម្លងតួអក្សរទាំងនោះមួយចំនួនត្រូវបានបង្កើតឡើង ។

២. សូមចម្លងតារាងខាងក្រោមចូលទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

| យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:៦៣–៦៥ | អេសាយ ២៩:១០–១២ |
|---|---|
| | |

យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:៦៣–៦៥ ប្រាប់ពីដំណើររឿងដែលម៉ាទិន ហារីស បានជួបជាមួយនឹងពួកសាស្ត្រាចារ្យ ។ ព្រឹត្តិការណ៍នេះត្រូវបានព្យាករដោយព្យាការី អេសាយ ពីបុរាណ ។ សូមអានវគ្គបទគម្ពីរនោះ រួចអាន អេសាយ ២៩:១០–១២ ។ ( វាក៏មានអត្ថប្រយោជន៍ប្រសិនបើអានការសង្ខេបជំពូក អេសាយ ២៩ ផងដែរនោះ ) ។ នៅពេលអ្នកអានវគ្គបទគម្ពីរទាំងនេះ សូមសង្ខេបនូវអ្វីដែលបានលើកឡើងទៅក្នុងចន្លោះដែលត្រូវគ្នាក្នុងតារាងរបស់អ្នក ។ នៅពេលអ្នកបានបំពេញតារាងទាំងសងខាងហើយ សូមស្វែងរកភាពស្រដៀងគ្នារវាងដំណើររឿងរបស់ម៉ាទីន ហារីស និងការព្យាករណ៍របស់អេសាយ រួចកត់ត្រាអ្វីដែលអ្នករកឃើញទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។



តើសេចក្ដីពិតអ្វីដែលការព្យាករណ៍របស់អេសាយ និង ដំណើររឿងរបស់ម៉ាទីន ហារីសក្នុងការបង្ហាញតួអក្សរទៅកាន់ពួកសាស្ត្រាចារ្យ បង្រៀនយើងពីបុព្វវិជ្ជានៃព្រះ និង ការព្យាករណ៍របស់អ្នកបម្រើរបស់ព្រះអម្ចាស់ ?

អ្នកអាចចង់សរសេរសេចក្ដីថ្លែងការណ៍នៃសេចក្ដីពិតតទៅនេះ ក្នុងព្រះគម្ពីររបស់អ្នកនៅក្បែរដំណើររឿងនេះក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៣–៦៥ ថា ៖ **ការព្យាករណ៍របស់អ្នកបម្រើព្រះអម្ចាស់នឹងកើតឡើង ។** តើអ្នកអាចគិតពីចំណេះចំណានខគម្ពីរមួយដែលបង្រៀនពីសេចក្ដីពិតដូចគ្នានេះដែរឬទេ ?

*ការចេះចាំ និង ការរំឭកពីចំណេះចំណានខគម្ពីរពីឆ្នាំដទៃទៀត*

យូរៗម្ដង សូមយកពេលខ្លះដើម្បីចេះចាំ ហើយរំឭកពីសេចក្ដីយោងចំណេះចំណានខគម្ពីរចេញពីឆ្នាំមុនៗ ឬ ឆ្នាំខាងមុខទៀត ។ ការធ្វើបែបនេះនឹងបង្កើនសមត្ថភាពរបស់អ្នកឲ្យចងចាំខគម្ពីរទាំងនោះ ហើយប្រើប្រាស់វាបានក្នុងគ្រប់ទិដ្ឋភាព ។ ចូរធ្វើបញ្ជីសេចក្ដីយោងចំណេះចំណានខគម្ពីរ ដែលអាចរកបានក្នុងសម្ភារថ្នាក់សិក្ខាសាលាលើគេហទំព័រ si.lds.org និងលើស្លាកចំណាំព្រះគម្ពីរដែលមានចំណេះចំណានខគម្ពីរ ។

ចំណេះចំណានខគម្ពីរចំនួនពីរដែលបង្រៀនថាការព្យាករណ៍របស់អ្នកបម្រើព្រះអម្ចាស់នឹងកើតឡើងគឺ គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៣៧–៣៨ និង អេម៉ុស ៣:៧ ។ អ្នកអាចចង់សរសេរបទគម្ពីរយោងទាំងនេះនៅក្បែរ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៥ ក្នុងព្រះគម្ពីររបស់អ្នក ។

បន្ទាប់ពី ម៉ាទិន ហារីស បានបង្ហាញតួអក្សរទៅដល់សាស្ត្រាចារ្យ អ៊ែនថុន និង បណ្ឌិត មិចឆែល ហើយ លោកក៏បានត្រឡប់ទៅកាន់ ប៉ាលម៉ៃរ៉ា វិញដោយមានការប្ដេជ្ញាចិត្តសាជាថ្មីថានឹងជួយដល់ការបោះពុម្ពព្រះគម្ពីរមរមន ។

៣. សូមសរសេរប្រយោគពីរបីក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកដោយសង្ខេបនូវអ្វីដែលអ្នកបានសិក្សាក្នុងមេរៀននៅថ្ងៃនេះ និងមូលហេតុដែលវាមានសារៈសំខាន់ចំពោះអ្នក ។ សូមគិតពីការចែកចាយនូវអ្វីដែលអ្នកបានសរសេរទៅកាន់គ្រួសារ ឬ មិត្តភក្ដិម្នាក់របស់អ្នក ។

៤. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៥–៦៥ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៣ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣; ១០

## បុព្វកថា

ចាប់ពីពាក់កណ្ដាលខែមេសា រហូតដល់ពាក់កណ្ដាលខែមិថុនា ឆ្នាំ ១៨២៨ ព្យាការី យ៉ូសែប ស្ម៊ីធ បានបកប្រែផ្ទាំងមាស ខណៈពេលដែលកំពុងរស់នៅភូមិហាម៉ូនី រដ្ឋប៉ែនសិលវេញ៉ា ។ កសិករ និង អ្នកជំនួញដ៏ធូរធារម្នាក់ឈ្មោះម៉ាទីស ហារីស បានធ្វើជាស្មៀនខណៈពេលដែលយ៉ូសែប បានបកប្រែព្រះគម្ពីរមរមន ។ ម៉ាទីន មានវ័យចំណាស់ជាងយ៉ូសែប ២២ ឆ្នាំ ហើយបានឧបត្ថម្ភប្រាក់ដល់យ៉ូសែប និងអិមម៉ា ចំនួន ៥០ ដុល្លា (ជាចំនួនទឹកប្រាក់ដ៏ច្រើននៅជំនាន់នោះ) ដើម្បីជួយពួកគេឲ្យផ្លាស់ទៅកាន់ ភូមិ ហាម៉ូនី រដ្ឋផែនផែនសិលវេញ៉ាជាកន្លែងដែលគ្រួសារអិមម៉ាបានរស់នៅ ដូច្នេះវាបានជួយគាំទ្រដល់ យ៉ូសែបខណៈពេលលោកបកប្រែផ្ទាំងចំណារ ។ ក្នុងខែ កុម្ភៈ ឆ្នាំ ១៨២៨ យ៉ូសែប បានអនុញ្ញាតឲ្យម៉ាទីនយកច្បាប់ចម្លងតួអក្សរចេញពីផ្ទាំងទាំងនោះទៅឲ្យពួកសាស្ត្រាចារ្យនៅទីក្រុង នូវ យ៉ោក ធ្វើការបញ្ជាក់ ( សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៣–៦៥ ) ។ លូស៊ី ហារីស ដែលជាភរិយារបស់ម៉ាទីន បានចាប់ផ្ដើមព្រួយបារម្ភកាន់តែខ្លាំងពីចំណាប់អារម្មណ៍ និងការបរិច្ចាគផ្នែកហិរញ្ញវត្ថុរបស់ម៉ាទីនទៅលើការបកប្រែផ្ទាំងទាំងនោះ ។ នាង និង មនុស្សដទៃទៀតបានចាប់ផ្ដើមដាក់សម្ពាធឲ្យម៉ាទីនរកភស្តុតាងមកបញ្ជាក់ពីភាពជាក់ស្តែងនៃផ្ទាំងទាំងនោះ ។ ដើម្បីឲ្យពួកគេបានស្កប់ចិត្ត នៅពាក់កណ្ដាលខែ មិថុនា ម៉ាទីន បានស្នើឲ្យយ៉ូសែបអនុញ្ញាតឲ្យគាត់យកច្បាប់សរសេរដៃចំនួន ១១៦ ទំព័រ ដែលពួកលោកបានបញ្ចប់ការបកប្រែទៅបង្ហាញជាភស្តុតាង ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:១–៣

*យ៉ូសែប ស្ម៊ីធ បានយល់ថាកិច្ចការរបស់ព្រះពុំអាចធ្វើឲ្យស្អុគស្មាញបានឡើយ ។*

សូមគិតពីស្ថានភាពដែលអ្នកអាចត្រូវបានល្បួងឲ្យស្ដាប់តាមមិត្តភក្ដិជាងធ្វើតាមឱវាទ ឬ ព្រះបញ្ញត្តិរបស់ព្រះវរបិតាសួគ៌ ។ ឧបមាថា អ្នកអាចនឹងត្រូវល្បួងបណ្ដោយឲ្យមិត្តម្នាក់ចម្លងកិច្ចការផ្ទះរបស់ខ្លួន ឬល្បួងឲ្យមើលភាពយន្ត ឬ វីដេអូនៅលើអ៊ិនធើរណែតដែលមិនសមរម្យជាមួយមិត្តភក្ដិរបស់អ្នក ។ ហេតុអ្វីបានជាពេលខ្លះមានការលំបាកដើម្បីប្រឈមមុខនឹងមិត្តភក្ដិកាលដែលពួកគេសុំឲ្យអ្នកធ្វើអ្វីមួយដែលអ្នកដឹងថាជារឿងខុសឆ្គងហើយនោះ ?

មកដល់ត្រឹមពាក់កណ្ដាលខែ មិថុនា ឆ្នាំ ១៨២៨ ព្យាការី យ៉ូសែប ស្ម៊ីធ ដែលមានម៉ាទីន ហារីស ជាស្មៀន បានបកប្រែច្បាប់សរសេរដៃចំនួន ១១៦ ទំព័រចេញពីផ្ទាំងមាស ។ ម៉ាទីន បានសុំយ៉ូសែប អនុញ្ញាតឲ្យលោកយកសំណៅសរសេរដៃនោះទៅ « អានឲ្យមិត្តរបស់គាត់ដែល [ ប្រហែលជា ] គាត់អាចផ្លាស់ប្រែចិត្តគំនិតរបស់ពួកគេឲ្យជឿលើសេចក្ដីពិត » ( *ប្រវត្តិ វ៉ុល ១ ៖ យ៉ូសែប ស្ម៊ីធ ប្រវត្តិ ឆ្នាំ ១៨៣២–១៨៤៤* វ៉ុល ១ នៃប្រវត្តិរបស់ *The Joseph Smith Papers* [ ឆ្នាំ ២០១២ ] ទំព័រ ១៥ ) ។ យ៉ូសែប បានទូលអង្វរដល់ព្រះអម្ចាស់តាមសំណើរបស់ម៉ាទីន ប៉ុន្តែលោកត្រូវបានប្រាប់ថាកុំឲ្យសំណៅសរសេរដៃនោះទៅមនុស្សផ្សេងឲ្យសោះ ។ ម៉ាទីន បានបញ្ចុះបញ្ចូលឲ្យយ៉ូសែបទូលសូមព្រះអម្ចាស់ម្ដងទៀត—ដែលក្រោយមកទទួលបានចម្លើយបដិសេធពីព្រះអម្ចាស់ជាលើកទីពីរ ។ ម៉ាទីន បានបញ្ចុះបញ្ចូលឲ្យយ៉ូសែបសូមម្ដងទៀត ហើយសម្រាប់សំណើជាលើកទីបីនេះ ព្រះអម្ចាស់បានប្រទានការអនុញ្ញាតឲ្យម៉ាទីនយកសំណៅសរសេរដៃនោះបាន តែក្នុងករណីដែលគាត់បង្ហាញច្បាប់សរសេរដៃនោះទៅកាន់ភរិយា និងសមាជិកគ្រួសាររបស់គាត់មួយចំនួនប៉ុណ្ណោះ ។ ប៉ុន្តែ ម៉ាទីន បានរំលងពាក្យសច្ចា រួចក៏បានធ្វើឲ្យបាត់សំណៅសរសេរដៃនោះទៅ ។ ដោយសារតែយ៉ូសែប ពុំបានធ្វើតាមឱវាទរបស់ព្រះអម្ចាស់តាំងតែពីដំបូងមកនោះ តែបែរជាចោល « អ្វីដែលពិសិដ្ឋទៅក្នុងកណ្ដាប់ដៃនៃមនុស្សទុច្ចរិត » ( គ. និង ស. ៣:១២ ) នោះមរ៉ូណៃបានដកហូតយកផ្ទាំងចំណារថែមទាំងយូរីម និង ធូមីម ពីព្យាការី ។ ទោះជាយ៉ាងណាក៏ដោយ ក៏យ៉ូសែបត្រូវបានប្រាប់ថាលោកអាចទទួលបានវត្ថុទាំងនោះវិញ ប្រសិនបើលោក « មានចិត្តទន់ទាប និង វិប្បដិសារី » ( លូស៊ី ម៉ាក ស្ម៊ីធ *History of Joseph Smith by His Mother,* ed. Preston Nibley [ ឆ្នាំ ១៩៥៨ ] ទំព័រ ១៣៤ ) ។



ដោយគិតពីអ្វីដែលអ្នកដឹងពីម៉ាទិន ហារីស និងពីអ្វីដែលគាត់បានធ្វើសម្រាប់យ៉ូសែប ស្ម៊ីធ តើអ្នកគិតថាហេតុអ្វីបានជាយ៉ូសែប ទទូចអង្វរដល់ព្រះថាតើម៉ាទិនអាចយកសំណៅសរសេរដៃនោះបានដែរឬទេ ទោះជាព្រះបានប្រទានចម្លើយយ៉ាងច្បាស់ដល់លោកជាលើកទីមួយ និងទីពីរហើយនោះ ?

បន្ទាប់ពីទំព័រទាំង ១១៦ បានបាត់ ព្យាការីបានមានការប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំងចំពោះព្រលឹងរបស់លោក ។ ក្នុងខែ កក្កដា ឆ្នាំ ១៨២៨ មរ៉ូណៃ បានប្រគល់ យូរីម និង ធូមីម មកឲ្យយ៉ូសែបវិញជាបណ្ដោះអាសន្នក្នុងគោលបំណងឲ្យលោកទទួលបានវិវរណៈដែលមានចែងក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:១–៣ រួចកត់ចំណាំពីសេចក្ដីពិតមួយដែលព្រះបានត្រាស់សម្ដែងដល់ព្យាការីយ៉ូសែប ស្ម៊ីធ នៅក្នុងខគម្ពីរទាំងនោះ ។

យើងស្វែងយល់ចេញពីខគម្ពីរទាំងនេះថា **គោលបំណងទាំងឡាយរបស់ព្រះពុំអាចធ្វើឲ្យស្អុតស្អាញបានឡើយ** ។ ដូចបានប្រើនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:១ វាអាចជួយយើងឲ្យយល់ថា ពាក្យ *ស្អុតស្អាញ* មានន័យថា ទប់ស្កាត់ពីការសម្រេចបានជោគជ័យ ។

១. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកពីរបៀបដែលសេចក្ដីពិតនេះអាចលួងលោមចិត្តដល់យ៉ូសែប ស្ម៊ីធ នៅគ្រានោះ ។ តើអ្នកគិតថាហេតុអ្វីបានជាវាមានសារៈសំខាន់ចំពោះអ្នកដែលមានចំណែកក្នុងការបម្រើដល់ព្រះអម្ចាស់ក៏ត្រូវយល់ផងដែរថា គម្រោងការណ៍របស់ព្រះពុំអាចធ្វើឲ្យស្អុតស្អាញបានឡើយនោះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:៤–១៥

*ព្រះអម្ចាស់បន្ទោសដល់យ៉ូសែប ស្ម៊ីធ ហើយទូន្មានឲ្យលោកប្រែចិត្ត*

ទោះជាព្រះអម្ចាស់បានលួងលោមដល់យ៉ូសែបក្ដី ក៏ទ្រង់មានព្រះទ័យឲ្យព្យាការីយក្មេងរូបនេះយល់ពីកំហុសដែលលោកបានធ្វើ និងលទ្ធផលមកពីកំហុសទាំងនោះដែរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:៤–៦ រួចស្វែងរកពាក្យ និង ឃ្លាទាំងឡាយដែលអាចជាពាក្យដ៏ពិបាកស្ដាប់សម្រាប់យ៉ូសែប ស្ម៊ីធ ។

ឥឡូវនេះសូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:១២–១៥ រួចស្វែងរកមូលហេតុដែលទង្វើរបស់យ៉ូសែបមានសភាពធ្ងន់ធ្ងរចំពោះព្រះនេត្រព្រះអម្ចាស់ ។ វាក៏អាចជាប្រយោជន៍ផងដែរ ក្នុងការយល់ពីអត្ថន័យដែលព្រះអម្ចាស់ចង់មានន័យ កាលដែលទ្រង់មានព្រះបន្ទូលហៅម៉ាទីន ហារីស ថាជា « មនុស្សទុច្ចរិត » ( គ. និង ស. ៣:១២ ) ។ ម៉ាទីន ពុំមែនជាមនុស្សដែលចូលចិត្តប្រព្រឹត្តបាប ដែលពុំចេះទទួលកំហុស ឬ ជាមនុស្សអសីលធម៌នោះទេ ។ ផ្ទុយទៅវិញ គាត់ជាមនុស្សដែលប្រព្រឹត្តបាបដោយការបណ្ដោយខ្លួនទៅតាមភាពទន់ខ្សោយដែលមានក្នុងខ្លួនគាត់ រួមបញ្ចូលទាំងភាពអួតអាងផងដែរ ។ ក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:១៣ សូមកត់ចំណាំពីមូលហេតុដែលព្រះអម្ចាស់បានពន្យល់ពីរបៀបដែលម៉ាទីនជាមនុស្សទុច្ចរិត ។

ព្រះអម្ចាស់បានរំឭកយ៉ូសែប ពីអ្វីដែលលោកគួរតែបានធ្វើកាលលោកស្ថិតនៅក្រោមសម្ពាធរបស់ម៉ាទីន ហារីស ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:៧ រួចបំពេញសេចក្ដីពិតតទៅនេះដោយផ្អែកទៅលើឱវាទរបស់ព្រះអម្ចាស់ទៅកាន់យ៉ូសែប ស្ម៊ីធ ៖ **យើងគួរខ្លាចព្រះជាង** .អ្នកអាចគូសចំណាំពាក្យ ឬ ឃ្លាក្នុង ខទី ៧ ដែលបង្រៀនពីគោលការណ៍នេះ ។

ការពន្យល់ខាងក្រោមនេះពី អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់អាចជួយអ្នកឲ្យយល់ពីសេចក្ដីពិតនេះបានកាន់តែច្បាស់ ៖



« មានកន្លែងជាច្រើនក្នុងព្រះគម្ពីរដែលទូន្មានដល់មនុស្សលោកឲ្យចេះកោតខ្លាចដល់ព្រះ ។ ក្នុងសម័យយើងនេះ យើងបកស្រាយអត្ថន័យនៃពាក្យ *កោតខ្លាច* ថាជា ‹ ការគោរព › ឬ ‹ គារវភាព › ឬ ‹ សេចក្ដីស្រឡាញ់ › ដែលការកោតខ្លាចដល់ព្រះ មានន័យថា សេចក្ដីស្រឡាញ់ដល់ព្រះ ឬ ការគោរពដល់ទ្រង់ រួមទាំងក្រឹត្យវិន័យរបស់ទ្រង់ ។ ជាញឹកញាប់ នោះអាចជាការអានដ៏ត្រឹមត្រូវមួយ ប៉ុន្តែខ្ញុំឆ្ងល់ពេលខ្លះ បើពាក្យ *ខ្លាច* ពុំមានន័យពិតថាជា *ខ្លាច* នៅពេលពួកព្យាការីនិយាយអំពីការភ័យខ្លាចធ្វើឲ្យព្រះអាក់អន់ព្រះទ័យ ដោយការមិនគោរពបទបញ្ញត្តិរបស់ទ្រង់នោះ ។. . .

« . . .យើងគួរតែស្រឡាញ់ និងមានគារវភាពចំពោះទ្រង់ ដែលយើងខ្លាចក្នុងការធ្វើអ្វីមួយខុសនៅចំពោះព្រះនេត្រទ្រង់ មិនថាអាចនឹងមានគំនិត ឬសម្ពាធមកពីអ្នកដទៃយ៉ាងណានោះទេ » ( "A Sense of the Sacred" [ ការប្រជុំពិសេសរបស់ប្រព័ន្ធអប់រំសាសនាចក្រសម្រាប់ពួកយុវមជ្ឈិមវ័យ ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ] ទំព័រ ៦–៧ ) ។

២. សូមពន្យល់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបដែលការកោតខ្លាច ការមានន័យថា សេចក្ដីស្រឡាញ់ និងការមានគារវភាព និងការខ្លាចញញើតថានឹងធ្វើឲ្យព្រះអាក់អន់ព្រះទ័យ ដូចបានពន្យល់ដោយអែលឌើរ គ្រីស្ទហ្វឺសិន អាចជួយអ្នកឲ្យធ្វើជម្រើសត្រឹមត្រូវទោះជាមានសម្ពាធពីសំណាក់មនុស្សដទៃយ៉ាងណាក្ដី ។

យ៉ូសែប ស្ម៊ីធ ត្រូវបានប្រាប់ពីការណ៍ដែលព្រះនឹងធ្វើ ប្រសិនបើយ៉ូសែប បានស្ដាប់តាមចម្លើយមកពីទ្រង់ចំពោះសំណើដំបូងរបស់ ម៉ាទិន ហារីស ។ សូមគូសចំណាំការអះអាងនេះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:៨ ។

៣. ចេញពីអ្វីដែលអ្នកបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:៨ សូមបំពេញគោលការណ៍ « បើសិនជា–នោះ/ខណៈនោះ » នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកថា ៖ **បើសិនជាយើងស្មោះត្រង់នឹងព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ នោះ. . .**

សូមគិតអំពីគ្រាមួយ ឬ គ្រាជាច្រើនដែលអ្នកបានជ្រើសរើសធ្វើតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ជាងធ្វើតាមការបញ្ចុះបញ្ចូល ឬ ឥទ្ធិពលពីសំណាក់មនុស្សដទៃ ។ តើអ្នកធ្លាប់បានឃើញថាការសន្យានេះត្រូវបានបំពេញនៅក្នុងជីវិតរបស់អ្នកតាមរបៀបណា ?

៤. នៅដើមមេរៀននេះ អ្នកត្រូវបានសូមឲ្យគិតពីស្ថានភាពដែលអ្នកអាចត្រូវបានល្បួងឲ្យស្ដាប់តាមមិត្តភក្ដិជាងគោរពប្រតិបត្តិតាមព្រះវរបិតាសួគ៌ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមពន្យល់ពីរបៀបដែលសេចក្ដីពិតដែលអ្នកបានសិក្សានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:៨ អាចជួយអ្នក កាលដែលអ្នកត្រូវបានល្បួង ឬ ទទួលរងសម្ពាធឲ្យធ្វើអ្វីមួយដែលអ្នកដឹងថាជារឿងមិនត្រឹមត្រូវ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:៩–១១ រួចស្វែងរកការសន្យានានាដែលព្រះអម្ចាស់បានប្រទានដល់យ៉ូសែប ស្ម៊ីធ ថ្វីបើលោកបានធ្វើកំហុសដ៏ធ្ងន់ធ្ងរក៏ដោយ ។ សូមគិតអំពីរបៀបដែលការសន្យានេះអនុវត្តចំពោះយើងកាលយើងប្រព្រឹត្តបាប ឬ ធ្វើកំហុស ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:១៦–២០

*ព្រះអម្ចាស់ពន្យល់ពីគោលបំណងទ្រង់ចំពោះព្រះគម្ពីរមរមន*

ក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:១៦–២០ គោលបំណងរបស់ព្រះអម្ចាស់ចំពោះព្រះគម្ពីរមរមនត្រូវបានពន្យល់ប្រាប់ ។ សូមអានខគម្ពីរទាំងនេះ រួចស្វែងរកមូលហេតុដែលកិច្ចការដែល យ៉ូសែប ស្ម៊ីធ កំពុងធ្វើមានសារៈសំខាន់ចំពោះព្រះអម្ចាស់ និងរាស្ត្ររបស់ទ្រង់ខ្លាំងម្ល៉េះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:១–៤

*ព្រះអម្ចាស់ប្រទានអំណោយទានដល់យ៉ូសែបដើម្បីបកប្រែម្ដងទៀត*

មិនយូរប៉ុន្មានបន្ទាប់ពីផ្ទាំងចំណារព្រះគម្ពីរមរមន រួមទាំងយូរីម និង ធូមីម ត្រូវបានប្រទានដល់លោកវិញ នោះព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលការដឹកនាំពីព្រះអម្ចាស់ស្ដីពីកិច្ចការដែលលោកត្រូវធ្វើអំពីចំណែកនៃផ្ទាំងចំណារដែលទាក់ទងនឹងទំព័រសរសេរដៃដែលបានបាត់ទៅហើយនោះ ។ ព្រះអម្ចាស់បានត្រាស់បញ្ជាឲ្យយ៉ូសែបកុំបកប្រែចំណែកនោះ រួចទ្រង់បានបើកសម្ដែងពីផែនការសម្ងាត់របស់សាតាំងដែលចង់បំផ្លាញកិច្ចការរបស់ព្រះ ។ ក្រោយមកទ្រង់បានត្រាស់បញ្ជាឲ្យយ៉ូសែប បកប្រែផ្ទាំងចំណារតូចនៃនីហ្វៃដែលនឹងត្រូវប្រើជំនួសឲ្យទំព័រទាំង ១១៦ ដែលបានបាត់នោះ ហើយទ្រង់បានពន្យល់ពីគោលបំណងនៃព្រះគម្ពីរមរមន និងតួនាទីរបស់វាក្នុងការស្ថាបនាសាសនាចក្ររបស់ទ្រង់ឡើង ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:១–២ ព្រះអម្ចាស់បានរំឭកយ៉ូសែបពីមូលហេតុដែលអំណាចនៃការបកប្រែត្រូវបានដកចេញពីលោក និងពីអ្វីដែលបានកើតឡើងដែលជាលទ្ធផលមកពីកំហុសរបស់លោក ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៣–៤ រួចស្វែងរកឱវាទដែលព្រះអម្ចាស់បានប្រទានដល់យ៉ូសែប ស្ម៊ីធ កាលលោកចាប់ផ្ដើមបកប្រែសាជាថ្មី ។

តើបទពិសោធន៍របស់យ៉ូសែបដែលមានចំពោះការបាត់បង់ច្បាប់សរសេរដៃ អាចធ្វើឲ្យលោកមានបំណងប្រាថ្នាធ្វើការកាន់តែខ្លាំងឡើងក្នុងកិច្ចការបកប្រែរបស់លោកយ៉ាងដូចម្ដេច ? ព្រះអម្ចាស់បានជ្រាបថា យ៉ូសែប ស្ម៊ីធ មានកិច្ចការអាទិភាពជាច្រើនក្នុងជីវិតដូចជាការមើលថែភរិយា និងផ្គត់ផ្គង់ជីវិតរស់នៅ ហើយទ្រង់បានទូន្មានលោកកុំឲ្យធ្វើការ ឬ បកប្រែលើសពីកម្លាំងដែលលោកមានឡើយ ។ តើដំបូន្មានដែលថាមិនឲ្យយើងរត់លឿនជាងកម្លាំងដែលយើងមាន អាចដឹកនាំយើងយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៥–៣៧

*សាតាំងព្យាយាមបំផ្លាញយ៉ូសែប ស្ម៊ីធ និង កិច្ចការរបស់ព្រះ*

តើអង្គប់ ឬ អន្ទាក់ដូចក្នុងរូបភាពនេះ អាចតំណាងឲ្យគោលបំណងរបស់សាតាំងដែលមានចំពោះយើងយ៉ាងដូចម្ដេច ?



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៥ រួចស្វែងរកអ្វីដែលព្រះអម្ចាស់បានត្រាស់បញ្ជាឲ្យព្យាការី យ៉ូសែប ស្ម៊ីធ ធ្វើដើម្បីចៀសផុតពីអង្គប់របស់សាតាំង ។ ( គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៥ គឺជាចំណេះចំណានខគម្ពីរមួយ ) ។

សូមបំពេញគោលការណ៍តទៅនេះដោយផ្អែកលើអ្វីដែលគោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៥ បង្រៀនអំពីពរជ័យដែលអាចកើតមានពីការអធិស្ឋាន ៖ **នៅពេលយើងអធិស្ឋានជានិច្ច** ____ ។ អ្នកអាចកត់ចំណាំពាក្យ ឬ ឃ្លាក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៥ ដែលបង្រៀនពីគោលការណ៍នេះ ។

ព្រះអម្ចាស់បានដាស់តឿនយ៉ូសែប ពីអង្គប់របស់សាតាំងដែលបានដាក់ដើម្បីបំផ្លាញយ៉ូសែប និងកិច្ចការរបស់ព្រះអម្ចាស់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៦, ១០–១៩ រួចស្វែងរកផែនការរបស់ជនទុច្ចរិតទាំងឡាយ ដែលពេលនោះមានការចង់បានច្បាប់សរសេរដៃដែល ម៉ាទិន ហារីស បានយកទៅផ្ទះ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:២០–២៩ ព្រះអម្ចាស់បានមានព្រះបន្ទូលអំពីឥទ្ធិពលរបស់សាតាំងដែលមានទៅលើជនដែលបានលួចយកទំព័រទាំង ១១៦ នៃច្បាប់សរសេរដៃ ។ ទ្រង់ក៏បានបើកបង្ហាញពីគោលបំណងរបស់សាតាំងផងដែរ ។ យើងស្វែងយល់ចេញពីខគម្ពីរទាំងនេះថា **សាតាំងចង់បំផ្លាញកិច្ចការរបស់ព្រះអម្ចាស់ និងព្រលឹងរបស់យើង ។**

៥. តើការស្គាល់ពីគោលបំណងរបស់សាតាំង និងកលល្បិចរបស់វា ជួយអ្នកឲ្យចៀសវាង និងរួចផុតពីអង្គប់របស់វាបានយ៉ាងដូចម្ដេច ? សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកនូវផែនការដែលអ្នកអាចអនុវត្ត ដើម្បីចៀសវាង ឬ រួចផុតពីអង្គប់របស់វា ដែលមានដូចជា ចៀសវាងការមើលរូបភាពអសីលធម៌ ប្រសិនបើវាលេចឡើងនៅពីមុខអ្នក ឬ ទៅកន្លែងដែលអ្នកដឹងថាមិនគួរទៅ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៣០–៣៧ យើងស្វែងយល់ថា ដោយសារតែផែនការជនទុច្ចរិតទាំងនោះដើម្បីបំផ្លាញកិច្ចការរបស់ព្រះ និងកិត្តិនាមរបស់យ៉ូសែប ស្ម៊ីធ នោះហើយ ទើបព្រះអម្ចាស់ត្រាស់បញ្ជាកុំឲ្យព្យាការីបកប្រែចំណែកនៃផ្ទាំងចំណារដែលមានចារនៅលើទំព័រដែលបានបាត់នោះឡើយ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៣៨–៤៥

*ព្រះអម្ចាស់បញ្ជាឲ្យយ៉ូសែប ស្ម៊ីធ បកប្រែផ្ទាំងនីហ្វៃ*

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៣៨–៤២ រួចស្វែងរកអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ឲ្យយ៉ូសែប ស្ម៊ីធ បកប្រែជំនួសឲ្យចំណែកនៃផ្ទាំងដែលត្រូវបានបកប្រែនៅលើច្បាប់សរសេរដៃដែលបានបាត់នោះ ។

ឯកសារដែលបានបាត់នោះមាននូវការបកប្រែនៃព្រះគម្ពីរលីហៃ ដែលមាននៅក្នុងការសង្ខេបរបស់មរមន សម្រាប់ផ្ទាំងធំនៃនីហ្វៃ ( មាន ៦០០ ឆ្នាំ ម. គ. ស. ដល់ ១៣០ ឆ្នាំ ម. គ. ស. ) ។ នីហ្វៃត្រូវបានបំផុសគំនិតឲ្យសរសេរផ្ទាំងតូចនៃនីហ្វៃ ហើយមរមនត្រូវបានបំផុសគំនិតឲ្យបញ្ចូលផ្ទាំងតូចនៃនីហ្វៃទៅក្នុងបញ្ជីប្រវត្តិរបស់លោកសម្រាប់ « គោលបំណងដ៏សំខាន់មួយ »

ដែលកាលនោះពួកលោកពុំបានយល់ច្បាស់នោះទេ ( សូមមើល នីហ្វៃទី១ ៩:៥; ពាក្យសម្ដីនៃមរមន ១:៣–៧) ។ ផ្ទាំងតូចនៃនីហ្វៃមានរយៈពេលស្ទើរតែដូចគ្នា ( ចាប់ពី ៦០០ ឆ្នាំ ម. គ. ស. ដល់ ១៣០ ឆ្នាំ ម. គ. ស. ) នឹងគម្ពីរលីហៃដែរ ។

តើការដឹងថា ព្រះបានរៀបចំផ្លូវទុកជាមុនរយៈពេលរាប់ពាន់ឆ្នាំដើម្បីទូទាត់នឹងសំណៅសរសេរដៃទាំង ១១៦ ទំព័រដែលបានបាត់នោះ ជួយអ្នកឲ្យទុកចិត្តលើទ្រង់កាន់តែខ្លាំងដោយរបៀបណា ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៤៦–៧០

*ព្រះអម្ចាស់ពន្យល់ពីគោលបំណងនៃព្រះគម្ពីរមរមន និងពីតួនាទីរបស់វាក្នុងការស្ថាបនាសាសនាចក្រទ្រង់ឡើង*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៤៦–៧០ យើងស្វែងយល់ថា ព្រះអម្ចាស់បានឆ្លើយតបនឹងការអធិស្ឋានដ៏ស្មោះត្រង់របស់ពួកសិស្សសាសន៍នីហ្វៃរបស់ទ្រង់ ដោយបានថែរក្សា និង នាំយកព្រះគម្ពីរមរមនមកឲ្យយើងក្នុងជំនាន់នេះ ។ ព្រះអម្ចាស់បានបង្រៀនព្យាការី យ៉ូសែប ស្ម៊ីធ ថា ព្រះគម្ពីរមរមន « នាំមកឯពន្លឺឲ្យឃើញនូវចំណុចដ៏ពិតអំពីគោលលទ្ធិរបស់ [ ទ្រង់ ] » ( គ. និង ស. ១០:៦២) ។ ព្រះអង្គសង្គ្រោះបានស្ថាបនាសាសនាចក្រទ្រង់ឡើងនៅថ្ងៃចុងក្រោយដោយផ្អែកទៅលើចំណុចនៃគោលលទ្ធិទាំងនោះ ។

## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៥

៦. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០:៥ ឡើងវិញ រួចសរសេរចូលទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកនូវគ្រាមួយដែលការអធិស្ឋានបានជួយអ្នកឲ្យយកឈ្នះលើសាតាំង ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៣ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤

## បុព្វកថា

ក្នុងខែ កុម្ភៈ ឆ្នាំ ១៨២៩ យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ និង លូស៊ី ជាភរិយារបស់លោក បានទៅសួរសុខទុក្ខកូនប្រុសរបស់ពួកលោក យ៉ូសែប ស្ម៊ីធ ជុញ៉័រ នៅភូមិហាម៉ូនី រដ្ឋ ប៉ែនសិលវេញ៉ា ។ យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ បានចង់ដឹងពីអ្វីដែលព្រះអម្ចាស់បានមានព្រះទ័យឲ្យគាត់ជួយក្នុងការងារនៃការស្ដារឡើងវិញ ។ កាលកំពុងសួរសុខទុក្ខនោះ យ៉ូសែប ស្ម៊ីធ ជុញ៉័រ បានទទួលវិវរណៈមួយ ។ វិវរណៈនេះបានប្រទានទៅដល់ឪពុករបស់ព្យាការី ដែលជាវិវរណៈទីមួយក្នុងចំណោមវិវរណៈមួយចំនួនដែលត្រូវបានប្រទានឲ្យបុគ្គលទាំងឡាយដែលបានបំណងជួយដល់កិច្ចការរបស់ព្រះអម្ចាស់ ( សូមមើល គ. និង ស. ៦; ៨–៩; ១១–១២; ១៤–១៦; ២៣; ២៥ ) ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:១–៣

*យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ ត្រូវបានហៅឲ្យបម្រើក្នុងការងារព្រះ*

តើអ្នកធ្លាប់មានបំណងបម្រើព្រះ ហើយចង់ស្គាល់ព្រះឆន្ទៈទ្រង់អំពីរបៀបដែលអ្នកអាចជួយដល់ទ្រង់បានយ៉ាងល្អបំផុតដែរឬទេ ? ឪពុកយ៉ូសែប ស្ម៊ីធបានមានបំណងប្រាថ្នាជួយព្រះអម្ចាស់នៅក្នុងកិច្ចការរបស់ទ្រង់ ប៉ុន្តែគាត់ពុំដឹងអំពីអ្វីដែលព្រះអម្ចាស់មានព្រះទ័យឲ្យគាត់ធ្វើឡើយ ។ គាត់បានសួរកូនប្រុសគាត់ដែលជាព្យាការីឲ្យសួរព្រះអម្ចាស់ជំនួសគាត់.គោលលទ្ធិ និង សេចក្ដីសញ្ញា ៤ គឺជាចម្លើយមកពីព្រះអម្ចាស់ ។ នៅក្នុងវិវរណៈនេះ ទ្រង់បានមានបន្ទូលពីគុណសម្បត្តិនានា ដែលទ្រង់មានព្រះទ័យរំពឹងពីអស់អ្នកដែលមានបំណងជួយដល់កិច្ចការរបស់ទ្រង់ ។ នៅពេលអ្នកអានកណ្ឌនេះ សូមកត់ចំណាំពីអ្វីដែលព្រះអម្ចាស់បានបង្រៀនដល់យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ អំពីរបៀបដែលយើងត្រូវបម្រើទ្រង់ ។



នៅពេលបានទទួលវិវរណៈនេះ សាសនាចក្រពុំទាន់បានបង្កើតឡើងនៅឡើយ ការបកប្រែព្រះគម្ពីរមរមនមិនទាន់បានបញ្ចប់ ហើយបព្វជិតភាពក៏មិនទាន់បានស្ដារឡើងវិញដែរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:១ ដោយស្វែងរករបៀបដែលព្រះអម្ចាស់បានពិពណ៌នាពីការស្ដារឡើងវិញនៃដំណឹងល្អដែលហៀបនឹងកើតមានឡើង ។ អ្នកអាចនឹងចង់កត់ចំណាំពាក្យដែលព្រះអម្ចាស់បានប្រើដើម្បីពិពណ៌នាពីការស្ដារឡើងវិញនៃដំណឹងល្អនៅថ្ងៃចុងក្រោយ ។ តើការស្ដារឡើងវិញនៃដំណឹងល្អ « អស្ចារ្យ » ដោយរបៀបណា ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:២ រួចស្វែងរកអ្វីដែលព្រះអម្ចាស់សូមពីអស់អ្នកដែលចាប់ផ្ដើម ឬ ចេញប្រតិបត្តិការធ្វើការបម្រើទ្រង់ ។ សូមបំពេញគោលការណ៍តទៅនេះដោយផ្អែកលើ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:២ ៖ **ប្រសិនបើយើងបម្រើទ្រង់ឲ្យអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំង លំដាប់នោះយើងអាច ។**

អ្នកក៏អាចចង់គូសចំណាំពាក្យ ឬ ឃ្លាដែលបង្រៀនពីគោលការណ៍នេះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:២ បានដែរ ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ការធ្វើអ្វីមួយដោយ « អស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងរបស់អ្នក » មានន័យថាដូចម្ដេច ?

ខ. តើការយល់ដឹង និង ការអនុវត្តន៍គោលការណ៍នេះ ជួយអ្នកយ៉ាងណា កាលដែលអ្នករួមចំណែកក្នុងកិច្ចការរបស់ព្រះអម្ចាស់ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៣ រួចស្វែងរកអ្វីដែលយើងត្រូវមាន ដែលនឹងជួយយើងឲ្យជោគជ័យក្នុងការជួយដល់កិច្ចការរបស់ព្រះអម្ចាស់ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

មនុស្សមួយចំនួនចាត់ទុក គោលលទ្ធិ និង សេចក្ដីសញ្ញា ៤ ថាជាការហៅបម្រើរបស់អ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ។ ទោះជាយ៉ាងណាក៏ដោយ យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ ដែលវិវរណៈនេះត្រូវបានប្រទានដល់លោកនោះ ពុំមែនត្រូវបានហៅឲ្យបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងឡើយ ។ ប៉ុន្តែលោកពិតជាបានធ្វើតាមដំបូន្មានដែលមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:២–៣ ពេញមួយជីវិតរបស់លោក ដោយបានបម្រើដោយការតាំងចិត្តមិនថាទីណា និងកន្លែងណាដែលលោកត្រូវបានហៅឲ្យទៅនោះទេ ។ លោកគឺជាសាក្សីមួយរូបក្នុងចំណោមសាក្សីទាំងប្រាំបីរូបនៃព្រះគម្ពីរមរមន និងមួយរូបក្នុងចំណោមអ្នកទទួលបុណ្យជ្រមុជទឹកដំបូងចូលក្នុងសាសនាចក្រ ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០ ។ លោកក៏បានបម្រើជាលោកអយ្យកោដំបូងរបស់សាសនាចក្រ និង ជាទីប្រឹក្សាជំនួយរបស់គណៈប្រធានទីមួយផងដែរ ។ សូមគិតពីមធ្យោបាយមួយចំនួនទៀត ក្រៅពីការបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ដែលអ្នកអាចជួយដល់កិច្ចការរបស់ព្រះអម្ចាស់បាន ។ ឧទាហរណ៍ ការដកស្រង់ខាងក្រោមចេញពីកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ក្រោមប្រធានបទនៃការបម្រើ ផ្ដល់នូវយោបល់មួយចំនួនស្ដីពីរបៀបដែលអ្នកអាចប្រព្រឹត្តចំពោះបំណងរបស់អ្នកក្នុងការជួយដល់កិច្ចការរបស់ព្រះអម្ចាស់នាពេលឥឡូវនេះថា ៖



« ការបម្រើដល់អ្នកដទៃគឺជាលក្ខណៈមួយដ៏សំខាន់អំពីសិស្សម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ ។ ជាសិស្សម្នាក់ គឺត្រូវមានឆន្ទៈដើម្បីសម្រាលបន្ទុករបស់អ្នកដទៃ និង ដើម្បី លួងលោម ដល់អ្នកទាំងឡាយដែលត្រូវការការលួងលោម ។ ជាញឹកញាប់ព្រះវរបិតាសួគ៌នឹងឆ្លើយតបចំពោះតម្រូវការរបស់អ្នកដទៃតាមរយៈអ្នក ។

« មានវិធីជាច្រើនដើម្បីបម្រើដល់អ្នកដទៃ ។ ការបម្រើដ៏សំខាន់បំផុតមួយចំនួន ដែលអ្នកអាចផ្ដល់បានគឺនៅក្នុងផ្ទះរបស់អ្នកផ្ទាល់ ។ អ្នកអាចបម្រើនៅក្នុងការចាត់តាំងពីសាសនាចក្រ សាលារៀន និង សហគមន៍របស់អ្នកបានផងដែរ ។ អ្នកអាចបម្រើដោយការធ្វើកិច្ចការពង្សប្រវត្តិ និង ព្រះវិហារបរិសុទ្ធ ។ អ្នកអាចបម្រើដោយការចែកចាយដំណឹងល្អជាមួយនឹងអ្នកដទៃឥឡូវនេះ និងក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងនាពេលអនាគត ។ ជាញឹកញាប់ការបម្រើដ៏មានអត្ថន័យបំផុត គឺត្រូវបានបង្ហាញតាមរយៈការធ្វើកិច្ចការល្អៗសាមញ្ញជារៀងរាល់ថ្ងៃ ។ ចូរស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធជារៀងរាល់ថ្ងៃ ដើម្បីដឹងថាតើត្រូវបម្រើនរណា និងពីរបៀបដើម្បីជួយស្របទៅតាមតម្រូវការទាំងឡាយរបស់ពួកគេ ។ សូមធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះនៅពេលអ្នកបម្រើដល់អ្នកដទៃ » (*ដើម្បីកម្លាំងនៃយុវជន* [ កូនសៀវភៅ ឆ្នាំ ២០១១ ] ទំព័រ ៣២) ។

២. សូមពិពណ៌នានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកនូវមធ្យោបាយជាក់លាក់មួយដែលអ្នកចង់ជួយដល់កិច្ចការព្រះអម្ចាស់នៅពេលនេះក្នុងជីវិតអ្នក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៤

*ស្រែសសំព្រុះល្មមច្រូតហើយ*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៤ ព្រះអម្ចាស់ចាត់ទុកមនុស្សលើពិភពលោកថាជាស្រែក្នុងវាល ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៤ រួចគូសចំណាំអ្វីដែលព្រះអម្ចាស់បានមានបន្ទូលពីវាលស្រែរបស់ទ្រង់ ( ឬមនុស្សលើពិភពលោក ) ។ វាអាចជួយអ្នកឲ្យយល់កាន់តែច្បាស់ពីខគម្ពីរនេះ ក្នុងការដឹងថាស្រូវសាលី និងស្រូវធម្មតាប្រែពណ៌នៅពេលវាលូតលាស់ ។ នៅពេលដែលដើមធញ្ញជាតិនៅខ្ចី វាមានពណ៌បៃតង ប៉ុន្តែ នៅពេលវាលូតលាស់ឡើងបន្តិច វាមានពណ៌ឡើង

ព្រលែត ។ នៅពេលដើមធញ្ញជាតិល្មមដើម្បីច្រូតកាត់ វាតែងបានគេពិពណ៌នាថាមាន « ពណ៌ស » ។ កាំបិតវែងរាងកោង ត្រូវបានហៅថាជា កណ្ដៀវ ប្រើសម្រាប់ច្រូតកាត់ធញ្ញជាតិ ។



៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថាឃ្លា « ស្រែសសំព្រះល្មមច្រូតហើយ » មានន័យដូចម្ដេច ?

ខ. តើអ្នកគិតថាការលូកកណ្ដៀវរបស់ខ្លួនដោយកម្លាំងរបស់ខ្លួន មានន័យដូចម្ដេច ?

គ. តើរង្វាន់ដែលបានលើកឡើងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៤ សម្រាប់អស់អ្នកដែលលូកកណ្ដៀវរបស់ខ្លួនដោយកម្លាំងរបស់ខ្លួន មានអ្វីខ្លះ ?

សេចក្ដីពិតមួយដែលយើងអាចស្វែងយល់ចេញពីខគម្ពីរនេះ អំពីឥទ្ធិពលនៃការងាររបស់យើងក្នុងការបម្រើដល់ព្រះអម្ចាស់ គឺថា **នៅពេលយើងបម្រើដោយឧស្សាហ៍ព្យាយាមដើម្បីនាំមនុស្សដទៃឲ្យមករកព្រះយេស៊ូវគ្រីស្ទ នោះយើងក៏អាចទទួលបានសេចក្ដីសង្គ្រោះសម្រាប់ខ្លួនយើងផងដែរ ។**

៤. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគ្រាមួយដែលអ្នកមានអារម្មណ៍ថាកាន់តែជិតស្និទ្ធនឹងព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទនៅពេលអ្នកខិតខំជួយដល់មនុស្សដទៃឲ្យមករកទ្រង់ទាំងពីរអង្គ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៥–៧

*ព្រះអម្ចាស់ណែនាំពីគុណសម្បត្តិ និង ឥរិយាបថចាំបាច់ទាំងឡាយដែលអស់អ្នកដែលបម្រើទ្រង់ត្រូវមាន*

សូមគិតពីការងារ អាជីព ឬ ជំនាញពីរបី ។ តើគុណសម្បត្តិ និង ឥរិយាបថចាំបាច់ណាខ្លះដែលមនុស្សម្នាក់ត្រូវមានដើម្បីសម្រេចបានការងារនីមួយៗនោះ ?

សូមស្វែងរករូបមន្តធ្វើម្ហូបមួយសម្រាប់អាហារដែលអ្នកចូលចិត្ត រួចអានបញ្ជីគ្រឿងផ្សំដែលមាននៅលើនោះ ។ តើនឹងមានអ្វីកើតឡើងប្រសិនបើអ្នកព្យាយាមធ្វើម្ហូបនោះ ប៉ុន្តែ ពុំបានដាក់គ្រឿងផ្សំមួយ ឬ ពីរ ? គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៥–៦ មាននូវបញ្ជី « គ្រឿងផ្សំ » ឬ ឥរិយាបថនានាដែលធ្វើឲ្យបុគ្គលម្នាក់មានគុណសម្បត្តិអាចជួយដល់កិច្ចការរបស់ព្រះអម្ចាស់បាន ។ សូមអានខគម្ពីរទាំងនេះ រួចគូសចំណាំពីឥរិយាបថដ៏ទេវភាពនីមួយៗដែលបានលើកឡើង ។ អ្នកក៏អាចចង់គូសចំណាំពាក្យ ឬ ឃ្លាដែលបង្រៀនពីគោលការណ៍នេះថា ៖ **នៅពេលយើងព្យាយាមអភិវឌ្ឍឥរិយាបថដ៏ទេវភាព នោះវានឹងជួយយើងឲ្យមានគុណសម្បត្តិអាចជួយដល់កិច្ចការរបស់ព្រះអម្ចាស់បាន ។**

សូមពិចារណាពីរបៀបដែលការអភិវឌ្ឍន៍ឥរិយាបថដ៏ទេវភាពនីមួយៗទាំងនេះ អាចជួយអ្នកឲ្យជួយដល់កិច្ចការរបស់ព្រះអម្ចាស់បានកាន់តែប្រសើរឡើង ។

៥. សូមជ្រើសរើសឥរិយាបថមួយចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៥–៦ ដែលអ្នកចង់អភិវឌ្ឍឲ្យបានកាន់តែពេញលេញ ។ ដោយប្រើធនធាននានាដែលមានសម្រាប់អ្នក ( ដូចជា Topical Guide និង សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ) សូមស្វែងរកខគម្ពីរផ្សេងទៀតចំនួនបីដែលបង្រៀនពីឥរិយាបថនោះ ។ ( អ្នកក៏អាចចង់អានព័ត៌មាននៅក្នុង *ពិតចំពោះសេចក្ដីជំនឿ* ឬនៅក្នុងសេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ សម្រាប់ឥរិយាបថដែលអ្នកបានជ្រើសរើស ) ។ សូមសរសេរការសង្ខេបខ្លីមួយនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្វីដែលអ្នកបានសិក្សាពីឥរិយាបថនោះ ក៏ដូចជាអ្វីដែលអ្នកអាចធ្វើនាពេលឥឡូវនេះ ដើម្បីចាប់ផ្ដើមអភិវឌ្ឍឥរិយាបថនោះ ។ អ្នកអាចចង់ចែកចាយផែនការរបស់អ្នកជាមួយឪពុកម្ដាយ ឬ មិត្តភក្ដិជិតស្និទ្ធ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤:៧ រួចស្វែងរកវបៀបដែលអ្នកអាចព្យាយាម ហើយអភិវឌ្ឍឥរិយាបថទាំងនេះ ។ សូមពិចារណាពីអត្ថន័យនៃ « សូម » និង « គោះ » ។ តើការអធិស្ឋានអាចជួយយើងឲ្យអភិវឌ្ឍឥរិយាបថដ៏ទេវភាពទាំងនេះយ៉ាងដូចម្ដេច ?

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៣ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្តីសញ្ញា ៥

## បុព្វកថា

ទោះជា ម៉ាទិន ហារីស បានធ្វើឲ្យបាត់សំណៅសរសេរដៃទាំង ១១៦ ទំព័រនៃព្រះគម្ពីរមរមនកាលពីរដូវក្តៅក្នុងឆ្នាំ ១៨២៨ យ៉ាងណាក្តី ក៏គាត់នៅតែមានបំណងជួយឲ្យព្រះគម្ពីរមរមនលេចឡើងចេញជារូបរាងដែរ ។ ក្នុងខែ មិនា ឆ្នាំ ១៨២៩ ម៉ាទិន បានគ្រោងធ្វើដំណើរចេញពីផ្ទះរបស់គាត់នៅទីក្រុង នូវ យ៉ោក ទៅសួរសុខទុក្ខយ៉ូសែប និង អិមម៉ា ស្ម៊ីធ នៅភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា ។ ទោះជាយ៉ាងណាក៏ដោយ ភរិយារបស់ម៉ាទិនគឺ លូស៊ី ហារីស ពុំសប្បាយចិត្តឡើយចំពោះពេលវេលា និងប្រាក់កាសដែលស្វាមីរបស់គាត់បានលះបង់សម្រាប់ការបោះពុម្ពព្រះគម្ពីរមរមន ។ នាងក៏បានខឹងនឹងយ៉ូសែប ស្ម៊ីធ ដែលបានបដិសេធនឹងសំណើរបស់គាត់ពីមុនដើម្បីសុំមើលផ្ទាំងចំណារមាស ។ គាត់បានដាក់បណ្តឹងតាមផ្លូវច្បាប់ប្រឆាំងនឹងយ៉ូសែប ហើយបានកេណ្ឌមនុស្សមួយចំនួនដែលចង់ធ្វើជាសាក្សីថាលោកបានកុហកថាមានផ្ទាំងចំណារមាស ។ បន្ថែមពីលើការគំរាមកំហែងខាងច្បាប់ប្រឆាំងនឹងយ៉ូសែប មនុស្សទាំងនេះបានព្រមានដល់ម៉ាទិន ហារីស ថាប្រសិនបើគាត់ពុំចូលរួមជាមួយនឹងពួកគេដើម្បីធ្វើជាសាក្សីចំពោះការបោកបញ្ឆោត និងការក្លែងបន្លំរបស់យ៉ូសែប ស្ម៊ីធ ទេនោះ ម៉ាទិន ក៏នឹងមានបញ្ហា ហើយជាប់គុកជាមួយយ៉ូសែបដែរ ។

នៅគ្រានោះ ម៉ាទិន ពុំទាន់បានឃើញផ្ទាំងចំណារមាសដោយផ្ទាល់នឹងភ្នែកគាត់នៅឡើយទេ ទោះជាគាត់មានតួនាទីជាស្មៀនរបស់យ៉ូសែបក៏ដោយ ។ បន្ទាប់ពីបានទៅដល់ផ្ទះរបស់យ៉ូសែបហើយនោះ ម៉ាទិន បានប្រាប់ពីបំណងប្រាថ្នារបស់គាត់ដើម្បីទទួលបានសាក្សីបន្ថែមចំពោះភាពជាក់ស្តែងនៃផ្ទាំងចំណារមាស ។ បន្ទាប់ពីបានឮសំណើរបស់ម៉ាទិនដើម្បីសុំមើលផ្ទាំងចំណារហើយនោះ លោកបានទូលសួរដល់ព្រះអម្ចាស់ ហើយបានទទួលវិវរណៈដែលមានចែងនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៥ ។ ព្រះអម្ចាស់បានមានព្រះបន្ទូលនៅក្នុងវិវរណៈនេះថា សាក្សីបីរូបនឹងត្រូវបានហៅឲ្យថ្លែងទីបន្ទាល់ពីព្រះគម្ពីរមរមន ហើយបានមានព្រះបន្ទូលប្រាប់ដល់ម៉ាទិន ពីអ្វីដែលគាត់ត្រូវតែធ្វើ ដើម្បីក្លាយជាសាក្សីមួយរូបក្នុងចំណោមសាក្សីទាំងបី ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ៥:១–២២

*ព្រះអម្ចាស់មានព្រះបន្ទូលថា ទ្រង់នឹងនាំព្រះបន្ទូលទ្រង់ចេញមកនៅថ្ងៃចុងក្រោយ ហើយពួកសាក្សីនឹងថ្លែងទីបន្ទាល់ពីវា*

តើអ្នកធ្លាប់ត្រូវបានគេសុំឲ្យធ្វើជាសាក្សីដែរឬទេ ? តើវាតម្រូវឲ្យធ្វើអ្វីខ្លះដើម្បីក្លាយជាសាក្សីដ៏ជំនាញ ? តើមានព្រឹត្តិការណ៍ក្នុងប្រវត្តិសាស្ត្រពិភពលោកណាខ្លះ ដែលអ្នកចង់ធ្វើជាសាក្សីដោយខ្លួនអ្នកផ្ទាល់ ? តើមានព្រឹត្តិការណ៍ក្នុងប្រវត្តិសាស្ត្រសាសនាចក្រណាខ្លះ ដែលអ្នកចង់ឃើញ ហើយធ្វើជាសាក្សី ? ហេតុអ្វី ?

នៅក្នុងបុព្វកថានៃមេរៀននេះ អ្នកបានរៀនថា ម៉ាទិន ហារីស មានបំណងចង់ឃើញផ្ទាំងចំណារមាស ។ តើអ្នកធ្លាប់មានអារម្មណ៍ចង់ឃើញផ្ទាំងចំណារមាសដែរឬទេ ? ហេតុអ្វី ?

សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៥:១–៣ រួចស្វែងរកអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ដល់យ៉ូសែប ស្ម៊ីធ ដើម្បីឆ្លើយតបទៅនឹងសំណើរបស់ ម៉ាទិន ហារីស ។ យោងតាមខគម្ពីរទាំងនេះ ហេតុអ្វីបានជាយ៉ូសែប ស្ម៊ីធ ពុំអាចបង្ហាញផ្ទាំងចំណារដល់ ម៉ាទិន ហារីស បាន ?



តើអ្នកធ្លាប់ឆ្ងល់ដែរឬទេថា ហេតុអ្វីបានជាព្រះអម្ចាស់ពុំបានអនុញ្ញាតឲ្យផ្ទាំងចំណារមាសត្រូវបានបង្ហាញដល់មនុស្សទូទៅ ? ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានពន្យល់ថា យ៉ាងហោចណាស់មានហេតុផលមួយដែលមនុស្សមានបំណងចង់ឃើញផ្ទាំងចំណារ ៖ « ជាញឹកញាប់ នៅពេល [មនុស្ស]. . . ស្តាប់រឿងអំពីការចេញមកនៃព្រះគម្ពីរមរមន នោះពួកគេសួរបើផ្ទាំងចំណារមាននៅក្នុងសារមន្ទីរខ្លះ ដែលពួកគេអាចមើលឃើញដែរឬទេ។ មនុស្សដែលមានការបំពាក់បំប៉នខាងវិទ្យាសាស្ត្រមួយចំនួន [ស្មាន] ថា បើមានអ្នកប្រាជ្ញាអាចមើលឃើញ និងពិនិត្យមើលផ្ទាំងចំណារ ហើយរៀនពីវា នោះពួកគេនឹងថ្លែងទីបន្ទាល់ពីសេចក្តីពិត និងសច្ចៈសីលភាពរបស់យ៉ូសែប ស្ម៊ីធ ហើយពិភពលោកទាំងមូលនឹងបានផ្លាស់ប្រែចិត្តជឿ » (*Church History and Modern Revelation,* វ៉ុល ២ [ ឆ្នាំ ១៩៥៣ ] ១:៤០ ) ។

នៅពេលអ្នកអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៥:៥–១០ សូមស្វែងរកមូលហេតុដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់យ៉ូសែប ស្ម៊ីធ កុំឲ្យបង្ហាញផ្ទាំងចំណារដល់មនុស្សទូទៅ ។

យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:៧ អស់អ្នកដែលមិនបានជឿដល់ព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលបានបើកសម្ដែងតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ទេ នោះក៏នឹងមិនជឿដដែល ទោះបីជាពួកគេបានឃើញផ្ទាំងចំណារនោះក៏ដោយ ។

១. ដោយផ្អែកលើអ្វីដែលអ្នកបានរៀនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:៥–១០ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវប្រយោគពីរបីស្ដីពីមូលហេតុដែលព្រះអម្ចាស់ពុំមានព្រះទ័យឲ្យ យ៉ូសែប ស្ម៊ីធ បង្ហាញផ្ទាំងចំណារនោះដល់មនុស្សទូទៅ ។

ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:១០ យើងស្វែងយល់ថា **ព្រះអម្ចាស់បានហៅឲ្យយ៉ូសែប ស្ម៊ីធ នាំយកព្រះបន្ទូលរបស់ទ្រង់ទៅកាន់ពិភពលោក ។** នេះគឺជាការហៅដែលគ្មានអ្វីប្រៀបផ្ទឹមបានសម្រាប់ព្យាការី យ៉ូសែប ស្ម៊ីធ ។ អ្នកអាចនឹងចង់គូសចំណាំពាក្យនានា ដែលបង្រៀនពីសេចក្ដីពិតនេះដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:១០ ។

២. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ពីមូលហេតុដែលអ្នកគិតថាវាមានសារៈសំខាន់ដើម្បីមានទីបន្ទាល់ពីសេចក្ដីពិតនេះ ។

ពីមុនទទួលបានវិវរណៈនេះ ម៉ាទិន ហារីស ត្រូវបានកោះហៅឲ្យឈរថ្លែងទីបន្ទាល់នៅចំពោះចៅក្រមនៅរដ្ឋ នូវ យ៉ោក ស្ដីអំពីការចោទប្រកាន់អំពីការបោកបញ្ឆោត និងការបន្លំ ទាស់នឹង យ៉ូសែប ស្ម៊ីធ ។ ម៉ាទីន បានថ្លែងទីបន្ទាល់ដោយម៉ឺងម៉ាត់អំពី ភាពស្មោះត្រង់ និងចរិតលក្ខណៈរបស់ យ៉ូសែប ស្ម៊ីធ ហើយបានប្រាប់តុលាការថា « ទាក់ទងនឹងផ្ទាំងចំណារដែលលោកអះអាងថាលោកមាន សុភាពបុរសទាំងឡាយ បើអ្នកមិនជឿវាទេ ប៉ុន្តែបន្តទាស់នឹងសេចក្ដីពិត នោះនៅថ្ងៃមួយ វានឹងក្លាយជាមធ្យោបាយនៃការកាត់ទោសដល់ព្រលឹងរបស់អ្នកហើយ » ( នៅក្នុង លូស៊ី ម៉ាក ស្ម៊ីធ *History of Joseph Smith by His Mother,* បានបោះពុម្ពដោយ Preston Nibley [ ឆ្នាំ ១៩៥៨ ] ទំព័រ ១៤៦ ) ។ បន្ទាប់ពីបានឮទីបន្ទាល់របស់ម៉ាទិនហើយ ចៅក្រមក៏បានបញ្ចប់រឿងក្ដីដែលប្រឆាំងនឹងយ៉ូសែប ស្ម៊ីធ នោះទៅ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:១១ រួចស្វែងរកអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលថានឹងធ្វើ ដើម្បីគាំទ្រដល់ទីបន្ទាល់របស់ព្យាការី យ៉ូសែប ស្ម៊ីធ អំពីព្រះគម្ពីរមរមន ។ យើងស្វែងយល់ចេញពីខគម្ពីរនេះថាព្រះអម្ចាស់បានមានបន្ទូលដូច្នេះថា **ទីបន្ទាល់របស់សាក្សីបីរូបនឹងឈរជាភស្ដុតាងចំពោះសេចក្ដីពិតដ៏ពេញលេញនៃព្រះគម្ពីរមរមន ។** សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:១១–១៥ ដោយរកមើលអ្វីដែលសាក្សីបីនាក់បានឮ ឃើញ និងត្រូវបានចាត់ឲ្យធ្វើ ។ ពេលអ្នកអាន អ្នកអាចគូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

៣. សូមសរសេរគំនិតរបស់អ្នកចំពោះសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ៖

ក. តើទីបន្ទាល់បន្ថែមរបស់សាក្សីទាំងបីរូបអំពីផ្ទាំងចំណារព្រះគម្ពីរមរមន អាចមានសារៈប្រយោជន៍ចំពោះអ្នកដែលមិនមែនជាសមាជិកសាសនាចក្រយ៉ាងដូចម្ដេច ?

ខ. តើសេចក្ដីពិតនេះអាចមានសារៈប្រយោជន៍ចំពោះអ្នកដែល *ជា* សមាជិកសាសនាចក្រយ៉ាងដូចម្ដេច ?

បន្ថែមលើការណែនាំដល់ យ៉ូសែប ស្ម៊ីធ និង សាក្សីទាំងបីរូបឲ្យថ្លែងទីបន្ទាល់របស់ខ្លួន ព្រះអម្ចាស់បានប្រទាននូវមធ្យោបាយមួយផ្សេងទៀត ដែលយើងអាចស្គាល់សេចក្ដីពិតដ៏ពេញលេញនៃព្រះគម្ពីរមរមន ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:១៦ រួចស្វែងរកអ្វីដែលព្រះអម្ចាស់បានសន្យាដល់អស់អ្នកដែលជឿលើព្រះគម្ពីរមរមន ។

ដោយផ្អែកលើអ្វីដែលអ្នកបានអាន សូមបំពេញសេចក្ដីពិតតទៅនេះ ៖ **ប្រសិនបើយើងនឹងជឿលើព្រះបន្ទូលរបស់ព្រះអម្ចាស់ ។** ( អ្នកក៏អាចនឹងសរសេរគោលការណ៍ដែលបានបំពេញហើយនៅក្នុងព្រះគម្ពីររបស់អ្នកនៅក្បែរ ខទី ១៦ ដែរ ) ។



ប្រធាន អែសរ៉ា ថាហ្វ បែនសឹន បានមានប្រសាសន៍ពីការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់យើងក្នុងការបង្កើន ហើយចែកចាយសក្ខីភាពនៃព្រះគម្ពីរមរមនថា ៖ « យើងម្នាក់ៗត្រូវការមានទីបន្ទាល់ផ្ទាល់ខ្លួនយើង អំពីព្រះគម្ពីរមរមន តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ បន្ទាប់មកទីបន្ទាល់របស់យើង ផ្គួបជាមួយនឹងព្រះគម្ពីរមរមន គួរតែចែកចាយជាមួយនឹងអ្នកដទៃដើម្បីពួកគេអាចដឹងតាមរយៈព្រះវិញ្ញាណបរិសុទ្ធផងដែរអំពីសេចក្ដីពិតពេញលេញរបស់វា » (The Book of Mormon and the Doctrine and Covenants, » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៨៧, ទំព័រ ៨៤ ) ។

៤. សូមសរសេរចំណុចមួយ ឬ ទាំងពីរខាងក្រោមនេះក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ទីបន្ទាល់ផ្ទាល់ខ្លួនរបស់អ្នកអំពីព្រះគម្ពីរមរមន

ខ. អ្វីដែលអ្នកអាចធ្វើ ដើម្បីបង្កើន ឬ ពង្រឹងសក្ខីភាពរបស់អ្នកដែលថាព្រះគម្ពីរមរមនគឺជាព្រះគម្ពីរពិត

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:២១-២២ ដោយដាក់ឈ្មោះរបស់អ្នកជំនួសឲ្យ « យ៉ូសែប » វិញ ។ សូមពិចារណាអំពីរបៀបដែលអ្នកអាចចៀសឲ្យផុតពីការស្ដាប់តាម « ការបញ្ចុះបញ្ចូលនៃមនុស្សលោក » ។

តើព្រះអម្ចាស់បានសន្យាថា យ៉ូសែប ស៊្មីធ នឹងទទួលបានអ្វីខ្លះ ប្រសិនបើលោកស្មោះត្រង់ សូម្បីតែលោកត្រូវ « គេសម្លាប់ » ក៏ដោយនោះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:២៣-៣៥

*ម៉ាទិន ហារីស អាចត្រូវបានហៅឲ្យធ្វើជាសាក្សីមួយរូបក្នុងចំណោមបីរូបប្រសិនបើគាត់ប្រែចិត្ត*

តើអ្វីជារបស់ចាំបាច់ ដើម្បីឲ្យអំពូលភ្លើងមានពន្លឺ ?



បន្ថែមលើថាមពលអគ្គិសនី យើងត្រូវមួលបញ្ចូលអំពូលភ្លើងទៅក្នុងចង្កៀងអគ្គិសនី ដោតខ្សែភ្លើង រួចបើកកុងតាក់ភ្លើង ។ ដូចជាត្រូវមានជំហានមួយចំនួនដើម្បីធ្វើឲ្យអំពូលភ្លើងភ្លឺដែរនោះ ម៉ាទិន ហារីស បានស្វែងយល់ថា មានជំហានមួយចំនួនដើម្បីទទួលបានសក្ខីភាពអំពីផ្ទាំងចំណារដែលលោកមានបំណងចង់បានពីព្រះអម្ចាស់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:២៣-២៤ រួចស្វែងរកការសន្យាដែលមានលក្ខខណ្ឌដែលព្រះអម្ចាស់បានប្រទានដល់ ម៉ាទិន ហារីស ។ នៅពេលអ្នកអាន សូមស្វែងរកពាក្យ *បើ* រួចស្វែងរកជំហានមួយចំនួន ឬ លក្ខខណ្ឌដែលមានលើកឡើងបន្ទាប់ពីពាក្យនោះ ។ សូមបំពេញសេចក្ដីថ្លែងតទៅនេះដោយផ្អែកលើអ្វីដែលអ្នកអាន ៖ *បើ* ម៉ាទិន ហារីស នឹង *នោះ* ព្រះអម្ចាស់នឹងប្រទានការអនុញ្ញាតឲ្យគាត់បានឃើញផ្ទាំងចំណារសមបំណងប្រាថ្នារបស់គាត់ ។ តាមរយៈការសន្យានេះ ព្រះអម្ចាស់បានប្រទានឱកាសឲ្យ ម៉ាទិន ហារីស ធ្វើជាសាក្សីចំពោះព្រះគម្ពីរមរមន ។

ការសន្យាដែលព្រះអម្ចាស់បានប្រទានដល់ ម៉ាទិន ហារីស ដែលមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:២៤ ក៏អនុវត្តចំពោះយើងផងដែរ ៖ **បើយើងអធិស្ឋានដោយរាបសា និង ដោយសេចក្ដីជំនឿ នោះយើងអាចទទួលបានចម្លើយស្របតាមបំណងប្រាថ្នាដ៏សុចរិតរបស់យើង ។**

> ***ការស្គាល់ពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយ***
>
> ការស្គាល់ពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អដែលមាននៅក្នុងព្រះគម្ពីរ តម្រូវឲ្យមានកិច្ចខិតខំ និង ការអនុវត្ត ។ របៀបមួយ គឺត្រូវស្វែងរកការសន្យាដែលព្រះអម្ចាស់បានប្រទានដល់បុគ្គលម្នាក់ៗ ឬ ក្រុមមនុស្សនៅក្នុងព្រះគម្ពីរ ក៏ដូចជាលក្ខខណ្ឌដែលតម្រូវឲ្យមានប្រយោជន៍ឲ្យការសន្យាទាំងនោះត្រូវបានបំពេញ រួចសរសេរការសន្យា និង លក្ខខណ្ឌទាំងនោះឡើងវិញ ដើម្បីឲ្យវាអាចអនុវត្តចំពោះអ្នកផងដែរ ។ របៀបមួយទៀត គឺត្រូវស្វែងរកពាក្យ និង ឃ្លាដូចជា « យ៉ាងនោះ យើងឃើញ » « ហេតុដូច្នេះហើយ » « ហេតុដូច្នេះហើយ » « មើលចុះ » ឬ « បើ . . . នោះ . . . » ដែលជាញឹកញាប់ វាបង្ហាញពីគោលការណ៍ ឬ សេចក្ដីថ្លែងនៃគោលលទ្ធិ ។ នៅពេលអ្នកស្វែងយល់ពីរបៀបស្គាល់គោលលទ្ធិ និង គោលការណ៍ដែលមាននៅក្នុងព្រះគម្ពីរ អ្នកអាចសិក្សាព្រះគម្ពីរបានកាន់តែមានប្រសិទ្ធភាព ។

សូមពិចារណាពីអត្ថន័យនៃការអធិស្ឋានដោយរាបសា ដោយសេចក្ដីជំនឿ និង ដោយស្មោះអស់ពីចិត្ត ។ សូមគិតអំពីពេលដែលអ្នកបានឮ ឬ បានថ្លៃការអធិស្ឋានដែលអ្នកដឹងថាត្រូវបានថ្លែងដោយរបៀបនេះ ។ តើអ្វីដែលធ្វើឲ្យការអធិស្ឋាននេះមានសភាពខុសប្លែកពីការអធិស្ឋានដទៃទៀតដែលអ្នកបានឮ ឬ បានថ្លែង ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:២៥-២៦ រួចស្វែងរកអ្វីដែលព្រះអម្ចាស់បានមានព្រះទ័យរំពឹងឲ្យ ម៉ាទិន ហារីស ធ្វើ បន្ទាប់ពីក្លាយជាសាក្សីម្នាក់ចំពោះព្រះគម្ពីរមរមនហើយ ។ បន្ទាប់មក សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:២៧-២៨, ៣២ រួចស្វែងរកដំបូន្មាន និង ការព្រមានបន្ថែម ដែលព្រះអម្ចាស់បានប្រទានដល់ ម៉ាទិន ហារីស ។

៥. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើព្រះអម្ចាស់បានទូន្មាន ហើយព្រមានដល់ ម៉ាទិន ហារីស ឲ្យធ្វើដូចម្ដេចខ្លះ ?

ខ. តើព្រះអម្ចាស់បានមានព្រះបន្ទូលថានឹងមានអ្វីកើតឡើងចំពោះ ម៉ាទិន ហារីស ប្រសិនបើគាត់ពុំបន្ទាបខ្លួនហើយ « ទទួលសាក្សី » ( គ. និង ស. ៥:៣២ ) ពីព្រះអម្ចាស់ទេនោះ ?

គ. តើយើងអាចអនុវត្តដំបូន្មានដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥:៣២ ទៅនឹងខ្លួនយើងបានយ៉ាងដូចម្ដេច ?

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៥ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៣ ៖ ថ្ងៃទី ៤

# យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:៦៦–៦៧; គោលលទ្ធិ និង សេចក្ដីសញ្ញា ៦–៧

## សេចក្ដីផ្ដើម

នានិទាឃរដូវក្នុងឆ្នាំ ១៨២៩ ព្យាការី យ៉ូសែប ស៊្មីធ បានទទួលអារម្មណ៍ថា ការបកប្រែព្រះគម្ពីរមរមនត្រូវធ្វើជាបន្ទាន់ ។ លោកបានឃើញថា ពេលវេលារបស់លោកដើម្បីបកប្រែមានកំណត់ព្រោះលោកត្រូវធ្វើការដើម្បីផ្គត់ផ្គង់ក្រុមគ្រួសារ ។ អិមម៉ា និង ប្អូនប្រុសរបស់យ៉ូសែបគឺ សាំយូអែល បានជួយធ្វើជាស្មៀន ប៉ុន្តែពួកគេពុំអាចធ្វើការឲ្យបានពេញម៉ោងនោះទេ ។ ផ្ទាំងចំណារត្រូវបានប្រទានដល់យ៉ូសែបជាងមួយឆ្នាំកន្លះ ហើយជាមួយនឹងការបាត់ច្បាប់សរសេរដៃទាំង ១១៦ ទំព័រ នោះមានតែប៉ុន្មានទំព័រប៉ុណ្ណោះដែលត្រូវបង្ហាញ ។ យ៉ូសែប បានអធិស្ឋានសូមឲ្យព្រះអម្ចាស់បញ្ជូនមនុស្សម្នាក់ដែលអាចជួយដល់លោកក្នុងកិច្ចការបកប្រែ ។ ក្នុងការឆ្លើយតបទៅនឹងការអធិស្ឋានរបស់យ៉ូសែប ព្រះអម្ចាស់បានបញ្ជូន អូលីវើរ ខៅឌើរី ឲ្យទៅបម្រើជាស្មៀន ។

វិវរណៈដែលមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦–៧ ត្រូវបានប្រទានឲ្យនៅមិនយូរប៉ុន្មានបន្ទាប់ពី អូលីវើរ ខៅឌើរី បានមកដល់ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦ មាននូវដំបូន្មានដល់អូលីវើរចំពោះតួនាទីរបស់គាត់ក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧ មាននូវទម្រង់បកប្រែនៃការសរសេរមួយចំនួនដោយ យ៉ូហាន សិស្សជាទីស្រឡាញ់ ជាសេចក្ដីបង្រៀនដែលថា ព្រះអម្ចាស់បានសម្រេចបំណងប្រាថ្នារបស់យ៉ូហានដើម្បីរស់នៅ ហើយនាំព្រលឹងទាំងឡាយមកឯព្រះយេស៊ូវគ្រីស្ទដរាបដល់ការយាងមកជាលើកទីពីរ ។

### យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:៦៦–៦៧ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:១–៩

*អូលីវើរ ខៅឌើរី ក្លាយជាស្មៀនរបស់ យ៉ូសែប ស៊្មីធ*

ជួនកាល វិវរណៈមកពីព្រះត្រូវបានប្រៀបទៅនឹងពន្លឺ ។ ប្រសិនបើវិវរណៈមកពីព្រះ ឬ ចម្លើយចំពោះការអធិស្ឋានដូចជាពន្លឺ នោះសូមប្រៀបធៀបការបកស្រាយខាងក្រោម ហើយគិតអំពីអ្វីដែលជាតំណាងល្អបំផុត ថាវាមានអារម្មណ៍យ៉ាងណានៅពេលអ្នកទទួលបានវិវរណៈ ឬចម្លើយចំពោះការអធិស្ឋានអ្នក ៖

- ពន្លឺដែលភ្លឺឡើងភ្លាម ៗនៅពេលអ្នកបើកកុងតាក់អំពូលភ្លើង
- ពន្លឺដែលភ្លឺឡើងដោយសន្សឹម ៗមកពីព្រះអាទិត្យ

អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានប្រើរឿងប្រដូចនេះដើម្បីបង្រៀនអំពីវិវរណៈផ្ទាល់ខ្លួនថា ៖





« អំពូលភ្លើងបើកនៅក្នុងបន្ទប់ងងឹត
គឺដូចជាការទទួលសារលិខិតមកពីព្រះយ៉ាងឆាប់ ទាំងស្រុង ហើយកើតឡើងម្តងក្នុងពេលតែមួយ ។ យើងរាល់គ្នាភាគច្រើន មានបទពិសោធន៍តាមគំរូនៃវិវរណៈនេះ ពេលយើងត្រូវបានប្រទានចម្លើយចំពោះ ការអធិស្ឋានដោយស្មោះ ឬត្រូវបានផ្តល់នូវការដឹកនាំ ឬការការពារដែលចាំបាច់ ស្របតាមព្រះឆន្ទៈ និងពេលវេលារបស់ទ្រង់ ។ ការពិពណ៌នាអំពីការបើកបង្ហាញភ្លាមៗ និងដ៏ខ្លាំងក្លា ត្រូវបានរកឃើញនៅក្នុងបទគម្ពីរ បានរៀបរាប់ឡើងវិញនៅក្នុងប្រវត្តិសាស្ត្រសាសនាចក្រ និងមានភស្តុតាងនៅក្នុងជីវិតរបស់យើងផ្ទាល់ ។ ប្រាកដណាស់ ការអព្ភូតហេតុដ៏អស្ចារ្យទាំងនេះពិតជាកើតឡើងមែន ។ ទោះជាយ៉ាងណាក៏ដោយ គំរូនៃវិវរណៈនេះ មានភាពកម្រជាងធម្មតា ។

« ការបង្កើនពន្លឺបន្តិចម្តងៗ មកពីពន្លឺព្រះអាទិត្យរះ គឺដូចជាការទទួលសារលិខិតមួយមកពីព្រះ ‹ មួយបន្ទាត់ម្តងៗ មួយសិក្ខាបទម្តងៗ › (នីហ្វៃទី ២ ២៨:៣០)។ ជានិច្ចកាល វិវរណៈកើតឡើងនៅក្នុងចំនួនដ៏តូចបន្តិចម្តងៗ ហើយត្រូវបានផ្តល់ឲ្យស្របតាមបំណងប្រាថ្នា ភាពសក្តិសម និងការរៀបចំខ្លួនរបស់យើង ។ ការប្រាស្រ័យទាក់ទងបែបនោះ ដែលមកពីព្រះវរបិតាសួគ៌បន្តិចម្តងៗ ‹ ចុះមកលើ [ ព្រលឹងរបស់យើង ] ដូចជាទឹកសន្សើមចុះពីលើមេឃ › (គ. និង ស. ១២១:៤៥ ) ។ លំនាំវិវរណៈនេះកើតឡើងជាញឹកញាប់ជាង » ( « The Spirit of Revelation » *Ensign* ឬ *Liahona* ខែឧសភា ឆ្នាំ ២០១១ ទំព័រ ៨៨ ) ។

១. សូមពិចារណាពីគ្រាដែលព្រះអម្ចាស់បានឆ្លើយតបនឹងការអធិស្ឋានរបស់អ្នកភ្លាមៗ និង គ្រាដែលទ្រង់ឆ្លើយតបបន្តិចម្តងៗ ។ សូមសរសេរអំពីបទពិសោធន៍មួយរបស់អ្នកទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ។

នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្តីសញ្ញា ៦ សូមស្វែងរកសេចក្តីពិតដែលនឹងជួយអ្នកឲ្យស្គាល់វិវរណៈដែលព្រះកំពុងប្រទានដល់អ្នក ។

សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៦–៦៧ រួចស្វែងរករបៀបដែល អូលីវើរ ខៅឌើរី បានដឹងអំពីព្យាការី យ៉ូសែប ស្ម៊ីធ និងកិច្ចការដែលលោកកំពុងតែធ្វើ ។ អូលីវើរ បានធ្វើដំណើរពី ភូមិប៉ាលម៉ៃរ៉ា រដ្ឋ ញូវ យ៉ោក ទៅជួបនឹងយ៉ូសែប នៅភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា ដែលមានចម្ងាយជាង ២២៥ គីឡូម៉ែត ( សូមមើល ផែនទីប្រវត្តិសាសនាចក្រ ១ «សហរដ្ឋភាគឦសាន ») ។

មិនយូរប៉ុន្មានបន្ទាប់ពី អូលីវើរ បានចាប់ផ្តើមធ្វើជាស្មៀនសម្រាប់យ៉ូសែប ស្ម៊ីធ នោះយ៉ូសែប បានទទួលវិវរណៈមួយដែលព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់អូលីវើរ ។ វិវរណៈនេះបង្ហាញពីបំណងប្រាថ្នារបស់អូលីវើរ ហើយបានឆ្លើយយ៉ាងច្បាស់ចំពោះការអធិស្ឋានរបស់គាត់ ដែលគាត់ពុំដែលបានជម្រាបដល់យ៉ូសែបឲ្យបានដឹងនោះទេ ។ សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៦:៥–៦, ៨ រួចស្វែងរកការបង្ហាញដែលថា ព្រះអម្ចាស់បានជ្រាបពីបំណងប្រាថ្នារបស់អូលីវើរ ។

២. សូមឆ្លើយនឹងសំណួរតទៅនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរអ្នក ៖ តើ គោលលទ្ធិ និង សេចក្តីសញ្ញា ៦:៥–៦, ៨ និង ការខិតខំរបស់ អូលីវើរ ខៅឌើរី ក្នុងការធ្វើដំណើរចម្ងាយជាង ២២៥ គីឡូម៉ែត បង្ហាញយើងអំពីអ្វី ?

*សូមចំណាំថា ៖* ព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៦:១–៩ ត្រូវបានលើកឡើងម្តងទៀតនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១១ ជាវិវរណៈមួយដែលណែនាំដល់ ហៃរុម ស្ម៊ីធ ហើយនឹងត្រូវពិភាក្សាបន្ថែមនៅក្នុងមេរៀននោះ ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ៦:១០–២៤

*ព្រះអម្ចាស់បានអះអាងពីសេចក្តីពិតពេញលេញនៃកិច្ចការនោះទៅដល់ អូលីវើរ ខៅឌើរី*

សូមពិចារណាថាអ្នកធ្លាប់ទទួលបានចម្លើយពីព្រះ ហើយក្រោយមកមានកង្វល់ ឬ ភាពច្របូកច្របល់ចំពោះចម្លើយនោះដែរឬទេ ។

នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៦:១០–១៣ យើងឃើញថា ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ អូលីវើរ ខៅឌើរី ថា អូលីវើរមាននូវអំណោយទានខាងវិវរណៈ ។ សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៦:១៤–១៧, ២០ រួចគូសចំណាំអ្វីដែលព្រះអម្ចាស់បានបង្រៀនដល់ អូលីវើរ អំពីការទទួល និង ការស្គាល់វិវរណៈ ។

៣. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ពីសេចក្តីពិតចំនួនពីរ ឬ បី ដែលអ្នករកឃើញនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៦:១៤–១៧, ២០ ដែលអាចជួយអ្នកឲ្យយល់ពីរបៀបទទួល ឬ ស្គាល់វិវរណៈ ។

សូមប្រៀបធៀបអ្វីដែលអ្នកបានសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ទៅនឹងសេចក្ដីពិតខាងក្រោម ដែលមាននៅក្នុងខគម្ពីរទាំងនេះ ៖

**នៅពេលយើងស្វែងរកចម្លើយពីព្រះវរបិតាសួគ៌ ទ្រង់នឹងប្រទានការណែនាំដល់យើង** ( សូមមើល គ. និង ស. ៦:១៤ ) ។ « ការណែនាំ » អាចសំដៅទៅលើយោបល់ ឬ ការយល់ដឹងដែលមានដល់គំនិតយើង ក៏ដូចជាបទពិសោធន៍នានាដែលអាចដឹកនាំ រៀបចំ ឬ ជួយយើងឲ្យធ្វើការសម្រេចចិត្តត្រឹមត្រូវ ។

**ព្រះអម្ចាស់នឹងបំភ្លឺគំនិតយើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។** ឃ្លា « បំភ្លឺគំនិតរបស់អ្នក » ( គ. និង ស. ៦:១៥ ) មានន័យថា ព្រះអម្ចាស់នឹងប្រទានយោបល់ និង ការយល់ដឹងដល់យើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ អ្នកអាចនឹងចង់គូសចំណាំឃ្លានេះនៅក្នុងព្រះគម្ពីររបស់អ្នក ។

**ព្រះទ្រង់ជ្រាបពីគំនិត និង បំណងដែលនៅក្នុងចិត្តរបស់យើង** ( សូមមើល គ. និង ស. ៦:១៦ ) ។

**នៅពេលយើងទទួលបានវិវរណៈហើយ យើងគួរតែរក្សាវាទុកនៅក្នុងចិត្តយើង ។** « រក្សា » ព្រះបន្ទូលរបស់ព្រះអម្ចាស់ ( គ. និង ស. ៦:២០ ) មានន័យថា ឲ្យតម្លៃលើព្រះបន្ទូលរបស់ព្រះអម្ចាស់—សិក្សា ពិចារណា ហើយប្រព្រឹត្តតាមការណ៍ដែលព្រះអម្ចាស់បើកសម្ដែង ហើយទុកចិត្តលើវិវរណៈដែលយើងទទួលបាន ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:២១–២៤ រួចស្វែងរករបៀបមួយទៀតដែលព្រះអម្ចាស់ទាក់ទងជាមួយនឹងយើង ។

សូមបំពេញក្នុងចន្លោះនូវអ្វីដែលអ្នកបានរកឃើញ ៖ **ព្រះអម្ចាស់មានព្រះបន្ទូល ទៅដល់គំនិតរបស់យើងជាសាក្សីនៃសេចក្ដីពិត ។** អ្នកអាចចង់គូសចំណាំឃ្លា ដែលបង្រៀនពីសេចក្ដីពិតនេះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:២៣ ។

សូមពិចារណាពីសំណួរនេះ ៖ តើពេលខ្លះ យើងអាចនឹងមើលរំលង ឬ ព្រងើយកន្តើយនឹងចម្លើយរបស់ព្រះអម្ចាស់ចំពោះការអធិស្ឋានរបស់យើងយ៉ាងដូចម្ដេច ?

អែលឌើរ បេដណា បានបន្តការប្រៀបប្រដូចនៃព្រះអាទិត្យរះ ដើម្បីបញ្ជាក់ឲ្យច្បាស់ពីរបៀបដែលទំនាក់ទំនងពីព្រះអម្ចាស់កើតមានជាញឹកញាប់ ៖



« ពេលខ្លះ ព្រះអាទិត្យរះនៅពេលព្រឹកមួយ ដែលមានពពកច្រើន ឬចុះអ័ព្ទ ។ ដោយសារតែអាកាសធាតុមិនល្អ ការទទួលបានពន្លឺគឺមានភាពលំបាកជាង ហើយការប្រាប់ដោយត្រឹមត្រូវអំពីពេលដែលព្រះអាទិត្យរះលើមេឃ គឺពុំអាចធ្វើទៅបានទេ ។ . . .

« ស្រដៀងគ្នានឹងនេះដែរ ភាគច្រើនយើងទទួលបានវិវរណៈដោយពុំបានដឹងពីរបៀប ឬ ពេលវេលាដែលយើងទទួលបានវិវរណៈនោះទេ » (« The Spirit of Revelation, » ទំព័រ ៨៩ ) ។

រហូតដល់ក្រោយពីវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦ ត្រូវបានទទួល ទើប អូលីវើរ ខៅឌើរី បានជម្រាបដល់ព្យាការីអំពី « យប់ » ដែលព្រះអម្ចាស់សំដៅដល់ក្នុង ខទី ២២ ។ យ៉ូសែប ស្ម៊ីធ បានកត់ត្រាថា « បន្ទាប់ពីពួកយើងបានទទួលវិវរណៈនេះហើយ អូលីវើរ ខៅឌើរី បានថ្លែងប្រាប់ខ្ញុំថា ក្រោយពីគាត់បានទៅរស់នៅជាមួយឪពុកខ្ញុំ គ្រួសារខ្ញុំបានប្រាប់គាត់ពីការដែលខ្ញុំមានផ្ទាំងចំណារ នៅយប់នោះពេលគាត់ចូលសម្រាក គាត់បានអំពាវនាវដល់ព្រះអម្ចាស់ដើម្បីដឹងថាតើរឿងទាំងនេះពិតដែរឬទេ ហើយព្រះអម្ចាស់បានបង្ហាញដល់គាត់ថាវាសុទ្ធតែជារឿងពិត ប៉ុន្តែ គាត់បានរក្សាទុករឿងនេះជាសម្ងាត់ ហើយពុំបានប្រាប់នរណាម្នាក់ឲ្យបានដឹងឡើយ ដូច្នេះក្រោយពីវិវរណៈនេះត្រូវបានប្រទានឲ្យ គាត់បានដឹងថាកិច្ចការនេះជាកិច្ចការពិត ព្រោះគ្មានមនុស្សណាមួយដែលបានដឹងពីការណ៍ដែលមាននៅក្នុងវិវរណៈមួយនោះទេ មានតែព្រះ និង ខ្លួនគាត់ផ្ទាល់តែប៉ុណ្ណោះ ( នៅក្នុង *History of the Church,* ១:៣៥ ) ។

៤. សូមគិតអំពីគ្រាទាំងឡាយនៅក្នុងជីវិតរបស់អ្នក នៅពេលដែលអ្នកបានដឹងថាគំនិតរបស់អ្នកត្រូវបានបំភ្លឺ ឬ ពេញដោយភាពសុខសាន្តចំពោះអ្វីដែលអ្នកបានអធិស្ឋាន ។ សូមសរសេរបទពិសោធន៍មួយទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក រួចសូមពិចារណាក្នុងការសរសេរការចងចាំទាំងនេះទៅក្នុងសៀវភៅទិនានុប្បវត្តិផ្ទាល់ខ្លួនរបស់អ្នក ។

សូមពិចារណាពីរបៀបដែលការចងចាំពីបទពិសោធន៍ទាំងនេះ និង ការទុកចិត្តលើវិវរណៈផ្ទាល់ខ្លួនដែលអ្នកទទួលបានក្នុងពេលកន្លងមកនេះ អាចជួយអ្នកនៅក្នុងពេលខាងមុខនៅពេលអ្នកត្រូវការវិវរណៈ ឬ ការដឹកនាំ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:២៥–៣៧

*ព្រះអម្ចាស់ទូន្មានដល់ យ៉ូសែប និង អូលីវើរ ឲ្យបកប្រែ ហើយកុំឲ្យមានការសង្ស័យ ឬ ភ័យខ្លាចអ្វីឡើយ*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:២៥–៣១ យើងរៀនថា ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ អូលីវើរ ខៅឌើរី ថា ប្រសិនបើគាត់មានបំណង គាត់អាចមានអំណោយទានខាងការបកប្រែ ។ ព្រះអម្ចាស់ក៏បានត្រាស់ហៅឲ្យគាត់បម្រើជាមួយ ព្យាការី យ៉ូសែប ស៊្មីធ ហើយ « នាំការងារបម្រើនេះមកឯពន្លឺ » ក្នុងនាមជាសាក្សីទីពីរនៃការស្ដារឡើងវិញ ។ ប្រសិនបើអ្នកជា អូលីវើរ តើអ្នកនឹងមានអារម្មណ៍ដូចម្ដេច កាលបានឮពីទំនួលខុសត្រូវដែលព្រះអម្ចាស់បានប្រទានដល់អ្នក ?

សូមគិតអំពីស្ថានភាពដែលអ្នកមានអារម្មណ៍សង្ស័យ ឬ ភ័យខ្លាចអំពីការណ៍ដែលព្រះអម្ចាស់ចង់ឲ្យអ្នកធ្វើ ដូចជាពេលអ្នក អង្គុយលើវេទិកាក្នុងការប្រជុំសាសនាចក្រ ហើយរង់ចាំថ្លែងសុន្ទរកថា មានអារម្មណ៍បំផុសគំនិតឲ្យចែកចាយដំណឹងល្អជាមួយ មិត្តម្នាក់ ឬ ការដឹងថាអ្នកត្រូវសុំការអភ័យទោសពីសមាជិកគ្រួសារចំពោះអ្វីដែលអ្នកបានប្រព្រឹត្ត ឬ វាចា ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:៣២–៣៧ រួចស្វែងរកដំបូន្មានដែលព្រះអម្ចាស់បានប្រទានដល់ យ៉ូសែប ស៊្មីធ និង អូលីវើរ ខៅឌើរី ចំពោះការសង្ស័យ និង ការភ័យខ្លាចក្នុងការធ្វើកិច្ចការដែលពួកលោកត្រូវចាត់ឲ្យធ្វើ ។

គោលការណ៍មួយដែលយើងអាចរៀនចេញពីដំបូន្មាននេះគឺ **នៅពេលយើងមើលទៅព្រះយេស៊ូវគ្រីស្ទ យើងអាចយកឈ្នះលើ ការសង្ស័យ និង ការភ័យខ្លាចបាន ។** ( គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:៣៦ គឺជាចំណេះចំណានខគម្ពីរមួយ ) ។

### ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:៣៦

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវសុន្ទរកថាខ្លីមួយ ( មិនលើសពីមួយ ទំព័រ ) ដោយផ្អែកលើ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:៣៦ ។ អ្នកអាចពិពណ៌នាពីរបៀបសាមញ្ញៗក្នុង ការធ្វើតាមដំបូន្មានដែលមានក្នុងចំណេះចំណានខគម្ពីរនេះ ។ អ្នកអាចប្រើធនធាននានាដូចជា Topical Guide ឬ សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ *ពិតចំពោះសេចក្ដីជំនឿ* ឬសមាជិកគ្រួសារដើម្បីជួយអ្នកឲ្យសរសេរ សុន្ទរកថារបស់អ្នក ។ សូមបញ្ចូលគំរូផ្ទាល់របស់ព្រះអង្គសង្គ្រោះក្នុងការជួយអ្នកឲ្យយកឈ្នះលើការសង្ស័យ ឬ ការភ័យខ្លាច ។ សូមសួរឪពុកម្ដាយរបស់អ្នកថាបើអ្នកអាចចែកចាយសុន្ទរកថារបស់អ្នកដែលបានរៀបចំនៅក្នុង រាត្រីជួបជុំក្រុមគ្រួសារដែរឬទេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧

*យ៉ូហានសិស្សជាទីស្រឡាញ់ ត្រូវបានសន្យាថា លោកនឹងរស់នៅ ហើយនាំយកព្រលឹងទាំងឡាយមកកាន់ព្រះគ្រីស្ទ ដរាបដល់ការយាងមកជាលើកទីពីរ*

គ្រាមួយក្នុងខែ មេសា ឆ្នាំ ១៨២៩ ខណៈដែល អូលីវើរ ខៅឌើរី កំពុងតែជួយដល់ព្យាការី យ៉ូសែប ស៊្មីធ ក្នុងការបកប្រែព្រះគម្ពីរ មរមន គាត់ និង យ៉ូសែប បានមាន « ទស្សនៈខុសពីគ្នា. . .អំពីដំណើររឿងរបស់ យ៉ូហានជាសាវក ដែលមានលើកឡើងក្នុង ព្រះគម្ពីរសញ្ញាថ្មី [ សូមមើល យ៉ូហាន ២១:២០–២៣ ដែលព្រះអង្គសង្គ្រោះបានសំដៅទៅលើសំណើរបស់យ៉ូហានដើម្បីរស់នៅ លើផែនដីដរាបដល់ការយាងមកជាលើកទីពីរ ] ថាលោកបានទទួលមរណភាពហើយ ឬ រស់នៅដល់សព្វថ្ងៃ » ( យ៉ូសែប ស៊្មីធ នៅក្នុង *History of the Church,* ១:៣៥–៣៦ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧:១–៣ ដើម្បីស្វែងរកចម្លើយចំពោះសំណួររបស់ យ៉ូសែប និង អូលីវើរ ។ ប្រសិនបើ អ្នកមានកង្វល់ក្នុងការស្វែងរកចម្លើយ សូមអានសេចក្ដីសង្ខេបកណ្ដាលសម្រាប់ ខទី ១–៣ ។

លើសពីអ្វីដែលបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ គ្មានអ្វីដែលត្រូវបានបានបើកសម្ដែងឲ្យឃើញពីការបម្រើជាក់លាក់ ឬ ទីសំចត ឬ ស្នាដៃទាំងឡាយរបស់យ៉ូហាន ដែលលោកបានបំពេញក្នុងនាមជាតួអង្គដែលមិនស្លាប់នោះទេ ហេតុដូច្នេះហើយ វាពុំមែនជារឿងត្រឹមត្រូវឡើយដើម្បីប៉ាន់ស្មានពីការណ៍ទាំងនោះ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ អ្នក ៖

*ខ្ញុំបានសិក្សា យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:៦៦–៦៧ និង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦–៧ ហើយបានបញ្ចប់ មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៤ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨–៩

## បុព្វកថា

ក្នុងខែ មេសា ឆ្នាំ ១៨២៩ អូលីវើរ ខៅឌើរី បានចាប់ផ្ដើមជួយព្យាការី យ៉ូសែប ស្ម៊ីធ ក្នុងការបកប្រែផ្ទាំងចំណារមាសដោយធ្វើជាស្មៀន ។ ដោយសារព្រះអម្ចាស់ បានផ្ដល់ដល់ អូលីវើរ នូវអំណោយទាននៃការបកប្រែ បើគាត់មានបំណងដូច្នោះ ( សូមមើល គ. និង ស. ៦:២៥ ) នោះអូលីវើរ « មានចិត្តរំភើបជាខ្លាំងដើម្បីមានអំណាចនៃការបកប្រែប្រទានមកដល់គាត់ » ( យ៉ូសែប ស្ម៊ីធ នៅក្នុង *History of the Church,* ១:៣៦ ) ។ ក្នុងការឆ្លើយតប ព្រះអម្ចាស់ បានមានបន្ទូលថា ទ្រង់នឹងផ្ដល់ដល់អូលីវើរ នូវសមត្ថភាពដើម្បីបកប្រែ ស្របតាមសេចក្ដីជំនឿរបស់អូលីវើរ ។

នៅពេលអូលីវើរព្យាយាមបកប្រែ ទោះជាគាត់បានចាប់ផ្ដើមល្អក្ដី ក៏គាត់« ពុំបានធ្វើតទៅទៀតដូចជា [ គាត់បាន ] ចាប់ផ្ដើម » ( គ. និង ស. ៩:៥ ) ។ ព្យាការីបានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩ ដែលពន្យល់ពីមូលហេតុដែលការខិតខំរបស់អូលីវើរក្នុងការបកប្រែពុំបានទទួលជោគជ័យ ។ ព្រះអម្ចាស់បានណែនាំដល់អូលីវើរថា ពុំមានការចាំបាច់អ្វីនឹងឲ្យគាត់ធ្វើការបកប្រែបន្តទៀតនោះទេ ។ ផ្ទុយទៅវិញ អូលីវើរ គួរតែផ្ដោតអារម្មណ៍ទៅលើតួនាទីរបស់គាត់ជាស្មៀនរបស់យ៉ូសែបវិញ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា កណ្ឌទី ៨–៩ ជាមួយនឹង កណ្ឌទី ៦ សុទ្ធតែជាវិវរណៈសំខាន់ៗអំពីព្រះវិញ្ញាណបរិសុទ្ធ និង របៀបដែលយើងអាចស្វែងរក ហើយស្គាល់វិវរណៈដែលបានមកពីព្រះអម្ចាស់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨

*ព្រះអម្ចាស់បង្រៀន អូលីវើរ ខៅឌើរី អំពីអំណោយទានខាងវិវរណៈ*

តើអ្នកធ្លាប់មានចម្ងល់ពីរបៀបស្គាល់វិវរណៈ នៅពេលព្រះកំពុងមានព្រះបន្ទូលមកកាន់អ្នក ឬ ឆ្លើយតបការអធិស្ឋានរបស់អ្នកដែរឬទេ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:១ ដើម្បីឃើញពីរបៀបដែលព្រះអម្ចាស់បានណែនាំដល់ អូលីវើរ ខៅឌើរី ឲ្យអធិស្ឋាន ។ បន្ទាប់មកសូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:២–៣ រួចគូសចំណាំឃ្លាដែលពិពណ៌នាពីអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលថា ទ្រង់នឹងឆ្លើយតបការអធិស្ឋានរបស់អូលីវើរ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:២–៣ គឺជាចំណេះចំណានខគម្ពីរ ។ អ្នកអាចនឹងចង់គូសចំណាំវានៅក្នុងរបៀបមួយដែលងាយសម្គាល់ ដើម្បីអ្នកអាចងាយរកវាឃើញនៅពេលខាងមុខ ។

១. សូមគូសប្រអប់ពីរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមសរសេរនៅក្នុងប្រអប់ទីមួយថា *ការស្វែងរកវិវរណៈពីព្រះ* ។ សូមសរសេរនៅក្នុងប្រអប់ទីពីរថា *ការទទួលបានវិវរណៈពីព្រះ* ។ សូមសរសេរនៅក្នុងប្រអប់ទីមួយ យ៉ាងហោចណាស់គោលការណ៍មួយដែលអ្នករៀនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:១ អំពីរបៀបស្វែងរកវិវរណៈ ។ សូមសរសេរនៅក្នុងប្រអប់ទីពី អំពីសេចក្ដីពិតដែលព្រះអម្ចាស់បានបង្រៀននៅក្នុងខទី ២–៣ អំពីរបៀបដែលទ្រង់មានព្រះបន្ទូលមកកាន់យើង ។



តើអ្នកចងចាំពីរឿងម៉ូសេញែកទឹកសមុទ្រក្រហមដែរឬទេ ? ព្រះអម្ចាស់បានបញ្ជាឲ្យម៉ូសេរំដោះកូនចៅអ៊ីស្រាអែលដែលជាប់ជាទាសករ ។ ក្រោយមក ដោយមានពួកទាហានអេស៊ីព្ទតាមប្រញឹកពីក្រោយ ម៉ូសេ បានឃើញថាខ្លួនលោក និងរាស្ត្រលោកត្រូវជាប់នៅត្រង់ឆ្នេរសមុទ្រក្រហម ។ យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:២–៣ តើព្រះអម្ចាស់បានបំផុសគំនិតឲ្យម៉ូសេញែកទឹកសមុទ្រក្រហមតាមរបៀបណា ?

សេចក្ដីពិតមួយដែលយើងរៀនចេញពីខគម្ពីរទាំងនេះគឺ **ព្រះអម្ចាស់មានព្រះបន្ទូលដល់គំនិត និង ចិត្តរបស់យើងតាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ** ។ សូមគិតអំពីគ្រាដែលព្រះអម្ចាស់បានមានព្រះបន្ទូលមកកាន់អ្នកតាមរបៀបនេះ ។

នៅក្នុងសេចក្ដីថ្លែងការណ៍ខាងក្រោម ប្រធាន ប៊ិយដ៍ ឃេ ផាកកឺ ប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ និង អែលឌើរ រីឆាដ ជី ស្កត ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានរៀបរាប់ពីរបៀបដែលព្រះមានព្រះបន្ទូលទៅកាន់ពួកលោក ។

ប្រធាន ផាកកឺ បានថ្លែងថា ៖



អ្នកអាចរៀនឥឡូវនេះ នៅក្នុងយុវវ័យរបស់អ្នក ដើម្បីត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ។

« ក្នុងនាមជាសាវកម្នាក់ ខ្ញុំស្ដាប់ឥឡូវនេះ ចំពោះការបំផុសគំនិតដូចគ្នា ដែលចេញមកពីប្រភពដូចគ្នា តាមវិធីដូចគ្នា ដែលខ្ញុំបានស្ដាប់កាលពីនៅក្មេង ។ សញ្ញាគឺមានកាន់តែច្បាស់ក្នុងពេលឥឡូវនេះ » (Prayers and Answers, » *Ensign* ខែវិច្ឆិកា ឆ្នាំ ១៩៧៩, ទំព័រ ២១) ។

អែលឌើរ ស្កត បានបង្រៀនថា ៖



« ចំណាប់អារម្មណ៍ចំពោះ *គំនិត* គឺជាក់លាក់ណាស់ ។

« ពាក្យលម្អិតអាចនឹងត្រូវបានស្ដាប់ឮ ឬទទួលអារម្មណ៍ ហើយសរសេរទុក ដូចជាការណែនាំត្រូវបានសរសេរតាមដូច្នោះដែរ ។

« ទំនាក់ទំនងទៅកាន់*ចិត្ត*គឺកាន់តែទូទៅជាង ។ ជាញឹកញាប់ ព្រះអម្ចាស់ ចាប់ផ្ដើមដោយការផ្ដល់នូវចំណាប់អារម្មណ៍។ ពេលដែលមាននូវការទទួលស្គាល់ពីសារៈសំខាន់របស់វា ហើយពួកគេបានគោរពតាម នោះអ្នកទទួលបានសមត្ថភាពកាន់តែច្រើន ដើម្បីទទួលការណែនាំលម្អិតកាន់តែច្រើននៅក្នុង*គំនិត*។ ចំណាប់អារម្មណ៍ក្នុងចិត្ត បើធ្វើតាម គឺត្រូវបានបន្ថែមដោយការណែនាំកាន់តែជាក់លាក់ទៅដល់គំនិត » ( « Helping Others to Be Spiritually Led » [ address to Church Educational System religious educators ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ ] ទំព័រ ៣–៤ si.lds.org) ។

## ចំណេះចំណានខគម្ពីរ–គោលលទ្ធិ និងសេចក្ដីសញ្ញា ៨:២–៣

ដើម្បីជួយអ្នកឲ្យចងចាំពីរបៀបដែលព្រះអម្ចាស់នឹងមានព្រះបន្ទូលទៅកាន់គំនិត និង ចិត្តរបស់អ្នក សូមសរសេរវគ្គបទគម្ពីរនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:២–៣ នៅលើកាត ឬ ក្រដាសមួយ ។ សូមប្រឹងប្រែងទន្ទេញខគម្ពីរទាំងនេះដោយសូត្រវាជារៀងរាល់ព្រឹក និង យប់ពីមុនអ្នកអធិស្ឋានផ្ទាល់ខ្លួន ។ នៅពេលអ្នកទន្ទេញវាចាំហើយនោះ អ្នកអាចចែកចាយវាជាមួយមិត្តភក្តិ ឬ សមាជិកគ្រួសារ ហើយពន្យល់ថាវាមានអត្ថន័យយ៉ាងណាចំពោះអ្នក ។

២. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ពីគ្រាមួយដែលព្រះវរបិតាសួគ៌បានមានព្រះបន្ទូលមកកាន់គំនិត និង ចិត្តរបស់អ្នកតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩

*ព្រះអម្ចាស់ពន្យល់ពីមូលហេតុដែល អូលីវើរ ខៅឌើរី ពិបាកក្នុងការបកប្រែ*

តើការសម្រេចចិត្តចាំបាច់ណាខ្លះ ដែលអ្នកនឹងធ្វើនៅឆ្នាំក្រោយ ? នៅ ៥ ឬ ១០ ឆ្នាំទៀត ? សូមពិចារណាពីមូលហេតុដែលអ្នកចង់បានការដឹកនាំពីព្រះអម្ចាស់ក្នុងការសម្រេចចិត្តចាំបាច់ទាំងនេះ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩ ព្រះអម្ចាស់ពន្យល់ពីមូលហេតុដែល អូលីវើរ ខៅឌើរី មានការពិបាកក្នុងការបកប្រែផ្ទាំងចំណារ ។ ការបកស្រាយរបស់ព្រះអម្ចាស់អាចជួយអ្នកឲ្យយល់ពីរបៀបស្វែងរក ហើយទទួលបានការដឹកនាំសម្រាប់ការសម្រេចចិត្តដែលអ្នកនឹងធ្វើក្នុងជីវិត ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:១–៤ រួចស្វែងរកកិច្ចការដែលព្រះអម្ចាស់បានណែនាំឲ្យអូលីវើរផ្ដោតអារម្មណ៍លើជាជាងលើការបកប្រែ ។ ក្រោយមកសូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៥–៦, ១១ រួចគូសចំណាំមូលហេតុដែលអូលីវើរពុំមានជោគជ័យកាលគាត់បានព្យាយាមបកប្រែ ។



ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានមានប្រសាសន៍ថា ៖ « ការបរាជ័យរបស់អូលីវើរ កើតឡើងដោយសារតែគាត់ពុំបន្តធ្វើដូចដែលគាត់ចាប់ផ្ដើម ហើយដោយសារការងារវាលំបាក នោះគាត់បានបោះបង់សេចក្ដីជំនឿចោល » (*Church History and Modern Revelation,* វ៉ុល ២ [ ឆ្នាំ ១៩៥៣ ] ១:៥១ ) ។

តើអ្វីដែលយើងអាចរៀនពីបទពិសោធន៍របស់អូលីវើរ អំពីអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបានវិវរណៈពីព្រះអម្ចាស់ ? តើការភ័យខ្លាច ឬ ការបាត់បង់សេចក្ដីជំនឿ អាចទប់ស្កាត់យើងពីការទទួលបាន ឬ ការប្រព្រឹត្តតាមវិវរណៈពីព្រះអម្ចាស់តាមរបៀបណា ?

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ថា ៖



« នៅក្នុងដំណើរការនៃវិវរណៈ និង ការធ្វើការសម្រេចចិត្ត នោះភាពភ័យខ្លាចដើរតួនាទីជាការបំផ្លាញពេលខ្លះធ្វើឲ្យស្លន់ ។ ចំពោះអូលីវើរ ខៅឌើរី ដែលបាត់បង់ឱកាសមានតែម្ដងក្នុងមួយជីវិត ដោយសារលោកពុំចាប់យកឱកាសនោះ ព្រះអម្ចាស់បានមានបន្ទូលថា ‹ អ្នកពុំបានធ្វើតទៅទៀត ដូចជាអ្នកបានចាប់ផ្ដើមឡើយ › ។ តើនោះវាស្រដៀងគ្នាទៅនឹងអ្នកទាំងឡាយដែលបានទទួលការណែនាំហើយតែបែរជាបោះបង់ចោលដោយសារតែគំនិតទីពីរ និងការសង្ស័យកើតមាននោះយ៉ាងដូចម្ដេច ?. . .

« . . .បន្ទាប់ពីអ្នកបានទទួលសារលិខិត បន្ទាប់ពីអ្នកបានបង់ថ្លៃដើម្បីដឹងពីក្ដីស្រឡាញ់របស់ទ្រង់ ហើយស្ដាប់តាមព្រះបន្ទូលទ្រង់ហើយ ចូរបន្តឆ្ពោះទៅមុខ ។ ចូរកុំខ្លាច កុំស្ទាក់ស្ទើរ កុំគិតលើរឿងដែលពុំសំខាន់ កុំរអ៊ូរទាំ ។. . . ដោយនូវវិញ្ញាណនៃវិវរណៈនេះ ចូរលះចោលនូវភាពភ័យខ្លាចរបស់អ្នក ហើយដើរដោយក្លាហានដោយមានទំនុកចិត្ត » ( « Cast Not Away Therefore Your Confidence » *Ensign* ខែ មីនា ឆ្នាំ ២០០០ ទំព័រ ១០ ) ។

សូមគិតអំពីគ្រាមួយដែលអ្នកត្រូវអនុវត្តសេចក្ដីជំនឿដើម្បីស្វែងរក ឬ ប្រព្រឹត្តតាមចម្លើយមកពីព្រះអម្ចាស់ ។ តើអ្នកអាចធ្វើអ្វីខ្លះដើម្បីស្វែងរកចម្លើយ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៧–៨ ដោយស្វែងរកមូលហេតុមួយទៀតដែលអូលីវើរ មានការលំបាកក្នុងការទទួលជំនួយពីព្រះអម្ចាស់ក្នុងការខិតខំរបស់គាត់ដើម្បីបកប្រែ ។ តើអ្នកគិតថា « សិក្សាក្នុងគំនិតរបស់អ្នក » មានន័យដូចម្ដេច ?

មេរៀនមួយយើងអាចរៀនចេញពីខគម្ពីរទាំងនេះគឺ **ការទទួល និង ការស្គាល់វិវរណៈ តម្រូវឲ្យមានការខិតខំក្នុងចំណែករបស់យើង ។** អ្នកអាចនឹងចង់បញ្ចូលសេចក្ដីពិតនេះទៅក្នុងបញ្ជីនៃរបៀបស្វែងរកវិវរណៈពីព្រះអម្ចាស់ ដែលអ្នកបានបង្កើតនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកសម្រាប់កិច្ចការទី ១ ។ សូមចងចាំថា យើងគួរតែសូមដល់ព្រះអម្ចាស់ថាតើសេចក្ដីសន្និដ្ឋានរបស់យើងត្រឹមត្រូវដែរឬទេបន្ទាប់ពីដំណើរការការសិក្សាពីការសម្រេចចិត្តរបស់យើងហើយ ។

៣. សូមឆ្លើយនឹងសំណួរតទៅនេះក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថា ហេតុអ្វីបានជាព្រះអម្ចាស់តម្រូវឲ្យយើងពិចារណា ហើយសិក្សាពីបញ្ហាដោយខ្លួនយើងសិន ទើបនាំយកការសម្រេចចិត្តនោះមកឯទ្រង់ដើម្បីធ្វើការបញ្ជាក់ ជាជាងការសូមដល់ទ្រង់ឲ្យធ្វើការសម្រេចចិត្តឲ្យយើង ?

សូមពិចារណាពីរបៀបដែលបុគ្គលទាំងឡាយខាងក្រោមនេះអាចប្រើសេចក្ដីពិតនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៧–៨ ដើម្បីទទួលបានវិវរណៈចំពោះកាលៈទេសៈរបស់ខ្លួន ។

- យុវជនម្នាក់ពុំប្រាកដថាត្រូវចូលរៀនសាកលវិទ្យាល័យ ឬ ត្រូវស្វែងរកការងារ និង ការបំពាក់បំប៉នវិជ្ជាជីវៈណាមួយនោះទេ ។
- យុវនារីម្នាក់កំពុងព្យាយាមសម្រេចចិត្តពីរបៀបដកខ្លួនចេញពីមិត្តភក្ដិដែលដាក់ឥទ្ធិពលអាក្រក់មកលើនាង ។
- អ្នកត្រឡប់មកពីផ្សព្វផ្សាយសាសនាម្នាក់កំពុងគិតពីអាពាហ៍ពិពាហ៍ ហើយចង់ដឹងថាតើមនុស្សជាក់លាក់ម្នាក់ជាដៃគូអស់កល្បពិតប្រាកដ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៨–៩ ដោយស្វែងរករបៀបដែល អូលីវើរ ខៅឌើរី អាចដឹងថាការសម្រេចចិត្តរបស់គាត់ត្រូវ ឬ ខុស ។ តើយើងអាចរៀនអ្វីខ្លះចេញពី ខទី ៨ អំពីរបៀបដែលព្រះអម្ចាស់នឹងឆ្លើយតប នៅពេលយើងសួរថាតើការសម្រេចចិត្តរបស់យើងត្រឹមត្រូវដែរឬទេនោះ ?

សេចក្ដីខ្វល់ខ្វាយក្នុងទ្រូងដែលត្រូវបានសន្យាដល់ អូលីវើរ ខៅឌើរី គឺជារបៀបតែមួយគត់ដែល ព្រះវិញ្ញាណបរិសុទ្ធអាចនឹងបញ្ជាក់ពីជម្រើសដ៏ត្រឹមត្រូវមួយបាន ។ ការបញ្ជាក់ពីព្រះវិញ្ញាណបរិសុទ្ធ អាចកើតឡើងតាមរបៀបផ្សេង ៗគ្នាដែលផ្ទាល់ខ្លួន និងស៊ីជម្រៅ ។



អែលឌើរ រីឆាដ ជី ស្កត បានមានប្រសាសន៍ពីរបៀបដែលព្រះអម្ចាស់អាចបណ្ដាលឲ្យយើង « មានអារម្មណ៍ថា ការណ៍នោះត្រឹមត្រូវ » (គ. និង ស. ៩:៨) ដូច្នេះថា ៖ « អារម្មណ៍សុខសាន្ត គឺជាសាក្សីបញ្ជាក់ដ៏សាមញ្ញបំផុត ដែលខ្ញុំបានទទួលបទពិសោធន៍ផ្ទាល់ខ្លួន ។ ពេលខ្ញុំខ្វល់ខ្វាយខ្លាំងអំពីរឿងសំខាន់មួយ លំបាកក្នុងការដោះស្រាយវាដោយគ្មានជោគជ័យ ខ្ញុំបានបន្តកិច្ចខិតខំទាំងឡាយដោយសេចក្ដីជំនឿ ។ ក្រោយមកភាពសុខសាន្តប្រកបដោយអានុភាពបំផុតមួយបានកើតមាន រម្ងាប់កង្វល់របស់ខ្ញុំ ដូចដែលទ្រង់បានសន្យាដូច្នោះមែន » ( Using the Supernal Gift of Prayer » *Ensign* ឬ*លីអាហូណា*ខែ ឧសភា ឆ្នាំ ២០០៧, ទំព័រ ១០ ) ។

អែលឌើរ ស្កត ក៏បានពន្យល់ពីចម្លើយដែលប្រាប់លោកថាការសម្រេចចិត្តលោកពុំត្រឹមត្រូវទេដូច្នេះថា ៖ « [ការអាប់គំនិត] នោះ សម្រាប់ខ្ញុំគឺជាអារម្មណ៍ពុំសុខស្រួល ពុំរម្ងាប់ » ។ ( Using the Supernal Gift of Prayer ទំព័រ ១០ ) ។

អ្នកអាចនឹងចង់សរសេរសេចក្ដីថ្លែងទីពីររបស់អែលឌើរ ស្កត នៅគែមព្រះគម្ពីររបស់អ្នកនៅក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៩ ឬ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:១០–១៤ ព្រះអម្ចាស់បានអះអាងដល់អូលីវើរថា ទ្រង់ពុំកាត់ទោសលោក ដែលបរាជ័យក្នុងការបកប្រែនោះទេ ។ ព្រះអម្ចាស់បានណែនាំឲ្យអូលីវើរបន្តការសរសេរសម្រាប់ព្យាការីបន្តទៀត ហើយ « ឈរឲ្យមាំមួនក្នុងកិច្ចការ » ដែលព្រះអម្ចាស់បានហៅអូលីវើរឲ្យធ្វើ ( គ. និង ស. ៩:១៤ ) ។ ព្រះអម្ចាស់បានសន្យាដល់អូលីវើរថា ការបន្តដោយឧស្សាហ៍ព្យាយាម និង គោរពប្រតិបត្តិនឹងនាំមកនូវជីវិតដ៏នៅអស់កល្បជានិច្ច ។

៤. ដោយប្រើនូវអ្វីដែលអ្នកបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨–៩ សូមសរសេរសុន្ទរកថាសម្រាប់រយៈពេលពីរបីនាទីស្ដីពីការទទួលបានវិវរណៈពីព្រះអម្ចាស់ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមបញ្ចូលការប្រឹក្សាស្ដីពីអ្វីដែលយើងត្រូវតែធ្វើដើម្បីទទួលបានវិវរណៈពីព្រះអម្ចាស់ និង ការណែនាំពីរបៀបដែលទ្រង់មានបន្ទូលមកកាន់យើង ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨–៩ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៤ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១១–១២

## សេចក្ដីផ្ដើម

មិនយូរប៉ុន្មានក្រោយពីបព្វជិតភាពអើរ៉ុនបានស្ដារឡើងវិញក្នុងខែ ឧសភា ឆ្នាំ ១៨២៩ បងប្រុសរបស់ យ៉ូសែប ស្ម៊ីធ គឺ ហៃរុម និង យ៉ូសែប ណៃត សុីញ៉រ បានមកលេងព្យាការីនៅ ភូមិហារម៉ូនី រដ្ឋផែនសិលវេញ៉ា ។ បុរសទាំងពីរនាក់បានបង្ហាញពីបំណងប្រាថ្នាដើម្បីបម្រើព្រះ ហើយជួយក្នុងការស្ដារឡើងវិញ ។.គោលលទ្ធិ និង សេចក្ដីសញ្ញា ១១ និង ១២ មាននូវព្រះបន្ទូលរបស់ព្រះអម្ចាស់ទៅកាន់ ហៃរុម ស្ម៊ីធ និង ព្រះបន្ទូលរបស់ព្រះអម្ចាស់ទៅកាន់ យ៉ូសែប ណៃត សុីញ៉រ ស្ដីពីរបៀបដែលពួកគាត់អាចជួយនាំកិច្ចការរបស់ព្រះអម្ចាស់ចេញមក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:១–១៤

*ហៃរុម ស្ម៊ីធ ស្វែងយល់ពីរបៀបដែលគាត់អាចជួយនាំកិច្ចការរបស់ព្រះអម្ចាស់ចេញមក ។*

តើអ្នកធ្លាប់ចង់រួមចំណែកក្នុងបុព្វហេតុដ៏អស្ចារ្យមួយដែលអ្នកបានដឹងថានឹងក្លាយជាគុណប្រយោជន៍សម្រាប់ជីវិតមនុស្ស និង ពិភពលោកដែរឬទេ ? នោះគឺជាអ្វីដែលមនុស្សជាច្រើនបានគិតអំពីសាសនាចក្រនៅជំនាន់នៃការស្ដារឡើងវិញពីមុន ។ តាមពិតទៅ នោះគឺជាអ្វីដែលមនុស្សជាច្រើនគិតអំពីការបម្រើក្នុងសាសនាចក្រ—ដែលជានគរព្រះនៅលើផែនដី—សព្វថ្ងៃនេះ ។ នៅក្នុង កណ្ឌទី ១១ និង ១២ នៃគោលលទ្ធិ និង សេចក្ដីសញ្ញា ព្រះអម្ចាស់ប្រទានឱវាទដល់ ហៃរុម ស្ម៊ីធ និង យ៉ូសែប ណៃ សុីញ៉រ ទាក់ទងនឹងការរួមចំណែកពួកគាត់ក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:២៧ និង ១២:៧ ដើម្បីស្វែងរកថាមាននរណាទៀតដែលព្រះអម្ចាស់បានមានព្រះបន្ទូលដល់នៅក្នុងវិវរណៈទាំងនេះ ។



ហៃរុម ស្ម៊ីធ ដែលជាបងប្រុសរបស់ យ៉ូសែប ទំនងជាបានដឹងពីហេតុការណ៍ដែលបានកើតឡើងនាពេលថ្មីៗនេះមានដូចជា ដំណើរទៅមុខនៃការបកប្រែព្រះគម្ពីរមរមន និង ការស្ដារឡើងវិញនៃបព្វជិតភាពអើរ៉ុន ។ គាត់បានចង់ដឹងពីរបៀបដែលគាត់អាចជួយដល់យ៉ូសែបក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។ យ៉ូសែបបានទូលសូមដល់ព្រះអម្ចាស់ ហើយបានទទួលវិវរណៈដែលមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១ សម្រាប់ហៃរុម ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:៣, ៨, ១០, ១៤, ១៧, ២១, និង ២៧ រួចគូសចំណាំពាក្យ *បំណង មានបំណង* និង *មានសេចក្ដីប៉ងប្រាថ្នា* ។ សូមគិតអំពីអារម្មណ៍ដ៏ស្មោះស្ម័គ្រដែលមនុស្សម្នាក់គួរតែមាន ជាអ្នកដែលពិតជាចង់ជួយដល់កិច្ចការរបស់ព្រះអម្ចាស់ ។

១. សូមគូសប្រអប់ពីរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមសរសេរនៅក្នុងប្រអប់ទីមួយថា *ពរជ័យដែលបានសន្យាដោយសារតែសេចក្ដីសុចរិតដែលគាត់ប្រាថ្នាចង់បាន* ។ សូមសរសេរនៅក្នុងប្រអប់ទីពីរថា *ការណ៍ដែលគាត់ត្រូវធ្វើដើម្បីទទួលបានពរជ័យទាំងនោះ* ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:៥–៨ ។ នៅក្នុងប្រអប់ទីមួយ សូមធ្វើបញ្ជីនៃពរជ័យទាំងឡាយដែលព្រះអម្ចាស់បានសន្យាដល់ ហៃរុម ស្ម៊ីធ ចំពោះបំណងប្រាថ្នារបស់គាត់ក្នុងការជួយដល់កិច្ចការរបស់ព្រះអម្ចាស់ ។ នៅក្នុងប្រអប់ទីពីរ សូមធ្វើបញ្ជីនៃការណ៍ដែលហៃរុមត្រូវធ្វើដើម្បីទទួលបានពរជ័យដ៏ទេវភាពទាំងនោះ ។

នៅពេលអ្នកសិក្សាខគម្ពីរទាំងនេះ អ្នកអាចនឹងរកឃើញសេចក្ដីពិតទាំងនេះ ៖ **យើងអាចទទួលបានពរជ័យពីព្រះស្របតាមបំណងប្រាថ្នាដ៏សុចរិតរបស់យើង ។ ប្រសិនបើយើងមានបំណងធ្វើកិច្ចការរបស់ព្រះ នោះយើងនឹងបានទៅជាមធ្យោបាយនៃការធ្វើល្អដ៏ច្រើន ។**

២. សូមបំពេញកិច្ចការខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមសរសេរចម្លើយមួយចំនួនចំពោះសំណួរតទៅនេះ ៖ តើអ្នកអាចធ្វើដូចម្ដេចដើម្បី « បានទៅជាមធ្យោបាយនៃការធ្វើល្អដ៏ច្រើន » នៅក្នុងតំណនេះ ?

ខ. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:៩–១៤ ដោយស្វែងរកឱវាទដែលព្រះអម្ចាស់បានប្រទាន ដែលនឹងជួយ ហៃរុម ឲ្យសម្រេចបាននូវការណ៍ល្អដ៏ច្រើន ។ សូមសរសេរដំបូន្មានរបស់ព្រះអម្ចាស់ដល់ហៃរុម ទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ហើយរកមើលថាតើដំបូន្មានរបស់ទ្រង់ត្រូវគ្នានឹងយោបល់មួយចំនួនដែលអ្នកបានសរសេរដែរឬទេ ។

គ. យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:១២–១៣ តើអ្នកស្គាល់អានុភាពនៃព្រះវិញ្ញាណតាមរបៀបណា ?

យើងរៀនចេញពីដំបូន្មានដែលហៃរុមបានទទួលថា **ព្រះវិញ្ញាណនៃព្រះអម្ចាស់ដឹកនាំយើងឲ្យធ្វើល្អ រាបសា និងវិនិច្ឆ័យដោយសុចរិត ។ ព្រះវិញ្ញាណក៏បំភ្លឺគំនិតរបស់យើង ហើយក៏បំពេញព្រលឹងរបស់យើងដោយសេចក្ដីអំណរដែរ ។** វាអាចនឹងមានប្រយោជន៍ក្នុងការដាក់បទគម្ពីរយោងសេចក្ដីពិតទាំងនេះដែលមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:១២–១៣ ជាមួយនឹងចំណេះចំណានខគម្ពីរដែលមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨:២–៣ ។

៣. សូមយកពេលបន្ដិច ហើយពិចារណាពីស្ថានភាពដែលអ្នកបានទទួលអារម្មណ៍ពីព្រះវិញ្ញាណ ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ពីបទពិសោធន៍ខាងក្រោមចំនួនមួយ ឬ ច្រើនជាងនេះដែលអ្នកធ្លាប់បានជួបប្រទះ ៖

ក. បទពិសោធន៍មួយដែលព្រះវិញ្ញាណបានដឹកនាំអ្នកឲ្យធ្វើល្អ

ខ. បទពិសោធន៍មួយនៅពេលដែលព្រះវិញ្ញាណបានបណ្ដាលអ្នកឲ្យមានភាពរាបសា

គ. បទពិសោធន៍មួយនៅពេលដែលព្រះវិញ្ញាណបានជួយអ្នកឲ្យធ្វើការវិនិច្ឆ័យត្រឹមត្រូវ

ឃ. បទពិសោធន៍មួយនៅពេលដែលព្រះវិញ្ញាណបានបំភ្លឺអ្នកអំពីប្រធានបទមួយ ឬ បញ្ហាផ្ទាល់ខ្លួន

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:១៥–៣០

*ព្រះអម្ចាស់បានត្រាស់បញ្ជា ហៃរុម ស្ម៊ីធ ឲ្យត្រៀមខ្លួនទទួលយកការហៅឲ្យទៅផ្សាយ*

សូមស្រមៃពីការមើលទៅការចាប់ផ្ដើមនៃអ្វីដែលអ្នកមានអារម្មណ៍ថាជាបុព្វហេតុដ៏ធំនៅក្នុងពិភពលោក ដោយដឹងថាអ្នកអាចជាចំណែកមួយនៅក្នុងបុព្វហេតុនោះ ។ តើអ្នកនឹងចំណាយពេលប៉ុន្មាន ដើម្បីគិតពីបុព្វហេតុនោះ ថែមទាំងការដាក់ផែនការណ៍ និង ការត្រៀមខ្លួនដើម្បីរួមចំណែក ? សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:១៥–១៦ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់មានព្រះទ័យឲ្យ ហៃរុម ស្ម៊ីធ ធ្វើ ។

តើអ្នកគិតថាហេតុអ្វីបានជាព្រះអម្ចាស់ត្រាស់បញ្ជា ហៃរុម ឲ្យ « ចាំបន្ដិច » ? សូមពិចារណាពីស្ថានភាពដែលសាសនាចក្រពុំទាន់បានបង្កើតឡើងជាផ្លូវការទាល់តែដល់ប៉ុន្មានខែខាងមុខទៀត និង ពីព្រះគម្ពីរមរមនដែលពុំទាន់បានបោះពុម្ពនៅឡើយនោះ ។ តើអ្នកគិតថាព្រឹត្តិការណ៍នាពេលអនាគតទាំងនេះនឹងមានឥទ្ធិពលលើការត្រៀមខ្លួនរបស់ ហៃរុម ក្នុងការជួយដល់កិច្ចការរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:១៨–២០ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលថា ហៃរុម ត្រូវធ្វើ ដើម្បីក្លាយជាគ្រឿងឧបករណ៍ដ៏មានប្រសិទ្ធិភាពនៅក្នុងព្រះហស្ដរបស់ព្រះអម្ចាស់ ។

៤. សូមឆ្លើយនឹងសំណួរខាងក្រោមមួយ ឬ ច្រើនជាងនោះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើយុវវ័យម្នាក់ដែលកំពុងត្រៀមខ្លួនបម្រើបេសកកម្មអាច « អំពាវនាវដល់ព្រះវិញ្ញាណ » បានយ៉ាងដូចម្ដេច ?

ខ. តើអ្នកគិតថា ការ « នៅជាប់នឹង [ ព្រះអម្ចាស់ ] ឲ្យអស់ពីចិត្ត » មានន័យដូចម្ដេច ?

គ. តើអ្វីដែលព្រះអម្ចាស់ទ្រង់តម្រូវឲ្យអ្នក « ជួយនាំមករកពន្លឺ » ?

ដោយប្រើ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:១៨–២០ សូមសរសេរគោលការណ៍មួយដែលថ្លែងពីរបៀបចាំបាច់មួយចំនួន ដែលអ្នកអាចត្រៀមខ្លួនដើម្បីបម្រើក្នុងនគររបស់ព្រះអម្ចាស់ ៖

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:២១–២២ រួចស្វែងរកការណ៍ផ្សេងទៀតដែលព្រះអម្ចាស់បានមានព្រះបន្ទូល ថា ហៃរុម ស្ម៊ីធ ត្រូវធ្វើ ដើម្បីជួយគាត់ឲ្យក្លាយជាគ្រូបង្រៀនដំណឹងល្អដ៏មានប្រសិទ្ធិភាពមួយរូប ។ តើព្រះអម្ចាស់បានមាន ព្រះបន្ទូលប្រាប់ហៃរុមដូចម្ដេចខ្លះ អំពីអ្វីដែលគាត់ត្រូវធ្វើដើម្បីអាចប្រកាសព្រះបន្ទូលរបស់ទ្រង់បាន ?



តើអ្នកគិតថា ការសិក្សាព្រះគម្ពីរដើម្បី « ឲ្យបានព្រះបន្ទូល [ របស់ព្រះអម្ចាស់ ] » មានលក្ខណៈខុសគ្នាពីការគ្រាន់តែអាន ព្រះគម្ពីរយ៉ាងដូចម្ដេច ? **អស់អ្នកដែលសិក្សាព្រះបន្ទូលរបស់ ព្រះអម្ចាស់នឹងទទួលបានព្រះវិញ្ញាណទ្រង់ និង ព្រះចេស្ដា ដើម្បីបញ្ចុះបញ្ចូលមនុស្សដទៃអំពីសេចក្ដីពិតនៃដំណឹងល្អ ។**

ដើម្បីឃើញថា ហៃរុម បានរក្សាព្រះបញ្ញត្តិទាំងឡាយរបស់ ព្រះអម្ចាស់ ហើយបានធ្វើតាមឱវាទរបស់ទ្រង់ សូមមើល សេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១ រួចកត់ចំណាំកាលបរិច្ឆេទដែលបានទទួលវិវរណៈនោះ ។ បន្ទាប់មកបើកទៅសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣ រួចកត់ចំណាំពីកាលបរិច្ឆេទនៃ វិវរណៈនោះ ។ តើនៅប៉ុន្មានខែក្រោយមក ដែលព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:២១ រួចក្រោយ មកអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣:៣ ។ តើអ្នកបាន ស្វែងយល់ពីអ្វីខ្លះ ? តើការណ៍នេះអនុវត្តយ៉ាងដូចម្ដេចចំពោះ ការត្រៀមខ្លួនចេញបម្រើបេសកកម្ម ?



សូមពិចារណាពីដំបូន្មានដែល អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួក សាវកដប់ពីរនាក់ បានផ្ដល់ដល់ក្រុម យុវជនអំឡុងពេលសម័យប្រជុំបព្វជិតភាពនៃសន្និសីទទូទៅថា ៖ « សេចក្ដីសង្ឃឹមដ៏ស្មោះអស់ពីចិត្ត របស់ខ្ញុំចំពោះប្អូនយុវជនម្នាក់ៗគឺថា ប្អូននឹងមិនចេញបេសកកម្មដោយងាយៗនោះទេ ផ្ទុយទៅវិញគឺថា ប្អូននឹងក្លាយជាអ្នកផ្សព្វផ្សាយសាសនារយៈពេលយូរពីមុនប្អូនដាក់ពាក្យស្នើចេញបេសកកម្មរបស់ប្អូន យូរពីមុនប្អូនទទួលការហៅឲ្យបម្រើ ពីមុនត្រូវបានញែកចេញដោយប្រធានស្ដេករបស់ប្អូន និង ពីមុនប្អូនចូលទៅក្នុង អឹម. ធី.ស៊ី » (« Becoming a Missionary » *Ensign* ឬ *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ៤៥ ) ។



៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីការណ៍មួយចំនួនដែលអ្នកមានអារម្មណ៍ បំផុសគំនិតឲ្យធ្វើឲ្យបានសម្រេច ឬ កែប្រែនៅពេលប៉ុន្មានខែទៀតនេះ ដើម្បីជួយអ្នកឲ្យទទួលបានព្រះបន្ទូល របស់ព្រះកាន់តែច្រើន ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២

*ព្រះអម្ចាស់ប្រទានឱវាទដល់ យ៉ូសែប ណៃ ស៊ីញ៉ារ អំពីរបៀបដែលគាត់អាចជួយស្ថាបនាបុព្វហេតុនៃស៊ីយ៉ូនឡើង*

សូមគិតពីឈ្មោះរបស់មនុស្សមានកិត្តិនាមមួយចំនួននៅក្នុងប្រវត្តិសាស្ត្រ ។ តើពួកគេមានគុណសម្បត្តិអ្វីខ្លះ ?

តើអ្នកធ្លាប់ឮរឿងរបស់បុរសម្នាក់ឈ្មោះ យ៉ូសែប ណៃត ស៊ូញ៉ារ ដែរឬទេ ?សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២ ដើម្បីរៀនពី យ៉ូសែប ណៃត ស៊ីញ៉ារ និង ពីគំរូនៃការបរិច្ចាគរបស់គាត់ទៅដល់នគរព្រះ ។

អ្នកអាចនឹងកត់ចំណាំថា ព្រះបន្ទូលព្រះអម្ចាស់ដែលមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២:១–៦ គឺជាព្រះបន្ទូល ដូចគ្នាដែលមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:១–៦ ។ ជារឿយៗ ព្រះអម្ចាស់នឹងមានព្រះបន្ទូលណែនាំ ដដែលៗទៅកាន់បុគ្គលផ្សេងៗគ្នា—« អ្វីក៏ដោយដែលយើងមានព្រះបន្ទូលដល់មនុស្សម្នាក់ នោះយើងមានព្រះបន្ទូលដល់

មនុស្សទាំងអស់ » ( គ. និង ស. ៨២:៥ ) ។ ករណីបែបនេះកើតឡើងជាមួយ ហៃរុម ស្ម៊ីធ ( គ. និង ស. ១១ ) និង យ៉ូសែប ណែត ស៊ីញ៉ារ ( គ. និង ស. ១២ ) ដែលមានការណែនាំមួយចំនួនដូចគ្នា ។

ថ្វីបើ យ៉ូសែប ណែត ស៊ីញ៉ារ ពុំមែនជាសមាជិកដែលមានកិត្តិនាមក្នុងសាសនាចក្រកាលពីសម័យមុនយ៉ាងណាក្ដី ក៏គាត់បានធ្វើអំពើល្អជាច្រើនក្នុងការស្ថាបនានគរព្រះឡើងដែរ ។ គាត់បានផ្ដត់ផ្គង់ជាអាហារ និង សម្ភារដទៃទៀតដល់ព្យាការីអំឡុងពេលធ្វើកិច្ចការបកប្រែដ៏តឹងតែង ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២:៦–៨ រួចគូសចំណាំពីលក្ខណៈសម្បត្តិដ៏សុចរិតនានា ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថាចាំបាច់ត្រូវមានសម្រាប់អស់អ្នកដែលចង់ជួយដល់កិច្ចការរបស់ព្រះអម្ចាស់ ។ សូមពិចារណាពីរបៀបដែលអ្នកនឹងអភិវឌ្ឍលក្ខណៈសម្បត្តិទាំងនេះនៅក្នុងជីវិតរបស់អ្នក ។

យ៉ូសែប ណែត ស៊ីញ៉ារ បានព្យាយាមរស់នៅតាមលក្ខណៈសម្បត្តិដ៏សុចរិតទាំងនេះជានិច្ច ។ គាត់បានជួយដល់ព្យាការីពេញក្នុងការបម្រើរបស់លោកទាំងខាងសាច់ឈាម និង ខាងវិញ្ញាណ ។ អស់រយៈពេលជាច្រើនឆ្នាំបន្ទាប់ពីព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២ លោកបានកត់ត្រាដូចតទៅថា ៖ « យ៉ូសែប ណែត ស៊ីញ៉ារ. . . បានស្មោះ ហើយពិតត្រង់ ហើយជាគំរូល្អ និង[ល្អ]ចំពោះមនុស្សគ្រប់រូប ប្រកបដោយគុណធម៌ និងចិត្តល្អ ពុំដែលងាករេឡើយ ។. . . គាត់ជាមនុស្សសុចរិតម្នាក់ » ( នៅក្នុង *History of the Church* ៥:១២៤ ) ។

៦. ដើម្បីជួយអ្នកឲ្យពិចារណា ហើយអនុវត្តអ្វីដែលអ្នកបានសិក្សានៅថ្ងៃនេះ សូមបំពេញបញ្ចប់ឃ្លានេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ *ដើម្បីជួយដល់ព្រះអម្ចាស់ធ្វើកិច្ចការរបស់ទ្រង់ ខ្ញុំនឹង . . .*

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១–១២ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៤ ៖ ថ្ងៃទី ៣

# យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៨–៧៥ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣

## សេចក្ដីផ្ដើម

ខណៈកំពុងបកប្រែចំណែកនៃផ្ទាំងចំណារមរមនអំពីការបម្រើនៅក្នុងចំណោមពួកសាសន៍នីហ្វៃរបស់ព្រះយេស៊ូវគ្រីស្ទដែលមានព្រះជន្មរស់ឡើងវិញ ( នីហ្វៃទី៣ ១១–២៨ ) ព្យាការី យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី បានមានចម្ងល់អំពីពិធីបុណ្យជ្រមុជទឹក ។ ពួកលោកបានចូលទៅក្នុងព្រៃក្បែរកសិដ្ឋានរបស់យ៉ូសែប នៅ ភូមិហារម៉ូនី រដ្ឋផែនសិលវេញ៉ា ដើម្បីទូលសួរដល់ព្រះអម្ចាស់អំពីបញ្ហាដ៏សំខាន់នេះ ។ កាលកំពុងអធិស្ឋាននោះ ទេវតាមួយអង្គបានបង្ហាញព្រះកាយឲ្យពួកលោកឃើញ ។ ទ្រង់បានប្រទានបព្វជិតភាពអើរ៉ុនដល់ពួកលោក ហើយបានណែនាំឲ្យពួកលោកធ្វើបុណ្យជ្រមុជទឹកឲ្យគ្នាទៅវិញទៅមកនៅក្នុងទន្លេ សុសគ្វីហាណា ដែលនៅក្បែរនោះ ។ ក្រោយពី យ៉ូសែប និង អូលីវើរ បានធ្វើបុណ្យជ្រមុជទឹកហើយនោះ ទេវតាបានណែនាំដល់ពួកលោកឲ្យតែងតាំងបព្វជិតភាពអើរ៉ុនដល់គ្នាទៅវិញទៅមក ។ យ៉ូសែប បានដាក់ដៃលើអូលីវើរមុន ហើយបានតែងតាំងគាត់នូវបព្វជិតភាពអើរ៉ុន ហើយក្រោយមកអូលីវើរ បានធ្វើដូចគ្នានោះចំពោះយ៉ូសែបដែរ ។

### យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៨–៧២ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣

*យ៉ូហាន បាទីស្ទ ប្រទានបព្វជិតភាពអើរ៉ុនដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី*

១. ដោយមិនចាំបាច់មើលក្នុងព្រះគម្ពីររបស់អ្នក សូមឆ្លើយនឹងសំណួរខាងក្រោមនេះដាក់ទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកតាមដែលអ្នកអាចធ្វើទៅបាន ៖

ក. តើបព្វជិតភាពអើរ៉ុនត្រូវបានស្ដារឡើងវិញនៅថ្ងៃខែឆ្នាំណា ?

ខ. តើទេវតាដែលបានស្ដារបព្វជិតភាពអើរ៉ុនឡើងវិញដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី មានព្រះនាមអ្វី ?

គ. តើទេវតាបានធ្វើដូចម្ដេចដើម្បីប្រទានបព្វជិតភាពអើរ៉ុនដល់យ៉ូសែប និង អូលីវើរ ?

ឃ. តើទេវតាបានមានបន្ទូលប្រាប់ដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ថាពួកលោកនឹងទទួលបានអ្វីទៀតបន្ទាប់ពីបព្វជិតភាពអើរ៉ុន ?

សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៨–៧២ រួចត្រួតពិនិត្យចម្លើយរបស់អ្នក ។ អ្នកអាចនឹងសរសេរគោលលទ្ធិដូចតទៅនេះនៅក្បែរ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៨ ៖ **បព្វជិតភាពនេះត្រូវបានប្រទានដោយការដាក់ដៃលើក្បាល ។** តាមរបៀបនោះហើយដែល យ៉ូហាន បាទីស្ទ ដែលជាបុគ្គលដែលបានរស់ឡើងវិញនោះ បានប្រទានបព្វជិតភាពអើរ៉ុនដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ។

សូមត្រឡប់ទៅមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៨ ដោយស្វែងរកអ្វីដែលយ៉ូសែប និង អូលីវើរ បានធ្វើដែលនាំឲ្យពួកលោកសូមសួរដល់ព្រះអម្ចាស់អំពីពិធីបុណ្យជ្រមុជទឹក ហើយទទួលបានការផ្ដាច់បាបរបស់ខ្លួន ។ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៩ មាននូវបន្ទូលរបស់ យ៉ូហាន បាទីស្ទ ទៅកាន់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ។

ការស្ដារបព្វជិតភាពអើរ៉ុនឡើងវិញមានសារៈសំខាន់បំផុតដែលពាក្យសម្ដីទាំងនេះក៏មានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា កណ្ឌទី ១៣ ដែលជាវគ្គចំណេះចំណានខគម្ពីរ ។ អ្នកអាចនឹងចង់គូសចំណាំវានៅក្នុងរបៀបមួយដែលងាយសម្គាល់ ដើម្បីអ្នកអាចងាយរកវាឃើញនៅពេលខាងមុខ ។



តើអ្វីជាមុខងារ និង គោលបំណងរបស់ទ្វារ ?

តើកូនសោមានទំនាក់ទំនងអ្វីទៅនឹងមុខងាររបស់ទ្វារ ?

ព្រះអម្ចាស់ប្រើប្រាស់កូនសោជានិមិត្តរូបតំណាងឲ្យសិទ្ធិអំណាចបព្វជិតភាពដែលចាក់សោឱកាស និង ពរជ័យដ៏នៅអស់កល្បជានិច្ច ។ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣ ដោយស្វែងរកកូនសោទាំងឡាយដែលមានទំនាក់ទំនងជាមួយនឹងបព្វជិតភាពអើរ៉ុន ។ សូមពិចារណាអំពីការគូសចំណាំកូនសោទាំងនេះដែលមានចែងនៅក្នុងព្រះគម្ពីររបស់អ្នកនៅពេលអ្នកស្វែងរកពួកវា ។

២. ក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមបំពេញនៅក្នុងបញ្ជីខាងក្រោមដោយសរសេរអំពីកូនសោទាំងបីដែលបានលើកឡើងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣ ៖

*បព្វជិតភាពអើរ៉ុនកាន់កូនសោនៃ ៖*

*១)*

*២)*

*៣)*

អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ពីកូនសោទាំងឡាយនៃបព្វជិតភាពអើរ៉ុន និង ពរជ័យដែលកូនសោបព្វជិតភាពទាំងនោះនាំឲ្យមានចំពោះសមាជិកសាសនាចក្រថា ៖



« តើបព្វជិតភាពអើរ៉ុនកាន់ ‹ កូនសោការបម្រើនៃពួកទេវតា › និង នៃ ‹ ដំណឹងល្អនៃការប្រែចិត្ត និងពិធីបុណ្យជ្រមុជទឹក និងការផ្ដាច់បាប › មានន័យយ៉ាងណា ? អត្ថន័យ អាចត្រូវរកបាននៅក្នុងពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹក និងនៅក្នុងពិធីសាក្រាម៉ង់ ។ ពិធីបុណ្យជ្រមុជទឹក គឺសម្រាប់ការផ្ដាច់បាប ហើយពិធីសាក្រាម៉ង់ គឺរំឭកសេចក្ដីសញ្ញា និងពរជ័យទាំងឡាយនៃពិធីបុណ្យជ្រមុជទឹក ។ ទាំងពីរ គួរតែដើរឈានមុខដោយការប្រែចិត្ត ។. . .

« គ្មាន [យើង] ណាម្នាក់ បានរស់នៅដោយគ្មានអំពើបាបសោះ ចាប់តាំងពីពិធីបុណ្យជ្រមុជទឹក [ របស់យើង ] ទៅនោះទេ ។ បើគ្មានការផ្ដល់នូវការលាងសម្អាតបន្ថែមខ្លះៗ ក្រោយពីពិធីបុណ្យជ្រមុជទឹកយើងទេ នោះយើងម្នាក់ៗនឹងត្រូវវង្វេងនូវរឿងខាងវិញ្ញាណមិនខាន ។. . .

« យើងត្រូវបានបញ្ជាឲ្យប្រែចិត្តពីអំពើបាបរបស់យើង ហើយមករកព្រះអម្ចាស់ដោយដួងចិត្តសង្រេង និងវិញ្ញាណទន់ទាប ហើយទទួលទានសាក្រាម៉ង់ដោយការគោរពតាមសេចក្ដីសញ្ញានានានៃពិធីសាក្រាម៉ង់ ។ នៅពេលយើងរំឭកពីសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់យើងតាមវិធីនេះ នោះព្រះអម្ចាស់នឹងរំឭកឥទ្ធិពលនៃការលាងសម្អាតនៃពិធីបុណ្យជ្រមុជទឹករបស់យើង ។. . .

« យើងពុំអាចថ្លែងបំផ្លើសពីសារៈសំខាន់នៃបព្វជិតភាពអើរ៉ុនក្នុងនេះនោះទេ។ ជំហានសំខាន់ៗទាំងអស់នេះ មាននូវការផ្ដាច់បាប ដែលត្រូវធ្វើឡើងតាមរយៈពិធីបរិសុទ្ធនៃការសង្គ្រោះនៃពិធីបុណ្យជ្រមុជទឹក និងការរំឭកពិធីបរិសុទ្ធនៃពិធីសាក្រាម៉ង់។ ពិធីបរិសុទ្ធទាំងពីរនេះ គឺត្រូវបានធ្វើឡើងដោយអ្នកកាន់បព្វជិតភាពអើរ៉ុន ក្រោមការដឹកនាំរបស់គណៈប៊ីស្សព ដែលអនុវត្តកូនសោនៃដំណឹងល្អនៃការប្រែចិត្ត និងនៃពិធីបុណ្យជ្រមុជទឹក និងសម្រាប់ការផ្ដាច់បាប » (« The Aaronic Priesthood and the Sacrament, » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៨, ទំព័រ ៣៧–៣៨ ) ។

សូមពិចារណាអំពីរបៀប ដែលកូនសោទាំងឡាយនៃបព្វជិតភាពអើរ៉ុនអាចជួយយើងឲ្យទទួលបានពរជ័យនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ យោងតាមអែលឌើរ អូក តើនរណាដែលជាអ្នកត្រួតត្រាលើកូនសោអំពីដំណឹងល្អនៃការប្រែចិត្ត និង ពិធីបុណ្យជ្រមុជទឹកនៅក្នុងវួដនីមួយ ?

ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានពន្យល់ពីកូនសោអំពីការបម្រើនៃពួកទេវតាតាមរបៀបនេះថា ៖



« កាលដែល វិលហ្វូឌ វូឌរុជ្ជ ជាបុរសដែលបានរស់នៅជាច្រើនឆ្នាំ ហើយមានបទពិសោធន៍យ៉ាងច្រើន គឺជាប្រធាននៃសាសនាចក្រ នោះលោកបានមានប្រសាសន៍ទៅកាន់យុវជននៃបព្វជិតភាពអើរ៉ុនថា ៖ ‹ ខ្ញុំមានបំណងដើម្បីសម្ដែងប្រាប់អ្នករាល់គ្នាអំពីការពិតថាវាពុំបានធ្វើឲ្យមានភាពខុសប្លែកគ្នាទេ ទោះជាបុរសនោះជាសង្ឃ ឬជាសាវកក្ដី បើគាត់តម្កើងការហៅរបស់គាត់នោះ ។ ជាសង្ឃម្នាក់កាន់កូនសោនៃការបម្រើនៃពួកទេវតា ›។ ‹ ទោះជាសាវក ជាពួកចិតសិបនាក់ ឬជាអែលឌើរ នៅក្នុងជីវិតខ្ញុំគឺពុំដែលបានទទួលការពារមកពីព្រះអម្ចាស់ច្រើនជាងកាលដែលខ្ញុំកាន់តំណែងជាសង្ឃនោះឡើយ ›។ (*Millennial Star,* ៥៣:៦២៩)។

« ចូរគិតអំពីវា យុវជនជាទីស្រឡាញ់របស់ខ្ញុំអើយ។ បព្វជិតភាពដែលអ្នកកាន់នេះ មាននូវកូនសោនៃការបម្រើនៃពួកទេវតា។ តាមដែលខ្ញុំយល់ នោះវាមានន័យថា បើអ្នករស់នៅដោយសក្ដិសមនៃបព្វជិតភាព នោះអ្នកមានសិទ្ធិដើម្បីទទួល និងរីករាយជាមួយនឹងព្រះចេស្ដានៃតួអង្គស្ថានសួគ៌ ដើម្បីដឹកនាំអ្នក ការពារអ្នក និងប្រទានពរអ្នក។ មែនហើយ បើគាត់ចេះគិតច្រើន តើគាត់នឹងមិនស្វាគមន៍នូវពរជ័យអស្ចារ្យដូច្នេះទេឬអី? (« The Priesthood of Aaron, » *Ensign,* ខែវិច្ឆិកា ឆ្នាំ ១៩៨២, ៤៥ ) ។

អែលឌើរ អូក បានផ្ដល់ជាការយល់ដឹងជ្រៅជ្រះបន្ថែមលើកូនសោអំពីការបម្រើនៃពួកទេវតាថា ៖



« ក្នុងនាមជាអ្នកកាន់បព្វជិតភាពអើរ៉ុនវ័យក្មេង ខ្ញុំពុំដែលគិតថា ខ្ញុំនឹងឃើញទេវតាទេ ហើយខ្ញុំបានងឿងឆ្ងល់អំពីលក្ខណៈដូចនោះ មានទាក់ទងអ្វីនឹងបព្វជិតភាពអើរ៉ុន។

« ប៉ុន្តែការបម្រើនៃពួកទេវតា ក៏អាចជារឿងអាថ៌កំបាំង។ សារលិខិតរបស់ទេវតា អាចត្រូវបានផ្ដល់ឲ្យដោយសម្លេង ឬដោយគំនិត ឬអារម្មណ៍ទំនាក់ទំនងនៅក្នុងចិត្ត ។. . .

« ជាទូទៅ ពរជ័យនៃការមានភាពជាដៃគូ និងទំនាក់ទំនងខាងវិញ្ញាណ គឺមានតែចំពោះអ្នកទាំងឡាយណាដែលស្អាតស្អំប៉ុណ្ណោះ ។. . . ដូច្នេះអ្នកទាំងឡាយដែលកាន់បព្វជិតភាពអើរ៉ុន បើកទ្វារសម្រាប់សមាជិកសាសនាចក្រទាំងអស់ ដែលទទួលទានពិធីសាក្រាម៉ង់ដោយសក្ដិសម ដើម្បីរីករាយនឹងភាពជាដៃគូនៃព្រះវិញ្ញាណនៃព្រះអម្ចាស់ និងការបម្រើនៃពួកទេវតា។ » ( « The Aaronic Priesthood and the Sacrament, » ទំព័រ ៣៩ )។

៣. សូមឆ្លើយនឹងសំណួរដូចតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការយល់ដឹងពីអំណាចនៃបព្វជិតភាពអើរ៉ុន អាចមានអានុភាពលើគំនិត ឬ ទង្វើរបស់អ្នកនៅពេលអ្នកត្រៀមខ្លួន បម្រើ ឬ ទទួលទានសាក្រាម៉ង់នៅថ្ងៃអាទិត្យនេះយ៉ាងដូចម្ដេច ?



## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣:១

៤. សូមសរសេរ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣:១ ចូលទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមសូត្រវគ្គបទគម្ពីរនោះឲ្យឮៗ ។ បន្ទាប់មក បិទផ្នែកខ្លះនៃវគ្គបទគម្ពីរ ហើយសូត្រវាម្ដងទៀត ។ សូមបន្តបិទវគ្គបទគម្ពីរបន្ថែមហើយ បន្ថែមទៀត រួចសូត្រវាឲ្យឮៗម្ដងហើយម្ដងទៀតដរាបដល់អ្នកទន្ទេញវាចាំរត់មាត់ ។

## យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៧៣–៧៥

*យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ទទួលបានព្រះពរមហិមាបន្ទាប់ពីបានធ្វើបុណ្យជ្រមុជទឹក*

ព្រះអម្ចាស់បានស្រោចស្រពព្រះពរមហិមាមកលើ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី បន្ទាប់ពីពួកលោកបានទទួលពិធីបុណ្យជ្រមុជទឹក ។ សូមអាន យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៧៣–៧៤ ។ អ្នកនឹងចង់គូសចំណាំពាក្យ ឬ ឃ្លាណាដែលពិពណ៌នាពីបទពិសោធន៍ដែលយ៉ូសែប និង អូលីវើរ បានទទួល ។

វាជាការចាំបាច់ដើម្បីកត់ចំណាំថា យ៉ូសែប និង អូលីវើរ បានទទួល *ព្រះចេស្ដា* នៃព្រះវិញ្ញាណបរិសុទ្ធ តាំងពីពួកលោកពុំទាន់ត្រូវបានប្រទានឲ្យនូវបព្វជិតភាពមិលគីស្សាដែកដើម្បីប្រគល់ *អំណោយទាន* នៃព្រះវិញ្ញាណបរិសុទ្ធមកម្ល៉េះ ( សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៧០ សូមមើលផងដែរ Bible Dictionary ឬ សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « ព្រះវិញ្ញាណបរិសុទ្ធ » ) ។

ចេញពីអ្វីដែលយ៉ូសែប និង អូលីវើរ បានទទួលក្នុងឱកាសនេះដែលបានពិពណ៌នានៅក្នុង យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៧៤ សូមបំពេញគោលការណ៍ដូចតទៅនេះ ៖ **ព្រះវិញ្ញាណបរិសុទ្ធជួយយើងឲ្យយល់ពី និង បទគម្ពីរទាំងឡាយ ។**

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ហេតុអ្វីបានជាយើងត្រូវការព្រះវិញ្ញាណបរិសុទ្ធដើម្បីជួយយើងឲ្យយល់ពីបទគម្ពីរទាំងឡាយ ?

ខ. តើនៅពេលណាខ្លះដែលអ្នកទទួលបានអារម្មណ៍ថា ព្រះវិញ្ញាណបរិសុទ្ធជួយអ្នកឲ្យយល់ពី « អត្ថន័យ និង គោលបំណង » នៃបទគម្ពីរទាំងឡាយ ?

គ. តើអ្នកអាចធ្វើខ្លះដើម្បីអញ្ជើញឲ្យមានជំនួយពីព្រះវិញ្ញាណបរិសុទ្ធនៅពេលអ្នកសិក្សាព្រះគម្ពីរ ?

ឃ. តើការរំឭកពីសេចក្ដីសញ្ញាពិធីបុណ្យជ្រមុជទឹករបស់អ្នកដោយការទទួលទានសាក្រាម៉ង់ មានអានុភាពលើការយល់ដឹងរបស់អ្នកអំពីបទគម្ពីរយ៉ាងដូចម្ដេច ?

ដើម្បីបញ្ចប់មេរៀននេះ សូមអានការពិពណ៌នារបស់ អូលីវើរ ខៅឌើរី ស្ដីពីព្រឹត្តិការណ៍នានាជុំវិញការស្ដារឡើងវិញនៃបព្វជិតភាពអើរ៉ុន ដែលមានចែងនៅបន្ទាប់ពីសេចក្ដីបញ្ចប់នៃយ៉ូសែប ស្ម៊ីធ—ប្រវត្តិ ។ នៅពេលអ្នកអាន អ្នកអាចនឹងចង់គូសចំណាំពាក្យ ឬ ឃ្លាណាដែលលេចធ្លោចំពោះអ្នក ។ តើអ្នកអាចរៀនអ្វីខ្លះចេញពីការពិពណ៌នារបស់អូលីវើរ ?

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៨–៧៥ និង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៤ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤–១៦

## បុព្វកថា

នៅថ្ងៃក្រោយៗមកទៀតក្នុងខែ ឧសភា ឆ្នាំ ១៨២៩ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី បានជួបប្រទះនឹងការគំរាមគំហែងពីសំណាក់ពួកមនុស្សកំណាច កាលកំពុងបញ្ចប់ការបកប្រែព្រះគម្ពីរមរមន ។ ដើម្បីជួយពួកលោកឲ្យរួចផុតពីសេចក្ដីបៀតបៀននោះ ដាវីឌ វិតមើរ បានជួយពួកលោកឲ្យប្ដូរទីលំនៅពីភូមិហារម៉ូនី រដ្ឋផែនសិលវេញ៉ា ទៅផ្ទះរបស់គ្រួសារវិតមើរក្នុងភូមិហ្វាយែត រដ្ឋនូវយ៉ោក ។ គ្រួសារវិតមើរ បានចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើព្រឹត្តការណ៍ដែលបានបើកបង្ហាញអំពីការស្ដារឡើងវិញ។ យ៉ូសែប ស្ម៊ីធ បានពិពណ៌នាអំពី ដេវីឌ វីតមើរ ចន វីតមើរ និង ពេត្រុស វីតមើរ ជុញ្ញ័រ ថាជា « មិត្ត និងជំនួយការដ៏មោះមុតបំផុត នៅក្នុងកិច្ចការហើយ. . . រំភើបដើម្បីដឹងអំពីកាតព្វកិច្ចរបស់ពួកគេម្នាក់ៗ » ( នៅក្នុង *History of the Church* ១:៤៩ ) ។ ព្យាការីបានអធិស្ឋាន ហើយបានទទួលព្រះបន្ទូលនៃព្រះអម្ចាស់ដែលប្រទានដល់ពួកបងប្អូនប្រុសទាំងបីនាក់នេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤

*ព្រះអម្ចាស់ហៅ ដាវីឌ វិតមើរ ឲ្យជួយដល់កិច្ចការនៅថ្ងៃចុងក្រោយ*

ដំណើររឿងខាងក្រោមនេះ ពិពណ៌នាពីព្រឹត្តិការណ៍ដ៏អស្ចារ្យដែលអនុញ្ញាតឲ្យ ដាវីឌ វិតមើរ ជួយដល់ អូលីវើរ ខៅឌើរី និង យ៉ូសែប ស្ម៊ីធ រត់គេចពីសេចក្ដីបៀតបៀនរបស់ពួកលោក ៖

ដាវីឌ វិតមើរ កំពុងតែសាបព្រោះដាំស្រូវសាលីក្នុងកសិដ្ឋានគ្រួសារមួយក្នុងភូមិវ៉ែតធើរលូ រដ្ឋនូវយ៉ោក ក្បែរភូមិហ្វាយែត ដែលកាលនោះគាត់ត្រូវបានស្នើឲ្យធ្វើដំណើរទៅភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា ដើម្បីជួយ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ។ គាត់បានប្ដេជ្ញាចិត្តថានឹងធ្វើកិច្ចការនេះនៅបន្ទាប់ពីគាត់បង្ហើយការងារកសិដ្ឋានរបស់គាត់ ។ គាត់អាចភ្ជួររាស់ស្រែរបស់គាត់បានទាំងស្រុងក្នុងពេលមួយថ្ងៃ គឺពីព្រលឹមដល់ព្រលប់ ។ នៅថ្ងៃបន្ទាប់ គាត់បានហៀបនឹងចេញទៅដាក់ជីក្នុងស្រែ ហើយបងស្រីរបស់គាត់បានតំណាលប្រាប់អំពីមួយថ្ងៃមុនមានបុរសបីនាក់ដែលនាងបានឃើញកំពុងសាបព្រួសនៅវេលា « ហៀបនឹងថ្ងៃត្រង់ » ។ ខាងក្រោមនេះគឺជាដំណើររឿងរបស់ លូស៊ី ម៉ាក ស្ម៊ីធ អំពីព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ ៖



« ដេវីឌ បានទៅចម្ការ ហើយបានឃើញថា គាត់មានការងារយ៉ាងច្រើនដែលត្រូវធ្វើការសម្រាប់រយៈពេលពីរថ្ងៃឯណោះ ។. . . រួចហើយគាត់បានចងសេះភ្ជាប់រនាស់ ហើយជំនួសឲ្យការបែកចែងចម្ការជារងៗ តាមដែលកសិករធ្លាប់ធ្វើ នោះគាត់បានទៅរាស់ជុំវិញចម្ការទាំងមូល គាត់បានបន្តរហូសថ្ងៃត្រង់ គាត់បានសម្រាកសម្រាប់អាហារពេលល្ងាច គាត់បានមើលជុំវិញ ហើយបានមានការភ្ញាក់ផ្អើលថា គាត់បានរាស់បានពាក់កណ្ដាលស្រែរួចទៅហើយ ។ បន្ទាប់ពីអាហារពេលល្ងាច គាត់បានទៅធ្វើដូចពីមុន ហើយដល់ល្ងាចឡើង គាត់បានបង្ហើយអស់ការងារ ដែលត្រូវធ្វើសម្រាប់រយៈពេលពីរថ្ងៃនោះ។

« ឪពុកគាត់ ពេលបានទៅចម្ការនៅល្ងាចនោះដែរ បានឃើញនូវអ្វីដែលបានធ្វើរួច ហើយគាត់បានស្រែកឡើងថា ‹ ច្បាស់ជាមានអំណាចពីស្ថានខ្ពស់ ជួយនៅក្នុងកិច្ចការនេះហើយ ហើយឪពុកគិតថា កូនត្រូវទៅរដ្ឋផែនសិលវេញ៉ាភ្លាម ពេលកូនបានបាចជីរួចរាល់ហើយនោះ ›។

« នាព្រឹកឡើង ដេវីឌ បានយកម៉ែត្រឈើមួយកាន់នឹងដៃ ហើយបានចេញទៅបាចជី ដែលគាត់បានទុកចោល កាលពីពីរថ្ងៃមុន គរទុកនៅជិតផ្ទះរបស់បងស្រីគាត់ ប៉ុន្តែពេលគាត់ទៅដល់ទីនោះ គាត់បានឃើញថា វាបានបាត់អស់រលីង ! រួចគាត់បានរត់ទៅរកបងស្រីរបស់គាត់ ហើយសួរគាត់ថា តើគាត់មានដឹងថាវាទៅណាទេ។ គាត់បាននិយាយដោយភ្ញាក់ផ្អើលថា ‹ ហេតុអ្វីមកសួរបងអញ្ចឹង? តើវាពុំត្រូវបានបាចកាលពីម្សិលមិញទេឬអី ? ›

ដេវីឌ បានឆ្លើយថា « ‹ ទេ តាមដែលខ្ញុំដឹងនោះ › ។

បងស្រីគាត់បានឆ្លើយថា « ‹ បងភ្ញាក់ផ្អើលនឹងរឿងនោះណាស់ ព្រោះក្មេងៗមករកបងកាលព្រឹកមិញ ហើយបានសុំអង្វរឲ្យបងចេញទៅមើល បុរសៗដែលបានបាចជីនៅក្នុងស្រែ ដោយនិយាយថា ពួកគេពុំធ្លាប់ឃើញនណា បាចជីលឿនដូច្នេះក្នុងជីវិតពួកគេនោះទេ។ បងបានទៅមើល ហើយបានឃើញបុរសបីនាក់នៅធ្វើការក្នុងស្រែ ដូចជាក្មេងបាននិយាយមែន ប៉ុន្តែបងស្មានថា ប្អូនបានជួលមនុស្សឲ្យមកជួយ ព្រោះប្អូនព្យាយាមចង់ធ្វើការនោះឲ្យហើយឆាប់នោះអី ខ្ញុំក៏បានទៅចូលក្នុងផ្ទះភ្លាមដោយពុំនិយាយអ្វីទៀតពីរឿងនោះ › ។

« ដាវីឌបានសាកសួរជាច្រើនដើម្បីដឹងរឿងដែលបានកើតឡើងនោះ ទាំងនៅក្នុងចំណោមសាច់ញាតិ និងអ្នកជិតខាងរបស់គាត់ ប៉ុន្តែគ្មាននរណាដឹងថាអ្នកណាបានធ្វើនោះទេ » ( *History of Joseph Smith by His Mother,* ed. Preston Nibley [ ឆ្នាំ ១៩៥៨ ] ទំព័រ ១៤៨–៤៩ ) ។

សូមស្រមៃថាអ្នកបានស្ថិតនៅក្នុងស្ថានភាពរបស់ ដាវីឌ វិតមើរ ។ តើអព្ភូតហេតុទាំងនេះអាចនឹងមានអានុភាពលើរូបអ្នកយ៉ាងដូចម្ដេច ?

បន្ទាប់ពី ដាវីឌ វិតមើរ បាននាំព្យាការី និង អូលីវើរ ខៅឌើរី ទៅដល់ភូមិហ្វាយែត រដ្ឋនូវយ៉ោក ព្រះអម្ចាស់បានមានព្រះបន្ទូលពីការលេចចេញមកនៃកិច្ចការរបស់ទ្រង់នៅថ្ងៃចុងក្រោយ និងពរជ័យដែលបានសន្យាដល់អស់អ្នកណាដែលរួមចំណែកក្នុងកិច្ចការនោះ ( សូមមើល គ. និង ស. ១៤:១–៥ ) ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤:៦–៧ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បានណែនាំឲ្យដាវីឌធ្វើ និង អំណោយទានដែលគាត់នឹងទទួលបានមកវិញ ។ តើអំណោយទានអ្វីដែលព្រះអម្ចាស់បានសន្យាជាមួយគាត់ ? តើដេវីឌត្រូវធ្វើអ្វីដើម្បីទទួលបានពរជ័យនេះ ?

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ជីវិតដ៏នៅអស់កល្បជានិច្ចមានន័យថា ការរស់នៅជានិរន្តរ៍ជាមួយក្រុមគ្រួសារក្នុងវត្តមានរបស់ព្រះ និងការប្រែក្លាយដូចជាទ្រង់ ។ តើនិយមន័យនេះជួយអ្នកឲ្យយល់ពីមូលហេតុដែលជីវិតដ៏នៅអស់កល្បជានិច្ច « គឺជាអំណោយទានដ៏មហិមាបំផុតនូវគ្រប់អំណោយទានទាំងឡាយនៃព្រះ » យ៉ាងដូចម្ដេច ?

ខ. តើការសន្យាអំពីជីវិតដ៏នៅអស់កល្បជានិច្ច អាចបំផុសគំនិតឲ្យអ្នករក្សាព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុតយ៉ាងដូចម្ដេច ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤:៧ ព្រះអម្ចាស់បានបង្រៀនអំពីគោលការណ៍មួយដ៏មានសារៈសំខាន់ ដែលអនុវត្តចំពោះយើងម្នាក់ៗថា ៖ **ប្រសិនបើយើងរក្សាព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត លំដាប់នោះយើងនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច** ។ សូមគិតអំពីការសរសេរគោលការណ៍នេះនៅក្នុងព្រះគម្ពីររបស់អ្នក ឬ ក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

ដើម្បីយល់គោលការណ៍នេះឲ្យបានកាន់តែច្បាស់ សូមពិចារណាថាការកាន់ខ្ជាប់ដរាបដល់ចុងបំផុតនៅក្នុងស្ថានភាពដូចខាងក្រោម អាចនឹងមានន័យយ៉ាងណា ៖

- យុវជនម្នាក់ដែលទើបតែបានចូលសាសនាចក្រនាពេលថ្មីៗនេះ មានអារម្មណ៍ថាគាត់គ្មានមិត្តភក្ដិនៅក្នុងវួដរបស់គាត់ ។
- យុវនារីម្នាក់មានជំងឺ ដែលតម្រូវឲ្យបន្តទទួលទានថ្នាំ និង មានការថែទាំផ្ទាល់ខ្លួនពីសំណាក់មនុស្សដទៃ ។
- ឪពុកម្ដាយរបស់យុវជន ឬ យុវនារីម្នាក់ទើបតែលែងលះគ្នានាពេលថ្មីៗនេះ ហើយឪពុក ឬ ម្ដាយនោះមានម្នាក់ពុំសកម្មនៅក្នុងសាសនាចក្រ ។
- យុវជន ឬ យុវនារីម្នាក់កំពុងពុះពារយ៉ាងខ្លាំងជាមួយនឹងការល្បួងដែលនាំទៅរកភាពញៀន ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤:៨ ដើម្បីស្វែងយល់ពីពរជ័យមួយទៀតដែលព្រះអម្ចាស់បានមានព្រះបន្ទូលថា ដាវីឌ វិតមើរ នឹងទទួលបានផ្អែកទៅលើការគោរពប្រតិបត្តិរបស់គាត់ ។

មិនយូរប៉ុន្មានបន្ទាប់ពីបានទទួលវិវរណៈនេះ ដាវីឌ វិតមើរ បានក្លាយទៅជាសាក្សីមួយរូបក្នុងចំណោមសាក្សីទាំងបីរូបនៃព្រះគម្ពីរមរមន ។ គាត់បានឃើញទេវតាម៉ូរ៉ូណៃ និង ផ្ទាំងចំណារមាស ហើយគាត់បានឮព្រះសូរសៀងរបស់ព្រះ ថ្លែងទីបន្ទាល់អំពីភាពពេញលេញនៃបញ្ជីប្រវត្តិនោះ ។

២. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤:១១ ជាខគម្ពីរដែលព្រះអម្ចាស់បានប្រទានដល់ ដាវីឌ វិតមើរ នូវការសន្យាមួយទៀតដោយផ្អែកទៅលើភាពស្មោះត្រង់របស់គាត់ ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សារបស់អ្នកជាពាក្យរបស់អ្នកផ្ទាល់ សូមសរសេរគោលការណ៍ « បើសិនជា–នោះ » ដែលអ្នករកឃើញក្នុងខគម្ពីរនេះ ។ ( របៀបមួយដើម្បីសរសេរគោលការណ៍នេះ មាននៅចុងបញ្ចប់នៃមេរៀននេះ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៥–១៦

*ព្រះយេស៊ូវគ្រីស្ទបង្រៀន យ៉ូហាន និង ពេត្រុស វិតមើរ អំពីអ្វីដែលមានតម្លៃបំផុតចំពោះពួកគាត់*

ដើម្បីសិក្សាអំពីវិវរណៈទាំងឡាយដែលត្រូវបានប្រទានឲ្យដល់ យ៉ូហាន និង ពេត្រុស វិតមើរ សូមអញ្ជើញសមាជិកគ្រួសារ ឬ មិត្តភក្តិម្នាក់អានខគម្ពីរមួយចំនួនជាមួយអ្នកប្រសិនបើអាចធ្វើទៅបាន ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៥:១ ដោយខ្លួនអ្នកផ្ទាល់ បន្ទាប់មក សូមឲ្យសមាជិកគ្រួសារ ឬ មិត្តភក្តិរបស់អ្នកអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៦:១ ។ សូមអានផងដែរខទី ២–៦ នៃកណ្ឌទាំងពីរ ដោយឆ្លាស់គ្នាម្ដងម្នាក់រវាងខគម្ពីរទាំងនេះតាមរបៀបដូចគ្នានេះ ។ សូមកំណត់អំពីការណ៍ដែលខុសគ្នាអំពីវិវរណៈទាំងពីរនេះ ។

តើភាពខុសគ្នាតែមួយគត់ក្នុងការប្រើពាក្យនៃវិវរណៈទាំងពីរនេះគឺជាអ្វី ?

ដោយសារតែខទី ២–៦ ក្នុងវិវរណៈនេះមានលក្ខណៈដូចគ្នាសុទ្ធសាធ នោះវាហាក់ដូចជាព្រះអម្ចាស់អាចប្រទានវិវរណៈមួយ ហើយបានមានព្រះបន្ទូលទៅកាន់បុរសទាំងពីរនាក់ ។ តើយើងអាចរៀនអ្វីខ្លះចេញពីការពិតដែលថា ទ្រង់បានយកពេលមានព្រះបន្ទូលទៅកាន់ យ៉ូហាន និង ពេត្រុស ទាំងពីរនាក់ដោយផ្ទាល់រៀងៗខ្លួន ?

ពេលខ្លះ ព្រះអម្ចាស់អាចនឹងបើកសម្ដែងសារលិខិតតែមួយទៅកាន់បុគ្គលជាច្រើន គឺដោយសារតែពួកគេមានតម្រូវការ កាលៈទេសៈ ឬ បំណងប្រាថ្នាស្រដៀងគ្នា ។ ដើម្បីស្គាល់បំណងប្រាថ្នាដែលយ៉ូហាន និង ពេត្រុស វិតមើរ បានមានដូចគ្នានោះ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៥:៣–៤ និង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៦:៣–៤ ម្ដងទៀត ។ តើ យ៉ូហាន និង ពេត្រុស វិតមើរ ទាំងពីរនាក់មានបំណងប្រាថ្នាដូចម្ដេច ?

ព្រះអម្ចាស់បានបង្រៀននៅក្នុងវិវរណៈទាំងនេះថា **កិច្ចខិតខំរបស់យើងដើម្បីនាំមនុស្សដទៃឲ្យមករកព្រះយេស៊ូវគ្រីស្ទ គឺមានតម្លៃបំផុតចំពោះយើង ។** នៅពេលអ្នកជួយនាំមនុស្សមកកាន់ព្រះយេស៊ូវគ្រីស្ទ ពួកគេក៏នឹងយល់ផងដែរថា ព្រះទ្រង់ជ្រាប ហើយមានព្រះទ័យស្រឡាញ់ពួកគេ ។

វិវរណៈទាំងនេះក៏បង្រៀនដូច្នេះដែរថា **ព្រះទ្រង់ជ្រាបពីយើងម្នាក់ៗ ។** ទ្រង់ជ្រាបនូវអ្វីដែលល្អបំផុតសម្រាប់យើង ។

៣. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកនូវគំនិតរបស់អ្នកអំពីរបៀបដែលពរជ័យបព្វជិតភាព ឬ ការហៅបេសកកម្ម អាចបង្ហាញថា ព្រះទ្រង់ជ្រាបពីយើងម្នាក់ៗ ។



អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានផ្ដល់ជាគំរូនៃសេចក្ដីពិតដែលថា ព្រះទ្រង់ជ្រាបពីយើងម្នាក់ៗ ៖

### ការប្រើពាក្យរបស់អ្នកផ្ទាល់

នៅពេលអ្នកបង្ហាញគោលលទ្ធិ និង គោលការណ៍ជាពាក្យរបស់អ្នកផ្ទាល់ នោះអ្នកបង្កើនសមត្ថភាព និង ទំនុកចិត្តដើម្បីពន្យល់ដំណឹងល្អទៅដល់មនុស្សដទៃ ។



« កាលលើកមុន ខ្ញុំបាននិយាយទៅកាន់អ្នកដឹកនាំបព្វជិតភាពម្នាក់ ដែលបានលើកទឹកចិត្តឲ្យទន្ទេញចាំឈ្មោះរបស់យុវវ័យទាំងអស់ដែលមានអាយុ ១៣ ទៅ ២១ ឆ្នាំ នៅក្នុងស្តេករបស់គាត់។ ការប្រើរូបថតដែលមិនដឹងខ្លួនរបស់យុវជន និងយុវនារី គាត់បានបង្កើតជាកាតបញ្ជាំង ដើម្បីគាត់អាចមើលពេលធ្វើដំណើរទៅធ្វើការ និងនៅពេលផ្សេងៗទៀត។ អ្នកដឹកនាំបព្វជិតភាពនេះ បានរៀនយ៉ាងឆាប់អំពីឈ្មោះរបស់យុវវ័យទាំងអស់។

« នៅយប់មួយ អ្នកដឹកនាំបព្វជិតភាពនោះ បានសុបិនអំពីយុវជនម្នាក់ដែលគាត់បានស្គាល់តែក្នុងរូបថត។ នៅក្នុងការសុបិននោះ គាត់បានឃើញយុវជននោះ ស្លៀកពាក់អាវពណ៌ស ហើយពាក់ស្លាកឈ្មោះអ្នកផ្សព្វផ្សាយសាសនា។ យុវជននោះ កំពុងបង្រៀនដល់គ្រួសារមួយ ដោយមានដៃគូអង្គុយជិតគាត់។ យុវជននោះ កាន់ព្រះគម្ពីរមរមននៅក្នុងដៃគាត់ ហើយគាត់បានមើលទៅដូចជា គាត់កំពុងថ្លែងទីបន្ទាល់អំពីភាពពេញលេញនៃព្រះគម្ពីរ។ រួចហើយអ្នកដឹកនាំបព្វជិតភាពនោះបានភ្ញាក់ដឹងខ្លួនពីសុបិន។

« នៅក្នុងការជួបជុំបព្វជិតភាពមួយ អ្នកដឹកនាំរូបនោះបានទៅជួបនឹងយុវជន ដែលគាត់បានឃើញក្នុងសុបិន ហើយបានសុំនិយាយនឹងយុវជននោះរយៈពេលពីរបីនាទី ។ បន្ទាប់ពីការណែនាំសង្ខេបៗមក អ្នកដឹកនាំបានហៅយុវជននោះដោយឈ្មោះ ហើយបាននិយាយថា ៖ ‹ ខ្ញុំពុំមែនជាមនុស្សរើសវាយទេ។ ខ្ញុំពុំដែលសុបិនឃើញសមាជិកនៅលើវណាម្នាក់ក្នុងស្តេកនេះទេ ក្រៅពីអ្នក។ ខ្ញុំចង់ប្រាប់អ្នកអំពីសុបិនរបស់ខ្ញុំ រួចហើយខ្ញុំចង់ឲ្យអ្នកជួយខ្ញុំយល់អំពីអត្ថន័យរបស់វា ›។

« អ្នកដឹកនាំបព្វជិតភាពបានរៀបរាប់ប្រាប់ពីសុបិននោះ ហើយបានសួរដល់យុវជននោះ អំពីអត្ថន័យនៃសុបិន ។ យុវជនម្នាក់បានឆ្លើយតបទាំងអួលដើមកថា ‹ វាមានន័យថា ព្រះជ្រាបដឹងថាខ្ញុំជានរណា › ។ ការសន្ទនាបន្ទាប់ទៀត រវាងយុវជននេះ និងអ្នកដឹកនាំបព្វជិតភាព គឺមានអត្ថន័យបំផុត ហើយពួកគាត់បានយល់ព្រមដើម្បីជួប ហើយប្រឹក្សាជាមួយគ្នាពីមួយគ្រាទៅមួយគ្រា អំឡុងពេលជាច្រើនខែបន្តបន្ទាប់មក » (The Tender Mercies of the Lord » *Ensign* ឬ *លីអាហូណា* ខែឧសភា ឆ្នាំ ២០០៥, ទំព័រ១០០)។

សូមពិចារណា ( ឬ ពិភាក្សាជាមួយមនុស្សដែលអ្នកបានអានជាមួយ ) អំពីមូលហេតុដែលវាអាចជាអត្ថប្រយោជន៍សម្រាប់យើងក្នុងការដឹងថា ព្រះទ្រង់ជ្រាបពីយើងម្នាក់ៗ ។

៤. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីស្ថានភាពនៃការយល់ដឹងថា ព្រះទ្រង់ជ្រាបពីអ្នកម្នាក់ៗដោយផ្ទាល់ បានជួយអ្នកតាមរបៀបមួយចំនួន ឬ សរសេរអំពីរបៀបដែលការយល់ដឹងថា ព្រះទ្រង់ជ្រាបពីអ្នកម្នាក់ៗដោយផ្ទាល់ អាចមានអានុភាពលើការសម្រេចចិត្តដែលអ្នកធ្វើជារៀងរាល់ថ្ងៃ ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤–១៦ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

*កំណត់ចំណាំសម្រាប់កិច្ចការទី ២ ៖* របៀបមួយដែលអ្នកអាចថ្លែងពីគោលការណ៍ដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៤:១១ គឺ ៖ **បើយើងជួយដល់កិច្ចការរបស់ព្រះអម្ចាស់ដោយមានចិត្តស្មោះត្រង់ ខណៈនោះ ទ្រង់នឹងប្រទានពរដល់យើងខាងវិញ្ញាណ និង ខាងសាច់ឈាម ។**

មេរៀនទី ៥ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧

## បុព្វកថា

កាលកំពុងបកប្រែព្រះគម្ពីរមរមន ព្យាការី យ៉ូសែប ស្ម៊ីធ បានស្វែងយល់ថា ពួកសាក្សីបីនាក់នឹងត្រូវបានអនុញ្ញាតឲ្យឃើញផ្ទាំងចំណារ « ដោយព្រះចេស្ដានៃព្រះ » ( សូមមើល នីហ្វៃទី២ ២៧:១២–១៤ អេធើរ ៥:២–៤ ) ។ នៅពេល អូលីវើរ ខៅឌើរី និង ដេវីឌ វិតមើរ បានស្វែងយល់ពីការណ៍នេះ ពួកគាត់ទាំងពីរនាក់មានការបំផុសគំនិតមួយចង់ធ្វើជាសាក្សី ។ នៅក្នុងវិវរណៈមុន ( គ. និង ស. ៥ ) ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ ម៉ាទិន ហារីស ថា ប្រសិនបើគាត់មានចិត្តរាបសា ហើយគោរពប្រតិបត្តិគ្រប់គ្រាន់ហើយនោះ គាត់នឹងត្រូវបានអនុញ្ញាតឲ្យឃើញផ្ទាំងចំណារ ។ អូលីវើរ ខៅឌើរី ដាវីឌ វិតមើរ និង ម៉ាទិន ហារីស បានសូមឲ្យព្យាការីទូលសួរដល់ព្រះអម្ចាស់ ថាតើពួកគាត់អាចនឹងបានអនុញ្ញាតឲ្យទទួលបានឱកាសនេះដែរឬទេ ។ វិវរណៈដែលអ្នកនឹងសិក្សានៅថ្ងៃនេះគឺ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧ បានបញ្ជាក់ប្រាប់ថា បុរសទាំងបីរូបនេះ នឹងត្រូវបានអនុញ្ញាតឲ្យឃើញផ្ទាំងចំណារ និង វត្ថុដែលទាក់ទងផ្សេងៗទៀត ប្រសិនបើពួកគាត់អនុវត្តសេចក្ដីជំនឿបានគ្រប់គ្រាន់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧

*ព្រះអម្ចាស់មានព្រះបន្ទូលប្រាប់ អូលីវើរ ខៅឌើរី ដាវីឌ វិតមើរ និង ម៉ាទិន ហារីស ថា ប្រសិនបើពួកគាត់មានសេចក្ដីជំនឿគ្រប់គ្រាន់ នោះពួកគាត់នឹងត្រូវបានអនុញ្ញាតឲ្យឃើញផ្ទាំងចំណារ និង វត្ថុពិសិដ្ឋដទៃទៀត ។*

មានកន្លែងចំនួនពីរនៅក្នុងព្រះគម្ពីរមរមន ដែលមានចែងនូវការព្យាករណ៍អំពីពួកសាក្សីដែលនឹងឃើញ ហើយថ្លែងទីបន្ទាល់អំពីព្រះគម្ពីរ ឬ ផ្ទាំងចំណារដែលមាននូវបញ្ជីប្រវត្តិ ។ សូមអាន នីហ្វៃទី២ ២៧:១២–១៤ និង អេធើរ ៥:២–៤ រួចគិតថាវានឹងមានលក្ខណៈដូចម្ដេចដើម្បីធ្វើជាសាក្សីមួយរូបចំពោះផ្ទាំងចំណារ ។ ចេញពីអ្វីដែលអ្នកបានរៀននៅក្នុងបទគម្ពីរទាំងនេះ តើពួកសាក្សីទាំងបីនាក់នោះ នឹងត្រូវបានបង្ហាញបញ្ជីប្រវត្តិឲ្យឃើញតាមរបៀបណា ?



លោកអូលីវើរ ខៅឌើរី លោកដាវីឌ វិតមើរ និង លោកម៉ាទិន ហារីស

តាមរយៈវិវរណៈនេះ ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ យ៉ូសែប ស្ម៊ីធ ថា អូលីវើរ ខៅឌើរី ដាវីឌ វិតមើរ និង ម៉ាទិន ហារីស នឹងត្រូវបានអនុញ្ញាតឲ្យឃើញផ្ទាំងចំណារ ។ សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧:១ ។ បន្ថែមពីលើផ្ទាំងចំណារនោះ តើមានវត្ថុអ្វីផ្សេងទៀតដែលពួកសាក្សីទាំងនេះនឹងអាចឃើញ ? ( លេខយោង ១ *ជ* មាននូវសេចក្ដីយោងទៅកាន់អ្វីដែលជា « របស់ដៅទិសដ៏អស្ចារ្យ » រួមបញ្ចូលទាំង នីហ្វៃទី១ ១៦:១០, ១៦, ២៦ និង អាលម៉ា ៣៧:៣៨–៤៧) ។

សូមគិតអំពីរបៀបដែលវត្ថុដ៏ពិសិដ្ឋទាំងនេះ ( មានដូចជា ដាវរបស់ឡាបាន់ និង លីអាហូណា ) អាចបន្ថែមភស្តុតាងលើភាពជាក់ស្ដែងនៃតួអង្គ និង ព្រឹត្តិការណ៍នានាដែលមានកត់ត្រានៅក្នុងព្រះគម្ពីរមរមន ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧:២–៣ ។ តើព្រះអម្ចាស់បានមានព្រះបន្ទូលថា ពួកសាក្សីត្រូវធ្វើអ្វីខ្លះពីមុនពួកគេអាចឃើញផ្ទាំងចំណារ ?

១. សូមឆ្លើយនឹងសំណួរដូចតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថា ហេតុអ្វីសាក្សីទាំងនេះត្រូវមានសេចក្ដីជំនឿមុនពួកគេអាចឃើញផ្ទាំងចំណារមាស ?

ទោះជាយើងអាចនឹងមិនទទួលបានសាក្សីមួយតាមរបៀបដូចគ្នាដែលពួកសាក្សីបីនាក់ក៏ដោយ ក៏យើងអាចទទួលបានសាក្សីនៃសេចក្ដីពិតដែលយើងចង់ដឹងដែរ ។ សូមពិចារណាអំពីអ្វីដែល គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧:១–៣ បង្រៀនយើងអំពីរបៀបដែលយើងអាចទទួលបានសាក្សីផ្ទាល់ខ្លួនអំពីសេចក្ដីពិតនៃដំណឹងល្អ ។ រួចសូមបំពេញគោលការណ៍ដូចតទៅនេះ ដោយផ្អែកទៅលើអ្វីដែលអ្នកស្វែងយល់ចេញពីខគម្ពីរទាំងនេះ ៖ **ប្រសិនបើយើង នោះយើងអាចទទួលបានសាក្សីនៃសេចក្ដីពិតដែលយើងចង់ដឹង ។**

២. សូមពិពណ៌នាដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបដែលអ្នកអនុវត្តសេចក្ដីជំនឿលើព្រះដើម្បីទទួលបានសាក្សីអំពីព្រះគម្ពីរមរមន និង សេចក្ដីពិតនៃដំណឹងល្អដទៃទៀត ។ ឬ ប្រសិនបើអ្នកមានអារម្មណ៍ថា មិនទាន់បានទទួលសាក្សីនៅឡើយ សូមពន្យល់ពីរបៀបដែលអ្នកអាចអនុវត្តសេចក្ដីជំនឿដើម្បីអ្នកអាចទទួលបានទីបន្ទាល់នៃព្រះគម្ពីរមរមន ។

ម្ដាយរបស់ យ៉ូសែប ស្ម៊ីធ គឺ លូស៊ី ម៉ាក ស្ម៊ីធ បានសរសេរពីរបៀបដែល ម៉ាទិន ហារីស ត្រូវបានព្រះមានបន្ទូលប្រាប់ថា គាត់អាចធ្វើជាសាក្សីម្នាក់ក្នុងចំណោមសាក្សីទាំងបីនាក់បាន ។ បន្ទាប់ពីរាត្រីដែលបានអាននៅក្នុងច្បាប់សរសេរដៃនៃព្រះគម្ពីរមរមនដែលត្រូវបានបញ្ចប់ថ្មីនោះ « នៅព្រឹកបន្ទាប់ ក្រោយពីបានធ្វើការងារដូចសព្វដងដូចជា ការអាន ច្រៀង និង អធិស្ឋាន យ៉ូសែបបានក្រោកពីលុតជង្គង់ ហើយបានដើរសំដៅទៅ ម៉ាទិន ហារីស ទាំងចិត្តមុតមាំ បើតាមខ្ញុំចាំ វាបានធ្វើឲ្យខ្ញុំរំជួលចិត្តដល់សព្វថ្ងៃនេះ គាត់បានពោលថា ‹ ម៉ាទីន ហារីស នៅថ្ងៃនេះលោកត្រូវតែមានចិត្តរាបសាចំពោះព្រះ ដល់កម្រិតដែលលោកអាចទទួលបានការអភ័យទោសដល់អំពើបាបរបស់លោក ។ បើលោកមានចិត្តរាបសាមែននោះ វាជាព្រះឆន្ទៈព្រះដែលលោកគួរតែអាចឃើញផ្ទាំងចំណារ ជាមួយនឹង អូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ › ( *History of Joseph Smith by His Mother,* ed. Preston Nibley [ ឆ្នាំ ១៩៥៨ ] ទំព័រ ១៥១–៥២ ) ។

សូមពិចារណាទៅលើសំណួរខាងក្រោមនេះ ៖

- តើអ្នកគិតថាហេតុអ្វីបានជាវាចាំបាច់ដើម្បីមានចិត្តរាបសា នៅពេលយើងស្វែងរកការអភ័យទោសពីព្រះ ?
- តើអ្នកគិតថាហេតុអ្វីបានជាយើងត្រូវស្វែងរកការអភ័យទោសពីព្រះនៅពេលយើងចង់ទទួលបានសាក្សីនៃសេចក្ដីពិតពីទ្រង់ ?

សូមគិតពីការដែលត្រូវបានជ្រើសរើសឲ្យធ្វើជាសាក្សីម្នាក់ក្នុងចំណោមសាក្សីទាំងបីនាក់ ដែលត្រូវបានអនុញ្ញាតឲ្យឃើញផ្ទាំងចំណារ « ដោយព្រះចេស្ដានៃព្រះ » ។ តើការទទួលខុសត្រូវបែបណាដែលអ្នកនឹងគិតថាមានបន្ទាប់ពីទទួលបានបទពិសោធន៍នេះ ? ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ពីការទទួលខុសត្រូវនៃការធ្វើជាសាក្សីនៃផ្ទាំងចំណារ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧:៣–៥ ដោយស្វែងរកការណ៍ដែលព្រះអម្ចាស់បានត្រាស់បញ្ជាឲ្យពួកសាក្សីបីនាក់ធ្វើ បន្ទាប់ពីបានឃើញផ្ទាំងចំណារហើយ ។

សូមពិចារណាអំពីការទទួលខុសត្រូវដែលយើងមាននៅពេលព្រះអម្ចាស់ប្រទានសាក្សីមួយនៃសេចក្ដីពិតដ៏ទេវភាពឲ្យយើង ។ អ្នកអាចនឹងចង់គូសចំណាំឃ្លាទាំងឡាយដែលមាននៅក្នុង ខទី ៣ ដែលបង្រៀនពីគោលការណ៍ដូចតទៅនេះ ៖ **បន្ទាប់ពីយើងទទួលបានសាក្សីនៃសេចក្ដីពិតហើយ យើងនឹងមានការទទួលខុសត្រូវក្នុងការថ្លែងទីបន្ទាល់អំពីសេចក្ដីពិតនោះ ។** សូមគិតអំពីរបៀបដែលឆន្ទៈរបស់អ្នកក្នុងការថ្លែងទីបន្ទាល់ពីសេចក្ដីពិត ក៏ជាការបង្ហាញសេចក្ដីជំនឿរបស់អ្នកលើព្រះយេស៊ូវគ្រីស្ទដែរ ។

៣. សូមធ្វើបញ្ជីដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគោលលទ្ធិ និង គោលការណ៍នៃដំណឹងល្អមួយចំនួនដែលអ្នកដឹងថាជាការពិត ។ សូមចែកចាយទីបន្ទាល់ អារម្មណ៍ ឬ គំនិតទាំងឡាយរបស់អ្នកអំពីគោលការណ៍ទាំងនេះជាមួយនឹងឪពុក/ម្ដាយ ឬ បងប្អូនបង្កើត ។

មិនយូរប៉ុន្មានបន្ទាប់ពីវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧ ត្រូវបានប្រទានឲ្យ នោះព្យាការី យ៉ូសែប ស្ម៊ីធ, ដាវីឌ វិតមើរ, អូលីវើរ ខៅឌើរី និង ម៉ាទិន ហារីស បានដើរចូលទៅក្នុងព្រៃក្បែរផ្ទះរបស់គ្រួសារ វិតមើរ ដើម្បី « ព្យាយាមទទួលតាមរយៈការអធិស្ឋានដ៏ក្លៀវក្លា និង រាបសា » នូវសាក្សីដែលបានសន្យានោះ ។ យ៉ូសែប ស្ម៊ីធ បានកត់ត្រាដូច្នេះ បន្ទាប់ពីការព្យាយាមអធិស្ឋានពីរដងមិនបានសម្រេច « ម៉ាទិន ហារីស បានសុំដកខ្លួន ដោយបង្ហាញថា គាត់ជឿថានេះបណ្ដាលមកពីវត្តមានរបស់គាត់ ទើបធ្វើឲ្យពួកយើងមិនអាចទទួលបាននូវអ្វីដែលយើងអធិស្ឋានសុំ ។ គាត់ក៏បានដកខ្លួនចេញដូចដែលបានគិតនោះទៅ រួចយើងបានលុតជង្គង់ចុះអធិស្ឋានសាជាថ្មី ហើយមិនទាន់បានពីរបីនាទីផង កាលយើងបានឃើញពន្លឺមួយចំពីលើយើងស្ថិតនៅក្នុងអាកាស ដែលភ្លឺចែងចាំងឥតឧបមា ហើយមើលចុះ មានទេវតាមួយអង្គបានឈរនៅចំពោះយើង ។ ក្នុងព្រះហស្តទ្រង់មាននូវផ្ទាំងចំណារដែលយើងបានអធិស្ឋាន. . . ដើម្បីចង់ឃើញ ។ ទ្រង់បានបើកសន្លឹកទំព័រមួយម្ដងៗ ដើម្បីយើងអាចឃើញ ហើយយល់ពីការចារឹកទាំងនោះបានយ៉ាងច្បាស់ ។. . . យើងបានស្ដាប់ឮសំឡេងមួយចេញមកពីក្នុងពន្លឺនៅ

ខាងលើយើង ដោយថ្លែងថា ‹ ផ្ទាំងចំណារទាំងនេះ ត្រូវបានបើកសម្ដែងឡើងដោយព្រះចេស្ដានៃព្រះ ហើយវាត្រូវបានបកប្រែដោយព្រះចេស្ដានៃព្រះ ។ ការបកប្រែរបស់វា ដែលអ្នកបានមើលឃើញគឺត្រឹមត្រូវ ហើយខ្ញុំបញ្ជាដល់អ្នកឲ្យថ្លែងទីបន្ទាល់អំពីអ្វីដែលឥឡូវអ្នកបានឃើញ និងស្ដាប់ឮនោះ › ។

« ឥឡូវខ្ញុំបានចាកចេញពីដេវីឌ និងអូលីវើរ ហើយបានទៅរកម៉ាទីន ហារិស ដែលខ្ញុំបានឃើញថា គាត់កំពុងតែអធិស្ឋានយ៉ាងក្លៀវក្លានៅកន្លែងឆ្ងាយមួយ។ ទោះជាយ៉ាងណាក៏ដោយ គាត់បានប្រាប់ខ្ញុំថា គាត់ពុំទាន់បានទទួលចម្លើយពីព្រះអម្ចាស់នៅឡើយ ហើយគាត់បានស្នើដោយចិត្តស្មោះឲ្យខ្ញុំចូលរួមអធិស្ឋានជាមួយគាត់ ដើម្បីឲ្យគាត់អាចទទួលបានពរជ័យដូចគ្នាដែលយើងទើបតែបានទទួលដែរ ។ យើងក៏បានអធិស្ឋានជាមួយគ្នាតាមសំណើររបស់គាត់ ហើយទីបំផុតបំណងប្រាថ្នាយើងបានសម្រេច ដ្បិតយើងមិនទាន់បានបញ្ចប់ការអធិស្ឋានផង ការនិមិត្តដូចគ្នាបានបង្ហាញឲ្យយើងឃើញ យ៉ាងហោចណាស់ខ្ញុំបានឃើញការនិមិត្តនោះជាលើកទីពីរ ហើយខ្ញុំបានឃើញ ហើយឮការណ៍ដដែលនេះម្ដងទៀត នៅពេលនោះ ម៉ាទីន ហារីស បានយំក្នុងអាកប្បកិរិយាត្រេកអរដោយសេចក្ដីអំណរបន្លឺថា « ‹ គ្រប់គ្រាន់ហើយ គ្រប់គ្រាន់ហើយ ភ្នែករបស់ខ្ញុំបានឃើញហើយ ភ្នែករបស់ខ្ញុំបានឃើញហើយ › » ( នៅក្នុង *History of the Church* ១:៥៤–៥៥ ) ។

សូមគិតអំពីការដែលត្រូវបានប្រាប់អំពីព័ត៌មានមួយចំនួន ដែលអ្នកមិនត្រូវបានអនុញ្ញាតឲ្យចែកចាយជាមួយនរណាម្នាក់អស់រយៈពេលជាយូរ ។ តើអ្នកនឹងមានអារម្មណ៍ដូចម្ដេចកាលនៅទីបំផុត អ្នកត្រូវបានអនុញ្ញាតឲ្យចែកចាយពីការណ៍នោះ ? សូមគិតអំពីស្ថានភាពដែល យ៉ូសែប ស្ម៊ីធ ត្រូវធ្វើជាសាក្សីតែម្នាក់ឯងចំពោះផ្ទាំងចំណារព្រះគម្ពីរមរមនអស់រយៈពេលជាច្រើនឆ្នាំ ។ តើអ្នកនឹងមានអារម្មណ៍យ៉ាងណាចំពោះស្ថានភាពរបស់លោក ? តើអ្នកគិតថា យ៉ូសែប ស្ម៊ីធ មានអារម្មណ៍ដូចម្ដេចដែលឥឡូវនេះ មនុស្សដទៃទៀតអាចបន្ថែមសាក្សី និង ទីបន្ទាល់របស់ខ្លួនទៅលើអ្វីដែលលោកមាន ?



ដំណើររឿងដូចតទៅនេះមកពី លូស៊ី ម៉ាក ស្ម៊ីធ ជាម្ដាយរបស់ យ៉ូសែប បានរៀបរាប់ពីអារម្មណ៍របស់យ៉ូសែប បន្ទាប់ពីពួកសាក្សីទាំងបីនាក់បានឃើញផ្ទាំងចំណារ ៖ « នៅពេលពួកគេបានត្រឡប់មកផ្ទះវិញ វាគឺចន្លោះម៉ោងបីទៅម៉ោងបួនរសៀល ដែលអ្នកស្រី វិតមើរ លោក ស្ម៊ីធ [ យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ ] និង ខ្ញុំ បានអង្គុយក្នុងបន្ទប់គេងមួយជាមួយគ្នានៅពេលនោះ ។ នៅពេលចូលមកដល់ យ៉ូសែប បានទម្លាក់ខ្លួនក្បែរខ្ញុំ ហើយបានពោលឮៗថា ‹ ពុក ម៉ែ លោកទាំងពីរពុំដឹងថាតើខ្ញុំរីករាយយ៉ាងណានោះទេ ៖ ឥឡូវនេះ ព្រះអម្ចាស់បានអនុញ្ញាតឲ្យផ្ទាំងចំណារត្រូវបានបង្ហាញដល់មនុស្សបីនាក់ទៀតក្រៅពីខ្ញុំ ។ ពួកគេបានមើលឃើញទេវតា ដែលបានថ្លែងទីបន្ទាល់ដល់ពួកគេ ហើយពួកគេនឹងធ្វើជាសាក្សីចំពោះ សេចក្ដីពិតនៃអ្វីដែលខ្ញុំបាននិយាយ ដ្បិតឥឡូវនេះ ពួកគេបានដឹងដោយផ្ទាល់ខ្លួនគេហើយថា ខ្ញុំពុំបានទៅបោកបញ្ឆោតមនុស្សទេ ហើយខ្ញុំមានអារម្មណ៍ដូចជាខ្ញុំត្រូវបានរួចពីបន្ទុកមួយ ដែលធ្ងន់យ៉ាងខ្លាំងស្ទើរតែខ្ញុំពុំអាចរែកបាននោះ ហើយវាធ្វើឲ្យព្រលឹងរបស់ខ្ញុំរីករាយ ដែលខ្ញុំឈប់ជាអ្នកដឹងតែឯងក្នុងលោកិយនេះទៀតហើយ ›។ បន្ថែមពីនេះ ម៉ាទិន ហារីស បានចូលមក ៖ គាត់មើលទៅហាក់ដូចជាពេញទៅដោយសេចក្ដីអំណរ ហើយបានថ្លែងទីបន្ទាល់យ៉ាងមុតមាំចំពោះការណ៍ដែលគាត់បានឃើញហើយឮនោះ ។ ហើយដាវីឌ និង អូលីវើរ ក៏បានសម្ដែងឲ្យឃើញដូច្នេះដែរ ដោយបន្ថែមថា គ្មានអណ្ដាតណាអាចនឹងថ្លែងពីសេចក្ដីអំណរដែលមានក្នុងចិត្តពួកគាត់ និង ពីភាពអស្ចារ្យដែលពួកគាត់បានឃើញ និង ឮនោះទេ » ( *History of Joseph Smith by His Mother* ទំព័រ ១៥២–៥៣ ) ។

៤. សូមពិពណ៌នាដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអារម្មណ៍នៃការមានមនុស្សដទៃទៀតជុំវិញខ្លួនអ្នកដែលទទួលបានសាក្សីចំពោះការណ៍ដែលអ្នកដឹងថាជាការពិត ។ តើទីបន្ទាល់របស់ពួកគេអាចជួយអ្នកដូចម្ដេចដែរ ?

អែលឌើរ ឡូរិន ស៊ី ដាន់ នៃពួកចិតសិបនាក់ បានមានប្រសាសន៍ពីសារៈសំខាន់នៃពួកសាក្សីក្នុងកិច្ចការរបស់ព្រះអម្ចាស់ថា ៖ « ក្រឹត្យវិន័យនៃសាក្សី គឺតែងតែជាផ្នែកមួយនៃកិច្ចការរបស់ព្រះអម្ចាស់នៅលើផែនដីនេះ ។ ក្រឹត្យវិន័យនេះថ្លែងថា ‹ គ្រប់ការទាំងអស់នឹងបានសម្រេចដោយនូវមាត់ស្មរបន្ទាល់ពីរ ឬ បីនាក់ › ( កូរិនថូស ទី១ ១៣:១; សូមមើលផងដែរ ចោទិយកថា ១៧:៦; ១៩:១៥; ម៉ាថាយ ១៨:១៥–១៦; យ៉ូហាន ៨:១២–២៩) ។ សាក្សីនេះបញ្ជាក់ថា ព្រឹត្តិការណ៍ជាក់លាក់មួយចំនួនបានកើតឡើង ហើយថាគោលលទ្ធិ និង គោលការណ៍នានាដែលព្រះបានប្រទានឲ្យសុទ្ធតែជាការណ៍ពិត » (“Witness,” *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ២៨ ) ។ ព្រះអម្ចាស់បានប្រើក្រឹត្យវិន័យនៃសាក្សីដើម្បីបញ្ជាក់ពីភាពជាក់ស្ដែងនៃផ្ទាំងចំណារ ។

នៅពីរបីថ្ងៃក្រោយពីផ្ទាំងចំណារត្រូវបានបង្ហាញដល់ពួកសាក្សីបីនាក់ដោយព្រះចេស្ដានៃព្រះ ព្យាការីយ៉ូសែប ស្ម៊ីធ ត្រូវបានអនុញ្ញាតឲ្យបង្ហាញផ្ទាំងចំណារទៅដល់ « មនុស្សមួយចំនួនតូច ស្របតាមព្រះហឫទ័យនៃព្រះ ដើម្បីធ្វើទីបន្ទាល់អំពីព្រះបន្ទូលរបស់ទ្រង់ប្រាប់ដល់កូនចៅមនុស្ស » (នីហ្វៃទី២ ២៧:១៣; សូមមើលផងដែរ អេធើរ ៥:២) ។ សូមអាន « ទីបន្ទាល់នៃពួកសាក្សីបីនាក់ » និង « ទីបន្ទាល់នៃពួកសាក្សីប្រាំបីនាក់ » ( ដែលមាននៅបន្ទាប់ពីបុព្វកថានៃព្រះគម្ពីរមរមន ) ។ សូមកត់ចំណាំពីភាពខុសគ្នានៅក្នុងបទពិសោធន៍ និង ភាពស្រដៀងគ្នានៃទីបន្ទាល់របស់ពួកគាត់ ។ ក៏សូមកត់ចំណាំផងដែរថា សាក្សីប្រាំបីនាក់បានរៀបរាប់ថាផ្ទាំងចំណារមាន « រូបរាងជាមាស » និងមាន « រូបរាងជាវត្ថុស្នាដៃបុរាណមួយយ៉ាងចំណាន » ។

ដោយសារតែពួកគាត់ពុំដឹងថាតើផ្ទាំងចំណារទាំងនេះជាមាសសុទ្ធ ឬ ថាការឆ្លាក់ត្រានៅលើនោះជាវត្ថុស្នាដៃបុរាណមួយយ៉ាងចំណានទេនោះ ពួកគាត់បានគ្រាន់តែថ្លែងទីបន្ទាល់យ៉ាងស្មោះត្រង់អំពីការណ៍ដែលពួកគាត់បានដឹងថាជាការពិតប៉ុណ្ណោះ ។

៥. សូមស្រមៃថាទីបន្ទាល់របស់អ្នកអំពីព្រះគម្ពីរមរមន អាចដាក់បញ្ចូលទៅក្នុងច្បាប់ចម្លងនីមួយ ៗនៃព្រះគម្ពីរមរមន ។ សូមបង្កើតទំព័រសាក្សីផ្ទាល់ខ្លួនរបស់អ្នកនៅលើសន្លឹកសៀវភៅទទេមួយទំព័រក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមបញ្ចូលការណ៍ដែលអ្នកដឹងថាជាការពិតអំពីព្រះគម្ពីរមរមន ដែលអ្នកចង់ឲ្យមនុស្សដទៃដឹងដូចជាអ្នកផងដែរ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧:៦ មាននូវទីបន្ទាល់របស់ព្រះអង្គសង្គ្រោះអំពីព្រះគម្ពីរមរមន ។ សូមគូសចំណាំសាក្សីដែលទ្រង់បានប្រទានដល់ពិភពលោកនៅក្នុងខគម្ពីរនេះ ឬ សរសេរទីបន្ទាល់របស់ទ្រង់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ អ្នកក៏អាចចង់សរសេរថា **ព្រះយេស៊ូវគ្រីស្ទ បានថ្លែងទីបន្ទាល់ថា ព្រះគម្ពីរមរមនជាព្រះគម្ពីរពិតនៅក្នុង**សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ឬ លើគែមព្រះគម្ពីររបស់អ្នកក្បែរ ខទី ៦ ។ សូមពិចារណាអំពីរបៀបដែលទីបន្ទាល់របស់ព្រះអម្ចាស់អំពីព្រះគម្ពីរមរមន មានអានុភាពលើទីបន្ទាល់របស់អ្នក ។

បន្ទាប់ពីបទពិសោធន៍គួរឲ្យកត់សម្គាល់របស់ពួកគាត់ សាក្សីទាំងបីនាក់ បានស៊ូទ្រាំនឹងការសាកល្បងធំៗ ហើយសេចក្ដីជំនឿលើព្រះ និង ទីបន្ទាល់របស់ពួកគាត់ចំពោះដំណឹងល្អបានជួបនឹងឧបសគ្គ ។ អំឡុងពេលការតស៊ូនោះ សាក្សីទាំងបីនាក់បានចេញពីសាសនាចក្រ យ៉ាងណាក្តីក្រោយមក ម៉ាទិន ហារីស និង អូលីវើរ ខៅឌើរី បានត្រឡប់មកសាសនាចក្រវិញ ហើយបានបន្តស្មោះត្រង់អស់មួយជីវិត ។ ទោះជាយ៉ាងណាក៏ដោយ គ្មាននរណាម្នាក់ក្នុងចំណោមសាក្សីបីនាក់ បានបដិសេធទីបន្ទាល់របស់ខ្លួនអំពីព្រះគម្ពីរមរមនឡើយ ។

ថ្វីបើយើងពុំដឹងពីមូលហេតុជាក់លាក់ដែលសាក្សីបីនាក់បានចាកចេញពីសាសនាចក្រ នៅបន្ទាប់ពីបានមានបទពិសោធន៍នៃសាក្សីដ៏អស្ចារ្យយ៉ាងណាក្ដី ក៏ការព្រមានរបស់ព្រះអម្ចាស់ទៅដល់ព្យាការីយ៉ូសែប ស្ម៊ីធ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣:៤ ជួយយើងឲ្យយល់ពីរបៀបដែលការណ៍នេះអាចកើតឡើងថា ៖ « ដ្បិតទោះជាមនុស្សអាចមានវិវរណៈជាច្រើន ហើយមានអំណាចអាចធ្វើកិច្ចការដ៏អស្ចារ្យជាច្រើនបានក៏ដោយ តែបើគេអួតអាងដោយកម្លាំងរបស់ខ្លួន ហើយចាត់ដំបូន្មានទាំងឡាយនៃព្រះទុកជាគ្មានតម្លៃ ហើយដើរតាមសេចក្ដីបញ្ចោរនៃបំណង និង សេចក្ដីប៉ងប្រាថ្នាខាងរូបកាយរបស់ខ្លួន អ្នកនោះត្រូវតែធ្លាក់ចុះ ហើយធ្វើឲ្យសេចក្ដីសងសឹកនៃព្រះដ៏យុត្តិធម៌មានមកលើខ្លួនឯង ។ ទោះជាយ៉ាងណាក៏ដោយ សាក្សីម្នាក់ៗបានបន្តថ្លែងទីបន្ទាល់ដ៏ស្មោះត្រង់ចំពោះព្រះគម្ពីរមរមនពេញមួយជីវិតខ្លួន ។



អូលីវើរ ខៅឌើរី បានថ្លែងទីបន្ទាល់ថា ៖ « ខ្ញុំបានសរសេរដោយស្លាបប៉ាកកាខ្ញុំផ្ទាល់ គឺព្រះគម្ពីរមរមនទាំងស្រុង ( លើកលែងតែពីរបីទំព័រ ) ដែលត្រូវបានថ្លែងចេញពីមាត់របស់ព្យាការី យ៉ូសែប ស្ម៊ីធ ហើយលោកបានបកប្រែវាដោយអំណោយទាន និង ព្រះចេស្ដានៃព្រះ ដោយប្រើ យូរីម និង ធូមីម ឬ តាមរបៀបដែលព្រះគម្ពីរនោះបានហៅថាជា ‹ អ្នកបកប្រែដ៏បរិសុទ្ធ › ។ ខ្ញុំបានឃើញដោយភ្នែករបស់ខ្ញុំផ្ទាល់ ហើយបានកាន់ដោយដៃខ្ញុំផ្ទាល់ ជាផ្ទាំងចំណារមាសដែលវាបានដកស្រង់ចេញ ។. . . គម្ពីរនោះគឺជា *ការពិត* ។ ស៊ីឌនី រិកដុន ពុំបានសរសេរវាទេ លោក ស្ពុលឌីង ពុំបានសរសេរវាទេ ។ ខ្ញុំបានសរសេរវាដោយខ្លួនឯង ជាសេចក្ដីដែលបានថ្លែងដោយមាត់របស់ព្យាការី ។ វាមាននូវដំណឹងល្អដ៏អស់កល្បអស់កាលជានិច្ច ។. . . វាមាននូវគោលការណ៍នៃសេចក្ដីសង្គ្រោះ ហើយឱអស់អ្នកស្ដាប់ទាំងឡាយរបស់ខ្ញុំអើយ ប្រសិនបើអ្នកនឹងដើរតាមពន្លឺរបស់វា ហើយធ្វើតាមសិក្ខាបទរបស់វា នោះអ្នកនឹងត្រូវបានសង្គ្រោះដោយនូវការសង្គ្រោះដ៏អស់កាលជានិច្ចនៅក្នុងនគរនៃព្រះដ៏ខ្ពស់បំផុត » ( នៅក្នុង “Last Days of Oliver Cowdery,” *Deseret News* ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៨៥៩ ទំព័រ ៤៨ ) ។



កាសែតមួយឈ្មោះថា *រីចមិន ដេម៉ូក្រាដ*បានពាំនាំយកដំណើររឿងដូចតទៅនេះអំពី ដាវីឌ វិតមើរ ថ្លែងទីបន្ទាល់អំពីព្រះគម្ពីរមរមននៅប៉ុន្មានថ្ងៃមុនពេលដែលគាត់បានទទួលមរណភាព ៖ « នៅល្ងាចថ្ងៃអាទិត្យវេលាម៉ោង ៥:៣០ ( ថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៨៨៨ ) លោក វិតមើរ បានហៅក្រុមគ្រួសារ និង មិត្តភក្ដិមួយចំនួនឲ្យមកប្រជុំគ្នានៅជុំវិញគ្រែរបស់គាត់ ។. . . រួចហើយគាត់បានប្រាប់ដោយខ្លួនគាត់ទៅដល់មនុស្សទាំងអស់ដែលនៅជុំវិញគ្រែគាត់នូវពាក្យទាំងនេះថា ៖ ‹ ឥឡូវ អ្នកទាំងអស់គ្នាត្រូវតែស្មោះត្រង់ចំពោះព្រះគ្រីស្ទ ។ ខ្ញុំចង់និយាយទៅកាន់អ្នកទាំងអស់គ្នាថា គម្ពីរប៊ីប និងកំណត់ត្រានៃពួកសាសន៍នីហ្វៃ ( ព្រះគម្ពីរមរមន) គឺជាការពិត ដូច្នេះអ្នកអាចនិយាយថា អ្នកបានស្ដាប់ឮខ្ញុំថ្លែងទីបន្ទាល់របស់ខ្ញុំពីលើគ្រែដែលខ្ញុំហៀបនឹងជិតស្លាប់នេះ ។ សូមអ្នកទាំងអស់គ្នាមានភាពស្មោះត្រង់ចំពោះព្រះគ្រីស្ទ ហើយរង្វាន់របស់អ្នក នឹងមានស្របតាមកិច្ចការរបស់អ្នក ។ សូមព្រះប្រទានពរដល់អ្នកទាំងអស់គ្នា ។ សេចក្ដីទុកចិត្តរបស់ខ្ញុំស្ថិតនៅលើព្រះគ្រីស្ទជាដរាបជាពិភពដែលគ្មានទីបញ្ចប់ ។ អាម៉ែន › » ( *រីចមិន ដេម៉ូក្រាដ* ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ១៨៨៨ បានដកស្រង់នៅក្នុង Andrew Jenson, *Latter–day Saint Biographical Encyclopedia,* វ៉ុល ៤ [ ឆ្នាំ ១៩០១ ] ១:២៧០ ) ។



ម៉ាទិន ហារីស បានថ្លែងទីបន្ទាល់នៅមិនយូរប៉ុន្មានពីមុនគាត់បានទទួលមរណភាពថា ៖ « មែនហើយ ខ្ញុំពិតជាបានឃើញផ្ទាំងចំណារដែលព្រះគម្ពីរមរមនត្រូវបានចារឹកនៅលើនោះ ខ្ញុំពិតជាបានឃើញទេវតា ខ្ញុំពិតជាបានឮព្រះសូរសៀងរបស់ព្រះ ហើយខ្ញុំពិតជាដឹងថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីរបស់ព្រះ ដែលកាន់កូនសោបព្វជិតភាពដ៏បរិសុទ្ធ » (“The Last Testimony of Martin Harris,” recorded by William H. Homer in a statement sworn before J. W. Robinson ថ្ងៃទី ៩ ខែមេសា ឆ្នាំ ១៩២៧ HDC ) ។ ( សូមមើលផងដែរ *គោលលទ្ធិ និង សេចក្ដីសញ្ញា សៀវភៅសិក្សារបស់សិស្ស* [ Church Educational System manual ឆ្នាំ ២០០១ ] ទំព័រ ៣៣) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧:៧–៩ រួចគូសចំណាំការសន្យាទាំងឡាយ ដែលព្រះអម្ចាស់បានធ្វើជាមួយពួកសាក្សីបីនាក់ នៅពេលដែលពួកគាត់មានចិត្តស្មោះត្រង់ក្នុងការប្រកាសអំពីទីបន្ទាល់របស់ខ្លួន ។ សូមកត់ចំណាំឃ្លា « គោលបំណងដ៏សុចរិត » នៅក្នុង ខទី ៩ ។ សូមគិតអំពីគោលបំណងដ៏សុចរិត ដែលព្រះអម្ចាស់បានមានព្រះទ័យឲ្យពួកសាក្សីបីនាក់បំពេញតាមរយៈការប្រកាសអំពីទីបន្ទាល់របស់ខ្លួនចំពោះផ្ទាំងចំណារមាស និង ព្រះគម្ពីរមរមន ។ ( អ្នកអាចនឹងចង់រំឭក គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧:៤ នៅពេលអ្នកគិតអំពីសំណួរនេះ ) ។

៦. សូមឆ្លើយនឹងសំណួរដូចតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្វីដែលអាចជាគោលបំណងដ៏សុចរិត ដែលព្រះអម្ចាស់អាចប្រទានដល់អ្នកនូវសាក្សីនៃសេចក្ដីពិតដែលអ្នកប្រាថ្នាចង់បាន ?

ចូរចងចាំថា យើងអាចបង្កើន ឬ ពង្រឹងទីបន្ទាល់បាននៅពេលយើងចែកចាយទីបន្ទាល់នោះ ។ ប្រធាន ប៊យដ៍ ឃេ ផាកកឺ ជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា ៖



« វាមិនមែនខុសប្រក្រតីអ្វីនោះទេ ដែលមានអ្នកផ្សព្វផ្សាយសាសនាពោលថា ‹ តើខ្ញុំអាចថ្លែងទីបន្ទាល់បានដោយរបៀបណា បើខ្ញុំមិនមានទីបន្ទាល់មួយផង ? តើខ្ញុំអាចថ្លែងទីបន្ទាល់ថា ព្រះមានព្រះជន្មរស់ថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ហើយថាដំណឹងល្អពិតដោយរបៀបណា ? បើខ្ញុំគ្មានទីបន្ទាល់ដូច្នេះផងនោះ តើទង្វើបែបនេះអាចជាការពុំទៀងត្រង់ដែរឬទេ ?

« ឱ បើខ្ញុំអាចបង្រៀនអ្នកអំពីគោលការណ៍មួយនោះ ។ ទីបន្ទាល់មួយអាច *កើតឡើង* នៅពេល *យើងថ្លែង* អំពីវា ! ត្រង់ណាដែលអ្នកស្វែងរកចំណេះដឹងខាងវិញ្ញាណ កន្លែងត្រង់នោះហើយដែលជា ‹ ការលោតផ្លោះនៃសេចក្ដីជំនឿ › ដូចដែលអ្នកទស្សនវិជ្ជាហៅដូច្នោះដែរ ។ វាជាគ្រាដែលអ្នកបានទៅដល់គែមពន្លឺ ហើយបានបោះជំហានចូលក្នុងភាពងងឹត ដើម្បីរកមើលថា តើផ្លូវនោះមានពន្លឺនៅខាងមុខ ឲ្យអ្នកបោះមួយ ឬពីរជំហានដែរឬទេ ។ ‹ វិញ្ញាណរបស់មនុស្ស › ដែលព្រះគម្ពីរបាននិយាយគឺជា ‹ ចង្កៀងនៃព្រះយេហូវ៉ា › ។ (សុភាសិត ២០:២៧) ។

« វាគឺជាអ្វីមួយដើម្បីទទួលបានសាក្សីមកពីការណ៍ដែលអ្នកបានអាន ឬពីការណ៍ដែលអ្នកផ្សេងទៀតបាននិយាយ ហើយនោះគឺជាការចាប់ផ្ដើមមានទីបន្ទាល់មួយដ៏ចាំបាច់ ។ វាគឺជាបទពិសោធន៍មួយផ្សេងទៀត ដើម្បីមានព្រះវិញ្ញាណមកបញ្ជាក់ដល់អ្នកនៅក្នុងទ្រូងអ្នកថា អ្វីដែល *អ្នក* បានថ្លែងទីបន្ទាល់គឺជាការពិត ។ តើអ្នកមិនយល់ថា វាត្រូវបានប្រទានឲ្យនៅពេលអ្នកចែកចាយទេឬអី ? នៅពេលអ្នកផ្ដល់នូវអ្វីដែលអ្នកមាន នោះការបន្ថែមមកវិញនឹងមានកាន់តែច្រើន !. . .

« ការថ្លែងចេញមក គឺជាការសាកល្បងនៃសេចក្ដីជំនឿរបស់អ្នក » ( “Candle of the Lord,” *Ensign,*ខែ មករា ឆ្នាំ ១៩៨៣ ទំព័រ ៥៤ ) ។

សូមពិចារណាអំពីមនុស្សដែលអ្នកអាចចែកចាយទីបន្ទាល់ជាមួយ ជាអ្នកដែលអាចទទួលបានអត្ថប្រយោជន៍ពីការស្ដាប់ទីបន្ទាល់របស់អ្នក ។ សូមចែកចាយទីបន្ទាល់ជាមួយមនុស្សម្នាក់នៅសប្ដាហ៍នេះ ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៧ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៥ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨

## បុព្វកថា

វិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨ ត្រូវបានប្រទានក្នុងខែ មិថុនា ឆ្នាំ ១៨២៩ នៅមិនយូរប៉ុន្មានបន្ទាប់ពី ពេត្រុស យ៉ាកុប និង យ៉ូហាន បានប្រទានបព្វជិតភាពមិលគីស្សាដែកដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ។ ការយាងមករបស់ទ្រង់ទាំងបីអង្គសង្កត់ធ្ងន់លើតួនាទីដ៏មានសារៈសំខាន់នៃពួកសាវកក្នុងគ្រឹះរបស់សាសនាចក្រនៃព្រះគ្រីស្ទ ។.គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១–១៦ ផ្ដោតសំខាន់ទៅលើការហៅដែល អូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ បានទទួលធ្វើជាអ្នកបម្រើរបស់ព្រះយេស៊ូវគ្រីស្ទ ហើយប្រកាសពីការប្រែចិត្តដល់មនុស្សដទៃ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៧–៤៧ បង្រៀនពីសារៈសំខាន់នៃការលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។ ព្រះអម្ចាស់ក៏បានមានព្រះបន្ទូលអំពីការហៅពួកសាវកដប់ពីរនាក់ដែលនឹងកើតមានឡើង និងបំណងប្រាថ្នាដែលពួកលោកនឹងមានដើម្បីលើកដាក់លើខ្លួនពួកលោកនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ « ដោយបំណងចិត្តដ៏ពោរពេញ » (គ. និង ស. ១៨:២៧) ។ ព្រះអម្ចាស់បានប្រទានដល់ អូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ នូវការទទួលខុសត្រូវដូចគ្នាដើម្បី « ស្វែងរកពួកដប់ពីរនាក់ » ( គ. និង ស. ១៨:៣៧ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១–៥

*ព្រះអម្ចាស់បង្រៀនពីរបៀបស្ថាបនាសាសនាចក្រទ្រង់ឡើង*

តើអ្នកធ្លាប់មានបទពិសោធន៍នៃភាពចលាចល និង ការបំផ្លិចបំផ្លាញនៃការរញ្ជួយដីឬទេ ? នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៨៩ វេលាម៉ោង ៥:០៤ ល្ងាច ការរញ្ជួយដីដ៏ខ្លាំងមួយ ( កម្លាំង ៦.៩ រីឆធើរ ស្កេល ) បានកើតឡើងនៅទីក្រុង សាន់ ហ្វ្រាន់ស៊ីស្កូ រដ្ឋកាលីហ្វ័រញ៉ា ជាតំបន់នៅសហរដ្ឋអាមេរិក ។ អគាររាប់ពាន់ខ្នងត្រូវបានកម្ទេច ឬ បំផ្លិចបំផ្លាញ ។ ផ្ទះមួយចំនួនមើលទៅហាក់ដូចជានៅល្អប្រសើរពីខាងក្រៅ ប៉ុន្តែ អាជ្ញាធរបានបំផ្លាញពួកវាចោលដោយសារតែគ្រឹះរបស់វាបានប្រេះស្រាំ ឬ មិនរឹងមាំ ។ តើកង្វល់អ្វីខ្លះដែលអ្នកអាចមានអំពីការរស់នៅក្នុងផ្ទះមួយដែលគ្រឹះរបស់វាពុំរឹងមាំ ?

ដូចបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨ ព្រះអម្ចាស់បានបើកសម្ដែងដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ពីរបៀបស្ថាបនាសាសនាចក្រទ្រង់ឡើងនៅលើគ្រឹះដ៏រឹងមាំ ។ នៅពេលចាប់ផ្ដើមវិវរណៈនេះ ព្រះអម្ចាស់បានសំដៅលើការណ៍ទាំងឡាយដែល អូលីវើរ ខៅឌើរី បានសរសេរ មានន័យថា ពាក្យពេចន៍នៃព្រះគម្ពីរមរមន ដែលអូលីវើរ បានកត់ត្រាកាលគាត់ធ្វើជាស្មៀនរបស់ព្យាការីយ៉ូសែប ស្ម៊ីធ ។




សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:២–៥ រួចស្វែងរកអ្វីដែលត្រូវបានសរសេរនៅក្នុងព្រះគម្ពីរមរមន ដែលព្រះអម្ចាស់បានត្រាស់បញ្ជាឲ្យពួកអ្នកបម្រើរបស់ទ្រង់ស្ថាបនាសាសនាចក្ររបស់ទ្រង់នៅលើនោះ ។

យើងស្វែងយល់ចេញពីការណែនាំរបស់ព្រះអម្ចាស់ អំពីលក្ខណៈពិសេសនៃសាសនាចក្ររបស់ព្រះអម្ចាស់ ។ សូមបំពេញគោលការណ៍ដូចតទៅដោយផ្អែកទៅលើវិវរណៈដែលបានប្រទានឲ្យនៅក្នុងខគម្ពីរទាំងនេះ ៖ **សាសនាចក្រដ៏ពិតត្រូវបានស្ថាបនានៅលើ** ។

ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនអំពីគ្រឹះ និង ថ្មដាដូចខាងក្រោមនេះថា ៖



« ព្រះគ្រីស្ទ គឺជាសិរសានៃសាសនាចក្រ ជាថ្មជ្រុងយ៉ាងឯក ជាថ្មដាខាងវិញ្ញាណដែលសាសនាចក្រត្រូវបានស្ថាបនាឡើង ហើយទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ [ សូមមើល ម៉ាថាយ ១៦:១៨; អេភេសូរ ២:២០] ។ ទ្រង់បានស្ថាបនានគរទ្រង់ឡើង បានជ្រើសរើសពួកសាវក ហើយបានតែងតាំងបព្វជិតភាពមិលគីស្សាដែកដល់ពួកគាត់ ដោយប្រទានដល់ពួកគាត់នូវអំណាច [ កូនសោនៃបព្វជិតភាព ] ដើម្បីចាត់ចែងក្នុងពិធីបរិសុទ្ធនៃដំណឹងល្អ » (*ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ*ឆ្នាំ ២០០៧ ] ទំព័រ ១៣៩) ។

« ព្រះយេស៊ូវមានព្រះបន្ទូលក្នុងការបង្រៀនរបស់ទ្រង់ថា ‹ ខ្ញុំនឹងតាំងពួកជំនុំខ្ញុំនៅលើថ្មដានេះ ហើយទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ › ។ [ ម៉ាថាយ ១៦:១៨ ] ។ តើជាថ្មដាអ្វីទៅ ? គឺជាវិវរណៈ » (*ការបង្រៀន ៖ យ៉ូសែប ស្ម៊ីធ* ទំព័រ ១៩៥) ។

ព្រះអម្ចាស់បានប្រទានការសន្យាជាក់លាក់ទៅដល់ពួកអ្នកបម្រើទ្រង់ ប្រសិនបើពួកគេនឹងស្ថាបនាសាសនាចក្រទ្រង់ឡើងនៅលើគ្រឹះដ៏រឹងមាំនៃដំណឹងល្អ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:៥ រួចស្វែងរកការសន្យារបស់ព្រះអម្ចាស់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:៦–១៦

*អូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ ត្រូវបានហៅឲ្យប្រកាសអំពីការប្រែចិត្ត*

តើអ្នកនឹងពិពណ៌នាយ៉ាងដូចម្ដេច អំពីបរិយាកាសខាងវិញ្ញាណ និង ក្រមសីលធម៌នៃពិភពលោកដែលយើងកំពុងតែរស់នៅសព្វថ្ងៃនេះ ? សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:៦ រួចកត់ចំណាំពីរបៀបដែលព្រះអម្ចាស់បានមានព្រះបន្ទូលពិពណ៌នាអំពីពិភពលោកនេះ ។ សូមស្វែងរកដំណោះស្រាយរបស់ព្រះអម្ចាស់ចំពោះការកើនឡើងនៃអំពើទុច្ចរិតលើពិភពលោកនេះ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:៩ ។

សូមគិតអំពីវត្ថុមួយដែលមាននៅក្នុងផ្ទះរបស់អ្នក ដែលអ្នកគិតថាជាវត្ថុមានតម្លៃ ។ តើអ្នកដឹងថា វត្ថុនោះមានតម្លៃគិតជាប្រាក់ប្រហែលជាប៉ុន្មាន ? របៀបមួយដើម្បីបង្កើតតម្លៃនៃវត្ថុមួយ គឺតាមរយៈការសម្រេចពីតម្លៃដែលមនុស្សម្នាក់ចង់ចំណាយលើវត្ថុនោះ ។ បុគ្គលម្នាក់អាចអះអាងថា វត្ថុពិសេសមួយមានតម្លៃជាប្រាក់មួយចំនួន ប៉ុន្តែ តម្លៃនោះមានភាពត្រឹមត្រូវលើកលែងតែមានបុគ្គលម្នាក់ទៀតចង់ចំណាយប្រាក់ចំនួននោះលើវត្ថុនោះប៉ុណ្ណោះ ។

តើព្រលឹងនៃបុគ្គលម្នាក់មានតម្លៃប៉ុន្មាន ? គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១០ បង្រៀនអំពីតម្លៃនៃបុគ្គលម្នាក់ចំពោះព្រះនេត្រនៃព្រះ ។ សូមអានខគម្ពីរនេះ ដោយស្វែងរកតម្លៃដែលព្រះអម្ចាស់បានប្រកាសថាយើងមាន ។

១. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលអ្នកគិតថា អ្នកជាព្រលឹងដ៏មានតម្លៃមហិមាចំពោះព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។



ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ក្នុងគណៈប្រធានទីមួយ បានពន្យល់ពីតម្លៃរបស់យើងចំពោះព្រះវរបិតាសួគ៌ថា ៖ « ព្រះទ្រង់ទតមើលអ្នកពុំមែនគ្រាន់តែជាសភាវៈមែងស្លាប់មួយដែលរស់នៅលើពិភពដ៏តូចមួយសម្រាប់មួយរយៈកាលខ្លីប៉ុណ្ណោះទេ—តែទ្រង់ទតមើលអ្នកថាជាបុត្ររបស់ទ្រង់ ។ ទ្រង់ទតមើលអ្នកថាជាសភាវៈ ដែលមានសមត្ថភាព និង ត្រូវបានបង្កើតឡើងឲ្យមានរូបរាងដូច្នេះ ។ ទ្រង់ចង់ឲ្យអ្នកដឹងថា អ្នកសំខាន់ចំពោះទ្រង់ » (You Matter to Him » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១,ទំព័រ ២២ ) ។

ព្រលឹងនីមួយៗសំខាន់ចំពោះព្រះអម្ចាស់ ហើយថ្នាក់ដឹកនាំសាសនាចក្រតែងតែត្រូវបានដឹកនាំដោយព្រះវិញ្ញាណដើម្បីបម្រើដល់បុគ្គលសំខាន់ម្នាក់ៗ ។ ឧទាហរណ៍ ប្រធាន ថូម៉ាស អេស ម៉នសុន បានធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណ ហើយបានផ្លាស់ប្ដូរសារលិខិតដែលលោកបានរៀបចំ ឲ្យទៅជាការថ្លែងទៅកាន់ក្មេងស្រីម្នាក់នៅអំឡុងពេលសន្និសីទទូទៅមួយទៅវិញ ៖



« នៅជួរខាងឆ្វេងដៃរបស់ខ្ញុំនេះ ខ្ញុំឃើញក្មេងស្រីស្រស់សោភាម្នាក់ប្រហែលជាអាយុដប់ឆ្នាំ ។ ក្មេងស្រីដ៏តូចអើយ ខ្ញុំពុំស្គាល់ឈ្មោះរបស់ប្អូន ឬ ថាតើប្អូនរស់នៅទីណានោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំដឹងថា ៖ ស្នាមញញឹមដ៏បរិសុទ្ធ និង មនោសញ្ចេតនាដែលចេញពីកែវភ្នែករបស់ប្អូន បានបណ្ដាលឲ្យចិត្តខ្ញុំ ទុកសារលិខិតដែលបានរៀបចំសម្រាប់សន្និសីទនេះ ចោលមួយអន្លើសិន ។ ថ្ងៃនេះ ខ្ញុំមានសេចក្ដីរីករាយដើម្បីថ្លែងទៅកាន់ប្អូន » ។

បន្ទាប់មក ប្រធាន ម៉នសុន បានចែកចាយបទពិសោធន៍ដែលបានពង្រឹងការយល់ដឹងរបស់លោកអំពីសេចក្ដីស្រឡាញ់ដ៏មហិមា ដែលព្រះយេស៊ូវគ្រីស្ទមានសម្រាប់កុមារ ។ លោកបានមានប្រសាសន៍អំពីក្មេងស្រីអាយុ ១០ ឆ្នាំម្នាក់ឈ្មោះ គ្រីស្ដល មែតវិន ដែលបានរស់នៅជាមួយគ្រួសារនាងក្នុងស្ដេក ស្រ្បីវផត លូវីស្យ៉ាអាណា ។ គ្រីស្ដល មានជំងឺមហារីកដែលបានរីករាលដាលដល់សួតទាំងពីររបស់នាង ។ « គ្រួសារ មែតវិន ពុំបានអស់សង្ឃឹមឡើយ ផ្ទុយទៅវិញ បានគ្រោងជិះយន្តហោះមកកាន់ទីក្រុង សលត៍ លេក ។ គ្រីស្ដល អាចទទួលបានការប្រសិទ្ធពរពីពួកអ្នកមានសិទ្ធិអំណាចទូទៅម្នាក់ ។ គ្រួសារ មែតវិន ពុំបានស្គាល់ពួកបងប្អូនប្រុសណាម្នាក់ដោយផ្ទាល់នោះទេ ដូច្នេះ ក៏បានបើករូបភាពនៃពួកអ្នកមានសិទ្ធិអំណាចទូទៅឲ្យគ្រីស្ដល ធ្វើការជ្រើសរើស ។ ដោយគាប់ជួន ឈ្មោះរបស់ខ្ញុំត្រូវបានជ្រើសរើស ។

« គ្រីស្តល ពុំអាចជិះយន្តហោះមកកាន់ទីក្រុង សលត៍ លេក ឡើយ ។ ស្ថានភាពរបស់នាងបានកាន់តែយ៉ាប់យឺនទៅៗ ។ ភាគរយសង្ឃឹមរស់មានតិចតួចណាស់ ។ ប៉ុន្តែ សេចក្តីជំនឿរបស់នាងពុំងាករេឡើយ ។ នាងបានពោលទៅកាន់ឪពុកម្តាយនាងថា ‹ តើសន្និសីទស្តេកនឹងប្រព្រឹត្តទៅក្នុងពេលឆាប់ៗនេះមែនទេ ? តើអ្នកមានសិទ្ធិអំណាចទូទៅត្រូវបានចាត់មកដែរឬទេ ? ហើយហេតុអ្វីបងប្រុស ម៉នសុន មិនត្រូវបានចាត់ ? បើខ្ញុំមិនអាចធ្វើដំណើរទៅជួបលោកបានទេនោះ ព្រះអម្ចាស់អាចបញ្ជូនលោកឲ្យមកឯខ្ញុំវិញ › ។

« ទន្ទឹមនឹងពេលនោះដែរ នៅទីក្រុង សលត៍ លេក ខ្ញុំពុំបានដឹងថា មានអ្វីកំពុងកើតឡើងនៅទីកុង្រ ស្រ្យឺវផត ទេ ហើយស្ថានភាពមិនប្រក្រតីមួយបានកើតឡើង ។ ដ្បិតអំឡុងចុងសប្តាហ៍នៃសន្និសីទទូទៅនៃស្តេក ស្រ្យឺវផត លូវីស្សីអាណា ខ្ញុំត្រូវបានចាត់ទៅទីក្រុង អែល ប៉ាសូ រដ្ឋ តិចសាស់ ។ ប្រធាន អ៊ែសរ៉ា ថាហ្វ បែ៊នសឹន បានហៅខ្ញុំទៅការិយាល័យរបស់លោក ហើយបានពន្យល់ថា មានពួកបងប្អូនប្រុសម្នាក់ទៀតបានបង្ហើយកិច្ចការរៀបចំមួយចំនួនដើម្បីបំបែកស្តេកក្នុងទីក្រុង អែល ប៉ាសូ ហើយ ។ លោកបានសួរ ថាតើខ្ញុំប្រកាន់ដែរឬទេ បើមានពួកបងប្អូនប្រុសម្នាក់ផ្សេងទៀតត្រូវបានចាត់ឲ្យទៅទីក្រុង អែល ប៉ាសូ ហើយខ្ញុំត្រូវបានចាត់ឲ្យទៅកន្លែងផ្សេងនោះ ។ ប្រាកដណាស់ ពិតជាមិនមានបញ្ហាអ្វីឡើយសម្រាប់ខ្ញុំ—ទីណាក៏បានសម្រាប់ខ្ញុំ ។ ប្រធាន បែ៊នសឹន បានមានប្រសាសន៍ថា ‹ បងប្រុស ម៉នសុន ខ្ញុំទទួលអារម្មណ៍យ៉ាងខ្លាំងដើម្បីចាត់លោកឲ្យទៅស្តេក ស្រ្យឺវផត លូវីស្សីអាណា › ។ ខ្ញុំក៏បានទទួលយកការចាត់តាំងនោះ ។ ថ្ងៃនោះបានមកដល់ ។ ខ្ញុំបានទៅដល់ទីក្រុង ស្រ្យឺវផត ។

« នៅរសៀលថ្ងៃសៅរ៍នោះ បានរវល់ទៅដោយការប្រជុំជាច្រើន ។. . . លោកប្រធានស្តេក ឆាលស៍ អេហ្វ ខេហ្គល បានសួរថាតើកាលវិភាគខ្ញុំអាចអនុញ្ញាតឲ្យខ្ញុំផ្តល់ការប្រសិទ្ធពរដល់ក្មេងស្រីអាយុដប់ឆ្នាំ ដែលរងទុក្ខដោយជំងឺមហារីកបានដែរឬទេ ។ នាងមានឈ្មោះថា ៖ គ្រីស្តល មែតវិន ។ ខ្ញុំបានឆ្លើយថា ខ្ញុំអាចផ្តល់ការប្រសិទ្ធពរឲ្យបាន តែបើអាចធ្វើទៅបាន សូមយកនាងមកកាន់សន្និសីទ ឬ តើនាងកំពុងស្នាក់នៅមន្ទីរពេទ្យ ស្រ្យឺវផត មែនទេ ? ដោយដឹងថា កាលវិភាគរបស់ខ្ញុំមានភាពមមាញឹកនោះ ប្រធាន ខេហ្គល និយាយប្រាប់ខ្ញុំទាំងខ្លាចចិត្តថា គ្រីស្តលត្រូវស្នាក់នៅផ្ទះរបស់នាងឯណោះ—*ដែលមានចម្ងាយជាងមួយរយម្ភៃប្រាំបីគីឡូម៉ែតឯណោះពីទីក្រុង ស្រ្យឺវផត !*

« ខ្ញុំបានពិនិត្យមើលកាលវិភាគនៃការប្រជុំទាំងឡាយនៅល្ងាចនោះ និង នៅព្រឹកបន្ទាប់—រួមទាំងការហោះហើរត្រឡប់ទៅវិញផងដែរ ។ ពុំមានពេលអាចធ្វើទៅបាននោះទេ ។ យោបល់ដែលអាចទៅរួចមួយបានលេចឡើងក្នុងគំនិតខ្ញុំ ។ តើយើងមិនអាចចងចាំពីក្មេងស្រីដ៏តូចនោះបាននៅក្នុងការអធិស្ឋានជាសាធារណៈក្នុងសន្និសីទទេឬ ? ប្រាកដណាស់ ព្រះអម្ចាស់ទ្រង់នឹងព្រះតម្រិះ ។ យើងបានធ្វើតាមដំណើរការនេះនៅក្នុងកាលវិភាគការប្រជុំ ។

« នៅពេលដំណឹងនេះត្រូវបានជម្រាបដល់គ្រួសារ មែតវិន ពួកគេមានការយោគយល់ ប៉ុន្តែ ទន្ទឹមនឹងនោះក៏មានការខកចិត្តបន្តិចបន្តួចដែរ ។ តើព្រះអម្ចាស់មិនបានឮសម្រែកការអធិស្ឋានរបស់ពួកគេទេឬអី ? តើទ្រង់មិនបានប្រទានបងប្រុស ម៉នសុន ឲ្យមកទីក្រុង ស្រ្យឺវផត ទេឬអី ? គ្រួសារនោះបានអធិស្ឋានម្តងទៀត ដោយសុំក្តីមេត្តាជាលើកចុងក្រោយ—ថាគ្រីស្តលដ៏មានតម្លៃរបស់ពួកគេអាចសម្រេចបានគោលបំណងរបស់នាង ។

« នៅគ្រាដែលគ្រួសារ មែតវិន បានលុតជង្គង់ចុះអធិស្ឋាននោះ ទ្រនិចនាឡិកានៅក្នុងមជ្ឈមណ្ឌលស្តេក បានចង្អុលប្រាប់ថាម៉ោង ៧:៤៥ ។ ការប្រជុំថ្នាក់ដឹកនាំបានប្រព្រឹត្តទៅដោយការបំផុសគំនិត ។ ខ្ញុំបានរៀបចំការឡើងនិយាយរបស់ខ្ញុំហើយបានត្រៀមខ្លួនឡើងលើវេទិកា ស្រាប់តែមានសំឡេងមួយថ្លែងមកកាន់វិញ្ញាណរបស់ខ្ញុំ ។ សារលិខិតនោះខ្លី ហើយពាក្យពេចន៍មានន័យស្រដៀងនេះថា ៖ ‹ ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរព្រះមានសុទ្ធតែមនុស្ស ដូចវារាល់គ្នាដែរ › ។ ( ម៉ាកុស ១០:១៤ ) ។ អត្ថបទឡើងនិយាយរបស់ខ្ញុំប្រែជាស្រពិចស្រពិល ។ គំនិតរបស់ខ្ញុំបែរជាទៅចាប់អារម្មណ៍លើក្មេងស្រីដែលត្រូវការការប្រសិទ្ធពរទៅវិញ ។ ខ្ញុំបានធ្វើការសម្រេចចិត្ត ។ កាលវិភាគប្រជុំត្រូវបានកែប្រែ ។ មនុស្សសំខាន់ជាងការប្រជុំណាៗទាំងអស់ ។. . .

« ខ្ញុំនឹងចងចាំជានិច្ច ហើយមិនដែលភ្លេចការធ្វើដំណើរនាព្រឹកព្រលឹមនោះ ទៅកាន់ស្ថានសួគ៌ដែលក្រុមគ្រួសារមែតវិនហៅថាជាគេហដ្ឋាន ។. . .

« ក្រុមគ្រួសារនោះបានឈរជុំវិញគ្រែរបស់គ្រីស្តល ។ ខ្ញុំបានសម្លឹងទៅកុមារដែលឈឺធុនដាបមិនអាចក្រោកបាន—ដែលស្ទើរតែមិនអាចនិយាយបានផងនោះ ។ ជំងឺរបស់នាងបានធ្វើឲ្យនាងមើលអ្វីមិនឃើញឡើយ ។ ខ្ញុំមានព្រះវិញ្ញាណខ្លាំងក្រៃកាលខ្ញុំលុតជង្គង់ចុះ ចាប់កាន់ដៃដ៏ទន់ខ្សោយរបស់នាង ហើយបានពោលថា ‹ គ្រីស្តល ខ្ញុំនៅទីនេះហើយ › ។ នាងបានហើបមាត់ ហើយពោលដោយខ្សាវៗថា ‹ បងប្រុស ម៉នសុន ខ្ញុំពិតជាដឹងថា លោកប្រាកដជាមក › ។ ខ្ញុំបានមើលទៅជុំវិញបន្ទប់ ។ គ្មាននរណាម្នាក់បានឈរនោះទេ ។ ម្នាក់ៗបានលុតជង្គង់ចុះ ។ ខ្ញុំបានផ្តល់ការប្រសិទ្ធពរ ។ ស្នាមញញឹមតិចៗបានលេចឡើងលើទឹកមុខរបស់គ្រីស្តល ។ នៅពេលបញ្ចប់ការប្រសិទ្ធពរ នាងបានពោលខ្សាវៗថា ‹ អរគុណ › ។. . .

« បួនថ្ងៃក្រោយមក គឺនៅថ្ងៃ ព្រហស្បត្តិ៍ នៅពេលសមាជិកសាសនាចក្រនៅទីក្រុង ស្រ្យឺវផត បានចូលរួមកម្សាន្តចិត្តជាមួយគ្រួសារ មែតវិន ហើយឈ្មោះរបស់គ្រីស្តល ត្រូវបានគេចងចាំនៅក្នុងការអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ដ៏សប្បុរស និង ជាទីស្រឡាញ់ នោះវិញ្ញាណរបស់គ្រីស្តល មែតវិន បានចាកចោលរូបកាយដែលរាតត្បាតដោយជំងឺមហារីកនោះទៅ ហើយបានចូលទៅក្នុងទីសម្រាករបស់ព្រះ ។. . .

> « ខ្ញុំសូមថ្លែងទៅកាន់អ្នក ឱមិត្តកុមារដ៏តូចរបស់ខ្ញុំដែលអង្គុយនៅជួរខាងលើអើយ និង ទៅដល់អ្នកជឿនៅគ្រប់ទីកន្លែង ខ្ញុំសូមថ្លែងសាក្សីថា ព្រះយេស៊ូវនៃណាសារ៉ែត ពិតជាមានព្រះទ័យស្រឡាញ់កុមារតូចៗ ថាទ្រង់ស្ដាប់ឮការអធិស្ឋាន ហើយឆ្លើយតបការអធិស្ឋានទាំងនោះ » ("The Faith of a Child," *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ២០–២២ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១១–១២ ដោយស្វែងរកថ្លៃលោះដែលព្រះអង្គសង្គ្រោះ យេស៊ូវគ្រីស្ទ បានបង់ដើម្បីប្រោសលោះយើង ។ ( ឃ្លា « មនុស្សលោកទាំងអស់ » សំដៅលើមនុស្សគ្រប់គ្នា—គ្រប់បុរស ស្ត្រី និង កុមារ ) ។ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១០–១១ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ អ្នកអាចនឹងចង់គូសចំណាំវានៅក្នុងរបៀបមួយដែលងាយសម្គាល់ ដើម្បីអ្នកអាចងាយរកវាឃើញកាន់តែស្រួល ) ។

ដោយសារតែតម្លៃនៃព្រលឹងនីមួយៗមហិមាណាស់ តើអ្នកគិតថា ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ មានព្រះទ័យដូចម្ដេច នៅពេលនរណាម្នាក់ប្រែចិត្ត ហើយទទួលយកពលិកម្មរបស់ព្រះអង្គសង្គ្រោះ ? សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៣ រួចស្វែងរកការឆ្លើយតបរបស់ព្រះអម្ចាស់ ។ សូមពិចារណាអំពីមូលហេតុដែលថា កាលយើងប្រែចិត្តនោះ គឺយើងនាំយកសេចក្ដីអំណរថ្វាយព្រះអម្ចាស់ ។

យើងរៀនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៤ ថា ព្រះអម្ចាស់បានហៅ អូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ ឲ្យ « ស្រែកប្រាប់ពីការប្រែចិត្តដល់ប្រជាជននេះ » ។ អែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ថា ៖ « ការស្រែកប្រាប់ពីការប្រែចិត្ត មានន័យយ៉ាងសាមញ្ញថា ជាការជួយមនុស្សឲ្យត្រឡប់មកករកព្រះវិញ » ( "Preparing for Your Spiritual Destiny" [ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១០ ] ទំព័រ ៧ speeches.byu.edu) ។

> ***មករកព្រះគ្រីស្ទ***
>
> ការ « មករកព្រះគ្រីស្ទ » មានន័យថា មានសេចក្ដីជំនឿលើទ្រង់ រក្សាព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ធ្វើសេចក្ដីសញ្ញាជាមួយព្រះ ហើយប្រែចិត្តនៅពេលយើងធ្វើកំហុស ( សូមមើល ម៉ូរ៉ូណៃ ១០:៣២–៣៤ ) ។

២. សូមធ្វើបញ្ជីដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមធ្យោបាយមួយចំនួនដែលយុវវ័យអាចជួយនរណាម្នាក់ឲ្យប្រែចិត្ត ឬ ត្រៀមខ្លួនត្រឡប់មកករកព្រះវិញ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៥–១៦ ដោយរកមើលពីអ្វីដែលបុគ្គលម្នាក់ៗទទួលបទពិសោធន៍ នៅពេលពួកគេជួយមនុស្សម្នាក់ឲ្យមករកព្រះយេស៊ូវគ្រីស្ទ ។ (គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៥–១៦ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ អ្នកអាចនឹងចង់គូសចំណាំវានៅក្នុងរបៀបមួយដែលងាយសម្គាល់ ដើម្បីអ្នកអាចងាយរកវាឃើញកាន់តែស្រួល ) ។ សូមបំពេញគោលការណ៍ដូចតទៅនេះ ដោយផ្អែកទៅលើការសន្យារបស់ព្រះអម្ចាស់នៅក្នុងខគម្ពីរទាំងនេះ ៖ **ប្រសិនបើយើងជួយមនុស្សដទៃឲ្យប្រែចិត្ត ហើយមករកព្រះអម្ចាស់ លំដាប់នោះសេចក្ដីអំណររបស់យើង** ។

៣. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីបទពិសោធន៍មួយដែលអ្នក ឬ នរណាម្នាក់ដែលអ្នកស្គាល់ បានទទួលបទពិសោធន៍នៃសេចក្ដីអំណរក្នុងការជួយមនុស្សឲ្យប្រែចិត្ត ឬ កាន់តែរីកចម្រើនទៅជិតព្រះអម្ចាស់ ។ ក៏សូមសរសេរអំពីការណ៍មួយ ដែលអ្នកនឹងធ្វើដើម្បីជួយក្នុងកិច្ចការជួយសង្គ្រោះព្រលឹងផងដែរ ។ សូមពិចារណាអំពីបុគ្គលជាក់លាក់ទាំងឡាយដែលអ្នកអាចនឹងជួយ ។

## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១០–១១

សូមសរសេរពាក្យពេចន៍ដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១០–១១ ដាក់នៅលើបណ្ណ ឬ ក្រដាសមួយសន្លឹកតូច ។ សូមដាក់វាតាមខ្លួនអ្នក ហើយបើកមើលវាយូរៗម្ដង ពេញមួយថ្ងៃ ដើម្បីជួយអ្នកឲ្យចងចាំពីតម្លៃរបស់អ្នក និង តម្លៃរបស់មនុស្សដទៃចំពោះព្រះនេត្ររបស់ព្រះ ។

៤. សូមសរសេរឃ្លាដូចតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ដោយសរសេរឈ្មោះរបស់អ្នកនៅក្នុងចន្លោះទាំងឡាយ ៖ **តម្លៃនៃ  គឺមហិមាណាស់ ទើបព្រះយេស៊ូវគ្រីស្ទ បានរងទុក្ខ ហើយសុគត ដើម្បី  អាចប្រែចិត្ត ហើយត្រឡប់ទៅឯព្រះវរបិតាសួគ៌វិញ** ។ បន្ទាប់មកសូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើការស្គាល់ពីសេចក្ដីពិតនេះ អាចមានអានុភាពលើរបៀបដែលអ្នកមើលឃើញពីខ្លួនឯងយ៉ាងដូចម្ដេចដែរ ?

ខ. តើការចងចាំពីថ្លៃលោះដែលព្រះយេស៊ូវគ្រីស្ទបានបង់សម្រាប់ព្រលឹងនៃមនុស្សដទៃ មានឥទ្ធិពលលើរបៀបដែលអ្នកប្រព្រឹត្តចំពោះពួកគេយ៉ាងដូចម្ដេចដែរ ?

## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៥–១៦

សូមសុំជំនួយពីសមាជិកគ្រួសារ ឬ មិត្តភក្ដិម្នាក់ដើម្បីជួយអ្នកទន្ទេញ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៥–១៦ ។ សូមឲ្យម្នាក់ចាប់ផ្ដើមជាមួយឃ្លាទីមួយនៃវគ្គចំណេះចំណានខគម្ពីរ ដូចមានបង្ហាញខាងក្រោម ។ បន្ទាប់មក មនុស្សម្នាក់ទៀតនឹងព្យាយាមសូត្រឃ្លាទីមួយឡើងវិញចេញពីការចងចាំ រួចក្រោយមកបន្ថែមឃ្លាបន្ទាប់ទៀត ។ សូមធ្វើដំណើរការនេះម្ដងហើយម្ដងទៀត ដោយផ្លាស់គ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ដោយសូត្រឃ្លាមុនៗ រួចបន្ថែមឃ្លានៃវគ្គបទគម្ពីរមួយឃ្លាម្ដងៗ រហូតដល់អស់ ។ អ្នកអាចនឹងចង់ធ្វើដំណើរការនេះម្ដងហើយម្ដងទៀត រហូតដល់អ្នកបានសូត្រវគ្គបទគម្ពីរនេះចប់បានបួនប្រាំដង ។

« ហើយបើសិនជាអ្នកត្រូវធ្វើការអស់មួយជីវិតអ្នក »

« ដោយស្រែកប្រាប់ពីការប្រែចិត្តដល់ប្រជាជននេះ »

« ហើយគ្រាន់តែនាំព្រលឹងតែមួយគត់មករកយើង »

« នោះអ្នកនឹងមានសេចក្ដីអំណរដ៏មហិមាជាមួយអ្នកនោះ »

« នៅក្នុងនគរនៃព្រះវរបិតារបស់យើង ! »

« ហើយឥឡូវនេះ បើសិនជាអ្នកនឹងមានសេចក្ដីអំណរដ៏មហិមាដល់ព្រលឹងតែមួយ »

« ហើយយ៉ាងណាទៅ ដែលអ្នកបាននាំមករកយើង »

« នៅក្នុងនគរនៃព្រះវរបិតារបស់យើង »

« នោះអ្នកនឹងមានសេចក្ដីអំណរដ៏មហិមា »

« បើសិនជាអ្នកបាននាំព្រលឹងជាច្រើនមករកយើង ! »

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន អំពីអ្វីដែលអ្នកបានទន្ទេញចាំពីវគ្គចំណេះចំណានខគម្ពីរនេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៧–២៥

*ព្រះយេស៊ូវគ្រីស្ទ បង្រៀន អូលីវើរ ខៅឌើរី និង ដាវីឌ វិតមើរ អំពីព្រះចេស្ដានៃព្រះនាមទ្រង់*

សូមគិតអំពីគោត្តនាម ( នាមត្រកូល ) របស់អ្នកមួយភ្លែត ។ តើអ្នកធ្លាប់ពិចារណាអំពីពរជ័យ និង ការទទួលខុសត្រូវទាំងឡាយដែលកើតឡើងពីការមានឈ្មោះរបស់អ្នក និង ការធ្វើជាកម្មសិទ្ធិរបស់ក្រុមគ្រួសារអ្នកដែរឬទេ ? ឯកសិទ្ធិទាំងនេះមួយចំនួន អាចរួមបញ្ចូលទាំងសេចក្ដីស្រឡាញ់ និង ការទទួលយក ទីកន្លែងរស់នៅ សុវត្ថិភាព និង មនុស្សមើលថែអ្នក ។ ការទទួលខុសត្រូវរបស់អ្នក អាចរួមបញ្ចូលទាំងការប្រព្រឹត្តដោយការគោរពចំពោះសមាជិកគ្រួសារ ការធ្វើការងារផ្ទះ និង ការធ្វើឲ្យគ្រួសារមានឈ្មោះល្អ ។

ទោះជាអ្នកពុំមានគ្រួសារល្អ និង មានអារម្មណ៍ថា ឈ្មោះគ្រួសារអ្នកពុំសំខាន់ក៏ដោយ ក៏អ្នកបានលើកដាក់មកលើខ្លួនរបស់អ្នកនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ កាលអ្នកបានទទួលបុណ្យជ្រមុជទឹកដែរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១៧–២៥ រួចស្វែងរកឯកសិទ្ធិ និង ការទទួលខុសត្រូវទាំងឡាយ ដែលកើតឡើងពីការលើកដាក់មកលើខ្លួនអ្នកនូវព្រះនាមរបស់ទ្រង់ ។ សូមសរសេរចម្លើយរបស់អ្នកនៅក្នុងតារាងខាងក្រោមនេះ ៖

| ឯកសិទ្ធិ | ការទទួលខុសត្រូវ |
|---|---|
| | |

យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:២៣ ហេតុអ្វីបានជាចាំបាច់សម្រាប់យើងក្នុងការលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ?

៦. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបមួយចំនួនដែលអ្នកអាចធ្វើឲ្យមនុស្សដទៃដឹងថា អ្នកបានលើកដាក់មកលើខ្លួនអ្នកនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:២៦-៤៧

*ព្រះអម្ចាស់បើកសម្ដែងអំពីការហៅ និង បេសកកម្មនៃពួកសាវកដប់ពីនាក់*

នៅក្នុងសន្និសីទដំបូងក្នុងនាមជាសាវកដែលទើបតែបានហៅ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន បានមានប្រសាសន៍ថា ៖



« ប្រាកដណាស់ វាគឺជាសេចក្ដីរីករាយ និង សេចក្ដីអំណរដ៏ធំដែលខ្ញុំមានឱកាសដូចជានីហ្វៃបានថ្លែង ដើម្បី ‹ និយាយអំពីព្រះគ្រីស្ទ. . .អររីករាយក្នុងព្រះគ្រីស្ទ. . .ផ្សាយអំពីព្រះគ្រីស្ទ [ និង ] ព្យាករអំពីព្រះគ្រីស្ទ › (នីហ្វៃទី២ ២៥:២៦) នៅគ្រប់ទីកន្លែងដែលខ្ញុំនឹងទៅ និង គ្រប់មនុស្សដែលខ្ញុំនឹងជួបដរាបដល់ខ្ញុំឃើញថា នេះជាវិនាទីចុងក្រោយនៃដង្ហើមជីវិតរបស់ខ្ញុំ ។ ប្រាកដណាស់ គ្មានគោលបំណង ឬ ឯកសិទ្ធិណាប្រសើរជាង ‹ [ សាក្សី ] ពិសេសអំពីព្រះនាមនៃព្រះគ្រីស្ទនៅពេញសព្វក្នុងពិភពលោក › នោះទេ (គ. និង ស. ១០៧:២៣) ។

« . . .លើសពីពាក្យសម្ដី និង ការបង្រៀន និង ទីបន្ទាល់ដែលបានថ្លែងរបស់ខ្ញុំ នោះជីវិតរបស់ខ្ញុំក៏ត្រូវតែជាផ្នែកក្នុងទីបន្ទាល់នៃព្រះយេស៊ូវគ្រីស្ទនោះដែរ ។ តួអង្គរបស់ខ្ញុំ ត្រូវតែឆ្លុះបញ្ចាំងអំពីទេវភាពនៃកិច្ចការនេះ ។ ខ្ញុំពុំអាចទទួលវាបានទេ បើអ្វីណាមួយដែលខ្ញុំនិយាយ ឬធ្វើ ដែលនឹងបង្អាក់សេចក្ដីជំនឿរបស់អ្នកទៅលើព្រះគ្រីស្ទ បង្អាក់សេចក្ដីស្រឡាញ់របស់អ្នកចំពោះសាសនាចក្រនេះ ឬបង្អាក់ការគោរពរបស់អ្នកចំពោះភាពជាសាវកដ៏បរិសុទ្ធនោះ ។

« ខ្ញុំសន្យានឹងអ្នក– ដូចខ្ញុំបានសន្យានឹងព្រះអម្ចាស់ និងបុរសទាំងនេះ–ថា ខ្ញុំនឹងព្យាយាមដើម្បីរស់នៅជំសក្ដិសមតាមទំនុកចិត្តនេះ ហើយបម្រើដោយពេញវង្វាស់នៃសមត្ថភាពរបស់ខ្ញុំ » (Miracles of the Restoration » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៤, ៣១ ) ។

ព្រះអម្ចាស់បានមានព្រះបន្ទូលអំពីការហៅ និង បេសកកម្មនៃពួកសាវកដប់ពីនាក់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:២៦-៣២, ៣៧-៤៧ ។

៧. យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:២៦-២៩ **ពួកសាវកដប់ពីនាក់ត្រូវបានហៅឲ្យផ្សាយ និងចាត់ចែងដំណឹងល្អទៅកាន់ពិភពលោកទាំងមូល ។** សូមអាន ខទី ៣០-៣២ រួចកត់ត្រានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីការណ៍ដទៃទៀត ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថាពួកសាវកដប់ពីនាក់ត្រូវធ្វើ ។

ហេតុអ្វីបានជាសំឡេងមួយចំនួនងាយស្រួលស្គាល់ជាងជាសំឡេងដទៃទៀត ? តើអ្នកធ្លាប់ឃើញថា វាមានការលំបាកក្នុងស្គាល់ព្រះសូរសៀងរបស់ព្រះអម្ចាស់កាលទ្រង់មានព្រះបន្ទូលមកកាន់អ្នកដែរឬទេ ?

យើងអាចស្ដាប់ឮព្រះសូរសៀងរបស់ព្រះអម្ចាស់បានតាមរយៈពួកអ្នកបម្រើទ្រង់ ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨ ព្រះអម្ចាស់បានពន្យល់ពីរបៀបបន្ថែម ដែលយើងអាចឮ ហើយស្គាល់ព្រះសូរសៀងរបស់ទ្រង់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:៣៤-៣៦, ៤៧ ដោយស្វែងរករបៀបសំខាន់មួយនេះ ដែលព្រះអម្ចាស់ទ្រង់ធ្វើការទាក់ទងមកយើង ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:៣៤ ឃ្លា « ព្រះបន្ទូលទាំងនេះ » សំដៅលើវិវរណៈទាំងឡាយ ដែលព្រះអម្ចាស់បានប្រទាន ដែលមានចែងនៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ។ យោងតាមខគម្ពីរទាំងនេះ តើអ្នកនឹងថ្លែងដូចម្ដេចទៅកាន់មនុស្សម្នាក់ ដែលចង់ដឹងពីរបៀបដែលយើងអាចឮព្រះអម្ចាស់មានព្រះបន្ទូលមកកាន់យើង ?

សូមសរសេរគោលការណ៍នេះដាក់នៅក្នុងព្រះគម្ពីររបស់អ្នក ឬ សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ **យើងអាចឮព្រះសូរសៀងនៃព្រះយេស៊ូវគ្រីស្ទ បាននៅពេលយើងអានព្រះគម្ពីរដោយនូវព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។**

យើងអាចឮព្រះសូរសៀងនៃព្រះអម្ចាស់តាមរបៀបនានា ដែលមិនមែនឮនៅក្នុងត្រចៀករបស់យើងនោះទេ ។ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ យើងអាចទទួលបានអារម្មណ៍ និង សារលិខិតចូលទៅក្នុងគំនិត និង ដួងចិត្តរបស់យើង ( សូមមើល គ. និង ស. ៨:២-៣ ) ។ អែលឌើរ អិម រ័សុល បាឡឺដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីនាក់បានបង្រៀនថា « នៅពេលយើងអាន ហើយសិក្សាអំពីវិវរណៈ នោះព្រះវិញ្ញាណអាចបញ្ជាក់នៅក្នុងដួងចិត្តរបស់យើងនូវសេចក្ដីពិតនៃអ្វីដែលយើងកំពុងស្វែងយល់ គឺតាមរបៀបនេះហើយ ដែលព្រះសូរសៀងនៃព្រះអម្ចាស់មានព្រះបន្ទូលមកកាន់យើងម្នាក់ៗ » ( “Marvelous Are the Revelations of the Lord,” *Ensign,* ខែ ឧសភា ឆ្នាំ ១៩៩៨ ទំព័រ ៣២ ) ។

សូមគិតអំពីបទពិសោធន៍មួយនៅពេលអ្នកទទួលអារម្មណ៍ថា ព្រះអម្ចាស់ទ្រង់បំផុសគំនិតអ្នកនៅពេលអ្នកអាន ឬ ពិចារណាអំពីបទគម្ពីរទាំងឡាយ ។ សូមពិចារណាទៅលើសំណួរខាងក្រោមនេះ ៖

- តើការដឹងថា ព្រះវិញ្ញាណបរិសុទ្ធអាចជួយអ្នកឲ្យស្ដាប់ឮព្រះសូរសៀងនៃព្រះអង្គសង្គ្រោះនៅពេលអ្នកអានព្រះបន្ទូលរបស់ទ្រង់ មានអានុភាពលើរបៀបដែលអ្នកពិចារណាអំពីបទគម្ពីរទាំងឡាយយ៉ាងដូចម្ដេច ?
- តើសេចក្ដីពិតនោះអាចបង្ហាញផ្លូវដល់អ្នកយ៉ាងដូចម្ដេច ដើម្បីជ្រើសរើសពេលវេលា ទីកន្លែង ឬ បរិយាកាសជុំវិញនៅពេលដែលអ្នកអានព្រះគម្ពីរ ?

៨. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៥ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១–២២

### សេចក្ដីផ្ដើម

នៅក្នុងខែមិថុនា ឆ្នាំ ១៨២៩ យ៉ូសែប ស្ម៊ីធ បានជួលម្ចាស់រោងពុម្ព ឈ្មោះ អ៊ែហ្គបើត ប៊ី ហ្គ្រានឌីន ដើម្បីបោះពុម្ពព្រះគម្ពីរចំនួន ៥០០០ ក្បាលក្នុងតម្លៃ ៣០០០ ដុល្លារ។ ទោះជាយ៉ាងណាក៏ដោយ ហ្គ្រានឌីន នឹងមិនចាប់ផ្ដើមបោះពុម្ព ឬសូម្បីតែទិញក្រដាសបោះពុម្ពឡើយ ទាល់តែគាត់ត្រូវបានអះអាងថា ទទួលបានប្រាក់បង់ថ្លៃសម្រាប់ការងារមុនសិន។ នៅក្នុងវិវរណៈ ដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩ ដែលទំនងជាត្រូវបានប្រទានឲ្យនៅរដូវក្ដៅឆ្នាំ ១៨២៩ នោះព្រះអម្ចាស់បានបញ្ជាម៉ាទិន ហារិសឲ្យ « ចំណាយផ្នែកនៃទ្រព្យសម្បត្តិរបស់អ្នក . . . [ហើយ] សងបំណុលដែលអ្នកបានយល់ព្រមជាមួយនឹងអ្នកបោះពុម្ព » (គ និង ស ១៩:៣៤–៣៥)។ ម៉ាទិន ហារិសផ្ទាល់បានធានាថានឹងសងការចំណាយថ្លៃបោះពុម្ពដោយខ្លួនគាត់ផ្ទាល់ ប្រសិនបើប្រាក់ដែលទទួលបានមកពីការលក់ព្រះគម្ពីរមរមន ពុំគ្រប់គ្រាន់សម្រាប់ការចំណាយទេនោះនោះគាត់នឹងកាត់ដីចម្ការគាត់ឲ្យខ្លះ ។

ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានពិពណ៌នាអំពីវិវរណៈនេះ ជាមួយនឹងការបង្រៀនរបស់វាអំពីដង្វាយធួនថាជា « វិវរណៈដ៏មហិមាមួយ ដែលត្រូវបានប្រទានឲ្យនៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ មានវិវរណៈមួយចំនួនដែលមាន [ សារៈសំខាន់ ] ច្រើនជាងនេះ » ( *Church History and Modern Revelation* វ៉ុល ២ [ ឆ្នាំ ១៩៥៣ ] ១:៨៥ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១–៣

*ព្រះអង្គសង្គ្រោះប្រកាសថា ទ្រង់បានសម្រេចតាមព្រះឆន្ទៈរបស់ព្រះបិតាហើយ*

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១–៣ រួចស្វែងរកការណ៍ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថា ទ្រង់ជានរណា ហើយទ្រង់បានធ្វើអ្វីខ្លះ ។ សូមគូសចំណាំពាក្យ ឬ ឃ្លាដែលបង្រៀនថា **ព្រះយេស៊ូវគ្រីស្ទបានសម្រេចតាមព្រះហឫទ័យនៃព្រះវរបិតាទ្រង់** ហើយថា **ព្រះយេស៊ូវគ្រីស្ទនឹងជំនុំជម្រះយើងតាមកិច្ចការទាំងឡាយរបស់យើង ។**

១. សូមពិពណ៌នាដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរអ្នកអំពីរបៀបដែលការស្គាល់សេចក្ដីពិតអំពីព្រះអង្គសង្គ្រោះ អាចនឹងជួយដល់ ម៉ាទិន ហារិស មានអារម្មណ៍សន្តិភាព និង ត្រូវបានប្រទានឲ្យនូវភាពរឹងមាំដើម្បីធ្វើតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៤–១២

*ព្រះយេស៊ូវគ្រីស្ទ ពន្យល់អំពីទារុណកម្មដ៏អស់កល្ប និងមិនចេះចប់*

ព្រះអម្ចាស់បានពន្យល់អំពីសេចក្ដីពិតមួយចំនួន ដែលអាចជួយយើងឲ្យយល់កាន់តែច្បាស់អំពីពលិកម្មធួនរបស់ទ្រង់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៤ រួចស្វែងរកពាក្យទាំងឡាយដែលនឹងបំពេញសេចក្ដីថ្លែងការណ៍នៃគោលលទ្ធិដូចតទៅនេះ ៖ **មនុស្សគ្រប់រូបត្រូវតែ បើមិនដូច្នេះទេនោះ** ។អ្នកអាចនឹងចង់គូសចំណាំឃ្លានេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។

សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៥ ។ តើព្រះអង្គសង្គ្រោះបានពិពណ៌នាយ៉ាងដូចម្ដេច អំពីសេចក្ដីវេទនានៃអស់អ្នកដែលពុំប្រែចិត្ត ហើយដោយហេតុនោះត្រូវទទួលការជំនុំជម្រះរបស់ទ្រង់នោះ ? តើការស្គាល់សេចក្ដីពិតនេះ ផ្ដល់នូវហេតុផលបន្ថែមមួយ ដើម្បីធ្វើឲ្យយើងប្រែចិត្តពីអំពើបាបរបស់យើងយ៉ាងដូចម្ដេច ?

សូមមើលត្រួសៗក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៦–៧ រួចស្វែងរកឃ្លាទាំងឡាយ ដែលជួនកាលត្រូវបានប្រើប្រាស់ដើម្បីពិពណ៌នាអំពីស្ថានភាពនៃមនុស្សដែលពុំប្រែចិត្ត ។ សូមគូសចំណាំឃ្លា « ការរងទុក្ខវេទនាដ៏មិនចេះចប់មិនចេះហើយ » និង « សេចក្ដីជាប់ទោសដ៏អស់កល្បជានិច្ច » ។ តើអ្នកគិតដូចម្ដេច នៅពេលអ្នកអានឃ្លាទាំងពីរនេះ ?

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៨–១២ ដោយស្វែងរកព័ត៌មានដើម្បីជួយអ្នកឲ្យយល់ពីមូលហេតុ ដែលឃ្លាទាំងនេះពុំសំដៅលើរយៈពេលដែលមនុស្សនឹងរងទុក្ខព្រោះអំពើបាបរបស់ខ្លួននោះទេ ។

**តើអ្នកសម្គាល់ឃើញថាពាក្យ « មិនចេះសូន្យឡើយ » គឺជាព្រះនាមរបស់ទ្រង់ដែរឬទេ ? ការណ៍នេះមានន័យថា « ទោសដ៏អស់កល្បជានិច្ច » ឬ « ទោសដ៏មិនចេះចប់មិនចេះហើយ » គឺជា « ទោសមកពីព្រះ » ។ តើអ្នកគិតថា « ទោសមកពីព្រះ » មានន័យដូចម្ដេច ?**



អែលឌើរ ជេម អ៊ី ថាល់មេហ្គ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ថា ៖ « នៅស្ថាននរក មានច្រកចេញមួយ ហើយក៏មានច្រកចូលមួយដែរ ។ ស្ថាននរកមិនមែនជាកន្លែងដែលចៅក្រមដែលចងគំនុំបញ្ជូនអ្នកទោសឲ្យទៅរងទុក្ខ និង ជាប់ទោសស្របតាមគោលការណ៍ ដើម្បីភាពរុងរឿងរបស់គាត់នោះទេ ប៉ុន្តែ វាគឺជាកន្លែងដែលរៀបចំឡើងឲ្យមានការបង្រៀន ការលុតដំចំពោះអ្នកដែលខកខានមិនបានរៀនកាលរស់នៅលើផែនដី គឺជាអ្វីដែលពួកគេគួរតែបានរៀន ។ ពិតណាស់ យើងបានអានអំពីទោសដ៏និរន្តរ៍ ការរងទុក្ខគ្មានទីបញ្ចប់ និង សេចក្ដីជាប់ទោសដ៏នៅអស់កល្បជានិច្ច ។ នោះគឺជាសំនួនវោហារគួរឲ្យខ្លាចញញើតមួយ ប៉ុន្តែ នៅក្នុងសេចក្ដីមេត្តាករុណារបស់ទ្រង់ ព្រះអម្ចាស់បានបើកសម្ដែងយ៉ាងច្បាស់អំពីអត្ថន័យនៃកន្សោមពាក្យទាំងនេះ ។ ទ្រង់មានព្រះបន្ទូលថា ‹ ទោសដ៏អស់កល្បជានិច្ច › គឺជាទោសមកពីព្រះ ដ្បិតទ្រង់គង់នៅដ៏អស់កល្បជានិច្ច ហើយស្ថានភាព ឬ សភាព ឬ លទ្ធភាពនោះ នឹងមានសម្រាប់អ្នកប្រព្រឹត្តអំពើបាប ដែលសមនឹងទទួល ហើយពិតជាត្រូវជាប់ទោសបែបនោះ ប៉ុន្តែ ការណ៍នេះពុំមានន័យថា អ្នកដែលរងទុក្ខ ឬ អ្នកប្រព្រឹត្តអំពើបាប ត្រូវទ្រាំទ្រ ហើយរងទុក្ខដ៏អស់កល្បជានិច្ច និង ដ៏និរន្តរ៍ឡើយ ។ គ្មាននរណាម្នាក់ នឹងត្រូវឃុំនៅក្នុងស្ថាននរកយូរជាងភាពចាំបាច់ដើម្បីនាំបុគ្គលនោះមកកាន់អ្វីមួយដែលល្អប្រសើរជាងនោះទេ ។ នៅពេលបុគ្គលនោះសម្រេចបានដំណាក់កាលនោះហើយ ច្រកចេញចូលស្ថានឃុំព្រលឹងនឹងបើកឡើង ហើយនឹងមានការស្រែកអបអរក្នុងចំណោមអ្នកដែលមកទទួលស្វាគមន៍បុគ្គលនោះចូលទៅឯដំណាក់កាលដែលប្រសើរជាងនេះ ។ ព្រះអម្ចាស់ពុំបន្ថយភាពតឹងរ៉ឹងក្នុងអ្វីដែលទ្រង់បានមានព្រះបន្ទូលកាលពីគ្រាកាន់កាប់ត្រួតត្រាដំបូងៗអំពីការអនុវត្តន៍នៃក្រឹត្យវិន័យ និង នៃដំណឹងល្អរបស់ទ្រង់ឡើយ ផ្ទុយទៅវិញ ទ្រង់បានបើកសម្ដែងឲ្យយើងដឹងយ៉ាងច្បាស់អំពីសេចក្ដីករុណា និង សេចក្ដីមេត្តារបស់ទ្រង់តាមរយៈការណ៍ដែលទ្រង់ធ្វើនេះ ដ្បិតវាគឺជាសិរីល្អ និង កិច្ចការទ្រង់ដើម្បីនាំមកឲ្យមានអមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » ( នៅក្នុង របាយការណ៍សន្និសីទ ខែ មេសា ឆ្នាំ ១៩៣០ ទំព័រ ៩៧ ) ។



ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានផ្ដល់ជាការយល់ដឹងជ្រៅជ្រះនេះថា ៖ « ទោសដដែលនេះតែងអនុវត្តត្រូវនឹងប្រភេទបទល្មើសដែលបានប្រព្រឹត្ត ស្របទៅតាមក្រឹត្យវិន័យនៃព្រះ ដែលជាអង្គដ៏នៅអស់កល្បជានិច្ច និង មិនចេះសូន្យឡើយ ដូចនេះ វាត្រូវបានហៅថា ទោសដ៏អស់កល្បជានិច្ច និង ទោសដ៏មិនចេះចប់មិនចេះហើយ ព្រោះវាគឺជាទោស ដែលព្រះបានបង្កើតដើម្បីសម្របតាមក្រឹត្យវិន័យដែលពុំអាចកែប្រែបាន ។ បុគ្គលម្នាក់អាចនឹងទទួលការរងទុក្ខវេទនាដ៏មិនចេះចប់មិនចេះហើយ ហើយកាលបុគ្គលនោះបានទទួលទារុណកម្មចំពោះការរំលងរបស់ខ្លួនហើយ គេនឹងត្រូវបានដោះលែង ប៉ុន្តែ ទោសនៅតែមាន ហើយទុកសម្រាប់អនុវត្តចំពោះអ្នកទោសក្រោយមកទៀត ហើយនឹងប្រព្រឹត្តអស់កាលជាអង្វែងទៅហោង » (*Doctrines of Salvation,* comp. Bruce R. McConkie វ៉ុល៣. [១៩៥៤–៥៦] ៣:១៥៨ ) ។

**ប្រធាន ជេ រ៉ូប៊ីន ក្លាក ក្នុងគណៈប្រធានទីមួយ បានផ្ដល់ជាការយល់ដឹងជ្រៅជ្រះបន្ថែមដោយការបង្រៀនអំពីលក្ខណៈសម្បត្តិដ៏ពិតរបស់ព្រះ ។ នៅពេលអ្នកអានការអត្ថាធិប្បាយរបស់គាត់ សូមគិតអំពីរបៀបដែលការយល់ដឹងពីលក្ខណៈសម្បត្តិរបស់ព្រះជួយយើងឲ្យយល់ពីទោសមកពីព្រះ ។**



« ខ្ញុំពុំអាចយល់ស្របនឹងគោលលទ្ធិថ្មីៗដែលប្រាប់ថា ព្រះពុំដាក់ទោសសោះឡើយនោះទេ ព្រោះខ្ញុំពុំអាចបោះបង់ចោលបទគម្ពីរទាំងឡាយដែលមាន ដើម្បីចាប់យកការសន្និដ្ឋាននោះឡើយ [ ប៉ុន្តែ ] ខ្ញុំទទួលអារម្មណ៍ថា នៅពេលព្រះអម្ចាស់យាងមកប្រទានរង្វាន់ដល់យើង. . . និង ដាក់ទោសយើង. . .នោះទ្រង់នឹងដាក់ទោសយើងយ៉ាងអប្បបរមាដែលអំពើរំលងរបស់យើងនឹងត្រូវបានធ្វើឲ្យសមហេតុផល ។ ខ្ញុំជឿថា ទ្រង់នឹងនាំមកដោយសេចក្ដីយុត្តិធម៌ទាំងអស់នៃក្ដីស្រឡាញ់ និងពរជ័យដ៏គ្មានទីបំផុត ព្រមទាំងក្ដីមេត្តាករុណា និងព្រះទ័យល្អ ហើយនឹងការយោគយល់ដែលទ្រង់បានមាន ។. . .

« ម្យ៉ាងទៀត ខ្ញុំជឿថា នៅពេលដល់ការប្រទានរង្វាន់ចំពោះទង្វើល្អរបស់យើង គឺទ្រង់នឹងប្រទានដល់យើងជាអតិបរមាតាមដែលអាចធ្វើបាន ដោយចាំក្នុងព្រះទ័យនូវទោស ដែលយើងបានប្រព្រឹត្ត » ( *"As Ye Sow . . . ,"* Brigham Young University Speeches of the Year [ ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៥៥ ] ទំព័រ ៦–៧ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៣–២២

*ព្រះអង្គសង្គ្រោះមានព្រះបន្ទូលអំពីការរងទុក្ខរបស់ទ្រង់ចំពោះអំពើបាប*

ព្រះអង្គសង្គ្រោះមានព្រះទ័យឲ្យជីវិតយើងមានពរ និង រីកចម្រើនតាមរយៈពលិកម្មធួនរបស់ទ្រង់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៣–១៧ រួចបំពេញសេចក្ដីថ្លែងការណ៍នេះ ៖ **អស់អ្នកដែលជ្រើសរើសមិនប្រែចិត្តនឹង** ___________ ។



អែលឌើរ នែល អេ ម៉ាក់ស្វែល ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានក្រើនរំឭកយើងថា យើងមានជម្រើសដែលត្រូវធ្វើ ៖ « យើងអាចសម្រេចយករបៀបរស់នៅដែលព្រះគ្រីស្ទមានក៏បាន ឬ របៀបរងទុក្ខដែលទ្រង់មានក៏បាន ! វាអាចនឹង ‹ ត្រូវរងទុក្ខដូចជាយើង › (គ និង ស ១៩:១៦–១៧) ឬយកឈ្នះ ‹ ដូចជា [ទ្រង់] . . . បានឈ្នះ › (វិវរណៈ ៣:២១)» (« Overcome . . . Even As I Also Overcame, » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៧, ទំព័រ ៧២ ) ។

សូមពិចារណាអំពីជម្រើសផ្ទាល់ខ្លួនរបស់អ្នក ។ តើជម្រើសទាំងនោះកំពុងដឹកនាំអ្នកទៅរកជីវិតដូចជាព្រះគ្រីស្ទដែរឬទេ ឬក៏ដឹកនាំអ្នកទៅរកការរងទុក្ខនាពេលអនាគតចំពោះអំពើបាបផ្ទាល់ខ្លួនរបស់អ្នក ?



ដំណើររឿងភាគច្រើនអំពីការរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទត្រូវបានតំណាលដោយមនុស្សផ្សេងទៀត ក្រៅពីព្រះអង្គទ្រង់ ( សូមមើល ម៉ាថាយ ២៦:៣៦–៣៩; លូកា ២២:៣៩–៤៤) ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩ មាននូវដំណើររឿងផ្ទាល់របស់ព្រះអង្គសង្គ្រោះ អំពីសេចក្ដីរងទុក្ខរបស់ទ្រង់ផ្ទាល់ ។

២. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៥, ១៨–១៩ រួចឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

   ក. តើព្រះអង្គសង្គ្រោះបានរៀបរាប់យ៉ាងដូចម្ដេច អំពីសេចក្ដីរងទុក្ខដែលទ្រង់បានមាននៅក្នុងសួនច្បារគែតសេម៉ានី ?

   ខ. តើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច អំពីការរងទុក្ខទោសរបស់ព្រះអង្គសង្គ្រោះចំពោះអំពើបាបរបស់អ្នក ?

   គ. តើការស្គាល់ពីសេចក្ដីរងទុក្ខរបស់ព្រះអង្គសង្គ្រោះ អាចជួយលើកទឹកចិត្តម៉ាទិន ហារីស ឲ្យប្រែចិត្តពីអំពើបាបរបស់គាត់យ៉ាងដូចម្ដេច ដូចជាអ្វីដែលព្រះអម្ចាស់បានណែនាំគាត់ឲ្យធ្វើនៅក្នុងវិវរណៈនេះ ?

៣. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២០ រួចឆ្លើយសំណួរខាងក្រោមនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

   ក. តើអ្នកគិតថា ហេតុអ្វីការគ្មានព្រះវិញ្ញាណបរិសុទ្ធ នឹងនាំទៅរកការរងទុក្ខដូច្នេះ ?

   ខ. ហេតុអ្វីបានជាវាអាចមានសារៈសំខាន់ដើម្បីចងចាំពីគ្រាទាំងឡាយ ដែលយើងត្រូវរងទុក្ខចំពោះលទ្ធផលនៃអំពើបាបរបស់យើង ?

សូមគិតអំពីគ្រាទាំងឡាយ ដែលអ្នកបានរងទុក្ខដោយសារតែអំពើបាបរបស់អ្នក ហើយបានទទួលអារម្មណ៍ថាត្រូវប្រែចិត្ត ។ នៅពេលអ្នកពិចារណាអំពីគ្រាទាំងនោះ សូមនឹកឡើងវិញពីពេលដែលអ្នកទទួលអារម្មណ៍ថាមានដៃគូព្រះវិញ្ញាណបរិសុទ្ធ និង ពេលដែលអ្នកទទួលអារម្មណ៍ថាព្រះវិញ្ញាណបរិសុទ្ធដកខ្លួនចេញពីអ្នក ។ តើអ្នកបានធ្វើដូចម្ដេចខ្លះ ដើម្បីបានរីករាយនឹងភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធសាជាថ្មី ?

៤. សូមប្រើ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៣–១៦, ២០ ដើម្បីឆ្លើយនឹងសំណួរដូចតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដែលបញ្ជាឲ្យប្រែចិត្ត បង្ហាញភស្តុតាងយ៉ាងដូចម្ដេច ចំពោះសេចក្ដីស្រឡាញ់របស់ទ្រង់ដែលមានសម្រាប់យើង ?

នៅពេលណាមួយអំឡុងសប្ដាហ៍ក្រោយ សូមចែកចាយទីបន្ទាល់របស់អ្នកជាមួយសមាជិកគ្រួសារ ឬ មិត្តម្នាក់ អំពីគោលលទ្ធិ ឬ គោលការណ៍មួយដែលអ្នកបានស្វែងយល់អំឡុងពេលសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១–២២ ។ សូមពិចារណាអំពីការស្ម័គ្រចិត្តចែកចាយបទពិសោធន៍ជាមួយគ្រូរបស់អ្នក ពេលជួបគាត់នៅពេលក្រោយ ។

*ការពន្យល់ ការចែកចាយ និង ការថ្លែងទីបន្ទាល់*

ការពន្យល់ពីគោលលទ្ធិ និង គោលការណ៍ ការចែកចាយពីគំនិត និង បទពិសោធន៍ដែលទាក់ទង និង ការធ្វើទីបន្ទាល់អំពីសេចក្ដីពិតដ៏ទេវភាពអាចបញ្ជាក់ពីការយល់ដឹងរបស់អ្នកអំពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អ ហើយបង្កើនសមត្ថភាពរបស់អ្នកក្នុងការបង្រៀនដំណឹងល្អដល់មនុស្សដទៃទៀត ។ នៅពេលអ្នកពន្យល់ ចែកចាយ ហើយថ្លែងទីបន្ទាល់ នោះព្រះវិញ្ញាណបរិសុទ្ធនឹងដឹកនាំអ្នកឲ្យមានទីបន្ទាល់កាន់តែរឹងមាំអំពីការណ៍ដែលអ្នកកំពុងតែបង្រៀននោះ ។

## ចំណេះចំណានខគម្ពីរ–គោលលទ្ធិ និងសេចក្ដីសញ្ញា ១៩:១៦–១៩

សូមធ្វើការទន្ទេញ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៦–១៩ ដោយសរសេរវគ្គចំណេះចំណានខគម្ពីរមួយពាក្យម្ដងៗនៅលើក្រដាសមួយសន្លឹក ។ ដោយប្រើក្រដាសរបស់អ្នក សូមអានវគ្គបទគម្ពីរឡេវៗឲ្យបានច្រើនដង ។ ក្រោយមក សូមបាំង ( ឬ លុប ) ពាក្យ ឬ ឃ្លាមួយចំនួនដែលមានសរសេរនៅលើក្រដាសរបស់អ្នកនោះ ។ សូមបន្តសូត្រវគ្គចំណេះចំណានខគម្ពីរដោយសូត្រទាំងកន្លែងដែលបាំងនោះចេញពីការចងចាំ ។ សូមធ្វើបែបនេះម្ដងហើយម្ដងទៀត រហូតដល់អ្នកមានអារម្មណ៍ថាអាចសូត្រវគ្គបទគម្ពីរបានទាំងអស់ ។

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន អំពីអ្វីដែលអ្នកបានទន្ទេញចាំពីវគ្គចំណេះចំណានខគម្ពីរនេះ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១–២២ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៥ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៣–៤១

## បុព្វកថា

នៅក្នុងបុព្វកថានៃមេរៀនមុន អ្នកបានរៀនថា ដើម្បីជានាដល់ អ៊ី ប៊ី ហ្គ្រានឌិន ចំពោះការបង់ថ្លៃនៃការបោះពុម្ពព្រះគម្ពីរមរមន ម៉ាទីន ហារិស បានចុះហត្ថលេខាលើកិច្ចសន្យាបញ្ចាំចម្ការរបស់គាត់មួយកន្លែង ។ នៅក្នុងផ្នែកទីពីរនៃវិវរណៈនេះ ដែលមានសម្រាប់ ម៉ាទិន ហារីស គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៣–៤១ ព្រះអម្ចាស់បានទូន្មានឲ្យ ម៉ាទីន ចំណាយទ្រព្យសម្បត្តិរបស់គាត់ដោយសេរីសម្រាប់ការបោះពុម្ពព្រះគម្ពីរមរមន ។ នៅទីបំផុត ម៉ាទីន បានលក់ចម្ការរបស់គាត់ទំហំ ៦១.១០ ហិចតា ដើម្បីបង់ថ្លៃឈ្នួលបោះពុម្ព ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៣–២៤

*ព្រះអង្គសង្គ្រោះថ្លែងទីទាល់ថា សេចក្ដីសុខសាន្តកើតចេញមកពីការរៀនអំពីទ្រង់*

តើមានពេលណា ដែលអ្នកត្រូវធ្វើនូវរឿងអ្វីមួយពិបាក ដែលអ្នកដឹងថាត្រឹមត្រូវ ប៉ុន្តែអ្នកពុំប្រាកដក្នុងចិត្ត ឬភ័យខ្លាចអំពីលទ្ធផលដែលវានឹងកើតឡើងនោះដែរឬទេ ? ( ឧទាហរណ៍ អ្នកអាចនឹងមានអារម្មណ៍ថាត្រូវនៅឲ្យឆ្ងាយពីមិត្តភក្តិមួយចំនួន ព្រោះពួកគេជះឥទ្ធិពលអាក្រក់មកលើអ្នក ) ។ តើអ្វីបានជួយអ្នកឲ្យមានសេចក្ដីជំនឿដើម្បីធ្វើនូវអ្វី ដែលអ្នកដឹងថាជារឿងត្រឹមត្រូវ ទោះជាវាមានការពិបាកយ៉ាងណាក្ដីនោះ ?

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើមានការណ៍ពិបាកៗមួយចំនួនណាខ្លះ ដែលអ្នកត្រូវបានស្នើឲ្យធ្វើ ឬ ជួនកាល អាចត្រូវបានស្នើឲ្យធ្វើដោយសារតែអ្នកជាសមាជិកសាសនាចក្រនោះ ? ហេតុអ្វីបានជាកិច្ចការទាំងនោះពិបាក ឬ ហេតុអ្វីបានជាកិច្ចការទាំងនោះនឹងពិបាកសម្រាប់អ្នកក្នុងការធ្វើ ?

ខ. តើអារម្មណ៍ និង ទង្វើរបស់អ្នក នឹងប្រែប្រួល អាស្រ័យទៅលើបុគ្គលដែលស្នើឲ្យអ្នកធ្វើនូវរឿងលំបាកនោះដែរឬទេ ? ហេតុអ្វីប្រែប្រួល ឬ ហេតុអ្វីមិនប្រែប្រួល ?

សូមអានក្បាលកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩ រួចគូសចំណាំពីអង្គ ដែលបានប្រទានព្រះបញ្ញត្តិ ដែលមាននៅក្នុងវិវរណៈនេះទៅដល់ ម៉ាទិន ហារីស ។ ប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពរបស់ ម៉ាទីន តើការដឹងថា ព្រះបញ្ញត្តិនេះ មកពីព្រះនឹងជួយដល់អ្នកយ៉ាងដូចម្ដេច ?

ម៉ាទិន ហារីស មានកង្វល់អំពីការដាក់បញ្ចាំចម្ការមួយចំណែករបស់គាត់ ដើម្បីបោះពុម្ពព្រះគម្ពីរមរមន ។ ព្រះអម្ចាស់ បានឆ្លើយតបចំពោះកង្វល់របស់ ម៉ាទីន ដោយការបើកសម្ដែងរឿងមួយចំនួន ដែលគាត់ចាំបាច់ត្រូវធ្វើ និងការណ៍មួយចំនួនដែលគាត់ចាំបាច់ត្រូវដឹង ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៣ រួចគូសចំណាំពីការសន្យារបស់ព្រះអម្ចាស់ទៅដល់ ម៉ាទិន ហារីស ។ ( គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៣ គឺជាវគ្គចំណេះចំណានខគម្ពីរ ) ។ អ្នកអាចសរសេរគោលការណ៍ដូចតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ **បើយើងរៀនអំពីព្រះគ្រីស្ទ ស្ដាប់តាមបន្ទូលទាំងឡាយរបស់ទ្រង់ ហើយដើរក្នុងភាពស្លូតបូតនៃព្រះវិញ្ញាណរបស់ទ្រង់ នោះយើងនឹងបានសេចក្ដីសុខសាន្ត ។**

២. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើនៅពេលណាដែលអ្នកធ្លាប់ទទួលអារម្មណ៍នៃភាពសុខសាន្តដែលបានសន្យានៅក្នុងគោលការណ៍នេះ នៅពេលអ្នកបានធ្វើការណ៍ផ្សេងៗដូចជា ការសិក្សាព្រះគម្ពីរ ការស្ដាប់សុន្ទរកថានៅក្នុងសន្និសីទទូទៅ និង ការប្រជុំដទៃទៀត ហើយពិចារណាអំពីពរជ័យទាំងឡាយនៃដំណឹងល្អ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៤ ដោយស្វែងរកអ្វីដែល ម៉ាទិន ហារីស បានរៀនអំពីព្រះយេស៊ូវគ្រីស្ទ ។ សូមពិចារណាអំពីរបៀបដែលការរៀនអំពីអ្វីទាំងនេះ អាចជួយអ្នកឲ្យទទួលអារម្មណ៍ភាពសុខសាន្ត នៅពេលអ្នកត្រូវបានស្នើឲ្យធ្វើកិច្ចការដ៏ពិបាកណាមួយសម្រាប់ព្រះអម្ចាស់ ។

### ចំណេះចំណានខគម្ពីរ–គោលលទ្ធិ និងសេចក្ដីសញ្ញា ១៩:២៣

៣. ដើម្បីជួយអ្នកឲ្យទន្ទេញចាំវគ្គចំណេះចំណានខគម្ពីរនេះ សូមសរសេរអក្សរពី ក ដល់ ឃ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ ក្រោយមក សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៣ ឲ្យបានច្រើនដងតាមដែលអាចធ្វើទៅបានក្នុងរយៈពេល ២ នាទី ។ ពេលដល់ម៉ោង សូមបិទព្រះគម្ពីររបស់អ្នក ហើយនៅជាប់នឹងអក្សរ ក–គ សូមសរសេរចំណុចបីដែលអ្នកត្រូវធ្វើ ។ បន្ទាប់មកនៅជាប់នឹងអក្សរ ឃ សូមសរសេរអ្វីដែលព្រះអម្ចាស់បានសន្យាថា យើងនឹងនឹងទទួលបានប្រសិនបើយើងធ្វើកិច្ចការទាំងបីនោះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៥–៣៥

*ព្រះអម្ចាស់បញ្ជា ម៉ាទីន ហារិស ឲ្យលក់ទ្រព្យសម្បត្តិរបស់គាត់ដើម្បីបោះពុម្ពព្រះគម្ពីរមរមន*

បន្ទាប់ពីបានសន្យា ម៉ាទិន ហារីស ដោយនូវភាពសុខសាន្តបន្ថែមលើការរៀនអំពីព្រះអង្គសង្គ្រោះ និង ការស្ដាប់តាមព្រះបន្ទូលទាំងឡាយរបស់ទ្រង់ហើយនោះ ព្រះអម្ចាស់បានប្រទានព្រះបញ្ញត្តិ និង ឱវាទបន្ថែមដល់គាត់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៦ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បានបញ្ជាឲ្យ ម៉ាទិន ហារីស ធ្វើ ។ ( ម៉ាទិន បានដាក់បញ្ចាំចម្ការទំហំ៦១.១០ ហិចតា ដែលបានធ្វើឲ្យការបោះពុម្ពព្រះគម្ពីរមរមនអាចដំណើរការបាន ) ។



សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៥–៣៥ ដោយស្វែងរកព្រះបញ្ញត្តិ និង ឱវាទ ដែលព្រះអម្ចាស់បានប្រទានដល់ ម៉ាទិន ហារីស ។ នៅពេលអ្នកអាន សូមស្វែងរក ហើយពិចារណាពីការគូសចំណាំឃ្លា « យើងបញ្ជា » និង « ចូរអ្នក » ។

ព្រះអម្ចាស់មានព្រះទ័យខ្វល់ខ្វាយពី ម៉ាទីន ហារិស ហើយបានប្រទានព្រះបញ្ញត្តិជាក់លាក់តាមស្ថានភាពនីមួយៗរបស់គាត់ ។ យើងពុំមានព័ត៌មានគ្រប់គ្រាន់ដើម្បីយល់ពីមូលហេតុដែលព្រះអម្ចាស់បានប្រទានព្រះបញ្ញត្តិជាក់លាក់ដល់ ម៉ាទីន ហារិស នោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់យ៉ាងច្បាស់នូវអ្វី ដែលនឹងកើតឡើង បើ ម៉ាទីន ពុំគោរពតាមព្រះបញ្ញត្តិទាំងឡាយទេនោះ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៣៣ ដោយស្វែងរកការណ៍ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថានឹងកើតឡើង បើ ម៉ាទីន « មិនអើពើដល់ពាក្យដំបូន្មានទាំងនេះ » ទេនោះ ? នៅក្នុងបរិបទនេះ ពាក្យ *មិនអើពើ* មានន័យថា មិនគោរពតាមអ្វីមួយ ដោយសារតែវាហាក់បីដូចជាពុំសំខាន់ ឬ ពុំសូវមានតម្លៃ ។ អ្នកអាចនឹងចង់សរសេរនិយមន័យនេះ នៅក្នុងព្រះគម្ពីររបស់អ្នកក្បែរពាក្យ *មិនអើពើ* ។

៤. សូមគិតអំពីព្រះបញ្ញត្តិមួយចំនួន និង ឱវាទ ដែលអ្នកបានទទួលពីព្រះអម្ចាស់តាមរយៈប្រសាសន៍របស់ពួកសាវក និង ព្យាការី ពរជ័យនៃបព្វជិតភាព ( រួមបញ្ចូលទាំងពររបស់លោកអយ្យកោ បើអ្នកមាន ) និង ថ្នាក់ដឹកនាំបព្វជិតភាព ។ សូមសរសេរដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលយើងចាំបាច់ត្រូវធ្វើតាមសេចក្ដីណែនាំនេះ ។



អែលឌើរ រ័សុល អិម ណិលសុន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានផ្ដល់ដំបូន្មានដូចតទៅនេះថា ៖ « សូមរក្សាព្រះបញ្ញត្តិ *ទាំងអស់* របស់ព្រះ ដោយដឹងថា ព្រះបញ្ញត្តិទាំងនោះត្រូវបានប្រទានឲ្យ ដើម្បីប្រទានពរដល់កូនចៅទ្រង់ និង នាំមកនូវសេចក្ដីអំណរដល់ពួកគេ ។ [ អ្នក ] នឹងជួបមនុស្សដែលរើសថា បទបញ្ញត្តិមួយណាដែលពួកគេនឹងរក្សា ហើយមិនអើពើនឹងបទបញ្ញត្តិផ្សេងទៀត ដែលពួកគេជ្រើសរើសមិនគោរពតាម ។ ខ្ញុំសូមហៅការណ៍នេះថាជាអាហារប៊ូហ្វេចំពោះការគោរពប្រតិបត្តិហើយ ។ ការអនុវត្តនៃការរើសពេក និងការជ្រើសរើសនេះ នឹងគ្មានបានការទេ ។ វានឹងនាំទៅរកសេចក្ដីវេទនា ។ ដើម្បីរៀបចំខ្លួនទៅជួបនឹងព្រះ បុគ្គលម្នាក់ត្រូវរក្សាព្រះបញ្ញត្តិរបស់ទ្រង់ *ទាំងអស់* ។ ដើម្បីគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងនោះ វាតម្រូវឲ្យមានសេចក្ដីជំនឿ ហើយការរក្សាព្រះបញ្ញត្តិទាំងឡាយ នឹងពង្រឹងសេចក្ដីជំនឿនោះ » ( « Face the Future with Faith » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៣៤ ) ។

សូមពិចារណាថាតើ អ្នកមានទំនោរមិនអើពើ ឬមិនគោរពចំពោះព្រះបញ្ញត្តិណាមួយ ដែលព្រះអម្ចាស់បានប្រទានដល់អ្នក និងថាតើមានព្រះបញ្ញត្តិជាក់លាក់ណាមួយ ដែលអ្នកអាចគោរពប្រតិបត្តិដោយមានការលះបង់កាន់តែច្រើនដែរឬទេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៣៦–៤១

*ព្រះអម្ចាស់ទូន្មានដល់ ម៉ាទីន ហារិស ស្ដីអំពីការបម្រើរបស់គាត់*

ដូចជា ម៉ាទីន ហារិស ផងដែរ យើងទាំងអស់គ្នាត្រូវតែសម្រេចចិត្តថាតើយើងនឹងចុះចូលឆន្ទៈរបស់យើងទៅតាមព្រះហឫទ័យរបស់ព្រះវរបិតាដែរឬទេ ទោះជាអ្វីដែលទ្រង់បានសុំឲ្យយើងធ្វើមានការលំបាកយ៉ាងណានោះ ។ ប្រធាន ថូម៉ាស អេស ម៉នសុន បានចែកចាយដំណើររឿងរបស់យុវជនម្នាក់ដែលបានសម្រេចចិត្តថាតើ គាត់ត្រូវចុះចូលឆន្ទៈរបស់គាត់នឹងព្រះហឫទ័យរបស់ព្រះវរបិតាដែរឬទេ ។ សូមអានផ្នែកទីមួយនៃដំណើររឿងនេះ រួចប្រៀបធៀបបទពិសោធន៍របស់យុវជននេះទៅនឹងបទពិសោធន៍របស់ ម៉ាទិន ហារីស ។



« ហូសេ ហ្គាសា មកពីប្រទេស ម៉ិកស៊ិក [ បាន ] កើតមកក្នុងភាពក្រីក្រ ប៉ុន្តែបានបីបាច់ដោយសេចក្ដីជំនឿ ហូសេ បានត្រៀមខ្លួនសម្រាប់ការហៅបម្រើបេសកកម្ម ។ ខ្ញុំបានមានវត្តមាននៅថ្ងៃ ដែលគាត់ទទួលបានអនុសាសន៍ ។ នោះមានសេចក្ដីថ្លែងការណ៍ថា៖ ‹ បងប្រុស ហ្គាសា នឹងបម្រើដោយការលះបង់ដ៏ធំធេងចំពោះគ្រួសាររបស់គាត់ ព្រោះគាត់ជាអ្នកផ្គត់ផ្គង់គ្រួសារ។ គាត់មានតែទ្រព្យមួយប៉ុណ្ណោះ–ជាការសន្សំតែមទុក– ដែលគាត់យល់ព្រមលក់វា បើចាំបាច់ ដើម្បីជួយរកថវិកាចេញបេសកកម្មរបស់គាត់ › ។

« ប្រធាន឵ ឃីមបឹល បានស្ដាប់ដោយយកចិត្តទុកដាក់ពេលសេចក្ដីថ្លែងនេះបានអានឲ្យលោកស្ដាប់ រួចហើយលោកបានតបថា ៖ ‹ ចូរឲ្យគាត់លក់តែមសន្សំរបស់គាត់ចុះ ។ ការលះបង់ដូច្នេះនឹងនាំមកនូវពរជ័យដល់គាត់ » (Profiles of Faith » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៧៨, ទំព័រ ៥៦ ) ។

៥. សូមឆ្លើយសំណួរដូចតទៅដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការសម្រេចចិត្តដ៏លំបាកៗ ដូចជាអ្វីដែល ហូសេ ចាំបាច់ត្រូវធ្វើនោះ អាចនឹងមានភាពកាន់តែងាយស្រួលយ៉ាងដូចម្ដេច បើយើងធ្លាប់មានបទពិសោធន៍នៃសេចក្ដីសុខសាន្តដែលមានមកពីការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ហើយនោះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:៣៦–៤១ ដោយស្វែងរកពាក្យ ឬ ឃ្លាដែលបង្រៀនពីគោលការណ៍ដូចតទៅនេះ ៖ **បើយើងធ្វើតាមព្រះហឫទ័យរបស់ព្រះអម្ចាស់ នោះទ្រង់នឹងប្រទានពរជ័យដល់យើង ដែលមានតម្លៃថ្លៃជាងទ្រព្យសម្បត្តិលើផែនដីទៅទៀត ។**

តើអ្នកគិតថា ពរជ័យអ្វីដែលមានតម្លៃថ្លៃជាងទ្រព្យសម្បត្តិលើផែនដីទៅទៀត ដែល ហូសេ នឹងទទួលបានតាមរយៈការបម្រើបេសកកម្មនោះ ? សូមអានសេចក្ដីបញ្ចប់នៃដំណើររឿងនេះ រួចស្វែងរកពរជ័យបន្ថែមដែល ហូសេ នឹងទទួលបានសម្រាប់ការអនុវត្តន៍គោលការណ៍នេះ ៖



« បន្ទាប់មក ដោយមានស្នាមញញឹមលើទឹកមុខ និងការព្រិចភ្នែក នោះព្យាការីដ៏ជាទីស្រឡាញ់រូបនេះ [ ប្រធាន ស្ពែនសើរ ដបុលយូ ឃីមបឹល ]បានមានប្រសាសន៍ថា ‹ រាល់ខែនៅការិយាល័យកណ្ដាលរបស់សាសនាចក្រ នោះយើងទទួលបានសំបុត្ររាប់ពាន់ពីគ្រប់ទីកន្លែងទាំងអស់លើពិភពលោក ។ ចូរយើងសន្សំតែមនោះទុក ហើយប្រគល់វាទៅឲ្យ ហូសេ នៅពេលគាត់បញ្ចប់បេសកកម្មរបស់គាត់ ។ គាត់នឹងមានតែមសន្សំដ៏ស្អាតបំផុតជាងយុវជនណាៗទាំងអស់ក្នុងប្រទេស មិកស៊ីក ដោយពុំត្រូវចំណាយប្រាក់ › » (Profiles of Faith, »ទំព័រ ៥៦ ) ។

សូមពិចារណាអំពីរបៀបដែលគោលលទ្ធិ ដែលអ្នកបានរៀនចេញពីមេរៀននេះ អាចជួយពង្រឹងឆន្ទៈរបស់អ្នកឲ្យចុះចូលទៅនឹងព្រះហឫទ័យរបស់ព្រះ ។

ម៉ាទិន ហារីស បានគោរពប្រតិបត្តិដោយដាក់បញ្ចាំចម្ការរបស់គាត់ មួយចំណែកដើម្បីចំណាយលើការបោះពុម្ពព្រះគម្ពីរមរមន ។ ដោយសារតែការជ្រើសរើសរបស់ ម៉ាទីន នោះជីវិតមនុស្សរាប់លាននាក់ ត្រូវបានប្រទានពរ ហើយនឹងនៅតែបន្តទទួលបានពរជ័យ ។ សូមពិចារណាអំពីអ្វីដែលអ្នកអាចធ្វើ ដើម្បីចុះចូលឆន្ទៈរបស់អ្នកទៅនឹងព្រះហឫទ័យរបស់ព្រះវរបិតាសួគ៌ឲ្យបានកាន់តែប្រសើរឡើង ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៣–៤១ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៦ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១–៣៦

## បុព្វកថា

« សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៅថ្ងៃចុងក្រោយទាំងនេះ [ ត្រូវបាន ] រៀបចំ និង តាំងឡើងស្របតាមច្បាប់របស់ [ សហរដ្ឋអាមេរិក ] » នៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០ ( គ. និង ស. ២០:១) ។ ក្នុងចំណោមសមាជិកសាសនាចក្រពីដំបូង មានវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២០ ត្រូវបានស្គាល់ថាជា « មាត្រា និង សេចក្ដីសញ្ញា » នៃសាសនាចក្រ ព្រោះវាបង្ហាញយ៉ាងពិស្ដារអំពីជំនឿ តំណែង ពិធីបរិសុទ្ធ និង ទម្រង់ការទាំងឡាយនៃសាសនាចក្រ ដែលទើបតែបានស្ដារឡើងវិញថ្មោងថ្មី ។ អមជាមួយ គោលលទ្ធិ និង សេចក្ដីសញ្ញា ២១–២២ ជាញឹកញាប់ កណ្ឌនេះត្រូវបានហៅថាជា « ធម្មនុញ្ញ » នៃសាសនាចក្រ ដែលបានស្ដារឡើងវិញ ។ ដោយសារតែប្រវែង និង មាតិការបស់វា នោះ គោលលទ្ធិ និង សេចក្ដីសញ្ញា ២០ ត្រូវបានបែងចែកចេញជាបីមេរៀន ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១–៤

*ព្រះបញ្ជាថា សាសនាចក្រនេះត្រូវស្ថាបនាឡើង*

សូមគិតអំពីការប្រជុំចុងក្រោយ ដែលអ្នកបានចូលរួម ដែលមានការថ្លែងទីបន្ទាល់ ។ ប្រសិនបើមិត្តភក្ដិម្នាក់ ដែលពុំមែនជាសមាជិកសាសនាចក្របានចូលរួមក្នុងការប្រជុំជាមួយអ្នក ហើយបានសួរថាតើទីបន្ទាល់គឺជាអ្វីនោះ តើអ្នកនឹងពន្យល់យ៉ាងដូចម្ដេច ?



សូមពិចារណាអំពីនិយមន័យនៃទីបន្ទាល់ដែលបានមានប្រសាសន៍ដោយ អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖ « ទីបន្ទាល់អំពីដំណឹងល្អ គឺជាសាក្សីផ្ទាល់ខ្លួនមួយ ដែលថ្លែងដល់ព្រលឹងយើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធថា ភាពពិតជាក់លាក់នៃសារៈសំខាន់ដ៏នៅអស់កល្បជានិច្ច គឺជាការពិត ហើយយើងដឹងថា វាជាការពិត » ( «Testimony » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ២៦ ) ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ២០ ត្រូវបានអានឮៗនៅក្នុងសន្និសីទមួយចំនួនរបស់សាសនាចក្រកាលពីជំនាន់ដំបូង ហើយមានតួនាទីជាការរំឭកដល់សមាជិកសាសនាចក្រ អំពីសេចក្ដីពិតដ៏ចាំបាច់ជាច្រើននៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១–២ ។ រួចសូមបំពេញគោលការណ៍ដូចតទៅនេះ ដោយបំពេញនៅក្នុងចន្លោះ ៖ **យ៉ូសែប ស៊្មីធ គឺជា របស់ព្រះ ហើយត្រូវបានបញ្ជាឲ្យរៀបចំ ។**

១. សូមពិចារណាអំពីទីបន្ទាល់ ឬ អារម្មណ៍ផ្ទាល់ខ្លួនរបស់អ្នកអំពីការហៅដ៏ទេវភាពរបស់ យ៉ូសែប ស្ម៊ីធ និង អំពីសេចក្ដីពិតដ៏ពោរពេញនៃសាសនាចក្រ ដែលលោកត្រូវបានបញ្ជាឲ្យរៀបចំឡើង ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីបទពិសោធន៍មួយ ឬ ច្រើនជាងនេះដែលអ្នកមាន ដែលបានជួយដល់អ្នកឲ្យទទួលបានសក្ខីភាព ឬ ភាពរីកចម្រើនផ្ទាល់ខ្លួន ឆ្ពោះទៅរកការទទួលបានសក្ខីភាពអំពីតួនាទីរបស់ យ៉ូសែប ស្ម៊ីធ ក្នុងនាមជាព្យាការី ដែលការស្ដារឡើងវិញនូវសាសនាចក្ររបស់ព្រះអម្ចាស់នៅលើផែនដី ។

សូមកត់ចំណាំថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១ ព្រះអម្ចាស់បានប្រទានកាលបរិច្ឆេទថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០ ជាថ្ងៃដែលសាសនាចក្រទ្រង់ត្រូវបានរៀបចំឡើង ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៥–១៦

*ប្រវត្តិសង្ខេបរបស់ព្រឹត្តិការណ៍ទាំងឡាយនៃការស្ដារឡើងវិញ*

គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៥–៦ សំដៅលើការយាងមកជាលើកដំបូងរបស់ទេវតា មរ៉ូណៃ មកជួប យ៉ូសែប ស៊្មីធ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៧–៨ រួចស្វែងរកអ្វីដែល មរ៉ូណៃ បានប្រទានដល់ យ៉ូសែប ស៊្មីធ ។

ព្រះគម្ពីរមរមនត្រូវបានបោះពុម្ពនៅថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ១៨៣០ ។ សាសនាចក្រត្រូវបានរៀបចំឡើងនៅពីរសប្ដាហ៍បន្ទាប់ពីបានបោះពុម្ពព្រះគម្ពីរ គឺនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០ ។ តើអ្នកគិតថា ហេតុអ្វីបានជាចាំបាច់ត្រូវបោះពុម្ពព្រះគម្ពីរមរមនឲ្យរួចជាស្រេច ពីមុនសាសនាចក្រត្រូវបានរៀបចំឡើង ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៩–១២ រួចស្វែងរកឃ្លាទាំងឡាយណា ដែលប្រាប់ពីរបៀបដែលព្រះគម្ពីរមរមនប្រទានពរដល់ពិភពលោក ។

២. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមបំពេញឃ្លាខាងក្រោមទាំងនេះដោយប្រើអ្វីដែលអ្នកបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៩–១២ ៖

ក. ព្រះគម្ពីរមរមនបង្ហាញភស្ដុតាងទៅកាន់ពិភពលោកថា ពួកទេវតានៅតែ

ខ. ព្រះគម្ពីរមរមនបង្ហាញភស្ដុតាងទៅកាន់ពិភពលោកថា ព្រះគម្ពីរដ៏បរិសុទ្ធទាំងឡាយគឺ

គ. ព្រះគម្ពីរមរមនបង្ហាញភស្ដុតាងទៅកាន់ពិភពលោកថា ព្រះពិតជាត្រាស់ហៅ ហើយ

ឃ. ព្រះគម្ពីរមរមនបង្ហាញភស្ដុតាងទៅកាន់ពិភពលោកថា ព្រះគឺជា

សេចក្ដីថ្លែងការណ៍ទាំងនេះជួយយើងឲ្យយល់ថា **ព្រះគម្ពីរមរមន គឺជាភស្ដុតាងថា ព្រះបានស្ដារដំណឹងល្អឡើងវិញនៅក្នុងជំនាន់របស់យើង ។** តើការស្គាល់ពីគោលការណ៍នេះ មានអានុភាពយ៉ាងដូចម្ដេច ទៅលើបំណងប្រាថ្នារបស់អ្នកដើម្បីចែកចាយព្រះគម្ពីរមរមនជាមួយនឹងនរណាម្នាក់ ?

៣. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១៤–១៥ រួចស្វែងរកការណ៍ ដែលព្រះអម្ចាស់បានសន្យាដល់អស់អ្នកដែលទទួលយកព្រះគម្ពីរមរមន ហើយរស់នៅតាមការបង្រៀនរបស់វា ។ សូមឆ្លើយសំណួរខាងក្រោមនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើព្រះអម្ចាស់សន្យាពរជ័យអ្វីខ្លះ ចំពោះអ្នកទាំងឡាយណា ដែលទទួលយកព្រះគម្ពីរមរមន « ដោយនូវសេចក្ដីជំនឿ » ?

ខ. តើមានវិធីណាខ្លះ ដែលមនុស្សម្នាក់អាចទទួលយកព្រះគម្ពីរមរមនដោយសេចក្ដីជំនឿនោះ ?

គ. តើព្រះគម្ពីរមរមនអាចដឹកនាំបុគ្គលម្នាក់ឲ្យ « ធ្វើការសុចរិតភាព » យ៉ាងដូចម្ដេច ?

ដើម្បីជួយអ្នកឲ្យពិចារណាអំពីរបៀប ដែលអ្នកទទួលយកព្រះគម្ពីរមរមនដាក់នៅក្នុងជីវិតរបស់អ្នក សូមគូសរង្វង់លើតារាងខាងក្រោម ដែលពិពណ៌នាយ៉ាងច្បាស់អំពីបទពិសោធន៍របស់អ្នកជាមួយព្រះគម្ពីរមរមនឥឡូវនេះ ៖

| *ភាពញឹកញាប់* | *គុណភាព* |
|---|---|
| ខ្ញុំអានព្រះគម្ពីរមរមនជារៀងរាល់ថ្ងៃ ។ | ខ្ញុំខិតខំដោយអស់ពីសមត្ថភាព ដើម្បីអនុវត្តនៅក្នុងជីវិតរបស់ខ្ញុំនូវអ្វីដែលខ្ញុំបានរៀន ។ |
| ខ្ញុំអានព្រះគម្ពីរមរមនស្ទើរតែរាល់ថ្ងៃ ។ | ជួនកាល ខ្ញុំអនុវត្តនៅក្នុងជីវិតរបស់ខ្ញុំ នូវអ្វីដែលខ្ញុំបានរៀន ។ |
| ខ្ញុំអានគម្ពីរមរមនយូរៗម្ដង តាមពេលវេលាដែលខ្ញុំទំនេរ ។ | ជាធម្មតា ខ្ញុំពុំផ្ដោតអារម្មណ៍ទៅលើអ្វីដែលខ្ញុំកំពុងអាននោះទេ ។ |
| ខ្ញុំពុំដែលអានព្រះគម្ពីរមរមនឡើយ ។ | |

តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីទទួលយកព្រះគម្ពីរមរមន « ដោយនូវសេចក្ដីជំនឿ » ឲ្យបានកាន់តែប្រសើរ ដាក់នៅក្នុងជីវិតរបស់អ្នក ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១៧–៣៦

*សេចក្ដីពិតដ៏មានសារៈសំខាន់អំពីក្រុមព្រះ និង ផែនការនៃសេចក្ដីសង្គ្រោះ ត្រូវបានបង្រៀន*

តើសេចក្ដីពិតសំខាន់ៗក្នុងផែនការនៃសេចក្ដីសង្គ្រោះមានអ្វីខ្លះ ? ប្រសិនបើមាននរណាម្នាក់ស្នើឲ្យអ្នកពន្យល់ដោយសង្ខេបអំពីផែនការនៃសេចក្ដីសង្គ្រោះ តើអ្នកនឹងបកស្រាយយ៉ាងដូចម្ដេច ? ដោយគ្រាន់តែប្រើ គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១៧–២៩ នោះអ្នកអាចផ្ដល់ការពន្យល់សង្ខេបអំពីផែនការនៃសេចក្ដីសង្គ្រោះបាន ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១៧, ២៩–៣១, ៣៥ រួចគូសចំណាំឃ្លា ដែលត្រូវបានថ្លែងដដែលៗនៅក្បែរដើមខគម្ពីរនីមួយៗ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១៧–៣៦ មាននូវការណ៍សំខាន់ៗមួយចំនួន ដែលសាសនាចក្ររបស់ព្រះអម្ចាស់ប្រកាសដល់ពិភពលោក ដែលយើងដឹងថាជាការពិត ។ នៅក្នុងចំណោមការណ៍ទាំងនេះ គឺជាសេចក្ដីពិតអំពីព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ និង ព្រះវិញ្ញាណបរិសុទ្ធ និងអំពីអ្វីដែលយើងត្រូវតែធ្វើ ដើម្បីបានសង្គ្រោះនៅក្នុងនគរនៃព្រះ ។

៤. សូមអានសេចក្ដីយោងបទគម្ពីរខាងក្រោម ក្រោយមក ឆ្លើយសំណួរទាំងឡាយដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១៧–១៩ ។ តើយើងដឹងអ្វីខ្លះ អំពីព្រះវរបិតាសួគ៌ ?

ខ. គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:២១–២៥ ។ តើយើងដឹងអ្វីខ្លះ អំពីព្រះយេស៊ូវគ្រីស្ទ ?

គ. គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:២៥–២៦ ។ តើយើងដឹងអ្វីខ្លះ អំពីនិស្ស័យដ៏ខ្ពង់ខ្ពស់នៃដង្វាយធួន ? ( សូមមើលផងដែរ ម៉ូសាយ ៤:៧) ។

ឃ. គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:២៦–២៨ ។ តើយើងដឹងអ្វីខ្លះ អំពីព្រះវិញ្ញាណបរិសុទ្ធ ?

ឃ្លា « យើងដឹង » គឺជាសំនួនវោហារ ដែលបង្កប់អត្ថន័យដល់សេចក្ដីថ្លែងការណ៍របស់ អែលឌើរ អូក ដែលថា « ទីបន្ទាល់អំពីដំណឹងល្អ គឺជាសាក្សីផ្ទាល់ខ្លួនមួយ ដែលថ្លែងដល់ព្រលឹងយើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធថា ភាពពិតជាក់លាក់នៃសារៈសំខាន់ដ៏នៅអស់កល្បជានិច្ច គឺជាការពិត ហើយយើងដឹងថា វាជាការពិត » ( «Testimony » ទំព័រ ២៦) ។

ចម្លើយមួយចំនួន ដែលអ្នកបានសរសេរចូលទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក អាចបង្ហាញអំពីសេចក្ដីពិតទាំងនេះ ៖ **ព្រះមានព្រះជន្មរស់ និង ជាអង្គដ៏ខ្ពង់ខ្ពស់ អស់កល្បជានិច្ច និង មិនប្រែប្រួល** (ខទី ១៧) ។ **យើងត្រូវបានបង្កើតឡើងតាមរូបអង្គទ្រង់ និងដូចជារូបរបស់ព្រះ** (ខទី ១៨) ។ **ព្រះប្រទានព្រះរាជបុត្រាសំណប់តែមួយគត់របស់ទ្រង់ ដើម្បីត្រូវគេឆ្កាង ហើយមានព្រះជន្មរស់ឡើងវិញម្ដងទៀត ដើម្បីមនុស្សទាំងអស់ដែលជឿ បានជ្រមុជទឹក ហើយកាន់ខ្ជាប់នៅក្នុងសេចក្ដីជំនឿ អាចបានសង្គ្រោះ រួមបញ្ចូលទាំងអស់អ្នកដែលបានរស់នៅពីមុនព្រះអង្គសង្គ្រោះបានប្រសូត្រផងដែរ** (ខទី ២១–២៥) ។ **ព្រះវិញ្ញាណបរិសុទ្ធ ថ្លែងទីបន្ទាល់អំពីព្រះវរបិតា និងព្រះរាជបុត្រា** (ខទី ២៧) ។ **ព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ ធ្វើការរួមគ្នាដើម្បីរៀបចំយើងឲ្យទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច** (ខទី ១៧–២៨) ។

៥. សូមជ្រើសរើសគោលលទ្ធិមួយពីខាងលើនេះ ដែលមានសារៈសំខាន់ចំពោះអ្នក ហើយដែលអ្នកដឹង ឬ ជឿថាជាការពិត ។ សូមស្រមៃថា អ្នកមានឱកាសសរសេរអត្ថបទមួយកថាខណ្ឌដាក់នៅលើទស្សនាវដ្ដី ឬ កាសែតដ៏ល្បី ដោយប្រកាសប្រាប់អំពីអ្វី ដែលអ្នកដឹង ឬ ជឿថាជាការពិតចំពោះគោលលទ្ធិនោះ ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគោលលទ្ធិណាមួយក្នុងចំណោមគោលលទ្ធិទាំងនេះ ដែលអ្នកនឹងជ្រើសរើស និង អំពីអ្វីដែលអ្នកនឹងចែកចាយ ហើយថ្លែងទីបន្ទាល់អំពីសេចក្ដីពិតនោះ ។

សូមមើលថាតើអ្នកអាចរៀបពាក្យដូចតទៅនេះបានត្រឹមត្រូវដែរឬទេ ៖ តួចិប្រែ វិតរាប់សុចការជា ជាវិការបសុទ្ធញែក ឡាស្រញ់ម្រើប យ៉ប្រត្ន ស្មាអធិន ។ ពាក្យទាំងនេះគូសបញ្ជាក់អំពីការទទួលខុសត្រូវ ដែលយើងត្រូវមានដើម្បីបង្ហាញថា យើងទទួលព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:២៩–៣៤ ដើម្បីស្វែងរកពាក្យបញ្ច្រាស់ទាំងនេះ ហើយបំពេញសេចក្ដីថ្លែងការណ៍ខាងក្រោមនេះ ៖

- « មនុស្សទាំងអស់ត្រូវតែ ហើយជឿដល់ព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ » ។
- មានន័យថា ត្រូវបានអភ័យទោស និង ប្រកាសថាគ្មានទោស ។
- មានន័យថា ក្លាយជាបរិសុទ្ធ បានបន្សុទ្ធពីផលប៉ះពាល់នៃអំពើបាប និង មានលក្ខណៈដូចជាព្រះគ្រីស្ទ ។
- ព្រះគុណរបស់ព្រះអង្គសង្គ្រោះនឹងជួយដល់អស់អ្នកណាដែល ហើយ ព្រះ ។
- យើងត្រូវតែ ហើយ ជានិច្ច ក្រែងធ្លាក់ទៅក្នុងការល្បួង ។

តើខគម្ពីរទាំងនេះបង្រៀនថា យើងត្រូវតែធ្វើអ្វីខ្លះ ដើម្បីបានសង្គ្រោះនៅក្នុងនគរព្រះ ?

សូមរំឭកអំពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយ ដែលបានបោះពុម្ពជាអក្សរដិតពេញមួយមេរៀននេះ ។ សូមពិចារណាថាតើសេចក្ដីពិតណាមួយ ដែលអ្នកបានដឹងដោយខ្លួនឯងថាជាការពិត ។ នៅពេលអ្នករំឭកអំពីគោលលទ្ធិ និង គោលការណ៍ទាំងនោះ វាអាចនឹងមានគុណប្រយោជន៍ បើអ្នកគូសសញ្ញាកែងមួយនៅក្បែរសេចក្ដីពិតទាំងនោះ ដែលអ្នកដឹងថាជាការពិត ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:១–៣៦ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៨–៦៧

## បុព្វកថា

ការរៀបចំសាសនាចក្រឡើងនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០ បានផ្ដល់ជាមធ្យោបាយដើម្បីឲ្យពិធីបរិសុទ្ធនៃបព្វជិតភាពត្រូវបានបម្រើដល់កូនចៅរបស់ព្រះវរបិតាសួគ៌ទូទាំងពិភពលោកនៅថ្ងៃចុងក្រោយ ។ នៅពីមុនការរៀបចំសាសនាចក្រ ព្រះអម្ចាស់បានចាប់ផ្ដើមបើកសម្ដែងករណីយកិច្ចនៃតំណែងនានារបស់បព្វជិតភាពទៅដល់ព្យាការី យ៉ូសែប ស្ម៊ីធ នៅដើមរដូវក្ដៅក្នុងឆ្នាំ ១៨២៩ ។. គោលលទ្ធិ និង សេចក្ដីសញ្ញា ២០ តាំងឡើងករណីយកិច្ចទាំងនេះជាច្រើន ហើយណែនាំដល់ពួកអ្នកកាន់បព្វជិតភាពអំពីការចាត់ចែងពិធីបរិសុទ្ធ ហើយមើលការខុសត្រូវ និង បម្រើដល់សមាជិកសាសនាចក្រ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៨–៥៩

*ករណីយកិច្ចទាំងឡាយនៃតំណែងបព្វជិតភាព ត្រូវបានតាំងឡើង*

តើអ្នកនឹងឆ្លើយយ៉ាងដូចម្ដេច ប្រសិនបើមាននរណាម្នាក់សួរថា « តើនរណាជាអ្នកចាត់ចែងនៅក្នុងសាសនាចក្ររបស់អ្នក » ? នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៨–៦៧ សូមគិតអំពីរបៀបដែលអ្នកអាចឆ្លើយសំណួរនេះ ។

១. សូមចម្លងងារ និង សេចក្ដីយោងខាងក្រោមនេះចូលទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ ក្រោយមកសូមអានបទគម្ពីរទាំងនេះ រួចធ្វើបញ្ជីករណីយកិច្ចនៃតំណែងបព្វជិតភាពនៅពីក្រោមចំណងជើងងារដ៏ត្រឹមត្រូវក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ។ វាអាចនឹងជួយអ្នក ក្នុងការយល់វាក្យសព្ទ « អែលឌើរ » ដែលមាននៅក្នុងខគម្ពីរទាំងនេះ ដែលសំដៅទៅលើអ្នកកាន់បព្វជិតភាពមិលគីស្សាដែក ។

| អែលឌើរ<br>(គ. និង ស. ២០:៣៨–៤៥) ។ | សង្ឃ<br>(គ. និង ស. ២០:៤៦–៥២) ។ | គ្រូ និង ឌីកុន<br>(គ. និង ស. ២០:៥៣–៥៩) ។ |
|---|---|---|
| | | |

បន្ទាប់ពីអ្នកបានសរសេរករណីយកិច្ចទាំងឡាយដាក់នៅពីក្រោមចំណងជើងងារដ៏ត្រឹមត្រូវហើយ សូមគូសបន្ទាត់ពីក្រោមចំណុចខុសគ្នា ដែលអ្នកសម្គាល់ឃើញរវាងករណីយកិច្ចរបស់អែលឌើរ សង្ឃ គ្រូ និង ឌីកុន ។ សូមគូសរង្វង់លើចំណុចស្រដៀងគ្នា ។

ឥឡូវ ដោយអ្នកបានសិក្សាបន្តិចរួចមកហើយអំពីករណីយកិច្ចនៃបព្វជិតភាព នោះសូមគូសបន្ទាត់ផ្គូផ្គងពីតំណែងបព្វជិតភាពទៅករណីយកិច្ចទាំងឡាយ ដែលអ្នកកាន់បព្វជិតភាពទាំងនោះមានសិទ្ធិអំណាចធ្វើ នៅក្នុងតារាងខាងក្រោមនេះ ៖

| | |
|---|---|
| អែលឌើរ | សិទ្ធិអំណាចប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ |
| សង្ឃ | សិទ្ធិអំណាចចាត់ចែង ( ប្រសិទ្ធពរ ) សាក្រាម៉ង់ |
| គ្រូ | សិទ្ធិអំណាចតែងតាំងឌីកុន |
| ឌីកុន | សិទ្ធិអំណាចបង្រៀន |

ចម្លើយសម្រាប់លំហាត់ផ្គូផ្គងនេះមាននៅចុងបញ្ចប់នៃមេរៀន ។ សូមកត់ចំណាំថា **តំណែងបព្វជិតភាពជាន់ខ្ពស់ ប្រូកបញ្ចូលករណីយកិច្ច និង សិទ្ធិអំណាចនៃបព្វជិតភាពដែលតូចជាង ។**

២. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគោលការណ៍មួយ ដែលសង្ខេបការទទួលខុសត្រូវរបស់អ្នកកាន់បព្វជិតភាពទាំងអស់ ។

សូមប្រៀបធៀបគោលការណ៍របស់អ្នកជាមួយគោលការណ៍ដូចតទៅនេះ ៖ **អ្នកកាន់បព្វជិតភាពទាំងអស់ មានការទទួលខុសត្រូវដើម្បីចាត់ចែងពិធីបរិសុទ្ធ និងមើលការខុសត្រូវលើសមាជិកនៃសាសនាចក្រ ហើយបម្រើពួកគេ។** អ្នកអាចនឹងចង់សរសេរសេចក្ដីពិតនេះនៅលើគែមព្រះគម្ពីររបស់អ្នកក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៨–៥៩ ។

ដើម្បីជួយអ្នកយល់កាន់តែច្បាស់ អំពីការទទួលខុសត្រូវរបស់អ្នកកាន់បព្វជិតភាពទាំងអស់ ក្នុងការមើលការខុសត្រូវ និង បម្រើដល់សមាជិកសាសនាចក្រ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៥៣–៥៤, ៥៩ រួចស្វែងរករបៀបទាំងឡាយ ដែលព្រះអម្ចាស់បានណែនាំអ្នកកាន់បព្វជិតភាពឲ្យបម្រើ និង ចម្រើនកម្លាំងសមាជិកសាសនាចក្រ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។ តើវិធីមួយចំនួនណាខ្លះ ដែលអ្នកកាន់បព្វជិតភាពអើរ៉ុន អាច « មើលការខុសត្រូវលើសាសនាចក្រ . . . ហើយនៅជាមួយ និង ចម្រើនកម្លាំងពួកគេ » ?



ករណីយកិច្ចរបស់អ្នកកាន់បព្វជិតភាពអើរ៉ុន ប្រព្រឹត្តទៅលើសពីការបម្រើពិធីបរិសុទ្ធទៅទៀត ។ សូមពិចារណាអំពីសាច់រឿងខាងក្រោម ហើយគិតអំពីរបៀបដែលអ្នកកាន់បព្វជិតភាពកំពុងធ្វើករណីយកិច្ចរបស់ខ្លួន ដើម្បីអញ្ជើញមនុស្សដទៃមករកព្រះគ្រីស្ទ និង របៀបដែលពួកគេមិនកំពុងតែធ្វើ ៖

- បន្ទាប់ពីអ្នកកាន់បព្វជិតភាពអើរ៉ុនម្នាក់ ជួយក្នុងការបម្រើសាក្រាម៉ង់ក្នុងការប្រជុំសាក្រាម៉ង់មួយ គាត់ចូលថ្នាក់សាលាថ្ងៃអាទិត្យ ហើយបានប្រព្រឹត្តចំពោះគ្រូបង្រៀន និង សមាជិកក្នុងថ្នាក់យ៉ាងទ្រគោះបោះបោក ។
- អ្នកកាន់បព្វជិតភាពវ័យក្មេងម្នាក់ ត្រឡប់មកពីបង្រៀនតាមផ្ទះវិញ ហើយចាប់ផ្ដើមចែកចាយដំណឹងរសើប ឬ ផ្ទាល់ខ្លួនអំពីផ្ទះដែលគាត់បានទៅបង្រៀន ។
- អ្នកកាន់បព្វជិតភាពមួយក្រុមជួបជុំគ្នាធ្វើការបម្រើមួយ ហើយចាប់ផ្ដើមនិយាយលេបខាយ និង ចំអន់សមាជិកក្នុងកូរ៉ុម ។

៣. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ ហេតុអ្វីបានជាសំខាន់ដែលអ្នកកាន់បព្វជិតភាពត្រូវដឹងថា ករណីយកិច្ចរបស់ខ្លួនគឺលើសពីការបម្រើពិធីបរិសុទ្ធទៅទៀត ?



អ្នកអាចនឹងចង់សរសេរសេចក្ដីថ្លែងការណ៍ដូចតទៅនេះដោយ អែលឌើរ រីឆាដ ជី ស្កុត ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដាក់នៅលើគែមព្រះគម្ពីរ ឬ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ « គោលបំណងរបស់សិទ្ធិអំណាចបព្វជិតភាព គឺត្រូវផ្ដល់ឲ្យ បម្រើ លើកតម្កើង បំផុសគំនិត » ( «Honor the Priesthood and Use It Well » *Ensign* ឬ *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៤៦ ) ។

សូមគិតអំពីពេលដែលអ្នកបានឃើញយុវជនក្នុងវួដ ឬ សាខារបស់អ្នកឲ្យតម្លៃដល់បព្វជិតភាពខ្លួន ដោយការមើលការខុសត្រូវ បម្រើ លើកតម្កើង បំផុសគំនិត ឬ ចម្រើនកម្លាំងមនុស្សដទៃ ។ ប្រសិនបើអ្នកគឺជាអ្នកកាន់បព្វជិតភាព សូមគិតពីការសរសេរគោលដៅមួយ ដែលនឹងជួយអ្នកបម្រើពិធីបរិសុទ្ធដោយស្មោះត្រង់ ហើយមើលការខុសត្រូវ និង ពង្រឹងសាសនាចក្រ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៦០–៦៧

*សេចក្ដីណែនាំស្ដីពីការតែងតាំងបព្វជិតភាពត្រូវបានផ្ដល់ឲ្យ*

តើអ្នកធ្លាប់មានបទពិសោធន៍ ឬ ធ្លាប់បានឃើញការតែងតាំងបព្វជិតភាពដែរឬទេ ? សូមគិតអំពីអារម្មណ៍ដែលអ្នកមាន នៅពេលអ្នកត្រូវបានតែងតាំង ឬ ធ្វើជាសាក្សីដល់មនុស្សណាម្នាក់ទៀតដែលត្រូវបានតែងតាំង ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៦០ រួចសូមស្វែងរកអំណាចដែលបុគ្គលដែលកំពុងធ្វើការតែងតាំងនោះគួរតែប្រើបន្ថែមពីលើបព្វជិតភាព ។ យោងតាមខគម្ពីរនេះ តើអំណាចអ្វី ដែលគួរដឹកនាំអ្នកកាន់បព្វជិតភាព នៅពេលគាត់ប្រើប្រាស់បព្វជិតភាព ?

តើអ្នកដឹកនាំបព្វជិតភាពម្នាក់ ប្រាកដបានយ៉ាងដូចម្ដេច ថាគាត់អនុវត្តករណីយកិច្ចរបស់គាត់ដោយនូវអំណាចមួយនេះ ? ប្រធាន ប៊ីយដ៏ ឃេ ជាកកឺ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ពីទីកន្លែងដែលអំណាចរបស់អ្នកកាន់បព្វជិតភាពកើតចេញមកថា ៖







« សិទ្ធិអំណាចរបស់អ្នក បានមកតាមរយៈការតែងតាំងរបស់អ្នក អំណាចរបស់អ្នក បានមកតាមរយៈការគោរពប្រតិបត្តិ និង ភាពសក្ដិសម ។

« អំណាចនៅក្នុងបព្វជិតភាព កើតចេញពីការអនុវត្តន៍ករណីយកិច្ចរបស់អ្នកនៅក្នុងកិច្ចការសាមញ្ញៗ ដូចជា ៖ ការចូលរួមការប្រជុំនានា ទទួលយកការចាត់តាំង អានព្រះគម្ពីរ គោរពពាក្យសម្ដីនៃប្រាជ្ញាវាងវៃ » ។

« ប្រធាន វិលហ្វូឌ វូឌហ្រ៊ុព្វ បានមានប្រសាសន៍ថា ៖ ‹ ខ្ញុំបានធ្វើដំណើររាប់ពាន់គីឡូម៉ែត ហើយបានប្រកាសដំណឹងល្អក្នុងនាមជាសង្ឃ ហើយពេលខ្ញុំបានថ្លែងទៅកាន់ក្រុមជំនុំលើកមុន ព្រះអម្ចាស់បានគាំទ្រខ្ញុំ ហើយបានសម្ដែងព្រះចេស្ដារបស់ទ្រង់ដើម្បីការពារជីវិតរបស់ខ្ញុំយ៉ាងច្រើន នៅពេលខ្ញុំកាន់តំណែងនោះ ក៏ដូចដែលទ្រង់បានធ្វើ ខណៈដែលខ្ញុំបានកាន់តំណែងជាសាវកម្នាក់ដែរ ។ ព្រះអម្ចាស់ គាំទ្របុរសណា ដែលកាន់ចំណែកមួយនៃបព្វជិតភាព ទោះជាគាត់ជាសង្ឃ ជាអែលឌើរ ជាពួកចិតសិបនាក់ ឬជាសាវកក្ដី បើគាត់តម្កើងការហៅរបស់គាត់ ហើយអនុវត្តករណីយកិច្ចរបស់គាត់ › » ( « The Unseen Power » *New Era* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ៧ សូមមើលផងដែរ «The Aaronic Priesthood » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨១ ទំព័រ ៣២–៣៣ ) ។

ប្រសិនបើអ្នកគឺជាយុវជនម្នាក់ សូមពិចារណាប្រកបដោយការអធិស្ឋាននូវអ្វីដែលព្រះអម្ចាស់នឹងតម្រូវឲ្យអ្នកធ្វើ ដើម្បីអញ្ជើញព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធឲ្យគង់នៅជាមួយអ្នក ពេលអ្នកអនុវត្តករណីយកិច្ចបព្វជិតភាពនាពេលបច្ចុប្បន្ន និង ពេលអនាគត ។ ប្រសិនបើអ្នកគឺជាយុវនារី សូមពិចារណាអំពីរបៀបដែលអ្នកអាចជួយយុវជនក្នុងការខិតខំរបស់ពួកគេដើម្បីមានព្រះវិញ្ញាណគង់នៅក្នុងជីវិត និង ការបម្រើខាងបព្វជិតភាពរបស់ពួកគេ ។

សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៦៥ ។ ចេញពីអ្វីដែលអ្នករៀនអំពីខគម្ពីរនេះ ហេតុអ្វីបានជានៅក្នុងសាសនាចក្រយើងលើកដៃដើម្បីបង្ហាញមតិគាំទ្រ ? ព្រះបញ្ញត្តិសម្រាប់សាសនាចក្រដើម្បីផ្ដល់មតិគាំទ្រជាសាធារណៈ គឺបានមកពីព្រះ ។

តើការលើកដៃរបស់អ្នក ហើយបង្ហាញមតិគាំទ្រចំពោះគ្នា មានន័យដូចម្ដេច ? អែលឌើរ ឡូរិន ស៊ី ដាន់ ដែលធ្លាប់ជាសមាជិកនៃពួកចិតសិបនាក់ បានពន្យល់អំពីការទទួលខុសត្រូវទាំងឡាយដែលមាននៅក្នុងនីតិវិធីនៃការគាំទ្រនេះថា ៖



« នៅពេលយើងគាំទ្រអ្នកកាន់តំណែងនានា យើងត្រូវបានប្រទានឱកាសនៃការគាំទ្រដល់អស់អ្នកដែលព្រះអម្ចាស់បានហៅជាស្រេចតាមរយៈវិវរណៈ ។. . .

« លំដាប់នោះ ព្រះអម្ចាស់ប្រទានដល់យើងនូវឱកាស ដើម្បីគាំទ្រដល់ទង្វើនៃការហៅដ៏ទេវភាពមួយ ឬក៏បង្ហាញការជំទាស់ ប្រសិនបើយើងមានអារម្មណ៍ផ្សេងពីនោះ ដោយប្រការណាមួយ ។

« ការគាំទ្រគឺជាការធ្វើឲ្យទង្វើចាក់ស្រែះទៅនឹងខ្លួនយើង ហើយតាំងចិត្តខ្លួនឯងដើម្បីទ្រទ្រង់ដល់អស់អ្នកដែលយើងបានគាំទ្រនោះ ។ នៅពេលបុគ្គលម្នាក់បានឆ្លងកាត់ទង្វើពិសិដ្ឋនៃការលើកដៃជាកែងនេះ គាត់គួរតែចងចាំដោយភ្ញាក់រឭកនូវអ្វីដែលគាត់បានធ្វើ ហើយចាប់ផ្ដើមប្រព្រឹត្តឲ្យស្របទៅនឹងការគាំទ្រមតិរបស់គាត់ទាំងជាសាធារណៈ និង ជាសម្ងាត់ផងដែរ » ( « We Are Called of God » *Ensign* ខែ កក្កដា ឆ្នាំ ១៩៧២ ទំព័រ ៤៣ ) ។

តើអ្នកធ្លាប់បានចូលរួមក្នុងការប្រជុំសាក្រាម៉ង់ ដែលក្រុមជំនុំបានគាំទ្រដល់យុវជនម្នាក់ ដើម្បីបានតែងតាំងក្នុងតំណែងបព្វជិតភាពអើរ៉ុនដែរឬទេ ? តើក្រុមជំនុំបានលើកដៃរបស់ពួកគេដែរឬទេ ? តើបទពិសោធន៍របស់យុវជននោះ ពេលឃើញមនុស្សដទៃគាំទ្រដល់ការតែងតាំងរបស់ខ្លួន អាចជួយគាត់ឲ្យបំពេញការទទួលខុសត្រូវរបស់គាត់បានយ៉ាងដូចម្ដេច ?

៤. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវប្រយោគពីរបី ដែលពន្យល់អំពីមូលហេតុដែលអ្នកមានអំណរគុណចំពោះសិទ្ធិអំណាចបព្វជិតភាព ។ សូមចែកចាយនូវអ្វីដែលអ្នកបានសរសេរជាមួយឪពុក/ម្ដាយ ឬ ថ្នាក់ដឹកនាំសាសនាចក្រ បងប្អូនបង្កើត ឬ មិត្តភក្ដិម្នាក់របស់អ្នក ។ សូមសុំឲ្យបុគ្គលនោះចែកចាយជាមួយអ្នកនូវអារម្មណ៍របស់ខ្លួនអំពីអត្ថន័យនៃបព្វជិតភាព ។



៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:២៣–៦៧ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

ចម្លើយសម្រាប់លំហាត់ផ្គូរផ្គង ៖

អែលឌើរ ៖ សិទ្ធិអំណាចប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ

អែលឌើរ ៖ សិទ្ធិអំណាចចាត់ចែង ( ប្រសិទ្ធពរ ) សាក្រាម៉ង់

អែលឌើរ និង សង្ឃ ៖ សិទ្ធិអំណាចតែងតាំងឌីកុន

អែលឌើរ សង្ឃ គ្រូ និង ឌីកុន ៖ សិទ្ធិអំណាចបង្រៀន

មេរៀនទី ៦ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧, ៦៨–៨៤

## បុព្វកថា

ការបង្កើតសាសនាចក្រនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០ បានធ្វើឲ្យពិធីបរិសុទ្ធនៃបព្វជិតភាពត្រូវបានបម្រើដល់កូនចៅរបស់ព្រះវរបិតាសួគ៌ទូទាំងពិភពលោកនៅថ្ងៃចុងក្រោយ ។ នៅពីមុនថ្ងៃដែលត្រូវបានរង់ចាំអស់រយៈពេលដ៏យូរមកនេះ ព្រះអម្ចាស់បានចាប់ផ្ដើមបើកសម្ដែងដល់ព្យាការី យ៉ូសែប ស្ម៊ីធ ស្ដីពីតម្រូវការ និង របៀបនានានៃការធ្វើពិធីបុណ្យជ្រមុជទឹក ការណ៍ដែលតម្រូវពីសមាជិកសាសនាចក្រ និង សេចក្ដីពិស្ដារនៃការបម្រើសាក្រាម៉ង់ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧, ៦៨–៧៤

*តម្រូវការ និង របៀបធ្វើពិធីបុណ្យជ្រមុជទឹកត្រូវបានកំណត់*

តើអ្នកនឹងថ្លែងយ៉ាងដូចម្ដេច ទៅកាន់មិត្តរបស់អ្នកដែលមិនមែនជាសមាជិក ដែលបានសួរថា « តើខ្ញុំត្រូវធ្វើខ្លះ ដើម្បីបានធ្វើបុណ្យជ្រមុជទឹកចូលទៅក្នុងសាសនាចក្ររបស់អ្នក » ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧ រួចស្វែងរកតម្រូវការនានា ដែលព្រះអម្ចាស់បានប្រទានដល់អស់អ្នកដែលមានបំណងប្រាថ្នាក្លាយទៅជាសមាជិកសាសនាចក្រ ។ អ្នកអាចនឹងចង់គូសចំណាំតម្រូវការនីមួយៗ ដែលអ្នករកឃើញនៅក្នុងវគ្គបទគម្ពីរនេះ ។

វាអាចនឹងមានប្រយោជន៍សម្រាប់អ្នកដើម្បីដឹងថា ការបង្ហាញពីចិត្តសង្រេង និង វិញ្ញាណទន់ទាប មានន័យថា បន្ទាបខ្លួន ហើយទទួលយកព្រះឆន្ទៈរបស់ព្រះ ។ វាក៏មានន័យថា ការមានអារម្មណ៍សោកស្ដាយយ៉ាងខ្លាំងចំពោះអំពើបាប ហើយមានបំណងប្រែចិត្តដោយអស់ពីចិត្ត ។



អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ថា ៖ « កាលពីសម័យបុរាណ នៅពេលមនុស្សចង់ថ្វាយបង្គំព្រះ ហើយស្វែងរកពរជ័យពីទ្រង់ នោះពួកគេតែងតែនាំយកអំណោយមកថ្វាយ ។ ឧទាហរណ៍ នៅពេលពួកគេទៅព្រះវិហារបរិសុទ្ធ នោះពួកគេបាននាំយកយញ្ញបូជាទៅតម្កល់នៅលើអាសនា ។ បន្ទាប់ពីការធ្វើដង្វាយធួន និង ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ នោះព្រះអង្គសង្គ្រោះបានមានព្រះបន្ទូលថា ទ្រង់នឹងពុំទទួលយកដង្វាយដុតជាសត្វទៀតឡើយ ។ អំណោយ ឬ យញ្ញបូជា ដែលទ្រង់នឹងទទួលនាពេលបច្ចុប្បន្ននេះគឺ ‹ ចិត្តសង្រេង និង វិញ្ញាណទន់ទាប › ។ [ នីហ្វៃទី៣៩:២០ ] ។ នៅពេលអ្នកស្វែងរកពរជ័យទាំងឡាយនៃការប្រែចិត្តជឿ នោះអ្នកអាចថ្វាយដល់ព្រះអម្ចាស់នូវអំណោយនៃចិត្តសង្រេង ឬ ប្រែចិត្ត និង វិញ្ញាណទន់ទាប ឬ ការគោរពប្រតិបត្តិរបស់អ្នក ។ ជាក់ស្ដែង វាគឺជាអំណោយនៃខ្លួនអ្នកផ្ទាល់តែម្ដង —គឺថាអ្នកជានរណា ហើយអ្នកនឹងក្លាយជានរណា » ( «When Thou Art Converted,” *Ensign* ឬ *Liahona,* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ១២ ) ។

តើអ្នកគិតថា ហេតុអ្វីបានជាលក្ខណៈសម្បត្តិទាំងនេះតម្រូវឲ្យមានពីមុនបុគ្គលម្នាក់ទទួលបុណ្យជ្រមុជទឹក ។

ចេញពីអ្វីដែលអ្នកបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧ សូមបំពេញគោលការណ៍ដូចតទៅនេះ ៖
**នៅពេលយើងធ្វើពិធីបុណ្យជ្រមុជទឹក យើងធ្វើសាក្សី ឬ បង្ហាញថា** ។

សូមពិចារណាអំពីរបៀបដែលអ្នកកំពុងធ្វើ ក្នុងការរស់នៅឲ្យស្របទៅតាមសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់អ្នក ។

តើអ្នកនឹងថ្លែងយ៉ាងដូចម្ដេច ទៅកាន់មិត្តម្នាក់របស់អ្នកដែលមិនមែនជាសមាជិក ប្រសិនបើពួកគេសួរបន្ថែមអំពីសំណួរនេះ ៖ « តើមនុស្សទទួលបុណ្យជ្រមុជទឹកចូលទៅក្នុងសាសនាចក្ររបស់អ្នកយ៉ាងដូចម្ដេច » ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៧២–៧៤ រួចគូសចំណាំពីរបៀបធ្វើបុណ្យជ្រមុជទឹក ដែលបានពិពណ៌នាដោយព្រះអម្ចាស់ ។ ចេញពីខគម្ពីរទាំងនេះ យើងរៀនថា **ពិធីបុណ្យជ្រមុជទឹកត្រូវតែធ្វើឡើងដោយការពន្លិច និង ត្រូវតែធ្វើឡើងដោយបុគ្គលម្នាក់រូប ដែលកាន់សិទ្ធិអំណាចត្រឹមត្រូវ** ( សូមមើលផងដែរ នីហ្វៃទី៣ ១១:២១–២៧ ) ។

តើអ្នកនឹងឆ្លើយដូចម្ដេច ប្រសិនបើមិត្តរបស់អ្នកសួរសំណួរទីបីថា ៖ « តើមនុស្សទាំងអស់តម្រូវឲ្យធ្វើអ្វីខ្លះ *បន្ទាប់ពី* ពួកគេបានធ្វើបុណ្យជ្រមុជទឹក ហើយបានក្លាយទៅជាសមាជិកសាសនាចក្ររបស់អ្នកហើយនោះ » ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៦៨–៦៩ រួចស្វែងរកការរំពឹងទុករបស់ព្រះអម្ចាស់ចំពោះយើងម្នាក់ៗ បន្ទាប់ពីយើងបានទទួលបុណ្យជ្រមុជទឹក ។ អ្នកអាចនឹងចង់គូសចំណាំការរំពឹងទាំងនេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៦៨ ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់យើងថា សមាជិកថ្មីត្រូវបង្រៀនដោយពួកអែលឌើរ នៅបន្ទាប់ពីពិធីបុណ្យជ្រមុជទឹក និង ពីមុនទទួលពិធីបញ្ជាក់ ។ នាពេលបច្ចុប្បន្ននេះ ការអនុវត្តការបង្រៀនមេរៀនអ្នកផ្សព្វផ្សាយសាសនាដល់សាសនាគន់ការី មុនពេលពិធីបុណ្យជ្រមុជទឹក នាំឲ្យមនុស្សទាំងអស់ទទួលបានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធភ្លាមបន្ទាប់ពីពួកគេបានទទួលបុណ្យជ្រមុជទឹកហើយ ។

យើងរៀនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៦៩ អំពីរបៀបដែលយើងអាចសម្ដែង ឬ បង្ហាញភាពសក្ដិសមរបស់យើងបន្ទាប់ពីបានទទួលពិធីបុណ្យជ្រមុជទឹកហើយ ។ សូមបំពេញគោលការណ៍ដូចតទៅនេះ ដោយប្រើការដឹកនាំរបស់ព្រះអម្ចាស់ចំពោះយើងនៅក្នុងខគម្ពីរនោះ ៖ **បន្ទាប់ពីបានទទួលពិធីបុណ្យជ្រមុជទឹក យើងបង្ហាញភាពសក្ដិសមរបស់យើងដល់ព្រះអម្ចាស់តាមរយៈ** ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីបានជាមានសារៈសំខាន់ ដែលអ្នកត្រូវមានភាពសក្ដិសមជានិច្ចបន្ទាប់ពីអ្នកបានទទួលពិធីបុណ្យជ្រមុជទឹកហើយ ?

ខ. តើអ្នកគិតថាវាមានន័យដូចម្ដេចដើម្បីសម្ដែង ឬ បង្ហាញពី « ដំណើរ និង វាចាដ៏សុចរិត » ?

២. សូមអានផ្នែក នេះនៃ *ដើម្បីកម្លាំងនៃយុវជន*ក្រោមចំណងជើង « ភាសា » ( [ ឆ្នាំ ២០១១ ] ទំព័រ ២០–២១ ) រួចស្វែងរករបៀបដែលយុវវ័យអាចសម្ដែង « ដំណើរ និង វាចាដ៏សុចរិត » បាន ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីបទពិសោធន៍នៅពេលអ្នកបានឃើញមនុស្សដទៃប្រព្រឹត្តការណ៍ទាំងនោះ ។ តើអ្នកគិតថាទង្វើ និងអាកប្បកិរិយារបស់ពួកគេ មានឥទ្ធិពលដល់មនុស្សជុំវិញខ្លួនពួកគេយ៉ាងដូចម្ដេច ?

សូមពិចារណាអំពីរបៀបដែលអ្នកនឹងសម្ដែង « ដំណើរ និង វាចាដ៏សុចរិត » នៅថ្ងៃខាងមុខ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៧៥–៧៩

*ព្រះអម្ចាស់ ប្រទានការណែនាំស្ដីអំពីការបម្រើពិធីសាក្រាម៉ង់*

តើអ្នកធ្លាប់មានមិត្តភក្ដិ ដែលមិនមែនជាសមាជិកសាសនាចក្រ បានមកចូលការប្រជុំសាក្រាម៉ង់ជាមួយអ្នកដែរឬទេ ? ប្រសិនបើមាន តើអ្នកបានពន្យល់អំពីពិធីបរិសុទ្ធនៃសាក្រាម៉ង់យ៉ាងដូចម្ដេច ? ប្រសិនបើអ្នកពុំដែលមានឱកាសធ្វើដូច្នេះទេនោះ តើអ្នកនឹងថ្លែងដូចម្ដេចទៅកាន់មិត្តអ្នក ដើម្បីជួយគាត់ឲ្យយល់អំពីពិធីសាក្រាម៉ង់ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៧៥ រួចស្វែងរកអ្វីដែលព្រះអម្ចាស់បានណែនាំឲ្យសមាជិកសាសនាចក្រធ្វើជាញឹកញាប់ ។

ព្រះអម្ចាស់បានពន្យល់នៅក្នុងវិវរណៈក្រោយៗមកទៀតថា « មិនជាសំខាន់ទេពីអ្វីដែលអ្នករាល់គ្នានឹងបរិភោគ ឬ ពីអ្វីដែលអ្នករាល់គ្នានឹងផឹក នៅពេលអ្នករាល់គ្នាទទួលទានសាក្រាម៉ង់ បើសិនជាអ្នករាល់គ្នាធ្វើឡើងដោយភ្នែកស្មោះត្រង់ទាំងស្រុងចំពោះសិរីល្អរបស់យើង—គឺដោយការចងចាំដល់ព្រះវរបិតា អំពីព្រះកាយរបស់យើងដែលបានដាក់ចុះដើម្បីអ្នក និង អំពីព្រះលោហិតរបស់យើងដែលបានច្រួចដើម្បីការផ្ដាច់បាបទាំងឡាយរបស់អ្នក » ( គ. និង ស. ២៧:២ ) ។ សព្វថ្ងៃនេះ យើងប្រើទឹកសម្រាប់សាក្រាម៉ង់ « ដោយនូវការចងចាំដល់ព្រះលោហិតនៃ[ ព្រះយេស៊ូវគ្រីស្ទ ] ដែលបានច្រួចជំនួស [ ពួកយើង ] » (គ. និង ស. ២០:៧៩ ) ជំនួសឲ្យស្រាទំពាំងបាយជូរវិញ ។

តើអ្នកគិតថា ហេតុអ្វីបានជាយើងត្រូវបានណែនាំឲ្យទទួលទានពិធីសាក្រាម៉ង់ជាមួយគ្នាញឹកញាប់ដូច្នេះ ? អែលឌើរ មេលវិន ជី បាឡាដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍អំពីពរជ័យពិសេសមួយដែលកើតឡើងពីការទទួលទានពិធីសាក្រាម៉ង់ជារៀងរាល់សប្ដាហ៍ ៖



« យើងចង់ឲ្យពួកបរិសុទ្ធថ្ងៃចុងក្រោយគ្រប់រូបមកឯតុសាក្រាម៉ង់ដោយសារវាគឺជាទីសម្រាប់បង្រៀនខ្លួនឯង សង្កេតមើលខ្លួនឯង ជាទីដែលយើងអាចរៀនកែតម្រូវទិសដៅខ្លួន ធ្វើឲ្យជីវិតប្រព្រឹត្តទៅដោយត្រឹមត្រូវ ដោយធ្វើឲ្យចុះសម្រុងនឹងការបង្រៀនរបស់សាសនាចក្រ និង ពួកបងប្អូនប្រុសស្រី ។. . .

« . . .រឿងមួយដែលនឹងផ្ដល់សុវត្ថិភាពដល់បុរស និងស្ត្រីគ្រប់រូប នោះគឺជាការមានមុខនៅតុសាក្រាម៉ង់ជារៀងរាល់ថ្ងៃបរិសុទ្ធ ។ យើងនឹងមិននៅឆ្ងាយពីព្រះមួយសប្ដាហ៍—គឺមិននៅឆ្ងាយពេកឡើយ បើមិនតាមរយៈដំណើរការនៃការសង្កេតមើលខ្លួនឯងទេ នោះយើងពុំអាចនឹងកំហុសឆ្គងនានា ដែលយើងបានប្រព្រឹត្តឡើយ ។. . . ផ្លូវទៅកាន់តុសាក្រាម៉ង់ គឺជាផ្លូវនៃសុខសុវត្ថិភាពសម្រាប់ពួកបរិសុទ្ធថ្ងៃចុងក្រោយ » ( នៅក្នុង Bryant S. Hinckley, *Sermons and Missionary Services of Melvin Joseph Ballard* [ ឆ្នាំ ១៩៤៩ ] ទំព័រ ១៥០–៥១ ) ។

**សូមពិចារណាអំពីមូលហេតុដែលការទទួលទានសាក្រាម៉ង់ជារៀងរាល់សប្ដាហ៍ អាចជាការការពារដល់អ្នក ។**

៣. ដើម្បីស្វែងយល់អំពីមូលហេតុ ដែលសាក្រាម៉ង់គឺជាផ្លូវនៃសុខសុវត្ថិភាពសម្រាប់អ្នក នោះសូមសរសេរចំណងជើងទាំងពីរខាងក្រោមនេះដាក់ក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

| *នៅពេលយើងទទួលទានសាក្រាម៉ង់ យើងធ្វើសាក្សីថា ៖* | *នៅពេលយើងស្មោះត្រង់ចំពោះការសន្យាទាំងឡាយ ដែលយើងបានធ្វើអំឡុងពេលពិធីសាក្រាម៉ង់ នោះព្រះអម្ចាស់ទ្រង់សន្យាថា ៖* |
|---|---|
| | |

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៧៧–៧៩ ដោយស្វែងរកការណ៍ដែលយើងធ្វើសាក្សី ឬ សន្យា នៅពេលយើងទទួលទានសាក្រាម៉ង់ ។ សូមសរសេរការណ៍ដែលអ្នករកឃើញនៅពីក្រោមចំណងជើង « នៅពេលយើងទទួលទានសាក្រាម៉ង់. . . » នៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ។ បន្ទាប់មក សូមអានខគម្ពីរទាំងនោះសាជាថ្មី ដោយស្វែងរកការណ៍ដែលព្រះអម្ចាស់សន្យា ។ សូមសរសេរការណ៍ដែលអ្នករកឃើញនៅពីក្រោមចំណងជើង « នៅពេលយើងស្មោះត្រង់. . . » នៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ។



សូមរំឭកអំពីតម្រូវការនៃពិធីបុណ្យជ្រមុជទឹក ដែលអ្នកបានរកឃើញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧ ។ តើមានភាពស្រដៀងគ្នាណាខ្លះ ដែលអ្នកឃើញមាននៅក្នុងសេចក្ដីសញ្ញា ដែលអ្នកបានធ្វើកាលពីពិធីបុណ្យជ្រមុជទឹក និងការសន្យាដែលអ្នកបានធ្វើអំឡុងពេលពិធីសាក្រាម៉ង់ ?

**នៅពេលយើងទទួលទានសាក្រាម៉ង់ នោះយើងរំឭកសេចក្ដីសញ្ញា ដែលយើងបានធ្វើ កាលយើងបានទទួលបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់ ។**

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកអាចបង្ហាញឆន្ទៈរបស់អ្នកក្នុងការលើកដាក់មកលើខ្លួនអ្នកនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទបានយ៉ាងដូចម្ដេច ?

ខ. តើមានការណ៍មួយចំនួនណាខ្លះ ដែលអ្នកអាចធ្វើ ដើម្បីចងចាំអំពីព្រះអង្គសង្គ្រោះពេញមួយសប្ដាហ៍បាន ? ( សូមមើលផងដែរ ម៉ូសាយ ១៨:៨–១០) ។

គ. តើការទទួលទានសាក្រាម៉ង់ ជួយអ្នកសម្ដែងនូវ « ដំណើរ និង វាចាដ៏សុចរិត » យ៉ាងដូចម្ដេច ( គ. និង ស. ២០:៦៩ ) ?

សូមអានសេចក្ដីថ្លែងដូចតទៅនេះ ស្ដីពីការរក្សា និង ការរំឭកសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក ៖ « អ្នកទទួលបានពរជ័យដ៏អស្ចារ្យ នៅពេលអ្នករក្សាសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក ។ នៅពេលអ្នករំឭកវា នោះព្រះអម្ចាស់រំឭកការសន្យាដែលបានធ្វើដើម្បីផ្ដាច់បាបរបស់អ្នក ។ បានស្អាតពីអំពើបាប អ្នកអាច ‹ មានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយនឹង [ អ្នក ] ជាដរាប › (គ និង ស ២០:៧៧)។ ការមានភាពជាដៃគូនៃព្រះវិញ្ញាណដ៏ខ្ជាប់ខ្ជួន គឺជាអំណោយដ៏ធំបំផុតមួយ ដែលអ្នកអាចទទួលបានក្នុងជីវិតរមែងស្លាប់។ ព្រះវិញ្ញាណនឹងដឹកនាំអ្នកនៅលើមាគ៌ានៃសេចក្ដីសុចរិត និងភាពសុខសាន្ត ដែលដឹកនាំអ្នកទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច ជាមួយនឹងព្រះវរបិតាសួគ៌របស់អ្នក និងព្រះយេស៊ូវគ្រីស្ទ » (*ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* [ ឆ្នាំ ២០០៤ ] ទំព័រ ១៤៨) ។

៥. សូមឆ្លើយសំណួរដូចតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការយល់ដឹងអំពីពរជ័យនៃការមានភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ លើកទឹកចិត្តយើងឲ្យគោរពដល់សេចក្ដីសញ្ញាពិធីបុណ្យជ្រមុជទឹកយើងយ៉ាងដូចម្ដេច ?

អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា យើងអាចនឹងរីករាយនឹងពរជ័យនៃការបម្រើនៃពួកទេវតាបាន នៅពេលយើងរំឭកសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់យើង តាមរយៈការទទួលទានសាក្រាម៉ង់ដោយមានភាពសក្ដិសម ៖



« ជំហានសំខាន់ៗដែលទាក់ទងទៅនឹងការផ្ដាច់បាប គឺត្រូវបានធ្វើឡើងតាមរយៈពិធីបរិសុទ្ធនៃការសង្គ្រោះនៃពិធីបុណ្យជ្រមុជទឹក និងពិធីបរិសុទ្ធនៃការរំឭកក្នុងពិធីសាក្រាម៉ង់ ។. . .

« . . .ពិធីបរិសុទ្ធនៃបព្វជិតភាពអើរ៉ុនទាំងនេះ គឺសំខាន់ផងដែរចំពោះការបម្រើនៃពួកទេវតា ។

. . .សារលិខិតរបស់ទេវតា អាចត្រូវបានផ្ដល់ឲ្យដោយសម្លេង ឬដោយគំនិត ឬអារម្មណ៍ទំនាក់ទំនងនៅក្នុងចិត្ត ។. . .

« . . . ទេវតាភាគច្រើនទំនាក់ទំនងតាមរយៈអារម្មណ៍ ឬ បានស្ដាប់ឮ ជាជាងការបានឃើញ ។

« ជាទូទៅ ពរជ័យនៃការមានភាពជាដៃគូ និងទំនាក់ទំនងខាងវិញ្ញាណ គឺមានតែចំពោះអ្នកទាំងឡាយណាដែលស្អាតស្អំប៉ុណ្ណោះ ។. . . តាមរយៈពិធីបរិសុទ្ធបព្វជិតភាពអើរ៉ុននៃពិធីបុណ្យជ្រមុជទឹក និង ពិធីសាក្រាម៉ង់ នោះយើងត្រូវបានស្អាតស្អំពីអំពើបាបរបស់យើង ហើយបានសន្យាថា បើយើងរក្សាសេចក្ដីសញ្ញាទាំងឡាយរបស់យើង នោះយើងនឹងមានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយយើងជានិច្ច ។ ខ្ញុំជឿថា ការសន្យាពុំសំដៅតែទៅលើព្រះវិញ្ញាណបរិសុទ្ធទេ ប៉ុន្តែក៏សំដៅទៅលើការបម្រើនៃពួកទេវតាដែរ ដ្បិត ‹ ពួកទេវតានិយាយដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ហេតុដូច្នោះហើយ ពួកទេវតានិយាយអំពីព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ › (នីហ្វៃទី២ ៣២:៣ ) ។ ដូច្នេះ គឺអ្នកទាំងឡាយដែលកាន់បព្វជិតភាពអើរ៉ុន ដែលបើកទ្វារសម្រាប់សមាជិកសាសនាចក្រទាំងអស់ ដែលទទួលទានពិធីសាក្រាម៉ង់ដោយសក្ដិសម ដើម្បីរីករាយនឹងភាពជាដៃគូនៃព្រះវិញ្ញាណនៃព្រះអម្ចាស់ និងការបម្រើនៃពួកទេវតា » ។ ( « The Aaronic Priesthood and the Sacrament » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ទំព័រ ៣៨–៣៩ ) ។

សូមពិចារណាអំពីរបៀបដែលអ្នកនឹងរៀបចំខ្លួនអ្នកផ្ទាល់ ដើម្បីទទួលទានសាក្រាម៉ង់ជារៀងរាល់សប្ដាហ៍ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៨០–៨៤

*កំណត់ត្រាសមាជិកភាពសាសនាចក្រគឺត្រូវរក្សាយ៉ាងត្រឹមត្រូវ*

គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៨១–៨៤ មាននូវសេចក្ដីណែនាំពីព្រះអម្ចាស់ថា ពួកអែលឌើរក្នុងសាសនាចក្រជំនាន់មុនត្រូវកត់ត្រាឈ្មោះរបស់មនុស្សដែលបានចូលរួមក្នុងសាសនាចក្រ ។ ពួកគេត្រូវបានប្រាប់ឲ្យនាំយកបញ្ជីឈ្មោះទាំងនេះទៅសន្និសីទនានា ដើម្បីឲ្យបញ្ជីទាំងនោះត្រូវបានរក្សាទុកនៅក្នុងសៀវភៅមួយ ។ ឈ្មោះរបស់អ្នកទាំងឡាយដែលបានចាកចេញពីសាសនាចក្រ ត្រូវបានដកចេញពីសៀវភៅនោះ ។ បន្ថែមពីលើនោះ សមាជិកនៃសាសនាចក្រដែលបានផ្លាស់ពីទីតាំងមួយទៅទីតាំងមួយទៀត គឺត្រូវយកវិញ្ញាបនបត្រនៃសមាជិកភាពរបស់ពួកគេទៅជាមួយ ដើម្បីប្រគល់ទៅឲ្យអ្នកដឹកនាំបព្វជិតភាពថ្មីរបស់ពួកគេ ។ នៅជំនាន់របស់យើង ថ្នាក់ដឹកនាំសាសនាចក្រ បន្តរក្សាកំណត់ត្រាសមាជិកភាពត្រឹមត្រូវ ប៉ុន្តែវិធីសាស្ត្រនៃការធ្វើវា គឺមានភាពងាយស្រួលច្រើន ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្តីសញ្ញា ២០:៣៧, ៦៨–៨៤ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៦ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២១–២៣

## បុព្វកថា

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០ ។ មានមនុស្សជិត ៦០ នាក់បានចូលរួមការប្រជុំថ្វាយបង្គំជាលើកដំបូង ។ ការប្រជុំនោះបានប្រព្រឹត្តទៅដោយមានការអធិស្ឋាន ការគាំទ្រ ការតែងតាំង ការបម្រើសាក្រាម៉ង់ និងពិធីបញ្ជាក់ ។ នៅក្នុងការប្រជុំនេះ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលឥឡូវនេះ បានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២១ ។ នៅប៉ុន្មានថ្ងៃក្រោយមក ព្រះអម្ចាស់បានស្រាយបំភ្លឺថា ពិធីបុណ្យជ្រមុជទឹកត្រូវតែធ្វើឡើងដោយអស់អ្នកដែលមានសិទ្ធិអំណាចបព្វជិតភាពត្រឹមត្រូវ ( សូមមើល គ. និង ស. ២២ ) ។ ទ្រង់ក៏បានប្រទានឱវាទដល់បុរសប្រាំរូប ដែលមានបំណងចង់ដឹងពីករណីយកិច្ចរបស់ខ្លួន ( សូមមើល គ. និង ស. ២៣ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២១

*ព្រះអម្ចាស់បានចាត់តាំង យ៉ូសែប ស្ម៊ីធ ជាព្យាការី និង អ្នកមើលឆុតទីមួយក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ។*

សូមស្ដាប់ ឬ អានទំនុកបទនៃទំនុកតម្កើង « យើងអរគុណទ្រង់ចំពោះព្យាការី » (*ទំនុកតម្កើង* លេខ ១០ ) ។ តើមូលហេតុមួយចំនួនណាខ្លះ ដែលអ្នកមានអារម្មណ៍នៃអំណរគុណចំពោះព្យាការី ? នៅពេលអ្នកសិក្សាមេរៀននៅថ្ងៃនេះ សូមស្វែងរកសេចក្ដីពិតដែលអាចបង្កើនកតវេទិតារបស់អ្នកចំពោះព្យាការី ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:១ ដោយស្វែងរកងារខុស ៗគ្នា ដែល យ៉ូសែប ស្ម៊ីធ នឹងត្រូវបានស្គាល់ ។ អ្នកអាចនឹងចង់គូសចំណាំសេចក្ដីពិតទាំងនោះ នៅក្នុងព្រះគម្ពីររបស់អ្នក ឬ សរសេរវានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

អែលឌើរ ចន អេ វីឌសូ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនអំពីអត្ថន័យជាទូទៅនៃងារ « ព្យាការី » និង របៀបដែលងារនេះរួមបញ្ចូលទាំងងារដទៃ ៗទៀតថា ៖



« ព្យាការី គឺជាគ្រូបង្រៀន ។ នោះគឺជាអត្ថន័យសំខាន់នៃពាក្យនេះ ។ លោកបង្រៀនអំពីសេចក្ដីពិតដំណឹងល្អ ដែលបានបើកសម្ដែងដោយព្រះអម្ចាស់ដល់មនុស្ស ហើយលោកពន្យល់អំពីការណ៍ទាំងនោះឲ្យមនុស្សបានយល់ដឹងនៅក្រោមការបំផុសគំនិត ។. . .

« តាមន័យថាព្យាការីគឺជាបុរសម្នាក់ដែលទទួលវិវរណៈមកពីព្រះអម្ចាស់ នោះងារ ‹ អ្នកមើលឆុត និង អ្នកទទួលវិវរណៈ › គ្រាន់តែពង្រីកឲ្យធំដល់អត្ថន័យដ៏ធំនៃងារជា ‹ ព្យាការី › ប៉ុណ្ណោះ ។. . .

« អ្នកមើលឆុត គឺជាអ្នកដែលមើលឃើញដោយភ្នែកខាងវិញ្ញាណ ។ គាត់ដឹងពីអត្ថន័យនៃនៃអ្វីដែលហាក់ដូចជាស្រពិចស្រពិលចំពោះអ្នកដទៃ ហេតុដូច្នេះហើយគាត់គឺជាអ្នកបកប្រែ និង អ្នកបញ្ជាក់ពីសេចក្ដីពិតដ៏អស់កល្បជានិច្ច ។ គាត់ព្យាករណ៍អនាគតកាលពីអតីតកាល និង បច្ចុប្បន្នកាល ។ ការណ៍នេះ គាត់ធ្វើដោយអំណាចនៃព្រះអម្ចាស់ដែលប្រតិបត្តិការតាមរយៈគាត់ដោយផ្ទាល់ ឬ មិនផ្ទាល់ជាមួយនឹងជំនួយនៃឧបករណ៍ដ៏ទេវភាពដូចជា យូរីម និង ធូមីម ។ សរុបមក គាត់គឺជាមនុស្សម្នាក់ដែលមើលឃើញ ដែលដើរនៅក្នុងពន្លឺរបស់ព្រះអម្ចាស់ដោយបើកភ្នែក ។ [ សូមមើល ម៉ូសាយ ៨:១៥–១៧] ។

« ដោយមានជំនួយពីព្រះអម្ចាស់ នោះអ្នកទទួលវិវរណៈ ធ្វើឲ្យអ្វីមួយត្រូវបានគេដឹង ដែលពីមុនគេមិនបានដឹងពីវា ។ វាអាចសេចក្ដីពិតថ្មី ឬត្រូវបានគេភ្លេច ឬ ការអនុវត្តនៃសេចក្ដីពិតដែលគេដឹងថ្មី ឬត្រូវបានគេភ្លេចចំពោះសេចក្ដីត្រូវការរបស់មនុស្ស ។. . .

« សរុបសេចក្ដីមក ៖ ព្យាការីគឺជាគ្រូបង្រៀនអំពីសេចក្ដីពិតដែលត្រូវបានធ្វើឲ្យដឹង អ្នកមើលឆុតគឺជាអ្នកយល់ដឹងដោយញាណនូវសេចក្ដីពិតដែលអាថ៌កំបាំង អ្នកទទួលវិវរណៈគឺជាអ្នកទទួលនូវសេចក្ដីពិតថ្មី ។ តាមន័យដ៏ទូលំទូលាយ អ្វីដែលត្រូវបានគេប្រើច្រើនបំផុត ងារព្យាការី បូកបញ្ចូលទាំងងារផ្សេងទៀត ហើយធ្វើជាព្យាការី គ្រូបង្រៀន អ្នកដឹងមុន និង អ្នកទទួលសេចក្ដីពិត ( *Evidences and Reconciliations,* arr. G. Homer Durham, វ៉ុល ៣ នៅក្នុង ១ [ ឆ្នាំ ១៩៦០ ] ទំព័រ ២៥៧–៥៨ ) ។

នៅក្នុងសេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ យើងរៀនស្វែងយល់ថា ព្យាការី គឺជា « បុរសម្នាក់ដែលត្រូវបានហៅដោយព្រះ ហើយថ្លែងជំនួសព្រះ ។ ក្នុងនាមជាសារទូតរបស់ព្រះ ព្យាការីទទួលព្រះបញ្ញត្តិ ព្យាករណ៍ និងវិវរណៈមកពីព្រះ ។ ទំនួលខុសត្រូវរបស់លោក គឺដើម្បីបង្ហាញពីព្រះហឫទ័យរបស់ព្រះ និងលក្ខណៈពិតរបស់ព្រះចំពោះមនុស្សលោក ហើយបង្ហាញពីអត្ថន័យនៃការទំនាក់ទំនងរបស់ទ្រង់ជាមួយពួកគេ។ ព្យាការីម្នាក់ ប្រកាសបដិសេធអំពើបាបទាំងស្រុង ហើយទាយទុកពីផលវិបាករបស់វា ។ លោកគឺជាអ្នកផ្សាយអំពីសេចក្ដីសុចរិត។ ក្នុងឱកាសខ្លះ ពួកព្យាការីអាចនឹងត្រូវបានបំផុសគំនិតឲ្យទាយទុកជាមុនអំពី អនាគតកាលសម្រាប់ជាប្រយោជន៍ដល់មនុស្សលោក។ ទោះជាយ៉ាងណាក៏ដោយ ការទទួលខុសត្រូវចម្បងរបស់លោក គឺត្រូវថ្លែងជាសាក្សីអំពីព្រះគ្រីស្ទ » ( Prophet, »scriptures.lds.org) ។

១. សូមឆ្លើយសំណួរតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើងារទាំងឡាយដែលត្រូវបានប្រទានដល់ យ៉ូសែប ស្ម៊ីធ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:១ ជួយអ្នកឲ្យយល់អំពីសារៈសំខាន់នៃតួនាទី និង ការទទួលខុសត្រូវជាច្រើនដែលលោកមាន ក្នុងការស្ដារឡើងវិញនៃភាពពេញលេញនៃដំណឹងល្អ និង សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៅលើផែនដីយ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:២–៣ ដោយស្វែងរកពាក្យ ឬ ឃ្លាដែលបង្ហាញថា **ព្រះបានបំផុសឲ្យ យ៉ូសែប ស្ម៊ីធ ស្ដារសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទឡើងវិញ ។** អ្នកអាចនឹងចង់គូសចំណាំពាក្យ ឬ ឃ្លាទាំងនេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។

២. សូមពន្យល់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលអ្នកគិតថា វាមានសារៈសំខាន់ដើម្បីដឹងថា យ៉ូសែប ស្ម៊ីធ ត្រូវបានហៅដោយព្រះ ដើម្បីស្ដារ ហើយដឹកនាំសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទឡើងវិញ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:៤–៥ រួចស្វែងរកសារលិខិតដ៏មានសារៈសំខាន់មួយ ដែលព្រះអម្ចាស់បានបើកសម្ដែងនៅថ្ងៃដែលសាសនាចក្រត្រូវបានរៀបចំឡើង ។

៣. សូមឆ្លើយសំណួរតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ ហេតុអ្វីបានជាពេលខ្លះវាតម្រូវឲ្យមាន « សេចក្ដីអត់ធន់ និង សេចក្ដីជំនឿ » ដើម្បីស្ដាប់តាមប្រសាសន៍របស់ព្យាការី ?



ប្រធាន វិលហ្វូឌ វូឌ្រុព្វ បានផ្ដល់ការអះអាងថា យើងអាចមានសេចក្ដីជំនឿជានិច្ចទៅលើព្យាការីរបស់ព្រះអម្ចាស់ ៖ « ព្រះអម្ចាស់នឹងពុំបណ្ដោយឲ្យខ្ញុំ ឬ បុរសដទៃទៀត ដែលឈរជាប្រធាននៃសាសនាចក្រ ដឹកនាំអ្នកឲ្យដើរផ្លូវខុសនោះទេ ។ វាពុំមាននៅក្នុងកម្មវិធីនោះទេ ។ វាពុំមែនជាព្រះតម្រិះរបស់ព្រះនោះទេ ។ ប្រសិនបើខ្ញុំមានបំណងធ្វើដូច្នោះ នោះព្រះអម្ចាស់នឹងដកខ្ញុំចេញពីតំណែងនេះជាមិនខាន » (*Teachings of Presidents of the Church: Wilford Woodruff* [ ឆ្នាំ ២០០៤ ] ទំព័រ ១៩៩) ។



ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ បានថ្លែងទីបន្ទាល់ស្រដៀងគ្នាដែរថា ៖ « ប្រសិនបើ [ ប្រធាននៃសាសនាចក្រ ] នឹងក្លាយជាមនុស្សពុំស្មោះត្រង់ នោះព្រះនឹងដកគាត់ចេញពីតំណែងរបស់គាត់ ។ ខ្ញុំសូមថ្លែងទីបន្ទាល់នៅក្នុងព្រះនាមនៃព្រះរបស់រាស្ត្រអ៊ីស្រាអែលថា ទ្រង់នឹងពុំបណ្ដោយឲ្យអ្នកដឹកនាំសាសនាចក្រ ដែលត្រូវបានជ្រើសតាំងឲ្យឈរនៅត្រង់ក្បាលម៉ាស៊ីន ប្រព្រឹត្តអំពើរំលងនឹងក្រឹត្យវិន័យទ្រង់ ហើយក្បត់សាសនានោះទេ ដ្បិតរំពេចណាដែលគាត់នឹងប្រព្រឹត្តដូចនោះ ព្រះទ្រង់នឹងដកគាត់ចេញភ្លាម ។ ហេតុអ្វី ? ព្រោះការបណ្ដោយឲ្យបុរសទុច្ចរិតម្នាក់កាន់តំណែងនោះ នឹងធ្វើឲ្យប្រកពប្រែជាមានភាពពុករលួយ គឺជាអ្វីមួយដែលទ្រង់នឹងមិនបណ្ដោយឲ្យកើតមានឡើងសោះឡើយ » ។ (*Teachings of Presidents of the Church: Joseph F. Smith* [ ឆ្នាំ ១៩៩៨ ] ទំព័រ ២២៧) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:៦ រួចដាក់លេខនៅលើពរជ័យចំនួនបី ដែលបានផ្ដល់ដល់អ្នកទាំងឡាយ ដែលទទួលយកពាក្យសម្ដីរបស់ព្យាការីដោយសេចក្ដីអត់ធន់ និង សេចក្ដីជំនឿ ។

**បញ្ជីទាំងឡាយនៃបទគម្ពីរ**
ជាញឹកញាប់ បទគម្ពីររួមបញ្ចូលទាំងបញ្ជីនៃការព្រមាន ឧបសគ្គ និង ពរជ័យ ។ ពេលដែលអ្នករកឃើញបញ្ជីមួយ នោះអ្នកអាចនឹងដាក់លេខរៀងនៅលើចំណុចនីមួយៗ ។

តើអ្នកនឹងសង្ខេបការសន្យាទាំងឡាយ ដែលបានប្រទានឲ្យដល់អ្នកទាំងឡាយណាដែលបានស្ដាប់តាមពាក្យសម្ដីរបស់ព្យាការីយ៉ាងដូចម្ដេច ? ( សេចក្ដីថ្លែងតទៅនេះជារបៀបមួយ ដើម្បីថ្លែងពីគោលការណ៍ ៖ **បើយើងស្ដាប់តាមពាក្យសម្ដីរបស់ព្យាការី នោះយើងនឹងត្រូវបានការពារទាស់នឹងមារសត្រូវ** ) ។

៤. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគ្រាមួយដែលអ្នក ឬ នរណាម្នាក់ដែលអ្នកស្គាល់ត្រូវបានប្រទានពរដោយសារការស្ដាប់ដំបូន្មាន និង ពាក្យសម្ដីរបស់ព្យាការីដែលកំពុងរស់នៅ ។ ការណ៍នេះអាចរួមបញ្ចូលទាំងដំបូន្មានខាងក្រោមនេះ ដែលបានថ្លែងនៅក្នុងសន្និសីទទូទៅ និង នៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន*



ប្រធាន ជេម អ៊ី ហ្វោស្ត ក្នុងកូរ៉ុមនៃគណៈប្រធានទីមួយ បានថ្លែងអំពីសារៈសំខាន់នៃការគាំទ្រព្យាការីដែលកំពុងរស់នៅថា ៖ « ខ្ញុំពុំជឿថា សមាជិកនៃសាសនាចក្រនេះ អាចដើរតាមព្រះអង្គសង្គ្រោះបានយ៉ាងពេញលេញ ដោយមិនបានគាំទ្រដល់ព្យាការីដែលកំពុងរស់នៅលើផែននេះ ដែលជាប្រធាននៃសាសនាចក្រនេះឡើយ ។ ប្រសិនបើយើងពុំគាំទ្រដល់ព្យាការីដែលកំពុងរស់នៅទេនោះ ទោះបើលោកជានរណាក៏ដោយ នោះយើងស្លាប់ខាងវិញ្ញាណហើយ ។ មនុស្សមួយចំនួនបានស្លាប់ខាងវិញ្ញាណដោយការធ្វើតាមតែព្យាការី ដែលបានលាចាកលោកនេះជាយូយាណាស់មកហើយប៉ុណ្ណោះ ។ មនុស្សឯទៀតមិនគាំទ្រដល់ព្យាការីដោយការធ្វើឲ្យខូចកិត្តិយសដល់ពួកលោក ទោះជាត្រូវប្រើល្បិចកលថោកទាបយ៉ាងក៏ដោយ » ( Continuing Revelation," *Ensign* ខែ សីហា ឆ្នាំ ១៩៩៦ ទំព័រ ៥ ) ។

សូមពិចារណាអំពីអ្វីដែលអ្នកត្រូវតែធ្វើ ដើម្បីចាប់យកពរជ័យដែលបានសន្យានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២១:៦ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២២

*ព្រះអម្ចាស់បើកសម្ដែងថា ពិធីបុណ្យជ្រមុជទឹកត្រូវតែបានធ្វើឡើងដោយសិទ្ធិអំណាចត្រឹមត្រូវ ។*

បុគ្គលមួយចំនួនដែលមានបំណងចូលរួមសាសនាចក្រក្នុងខែ មេសា ឆ្នាំ ១៨៣០ ធ្លាប់បានទទួលពិធីបុណ្យជ្រមុជទឹកក្នុងសាសនាចក្រដទៃ ហើយបានឆ្ងល់ថាតើហេតុអ្វីពួកគេត្រូវទទួលពិធីបុណ្យជ្រមុជទឹកម្ដងទៀត ( សូមមើល សេចក្ដីណែនាំអំពីកណ្ឌនៃ គ. និង ស. ២២ ) ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានទូលសួរដល់ព្រះអម្ចាស់អំពីភាពចាំបាច់នៃការទទួលពិធីបុណ្យជ្រមុជទឹកឡើងវិញរបស់ពួកគេ ។ ក្នុងការឆ្លើយតបរបស់ទ្រង់ ព្រះអម្ចាស់បានមានព្រះបន្ទូលអំពីគោលបំណងដ៏មានសារៈសំខាន់ក្នុងការស្ដារដំណឹងល្អ និង សាសនាចក្រឡើងវិញ ។

សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ២២ ។ តើព្រះអម្ចាស់បានមានព្រះបន្ទូល អំពីមូលហេតុដែលពិធីបុណ្យជ្រមុជទឹកដោយមានសិទ្ធិអំណាចត្រឹមត្រូវ គឺជាការចាំបាច់យ៉ាងដូចម្ដេច ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២២:១ ព្រះអម្ចាស់បានមានព្រះបន្ទូលអំពី « សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច » ។ នៅក្នុងការពន្យល់ខាងក្រោម សូមគូសចំណាំពាក្យទាំងឡាយណា ដែលអាចនឹងជួយអ្នកឲ្យយល់អំពីអត្ថន័យនៃឃ្លានេះ ៖

សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចគឺជា « ភាពពោរពេញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ( គ. និង ស. ៦៦:២ ) ។ វាមានសភាពថ្មីគ្រប់ពេល ដែលវាត្រូវបានបើកសម្ដែងសាជាថ្មីបន្ទាប់ពីការក្បត់សាសនាមួយរយៈ ។ វាមានសភាពអស់កល្បអស់កាលជានិច្ច ក្នុងន័យដែលថាវាគឺជាសេចក្ដីសញ្ញារបស់ព្រះ ហើយត្រូវបានរីករាយក្នុងគ្រាកាន់កាប់ត្រួតត្រានៃដំណឹងល្អគ្រប់ជំនាន់ ដែលមនុស្សមានឆន្ទៈដើម្បីទទួលយកវា ។ សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ត្រូវបានបើកសម្ដែងសាជាថ្មីដល់មនុស្សនៅលើផែនដី ដោយព្រះយេស៊ូវគ្រីស្ទ តាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ។ វាមាននូវពិធីបរិសុទ្ធដ៏ពិសិដ្ឋៗ ដែលត្រូវបានបម្រើដោយសិទ្ធិអំណាចបព្វជិតភាព—មានដូចជាពិធីបុណ្យជ្រមុជទឹក និង អាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ—ដែលធ្វើឡើងឲ្យមានការសង្គ្រោះ អមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » ( Guide to the Scriptures, New and Everlasting Covenant," scriptures.lds.org) ។

នៅពេលយើងយល់សេចក្ដីពិតទាំងនេះអំពី សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចហើយនោះ យើងដឹងយ៉ាងច្បាស់ថា **ពិធីបុណ្យជ្រមុជទឹកត្រូវតែធ្វើឡើងដោយបុគ្គលម្នាក់ ដែលមានសិទ្ធិអំណាចពីព្រះ** ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២២:២–៤ រួចស្វែងរកឃ្លាទាំងឡាយណា ដែលបង្ហាញថា ព្រះអម្ចាស់ពុំទទួលស្គាល់ពិធីបុណ្យជ្រមុជទឹក ដែលធ្វើឡើងដោយគ្មានសិទ្ធិអំណាចបព្វជិតភាពត្រឹមត្រូវឡើយ ។ វាអាចនឹងមានប្រយោជន៍ដើម្បីដឹងថា នៅក្នុង ខទី ២ ព្រះអម្ចាស់បានសំដៅលើពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹកថាជាការចូល « ទៅតាមទ្វារចង្អៀត » ( សូមមើល នីហ្វៃទី២ ៣១:១៧ ) ។

៥. សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ មានសិទ្ធិអំណាចបព្វជិតភាពដែលចាំបាច់ ដើម្បីធ្វើពិធីបរិសុទ្ធសំខាន់ៗ ដូចជាពិធីបុណ្យជ្រមុជទឹក ។ សូមឆ្លើយសំណួរតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកទទួលបានពរជ័យយ៉ាងដូចម្ដេចតាមរយៈសមាជិកភាពរបស់អ្នកនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣

*សិស្សប្រាំនាក់ត្រូវបានហៅឲ្យពង្រឹងដល់សាសនាចក្រ*

សូមគូសចំណាំឈ្មោះតទៅនេះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣ ៖ អូលីវើរ ហៃរុម សាំយូអែល យ៉ូសែប និង យ៉ូសែប ណៃត ។ សូមអានសេចក្ដីណែនាំអំពីកណ្ឌ ដើម្បីស្វែងយល់អំពីអ្វីដែលបុរសទាំងនេះប្រាថ្នាចង់បានពីព្រះអម្ចាស់ ។

ព្រះអម្ចាស់បានមានព្រះបន្ទូលទៅកាន់ អូលីវើរ ខៅឌើរី មុនគេបង្អស់ ។ អូលីវើរ គឺជាជំនួយដ៏អស្ចារ្យចំពោះព្យាការី យ៉ូសែប ស៊្មីធ អំឡុងពេលព្រឹត្តិការណ៍ដំបូងនៃការស្ដារឡើងវិញ រួមបញ្ចូលទាំងការនាំចេញមកនៃព្រះគម្ពីរមរមន និង ការរៀបចំសាសនាចក្រ ។ គាត់មានអំណោយទាន និង បំណងប្រាថ្នាសុចរិតជាច្រើន ។ គាត់ត្រូវបានហៅឲ្យធ្វើជាអែលឌើរទីពីរនៃសាសនាចក្រ ( សូមមើល គ. និង ស. ២០:៣ ) និងត្រូវបានតែងតាំងស្របពេលជាមួយនឹង ដាវីឌ វិតមើរ ដើម្បីជួយក្នុងការជ្រើសតាំងពួកសាវកដប់ពីរនាក់ ។ ជាអកុសល អូលីវើរ បានបណ្ដោយឲ្យឯកសិទ្ធិដំបូងជាច្រើនទាំងនេះដឹកនាំគាត់ឲ្យមានភាពឆ្មើងឆ្មៃ ហើយបានដើរចេញពីសាសនាចក្រអស់មួយរយៈ ។ នៅទីបំផុត គាត់បានទទួលកំហុសខ្លួន ហើយបានទទួលពិធីបុណ្យជ្រមុជទឹកសាជាថ្មី ។

៦. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣:១–២ រួចស្វែងរកការព្រមានដែលព្រះអម្ចាស់បានប្រទានដល់ អូលីវើរ ខៅឌើរី ។ សូមឆ្លើយសំណួរខាងក្រោមនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើភាពឆ្មើងឆ្មៃអាចនាំទៅរកការល្បួងយ៉ាងដូចម្ដេច ?

ខ. តាមគំនិតរបស់អ្នក តើវិធីមួយចំនួនណាខ្លះ ដែលយើងអាចចៀសពីអារម្មណ៍នៃភាពឆ្មើងឆ្មៃ ដែលនឹងនាំយើងទៅរកការល្បួង ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣:៣–៥ ដោយស្វែងរកភាពស្រដៀងគ្នានៅក្នុងសេចក្ដីណែនាំ ដែលព្រះអម្ចាស់បានប្រទានទៅឲ្យ ហៃរ៉ុម ស៊្មីធ សាំយូអែល ស៊្មីធ និង យ៉ូសែប ស៊្មីធ ស៊ីញ៉ ័រ ។

ការហៅឲ្យដាស់តឿន សំដៅទៅលើការទទួលខុសត្រូវដើម្បីបង្រៀនដំណឹងល្អដល់មនុស្សដទៃ ។ សូមកត់ចំណាំរបៀបដែល ហៃរុម សាំយូអែល និង យ៉ូសែប ស៊្មីធ ស៊ីញ៉ ័រ ម្នាក់ៗបានបំពេញការទទួលខុសត្រូវនេះ នៅពេលអ្នកអានព័ត៌មានខាងក្រោមនេះអំពីពួកលោក ៖

ហៃរ៉ុម ស៊្មីធ បានជួយក្នុងការបោះពុម្ពព្រះគម្ពីរមរមនដោយការធ្វើការដោយផ្ទាល់ជាមួយនឹងអ្នកបោះពុម្ព ។ គាត់បានទទួលពិធីបុណ្យជ្រមុជទឹកក្នុងខែ មិថុនា ឆ្នាំ ១៨២៩ គឺនៅមិនយូរប៉ុន្មានបន្ទាប់ពីបព្វជិតភាពត្រូវបានស្ដារឡើងវិញ ។ គាត់បានបម្រើជាប្រធានសាខាដំបូងបង្អស់របស់សាសនាចក្រនៅ ខូលស្វិល រដ្ឋ នូវ យ៉ោក ។ ដោយបានស្គាល់ពីការបន្ទាបខ្លួន និង ភក្ដីភាពរបស់គាត់ ហៃរ៉ុម មានភាពស្មោះត្រង់ចំពោះព្រះអម្ចាស់ និង សាសនាចក្រពេញមួយជីវិតរបស់គាត់ ។ គាត់បានអស់ជីវិតទៅក្នុងនាមជាបុគ្គលដែលត្រូវបានធ្វើឃាតដោយសាសនា ជាមួយនឹងប្អូនប្រុសរបសគាត់ យ៉ូសែប នៅក្នុង គុកកាតធេច រដ្ឋអិលលីណោយ ។

សាំយូអែល ស៊្មីធ ដែលជាប្អូនប្រុសរបស់ព្យាការី យ៉ូសែប ស៊្មីធ បានទទួលពិធីបុណ្យជ្រមុជទឹកក្នុងខែ ឧសភា ឆ្នាំ ១៨២៩ គឺនៅមិនយូរប៉ុន្មានបន្ទាប់ពីការស្ដារឡើងវិញនៃបព្វជិតភាពអើរ៉ុន ។ ជាញឹកញាប់ គាត់ត្រូវបានគេផ្ដល់កិត្តិយស ដោយបានធ្វើជាអ្នកផ្សព្វផ្សាយដំបូងរបស់សាសនាចក្រ ។ ក្នុងខែ មិថុនា ឆ្នាំ ១៨៣០ គាត់បានធ្វើដំណើរទៅបេសកកម្មមួយ ហើយបានដាក់លក់ព្រះគម្ពីរមរមន ដែលទីបំផុតបាននាំឲ្យមានការប្រែចិត្តជឿដល់ ព្រិកហាំ យ៉ង់ និងសមាជិកគ្រួសារគាត់ជាច្រើននាក់ទៀត ។ សាំយូអែល មានភក្ដីភាពចំពោះគ្រួសារគាត់ និងសាសនាចក្រពេញមួយជីវិតរបស់គាត់ ។

យ៉ូសែប ស៊្មីធ ស៊ីញ៉ ័រ ដែលជាឪពុករបស់ព្យាការី បានចូលរួមសាសនាក្រ នៅចំថ្ងៃដែលសាសនាចក្របានរៀបចំឡើង ។ នៅរដូវក្ដៅក្រោយមក គាត់ និងកូនប្រុសរបស់គាត់ ដុន ខាឡុស បានចាប់ផ្ដើមបេសកកម្មមួយទៅដល់គ្រួសារសាច់ញាតិនៅរដ្ឋ នូវយ៉ោក ។ គាត់បានក្លាយជាសង្ឃជាន់ខ្ពស់ម្នាក់ ហើយជាលោកអយ្យកោទីមួយនៃសាសនាចក្រ ។ នៅពិធីបុណ្យសពរបស់គាត់ គាត់ត្រូវបានពិពណ៌នាថាជា « បុរសស្មោះត្រង់ចំពោះព្រះរបស់គាត់ និង ចំពោះសាសនាចក្រក្នុងគ្រប់ស្ថានភាពទាំងអស់ និង ក្រោមកាលៈទេសៈទាំងអស់ ដែលគាត់បានឆ្លងកាត់ » ( Robert B. Thompson នៅក្នុង *History of the Church* ៤:១៩២ ) ។

បុគ្គលចុងក្រោយ ដែលព្រះអម្ចាស់បានមានព្រះបន្ទូលនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣ គឺ យ៉ូសែប ណៃ ស៊ីញ៉័រ ។ គាត់គឺជាមិត្តជិតស្និទ្ធរបស់ យ៉ូសែប ណៃត ជុញ៉័រ ហើយបានបង្ហាញសណ្ដានចិត្តដ៏ល្អសម្រាប់គាត់ ។ គាត់បានផ្ដល់ជាសម្ភារ ដល់ព្យាការី មានដូចជា ក្រដាស និង អាហារ ខណៈដែលកំពុងបកប្រែព្រះគម្ពីរមរមន ។ នៅពេលដែល គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣ ត្រូវបានទទួល យ៉ូសែប ណៃត ស៊ីញ៉័រ ពុំទាន់បានទទួលពិធីបុណ្យជ្រមុជទឹកនៅឡើយ ។ គាត់មានបំណងប្រាថ្នាចង់ទទួលពិធីបុណ្យជ្រមុជទឹកជាមួយមនុស្សដទៃទៀតនៅថ្ងៃដែលសាសនាចក្រត្រូវបានបង្កើតឡើង ប៉ុន្តែគាត់បានរង់ចាំសិន ដោយសារគាត់ចង់សិក្សាព្រះគម្ពីរមរមនបន្ថែម ។ យ៉ាងណាក៏ដោយ ក្រោយមក គាត់បានសរសេរថា « ខ្ញុំនឹង [ មាន ] អារម្មណ៍ល្អជាង បើខ្ញុំឆ្ពោះទៅមុខ » ដើម្បីទទួលពិធីបុណ្យជ្រមុជទឹកនោះ ( សូមមើល Larry Porter «The Joseph Knight Family » *Ensign* ខែ តុលា ឆ្នាំ ១៩៧៨ ទំព័រ ៤០ spelling and capitalization standardized ) ។

សូមសិក្សាការទូន្មានរបស់ព្រះអម្ចាស់ដល់ យ៉ូសែប ណៃត ស៊ីញ៉័រ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣:៦–៧ ដោយរកមើលអ្វីដែលព្រះអម្ចាស់បញ្ជាឲ្យគាត់ធ្វើ ។ ឃ្លា « លើកលីឈើឆ្កាងរបស់អ្នក » នៅក្នុងបរិបទនេះមានន័យថាធ្វើអ្វីដែលពិបាកសម្រាប់អ្នក ។

៧. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីបានជាពេលខ្លះព្រះអម្ចាស់ត្រាស់បង្គាប់ឲ្យយើងធ្វើនូវអ្វីដែលយើងពិបាកនឹងធ្វើ ?

ខ. តើមានភស្តុតាងអ្វីខ្លះ ដែលអ្នកបានឃើញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣:៧ ដែលព្រះអម្ចាស់មានព្រះបំណងប្រទានពរដល់ យ៉ូសែប ណៃត ស៊ីញ៉័រ ?

មិនយូរប៉ុន្មានបន្ទាប់ពីព្រះអម្ចាស់បានប្រទានវិវរណៈនេះ យ៉ូសែប ណៃត ស៊ីញ៉័រ បានជ្រើសរើសទទួលពិធីបុណ្យជ្រមុជទឹក ។ គាត់បានបន្តស្មោះត្រង់ចំពោះសាសនាចក្រពេញមួយជីវិតរបស់គាត់ ដោយបានការពារដល់ព្យាការី យ៉ូសែប ស៊្មីធ ដោយសម្ងាត់ និង ជាសាធារណៈ ។ ព្យាការី ក្រោយមកបានពិពណ៌នាអំពី យ៉ូសែប ណៃត ស៊ីញ៉័រ ថាជា « មនុស្សស្មោះ និងពិតត្រង់ ហើយជាជំនួយ និងជាគំរូ ហើយប្រកបដោយគុណធម៌ និងសន្ដានចិត្តល្អ ពុំដែលងាកចេទៅឆ្វេង ឬទៅស្ដាំឡើយ » ( *Teachings of Presidents of the Church: Joseph Smith* [ ឆ្នាំ ២០០៧ ] ៤៦២) ។

ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣ យើងរៀនថា **នៅពេលយើងមានបំណងប្រាថ្នាដើម្បីបម្រើព្រះអម្ចាស់ យើងអាចទទួលបានការដឹកនាំផ្ទាល់ខ្លួនមកពីទ្រង់។** យើងក៏រៀនផងដែរថា **ព្រះអម្ចាស់ នឹងប្រទានពរយើង នៅពេលយើងធ្វើតាមការណែនាំដែលទ្រង់បានប្រទានដល់យើង** ។ សូមពិចារណាអំពីការណែនាំដែលអ្នកបានទទួលមកពីព្រះអម្ចាស់ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ប្រសាសន៍របស់ព្យាការីដែលកំពុងរស់នៅ និង ព្រះគម្ពីរ ។ សូមដាក់ផែនការដើម្បីធ្វើតាមការណែនាំដែលអ្នកបានទទួល ។

៨. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២១–២៣ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៧ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤–២៦

## បុព្វកថា

សេចក្ដីបៀតបៀនទាស់នឹងព្យាការី យ៉ូសែប ស្ម៊ីធ និង សមាជិកសាសនាចក្រ បានចាប់ផ្ដើមកាន់តែខ្លាំងឡើងក្នុងរដូវក្ដៅឆ្នាំ ១៨៣០ ។ អំឡុងគ្រាដ៏តឹងតែងនេះ ព្រះអម្ចាស់បានចម្រើនកម្លាំង ហើយបានណែនាំដល់ យ៉ូសែប ស្ម៊ីធ អិមម៉ា ស្ម៊ីធ និង ថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រ តាមរយៈវិវរណៈទាំងឡាយដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤–២៦ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤

*យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ទទួលបានឱវាទអំពីការហៅរបស់ពួកលោក*

សូមគិតអំពីថ្ងៃ ឬ សប្ដាហ៍ណាមួយដែលមានសភាពលំបាក ឬ បរាជ័យ ដែលអ្នកធ្លាប់ជួបប្រទះ ។ តើអ្នកបានដោះស្រាយនឹងភាពលំបាក ដែលអ្នកបានជួបប្រទះនោះយ៉ាងដូចម្ដេច ?

ព្យាការី យ៉ូសែប ស្ម៊ីធ បានជួបនឹងគ្រាលំបាកជាច្រើននៅក្នុងជីវិតរបស់លោក ។ គ្រានោះបានកើតឡើងក្នុងរដូវក្ដៅឆ្នាំ ១៨៣០ ។ ក្នុងខែ មិថុនា ឆ្នាំ ១៨៣០ យ៉ូសែប ស្ម៊ីធ និងសហការីពីរបីនាក់ បានចេញទៅ ខូលស្វិល រដ្ឋនូវយ៉ោក ដើម្បីជួបនឹងមនុស្សដែលចាប់អារម្មណ៍ចង់ទទួលពិធីបុណ្យជ្រមុជទឹក ។ ស្ទឹងមួយកន្លែងត្រូវបានទប់ទឹកដើម្បីរៀបចំធ្វើពិធីបុណ្យជ្រមុជទឹកនៅថ្ងៃបន្ទាប់នោះ ( គឺថ្ងៃអាទិត្យ ) ប៉ុន្ដែ មានមនុស្សកំណាចមួយក្រុមបានមកទម្លាយទំនប់នោះនៅពេលយប់ ។

នៅព្រឹកថ្ងៃចន្ទ ទំនប់ទឹកត្រូវបានសង់ឡើងវិញ ហើយមនុស្សចំនួន ១៣ នាក់ត្រូវបានទទួលបុណ្យជ្រមុជទឹក រួមទាំង អិមម៉ា ស្ម៊ីធ ផង ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលពិធីបុណ្យជ្រមុជទឹកបានបង្ហើយ មានក្រុមមនុស្សកំណាចប្រមាណ ៥០ នាក់បានប្រមូលគ្នាមកជេរប្រមាថ ហើយគំរាមកំហែងថានឹងធ្វើទុក្ខទោសដល់ពួកបរិសុទ្ធ ។

នៅល្ងាចនោះដែរ ពួកបរិសុទ្ធបានជួបជុំធ្វើពិធីបញ្ជាក់ដល់អស់អ្នកដែលបានធ្វើបុណ្យជ្រមុជទឹកកាលពីព្រឹក ប៉ុន្ដែ នៅពីមុនពិធីបញ្ជាក់នោះអាចត្រូវបានធ្វើឡើង យ៉ូសែប ត្រូវគេចាប់ខ្លួនអំពីបទ « រំខានដល់អ្នកដទៃ ធ្វើឲ្យប្រទេសមានភាពចលាចលដោយការប្រកាសពីព្រះគម្ពីរមរមន » ( យ៉ូសែប ស្ម៊ីធ នៅក្នុង *History of the Church* ១:៨៨ ) ។

នៅតាមផ្លូវទៅកាន់សាលាក្ដី យ៉ូសែប បានរួចផុតពីមនុស្សកំណាចដោយមានជំនួយពីមន្ដ្រីប៉ូលីសដ៏សប្បុរសម្នាក់ ។ បន្ទាប់ពីបានចូលសាលាក្ដី ហើយបានសម្រេចក្ដីដោះលែងខ្លួនពីបទចោទប្រកាន់ទាំងឡាយហើយនោះ យ៉ូសែប ត្រូវបានចាប់ខ្លួនម្ដងទៀតភ្លាមៗនៅទីក្រុងមួយផ្សេងទៀត ។ នៅយប់នោះ យ៉ូសែប ត្រូវបានគេចំអក និងរំលោភបំពានដោយ « មនុស្សមួយក្រុមដែលប្រើគ្រប់មធ្យោបាយដើម្បីរំលោភបំពាន ចំអក ពោលពាក្យប្រមាថ » ដល់លោក ( យ៉ូសែប ស្ម៊ីធ នៅក្នុង *History of the Church,* ១:៩១ ) ។ នៅព្រឹកបន្ទាប់ យ៉ូសែប បានចូលសាលាក្ដីសាជាថ្មី ហើយលោកត្រូវបានសម្រេចក្ដីដោះលែងខ្លួនម្ដងទៀត ហើយបានរួចផុតពីមនុស្សកំណាចមួយក្រុមទៀតនៅតាមផ្លូវត្រឡប់មកផ្ទះវិញ ។

យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី បានព្យាយាមជួបជុំសមាជិកដែលទើបតែបានទទួលពិធីបុណ្យជ្រមុជទឹកនៅ ខូលស្វិល ម្ដងទៀត ប៉ុន្ដែ ក្រុមមនុស្សកំណាចបានមកប្រមូលគ្នានៅបន្ទាប់ពីពួកលោកបានទៅដល់ ។ យ៉ូសែប និង អូលីវើរ បានបង្ខំចិត្តគេចខ្លួន ហើយគ្រាន់តែពួកលោកបានភៀសខ្លួនបានបន្តិច ក្រុមមនុស្សកំណាចបានដេញតាមពួកលោកពេញមួយយប់ ។

យ៉ូសែប បានមានប្រសាសន៍អំពីគ្រាដ៏តានតឹងនេះថា « ដោយមិនគិតពីភាពឃោរឃៅទាំងឡាយដែលសត្រូវរបស់យើងមាននោះទេ យើងនៅតែមានការលួងលោមចិត្តជាច្រើន ថែមទាំងមានរឿងជាច្រើនបានកើតឡើងដើម្បីពង្រឹងសេចក្ដីជំនឿ ហើយធ្វើឲ្យចិត្តយើងរីករាយឡើង » ( នៅក្នុង *History of the Church,* ១:១០១ ចំពោះដំណើររឿងរបស់ យ៉ូសែប ស្ម៊ីធ ក្នុងព្រឹត្តិការណ៍នេះនៅ ខូលស្វិល សូមមើល *History of the Church,* ១:៨៦–៩៧ ទំព័រ ១០១ ) ។

សូមអានក្បាលជំពូកនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤ ដោយស្វែងរកគោលបំណងនៃវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤–២៦ ។

១. សូមបំពេញលំហាត់ខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមគូសតារាងពីរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមសរសេរនៅក្នុងតារាងទីមួយដាក់ចំណងជើងថា *ពង្រឹង ហើយលើកទឹកចិត្ត* សូមសរសេរនៅក្នុងតារាងទីពីរដាក់ចំណងជើងថា *ណែនាំ* ។ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤:១–១២ រួចបង្កើតបញ្ជីនៃឃ្លាទាំងឡាយណា ដែលអាចពង្រឹង ហើយលើកទឹកចិត្ត ឬ ណែនាំដល់ យ៉ូសែប និង អូលីវើរ ដាក់នៅក្នុងតារាងត្រឹមត្រូវ ។

ខ. សូមជ្រើសរើសឃ្លាមួយចេញពីតារាង ដែលមានអត្ថន័យចំពោះអ្នក ។ សូមសរសេរប្រយោគចំនួនពីរទៅបី ដោយពន្យល់អំពីរបៀបដែលការលើកទឹកចិត្ត ឬ ការណែនាំដ៏ជាក់លាក់នោះពីព្រះអម្ចាស់ អាចនឹងជួយនរណាម្នាក់ដែលកំពុងឆ្លងកាត់បទពិសោធន៍ដ៏លំបាកមួយ ។

សេចក្ដីថ្លែងការណ៍ដ៏សំខាន់មួយអំពីការលើកទឹកចិត្ត និង ការណែនាំមកពីព្រះអម្ចាស់មានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤:៨ ។ សូមសរសេរជាពាក្យរបស់អ្នកផ្ទាល់ អំពីគោលការណ៍ដែលបានបង្រៀននៅក្នុងខគម្ពីរនេះ ៖

ការឈឺចាប់គឺជាបុព្វហេតុ ឬ ស្ថានភាពនៃការរងទុក្ខ ទុក្ខព្រួយ ឬ សេចក្ដីលំបាក ។ តើអ្នកគិតថាវាមានន័យដូចម្ដេច ដើម្បី « អត់ធន់ក្នុងការឈឺចាប់ » ហើយ « ទ្រាំទ្រចុះ » ? ការអត់ធន់ និង ការទ្រាំទ្រការឈឺចាប់របស់យើងពុំមែនងាយស្រួលជានិច្ចនោះទេ ប៉ុន្តែព្រះអម្ចាស់សន្យាថា ទ្រង់នឹងគង់នៅជាមួយយើងក្នុងអស់ទាំងការឈឺចាប់នោះ ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកធ្លាប់ឃើញនរណាម្នាក់អនុវត្តការអត់ធន់ ហើយបន្តស្មោះត្រង់ខណៈទ្រាំទ្រការឈឺចាប់ដែរឬទេ ?

ខ. តើបុគ្គលនេះថ្លែងដូចម្ដេច ឬ តើអ្នកបានឃើញអ្វី ដែលបង្ហាញថាព្រះអម្ចាស់បានគង់នៅជាមួយនឹងបុគ្គលរូបនេះ ?

គ. តើការមានសេចក្ដីជំនឿថាព្រះអម្ចាស់នឹងគង់ជាមួយអ្នកនៅគ្រានៃការសាកល្បង ជួយអ្នកឲ្យមានភាពក្លាហាន និង ភាពរឹងមាំដើម្បីធ្វើកិច្ចការលំបាកៗយ៉ាងដូចម្ដេច ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤:១៣–១៩ ព្រះអម្ចាស់បានប្រទានការណែនាំបន្ថែមដល់ព្យាការី យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី អំពីរបៀបបំពេញការហៅរបស់ពួកលោក និង អំពីអ្វីដែលនឹងកើតឡើងចំពោះជនទាំងឡាយណាដែលបដិសេធ ហើយជំទាស់ពួកលោក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥

*អិមម៉ា ស្ម៊ីធ ទទួលបានឱវាទអំពីការណើយកិច្ចរបស់នាងក្នុងគ្រួសារ និង ក្នុងសាសនាចក្រ*

ដូចបានលើកឡើងពីមុនដែរថា អិមម៉ា ស្ម៊ីធ គឺជាម្នាក់ក្នុងក្រុមដែលបានទទួលពិធីបុណ្យជ្រមុជទឹកនៅ ខូលស្វិល រដ្ឋ ញូវយ៉ោក ក្នុងខែ មិថុនា ឆ្នាំ ១៨៣០ ប៉ុន្តែ ដោយសារតែមានការបៀតបៀនពីសំណាក់ក្រុមមនុស្សកំណាច នោះនាងពុំបានទទួលពិធីបញ្ជាក់រហូតដល់ដើមខែសីហា ( សូមមើល *History of the Church*, ១:១០៦ ទំព័រ ១០៨ ) ។ មានគ្រាមួយនៅចន្លោះពេលដែល អិមម៉ា បានទទួលពិធីបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់ នោះព្យាការី យ៉ូសែប បានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានប្រទានការលួងលោមចិត្ត និង ការណែនាំសម្រាប់អិមម៉ា ដែលនឹងដកពិសោធការសាកល្បង ហើយធ្វើការលះបង់ដ៏ធំធេងពេញមួយជីវិតរបស់នាង ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥ ។ បន្ទាប់មក សូមគិតអំពីការលួងលោមចិត្ត និង ឱវាទ ដែលបានប្រទាន ដល់ អិមម៉ា នៅក្នុងវិវរណៈនេះ នៅពេលអ្នកអានសេចក្ដីពិស្ដារខាងក្រោមនេះទាក់ទងនឹងជីវិតរបស់នាង ៖



អិមម៉ា ហេល ស្ម៊ីធ បានដឹងក្ដីឡើងនៅក្នុងគ្រួសារស្ដុកស្ដម មួយ ប៉ុន្តែ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ហើយ នាងបានរស់នៅក្នុងស្ថានភាពដ៏លំបាកក្រៃលែង ។ នាងបានធ្វើជាស្មៀន កាលយ៉ូសែប បានបកប្រែផ្ទាំងចំណារមាសនៅពេលទើបតែចាប់ផ្ដើមការបកប្រែ ។ ទោះជានាងបានឃើញជាញឹកញាប់នូវផ្ទាំងចំណារដាក់ទុកនៅលើតុ ដោយមានក្រណាត់ឯកទេសគ្របពីលើក្ដី ក៏នាងពុំដែលបង្ហើបក្រណាត់ដើម្បីមើលផ្ទាំងចំណារនោះដែរ ។

កូនទាំងបីនាក់ដំបូងរបស់យ៉ូសែប និង អិមម៉ាបានស្លាប់ មិនយូរប៉ុន្មានក្រោយពេលដែលបានកើតមក ។ ពេញមួយជីវិតនាង នាងបានទ្រាំទ្រការស្លាប់នៃកូនបង្កើតប្រាំនាក់ និង កូនចិញ្ចឹមម្នាក់ ។ មិនតែប៉ុណ្ណោះទេ នាង ព្រមទាំងស្វាមីរបស់នាង បានលុយកាត់សេចក្ដីបៀតបៀនឥតស្រាកស្រាន្ត ។ ពេញមួយជីវិតអាពាហ៍ពិពាហ៍របស់ពួកលោក យ៉ូសែប និង អិមម៉ា បានបង្ខំចិត្តចាកចោលផ្ទះសម្បែងខ្លួនដោយសារតែការគំរាមកំហែងពីសំណាក់ក្រុមមនុស្សកំណាច ។ ផ្ទះរបស់ អិមម៉ា ត្រូវបានមនុស្សកំណាចទម្លាយចូល ជាញឹកញាប់ នាងត្រូវផ្លាស់ទីលំនៅចេញពីផ្ទះខ្លួនទៅរស់នៅជាមួយមនុស្សដទៃ អាស្រ័យទៅលើសណ្ដានចិត្តរបស់ពួកគេដើម្បីបានទីស្នាក់នៅបណ្ដោះអាសន្ន នៅទីបំផុត យ៉ូសែបជាស្វាមីសំណព្វចិត្តរបស់នាងត្រូវបានគេចាប់យកទៅ ហើយធ្វើឃាត ។

### *ការដាក់បញ្ចូលឈ្មោះរបស់អ្នកទៅក្នុងបទគម្ពីរ*

មានម្ដងនោះ ព្រិកហាំ យ៉ង់ បានចោទជាសំណួរថា ៖ « តើអ្នកអានព្រះគម្ពីរ . . . ដូចជាអ្នកបានឈរនៅក្នុងទីតាំងរបស់ពួកបុរសដែលបានចារឹកព្រះគម្ពីរទាំងនោះដែរឬទេ ?. . . វាជាឯកសិទ្ធិរបស់អ្នកដើម្បីធ្វើដូច្នោះ ថាអ្នកអាចបានស្គាល់ព្រះវិញ្ញាណច្បាស់ និង យល់ច្បាស់អំពីអត្ថន័យនៃព្រះបន្ទូលព្រះ ដែលបានចារឹកនោះ ដូចជាអ្នកស្គាល់ និង យល់ច្បាស់ពីដំណើរ និង ការសន្ទនាប្រចាំថ្ងៃរបស់អ្នកដែរ » (*Teachings of Presidents of the Church: Brigham Young* [ ឆ្នាំ ១៩៩៧ ] ទំព័រ ១១៩) ។

៣. ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ អិមម៉ា ស្ម៊ីធ ឲ្យ « ធ្វើការជម្រើសយកទំនុកសរសើរតម្កើងព្រះដ៏ពិសិដ្ឋទាំងឡាយ . . . ដើម្បីឲ្យមាននៅក្នុងសាសនាចក្ររបស់យើង » ( គ. និង ស. ២៥:១១ ) ។ សូមពួក គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:១២ រួចឆ្លើយសំណួរខាងក្រោមនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថាឃ្លា « បទចម្រៀងពីចិត្ត » មានអត្ថន័យដូចម្ដេច ?

ខ. តើ « បទចម្រៀងនៃពួកសុចរិត » គឺជាបទអធិស្ឋានតាមរបៀបណា ?

គ. សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះ ៖

« តន្ត្រីអាចពង្រីកជីវិតរបស់អ្នក ។ តន្ត្រីអាចស្ថាង និងបំផុសដល់អ្នក និងជួយអ្នកឲ្យខិតកាន់តែជិតព្រះវរបិតាសួគ៌ ។ តន្ត្រីមាននូវឥទ្ធិពលដ៏ជ្រាលជ្រៅទៅលើគំនិត វិញ្ញាណ និង អាកប្បកិរិយារបស់អ្នក ។

ចូរជ្រើសរើសតន្ត្រីសម្រាប់ស្ដាប់ ដោយប្រុងប្រយ័ត្ន ។ សូមយកចិត្តទុកដាក់ពីអារម្មណ៍ដែលអ្នកមាន នៅពេលដែលអ្នកស្ដាប់ ។ តន្ត្រីមួយចំនួន អាចនាំមកនូវវិញ្ញាណអាក្រក់ និងសារដែលបំភ្លិចបំផ្លាញ ។ សូមកុំស្ដាប់តន្ត្រីណាដែលលើកទឹកចិត្តឲ្យមានភាពអសីលធម៌ ឬតម្កើងដល់ហិង្សាតាមរយៈទំនុក ចង្វាក់ភ្លេង ឬប្រពលភាពរបស់វាឡើយ ។ ចូរកុំស្ដាប់តន្ត្រីដែលប្រើភាសាអសុរស ឬចោកទាប ឬលើកតម្កើងការធ្វើអាក្រក់នោះឡើយ ។ តន្ត្រីប្រភេទនេះ អាចបណ្ដាលឲ្យការយល់ដឹងខាងវិញ្ញាណរបស់អ្នកចុះអន់ថយបាន » (*ដើម្បីកម្លាំងនៃយុវជន* [កូនសៀវភៅ ឆ្នាំ ២០១១ ] ទំព័រ ២២) ។

តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យខ្លួនអ្នក រុំព័ទ្ធទៅដោយតន្ត្រីដែលសក្តិសម ?

៤. យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:១៦ ឱវាទ និង ការសន្យាទាំងឡាយ ដែលត្រូវបានប្រទានដល់ អិមម៉ា ស្ម៊ីធ នៅក្នុងវិវរណៈនេះ ក៏អនុវត្តចំពោះយើងម្នាក់ៗផងដែរ ។ សូមបំពេញកិច្ចការខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ចេញពីអ្វីដែលអ្នកបានអាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥ សូមសរសេរឲ្យបានយ៉ាងហោចណាស់ បួនគោលការណ៍ ដែលអ្នកបានរៀនចេញពីឱវាទដែលបានប្រទានដល់ អិមម៉ា ។ ( ឧទាហរណ៍ **បើយើងរក្សាព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ នោះយើងនឹងទទួលបានមកុដនៃសេចក្ដីសុចរិត** [ ខទី ១៥ ] ដែលជានិមិត្តរូបនៃការទទួលបានសិរីល្អសេឡេស្ទាលក្នុងនគរព្រះ ) ។

ខ. សូមជ្រើសរើសគោលការណ៍មួយ ដែលអ្នកបានសរសេរក្នុងបញ្ជី ដែលអ្នកទទួលអារម្មណ៍ថាត្រូវនឹងអ្នក រួចសរសេរអំពីរបៀបដែលអ្នកអាចអនុវត្តគោលការណ៍នេះនៅក្នុងជីវិតរបស់អ្នកនាពេលឥឡូវនេះ ។

ព្រះអម្ចាស់បានមានព្រះបន្ទូលថា អិមម៉ា ស្ម៊ីធ គឺជា « ស្ត្រីរើសតាំងមួយរូប » ( គ. និង ស. ២៥:៣ ) ។ នៅពេលក្រោយមកទៀត ព្យាការី យ៉ូសែប ស្ម៊ីធ ត្រូវបានបង្រៀនថា « ជ្រើសតាំងមានន័យដល់ការដែលត្រូវបានជ្រើសតាំងឲ្យធ្វើកិច្ចការជាក់លាក់មួយ » ( នៅក្នុង *History of the Church,* ៤:៥៥២ ) ។ សូមរំឭក គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥ ដោយស្វែងរកអ្វីដែល អិមម៉ា ស្ម៊ីធ ត្រូវបានជ្រើសតាំង ( ត្រូវបានរើស ឬ ហៅ ) ឲ្យធ្វើនៅគ្រានេះ និង អ្វីដែលនាងត្រូវបាន « តែងតាំង » ( ប្រទានឲ្យសិទ្ធិអំណាច ) ឲ្យធ្វើ ( គ. និង ស. ២៥:៧ ) ។

ប្រមាណ ១២ ឆ្នាំក្រោយមក ប្រធាន យ៉ូហាន ថេល័រ ប្រព្រឹត្តតាមការដឹកនាំរបស់ព្យាការី យ៉ូសែប ស្ម៊ីធ បានញែក អិមម៉ា ឲ្យបម្រើជាប្រធានសមាគមសង្គ្រោះទូទៅរបស់សាសនាចក្រ ។ ប្រធាន ថេល័រ បានមានប្រសាសន៍ថា ៖ « នៅក្នុងការប្រជុំនោះ ព្យាការី បានហៅ បងស្រី អិមម៉ា ឲ្យធ្វើជាស្ត្រីរើសតាំង ។ ការណ៍នោះមានន័យថា នាងត្រូវបានហៅឲ្យធ្វើកិច្ចការជាក់លាក់មួយ ហើយថានោះគឺជាការបំពេញតាមវិវរណៈជាក់លាក់មួយ [ គ. និង ស. ២៥ ] អំពីនាង ។ នាងត្រូវបានរើសតាំងឲ្យធ្វើជាអធិបតីលើសមាគមសង្គ្រោះ ហើយនាងត្រូវបានតែងតាំងឲ្យបកស្រាយបទគម្ពីរ ។ ជាកិច្ចព្រមព្រៀងនឹងសំណើរបស់ [ បងប្រុស ] យ៉ូសែប ខ្ញុំបានញែកនាងចេញ ។. . . បងស្រី អិមម៉ា ត្រូវបានរើសតាំងជាអ្នកបកស្រាយបទគម្ពីរ និងដើម្បីធ្វើជាអធិបតីលើសមាគមសង្គ្រោះ » ( "Discourse by President John Taylor," *Deseret News,* ថ្ងៃទី ៩ ខែ មិនា ឆ្នាំ ១៨៨១ ទំព័រ ៨៣ ) ។



ម្ដាយរបស់ យ៉ូសែប ស្ម៊ីធ គឺ លូស៊ី ម៉ាក ស្ម៊ីធ បានផ្ដល់ជាសេចក្ដីបញ្ជាក់អំពី អិមម៉ា ដែលជាកូនប្រសារស្រីរបស់គាត់ថា ៖ « ខ្ញុំមិនដែលឃើញស្ត្រីណាម្នាក់ក្នុងជីវិតរបស់ខ្ញុំ ដែលបានទ្រាំទ្រវាល់ការនឿយហត់ និង ការលំបាកគ្រប់ជំពូក ពីមួយខែទៅមួយខែ ពីមួយឆ្នាំទៅមួយឆ្នាំ ដោយមានភាពក្លាហាន ថាមពល និង ការអត់ធន់ឥតរាថយ ដែលនាងបានធ្វើ ដ្បិតខ្ញុំដឹងពីអ្វីដែលនាងបានធ្វើក្នុងការអត់ធន់នោះ—គឺនាងបានធ្វើទៅដោយភាពមិនប្រាកដក្នុងចិត្តនោះទេ—គឺនាងបានរងទុក្ខសេចក្ដីបៀតបៀនពន់ពេកក្រៃ ហើយបានតស៊ូនឹងភាពឃោរឃៅនៃមនុស្ស និង ពួកអារក្ស ដែលបានយកឈ្នះលើស្ត្រីស្ទើរតែគ្រប់រូបទៅហើយ » ( *History of Joseph Smith by His Mother,* ed. Preston Nibley [ ឆ្នាំ ១៩៥៨ ] ទំព័រ ១៩០–៩១ ) ។

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីកំណត់ចំណាំខ្លីមួយនៃការដឹងគុណ និងការកោតសរសើរចំពោះស្ត្រីមួយរូប ដែលអ្នកស្គាល់ ដែលមាននូវគុណសម្បត្តិលក្ខណៈដូចជា អិមម៉ា ស្ម៊ីធ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥ និងសេចក្ដីថ្លែងការណ៍របស់ លូស៊ី ម៉ាក ស្ម៊ីធ ។ សូមពិចារណាអំពីការផ្ដល់ច្បាប់ចម្លងនៃកំណត់ចំណាំរបស់អ្នកមួយច្បាប់ទៅដល់ស្ត្រីរូបនោះ ។

## ចំណេះចំណានខគម្ពីរ—គ. និង ស. ២៥:១៣

គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:១៣ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ អ្នកអាចនឹងចង់គូសចំណាំវានៅក្នុងរបៀបមួយដែលងាយសម្គាល់ ដើម្បីអ្នកអាចងាយរកវាឃើញនៅពេលខាងមុខ ។ ឃ្លា « ចូរនៅជាប់នឹងសេចក្ដីសញ្ញាទាំងឡាយ » មានន័យថា ធ្វើតាមដោយហ្មត់ចត់ ឬ តោងជាប់នឹងសេចក្ដីសញ្ញាទាំងឡាយដែលយើងបានធ្វើជាមួយព្រះ ។ អ្នកអាចចង់សរសេរនិយមន័យនេះនៅលើគែមព្រះគម្ពីររបស់អ្នកក្បែរខគម្ពីរនោះ ។

៦. សូមពន្យល់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវអ្វីដែល គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:១៣ មានន័យចំពោះអ្នក ។

ដើម្បីជួយអ្នកឲ្យចងចាំអំពីការដាក់តឿនរបស់ព្រះអម្ចាស់ ដែលតម្រូវឲ្យអ្នកនៅជាប់នឹងសេចក្ដីសញ្ញា នោះសូមសរសេរពាក្យទាំងឡាយនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:១៣ នៅលើក្រដាសមួយសន្លឹកតូច ឬ បណ្ណមួយ ។ សូមដាក់ក្រដាសនោះតាមខ្លួនរបស់អ្នកពីរបីថ្ងៃ សូមគិតអំពីពាក្យទាំងនោះ ហើយព្យាយាមទន្ទេញវា ។ អ្នកអាចនឹងចង់សូត្រ ហើយពន្យល់អំពីអត្ថន័យនៃខគម្ពីរនេះទៅកាន់មិត្តភក្តិ ឬ សមាជិកគ្រួសារម្នាក់ នៅពេលដែលអ្នកបានទន្ទេញវាចាំហើយនោះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៦

*ព្រះអម្ចាស់ណែនាំដល់ យ៉ូសែប ស្ម៊ីធ អូលីវើរ ខៅឌើរី និង យ៉ូហាន វិតមើរ*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៦:១ ព្រះអម្ចាស់បានណែនាំដល់ យ៉ូសែប ស្ម៊ីធ អូលីវើរ ខៅឌើរី និង យ៉ូហាន វិតមើរ អំពីការងារខាងវិញ្ញាណ និង ខាងសាច់ឈាម ដែលពួកលោកត្រូវធ្វើ ។ បន្ទាប់មក ព្រះអម្ចាស់បានបង្រៀនពួកលោក អំពីគោលការណ៍សំខាន់មួយនៃការគ្រប់គ្រងសាសនាចក្រ ។

សូមស្រមៃថាមានមិត្តភក្តិម្នាក់ដែលមានជំនឿផ្សេង អង្គុយជាមួយអ្នកក្នុងការប្រជុំមួយ ដែលមានអ្នកកាន់តំណែងក្នុងសាសនាចក្រជាច្រើនត្រូវបានគាំទ្រក្នុងការហៅរបស់ពួកលោក ( ដូចជាក្នុងសន្និសីទវួដ ឬ សាខា ឬ ស្តេក ) ។ សូមគិតអំពីរបៀបដែលអ្នកនឹងពន្យល់ទៅកាន់មិត្តភក្តិរបស់អ្នកអំពីការអនុវត្តការគាំទ្រ ដល់អ្នកកាន់តំណែងខុស ៗគ្នាក្នុងសាសនាចក្រ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៦:២ រួចស្វែងរកឃ្លាមួយដែលទាក់ទងទៅនឹងការគាំទ្រ ។ អ្នកអាចនឹងចង់គូសចំណាំគោលការណ៍ **របស់ទាំងអស់នឹងត្រូវបានសម្រេច ដោយសារការយល់ព្រមទូទៅនៅក្នុងសាសនាចក្រ ។**

តើអ្នកគិតថា « ការយល់ព្រមទូទៅ » មានន័យដូចម្តេច ?

« ការយល់ព្រមទូទៅ » សំដៅលើការអនុវត្តរបស់សមាជិកសាសនាចក្រ លើការគាំទ្រដល់អស់អ្នកដែលត្រូវបានហៅឲ្យបម្រើនៅក្នុងសាសនាចក្រ ក៏ដូចជាការគាំទ្រដល់ការសម្រេចដទៃទៀតរបស់សាសនាចក្រ ដែលតម្រូវឲ្យមានការគាំទ្រពីសំណាក់សមាជិក ។ ជាធម្មតា ការណ៍នេះត្រូវបានបង្ហាញដោយការលើកដៃស្តាំ ។

មានភាពខុសគ្នារវាងការគាំទ្រដោយការសម្តែងការយល់ព្រមទូទៅ និង ការបោះឆ្នោតជ្រើសតាំង ។ នៅក្នុងនគររបស់ព្រះអម្ចាស់ ព្រះអម្ចាស់បំផុសគំនិតដល់ថ្នាក់ដឹកនាំដែលបានតែងតាំងរបស់ទ្រង់ ជាអ្នកដែលត្រូវធ្វើការសម្រេចចិត្ត ដោយសិទ្ធិអំណាចដែលទ្រង់បានប្រទានដល់ពួកលោក ។ ភ្លាមនោះ ថ្នាក់ដឹកនាំស្វែងរកការបញ្ជាក់ពីព្រះអម្ចាស់ ចំពោះការសម្រេចចិត្តរបស់ពួកលោក ។ ការលើកដៃស្តាំពុំមែនជារបៀបដែលសមាជិកបោះឆ្នោតនោះទេ ប៉ុន្តែ ជារបៀបបង្ហាញការយល់ព្រមរបស់ពួកគេ ( ឬ ការជំទាស់ ) ចំពោះការសម្រេចចិត្តដែលបានធ្វើឡើងនោះ ។



បន្ថែមពីលើការបង្ហាញការយល់ព្រម ឬ ការអនុមតិរបស់ពួកគេ នៅពេលលើកដៃស្តាំ សមាជិកក៏បង្ហាញ អំពីឆន្ទៈខ្លួនក្នុងការគាំទ្រដល់បុគ្គល ឬសកម្មភាពដែលកំពុងបង្ហាញនោះដែរ ។ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានបង្រៀនថា ៖ « នីតិវិធីនៃការគាំទ្រគឺលើសពីការលើកដៃគាំទ្រជាទំនៀមទម្លាប់មួយទៅទៀត ។ វាគឺជាការតាំងចិត្តមួយដើម្បីលើកស្ទួយ គាំទ្រជួយដល់អ្នកទាំងឡាយ ដែលត្រូវបានជ្រើសរើស » (This Work Is Concerned with People » *Ensign* ខែឧសភា ឆ្នាំ ១៩៩៥ ទំព័រ ៥១ ) ។

សូមពិចារណាអំពីអ្វីដែលអ្នកអាចធ្វើបាន ដើម្បីបំពេញការប្តេជ្ញាចិត្តរបស់អ្នកក្នុងការគាំទ្រដល់នរណាម្នាក់ ដែលត្រូវបានហៅ ហើយគាំទ្រឲ្យបម្រើអ្នកនៅក្នុងវួដ ឬ សាខារបស់អ្នក ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៤–២៦ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៧ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧

## បុព្វកថា

អិមម៉ា ស្ម៊ីធ និង មនុស្ស ១២ នាក់ទៀត រួមមាន នូវល ណៃត៍ និង សាលី ដែលជាភរិយាគាត់ បានទទួលពិធីបុណ្យជ្រមុជទឹកនៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៨៣០ នៅ ខូលស្វិល រដ្ឋ នូវ យ៉ោក ។ ទោះជាយ៉ាងណាក៏ដោយ ពួកគាត់ពុំបានទទួលពិធីបញ្ជាក់ភ្លាមៗនោះទេ ព្រោះពួកមនុស្សកំណាចក្នុងតំបន់នោះបានមកធាផៅពិធីនោះ ហើយព្យាការី យ៉ូសែប ស្ម៊ីធ ត្រូវគេចាប់ខ្លួន « អំពីបទរំខានដល់អ្នកដទៃធ្វើឲ្យប្រទេសមានភាពចលាចលដោយការប្រកាសពីព្រះគម្ពីរមរមន ជាដើម » ។ ( សូមមើល *History of the Church,* ១:៨៦–៨៨ ) ។ យ៉ូសែប ត្រូវបានដោះលែងពីបទល្មើសទាំងនោះ ប៉ុន្តែ ពួកមនុស្សកំណាចនៅតែបន្តរាំងលោកមិនឲ្យចូលទៅ ខូលស្វិល រហូតដល់ខែ សីហា ឆ្នាំ ១៨៣០ ជាពេលដែលនៅទីបំផុត លោកអាចធ្វើពិធីបញ្ជាក់ដល់អ្នកប្រែចិត្តជឿថ្មីជាច្រើននាក់ ។ ក្រោយមក យ៉ូសែប ស្ម៊ីធ បានត្រឡប់ទៅផ្ទះរបស់លោកវិញនៅភូមិហាម៉ូនី រដ្ឋផែនសីលវេញ៉ា ។

នៅដើមខែ សីហា ឆ្នាំ ១៨៣០ នូវល ណៃត៍ និង ភរិយារបស់គាត់ បានធ្វើដំណើរទៅសួរសុខទុក្ខ យ៉ូសែប និង អិមម៉ា ស្ម៊ីធ ។ ដោយសារ សាលី ណៃត៍ និង អិមម៉ា ពុំទាន់បានទទួលពិធីបញ្ជាក់នៅឡើយ នោះវាត្រូវបានសម្រេចថា ពួកគេអាចទទួលបានពិធីបញ្ជាក់ ហើយថាពួកអ្នកដែលបានប្រជុំគ្នានឹងទទួលទានសាក្រាម៉ង់ ។ នៅតាមផ្លូវដែលលោកទៅរកស្រាទំពាំងបាយជូរមកធ្វើពិធីសាក្រាម៉ង់ ព្យាការី យ៉ូសែប ស្ម៊ីធ បានជួបនឹងសារទូតមកពីស្ថានសួគ៌មួយអង្គ ហើយបានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧ ( សូមមើល *History of the Church,* ១:១០៦ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១–៤

*ព្រះអម្ចាស់ប្រទានការណែនាំអំពីតំណាងនៃពិធីសាក្រាម៉ង់*

តើអ្នកនឹងគិតដូចម្ដេច ប្រសិនបើអ្នកឃើញដំឡូងបារាំងដែលបានចិតសំបក ត្រូវបានប្រើប្រាស់សម្រាប់ពិធីសាក្រាម៉ង់ ?

ប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន បានធ្វើទស្សនកិច្ចភ្លាមៗនៅអឺរ៉ុប ដែលបានរងការខ្ទេចខ្ទាំបន្ទាប់ពីសង្គ្រាមលោកលើកទី ២ ។ នៅគ្រានោះ ពុំសូវមានអាហារសម្រាប់បរិភោគឡើយ ហើយមនុស្សជាច្រើនបានតស៊ូគ្រាន់តែឲ្យបានរស់រានមានជីវិតប៉ុណ្ណោះ ។ កង្វះអាហារបានធ្វើឲ្យសមាជិកសាសនាចក្រចាំបាច់ត្រូវជំនួសរបស់ ដែលគេប្រើប្រាស់ជាផ្នែកនៃពិធីសាក្រាម៉ង់ ។ ប្រធាន ប៊ែនសឹន នៅចាំថា ៖ « ខ្ញុំនៅតែចាំអំពីពួកបរិសុទ្ធជនជាតិបារាំង ដែលពុំអាចរកនំប៉័ងបាន ហើយបានប្រើប្រាស់ដំឡូងបារាំងដែលចិតសំបកមកធ្វើជាតំណាងនៃពិធីសាក្រាម៉ង់ » ( Prepare for the Days of Tribulation *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨០ ៣៣–៣៤ )

១. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១–២ រួចស្វែងរកអ្វីដែលទេវតា បានមានបន្ទូលប្រាប់ យ៉ូសែប ស្ម៊ីធ អំពីតំណាងនៃពិធីសាក្រាម៉ង់ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើអ្នកគិតថា ហេតុអ្វីបានជាវាអាចទទួលយកបាននៅក្នុងកាលៈទេសៈនោះ ដែលពួកបរិសុទ្ធជនជាតិបារាំងបានប្រើប្រាស់អ្វីមួយផ្សេងទៀតក្រៅពីនំប៉័ង មកធ្វើជាតំណាងពិធីសាក្រាម៉ង់ ?

ខ. យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:២ តើអ្វីដែលយើងគួរតែផ្ដោតអារម្មណ៍ទៅលើ នៅពេលយើងទទួលទានសាក្រាម៉ង់ ?

សូមបញ្ចប់គោលការណ៍តទៅនេះ ដោយបំពេញនៅក្នុងចន្លោះ ៖ **នៅពេលយើងទទួលទាន យើងត្រូវ អំពីពលិកម្មធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។**

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ការទទួលទានសាក្រាម៉ង់ « ដោយភ្នែកស្មោះត្រង់ទាំងស្រុង ចំពោះសិរីល្អ [ របស់ព្រះ ] » មានន័យដូចម្ដេច ?

ខ. តើអ្នកអាចចងចាំអំពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះបានកាន់តែពេញលេញ នៅពេលអ្នកទទួលទានសាក្រាម៉ង់ តាមរបៀបណា ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:៣–៤ ព្រះអម្ចាស់បានព្រមាន យ៉ូសែប ស្ម៊ីធ មិនឲ្យប្រើប្រាស់ស្រាទំពាំងបាយជូរ ឬ ភេសជ្ជៈដែលមានជាតិសុរា ( ភេសជ្ជៈដែលមានសារជាតិស្រវឹង ) សម្រាប់ពិធីសាក្រាម៉ង់ ដែលទិញពីខ្មាំងសត្រូវរបស់ពួកគេឡើយ ។ មានតែស្រាទំពាំងបាយជូរដែលបានផលិតឡើងដោយពួកបរិសុទ្ធប៉ុណ្ណោះ ទើបអាចប្រើប្រាស់បាន ( គ្រានោះបានកើតឡើងនៅជាងពីរឆ្នាំមុនពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ដែលមាននៅក្នុង [ គ. និង ស. ៨៩ ] ត្រូវបានបើកសម្ដែង ) ។ សព្វថ្ងៃនេះ ទឹកត្រូវបានប្រើប្រាស់ក្នុងពិធីសាក្រាម៉ង់ជំនួសឲ្យស្រាទំពាំងបាយជូរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:៥–១៤

*ព្រះអម្ចាស់នឹងទទួលទានសាក្រាម៉ង់ម្ដងទៀតនៅលើផែនដី*

សូមពិចារណាអំពីរបៀបដែលបទពិសោធន៍របស់អ្នកនៃការទទួលទានសាក្រាម៉ង់ អាចនឹងមានលក្ខណៈខុសគ្នា ប្រសិនបើអ្នកធ្វើដូច្នេះនៅក្នុងវត្តមានរបស់ព្រះអង្គសង្គ្រោះ ។

នៅពេលព្រះអង្គសង្គ្រោះ បានណែនាំអំពីពិធីបរិសុទ្ធនៃសាក្រាម៉ង់ទៅកាន់ពួកសាវកទ្រង់នៅអាហារយប់ថ្ងៃចុងក្រោយ ទ្រង់បានព្យាករអំពីគ្រាមួយ ដែលទ្រង់នឹងយាងត្រឡប់មកលើផែនដីវិញ ហើយទទួលទានសាក្រាម៉ង់ជាមួយនឹងពួកសិស្សទ្រង់ម្ដងទៀត ( សូមមើល ម៉ាថាយ ២៦:២៦–២៩ ) ។

ពេញមួយប្រវត្តិសាស្ត្រ ព្រះអម្ចាស់បានប្រទានសិទ្ធិអំណាចបព្វជិតភាពទៅដល់បុរសសុចរិត ដើម្បីបម្រើពិធីបរិសុទ្ធនៃដំណឹងល្អរបស់ទ្រង់ ។ ទ្រង់ក៏បានប្រទានកូនសោទាំងឡាយនៃបព្វជិតភាពទៅដល់ថ្នាក់ដឹកនាំបព្វជិតភាព ដើម្បីពួកលោកអាចដឹកនាំត្រួតត្រា និង និងគ្រប់គ្រងលើការប្រើប្រាស់បព្វជិតភាពរបស់ទ្រង់នៅលើផែនដី ។

៣. នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:៥–១២ យើងរៀនអំពីមនុស្សមួយចំនួន ដែលនឹងចូលរួមការប្រជុំសាក្រាម៉ង់នេះជាមួយព្រះយេស៊ូវគ្រីស្ទ ។ សូមអានខគម្ពីរទាំងនេះ រួចបង្កើតបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីបុគ្គលទាំងឡាយ ដែលនឹងចូលរួមការប្រជុំនេះ និង កូនសោ ឬ ការទទួលខុសត្រូវអ្វីដែលពួកគេមាន ប្រសិនបើមានលើកឡើង ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៣ រួចស្វែងរកកូនសោទាំងឡាយ ដែលព្រះអម្ចាស់បានប្រទានទៅដល់ព្យាការី យ៉ូសែប ស្ម៊ីធ ។ អ្នកអាចនឹងចង់គូសចំណាំឃ្លា « ការកាន់កាប់ត្រួតត្រានៃដំណឹងល្អសម្រាប់ពេលចុងក្រោយបង្អស់ និងសម្រាប់កំណត់កាលដ៏ពោរពេញ » ។ យើងរៀនចេញពីខគម្ពីរនេះថា **ការកាន់កាប់ត្រួតត្រានៃកំណត់កាលដ៏ពោរពេញនាំមកជាមួយនូវកូនសោទាំងអស់នៃដំណឹងល្អ ពិធីបរិសុទ្ធ និង សេចក្ដីពិតនៃគ្រាកាន់កាប់ត្រួតត្រាដែលបានកន្លងហួសទៅ ។**

គ្រាកាន់កាប់ត្រួតត្រាគឺជាអំឡុងពេលដែលព្រះអម្ចាស់បើកសម្ដែងនូវគោលលទ្ធិ ពិធីបរិសុទ្ធ និង បព្វជិតភាពរបស់ទ្រង់ ។ វាគឺជាអំឡុងពេលមួយ « ដែលយ៉ាងហោចណាស់ ព្រះអម្ចាស់មានអ្នកបម្រើដែលមានសិទ្ធិអំណាចម្នាក់នៅលើផែនដី ដែលកាន់បព្វជិតភាពដ៏បរិសុទ្ធ និង កូនសោទាំងឡាយ និង ជាអ្នកដែលមានការចាត់តាំងដ៏ទេវភាពដើម្បីចែកចាយដំណឹងល្អទៅដល់ប្រជាជាតិនានានៅលើផែនដី ។ នៅពេលការណ៍នេះកើតឡើង ដំណឹងល្អត្រូវបានបើកសម្ដែងសាជាថ្មី ដើម្បីកុំឲ្យមនុស្សដែលរស់នៅក្នុងគ្រាកាន់កាប់ត្រួតត្រានោះ ពឹងផ្អែកជាទូទៅលើចំណេះដឹងនៃផែនការនៃសេចក្ដីសង្គ្រោះក្នុងគ្រាកាន់កាប់ត្រួតត្រាដែលបានកន្លងហួសទៅហើយ » ( Bible Dictionary, "Dispensations" ) ។

គ្រាកាន់កាប់ត្រួតត្រារបស់យើង គឺជាគ្រាកាន់កាប់ត្រួតត្រាចុងក្រោយបង្អស់ ។ ជាញឹកញាប់វាត្រូវបានហៅថា « ការកាន់កាប់ត្រួតត្រាក្នុងកាលដែលពេលពេញកំណត់ » ដោយសារតែកូនសោទាំងអស់នៃបព្វជិតភាព ដែលព្រះអម្ចាស់បានបើកសម្ដែងសម្រាប់ជាពរជ័យនៃកូនចៅរបស់ទ្រង់ ដែលបានស្ដារឡើងវិញ ( សូមមើល អេភេសូរ ១:១០ ) ។ ព្យាការី យ៉ូសែប ស្ម៊ីធ គឺជាអ្នកនាំមុខ អ្នកដឹកនាំ ក្នុងគ្រាកាន់កាប់ត្រួតត្រានៃដំណឹងល្អនេះដូចជា អ័ដាម អេណុក ណូអេ និង ម៉ូសេ ដែលជាអ្នកនាំមុខគ្រាកាន់កាប់ត្រួតត្រានៃដំណឹងល្អកាលពីជំនាន់មុនៗ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៤ រួចស្វែងរកថាតើមាននរណាទៀត ដែលនឹងមានវត្តមាននៅក្នុងការប្រជុំសាក្រាម៉ង់ជាមួយព្រះអង្គសង្គ្រោះ ។

តើអ្នកគិតថា « អស់អ្នកណាដែលព្រះវរបិតារបស់យើងបានប្រទានដល់យើងចេញពីលោកិយផង » នោះ ព្រះអង្គសង្គ្រោះទ្រង់សំដៅទៅលើនរណា ?



អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី បានថ្លែងថា ៖ « គ្រប់មនុស្សស្មោះត្រង់ទាំងអស់នៅក្នុងប្រវត្តិសាស្ត្រពិភពលោកទាំងមូល គ្រប់មនុស្សទាំងអស់ដែលបានរស់នៅដោយស្មោះត្រង់ដូចនេះក្នុងគោលបំណងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចនៃព្រះវរបិតានោះ នឹងមានវត្តមាន ហើយនឹងទទួលទានសាក្រាម៉ង់ជាមួយព្រះអម្ចាស់ » (*The Promised Messiah: The First Coming of Christ* [ ឆ្នាំ ១៩៧៨ ] ទំព័រ ៥៩៥ ) ។

៤. សូមសរសេរឈ្មោះរបស់អ្នកនៅក្រោមបញ្ជីឈ្មោះនៃអស់អ្នកទាំងឡាយណា ដែលត្រូវបានសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ បន្ទាប់មក សូមឆ្លើយសំណួរដូចតទៅនេះ ៖ តើអ្នកមានអារម្មណ៍ដូចម្ដេច នៅពេលដឹងថា អ្នកអាចមានវត្តមាននៅក្នុងការប្រជុំសាក្រាម៉ង់ជាមួយព្រះអម្ចាស់ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៥–១៨

*ព្រះអម្ចាស់ត្រាស់បញ្ជាពួកបរិសុទ្ធរបស់ទ្រង់ឲ្យពាក់គ្រប់គ្រឿងសឹករបស់ព្រះ*

គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៥–១៨ មាននូវឱវាទ ដែលនឹងជួយយើងឲ្យមានភាពសក្ដិសមដើម្បីទទួលបានពរជ័យពីព្រះអម្ចាស់ រួមមានពរជ័យនៃការចូលរួមការប្រជុំសាក្រាម៉ង់ ដែលបានលើកឡើងនៅក្នុង ខទី ៤–១៤ ។

តើអ្នកនឹងចង់បំពាក់ទៅដោយសំលៀកបំពាក់ដូចម្ដេច ប្រសិនបើអ្នកដឹងថាអ្នកនឹងចេញទៅច្បាំង ?

៥. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៥ រួចឆ្លើយសំណួរខាងក្រោមនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើព្រះអម្ចាស់បានប្រទានឱវាទដល់យើង ឲ្យត្រៀមខ្លួនសម្រាប់ចម្បាំងខាងវិញ្ញាណរបស់យើងយ៉ាងដូចម្ដេច ?

ខ. ព្រះអម្ចាស់បានសន្យាថា **បើយើងបំពាក់គ្រប់គ្រឿងសឹករបស់ព្រះមកលើខ្លួនយើង នោះយើងនឹងអាចតតាំងនឹងថ្ងៃអាក្រក់បាន ។** តើអ្នកគិតថា « ថ្ងៃអាក្រក់ » សំដៅទៅលើអ្វី ? តើអ្នកគិតថា « ការឈរ » នៅពេលនោះមានន័យដូចម្ដេច ?

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧:១៥–១៨ រួចសរសេរឈ្មោះនៅលើចំណែកនៃគ្រឿងសឹកនីមួយៗ នៅក្នុងរូបភាពដែលមានមកជាមួយដោយពាក្យ ឬ ឃ្លាចេញពីខគម្ពីរទាំងនោះ ។



៦. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ហេតុអ្វីបានជាព្រះអម្ចាស់អញ្ជើញយើងឲ្យពាក់ *គ្រប់* គ្រឿងសឹកនៃព្រះ ?

ខ. តើលក្ខណៈនានា ដែលទាក់ទងនឹងចំណែកនីមួយៗនៃគ្រឿងសឹក អាចការពារយើងទាស់នឹងការល្បួង និង សេចក្ដីអាក្រក់បានយ៉ាងដូចម្ដេច ?

គ. តើអ្នកធ្លាប់ទទួលបានអារម្មណ៍នៃការការពារនៅក្នុងជីវិតអ្នក នៅពេលអ្នកព្យាយាមពាក់គ្រឿងសឹកនៃព្រះតាមរបៀបណា ?

សូមពិចារណាអំពីការណ៍ដែលអ្នកអាចធ្វើ ដើម្បីពាក់គ្រប់គ្រឿងសឹកនៃព្រះបានយ៉ាងពេញលេញ ដោយគិតអំពីថាតើ មានចំណុចណាខ្លះទៀតនៅក្នុងជីវិតអ្នកដែលត្រូវការពង្រឹង ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៧ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៧ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨

## បុព្វកថា

នៅចន្លោះខែ មេសា និង ខែ កញ្ញា ឆ្នាំ ១៨៣០ សមាជិកសាសនាចក្រមួយចំនួនបានយល់ច្រឡំអំពីគោលការណ៍ទាំងឡាយ ដែលគ្រប់គ្រងវិវរណៈក្នុងសាសនាចក្រ ។ ការយល់ច្រឡំទាំងនេះ បានបង្កើតបានជាឧបសគ្គចំពោះព្យាការី យ៉ូសែប ស្ម៊ីធ ។ ក្នុងវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨ ព្រះអម្ចាស់បានបើកសម្ដែងសេចក្ដីពិត ដែលបានផ្ដល់ជាដំណោះស្រាយចំពោះឧបសគ្គទាំងនោះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:១–៧

*ព្រះអម្ចាស់ពន្យល់ថា វិវរណៈដើម្បីគ្រប់គ្រងលើសាសនាចក្រទ្រង់ គឺត្រូវបានប្រទានតាមរយៈព្យាការីរបស់ទ្រង់ដែលបានតែងតាំង ។*

មានឧទាហរណ៍ជាច្រើននៅលើលោកនេះអំពីការណ៍ដែលក្លែងត្រាប់តាមការណ៍ទាំងឡាយដែលត្រឹមត្រូវ ពិតប្រាកដ និងប្រសើរជាង ។ តើនៅពេលណា ដែលវាអាចនឹងធ្វើឲ្យមានការខូចខាត ក្នុងការដែលធ្វើកំហុសតាមការណ៍ក្លែងក្លាយ ដោយយល់ថាវាជាអ្វីដែលពិតនោះ ?

ភាពក្លែងក្លាយខាងវិញ្ញាណគឺជាគ្រោះថ្នាក់ដ៏កាចសាហាវមួយ ។ អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានព្រមានថា ៖ « អារក្សគឺជាបិតានៃសេចក្ដីកុហក ហើយវាអន្ទះអន្ទែងក្នុងការធ្វើឲ្យកិច្ចការរបស់ព្រះមានភាពស្មុគស្មាញដោយភាពក្លែងក្លាយដ៏ឈ្លាសវៃរបស់វា » ( Two Lines of Communication," *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ៨៤ ) ។

សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨ នៅក្នុងព្រះគម្ពីររបស់អ្នក ។ នៅពេលអ្នកអាន សូមស្វែងរកភាពក្លែងក្លាយដែលសាតាំងបានប្រើ ដើម្បីបញ្ឆោតសមាជិកមួយចំនួននៅជំនាន់ដំបូងនៃសាសនាចក្រ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

ដោយសារតែហាក់បីដូចជាឃើញមានភាពស្រដៀងគ្នារវាងការប្រកាសរបស់ ហៃរ៉ាំ ភេច អំពីការទទួលបានវិវរណៈតាមរយៈត្បូង និងរបៀបដែលពួកគេបានគិតថា ព្រះបានបើកសម្ដែងសេចក្ដីពិតទៅដល់ព្យាការី យ៉ូសែប ស្ម៊ីធ នោះសមាជិកសាសនាចក្រ រួមបញ្ចូលទាំង អូលីវើរ ខៅឌើរី ផងដែរនោះ អាចទំនងជាជឿទៅលើវិវរណៈក្លែងក្លាយ ដែលសាតាំងបានបង្ហាញដល់ ហៃរ៉ាំ ភេច ។ នៅពេលអ្នកសិក្សាអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់មានបន្ទូលទៅកាន់ អូលីវើរ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨ សូមស្វែងរកសេចក្ដីពិតដ៏មានសារៈសំខាន់ ដែលអាចការពារអ្នកពីការយល់ខុសដោយភាពក្លែងក្លាយ និង ការក្លែងបន្លំរបស់សាតាំង ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:១–៥ ។ សេចក្ដីពិតដ៏មានសារៈសំខាន់ ដែលយើងរៀនគឺថា **ប្រធាននៃសាសនាចក្រ គឺជាបុគ្គលតែម្នាក់គត់ ដែលអាចទទួលបានវិវរណៈសម្រាប់សាសនាចក្រទាំងមូល** ។ អ្នកអាចនឹងចង់សរសេរគោលការណ៍នេះ ក្បែរខគម្ពីរទាំងនេះនៅលើគែមនៃព្រះគម្ពីររបស់អ្នក ។

១. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើការស្គាល់ពីគោលការណ៍នេះ អាចជួយសមាជិកសាសនាចក្រ ចៀសឲ្យផុតពីការបំភាន់បានយ៉ាងដូចម្ដេច ?

ខ. តើមានភាពខុសគ្នាដូចម្ដេចខ្លះ រវាងការទទួលខុសត្រូវរបស់ អូលីវើរ ខៅឌើរី ក្នុងនាមជាអែលឌើរទីពីរក្នុងសាសនាចក្រ និង ការទទួលខុសត្រូវរបស់ យ៉ូសែប ស្ម៊ីធ ក្នុងនាមជាប្រធាននៃសាសនាចក្រ ?

មិនយូរប៉ុន្មានពីមុនព្រះអម្ចាស់បានប្រទានវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨ មានការណ៍មួយបានកើតឡើង ដែលបង្ហាញពីការដែល អូលីវើរ ខៅឌើរី ពុំបានយល់ច្បាស់អំពីភាពខុសគ្នារវាងការទទួលខុសត្រូវរបស់គាត់នៅក្នុងសាសនាចក្រ និង តួនាទីរបស់ យ៉ូសែប ស្ម៊ីធ ក្នុងនាមជាព្យាការី និង ជាប្រធាននៃសាសនាចក្រ ។

កាលកំពុងរស់នៅ ភូមិហារម៉ូនី រដ្ឋផែនសីលវេញ៉ា យ៉ូសែប ស្ម៊ីធ បានទទួលសំបុត្រមួយច្បាប់ពី អូលីវើរ ខៅឌើរី ដែលរស់នៅ ភូមិហ្វាយែត រដ្ឋនូវ យ៉ោក ។ ព្យាការីបានកត់ត្រាថា ៖



« គាត់បានសរសេរមកប្រាប់ខ្ញុំថា គាត់បានឃើញថាមានភាពខុសឆ្គងមួយនៅក្នុងព្រះបញ្ញត្តិ [ ក្នុងវិវរណៈដែលសព្វថ្ងៃនេះមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា កណ្ឌទី ២០] ហើយបានបន្ថែមថា ៖ ‹ ខ្ញុំបញ្ជាលោកនៅក្នុងព្រះនាមនៃព្រះ ឲ្យលុបពាក្យពេចន៍ទាំងនោះចេញ ដើម្បីកុំឲ្យមានឧបាយកល្បផ្នែកសង្ឃកើតមានឡើងក្នុងចំណោមពួកយើង ! ›

« រំពេចនោះ ខ្ញុំបានសរសេរតបទៅគាត់វិញ ដោយបានសួរគាត់ថាតាមរយៈសិទ្ធិអំណាចអ្វី ដែលគាត់បានលើកដាក់នៅលើខ្លួន ដើម្បីបញ្ជាខ្ញុំឲ្យកែប្រែ ឬ លុបចោល បន្ថែម ឬ បន្ថយ ចេញពីវិវរណៈ ឬ ព្រះបញ្ញត្តិដែលទទួលបានពីព្រះដ៏មានគ្រប់ព្រះចេស្ដាយ៉ាងដូច្នេះ ។

« ប៉ុន្មានថ្ងៃក្រោយមក ខ្ញុំបានទៅជួបគាត់ និង ក្រុមគ្រួសាររបស់លោក វិតមើរ ហើយខ្ញុំបានឃើញគ្រួសារនោះកំពុងមានគំនិតព្រួយបារម្ភចំពោះពាក្យពេចន៍ទាំងនោះ. . . ហើយវាមិនមែនជាការប្រឹងប្រែងដ៏តិចតួច និង មិនសូវស្ទិតស្ទាញក្នុងការបញ្ចុះបញ្ចូលពួកគេ ឲ្យយល់ឲ្យបានច្បាស់ទៅលើប្រធានបទនេះនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ. . .នៅទីបំផុត. . . ខ្ញុំសម្រេចបានជោគជ័យមិនត្រឹមតែជាមួយក្រុមគ្រួសារ វិតមើរ នោះទេ គឺថែមទាំងធ្វើឲ្យ អូលីវើរ ខៅឌើរី ទទួលស្គាល់ថា ពួកគេពិតជាមានគំនិតខុសឆ្គងប្រាកដមែន » ( នៅក្នុង *History of the Church* ១:១០៥ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:៦–៧ រួចស្វែងរកការណែនាំ ដែលព្រះអម្ចាស់បានប្រទានដល់ អូលីវើរ ខៅឌើរី ។ ខទី ៦ ជួយយើងឲ្យយល់ថា **នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ សមាជិកម្នាក់ៗ ពុំទទួលបានវិវរណៈ ដើម្បីណែនាំដល់នរណាម្នាក់ដែលធ្វើជាអធិបតីលើពួកគេឡើយ ។**



ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនថា ៖ « វាមានសភាពខុសស្រឡះពីរបៀបរបស់ព្រះចំពោះសមាជិកសាសនាចក្រ ឬ មនុស្សគ្រប់គ្នា ដើម្បីទទួលបានការណែនាំសម្រាប់អ្នកដែលមានសិទ្ធិអំណាច ដែលមានតំណែងខ្ពស់ជាងខ្លួន ហេតុដូច្នេះហើយ អ្នកនឹងឃើញមានភាពខុសឆ្គងក្នុងការស្ដាប់តាមបង្គាប់ពួកលោក ប៉ុន្តែ ប្រសិនបើបុគ្គលណាម្នាក់មានការនិមិត្ត ឬ ការយាងមកជួបរបស់សារទូតពីស្ថានសួគ៌ វាត្រូវតែជាប្រយោជន៍ និង សេចក្ដីណែនាំសម្រាប់ខ្លួនគេផ្ទាល់ ដ្បិត គោលការណ៍គ្រឹះ ការគ្រប់គ្រង និង គោលលទ្ធិនៃសាសនាចក្រ ត្រូវបានប្រទានឲ្យនៅក្នុងកូនសោទាំងឡាយនៃនគរស្រេចទៅហើយ » (*ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* [ ឆ្នាំ ២០០៧ ] ទំព័រ ១៩៧–៩៨) ។

២. សូមឆ្លើយសំណួរដូចតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការយល់ដឹង និង ការធ្វើតាមគោលការណ៍ទាំងឡាយនៃការគ្រប់គ្រងការទទួលបានវិវរណៈនៅក្នុងសាសនាចក្រ ជួយអ្នកឲ្យទ្រទ្រង់ ហើយគាំទ្រថ្នាក់ដឹកនាំសាសនាចក្ររបស់យើងយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:៨–១០

*ព្រះអម្ចាស់ត្រាស់ហៅ អូលីវើរ ខៅឌើរី ឲ្យផ្សព្វផ្សាយដំណឹងល្អទៅកាន់ពួកសាសន៍លេមិន*

សូមមើលទៅតួនាទី និង ការហៅដែលមាននៅក្នុងបញ្ជីខាងក្រោម រួចគូសរង្វង់លើអ្នកទាំងឡាយណា ដែលអ្នកគិតថាមានសិទ្ធិទទួលបានវិវរណៈដើម្បីជួយពួកគេបំពេញការទទួលខុសត្រូវរបស់ខ្លួន ។

| | | | |
|---|---|---|---|
| ឪពុកម្ដាយ | អ្នកមានសិទ្ធិអំណាចទូទៅ | គ្រូបង្រៀន ឬ សួរសុខទុក្ខតាមផ្ទះ | ប៊ីស្សព ឬ ប្រធានសាខា |
| គ្រូបង្រៀនថ្នាក់សាលាថ្ងៃអាទិត្យ | អ្នកផ្សព្វផ្សាយសាសនា | ប្រធានកូរ៉ុមគ្រូ ឬ ម៉ែម៉េត | ប្រធានសមាគមសង្គ្រោះ |

យើងអាចស្វែងយល់អំពីបុគ្គល ដែលមានសិទ្ធិទទួលបានវិវរណៈ ដើម្បីជួយក្នុងការបំពេញការទទួលខុសត្រូវខ្លួនចេញពីអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ អូលីវើរ ខៅឌើរី នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:៨–១០ ។ សូមអានខគម្ពីរទាំងនេះ រួចស្វែងរកការណ៍ដែលព្រះអម្ចាស់បានត្រាស់ហៅ អូលីវើរ ឲ្យធ្វើ ។

នៅក្នុងព្រះគម្ពីរមរមន វាក្យសព្ទ *ពួកសាសន៍លេមិន* សំដៅទៅលើក្រុមមនុស្សដ៏ជាក់លាក់មួយក្រុម ដែលមួយចំនួនជាប់ខ្សែស្រឡាយរបស់លេមិន ដែលជាកូនប្រុសច្បងរបស់លីហៃ ។ វាក្យសព្ទ *ពួកសាសន៍លេមិន* នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:៨ សំដៅទៅលើពួកអាមេរិកាំងជនជាតិដើម ដែលរស់នៅលើព្រំដែនប៉ែកបច្ចឹមនៃសហរដ្ឋ ដែលមួយចំនួនអាចជាប់ខ្សែស្រឡាយរបស់ប្រជាជននៅក្នុងព្រះគម្ពីរមរមន ។

សូមគូសចំណាំការសន្យា និង ឱវាទ ដែលព្រះអម្ចាស់បានប្រទានដល់ អូលីវើរ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:៨ ដែលនឹងជួយយើងឲ្យស្គាល់បុគ្គល ដែលមានសិទ្ធិទទួលបានវិវរណៈ ដើម្បីជួយពួកគេបំពេញការទទួលខុសត្រូវរបស់ខ្លួន ។

ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ អូលីវើរ ខៅឌើរី ថា គាត់អាចទទួលបានវិវរណៈ ដើម្បីជួយខ្លួនគាត់ក្នុងកិច្ចការផ្សព្វផ្សាយសាសនា ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:៨ ជួយយើងឲ្យយល់ថា **យើងអាចនឹងទទួលបានវិវរណៈសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន និង ដើម្បីជួយយើងបំពេញការហៅ និង ការចាត់តាំងដែលបានប្រគល់ដល់យើង ។**

អ្នកអាចគូសរង្វង់លើតួនាទី និង ការហៅនីមួយៗ ដែលមាននៅក្នុងបញ្ជី នៅពេលចាប់ផ្ដើមនៃកណ្ឌនេះ ព្រោះបុគ្គលម្នាក់ៗទាំងនោះ មានសិទ្ធិទទួលបានវិវរណៈក្នុងការបំពេញការទទួលខុសត្រូវរៀងៗខ្លួន ។ តើអ្នកគិតថា បុគ្គលទាំងនេះទទួលបានវិវរណៈដើម្បីជាគុណប្រយោជន៍សម្រាប់នរណា ? តើការទទួលបានវិវរណៈសម្រាប់បុគ្គលទាំងឡាយណាដែលពួកគេមានការទទួលខុសត្រូវលើនោះ ជួយពួកគេយ៉ាងដូចម្ដេច ?

សូមគិតអំពីរបៀបដែលវិវរណៈអាចជួយអ្នកក្នុងជីវិតផ្ទាល់ខ្លួន ឬ ក្នុងការហៅ ឬ ការចាត់តាំងដែលអ្នកមាននៅក្នុងសាសនាចក្រ ។

ប្រធាន ប៊យដ៏ ឃេ ផាកកឺ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានព្រមានថា វិវរណៈផ្ទាល់ខ្លួនពុំមែនមានដើម្បីឲ្យបុគ្គលម្នាក់ទទួលបានវិវរណៈ ទៅដឹកនាំបុគ្គលម្នាក់ទៀត ដែលធ្វើជាអធិបតីលើបុគ្គលនោះ ហើយផ្ដល់ដំបូន្មានអំពីវិវរណៈផ្ទាល់ខ្លួនដែលគាត់មាននោះទេ ៖



« វិវរណៈកើតឡើងតាមរបៀបដ៏ត្រឹមត្រូវនៅក្នុងសាសនាចក្រ ។ យើងអាចទទួលបានវិវរណៈផ្ទាល់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ លើកលែងតែយើងត្រូវបានញែកចេញក្នុងតំណែងជាអធិបតីមួយចំនួន បើមិនដូច្នោះទេ យើងនឹងមិនអាចទទួលបានវិវរណៈចំពោះអ្វីដែលមនុស្សដទៃគួរតែធ្វើឡើយ ។

« វិវរណៈក្នុងសាសនាចក្រ កើតមានដល់អ្នកទាំងឡាយដែលត្រូវបានហៅ បានគាំទ្រ បានតែងតាំង ឬបានញែកចេញដោយត្រឹមត្រូវ ។. . .

« បទពិសោធន៍ខាងវិញ្ញាណមិនប្រក្រតីមួយ គួរតែពុំត្រូវបានចាត់ទុកថាជាការហៅផ្ទាល់ខ្លួនដើម្បីដឹកនាំមនុស្សដទៃឡើយ ។ វាគឺជាភាពជឿជាក់របស់ខ្ញុំថា បទពិសោធន៍នៃលក្ខណៈសម្បត្តិពិសេស ពិសិដ្ឋ គឺជារឿងផ្ទាល់ខ្លួន ហើយគួរតែត្រូវបានរក្សាទុកសម្រាប់ខ្លួនឯង ។

« ការណ៍មួយចំនួនរំខានដល់ដំណើរការនៃវិវរណៈខ្លាំងបំផុត នៅពេលអ្នកដែលយល់ច្រឡំ ហើយគិតថាពួកគេត្រូវបានរើសឲ្យណែនាំមនុស្សដទៃ កាលពួកគេពុំត្រូវបានរើសទាល់តែសោះនោះ » ( Revelation in a Changing World," *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៩ ទំព័រ ១៤–១៥ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:១១–១៦

*ព្រះអម្ចាស់ណែនាំ អូលីវើរ ខៅឌើរី ឲ្យកែតម្រូវ ហៃរ៉ាំ ភេច ហើយជួយផ្សះផ្សាសាសនាចក្រឡើងវិញ*

សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨ ឡើងវិញ ។ បន្ទាប់មក សូមអានការណែនាំរបស់ព្រះអម្ចាស់ទៅដល់ អូលីវើរ ខៅឌើរី នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:១១–១៤ ។ តើ អូលីវើរ ត្រូវបានបញ្ជាឲ្យធ្វើអ្វីដើម្បីជួយដោះស្រាយបញ្ហាជាមួយ ហៃរ៉ាំ ភេច ?

ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:១១–១៤ យើងរៀនថា **ថ្នាក់ដឹកនាំសាសនាចក្រមានការទទួលខុសត្រូវ ដើម្បីកែតម្រូវអ្នកទាំងឡាយណាដែលកំពុងដឹកនាំមនុស្សដទៃឲ្យដើរផ្លូវខុស ។** សូមកត់ចំណាំឃ្លា « អ្នកត្រូវនាំ ហៃរ៉ាំ ភេច ជាបងប្អូនរបស់អ្នក ដោយមានតែអ្នក ហើយនឹងគាត់ » ( គ. និង ស. ២៨:១១ ) ។ ការណ៍នេះបង្រៀនថា ការកែតម្រូវគួរតែត្រូវបានធ្វើឡើងដោយសម្ងាត់ និង ប្រុងប្រយ័ត្ន ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:១៣ ក៏បង្រៀនផងដែរថា **អ្វីៗគ្រប់យ៉ាងនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ត្រូវតែធ្វើឡើងដោយមានសណ្ដាប់ធ្នាប់ ។**

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨:១៥–១៦ ដើម្បីសិក្សាអំពីឱវាទចុងក្រោយ ដែលព្រះអម្ចាស់បានប្រទានដល់ អូលីវើរ ខៅឌើរី ។ មិនយូរប៉ុន្មានបន្ទាប់ពី ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨ នោះមានសន្និសីទមួយត្រូវបានរៀបចំឡើង ។ យ៉ូសែប ស្ម៊ីធ បានសរសេរថា « ប្រធានបទអំពីត្បូងដែលបានលើកឡើងពីដំបូងនោះ ត្រូវបានពិភាក្សា ហើយបន្ទាប់ពីការស្រាវជ្រាវយ៉ាងល្អិតល្អន់ បងប្រុស [ ហៃរ៉ាំ ] ភេច ក៏ដូចជាសមាជិកក្នុងសាសនាចក្រទាំងមូលដែលមានវត្តមាន បានប្រកាសបដិសេធត្បូងដែលបាននិយាយដល់នោះ និង ការណ៍គ្រប់យ៉ាងដែលទាក់ទងនឹងវា ដើម្បីជាការស្កប់ចិត្ត និង សុភមង្គលដល់យើង » ( នៅក្នុង *History of the Church* ១:១១៥ ) ។

៣. ដើម្បីជួយអ្នកអនុវត្តគោលការណ៍ និង គោលលទ្ធិទាំងឡាយដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨ សូមអានសេចក្ដីថ្លែងខាងក្រោមនេះ បន្ទាប់មក សរសេរសេចក្ដីពិតសំខាន់ៗ ដែលអ្នករៀនចេញពីមេរៀននៅថ្ងៃនេះ ដែលអ្នកមានអារម្មណ៍ថាគួរអនុវត្តល្អបំផុត ។ សេចក្ដីពិតទីមួយត្រូវបានឆ្លើយសម្រាប់ជាឧទាហរណ៍ដល់អ្នក ។

ក. អ្នកកំពុងរៀបចំដើម្បីឡើងនិយាយក្នុងការប្រជុំសាក្រាម៉ង់ ហើយបានរកឃើញខគម្ពីរ ប្រសាសន៍ដកស្រង់ និង ដំណើររឿងជាច្រើនដែលអ្នកអាចបញ្ចូលទៅក្នុងការឡើងនិយាយរបស់អ្នក ។ អ្នកពុំប្រាកដថាត្រូវប្រើប្រាស់មួយណា ឬ ត្រូវនិយាយអ្វីនោះទេ ។

គោលការណ៍ ៖ **យើងអាចនឹងទទួលបានវិវរណៈសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន និង ដើម្បីជួយយើងបំពេញការហៅ និង ការចាត់តាំងដែលបានប្រគល់ដល់យើង ។**

ខ. អ្នកទទួលបានសារអេឡិចត្រូនិកមួយ ដែលប្រកាសថាមានព័ត៌មានស្ដីពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មាននោះពុំស្របទៅនឹងការបង្រៀនរបស់ព្យាការីដែលកំពុងរស់នៅឡើយ ។

គ. មិត្តភក្ដិម្នាក់មិនសូវសប្បាយចិត្តនឹងប៊ីស្សពរបស់នាង ដែលគាត់ទើបតែបានហៅប្រធានថ្នាក់យុវនារីថ្មីម្នាក់នៅក្នុងវួដរបស់នាង ។ មិត្តភក្ដិរបស់អ្នកមានអារម្មណ៍ថា មនុស្សផ្សេងទៀតគួរតែត្រូវបានហៅឲ្យធ្វើកិច្ចការនេះ ។

ឃ. បងស្រីរបស់អ្នកបានដើរលេងជាគូជាមួយនឹងសមាជិកសាសនាចក្រម្នាក់ ។ គាត់បានប្រាប់នាងថា ក្នុងនាមជាអ្នកកាន់បព្វជិតភាពម្នាក់ គាត់ទទួលបានវិវរណៈថា នាងគួរតែរៀបការជាមួយគាត់ ។ ទោះជាយ៉ាងណាក៏ដោយ នាងបានអធិស្ឋានអំពីការសម្រេចចិត្តនេះ ហើយពុំទាន់បានទទួលចម្លើយច្បាស់លាស់មួយឡើយ ផ្ទុយទៅវិញ នាងមានអារម្មណ៍ថាច្របូកច្របល់ក្នុងចិត្ត និង ត្រូវគេដាក់សម្ពាធលើ ។

៤. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៨ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៧ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១–៣០

## បុព្វកថា

នៅមិនយូរប៉ុន្មានពីមុនសន្និសីទសាសនាចក្រថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៨៣០ ព្រះអម្ចាស់បានប្រទានវិវរណៈដែលមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩ « នៅក្នុងវត្តមានពួកអែលឌើរប្រាំមួយនាក់ » (ក្បាលកណ្ឌ គ. និង ស. ២៩ ) ។ សេចក្ដីណែនាំទាំងឡាយនៅក្នុងវិវរណៈនេះ អនុវត្តចំពោះអស់អ្នកទាំងឡាយដែលត្រូវបានហៅឲ្យប្រកាសដំណឹងល្អ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១–៥

*ព្រះអម្ចាស់ថ្លែងទីបន្ទាល់អំពីដង្វាយធួន និង ព្រះបំណងទ្រង់ក្នុងការប្រមូលរាស្ត្ររបស់ទ្រង់ ។*

តើអ្នកធ្លាប់ឆ្ងល់ថាតើព្រះនឹងស្រឡាញ់ ការពារ ហើយអភ័យទោសដល់អ្នកដែរឬទេ ? សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១–៥ រួចស្វែងរករបៀបដែលព្រះអង្គសង្គ្រោះស្រឡាញ់ ការពារ ហើយអភ័យទោសដល់យើង ។

យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:២ តើព្រះអង្គសង្គ្រោះបានប្រៀបធៀបព្រះអង្គទ្រង់ទៅនឹងអ្វី ?

នៅពេលមេមាន់ដឹងថាមានគ្រោះថ្នាក់ វានឹងកៀងកូនរបស់វា ។ កូនៗរបស់វានឹងរត់មករកវា ហើយវានឹងប្រមូលកូនៗទាំងនោះនៅក្រោមស្លាបរបស់វាដើម្បីការពារ ។ វានឹងលះបង់ខ្លួនដើម្បីជួយសង្គ្រោះកូនៗរបស់វា ។



សូមពិចារណាអំពីការណ៍ដែលកូនមាន់ត្រូវតែធ្វើ ដើម្បីមានសុវត្ថិភាពនៅក្រោមការការពាររបស់មេ ។ តើអាចនឹងមានអ្វីកើតឡើងដល់កូនមាន់ បើពួកវាពុំធ្វើទៅតាមអ្វីដែលវាត្រូវតែធ្វើទេនោះ ? តើព្រះអង្គសង្គ្រោះមានលក្ខណៈដូចជាមេមាន់ដែលក្រុងការពារកូនវាយ៉ាងដូចម្ដេច ?

សូមរំពឹក គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:២ រួចគិតអំពីអ្វីដែលយើងត្រូវតែធ្វើ ដើម្បីត្រូវបានប្រមូលមកឯព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យបានសុខសុវត្ថិភាព ។ សូមគូសចំណាំពាក្យ ឬ ឃ្លានៅក្នុង ខទី ១–២ ដែលបង្រៀនអំពីសេចក្ដីពិតនេះថា ៖ **ព្រះយេស៊ូវគ្រីស្ទ នឹងប្រមូលយើងទាំងអស់គ្នានៅក្រោមព្រះពាហុនៃសេចក្ដីមេត្តាករុណាទ្រង់ បើយើងស្ដាប់តាមព្រះសូរសៀងទ្រង់ បន្ទាបខ្លួន ហើយអំពាវដល់ទ្រង់ក្នុងការអធិស្ឋាន ។** ( សូមចងចាំពាក្យ *ចូរស្ដាប់តាម* មានន័យថា ស្ដាប់ដោយយកចិត្តទុកដាក់ ហើយគោរពប្រតិបត្តិតាម ) ។



១. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើអ្នកអាចធ្វើអ្វី ដើម្បីស្ដាប់តាមព្រះសូរសៀងរបស់ព្រះអម្ចាស់នាពេលនេះក្នុងជីវិតរបស់អ្នក ? តើអ្នកអាចធ្វើអ្វីបានទៀត ?

ខ. តើអ្នកធ្លាប់មានអារម្មណ៍ថាខិតកាន់តែជិតព្រះអង្គសង្គ្រោះ ដោយការស្ដាប់តាមព្រះសូរសៀងរបស់ទ្រង់ ឬ តាមរយៈការអធិស្ឋានយ៉ាងដូចម្ដេច ?

គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៥ ចាប់ផ្ដើមជាមួយឃ្លា « ចូរលើកចិត្តអ្នកឡើង ហើយអរសប្បាយចុះ » ។ ( អ្នកអាចនឹងចង់គូសចំណាំឃ្លាទាំងនេះ នៅក្នុងព្រះគម្ពីររបស់អ្នក ) ។ ហេតុអ្វីបានជាព្រះអម្ចាស់បានមានព្រះបន្ទូលថា ពួកគេគួរតែអរសប្បាយ ? តើយើងអាចរៀនអ្វីខ្លះចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១–៥ អំពីមូលហេតុដែលយើងអាចលើកចិត្តយើងឡើង ហើយអរសប្បាយ ?

គោលការណ៍ដែលយើងអាចរៀនគឺថា **ដោយសារព្រះយេស៊ូវគ្រីស្ទ បានធ្វើឲ្យធួននឹងអំពើបាបទាំងឡាយរបស់យើង និង ជាព្រះដ៏គាំទ្រចំពោះព្រះវរបិតា នោះយើងអាចលើកចិត្តយើងឡើង ហើយអរសប្បាយ ។** អ្នកអាចនឹងចង់សរសេរសេចក្ដីពិតនៅលើគែមព្រះគម្ពីររបស់អ្នកក្បែរ ខទី ៥ ។

២. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបដែលដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ បាននាំមកនូវសុភមង្គល និង សេចក្ដីអំណរទៅដល់ជីវិតរបស់អ្នក ឬ ជីវិតរបស់មនុស្សដែលអ្នកស្គាល់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៦–១៣

*ព្រះយេស៊ូវគ្រីស្ទ នឹងប្រមូលអ្នកដែលទ្រង់បានរើសតាំង ដើម្បីរៀបចំសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ។*

បន្ទាប់ពីយើងទទួលបានទីបន្ទាល់មួយអំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទហើយនោះ យើងមានទំនួលខុសត្រូវមួយដើម្បីចែកចាយដំណឹងនេះជាមួយមនុស្សដទៃ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៧–៨ ដោយស្វែងរកបុគ្គល ដែលព្រះអម្ចាស់មានព្រះទ័យឲ្យពួកអែលឌើរទាំងនេះ ប្រមូលតាមរយៈការប្រកាសដំណឹងល្អរបស់ពួកគេ ។ តើព្រះអម្ចាស់បានមានព្រះបន្ទូលដូចម្ដេចអំពីអ្នកដែលទ្រង់បានរើស ខទី ៧ ?

៣. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ ចេញពីអ្វីដែលអ្នកបានរៀនអំពីអ្នកដែលព្រះអម្ចាស់បានរើស តើអ្នកអាចធ្វើអ្វីនៅក្នុងជីវិតអ្នក ដើម្បីក្លាយជាម្នាក់ដែលព្រះបានរើស ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១០–១៣ ព្រះអង្គសង្គ្រោះបានបង្រៀនថា ទ្រង់នឹង « សម្ដែង [ ព្រះកាយទ្រង់ ] ពីស្ថានសួគ៌ ដោយព្រះចេស្ដា និង សិរីល្អដ៏ធំ » ( ខទី ១១ ) ឬ យើងអាចនិយាយបានម៉្យាងទៀតថា ទ្រង់នឹងយាងមកពីស្ថានសួគ៌មកផែនដីម្ដងទៀត ហើយទ្រង់នឹងសោយរាជ្យនៅក្នុងសេចក្ដីសុចរិតអស់ ១,០០០ ឆ្នាំ ។ នៅពេលទ្រង់យាងមកម្ដងទៀត ដោយមានទាំងពួកសាវករបស់ទ្រង់ឈរ « ខាងស្ដាំដៃ » ទ្រង់ ( ខទី ១២ ) នោះទ្រង់នឹងជំនុំជម្រះរាស្ត្រនៅលើផែនដី ហើយពួកសុចរិតដែលបានស្លាប់ទៅនឹងបានរស់ឡើងវិញ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១៤–២១

*ព្រះអម្ចាស់ពិពណ៌នាអំពីទីសម្គាល់មួយចំនួន ដែលនឹងកើតឡើងមុនការយាងមកជាលើកទីពីររបស់ទ្រង់*

ទោះជាគ្មានបុគ្គលណាម្នាក់នៅលើផែនដី ដឹងអំពីពេលវេលានៃការយាងមកជាលើកទីពីរយ៉ាងណាក្ដី ក៏ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ពីទីសម្គាល់ ដែលនឹងកើតឡើងពីមុនការយាងមកជាលើកទីពីរដែរ ដើម្បីឲ្យពួកសុចរិតអាចបានត្រៀមខ្លួនជាស្រេច ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១៤–២១ រួចគូសចំណាំព្រឹត្តិការណ៍មួយចំនួន ដែលនឹងកើតឡើងពីមុនការយាងមកជាលើកទីពីរ ។

៤. សូមពិពណ៌នានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបដែលការស្គាល់ទីសម្គាល់នានានៃការយាងមកជាលើកទីពីរ អាចជួយយើងឲ្យបន្តស្មោះត្រង់ ។

ការចងចាំអំពីរឿងប្រដូចនៃមេមាន់កៀងកូនរបស់វា នឹងជួយអ្នកឲ្យយល់អំពីសារលិខិតរបស់ព្រះអង្គសង្គ្រោះនៅក្នុងខគម្ពីរទាំងនេះ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១៧ រួចស្វែងរកការណ៍ ដែលនឹងកើតឡើងចំពោះអ្នកដែលពុំស្ដាប់តាមសេចក្ដីអំពាវនាវរបស់ព្រះអង្គសង្គ្រោះ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១៧ យើងរៀនអំពីគោលការណ៍ដែលថា **បើយើងពុំប្រែចិត្តទេនោះ ព្រះលោហិតដ៏ធួនរបស់ព្រះអង្គសង្គ្រោះនឹងមិនសម្អាតយើងឡើយ ។**

សូមពិចារណាថាតើមានអ្វីមួយក្នុងជីវិតអ្នក ដែលអ្នកត្រូវប្រែចិត្ត និង អ្វីដែលអ្នកត្រូវតែធ្វើដើម្បីបានស្អាតស្អំដែរឬទេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:២២–៣០

*សហស្សវត្សរ៍ និង សេចក្ដីជំនុំជម្រះចុងក្រោយ*

បន្ទាប់ពីបានបង្រៀនអំពីការយាងមកជាលើកទីពីរ ព្រះអម្ចាស់បានបង្រៀនពួកបរិសុទ្ធអំពីអ្វី ដែលនឹងកើតឡើងបន្ទាប់ពីសហវត្ស ។ សហស្សវត្សរ៍ គឺជារយៈពេលនៃសេចក្ដីសុខសាន្ត ១,០០០ ឆ្នាំ ដែលនឹងចាប់ផ្ដើមនៅពេលព្រះគ្រីស្ទយាងត្រឡប់មកសោយរាជ្យដោយព្រះអង្គទ្រង់នៅលើផែនដី ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:២២–៣០ រួចស្វែងរកអ្វីដែលនឹងកើតឡើងបន្ទាប់ពីសហស្សវត្សរ៍ ។ ( វាអាចនឹងជួយអ្នកឲ្យដឹងថា មីកែល ជាមហាទេវតា ដែលបានលើកឡើងនៅក្នុងខទី ២៦ គឺជា អ័ដាម [ សូមមើល គ. និង ស. ១០៧:៥៤ ] ) ។

សូមពិចារណាអំពីរបៀបដែលការស្គាល់ពីសេចក្ដីពិតទាំងនេះ អាចបានជួយពួកអ្នកផ្សព្វផ្សាយសាសនាកាលពីជំនាន់ដំបូងឲ្យបំពេញការហៅរបស់ខ្លួនបានកាន់តែប្រសើរឡើង ក្នុងការប្រកាសដំណឹងល្អ ហើយប្រមូលអ្នកដែលទ្រង់បានរើស ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:២៧ ម្ដងទៀត ដោយស្វែងរកពរជ័យដែលបានប្រទានដល់អស់អ្នកដែលត្រូវបានប្រមូលនៅឯព្រះអង្គសង្គ្រោះ ។ អ្នកអាចនឹងចង់គូសចំណាំ ពាក្យ ឬ ឃ្លា ដែលបង្រៀនពីគោលការណ៍នេះ ៖ **អស់អ្នកដែលបានរស់នៅដោយសុចរិត ហើយមករកព្រះយេស៊ូវគ្រីស្ទ នឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។**

៥. សូមពិចារណាពីទីដែលអ្នកឈរក្នុងការខិតខំរបស់អ្នក ដើម្បីមករកព្រះយេស៊ូវគ្រីស្ទ ។ តើអ្នកអាចធ្វើអ្វីខ្លះដើម្បីខិតជិតទ្រង់ ? សូមសរសេរចម្លើយរបស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១–៣០ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៨ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣១–៥០

## សេចក្ដីផ្ដើម

នៅមិនយូរប៉ុន្មានពីមុនសន្និសីទសាសនាចក្រថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៨៣០ ព្រះអម្ចាស់បានប្រទានវិវរណៈដែលមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩ « នៅក្នុងវត្តមានពួកអែលឌើរប្រាំមួយនាក់ » ( ក្បាលកណ្ឌ គ. និង ស. ២៩ ) ។ នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:១–៣០ នៅអំឡុងមេរៀនមុន អ្នកបានរៀនអំពីការប្រមូលអ្នកដែលព្រះអម្ចាស់បានរើស និង ការស្ថាបនាទីក្រុង ស៊ីយ៉ូន ឡើង ។ មេរៀននេះផ្ដោតទៅលើគុណៈសម្បត្តិនៃការធ្លាក់របស់អ័ដាម ដែលបើកសម្ដែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣១–៥០ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣១–៣៥

*ព្រះអង្គសង្គ្រោះពន្យល់ថា គ្រប់ការណ៍ទាំងអស់សុទ្ធតែជាការណ៍ខាងវិញ្ញាណចំពោះទ្រង់*

សូមពិចារណាអំពីរបៀប ដែលយើងឆ្លើយតបទៅនឹងស្ថានភាពខាងក្រោម ៖

**ស្ថានភាពទី ១** ៖ សូមស្រមៃថាមានមិត្តភក្តិអ្នកម្នាក់ ដែលកំពុងមានឥរិយាបថមិនសមរម្យ ដែលអ្នកដឹងថានឹងមានទុក្ខទោសដល់ខ្លួនគាត់ ។ ក្នុងឱកាសមួយ អ្នកព្យាយាមលើកទឹកចិត្តមិត្តភក្តិរបស់អ្នក ឲ្យបញ្ឈប់ឥរិយាបថនេះ ប៉ុន្តែ គាត់ប្រាប់អ្នកថា ជម្រើសរបស់គាត់នេះពុំមែនជាបញ្ហាអ្វីនោះទេ ព្រោះគ្មានអ្វីអាក្រក់បានកើតឡើងចំពោះគាត់ឡើយ ។ តើគោលការណ៍នៃដំណឹងល្អមួយណា ដែលអាចជួយមិត្តភក្តិរបស់អ្នក ឲ្យយល់អំពីសារៈសំខាន់នៃជម្រើសរបស់គាត់ ?

**ស្ថានភាពទី ២** ៖ សូមនឹកស្រម៉ៃថា មានមិត្តភក្តិម្នាក់បានមករកអ្នក ហើយនិយាយថា មានអារម្មណ៍បាក់ទឹកចិត្តបន្តិចបន្តួច ។ នាងប្រាប់អ្នកថា នាងពុំដឹងថាតើការរក្សាព្រះបញ្ញត្តិមានតម្លៃស្មើនឹងការខិតខំដែរឬទេ ។ នាងពន្យល់ថា ទោះជានាងបានព្យាយាមគោរពតាមព្រះបញ្ញត្តិនានាក្ដី ក៏នាងពុំឃើញថា ស្ថានភាពរបស់នាងមានសភាពល្អប្រសើរជាងជីវិតរបស់មិត្តភក្តិនាង ដែលជ្រើសរើសធ្វើអំពើបាបនោះដែរ ។ តើគោលការណ៍នៃដំណឹងល្អមួយណា ដែលអាចជួយមិត្តភក្តិរបស់អ្នក ឲ្យបន្តគោរពប្រតិបត្តិ ?

នៅពេលអ្នកសិក្សាអំពីផ្នែកចុងក្រោយនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩ សូមស្វែងរកគោលការណ៍ និង គោលលទ្ធិ ដែលអាចប្រើប្រាស់បាន ដើម្បីជួយបុគ្គលទាំងឡាយណាដែលមានស្ថានភាពដូចនេះ ។

ក្នុងឆ្នាំ ១៨៣០ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ត្រូវបានស្ដារឡើងវិញ ហើយរៀបចំឡើងម្ដងទៀតនៅលើផែនដី ហើយភាពពោរពេញនៃដំណឹងល្អត្រូវបានបើកសម្ដែងដល់សមាជិកសាសនាចក្រ តាមរយៈព្យាការី យ៉ូសែប ស៊្មីធ ។ នៅក្នុងវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩ ព្រះអម្ចាស់បានជួយពួកបរិសុទ្ធថ្ងៃចុងក្រោយ ឲ្យយល់កាន់តែច្បាស់អំពីការធ្លាក់របស់អ័ដាម ហើយបានបើកសម្ដែងពីគោលបំណងនៃព្រះបញ្ញត្តិរបស់ទ្រង់ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣១–៣៣ បង្រៀនថា ព្រះបានបង្កើតគ្រប់ការណ៍ទាំងអស់ខាងវិញ្ញាណ ។ អត្ថន័យមួយនៃការណ៍នេះគឺថា ការណ៍ទាំងនោះអាចកើតឡើងនៅក្នុងវត្តមានទ្រង់ ហើយពុំចេះស្លាប់ឡើយ ។ ទ្រង់បានរៀបចំរបៀបមួយសម្រាប់ការបង្កើតរបស់ទ្រង់ដើម្បីក្លាយទៅជាខាងសាច់ឈាម មានន័យថា ការបង្កើតទាំងនោះនឹងបែកចេញពីវត្តមានរបស់ទ្រង់ ហើយត្រូវតែស្លាប់ ។ ព្រះក៏បានបង្កើតរបៀបមួយដើម្បីឲ្យការបង្កបង្កើតរបស់ទ្រង់យកឈ្នះលើសេចក្ដីស្លាប់ ហើយត្រឡប់ទៅឯវត្តមានរបស់ទ្រង់វិញ ។ នេះគឺជាផ្នែកទាំងអស់នៃផែនការរបស់ទ្រង់ ដើម្បីប្រទានឱកាសទៅដល់កូនចៅទ្រង់ឲ្យប្រែក្លាយដូចជាទ្រង់ដែរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣៤–៣៥ រួចស្វែងយល់ ថាតើព្រះអម្ចាស់ទ្រង់ចាត់ទុកព្រះបញ្ញត្តិទាំងឡាយ ដែលទ្រង់ប្រទានដល់ពួកយើងនោះថាជាអ្វី ។ សូមកត់ចំណាំសេចក្ដីពិតនេះនៅក្នុងបទគម្ពីររបស់អ្នក ៖ **ព្រះបញ្ញត្តិទាំងអស់របស់ព្រះសុទ្ធតែជាខាងវិញ្ញាណ ។** ព្រះបញ្ញត្តិនីមួយៗដែលព្រះប្រទានឲ្យ មានគោលបំណងខាងវិញ្ញាណ ហើយត្រូវបានបង្កើតឡើងដើម្បីជួយយើងឲ្យត្រឡប់ទៅឯវត្តមានរបស់ទ្រង់វិញ ។

១. សូមពិចារណាអំពីពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ទុកជាឧទាហរណ៍មួយនៃគោលលទ្ធិដែលថា ព្រះបញ្ញត្តិទាំងឡាយរបស់ព្រះទាំងអស់សុទ្ធតែជាខាងវិញ្ញាណ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើការគោរពប្រតិបត្តិតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ អាចមានឥទ្ធិពលមកលើយើងខាងសាច់ឈាមយ៉ាងដូចម្ដេច ?

ខ. តើការគោរពប្រតិបត្តិតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ អាចមានឥទ្ធិពលមកលើយើងខាងវិញ្ញាណយ៉ាងដូចម្ដេច ?

វាអាចនឹងមានលទ្ធផលខាងសាច់ឈាមដែលបណ្ដាលមកពីការមិនគោរពប្រតិបត្តិតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ប៉ុន្តែ លទ្ធផលដ៏ធំជាងគេនោះគឺ លក្ខណៈខាងវិញ្ញាណ ជាពិសេសចំពោះសមាជិកសាសនាចក្រ ដែលបានធ្វើសេចក្ដីសញ្ញាដើម្បីគោរពប្រតិបត្តិតាមព្រះបញ្ញត្តិនោះ ។ ដោយសារតែព្រះបញ្ញត្តិទាំងឡាយរបស់ព្រះគឺសុទ្ធតែជាខាងវិញ្ញាណ រួមបញ្ចូលទាំងពាក្យសម្ដីនៃប្រាជ្ញាវាងវៃផងដែរនោះ ការគោរពប្រតិបត្តិនាំមកនូវពរជ័យខាងវិញ្ញាណនៅក្នុងជីវិតរបស់យើង ។ ផ្ទុយទៅវិញ ការមិនគោរពប្រតិបត្តិចំពោះព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ រារាំងយើងពីការទទួលបាន ឬ បណ្ដាលឲ្យយើងបាត់បង់ពរជ័យខាងវិញ្ញាណ ។



សូមពិចារណាអំពីរបៀបដែលការដឹងថាព្រះបញ្ញត្តិទាំងឡាយរបស់ព្រះសុទ្ធតែជាខាងវិញ្ញាណ អាចជួយបុគ្គលទាំងឡាយដែលស្ថិតនៅក្នុងស្ថានភាព ដែលអ្នកបានអានកាលចាប់ផ្ដើមមេរៀននេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣៦–៤១

*ការធ្លាក់របស់អ័ដាមនាំឲ្យមានសេចក្ដីស្លាប់ខាងសាច់ឈាម*

ខណៈពេលដែលព្រះប្រទានព្រះបញ្ញត្តិដើម្បីប្រទានពរយើងខាងវិញ្ញាណ នោះសូមកត់ចំណាំនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣៥ ដែលទ្រង់អនុញ្ញាតឲ្យយើងធ្វើជាភ្នាក់ងារចំពោះខ្លួនយើងផ្ទាល់ ។ ការណ៍នេះមានន័យថា ព្រះប្រទានសិទ្ធិជ្រើសរើសដល់កូនចៅទ្រង់ ហើយអនុញ្ញាតឲ្យពួកគេជ្រើសរើសថាតើ នឹងគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទ្រង់ដែរឬទេ ។

២. សូមគូសតារាងខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ បន្ទាប់មក សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣៦–៤១ រួចបំពេញជម្រើស និងលទ្ធផលនៃមនុស្ស ឬ ក្រុមមនុស្សនោះ ៖

| | ជម្រើស | លទ្ធផល |
|---|---|---|
| អារក្ស | | |
| « មួយភាគបីនៃពួកពលបរិវារស្ថានសួគ៌ » | | |
| អ័ដាម | | |

សូមគិតពីការសរសេរគោលការណ៍តទៅនេះ ដាក់ក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ៖ **ព្រះបានប្រទានអំណោយនៃសិទ្ធិជ្រើសរើស ដើម្បីធ្វើការជ្រើសរើស ហើយទទួលបានលទ្ធផលនៃជម្រើសទាំងនោះ ។**

ពីមុនអ័ដាម បានទទួលទានផ្លែដែលហាមឃាត់ គាត់បានរស់នៅលើផែនដីនៅក្នុងសួនច្បារអេដែន ហើយអាចរស់នៅក្នុងវត្តមានរបស់ព្រះ ។ បន្ទាប់ពីគាត់បានទទួលទានផ្លែនោះ គាត់នៅតែអាចរស់នៅលើផែនដីបាន ប៉ុន្តែ គាត់ពុំអាចរស់នៅក្នុងវត្តមានរបស់ព្រះបានទៀតនោះទេ ។ ដោយសារតែអ័ដាម បានបណ្ដោយខ្លួនទៅតាមការល្បួង ហើយបានទទួលទានផ្លែដែលហាមឃាត់នោះយើងទាំងអស់គ្នាស្ថិតនៅក្នុងស្ថានភាពខាងសាច់ឈាមមួយ ( ដែលចេះស្លាប់ ) ហើយបែកចេញពីវត្តមានរបស់ព្រះ ។ យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤១ តើការបែកចេញនេះត្រូវបានហៅថាដូចម្ដេច ?

៣. សូមគូសដ្យាក្រាមខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖




លើដ្យាក្រាមនេះ សូមសរសេរនៅក្រោមឃ្លា « ផែនដីដែលបានធ្លាក់ ( ខាងសាច់ឈាម ) » ថា ៖ **សេចក្ដីស្លាប់ខាងវិញ្ញាណ គឺជាការដែលត្រូវបានកាត់ចេញពីវត្តមានរបស់ព្រះ ។** បន្ទាប់មក សូមឆ្លើយសំណួរដូចតទៅនេះ ៖ តើអ្នកគិតថា ហេតុអ្វីបានជាវាជាកាចាំបាច់សម្រាប់យើង ដើម្បីបែកចេញពីវត្តមានរបស់ព្រះមួយរយៈពេល ?

សូមអានសេចក្ដីថ្លែងការណ៍ដូចតទៅនេះ អំពីការធ្លាក់ និង មូលហេតុដែលយើងត្រូវតែបែកចេញពីព្រះមួយរយៈ ៖ « ការធ្លាក់គឺជាផ្នែកមួយយ៉ាងសំខាន់ នៃផែនការនៃសេចក្ដីសង្គ្រោះរបស់ព្រះវរបិតាសួគ៌ ( សូមមើល នីហ្វៃទី២ ២:១៥–១៦; ៩:៦ ) ។ វាមានទិសដៅពីរ—ធ្លាក់ចុះ ដើម្បីរីកចម្រើន ។ បន្ថែមទៅលើការណែនាំអំពីការស្លាប់ខាងសាច់ឈាម និង ខាងវិញ្ញាណ វាបានផ្ដល់ឲ្យយើងនូវឱកាសកើតមកលើផែនដីនេះ ដើម្បីរៀន និង អភិវឌ្ឍ » (*ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* [ ឆ្នាំ ២០០៤ ] ទំព័រ ៥៧ សូមមើលផងដែរ នីហ្វៃទី២ ២:២៥ ) ។

អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនអំពីការធ្លាក់ដូចតទៅនេះថា ៖



« ព្រឹត្តិការណ៍ដ៏សំខាន់បំផុតដែលធ្លាប់មាន ឬ ដែលនឹងកើតឡើងនៅក្នុងគ្រប់ទាំងភាពអស់កល្ប . . . គឺជាការបង្កើត ការធ្លាក់ និង ដង្វាយធួន ។

« មុនពេលយើងអាចចាប់ផ្ដើមយល់អំពីការបង្កើតអ្វីៗទាំងអស់ខាងសាច់ឈាម យើងត្រូវតែដឹងពីរបៀប និង តាមវិធីណាដែលភាពពិតដ៏អស់កល្បទាំងបីនេះ —ការបង្កើត ការធ្លាក់ និង ដង្វាយធួន— គឺត្រូវត្បាញជាប់គ្នាបំបែកមិនបានដើម្បីបង្កើតជាផែនការសង្គ្រោះមួយ ។ គ្មានចំណុចណាមួយនៅឈរម្នាក់ឯងឡើយ ចំណុចមួយៗភ្ជាប់ទៅនឹងចំណុចពីរទៀត ហើយដោយគ្មានចំណេះដឹងមួយនៃចំណុចទាំងអស់ នោះវាមិនអាចទៅរួចទេ ដែលដឹងពីសេចក្ដីពិតអំពីចំណុចវានីមួយៗនោះ ។. . .

« . . . សូមឲ្យចងចាំថា ដង្វាយធួនបានមកដោយសារការធ្លាក់ ។ ព្រះគ្រីស្ទបង់ថ្លៃសម្រាប់អំពើរំលងរបស់អ័ដាម ។ ប្រសិនបើគ្មានការធ្លាក់ទេនោះ នឹងគ្មានដង្វាយធួនដែលភ្ជាប់មកជាមួយនូវអមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដែលជាលទ្ធផលរបស់វានោះទេ ។ ហេតុដូច្នេះហើយ វាប្រាកដជាក់ដូចជាសេចក្ដីសង្គ្រោះកើតមានតាមរយៈដង្វាយធួន ដូច្នេះ សេចក្ដីសង្គ្រោះក៏កើតមានដោយសារតែការធ្លាក់ដែរ ។

« ជីវិតរមែងស្លាប់ និង ការបង្កបង្កើត និង សេចក្ដីស្លាប់ សុទ្ធតែមានការចាប់ផ្ដើមរបស់វាជាមួយនឹងការធ្លាក់ » ( Christ and the Creation," *Ensign* ខែ មិថុនា ឆ្នាំ ១៩៨២ ទំព័រ ៩ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤២–៥០

*ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ប្រោសយើងពីសេចក្ដីស្លាប់ខាងវិញ្ញាណ*

សូមពិចារណាអំពីសំណួរដូចតទៅនេះ ៖ តើនរណានឹងត្រឡប់ទៅឯវត្តមានរបស់ព្រះវិញ ?

ដើម្បីយល់អំពីការបង្រៀនរបស់ព្រះអម្ចាស់ដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩ វាចាំបាច់ដែលត្រូវដឹងថា មនុស្សទាំងអស់នឹងត្រឡប់ទៅឯវត្តមានរបស់ព្រះវិញ បន្ទាប់ពីបានរស់ឡើងវិញ ។ នេះគឺដោយសារតែដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ប្រោសមនុស្សលោកទាំងអស់ពីអានុភាពនៃការធ្លាក់ខាងសាច់ឈាម និង ខាងវិញ្ញាណ ( សូមមើល ហេលេមិន ១៤:១៥–១៨ ) ។

៤. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរនៅផ្នែកខាងស្ដាំនៃដ្យាក្រាម ក្រោមឃ្លា « វត្តមានរបស់ព្រះ » ថា ៖ **តាមរយៈដង្វាយធួន នោះមនុស្សលោកទាំងអស់នឹងត្រូវបានប្រោសពីសេចក្ដីស្លាប់ខាងសាច់ឈាម និង ខាងវិញ្ញាណ ដែលបណ្ដាលមកពីការធ្លាក់របស់អ័ដាម ។** បន្ទាប់មក សូមឆ្លើយសំណួរដូចតទៅនេះ ៖ បើយើងទាំងអស់គ្នានឹងត្រូវបាននាំទៅឯវត្តមានរបស់ព្រះនៅទីបំផុតនោះ តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ទោះជាយើងបានធ្វើជម្រើសត្រឹមត្រូវ ឬ អត់ កាលនៅលើផែនដីនោះ ?



តាមរយៈដង្វាយធួនទ្រង់ ព្រះយេស៊ូវគ្រីស្ទ បានប្រទានការអភ័យទោស និង ជីវិតដ៏នៅអស់កល្បជានិច្ច ដល់អស់អ្នកទាំងឡាយណា ដែលអនុវត្តសេចក្ដីជំនឿលើទ្រង់ ហើយប្រែចិត្តចេញពីអំពើបាបរបស់ខ្លួន ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤២–៤៣ រួចស្វែងរកការណ៍ ដែលយើងត្រូវធ្វើដើម្បីមានភាពសក្ដិសម ដើម្បីបាននៅក្នុងវត្តមានរបស់ព្រះជានិច្ច ។ សូមពិចារណាអំពីការណ៍ទាំងឡាយ ដែលអ្នកអាចធ្វើដើម្បីប្រែចិត្ត ដើម្បីអ្នកអាចបាននៅក្នុងវត្តមានរបស់ព្រះជានិច្ច ។

ទោះជាមនុស្សលោកទាំងអស់នឹងបានរស់ឡើងវិញ ហើយបានប្រោសពីសេចក្ដីស្លាប់ខាងវិញ្ញាណ និង ត្រូវបាននាំត្រឡប់ទៅវត្តមានរបស់ព្រះដើម្បីទទួលការជំនុំជម្រះយ៉ាងណាក្ដី ក៏មិនមានន័យថា មនុស្សគ្រប់គ្នានឹងទៅទីនោះជាដរាបនោះទេ ។

៥. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមគូសនៅផ្នែកខាងស្ដាំនៃដ្យាក្រាមដោយនូវសញ្ញាព្រួញមួយចេញពីវត្តមានរបស់ព្រះ ។ បន្ទាប់មក សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤៤–៤៥ រួចឆ្លើយនឹងសំណួរខាងក្រោមនេះ ៖

ក. តើជម្រើសណាខ្លះ ដែលធ្វើឲ្យមនុស្សមិនមានភាពសក្ដិសមដើម្បីបាននៅក្នុងវត្តមានរបស់ព្រះជានិច្ច ?

ខ. តើអ្វីជាលទ្ធផលនៃជម្រើសរបស់ពួកគេ ?

៦. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នៅក្បែរបន្ទាត់ដាច់ៗក្នុងដ្យាក្រាមថា ៖ **អ្នកទាំងឡាយណា ដែលពុំអនុវត្តសេចក្ដីជំនឿ ឬ ប្រែចិត្ត ពុំអាចបាននៅក្នុងវត្តមានរបស់ព្រះជានិច្ចឡើយ ។**

ខាងក្រោមនេះ បង្ហាញអំពីទម្រង់ដែលដ្យាក្រាមរបស់អ្នកគួរតែលេចឡើងនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖



៧. សូមរំឭកអំពីស្ថានភាពចំនួនពីរ ដែលបានពិភាក្សានៅពេលចាប់ផ្ដើមនៃមេរៀននេះ ។ បន្ទាប់មកសូមឆ្លើយសំណួរខាងក្រោមនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកបានរៀនអ្វីខ្លះនៅថ្ងៃនេះ ដែលអាចជួយមិត្តភក្តិក្នុងស្ថានភាពទី ១ ?

ខ. តើអ្នកបានរៀនអ្វីខ្លះនៅថ្ងៃនេះ ដែលអាចជួយមិត្តភក្តិក្នុងស្ថានភាពទី ២ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៤៩ រួចគិតអំពីការរំពឹងទុកទាំងឡាយ ដែលព្រះអម្ចាស់បានតម្រូវពីអ្នក ។ សូមដាក់គោលដៅដើម្បីបន្តអនុវត្តដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ នៅក្នុងជីវិតរបស់អ្នក តាមរយៈការប្រែចិត្តពីអំពើបាបទាំងឡាយរបស់អ្នក និង ការត្រៀមខ្លួនអ្នកដើម្បីបានរស់នៅក្នុងវត្តមានរបស់ព្រះម្ដងទៀត ។

៨. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ២៩:៣១–៥០ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៨ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០–៣២

## សេចក្ដីផ្ដើម

ក្នុងវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០ ព្រះអម្ចាស់បានប្រទានការណែនាំដល់ ដាវីឌ វិតមើរ ពេត្រុស វិតមើរ ជុញ្ញ័រ និង យ៉ូហាន វិតមើរ ។ ថូម៉ាស ប៊ី ម៉ាស ទទួលបានការហៅឲ្យផ្សាយដំណឹងល្អ ដូចបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១ ។ ក្នុងវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣២ ព្រះអម្ចាស់បានហៅ ប៉ាលី ភី ប្រាត្ត និង សៃបា ភីតើសុន ឲ្យចេញបេសកកម្មផ្សាយដំណឹងល្អទៅកាន់ពួកសាសន៍លេមិន ។ នៅពេលអ្នកសិក្សាកណ្ឌទាំងនេះ សូមកត់ចំណាំអំពីឱវាទ និង ការសន្យាទាំងឡាយដែលព្រះអម្ចាស់បានប្រទានដល់អ្នកផ្សព្វផ្សាយសាសនាទាំងនេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០

*ព្រះអម្ចាស់ត្រាស់ហៅ ដាវីឌ វិតមើរ ពេត្រុស វិតមើរ ជុញ្ញ័រ និង យ៉ូហាន វិតមើរ ឲ្យផ្សាយដំណឹងល្អ ។*

សូមគិតស្រមៃ ថាតើការទទួលបានការហៅបម្រើព្រះអម្ចាស់ ជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង មានសភាពបែបណា ? សូមសរសេរអារម្មណ៍ ដែលអ្នកគិតថាអាចមាន នៅពេលទទួលបានការហៅដូចនោះ ៖

ព្រះអម្ចាស់បានត្រាស់ហៅពួកបងប្អូនប្រុស វិតមើរ ទាំងបីនាក់គឺ ដាវីឌ ពេត្រុស ជុញ្ញ័រ និង យ៉ូហាន ឲ្យផ្សាយដំណឹងល្អ ហើយបានប្រទានឱវាទជាក់លាក់ទៅដល់ពួកគាត់រៀងៗខ្លួន ។

សូមអានខគម្ពីរចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០ នៅក្នុងប្រអប់ទីមួយក្នុងតារាងខាងក្រោម រួចស្វែងរកគោលការណ៍នៅក្នុងប្រអប់ទីពីរ ដែលត្រូវបានបង្រៀននៅក្នុងខគម្ពីរទាំងនោះ ។ សូមសរសេរលិខិតនៃសេចក្ដីថ្លែងការណ៍នៅលើបន្ទាត់ក្បែរឈ្មោះ និង សេចក្ដីយោងបទគម្ពីរ ។ ចម្លើយដែលត្រឹមត្រូវគឺមាននៅខាងចុងនៃមេរៀននេះ ។

| | |
|---|---|
| ____ ១. ដាវីឌ ( ខទី ១–៤ )<br>____ ២. ពេត្រុស ( ខទី ៥–៨ )<br>____ ៣. យ៉ូហាន ( ខទី ៩–១១ ) | ក. **យើងគួរតែបម្រើព្រះអម្ចាស់ឲ្យអស់ពីព្រលឹងយើង ព្រោះទ្រង់នឹងគង់នៅជាមួយនឹងយើង ។**<br>ខ. **ផ្ទុយពី ការភោគខ្លាចមនុស្ស យើងគួរតែពឹងផ្អែកលើភាពរឹងមាំពីព្រះអម្ចាស់ ។**<br>គ. **យើងត្រូវគាំទ្រ ហើយទ្រទ្រង់ អ្នកទាំងឡាយណា ដែលព្រះអម្ចាស់បានហៅឲ្យដឹកនាំកិច្ចការរបស់ទ្រង់ ។** |

១. សូមជ្រើសរើសគោលការណ៍អក្សរដិតមួយនៅក្នុងតារាងមុននេះ ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីស្ថានភាពមួយ ដែលអ្នកអាចនឹងជួបប្រទះ ដែលគោលការណ៍នេះអាចមានអត្ថប្រយោជន៍ជាពិសេសសម្រាប់អ្នក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:១–៨

*ព្រះអម្ចាស់បានហៅ ថូម៉ាស ប៊ី ម៉ាស ឲ្យផ្សាយដំណឹងល្អ ហើយជួយស្ថាបនាសាសនាចក្រ*

សូមគិតអំពីក្រុមគ្រួសាររបស់អ្នក និង អារម្មណ៍ដែលអ្នកមានចំពោះពួកគេ ។ តើមាននរណាម្នាក់ក្នុងគ្រួសារអ្នក ដែលពុំមែនជាសមាជិកនៃសាសនាចក្រ ឬ បច្ចុប្បន្ននេះពុំបានរស់នៅតាមសេចក្ដីសញ្ញា ដែលពួកគាត់បានធ្វើជាមួយនឹងព្រះអម្ចាស់ដែរឬទេ ? បើអ្នកមាន តើសេចក្ដីសង្ឃឹមអ្វីខ្លះ ដែលអ្នកមានសម្រាប់គាត់ ? នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១ យើងអានអំពីវិវរណៈ ដែលបានណែនាំដល់អ្នកប្រែចិត្តជឿថ្មីគឺ ថូម៉ាស ប៊ី ម៉ាស ។ ផ្នែកមួយចំនួន ប្រាប់អំពីក្រុមគ្រួសាររបស់គាត់ ។ ថូម៉ាស បានរៀបការ ហើយមានកូនតូចៗបីនាក់ កាលវិវរណៈនេះត្រូវបានប្រទានឲ្យ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:១–២ ដោយស្វែងរកការសន្យាទាំងឡាយ ដែលព្រះអម្ចាស់បានប្រទានដល់ ថូម៉ាស អំពីក្រុមគ្រួសាររបស់គាត់ ។

យើងរៀនចេញពីខគម្ពីរទាំងនេះថា **តាមរយៈសេចក្ដីស្មោះត្រង់របស់យើង នោះគ្រួសារយើង អាចនឹងត្រូវបានប្រទានពរឲ្យជឿ ហើយស្គាល់សេចក្ដីពិត** ។ សូមពិចារណាអំពីរបៀប ដែលគោលការណ៍នេះ អាចមានអត្ថប្រយោជន៍សម្រាប់អ្នក បើអ្នកមានសមាជិកគ្រួសារ ដែលមិនមែនជាសមាជិកសាសនាចក្រ ឬ មិនបន្តរស់នៅតាមសេចក្ដីសញ្ញារបស់ខ្លួន ។

២. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើបុគ្គលម្នាក់ៗអាចត្រូវបានប្រទានពរតាមរយៈសេចក្ដីស្មោះត្រង់នៃសមាជិកគ្រួសារគេ តាមវិធីណាខ្លះ ?

ខ. តើអ្នកធ្លាប់បានឃើញគំរូដូចម្ដេចខ្លះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:៣–៤ រួចស្វែងរកអ្វីដែលព្រះអម្ចាស់បានត្រាស់ហៅឲ្យ ថូម៉ាស ប៊ី ម៉ាស ធ្វើ ។

វាអាចពុំមែនជាការងាយស្រួលនោះទេចំពោះ ថូម៉ាស ដើម្បីចាកចេញពីក្រុមគ្រួសារគាត់ទៅផ្សាយដំណឹងល្អ ក៏ពុំមែនជាការងាយស្រួលនោះទេ ចំពោះអ្នកផ្សព្វផ្សាយសាសនានាពេលបច្ចុប្បន្ននេះដែរ ។ សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះ រួចគូសចំណាំការសន្យា ដែលប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានធ្វើជាមួយអ្នកទាំងឡាយណាដែលបម្រើព្រះអម្ចាស់ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ៖ « អ្នកនឹងផ្ដល់ពរដល់ជីវិតមនុស្សដែលអ្នកបង្រៀន ថែមទាំងសណ្ដានក្រោយពួកគេទៀតផង ។ អ្នកនឹងផ្ដល់ពរដល់ជីវិតផ្ទាល់ខ្លួនរបស់អ្នក ។ អ្នកនឹងប្រទានពរដល់ជីវិតនៃគ្រួសារអ្នក ដែលនឹងគាំទ្រអ្នក ហើយអធិស្ឋានសម្រាប់អ្នក » (Of Missions, Temples, and Stewardship, » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥, ៥២ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:៥–៨ រួចស្វែងរកពរជ័យទាំងឡាយ ដែលនឹងកើតមានដល់មនុស្សដែល ថូម៉ាស ប៊ី ម៉ាស នឹងបង្រៀនក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ។ សូមស្វែងរកផងដែរនូវ ពរជ័យទាំងឡាយ ដែលនឹងកើតមានចំពោះ ថូម៉ាស និង ក្រុមគ្រួសាររបស់គាត់ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:៩–១៣

*ព្រះយេស៊ូវគ្រីស្ទ ប្រទានឱវាទដោយផ្ទាល់ទៅដល់ ថូម៉ាស ប៊ី ម៉ាស*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:៩–១៣ មាននូវឱវាទ ដើម្បីជួយដល់ ថូម៉ាស ប៊ី ម៉ាស នៅក្នុងបេសកកម្ម និង ជីវិតផ្ទាល់ខ្លួនរបស់គាត់ ។

៣. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមស្វែងរកចំណុចមួយនៃឱវាទ ដែលព្រះអម្ចាស់បានប្រទានដល់ ថូម៉ាស ប៊ី ម៉ាស ដែលអ្នកគិតថាមានសារៈសំខាន់ចំពោះអ្នក ដើម្បីធ្វើតាមនៅក្នុងជីវិត រួចសូមឆ្លើយសំណួរដូចតទៅនេះ ៖ តើអ្នកគិតថា ហេតុអ្វីបានជាឱវាទនេះមានសារៈសំខាន់ចំពោះអ្នក ហើយតើអ្នកអាចទទួលបានផលប្រយោជន៍ពីការធ្វើតាមឱវាទនោះយ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:១៣ ម្ដងទៀត រួចស្វែងរកការសន្យាដែលបានប្រទានដល់ ថូម៉ាស ប៊ី ម៉ាស បើគាត់ស្មោះត្រង់ក្នុងការគោរពប្រតិបត្តិតាមឱវាទ ដែលព្រះអម្ចាស់បានប្រទានដល់គាត់ ។

ដោយប្រើពាក្យ *បើ* និង *នោះ* សូមសរសេរការសន្យានោះក្នុងទម្រង់ជាសេចក្ដីថ្លែងការណ៍នៃគោលលទ្ធិមួយ ។

**បើ នោះ** ។

៤. សូមគូសប្រអប់ពីរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមសរសេរនៅក្នុងប្រអប់ទីមួយថា *ទម្លាប់ដ៏សុចរិត* និង ក្នុងប្រអប់មួយទៀតថា *ជម្រើសដ៏សុចរិត* ។ សូមរាយជាបញ្ជីអនុវត្តន៍ទាំងឡាយ ដែលអ្នកបានអនុវត្តតាម ឬ ត្រូវអនុវត្តតាម និង ជម្រើសនានា ដែលអ្នកបានធ្វើ ឬ ត្រូវធ្វើនាពេលឥឡូវនេះ និង ក្នុងពេលអនាគត ដែលនឹងជួយអ្នកឲ្យ « មានចិត្តស្មោះត្រង់រហូតដល់ទីបំផុត » ( គ. និង ស. ៣១:១៣ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣២

*ព្រះអម្ចាស់ត្រាស់ហៅ ប៉ាលី ភី ប្រាត្ត និង សែបា ភីតើសុន ឲ្យចេញបេសកកម្មផ្សាយដំណឹងល្អទៅកាន់ពួកសាសន៍លេមិន*

វិវរណៈដែលអ្នកបានសិក្សានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០–៣១ និង វិវរណៈទាំងឡាយដែលអ្នកនឹងសិក្សានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣២–៣៤ គឺអំពីការហៅបម្រើបេសកកម្ម កិច្ចការផ្សព្វផ្សាយសាសនា និង ការត្រៀមខ្លួនបង្រៀនដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ។ ក្នុងខែ តុលា ឆ្នាំ ២០១២ ប្រធាន ថូម៉ាស អេស ម៉នសុន បានចេញសេចក្ដីប្រកាសស្ដីពី អាយុចេញបម្រើផ្សព្វផ្សាយសាសនាដោយផ្ដេកទៅលើ ការគោរពប្រតិបត្តិ សេចក្ដីស្មោះត្រង់ និង ភាពចាស់ចិត្តចាស់គំនិតនៃជំនាន់ដែលកំពុងពេញវ័យ ។



« ខ្ញុំរីករាយដើម្បីប្រកាសពីប្រសិទ្ធិភាពនោះភ្លាមៗថា យុវជនដែលស័ក្ដិសម និង មានសមត្ថភាព ទាំងអស់ដែលបានរៀនចប់វិទ្យាល័យ ឬ សាលាប្រហាក់ប្រហែលគ្នា ដោយមិនគិតពីទីកន្លែងដែលពួកគេរស់នៅ នឹងមានជម្រើសឲ្យបម្រើបេសកកម្មចាប់តាំងពីអាយុ ១៨ ជំនួសឲ្យអាយុ ១៩ ឆ្នាំវិញ ។ ខ្ញុំមិនមែនណែនាំឲ្យ យុវជនទាំងអស់នឹង—ឬ គួរតែ—បម្រើនៅអាយុក្មេងបែបនេះនោះទេ ។ ប៉ុន្តែដោយផ្អែកលើកាលៈទេសៈរបស់បុគ្គលម្នាក់ៗ ក៏ដូចជាការសម្រេចចិត្តដោយថ្នាក់ដឹកនាំបព្វជិតភាពនានា ជម្រើសនេះបានអនុវត្តហើយ ។

« នៅពេលយើងបានសញ្ជឹងគិតដោយការអធិស្ឋានពីអាយុ ដែលយុវជនអាចចាប់ផ្ដើមការបម្រើបេសកកម្មរបស់ពួកគេនោះយើងក៏បានពិចារណាពីអាយុ ដែលយុវនារីអាចបម្រើផងដែរ ។ ថ្ងៃនេះ ខ្ញុំរីករាយដើម្បីប្រកាសថា យុវនារីដែលមានសមត្ថភាព មានភាពស័ក្តិសម ដែលមានបំណងចង់បម្រើ អាចលើកទឹកចិត្តឲ្យបម្រើបេសកកម្មចាប់ពីអាយុ ១៩ ជំនួសឲ្យអាយុ ២១ ឆ្នាំវិញ ។

« យើងសូមបញ្ជាក់ថា កិច្ចការផ្សព្វផ្សាយសាសនា គឺជាករណីយកិច្ចបព្វជិតភាពមួយ—ហើយយើងសូមលើកទឹកចិត្តដល់យុវជនទាំងអស់ ដែលមានភាពស័ក្តិសម និង ដែលមានសមត្ថភាពខាងរាងកាយ និង ខាងស្មារតី ឲ្យឆ្លើយតបទៅនឹងការហៅបម្រើនេះ ។ យុវនារីជាច្រើនក៏បម្រើដែរ ប៉ុន្តែពួកគេមិននៅក្រោមការបញ្ជាឲ្យបម្រើដូចគ្នានឹងយុវជននោះទេ ។ ទោះយ៉ាងណា យើងសូមអះអាងនឹងយុវនារីទាំងឡាយក្នុងសាសនាចក្រថា ពួកគេនឹងចូលរួមចំណែកយ៉ាងមានតម្លៃក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ហើយយើងសូមស្វាគមន៍ចំពោះការបម្រើរបស់ពួកគេ ។ ( Welcome to Conference," *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៤–៥ ) ។

នៅពេលអ្នកបន្តសិក្សាវិវរណៈទាំងនេះអំពីកិច្ចការផ្សព្វផ្សាយសាសនា សូមគិតអំពីភាពស្រដៀងគ្នា និង ភាពខុសគ្នាក្នុងការរៀបចំខ្លួន និង កិច្ចការនៃពួកអ្នកផ្សព្វផ្សាយសាសនាពីជំនាន់ដំបូង និង ពួកអ្នកផ្សព្វផ្សាយសាសនាទូទាំងពិភពលោក ។




ទីតាំង ភូមិហ្វាយែត រដ្ឋនូវ យ៉ោក និង អ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី នៅលើផែនទីដែលភ្ជាប់មកជាមួយ ( សូមមើលផងដែរ Church history map ៦, "The Westward Movement of the Church," នៅក្នុងព្រះគម្ពីររបស់អ្នក ឬ LDS.org ) ។ តើអ្នកគិតថា ទីតាំងទាំងនេះមានចម្ងាយឆ្ងាយពីគ្នាប៉ុន្មាន ?

ព្រះអម្ចាស់បានត្រាស់ហៅ អូលីវើរ ខៅឌើរី និង ពេត្រុស វិតមើរ ជុញ្ញ័រ ឲ្យធ្វើដំណើរពី រដ្ឋ នូវ យ៉ោក ទៅ រដ្ឋ មិសសួរី ដើម្បីផ្សាយដំណឹងល្អទៅកាន់ពួកសាសន៍លេមិន នៅព្រំដែនប៉ែកខាងលិច រដ្ឋ មិសសួរី ( សូមមើល គ. និង ស. ២៨:៨; ៣០:៥ ) ។ បេសកកម្មទៅកាន់ពួកសាសន៍លេមិននេះ បានធ្វើឲ្យមានការរីកចំរើនដ៏ធំក្នុងចំណោមពួកអែលឌើរនៃសាសនាចក្រ ហើយមនុស្ស

មួយចំនួនបានប្រាថ្នាចង់ដឹង ថាតើមានពួកអែលឌើរណាទៀត ដែលអាចនឹងត្រូវបានបញ្ជូនឲ្យចេញបេសកកម្មជាមួយ អូលីវើរ និង ពេត្រុស ។ វិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣២ គឺជាចម្លើយរបស់ព្រះអម្ចាស់ ។

ប៉ាលី ភី ប្រាត្ត បានទទួលពិធីបុណ្យជ្រមុជទឹកក្នុងខែ កញ្ញា ឆ្នាំ ១៨៣០ គឺមួយខែគត់ ពីមុនវិវរណៈនេះត្រូវបានប្រទានឲ្យ ។ គាត់បានស្វែងយល់អំពីព្រះគម្ពីរមរមន កាលកំពុងធ្វើដំណើរទៅកាន់រដ្ឋ នូវ យ៉ោក អំឡុងពេលរដូវក្ដៅឆ្នាំ ១៨៣០ ។ ក្រោយមក គាត់បានសរសេរលិខិតឆ្លើយតបរបស់គាត់ បន្ទាប់ពីគាត់ទទួលបានព្រះគម្ពីរមរមនមួយក្បាលថា ៖



« ខ្ញុំបានបើកមើលវាដោយមានចិត្តចង់ដឹងជាខ្លាំង ហើយបានអានទំព័រចំណងជើងនៃសៀវភៅនេះ ។ ក្រោយមក ខ្ញុំបានអានទីបន្ទាល់របស់សាក្សីមួយចំនួនដែលទាក់ទងទៅនឹងរបៀបដែលវាត្រូវបានចងក្រងឡើង និង បកប្រែ ។ បន្ទាប់មក ខ្ញុំបានចាប់ផ្ដើមអានមាតិកាមួយវគ្គម្ដងៗ ។ ខ្ញុំបានអានពេញមួយថ្ងៃ ដែលការទទួលទានអាហាររបស់ខ្ញុំពុំសូវសំខាន់ទៀតឡើយ ខ្ញុំពុំចង់បរិភោគអាហារទេ កាលរាត្រីចូលមកដល់ ការសម្រាន្តពុំសូវសំខាន់ទេ ដ្បិតខ្ញុំចង់អានជាងការសម្រាន្តទៅទៀត ។

« នៅពេលខ្ញុំអាន ព្រះវិញ្ញាណនៃព្រះអម្ចាស់សណ្ឋិតនៅលើខ្ញុំ ហើយខ្ញុំដឹង ហើយបានយល់ថា ព្រះគម្ពីរនេះគឺជាការពិត ដែលច្បាស់ ហើយជាក់ស្ដែង ដូចជាមនុស្សម្នាក់ដែលយល់ ហើយដឹងថា គាត់ពិតជាមានជីវិតដូច្នោះដែរ » ( *Autobiography of Parley P. Pratt,* បានបោះពុម្ពដោយ ប៉ាលី ភី ប្រាត្ត [ ១៩៣៨ ] ទំព័រ ៣៧ ) ។

ប៉ាលី បានធ្វើដំណើរទៅកាន់ ភូមិប៉ាលម៉ៃរ៉ា រដ្ឋនូវយ៉ោក ជាកន្លែងដែលគាត់បានរៀនបន្ថែមអំពី ការស្ដារឡើងវិញនៃដំណឹងល្អពី ហៃរុម ស្ម៊ីធ ។ មិនយូរប៉ុន្មាន ហៃរុម និង ប៉ាលី បានធ្វើដំណើរទៅកាន់ ភូមិហ្វាយែត ជាកន្លែងដែល ប៉ាលី បានចូលសាសនាចក្រ ហើយត្រូវបានតែងតាំងជាអែលឌើរមួយរូបដោយ អូលីវើរ ខៅឌើរី ។

យើងពុំសូវដឹងច្រើនអំពីការប្រែចិត្តជឿរបស់ សែបា ភីតើសុន នោះទេ ក្រៅពីគាត់បានទទួលពិធីបុណ្យជ្រមុជទឹកដោយ អូលីវើរ ខៅឌើរី ក្នុងខែ មេសា ឆ្នាំ ១៨៣០ ហើយបានតែងតាំងជាអែលឌើរមួយរូបក្នុងខែ មិថុនា ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣២:១–៥ ដើម្បីស្វែងយល់អំពីការណ៍ ដែលព្រះអម្ចាស់បានត្រាស់ហៅ ប៉ាលី និង សែបា ឲ្យធ្វើ ក៏ដូចជាការណ៍ដែលព្រះអម្ចាស់បានសន្យាដល់ពួកគាត់ ។

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការសន្យានេះដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣២:៣ មានភាពស្រដៀងគ្នាទៅនឹងការសន្យា ដែលព្រះអម្ចាស់បានប្រទានដល់ យ៉ូហាន វិតមើរ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០:១១ និង ដល់ ថូម៉ាស ប៊ី ម៉ាស នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣១:១៣ យ៉ាងដូចម្ដេច ?

ខ. តើការសន្យាទាំងនេះ បង្រៀនអ្នកអំពីអារម្មណ៍របស់ព្រះអម្ចាស់ ចំពោះអ្នកដែលបម្រើទ្រង់ ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាយ៉ាងដូចម្ដេច ?



អំឡុងពេលក្នុងរដូវរងានាឆ្នាំ ១៨៣០–៣១ អូលីវើរ ខៅឌើរី ពេត្រុស វីតមើរ ជុញ្ញ័រ ប៉ាលី ភី ប្រាត្ត និង សែបា ភីតើសុន បានធ្វើដំណើរពីភូមិហ្វាយែត រដ្ឋនូវ យ៉ោក ទៅកាន់ ភូមិអ៊ិនឌីប៉ែនដែនស៍ រដ្ឋមិសសួរី ក្នុងចម្ងាយប្រមាណ ២,៤០០ គីឡូម៉ែត ដែលភាគច្រើនធ្វើដំណើរដោយថ្មើរជើង ។ ពួកគាត់បានតស៊ូដើរកាត់ព្រិលកម្រាស់ក្រាស់ៗ ភាពត្រជាក់ខ្លាំង ខ្យល់បោកបក់ និង ការនឿយហត់ ដែលការរស់នៅដោយបរិភោគនំប៉ុងកកធ្វើពីពោត និងសាច់ជ្រូកឆៅជាចម្បង ។

ទោះជាមានភាពលំបាកទាំងនេះក្ដី ក៏ពួកអ្នកផ្សព្វផ្សាយសាសនាទាំងនេះ បានទទួលជោគជ័យក្នុងការណែនាំដំណឹងល្អទៅកាន់ពួកកុលសម្ព័ន្ធអាមេរិកាំងជនជាតិដើមនៅ នូវ យ៉ោក អូហៃអូ និង មិសសួរី ដែរ ។ ពួកគាត់ក៏បានផ្សាយដំណឹងល្អនៅ ខឺតឡង់

រដ្ឋអូហៃអូ ទៅដល់ក្រុមជំនុំនៃប្រជាជន ដែលកំពុងស្វែងរកការស្ដារឡើងវិញនៃគ្រីស្ទចក្រសញ្ញាថ្មី ។ ប្រជាជនទាំងនោះភាគច្រើន បានចូលសាសនាចក្រ ។ ម្នាក់ក្នុងចំណោមអ្នកប្រែចិត្តជឿទាំងនោះមកពី អូហៃអូ ឈ្មោះ ហ្វ្រេឌើរិក ជី វិលលាម្ស បានរួមដំណើរជាមួយពួកអ្នកផ្សព្វផ្សាយសាសនាក្នុងការធ្វើដំណើររបស់ពួកគាត់ទៅកាន់ រដ្ឋមិសសួរី ។ ព្រះអម្ចាស់បានបំពេញការសន្យារបស់ទ្រង់ថា ទ្រង់នឹងគង់នៅជាមួយអ្នកផ្សព្វផ្សាយសាសនាទាំងនេះ ហើយថាគ្មានអ្វី ដែលនឹងយកឈ្នះលើពួកគាត់នោះទេ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០–៣២ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

ចម្លើយលំហាត់ផ្គូរផ្គងសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣០ ៖ (១) ខ (២) គ (៣) ក ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣–៣៤

## បុព្វកថា

ក្នុងវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣ ព្រះអម្ចាស់បានត្រាស់ហៅ អែសរ៉ា ធេយ័រ និង ណូរត្រុព ស្ម៊ីត ឲ្យផ្សាយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ ព្រះអម្ចាស់ក៏បានប្រទានការណែនាំដល់បុរសទាំងនេះ អំពីការបង្រៀនដំណឹងល្អផងដែរ ។ ដូចបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤ ព្រះអម្ចាស់បានទុកព្រះទ័យលើ អ័រសុន ប្រាត្ត ចំពោះសេចក្ដីជំនឿរបស់គាត់ ហើយក៏បានត្រាស់បញ្ជាឲ្យគាត់ទៅផ្សាយដំណឹងល្អផងដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:១–៦

*ព្រះអម្ចាស់ត្រាស់ហៅ អែសរ៉ា ធេយ័រ និង ណូរត្រុព ស្ម៊ីត ឲ្យប្រកាសដំណឹងល្អទ្រង់*

ព្រះទ្រង់ទាក់ទងមកកាន់កូនចៅទ្រង់តាមរបៀបជាច្រើន ។ តើមានឧទាហរណ៍ណាមួយ អំពីរបៀបដែលទ្រង់ទាក់ទងមកកាន់អ្នក និង ទៅកាន់មនុស្សដែលអ្នកស្គាល់ ?

របៀបមួយ ដែលព្រះអម្ចាស់អាចនឹងទាក់ទងមកកាន់យើងគឺ តាមរយៈសុបិន និង ការនិមិត្ត ។ សូមអានដំណើររឿងនៃការនិមិត្តខាងក្រោមនេះ ដែលបានដកពិសោធន៍ដោយ អែសរ៉ា ធេយ័រ ។ សូមពិចារណា ថាតើការនិមិត្តរបស់គាត់ ទាក់ទងដូចម្ដេចទៅនឹងរមូរក្រដាស ត្រចៀក និង ត្រែ ។ សូមគិតផងដែរអំពីអត្ថន័យនៃការនិមិត្តនេះ ។

> « មានបុរសម្នាក់បានមកជួបខ្ញុំ ថែមទាំងបាននាំយករមូរក្រដាសមួយដុំ ហើយបានបង្ហាញវាមកឲ្យខ្ញុំ ក៏មានត្រែមួយ ហើយបានប្រាប់ខ្ញុំឲ្យផ្លុំត្រែនោះ ។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំមិនដែលចេះផ្លុំឧបករណ៍អ្វីឡើយក្នុងមួយជីវិតខ្ញុំនេះ ។ គាត់បានពោលថា លោកអាចផ្លុំវាបាន សូមសាកល្បងម្ដងចុះ ។ ខ្ញុំបានដាក់វានៅក្នុងមាត់របស់ខ្ញុំ ហើយបានផ្លុំវា ហើយបានបញ្ចេញសូរសំឡេងដ៏ពិរោះ ដែលខ្ញុំមិនដែលធ្លាប់បានឮពីមុនមក » ( "Testimony of Brother E. Thayre," *The True Latter Day Saints' Herald* ខែ តុលា ឆ្នាំ ១៨៦២ ទំព័រ ៨២ ) ។

អែសរ៉ា ធេយ័រ បានរស់នៅភូមិប៉ាលម៉ៃរ៉ា រដ្ឋនូវយ៉ោក ហើយបានស្គាល់ក្រុមគ្រួសារស្ម៊ីធ តាមរយៈការងារ ដែលគាត់បានធ្វើឲ្យលោកជាច្រើនដង ។ ក្នុងខែ តុលា ឆ្នាំ ១៨៣០ អែសរ៉ា ធេយ័រ និងអ្នករស់នៅភូមិប៉ាលម៉ៃរ៉ា ម្នាក់ទៀតឈ្មោះ ណូរត្រុព ស្ម៊ីត បានទទួលពិធីបុណ្យជ្រមុជទឹកចូលក្នុងសាសនាចក្រ ។ មិនយូរប៉ុន្មានបន្ទាប់ពី អែសរ៉ា ធេយ័រ និង ណូរត្រុព ស្ម៊ីត បានទទួលពិធីបុណ្យជ្រមុជទឹក នោះព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈមួយដែលថ្លែងទៅកាន់បុរសទាំងពីររូបនេះ ដែលឥឡូវត្រូវបានកត់ត្រាទុកនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣ ។ ជាច្រើនឆ្នាំក្រោយមក អែសរ៉ា បានពន្យល់ថា « រមូរក្រដាសនោះគឺជាវិវរណៈចំពោះខ្ញុំ និង ណូរត្រុព ស្ម៊ីត » ( "Testimony of Brother E. Thayre," ទំព័រ ៨២ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:១–២ រួចស្វែងរកពាក្យ និង ឃ្លា ដែលទាក់ទងនឹងរមូរក្រដាស ត្រចៀក និង ត្រែ ។

សូមពិចារណាថាតើវាមានន័យដូចម្ដេចដើម្បី « បើក. . .ត្រចៀក ហើយស្ដាប់តាមសំឡេងនៃព្រះអ ម្ចាស់ ជាព្រះរបស់អ្នកចុះ » ( គ. និង ស. ៣៣:១ ) ។ សូមពិចារណាអំពីរបៀប ដែលអ្នកអាចបង្ហាញដល់ព្រះអម្ចាស់ថា ត្រចៀករបស់អ្នកត្រូវបើកដើម្បីស្ដាប់តាមសំឡេងរបស់ទ្រង់យ៉ាងដូចម្ដេច ?

១. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើអ្នកគិតថា វាមានន័យដូចម្ដេច ដើម្បីប្រកាសដំណឹងល្អ « ហាក់ដូចជាដោយសំឡេងត្រែ » ? ( គ. និង ស. ៣៣:២ ) ?

ខ. នៅក្នុងការនិមិត្តរបស់ អែសរ៉ា ធេយ័រ កាលគាត់បានផ្លុំត្រែនោះ វាបានបញ្ចេញសូរសំឡេងពិរោះ ដែលគាត់មិនដែលធ្លាប់បានឮពីមុនមក ។ ចេញពីអ្វីដែលអ្នកបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:២ តើអ្នកគិតថា ហេតុអ្វីបានជាសំឡេងត្រែនោះពិរោះ ?

### *ការយល់អំពីនិមិត្តរូបនៅក្នុងបទគម្ពីរ*

ព្រះអម្ចាស់ និង ពួកព្យាការីទ្រង់តែងតែប្រើនិមិត្តរូប ដើម្បីជួយបង្រៀនសេចក្ដីពិតនៃដំណឹងល្អ ។ បទគម្ពីរពោរពេញទៅដោយនិមិត្តរូប និង គំនិតជាច្រើន ដែលនាំមកនូវអត្ថន័យដ៏ជ្រាលជ្រៅ ។ នៅពេលអ្នកសិក្សាព្រះគម្ពីរ សូមស្វែងរកនិមិត្តរូបនានា ។ នៅពេលអ្នកស្វែងរកវាឃើញហើយ សូមឈប់ហើយគិតថាតើនិមិត្តរូបទាំងនោះតំណាងឲ្យអ្វីខ្លះ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:៣ ព្រះអម្ចាស់បានប្រើនិមិត្តរូបបន្ថែម ដើម្បីបង្រៀន អែសរ៉ា និង ណូរត្រុព អំពីការហៅរបស់ពួកគាត់ ឲ្យធ្វើជាអ្នកផ្សព្វផ្សាយសាសនា ។ សូមអានខគម្ពីរនេះ រួចគិតអំពីនិមិត្តរូបដែលវាមាន ។ នៅក្នុងលំហាត់ខាងក្រោមនេះ សូមគូសបន្ទាត់ផ្គូផ្គងនិមិត្តរូបនីមួយៗទៅនឹងអត្ថន័យរបស់វា ។

| និមិត្តរូប | អត្ថន័យ |
|---|---|
| ស្រែ ឬ ចម្ការទំពាំងបាយជូរ | សមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ដែលបម្រើក្នុងការស្ដាបនានគរព្រះលើផែនដី |
| អ្នកធ្វើការ | លោកិយ |
| ម៉ោងទីដប់មួយ | គ្រាកាន់កាប់ត្រួតត្រាចុងក្រោយនៃដំណឹងល្អ និង គ្រាចុងក្រោយ ដែលព្រះអម្ចាស់នឹងរៀបចំនគររបស់ទ្រង់ឡើងនៅលើផែនដី មុនពេលការយាងមកជាលើកទីពីររបស់ទ្រង់ ( សូមមើល Bible Dictionary, “Dispensations” ) |

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:៤ ដោយស្វែងរករបៀបដែលព្រះអម្ចាស់ បានពិពណ៌នាអំពីស្ថានភាពនៃលោកិយក្នុងឆ្នាំ ១៨៣០ ។ តើអ្នកឃើញមានឧបសគ្គអ្វីខ្លះ នៅក្នុងចម្ការទំពាំងបាយជូររបស់ព្រះអម្ចាស់នាពេលបច្ចុប្បន្ននេះ ?

សូមពិចារណាអំពីការណ៍ ដែលព្រះអម្ចាស់បានធ្វើ ឬ កំពុងតែធ្វើ ដើម្បីជួយអ្នកឲ្យរស់នៅក្នុងលោកិយពុករលួយនេះបាន ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:៥–៦ ។ តើព្រះអម្ចាស់បានមានព្រះបន្ទូលថា ទ្រង់បានធ្វើអ្វីខ្លះដើម្បីជួយដល់យើង ?

២. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមគូររូបមួយ ដែលបង្ហាញអំពីរបៀបមួយ ដែលព្រះបានជួយរាស្ត្រទ្រង់ចៀសឲ្យឆ្ងាយពីភាពពុករលួយនៃលោកិយនេះ ។

អ្នកអាចនឹងចង់គូសចំណាំ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:៥–៦ ដែលបង្រៀនសេចក្ដីពិតតទៅនេះ ៖ **ព្រះអម្ចាស់បានស្ដាបនាសាសនាចក្រទ្រង់ឡើង ហើយកំពុងប្រមូលអ្នកដែលទ្រង់បានរើសតាំងនៅថ្ងៃចុងក្រោយ ។**

៣. ដើម្បីជួយអ្នកឲ្យកាន់តែយល់ច្បាស់អំពីសេចក្ដីពិតនេះ និង សារៈសំខាន់របស់វា សូមឆ្លើយសំណួរទាំងឡាយខាងក្រោមនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:៦ តើនរណាគឺជាអ្នកដែលទ្រង់បានរើសតាំង ?

ខ. នៅពេលពិចារណាអំពីភាពពុករលួយនៃលោកិយ ហេតុអ្វីបានជាវាសំខាន់ ដើម្បីប្រមូលផ្ដុំពួករើសតាំងរបស់ព្រះអម្ចាស់ ?

គ. តើសាសនាចក្រ បានជួយអ្នកឲ្យចៀសឲ្យឆ្ងាយពីភាពពុករលួយនៃលោកិយយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:៧–១៨

*ព្រះអម្ចាស់បានប្រទានការណែនាំដល់ អែសរ៉ា ធេយ័រ និង ណូរត្រុព ស្វ៊ីត សម្រាប់ការបង្រៀនដំណឹងល្អ*

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:៧–១០ ដើម្បីរៀនអំពីការណ៍ ដែលព្រះអម្ចាស់បានបង្រៀន អែសរ៉ា ធេយ័រ និង ណូរត្រុព ស្វ៊ីត ថាពួកគាត់ត្រូវធ្វើដោយប្រើមាត់របស់ពួកគាត់ ។ នៅក្បែររូបភាពខាងក្រោមនេះ សូមសរសេរគោលការណ៍មួយដោយផ្អែកទៅលើអ្វីដែលអ្នកបានស្វែងយល់ចេញពីខគម្ពីរទាំងនេះ ។ គោលការណ៍នេះអាចចាប់ផ្ដើមដោយថា ៖ **បើយើងបើកមាត់របស់យើងប្រកាសដំណឹងល្អ នោះព្រះអម្ចាស់នឹង. . .**



៤. សូមគិតអំពីពេលមួយ ដែលអ្នកបានទទួលអារម្មណ៍ថា គួរតែបានថ្លែងចេញមកនូវដំណឹងល្អ ប៉ុន្តែ អ្នកមិនបានធ្វើ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើមានស្ថានភាពមួយចំនួនណាខ្លះ ដែលអ្នកអាចនឹងស្ទាក់ស្ទើរ ក្នុងការបើកមាត់របស់អ្នកប្រាប់អំពីដំណឹងល្អ ?

២. តើនៅពេលណាខ្លះ ដែលអ្នកធ្លាប់បានចែកចាយដំណឹងល្អ ហើយទទួលអារម្មណ៍បំផុសគំនិតឲ្យដឹងនូវអ្វីដែលត្រូវនិយាយ ? ឬ តើនៅពេលណាខ្លះ ដែលអ្នកបានឃើញមនុស្សដទៃ ចែកចាយដំណឹងល្អ ហើយទទួលអារម្មណ៍ថា ពួកគេត្រូវបានបំផុសគំនិតនៅក្នុងអ្វីដែលពួកគេបានថ្លែងនោះ ?

គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:១០–១៥ មាននូវការណែនាំពីព្រះអម្ចាស់ទៅដល់ អ៊ែសរ៉ា និង ណូរត្រុព ឲ្យផ្សាយគោលការណ៍ និងពិធីបរិសុទ្ធដំបូងៗទាំងឡាយនៃដំណឹងល្អ ( សេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ការប្រែចិត្ត ពិធីបុណ្យជ្រមុជទឹក និង អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ) ។ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:១៦–១៨ ដើម្បីរៀនអំពីឱវាទបន្ថែម ដែលព្រះអម្ចាស់បានប្រទានដល់ អ៊ែសរ៉ា និង ណូរត្រុព ដែលនឹងជួយពួកគាត់ឲ្យដឹងនូវអ្វី ដែលត្រូវនិយាយក្នុងនាមជាអ្នកជំរុញផ្សាយសាសនា ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។ ឱវាទដែលមាននៅក្នុង ខទី ១៧ ការមាន « ចង្កៀងបង្កាត់ ហើយឆេះ ហើយមានប្រេងនៅជាមួយអ្នកផង » មានន័យថា ត្រៀមខ្លួនជាស្រេចខាងវិញ្ញាណ និង រួចរាល់គ្រប់ពេលវេលាសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវចំណុចមួយនៃឱវាទដែលបានប្រទានឲ្យនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣:១៦–១៨ រួចពន្យល់អំពីរបៀប ដែលវាអាចជួយអ្នកឲ្យត្រៀមខ្លួនជាស្រេច ដើម្បីបើកមាត់អ្នក ហើយចែកចាយដំណឹងល្អជាមួយមនុស្សដទៃនៅគ្រប់ពេលវេលាទាំងអស់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤

*ព្រះអម្ចាស់ទុកព្រះទ័យលើ អូរសុន ប្រាត្ត ចំពោះសេចក្ដីជំនឿរបស់គាត់ ហើយបានត្រាស់ហៅឲ្យគាត់ផ្សាយដំណឹងល្អ*

គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤ ផ្ដល់នូវឧទាហរណ៍មួយអំពីមនុស្សម្នាក់ ដែលត្រូវបានប្រទានពរ នៅពេលមានមនុស្សម្នាក់ទៀត បានបើកមាត់របស់គាត់ចែកចាយដំណឹងល្អ ។ សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃវិវរណៈនេះ នៅក្នុងព្រះគម្ពីររបស់អ្នក ដើម្បីស្វែងយល់អំពីមនុស្ស ដែលបានបើកមាត់របស់គាត់ ដើម្បីចែកចាយដំណឹងល្អជាមួយ អូរសុន ប្រាត្ត ។

អូរសុន ប្រាត្ត បានមានអាយុ ១៩ ឆ្នាំ កាលគាត់បានទទួលពិធីបុណ្យជ្រមុជទឹក ដោយបងប្រុសរបស់គាត់គឺ ប៉ាលី ។ សូមអានគោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤:១ រួចកត់ចំណាំអំពីរបៀប ដែលព្រះអម្ចាស់បានមានព្រះបន្ទូលទៅកាន់ អូរសុន ។

ឥឡូវនេះ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤:២–៣ ដោយស្វែងរកមូលហេតុ ដែលព្រះអម្ចាស់ហៅ អូរសុន ថាជាបុត្ររបស់ទ្រង់ ។

អ្នកអាចនឹងបានកត់ចំណាំនៅក្នុង ខទី ៣ ថា អ្នកទាំងអស់ណា ដែលជឿលើ ព្រះយេស៊ូវគ្រីស្ទ ក្លាយទៅជាបុត្រារបស់ទ្រង់ ។ នេះគឺជានិមិត្តរូបនៃជីវិតថ្មី ដែលយើងទទួលបាន នៅពេលយើងទទួលយកដំណឹងល្អនៃព្រះអង្គសង្គ្រោះ ។ យើងរៀនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ២៥:១ ថា ការសន្យានេះអនុវត្តដូចគ្នាផងដែរសម្រាប់ស្ត្រីៗ ដែលក្លាយទៅជាបុត្រីរបស់ព្រះយេស៊ូវគ្រីស្ទ នៅពេលពួកគេទទួលយកដំណឹងល្អទ្រង់ ។

នៅពេលអ្នកអានព័ត៌មានខាងក្រោមដែល អូរសុន ប្រាត្ត បានសរសេរអំពីជីវិតកាលពីមុនរបស់គាត់ សូមគូសចំណាំអ្វី ដែលគាត់បានធ្វើដើម្បីបង្ហាញថា គាត់បានជឿលើព្រះអម្ចាស់ ៖



« ចាប់តាំងពីអាយុដប់ឆ្នាំដល់ដប់ប្រាំបួនឆ្នាំ ខ្ញុំបានធ្វើដំណើរតាមជនបទជាច្រើន ហើយបានផ្លាស់ទីលំនៅជាញឹកញាប់ ប៉ុន្តែតាមរយៈព្រះគុណរបស់ព្រះ ខ្ញុំត្រូវបានការពារពីសេចក្ដីអាក្រក់ជាច្រើន ដែលមនុស្សវ័យក្មេងបានជួបប្រទះ ដែលចំណាប់អារម្មណ៍ពីមុន អំពីសីលធម៌ និងសាសនា បានដក់ក្នុងគំនិតខ្ញុំ តាមរយៈឪពុកម្ដាយខ្ញុំ វាតែងតែដិតជាប់នឹងខ្ញុំ ហើយជាញឹកញាប់ ខ្ញុំមានអារម្មណ៍កើបដ៏ខ្លាំងដើម្បីត្រៀមខ្លួនសម្រាប់ស្ថានភាពនាពេលអនាគតមួយ ប៉ុន្តែពុំដែលបានចាប់ផ្ដើមស្វែងរកព្រះអម្ចាស់ដ៏ពិតទេ រហូតមកដល់រដូវស្លឹកឈើជ្រុះក្នុងឆ្នាំ ១៨២៩ ។ បន្ទាប់មក ខ្ញុំបានចាប់ផ្ដើមអធិស្ឋានយ៉ាងក្លៀវក្លា ប្រែចិត្តពីគ្រប់អំពើបាបរបស់ខ្ញុំ ។ ក្នុងភាពស្ងប់ស្ងាត់នាពេលរាត្រី កាលដែលអ្នកដទៃទៀតបានលង់លក់នៅក្នុងដំណេក ជាញឹកញាប់ខ្ញុំបានចូលទៅកន្លែងស្ងាត់ខ្លះៗក្នុងទីវាលតែឯង ឬវាលរហោស្ថានស្ងាត់ដាច់ពីគេ ហើយឱនក្បាលចំពោះព្រះអម្ចាស់ ហើយបានអធិស្ឋានរាប់ម៉ោង ដោយដួងចិត្តសង្រេង និង វិញ្ញាណទន់ទាប ជឿថាការធ្វើបែបនេះជាការលួងលោមចិត្ត និង សេចក្ដីរីករាយចំពោះខ្ញុំ ។ បំណងប្រាថ្នាដ៏ធំនៃចិត្តរបស់ខ្ញុំ គឺដើម្បីឲ្យព្រះអម្ចាស់សម្ដែងព្រះឆន្ទៈទ្រង់អំពីខ្ញុំ ។ ខ្ញុំបានបន្តអធិស្ឋានតាមរបៀបដ៏ក្លៀវក្លានេះរហូតដល់ខែ កញ្ញា ឆ្នាំ ១៨៣០ ជាពេលដែលអែលឌើរពីរូបនៃ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ បានមកជួបអ្នកជិតខាងខ្ញុំ ដែលជាបងប្រុសរបស់ខ្ញុំគឺ ប៉ាលី ។ ខ្ញុំបានចូលរួមការណាត់ជួបមួយចំនួនរបស់ពួកគាត់ ។

> « ដោយបានជឿលើ យថាភាពដ៏ទេវភាពនៃគោលលទ្ធិ ដែលពួកគាត់បានបង្រៀន ខ្ញុំបានទទួលពិធីបុណ្យជ្រមុជទឹកនៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៨៣០ ។ នេះគឺចំថ្ងៃកំណើតគម្រប់ដប់ប្រាំបួនឆ្នាំរបស់ខ្ញុំ ។ ខ្ញុំគឺជាបុគ្គលតែម្នាក់គត់នៅក្នុង [ តំបន់ ] នោះ ដែលបានទទួលយក ហើយគោរពប្រតិបត្តិតាមសារលិខិត » ( នៅក្នុង *The Orson Pratt Journals,* comp. Elden J. Watson [ ឆ្នាំ ១៩៧៥ ] ទំព័រ ៨–៩ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤:៤–៦ ដើម្បីឃើញអ្វី ដែលព្រះអម្ចាស់បានត្រាស់ហៅ អូរសុន ប្រាត្ត ឲ្យធ្វើ ដើម្បីទទួលបានពរជ័យបន្ថែម ។ សូមពិចារណាអំពីមូលហេតុ ដែលយើងទទួលបានពរជ័យកាន់តែច្រើន នៅពេលយើងបង្រៀនដំណឹងល្អទៅកាន់មនុស្សដទៃ ។

ព្រះអម្ចាស់បានមានព្រះបន្ទូលទៅកាន់ អូរសុន អំពីទីសម្គាល់មួយចំនួន ដែលនឹងកើតឡើងនៅពីមុនការយាងមកជាលើកទីពីររបស់ទ្រង់ ( សូមមើល គ. និង ស. ៣៤:៧–៩ ) ។ បន្ទាប់មក ទ្រង់បានបញ្ចប់វិវរណៈនេះដោយបានលើកទឹកចិត្ត អូរសុន ក្នុងការហៅរបស់គាត់ដើម្បីផ្សាយដំណឹងល្អ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤:១០–១២ ដោយស្វែងរកសេចក្ដីពិតតទៅនេះ ៖ **អ្នកទាំងឡាយណា ដែលបង្រៀនដំណឹងល្អដោយឧស្សាហ៍ព្យាយាម នឹងធ្វើដូច្នោះតាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។ បើយើងមានចិត្តស្មោះត្រង់ នោះព្រះអម្ចាស់នឹងគង់នៅជាមួយយើង ។**

តើការសន្យារបស់ព្រះអម្ចាស់ដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៤:១១ អាចជួយលួងលោម ហើយពង្រឹងមនុស្សម្នាក់នៅក្នុងគ្រាដែលបាក់ទឹកចិត្តយ៉ាងដូចម្ដេច ?

៦. សូមពិពណ៌នាដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលអ្នកគិតថា វាចាំបាច់ត្រូវមានព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ដើម្បីជួយអ្នកឲ្យបង្រៀនដំណឹងល្អទៅដល់មនុស្សដទៃ ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៣–៣៤ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៨ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥

## បុព្វកថា

ក្នុងរយៈពេលប្រាំមួយខែចាប់តាំងពីការរៀបចំសាសនាចក្រ មានអ្នកផ្សព្វផ្សាយសាសនាចំនួនបួនរូប រួមទាំង ប៉ាលី ភី ប្រាត្ត ដែលបានធ្វើដំណើរទៅប៉ែកខាងលិច ដើម្បីផ្សាយដំណឹងល្អទៅកាន់ពួកអាមេរិកាំងជនជាតិដើម ។ នៅតាមផ្លូវរបស់ពួកគាត់ទៅកាន់ព្រំដែនប៉ែកខាងលិចនៃ រដ្ឋមិសសួរី ពួកគាត់បានឈប់សម្រាកនៅតំបន់ជុំវិញទីក្រុង ខឺតឡង់ រដ្ឋអូហៃអូ ជាកន្លែងដែល ប៉ាលី បានរស់នៅទីនោះអស់មួយរយៈ ។ ពួកគាត់បានចែកចាយសារលិខិតជាមួយនឹងមិត្តភក្ដិរបស់អែលឌើរ ប្រាត្ត ដែលជាអាចារ្យសាសនាដ៏ល្បីម្នាក់ឈ្មោះ ស៊ីឌនី រិកដុន ។ ក្នុងរយៈពេលដ៏ខ្លីមានមនុស្សជាង ១០០ នាក់រួមទាំង ស៊ីឌនី រិកដុន និង សមាជិកជាច្រើននាក់ទៀតនៃក្រុមជំនុំរបស់គាត់ បានទទួលពិធីបុណ្យជ្រមុជទឹក ដែលចំនួននោះបានបង្កើនសមាជិកភាពសរុបនៃសាសានាចក្រទ្វេដង ។ ស៊ីឌនី និង ភរិយាគាត់ ហ្វេបី បានដឹងថា ការចូលសាសនាចក្រនេះនឹងតម្រូវឲ្យពួកគាត់ធ្វើការលះបង់យ៉ាងធំ ។ គាត់បានដឹងថា ការរកស៊ីចិញ្ចឹមជីវិតជាអាចារ្យសាសនា និង កិត្តិនាមរបស់គាត់នៅក្នុងសហគមន៍នឹងត្រូវខាតបង់ ប៉ុន្តែ គាត់បានប្ដេជ្ញាចិត្តធ្វើតាមសេចក្ដីពិត ។

បន្ទាប់ពីពួកអែលឌើរ បានចាកចេញពីទីក្រុង ខឺតឡង់ ដើម្បីបន្តដំណើររបស់ពួកគាត់ នោះ ស៊ីឌនី រិកដុន និង មិត្តភក្ដិម្នាក់ឈ្មោះ អែតវឺត ប៉ាទ្រិច បានធ្វើដំណើរទៅ រដ្ឋនូវ យ៉ោក ដើម្បីជួបនឹងព្យាការី យ៉ូសែប ស្ម៊ីធ ។ មិនយូរប៉ុន្មាន បន្ទាប់ពីពួកគាត់បានទៅដល់ ព្យាការីបានទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥ ។ ក្នុងវិវរណៈនោះ ព្រះអម្ចាស់បានប្រទានការទទួលខុសត្រូវជាក់លាក់នានាដល់ ស៊ីឌនី រិកដុន នៅក្នុងសាសនាចក្រដែលទើបតែបានស្ដារឡើងវិញថ្មីៗនេះ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១–១២

*ព្រះអម្ចាស់មានព្រះបន្ទូលប្រាប់ ស៊ីឌនី រិកដុន ថាគាត់ត្រូវបានរៀបចំឲ្យធ្វើកិច្ចការដ៏លើលលែងទៅទៀត*

១. សូមឆ្លើយសំណួរតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកធ្លាប់មានបទពិសោធន៍ ដែលជួយអ្នកឲ្យដឹងថា ព្រះទ្រង់ស្គាល់អ្នកដែរឬទេ ?

វិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥ បង្ហាញថា ព្រះអម្ចាស់ទ្រង់ស្គាល់ ស៊ីឌនី រិកដុន ហើយទ្រង់បានមានព្រះបន្ទូលទៅកាន់ ស៊ីឌនី អំពីតួនាទីរបស់គាត់ក្នុងការជួយដល់ព្យាការី យ៉ូសែប ស្ម៊ីធ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១–៣ ដោយស្វែងរកភស្ដុតាង ដែលបង្ហាញថា ព្រះអម្ចាស់បានស្គាល់ ស៊ីឌនី រិកដុន ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:៣ ម្ដងទៀត ដោយដាក់ឈ្មោះរបស់អ្នកជំនួសឲ្យ ស៊ីឌនី វិញ ។ តើព្រះបន្ទូលរបស់ព្រះអម្ចាស់ បង្រៀនអ្វីខ្លះអំពីការដែលទ្រង់ស្គាល់យើងម្នាក់ៗ ?



អែលឌើរ នែល អេ ម៉ាក់ស្វែល ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានថ្លែងទីបន្ទាល់អំពីការដែលទ្រង់ស្គាល់យើងម្នាក់ៗថា ៖ « ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះទ្រង់ស្គាល់យើងម្នាក់ៗ. . . ជាយូរលង់ណាស់មកហើយ ( សូមមើល គ. និង ស. ៩៣:២៣ ) ។ ទ្រង់ស្រឡាញ់អ្នកជាយូរលង់មកហើយ ។. . . ទ្រង់ស្គាល់ឈ្មោះរបស់អ្នក និងការឈឺចាប់ទាំងអស់របស់អ្នក និងក្ដីអំណររបស់អ្នក ! » ( Remember How Merciful the Lord Hath Been,” *Ensign* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ៤៦ ) ។

គោលការណ៍មួយដែលយើងរៀនមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:៣ គឺថា **ព្រះអម្ចាស់ស្គាល់យើង ហើយថាទ្រង់មានកិច្ចការសម្រាប់យើងម្នាក់ៗឲ្យធ្វើ ។** តើអ្នកធ្លាប់ឆ្ងល់ទេថា តើព្រះអម្ចាស់មានកិច្ចការជាក់លាក់អ្វីខ្លះឲ្យអ្នកធ្វើនៅក្នុងជីវិតរបស់អ្នក ?

ពីមុនដែលគាត់បានរៀនអំពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ស៊ីឌនី រិកដុន បានធ្វើកិច្ចការដ៏ប្រពៃក្នុងនាមជាអាចារ្យសាសនានៃសាសនាចក្រមួយផ្សេងទៀត ។ ក្រោយពីបានចូលសាសនាចក្ររបស់ព្រះអម្ចាស់ដែលបានស្ដារឡើងវិញហើយនោះ គាត់មានលទ្ធភាពធ្វើ « កិច្ចការដ៏លើសលែងទៅទៀត » ( គ. និង ស. ៣៥:៣ ) ដើម្បីនគរនៃព្រះអម្ចាស់ ។ មនុស្សដែលមានជំនឿផ្សេង អាចប្រព្រឹត្តកិច្ចការល្អជាច្រើន ។ វាគឺជាការទទួលខុសត្រូវរបស់យើង ដើម្បីចែកចាយភាពពេញលេញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យពួកគេអាចធ្វើ « កិច្ចការដ៏លើសលែងទៅទៀត » ។

ស្រដៀងគ្នានេះដែរ យើងអាចមានទំនុកចិត្តថា ព្រះអម្ចាស់ទ្រង់ស្គាល់យើងម្នាក់ៗ ហើយនៅពេលយើងពុះពារដើរតាមទ្រង់ នោះទ្រង់នឹងជួយយើងឲ្យសម្រេចបានកិច្ចការ ដែលយើងត្រូវបានរៀបចំឲ្យធ្វើ ។



ក្នុងនាមជាអ្នករៀបចំផ្លូវថ្វាយព្រះយេស៊ូវគ្រីស្ទ យ៉ូហាន បាទីស្ទ បានរៀបចំដួងចិត្តមនុស្សជាច្រើនរង់ចាំទទួលការយាងមករបស់ទ្រង់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:៤–៦ រួចស្វែងរកចំណុចដែល ស៊ីឌនី រិកដុន មានលក្ខណៈដូចគ្នាទៅនឹង យ៉ូហាន បាទីស្ទ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

ទោះជា ស៊ីឌនី រិកដុន មានលក្ខណៈដូចជា យ៉ូហាន បាទីស្ទ ត្រង់ចំណុចមួយចំនួនក្ដី ក៏គាត់មានលក្ខណៈខុសពី យ៉ូហាន បាទីស្ទ ដែរ ព្រោះកាល ស៊ីឌនី បានធ្វើពិធីបុណ្យជ្រមុជទឹកឲ្យសមាជិកក្នុងក្រុមជំនុំរបស់គាត់ គាត់ពុំមានសិទ្ធិអំណាចពីព្រះដើម្បីធ្វើកិច្ចការនោះឡើយ ( សូមមើល គ. និង ស. ៣៥:៥–៦ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:៧–១១ រួចស្វែងរកអ្វីដែលនឹងកើតឡើងនៅក្នុងជីវិតរបស់អ្នកទាំងឡាយណា ដែលជឿ ហើយអនុវត្តសេចក្ដីជំនឿទៅលើព្រះ នៅថ្ងៃចុងក្រោយ ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើយើងអាចរៀនអ្វីខ្លះចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:៧–១១ អំពីអ្វីដែល ព្រះអម្ចាស់បានសន្យាថានឹងបង្ហាញដល់អ្នកទាំងឡាយណា ដែលដើរតាមទ្រង់ដោយសេចក្ដីជំនឿ ? ( ពាក្យ *ពួកសាសន៍ដទៃ* នៅក្នុង ខទី ៧ សំដៅទៅលើអស់អ្នកដែលពុំទាន់ស្គាល់ភាពពេញលេញនៃដំណឹងល្អ ។ ពាក្យ *បាប៊ីឡូន* នៅក្នុង ខទី ១១ សំដៅលើលោកិយ ) ។

ខ. តើអ្នកគិតថា ហេតុអ្វីបានជាអព្ភូតហេតុទាំងឡាយ ត្រូវបានភ្ជាប់គ្នាយ៉ាងជាប់ទៅនឹងសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ ? ( សូមគិតថា អព្ភូតហេតុនានាអាចជាការល្អិតល្អន់ដូចជាការផ្លាស់ប្ដូរនៅក្នុងដួងចិត្ត ឬ ការអត់ទោសដល់អំពើបាប ហើយអព្ភូតហេតុទាំងនោះបានមកតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១៣–១៩

*ព្រះអម្ចាស់សន្យាថា នឹងជួយដល់អ្នក ដែលបន្ទាបខ្លួនក្នុងការធ្វើកិច្ចការរបស់ទ្រង់*

សូមស្រមៃថា អ្នកកំពុងបង្កើតក្រុមកីឡាមួយជាមួយគ្នា ( សូមគិតអំពីកីឡាមួយដែលអ្នកចេះលេង ) ។ សូមពិពណ៌នាអំពីភាពខ្លាំង និង ភាពស្ទាត់ជំនាញ ដែលអ្នកចង់ឲ្យកីឡាកររបស់អ្នកមាន នៅក្នុងចន្លោះដែលមានផ្ដល់ឲ្យ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១៣ ដោយស្វែងរកបុគ្គល ដែលព្រះអម្ចាស់បានរើសតាំងឲ្យបំពេញកិច្ចការរបស់ទ្រង់ ។ សូមកត់ចំណាំអំពីលក្ខណៈសម្បត្តិទាំងឡាយនៃមនុស្ស ដែលព្រះអម្ចាស់ជ្រើសតាំងឲ្យជួយដល់ទ្រង់ ដែលមានសភាពមិនប្រក្រតីចំពោះបទដ្ឋានរបស់លោកិយ ។ « ពួកកំសោយនៅលោកិយ » សំដៅទៅលើពួកអ្នកបម្រើព្រះអម្ចាស់ ។ ពាក្យ *បញ្ជាន់* ឬ *បោក* នៅក្នុងខគម្ពីរនេះ សំដៅទៅលើការបញ្ជាន់ ដែលជាសកម្មភាពនៃការបោកបែនគ្រាប់ស្រូវចេញពីទង ឬ សំបករបស់វា ។ នៅក្នុងខគម្ពីរនេះ វាសំដៅទៅលើការបំបែក និង ការប្រមូលរាស្ត្រ ដែលត្រៀមខ្លួនជាស្រេចដើម្បីទទួលយកដំណឹងល្អ ចេញពីរាស្ត្រដែលពុំបានត្រៀមខ្លួននៅឡើយ ។ របៀបមួយដែលកិច្ចការនេះត្រូវបានបំពេញគឺ តាមរយៈការដើរស្វែងរកមនុស្សរបស់ពួកអ្នកផ្សព្វផ្សាយសាសនា និង ការរៀបចំពួកគេឲ្យធ្វើ ហើយរក្សាសេចក្ដីសញ្ញាពិសិដ្ឋ ។

យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១៣ យើងរៀនថា **ព្រះគ្រាស់ហៅ អ្នកកំសោយឲ្យបំពេញកិច្ចការរបស់ទ្រង់តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណទ្រង់ ។**

៣. សូមឆ្លើយសំណួរដូចតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថា ហេតុអ្វីបានជាព្រះអម្ចាស់ហៅពួកអ្នកបម្រើទ្រង់ថាជា « អ្នកកំសោយ » « ល្ងង់ខ្លៅ » និង « ត្រូវគេប្រមាថ » ?



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១៤–១៥ ដោយស្វែងរកការសន្យា ដែលព្រះអម្ចាស់បានធ្វើដល់អ្នកដែលជួយក្នុងកិច្ចការទ្រង់ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។ អ្នកក៏អាចនឹងដាក់ខគម្ពីរទាំងនេះជាខគម្ពីរផ្ទាល់ខ្លួន ដោយការអានខគម្ពីរទាំងនោះម្ដងទៀត ហើយដាក់បញ្ចូលឈ្មោះរបស់អ្នក ។

៤. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរពីរ ឬ ទាំងអស់នៃសំណួរខាងក្រោមនេះ ៖

ក. តើការដឹងថា ព្រះប្រើពួកកំសោយនៅលោកិយ ឲ្យបំពេញកិច្ចការរបស់ទ្រង់តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណរបស់ទ្រង់ អាចជួយដល់យុវជនម្នាក់ ដែលមានអារម្មណ៍ថា ភ័យខ្លាចក្នុងការបម្រើបេសកកម្មបានយ៉ាងដូចម្ដេច ?

ខ. តើការយល់ដឹងនេះ អាចជួយយុវនារីម្នាក់ ដែលត្រូវបានស្នើឲ្យបង្រៀនថ្នាក់មួយក្នុងសាសនាចក្រ ហើយមានអារម្មណ៍ថាមិនសូវចេះយ៉ាងដូចម្ដេច ?

គ. តើការយល់ដឹងនេះ ជួយយើងទាំងអស់គ្នាយ៉ាងដូចម្ដេច កាលយើងទទួលបានអារម្មណ៍បំផុតគំនិតឲ្យចែកចាយដំណឹងល្អជាមួយនរណាម្នាក់នោះ ?



ប្រធាន ថូម៉ាស អេស ម៉នសុន បានលើកទឹកចិត្តអ្នកដែលអាចនឹងមានអារម្មណ៍ថាខ្លួនឯងជាមនុស្សកំសោយ ឬ មិនសូវចេះ ឲ្យជួយក្នុងកិច្ចការរបស់ព្រះអម្ចាស់ថា ៖ « មនុស្សមួយចំនួនអាចនឹងមានការអៀនប្រៀនពីកំណើត ឬ គិតថាខ្លួនមិនសូវចេះក្នុងការឆ្លើយតបដោយមោះមុតចំពោះការហៅបម្រើ ។ ចូរចាំថា កិច្ចការនេះ គឺពុំមែនជារបស់អ្នក និង ខ្ញុំតែឯងនោះទេ ។ វាជាកិច្ចការរបស់ព្រះអម្ចាស់ ហើយពេលយើងស្ថិតនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ នោះយើងនឹងទទួលបានជំនួយពីព្រះអម្ចាស់ ។ ចូរចាំថា ព្រះអម្ចាស់ នឹងដុសខាត់ខ្នងដើម្បីកែបន្ទុកដែលនឹងដាក់មកលើ » ( « To Learn, to Do, to Be » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៨, ទំព័រ ៦២ ) ។

#### *ការដាក់ប្រជុំបទគម្ពីរទៅជារឿងផ្ទាល់ខ្លួន*

ការដាក់បញ្ចូលឈ្មោះរបស់អ្នកទៅក្នុងខគម្ពីរ អាចជួយឲ្យសេចក្ដីពិតនៃវគ្គបទគម្ពីរនោះ មានន័យកាន់តែជ្រាលជ្រៅចំពោះអ្នក ។ ការអានព្រះគម្ពីរឲ្យដូចជាវាត្រូវបានសរសេរឡើងសម្រាប់អ្នក អាចជារបៀបដ៏មានអត្ថប្រយោជន៍ដើម្បី « ឮព្រះសូរសៀងរបស់ព្រះអម្ចាស់ យេស៊ូវគ្រីស្ទ មានព្រះបន្ទូលទៅកាន់ [ អ្នក ] » ( Explanatory Introduction to the Doctrine and Covenants ) ។

ព្យាការី យ៉ូសែប ស្ម៊ីធ ត្រូវបានចាត់ទុកដោយមនុស្សមួយចំនួនថាជា មនុស្សកំសោយខាងចំណេះដឹងទូទៅ និង សមត្ថភាពផ្សេង ៗទៀត ។ បើប្រៀបធៀបនឹង ស៊ីឌនី រិកដុន គាត់គឺជាបុគ្គលដែលមានការអប់រំខ្ពស់ និង មានអំណោយទានជាច្រើន ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១៧–១៩ រួចស្វែងរកឱវាទ ដែលព្រះអម្ចាស់បានប្រទានដល់ ស៊ីឌនី រិកដុន អំពីព្យាការី យ៉ូសែប ។

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីបានជាឱវាទដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:១៧–១៩ មានសារៈសំខាន់ចំពោះអាចារ្យសាសនាដែលមានការអប់រំខ្ពស់ដូចជា ស៊ីឌនី រិកដុន ដែលគាត់ត្រូវយល់ ?

ខ. តើវានឹងមានអត្ថប្រយោជន៍ដូចម្ដេចចំពោះយើង ក្នុងការចងចាំអំពីឱវាទនេះ ដោយការគោរពដល់ថ្នាក់ដឹកនាំសាសនាចក្រយើងដែលកំពុងតែដឹកនាំ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:២០-២៧

*ស៊ីឌនី រិកដុន ត្រូវបានបានបញ្ជាឲ្យធ្វើជាស្មៀនរបស់ យ៉ូសែប ស្ម៊ីធ ដើម្បីផ្សាយដំណឹងល្អ ហើយរក្សាសេចក្ដីសញ្ញារបស់គាត់ ។*

តើអ្នកមានការហៅ ឬ ករណីយកិច្ចជាក់លាក់ណាមួយ នៅក្នុងសាសនាចក្រដែរឬទេ ? សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:២០-២៤ រួចស្វែងរកករណីយកិច្ចជាក់លាក់ ដែល ស៊ីឌនី រិកដុន ត្រូវបានហៅឲ្យបំពេញ ។

ព្រះអម្ចាស់បានត្រាស់ហៅ ស៊ីឌនី ឲ្យបំពេញតួនាទីជាស្មៀនរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ដែលបានបន្តការបកប្រែរបស់លោកលើព្រះគម្ពីរប៊ីប ។ ការបកប្រែនេះ មិនមែនបានធ្វើឡើង ចេញពីភាសាមួយទៅភាសាមួយទៀតនោះទេ ។ ព្យាការីបានធ្វើកំណែ និង កែតម្រូវ លើព្រះគម្ពីរប៊ីបអស់រយៈពេលជាង ១៦ ឆ្នាំ ។ យើងហៅកំណែនេះថាជា ការបកប្រែរបស់ យ៉ូសែប ស្ម៊ីធ ។ ការកែតម្រូវទាំងនេះភាគច្រើន អាចរកមើលបាននៅលើលេខយោង និង សេចក្ដីបន្ថែមនៃការបោះពុម្ពព្រះគម្ពីរប៊ីប អិល.ឌី.អេស ។ ព្រះគម្ពីរម៉ូសេ និង យ៉ូសែប ស្ម៊ីធ—ម៉ាថាយ នៅក្នុង មុក្ដាដ៏មានតម្លៃមហិមា ក៏ស្ថិតនៅក្នុងផ្នែកនៃការបកប្រែរបស់ យ៉ូសែប ស្ម៊ីធ ដែរ ។

សូមកត់ចំណាំនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:២៣ ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ ស៊ីឌនី រិកដុន ថា ក្រៅពីការធ្វើជាស្មៀនឲ្យ យ៉ូសែប ស្ម៊ីធ គាត់ក៏គួរតែផ្សាយដំណឹងល្អផងដែរ ដោយប្រើចំណេះដឹងខាងបទគម្ពីរដើម្បីគាំទ្រប្រសាសន៍របស់ព្យាការី ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:២៤ តើពរជ័យអ្វីខ្លះ ដែលព្រះអម្ចាស់បានសន្យាដល់ ស៊ីឌនី រិកដុន ប្រសិនបើគាត់គោរពតាមសេចក្ដីសញ្ញារបស់គាត់ ? គោលការណ៍មួយ ដែលយើងអាចរៀនចេញពីខគម្ពីរនេះគឺ **នៅពេលយើងគោរពតាមព្រះបញ្ញត្តិទាំងឡាយ ហើយរក្សាសេចក្ដីសញ្ញារបស់យើង នោះព្រះអម្ចាស់នឹងជួយយើងឲ្យបំពេញកិច្ចការរបស់ទ្រង់ ។**

៦. សូមមើលទៅគោលការណ៍ទាំងបី ដែលបានបង្ហាញនៅក្នុងមេរៀននេះ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើគោលការណ៍ទាំងបីនៅក្នុងមេរៀននេះ ទាក់ទងគ្នាទៅវិញទៅមកយ៉ាងដូចម្ដេច ?

ខ. តើនៅពេលណាដែល អ្នកធ្លាប់ដឹង ឬ ធ្វើសាក្សីចំពោះជំនួយពីព្រះអម្ចាស់ដែលបានប្រទានដល់អ្នក ឬ ដល់នរណាម្នាក់ដែលអ្នកស្គាល់ កាលកំពុងធ្វើកិច្ចការរបស់ព្រះអម្ចាស់ ?

ដើម្បីបញ្ចប់មេរៀន សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥:២៦-២៧ ។ ចេញពីអ្វីដែលអ្នកបានរៀនអំឡុងការសិក្សារបស់អ្នកអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥ នៅថ្ងៃនេះ តើអ្នកគិតថា ហេតុអ្វីបានជា ស៊ីឌនី រិកដុន មានហេតុផលនឹងលើកចិត្តរបស់គាត់ឡើង ហើយអរសប្បាយ ? តើអ្នកមានហេតុផលអ្វីខ្លះ ដើម្បីលើកចិត្តអ្នកឡើង ហើយអរសប្បាយ ?

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៥ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦–៣៧

## សេចក្ដីផ្ដើម

ក្នុងខែ ធ្នូ ឆ្នាំ ១៨៣០ ស៊ីឌនី រិកដុន បានធ្វើដំណើរពី រដ្ឋអូហៃអូ ទៅ រដ្ឋនូវ យ៉ោក ជាមួយ អែតវឺត ប៉ាទ្រិច ដើម្បីជួបនឹងព្យាការី យ៉ូសែប ស្ម៊ីធ ។ ទោះជា ស៊ីឌនី ទើបតែបានទទួលពិធីបុណ្យជ្រមុជទឹកថ្មីៗក្ដី ក៏ អែតវឺត ពុំទាន់បានប្រែចិត្តជឿលើភាពពេញលេញនៃដំណឹងល្អដែលបានស្ដារឡើងវិញនៅឡើយដែរ ។ បន្ទាប់ពីបានជួបព្យាការី ហើយជជែកជាមួយអ្នកដែលស្គាល់លោកហើយនោះ អែតវឺត បានសុំឲ្យព្យាការីធ្វើពិធីបុណ្យជ្រមុជទឹកឲ្យគាត់ ។ ក្នុងដើមខែ ធ្នូ ឆ្នាំ ១៨៣០ ពីមុន អែតវឺត ប៉ាទ្រិច បានទទួលពិធីបុណ្យជ្រមុជទឹក នោះ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦ ។ នៅក្នុងវិវរណៈនោះ ព្រះអម្ចាស់បានត្រាស់ហៅ ហើយបញ្ជាឲ្យ អែតវឺត ប៉ាទ្រិច ផ្សាយដំណឹងល្អ ។

នៅអំឡុងប្រាំមួយខែចុងក្រោយក្នុងឆ្នាំ ១៨៣០ សេចក្ដីបៀតបៀនទាស់នឹងសាសនាចក្រមានកាន់តែខ្លាំងឡើង ។ ក្នុងខែ ធ្នូ ឆ្នាំ ១៨៣០ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៣៧ ដែលព្រះអម្ចាស់បានបញ្ជាឲ្យពួកបរិសុទ្ធចាកចេញពីរដ្ឋនូវ យ៉ោក ហើយទៅប្រមូលផ្ដុំគ្នានៅរដ្ឋ អូហៃអូ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:១–៣

*ព្រះអម្ចាស់បានអត់ទោសឲ្យ អែតវឺត ប៉ាទ្រិច ពីអំពើបាបរបស់គាត់ ហើយហៅគាត់ឲ្យផ្សាយដំណឹងល្អ*

សូមគិតអំពីរបស់របរមួយចំនួន ដែលពួកអ្នកផ្សព្វផ្សាយសាសនាយកទៅជាមួយ ដើម្បីជួយពួកគេឲ្យបំពេញការងាររបស់ខ្លួន ។



របស់របរមួយចំនួនដែលអ្នកផ្សព្វផ្សាយសាសនាត្រូវការពីមុនពួកគេអាចផ្សាយដំណឹងល្អបានយ៉ាងមានប្រសិទ្ធភាពនោះ ពុំអាចវេចខ្ចប់បាននៅក្នុងវ៉ាលីនោះទេ ។ នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦ សូមស្វែងរកប្រការមួយចំនួន ដែលអ្នកផ្សព្វផ្សាយសាសនាត្រូវការ និង ត្រូវតែធ្វើពីមុនពួកគេត្រៀមខ្លួនរួចរាល់ដើម្បីបម្រើបេសកកម្ម ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦ ព្រះអម្ចាស់បានត្រាស់ហៅ អែតវឺត ប៉ាទ្រិច ឲ្យបម្រើបេសកកម្ម ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:១ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ អែតវឺត ប៉ាទ្រិច នៅពីមុនដែលទ្រង់បានត្រាស់ហៅឲ្យគាត់ផ្សាយដំណឹងល្អ ។

១. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលអ្នកគិតថា វាមានសារៈសំខាន់ ចំពោះអ្នកទាំងឡាយដែលត្រូវបានហៅឲ្យផ្សាយដំណឹងល្អ ត្រូវប្រែចិត្ត ហើយត្រូវបានអត់ទោសពីអំពើបាបរបស់ពួកគេដូច្នេះ ។ សូមពិចារណាអំពីរបៀបដែលត្រូវបានជ្រះស្អាតពីអំពើបាប នឹងជួយ អែតវឺត ប៉ាទ្រិច ឲ្យផ្សាយដំណឹងល្អ « ហាក់ដូចជាដោយសំឡេងត្រែ » ( គ. និង ស. ៣៦:១ ) ។

សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមពីអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ រួចគូសចំណាំពាក្យ ឬ ឃ្លា ដែលជួយអ្នកឲ្យយល់អំពីមូលហេតុដែលវាមានសារៈសំខាន់ ចំពោះអ្នកដែលត្រូវបានហៅឲ្យផ្សាយដំណឹងល្អ ត្រូវមានភាពស្អាតស្អំ ៖



« នៅក្នុងការប្រកួតរវាងសេចក្ដីល្អ និងសេចក្ដីអាក្រក់នេះ អ្នកពុំអាចលេងឲ្យខាងមារសត្រូវ នៅពេលណាមានការល្បួងកើតឡើង រួចមករំពឹងទុកថា ខ្លួនបែរត្រូវខាងព្រះអង្គសង្គ្រោះវិញ នៅឯព្រះវិហារបរិសុទ្ធ និងនៅពេលចេញបេសកកម្ម ដែលហាក់ដូចជាគ្មានអ្វីបានកើតឡើងបាននោះទេ ។ មិត្តយុវវ័យខ្ញុំអើយ នោះអ្នកពុំអាចធ្វើបានឡើយ ។ ព្រះនឹងពុំត្រូវបានចំអកឡើយ ។

« . . . ក្នុងការប្រកួតកីឡាស្ទើរតែគ្រប់ទាំងអស់ដែលខ្ញុំដឹង មានគំនូសខ្សែនៅលើផ្ទៃ ឬ តារាង ដែលអ្នកចូលរួមប្រកួតគ្រប់រូបត្រូវតែឈរនៅទីនោះដើម្បីប្រកួត ។ ព្រះអម្ចាស់ បានគូសបន្ទាត់ភាពសក្តិសមសម្រាប់អ្នកទាំងឡាយដែលត្រូវបានហៅឲ្យធ្វើការជាមួយទ្រង់ក្នុងកិច្ចការនេះ ។ គ្មានអ្នកផ្សព្វផ្សាយសាសនាណា អាចមិនប្រែចិត្តពីអំពើរំលងខាង

ផ្លូវភេទ ឬភាសាអាសគ្រោម ឬបណ្ដោយខ្លួនតាមភាពអាសគ្រោម ហើយមករំពឹងឲ្យអ្នកដទៃប្រែចិត្តពីរឿងទាំងអស់នេះនោះទេ ! អ្នកមិនអាចធ្វើដូច្នោះបានឡើយ ។ ព្រះវិញ្ញាណនឹងពុំគង់នៅជាមួយអ្នកឡើយ ហើយពាក្យទាំងឡាយនឹងត្រូវស្លាក់នៅក្នុងបំពង់កអ្នក ពេលអ្នកថ្លែងវាចេញមក ។ អ្នកពុំអាចធ្វើដំណើរតាមផ្លូវដែល លីហៃ បានហៅថា ‹ ផ្លូវហាមឃាត់ › នោះឡើយ [នីហ្វៃទី ១ ៨:២៨] ហើយរំពឹងថាដឹកនាំអ្នកដទៃឲ្យដើរលើ ‹ ផ្លូវត្រង់ និងចង្អៀត › នោះឡើយ [នីហ្វៃទី ២ ៣១:១៨] វាពុំអាចធ្វើទៅរួចទេ » ( We Are All Enlisted » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១,ទំព័រ ៤៥ ) ។

សូមពិចារណាអំពីស្ថានភាពដែលនឹងទៅជាដូចម្ដេចចំពោះអ្នក ក្នុងការចែកចាយដំណឹងល្អជាមួយមនុស្សដទៃ ខណៈអ្នកដឹងខ្លួនឯងថា ពុំបានរស់នៅតាមសេចក្ដីពិតដែលអ្នកកំពុងបង្រៀនផងនោះ ។ ឥឡូវនេះ សូមពិចារណាអំពីស្ថានភាពដែលនឹងទៅជាដូចម្ដេច ក្នុងការចែកចាយដំណឹងល្អជាមួយមនុស្សដទៃ ដោយមានទំនុកចិត្តដែលកើតមានពីការត្រូវបានសម្អាតពីការធ្វើខុសទាំងឡាយ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។



អែលឌើរ ហូឡិន បានមានប្រសាសន៍អំពីការណ៍ដែលអ្នកអាចធ្វើបាននាពេលឥឡូវនេះ ដើម្បីមានភាពស្អាតស្អំក្នុងការបម្រើបេសកកម្មថា ៖ « មិនថាអ្នកជានរណា និង អ្នកជាអ្វីនោះទេ អ្នកអាចត្រូវបានអត់ទោសឲ្យ ។ អ្នកទាំងអស់គ្នា . . . អាចទុកចោលអំពើរំលងសព្វបែបយ៉ាង ដែលអ្នកអាចនឹងមានបញ្ហា ។ វាគឺជាអព្ភូតហេតុនៃការអភ័យទោស វាគឺជាអព្ភូតហេតុនៃដង្វាយធួនរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។ ប៉ុន្តែអ្នកពុំអាចធ្វើវាបានដោយគ្មានការតាំងចិត្តដ៏សកម្មមួយចំពោះដំណឹងល្អនោះទេ ហើយអ្នកពុំអាចធ្វើវាបានដោយគ្មានការប្រែចិត្ត ពេលដែលវាចាំបាច់តម្រូវឲ្យមាននោះឡើយ ។ ខ្ញុំសុំឲ្យអ្នក. . . សកម្ម ហើយស្អាតស្អំ ។ បើវាចាំបាច់ ខ្ញុំសុំឲ្យអ្នក *មាន* ភាពសកម្ម ហើយ *មាន* ភាពស្អាតស្អំ » ( «We Are All Enlisted » ទំព័រ ៤៥ ) ។

សូមពិចារណាអំពីអ្វីដែលអ្នកត្រូវធ្វើនាពេលឥឡូវនេះ ដើម្បីឲ្យមានភាពស្អាតស្អំ ឬ បន្តមានភាពស្អាតស្អំ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:២–៣ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានសន្យាថាប្រទានដល់ អែតវឺត ប៉ាទ្រិច នៅពីមុនដែលទ្រង់នឹងបញ្ជូនគាត់ទៅផ្សាយដំណឹងល្អ ។



ប្រធាន ហារ៉ូល ប៊ី លី បានពន្យល់អំពីអត្ថន័យនៃឃ្លា « យើងនឹងដាក់ដៃលើអ្នក ដោយដៃអ្នកបម្រើរបស់យើង » មានចែងនៅក្នុង ខទី ២ ថា ៖ « ព្រះអម្ចាស់កំពុងមានព្រះបន្ទូលនៅខនេះថា ពេលអ្នកបម្រើរបស់ទ្រង់ម្នាក់ដែលបានទទួលការអនុញ្ញាត ដាក់ដៃរបស់គាត់ដោយសិទ្ធិអំណាចនៅលើក្បាលរបស់បុគ្គលម្នាក់ដែលត្រូវការការប្រសិទ្ធពរ វាគឺដូចជាទ្រង់ផ្ទាល់ព្រះអង្គ ដែលបានដាក់ព្រះហស្តទ្រង់នៅលើពួកគេដើម្បីធ្វើពិធីបរិសុទ្ធនោះដូច្នោះដែរ ។ ដូច្នេះ យើងឃើញពីរបៀបដែលទ្រង់សម្ដែងព្រះចេស្ដាទ្រង់ ក្នុងចំណោមពួកអ្នកបម្រើទ្រង់ ដែលទ្រង់បានប្រទានកូនសោទាំងឡាយនៃសិទ្ធិអំណាចដល់ពួកគេ » ( *Be Secure in the Gospel of Jesus Christ,* Brigham Young University Speeches of the Year [ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៥៨ ] ទំព័រ ៦ ) ។

វាក៏នឹងមានប្រយោជន៍ផងដែរចំពោះអ្នក ដើម្បីដឹងថា ឃ្លា « បង្រៀនអ្នកអំពីការណ៍ទាំងឡាយដ៏ប្រកបដោយសេចក្ដីសុខសាន្តនៃនគរ » នៅក្នុង ខទី ២ គឺសំដៅទៅលើការបំផុសគំនិត និង សេចក្ដីណែនាំ ដែលយើងទទួលបានពីព្រះវិញ្ញាណបរិសុទ្ធ កាលយើងរស់នៅតាមដំណឹងល្អ ។

សូមកត់ចំណាំនៅក្នុង ខទី ៣ អំពីអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់គាត់ឲ្យធ្វើ ដោយនូវអ្វីដែលព្រះវិញ្ញាណបរិសុទ្ធបានបង្រៀនដល់គាត់ ។

២. សូមឆ្លើយសំណួរដូចតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរអ្នក ៖ តើអ្នកគិតថា ហេតុអ្វីបានជាវាមានសារៈសំខាន់ចំពោះអ្នកផ្សព្វផ្សាយសាសនា ដែលត្រូវមានព្រះវិញ្ញាណបរិសុទ្ធជាដៃគូនោះ ? បន្ទាប់ពីបានឆ្លើយសំណួរនេះហើយ អ្នកក៏អាចសរសេរអំពីគ្រាមួយ ដែលព្រះវិញ្ញាណបរិសុទ្ធបានបង្រៀនអ្វីមួយអំពី « ការណ៍ទាំងឡាយដ៏ប្រកបដោយសេចក្ដីសុខសាន្តនៃនគរ » ( គ. និង ស. ៣៦:២ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:៤–៨

*ព្រះអម្ចាស់ប្រទានព្រះបញ្ញត្តិមួយ ស្ដីអំពីអ្នកទាំងឡាយដែលត្រូវបានហៅឲ្យផ្សាយដំណឹងល្អ*

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:៤–៥, ៧ ។ សូមកត់ចំណាំថា នៅក្នុងខគម្ពីរទាំងនេះ ព្រះអម្ចាស់កំពុងមានព្រះបន្ទូលទៅកាន់ « ពួកអែលឌើរនៃសាសនាចក្រ [ របស់ទ្រង់ ] ( គ. និង ស. ៣៦:៧ ) ។ នៅពេលអ្នកអាន សូមស្វែងរកទំនួលខុសត្រូវមួយ ដែលព្រះអម្ចាស់បានប្រទានទៅឲ្យពួកអ្នកកាន់បព្វជិតភាព ។

យោងតាមអ្វីដែលអ្នកបានអាននៅក្នុងខគម្ពីរទាំងនេះ សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ដែលស្ដីពីទំនួលខុសត្រូវនៃអ្នកកាន់បព្វជិតភាពទាំងអស់នាពេលបច្ចុប្បន្ននេះ ៖ **អ្នកកាន់បព្វជិតភាពទាំងឡាយត្រូវបានហៅឲ្យ** ។



ប្រធាន ថូម៉ាស អេស ម៉នសុន បានផ្ដល់អនុសាសន៍លើគោលការណ៍នេះថា ៖ « ខ្ញុំសូមរំឭកឡើងវិញនូវអ្វីដែលពួកព្យាការីបានបង្រៀនជាយូរលង់មកហើយ– ថារាល់យុវជនដែលមានភាពសក្ដិសម និងមានសមត្ថភាពគ្រប់រូប គួរតែត្រៀមខ្លួនបម្រើបេសកកម្ម ។ កិច្ចការផ្សព្វផ្សាយសាសនា គឺជាកាតព្វកិច្ចបព្វជិតភាពមួយ–ជាកាតព្វកិច្ចមួយ ដែលព្រះអម្ចាស់រំពឹងពីយើង ដែលត្រូវបានប្រទានឲ្យយ៉ាងច្រើននោះ » (As We Meet Together Again, » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១០, ទំព័រ ៥–៦ ) ។

ប៊ីស្សព និង ប្រធានសាខា ធ្វើការជាមួយពួកយុវជន និង យុវនារី ដើម្បីកំណត់ពីភាពសក្ដិសម និង សមត្ថភាព ក្នុងការបម្រើព្រះអម្ចាស់ ជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ។ យុវជនមួយចំនួនអាចត្រូវបានលើកលែងពីការបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង បានដោយសារបញ្ហាសុខភាព ឬ ពិការភាពផ្សេងៗ ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីនេះ ពួកគេត្រូវរក្សាភាពសក្ដិសមរបស់ខ្លួន ហើយត្រៀមខ្លួនបម្រើព្រះអម្ចាស់តាមមធ្យោបាយផ្សេងៗទៀត ។

សូមរំឭក គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:៥, ៧ ដើម្បីឃើញពីអ្វី ដែលអ្នកកាន់បព្វជិតភាពចាំបាច់ត្រូវធ្វើ ពីមុនពួកគាត់ត្រូវបានតែងតាំង ហើយបញ្ជូនទៅផ្សាយដំណឹងល្អ ?

៣. សូមឆ្លើយសំណួរដូចតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើយុវជនម្នាក់អាចបង្ហាញដល់ព្រះអម្ចាស់យ៉ាងដូចម្ដេច ថាគាត់ស្រឡាញ់ព្រះបញ្ញត្តិ ដែលបញ្ជាឲ្យផ្សាយដំណឹងល្អ ?



ទោះជាការបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង គឺជាករណីយកិច្ចបព្វជិតភាពក្ដី ក៏យុវនារីអាចបម្រើបានផងដែរ ។ ប្រធាន ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា ៖ « ខ្ញុំសូមថ្លែងទៅកាន់យុវនារីទាំងឡាយ ៖ ខណៈដែលអ្នកពុំមាននូវទំនួលខុសត្រូវបព្វជិតភាពដូចគ្នានឹងយុវជន ដើម្បីបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងក្ដី ក៏អ្នកអាចរួមចំណែកដ៏មានតម្លៃជាអ្នកផ្សព្វផ្សាយសាសនាបានផងដែរ ហើយយើងសូមស្វាគមន៍ចំពោះការបម្រើរបស់អ្នក » ( «As We Meet Together Again » ទំព័រ ៦) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:៦ ដោយស្វែងរកសារលិខិត ដែលព្រះអម្ចាស់បញ្ជាដល់ពួកអ្នកផ្សព្វផ្សាយសាសនារបស់ទ្រង់ឲ្យបង្រៀន ។ ឃ្លា « អាវដែលត្រូវស្មោកគ្រោកដោយសាច់ឈាម » សំដៅទៅលើសំលៀកបំពាក់ដែលត្រូវបានចម្លងដោយជំងឺ ។ អ៊ីស្រាអែលជំនាន់បុរាណ សំលៀកបំពាក់បែបនេះ ត្រូវបានដុតចោលដើម្បីបង្ការការឆ្លងរាលដាលនៃជំងឺនោះ ។ នៅក្នុង ខទី ៦ ព្រះអម្ចាស់ប្រៀបធៀបជំងឺជាអំពើបាប ហើយដូច្នេះ ទ្រង់បានបញ្ជាដល់យើងឲ្យចៀសវាងនូវអ្វីៗទាំងអស់ដែលទាក់ទងនឹងអំពើបាប ។

តើសារលិខិតដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:៦ ដែលប្រាប់ថា អ្នកផ្សព្វផ្សាយសាសនាត្រូវប្រកាសអំពីការប្រែចិត្ត ទាក់ទងទៅនឹងសេចក្ដីថ្លែងការណ៍របស់អែលឌើរ ហូឡិន អំពីរបៀបដែលពួកអ្នកផ្សព្វផ្សាយសាសនាត្រូវត្រៀមខ្លួនដែលមាននៅដើមមេរៀននេះយ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦:៨ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ អែតវឺត ប៉ាទ្រិច នៅចុងបញ្ចប់នៃវិវរណៈនេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៧

*ព្រះអម្ចាស់បញ្ជាសមាជិកសាសនាចក្រទ្រង់ឲ្យប្រមូលគ្នានៅរដ្ឋ អូហៃអូ*

នៅអំឡុងប៉ុន្មានខែពីមុនពេលដែល អែតវឺត ប៉ាទ្រិច បានធ្វើដំណើរទៅជួប យ៉ូសែប ស្ម៊ីធ នោះមានសេចក្ដីបៀតបៀនដល់ពួកបរិសុទ្ធកាន់តែកើនឡើងនៅរដ្ឋ នូវ យ៉ោក ។ នៅជិតចុងខែធ្នូ ឆ្នាំ ១៨៣០ ប៉ុន្មានសប្ដាហ៍បន្ទាប់ពី ស៊ីឌនី រិកដុន និង អែតវឺត ប៉ាទ្រិច បានមកដល់រដ្ឋ នូវ យ៉ោក នោះយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈមួយ ដែលព្រះអម្ចាស់បានបញ្ជាឲ្យពួកបរិសុទ្ធផ្លាស់ទៅរដ្ឋ អូហៃអូ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៧:១–៤ រួចស្វែងរកអ្វី ដែលព្រះអម្ចាស់មានព្រះទ័យឲ្យពួកការីធ្វើ ពីមុនផ្លាស់ទៅរដ្ឋ អូហៃអូ ។ សូមកត់ចំណាំនៅក្នុង ខទី ២ អំពីមូលហេតុដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ យ៉ូសែប ស្ម៊ីធ ឲ្យចេញទៅហើយចម្រើនកម្លាំងដល់សមាជិកនៅភូមិ ខូលស្វិល រដ្ឋ នូវ យ៉ោក ។

តើគោលការណ៍អ្វីខ្លះអំពីការអធិស្ឋាន ដែលយើងអាចរៀនចេញពីខគម្ពីរទាំងនេះ ?

៤. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរគោលការណ៍ដែលអ្នករៀនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៧:២ អំពីការអធិស្ឋាន ។ សូមពន្យល់ផងដែរ អំពីអ្វីដែលអ្នកនឹងធ្វើ ដើម្បីប្រព្រឹត្តតាមគោលការណ៍នេះ ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៦–៣៧ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៩ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨

## បុព្វកថា

ក្នុងខែ ធ្នូ ឆ្នាំ ១៨៣០ ព្រះអម្ចាស់បានបញ្ជាឲ្យសមាជិកសាសនាចក្រប្រមូលគ្នានៅរដ្ឋ អូហៃអូ ( សូមមើល គ. និង ស. ៣៧ ) ។ នៅថ្ងៃទី ២ ខែ មករា ឆ្នាំ ១៨៣១ ពួកបរិសុទ្ធមកពីសាខាផ្សេងៗ នៅរដ្ឋ នូវ យ៉ោក បានប្រជុំគ្នាធ្វើសន្និសីទសាសនាចក្រលើកទី ៣ ។ អំឡុងពេលសន្និសីទនោះ វិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨ ត្រូវបានទទួល ជាកណ្ឌដែលព្រះអម្ចាស់បានលើកទឹកចិត្តដល់ពួកបរិសុទ្ធ ហើយបានជួយពួកគេឲ្យយល់ពីព្រះបញ្ញត្តិទ្រង់ដែលបញ្ជាឲ្យពួកគេផ្លាស់ទៅរដ្ឋ អូហៃអូ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១–៧

*ព្រះយេស៊ូវគ្រីស្ទមានព្រះបន្ទូលប្រាប់សមាជិកសាសនាចក្ររបស់ទ្រង់ថា ទ្រង់គង់នៅក្នុងចំណោមពួកគេ*

តើអ្នកធ្លាប់បានកត់ចំណាំថា ព្រះបញ្ញត្តិមួយចំនួនអាចនឹងមានភាពងាយស្រួលសម្រាប់អ្នកក្នុងការគោរពប្រតិបត្តិតាម និងផ្សេងទៀតអាចនឹងមានការលំបាកដែរឬទេ ? សូមបង្កើតបញ្ជីព្រះបញ្ញត្តិមួយចំនួន ដែលអ្នកគិតថាមានភាពងាយស្រួលសម្រាប់អ្នកក្នុងការគោរពប្រតិបត្តិតាម ៖

ឥឡូវនេះ សូមពិចារណាថាតើព្រះបញ្ញត្តិមួយណាដែលអាចនឹងមានការលំបាកសម្រាប់អ្នកក្នុងការគោរពប្រតិបត្តិតាម ហើយ មូលហេតុអ្វី ។




អំឡុងពេលសន្និសីទនៃសាសនាចក្រក្នុងខែ មករា ឆ្នាំ ១៨៣១ ពួកបរិសុទ្ធមួយចំនួនក្នុងរដ្ឋ នូវ យ៉ោក បានចោទជាសំណួរអំពីព្រះបញ្ញត្តិដែលបញ្ជាឲ្យពួកគេផ្លាស់ទៅរដ្ឋ អូហៃអូ ។ សូមពិចារណាអំពីមូលហេតុដែល វាអាចជាការលំបាកសម្រាប់សមាជិកសាសនាចក្រមួយចំនួនទាំងនេះ ក្នុងការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិនេះ ។

ពួកបរិសុទ្ធមួយចំនួននៅរដ្ឋ នូវ យ៉ោក បានស្ទាក់ស្ទើរក្នុងការចាកចោលកសិដ្ឋានដ៏រីកចម្រើន និង ស្ថានភាពសុខស្រួលរបស់ពួកគេ ដើម្បីទៅកាន់កន្លែងថ្មីដែលមិនប្រាកដប្រជានោះ ។ មិនតែប៉ុណ្ណោះ មនុស្សមួយចំនួនបានប្រឈមមុខនឹងការខាតបង់ប្រាក់កាសក្នុងការដោះដូរទ្រព្យសម្បត្តិខ្លួន បើគេអាចលក់ចេញទ្រព្យសម្បត្តិរបស់គេនោះ ។

ក្នុងការឆ្លើយតបទៅនឹងកង្វល់របស់ពួកបរិសុទ្ធ យ៉ូសែប ស្ម៊ីធ បានអធិស្ឋានដើម្បីស្វែងយល់បន្ថែមអំពីព្រះបញ្ញត្តិក្នុងការប្រមូលគ្នានៅរដ្ឋ អូហៃអូ នេះ ហើយលោកបានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨ ។ នៅពេលអ្នកសិក្សាអំពីវិវរណៈនេះ អ្នកនឹងរៀនអំពីសេចក្ដីពិតនានា ដែលអាចជួយអ្នកឲ្យគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ដោយស្ម័គ្រចិត្ត ទោះជាព្រះបញ្ញត្តិទាំងនោះមានសភាពកាន់តែពិបាកសម្រាប់អ្នកក្នុងការគោរពប្រតិបត្តិយ៉ាងណាក្ដី ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១–៣ ដោយស្វែងរកគោលការណ៍ទាំងឡាយ ដែលអ្នកបានរៀនអំពីព្រះយេស៊ូវគ្រីស្ទ ។ ( អ្នកអាចនឹងចង់គូសចំណាំនៅក្នុងព្រះគម្ពីររបស់អ្នក ឬ កត់ចំណាំនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវអ្វីដែលអ្នកស្វែងយល់ ) ។

គោលការណ៍សំខាន់មួយ ដែលយើងរៀនចេញពី ខទី ២ គឺថា **ព្រះយេស៊ូវគ្រីស្ទ ជ្រាបដឹងគ្រប់ការណ៍ទាំងអស់** ។ សូមគិតអំពីរបៀបដែលការយល់ដឹងអំពីគោលការណ៍នេះ អាចជួយដល់ពួកបរិសុទ្ធទាំងនោះ ដែលបានពុះពារក្នុងការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិឲ្យចាកចេញពីរដ្ឋ នូវ យ៉ោក ហើយផ្លាស់លំនៅទៅរដ្ឋ អូហៃអូ ។

១. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវប្រយោគមួយចំនួន អំពីរបៀបដែលគោលការណ៍នេះ ក៏អាចនឹងជួយអ្នកក្នុងគ្រាដែលអ្នកពុះពារក្នុងការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយដែលព្រះអម្ចាស់បានប្រទានដល់អ្នកដែរ ។

ពីមុនបានទទួលវិវរណៈនេះ ព្យាការី យ៉ូសែប ស្ម៊ីធ បានធ្វើការបកប្រែដ៏បំផុសគំនិតនៅក្នុងព្រះគម្ពីរប៊ីប ហើយបានទទួលបាននូវការណ៍ ដែលសព្វថ្ងៃនេះមាននៅក្នុង ម៉ូសេ ៦–៧ នៅក្នុងមុក្ដាដ៏មានតម្លៃមហិមា ។ ជំពូកទាំងនេះផ្ដល់នូវដំណើររឿងមួយរបស់ព្យាការី ហេណុក និង រាស្ត្ររបស់លោក ដែលត្រូវបានហៅថាជាទីក្រុង ស៊ីយ៉ូន ដោយសារតែសេចក្ដីសុចរិតរបស់ពួកគេ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៤ ដោយស្វែងរកការណ៍ដែលព្រះអម្ចាស់បានធ្វើសម្រាប់ ហេណុក និង រាស្ត្ររបស់លោក ។ វាអាចនឹងមានប្រយោជន៍សម្រាប់អ្នកដើម្បីដឹងថា នៅពេលព្រះអម្ចាស់បានមានព្រះបន្ទូលថា « ឱរារបស់យើង » គឺទ្រង់សំដៅទៅលើវត្តមានរបស់ទ្រង់ ។

នៅចុងបញ្ចប់នៃ ខទី ៤ តើព្រះអង្គសង្គ្រោះបានមានព្រះបន្ទូលថា ទ្រង់បានធ្វើអ្វីខ្លះ សម្រាប់អ្នកទាំងឡាយដែលបានជឿលើព្រះនាមទ្រង់ ?

សូមពិចារណាអំពីការដឹងថា ព្រះយេស៊ូវគ្រីស្ទ អង្វរចំពោះព្រះវរបិតាសួគ៌ជំនួសអ្នកទាំងឡាយដែលជឿលើព្រះនាមទ្រង់ អាចជួយដល់បុគ្គលដែលកំពុងពុះពារក្នុងការបន្តការព្យាយាមយ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៥–៧ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូល អំពីកន្លែងដែលទ្រង់គង់នៅ ។

២. សូមឆ្លើយសំណួរដូចតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការជឿលើគោលការណ៍ ដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៧ ជួយនាំយកនូវការលួងលោមចិត្ត ក៏ដូចជាសេចក្ដីក្លាហានដល់អ្នកយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៨–១២

*ព្រះអម្ចាស់ពិពណ៌នាអំពីបុគ្គលដែលនឹងធន់នៅក្នុងការយាងមកជាលើកទីពីរ*

នៅពេលព្រះអង្គសង្គ្រោះជួយដល់ពួកបរិសុទ្ធនៅរដ្ឋ ញូវ យ៉ោក ឲ្យយល់អំពីសារៈសំខាន់នៃការប្រមូលផ្ដុំគ្នានៅឯរដ្ឋ អូហៃអូ នោះទ្រង់បានមានព្រះបន្ទូលអំពីការយាងមកជាលើកទីពីររបស់ទ្រង់ ។



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៨–១០ រួចស្វែងរកការណ៍ ដែលព្រះអង្គសង្គ្រោះបានបើកសម្ដែងអំពីការយាងមកជាលើកទីពីររបស់ទ្រង់ ។ វាអាចនឹងជួយអ្នកក្នុងការដឹងថា បុគ្គលទាំងឡាយណាដែល « ធន់នៅថ្ងៃនោះ » ( គ និង ស ៣៨:៨ ) នៃការយាងមកជាលើកទីពីរ គឺជាបុគ្គលដែលនឹងអាចបន្តរស់នៅលើផែនដីជាមួយនឹងព្រះអង្គសង្គ្រោះនៅពេលដែលទ្រង់យាងមកនោះ ហើយមិនត្រូវបានបំផ្លាញចោលឡើយ ។ សូមពិចារណាអំពីរបៀបដែលព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុង ខទី ៨–១០ អាចជួយអ្នកឲ្យយល់អំពីសារៈសំខាន់នៃការជ្រះបរិសុទ្ធ និង ស្អាតបាត ពីមុនការយាងមកជាលើកទីពីរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១១–១២ ដើម្បីស្វែងយល់អំពីស្ថានភាពមួយចំនួន ដែលនឹងកើតឡើងលើផែនដី ពីមុនការយាងមកជាលើកទីពីរ ។ និមិត្តរូបនៃពួកទេវតាកំពុងរង់ចាំ « ច្រូតទម្លាក់ផែនដី » គឺជាសេចក្ដីយោង ចំពោះរឿងប្រដូចរបស់ព្រះអង្គសង្គ្រោះ អំពីស្រូវ និង ស្រងែ ( សូមមើល ម៉ាថាយ ១៣:២៤–៣០; គ. និង ស. ៨៦:១–៧ ) ដែលស្រូវ ( ពួកសុចរិត ) ត្រូវបានប្រមូលមុនស្រងែ ( ពួកទុច្ចរិត ) ដែលត្រូវបានប្រមូល ហើយដុតចោល ។

សូមពិចារណាអំពីអ្វីដែលអ្នកអាចធ្វើ ដើម្បីត្រៀមខ្លួនអ្នកឲ្យបានកាន់តែប្រសើរឡើង ដើម្បី « ធន់នៅថ្ងៃនោះ » សម្រាប់ការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ ហើយមិនមានវត្តមាននៅក្នុងពួកស្រងែ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១៣–៣៣

*ព្រះយេស៊ូវគ្រីស្ទពន្យល់អំពីមូលហេតុ ដែលទ្រង់បានបញ្ជាឲ្យសមាជិកសាសនាចក្រទ្រង់ទៅប្រមូលផ្ដុំគ្នានៅរដ្ឋ អូហៃអូ ។*

សូមគិតអំពីគ្រាមួយដែលអ្នកបានដឹងថាអ្នកកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់ ទោះជាខាងសាច់ឈាម ឬ ខាងវិញ្ញាណ ក្ដី ។ តើមានការព្រមានអ្វីខ្លះ ដែលជួយអ្នកឲ្យដឹងថាអ្នកកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់ ?

ព្រះអម្ចាស់បានព្រមានដល់ពួកបរិសុទ្ធអំពីគ្រោះថ្នាក់នានា ដែលពួកគេនឹងជួបប្រទះ ប្រសិនបើពួកគេពុំចាកចេញពីរដ្ឋ នូវ យ៉ោក ទេនោះ ។ សូមមើលទៅឃ្លាចុងក្រោយនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១២ ។ តើព្រះអម្ចាស់បានមានព្រះបន្ទូលថា ដូចម្ដេច អំពីខ្មាំងសត្រូវរបស់ពួកបរិសុទ្ធ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១៣, ២៨–២៩ ដោយស្វែងរកមើលការប៉ុនប៉ងរបស់ខ្មាំងសត្រូវ ដែលបានឲ្យបួម គ្នានោះ ។ យើងស្វែងយល់ចេញពីខគម្ពីរទាំងនេះថា **ព្រះអម្ចាស់អាចព្រមានយើងអំពីគ្រោះថ្នាក់** ។ ការព្រមានបែបនេះ អាច កើតមានតាមរយៈការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ឬ តាមរយៈការបង្រៀននៃពួកអ្នកបម្រើរបស់ព្រះអម្ចាស់ រួមបញ្ចូលទាំង សុន្ទរកថា ដែលបានផ្ដល់ឲ្យក្នុងពេលសន្និសីទទូទៅ ។

៣. តើអ្នក ឬ មនុស្សដែលអ្នកស្គាល់ ធ្លាប់ត្រូវបានព្រមានដោយព្រះអម្ចាស់អំពីគ្រោះថ្នាក់ខាងវិញ្ញាណ ឬ ខាង សាច់ឈាមនៅពេលណាខ្លះ ? សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពី ការព្រមានមួយ ដែលអ្នក ឬ សមាជិកគ្រួសារ ឬ មិត្តម្នាក់បានទទួលពីព្រះអម្ចាស់ និង អ្វីដែលអ្នកបានធ្វើ ( ឬ ប្រាថ្នាថាអ្នកបានធ្វើវា ) ឬ អ្វីដែលសមាជិកគ្រួសារ ឬ មិត្តម្នាក់បានធ្វើក្នុងការឆ្លើយតបទៅនឹងការព្រមាននោះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១៤–១៥, ៣០ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានបញ្ជាឲ្យពួកបរិសុទ្ធធ្វើ ។ ចេញមកពីអ្វីដែលអ្នករៀននៅចុងបញ្ចប់នៃ ខទី ៣០ សូមបំពេញគោលការណ៍ដូចទៅនេះ ៖ **ប្រសិនបើ នោះ** ។

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ហេតុអ្វីបានជាការត្រៀមខ្លួន ផ្ដល់ឲ្យយើងនូវទំនុកចិត្តក្នុងការប្រឈមមុខនឹងការប្រឆាំង ឬ គ្រោះថ្នាក់ ?

ខ. តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីត្រៀមខ្លួនជាស្រេចប្រឆាំងនឹងការស្វះស្វែងរបស់បច្ចាមិត្តក្នុងការធ្វើទុក្ខទោសដល់អ្នក នោះ ?

សូមចងចាំថា ពួកបរិសុទ្ធមួយចំនួនក្នុងរដ្ឋ នូវ យ៉ោក បានចោទជាសំណួរថា ហេតុអ្វីបានជាពួកគេត្រូវបានបញ្ជាឲ្យចាកចេញពី រដ្ឋ អូហៃអូ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:១៦, ៣១–៣៣ រួចស្វែងរករបៀបដែលពួកបរិសុទ្ធនឹងត្រូវបានពរ បើពួកគេគោរពប្រតិបត្តិតាមព្រះបញ្ញត្តិនេះ ។

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើព្រះបញ្ញត្តិដែលបញ្ជាឲ្យចាកចេញពីរដ្ឋ នូវ យ៉ោក អាចជាសេចក្ដីសង្គ្រោះខាងសាច់ឈាមដល់ពួកបរិសុទ្ធ យ៉ាងដូចម្ដេច ?

ខ. តើព្រះបញ្ញត្តិបញ្ជាឲ្យប្រមូលផ្ដុំគ្នានៅរដ្ឋ អូហៃអូ អាចក្លាយទៅជាសេចក្ដីសង្គ្រោះខាងវិញ្ញាណរបស់ពួកគេយ៉ាង ដូចម្ដេច ?

យើងស្វែងយល់ចេញពីខគម្ពីរទាំងនេះថា **ព្រះអម្ចាស់ពុំគ្រាន់តែព្រមានយើងអំពីគ្រោះថ្នាក់តែប៉ុណ្ណោះទេ ទ្រង់ថែមទាំងប្រទាន ព្រះបញ្ញត្តិដើម្បីជាការការពារដល់ពួកយើងផងដែរ** ។

៦. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវប្រយោគមួយចំនួន ដែលពន្យល់អំពី របៀបដែលការរក្សាព្រះបញ្ញត្តិទាំងឡាយ អាចការពារយើងបានទាំងខាងសាច់ឈាម និង ខាងវិញ្ញាណផង ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៣៤–៤២

*សមាជិកសាសនាចក្រត្រូវបានប្រទានព្រះបញ្ញត្តិទាំងឡាយស្ដីពីការប្រមូលផ្ដុំគ្នានៅរដ្ឋ អូហៃអូ*

គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៣៤–៤២ មាននូវព្រះបញ្ញត្តិ និង ឱវាទ ដែលនឹងជួយពួកបរិសុទ្ធក្នុងការផ្លាស់ទីលំនៅរបស់ពួកគេទៅរស់នៅឯរដ្ឋ អូហៃអូ ។ សម្រាប់ពួកបរិសុទ្ធជាច្រើន ធនធានតែមួយគត់ក្នុងជីវភាពរស់នៅគឺជាកសិដ្ឋានរបស់ពួកគេ ។ ដោយមានសមាជិកសាសនាចក្រជាច្រើនបានដាក់លក់ដីធ្លីរបស់ខ្លួនក្នុងពេលតែមួយ នោះការលក់ចេញដីបានមានច្រើនបរិបូរណ៍មួយរំពេច ។ ដោយមានជម្រើសច្រើន នោះអតិថិជនបានទិញដីកសិដ្ឋានរបស់ពួកបរិសុទ្ធក្នុងតម្លៃថោកជាងធម្មតា ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៣៧, ៣៩ ដោយស្វែងរកឱវាទទៅដល់ពួកបរិសុទ្ធ អំពីដីកសិដ្ឋានរបស់ពួកគេ ។ សូមពិចារណាអំពីរបៀបដែល ការមានសេចក្ដីជំនឿលើការសន្យាដ៏អស់កល្បជានិច្ចរបស់ព្រះអម្ចាស់ អាចជួយយើងឲ្យគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ទោះជាព្រះបញ្ញត្តិទាំងនោះតម្រូវឲ្យមានការលះបង់មួយចេញយើងក្ដី ។

ពួកបរិសុទ្ធជាច្រើននៅរដ្ឋ នូវ យ៉ោក បានគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ហើយបានលះបង់ដ៏មហិមាដើម្បីទៅប្រមូលផ្ដុំគ្នានៅរដ្ឋ អូហៃអូ ។

៧. នៅដើមមេរៀនថ្ងៃនេះ អ្នកត្រូវបានសុំឲ្យគិតអំពីព្រះបញ្ញត្តិមួយចំនួន ដែលអាចកាន់តែមានការលំបាកសម្រាប់អ្នកក្នុងការគោរពប្រតិបត្តិតាមជាងព្រះបញ្ញត្តិផ្សេង ៗទៀត ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបដែលការយល់ដឹងពីគោលការណ៍ ដែលអ្នកបានរៀននៅក្នុងមេរៀននេះ អាចជួយអ្នកឲ្យមានសេចក្ដីជំនឿ និង ទំនុកចិត្តដែលអ្នកត្រូវការ ដើម្បីគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងនោះ ។

៨. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

   *ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

   *សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩–៤០

## បុព្វកថា

ក្នុងខែ មករា ឆ្នាំ ១៨៣១ អាចារ្យសាសនានិកាយប្រូតេស្តង់មួយរូបឈ្មោះ យ៉េម្ស ខូវ៉ល ( ជាញឹកញាប់ត្រូវបានប្រកបថា ខូវិល ក្នុងកំណត់ត្រាប្រវត្តិសាស្ត្រសាសនាចក្រ ) បានទៅជួប យ៉ូសែប ស្ម៊ីធ នៅភូមហ្វាយែត រដ្ឋ នូវ យ៉ោក ហើយ « បានធ្វើសេចក្តីសញ្ញាជាមួយព្រះអម្ចាស់ ថាគាត់នឹងគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងអស់ ដែលព្រះអម្ចាស់នឹងប្រទានដល់គាត់តាមរយៈ . . . អ្នកបម្រើរបស់ទ្រង់ [ ព្យាការី យ៉ូសែប ស្ម៊ីធ ] » ( Joseph Smith, នៅក្នុង *History of the Church* ១:១៤៣ ) ។ ក្រោយមក យ៉ូសែប បានទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩ ។

នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានណែនាំដល់ យ៉េម្ស ខូវ៉ល ឲ្យទទួលពិធីបុណ្យជ្រមុជទឹក ហើយផ្សាយអំពីភាពពោរពេញនៃដំណឹងល្អនៅរដ្ឋ អូហៃអូ ។ ទោះជាយ៉ាងណាក៏ដោយ នៅថ្ងៃបន្ទាប់ពីបានទទួលវិវរណៈនេះ យ៉េម្ស បានចាកចេញពីភូមិហ្វាយែត ដោយគ្មានវាចាអ្វីសោះឡើយ ។ ភ្លាមនោះ ព្រះអម្ចាស់បានប្រទានវិវរណៈទៅដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ដោយពន្យល់អំពីមូលហេតុដែល យ៉េម្ស ពុំបានគោរពប្រតិបត្តិតាមព្រះបញ្ញត្តិដែលបានប្រទានដល់គាត់ ។ វិវរណៈនោះ ត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៤០ ។ ( សូមមើល *Documents វ៉ុល ១ ៖ ខែ កក្កដា ឆ្នាំ ១៨២៨–ខែ មិថុនា ឆ្នាំ ១៨៣១* វ៉ុល ១ នៃកម្រង Documents នៃ *The Joseph Smith Papers* [ ឆ្នាំ ២០១៣ ] ទំព័រ ២៣៣–៣៧ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:១–១២

*ព្រះយេស៊ូវគ្រីស្ទអញ្ជើញ យ៉េម្ស ខូវ៉ល ឲ្យទទួលយកដំណឹងល្អរបស់ទ្រង់ ហើយទទួលពិធីបុណ្យជ្រមុជទឹក*

សូមស្រមៃថា អ្នកត្រូវបានប្រទានឲ្យនូវអំណោយមួយដ៏អស្ចារ្យតាមរយៈឪពុកម្ដាយ ឬ មនុស្សជាទីស្រឡាញ់ ។ តើអ្នកអាចគិតអំពីមូលហេតុណាមួយ ដែលបណ្ដាលឲ្យអ្នកមិនជ្រើសរើសយកអំណោយនោះដែរឬទេ ?



សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:១–៣ ដោយស្វែងរកអំណោយ ដែលព្រះវរបិតាសួគ៌ បានប្រទានដល់កូនចៅទ្រង់ តែពួកគេមួយចំនួនបានជ្រើសរើសមិនទទួលយកអំណោយនោះ ។ ព្រះអម្ចាស់ប្រើឃ្លា « រាស្ត្ររបស់យើង » ដើម្បីសំដៅទៅលើរាស្ត្រ ដែលទ្រង់បានបម្រើនៅក្នុងជីវិតរមែងស្លាប់ អំឡុងពេលនៃ « កាលដ៏ខ្ពង់ខ្ពស់បំផុត » ។

អំណោយដែលរាស្ត្រទាំងនេះ បានជ្រើសរើសមិនទទួលយក គឺ ព្រះយេស៊ូវគ្រីស្ទ ។ នៅពេលយើងជ្រើសរើសទទួលយកអំណោយជាព្រះយេស៊ូវគ្រីស្ទ និង ដង្វាយធួនរបស់ទ្រង់ នោះមានន័យថា យើងទទួលបានពរជ័យ និង អំណោយកាន់តែលើសលែងទៅទៀត ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:៤ រួចស្វែងរកអំណោយមួយ ដែលព្រះអង្គសង្គ្រោះបានមានព្រះបន្ទូលថា ទ្រង់ប្រទានដល់អ្នកទាំងឡាយណាដែលទទួលយកទ្រង់ ។

យើងស្វែងយល់ចេញពីខគម្ពីរទាំងនេះថា **បើយើងទទួលយកព្រះយេស៊ូវគ្រីស្ទ នោះទ្រង់នឹងប្រទានឲ្យយើងនូវអំណាចដើម្បីក្លាយទៅជាកូនចៅរបស់ទ្រង់** ។ សូមគិតអំពីការគូសចំណាំពាក្យទាំងឡាយ ដែលបង្រៀនអំពីគោលការណ៍នេះនៅក្នុង ខទី ៤ ។

សូមអានសេចក្ដីថ្លែងការណ៍ពីប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ដើម្បីជួយអ្នកឲ្យយល់កាន់តែច្បាស់អំពីអត្ថន័យនៃការប្រែក្លាយទៅជាបុត្រា និង បុត្រីនៃព្រះយេស៊ូវគ្រីស្ទ ៖

### *ការសរសេរគោលការណ៍*

ការសរសេរគោលលទ្ធិ និង គោលការណ៍ដែលអ្នករកបាន ឬ ការបង្កើតគោលការណ៍ទាំងនោះនៅក្នុងបទគម្ពីររបស់អ្នក អាចជួយស្រាយបំភ្លឺសេចក្ដីពិតទាំងនេះនៅក្នុងគំនិតរបស់អ្នកបាន ។ ការធ្វើដូចនេះក៏អាចជួយអ្នក ឲ្យយល់អំពីគំនិតសំខាន់របស់បណ្ដុំបទគម្ពីរ ដែលអ្នកកំពុងសិក្សាផងដែរ ។



« នៅក្នុងន័យរបស់វាក្យសព្ទ ដែលបានប្រើនៅក្នុងបទគម្ពីរ ព្រះអង្គសង្គ្រោះក្លាយទៅជាព្រះបិតារបស់យើង ព្រោះទ្រង់ប្រទានដល់យើងនូវជីវិត ដែលជាជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈដង្វាយធួនដែលបានធ្វើឡើងដើម្បីយើង ។. . .

« ដូច្នេះ យើងក្លាយទៅជាកូនចៅរបស់ទ្រង់ គឺជាបុត្រា និង បុត្រីនៃព្រះយេស៊ូវគ្រីស្ទ តាមរយៈសេចក្ដីសញ្ញានៃការគោរពប្រតិបត្តិរបស់យើងដែលមានចំពោះទ្រង់ ។ ដោយសារតែសិទ្ធិអំណាចដ៏ទេវភាព និង ពលិកម្មរបស់ទ្រង់នៅលើឈើឆ្កាង នោះយើងក្លាយទៅជាបុត្រា និង បុត្របង្កើតខាងវិញ្ញាណរបស់ទ្រង់ ហើយទ្រង់គឺជា ព្រះបិតារបស់យើង » (*Doctrines of Salvation*, comp Bruce R. McConkie 3vols. [១៩៥៤–៥៦] ១:២៩ ) ។

១. យោងតាមអ្វីដែលប្រធាន ស៊្មីធ បានបង្រៀន សូមសរសេរជាពាក្យពេចន៍ផ្ទាល់ខ្លួនដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបដែលយើងអាចក្លាយទៅជាកូនចៅរបស់ព្រះយេស៊ូវគ្រីស្ទ ។



ដូចដែលអ្នកបានស្វែងយល់រួចមកហើយថា យើងត្រូវតែជ្រើសរើសទទួលយកព្រះយេស៊ូវគ្រីស្ទ ពីមុនយើងទទួលបានអំណាចដើម្បីក្លាយទៅជាបុត្រា និង បុត្រីទ្រង់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:៥–៦ ដោយស្វែងរកការណ៍ ដែលយើងត្រូវតែធ្វើ ដើម្បីទទួលយកទ្រង់និង អំណាចរបស់ទ្រង់ដើម្បីក្លាយទៅជាបុត្រា និង បុត្រីទ្រង់ ។

សូមសង្ខេបជាពាក្យពេចន៍ផ្ទាល់ខ្លួនរបស់អ្នក នូវអ្វីដែលយើងត្រូវតែធ្វើ ដើម្បីក្លាយទៅជាបុត្រា និង បុត្រីរបស់ព្រះយេស៊ូវគ្រីស្ទ ៖

ដូចដែលអ្នកបានរៀនអំពីបុព្វកថានៃមេរៀននេះ វិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩ ត្រូវបានប្រទានឲ្យអាចារ្យសាសនានិកាយប្រូតេស្តង់មួយរូបឈ្មោះ យ៉េម្ស ខូវ៉ល ភ្លាមៗបន្ទាប់ពីគាត់បានស្វែងយល់អំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ហើយគាត់បានធ្វើសេចក្ដីសញ្ញា ដើម្បីគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងអស់ដែលគាត់បានទទួលតាមរយៈព្យាការី យ៉ូសែប ស៊្មីធ ។

២. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ថាតើអ្នកគិតថា ការបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:១–៦ អនុវត្តចំពោះ យ៉េម្ស ខូវ៉ល យ៉ាងណាដែរ ។ សូមសរសេរផងដែរអំពីគំនិតរបស់អ្នក ថាតើខគម្ពីរទាំងនេះអនុវត្តចំពោះអ្នកយ៉ាងដូចម្ដេច ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:៧–៩ ។ តើព្រះអម្ចាស់បានមានព្រះបន្ទូលដូចម្ដេច អំពីស្ថានភាពនៃចិត្តរបស់ យ៉េម្ស ខូវ៉ល នៅគ្រាដែលវិវរណៈនេះត្រូវបានប្រទានដល់គាត់ ? ( អ្នកអាចនឹងចង់គូសចំណាំពាក្យ *ឥឡូវនេះ* នៅក្នុង ខទី ៨ ) ។ តើហេតុផលណាខ្លះ ដែលព្រះអម្ចាស់បានលើកឡើងអំពីមូលហេតុដែល យ៉េម្ស បានបដិសេធទ្រង់កាលពីមុននោះ ? ប្រសិនបើអ្នកធ្លាប់មានស្ថានភាពដូចជា យ៉េម្ស តើអ្នកអាចនឹងមានអារម្មណ៍ដូចម្ដេច ក្រោយពីបានឮព្រះបន្ទូលទាំងនេះហើយ ? ហេតុអ្វីទៅ ?

៣. សូមចម្លងតារាងខាងក្រោមចូលទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

| បើអ្នកនឹង . . . | នោះ . . . |
|---|---|
| | |

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:១០–១២ ។ ពេលអ្នកអាន សូមរកមើលអ្វីដែលព្រះអម្ចាស់បង្គាប់ដល់ យ៉េម្ស ខូវ៉ល ឲ្យធ្វើ ។ សូមសរសេរការបង្គាប់នោះក្រោមពាក្យថា « ប្រសិនបើអ្នកនឹង . . . » នៅលើតារាង ។ លើសពីនេះទៅទៀត សូមស្វែងរកការណ៍ដែលព្រះអម្ចាស់បានសន្យាជាមួយ យ៉េម្ស ខូវ៉ល ថាគាត់នឹងទទួលបានការណ៍នោះ បើគាត់គោរពប្រតិបត្តិតាមព្រះអម្ចាស់ ។ សូមសរសេរពរជ័យដែលបានសន្យាទាំងនេះ ដាក់នៅក្រោមចំណងជើង « នោះ . . . » នៅលើតារាង ។

សូមពិចារណាអំពីពរជ័យ ដែលព្រះអម្ចាស់បានប្រទានដល់ យ៉េម្ស ខូវ៉ុល ។ ទោះជា យ៉េម្ស បានបម្រើជាអាចារ្យសាសនា អស់រយៈពេល ៤០ ឆ្នាំមកហើយក្ដី ក៏ព្រះអម្ចាស់បានប្រទានដល់គាត់នូវភាពពោរពេញនៃដំណឹងល្អ ដែលរួមបញ្ចូលទាំង ការទទួលខុសត្រូវ និង ពរជ័យនានា ដែលគាត់ពុំធ្លាប់មានពីមុនមកមានដូចជា អំណោយទានព្រះវិញ្ញាណបរិសុទ្ធ និង ការតែងតាំងបព្វជិតភាព ។

សូមកត់ចំណាំពាក្យ *បើសិនជា* នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:១០–១១ ។ អ្នកអាចនឹងចង់គូសចំណាំឃ្លានេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។ សូមពិចារណាអំពីចំណុចពិសេសនៃពាក្យ *បើសិនជា* នៅក្នុងខគម្ពីរទាំងនេះ និង អ្វីដែលព្រះអម្ចាស់ បានមានព្រះបន្ទូលប្រាប់ យ៉េម្ស ខូវ៉ុល ថាគាត់នឹងត្រូវធ្វើ ដើម្បីទទួលបានពរជ័យនានាដែលបានសន្យាទុក ។

យើងរៀនចេញពីខគម្ពីរទាំងនេះថា **ពរជ័យនានាដែលព្រះអម្ចាស់បានសន្យាទុកនោះ គឺស្របទៅតាមការស្ដាប់តាមព្រះសូរសៀងរបស់ទ្រង់** ។ អ្នកអាចនឹងសរសេរសេចក្ដីពិតនេះនៅក្នុងព្រះគម្ពីររបស់អ្នក ក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:១០–១១ ។

៤. សូមគិតអំពីពរជ័យមួយចំនួន ដែលព្រះអម្ចាស់បានសន្យានឹងប្រទានឲ្យអ្នក ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវពរជ័យទាំងនេះចំនួនបី ថែមទាំងអ្វីដែលអ្នកត្រូវតែធ្វើដើម្បីទទួលបានពរជ័យទាំងនោះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:១៣–២៤

*យ៉េម្ស ខូវ៉ុល ត្រូវបានហៅឲ្យផ្សាយអំពីភាពពោរពេញនៃដំណឹងល្អនៅរដ្ឋ អូហៃអូ*

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:១៣–១៤ រួចស្វែងរកទីកន្លែង ដែលព្រះអម្ចាស់បានត្រាស់ហៅឲ្យ យ៉េម្ស ខូវ៉ុល ទៅផ្សាយដំណឹងល្អ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:១៥–២៤ ព្រះអម្ចាស់បានប្រទានសេចក្ដីណែនាំទៅដល់ យ៉េម្ស ខូវ៉ុល អំពីការណ៍ ដែលគាត់ត្រូវបង្រៀន ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:២២ រួចពិចារណា ថាតើវាទាក់ទងទៅនឹងគោលការណ៍ ដែលអ្នកបានរៀននៅក្នុងវិវរណៈនេះយ៉ាងដូចម្ដេច ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤០

*ព្រះអម្ចាស់បើកសម្ដែងអំពីមូលហេតុដែល យ៉េម្ស ខូវ៉ុល បានបដិសេធព្រះបន្ទូលទ្រង់*

នៅថ្ងៃបន្ទាប់ពីបានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩ យ៉េម្ស ខូវ៉ុល បានចាកចេញពីភូមិហ្វាយែត រដ្ឋ នូវ យ៉ោក ដោយគ្មានវាចាអ្វីសោះឡើយ ។ ព្រះអម្ចាស់បានបើកសម្ដែងដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន អំពីមូលហេតុ ដែល យ៉េម្ស ពុំបានគោរពប្រតិបត្តិតាមសេចក្ដីណែនាំរបស់ទ្រង់ ហើយទទួលយកពរជ័យដែលបានសន្យាទុកនោះ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤០:១–៣ ដោយស្វែងរកមូលហេតុ ដែលគាត់ពុំបានស្ដាប់តាមព្រះសូរសៀងរបស់ព្រះអម្ចាស់ ។

សូមប្រៀបធៀប គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:៨ និង ៤០:១ ដើម្បីឃើញថា ដួងចិត្តរបស់ យ៉េម្ស ខូវ៉ុល បានផ្លាស់ប្ដូរ យ៉ាងដូចម្ដេច ។ អ្នកអាចនឹងចង់គូសចំណាំពាក្យ *បាន* នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤០:១ ។

សូមប្រៀបធៀប គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩:៩ និង ៤០:២ ។ យោងតាមខគម្ពីរទាំងនោះ សូមបង្កើតបញ្ជីហេតុផល ចំនួនបី អំពីមូលហេតុដែលបណ្ដាលឲ្យ យ៉េម្ស ខូវ៉ុល បានបដិសេធព្រះបន្ទូលរបស់ព្រះអម្ចាស់ ៖



ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានបកស្រាយបំភ្លឺថា ៖ « [ យ៉េម្ស ខូវ៉ុល ] បានប្រែចិត្តជឿលើ សេចក្ដីពិតទៅហើយ ដ្បិតវាមានសភាពច្បាស់លាស់ ដែលព្រះអម្ចាស់បានបើកសម្ដែងដល់គាត់ អំពី ការណ៍ដែលមានតែគាត់ និង ព្រះអម្ចាស់ប៉ុណ្ណោះ ដែលដឹងថាជាសេចក្ដីពិតនោះ ។ ទោះជាយ៉ាងណា ក៏ដោយ នៅពេលដែលគាត់បានដកខ្លួនចេញពីអានុភាពនៃព្រះវិញ្ញាណនៃព្រះអម្ចាស់ ហើយយកពេល ទៅគិតអំពីបញ្ហាថាគាត់នឹងបាត់បង់មិត្តភក្ដិនៃលោកិយ ថែមទាំងទីតាំង និង មុខតំណែងក្នុងចំណោម ពួកអ្នកជឿរបស់គាត់ផងនោះ គឺគាត់បានចុះចាញ់ ហើយបានបដិសេធចោលនូវការសន្យា និង ពរជ័យ ដែលព្រះអម្ចាស់បានប្រទានដល់គាត់ » ( *Church History and Modern Revelation* វ៉ុល ២ [ ឆ្នាំ ១៩៥៣ ] ១:១៧៤ ) ។

តើសព្វថ្ងៃនេះ មានអ្វីដែលអាចល្បួងយើងឲ្យបដិសេធចោលព្រះបន្ទូលព្រះ ? អ្នកអាចសរសេរគោលការណ៍ដូចតទៅនេះដាក់នៅក្នុងបទគម្ពីររបស់អ្នកក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤០ និង ក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ **សេចក្ដីកោតខ្លាច និង ការខ្វាយខ្វល់ពីលោកិយ អាចនាំឲ្យយើងបដិសេធចោលព្រះបន្ទូលព្រះ ។**

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីសេចក្ដីកោតខ្លាច និង ការខ្វាយខ្វល់ពីលោកិយ ដែលអាចរារាំងយើងមិនឲ្យដើរតាមព្រះអម្ចាស់ដោយអស់ពីដួងចិត្ត ។ ក្រោយមក សូមសរសេរអ្វីដែលអ្នកអាចធ្វើបាន ដើម្បីមានសេចក្ដីជំនឿក្នុងការយកឈ្នះលើសេចក្ដីកោតខ្លាច ឬ ការខ្វាយខ្វល់ពីលោកិយ ហើយទទួលយកព្រះអម្ចាស់ដោយស្មោះស្ម័គ្រ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៩–៤០ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៩ ៖ ថ្ងៃទី ៤

# នៅរដ្ឋ អូហៃអូ

## បុព្វកថា

នៅចុងខែ មករា ឆ្នាំ ១៨៣១ ព្យាការី យ៉ូសែប ស្ម៊ីធ និង ភរិយារបស់លោកគឺ អិមម៉ា ស៊ីឌនី រិកដុន និង អែតវឺត ប៉ាទ្រិច បានផ្លាស់ទីលំនៅពីរដ្ឋ នូវ យ៉ោក ទៅរដ្ឋ អូហៃអូ ។ សមាជិកដទៃទៀតនៃសាសនាចក្រនៅរដ្ឋ នូវ យ៉ោក បានផ្លាស់ទីលំនៅទៅតាមក្រោយនៅប្រាំខែបន្ទាប់ ។

ពួកបរិសុទ្ធទាំងនោះ ដែលបានប្រមូលផ្ដុំគ្នានៅរដ្ឋ អូហៃអូ បានទទួលពរជ័យដ៏ធំក្រៃលែង ។ វិវរណៈដែលមានជាបន្តបន្ទាប់តាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ បាននាំឲ្យពួកគេយល់ដឹងកាន់តែជ្រាលជ្រៅអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ លើសពីនេះទៅទៀត ពួកគេទទួលបានពរជ័យ ដែលកើតឡើងពីការកសាងព្រះវិហារបរិសុទ្ធ និង ការផ្សាយដំណឹងល្អ ។ ទន្ទឹមនឹងពេលដែលសាសនាចក្របានរីកចម្រើនក្នុងបរិមាណ និង ភាពរឹងមាំខាងវិញ្ញាណនៅរដ្ឋ អូហៃអូ នោះការប្រឆាំងក៏បានកើនឡើងទាស់នឹងសាសនាចក្រ និង ថ្នាក់ដឹកនាំរបស់សាសនាចក្រដែរ ។ នៅទីបំផុត ក្នុងខែ មករា ឆ្នាំ ១៨៣៨ សមាជិកសាសនាចក្រជាច្រើន ត្រូវភៀសខ្លួនចេញពីរដ្ឋ អូហៃអូ ហើយចូលរួមជាមួយពួកបរិសុទ្ធដែលរស់នៅរដ្ឋ មិសសួរី ។ មេរៀននេះនឹងផ្ដល់ដល់អ្នក នូវការសង្ខេបមួយអំពីបទពិសោធន៍ទាំងឡាយរបស់ពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ ។ អ្នកនឹងរៀនកាន់តែពិស្ដារអំពីព្រឹត្តិការណ៍ទាំងនេះ និង អំពីការបង្រៀននានា នៅក្នុងមេរៀនក្រោយៗមកទៀត ។

## ព្រះអម្ចាស់បញ្ជាឲ្យពួកបរិសុទ្ធទៅប្រមូលផ្ដុំគ្នានៅរដ្ឋ អូហៃអូ ដើម្បីទទួលបានពរជ័យដែលបានសន្យាទុក

តើអ្នក ឬ នរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ្នក ធ្លាប់ផ្លាស់ទីលំនៅទៅកាន់ផ្ទះថ្មីដែរឬទេ ? តើមានឧបសគ្គអ្វីខ្លះ ដែលបានជួបប្រទះនៅក្នុងការផ្លាស់ទីលំនៅនេះ ? តើមានពរជ័យអ្វីខ្លះ ដែលបានកើតឡើងជាលទ្ធផលនៃការផ្លាស់ទីលំនៅនេះ ?

ទោះជាហេតុផលនៃការដែលពួកគេផ្លាស់ទីលំនៅនោះអាចប្រែប្រួល ក៏ប្រជាជនតែងតែលះបង់ដើម្បីផ្លាស់ទីលំនៅទៅកាន់កន្លែងថ្មី ព្រោះពួកគេជឿថា ជីវិតនឹងមានសភាពកាន់តែប្រសើរឡើងសម្រាប់ពួកគេនៅកន្លែងថ្មីនោះ ។

សូមរំឭកការសិក្សារបស់អ្នកអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៧–៣៨ ដែលជាព្រឹត្តិការណ៍ជុំវិញព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ដែលបញ្ជាឲ្យពួកបរិសុទ្ធចាកចេញពីរដ្ឋ នូវ យ៉ោក ហើយផ្លាស់លំនៅទៅរដ្ឋ អូហៃអូ ។ នៅពេលព្រះអម្ចាស់បានបញ្ជាឲ្យពួកគេប្រមូលផ្ដុំគ្នានៅរដ្ឋ អូហៃអូ ទ្រង់ក៏បានសន្យាថា ពួកគេនឹងទទួលបានពរជ័យពិសេសៗនៅទីនោះ ។

១. សូមចម្លងតារាងខាងក្រោមនេះចូលទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

| | ការសន្យាទាំងឡាយ |
|---|---|
| គ. និង ស. ៣៨:៣១–៣២ | ក.<br>ខ.<br>គ.<br>ឃ. |
| គ. និង ស. ៣៨:៣៣ | ង. |
| គ. និង ស. ៤២:៦១ | ច. |

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៣១–៣២ រួចធ្វើបញ្ជីការណ៍ទាំងបួនចំណុច ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថា ពួកបរិសុទ្ធនឹងទទួលបាននៅពេលបានទៅដល់រដ្ឋ អូហៃអូ នៅក្នុងប្រអប់ « ការសន្យាទាំងឡាយ » ទុកជាចម្លើយពី *ក* ដល់ *ឃ* ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:៣៣ រួចធ្វើបញ្ជីនៃទីកន្លែង ដែលទ្រង់នឹងបញ្ជូនពួកអ្នកផ្សព្វផ្សាយសាសនាទៅ ទុកជាចម្លើយ *ង* នៅលើតារាង ។

នៅមិនយូរប៉ុន្មានបន្ទាប់ពី យ៉ូសែប ស្ម៊ីធ បានទៅដល់រដ្ឋ អូហៃអូ នោះលោកទទួលបានវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៦១ ដោយស្ងៀមស្ងាត់ ហើយរកមើល ... ដោយត្រួសៗ រួចស្វែងរក ការសន្យាបន្ថែម ដែលព្រះអម្ចាស់បានប្រទានឲ្យ ។ សូមសរសេរ « ទទួលវិវរណៈថែមទៅលើវិវរណៈ » ទុកជាចម្លើយ *ច* នៅលើតារាង ។

កណ្ឌបន្ទាប់ទាំងបួនក្នុងមេរៀននេះ នឹងជួយអ្នកឲ្យរៀនកាន់តែច្រើន អំពីរបៀបដែលព្រះអម្ចាស់បានបំពេញការសន្យាទាំងនេះ នៅពេលរាស្ត្ររបស់ទ្រង់បានប្រមូលផ្ដុំគ្នានៅរដ្ឋ អូហៃអូ ពីឆ្នាំ ១៨៣១ ដល់ ឆ្នាំ ១៨៣៨ ។

## « យើងនឹងប្រទានក្រឹត្យវិន័យមួយដល់អ្នក » (គ. និង ស. ៣៨:៣២ ) ។

ព្រះអម្ចាស់បានសន្យាថា ទ្រង់នឹងប្រទានក្រឹត្យវិន័យដល់ពួកបរិសុទ្ធ នៅពេលពួកគេបានប្រមូលផ្ដុំគ្នានៅរដ្ឋ អូហៃអូ ។ ហេតុអ្វីបានជាក្រឹត្យវិន័យមានសារៈសំខាន់ ? ហេតុអ្វីបានជាក្រឹត្យវិន័យមានសារៈសំខាន់នៅក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ ?

សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២ ។ បន្ទាប់ពីពួកបរិសុទ្ធបានទៅដល់រដ្ឋ អូហៃអូ ក្នុងឆ្នាំ ១៨៣១ ហើយនោះ ព្រះអម្ចាស់បានបំពេញការសន្យារបស់ទ្រង់ ហើយបានប្រទានវិវរណៈមួយត្រូវបានចាត់ទុកថាជាក្រឹត្យវិន័យនៃសាសនាចក្រ ។ ក្រឹត្យវិន័យនេះ រួមបញ្ចូលទាំងព្រះបញ្ញត្តិ និង សេចក្ដីណែនាំនានា ដែលដឹកនាំអ្នកកាន់តំណែងសាសនាចក្រ ។

សូមអានសេចក្ដីសង្ខេបអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២ ដោយស្វែងរកក្រឹត្យវិន័យ និង ព្រះបញ្ញត្តិមួយចំនួនដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធ ។ ( សេចក្ដីសង្ខេបអំពីកណ្ឌមាននៅមុនខទីមួយ ។ វាផ្ដល់នូវលេខខគម្ពីរ និង សេចក្ដីសង្ខេបខ្លីអំពីខគម្ពីរទាំងនោះ ) ។ នៅពេលអ្នកអាន អ្នកអាចនឹងចង់គូសចំណាំឃ្លា « ក្រឹត្យវិន័យទាំងឡាយសម្រាប់ត្រួតលើការថ្វាយទ្រព្យសម្បត្តិត្រូវបានចែងប្រាប់ » ។

នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានប្រទានក្រឹត្យវិន័យនៃការថ្វាយ ។ ក្រឹត្យវិន័យនេះគឺជា « គោលការណ៍ដ៏ទេវភាពមួយ ដែលបុរស និង ស្ត្រីទាំងឡាយលះបង់ថ្វាយពេលវេលា ទេពកោសល្យ និង ទ្រព្យសម្បត្តិរបស់ខ្លួនដោយស្ម័គ្រចិត្ត ទៅក្នុងការកសាង និង ការស្ថាបនានគរព្រះឡើង » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ក្រឹត្យវិន័យនៃការថ្វាយ » scriptures.lds.org) ។ ថ្នាក់ដឹកនាំសាសនាចក្រត្រូវបានបញ្ជាឲ្យបង្កើតសហគ្រាសរួបរួម ( ត្រូវបានហៅថា សហគ្រាសសណ្ដាប់ធ្នាប់ផងដែរ ) ដើម្បីគ្រប់គ្រងលើកិច្ចការខាងសាច់ឈាម ឬ ខាងជំនួញរបស់សាសនាចក្រ ជួយដល់ជនក្រីក្រ និង ជួយកាត់បន្ថយសេចក្ដីខ្វះខាតចេញពីចំណោមពួកបរិសុទ្ធ ។ នេះគឺជាពរជ័យចំពោះពួកបរិសុទ្ធនៅគ្រានោះ ព្រោះពួកបរិសុទ្ធជាច្រើនដែលបានផ្លាស់ទីលំនៅមកពីរដ្ឋ នូវ យ៉ោក បានតម្រូវឲ្យទុកចោលផ្ទះសម្បែង និង ទ្រព្យសម្បត្តិរបស់ខ្លួន ។ សហគ្រាសរួបរួម ក៏បានផ្ដល់ជាប្រាក់កាសដើម្បីធ្វើជាហិរញ្ញប្បទានដល់បន្ទុកទាំងឡាយរបស់សាសនាចក្រមានដូចជា កិច្ចការផ្សព្វផ្សាយសាសនា និង ការបោះពុម្ពវិវរណៈ ។ អ្នកនឹងរៀនបន្ថែមអំពី ក្រឹត្យវិន័យនៃការថ្វាយ និង ឥទ្ធិពលរបស់វាទៅលើពួកបរិសុទ្ធនៅក្នុងមេរៀនក្រោយៗ ។

## « អ្នកនឹងត្រូវបានទទួលព្រះចេស្ដាមកពីស្ថានលើ » ( គ. និង ស. ៣៨:៣២ )

ព្រះអម្ចាស់ក៏បានសន្យាថានឹងប្រទានដល់ពួកបរិសុទ្ធ « ដោយនូវព្រះចេស្ដាមកពីស្ថានលើ » នៅពេលពួកគេបានទៅដល់រដ្ឋ អូហៃអូ ( គ. និង ស. ៣៨:៣២ ) ។ អំណោយទានពិសិដ្ឋ គឺជាអំណោយមួយ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៩ ដោយស្វែងរកព្រះបញ្ញត្តិ ដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ ។ « គេហដ្ឋាន » នៅក្នុងខគម្ពីរនេះ សំដៅទៅលើព្រះវិហារបរិសុទ្ធ ។ ព្រះវិហារបរិសុទ្ធនៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ គឺជាព្រះវិហារបរិសុទ្ធដំបូងគេដែលត្រូវបានសាងសង់ឡើងនៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥:៨ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ថា ទ្រង់នឹងប្រទានឲ្យពួកគេនៅក្នុងព្រះវិហារបរិសុទ្ធ ។



ព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ បានចំណាយពេលវេលាអស់បីឆ្នាំក្នុងការសាងសង់ ។ បន្ទាប់ពីបានឧទ្ទិសឆ្លងក្នុងឆ្នាំ ១៨៣៦ ព្រះអម្ចាស់បានចាប់ផ្ដើមបំពេញការសន្យាទ្រង់ ដែលប្រទានដល់ពួកបរិសុទ្ធដោយនូវព្រះចេស្ដា ហើយពួកគេបានដកពិសោធន៍ពរជ័យខាងវិញ្ញាណដ៏គួរឲ្យស្ញប់ស្ញែង ។ ឧទាហរណ៍មានដូចជា ព្រះអម្ចាស់បានបញ្ជូនសារទូតសួគ៌បីអង្គឲ្យបង្ហាញព្រះកាយនៅព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់—គឺ ម៉ូសេ អេលីយ៉ាស និង អេលីយ៉ា—ដើម្បីស្ដារកូនសោបព្វជិតភាពសំខាន់ៗឡើងវិញ នៅលើផែនដី ។ កូនសោទាំងនេះ នឹងផ្ដល់ឲ្យពួកបរិសុទ្ធនូវសិទ្ធិអំណាចដើម្បីធ្វើពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ និង

ដើម្បីផ្សារភ្ជាប់ក្រុមគ្រួសារទាំងអ្នកដែលនៅមានជីវិត និង អ្នកដែលចែកឋានទៅហើយនោះ សម្រាប់ភាពអស់កល្បជានិច្ច ។ លើសពីនេះទៅទៀត « កូនសោទាំងឡាយនៃការប្រមូលសាសន៍អ៊ីស្រាអែល » ក៏ត្រូវបានស្ដារឡើងវិញនៅគ្រានេះដែរ ( គ. និង ស. ១១០:១១ ) ។ តាមរយៈកូនសោទាំងនេះ ពួកអ្នកផ្សព្វផ្សាយសាសនា ត្រូវបានប្រគល់អំណាច ដើម្បីបង្រៀនដំណឹងល្អទូទាំងពិភពលោក ។

## អ្នក « នឹងចេញទៅក្នុងចំណោមគ្រប់អស់ទាំងសាសន៍ » ( គ. និង ស. ៣៨:៣៣ )

នៅពេលព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ត្រូវបានឧទ្ទិសឆ្លង និង កូនសោទាំងឡាយសម្រាប់ការប្រមូលសាសន៍អ៊ីស្រាអែល ត្រូវបានស្ដារឡើងវិញ នោះដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ បានចាប់ផ្ដើមរីកសាយទៅដល់ទីកន្លែងកាន់តែច្រើន ។ សូមបើកទៅផែនទីទី ៣ « តំបន់ នូវ យ៉ោក ផែនស៊ិលវេញ៉ា និង អូហៃអូ នៃសហរដ្ឋ អាមេរិក » នៅក្នុងផែនទីប្រវត្តិសាស្ត្រសាសនាចក្រ ដែលមាននៅខាងក្រោយបណ្ដុំព្រះគម្ពីររបស់អ្នក ។ សូមកត់ចំណាំថា ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ គឺជាកន្លែងដ៏ប្រសើរជាងគេ ដើម្បីចាប់ផ្ដើមបញ្ជូនអ្នកផ្សព្វផ្សាយសាសនាទៅកាន់ពាសពេញពិភពលោក ដើម្បីបង្រៀនដំណឹងល្អ « ក្នុងចំណោមគ្រប់អស់ទាំងសាសន៍ » ( គ. និង ស. ៣៨:៣៣ ) ។ ទីក្រុង ខឺតឡង់ ជាទីក្រុងដែលស្ថិតនៅជិតផ្លូវគមនាគមន៍ធំៗ នៅក្នុងសហរដ្ឋ ។ ពួកអ្នកផ្សព្វផ្សាយសាសនា គ្រាន់តែត្រូវធ្វើដំណើរជិតៗ ដើម្បីទៅជិះកប៉ាល់នៅក្នុងទន្លេធំៗរបស់សហរដ្ឋ និង បឹង អ៊ែរី ។ ពួកគេក៏អាចទៅដល់ខ្សែផ្លូវជាតិដែលនាំទៅកាន់ភាគខាងត្បូង និង ខ្សែផ្លូវទឹកដែលនាំទៅកាន់ភាគខាងជើងដែរ ។ ដោយសារតែការណ៍ទាំងនេះហើយ ទើបទីក្រុង ខឺតឡង់ គឺជាចំណុចចេញដំណើរទៅបេសកកម្ម កាណាដា ផ្នែកផ្សេងៗទៀតក្នុងសហរដ្ឋ និង ចក្រភពអង់គ្លេស ។

ដោយសារមានអ្នកផ្សព្វផ្សាយសាសនាធ្វើការនៅអំឡុងគ្រានេះ នោះសមាជិកភាពក្នុងសាសនាចក្រទូទាំងពិភពលោក បានកើនឡើងដល់រាប់ពាន់នាក់ ។ ក្នុងឆ្នាំ ១៨៣៧ អែលឌើរ ហ៊ីប៊ើរ ស៊ី឵ ឃិមប៊ល និង អូរសុន ហៃឌ រួមទាំងសមាជិកប្រាំនាក់ទៀត ត្រូវបានហៅឲ្យបម្រើបេសកកម្មនៅចក្រភពអង់គ្លេស ហើយពួកគេបានធ្វើបុណ្យជ្រមុជទឹកឲ្យមនុស្សចំនួន ២,០០០ នាក់ ។ ត្រឹមឆ្នាំ ១៨៣៨ កាលពួកបរិសុទ្ធបានផ្លាស់លំនៅចេញពីទីក្រុង ខឺតឡង់ ដោយសារតែមានសេចក្ដីបៀតបៀន នោះមានសមាជិកសាសនាចក្រទូទាំងពិភពលោកជិត ១៨,០០០ នាក់ ដែលក្នុងនោះមានសមាជិកប្រមាណ ២,០០០ នាក់ រស់នៅទីក្រុង ខឺតឡង់ ។

## « អ្នកនឹងបានទទួលវិវរណៈ ថែមទៅលើវិវរណៈ » ( គ. និង ស. ៤២:៦១ )

សូមបើកទៅកាន់ លំដាប់មាតិកាដែលរៀបតាមកាល នៃគោលលទ្ធិ និង សេចក្ដីសញ្ញា ( នៅបន្ទាប់ពីបុព្វកថា ) ហើយកត់ចំណាំអំពីទីតាំង ដែលទទួលបានវិវរណៈភាគច្រើន ។

ដូចដែលអ្នកអាចសង្កេតដូច្នេះដែរថា វិវរណៈជាច្រើនត្រូវបានទទួលនៅរដ្ឋ អូហៃអូ ជាងកន្លែងណាផ្សេងទៀតទាំងអស់ ។ ការសន្យារបស់ព្រះអម្ចាស់ថា ពួកបរិសុទ្ធនឹងទទួលបានវិវរណៈថែមទៅលើវិវរណៈ នៅពេលពួកគេប្រមូលផ្ដុំគ្នានៅរដ្ឋ អូហៃអូ នោះ ត្រូវបានសម្រេច ។

២. សូមអានសេចក្ដីណែនាំអំពីកណ្ឌ និង សេចក្ដីសង្ខេបអំពីកណ្ឌ នៃកណ្ឌនីមួយៗខាងក្រោមនេះ ។ រួចសូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវពាក្យពេចន៍មួយចំនួន ដោយសង្ខេបអ្វីដែលមាននៅក្នុងវិវរណៈនេះ និង ប្រយោគមួយ ឬ ពីរដោយពិពណ៌នាអំពីរបៀបដែលវិវរណៈនោះ បានប្រទានពរដល់សមាជិកសាសនាចក្រ និង ជីវិតផ្ទាល់ខ្លួនរបស់អ្នក ។

ក. គ. និង ស. ៧៦

ខ. គ. និង ស. ៨៤

គ. គ. និង ស. ៨៩

ខណៈដែលពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ ព្រះអម្ចាស់ក៏បានណែនាំដល់ព្យាការី យ៉ូសែប ស្ម៊ីធ ឲ្យបង្កើតថ្នាក់ដឹកនាំសាសនាចក្រ ។ គណៈប្រធានទីមួយ កូរ៉ុមនៃពួកសាវកទាំងដប់ពីរ និង កូរ៉ុមនៃពួកចិតសិបនាក់ ត្រូវបានបង្កើតឡើង ។ អំឡុងពេលនេះផងដែរ យ៉ូសែប ស្ម៊ីធ ក៏បានបន្តកិច្ចការបកប្រែរបស់លោកលើព្រះគម្ពីរប៊ីប ។

## ការប្រឆាំង និង ការក្បត់សាសនា ក្រកួនដល់ពួកបរិសុទ្ធស្មោះត្រង់នៅរដ្ឋ អូហៃអូ

ទោះជាព្រះអម្ចាស់បានប្រទានពរដល់ពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ យ៉ាងណាក្តី ក៏ការប្រឆាំងទាស់នឹងសាសនាចក្របានកើនឡើងផងដែរ ។ នៅមិនយូរបន្ទាប់ពីពួកបរិសុទ្ធបានទៅដល់ទីក្រុង ខឺតឡង់ ពួករិះគន់ប្រឆាំងនឹងពួកមរមន បានចាប់ផ្តើមវាយប្រហារមកលើសាសនាចក្រ ។ ការវាយប្រហារជាច្រើន បានកើតឡើងជាទម្រង់នៃការចុះផ្សាយរឿង និង អត្ថបទបង្ខូចកេរ្តិ៍ឈ្មោះតាមរយៈកាសែត ។



ព្យាការី យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍អំពីការចុះផ្សាយទាំងនេះថា ៖ « របាយការណ៍ក្លែងបន្លំ ការកុហក និង រឿងរ៉ាវដ៏ឆ្កួតលីលា ត្រូវបានចុះផ្សាយនៅលើទំព័រកាសែត ហើយបានធ្វើចរាចរណ៍ទៅគ្រប់ទីកន្លែង ដើម្បីរារាំងមនុស្សកុំឲ្យសិក្សាស្វែងយល់អំពីកិច្ចការនេះ ឬ ឱបក្រសោបយកសេចក្តីជំនឿនេះឡើយ » ( នៅក្នុង *History of the Church* ១:១៥៨ ) ។

ទោះជាមានទុក្ខលំបាកទាំងនេះ ឬ ផ្សេងទៀតក្តី ក៏ពួកបរិសុទ្ធបានបន្តប្រមូលផ្តុំគ្នានៅទីក្រុង ខឺតឡង់ ជាពិសេសអំឡុងឆ្នាំ ១៨៣៦–៣៨ ដែរ ។ ក្នុងឆ្នាំ ១៨៣៦ យ៉ូសែប ស្ម៊ីធ បានគិតអំពីបន្ទុកលើបំណុលនៃតម្លៃសាងសង់ព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។ ទោះជាសាសនាចក្រមានដីធ្លីជាច្រើនកន្លែងក្តី ក៏សាសនាចក្រត្រូវការប្រាក់ដើម្បីដោះបំណុលនានា ដែលនៅជំណាក់នោះដែរ ។ ដោយសារតែមានតម្រូវការខាងឥណទានសម្រាប់សាសនាចក្រ និង ការកើនឡើងនៃសមាជិកក្នុងទីក្រុង ខឺតឡង់ នោះថ្នាក់ដឹកនាំសាសនាចក្របានគ្រោងនឹងប្រើប្រាស់ធនាគារក្នុងមូលដ្ឋានមួយ ។ សំណើរបស់ពួកគេ ដើម្បីប្រើប្រាស់ធនាគារត្រូវបានច្រានចោលដោយសភារដ្ឋ អូហៃអូ ។ ជំនួសឲ្យការប្រើប្រាស់ធនាគារ នោះពួកបរិសុទ្ធបានបង្កើតក្រុមហ៊ុនមួយហៅថា ក្រុមហ៊ុននិរភ័យសង្គម ខឺតឡង់ ដែលដំណើរការដូចជាធនាគារដែរ ។

ក្នុងឆ្នាំ ១៨៣៧ វិបត្តិសេដ្ឋកិច្ចមួយ បានរាតត្បាតពេញសហរដ្ឋ ។ ប្រទេសទាំងមូលបានរងឥទ្ធិពលដោយវិបត្តិនេះ ហើយធនាគារមួយចំនួនបានក្ស័យធន ។ លើសពីនេះទៅទៀត ជនមួយចំនួនដែលមានតំណែងជាអ្នកគ្រប់គ្រងក្រុមហ៊ុននិរភ័យសង្គម ខឺតឡង់ ពុំមានភាពស្មោះត្រង់ក្នុងកិច្ចព្រមព្រៀងរបស់ខ្លួននោះឡើយ ។ ក្រុមហ៊ុននិរភ័យសង្គម ខឺតឡង់ ត្រូវបានបង្ខំចិត្តបិទទ្វារ ហើយមនុស្សរាប់រយនាក់ ដែលបានធ្វើវិនិយោគទុនជាមួយក្រុមហ៊ុននេះ បានខាតបង់ស្ទើរតែអ្វីទាំងអស់នូវអ្វីដែលពួកគេបានវិនិយោគ ។ មេរៀនរបស់យ៉ូសែប ស្ម៊ីធប្រសើរជាងមេរៀនមនុស្សផ្សេងទៀត ។ ពួកបរិសុទ្ធជាច្រើននាក់បានចោទប្រកាន់ព្យាការីឲ្យទទួលខុសត្រូវចំពោះបញ្ហាហិរញ្ញវត្ថុរបស់ពួកគេ និងមានការប្តឹងផ្តល់ជាច្រើនបន្តបន្ទាប់ទៀត ។ ថ្នាក់ដឹកនាំសាសនាចក្រ ដែលបានជួយបង្កើតក្រុមហ៊ុននិរភ័យសង្គម ខឺតឡង់ បានស្មានខុសថា បុគ្គលម្នាក់ៗមានសិទ្ធិបង្កើតក្រុមហ៊ុនផ្ទាល់ខ្លួន ដែលបានរួមចំណែកក្នុងកិច្ចការធនាគារ ហើយតុលាការបានសម្រេចក្តីពិន័យជាប្រាក់ចំនួន ១,០០០ ដុល្លា ប្រឆាំងនឹងពួកគេពីបទរំលោភសិទ្ធិច្បាប់ធនាគាររដ្ឋ អូហៃអូ ។

ព្រឹត្តិការណ៍ដ៏លំបាកនេះ បាននាំឲ្យសមាជិកមួយចំនួននៃសាសនាចក្រ ក្បត់សាសនា ។ សេចក្តីបៀតបៀន បានមានកាន់តែខ្លាំងអំឡុងរដូវរងាឆ្នាំ ១៨៣៧ និង នៅនិទាឃរដូវឆ្នាំ ១៨៣៨ ដែលពួកបរិសុទ្ធភាគច្រើន ត្រូវបានបង្ខំចិត្តឲ្យចាកចេញពីរដ្ឋ អូហៃអូ ។ ថ្នាក់ដឹកនាំសាសនាចក្រមួយចំនួន រួមមាន យ៉ូសែប ស្ម៊ីធ ស៊ីឌនី រិកដុន និង ព្រិកហាំ យ៉ង់ ត្រូវភៀសខ្លួនពីទីក្រុង ខឺតឡង់ ដើម្បីមានសុវត្ថិភាពក្នុងការរស់នៅ ។

៣. យោងតាមអ្វីដែលអ្នកបានរៀននៅក្នុងមេរៀននេះ សូមសរសេរប្រយោគមួយចំនួននៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីថាតើអ្នកនឹងគិតដូចម្តេច ចំពោះការរស់នៅក្នុងរដ្ឋ អូហៃអូ អំឡុងគ្រានេះនៃប្រវត្តិសាស្ត្រសាសនាចក្រ ។ សូមសរសេរបញ្ចូលទាំងអ្វីដែលអ្នកចង់មានចំណែក និង អ្វីដែលអ្នកគិតថាជាឧបសគ្គសម្រាប់អ្នក ។

៤. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សាមេរៀនអំពី « នៅរដ្ឋ អូហៃអូ » ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១០ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១

## សេចក្ដីផ្ដើម

ក្នុងខែធ្នូ ឆ្នាំ ១៨៣០ ព្រះអម្ចាស់ បានបញ្ជាដល់ពួកបរិសុទ្ធឲ្យផ្លាស់ទៅរដ្ឋ អូហៃអូ ជាកន្លែងដែលពួកគេនឹងទទួលក្រឹត្យវិន័យរបស់អម្ចាស់ ( សូមមើល គ. និង ស. ៣៧:៣; ៣៨:៣២ ) ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១ នៅថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ១៨៣១ —ជាថ្ងៃដែលលោកបានទៅដល់រដ្ឋ អូហៃអូ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានប្រទានសេចក្ដីណែនាំបន្ថែម ដែលនឹងជួយត្រៀមខ្លួនពួកបរិសុទ្ធឲ្យទទួលក្រឹត្យវិន័យរបស់ទ្រង់ ។ មិនតែប៉ុណ្ណោះ ទ្រង់បានត្រាស់ហៅ អែតវឺត ប៉ាទ្រិច ឲ្យធ្វើជាប៊ីស្សពដំបូងរបស់សាសនាចក្រ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:១–៨

*ព្រះអម្ចាស់ ពិពណ៌នាអំពីរបៀបក្លាយទៅជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ*

តើអ្នករីករាយ ឬ ពេញចិត្តនឹងធ្វើអ្វីខ្លះ ? តើអ្នកគិតថា ព្រះអម្ចាស់សព្វព្រះហឫទ័យនឹងធ្វើអ្វីខ្លះ ? សូមពិចារណា ថាតើការរីករាយ ឬ ការស្វែងរកសេចក្ដីអំណរដើម្បីធ្វើរឿងអ្វីមួយ មានន័យដូចម្ដេច ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:១ រកមើលអ្វីដែលព្រះអម្ចាស់មានព្រះទ័យនឹងធ្វើ ។ សូមសម្គាល់ពីអ្វីដែលយើងត្រូវធ្វើដើម្បីទទួល « ព្រះពរដ៏ប្រសើរបំផុតជាងព្រះពរទាំងអស់ » ដែលទ្រង់មានព្រះទ័យប្រទានដល់យើង ។

យោងតាមអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលនៅក្នុង ខទី ១ សូមបំពេញគោលការណ៍ដូចតទៅនេះ ៖ **ព្រះអម្ចាស់សព្វព្រះហឫទ័យនឹង នៅពេលយើង** ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើនៅពេលណាខ្លះ ដែលអ្នកធ្លាប់ដឹងថា ព្រះអម្ចាស់បានសព្វព្រះហឫទ័យនឹងប្រទានពរដល់អ្នកដោយសារតែអ្នកបានស្ដាប់តាមទ្រង់ ?

ខ. តើវាមានន័យដូចម្ដេចចំពោះអ្នក ដែលដឹងថា ព្រះអម្ចាស់មានសេចក្ដីអំណរ ក្នុងការប្រទានពរដល់អ្នក ចំពោះការស្ដាប់តាមទ្រង់នោះ ?

ព្យាការី យ៉ូសែប ស្ម៊ីធ បានគោរពប្រតិបត្តិតាមឱវាទព្រះអម្ចាស់ក្នុងការប្រមូលពួកបរិសុទ្ធទៅឯរដ្ឋ អូហៃអូ ។ យ៉ូសែប និង អិមម៉ា បានផ្លាស់ទីលំនៅប្រាំពីរដងក្នុងរយៈពេលបួនឆ្នាំ ចាប់តាំងពីបានរៀបការមក ហើយ អិមម៉ា ទើបតែបានជាសះស្បើយពីជំងឺរុំារ៉ៃពេញមួយខែ ហើយមានផ្ទៃពោះប្រាំមួយខែ កាលពួកគាត់បានចាកចេញពីរដ្ឋ នូវ យ៉ោក ធ្វើដំណើរជិត ៤៨២ គីឡូម៉ែតដោយរទេះទៅកាន់ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ នៅចុងខែ មករា ឆ្នាំ ១៨៣១ ។

នៅពេល យ៉ូសែប និង អិមម៉ា បានទៅដល់ទីក្រុង ខឺតឡង់ នោះពួកគាត់បានឈប់នៅខាងមុខហាងរបស់ ហ្គីលប៊ើត និង វីតនី ។ « [ យ៉ូសែប ] ប្រញាប់ប្រញាល់ដើរចូលទៅក្នុងហាង ហើយសំដៅទៅរកដៃគូប្អូនដែលកំពុងឈរ ។ លោកបានបន្លឺសំឡេងឡើង ដោយហុចដៃរបស់លោកទៅយ៉ាងរីករាយ ដូចជាធ្វើចំពោះមិត្តចាស់ ដែលស្គាល់ជិតស្និតដូច្នោះដែរថា ‹ នូវែល ឃេ វីតនី ! លោកគឺជាបុរសម្នាក់នោះហើយ ! › [ នូវែល ឃេ វីតនី ] បានតបថា ‹ លោកមានប្រៀបលើខ្ញុំហើយ › កាលដែលគាត់លូកចាប់ដៃលោកវិញ ‹ ខ្ញុំមិនអាចហៅឈ្មោះលោកបាន ដូចដែលលោកបានហៅឈ្មោះខ្ញុំនោះទេ › ។ ‹ ខ្ញុំគឺ យ៉ូសែប ជាព្យាការី › មនុស្សប្លែកមុខនោះបាននិយាយដោយញញឹម ។ ‹ លោកបានអធិស្ឋានឲ្យខ្ញុំមកទីនេះ ឥឡូវនេះ តើលោកប្រាថ្នាអ្វីពីខ្ញុំ › » ? ( នៅក្នុង *History of the Church* ១:១៤៦ ) ។

យ៉ូសែប បានពន្យល់ថា នៅក្នុងការនិមិត្តមួយ លោកបានឃើញ នូវែល វីតនី អធិស្ឋានឲ្យលោកមកទីក្រុង ខឺតឡង់ ។ ក្រុមគ្រួសារ វីតនី បានទទួល យ៉ូសែប និង អិមម៉ា ស្ម៊ីធ ដោយសណ្ដានចិត្តល្អ ហើយ យ៉ូសែប និង អិមម៉ា បានរស់នៅជាមួយពួកគេមួយរយៈ ( សូមមើល *History of the Church* ១:១៤៥–៤៦ ) ។

ពួកបរិសុទ្ធនៅរដ្ឋ នូវ យ៉ោក ភាគច្រើន បានផ្លាស់ទីលំនៅទៅរដ្ឋ អូហៃអូ ក្នុងអំឡុងពេលប្រាំខែបន្ទាប់ពីព្រះអម្ចាស់បានបញ្ជាឲ្យទៅប្រមូលផ្ដុំគ្នានៅទីនោះ ។ សមាជិកសាសនាចក្រមួយចំនួនទាំងនោះ បានធ្វើដូច្នោះដោយមានការបូជាដ៏ធំ ។ ពួកគេបានលក់ទ្រព្យសម្បត្តិរបស់ខ្លួនក្នុងតម្លៃថោក ឬ បានចាកចោលផ្ទះសម្បែង និង ទ្រព្យសម្បត្តិដោយពុំបានលក់ចេញសោះ ហើយចេញទៅរដ្ឋ អូហៃអូ ដើម្បីធ្វើតាមព្យាការី ។ សូមអានដំណើររឿងខាងក្រោម ហើយស្វែងរកឧទាហរណ៍មួយអំពីរបៀប ដែលព្រះអម្ចាស់បានប្រទានពរដល់ពួកបរិសុទ្ធទាំងនេះ នៅពេលពួកគេបានស្ដាប់តាមការបញ្ជារបស់ទ្រង់ ដែលឲ្យផ្លាស់ទីលំនៅទៅកាន់រដ្ឋ អូហៃអូ ៖



ម្ដាយរបស់ព្យាការី យ៉ូសែប ស្ម៊ីធ គឺ លូស៊ី ម៉ាក ស្ម៊ីធ បានដឹកនាំក្រុមមួយដែលមានសមាជិកសាសនាចក្រចំនួន ៨០ នាក់ ចេញពី ភូមិ ហ្វាយែត រដ្ឋ នូវ យ៉ោក ទៅកាន់រដ្ឋ អូហៃអូ ។ នៅពេលពួកគេបានធ្វើដំណើរតាមទូកនៅលើព្រែក ខាយូហ្គា និង សេនេកា ទៅកាន់ ភូមិបាហ្វូឡូ រដ្ឋ នូវ យ៉ោក លូស៊ី បាននឹកចាំថា ពួកបរិសុទ្ធដែល « បានធ្វើដំណើរដោយសារតែការបញ្ជារបស់ព្រះអម្ចាស់ គឺដូចជាលោកឪពុកលីហៃ កាលលោកបានចាកចោលទីក្រុងយេរូសាឡិម ហើយដោយភក្ដីភាព នោះ [ ពួកគាត់ ] មានហេតុផលនឹងរំពឹងពរជ័យដូចគ្នាមកពីព្រះ » ( *History of Joseph Smith by His Mother* បានបោះពុម្ពដោយ Preston Nibley [ ១៩៥៨ ] ទំព័រ ១៩៦ ) ។

នៅពេលពួកគេបានទៅដល់ភូមិបាហ្វូឡូ រដ្ឋ នូវ យ៉ោក ពួកគេបានជួបសមាជិកសាសនាចក្រដែលមកពី ខូលស្វិល ដែលចង់ធ្វើដំណើរទៅកាន់រដ្ឋ អូហៃអូ ដែរ ហើយដែលបានតែលតោលនៅភូមិបាហ្វូឡូនោះអស់មួយសប្ដាហ៍មកហើយ ។ ផ្លូវដំណើរតាមព្រែកនោះត្រូវបានរាំងស្ទះដោយទឹកកក « ដែលគរឡើងកម្រាស់ប្រាំមួយម៉ែត្រ » ហើយពួកគេត្រូវបានគេប្រាប់ថាត្រូវ « នៅកំពង់ផែនោះយ៉ាងហោចណាស់ពីរសប្ដាហ៍ជាបន្តទៀត » ។ ពួកបរិសុទ្ធជាច្រើនក្នុងក្រុមរបស់ លូស៊ី បានបាក់ទឹកចិត្ត ។ ពួកគេមានការស្រេកឃ្លាន ចំណែកឯកុមារមួយចំនួនបានធ្លាក់ខ្លួនឈឺ ។ ពួកគេបានជួលទូកមួយទៀតផ្សេងទៀត ដោយដាក់ឥវ៉ាន់របស់ពួកគេនៅលើទូកនោះ ហើយ លូស៊ី បានរកកន្លែងជ្រកបណ្ដោះអាសន្នសម្រាប់ស្ត្រី និង កុមារតូចៗដែលឈឺនោះ រហូតដល់ព្រឹកស្អែកឡើង ។ ( សូមមើល *History of Joseph Smith by His Mother* ទំព័រ ១៩៩–២០២ ) ។

នៅពេលពួកគេបានឡើងលើទូកវិញ លូស៊ី បានថ្លែងទីបន្ទាល់ទៅកាន់សមាជិកក្នុងក្រុមគាត់ថា « ឥឡូវនេះ ឱបងប្អូនប្រុសស្រីទាំងឡាយអើយ ប្រសិនបើបងប្អូនទាំងអស់គ្នានឹងអំពាវនាវទៅដល់ស្ថានសួគ៌ អំពីបំណងប្រាថ្នារបស់បងប្អូន ដើម្បីឲ្យដុំទឹកកកនេះអាចនឹងបែក ហើយដើម្បីឲ្យយើងអាចបន្តដំណើរទៅមុខបាន ប្រាកដដូចជាព្រះអម្ចាស់មានព្រះជន្មរស់ នោះវានឹងសម្រេចបានយ៉ាងដូច្នោះ » ។ ហើយគាត់បានពិពណ៌នាអំពីអ្វីដែលបានកើតឡើងបន្ទាប់មកទៀតថា ៖ « រំពេចនោះ មានសំឡេងមួយបន្លឺឡើង ដូចជាផ្គរលាន់ ។ អ្នកបើកទូកបានស្រែកថា ‹ អ្នកគ្រប់គ្នា ចូរទៅកាន់កន្លែងរៀងខ្លួន › ។ ដុំទឹកកកនោះបានបែកប្រេះចេញ ដោយទុកច្រកតូចមួយសម្រាប់ទូក ហើយនៅពេលទូកបានឆ្លងកាត់តាមផ្លូវតូចចង្អៀតនោះ ពោងទឹកបានរហែកដោយសារតែទង្គិចនឹងមុខបែករបស់ទឹកកក ។. . . យើងបានឆ្លងផុតតែបន្តិចតាមផ្លូវដែលទឹកកកនោះបានប្រេះចេញពីគ្នា ពីមុនពេលដែលទឹកកកកកិតជាប់គ្នាវិញម្ដងទៀត ហើយពួកបងប្អូនប្រុសខូលស្វិល ត្រូវបានជាប់នៅបាហ្វូឡូ ដោយពុំអាចតាមយើងទាន់ឡើយ » ( *History of Joseph Smith by His Mother* ២០៤–៥ ) ។

២. សូមសង្ខេបចេញពីដំណើររឿងដែលអ្នកបានអានអំពីក្រុមពួកបរិសុទ្ធ ដែលបានដឹកនាំដោយ លូស៊ី ម៉ាក ស្ម៊ីធ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបដែលពួកបរិសុទ្ធទាំងនេះបានបង្ហាញសេចក្ដីជំនឿរបស់ខ្លួនលើព្រះអម្ចាស់ ។ សូមសរសេរផងដែរ អំពីរបៀបដែលបទពិសោធន៍របស់ពួកគេអំឡុងពេលស្ថានភាពដ៏លំបាកនេះបង្ហាញថា ព្រះអម្ចាស់ទ្រង់ជ្រាបពីយើង ហើយនៅពេលយើងស្ដាប់តាមទ្រង់ នោះទ្រង់នឹងជួយយើងឲ្យយកឈ្នះលើឧបសគ្គទាំងឡាយ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:២–៤ រួចស្វែងរកព្រះបញ្ញត្តិ និង សេចក្ដីណែនាំទាំងឡាយ ដែលព្រះអម្ចាស់បានប្រទានដល់ប្រជាជននោះ ។ នៅក្នុងបញ្ជីខាងក្រោមនេះ សូមគូសបន្ទាត់មួយទៅកាន់សេចក្ដីណែនាំដែលពួកបរិសុទ្ធ *ពុំ* ត្រូវបានបញ្ជាឲ្យធ្វើតាម ៖

- ប្រជុំគ្នាដើម្បីព្រមព្រៀងលើព្រះបន្ទូលព្រះ ។
- ទទួលក្រឹត្យវិន័យដោយសារការអធិស្ឋានដោយនូវសេចក្ដីជំនឿ ។
- ឃើញថាក្រឹត្យវិន័យត្រូវបានគោរពតាម ។
- ប្រមូលផ្ដុំគ្នានៅ ឃុំចាកសុន រដ្ឋ មិសសួរី ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:៣ សូមគូសចំណាំលើគោលបំណងនៃក្រឹត្យវិន័យ ដែលប្រជាជនត្រូវទទួល « ដោយសារការអធិស្ឋានដោយនូវសេចក្ដីជំនឿ [ របស់ពួកគេ ] » ។ ក្រឹត្យវិន័យដែលព្រះអម្ចាស់បានលើកឡើង មាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២ ។ អ្នកនឹងសិក្សាក្រឹត្យវិន័យនេះជាសេចក្ដីលម្អិតនៅក្នុងពីរបីមេរៀនក្រោយ ។

៣. សូមពិពណ៌នានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ថាតើអ្នកគិតដូចម្ដេច អំពីការទទួលយកក្រឹត្យវិន័យ និង ព្រះបញ្ញត្តិរបស់ព្រះ គឺជាពរជ័យមួយ ។ លើសពីនេះទៅទៀត សូមពន្យល់អំពីរបៀបដែលក្រឹត្យវិន័យរបស់ព្រះជួយយើងឲ្យ « មានអ្វីត្រឹមត្រូវសព្វគ្រប់នៅចំពោះ [ ទ្រង់ ] ( គ. និង ស. ៤១:៣ ) ។

សូមគិតអំពីរបៀបដែលយោបល់ទាំងពីរខាងក្រោមនេះ អាចមានសភាពស្រដៀងគ្នា និង របៀបដែលពួកវាអាចនឹងមានសភាពខុសគ្នា ៖

| អ្នកជឿ | សិស្ស |
|---|---|

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:៥ រួចបំពេញគោលការណ៍ដូចតទៅនេះ ៖ **យើងក្លាយជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទបាន នៅពេលយើង** ។

តើមានភាពខុសគ្នាដែរឬទេ រវាងការជឿលើក្រឹត្យវិន័យនៃព្រះយេស៊ូវគ្រីស្ទ និង ការទទួលយកក្រឹត្យវិន័យទាំងនោះ ? ទន្ទឹមនឹងពេលដែលការជឿលើក្រឹត្យវិន័យរបស់ព្រះ គឺជាផ្នែកដ៏សំខាន់មួយនៃការប្រែក្លាយជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ នោះការទទួលយកក្រឹត្យវិន័យរបស់ទ្រង់—ដែលជាការទទួលយក និង ការគោរពប្រតិបត្តិតាម—ស្ដាបនាសេចក្ដីជំនឿទៅលើព្រះអង្គសង្គ្រោះ ។

៤. ដើម្បីជួយអ្នកឲ្យអនុវត្តគោលការណ៍ដែលថា យើងក្លាយជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទនៅពេលយើងទទួលយក ហើយរស់នៅតាមក្រឹត្យវិន័យទ្រង់ នោះសូមជ្រើសរើស ហើយអានបទដ្ឋានមួយចេញពីកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ។ ក្រោយមក សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្វីដែលអ្នកគិតថា អ្នកនឹងចង់ធ្វើ ដើម្បីទទួលយក ហើយរស់នៅតាមបទដ្ឋាននោះឲ្យបានកាន់តែប្រសើរជាងនេះបន្តិច ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:៧ ព្រះអម្ចាស់បានណែនាំឲ្យពួកបរិសុទ្ធ សង់ផ្ទះមួយសម្រាប់ យ៉ូសែប ស្ម៊ីធ និង ក្រុមគ្រួសាររបស់លោកបានស្នាក់នៅ ហើយលោកអាចបន្ដការបកប្រែព្រះគម្ពីរប៊ីបជាបន្ដទៀត ។ ពួកបរិសុទ្ធបានធ្វើតាមសេចក្ដីណែនាំនេះ ហើយផ្ទះដ៏តូចមួយត្រូវបានសាងសង់ឡើង ដែល យ៉ូសែប និង អិមម៉ា បានរស់នៅបានបីបួនខែ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:៩–១២

*ព្រះអម្ចាស់ហៅ អែតវើត ប៉ាទ្រិច ឲ្យធ្វើជាប៊ីស្សពទីមួយនៃសាសនាចក្រ*

សូមនឹកស្រមៃថា វួដរបស់អ្នកត្រូវការប៊ីស្សពថ្មីមួយរូប ។ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:៩ រួចគូសចំណាំពាក្យ ឬ ឃ្លាទាំងឡាយណា ដែលបង្រៀនគោលការណ៍ដូចតទៅនេះ ៖ **ប៊ីស្សពត្រូវបានហៅដោយព្រះ គាំទ្រដោយសំឡេងនៃសមាជិក និង ត្រូវបានតែងតាំងដោយសិទ្ធិអំណាចត្រឹមត្រូវ** ។

ឃ្លា « បានតាំងដោយសំឡេងនៃសាសនាចក្រ » មានន័យថា សមាជិកនៃសាសនាចក្រ គាំទ្របុគ្គលដែលត្រូវបានហៅដោយព្រះ ។ ឃ្លា « ចំណាយពេលទាំងអស់ដែលគាត់មាន សម្រាប់ការងារនៃសាសនាចក្រ » ត្រូវបានណែនាំយ៉ាងច្បាស់លាស់ទៅដល់ អែតវើត ប៉ាទ្រិច ហើយវាក៏អនុវត្តចំពោះសមាជិកក្នុងគណៈប៊ីស្សពជាអធិបតី នាពេលសព្វថ្ងៃនេះដែរ ។ វាពុំអនុវត្តចំពោះប៊ីស្សពនៃវួដ ដែលបន្ដការងារធម្មតាផ្ទាល់ខ្លួន កាលពួកគាត់កំពុងបម្រើក្នុងសាសនាចក្រនោះទេ ។

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលវាមានសារៈសំខាន់ចំពោះអ្នក ដើម្បីដឹងថា ប៊ីស្សព ឬ ប្រធានសាខារបស់អ្នក ត្រូវបានហៅដោយព្រះ និង បានតែងតាំងដោយសិទ្ធិអំណាចបព្វជិតភាពត្រឹមត្រូវ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:១១ ដោយស្វែងរកលក្ខណៈសម្បត្តិទាំងឡាយណា ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថា អែតវឺត ប៉ាទ្រិច ត្រូវមាន ដែលអាចនឹងជួយគាត់ក្នុងការហៅរបស់ខ្លួនជាប៊ីស្សព ។ អ្នកអាចនឹងចង់សរសេរកំណត់សម្គាល់នៅក្នុងព្រះគម្ពីររបស់អ្នកថាពាក្យ *ចិត្តឧបាយ* សំដៅទៅលើការកេងប្រវ័ញ្ច ឬ ការលាក់ពុត ។ ហេតុដូច្នោះហើយ អែតវឺត គឺជាបុរសស្មោះត្រង់ដែលមានភាពថ្លៃថ្នូរ ។

៦. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១:១២ ដោយស្វែងរកការព្រមានរបស់ព្រះអម្ចាស់ ។ រួចសូមឆ្លើយសំណួរខាងក្រោមនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា វាមានន័យដូចម្ដេច ដើម្បីប្រយ័ត្នពីរបៀបដែលយើង « គិត » ពីព្រះបន្ទូលទាំងឡាយរបស់ព្រះអម្ចាស់ ?

ខ. តើការប្រយ័ត្នចំពោះអ្វី ដែលអ្នកប្រព្រឹត្តចំពោះព្រះបន្ទូលរបស់ព្រះអម្ចាស់ អាចទាក់ទងទៅនឹងអ្វី ដែលអ្នកបានរៀនអំពីការធ្វើជាសិស្សនៃព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ?



នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍ដូចតទៅនេះពី អែលឌើរ នែល អេ ម៉ាក់ស្វែល ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ សូមពិចារណាអំពីរបៀបដែលវាទាក់ទងទៅនឹងអ្វី ដែលអ្នកបានរៀនអំពីភាពជាសិស្សនៅក្នុងមេរៀននេះ ៖ « ជារៀងរាល់ថ្ងៃ យើងកំណត់ពីកម្រិតនៃភាពជាសិស្សរបស់យើង ។ ជារៀងរាល់ថ្ងៃ យើងឆ្លើយនឹងសំណួរ ‹ តើនរណាស្ថិតនៅក្នុងភាគីរបស់ព្រះអម្ចាស់ ? នរណា ? › » ( My Servant Joseph," *Ensign* ខែ ឧសភា ឆ្នាំ ១៩៩២ ទំព័រ ៣៩ ) ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤១ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

## មេរៀនទី ១០ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្តីសញ្ញា ៤២:១–២៩

### បុព្វកថា

នៅថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ១៨៣១ មិនយូរប៉ុន្មានបន្ទាប់ពីបានទៅដល់ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ព្យាការី យ៉ូសែប ស៊្មីធ បានទទួលវិវរណៈ ដែលឥឡូវនេះបានបញ្ចូលទៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៤២:១–៧២ ។ លោកបានទទួលការណែនាំបន្ថែមនៅថ្ងៃទី ២៣ ខែ កុម្ភៈ ( សូមមើល គ. និង ស. ៤២:៧៣–៩៣ ) ។ នៅពេលដាក់បញ្ចូលជាមួយគ្នា វិវរណៈទាំងនេះត្រូវបានស្គាល់ថាជា « ក្រឹត្យវិន័យនៃសាសនាចក្រ » ( សូមមើល សេចក្តីណែនាំអំពីកណ្ឌនៃ គ. និង ស. ៤២ ) ។ គោលលទ្ធិ និង សេចក្តីសញ្ញា ៤២ ត្រូវបានបែងចែកជាពីរមេរៀន ។ មេរៀននេះមាន ខទី ១–២៩ ដែលផ្តល់នូវសេចក្តីណែនាំលើការបង្រៀនដំណឹងល្អ និង ការចេញក្រឹត្យវិន័យទូទៅនៃការប្រព្រឹត្តរបស់សមាជិកសាសនាចក្រ ។

### គោលលទ្ធិ និង សេចក្តីសញ្ញា ៤២:១–១០

*ព្រះអម្ចាស់ត្រាស់ហៅពួកអែលឌើរ ឲ្យបង្រៀនដំណឹងល្អ ហើយស្ថាបនាសាសនាចក្រទ្រង់ឡើង*

សូមគូសរង្វង់លើពាក្យខាងក្រោម ដែលអ្នកគិតថាប្រើចំពោះក្រឹត្យវិន័យ និង ព្រះបញ្ញត្តិរបស់ព្រះ ៖

| | | | |
|---|---|---|---|
| ភាពតឹងតែង | ពរជ័យ | ពិបាក | ត្រួតត្រា |
| អំណោយ | ដាក់កំហិត | វង្វាន់ | សេរីភាព |

ហេតុអ្វីបានជាពេលខ្លះ យើងគិតអវិជ្ជមានចំពោះក្រឹត្យវិន័យ និង ព្រះបញ្ញត្តិរបស់ព្រះ ? ហេតុអ្វីបានជាវាមានសារៈសំខាន់ដើម្បីយល់ថា ក្រឹត្យវិន័យ និង ព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់គឺជាអំណោយ ឬ ពរជ័យ ? តើការគោរពប្រតិបត្តិតាមក្រឹត្យវិន័យ និង ព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ រំដោះយើងចេញពីលទ្ធផលនៃអំពើបាបយ៉ាងដូចម្តេច ?

នៅពេលអ្នកសិក្សាមេរៀនថ្ងៃនេះ សូមស្វែងរករបៀបដែលពួកបរិសុទ្ធចាត់ទុក ការទទួលយកក្រឹត្យវិន័យរបស់ព្រះ ហើយពិចារណាអំពីលក្ខណៈសម្បត្តិផ្ទាល់ខ្លួនរបស់អ្នកចំពោះព្រះបញ្ញត្តិ ។

ព្រះអម្ចាស់បានបញ្ជាពួកបរិសុទ្ធនៅរដ្ឋ នូវ យ៉ោក ឲ្យទៅរដ្ឋ អូហៃអូ ហើយបានសន្យាថា ទ្រង់នឹងប្រទានក្រឹត្យវិន័យទ្រង់ដល់ពួកគេបន្ទាប់ពីបានទៅដល់ទីនោះ ( សូមមើល គ. និង ស. ៣៨:៣២ ) ។ តាមរយៈការបូជាដ៏ធំ ពួកគេបានចាកចោលផ្ទះសម្បែង និង ទ្រព្យសម្បត្តិរបស់ខ្លួន ហើយបានគោរពប្រតិបត្តិតាមការបញ្ជាឲ្យទៅប្រមូលផ្តុំគ្នានៅរដ្ឋ អូហៃអូ ។ ពួកបរិសុទ្ធភាគច្រើននៅរដ្ឋ នូវ យ៉ោក បានគោរពប្រតិបត្តិតាមការបញ្ជាឲ្យទៅប្រមូលផ្តុំគ្នានៅរដ្ឋ អូហៃអូ ។ បន្ទាប់ពីពួកគេបានទៅដល់ទីក្រុង ខឺតឡង់ ពួកអែលឌើរចំនួន ១២ នាក់ បានមកជួបព្យាការី យ៉ូសែប ស៊្មីធ ហើយបានអំពាវនាវដល់ព្រះអម្ចាស់ ។ សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៤២:១–៣ ដោយស្វែងរកមូលហេតុ ដែលពួកអែលឌើរនៃសាសនាចក្របានមកជួបជុំគ្នា ។

ពួកអែលឌើរទាំងនេះបានមកជួបជុំគ្នា ព្រោះពួកគាត់ត្រូវបានបញ្ជាឲ្យធ្វើដូច្នោះ ដើម្បីព្រះអម្ចាស់អាចប្រទានក្រឹត្យវិន័យដល់ពួកគាត់ ។ សេចក្តីណែនាំដំបូងពីព្រះអម្ចាស់ដល់ពួកគាត់ គឺពួកគាត់ត្រូវចេញទៅធ្វើជាអ្នកផ្សព្វផ្សាយសាសនា ពីរនាក់ៗ ដើម្បីចែកចាយដំណឹងល្អ ស្ថាបនាសាសនាចក្រឡើងក្នុងគ្រប់ទាំងភូមិភាគ ដែលពួកគាត់ត្រូវបានហៅឲ្យទៅ ដរាបដល់មនុស្សទាំងអស់បានប្រមូលគ្នាតែមួយ ( សូមមើល គ. និង ស. ៤២:៤–១០ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១១–១៧

*ព្រះអម្ចាស់ចេញគោលការណ៍នៃការបង្រៀនដំណឹងល្អ*

សូមស្រមៃថាអ្នកកំពុងអង្គុយនៅក្នុងសាលាជំនុំ រង់ចាំការប្រជុំសាក្រាម៉ង់ចាប់ផ្ដើម ។ ពុំមានវត្តមានសមាជិកក្នុងគណៈប៊ីស្សព ឬ គណៈប្រធានសាខានៅទីនោះឡើយ ។ មានមនុស្សម្នាក់នៅក្នុងក្រុមជំនុំក្រោកឈរឡើង ហើយពន្យល់ថា គាត់ចង់បន្តការហៅមួយចំនួន ហើយបង្រៀនអំពីគោលលទ្ធិថ្មីខ្លះៗ ដែលបានបើកសម្ដែងដល់គាត់ ។ តើអ្នកនឹងគិតដូចម្ដេចចំពោះស្ថានភាពនេះ ? ហេតុអ្វី ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១១ រួចស្វែងរកអ្វីដែលត្រូវធ្វើ ពីមុនបុគ្គលម្នាក់អាចផ្សាយដំណឹងល្អ ឬ ស្ថាបនាសាសនាចក្រឡើង ក្នុងនាមជាអ្នកតំណាងជាផ្លូវការនៃសាសនាចក្រ ។ សេចក្ដីណែនាំអំពីការតែងតាំងនេះ ពុំគ្រាន់តែអនុវត្តចំពោះពួកអ្នកផ្សព្វផ្សាយសាសនាប៉ុណ្ណោះទេ គឺថែមទាំងអនុវត្តចំពោះអ្នកដែលត្រូវបានញែកចេញឲ្យបង្រៀន ហើយដឹកនាំក្នុងសាសនាចក្រដែរ ។ អ្នកអាចនឹងគូសចំណាំពាក្យ ឬ ឃ្លានៅក្នុងខគម្ពីរនេះ ដែលបង្រៀនអំពីគោលការណ៍ដូចតទៅនេះ ៖ **អ្នកទាំងឡាយណាដែលបង្រៀន ហើយស្ថាបនាសាសនាចក្រឡើង ត្រូវបានហៅដោយព្រះ និង ត្រូវបានតែងតាំង ឬ ញែកចេញដោយថ្នាក់ដឹកនាំសាសនាចក្រដែលទទួលបានសិទ្ធិអំណាច ។**

សូមគិតអំពីរបៀបដែលការអនុវត្តនៃការប្រកាសជាសាធារណៈ និង ការគាំទ្រដល់ថ្នាក់ដឹកនាំសាសនាចក្រ និង ដល់សមាជិកក្នុងការហៅរបស់ខ្លួន អាចបំពេញតាមការបង្គាប់បញ្ជារបស់ព្រះអម្ចាស់ ដែលថាសិទ្ធិអំណាចរបស់ពួកគេ « បានស្គាល់ដោយសាសនាចក្រ » ( គ. និង ស. ៤២:១១ សូមមើល គ. និង ស. ២៨:១៣ ) ។ តើការណ៍នេះធ្វើឲ្យសាសនាចក្រមានសណ្ដាប់ធ្នាប់ ហើយការពារយើងឲ្យមានសុវត្ថិភាពពីការបំភាន់យ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១២–១៣ រួចគូសចំណាំការទទួលខុសត្រូវទាំងឡាយ ដែលត្រូវបានប្រទានដល់អ្នក ដែលបង្រៀន ហើយដឹកនាំក្នុងសាសនាចក្រ ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១២ តើគ្រូបង្រៀននៅក្នុងសាសនាចក្រ បង្រៀនអំពី *អ្វី* ?

ខ. យោងតាម ខទី ១៣ តើពួកគេបង្រៀនតាម *របៀបណា* ?

២. សូមកត់ចំណាំឃ្លា « ធ្វើតាមសេចក្ដីសញ្ញា និង មាត្រាទាំងឡាយនៃសាសនាចក្រ » នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១៣ ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលវាមានសារៈសំខាន់ចំពោះគ្រូបង្រៀន និង ថ្នាក់ដឹកនាំសាសនាចក្រ ដែលពួកគាត់ត្រូវរស់នៅស្របទៅតាមអ្វីដែលពួកគាត់បង្រៀន ។ តើជីវិតអ្នក ឬ ជីវិតមនុស្សណាម្នាក់ដែលអ្នកស្គាល់ ធ្លាប់មានពរនៅដោយសារតែគ្រូបង្រៀន ឬ អ្នកដឹកនាំបានរស់នៅតាមគោលលទ្ធិ និង គោលការណ៍ ដែលគាត់បានបង្រៀនយ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១៤ រួចស្វែងរកអ្វី ដែលអ្នកបង្រៀនគប្បីធ្វើ ដើម្បីទទួលបានការដឹកនាំពីព្រះវិញ្ញាណ ។ បន្ទាប់មក សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ៖ **បើយើង នោះយើងអាចទទួលបានព្រះវិញ្ញាណ ជួយយើងឲ្យបង្រៀនដល់មនុស្សដទៃ ទៀត ។** ( អ្នកអាចនឹងចង់គូសចំណាំពាក្យដែលមាននៅក្នុងខគម្ពីរ ដែលបង្រៀនអំពីគោលការណ៍នេះ ឬ សរសេរគោលការណ៍នេះនៅលើគែមព្រះគម្ពីររបស់អ្នក ) ។

គោលការណ៍មួយទៀតដែលមានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១៤ គឺ **បើយើងពុំមានព្រះវិញ្ញាណទេ នោះយើងនឹងមិនបង្រៀនឡើយ ។**

ដើម្បីជួយអ្នកឲ្យយល់អំពីមូលហេតុវាមានសារៈសំខាន់ ដែលត្រូវមានព្រះវិញ្ញាណនៅពេលអ្នករៀន ហើយបង្រៀនដំណឹងល្អ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១៦–១៧ រួចស្វែងរកអ្វី ដែលព្រះវិញ្ញាណបរិសុទ្ធទ្រង់ជ្រាប ហើយធ្វើ ។ វាក្យសព្ទ *ព្រះដ៏ជាជំនួយ* ដែលត្រូវបានប្រើនៅក្នុងខគម្ពីរទាំងនេះ គឺជាព្រះនាមមួយរបស់ព្រះវិញ្ញាណបរិសុទ្ធ ។ នៅក្នុងចន្លោះដែលផ្ដល់ឲ្យ សូមបញ្ចប់ការបង្រៀនដែលជាគោលការណ៍ចេញពី ខទី ១៧ ដូចតទៅនេះ ៖ **ព្រះវិញ្ញាណបរិសុទ្ធទ្រង់ជ្រាប ហើយធ្វើទីបន្ទាល់ពី ។**

យោងតាមសេចក្ដីពិតនេះ តើព្រះវិញ្ញាណបរិសុទ្ធ អាចជួយអ្នកបង្រៀនយ៉ាងដូចម្ដេច ?

ដោយសារព្រះវិញ្ញាណបរិសុទ្ធជ្រាបគ្រប់ទាំងអស់ នោះទ្រង់ជ្រាបពីអ្វី ដែលយើងទាំងអស់គ្នាធ្លាប់មានបទពិសោធន៍ និង ត្រូវការក្នុងជីវិតយើង ។ អ្នកទាំងឡាយណាដែលបង្រៀន ថ្លែងទីបន្ទាល់ ឬ ពន្យល់អំពីសេចក្ដីពិតនៃដំណឹងល្អ តាមរយៈការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ អាចត្រូវបានដឹកនាំទៅជួយមនុស្សដទៃ ឲ្យទទួលបានអ្វី ដែលព្រះអម្ចាស់ទ្រង់ជ្រាបថាពួកគេត្រូវការ ។

៣. សូមពិពណ៌នានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគ្រាមួយដែលអ្នកបានទទួលអារម្មណ៍ពីអានុភាពនៃព្រះវិញ្ញាណបរិសុទ្ធនៅពេលអ្នកបង្រៀន ចែកចាយ ពន្យល់ ឬ ថ្លែងទីបន្ទាល់អំពីដំណឹងល្អ ។ សូមសរសេរផងដែរអំពីពេលដែលអ្នកបានទទួលអារម្មណ៍ថា ព្រះវិញ្ញាណបរិសុទ្ធថ្លែងទីបន្ទាល់ទៅកាន់អ្នកអំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ ប្រសិនបើអ្នកពុំប្រាកដថា អ្នកធ្លាប់មានបទពិសោធន៍បែបនេះទេនោះ សូមសួរសមាជិកគ្រួសារ ឬ មិត្តភក្ដិរបស់អ្នកអំពីបទពិសោធន៍ដែលពួកគេបានទទួលអារម្មណ៍ពីអានុភាពនៃព្រះវិញ្ញាណបរិសុទ្ធ រួចសរសេរអំពីអ្វីដែលអ្នករៀនចេញពីដំណើររឿងរបស់បុគ្គលនោះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១៨–២៩

*ព្រះអម្ចាស់ប្រទានក្រឹត្យវិន័យ និង ព្រះបញ្ញត្តិដល់សមាជិកសាសនាចក្រ*

បន្ទាប់ពីព្រះអម្ចាស់ បានប្រទានសេចក្ដីណែនាំស្ដីពីការបង្រៀននៅក្នុងសាសនាចក្រហើយ ទ្រង់បានបើកសម្ដែងក្រឹត្យវិន័យ និង ព្រះបញ្ញត្តិទាំងឡាយ ដែលអនុវត្តចំពោះសមាជិកសាសនាចក្រទាំងអស់គ្នា ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១៨–២៩ រួចស្វែងរកព្រះបញ្ញត្តិទាំងឡាយ ដែលបានបង្រៀននៅក្នុងខគម្ពីរទាំងនោះ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

ទោះជា ខទី ១៩ ថ្លែងថា « អ្នកណាដែលសម្លាប់ នោះនឹងត្រូវស្លាប់ » យ៉ាងណាក្ដី ក៏ ខទី ៧៩ ជួយឲ្យយើងយល់ថា ឃាតករសម្លាប់គេ នឹងត្រូវបញ្ជូនទៅអាជ្ញាធរក្នុងស្រុក « កាត់ក្ដីតាមច្បាប់ទាំងឡាយនៃប្រទេស » ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:២០–២៨ ត្រូវ « បណ្ដេញចេញ » មានន័យថា ត្រូវកាត់កាលចេញ ឬ ដកសមាជិកភាពរបស់បុគ្គលម្នាក់ចេញពីសាសនាចក្រ ។ ទោះជាខគម្ពីរទាំងនេះបង្រៀនថា ការកាត់កាលចេញ គឺអនុវត្តចំពោះអ្នកដែលនឹងមិនប្រែចិត្ត ក៏លទ្ធផលនៃការកាត់កាលចេញចំពោះអំពើបាបធ្ងន់ធ្ងរខ្លះ អាចជាផ្នែកនៃដំណើរការនៃការប្រែចិត្តដល់បុគ្គលមួយចំនួនដែលបន្ទាបខ្លួន ប្រែចិត្ត ដែលស្វែងរកការអភ័យទោសចំពោះអំពើបាបខ្លួនដែរ ។ ទង្វើលត់ដំក្នុងសាសនាចក្រ គឺដើម្បីការពារសមាជិកសាសនាចក្រ និង ដើម្បីជួយអ្នកប្រព្រឹត្តបាបឲ្យប្រែចិត្ត ហើយទទួលបានពរជ័យពីដង្វាយធួននៃព្រះអង្គសង្គ្រោះ ។

៤. ដើម្បីបង្កើនការយល់ដឹងអំពីគោលការណ៍មួយចំនួន ដែលមានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១៨–២៩ សូមឆ្លើយសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ហេតុអ្វីបានជាមនុស្សសព្វថ្ងៃនេះត្រូវបានល្បួងឲ្យលួចប្លន់ ? តើអ្នកគិតថា អ្វីដែលអាចជួយបុគ្គល ដែលជាញឹកញាប់ត្រូវបានល្បួងឲ្យលួចប្លន់នោះ ?

ខ. ទម្រង់មួយនៃការកុហក គឺការបន្លំ ។ តើអ្នកគិតថា ហេតុអ្វីបានជាការកុហក និង ការបន្លំគឺជាអំពើបាបធ្ងន់ធ្ងរ ?

គ. ដោយគិតអំពីបទពិសោធន៍ដែលអ្នកមាន ហេតុអ្វីបានជាការពោលពាក្យអាក្រក់អំពីមនុស្សដទៃគឺជាទង្វើខុសឆ្គង និង ធ្វើឲ្យមានទុក្ខទោស ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:២២–២៣ រួចគូសចំណាំពាក្យទាំងឡាយ ដែលបង្រៀនអំពីគោលការណ៍នេះ ៖ **បើយើងមានតម្រេកសម្រើបចង់បានបុគ្គលណាមួយ នោះយើងនឹងបោះបង់ចោលសេចក្ដីជំនឿ ហើយនឹងមិនមានព្រះវិញ្ញាណឡើយ ។**

> ***បុព្វហេតុ និង លទ្ធផល***
> ដើម្បីជួយអ្នកស្គាល់គោលការណ៍ទាំងឡាយនៃដំណឹងល្អនៅក្នុងបទគម្ពីរនានា សូមរកមើលពាក្យទំនាក់ទំនងគ្នា បើ–នោះ និង ពីព្រោះ–ហេតុដូច្នោះហើយ ។ សូមសាកល្បងប្រើវិធីសាស្ត្រនេះជាមួយនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:២៣ ។

តម្រេកសម្រើបពុំមែនជាសេចក្ដីស្រឡាញ់នោះទេ ។ បុគ្គលដែលមានតម្រេកសម្រើបចង់បាននរណាម្នាក់នោះ គឺជាបុគ្គលដែលខ្វល់ខ្វាយតែពីការបំពេញតាមកិលេសរបស់ខ្លួនយ៉ាងអាត្មានិយមបំផុត ។ បុគ្គលទាំងនោះចាត់ទុកមនុស្សដទៃថាជាវត្ថុ ហើយពុំអាចគ្រប់គ្រងខ្លួនឯងបាន ។ តម្រេកសម្រើបកែប្រែ និង ធ្វើឲ្យខុសពីភាពដើមនូវរបៀបដែលអ្នកចាត់ទុកមនុស្សដទៃ ។ វាបណ្ដាលឲ្យអ្នកបាត់បង់ការដឹកនាំពីព្រះវិញ្ញាណ ហើយអាចបំផ្លាញលទ្ធភាពរបស់អ្នកក្នុងការមានទំនាក់ទំនងល្អជាមួយនឹងមនុស្សដទៃ ជាពិសេសអនាគតភរិយា/ស្វាមីរបស់អ្នក ។ វាកំណត់ពីលទ្ធភាពរបស់អ្នក ក្នុងការមានអារម្មណ៍ពីសេចក្ដីស្រឡាញ់ដ៏ពិតប្រាកដ ។ តម្រេកសម្រើបបង្ហាញពីកង្វះសេចក្ដីជំនឿលើព្រះ ហើយប្រឆាំងនឹងអ្វីដែលទ្រង់រំពឹងឲ្យយើងចាត់ទុកមនុស្សដទៃ ។

របៀបមួយដែលតម្រេកសម្រើប រាលដាលនាពេលបច្ចុប្បន្ននេះគឺ ការណ៍អាសគ្រាម ។ អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានព្រមានថា ៖



« រូបអាសគ្រាមបណ្ដាលឲ្យលទ្ធភាពរបស់បុគ្គលម្នាក់ ចុះអន់ថយក្នុងការរីករាយនឹងទំនាក់ទំនងខាងអារម្មណ៍ ខាងមនោសញ្ចេតនា និង ខាងវិញ្ញាណជាមួយនឹងមនុស្សភេទផ្ទុយគ្នា ។. . .

« ការណ៍អាសគ្រាម ក៏ធ្វើឲ្យញៀនផងដែរ ។ វាធ្វើឲ្យលទ្ធភាពនៃការសម្រេចចិត្តចុះអន់ថយ ហើយវា ‹ ចាប់ › អ្នកដែលបើកមើលវា ដោយធ្វើឲ្យពួកគេចេះតែវិលវាយទៅៗ ។. . .

« ចូរធ្វើអ្វីទាំងអស់ ដែលអ្នកអាចធ្វើទៅបាន ដើម្បីចៀសវាងពីការណ៍អាសគ្រាម ។ បើអ្នកឃើញថា ខ្លួនអ្នកស្ថិតនៅក្នុងចំណោមការណ៍អាសគ្រាម—ដែលអាចកើតឡើងចំពោះមនុស្សគ្រប់រូបលើពិភពលោក ដែលយើងរស់នៅនោះ—សូមធ្វើតាមគំរូរបស់ យ៉ូសែប ដែលនៅស្រុក អេហ្ស៊ីប ។ កាលការល្បួងបានធ្វើឲ្យគាត់ត្រូវបានជាប់នៅក្នុងកណ្ដាប់ដៃនាង គាត់បានគេចចេញពីការល្បួង ហើយបាន ‹ រត់ចេញទៅក្រៅទៅ › ( លោកុប្បត្តិ ៣៩:១២ ) ។

« ចូរកុំបំពេញតាមតម្រូវចិត្តនៃការល្បួងគ្រប់កម្រិតណាឲ្យសោះ ។ ចូរទប់ស្កាត់កុំឲ្យមានអំពើបាប ហើយចៀសវាងពីការពាក់ព័ន្ធទៅនឹងសេចក្ដីបំផ្លិចបំផ្លាញដែលចៀសមិនរួចរបស់វា ។ ដូច្នេះ ចូរបិទវាចោលទៅ ! សម្លឹងមើលទៅឲ្យឆ្ងាយ ! ចូរចៀសវាងពីគ្រប់រូបភាពទាំងអស់ ។ ចូរដឹកនាំគំនិតរបស់អ្នក ឲ្យទៅតាមមាគ៌ាដ៏ត្រឹមត្រូវ ។. . .

« . . .ចូរកុំគាំទ្រការណ៍អាសគ្រាម ។ ចូរកុំប្រើប្រាស់ឥទ្ធិពលនៃការជ្រួញជួររបស់អ្នក មកគាំទ្រការបន្ទាបបន្ថោកខាងសីលធម៌ឲ្យសោះ ។ ចំណែកឯក្រុមយុវនារី សូមយល់ថា ប្រសិនបើប្អូនៗស្លៀកពាក់ពុំសមរម្យ មានន័យថា ប្អូនៗកំពុងតែចូលដៃក្នុងបញ្ហានេះ ដោយប្រព្រឹត្តការណ៍អាសគ្រាមទៅកាន់បុរសមួយចំនួន ដែលមើលមកប្អូនៗ » ( Pornography," *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៥ ទំព័រ ៨៩–៩០ ) ។

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវកថាខណ្ឌមួយ ដែលពិពណ៌នាអំពីអ្វីដែលអ្នកអាចធ្វើ ដើម្បីពង្រឹងខ្លួនអ្នកប្រឆាំងនឹងការល្បួងនៃតម្រេកសម្រើប ។ សូមបញ្ចូលហេតុផលនានាទៅក្នុងកថាខណ្ឌរបស់អ្នកអំពីមូលហេតុដែលអ្នកគិតថា ព្រះបញ្ញត្តិនេះមានសារៈសំខាន់ ។ ( អ្នកអាចសិក្សាប្រធានបទ « ព្រហ្មចារីភាព » នៅក្នុងសៀវភៅ *ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* [ ឆ្នាំ ២០០៤ ] សម្រាប់យោបល់បន្ថែម ) ។

ដើម្បីបញ្ចប់មេរៀននេះ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:២៩ រួចស្វែងរកគោលការណ៍ដែលបានបង្រៀននៅក្នុងខគម្ពីរនេះ ។

៦. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ថាតើអ្នកគិតថា ការគោរពតាមក្រឹត្យវិន័យ និង ព្រះបញ្ញត្តិរបស់ព្រះ បង្ហាញសេចក្ដីស្រឡាញ់របស់អ្នកចំពោះទ្រង់យ៉ាងដូចម្ដេច ។ តើការគោរពតាមព្រះបញ្ញត្តិទាំងឡាយ បាននាំឲ្យអ្នកខិតទៅកាន់តែជិតព្រះយ៉ាងដូចម្ដេច ?

នៅអំឡុងសប្ដាហ៍ក្រោយ សូមបង្ហាញសេចក្ដីស្រឡាញ់ចំពោះព្រះឲ្យបានកាន់តែច្រើន តាមរយៈការខិតខំគោរពប្រតិបត្តិតាមក្រឹត្យវិន័យ ឬ ព្រះបញ្ញត្តិរបស់ទ្រង់ណាមួយ ឲ្យបានកាន់តែប្រសើរជាងមុន ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:១–២៩ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១០ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣០–៩៣

## សេចក្ដីផ្ដើម

នៅពេលអ្នកអានសេចក្ដីណែនាំនៃមេរៀនថ្ងៃទី ២ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២ « ក្នុងការបំពេញសេចក្ដីសន្យា ដែលព្រះអម្ចាស់ទ្រង់បានធ្វើរួចមកហើយថា ‹ ក្រឹត្យវិន័យ › នឹងត្រូវបានប្រទានឲ្យមកនៅរដ្ឋ អូហៃអូ » ( សេចក្ដីណែនាំអំពីកណ្ឌនៃ គ. និង ស. ៤២ ) ។ នៅក្នុងមេរៀននេះអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២ សិក្សាលើ ខទី ៣០–៩៣ អ្នកនឹងស្វែងយល់ថា ព្រះអម្ចាស់បានមានព្រះបន្ទូលណែនាំអំពីក្រឹត្យវិន័យខាងសាច់ឈាម ខាងសេដ្ឋកិច្ច និង ខាងវិញ្ញាណ ដោយដឹកនាំឲ្យសមាជិកសាសនាចក្រជួយដល់ជនក្រីក្រ ផ្ដល់ហិរញ្ញប្បទានដល់បន្ទុកទាំងឡាយរបស់សាសនាចក្រ ហើយជួយដល់ពួកបរិសុទ្ធដទៃទៀត ដែលបានធ្វើដំណើរមកដល់រដ្ឋ អូហៃអូ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣០–៤២

*ព្រះអម្ចាស់ចេញក្រឹត្យវិន័យនៃការថ្វាយ*

គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣០–៤២ មានចែងនូវក្រឹត្យវិន័យនៃការថ្វាយរបស់ព្រះអម្ចាស់ ។ ដើម្បីជួយអ្នកឲ្យស្វែងយល់ ហើយយល់ដឹងអំពីក្រឹត្យវិន័យនេះ សូមធ្វើកិច្ចការមួយដោយរៀបចំមេរៀនមួយ ហើយបង្រៀនសមាជិកគ្រួសារ ឬ មិត្តភក្ដិរបស់អ្នកអំពីក្រឹត្យវិន័យនៃការថ្វាយ ដែលបានប្រទានឲ្យនៅក្នុងខគម្ពីរទាំងនេះ ។ នឹងមានឱកាសមួយនៅពេលក្រោយក្នុងមេរៀននៅថ្ងៃនេះ ដើម្បីកត់ត្រា អំពីបទពិសោធន៍របស់អ្នក ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

ដើម្បីត្រៀមខ្លួនបង្រៀនមេរៀននេះ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣០–៤២ រួចធ្វើតាមជំហានដូចខាងក្រោម ៖

- សូមប្រើបង់ស្អិត ឬ ហ្វឺត ដើម្បីគូសបន្ទាត់មួយនៅលើកែវទឹកដឹកចំនួនប្រាំមួយកែវ ។ ( សូមប្រើកែវទឹកថ្លាដែលអាចមើលឃើញទឹក ប្រសិនបើមាន ) ។ សូមគូសបន្ទាប់នៅកម្រិតខុសគ្នាលើកែវទឹកនីមួយៗ ។ បន្ទាប់មក សូមបាំង ឬ គ្របកែវទាំងនោះ ដើម្បីកុំឲ្យមនុស្សដែលអ្នកបង្រៀនអាចឃើញវា ។
- សូមយកថូទឹកមួយ ដែលមានទឹកច្រើនលើសពីគ្រប់គ្រាន់មកចាក់បំពេញ កែវទឹកទាំងអស់ឲ្យត្រឹមបន្ទាត់ដែលបានគូសនៅលើកែវទឹកទាំងនោះ ។ ( ប្រសិនបើអាច អ្នកអាចដាក់ពណ៌ចូលទៅក្នុងទឹក ) ។

សូមបង្ហាញថូទឹកទៅដល់មនុស្សដែលអ្នកបង្រៀន ហើយប្រាប់ពួកគេថា ទឹកតំណាងឲ្យភោគទ្រព្យ និង ធនធាននានាដែលមាននៅក្នុងសហគមន៍ ។ សូមពន្យល់ថា ក្នុងខែ កុម្ភៈ ឆ្នាំ ១៨៣១ សមាជិកនៃសាសនាចក្រនៅទីក្រុង ខឺតឡង់ បានត្រូវការជំនួយសម្រាប់ជនក្រីក្រ ជួយដល់អ្នកចំណូលថ្មី ដែលបានលះបង់ជាច្រើនសន្ធឹក ដើម្បីមកប្រមូលផ្ដុំគ្នានៅរដ្ឋ អូហៃអូ និង ជួយផ្ដល់ហិរញ្ញប្បទានដល់កិច្ចការទាំងឡាយក្នុងសាសនាចក្រ ។

សូមឲ្យមនុស្សដែលអ្នកបង្រៀនអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣០ ដោយឮៗ រួចស្វែងរកអ្វី ដែលព្រះអម្ចាស់បានបើកសម្ដែងទាក់ទងនឹងជនក្រីក្រ ។ សូមឲ្យពួកគេគូសចំណាំពាក្យ *ថ្វាយ* ។



សូមអាននិយមន័យនៃពាក្យ *ថ្វាយ* ដូចតទៅនេះ ដែលបានផ្ដល់ដោយ អែលឌើរ ឌី ថដ គ្រីស្ដូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖ « ការថ្វាយ គឺជាការញែក ឬ ឧទ្ទិសអ្វីមួយឲ្យទៅជាវត្ថុពិសិដ្ឋ ដើម្បីលះបង់ចំពោះគោលបំណងដ៏បរិសុទ្ធ » ( Reflections on a Consecrated Life,” *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១៦ ) ។

អ្នកអាចនឹងអញ្ជើញមនុស្សដែលអ្នកបង្រៀន ឲ្យសរសេរនិយមន័យនេះ នៅលើគែមព្រះគម្ពីររបស់ពួកគេក្បែរ ខទី ៣០ ។

សូមពន្យល់ថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២ មាននូវគោលការណ៍នៃក្រឹត្យវិន័យ ដែលត្រូវបានហៅថាជា ក្រឹត្យវិន័យនៃការថ្វាយ ។ ដើម្បីជួយមនុស្សដែលអ្នកបង្រៀន ឲ្យយល់អំពីគោលការណ៍គ្រឹះទាំងនេះ នោះអ្នកអាចអានដោយឮៗ អំពីការពន្យល់ខាងក្រោមនេះដោយ ប្រធាន ជេ រ៉ូប៊ីន ក្លាក ក្នុងគណៈប្រធានទីមួយ ៖



« គោលការណ៍គ្រឹះនៃ [ ក្រឹត្យវិន័យនៃការថ្វាយ ] គឺថា អ្វីគ្រប់យ៉ាងដែលយើងមាន គឺជារបស់ផងព្រះអម្ចាស់ ហេតុដូច្នេះហើយ ព្រះអម្ចាស់អាចហៅឲ្យយើងលះបង់ទ្រព្យសម្បត្តិណាមួយ ឬ ទាំងអស់ដែលយើងមាន ដ្បិតវាគឺជារបស់ផងទ្រង់ » ( នៅក្នុង របាយការណ៍សន្និសីទ ខែ តុលា ឆ្នាំ ១៩៤២ ទំព័រ ៥៥ ) ។

សុំឲ្យមនុស្សដែលអ្នកបង្រៀនសង្ខេបនូវអ្វីដែល គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣០ បង្រៀនអំពីការទទួលខុសត្រូវរបស់យើងចំពោះជនក្រីក្រ និង អ្នកដែលខ្វះខាត ។ ( មនុស្សដែលអ្នកបង្រៀនអាចនឹងឆ្លើយ ដោយនូវចម្លើយដែលស្រដៀងគ្នាទៅនឹងគោលការណ៍ដូចតទៅនេះ ៖ **យើងត្រូវខ្វាយខ្វល់ពីអ្នកទាល់ក្រ និង អ្នកដែលខ្វះខាត ។** សូមលើកទឹកចិត្តឲ្យគាត់គូសចំណាំពាក្យ ឬ ឃ្លាទាំងឡាយ នៅក្នុងខគម្ពីរនោះ ដែលបង្រៀនអំពីគោលការណ៍នេះ ) ។

សូមបង្ហាញកែវទឹកទទេ ដែលមានគូសបន្ទាត់នៅលើនោះ រួចចាប់ផ្ដើមចាក់ទឹកចូលពីថូ ។ សូមចាក់ទឹកចូលក្នុងកែវទឹកមួយឲ្យត្រឹមបន្ទាត់ដែលអ្នកបានគូស ចាក់ទឹកចូលកែវទឹកបី ឲ្យលើបន្ទាត់ដែលអ្នកបានគូស ហើយចាក់ទឹកចូលកែវទឹកពីរ ឲ្យក្រោមបន្ទាត់ដែលអ្នកបានគូស ។ សូមពន្យល់ថា បន្ទាត់ទាំងនោះដែលបានគូសនៅលើកែវទឹកនីមួយៗ តំណាងឲ្យសេចក្ដីត្រូវការ និង ការចង់បានដ៏សុចរិតនៃក្រុមគ្រួសារខុសៗគ្នាទាំងឡាយ ។ ឧទាហរណ៍ តម្រូវការនៃក្រុមគ្រួសារដែលមានកូនតូចម្នាក់ អាចនឹងខុសពី តម្រូវការនៃក្រុមគ្រួសារដែលមានកូនប្រាំនាក់ ។ សូមពន្យល់ថា ទឹកតំណាងឲ្យភោគទ្រព្យ និង ធនធាននៃក្រុមគ្រួសារនីមួយៗ ។ កែវទឹកដែលមានទឹកក្រោមបន្ទាត់ តំណាងឲ្យក្រុមគ្រួសារ ដែលពុំមានប្រាក់កាស ឬ របស់ទ្រព្យគ្រប់គ្រាន់ ដើម្បីផ្គត់ផ្គង់ដល់តម្រូវការខ្លួន ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣១ ដោយឮៗ រួចអញ្ជើញមនុស្សដែលអ្នកបង្រៀន ឲ្យអានព្រះគម្ពីររបស់ពួកគេតាមក្នុងចិត្ត ។ បន្ទាប់មក សូមសួរសំណួរដូចខាងក្រោមនេះ ៖

- សម្រាប់ពួកបរិសុទ្ធ តើដំណាក់កាលដំបូងក្នុងការរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយគឺជាអ្វី ? ( ត្រូវផ្ដល់ទ្រព្យធនរបស់ខ្លួនមានដូចជា—ប្រាក់កាស របស់ទ្រព្យ ថែមទាំងកម្មសិទ្ធិនានា—ទៅកាន់ប៊ីស្សព ) ។
- តើនៅពេលយើងបរិច្ចាគទៅដល់ជនក្រីក្រ មានន័យថា យើងកំពុងថ្វាយទៅដល់នរណាទៀត ? ( ព្រះអម្ចាស់ ) ។

ដើម្បីបង្ហាញថា សមាជិកសាសនាចក្រ ថ្វាយទ្រព្យសម្បត្តិខ្លួនទៅដល់សាសនាចក្រ នោះសូមចាក់ទឹកដែលមាននៅក្នុងកែវទឹកចូលទៅក្នុងថូវិញ ។

សូមអញ្ជើញមនុស្សដែលអ្នកបង្រៀនអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣២ ឲ្យឮៗ ដោយស្វែងរកដំណាក់កាលទីពីរក្នុងការរស់នៅ តាមក្រឹត្យវិន័យនៃការថ្វាយ ។ បន្ទាប់មកសូមសួរ ៖

- តើដំណាក់កាលទីពីរក្នុងការរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយគឺជាអ្វី ? ( គ្រួសារទាំងអស់ ទទួលបានចំណែកនៃធនធានពីប៊ីស្សព ស្របទៅតាមអ្វីដែលជាតម្រូវការ ) ។

សូមពន្យល់ថា បន្ទាប់ពីផ្ដល់ ឬ ថ្វាយទ្រព្យសម្បត្តិខ្លួនទៅដល់សាសនាចក្រហើយ ក្រុមគ្រួសារទាំងឡាយ ត្រូវបានផ្ដល់ឲ្យមកវិញនូវអ្វីដែលពួកគេត្រូវការ ។ ចំណែកនេះ បានក្លាយទៅជាទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ក្រុមគ្រួសារ ។ ក្រុមគ្រួសារទាំងឡាយត្រូវធ្វើជានាយកតម្រួតការលើទ្រព្យសម្បត្តិខ្លួន ហើយពួកគេត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់វាតាមសមគួរ ប៉ុន្តែ ពួកគេត្រូវទទួលខុសត្រូវចំពោះព្រះ នូវរបៀបដែលពួកគេប្រើប្រាស់វានោះ ។

សូមចាក់ទឹកចេញពីថូ ទៅក្នុងកែវទឹកនីមួយៗឲ្យបានត្រឹមបន្ទាត់របស់វា ។ សូមពន្យល់ថា នៅក្រោមក្រឹត្យវិន័យនៃការថ្វាយនោះក្រុមគ្រួសារនីមួយៗទទួលបាន ស្របទៅតាមសេចក្ដីត្រូវការ និង ការចង់បានដ៏សុចរិតរបស់ក្រុមគ្រួសារ ។ ការសម្រេចចិត្តទាំងនេះ ត្រូវបានធ្វើឡើងដោយការប្រឹក្សាជាមួយគ្នារវាងប៊ីស្សព និង មេគ្រួសារ ។ ក្រុមគ្រួសារទាំងឡាយទទួលស្គាល់ថា ភាពជាម្ចាស់លើទ្រព្យសម្បត្តិខ្លួន គឺជាអំណោយមកពីព្រះអម្ចាស់ ហើយនៅពេលធ្វើជានាយកតម្រួតការលើវា នោះពួកគេត្រូវទទួលខុសត្រូវ ក្នុងការប្រើប្រាស់នូវអ្វីដែលពួកគេត្រូវបានប្រទានឲ្យ ដើម្បីស្ថាបនានគរព្រះអម្ចាស់ឡើង ។

សូមចង្អុលបង្ហាញថា ទឹកមាននៅសល់ក្នុងថូ ។ សូមអញ្ជើញមនុស្សដែលអ្នកបង្រៀនអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣៣–៣៥ ដោយឮៗ រួចស្វែងរកថាតើ « របស់ដែលនៅសល់ទាំងប៉ុន្មាន » ឬ អ្វីដែលនៅសល់ពីទ្រព្យសម្បត្តិដែលបានថ្វាយនោះ ទុកសម្រាប់ធ្វើអ្វី ។ បន្ទាប់មក សូមសួរសំណួរដូចខាងក្រោមនេះ ៖

- តើព្រះអម្ចាស់បានមានព្រះបន្ទូលណែនាំពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ ជាមួយនឹងទ្រព្យសម្បត្តិដែលនៅសល់ ឬ « របស់ដែលនៅសល់ទាំងប៉ុន្មាន » នោះ ? ( ពួកគេត្រូវប្រើវាដើម្បីជួយដល់ជនក្រីក្រ ផ្ដល់ហិរញ្ញប្បទានដល់ការសាងសង់សាសនាចក្រ និងជួយសមាជិកដែលមានសេចក្ដីត្រូវការ ) ។
- ចេញពីអ្វីដែលអ្នកបានរៀននៅក្នុង ខទី ៣៤ តើអ្នកគិតថា ថូទឹកតំណាងឲ្យអ្វី ? ( ឃ្លាំងស្ដុក ) ។

សូមអញ្ជើញឲ្យមនុស្សដែលអ្នកបង្រៀន អាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣៨ ដោយព្ងៗ ហើយស្វែងរកសេចក្ដីពិតដែលនឹងជួយបុគ្គលទាំងឡាយ ឲ្យមានបំណងរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ដោយមិនគិតពីស្ថានភាពរបស់ពួកគេ ។ បន្ទាប់មកសូមសួរ ៖

- តើគោលការណ៍អ្វី ដែលព្រះអម្ចាស់បានបង្រៀនអំពីទង្វើល្អចំពោះមនុស្សដទៃ ? ( ចម្លើយគួរតែមានភាពស្រដៀងគ្នាទៅនឹងគោលការណ៍តទៅនេះ ៖ **នៅពេលយើងប្រព្រឹត្តល្អចំពោះមនុស្សដទៃ នោះមានន័យថា យើងប្រព្រឹត្តល្អចំពោះព្រះអម្ចាស់ដែរ ។** សូមគិតពីការសូមឲ្យមនុស្សដែលអ្នកបង្រៀន គូសចំណាំសេចក្ដីពិតនេះនៅក្នុងព្រះគម្ពីររបស់ខ្លួន )។
- តើសេចក្ដីពិតនេះបានជួយពួកបរិសុទ្ធ ឲ្យមានឆន្ទៈក្នុងការថ្វាយទ្រព្យសម្បត្តិខ្លួនយ៉ាងដូចម្ដេច ? តើការស្គាល់ពីគោលការណ៍នេះ អាចជួយអ្នកនៅក្នុងជីវិតដោយរបៀបណា ?
- តើនៅពេលណាខ្លះ ដែលអ្នកបានបម្រើព្រះអម្ចាស់ នៅពេលអ្នកបានធ្វើអ្វីមួយដើម្បីជួយដល់មនុស្សដទៃ ?

សូមពន្យល់ថា ទោះជាយើងមិនត្រូវបានបញ្ជាឲ្យរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ទៅតាមរបៀបដូចគ្នានឹងពួកបរិសុទ្ធពីជំនាន់ដំបូងក្ដី ក៏ក្រឹត្យវិន័យនេះនៅតែអនុវត្តនាពេលសព្វថ្ងៃនេះដែរ ។ សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមពីប្រធានស្ពែនស៊ើរ ដបុលយូ឴ ឃីមបឹល ដោយព្ងៗ រួចសូមឲ្យមនុស្សដែលអ្នកបង្រៀន ស្ដាប់ថាតើវាមានអត្ថន័យដូចម្ដេចសម្រាប់យើងនាពេលសព្វថ្ងៃនេះ ដើម្បីរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ៖ « ការថ្វាយគឺជាការផ្ដល់ឲ្យនូវពេលវេលា ទេពកោសល្យ និង ទ្រព្យសម្បត្តិរបស់មនុស្សម្នាក់ ដើម្បីថែរក្សាអ្នកដែលមានតម្រូវការ—ទោះជាខាងវិញ្ញាណ ឬ សាច់ឈាមក្ដី—និង ក្នុងការស្ថាបនានគរព្រះអម្ចាស់ឡើង » ( Welfare Services: The Gospel in Action," *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ទំព័រ ៧៨ ) ។

អ្នកអាចនឹងឲ្យមនុស្សដែលអ្នកបង្រៀន សរសេរនិយមន័យនេះ នៅលើគែមព្រះគម្ពីររបស់ពួកគេក្បែរ ខទី ៣០ ។ បន្ទាប់ពីអ្នកបានអានសេចក្ដីថ្លែងការណ៍ពីប្រធាន ឃីមបឹល ហើយ សូមសួរថា ៖

- តើពេលវេលា ទេពកោសល្យ និង ទ្រព្យសម្បត្តិអ្វីខ្លះ ដែលអ្នកមាន ដែលអ្នកអាចប្រើដើម្បីជួយមនុស្សដែលមានសេចក្ដីត្រូវការ ?

សូមចែកចាយបទពិសោធន៍មួយ អំពីគ្រាដែលអ្នកត្រូវបានប្រទានពរដោយនរណាម្នាក់ ដែលបានលះបង់ពេលវេលា ទេពកោសល្យ ឬ ទ្រព្យសម្បត្តិដើម្បីជួយដល់អ្នក ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីសារៈសំខាន់នៃការប្រព្រឹត្តល្អចំពោះមនុស្សដទៃ ។ នៅពេលអ្នកបញ្ចប់ការថ្លែងទីបន្ទាល់ សូមប្រាកដថា អ្នកថ្លែងអំណរគុណដល់មនុស្សដែលអ្នកបង្រៀន ចំពោះការចូលរួមក្នុងមេរៀនរបស់អ្នក ។

១. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវឈ្មោះនៃបុគ្គលដែលអ្នកបានបង្រៀនដោយមានកាលបរិច្ឆេទដែលអ្នកបានបញ្ចប់កិច្ចការនេះ ។ សូមសរសេរការរៀបរាប់មួយ អំពីអ្វីដែលអ្នកគិតថាបានប្រព្រឹត្តទៅបានយ៉ាងល្អប្រសើរ ក្នុងបទពិសោធន៍ការបង្រៀនរបស់អ្នក និង អ្វីដែលមានការលំបាក ។ លើសពីនេះទៅទៀត សូមរៀបរាប់ ថាតើអ្នកមានទទួលអារម្មណ៍ថាមានពរយ៉ាងដូចម្ដេច នៅពេលអ្នកបានរស់នៅតាមគោលការណ៍ដែលថា **នៅពេលយើងប្រព្រឹត្តល្អចំពោះមនុស្សដទៃ នោះមានន័យថា យើងប្រព្រឹត្តល្អចំពោះព្រះអម្ចាស់ដែរ ។**

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៤៣–៥៥

*ព្រះអម្ចាស់ប្រទានឱវាទអំពីសេចក្ដីស្លាប់ និង ការព្យាបាល*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៤៣–៥៥ ព្រះអម្ចាស់បានបង្រៀន អំពីសេចក្ដីស្លាប់ និង ការព្យាបាល ។ ទ្រង់បានមានព្រះបន្ទូលពន្យល់ថា សេចក្ដីស្លាប់ គឺជាសេចក្ដីផ្អែមល្ហែមដល់អស់អ្នកទាំងឡាយណា ដែលបាត់បង់ជីវិតទៅក្នុងទ្រង់ ប៉ុន្តែជាសេចក្ដីល្វីងជូរចត់ចំពោះអស់អ្នកទាំងឡាយណាដែលពុំអស់ជីវិតទៅក្នុងទ្រង់ ។ ទ្រង់ក៏បានមានព្រះបន្ទូលផងដែរថា អ្នកទាំងឡាយណាដែលឈឺនឹង « ត្រូវបានថែទាំឲ្យចំណី ដោយអស់ពីភាពទន់ភ្លន់ » ( គ. និង ស. ៤២:៤៣) ហើយទទួលបានពរជ័យនៃបព្វជិតភាព ។ មនុស្សមួយចំនួននឹងត្រូវបានព្យាបាលឲ្យជាសះស្បើយតាមរយៈសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ ( សូមមើល គ. និង ស. ៤២:៤៨ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៥៦–៦៩

*ព្រះអម្ចាស់សន្យាថា នឹងបើកសម្ដែងបទគម្ពីរបន្ថែម និង វិវរណៈទៅកាន់ព្យាការី យ៉ូសែប ស្ម៊ីធ ។*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៥៦–៦៩ ព្យាការី យ៉ូសែប ស្ម៊ីធ បានស្វែងយល់ថា ព្រះអម្ចាស់នឹងបន្តប្រទាន វិវរណៈ បើគាត់បន្តស្វែងរកវា ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៦១ រួចស្វែងរកគោលការណ៍អំពីការទទួលបាន វិវរណៈ ។ ថ្នាក់ដឹកនាំយើងសព្វថ្ងៃនេះ ដឹកនាំ ហើយណែនាំសមាជិកសាសនាចក្រ ដោយប្រើគោលការណ៍នៃវិវរណៈដែលមាន ជាបន្តបន្ទាប់ ។

២. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរសេចក្ដីថ្លែងការណ៍ បើសិនជា–នោះ អំពីគោលការណ៍ដែលអ្នករៀនចេញពី ខទី ៦១ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៧០–៨៧

*ថ្នាក់ដឹកនាំបព្វជិតភាព ទទួលបានសេចក្ដីណែនាំ ស្ដីពីការដោះស្រាយជាមួយសមាជិកសាសនាចក្រ ដែលបាន ប្រព្រឹត្តអំពើបាបដ៏ធ្ងន់ធ្ងរ ។*

គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៧០–៨៧ មាននូវគោលការណ៍គ្រឹះ និង ក្រឹត្យវិន័យមួយចំនួន ដែលគ្រប់គ្រងលើវិន័យក្នុង សាសនាចក្រ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៧៨ រួចគូសចំណាំព្រះបញ្ញត្តិ ដែលព្រះអម្ចាស់បានប្រទានដល់ សមាជិកសាសនាចក្រគ្រប់រូប ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៨៨–៩៣

*ព្រះអម្ចាស់ណែនាំពួកបរិសុទ្ធ អំពីរបៀបដោះស្រាយជាមួយហេតុទាស់ផ្ទាល់ខ្លួន*

សូមគិតអំពីគ្រាមួយ ដែលអ្នកបានឃើញនរណាម្នាក់ មានហេតុទាស់នឹងពាក្យសម្ដី ឬ ទង្វើនៃមនុស្សម្នាក់ទៀត ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៨៨–៨៩ ដោយស្វែងរកសេចក្ដីណែនាំពីព្រះអម្ចាស់ ស្ដីពីអ្វីដែលយើងគួរតែធ្វើ បើមាន នរណាម្នាក់បានមានហេតុទាស់នឹងយើង ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្វីដែលជាកិច្ចការដំបូងយើងគួរតែធ្វើ បើមាននរណាម្នាក់បានមានហេតុទាស់នឹងយើង ?

ខ. តើអ្នកគិតថា ហេតុអ្វីបានជាការធ្វើបែបនេះ អាចមានប្រយោជន៍ ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៩០–៩១ យើងរៀនថា អំពើបាប ឬ ហេតុទាស់មួយចំនួន ដែលដឹងជាសាធារណៈ តម្រូវឲ្យមានការសារភាពកំហុស ឬ ការបន្ទោសដ៏សមរម្យមួយជាសាធារណៈ ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៩២–៩៣ យើងរៀនអំពីគោលការណ៍ដូចតទៅនេះ ៖ **ហេតុទាស់ដែលបានធ្វើឡើងដោយសម្ងាត់ គួរតែត្រូវបាន ដោះស្រាយដោយសម្ងាត់ ។**

៤. សូមពិពណ៌នានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលអ្នកគិតថា វាជារឿងដ៏ ល្អបំផុតដែលហេតុទាស់ជាសម្ងាត់ ត្រូវដោះស្រាយជាសម្ងាត់ ។

វាទាមទារឲ្យមានភាពក្លាហាន ដើម្បីទៅជួបអ្នកដែលបានមានហេតុទាស់នឹងអ្នក ។ សូមអធិស្ឋានសុំជំនួយពីព្រះវរបិតាសួគ៌ នៅពេលអ្នកព្យាយាមដោះស្រាយយ៉ាងសមហេតុផល នូវអារម្មណ៍មិនល្អទាំងឡាយ ដែលអ្នកអាចមានអំពីមនុស្សដទៃ ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣០–៩៣ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣–៤៤

## សេចក្ដីផ្ដើម

ដូចបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣ ក្នុងខែ កុម្ភៈ ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានណែនាំដល់សមាជិកសាសនាចក្រ អំពីតួនាទីសំខាន់របស់ព្យាការី ក្នុងការទទួលបានវិវរណៈសម្រាប់សាសនាចក្រ ក៏ដូចជាតម្រូវការចំពោះពួកអែលឌើរនៃសាសនាចក្រ ឲ្យទៅផ្សាយអំពីការប្រែចិត្ត ក្នុងការប្រុងប្រៀបខ្លួនសម្រាប់ព្រឹត្តិការណ៍នាពេលអនាគត ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៤ មាននូវសេចក្ដីណែនាំពីព្រះអម្ចាស់ចំពោះពួកអែលឌើរនៃសាសនាចក្រ ឲ្យជួបជុំគ្នាជាសន្និសីទមួយ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:១–៧

*ព្រះអម្ចាស់ប្រកាសថា វិវរណៈ និង ព្រះបញ្ញត្តិទាំងឡាយ គឺមានតាមតែរយៈព្យាការីដែលត្រូវបានតែងតាំងរបស់ទ្រង់ប៉ុណ្ណោះ*

សូមស្រមៃអំពីមនុស្សពីរនាក់ផ្សេងគ្នា ដែលព្យាយាមដឹកនាំអ្នកឲ្យច្រៀងចម្រៀងពីរបទខុសគ្នា នៅពេលតែមួយ ។ តើអ្នកនឹងអាចច្រៀងចម្រៀងទាំងពីរបទ តំណាលគ្នាក្នុងពេលតែមួយបានដែរឬទេ ? តើអ្នកនឹងជ្រើសរើស ថាតើត្រូវច្រៀងតាមអ្នកដឹកនាំចម្រៀងម្នាក់ណា តាមរបៀបណា ?

ក្នុងខែ កុម្ភៈ ឆ្នាំ ១៨៣១ មានអ្នកប្រែចិត្តជឿថ្មីម្នាក់នៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ គឺ អ្នកស្រី ហ៊ឹបប៊ិល បានអះអាងថាគាត់ទទួលបានវិវរណៈ និង ព្រះបញ្ញត្តិទាំងឡាយសម្រាប់សាសនាចក្រ ។ សមាជិកសាសនាចក្រមួយចំនួន ត្រូវបានបំភាន់ដោយសារការអះអាងរបស់គាត់ ។ ព្យាការី យ៉ូសែប ស៊្មីធ បានទូលសួរព្រះអម្ចាស់ អំពីការអះអាងរបស់អ្នកស្រី ហ៊ឹបប៊ិលចំណែកឯការឆ្លើយតបមកវិញនោះ លោកបានទទួលនៅក្នុងវិវរណៈ ដែលសព្វថ្ងៃនេះ ត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:១–៥ ដោយស្វែងរកថា នរណាដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ថា នឹងទទួលបានវិវរណៈសម្រាប់សាសនាចក្រទាំងមូល ។

ខគម្ពីរទាំងនេះបានជួយដល់សមាជិកសាសនាចក្រពីជំនាន់ដំបូង ឲ្យយល់ថា មានតែព្យាការី យ៉ូសែប ស៊្មីធ ប៉ុណ្ណោះ ដែលមានសិទ្ធិអំណាចទទួលបានព្រះបញ្ញត្តិ និង វិវរណៈ សម្រាប់សាសនាចក្រទាំងមូល ។ ខគម្ពីរទាំងនេះក៏ជួយយើងឲ្យយល់ថា **មានតែព្យាការីនៃសាសនាចក្រតែប៉ុណ្ណោះ ដែលនឹងទទួលបានវិវរណៈសម្រាប់សាសនាចក្រទាំងមូល** ។ អ្នកអាចនឹងចង់សរសេរគោលលទ្ធិនេះនៅក្នុងព្រះគម្ពីររបស់អ្នកក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:៣–៤ ឬ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

១. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ ហេតុអ្វីបានជាវាសំខាន់ ដែលត្រូវដឹងថា មានតែប្រធាននៃសាសនាចក្រ ( ឬ គណៈប្រធានទីមួយ ) តែប៉ុណ្ណោះ ដែលនឹងទទួលបានវិវរណៈសម្រាប់សាសនាចក្រទាំងមូល ?

ដូចជាអ្នកស្រី ហ៊ឹបប៊ិល និង មនុស្សដទៃទៀត បានអះអាងខុសឆ្គង ដែលបានបំភាន់ពួកបរិសុទ្ធមួយចំនួននៅជំនាន់ដំបូងនៃសាសនាចក្រ នោះក៏មានមនុស្សបន្លំ និង បំភាន់ជាច្រើននាពេលសព្វថ្ងៃនេះ ដែលប្រកាសពីគំនិតដ៏ខុសឆ្គងដែរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:៥–៧ រួចស្វែងរករបៀប ដែលព្រះអម្ចាស់បានបើកសម្ដែង ដើម្បីជួយយើងកុំឲ្យត្រូវគេបំភាន់ដោយបុគ្គលដែលប្រកាសពីគំនិតដ៏ខុសឆ្គង ឬ អះអាងថា ទទួលបានវិវរណៈសម្រាប់មនុស្សដទៃ ប៉ុន្តែផ្ទុយទៅវិញ ពុំមានសិទ្ធិអំណាចដើម្បីធ្វើដូច្នោះឡើយ ។

សូមពិពណ៌នាដាក់នៅក្នុងចន្លោះដែលបានផ្ដល់ឲ្យ អំពីរបៀបដែលព្រះអម្ចាស់បានបើកសម្ដែង ដើម្បីបង្ការយើងពីការបំភាន់នាពេលសព្វថ្ងៃនេះ ៖



សេចក្តីថ្លែងការណ៍ដូចតទៅនេះពីប្រធាន យ៉ូសែប ហ្វីលឌីង ស៊្មីធ ជួយយើងឲ្យយល់ថា ដើម្បី « មកតាមទ្វារ » នោះ ( គ. និង ស. ៤៣:៧ ) គឺត្រូវធ្វើកិច្ចការ ដែលត្រឹមត្រូវ និង មានការអនុញ្ញាត ៖ « ព្រះអម្ចាស់នឹងធ្វើឲ្យយើងដឹងថា ទ្រង់ធ្វើអ្វីគ្រប់យ៉ាងទៅតាមរបៀបរៀបរយ ហើយនៅពេលដែលទ្រង់ត្រាស់ហៅបុគ្គលម្នាក់ ឲ្យដឹកនាំសាសនាចក្រ បុគ្គលនោះនឹងចូលមកតាមទ្វារ ហើយបានតែងតាំងដោយអ្នកដែលកាន់សិទ្ធិអំណាច ។ វាបានប្រព្រឹត្តទៅយ៉ាងដូច្នេះ ចាប់តាំងពីដំបូងមកម្ល៉េះ ហើយនឹងបន្តយ៉ាងដូច្នេះដរាបដល់ទីបំផុត » ( *Church History and Modern Revelation* វ៉ុល ២ [ ឆ្នាំ ១៩៥៣ ] ១:១៣៨ ) ។ ដើម្បី « មកតាមទ្វារ » នោះ គឺត្រូវចូលទៅតាមមាគ៌ា ដែលត្រូវបានទទួល និង ត្រូវបានស្គាល់ ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ៤៣:៨–១៦

*ពួកអែលឌើត្រូវបានបញ្ជាឲ្យជួបជុំគ្នា ដើម្បីបង្ហាប់ ស្អាងគ្នា និង បានញែកចេញជាបរិសុទ្ធ*

២. សូមធ្វើបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីការប្រជុំខុស ៗគ្នា ដែលអ្នកចូលរួម ក្នុងនាមជាសមាជិកសាសនាចក្រ ។ សូមសរសេរអំពីអ្វីដែលជាគោលបំណងរបស់វា ដាក់នៅក្បែរការប្រជុំនីមួយ ៗ ។

សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៤៣:៨ រួចគូសចំណាំពាក្យ ឬ ឃ្លាទាំងឡាយ ដែលបង្រៀនអំពីគោលការណ៍ដូចតទៅនេះ ៖ **នៅពេលយើងប្រជុំគ្នា យើងត្រូវបង្ហាប់ ហើយស្អាងគ្នាទៅវិញទៅមក ដើម្បីយើងអាចរៀនអំពីរបៀបប្រព្រឹត្ត និង ដឹកនាំសាសនាចក្រ ។** ព្រះបញ្ញត្តិដែលបញ្ជាឲ្យស្អាងគ្នាទៅវិញទៅមក មានន័យថា យើងត្រូវស្ថាបនា ហើយពង្រឹងគ្នាទៅវិញទៅមកខាងវិញ្ញាណ ។ ឃ្លា « ដឹកនាំសាសនាចក្ររបស់យើង » នៅក្នុងខគម្ពីរនេះ សំដៅទៅលើសមាជិកសាសនាចក្រ ត្រូវបានដឹកនាំលើរបៀបបំពេញករណីយកិច្ចខ្លួន ។ ការប្រជុំទាំងឡាយត្រូវបានធ្វើឡើងដើម្បីជួយសមាជិកសាសនាចក្រ ឲ្យរក្សាសេចក្តីសញ្ញា ហើយតម្កើងការហៅរបស់ខ្លួន ដែលមានន័យថា ការបំពេញការទទួលខុសត្រូវនៃការហៅរបស់ពួកគេ ។

៣. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីបទពិសោធន៍មួយដែលអ្នកទទួលបានអារម្មណ៍ថា ត្រូវបានស្អាង—ស្ថាបនា ហើយពង្រឹងខាងវិញ្ញាណ—កាលអ្នកបានចូលរួមក្នុងការប្រជុំមួយក្នុងសាសនាចក្រ ។

សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៤៣:៩–១១ រួចស្វែងរកអ្វីដែលយើងត្រូវធ្វើ បន្ទាប់ពីយើងរៀនអំពីក្រឹត្យវិន័យ និង ព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ ។ នៅក្នុង ខទី ៩ ឃ្លា « បានញែកចេញជាបរិសុទ្ធ » មានន័យថា ត្រូវបានធ្វើឲ្យបរិសុទ្ធ ឬ ស្អាតស្អំពីអំពើបាបទាំងឡាយនៃលោកិយ ។ សេចក្តីពិតមួយ ដែលយើងស្វែងយល់ចេញពី ខទី ៩ គឺថា **យើងត្រូវភ្ជាប់ខ្លួនយើង ទៅនឹងការប្រព្រឹត្តតាមសេចក្តីពិត ដែលយើងរៀន ។** ( អ្នកអាចនឹងចង់គូសចំណាំគោលការណ៍នេះ នៅក្នុងព្រះគម្ពីររបស់អ្នក ) ។

*ការវាយតម្លៃលើជីវិតរបស់យើង*

នៅពេលយើងឆ្លៀតពេល ដើម្បីវាយតម្លៃដោយត្រង់ លើគុណភាពនៃការរស់នៅរបស់យើង តាមគោលការណ៍នៃដំណឹងល្អជាក់លាក់មួយនោះ យើងផ្តល់ឱកាសឲ្យព្រះវិញ្ញាណបរិសុទ្ធ ជួយយើងឲ្យទទួលស្គាល់អំពីអ្វី ដែលយើងកំពុងតែធ្វើបានយ៉ាងល្អ និង របៀបដែលយើងអាចពង្រឹងបន្ថែម ។ នៅពេលអ្នកវាយតម្លៃលើខ្លួនអ្នក សូមព្យាយាមស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ហើយស្មោះត្រង់ទាំងស្រុង ។

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការប្រព្រឹត្តតាមអ្វីដែលយើងរៀននៅក្នុងការប្រជុំទាំងឡាយ ជួយយើងឲ្យបានញែកចេញជាបរិសុទ្ធយ៉ាងដូចម្តេច ?

ខ. តើអ្នកគិតថា ពិធីបុណ្យជ្រមុជទឹក និង ពិធីសាក្រាម៉ង់ មានតួនាទីយ៉ាងដូចម្តេច ក្នុងការបានញែកចេញជាបរិសុទ្ធរបស់យើង ?

គ. តើនៅពេលណា ដែលអ្នកបានតាំងចិត្តប្រព្រឹត្តតាមអ្វី ដែលអ្នកបានរៀននៅក្នុងការប្រជុំ ហើយក្រោយមកសម្រេចបានការតាំងចិត្តនោះ ? តើអ្នកបានទទួលពរដោយព្រោះការធ្វើដូច្នោះយ៉ាងដូចម្តេចដែរ ?




នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៤៣:១២–១៤ ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ពួកបរិសុទ្ធថា ពួកគេនឹងទទួលបានសិរីល្អនៃនគរ ប្រសិនបើពួកគេគាំទ្រដល់ព្យាការី ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:១៧–៣៥

*ពួកអ្នកបម្រើរបស់ព្រះ ត្រូវផ្សាយអំពីការប្រែចិត្ត ក្នុងការប្រុងប្រៀបខ្លួនសម្រាប់ការយាងមកជាលើកទីពីរ និង សហស្សវត្សរ៍*

សូមគិតអំពីសកម្មភាព និង ព្រឹត្តិការណ៍ ដែលតម្រូវឲ្យមានការប្រុងប្រៀបខ្លួនដោយប្រុងប្រយ័ត្នបំផុតដូចជា បេសកកម្មពេញម៉ោង ការប្រកួតកីឡា ផលិតកម្មតន្ត្រី ការចាត់តាំងបង្រៀន ឬ ការប្រឡង ។ តើអ្នកគិតថា បុគ្គលម្នាក់អាចនឹងមានអារម្មណ៍ដូចម្ដេច ប្រសិនបើគាត់ពុំបានត្រៀមខ្លួន កាលដែលពេលវេលាបានមកដល់ ដើម្បីចូលរួមក្នុងសកម្មភាព ឬ ព្រឹត្តិការណ៍នោះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:១៧–២២ ដោយស្វែងរកព្រឹត្តិការណ៍មួយ ដែលតម្រូវឲ្យមានការប្រុងប្រៀបខ្លួនដោយប្រុងប្រយ័ត្ន ។

ព្រះអម្ចាស់បានមានព្រះបន្ទូលណែនាំ ដល់ពួកអែលឌើរ ឲ្យចេញទៅប្រាប់ដល់អស់ទាំងសាសន៍ ឲ្យប្រុងប្រៀបខ្លួន សម្រាប់ការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ ។ ចេញពីអ្វីដែលអ្នករៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:២០ សូមបំពេញនៅក្នុងចន្លោះ ដោយប្រើពាក្យត្រឹមត្រូវទាំងឡាយ ដែលបញ្ចប់គោលការណ៍នេះ ៖ **យើងត្រូវប្រែចិត្ត ហើយ ខ្លួនយើងសម្រាប់ការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ ។**

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:២៥–២៨ ដោយស្វែងរកមធ្យោបាយមួយចំនួន ដែលព្រះអម្ចាស់ត្រាស់ហៅឲ្យមនុស្សទាំងអស់ប្រែចិត្ត ហើយបានសង្គ្រោះ ។ តើអ្នកគិតថា ហេតុអ្វីបានជាព្រះអម្ចាស់ប្រើសំឡេងជាច្រើន មកព្រមានយើង ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣:២៩–៣១ រួចស្វែងរកអ្វី ដែលនឹងកើតឡើងបន្ទាប់ពីការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ ។

អ្នកអាចនឹងចង់គូសចំណាំពាក្យ ឬ ឃ្លាទាំងឡាយ ដែលបង្រៀនថា **អំឡុងពេលសហស្សវត្សរ៍ សាតាំងនឹងត្រូវបានចង ហើយព្រះយេស៊ូវគ្រីស្ទ នឹងសោយរាជ្យជាមួយរាស្ត្រទ្រង់នៅលើផែនដី ។**



ប្រធាន ចច឴ យ្យូ ខានុន ក្នុងគណៈប្រធានទីមួយ បានពន្យល់អំពី របៀបដែលសាតាំងនឹងត្រូវបានចងអំឡុងពេលសហស្សវត្សរ៍ ៖ « យើងនិយាយអំពីសាតាំងត្រូវបានចង ។ សាតាំងនឹងត្រូវបានចងដោយព្រះចេស្ដានៃព្រះ ប៉ុន្តែ វាក៏នឹងត្រូវបានចងផងដែរ ដោយការប្ដេជ្ញាចិត្តរបស់រាស្ត្រនៃព្រះ ដែលមិនស្ដាប់តាមវា ដោយមិនអនុញ្ញាតឲ្យវាគ្រប់គ្រងលើបាន » ( *Gospel Truth: Discourses and Writings of President George Q. Cannon* ជ្រើសរើសដោយ Jerreld L. Newquist វ៉ុល ២ [ ឆ្នាំ ១៩៥៧–៧៤ ] ១:៨៦ ) ។



ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនថា ៖ « ព្រះគ្រីស្ទ និង ពួកបរិសុទ្ធដែលបានរស់ឡើងវិញ នឹងសោយរាជ្យលើផែនដីអំឡុងពេលមួយពាន់ឆ្នាំ ។ ពួកគាត់ប្រហែលជានឹងមិនអាស្រ័យលើផែនដីនេះទេ ផ្ទុយទៅវិញ ពួកគាត់នឹងមកធ្វើទស្សនកិច្ចនៅពេលពួកគេចង់ធ្វើដូច្នោះ ឬ នៅពេលដែលចាំបាច់ត្រូវត្រួតត្រាលើវា » ( នៅក្នុង *History of the Church* ៥:២១២ ) ។

៥. សូមពិចារណាជាពិសេស អំពីអ្វីដែលអ្នកអាចនឹងត្រូវធ្វើ ដើម្បីប្រែចិត្ត ហើយប្រុងប្រៀបខ្លួន សម្រាប់ការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ និង សហស្សវត្សរ៍ ។ ដោយសារលក្ខណៈផ្ទាល់ខ្លួននៃកិច្ចការនេះ សូមសរសេរថា *បានបញ្ចប់កិច្ចការទី ៥* នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នៅពេលអ្នកបានបញ្ចប់ការចាត់តាំងនេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៤

*ព្រះអម្ចាស់ បញ្ជាពួកអ្នកបម្រើទ្រង់ឲ្យជួបជុំគ្នា*



នៅក្នុងមជ្ឈមណ្ឌលសន្និសីទ នៅទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍ និង នៅក្នុងអគារនានាទូទាំងពិភពលោក សមាជិក សាសនាចក្រ ជួបជុំគ្នារាល់ប្រាំមួយខែម្ដង ដើម្បីស្ដាប់ពួក អ្នកមានសិទ្ធិអំណាចទូទៅ និង ថ្នាក់ដឹកនាំដទៃទៀតនៃ សាសនាចក្រឡើងថ្លែងសុន្ទរកថា ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៤ ព្រះអម្ចាស់បាន ណែនាំពួកអែលឌើរនៃសាសនាចក្រ ឲ្យជួបជុំគ្នាជាសន្និសីទ មួយ ។ សន្និសីទនេះនឹងក្លាយទៅជាសន្និសីទទូទៅលើកទី បួននៃសាសនាចក្រ និង ជាសន្និសីទដំបូងដែលបានធ្វើឡើង នៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ។ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៤:១–៤ ដោយស្វែងរកមូលហេតុ ដែល ព្រះអម្ចាស់បានបញ្ជាពួកបរិសុទ្ធឲ្យធ្វើសន្និសីទនេះឡើង ។

សូមបំពេញចន្លោះ នៅក្នុងសេចក្ដីថ្លែងការណ៍ដូចតទៅនេះ ដោយប្រើអ្វីដែលអ្នកបានរៀនចេញពីខគម្ពីរទាំងនេះ ៖ ព្រះអម្ចាស់ បានបញ្ជាពួកអែលឌើរនៃសាសនាចក្រទ្រង់ឲ្យ .នៅឯសន្និសីទ ព្រះអម្ចាស់បានសន្យាថានឹង .នៅឯសន្និសីទ ពួកអែលឌើរត្រូវ . ជាលទ្ធផល មនុស្សជាច្រើននឹង ។

នៅពេលអ្នកបញ្ចប់មេរៀននេះ សូមគិតម្ដងទៀត អំពីអ្វីដែលអ្នកនឹងធ្វើ ដើម្បីប្រព្រឹត្តតាមគោលការណ៍ទាំងឡាយ ដែលអ្នកបាន រៀន ។ ព្រះអម្ចាស់នឹងប្រទានពរដល់អ្នក នៅពេលអ្នកប្រព្រឹត្តតាមសេចក្ដីពិតទាំងនេះ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៣–៤៤ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១១ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១–១៥

## សេចក្ដីផ្ដើម

សាសនាចក្របានបន្តរីកចម្រើននៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ហើយការប្រឆាំង និង សេចក្ដីរាយការណ៍ក្លែងក្លាយអំពីសាសនាចក្រក៏បានកើនឡើងដែរ ។ វិវរណៈដែលមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ ត្រូវបានទទួលក្នុងខែ មិនា ឆ្នាំ ១៨៣១ បាននាំសេចក្ដីអំណរដល់ពួកបរិសុទ្ធ នៅពេលពួកគេបានប្រឈមមុខនឹងសេចក្ដីលំអៀងនៅក្នុងមូលដ្ឋាន ។ អ្នកនឹងសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ ជាពីរមេរៀន ។ នៅក្នុងផ្នែកទីមួយនៃវិវរណៈនេះ ព្រះយេស៊ូវគ្រីស្ទ បានថ្លែងទីបន្ទាល់អំពីតួនាទីរបស់ទ្រង់ ក្នុងនាមជាព្រះរាជបុត្រានៃព្រះ ។ ទ្រង់ក៏បានមានព្រះបន្ទូលអំពីទីក្រុងរបស់ ហេណុក ផងដែរ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១–៥

*ព្រះយេស៊ូវគ្រីស្ទ ថ្លែងទីបន្ទាល់អំពីតួនាទីរបស់ទ្រង់ ក្នុងនាមជាព្រះរាជបុត្រានៃព្រះ*

នៅពេលអ្នកជួបប្រទះនឹងឧបសគ្គ ឬ ការសម្រេចចិត្តដ៏លំបាកមួយ តើអ្នកនឹងទៅរកនរណាឲ្យផ្ដល់ដំបូន្មានដល់អ្នក ? តើលក្ខណៈសម្បត្តិបែបណាខ្លះ ដែលបុគ្គលនោះត្រូវមាន ដែលផ្ដល់នូវទំនុកចិត្តដល់អ្នក ក្នុងការចែកចាយអារម្មណ៍របស់អ្នក ហើយស្ដាប់តាមដំបូន្មានរបស់គាត់ ?

យើងមុខជាចង់ស្ដាប់តាមបុគ្គល ដែលយើងមានអារម្មណ៍ថាបានយកចិត្តទុកដាក់ចំពោះយើងដោយផ្ទាល់ និង ជាបុគ្គលដែលធ្លាប់មានជោគជ័យក្នុងបញ្ហានោះ ដោយប្រើដំបូន្មានដែលគាត់ផ្ដល់ឲ្យនេះ ។ វិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ បានកើតឡើងនៅចំគ្រា ដែលពួកបរិសុទ្ធថ្ងៃចុងក្រោយ និង មនុស្សដទៃទៀត បានស្ដាប់ និង អានសារលិខិតដែលទាស់នឹងសាសនាចក្រ ។ សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ រួចស្វែងរកស្ថានភាពនានា ដែលពួកបរិសុទ្ធបានជួបប្រទះ ពេលដែលព្រះអម្ចាស់បានប្រទានវិវរណៈនេះដល់ពួកគេ ។

សូមកត់ចំណាំពាក្យ *ចូរប្រុងស្ដាប់* នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១ ។ អ្នកអាចនឹងចង់គូសចំណាំវាទុក ។ ការប្រុងស្ដាប់តាមនរណាម្នាក់ មានន័យថាការស្ដាប់តាមដោយប្រុងប្រយ័ត្ន ហើយវាក៏អាចរួមមានទាំងការស្ដាប់តាម និង ការគោរពប្រតិបត្តិតាមផងដែរ ។ នៅពេលយើងស្ដាប់ព្រះអម្ចាស់យ៉ាងពិតប្រាកដ នោះយើងនឹងធ្វើតាមឱវាទ និងព្រះបញ្ញត្តិរបស់ទ្រង់។ នៅដើមដំបូងនៃវិវរណៈនេះ ព្រះអម្ចាស់បានធ្វើការប្រកាសអំពីតួនាទីរបស់ទ្រង់មួយចំនួន និង កិច្ចខិតខំខ្នែងទ្រង់ក្នុងការជួយដល់យើង ។ នៅពេលយើងអានសេចក្ដីប្រកាសទាំងនេះ យើងអាចរកឃើញមូលហេតុ ដែលយើងត្រូវស្ដាប់តាមព្រះបន្ទូលទ្រង់ ។ សូមរកមើលពាក្យ *ចូរស្ដាប់តាម* និង *ស្ដាប់* នៅក្នុងខគម្ពីរ ដែលអ្នកសិក្សានៅក្នុងមេរៀនថ្ងៃនេះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូល អំពីព្រះអង្គទ្រង់ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

តើការដឹងថា ព្រះយេស៊ូវគ្រីស្ទគឺជាអង្គបង្កបង្កើតផែនដី ដែលជាកន្លែងយើងត្រូវបានបញ្ជូនមកនេះ ជួយយើងឲ្យស្ដាប់តាមអ្វីដែលទ្រង់មានព្រះបន្ទូលយ៉ាងដូចម្ដេចដែរ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:២–៣ រួចស្វែងរកមូលហេតុបន្ថែម ដែលយើងត្រូវស្ដាប់តាមព្រះអង្គសង្គ្រោះ ។ សូមកត់ចំណាំពីភាពបន្ទាន់នៅក្នុង ខទី ២ ។ យើងគួរតែស្ដាប់តាមព្រះអង្គសង្គ្រោះ កាលនៅមានពេលធ្វើតាមអ្វីដែលទ្រង់មានព្រះបន្ទូល ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៣ បង្រៀនយើងថា **ព្រះយេស៊ូវគ្រីស្ទ គឺជាអ្នកគាំទ្រយើងជាមួយនឹងព្រះវរបិតាដែលគង់នៅស្ថានសួគ៌** ។ សូមកត់ចំណាំពាក្យ *ជា* នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៣ ។ តើអ្នកយល់អំពីភាពខុសគ្នារវាងការនិយាយថា « ព្រះយេស៊ូវគ្រីស្ទ *នឹងធ្វើជា* អ្នកគាំទ្ររបស់យើង » និង « ព្រះយេស៊ូវគ្រីស្ទ *ជា* អ្នកគាំទ្ររបស់យើង » ដែរឬទេ ? ព្រះអង្គសង្គ្រោះពុំត្រឹមតែអង្វរជំនួសរឿងក្ដីរបស់យើងនៅឯការជំនុំជម្រះចុងក្រោយនោះទេ ទ្រង់ថែមទាំងឈរជាអ្នកគាំទ្រជារៀងរាល់ថ្ងៃទៀតផង នៅពេលយើងអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ ប្រែចិត្ត ហើយព្យាយាមធ្វើឲ្យមានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយយើង ។ សូមពិចារណាថាតើអ្នកត្រូវការព្រះយេស៊ូវគ្រីស្ទ ឲ្យធ្វើជាអ្នកគាំទ្រអ្វីខ្លះ នៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក ។

ដើម្បីជួយអ្នកឲ្យយល់ពាក្យ *អ្នកគាំទ្រ* និង ទំនាក់ទំនងនៃអ្នកគាំទ្រជាមួយនឹងជនជាប់ចោទ សូមគូសបន្ទាត់ដោយផ្គូផ្គងតួនាទីនៃបុគ្គលនៅខាងឆ្វេង ទៅនឹងអត្ថន័យដ៏ត្រឹមត្រូវនៅខាងស្ដាំ ។

| | |
|---|---|
| ចុងចោទ | បុគ្គលរូបនេះ ត្រូវគេសង្ស័យថា បានប្រព្រឹត្តបទឧក្រិដ្ឋ ។ |
| ចៅក្រម | បុគ្គលរូបនេះ ការពាររឿងក្ដីឲ្យគេ ។ |
| មេធាវី | បុគ្គលរូបនេះ ស្ដាប់សាក្សី ហើយសម្រេចក្ដីស្របទៅតាមច្បាប់ ។ |

សូមស្រមៃថា អ្នកបានប្រព្រឹត្តខុសច្បាស់ ហើយត្រូវគេនាំទៅឈរនៅចំពោះមុខចៅក្រម ។ តើអ្នកនឹងមានអារម្មណ៍យ៉ាងណា ? ហេតុអ្វីបានជាអ្នកមានអំណរគុណ ចំពោះមេធាវី ដែលបានការពារក្ដីឲ្យអ្នក ?

១. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៤–៥ ដោយស្វែងរករបៀបដែលព្រះយេស៊ូវគ្រីស្ទ បំពេញតួនាទីរបស់ទ្រង់ ក្នុងនាមជាអ្នកគាំទ្រ និង អង្វរឲ្យមានសេចក្ដីសង្គ្រោះដល់យើង ។ រួចសូមឆ្លើយសំណួរខាងក្រោមនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីបានជាព្រះយេស៊ូវគ្រីស្ទ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីធ្វើជាអ្នកគាំទ្រយើង ?

ខ. តើព្រះអង្គសង្គ្រោះ បានទូលសុំឲ្យព្រះវរបិតាសួគ៌ទតមើលអ្វី ?



អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានថ្លែងទីបន្ទាល់អំពីចំណាប់អារម្មណ៍របស់ ព្រះអង្គសង្គ្រោះ ចំពោះស្ថានភាពបច្ចុប្បន្ន ក៏ដូចជាការជំនុំជម្រះចុងក្រោយរបស់យើងថា ៖ « ខ្ញុំមានអំណរគុណជាពិសេស ហើយវាមានសារៈសំខាន់ខ្លាំងណាស់ចំពោះខ្ញុំ ដែលខ្ញុំត្រូវអធិស្ឋានទៅកាន់បល្ល័ង្កនៃព្រះគុណនៅគ្រប់គ្រា និង គ្រប់កាលៈទេសៈ ដើម្បីឲ្យព្រះវរបិតាសួគ៌ខ្ញុំស្ដាប់ឮការទូលសុំរបស់ខ្ញុំ ដើម្បីឲ្យព្រះអង្គគាំទ្ររបស់ខ្ញុំ ជាអង្គគ្មានអំពើបាប ដែលបានបង្ហូរព្រះលោហិតរបស់ទ្រង់ នឹងទូលអង្វរសម្រាប់រឿងក្ដីរបស់ខ្ញុំ ។ ( សូមមើល គ. និង ស. ៤៥:៣–៥ ) ។ ខ្ញុំពឹងផ្អែកទាំងស្រុងទៅលើការប្រព្រឹត្តបែបនោះចំពោះព្រះ ដែលទ្រង់ប្រទានដល់កូនចៅទាំងអស់របស់ទ្រង់ ដ្បិតទ្រង់ពិតជាមិនរើសមុខអ្នកណាទេ ហើយអស់អ្នកណាដែលទូលសុំ នោះនឹងបានទទួល » ( I Know in Whom I Have Trusted,” *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៣ ទំព័រ ៨៣ ) ។

របៀបដែលព្រះយេស៊ូវអង្វរជំនួសយើង មានសភាពខុសពីមេធាវីនៅក្នុងតុលាការ ដែលអនុវត្តច្បាប់របស់មនុស្ស ព្រោះទ្រង់បានបង់ថ្លៃការជាប់ទោសចំពោះអំពើបាបស្រេចទៅហើយ ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកមានអារម្មណ៍ដូចម្ដេច អំពីព្រះយេស៊ូវគ្រីស្ទ ក្នុងការដែលទ្រង់គឺជាអង្គគាំទ្ររបស់អ្នក ហើយមិនត្រឹមតែទូលអង្វរសម្រាប់រឿងក្ដីរបស់អ្នកប៉ុណ្ណោះទេ ថែមទាំងបង់ថ្លៃការជាប់ទោសចំពោះអំពើបាបរបស់អ្នកទៀតផងនោះ ។

ខ. តើអ្នកមានអារម្មណ៍ថា ព្រះអង្គសង្គ្រោះមានព្រះទ័យឲ្យអ្នកធ្វើអ្វីខ្លះឲ្យបានកាន់តែប្រសើរជាងមុន ដើម្បីមកឯទ្រង់ ហើយទទួលយកទ្រង់ធ្វើជាអង្គគាំទ្ររបស់អ្នក ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦–១០

*ព្រះអង្គសង្គ្រោះអញ្ជើញមនុស្សទាំងអស់ ឲ្យមកធ្វើសេចក្ដីសញ្ញាដ៏នៅអស់កល្បអស់កាលជានិច្ចជាមួយទ្រង់*

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦–១០ ដោយស្វែងរកមូលហេតុនានា ដែលព្រះអង្គសង្គ្រោះបានប្រទានឲ្យយើង ដើម្បីស្ដាប់តាមទ្រង់ ។

សេចក្ដីសញ្ញាដ៏នៅអស់កល្បអស់កាលជានិច្ចរបស់ព្រះអម្ចាស់ ដែលបានថ្លែងនៅក្នុង ខទី ៩–១០ គឺជា « ភាពពោរពេញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។. . . វាមានសភាពអស់កល្បអស់កាលជានិច្ច ក្នុងន័យដែលថា វាគឺជាសេចក្ដីសញ្ញារបស់ព្រះ ហើយត្រូវបានរីករាយក្នុងគ្រាកាន់កាប់ត្រួតត្រានៃដំណឹងល្អគ្រប់ជំនាន់ ដែលមនុស្សមានឆន្ទៈដើម្បីទទួលយកវា » ( Guide to the Scriptures, New and Everlasting Covenant,"scriptures.lds.org) ។

សូមកត់ចំណាំនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៩ ថា ព្រះយេស៊ូវគ្រីស្ទ បានបញ្ជូនសេចក្ដីសញ្ញាដ៏នៅអស់កល្បអស់កាលជានិច្ច « ដើម្បីធ្វើជាពន្លឺដល់មនុស្សលោក ហើយដើម្បីធ្វើជាបមាណីយដល់រាស្ត្រ [ របស់ទ្រង់ ] . . . ហើយដើម្បីធ្វើជាសារទូតនៅចំពោះព្រះភក្ត្រ [ របស់ទ្រង់ ] ដើម្បីរៀបចំផ្លូវថ្វាយ [ ទ្រង់ ] » ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា វាមានអត្ថន័យដូចម្ដេច ដើម្បី « មក . . . រក » សេចក្ដីសញ្ញានោះចុះ ( គ. និង ស. ៤៥:១០ ) ?

ខ. តើអ្នកធ្លាប់បានឃើញដំណឹងល្អគឺជាពន្លឺ ឬ ជាបមាណីយដល់មនុស្សដទៃ តាមរបៀបណាខ្លះ ?

គ. តើសេចក្ដីសញ្ញាដ៏នៅអស់កល្បអស់កាលជានិច្ច ឬ ភាពពោរពេញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ជួយរៀបចំផ្លូវសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ តាមរបៀបណា ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១១–១៥

*ព្រះអង្គសង្គ្រោះមានព្រះបន្ទូលអំពី ហេណុក និង រាស្ត្ររបស់លោក*

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១១ដោយស្វែងរកការណ៍ ដែលព្រះអម្ចាស់ចែកចាយដល់អ្នកទាំងឡាយណាដែលស្ដាប់តាមទ្រង់ ។



ព្រះអម្ចាស់បានមានព្រះបន្ទូលថា រាស្ត្រមួយចំនួនបានហៅទ្រង់ថា « ព្រះនៃលោកហេណុក » ( គ. និង ស. ៤៥:១១ ) ។ ហេណុកគឺជាព្យាការីដ៏ឆ្នើម ដែលបានរស់នៅពីមុនជំនាន់លោកណូអេ និងសម័យនៃការជន់លិច ។ ផែនដីនៅជំនាន់របស់លោកហេណុកបានគ្របដណ្ដប់ទៅដោយអំពើទុច្ចរិត គឺដូចជាជំនាន់នៃយាងមកវិញជាលើកទីពីររបស់ព្រះអង្គសង្គ្រោះដែរ ប៉ុន្តែ លោកហេណុកបានដឹកនាំក្រុមប្រជារាស្ត្រសុចរិត ដែលបានរស់នៅក្នុងទីក្រុងមួយឈ្មោះថា ទីក្រុង ស៊ីយ៉ូន ។ នៅទីបំផុត ប្រជារាស្ត្រទីក្រុង ស៊ីយ៉ូនត្រូវបាន « បែកចេញពីផែនដី » ឬ ត្រូវបានលើកឡើងទៅឯស្ថានសួគ៌ ដោយព្រោះតែសុចរិតភាពរបស់ពួកគេ ( សូមមើល គ. និង ស. ៤៥:១២ ម៉ូសេ ៧:៦៩ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១២ ដោយស្វែងរកថាតើទីក្រុង ស៊ីយ៉ូន ត្រូវបានរក្សាទុកសម្រាប់អ្វី ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១២–១៤ បង្រៀនយើងថា ព្រះអម្ចាស់បានទទួលប្រជារាស្ត្រទីក្រុង ស៊ីយ៉ូន ឡើងទៅឯទ្រង់ ហើយថាទ្រង់នឹងរក្សាពួកគេទុក « រហូតដល់ថ្ងៃនៃសេចក្ដីសុចរិតនឹងមកដល់ » ។ នៅថ្ងៃនោះ ហេណុក និង រាស្ត្ររបស់លោក នឹងត្រឡប់មកផែនដីវិញ ដើម្បីជួបជាមួយរាស្ត្ររបស់ព្រះអម្ចាស់នៅទីក្រុង យេរូសាឡិមថ្មី ដែលក៏នឹងត្រូវបានហៅថា ទីក្រុង ស៊ីយ៉ូន ដែរ ( សូមអាន ម៉ូសេ ៧:៦២–៦៤ ) ។ ព្យាការីទាំងអស់បានទន្ទឹងរង់ចាំថ្ងៃនោះ ។ ដោយសារតែអំពើទុច្ចរិតនៃប្រជាជនដែលរស់នៅលើផែនដី ទើបថ្ងៃនោះមិនទាន់បានមកដល់នៅឡើយទេ ទោះជាយ៉ាងណាក៏ដោយ បុរសដ៏បរិសុទ្ធជាច្រើនដែលបានទន្ទឹងរង់ចាំថ្ងៃនោះ នឹងបានឃើញថ្ងៃនោះជាប្រាកដ ។

៤. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១៥ ។ បន្ទាប់មកសូមមើលត្រឡប់ទៅ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១–១៤ រួចពិចារណាអំពីតួនាទី ឬ លក្ខណៈសម្បត្តិរបស់ព្រះអង្គសង្គ្រោះ ដែលជួយអ្នកឲ្យមានបំណងស្ដាប់តាមទ្រង់ ។ សូមពន្យល់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលតួនាទី ឬ លក្ខណៈសម្បត្តិរបស់ព្រះអង្គសង្គ្រោះនោះ ជួយអ្នកឲ្យមានបំណងស្ដាប់តាមទ្រង់ ។

គោលការណ៍មួយ ដែលអ្នកអាចរៀនចេញពីខគម្ពីរទាំងនេះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ គឺថា **ការរៀនអំពីព្រះអង្គសង្គ្រោះ និង អំពីអ្វីដែលទ្រង់បានធ្វើសម្រាប់យើង អាចបង្កើនបំណងប្រាថ្នាយើងឲ្យស្ដាប់តាមទ្រង់ ។** ព្រះអម្ចាស់បានណែនាំអំពីព្រះអង្គទ្រង់ ហើយបានអញ្ជើញពួកបរិសុទ្ធឲ្យស្ដាប់តាមទ្រង់ ដោយសារតែមានភាពសំខាន់នៅក្នុងខគម្ពីរដែលនៅសល់ទាំងប៉ុន្មាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១៥–១៦ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ថា ទ្រង់នឹងថ្លែង ហើយព្យាករ ។ តើអ្នកអាចរៀបចំខ្លួនអ្នកយ៉ាងដូចម្ដេច ដើម្បីស្ដាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ នៅពេលអ្នកសិក្សាខគម្ពីរដែលនៅសល់ទាំងប៉ុន្មាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ ដែលមាននៅក្នុងមេរៀនបន្ទាប់ ?

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១–១៥ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១១ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១៦–៧៥

## បុព្វកថា

ពេញមួយប្រវត្តិសាស្ត្រ មនុស្សជាច្រើនបានមានយោបល់ខុសគ្នាអំពីការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ ។ ការណ៍នេះបានកើតឡើងយ៉ាងប្រាកដក្នុងខែ មិនា ឆ្នាំ ១៨៣១ នៅពេលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ ត្រូវបានទទួល ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់ប្រទានសេចក្ដីពិស្ដារអំពីព្រឹត្តិការណ៍ និង ទីសម្គាល់ជាក់លាក់ទាំងឡាយ ដែលទាក់ទងទៅនឹងការយាងមកជាលើកទីពីររបស់ទ្រង់ រួមបញ្ចូលទាំងការស្ថាបនាទីក្រុង យេរូសាឡិមថ្មី ( ឬទីក្រុងស៊ីយ៉ូន ) ។ ព្រះអម្ចាស់ក៏បានណែនាំព្យាការី យ៉ូសែប ស៊្មីធ ឲ្យចាប់ផ្ដើមបកប្រែព្រះគម្ពីរសញ្ញាថ្មី ដើម្បីត្រៀមខ្លួនពួកបរិសុទ្ធចំពោះអ្វីដែលនឹងកើតឡើង ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១៦–៤៦

*ព្រះអង្គសង្គ្រោះបើកសម្ដែងទីសម្គាល់ និង ព្រឹត្តិការណ៍នានា ដែលនឹងកើតឡើងពីមុនការយាងមកជាលើកទីពីររបស់ទ្រង់*

តើអ្នកដឹងអំពីពេលវេលា ដែលព្យុះនឹងបោកបក់មកដល់តាមរបៀបណា ? ហេតុអ្វីបានជាវាមានសារៈសំខាន់ ដើម្បីស្គាល់អំពីទីសម្គាល់ទាំងនោះ ?

អ្នកទាំងឡាយណាដែលស្គាល់អំពីទីសម្គាល់នានានៃព្រឹត្តិការណ៍ដែលនឹងកើតឡើង អាចត្រៀមខ្លួនបានជាស្រេចចំពោះព្រឹត្តិការណ៍នោះ ។ តើទីសម្គាល់ណាខ្លះ ដែលអ្នកត្រូវស្គាល់ ដើម្បីជាស់តឿនខ្លួនឯងថា ព្រឹត្តិការណ៍ខាងក្រោមនេះកំពុងតែកើតឡើង ឬ នឹងកើតឡើង ?

- ថ្ងៃចុងក្រោយបង្អស់
- ការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ

ដូចបានបង្ហាញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១៦ មនុស្សនៅជំនាន់ដែលព្រះយេស៊ូវគ្រីស្ទបានបម្រើនៅក្នុងជីវិតរមែងស្លាប់ ក៏ដូចជាមនុស្សដែលបានរស់នៅជំនាន់របស់ យ៉ូសែប ស៊្មីធ និង ពេលសព្វថ្ងៃនេះ បានចាប់អារម្មណ៍ស្គាល់អំពីព្រឹត្តិការណ៍នានា ដែលនឹងកើតឡើងនៅពីមុនការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ ព្រះអម្ចាស់បានពិពណ៌នាអំពីទីសម្គាល់ ដែលដាស់តឿនយើងអំពីព្រឹត្តិការណ៍ដែលនឹងកើតឡើងនេះ ។ វគ្គបទគម្ពីរជាច្រើននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ គឺជាអ្វីដែលព្រះអម្ចាស់បានបើកសម្ដែងដល់ពួកសិស្សទ្រង់ដែលបានរស់នៅជាមួយទ្រង់ក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ( សូមមើល ម៉ាថាយ ២៤ ) ។

១. ដើម្បីស្វែងរកទីសម្គាល់នានា ដែលព្រះអង្គសង្គ្រោះបានមានព្រះបន្ទូលថានឹងកើតឡើងនៅពីមុនការយាងមកជាលើកទីពីររបស់ទ្រង់ សូមសរសេរសេចក្ដីយោងដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក រួចសរសេរសេចក្ដីយោងនៅលើបន្ទាត់ខុសពីគ្នា ហើយទុកឲ្យមានចន្លោះដើម្បីសរសេរទីសម្គាល់នានា ៖ *គ. និង ស. ៤៥:១៨–២១; គ. និង ស. ៤៥:២២–២៧; គ. និង ស. ៤៥:២៨–៣១, ៣៣; គ. និង ស. ៤៥:៤០–៤៣ ។* បន្ទាប់មក សូមអានខគម្ពីរទៅតាមសេចក្ដីយោងនីមួយៗ ដោយស្វែងរកទីសម្គាល់នានាដែលកើតឡើងនៅពីមុនការយាងមកជាលើកទីពីរ រួចកត់ត្រាទីសម្គាល់ទាំងឡាយដាក់នៅក្បែរសេចក្ដីយោងទាំងនោះ ។ បើអ្នកជ្រើសរើសធ្វើដូច្នេះ សូមគូររូបភាពនៃអ្វីដែលអ្នកបានអាន ជំនួសឲ្យការសរសេរពីទីសម្គាល់នានា ។

ទីសម្គាល់នៃការយាងមកជាលើកទីពីរទាំងនេះមួយចំនួន បានកើតឡើងខ្លះរួចទៅហើយ ។ ឧទាហរណ៍ព្រះវិហារបរិសុទ្ធនៅយេរូសាឡិមត្រូវបានបង្ហាញដោយពួករ៉ូមក្នុងឆ្នាំ ៧០ នៃ គ.ស. ( សូមមើល គ. និង ស. ៤៥:១៨–២១) ។ ឃ្លា « ពេលវេលានៃពួកសាសន៍ដទៃ » នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:២៥ សំដៅទៅលើ ជំនាន់ដែលដំណឹងល្អត្រូវបាននាំយកទៅដល់ពួកសាសន៍ដទៃជាអាទិ៍ ឬ អ្នកទាំងឡាយមិនមែនជាខ្សែស្រឡាយពួកសាសន៍យូដា គឺជាជំនាន់ដែលយើងរស់នៅនាពេលសព្វថ្ងៃនេះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៣៤ ដោយស្វែងរកមើល ថាតើពួកសិស្សមានអារម្មណ៍យ៉ាងដូចម្ដេចនៅអំឡុងពេលការបម្រើរបស់ព្រះអង្គសង្គ្រោះ កាលទ្រង់បានមានព្រះបន្ទូលប្រាប់ពួកគេអំពីរឿងទាំងនេះ ។ តើអ្នកគិតថា ហេតុអ្វីបានជាមនុស្សនាពេលសព្វថ្ងៃនេះ អាចនឹងមានអារម្មណ៍ស្រដៀងគ្នានេះ អំពីទីសម្គាល់ទាំងឡាយនៃការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៣៨ ដោយស្វែងរកការណ៍ដែលយើងនឹងដឹង នៅពេលយើងឃើញទីសម្គាល់កើតឡើង ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៣២, ៣៩ ។ នៅពេលអ្នកសិក្សាខគម្ពីរទាំងនេះ សូមស្វែងរកការណ៍ ដែលអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទនាពេលសព្វថ្ងៃនេះនឹងធ្វើ ដើម្បីត្រៀមខ្លួនឲ្យបានរួចរាល់សម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមមើលទៅ ខទី ៣៩ លេខយោង *ក* ដើម្បីរៀនពាក្យមួយទៀតគឺ « កោតខ្លាច » ។

យោងតាមអ្វីដែលអ្នកបានសិក្សា តើព្រះអម្ចាស់សន្យាយ៉ាងដូចម្ដេច ដល់អ្នកដែលឈរនៅទីបរិសុទ្ធ និង គារវភាពចំពោះទ្រង់ ? សូមបញ្ចប់គោលការណ៍នេះ ៖ **បើយើងឈរនៅទីបរិសុទ្ធ ហើយទន្ទឹងរង់ចាំមើលទីសម្គាល់ នោះយើងនឹង** ។

ជាញឹកញាប់ យើងគិតអំពី « ទីបរិសុទ្ធ » ថាជាទីតាំងសាសនាចក្រមានដូចជា ព្រះវិហារបរិសុទ្ធ ឬ សាលាប្រជុំ ។ នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះ សូមស្វែងរករបៀបមួយផ្សេងទៀត ដែលយើងអាចឈរនៅទីបរិសុទ្ធបាន ៖

> « ‹ ទីបរិសុទ្ធ › អាចមានកត្តាជាច្រើនតម្រូវឲ្យធ្វើជាមួយនឹង *របៀប* ដែលបុគ្គលម្នាក់រស់នៅ ជាជាង *ទីកន្លែង* ដែលបុគ្គលនោះរស់នៅ ។ ប្រសិនបើយើងរស់នៅដោយស្អាតស្អំដោយមានដៃគូជាព្រះវិញ្ញាណបរិសុទ្ធឥតដាច់នោះ យើងនឹងឈរនៅក្នុងទីបរិសុទ្ធមួយហើយ ។. . .
>
> « ទីបរិសុទ្ធស្ថិតនៅគ្រប់ទីកន្លែងទាំងអស់ ជាទីដែលបុគ្គលម្នាក់រីករាយនឹងព្រះវិញ្ញាណនៃព្រះ » (*គោលលទ្ធិ និង សេចក្ដីសញ្ញា សៀវភៅសិក្សារបស់សិស្ស*ការបោះពុម្ពជាលើកទី ២ [ សៀវភៅសិក្សារបស់ប្រព័ន្ធអប់រំសាសនាចក្រ ឆ្នាំ ២០០១ ] ទំព័រ ១៩៦) ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើយើងអាចរស់នៅក្នុងលោកិយនាពេលសព្វថ្ងៃនេះ ហើយនៅតែអាចឈរនៅទីបរិសុទ្ធបានយ៉ាងដូចម្ដេច ?

ខ. តើអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ កោតខ្លាច ឬ គោរពតាមទ្រង់នៅលើមូលដ្ឋានគ្រឹះជាប្រចាំយ៉ាងដូចម្ដេច ? សូមពិពណ៌នាអំពីបុគ្គលម្នាក់ដែលអ្នកស្គាល់ ជាអ្នកដែលប្រព្រឹត្តការណ៍នេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៤៧–៥៩

*ព្រះអង្គសង្គ្រោះបើកសម្ដែងទីសម្គាល់ និង រឿងអច្ឆរិយជាច្រើន ដែលនឹងជាផ្នែកនៃការបង្ហាញព្រះកាយទ្រង់ទៅដល់ពួកសាសន៍យូដា*

នៅពេលព្រះយេស៊ូវគ្រីស្ទយាងត្រឡប់មកវិញ ទ្រង់នឹងបង្ហាញព្រះកាយទៅដល់ក្រុមមនុស្សដ៏ជាក់លាក់ ។ លំដាប់នោះ ទ្រង់នឹងបង្ហាញព្រះកាយក្នុងព្រះចេស្ដា អានុភាព និង សិរីល្អដ៏មហស្ចារ្យ ជារបៀបដែលមនុស្សលោកទាំងអស់នឹងបានឃើញទ្រង់ ។ អំឡុងពេលនៃការបង្ហាញព្រះកាយរបស់ទ្រង់ នោះទ្រង់នឹងឈរលើភ្នំអូលីវ នៅទីក្រុង យេរូសាឡិម ទន្ទឹមនឹងពេលពួកសាសន៍យូដាត្រូវបានគេជិះជាន់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៤៨ ដោយស្វែងរកអ្វីដែលនឹងកើតឡើងនៅលើភ្នំនេះ រួមទាំងផែនដី កាលព្រះអង្គសង្គ្រោះឈរនៅលើនោះ ។

សូមបំពេញតារាងខាងក្រោម ដោយអានខគម្ពីរទាំងឡាយ រួចឆ្លើយនឹងសំណួរដោយប្រើពាក្យពេចន៍របស់អ្នកផ្ទាល់ ៖

| *គ. និង ស. ៤៥:៤៩–៥០* ៖ តើនឹងមានអ្វីកើតឡើងចំពោះសាសន៍ទាំងឡាយនៃផែនដី នៅគ្រានៃការយាងមកជាលើកទីពីរ ? | *គ. និង ស. ៤៥:៥១–៥៣* ៖ ហេតុអ្វីបានជាពួកសាសន៍យូដានឹងយំ នៅពេលព្រះអម្ចាស់យាងត្រឡប់មកវិញ ? |
|---|---|
| | |

ប្រសិនបើអ្នកពុំស្គាល់រឿងប្រដូចនៃស្រ្តីព្រហ្មចារិយទាំងដប់នាក់ទេនោះ សូមអាន ម៉ាថាយ ២៥:១–១៣ ។ តើស្រ្តីព្រហ្មចារិយប្រាំនាក់មានគំនិតដោយរបៀបណា ? សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៤៥:៥៦–៥៧ រួចស្វែងរករបៀបដែលយើងអាចមានគំនិតត្រៀមខ្លួន សម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ។ សូមគិតពីការគូសចំណាំអ្វីដែលអ្នករកឃើញ ។



សូមសរសេរគោលការណ៍ « បើ–នោះ » ដោយពន្យល់អំពីអ្វី ដែលយើងត្រូវតែធ្វើ ដើម្បីមានគំនិត ហើយត្រៀមខ្លួនជាស្រេចសម្រាប់ការយាងមកជាលើកទីពីរ ៖

______________________________

______________________________



អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍អំពីរឿងប្រដូចនេះ និង អំពីអ្វីដែលជាតំណាងឲ្យស្រ្តីព្រហ្មចារិយទាំងដប់នាក់នោះថា ៖ « ចំណោទនៃរឿងប្រដូចនេះ គួរឲ្យភ័យខ្លាច ។ ស្រ្តីព្រហ្មចារិយទាំងដប់នាក់ តំណាងឲ្យសមាជិកនៃសាសនាចក្ររបស់ព្រះគ្រីស្ទ ដ្បិតសមាជិកទាំងអស់គ្នាត្រូវបានអញ្ជើញឲ្យទទួលភោជនាអាហារ ហើយសមាជិកទាំងអស់គ្នាបានដឹង ហើយថា ត្រូវបានអនុញ្ញាតឲ្យចូលទៅ នៅពេលកូនកម្លោះបានមកដល់ ។ ប៉ុន្តែមានតែសមាជិកពាក់កណ្តាលប៉ុណ្ណោះ ដែលត្រៀមខ្លួនជាស្រេចនៅពេលកូនកម្លោះបានមកដល់នោះ » ( Preparation for the Second Coming, » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ៨ ) ។

ប្រធាន ស្ពែនស៊ើរ ដបុលយូ឵ ឃីមប៊ល បានប្រើរឿងប្រដូចនៃស្រ្តីព្រហ្មចារិយទាំងដប់នាក់ ដើម្បីបង្រៀនអំពីរបៀបដែលយើងអាចត្រៀមខ្លួនជាស្រេចសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះថា ៖



« ខ្ញុំជឿថា ស្រ្តីព្រហ្មចារិយទាំងដប់នាក់ តំណាងឲ្យសមាជិកក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ហើយមិនមែនជាមនុស្សទាំងអស់នៅលើផែនដីនេះនោះទេ ។ ស្រ្តីព្រហ្មចារិយទាំងអស់ ទាំងមានគំនិត និង អត់គំនិត ទទួលបានការអញ្ជើញឲ្យទៅទទួលភោជនាអាហារពីធីមង្គលការ ដូច្នេះពួកគេបានដឹងអំពីរបៀបវារៈកម្មវិធី ហើយត្រូវបានដាស់តឿនអំពីទិវាដ៏មានសារៈសំខាន់ដែលនឹងមកដល់នោះ ។. . .

« ពេលកណ្តាលអធ្រាត្របានមកដល់ ! ជាក់ស្តែងនៅពេលកណ្តាលអធ្រាត្រ កាលពុំបានគិតស្មានដល់សោះ នោះកូនកម្លោះក៏បានមកដល់ ។ នៅពេលលោកិយពោរពេញទៅដោយសេចក្តីទុក្ខសោក និង ត្រូវការជំនួយ ប៉ុន្តែហាក់បីដូចជាគ្រានោះត្រូវតែកន្លងហួសទៅ ចំណែកឯសេចក្តីសង្ឃឹមត្រូវរលាយបាត់បង់ លំដាប់នោះ ព្រះគ្រីស្ទនឹងយាងមក ។ ពេលកណ្តាលអធ្រាត្រនៃជីវិត គឺជាគ្រាដែលស្ថានសួគ៌ប្រទានសេចក្តីអំណរដល់មនុស្សកាលពួកគេកំពុងជួបប្រទះនឹងសេចក្តីទុក្ខព្រួយ ។ ប៉ុន្តែ កាលវេលានោះបានមកដល់ ពួកគេពុំមានពេលគ្រប់គ្រាន់ក្នុងការត្រៀមខ្លួនឡើយ ។. . .

« ស្រ្តីព្រហ្មចារិយអត់គំនិតបានសុំស្រ្តីដទៃទៀតឲ្យចែកប្រេងដល់ខ្លួន ប៉ុន្តែ ការត្រៀមខ្លួនជាស្រេចខាងវិញ្ញាណពុំអាចចែកចាយឲ្យបានមួយរំពេចនោះទេ ។ ស្រ្តីព្រហ្មចារិយមានគំនិតបានចេញទៅ បើមិនដូច្នោះទេកូនកម្លោះនឹងពុំមាននរណាមកទទួលឡើយ ។ ពួកគេត្រូវការប្រេងរបស់គេបម្រុងសម្រាប់ខ្លួនគេផ្ទាល់ ដូច្នេះ ពួកគេពុំអាចទុកសម្រាប់ស្រ្តីព្រហ្មចារិយអត់គំនិតបានឡើយ ។ ការទទួលខុសត្រូវបានធ្លាក់ទៅលើខ្លួនគេម្នាក់ៗ ។

« ទង្វើបែបនេះពុំមែនជាអត្តទត្តភាព ឬ ការមិនមានសណ្តានចិត្តនោះទេ ។ ប្រេងដែលយើងត្រូវការដើម្បីស្វែងរកការដឹកនាំ និង បង្កើនចំណេះដឹង មិនអាចចែកចាយបានឡើយ ។ តើយើងអាចចែកចាយការគោរពប្រតិបត្តិចំពោះគោលការណ៍នៃដង្វាយមួយភាគក្នុងដប់ សេចក្តីរម្ងាប់ទុក្ខដែលកើតចេញពីការរស់នៅដោយសុចរិតភាព ឬ ចែកចាយភាពរីកចម្រើននៃចំណេះដឹង បានយ៉ាងដូចម្តេចទៅ ? តើបុគ្គលម្នាក់អាចចែកចាយសេចក្តីជំនឿ ឬ ទីបន្ទាល់បានយ៉ាងដូចម្តេចទៅ ? តើបុគ្គលម្នាក់អាចចែកចាយឥរិយាបថ ឬ បរិសុទ្ធភាព ឬ ចែកចាយបទពិសោធន៍ក្នុងបេសកកម្ម បានយ៉ាងដូចម្តេចទៅ ?

តើបុគ្គលម្នាក់អាចចែកចាយអាទិភាព ដើម្បីចូលក្នុងព្រះវិហារបរិសុទ្ធបានយ៉ាងដូចម្ដេចទៅ ? បុគ្គលម្នាក់ៗត្រូវតែមានប្រេងនោះផ្ទាល់ខ្លួន ។

« ស្ត្រីព្រហ្មចារិយអត់គំនិត ពុំបានផ្តោតអារម្មណ៍ទៅលើការទិញប្រេងនោះទេ ។ ពួកគេដឹងថា ពួកគេគួរតែមានប្រេង ។ ពួកគេបានពន្យារពេលឲ្យកន្លងហួសទៅធម្មតា ដោយពុំបានដឹងអំពីពេលវេលាដែលកូនកម្លោះនឹងមកដល់ឡើយ ។

« ក្នុងរឿងប្រដូចនោះ ប្រេងអាចរកទិញបាននៅឯផ្សារ ។ នៅក្នុងជីវិតយើង ប្រេងនៃការត្រៀមខ្លួនជាស្រេច ស្រក់មកមួយតំណក់ម្តងៗតាមរយៈការរស់នៅដោយសុចរិត ។ ការចូលរួមក្នុងការប្រជុំសាក្រាម៉ង់ បន្ថែមប្រេងទៅក្នុងចង្កៀងរបស់យើងមួយតំណក់ម្តងៗអស់ជាច្រើនឆ្នាំ ។ ការតមអាហារ ការអធិស្ឋានជាគ្រួសារ ការបង្រៀនតាមផ្ទះ ការគ្រប់គ្រងលើចំណង់ខាងសាច់ឈាម ការផ្សាយដំណឹងល្អ ការសិក្សាព្រះគម្ពីរ– ទង្វើនៃការលះបង់នីមួយៗ និង ការគោរពប្រតិបត្តិ គឺជាដំណក់ប្រេងដែលបានស្រក់បន្ថែមទៅក្នុងដបប្រេងរបស់យើង ។ ទង្វើនៃការមានសណ្ដានចិត្តល្អ ការថ្វាយដង្វាយផ្សេងៗ និង ដង្វាយមួយភាគក្នុងដប់ គំនិត និង ទង្វើបរិសុទ្ធ អាពាហ៍ពិពាហ៍ក្នុងសេចក្ដីសញ្ញាសម្រាប់ភាពដ៏នៅអស់កល្បជានិច្ច— ការណ៍ទាំងនេះរួមចំណែកយ៉ាងសំខាន់ផងដែរដល់កំណក់ប្រេង ដែលយើងអាចចាក់ចូលទៅក្នុងចង្កៀងរបស់យើង ដែលជិតរលត់ទៅហើយនោះនៅពាក់កណ្ដាលអធ្រាត្រ » ( *Faith Precedes the Miracle* [ ឆ្នាំ ១៩៧២ ] ទំព័រ ២៥៣–៥៦ ) ។

៣. សូមសូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច តាមរយៈការទទួលយកសេចក្ដីពិត និង ការយកព្រះវិញ្ញាណបរិសុទ្ធធ្វើជាអង្គដឹកនាំ ?

ប្រធាន ប៊យដ៏ ឃេ ផាកកឺ ប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានថ្លែងទីបន្ទាល់ អំពីសារៈសំខាន់នៃការមានព្រះវិញ្ញាណគង់នៅជាមួយក្នុងគ្រាលំបាកថា ៖



« យើងរស់នៅក្នុងគ្រាដ៏លំបាក—ដែលជាគ្រាដ៏លំបាកពេកពន់ ។ យើងសង្ឃឹម យើងអធិស្ឋាន សូមឲ្យស្ថានភាពកាន់តែប្រសើរឡើង ។ ប៉ុន្តែការណ៍នោះមិនកើតឡើងទាល់តែសោះ ។ ការព្យាករណ៍បានប្រាប់យើងថាដូច្នោះ ។ យើងនឹងមិនធ្វើជាមនុស្ស ក្រុមគ្រួសារ ឬ បុគ្គល ដែលរួចចាកផុតពីការសាកល្បងដែលនឹងកើតឡើងនោះទេ ។. . .

« យើងមិនត្រូវរស់នៅដោយកិតភ័យនឹងអនាគតឡើយ ។ យើងមានគ្រប់ហេតុផលដើម្បីបានរីករាយ និង ហេតុផលតូចបំផុតដើម្បីនឹងកិតភ័យ ។ បើយើងធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណ នោះយើងនឹងមានសុខសុវត្ថិភាព ទោះជាអនាគតទៅជាយ៉ាងក៏ដោយ ។ យើងនឹងត្រូវបានបង្ហាញនូវអ្វីដែលត្រូវធ្វើ » ( « The Cloven Tongues of Fire, » *Ensign* ខែ ឧសភា ឆ្នាំ ២០០០ ទំព័រ ៨ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦០–៦១

*ព្រះអម្ចាស់ណែនាំព្យាការី យ៉ូសែប ស្ម៊ីធ ឲ្យចាប់ផ្តើមការបកប្រែរបស់លោកលើព្រះគម្ពីរសញ្ញាថ្មី*

សូមអាន ឬ ដកស្រង់ចេញពីមាត្រានៃសេចក្ដីជំនឿទីប្រាំបី ។ តើឃ្លា « បើសិនជាបានបកប្រែត្រឹមត្រូវ » ណែនាំយើងដូចម្ដេចអំពីព្រះគម្ពីរប៊ីប ? យ៉ូសែប ស្ម៊ីធ បានបើកទៅវគ្គបទគម្ពីរនៅក្នុងព្រះគម្ពីរប៊ីប នៅកាលដែលលោកបានព្យាយាម ដើម្បីឲ្យបានដឹងថាតើសាសនាចក្រមួយណាដែលត្រូវចូលរួម ។ លោកស្រឡាញ់ព្រះគម្ពីរប៊ីប ហើយបានរកឃើញការលួងលោមចិត្តចេញពីព្រះបន្ទូលនៅក្នុងនោះ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលលោកសិក្សាអំពីវានោះ លោកបានកត់សម្គាល់ថាមានកំហុស និង ភាពផ្ទុយគ្នាទាំងឡាយ ហើយបានដឹងថា ព្រះបន្ទូលមួយចំនួនត្រូវបានដកចេញ ឬ មិនពេញលេញ ហើយលោកបានពន្យល់ថា « វាបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ចំណុចសំខាន់ជាច្រើនទាក់ទងនឹងសេចក្ដីសង្គ្រោះរបស់មនុស្សលោក ត្រូវបានដកចេញពីព្រះគម្ពីរប៊ីប ឬ បាត់បង់ពីមុនព្រះគម្ពីរនេះត្រូវបានចងក្រងឡើង » (*ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* [ ឆ្នាំ ២០០៧ ] ទំព័រ ២១៧ សូមមើលផងដែរ Bible Dictionary, Bible» ) ។

លោកក៏បានមានប្រសាសន៍ផងដែរថា ៖ « ខ្ញុំជឿលើព្រះគម្ពីរប៊ីប បើសិនជាវាត្រូវបានសរសេរដោយដងប៉ាកានៃអ្នកនិពន្ធដើម ។ អ្នកបកប្រែគ្មានវិជ្ជាជីវៈ អ្នកចម្លងដោយគ្មានការយកចិត្តទុកដាក់ ឬ ពួកសង្ឃដែលក្លែងបន្លំ និង ពុករលួយ បានបង្កើតឲ្យមានកំហុសជាច្រើន » (*Teachings: Joseph Smith,* ទំព័រ ២០៧ សូមមើលផងដែរ នីហ្វៃទី១ ១៣:២៥–២៩ ) ។

នារដូវស្លឹកឈើជ្រុះឆ្នាំ ១៨៣០ ព្រះអម្ចាស់បានបញ្ជាឲ្យព្យាការី យ៉ូសែប ស្ម៊ីធ បកប្រែព្រះគម្ពីរប៊ីប ។ « ការបកប្រែ » នេះមិនមែនធ្វើឡើងចេញពីភាសាមួយទៅភាសាមួយទៀតនោះទេ ហើយព្យាការីក៏មិនមានសំណៅព្រះគម្ពីរប៊ីបដើមដើម្បីបកប្រែដែរ ។ ផ្ទុយទៅវិញ លោកបានអាន ហើយសិក្សាវគ្គបទគម្ពីរចេញពីកំណែថ្មីនៃព្រះគម្ពីរប៊ីបរបស់ស្ដេចជេមស៍ ហើយបានធ្វើកំណែ និង ការបន្ថែមតាមការបំផុសគំនិតពីព្រះវិញ្ញាណ ។ ដោយមានការពិនិត្យឡើងវិញដ៏បំផុសគំនិត ការបកប្រែរបស់ព្យាការី

យ៉ូសែប ស្ម៊ីធ ( JST ) បានប្រទានពរដល់ពិភពលោក ដោយបានបញ្ជាក់យ៉ាងច្បាស់អំពីអត្ថន័យនៃគោលលទ្ធិក្នុងព្រះគម្ពីរប៊ីប ជាពិសេសអំពីបេសកកម្មនៃព្រះយេស៊ូវគ្រីស្ទ និង និស្ស័យនៃព្រះ ។

នៅពេលវិវរណៈដែលមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥ ត្រូវបានប្រទានឲ្យនៅថ្ងៃទី ៧ ខែ មិនា ឆ្នាំ ១៨៣១ យ៉ូសែប ស្ម៊ីធ បានធ្វើការត្រួតពិនិត្យឡើងវិញដ៏បំផុសគំនិតលើព្រះគម្ពីរសញ្ញាចាស់ ។ នៅថ្ងៃបន្ទាប់ពីយ៉ូសែប បានទទួលវិវរណៈនេះ លោកបានចាប់ផ្ដើមបកប្រែព្រះគម្ពីរសញ្ញាថ្មី ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦០–៦១ ដើម្បីស្វែងរកមូលហេតុ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦២–៦៤

*ពួកបរិសុទ្ធត្រូវបានព្រមានទុកជាមុន ឲ្យទៅជួបជុំគ្នានៅភូមិភាគខាងលិចទាំងឡាយ*

ព្រះអម្ចាស់បានណែនាំឲ្យពួកបរិសុទ្ធផ្លាស់ទៅភូមិភាគខាងលិច « ពីដែនដីខាងកើត » ( គ. និង ស. ៤៥:៦៤ ) ។ សូមមើលតំបន់នេះ នៅក្នុងផែនទីខាងក្រោម ។




សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦២–៦៤ ដើម្បីស្វែងរកមូលហេតុ ដែលព្រះអម្ចាស់បានបញ្ជាឲ្យពួកបរិសុទ្ធទ្រង់ទៅជួបជុំគ្នានៅ « ភូមិភាគខាងលិចទាំងឡាយ » ( គ. និង ស. ៤៥:៦៤ ) ។

តើព្រះអម្ចាស់មានព្រះបន្ទូលអំពីអ្វីទាក់ទងនឹងឃ្លា « គឺនៅមាត់ទ្វារ » ( គ. និង ស. ៤៥:៦៣ ) ?

សូមពិចារណាអំពីអត្ថន័យនៃការប្រៀបធៀបនៃឃ្លា « គឺនៅមាត់ទ្វារ » ។

ក្នុងឆ្នាំ ១៨៣១ ព្រំដែនភូមិភាគខាងលិចនៃសហរដ្ឋអាមេរិក លាតសន្ធឹងលើព្រំប្រទល់នៃរដ្ឋ មិសសួរី ។ ពេលក្រោយមកទៀត ព្រះអម្ចាស់បានដឹកនាំពួកបរិសុទ្ធទៅកាន់តែឆ្ងាយនៅប៉ែកខាងលិច—ដល់ទីតាំងមួយដែលត្រូវបានស្គាល់ថាជារដ្ឋ យូថាហ៍ ។ នៅពេលពួកបរិសុទ្ធបានគោរពប្រតិបត្តិតាមឱវាទរបស់ព្រះអម្ចាស់ នោះពួកគេត្រូវបានដឹកនាំឲ្យចេញពីសេចក្ដីវិនាសទាំងឡាយនៃសង្គ្រាមស៊ីវិល ក្នុងប្រទេសអាមេរិក ( ១៨៦១–៦៥ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦៥–៧៥

*ព្រះអម្ចាស់ពិពណ៌នាអំពីទីក្រុង យេរ៉ូសាឡិមថ្មី ( ទីក្រុង ស៊ីយ៉ូន )*

បើអ្នកអាចរស់នៅទីណាក៏បាននោះ តើអ្នកនឹងចង់រស់នៅទីណា ? ហេតុអ្វី ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦៥–៦៧ ដោយស្វែងរកឈ្មោះនៃដែនដីកេរអាករ និង មូលហេតុនានាដែលធ្វើឲ្យវាក្លាយជាដែនដីដែលគួរឲ្យចង់រស់នៅ ។

៤. សូមធ្វើបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវមូលហេតុដែលទីក្រុង យេរ៉ូសាឡិមថ្មី ជាទីតាំងដែលអ្នកចង់រស់នៅ ។

ខគម្ពីរទាំងនេះបង្រៀនថា **ទីក្រុង យេរ៉ូសាឡិមថ្មី នឹងត្រូវក្លាយជាទីកន្លែងនៃសន្តិភាព និង សុខសុវត្ថិភាព ហើយសិរីល្អនៃព្រះអម្ចាស់នឹងស្ថិតនៅទីនោះ ។** នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦៧ សូមកត់ចំណាំអំពីអ្វីដែលនឹងស្ថិតនៅទីនោះ

បន្ថែមពីលើសិរីល្អនៃព្រះអម្ចាស់ ។ តើព្រះអម្ចាស់បានមានព្រះបន្ទូលថា អ្វីជាលទ្ធផលនៃការមាន « សេចក្ដីកោតខ្លាចដល់ព្រះអម្ចាស់ » ក៏នឹងមានវត្តមាននៅទីនោះដែរនោះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:៦៨–៧១ ដោយស្វែងរកមើលថា នរណាដែលនឹងទៅជួបជុំគ្នានៅឯទីក្រុងយេរ៉ូសាឡិមថ្មី ( ទីក្រុង ស៊ីយ៉ូន ) ។

៥. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមបញ្ចប់សេចក្ដីថ្លែងការណ៍នេះ ៖ *ដោយសារតែការណ៍ដែលខ្ញុំបានរៀននៅថ្ងៃនេះ នោះខ្ញុំនឹងត្រៀមខ្លួនសម្រាប់ព្រឹត្តិការណ៍ដែលនឹងកើតឡើងដោយ . . .*

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៥:១៦–៧៥ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១១ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦

## បុព្វកថា

វិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦ ត្រូវបានទទួលនៅថ្ងៃទី ៨ ខែ មិនា ឆ្នាំ ១៨៣១—គឺជិតមួយឆ្នាំ ក្រោយពីសាសនាចក្រត្រូវបានបង្កើតឡើង ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានដាស់តឿនពួកបរិសុទ្ធថា ការប្រជុំទាំងឡាយនៅក្នុងសាសនាចក្រ គឺត្រូវធ្វើឡើងដោយព្រះវិញ្ញាណ ហើយទ្រង់បានគូសសម្គាល់ថា មនុស្សដែលមិនមែនជាសមាជិកសាសនាចក្រ មិនគួរត្រូវបានដេញចេញពីការប្រជុំជាសាធារណៈឡើយ ។ ព្រះអម្ចាស់ក៏បានពន្យល់ អំពីគោលបំណងនៃអំណោយទានទាំងឡាយនៃព្រះវិញ្ញាណផងដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:១–៦

*ព្រះអម្ចាស់ណែនាំពួកបរិសុទ្ធ ស្ដីពីការប្រជុំទាំងឡាយនៅក្នុងសាសនាចក្រ*

សូមស្រមៃថា អ្នកត្រូវបានស្នើឲ្យរៀបចំការប្រជុំសាក្រាម៉ង់ទាំងមូល ។ តើអ្នកនឹងជ្រើសរើសចម្រៀង អ្នកអធិស្ឋាន ប្រធានបទការឡើងនិយាយ អ្នកឡើងនិយាយ និង លំដាប់លំដោយនៃការឡើងនិយាយ ដោយរបៀបណា ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:១–២ ដោយស្វែងរកសេចក្ដីណែនាំ ដែលព្រះអម្ចាស់បានប្រទាន អំពីរបៀបដែលការប្រជុំទាំងឡាយត្រូវបានដឹកនាំ ។ ពាក្យ *ដឹកនាំ* នៅក្នុង ខទី ២ មានបញ្ចូលទាំងការរៀបចំ និង ការដឹកនាំការប្រជុំទាំងឡាយនៅក្នុងសាសនាចក្រ ។

១. សូមពិពណ៌នាដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ថាតើអ្នកគិតថា ការប្រជុំមួយមានសភាពដូចម្ដេច នៅពេលវាត្រូវបាន « ដឹកនាំ និង ណែនាំដោយព្រះវិញ្ញាណបរិសុទ្ធ » ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

   ក. តើថ្នាក់ដឹកនាំ និង សមាជិកសាសនាចក្រអាចនឹងត្រូវធ្វើអ្វី ដើម្បីឲ្យការប្រជុំក្នុងសាសនាចក្រត្រូវបានដឹកនាំ និង ណែនាំដោយព្រះវិញ្ញាណបរិសុទ្ធ ?

   ខ. តើអ្នកត្រូវធ្វើអ្វី ដើម្បីនាំឲ្យមានអានុភាពនៃព្រះវិញ្ញាណ ស្ថិតនៅក្នុងការប្រជុំក្នុងសាសនាចក្រ ?

សូមគូសចំណាំពាក្យ ឬ ឃ្លាដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:២ ដែលបង្រៀនអំពីគោលការណ៍ដូចតទៅនេះ ៖ **ថ្នាក់ដឹកនាំសាសនាចក្រត្រូវតែបានណែនាំដោយព្រះវិញ្ញាណបរិសុទ្ធ នៅពេលពួកគាត់ដឹកនាំសាសនាចក្រ ។**

សូមគិតអំពីទីកន្លែងមួយចំនួនដែលអ្នកធ្លាប់បានឃើញស្លាកដែលមានឃ្លា « សូមស្វាគមន៍ភ្ញៀវទស្សនា » ។ សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦ ដោយស្វែងរកអ្នកដែលពួកបរិសុទ្ធបានអនុញ្ញាតឲ្យចូលរួមក្នុងការប្រជុំទាំងឡាយរបស់ពួកគេ ។ បន្ទាប់មក សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៣–៦ ដើម្បីស្វែងរកឃ្លា និងពាក្យទាំងឡាយដែលបង្ហាញថា **ព្រះអម្ចាស់បានបញ្ជាយើងឲ្យស្វាគមន៍ដល់មនុស្សទាំងអស់មកដល់ការប្រជុំជាសាធារណៈរបស់យើង ។** អ្នកអាចដឹងរួចមកហើយថា ឃ្លា « សូមស្វាគមន៍ភ្ញៀវទស្សនា » ត្រូវបានសរសេរនៅខាងមុខសាលាប្រជុំនៃសាសនាចក្រ ។

សូមពិចារណាអំពីស្ថានភាពដូចតទៅនេះ ៖ យុវនារីម្នាក់ទៅលេងវួដថ្មីមួយ ជាមួយក្រុមគ្រួសាររបស់នាងជាលើកទីមួយ ។ បន្ទាប់ពីការប្រជុំសាក្រាម៉ង់ មានសមាជិកក្នុងវួដម្នាក់ មកទទួលរាក់ទាក់ក្រុមគ្រួសារនោះ ហើយបង្ហាញពួកគេអំពីថ្នាក់សាលាថ្ងៃអាទិត្យ ។ គាត់បាននាំយុវនារីរូបនោះចូលទៅក្នុងថ្នាក់ ហើយណែនាំនាងឲ្យស្គាល់គ្រូបង្រៀន ។ យុវជន និង យុវនារីនៅក្នុងថ្នាក់នោះ ទទួលយុវនារីនោះបានតែមួយភ្លែត ហើយបានបន្តជជែកគ្នាតែក្នុងចំណោមគ្នាគេ ដោយមិនអើពើពីនាងឡើយ ។

តើស្ថានភាពនេះអាចមានសភាពខុសគ្នាយ៉ាងដូចម្ដេច ប្រសិនបើសិស្សក្នុងថ្នាក់សាលាថ្ងៃអាទិត្យនោះ យល់ច្បាស់អំពីព្រះបញ្ញត្តិក្នុងការស្វាគមន៍មនុស្សទាំងអស់មកដល់ការប្រជុំជាសាធារណៈនោះ ?

៣. សូមធ្វើបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមធ្យោបាយមួយចំនួន ដែលអ្នកអាចជួយដល់មនុស្សដែលមិនមែនជាសមាជិកសាសនាចក្រ សមាជិកដែលពុំបានទៅព្រះវិហារអស់មួយរយៈ សមាជិកថ្មីនៅក្នុងវួដ ឬ សាខា និង ភ្ញៀវទស្សនា ឲ្យមានអារម្មណ៍ថាមានគេទទួលស្វាគមន៍ ។

មធ្យោបាយមួយចំនួន ដែលអ្នកបានលើកឡើង អាចជាការពិបាកក្នុងការប្រព្រឹត្ត ប៉ុន្តែ សូមគិតអំពីពេលដែលអ្នកបានចូលរួមក្នុងការប្រជុំ ឬ សកម្មភាពនៅក្នុងវួដ ឬ សាខាផ្សេងទៀតក្នុងសាសនាចក្រ ។ តើសមាជិកសាសនាចក្រដទៃទាំងនោះបានធ្វើអ្វី ឬ អ្វីដែលអ្នកនឹងចង់ឲ្យពួកគេធ្វើ ដើម្បីជួយអ្នកឲ្យមានអារម្មណ៍ថាមានគេស្វាគមន៍ ? សូមគិត ហើយអធិស្ឋានអំពីរបៀបដែលអ្នកអាចជួយមនុស្សដទៃ ឲ្យមានអារម្មណ៍ថាកាន់តែមានគេស្វាគមន៍នៅឯការប្រជុំ និង សកម្មភាពទាំងឡាយនៃសាសនាចក្រ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៧–៣៣

*ព្រះអម្ចាស់ពន្យល់ អំពីគោលបំណងនៃអំណោយទានទាំងឡាយនៃព្រះវិញ្ញាណ*

តើការដែលត្រូវគេបញ្ឆោតមានន័យដូចម្ដេច ? តើអ្នកអាចគិតអំពីគ្រាមួយ កាលអ្នកមានអារម្មណ៍ថា ត្រូវបានគេបញ្ឆោតដែរឬទេ ? តើយើងអាចធ្វើអ្វីខ្លះ ដើម្បីចៀសវាងពីការដែលត្រូវគេបញ្ឆោត ?

នៅពេលព្យាការី យ៉ូសែប ស៊្មីធ បានមកដល់រដ្ឋ អូហៃអូ លោកបានឃើញថាមានឫកពារចម្លែក និង ជ្រុលនិយមនៅក្នុងសមាជិកមួយចំនួននៃសាសនាចក្រ ឧទាហរណ៍ សមាជិកខ្លះបានអះអាងថា ប្រព្រឹត្តទៅនៅក្រោមអានុភាពនៃព្រះវិញ្ញាណ ប៉ុន្តែ បង្ហាញចេញឫកពារដែលពុំចុះសម្រុងទៅនឹងព្រះវិញ្ញាណបរិសុទ្ធ ។ ថ្នាក់ដឹកនាំ និង សមាជិកដទៃទៀត បានសង្ស័យថា ឫកពារនោះបានមកពីអានុភាពរបស់អារក្សអាសោចិ៍ ។ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៧–៨ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានប្រទានឱវាទដល់ពួកបរិសុទ្ធទ្រង់ឲ្យធ្វើ ដើម្បីពួកគេនឹងមិនត្រូវបញ្ឆោតដោយស្មារតីក្លែងបន្លំ ឬ គោលលទ្ធិខុសឆ្គង ។

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៧–៨ តើអ្វីទៅ ដែលអាចជួយយើងឲ្យចៀសវាងពីការដែលត្រូវគេបញ្ឆោតបាន ?

ខ. ហេតុអ្វីបានជាអ្នកគិតថា ការណ៍នោះអាចជួយបុគ្គលម្នាក់មិនឲ្យគេបញ្ឆោតបាន ?

គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៧ បង្រៀនយើងអំពីគោលការណ៍ដូចតទៅនេះ ៖ **នៅពេលយើងធ្វើតាមការដឹកនាំនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងគ្រប់ភាពបរិសុទ្ធ ហើយធ្វើសកម្មភាពទាំងអស់ដោយនូវការអធិស្ឋាន និង សេចក្ដីថ្លែងអំណរគុណ នោះយើងអាចចៀសវាងពីការដែលត្រូវគេបញ្ឆោតបាន ។**

អ្នកអាចនឹងចង់គូសចំណាំនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៨ នូវការណ៍ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថា យើងនឹងស្វែងរកដោយស្មោះត្រង់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៩–១២, ២៦ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់មានព្រះទ័យឲ្យយើងយល់ដឹងអំពីអំណោយទានទាំងឡាយនៃព្រះវិញ្ញាណ ។ ( អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ) ។ យោងតាមអ្វីដែលអ្នកបានរៀនចេញពីខគម្ពីរទាំងនេះ សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ៖ **បើយើងស្វែងរកអំណោយទានទាំងឡាយដោយស្មោះត្រង់** ។

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលអ្នកគិតថា វាមានសារៈសំខាន់ ដែលយើងស្វែងរកអំណោយទានខាងវិញ្ញាណដើម្បីជាប្រយោជន៍ដល់កូនចៅរបស់ព្រះ ជាជាងដើម្បីគោលបំណងដ៏អាត្មានិយម ។ បន្ទាប់មក សូមឆ្លើយសំណួរដូចតទៅនេះ ៖ យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:១១–១២ ហេតុអ្វីបានជាអំណោយទានខាងវិញ្ញាណនៃបុគ្គលម្នាក់ៗ មានសារៈសំខាន់ចំពោះសាសនាចក្រ ? ( សូមមើលផងដែរ កូរិនថូស ទី១ ១២ ) ។

ទោះជាអំណោយទានខាងវិញ្ញាណរបស់យើងអាចមានច្រើនខុសៗគ្នាក្ដី ក៏សាសនាចក្រព្រះអម្ចាស់ត្រូវការពួកគេទាំងអស់គ្នាដែរ ។ មនុស្សគ្រប់រូបមានតួនាទី និង ការទទួលខុសត្រូវមួយ ក្នុងការស្ថាបនានគរព្រះនៅលើផែនដី ។ សូមសិក្សាអំណោយទានទាំងឡាយខាងវិញ្ញាណ ដែលព្រះអម្ចាស់បានប្រទាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:១៣–២៧ ។ អ្នកអាចនឹងចង់គូសចំណាំនូវអំណោយទានទាំងនោះ ។

ដើម្បីជួយអ្នកឲ្យយល់កាន់តែច្បាស់អំពីអំណោយទានទាំងឡាយខាងវិញ្ញាណទាំងនេះ សូមផ្គូផ្គងអំណោយទានដែលមាននៅក្នុងតារាងខាងក្រោម ទៅនឹងសេចក្ដីពន្យល់ដែលត្រូវនឹងវា ។ ( ចម្លើយមាននៅចុងមេរៀន ) ។

| អំណោយទាន | សេចក្ដីពន្យល់ |
|---|---|
| ____ ១. អំណោយទាន « ឲ្យដឹងពីការសម្ដែងផ្សេងៗពីគ្នា » ( គ. និង ស. ៤៦:១៥ ) | ក. អំណោយទាននេះក៏សម្ដែងឡើងដូចគ្នានៅចំពោះពួកអ្នកផ្សព្វផ្សាយសាសនា ដែលអាចរៀនចេះ ហើយយល់ភាសាបានយ៉ាងឆាប់រហ័សដែរ ។ |
| ____ ២. អំណោយទាន « ឲ្យដឹងពីការងារផ្សេងៗពីគ្នា » ( គ. និង ស. ៤៦:១៦ ) | ខ. អំណោយទាននេះអនុញ្ញាតឲ្យបុគ្គលម្នាក់ស្គាល់ ឬ យល់អំពីបំណងដ៏ពិត និង ហេតុផលដែលបានលាក់ទុក ។ វាជួយឲ្យបុគ្គលម្នាក់មើលឃើញសេចក្ដីអាក្រក់ដែលលាក់បាំង ហើយមើលឃើញសេចក្ដីល្អនៅក្នុងមនុស្សដទៃ ។ |
| ____ ៣. អំណោយទាននៃ « ការចេះសង្កេតស្គាល់វិញ្ញាណទាំងឡាយ » ( គ. និង ស. ៤៦:២៣ ) | គ. ជាញឹកញាប់ អំណោយទាននេះ សម្ដែងចេញនៅក្នុងថ្នាក់ដឹកនាំ ដែលស្គាល់ពីរបៀបដែលអំណោយទានរបស់មនុស្សដទៃអាចមានប្រយោជន៍ដើម្បីបម្រើក្នុងតំណែងនានា ទោះជាអំណោយទានទាំងនោះមានសភាពខុសៗពីគ្នាយ៉ាងណាក្ដី ។ |
| ____ ៤. អំណោយទាន«ឲ្យចេះនិយាយភាសាដទៃផ្សេងៗ» និង « បកប្រែភាសាដទៃ » ( គ. និង ស. ៤៦:២៤–២៥ ) | ឃ. អំណោយទាននេះ សម្ដែងចេញក្នុងសមត្ថភាពរបស់បុគ្គលម្នាក់ ដើម្បីឲ្យឃើញភាពខុសប្លែកពីគ្នារវាងអំណោយទានដ៏ពិតប្រាកដ ឬ ដំណើរការនៃព្រះវិញ្ញាណ និង វិញ្ញាណក្លែងបន្លំ គោលលទ្ធិខុសឆ្គង ឬ ព្រះបញ្ញត្តិក្លែងក្លាយ ។ |

បញ្ជីនៃអំណោយទានទាំងឡាយនៃព្រះវិញ្ញាណ ដែលមានលើកឡើងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦ គ្រាន់តែជាអំណោយទានមួយចំនួននៃអំណោយទានទាំងឡាយដែលមានតែប៉ុណ្ណោះ ។ អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ថា ៖ « អំណោយទានទាំងឡាយខាងវិញ្ញាណមានច្រើនសន្ធឹកសន្ធាប់ និង មិនចេះចប់មិនចេះហើយឡើយ ។ អំណោយទានទាំងឡាយដែលមានសម្ដែងចេញនោះ គឺជាការបង្ហាញឲ្យឃើញអំពីការចាក់បង្ហូរព្រះគុណដ៏ឥតព្រំដែន ដែលព្រះដ៏ប្រកបដោយសេចក្ដីមេត្តាករុណា ប្រទានដល់បុគ្គលដែលស្រឡាញ់ ហើយបម្រើទ្រង់ » ( *A New Witness for the Articles of Faith* [ ឆ្នាំ ១៩៨៥ ] ទំព័រ ៣៧១ ) ។

តើអ្នកអាចគិតអំពីអំណោយទានទាំងឡាយខាងវិញ្ញាណ ដែលអ្នកធ្លាប់ឃើញ ឬ អាចលើកឡើងពីអំណោយទានណាដែលមិនមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦ ដែរឬទេ ?

ប្រសិនបើអ្នកបានទទួលពររបស់លោកអយ្យកោហើយនោះ ព្រះអម្ចាស់អាចនឹងបានធ្វើបញ្ជីអំណោយទានមួយចំនួន ដែលទ្រង់បានប្រទានឲ្យអ្នក ។ អ្នកក៏អាចនឹងទទួលបទពិសោធន៍នៃអំណោយទានទាំងឡាយខាងវិញ្ញាណដែរ នៅពេលអ្នកបម្រើព្រះវរបិតាសួគ៌ និង កូនចៅទ្រង់នៅក្នុងការហៅនានានៅក្នុងសាសនាចក្រ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦ បង្រៀនថាអស់អ្នកដែលត្រូវបានហៅឲ្យ « មើលគន់លើសាសនាចក្រ » ត្រូវបានប្រទានឲ្យនូវអំណោយទានដើម្បីធ្វើការវិនិច្ឆ័យ ថាតើអំណោយទានទាំងឡាយខាងវិញ្ញាណមួយណាដែលបានមកពីព្រះ ( សូមមើល គ. និង ស. ៤៦:២៧ ) ។ អ្នកអាចទុកចិត្តលើសមត្ថភាពប៊ីស្សពរបស់អ្នក ដើម្បីញាណដឹងអំពីអំណោយទានរបស់អ្នក និង តំណែងដែលអ្នកអាចមានលទ្ធភាពបម្រើបានយ៉ាងល្អបំផុត ហើយប្រទានពរដល់មនុស្សដទៃនៅក្នុងសាសនាចក្រ ទោះជាអ្នកពុំទាន់ដឹងអំពីអំណោយទានទាំងនោះក្ដី ។

វាក៏អាចនឹងមានប្រយោជន៍ផងដែរ ដើម្បីយល់ដឹងឲ្យបានកាន់តែច្បាស់អំពីអំណោយទានខាងភាសា ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនអំពីអំណោយទាននៃព្រះវិញ្ញាណមួយនេះដូច្នេះថា ៖



« [ អំណោយទានខាងភាសាត្រូវបាន ] ប្រទានឲ្យដើម្បីជាគោលបំណងនៃការប្រកាសដំណឹងល្អ ទៅក្នុងចំណោមមនុស្សដែលនិយាយភាសាផ្សេងដូចនៅបុណ្យថ្ងៃទីហាសិប ជាដើម ហើយវាពុំចាំបាច់ឡើយ ដែលភាសាទាំងឡាយត្រូវតែបានបង្រៀនទៅដល់សមាជិកក្នុងសាសនាចក្រជាពិសេសនោះ ដ្បិតមនុស្សណាក៏ដោយ ដែលមានព្រះវិញ្ញាណបរិសុទ្ធ អាចថ្លែងអំពីការណ៍ទាំងឡាយនៃព្រះបានជាភាសារបស់ខ្លួន ក៏ដូចជាថ្លែងជាភាសាមួយផ្សេងទៀតដែរ ព្រោះសេចក្ដីជំនឿពុំមែនកើតឡើងដោយសារទីសម្គាល់នោះទេ ផ្ទុយទៅវិញ គឺដោយការឮព្រះបន្ទូលនៃព្រះទេតើ » (*ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* [ ឆ្នាំ ២០០៧ ] ទំព័រ ៣៨៣–៨៤) ។

« ប្រសិនបើការណ៍ណាមួយត្រូវបានបង្រៀនដោយអំណោយទានខាងភាសានោះ វាពុំមែនត្រូវបានទទួលសម្រាប់គោលលទ្ធិនោះទេ » (*ការបង្រៀន ៖ យ៉ូសែប ស្ម៊ីធ* ទំព័រ ៣៨៤) ។

« ចូរកុំថ្លែងដោយនូវអំណោយទានខាងភាសាឡើយ ប្រសិនបើគ្មានការយល់ដឹងអំពីវា ឬ ដោយគ្មានការបកប្រែទេនោះ ។ អារក្សអាចនិយាយបានច្រើនភាសា បច្ចាមិត្តនឹងមកជាមួយនឹងកិច្ចការរបស់វា វាអាចល្បួងមនុស្សបានគ្រប់ជាន់ថ្នាក់ វាអាចនិយាយជាភាសាអង់គ្លេស ឬ ភាសាហូឡង់ ។ ចូរកុំឲ្យមាននរណាម្នាក់ថ្លែងជាច្រើនភាសាឡើយ លើកលែងតែបុគ្គលនោះចេះបកប្រែ ដោយមានការអនុមតិពីម្នាក់គ្រប់គ្រងពីលើ លំដាប់នោះ បុគ្គលនោះអាចញាណដឹង ឬ អាចបកប្រែបាន ឬ បុគ្គលម្នាក់ទៀតអាចធ្វើបាន » (*ការបង្រៀន ៖ យ៉ូសែប ស្ម៊ីធ* ទំព័រ ៣៨៤) ។



អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ថា ៖ « អំណោយទានខាងភាសា និង ការបកប្រែ ត្រូវបានប្រទានឲ្យក្នុងគោលបំណងពិសេស ដើម្បីប្រើប្រាស់ក្នុងកាលៈទេសៈពិសេសៗ ។ មានអំណោយទានជាច្រើន ដែលមានសារៈសំខាន់បំផុត ចំណែកឯការប្រើប្រាស់របស់វាវិញនោះ គឺធ្វើឲ្យការបំភាន់បាត់បង់ឱកាសរបស់វា ។ អំណោយទាននៃការដាស់តឿន នៃការប្រកាសដំណឹងល្អ នៃការបកស្រាយគោលលទ្ធិ នៃការបង្រៀនដំណឹងល្អ—ទោះជាមិនមានសេចក្ដីរំភើបខ្លាំងក្ដី—ក៏វាមានសភាពប្រសើរ និង មានតម្លៃជាងភាសាដែរ » ( *Mormon Doctrine* ការបោះពុម្ពលើកទី ២ [ ឆ្នាំ ១៩៦៦ ] ទំព័រ ៨០០ ) ។

សូមពិចារណាមួយស្របក់អំពីរបៀបដែលអំណោយទានទាំងឡាយនៃព្រះវិញ្ញាណបានផ្ដល់អត្ថប្រយោជន៍ដល់អ្នក ។ សូមគិតផងដែរ អំពីរបៀបដែលអ្នកអាចស្វែងរក ហើយប្រើប្រាស់អំណោយទានទាំងឡាយដើម្បីប្រទានពរដល់កូនចៅរបស់ព្រះ ។

ព្រះអម្ចាស់បានបញ្ចូលវិវរណៈនេះតាមរយៈការបង្គាប់ឲ្យអ្នកដើរតាមទ្រង់អំពីអ្វីដែលពួកគេត្រូវធ្វើ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៥–៦ ដោយស្វែងរកអ្វីដែលទ្រង់បានបង្រៀន ។

## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៣៣

សូមចំណាយពេលពីរបីនាទីទន្ទេញ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:៣៣ ។ ប្រសិនបើអាច សូមសូត្រខគម្ពីរនេះឲ្យសមាជិកគ្រួសារ ឬ មិត្តភក្ដិម្នាក់ស្ដាប់ ។

៦. សូមធ្វើបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមធ្យោបាយមួយចំនួនដែលអ្នកអាច « ប្រព្រឹត្តដោយគុណធម៌ និង ដោយបរិសុទ្ធភាព » ។ នៅពេលអ្នកធ្វើបញ្ជីរបស់អ្នក សូមជ្រើសរើសយកពីរ ឬ បីជំពូកចេញពីកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ហើយប្រើប្រាស់ជំពូកទាំងនោះ ដើម្បីជួយអ្នកឲ្យមានចំណុចបញ្ចូលទៅក្នុងបញ្ជីនោះ ។ សូមសរសេរគោលដៅអំពី របៀបដែលអ្នកគ្រោងដើម្បីប្រព្រឹត្តដោយគុណធម៌ និង បរិសុទ្ធភាពនៅចំពោះព្រះអម្ចាស់ ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

ចម្លើយសម្រាប់លំហាត់ផ្គូផ្គង ៖ ១) គ, ២) ឃ, ៣) ខ, ៤) ក ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧–៤៨

## បុព្វកថា

ក្នុងខែ មិនា ឆ្នាំ ១៨៣១ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧ និង ៤៨ ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧ ព្រះអម្ចាស់បានតែងតាំង យ៉ូហាន វិតមើរ ឲ្យធ្វើជាអ្នកសរសេរប្រវត្តិសាស្ត្រ និង ជាអ្នកកត់បញ្ជីសម្រាប់សាសនាចក្រជំនួស អូលីវើរ ខៅឌើរី ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៨ ព្រះអម្ចាស់បានណែនាំឲ្យពួកបរិសុទ្ធនៅរដ្ឋអូហៃអូ ជួយជុះដល់សមាជិកសាសនាចក្រដែលធ្វើដំណើរមកពីរដ្ឋ នូវ យ៉ោក ។ ព្រះអម្ចាស់ក៏បានណែនាំឲ្យសមាជិកសាសនាចក្រត្រៀមខ្លួនទិញដី ដើម្បីស្ថាបនាទីក្រុង ស៊ីយ៉ូនឡើងនៅរដ្ឋ មិសសួរី ផងដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧

*ព្រះអម្ចាស់បានតែងតាំង យ៉ូហាន វិតមើរ ឲ្យរក្សាប្រវត្តិសាស្ត្រសាសនាចក្រដែលបានកត់ត្រាទុក ។*

សូមគិតអំពីព្រឹត្តិការណ៍កន្លងទៅជាមួយនឹងចំណាប់អារម្មណ៍ខាងវិញ្ញាណ ដែលអ្នកបានរួមចំណែក ហើយដឹងថាវាមានតម្លៃគួរតែចងចាំ ( ឧទាហរណ៍ ៖ ពិធីឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ ការប្រជុំមួយក្នុងសាសនាចក្រ ឬ កម្មវិធីក្នុងក្រុមគ្រួសារមានដូចជាអាពាហ៍ពិពាហ៍ ឬ បុណ្យសព ) ។

ប្រសិនបើអាច សូមនិយាយប្រាប់សមាជិកគ្រួសារម្នាក់អំពីព្រឹត្តិការណ៍នោះ ហើយឆ្លើយសំណួរខាងក្រោមនេះ ។ ( ប្រសិនបើមិនមានសមាជិកគ្រួសារដើម្បីប្រាប់ទេនោះ សូមពិចារណាអំពីសំណួរទាំងនេះ ) ។

- តើនៅក្នុងព្រឹត្តិការណ៍នេះ អ្វីទៅដែលដក់ជាប់នៅក្នុងចិត្តរបស់អ្នកជាងគេ ?
- តើការចងចាំអំពីព្រឹត្តិការណ៍នេះ មានតម្លៃយ៉ាងដូចម្ដេចដែរ ?
- តើការដឹងអំពីព្រឹត្តិការណ៍នេះ អាចប្រទានពរដល់កូនចៅជំនាន់ក្រោយរបស់អ្នកក្នុងរយៈពេល ១០០ ឆ្នាំខាងមុខទៀតយ៉ាងដូចម្ដេច ?

សូមអានវគ្គសេចក្ដីណែនាំនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧ និង ខទី ១–៣ នៃវគ្គនេះដើម្បីរកមើលអ្វីដែលព្រះអម្ចាស់បានហៅឲ្យ យ៉ូហាន វិតមើរ ធ្វើ ។ ហេតុអ្វីអ្នកគិតថា វាសំខាន់សម្រាប់បុគ្គលម្នាក់ដើម្បីសរសេរប្រវត្តិរបស់សាសនាចក្រ ?

សូមគិតអំពីព្រឹត្តិការណ៍មួយចេញពីប្រវត្តិសាស្ត្រសាសនាចក្រដែលមានការបំផុតគំនិតចំពោះអ្នក ។ តើអ្នកបានរៀនអំពីព្រឹត្តិការណ៍នោះយ៉ាងដូចម្ដេច ?

យើងស្គាល់ព្រឹត្តិការណ៍កន្លងហួសទៅក្នុងប្រវត្តិសាស្ត្រសាសនាចក្របាន ដោយសារតែមានមនុស្សសរសេរ ហើយរក្សាកំណត់ហេតុនៃព្រឹត្តិការណ៍ទាំងនោះ ដើម្បីបានរក្សាទុកសម្រាប់មនុស្សជំនាន់នេះ និង ជំនាន់ខាងមុខទៀត ។ សូមចងចាំថា នៅក្នុងវិវរណៈមួយកាលពីមុន ព្រះអម្ចាស់បានមានព្រះបន្ទូលថា « នឹងមានបញ្ជីមួយកត់ទុកនៅក្នុងចំណោមអ្នករាល់គ្នា » ( គ. និង ស. ២១:១ ) ។ បច្ចុប្បន្ននេះ មានអ្នកសរសេរ និង កត់បញ្ជីមួយរូបនៅក្នុងសាសនាចក្រ ត្រូវបានតែងតាំងដោយគណៈប្រធានទីមួយ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកសរសេរប្រវត្តិសាស្ត្ររូបនេះ ពុំអាចសង្កេតហើយកត់ត្រាគ្រប់ហេតុការណ៍ដែលកើតឡើងនៅក្នុង



យ៉ូហាន វិតមើរ បានចម្លងវិវរណៈដែល យ៉ូសែប ស្ម៊ីធ បានទទួលកាលពីមុនៗ ចូលទៅក្នុងសៀវភៅដែលសព្វថ្ងៃនេះត្រូវបានស្គាល់ថាជាសៀវភៅវិវរណៈទី ១ ។ សៀវភៅនេះមាននូវសំណៅពីដំបូងៗជាច្រើននៃវិវរណៈទាំងនេះ ។

សាសនាចក្របានទាំងអស់ឡើយ ដូច្នេះ គាត់ត្រូវបានណែនាំឲ្យជ្រើសរើសរឿងប្រវត្តិពីមនុស្សដទៃ ។ ក្នុងន័យទូទៅមានន័យថា បទពិសោធន៍របស់សមាជិកសាសនាចក្រ គឺជាចំណែកនៃប្រវត្តិសាសនាចក្រ ហើយអាចមានឥទ្ធិពលដល់មនុស្សជំនាន់ខាងមុខ ។

អែលឌើរ ម៉ាលីន ឃេ ជែនសិន នៃក្រុមចិតសិបនាក់ ដែលបានបម្រើជាអ្នកសរសេរប្រវត្តិសាស្ត្រ និង អ្នកកត់បញ្ជីសម្រាប់សាសនាចក្រពីឆ្នាំ ២០០៥–១២ បានបង្រៀនថា « រឿងប្រវត្តិដ៏អស្ចារ្យបំផុតជាច្រើននៃសាសនាចក្រ មាននៅក្នុងរឿងប្រវត្តិរបស់បុគ្គល និង ក្រុមគ្រួសារ ហើយទាំងនេះគឺជាចំណែកមួយនៃកេរដំណែលរបស់បុគ្គលម្នាក់ៗ និង ក្រុមគ្រួសារ » ( «There Shall Be a Record Kept among You» *Ensign* ឬ *លីអាហូណា* ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៣១ ) ។

១. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ ហេតុអ្វីបានជាប្រវត្តិផ្ទាល់ខ្លួនរបស់អ្នក មានសារៈសំខាន់ ?

២. សូមគិតអំពីព្រឹត្តិការណ៍សំខាន់ខាងវិញ្ញាណនៅក្នុងជីវិតរបស់អ្នក ដែលអ្នកដឹងថាមានតម្លៃក្នុងការចងចាំ ។ សូមស្រមៃថា កូនៗ និង ចៅៗអ្នក នឹងអានបញ្ជីប្រវត្តិផ្ទាល់ខ្លួនរបស់អ្នកអំពីព្រឹត្តិការណ៍មួយក្នុងចំណោមព្រឹត្តិការណ៍ទាំងនេះ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមប្រាប់អំពីប្រភេទព្រឹត្តិការណ៍នោះ រួចឆ្លើយសំណួរខាងក្រោមនេះ ៖

   ក. តើអ្នកនឹងសរសេរអំពីផ្នែកណាមួយនៃព្រឹត្តិការណ៍នោះ ?

   ខ. តើអ្នកនឹងចង់ឲ្យកូនចៅជំនាន់ក្រោយរបស់អ្នកដឹង ហើយស្គាល់អ្វីអំពីព្រឹត្តិការណ៍នោះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧:៤ ដើម្បីស្វែងយល់អំពីអ្វី ដែលព្រះអម្ចាស់បានសន្យាជាមួយ យ៉ូហាន វិតមើរ ថានឹងប្រទានដល់កិច្ចខិតខំរបស់គាត់ « ក្នុងការកត់បញ្ជី និង ប្រវត្តិសាសនាចក្រជានិច្ច » ( គ. និង ស. ៤៧:៣ ) ។

យោងតាមអ្វីដែលអ្នកបានអាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧:៤សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ៖ **បើយើង ______ នោះព្រះវិញ្ញាណអាចជួយយើងឲ្យ ______** ។

ព្រះវិញ្ញាណបរិសុទ្ធអាចនាំយកគ្រប់ទាំងសេចក្ដីមកកាន់ការចងចាំរបស់យើង ( សូមមើល យ៉ូហាន ១៤:២៦ ) ហើយជួយយើងឲ្យសរសេរអំពីព្រឹត្តិការណ៍ និង ស្ថានភាពនានា ទៅតាមរបៀបដែលនឹងប្រទានពរដល់សមាជិកគ្រួសារ រួមទាំងមនុស្សដទៃទៀតនៅជំនាន់ខាងមុខ ។ សូមអធិស្ឋាន ហើយរស់នៅដោយសក្ដិសមដើម្បីមានជំនួយពីព្រះវិញ្ញាណ នៅពេលអ្នកខិតខំរក្សាប្រវត្តិផ្ទាល់ខ្លួន ។

សូមពិចារណាអំពីរបៀបផ្សេងៗទៀត ដែលអ្នកអាចបង្កើនការខិតខំរក្សាកំណត់ហេតុផ្ទាល់ខ្លួនមួយ ឬ នៅពេលអ្នកសរសេរព្រឹត្តិការណ៍សំខាន់ខាងវិញ្ញាណផ្ទាល់ខ្លួន ពិធីបរិសុទ្ធ និង មនុស្សដែលនៅក្នុងជីវិតរបស់អ្នក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៨

*ពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ ត្រូវជួយផ្គត់ផ្គង់ដល់ពួកបរិសុទ្ធ ដែលធ្វើដំណើរមកពីរដ្ឋ នូវ យ៉ោក ហើយត្រៀមខ្លួនទទួលមរតករបស់ខ្លួននៅទីក្រុង ស៊ីយ៉ូន*

សូមស្រមៃថា ថ្មីៗនេះ មានសមាជិកសាសនាចក្រ ដែលរស់នៅតំបន់ដាច់ស្រយាលមួយបានរងទុក្ខដោយគ្រោះធម្មជាតិ ហើយត្រូវបានជម្លៀសចេញពីផ្ទះសម្បែងរបស់ខ្លួន ។ ថ្នាក់ដឹកនាំសាសនាចក្របានស្នើឲ្យអ្នក និងគ្រួសារអ្នក ផ្ដល់ជាជម្រកដល់អ្នកដែលបាត់បង់ជម្រកមួយចំនួន សម្រាប់រយៈពេលបីបួនខែ ។ តើសំណួរ និង កង្វល់អ្វីខ្លះ ដែលអ្នក និង គ្រួសារអ្នកនឹងមាន ? តើកង្វល់ និង អារម្មណ៍ដូចម្ដេចខ្លះ ដែលអ្នកគិតថា អ្នកដែលផ្លាស់មកស្នាក់នៅក្នុងផ្ទះរបស់អ្នកនោះ នឹងមាន ?

សូមមើលទៅផែនទីប្រវត្តិសាស្ត្រសាសនាចក្រទី ៣ នៅក្នុងព្រះគម្ពីររបស់អ្នក ៖ « តំបន់នូវ យ៉ោក ផែនសិលវេញ៉ា និង អូហៃអូ នៃស.រ.អា » ។ ទីតាំង ប៉ាលម៉ៃរ៉ា រដ្ឋ នូវយ៉ោក និង ខឺតឡង់ រដ្ឋ អូហៃអូ ។ តើទីក្រុងទាំងនេះមានចម្ងាយពីគ្នាប្រហែលប៉ុន្មានគីឡូម៉ែត្រ ?

ក្នុងខែ កុម្ភៈ ឆ្នាំ ១៨៣១ ព្យាការី យ៉ូសែប ស្ម៊ីធ បានផ្លាស់ទីលំនៅពីភូមិ ប៉ាលម៉ៃរ៉ា រដ្ឋ នូវយ៉ោក ទៅកាន់ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ។ សមាជិកសាសនាចក្រជាច្រើន បានផ្លាស់លំនៅទៅតាមក្រោយអំឡុងប្រាំមួយខែក្រោយមក ។ សមាជិកទាំងនេះបានទុកចោលទ្រព្យសម្បត្តិ និង ធនធានខាងលោកិយជាច្រើន ដើម្បីធ្វើតាមព្រះបញ្ញត្តិរបស់ព្រះ ហើយផ្លាស់លំនៅទៅរដ្ឋ អូហៃអូ ហើយពួកគេបានត្រូវការជំនួយ ។ តើអ្នកគិតថា ព្រះអម្ចាស់អាចនឹងតម្រូវអ្វីខ្លះពីអ្នក ប្រសិនបើអ្នកបានរស់នៅរដ្ឋ អូហៃអូ ហើយបានឃើញពួកបរិសុទ្ធទាំងនេះ ផ្លាស់ទីលំនៅទៅកាន់តំបន់របស់អ្នកដោយគ្មានផ្ទះសម្បែង និងមានប្រាក់កាសបន្តិចបន្តួចនោះ ?

### ការនឹកស្រមៃក្នុងចិត្ត

សូមស្វែងរកការពិពណ៌នាលម្អិត ដែលអាចជួយអ្នកឲ្យបង្កើតរូបភាពក្នុងគំនិតពេលអ្នកអាន ។ សូមស្រមៃថាអ្នកកំពុងមានវត្តមានក្នុងព្រឹត្តការណ៍ជាក់លាក់នានា ។ ការធ្វើដូចនេះនឹងជួយពង្រឹងទីបន្ទាល់របស់អ្នកអំពីភាពពិតនៃការណ៍ដែលអ្នកអានក្នុងព្រះគម្ពីរ ។ សូមសាកល្បងវិធីនេះជាមួយនឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៨ ។ ឧទាហរណ៍ សូមស្រមៃអំពីស្ថានភាពលំបាកដែលអាចនឹងកើតឡើង ក្នុងការធ្វើដំណើរលើចម្ងាយផ្លូវពីភូមិប៉ាលម៉ៃរ៉ា រដ្ឋនូវយ៉ោក ទៅកាន់ ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ អំឡុងពេលរដូវរងាក្នុងឆ្នាំ ១៨៣១ ។ តើអ្នកនឹងមានអារម្មណ៍ដូចម្ដេច អំពីការផ្លាស់ទីលំនៅទៅកាន់ទីក្រុងមួយដែលអ្នកមិនដែលស្គាល់ នៅចំពេលដែលអ្នកគ្មានកន្លែងសម្រាប់រស់នៅសោះនោះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៨:១–៣ ដើម្បីស្វែងរកការណ៍ដែលព្រះអម្ចាស់ បានមានព្រះបន្ទូលប្រាប់សមាជិកសាសនាចក្រក្នុងរដ្ឋ អូហៃអូ ឲ្យធ្វើ សម្រាប់សមាជិកសាសនាចក្រ ដែលផ្លាស់ទីលំនៅទៅកាន់ភូមិភាគនោះ ។ គោលការណ៍មួយដែលយើងរៀនចេញពីខគម្ពីរទាំងនេះគឺថា **ព្រះអម្ចាស់បញ្ជាឲ្យពួកបរិសុទ្ធថ្ងៃចុងក្រោយ ចែកចាយអ្វីដែលខ្លួនមានទៅដល់អ្នកដែលខ្វះខាត ។** អ្នកអាចនឹងចង់សរសេរគោលការណ៍នេះនៅក្បែរ ខទី ២ ។

សូមកត់ចំណាំនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៨:៣ ថាព្រះអម្ចាស់បានរំពឹងពីអ្នកដែលមានធនធាន និង ប្រាក់កាសបន្តិចបន្តួច ដែលបានផ្លាស់ទីលំនៅទៅកាន់រដ្ឋ អូហៃអូ ដើម្បីទិញដីធ្លីនៅទីនោះ ។ ដូចគ្នានេះដែរ ព្រះអម្ចាស់រំពឹងឲ្យយើងម្នាក់ៗ ប្រើប្រាស់ធនធានទាំងឡាយដែលយើងមាន ហើយមិនពឹងផ្អែកឲ្យមនុស្សដទៃជួយយើងឡើយ ។

៣. សូមឆ្លើយនឹងសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើយើងអាចចែករំលែកអ្វីដែលយើងមាន ជាមួយសមាជិកដទៃនៅក្នុងសាសនាចក្របានតាមរបៀបណាខ្លះ ?

នៅពេលអ្នកអានរឿងខាងក្រោមនេះ ដែលបានប្រាប់ដោយប្រធាន ជេមស៍ អ៊ី ហ្វោស្ដ ក្នុងគណៈប្រធានទីមួយ សូមពិចារណាអំពីរបៀបដែលយុវជនម្នាក់ បានបំពេញព្រះបញ្ញត្តិរបស់ព្រះក្នុងការចែករំលែកជាមួយអ្នកដែលខ្វះខាត ៖



« អស់ជាច្រើនឆ្នាំកន្លងទៅ មានក្រុមសង្ឃមួយ បានសម្រេចចិត្តប្រមូលអាហារសម្រាប់ជនខ្វះខាតជាគម្រោងបម្រើ ។ ជីម ជាសង្ឃម្នាក់ ដែលមានចិត្តរំភើបចូលរួម ហើយបានតាំងចិត្តថាប្រមូលអាហារឲ្យបានច្រើនជាងអ្នកផ្សេងទៀត ។ ពេលវេលាបានមកដល់ ដែលពួកសង្ឃមកជួបជុំគ្នានៅរោងថ្វាយបង្គំ ។ ពួកគេទាំងអស់គ្នាបានចេញទៅក្នុងពេលតែមួយ ហើយត្រឡប់មកវិញក្នុងពេលជាក់លាក់មួយនៅពេលល្ងាច ។ មនុស្សគ្រប់គ្នាភ្ញាក់ផ្អើល ព្រោះរទេះរបស់ ជីម គ្មានអ្វីទាល់តែសោះ ។ គាត់មើលទៅដូចជា [ ស្រងូតស្រងាត់ ] ណាស់ ហើយក្មេងប្រុសផ្សេងទៀតបានសើចចំអកដាក់គាត់ ។ ដោយឃើញដូចនេះ ហើយដឹងថា ជីម ចូលចិត្តឡាន នោះអ្នកដឹកនាំបានប្រាប់គាត់ ‹ ជីម ចេញទៅក្រៅទៅ ។ ខ្ញុំចង់ឲ្យឯងទៅមើលឡានខ្ញុំ ។ វាដើរមិនស្រួលទាល់តែសោះ › ។

« អ្នកដឹកនាំបានសួរ ជីម ថាគាត់អន់ចិត្តឬទេ ។ ជីម បានតបថា ‹ ទេ អត់ទេ ។ ប៉ុន្តែនៅពេលខ្ញុំបានចេញដើម្បីប្រមូលអាហារ ខ្ញុំពិតជាទទួលបានច្រើនណាស់ ។ រទេះរបស់ខ្ញុំពេញដោយអាហារ ។ នៅពេលខ្ញុំត្រឡប់មករោងថ្វាយបង្គំវិញ ខ្ញុំបានឈប់នៅផ្ទះរបស់ស្ត្រីម្នាក់ដែលមិនមែនជាសមាជិក ដែលបានលែងលះប្ដី ហើយរស់នៅក្នុងព្រំប្រទល់វួដរបស់យើង ។ ខ្ញុំបានគោះទ្វារ ហើយពន្យល់អំពីអ្វីដែលយើងកំពុងធ្វើ ហើយគាត់បានអញ្ជើញខ្ញុំឲ្យចូលក្នុងផ្ទះ ។ គាត់បានចាប់ផ្ដើមរកមើលអ្វីមួយឲ្យខ្ញុំ ។ គាត់បានបើកទូទឹកកក ហើយខ្ញុំអាចមើលឃើញថា គាត់គ្មានអ្វីនោះទេ ។ ទូរបស់គាត់ទទេស្អាត ។ ទីបំផុត គាត់រកបានផ្លែប៉ែសមួយកំប៉ុងតូច ។

« ‹ ខ្ញុំស្ទើរតែពុំជឿទេ ។ មានកូនតូចៗរត់ពេញក្នុងផ្ទះ ដែលត្រូវការអាហារ ហើយគាត់បែរជាហុចផ្លែប៉ែសកំប៉ុងនោះមកឲ្យខ្ញុំទៅវិញ ។ ខ្ញុំបានយកវា ហើយបានដាក់វាក្នុងរទេះរបស់ខ្ញុំ ហើយក៏ចេញដើរមកតាមផ្លូវ ។ ពេលខ្ញុំបានដើរបានពាក់កណ្ដាលផ្លូវនោះ ខ្ញុំមានអារម្មណ៍កក់ក្ដៅពីក្បាលដល់ចុងជើង ហើយបានដឹងថា ខ្ញុំចាំបាច់ត្រូវត្រឡប់ទៅផ្ទះនោះវិញ ។ ខ្ញុំបានឲ្យអាហារទាំងអស់ដល់គាត់ › ។

« អ្នកដឹកនាំបានវាចាថា ‹ ជីម ឯងនឹងមិនភ្លេចនូវអារម្មណ៍ដែលឯងមាននៅយប់នេះនោះទេ ព្រោះនោះហើយជាអ្វីដែលយើងត្រូវធ្វើ › » ( “Spiritual Nutrients,” *Ensign* ឬ *Liahona,* ខែ តុលា ឆ្នាំ ២០០៦ ទំព័រ ៥៤ ) ។

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា អ្វីបានកើតឡើងចំពោះ ជីម កាលគាត់ទទួលអារម្មណ៍ថាគាត់គួរតែត្រឡប់ក្រោយវិញនោះ ?

ខ. នៅពេលអ្នកដឹកនាំបានប្រាប់គាត់ថា អ្វីដែល ជីម បានទទួលអារម្មណ៍នៅពេលនោះគឺជា « អ្វីដែលយើងត្រូវធ្វើ » តើអ្នកគិតថា គាត់ចង់មានន័យដូចម្ដេច ?

៥. សូមស្វែងរកវិធីដែលអ្នកអាចជួយបំពេញសេចក្ដីត្រូវការរបស់នរណាម្នាក់ ដែលប្រហែលជាដោយការចែករំលែកនូវអ្វីដែលអ្នកមាន ។ ឧទាហរណ៍ អ្នកអាចជួយសមាជិកគ្រួសារ មិត្តភក្ដិ នរណាម្នាក់នៅក្នុងថ្នាក់រៀន ឬ ក្រុមក្នុងសាសនាចក្រ ឬ នរណាម្នាក់ដែលជាអ្នកជិតខាង ឬ ជាអ្នករួមសាលាជាមួយគ្នា ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្វីដែលអ្នកនឹងធ្វើដើម្បីជួយបុគ្គលដែលអ្នកគិតដល់ ក្រោយមកតាមដានផែនការរបស់អ្នក ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៨:៤–៦ ព្រះអម្ចាស់បានពន្យល់ថា ទ្រង់សព្វព្រះទ័យឲ្យពួកបរិសុទ្ធត្រៀមខ្លួនទិញដីធ្លី នៅពេលទ្រង់បើកសម្ដែងអំពីទីតាំងនៃទីក្រុង ស៊ីយ៉ូន ឬ យេរ៉ូសាឡិមថ្មី ។ ព្រះអម្ចាស់បញ្ជាឲ្យពួកគេសន្សំប្រាក់ទាំងអម្បាលម៉ានដែលពួកអាចធ្វើទៅបាន ដើម្បីត្រៀមខ្លួនចាក់គ្រឹះទីក្រុងនេះ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧–៤៨ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១២ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩

## បុព្វកថា

លីម៉ាន ខូព្លី ជាអ្នកប្រែចិត្តជឿថ្មីម្នាក់ចូលក្នុងសាសនាចក្រ បានចង់ឲ្យអ្នកផ្សព្វផ្សាយសាសនា ផ្សាយដំណឹងល្អទៅដល់សមាជិកនៃក្រុមសាសនារបស់គាត់ពីមុន ដែលជាក្រុម សេកើរ ។ ទោះជាយ៉ាងណាក៏ដោយ គាត់បានបន្តកាន់តាមជំនឿខុសឆ្គងមួយចំនួនមកពីសាសនានោះ ។ ដោយមានកង្វល់អំពីជំនឿរបស់ លីម៉ាន នោះ យ៉ូសែប ស្ម៊ីធ បានទូលសួរដល់ព្រះអម្ចាស់នៅថ្ងៃទី ៧ ខែឧសភា ឆ្នាំ ១៨៣១ ហើយបានទទួលវិវរណៈដែលឥឡូវនេះ ត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានបញ្ជាស៊ីឌនី រិកដុន និង ប៉ាលី ភី ប្រាត្ត ឲ្យរួមដំណើរនឹង លីម៉ាន ក្នុងការផ្សាយដំណឹងល្អទៅកាន់ក្រុម សេកើរ ។ ព្រះអម្ចាស់ក៏បានស្រាយបំភ្លឺគោលលទ្ធិ ដែលពួកសេកើរបានយល់ខុស រួមទាំងលក្ខណៈនៃការយាងមកជាលើកទីពីរនៃព្រះគ្រីស្ទ តម្រូវការឲ្យធ្វើពិធីបុណ្យជ្រមុជទឹក សារៈសំខាន់នៃអាពាហ៍ពិពាហ៍ និង ក្រុមគ្រួសារ និង ការប្រើប្រាស់សត្វជាអាហារ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩:១–៤

*ព្រះអម្ចាស់ បានហៅ ស៊ីឌនី រិកដុន, ប៉ាលី ភី ប្រាត្ត និង លីម៉ាន ខូព្លី ឲ្យផ្សាយដំណឹងល្អទៅកាន់ពួកសេកើរ*

តើអ្នកធ្លាប់ឃើញអន្ទាក់ចាប់សត្វស្វាដែរឬទេ ? របៀបមួយដើម្បីចាប់សត្វស្វាគឺត្រូវដាក់វត្ថុមួយ ដូចជាសណ្ដែកដី ឬអាហារមួយដុំនៅក្នុងផុងមួយដែលមានប្រហោងធំល្មមដើម្បីឲ្យសត្វស្វានោះដាក់ដៃវាចូលបាន ។ ផុងនោះត្រូវបានចងជាប់នឹងខ្សែ ឬខ្សែភ្លើងដើម្បីកុំឲ្យស្វានោះអាចរត់ចេញពីអន្ទាក់បាន ។ នៅពេលស្វាលូកចូលដល់ក្នុង ហើយចាប់បានវត្ថុនោះហើយ វាពុំអាចដកដៃចេញមកវិញបានឡើយ ព្រោះកណ្ដាប់ដៃរបស់វាធំជាងប្រហោងដែលលូកចូលទៅទៀត ។ ដោយការតាំងចិត្តរបស់វាកាន់យ៉ាងជាប់នឹងរបស់នោះ ស្វាមួយចំនួននឹងបណ្ដោយឲ្យខ្លួនវាត្រូវគេចាប់បាន ។

សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩ ដោយស្វែងរកស្ថានភាព ដែលបានពិពណ៌នាអំពីអន្ទាក់ស្វា ។ តើជំនឿខុសឆ្គងអ្វីខ្លះដែល លីម៉ាន ខូព្លី ពុំចង់បោះបង់ចោល ?





១. សូមសរសេរអំពី *ជំនឿរបស់ពួកសេកើរ* ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ បន្ទាប់មកសូមធ្វើបញ្ជីអំពីជំនឿចំនួនបួនរបស់ពួកសេកើរ ដែលមានលើកឡើងនៅក្នុងសេចក្ដីណែនាំអំពីកណ្ឌ ។ អ្នកអាចចង់គូសចំណាំវានៅក្នុងព្រះគម្ពីររបស់អ្នក ។

សមាជិកនៃសហគមន៍រួមនៃពួកអ្នកជឿលើការលេចឡើងនៃព្រះគ្រីស្ទជាលើកទីពីរ ជាធម្មតាត្រូវបានហៅថាជាពួកសេកើរ ព្រោះរបៀបនៃការថ្វាយបង្គំរបស់ពួកគេមានបញ្ចូលទាំងការឡកកញ្ជ្រោលនៅពេលពួកគេច្រៀង រាំ ហើយទះដៃទៅនឹងចង្វាក់ភ្លេង ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩:១–៤ រួចស្វែងរកអ្វី ដែលព្រះអម្ចាស់បានបើកសម្ដែងអំពីជំនឿរបស់ពួកសេកើរ ។ នៅក្នុង ខទី ២ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូល អំពីបំណងប្រាថ្នារបស់ពួកសេកើរ ។



២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថាវាមានន័យដូចម្ដេចដើម្បី « ដឹងពីសេចក្ដីពិតតាមភាគៗ ប៉ុន្តែមិនមែនទាំងអស់ទេ » ( គ. និង ស. ៤៩:២ ) ?

ខ. តើមានឧទាហរណ៍បែបណា ដែលបញ្ជាក់ប្រាប់ថាសមាជិកសាសនាចក្រអាចនឹងទទួលយកសេចក្ដីពិត ឬ បទដ្ឋានមួយចំនួននៃដំណឹងល្អ ប៉ុន្តែច្រានចោលសេចក្ដីពិត ឬ បទដ្ឋានផ្សេងទៀត ?

តើអ្នកនឹងដាក់ពាក្យអ្វីចូលទៅក្នុងចន្លោះ ដើម្បីបញ្ចប់គោលការណ៍ខាងក្រោមនេះដែលមានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩:២ ? **ដើម្បីឲ្យបានត្រឹមត្រូវចំពោះព្រះអម្ចាស់ គឺរួមបញ្ចូលទាំងបំណងប្រាថ្នាដើម្បីទទួល នៃសេចក្ដីពិតដែលទ្រង់បានបើកសម្ដែង ។**

អ្នកអាចនឹងចង់សរសេរគោលការណ៍នេះនៅក្នុងព្រះគម្ពីររបស់អ្នកក្បែរ ខទី ២ ។ សូមពិចារណាអំពីពរជ័យ ដែលបុគ្គលម្នាក់អាចនឹងបាត់បង់ដោយការគ្រាន់តែជ្រើសរើសទទួលយកសេចក្ដីពិតតាមភាគៗ ។

អ្នកអាចគិតអំពីអន្ទាក់មួយចំនួនដែលសមាជិកសាសនាចក្របានជាប់ ។ សមាជិកមួយចំនួនអាចទទួលយកការបង្រៀន ឬ បទដ្ឋានមួយចំនួន ប៉ុន្តែមិនទាំងអស់ ខណៈដែលសមាជិកមួយចំនួនផ្សេងទៀតអាចតោងជាប់នឹងឥរិយាបថដែលរារាំងពួកគេ « មិនត្រឹមត្រូវនៅចំពោះ [ ព្រះអម្ចាស់ ] » (គ. និង ស. ៤៩:២) ។ ឧទាហរណ៍ បុគ្គលម្នាក់អាចនឹងទៅព្រះវិហារនៅថ្ងៃអាទិត្យ ប៉ុន្តែ ពេលត្រឡប់មកវិញបានធ្វើកម្មវិធី ដែលមិនគោរពដល់ថ្ងៃឈប់សម្រាក ។ បុគ្គលម្នាក់ទៀតអាចនឹងអានព្រះគម្ពីរ ហើយអធិស្ឋានសូមឲ្យមានព្រះវិញ្ញាណ ប៉ុន្តែក្រោយមក បែរជាស្ដាប់តន្ត្រីដែលបណ្ដេញព្រះវិញ្ញាណបរិសុទ្ធទៅវិញ ។

អែលឌើរ យ៉ូសែប ប៊ី វ៉ឺតលីន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖



« សាតាំងគឺជាមេនៃសេចក្ដីបញ្ឆោត និង ជាបិតានៃអស់ទាំងសេចក្ដីកុហក ។ មានតែតាមរយៈការអនុវត្តសេចក្ដីជំនឿលើព្រះអង្គសង្គ្រោះ និង ពលិកម្មធួនរបស់ទ្រង់ រួមទាំងការរក្សាព្រះបញ្ញត្តិទាំងអស់ប៉ុណ្ណោះ ដែលអ្នកអាចបានការពារពីការប៉ុនប៉ងដ៏មិនរាថយ និង ដ៏បោកបញ្ឆោតរបស់សាតាំងក្នុងការដឹកនាំអ្នកយ៉ាងឈ្លាសវៃឲ្យធ្លាក់ទៅក្នុងអំណាចរបស់វា ។

« អ្នកមិនអាចដើរតាមផ្លូវនៃដំណឹងល្អបាន ដូចដែលអ្នកចាប់ម្ហូបប៊ូហ្វេ ដោយជ្រើសរើសយកពីនេះបន្តិច ពីនោះបន្តិចបានឡើយ ។ អ្នកត្រូវតែអង្គុយចុះនៅចំពោះមុខម្ហូបទាំងអស់ ហើយរស់នៅតាមព្រះបញ្ញត្តិគួរជាទីពេញចិត្តរបស់ព្រះអម្ចាស់យ៉ាងពេញលេញ ។

« អ្នកបានរៀនអំពីព្រះបញ្ញត្តិទាំងឡាយរួចមកហើយ ។ អ្នកស្គាល់អ្វីដែលត្រូវធ្វើមានដូចជា ៖ អធិស្ឋាន សិក្សាព្រះគម្ពីរ តមអាហារ ថ្វាយដង្វាយមួយភាគក្នុងដប់ និង ដង្វាយផ្សេងៗ ចូលរួមរាល់ការប្រជុំ ទទួលទានសាក្រាម៉ង់ តម្កើងរាល់ការហៅរបស់អ្នក ហើយបម្រើមនុស្សដទៃ គាំទ្រដល់ថ្នាក់ដឹកនាំសាសនាចក្រ ចុះសេចក្ដីសញ្ញា ហើយរក្សាសេចក្ដីសញ្ញាពិសិដ្ឋនោះ ចែកចាយដំណឹងល្អ មានភាពទៀងត្រង់ ស្មោះត្រង់ បរិសុទ្ធខាងផ្លូវភេទ មានចិត្តមេត្តា និង មានគុណធម៌ » ( « It's Your Choice » *New Era* ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ទំព័រ ៤ ) ។

៣. សូមពន្យល់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគ្រោះថ្នាក់នៃការទទួលយកព្រះបញ្ញត្តិ ឬ បទដ្ឋានមួយចំនួន ប៉ុន្តែ កាន់ជំនឿ ឬ លទ្ធិខុសឆ្គង ។ តើការធ្វើដូចនេះ អាចជា « អន្ទាក់ » ខាងវិញ្ញាណតាមរបៀបណា ?

សូមពិចារណាអំពីអ្វីទាំងឡាយណាដែលអ្នកអាចនឹងត្រូវទុកចោលមួយអន្លើ ដើម្បីទទួលបានពរជ័យដែលព្រះវរបិតាសួគ៌មានព្រះទ័យប្រទានឲ្យអ្នក ។ អ្នកអាចនឹងចង់សរសេរគោលដៅមួយដើម្បីទុកចោលការណ៍ណាមួយដោយអន្លើ ជាការណ៍ដែលរារាំងអ្នកពីការធ្វើឲ្យបានត្រឹមត្រូវចំពោះព្រះអម្ចាស់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩:៥–២៨

*ព្រះអម្ចាស់កែតម្រូវគោលលទ្ធិខុសឆ្គងមួយចំនួនរបស់ពួកសេកើរ ហើយបញ្ជាពួកអ្នកបម្រើទ្រង់ឲ្យអញ្ជើញពួកគេប្រែចិត្ត ហើយទទួលពិធីបុណ្យជ្រមុជទឹក*

ព្រះអម្ចាស់បានបញ្ជា លីម៉ាន ខូព្លី ស៊ីឌនី រិកដុន និង ប៉ាលី ភី ប្រាត្ត ឲ្យផ្សាយដំណឹងល្អទៅកាន់ពួកសេកើរ ( សូមមើល គ. និង ស. ៤៩:១–៤ ) ។ លីម៉ាន ខូព្លី បានសង្ឃឹមថា ពួកអែលឌើរមួយចំនួននឹងផ្សាយដំណឹងល្អទៅកាន់សមាជិកក្នុងក្រុមជំនុំពីមុនរបស់គាត់ ។

តើអ្នកអាចរមិលមើលខ្លួនឯងបានដែរឬទេ អំពីការប្រាប់ទៅដល់មនុស្សមួយក្រុមថា ជំនឿរបស់ពួកគេខ្លះខុសឆ្គង ហើយបន្ទាប់មកបង្រៀនពួកគេអំពីគោលការណ៍នៃដំណឹងល្អដែលត្រឹមត្រូវ ? នៅពេល ប៉ាលី ភី ប្រាត្ត ស៊ីឌនី រិកដុន និង លីម៉ាន ខូព្លី បានទៅជួបពួកសេកើរ ពួកគាត់បានយកវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩ មួយច្បាប់ទៅជាមួយ ហើយបានអានឲ្យពួកគេស្ដាប់ ។

សូមសិក្សាវគ្គបទគម្ពីរនីមួយៗដែលមាននៅក្នុងប្រអប់ខាងឆ្វេងក្នុងតារាងខាងក្រោម ហើយបន្ទាប់មក ផ្គូផ្គងវាទៅនឹងគោលការណ៍ដែលវាបង្រៀននៅក្នុងប្រអប់ខាងស្ដាំ ។ រួចសូមពិចារណាអំពីសំណួរដែលភ្ជាប់មកជាមួយ ។

| | |
|---|---|
| _____១. គ. និង ស. ៤៩:៥–៨ | ក. **គ្មាននរណាម្នាក់ដឹងអំពីពេលនៃការយាងមកជាលើកទីពីរឡើយ ។** |
| _____២. គ. និង ស. ៤៩:១១–១៤ | ខ. **ប្រសិនបើយើងស្គាល់អំពីទីសម្គាល់នៃការយាងមកជាលើកទីពីរ នោះយើងនឹងពុំត្រូវបញ្ឆោតដោយសេចក្ដីអះអាងខុសឆ្គងឡើយ ។** ហេតុអ្វីបានជាវាមានសារៈសំខាន់ចំពោះយើង ដើម្បីឲ្យស្គាល់អំពីទីសម្គាល់ទាំងឡាយនៃការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ? |
| _____៣. គ. និង ស. ៤៩:១៥–១៧ | គ. **ព្រះយេស៊ូវគ្រីស្ទបានបញ្ជាពួកអ្នកបម្រើទ្រង់ ឲ្យអំពាវនាវដល់ប្រជាជនឲ្យជឿលើទ្រង់ ប្រែចិត្ត ទទួលពិធីបុណ្យជ្រមុជទឹក ហើយទទួលអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ។** ហេតុអ្វីបានជាអ្នកមានអំណរគុណ ដែលអ្នកបានទទួលពិធីបុណ្យជ្រមុជទឹក ហើយបានទទួលអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ? ហេតុអ្វីបានជាអ្នកទន្ទឹងជួយមនុស្សដទៃឲ្យទទួលពិធីបរិសុទ្ធទាំងនេះ ? |
| _____៤. គ. និង ស. ៤៩:១៨–២១ | ឃ. **ព្រះអម្ចាស់បានប្រទានសត្វនៅលើផែនដីសម្រាប់ជាការប្រើប្រាស់របស់យើង ។** ហេតុអ្វីបានជាព្រះអម្ចាស់ពុំសប្បាយព្រះទ័យ ចំពោះជនដែលសម្លាប់សត្វដោយមិនចាំបាច់អ្វីសោះ ? |
| _____៥. គ. និង ស. ៤៩:២២–២៥ | ង. **អាពាហ៍ពិពាហ៍រវាងបុរស និង ស្ត្រី គឺត្រូវបានតែងតាំងមកពីព្រះ ហើយស្វាមី និង ភរិយាត្រូវបានបញ្ជាឲ្យទៅជាសាច់តែមួយសុទ្ធ ហើយបង្កើតកូនចៅ ។** ( ឃ្លា « ដើម្បីឲ្យផែនដីអាចបំពេញគោលបំណងនៃការបង្កបង្កើត. . . ដើម្បីឲ្យវាបានពេញទៅដោយមនុស្ស » បង្ហាញអំពីគោលបំណងមួយនៃការបង្កបង្កើតផែនដី ) ។ តើគោលបំណងអ្វីខ្លះ ដែលអាពាហ៍ពិពាហ៍រវាងបុរសម្នាក់ និង ស្ត្រីម្នាក់ បំពេញនៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌ ? |

គណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា ៖ « ព្រះបញ្ញត្តិទីមួយ ដែលព្រះបានប្រទានដល់អ័ដាម និង អេវ៉ា ទាក់ទងទៅនឹងសក្តានុពលរបស់ពួកគាត់ជាឪពុកម្ដាយ ក្នុងនាមជាស្វាមី និង ភរិយា ។ « យើងសូមប្រកាសថា ព្រះបញ្ញត្តិរបស់ព្រះសម្រាប់ឲ្យកូនចៅរបស់ទ្រង់បង្កើតកូនឲ្យចម្រើនជាច្រើនឡើង ឲ្យមានពាសពេញលើផែនដីនេះនៅតែឲ្យប្រតិបត្តិនៅឡើយ ។ យើងក៏សូមប្រកាសផងដែរថា អំណាចដ៏ពិសិដ្ឋនៃការបង្កើតជីវិត គឺត្រូវបានប្រើរវាងបុរស និងស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ជាស្វាមីភរិយាប៉ុណ្ណោះ » ( « *គ្រួសារ ៖ ការប្រកាសដល់ពិភពលោក* » *Ensign* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២៩ ) ។

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ហេតុអ្វីបានជាសាតាំងព្យាយាមបំផ្លាញអាពាហ៍ពិពាហ៍ ? ហេតុអ្វីបានជាវាព្យាយាមបញ្ចុះបញ្ចូលមនុស្សមិនឲ្យរៀបអាពាហ៍ពិពាហ៍ ?

ខ. ហេតុអ្វីបានជាអាពាហ៍ពិពាហ៍រវាងបុរស និង ស្ត្រីគឺជាផ្នែកមួយដ៏សំខាន់ក្នុងផែនការរបស់ព្រះអម្ចាស់ ? ហេតុអ្វីបានជាអាពាហ៍ពិពាហ៍ភេទដូចគ្នា រារាំងផែនការរបស់ព្រះអម្ចាស់ ?

គ. តើយើងអាចធ្វើអ្វីខ្លះនាពេលនេះ ដើម្បីត្រៀមខ្លួនសម្រាប់អាពាហ៍ពិពាហ៍សេឡេស្ទាល ?

សូមគិតអំពីអន្ទាក់ស្វា ។ សូមពិចារណាអំពីគោលការណ៍ ដែលយើងត្រូវទទួលយករាល់ការបង្រៀនរបស់ព្រះអម្ចាស់ ដើម្បីឲ្យបានត្រឹមត្រូវចំពោះទ្រង់ ។ បន្ទាប់មក សូមអានឱវាទ និង ការសន្យារបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩:២៦–២៨ ។ នៅពេលអ្នកអានខគម្ពីរនេះ សូមស្រមៃថា ព្រះអម្ចាស់កំពុងមានព្រះបន្ទូលទៅកាន់អ្នកដោយផ្ទាល់ អំពីការខិតខំរបស់អ្នកដើម្បីឲ្យបានត្រឹមត្រូវចំពោះទ្រង់ ។ សូមពិចារណាអំពីរបៀបដែលឱវាទ និង ការសន្យារបស់ទ្រង់អនុវត្តចំពោះអ្នក ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៩ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

ចម្លើយសម្រាប់លំហាត់ផ្គូផ្គង ៖ ១) ក, ២) គ, ៣) ង, ៤) ឃ, ៥) ខ ។

មេរៀនទី ១២ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០

## សេចក្ដីផ្ដើម

នៅពេលព្យាការី យ៉ូសែប ស៊្មីធ បានមកដល់ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ លោកបានសង្កេតឃើញថាមាន « គំនិតប្លែក និង វិញ្ញាណក្លែងក្លាយខ្លះកើតមានឡើងក្នុងចំណោម » ពួកបរិសុទ្ធមួយចំនួន ។ លោកបានចាប់ផ្ដើមបង្រៀនដោយប្រើ « បម្រាម និង . . . ប្រាជ្ញា » ដើម្បីយកឈ្នះលើអ្វីទាំងនេះ ( សូមមើល *History of the Church* ១:១៤៦ ) ។ អែលឌើរ ប៉ាលី ភី ប្រាត្ត បានត្រឡប់មកពីបេសកកម្មវិញ ហើយបានសង្កេតឃើញមានឥរិយាបថស្រដៀងៗគ្នានៅក្នុងសាខាទាំងឡាយក្នុងសាសនាចក្រនៅក្រៅទីក្រុង ខឺតឡង់ ។ គាត់ និង ពួកអែលឌើរដទៃទៀតបានទៅជួប យ៉ូសែប ដើម្បីទទួលបានការណែនាំ ( សូមមើល *History of the Church* ១:១៧០ ) ។ ក្នុងខែ ឧសភា ឆ្នាំ ១៨៣១ ព្យាការី បានទូលសូមព្រះអម្ចាស់ ហើយទទួលបានវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានណែនាំពួកបរិសុទ្ធឲ្យបង្រៀន ហើយទទួលដំណឹងល្អដោយព្រះវិញ្ញាណនៃសេចក្ដីពិត ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:១–៩

*ព្រះអម្ចាស់ព្រមានពួកអែលឌើរក្នុងសាសនាចក្រអំពីវិញ្ញាណក្លែងក្លាយ*

តើអ្នកដឹងថាការស្អាងនរណាម្នាក់មានន័យដូចម្ដេច ? វាមានន័យថា ការអភិវឌ្ឍន៍នរណាម្នាក់—ជាពិសេសពង្រឹងនរណាម្នាក់ខាងវិញ្ញាណ ឬ ខាងសតិអារម្មណ៍ ឬ ណែនាំ និង បំភ្លឺនរណាម្នាក់ ។ តើអ្នកអាចគិតអំពីគ្រាមួយ កាលអ្នកមានអារម្មណ៍ថាបានស្អាងឡើង នៅពេលនរណាម្នាក់បានបង្រៀនគោលការណ៍នៃដំណឹងល្អដល់អ្នកដែរឬទេ ? តើអ្នកធ្លាប់មានអារម្មណ៍ថា បានជួយស្អាងមនុស្សដទៃនៅពេលណាខ្លះ ?

សូមរំឭកអំពីសេចក្ដីផ្ដើមនៃមេរៀននេះឡើងវិញ ។ សមាជិកថ្មីនៃសាសនាចក្រនៅតំបន់ទីក្រុង ខឺតឡង់ បានបង្ហាញពីទង្វើប្លែកស្រែកឡូឡា និង បែកឆ្វេងនៅក្នុងការប្រជុំថ្វាយបង្គំរបស់ពួកគេ ។ ទង្វើទាំងនេះធ្វើឲ្យអារម្មណ៍មនុស្សរំជើបរំជួល ប៉ុន្ដែ ពួកគេពុំទទួលបានការស្អាងឡើយ ។



ព្យាការី យ៉ូសែប ស៊្មីធ បានសរសេរអំពីឥទ្ធិពលមួយចំនួននៃវិញ្ញាណក្លែងក្លាយដូចតទៅនេះ ៖ « មិនយូរប៉ុន្មានក្រោយពីដំណឹងល្អត្រូវបានស្ថាបនាឡើងនៅទីក្រុង ខឺតឡង់ ហើយអំឡុងពេលពួកអ្នកមានសិទ្ធិអំណាចមិនមានវត្តមាននៅទីនោះ មានវិញ្ញាណក្លែងក្លាយជាច្រើនត្រូវបានសម្ដែងចេញ ទស្សនៈប្លែកជាច្រើនត្រូវបានបង្ហាញឲ្យឃើញ ថែមទាំងគំនិតកើតដោយឯកឯង ដែលធ្វើឲ្យមនុស្សរំជើបរំជួលត្រូវបានគេទទួលយក បុរសៗរត់ចេញទៅក្រៅដោយនូវអានុភាពនៃវិញ្ញាណនោះ ពួកគេខ្លះចំពប់ជើងដួលនឹងដើមឈើ ហើយបានស្រែកឡើង ហើយសកម្មភាពមិនប្រក្រតីទាំងអស់បានបង្កើតឡើងដោយពួកគេ មានបុរសម្នាក់តាមចាប់ដុំមូលមួយ ដែលគាត់ថាបានឃើញវាហោះនៅក្នុងអាកាសរហូតគាត់បានរត់ទៅដល់ជ្រោះមួយ ហើយគាត់បានលោតទៅលើចុងឈើមួយដែលបានជួយសង្គ្រោះជីវិតគាត់ និង ការណ៍គួរឲ្យអស់សំណើចជាច្រើនបានកើតឡើង ដែលធ្វើឲ្យអាប់ឱនដល់សាសនាចក្រនៃព្រះ ហើយបណ្ដាលឲ្យព្រះវិញ្ញាណនៃព្រះដកខ្លួនចេញ ហើយដកយក និង បំផ្លាញគោលការណ៍ដ៏ត្រចះត្រចង់ទាំងនោះ ដែលបានបង្កើតឡើងសម្រាប់ជាសេចក្ដីសង្គ្រោះនៃក្រុមគ្រួសារមនុស្សលោក » ( នៅក្នុង *History of the Church* ៤:៥៨០ ) ។

ពួកអែលឌើរមួយចំនួននៃសាសនាចក្រ ពុំបានយល់អំពីអ្វីដែលកំពុងតែកើតឡើងនោះទេ ដូច្នេះពួកគាត់បានសុំដំបូន្មានពី យ៉ូសែប ស៊្មីធ ។ លោកបានទូលសូមពីព្រះអម្ចាស់ ហើយបានទទួលវិវរណៈដែលនឹងជួយពួកបរិសុទ្ធឲ្យស្អាងគ្នាទៅវិញទៅមកនៅពេលពួកគេបង្រៀន និង រៀនអំពីសេចក្ដីពិតនៃដំណឹងល្អ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:១–៣ ដោយស្វែងរកអំណាចដែលបានដឹកនាំពួកបរិសុទ្ធ ឲ្យប្រព្រឹត្តតាមរបៀបដែលពុំមានការស្អាងគ្នាឡើង ។ យោងតាម ខទី ៣ ហេតុអ្វីបានជាសាតាំងចង់បោកបញ្ឆោតពួកបរិសុទ្ធ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:៤–៩ ដោយស្វែងរកការព្រមានពីព្រះអម្ចាស់ អំពីមនុស្សមួយចំនួនក្នុងចំណោមសមាជិកសាសនាចក្រក្នុងរដ្ឋ អូហៃអូ ។ មនុស្សកំពុត គឺជាជនដែលពុំប្រព្រឹត្តឲ្យដូចអ្វីដែលជាជំនឿខ្លួន ឬ ជាជនដែលធ្វើពុត

ជាមានគុណធម៌ ប៉ុន្តែ តាមពិតទៅពុំមានទាល់តែសោះ ( សូមមើល ម៉ាថាយ ៦:២ លេខយោង ២*ក* ) ។ សូមគូសចំណាំអំពីអ្វីដែលព្រះអម្ចាស់ បានមានព្រះបន្ទូលថានឹងកើតឡើងចំពោះពួកគេនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:៦, ៨ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:១០–៣៦

*ព្រះអម្ចាស់មានព្រះបន្ទូលថា យើងត្រូវតែបង្រៀន ហើយរៀនដោយព្រះវិញ្ញាណ*

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើតម្រូវឲ្យមានអ្វីខ្លះ ដើម្បីធ្វើជាគ្រូបង្រៀនដំណឹងល្អដ៏មានប្រសិទ្ធភាព ?

ខ. តើតម្រូវឲ្យមានអ្វីខ្លះ ដើម្បីធ្វើជាអ្នករៀនដំណឹងល្អដ៏មានប្រសិទ្ធភាព ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:១៣–២០ ដោយស្វែងរកចម្លើយចំពោះសំណួរទាំងនេះ ។ សូមគិតពីការគូសចំណាំអ្វី ដែលអ្នករកឃើញក្នុងព្រះគម្ពីរអ្នក ហើយសរសេរចូលទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមកត់ចំណាំថាតើព្រះអម្ចាស់សង្កត់ធ្ងន់ទៅលើ តម្រូវការឲ្យមានព្រះវិញ្ញាណបរិសុទ្ធក្នុងការបង្រៀន និង ការរៀនដំណឹងល្អដល់កម្រិតណា ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធដែលមានលើកឡើងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:១៤ មានអ្វីខ្លះ ?

ខ. តើអ្នកគិតថា ការបង្រៀនដំណឹងល្អ « ដោយសារព្រះវិញ្ញាណ » មានន័យដូចម្ដេច ( គ. និង ស. ៥០:១៤ ) ? តើអ្នកគិតថា ការបង្រៀនដំណឹងល្អតាម « មាគ៌ាណាមួយទៀត » មានន័យដូចម្ដេច ( គ. និង ស. ៥០:១៧ ) ?

គ. តើអ្នកគិតថា « ការទទួល [ ព្រះបន្ទូលនៃសេចក្ដីពិត ] ដោយសារព្រះវិញ្ញាណនៃសេចក្ដីពិត » មានន័យដូចម្ដេច ( គ. និង ស. ៥០:១៩ ) ? តើអ្នកគិតថា ការទទួលដំណឹងល្អតាម « មាគ៌ាណាមួយទៀត » មានន័យដូចម្ដេច ( គ. និង ស. ៥០:១៩ ) ?

សូមមើលទៅសេចក្ដីយោងបទគម្ពីរ ដែលមាននៅក្នុង Topical Guide សម្រាប់ពាក្យ « Holy Ghost, Mission of » ។ សូមស្វែងរកបទគម្ពីរនានា ដែលជួយអ្នកឲ្យយល់អំពីអត្ថន័យនៃការបង្រៀន និង ការទទួល ( ត្រូវបានបង្រៀនអំពី ) សេចក្ដីពិត ដោយសារព្រះវិញ្ញាណនៃសេចក្ដីពិត ។

សូមគូសរង្វង់លើបរិយាកាសខាងក្រោមនេះ ដែលអ្នកធ្លាប់បានមានឱកាសបង្រៀន ឬ ថ្លែងទីបន្ទាល់អំពីដំណឹងល្អ ៖

| | | |
|---|---|---|
| រាត្រីជួបជុំក្រុមគ្រួសារ | ជាមួយមិត្តភក្ដិ | ថ្នាក់សិក្ខាសាលា |
| ការប្រជុំទាំងឡាយនៃសាសនាចក្រ | ការបង្រៀនតាមផ្ទះ | |

នៅពេលអ្នកមានឱកាសបង្រៀនដំណឹងល្អ តើការយល់ដឹងរបស់អ្នកអំពីព្រះវិញ្ញាណបរិសុទ្ធ មានឥទ្ធិពលលើរបៀបដែលអ្នករៀបចំ និង បង្រៀនយ៉ាងដូចម្ដេច ?

សូមគូសរង្វង់លើបរិយាកាសខាងក្រោមនេះ ដែលអ្នកធ្លាប់ត្រូវបានគេបង្រៀន ៖

| | | |
|---|---|---|
| រាត្រីជួបជុំក្រុមគ្រួសារ | ជាមួយមិត្តភក្ដិ | ថ្នាក់សិក្ខាសាលា |
| ការប្រជុំទាំងឡាយនៃសាសនាចក្រ | ការបង្រៀនតាមផ្ទះ | ក្នុងការសន្ទនានៅឯផ្ទះ |

៣. សូមជ្រើសរើសបរិយាកាសមួយ ដែលអ្នកបានគូសរង្វង់លើនៅក្នុងបញ្ជីពីមុននេះ ដែលអ្នកបានបង្រៀន និងត្រូវបានបង្រៀនដោយសារព្រះវិញ្ញាណ ។ សូមសរសេរបទពិសោធន៍នេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ហើយគិតពីការចែកចាយនូវអ្វីដែលអ្នកបានរៀននេះ ជាមួយសមាជិកគ្រួសារ ឬ មិត្តភក្ដិ ។

សូមពិចារណាអំពីអ្វីដែលអ្នកអាចធ្វើ ដើម្បីខិតខំបន្ថែមទៀតក្នុងការរៀនដោយសារព្រះវិញ្ញាណនៅក្នុងបរិយាកាសទាំងនេះ ។

អែលឌើរ ចាក អេក ហ្គោសលីន នៃពួកចិតសិបនាក់ បានចែកចាយអំពីបទពិសោធន៍នៃយុវជនម្នាក់ ដែលបានដឹងខ្លួនថាទង្វើ និង ឥរិយាបថគាត់ បានប៉ះពាល់ដល់លទ្ធភាពរបស់គាត់ក្នុងការរៀនដោយសារព្រះវិញ្ញាណ ៖

### *ការពិចារណា*

ការពិចារណារួមមានការរិះគិត ការស្មឹងស្មាធ ការសួរសំណួរ និង ការវាយតម្លៃលើអ្វីៗដែលអ្នកដឹង និង អ្វីៗដែលអ្នកកំពុងតែព្យាយាមស្វែងយល់ ។ ការពិចារណាជាញឹកញាប់ជួយយើងឲ្យយល់អំពីអ្វី ដែលយើងត្រូវធ្វើដើម្បីអនុវត្តគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០ សូមគិតពីការយកពេលទៅពិចារណា លើវគ្គបទគម្ពីរ ដែលអ្នកចង់យល់ឲ្យបានកាន់តែច្បាស់ ។



« តើអ្នកទាំងអស់គ្នាប៉ុន្មាននាក់ ដែលបង្ហាញ ‹ ឥរិយាបថធុញទ្រាន់ » អំឡុងពេលការប្រជុំសាក្រាម៉ង់ ? អ្នកដឹងទេ ឥរិយាបថមានដូចជា ៖ អង្គុយឱនទៅខាងមុខ យកដៃច្រត់ចង្កា ដាក់កែងដៃនៅលើក្បាលជង្គង់ សម្លឹងមើលទៅក្រោម ។ តើអ្នកធ្លាប់មានឥរិយាបថបែបនេះ ដែលជា *ជម្រើស*របស់អ្នក ទោះជាការប្រជុំនោះមានការចាប់អារម្មណ៍ ឬ អត់ដែរឬទេ ?. . .

« ប្រធាន ស្ពែនសើរ ដបុលយូ ឃឹមបឹល បានមានប្រសាសន៍អំពីការថ្វាយបង្គំបែបនោះថា ‹ ជាការទទួលខុសត្រូវផ្ទាល់ខ្លួនមួយ ហើយទោះជាអ្វីដែលត្រូវបានថ្លែងចេញពីវេទិកាក៏ដោយ ប្រសិនបើបុគ្គលម្នាក់មានបំណងថ្វាយបង្គំព្រះអម្ចាស់តាមវិញ្ញាណ និង តាមសេចក្ដីពិត នោះគាត់អាចធ្វើដូចនោះបាន ។. . . ប្រសិនបើការប្រជុំនោះជាការធ្វេសប្រហែសចំពោះអ្នក អ្នកបានបរាជ័យហើយ ។ គ្មាននរណាម្នាក់អាចថ្វាយបង្គំជំនួសអ្នកបានឡើយ អ្នកត្រូវតែចាំទទួលព្រះអម្ចាស់ដោយខ្លួនអ្នកផ្ទាល់ › ។ ( *Ensign* ខែ មករា ឆ្នាំ ១៩៧៨ ៥) ។

« យុវវ័យម្នាក់បានប្រាប់អំពីបទពិសោធន៍ដំបូង ដែលគាត់មានអំពីវិញ្ញាណនៃការថ្វាយបង្គំ ។ គាត់ពុំសូវមានភាពសកម្មក្នុងការកាន់បព្វជិតភាពអើរ៉ុនរបស់គាត់ឡើយ អស់រយៈពេលជាច្រើនឆ្នាំ ។ នៅពេលគាត់ចូលរួមការប្រជុំសាក្រាម៉ង់ ជាធម្មតាគាត់អង្គុយនៅខាងក្រោយជាមួយក្រុមមិត្តភក្ដិរបស់គាត់ ហើយគាត់ពុំបានធ្វើជាគំរូល្អក្នុងការមានគារវភាពឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ថ្ងៃមួយគាត់បានមកយឺតពេល ហើយពុំមានកន្លែងអង្គុយក្បែរមិត្តភក្ដិរបស់គាត់នោះទេ ។ គាត់បានអង្គុយតែឯង ហើយនោះជាលើកទីមួយហើយនៅក្នុងជីវិតរបស់គាត់ដែលអង្គុយតែឯង គាត់បានបិទភ្នែកពេលអធិស្ឋាន គាត់បានច្រៀងទំនុកតម្កើង គាត់បានស្ដាប់ការអធិស្ឋានសាក្រាម៉ង់ ហើយគាត់បានយកចិត្តទុកដាក់លើអ្នកឡើងនិយាយ ។ នៅពេលអ្នកឡើងនិយាយទីមួយ និយាយបានប្រហែលពាក់កណ្ដាល គាត់ឃើញថា ទឹកភ្នែកគាត់បានស្រក់ពីភ្នែករបស់គាត់ ។ ដោយការអៀនប្រៀនបន្តិច គាត់បានសម្លឹងមើលទៅជុំវិញខ្លួនដោយប្រុងប្រយ័ត្ន ប៉ុន្តែ គ្មាននរណាម្នាក់មានអារម្មណ៍រំជួលដូចជាគាត់ឡើយ ។ គាត់ពុំបានដឹងថា មានអ្វីបានកើតឡើងចំពោះគាត់នោះទេ ប៉ុន្តែ បទពិសោធន៍នោះបានកែប្រែជីវិតរបស់គាត់ ។ អំឡុងពេលការប្រជុំនោះហើយ ដែលគាត់បានចាប់ផ្ដើមត្រៀមខ្លួនយ៉ាងប្រាកដប្រជាខាងវិញ្ញាណដើម្បីបម្រើបេសកកម្ម ។ គាត់ *បានដឹងពី*អ្វីមួយ ហើយជាកុសលល្អ គាត់បានធ្វើតាម ហើយគាំទ្រអារម្មណ៍ទាំងនោះ » (Yagottawanna » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩១, ទំព័រ ៤៦ ) ។

**៤. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវវិធីជាក់លាក់មួយដែលអ្នកអាចបង្កើនការខិតខំរបស់អ្នក ដើម្បីអ្នកអាចរៀនដោយព្រះវិញ្ញាណបាន ។**

តើអ្នកអាចប្រាប់ថា អ្នកកំពុងបង្រៀន និង រៀនដោយព្រះវិញ្ញាណយ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:២១–២២ ដោយស្វែងរកសេចក្ដីណែនាំពីព្រះអម្ចាស់ ស្ដីពីរបៀបកំណត់ថាតើអ្នកកំពុងបង្រៀន និង រៀនដោយព្រះវិញ្ញាណដែរឬទេ ។

តើអ្នកនឹងសង្ខេបអំពីការបង្រៀនរបស់ព្រះអម្ចាស់ ដែលមាននៅក្នុងខគម្ពីរទាំងនោះយ៉ាងដូចម្ដេច ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:២៣–២៥ សូមកត់ចំណាំអំពីភាពខុសគ្នារវាងអ្វីដែលកើតឡើង នៅពេលមនុស្សបង្រៀនដោយព្រះវិញ្ញាណ និង អំពីអ្វីដែលកើតឡើងនៅពេលមនុស្សបង្រៀន និង រៀនដោយ « មាគ៌ាណាមួយទៀត » ( គ. និង ស. ៥០:១៧ ) ។

តើព្រះអម្ចាស់ពិពណ៌នាយ៉ាងដូចម្ដេច អំពីការបង្រៀន ដែលពុំស្អាងឡើង ? តើទ្រង់បានពិពណ៌នាយ៉ាងដូចម្ដេច អំពីការបង្រៀនដែល « មកពីព្រះ » ( គ. និង ស. ៥០:២៤ ) ?

ចេញពីខគម្ពីរទាំងនេះ យើងអាចរៀនគោលការណ៍ដូចតទៅនេះ ៖ **អ្វីដែលមកពីព្រះបំភ្លឺ ហើយស្អាងឡើង ប៉ុន្តែ អ្វីដែលមិនមែនមកពីព្រះទេនោះ នាំមកនូវភាពច្របូកច្របល់ និង សេចក្ដីងងឹតសូន្យសុង ។**

តើនៅពេលណាខ្លះ ដែលអ្នកធ្លាប់បានឃើញ ឬ មានអារម្មណ៍ថាអ្វីមួយមិនមែនមកពីព្រះ ? តើព្រះវិញ្ញាណជួយអ្នក ឲ្យស្គាល់ការណ៍នោះយ៉ាងដូចម្ដេច ?

នឹងមានគ្រាជាច្រើន ដែលអ្នកនឹងឮ ហើយឃើញសារលិខិត ដែលបម្រុងនឹងបំបាក់សេចក្ដីជំនឿរបស់អ្នក ។ គោលការណ៍ទាំងឡាយ ដែលអ្នករៀននៅថ្ងៃនេះ អាចពង្រឹងអ្នកជំទាស់នឹងសារលិខិតទាំងនោះ ។ សូមអធិស្ឋានឲ្យមានព្រះវិញ្ញាណក្នុងរាល់ការរៀនរបស់អ្នក ហើយយកចិត្តទុកដាក់ជាពិសេសដល់អានុភាពនៃការបង្រៀនដោយព្រះវិញ្ញាណ ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:១៣–២២ យើងរៀនថា **នៅពេលយើងបង្រៀនដោយព្រះវិញ្ញាណ យើងយល់គ្នាទៅវិញទៅមក ហើយយើងទាំងពីរនាក់ត្រូវបានស្អាងឡើង និង ត្រេកអរជាមួយគ្នា ។** ការណ៍នេះមានសភាពខុសគ្នាពីភាពច្របូកច្របល់ និង សេចក្ដីងងឹតសូន្យសុង នៅពេលអ្វីមួយត្រូវបានបង្រៀន « ដោយមាគ៌ាណាមួយទៀត » ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:២៦–៣៦ សូមអានឱវាទរបស់ព្រះអម្ចាស់ប្រទានទៅដល់ពួកអ្នកកាន់បព្វជិតភាព ស្ដីពីអំណាច និង ការទទួលខុសត្រូវទាំងឡាយ ដែលមានមកជាមួយការតែងតាំងរបស់ពួកគាត់ ។ ទ្រង់បានមានព្រះបន្ទូលថា ពួកអ្នកកាន់បព្វជិតភាព ត្រូវបម្រើ ហើយរក្សាខ្លួនពួកគាត់ឲ្យបានបរិសុទ្ធ ។ នៅពេលពួកគាត់ធ្វើដូច្នោះ ព្រះអម្ចាស់នឹងប្រទានឲ្យពួកគេនូវអំណាច ដើម្បីយកឈ្នះលើវិញ្ញាណខុសឆ្គង ដូចជាវិញ្ញាណខុសឆ្គងទាំងឡាយ ដែលមាននៅក្នុងចំណោមពួកបរិសុទ្ធមួយចំនួនដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:៣៧–៤៦

*ព្រះអម្ចាស់លើកទឹកចិត្តពួកអ្នកបម្រើទ្រង់ ឲ្យបន្តរីកចម្រើនក្នុងព្រះគុណ និង សេចក្ដីពិត ហើយទ្រង់ធានាថានឹងគង់នៅជាមួយពួកគាត់*



សូមស្រមៃថាកុមារក្នុងវួដ ឬ សាខារបស់អ្នក នឹងបម្រើបេសកកម្មពេញម៉ោងនៅពេលពួកគេធំឡើង ។ តើពួកគេត្រូវការអ្វីខ្លះ ដើម្បីត្រៀមខ្លួនបម្រើ ? តើយើងមានលក្ខណៈអ្វីខ្លះដែលដូចទៅនឹងកុមារទាំងនេះ ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:៣៧–៤៦ ព្រះអម្ចាស់បានមានព្រះបន្ទូលជាពិសេសទៅកាន់ពួកអែលឌើរមួយចំនួន ដែលបានបម្រើក្នុងឆ្នាំ ១៨៣១ ។ ទោះជាយ៉ាងណាក៏ដោយ ព្រះបន្ទូលរបស់ទ្រង់ទាំងនេះ ក៏អនុវត្តចំពោះយើងដែរ ។ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:៤០–៤៦ដោយស្វែងរកពាក្យ ឬ ឃ្លានៃការលួងលោម និង ការធានា ។ សូមគិតពីការគូសចំណាំអ្វីដែលអ្នករកឃើញ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:៤០ ព្រះអម្ចាស់បានមានព្រះបន្ទូលថា « អ្នករាល់គ្នាត្រូវតែចម្រើនឡើងក្នុងព្រះគុណ » ។ តើអ្នកគិតថា « ចម្រើនឡើងក្នុងព្រះគុណ » មានន័យដូចម្ដេច ?

នៅពេលអ្នកគិតអំពីសំណួរនេះ អ្នកអាចនឹងចង់អាននិយមន័យនៃ *ព្រះគុណ*នៅក្នុង Bible Dictionary ឬ នៅក្នុង *ពិតចំពោះសេចក្ដីជំនឿ* ។ អ្វីដែលយើងរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:៣៧–៤៦ ជួយយើងឲ្យដឹងថា **ព្រះអង្គសង្គ្រោះមានព្រះទ័យឲ្យយើងរីកចម្រើនក្នុងព្រះគុណ និង ក្នុងចំណេះដឹងនៃសេចក្ដីពិត និង មានទំនុកចិត្តលើទ្រង់** ។ ដូចជាអ្វីដែលទ្រង់បានសន្យាដល់ពួកអែលឌើរទាំងនោះដែរថា ទ្រង់នឹងមើលថែយើង នៅពេលយើងទុកចិត្តលើទ្រង់ ហើយព្យាយាមធ្វើតាមព្រះឆន្ទៈទ្រង់ ។

តើវាមានន័យយ៉ាងណាចំពោះអ្នក នៅពេលព្រះអម្ចាស់មានព្រះបន្ទូលថា « អ្នករាល់គ្នាជារបស់ផងយើង » ? តើការធានាបែបនេះ ជួយយើង « មិនឲ្យខ្លាច » តាមរបៀបណា ( គ. និង ស. ៥០:៤១ ) ?

តើមានការសន្យាអ្វីផ្សេងទៀតដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០:៤០–៤៦ ដែលមានន័យជ្រាលជ្រៅចំពោះអ្នក ?

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# គោលលទ្ធិ និង សេចក្តីសញ្ញា ៥១–៥២

## បុព្វកថា

នៅពេលពួកបរិសុទ្ធមួយចំនួនកំពុងផ្លាស់ទីលំនៅពីភាគខាងកើតនៃសហរដ្ឋ បានចាប់ផ្តើមទៅដល់រដ្ឋ អូហៃអូ ក្នុងខែ ឧសភា ឆ្នាំ ១៨៣១ នោះព្រះអម្ចាស់បានបើកសម្តែងព្រះឆន្ទៈរបស់ទ្រង់ទៅកាន់ប៊ីស្សព អែតវឺត ប៉ាទ្រិច តាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ។ នៅក្នុងវិវរណៈនោះ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៥១ ពួកបរិសុទ្ធដែលផ្លាស់ទីលំនៅមកពីភូមិខូលស្វិល រដ្ឋ នូវ យ៉ោក ត្រូវបានដឹកនាំទៅកាន់ភូមិថមសុន រដ្ឋ អូហៃអូ ជាទីតាំងដែលពួកគេបានរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ។ ការថ្វាយ និង កិច្ចត្រួតត្រា សុទ្ធតែជាគោលការណ៍ និង ក្រឹត្យវិន័យ ដែលសហគមន៍ស៊ីយ៉ូន ត្រូវផ្អែកទៅលើ ។ សហគ្រាសរួបរួម ( ក្រោយមកត្រូវបានហៅថា សហគ្រាសសណ្តាប់ធ្នាប់ ) គឺជាអង្គការមួយ ដែលប្រើដើម្បីគ្រប់គ្រងក្រឹត្យវិន័យនោះ នៅពេលនោះ ។ នៅចុងបញ្ចប់នៃសន្និសីទទីបួននៃសាសនាចក្រ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ៣–៦ ខែ មិថុនា ឆ្នាំ ១៨៣១ នៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ នោះព្រះអម្ចាស់បានបញ្ជាឲ្យ យ៉ូសែប ស្ម៊ីធ និង ពួកអែលឌើរប៉ុន្មាននាក់ទៀត ធ្វើដំណើរជាគូៗទៅកាន់រដ្ឋ មិសសួរី ទាំងផ្សាយដំណឹងល្អនៅតាមផ្លូវផង ។ នៅក្នុងវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៥២ ព្រះអម្ចាស់បានហៅដៃគូនីមួយៗ ហើយបានប្រទានដល់ពួកគាត់នូវរបៀប ដែលអាចជួយពួកគាត់ឲ្យចៀសវាងពីការបញ្ឆោត ។

### គោលលទ្ធិ និង សេចក្តីសញ្ញា ៥១

*ព្រះអម្ចាស់ណែនាំប៊ីស្សព អែតវឺត ប៉ាទ្រិច ឲ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការខាងសាច់ឈាមរបស់ពួកបរិសុទ្ធ*

តើក្រុមដែលមានសាមគ្គីភាពជាងគេបំផុត ដែលអ្នកធ្លាប់បានរួមចំណែក គឺជាក្រុមអ្វី ? តើអ្នកដឹងថាក្រុមនៃមនុស្សនោះមានសាមគ្គីភាពតាមរបៀបណា ? តើការអនុវត្តន៍ និង ព្រឹត្តិការណ៍បែបណាខ្លះ ដែលជួយឲ្យក្រុមមួយមានសាមគ្គីភាព ?

នៅពេលពួកបរិសុទ្ធបានមកដល់រដ្ឋ អូហៃអូ ព្រះអម្ចាស់បានបើកសម្តែងដល់ពួកគេនូវក្រឹត្យវិន័យនៃការថ្វាយ ( សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ៤២:៣០–៤២ ) ។ នៅក្រោមក្រឹត្យវិន័យនេះ បុរស និង ស្ត្រី លះបង់ពេលវេលា ទេពកោសល្យ និង ទ្រព្យសម្បត្តិខាងលោកិយរបស់ខ្លួនដោយស្ម័គ្រចិត្ត ដើម្បីកសាង និង ស្ថាបនានគរព្រះឡើង ។ សូមអានសេចក្តីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្តីសញ្ញា ៥១ ដោយស្វែងរកការទទួលខុសត្រូវដែលប៊ីស្សព អែតវឺត ប៉ាទ្រិច មាន ទាក់ទងទៅនឹងក្រឹត្យវិន័យនេះ ។

គោលលទ្ធិ និង សេចក្តីសញ្ញា ៥១:១–៨ មាននូវសេចក្តីណែនាំពីព្រះអម្ចាស់ទៅកាន់ប៊ីស្សព ប៉ាទ្រិច អំពីពួកបរិសុទ្ធដែលនឹងធ្វើដំណើរមកដល់ ។ ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ប៊ីស្សព ប៉ាទ្រិច ឲ្យ « ប្រគល់ចំណែកដល់ប្រជារាស្ត្រនេះរៀងៗខ្លួន » នូវដីធ្លី និង ទ្រព្យសម្បត្តិ « តាមកាលៈទេសៈ [ របស់ពួកគេ ] និង សេចក្តីត្រូវការ [ របស់ពួកគេ ] » ( គ. និង ស. ៥១:៣ ) ។ ( សូមចំណាំថា និយមន័យមួយនៃពាក្យ *សេចក្តីត្រូវការ* គឺជាការខ្វះអ្វីមួយ ។ ការបញ្ជាពីព្រះអម្ចាស់ឲ្យបំពេញ « តាមសេចក្តីត្រូវការនៃប្រជារាស្ត្រនេះ » គឺជាការបញ្ជាឲ្យជួយប្រជារាស្ត្រទទួលបានរបស់ចាំបាច់ ដែលពួកគេពុំមាន ) ។ ប៊ីស្សព ប៉ាទ្រិច ត្រូវផ្តល់កម្មសិទ្ធិទ្រព្យសម្បត្តិពេញលេញទៅដល់ក្រុមគ្រួសារទាំងឡាយ ហើយត្រូវធានាថា មនុស្សគ្រប់គ្នាមានអាហារបរិភោគ និង សំលៀកបំពាក់ស្លៀកពាក់គ្រប់គ្រាន់ ។

ព្រះអម្ចាស់បានមានព្រះបន្ទូលពន្យល់អំពី របៀបដែលពួកបរិសុទ្ធគួរតែធ្វើ ពេលរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ។ សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៥១:៩ ដោយស្វែងរកសេចក្តីណែនាំពីព្រះអម្ចាស់ទៅកាន់ពួកបរិសុទ្ធ ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការដែលក្រុមនៃប្រជារាស្ត្រត្រូវ « មានចិត្តតែមួយ » មានន័យដូចម្តេច ? ( អ្នកអាចនឹងចង់អាន ម៉ូសេ ៧:១៨ ដើម្បីជាជំនួយក្នុងការឆ្លើយនឹងសំណួរនេះ ) ។

ខ. យោងតាម គោលលទ្ធិ និង សេចក្តីសញ្ញា ៥១:៩ តើព្រះអម្ចាស់បានណែនាំពួកបរិសុទ្ធឲ្យធ្វើអ្វី ដើម្បីឲ្យបានរួមគ្នាតែមួយ ? តើអ្នកគិតថាដើម្បីបាន « រាប់ដូចគ្នា » និង « ទទួលដូចគ្នា » មានន័យដូចម្តេច ?

នៅពេលអ្នកអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥១:១០–២០ អ្នកនឹងឃើញថា ព្រះអម្ចាស់បានណែនាំឲ្យប៊ីស្សព ប៉ាទ្រិច តាំងឃ្លាំងមួយឡើង ជាកន្លែងដែលពួកបរិសុទ្ធអាចរក្សាទុករបស់របរដែលមានច្រើនជាងសេចក្ដីត្រូវការ ។ ព្រះអម្ចាស់បានមានព្រះបន្ទូលថា ការរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ គឺជាអភ័យឯកសិទ្ធិមួយ ។ ទ្រង់បានមានព្រះបន្ទូលពន្យល់ថា ទោះបីពួកបរិសុទ្ធនឹងតាំងលំនៅលើដីធ្លីរបស់ខ្លួនតែមួយរដូវតូចក្ដី ក៏ពួកគេគួរតែដាក់ផែនការ ដើម្បីមានភាពស្មោះត្រង់ ឈ្លាសវៃ និងយុត្តិធម៌លើអ្វីដែលពួកគេទទួលបាន ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១–១៣, ២២–៣៤

*ព្រះអម្ចាស់បញ្ជាព្យាការី និង ពួកអែលឌើរប៉ុន្មានទៀត ឲ្យធ្វើដំណើរទៅរដ្ឋ មិសសួរី ហើយផ្សាយដំណឹងល្អនៅតាមផ្លូវ*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១–១៣, ២២–៣៤ ព្រះអម្ចាស់បានណែនាំព្យាការី យ៉ូសែប ស៊្មីធ និង ពួកអែលឌើរប៉ុន្មាននាក់ទៀត ឲ្យធ្វើដំណើរជាគូៗទៅរដ្ឋ មិសសួរី ហើយផ្សាយដំណឹងល្អនៅតាមផ្លូវ ។ ព្រះអម្ចាស់បានបើកសម្ដែងកាលពីមុនរួចមកហើយថា ពួកបរិសុទ្ធនឹងស្ថាបនាសហគមន៍មួយឡើង ដែលត្រូវបានហៅថា ទីក្រុង ស៊ីយ៉ូន ( សូមមើល គ. និង ស. ២៨:៩ ) ប៉ុន្តែ ទ្រង់ពុំបានបើកសម្ដែងអំពីទីតាំងរបស់វាឡើយ ។ នៅក្នុងវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២ ទ្រង់បានសន្យានឹងពួកគេថា បើ យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន ស្មោះត្រង់ចំពោះសេចក្ដីណែនាំមកពីទ្រង់ នោះទ្រង់នឹងបើកសម្ដែងដល់ពួកលោកអំពីទីតាំងនៃ « ដែនដីនៃកេរអាករ [ របស់ពួកបរិសុទ្ធ ] » ( គ. និង ស. ៥២:៥ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១៤–២១, ៣៥–៣៦

*ព្រះអម្ចាស់បើកសម្ដែងរបៀប ដែលជួយយើងឲ្យចៀសវាងពីការត្រូវបានបញ្ឆោតដោយសាតាំង*

នៅក្នុងវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥០ ព្រះអម្ចាស់បានមានព្រះបន្ទូលព្រមានពួកអែលឌើរមួយចំនួនក្នុងសាសនាចក្រ អំពីវិញ្ញាណក្លែងក្លាយ ហើយទ្រង់បានប្រទានសេចក្ដីណែនាំនានា ដែលនឹងជួយពួកបរិសុទ្ធឲ្យស្គាល់គ្នាទៅវិញទៅមក នៅពេលពួកគេបង្រៀន និង រៀនអំពីសេចក្ដីពិតនៃដំណឹងល្អ ។

នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១៤–២១ សូមស្វែងរកសេចក្ដីណែនាំបន្ថែមពីព្រះអម្ចាស់ ដើម្បីជួយពង្រឹងសមាជិកសាសនាចក្រ ជាពិសេសអ្នកដែលទ្រង់បានហៅ ឲ្យផ្សាយដំណឹងល្អ នៅពេលពួកគេធ្វើដំណើរទៅរដ្ឋ មិសសួរី ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១៤ រួចស្វែងរកឃ្លា ដែលព្រះអម្ចាស់បានប្រើដើម្បីពិពណ៌នាអំពីអ្វី ដែលទ្រង់បានហៀបនឹងប្រទានដល់អ្នកផ្សព្វផ្សាយសាសនាទាំងនេះ ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា គោលបំណងនៃគំរូមួយគឺជាអ្វី ?

ខ. តើមូលហេតុអ្វីបានជាព្រះអម្ចាស់ ប្រទានគំរូដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១៤–២១ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១៥–១៩ ដោយស្វែងរកទង្វើ និង ឥរិយាបថ ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថានឹងជួយដល់រាស្ត្រទ្រង់ឲ្យចៀសវាងពីការត្រូវបានបញ្ឆោតដោយសាតាំង ។ នៅពេលអ្នកព្យាយាមយល់ពីសេចក្ដីណែនាំរបស់ព្រះអម្ចាស់ដែលមាននៅក្នុងខគម្ពីរទាំងនេះ សូមពិចារណាអំពីការបកស្រាយដូចខាងក្រោមនេះ ៖

- បុគ្គល « ដែលមានវិញ្ញាណទន់ទាប » ( គ. និង ស. ៥២:១៥ ) មាននូវឥរិយាបថជាអ្នកប្រែចិត្ត ។
- ការបញ្ជាឲ្យ « គោរពពិធីបរិសុទ្ធទាំងឡាយរបស់យើង » ( គ. និង ស. ៥២:១៥ ) សំដៅទៅលើតម្រូវការឲ្យទទួលពិធីបរិសុទ្ធទាំងឡាយមានដូចជា ពិធីបុណ្យជ្រមុជទឹក និង រក្សាសេចក្ដីសញ្ញាដែលទាក់ទងទៅនឹងពិធីបរិសុទ្ធទាំងនោះ ។
- បុគ្គល « ដែលប្រើពាក្យសម្ដីសុភាព ហើយស្អាងឡើង » ( គ. និង ស. ៥២:១៦ ) គឺជាបុគ្គលដែលវាចាចេញពាក្យពេចន៍ ដែលរាបសា ហើយលើកតម្កើង និង ធ្វើឲ្យមនុស្សដទៃរីកចម្រើន ។
- បុគ្គលដែល « ញ័ររន្ធត់នៅក្រោមព្រះចេស្ដា [ របស់ព្រះអម្ចាស់ ] » ( គ. និង ស. ៥២:១៧ ) គឺជាបុគ្គល ដែលមានគារវភាពចំពោះព្រះចេស្ដានៃព្រះ ។
- ដើម្បី « នាំផល » ( គ. និង ស. ៥២:១៧ ) គឺត្រូវបង្កើតអ្វីល្អៗ ( មានដូចជា « ការសរសើរ និង ប្រាជ្ញា » ) ដោយការធ្វើតាមវិវរណៈដែលព្រះបានប្រទានឲ្យ ។

គោលការណ៍ដូចតទៅនេះ សង្ខេបអំពីទស្សនដែលបានរៀនចេញពីវិវរណៈនេះថា ៖ **ដើម្បីចៀសវាងពីការត្រូវបានបញ្ឆោតដោយសាតាំង បុគ្គលម្នាក់ត្រូវតែធ្វើតាមតាមពិធីបរិសុទ្ធទាំងឡាយរបស់ព្រះអម្ចាស់ ហើយរស់នៅតាមវិវរណៈដែលទ្រង់បានប្រទានឲ្យ ។**

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:៣៦ ដោយស្វែងរកសេចក្ដីណែនាំបន្ថែម ដែលព្រះអម្ចាស់បានប្រទានឲ្យ ។ តើព្រះអម្ចាស់បានណែនាំឲ្យពួកអែលឌើរនៃសាសនាចក្រ ប្រកាសអំពីអ្វី ?

៣. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្នកដឹកនាំ ឬ គ្រូបង្រៀនម្នាក់ ដែលអ្នកស្គាល់ ថាជាអ្នកដែលរស់នៅតាមគំរូ ដែលព្រះអម្ចាស់បានប្រទានឲ្យនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:១៤–១៩, ៣៦ ។ តើអ្នកបានទទួលអត្ថប្រយោជន៍ ពីការបង្រៀន និង គំរូរបស់បុគ្គលនេះតាមរបៀបណាខ្លះ ?

សូមគិតអំពីសមាជិកក្នុងគណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ រួចពិចារណាអំពីរបៀបដែលពួកលោកបង្ហាញគំរូមកពីព្រះអម្ចាស់ ក្នុងការមិនឲ្យត្រូវបានបញ្ឆោតដោយសាតាំង ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:៣៧–៤៤

*ព្រះអម្ចាស់ប្រទានឱវាទទៅដល់ថ្នាក់ដឹកនាំ ដែលបន្តរស់នៅក្នុងរដ្ឋ អូហៃអូ*

ទន្ទឹមនឹងពេលព្រះអម្ចាស់បានហៅអ្នកកាន់បព្វជិតភាពជាច្រើនក្នុងជំនាន់ដំបូង ឲ្យផ្សាយដំណឹងល្អនៅតាមផ្លូវទៅកាន់រដ្ឋមិសសួរី ឬ ទីកន្លែងដទៃទៀតនោះ ទ្រង់ក៏បានបញ្ជាឲ្យពួកអែលឌើរប៉ុន្មាននាក់ទៀត ឲ្យបន្តរស់នៅក្នុងរដ្ឋ អូហៃអូ ដែរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:៣៩–៤០ ដោយស្វែងរកសេចក្ដីណែនាំ ដែលព្រះអម្ចាស់បានប្រទានដល់ពួកអែលឌើរដែលបន្តរស់នៅរដ្ឋ អូហៃអូ ។ ( នៅពេលអ្នកអាន វាអាចនឹងមានប្រយោជន៍ ដើម្បីស្គាល់ថាពាក្យ *ដែលនៅសល់* សំដៅទៅលើអ្នកដែលបន្តរស់នៅ ) ។ សូមគិតពីការគូសចំណាំអ្វីដែលអ្នករកឃើញ ។

សូមគិតអំពីសំណួរដូចតទៅនេះ ៖ តើអ្នកគិតថា ដើម្បី « នឹកចាំក្នុងគ្រប់ការណ៍ទាំងអស់ ពីមនុស្សទាល់ក្រ និង មនុស្សកំសត់ទុរគត » មានន័យដូចម្ដេច ( គ. និង ស. ៥២:៤០ ) ? ហេតុអ្វីបានជាការគ្រាន់តែគិតអំពីមនុស្សកំសត់ទុរគត មិនគ្រប់គ្រាន់ដើម្បីបំពេញតាមព្រះបញ្ញត្តិពីព្រះអម្ចាស់ ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥២:៤០ តើព្រះអម្ចាស់បានមានព្រះបន្ទូលដូចម្ដេច អំពីរាស្ត្រ ដែលបដិសេធមិនជួយដល់មនុស្សកំសត់ទុរគត ?

យោងតាមខគម្ពីរនេះ សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ៖ **សិស្សរបស់ព្រះយេស៊ូវគ្រីស្ទមើលថែ ហើយខ្វាយខ្វល់ពី ។**

៤. សូមគិតអំពីមនុស្សដែលអ្នកស្គាល់ ជាបុគ្គលដែលអ្នកចាត់ទុកថាជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបដែលមនុស្សទាំងនេះ មើលថែ ហើយខ្វាយខ្វល់ពីមនុស្សកំសត់ទុរគត ។

សូមគិតអំពីគ្រា ដែលអ្នកបានមានឱកាសខ្វាយខ្វល់ពីមនុស្សទាល់ក្រ និង មនុស្សទុរគត អ្នកជំងឺ និង អ្នករងទុក្ខ ។ សូមគិតអំពីការដាក់គោលដៅជាក់លាក់មួយ ដើម្បីបំពេញតាមសេចក្ដីត្រូវការរបស់នរណាម្នាក់ និង ដើម្បីធ្វើជាសិស្សនៃព្រះយេស៊ូវគ្រីស្ទឲ្យបានកាន់តែប្រសើរឡើង ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៥១–៥២ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១២ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣–៥៦

## បុព្វកថា

ក្នុងខែ មិថុនា ឆ្នាំ ១៨៣១ ព្យាការី យ៉ូសែប ស៊្មីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣–៥៥ ។ វិវរណៈនេះមាននូវការណែនាំរបស់ព្រះអម្ចាស់ទៅកាន់សមាជិកមួយចំនួននៃសាសនាចក្រ ដែលបានរស់នៅក្នុងរដ្ឋ អូហៃអូ ប៉ុន្តែ មិនយូរប៉ុន្មានបានផ្លាស់ទៅរដ្ឋ មីសសួរី វិញ ។ ក្នុងវិវរណៈទាំងនេះ ព្រះអម្ចាស់បានមានព្រះបន្ទូលទៅកាន់ ស៊ីឌនី គិលបឺត, នូវែល ណៃត៍ និង វិលលាម ដ័បបុលយូ ហ្វែប្ស ដោយបានប្រទានដល់ពួកគាត់នូវសេចក្ដីណែនាំនានា ដែលមានភាពជាក់លាក់ចំពោះកិច្ចការចាត់តាំងក្នុងសាសនាចក្រ និង ទេពកោសល្យរបស់ពួកគាត់ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣

*ព្រះអម្ចាស់ហៅ ស៊ីឌនី គិលបឺត ឲ្យធ្វើជាអែលឌើរ ហើយធ្វើដំណើរជាមួយ យ៉ូសែប ស៊្មីធ ទៅរដ្ឋមិសសួរី*

បន្ទាប់ពី ស៊ីឌនី គិលបឺត បានឃើញថា ឈ្មោះរបស់គាត់ពុំមាននៅក្នុងបញ្ជីអ្នកផ្សព្វផ្សាយសាសនា ដែលត្រូវបានហៅឲ្យធ្វើដំណើរទៅកាន់រដ្ឋ មិសសួរី ទេ ( សូមមើល គ. និង ស. ៥២:២២–៣២ )នោះគាត់បានទៅជួបព្យាការី យ៉ូសែប ស៊្មីធ ហើយបានទូលសួរអំពីអ្វីដែលព្រះអម្ចាស់មានព្រះទ័យឲ្យគាត់ធ្វើ ។ យ៉ូសែបបានទូលសូមដល់ព្រះអម្ចាស់ ហើយបានទទួលវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣ ។ នៅក្នុងវិវរណៈនោះ ព្រះអម្ចាស់បានណែនាំឲ្យបងប្រុស គិលបឺត ត្រូវបានតែងតាំងជាអែលឌើរ ហើយបម្រើជាអ្នកតំណាងឲ្យប៊ីស្សព អែតវើត ប៉ាទ្រិច ។ តួនាទីរបស់បងប្រុស គិលបឺត ក្នុងនាមជាអ្នកតំណាងឲ្យប៊ីស្សព ត្រូវបានពន្យល់កាន់តែច្បាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧:៦–១០, ១៥ ។ ព្រះអម្ចាស់ក៏បានបញ្ជា ស៊ីឌនី ឲ្យទៅរដ្ឋ មិសសួរី ជាមួយ យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន ដែរ ។

សូមពិចារណាអំពីបទពិសោធន៍របស់យុវជនខាងក្រោមនេះ ដែលបានចង់ដឹងអំពីអ្វីដែលព្រះអម្ចាស់មានព្រះទ័យឲ្យគាត់ធ្វើ ៖

« អេលីស្សា ក្រេមើរ បានទទួលចម្លើយចំពោះការអធិស្ឋានរបស់នាងនៅក្នុងប្រទេសចិន ។ ចម្លើយរបស់នាងសាមញ្ញ ប៉ុន្តែទន្ទឹមនឹងនោះក៏លំបាកក្នុងការធ្វើដែរ ។ នាងត្រូវបោះបង់ចោលក្ដីស្រមៃដែលនាងមានតាំងពីយូរមកហើយនោះ ដោយត្រឡប់ទៅប្រទេសវិញ ហើយរស់នៅក្នុងជីវិតជានិស្សិតសាកលវិទ្យាល័យទូទៅមួយ ។ ចម្លើយនោះបានធ្វើឲ្យនាងភ្ញាក់ផ្អើល ប៉ុន្តែ នាងមានឆន្ទៈធ្វើតាម ការណ៍ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ឲ្យនាងធ្វើ ។

« អេលីស្សា. . . បានក្លាយទៅជាកីឡាការិនីបាល់ទាត់ដ៏កំពូលមួយរូប ។ នាងសម្រេចបានគោលដៅជាច្រើនរបស់នាង ដោយខិតខំប្រឹងប្រែងដើម្បីបានក្លាយទៅជាសមាជិកមួយរូបនៃក្រុមកីឡាការិនីថ្នាក់ជាតិប្រចាំសហរដ្ឋ ដែលបានផ្ដល់ឱកាសឲ្យនាងបានប្រកួតនៅក្នុងការប្រកួតកីឡាពានរង្វាន់ពិភពលោកនិង ការប្រកួតកីឡាអូឡាំពិកឆ្នាំ ២០០៤ ។




« នាងបានសម្រេចអ្វីគ្រប់យ៉ាងដែលនាងចង់ធ្វើ ។ ប៉ុន្តែ វាមិនបានធ្វើឲ្យនាងសប្បាយចិត្តនោះទេ ។

« អេលីស្សា បានរំឭកថា ‹ ខ្ញុំមានអ្វីគ្រប់យ៉ាង ។ ‹ ខ្ញុំមានក្រុមគ្រួសារមួយដ៏ល្អ ។ ខ្ញុំមានមិត្តភក្តិជាច្រើន ។ ខ្ញុំកំពុងសិក្សានៅសាលា ប៊ី. វ៉ាយ យូ ។ ខ្ញុំលេងបានយ៉ាងល្អសម្រាប់ក្រុមជម្រើសជាតិ ។ ប៉ុន្តែ តើខ្ញុំនឹងបន្តខិតខំប្រឹងប្រែងឆ្ពោះទៅមុខ ក្នុងការបង្កើតក្រុមប្រកួតពានរង្វាន់ពិភពលោក ហើយនៅតែមានអារម្មណ៍ទទេស្អាតយ៉ាងនេះម៉េចនឹងកើតទៅ ? ›

« ក្រោយមក កាលកំពុងប្រកួត នៅប្រទេសចិន អេលីស្សា បានភ្ញាក់ឡើងកណ្ដាលរាត្រីទាំងយំផង ។ នាងទទួលបានអារម្មណ៍កក់ក្ដៅ ជាអារម្មណ៍លួងលោមចិត្ត ។ ‹ ខ្ញុំនៅចាំបានថា ខ្ញុំដាក់ដៃលើទ្រូង ហើយភ្លាមនោះ មានគំនិតទាំងនេះបានលេចឡើងថា ៖ « អ្នកត្រូវតែចាកចេញពីក្រុមកីឡាការិនី

ថ្នាក់ជាតិនោះ ។ វាមិនត្រឹមត្រូវទេ ដែលអ្នកត្រូវរំលងច្បាប់ថ្ងៃឈប់សម្រាកនោះ ។ វាមិនថ្មីទេ ដែលអ្នកដើរតាមមាគ៌ាផ្សេងពីនេះ ។ អ្វីៗនឹងដំណើរការល្អ › » ។ នាងបានរ៉ាយរ៉ាប់ថា នាងបានពេញទៅដោយព្រះវិញ្ញាណ និង មានបទពិសោធន៍ដដែលៗកើតឡើងបីបួនរាត្រីជាប់ៗគ្នា ។

« ទោះជានាងជាសមាជិកនៃសាសនាចក្រតាំងពីនាងកើតមកក្ដី ក៏ចំណាប់អារម្មណ៍របស់អេលីស្សា ទៅលើដំណឹងល្អបានកើតឡើងជាលំដាប់ដែរ ។ នាងអានព្រះគម្ពីរយ៉ាងហោចណាស់ ៣០ នាទីជារៀងរាល់ថ្ងៃ ហើយនាងបានសម្គាល់ថា ការអធិស្ឋានរបស់នាងកំពុងតែផ្លាស់ប្ដូរ ។ នាងបានទូលសួរព្រះអម្ចាស់នូវអ្វីដែលទ្រង់ចង់ឲ្យនាងធ្វើ ។ ហើយនៅក្នុងប្រទេសចិន នាងបានទទួលចម្លើយរបស់ខ្លួន ។

« ‹ ខ្ញុំមិនដែលមានអារម្មណ៍ដូចនោះពីមុនមកទេ ដែលជាអារម្មណ៍លួងលោម និង កក់ក្ដៅ ។ ខ្ញុំប្រាថ្នាសូមឲ្យមានបទពិសោធន៍ទាំងនោះ គ្រប់ពេលដែលខ្ញុំមានសំណួរ ។ អ្វីគ្រប់យ៉ាងហាក់ដូចជាមានភាពច្បាស់លាស់ ។ វាបានធ្វើឲ្យខ្ញុំយល់យ៉ាងច្បាស់ › ។

« អេលីស្សា បានធ្វើតាមការបំផុសគំនិត ដែលនាងបានទទួល ។ នាងបន្លឺថា ‹ នៅពេលអ្នកទទួលបានការបំផុសគំនិត អ្នកត្រូវធ្វើតាមការបំផុសគំនិតនោះភ្លាម ។ ប្រសិនបើខ្ញុំនិយាយថា « មែន វាត្រឹមត្រូវហើយ ។ ប៉ុន្តែ ខ្ញុំពិតជាចង់ប្រកួតក្នុងការប្រកួតកីឡាពានរង្វាន់ពិភពលោក ដូច្នេះខ្ញុំនឹងធ្វើតាមការបំផុសគំនិតតាមក្រោយ » នោះអ្វីៗអាចនឹងមិនដំណើការស្របទៅតាមអ្វីដែលត្រូវបានរំពឹងទុកនោះឡើយ › ។. . .

« មិនមែនការចូលរួមក្នុងក្រុមកីឡាវិនីជាតិនោះទេ ដែលបានផ្ដល់ពេលវេលាឲ្យ អេលីស្សា សាកល្បងអ្វីដែលថ្មីៗ » ។ វាគឺអំឡុងពេលដែលនាងបានចាប់ផ្ដើមដើរលេងជាគូជាមួយនឹងយុវជនម្នាក់ ដែលបានបង្រៀននាងលេងហ្គីតា ហើយក្រោយមកពួកគេបានរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ ។

« អេលីស្សា បានពោលថា ‹ ខ្ញុំប្រាកដណាស់ថា ខ្ញុំត្រូវបានរៀបចំឲ្យមានការផ្លាស់ប្ដូរនេះ តាមរយៈអ្វីដែលបានកើតឡើងនៅប្រទេសចិន ។ ខ្ញុំបានលះបង់អ្វីមួយចោល ហើយទទួលបានអ្វីមួយដែលកាន់តែប្រសើរជាងនោះទៅទៀត › ។

« . . .នាងនៅតែចង់ប្រឹងប្រែងធ្វើការ ប៉ុន្តែ ឥឡូវនេះវាជាការប្រឹងប្រែងដើម្បីគ្រូសារផ្ទាល់ខ្លួនរបស់នាង ។

« [ អេលីស្សា ] ស្ដាប់តាមគ្រូបង្វឹកដ៏ឆ្នើមបំផុត គឺព្រះវរបិតាសួគ៌ ដែលជាអ្នកអាចដឹកនាំនាង ហើយប្រទានឲ្យនាងនូវការដឹកនាំ និង ការបំផុសគំនិត ។ ដូចអេលីស្សា បានពោលថា ‹ ព្រះអម្ចាស់ទ្រង់ជ្រាបពីយើងម្នាក់ៗ ។ ចំពោះខ្ញុំ នោះជារឿងប្រពៃណាស់ដើម្បីដឹង ហើយមានទីបន្ទាល់អំពីការណ៍នោះ › » ( Janet Thomas « The Playmaker » *New Era* ខែ វិច្ឆិកា ឆ្នាំ ២០០៣ ទំព័រ ២១, ២៣ ) ។

សូមពិចារណាអំពីវិធី ដែលអ្នកអាចទទួលបានការដឹកនាំពីព្រះអម្ចាស់អំពីជីវិតរបស់អ្នក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៤

*ព្រះអម្ចាស់ណែនាំ នូវែល ណៃត៍ ឲ្យដឹកនាំពួកបរិសុទ្ធនៅភូមិខូលស្វិល ទៅកាន់រដ្ឋ មិសសួរី ។*

ក្នុងខែ មេសា ឆ្នាំ ១៨៣១ នូវែល ណៃត៍ បានដឹកនាំពួកបរិសុទ្ធចេញពីភូមិខូលស្វិល រដ្ឋ នូវ យ៉ោក ទៅចូលរួមជាមួយពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ ។ ក្នុងខែ ឧសភា ព្យាការី យ៉ូសែប ស្ម៊ីធ បានណែនាំប៊ីស្សព អែតវឺត ប៉ាទ្រិច ឲ្យរៀបចំពួកបរិសុទ្ធតាំងលំនៅលើដីធ្លីក្នុងភូមិថមសុន រដ្ឋ អូហៃអូ ដែល លីម៉ាន ខូព្លី បានចុះសេចក្ដីសញ្ញា ( ឬ សន្យា ) ថានឹងប្រគល់ឲ្យទុកសម្រាប់ជាគោលបំណងនោះ ។ ពួកគេបានដាំដំណាំនៅទីនោះ ហើយបានចាប់ផ្ដើមបង្កបង្កើនផលនៅលើដីធ្លីនោះ ។ ប៉ុន្តែ ទោះជាពួកគេធ្វើការរួមគ្នាដើម្បីបង្កើនដីនោះក្ដី ក៏ពួកគេបានចាប់ផ្ដើមមានភាពអាត្មានិយម និង ភាពលោភលន់ ។ ស្ថានភាពរបស់ពួកគេមានសភាពកាន់តែអាក្រក់ទៅៗនៅពេល លីម៉ាន ខូព្លី បានត្រឡប់មកពីបេសកកម្មផ្សាយទៅកាន់ពួកសេកើរវិញ ( សូមមើល គ. និង ស. ៤៩ ) ហើយបានចាប់ផ្ដើមសង្ស័យលើសេចក្ដីជំនឿរបស់ខ្លួន ។ គាត់បដិសេធទីបន្ទាល់ដែលកំពុងរីកលូតលាស់របស់គាត់ចំពោះដំណឹងល្អដែលបានស្ដារឡើងវិញ ហើយបានបញ្ជាឲ្យពួកបរិសុទ្ធចាកចេញពីដីធ្លី ។ គាត់ក៏បានទារថ្លៃពីពួកគេចំនួន ៦០ ដុល្លា ។ ដោយសារតែលីម៉ាន ខូព្លី បានល្មើសនឹងសេចក្ដីសញ្ញារបស់គាត់ នោះពួកបរិសុទ្ធពុំមានកន្លែងណានឹងរស់នៅឡើយ ។ នូវែល ណៃត៍ និង អ្នកដទៃទៀត បានសួរព្យាការីថាតើគួរធ្វើដូចម្ដេច ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៤:១–៣ រួចគូសសម្គាល់អ្វី ដែលព្រះអម្ចាស់បានមានព្រះទ័យចង់ឲ្យពួកបរិសុទ្ធទាំងនេះធ្វើ ដើម្បីជួយឲ្យស្ថានភាពរបស់ពួកគេមានសភាពប្រសើរឡើង ។ បន្ទាប់មក សូមពិចារណាអំពីសំណួរដូចតទៅនេះ ៖ ហេតុអ្វីបានជាអ្នកគិតថា ការប្រែចិត្ត និង ការបន្ទាបខ្លួន នឹងជួយដល់ពួកបរិសុទ្ធទាំងនេះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៤:៦ រួចគូសសម្គាល់ពរជ័យមួយ ដែលត្រូវបានប្រទានដល់ពួកបរិសុទ្ធទាំងនោះដែលបានរក្សាសេចក្ដីសញ្ញាក្នុងការថ្វាយទ្រព្យសម្បត្តិពួកគេ ។

យោងតាមការបង្រៀនរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៤:១–៦ សូមបំពេញគោលការណ៍ដូចតទៅនេះ ៖ **បើយើងរក្សាសេចក្ដីសញ្ញារបស់យើង ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ នោះយើងនឹងទទួលបាន ។**

រាល់ពរជ័យដែលយើងទទួលបាន គឺជាទង្វើនៃសេចក្ដីមេត្តាករុណារបស់ព្រះអម្ចាស់ ។ គំរូមួយនៃសេចក្ដីមេត្តាករុណារបស់ព្រះអម្ចាស់ គឺនៅពេលដែលទ្រង់អភ័យទោសដល់យើងពីអំពើបាប ។ នៅពេលយើងរក្សាសេចក្ដីសញ្ញា ដែលយើងធ្វើនៅពេលពិធីបុណ្យជ្រមុជទឹក ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ នោះយើងនឹងមិនគ្រាន់តែទទួលបានសេចក្ដីមេត្តាករុណានៅក្នុងជីវិតនេះទេ គឺថែមទាំងបន្តទៅដល់សេចក្ដីជំនុំជម្រះចុងក្រោយទៀត ។

អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនអំពីវិធីមួយចំនួន ដែលព្រះអម្ចាស់បន្តមានសេចក្ដីមេត្តាករុណា នៅពេលយើងរក្សាសេចក្ដីសញ្ញារបស់យើង ៖



« សេចក្ដីមេត្តាករុណាដ៏ទន់ភ្លន់ទាំងឡាយនៃព្រះអម្ចាស់ គឺជាពរជ័យផ្ទាល់ខ្លួន និង សម្រាប់បុគ្គលម្នាក់ៗ ជាកម្លាំង ជាការការពារ ជាការធានាអះអាង ជាការដឹកនាំ ជាសេចក្ដីសប្បុរស ដែលពោរពេញដោយសេចក្ដីស្រឡាញ់ ជាការលួងលោមចិត្ត ជាការគាំទ្រ និង ជាអំណោយទានទាំងឡាយខាងវិញ្ញាណ ដែលយើងបានទទួល និង ក៏ដោយសារតែតាមរយៈព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។. . .

« . . . សេចក្ដីមេត្តាករុណាដ៏ទន់ភ្លន់ទាំងឡាយនៃព្រះអម្ចាស់ មិនកើតឡើងដោយចៃដន្យ ឬ គ្រាន់តែជាការគាប់ជួននោះទេ ។ ភាពស្មោះត្រង់ ការគោរពប្រតិបត្តិ និង ការបន្ទាបខ្លួននាំឲ្យសេចក្ដីមេត្តាករុណាដ៏ទន់ភ្លន់ទាំងឡាយ កើតមានក្នុងជីវិតរបស់យើង ហើយជាញឹកញាប់ វាកើតមានតាមកាលកំណត់របស់ព្រះអម្ចាស់ដែលអាចធ្វើឲ្យយើងទទួលស្គាល់ និង ឲ្យតម្លៃខ្ពស់ចំពោះពរជ័យសំខាន់ៗទាំងនេះ » ( « The Tender Mercies of the Lord » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៥ ទំព័រ ៩៩–១០០ ) ។

១. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីពរជ័យមួយចំនួន ដែលអ្នកមានអារម្មណ៍ថាព្រះអម្ចាស់បានប្រទានដល់អ្នកនាពេលថ្មីៗនេះ ដោយសារតែភាពស្មោះត្រង់របស់អ្នកដែលមានចំពោះសេចក្ដីសញ្ញា និង ការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៤:៧–១០ យើងអានថា បន្ទាប់ពីពួកបរិសុទ្ធទាំងនេះបានបាត់បង់ផ្ទះសម្បែងខ្លួននៅលើដីធ្លីរបស់ លីម៉ាន ខូព្លី នោះព្រះអម្ចាស់បានបញ្ជាពួកគេឲ្យធ្វើដំណើរទៅកាន់រដ្ឋ មិសសួរី ។ ពួកគេត្រូវតាំងនរណាម្នាក់ឲ្យបង់ប្រាក់សម្រាប់ការចំណាយនៅតាមផ្លូវ ហើយពួកគេត្រូវធ្វើការដើម្បីផ្គត់ផ្គង់ជីវិតរស់នៅនៅទីនោះ រហូតដល់ព្រះអម្ចាស់នឹងរៀបចំកន្លែងមួយឲ្យពួកគេតាំងលំនៅ ។ ព្រះអម្ចាស់ក៏បានប្រទានឱវាទដល់ពួកគេ ឲ្យមានការអត់ធន់ក្នុងសេចក្ដីលំបាក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៥

*ព្រះអម្ចាស់ហៅ វិលលាម ដ័បបុលយូ ហ្វែប្ស ឲ្យជួយក្នុងការសរសេរ និង ការបោះពុម្ពសៀវភៅផ្សេងៗនៃសាសនាចក្រ*



សូមគិតអំពីទេពកោសល្យ ឬ ជំនាញមួយចំនួនរបស់អ្នក ។ រួចគិតអំពីទេពកោសល្យ ឬ ជំនាញមួយចំនួន ដែលមិត្តភក្ដិអ្នកម្នាក់មាន ។ ដោយសារតែសមត្ថភាពរបស់យើងមានច្រើនខុសៗគ្នា នោះយើងអាចជួយក្នុងកិច្ចការរបស់ព្រះអម្ចាស់តាមវិធីផ្សេងៗគ្នា ។ **ព្រះអាចប្រើប្រាស់ទេពកោសល្យ ជំនាញ និង សមត្ថភាពនានាដើម្បីប្រទានពរដល់កូនចៅទ្រង់ ។** វិលលាម ដ័បបុលយូ ហ្វែប្ស គឺជាគំរូនៃគោលការណ៍នេះ ។ មុនពេលគាត់បានទៅដល់ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ គាត់បានជាវព្រះគម្ពីរមរមនមួយក្បាលនៅពីរសប្ដាហ៍បន្ទាប់ពីវាត្រូវបានដាក់លក់ ។ ការណ៍នេះបាននាំឲ្យគាត់មានការប្រែចិត្តជឿ ។

សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៥ ដោយស្វែងរកជំនាញ ឬ សមត្ថភាព

មួយរបស់ វិលលាម ដ័បបុលយូ ហ្វេប្ស ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៥:៤ ដោយស្វែងរកទេពកោសល្យមួយទៀតដែលគាត់មាន ។ ព្រះអម្ចាស់បានហៅបងប្រុស ហ្វេប្ស ឲ្យប្រើប្រាស់ទេពកោស្យ និង ជំនាញទាំងឡាយរបស់គាត់ ដើម្បីជួយក្នុងការសរសេរ និង ការបោះពុម្ពសៀវភៅផ្សេងៗនៃសាសនាចក្រក្នុងរដ្ឋ មិសសួរី ( សូមមើល គ. និង ស. ៥៥:៥ ) ។ កិច្ចខិតខំរបស់បងប្រុស ហ្វេប្ស នៅទីនោះ បានប្រទានពរដល់សាសនាចក្រតាមវិធីជាច្រើន ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកធ្លាប់បានឃើញព្រះអម្ចាស់ប្រើប្រាស់ទេពកោសល្យ និង សមត្ថភាពរបស់វាស្ត្រទ្រង់ ទៅប្រទានពរដល់មនុស្សដទៃតាមរបៀបណា ?

ខ. តើទេពកោសល្យ និង សមត្ថភាពរបស់អ្នក អាចនឹងប្រទានពរ ហើយលើកទឹកចិត្តមនុស្សដទៃ ហើយជម្រុញកិច្ចការព្រះអម្ចាស់ឲ្យឆ្ពោះទៅមុខយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១–១៣

*ព្រះអម្ចាស់ដកហូតការហៅបម្រើបេសកកម្មរបស់ អែសរ៉ា ធេយ័រ ហើយព្រមានគាត់ឲ្យប្រែចិត្ត*

៣. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមនុស្សម្នាក់ដែលអ្នកស្គាល់ ដែលបានលះបង់អ្វីមួយដែលសំខាន់បំផុតចំពោះពួកគេ ដើម្បីគោរពប្រតិបត្តិតាមព្រះបញ្ញត្តិ ។ ( ឧទាហរណ៍អាចរួមបញ្ចូលទាំងការលះបង់របស់មនុស្សម្នាក់ ដើម្បីចូលសាសនាចក្រ ចេញបេសកកម្ម ឬ គោរពប្រតិបត្តិតាមបទដ្ឋានមួយចំនួនរបស់សាសនាចក្រ ) ។

អែសរ៉ា ធេយ័រ ត្រូវបានចាត់តាំងឲ្យរស់នៅ ហើយធ្វើការជាមួយ យ៉ូសែប ស៊្មីធ ស៊ីញ៉័រ ក្នុងកសិដ្ឋានរបស់ ហ្វ្រេឌើរិក ជី វិលលាម្ស នៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ។ បន្ថែមលើការធ្វើការក្នុងកសិដ្ឋាន អែសរ៉ា ក៏បានជួយបង់ថ្លៃបំណុលខ្លះដែលជំពាក់លើដីធ្លីដែរ ។ នៅពេលគាត់ត្រូវបានហៅឲ្យទៅបេសកកម្មមិសសួរី ជាមួយ ថូម៉ាស ប៊ី ម៉ាស ( សូមមើល គ. និង ស. ៥២:២២ ) គាត់បានសុំយកកម្មសិទ្ធចំណែកលើដីធ្លីនៃសាសនាចក្រ ដែលគាត់គិតថាខ្លួនសមនឹងទទួលបានដីធ្លីនោះ ។ ដោយសារតែការខ្វល់ខ្វាយរបស់គាត់ចំពោះទ្រព្យសម្បត្តិ និង ប្រាក់កាស នោះអែសរ៉ា ធេយ័រ ពុំបានត្រៀមខ្លួនរួចរាល់ដើម្បីចេញទៅបម្រើបេសកកម្មនោះឡើយ ទន្ទឹមនឹងពេលដែល ថូម៉ាស បានត្រៀមខ្លួនរួចរាល់ហើយនោះ ដូច្នេះហើយ ថូម៉ាស ក៏បានទៅជួបព្យាការី យ៉ូសែប ស៊្មីធ ហើយបានសួរអំពីអ្វីដែលគាត់គួរតែធ្វើ ។

ក្នុងវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦ ព្រះអម្ចាស់បានដកហូតការហៅបម្រើបេសកកម្មពី អែសរ៉ា ធេយ័រ មកវិញ ហើយចាត់ដៃគូថ្មីសម្រាប់បងប្រុស ម៉ាស ។ ក្រោយមក ព្រះអម្ចាស់បានព្រមានអំពីភាពឆ្មើងឆ្មៃ ហើយបានបង្រៀនពួកបរិសុទ្ធថា ទ្រង់មានពរជ័យទុកសម្រាប់ប្រទានឲ្យច្រើនជាងដីធ្លី និង ប្រាក់កាសទាំងនេះទៅទៀត ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:៣–៥ ដោយស្វែងរកអ្វីដែលបានកើតឡើង ដោយសារតែ អែសរ៉ា ធេយ័រ ពុំបានត្រៀមខ្លួនរួចរាល់ដើម្បីចេញទៅជាមួយ ថូម៉ាស ប៊ី ម៉ាស ទៅកាន់រដ្ឋ មិសសួរី ។ នៅពេលអ្នកអាន វាអាចនឹងមានប្រយោជន៍ដើម្បីស្គាល់ថាពាក្យ *ដកហូត* មានន័យថា ដកយកមកវិញ ឬ បោះបង់ ។ តើអែសរ៉ា បានបាត់បង់អ្វីខ្លះ ដោយសារតែការពុំទាន់ត្រៀមខ្លួនរួចរាល់ដើម្បីចេញទៅជាមួយបងប្រុស ម៉ាស នោះ ?

គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:៤ បង្រៀនយើងថា **ព្រះអម្ចាស់អាចបញ្ជា ឬ ដកហូតព្រះបញ្ញត្តិមួយវិញ នៅពេលទ្រង់ព្រះតម្រិះឃើញថាសមនឹងធ្វើ ។** អ្នកអាចគូសចំណាំពាក្យ ឬ ឃ្លា ដែលបង្រៀនអំពីគោលការណ៍នេះ ។

ចំណុចខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួនចេញពីបទគម្ពីរ និង ប្រវត្តិសាសនាចក្រនៃការប្រទានឲ្យ ឬ ការដកហូតព្រះបញ្ញត្តិមកវិញ ៖

- បន្ទាប់ពីព្រះអម្ចាស់បានប្រទានក្រឹត្យវិន័យមួយដែលកាន់តែពិបាកទៅដល់ម៉ូសេ និង រាស្ត្ររបស់លោក នោះពួកកូនចៅអ៊ីស្រាអែលបានបះបោរ ហើយបានចាប់ផ្ដើមថ្វាយបង្គំរូបសំណាកគោធ្វើពីមាស ។ រួចព្រះអម្ចាស់បានប្រទានដល់ពួកគេ នូវក្រឹត្យវិន័យមួយដែលស្រួលជាងនេះ ។ ( សូមមើល ការបកប្រែរបស់ យ៉ូសែប ស្ម៊ីធ និក្ខមនំ ៣២:១៤; ៣៣:២០; ៣៤:១–២ [ នៅក្នុងសេចក្ដីបន្ថែមព្រះគម្ពីរប៊ីប ] ) ។
- អំឡុងពេលការបម្រើរបស់ព្រះអង្គនៅលើផែនដី ទ្រង់បានមានព្រះបន្ទូលប្រាប់ពួកសាវកទ្រង់ឲ្យផ្សាយដំណឹងល្អទៅត្រឹមតែពួកសាសន៍យូដាប៉ុណ្ណោះ ( សូមមើល ម៉ាថាយ ១០:៥) ។ មិនយូរប៉ុន្មានបន្ទាប់ពីការសុគតរបស់

ព្រះអង្គសង្គ្រោះ ពេត្រុស បានទទួលវិវរណៈមួយថា ដល់ពេលដែលត្រូវផ្សាយដំណឹងល្អទៅកាន់មនុស្សនៃអស់ទាំងសាសន៍ហើយ ( សូមមើល ម៉ាថាយ ២៨:១៩) ។

- នៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ ព្រះអម្ចាស់បានបញ្ជាឲ្យពួកបរិសុទ្ធជំនាន់ដំបូងមួយចំនួនអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ ព្យាការី យ៉ូសែប ស្ម៊ីធ និង ថ្នាក់ដឹកនាំសាសនាចក្រជាច្រើនទៀត បានឃើញថា ព្រះបញ្ញត្តិនេះពិបាកនឹងអនុវត្ត ប៉ុន្តែ ពួកលោកបានគោរពប្រតិបត្តិតាម ។ ច្រើនឆ្នាំក្រោយមក បន្ទាប់ពីបានទទួលវិវរណៈ ប្រធាន វិលហ្វូឌ វូឌរ័ដ្រុព្វ បានចេញជាសេចក្ដីថ្លែងការណ៍លាយលក្ខណ៍អក្សរ—សេចក្ដីប្រកាស—ដែលត្រូវបានទទួលយកជាផ្លូវការដោយសាសនាចក្រ និង បានចងក្រងនៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៨៩០ ។ សេចក្ដីថ្លែងការណ៍នេះ បានបញ្ចប់ការអនុវត្តន៍អាពាហ៍ពិពាហ៍ពហុពន្ធភាពនៅក្នុងសាសនាចក្រ ( សូមមើល សេចក្ដីប្រកាសជាផ្លូវការទី១ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:៨–១១ ដោយស្វែងរកការណ៍ដែលព្រះអម្ចាស់បានបញ្ជាឲ្យ អែសរ៉ា ធេយែរ ធ្វើបន្ទាប់ពីការហៅបម្រើបេសកកម្មរបស់គាត់ត្រូវបានដកហូត ។ ជាសំណាងល្អ អែសរ៉ា បានជ្រើសរើសប្រែចិត្ត ហើយប្រាំពីរខែក្រោយមក គាត់ត្រូវបានហៅម្ដងទៀតឲ្យបម្រើជាអ្នកផ្សព្វផ្សាយសាសនាជាមួយ ថូម៉ាស បី ម៉ាស ( សូមមើល គ. និង ស. ៧៥:៣១ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១៤–២០

*ព្រះអម្ចាស់ព្រមានពួកបរិសុទ្ធប្រឆាំងនឹងភាពលោភលន់ និង ចិត្តឆ្មើងឆ្មៃ*

មនុស្សខ្លះគិតថា ភាពឆ្មើងឆ្មៃគឺជាលក្ខណៈសម្បត្តិមួយដែលមានក្នុងចិត្តរបស់អ្នកមានទ្រព្យសម្បត្តិ ។ ទោះជាយ៉ាងណាក៏ដោយ ការណ៍នេះមិនពិតប្រាកដជានិច្ចនោះទេ នៅពេលដែលអ្នកបានរៀនក្នុងខគម្ពីរខាងក្រោមនេះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១៦–១៧ ដោយស្វែងរកថាតើចិត្តដែលមិនបានកែប្រែនោះ សម្ដែងចេញក្នុងអ្នកមាន និង អ្នកក្រយ៉ាងដូចម្ដេច ។ សូមគិតពីការគូសចំណាំអ្វីដែលអ្នករកឃើញ ។ សូមពិចារណាអំពីមូលហេតុដែលភាពឆ្មើងឆ្មៃ និង ភាពលោភលន់ មានលក្ខណៈដូចគ្នា ទោះជាអ្នកមាន ឬ អ្នកក្រក្ដី ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១៨ ដោយស្វែងរកការពិពណ៌នារបស់ព្រះអម្ចាស់ស្ដីពីចិត្ត និង វិញ្ញាណនៃបុគ្គលទាំងឡាយណាដែលនឹងទទួលបានពរ ។ សូមប្រើលេខយោង ដើម្បីយល់ពាក្យមួយចំនួន ដែលព្រះអម្ចាស់ប្រើ ។



អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖ « នៅពេលអ្នកស្វែងរកពរជ័យទាំងឡាយនៃការប្រែចិត្តជឿ នោះអ្នកអាចថ្វាយដល់ព្រះអម្ចាស់នូវអំណោយនៃចិត្តសង្រេង ឬ ប្រែចិត្ត និង វិញ្ញាណទន់ទាប ឬ គោរពប្រតិបត្តិរបស់អ្នក ។ ជាក់ស្ដែង វាគឺជាអំណោយនៃខ្លួនអ្នកផ្ទាល់តែម្ដង —គឺថាអ្នកជានរណា ហើយអ្នកនឹងក្លាយជានរណា » ( « When Thou Art Converted » *Ensign* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ១២ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១៩–២០ ដោយស្វែងរកពរជ័យ ដែលព្រះអម្ចាស់បានសន្យាដល់អ្នកដែលមានចិត្តទន់ទាប ។ វាអាចនឹងជួយអ្នកឲ្យដឹងថា « រង្វាន់ » របស់ព្រះអម្ចាស់មានន័យថា ទ្រង់នឹងសងនូវគ្រប់កិច្ចការល្អ និង អាក្រក់ទាំងអស់ដែលបានប្រព្រឹត្ត ។

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើពរជ័យទាំងឡាយដែលមានរ៉ាយរ៉ាប់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៦:១៨–២០ បើប្រៀបធៀបទៅនឹងទ្រព្យសម្បត្តិ និង ប្រាក់កាសដែល អែសរ៉ា ធេយែរ និង មនុស្សដទៃទៀតបានខ្វល់ខ្វាយនោះ មានលក្ខណៈដូចម្ដេច ?

ខ. តើអ្នកអាចធ្វើដូចម្ដេច ដើម្បីមានដួងចិត្ត ដែលនឹងទទួលបានពរជ័យ ដូចមាននៅក្នុងខគម្ពីរទាំងនេះ ?

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៣–៥៦ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

## មេរៀនទី ១៣ ៖ ថ្ងៃទី ១

# កន្លែងកណ្ដាលនៃក្រុងស៊ីយ៉ូន

### សេចក្ដីផ្ដើម

មេរៀននេះរំឭកអំពីព្រឹត្តិការណ៍បីបួនក្នុងប្រវត្តិសាសនាចក្រ ដែលកើតឡើងនៅយ៉ុំចាកសុន រដ្ឋ មិសសួរី ។ ក្នុងរដូវក្ដៅឆ្នាំ ១៨៣១ ពួកបរិសុទ្ធមួយចំនួន ដែលបានប្រមូលគ្នានៅរដ្ឋ អូហៃអូ បានចាប់ផ្ដើមធ្វើដំណើរទៅតាំងលំនៅនៅយ៉ុំចាកសុន រដ្ឋ មិសសួរី ។ ក្នុងវិវរណៈដែលបានប្រទានដល់ព្យាការី យ៉ូសែប ស្ម៊ីធ ក្នុងខែ កក្កដា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានចង្អុលបង្ហាញថា ក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី គឺជា « កន្លែងកណ្ដាល » នៃក្រុងស៊ីយ៉ូន ( គ. និង ស. ៥៧:៣ ) ។ ពួកបរិសុទ្ធបានចាប់ផ្ដើមស្ថាបនាទីក្រុង ហើយបានខ្នះខ្នែងរស់នៅតាមក្រឹត្យវិន័យទាំងឡាយនៃព្រះ ។ ទោះជាយ៉ាងណាក៏ដោយ ការទាស់ទែងគ្នាបានកើតឡើងរវាងពួកបរិសុទ្ធ និង ប្រជាជននៃរដ្ឋ មិសសួរី ដទៃទៀត ដែលបណ្ដាលឲ្យមានហិង្សាពីមនុស្សកំណាចប្រឆាំងនឹងពួកបរិសុទ្ធ ។ ពួកបរិសុទ្ធត្រូវបានបង្ខំឲ្យចាកចេញពីយ៉ុំចាកសុន ក្នុងខែ វិច្ឆិកា និង ខែ ធ្នូ ឆ្នាំ ១៨៣៣ ។

## ព្រះអម្ចាស់បានចង្អុលបង្ហាញថា ក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី គឺជាកន្លែងកណ្ដាលនៃក្រុងស៊ីយ៉ូន

សូមស្រមៃថា អ្នកកំពុងតែបោះជំរំ ហើយអ្នកដឹងថាមានព្យុះមួយនឹងបោកបក់មកដល់ ។ តើមានវិធីមួយចំនួនណាខ្លះ ដែលអ្នកអាចនឹងបានការការពារពីព្យុះនោះ ? តើត្រសាលអាចមានសារៈសំខាន់នៅក្នុងស្ថានភាពនេះដែរឬទេ ?

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ព្យាការី អេសាយ បានប្រើពាក្យត្រសាល ប្រដូចទៅនឹងក្រុងស៊ីយ៉ូនដែលត្រូវបានស្ថាបនាឡើងនៅថ្ងៃចុងក្រោយ ទុកជាការការពារសម្រាប់ពួកបរិសុទ្ធ ( សូមមើល អេសាយ ៥៤:២ ) ។ ពួកអ៊ីស្រាអែលបានប្រើត្រសាលធ្វើជាទីជម្រក ហើយស្នាក់នៅ កាលពួកគេរស់នៅ និង ធ្វើដំណើរក្នុងទីវាលរហោស្ថាន ។ ប្រធាន អ៊ែសរ៉ា ថាហ្វ បែនសឹន បានបង្រៀនអំពីនិមិត្តរូបដែលទាក់ទងទៅនឹងត្រសាលថា ៖



« សូមស្រមៃក្នុងចិត្តរបស់អ្នកអំពីត្រសាលដ៏ធំមួយ ដែលត្រូវបានចងដោយខ្សែភ្ជាប់ទៅនឹងស្នឹងជាច្រើនដែលត្រូវបានដំចូលទៅក្នុងដីយ៉ាងមាំ ។

« ព្យាការីបានប្រៀបប្រដូចស៊ីយ៉ូននៅថ្ងៃចុងក្រោយទៅនឹងត្រសាលដ៏ធំមួយនៅលើផែនដី ។ ត្រសាលនោះត្រូវបានចងដោយខ្សែយ៉ាងជាប់ ទៅនឹងចំរឹង ។ មែនហើយ ចំរឹងទាំងនោះគឺជាតំបន់ភូមិសាស្ត្រខុសៗគ្នាដែលមានទូទាំងផែនដី ។ ថ្មីៗនេះ សាសន៍អ៊ីស្រាអែលត្រូវបានប្រមូលផ្ដុំនៅស្តេកខុសៗគ្នានៃទីក្រុងស៊ីយ៉ូន » ( “Strengthen Thy Stakes,” *Ensign,* ខែ មករា ឆ្នាំ ១៩៩១ ទំព័រ ២ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:៦ ដោយស្វែងរកមើលប្រភេទនៃការការពារ ដែលព្រះអម្ចាស់បានសន្យាដល់អស់អ្នកដែលនឹងមកប្រមូលគ្នានៅក្រុងស៊ីយ៉ូន នៅថ្ងៃចុងក្រោយបង្អស់ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

ពួកបរិសុទ្ធថ្ងៃចុងក្រោយពីជំនាន់ដំបូង បានគិតថា ក្រុងស៊ីយ៉ូនជាទីកន្លែងសុខសាន្ត សុវត្ថិភាព និង ជាទីការពារពីពួកទុច្ចរិត ( សូមមើល គ. និង ស. ៤៥:៦៦–៧១ ) ។ ពួកគេបានរង់ចាំដោយអន្ទះសា ឲ្យព្រះអម្ចាស់បើកសម្ដែងពីទីតាំងនៃក្រុងស៊ីយ៉ូន ដើម្បីពួកគេអាចចាប់ផ្ដើមស្ថាបនាក្រុងស៊ីយ៉ូនដ៏បរិសុទ្ធរបស់ទ្រង់ឡើង ។ ក្នុងខែ កក្កដា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានប្រកាសថា ដែនដីមិសសួរី គឺជាដែនដីស៊ីយ៉ូនដែលបានសន្យា ហើយថា ក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី គឺជា « កន្លែងកណ្ដាល » នៃក្រុងស៊ីយ៉ូន ( សូមមើល គ. និង ស. ៥៧:១–៣ ) ។




១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ប្រសិនបើអ្នកគឺជាសមាជិកនៃសាសនាចក្រជំនាន់ដំបូង តើអ្នកអាចនឹងមានអារម្មណ៍ដូចម្ដេច នៅពេលបានដឹងអំពីទីកន្លែងដែលក្រុងស៊ីយ៉ូននឹងត្រូវបានស្ថាបនាឡើងនោះ ?

ខ. តើអ្នកនឹងចង់ចាប់ផ្ដើមស្ថាបនាក្រុងនោះឡើងនៅពេលណា ? ហេតុអ្វី ?

តើអ្នកធ្លាប់ដំឡើងត្រសាលដោយពុំត្រឹមត្រូវ ឬ ព្យាយាមដំឡើងវាដោយពុំប្រើប្រាស់ផ្នែកទាំងអស់របស់វាដែរឬទេ ? តើមានអ្វីបានកើតឡើង ឬ តើអ្នកគិតថានឹងមានអ្វីកើតឡើង ?

ដូចជាត្រសាលដែលត្រូវដំឡើងទៅតាមរបៀបត្រឹមត្រូវ និង ដោយប្រើប្រាស់ផ្នែកទាំងអស់របស់វា នោះក្រុងស៊ីយ៉ូនក៏ត្រូវតែបានស្ថាបនាឡើងស្របទៅតាមរបៀបជាក់លាក់មួយដែរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:៥ ដោយស្វែងរករបៀបដែល « ត្រសាល » នៃក្រុងស៊ីយ៉ូនត្រូវតែបានស្ថាបនាឡើង ដើម្បីឲ្យព្រះអម្ចាស់ទទួលយក ។

សូមកត់ចំណាំថា **ក្រុងស៊ីយ៉ូនត្រូវតែបានស្ថាបនាឡើងនៅលើគោលការណ៍នៃសុចរិតភាព ។** បន្ទាប់ពីព្រះអម្ចាស់បានបើកសម្ដែងពីទីតាំងនៃដែនដីក្រុងស៊ីយ៉ូនក្នុងឆ្នាំ ១៨៣១ ទ្រង់បានប្រទានវិវរណៈជាច្រើននៅពីរឆ្នាំក្រោយមក ដោយពិពណ៌នាអំពីគោលការណ៍ ដែលពួកបរិសុទ្ធគួរតែស្ថាបនាក្រុងស៊ីយ៉ូនឡើង ។

សូមអានវគ្គបទគម្ពីរខាងក្រោម ដោយស្វែងរកគោលការណ៍នៃសុចរិតភាព និង ព្រះបញ្ញត្តិទាំងឡាយដែលពួកបរិសុទ្ធត្រូវធ្វើតាមដើម្បីស្ថាបនាក្រុងស៊ីយ៉ូនឡើងដោយជោគជ័យ ។ នៅក្នុងចន្លោះដែលបានផ្ដល់ឲ្យ សូមសរសេរគោលការណ៍ និង ព្រះបញ្ញត្តិមួយចំនួន ដែលអ្នករកឃើញ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១៤–១៩

គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:១០–១៦

គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:២១–២២, ២៥–២៧ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤–៩

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការរស់នៅតាមគោលការណ៍នៃសុចរិតភាពទាំងនេះ បានជួយដល់ពួកបរិសុទ្ធឲ្យស្ថាបនាក្រុងស៊ីយ៉ូនឡើង ហើយត្រូវបានការពារពីព្យុះខាងវិញ្ញាណតាមរបៀបណា ?

ខ. តើការរស់នៅតាមគោលការណ៍ទាំងនេះ អាចនឹងជួយការពារយើងនាពេលសព្វថ្ងៃនេះយ៉ាងដូចម្ដេច ?

## ការទាស់ទែងគ្នាកើតឡើងរវាងពួកបរិសុទ្ធ និង ប្រជាជនរដ្ឋ មិសសួរី

បន្ទាប់ពីព្រះអម្ចាស់បានបើកសម្ដែងទីតាំងនៃក្រុងស៊ីយ៉ូនក្នុងខែ កក្កដា ឆ្នាំ ១៨៣១ ពួកបរិសុទ្ធជាច្រើនបានធ្វើដំណើរជិត ១៤៤៨ គីឡូម៉ែត្រពីទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ទៅកាន់ក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ដើម្បីតាំងលំនៅ និងស្ថាបនាក្រុងស៊ីយ៉ូនឡើង ។




សូមមើលទៅការណែនាំអំពីត្រសាលនៅដើមមេរៀននេះ ។ ជាញឹកញាប់ ត្រសាលពីបុរាណអាចពង្រីកទំហំបាន ដើម្បីបំពេញតាមការរីកធំឡើងនៃក្រុមគ្រួសារ ។ ក្នុងការបំពេញតាមការព្យាករណ៍មួយផ្នែករបស់ព្យាការី អេសាយគឺថា ព្រំដែននៃត្រសាលស៊ីយ៉ូនត្រូវបានពង្រីក ខ្សែត្រូវបានបន្លាយ ហើយស្នឹងត្រូវបានពង្រឹង ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ត្រូវបានចង្អុលបង្ហាញថាជា

« ស្តេកមួយដល់ក្រុងស៊ីយ៉ូន » ( គ. និង ស. ៨២:១៣ ) គឺនៅបន្ទាប់ពីកន្លែងកណ្ដាលនៃក្រុងស៊ីយ៉ូនត្រូវបានស្ថាបនាឡើង នៅក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ។ ទាំងក្នុងសាសនាចក្រពីជំនាន់ដំបូង និង ក្នុងសាសនាចក្រនៅជំនាន់សព្វថ្ងៃនេះ ពួកបរិសុទ្ធដែលប្រមូលគ្នានៅក្រុងស៊ីយ៉ូន ទទួលបានពរជ័យនៃការការពារពីក្រុងស៊ីយ៉ូន ។ ការណ៍នេះមានន័យថា ពួកបរិសុទ្ធដែលរស់នៅក្នុងស្តេកនៃស៊ីយ៉ូន អាចរីករាយនឹងពរជ័យ និង ការការពារដូចគ្នាទៅនឹងពួកបរិសុទ្ធដែលរស់នៅចំកន្លែងកណ្ដាលនៃក្រុងស៊ីយ៉ូនដែរ ។

សូមអានព័ត៌មានខាងក្រោមនេះ អំពីរបៀបដែលពួកបរិសុទ្ធដែលរស់នៅក្នុងស្តេកនៃស៊ីយ៉ូននៅទីក្រុង ខឺតឡង់ បានជួយជ្រោមជ្រែងក្នុងការស្ថាបនាកន្លែងកណ្ដាលនៃក្រុងស៊ីយ៉ូនឡើងនៅរដ្ឋ មិសសួរី ។ សូមស្វែងរកការណ៍ ដែលពួកបរិសុទ្ធនៅទីក្រុង ខឺតឡង់ បានធ្វើដើម្បីជួយស្ថាបនាក្រុងស៊ីយ៉ូនឡើង ។ អ្នកអាចនឹងចង់គូសចំណាំការយល់ដឹងមួយចំនួន ដែលអ្នកគិតថាមានប្រយោជន៍ ។

**ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ៖** ក្នុងសម័យប្រជុំសន្និសីទទូទៅមួយដែលបានប្រព្រឹត្តទៅក្នុងខែ វិច្ឆិកា ឆ្នាំ ១៨៣១ ព្យាការី យ៉ូសែប ស្ម៊ីធ និង ថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រ បានចងក្រងផ្ដុំគ្នានូវវិវរណៈទាំងឡាយ ដែលបានទទួលរហូតដល់ពេលនោះ ហើយបានគ្រោងនឹងបោះពុម្ពវិវរណៈទាំងនោះចេញជាព្រះគម្ពីរ ។ អូលីវើរ ខៅឌើរី និង យ៉ូហាន វិតមើរ បានទទួលខុសត្រូវក្នុងការនាំយកវិវរណៈទាំងនោះទៅកាន់រដ្ឋ មិសសួរី ដើម្បីឲ្យ វិលលាម ដ័បបុលយូ ហ្វែប្ស អាចបោះពុម្ពចេញជាព្រះគម្ពីរនៃបទបញ្ញត្តិ ។ អំឡុងឆ្នាំ ១៨៣១–៣២ យ៉ូសែប ស្ម៊ីធ បានបន្តទទួលវិវរណៈ ហើយខិតខំបកប្រែដ៏បំផុសគំនិតលើព្រះគម្ពីរប៊ីប ។ នារដូវផ្ការីកក្នុងឆ្នាំ ១៨៣២ លោកបានធ្វើដំណើរទៅកាន់រដ្ឋ មិសសួរី ដើម្បីសួរសុខទុក្ខដល់ពួកបរិសុទ្ធនៅក្រុងស៊ីយ៉ូន ដើម្បីព្រមានពួកគេថា សាតាំងកំពុងតែព្យាយាម « ដើម្បីបំបែរចិត្តពួកគេចេញពីសេចក្ដីពិត » ( គ. និង ស. ៧៨:១០ ) និង ដើម្បីចាត់ចែងឃ្លាំងរបស់ប៊ីស្សពនៅទីក្រុង ខឺតឡង់ និង ក្រុង អ៊ិនឌីប៉ែនដែនស៍ ។ ពួកបរិសុទ្ធជាច្រើនបានបន្តផ្លាស់លំនៅទៅកាន់ក្រុងស៊ីយ៉ូន ហើយត្រឹមចុងឆ្នាំ ១៨៣២ មានសមាជិកសាសនាចក្រប្រមាណមួយភាគបី បានរស់នៅក្នុងឃុំចាកសុន រដ្ឋ មិសសួរី ។ នៅក្នុងសាសនាចក្រជំនាន់ដំបូង ពួកបរិសុទ្ធរស់នៅរដ្ឋ អូហៃអូ និង ពួកបរិសុទ្ធរស់នៅរដ្ឋ មិសសួរី បានធ្វើការជាមួយគ្នា ដើម្បីផ្ដល់មូលនិធិជាប្រាក់ និង ជាធនធានក្នុងការស្ថាបនាក្រុងស៊ីយ៉ូនឡើង ។

សូមពិចារណាអំពីរបៀប ដែលព្យាការី យ៉ូសែប ស្ម៊ីធ និង ពួកបរិសុទ្ធដទៃទៀតក្នុងរដ្ឋ អូហៃអូ បានជួយដល់ពួកបរិសុទ្ធក្នុងរដ្ឋ មិសសួរី ស្ថាបនាក្រុងស៊ីយ៉ូនឡើង ។

សូមអានព័ត៌មានខាងក្រោម អំពីក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ដោយស្វែងរកអ្វីដែលរារាំងពួកបរិសុទ្ធពីការស្ថាបនាក្រុងស៊ីយ៉ូនឡើង ។ អ្នកអាចនឹងចង់គូសចំណាំការយល់ដឹងមួយចំនួន ដែលអ្នកគិតថាមានប្រយោជន៍ ។

**ក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ៖** ប៉ាលី ភី ប្រាត្ត បានពិពណ៌នាអំពីការតាំងលំនៅរបស់ពួកបរិសុទ្ធនៅក្រុងស៊ីយ៉ូន ដោយប្រកាសថា « សន្តិភាព និង ភាពសម្បូរសប្បាយបានបំពាក់មកុដដល់អ្នកប្រឹងប្រែងធ្វើការ ហើយទីរហោស្ថានបានក្លាយទៅជាចម្ការដែលពាសពេញទៅដោយភោគផល » ( *Autobiography of Parley Parker Pratt* ការបោះពុម្ពរបស់ ប៉ាលី ភី ប្រាត្ត [ ឆ្នាំ ១៩៣៨ ] ទំព័រ ៩៣ ) ។ ថ្នាក់ដឹកនាំនៃសាសនាចក្រនៅរដ្ឋ មិសសួរី បានទិញដី សាងសង់ឃ្លាំង និង ដំឡើងម៉ាស៊ីនបោះពុម្ព ហើយបានបំពេញតាមតម្រូវការរបស់ពួកបរិសុទ្ធដែលនឹងធ្វើដំណើរមកដល់ ។ ត្រឹមខែ កក្កដា ឆ្នាំ ១៨៣៣ ចំនួនសមាជិកនៃពួកបរិសុទ្ធថ្ងៃចុងក្រោយនៅទីនោះ បានកើនឡើងដល់ជិត ១២០០ នាក់ ។ ប៉ុន្តែ ថ្នាក់ដឹកនាំសាសនាចក្រ និង សមាជិកពុំមែនរស់នៅដោយពុំមានបញ្ហានោះទេ ។ សមាជិកមួយចំនួនបានអនុញ្ញាតឲ្យភាពអាត្មានិយម និង ភាពលោភលន់មករារាំងពួកគេពីការរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ។ មិនតែប៉ុណ្ណោះ អ្នកដែលរស់នៅក្នុងតំបន់នោះដែរ បានមានកង្វល់កាន់តែខ្លាំងអំពីវឌ្ឍនភាពយ៉ាងរហ័សរបស់ « ពួកមរមន » និង ឥទ្ធិពលរបស់ពួកគេទៅលើសេដ្ឋកិច្ច និង នយោបាយក្នុងស្រុក ។ ថ្នាក់ដឹកនាំសាសនាក្នុងតំបន់នោះ បានបរិសេធជំនឿរបស់ពួកបរិសុទ្ធ ។ ថ្នាក់ដឹកនាំសាសនាម្នាក់ បានរាលដាលពាក្យចចាមអារ៉ាមអំពីសមាជិកសាសនាចក្រ ហើយបានញុះញង់ឲ្យប្រជាជនប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងពួកគេ ។ ទីបំផុតការប៉ះទង្គិចគ្នាបានផ្ទុះឡើងក្នុងសណ្ឋានបែបជានយោបាយ រួមទាំងបញ្ហានៃទាសភាពផងដែរ ។ បន្ទាប់ពី វិលលាម ដ័បបុលយូ ហ្វែប្ស បានបោះពុម្ពអត្ថបទក្រោមចំណងជើងថា « ដោះលែងពួកស្បែកខ្មៅ » ជាអត្ថបទ ដែលប្រជាជនរដ្ឋ មិសសួរី ដែលភាគច្រើនជាអ្នកគាំទ្រទាសភាព សន្និដ្ឋានយ៉ាងខុសស្រឡះថា ពួកបរិសុទ្ធកំពុងតែអញ្ជើញពួកទាសករដែលត្រូវបានដោះលែងឲ្យទៅរដ្ឋ មិសសួរី ។ នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៨៣៣ មនុស្សកំណាចមួយក្រុមបានទៅក្រុងអ៊ិនឌីប៉ែនដែនស៍ បានគ្រវែងម៉ាស៊ីនបោះពុម្ពទៅលើផ្លូវ វាយកំទេចការិយាល័យបោះពុម្ព បំផ្លាញសន្លឹកទំព័រនៃព្រះគម្ពីរនៃបទបញ្ញត្តិដែលពុំទាន់បានកីបភ្ជាប់ លាបជ័រកៅស៊ូ ហើយចាក់ស្លាបសត្វនៅខ្លួនប៊ីស្សព អែតវឺត ប៉ាទ្រិច និង អ្នកប្រែចិត្តជឿឈ្មោះ ឆាលស៍ អេលែន ព្រមទាំងបានធ្វើឲ្យទីក្រុងទាំងមូលមានការភ័យរន្ធត់ ។ ការប្រទូសរ៉ាយបានបន្តកើតឡើង ហើយពួកបរិសុទ្ធត្រូវបានបង្ខំឲ្យចាកចេញពីឃុំចាកសុន ក្នុងខែ វិច្ឆិកា និង ខែ ធ្នូ ក្នុងឆ្នាំនោះឯង ។

សូមស្រមៃថាតើអ្នកអាចនឹងមានអារម្មណ៍ដូចម្ដេច ប្រសិនបើអ្នកគឺជាម្នាក់ក្នុងចំណោមពួកបរិសុទ្ធ ដែលបានសង្ឃឹមឲ្យមានការការពារពីព្រះអម្ចាស់ ប៉ុន្តែ បែរជាត្រូវបានបង្ខំឲ្យចាកចេញពីក្រុងស៊ីយ៉ូនទៅវិញ ។



៣. យោងតាមអ្វីដែលអ្នកបានរៀន សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលពួកបរិសុទ្ធជំនាន់ដំបូងបានពុះពារស្ថាបនាក្រុងស៊ីយ៉ូន ។ តើអ្នកអាចរៀនអ្វីខ្លះ ចេញពីបទពិសោធន៍របស់ពួកគេ ?

## តើក្រុងស៊ីយ៉ូននឹងទៅជាយ៉ាងណានៅពេលខាងមុខ ?

តើអ្នកធ្លាប់បានសង្ឃឹម ឬ រំពឹងឲ្យមានអ្វីមួយកើតឡើង ដែលពុំបានកើតឡើងដែរឬទេ ? តើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេចដែរ ?

សូមស្រមៃអំពីការខកចិត្ត និង ការភាន់ភាំងដែលពួកបរិសុទ្ធជំនាន់ដំបូងបានជួបប្រទះ នៅពេលសមាជិកសាសនាចក្រត្រូវបានបណ្ដេញចេញពីឃុំចាកសុន រដ្ឋ មិសសួរី ។ នៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ព្យាការី យ៉ូសែប ស៊្មីធ បានសរសេរសំបុត្រមួយច្បាប់ទៅកាន់ ពួកបរិសុទ្ធដែលត្រូវបាននិរទេស នៅមិនយូរប៉ុន្មានដែលពួកគេបានភៀសខ្លួនចេញពីឃុំចាកសុន ។ នៅក្នុងសំបុត្រនោះលោកបានសរសេរថា « នៅពេលយើងដឹងអំពីការរងទុក្ខរបស់បងប្អូនទាំងអស់គ្នា វាបានដាស់ឲ្យដួងចិត្តយើងមានការអាណិតអាសូរ វាធ្វើឲ្យយើងមានទុក្ខព្រួយ យើងមិនអាចទប់ទឹកភ្នែកមិនឲ្យស្រក់បានឡើយ » ( នៅក្នុង *History of the Church* ១:៤៥៤ ) ។



នៅក្នុងសំបុត្រនោះដែរ ព្យាការីបានសរសេរអំពីការទូលសួររបស់លោកចំពោះព្រះអម្ចាស់អំពីមូលហេតុដែលការរំពឹងទុករបស់ពួកបរិសុទ្ធចំពោះក្រុងស៊ីយ៉ូនត្រូវបានលោយសាបសូន្យថា ៖ « ខ្ញុំដឹងថា ក្រុងស៊ីយ៉ូននឹងត្រូវបានស្រោចស្រង់ស្របតាមពេលវេលារបស់ព្រះអម្ចាស់ ប៉ុន្តែ នៅពេលខ្ញុំទូលសួរអំពីបញ្ហាទាំងនេះថា តើនឹងមានថ្ងៃនៃការបន្សុទ្ធ ទុក្ខព្រួយ និង សេចក្ដីវេទនា ប៉ុណ្ណាទៀតដែលព្រះអម្ចាស់មិនទាន់បានបង្ហាញប្រាប់ នោះព្រះសូរសៀងនៃព្រះអម្ចាស់បានបន្លឺថា ៖ ចូរនៅឲ្យស្ងៀម ហើយចូរដឹងថា យើងគឺជាព្រះ ! អស់អ្នកដែលរងទុក្ខដោយសារតែព្រះនាមយើង នឹងបានសោយរាជ្យជាមួយយើង ហើយអ្នកណាដែលប្ដូរជីវិតរបស់ខ្លួនដោយយល់ដល់ព្រះនាមរបស់យើង នោះនឹងបានមកវិញ » ( នៅក្នុង *History of the Church* ១:៤៥៣–៥៤ ) ។

តើព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ យ៉ូសែប ស៊្មីធ ឲ្យធ្វើអ្វី កាលលោកបានទូលសួរអំពីមូលហេតុ ដែលពួកបរិសុទ្ធបានបរាជ័យក្នុងការស្ថាបនាក្រុងស៊ីយ៉ូន ? សូមគិតថាតើរបៀប ដែលព្រះអម្ចាស់បានឆ្លើយតបទៅនឹងសំណួររបស់ព្យាការី អាចជាប្រយោជន៍នៅពេលបញ្ហាទាំងឡាយក្នុងជីវិតអ្នកពុំដំណើរការទៅតាមអ្វី ដែលអ្នកសង្ឃឹម ឬ រំពឹងទុកតាមរបៀបណា ។

ក្រោយមក ព្រះអម្ចាស់បានប្រទានការយល់ដឹងបន្ថែម ទៅលើមូលហេតុដែលការព្យាយាមរបស់ពួកបរិសុទ្ធក្នុងការស្ថាបនាក្រុងស៊ីយ៉ូនត្រូវបានបរាជ័យ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:៥–៦, ៩–១០, ២៣–២៤ ដោយស្វែងរកការណ៍ដែលព្រះអម្ចាស់តម្រូវឲ្យរាស្ត្ររបស់ទ្រង់ធ្វើ ពីមុនក្រុងស៊ីយ៉ូនត្រូវបានស្ថាបនាឡើង ។

នៅក្នុងមេរៀននេះ ក្រុងស៊ីយ៉ូនត្រូវបានសំដៅទៅលើកន្លែង ដែលពួកបរិសុទ្ធស្ថាបនាទីក្រុងដ៏បរិសុទ្ធមួយ ដែលជាទីក្រុងយេរូសាឡិមថ្មី ។ ប៉ុន្តែ អត្ថន័យកង្រស៊ីយ៉ូន គឺជ្រាលជ្រៅជាងទីតាំងជាក់លាក់មួយ ដែលពួកបរិសុទ្ធអាចស្វែងរកការការពារទៅទៀត ។ ពួកបរិសុទ្ធជំនាន់ដំបូងអាចគិតថា វាគ្រាន់តែជាការស្ថាបនាទីក្រុងមួយតែប៉ុណ្ណោះ ប៉ុន្តែ ព្រះអម្ចាស់បានមានព្រះទ័យចង់ស្ថាបនាមនុស្សសុចរិតឲ្យដូចជាស្ថាបនាទីក្រុងដែរ ។ « ត្រសាល » ការពារនៃក្រុងស៊ីយ៉ូន អាចមាននៅគ្រប់ទីកន្លែងដែលប្រជាជនគោរពប្រតិបត្តិតាមក្រឹត្យវិន័យនៃនគរសេឡេស្ទាល ( សូមមើល គ. និង ស. ១០៥:៥ ) ។

អ្នកអាចនឹងចងចាំចេញពីការសិក្សារបស់អ្នកនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:២១ ដែលព្រះអម្ចាស់បានពន្យល់ថា **ក្រុងស៊ីយ៉ូនគឺជាក្រុងដែលមានចិត្តល្អសុទ្ធសាធ** ។ សូមរំឭកឡើងវិញ អំពីគោលការណ៍នៃសុចរិតភាព និង ព្រះបញ្ញត្តិទាំងឡាយដែលអ្នករកបាននៅមុននេះបន្តិចក្នុងមេរៀននេះ ។ សូមគិតអំពីរបៀបដែលគោលការណ៍សុចរិតទាំងនេះ ជួយបុគ្គលម្នាក់ឲ្យមានចិត្តល្អសុទ្ធសាធ ។

**អែលឌើរ ដេវីឌ អ័រ ស្ទូន នៃពួកចិតសិបនាក់ បានពន្យល់អំពីរបៀប ដែលយើងអាចស្ថាបនាក្រុងស៊ីយ៉ូនឡើងនៅជំនាន់យើងនេះថា ៖**



« ទោះជាយើងនៅទីណាក៏ដោយ ទោះជាទីក្រុងណាដែលយើងរស់នៅក៏ដោយ យើងអាចស្ថាបនាទីក្រុងស៊ីយ៉ូនផ្ទាល់ខ្លួនរបស់យើងដោយរស់នៅតាមគោលការណ៍នៃនគរសេឡេស្ទាល ហើយព្យាយាមឲ្យមានចិត្តល្អសុទ្ធសាធ ។ ក្រុងស៊ីយ៉ូនគឺជាក្រុងដែលមានសម្រស់ស្រស់ត្រកាល ហើយព្រះអម្ចាស់បានទ្រវាដោយព្រះហស្តទ្រង់ផ្ទាល់ ។ គេហដ្ឋានរបស់យើង អាចជាទីជ្រកកោន និង ទីការពារ ដូចជាក្រុងស៊ីយ៉ូនដែរ ។

« យើងពុំចាំបាច់ត្រូវធ្វើតាមវប្បធម៌នៃទីកន្លែង និង ពេលវេលានោះឡើយ ។ យើងអាចក្លាហានឡើង ហើយអាចដើរក្នុងមាគ៌ារបស់ព្រះអម្ចាស់ និង ដើរតាមស្នាមព្រះបាទាទ្រង់ ។ ហើយបើយើងធ្វើដូចនោះ យើងនឹងត្រូវបានហៅថាជាក្រុងស៊ីយ៉ូន ហើយយើងនឹងក្លាយជារាស្ត្រនៃព្រះអម្ចាស់ » ( « Zion in the Midst of Babylon » *Ensign* ឬ *លីអាហូណា* ខែឧសភា ឆ្នាំ ២០០៦ ទំព័រ ៩៣ ) ។

៤. សូមសង្ខេបនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្វីដែលអ្នកបានរៀននៅក្នុងមេរៀននេះអំពីក្រុងស៊ីយ៉ូន ។ តើអ្នកមានតួនាទីអ្វីខ្លះ ក្នុងការស្ថាបនាក្រុងស៊ីយ៉ូនឡើងនៅកន្លែងដែលអ្នករស់នៅ ?

៥. សូមពិចារណាអំពីគោលការណ៍នៃសុចរិតភាព ដែលអ្នកបានរាយនៅមុននេះបន្តិចក្នុងមេរៀននេះ ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគោលដៅមួយ ដែលនឹងជួយអ្នកឲ្យរស់នៅតាមគោលការណ៍មួយក្នុងចំណោមគោលការណ៍ទាំងនោះ ឲ្យបានកាន់តែស្មោះត្រង់ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សាមេរៀនអំពី កន្លែងកណ្ដាលនៃក្រុងស៊ីយ៉ូន ហើយបានបញ្ចប់វានៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៣ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧

## សេចក្ដីផ្ដើម

ក្នុងខែ មិថុនា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានបញ្ជាដល់ យ៉ូសែប ស្ម៊ីធ និង ពួកអែលឌើរដទៃទៀត ឲ្យកោះហៅប្រជុំគ្នាជាសន្និសីទនៃសាសនាចក្រនៅរដ្ឋ មិសសួរី ( សូមមើល គ. និង ស. ៥២ ) ។ ដោយបានគោរពប្រតិបត្តិចំពោះការបញ្ជានោះ យ៉ូសែប ស្ម៊ីធ និង អ្នកដទៃទៀត បានធ្វើដំណើរប្រមាណជា ១៤៤៨ គីឡូម៉ែត្រពីរដ្ឋ អូហៃអូ ទៅរដ្ឋ មិសសួរី ។ បន្ទាប់ពីព្យាការីបានធ្វើដំណើរទៅដល់រដ្ឋ មិសសួរី នោះលោកបានទទួលវិវរណៈ ដែលឥឡូវនេះបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានបើកសម្ដែងទីតាំងសម្រាប់ទីក្រុងស៊ីយ៉ូន ដែលបំពេញការសន្យាមួយ ដែលទ្រង់បានធ្វើពីដើមជាមួយពួកបរិសុទ្ធ ( សូមមើល គ. និង ស. ៥២ ) ។ ព្រះអម្ចាស់ ក៏បានណែនាំផងដែរដល់បុគ្គលជាច្រើន ទាក់ទងនឹងតួនាទីរបស់ពួកគេនៅក្នុងការស្ថាបនាទីក្រុងស៊ីយ៉ូនឡើង ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧:១–៦

*ព្រះអម្ចាស់បើកសម្ដែងទីតាំងនៃទីក្រុងស៊ីយ៉ូន*

សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោម ដោយព្យាការី យ៉ូសែប ស្ម៊ីធ ដើម្បីយល់ឲ្យបានកាន់តែច្បាស់អំពីអារម្មណ៍របស់លោកក្នុងការស្ថាបនា និង កសាងទីក្រុងស៊ីយ៉ូនឡើង ៖



« ការប្រជុំជាមួយពួកបងប្អូនប្រុស [ អូលីវើរ ខៅឌើរី, ពេត្រុស វីតមើរ ជុញ៉រ, សែបា ភីតើសុន និង ហ្វ្រេឌើរិក ជី វិលលាម្ស ជាមនុស្សទាំងអស់ដែលបានទៅធ្វើជាអ្នកផ្សព្វផ្សាយសាសនានៅរដ្ឋ មិសសួរី ] ដែលបានរង់ចាំការធ្វើដំណើរមកដល់របស់យើងអស់រយៈពេលជាយូរមកហើយនោះ បានប្រព្រឹត្តទៅជាការប្រជុំមួយដ៏អស្ចារ្យ ហើយពោរពេញទៅដោយទឹកភ្នែក ។ វាហាក់ដូចជារឿងមួយដ៏ប្រពៃ និង គួរឲ្យរីករាយសម្រាប់ពួកបងប្អូនប្រុសដើម្បីជួបប្រជុំគ្នាក្នុងសាមគ្គីភាព ។ ប៉ុន្ដែ ការយល់ឃើញរបស់យើងមានច្រើន កើតមានឡើងដោយសារយើងមកពីរដ្ឋដែលមានការរីកចម្រើនខ្ពស់ក្នុងសង្គមភាគខាងកើត ហើយឥឡូវនេះ យើងកំពុងស្ថិតនៅក្នុងតំបន់ព្រំដែនភាគខាងលិចនៃសហរដ្ឋ ដោយសម្លឹងមើលទៅវាលរហោស្ថានដ៏ធំល្វឹងល្វើយនៃមនុស្សដែលបានរស់នៅក្នុងពិភពងងឹត ជ្បិតប្រាកដណាស់វាត្រូវសង្កេតឲ្យឃើញអំពី សភាពទាបថោក កង្វះបញ្ញា ភាពសាហាវឃោរឃៅ និង ភាពនិន្នាឈ្នានីសពីសំណាក់មនុស្ស ដែលពុំដើរឲ្យទាន់សម័យកាល ហើយត្រូវមានអារម្មណ៍អាណិតអាសូរដល់សាធុជនទាំងឡាយ ដែលបានធ្វើដំណើរត្រាច់ចរដោយគ្មានបានបង្កើនភាពរីកចម្រើនភាពថ្លៃថ្នូរ ឬ សាសនាអ្វីទាល់តែសោះ មែនហើយ ហើយបន្លឺឡើងដោយភាសានៃពួកព្យាការីថា ៖ ‹ តើទីវាលរហោស្ថាននេះ នឹងក្លាយទៅជាសួនកុលាបដ៏រីកស្គុះស្គាយនៅពេលណា ? តើទីក្រុងស៊ីយ៉ូននឹងត្រូវបានស្ថាបនាឡើងក្នុងសិរីល្អរបស់វានៅពេលណា ហើយតើព្រះវិហារបរិសុទ្ធរបស់ទ្រង់នឹងសាងសង់ឡើងនៅទីណា ដែលគ្រប់អស់ទាំងសាសន៍នឹងនាំគ្នាចូលមកនៅថ្ងៃចុងក្រោយបង្អស់នោះ › ? មិនយូរប៉ុន្មាន ក្ដីអន្ទះសាររបស់យើងបានរសាយទៅដោយបានទទួលវិវរណៈក្រោយមកទៀត [ វិវរណៈ ៖ គ. និង ស. ៥៧ ] » ( នៅក្នុង *History of the Church* ១:១៨៩ ) ។

សូមគិតអំពីគ្រាដែលអ្នកបានរួមចំណែកក្នុងអ្វីមួយដោយភាពក្លៀវក្លាមានដូចជា ការប្រារព្ធពិធីបុណ្យ ឬ ថ្ងៃខួបកំណើត ការបម្រើបេសកកម្ម ការទៅព្រះវិហារបរិសុទ្ធ ការទទួលបានអំណោយមួយ ឬ ការទៅសួរសុខទុក្ខមនុស្សជាទីស្រឡាញ់ម្នាក់ ។ តើអ្នកបានមានអារម្មណ៍ដូចម្ដេច កាលព្រឹត្តិការណ៍នោះបានខិតជិតមកដល់ ? ហេតុអ្វីបានជាព្រឹត្តិការណ៍នេះ មានសារៈសំខាន់ដល់ម្ល៉េះចំពោះអ្នក ? តើទង្វើរបស់អ្នក ឆ្លុះបញ្ចាំងឲ្យឃើញភាពរំជើបរំជួលរបស់អ្នកចំពោះព្រឹត្តិការណ៍នេះយ៉ាងដូចម្ដេចដែរ ?

ពួកបរិសុទ្ធជំនាន់ដំបូងជាច្រើននាក់ បានរួមចំណែកយ៉ាងអន្ទះសាក្នុងការស្វែងយល់ពីទីតាំងពិតប្រាកដនៃទីក្រុងស៊ីយ៉ូន ។ ពីមុនវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧ ត្រូវបានប្រទានឲ្យ ពួកគេបានអានព្រះគម្ពីរមរមនអំពីទីក្រុងយេរ៉ូសាឡិមថ្មី ដែលនឹងត្រូវស្ថាបនាឡើងនៅលើទ្វីបអាមេរិក ( សូមមើល នីហ្វៃទី៣ ២០–២១ អេធើរ ១៣ ) ។ តាមរយៈវិវរណៈ ដែលត្រូវបានប្រទានដល់ ព្យាការី យ៉ូសែប ស្ម៊ីធ ពួកបរិសុទ្ធបានស្វែងយល់ថា ទីក្រុងស៊ីយ៉ូននឹងត្រូវស្ថាបនាឡើងនៅទីតាំងណាមួយក្នុងរដ្ឋ មិសសួរី ( សូមមើល គ. និង ស. ៥២:២, ៥, ៤២ ) ។

សូមចងចាំថា សមាជិកសាសនាចក្រទាំងបីក្រុមធំៗ ត្រូវបានហៅឲ្យធ្វើដំណើរជិត ១៤៤៨ គីឡូម៉ែត្រ ទៅកាន់រដ្ឋ មិសសួរី ៖ ព្យាការី និង ក្រុមតូចមួយនៃពួកអែលឌើរ ( សូមមើល គ. និង ស. ៥២–៥៣ ) ក្រុមអ្នកផ្សព្វផ្សាយសាសនា ដែលត្រូវបានហៅឲ្យផ្សាយដំណឹងល្អនៅតាមផ្លូវ ( សូមមើល គ. និង ស. ៥២ ) និង ពួកបរិសុទ្ធមកពីភូមិ ខូលស៊ីល រដ្ឋ នូវ យ៉ោក ដែលត្រូវបានដឹកនាំដោយ នូវល ណៃត៍ ( សូមមើល គ. និង ស. ៥៤ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧:១–៣ រួចគូសចំណាំអំពីទីតាំង ដែលទីក្រុងស៊ីយ៉ូនត្រូវបានស្ថាបនាឡើង ។

យោងតាមខគម្ពីរទាំងនោះ តើក្រុង អ៊ិនឌីប៉ែនដែនស៍មានទីតាំងនៅ កន្លែងណា នៃទីក្រុងស៊ីយ៉ូន ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧:៣ ឡើងវិញ រួចគូសចំណាំអំពីអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថានឹងត្រូវបានសាងសង់ឡើងនៅក្រុង អ៊ិនឌីប៉ែនដែនស៍ ឬ កន្លែងកណ្ដាលនៃទីក្រុងស៊ីយ៉ូននោះ ។

អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចតទៅនេះ ដាក់នៅលើគែមព្រះគម្ពីររបស់អ្នក ៖ **ព្រះវិហារបរិសុទ្ធស្ថិតនៅកន្លែងកណ្ដាលនៃទីក្រុងស៊ីយ៉ូន ។**

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ហេតុអ្វីបានជាមានសារៈសំខាន់ ដែលព្រះវិហារបរិសុទ្ធត្រូវមានទីតាំងនៅកន្លែងកណ្ដាលនៃទីក្រុងស៊ីយ៉ូន ?

ខ. ហេតុអ្វីបានជាវាអាចនឹងមានសារៈសំខាន់ ដែលត្រូវមានព្រះវិហារបរិសុទ្ធស្ថិតនៅក្នុងជីវិតរបស់យើង ?

សូមគិតអំពីការណ៍ទាំងឡាយ ដែលអាចបង្អាក់បុគ្គលម្នាក់ៗ ពីការទទួលបានពរជ័យទាំងឡាយនៃព្រះវិហារបរិសុទ្ធ ។ តើអាចនឹងមានអ្វីកើតឡើងចំពោះមនុស្ស ដែលផ្ដោតជីវិតខ្លួនទៅលើកិច្ចការខាងលោកិយ ?

២. សូមគូររូបផ្ទាំងស៊ីបមួយនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ដោយមានរង្វង់គោលដៅមួយនៅចំណុចកណ្ដាល ។ សូមសរសេរនៅលើផ្ទាំងស៊ីបនោះថា *ព្រះវិហារបរិសុទ្ធ* ។ បន្ទាប់មកសូមឆ្លើយសំណួរខាងក្រោមនេះ ៖



ក. តើជីវិតរបស់អ្នកអាចនឹងមានភាពខុសគ្នាយ៉ាងដូចម្ដេច ប្រសិនបើអ្នកផ្ដោតជីវិតអ្នកទាំងស្រុងទៅលើកិច្ចការខាងវិញ្ញាណ ដូចជាព្រះវិហារបរិសុទ្ធ ?

ខ. តើការដាក់ព្រះវិហារបរិសុទ្ធនៅចំណុចកណ្ដាលនៃជីវិតយើង អាចនឹងជួយយើងឲ្យផ្ដោតជីវិតយើងទៅលើព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ?

សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោម ដែលពិពណ៌នាអំពីពរជ័យទាំងឡាយ ដែលអ្នកអាចទទួលបាន នៅពេលអ្នកផ្ដោតជីវិតអ្នកទៅលើព្រះវិហារបរិសុទ្ធ ។ នៅពេលអ្នកអាន សូមគូសចំណាំពរជ័យណាមួយនៃពរជ័យទាំងនេះ ដែលអ្នកធ្លាប់ទទួលបាន ។



« ចំពោះអ្នកដែលមានភាពសក្ដិសម ហើយមានលទ្ធភាពចូលព្រះវិហារបរិសុទ្ធ ខ្ញុំសូមដាស់តឿនអ្នកឲ្យចូលព្រះវិហារបរិសុទ្ធជាញឹកញាប់ ។ ព្រះវិហារបរិសុទ្ធ គឺជាកន្លែងមួយ ដែលយើងអាចរកឃើញភាពសុខសាន្ត ។ នៅទីនោះ យើងទទួលបានការប្ដេជ្ញាចិត្តជាថ្មីចំពោះដំណឹងល្អ ហើយការតាំងចិត្តរបស់យើងត្រូវបានពង្រឹងបន្ថែមដើម្បីគោរពតាមព្រះបញ្ញត្តិទាំងឡាយ » ( ថូម៉ាស អេស ម៉នសុន « លុះត្រាយើងជួបគ្នាម្ដងទៀត » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ១១៣ ) ។



« ជួនកាល គំនិតយើងស្មុគស្មាញយ៉ាងខ្លាំង ដោយបញ្ហាផ្សេងៗ ហើយយើងមានរឿងជាច្រើន ដែលទាមទារឲ្យដោះស្រាយក្នុងពេលតែមួយ ដែលយើងមិនអាចគិតឃើញច្បាស់លាស់បាននោះទេ ។ នៅក្នុងព្រះវិហារបរិសុទ្ធ ធូលីដីនៃការរំខាន ហាក់ដូចជាត្រូវបានបោសសម្អាត អ័ព្ទ និង ព្រិល ហាក់ដូចជាបានរសាត់បាត់ ហើយយើងអាច ‹ មើលឃើញ › អ្វីៗ ដែលយើងពុំអាចមើលឃើញពីមុន ថែមទាំងរកឃើញមធ្យោបាយមួយ ដើម្បីដោះស្រាយបញ្ហាទាំងឡាយ ដែលយើងពុំបានដឹងពីមុន » ( ប៊ិយដ៍ ឃេ ផាកកឺ « *The Holy Temple* » *Ensign* ខែ តុលា ឆ្នាំ ២០១០ ទំព័រ ៣៥ ) ។



« នៅពេលយើងចូលចិត្ត ហើយស្រឡាញ់ព្រះវិហារបរិសុទ្ធ នោះជីវិតរបស់យើងនឹងឆ្លុះបញ្ចាំងឲ្យឃើញអំពីសេចក្ដីជំនឿរបស់យើង ។ នៅពេលយើងទៅព្រះដំណាក់ដ៏បរិសុទ្ធនេះ ហើយចងចាំនូវសេចក្ដីសញ្ញា ដែលយើងបានធ្វើនៅទីនោះ នោះយើងនឹងអាចប្រឈមមុខនឹងរាល់ការសាកល្បង ហើយយកឈ្នះលើរាល់ការល្បួងបាន ។ ព្រះវិហារបរិសុទ្ធផ្ដល់នូវគោលបំណងសម្រាប់ជីវិតយើង ។ វានាំយកភាពសុខសាន្តមកដល់ព្រលឹងយើង » ( ថូម៉ាស អេស ម៉នសុន « *Blessings of the Temple* » *Ensign* ខែ តុលា ឆ្នាំ ២០១០ ទំព័រ ១៥ ) ។



« ប្រសិនបើយើងគឺជាមនុស្សដែលចូលចិត្តទៅព្រះវិហារបរិសុទ្ធ នោះយើងនឹងក្លាយទៅជាមនុស្សកាន់តែប្រពៃឡើង ។. . . ខ្ញុំដឹងថា ជីវិតរបស់អ្នកមានការមមាញឹកណាស់ ។ ខ្ញុំដឹងថា អ្នកមានកិច្ចការច្រើនត្រូវធ្វើ ។ ប៉ុន្តែ ខ្ញុំសូមសន្យានឹងអ្នកថា ប្រសិនបើអ្នកទៅដំណាក់នៃព្រះអម្ចាស់ នោះអ្នកនឹងមានពរ ជីវិតនឹងមានសភាពកាន់តែប្រសើរឡើងសម្រាប់អ្នក » ( ហ្គរដុន ប៊ី ហ៊ិងគ្លី « Excerpts from Recent Addresses of President Gordon B. Hinckley » *Ensign* ខែ កក្កដា ឆ្នាំ ១៩៩៧ ទំព័រ ៧៣ ) ។



« ចូរយើងធ្វើជាមនុស្សដែលចូលចិត្តចូលរួម ហើយស្រឡាញ់ព្រះវិហារបរិសុទ្ធ ។ ចូរយើងប្រញាប់ទៅកាន់ព្រះវិហារបរិសុទ្ធ កាន់តែញឹកញាប់តាមពេលវេលា តាមមធ្យោបាយ និងតាមស្ថានភាពរបស់យើងផ្ទាល់តាមដែលអាចធ្វើទៅបាន ។ ចូរយើងទៅមិនសម្រាប់តែមរណជនរបស់យើងប៉ុណ្ណោះនោះទេ តែចូរយើងទៅ សម្រាប់ពរជ័យផ្ទាល់ខ្លួនរបស់យើង សម្រាប់ការថ្វាយបង្គំក្នុងព្រះវិហារបរិសុទ្ធ សម្រាប់បរិសុទ្ធភាព និងសុវត្ថិភាព ដែលត្រូវបានផ្ដល់ឲ្យនៅក្នុងជញ្ជាំងដ៏សក្ដិសិទ្ធ និង ឧទ្ទិសទាំងនោះផងដែរ ។ ព្រះវិហារបរិសុទ្ធជាទីដែលមានសោភ័ណភាពស្រស់ស្អាត ជាទីនៃវិវរណៈ វាជាទីដែលមានសេចក្ដីសុខសាន្ត ។ វាជាព្រះដំណាក់របស់ព្រះអម្ចាស់ ។ វាជាទីបរិសុទ្ធចំពោះព្រះអម្ចាស់ ។ វានឹងជាទីបរិសុទ្ធចំពោះយើង » ( ហាវើដ ដបុលយូ ហ៊ីនធើរ The Great Symbol of Our Membership » *Ensign* ខែ តុលា ឆ្នាំ ១៩៩៤ ទំព័រ ៥ ) ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើពរជ័យណាខ្លះដែលបានលើកឡើងនៅក្នុងសេចក្ដីថ្លែងការណ៍ខាងលើ ដែលអ្នកធ្លាប់ទទួលបាន ?

ខ. តើពរជ័យទាំងនេះ មានឥទ្ធិពលទៅលើជីវិតរបស់អ្នកយ៉ាងដូចម្ដេច ?



សូមពិចារណាអំពីអ្វីដែលអ្នកអាចធ្វើបានកាន់តែពេញលេញ ដើម្បីធ្វើឲ្យព្រះវិហារបរិសុទ្ធក្លាយជាចំណុចកណ្ដាលនៃជីវិតអ្នក ។ សូមដាក់គោលដៅដើម្បីបន្ត ឬ មានភាពសក្ដិសមកាន់បណ្ណចូលព្រះវិហារបរិសុទ្ធ និង ដើម្បីចូលព្រះវិហារបរិសុទ្ធជាញឹកញាប់តាមអំណោយផលនៃពេលវេលា ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧:៤–៦ កត់ត្រាថា ព្រះអម្ចាស់បានបញ្ជាពួកបរិសុទ្ធឲ្យទិញដីធ្លីនៅក្នុង និង ជុំវិញឃុំចាកសុនរដ្ឋ មិសស៊ូរី ដែលអាចឲ្យពួកគេចាប់ផ្ដើមស្ថាបនាទីក្រុងស៊ីយ៉ូនឡើង ហើយកសាងព្រះវិហារបរិសុទ្ធ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧:៧–១៦

*ព្រះអម្ចាស់ ណែនាំដល់បុគ្គលជាច្រើននាក់ ទាក់ទងនឹងតួនាទីរបស់ពួកគេនៅក្នុងការស្ថាបនាទីក្រុងស៊ីយ៉ូនឡើង*

សូមស្រមៃថា អ្នកមានវត្តមានជាមួយពួកបរិសុទ្ធនៅរដ្ឋ មិសសួរី កាលព្រះអម្ចាស់បានបើកសម្ដែងអំពីទីតាំងនៃទីក្រុងស៊ីយ៉ូន ហើយថាអ្នកត្រូវបានស្នើឲ្យបន្តនៅទីនោះ ដើម្បីជួយស្ថាបនាទីក្រុងនោះនៅក្រុង អ៊ិនឌីប៉ែនដែនស៍ ។ តើអ្នកនឹងមានអារម្មណ៍ដូចម្ដេច ដោយដឹងថាអ្នកមានការទទួលខុសត្រូវមួយដ៏សំខាន់បែបនោះ ? តើអ្នកនឹងចាប់ផ្ដើមស្ថាបនាទីក្រុងឡើង សម្រាប់ព្រះអម្ចាស់យ៉ាងដូចម្ដេច ? តើអ្នកនឹងចង់ឲ្យនរណាជួយអ្នកស្ថាបនាវាឡើង ?

៤. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧:៧–១៣ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមបង្កើតបញ្ជីឈ្មោះនៃបុរសទាំងបួននាក់ ដែលព្រះអម្ចាស់បានចាត់តាំងឲ្យជួយស្ថាបនាទីក្រុងស៊ីយ៉ូនឡើង និង អ្វីដែលទ្រង់បានចាត់ឲ្យពួកគេធ្វើ ។

បុរសម្នាក់ៗដែលត្រូវបានស្នើឲ្យតាំងលំនៅនៅរដ្ឋ មិសសួរី បានមានអំណោយទាន និង ទេពកោសល្យផ្សេងៗ ដែលត្រូវការដើម្បីជួយស្ថាបនាទីក្រុងស៊ីយ៉ូនឡើង ។ អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចតទៅនេះ ដាក់នៅលើគែមព្រះគម្ពីររបស់អ្នក ៖ **យើងគួរប្រើភាពខ្លាំងផ្ទាល់ខ្លួនយើង ដើម្បីជួយស្ថាបនានគរព្រះអម្ចាស់ឡើងនៅពេលទ្រង់ហៅយើងឲ្យធ្វើ ។**

សូមគិតអំពីមនុស្សដែលអ្នកស្គាល់ ដែលស្ថាបនាសាសនាចក្រឡើង ដោយប្រើភាពខ្លាំង អំណោយទានខាងវិញ្ញាណ ឬ ជំនាញផ្ទាល់ខ្លួន ។

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើភាពខ្លាំងរបស់អ្នកគឺជាអ្វី ?

ខ. តើអ្នកអាចប្រើភាពខ្លាំងរបស់អ្នកទៅផ្ដល់ពរដល់ក្រុមគ្រួសាររបស់អ្នក និង សាសនាចក្រយ៉ាងដូចម្ដេច ?

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៧ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៣ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨

## សេចក្តីផ្តើម

នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ១៨៣១ គឺជិតពីសប្តាហ៍បន្ទាប់ពីព្រះអម្ចាស់ចាត់តាំងក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ជាចំណុចកណ្ដាលនៃទីក្រុងស៊ីយ៉ូន នោះព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨ ។ វិវរណៈនេះត្រូវបានប្រទានជាចម្លើយដល់ អ្នកដែលអន្ទះសាចង់ដឹងអំពីព្រះឆន្ទៈរបស់ព្រះអម្ចាស់ ដែលមានចំពោះពួកគេនៅក្នុងដែនដីថ្មីនេះ ។

នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានប្រទានឱវាទដល់ពួកបរិសុទ្ធឲ្យស្មោះត្រង់ក្នុងទុក្ខលំបាករបស់ពួកគេ ហើយបានពន្យល់អំពីមូលហេតុដែលទ្រង់បានបញ្ជូនពួកគេទៅទីក្រុងស៊ីយ៉ូន ។ ព្រះអម្ចាស់ក៏បានលើកទឹកចិត្តពួកបរិសុទ្ធ ឲ្យប្រើសិទ្ធិជ្រើសរើសខ្លួន ដើម្បីនាំឲ្យមានសុចរិតភាព ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:១–១៣

*ព្រះអម្ចាស់បានប្រទានឱវាទដល់ពួកបរិសុទ្ធឲ្យស្មោះត្រង់ក្នុងទុក្ខលំបាករបស់ពួកគេ*

តើឧបសគ្គមួយចំនួនណាខ្លះ ដែលអ្នកកំពុងប្រឈមមុខនៅក្នុងជីវិតនាពេលបច្ចុប្បន្ន ?

នៅពេលអ្នកអានកថាខណ្ឌខាងក្រោមនេះ សូមស្វែងរកឧបសគ្គនានា ដែលពួកបរិសុទ្ធបានប្រឈមមុខនៅរដ្ឋ មិសសួរី ក្នុងឆ្នាំ ១៨៣១ ៖

ក្នុងខែ មករា ឆ្នាំ ១៨៣១ ពួកអ្នកផ្សព្វផ្សាយសាសនាបានជួបនឹងក្រុមឥណ្ឌាដេឡាវ៉ែ ( អាមេរិកកាំងដើម ) រស់នៅលើដែនដីពួកឥណ្ឌាលើព្រំប្រទល់រដ្ឋ មិសសួរី ។ ពួកឥណ្ឌាដេឡាវ៉ែ បានចាប់អារម្មណ៍រៀនដំណឹងល្អដែលមាននៅក្នុងព្រះគម្ពីរមរមន ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែពួកអ្នកផ្សព្វផ្សាយសាសនាពុំមានការអនុញ្ញាតឲ្យចូលទៅក្នុងដែនដីពួកឥណ្ឌា ហើយផ្សាយដំណឹងល្អ ហើយដោយសារតែមានការប្រឆាំងពីសំណាក់ភ្នាក់ងារ និង មេកន្ទ្រាញក្នុងមូលដ្ឋានរបស់ពួកឥណ្ឌា ទើបពួកអ្នកផ្សព្វផ្សាយសាសនានៃសាសនាចក្រ ត្រូវបានបង្ខំឲ្យចាកចេញពីដែនដីនោះទៅ ។ ក្រោយមក ពួកអ្នកផ្សព្វផ្សាយសាសនាបានព្យាយាមបង្រៀនអ្នកស្រុកស្បែក–សនៅក្រុង អ៊ិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី និង នៅតំបន់ជុំវិញនោះ ប៉ុន្តែ មានអ្នកប្រែចិត្តជឿមិនដល់ ១០ នាក់នោះទេ ដែលបានចូលសាសនាចក្រត្រឹមខែ កក្កដា ឆ្នាំ ១៨៣១ ។ នៅពេលពួកអែលឌើរនៃសាសនាចក្រដែលមកពីរដ្ឋ អូហៃអូ បានចាប់ផ្តើមមកដល់រដ្ឋ មិសសួរី ក្នុងខែ កក្កដា ឆ្នាំ ១៨៣១ នោះមានពួកអែលឌើរមួយចំនួនបានខកចិត្តចំពោះអ្វីដែលពួកគាត់បានឃើញ ។ ពួកគាត់មួយចំនួនបានរំពឹងចង់ឃើញសហគមន៍នៃពួកអ្នកជឿមួយដែលមានការរីកចម្រើនយ៉ាងឆាប់រហ័ស និង ការតាំងលំនៅដែលបានរៀបចំជាស្រេចសម្រាប់សមាជិកសាសនាចក្រដែលធ្វើសំណាក់ស្រុក ។ ពួកគាត់មួយចំនួនសម្តែងការព្រួយបារម្ភដោយសារតែនៅក្រុង អ៊ីនឌីប៉ែនដែនស៍ ស្ថិតនៅក្នុងស្ថានភាពពុំទាន់អភិវឌ្ឍនៅឡើយ ហើយនឹងតម្រូវឲ្យមានការខិតខំជាខ្លាំងដើម្បីអភិវឌ្ឍ ។ ពួកបងប្អូនប្រុសមួយចំនួន ត្រូវបានលើកទឹកចិត្តឲ្យស្នាក់នៅរដ្ឋ មិសសួរី ហើយទិញដីធ្លីដើម្បីត្រៀមស្ថាបនាទីក្រុងស៊ីយ៉ូនសម្រាប់ពួកបរិសុទ្ធដែលនឹងមកដល់ក្រោយៗមកទៀត ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:១–២ ដោយស្វែងរកការណ៍ដែលព្រះអម្ចាស់ បានមានព្រះបន្ទូលប្រាប់ពួកអែលឌើរ ដែលព្រះបន្ទូលទាំងនោះអាចនឹងជួយពួកគាត់ឲ្យមានអារម្មណ៍ប្រសើរឡើងវិញ ចំពោះឧបសគ្គដែលពួកគាត់បានប្រឈមមុខ ។

ចេញពីអ្វីដែលអ្នកបានរៀននៅក្នុង ខទី ២ សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ៖

**យើងនឹងមានពរបើយើង** ។

**រង្វាន់ដ៏អស់កល្បរបស់យើងនឹងប្រសើរជាងបើយើង** ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៣–៥ ដោយស្វែងរកការណ៍ដែលយើងពុំអាចមើលឃើញ ឬ យល់ នៅពេលយើងឆ្លងកាត់ការសាកល្បងនានា ។

ព្រះអម្ចាស់បានប្រទានឱវាទដល់ពួកអែលឌើរឲ្យមានសេចក្តីជំនឿលើទ្រង់ ហើយសម្លឹងមើលឲ្យហួសពីការសាកល្បងទាំងឡាយដែលពួកគាត់កំពុងតស៊ូ ហើយផ្តោតអារម្មណ៍ជំនួសវិញទៅលើសិរីល្អនាពេលអនាគត ដែលពួកគាត់នឹងជួបប្រទះ បើពួកគាត់

មានចិត្តស្មោះត្រង់ ។ សារលិខិតពីព្រះអម្ចាស់ទៅដល់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី អាចជួយយើងឲ្យតស៊ូក្នុងឧបសគ្គនានា ដោយរក្សាយើងឲ្យផ្ដោតអារម្មណ៍លើពរជ័យទាំងឡាយ ដែលបានសន្យាដល់អ្នកដែលតស៊ូក្នុងក្ដីវេទនាយ៉ាងស្មោះត្រង់ ។

១. សូមឆ្លើយសំណួរមួយ ឬ សំណួរទាំងពីរខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការជឿថាព្រះអម្ចាស់នឹងប្រទានពរដល់អ្នក អាចជួយអ្នកឲ្យតស៊ូក្នុងក្ដីវេទនាយ៉ាងស្មោះត្រង់យ៉ាងដូចម្ដេច ?

ខ. តើនៅពេលណាខ្លះ ដែលអ្នកធ្លាប់មានអារម្មណ៍ថា មានពរសម្រាប់ការមានចិត្តស្មោះត្រង់អំឡុងពេលក្ដីវេទនា ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៦–១៣ ព្រះអម្ចាស់បានបើកសម្ដែងវិធីមួយចំនួន ដែលពួកបរិសុទ្ធនឹងមានពរសម្រាប់ការគោរពប្រតិបត្តិរបស់ពួកគេក្នុងការជួយស្ថាបនាទីក្រុងស៊ីយ៉ូនឡើង ។ សូមធ្វើការតាំងចិត្តដើម្បីបន្តស្មោះត្រង់អំឡុងពេលអ្នកជួបឧបសគ្គ ដើម្បីអ្នកអាចទទួលបានរង្វាន់ដែលព្រះអម្ចាស់បានរៀបចំសម្រាប់អ្នក ទាំងពេលឥឡូវនេះ និង នាពេលអនាគត ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:១៤–២៣

*ព្រះអម្ចាស់បកស្រាយអំពីការទទួលខុសត្រូវរបស់ប៊ីស្សព និង ការបញ្ជាពួកបរិសុទ្ធឲ្យរក្សាច្បាប់ភូមិបាល ។*

ព្រះអម្ចាស់បានណែនាំប៊ីស្សព អែតវឺត ប៉ាទ្រិច និង ស៊ីឌនី គិលបឺត ឲ្យស្នាក់នៅរដ្ឋ មិសសួរី ដើម្បីគ្រប់គ្រងលើទ្រព្យសម្បត្តិសាសនាចក្រ ហើយទិញដីធ្លីនៅក្នុង និង ជុំវិញក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ( សូមមើល គ. និង ស. ៥៧:៧–៨ ) ។ ប៊ីស្សព ប៉ាទ្រិច បានជំទាស់ព្យាការី យ៉ូសែប ស្ម៊ីធ អំពីគុណភាពនៃដីធ្លីដែលបានជ្រើសរើស ។ គាត់បានមានអារម្មណ៍ថា គួរតែទិញដីឡូដ៍ផ្សេងទៀតវិញ ។ ការខ្វែងគំនិតគ្នានេះ បណ្ដាលឲ្យមានអារម្មណ៍មិនល្អកើតឡើង ។

សូមរំឭក គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៣ រួចអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:១៤–១៥ ដោយស្វែងរកការណ៍ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ប៊ីស្សព ប៉ាទ្រិច ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើគោលការណ៍ដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៣ អាចជួយដល់ប៊ីស្សព ប៉ាទ្រិច ឲ្យជ្រើសរើសប្រែចិត្ត ពីការជំទាស់ព្យាការី អំពីដីឡូដ៍ដែលគួរតែទិញនោះយ៉ាងដូចម្ដេច ?

ខ. សូមពិចារណាអំពីបញ្ហា ឬ ស្ថានភាពបច្ចុប្បន្ន ដែលសមាជិកមួយចំនួនអាចនឹងឆ្លើយតបទៅកាន់ថ្នាក់ដឹកនាំសាសនាចក្ររបស់ពួកគេដោយ « ការឥតជំនឿ និង ការខ្វាក់រឹងទទឹងនៃចិត្ត » ( គ. និង ស. ៥៨:១៥ ) ។ តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីចៀសវាងកំហុសមួយនោះ ?

ប៊ីស្សព ប៉ាទ្រិច បានទទួលយកការបន្ទោសពីព្រះអម្ចាស់ដោយរាបសា ហើយគាត់ត្រូវបានអត់ទោសឲ្យ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:១៦–២៣ ដោយស្វែងរកការណ៍ដែលព្រះអម្ចាស់បានបញ្ជាឲ្យ ប៊ីស្សព ប៉ាទ្រិច ធ្វើ ដើម្បីបំពេញការហៅបម្រើរបស់គាត់ ។ យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ២១–២៣ តើព្រះអម្ចាស់បានណែនាំពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ ? តើខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះ អំពីអ្នកដែលព្យាយាមប្រើក្រឹត្យវិន័យរបស់ព្រះដើម្បីបង្ហាញការមិនគោរពតាមច្បាប់ភូមិបាល ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:២៤–៣៣

*ព្រះអម្ចាស់ប្រទានឱកាសឲ្យពួកបរិសុទ្ធប្រើសិទ្ធិជ្រើសរើសខ្លួន ដើម្បីប្រព្រឹត្តល្អ*

សូមស្រមៃថា អ្នកកំពុងដើរតាមផ្លូវ ហើយបានឃើញមនុស្សចាស់ជរាម្នាក់ដើរដួល ។ សូមគូសរង្វង់លើអ្វីដែលអ្នកគួរតែធ្វើនៅក្នុងតារាងខាងក្រោមនេះ ។

| | |
|---|---|
| រង់ចាំព្រះវិញ្ញាណបំផុសឲ្យអ្នកជួយ ។ | រង់ចាំមើលថាតើមាននរណាម្នាក់នឹងជួយដែរឬទេ ។ |
| រង់ចាំមើលនរណាម្នាក់មកប្រាប់អ្នកថា ត្រូវធ្វើដូចម្ដេច ។ | ទៅជួយមនុស្សដែលដើរដួលនោះ ។ |

ហេតុអ្វីអ្នកជ្រើសរើសចម្លើយនោះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:២៤–២៨ ដោយស្វែងរកគោលការណ៍ ដែលព្រះអម្ចាស់បានបង្រៀនពួកបរិសុទ្ធនៅពេលពួកគេប្រឈមមុខនឹងឧបសគ្គនៃការស្ថាបនាទីក្រុងស៊ីយ៉ូនឡើង ។ អ្នកអាចនឹងចង់គូសចំណាំនូវគោលលទ្ធិ ដែលអ្នករកឃើញ ។ គោលការណ៍មួយដែលត្រូវបានបង្រៀននៅក្នុងខគម្ពីរទាំងនេះគឺ **យើងគួរតែឧស្សាហ៍ចូលរួមក្នុងការជ្រើសរើសធ្វើការណ៍ល្អ ហើយនាំមកនូវសេចក្ដីសុចរិត ។** ( ឃ្លា « អ្នកណាដែលត្រូវគេបង្ខំនូវគ្រប់អ្វីៗទាំងអស់ » [ គ. និង ស. ៥៨:២៦ ] សំដៅលើមនុស្សដែលមិនប្រព្រឹត្តអ្វីសោះ លុះត្រាតែត្រូវបានគេប្រាប់ឲ្យធ្វើ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:២៧ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ អ្នកអាចនឹងចង់គូសចំណាំវានៅក្នុងរបៀបមួយដែលងាយសម្គាល់ ដើម្បីអ្នកអាចងាយរកវាឃើញនៅពេលខាងមុខ ) ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

   ក. តើ « រង្វាន់ » អ្វី ដែលខគម្ពីរទាំងនេះសំដៅលើ ? តើការធ្វើកិច្ចការល្អជាច្រើនដោយឆន្ទៈយើងផ្ទាល់ នឹងមានអានុភាពយ៉ាងដូចម្ដេច ទៅលើការដែលយើងអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ឬ អត់នោះ ?

   ខ. តើមានរបៀបមួយចំនួនណាខ្លះ ដែលអ្នកអាចឧស្សាហ៍ចូលរួមក្នុងប្រយោជន៍ល្អនៅឯផ្ទះបាន ? នៅសាលាមានអ្វីខ្លះ ? នៅក្នុងវួដ ឬ សាខារបស់អ្នក ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:២៩–៣៣ ដោយស្វែងរកអ្វីដែលកើតឡើង ចំពោះអ្នកដែលប្រើសិទ្ធិជ្រើសរើសខ្លួនដើម្បីធ្វើប្រយោជន៍ល្អ ឬ ជាអ្នកដែលសង្ស័យនឹងព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ។ សូមគិតពីការគូសចំណាំអ្វីដែលអ្នករកឃើញ ។

## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:២៧

៤. ដើម្បីជួយអ្នកឲ្យទន្ទេញ គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:២៧ សូមសរសេរតួអក្សរដំបូងគេនៃពាក្យនីមួយៗនៅក្នុង ខទី ២៧ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមប្រើតួអក្សរដែលអ្នកបានសរសេរ ដើម្បីជួយអ្នកឲ្យសូត្រវគ្គបទគម្ពីរនោះ ។ ប្រសិនបើចាំបាច់ សូមបើកព្រះគម្ពីរមើល ។ សូមធ្វើដូចនេះម្ដងហើយម្ដងទៀត ដរាបដល់អ្នកអាចសូត្រវគ្គបទគម្ពីរបាន ដោយប្រើតួអក្សរដំបូង ឬ ដរាបដល់អ្នកអាចសូត្រខគម្ពីរនោះបានចេញពីការចងចាំ ។ សូមគិតអំពីការសូត្រ និង ពន្យល់អំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:២៧ ទៅដល់សមាជិកគ្រួសារ ឬ មិត្តភក្តិ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៣៤–៦៥

*ព្រះអម្ចាស់ប្រទានការណែនាំអំពីទីក្រុងស៊ីយ៉ូន ហើយបង្រៀនគោលការណ៍នៃការប្រែចិត្ត*

តើអ្នកដឹងយ៉ាងដូចម្ដេចថា ព្រះអម្ចាស់បានអភ័យទោសដល់អំពើបាបរបស់អ្នក ? សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៤២–៤៣ រួចគូសចំណាំការណ៍ ដែលព្រះអម្ចាស់បានបង្រៀនអំពីការអភ័យទោស ។ ( គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៤២–៤៣ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ អ្នកអាចនឹងចង់គូសចំណាំវានៅក្នុងរបៀបមួយដែលងាយសម្គាល់ ដើម្បីអ្នកអាចងាយរកវាឃើញនៅពេលខាងមុខ ) ។

សូមបញ្ចប់គោលការណ៍ដូចតទៅនេះចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៤២ ៖ **បើយើង នោះព្រះអម្ចាស់នឹងអត់ទោសឲ្យយើង ហើយមិនចាំពីអំពើបាបទាំងនោះទៀតទេ ។**

ឃ្លា « មិនចាំពីអំពើបាបទាំងនោះទៀតទេ » ពុំមានន័យថា ព្រះបំភ្លេចអំពើបាបរបស់យើងឡើយ ។ ព្រះទ្រង់ប្រកបដោយសព្វញាណ ដោយព្រះញ្ញាណដឹងនូវអ្វីគ្រប់ទាំងអស់—ដូច្នេះ ទ្រង់ពុំភ្លេចអ្វីសោះឡើយ ។ ទោះជាយ៉ាងណាក៏ដោយ អំពើបាបទាំងឡាយដែលបានប្រែចិត្តឡើងវិញ គឺត្រូវបានអត់ទោសឲ្យ ហើយនឹងមិនត្រូវចងចាំទៀតទេ ដោយការមិនប្រព្រឹត្តសាជាថ្មីនោះ ។

៥. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថាមានភាពខុសប្លែកយ៉ាងដូចម្ដេច នៅពេលបុគ្គលម្នាក់ជឿថា ព្រះអម្ចាស់នឹងអត់ទោសដល់អំពើបាបរបស់ខ្លួន ហើយមិនចាំពីអំពើបាបទាំងនោះទៀតទេនោះ ?

គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៤៣ បង្រៀនអំពីរបៀបដែលយើងអាចដឹង ថាតើយើងបានប្រែចិត្តពីអំពើបាបទាំងឡាយរបស់យើងហើយឬនៅ ។ សូមអានខគម្ពីរនេះ រួចបញ្ចប់គោលការណ៍ដូចតទៅនេះ ៖ **ដើម្បីប្រែចិត្ត យើងត្រូវតែ ហើយ អំពើបាបទាំងឡាយរបស់យើង ។**

ដើម្បីលោស់ចោលអំពើបាបមានន័យថា បែរចេញពីអំពើបាបទាំងស្រុង ហើយឈប់ប្រព្រឹត្តវាទៀត ។ នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍ដូចតទៅនេះដោយប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ក្នុងគណៈប្រធានទីមួយ សូមគិតអំពីគ្រា ដែលអ្នកបានប្រែចិត្ត ហើយទទួលបានអារម្មណ៍ថាព្រះអម្ចាស់បានអត់ទោសឲ្យ ៖ « នៅពេលយើងបានប្រែចិត្តយ៉ាងពិតប្រាកដ នោះព្រះគ្រីស្ទនឹងដកយកបន្ទុកនៃកំហុសចំពោះអំពើបាបរបស់យើងចេញ ។ យើងអាចដឹងដោយខ្លួនឯងថា យើងត្រូវបានអត់ទោសឲ្យ ហើយបានធ្វើឲ្យស្អាតស្អំ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងបញ្ជាក់ពីការណ៍នេះដល់យើង ។ ទ្រង់គឺជាអ្នកញែកឲ្យបរិសុទ្ធ ។ គ្មានទីបន្ទាល់ណាផ្សេងទៀតនៃការអភ័យទោស អាចអស្ចារ្យជាងនេះនោះទេ » ( Point of Safe Return, » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ១០១ ) ។



## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និងសេចក្ដីសញ្ញា ៥៨:៤២–៤៣

៦. សូមសរសេរវគ្គបទគម្ពីរនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:៤២–៤៣ នៅលើបណ្ណ ឬ ក្រដាសមួយសន្លឹក រួចសូត្រវារាល់ពេលដែលអ្នកលុតជង្គង់អធិស្ឋាន ។ ការធ្វើបែបនេះអាចជួយអ្នកឲ្យចងចាំអំពីវគ្គបទគម្ពីរនេះ ហើយរំឭកអ្នកឲ្យអធិស្ឋានសុំជំនួយក្នុងការខិតខំ ដើម្បីសារភាពកំហុស ហើយលោស់ចោលអំពើបាបទាំងឡាយ ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៣ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩

## បុព្វកថា

នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៨៣១ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩ កាលកំពុងស្នាក់នៅឃុំចាកសុន រដ្ឋ មិសសួរី ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានលើកឡើងអំពីការរំពឹងទុករបស់ទ្រង់ចំពោះពួកបរិសុទ្ធ ដែលទើបតែបានធ្វើដំណើរមកដល់ទីក្រុងស៊ីយ៉ូន រួមបញ្ចូលទាំងការរក្សាថ្ងៃឈប់សម្រាកឲ្យបានត្រឹមត្រូវ ។ ព្រះអម្ចាស់ក៏បានបញ្ជាក់ផងដែរថា អ្នកដែលគោរពតាមព្រះបញ្ញត្តិទាំងឡាយនឹងទទួលបានពរជ័យខាងវិញ្ញាណ និង ខាងសាច់ឈាម ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:១–៤

*ព្រះអម្ចាស់ពិពណ៌នាអំពីពរជ័យទាំងឡាយ ដែលទ្រង់នឹងប្រទានដល់ពួកបរិសុទ្ធស្មោះត្រង់នៅទីក្រុងស៊ីយ៉ូន ។*

ផូលី ណៃត៍ ដែលជាម្ដាយរបស់ នូវល ណៃត៍ បានធ្វើដំណើរជាមួយក្រុមពួកបរិសុទ្ធជិត ១៤៤៨ គីឡូម៉ែត ពីទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ទៅកាន់ ឃុំចាកសុន រដ្ឋ មិសសួរី ។ បងស្រី ណៃត៍ បានធ្លាក់ខ្លួនឈឺជាទម្ងន់នៅតាមផ្លូវទៅកាន់រដ្ឋ មិសសួរី ប៉ុន្តែគាត់ពុំព្រមឈប់ធ្វើដំណើរនោះទេ ដោយប្រាប់គេឯងថា បំណងប្រាថ្នាដ៏ធំបំផុតរបស់គាត់គឺ ឲ្យបានជាន់លើទឹកដីនៃទីក្រុងស៊ីយ៉ូន ហើយសពគាត់ត្រូវបញ្ចុះនៅទីនោះ ។ កូនប្រុសរបស់គាត់ នូវល កត់ត្រាថា នៅគ្រាមួយអំឡុងការធ្វើដំណើររបស់ពួកគេនោះគាត់ « បានទិញឈើមកធ្វើក្ដាមឈូស ក្នុងករណីបងស្រី ណៃត៍ អស់ជីវិតពីមុនយើងទៅដល់ទិសដៅ—ព្រោះស្ថានភាពគាត់ចុះអន់ថយយ៉ាងឆាប់រហ័ស ។ ប៉ុន្តែ ព្រះអម្ចាស់បានសម្រេចបំណងប្រាថ្នានៅក្នុងចិត្តរបស់គាត់ ហើយបានជីវិតរហូតដល់បានឈរនៅលើដែនដីនោះ » (*Scraps of Biography: Tenth Book of the Faith–Promoting Series* [ ឆ្នាំ ១៨៨៣ ] ទំព័រ ៧០ សូមមើលផងដែរ *History of the Church* ១:១៩៩ ) ។ បងស្រី ណៃត៍ បានទទួលមរណភាពទៅនៅពីរសប្ដាហ៍បន្ទាប់ពីបានធ្វើដំណើរទៅដល់ឃុំចាកសុន រដ្ឋ មិសសួរី ( ទីក្រុងស៊ីយ៉ូន ) ។

១. នៅថ្ងៃដែល ផូលី ណៃត៍ បានទទួលមរណភាពនោះ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩ ។ សូមស្រមៃថា អ្នកត្រូវបានស្នើឲ្យថ្លែងនៅក្នុងពិធីបុណ្យសពរបស់បងស្រី ណៃត៍ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:១–២ រួចស្វែងរកឃ្លាដែលអ្នកអាចចែកចាយនៅក្នុងសុន្ទរកថារបស់អ្នក ដែលអាចនឹងមានអត្ថន័យជ្រាលជ្រៅចំពោះមិត្តភក្តិ និង មនុស្សជាទីស្រឡាញ់របស់គាត់ ។ សូមកត់ត្រានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក យ៉ាងហោចណាស់ឲ្យបានពីរឃ្លា ហើយពន្យល់អំពីមូលហេតុដែលឃ្លាទាំងនោះ ត្រូវនឹង ផូលី ណៃត៍ ។

សូមកត់ចំណាំថា នៅក្នុង ខទី ១ ព្រះអម្ចាស់បានប្រទានវិវរណៈដល់ពួកបរិសុទ្ធដូចជា ផូលី ណៃត៍ ដែលបានគោរពប្រតិបត្តិតាមព្រះបញ្ញត្តិ ក្នុងការមកឲ្យដល់ដែនដីនៃទីក្រុងស៊ីយ៉ូន ដោយភ្នែកស្មោះត្រង់ទាំងស្រុងចំពោះសិរីល្អរបស់ទ្រង់ ។ អ្នកអាចនឹងចង់គូសចំណាំឃ្លានេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។ ដើម្បីជួយអ្នកឲ្យយល់កាន់តែច្បាស់ អំពីអត្ថន័យនៃការមានភ្នែកស្មោះត្រង់ទាំងស្រុងចំពោះសិរីល្អរបស់ព្រះ សូមសាកល្បងធ្វើសកម្មភាពដូចខាងក្រោមនេះ ៖

ក្ដាប់ដៃរបស់អ្នកធូរៗ ( គ្រាន់តែល្មមឲ្យមេដៃ និង ម្រាមដៃរបស់អ្នកប៉ះគ្នា ) ។ បិទភ្នែកម្ខាង ហើយសំឡឹងទៅរូបភាពព្រះអង្គសង្គ្រោះនៅលើទំព័រនេះតាមប្រហោងកន្ដាប់ដៃរបស់អ្នក ។ រួចបើកភ្នែកម្ខាងទៀត ហើយសម្លឹងមើលទៅរូបភាពដោយភ្នែកទាំងគូ ។ សូមកត់ចំណាំអ្វីផ្សេងទៀត នៅក្នុងចក្ខុនិមិត្តអ្នក នៅពេលអ្នកប្រើកែវភ្នែកទាំងគូសម្លឹងមើល ។ តើមានភាពខុសប្លែកអ្វីខ្លះ នៅពេលអ្នកមើលទៅរូបភាពដោយភ្នែកតែម្ខាង ?



ដោយប្រើប្រាស់អ្វីដែលអ្នកបានរៀននៅក្នុងសកម្មភាពនេះជាការប្រដូច តើអ្នកគិតថា ការមានភ្នែកស្មោះត្រង់ទាំងស្រុងចំពោះសិរីល្អរបស់ព្រះ មានន័យដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៣–៤ សូមស្វែងរកទាំងពរជ័យខាងសាច់ឈាម ( លោកិយ ) និង ខាងវិញ្ញាណ ដែលបានសន្យាដល់អ្នកដែលបានគោរពប្រតិបត្តិដល់ព្រះអម្ចាស់ ដោយភ្នែកស្មោះត្រង់ទាំងស្រុងចំពោះសិរីល្អរបស់ទ្រង់ ។ សូមកត់ចំណាំថា នៅក្នុង ខទី ៤ ព្រះអម្ចាស់សន្យាថានឹងប្រទានពរដល់ពួកបរិសុទ្ធទ្រង់ដែលស្មោះត្រង់ដោយ « ព្រះបញ្ញត្តិទាំងឡាយដ៏មិនតិច » ។ តើអ្នកគិតថា ហេតុអ្វីបានជាព្រះអម្ចាស់បានសន្យាថានេះគឺជាពរជ័យ កាលមនុស្សមួយចំនួនមិនចាត់ទុកព្រះបញ្ញត្តិទាំងឡាយថាជាពរជ័យផងនោះ ? សូមពិចារណាអំពីរបៀប ដែលការធ្វើតាមព្រះបញ្ញត្តិទាំងឡាយប្រទានពរដល់ជីវិតរបស់អ្នក ។

២. សូមគូសប្រអប់ឈរពីរនៅលើទំព័រមួយ ក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមសរសេរនៅក្នុងប្រអប់ឈរទីមួយថា *ពរជ័យខាងសាច់ឈាម* និង នៅក្នុងប្រអប់ឈរទីពីរថា *ពរជ័យខាងវិញ្ញាណ* ។ សូមសរសេរពរជ័យដែលអ្នកបានរកឃើញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:១–៤ នៅក្នុងប្រអប់ឈរដែលត្រឹមត្រូវ ។

អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចតទៅនេះ ដាក់នៅលើគែមព្រះគម្ពីររបស់អ្នក ៖ **បើយើងគោរពតាមព្រះបញ្ញត្តិទាំងឡាយ ដោយភ្នែកស្មោះត្រង់ទាំងស្រុងចំពោះសិរីល្អរបស់ព្រះ នោះយើងនឹងមានពរទាំងខាងសាច់ឈាម និង ខាងវិញ្ញាណផង ។** សូមស្វែងរកឧទាហរណ៍បន្ថែមអំពីគោលការណ៍នេះ នៅពេលអ្នកបន្តសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៥–៨

*ព្រះអម្ចាស់ប្រទានព្រះបញ្ញត្តិទៅដល់ពួកបរិសុទ្ធ*



ព្រះអម្ចាស់បានបន្តវិវរណៈនេះ ដោយបានប្រទានព្រះបញ្ញត្តិមួយចំនួនដល់ពួកបរិសុទ្ធនៅទីក្រុងស៊ីយ៉ូន ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៥ រួចគូសចំណាំព្រះបញ្ញត្តិទីមួយដែលព្រះអម្ចាស់បានប្រទាន ៖ **យើងត្រូវស្រឡាញ់ដល់ព្រះឲ្យអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងនៃយើង ។**

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ការស្រឡាញ់ព្រះអម្ចាស់ឲ្យអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងរបស់អ្នក មានន័យដូចម្ដេច ?

ខ. តើសកម្មភាព ឬ អាកប្បកិរិយាមួយចំនួនណាខ្លះ ដែលអ្នកអាចមើលឃើញនៅក្នុងមនុស្ស ដែលស្រឡាញ់ព្រះអម្ចាស់ដោយអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងរបស់ពួកគេ ?

សូមគិតអំពីរបៀបដែលព្រះបញ្ញត្តិឲ្យស្រឡាញ់ព្រះឲ្យអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំង អាចមានឥទ្ធិពលលើរបៀប ដែលយើងប្រព្រឹត្តចំពោះព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ។ សូមចែកចាយជាមួយសមាជិកគ្រួសារ ឬ មិត្តភក្តិ អំពីគ្រាមួយដែលសេចក្ដីស្រឡាញ់របស់អ្នកដែលមានចំពោះព្រះអម្ចាស់ បានមានឥទ្ធិពលទៅលើការសម្រេចចិត្តដែលអ្នកបានធ្វើ ។ អ្នកអាចនឹងចង់សួរបុគ្គល ដែលអ្នកជជែកជាមួយនោះ ថាតើការស្រឡាញ់ព្រះអម្ចាស់ បានមានឥទ្ធិពលលើរបៀបដែលគាត់ប្រព្រឹត្តចំពោះព្រះបញ្ញត្តិទាំងឡាយរបស់ព្រះយ៉ាងដូចម្ដេច ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៦–៨ មានបញ្ចូលព្រះបញ្ញត្តិបន្ថែម ដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធនៅគ្រានេះ ។ នៅពេលអ្នកអានខគម្ពីរទាំងនេះ សូមពិចារណាអំពីរបៀបដែលការគោរពតាមព្រះបញ្ញត្តិទាំងនេះ អាចអនុញ្ញាតឲ្យយើងបង្ហាញសេចក្ដីស្រឡាញ់ចំពោះព្រះអម្ចាស់ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៦ ព្រះអម្ចាស់សំដៅទៅលើឃាតករសម្លាប់មនុស្ស ហើយបានមានព្រះបន្ទូលថា យើងមិនត្រូវ « ប្រព្រឹត្តអំពើអ្វីដូចនោះឲ្យសោះ » ។ តើការរំលូតកូន « ដូចជា » ឃាតករសម្លាប់មនុស្សយ៉ាងដូចម្ដេច ? ( សូមមើល *ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ*[ឆ្នាំ ២០០៤ ] ទំព័រ ៤–៥) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៩–១៩

*ព្រះអម្ចាស់បង្រៀនដល់ពួកបរិសុទ្ធអំពីថ្ងៃឈប់សម្រាក*

ព្រះអម្ចាស់ប្រទានព្រះបញ្ញត្តិមួយ ដែលអាចជួយពួកបរិសុទ្ធឲ្យដាក់ព្រះជាត្រីមុខនៅក្នុងជីវិតពួកគេ ហើយពង្រឹងទំនាក់ទំនងពួកគេជាមួយនឹងព្រះ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៩–១០ រួចស្វែងរកព្រះបញ្ញត្តិ ដែលព្រះអម្ចាស់បានគូសបញ្ជាក់នៅក្នុងខគម្ពីរទាំងនេះ ។

នៅក្នុង ខទី ៩ ព្រះអម្ចាស់សន្យាថានឹងប្រទានពរជ័យដ៏មហិមាមួយ ចំពោះអ្នកទាំងឡាយដែលរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។ សូមរំឭក ខទី ៩ រួចស្វែងរកការសន្យា ដែលព្រះអម្ចាស់បានប្រទានឲ្យ ។ វាអាចនឹងមានប្រយោជន៍ដើម្បីដឹងថា « ការមិនប្រឡាក់ពីលោកិយ » សំដៅទៅលើ ការស្អាតស្អំពីការពេញទៅដោយអំពើបាបនៃលោកិយ ។ ដោយប្រើអ្វីដែលខគម្ពីរនេះបង្រៀន សូមបញ្ចប់គោលការណ៍ដូចតទៅនេះជាពាក្យពេចន៍របស់អ្នកផ្ទាល់ ៖ **បើយើង នោះវានឹងជួយយើង** ។



អែលឌើរ ម៉ាក អ៊ី ភីធើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានថ្លែងអំពីព្រះបញ្ញត្តិនៃការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ៖ « ការប្រតិបត្តិតាម ឬ មិនប្រតិបត្តិតាមថ្ងៃឈប់សម្រាករបស់យើង គឺជារង្វាស់ដ៏ពិតប្រាកដមួយនៃឥរិយាបថរបស់យើងផ្ទាល់ ចំពោះព្រះអម្ចាស់ និង ចំពោះការរងទុក្ខរបស់ទ្រង់នៅក្នុងច្បារ គែតសេម៉ានី ការសុគតរបស់ទ្រង់នៅលើឈើឆ្កាង និង ការមានព្រះជន្មរស់ឡើងពីការសុគតរបស់ទ្រង់វិញ ។ វាគឺជាទីសម្គាល់មួយ ថាតើយើងគឺជាពួកគ្រីស្ទាននៅក្នុងគ្រប់ទង្វើដៃឬទេ ថាតើការប្រែចិត្តជឿរបស់យើងរាក់កំភែល ដែលការរំឭកអំពីការបូជាដ៏ធួនរបស់ទ្រង់នោះ មានន័យតិចតួច ឬ គ្មានន័យអ្វីសោះចំពោះយើង » ( "The Sabbath Day," ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ៤៩ ) ។

តើអ្នកបង្ហាញសេចក្ដីស្រឡាញ់របស់អ្នកដល់ព្រះអម្ចាស់ នៅថ្ងៃឈប់សម្រាកយ៉ាងដូចម្ដេច ?

៤. សូមចែកចាយនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបដែលការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ បានផ្ដល់ ឬ អាចផ្ដល់អំណាចឲ្យអ្នកក្លាយជាស្អាតស្អំ ហើយបន្តស្អាតស្អំពីភាពពេញទៅដោយអំពើបាបនៃលោកិយនេះ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៩–១៥ ជួយយើងឲ្យយល់ អំពីគោលដៅនៃថ្ងៃឈប់សម្រាក និង អំពីអ្វីដែលយើងអាចធ្វើដើម្បីរក្សាវាឲ្យបានបរិសុទ្ធ ។ សូមអាន ខទី ៩–១៥ ដោយប្រុងប្រយ័ត្ន ដោយស្វែងរកការយល់ដឹងជ្រាលជ្រៅនៃរបៀបដែលយើងអាចរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។ ឧទាហរណ៍ នៅក្នុង ខទី ៩ អ្នកអាចរកឃើញថា « ការទៅដំណាក់នៃការអធិស្ឋាន » ( ការទៅព្រះវិហារ ) គឺជាផ្នែកមួយដ៏សំខាន់ក្នុងការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។ សូមមើលការយល់ដឹងជ្រាលជ្រៅដទៃទៀត ដែលអ្នកអាចស្វែងរកបាននៅពេលអ្នកអានខគម្ពីរទាំងនេះ ។ ( វាអាចនឹងមានប្រយោជន៍ ដើម្បីដឹងថា ឃ្លា « ថ្វាយភក្ដីភាពរបស់អ្នក » ដែលមាននៅក្នុង ខទី ១០ មានន័យថា ការថ្វាយបង្គំ ឬ ការបង្ហាញសេចក្ដីស្រឡាញ់ និង ភាពស្មោះស្ម័គ្ររបស់យើង ។ ក៏មានលេខយោងទី ១២ *ក* ផងដែរ ដែលពន្យល់អំពីពាក្យ *ដង្វាយទាំងឡាយ* ដែលសំដៅទៅលើ « ពេលវេលា ឬ ការប៉ិនប្រសប់ ឬ របស់របរនានាក្នុងការបម្រើព្រះ និង មនុស្សទូទៅ » ពាក្យ *របស់របរ* ជាទូទៅសំដៅទៅលើប្រាក់កាស ឬ ធនធាន ដែលយើងបរិច្ចាគទៅក្នុងសាសនាចក្រ ) ។

៥. សូមធ្វើបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ឲ្យបានយ៉ាងហោចណាស់ការយល់ដឹងជ្រាលជ្រៅចំនួនប្រាំមួយ ដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:៩–១៥ អំពីការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។ ការយល់ដឹងជ្រាលជ្រៅទាំងនេះរួមបញ្ចូលទាំងការណ៍ដែលសកម្មភាព ឬ ឥរិយាបថយើងគួរតែមាន ឬ គោលបំណងនៃថ្ងៃឈប់សម្រាករបស់ព្រះអម្ចាស់ ។ នៅពេលអ្នកបានបញ្ចប់បញ្ជីរបស់អ្នក សូមពិចារណាអំពីរបៀបដែលការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធដែលមាននៅក្នុងប្រធានបទនេះ បានមានឥទ្ធិពលលើទំនាក់ទំនងរបស់អ្នកជាមួយព្រះអម្ចាស់ ។

*ការធ្វើបញ្ជី*

បញ្ជីអាចជួយអ្នកឲ្យរៀបចំអ្វី ដែលអ្នកបានរៀនចេញពីព្រះគម្ពីរ ដើម្បីអ្នកអាចចងចាំវា ហើយចែកចាយអ្វីដែលអ្នកដឹងជាមួយមនុស្សដទៃ ។ នៅពេលបង្កើតបញ្ជី សូមបង្កើតចំណងជើងឲ្យច្បាស់ ហើយបញ្ចូលព័ត៌មានឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យអ្នកអាចចងចាំអំពីគោលបំណងនៃបញ្ជីនេះនៅពេលក្រោយមកទៀត ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:១៥–១៩ ព្រះអម្ចាស់សន្យាថានឹងប្រទានពរជ័យដល់អ្នកទាំងឡាយ ដែលគោរពថ្ងៃឈប់សម្រាក ។

៦. សូមសរសេរគោលដៅផ្ទាល់ខ្លួននៃអ្វី ដែលអ្នកនឹងធ្វើ ដើម្បីជួយខ្លួនអ្នកឲ្យរក្សាថ្ងៃឈប់សម្រាកជាបរិសុទ្ធ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:២០–២៤

*ព្រះអម្ចាស់ប្រកាសអំពីពរជ័យខាងលោកិយ និង ជីវិតអស់កល្បជានិច្ចដល់ពួកស្មោះត្រង់*

តើព្រះបានប្រទានពរដល់អ្នកនាពេលថ្មីៗនេះ តាមរបៀបណាខ្លះ ? តើអ្នកមានអារម្មណ៍ដឹងគុណ ដល់ពរជ័យណាមួយខ្លាំងជាងគេ ? សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:២០–២១ រួចស្វែងរករបៀបដែលព្រះទ្រង់ព្រះតម្រិះ ចំពោះការប្រទានពរដល់យើង និង របៀបដែលយើងគួរប្រព្រឹត្តចំពោះទ្រង់វិញ ។ តើមានន័យដូចម្ដេចចំពោះអ្នក ដែលត្រូវដឹងថា ព្រះសព្វព្រះហឫទ័យកាលទ្រង់ប្រទានពរដល់អ្នក ?

គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:២១ បង្រៀនយើងថា **យើងជំទាស់នឹងព្រះ នៅពេលយើងពុំបង្ហាញនូវការដឹងគុណចំពោះទ្រង់ ហើយមិនគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។** ការជំទាស់ និង សេចក្ដីក្រោធរបស់ព្រះ ដែលបានពិពណ៌នានៅក្នុងខទី ២១ គឺជាភស្ដុតាងនៃសេចក្ដីស្រឡាញ់របស់ទ្រង់ ដែលមានចំពោះយើង ។ ទ្រង់ពុំសព្វព្រះឫទ័យទេ នៅពេលយើងរមិលគុណ ហើយមិនគោរពប្រតិបត្តិតាមនោះ ដោយសារឥរិយាបថទាំងនេះហើយ ទើបនាំយើងឲ្យឃ្លាតឆ្ងាយពីទ្រង់ ។

សូមពិចារណាអំពីរបៀប ដែលទំនាក់ទំនងរបស់យើងជាមួយព្រះ អាចត្រូវប្រេះឆា នៅពេលយើងពុំមានអំណរគុណចំពោះពរជ័យដែលយើងទទួលបាននោះ ។

ព្រះអម្ចាស់បានបញ្ចប់វិវរណៈនេះ ដោយមានព្រះបន្ទូលសាជាថ្មី អំពីព្រះរាជបំណងទ្រង់ក្នុងការប្រទានពរឲ្យយើង ទាំងនៅជីវិតនេះ និង នៅជីវិតបន្ទាប់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩:២៣–២៤ រួចស្វែងរករបៀបដែលព្រះអម្ចាស់នឹងប្រទានពរដល់អ្នកទាំងឡាយ ដែលគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

ពេញមួយថ្ងៃនេះ ឬ ថ្ងៃស្អែក សូមពិចារណាអំពីរបៀបជាច្រើន ដែលព្រះបានប្រទានពរដល់អ្នកចំពោះការរក្សាព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ សូមស្វែងរកឱកាសបង្ហាញសេចក្ដីស្រឡាញ់ និង ការដឹងគុណរបស់អ្នកចំពោះទ្រង់ ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៩ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៤ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦២

## សេចក្ដីផ្ដើម

នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៨៣១ យ៉ូសែប ស្ម៊ីធ និង ពួកអែលឌើរជាច្រើននាក់ទៀត បានត្រៀមខ្លួនចេញដំណើរពីក្រុង អិនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ហើយត្រឡប់ទៅរដ្ឋ អូហៃអូ វិញ ។ ព្រះអម្ចាស់បានណែនាំពួកអែលឌើរឲ្យផ្សាយដំណឹងល្អ នៅពេលពួកគាត់ធ្វើដំណើរនៅតាមផ្លូវ–ការណែនាំនោះ ឥឡូវត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០ ។ នៅថ្ងៃទីបីនៃការធ្វើដំណើររបស់ពួកគាត់ ក្រុមនោះបានជួបនឹងគ្រោះថ្នាក់នៅទន្លេ មិសសួរី ។ នៅពីរថ្ងៃក្រោយមក គឺនៅថ្ងៃទី ១២ និង ១៣ ខែ សីហា ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈចំនួនពីរមកពីព្រះអម្ចាស់ ។ វិវរណៈទាំងនោះ ឥឡូវត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦១ និង ៦២ ។ វិវរណៈទាំងនេះ មានទាំងពាក្យណែនាំ ការព្រមាន ការលួងលោមចិត្ត និងការលើកទឹកចិត្ត ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០

*ព្រះអម្ចាស់បញ្ជាឲ្យពួកអែលឌើរ ផ្សាយដំណឹងល្អនៅពេលពួកគាត់ធ្វើដំណើរពីរដ្ឋ មិសសួរី ទៅរដ្ឋ អូហៃអូ*



សូមគិតអំពីគ្រាមួយ ដែលអ្នកបានស្ទាក់ស្ទើរក្នុងការប្រាប់មនុស្សដទៃ អំពីជំនឿរបស់អ្នក ឬ ស្ទាក់ស្ទើរក្នុងការចែកចាយទីបន្ទាល់របស់អ្នកអំពីដំណឹងល្អ ។

ព្រះអម្ចាស់បានបន្ទោសដល់ពួកអែលឌើរមួយចំនួន ដែលបានធ្វើដំណើរទៅកាន់ក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០:១–២ ដើម្បីស្វែងយល់អំពីមូលហេតុ ដែលព្រះអម្ចាស់ពុំសព្វព្រះហឫទ័យនឹងពួកអែលឌើរមួយចំនួនទាំងនេះ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នកយល់ឃើញ ។

ពួកអែលឌើរដែលបានពិពណ៌នានៅក្នុង ខទី ១–២ បានធ្វើដំណើរពីរដ្ឋ អូហៃអូ ទៅកាន់ក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ដើម្បីចូលរួមការឧទ្ទិសឆ្លងដី និង ទីតាំងព្រះវិហារបរិសុទ្ធ ។ ព្រះអម្ចាស់បានបញ្ជាពួកគេឲ្យផ្សាយដំណឹងល្អដល់មនុស្សដទៃនៅតាមផ្លូវធ្វើដំណើរទៅរដ្ឋ មិសសួរី ( សូមមើល គ. និង ស. ៥៩:៩–១០ ) ។ ទោះជាយ៉ាងណាក៏ដោយ ពួកអែលឌើរមួយចំនួន ពុំបានគោរពប្រតិបត្តិតាមព្រះបញ្ញត្តិនេះទេ ។ ព្រះអម្ចាស់បានមានព្រះបន្ទូលថា « ពួកគេមិនព្រមបើកមាត់គេឡើយ ប៉ុន្តែពួកគេលាក់ការប៉ិនប្រសប់របស់ខ្លួន ដែលយើងបានប្រទានដល់ពួកគេទៅវិញ » (គ. និង ស. ៦០:២ ) ។ និយាយម្យ៉ាងទៀតថាពួកគាត់ពុំចែកចាយទីបន្ទាល់របស់ខ្លួនអំពីដំណឹងល្អនោះទេ ។

យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០:២ ហេតុអ្វីពួកអែលឌើរមួយចំនួនពុំចែកចាយទីបន្ទាល់របស់ពួកគាត់ ជាមួយនឹងមនុស្សដទៃ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០:៣ ដើម្បីស្វែងយល់ ថាតើមានអ្វីកើតឡើងប្រសិនបើយើងពុំចែកចាយទីបន្ទាល់របស់យើងជាទេនោះ ។

អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចតទៅនេះ ដាក់នៅក្នុងព្រះគម្ពីររបស់អ្នក ៖ **បើយើងមិនចែកចាយទីបន្ទាល់របស់យើងទេ នោះយើងនឹងបាត់បង់វា ។** ការចែកចាយទីបន្ទាល់ ពុំសំដៅតែលើការឡើងថ្លែងទីបន្ទាល់ជាផ្លូវការនៅក្នុងការប្រជុំនៃសាសនាចក្រនោះទេ ។ សមាជិកមួយចំនួននៃសាសនាចក្រ ដែលពុំមាន ឬ កម្រនឹងមានឱកាសឡើងថ្លែងនៅក្នុងការប្រជុំនៃសាសនាចក្រ ចែកចាយទីបន្ទាល់របស់ខ្លួន តាមរយៈរបៀបដែលពួកគេរស់នៅ ។ សមាជិកខ្លះ ថ្លែងទីបន្ទាល់អំពីដំណឹងល្អតាមរយៈការពុះពារនឹងបញ្ហាសុខភាព ឬ ការលំបាកផ្សេងៗ ។ សមាជិកខ្លះទៀត ថ្លែងទីបន្ទាល់យ៉ាងសាមញ្ញទៅកាន់សមាជិកគ្រួសារ ឬ មិត្តភក្ដិ តាមរយៈការបង្ហាញសេចក្ដីសង្ឃឹម និង សេចក្ដីជំនឿ ។

ប្រធាន ប៊ិយដ៏ ឃេ ផាកកឺ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានថ្លែងទីបន្ទាល់ អំពីសារៈសំខាន់នៃការចែកចាយទីបន្ទាល់របស់យើង ៖



« ស្មារតី និង ទីបន្ទាល់អំពីព្រះគ្រីស្ទ នឹងកើតមាននៅនឹងអ្នកជាផ្នែកមួយដ៏ធំ *នៅពេល* អ្នកចែកចាយវា *នោះ* វានឹងនៅស្ថិតស្ថេរជាមួយអ្នក ។ ដំណើរការនោះគឺជា *ចំណុចសំខាន់* នៃដំណឹងល្អ ។

« តើនេះមិនមែនជាការបង្ហាញមួយដ៏ល្អឥតខ្ចោះនៃគ្រិស្តសាសនាទេឬអី ? អ្នកមិនអាចរកវាឃើញ ឬ ក្សោវាទុក ឬ ពង្រីកវាបន្ថែមបាននោះទេ លុះត្រាតែ និង រហូតទាល់តែអ្នកមានបំណងចែកចាយវាតែប៉ុណ្ណោះ ។ ដោយសារតែអ្នកផ្ដល់វា ទើបវាក្លាយជារបស់អ្នក » ( The Candle of the Lord » *Ensign* ខែ មករា ឆ្នាំ ១៩៨៣ ទំព័រ ៥៥ ) ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើនៅពេលណាខ្លះ ដែលអ្នកមានអារម្មណ៍ថា ទីបន្ទាល់របស់អ្នកបានរីកចម្រើនកាន់តែរឹងមាំដោយសារអ្នកបានចែកចាយវានោះ ?

ខ. តើនៅពេលណាក្នុងសប្ដាហ៍ក្រោយ ដែលអ្នកអាចនឹងមានឱកាស ដើម្បីចែកចាយទីបន្ទាល់របស់អ្នក ?

ក្នុងខគម្ពីរដែលនៅសល់នៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០ អ្នកនឹងអានឃើញថា ព្រះអម្ចាស់បានបញ្ជាដល់ពួកអែលឌើរទាំងនេះ ឲ្យប្រកាសដំណឹងល្អនៅតាមផ្លូវធ្វើដំណើរត្រឡប់ទៅរដ្ឋ អូហៃអូ វិញ ។ នៅពេលអ្នកសិក្សា អ្នកអាចនឹងគូសបន្ទាត់ពីក្រោមពាក្យ ឬ ឃ្លា ដែលទាក់ទងនឹងការថ្លែងទីបន្ទាល់មានដូចជា « ប្រកាសព្រះបន្ទូលរបស់យើង » ឬ « ផ្សាយ » ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦១

*ព្រះអម្ចាស់បានប្រទានការដឹកនាំសម្រាប់ យ៉ូសែប ស៊្មីធ និង ពួកអែលឌើរដទៃទៀត អំពីការធ្វើដំណើរត្រឡប់ទៅរដ្ឋ អូហៃអូ វិញ*

ព្យាការី យ៉ូសែប ស៊្មីធ និង ពួកអែលឌើរចំនួន ១០ នាក់ បានឃើញថា ពួកគាត់ស្ថិតនៅក្នុងគ្រោះថ្នាក់ នៅពេលពួកគាត់ធ្វើដំណើរតាមទូកក្នុងចរន្តទឹកហូរដ៏ខ្លាំងក្នុងទន្លេ មិសសួរី ។ នៅពេលអ្នកអានដំណើររឿងខាងក្រោមនេះ សូមគិតអំពីអារម្មណ៍ដែលអ្នកអាចនឹងមាន បើអ្នកមានវត្តមាននៅទីនោះ ។



ទន្លេ មិសសួរី ចំណុចផ្លូវកោង មិកខលវែន

យ៉ូសែប ស៊្មីធ នៅចាំអំពីថ្ងៃទីបីនៃការធ្វើដំណើរនោះថា « គ្រោះថ្នាក់ជាច្រើនបានកើតឡើងនៅគ្រប់ទីកន្លែង នៅលើទឹកនៃតំបន់ប៉ែកខាងលិច ហើយបន្ទាប់ពីយើងបានទៅដល់ច្រាំងទន្លេ. . . បងប្រុស [ វិលលាម ដឺបប៊ុលយូ ] ហ្វែប្ស បានមានការនិមិត្តមួយទាំងកណ្ដាលថ្ងៃត្រង់ ឃើញមេបំផ្លាញកំពុងតែរេរានៅលើផ្ទៃទឹកដោយអំណាចដ៏ខ្លាំងសម្បើម ហើយមនុស្សដទៃទៀតបានឮសំឡេង ប៉ុន្តែ ពុំបានមានការនិមិត្តនោះទេ » ( នៅក្នុង *History of the Church* ១:២០៣ ) ។ ពីមុនការនិមិត្តនេះ « មានការខ្វែងគំនិត និង អារម្មណ៍មិនល្អខ្លះៗ បានកើតមានឡើងនៅក្នុងចំណោមពួកបងប្អូនប្រុសទាំងនោះ » ( B. H. Roberts *A Comprehensive History of the Church* ១:២៦២–៦៣ ) ។ នាល្ងាចនោះ ពួកបងប្អូនប្រុសទាំងនោះ បានជជែកអំពីការលំបាករបស់ពួកគាត់ ហើយពួកគាត់ភាគច្រើនបានអភ័យទោសដល់គ្នាទៅវិញទៅមក ។ លុះព្រឹកស្អែកឡើង យ៉ូសែប ស៊្មីធ បានអធិស្ឋាន ហើយបានទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦១ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦១:២, ២០, ៣៦–៣៧ រួចគូសចំណាំឃ្លា ដែលអាចនាំឲ្យពួកអែលឌើរទាំងនេះទទួលបានការលួងលោមចិត្ត ។

ព្រះអម្ចាស់មិនត្រឹមតែបានអភ័យទោសដល់ពួកអែលឌើរទាំងនេះពីអំពើបាបរបស់ពួកគាត់ប៉ុណ្ណោះនោះទេ ទ្រង់ថែមទាំងបានពន្យល់ថា « មានការបំផ្លិចបំផ្លាញជាច្រើន » នឹងកើតមានឡើងនៅលើផ្ទៃទឹកនៅថ្ងៃចុងក្រោយ ( សូមមើល គ. និង ស. ៦១:៥, ១៤–១៩ ) ។ ព្រះអម្ចាស់ក៏បានមានព្រះបន្ទូលអំពីព្រះចេស្ដារបស់ទ្រង់ផងដែរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦១:១, ៦, ១០ រួចស្វែងរកការណ៍ ដែលព្រះអម្ចាស់បានបង្រៀនអំពីព្រះចេស្ដារបស់ទ្រង់ ។

ដោយសារតែការនិមិត្តរបស់ វិលាម ដ័បុលយូ ហ្វែល្ប អំពីមេបំផ្លាញនៅលើផ្ទៃទឹក នោះមានមនុស្សមួយចំនួនបានសន្និដ្ឋានថា សាតាំងមានអំណាចនៅលើផ្ទៃទឹក ។ ទោះជាយ៉ាងណាក៏ដោយ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦១:១ បញ្ជាក់ថា ព្រះអម្ចាស់មានគ្រប់ព្រះចេស្ដា ។ ការណ៍នេះក៏រួមបញ្ចូលទាំងព្រះចេស្ដានៅលើផ្ទៃទឹកផងដែរ ។. ខទី ៦ និង ១០ បញ្ជាក់អំពីលទ្ធភាពរបស់ព្រះអម្ចាស់ក្នុងការការពារយើង ។ អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចតទៅនេះ ដាក់នៅក្នុងព្រះគម្ពីររបស់អ្នក ៖ **ព្រះអម្ចាស់មានគ្រប់ព្រះចេស្ដា ហើយទ្រង់អាចការពារយើងបាន ។**

ខគម្ពីរដែលនៅសល់នៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦១ មាននូវសេចក្ដីណែនាំពីព្រះអម្ចាស់ទៅដល់ពួកអែលឌើរទាំងនេះ ដើម្បីដឹកនាំពួកគាត់ត្រឡប់ទៅកាន់រដ្ឋ អូហៃអូ វិញ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦២

*ព្រះអម្ចាស់បានសរសើរដល់ភាពស្មោះត្រង់របស់ក្រុមអែលឌើរមួយក្រុម ដែលធ្វើដំណើរទៅក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ។*

នៅក្នុងតារាងខាងក្រោម សូមគូសសញ្ញា « x » នៅក្បែរសំណួរ ដែលអ្នកគិតថា អាចនឹងសំខាន់បំផុតចំពោះព្រះអម្ចាស់ ។

| | |
|---|---|
| | តើខ្ញុំគួរទៅព្រះវិហារនៅថ្ងៃអាទិត្យដែរឬទេ ? |
| | តើខ្ញុំគួរស្លៀកសំពត់ពណ៌ខ្មៅ ឬ ពណ៌បៃតងទៅព្រះវិហារ ?<br>តើខ្ញុំគួរពាក់ក្រវ៉ាត់កពណ៌ក្រហម ឬ ពណ៌ខៀវ ? |
| | តើខ្ញុំគួរបម្រើបេសកកម្មដែរឬទេ ? បើដូច្នោះ<br>តើនៅពេលណា ? |
| | បើម្ដាយរបស់ខ្ញុំប្រាប់ថា គាត់នឹងចម្អិនអាហារដែលខ្ញុំពេញចិត្ត តើខ្ញុំគួរជ្រើសរើសយកមុខម្ហូបមួយណា ? |

ដោយអាស្រ័យទៅតាមកាលៈទេសៈ ការសម្រេចចិត្តជាច្រើន ដែលយើងធ្វើអាចនឹងសំខាន់ចំពោះព្រះអម្ចាស់ ប៉ុន្តែ ការសម្រេចចិត្តខ្លះទៀតពុំសំខាន់សោះឡើយ ។ ក្នុងវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦២ ព្រះអម្ចាស់បានជួយពួកអែលឌើរនៃសាសនាចក្រទ្រង់ឲ្យយល់ថា ការសម្រេចចិត្តមួយចំនួន ដែលពួកគាត់ត្រូវធ្វើ សំខាន់ខ្លាំងចំពោះទ្រង់ជាងការសម្រេចចិត្តឯទៀតៗ ។ នៅពេលអ្នកបន្តសិក្សាវិវរណៈទាំងនេះ អ្នកអាចបង្កើនការយល់ដឹងជ្រាលជ្រៅដើម្បីដឹកនាំអ្នកក្នុងការសម្រេចចិត្ត ។

ដើម្បីយល់អំពីព្រឹត្តិការណ៍នៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦២ សូមអានសេចក្ដីណែនាំអំពីកណ្ឌ ។

ពួកអែលឌើរដែលត្រូវបានលើកឡើងនៅក្នុងសេចក្ដីណែនាំអំពីកណ្ឌ បានធ្វើដំណើរយ៉ាងយឺតទៅក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី គឺយឺតជាងពួកអែលឌើរខ្លះទៀត ដោយសារតែពួកគាត់បានរវល់តែខ្នះខ្នែងយ៉ាងឧស្សាហ៍ក្នុងការផ្សាយដំណឹងល្អ ។ ដោយហេតុនោះហើយ ពួកគាត់បានខកខានមិនបានចូលរួមសន្និសីទ ដែលបានប្រព្រឹត្តទៅលើដី និង ទីតាំងដែលព្រះវិហារបរិសុទ្ធត្រូវបានឧទ្ទិសឆ្លង ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦២:១–៣ ដោយស្វែងរកពរជ័យមួយចំនួន ដែលមានចំពោះអ្នកដែលផ្សាយដំណឹងល្អ ហើយចែកចាយទីបន្ទាល់របស់ខ្លួន ។

សូមសិក្សាសេចក្ដីយោងបទគម្ពីរ ដែលមាននៅក្នុងប្រអប់ឈរខាងឆ្វេងនៃតារាងខាងក្រោម ។ សូមសរសេរនៅក្នុងប្រអប់ឈរដែលត្រឹមត្រូវ នូវអ្វីដែលសំខាន់ចំពោះព្រះអម្ចាស់ និង អ្វីដែលពុំសំខាន់ចំពោះទ្រង់ ។

| | តើអ្វីដែលសំខាន់ចំពោះព្រះអម្ចាស់ ? | តើអ្វីដែលមិនសំខាន់ចំពោះព្រះអម្ចាស់ ? |
|---|---|---|
| គ. និង ស. ៦០:៥ | | |
| គ. និង ស. ៦១:២១–២២ | | |
| គ. និង ស. ៦២:៥–៧ | | |

២. នៅក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរដូចតទៅនេះ អំពីបទគម្ពីរដែលអ្នកបានសិក្សានៅក្នុងតារាង ៖ តើភាពខុសគ្នាអ្វីខ្លះ ដែលអ្នកបានសម្គាល់ឃើញរវាងអ្វីដែលសំខាន់ និង អ្វីដែលពុំសំខាន់ចំពោះព្រះអម្ចាស់ ?

នៅក្នុងសេចក្ដីថ្លែងការណ៍ខាងក្រោមដោយ អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ សូមគូសបន្ទាត់ពីក្រោមពាក្យ ឬ ឃ្លា ដែលជួយអ្នកឲ្យយល់អំពីអ្វី ដែលព្រះអម្ចាស់បានបង្រៀនពួកអែលឌើរ កាលទ្រង់បានមានព្រះបន្ទូលថា ការណ៍មួយចំនួនសំខាន់ចំពោះទ្រង់ ប៉ុន្តែ ការណ៍មួយចំនួនទៀតពុំសំខាន់នោះទេ ៖



« ច្បាស់ណាស់ ព្រះអង្គសង្គ្រោះពុំបានមានព្រះបន្ទូលទៅកាន់អ្នកផ្សព្វផ្សាយសាសនាទាំងនេះថា ទ្រង់ពុំយកព្រះទ័យទុកដាក់លើអ្វីដែលពួកគេកំពុងតែធ្វើនោះទេ ។ ផ្ទុយទៅវិញ ទ្រង់បានគូសសម្គាល់អំពីសារៈសំខាន់នៃការដាក់អ្វីដែលសំខាន់ជាចម្បង ហើយផ្ដោតអារម្មណ៍ទៅលើអ្វីដែលត្រូវ ។. . . អ្វីដែលចាំបាច់នោះគឺជាកិច្ចការ ដែលពួកគាត់ត្រូវបានហៅឲ្យធ្វើ ចំណែកឯរបៀបដែលពួកគេទៅដល់ទីនោះមានសារៈសំខាន់ដែរ ប៉ុន្តែ ពុំចាំបាច់ឡើយ » ( « A Reservoir of Living Water » [ Church Educational System fireside for young adults ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៧ ] ទំព័រ ៤ LDS.org) ។

៣. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើគំរូនៃអ្វីដែលសំខាន់ចំពោះព្រះអម្ចាស់ និង អ្វីដែលមិនសំខាន់ចំពោះទ្រង់ ដឹកនាំអ្នកនៅពេលអ្នកធ្វើការសម្រេចចិត្តយ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦២:៨ រួចស្វែងរកការណ៍ចំនួនពីរ ដែលយើងអាចពឹងផ្អែកទៅលើ កាលយើងធ្វើការសម្រេចចិត្ត ។ រួចសូមបញ្ចប់គោលការណ៍តទៅនេះ ដោយបំពេញចន្លោះ ៖ **នៅពេលធ្វើការសម្រេចចិត្ត យើងត្រូវពឹងផ្អែកទៅលើ និង** ។

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថាហេតុអ្វីបានជាវាសំខាន់ដែលត្រូវពឹងផ្អែកទៅលើការវិនិច្ឆ័យរបស់យើង ក៏ដូចជាការដឹកនាំមកពីព្រះវិញ្ញាណ ?

ខ. តើនៅពេលណា ដែលអ្នកបានធ្វើការសម្រេចចិត្ត ដោយផ្អែកទៅលើការវិនិច្ឆ័យផ្ទាល់ខ្លួន ក៏ដូចជាផ្អែកទៅលើការដឹកនាំមកពីព្រះវិញ្ញាណ ? តើអ្នកបានទទួលពរដោយព្រោះការធ្វើដូច្នោះយ៉ាងដូចម្ដេចដែរ ?

សូមគិតអំពីរបៀប ដែលអ្នកអាចប្រព្រឹត្តតាមគោលការណ៍មួយ ឬ ច្រើន ដែលអ្នកបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦២ ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦០–៦២ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៤ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣

## បុព្វកថា

នារដូវក្ដៅក្នុងឆ្នាំ ១៨៣១ កាលព្យាការី យ៉ូសែប ស្ម៊ីធ កំពុងមើលការខុសត្រូវលើការឧទ្ទិសឆ្លងដី ដែលពួកបរិសុទ្ធត្រូវស្ថាបនាទីក្រុងស៊ីយ៉ូននៅក្រុងអ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី នោះមានសមាជិកសាសនាចក្រមួយចំនួន បានបែរចេញពីព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ ហើយប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានត្រឡប់ទៅទីក្រុង ខឺតឡង់ វិញនៅថ្ងៃទី ២៧ ខែ សីហា ហើយនៅថ្ងៃទី ៣០ ខែ សីហា លោកបានទទួលវិវរណៈដែលមានកត់ត្រានៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានព្រមានពួកបរិសុទ្ធអំពីផលវិបាកនៃអំពើទុច្ចរិត និង ការបះបោរ ពរជ័យដែលបានសន្យាទុកសម្រាប់ពួកបរិសុទ្ធ ដែលស្មោះត្រង់នៅថ្ងៃចុងក្រោយបង្អស់ ហើយទ្រង់បានទូន្មានដល់ពួកអ្នកបម្រើទ្រង់ឲ្យចងចាំអំពីភាពពិសិដ្ឋនៃព្រះនាមទ្រង់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:១–២១

*ព្រះអម្ចាស់ព្រមានពួកបរិសុទ្ធអំពីផលវិបាកនៃសេចក្ដីទុច្ចរិត និង ការបះបោរ*

តើអ្នកគិតថា ហេតុអ្វីបានជាវាមានសារៈសំខាន់ ដែលយើងត្រូវរស់នៅឲ្យស្របតាមជំនឿរបស់យើងក្នុងនាមជា សមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ?

សូមរំឭកសេចក្ដីណែនាំអំពីមេរៀននេះឡើងវិញ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:១–២, ៦ ដោយស្វែងរកការណ៍ ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ដល់ពួកទុច្ចរិត និង ពួកបះបោរ ។

តើអ្នកគិតថា ហេតុអ្វីបានជាសំខាន់ដែលសមាជិកសាសនាចក្រត្រូវបើកចិត្ត ហើយស្ដាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ ?

សូមកត់ចំណាំឃ្លា « ចូរឲ្យពួកដែលឥតជឿទប់មាត់របស់ពួកគេទុក » ( គ. និង ស. ៦៣:៦ ) ។ នៅគ្រានេះ សមាជិកសាសនាចក្រមួយចំនួន បានឈប់ជឿទៅលើសេចក្ដីពិតពេញលេញនៃសាសនាចក្រ ហើយបាននិយាយជាសាធារណៈទាស់នឹងយ៉ូសែប ស្ម៊ីធ និងថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រ ។ មនុស្សម្នាក់ដែលរិះគន់សាសនាចក្រខ្លាំងបំផុត គឺជាបុរសម្នាក់ឈ្មោះថា អេសរ៉ា ប៊ូស ។

ពីមុនចូលរួមសាសនាចក្រ អែសរ៉ា ប៊ូស គឺជាអាចារ្យសាសនាមេតូឌីស ។ គាត់បានចាប់អារម្មណ៍ទៅលើការស្ដារឡើងវិញនៅដើមឆ្នាំ ១៨៣១ បន្ទាប់ពីបានអានព្រះគម្ពីរមរមន ។ គាត់បានធ្វើដំណើរទៅខឺតឡង់ ជាមួយយ៉ូហាន និង អាលីស ចនសុន ដើម្បីជួបនឹងព្យាការី ។ អ្នកស្រី ចនសុន បានរងទុក្ខនឹងរោគសន្លាក់ឆ្អឹង ដែលបណ្ដាលឲ្យមានការឈឺចាប់ ហើម និងរឹងដៃ ។ នៅពេលគាត់បានជួបនឹងយ៉ូសែប ស្ម៊ីធដំបូង គាត់ពុំអាចលើកដៃរបស់គាត់ដាក់លើក្បាលជិតពីរឆ្នាំ ។

« អំឡុងពេលការសម្ភាសន៍ ការសន្ទនាបានបង្វែរទៅលើប្រធានបទអំពីអំណោយទានដ៏ហួសវិស័យ ដូចជាដែលត្រូវបានប្រគល់ឲ្យនៅក្នុងជំនាន់នៃពួកសាវក ។ មានម្នាក់បាននិយាយថា ‹ នេះជាអ្នកស្រី ចនសុន ដែលពិការដៃ តើព្រះបានប្រទានអំណាចអ្វីដល់មនុស្សលើផែនដីក្នុងពេលនេះដើម្បីព្យាបាលគាត់ ? › បន្តិចក្រោយមក នៅពេលការសន្ទនាបានបង្វែរទៅរកទិសដៅមួយទៀត [ យ៉ូសែប ] ស្ម៊ីធ បានក្រោកឡើង ហើយដើរកាត់បន្ទប់ ដឹកដៃអ្នកស្រី ចនសុន ហើយបានថ្លែងដោយឧឡារិក និងអស្ចារ្យថា ៖ ‹ ស្ត្រីអើយ នៅក្នុងព្រះនាមនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ខ្ញុំបញ្ជាឲ្យអ្នកបានជាសះស្បើយ › រួចក៏បានចេញពីបន្ទប់ភ្លាមទៅ ។. . . អ្នកស្រី ចនសុន ក៏អាចលើក [ ដៃរបស់គាត់ ] បានយ៉ាងងាយ ហើយពេលគាត់ត្រឡប់ទៅផ្ទះវិញនៅថ្ងៃស្អែកឡើង គាត់អាចធ្វើការបោកគក់ដុះលាងដោយគ្មានការលំបាក ឬ ឈឺចាប់អ្វីសោះឡើយ » ( ចេញពី *Haydn's History of the Disciples* ត្រូវបានដកស្រង់នៅក្នុង *History of the Church* ១:២១៥–១៦ ) ។



សូមគិតថាតើអ្នកអាចមានអារម្មណ៍ដូចម្ដេច បើអ្នកបានឃើញអព្ភូតហេតុដូចនេះដោយផ្ទាល់ភ្នែក ?
មិនយូរប៉ុន្មានបន្ទាប់ពី អេសរ៉ា ប៊ូស បានឃើញអព្ភូតហេតុនេះ គាត់បានទទួលពិធីបុណ្យជ្រមុជទឹក ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:៧–៩ រួចស្វែងរកការណ៍ ដែលព្រះអម្ចាស់បានបង្រៀនអំពីទីសម្គាល់ និង សេចក្ដីជំនឿ ។ ក្រោយមក សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ៖ **សេចក្ដីជំនឿមិនមែនកើតឡើងដោយសារ** នោះទេ ។

បន្ទាប់ពីគាត់បានទទួលពិធីបុណ្យជ្រមុជទឹកហើយ គាត់បានទទួលបព្វជិតភាព ហើយត្រូវបានបញ្ជូនឲ្យទៅបម្រើបេសកកម្មមួយនៅរដ្ឋ មិសសួរី ។ គាត់បានចាប់ផ្ដើមបម្រើបេសកកម្មរបស់គាត់ដោយការរំពឹងទុកដ៏ខ្ពស់ ដោយស្មានថា គាត់នឹងអាចផ្លាស់ប្រែមនុស្សឲ្យបានច្រើន តាមរយៈការបង្ហាញអំពីទីសម្គាល់ និង ការបង្កើតអព្ភូតហេតុ ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីបានផ្សាយដំណឹងល្អបានមួយរយៈពេលខ្លីមក ហើយពុំបានឃើញលទ្ធផលដូចដែលគាត់បានស្មានទុកទេ នោះ អេសរ៉ា ប៊ូស « បានបែរចេញ » ហើយបានក្បត់សាសនា ( យ៉ូសែប ស្ម៊ីធ នៅក្នុង *History of the Church* ១:២១៦ ) ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានធ្វើការសង្កេតលើ អេសរ៉ា ប៊ូស ៖ « នៅពេលគាត់បានស្វែងយល់ដោយប្រាកដថា សេចក្ដីជំនឿ ការបន្ទាបខ្លួន ការអត់ធ្មត់ និង ការលំបាក ត្រូវកើតមានពីមុនទទួលបានពរជ័យ ហើយថាព្រះនឹងនាំឲ្យមនុស្សរាបសារ មុននឹងទ្រង់តម្កើងគេឡើង ជំនួសឲ្យ ‹ ការដែលព្រះអង្គសង្គ្រោះប្រទានអំណាចដល់គាត់ដើម្បីវាយមនុស្ស ហើយធ្វើឲ្យពួកគេជឿ › វិញ. . . នោះគាត់បានខកចិត្ត » ( នៅក្នុង *History of the Church* ១:២១៦ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:១០–១២ ដោយស្វែងរកគោលការណ៍បន្ថែម អំពីទីសម្គាល់ និង សេចក្ដីជំនឿ ។ អ្នកអាចចង់គូសចំណាំពាក្យ ឬ ឃ្លានៅក្នុង ខទី ១០ ដែលបង្រៀនអំពីគោលការណ៍ដូចតទៅនេះ ៖ **ទីសម្គាល់មានឡើងដោយសារសេចក្ដីជំនឿ ស្របតាមព្រះហឫទ័យនៃព្រះ ។**



១. សូមពន្យល់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលអ្នកគិតថា យើងទទួលបានទីសម្គាល់ *បន្ទាប់ពី* យើងអនុវត្តសេចក្ដីជំនឿ ។ សូមរាយឧទាហរណ៍មួយ ឬ ពីរ ចេញពីបទគម្ពីរ នៃមនុស្សដែលបានឃើញទីសម្គាល់ ឬ អព្ភូតហេតុដ៏អស្ចារ្យ ប៉ុន្តែ ពុំបង្ហាញសេចក្ដីជំនឿ និង សេចក្ដីសុចរិតដ៏យូរអង្វែងឡើយ ។ ( បើអ្នកត្រូវការជំនួយ សូមមើល នីហ្វៃទី១ ១៧:៤៣–៤៥ ) ។

វាមានប្រយោជន៍ដែលត្រូវចងចាំថា ទីសម្គាល់ និង ការអស្ចារ្យទាំងឡាយ ពុំបង្ហាញឲ្យឃើញភាពអស្ចារ្យជានិច្ចនោះទេ ។ ជាញឹកញាប់ យើងអាចនឹងទទួលបានទីសម្គាល់មួយ ឬសាក្សីមួយអំពីសេចក្ដីពិតពេញលេញនៃដំណឹងល្អ តាមរបៀបដ៏ស្ងប់ស្ងាត់ និង ផ្ទាល់ខ្លួនមួយ នៅពេលយើងអនុវត្តសេចក្ដីជំនឿរបស់យើង ។ យើងអាចអនុវត្តសេចក្ដីជំនឿដោយការអធិស្ឋាន ការសិក្សាព្រះគម្ពីរ ការតមអាហារ ការបម្រើ និង ការរស់នៅតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។

២. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបដែលការអនុវត្តន៍សេចក្ដីជំនឿបានជួយអ្នក និង មនុស្សដែលអ្នកស្គាល់ ឲ្យទទួលបានសាក្សីនៃភាពពោរពេញនៃដំណឹងល្អ ។

ដូចបានលើកឡើងខាងលើ មិនត្រឹមតែការស្វែងរកទីសម្គាល់ប៉ុណ្ណោះទេ សមាជិកសាសនាចក្រមួយចំនួននៅរដ្ឋ អូហៃអូ ក៏បាន « បែរចេញពីព្រះបញ្ញត្តិទាំងឡាយ » ( គ. និង ស. ៦៣:១៣ ) ហើយបានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរដែរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:១៤–១៩ រួចស្វែងរកអំពើបាបមួយចំនួន ដែលពួកគេបានប្រព្រឹត្ត ។ វាអាចនឹងជួយអ្នកឲ្យយល់ ខទី ១៧ បើអ្នកស្គាល់និយមន័យនៃពាក្យដូចតទៅនេះ ៖ មនុស្សកំផិត គឺជាជនដែលរួមចំណែកក្នុងអំពើបាបខាងផ្លូវភេទ ។ មនុស្សមន្តអាគម គឺជាជនរួមចំណែកក្នុងសកម្មភាព ដែលអញ្ជើញឲ្យមានឥទ្ធិពលនៃវិញ្ញាណអាក្រក់ ។ ឃ្លា « បឹងដែលឆេះជាភ្លើង និង ស្ពាន់ធ័រ » ត្រូវបានប្រើជាពាក្យប្រដូចទៅនឹងស្ថានភាពនៃទុក្ខវេទនាដ៏ធ្ងន់ធ្ងរ ដែលកំពុងរង់ចាំមនុស្សទុច្ចរិតបន្ទាប់ពីពួកគេស្លាប់ទៅ ( សូមមើល ម៉ូសាយ ៣:២៧ ) ។ ពាក្យប្រដូចនេះក៏ដូចជាអ្វីដែល « សេចក្ដីស្លាប់ទីពីរ » មាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:១៧ សំដៅទៅលើ ( សូមមើល សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ សេចក្ដីស្លាប់, ខាងវិញ្ញាណ » scriptures.lds.org) ។

អ្នកអាចនឹងចង់គូសចំណាំពាក្យនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:១៦ ដែលបង្រៀនអំពីគោលការណ៍ដូចតទៅនេះ ៖ **បើយើងក្រឡេកឃើញមនុស្សដទៃដោយតម្រេកសម្រើបចង់បាន នោះយើងនឹងមិនមានព្រះវិញ្ញាណឡើយ ប៉ុន្តែ យើងនឹងបដិសេធចោលសេចក្ដីជំនឿវិញ** ។ ការមានតម្រេកសម្រើបចង់បាន រួមបញ្ចូលទាំងការណ៍អាសគ្រាមផងដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:២២–៦៦

*ព្រះអម្ចាស់សន្យាថា នឹងប្រទានពរដល់ពួកស្មោះត្រង់នៅថ្ងៃចុងក្រោយបង្អស់*

ក្នុងវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣ ព្រះអម្ចាស់បានមានព្រះបន្ទូលអំពីការបំផ្លិចបំផ្លាញដែលនឹងកើតមានមកលើពួកទុច្ចរិតនៅថ្ងៃចុងក្រោយបង្អស់ ប៉ុន្តែ ទ្រង់ក៏បានធ្វើការសន្យាដ៏មានអានុភាពផងដែរចំពោះពួកបរិសុទ្ធ ។

នៅពេលអ្នករៀនអំពីការបំផ្លិចបំផ្លាញ និង ការសន្យាដែលព្រះអម្ចាស់បានមានព្រះបន្ទូលនោះ សូមបំពេញសេចក្ដីថ្លែងការណ៍ខាងក្រោមនេះ ដោយសម្គាល់ពាក្យ ត្រូវ ( ត ) ឬ ខុស ( ខ ) បន្ទាប់ពីបានអានសេចក្ដីយោងព្រះគម្ពីរ ។ នៅពេលធ្វើលំហាត់នេះ អ្នកអាចនឹងចង់គូសចំណាំនៅក្នុងព្រះគម្ពីររបស់អ្នក នូវគោលការណ៍សំខាន់ៗ ដែលអ្នកបានរៀន ។

____១. អំឡុងសង្គ្រាមនៅថ្ងៃចុងក្រោយបង្អស់ មនុស្សទុច្ចរិតនឹងបំផ្លាញគ្នាទៅវិញទៅមក ។ ( សូមមើល គ. និង ស. ៦៣:៣២–៣៣ ) ។

____២. ពួកបរិសុទ្ធនឹងចៀសផុតពីគ្រប់ការជំនុំជម្រះ និង ការបំផ្លិចបំផ្លាញនៅថ្ងៃចុងក្រោយបង្អស់ដោយងាយ ។ ( សូមមើល គ. និង ស. ៦៣:៣៤ ) ។

____៣. នៅពេលព្រះយេស៊ូវគ្រីស្ទយាងមកម្ដងទៀត ទ្រង់នឹងបំផ្លាញពួកទុច្ចរិត ដែលសេសសល់នៅលើផែនដី ។ ( សូមមើល គ. និង ស. ៦៣:៣៤ ) ។

____៤. អ្នកទាំងឡាយដែលមានចិត្តស្មោះត្រង់ នឹងឈ្នះលើឧបសគ្គទាំងអស់ក្នុងជីវិតនេះ ។ ( សូមមើល គ. និង ស. ៦៣:៤៧–៤៨ ) ។

____៥. ពួកសុចរិត ដែលបានស្លាប់ពីមុនការយាងមកជាលើកទីពីរ នឹងបានរស់ឡើងវិញ នៅពេលព្រះអង្គសង្គ្រោះយាងមកលើផែនដី ។ ( សូមមើល គ. និង ស. ៦៣:៤៩ ) ។

____៦. ពួកសុចរិត ដែលកំពុងរស់នៅលើផែនដី នៅគ្រាដែលការយាងមកជាលើកទីពីរ នឹងមិនស្លាប់ឡើយ ។ ( សូមមើល គ. និង ស. ៦៣:៥០–៥១ ) ។

សេចក្ដីថ្លែងការណ៍ទី ១ គឺត្រូវ និង សេចក្ដីថ្លែងការណ៍ទី ២ គឺខុស ។ សេចក្ដីថ្លែងការណ៍ដូចតទៅនេះដោយព្យាការី យ៉ូសែប ស្ម៊ីធ ពន្យល់អំពីមូលហេតុដែលសេចក្ដីថ្លែងការណ៍ទី ២ មានសភាពខុសឆ្គងយ៉ាងដូច្នេះ ៖ « វាគឺជាគំនិតខុសឆ្គងមួយ ដែលថាពួកបរិសុទ្ធ នឹងចៀសផុតពីគ្រប់ការជំនុំជម្រះ ខណៈពេលដែលពួកទុច្ចរិតរងទុក្ខនោះ ដ្បិតគ្រប់សាច់ឈាម គឺស្ថិតនៅក្រោមការរងទុក្ខ ហើយ ‹ ពួកសុចរិតវិះនឹងគេចខ្លួនមិនរួចដែរ › យ៉ាងណាក្ដី ពួកបរិសុទ្ធជាច្រើននឹងបានចៀសផុត ដ្បិតពួកសុចរិតនឹងរស់នៅដោយសេចក្ដីជំនឿរបស់ខ្លួន ប៉ុន្តែពួកសុចរិតជាច្រើន នឹងរងគ្រោះដោយសារជំងឺ អាសន្នរោគ ជាដើម ដោយសារតែមូលហេតុនៃភាពទន់ខ្សោយខាងសាច់ឈាម ទោះជាយ៉ាងណាក៏ដោយ គង់តែនឹងត្រូវបានសង្គ្រោះនៅក្នុងនគរព្រះដែរ » ( នៅក្នុង *History of the Church* ៤:១១ ) ។

សេចក្ដីថ្លែងការណ៍ទី ៣–៥ គឺត្រូវ និង សេចក្ដីថ្លែងការណ៍ទី ៦ គឺខុស ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:៤៧ មាននូវការសន្យាពីព្រះអម្ចាស់ ។ សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ដោយផ្អែកលើខគម្ពីរនេះ ៖ **បើយើង នោះយើងនឹង** ។

តើព្រះអម្ចាស់អាចជួយអ្នកឲ្យ « ឈ្នះលើលោកិយនេះ » នៅក្នុងជីវិតរបស់អ្នកបានយ៉ាងដូចម្ដេច ?

ដូចព្យាការី យ៉ូសែប ស្ម៊ីធ បានពន្យល់ដូច្នេះដែរថា យើងនឹងមិនអាចចៀសផុតពីទុក្ខលំបាក ដែលមានក្នុងជីវិតនេះលើលោកិយឡើយ ។ ទោះជាយ៉ាងណាក៏ដោយ បើយើងជាមនុស្សសុចរិត នោះយើង « គង់តែនឹងត្រូវបានសង្គ្រោះនៅក្នុងនគរព្រះដែរ » ( នៅក្នុង *History of the Church* ៤:១១ ) ។ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:៤៩ ដោយស្វែងរកពរជ័យដែលត្រូវបានទទួលដោយ ពួកអ្នកស្មោះត្រង់ដែលបានឈ្នះលើលោកិយនេះ ។

មធ្យោបាយមួយដែលយើងអាចបង្ហាញភាពស្មោះត្រង់របស់យើង គឺតាមរយៈរបៀបដែលយើងប្រើប្រាស់ព្រះនាមនៃព្រះអម្ចាស់ ដូចបានពន្យល់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣:៥៩–៦៤ ។ នៅពេលអ្នកអានខគម្ពីរទាំងនេះ សូមស្វែងរកពាក្យ ឬ

ឃ្លាដែលបង្រៀនអំពីគោលការណ៍ដូចតទៅនេះ ៖ **ព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ គឺពិសិដ្ឋ ហើយត្រូវតែបានពោលដល់យកចិត្តទុកដាក់** ។ អ្នកអាចនឹងចង់គូសចំណាំនៅក្នុងព្រះគម្ពីររបស់អ្នក នូវពាក្យ ឬ ឃ្លា ដែលបង្រៀនអំពីគោលការណ៍នេះ ។

៣. សូមធ្វើបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីស្ថានភាពមួយចំនួន ជាពេលដែលអ្នកអាចនឹងប្រើប្រាស់ព្រះនាមនៃព្រះយេស៊ូវគ្រីស្ទដោយខុសឆ្គង ។ បន្ទាប់មកសូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើអ្នកគិតថា ហេតុអ្វីបានជាយើងប្រើប្រាស់ព្រះនាមនៃព្រះអង្គសង្គ្រោះ នៅពេលយើងអធិស្ឋាន ហើយថ្លែងទីបន្ទាល់ និង ធ្វើពិធីបរិសុទ្ធនៃបព្វជិតភាព ?

ខ. នៅពេលអ្នកប្រើប្រាស់ព្រះនាមរបស់ព្រះអង្គសង្គ្រោះ តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីចងចាំថា ព្រះនាមទ្រង់គឺពិសិដ្ឋ ហើយត្រូវតែបានពោលដល់ដោយយកចិត្តទុកដាក់ ?

គោលការណ៍នេះ មិនត្រឹមតែអនុវត្តចំពោះព្រះនាមនៃព្រះអង្គសង្គ្រោះប៉ុណ្ណោះទេ ។ សូមគិតអំពីពាក្យ ឬ អ្វីដែល « មកពីលើ » ហើយមានលក្ខណៈពិសិដ្ឋ ។ សូមគិតអំពីរបៀបដែលអ្នកអាចធ្វើឲ្យប្រាកដថា អ្នកពោលដល់អ្វីទាំងនោះ « ដោយយកចិត្តទុកដាក់ » ។



អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា គោលការណ៍ដែលអ្នកបានរៀន អំពីព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ក៏អនុវត្តផងដែរចំពោះព្រះនាមនៃព្រះវរបិតាសួគ៌ ៖ « ពុំមានពាក្យដ៏ពិសិដ្ឋ ឬ វិសេសវិសាលណាផ្សេងទៀត នៅក្នុងគ្រប់ភាសាជាង ព្រះនាមនៃព្រះជាព្រះវរបិតា និង ព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទនោះទេ » ( Reverent and Clean » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៦ ទំព័រ ៥០ ) ។

៤. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៣ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១–១៩

## បុព្វកថា

ក្នុងខែ កញ្ញា ឆ្នាំ ១៨៣១ ព្យាការី យ៉ូសែប ស្ម៊ីធ និង ពួកអែលឌើរមួយចំនួន ទើបតែបានត្រឡប់ទៅរដ្ឋ អូហៃអូ វិញពីការធ្វើដំណើរទៅឧទ្ទិសឆ្លងដី និង ទីតាំងព្រះវិហារបរិសុទ្ធនៅទីក្រុង ស៊ីយ៉ូន ឬ ក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ។ នៅអំឡុងពេលធ្វើដំណើរនេះ ពួកអែលឌើរបានមានបទពិសោធន៍នៃការខ្វែងគំនិតគ្នា និង ការមានអារម្មណ៍មិនល្អចំពោះគ្នា ប៉ុន្តែ ភាគច្រើនពួកគាត់អាចស្រុះស្រួលនឹងគ្នាបាន ។ នៅថ្ងៃទី ១១ ខែ កញ្ញា ព្យាការីបានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១–៧

*ព្រះអម្ចាស់បានអះអាងដល់ពួកអែលឌើរថា ទ្រង់មានព្រះឆន្ទៈនឹងអត់ទោសដល់ពួកគាត់*

សូមគិតអំពីគ្រាមួយ ដែលអ្នកមានការឈឺចាប់ដោយសារពាក្យសម្ដី ឬ ទង្វើរបស់បុគ្គលម្នាក់ និង អំពីរបៀបដែលអ្នកប្រព្រឹត្តចំពោះបុគ្គលនោះវិញ ។

ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤ អំពីមួយខែក្រោយមកបន្ទាប់ពីលោក និង ពួកអែលឌើរមួយក្រុមបានត្រឡប់ទៅកាន់រដ្ឋ អូហៃអូ ពីក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរីវិញ ។ ពួកអែលឌើរទាំងនេះ និង សមាជិកសាសនាចក្របានជួបប្រទះនឹងការលំបាកដោយសារតែការខ្វែងគំនិតគ្នា និង ការមានអារម្មណ៍មិនល្អចំពោះគ្នាក្នុងចំណោមពួកគេ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានមានព្រះបន្ទូលថា « មានពួកអ្នកនៅក្នុងចំណោមអ្នករាល់គ្នា ដែលបានធ្វើបាប » ( គ. និង ស. ៦៤:៣ ) ។ ព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលមាននៅក្នុងវិវរណៈនេះ បង្រៀនយើងអំពីរបៀបដែលយើងប្រព្រឹត្តចំពោះមនុស្សដែលបានធ្វើឲ្យយើងឈឺចាប់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១–៤ ដោយស្វែងរកឃ្លាទាំងឡាយ ដែលពិពណ៌នាអំពីរបៀប ដែលព្រះអម្ចាស់បានប្រព្រឹត្តចំពោះអ្នកដែលបានធ្វើបាប ។ សូមសរសេរឃ្លាទាំងនោះ ដាក់នៅក្នុងតារាងខាងក្រោមនេះ ៖ ( អ្នកក៏អាចចង់គូសចំណាំឃ្លាទាំងនោះនៅក្នុងព្រះគម្ពីររបស់អ្នកដែរ ) ។

| គ. និង ស. ៦៤:២ | គ. និង ស. ៦៤:៣ | គ. និង ស. ៦៤:៤ |
|---|---|---|
| | | |

១. គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១–៤ បង្រៀនយើងថា **ព្រះអម្ចាស់ជាព្រះពេញដោយក្ដីសណ្ដោស អត់ទោស និង ដ៏មានសេចក្ដីមេត្តាករុណា** ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលគោលការណ៍អំពីព្រះអង្គសង្គ្រោះនេះ មានសារៈសំខាន់ចំពោះអ្នក ។

នៅគ្រាដែលបានទទួលវិវរណៈនេះ សមាជិកសាសនាចក្រមួយ រួមទាំងពួកអែលឌើរមួយចំនួន ដែលបានធ្វើដំណើរជាមួយយ៉ូសែប ស្ម៊ីធ បែរជាចាប់ផ្ដាក់ស្ដីបន្ទោសដល់ព្យាការីទៅវិញ ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៦ ព្រះអម្ចាស់បានសំដៅការចាប់ផ្ដាក់ស្ដីបន្ទោសដល់ព្យាការីនោះ ដោយប្រើឃ្លាមួយថា « ស្វែងរកឱកាសទាស់នឹងលោក » ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៥–៦ ដោយស្វែងរកការណ៍ ដែលព្រះអម្ចាស់បានបង្រៀន ។

សូមពិចារណាទៅលើសំណួរខាងក្រោមនេះ ៖

- តើព្រះអម្ចាស់បានមានព្រះបន្ទូលដូចម្ដេចខ្លះ អំពីយ៉ូសែប ស្ម៊ីធ ?
- តើយើងអាចរៀនអ្វីខ្លះមកពីខគម្ពីរទាំងនេះ ?

ព្រះអម្ចាស់ក៏ពន្យល់អំពីលក្ខខណ្ឌមួយចំនួននៃការអត់ទោសដែរ ។ យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៧ តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានការអត់ទោសពីព្រះអម្ចាស់ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៨–១៩

*ព្រះអម្ចាស់បញ្ជាពួកអ្នកបម្រើទ្រង់ ឲ្យអត់ទោសដល់គ្នាទៅវិញទៅមក*

បន្ថែមពីលើអារម្មណ៍នៃការឈឺចាប់ខាងរូបកាយ តើវេទនាអារម្មណ៍អ្វីដែលអ្នកនឹងមាន ប្រសិនបើអ្នកត្រូវបានសត្វអសិរពិសចឹក ? ពស់កន្ទុយកណ្ដឹង គឺជាពស់អសិរពិសដែលសម្បូរមាននៅលើទ្វីបអាមេរិក ។ ពស់កន្ទុយកណ្ដឹងចឹកបណ្ដាលឲ្យមានការឈឺចាប់ ឡើងហើម ស្ពឹកស្រពន់ និង ភាពស្លេកស្លាំង ។ ប្រសិនបើមិនបានព្យាបាលទេនោះ វាអាចបណ្ដាលឲ្យមានការខូចជាលិកាពុំរ៉ៃ ឬ អាចស្លាប់បាន ។





អែលឌើរ ម៉ារ៉ុន ឌី ហាងស៍ នៃពួកចិតសិបនាក់ បានថ្លែងអំពីជម្រើសដែលបុគ្គលម្នាក់នឹងមាន ប្រសិនបើគេត្រូវបានចឹកដោយពស់កន្ទុយកណ្ដឹង ៖ « មានសកម្មភាពចំនួនពីរ ដែលអាចធ្វើនៅពេលមនុស្សម្នាក់ត្រូវបានចឹកដោយពស់កន្ទុយកណ្ដឹង ។ មនុស្សម្នាក់អាចដេញតាមសត្វពស់នោះ ហើយប្រហារវាចោលដោយកំហឹង ភ័យខ្លាច ឬ ការគុំគួន ។ ឬ គេអាចនឹងប្រញាប់ប្រញាល់បឺតយកពិសចេញពីក្នុងខ្លួនគេ » ( «Forgiveness: The Ultimate Form of Love, *Ensign* ខែ មករា ឆ្នាំ ១៩៧៤ ទំព័រ ២១ ) ។

ទង្វើរទាំងពីរនេះ តើទង្វើមួយណាដែលអ្នកគិតថាមានភាពឆ្លាតវៃជាង ? ហេតុអ្វី ?



អែលឌើរ ហាងស៍ បានថ្លែងថា « ប្រសិនបើយើងធ្វើតាមសកម្មភាព [ ទីពីរ ] នោះយើងអាចនឹងនៅមានជីវិត ប៉ុន្តែ ប្រសិនបើយើងប៉ុនប៉ងធ្វើតាមសកម្មភាព [ ទីមួយ ] នោះយើងនឹងមិនអាចរស់រហូតដល់បានប្រហារវាបានសម្រេចឡើយ ( « Forgiveness » ទំព័រ ២១ ) ។

ជម្រើសរបស់បុគ្គលម្នាក់បន្ទាប់ពីត្រូវពស់កន្ទុយកណ្ដឹងចឹក អាចប្រៀបធៀបទៅនឹងជម្រើសដែលយើងមាន នៅពេលយើងមានអារម្មណ៍ឈឺចាប់ដោយសារតែពាក្យសម្ដី ឬ ទង្វើរបស់បុគ្គលម្នាក់ទៀត ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៨ ដោយស្វែងរកលទ្ធផល ដែលពួកសិស្សមួយចំនួននៃព្រះអម្ចាស់បានប្រឈមមុខ ដោយសារតែពួកគេមិនអត់ទោសចំពោះគ្នាទៅវិញទៅមក ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើបុគ្គលម្នាក់អាចមានការសៅហ្មងចិត្ត ( ឬ ឈឺចាប់ ) ដោយមិនបានអត់ទោសដល់មនុស្សដទៃយ៉ាងដូចម្ដេច ?

ខ. តើទង្វើនេះមានសភាពដូចជា លទ្ធផលនៃការតាមព្យាបាទពស់កន្ទុយកណ្ដឹង ដែលបានចឹកគេយ៉ាងដូចម្ដេច ?

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៩ ដោយស្វែងរកលទ្ធផលមួយទៀត នៃការមិនអត់ទោសដល់មនុស្សដទៃ ។

យើងរៀនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៩ ថា **បើយើងមិនអត់ទោសដល់មនុស្សដទៃទេ នោះយើងនឹងជាប់ទោសនៅចំពោះអម្ចាស់ ។**

មេរៀនដែលអាចនឹងមានសារៈសំខាន់បំផុតចំពោះយើង ដើម្បីរៀនចេញពីវគ្គបទគម្ពីរនេះ គឺត្រូវចេះអត់ទោស ។ យើងទទួលបានភាពសុខសាន្តដ៏ធំធេងនៅក្នុងជីវិតយើង នៅពេលយើងអត់ទោសដល់មនុស្សដទៃ ។ នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍

ដូចតទៅនេះដោយ អែលឌើរ ដាវីឌ អ៊ី សូរេនសិន នៃពួកចិតសិបនាក់ សូមគិតអំពីរបៀបដែលវាទាក់ទងទៅនឹងសេចក្ដីពិតនេះ ៖ « វាអាចនឹងជាការលំបាកពេកពន់ដើម្បីអត់ទោសដល់នរណាម្នាក់ដែលបានធ្វើទុក្ខទោសចំពោះយើង ប៉ុន្តែ នៅពេលយើងធ្វើដូច្នោះ យើងធ្វើឲ្យខ្លួនយើងមានអនាគតកាន់តែភ្លឺស្វាងឡើង ។ ទង្វើមិនគប្បីរបស់មនុស្សម្នាក់ ពុំអាចគ្រប់គ្រងលើសកម្មភាពរបស់យើងបានទៀតឡើយ ។ នៅពេលយើងអភ័យទោសដល់អ្នកដទៃ វារំដោះយើងឲ្យមានសេរីភាព ដើម្បីជ្រើសរើសថាតើយើងនឹងរស់នៅក្នុងជីវិតរបស់យើងតាមរបៀបណា ។ ការអភ័យទោសមានន័យថា បញ្ហាកាលពីអតីតកាលឈប់សម្រេចជោគវាសនារបស់យើងទៀតហើយ ហើយយើងអាចផ្ដោតទៅលើអនាគតកាលដោយក្ដីស្រឡាញ់របស់ព្រះនៅក្នុងដួងចិត្តរបស់យើង » ( "Forgiveness Will Change Bitterness to Love," *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៣ ទំព័រ ១២ ) ។

សូមសិក្សាដោយយកចិត្តទុកដាក់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១០–១១ ដោយស្វែងរកគោលការណ៍បន្ថែមដែលព្រះអម្ចាស់បានបង្រៀនអំពីការអត់ទោស ។

៣. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមពន្យល់អំពីរបៀបដែលគោលការណ៍ ដែលអ្នកបានរៀនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១០–១១ អាចជួយបុគ្គលម្នាក់ ដែលស្ថិតនៅក្នុងស្ថានភាពខាងក្រោមនេះ ៖

ក. យុវនារីម្នាក់ឈឺចិត្ត និង មានការអាម៉ាស់បន្ទាប់ពីបានដឹងថា មិត្តភក្ដិមួយចំនួនរបស់នាងបានផ្សាយពាក្យចចាមអារ៉ាមអំពីនាង ។ ក្រោយមក មានមនុស្សមួយចំនួនបានសុំទោស ប៉ុន្តែ មនុស្សឯទៀតពុំបានសុំទោសនាងឡើយ ។ យុវនារីរូបនោះបានអត់ទោសឲ្យមនុស្ស ដែលបានសុំទោសនាង ប៉ុន្តែ នៅតែចងកំហឹងនឹងមនុស្សឯទៀតដែលមិនបានសុំទោស ។

ខ. យុវជនម្នាក់ បានរំលងក្រឹត្យវិន័យមួយ ។ គាត់បានអធិស្ឋានដើម្បីបានអត់ទោស ហើយបានពិភាក្សាជាមួយប៊ីស្សពរបស់គាត់ ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីប៊ីស្សពបានអះអាងទៅដល់យុវជននោះថា គាត់បានប្រែចិត្តទាំងស្រុងហើយ ក៏យុវជនរូបនោះនៅតែមានអារម្មណ៍ថា ពុំមានភាពសក្ដិសមដោយសារតែអំពើបាបពីអតីតកាលរបស់គាត់ដែរ ។

គ. យុវនារីម្នាក់មានអារម្មណ៍ក្រៀមក្រំ និង ច្របូកច្របល់ដោយសារតែទង្វើរបស់ឪពុកនាង ។ គាត់បានបោះបង់គ្រួសារចោល ។ ពីមុនគាត់ចាកចេញ គាត់កម្របង្ហាញសេចក្ដីស្រឡាញ់ដល់ក្រុមគ្រួសារ ឬមានចរិកឃោរឃៅជាញឹកញាប់ ។ នាងពុំយល់សោះថាតើហេតុអ្វីបានជាឪពុកនាងប្រព្រឹត្តទង្វើដូច្នេះ ហើយនាងប្រកាន់អារម្មណ៍ខឹងចំពោះគាត់ ។ នាងដឹងថានាងគួរតែព្យាយាមអត់ទោសឲ្យគាត់ ប៉ុន្តែ នាងគិតថានាងពុំអាចធ្វើបាននោះទេ ។

សូមពិចារណាថាតើ មាននរណាម្នាក់ដែលអ្នកត្រូវអត់ទោសឲ្យដែរឬទេ ។ នៅគ្រាជាច្រើន វាអាចជាការលំបាកក្រៃលែង ដើម្បីអត់ទោសឲ្យមនុស្សម្នាក់ទៀត ។ នៅពេលអ្នកអានដំបូន្មានដូចតទៅនេះពីប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី សូមស្វែងរកអ្វីដែលអ្នកអាចធ្វើ បើអ្នកកំពុងពុះពារក្នុងការអត់ទោសឲ្យមនុស្សដទៃ ៖ « បើមាននរណាម្នាក់បណ្ដុះអារម្មណ៍ខឹងសម្បារនៅក្នុងចិត្តចំពោះគ្នាទៅវិញទៅមក នោះខ្ញុំសូមអង្វរឲ្យអ្នកទូលសូមដល់ព្រះអម្ចាស់ដើម្បីទទួលបានកម្លាំងក្នុងការអត់ទោសឲ្យ ។ . . . វាប្រហែលជាពុំងាយស្រួលទេ ហើយវាអាចនឹងប្រហែលជាពុំកើតមានយ៉ាងឆាប់រហ័សផងដែរ ។ ប៉ុន្តែ បើអ្នកនឹងស្វែងរកវាដោយចិត្តស្មោះសរ ហើយបណ្ដុះវាឡើង នោះវា *នឹង* កើតមានឡើង » (Of You It Is Required to Forgive » *Ensign* ខែ មិថុនា ឆ្នាំ ១៩៩១ ទំព័រ ៥ ) ។

៤. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថាការអធិស្ឋានឲ្យមានកម្លាំង អាចជួយអ្នកឲ្យអត់ទោសយ៉ាងដូចម្ដេច ?

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១២–១៤ ។ សូមកត់ចំណាំថា ព្រះអម្ចាស់បានបង្រៀនថា ជម្រើសរបស់យើងក្នុងការប្រទានពរដល់មនុស្សដទៃ ពុំដោះលែងពួកគេពីការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនឡើយ ។ ពួកគេនៅតែមានការទទួលខុសត្រូវចំពោះព្រះអម្ចាស់ សម្រាប់អំពើខុសឆ្គងដែលពួកគេបានប្រព្រឹត្ត ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១៥–១៧ ហើយកត់ចំណាំថា ព្រះអម្ចាស់បានមានព្រះបន្ទូលយ៉ាងច្បាស់លាស់ថាទ្រង់នឹងអត់ទោសឲ្យពួកអ្នកបម្រើទ្រង់គឺ អ៊ីសាក មូរលី និង អែតវីត ប៉ាទ្រិច ព្រោះពួកគាត់បានប្រែចិត្តពីអំពើបាបរបស់ខ្លួន ។

នៅដើមដំបូងនៃមេរៀននេះ អ្នកបានរៀនថា ព្រះអម្ចាស់ពេញដោយក្ដីសណ្ដោស អត់ទោស និង មានសេចក្ដីមេត្តាករុណា ។ នៅពេលអ្នកអត់ទោស អ្នកអាចប្រែក្លាយកាន់តែដូចជាទ្រង់ ។ សូមសម្រេចចិត្តអំពីរបៀបដែលអ្នកអាចអនុវត្តគោលការណ៍នៃការអត់ទោស ដែលអ្នកបានរៀននៅថ្ងៃនេះ ។

## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និងសេចក្តីសញ្ញា ៦៤:៩–១១

សូមចំណាយពេលពីរបីនាទីអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៦៤:៩–១១ ដោយឮៗ ។ នៅពេលអ្នកសូត្រវគ្គបទគម្ពីរនេះបានយ៉ាងហោចណាស់ប្រាំដង នោះសូមស្វែងរកបងប្អូនបង្កើត ឪពុកម្តាយ ឬ មិត្តភក្តិ ដែលនឹងអាចជួយអ្នកឲ្យហ្វឹកហាត់ទន្ទេញវា ។ សូមសូត្រវគ្គបទគម្ពីរទៅកាន់បុគ្គលម្នាក់នោះ រហូតដល់អ្នកអាចទន្ទេញវាចាំ ។ សូមពន្យល់បុគ្គលនោះអំពីរបៀបដែលគោលការណ៍នៅក្នុងខគម្ពីរនេះ អាចជួយអ្នកពេញមួយជីវិត ។ បន្ទាប់មក សូមសុំឲ្យបុគ្គលនោះចុះហត្ថលេខាលើសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្តីសញ្ញា ៦៤:១–១៩ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# មេរៀនទី ១៤ ៖ ថ្ងៃទី ៤ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០–៤៣

## បុព្វកថា

ព្យាការី យ៉ូសែប ស៊្មីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤ នៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៨៣១ ។ ប្រមាណជាពីរសប្ដាហ៍ពីមុនលោកបានទទួលវិវរណៈនេះ ព្យាការីបានត្រឡប់ទៅរដ្ឋ អូហៃអូ វិញ បន្ទាប់ពីបានមើលការខុសត្រូវលើការឧទ្ទិសឆ្លងដី និង ទីតាំងព្រះវិហារបរិសុទ្ធនៃស៊ីយ៉ូន នៅក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ។. គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០–៤៣ មាននូវការបង្រៀនរបស់ព្រះអម្ចាស់អំពីពលិកម្ម ដែលទ្រង់តម្រូវឲ្យពួកបរិសុទ្ធមាន និងអំពីការស្ថាបនាស៊ីយ៉ូននៅថ្ងៃចុងក្រោយ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០–២៥

*ព្រះអម្ចាស់បង្រៀនថា ទ្រង់តម្រូវចិត្តពីយើង*

នៅលើបន្ទាត់ខាងក្រោមនេះ សូមសរសេរអំពីគ្រាមួយ ដែលអ្នកមានអារម្មណ៍ថា បានលះបង់ដើម្បីធ្វើតាមព្រះបញ្ញត្តិព្រះអម្ចាស់ ( ដូចជាចៀងវាងពីការចូលរួមព្រឹត្តិការណ៍កីឡា ឬ សកម្មភាពស្រដៀងនឹងនេះ ដើម្បីរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ) ៖

សូមគិតអំពីរបៀបដែលអ្នកអាចបានពរ ដោយសារតែការលះបង់របស់អ្នក ។ អ្នកអាចរៀនកាន់តែច្រើនអំពីការលះបង់ដែលព្រះអម្ចាស់តម្រូវឲ្យយើងធ្វើ នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០–៤៣ រួចអានព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដែលបានដាក់ដល់ អ៊ីសាក មូលី, ហ្វ្រេឌើរិក ជី វិលលាម្ស និង សមាជិកសាសនាចក្រកាលពីជំនាន់ដំបូងដទៃទៀត ។

អ៊ីសាក មូលី មានដីស្រែដ៏ធំមួយនៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ។ គាត់បានអញ្ជើញសមាជិកសាសនាចក្រដោយស្មោះ រួមទាំង យ៉ូសែប ស៊្មីធ និង ក្រុមគ្រួសាររបស់លោកផងដែរ ឲ្យមករស់នៅលើដីស្រែនេះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០ ដោយស្វែងរកការណ៍ដែលព្រះអម្ចាស់បានបញ្ជាឲ្យ អ៊ីសាក មូលី ធ្វើជាមួយនឹងដីស្រែរបស់គាត់នោះ ។ សូមសរសេរអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលឲ្យ អ៊ីសាក មូលី ធ្វើ ដាក់នៅក្នុងចន្លោះត្រឹមត្រូវនៃតារាងខាងក្រោមនេះ ។



ដីស្រែរបស់ អ៊ីសាក មូលី ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ

| | ចំណេះចំណានឧតម្ភ៏រ— ( គ. និង ស. ៦៤:២០ ) | ហ្វ្រេឌើរិក ជី វិលលាម្ស ( គ. និង ស. ៦៤:២១ ) |
|---|---|---|
| តើព្រះអម្ចាស់បានមានព្រះបន្ទូលថាគាត់គួរតែធ្វើអ្វីខ្លះ ? | | |
| តើគាត់មានប្រតិកម្មបែបណាចំពោះការបញ្ជានោះមកពីអម្ចាស់ ? ( សូមមើលព័ត៌មានខាងលើ ) ។ | | |

| | ចំណេះចំណានខគម្ពីរ—( គ. និង ស. ៦៤:២០ ) | ហ្វ្រេឌើរិក ជី វិលលាម្ស ( គ. និង ស. ៦៤:២១ ) |
|---|---|---|
| តើការគោរពប្រតិបត្តិតាមការបញ្ជារបស់ព្រះអម្ចាស់ មានលទ្ធផលដូចម្ដេចខ្លះ ? ( សូមមើលព័ត៌មានខាងលើ ) ។ | | |

នេះគឺជាការលះបង់មួយដ៏ធំចំពោះ អ៊ីសាក មួលី ។ ប្រាក់មួយចំនួនធំដែលបានមកពីការលក់ដីស្រែនោះ ត្រូវបានប្រើប្រាស់ដើម្បីទិញដីសម្រាប់សមាជិកដទៃទៀតនៃសាសនាចក្រនៅក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ។

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០ ដោយស្វែងរកពរជ័យដែលព្រះអម្ចាស់បានសន្យាប្រទានឲ្យ អ៊ីសាក មួលី ប្រសិនបើគាត់លក់ដីស្រែរបស់គាត់នោះ ។ យើងរៀនចេញពីខគម្ពីរនេះថា **បើយើងធ្វើតាមព្រះឆន្ទៈដែលព្រះមានចំពោះយើង នោះយើងនឹងមិនត្រូវបានល្បួងហួសកម្រិតដែលយើងអាចទ្រាំបានឡើយ ។**

អ៊ីសាក មួលី បានធ្វើតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ដែលត្រូវលក់ដីស្រែរបស់គាត់នោះ ហើយត្រូវបានព្រះប្រទានពរឲ្យមានលទ្ធភាពក្នុងការតតាំងនឹងការល្បួង ។ គាត់គឺជាម្នាក់ក្នុងចំណោមពួកបរិសុទ្ធជំនាន់ដំបូង ដែលតាំងលំនៅនៅក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ជាទីដែលគាត់បានប្រឹងប្រែងស្ថាបនាទីក្រុង ស៊ីយ៉ូន ឡើង ។ គាត់បានបម្រើព្រះអម្ចាស់យ៉ាងស្មោះត្រង់ ពេញមួយជីវិតរបស់គាត់ ។ សូមសរសេរអំពីប្រតិកម្មរបស់ អ៊ីសាក និង លទ្ធផលនៃទង្វើរបស់គាត់នោះ ដាក់នៅក្នុងតារាង ។

១. សូមធ្វើបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីព្រះបញ្ញត្តិចំនួនពីរ ឬ បី ដែលព្រះអម្ចាស់បានប្រទានដល់យើងទាំងអស់គ្នា ( មានដូចជា ព្រះបញ្ញត្តិដែលបញ្ជាឲ្យយើងអធិស្ឋានជានិច្ច ) ។ ក្រោយមក សូមពន្យល់អំពីរបៀបដែល ការគោរពប្រតិបត្តិទាំងនេះ អាចជួយអ្នកឲ្យចៀសផុតពីការល្បួង ។

បុរសម្នាក់ទៀតគឺ ហ្វ្រេឌើរិក ជី វិលលាម្ស ក៏មានដីស្រែមួយនៅទីក្រុង ខឺតឡង់ ដែរ ។ នៅលើដីស្រែគាត់មានផ្ទះពីរខ្នង ជង្រុកស្រូវដ៏ធំមួយ និង ផ្ទៃដីរាប់ហិចតា ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២១ ដោយស្វែងរកព្រះបញ្ញត្តិដែលព្រះអម្ចាស់បានប្រទានឲ្យដល់ ហ្វ្រេឌើរិក ជី វិលលាម្ស ។

សូមសរសេរអ្វីដែលព្រះអម្ចាស់បានបញ្ជាឲ្យ ហ្វ្រេឌើរិក ជី វិលលាម្ស ធ្វើ ជាមួយនឹងដីស្រែរបស់គាត់ ដាក់នៅក្នុងតារាងខាងលើ ។

ទោះជា ហ្វ្រេឌើរិក ជី វិលលាម្ស ពុំត្រូវបានតម្រូវឲ្យលក់ដីស្រែរបស់គាត់ដូចជា អ៊ីសាក មួលី យ៉ាងណាក៏ដោយ ក៏គាត់នៅតែបង្ហាញឆន្ទៈចង់ធ្វើការលះបង់ដែរ ។ គាត់បានជម្រាបព្យាការី យ៉ូសែប ស្ម៊ីធ ថា ដីស្រែគាត់អាចត្រូវបានប្រើប្រាស់ដើម្បីសង់ផ្ទះ ឲ្យសមាជិកដែលខ្វះខាត រួមទាំងឪពុកម្ដាយរបស់ព្យាការីផងដែរ ។ មិនតែប៉ុណ្ណោះ បងប្រុស វិលលាម្ស បានអនុញ្ញាតឲ្យធ្វើដំណាំកសិផល ហើយចិញ្ចឹមសត្វនៅលើដីស្រែនោះ ថែមទាំងផ្គត់ផ្គង់ដល់ពួកបរិសុទ្ធទៀតផង ។ ក្រោយមកទៀត គាត់បានប្រគល់ដីស្រែទាំងមូលរបស់គាត់ទៅដល់សាសនាចក្រ ដោយមិនគិតថ្លៃអ្វីសោះឡើយ ។ តាមរយៈការលះបង់របស់ ហ្វ្រេឌើរិក ជី វិលលាម្ស និង ពួកបរិសុទ្ធដ៏ស្មោះត្រង់ដទៃទៀតនៅរដ្ឋ អូហៃអូ នោះព្រះអម្ចាស់បានទុក « កន្លែងមាំមួនមួយនៅក្នុងដែនដីខឺតឡង់ សម្រាប់អំឡុងពេលប្រាំឆ្នាំ » ( គ. និង ស. ៦៤:២១ ) ។ អំឡុងពេលប៉ុន្មានឆ្នាំនេះ ពួកបរិសុទ្ធបានសាងសង់ព្រះវិហារបរិសុទ្ធ ទីក្រុង ខឺតឡង់ ។ ពួកគេបានឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធក្នុងឆ្នាំ ១៨៣៦ គឺប្រាំបន្ទាប់ពីបានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤ ។

សូមបំពេញប្រអប់ឈរសម្រាប់ ហ្វ្រេឌើរិក ជី វិលលាម្ស ដោយសរសេរនៅក្នុងចន្លោះត្រឹមត្រូវនៃតារាង អំពីអ្វីដែលគាត់បានធ្វើ និង លទ្ធផលនៃទង្វើនោះ ។

យើងរៀនពីគំរូរបស់ អ៊ីសាក មួលី និង ហ្វ្រេឌើរិក ជី វិលលាម្ស អំពីគោលការណ៍ដូចតទៅនេះ ៖ **យើងមានពរនៅពេលយើងគោរពប្រតិបត្តិព្រះអម្ចាស់ ហើយលះបង់ទៅតាមអ្វីដែលទ្រង់បញ្ជាឲ្យយើងលះបង់** ។ អ្នកអាចនឹងចង់គូសចំណាំគោលការណ៍នេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។

ការលះបង់ដែល អ៊ីសាក មួលី និង ហ្វ្រេឌើរិក ជី វិលលាម្ស បានធ្វើជាមួយនឹងដីស្រែរបស់គាត់ បង្ហាញពីការលះបង់មួយទៀត ដែលព្រះអម្ចាស់បានតម្រូវពីពួកគាត់ ហើយទ្រង់ក៏តម្រូវពីយើងផងដែរនាពេលបច្ចុប្បន្ននេះ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២២ ដោយស្វែងរកការលះបង់ ដែលព្រះអម្ចាស់តម្រូវពីយើង ។

អ្នកអាចនឹងចង់គូសចំណាំគោលការណ៍ដូចតទៅនេះនៅក្នុង ខទី ២២ ៖ **ព្រះអម្ចាស់តម្រូវចិត្តពីយើង ។**

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា វាមានន័យយ៉ាងណាដែលថា ព្រះអម្ចាស់តម្រូវចិត្តពីយើងនោះ ?

ខ. តើអ្នកអាចបង្ហាញដល់ព្រះអម្ចាស់ថា អ្នកមានឆន្ទៈថ្វាយចិត្តចំពោះទ្រង់ដែរឬទេ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២៣–២៥ រួចស្វែងរកព្រះបញ្ញត្តិដែលយើងអាចគោរពប្រតិបត្តិ ដើម្បីបង្ហាញថា យើងបានថ្វាយចិត្តរបស់យើងចំពោះព្រះអម្ចាស់ ។

អំឡុងពេលនេះនៅក្នុងប្រវត្តិសាសនាចក្រ វាក្យសព្ទ « ដង្វាយមួយភាគក្នុងដប់ » សំដៅទៅលើដង្វាយ ឬ ការបរិច្ចាគដ៏សុទ្ធចិត្តទៅដល់សាសនាចក្រ ។ ក្នុងឆ្នាំ ១៨៣៨ ដង្វាយមួយភាគក្នុងដប់ ត្រូវបានឲ្យនិយមន័យថាជា មួយភាគនៃប្រាក់ចំណូលរបស់បុគ្គលម្នាក់ ( សូមមើលក្បាលកណ្ឌនៃ គ. និង ស. ១១៩) ។ ចាប់តាំងពីពេលនោះមក សមាជិកទាំងអស់ត្រូវបានតម្រូវឲ្យថ្វាយ ១០ ភាគរយនៃប្រាក់ចំណូលរបស់ខ្លួនជារៀងរាល់ឆ្នាំ ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការថ្វាយដង្វាយមួយភាគក្នុងដប់ បង្ហាញថាយើងបានថ្វាយចិត្តរបស់យើងចំពោះព្រះអម្ចាស់យ៉ាងដូចម្ដេច ?

ខ. តើពរជ័យនៃការថ្វាយដង្វាយមួយភាគក្នុងដប់យ៉ាងពេញលេញ និង ដោយស្មោះមានអ្វីខ្លះ ?

សូមរំឭក គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២៣ ដោយស្វែងរកការសន្យា ដែលព្រះអម្ចាស់បានប្រទានដល់អ្នកដែលបង់ដង្វាយមួយភាគក្នុងដប់ ។

ទន្ទឹមនឹងពរជ័យដែលបានលើកឡើងនៅក្នុង ខទី ២៣ អនុវត្តនៅក្នុងពេលអនាគត នោះព្រះអម្ចាស់ក៏នឹងប្រទានពរដល់យើងនាពេលបច្ចុប្បន្ននេះ ចំពោះការថ្វាយដង្វាយមួយភាគក្នុងដប់ដែរ ។ សូមគិតអំពីបទពិសោធន៍នានា ដែលអ្នកបានមាននៅពេលអ្នក ឬ ក្រុមគ្រួសារអ្នកមានពរ ដែលជាលទ្ធផលនៃការថ្វាយដង្វាយមួយភាគក្នុងដប់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២៦–៤៣

*ព្រះអម្ចាស់ ប្រទានការណែនាំអំពីការស្ថាបនាទីក្រុង ស៊ីយ៉ូន*

សូមគិតអំពីគ្រាមួយដែលអ្នកត្រូវបានហៅឲ្យបំពេញកិច្ចការមួយ ដែលមានការលំបាក ឬ មានអារម្មណ៍ថាលើសកម្រិត ។

ក្នុងខែ សីហា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធនូវកិច្ចការមួយដ៏ធំ ដែលរកប្រាក់ទិញដីធ្លីដែលត្រូវការ ដើម្បីស្ថាបនាទីក្រុង ស៊ីយ៉ូន ឡើងនៅឃុំចាកសុន រដ្ឋ មិសសួរី ។ ពួកបរិសុទ្ធបានដឹងថា ដរាបណាដែលពួកគេបានទិញដីធ្លីហើយ នោះពួកគេនឹងត្រូវធ្វើការយ៉ាងសស្រាក់សស្រាំ ដើម្បីស្ថាបនាទីក្រុង និង សាងសង់ព្រះវិហារបរិសុទ្ធឡើង ។



គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២៦–២៩ មាននូវព្រះបញ្ញត្តិពីព្រះអម្ចាស់ទៅដល់ពួកអ្នកបម្រើទ្រង់ចំនួនពីរនាក់ គឺ នូវល ខេ វិតនី និង ស៊ីឌនី គិលប៊ឺត ដែលត្រូវប្រើផ្សាររបស់ពួកគេនៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ដើម្បីផ្គត់ផ្គង់តម្រូវការរបស់ពួកបរិសុទ្ធ ។ នេះគឺជាគំរូមួយនៃរបៀបដែលពួកបរិសុទ្ធមួយចំនួន ត្រូវបានបញ្ជាឲ្យលះបង់ ហើយបរិច្ចាគទៅក្នុងការស្ថាបនាទីក្រុង ស៊ីយ៉ូន ឡើង ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៣០–៣៣ ដោយស្វែងរកឃ្លាទាំងឡាយ ដែលប្រហែលជាបានលើកទឹកចិត្តដល់ពួកបរិសុទ្ធ ដែលប្រឹងប្រែងបំពេញកិច្ចការដ៏ធំនៃការស្ថាបនាទីក្រុង ស៊ីយ៉ូន ឡើង ។

យោងតាមអ្វីដែលអ្នកបានរៀនចេញពីការអានខគម្ពីរទាំងនេះ សូមបញ្ចប់គោលការណ៍ខាងក្រោមនេះ ៖

**បើយើង នោះយើងនឹងអាចសម្រេចកិច្ចការដ៏ធំធេងបាន ។**

បន្ទាប់ពីព្រះអម្ចាស់បានលើកទឹកចិត្តដល់ពួកបរិសុទ្ធឲ្យឧស្សាហ៍ធ្វើកិច្ចការល្អ នោះទ្រង់បានមានព្រះបន្ទូលអំពីការគោរពប្រតិបត្តិសាជាថ្មី ។ តើអ្នកធ្លាប់គោរពប្រតិបត្តិឪពុកម្ដាយ ថ្នាក់ដឹកនាំសាសនាចក្រ គ្រូបង្រៀន ឬ គ្រូបង្វឹករបស់អ្នក ប៉ុន្តែធ្វើវាដោយមានឥរិយាបថគំរោះគំរើយដែរឬទេ ? សូមកត់ចំណាំនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៣៤ នូវពាក្យដែលពិពណ៌នាអំពីឥរិយាបថ ដែលយើងគួរតែមាន នៅពេលយើងគោរពប្រតិបត្តិព្រះអម្ចាស់ ។

អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចតទៅនេះដាក់នៅក្នុងព្រះគម្ពីររបស់អ្នកក្បែរ ខទី ៣៤ ៖ **យើងត្រូវគោរពប្រតិបត្តិព្រះអម្ចាស់ដោយចិត្ត និង ដោយគំនិតដែលស្ម័គ្រតាម ។**

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ការគោរពប្រតិបត្តិព្រះអម្ចាស់ដោយ « ចិត្ត និង គំនិតដែលស្ម័គ្រតាម » មានន័យដូចម្ដេច ?

ខ. សូមគិតអំពីគ្រាមួយ ដែលអ្នកបានគោរពប្រតិបត្តិព្រះអម្ចាស់ ដោយចិត្ត និង គំនិតដែលស្ម័គ្រតាម ។ តើទង្វើនេះមានសភាពខុសគ្នាយ៉ាងដូចម្ដេច ពីគ្រាដែលអ្នកពុំបានគោរពប្រតិបត្តិដោយស្ម័គ្រតាម ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៤១–៤៣ ដោយស្វែងរកព័ត៌មាន ស្ដីពីការស្ថាបនាទីក្រុង ស៊ីយ៉ូន ឡើងនៅថ្ងៃចុងក្រោយបង្អស់ ។ វាសំខាន់ដែលត្រូវចងចាំថា នៅថ្ងៃចុងក្រោយបង្អស់ ទីក្រុង ស៊ីយ៉ូន នឹងមិនត្រូវបានស្ថាបនាឡើងនៅក្នុងទីតាំងភូមិសាស្ត្រតែមួយដូចជា ក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី នោះទេ ។ ទីក្រុង ស៊ីយ៉ូន នឹងត្រូវបានស្ថាបនាឡើងនៅក្នុងគ្រប់ជាតិសាសន៍ ដែលមានមនុស្សគោរពប្រតិបត្តិព្រះអម្ចាស់ដោយចិត្ត និង គំនិតស្ម័គ្រតាម ។

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវគោលដៅនៃអ្វីមួយ ដែលអ្នកនឹងធ្វើដើម្បីគោរពប្រតិបត្តិព្រះអម្ចាស់ដោយស្មោះត្រង់ និង ការគោរពប្រតិបត្តិដែលស្ម័គ្រតាម ។ នៅពេលអ្នកកំពុងខិតខំសម្រេចគោលដៅនេះ សូមកត់ចំណាំអំពីភាពខុសប្លែក ដែលការគោរពប្រតិបត្តិនេះធ្វើឲ្យមាននៅក្នុងជីវិតអ្នក ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:២០–៤៣ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៥ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥–៦៦

### សេចក្ដីផ្ដើម

នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៨៣១ យ៉ូសែប ស្ម៊ីធ និង ក្រុមគ្រួសារលោក បានផ្លាស់ទីលំនៅពីទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ទៅ ភូមិ ហៃរ៉ាំ រដ្ឋ អូហៃអូ ដែលមានចម្ងាយប្រមាណ ៤៨ គីឡូម៉ែត្រទៅភាគអាគ្នេយ៍នៃទីក្រុង ខឺតឡង់ ។ ពួកគាត់ធ្វើដូច្នេះដើម្បីឆ្លើយតបទៅនឹងការបញ្ជារបស់ព្រះអម្ចាស់ ( សូមមើល គ. និង ស. ៦៣:៦៥ ) ។ ព្យាការី និង ក្រុមគ្រួសាររបស់លោកបានផ្លាស់ទីលំនៅទៅជាមួយក្រុមគ្រួសាររបស់ ចន និង អាលីស ចនសុន ដែលជាអ្នកប្រែចិត្តជឿថ្មីនៅក្នុងសាសនាចក្រ ។ មូលហេតុចម្បងនៃការផ្លាស់ទីលំនៅពីទីក្រុង ខឺតឡង់ គឺដើម្បីបន្តការងារបកប្រែដ៏បំផុសគំនិតលើព្រះគម្ពីរប៊ីប ( ដែលជាញឹកញាប់សំដៅទៅលើ ការបកប្រែរបស់ យ៉ូសែប ស្ម៊ីធ ឬ ក.យ.ស. ) ។ នៅពេលទៅដល់ភូមិ ហៃរ៉ាំ យ៉ូសែប បានចាប់ផ្ដើមការងារនោះសាជាថ្មី ។ នៅថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៨៣១ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បង្រៀនថា ដំណឹងល្អនឹងត្រូវបានចែកចាយពាសពេញលើផែនដី ជាការប្រុងប្រៀបខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ហើយពួកបរិសុទ្ធត្រូវអធិស្ឋាន ដើម្បីឲ្យមានវឌ្ឍនភាពចំពោះនគរព្រះ ។

វិលលាម អ៊ី ម៉ុកឡេលិន បានទទួលពិធីបុណ្យជ្រមុជទឹកនៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៨៣១ ។ មិនយូរប៉ុន្មានបន្ទាប់ពីគាត់ត្រូវបានតែងតាំងជាអែលឌើរ គាត់បានចូលរួមធ្វើជាអ្នកផ្សព្វផ្សាយជាមួយ ហៃរុម ស្ម៊ីធ សម្រាប់ពេលពីរបីសប្ដាហ៍ ។ ក្នុងខែ តុលា គាត់បានធ្វើដំណើរទៅកាន់រដ្ឋ អូហៃអូ ដើម្បីចូលរួមសន្និសីទនៃសាសនាចក្រ ។ កាលកំពុងនៅទីនោះ គាត់បានជួបនឹងព្យាការី យ៉ូសែប ស្ម៊ីធ ។ តាមរយៈព្យាការី ព្រះអម្ចាស់បានប្រទានសេចក្ដីណែនាំ និង ការព្រមានដើម្បីជួយគាត់ឲ្យនៅតែស្មោះត្រង់ ហើយទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចនៅទីបំផុត ។ វិវរណៈនេះ មានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៦៦ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥

*ព្រះអម្ចាស់ប្រកាសថា ដំណឹងល្អនឹងមានពាសពេញផ្ទៃផែនដី*

១. សូមធ្វើបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីការណ៍មួយចំនួនដែលអ្នកអធិស្ឋានទូលសុំជាប្រចាំ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥ គឺជាវិវរណៈអំពីការអធិស្ឋាន ។ នៅពេលអ្នកសិក្សាវិវរណៈនេះ អ្នកនឹងឃើញមានឱវាទព្រះអម្ចាស់ស្ដីពីការណ៍ដែលអ្នកគួរតែអធិស្ឋានសុំ—ជាពិសេសនៅពេលយើងធ្វើសាក្សីចំពោះការសម្រេចបាននូវព្រឹត្តិការណ៍ទាំងឡាយ ដែលបានព្យាករឲ្យកើតឡើងនៅថ្ងៃចុងក្រោយ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥:១–២ ដោយស្វែងរករបៀបដែលព្រះអម្ចាស់ បានពិពណ៌នាអំពីការចែកចាយដំណឹងល្អ ។ អ្នកអាចនឹងចង់គូសចំណាំអំពីទីកន្លែង ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថាដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនឹងទៅដល់ ។

សូមកត់ចំណាំថាព្រះអម្ចាស់បានមានព្រះបន្ទូលថា « កូនសោទាំងឡាយនៃនគរព្រះ ត្រូវបានផ្ទុកផ្ដាក់ដល់មនុស្សនៅលើផែនដី » ( គ. និង ស. ៦៥:២ ) ។ ឃ្លា « កូនសោទាំងឡាយនៃនគរ » សំដៅទៅលើសិទ្ធអំណាចបព្វជិតភាពដើម្បីធ្វើអធិបតី និង ដើម្បីអនុញ្ញាតឲ្យមានការគ្រប់គ្រង និង ការធ្វើពិធីបរិសុទ្ធនៃបព្វជិតភាពដែលមានក្នុងសាសនាចក្រ ។ ដោយមានកូនសោបព្វជិតភាពទាំងនេះ នោះប្រធាននៃសាសនាចក្រ ដឹកនាំឲ្យមានកិច្ចខិតខំផ្សាយដំណឹងល្អ ។



តើអ្នកដឹងអ្វីខ្លះ អំពីការស្រាយសុបិនរបស់ ដានីយ៉ែល ថ្វាយស្ដេច នេប៊ូក្នេសា ដែលមានកត់ត្រានៅក្នុង ដានីយ៉ែល ២ ក្នុងព្រះគម្ពីរសញ្ញាចាស់ ?

អ្នកអាចរំឭកថា ស្ដេច នេប៊ូក្នេសា មិនសប្បាយព្រះទ័យដោយសារសុបិនមួយ ហើយថាព្រះអម្ចាស់បានបើកសម្ដែងសុបិននោះ ថែមទាំងអត្ថន័យរបស់វាទៅដល់ព្យាការី ដានីយ៉ែល ។ នៅក្នុងសុបិន រូបមួយយ៉ាងធំនោះតំណាងឲ្យនគរជាច្រើន ដែលត្រូវបានបំផ្លាញដោយការដាប់ផ្ដាច់ថ្មចេញពីភ្នំឥតមានដៃណាធ្វើឡើយ ។ ថ្មនោះបានចាប់ផ្ដើមពីទំហំតូច ប៉ុន្តែបានរីកធំឡើងរហូតដល់បានបំពេញផ្ទៃផែនដី ។ ( សូមមើល ដានីយ៉ែល ២:៣១–៤៥ ) ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥:២ ឃ្លា « នគរព្រះ » សំដៅទៅលើនគរព្រះនៅលើផែនដី—ដែលជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥:៥–៦ ) ។ អ្នកអាចនឹងចង់សរសេរគោលការណ៍នេះនៅក្នុងព្រះគម្ពីររបស់អ្នកក្បែរ ខទី ២ ។

សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះពី ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ដោយស្វែងរកអ្វីដែលលោកបានមានព្រះបន្ទូលអំពីនគរព្រះ ៖



« យើងគឺជាពលរដ្ឋនៅក្នុងនគរដ៏ធំបំផុតនៅលើផែនដី–ជានគរមួយដែលពុំត្រូវបានដឹកនាំដោយប្រាជ្ញាមនុស្សឡើយ ប៉ុន្តែបានដឹកនាំដោយព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ។ វត្តមានរបស់នគរគឺមានពិតមែន ។ ជោគវាសនារបស់នគរ គឺមានជាក់ ។ នេះគឺជានគរដែលព្យាការី ដានីយ៉ែល បានថ្លែង– ថ្មមួយដុំ ដែលគួរតែត្រូវបានកាត់ផ្ដាច់ពីភ្នំដោយឥតដៃណាធ្វើ ហើយរមៀលចេញទៅ រហូតដល់បានពេញផែនដីទាំងមូល ។ ( សូមមើល ដានីយ៉ែល ២:៣៤–៣៥ ) ។

« គ្មានមនុស្សខាងសាច់ឈាមណា បានបង្កើតព្រះនគរនេះឡើងនោះទេ ។ វាកើតឡើងតាមរយៈវិវរណៈ ដែលបានមកពីអង្គដឹកនាំនៅស្ថានសួគ៌ ។ ហើយចាប់តាំងពីសតវត្សរ៍ទីដប់ប្រាំបួននៃការកកើតព្រះនគរនេះមក វាបានរីកធំឡើង ដូចជាដុំព្រិលដែលរមៀលចេញទៅមានទំហំកាន់តែធំឡើងដូច្នោះដែរ » ( « Pillars of Truth » *Ensign* ខែ មករា ឆ្នាំ ១៩៩៤ ទំព័រ ៤ ) ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកឃើញថា ការព្យាករណ៍របស់ ដានីយ៉ែល កំពុងត្រូវបានបំពេញនាពេលបច្ចុប្បន្ននេះតាមរបៀបណាខ្លះ ? តើការណ៍នេះពង្រឹងទីបន្ទាល់របស់អ្នកអំពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយយ៉ាងដូចម្ដេច ?

ខ. តើការធ្វើជាចំណែកមួយនៃនគរព្រះលើផែនដី មានន័យដូចម្ដេចចំពោះអ្នក ?

សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយ អែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ រួចគិតអំពីរបៀបដែលអ្នកនឹងបញ្ចប់ប្រយោគចុងក្រោយបំផុត ៖



« តើអ្នកធ្លាប់គិតអំពីមូលហេតុ ដែលអ្នកត្រូវបានបញ្ជូនឲ្យមកកើតនៅលើផែនដីនៅជំនាន់ដ៏ពិសេសនេះដែរឬទេ ? អ្នកពុំកើតមកអំឡុងជំនាន់របស់អ័ដាម និង អេវ៉ា ឬនៅពេលដែល ផារ៉ោន បានគ្រប់គ្រងលើប្រទេសអេស៊ីព្ទ ឬអំឡុងពេល រាជវង្ស មីងនោះទេ ។ អ្នកបានមកកាន់ផែនដីនៅគ្រានេះ ២០ សតវត្សរ៍ បន្ទាប់ពីការយាងមករបស់ព្រះគ្រីស្ទពីដំបូង ។ បព្វជិតភាពរបស់ព្រះ ត្រូវបានស្ដារឡើងវិញនៅលើផែនដី ហើយព្រះអម្ចាស់បានដាក់ព្រះហស្ដទ្រង់រៀបចំពិភពលោកសម្រាប់ការត្រឡប់មកវិញដ៏រុងរឿងរបស់ទ្រង់ ។ ទាំងនេះ គឺជាបណ្ដាពេលវេលានៃឱកាស និងការទទួលខុសត្រូវទាំងឡាយដ៏សំខាន់ ។ ទាំងនេះ គឺជាពេលវេលារបស់អ្នក ។

« ដោយនូវពិធីបុណ្យជ្រមុជទឹករបស់អ្នក អ្នកបានប្រកាសអំពីសេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ។. . . ទំនួលខុសត្រូវសំខាន់មួយរបស់អ្នក គឺត្រូវ . . . » (Preparing the World for the Second Coming, » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១១, ទំព័រ ៤៩ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥:៣–៤ ដោយស្វែងរកការទទួលខុសត្រូវទាំងឡាយ ដែលអ្នកមានក្នុងនាមជាសមាជិកនៃនគរព្រះនៅលើផែនដី ។

នៅក្នុង ខទី ៣ ឃ្លា « ចូររៀបចំភោជនាអាហារទទួលកូនចៀម » សំដៅលើការទទួលខុសត្រូវក្នុងការរៀបចំលោកិយសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចតទៅនេះ ដាក់នៅក្នុងព្រះគម្ពីររបស់អ្នកក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥:៣–៤ ៖ **យើងមានការទទួលខុសត្រូវក្នុងការត្រៀមខ្លួនយើង និង មនុស្សដទៃសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។**

អែលឌើរ អាន់ឌើរសិន បានថ្លែងទីបន្ទាល់អំពីសេចក្ដីពិតនេះ ។ លោកបានបញ្ចប់ប្រយោគចុងក្រោយបង្អស់នៅក្នុងសេចក្ដីថ្លែងការណ៍ខាងលើដោយប្រសាសន៍ទាំងនេះ ៖ « ការទទួលខុសត្រូវដ៏ចាំបាច់មួយរបស់អ្នកគឺត្រូវ ជួយរៀបចំលោកិយសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ » ( Preparing the World for the Second Coming » ទំព័រ ៤៩ ) ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. នៅពេលអ្នកគិតអំពីការទទួលខុសត្រូវរបស់អ្នកក្នុងការរៀបចំខ្លួនឯង និង មនុស្សដទៃសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ តើអ្នកមានគំនិត និង អារម្មណ៍យ៉ាងដូចម្ដេចខ្លះ ?

ខ. សូមកត់ចំណាំនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥:៤ ថា យើងត្រូវ « ប្រកាសប្រាប់ពីកិច្ចការដ៏អស្ចារ្យ [ របស់ព្រះអម្ចាស់ ] នៅក្នុងចំណោមប្រជាជន ។ តើមានមធ្យោបាយមួយចំនួនណាខ្លះ ដែលអ្នកអាចធ្វើកិច្ចការនេះបាន ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥:៥–៦ រួចគូសចំណាំឲ្យបានយ៉ាងហោចណាស់ ការណ៍ចំនួនបីដែលអ្នកគួរតែអធិស្ឋានសូមឲ្យកើតឡើង ។

តើការអធិស្ឋានសម្រាប់ការណ៍ទាំងបីនេះ ជួយអ្នកឲ្យត្រៀមខ្លួនឯង និង មនុស្សដទៃសម្រាប់ការយាងមកជាលើកទីពីរយ៉ាងដូចម្ដេច ?

សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយ ប្រធាន ថូម៉ាស អេស ម៉នសុន ៖ សូមស្វែងរកអ្វីមួយដែល ប្រធាន ម៉នសុន បានស្នើឲ្យយើងបន្តអធិស្ឋានសូមឲ្យកើតឡើង ហើយសូមគិតថាតើការអធិស្ឋានបែបនេះ អាចជួយរៀបចំលោកិយសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទតាមរបៀបណា ។



« ខ្ញុំស្នើសុំឲ្យសេចក្ដីជំនឿ និងការអធិស្ឋានរបស់អ្នកបន្តធ្វើឡើង ដល់គ្រប់តំបន់ទាំងឡាយ ដែលឥទ្ធិពលរបស់យើងនៅមានកំណត់ ហើយនៅកន្លែងដែលយើងពុំត្រូវអនុញ្ញាត ឲ្យចែកចាយដំណឹងល្អដោយសេរីក្នុងពេលនេះ ។ អព្ភូតហេតុទាំងឡាយនឹងកើតឡើងប្រសិនបើយើងធ្វើដូច្នេះ » (Welcome to Conference » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៩, ទំព័រ ៦ ) ។

៤. ចេញពីអ្វីដែលអ្នកបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥ សូមសរសេរអំពីអ្វីមួយ ដែលអ្នកនឹងធ្វើដើម្បីជួយត្រៀមខ្លួនអ្នក និង មនុស្សដទៃសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦

*ព្រះអម្ចាស់ប្រទានឱវាទដល់ វិលលាម អ៊ី ម៉ុកឡេលិន ដើម្បីបន្តស្មោះត្រង់ដរាបដល់ចុងបំផុត ។*

វិលលាម អ៊ី ម៉ុកឡេលិន បានអធិស្ឋានដោយសម្ងាត់ ដោយទូលសូមឲ្យព្រះអម្ចាស់ប្រទានចម្លើយចំពោះសំណួរជាក់លាក់ចំនួនប្រាំ តាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ។ ដោយពុំបានលើកឡើងអំពីសំណួរ វិលលាម បានស្នើឲ្យមានវិវរណៈ ។ នៅថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៨៣១ នៅពេលព្យាការី យ៉ូសែប បានកត់ត្រាវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦ វិលលាម បានឃើញថា សំណួរនីមួយៗរបស់គាត់ត្រូវបានឆ្លើយ ។

ទោះជា វិលលាម អ៊ី ម៉ុកឡេលិន ពុំបន្តស្មោះត្រង់យ៉ាងណាក្ដី ក៏មានការសរសេរមួយនៅ ១០ ឆ្នាំបន្ទាប់ពីគាត់បានចាកចេញពីសាសនាចក្រ ថាគាត់ពុំអាចបដិសេធចំពោះការដែល ព្យាការី យ៉ូសែប ស្ម៊ីធ ត្រូវបានបំផុសគំនិតនោះឡើយ ។ គាត់បានកត់ត្រាអំពីវិវរណៈដូចតទៅនេះ ៖ « ឥឡូវនេះ ខ្ញុំសូមថ្លែងទីបន្ទាល់នៅក្នុងការកោតខ្លាចដល់ព្រះ ថារាល់សំណួរដែលខ្ញុំបានទូលសូមពុទ្ធដល់ព្រះកាណ៌របស់ព្រះអម្ចាស់នៃពួកពលបរិវារនោះ ត្រូវបានឆ្លើយតបធ្វើឲ្យខ្ញុំស្កប់ចិត្តយ៉ាងខ្លាំង ។ ខ្ញុំចង់ឲ្យវាធ្វើជាទីបន្ទាល់ចំពោះការបំផុសគំនិតរបស់ យ៉ូសែប ។ ហើយខ្ញុំសូមថ្លែងនៅថ្ងៃនេះ ចាត់ទុកថាជាភស្តុតាងដែលខ្ញុំពុំអាចបដិសេធបានឡើយ » ( នៅក្នុង Jan Shipps and John W. Welch, eds., *The Journals of William E. McLellin 1831–1836* [ ឆ្នាំ ១៩៩៤ ] ទំព័រ ៥៧ ) ។

*ការដាក់បញ្ចូលឈ្មោះរបស់អ្នកទៅក្នុងបទគម្ពីរ*

ដើម្បីធ្វើឲ្យការបង្រៀនបទគម្ពីរកាន់តែមានលក្ខណៈផ្ទាល់ខ្លួន សូមពិចារណាអំពីការដាក់បញ្ចូលឈ្មោះផ្ទាល់របស់អ្នកទៅក្នុងខគម្ពីរមួយ ។ ឧទាហរណ៍ អ្នកអាចដាក់បញ្ចូលឈ្មោះរបស់អ្នកនៅខាងដើម គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦:១២ ដោយស្រមៃថា ព្រះអម្ចាស់កំពុងតែមានព្រះបន្ទូលមកកាន់អ្នកដោយផ្ទាល់ ។

នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៦ សូមស្វែងរកការសន្យាលើកទឹកចិត្ត ដែលព្រះអម្ចាស់បានប្រទានទៅដល់វិលលាម អ៊ី ម៉ុកឡេលិន ។ សូមស្វែងរកផងដែរនូវព្រះបន្ទូលកែតម្រូវ និង ការព្រមាន ។

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីការសន្យាមួយ និង ការព្រមានមួយ ដែលព្រះអម្ចាស់បានប្រទានដល់បងប្រុស ម៉ុកឡេលិន រួមបញ្ចូលទាំងលេខខគម្ពីរដែលមានសរសេរអំពីការណ៍ទាំងនោះ ។ រួចសរសេរប្រយោគចំនួនមួយ ឬ ពីរ ដោយពន្យល់អំពីការសន្យា និង ការព្រមានដែលបង្រៀនអ្នកអំពីព្រះអម្ចាស់ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៥–៦៦ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៥ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧

## បុព្វកថា

នៅខែវិច្ឆិកា ឆ្នាំ ១៨៣១ ក្រុមនៃពួកអែលឌើរមួយក្រុមបានមកជួបជុំគ្នាសម្រាប់សន្និសីទពិសេសមួយនៅ ហៃរ៉ាំ រដ្ឋ អូហៃអូ ។ ប្រធានបទនៃការពិភាក្សាមួយនៅក្នុងសន្និសីទនោះ គឺជាការបោះពុម្ពវិវរណៈទាំងឡាយ ដែលព្យាការី យ៉ូសែប ស៊្មីធ បានទទួល ។ នៅអំឡុងការប្រជុំនោះ ព្រះអម្ចាស់បានប្រទានវិវរណៈទៅដល់ យ៉ូសែប ស៊្មីធ ហើយបានកំណត់វិវរណៈនោះថាជា អារម្ភកថានៃព្រះគម្ពីរវិវរណៈដែលនឹងត្រូវបោះពុម្ព ។ សព្វថ្ងៃនេះ វិវរណៈនោះ គឺជាកណ្ឌទី ១ ក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ។ ក្រោយមក នៅក្នុងសន្និសីទនោះ ព្រះអម្ចាស់បានប្រទានវិវរណៈ ដែលសព្វថ្ងៃនេះត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧ ។ នៅក្នុងវិវរណៈនោះ ព្រះអម្ចាស់បានមានព្រះបន្ទូលទៅកាន់ពួកបងប្អូនប្រុស ដែលបានមានសំណួរអំពីភាសានៃវិវរណៈ ដែលទ្រង់បានប្រទានដល់ព្យាការី ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:១–៣

*ព្រះអង្គសង្គ្រោះទ្រង់ជ្រាបអំពីគំនិត និង ចិត្តរបស់មនុស្ស*

តើអ្នកធ្លាប់ឆ្ងល់ ថាតើហេតុអ្វីបានជាមនុស្សមួយចំនួនទទួលបានទីបន្ទាល់អំពីគោលលទ្ធិនៃដំណឹងល្អ ចំណែកឯមនុស្សមួយចំនួនទៀតពុំទទួលបាន ?

ក្នុងខែ វិច្ឆិកា ឆ្នាំ ១៨៣១ មានពួកអែលឌើរមួយក្រុម រួមបញ្ចូលទាំងព្យាការី យ៉ូសែប ស៊្មីធ បានប្រជុំគ្នាពិភាក្សាអំពីការបោះពុម្ពវិវរណៈដែលព្យាការីបានទទួល ។ ពួកអែលឌើរមួយចំនួនបានទទួលទីបន្ទាល់ថា វិវរណៈទាំងឡាយនោះគឺពិត ។ ទោះជាយ៉ាងណាក៏ដោយ ពួកអែលឌើរមួយចំនួនទៀត នៅតែសង្ឃឹមថានឹងទទួលបានទីបន្ទាល់ដូចគ្នានោះដែរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:១–២ ដោយស្វែងរកការណ៍ ដែលព្រះអម្ចាស់បានមានព្រះបន្ទូលអំពីការអធិស្ឋាន ។

ចេញពីអ្វីដែលអ្នកបានរៀននៅក្នុង ខទី ១–២ សូមបំពេញនៅក្នុងចន្លោះនៃគោលការណ៍ដូចតទៅនេះ ៖ **ព្រះអម្ចាស់ឮ ហើយជ្រាបអំពី** របស់ខ្ញុំ ។



១. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការដឹងអំពីគោលការណ៍នេះ អាចជួយអ្នកធ្វើឲ្យការអធិស្ឋានរបស់អ្នកមានសភាពកាន់តែប្រសើរថែមទៀតតាមរបៀបណា ? បន្ទាប់មក សូមសរសេរអំពីបទពិសោធន៍មួយរបស់អ្នក ដែលបានជួយអ្នក ឬ មនុស្សណាម្នាក់ដែលអ្នកស្គាល់ ឲ្យបង្កើនការអះអាងខាងវិញ្ញាណអំពីសេចក្ដីពិតនៃដំណឹងល្អ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:៣ ដោយស្វែងរកមូលហេតុដែលពួកអែលឌើរមួយចំនួន ពុំទទួលបានពរជ័យ ដែលព្រះអម្ចាស់បានប្រទានដល់ពួកគាត់ ។ អ្នកអាចនឹងចង់គូសចំណាំឃ្លា ដែលលេចធ្លោចំពោះអ្នក ។



២. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការអនុញ្ញាតឲ្យសេចក្ដីភ័យខ្លាចមាននៅក្នុងចិត្តអ្នកអាចរារាំងអ្នកមិនឲ្យទទួលបានពរជ័យយ៉ាងដូចម្ដេចដែរ ? រួចសូមបង្កើតបញ្ជីនៃសេចក្ដីភ័យខ្លាច ដែលអាចនឹងបញ្ឈប់មនុស្សពីការទទួលបានពរជ័យ ។



សូមពិចារណាអំពីព្រះចេស្តានៃព្រះអម្ចាស់ ដើម្បីជួយយើងឲ្យជំនួសសេចក្តីភ័យខ្លាចដោយនូវសេចក្តីជំនឿវិញ ។ តើការយល់ដឹងបែបនេះ ជួយមនុស្សម្នាក់ឲ្យបន្តបង្កើនទីបន្ទាល់យ៉ាងដូចម្តេច ?

## គោលលទ្ធិ និង សេចក្តីសញ្ញា ៦៧:៤–៩

*ព្រះអម្ចាស់សាកល្បងមនុស្សដែលបានរិះគន់ដល់វិវរណៈទាំងឡាយរបស់ទ្រង់*

តើអ្នកធ្លាប់ឆ្ងល់ដែរឬទេ ថាតើហេតុអ្វីបានជាយើងគួរតែធ្វើតាមថ្នាក់ដឹកនាំសាសនាចក្រ ទោះបីជាពួកលោកពុំល្អឥតខ្ចោះយ៉ាងណាក៏ដោយនោះ ?

សូមអានសេចក្តីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្តីសញ្ញា ៦៧ និង ខទី ៥ ដោយស្វែងរកឥរិយាបថខុស ៗគ្នា ដែលពួកអែលឌើរមួយចំនួនបានមានចំពោះវិវរណៈទាំងឡាយ ។ ( សូមចងចាំថា ការចងក្រងដំបូងនៃវិវរណៈរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ត្រូវបានឲ្យឈ្មោះថាជា ព្រះគម្ពីរនៃបទបញ្ញត្តិ ។ ក្រោយមក ឈ្មោះនោះត្រូវបានប្តូរទៅជា គោលលទ្ធិ និង សេចក្តីសញ្ញា វិញ ) ។ សូមកត់ចំណាំនៅក្នុងសេចក្តីណែនាំអំពីកណ្ឌថា « ពួកបងប្អូនប្រុស ៗភាគច្រើន បានថ្លែងទីបន្ទាល់យ៉ាងម៉ឺងម៉ាត់ » អំពីភាពពេញលេញនៃវិវរណៈទាំងឡាយ ។ ទោះជាយ៉ាងណាក៏ដោយ « ការសន្ទនាជំទាស់មួយអំពីរបៀបប្រើភាសានៅក្នុងវិវរណនេះ បានកើតឡើង » ។ យោងតាម ខទី ៥ ពួកអែលឌើរមួយចំនួនបានគិតថា ពួកគាត់អាច « ថ្លែងបានប្រសើរជាងភាសារបស់ [ របស់ យ៉ូសែប ស្ម៊ីធ ] » ។ ដោយសារតែភាពឆ្មើងឆ្មៃក្នុងបញ្ញារបស់ខ្លួន នោះពួកគេមានអារម្មណ៍ថា ខ្លួនមានគុណសម្បត្តិច្រើនជាងព្យាការីដែលព្រះអម្ចាស់បានចាត់តាំង ដើម្បីសរសេរវិវរណៈទាំងឡាយនោះ ( សូមមើល នីហ្វៃទី២ ៩:២៨–២៩ ) ។

សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៦៧:៤ រួចសូមអាន ខទី ៥ សាជាថ្មីផងដែរ ។ សូមស្វែងរករបៀបដែលព្រះអម្ចាស់បានឆ្លើយតបទៅនឹងកង្វល់របស់ពួកអែលឌើរ អំពីការប្រើភាសានៅក្នុងវិវរណៈនេះ ។

តើអ្នកគិតថា ហេតុអ្វីបានជាវាមានសារៈសំខាន់ចំពោះពួកអែលឌើរ ដែលត្រូវយល់ថា ព្រះអម្ចាស់ទ្រង់ជ្រាបថាទ្រង់កំពុងធ្វើការជាមួយអ្នកបម្រើទ្រង់ដែលមិនល្អឥតខ្ចោះ ?

សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៦៧:៦–៩ ដោយស្វែងរកការសាកល្បង ដែលព្រះអម្ចាស់បានប្រទានដល់អ្នកដែលមានកង្វល់អំពីការប្រើភាសានៅក្នុងវិវរណៈនេះ ។

វិលលាម អ៊ី ម៉ុកខ្លេលិន បានសម្រេចចិត្តទទួលយកសំណូមពរពីព្រះអម្ចាស់ ដើម្បីសរសេរវិវរណៈមួយប្រៀបធៀបទៅនឹងវិវរណៈដែលព្យាការី យ៉ូសែប ស្ម៊ីធ បានទទួល ។ យ៉ូសែប ស្ម៊ីធ បានកត់ត្រារឿងដូចតទៅនេះនៅក្នុងប្រវត្តិរបស់លោក ៖ « វិលលាម អ៊ី ម៉ុកខ្លេលិន បានគិតថាខ្លួនគឺជាមនុស្សដែលមានប្រាជ្ញាជាងគេ ដោយសំអាងលើចំណេះវិជ្ជា ជាជាងការប្រើការញ្ញាណដឹង បានព្យាយាមសរសេរព្រះបញ្ញត្តិមួយឲ្យស្រដៀងគ្នាទៅនឹងព្រះបញ្ញត្តិដែលតូចបំផុតរបស់អម្ចាស់ ប៉ុន្តែ បានបរាជ័យ ដ្បិតវាគឺជាការទទួលខុសត្រូវមួយដ៏លើសលុបដើម្បីសរសេរនៅក្នុងព្រះនាមនៃព្រះអម្ចាស់ ។ ពួកអែលឌើរ និងមនុស្សទាំងអស់ដែលបានមើលឃើញការព្យាយាមដែលមិនបានទទួលជោគជ័យនៃបុរសក្លែងម្នាក់នេះធ្វើតាមរបៀបប្រើភាសានៃព្រះយេស៊ូវគ្រីស្ទ បានចាប់ផ្តើមសេចក្តីជំនឿរបស់ខ្លួនទៅលើភាពពេញលេញនៃដំណឹងល្អសាជាថ្មី និង លើសេចក្តីពិតនៃព្រះបញ្ញត្តិ និង វិវរណៈទាំងឡាយ ដែលព្រះអម្ចាស់បានប្រទានដល់សាសនាចក្រតាមរយៈរូបខ្ញុំ ដែលជាឧបករណ៍របស់ទ្រង់ ហើយពួកអែលឌើរបានបង្ហាញឆន្ទៈដើម្បីថ្លែងទីបន្ទាល់អំពីសេចក្តីពិតរបស់ខ្លួនទៅកាន់ពិភពលោក » ( នៅក្នុង *History of the Church* ១:២២៦ ) ។

បន្ទាប់ពីព្រឹត្តិការណ៍នេះ ពួកអែលឌើរទាំងប៉ុន្មាននាក់ដែលបានមានវត្តមាននៅទីនោះ បានព្រមព្រៀងចុះហត្ថលេខាលើឯកសារមួយ ដោយបានថ្លែងទីបន្ទាល់ជាផ្លូវការ អំពីភាពពេញលេញនៃវិវរណៈ ដែលមាននៅក្នុងព្រះគម្ពីរនៃបទបញ្ញត្តិ ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ហេតុអ្វីបានជា យ៉ូសែប ស្ម៊ីធ ដែលមានការអប់រំទាប អាចសរសេរវិវរណៈទាំងនេះបាន ប៉ុន្តែ វិលលាម អ៊ី ម៉ុកខ្លេលិន ដែលជាអ្នកមានការអប់រំខ្ពស់នោះ បែរជាមិនអាចធ្វើបានទៅវិញ ?

ខ. តើអ្នកអាចរៀនអ្វីខ្លះ ចេញពីដំណើររឿងនេះ អំពីការវិនិច្ឆ័យដល់ថ្នាក់ដឹកនាំរបស់យើងដោយសារតែភាពមិនល្អឥតខ្ចោះរបស់ពួកលោក ?

សូមពិចារណាអំពីការតាំងចិត្ត ដើម្បីធ្វើតាមថ្នាក់ដឹកនាំរបស់អ្នកដោយសេចក្តីសុចរិត ទោះជាអ្នក ឬ មនុស្សដទៃទៀតបានឃើញមានភាពមិនល្អឥតខ្ចោះដែលពួកលោកមានយ៉ាងណាក៏ដោយ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:១០–១៤

*ព្រះអម្ចាស់ប្រទានឱវាទដល់ពួកអ្នកដើរតាមទ្រង់ អំពីរបៀបត្រៀមខ្លួនចូលទៅក្នុងវត្តមានរបស់ព្រះ*

៤. សូមគូសតារាងមួយ ដែលមានប្រអប់ឈរពីរ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមសរសេរនៅលើប្រអប់ឈរទីមួយថា *រង្វាន់* និង លើប្រអប់ឈរទីពីរថា *របៀបទទួលបានរង្វាន់* ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:១០–១៤ ដោយស្វែងរករង្វាន់ ដែលព្រះអង្គសង្គ្រោះបានសន្យាដល់ពួកបងប្អូនប្រុសទាំងនេះ និង ទង្វើចាំបាច់ៗដែលពួកគេត្រូវប្រព្រឹត្ត ដើម្បីទទួលបានរង្វាន់នោះ ។ សូមសរសេរចម្លើយរបស់អ្នក ដាក់នៅក្នុងប្រអប់ឈរដែលត្រឹមត្រូវ ៖

យោងតាមខគម្ពីរទាំងនេះ តើពួកបងប្អូនប្រុសទាំងនេះ ត្រូវធ្វើអ្វីដើម្បីបាននៅក្នុងវត្តមាននៃព្រះ ? ( ពាក្យ *បាននៅក្នុង* មានន័យថា ការកាន់ខ្ជាប់ ឬ ស្ថិតស្ថេរនៅក្នុងទីកន្លែងជាក់លាក់មួយ ) ។ បើពួកគេដកខ្លួនចេញពីការច្រណែនឈ្នានីស និង ការភ័យខ្លាច ហើយបន្ទាបខ្លួន នោះពួកគេនឹងអាចនៅក្នុងវត្តមាននៃព្រះបាន ។

ដូចបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:១៣ ពួកបងប្អូនប្រុសទាំងនេះ ត្រូវបានលើកទឹកចិត្តឲ្យ « ស៊ូនៅក្នុងសេចក្ដីអត់ធន់ » រហូតដល់ពួកគេបានល្អឥតខ្ចោះ ។ សូមអានដំណើររឿងខាងក្រោមនេះ ដែលបានចែកចាយដោយប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ក្នុងគណៈប្រធានទីមួយ ដែលបង្រៀនយើងអំពីសារៈសំខាន់នៃការអត់ធន់នៅក្នុងដំណើរការនៃការប្រែក្លាយជាល្អឥតខ្ចោះ ៖



« អំឡុងទសវត្សរ៍ឆ្នាំ ១៩៦០ មានសាស្ត្រាចារ្យមួយរូបនៅសាកលវិទ្យាល័យ ស្ទែនហ្វដ បានធ្វើការសាកល្បងធ្វើបទពិសោធន៍តូចមួយអំពីកម្លាំងឆន្ទៈរបស់កុមារតូចៗ ដែលមានអាយុបួនឆ្នាំ ។ គាត់ដាក់នំម៉ាស្សម៉ាឡូដ៏ធំមួយនៅចំពោះមុខកុមារតូចៗនោះ ហើយបានប្រាប់កុមារទាំងនោះថា ពួកគេអាចញុំានំនោះភ្លាមតែម្ដង ឬ បើអាចចាំតែ ១៥ នាទីទៀត នឹងទទួលបាននំម៉ាស្សម៉ាឡូនោះដល់ទីពីរ ។

« បន្ទាប់មក គាត់បានទុកឲ្យកុមារនោះនៅតែឯង ហើយឃ្លាំមើលពីក្រោយកញ្ចក់ដែលអាចឃើញតែម្ខាង ។ កុមារខ្លះបានញុំានំ ម៉ាស្សម៉េលូ ភ្លាមតែម្ដង ហើយខ្លះទៀតអាច រង់ចាំបានតែប៉ុន្មាននាទីមុនពេលពួកវាចុះចាញ់ការល្បួង ។ មានតែ ៣០ ភាគរយប៉ុណ្ណោះដែលអាចរង់ចាំបាន » (បន្តដោយភាពអត់ធន់ » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៥៦ ) ។

តើអ្នកគិតថា ការពិសោធន៍ និង ការរកឃើញរបស់សាស្ត្រាចារ្យរូបនេះ អាចអនុវត្តចំពោះយុវវ័យនាពេលបច្ចុប្បន្ននេះយ៉ាងដូចម្ដេច ?

បន្ទាប់មកប្រធាន អុជដូហ្វ បានថ្លែងអំពីការរកឃើញ ដែលចេញពីការពិសោធន៍លើនំម៉ាស្សម៉ាឡូនោះថា ៖



« ប៉ុន្តែនៅពេលដែលពេលវេលាកន្លងទៅ [សាស្ត្រាចារ្យ] បាន តាមដានកុមារទាំងនោះ ហើយចាប់ផ្ដើមសំគាល់ ឃើញនូវភាពស្របគ្នាដ៏គួរឱ្យចាប់អារម្មណ៍ថា៖ កុមារទាំងនោះដែលមិនអាចរង់ចាំបាន ក្រោយមកតែងនឹងមានបញ្ហានៅក្នុងជីវិត និង មានបញ្ហាផ្នែកអាកប្បកិរិយាជាងកុមារដែលអាចរង់ចាំបាន នៅពេលដែលកុមារដែលអាចរង់ចាំបាន ទំនងជាមានភាពវិជ្ជមានជាង និងមានការលើកទឹកចិត្តជាង មានពិន្ទុ និងចំណូលខ្ពស់ជាង ហើយមានទំនាក់ទំនងល្អជាងកុមារដែលមិនអាចរង់ចាំបាន ។

« អ្វីដែលបានចាប់ផ្ដើមដោយការពិសោធន៍យ៉ាងសាមញ្ញមួយជាមួយកុមារ ហើយនិងនំម៉ាស្សម៉ាឡូ នឹងក្លាយទៅជាការសិក្សាគំរូសំខាន់មួយដែលបង្ហាញថា លទ្ធភាពដើម្បីរង់ចាំ—អត់ធន់—គឺជាលក្ខណៈសម្បត្តិ អត្តចរិកជាគន្លឹះ ដែលអាចព្យាករនូវជោគជ័យក្រោយមកក្នុងជីវិត ។. . .

« ការរង់ចាំអាចជាការលំបាក ។ កុមារដឹងថា វាលំបាក ហើយមនុស្សពេញវ័យក៏ដឹងដូច្នោះដែរ ។ យើងរស់នៅក្នុងពិភពលោកមួយ ដែលមានភោជនីយដ្ឋានលក់អាហាររហ័សទាន់ចិត្ត ការផ្ញើសារបន្ទាន់ ខ្សែភាពយន្តដែលអាចរើសបានតាមចិត្ត និង ឆ្លើយតបភ្លាមៗលើសំណួរជ្រៅៗ ឬ សំណួររាក់កំផែល ។ យើងមិនចូលចិត្តរង់ចាំនោះទេ ។. . .

« ភាពអត់ធន់—ជាលទ្ធភាពដើម្បីដាក់ចំណង់របស់យើងឲ្យនៅស្ងៀមក្នុងរយៈពេលមួយ—គឺជាគុណធម៌ដ៏មានតម្លៃ និង កម្រ ។ យើងចង់បានអ្វីដែលយើងចង់បាន ហើយយើងចង់បានវាឥឡូវនេះ ។ ហេតុដូច្នោះហើយ គំនិតនៃភាពអត់ធ្មត់នោះឯង ដែលវាហាក់ដូចជាមិនទទួលបានការពេញចិត្ត ហើយមានរសជាតិល្វីងជូរចត់ ។

« យ៉ាងណាក្តី ដោយគ្មានការអត់ធន់ យើងមិនអាចធ្វើឲ្យព្រះសព្វព្រះហឫទ័យឡើយ យើងមិនអាចទទួលបានភាពគ្រប់លក្ខណ៍ឡើយ ។ យ៉ាងពិតប្រាកដ ការអត់ធន់ គឺជាដំណើរការឲ្យមានបរិសុទ្ធភាព ដែលដុសខាត់ការយល់ដឹង បង្កើនសុភមង្គល ផ្តោតទង្វើ ហើយនិងផ្តល់ក្តីសង្ឃឹមសម្រាប់ភាពសុខសាន្ត » ( « បន្តដោយភាពធត់ធន់ » ទំព័រ ៥៦) ។

៥. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថាហេតុអ្វីបានជាការអត់ធន់ចាំបាច់ នៅក្នុងការខិតខំរបស់អ្នកឲ្យមានភាពសក្តិសម ហើយនៅក្នុងវត្តមាននៃព្រះអម្ចាស់ ? សូមយកពេលពីរបីនាទីផងដែរ ទៅពិចារណាអំពីចំណុចទាំងឡាយនៅក្នុងជីវិតរបស់អ្នក ដែលអ្នកអាចត្រូវមានការអត់ធន់ឲ្យបានកាន់តែច្រើនជាមួយខ្លួនឯង និង ជាមួយមនុស្សដទៃ ។ ប្រសិនបើអ្នកមានអារម្មណ៍ល្អក្នុងការធ្វើដូចនេះ សូមសរសេរគោលដៅមួយ ដែលរួមបញ្ចូលទាំងការមានអត់ធន់ឲ្យបានកាន់តែច្រើនក្នុងការខិតខំរបស់អ្នក ដើម្បីមានភាពបរិសុទ្ធនៅចំពោះព្រះ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្តីសញ្ញា ៦៧ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៥ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្តីសញ្ញា ៦៨

## សេចក្តីផ្តើម

នៅថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៨៣១ ព្យាការី យ៉ូសែប ស្ម៊ីធ បានជួបនឹងពួកអែលឌើរមួយក្រុមនៅភូមិហៃរ៉ាំ រដ្ឋ អូហៃអូ ដើម្បីធ្វើសន្និសីទពិសេសមួយ ។ ពួកលោកបានពិភាក្សាអំពីការបោះពុម្ពព្រះគម្ពីរនៃបទបញ្ញត្តិ ដែលជាការជ្រើសរើសចេញពីវិវរណៈទាំងឡាយ ដែលព្យាការីបានទទួល ។ មានពួកអែលឌើរបួនរូបនៅក្នុងសន្និសីទនេះ បានស្នើឲ្យ យ៉ូសែប ស្ម៊ីធ ទូលសូមដល់ព្រះអម្ចាស់អំពីព្រះឆន្ទៈទ្រង់ដែលមានចំពោះពួកគាត់ ។ ដើម្បីឆ្លើយតបទៅនឹងសំណើនេះ នោះព្យាការីបានទទួលវិវរណៈដែលសព្វថ្ងៃនេះត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៦៨ ។ វិវរណៈនេះរួមបញ្ចូលទាំងឱវាទទៅដល់ អ្នកដែលត្រូវបានហៅឲ្យផ្សាយដំណឹងល្អ សេចក្តីណែនាំអំពីការហៅបម្រើរបស់ប៊ីស្សព និង ព្រះបញ្ញត្តិដែលមានចំពោះឪពុកម្តាយដែលត្រូវបង្រៀនអំពីគោលការណ៍ និង គោលលទ្ធិទាំងឡាយនៃដំណឹងល្អទៅដល់កូនចៅរបស់ខ្លួន ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ៦៨:១–១២

*ព្រះអង្គសង្គ្រោះប្រទានឱវាទទៅដល់អ្នកទាំងឡាយ ដែលត្រូវបានហៅឲ្យផ្សាយដំណឹងល្អ*



សូមពិចារណាសំណួរខាងក្រោម ៖

- តើការបារម្ភ ឬកង្វល់អ្វីខ្លះ អាចកើតមានចំពោះមនុស្សដែលហៀបនឹងបម្រើបេសកកម្មពេញម៉ោង ?
- តើមានហេតុផលមួយចំនួនណាខ្លះ ដែលពេលខ្លះមនុស្សមានអារម្មណ៍ភ័យខ្លាច អំពីការចែកចាយដំណឹងល្អជាមួយសមាជិកក្រុមគ្រួសារ និង មិត្តភក្តិរបស់ខ្លួន ?

នៅអំឡុងសន្និសីទនៅថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៨៣១ ពួកអែលឌើរចំនួនបួនរូប ដែលនឹងបម្រើជាអ្នកផ្សព្វផ្សាយសាសនា បានចូលទៅជួបព្យាការី យ៉ូសែប ស្ម៊ីធ ហើយបានសុំដឹងអំពីព្រះឆន្ទៈរបស់ព្រះអម្ចាស់ ដែលមានចំពោះពួកគាត់ ។ ដើម្បីឆ្លើយតប ព្រះអម្ចាស់បានបើកសម្តែងលំនាំមួយនៃការផ្សាយដំណឹងល្អ ។

សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៦៨:១–៥ ដោយស្វែងរកលំនាំមួយនៃការផ្សាយដំណឹងល្អ ។ សូមគិតពីការគូសចំណាំអ្វីដែលអ្នករកឃើញ ។ ( អ្នកនឹងរកឃើញពាក្យ *គំរូ* នៅក្នុង ខទី ២ និង ទី ៣ ។ គំរូ គឺជាលំនាំ ឬ តួយ៉ាង ) ។

ចំណុចខាងក្រោមនេះ តើមួយណាដែល *មិនមែនជា* ផ្នែកនៃលំនាំនៃការផ្សាយដំណឹងល្អ ដែលមាននៅក្នុង ខទី ១ ?

- ច្រៀងចម្រៀងនៃសេចក្តីស្រឡាញ់ដ៏អស់កល្បជានិច្ច ។
- ប្រកាសដំណឹងល្អដោយព្រះវិញ្ញាណ ។
- ពិភាក្សាជាមួយមនុស្សដែលអ្នកបង្រៀន ។
- បរិយាយបទគម្ពីរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:៦ ដោយស្វែងរកការលើកទឹកចិត្តបន្ថែម ដែលព្រះអម្ចាស់បានប្រទានឲ្យដល់ពួកអ្នកបម្រើរបស់ទ្រង់ ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើមានគោលការណ៍អ្វីខ្លះ ដែលអ្នកឃើញមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨: ៦ ដែលអាចនឹងនាំមកនូវការលួងលោមចិត្តដល់អ្នកផ្សព្វផ្សាយសាសនា ?

ខ. ហេតុអ្វីបានជាវាមានសារៈសំខាន់ចំពោះអ្នក ដែលត្រូវដឹងថា ព្រះអម្ចាស់ទ្រង់គង់នៅក្បែរអ្នកផ្សព្វផ្សាយសាសនាដ៏ស្មោះត្រង់របស់ទ្រង់ ?

គ. តើការសន្យានេះ អាចជួយអ្នកនៅក្នុងកិច្ចខិតខំដើម្បីផ្សាយដំណឹងល្អនាពេលបច្ចុប្បន្ននេះយ៉ាងដូចម្ដេច ?

អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចតទៅនេះដាក់នៅក្នុងព្រះគម្ពីររបស់អ្នកក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:៤ ៖ **នៅពេលពួកអ្នកបម្រើរបស់ព្រះអម្ចាស់ត្រូវបានបណ្ដាលដោយព្រះវិញ្ញាណបរិសុទ្ធ នោះពាក្យសម្ដីរបស់ពួកលោកនឹងដឹកនាំមនុស្សទៅរកសេចក្ដីសង្គ្រោះ ។**



ទន្ទឹមនឹងពេលអ្នកដែលត្រូវបានតែងតាំងឲ្យផ្សាយដំណឹងល្អអាចជួយយើងឲ្យដឹងអំពីព្រះឆន្ទៈរបស់ព្រះអម្ចាស់ នោះមានតែប្រធាននៃសាសនាចក្រតែម្នាក់គត់ ដែលមានសិទ្ធិទទួលបាន ហើយប្រកាសអំពីព្រះឆន្ទៈរបស់ព្រះអម្ចាស់សម្រាប់សាសនាចក្រទាំងមូល ។ នៅក្រោមការដឹកនាំរបស់លោកនោះសមាជិកក្នុងគណៈប្រធានទីមួយ និង ក្រុមនៃពួកសាវកដប់ពីរនាក់ ក៏មានសិទ្ធអំណាចប្រកាសអំពីព្រះឆន្ទៈរបស់ព្រះអម្ចាស់សម្រាប់យើងដែរ ។ ដូច្នេះ គោលការណ៍ដែលមានបង្រៀននៅក្នុង ខទី ៤ អាចអនុវត្តនៅគ្រប់ពេលដែលសមាជិកក្នុងគណៈប្រធានទីមួយ ឬ ក្រុមនៃពួកសាវកដប់ពីរនាក់ ឡើងថ្លែងសុន្ទរកថានៅក្នុងសន្និសីទទូទៅ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:៣–៥ ម្ដងទៀត រួចស្វែងរកការសន្យា ដែលព្រះអម្ចាស់បានប្រទានឲ្យដល់ពួកអ្នកបម្រើរបស់ទ្រង់ដែលត្រូវបានតែងតាំងនោះ ។ សូមបញ្ចប់សេចក្ដីថ្លែងការណ៍ដូចតទៅនេះ ៖ នៅពេលពួកអ្នកបម្រើរបស់ព្រះអម្ចាស់ថ្លែងកាលបណ្ដាលដោយព្រះវិញ្ញាណបរិសុទ្ធ នោះពាក្យសម្ដីរបស់ពួកលោកក៏នឹងដឹកនាំទៅតាមព្រះវិញ្ញាណដែរ ។

២. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើមានមធ្យោបាយណាខ្លះ ដែលយើងអាចអញ្ជើញឲ្យមានអានុភាពនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលយើងចែកចាយដំណឹងល្អ ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:៧–១២ យើងអានថា ព្រះអម្ចាស់បានហៅពួកអែលឌើរទាំងបួនរូបនេះ ឲ្យផ្សាយដំណឹងល្អ ហើយធ្វើពិធីបុណ្យជ្រមុជទឹកឲ្យអ្នកដែលនឹងទទួលជឿ ។ យើងក៏អានផងដែរអំពីពរជ័យទាំងឡាយ ដែលកើតមានចំពោះពួកគាត់ និង ចំពោះអ្នកដែលជឿដល់ពាក្យសម្ដីរបស់ពួកគាត់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:១៣–២៤

*ព្រះអម្ចាស់បើកសម្ដែងអំពីគុណសម្បត្តិសម្រាប់តំណែងនៃប៊ីស្សព*

សូមស្រមៃថា មានមិត្តភក្តិម្នាក់ដែលមានជំនឿផ្សេងសួរថា « តើប៊ីស្សពរបស់អ្នកត្រូវបានជ្រើសតាំងយ៉ាងដូចម្ដេច » ? តើអ្នកនឹងនិយាយថាដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:១៤–១៥, ២០ ដោយស្វែងរករបៀប ដែលប៊ីស្សពត្រូវបានជ្រើសតាំង ។

ឃ្លា « ពូជពង្សនៃលោកអើរ៉ុនពិត » សំដៅទៅលើខ្សែស្រឡាយនៃប្អូនប្រុសរបស់ ម៉ូសេ គឺ អើរ៉ុន នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ ខ្សែស្រឡាយនេះ នឹងមានសិទ្ធិចំពោះតំណែងនៃប៊ីស្សពជាអធិបតី ប្រសិនបើត្រូវបានហៅ ហើយអនុមតិដោយគណៈប្រធានទីមួយ ។ នៅជំនាន់របស់ ម៉ូសេ មានតែខ្សែស្រឡាយនៃអំបូរលេវីតែប៉ុណ្ណោះ ដែលបានកាន់បព្វជិតភាពលេវី ឬ បព្វជិតភាពអើរ៉ុន ។ បុគ្គលម្នាក់ត្រូវតែមានឈាមជ័រជាខ្សែស្រឡាយនេះ ទើបត្រូវបានប្រគល់បព្វជិតភាពឲ្យ ។ សិទ្ធិទទួលបានបព្វជិតភាពនេះ គឺផ្ដល់ពីឪពុកទៅកូន ។ នៅជំនាន់នោះ ប្រសិនបើឪពុកពុំបានកាន់បព្វជិតភាពទេនោះ កូនប្រុសក៏នឹងមិនមានឱកាសកាន់បព្វជិតភាពដែរ ។

សូមសរសេរគោលការណ៍ដូចតទៅនេះដាក់នៅក្នុងព្រះគម្ពីររបស់អ្នក ៖ **ប៊ីស្សពត្រូវតែបានអនុមតិដោយគណៈប្រធានទីមួយ និង ត្រូវបានតែងតាំងដោយអ្នកមានសិទ្ធអំណាចត្រឹមត្រូវ ។**

នៅជំនាន់ដំបូងនៃសាសនាចក្រ សមាជិកក្នុងគណៈប្រធានទីមួយ តែងតាំង ហើយញែកចេញចំពោះប៊ីស្សពទាំងឡាយ ។ នៅក្នុងសាសនាចក្រនាពេលបច្ចុប្បន្ន របៀបនេះនៅតែអនុវត្តចំពោះប៊ីស្សពជាអធិបតី ។ ទោះជាយ៉ាងណាក៏ដោយ ការហៅ ការតែងតាំង និងការញែកចេញនៃពួកប៊ីស្សព គឺត្រូវបានដឹកនាំដោយប្រធានស្ដេក នៅក្រោមការដឹកនាំរបស់ គណៈប្រធានទីមួយ ។ ប្រធានស្ដេកម្នាក់ ដោយមានការគាំទ្រមកពីទីប្រឹក្សារបស់លោក នៅក្នុងគណៈប្រធានស្ដេក ស្វែងរកវិវរណៈ ដើម្បីស្គាល់នៅពេលណាត្រូវហៅប៊ីស្សពថ្មី ឬត្រូវហៅនរណា ។ លោកផ្ញើអនុសាសន៍ទៅកាន់គណៈប្រធានទីមួយ ដើម្បីធ្វើការអនុមតិ ។ នៅពេលគណៈប្រធានទីមួយអនុមតិការហៅនេះ នោះពួកលោកអនុញ្ញាតឲ្យប្រធានស្ដេក តែងតាំង ហើយញែកចេញចំពោះប៊ីស្សពថ្មី ។

៣. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ ហេតុអ្វីបានជាវាមានសារៈសំខាន់ចំពោះអ្នក ដែលត្រូវដឹងថា គណៈប្រធានទីមួយ អនុមតិចំពោះការហៅរបស់ប៊ីស្សព ?

ពីមុនព្យាការី យ៉ូសែប ស៊្មីធ បានទទួលវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨ អែតវឺត ប៉ាទ្រិច គឺជាប៊ីស្សពតែម្នាក់គត់នៅក្នុងសាសនាចក្រ ។ នៅពេលប៊ីស្សពឯទៀតត្រូវបានហៅ នោះប៊ីស្សព ប៉ាទ្រិច បានបម្រើជាប៊ីស្សពជាអធិបតី ។ សព្វថ្ងៃនេះ ប៊ីស្សពជាអធិបតី គឺជាអ្នកមានសិទ្ធិអំណាចទូទៅ ហើយទទួលខុសត្រូវលើកិច្ចការអាណាចក្ររបស់សាសនាចក្រទាំងមូល ( សូមមើល គ. និង ស. ១០៧:៦៨ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:២៥–៣៥

*ព្រះអម្ចាស់បញ្ជាឲ្យឪពុកម្ដាយ បង្រៀនកូនចៅរបស់ខ្លួន*

តើអ្នកធ្លាប់គិតអំពីលទ្ធភាពនៃការដែលបានរៀបការហើយ និង ការដែលមានកូនចៅនៅប៉ុន្មានឆ្នាំខាងមុខទៀតដែរឬទេ ?

សូមធ្វើបញ្ជីនៃអ្វីដែល អ្នកនឹងចង់បង្រៀនកូនចៅរបស់អ្នក ៖



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:២៥–២៧ រួចគូសចំណាំគោលលទ្ធិ ដែលព្រះអម្ចាស់បានបញ្ជាឲ្យឪពុកម្ដាយ បង្រៀនដល់កូនចៅរបស់ខ្លួន ។ ប្រសិនបើអ្វីទាំងនេះមិនមាននៅក្នុងបញ្ជីរបស់អ្នកទេនោះ សូមសរសេរបញ្ចូលបន្ថែម ។

៤. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីថាតើអ្នកគិតថា ហេតុអ្វីបានជាឪពុកម្ដាយត្រូវបានបញ្ជាឲ្យបង្រៀនកូនចៅខ្លួន ដើម្បីឲ្យពួកគេយល់អំពីគោលលទ្ធិនៃការប្រែចិត្ត សេចក្ដីជំនឿលើព្រះគ្រីស្ទ ពិធីបុណ្យជ្រមុជទឹក និង អំណោយទានព្រះវិញ្ញាណបរិសុទ្ធ ។ តើឪពុកម្ដាយរបស់អ្នកបានជួយអ្នកឲ្យរៀនអំពីដំណឹងល្អយ៉ាងដូចម្ដេច ? សូមគិតអំពីការសរសេរលិខិតថ្លែងអំណរគុណមួយច្បាប់ ដើម្បីជូនចំពោះពួកលោក ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:២៨–៣១ ព្រះអម្ចាស់បានប្រទានឱវាទបន្ថែមទៅដល់ឪពុកម្ដាយទាំងឡាយ ក៏ដូចជាទៅដល់ពួកបរិសុទ្ធនៅទីក្រុង ស៊ីយ៉ូន ដែរ ។

៥. ដើម្បីជួយអ្នកឲ្យត្រៀមខ្លួនធ្វើជាឪពុកម្ដាយ សូមធ្វើលំហាត់ខាងក្រោមពីរ ឬ ច្រើនជាងនេះ ។ សូមឆ្លើយសំណួរទាំងឡាយ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

ក. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:២៨ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បញ្ជាឲ្យឪពុកម្ដាយបង្រៀនដល់កូនចៅរបស់ខ្លួន ។

- ហេតុអ្វីអ្នកគិតថា វានឹងសំខាន់ចំពោះអ្នកដើម្បីបង្រៀនកូនចៅឲ្យអធិស្ឋាន ?
- តើអ្នកត្រូវបានបង្រៀនឲ្យចេះអធិស្ឋានតាមរបៀបណា ?
- តើការអធិស្ឋានបានប្រទានពរដល់អ្នក និង ក្រុមគ្រួសារអ្នកតាមរបៀបណា ?

- តាមគំនិតរបស់អ្នក តើការអធិស្ឋានជួយយើងឲ្យ « ដើរដោយទៀងត្រង់នៅចំពោះព្រះអម្ចាស់ » តាមរបៀបណា ?

ខ. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:២៩ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បញ្ជាឲ្យបណ្ដាជននៃទីក្រុង ស៊ីយ៉ូន ( សមាជិកសាសនាចក្រ ) ធ្វើ ។

- តើអ្នកបានរៀនពីឪពុកម្ដាយរបស់អ្នក ឬ មនុស្សដទៃទៀត អំពីការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធយ៉ាងដូចម្ដេច ?
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីជួយក្រុមគ្រួសាររបស់អ្នក ឲ្យរក្សាថ្ងៃឈប់សម្រាកជាបរិសុទ្ធ ?

គ. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:៣០ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បញ្ជាដល់ឪពុកម្ដាយ និង កូនចៅធ្វើ ។ ( សូមកត់ចំណាំថា ពាក្យ *មនុស្សខ្ជិលច្រអូស* សំដៅទៅលើមនុស្សដែលខ្ជិល ឬ គ្មានឆន្ទៈនឹងចូលរួមក្នុងសកម្មភាពដែលមានប្រយោជន៍ ) ។

- តើអ្នកធ្លាប់បានឃើញពរជ័យ ដែលកើតចេញពីការខិតខំធ្វើការនៅពេលណាខ្លះ ?

> សូមអានព័ត៌មានដូចតទៅនេះអំពីភាពខ្ជិលច្រអូស ៖ « ព្រះអម្ចាស់បានបញ្ជា កុំឲ្យយើងខ្ជិលច្រអូស ។ ភាពខ្ជិលច្រអូសអាចនាំទៅរកអាកប្បកិរិយាមិនសមរម្យ ទំនាក់ទំនងមិនល្អ និង អំពើបាប ។ ទម្រង់មួយនៃភាពខ្ជិលច្រអូសគឺការចំណាយពេលហួសហេតុទៅលើសកម្មភាពទាំងឡាយ ដែលរារាំងអ្នកពីកិច្ចការដែលមានប្រយោជន៍ ដូចជាការប្រើអ៊ីនធឺណែត លេងវីដេអូហ្គេម និង មើលទូរទស្សន៍ជាដើម » (*ដើម្បីកម្លាំងនៃយុវជន*កូនសៀវភៅ [ឆ្នាំ ២០១១ ] ទំព័រ ៤០) ។

- តើភាពខ្ជិលច្រអូលនាំទៅរកសេចក្ដីទុច្ចរិតយ៉ាងដូចម្ដេច?
- តើកត្តាណាខ្លះ ដែលអាចជួយបុគ្គលម្នាក់ឲ្យយកឈ្នះលើការទោរទន់ទៅរកភាពខ្ជិលច្រអូសបាន ?

ឃ. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨:៣១–៣២ ដោយស្វែងរកការណ៍ ដែលព្រះអម្ចាស់បញ្ជាឲ្យឪពុកម្ដាយ និង ពួកកូនចៅធ្វើ ។

- តើអ្នកគិតថាការលោភលន់អាចនឹងជះឥទ្ធិពលដល់គ្រួសារមួយយ៉ាងដូចម្ដេច ?
- តើអ្នកអាចធ្វើអ្វីខ្លះក្នុងជីវិត ដើម្បីយកឈ្នះលើភាពអាត្មានិយម និង ភាពលោភលន់បាន ?

៦. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីបានជាវាមានសារៈសំខាន់ ដែលត្រូវត្រៀមខ្លួននាពេលឥឡូវនេះ ដើម្បីធ្វើជាឪពុកម្ដាយដ៏ល្អ ?

ខ. តើគោលដៅអ្វីដែលអ្នកនឹងដាក់ ដែលនឹងជួយអ្នកឲ្យត្រៀមខ្លួនធ្វើជាឪពុកម្ដាយដ៏ល្អ ?

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៨ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩–៧១

## បុព្វកថា

នៅចុងខែតុលា ឬដើមខែវិច្ឆិកា ឆ្នាំ ១៨៣១ អូលីវើរ ខៅឌើរី បានទទួលការចាត់តាំងមួយដើម្បីនាំយកឯកសារសរសេរដោយដៃសម្រាប់ព្រះគម្ពីរនៃព្រះបញ្ញត្តិមកពីរដ្ឋ អូហៃអូ ទៅកាន់ រដ្ឋមិសសួរី ។ នៅរដ្ឋ មិសសួរី វិលលាម ដ័បបុលយូ ហ្វែលប្ស បានបោះពុម្ពព្រះគម្ពីរនោះនៅរោងពុម្ពរបស់គាត់ ។ នៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានចាត់តាំង យ៉ូហាន វិតមើរ ឲ្យធ្វើជាដៃគូធ្វើដំណើរជាមួយ អូលីវើរ ហើយបានបញ្ជាគាត់ឲ្យបន្តតួនាទីជាអ្នកសរសេរប្រវត្តិសាសនាចក្រ ( សូមមើល គ. និង ស. ៦៩ ) ។ លុះស្អែកឡើង ព្រះអម្ចាស់បានចាត់តាំងបុរសប្រាំមួយនាក់ ឲ្យបម្រើជាអ្នកកាន់កាប់លើវិវរណៈទាំងឡាយ ( សូមមើល គ. និង ស. ៧០ ) ។ ក្នុងខែ ធ្នូ ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានបញ្ជាព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ឲ្យបម្រើបេសកកម្ម ដើម្បីលុបបំបាត់អារម្មណ៍មិនស្និទ្ធស្នាលដែលមានចំពោះសាសនាចក្រ និង ដើម្បីរៀបចំផ្លូវសម្រាប់វិវរណៈទាំងឡាយ និង ព្រះបញ្ញត្តិ ដែលត្រូវបានបោះពុម្ព ( សូមមើល គ. និង ស. ៧១ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩

*ព្រះអម្ចាស់បើកសម្ដែងអំពីសារៈសំខាន់នៃការរក្សាប្រវត្តិ*



តើធ្លាប់មាននរណាម្នាក់បានទុកចិត្តអ្នក ឲ្យថែរក្សាវត្ថុណាមួយដ៏មានតម្លៃដែរឬទេ ? តើវត្ថុនោះគឺជាអ្វី ? តើការទុកចិត្តបែបនោះ មានឥទ្ធិពលលើរបៀបដែលអ្នកថែរក្សាវត្ថុដ៏មានតម្លៃនោះយ៉ាងដូចម្ដេច ?

សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩ រួចគូសសម្គាល់អ្វីដែល អូលីវើរ ខៅឌើរី ត្រូវបានផ្ទុកផ្ដាក់ឲ្យធ្វើ ។

ប្រសិនបើវត្ថុមានតម្លៃទាំងនេះត្រូវបានប្រគល់ទៅឲ្យអ្នក តើអ្នកនឹងថែរក្សាវាយ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩:១–២ រួចស្វែងរកឱវាទ ដែលព្រះអម្ចាស់បានប្រទានចំពោះវត្ថុដ៏មានតម្លៃទាំងនេះ ។

តើអ្នកគិតថា ហេតុអ្វីបានជាវាជារឿងឆ្លាតវៃដើម្បីមានមនុស្សច្រើនជាងម្នាក់ ដើម្បីថែរក្សាវត្ថុដ៏មានតម្លៃទាំងនេះ ?

ព្រះអម្ចាស់បានទុកព្រះទ័យលើ យ៉ូហាន វិតមើរ ឲ្យមានការទទួលខុសត្រូវមួយផ្សេងទៀត បន្ថែមពីលើការជួយដល់ អូលីវើរ ខៅឌើរី ក្នុងការជញ្ជូនវិវរណៈទាំងឡាយ និង ប្រាក់កាសទៅកាន់រដ្ឋ មិសសួរី ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩:៣–៨ ដោយស្វែងរកតួនាទីមួយទៀត ដែលព្រះអម្ចាស់បានចាត់តាំងដល់ យ៉ូហាន វិតមើរ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

សូមរំឭកអំពីអ្វីដែល គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៧ បង្រៀនអំពីការចាត់តាំងរបស់ យ៉ូហាន វិតមើរ ក្នុងនាមជាអ្នកសរសេរប្រវត្តិសាសនាចក្រ និង អ្នកកត់ត្រា ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩:៨ ហេតុអ្វីបានជាវាមានសារៈសំខាន់ចំពោះ យ៉ូហាន វិតមើរ ដែលត្រូវរក្សាប្រវត្តិនៃសាសនាចក្រ ?

ខ. ហេតុអ្វីបានជាការណ៍នេះអាចជាហេតុផលមួយដ៏សមស្របចំពោះអ្នក ដែលត្រូវរក្សាប្រវត្តិផ្ទាល់ខ្លួនមួយ ?

សូមពិចារណាអំពីការសរសេរគោលការណ៍ដូចតទៅនេះ នៅលើគែមព្រះគម្ពីររបស់អ្នក ៖ **ព្រះអម្ចាស់រំពឹងឲ្យមានប្រវត្តិដែលត្រូវបានរក្សា សម្រាប់ជាការល្អដល់សាសនាចក្រ និង តំណមនុស្សមានវ័យធំឡើង ។**

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តាមគំនិតរបស់អ្នក តើការរក្សាប្រវត្តិសាសនាចក្រ និង ប្រវត្តិផ្ទាល់ខ្លួន ផ្ដល់អត្ថប្រយោជន៍យ៉ាងដូចម្ដេចដល់សាសនាចក្រ ?

ខ. តើការណ៍ទាំងនេះអាច ផ្ដល់អត្ថប្រយោជន៍ដល់តំណមនុស្សមានវ័យធំឡើងយ៉ាងដូចម្ដេច ?

៣. សូមធ្វើលំហាត់មួយ ឬ ទាំងពីរខាងក្រោមនេះ ហើយបន្ទាប់មក សូមសរសេរសេចក្ដីសង្ខេបអំពីបទពិសោធន៍របស់អ្នក ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមគិតអំពីដំណើររឿងមួយ ទោះជាប្រវត្តិសាសនាចក្រ ឬ ប្រវត្តិគ្រួសារក៏ដោយ ដែលបានជួយដល់អ្នកតាមរបៀបណាមួយ ។ សូមចែកចាយប្រវត្តិនេះ ជាមួយនឹងសមាជិកគ្រួសារ ឬមិត្តភក្ដិ ។

ខ. សូមសុំឲ្យសមាជិកគ្រួសារម្នាក់ តំណាលប្រាប់អ្នកអំពីប្រវត្តិគ្រួសារ ដែលបានផ្ដល់អត្ថប្រយោជន៍ដល់គាត់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧០:១–៤

*ព្រះអង្គសង្គ្រោះចាត់តាំងអ្នកត្រួតត្រា ឲ្យថែរក្សាវិវរណៈទាំងឡាយរបស់ទ្រង់*

ព្យាការី យ៉ូសែប ស្ម៊ីធ ក៏បានកត់ត្រាប្រវត្តិផ្ទាល់ខ្លួនផងដែរ ។ សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧០ រួចគូសចំណាំអំពីអ្វីដែល ប្រវត្តិ យ៉ូសែប ស្ម៊ីធ ប្រាប់អំពីគោលលទ្ធិ និង សេចក្ដីសញ្ញា ។

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើតាមរបៀបមួយចំនួនណាខ្លះ ដែល គោលលទ្ធិ និង សេចក្ដីសញ្ញា ផ្ដល់ជាអត្ថប្រយោជន៍ដល់ពិភពលោក ?

ខ. តើគោលលទ្ធិ និង សេចក្ដីសញ្ញា បានផ្ដល់អត្ថប្រយោជន៍ដល់អ្នកយ៉ាងដូចម្ដេច ?



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧០:១ រួចស្វែងរកឈ្មោះទាំងប្រាំមួយ ដែលបានលើកឡើង ។ បន្ទាប់មក សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧០:២–៤ ដោយស្វែងរកការទទួលខុសត្រូវ ដែលព្រះអម្ចាស់បានប្រទានឲ្យដល់បុរសទាំងប្រាំមួយនាក់នេះ ។

តើអ្នកគិតថាឃ្លា « ដំណើររឿងអំពីការកាន់កាប់ត្រួតត្រានេះ យើងនឹងតម្រូវពីពួកគេ » (គ. និង ស. ៧០:៤ ) មានន័យដូចម្ដេច ? ខណៈដែលការទទួលខុសត្រូវ ដែលព្រះអម្ចាស់ប្រទានឲ្យយើង អាចនឹងជាប្រភេទនៃការកាន់កាប់ត្រួតត្រាដូចគ្នាទៅនឹងបុរសទាំងនេះដែរនោះ តើគោលការណ៍នេះណែនាំយ៉ាងដូចម្ដេច អំពីអ្វីដែលព្រះអម្ចាស់នឹងតម្រូវពីយើងនៅថ្ងៃជំនុំជម្រះ ?

ចេញពីអ្វីដែលអ្នកបានរៀននៅក្នុងខគម្ពីរទាំងនេះ នោះសូមបំពេញនៅក្នុងចន្លោះនៃគោលការណ៍ដូចតទៅនេះ ៖ **ព្រះអម្ចាស់នឹង ចំពោះតួនាទី ដែលទ្រង់បានប្រទានដល់យើង ។**

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើគោលការណ៍នេះ អាចមានឥទ្ធិពលលើរបៀបដែលយើងឆ្លើយតបទៅនឹងការហៅ និង ការចាត់តាំងក្នុងសាសនាចក្រយ៉ាងដូចម្ដេច ?

ខ. តើការទទួលខុសត្រូវរបស់អ្នកមួយចំនួនណាខ្លះ ដែលព្រះអម្ចាស់នឹងចាត់ឲ្យអ្នកមាន ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧០:៥–១៨

*ព្រះអម្ចាស់ពន្យល់អំពីរបៀបបំពេញតម្រូវការខាងសាច់ឈាម នៃអស់អ្នកដែលបម្រើសាសនាចក្រពេញម៉ោង*

គោលលទ្ធិ និង សេចក្ដីសញ្ញា ៧០:៥–១៨ បង្រៀនថា បុរសដែលត្រូវបានប្រគល់ការកាន់កាប់ត្រួតត្រាលើវិវរណៈ និង ព្រះបញ្ញត្តិទាំងឡាយ ត្រូវធ្វើឲ្យការបោះពុម្ព និងការចែកចាយការបោះពុម្ពរបស់សាសនាចក្រ ទៅជាការងាររបស់ខ្លួន ។

នាពេលសព្វថ្ងៃនេះ ពួកអ្នកមានសិទ្ធិអំណាចទូទៅនៃសាសនាចក្រ លះបង់អាជីពចិញ្ចឹមជីវិតទៅបម្រើពេញម៉ោង ដូច្នេះ ពួកលោកទទួលបានប្រាក់ឧបត្ថម្ភជីវិតប្រចាំថ្ងៃសមស្រប—គ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ខ្លួនឯង និង ក្រុមគ្រួសារ ។

ហេតុអ្វីបានជានោះជារឿងត្រឹមត្រូវសម្រាប់ថ្នាក់ដឹកនាំសាសនាចក្រ ដែលត្រូវបានហៅឲ្យបម្រើពេញម៉ោងនោះ ទទួលបានការទូទាត់ចំពោះសេចក្ដីត្រូវការទាំងឡាយរបស់ខ្លួន ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧១

*ព្រះអម្ចាស់បង្រៀនព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន អំពីរបៀបឆ្លើយតបទៅនឹងអ្នកដែលរិះគន់ដល់សាសនាចក្រ*

តើអ្នកធ្លាប់បានឮការរិះគន់អំពីសាសនាចក្រដែរឬទេ ? តើមានមធ្យោបាយសមរម្យណាខ្លះ ដើម្បីឆ្លើយតបទៅនឹងការរិះគន់អំពីសាសនាចក្រ ?

ដើម្បីជួយអ្នកឲ្យយល់អំពីប្រវត្តិសង្ខេបនៃវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧១ សូមអានកថាខណ្ឌខាងក្រោមនេះ ។ នៅពេលអ្នកអាន សូមស្វែងរកថាតើសាសនាចក្រ និង ថ្នាក់ដឹកនាំរបស់សាសនាចក្រ ត្រូវបានរិះគន់នៅគ្រាដែលវិវរណៈនេះត្រូវបានប្រទានឲ្យយ៉ាងដូចម្ដេចខ្លះ ។

អែសរ៉ា ប៊ូត គឺជាអតីតអាចារ្យសាសនាមេតូឌីស្ទម្នាក់ ដែលបានចូលសាសនាចក្របន្ទាប់ពីបានឃើញការព្យាបាលជំងឺ ។ គាត់បានធ្វើដំណើរក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាទៅកាន់រដ្ឋ មិសសួរី ប៉ុន្តែ គាត់បានខកចិត្ត កាលគាត់ពុំអាចបង្កើតអព្ភូតហេតុដើម្បីប្រែចិត្តមនុស្សដទៃ ឲ្យជឿលើសេចក្ដីពិតបាន ។ មិនតែប៉ុណ្ណោះ បងប្រុស ប៊ូត ពុំបានជឿថា ការដឹកនាំរបស់ យ៉ូសែប ស្ម៊ីធ គឺជាការដឹកនាំដ៏ត្រឹមត្រូវក្នុងនាមជាព្យាការី ឬ ជាអ្នកដឹកនាំដ៏បំផុសគំនិតឡើយ ។ គាត់បែរជារិះគន់យ៉ាងខ្លាំងអំពីព្យាការី យ៉ូសែប ស្ម៊ីធ ថែមទាំងបានចាកចេញពីសាសនាចក្រ ហើយបានសរសេរលិខិតរិះគន់ចំនួនប្រាំបួនច្បាប់ អំពីសាសនាចក្រ និង ថ្នាក់ដឹកនាំសាសនាចក្រ ។ លិខិតទាំងនេះត្រូវបានបោះពុម្ពនៅក្នុងទំព័រកាសែត *Ohio Star* ដែលបានបណ្ដាលមនុស្សមួយចំនួន បង្កើនអារម្មណ៍មិនស្និទ្ធស្នាលទាស់នឹងសាសនាចក្រ និង ថ្នាក់ដឹកនាំសាសនាចក្រ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានកត់ត្រាថា ការសរសេររបស់ អែសរ៉ា ប៊ូត គឺជា « ប្រភេទសំបុត្រដែល ដោយការលាបពណ៌នៃភាពមិនពិត និង ផែនការដ៏ឥតប្រយោជន៍ដើម្បីផ្ដួលរំលំកិច្ចការរបស់ព្រះអម្ចាស់នោះ បានបង្ហាញអំពីគុណវិបត្តិ ភាពទុច្ចរិត និង ភាពខ្វះឧត្តមគតិ [ របស់ អែសរ៉ា ប៊ូត ] បានបន្សល់ទុកឲ្យគាត់នូវស្នាដៃ ដែលកើតចេញពីទង្វើគួរឲ្យអាម៉ាស់ ដើម្បីធ្វើឲ្យពិភពលោកមានការងឿងឆ្ងល់ » ( នៅក្នុង *History of the Church* ១:២១៦–១៧ ) ។

សាយមិន រ៉ាយឌើរ គឺជាសមាជិកសាសនាចក្រម្នាក់ទៀតដែលមិនស្មោះត្រង់ បានឲ្យច្បាប់ចម្លងនៃវិវរណៈមួយចំនួនទៅក្រុមហ៊ុនសារព័ត៌មានមួយទៀត ក្នុងគោលបំណងបំបាក់ទឹកចិត្តប្រជាជនពីការចូលសាសនាចក្រ ។ ការព្រួយបារម្ភដែលបណ្ដាលមកពី អែសរ៉ា ប៊ូត និង សាយមិន រ៉ាយឌើរ បានរីកធំឡើងជាបញ្ហាមួយដ៏ធ្ងន់ធ្ងរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧១:១–៤ ដោយស្វែងរកការណ៍ ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ឲ្យធ្វើ ដើម្បីរម្ងាប់អារម្មណ៍មិនស្និទ្ធស្នាល ដែលជាលទ្ធផលចេញពីអត្ថបទនៅលើទំព័រកាសែតទាំងនោះ ។

សូមកត់ចំណាំនៅក្នុង ខទី ១ អំពីរបៀបដែល យ៉ូសែប និង ស៊ីឌនី ត្រូវប្រកាសដំណឹងល្អ ។ តើគោលការណ៍អ្វី ដែលយើងអាចរៀនចេញពីសេចក្ដីណែនាំនេះ អំពីរបៀបឆ្លើយតបទៅនឹងការរិះគន់អំពីសាសនាចក្រ ?

៦. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកអាចធ្វើអ្វីនាពេលឥឡូវនេះ ដើម្បីត្រៀមខ្លួនឆ្លើយតបទៅនឹងការរិះគន់ទាស់នឹងសាសនាចក្រ ឬ ថ្នាក់ដឹកនាំសាសនាចក្រ ?

អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចតទៅនេះ នៅលើគែមព្រះគម្ពីររបស់អ្នកក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧១:១ ៖ **នៅពេលមនុស្សរិះគន់សាសនាចក្រ យើងអាចឆ្លើយតបដោយការចែកចាយសេចក្ដីពិតចេញពីបទគម្ពីរ និង ការធ្វើតាមការណែនាំពីព្រះវិញ្ញាណ ។**



អែលឌើរ រ៉ូប៊ឺត ឌី ហែល ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់អំពីរបៀបដែលព្រះវិញ្ញាណ អាចជួយយើងឲ្យឆ្លើយតបទៅនឹងការរិះគន់ប្រឆាំងទាស់នឹងសាសនាចក្រ ៖ « នៅពេលយើងឆ្លើយទៅនឹងមនុស្សដទៃ កាលៈទេសៈនីមួយៗនឹងមានលក្ខណៈខុសប្លែកពីគ្នា ។ សំណាងល្អ ព្រះអម្ចាស់ជ្រាបពីដួងចិត្តនៃអ្នកចោទប្រកាន់យើង និង របៀបដែលយើងអាចឆ្លើយតបទៅកាន់ពួកគេវិញដោយមានប្រសិទ្ធភាពបំផុត ។. *ក្នុងនាមជាសិស្សដ៏ពិតស្វែងរកការណែនាំមកពីព្រះវិញ្ញាណ នោះពួកគេទទួលបានការបំផុសគំនិតដែលទាក់ទងនឹងរឿងប្រឈមនីមួយៗ* ។ ហើយនៅគ្រប់ការប្រឈមនីមួយៗ

### *ការអនុវត្តការពន្យល់អំពីសេចក្ដីពិតនៃដំណឹងល្អ*

ពេញមួយជីវិតអ្នក អ្នកនឹងមានឱកាសពន្យល់អំពីជំនឿ និង ការបង្រៀនអំពីដំណឹងល្អ—ជាអ្នកផ្សព្វផ្សាយសាសនាការហៅបម្រើក្នុងសាសនាចក្រ ឬ បង្រៀនទៅដល់ក្រុមគ្រួសារ មិត្តភក្ដិ និង មនុស្សទើបតែស្គាល់គ្នារបស់អ្នក ។ នៅពេលអ្នកអនុវត្តការពន្យល់អំពីដំណឹងល្អដោយការសរសេរ នោះវាអាចផ្ដល់អត្ថប្រយោជន៍ ដែលអ្នកត្រូវស្រមៃថា អ្នកកំពុងសរសេរទៅកាន់បុគ្គលជាក់លាក់ណាម្នាក់ ។ ការសរសេរដោយមានបុគ្គលណាម្នាក់នៅក្នុងគំនិតអាចជួយអ្នកឲ្យផ្ដោតអារម្មណ៍ទៅលើការអនុវត្តន៍សារលិខិតនៃដំណឹងល្អចំពោះសេចក្ដីត្រូវការនៃបុគ្គលនោះ ។ តើអ្នកបានរៀនអ្វីខ្លះចេញពីគោលលទ្ធិនៃការប្រែចិត្ត ដែលអ្នកអាចបង្រៀនទៅកាន់មិត្តភក្ដិ ឬ សមាជិកក្រុមគ្រួសារ ?

*សិស្សដ៏ពិតឆ្លើយតបតាមរបៀបដែលអញ្ជើញព្រះវិញ្ញាណនៃព្រះអម្ចាស់* » (Christian Courage: The Price of Discipleship » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ២០០៨ ទំព័រ ៧៣ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧១:៥–១១ ដោយស្វែងរកឱវាទ និង ការលួងលោមដែលព្រះអម្ចាស់បានប្រទានដល់ព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន នៅពេលពួកលោកឆ្លើយតបទៅនឹងការរិះគន់ទាស់នឹងសាសនាចក្រ ។ សូមស្វែងរកផងដែរ នូវការសន្យាដែលព្រះអម្ចាស់បានប្រទានដល់ពួកលោកនៅក្នុង ខទី ៧ និង ១០ ។

សូមកត់ចំណាំថា វិវរណៈនេះណែនាំទៅដល់អ្នកដឹកនាំសាសនាចក្រចំនួនពីរនាក់—គឺព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន—ដែលត្រូវទៅជួបនឹងអ្នកដែលវាយប្រហារសាសនាចក្រ ដោយបើកមុខ និង ដោយសម្ងាត់ ហើយត្រូវព្យាយាមបំភាន់អ្នកទាំងនោះនៅក្នុងសេចក្ដីកំភូត ដែលពួកគេកំពុងប្រកាស ។ ជាទូទៅ នេះគឺជាការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំសាសនាចក្រ លុះត្រាតែថ្នាក់ដឹកនាំបព្វជិតភាពបង្គាប់ ឬ ចាត់តាំងមនុស្សឯទៀតឲ្យធ្វើ ។ ទោះជាយ៉ាងណាក៏ដោយ យុវវ័យនៃសាសនាចក្រគួរតែត្រៀមខ្លួនជាស្រេច ដើម្បីឆ្លើយតបទៅនឹងសេចក្ដីកុហកអំពីសាសនាចក្រ នៅតាមរបៀបដែលត្រូវបានពិពណ៌នាដោយអែលឌើរ ហែល ខាងលើនេះ ។



អែលឌើរ ហែល ក៏បានផ្ដល់ដំបូន្មាន អំពីឥរិយាបថរបស់យើងចំពោះមនុស្សដែលរិះគន់សាសនាចក្រ ឬ ថ្នាក់ដឹកនាំសាសនាចក្រផងដែរ ៖ « *ក្នុងនាមជាសិស្សដ៏ពិត សេចក្ដីបារម្ភចម្បងរបស់យើងត្រូវតែជាសុខុមាលភាពរបស់មនុស្សដទៃ មិនមែនជាការយកឈ្នះខ្លួននោះទេ* ។ សំណួរ និង ការរិះគន់ផ្ដល់ដល់យើងនូវឱកាសមួយ ដើម្បីឈោងទៅជួយមនុស្សដទៃ ហើយបង្ហាញថា ពួកគេសំខាន់ចំពោះព្រះវរបិតាសួគ៌របស់យើង និង ចំពោះយើងផងដែរ ។ គោលបំណងរបស់យើងគួរតែជួយពួកគេឲ្យយល់អំពីសេចក្ដីពិត មិនមែនការពារតែអាត្មាខ្លួនឯង ឬ ទទួលបានពិន្ទុនៅក្នុងការជជែកវែកញែកអំពីទ្រឹស្ដីនោះទេ ។ ទីបន្ទាល់ដ៏ស្មោះត្រង់របស់យើង គឺជាចម្លើយដ៏មានឥទ្ធិពលបំផុតដែលយើងអាចឲ្យទៅដល់អ្នកដែលចោទប្រកាន់យើង ។ ហើយទីបន្ទាល់ដូចនោះ អាចត្រូវថ្លែងបានតែក្នុងសេចក្ដីស្រឡាញ់ និង ភាពស្លូតបូតប៉ុណ្ណោះ » ( « Christian Courage » ទំព័រ ៧៣–៧៤ ) ។

ស៊ីឌនី រិកដុន បានគោរពប្រតិបត្តិតាមឱវាទរបស់ព្រះអម្ចាស់ ហើយបានអញ្ជើញ អែសរ៉ា ប៊ូថ ឲ្យមកចូលរួមជាមួយគាត់នៅក្រុង រ៉ាវែណា រដ្ឋ អូហៃអូ ដែលពួកគាត់បានពិភាក្សាគ្នាដោយបើកមុខ អំពីលិខិតដែល អែសរ៉ា បានផ្ញើទៅកាន់ក្រុមហ៊ុនសារព័ត៌មាន ។ ស៊ីឌនី ក៏បានអញ្ជើញ សាយមិន រ៉ាយឌើរ មកពិភាក្សាតទល់ដោយបើកមុខ ស្ដីពីព្រះគម្ពីរមរមនដែរ ។ បុរសទាំងពីរនាក់ ពុំទទួលយកការអញ្ជើញនោះទេ ។ ស៊ីឌនី នៅតែបន្តថ្លែងទីបន្ទាល់អំពីសេចក្ដីពិតនៅក្រុង រ៉ាវែណា និង នៅទីតាំងដទៃទៀត ។

៧. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧១:៨–៩ អាចលួងលោមដល់អ្នកឆ្លើយតបទៅនឹងការរិះគន់ទាស់នឹងសាសនាចក្រយ៉ាងដូចម្ដេច ?

ខ. យោងតាម ខទី ១០ ហេតុអ្វីបានជាយើងមិនគួរបារម្ភហួសពេក នៅពេលមនុស្សរិះគន់អំពីសាសនាចក្រ ?

សូមពិចារណាអំពីអ្វីដែលអ្នកនឹងធ្វើ ដើម្បីត្រៀមខ្លួនឲ្យបានកាន់តែប្រសើរ ក្នុងការឆ្លើយតបទៅនឹងការរិះគន់ទាស់នឹងសាសនាចក្រ ។

៨. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៩–៧១ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ* ៖

មេរៀនទី ១៦ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២–៧៤

## សេចក្ដីផ្ដើម

នៅថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ១៨៣១ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២ ជាកណ្ឌដែលព្រះអម្ចាស់បានហៅប៊ីស្សពថ្មីនៅរដ្ឋ អូហៃអូ ហើយបានបើកសម្ដែងករណីយកិច្ចមួយចំនួនរបស់លោក ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៣ ត្រូវបានប្រទានឲ្យក្នុងខែមករា ឆ្នាំ ១៨៣២ ព្រះអម្ចាស់បានណែនាំ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ឲ្យចាប់ផ្ដើមកិច្ចការបកប្រែលើព្រះគម្ពីរប៊ីបឡើងវិញ ។ ជាលទ្ធផលនៃកិច្ចការលើព្រះគម្ពីរមរមនរបស់ពួកគាត់នោះ ព្រះអម្ចាស់បានប្រទានវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៤ ដែលជាការបកស្រាយនៃ កូរិនថូស ទី១ ៧:១៤ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២:១–៨

*ព្រះអម្ចាស់ហៅ នូវល ខេ វិតនី ធ្វើជាប៊ីស្សពនៅរដ្ឋ អូហៃអូ*

តើអ្នកធ្លាប់បានទទួលការហៅ ឬ ត្រូវបានហៅឲ្យធ្វើអ្វីមួយលំបាក នៅក្នុងសាសនាចក្រ ហើយមានអារម្មណ៍ថា លើសកម្រិត ឬ មិនមានលទ្ធភាពធ្វើដែរឬទេ ? សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២:១–២ ដោយស្វែងរកការហៅ ដែលត្រូវតែមាននៅរដ្ឋ អូហៃអូ ( « នៅក្នុងផ្នែកនេះនៃចម្ការទំពាំងបាយជូររបស់ព្រះអម្ចាស់ » ) ។



នារដូវក្ដៅឆ្នាំ ១៨៣១ ប៊ីស្សព អែតវឺត ប៉ាទ្រិច ដែលជាប៊ីស្សពដំបូងត្រូវបានហៅនៅក្នុងសាសនាចក្រ បានផ្លាស់ទីលំនៅជិត ១៤៤៨ គីឡូម៉ែត្រ ទៅភាគខាងលិច ពីទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ទៅកាន់ទីក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ដើម្បីបម្រើជាប៊ីស្សពនៅទីក្រុង ស៊ីយ៉ូន ។ ជាលទ្ធផល ព្រះអម្ចាស់បានប្រកាសរដ្ឋ អូហៃអូ ត្រូវការប៊ីស្សពថ្មី ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២:៣–៦ រួចស្វែងរកឃ្លា ដែលពន្យល់អំពីមូលហេតុដែលពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ ដែលជាអ្នកកាន់កាប់ត្រួតត្រារស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ត្រូវការប៊ីស្សព ។ ( អ្នកត្រូវបានបង្រៀនឲ្យស្គាល់ក្រឹត្យវិន័យនៃការថ្វាយនៅក្នុង « មេរៀនទី ១០ ៖ ថ្ងៃទី ៣ » នៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៤២:៣០–៤២ នៅក្នុងសៀវភៅមេរៀននេះ ) ។

សូមពិចារណាអំពីរបៀបដែលប៊ីស្សព និង ប្រធានសាខារបស់អ្នក ជួយអ្នកឲ្យរ៉ាប់រងលើការទទួលខុសត្រូវ ក្នុងនាមជាសមាជិកសាសនាចក្រនាពេលបច្ចុប្បន្ននេះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២:៧–៨ រួចកត់ចំណាំអំពីបុគ្គល ដែលព្រះអម្ចាស់បានហៅឲ្យធ្វើជាប៊ីស្សពថ្មីនៅរដ្ឋ អូហៃអូ ។

នៅពេល នូវល ខេ វិតនី ត្រូវបានហៅឲ្យធ្វើជាប៊ីស្សពនៅរដ្ឋ អូហៃអូ នោះគាត់បានមានអារម្មណ៍ថាមិនសក្ដិសមដើម្បីបម្រើនៅក្នុងតំណែងនេះទេ ។ ព័ត៌មានខាងក្រោមនេះ បានមកពីចៅប្រុសរបស់គាត់គឺ អែលឌើរ អ៊ូសុន អែហ្វ វិតនី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ជួយយើងឲ្យយល់អំពីរបៀបដែល នូវល ខេ វិតនី បានមានអារម្មណ៍ និង អ្វីដែលគាត់បានស្វែងយល់អំពីថា តើការហៅរបស់គាត់នេះ គឺបានមកពីណា ៖



« គំនិតនៃការសន្មត់អំពីការទទួលខុសត្រូវដ៏មានសារៈសំខាន់នេះ ( តំណែងជាប៊ីស្សព ) ស្ទើរតែមានកម្រិតលើសពីអ្វីដែលគាត់អាចទទួលយកទៅទៀត ។ ទោះជាក្នុងអំណោយទានពីធម្មជាតិ ដែលបុរសមួយចំនួនមានគុណសម្បត្តិចំពោះតំណែងនេះយ៉ាងណាក្ដី ក៏គាត់នៅតែមិនទុកចិត្តលើសមត្ថភាពខ្លួនឯង ហើយ [ បានមានអារម្មណ៍ ] ថាមិនមានលទ្ធភាពទទួលយកការទុកព្រះទ័យដ៏ខ្ពង់ខ្ពស់ និង ដ៏បរិសុទ្ធនេះដែរ ។ គាត់បានថ្លែងប្រាប់ព្យាការី ដោយភាពអល់អែក ៖

« ‹ បងប្រុស យ៉ូសែប ខ្ញុំពុំអាចមើលឃើញខ្លួនឯងថាសមជាប៊ីស្សពនោះទេ ប៉ុន្តែ បើបងប្រុសមានប្រសាសន៍ថា នេះគឺជាព្រះឆន្ទៈរបស់ព្រះអម្ចាស់ហើយនោះ ខ្ញុំនឹងព្យាយាម › ។

« ព្យាការីបានបន្លឺតបទៅវិញថា ‹ បងប្រុស ពុំចាំបាច់គ្រាន់តែស្ដាប់តាមពាក្យសម្ដីរបស់ខ្ញុំប៉ុណ្ណោះទេ សូមទៅ ហើយទូលសួរដល់ព្រះវរបិតាដោយខ្លួនបងប្រុសផ្ទាល់ចុះ › ។

« នូវល. . . បានសម្រេចចិត្តធ្វើតាមអ្វីដែល [ ព្យាការី ] បានទូន្មាន ។ ការអធិស្ឋានដ៏រាបសា និង ស្មោះអស់ពីចិត្តរបស់គាត់ត្រូវបានឆ្លើយតប ។ នារាត្រីដ៏សែនស្ងាត់ និង ក្នុងបន្ទប់ដាច់តែឯង គាត់បានឮសំឡេងមួយចេញមកពីស្ថានសួគ៌ ៖ ‹ *ភាពរឹងមាំរបស់អ្នក ស្ថិតនៅលើយើង* › ។ ព្រះបន្ទូលទាំងនេះមានតែប៉ុន្មានម៉ាត់ប៉ុណ្ណោះ ហើយងាយយល់ ប៉ុន្តែ មានអត្ថន័យជ្រាលជ្រៅ ។ មន្ទិលរបស់គាត់បានរលាយសាបសូន្យទៅ ដូចជាទឹកសន្សើមត្រូវពន្លឺថ្ងៃដូច្នោះដែរ ។ គាត់បានទៅជួបព្យាការី ជម្រាបលោកថា គាត់មានចិត្តសោមនស្ស ហើយមានឆន្ទៈនឹងទទួលយកតំណែង ដែលគាត់ត្រូវបានហៅនោះ » ( នៅក្នុង B. H. Roberts, *A Comprehensive History of the Church* ១:២៧១ ) ។

១. សូមឆ្លើយតបទៅនឹងស្ថានភាពដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ សូមស្រមៃថា មិត្តភក្ដិ ឬ សមាជិកគ្រួសារម្នាក់ ទទួលបានការហៅឲ្យបម្រើនៅក្នុងសាសនាចក្រ ហើយមានអារម្មណ៍ថាលើសកម្រិត ហើយមិនមានលទ្ធភាពបំពេញការហៅនោះ ។ ដោយផ្អែកទៅលើអ្វី ដែលអ្នកបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២ និង បទពិសោធន៍ ដែល នូវល ខេ វិតនី បានមានចំពោះការហៅរបស់គាត់ សូមសរសេរដំបូន្មាន ឬ ទីបន្ទាល់ ពីរបីប្រយោគដែលអ្នកនឹងផ្ដល់ឲ្យ ដើម្បីជួយបុគ្គលនេះ ឲ្យមានអារម្មណ៍ទុកចិត្តក្នុងការទទួលយក ហើយបំពេញការហៅនេះ ។

ប្រធាន ហិនរី ប៊ី អាវរិង ក្នុងគណៈប្រធានទីមួយ ក៏បានបង្រៀនអំពីប្រភពនៃការហៅឲ្យបម្រើនៅក្នុងសាសនាចក្រដែរ ៖



« ខ្ញុំសូមទូន្មានដល់មនុស្សគ្រប់គ្នាទាំង បុរស ឬ ស្ត្រី ក្មេងស្រី ឬ ក្មេងប្រុស ដែលត្រូវបានហៅ ឬ នឹងត្រូវបានហៅ ។ មានរឿងមួយចំនួន ដែលអ្នកត្រូវតែដឹង ដែលជាការរឿងពិត ។. . .

« ដំបូង អ្នកត្រូវបានហៅដោយព្រះ ។ ព្រះអម្ចាស់ស្គាល់អ្នក ។ ទ្រង់ស្គាល់អ្នកដែលទ្រង់មានព្រះទ័យឲ្យបម្រើ នៅក្នុងគ្រប់តួនាទីក្នុងសាសនាចក្ររបស់ទ្រង់ ។ ទ្រង់បានរើសអ្នក ។. . . បុគ្គលដែលត្រូវបានបំផុតគំនិតឲ្យស្នើដល់អ្នកចំពោះការហៅនេះ ពុំបានធ្វើដូច្នោះដោយសារតែ ពួកគាត់ចូលចិត្តអ្នក ឬ ពួកគាត់ត្រូវការនរណាម្នាក់ឲ្យធ្វើកិច្ចការដាក់លាក់ណាមួយឡើយ ។ ពួកគាត់បានអធិស្ឋាន ហើយបានទទួលចម្លើយថា អ្នកគឺជាបុគ្គលដែលត្រូវតែបានហៅ ។

« បុគ្គលដែលបានហៅអ្នក ពុំផ្ដល់ការហៅនោះឲ្យអ្នកដោយធម្មតានោះទេ ព្រោះគាត់បានស្វែងយល់ដោយបទសម្ភាសន៍ជាមួយអ្នកថា អ្នកមានភាពសក្ដិសម និង មានឆន្ទៈក្នុងការបម្រើ ។ គាត់បានអធិស្ឋានដើម្បីដឹង អំពីព្រះឆន្ទៈរបស់ព្រះអម្ចាស់ដែលមានសម្រាប់អ្នក ។ វាគឺជាការអធិស្ឋាន និង វិវរណៈដែលបានប្រទានដល់ពួកអ្នកដែលមានសិទ្ធិអំណាចរបស់ព្រះអម្ចាស់ ដែលនាំឲ្យអ្នកមកកាន់តំណែងនេះ » ( « Rise to Your Call » *Ensign* ខែ វិច្ឆិកា ឆ្នាំ ២០០២ ទំព័រ ៧៥–៧៦ ) ។

២. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការយល់ថា **ការហៅឲ្យបម្រើនៅក្នុងសាសនាចក្ររបស់អម្ចាស់ គឺចេញមកពីព្រះ** អាចជួយអ្នកឲ្យទទួលយក ហើយខិតខំបំពេញការហៅរបស់អ្នកដោយឧស្សាហ៍ព្យាយាមយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២:៩–២៦

*ព្រះអម្ចាស់ពន្យល់អំពីករណីយកិច្ចរបស់ប៊ីស្សព*

៣. សូមរាយជាបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីករណីយកិច្ច និង ការទទួលខុសត្រូវទាំងអស់នៃប៊ីស្សព និង ប្រធានសាខា ដែលអ្នកអាចគិតឃើញ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២:៩–២៦ ព្រះអម្ចាស់បានបើកសម្ដែងករណីយកិច្ចមួយចំនួនរបស់ប៊ីស្សព នូវែល ខេ វិតនី ។ ករណីយកិច្ចដែលព្រះអម្ចាស់បានប្រទាន គឺទាក់ទងជាចម្បងទៅនឹងតួនាទីរបស់ប៊ីស្សព វិតនី នៅក្រោមក្រឹត្យវិន័យនៃការថ្វាយ ។ ទោះជាយ៉ាងណាក៏ដោយ ការទទួលខុសត្រូវមួយចំនួននៃប៊ីស្សព និង ប្រធានសាខានៅក្នុងសាសនាចក្រសព្វថ្ងៃនេះទាក់ទងទៅនឹងករណីយកិច្ចទាំងនេះនៃប៊ីស្សពដំបូងបង្អស់នៃសាសនាចក្រ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២:១០–១២ ដោយស្វែងរកករណីយកិច្ច ដែលព្រះអម្ចាស់បានប្រទានឲ្យដល់ប៊ីស្សព វិតនី ។ សូមគូសរង្វង់លើករណីយកិច្ចទាំងឡាយណា ដែលអ្នកបានរាយក្នុងបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ដែលមានលក្ខណៈស្រដៀងទៅនឹងករណីយកិច្ចដែលមាននៅក្នុងខគម្ពីរទាំងនេះ ។

ករណីយកិច្ចមួយចំនួន ដែលព្រះអម្ចាស់បានបង្គាប់ដល់ប៊ីស្សព វិតនី ឲ្យបំពេញ មានលក្ខណៈស្រដៀងទៅនឹងការទទួលខុសត្រូវ ដែលតម្រូវឲ្យប៊ីស្សពធ្វើនាពេលសព្វថ្ងៃនេះដែរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២:១៦–១៨ ដោយស្វែងរកអ្វីដែលប៊ីស្សព វិតនី ត្រូវផ្ដល់ឲ្យសមាជិកដែលផ្លាស់ទីលំនៅទៅកាន់រដ្ឋ មិសសួរី ។

ពួកបរិសុទ្ធដែលផ្លាស់ទីលំនៅទៅរដ្ឋ មិសសួរី ត្រូវកាន់បណ្ណទៅឲ្យប៊ីស្សព ប៉ាទ្រិច ដែលជាប៊ីស្សពនៃទីក្រុង ស៊ីយ៉ូន ដោយបញ្ជាក់ថា ពួកគេសក្ដិសមនឹងទទួលមរតកទីក្រុង ស៊ីយ៉ូន ។ នាពេលបច្ចុប្បន្ននេះ បណ្ណចូលព្រះវិហារបរិសុទ្ធដើរតួរជា « បណ្ណ » ដែលប៊ីស្សព និង ប្រធានសាខាផ្ដល់ឲ្យសមាជិក ដើម្បីបញ្ជាក់អំពីភាពសក្ដិសមរបស់ពួកគេ ហើយអនុញ្ញាតឲ្យពួកគេចូលទៅក្នុងព្រះវិហារបរិសុទ្ធ ។

យើងរៀនចេញពីវិវរណៈនេះ ដែលទាក់ទងនឹងករណីយកិច្ចរបស់ប៊ីស្សព វិតនី ថា **ប៊ីស្សព និង ប្រធានសាខា គ្រប់គ្រងកិច្ចការខាងសាច់ឈាម និង ខាងវិញ្ញាណនៃសាសនាចក្រ នៅក្នុងវួដ និង សាខារបស់ពួកគាត់ ។** ( ពាក្យ *ខាងសាច់ឈាម* សំដៅទៅលើកិច្ចការទាំងឡាយទាក់ទងនឹងជីវិតរូបកាយមានដូចជា សម្លៀកបំពាក់ អាហារ ទ្រព្យធន និង ប្រាក់កាស ) ។

សូមពិចារណាអំពីរបៀបដែល ជីវិតរបស់អ្នកមានពរដោយសារព្រះអម្ចាស់បានហៅប៊ីស្សព ឬ ប្រធានសាខារបស់អ្នក ឲ្យបម្រើអ្នក និង ក្រុមគ្រួសាររបស់អ្នក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៣

*ព្រះអម្ចាស់ណែនាំឲ្យ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បន្តការបកប្រែលើព្រះគម្ពីរប៊ីប*

សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៣រួចស្វែងរកអ្វីដែលព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានធ្វើ ចាប់តាំងពីដើមខែធ្នូ ឆ្នាំ ១៨៣១ ។



យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានផ្សាយ ដើម្បីជួយតតាំងទៅនឹងព័ត៌មានខុសឆ្គងអំពីសាសនាចក្រ ដែលជាលទ្ធផលនៃការបោះពុម្ពផ្សាយនៃលិខិតរបស់ អែសរ៉ា ប៊ូត ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៣:១–២ ព្រះអម្ចាស់បានបើកសម្ដែងថា ពួកអែលឌើរដែលបានកំពុងផ្សាយផងដែរនោះ ត្រូវបន្តផ្សាយរហូតដល់សន្និសីទលើកក្រោយ ។ សន្និសីទនេះបានប្រព្រឹត្តទៅ នៅពីរសប្ដាហ៍ក្រោយមកទៀត ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៣:៣–៤ ដោយស្វែងរកកិច្ចការ ដែលព្រះអម្ចាស់បញ្ជាឲ្យ យ៉ូសែប និង ស៊ីឌនី ផ្ដោតអារម្មណ៍នៅពេលនោះ ។ « កិច្ចការនៃការបកប្រែនេះ » យ៉ូសែប និង ស៊ីឌនី ត្រូវចាប់ផ្ដើមផ្ដោតអារម្មណ៍ម្ដងទៀតទៅលើកំណែដ៏បំផុសគំនិតនៃព្រះគម្ពីរប៊ីប ។ សព្វថ្ងៃនេះ កំណែដ៏បំផុសគំនិតរបស់ព្យាការី យ៉ូសែប ស្ម៊ីធ មាននៅក្នុង

លេខយោង ( JST ) ពាសពេញព្រះគម្ពីរប៊ីប និង នៅក្នុងជំពូកនៃសេចក្ដីបន្ថែមរបស់ព្រះគម្ពីរប៊ីប ( ការបកប្រែរបស់ យ៉ូសែប ស្ម៊ីធ ) ។ ព្រះគម្ពីរម៉ូសេ និង យ៉ូសែប ស្ម៊ីធ—ម៉ាថាយ នៅក្នុង មុក្ដាដ៏មានតម្លៃមហិមា ក៏បានមកពីការបកប្រែដ៏បំផុសគំនិតដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៤

*ព្រះអម្ចាស់បកស្រាយអត្ថន័យនៃ កូរិនថូស ទី១ ៧:១៤*

សូមស្រមៃថាអ្នកកំពុងបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង សម្រាប់សាសនាចក្រ ។ ខណៈពេលអ្នកកំពុងតែបង្រៀនគូស្វាមីភរិយាមួយគូ ដែលកំពុងស្វែងយល់អំពីសាសនាចក្រ នោះអ្នកទទួលដំណឹងថា ពួកគេបានមានកូនប្រុសម្នាក់បានស្លាប់កាលនៅអាយុទើបតែប៉ុន្មានខែប៉ុណ្ណោះ ។ អ្នកដឹកនាំសាសនារបស់គូស្វាមីភរិយានោះបានប្រាប់ពួកគេថា កូននោះមិនអាចគ្រងស្ថានសួគ៌បានឡើយ ព្រោះគាត់ពុំបានទទួលពិធីបុណ្យជ្រមុជទឹកពីមុនបាត់បង់ជីវិតនោះទេ ។ ឪពុកម្ដាយរូបនោះក្រៀមក្រំយ៉ាងខ្លាំងដោយសារតែការបាត់បង់កូនរបស់ខ្លួន និង ដោយសារតែពួកគេជឿថា ទារកតូចនោះបានបាត់បង់សេចក្ដីសង្គ្រោះហើយ ។

តើអ្នកនឹងថ្លែងដូចម្ដេច ទៅកាន់ពួកគេ ? ( អ្នកនឹងមានឱកាសសរសេរចម្លើយរបស់អ្នក នៅពេលក្រោយអំឡុងពេលមេរៀននេះ ) ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៤ មាននូវការបកស្រាយអំពី កូរិនថូស ទី១ ៧:១៤ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៤:១ ដែលជាប្រសាសន៍របស់សាវក ប៉ុល ចេញពី កូរិនថូស ទី១ ៧:១៤ ។ ពាក្យ *ដែលមិនជឿ* នៅក្នុង ខទី ១ សំដៅទៅលើពួកសាសន៍យូដា ដែលពុំបានទទួលយកដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ ប៉ុល ពុំមែនមានប្រសាសន៍ថា បុគ្គលម្នាក់អាចត្រូវបានសង្គ្រោះដោយសារប្ដី ឬ ប្រពន្ធដ៏សុចរិតរបស់ខ្លួននោះទេ ប៉ុន្តែ ការប្រែចិត្តជឿរបស់ប្ដី ឬ ប្រពន្ធ អាចនាំឲ្យមានឥទ្ធិពលនៃការញែកឲ្យបរិសុទ្ធទៅដល់ក្រុមគ្រួសារ ។ឃ្លា « ពុំនោះកូនចៅគេមិនស្អាតទេ » នៅក្នុង កូរិនថូស ទី១ ៧:១៤ ត្រូវបានគេប្រើដើម្បីបង្ហាញឲ្យឃើញថា ការអនុវត្តនៃពិធីបុណ្យជ្រមុជទឹករបស់គេនោះ សម្រាប់ក្មេងតូចៗជាការត្រឹមត្រូវ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៤:២–៦ ដោយស្វែងរកបញ្ហាទាំងឡាយ ដែលបានកើតឡើងនៅជំនាន់របស់សាវកប៉ុល កាលប្រពន្ធដែលបានរៀបការ បានប្រែចិត្តជឿលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយប្ដីនៅតែអនុវត្ត ក្រឹត្យវិន័យនៃលោកម៉ូសេ ។

ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ បានបំពេញក្រឹត្យវិន័យនៃលោកម៉ូសេ ហើយការកាត់ស្បែកក៏ពុំតម្រូវឲ្យមានទៀតដែរ ។ ទោះជាយ៉ាងណាក៏ដោយ ពួកសាសន៍យូដាដែលបានគោរពតាមក្រឹត្យវិន័យនៃលោកម៉ូសេ ជឿថា កុមារម្នាក់ពុំមានភាពស្អាតស្អំបានឡើយ លើកលែងតែកុមារនោះកាត់ស្បែក ដែលជាធម្មតាត្រូវបានធ្វើឡើងនៅអាយុប្រាំបីថ្ងៃ ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៤:២–៦ ព្រះអម្ចាស់បានពន្យល់អំពីរបៀប ដែលជំនឿដ៏ខុសឆ្គងនេះទាក់ទងនឹងស្ថានភាពខាងវិញ្ញាណរបស់កុមារ និង របៀបដែលការអនុវត្តការកាត់ស្បែកបានបណ្ដាលឲ្យមានបញ្ហាកើតឡើងនៅក្នុងក្រុមគ្រួសារ ដែលមានតែឪពុក ឬ ម្ដាយជឿទៅលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និង ទៅលើក្រឹត្យវិន័យនៃលោកម៉ូសេ ។ វិវាទខាងជំនឿសាសនា និង ការប្រតិបត្តិស្រដៀងនេះ អាចកើតមាននាពេលបច្ចុប្បន្ននេះ នៅក្នុងក្រុមគ្រួសារដែលមានប្ដី ឬ ប្រពន្ធជាសមាជិកសាសនាចក្រ និង មិនមែនសមាជិក ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៤:៧ រួចពិចារណាអំពីការគូសចំណាំគោលលទ្ធិ ដែលព្រះអម្ចាស់បានបង្រៀនអំពីកូនក្មេង ។ ក្រោយមក សូមអាន មរ៉ូណៃ ៨:៨–១២ ។ សូមពិចារណាអំពីរបៀបដែលខគម្ពីរទាំងនេះ អនុវត្តចំពោះស្ថានភាពនៃអ្នកផ្សព្វផ្សាយសាសនាដែលបានលើកឡើងពីដំបូង ។ អ្នកអាចនឹងចង់សរសេរ *មរ៉ូណៃ ៨:៨–១២* ជាខគម្ពីរយោងនៅក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៤:៧ ។

៤. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្វីដែលអ្នកនឹងបង្រៀនដល់ប្ដីប្រពន្ធដែលបានរៀបការហើយ ដែលជឿថា ទារករបស់ពួកគេដែលបានស្លាប់ទៅហើយនោះ ពុំអាចគ្រងស្ថានសួគ៌បាន ។ តើអ្នកនឹងជួយពួកគេឲ្យយល់តាមរបៀបណា អំពីគោលលទ្ធិ ដែលបានបង្រៀននៅក្នុងខគម្ពីរទាំងនេះដែលថា **កូនក្មេងសុទ្ធតែបរិសុទ្ធ ដែលត្រូវបានញែកឲ្យបរិសុទ្ធតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ** ?

អែលឌើរ សាយអាន អែម បូវែន ក្នុងកូរ៉ុមនៃពួកចិតសិបនាក់ បានចែកចាយបទពិសោធន៍មួយ ដែលគាត់មានកាលនៅជាអ្នកផ្សព្វផ្សាយសាសនាវ័យក្មេងក្នុងប្រទេស ឈីលី ។ សូមកត់ចំណាំអំពីលទ្ធផល ដែលការរៀនអំពីគោលលទ្ធិពិតដែលប្រាប់ថាកូនក្មេងត្រូវបានញែកឲ្យបរិសុទ្ធតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទនោះ បានមានចំពោះស្ត្រីដែលអែលឌើរ បូវែន និង ដៃគូរបស់គាត់បានបង្រៀន ។



« បងស្រី រ៉ាម៉ែរ៉េស បានរៀនមេរៀនយ៉ាងឆាប់រហ័ស ។ គាត់ចង់រៀនគោលលទ្ធិទាំងអស់ដែលយើងបានបង្រៀន ។ នាល្ងាចមួយ នៅពេលយើងកំពុងពិភាក្សាពីការធ្វើបុណ្យជ្រមុជទឹកឲ្យទារក យើងបានបង្រៀនថា កុមារតូចៗគ្មានបាបទេ ហើយមិនត្រូវការពិធីបុណ្យជ្រមុជទឹកឡើយ ។ យើងបានអញ្ជើញឲ្យគាត់អានព្រះគម្ពីរមរ៉ូណៃ [មរ៉ូណៃ ៨:១០–១២ ] ។. . .

« បន្ទាប់ពីការអានខគម្ពីរនេះ បងស្រី រ៉ាម៉ែរ៉េស ចាប់ផ្ដើមយំ ។ ដៃគូខ្ញុំ និងខ្ញុំមានអារម្មណ៍ច្របូកច្របល់ ។ ខ្ញុំបានសួរថា ‹ បងស្រី រ៉ាម៉ែរ៉េស តើយើងបាននិយាយ ឬធ្វើអ្វីមួយដែលធ្វើឲ្យបងអន់ចិត្តឬ ? ›

គាត់បាននិយាយថា « អ៎ូ ទេ អែលឌើរ ពុំបានធ្វើអ្វីខុសទេ ។ កាលពីប្រាំមួយឆ្នាំមុន ខ្ញុំមានកូនប្រុសតូចម្នាក់ ។ គេបានស្លាប់មុនពេលយើងឲ្យគាត់ទទួលបុណ្យជ្រមុជទឹក ។ សង្ឃរបស់យើងបានប្រាប់យើងថា ដោយសារគាត់ពុំបានទទួលបុណ្យជ្រមុជទឹក នោះគេនឹងទៅនៅកន្លែងឃុំឃាំងជារៀងរហូត ។ អស់រយៈពេលប្រាំមួយឆ្នាំហើយ ដែលខ្ញុំរែកនូវបន្ទុកនិងកំហុសនោះ ។ បន្ទាប់ពីអានខគម្ពីរនេះហើយ ខ្ញុំដឹងដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធថា វាគឺជាការពិត ។ ខ្ញុំបានដឹងថា ទម្ងន់ដ៏ធ្ងន់បានដកចេញពីខ្ញុំ ហើយទាំងនេះគឺជាទឹកភ្នែកនៃក្ដីអំណរ › ។. . .

បន្ទាប់ពីគាត់រងទុក្ខក្នុងទុក្ខព្រួយ និងការឈឺចាប់ដែលស្ទើរតែពុំអាចរែកពន់បានអស់រយៈពេលប្រាំមួយឆ្នាំ គោលលទ្ធិពិតដែលបានបើកសម្ដែងដោយព្រះវរបិតាសួគ៌ជាទីស្រឡាញ់ តាមរយៈព្យាការីនៅរស់ នាំមកនូវភាពសុខសាន្តដ៏ផ្អែមល្ហែមដល់ស្ត្រីដែលរងទុក្ខនេះ ។ ដោយមិនចាំបាច់និយាយ បងស្រី រ៉ាម៉ែរ៉េស និងកូនៗរបស់គាត់ដែលមានអាយុប្រាំបីឆ្នាំឡើងទៅបានទទួលបុណ្យជ្រមុជទឹក » ( « Because I Live, Ye Shall Live Also » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១២, ទំព័រ ១៥–១៦ ) ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧២–៧៤ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៦ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥

## បុព្វកថា

នៅក្នុងសន្និសីទនៃសាសនាចក្រដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៨៣២ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈចំនួនពីរ ដែលទាំងពីរនោះមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥ ។ វិវរណៈទីមួយដែលមានកត់ត្រានៅក្នុង ខទី ១–២២ ត្រូវបានប្រទានដល់ពួកអែលឌើរមួយក្រុម ដែលបានបញ្ជូនឈ្មោះដើម្បីបម្រើបេសកកម្ម ។ ព្រះអម្ចាស់បានណែនាំដល់ពួកអែលឌើរទាំងនេះអំពីករណីយកិច្ចនៃការផ្សព្វផ្សាយសាសនារបស់ពួកគេ ហើយបានចាត់តាំងដៃគូបេសកកម្មឲ្យពួកគេ ។ វិវរណៈទីពីរដែលមានកត់ត្រានៅក្នុង ខទី ២៣–៣៦ ត្រូវបានប្រទានដល់ពួកអែលឌើរក្រុមទីពីរ ដែលបានចង់ដឹងអំពីព្រះឆន្ទៈ របស់ព្រះអម្ចាស់ ដែលមានចំពោះពួកគេ ។ ព្រះអម្ចាស់បានណែនាំពួកអែលឌើរទាំងនេះត្រូវឲ្យប្រាកដថាក្រុមគ្រួសាររបស់ពួកគេត្រូវបានទ្រទ្រង់ ហើយឲ្យពួកគេទទួលយកការហៅឲ្យប្រកាសដំណឹងល្អ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:១–៥

*ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់ អ្នកដែលមានបំណងប្រាថ្នាប្រកាសដំណឹងល្អ*

តើនៅប៉ុន្មានឆ្នាំទៀត ដែលអ្នកនឹងមានលក្ខណៈគ្រប់គ្រាន់អាចបម្រើបេសកកម្មពេញម៉ោងបាន ? នៅពេលអ្នកគិតអំពីលទ្ធភាពនៃការបម្រើបេសកកម្មពេញម៉ោង តើពរជ័យអ្វីខ្លះ ដែលអ្នករំពឹងថានឹងទទួលបានដោយការចែកចាយដំណឹងល្អជាមួយមនុស្សដទៃ ? សូមសរសេរពរជ័យមួយចំនួនទាំងនោះ នៅក្នុងចន្លោះដែលមាន ៖

ដូចបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥ ព្រះអម្ចាស់បានសន្យាថានឹងប្រទានពរជ័យជាច្រើន ទៅដល់អ្នកដែលទ្រង់បានហៅឲ្យប្រកាសដំណឹងល្អ ។ ទ្រង់ក៏ប្រទានដល់ពួកគេ នូវការណែនាំទាំងឡាយដើម្បីជួយពួកគេទទួលបានជោគជ័យ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:១–៤ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់មានព្រះទ័យឲ្យពួកអែលឌើរទាំងនេះធ្វើ នៅពេលកំពុងប្រកាសដំណឹងល្អ ។ អ្នកអាចនឹងចង់គូសចំណាំអ្វី ដែលអ្នករកឃើញនៅក្នុងព្រះគម្ពីររបស់អ្នក ។

១. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលអ្នកគិតថា វាមានសារៈសំខាន់ ដែលអ្នកផ្សព្វផ្សាយសាសនាត្រូវប្រកាសដំណឹងល្អ ទៅតាមបែបបទដែលព្រះអម្ចាស់បានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:៥ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានសន្យាដល់ពួកអែលឌើរទាំងនេះ ប្រសិនបើពួកគាត់នឹងប្រកាសដំណឹងល្អរបស់ទ្រង់ដោយស្មោះត្រង់នោះ ។ វាអាចនឹងមានប្រយោជន៍ដែលត្រូវស្គាល់ថា ពាក្យ *កណ្ដាប់ស្រូវ* សំដៅទៅលើដើមស្រូវ ដែលត្រូវបានច្រូត ហើយចងជាកណ្ដាប់ ។ ការផ្ទុក « កណ្ដាប់ស្រូវ » មានន័យថា ការច្រូតកាត់បានច្រើន ។ តើអ្នកគិតថា « កណ្ដាប់ស្រូវ » អាចជានិមិត្តរូបអ្វី នៅក្នុងកិច្ចការផ្សព្វផ្សាយសាសនា ?

បន្ថែមពីលើពរជ័យនៃការទទួលបានផ្លែផ្កាពីកិច្ចការរបស់យើង នៅពេលយើងចែកចាយដំណឹងល្អជាមួយមនុស្សដទៃ នោះព្រះអម្ចាស់បានសន្យាថានឹងប្រទានពរជ័យដ៏នៅអស់កល្បជានិច្ចនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:៥ ។ តើការសន្យារបស់ព្រះអម្ចាស់មាននៅក្នុង ខទី ៥ អាចនឹងលើកទឹកចិត្តអ្នក ឲ្យចែកចាយដំណឹងល្អ ជាមួយមនុស្សដទៃយ៉ាងដូចម្ដេច ?

២. ដោយប្រើអ្វីដែលអ្នករៀននៅក្នុង ខទី ៥ សូមបំពេញគោលការណ៍ដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ **បើយើងស្មោះត្រង់ក្នុងការប្រកាសដំណឹងល្អ នោះព្រះអម្ចាស់នឹងប្រទានពរយើងដោយនូវ** . . .



កណ្ដាប់ស្រូវនៅក្នុងវាលស្រែ

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:៦-២២

*ព្រះអម្ចាស់ហៅ ហើយណែនាំដល់ដៃគូផ្សព្វផ្សាយសាសនាទាំងឡាយ*

បន្ទាប់ពីព្រះអម្ចាស់បានប្រទានការណែនាំ និង ការសន្យាទៅដល់ពួកអែលឌើរ ដែលនឹងបម្រើបេសកកម្មហើយ នោះទ្រង់បានចាត់ពួកគាត់ជាគូៗ ហើយបានប្រទានសេចក្ដីណែនាំជាក់លាក់ទៅដល់ដៃគូនីមួយៗ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:៦–១២ ដើម្បីរៀនអំពីដៃគូទីមួយ និង ការសន្យាដែលព្រះអម្ចាស់បានប្រទានដល់ពួកគាត់ ប្រសិនបើពួកគាត់ប្រកាសដំណឹងល្អដោយស្មោះត្រង់ ។

វាអាចនឹងជួយអ្នកដែលត្រូវដឹងថា នៅថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៨៣១ វិលលាម អ៊ី ម៉ុកខ្លេលិន បានទទួលការហៅឲ្យបម្រើបេសកកម្មនៅភាគខាងកើតនៃសហរដ្ឋ និង សាំយូអែល អេច ស្ម៊ីធ ត្រូវបានហៅឲ្យធ្វើជាដៃគូរបស់គាត់ ( សូមមើល គ. និង ស. ៦៦:៥–៨ ) ។ វិលលាម បានគោរពប្រតិបត្តិតាមការហៅនេះមុនគេបង្អស់ ។ បេសកកម្មរបស់គាត់បានបញ្ចប់មុនគេ ហើយបានត្រឡប់ទៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ វិញនៅចុងខែ ធ្នូ ឆ្នាំ ១៨៣១ ។ ដូចបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:៦–១២ ព្រះអម្ចាស់បានវាយផ្ចាល វិលលាម អ៊ី ម៉ុកខ្លេលិន ចំពោះការរអ៊ូរទាំរបស់គាត់ ដោយត្រូវបានដកការហៅឲ្យបម្រើនៅរដ្ឋទាំងឡាយ នៅភាគខាងកើត ហើយទ្រង់បានហៅ អូរសុន ហៃឌ ឲ្យបម្រើជំនួសគាត់ជាដៃគូរបស់សាំយូអែល ស្ម៊ីធ ។ ទោះជាយ៉ាងណាក៏ដោយ ព្រះអម្ចាស់បានបន្តហៅ វិលលាម ឲ្យបម្រើ ដើម្បីប្រកាសដំណឹងល្អនៅភាគខាងត្បូងនៃសហរដ្ឋ ដោយមាន លូកា ចនសុន ធ្វើជាដៃគូ ។ វិលលាម បានទទួលការហៅឲ្យបម្រើនោះ ប៉ុន្តែ គាត់ពុំបានបន្តបម្រើដោយស្មោះត្រង់នោះទេ ។ មិនយូរប៉ុន្មាន គាត់បានថ្លែងចេញមកថា គាត់ធុញទ្រាន់មិនចង់បន្តបេសកកម្មទៀតឡើយ ។ បន្ទាប់ពីបានបញ្ចប់បេសកកម្មរបស់គាត់ហើយនោះ គាត់បានធ្វើដំណើរទៅកាន់ភូមិហៃរាំ រដ្ឋ អូហៃអូ វិញ ហើយបានរៀបការនឹងអិមីលីន មិលើរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:១១, ១៣–១៤ ដោយស្វែងរកការសន្យាដែលព្រះអម្ចាស់បានមានព្រះបន្ទូលម្ដងហើយម្ដងទៀត ទៅកាន់ដៃគូផ្សព្វផ្សាយសាសនាទាំងនោះ ប្រសិនបើពួកគេនឹងប្រកាសដំណឹងល្អដោយស្មោះត្រង់ ។ អ្នកអាចនឹងចង់គូសចំណាំឃ្លានៅក្នុងខគម្ពីរទាំងនេះ ដែលអះអាងចំពោះយើងថា **បើយើងមានចិត្តស្មោះត្រង់ក្នុងការប្រកាសដំណឹងល្អ នោះព្រះអម្ចាស់នឹងគង់នៅជាមួយយើង ។**

៣. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីបទពិសោធន៍មួយដែលអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ បានមាន ដែលអះអាងចំពោះអ្នកថា ព្រះអម្ចាស់នឹងគង់នៅជាមួយយើង នៅពេលយើងចែកចាយដំណឹងល្អរបស់ទ្រង់ដោយស្មោះត្រង់ ។

៤. សូមស្រមៃថា អ្នកមានមិត្តភក្ដិ ឬ សមាជិកម្នាក់ ដែលកំពុងមានការលំបាកក្នុងការបម្រើបេសកកម្មពេញម៉ោង ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ជាសំបុត្រលើកទឹកចិត្តមួយច្បាប់ទៅកាន់បុគ្គលនោះ ដោយប្រើគោលការណ៍ដែលអ្នកបានរៀននៅក្នុងមេរៀននៅថ្ងៃនេះ ។ សូមចែកចាយនៅក្នុងសំបុត្រនោះ អំពីអ្វីដែលអ្នកផ្សព្វផ្សាយសាសនាអាចធ្វើ ដើម្បីប្រកាសដំណឹងល្អកាន់តែមានភាពស្មោះត្រង់ និង អ្វីដែលជាពរជ័យមួយចំនួន ដែលកើតឡើងចំពោះអ្នកដែលធ្វើដូច្នោះ ។ ( ប្រសិនបើអ្នកស្គាល់អ្នកផ្សព្វផ្សាយសាសនាពេញម៉ោងណាម្នាក់ អ្នកអាចសរសេរសំបុត្រទៅកាន់គាត់ ។ បន្ទាប់មក សូមកត់ចំណាំនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ដោយសរសេរថា អ្នកបានធ្វើកិច្ចការនោះហើយ ) ។


ហ្គរដុន ប៊ី ហ៊ិងគ្លី កាលនៅជាអ្នកផ្សព្វផ្សាយសាសនាវ័យក្មេង បានប្រកាសដំណឹងល្អនៅ ហៃដ ផាក ទីក្រុង ឡុងដ៍

យើងអាចជួបប្រទះនឹងឧបសគ្គនានា ក្នុងការខិតខំឲ្យមានចិត្តស្មោះត្រង់ក្នុងការប្រកាសដំណឹងល្អ ។ នៅក្នុងអត្ថបទមួយអំពីប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានសរសេរអំពីការពុះពារមួយដែលប្រធាន ហ៊ិងគ្លី បានជួបប្រទះកាលកំពុងបម្រើជាអ្នកផ្សព្វផ្សាយសាសនានៅប្រទេស អង់គ្លេស ៖

« អែលឌើរ ហ៊ិងគ្លី បានមានការបាក់ទឹកចិត្ត ដែលដូចគ្នាទៅនឹងអ្នកផ្សព្វផ្សាយសាសនាដ៏ទៃទៀតកំពុងប្រឈមមុខទៅនឹងកាលៈទេសៈថ្មីលើទឹកដីថ្មី ។ គាត់ពុំសូវស្រួលខ្លួននោះទេ ហើយនៅពេលគាត់បានទៅការប្រជុំជាសាធារណៈជាលើកដំបូងរបស់គាត់ . . . គាត់នៅចាំ ៖ ‹ ខ្ញុំបានភ័យញ័រ ។ ខ្ញុំបានឡើងលើវេទិកាតូចមួយ ហើយបានសម្លឹងមើលទៅបណ្ដាជនដែលបានមកជួបជុំគ្នា ។. . . ពួកគេពុំបានសម្លឹងមកខ្ញុំវិញដោយទឹកមុខឃោរឃៅ ឬ កាចសាហាវនោះទេ ប៉ុន្តែ ខ្ញុំមិនដឹងថាហេតុអ្វីបានជាខ្ញុំពិបាកថ្លែងចេញនូវអ្វីដែលខ្ញុំត្រូវថ្លែងនោះឡើយ › ។

« ដោយការបាក់ស្មារតី និង ការប្រឈមមុខនឹងការបរាជ័យក្នុងកិច្ចខិតខំផ្សព្វផ្សាយសាសនា ហ្គរដុន បានសរសេរសំបុត្រទៅកាន់ឪពុករបស់គាត់ ៖ ‹ ខ្ញុំកំពុងតែខ្ជះខ្ជាយពេលវេលា និងប្រាក់កាសរបស់លោកឪពុកហើយ ។ ខ្ញុំពុំមានជោគជ័យអ្វីទាល់តែសោះនៅទីនេះ › ។ មិនយូរប៉ុន្មាន សំបុត្រមួយច្បាប់ដ៏ផ្អែមល្ហែម ប៉ុន្តែ ខ្លីបានសរសេរតបមកពីឪពុករបស់លោក ។ សំបុត្រនោះមានសេចក្ដីចែងមក ៖ ‹ ហ្គរដុន ជាទីស្រឡាញ់ ។ ឪពុកបានទទួលសំបុត្ររបស់កូន [ នៅកាលបរិច្ឆេទ ] ។ ឪពុកមានតែយោបល់មួយគត់សម្រាប់កូន ។ បំភ្លេចខ្លួនឯង ហើយចេញទៅធ្វើការ ។ ដោយសេចក្ដីស្រឡាញ់ ឪពុករបស់កូន › ។

« ប្រធាន ហ៊ិងគ្លី មានប្រសាសន៍អំពីគ្រាមួយនោះថា ‹ ខ្ញុំបានពិចារណាអំពីចម្លើយតបរបស់គាត់ ហើយនៅព្រឹកស្អែកឡើងនៅក្នុងថ្នាក់សិក្សាព្រះគម្ពីររបស់យើង យើងបានអានព្រះបន្ទូលថ្លែងការណ៍របស់ព្រះអម្ចាស់ដ៏គួរឲ្យកត់សម្គាល់បំផុតនោះថា « ដ្បិតអ្នកណាដែលចង់ឲ្យរួចជីវិត នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលបានបាត់ជីវិតដោយព្រោះយល់ដល់ខ្ញុំ ហើយនឹងដំណឹងល្អ នោះនឹងបានជីវិតវិញ » ( ម៉ាកុស ៨:៣៥ ) ។

« ‹ ព្រះបន្ទូលថ្លែងការណ៍នោះ ការសន្យានោះ បានធ្វើឲ្យខ្ញុំរំជួលចិត្ត ។ ខ្ញុំបានលុតជង្គង់ចុះ ហើយបានធ្វើសេចក្ដីសញ្ញាជាមួយព្រះអម្ចាស់ថា ខ្ញុំនឹងព្យាយាមបំភ្លេចខ្លួនឯង ហើយចេញទៅធ្វើការ ។ ខ្ញុំចាត់ទុកថ្ងៃនោះថា ជាថ្ងៃនៃការសម្រេចចិត្តនៅក្នុងជីវិតរបស់ខ្ញុំ ។ អ្វីៗល្អគ្រប់យ៉ាង ដែលបានកើតឡើងចំពោះខ្ញុំចាប់តាំងពីពេលនោះមក ខ្ញុំអាចក្រឡេកមើលទៅការសម្រេចចិត្តដែលខ្ញុំបានធ្វើនៅគ្រានោះ › » ( « President Gordon B. Hinckley: Stalwart and Brave He Stands » *Ensign* ខែ មិថុនា ឆ្នាំ ១៩៩៥ ទំព័រ ៨ ) ។

ដូចបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:១៥–២២ ព្រះអម្ចាស់បានណែនាំអ្នកផ្សព្វផ្សាយសាសនាឲ្យប្រទានពរដល់ផ្ទះ ដែលបានទទួលពួកគេ ។ ទ្រង់ក៏បានបង្រៀនពួកគាត់អំពីអ្វីដែលត្រូវធ្វើ នៅពេលពួកគាត់ត្រូវបានគេបដិសេធដោយមនុស្សដែលពួកគេបានចែកចាយដំណឹងល្អជាមួយ ។ ការលាស់ធូលីដីពីជើងពួកគាត់ចេញ ទុកជាទីបន្ទាល់ទាស់នឹងពួកគាត់ ដែលបានបដិសេធពួកគាត់ ពុំត្រូវបានអនុវត្តដោយអ្នកផ្សព្វផ្សាយសាសនា នាពេលបច្ចុប្បន្ននេះទេ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:២៣–២៩

*ព្រះអម្ចាស់ពន្យល់អំពីរបៀបដែលក្រុមគ្រួសារនៃអ្នកដែលត្រូវបានហៅឲ្យបម្រើបេសកកម្មទាំងនោះ គប្បីត្រូវបានទ្រទ្រង់*

វិវរណៈទីពីរនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥ ដែលមានកត់ត្រានៅក្នុង ខទី ២៣–៣៦ ត្រូវបានប្រទានឲ្យដល់ពួកអែលឌើរមួយក្រុមទៀត ។ នៅជំនាន់ដំបូងនៃសាសនាចក្រ មានបុរសជាច្រើនដែលត្រូវបានហៅបម្រើបេសកកម្ម មានប្រពន្ធ

និង កូន ដែលពឹងផ្អែកទៅលើការទ្រទ្រង់របស់ពួកគេ ។ ការទទួលយកការហៅឲ្យបម្រើ គឺជាការលះបង់មួយដ៏ធំសម្បើមពីសំណាក់ក្រុមគ្រួសារទាំងមូល ។ ការព្រួយបារម្ភជាទូទៅមួយសម្រាប់ពួកអែលឌើរជាច្រើន អាចជាអ្វីដែលនឹងកើតឡើងចំពោះក្រុមគ្រួសាររបស់ពួកគាត់ ប្រសិនបើពួកគាត់ទទួលយកការហៅឲ្យប្រកាសដំណឹងល្អនៅឆ្ងាយពីផ្ទះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:២៤–២៨ ដោយស្វែងរកសេចក្ដីណែនាំពីព្រះអម្ចាស់ទៅដល់ពួកអែលឌើរ ដែលត្រូវប្រកាសដំណឹងល្អ ប៉ុន្តែ មានក្រុមគ្រួសារដែលត្រូវមើលថែ ។

ព្រះអម្ចាស់បានមានព្រះបន្ទូលនៅក្នុងខគម្ពីរទាំងនេះថា សាសនាចក្រគប្បីជួយដល់ក្រុមគ្រួសារនោះ នៅពេលមានឪពុក ឬស្វាមីទទួលយកការហៅឲ្យចេញទៅបម្រើបេសកកម្ម ។ សូមកត់ចំណាំនៅក្នុង ខទី ២៦ នូវអ្វីដែលព្រះអម្ចាស់បង្គាប់ឲ្យពួកអែលឌើរទាំងនេះធ្វើ ប្រសិនបើពួកគេមានលទ្ធភាពរកកន្លែងមួយ ដែលក្រុមគ្រួសាររបស់ពួកគេអាចត្រូវបានទ្រទ្រង់ ។

នៅក្នុង ខទី ២៨ ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ពួកអែលឌើរដែលពុំមានលទ្ធភាពស្វែងរកការផ្គត់ផ្គង់ដល់ក្រុមគ្រួសារខ្លួនថា ពួកគាត់ត្រូវបានលើកលែងពីការធ្វើដំណើរ ហើយទ្រង់បានអះអាងដល់ពួកគាត់ថា ពួកគាត់នឹងមិនបាត់បង់ឱកាសទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចឡើយ ។ ពួកអែលឌើរទាំងនេះនៅតែរំពឹងឲ្យធ្វើការ នៅក្នុងសាសនាចក្រទៅតាមតំបន់របស់ខ្លួន ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:២៩ ដោយស្វែងរកឱវាទ ដែលព្រះអម្ចាស់បានប្រទានដល់បុរសទាំងអស់នេះ ។ វាអាចផ្ដល់អត្ថប្រយោជន៍ក្នុងការដឹងថា មនុស្សខ្ជិលច្រអូស គឺជាបុគ្គលដែលពុំមានឆន្ទៈធ្វើការ ហើយដែលត្រូវ « មានចិត្តឧស្សាហ៍ក្នុងគ្រប់ជំពូកទាំងអស់ » មានន័យថា ស្ថិតស្ថេរ ព្យាយាម យកចិត្តទុកដាក់ និង ប្រឹងប្រែងធ្វើការ ។

អ្នកអាចនឹងចង់គូសចំណាំសេចក្ដីណែនាំរបស់ព្រះអម្ចាស់នៅក្នុង ខទី ២៩ ដែលបង្រៀនអំពីគោលការណ៍ដូចតទៅនេះ ៖ **ព្រះអម្ចាស់បញ្ជាយើងឲ្យមានចិត្តឧស្សាហ៍ក្នុងគ្រប់ជំពូកទាំងអស់ ។**

៥. សូមពិចារណាអំពីទិដ្ឋភាពមួយចំនួននៃជីវិតរបស់អ្នក ដែលអ្នកដឹងថា អ្នកអាចធ្វើឲ្យមានចិត្តកាន់តែឧស្សាហ៍ព្យាយាមជាងមុន ។ សូមសរសេរនៅលើក្រដាសមួយសន្លឹក នូវគោលដៅនៃអ្វីមួយដែលអ្នកនឹងធ្វើ ដើម្បីឲ្យមានចិត្តកាន់តែឧស្សាហ៍ព្យាយាមជាងមុន ។ សូមបិទគោលដៅនេះ នៅទីកន្លែងដែលអ្នកអាចមើលឃើញវារាល់ថ្ងៃ ។ នៅពេលអ្នកបានបញ្ចប់កិច្ចការនេះ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ *ខ្ញុំបានសរសេរគោលដៅរបស់ខ្ញុំ ហើយបានបិទវានៅទីកន្លែងដែលខ្ញុំអាចមើលឃើញវារាល់ថ្ងៃ ។*

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥:៣០–៣៦

*ព្រះអម្ចាស់ចាត់តាំងពួកអែលឌើរ ឲ្យបម្រើជាដៃគូអ្នកផ្សព្វផ្សាយសាសនា*

នៅចុងបញ្ចប់នៃវិវរណៈទីពីរ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥ ព្រះអម្ចាស់បានចាត់តាំងដៃគូផ្សព្វផ្សាយសាសនា ដល់ពួកអែលឌើរក្នុងក្រុមនេះ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៥ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៦ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្តីសញ្ញា ៧៦:១–៤៩

## សេចក្តីផ្តើម

នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៨៣២ ព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានធ្វើការលើកំណែដ៏បំផុសគំនិតលើព្រះគម្ពីរប៊ីប ។ កាលកំពុងពិចារណាអំពីអត្ថន័យនៃ យ៉ូហាន ៥:២៩ ពួកលោកបានឃើញការនិមិត្តមួយ ។ ការនិមិត្តនេះ ដែលត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៧៦ បានបញ្ជាក់អំពីភាពជាក់ស្តែង និង ទេវភាពនៃព្រះយេស៊ូវគ្រីស្ទ ដែលបានបង្រៀនអំពីការធ្លាក់ចុះរបស់សាតាំង និង ពួកកូនអន្តរធាន ហើយបានពិពណ៌នាអំពីនគរនៃសិរីល្អទាំងបី និង មនុស្សដែលនឹងគ្រងនគរនីមួយៗនោះ ។

គោលលទ្ធិ និង សេចក្តីសញ្ញា ៧៦ នឹងត្រូវបានបំបែកជាបីមេរៀន ។ នៅក្នុងមេរៀនទីមួយនេះ អ្នកនឹងរៀនអំពីព្រះឆន្ទៈរបស់ព្រះអម្ចាស់ដែលមានព្រះទ័យប្រទានពរយើង និង អំពីសកម្មភាពនានារបស់ព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ដែលនាំឲ្យពួកលោកទទួលបានការនិមិត្តនោះ ។ អ្នកក៏នឹងរៀនផងដែរ អំពីការធ្លាក់ចុះរបស់សាតាំង និង ជោគវាសនានៃអស់អ្នកដែលដើរតាមវា ។




## គោលលទ្ធិ និង សេចក្តីសញ្ញា ៧៦:១–១០

*ព្រះអម្ចាស់សន្យាថានឹងប្រទានពរ ដល់អស់អ្នកដែលមានចិត្តស្មោះត្រង់ចំពោះទ្រង់*

ប្រសិនបើអ្នកអាចជ្រើសរើសបុគ្គលណាម្នាក់ដើម្បីផ្តល់កិត្តិយសឲ្យ តើនរណានឹងជាបុគ្គលនោះ និង ហេតុអ្វីបានជាអ្នកជ្រើសរើសបុគ្គលនោះ ?

គោលលទ្ធិ និង សេចក្តីសញ្ញា ៧៦:១–៥ បង្រៀនថា ព្រះអម្ចាស់ជាព្រះប្រកបដោយព្រះបញ្ញាញាណ ព្រះចេស្តា អស់កល្បជានិច្ច ដ៏មានសេចក្តីមេត្តាករុណា និង សេចក្តីសប្បុរស ។ ខទី ៥ ក៏បង្រៀនថា ទ្រង់នឹងប្រទានកិត្តិយសដល់យើងដែរ ប្រសិនបើយើងធ្វើល្អនោះ ។ សូមអាន ខទី ៥ រួចស្វែងរកអ្វីដែលយើងត្រូវតែធ្វើ ដើម្បីត្រូវបានប្រទានកិត្តិយសដោយព្រះយេស៊ូវគ្រីស្ទ ។

នៅក្នុងបរិបទនេះ ការកោតខ្លាចដល់ព្រះអម្ចាស់មានន័យថា ការសរសើរតម្កើង ការថ្វាយកិត្តិយស ការគោរព និង ការស្រឡាញ់ដល់ទ្រង់ ។ យោងតាមព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុង ខទី ៥ យើងរៀនថា **បើយើងសរសើរតម្កើង ហើយបម្រើព្រះអម្ចាស់ នោះទ្រង់នឹងប្រទានកិត្តិយសដល់យើង ។**

សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៧៦:៦–៩ ដោយស្វែងរកការរៀប ដែលព្រះអម្ចាស់នឹងប្រទានកិត្តិយសដល់អ្នកទាំងឡាយណា ដែលសរសើរតម្កើង ហើយបម្រើទ្រង់ ។ នៅពេលអ្នកអាន វាអាចនឹងផ្តល់អត្ថប្រយោជន៍ ដែលត្រូវដឹងថា នៅក្នុងបទគម្ពីរ វាក្យសព្ទ *សេចក្តីអាថ៌កំបាំង* ជាទូទៅសំដៅទៅលើ សេចក្តីពិតខាងវិញ្ញាណ ដែលអាចរៀនបានតែតាមរយៈវិវរណៈប៉ុណ្ណោះ ។

យោងតាមអ្វីដែលអ្នកអាននៅក្នុង ខទី ៦–៩ សូមបន្ថែមលើគោលការណ៍ពីមុន ៖ **បើយើងសរសើរតម្កើង ហើយបម្រើព្រះអម្ចាស់ នោះទ្រង់នឹងប្រទានកិត្តិយសដល់យើងដោយ** ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១០ រួចស្វែងរកគោលការណ៍មួយអំពីរបៀប ដែលព្រះអម្ចាស់នឹងបើកសម្ដែងសេចក្ដីពិតដល់យើង ។

១. សូមពិចារណាអំពីគោលការណ៍ដែលថា **ព្រះអម្ចាស់បំភ្លឺយើងដោយព្រះវិញ្ញាណ** ។ ដើម្បីជួយអ្នកឲ្យចងចាំអំពីគ្រា ដែលព្រះអម្ចាស់បានបំភ្លឺអ្នកដោយវិញ្ញាណ សូមបញ្ចប់ឃ្លាខាងក្រោមនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ *ថ្មីៗនេះ ខ្ញុំត្រូវបានបំភ្លឺដោយព្រះវិញ្ញាណ នៅពេលខ្ញុំ . . .*

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១១–១៩

*យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ពិពណ៌នាអំពីកាលៈទេសៈ ដែលបាននាំឲ្យពួកលោកទទួលបាននិមិត្តនោះ*

និមិត្តដែលត្រូវបានបង្ហាញដល់ព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន គឺជាការបំពេញការសន្យារបស់ព្រះអម្ចាស់ដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥–១០ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១១–១៤ រួចកត់ចំណាំអំពីរបៀបដែលព្រះអម្ចាស់បានប្រទានកិត្តិយសដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ដោយការបើកសម្ដែងសេចក្ដីពិតទៅដល់ពួកលោក ។



និមិត្តដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ត្រូវបានទទួលនៅក្នុងចម្ការរបស់ យ៉ូហាន ចនសុន នៅភូមិហៃរ៉ាំ រដ្ឋ អូហៃអូ ។

តើអ្នកធ្លាប់ចំណាយពេលអានព្រះគម្ពីរ ហើយពុំយល់អំពីអ្វីដែលអ្នកបានអានដែរឬទេ ? តើអ្នកបានធ្វើអ្វីខ្លះ ដើម្បីយល់អំពីបទគម្ពីរឲ្យបានកាន់តែច្បាស់ ?

អ្វីដែល យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានធ្វើពីមុនពួកលោកទទួលបាននិមិត្តនេះ អាចបង្រៀនយើងអំពីរបៀបដែលយើងអាចយល់បទគម្ពីរឲ្យបានកាន់តែច្បាស់ ហើយអញ្ជើញព្រះវិញ្ញាណឲ្យបើកសម្ដែងសេចក្ដីពិតដល់យើង ។ សូមអាន សេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ រួចអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១៥–១៩ ។ នៅពេលអ្នកអាន សូមស្វែងរកអ្វីដែល យ៉ូសែប និង ស៊ីឌនី បានធ្វើ ដែលអាចធ្វើឲ្យពួកលោកទទួលបានការយល់ដឹងអំពីបទគម្ពីរតាមរយៈនិមិត្ត ។

សូមកត់ចំណាំថា គឺនៅខណៈពេលដែលពួកលោកបានសិក្សា ហើយពិចារណាលើបទគម្ពីរនោះ ដែលព្រះវិញ្ញាណបានបំភ្លឺដល់ការយល់ដឹងរបស់ពួកលោក ។ ការសញ្ជឹងគិតលើបទគម្ពីរមានន័យថា ការពិចារណា ឬ គិតអំពីអ្វីដែលអ្នកបានអាន ។ គំរូរបស់ យ៉ូសែប និង ស៊ីឌនី បង្ហាញយើងថា **បើយើងសិក្សាដោយយកចិត្តទុកដាក់ ហើយពិចារណាលើបទគម្ពីរ នោះព្រះអម្ចាស់អាចបង្កើនការយល់ដឹងរបស់យើង ។**



អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់អំពីរបៀបសិក្សា ហើយពិចារណាប្រកបដោយការអធិស្ឋានទៅលើបទគម្ពីរ ៖ « នៅពេលខ្ញុំនិយាយថា ‹ សិក្សា › ខ្ញុំចង់មានន័យជ្រៅជាងការអានទៅទៀត ។. . . ខ្ញុំឃើញថា ពេលខ្លះអ្នកអានពីរបីខគម្ពីរ ឈប់ ដើម្បីសញ្ជឹងគិតអំពីខគម្ពីរនោះ សូមអានខគម្ពីរនេះម្ដងទៀតដោយយកចិត្តទុកដាក់ ហើយនៅពេលអ្នកគិតអំពីអត្ថន័យរបស់វា សូមអធិស្ឋានដើម្បីទទួលបានការយល់ដឹង សួរសំណួរនៅក្នុងគំនិតរបស់អ្នក រង់ចាំការបំផុសគំនិតខាងវិញ្ញាណ រួចសរសេរទុកនូវការបំផុសគំនិត និង ទស្សនវិស័យជ្រៅជ្រះដែលនឹងកើតមានដើម្បីឲ្យអ្នកអាចចងចាំ ហើយរៀនសូត្របានកាន់តែប្រសើរឡើង ។ ការសិក្សារបៀបនេះ អ្នកប្រហែលមិនបានអានច្រើនជំពូក ឬ ច្រើនខគម្ពីរនៅក្នុងរយៈពេលកន្លះម៉ោងនោះទេ ប៉ុន្តែអ្នកនឹងទុកកន្លែងមួយសម្រាប់ព្រះបន្ទូលនៃព្រះនៅក្នុងដួងចិត្តរបស់អ្នក ហើយទ្រង់នឹងមានព្រះបន្ទូលមកកាន់អ្នក » ។ (When Thou Art Converted, » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៤, ទំព័រ ១១ ) ។

២. សូមឆ្លើយសំណួរខាងក្រោមនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើមានលទ្ធផលអ្វីខ្លះ ដែលអ្នកធ្លាប់ទទួលបានដោយការសិក្សា និង ការពិចារណាប្រកបដោយការអធិស្ឋានទៅលើបទគម្ពីរ ?

ខ. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីសកម្មភាពមួយដែលបានលើកឡើងដោយ អែលឌើរ គ្រីស្ទហ្វឺសិន ដែលអ្នកនឹងអនុវត្ត ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២០–២៤

*យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ឃើញព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ*

នៅពេលការនិមិត្តត្រូវបានសម្ដែង ព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានឃើញ ព្រះយេស៊ូវគ្រីស្ទ នៅក្នុងព្រះចេស្ដា និងសិរីល្អនៃទ្រង់ ។

៣. សូមគូសតារាងមួយដែលដាក់ចំណងជើងដូចខាងក្រោម នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

| *អ្វីដែលពួកលោកបានឃើញ ៖* | *អ្វីដែលពួកលោកបានឮ ៖* | *អ្វីដែលពួកលោកបានរៀន ៖* |
|---|---|---|
| | | |

ក. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២០–២៤ រួចសរសេរពាក្យ ឬ ឃ្លាចេញពីខគម្ពីរទាំងនេះ ដែលត្រូវនឹងចំណងជើងនីមួយៗ ។

ខ. យោងតាមអ្វីដែល យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានឃើញ បានឮ និង បានរៀន សូមរាយសេចក្ដីពិតយ៉ាងហោចណាស់ចំនួនពីរដែលបានបង្រៀននៅក្នុងខគម្ពីរទាំងនេះ អំពីព្រះយេស៊ូវគ្រីស្ទ ។ សូមសរសេរទីបន្ទាល់របស់អ្នកអំពីសេចក្ដីពិតមួយក្នុងចំណោមសេចក្ដីពិតទាំងនេះ និង របៀបដែលអ្នកដឹង ឬ មូលហេតុដែលអ្នកជឿថាវាគឺជាការពិត ។

### ចំណេះចំណានខគម្ពីរ—គ. និង ស. ៧៦:២២–២៤

គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២២–២៤ គឺជាចំណេះចំណានខគម្ពីរ ។ អ្នកអាចនឹងចង់គូសចំណាំវានៅក្នុងរបៀបមួយដែលជួយអ្នកអាចងាយរកវាឃើញនៅពេលខាងមុខ ។

៤. ព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទ គឺជាអង្គដែលមានព្រះជន្មរស់ និង ពេញទៅដោយសិរីល្អ ។ សូមស្វែងរកឧទាហរណ៍ពីរទៀតនៅក្នុងបទគម្ពីរនេះ អំពីគ្រាដែលមនុស្សម្នាក់ទៀតបានឃើញព្រះអង្គសង្គ្រោះដ៏មានព្រះជន្មរស់ឡើងវិញ ។ សូមប្រើលេខយោង Topical Guide ឬ សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ដើម្បីជួយដល់អ្នក ។ សូមសរសេរសេចក្ដីយោងសម្រាប់ឧទាហរណ៍ដែលអ្នករកឃើញដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

> *បទគម្ពីរយោង*
>
> ជាញឹកញាប់ វគ្គបទគម្ពីរមួយ អាចពន្យល់ ឬ បញ្ជាក់ច្បាស់នូវឃ្លា ឬ បរិបទមួយ ដែលមាននៅក្នុងវគ្គបទគម្ពីរផ្សេងទៀត ។ សូមតភ្ជាប់វគ្គបទគម្ពីរជាមួយគ្នា ដោយប្រើលេខយោងបទគម្ពីរលិបិក្រម ឬ Topical Guide ឬ សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ដើម្បីជួយបង្ហាញអត្ថន័យនៃវគ្គបទគម្ពីរមួយ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២៥–២៩

*យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ឃើញការនិមិត្តអំពីការធ្លាក់នៃសាតាំង*

សូមធ្វើលំហាត់ខាងក្រោមនេះ ដោយសរសេរថាពិត ( ព ) ឬ មិនពិត ( ម ) ។

____១. សាតាំងត្រូវបានស្គាល់ថាជា លូស៊ីហ្វើរ ។

____២. សាតាំងគឺជាវិញ្ញាណមួយ ដែលមានសិទ្ធិអំណាចនៅក្នុងវត្តមាននៃព្រះ ។

____៣. សាតាំងពុំមានចេតនាបះបោរនឹងព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទនោះទេ ។

____៤. មានការអរសប្បាយនៅឯស្ថានសួគ៌ កាលសាតាំងត្រូវបានទម្លាក់ចុះ ។

____៥. សាតាំងបានធ្វើសង្គ្រាមជាមួយនឹងពួកបរិសុទ្ធនៃព្រះ ។

បន្ទាប់ពីអ្នកបានធ្វើលំហាត់នេះហើយ សូមរំឭក គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២៥–២៩ ដែលពិពណ៌នាអំពីការនិមិត្ត របស់ព្យាការី យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន អំពីការធ្លាក់ចុះរបស់សាតាំង ។ សូមកែចម្លើយរបស់អ្នកឲ្យស្របទៅតាមអ្វីដែល អ្នកបានអាន រួចសូមផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក ជាមួយនឹងចម្លើយដែលមាននៅចុងបញ្ចប់នៃមេរៀននេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៣០–៤៩

*យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន ឃើញការនិមិត្តអំពីសេចក្ដីទុក្ខលំបាកនៃកូនអន្តរធាន*

នៅពេលធ្វើសង្គ្រាម តើជនក្បត់គឺជានរណា ? គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៣០–៤៩ គឺសំដៅទៅលើបុគ្គលទាំងឡាយ ដែលជ្រើសរើសធ្វើជាជនក្បត់នឹងព្រះអង្គសង្គ្រោះ ។ បុគ្គលទាំងនេះត្រូវបានស្គាល់ថា ពួកកូនអន្តរធាន ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៣០–៣៥ ដោយស្វែងរកជម្រើស ដែលដឹកនាំបុគ្គលទាំងឡាយឲ្យក្លាយទៅជាពួកកូនអន្តរធាន ។

ពួកកូនអន្តរធានមានសភាពខុសគ្នាពីសមាជិកសាសនាចក្រ ដែលធ្លាប់តែមានទីបន្ទាល់អំពីសេចក្ដីពិត ប៉ុន្តែ ក្រោយមកបានបែក ចេញឆ្ងាយពីសកម្មភាព និង ការធ្វើតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ ពួកកូនអន្តរធាន បានប្រព្រឹត្តអំពើបាបដែល មិនអាចលើកលែងឲ្យបាន គឺការបដិសេធព្រះវិញ្ញាណបរិសុទ្ធ ។



ព្យាការី យ៉ូសែប ស៊្មីធ បានបង្រៀនអំពី អំពើបាបដែលមិនអាចលើកលែងឲ្យបានដូចតទៅនេះ ៖ « តើមនុស្សម្នាក់ប្រព្រឹត្តអំពើដូចម្ដេច ទើបចាត់ទុកថាបានប្រព្រឹត្តអំពើបាបដែលមិនអាចលើកលែងឲ្យ បាន ? គាត់ត្រូវតែទទួលព្រះវិញ្ញាណបរិសុទ្ធ បានឲ្យស្ថានសួគ៌បើកចំហរដល់គាត់ ហើយស្គាល់ព្រះ ហើយបន្ទាប់មកបានធ្វើអំពើបាប ។ ក្រោយពីមនុស្សម្នាក់បានធ្វើអំពើបាបប្រឆាំងនឹងព្រះវិញ្ញាណ បរិសុទ្ធ នោះគ្មានការប្រែចិត្តសម្រាប់គេទេ ។ គាត់ត្រូវតែជាម្នាក់ដែលពោលថា ព្រះអាទិត្យពុំរះសោះ ខណៈដែលគាត់មើលឃើញព្រះអាទិត្យ ហើយបដិសេធព្រះយេស៊ូវគ្រីស្ទកាលស្ថានសួគ៌បានបើកចំហ នៅចំពោះមុខគាត់ ហើយបដិសេធផែនការនៃសេចក្ដីសង្គ្រោះដែលភ្នែករបស់គាត់មើលឃើញសេចក្ដីពិតស្រាប់ទៅហើយ នោះ » ( នៅក្នុង *History of the Church* ៦:៣១៤ ) ។

ការប្រព្រឹត្តអំពើបាបដែលមិនអាចលើកលែងឲ្យបាន តម្រូវឲ្យមានការចេះដឹងពិសេសមួយអំពីព្រះអង្គសង្គ្រោះ ដែលត្រូវបាន បង្កើនតាមរយៈបទពិសោធន៍ដ៏ពិសិដ្ឋជាមួយទ្រង់ ។ ប្រធាន ស្ពែនស៊ើរ ដបុលយូ឵ ឃឹមបឹល បានជួយយើងឲ្យយល់អំពីអត្ថន័យ នៃការណ៍នេះ ចំពោះសមាជិកសាសនាចក្រភាគច្រើន ៖ « អំពើបាបទទឹងនឹងព្រះវិញ្ញាណបរិសុទ្ធ តម្រូវឲ្យមានចំណេះដឹង បែបនោះ ដែលវាមិនអាចទៅរួចឡើយ ដែលក្រុមមនុស្សលោកយើងអាចនឹងប្រព្រឹត្តបាបប្រភេទនេះបាន » ( *The Miracle of Forgiveness* [ ឆ្នាំ ១៩៦៩ ] ទំព័រ ១២៣ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៣៦–៣៨, ៤៤–៤៩ ដោយស្វែងរកស្ថានភាពរបស់ពួកកូនអន្តរធាន ។

ពួកកូនអន្តរធាន នឹងមិនត្រូវបានប្រោសលោះពីសេចក្ដីស្លាប់ខាងវិញ្ញាណ ឬ សេចក្ដីស្លាប់ជាលើកទីពីរឡើយ ហើយនឹងមិនស្នង នគរនៃសិរីល្អទុកជាមរតក បន្ទាប់ពីពួកគេបានរស់ឡើងវិញនោះដែរ ។ ផ្ទុយទៅវិញ ពួកវានឹងរងទុក្ខដ៏នៅអស់កល្បជានិច្ច ។

ពេលកំពុងទទួលបានការនិមិត្តអំពីពួកកូនអន្តរធាន នោះព្យាការី យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន បានរៀនអំពីគោលការណ៍ មួយនៃសេចក្ដីសង្ឃឹម ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៣៩–៤៣ ដោយស្វែងរកពាក្យ ឬ ឃ្លាដែលបង្រៀន គោលការណ៍ដូចតទៅនេះ ៖ **តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ កូនចៅទាំងអស់របស់ព្រះ លើកលែងតែពួកកូនអន្តរធាន អាចត្រូវបានសង្គ្រោះចេញពីអំពើបាបផង និង សេចក្ដីស្លាប់ផង ។**

### ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៤០–៤១

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៤០–៤១ ។ ដោយសារតែវគ្គបទគម្ពីរនេះ គឺជាចំណេះចំណានខគម្ពីរ អ្នកអាច នឹងចង់គូសចំណាំវានៅក្នុងរបៀបមួយ ដែលជួយអ្នកអាចងាយរកវាឃើញនៅពេលខាងមុខ ។ ពាក្យ *ដំណឹងល្អ* មានន័យថា ដំណឹងល្អដ៏ប្រពៃ ។

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីការសង្ខេបមួយនៃដំណឹងដ៏ប្រពៃដែល ត្រូវបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៤០–៤១ ។ រួចសរសេរពីរបីប្រយោគ ដែលពិពណ៌នា អំពីមូលហេតុដែលនេះគឺជាដំណឹងដ៏ប្រពៃចំពោះអ្នក ។ អ្នកអាចនឹងចង់សរសេរវគ្គបទគម្ពីរនេះ ហើយបិទវានៅ កន្លែងដែលអ្នកអាចទន្ទេញវាបាន នៅប៉ុន្មានថ្ងៃក្រោយមកទៀត ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១–៤៩ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

ចម្លើយចំពោះលំហាត់ ពិត–មិនពិត ៖

សេចក្ដីថ្លែងការណ៍ទី ១ ពិត ( សូមមើល គ. និង ស. ៧៦:២៦, ២៨ ) ។

សេចក្ដីថ្លែងការណ៍ទី ២ ក៏ពិតដែរ ( សូមមើល គ. និង ស. ៧៦:២៥–២៧ ) ។ ឈ្មោះ លូស៊ីហ្វើរ មានន័យថា អ្នកនាំពន្លឺ ឬ អ្នកមានពន្លឺ ។ លូស៊ីហ្វើរ គឺជា « បុត្រានៃពេលព្រឹក » ដែលប្រាប់ថា « វាគឺជាកូនវិញ្ញាណមួយក្នុងចំណោមកូនវិញ្ញាណ ដែលបានកើតមុនគេរបស់ព្រះវរបិតា » ( Bruce R. McConkie, *Mormon Doctrine* ការបោះពុម្ពលើកទី ២ [ ឆ្នាំ ១៩៦៦ ] ទំព័រ ៧៤៤ ) ។

សេចក្ដីថ្លែងការណ៍ទី ៣ មិនពិត ( សូមមើល គ. និង ស. ៧៦:២៥, ២៨ ) ។ សាតាំងបានព្យាយាមទម្លាក់រាជ្យព្រះវរបិតាសួគ៌ ហើយយកព្រះចេស្ដា នគរ និង សិរីល្អរបស់ទ្រង់ ។ **នៅក្នុងជីវិតមុនផែនដី លូស៊ីហ្វើរ បានបះបោរទាស់នឹងព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ហើយត្រូវបានបណ្ដេញចេញ ។**

សេចក្ដីថ្លែងការណ៍ទី ៤ ក៏មិនពិតដែរ ( សូមមើល គ. និង ស. ៧៦:២៦ ) ។ ស្ថានសួគ៌បានយំដោយសារបាត់បង់លូស៊ីហ្វើរ ហើយវាត្រូវបានហៅថា កូនអន្តរធាន ដែលមានន័យថា បំផ្លិចបំផ្លាញ ឬ ហិនវិនាស ។

សេចក្ដីថ្លែងការណ៍ទី ៥ ពិត ( សូមមើល គ. និង ស. ៧៦:២៩ ) ។ សូមគិតអំពីការគូសចំណាំឃ្លានៅក្នុង ខទី ២៩ ដែលបង្រៀនថា **សាតាំងធ្វើសង្គ្រាមជាមួយពួកបរិសុទ្ធនៃព្រះ ។** សូមពិចារណាអំពីរបៀបដែលអ្នកធ្លាប់បានឃើញ សាតាំងចាប់ផ្ដើមធ្វើសង្គ្រាមទាស់នឹងពួកបរិសុទ្ធនៃព្រះ នាពេលសព្វថ្ងៃនេះ ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០–៨០

## សេចក្ដីផ្ដើម

បន្ទាប់ពីបានឃើញការនិមិត្តអំពីសិរីល្អនៃបុត្រា ការធ្លាក់របស់ លូស៊ីហ្វើរ និង ស្ថានភាពនៃពួកកូនអន្តរធាន នោះព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានឃើញមនុស្សទាំងឡាយដែលនឹងចេញមកក្នុងដំណើររស់ឡើងវិញនៃមនុស្សសុចរិត ៖ បណ្ដាជននៃនគរសេឡេស្ទាល និង ទេវសេទ្រាល ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០–៧០

*ព្រះអម្ចាស់បើកសម្ដែងលក្ខខណ្ឌ និង ពរជ័យទាំងឡាយនៃការទទួលបានសិរីល្អខាងសេឡេស្ទាល*

ពេលកំពុងបកប្រែព្រះគម្ពីរប៊ីបនៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៨៣២ ព្យាការី យ៉ូសែប ស្ម៊ីធ បានធ្វើការកែប្រែដ៏បំផុសគំនិតទៅលើពាក្យពេចន៍នៃ យ៉ូហាន ៥:២៩ ដែលប្រាប់អំពីការរស់ឡើងវិញនៃមនុស្សសុចរិត និង មនុស្សឥតសុចរិត ( សូមមើល គ. និង ស. ៧៦:១៥–១៧ ) ។ លោក និង ស៊ីឌនី រិកដុន បានពិចារណាលើការពិពណ៌នាអំពីការរស់ឡើងវិញនៃមនុស្សសុចរិត និង ការរស់ឡើងវិញនៃមនុស្សឥតសុចរិត នៅពេលពួកលោកទទួលបានវិវរណៈដែលមានបញ្ចូលនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០ ដោយស្វែងរកមនុស្សប្រភេទណា ដែល យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានឃើញបន្ទាប់ពីវិវរណៈនៃពួកកូនអន្តរធាន ។ ( នៅពេលអ្នកអាន វាអាចនឹងផ្ដល់អត្ថប្រយោជន៍ដែលត្រូវដឹងថា នៅក្នុងខគម្ពីរនេះ ពាក្យ *សុចរិត* មានន័យថា មនុស្សសុចរិត ។ អ្នកអាចនឹងចង់សរសេរនិយមន័យនេះនៅលើគែមព្រះគម្ពីររបស់អ្នកក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០ ) ។



បន្ទប់ដែលការនិមិត្ត ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ត្រូវបានទទួល ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៧០ រួចគូសចំណាំប្រភេទមនុស្សដែលនៅក្នុងក្រុមទីមួយ ដែល យ៉ូសែប និង ស៊ីឌនី បានឃើញ ដែលនឹងរស់ឡើងវិញនៅអំឡុងពេលនៃការរស់ឡើងវិញនៃមនុស្សសុចរិត ។ ជាផ្នែកមួយនៃការនិមិត្តនេះ ព្រះអម្ចាស់បានបើកសម្ដែងលក្ខខណ្ឌនៃអស់អ្នកដែលនឹងគ្រងនគរសេឡេស្ទាល ។

១. សូមសរសេរចំណងជើងថា *ការក្លាយទៅជាអ្នកគ្រងនគរសេឡេស្ទាល* នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥១–៥៣ រួចរាយនៅក្រោមចំណងជើងដែលបានសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីលក្ខខណ្ឌដែលបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ ចំពោះអ្នកដែលនឹងគ្រងនគរសេឡេស្ទាល ។ សូមព្យាយាមស្វែងរកឲ្យបានយ៉ាងហោចណាស់លក្ខខណ្ឌចំនួនបួន ។

ដើម្បីជួយអ្នកឲ្យយល់កាន់តែច្បាស់ អំពីឃ្លាមួយចំនួនដែលអ្នករកឃើញ នោះវាអាចនឹងមានប្រយោជន៍ ដែលត្រូវដឹងថា « [ ទទួល ] ទីបន្ទាល់ពីព្រះយេស៊ូវ » ( គ. និង ស. ៧៦:៥១ ) គឺទទួលបានទីបន្ទាល់មួយ តាមរយៈវិវរណៈផ្ទាល់ខ្លួនដែលថាព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះ ហើយត្រូវប្រព្រឹត្តឲ្យស្របទៅតាមទីបន្ទាល់នោះនៅក្នុងជីវិតរបស់អ្នក ។

*បញ្ជីទាំងឡាយនៃបទគម្ពីរ*

ជាញឹកញាប់បទគម្ពីរ មានទូវបញ្ជីនៃរឿងដូចជា ការណែនាំ ឬការព្រមាន ។ នៅពេលអ្នករកឃើញបញ្ជីទាំងឡាយ សូមពិចារណាអំពីការដាក់លេខលើលក្ខខណ្ឌនីមួយៗ ។

« ឈ្នះដោយសារសេចក្ដីជំនឿ » ( គ. និង ស. ៧៦:៥៣ ) គឺឈ្នះលើការល្បួង និង អំពើបាបទាំងឡាយ ដោយការអនុវត្ត សេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ ។ បុគ្គលម្នាក់ « ត្រូវបានភ្ជាប់ដោយសារព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា » ( គ. និង ស. ៧៦:៥៣ សូមមើលផងដែរ គ. និង ស. ១៣២:៧) នៅពេលព្រះវិញ្ញាណបរិសុទ្ធបញ្ជាក់ថា ពិធីបរិសុទ្ធទាំងឡាយនៃបព្វជិតភាពត្រូវបានទទួល ហើយសេចក្ដីសញ្ញាដែលបានធ្វើឡើងនោះ ត្រូវបានទទួលស្គាល់ដោយព្រះ ។ ការអនុមតិនេះអាស្រ័យលើភាពស្មោះត្រង់របស់បុគ្គលម្នាក់ ។

២. ដើម្បីជួយអ្នកឲ្យយល់កាន់តែច្បាស់អំពីបុគ្គលដែលគ្រងនគរសេឡេស្ទាល សូមឆ្លើយសំណួរខាងក្រោមនេះចំនួនពីរ ឬ ច្រើនជាងនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកធ្លាប់បានធ្វើដូចម្ដេច ដើម្បីទទួលបានទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ ហើយរក្សាទីបន្ទាល់នោះឲ្យរឹងមាំ ?

ខ. តើអ្នកអាចធ្វើដូចម្ដេច ដើម្បីទទួលបានទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទឲ្យបានកាន់តែច្រើន ?

គ. តើការទទួលបានទីបន្ទាល់នៃព្រះយេស៊ូវគ្រីស្ទ និង ការរក្សាព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ជួយមនុស្សម្នាក់ឲ្យប្រែក្លាយកាន់តែសក្តិសម ដើម្បីគ្រងនគរនគរសេឡេស្ទាលតាមរបៀបណា ?



បន្ថែមពីលើការបើកសម្ដែងលក្ខខណ្ឌមួយចំនួនទាំងនេះ អំពីអ្នកដែលនឹងគ្រងនគរសេឡេស្ទាល នោះព្រះអម្ចាស់បានបន្តពិពណ៌នាអំពីពរជ័យមួយចំនួន ដែលបណ្ដាជននៃនគរសេឡេស្ទាលនឹងទទួលបាន ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥៤–៦៨ ហើយស្វែងរកពរជ័យទាំងនេះ ។ សូមពិចារណាអំពីការគូសចំណាំពរជ័យទាំងឡាយណា ដែលមានន័យជាពិសេសចំពោះអ្នក ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៦៩–៧០ ដោយស្វែងរកអ្វីដែលកើតឡើងចំពោះ អ្នកដែលសក្តិសមគ្រងនគរសេឡេស្ទាល ។ នៅពេលអ្នកអាន វាអាចនឹងផ្ដល់អត្ថប្រយោជន៍ដែលត្រូវដឹងថាពាក្យ *ល្អឥតខ្ចោះ* នៅក្នុង ខទី ៦៩ ពុំមានន័យថា មិនមានកន្លែងខុសនោះទេ ប៉ុន្តែ វាមានន័យថា ពេញលេញ ។ ( ម៉ាថាយ ៥:៤៨ លេខយោង *ខ* ពន្យល់ថា ការបកប្រែពីភាសាក្រិកមានន័យថា « ពេញលេញ បញ្ចប់ រីកចម្រើនពេញលេញ » ) ។

ទោះជាពេលដែលយើងប្រឹងប្រែងដោយអស់ពីសមត្ថភាព ដើម្បីរក្សាព្រះបញ្ញត្តិទាំងឡាយមិនធ្វើឲ្យយើងបានល្អឥតខ្ចោះ យ៉ាងណាក្តី ក៏ការប្រឹងប្រែងរបស់យើង ធ្វើឲ្យយើងអាចទទួលបានព្រះគុណរបស់ព្រះអង្គសង្គ្រោះ ហើយបានស្អាតស្អំដោយ « ដង្វាយធួនដ៏ល្អឥតខ្ចោះ តាមរយៈការច្រួចព្រះលោហិតរបស់ព្រះអង្គទ្រង់ » ផ្ទាល់ដែរ (គ. និង ស. ៧៦:៦៩ ) ។ យើងម្នាក់ៗអាចធ្វើឲ្យបានល្អឥតខ្ចោះ តាមរយៈព្រះយេស៊ូវគ្រីស្ទ និង ត្រូវបានតម្កើងឡើងជាមួយក្រុមគ្រួសារនៅក្នុងកម្រិតខ្ពស់ជាងគេនៃនគរសេឡេស្ទាល ( សូមមើល មរ៉ូណៃ ១០:៣២–៣៣ ) ។ សេចក្ដីពិតនេះអាចលើកទឹកចិត្តយើង ឲ្យរក្សាព្រះបញ្ញត្តិ ហើយទទួលបានពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ ដើម្បីយើងអាចទទួលបានពរជ័យដ៏មហិមាទាំងនេះ ។ ដូច្នេះ **យើងអាចធ្វើឲ្យបានល្អឥតខ្ចោះ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។** អ្នកអាចនឹងចង់សរសេរគោលការណ៍នេះនៅក្រោម ចំណងជើង « ការក្លាយទៅជាអ្នកគ្រងនគរសេឡេស្ទាល » នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើគោលការណ៍ដែលបានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៦៩–៧០ ពង្រឹងសេចក្ដីជំនឿរបស់អ្នក ហើយបំផុសអ្នកឲ្យស្វែងរកភាពតម្កើងឡើងនៅក្នុងនគរសេឡេស្ទាលយ៉ាងដូចម្ដេច ?

ខ. តើគោលការណ៍ទាំងឡាយដែលបានបង្រៀននៅក្នុងខគម្ពីរទាំងនេះ ជួយយើងឲ្យយកឈ្នះលើការបាក់ទឹកចិត្តពេលយើងពុះពារឲ្យបានសិរីល្អសេឡេស្ទាលយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៧១–៨០

*យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានឃើញការនិមិត្តអំពីនគរទេរេសស្ទ្រាល*

ប្រសិនបើអ្នកត្រូវសួរមិត្តភក្តិរបស់អ្នក ថាតើពួកគេជឿថាពួកគេអាចគ្រងនគរសេឡេស្ទាល—ដើម្បីត្រឡប់ទៅរស់នៅដ៏អស់កល្បជានិច្ចជាមួយព្រះវរបិតាសួគ៌ជាមួយក្រុមគ្រួសាររបស់ពួកគេ—តើអ្នកគិតថា ពួកគេប៉ុន្មាននាក់ដែលនឹងនិយាយថា ពួកគេជឿថាពួកគេអាច ? តើអ្នកជឿថា *អ្នក* អាចគ្រងនគរសេឡេស្ទាលបានយ៉ាងដូចម្ដេច ?

ប៊ីស្សព យ៉ូសែប អិល វើតលីន ក្នុងគណៈប៊ីស្សពជាអធិបតី បានថ្លែងទីបន្ទាល់ថា « យើងទាំងអស់គ្នា គឺជាអ្នកដែលនឹងចូលទៅក្នុងនគរសេឡេស្ទាល » ( នៅក្នុងរបាយការណ៍សន្និសីទ ខែ មេសា ឆ្នាំ ១៩៥២ ទំព័រ ១១៨ ) ។ អ្នកអាចនឹងចង់សរសេរសេចក្ដីថ្លែងការណ៍នេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ឬ នៅលើគែមនៃព្រះគម្ពីររបស់អ្នក ។

ទោះជាមនុស្សទាំងអស់គឺជាអ្នកដែលនឹងចូលទៅក្នុងនគរសេឡេស្ទាលក្ដី ក៏មនុស្សមួយចំនួនជ្រើសរើសមិនរស់នៅតាមសក្ដានុពលរបស់ខ្លួនដែរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៧១ រួចគូសចំណាំអ្វីដែលព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានឃើញក្រោយមកទៀតក្នុងការនិមិត្ត ។

សូមកត់ចំណាំអំពីរបៀបដែលបទគម្ពីរទាំងនេះ ប្រើប្រាស់ភាពខុសគ្នារវាងពន្លឺដែលចាំងឆ្លុះពីព្រះចន្ទ និង ពន្លឺដែលជះចេញដោយផ្ទាល់ពីព្រះអាទិត្យ ដើម្បីតំណាងឲ្យភាពខុសគ្នារវាងសិរីល្អនៃនគរទេរេសទ្រាល និង សេឡេស្ទាល ។ ទន្ទឹមនឹងពេលដែលបណ្ដាជននៃនគរសេឡេស្ទាល និង ទេរេសទ្រាល ទាំងពីរត្រូវបានបញ្ចូលទៅក្នុងការរស់ឡើងវិញនៃមនុស្សសុចរិត នោះអ្នកដែលនឹងទទួលបានរូបកាយសេឡេស្ទាល ក៏នឹងរស់ឡើងវិញដោយមានសិរីល្អ និង ពរជ័យកាន់តែប្រសើរជាង អ្នកដែលនឹងទទួលបានរូបកាយខាងទេរេសទ្រាលដែរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៧២–៨០ ដោយស្វែងរកកត្តាដែលបណ្ដាជននៃនគរទេរេសទ្រាល មានសភាពខុសគ្នាពីបណ្ដាជននៃនគរសេឡេស្ទាល ។

សូមរំឭក គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៧១–៧៩ រួចគូសចំណាំអ្វីដែលអ្នករកឃើញអំពី អ្នកដែលនឹងគ្រងនគរទេរេសទ្រាល ។ « ចូរចងចាំថាមានតែព្រះទ្រង់មួយអង្គគត់ ជាព្រះដែលជ្រាបពីដួងចិត្តនៃបុគ្គលម្នាក់ៗ ទើបអាចជំនុំជម្រះដល់បុគ្គលទាំងអស់បាន ( សូមមើល វិវរណៈ ២០:១២; នីហ្វៃទី៣ ២៧:១៤; គ. និង ស. ១៣៧:៩ ) » (*ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* [ឆ្នាំ ២០០៤] ទំព័រ ៩០ ) ។ មានតែព្រះអម្ចាស់ទេ ដែលអាចជ្រាបអំពីដួងចិត្តរបស់យើងបាន ដូច្នេះ យើងគួរតែប្រយ័ត្នដោយមិនវិនិច្ឆ័យលើនគរណាមួយ ដែលយើងជឿថាមនុស្សដទៃនឹងគ្រង ។

៤. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើមនុស្សមួយចំនួនសព្វថ្ងៃនេះ កំពុងត្រូវបានបំភាន់ដោយកលល្បិចនៃមនុស្សយ៉ាងដូចម្ដេច ?

ភាពខុសគ្នាដ៏គួរឲ្យកត់សម្គាល់មួយរវាង មនុស្សដែលនឹងគ្រងនគរសេឡេស្ទាល និង មនុស្សដែលនឹងគ្រងនគរទេរេសទ្រាល គឺជាអ្វីដែលពួកគេប្រព្រឹត្តចំពោះទីបន្ទាល់របស់ខ្លួនអំពីព្រះយេស៊ូវគ្រីស្ទ ។ មនុស្សដែលគ្រងនគរទេរេសទ្រាល « ពុំក្លាហានក្នុងទីបន្ទាល់ពីព្រះយេស៊ូវ » ឡើយ (គ. និង ស. ៧៦:៧៩ ) ។ អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ ៖



« តើភាពក្លាហានក្នុងទីបន្ទាល់ពីព្រះយេស៊ូវ មានន័យដូចម្ដេច ?

« វាតម្រូវឲ្យមានភាពអង់អាច និង មោះមុត ដើម្បីប្រើភាពខ្លាំង ថាមពល និង សមត្ថភាពរបស់យើងនៅក្នុងចម្បាំងជាមួយលោកិយ ដើម្បីច្បាំងសម្រាប់សេចក្ដីល្អនៃសេចក្ដីជំនឿ ។. . . មូលដ្ឋានគ្រឹះដ៏ធំនៃភាពក្លាហាននៅក្នុងបុព្វហេតុនៃសុចរិតភាព គឺជាការគោរពប្រតិបត្តិចំពោះក្រឹត្យវិន័យទាំងអស់នៃដំណឹងល្អទាំងស្រុង ។. . .

« ដើម្បីមានភាពក្លាហាននៅក្នុងទីបន្ទាល់នៃដំណឹងល្អនៃព្រះយេស៊ូវ គឺត្រូវជឿលើព្រះយេស៊ូវគ្រីស្ទ និង ដំណឹងល្អរបស់ទ្រង់ ដោយមានជំនឿស៊ប់ដ៏ខ្ជាប់ខ្ជួន ។ វាតម្រូវឲ្យស្គាល់សច្ចភាព [ ភាពស្មោះត្រង់ ] និង ទេវភាពនៃកិច្ចការរបស់ព្រះអម្ចាស់នៅលើផែនដី ។

> « ប៉ុន្តែ វាពុំទាន់អស់នៅឡើយទេ ។ វាលើសពីការជឿ និង ការដឹងទៅទៀត ។ យើងត្រូវតែធ្វើជាអ្នករស់នៅតាមព្រះបន្ទូល ពុំមែនគ្រាន់តែជាអ្នកស្ដាប់នោះឡើយ ។ វាលើសពីការថាបម្រើតែមាត់ វាពុំមែនគ្រាន់តែជាការសារភាពតែនឹងមាត់ពីភាពជាព្រះរាជបុត្រារបស់ព្រះអង្គសង្គ្រោះប៉ុណ្ណោះទេ ។ វាគឺជាការគោរពប្រតិបត្តិ និង ការធ្វើតាមវិន័យ និងសេចក្ដីសុចរិតផ្ទាល់ខ្លួន ។. . .
>
> « ដើម្បីក្លាហាននៅក្នុងទីបន្ទាល់ពីព្រះយេស៊ូវគឺត្រូវ . . . ‹ កាន់ខ្ជាប់ជរាបដល់ចុងបំផុត › ។ (នីហ្វៃទី ២ ៣១:២០) ។ គឺត្រូវរស់នៅតាមសាសនារបស់យើង ដើម្បីអនុវត្តនូវអ្វីដែលយើងផ្សាយ ដើម្បីរក្សាបទបញ្ញត្តិទាំងឡាយ » (Be Valiant in the Fight of Faith, » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៧៤ ទំព័រ ៣៥ ) ។

យើងម្នាក់ៗមានសក្ដានុពលដើម្បីគ្រងនគរសេឡេស្ទាល តាមរយៈជម្រើសដែលយើងធ្វើ ។ ដូចបានបង្រៀននៅក្នុងបទគម្ពីរដែលអ្នកបានសិក្សានៅក្នុងមេរៀននេះថា **បើយើងមានភាពក្លាហានក្នុងទីបន្ទាល់ពីព្រះយេស៊ូវ នោះយើងអាចគ្រងនគរសេឡេស្ទាលនៃព្រះបាន ។** សូមសរសេរបញ្ចូលគោលការណ៍នេះ នៅពីក្រោមចំណងជើង « ការក្លាយទៅជាអ្នកគ្រងនគរសេឡេស្ទាល » នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

   ក. សូមគិតអំពីមនុស្សដែលអ្នកស្គាល់ ជាបុគ្គលដែលអ្នកចាត់ទុកថាមានភាពក្លាហានក្នុងទីបន្ទាល់នៃព្រះយេស៊ូវគ្រីស្ទ ។ តើលក្ខណៈសម្បត្តិ និង ទង្វើបែបណាខ្លះ ដែលបង្ហាញអំពីភាពក្លាហានរបស់គាត់ ?

   ខ. តើអ្វីបានជួយអ្នកឲ្យមានភាពក្លាហាន ក្នុងទីបន្ទាល់របស់អ្នកពីព្រះយេស៊ូវគ្រីស្ទ ?

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

   *ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៥០–៨០ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

   *សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៧ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–១១៩; ៧៧

### បុព្វកថា

មេរៀននេះពិភាក្សាអំពីការនិមិត្តអំពីនគរទេឡេស្ទាល ដែលបានបង្ហាញដល់ព្យាការី យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន ដូចបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ។ វិវរណៈនេះត្រូវបានប្រទានឲ្យនៅភូមិហៃរ៉ាំ រដ្ឋ អូហៃអូ នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៨៣២ ។ យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន បានពិពណ៌នាអំពីអ្វីដែលពួកលោកបានរៀនអំពីអ្នកទាំងឡាយ ដែលនឹងគ្រងនគរទេឡេស្ទាល និង អំពីលទ្ធផលនៃការបដិសេធទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ ។ ពួកលោកក៏បានពិពណ៌នាផងដែរ អំពីលក្ខណៈដែលនគរទេឡេស្ទាល មានសភាពខុសគ្នាពីនគរនៃសិរីល្អដទៃទៀត ហើយបានពន្យល់អំពីអ្វីដែលបុគ្គលទាំងឡាយអាចធ្វើ ដើម្បីសមនឹងឃើញ ហើយយល់ដោយខ្លួនគេផ្ទាល់ នូវអាថ៌កំបាំងនៃនគរព្រះ ។ ក្រោយមក ក្នុងខែ មិនា ឆ្នាំ ១៨៣២ យ៉ូសែប ស៊្មីធ បានកត់ត្រាចម្លើយរបស់ព្រះអម្ចាស់ ដែលឆ្លើយចំពោះសំណួររបស់លោកស្ដីពីព្រះគម្ពីរវិវរណៈ ។ វិវរណៈនេះ មានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៧៧ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–១១២

*ព្រះអម្ចាស់បង្ហាញដល់ យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន នូវការនិមិត្តមួយអំពីនគរទេឡេស្ទាល*

សូមស្រមៃថា អ្នកមានការពិភាក្សាអំពីសាសនាជាមួយមិត្តភក្ដិម្នាក់ ដែលជាសមាជិកមកពីនិកាយសាសនាគ្រិស្តមួយផ្សេងទៀត ។ មិត្តភក្ដិរបស់អ្នកវាចាថា « នៅឯព្រះវិហារកាលពីសប្ដាហ៍មុន គ្រូគង្វាលរបស់ខ្ញុំបានប្រាប់ពួកយើងថា បន្ទាប់ពីយើងស្លាប់ទៅ យើងអាចនឹងទៅស្ថានសួគ៌ផង ឬ ស្ថាននរកផង ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំពុំល្អគ្រប់គ្រាន់ដើម្បីទៅស្ថានសួគ៌នាពេលឥឡូវនេះទេ ប៉ុន្តែ ខ្ញុំក៏ពុំមានអារម្មណ៍ថា ខ្ញុំអាក្រក់ខ្លាំង ដែលនឹងធ្លាក់ទៅស្ថាននរកនោះដែរ ។ តើសាសនារបស់អ្នកបង្រៀនអ្វីខ្លះ អំពី ស្ថានសួគ៌ និង ស្ថាននរក » ?

សូមមើលទៅដ្យាក្រាម « គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ៖ សេចក្ដីណែនាំអំពីការនិមិត្ត » ចេញពីមេរៀនទី ១៦ ៖ ថ្ងៃទី ៣ មេរៀននៅក្នុងសៀវភៅសិក្សានេះ ។ សូមកត់ចំណាំថា នគរនៃសិរីល្អចុងក្រោយគេ ដែលព្យាការី យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន បានឃើញនៅក្នុងការនិមិត្តនោះ គឺជានគរទេឡេស្ទាល ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–៨៣, ១០៣ ដោយស្វែងរកពាក្យ និង ឃ្លាទាំងឡាយ ដែលពិពណ៌នាអំពីមនុស្សដែលនឹងគ្រងនគរទេឡេស្ទាល ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នករកឃើញ ។

> ***ការផ្ទុយ***
> ជាញឹកញាប់ បទគម្ពីរបង្ហាញអំពីការផ្ទុយគ្នារវាងគំនិត ព្រឹត្តការណ៍ និងមនុស្ស ។ ការផ្ទុយទាំងនេះ គូសបញ្ជាក់អំពីគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ សូមស្វែងរកមើលការផ្ទុយនៅក្នុងខគម្ពីរនីមួយៗ ក្នុងជំពូក និងជំពូកដែលទាក់ទងគ្នា និង គម្ពីរនានា ។ ឧទាហរណ៍ នៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៧៦ វិវរណៈធ្វើឲ្យមានការផ្ទុយរវាងពួកកូនអន្តរធាន និង អ្នកទាំងឡាយដែលមានគុណសម្បត្តិគ្រប់គ្រាន់នឹងគ្រងនគរនៃសិរីល្អ ។

នៅក្នុង ខទី ១០៣ *ពួកមន្តអាគម* គឺជាមនុស្សដែលព្យាយាមគ្រប់គ្រង ហើយប្រើប្រាស់អំណាចតាមរយៈជំនួយមកពីប្រភពដ៏អាក្រក់ ។ *ពួកកំផិត* គឺជាមនុស្សដែលចូលរួមក្នុងអំពើសាហាយស្មន់ និង អំពើបាបខាងផ្លូវភេទដទៃទៀត ។

លក្ខណៈមួយដែលកំណត់ថាតើនគរនៃសិរីល្អមួយណា ដែលបុគ្គលម្នាក់នឹងគ្រងនោះ គឺជារបៀបដែលបុគ្គលនោះប្រព្រឹត្តចំពោះដំណឹងល្អ និង ទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ ។ សូមអានសេចក្ដីយោងបទគម្ពីរ នៅក្នុងតារាងខាងក្រោមនេះ ។ នៅក្នុងចន្លោះដែលមាន សូមពិពណ៌នាអំពីរបៀបដែលបណ្ដាជនដែលនឹងគ្រងនគរទាំងនេះ ប្រព្រឹត្តចំពោះដំណឹងល្អ និង ទីបន្ទាល់នៃព្រះយេស៊ូវគ្រីស្ទ ។

| នគរ | ការប្រព្រឹត្តចំពោះដំណឹងល្អ និង ទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ |
|---|---|
| សេឡេស្ទាល ( គ. និង ស. ៧៦:៥០–៥១ ) | |
| ទេរេសទ្រាល ( គ. និង ស. ៧៦:៧៤, ៧៩ ) | |
| ទេឡេស្ទាល ( គ. និង ស. ៧៦:៨២, ១០១ ) | |

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកព្យាយាមពង្រឹងទីបន្ទាល់របស់អ្នកពីព្រះយេស៊ូវគ្រីស្ទ តាមរបៀបណាខ្លះ ?

ខ. តើអ្នកគិតថា ហេតុអ្វីបានជាការប្រព្រឹត្តរបស់បុគ្គលម្នាក់ចំពោះដំណឹងល្អ និង ទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ ជះឥទ្ធិពលយ៉ាងសំខាន់ទៅលើនគរ ដែលគេនឹងគ្រង ?

គ. តើអ្នកអាចមានភាពក្លាហាន ក្នុងទីបន្ទាល់របស់អ្នកពីព្រះយេស៊ូវគ្រីស្ទបានយ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨៤–៨៥, ១០៤–៦ រួចគូសចំណាំឃ្លា ដែលបង្រៀនអំពីសេចក្ដីពិតដូចតទៅនេះ ៖ **អ្នកដែលនឹងគ្រងនគរទេឡេស្ទាល ត្រូវតែរងទុក្ខក្នុងស្ថាននរកពីមុនពួកគេនឹងត្រូវបានប្រោសលោះដោយព្រះអង្គសង្គ្រោះ ។**

វាមានប្រយោជន៍ក្នុងការដឹងថា បទគម្ពីរនេះប្រើពាក្យសព្ទ *ស្ថាននរក* យ៉ាងហោចណាស់តាមពីរ របៀប ។ ទីមួយ ស្ថាននរកគឺជាផ្នែកនៃពិភពវិញ្ញាណដែលបានគ្រងដោយពួកទុច្ចរិត ហើយគឺជាការពិតមួយ ប៉ុន្តែ ជាស្ថានភាពបណ្ដោះអាសន្ននៃទណ្ឌកម្ម និង ការរងទុក្ខខាងវិញ្ញាណ ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨៤–៨៥, ១០៤–៦ ) ។ « ភ្លើងឆេះដ៏អស់កល្បជានិច្ច » គឺជាសំនួនវោហារ ដែលសំដៅទៅលើទារុណកម្មដ៏សែនឈឺចាប់ និង ការរងទុក្ខដែលនឹងកើតឡើងនៅឯស្ថាននរក ។ ទីពីរ ពេលខ្លះបទគម្ពីរប្រើពាក្យ *ស្ថាននរក* ដើម្បីសំដៅទៅលើទីងងឹតខាងក្រៅ ដែលពេលខ្លះសំដៅទៅលើស្ថានភាពជាអចិន្ត្រៃយ៍នៃទារុណកម្ម និង ការរងទុក្ខ ដែលបន្តចំពោះពួកកូនអន្តរធានបន្ទាប់ពីពួកគេបានរស់ឡើងវិញ ហើយត្រូវបានជំនុំជម្រះ ក៏ដូចជាសាតាំង និង ពួកអ្នកដើរតាមទាំងឡាយរបស់វាចេញពីជីវិតមុនផែនដីមកដែរ ។ ( សូមមើល Bible Dictionary, Hell » សេចក្ដីណែនាំដល់ព្រះគម្ពីរ Hell » scriptures.lds.org) ។

អែលឌើរ ជេម អ៊ី ថាលម៉េហ្គ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនអំពីស្ថាននរកដូចតទៅថា ៖



« នៅស្ថាននរក មានច្រកចេញមួយក៏ដូចជាច្រកចូលមួយដែរ ។. . . វាគឺជាកន្លែងដែលបានរៀបចំសម្រាប់ការបង្រៀន ការលុតដំបំពោះអ្នកដែលមិនបានរៀនកាលនៅលើផែនដីនេះ នូវអ្វីដែលពួកគេគួរតែរៀន » ( នៅក្នុង របាយការណ៍សន្និសីទទូទៅ ខែ មេសា ឆ្នាំ ១៩៣០ ទំព័រ ៩៧ ) ។

« ចំពោះរយៈពេលនៃទារុណកម្ម យើងអាចនឹងអះអាងថា វានឹងត្រូវបានកំណត់ដោយយោងទៅតាមអំពើបាបនោះ ហើយដែលថា ការលើកលែងទោសចំពោះអំពើបាបនឹងមានជាដរាប [ គ្មានទីបញ្ចប់ ] នោះ គឺជាគំនិតខុសឆ្គង [ សូមមើល គ. និង ស. ១៩:៦–១២; ៧៦:៣៦, ៤៤ ] ។ ទោះជាលទ្ធផលនៃទង្វើក្នុងជីវិតលើផែនដីនេះ មានឥទ្ធិពលលើជីវិតបន្ទាប់ពីស្លាប់ក្ដី និង ទោះជាយើងនឹងត្រូវទទួលខុសត្រូវលើការមិនប្រែចិត្តក្ដី ក៏ព្រះនៅតែមានព្រះចេស្ដាដើម្បីអត់ទោសបន្ទាប់ពីបានស្លាប់ហើយទៅដែរ ។ ទោះជាយ៉ាងណាក៏ដោយ បទគម្ពីរថ្លែងប្រាប់អំពីទោសដ៏នៅអស់កល្បជានិច្ច និង ដ៏មិនចេះចប់មិនចេះហើយ ។ ទោសដែលមកពីព្រះគឺអស់កល្បជានិច្ច ដ្បិតទ្រង់ជាអង្គអស់កល្បជានិច្ច [ សូមមើល គ. និង ស. ១៩:១០–១២ ] ។ ទោសរបស់ទ្រង់គឺជាទារុណកម្មដ៏មិនចេះចប់មិនចេះហើយ ដ្បិតវានឹងកើតឡើងជានិច្ច ជាទីកន្លែង ឬ ស្ថានភាពដែលបានរៀបចំសម្រាប់វិញ្ញាណដែលមិនគោរពប្រតិបត្តិ ប៉ុន្តែ ការរងទុក្ខនៃការផ្ដន្ទាទោសនោះ នឹងមានទីបញ្ចប់ក្នុងគ្រប់ករណីនៃការប្រែចិត្ត និង សំណងដែលអាចទទួលយកបាន » (*The Articles of Faith*, 12th ed. [ ឆ្នាំ ១៩២៤ ] ទំព័រ ៦០–៦១ ) ។

តើឃ្លាណាខ្លះ ចេញមកពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨៥, ១០៦ ដែលបង្រៀនថា ស្ថាននរកនឹងជាស្ថានភាពបណ្ដោះអាសន្នមួយ សម្រាប់អ្នកទាំងឡាយដែលនឹងគ្រងនគរទេឡេស្ទាល ?



ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានពន្យល់អំពីលទ្ធផលនៃការរងទុក្ខនៅឯស្ថាននរក ចំពោះអ្នកដែលនឹងគ្រងនគរទេឡេស្ទាលថា ៖ « ការរងទុក្ខនេះនឹងក្លាយទៅជាវិធីមួយដើម្បីសម្អាត ឬ បន្សុទ្ធ ហើយតាមរយៈការបន្សុទ្ធនេះ ពួកទុច្ចរិតនឹងត្រូវបាននាំទៅឯស្ថានភាពមួយ ដែលពួកគេអាចទទួលបានអមតភាព តាមរយៈការប្រោសលោះនៃព្រះយេស៊ូវគ្រីស្ទ ។ វិញ្ញាណ និង រូបកាយរបស់ពួកគេនឹងត្រូវបានផ្គុំគ្នាសាជាថ្មី ហើយពួកគេនឹងរស់នៅក្នុងនគរទេឡេស្ទាល ។ ប៉ុន្តែការរស់ឡើងវិញនឹងពុំកើតឡើងឡើយរហូតដល់ចុងបំផុតនៃពិភពលោក » (*Doctrines of Salvation,* comp . Bruce R. McConkie វ៉ុល៣. [១៩៥៤–៥៦] ២:២៩៨ ) ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១០៦–៨ យើងស្វែងយល់ថា ពួកទុច្ចរិតនឹងរងទុក្ខចំពោះអំពើបាបរបស់ពួកគេ រហូតដល់ព្រះយេស៊ូវគ្រីស្ទ បញ្ចប់កិច្ចការរបស់ទ្រង់ ហើយលើកនគរនៃព្រះនៅលើផែនដីឡើងទៅថ្វាយព្រះបិតាទ្រង់ ដែលនឹងកើតឡើងនៅបន្ទាប់ពីសហស្សវត្សរ៍ ។ ពេលនោះ ព្រះគ្រីស្ទ នឹងត្រូវបំពាក់មកុដដោយសិរីល្អ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១១១ និង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:៩ ដោយស្វែងរកអ្វីដែលនឹងកំណត់អំពីនគរនៃសិរីល្អ ដែលពួកយើងនឹងគ្រងនោះ ។

គោលការណ៍មួយដែលយើងអាចរៀនចេញពីខគម្ពីរទាំងនេះគឺថា **នគរនៃសិរីល្អ ដែលយើងគ្រង នឹងត្រូវបានកំណត់ដោយកិច្ចការទាំងឡាយរបស់យើងនៅក្នុងជីវិតនេះ និង ដោយសេចក្ដីប៉ងប្រាថ្នានៃដួងចិត្តរបស់យើង ។**



សេចក្ដីថ្លែងការណ៍ដូចតទៅនេះដោយ អែលឌើរ រ័សុល អិម ណិលសុន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ អាចជួយអ្នកឲ្យយល់កាន់តែច្បាស់អំពីគោលការណ៍នេះ ៖ « បងប្អូនទាំងអស់គ្នានឹងត្រូវបានជំនុំជម្រះ ស្របទៅតាមកិច្ចការទាំងឡាយ និង សេចក្ដីប៉ងប្រាថ្នានៃដួងចិត្តរបស់បងប្អូន [ សូមមើល គ. និង ស. ១៣៧:៩ ] ។ បងប្អូននឹងមិនចាំបាច់សងបំណុល ជំនួសមនុស្សណាផ្សេងទៀតនោះទេ ។ ទីកន្លែងចុងក្រោយរបស់បងប្អូននៅក្នុងនគរសេឡេស្ទាល ទេរេសទ្រាល ឬ ទេឡេស្ទាល នឹងមិនត្រូវបានកំណត់ដោយយថាហេតុនោះទេ ។ ព្រះអម្ចាស់បានដាក់កម្រិតចំពោះ គុណសម្បត្តិទាំងឡាយដែលមិនអាចកែប្រែបានសម្រាប់យើងម្នាក់ៗហើយ ។ បងប្អូនអាចដឹងអំពីអ្វីដែលបទគម្ពីរបង្រៀន ហើយបត់បែនជីវិតរបស់បងប្អូនឲ្យស្របទៅតាមគុណសម្បត្តិទាំងនោះ [ សូមមើល យ៉ូហាន ១៤:២; កូរិនថូស ទី១ ១៥:៤០–៤១; គ. និង ស. ៧៦:៥០–១១៩; ៨៨:១៨ ] » (Constancy amid Change » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ទំព័រ ៣៥ ) ។

២. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការយល់ដឹងអំពីគោលការណ៍នេះ អាចមានឥទ្ធិពលលើជម្រើស ដែលអ្នកជ្រើសរើសយកនៅថ្ងៃនេះយ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨៦–៨៩, ៩៨, ១១២ ដោយស្វែងរកមើលពាក្យ ឬ ឃ្លាដែលពិពណ៌នាអំពីសភាពនៃអមតភាព ចំពោះអ្នកទាំងឡាយដែលគ្រងនគរទេឡេស្ទាល ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

នៅពេលព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានពិពណ៌នាអំពីបណ្ដាជននៃនគរទេឡេស្ទាល ពួកលោកបានសរសេរបញ្ចូលការបកស្រាយអំពីការប្រៀបធៀបរវាងនគរនៃសិរីល្អទាំងបីនេះ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៩១–៩៨ ដោយស្វែងរកថាតើនគរទាំងបីនេះ ប្រៀបធៀបចំពោះគ្នាយ៉ាងដូចម្ដេច ។

តើសិរីល្អនៃនគរសេឡេស្ទាល ខុសពីសិរីល្អនៃនគរទេរេទ្រាល និង ទេឡេស្ទាលយ៉ាងដូចម្ដេច ?

ភាពខុសគ្នានៃសិរីល្អរវាងនគរសេឡេស្ទាល ទេរេសទ្រាល និង ទេឡេស្ទាល អាចត្រូវបានបង្ហាញដោយភាពខុសគ្នានៃរស្មីព្រះអាទិត្យ ព្រះចន្ទ និង តារា ដែលមើលមកពីផែនដី ។ នៅពេលយើងមើលពីផែនដីទៅ តារាដែលចែងចាំងបំផុត ភ្លឺជាងតារាដែលស្រអាប់ប្រមាណជា ១០០ ដង ។ ព្រះចន្ទភ្លឺជាងតារាដែលចែងចាំងបំផុតនោះប្រមាណជា ៣០,០០០ ដង ។ ព្រះអាទិត្យភ្លឺជាងព្រះចន្ទពេញបរមីប្រមាណជា ៤០០,០០០ ដង ។ ភាពខុសគ្នាខាងរស្មីទាំងនេះ ជួយបង្ហាញអំពីភាពខុសគ្នាដែល យ៉ូសែប និង ស៊ីឌនី បានសង្កេតឃើញរវាងនគរនៃសិរីល្អទាំងនេះ ។ ដូចដែលអ្នកអាចឃើញចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៩៤–៩៥ ពរជ័យដែលបានទទួលដោយអ្នកទាំងឡាយ ដែលមានគុណសម្បត្តិគ្រងនគរសេឡេស្ទាល មានសភាពថ្លៃថ្លាក្រៃលែងជាងពរជ័យដែលបានទទួលដោយអ្នកទាំងឡាយដែលគ្រងនគរទេឡេស្ទាល ។



## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១១៣–១៩

*យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ពន្យល់អំពីអ្វីដែលបុគ្គលទាំងឡាយត្រូវតែធ្វើ ដើម្បីសមនឹងមើលឃើញ ហើយយល់ដោយខ្លួនគេផ្ទាល់ នូវអាថ៌កំបាំងនៃនគរព្រះ ។*

គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១១៣–១៩ មាននូវការបកស្រាយរបស់ព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ថា ពួកលោកមិនត្រូវសរសេរនូវអ្វីទាំងអស់ ដែលពួកលោកបានឃើញនោះទេ ។ ពួកលោកក៏បានពន្យល់ផងដែរនូវអ្វីដែលយើងត្រូវតែធ្វើ ដើម្បីអាចមើលឃើញ ហើយយល់ដោយខ្លួនគេ នូវអាថ៌កំបាំងនៃនគរព្រះ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:១១៦ ដោយស្វែងរករបៀបដែលបុគ្គលម្នាក់អាចសមនឹងមើលឃើញ ហើយយល់អាថ៌កំបាំងនៃនគរព្រះ ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។

យោងតាម ខទី ១១៦ តើបុគ្គលម្នាក់ត្រូវតែធ្វើអ្វី ដើម្បីបានមើលឃើញ ហើយយល់អាថ៌កំបាំងនៃនគរព្រះ ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ?

៣. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវចម្លើយចំពោះឈុតឆាកស្រមើស្រមៃដែលបានបង្ហាញនៅដើមមេរៀននេះ ដែលមិត្តភក្ដិម្នាក់របស់អ្នកបានចោទសំណួរអំពី ថាតើសាសនាចក្រយើងបង្រៀនយ៉ាងដូចម្ដេច អំពីស្ថានសួគ៌ និង ស្ថាននរក ។ សូមឆ្លើយសំណួរខាងក្រោមនេះ ទុកជាផ្នែកមួយនៃចម្លើយចំពោះសំណួររបស់មិត្តភក្ដិអ្នក ។

ក. តើព្រះអម្ចាស់បានបើកសម្ដែងអ្វីខ្លះ អំពីស្ថានសួគ៌ និង ស្ថាននរក នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ?

ខ. តើភាពខុសគ្នារវាងនគរនៃសិរីល្អនីមួយៗ និង ទីងងឹតខាងក្រៅមានអ្វីខ្លះ ?

គ. តើភាពខុសគ្នានៃជម្រើសដែលបានធ្វើឡើងដោយអ្នកដែលគ្រងនគរទាំងបី និង អ្នកធ្លាក់ទៅទីងងឹតខាងក្រៅមានអ្វីខ្លះ ?

៤. ដើម្បីជួយអ្នកឲ្យអនុវត្តអ្វី ដែលអ្នកបានរៀនចេញពីការសិក្សា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ សូមបញ្ចប់សេចក្ដីថ្លែងការណ៍នីមួយៗខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ជាលទ្ធផលនៃអ្វីដែលខ្ញុំបានរៀនចេញពីការសិក្សា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ៖*

ក. *ខ្ញុំជឿ ឬ ដឹងថា . . .*

ខ. *ខ្ញុំចង់ . . .*

គ. *ខ្ញុំនឹង . . .*

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧

*ព្រះអម្ចាស់បើកសម្ដែងចម្លើយចំពោះសំណួររបស់ យ៉ូសែប ស្ម៊ីធ អំពីព្រះគម្ពីរវិវរណៈ*

សូមបើកទៅ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ រួចកត់ចំណាំអំពីរបៀបដែលខគម្ពីរទាំងនេះត្រូវបានរៀបរៀងឡើងខុសគ្នាពីខគម្ពីរនៅក្នុងកណ្ឌដទៃៗទៀតនៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ។ សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ ដោយស្វែងរកអ្វីដែលព្យាការី យ៉ូសែប ស្ម៊ីធ កំពុងតែធ្វើ កាលលោកបានទទួលវិវរណៈនេះ ។

ចាប់ផ្ដើមពីខែ មិនា ឆ្នាំ ១៨៣១ ដល់ខែ កក្កដា ឆ្នាំ ១៨៣៣ ព្យាការីយ៉ូសែប ស្ម៊ីធ បានធ្វើកំណែដ៏បំផុសគំនិតលើព្រះគម្ពីរសញ្ញាថ្មី ។ ( កំណែថ្មីទាំងនេះជាច្រើន ត្រូវបានរាយនៅក្នុងការបោះពុម្ពរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយ នៃព្រះគម្ពីរប៊ីបរបស់ស្ដេចជេមស៍ មានលេខយោងជា ក.យ.ស និង នៅក្នុងផ្នែកនៃការបកប្រែដោយ យ៉ូសែប ស្ម៊ីធ នៅក្នុងសេចក្ដីបន្ថែមនៃព្រះគម្ពីរប៊ីប ដែលមានពាក្យត្រូវបានកែប្រែសរសេរជាអក្សរទ្រេត ) ។ កាលកំពុងបកប្រែព្រះគម្ពីរវិវរណៈ ព្យាការីបានទូលសួរព្រះអម្ចាស់ អំពីអត្ថន័យនៃខគម្ពីរទាំងនេះមួយចំនួន ។ សំណួររបស់ យ៉ូសែប និង ចម្លើយរបស់ព្រះអម្ចាស់ ត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ ។ សូមអានខគម្ពីរទាំងនេះមួយចំនួន រួចកត់ចំណាំពាក្យពេចន៍ដែលផ្នែក *សំណួរ* ចោទឡើងដែលទូលសួរដោយ យ៉ូសែប ស្ម៊ីធ និង ផ្នែក *ចម្លើយ* ឆ្លើយដោយព្រះអម្ចាស់ ។

បទពិសោធន៍របស់ យ៉ូសែប ស្ម៊ីធ ជាមួយនឹងការទទួលបានវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧ បង្រៀនយើងថា **ព្រះអម្ចាស់បើកសម្ដែងការបកស្រាយព្រះគម្ពីរដ៏ត្រឹមត្រូវ តាមរយៈពួកព្យាការីរបស់ទ្រង់** ។ យើងក៏អាចស្វែងយល់ផងដែរថា **បើយើងទូលសួរដល់ព្រះអម្ចាស់ នោះទ្រង់អាចជួយយើងឲ្យយល់អំពីបទគម្ពីរទាំងឡាយ** ។

វាអាចនឹងមានប្រយោជន៍ ក្នុងការយល់ថា នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៧:៦ ៧,000 ឆ្នាំ សំដៅលើការរស់នៅខាងសាច់ឈាមនៃផែនដី មានន័យចាប់តាំងពីការធ្លាក់នៃលោកអ័ដាម ។ នេះមិនមែនជាការពន្យល់ប្រាប់អំពី អាយុកាលនៃផែនដីឡើយ ។



៥. សូមសរសេរឃ្លាខាងក្រោមនេះពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:៨១–១១៩; ៧៧ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*



### *ការសញ្ជឹងគិតលើសំណួរ*

ការសញ្ជឹងគិតលើសំណួរ នៅពេលអ្នកសិក្សាព្រះគម្ពីរ នឹងដាស់តឿនដល់បំណងប្រាថ្នារបស់អ្នកឲ្យស្រាវជ្រាវបទគម្ពីរដើម្បីរកចម្លើយ ។ វាក៏នឹងបង្កើនសមត្ថភាពអ្នកឲ្យយល់អំពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយដែលអ្នករកឃើញនៅក្នុងបទគម្ពីរ ហើយយកមកអនុវត្តនៅក្នុងជីវិត ។ សូមពិចារណាអំពីការសរសេរសំណួរមួយចំនួនរបស់អ្នកផ្ទាល់ ដើម្បីសញ្ជឹងគិតពេលអ្នកសិក្សាបទគម្ពីរនេះ ។ ការធ្វើដូចនេះរួមបញ្ចូលទាំងសំណួរអំពីអត្ថន័យនៃពាក្យ ឬ ឃ្លា ប្រវត្តិនៃរឿងរ៉ាវដែលអ្នកកំពុងអាន ឬ អត្ថន័យនៃខគម្ពីរពិសេសមួយ ។

មេរៀនទី ១៧ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្តីសញ្ញា ៧៨–៨០

## សេចក្តីផ្តើម

នៅថ្ងៃទី ១ ខែ មិនា ឆ្នាំ ១៨៣២ ព្រះអម្ចាស់បានបើកសម្តែងដល់ យ៉ូសែប ស្ម៊ីធ នូវវិវរណៈដែលសព្វថ្ងៃនេះបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៧៨ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានបញ្ជាឲ្យព្យាការីបង្កើតសហគ្រាសមួយឡើង ( ក្រោយមកត្រូវបានស្គាល់ថាជា សហគ្រាសសាមគ្គីភាព ) ដើម្បីគ្រប់គ្រងលើឃ្លាំង និង ការងារពោងពុម្ពរបស់សាសនាចក្រ ។ ព្រះអម្ចាស់ក៏បានពិពណ៌នាផងដែរអំពីពរជ័យ ដែលពួកបរិសុទ្ធនឹងទទួលបាន បើពួកគេគោរពប្រតិបត្តិតាមព្រះបញ្ញត្តិ ដែលត្រូវបង្កើតសហគ្រាសនេះឡើង ។ នៅក្នុងការប្រឹងប្រែងដើម្បីការពារកិច្ចការដែលធ្វើឡើងដោយសាសនាចក្រពីពួកសត្រូវ ភាសាមួយចំនួននៃវិវរណៈនេះត្រូវបានកែប្រែ នៅពេលវាត្រូវបានបោះពុម្ពជាលើកទីមួយក្នុងឆ្នាំ ១៨៣៥ នៃគោលលទ្ធិ និង សេចក្តីសញ្ញា ។ ឧទាហរណ៍ ពាក្យ *សហគ្រាស* ត្រូវបានកែប្រែទៅជា *របៀប* ( សូមមើល គ. និង ស. ៧៨:៤ ) ។

នៅប្រហែលជាពេលតែមួយ ដែលព្រះអម្ចាស់បានបញ្ជាឲ្យ យ៉ូសែប ស្ម៊ីធ បង្កើតសហគ្រាសសាមគ្គីភាពឡើងនោះហើយ ដែលទ្រង់បានប្រទានវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៧៩–៨០ ។ នៅក្នុងវិវរណៈទាំងនេះ ព្រះអម្ចាស់បានហៅ យ៉ារេឌ ខារតើរ, ស្ទេផាន បើរណែត, និង អេដែន ស្ម៊ីធ ឲ្យបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ៧៨:១–១៦

*ព្រះអម្ចាស់បញ្ជាឲ្យព្យាការី យ៉ូសែប ស្ម៊ីធ បង្កើតសហគ្រាសសាមគ្គីភាព*

ប្រាក់គឺជាផ្នែកមួយដ៏សំខាន់លើពិភពលោកដែលយើងរស់នៅនេះ ហើយវាអាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងសុចរិត និង ទុច្ចរិត ។ នៅក្នុងចន្លោះខាងក្រោមនេះ សូមធ្វើបញ្ជីនៃរបៀបមួយចំនួន ដែលប្រាក់អាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងសុចរិត និង មួយចំនួនទៀតអាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងទុច្ចរិត ។

| គោលបំណងសុចរិត | គោលបំណងទុច្ចរិត |
|---|---|
| | |

ក្នុងខែ ឧសភា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានបញ្ជាថា ឃ្លាំងត្រូវតែបានសាងសង់ឡើង ដើម្បីប្រមូលទ្រព្យសម្បត្តិ និង ប្រាក់កាសបន្ថែមសម្រាប់ជំនួយដល់មនុស្សទាល់ក្រ ( សូមមើល គ. និង ស. ៥១ ) ។ សាសនាចក្រក៏ត្រូវការមូលនិធិដើម្បីទិញដី និង ដើម្បីធ្វើហិរញ្ញប្បទានដល់ការបោះពុម្ពវិវរណៈ ដែលព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលផងដែរ ។ អង្គការបីផ្សេងគ្នាត្រូវបានបង្កើតឡើង ដើម្បីទាញយកមូលនិធិទាំងនេះ ៖ (១) ផ្សាររបស់ នូវល ខេ វិតនី នៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ (២) ផ្សារដែលបើកដោយ ស៊ីឌនី គិលប៊ឺត នៅរដ្ឋមិសសួរី និង (៣) សហគ្រាសអក្ខរកម្ម ដែលត្រូវបានបង្កើតឡើងដើម្បីមើលការខុសត្រូវលើការបោះពុម្ពទាំងឡាយរបស់សាសនាចក្រ ។ សេចក្តីណែនាំរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៧៨:៣ បាននាំទៅដល់ការបញ្ចូលអង្គការទាំងបីនេះទៅជាអង្គការតែមួយ ។ អង្គការថ្មីនឹងត្រូវបានហៅថា សហគ្រាសសាមគ្គីភាព ដោយមាន យ៉ូសែប ស្ម៊ីធ, ស៊ីឌនី រិកដុន, នូវល ខេ វិតនី, អែតវីត ប៉ាទ្រិច, ស៊ីឌនី គិលប៊ឺត, អូលីវើរ ខៅឌើរី, យ៉ូហាន វិតមើរ, វិលលាម ដឹបបុលយូ ហ្វែប្ស និង ម៉ាទិន ហារីស ។



នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៧៨ ពាក្យ *របៀប* សំដៅទៅលើសហគ្រាសសាមគ្គីភាព ។ សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៧៨:៣–៤ ដោយស្វែងរកថាតើ សហគ្រាស ឬ របៀបមួយនេះ នឹងអនុញ្ញាតឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះ ។

១. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:៤ តើសម្រាប់បុព្វហេតុអ្វី ដែលព្រះអម្ចាស់បានមានព្រះទ័យបង្កើតតាមរយៈ សហគ្រាសសាមគ្គីភាពនេះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:៥–៦ ដោយស្វែងរកមូលហេតុ ដែលព្រះអម្ចាស់បានបញ្ជាឲ្យពួកបរិសុទ្ធជួយ « មនុស្សទាល់ក្រក្នុងរាស្ត្រ [ របស់ទ្រង់ ] » ( គ. និង ស. ៧៨:៣ ) ។

ដូចបានលើកឡើងនៅក្នុងខគម្ពីរទាំងនេះ អ្វីៗខាងស្ថានសួគ៌រួមមានពរជ័យនៃលក្ខណៈដ៏អស់កល្បជានិច្ច មានដូចជា ចំណេះដឹង ទីបន្ទាល់ និង ឱកាសដើម្បីទទួលបានពិធីបរិសុទ្ធទាំងឡាយនៃការសង្គ្រោះ ។

វាអាចនឹងមានប្រយោជន៍ក្នុងការដឹងថា ការមានភាពស្មើគ្នានៃអ្វីៗខាងផែនដី ពុំសបញ្ជាក់ឲ្យឃើញថា មនុស្សគ្រប់រូបនឹងមាន ទ្រព្យសម្បត្តិស្មើគ្នាទាំងស្រុងនោះទេ ប៉ុន្តែគឺថា គ្រប់ក្រុមគ្រួសារនឹងមានធនធានគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ដល់សេចក្ដីត្រូវការ និង សេចក្ដីប៉ងប្រាថ្នារបស់ខ្លួន ដោយផ្អែកទៅលើកាលៈទេសៈផ្ទាល់ខ្លួន ។

២. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរពីរបីប្រយោគដោយពន្យល់ថាតើ អ្នកគិត យ៉ាងដូចម្ដេច អំពីការមានភាពស្មើគ្នាក្នុងអ្វីៗខាងផែនដី អនុញ្ញាតឲ្យយើងមានភាពស្មើគ្នាក្នុងការទទួលអ្វីៗខាង ស្ថានសួគ៌ដែរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:៧ ។ នៅពេលអ្នកអាន សូមស្វែងរកមូលហេតុបន្ថែម ដែលព្រះអម្ចាស់បាន បញ្ជាឲ្យពួកបរិសុទ្ធបង្កើតសហគ្រាសសាមគ្គីភាពឡើង ហើយមើលថែមនុស្សទាល់ក្រ ។ បន្ទាប់មក សូមបញ្ចប់គោលការណ៍ ដូចតទៅនេះ ៖ **ការធ្វើនូវអ្វីៗដែលព្រះអម្ចាស់បានបញ្ជា រៀបចំយើងសម្រាប់** ។

តើអ្នកគិតថា ការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិដើម្បីបង្កើតសហគ្រាសរួបរួមឡើង នឹងជួយរៀបចំពួកបរិសុទ្ធឲ្យគ្រងកន្លែងមួយ នៅក្នុងនគរសេឡេស្ទាលយ៉ាងដូចម្ដេច ?

៣. សូមធ្វើបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវព្រះបញ្ញត្តិច្រើនតាមដែលអ្នកអាចរកបាន នៅក្នុងពេលមួយនាទី ។ បន្ទាប់មក សូមជ្រើសរើសព្រះបញ្ញត្តិមួយដែលអ្នកបានរាយក្នុងបញ្ជីនោះ ហើយសរសេរ ពីរបីប្រយោគពន្យល់អំពីរបៀប ដែលការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិនោះ អាចជួយរៀបចំអ្នកឲ្យទទួលបាន កន្លែងមួយនៅក្នុងនគរសេឡេស្ទាល ។



នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍ដូចតទៅនេះដោយ អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួក សាវកដប់ពីរនាក់ សូមពិចារណាអំពីមូលហេតុ ដែលវាសំខាន់ត្រូវយល់អំពីគោលបំណងរបស់ ព្រះអម្ចាស់ក្នុងការប្រទានព្រះបញ្ញត្តិដល់យើង ៖ « សេចក្ដីជំនុំជម្រះចុងក្រោយបំផុត ពុំគ្រាន់តែជា ការវាយតម្លៃលើការទូទាត់សរុបនៃទង្វើល្អ និង អាក្រក់—ដែលជាអ្វីយើងបាន *ប្រព្រឹត្ត* នោះទេ ។ វាជាការទទួលស្គាល់មួយអំពីឥទ្ធិពលនៃទង្វើ និង គំនិតរបស់យើងនៅចុងបំផុត—ជាអ្វីដែលយើងបាន *ប្រែក្លាយ* ។ វាមិនគ្រប់គ្រាន់ទេសម្រាប់នរណាម្នាក់ ដែលគ្រាន់តែធ្វើអ្វីមួយដោយគ្មានការគិតពិចារណា អំពីវានោះ ។ ព្រះបញ្ញត្តិ ពិធីបរិសុទ្ធ និង សេចក្ដីសញ្ញាទាំងឡាយ នៃដំណឹងល្អ គឺមិនមែនជាបញ្ជីនៃការដាក់ប្រាក់ ដែល តម្រូវឲ្យដាក់នៅក្នុងគណនីសួគ៌មួយចំនួននោះទេ ។ ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាផែនការមួយដែលបង្ហាញយើង ពីរបៀបដើម្បីប្រែក្លាយជាអ្វីដែលព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យយើងប្រែក្លាយ » (The Challenge to Become, » *Ensign*, ខែវិច្ឆិកា ឆ្នាំ ២០០០, ទំព័រ ៣២)។

៤. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការយល់ អំពីគោលបំណងរបស់ព្រះអម្ចាស់ក្នុងការប្រទានព្រះបញ្ញត្តិដល់យើង ជួយយើងឲ្យគោរពប្រតិបត្តិទ្រង់ដោយ ភាពស្មោះត្រង់កាន់តែធំធេងយ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:៨–៩ ដោយស្វែងរកឈ្មោះនៃអ្នកទាំងឡាយ ដែលព្រះអម្ចាស់បានចាត់តាំងឲ្យ បង្កើតសហគ្រាសសាមគ្គីភាពឡើង ។

សូមកត់ចំណាំនៅក្នុង ខទី ៩ ថា ព្រះអម្ចាស់បានបញ្ជាបុរសទាំងនេះ ឲ្យអង្គុយប្រឹក្សាជាមួយពួកបរិសុទ្ធនៅក្រុងស៊ីយ៉ូន មាន ន័យថា សមាជិកសាសនាចក្រនៅទីក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ។ ដើម្បីគោរពប្រតិបត្តិតាមព្រះបញ្ញត្តិនេះ យ៉ូសែប ស្ម៊ីធ, នូវល ខេ វិតនី និង ស៊ីឌនី រិកដុន ត្រូវធ្វើដំណើរជិត ១,៦០០ គីឡូម៉ែត្រ ( ទៅ ឬ មក ) រវាងភូមិហៃរ៉ាំ រដ្ឋ អូហៃអូ និង ក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ។ ក្នុងខែ មេសា ឆ្នាំ ១៨៣២ គឺតិចជាងមួយខែបន្ទាប់ពីវិវរណៈនេះត្រូវបានទទួល បុរស ទាំងបីរូបនេះបានគោរពប្រតិបត្តិតាមព្រះបញ្ញត្តិនេះ ហើយបានធ្វើដំណើរទៅកាន់រដ្ឋ មិសសួរី ។

តើការប្រព្រឹត្តរបស់ពួកគាត់ បង្រៀនអ្នកអំពីសេចក្ដីជំនឿ និង ការគោរពប្រតិបត្តិចំពោះព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដូចម្ដេចខ្លះ ?

មិនយូរប៉ុន្មានបន្ទាប់ពីពួកគាត់បានធ្វើដំណើរទៅឯរដ្ឋ មិសសួរី បុរសទាំងបីរូបនេះ បានប្រជុំក្រុមប្រឹក្សាមួយដែលពួកគាត់បានបង្កើតសហគ្រាសសាមគ្គីភាព ឲ្យស្របទៅតាមការបង្គាប់បញ្ជានៅក្នុងវិវរណៈនោះ ។ កម្រៃដែលទទួលបានពីការងារនៃសហគ្រាសនេះ ត្រូវបានទុកដាក់នៅក្នុងឃ្លាំង ដើម្បីមើលថែមនុស្សទាល់ក្រ និង ដើម្បីធ្វើហិរញ្ញប្បទានដល់សេចក្ដីត្រូវការទាំងឡាយនៃសាសនាចក្រ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:១០–១៦ ព្រះអម្ចាស់បានគូសបញ្ជាក់អំពីសារៈសំខាន់នៃសហគ្រាសសាមគ្គីភាពនេះ ។ ទ្រង់បានពន្យល់ថា បើពួកបរិសុទ្ធធ្វើតាមសេចក្ដីណែនាំរបស់ទ្រង់ នោះពួកគេនឹងមានជំនួយមកពីទ្រង់ក្នុងការបំពេញតាមព្រះបញ្ញត្តិទាំងឡាយ រីឯសាសនាចក្រនឹងអាចឈរឡើងដោយឯករាជ្យពីស្ថាប័នលោកិយដទៃទៀត ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:១៧–២២

*ព្រះអម្ចាស់ពិពណ៌នាអំពីពរជ័យ ដែលមានដល់ពួកអ្នកដែលរក្សាព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់*

សូមគិតអំពីអំណោយទាន ឬ ពរជ័យមួយចំនួន ដែលអ្នកទទួលបានកាលអ្នកនៅក្មេងជាងនេះ ហើយជាពរជ័យដែលអ្នកមានអំណរគុណកាន់តែខ្លាំងនាពេលឥឡូវនេះដែលអ្នកចម្រើនវ័យឡើង ។ ហេតុអ្វីបានជាអ្នកមានអំណរគុណកាន់តែខ្លាំងនាពេលឥឡូវនេះ ចំពោះអំណោយទាន ឬ ពរជ័យទាំងនេះ ? សូមគិតអំពីរបៀបដែលការណ៍នេះ អាចទាក់ទងទៅនឹងពរជ័យទាំងឡាយដែលព្រះវរបិតាសួគ៌បានបម្រុងទុកសម្រាប់យើង ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:១៧–១៨ រួចរកមើលថាតើ ពួកបរិសុទ្ធមានលក្ខណៈដូចជាកូនក្មេងតូច ៗយ៉ាងដូចម្ដេច ។ អ្នកអាចនឹងចង់ពិចារណាអំពី ការដាក់ឈ្មោះរបស់អ្នកជំនួសឲ្យសព្វនាម *អ្នក*, *អ្នករាល់គ្នា* និង *របស់ផងអ្នករាល់គ្នា* ដើម្បីជួយអ្នកឲ្យប្រើប្រាស់ខគម្ពីរទាំងនេះទៅនឹងខ្លួនរបស់អ្នកផ្ទាល់ ) ។



សូមពិចារណាអំពីរបៀបដែលការដឹងថាព្រះអម្ចាស់ « នឹងដឹកនាំ [ យើងរាល់គ្នា ] » ( គ. និង ស. ៧៨:១៨ ) អាចជួយឲ្យយើងមានសង្ឃឹមឡើង ទោះជាយើងពុំអាចយល់ ឬ ទ្រាំទ្រការណ៍ទាំងអស់បានយ៉ាងណាក៏ដោយ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:១៩ ដោយស្វែងរកឱវាទ ដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធ ។ ( គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:១៩ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ អ្នកអាចនឹងចង់គូសចំណាំវានៅក្នុងរបៀបមួយដែលងាយស្រួលរកឃើញ ) ។

សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ដោយផ្អែកទៅលើអ្វីដែលអ្នកស្វែងយល់ចេញពី ខទី ១៩ ៖ **បើយើង នោះព្រះអម្ចាស់នឹងប្រទានពរដល់យើងកាន់តែច្រើន ។**

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកអាចទទួលបានអ្វីគ្រប់យ៉ាងដោយមានអំណរគុណកាន់តែពេញលេញ បានយ៉ាងដូចម្ដេច ?

ខ. តើការជ្រើសរើសដើម្បីទទួលបានអ្វីគ្រប់យ៉ាងដោយមានអំណរគុណ អាចជួយអ្នកឲ្យមានសង្ឃឹមឡើងបានយ៉ាងដូចម្ដេច ?

## ចំណេះចំណានខគម្ពីរ—គ. និង ស. ៧៨:១៩

៦. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវសុន្ទរកថាមួយ ប្រមាណពីរនាទី ដោយផ្អែកលើ គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:១៩ ។ នៅក្នុងសុន្ទរកថារបស់អ្នក សូមប្រាកដថាអ្នកបញ្ចូលចំណុចដូចតទៅនេះ ៖ (១) ព័ត៌មានអំពីជីវប្រវត្តិ ដែលទាក់ទងនឹងវគ្គបទគម្ពីរនេះ (២) គោលការណ៍ដែលវគ្គបទគម្ពីរនេះបង្រៀន និង (៣) បទពិសោធន៍ផ្ទាល់ខ្លួនមួយ ដែលបង្ហាញអំពីសេចក្ដីពិតដែលវគ្គបទគម្ពីរនេះបង្រៀន ។ នៅពេលអ្នកបញ្ចប់ការសរសេរសុន្ទរកថានេះហើយ សូមចែកចាយជាមួយសមាជិកគ្រួសារ ឬ មិត្តភក្ដិ ។ គ្រូបង្រៀនរបស់អ្នក ក៏អាចនឹងអញ្ជើញអ្នកឲ្យថ្លែងសុន្ទរកថារបស់អ្នកនៅក្នុងថ្នាក់រៀនដែរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨:២០–២២ ដោយស្វែងរកឱវាទ ដែលព្រះអម្ចាស់បានប្រទានឲ្យ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៩–៨០

*យ៉ារេឌ ខារតើរ, ស្ទេផាន បើរណែត, និង អេដែន ស្មីធ ត្រូវបានហៅឲ្យបម្រើបេសកកម្ម*

នៅក្នុងវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៩ និង ៨០ ព្រះអម្ចាស់បានហៅបុរសបីនាក់ ឲ្យបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ សូមអានកណ្ឌនីមួយៗ ដោយស្វែងរកគោលការណ៍នានា ដែលអនុវត្តនៅក្នុងកិច្ចការផ្សព្វផ្សាយសាសនា ។ សូមពិចារណាអំពីរបៀបដែលអ្នកអាចអនុវត្តគោលការណ៍នានា ដែលអ្នកបានរកឃើញ ដើម្បីអ្នកអាចចែកចាយដំណឹងល្អកាន់តែមានប្រសិទ្ធភាព ជាមួយមនុស្សដែលអ្នកស្គាល់ ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨–៨០ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១

## បុព្វកថា

នៅថ្ងៃទី ៨ ខែ មិនា ឆ្នាំ ១៨៣២ ព្រះអម្ចាស់បានហៅ ចែស៊ី កស និង ស៊ីឌនី រិកដុន ឲ្យបម្រើជាទីប្រឹក្សារបស់ យ៉ូសែប ស្ម៊ីធ ។ មួយសប្ដាហ៍ក្រោយមក នៅថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៨៣២ ព្រះអម្ចាស់បានប្រទានវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១ ។ នៅក្នុងវិវរណៈនេះ ទ្រង់បានពិពណ៌នាអំពីតួនាទីរបស់ទីប្រឹក្សាក្នុងគណៈប្រធានទីមួយ ហើយបានសន្យាថានឹងប្រទានជីវិតដ៏នៅអស់កល្បជានិច្ចដល់ ចែស៊ី កស បើគាត់បន្តស្មោះត្រង់ដរាបដល់ចុងបំផុត ។ ចែស៊ី កស ពុំបានបន្តស្មោះត្រង់នោះទេ ហើយព្រះអម្ចាស់បានផ្ទេរការហៅបម្រើជាទីប្រឹក្សាក្នុងគណៈប្រធានទីមួយទៅឲ្យ ហ្វ្រេឌើរិក ជី វិលលាម្ស ដែលឈ្មោះរបស់គាត់ត្រូវបានលើកឡើងជាញឹកញាប់នៅក្នុងវិវរណៈនេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១

*ព្រះអម្ចាស់ពិពណ៌នាអំពីតួនាទីរបស់ទីប្រឹក្សាក្នុងគណៈប្រធានទីមួយ*

ហេតុអ្វីបានជាព្រះអម្ចាស់ ប្រទានការហៅបម្រើដល់យើង នៅក្នុងសាសនាចក្ររបស់ទ្រង់ ? តើពរជ័យនៃការបំពេញការហៅបម្រើដោយស្មោះត្រង់ មានអ្វីខ្លះ ? តើនឹងមានអ្វីកើតឡើង ប្រសិនបើមនុស្សម្នាក់ជ្រើសរើសមិនបំពេញការហៅរបស់ខ្លួនដោយស្មោះត្រង់នោះ ? ទោះជាអ្នកដឹកនាំសាសនាចក្រអាចទទួលបានការបំផុសគំនិត ហៅសមាជិកនៃសាសនាចក្រម្នាក់ ឲ្យកាន់តំណែងជាក់លាក់ណាមួយក្ដី ក៏វាអាស្រ័យទៅលើបុគ្គលដែលទទួលការហៅនោះ ប្រព្រឹត្តដោយស្មោះត្រង់ដែរ ។

សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១ ដោយស្វែងរកថាតើនរណា ដែលត្រូវបានហៅឲ្យបម្រើជាទីប្រឹក្សាក្នុងគណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ ( គណៈប្រធានទីមួយ ) ដំបូងគេបង្អស់ និង អ្វីបានកើតឡើងចំពោះគាត់ ។

ចែស៊ី កស ត្រូវបានហៅឲ្យបម្រើជាទីប្រឹក្សាក្នុងគណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ ( គណៈប្រធានទីមួយ ) ក្នុងខែ មិនា ឆ្នាំ ១៨៣២ ។ ប្រាំមួយខែក្រោយមក នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ១៨៣២ គាត់បានចេញទៅបម្រើបេសកកម្មជាមួយ សេបេដេ ខូលទ្រិន ។ ចែស៊ី បានទៅសួរសុខទុក្ខភរិយារបស់គាត់ ហើយបានព្យាយាមបញ្ចុះបញ្ចូលនាង អំពីភាពពេញលេញនៃសាសនាចក្រដែលបានស្ដារឡើងវិញ ប៉ុន្តែ នាងបដិសេធមិនព្រមចូលសាសនាចក្រឡើយ ។ មិនយូរប៉ុន្មាន ដៃគូផ្សព្វផ្សាយរបស់ ចែស៊ី គឺ សេបេដេ បានធ្លាក់ខ្លួនឈឺខ្លាំង ហើយត្រូវត្រឡប់ទៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ វិញ ។ ដោយនៅតែឯង ចែស៊ី ពុំបានបញ្ចប់បេសកកម្មរបស់គាត់នោះទេ ហើយពុំបានបន្តស្មោះត្រង់នៅក្នុងសាសនាចក្រទៀតឡើយ ។ គាត់ត្រូវបានកាត់កាលចេញពីសាសនាចក្រនៅខែ ធ្នូ ឆ្នាំ ១៨៣២ ។

យោងតាមសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១ តើនរណាដែលព្រះអម្ចាស់បានហៅឲ្យជំនួសតំណែងរបស់ ចែស៊ី ?

អ្នកអាចនឹងចង់គូសចំណាំឃ្លាដូចតទៅនេះ ដែលមានចែងនៅក្នុងសេចក្ដីណែនាំអំពីកណ្ឌ ៖ « វិវរណៈ . . . ត្រូវបានរាប់ថាជាជំហានឆ្ពោះទៅរកការរៀបចំតាមផ្លូវការ នៃគណៈប្រធានទីមួយ » ។ ព្រះអម្ចាស់ពុំបានបើកសម្ដែងការរៀបចំទាំងស្រុងនៃសាសនាចក្រទ្រង់ ទៅដល់ព្យាការីក្នុងពេលតែមួយនោះទេ ។ ផ្ទុយទៅវិញ ទ្រង់បានបើកសម្ដែងផ្នែកផ្សេង ៗគ្នានៃការរៀបចំនៅពេលមានសេចក្ដីត្រូវការ និង នៅពេលពួកបរិសុទ្ធត្រៀមខ្លួនរួចរាល់ដើម្បីទទួលបានការរៀបចំនោះ ។ ក្នុងខែ មិនា ឆ្នាំ ១៨៣២ ព្រះអម្ចាស់បានបើកសម្ដែងថា ពេលវេលាបានមកដល់ហើយ ដើម្បីរៀបចំគណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ ។

នៅក្នុងវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១ ព្រះអម្ចាស់បានពន្យល់អំពីតួនាទីសំខាន់មួយនៃគណៈប្រធានទីមួយ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១:១–២ រួចគូសចំណាំពាក្យដែលបង្រៀនថា **គណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ កាន់កូនសោទាំងឡាយនៃនគរព្រះនៅលើផែនដី ។**

សូមចងចាំថា កូនសោបព្វជិតភាពគឺជាសិទ្ធិអំណាច ដើម្បីធ្វើអធិបតីលើសាសនាចក្រ ហើយដឹកនាំការប្រើប្រាស់សិទ្ធិអំណាចបព្វជិតភាព ។ ក្រោយមក គណៈប្រធានទីមួយត្រូវបានបង្កើតឡើង ។ កូនសោនៃនគរ តែងតែត្រូវបានកាន់ដោយគណៈប្រធានទីមួយ ដែលត្រូវបានធ្វើអធិបតីលើ ដោយប្រធាននៃសាសនាចក្រ ។



ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានពន្យល់អំពីកិច្ចការ ដែលកូនសោទាំងឡាយនៃនគរ អាចឲ្យគណៈប្រធានទីមួយធ្វើ នាពេលបច្ចុប្បន្ននេះ ៖ « កូនសោទាំងនេះគឺជាសិទ្ធិរបស់គណៈប្រធាន ដ្បិតវាជាអំណាច និង សិទ្ធិអំណាចដើម្បីគ្រប់គ្រង ហើយដឹកនាំអស់ទាំងកិច្ចការរបស់ព្រះអម្ចាស់នៅលើផែនដី ។ អ្នកទាំងឡាយដែលកាន់កូនសោទាំងនេះ មានអំណាចគ្រប់គ្រង និង ត្រួតត្រាលើរបៀបដែលមនុស្សដទៃអាចបម្រើក្នុងបព្វជិតភាព » ( « Eternal Keys and the Right to Preside » *Ensign* ខែ កក្កដា ឆ្នាំ ១៩៧២ ទំព័រ ៨៧ ) ។


គណៈប្រធានទីមួយ ឆ្នាំ ២០១៣

របៀបមួយដែលគណៈប្រធានទីមួយដឹកនាំ និង គ្រប់គ្រងសាសនាចក្រ គឺតាមរយៈការបង្រៀនរបស់ពួកលោក ។

១. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវឧទាហរណ៍មួយអំពីរបៀបដែលអ្នកបានទទួលពរ តាមរយៈការបង្រៀនរបស់គណៈប្រធានទីមួយ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១:៣ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ឲ្យ ហ្វ្រេឌើរិក ជី វិលលាម្ស ធ្វើ ក្នុងនាមជាទីប្រឹក្សាក្នុងគណៈប្រធានទីមួយ ។

២. សូមសរសេរចំណងជើង *ទីប្រឹក្សាក្នុងគណៈប្រធានទីមួយ* នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ នៅក្រោមចំណងជើងនេះ សូមរាយបញ្ជីការទទួលខុសត្រូវនានា ដែលអ្នកបានរកឃើញនៅក្នុងខទី ៣ ។ បន្ថែមពីលើនោះ សូមសរសេរថាតើអ្នកគិតថាវាមានន័យដូចម្ដេច សម្រាប់ទីប្រឹក្សាដែលត្រូវ « មានចិត្តស្មោះត្រង់ក្នុងការទូន្មាន » ចំពោះប្រធានរបស់ខ្លួន ។

ដើម្បីជួយអ្នកឲ្យយល់កាន់តែច្បាស់ថាតើ វាមានន័យដូចម្ដេច សម្រាប់ទីប្រឹក្សាដែលត្រូវ « មានចិត្តស្មោះត្រង់ក្នុងការទូន្មាន » ចំពោះប្រធាននោះ សូមពិចារណាអំពីអ្វីដែលប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានបង្រៀនអំពីរបៀបដែលទីប្រឹក្សានឹងទូន្មានជាមួយប្រធាន ។



« [ ទីប្រឹក្សាម្នាក់ ] គឺជា *ជំនួយការនៃប្រធានរបស់គាត់ ។. . .*

« ក្នុងនាមជាជំនួយការម្នាក់ នោះទីប្រឹក្សាមិនមែនជាប្រធានឡើយ ។ គាត់មិនអាចសន្មត់អំពីការទទួលខុសត្រូវ ហើយនាំមុខប្រធានរបស់ខ្លួននោះទេ ។

« នៅក្នុងការប្រជុំគណៈប្រធាន ទីប្រឹក្សាម្នាក់ៗមានសេរីភាពបញ្ចេញមតិរបស់ខ្លួន ទៅលើបញ្ហាដែលមានចំពោះមុខគណៈប្រធាន ។ ទោះជាយ៉ាងណាក៏ដោយ វាគឺជាបុព្វសិទ្ធិរបស់ប្រធានដើម្បីធ្វើការសម្រេចចិត្ត ហើយវាគឺជាករណីយកិច្ចរបស់ទីប្រឹក្សា ដែលត្រូវគាំទ្រលោកលើការសម្រេចចិត្តនោះ ។ ការសម្រេចចិត្តរបស់លោក បន្ទាប់មកក្លាយជាការសម្រេចចិត្តរបស់ពួកគេ មិនថាគំនិតពីមុនរបស់ពួកគេយ៉ាងណាទេ » (In . . . Counsellors There Is Safety » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩០ ទំព័រ ៤៩ ) ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការយល់អំពីករណីយកិច្ចរបស់ទីប្រឹក្សា អាចនឹងជួយមនុស្សម្នាក់ដែលកំពុងបម្រើជាទីប្រឹក្សានៅក្នុងគណៈប្រធានណាមួយនៃសាសនាចក្រ យ៉ាងដូចម្ដេច ?

ខ. ហេតុអ្វីបានជាទីប្រឹក្សានៅក្នុងគណៈប្រធាន គួរតែគាំទ្រ ហើយពង្រឹងដល់ប្រធានរបស់ខ្លួន ?

គ. តើអ្នកអាចធ្វើអ្វីដើម្បីបម្រើនៅក្នុងគណៈប្រធានដោយមានប្រសិទ្ធិភាព ប្រសិនបើអ្នកមានឱកាសនោះ ?

ព្រះអម្ចាស់បានប្រទានការសន្យាដ៏មានអានុភាពដល់ ហ្វ្រេឌើរិក ជី វិលលាម្ស បើគាត់នឹងមានចិត្តស្មោះត្រង់ក្នុងការហៅរបស់គាត់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១:៤ រួចស្វែងរកការសន្យានោះ ។

ឃ្លា « តម្កើងសិរីល្អនៃ. . . ព្រះអម្ចាស់របស់អ្នក » នៅក្នុងបរិបទនេះបញ្ជាក់ថា ដោយសារការមានចិត្តស្មោះត្រង់ក្នុងការហៅរបស់យើង នោះយើងអាចជួយដឹកនាំមនុស្សឲ្យប្រតិបត្តិ និង ថ្វាយបង្គំព្រះអម្ចាស់ ។ ការសន្យានេះក៏អនុវត្ត ចំពោះពួកយើងផងដែរ ។ អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចតទៅនេះ នៅលើគែមព្រះគម្ពីររបស់អ្នក ៖ **បើយើងមានចិត្តស្មោះត្រង់ក្នុងការហៅរបស់យើង នោះយើងអាចប្រព្រឹត្តល្អបំផុតចំពោះមនុស្សទូទៅ ហើយតម្កើងសិរីល្អនៃព្រះ ។**

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការបម្រើយ៉ាងស្មោះត្រង់នៅក្នុងការហៅ ក្នុងសាសនាចក្រ អាចនឹងជួយយើងឲ្យប្រព្រឹត្តល្អបំផុតចំពោះមនុស្សទូទៅ បានយ៉ាងដូចម្ដេច ?

ខ. តើនៅពេលណាខ្លះ ដែលអ្នកធ្លាប់បានឃើញសមាជិកនៃសាសនាចក្រ ប្រព្រឹត្តល្អបំផុតចំពោះមនុស្សទូទៅ ដោយសារតែពួកគាត់មានចិត្តស្មោះត្រង់ក្នុងការហៅរបស់គាត់នោះ ? សូមសរសេរអំពីអ្វី ដែលអ្នកបានសង្កេតឃើញ ។

គ. តើការបម្រើដោយមានចិត្តស្មោះត្រង់ នៅក្នុងការហៅក្នុងសាសនាចក្ររបស់អ្នក អាចនឹងជួយអ្នកឲ្យតម្កើងសិរីល្អនៃព្រះ យ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១:៥ដោយស្វែងរកឱវាទបន្ថែម ដែលព្រះអម្ចាស់បានប្រទានឲ្យដល់ ហ្វ្រេឌើរិក ជី វិលលាម្ស ។

ដោយផ្អែកទៅលើអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ ហ្វ្រេឌើរិក នៅក្នុង ខទី ៥ តើយើងអាចរៀនអ្វីខ្លះ អំពីការមានចិត្តស្មោះត្រង់ ក្នុងការហៅបម្រើក្នុងសាសនាចក្រ ឬ ធ្វើជាសមាជិកដ៏ស្មោះត្រង់នៃសាសនាចក្រ ?



សេចក្ដីថ្លែងការណ៍ដូចតទៅនេះពី អែលឌើរ ម៉ាវីន ជេ អាស្តុន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ អាចជួយអ្នកឲ្យយល់អំពីឱវាទរបស់ព្រះអម្ចាស់នេះ ៖ « នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១:៥ ខគម្ពីរនេះអាចត្រូវបានបកស្រាយថាជាការជំរុញចិត្តពីព្រះអម្ចាស់ដល់ ហ្វ្រេឌើរិក ជី វិលលាម្ស ឲ្យផ្តល់កម្លាំងដល់អ្នកទន់ខ្សោយ ( ‹ ជួយអ្នកទន់ខ្សោយ › ) ផ្តល់ការលើកទឹកចិត្តដល់អ្នកដែលនឿយហត់ ឬ ខូចចិត្ត ( ‹ លើកដៃដែលពោយ › ) ហើយផ្តល់កម្លាំងចិត្ត និង ភាពរឹងមាំដល់អ្នកមានក្បាលជង្គង់ញ័រ និង ចិត្តភ័យខ្លាច » ( « Strengthen the Feeble Knees » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩១ ទំព័រ ៧០ ) ។

៥. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរអំពីបទពិសោធន៍មួយ នៅពេលដែលអ្នកត្រូវបានលើកឡើង ឬ ពង្រឹង ដោយនរណាម្នាក់ ។ រួចធ្វើបញ្ជីឲ្យបានយ៉ាងហោចណាស់កិច្ចការចំនួនបី ដែលអ្នកអាចធ្វើ ដើម្បី « ជួយអ្នកទន់ខ្សោយ លើកដៃដែលពោយ ហើយចម្រើនកម្លាំងដល់ក្បាលជង្គង់ដែលញ័រ » នៃមនុស្សទូទៅ ។ សូមដាក់គោលដៅមួយ ដើម្បីជួយដល់មនុស្សម្នាក់អំឡុងសប្ដាហ៍នេះ ដោយប្រព្រឹត្តតាមកិច្ចការដែលនៅក្នុងបញ្ជីរបស់អ្នក ។



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១:៦–៧ ដោយស្វែងរកពរជ័យ ដែលព្រះអម្ចាស់បានសន្យាថានឹងប្រទានដល់ ហ្វ្រេឌើរិក ជី វិលលាម្ស បើគាត់នឹងមានចិត្តស្មោះត្រង់ដរាបដល់ចុងបំផុត ។

ការសន្យានេះក៏កើតមាន ចំពោះអ្នកផងដែរ ។ បើអ្នកជ្រើសរើសមានចិត្តស្មោះត្រង់ចំពោះព្រះអម្ចាស់ ដែលរួមបញ្ចូលទាំងការមានចិត្តស្មោះត្រង់ក្នុងការហៅរបស់អ្នក និង ការជួយដល់មនុស្សជុំវិញខ្លួនអ្នកផង នោះអ្នកក៏នឹងមានគុណសម្បត្តិទទួលបានពរជ័យពីព្រះអម្ចាស់ដែរ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨១ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៧ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២–៨៣

### បុព្វកថា

វិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២ ត្រូវបានទទួលនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៨៣២ អំឡុងការប្រជុំក្រុមប្រឹក្សាពួកសង្ឃជាន់ខ្ពស់ និង ពួកអែលឌើរនៃសាសនាចក្រនៅក្រុង អ៊ីនឌីប៉ែនដែនស៍ ឃុំចាកសុន រដ្ឋ មិសសួរី ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានអត់ទោសដល់ពួកបងប្អូនប្រុស ពីកំហុសរបស់ពួកគាត់ ហើយបានព្រមានពួកគាត់កុំឲ្យប្រព្រឹត្តបាបបន្តទៀត ។ ព្រះអម្ចាស់ក៏បានណែនាំពួកបងប្អូនប្រុសទាំងនេះនៅរដ្ឋ មិសសួរី ផងដែរ ស្ដីពីរបៀបគ្រប់គ្រងកិច្ចការអាណាចក្រនៃទីក្រុង ស៊ីយ៉ូន ។ បួនថ្ងៃក្រោយមក ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៣ ជាវិវរណៈដែលព្រះអម្ចាស់បានណែនាំ ដល់ថ្នាក់ដឹកនាំសាសនាចក្រស្ដីពីរបៀបមើលថែស្រីមេម៉ាយ និង កូនកំព្រា ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១–៧

*ព្រះអម្ចាស់ព្រមានដល់អ្នកទាំងឡាយណា ដែលទទួលបានច្រើនពីទ្រង់*

សូមគិតអំពីគ្រាដែលអ្នកបានមានការខ្វែងគំនិតជាមួយមិត្តភក្តិ ឬ សមាជិកគ្រួសារ ដែលនៅទីបំផុតត្រូវបានដោះស្រាយ ។ តើអ្នកបានមានអារម្មណ៍ដូចម្ដេច បន្ទាប់ពីបានដោះស្រាយការខ្វែងគំនិតនោះហើយ ?

អស់រយៈពេលបីបួនខែ អារម្មណ៍គ្រោតគ្រាតកើតឡើងរវាង ស៊ីឌនី រិកដុន នៅរដ្ឋ អូហៃអូ និង ប៊ីស្សព អែតវឺត ប៉ាទ្រិច នៅរដ្ឋ មិសសួរី ។ ក្នុងខែ មេសា ឆ្នាំ ១៨៣២ ព្យាការី យ៉ូសែប ស្ម៊ីធ និង ថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រ បានធ្វើដំណើរទៅកាន់រដ្ឋ មិសសួរី ដើម្បីគោរពប្រតិបត្តិតាមការបញ្ជារបស់ព្រះអម្ចាស់ថា ពួកលោកត្រូវ « អង្គុយប្រឹក្សាជាមួយពួកបរិសុទ្ធ ដែលនៅក្រុងស៊ីយ៉ូន » ( គ. និង ស. ៧៨:៩ ) ។ កាលពួកលោកបានធ្វើដំណើរទៅដល់ នោះការប្រជុំក្រុមប្រឹក្សានៃពួកសង្ឃជាន់ខ្ពស់ និង ពួកអែលឌើរនៃសាសនាចក្រ ត្រូវបានធ្វើឡើង ។ នៅចន្លោះសម័យប្រជុំពេលព្រឹក និង ពេលរសៀលនៃសន្និសីទ ស៊ីឌនី រិកដុន និង អែតវឺត ប៉ាទ្រិច បានដោះស្រាយការខ្វែងគំនិតរបស់ពួកគាត់ ។ វិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២ ត្រូវបានទទួលនៅអំឡុងសម័យប្រជុំពេលរសៀល ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ ស៊ីឌនី រិកដុន និង វិល្លាម ប៉ាទ្រិច អំពីការដោះស្រាយការខ្វែងគំនិតរបស់ពួកគាត់ ។

ដោយផ្អែកទៅលើអ្វី ដែលអ្នករៀននៅក្នុង ខទី ១ សូមបំពេញគោលការណ៍ដូចតទៅនេះ ដែលប្រាប់អំពីទំនាក់ទំនងរវាងការអត់ទោសដល់មនុស្សទូទៅ និង ការទទួលបានការអត់ទោសពីព្រះអម្ចាស់ ៖ **គឺជាផ្នែកមួយដ៏ចាំបាច់នៃការទទួលបានការអត់ទោស ពីព្រះអម្ចាស់ចំពោះអំពើបាបរបស់យើង ។** ( សូមប្រៀបធៀបទៅនឹង គ. និង ស. ៦៤:៩–១១ ) ។

ទោះជាព្រះអម្ចាស់បានប្រទានការអត់ទោសនៅពេលនេះក្ដី ក៏ទ្រង់បានប្រទានការព្រមានមួយដល់ពួកគាត់ផងដែរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:២ ដោយស្វែងរកការព្រមាន ដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធទាំងនេះ ។

នៅពេលសមាជិកសាសនាចក្របានផ្លាស់ទីលំនៅទៅកាន់រដ្ឋ មិសសួរី ពួកគាត់ជាច្រើននាក់ពុំបានគោរពប្រតិបត្តិតាមដំបូន្មានរបស់ថ្នាក់ដឹកនាំនៃសាសនាចក្រឡើយ ហើយខ្លះទៀតបានបដិសេធមិនរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ។ ជាលទ្ធផល សមាជិកសាសនាចក្រទាំងនោះមួយចំនួន បានធ្វើកំហុសដោយសេចក្ដីច្រណែន លោភៈ និង មិនព្រមបំពេញករណីយកិច្ចរបស់ខ្លួន ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:៣–៤ ដោយស្វែងរកមូលហេតុ ដែលសេចក្ដីជំនុំជម្រះរបស់ព្រះអម្ចាស់ នឹងធ្លាក់ទៅលើអស់អ្នកដែលបន្តប្រព្រឹត្តបាប ។

១. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវគោលការណ៍មួយ ដែលព្រះអម្ចាស់បានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:៣ ។ បន្ទាប់មក សូមឆ្លើយសំណួរដូចតទៅនេះ ៖ តើអ្នកគិតថា ហេតុអ្វីបានជាអ្នកទាំងឡាយដែលបានទទួលច្រើនពីព្រះអម្ចាស់ ក៏នឹងត្រូវទាមទារជាច្រើនវិញដែរ ?

២. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមធ្វើបញ្ជីនៃពរជ័យ ដែលអ្នកបានទទួលពីព្រះអម្ចាស់ឲ្យបានច្រើន តាមដែលអ្នកអាចគិតបាន ក្នុងរយៈពេលពីរនាទី ។ សូមសរសេរបញ្ចូលពរជ័យដែលអ្នកទទួលបានក្នុងនាមជាសមាជិកនៃសាសនាចក្រ ។ បន្ទាប់មក ជ្រើសរើសពរជ័យមួយដែលអ្នកបានសរសេរ រួចឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើអ្នកគិតថា ព្រះអម្ចាស់មានព្រះទ័យរំពឹងឲ្យអ្នកធ្វើដូចម្ដេច ជាមួយនឹងពរជ័យនេះ ? ( ឧទាហរណ៍ បើអ្នកទទួលស្គាល់ថាអ្នកត្រូវបានប្រទានពរឲ្យមានសេចក្ដីពិតនៃដំណឹងល្អនៅក្នុងជីវិតអ្នក ការរំពឹងទុកមួយអាចជាការដែលអ្នកចែកចាយសេចក្ដីពិតទាំងនេះជាមួយមនុស្សទូទៅ ) ។

ខ. តើអ្នកអាចចាប់ផ្ដើមធ្វើអ្វីខ្លះ ដើម្បីបំពេញតាមការរំពឹងទុកនោះ ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:៥–៦ ព្រះអម្ចាស់បានព្រមានពួកបរិសុទ្ធថា អាណាចក្រ និង អំណាចរបស់សាតាំងនៅលើផែនដីនេះ កំពុងតែពង្រីកឡើង ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:៧ ដោយស្វែងរកការព្រមានបន្ថែមដែលព្រះអម្ចាស់បានប្រទានឲ្យដល់សមាជិកនៃសាសនាចក្រទាំងនេះ ស្ដីពីអំពើបាប ។ យើងរៀនចេញពីខគម្ពីរនេះថា វាចាំបាច់ដែលត្រូវរលាស់ចោលអំពើបាបទាំងឡាយរបស់យើង ព្រោះបើយើងប្រព្រឹត្តបាបម្ដងទៀតបន្ទាប់ពីបានប្រែចិត្តហើយ នោះអំពើបាបពីដើមរបស់យើង នឹងវិលមកវិញ ។

៣. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលអ្នកគិតថា អំពើបាបពីដើមរបស់យើងវិលមកវិញ នៅពេលយើងប្រព្រឹត្តវាម្ដងទៀតដោយចេតនា បន្ទាប់ពីបានស្វែងរកការអត់ទោសពីព្រះអម្ចាស់ហើយនោះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:៨–២៤

*ព្រះអម្ចាស់បញ្ជាបុរសប្រាំបួននាក់ ឲ្យបង្កើតសហគ្រាសមួយដើម្បីគ្រប់គ្រង កិច្ចការអាណាចក្រនៃសាសនាចក្រ*

សូមគិតអំពីស្ថានភាពមួយនៅពេលដែលអ្នក ឬ មនុស្សម្នាក់ដែលអ្នកស្គាល់ ត្រូវការឲ្យគេអះអាងថា ព្រះរក្សាការសន្យារបស់ទ្រង់ ។ អំឡុងពេលការប្រជុំក្រុមប្រឹក្សាពួកសង្ឃជាន់ខ្ពស់ និង ពួកអែលឌើរនៅរដ្ឋ មិសសួរី នោះព្រះអម្ចាស់បានប្រទានការសន្យាអះអាងដល់អ្នកទាំងឡាយ ដែលគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទ្រង់ ។ នៅពេលអ្នកបន្តការសិក្សាអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២ សូមស្វែងរកគោលការណ៍នានា ដែលអាចផ្ដល់ការអះអាងទៅដល់មនុស្សម្នាក់ ដែលស្ថិតនៅក្នុងស្ថានភាពដូចដែលអ្នកបានគិតខាងលើនេះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:៨–៩ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់នៅក្នុងការប្រជុំក្រុមប្រឹក្សានេះ ថាទ្រង់នឹងប្រទាន ។ អ្នកអាចនឹងចង់គូសចំណាំ មូលហេតុដែលព្រះអម្ចាស់ប្រទានព្រះបញ្ញត្តិថ្មីនេះដល់ពួកគាត់ ។ សូមពិចារណាថាតើមូលហេតុទាំងនេះ អាចអនុវត្តចំពោះរាល់ព្រះបញ្ញត្តិដែលព្រះអម្ចាស់បានប្រទានដល់យើងយ៉ាងដូចម្ដេច ។

៤. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១០ ( វគ្គចំណេះចំណានខគម្ពីរ ) ដោយស្វែងរកគោលការណ៍មួយ ដែលអាចផ្ដល់ការទុកចិត្តនៅពេលយើងខ្មីឃ្មាតគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ ។ ( អ្នកអាចនឹងចង់គូសចំណាំវានៅក្នុងរបៀបមួយដែលងាយសម្គាល់ ដើម្បីអ្នកអាចងាយរកវាឃើញនៅពេលខាងមុខ ) ។ សូមសរសេរកិច្ចការខាងក្រោមនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ៖ **បើយើងគោរពប្រតិបត្តិតាមព្រះអម្ចាស់ នោះទ្រង់នឹង** . . .

ខ. សូមពិចារណាអំពីបទពិសោធន៍នានា ដែលអ្នកបានមាន ដែលបង្ហាញថាគោលការណ៍នេះពិត រួចសរសេរអំពីបទពិសោធន៍មួយក្នុងចំណោមបទពិសោធន៍ទាំងនោះ ។

នៅពេលអ្នកបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨ ព្រះអម្ចាស់បានបញ្ជាថ្នាក់ដឹកនាំសាសនាចក្រនៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ឲ្យបង្កើតសហគ្រាសមួយ ដែលជាសមាគមការងារសាសនាចក្រ ត្រូវបានស្គាល់ថាជា សហគ្រាសសាមគ្គីភាព ។ ធនធានដែលបានមកពីប្រតិបត្តិការការងារនៃសហគ្រាសនេះ ត្រូវប្រើប្រាស់ដើម្បីមើលថែមនុស្សទាល់ក្រ ហើយធ្វើហិរញ្ញប្បទានសម្រាប់សេចក្ដីត្រូវការទាំងឡាយរបស់សាសនាចក្រ ។ ដូចមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១១, ១៥–១៧ ព្រះអម្ចាស់បានបញ្ជាថ្នាក់ដឹកនាំសាសនាចក្រនៅរដ្ឋ មិសសួរី ឲ្យចូលរួមក្នុងសហគ្រាសសាមគ្គីភាពនេះដោយសេចក្ដីសញ្ញា ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១២ ដោយស្វែងរកគោលបំណងនៃសហគ្រាសសាមគ្គីភាពនេះ ។ នៅពេលអ្នកអាន វាអាចនឹងជួយអ្នកឲ្យនឹកឃើញថា កណីយកិច្ចមួយរបស់ប៊ីស្សព គឺត្រូវជួយបំពេញសេចក្ដីត្រូវការខាងសាច់ឈាមនៃសមាជិកសាសនាចក្រ ។



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១៤, ១៨–១៩ ដោយស្វែងរកពាក្យ និង ឃ្លាដែលពន្យល់បន្ថែមអំពីមូលហេតុដែលព្រះអម្ចាស់បានបញ្ជាថ្នាក់ដឹកនាំសាសនាចក្រ ឲ្យបង្កើតសហគ្រាសរួបរួមឡើង ។ អ្នកអាចនឹងចង់គូសចំណាំពាក្យ ឬ ឃ្លាដែលអ្នករកឃើញ ។

ដូចមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:២០–២៤ ព្រះអម្ចាស់បានបញ្ចប់វិវរណៈនេះ ដោយការព្រមានថ្នាក់ដឹកនាំសាសនាចក្រឲ្យមានចិត្តស្មោះត្រង់ចំពោះសេចក្ដីសញ្ញា ដែលពួកគាត់បានធ្វើក្នុងនាមជាសមាជិកនៃសហគ្រាសសាមគ្គីភាព ។

## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១០

គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:១០ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ សូមព្យាយាមទន្ទេញវា ដោយការសូត្រម្ដងហើយម្ដងទៀតចំនួនបីបួនដង ។ បន្ទាប់ពីអ្នកបានទន្ទេញវាចាំហើយ សូមសូត្រវាឲ្យសមាជិកគ្រួសារ ឬ មិត្តភក្តិស្ដាប់ ហើយចែកចាយអំពីអ្វីដែលអ្នកបានមានបទពិសោធន៍ ដែលបានបញ្ជាក់ប្រាប់ដល់អ្នកថា ព្រះអម្ចាស់ពិតជារក្សាការសន្យារបស់ទ្រង់ចំពោះយើង នៅពេលយើងធ្វើតាមអ្វីដែលទ្រង់បញ្ជា ។

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្វីដែលអ្នកបានចែកចាយជាមួយសមាជិកគ្រួសារ ឬ មិត្តភក្តិ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៣

*ព្រះអម្ចាស់បើកសម្ដែងរបៀប ដែលត្រូវមើលថែដល់ស្រីមេម៉ាយ និង កូនកំព្រា*

បួនថ្ងៃបន្ទាប់ពីបានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈអំពីរបៀបបំពេញសេចក្ដីត្រូវការខាងសាច់ឈាមរបស់ពួកបរិសុទ្ធ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៣:១ ដោយស្វែងរកថាតើវិវរណៈនេះ សំដៅទៅលើសេចក្ដីត្រូវការរបស់នរណា ។

ដើម្បីយល់អំពីកណ្ឌនេះ សូមរំឭកថា ពួកបរិសុទ្ធជាច្រើនបានរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ហើយបានទទួល « កេរមរតក » ឬ ទ្រព្យសម្បត្តិពីសាសនាចក្រ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានបើកសម្ដែងអ្វីដែលនឹងកើតឡើងចំពោះកេរមរតកគ្រួសារ បើស្វាមី ឬ ឪពុកបានទទួលមរណភាព ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៣:២–៣ ដោយស្វែងរកសេចក្ដីណែនាំពីព្រះអម្ចាស់ អំពីការមើលថែដល់ស្ត្រី ដែលស្វាមីរបស់ពួកគេបានស្លាប់ ។ ( វាអាចនឹងជួយអ្នក ក្នុងការដឹងថា នៅពេលនោះ ស្ត្រីភាគច្រើនពឹងផ្អែកទៅលើការផ្គត់ផ្គង់ខាងសាច់ឈាមពីស្វាមីរបស់ខ្លួន ។ « ត្រូវបានទទួលការរាប់អាននៅក្នុងសាសនាចក្រ » មានន័យថា ដោយសារតែអ្នកផ្គត់ផ្គង់របស់ភរិយាបានស្លាប់ទៅហើយនោះ សាសនាចក្រនឹងបំពេញសេចក្ដីត្រូវការរបស់នាង ) ។ រួចសូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៣:៤–៦ ដោយស្វែងរករបៀប ដែលសាសនាចក្រមើលថែកូនកំព្រា និង ស្រីមេម៉ាយ ។

៦. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរអ្វីដែល គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៣ បង្រៀនអ្នកអំពីរបៀបដែលព្រះអម្ចាស់ទ្រង់ព្រះតម្រិះ អំពីស្រីមេម៉ាយ កូនកំព្រា និង អ្នកដែលមានសេចក្ដីត្រូវការទាំងនោះ ?



៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង*
*សេចក្ដីសញ្ញា ៨២–៨៣ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៨ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១–៤២

## សេចក្ដីផ្ដើម

ក្នុងខែ កញ្ញា ឆ្នាំ ១៨៣២ ពួកអ្នកផ្សព្វផ្សាយសាសនាបានត្រឡប់ទៅកាន់ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ វិញ បន្ទាប់ពីបានប្រកាសដំណឹងល្អនៅភាគខាងកើតនៃសហរដ្ឋ ។ អំឡុងការជួបជុំដ៏រីករាយរបស់ពួកគេនោះ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤ ។ លោកទទួលបានវិវរណៈរយៈពេលពីរថ្ងៃ ៖ ថ្ងៃទី ២២ និង ២៣ ខែ កញ្ញា ។ ( មានភស្តុតាងជាប្រវត្តិសាស្ត្រមួយចំនួនដែល ខទី ១–៤១ ត្រូវបានទទួលនៅថ្ងៃទី ២២ ខែ កញ្ញា និង ដែល ខទី ៤២–១២០ ត្រូវបានទទួលនៅថ្ងៃទី ២៣ ខែ កញ្ញា ) ។ ការសិក្សារបស់អ្នកអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤ ត្រូវបានបែងចែកជាពីរមេរៀន ។ មេរៀនទីមួយផ្ដោតទៅលើ សេចក្ដីណែនាំរបស់ព្រះអម្ចាស់ អំពីបព្វជិតភាព និង របៀបដែលបព្វជិតភាពអាចរៀបចំយើង ឲ្យទទួលបានអ្វីគ្រប់យ៉ាងដែលព្រះវរបិតាមាន ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១–៣០

*ព្រះអម្ចាស់ប្រកាសថា ព្រះវិហារបរិសុទ្ធនឹងត្រូវបានកសាងឡើង ហើយទ្រង់ពន្យល់អំពីគោលបំណងនៃបព្វជិតភាព*

សូមគិតអំពីព្រះវិហារបរិសុទ្ធ ដែលអ្នកបានទៅ ឬ ចង់ទៅ ។ តើអ្នកនឹងពន្យល់ប្រាប់មិត្តភក្ដិម្នាក់ ដែលមានជំនឿខុសពីអ្នកអំពីភាពខុសគ្នារវាងព្រះវិហារបរិសុទ្ធ និង អគារដទៃទៀតនៅក្នុងសហគមន៍យ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:២–៥ រួចគូសចំណាំពាក្យ ឬ ឃ្លាដែលព្រះអម្ចាស់បានប្រើប្រាស់ ដើម្បីជួយពួកបរិសុទ្ធឲ្យយល់អំពីសារៈសំខាន់នៃអគារព្រះវិហារបរិសុទ្ធ ។



ខគម្ពីរទាំងនេះប្រាប់ឡើងវិញអំពីការព្យាករណ៍ដែលទីក្រុង យេរ៉ូសាឡិម ថ្មី និង ព្រះវិហារបរិសុទ្ធនឹងត្រូវបានសាងឡើងនៅឃុំ ចាកសុន រដ្ឋ មិសសួរី ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រោយមកក្នុងឆ្នាំ ១៨៤១ ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ពួកបរិសុទ្ធថា ពួកគាត់ពុំតម្រូវឲ្យសាងទីក្រុង ឬ ព្រះវិហារបរិសុទ្ធឡើងនៅរដ្ឋ មិសសួរី ក្នុងពេលនោះឡើយ ដោយសារតែមានសេចក្ដីបៀតបៀនយ៉ាងខ្លាំង ពីសំណាក់ខ្មាំងសត្រូវរបស់សាសនាចក្រ ( សូមមើល គ. និង ស. ១២៤:៤៩ ) ។ ឃ្លា « តំណនេះ » នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៥ សំដៅទៅលើការព្យាករណ៍អំពីការសាងទីក្រុង យេរ៉ូសាឡិមថ្មី និង ព្រះវិហារបរិសុទ្ធឡើង—ដែលវានឹងនៅតែកើតឡើង និង ត្រូវបានបំពេញនៅពេលណាមួយក្នុងអនាគតកាលជាមិនខាន ( សូមមើល ម៉ូសេ ៧:៦២ ) ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤ ផ្ដល់ឱកាសមួយដើម្បីរៀនអំពីសារៈសំខាន់នៃពរជ័យទាំងឡាយ ដែលអ្នកអាចទទួលបាននៅក្នុងព្រះវិហារបរិសុទ្ធ ។ ពីមុនបន្តការសិក្សារបស់អ្នកអំពីកណ្ឌនេះ វានឹងផ្ដល់អត្ថប្រយោជន៍ក្នុងការរំឭក អំពីវាក្យសព្ទគន្លឹះៗមួយចំនួន ដែលទាក់ទងទៅនឹងគោលការណ៍នានា ដែលព្រះអម្ចាស់បានបង្រៀននៅក្នុងវិវរណៈនេះ ។ នៅក្នុងតារាងខាងក្រោមនេះ សូមអាននិយមន័យគោលលទ្ធិនៅផ្នែកខាងស្ដាំដោយយកចិត្តទុកដាក់ ។ សូមផ្គូផ្គងនិយមន័យនីមួយៗ ទៅនឹងវាក្យសព្ទដែលត្រូវនឹងនិយមន័យនោះ នៅផ្នែកខាងឆ្វេង ។

| វាក្យសព្ទ | និយមន័យ |
|---|---|
| _____១. សេចក្ដីសញ្ញា<br>_____២. ពិធីបរិសុទ្ធនៃការសង្គ្រោះ<br>_____៣. បព្វជិតភាពមិលគីស្សាដែក<br>_____៤. បព្វជិតភាពអើរ៉ុន | ក. បព្វជិតភាពជាន់ខ្ពស់ និង ធំជាងនេះ ដែលគ្រប់គ្រងលើកិច្ចការនានាខាងវិញ្ញាណ<br>ខ. បព្វជិតភាពត្រៀម ដែលកាន់កូនសោនៃការបម្រើនៃពួកទេវតា និង នៃដំណឹងល្អនៃការប្រែចិត្ត និង នៃពិធីបុណ្យជ្រមុជទឹក<br>គ. កិច្ចព្រមព្រៀងដ៏ពិសិដ្ឋមួយ ដែលធ្វើឡើងរវាងព្រះ និង មនុស្ស ។<br>ឃ. សកម្មភាពដ៏ពិសិដ្ឋមួយ ដែលចាំបាច់ចំពោះភាពតម្កើងឡើង និង ត្រូវបានភ្ជាប់មកជាមួយដោយសេចក្ដីសញ្ញានានា |

( សូមមើល ចម្លើយសម្រាប់លំហាត់ផ្គូផ្គងនេះ នៅចុងបញ្ចប់នៃមេរៀន ) ។

សូមអានបញ្ជីនៃពិធីបរិសុទ្ធបព្វជិតភាព និង ពរជ័យទាំងឡាយខាងក្រោមនេះ រួចគូសសញ្ញាកែងនៅក្នុងប្រអប់ឈរ ក្បែរចំណុចដែលនឹងត្រូវបានចាត់ទុកថាជាពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ ៖

| | |
|---|---|
| | ពិធីបុណ្យជ្រមុជទឹក |
| | ពិធីបញ្ជាក់ |
| | ពិធីដាក់ឈ្មោះ និង ប្រសិទ្ធពរឲ្យកុមារ |
| | ពិធីប្រគល់បព្វជិតភាពមិលគីស្សាដែក ( សម្រាប់បុរស ) |
| | ការព្យាបាលអ្នកឈឺ |
| | អំណោយទានពិសិដ្ឋក្នុងព្រះវិហារបរិសុទ្ធ |
| | ពិធីផ្សារភ្ជាប់អាពាហ៍ពិពាហ៍ |

ចំណុចនីមួយៗដែលមាននៅក្នុងបញ្ជី គឺជាពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ លើកលែងតែ ពិធីដាក់ឈ្មោះ និង ប្រសិទ្ធពរឲ្យកុមារ និង ការព្យាបាលអ្នកឈឺប៉ុណ្ណោះ ។ ពិធីបរិសុទ្ធនៃបព្វជិតភាពអំពី ការដាក់ឈ្មោះ និង ប្រសិទ្ធពរឲ្យកុមារ និង ការព្យាបាលអ្នកឈឺ ប្រទានពរដល់ជីវិតនៃអ្នកទាំងឡាយណាដែលទទួលបានវា ប៉ុន្តែ ពិធីទាំងនោះពុំចាំបាច់ចំពោះសេចក្ដីសង្គ្រោះឡើយ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៦–១៩ យើងស្វែងយល់ថា ម៉ូសេ កាន់បព្វជិតភាពមិលគីស្សាដែក ឬ « បព្វជិតភាពដ៏ធំជាងនេះ » ( គ. និង ស. ៨៤:១៩ ) ។ លោកអាចប្រគល់សិទ្ធអំណាចបព្វជិតភាពត្រឡប់ទៅឲ្យព្រះវិញ ។ ក្នុងនាមជាថ្នាក់ដឹកនាំបព្វជិតភាពដ៏សុចរិតម្នាក់ គោលបំណងរបស់ម៉ូសេ គឺដើម្បីជួយមនុស្សទូទៅឲ្យខិតកាន់តែជិតព្រះ តាមរយៈពិធីបរិសុទ្ធនៃការសង្គ្រោះរបស់បព្វជិតភាព ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១៩–២២ ដោយស្វែងរកពរជ័យ ដែលយើងអាចទទួលបានតាមរយៈបព្វជិតភាពមិលគីស្សាដែក ។

សូមកត់ចំណាំនៅក្នុង ខទី ២០ ដែល **នៅក្នុងពិធីបរិសុទ្ធទាំងឡាយនៃបព្វជិតភាពមិលគីស្សាដែក នោះអំណាចនៃព្រះត្រូវបានបង្ហាញ** ។ លើកលែងតែពិធីបុណ្យជ្រមុជទឹក ពិធីបរិសុទ្ធទាំងឡាយដែលមាននៅក្នុងតារាងមុននេះ ត្រូវតែបានចាត់ចែងដោយសិទ្ធអំណាចបព្វជិតភាពមិលគីស្សាដែក ។ តើអ្នកមានអារម្មណ៍ថា អំណាចនៃព្រះត្រូវបានបង្ហាញនៅក្នុងពិធីបរិសុទ្ធទាំងនេះយ៉ាងដូចម្ដេច ?

ពិធីបរិសុទ្ធនៃការសង្គ្រោះរបស់បព្វជិតភាពមិលគីស្សាដែក—អំណោយទានពិសិដ្ឋក្នុងព្រះវិហារបរិសុទ្ធ និង ពិធីផ្សារភ្ជាប់អាពាហ៍ពិពាហ៍—អាចទទួលបានតែនៅក្នុងព្រះវិហារបរិសុទ្ធប៉ុណ្ណោះ ។ យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:២២ ហេតុអ្វីបានជាវាមានសារៈសំខាន់ ដែលយើងត្រូវទទួលពិធីបរិសុទ្ធនៃការសង្គ្រោះរបស់បព្វជិតភាពមិលគីស្សាដែក ?

ខទី ២២ អាចសំដៅទៅលើការមើលឃើញព្រះនៅក្នុងជីវិតនេះ ប៉ុន្តែ នៅទីបំផុតវាសំដៅទៅលើសមត្ថភាពរបស់យើងដើម្បីរស់នៅក្នុងវត្តមានរបស់ព្រះវរបិតាសួគ៌សម្រាប់ភាពដ៏នៅអស់កល្បជានិច្ច ។ អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចតទៅនេះ នៅលើគែមព្រះគម្ពីររបស់អ្នកក្បែរ ខទី ២១–២២ ៖ **ដើម្បីប្រែក្លាយឲ្យដូចជាព្រះ និង រស់នៅក្នុងវត្តមានរបស់ទ្រង់ នោះយើងត្រូវតែទទួលពិធីបរិសុទ្ធនៃការសង្គ្រោះរបស់បព្វជិតភាពមិលគីស្សាដែក** ។

១. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរអ្នកអំពីរបៀបដែលគោលការណ៍ដែលអ្នកបានរៀននៅក្នុងមេរៀននៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤ បានជួយអ្នកឲ្យយល់អំពីសារៈសំខាន់នៃបព្វជិតភាព និង នៃព្រះវិហារបរិសុទ្ធ ។



នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍ដូចតទៅនេះដោយ អែលឌើរ រ័សុល អិម ណិលសុន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នោះសូមគិតអំពីមូលហេតុដែលវាមានសារៈសំខាន់ចំពោះអ្នក ដែលត្រូវទទួលបានពិធីបរិសុទ្ធនៃការសង្គ្រោះក្នុងដំណឹងល្អ—ដែលរួមមានពិធីបរិសុទ្ធដែលមាននៅក្នុងព្រះវិហារបរិសុទ្ធ ៖ « ព្រះវិហារបរិសុទ្ធគឺជាគោលបំណងនៃគ្រប់សកម្មភាព គ្រប់មេរៀន គ្រប់ជំហានវឌ្ឍនភាពនៃសាសនាចក្រ ។ រាល់ការខិតខំទាំងអស់របស់យើងនៅក្នុងការប្រកាសដំណឹងល្អ ការធ្វើឲ្យពួកបរិសុទ្ធបានល្អឥតខ្ចោះ និង ការប្រោសលោះមនុស្សស្លាប់ ដឹកនាំទៅរកព្រះវិហារបរិសុទ្ធ ។ ពិធីបរិសុទ្ធទាំងឡាយក្នុងព្រះវិហារបរិសុទ្ធ គឺសំខាន់ខ្លាំងណាស់ ។ យើងពុំអាចត្រឡប់ទៅរកសិរីល្អនៃព្រះដោយគ្មានវាបានឡើយ » (Prepare for the Blessings of the Temple, » *Ensign* ខែ តុលា ឆ្នាំ ២០១០ ទំព័រ ៤១ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:២៣ រកមើលអ្វីដែលម៉ូសេព្យាយាមធ្វើ ។ សូមចាំថាពាក្យ *ញែកចេញជាបរិសុទ្ធ* មានន័យថាស្អាតបាត និងធ្វើឲ្យបរិសុទ្ធ ។ បន្ទាប់មក សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:២៤–២៥ រួចស្វែងរករបៀបដែលកូនចៅអ៊ីស្រាអែល បានប្រព្រឹត្តចំពោះការខិតខំរបស់ម៉ូសេក្នុងការបង្រៀនដល់ពួកគេ ។ តើអ្វីជាលទ្ធផលនៃទង្វើរបស់ពួកគេ ?

ដូចអ្នកបានដឹងថា កូនចៅអ៊ីស្រាអែលបានបាត់បង់ឱកាសទទួលបានពិធីបរិសុទ្ធនៃការសង្គ្រោះរបស់បព្វជិតភាពមិលគីស្សាដែក ។ ទោះជាយ៉ាងណាក៏ដោយ ព្រះអម្ចាស់ពុំបានឈប់ព្យាយាមជួយឲ្យពួកគេរីកចម្រើនឡើយ ។ ទ្រង់បានអនុញ្ញាតឲ្យបព្វជិតភាពតូចជាង ឬ បព្វជិតភាពអើរ៉ុន បន្តស្ថិតស្ថេរនៅជាមួយពួកគេ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:២៦–២៨ រួចស្វែងរករបៀប ដែលព្រះអម្ចាស់បានបន្តប្រទានពរដល់កូនចៅអ៊ីស្រាអែល ។ នៅពេលអ្នកសិក្សា អ្នកអាចនឹងចង់គូសចំណាំពរជ័យ ដែលយើងអាចទទួលបានតាមរយៈបព្វជិតភាពអើរ៉ុន ។

វាអាចនឹងផ្ដល់អត្ថប្រយោជន៍ ក្នុងការយល់ថា នៅក្នុង ខទី ២៨ ឃ្លា « លោកត្រូវបានទទួលបុណ្យជ្រមុជទឹកតាំងពីលោកនៅក្មេង » សំដៅទៅលើពិធីបុណ្យជ្រមុជទឹករបស់ យ៉ូហាន កាលនៅអាយុប្រាំបីឆ្នាំ ។ ឃ្លា « ត្រូវបានតែងតាំងដោយទេវតានៃព្រះក្នុងកាលលោកមានអាយុប្រាំបីថ្ងៃ » មានន័យថា យ៉ូហាន ត្រូវបានញែកចេញ « ដើម្បីតម្រង់ផ្លូវថ្វាយព្រះអម្ចាស់ [ និង ] ដើម្បីរៀបចំ [ រាស្ត្រ ] សម្រាប់ការយាងមករបស់ព្រះអម្ចាស់ » ។ វាពុំសំដៅទៅលើពេល ដែល យ៉ូហាន បានទទួលបព្វជិតភាពអើរ៉ុននោះទេ ។ ការតែងតាំងបព្វជិតភាពរបស់ យ៉ូហាន ដល់បព្វជិតភាពអើរ៉ុន បានធ្វើឡើងបន្ទាប់ពីពិធីបុណ្យជ្រមុជទឹករបស់គាត់ ។ ( សូមមើល ប្រ៊ូស អ័រ ម៉ាក់ខន់ឃី *The Mortal Messiah: From Bethlehem to Calvary* វ៉ុល ៤ [ ឆ្នាំ ១៩៧៩–៨១ ] ១:៣៨៤–៨៥ ) ។

បព្វជិតភាពអើរ៉ុនរៀបចំខ្លួនយើង ឲ្យទទួលពិធីបរិសុទ្ធ និង ពរជ័យទាំងឡាយនៃបព្វជិតភាពមិលគីស្សាដែក ។ ឧទាហរណ៍ បន្ទាប់ពីពិធីបុណ្យជ្រមុជទឹក ដែលជាពិធីបរិសុទ្ធរបស់បព្វជិតភាពអើរ៉ុន នោះយើងទទួលអំណោយទានព្រះវិញ្ញាណបរិសុទ្ធតាមរយៈសិទ្ធអំណាចបព្វជិតភាពមិលគីស្សាដែក ។ នៅពេលយើងទទួលទានសាក្រាម៉ង់ ដែលជាពិធីបរិសុទ្ធមួយរបស់បព្វជិតភាពអើរ៉ុន នោះយើងរំឭកសេចក្ដីសញ្ញាដែលជួយញែកយើងឲ្យបរិសុទ្ធ និង ឲ្យយើងទទួលបានដៃគូព្រះវិញ្ញាណបរិសុទ្ធ និង ដើម្បីជួយយើងឲ្យត្រៀមខ្លួនទទួលបានពិធីបរិសុទ្ធ និង ធ្វើសេចក្ដីសញ្ញានៅក្នុងព្រះវិហារបរិសុទ្ធ ។ ការបម្រើរបស់យុវជនម្នាក់ក្នុងនាមជាអ្នកកាន់បព្វជិតភាពអើរ៉ុន រៀបចំខ្លួនគាត់ឲ្យទទួលបានបព្វជិតភាពមិលគីស្សាដែក ។

២. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកអាចធ្វើអ្វីនាពេលឥឡូវនេះ ដើម្បីត្រៀមខ្លួនទទួលពិធីបរិសុទ្ធនៃការសង្គ្រោះនៃដំណឹងល្អ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៣១–៤២

*ព្រះអម្ចាស់បង្រៀនអំពីសម្បថ និង សេចក្ដីសញ្ញានៃបព្វជិតភាព*



នៅពេលអ្នកសិក្សាអំពីសម្បថ និង សេចក្ដីសញ្ញានៃបព្វជិតភាព សូមចងចាំនៅក្នុងចិត្តថា « សម្បថគឺជាសេចក្ដីអះអាងដែលបានសច្ចា ថានឹងមានភក្ដីភាព និង ចិត្តស្មោះត្រង់ចំពោះការសន្យាទៅកាន់នរណាម្នាក់ ។ សេចក្ដីសញ្ញាគឺជាការសន្យាដ៏មុតមាំ រវាងភាគីទាំងពីរ ។ បព្វជិតភាពអើរ៉ុនត្រូវបានប្រទានឲ្យ តាមតែរយៈសេចក្ដីសញ្ញាប៉ុណ្ណោះ ។ អ្នកកាន់បព្វជិតភាពមិលគីស្សាដែក ទទួលបានបព្វជិតភាពដោយសម្បថ ក៏ដូចជាសេចក្ដីសញ្ញាដែលមិនមានការថ្លែងចេញមក ។ នៅពេលពួកអ្នកកាន់បព្វជិតភាពមានចិត្តស្មោះត្រង់ ហើយតម្កើងការហៅរបស់ខ្លួនទៅតាមអ្វីដែលព្រះត្រាស់បង្គាប់ នោះទ្រង់ប្រទានពរដល់ពួកគាត់ ។ ពួកអ្នកកាន់បព្វជិតភាពដែលមានចិត្តស្មោះត្រង់ដរាបដល់ទីបំផុត ហើយធ្វើនូវអ្វីដែលទ្រង់តម្រូវ នោះពួកគាត់នឹងទទួលបាននូវអ្វីគ្រប់យ៉ាងដែលព្រះវរបិតាមាន (គ. និង ស. ៨៤:៣៣–៣៩ ) » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « សម្បថ និង សេចក្ដីសញ្ញានៃបព្វជិតភាពscriptures.lds.org) ។ « សេចក្ដីសញ្ញា » គឺជាសេចក្ដីព្រមព្រៀងរបស់មនុស្សជាមួយព្រះ ហើយ « សម្បថ » គឺជាការសន្យាដ៏មុតមាំរបស់ព្រះជាមួយ អ្នកទាំងឡាយណាដែលរក្សាសេចក្ដីសញ្ញានោះ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៣១–៣២ បង្រៀនថា ពួកអ្នកកាន់បព្វជិតភាពនៅថ្ងៃចុងក្រោយ ( « ពួកកូនប្រុសរបស់ម៉ូសេ និង របស់អើរ៉ុន » ) នឹងធ្វើការនៅក្នុងដំណាក់ព្រះអម្ចាស់ ( ព្រះវិហារបរិសុទ្ធ ) ហើយពេញទៅដោយសិរីល្អនៃព្រះអម្ចាស់ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៣៣–៤៤ មានសម្បថ និងសេចក្ដីសញ្ញានៃបព្វជិតភាព ។ យើងរៀនចេញពីគោលការណ៍នេះ ៖ **បើអ្នកទាំងឡាយដែលបានទទួលបព្វជិតភាព តម្កើងការហៅរបស់ខ្លួន នោះព្រះនឹងញែកពួកគាត់ឲ្យបរិសុទ្ធ ហើយប្រទានដល់ពួកគាត់នូវអ្វីគ្រប់យ៉ាងដែលទ្រង់មាន ។**

៣. សូមសរសេរគោលការណ៍ដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ *ព្រះអម្ចាស់សន្យាថានឹង* . . . បន្ទាប់មក សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៣៣–៤៤ រួចស្វែងរកឲ្យបានយ៉ាងហោចណាស់ ការសន្យាចំនួនប្រាំ ដែលព្រះអម្ចាស់ប្រទានដល់អ្នកទាំងឡាយ ដែលធ្វើសម្បថ និង សេចក្ដីសញ្ញានៃបព្វជិតភាព ។ ( អ្នកអាចផ្ទៀងផ្ទាត់ ចម្លើយរបស់អ្នកជាមួយនឹងចម្លើយដែលមាននៅចុងបញ្ចប់នៃមេរៀននេះ ) ។

ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានបង្រៀនដូចខាងក្រោមនេះ អំពីការតម្កើងរបស់ពួកអ្នកកាន់បព្វជិតភាពលើការហៅរបស់ខ្លួន ៖



« យើងតម្កើងបព្វជិតភាពយើង ហើយពង្រីកការហៅរបស់យើង នៅពេលយើងបម្រើដោយមានចិត្តឧស្សាហ៍ព្យាយាម និង សេចក្ដីសោមនស្សក្នុងការទទួលខុសត្រូវដែលយើងត្រូវបានហៅដោយសិទ្ធអំណាចត្រឹមត្រូវ ។. . .

« យើងតម្កើងការហៅយើង យើងពង្រីកសក្ដានុពលនៃបព្វជិតភាពយើង នៅពេលយើងឈោងទៅជួយអ្នកដែលមានទុក្ខព្រួយ ហើយចម្រើនកម្លាំងដល់អ្នកដែលជំពប់ជើងដួល ។. . .

យើងតម្កើងការហៅរបស់យើង នៅពេលយើងដើរដោយទៀងត្រង់ និងសេចក្ដីសុចរិត » (Magnify Your Calling, » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៩ ទំព័រ ៤៨–៤៩ ) ។

សមាជិកសាសនាចក្រទាំងអស់ ដែលទទួលការហៅ និង ត្រូវបានញែកចេញ ទទួលបានពរជ័យតាមរយៈបព្វជិតភាពមិលគីស្សាដែកដើម្បីតម្កើងការហៅក្នុងសាសនាចក្រ ។ ប្រធាន ថូម៉ាស អេស ម៉នសុន បានផ្ដល់ការពន្យល់ដ៏សាមញ្ញមួយ អំពីរបៀបដែលយើងម្នាក់ៗ អាចតម្កើងការហៅរបស់យើង ៖ « តើបុគ្គលម្នាក់ តម្កើងការហៅយ៉ាងដូចម្ដេច ? គឺយ៉ាងសាមញ្ញដោយធ្វើការបម្រើ ដែលទាក់ទងទៅនឹងការហៅនោះ » ( « Priesthood Power » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ទំព័រ ៥១ ) ។



៤. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរខាងក្រោមនេះ អំពីអត្ថន័យនៃការតម្កើងការហៅ ៖

ក. តើអ្នកកាន់បព្វជិតភាព តម្កើងការហៅរបស់ខ្លួននៅក្នុងបព្វជិតភាពយ៉ាងដូចម្ដេច ?

ខ. តើអ្នកធ្លាប់មានពរ ដោយសារតែនរណាម្នាក់បានតម្កើងការហៅរបស់ខ្លួនដែរឬទេ ?

ករណីយកិច្ចរបស់ពួកអ្នកកាន់បព្វជិតភាពទាំងអស់ គឺត្រូវរៀបចំខ្លួនឯង និង មនុស្សទូទៅ ឲ្យទទួលពិធីបរិសុទ្ធនៃការសង្គ្រោះនៃដំណឹងល្អ ហើយរស់នៅតាមសេចក្ដីសញ្ញាដែលទាក់ទង ដើម្បីពួកគាត់អាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចជាមួយព្រះវរបិតាសួគ៌ ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១–៤២ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

ចម្លើយរបស់សកម្មភាពផ្គូផ្គង ៖ ( ១ ) គ, ( ២ ) ឃ, ( ៣ ) ក, ( ៤ ) ខ ។

ចម្លើយសម្រាប់លំហាត់ទី ៣ ដែលបង្ហាញអំពីការសន្យារបស់ព្រះអម្ចាស់ទៅដល់អ្នកទាំងឡាយ ដែលធ្វើសម្បថ និង សេចក្ដីសញ្ញានៃបព្វជិតភាព ( ចេញពី គ. និង ស. ៨៤:៣៣–៤៤ ) ៖ ព្រះអម្ចាស់នឹង (១) ញែកយើងជាបរិសុទ្ធដោយសារព្រះវិញ្ញាណ ( សូមមើល ខទី ៣៣ ) (២) សាងរូបកាយរបស់យើងជាថ្មី ( សូមមើល ខទី ៣៣ ) (៣) រាប់យើងក្នុងចំណោមកូនចៅអ័ប្រាហាំ—អាចនិយាយបានម្យ៉ាងទៀតថា ទ្រង់ប្រទានឲ្យយើងនូវពរជ័យដែលបានសន្យាដល់អ័ប្រាហាំ និង ពូជពង្សលោក ( សូមមើល ខទី ៣៤ ) (៤) ធ្វើឲ្យយើងជាពួករើសតាំង និង ជ្រើសរើសរបស់ទ្រង់ ( សូមមើល ខទី ៣៤ ) (៥) ប្រទានឲ្យយើងគ្រប់អ្វីៗទាំងអស់ ដែលព្រះវរបិតាមាន ( សូមមើល ខទី ៣៨) និង (៦) ប្រទានពួកទេវតាឲ្យថែរក្សាយើង ( សូមមើល ខទី ៤២ ) ។

មេរៀនទី ១៨ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៣–១២០

## សេចក្ដីផ្ដើម

នៅថ្ងៃទី ២២ និង ២៣ ខែ កញ្ញា ឆ្នាំ ១៨៣២ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានបង្រៀនពួកបរិសុទ្ធ អំពីសារៈសំខាន់នៃការស្ដាប់តាមព្រះបន្ទូលព្រះ ហើយបានវាយផ្ចាលពួកគេចំពោះការរាប់ដល់ព្រះគម្ពីរមរមន និង ព្រះបញ្ញត្តិមុនៗ ទុកជាគ្មានផលប្រយោជន៍ ។ បន្ថែមពីលើនោះ ទ្រង់បានគូសសម្គាល់អំពីប្រតិបត្តិការរបស់ពួកសាវក និង អ្នកកាន់បព្វជិតភាពទូទៅ ក្នុងការប្រកាសដំណឹងល្អពាសពេញពិភពលោក ហើយទ្រង់បានពន្យល់អំពីរបៀបដែលកិច្ចការនេះត្រូវបានសម្រេច ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៣–៦១

*ព្រះអម្ចាស់បង្រៀនអំពីសារៈសំខាន់ នៃការស្ដាប់តាមព្រះបន្ទូលព្រះ*

សូមពិចារណាអំពីការខិតខំរបស់អ្នក ក្នុងការសិក្សាព្រះគម្ពីរជារៀងរាល់ថ្ងៃ ។ តើអ្នកធ្វើបានល្អកម្រិតណា ក្នុងការសម្រេចបានគោលដៅនេះ ?

១. ជួនកាល វាមានការលំបាកដើម្បីមានទម្លាប់នៃការសិក្សាព្រះគម្ពីរជារៀងរាល់ថ្ងៃ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមរាយបញ្ជីឧបសគ្គមួយចំនួន ដែលអ្នកប្រឈមមុខក្នុងការព្យាយាមសិក្សាព្រះគម្ពីររាល់ថ្ងៃ ។ សូមសរសេរអំពីគ្រាមួយ ដែលអ្នកជ្រើសរើសសិក្សាព្រះគម្ពីរ ទោះជាមានការលំបាកយ៉ាងណាក្ដី ។ តើអ្នកបានទទួលពរ ដោយព្រោះការធ្វើដូច្នោះយ៉ាងដូចម្ដេចដែរ ?

នៅពេលអ្នកបន្តសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤ អ្នកនឹងរៀនសេចក្ដីពិត ដែលអាចបំផុសគំនិតអ្នកឲ្យបន្តខិតខំសិក្សាព្រះគម្ពីរជាប្រចាំថ្ងៃ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៣–៤៤ រួចស្វែងរកពាក្យ និង ឃ្លា ដែលបង្រៀនអំពីសារៈសំខាន់នៃការសិក្សា និង ការអនុវត្តន៍តាមព្រះបន្ទូលព្រះអម្ចាស់ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

### សិក្សាព្រះគម្ពីរជាប្រចាំថ្ងៃ

ការសិក្សាព្រះគម្ពីរជាប្រចាំថ្ងៃ នឹងបង្កើនសេចក្ដីជំនឿរបស់អ្នកទៅលើព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ វាក៏នឹងជួយអ្នកឲ្យយល់អំពី ផែនការនៃសេចក្ដីសង្គ្រោះដែរ ។ ប្រធាន ហាវើដ ដបុលយូ ហឹនធើរ បានបង្រៀនថា « វាប្រាកដណាស់ថា អ្នកដែលសិក្សាព្រះគម្ពីរជារៀងរាល់ថ្ងៃ សម្រេចបានឆ្ងាយជាង អ្នកដែលចំណាយពេញមួយថ្ងៃសិក្សាព្រះគម្ពីរ ហើយបន្ទាប់មកចេះតែឲ្យពេលកន្លងទៅពីមុនសិក្សាបន្តទៀត » ( « Reading the Scriptures » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ ទំព័រ ៦៤ ) ។

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៥–៤៦ ។ ខគម្ពីរទាំងនេះជួយយើងឲ្យយល់ថា **បើយើងស្ដាប់តាមព្រះបន្ទូលព្រះដោយឧស្សាហ៍ នោះយើងនឹងត្រូវបានបំភ្លឺតាមរយៈព្រះវិញ្ញាណនៃព្រះគ្រីស្ទ ។**

សូមកត់ចំណាំឃ្លា « ព្រះវិញ្ញាណនៃព្រះគ្រីស្ទ » នៅក្នុង ខទី ៤៥ ។ ឃ្លាមួយទៀតដែល មានន័យស្រដៀងនឹងនេះគឺ « ពន្លឺនៃព្រះគ្រីស្ទ » ។ ពន្លឺនៃព្រះគ្រីស្ទ គឺជា « អានុភាពមួយនៃសេចក្ដីល្អ ដែលមាននៅក្នុងមនុស្សទូទៅ ។. . . នៅក្នុងព្រះគម្ពីរ ពន្លឺនៃព្រះគ្រីស្ទ ពេលខ្លះត្រូវបានហៅថា ព្រះវិញ្ញាណនៃព្រះអម្ចាស់ ព្រះវិញ្ញាណនៃព្រះ ព្រះវិញ្ញាណនៃព្រះគ្រីស្ទ ឬ ពន្លឺនៃជីវិត ។

« ពន្លឺនៃព្រះគ្រីស្ទ មិនគួរយល់ច្រឡំជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធទេ ។ ពន្លឺនៃព្រះគ្រីស្ទមិនមែនជាតួអង្គ ដូចជាព្រះវិញ្ញាណបរិសុទ្ធនោះទេ ។ វាមានឥទ្ធិពលដឹកនាំមនុស្ស ឲ្យស្វែងរកដំណឹងល្អពិត ធ្វើបុណ្យជ្រមុជទឹក និង ទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ » (*ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* [ ឆ្នាំ ២០០៤ ] ទំព័រ ១១៨) ។

ប្រធាន ប៊ិយដ៍ ឃេ ផាកកឺ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា ពន្លឺនៃព្រះគ្រីស្ទគឺមាននៅក្នុងមនុស្សគ្រប់រូប ហើយ « ចំណេះដឹងអំពីភាពត្រឹមត្រូវ និង ភាពខុសឆ្គងនេះ ត្រូវបានហៅថា ពន្លឺនៃព្រះគ្រីស្ទ ការយល់ដឹងក្រមសីលធម៌ ឬ សតិសម្បជញ្ញៈ វាអាចដឹកនាំយើងឲ្យគ្រប់គ្រងទង្វើរបស់យើងបាន—លើកលែងតែយើងមានចិត្តមានះ ឬ មិនធ្វើតាមវា » ( The Light of Christ » *Ensign* ឬ *Liahona* ខែ មេសា ឆ្នាំ ២០០៥ ទំព័រ ៨–៩ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៧រួចបញ្ចប់គោលការណ៍ដូចតទៅនេះ ដោយយោងតាមអ្វីដែលអ្នករកឃើញ ៖ **បើយើងស្ដាប់តាមព្រះវិញ្ញាណ នោះយើងនឹង** ។

នៅពេលអ្នកអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៨ សូមកត់ចំណាំអ្វី ដែលព្រះវរបិតានឹងធ្វើ នៅពេលយើងមករកទ្រង់ ។

បន្ថែមពីលើការមានពន្លឺនៃព្រះគ្រីស្ទ បុគ្គលទាំងឡាយអាចទទួលបានដៃគូជាព្រះវិញ្ញាណបរិសុទ្ធ បន្ទាប់ពីពួកគេបានធ្វើសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក ។ តាមរយៈអំណោយទានព្រះវិញ្ញាណបរិសុទ្ធ នោះពួកគេអាចទទួលបានពន្លឺបន្ថែម ហើយត្រូវបានដឹកនាំត្រឡប់ទៅកាន់វត្តមានរបស់ព្រះវរបិតាវិញ ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

សូមគិតអំពីគ្រាមួយ ដែលអ្នកបានព្យាយាមដើរនៅក្នុងកន្លែងងងឹតស្លុង ។ តើមានភាពខុសប្លែកគ្នានៅក្នុងរបៀប ដែលអ្នកដើរកាលនៅក្នុងកន្លែងងងឹតស្លុង និង កាលនៅកន្លែងមានពន្លឺដែរឬទេ ? ជាញឹកញាប់ បទគម្ពីរលើកឡើងអំពីកន្លែងងងឹត ដើម្បីជានិមិត្តរូបនៃស្ថានភាពមួយខាងវិញ្ញាណ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៩–៥៣ រួចស្វែងរកថាតើនរណា ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថា ស្ថិតនៅក្នុងសេចក្ដីងងឹត និង មូលហេតុដែលបណ្ដាលឲ្យពួកគេស្ថិតនៅក្នុងស្ថានភាពនោះ ។

២. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការរស់នៅក្រោមចំណងនៃអំពើបាប មានសភាពដូចជាការស្ថិតនៅក្នុងសេចក្ដីងងឹតយ៉ាងដូចម្ដេច ?

សូមពិចារណាអំពីអ្វីដែលអ្នកគិតថាអ្នកត្រូវធ្វើ ដើម្បីស្ដាប់ឮព្រះសូរសៀងទ្រង់ឲ្យបានកាន់តែច្បាស់ ហើយចៀសវាងពីចំណងនៃអំពើបាប ។

បន្ថែមពីលើព្រះបន្ទូលដែលថា ពិភពលោកស្ថិតនៅក្នុងសេចក្ដីងងឹត នោះព្រះអម្ចាស់បានមានព្រះបន្ទូលថា គំនិតរបស់សមាជិកសាសនាចក្រត្រូវបានធ្វើឲ្យងងឹត ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៥៤–៥៦ ដោយស្វែងរកមូលហេតុចំនួនពីរថាតើហេតុអ្វីបានជាគំនិតរបស់ពួកគេក្លាយជាងងឹតទៅវិញ ។

ការរាប់អ្វីមួយទុកជាគ្មានផលប្រយោជន៍ មានន័យថា ការមិនអើពើ ឬ ប្រព្រឹត្តចំពោះវាដោយព្រហើន ឬ ខ្វះការយកចិត្តទុកដាក់ ។ តើគំនិតរបស់បុគ្គលម្នាក់ អាចត្រូវបានងងឹតដោយការរាប់អ្វីដែលពិសិដ្ឋ ទុកជាគ្មានផលប្រយោជន៍ យ៉ាងដូចម្ដេច ? នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៥៤ ឃ្លា « អ្នកបានរាប់ការណ៍ទាំងឡាយ ដែលអ្នកបានទទួលមក ទុកជាគ្មានផលប្រយោជន៍វិញ » សំដៅជាពិសេសទៅលើ ពួកបរិសុទ្ធដែលមិនប្រព្រឹត្តតាមអ្វី ដែលមានចែងនៅក្នុងព្រះគម្ពីរមរមន និង ព្រះបញ្ញត្តិមុនៗ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៥៧–៥៨ ដើម្បីស្វែងរកអ្វីដែលពួកបរិសុទ្ធ បានរាប់ទុកជាគ្មានផលប្រយោជន៍ និង អ្វីដែលពួកគេត្រូវធ្វើ ដើម្បីចៀសវាងពីការវាយ និង សេចក្ដីជំនុំជម្រះ ។ ( ពាក្យ *ការវាយ* នៅក្នុងខគម្ពីរទាំងនេះ សំដៅទៅលើទោសមកពីព្រះ ឬ ការកាត់ទោស ) ។

សូមកត់ចំណាំថា ពួកបរិសុទ្ធបានធ្វេសប្រហែសនឹងព្រះគម្ពីរមរមនក៏ដូចជា « ព្រះបញ្ញត្តិមុនៗ » ដែលព្រះអម្ចាស់បានប្រទានដល់ពួកគាត់ ។ អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ ៖ « ព្រះបញ្ញត្តិមុនៗទាំងនេះច្បាស់ជាវិវរណៈមុនៗរបស់ព្រះអម្ចាស់ ដូចមានចែងនៅក្នុងព្រះគម្ពីរប៊ីប ( ព្រះគម្ពីរសញ្ញាចាស់ និង សញ្ញាថ្មី ) និង វិវរណៈសម័យថ្មីទាំងឡាយ ដែលត្រូវបានប្រទានដល់ពួកបរិសុទ្ធ ( សូមមើល *History of the Church*, ១:៣១៨ ទំព័រ ៣២០ ) » ( Another Testament of Jesus Christ » *Ensign* ខែ មិនា ឆ្នាំ ១៩៩៤ ទំព័រ ៦៣ ) ។

ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៥៧–៥៨ យើងរៀនគោលការណ៍ដូចតទៅនេះ ៖ **បើយើងរាប់ព្រះបន្ទូលព្រះទុកជាគ្មានផលប្រយោជន៍ នោះចិត្តរបស់យើងនឹងត្រូវបានធ្វើឲ្យងងឹត ហើយយើងនឹងត្រូវបានដាក់នៅក្រោមការដាក់ទោស ។**

សូមអានសុន្ទរកថាខាងក្រោមនេះ ដែលថ្លែងដោយប្រធាន អ៊ែសរ៉ា ថាហ្វ បែនសឹន ៖



« តើលទ្ធផលដ៏អស់កល្បជានិច្ច ស្ថិតនៅលើការប្រព្រឹត្តរបស់យើង ចំពោះ [ ព្រះគម្ពីរមរមន ] ដែរឬទេ ? ពិតមែនហើយ វានាំឲ្យមានពរជ័យផង និង ការដាក់ទោសផង ។

« ពួកបរិសុទ្ធថ្ងៃចុងក្រោយគ្រប់រូប គួតែសិក្សាព្រះគម្ពីរនេះពេញមួយជីវិតខ្លួន ។ បើមិនដូច្នោះទេ ពួកគេកំពុងតែធ្វើឲ្យព្រលឹងខ្លួនធ្លាក់ក្នុងហានិភ័យ ហើយធ្វេសប្រហែសចំពោះការណ៍ ដែលអាចផ្ដល់ភាពរួមគ្នាខាងវិញ្ញាណ និង បញ្ញាពេញមួយជីវិតពួកគេ ។ មានភាពខុសគ្នាមួយរវាងអ្នកប្រែចិត្តជឿ ដែលសង់គ្រឹះនៅលើសិលានៃព្រះគ្រីស្ទ តាមរយៈព្រះគម្ពីរមរមន ហើយកាន់ខ្ជាប់ដំបងដែកនោះ និង អ្នកដែលមិនបានធ្វើដូចនោះសោះ ( « The Book of Mormon Is the Word of God » *Ensign* ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ៦៥ សូមមើលផងដែរ « The Book of Mormon Is the Word of God » *Ensign* ខែ មករា ឆ្នាំ ១៩៨៨ ទំព័រ ៥ ) ។

« បើសិនជាមានពួកបរិសុទ្ធជំនាន់ដំបូង ត្រូវបានស្ដីបន្ទោស ចំពោះការរាប់ព្រះគម្ពីរមរមនទុកជាគ្មានផលប្រយោជន៍នោះ តើយើងស្ថិតនៅក្រោមការដាក់ទោស តិចជាងពួកគេឬអី បើសិនជាយើងធ្វើដូចគ្នានោះដែរនោះ ?. . .

« . . .ចូរយើងកុំនៅក្រោមសេចក្ដីដាក់ទោសឡើយ ជាមួយនឹងទុក្ខទោស និងការវិនិច្ឆ័យរបស់វា ដោយការមិនយកចិត្តទុកដាក់ចំពោះអំណោយទានដ៏មហិមានិងអស្ចារ្យ ដែលព្រះអម្ចាស់បានប្រទានដល់យើងនេះឡើយ ។ ផ្ទុយទៅវិញ ចូរយើងបំពេញការសន្យា ដែលបានភ្ជាប់មកជាមួយនឹងការរក្សាការសន្យានោះទុកនៅក្នុងដួងចិត្តរបស់យើង » ( « The Book of Mormon—Keystone of Our Religion » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ទំព័រ ៤–៥, ៧ ) ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកនឹងប្រាប់អំពីការប្រព្រឹត្តរបស់អ្នក ចំពោះព្រះគម្ពីរមរមនយ៉ាងដូចម្តេច ?

ខ. តើអ្នកអាចធ្វើអ្វី ដើម្បីធ្វើឲ្យការសិក្សាព្រះគម្ពីររបស់អ្នក ប្រព្រឹត្តទៅពេញមួយជីវិតបាន ?

គ. តើអ្នកនឹងធ្វើអ្វី ដើម្បីសិក្សាព្រះគម្ពីរឲ្យកាន់តែមានភាពឧស្សាហ៍ព្យាយាម ហើយរស់នៅតាមសេចក្តីពិតទាំងឡាយ ដែលអ្នករៀនចេញពីព្រះគម្ពីរនោះ ?

## គោលលទ្ធិ និង សេចក្តីសញ្ញា ៨៤:៦២–១២០

*ព្រះអម្ចាស់ប្រទានសេចក្ដីណែនាំទៅដល់អ្នកទាំងឡាយ ដែលត្រូវបានហៅឲ្យផ្សាយដំណឹងល្អរបស់ទ្រង់*

សូមគិតអំពីមនុស្សរាប់កោដិនាក់ ដែលរស់នៅលើផែនដីនេះ ។ មនុស្សម្នាក់ៗត្រូវការមានឱកាស ដើម្បីរៀនអំពីដំណឹងល្អ ។ ទោះជាយ៉ាងណាក៏ដោយ វាមិនអាចសម្រេចបាននោះទេ ដែលគណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ត្រូវទទួលទទួលបន្ទុកប្រកាសដំណឹងល្អទៅកាន់អស់ទាំងជាតិសាសន៍ ដើម្បីបង្រៀនមនុស្សគ្រប់គ្នានោះ ។

សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៨៤:៦២ ដោយស្វែងរកការដឹកនាំ ដែលព្រះអម្ចាស់បានប្រទានដល់អ្នក ដែលមានការទទួលខុសត្រូវ ក្នុងការប្រកាសដំណឹងល្អ ។

សូមកត់ចំណាំថា ដោយសារតែថ្នាក់ដឹកនាំសាសនាចក្រ ពុំអាចទៅគ្រប់ទីកន្លែងដើម្បីប្រកាសដំណឹងល្អបាន នោះពួកលោកត្រូវបញ្ជូនមនុស្សដទៃទៀតឲ្យជួយដល់ពួកលោក ។ គោលលទ្ធិ និង សេចក្តីសញ្ញា ៨៤:៦២ អាចជួយយើងឲ្យយល់ថា **ពួកបរិសុទ្ធថ្ងៃចុងក្រោយទាំងអស់ មានការទទួលខុសត្រូវក្នុងការនាំដំណឹងល្អទៅកាន់ពិភពលោកទាំងមូល ។**

ប្រធាន ស្ពេនសើរ ដបុលយូ឵ ឃីមប៊ល បានមានប្រសាសន៍ ៖



« បទគម្ពីរបានថ្លែងយ៉ាងច្បាស់ថា សមាជិកនៃសាសនាចក្រទាំងអស់ មានការទទួលខុសត្រូវដើម្បីធ្វើកិច្ចការផ្សព្វផ្សាយសាសនា ៖ ‹ វាតម្រូវឲ្យមនុស្សម្នាក់ៗណាដែលបានព្រមាន នោះត្រូវព្រមានអ្នកជិតខាងរបស់ខ្លួន › ។ ( គ. និង ស. ៨៨:៨១ ) ។

« ពួកព្យាការីក្នុងគ្រាកាន់កាប់ត្រួតត្រានេះ ក៏បានបង្រៀនយ៉ាងច្បាស់អំពីបរិបទដែលថា ការងារផ្សព្វផ្សាយសាសនាគឺជាការទទួលខុសត្រូវរបស់សមាជិកទាំងអស់ដែរ ។ ប្រធាន ដេវីឌ អូ មិកឃេ បានបង្រៀនអំពីគោលការណ៍នេះ ដោយមានប្រសាសន៍អញ្ជើញថា ‹ សមាជិកគ្រប់រូបគឺជាអ្នកផ្សព្វផ្សាយសាសនា ! › ( សូមមើល *របាយការណ៍សន្និសីទ* ខែ មេសា ឆ្នាំ ១៩៥៩ ទំព័រ ១២២ ) » (« It Becometh Every Man, » *Ensign,* ខែ តុលា ឆ្នាំ ១៩៧៧,ទំព័រ ៣ ) ។

សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៨៤:៦៤–៧៥ រួចពិចារណាអំពីមូលហេតុដែលវាមានសារៈសំខាន់ ដែលដំណឹងល្អត្រូវតែបានប្រកាសទៅកាន់ពិភពលោកទាំងមូល ។

៤. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ យោងតាមអ្វីដែលអ្នកបានអាននៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៨៤:៦៤–៧៥ តើអ្នកនឹងសង្ខេបអំពីសារៈសំខាន់នៃការបង្រៀនដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដល់មនុស្សដទៃយ៉ាងដូចម្តេច ? បន្ទាប់មក សូមបញ្ចប់សេចក្ដីថ្លែងការណ៍ដូចតទៅនេះ ៖ *ខ្ញុំនឹងបំពេញការទទួលខុសត្រូវរបស់ខ្ញុំ ក្នុងការចែកចាយដំណឹងល្អដោយ . . .*

នៅក្នុងតារាងដូចតទៅនេះ សូមគូសបន្ទាត់ពីក្រោមការភ័យខ្លាចទាំងឡាយ ដែលអាចបណ្ដាលឲ្យអ្នកស្ទាក់ស្ទើរក្នុងការបម្រើព្រះអម្ចាស់ ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ៖ ភ័យខ្លាចក្នុងការចាកចេញពីផ្ទះ ក្រុមគ្រួសារ និង មិត្តភក្តិ ភ័យខ្លាចក្នុងការបាត់បង់ឱកាសអប់រំ និង ការងារ ភ័យខ្លាចថាមិនមានលទ្ធភាពបង់ប្រាក់បម្រើបេសកកម្ម ភ័យខ្លាចក្នុងការថ្លែងទៅកាន់មនុស្សទូទៅអំពីដំណឹងល្អ និង ភ័យខ្លាចក្នុងការរៀនភាសាថ្មី ។

ព្រះអម្ចាស់អះអាងជាថ្មីទៀតដល់អ្នក ដែលស្ទាក់ស្ទើរ ឬ ភ័យខ្លាចក្នុងការបម្រើទ្រង់ ជាអ្នកផ្សព្វផ្សាយសាសនា ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៨០, ៨៥, ៨៧–៨៨ ដោយស្វែងរកការទទួលខុសត្រូវ និង ពរជ័យនៃការងារផ្សព្វផ្សាយសាសនា ។ សូមបំពេញនៅក្នុងតារាង នូវអ្វីដែលអ្នករកឃើញ ៖

| ការទទួលខុសត្រូវនៃការងារផ្សព្វផ្សាយសាសនា | ពរជ័យនៃការងារផ្សព្វផ្សាយសាសនា |
|---|---|
| | |

ខគម្ពីរទាំងឡាយដែលអ្នកបានសិក្សា បញ្ជាក់ថា **នៅពេលយើងចែកចាយដំណឹងល្អ នោះព្រះអម្ចាស់នឹងគង់នៅជាមួយយើង នឹងការពារយើង ហើយនឹងពង្រឹងយើង ។**

៥. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមពន្យល់អំពីរបៀបដែលការសន្យាដែលបានមានព្រះបន្ទូលនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៨០, ៨៥, ៨៨ អាចនឹងមានអានុភាពលើបំណងប្រាថ្នា និង សមត្ថភាពរបស់អ្នក ក្នុងការចែកចាយដំណឹងល្អ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៨៩–៩៧ ព្រះអម្ចាស់បានអះអាងថា មនុស្សណាដែលទទួលអ្នកផ្សព្វផ្សាយសាសនារបស់ទ្រង់ នោះពួកគេក៏ទទួលទ្រង់ដែរ ហើយក៏នឹងមានពរ ។ ទ្រង់ក៏បានបង្រៀនផងដែរថា មនុស្សណាដែលមិនទទួលពួកអ្នកបម្រើទ្រង់ ថែមទាំងព្រះបន្ទូលទ្រង់នោះ នឹងបាត់បង់ពរជ័យ ហើយត្រូវបណ្ដាសា ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៩៨–១០២ ។ ខគម្ពីរទាំងនេះមាននូវទំនុកបទចម្រៀងនៃសេចក្ដីអំណរ និង ទំនុកសរសើរតម្កើង ដែលទាក់ទងទៅនឹងការប្រោសលោះនៃទីក្រុង ស៊ីយ៉ូន ។ ការប្រោសលោះនៃទីក្រុង ស៊ីយ៉ូន សំដៅទៅលើស្ថានភាព ដែលរាស្ត្រនៃសេចក្ដីសញ្ញារបស់ព្រះអម្ចាស់នឹងរីករាយ នៅពេលពួកគេជ្រើសរើសមករកទ្រង់ ហើយទទួលពិធីបរិសុទ្ធទាំងអស់ និង ពរជ័យទាំងឡាយនៃដំណឹងល្អ ។

តើអ្នកគិតថា ហេតុអ្វីបានជាព្រះអម្ចាស់ហៅអ្នកផ្សព្វផ្សាយសាសនាឲ្យបម្រើជាដៃគូ ?

សូមគិតអំពីការហៅដទៃទៀតនៅក្នុងសាសនាចក្រ ដែលសមាជិកសាសនាចក្របម្រើជាមួយមនុស្សម្នាក់ ឬ មនុស្សច្រើននាក់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១០៦, ១០៩–១០ រួចស្វែងរកការណ៍ដែលព្រះអម្ចាស់បានណែនាំឲ្យសមាជិកសាសនាចក្រធ្វើ ដើម្បីពង្រឹងគ្នាទៅវិញទៅមក ។



គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:១០៦ បង្រៀនថា **អ្នកដែលមានកម្លាំងខ្លាំងក្នុងវិញ្ញាណ ត្រូវស្អាងអ្នកដែលទន់ខ្សោយឡើង ។**

៦. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើនៅពេលណា ដែលអ្នកធ្លាប់ត្រូវបានស្អាងឡើងដោយការធ្វើការជាមួយនរណាម្នាក់ដែលមានកម្លាំងខ្លាំងក្នុងវិញ្ញាណ ?

ខ. តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីស្វែងរកវិធីលើកទឹកចិត្ត ហើយពង្រឹងមនុស្សទូទៅបាន ?

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៤៣–១២០ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៨ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥–៨៦

## សេចក្ដីផ្ដើម

គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥ គឺជាចំណែកមួយនៃសំបុត្រដ៏បំផុសគំនិត ដែលព្យាការី យ៉ូសែប ស្ម៊ីធ បានផ្ញើជូន វិលលាម ដ័បបុលយូ ហ្វែប្ស នៅថ្ងៃទី ២៧ វិច្ឆិកា ឆ្នាំ ១៨៣២ ។ នៅក្នុងសំបុត្រនេះ ព្យាការីបានពន្យល់ថា ព្រះអម្ចាស់មានព្រះទ័យឲ្យបញ្ជីប្រវត្តិដ៏ត្រឹមត្រូវមួយ ត្រូវបានធ្វើឡើងអំពីអ្នកដែលបានរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ នៅរដ្ឋ មិសសួរី ។ ក្រោយមក នៅថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ១៨៣២ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៦ នៅពេលលោកកំពុងធ្វើកំណែដ៏បំផុសគំនិតលើព្រះគម្ពីរប៊ីប ។ វិវរណៈនេះបានផ្ដល់ការបកស្រាយបន្ថែមអំពីរឿងប្រដូចនៃស្រូវ និង ស្រងែ និង អំពីតួនាទីរបស់បព្វជិតភាពក្នុងការជួយដល់ព្រះអម្ចាស់ ប្រមូលពួកសុចរិតនៅថ្ងៃចុងក្រោយបង្អស់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥

*ស្មៀនរបស់ព្រះអម្ចាស់ ត្រូវរក្សាបញ្ជីប្រវត្តិនៃរាស្ត្ររបស់ព្រះ*

សូមស្រមៃថាអ្នកស្ថិតនៅក្នុងក្រុមកីឡាមួយក្រុម ដែលមានសមត្ថភាពក្លាយទៅជាក្រុមមួយដ៏ឆ្នើម ។ បន្ទាប់ពីប៉ុន្មានថ្ងៃក្រោយពីការលេងជាមួយក្រុមនេះ អ្នកសង្កេតឃើញថា មានសមាជិកក្រុមម្នាក់គឺជាកីឡាករអាត្មានិយម ខ្លះទៀតមិនលេងក្នុងទីតាំងខ្លួនឲ្យបានត្រឹមត្រូវ និង ខ្លះទៀតមិនស្ដាប់តាមគ្រូបង្វឹកឡើយ ។ ហេតុអ្វីបានជាវាអាចនឹងមានការលំបាក សម្រាប់ក្រុមរបស់អ្នកដើម្បីប្រកួតយកឈ្នះ ? តើមានអ្វីដែលតម្រូវឲ្យកែប្រែ ដើម្បីឲ្យក្រុមនេះអាចប្រកួតបានកាន់តែប្រសើរឡើង ?

ស្ថានភាពស្រដៀងគ្នានេះ បានចាប់ផ្ដើមកើតឡើងក្នុងឆ្នាំ ១៨៣២ នៅពេលមានសមាជិកសាសនាចក្របានធ្វើដំណើរមកដល់រដ្ឋ មិសសួរី កាន់តែច្រើនឡើងៗ ។ ពួកបរិសុទ្ធជាច្រើននៅរដ្ឋ មិសសួរី បានរស់នៅដោយធ្វើតាមក្រឹត្យវិន័យទាំងឡាយដែលព្រះអម្ចាស់បានដាក់ចំពោះការស្ថាបនាទីក្រុង ស៊ីយ៉ូន ឡើង ។ ទោះជាយ៉ាងណាក៏ដោយ សមាជិកសាសនាចក្រមួយចំនួនពុំបានគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់នោះទេ ហើយបានធ្វើដំណើរទៅកាន់រដ្ឋ មិសសួរី ដោយពុំមានបណ្ណចេញពីថ្នាក់ដឹកនាំរបស់ពួកគេឡើយ ( ដែលតម្រូវដោយក្រឹត្យវិន័យរបស់ព្រះអម្ចាស់ មាននៅក្នុង គ. និង ស. ៧២:១៧–១៨, ២៥ ) ។ បណ្ណនោះគឺជាក្រដាសមួយសន្លឹកដែលមានហត្ថលេខារបស់ប៊ីស្សពនៃសាសនាចក្រ ឬ ពួកអែលឌើរជាអធិបតីបីរូបនៃសាសនាចក្រ ថ្លែងថា បុគ្គលនេះសក្ដិសម និង មានជំហរល្អ ហើយអាចធ្វើកិច្ចត្រួតត្រាបាន ។ ទោះជា សមាជិកសាសនាចក្រទាំងអស់នៅរដ្ឋ មិសសួរី ត្រូវបានត្រាស់បង្គាប់ឲ្យថ្វាយទ្រព្យសម្បត្តិខ្លួនទៅកាន់សាសនាចក្រក្តី ក៏សមាជិកមួយចំនួនបានធ្វើដំណើរមកដល់ដោយពុំមានធនធានអ្វីដើម្បីថ្វាយឡើយ ដែលប្រជាជនកាន់តែមានការលំបាក ។ យ៉ាងហោចណាស់ មានសមាជិកម្នាក់ដែលបានថ្វាយទ្រព្យសម្បត្តិ បានទាមទារយកទៅវិញ នៅពេលពួកគេចាកចេញពីសាសនាចក្រ ។ សមាជិកខ្លះទៀតនៅរដ្ឋ មិសសួរី បានបដិសេធមិនថ្វាយទ្រព្យសម្បត្តិរបស់ខ្លួនទៅដល់សាសនាចក្រឡើយ ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

   ក. តើឥរិយាបថដែលបានប្រកាន់ដោយសមាជិកសាសនាចក្របែបនេះ មានសភាពដូចជាកីឡាករដែលមិនសកម្មក្នុងក្រុមយ៉ាងដូចម្ដេច ?

   ខ. ហេតុអ្វីបានជាវាអាចជាការលំបាក ក្នុងការស្ថាបនាទីក្រុង ស៊ីយ៉ូន ឡើងនៅក្នុងស្ថានភាពបែបនេះ ?

សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥ ដើម្បីយល់អំពីរបៀបដែលព្យាការី យ៉ូសែប ស្ម៊ីធ បានឆ្លើយតបទៅនឹងឧបសគ្គទាំងនេះនៅរដ្ឋ មិសសួរី ។


យ៉ូហាន វិតមើរ

សំបុត្ររបស់ យ៉ូសែប ស្ម៊ីធ បានចែងអំពីសេចក្ដីណែនាំចំពោះស្មៀនរបស់ព្រះអម្ចាស់គឺ យ៉ូហាន វិតមើរ ដែលបានរស់នៅក្នុងរដ្ឋ មិសសួរី ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥:១–២ ដោយស្វែងរកការណ៍ ដែលព្រះអម្ចាស់បានណែនាំឲ្យស្មៀនសាសនាចក្រនៅរដ្ឋ មិសសួរី ធ្វើ ។ ( នៅពេលអ្នកសិក្សាខគម្ពីរទាំងនេះ វាអាចនឹងជួយក្នុងការដឹងថា ពួកអ្នកក្បត់សាសនាគឺជាពួកដែលបានក្បត់នឹងសាសនា ឬ ដកខ្លួនចេញពីសាសនាចក្រ ហើយមិនទទួលស្គាល់សេចក្ដីជំនឿ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥:៣–៥ ដោយស្វែងរកមូលហេតុ ដែលមនុស្សមួយចំនួនពុំមានឈ្មោះនៅក្នុងកំណត់ត្រាសាសនាចក្រ ។ នៅក្នុង ខទី ៣ ឃ្លា « ពួកអ្នកទាំងនោះដែលពុំបានទទួលកេរមរតករបស់ខ្លួន » សំដៅទៅលើសមាជិកសាសនាចក្រ ដែលបដិសេធមិនរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ដូចដែលព្រះអម្ចាស់បានត្រាស់បង្គាប់ ។

គឺដូចជាកំណត់ត្រាដែលបានរក្សាទុកនៅជំនាន់ដំបូងរបស់សាសនាចក្រដែរ នោះកំណត់ត្រាក៏ត្រូវបានរក្សាទុកនៅជំនាន់របស់យើងនេះ ដើម្បីឲ្យបានគង់វង្សជាកំណត់ត្រានៃឈ្មោះសមាជិកដ៏ស្មោះត្រង់ ក៏ដូចជាប្រវត្តិនៃកិច្ចការរបស់ពួកគេផងដែរ ។ គោលការណ៍មួយ ដែលយើងរៀនចេញពីសំបុត្ររបស់ព្យាការីគឺ **បើយើងរស់នៅតាមក្រឹត្យវិន័យទាំងឡាយរបស់ព្រះ នោះឈ្មោះរបស់យើងនឹងត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុនៃសាសនាចក្រ ជាសមាជិកដ៏ស្មោះត្រង់ ។**

២. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីការណ៍ដែលអ្នកត្រូវតែធ្វើដើម្បីឲ្យឈ្មោះរបស់អ្នក ត្រូវបានកត់ត្រាជាសមាជិកសាសនាចក្រដ៏ស្មោះត្រង់ ។ ( បន្ទាប់ពីអ្នកបានបញ្ចប់លំហាត់នេះហើយ សូមផ្ទៀងផ្ទាត់អ្វីដែលអ្នកបានសរសេរជាមួយនឹង ចម្លើយដែលមាននៅចុងបញ្ចប់នៃមេរៀននេះ ) ។

សេចក្ដីយោងចំពោះ « អ្នកខ្លាំងពូកែ និង មានឫទ្ធម្នាក់ » ( គ. និង ស. ៨៥:៧ ) ជាអ្នកដែលត្រូវតាំងដំណាក់នៃព្រះឲ្យមានរបៀបរៀបរយ និង សេចក្ដីយោងចំពោះ « ដាក់ដៃទៅទប់ហឹបធំនៃព្រះ » ( គ. និង ស. ៨៥:៨ ) ត្រូវបានប្រើប្រាស់ដោយពួកអ្នកក្បត់សាសនាជាច្រើន ដើម្បីអះអាងថាការបែកចេញពីសាសនាចក្ររបស់ពួកគេនោះ គឺជារឿងត្រឹមត្រូវ ។ ពួកគេអះអាងថាប្រធានជាច្រើននៃសាសនាចក្របានបាត់បង់ការសព្វព្រះទ័យពីព្រះអម្ចាស់ ហើយត្រូវបានបោះបង់ចោល ហើយថាពួកគេដែលជាអ្នកក្បត់សាសនានោះ គឺជា « អ្នកខ្លាំងពូកែ និង មានឫទ្ធម្នាក់ » ដែលត្រូវបានហៅដោយព្រះដើម្បីរៀបចំអ្វីៗឲ្យបានត្រឹមត្រូវ ។ សេចក្ដីអះអាងបែបនេះ មានសភាពផ្ទុយគ្នាពីអត្ថន័យនៃបទគម្ពីរ ។ នៅក្នុងសេចក្ដីថ្លែងការណ៍ជាផ្លូវការមួយ ចេញក្នុងឆ្នាំ ១៩០៥ គណៈប្រធានទីមួយ ( យ៉ូសែប អេហ្វ ស្ម៊ីធ, យ៉ូហាន អ័រ វិនឌើរ និង អាន់ថុន អេជ ឡាន់ ) បានពិភាក្សាអំពីស្ថានភាពដែលនាំឲ្យមានវិវរណៈនេះ និង អ្នកទាំងឡាយដែល ឃ្លាទាំងពីរនេះសំដៅទៅលើ ៖

> « ជាដំបូងបង្អស់ វាត្រូវបានសង្កេតឃើញថា ប្រធានបទនៃអត្ថន័យសំបុត្រនេះទាំងស្រុង [ សំបុត្ររបស់ព្យាការី ជូនដល់ វិលលាម ដ័បបុលយូ ហ្វែប្ស ] ដែលផ្នែករបស់វា ក៏ត្រូវបានទទួលស្គាល់ថាជាវិវរណៈ នៅពេលក្រោយៗមកទៀតដែរនោះ [គ. និង ស. ៨៥ ] ទាក់ទងទៅនឹងកិច្ចការសាសនាចក្រនៅរដ្ឋ មិសសួរី ការប្រមូលផ្ដុំពួកបរិសុទ្ធទៅកាន់ដែនដីនោះ និង ការទទួលបានកេរមរតក នៅក្រោមក្រឹត្យវិន័យនៃការថ្វាយ និង កិច្ចត្រួតត្រា ហើយព្យាការីដោះស្រាយជាពិសេសជាមួយបញ្ហានៃអ្វីដែលកើតឡើង អំពីអ្នកដែលពុំអាចទទួលបានកេរមរតករបស់ខ្លួនតាមរយៈលិខិតបង្គាប់ ឬ បណ្ណកម្មសិទ្ធពីប៊ីស្សព ។
>
> « វាបានកើតឡើងនៅអំឡុងពេលស្ថានភាពនៃការបះបោរ និន្នាឈ្នានីស ភាពធ្មើងឆ្មៃ ការឥតជំនឿ និង ភាពរឹងរូសនៃចិត្ត បានរីករាលដាលក្នុងចំណោមពួកបងប្អូនប្រុសនៅទីក្រុង ស៊ីយ៉ូន—គឺ ឃុំចាកសុន រដ្ឋ មិសសួរី—នៅក្នុងគ្រប់កិច្ចការទាំងអស់ដែលប៊ីស្សព ប៉ាទ្រិច បានចូលរួម ដែលពាក្យពេចន៍ទាំងឡាយនៃវិវរណៈនេះ ត្រូវបានដកស្រង់ចេញពីសំបុត្រផ្ញើជូន វិលលាម ដ័បបុលយូ ហ្វែប្ស ចុះនៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៨៣២ ។ ‹ មនុស្សនោះដែលត្រូវបានហៅពីព្រះ ហើយបានតែងតាំងឡើង › ឲ្យ ‹ ចែកដល់ពួកបរិសុទ្ធ នូវកេរអាកររបស់ពួកគេ ›—គឺ អែតវឺត ប៉ាទ្រិច—បានគិតខុសឆ្គងនៅពេលនោះ ធ្វេសប្រហែសនឹងករណីយកិច្ចរបស់ខ្លួន ហើយដាក់ ‹ ដៃរបស់គាត់ទៅទប់ហឹបធំនៃព្រះ › ដូច្នេះហើយ គាត់ត្រូវបានព្រមានអំពីសេចក្ដីជំនុំជម្រះរបស់ព្រះដែលនឹងកើតឡើង ហើយការព្យាករណ៍ត្រូវបានធ្វើឡើងថា ‹ អ្នកខ្លាំងពូកែ និង មាន

> ឬទ្ធម្នាក់ › នឹងត្រូវបានបញ្ជូនពីព្រះមកជំនួសតំណែងរបស់គាត់ ជាគណៈប៊ីស្សព—ជាម្នាក់ដែលមានស្មារតី និង អំណាចនៃតំណែងជាន់ខ្ពស់នោះស្ថិតនៅជាមួយ ដែលគាត់នឹងមានអំណាចដើម្បី ‹ តាំងដំណាក់នៃព្រះឲ្យមានរបៀបរៀបរយ និង ដើម្បីរៀបចំតាមប្លង់នូវកេរមរតកនៃពួកបរិសុទ្ធ › និយាយបានម្យ៉ាងទៀតគឺ បុគ្គលម្នាក់នឹងធ្វើកិច្ចការ ដែល ប៊ីស្សព អែតវឺត ប៉ាទ្រិច ត្រូវបានចាត់តាំង ប៉ុន្តែ ពុំអាចសម្រេចវាបាន ។. . .
>
> « . . . ហើយដោយហេតុថាតាមរយៈការប្រែចិត្ត និង ការលះបង់ និង ការរងទុក្ខរបស់គាត់ នោះប៊ីស្សព អែតវឺត ប៉ាទ្រិច ទទួលបានដោយឥតសង្ស័យនូវការបន្ធូរបន្ថយ លើសេចក្ដីជំនុំជម្រះដ៏គួរឲ្យភ័យខ្លាចទាស់នឹងគាត់ ‹ ដោយសារព្រួញនៃសេចក្ដីស្លាប់ ដូចជាដើមឈើដែលត្រូវកម្ទេចដោយរន្ទះបាញ់ › ដូច្នេះ ឱកាសនៃការបញ្ជូនបុគ្គលម្នាក់ទៀតទៅកាន់តំណែងគាត់—ដែលជា ‹ អ្នកខ្លាំងពូកែ និង មានឬទ្ធម្នាក់ ដើម្បីតាំងដំណាក់នៃព្រះឲ្យមានរបៀបរៀបរយ និង ដើម្បីរៀបចំតាមប្លង់នូវកេរមរតកនៃពួកបរិសុទ្ធ › នោះ ក៏អាចត្រូវបានចាត់ទុកជារឿងកន្លងហួសទៅ ហើយហេតុការណ៍នៃការព្យាករណ៍ទាំងមូលត្រូវបានបញ្ចប់ » ( នៅក្នុង James R. Clark, comp., *សារលិខិតគណៈប្រធានទីមួយ នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ* វ៉ុល ៦ [ ឆ្នាំ ១៩៦៥–៧៥] ៤:១១២, ១១៥, ១១៧ ) ។

សូមស្រមៃថា អ្នកមានផែនការចូលរួមក្នុងព្រឹត្តិការណ៍ដ៏មានកិត្យានុភាពមួយ ( ឧទាហរណ៍ អាពាហ៍ពិពាហ៍របស់មនុស្សល្បីល្បាញម្នាក់ ឬ ពិធីទទួលទានអាហារពេលល្ងាចជាមួយ នរណាម្នាក់ដែលអ្នកតែងប្រាថ្នាចង់ជួប ) ។ តើអ្នកនឹងមានអារម្មណ៍ដូចម្ដេច នៅពេលអ្នកបានទៅដល់ពិធីនោះ ប៉ុន្តែ ពុំត្រូវបានអនុញ្ញាតឲ្យចូលរួមដោយសារតែអ្នកពុំមានឈ្មោះនៅក្នុងបញ្ជីភ្ញៀវកិត្តិយស ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥:៩–១១ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលថានឹងកើតឡើងចំពោះពួកបរិសុទ្ធជំនាន់ដំបូងទាំងនោះ ដែលឈ្មោះរបស់ខ្លួនពុំបានសរសេរទុកនៅក្នុងសៀវភៅរំឭករបស់ព្រះអម្ចាស់ ឬ សៀវភៅច្បាប់របស់ព្រះ ។ ( សូមចងចាំថា ចំណងជើងសៀវភៅទាំងនេះសំដៅទៅលើដំណើររឿងនៃសេចក្ដីជំនឿ និង កិច្ចការរបស់ពួកបរិសុទ្ធនៅជំនាន់ដំបូង ) ។

កំណត់ត្រាត្រូវបានរក្សាទុកទាំងនៅលើផែនដី និង នៅឯស្ថានសួគ៌ ។ យើងទាំងអស់គ្នានឹងត្រូវកត់ត្រាអំពីការប្រព្រឹត្ត និង សេចក្ដីជំនឿរបស់យើងនៅក្នុងការរស់នៅតាមក្រឹត្យវិន័យរបស់ព្រះ ។ សូមពិចារណាអំពីឥរិយាបថ និង ការគោរពប្រតិបត្តិចំពោះក្រឹត្យវិន័យទាំងឡាយនៃព្រះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៦

*ព្រះអម្ចាស់ពន្យល់បន្ថែម អំពីរឿងប្រដូចនៃស្រូវសាលី និង ស្រងែ*

រឿងប្រដូច គឺជារឿងដែលប្រើប្រាស់ការប្រៀបធៀប ដើម្បីបង្រៀនអំពីសេចក្ដីពិតមួយ ។ សូមអានរឿងប្រដូចនៃស្រូវសាលី និង ស្រងែនៅក្នុង ម៉ាថាយ ១៣:២៤–៣០ ។




តើអ្នកគិតថា ស្រូវសាលីតំណាងឲ្យអ្វី ?

តើអ្នកគិតថា ស្រងែតំណាងឲ្យអ្វី ?

អ្នកអាចផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក ចំពោះសំណួរខាងលើនេះ ដោយយោងទៅលើ ម៉ាថាយ ១៣:៣៨ ។

៣. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ ហេតុអ្វីបានជាបុរសនៅក្នុងរឿងប្រដូចនោះ ចង់រង់ចាំការដកស្រងែចេញ ?

ស្រងែគឺជាស្មៅមួយប្រភេទដែលចង្រៃ ។ ស្រូវសាលី និង ស្រងែមានលក្ខណៈស្ទើរតែដូចគ្នាសុទ្ធសាធ នៅពេលវាបញ្ចេញពន្លកមក ប៉ុន្តែ គេអាចបែងចែកវាបាននៅពេលវាដុះធំឡើង ។ បើអ្នកច្រូតកាត់ព្យាយាមដកស្រងែចេញ ពីមុនស្រូវសាលី និង ស្រងែទុំសុស នោះស្រូវសាលីជាច្រើនក៏នឹងត្រូវបំផ្លាញដែរ ។

៤. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៦:១–៦ ដោយស្វែងរកអត្ថន័យនៃស្រែ អ្នកព្រួសគ្រាប់ពូជ និង ខ្មាំងសត្រូវ ។ សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ ដោយផ្អែកទៅលើការពន្យល់របស់ព្រះអម្ចាស់អំពីនិមិត្តរូបទាំងឡាយ តើអ្នកនឹងសង្ខេបអត្ថន័យនៃរឿងប្រដូចនេះយ៉ាងដូចម្ដេច ?

ព្យាការី យ៉ូសែប ស្ម៊ីធ បានកំពុងតែត្រួតពិនិត្យ ហើយកែប្រែលើកំណែព្រះគម្ពីរប៊ីប នៅពេលលោកបានទទួលវិវរណៈនេះ ។ យោងតាម ម៉ាថាយ ១៣:៣០ ព្រះអម្ចាស់បានត្រាស់សម្ដែងថា ស្រងែនឹងត្រូវប្រមូលជាដំបូង ហើយចងជាកណ្ដាប់ទុកសម្រាប់ដុត ឯស្រូវសាលី ឲ្យប្រមូលដាក់ក្នុងជង្រុកវិញ ( សូមមើល ការបកប្រែរបស់ យ៉ូសែប ស្ម៊ីធ ម៉ាថាយ ១៣:២៩ [ នៅក្នុង ម៉ាថាយ ១៣:៣០ លេខយោង *ខ* ] ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៦:៧ ដោយស្វែងរកការយល់ដឹង ដែលវិវរណៈនេះផ្ដល់ឲ្យអំពីរបៀបនៃការប្រមូល ។ តើអ្នកគិតថា ពួកសុចរិតនឹងត្រូវបានប្រមូលនៅថ្ងៃចុងក្រោយបង្អស់យ៉ាងដូចម្ដេច ?



សូមពិចារណាអំពីរបៀបដែលអ្នកផ្សព្វផ្សាយសាសនាបង្រៀនមនុស្ស អំពីដំណឹងល្អដែលបានស្ដារឡើងវិញ ទាក់ទងទៅនឹងរឿងប្រដូចនៃស្រូវសាលី និង ស្រងែ ។

យើងក៏អាចជួយក្នុងការប្រមូលពួកសុចរិតបាន ដោយការចែកចាយដំណឹងល្អជាមួយមនុស្សទូទៅ ។ មនុស្សត្រូវបានប្រមូលទៅក្នុងក្រោល នៅពេលពួកគេទទួលស្គាល់ព្រះគ្រីស្ទ ហើយទទួលពិធីបុណ្យជ្រមុជទឹក ។ ការចងចាំអំពីរបៀបជាច្រើនដែលយើងមានពរក្នុងនាមជាសមាជិកសាសនាចក្រនៃព្រះអម្ចាស់ អាចធ្វើឲ្យយើងកាន់តែមានបំណងប្រាថ្នាចែកចាយពរជ័យនោះជាមួយមនុស្សទូទៅ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៦:៨–១០ រួចស្វែងរករបៀបដែលយើងមានពរ ក្នុងនាមជាសមាជិកក្នុងសាសនាចក្រនៃព្រះអម្ចាស់ ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នករកឃើញ ។

ឃ្លា « អ្នករាល់គ្នាជាអ្នកគ្រងមរតកពេញច្បាប់ » នៅក្នុង ខទី ៩ មានន័យថា សមាជិកក្នុង សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជាផ្នែកនៃសេចក្ដីសញ្ញាដែលព្រះបានធ្វើជាមួយ អ័ប្រាហាំ តាមរយៈសេចក្ដីសញ្ញាដែលអ័ប្រាហាំត្រូវបានសន្យាថា ពូជពង្សរបស់លោកនឹងរីករាយជាមួយនឹងពរជ័យនៃបព្វជិតភាព ហើយនឹងចែកចាយពរជ័យទាំងនោះជាមួយមនុស្សទូទៅ ( សូមមើល អ័ប្រាហាំ ២:៩–១១ ) ។

សូមពិចារណាអំពីសំណួរដូចតទៅនេះ ៖ តើអ្នកធ្លាប់មានពរតាមរយៈបព្វជិតភាពដូចម្ដេចខ្លះ ?

ខណៈពេលពិចារណាអំពីសំណួរខាងលើនេះ អ្នកអាចនឹងគិតអំពីពិធីបរិសុទ្ធនានា ដែលអ្នកអាចទទួលបានតាមរយៈបព្វជិតភាព រួមបញ្ចូលទាំងពិធីបរិសុទ្ធនៃការសង្គ្រោះនៃពិធីបុណ្យជ្រមុជទឹក និង អំណោយទានព្រះវិញ្ញាណបរិសុទ្ធ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៦:១១ រួចស្វែងរករបៀប ដែលយើងត្រូវជួយដល់មនុស្សទូទៅ ។

ឃ្លា « ពន្លឺដល់ពួកសាសន៍ដទៃ » មានន័យថា ការធ្វើជាគំរូសុចរិតដល់មនុស្ស ដែលពុំមានពរជ័យនៃដំណឹងល្អ ។ ខទី ១១ បង្រៀនថា **យើងអាចនាំយកសេចក្ដីសង្គ្រោះទៅដល់មនុស្សដទៃ ដោយការជួយពួកគេឲ្យទទួលបានពរជ័យនៃបព្វជិតភាព ។** អ្នកអាចនឹងចង់សរសេរគោលការណ៍នេះ នៅគែមលើព្រះគម្ពីររបស់អ្នក ។

សូមពិចារណាអំពីបទពិសោធន៍នៅពេលអ្នក ឬ នរណាម្នាក់ដែលអ្នកស្គាល់ ធ្វើគំរូល្អចំពោះនរណាម្នាក់ ឬ បានជួយមនុស្សម្នាក់ទៀត ឲ្យទទួលបានពរជ័យទាំងឡាយនៃបព្វជិតភាព ។

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្វីដែលអ្នកនឹងធ្វើ ដើម្បីធ្វើជា « ពន្លឺ » ដល់មនុស្សទូទៅ ដើម្បីឲ្យពួកគេអាចទទួលបានពិធីបរិសុទ្ធ និង ពរជ័យទាំងឡាយនៃបព្វជិតភាព ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៥–៨៦ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

*សូមផ្ទៀងផ្ទាត់គំនិតខាងក្រោមទៅនឹង គំនិតរបស់អ្នកដែលបានសរសេរនៅក្នុង សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក លំហាត់ទី ២ ៖* ដើម្បីមានឈ្មោះរបស់យើងកត់ត្រានៅក្នុងសៀវភៅវិន័យរបស់ព្រះ ឬ សៀវភៅពង្ស យើងត្រូវតែទទួលពិធីបុណ្យជ្រមុជទឹក ហើយទទួលពិធីបរិសុទ្ធដែលចាំបាច់ មានដូចជា ពិធីបញ្ជាក់ ការតែងតាំងបព្វជិតភាពដល់បុរស និង អំណោយទានពិសិដ្ឋ និង ពិធីបរិសុទ្ធនៃការផ្សារភ្ជាប់ ដែលធ្វើឡើងនៅក្នុងព្រះវិហារបរិសុទ្ធ ។ ការមានចិត្តស្មោះត្រង់ក្នុងការចូលរួមការប្រជុំក្នុងព្រះវិហារ និង ការថ្វាយដង្វាយមួយភាគក្នុងដប់ ក៏ត្រូវបានកត់ត្រានៅក្នុងកំណត់ត្រានៃសាសនាចក្រដែរ ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧

## សេចក្ដីផ្ដើម

ពេញមួយឆ្នាំ ១៨៣២ ព្យាការី យ៉ូសែប ស្ម៊ីធ និង សមាជិកដទៃទៀតនៃសាសនាចក្រ ហាក់បីដូចជាបានដឹងតាមរយៈការចុះផ្សាយសារព័ត៌មាន អំពីទុក្ខសោកដែលកើតមានឡើងទូទៅក្នុងពិភពលោក ។ នៅជិតចុងឆ្នាំនោះដែរ ព្យាការី បានមានប្រសាសន៍ថា « ការលេចឡើងនូវសេចក្ដីអំពល់ក្នុងចំណោមជាតិសាសន៍ទាំងឡាយ បានមានកាន់តែច្រើនឡើងៗ ជាងពេលណាៗទាំងអស់ ចាប់តាំងពីពេលដែលសាសនាចក្របានចាប់ផ្ដើមធ្វើដំណើរចេញពីទីរហោស្ថានមក » (*ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* [ ឆ្នាំ ២០០៧ ] ទំព័រ ២៤៩) ។ នៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៨៣២ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈមួយ ដែលសព្វថ្ងៃនេះមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧ ដែលមានបញ្ចូលនូវការព្យាករណ៍អំពីសង្គ្រាម និង សេចក្ដីជំនុំជម្រះ ដែលនឹងធ្លាក់មកលើអស់ទាំងសាសន៍នៅថ្ងៃចុងក្រោយ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧

*យ៉ូសែប ស្ម៊ីធ ព្យាករថា សង្គ្រាមនឹងធ្លាក់មកលើអស់ទាំងសាសន៍ ។*

ការព្យាករណ៍គឺជាសេចក្ដីប្រកាសមួយ ដែលធ្វើឡើងដោយព្យាការីដ៏ពិតម្នាក់ អំពីទីសម្គាល់ ឬ ព្រឹត្តិការណ៍មួយនាពេលអនាគត ដែលបានបើកសម្ដែងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧:១–៤ រួចស្វែងរកការព្យាករណ៍មួយ ដែលបានប្រទានឲ្យតាមរយៈ យ៉ូសែប ស្ម៊ីធ ។ នៅពេលអ្នកសិក្សាខគម្ពីរទាំងនេះ វាអាចនឹងផ្ដល់អត្ថប្រយោជន៍ក្នុងការដឹងថា រដ្ឋ សៅខារ៉ូឡាញណា គឺជារដ្ឋមួយដែលមានទីតាំងនៅភាគខាងត្បូងនៃសហរដ្ឋ ។

សហរដ្ឋអាមេរិកនៅក្នុង ឆ្នាំ ១៨៤៧




គោលការណ៍មួយដែលយើងអាចរៀនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧:១–៤ គឺថា នៅក្នុងជំនាន់របស់យើងនេះ គឺដូចជាជំនាន់បូរាណដែរ **ព្រះអម្ចាស់អាចបើកសម្ដែងអំពីអនាគតកាលសម្រាប់យើង តាមរយៈពួកព្យាការីរបស់ទ្រង់ ។**

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការដឹងថា ព្រះអម្ចាស់បើកសម្ដែង អំពីព្រឹត្តិការណ៍នាពេលអនាគតតាមរយៈពួកព្យាការីរបស់ទ្រង់ អាចជាពរជ័យមួយដល់សាសនាចក្រដោយរបៀបណា ?

ខ. តើការដឹងបែបនេះ អាចជាពរជ័យដល់អ្នក និង ក្រុមគ្រួសាររបស់អ្នកបានយ៉ាងដូចម្ដេច ?

សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧ ។ សូមស្វែងរកកាលបរិច្ឆេទនៃវិវរណៈនេះ ដែលត្រូវបានប្រទានឲ្យ និង អំពីបញ្ហាដែល យ៉ូសែប ស្ម៊ីធ ឆ្លុះបញ្ចាំងនៅពេលនេះ ។

យ៉ូសែប ស្ម៊ីធ បានដឹងអំពីទំនាស់ខាងនយោបាយរវាង រដ្ឋ សៅខារូឡាញណា និង រដ្ឋាភិបាលនៃសហរដ្ឋ អំពីតម្លៃគយ ។ ( តម្លៃគយ គឺជាពន្ធនៃការនាំចូល ) ។ ដោយសារតែប្រជាជននៃរដ្ឋ សៅខារូឡាញណា ពឹងផ្អែកទៅលើផលិតផលនាំចូល ច្រើនជាងប្រជាជននៅរដ្ឋភាគខាងជើង នោះពួកគេគិតថា តម្លៃគយរបស់រដ្ឋពុំត្រឹមត្រូវ ហើយថាពួកគេត្រូវបានប្រមូលដោយចេតនាលើវាល់ការចំណាយនៃភាគខាងត្បូង ។ ថ្នាក់ដឹកនាំរដ្ឋាភិបាលនៅរដ្ឋ សៅខារូឡាញណា បានបង្កើតច្បាប់មួយដែលមិនអាចទទួលយកបាន ឬ ទុកជាមោឃៈ ដែលជាច្បាប់រដ្ឋ ហើយប្រជាជនរដ្ឋ សៅខារូឡាញណា ជាច្រើន បានចាប់ផ្ដើមត្រៀមខ្លួនធ្វើសង្គ្រាមប្រឆាំងនឹងរដ្ឋាភិបាល ។ ប្រធានាធិបតីនៃសហរដ្ឋ បានពោលអះអាងថា គាត់នឹងរក្សាច្បាប់នៃសហរដ្ឋ ដោយកងកម្លាំង ។

ក្នុងខែ ធ្នូ ឆ្នាំ ១៨៣២ សារព័ត៌មានពាសពេញសហរដ្ឋ បានចុះផ្សាយអំពីទំនាស់នេះ ។ គឺនៅពេលនេះហើយ ដែល យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧ ដែលបានព្យាករថា « សង្គ្រាមទាំងឡាយ. . . នឹងកើតឡើងនៅពេលឆាប់ៗដូច្នេះថា គឺចាប់ផ្ដើមនឹងការបះបោរពីរដ្ឋ សៅខារូឡាញណា » ( គ. និង ស. ៨៧:១ ) ។ នៅដើមឆ្នាំ ១៨៣៣ មិនយូរប៉ុន្មានបន្ទាប់ពីការព្យាករណ៍នេះត្រូវបានផ្ដល់ឲ្យ រដ្ឋាភិបាលនៃសហរដ្ឋ បានដោះស្រាយបញ្ហានេះជាមួយរដ្ឋ សៅខារូឡាញណា ដោយសន្តិវិធី ។ មនុស្សមួយចំនួនបានជឿថា វិបត្តិនេះបានបញ្ចប់ទៅហើយ ហើយថាការព្យាករណ៍នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧:១–៤ នឹងមិនត្រូវបានសម្រេចឡើយ ប៉ុន្តែ វិបត្តិនេះត្រូវបានបញ្ឈប់ក្នុងរយៈពេលខ្លីប៉ុណ្ណោះ ហើយរដ្ឋ សៅខារូឡាញណា បាននៅតែបន្តបះបោរ ។

២. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកឆ្លើយតបយ៉ាងដូចម្ដេច ប្រសិនបើប្រសាសន៍របស់ព្យាការី ពុំបានសម្រេចទៅតាមរបៀប ឬ នៅអំឡុងពេលមួយ ដែលអ្នករំពឹងទុកនោះ ?

អ្នកអាចនឹងចង់គូសចំណាំ បទគម្ពីរយោងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧:១ លេខយោង *គ* ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១២–១៣ ។ តើ ព្យាការី យ៉ូសែប ស្ម៊ីធ បានអះអាងយ៉ាងដូចម្ដេច នៅក្នុងបទគម្ពីរទាំងនេះ ?

សូមយោងទៅ សេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០ រួចស្វែងរកឆ្នាំ ដែលព្យាការី យ៉ូសែប ស្ម៊ីធ បានផ្ដល់ការអះអាងនៃការព្យាករណ៍នេះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧ ។

តើការអះអាងនៃការព្យាករណ៍របស់ យ៉ូសែប ស្ម៊ីធ ដែលលោកបានទទួល ១០ ឆ្នាំ មុន អាចបង្រៀនអ្នកអំពីអ្វីខ្លះអំពីសេចក្ដីជំនឿរបស់លោក ?

វិបត្តិរវាងរដ្ឋាភិបាលនៃសហរដ្ឋ និង រដ្ឋ សៅខារូឡាញណា បានដោះស្រាយ ១០ ឆ្នាំមុន ក្នុងឆ្នាំ ១៨៣៣ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានបន្តរក្សាសេចក្ដីជំនឿទៅលើការព្យាករណ៍ ដែលព្រះអម្ចាស់បានបើកសម្ដែងតាមរយៈលោក ទោះជាមានមនុស្សជាច្រើនពុំបានជឿថា សង្គ្រាមស៊ីវិលនឹងកើតឡើងនៅសហរដ្ឋយ៉ាងណាក៏ដោយ ។



ក្នុងឆ្នាំ ១៨៦១ នាវាចម្បាំងនៅភាគខាងត្បូង បានចាប់ផ្ដើមបាញ់ពួកទាហានសហរដ្ឋ ដែលបោះទីតាំងនៅក្នុងបន្ទាយទាហាន ហ្វដ សាំធើរ នៅទីក្រុង ឆាលស្តុន ហារបើរ រដ្ឋ សៅខារូឡាញណា ។ រដ្ឋភាគខាងត្បូងដទៃទៀត បានចូលរួមជាមួយរដ្ឋ សៅខារូឡាញណា នៅក្នុងសង្គ្រាមស៊ីវិល ប្រឆាំងនឹងរដ្ឋភាគខាងជើងទាំងឡាយ ។ នៅគ្រានោះ រដ្ឋភាគខាងត្បូង បានអំពាវនាវរកជំនួយពីចក្រភពអង់គ្លេស ។ មិនតែប៉ុណ្ណោះ មានមនុស្សជាច្រើនដែលធ្លាប់ជាទាសករនៅភាគខាងត្បូង បានចូលរួមនឹងពួកទាហាននៃភាគខាងជើង ហើយបានច្បាំងនឹងពួកចៅហ្វាយរបស់ខ្លួន ។ សង្គ្រាមស៊ីវិលអាមេរិក បានបន្តរហូតដល់ឆ្នាំ ១៨៦៥ ហើយបានបន្សល់ទុកសាកសពទាហានប្រមាណ ៦២០,០០០ នាក់ ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើព្រឹត្តិការណ៍នេះ ជួយយើងឲ្យដឹងថា **យ៉ូសែប ស្ម៊ីធ គឺជាព្យាការីដ៏ពិតយ៉ាងដូចម្ដេច ?**

ខ. ហេតុអ្វីបានជាវាមានសារៈខាន់ចំពោះអ្នកដែលត្រូវដឹងថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីដ៏ពិតរបស់ព្រះ ?



បន្ទាយទាហាន ហ្វដ សាំធើរ នៅទីក្រុង ឆាលស្តុន ហារបើរ រដ្ឋ សៅខារូឡាញណា

រាល់ការព្យាករណ៍នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧ បានសម្រេច ឬ នឹងត្រូវបានសម្រេច ។

បន្ថែមពីលើព្រឹត្តិការណ៍ ដែលបានបើកសម្ដែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧:១–៤ យ៉ូសែប ស្ម៊ីធ បានព្យាករអំពីរឿងផ្សេងៗទៀត ដែលនឹងកើតឡើង ។ ខទី ៥ លើកឡើងថា « ពួកសំណល់ទាំងប៉ុន្មាន ដែលនៅសេសសល់លើផែនដីក៏នឹង . . . ធ្វើទុក្ខពួកសាសន៍ដទៃ » ។

« ពាក្យ *ពួកសំណល់* ជាញឹកញាប់ត្រូវបានប្រើនៅក្នុងព្រះគម្ពីរ ដើម្បីសំដៅទៅលើចំណែកមួយនៃវង្សអ៊ីស្រាអែល ( សូមមើល Topical Guide, « remnant » ៤១៩ ) ។ ដោយសារតែព្រះអង្គសង្គ្រោះ បានធ្វើការសន្យាជាក់លាក់អំពីពួកសំណល់នៃសាសន៍នីហ្វៃ និង សាសន៍លេមិន ( សូមមើល នីហ្វៃទី៣ ២០:១០, ១៦; ២១:២, ៤ ) នោះមានមនុស្សជាច្រើនបានសន្មត់ថា ខគម្ពីរនេះសំដៅទៅលើប្រជាជនលេមិន ដែលអាចនឹងក្រោកឡើងនៅពេលណាមួយ ហើយ ‹ ធ្វើទុក្ខពួកសាសន៍ដទៃ › ( គ. និង ស. ៨៧:៥ ) ។

« ប្រធាន យ៉ូសែប ហ្វីលឌិង ស្ម៊ីធ បានសរសេរ ៖ ‹ ប្រវត្តិនៃទ្វីបអាមេរិកនេះ. . . ផ្ដល់នូវភស្តុតាងដែលបង្ហាញថា ពួកសាសន៍លេមិនបានក្រោកឡើងក្នុងកំហឹង ហើយបានធ្វើទុក្ខពួកសាសន៍ដទៃ ។ សង្គ្រាមនេះអាចនឹងមិនបញ្ចប់ឡើយ ។ វាជាការយល់ឃើញដ៏ខុសឆ្គងមួយរបស់មនុស្ស ដែលរស់នៅសហរដ្ឋ ដែលគិតថា ពាក្យពេចន៍ព្យាករណ៍នេះសំដៅទៅលើពួកឥណ្ឌាស្បែកក្រហមរស់នៅសហរដ្ឋ ប៉ុន្តែ យើងត្រូវចងចាំថា មាន « ពួកសំណល់ » រាប់លាននាក់នៅក្នុងប្រទេស ម៉ិកស៊ិក ដែលជាអាមេរិកកណ្ដាល និង ខាងត្បូង ។ នោះគឺអំឡុងសង្គ្រាមស៊ីវិល ដែលពួកឥណ្ឌាស្បែកក្រហមនៅប្រទេស ម៉ិកស៊ិក បានក្រោកឡើង ហើយស្វែងរកសេរីភាពពីការសង្កត់សង្កិន ដែលស្ដេច ណាប៉ូឡេអុង បានស្វះស្វែងដាក់ទោសដល់ពួកគេ

ដែលផ្ទុយទៅនឹងការព្យាករណ៍របស់យ៉ាកុប នៅក្នុងព្រះគម្ពីរមរមនថា នឹងពុំមានស្ដេចនៅក្នុងចំណោមពួកសាសន៍ដទៃនៅលើដែនដីនេះឡើយ ។ ឯករាជ្យរបស់ប្រទេស ម៉ិកស៊ិក និង ប្រទេសដទៃទៀតនៅអាមេរិកខាងត្បូង ត្រូវបានសម្រេចដោយការក្រោកឡើងរបស់ « ពួកសំណល់ » នៅលើដែនដីនោះ ។ ទោះជាយ៉ាងណាក៏ដោយ ចូរយើងកុំគិតថា ការព្យាករណ៍នេះបានសម្រេចទាំងស្រុងហើយនោះឡើយ › ។ ( *Church History and Modern Revelation,* ១:១៦៣ ) » ។ (*គោលលទ្ធិ និង សេចក្ដីសញ្ញា សៀវភៅសិស្ស* ការបោះពុម្ពលើកទី ២ [ Church Educational System manual ឆ្នាំ ២០០១ ] ទំព័រ ១៩៥) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧:៦–៧ រួចស្វែងរកព្រឹត្តិការណ៍ដទៃទៀត ដែល យ៉ូសែប ស៊្មីធ បានព្យាករថានឹងកើតឡើងនៅថ្ងៃចុងក្រោយបង្អស់ ។

« ព្រះហស្តសម្រាប់ប្រៀនប្រដៅ » របស់ព្រះ សំដៅទៅលើហេតុការណ៍ ដែលព្រះអម្ចាស់ប្រើប្រាស់សេចក្ដីជំនុំជម្រះរបស់ទ្រង់ដើម្បីបំផុសឲ្យកូនចៅទ្រង់ប្រែចិត្តពីអំពើបាបរបស់ខ្លួន ។ មិនតែប៉ុណ្ណោះ សេចក្ដីជំនុំជម្រះមួយចំនួន ដែលបានពិពណ៌នានៅក្នុងខគម្ពីរនេះ នឹងកើតឡើងនៅពេលព្រះអម្ចាស់ដាក់ទោសដល់ពួកទុច្ចរិតចំពោះការប្រព្រឹត្តដ៏អយុត្តិធម៌របស់ពួកគេ មកលើពួកសុចរិត ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧:៨ ដើម្បីរៀនអំពីអ្វី ដែលព្រះអម្ចាស់បង្គាប់ឲ្យយើងធ្វើ ដើម្បីយើងនឹងបានត្រៀមខ្លួនប្រឈមមុខនឹងសង្គ្រាម និង សេចក្ដីវិនាស ដែលនឹងកើតឡើងនៅលើផែនដីនៅថ្ងៃចុងក្រោយបង្អស់ ។ គោលការណ៍មួយ ដែលយើងរៀនចេញពីខគម្ពីរនេះគឺថា **យើងត្រូវឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ហើយចូរកុំរើឡើយ រហូតដល់ថ្ងៃនៃព្រះអម្ចាស់មកដល់ ។**

ទីបរិសុទ្ធមានន័យថា ទីកន្លែងដែលយើងអាចមានអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ដែលជួយយើងឲ្យខិតទៅជិតព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ហើយរៀនអំពីទ្រង់ទាំងពីរអង្គ ។ ការឈរនៅក្នុងទីបរិសុទ្ធ ជាញឹកញាប់មានរឿងច្រើន ដែលត្រូវធ្វើជាមួយនឹង *របៀប* ដែលយើងរស់នៅ ជាជាង *ទីកន្លែង* ដែលយើងរស់នៅ ។ បើអ្នករស់នៅសក្ដិសមមានព្រះវិញ្ញាណបរិសុទ្ធជាដៃគូជាប្រចាំ នោះអ្នកឈរនៅក្នុងទីបរិសុទ្ធមួយហើយ ។ សូមព្យាយាមធ្វើឲ្យគេហដ្ឋានរបស់អ្នកក្លាយជាទីបរិសុទ្ធ មានពេញទៅដោយព្រះវិញ្ញាណនៃព្រះអម្ចាស់ ។

៤. សូមរាយបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីទីកន្លែងបីបួន ដែលអ្នកចាត់ទុកថាជាទីបរិសុទ្ធ ។ បន្ទាប់មក ជ្រើសរើសកន្លែងមួយដែលអ្នករាយក្នុងបញ្ជីនោះ រួចពិពណ៌នាអំពីរបៀបដែលការស្ថិតនៅក្នុងទីបរិសុទ្ធនោះ បានជួយអ្នកឲ្យនៅជិតព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ តើអ្នកអាចខិតខំធ្វើឲ្យគេហដ្ឋានរបស់អ្នក ក្លាយទៅជាទីបរិសុទ្ធបានតាមរបៀបណា ? ប្រសិនបើព្យាការីត្រូវទៅឃើញទីកន្លែងអ្នករស់នៅ បន្ទប់របស់អ្នក ទូសម្លៀកបំពាក់ ឬ កន្លែងអ្នកប្រើជាប្រចាំ តើលោកនឹងឃើញថា ទីនោះជាទីបរិសុទ្ធដែរឬទេ ?

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតវាមានន័យដូចម្ដេច ដែលត្រូវ « ឈរ . . . នៅក្នុងទីបរិសុទ្ធទាំងឡាយ ហើយចូរកុំរើឡើយ » ( គ. និង ស. ៨៧:៨ ) ?

ខ. តើបុគ្គលម្នាក់អាចរើចេញពីទីបរិសុទ្ធបានតាមរបៀបណា ?

គ. តើអ្នកនឹងធ្វើអ្វីខ្លះ ដើម្បីឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ឲ្យមានចិត្តកាន់តែស្មោះត្រង់ និង មិនរើចេញពីទីបរិសុទ្ធទាំងនោះ ?

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៧ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៩ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១–៤០

## សេចក្ដីផ្ដើម

ប្រធាន យ៉ូសែប ហ្វីលឌិង ស្មីធ បានថ្លែងថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨ « គឺជាវិវរណៈមួយដ៏សំខាន់បំផុតក្នុងចំណោមវិវរណៈទាំងឡាយ ដែលធ្លាប់បានប្រទានឲ្យដល់សាសនាចក្រ ហើយពេលវេលាចំនួនបីបួនសប្ដាហ៍ អាចត្រូវបានចំណាយយ៉ាងមានតម្លៃក្នុងការពិភាក្សាអំពីវិវរណៈនេះ » ( *Church History and Modern Revelation* វ៉ុល ២ [ ១៩៥៣ ] ១:៣៦៦ ) ។ នេះគឺជាមេរៀនដំបូងគេនៃមេរៀនទាំងបី ដែលផ្ដោតទៅលើ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨ ។ ព្យាការី យ៉ូសែប ស្មីធ បានទទួលវិវរណៈនេះរយៈពេលបីថ្ងៃ—គឺថ្ងៃទី ២៧–២៨ ខែ ធ្នូ ឆ្នាំ ១៨៣២ និង ថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៨៣៣ ។ ចំណែកនៃវិវរណៈដែលមានពាសពេញក្នុងមេរៀននេះ មាននូវការបង្រៀនរបស់ព្រះអម្ចាស់អំពីពន្លឺនៃព្រះគ្រីស្ទ និង ការបកស្រាយរបស់ទ្រង់ អំពីក្រឹត្យវិន័យនានា ដែលគ្រប់គ្រងនគរទាំងឡាយរបស់ទ្រង់ និង បណ្ដាជននៃនគរទាំងនោះ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១–១៣

*ព្រះអម្ចាស់ប្រកាសថា ទ្រង់គឺជាពន្លឺ ដែលបំភ្លឺអ្វីគ្រប់យ៉ាងទាំងអស់*

តើអ្នកធ្លាប់អធិស្ឋានឲ្យបានដឹង អំពីព្រះឆន្ទៈរបស់ព្រះអម្ចាស់ អំពីជម្រើសដែលអ្នកធ្វើនៅក្នុងជីវិតដែរឬទេ ? ព្យាការី យ៉ូសែប ស្មីធ បានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨ បន្ទាប់ពីពួកសង្ឃជាន់ខ្ពស់បានអធិស្ឋានរៀងៗខ្លួន និងដោយបញ្ចេញសំឡេងនៅក្នុងសន្និសីទមួយ ដើម្បីដឹងអំពីព្រះឆន្ទៈរបស់ព្រះអម្ចាស់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១–២ ដោយស្វែងរកការណ៍ដែលព្រះអម្ចាស់បានមានព្រះបន្ទូល ថាតើទ្រង់ និង ពួកទេវតាទ្រង់បានមានព្រះទ័យយ៉ាងដូចម្ដេច នៅពេលពួកអ្នកបម្រើទ្រង់ព្យាយាមស្គាល់ព្រះឆន្ទៈទ្រង់នោះ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៣–៥ ព្រះអម្ចាស់បានបង្រៀនពួកបងប្អូនប្រុសទាំងនេះថា ពួកគាត់អាចទទួលបានការអះអាងអំពីជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដែលត្រូវបានហៅផងដែរថាជា ព្រះដ៏ជាជំនួយ និង ព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសញ្ញា ។

ព្រះអម្ចាស់ក៏បង្រៀងផងដែរ អំពីសារៈសំខាន់នៃពន្លឺ ។ តើអ្នកធ្លាប់ស្ថិតនៅក្នុងទីងងឹតសូន្យសុងដែរឬទេ ? តើបទពិសោធន៍នៃការស្ថិតនៅក្នុងទីងងឹតសូន្យសុង អាចជួយអ្នកឲ្យមានអំណរគុណចំពោះពរជ័យនៃពន្លឺយ៉ាងដូចម្ដេច ? តើពន្លឺតំណាងឲ្យអ្វី នៅក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦–១៣ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានបង្រៀន អំពីប្រភពនៃពន្លឺ ។

នៅក្នុង ខទី ៧ តើវាក្យសព្ទណាមួយ ដែលត្រូវបានប្រើដើម្បីសំដៅទៅលើសេចក្ដីពិត ដែល « ភ្លឺ » ?

យោងតាម ខទី ១២តើពន្លឺទាំងអស់ មានប្រភពចេញមកពីណា ?

ខគម្ពីរទាំងនេះបង្រៀនថា **តាមរយៈពន្លឺនៃព្រះគ្រីស្ទ ព្រះបានប្រទានពន្លឺ និង ជីវិតដល់អ្វីគ្រប់យ៉ាងទាំងអស់** ។ អ្នកអាចនឹងចង់សរសេរគោលការណ៍នេះ នៅលើគែមព្រះគម្ពីររបស់អ្នក ។ ពន្លឺនៃព្រះគ្រីស្ទក៏ជាក្រឹត្យវិន័យ ដែលគ្រប់គ្រងលើកភព និង បណ្ដាជនរបស់វា ហើយវា « ប្រោស » យោបល់ដល់អ្នកដែរ ។. *ប្រោស* មានន័យថា ធ្វើឲ្យរស់រើក ។ អ្នកអាចនឹងចង់សរសេរនិយមន័យនេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។

« ពន្លឺនៃព្រះគ្រីស្ទ . . . គឺជាអានុភាពមួយនៃសេចក្ដីល្អ ដែលមាននៅក្នុងជីវិតមនុស្សទូទៅ ( សូមមើល យ៉ូហាន ១:៩ គ. និង ស. ៩៣:២ ) ។ នៅក្នុងព្រះគម្ពីរ ពន្លឺនៃព្រះគ្រីស្ទ ពេលខ្លះត្រូវបានហៅថា ព្រះវិញ្ញាណនៃព្រះអម្ចាស់ ព្រះវិញ្ញាណនៃព្រះ ព្រះវិញ្ញាណនៃព្រះគ្រីស្ទ ឬ ពន្លឺនៃជីវិត ។

*ស្វែងរកនិយមន័យពាក្យពិបាកៗ*

វាជាការសំខាន់ ដែលត្រូវស្វែងរកនិយមន័យពាក្យពិបាកៗ នៅពេលអ្នកសិក្សាបទគម្ពីរទាំងឡាយ ។ ការធ្វើបែបនេះ នឹងជួយអ្នកឲ្យយល់បទគម្ពីរទាំងនោះ កាន់តែច្បាស់ឡើង ។ សូមបើកមើលលេខយោងខគម្ពីរ ដោយប្រើប្រាស់ Bible Dictionary សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ឬ វចនានុក្រមដទៃទៀត ឬ សួរឪពុកម្ដាយ ឬ គ្រូបង្រៀន នៅពេលអ្នកជួបនឹងពាក្យដែលអ្នកពុំយល់នោះ ។ វាអាចផ្ដល់អត្ថប្រយោជន៍ ក្នុងការសេរសេរអត្ថន័យនៃពាក្យទាំងនោះ ដាក់នៅក្នុងព្រះគម្ពីររបស់អ្នក ។

« ពន្លឺនៃព្រះគ្រីស្ទ មិនគួរយល់ច្រឡំជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធទេ ។ វាមិនមែនជាតួអង្គ ដូចជាព្រះវិញ្ញាណបរិសុទ្ធនោះទេ ។ វាមានឥទ្ធិពលដឹកនាំមនុស្ស ឲ្យស្វែងរកដំណឹងល្អដ៏ពិត ធ្វើបុណ្យជ្រមុជទឹក និង ទទួលអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ( សូមមើល យ៉ូហាន ១២:៤៦; អាលម៉ា ២៦:១៤–១៥ ) ។

« សតិសម្បជញ្ញៈ គឺជាការបង្ហាញពីពន្លឺនៃព្រះគ្រីស្ទ ដែលធ្វើឲ្យយើងដឹងល្អ និង អាក្រក់ ។ ព្យាការី មរមន បានបង្រៀន ៖ ‹ ព្រះវិញ្ញាណនៃព្រះគ្រីស្ទ ត្រូវបានប្រទានដល់មនុស្សគ្រប់រូប ដើម្បីឲ្យគេអាចដឹងខុស និង ត្រូវ ហេតុដូច្នេះហើយ ខ្ញុំបង្ហាញដល់អ្នកនូវវិធីវិនិច្ឆ័យ ដ្បិតគ្រប់ទាំងអ្វីៗដែលអញ្ជើញឲ្យធ្វើល្អ ហើយដែលបញ្ចុះបញ្ចូលឲ្យជឿដល់ព្រះគ្រីស្ទ នោះគឺបានចាត់មកពីព្រះចេស្ដា និងអំណោយទាននៃព្រះគ្រីស្ទ ហេតុដូច្នោះហើយ អ្នករាល់គ្នាអាចដឹងដោយតម្រិះដ៏ឥតខ្ចោះថា មកពីព្រះ ។. . . ហើយឥឡូវនេះ ឱបងប្អូនរបស់ខ្ញុំអើយ ដោយឃើញថា អ្នករាល់គ្នាស្គាល់នូវពន្លឺ ដែលអ្នករាល់គ្នាអាចយកទៅវិនិច្ឆ័យ ឯពន្លឺនោះគឺជាពន្លឺនៃព្រះគ្រីស្ទ នោះចូរឲ្យឃើញថា អ្នករាល់គ្នាមិនវិនិច្ឆ័យដោយខុសឆ្គងឡើយ ដ្បិតដោយការវិនិច្ឆ័យដដែលនេះហើយ ដែលអ្នករាល់គ្នានឹងត្រូវបានវិនិច្ឆ័យវិញ › (មរ៉ូណៃ ៧:១៦, ១៨ ) » (*ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* [ ឆ្នាំ ២០០៤ ] ទំព័រ ៩៦) ។

ប្រធាន ប៊យដ៏ ឃេ ផាកកឺ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានផ្ដល់អនុសាសន៍ស្ដីពីភាពដាច់ដោយឡែកពីគ្នា និង អន្តរកម្ម រវាងពន្លឺនៃព្រះគ្រីស្ទ និង ព្រះវិញ្ញាណបរិសុទ្ធ ៖



« មនុស្សគ្រប់រូបរស់នៅគ្រប់ទីកន្លែង មានព្រះវិញ្ញាណនៃព្រះគ្រីស្ទ ហើយកាលវិញ្ញាណនៃព្រះវិញ្ញាណបរិសុទ្ធអាចយាងទៅក្បែរបុគ្គលណាម្នាក់នោះ *អំណោយទាន* ព្រះវិញ្ញាណបរិសុទ្ធ គឺត្រូវបានទទួល ‹ ដោយសារការគោរពតាមក្រឹត្យវិន័យ និង ពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ › ( មាត្រានៃសេចក្ដីជំនឿ ១:៣ ) តាមរយៈចូលទៅក្នុង ‹ បុណ្យជ្រមុជទឹកដោយការពន្លិចសម្រាប់ការផ្ដាច់បាប [ និង ការ] ដាក់ដៃលើសម្រាប់អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ › ( មាត្រានៃសេចក្ដីជំនឿ ១:៤ ) ។ វាមិនអាចទទួលបានដោយស្វ័យប្រវត្តិ ដូចជាព្រះវិញ្ញាណនៃព្រះគ្រីស្ទនោះទេ ។ អំណោយទាននេះ ត្រូវតែបានប្រគល់ដោយ បុគ្គលម្នាក់ដែលកាន់សិទ្ធអំណាច ( សូមមើល មាត្រានៃសេចក្ដីជំនឿ ១:៥ ) ។

« នោះគឺជាអ្វីដែលយើងត្រូវបានបង្គាប់ឲ្យធ្វើ ដើម្បីផ្សព្វផ្សាយអំពីពន្លឺនៃព្រះគ្រីស្ទ ដែលមាននៅក្នុងព្រលឹងដែលយើងជួប ហើយនាំព្រលឹងទាំងឡាយទៅកាន់កម្រិតមួយ ដែលព្រះវិញ្ញាណបរិសុទ្ធអាចយាងមកក្បែរពួកគេបាន ។ ហើយលំដាប់នោះកាលកំណត់មកដល់ ពួកគេអាចទទួលបានតាមរយៈពិធីបរិសុទ្ធ អំណោយទានព្រះវិញ្ញាណបរិសុទ្ធ ដែលត្រូវបានប្រគល់ឲ្យដល់គ្រប់សមាជិកនៃសាសនាចក្រ ។

« នៅពេលបុគ្គលម្នាក់ទទួលបានអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ហើយអាចបណ្ដុះវាឡើងជាមួយពន្លឺនៃព្រះគ្រីស្ទ ដែលគាត់មានជាស្រេចហើយនោះ លំដាប់នោះភាពពោរពេញនៃដំណឹងល្អ ត្រូវបានលាតត្រដាងចំពោះយោបល់របស់គាត់ ។ ព្រះវិញ្ញាណបរិសុទ្ធអាចធ្វើការ តាមរយៈពន្លឺនៃព្រះគ្រីស្ទ ។

« ពន្លឺនៃព្រះគ្រីស្ទ មានលក្ខណៈទូលំទូលាយដូចជាពន្លឺព្រះអាទិត្យដែរ ។ ទីណាដែលមានជីវិតមនុស្សរស់នៅ ទីនោះមានព្រះវិញ្ញាណនៃព្រះគ្រីស្ទ ។ គ្រប់ព្រលឹងនៃភាវរស់ តែងមានវាជានិច្ច ។ វាគឺជាអ្នកធានាអំពី អ្វីគ្រប់យ៉ាងដែលជាការល្អ ។ វាគឺជាអ្នកបំផុសអំពីអ្វីដែលនឹងប្រទានពរ ហើយផ្ដល់អត្ថប្រយោជន៍ដល់មនុស្សលោក ។ វាចិញ្ចឹមបីបាច់សេចក្ដីល្អផ្ទាល់ » (The Light of Christ, » *Ensign* ខែ មេសា ឆ្នាំ ២០០៥ ទំព័រ ១៣ ) ។

១. ដើម្បីជួយអ្នកគិតអំពី ថាតើពន្លឺនៃព្រះគ្រីស្ទប្រទានពរដល់អ្នកដូចម្ដេចខ្លះ នោះសូមឆ្លើយសំណួរខាងក្រោមពីរ ឬច្រើនជាងនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧–១០ យើងរៀនថា ពន្លឺខាងសាច់ឈាមទាំងអស់មានដូចជាពន្លឺព្រះអាទិត្យ គឺជាផ្នែកនៃពន្លឺនៃព្រះគ្រីស្ទ ។ តើពន្លឺខាងសាច់ឈាម ប្រទានពរដល់ជីវិតរបស់អ្នកយ៉ាងដូចម្ដេច ?

ខ. *ប្រោស* ឬ *បានប្រោស* មានន័យថា នាំឲ្យមានជីវិត ឬ ធ្វើឲ្យរស់រវើក ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១ យើងរៀនថា ពន្លឺនៃព្រះគ្រីស្ទគឺជាមធ្យោបាយមួយ ដែលតាមរយៈមធ្យោបាយនោះ ការយល់ដឹងរបស់យើងអំពីការណ៍ទាំងឡាយ អាចត្រូវបានប្រោស ឬ ធ្វើឲ្យរស់រវើក ។ តើអ្នកធ្លាប់មានអារម្មណ៍ថា ការសិក្សា និង ការយល់ដឹងរបស់អ្នក ត្រូវបានប្រោសនៅពេលណាខ្លះ ?

គ. នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២–១៣ យើងរៀនថា ពន្លឺនៃព្រះគ្រីស្ទ ផ្ដល់ជីវិតដល់គ្រប់ទាំងអស់ ដែលរាប់បញ្ចូលទាំងសត្វ រុក្ខជាតិ និង ពួកយើងផងដែរ ។ តើអ្នកបានទទួលពរជ័យ ដោយសារតែភាវរស់នៅជុំវិញខ្លួនអ្នកតាមរបៀបណា ?

ឃ. នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១៣ យើងក៏រៀនដែរថា ពន្លឺនៃព្រះគ្រីស្ទ គឺជាក្រឹត្យវិន័យមួយ ដែលតាមរយៈក្រឹត្យវិន័យនេះ អ្វីគ្រប់ទាំងអស់ត្រូវបានគ្រប់គ្រង ។ ក្រឹត្យវិន័យនេះរួមបញ្ចូលទាំងក្រឹត្យវិន័យខាងសាច់ឈាមដែរដូចជា ទំនាញផែនដី និង ថែមទាំងក្រឹត្យវិន័យខាងសាច់ឈាម និង ព្រះបញ្ញត្តិទាំងឡាយ ។ តាមរយៈពន្លឺនៃព្រះគ្រីស្ទ ពេលខ្លះត្រូវបានហៅថា សតិសម្បជញ្ញៈរបស់យើង នោះយើងម្នាក់ៗអាចញាណដឹងអំពីភាពខុសគ្នារវាងការល្អ និង ការអាក្រក់ ។ តើក្រឹត្យវិន័យខាងសាច់ឈាម និង ខាងវិញ្ញាណមានឥទ្ធិពលទៅលើអ្នក ជារៀងរាល់ថ្ងៃយ៉ាងដូចម្ដេច ?

២. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើសេចក្ដីពិតដែលអ្នកបានរៀននេះ អាចជួយអ្នកឲ្យមានអំណរគុណចំពោះព្រះចេស្ដារបស់ព្រះ ដែលមានក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក —តាមរបៀបដែលបានកត់ចំណាំផង និង មិនបានកត់ចំណាំជាទូទៅផង យ៉ាងដូចម្ដេច ? សូមសរសេរបញ្ចូលគំនិតមួយចំនួន អំពីរបៀបដែលការណ៍នេះ មានឥទ្ធិពលលើជីវិតប្រចាំថ្ងៃរបស់អ្នក នៅពេលខាងមុខ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១៤–៤០

*ព្រះអម្ចាស់ពន្យល់ថា មានក្រឹត្យវិន័យនានា ដែលទាក់ទងទៅនឹងនគរនៃសិរីល្អ*

នៅពេលអ្នកពាក់ស្រោមដៃ នោះដៃរបស់អ្នកធ្វើចលនា ឬ ផ្ដល់ជីវិតដល់ស្រោមដៃនោះ ។ ប្រសិនបើអ្នកបង្រៀនមនុស្សម្នាក់អំពីផែនការនៃសេចក្ដីសង្គ្រោះ ហើយអ្នកប្រើស្រោមដៃដើម្បីតំណាងឲ្យរូបកាយសាច់ឈាម ដែលយើងទទួលបាននៅពេលចាប់កំណើតមក នោះតើដៃរបស់អ្នកតំណាងឲ្យអ្វី ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១៥ ដោយស្វែងរក ថាតើព្រះអម្ចាស់បានហៅ ការប្រមូលផ្ដុំនៃវិញ្ញាណ និង រូបកាយថាយ៉ាងដូចម្ដេច ។



អ្នកអាចនឹងចង់គូសចំណាំគោលលទ្ធិ ដែលថា **វិញ្ញាណ និង រូបកាយ គឺជាព្រលឹងនៃមនុស្ស ។**

៣. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការណ៍នានាដែលប៉ះពាល់ដល់រូបកាយសាច់ឈាមរបស់យើង អាចប៉ះពាល់ដល់វិញ្ញាណរបស់យើងយ៉ាងដូចម្ដេច ? តើមានឧទាហរណ៍អ្វីខ្លះ ?

សេចក្ដីថ្លែងការណ៍ខាងក្រោមនេះពីប្រធាន អ៊ែសរ៉ា ថាហ្វ បែនសឹន ជួយពន្យល់អំពីទំនាក់ទំនងរវាងរូបកាយសាច់ឈាម និង វិញ្ញាណរបស់យើង ៖



« ពុំត្រូវចោទសួរថាតើសុខភាពរូបកាយ ប៉ះពាល់ដល់វិញ្ញាណដែរឬទេនោះឡើយ បើពុំសោតទេនោះព្រះអម្ចាស់នឹងមិនចាំបាច់បើកសម្ដែងពាក្យសម្ដីនៃប្រាជ្ញាវាងវៃនោះទេ ។ ព្រះមិនប្រទានព្រះបញ្ញត្តិខាងសាច់ឈាមណា—ដែលប៉ះពាល់ដល់រូបកាយយើង រួមទាំងប៉ះពាល់ដល់ព្រលឹងយើងនោះឡើយ ។. . .

« . . . អំពើបាបធ្វើឲ្យយើងទន់ខ្សោយ ។ វាមិនត្រឹមតែប៉ះពាល់ដល់ព្រលឹងយើងនោះទេ វាក៏ប៉ះពាល់ដល់រូបកាយយើងដែរ ។ បទគម្ពីរមានពោរពេញទៅដោយគំរូនានានៃអំណាចរូបកាយ ដែលអាចការពារពួកសុចរិតបាន ។ ផ្ទុយទៅវិញ អំពើបាបដែលពុំប្រែចិត្ត អាចធ្វើឲ្យថាមពលសាយភាយ ហើយនាំឲ្យកើតមានជំងឺទាំងខាងសតិអារម្មណ៍ និង ខាងរូបកាយ » ( In His Steps » *Ensign* ខែ កញ្ញា ឆ្នាំ ១៩៨៨ ទំព័រ ៥ ) ។

សូមកត់ចំណាំថា នៅក្នុងខគម្ពីរទាំងនេះ ពាក្យ *ព្រលឹង* ត្រូវបានប្រើយ៉ាងជាក់លាក់ នៅក្នុងសេចក្ដីយោងទៅកាន់រូបកាយរបស់វិញ្ញាណ ( ឧទាហរណ៍ សូមមើល អាលម៉ា ៤០:១៥–២៣ ) ។

៤. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការយល់ដឹងអំពីទំនាក់ទំនងរវាងរូបកាយ និង វិញ្ញាណរបស់អ្នក អាចជួយអ្នកឲ្យធ្វើជម្រើសដ៏ត្រឹមត្រូវតាមរបៀបណា ?



សូមពិចារណាអំពីគោលលទ្ធិ និង គោលការណ៍បន្ថែមមួយចំនួនទៀត ដែលអាចបង្ហាញដោយការប្រើដៃ និង ស្រោមដៃ ៖ សូមស្រមៃអំពីការដកដៃចេញពីស្រោមដៃនោះ ។ តើសកម្មភាពនេះ បង្ហាញអំពីអ្វី ? តើមានអ្វីកើតឡើងចំពោះព្រលឹង—ដែលជាវិញ្ញាណ និង រូបកាយ—នៅពេលស្លាប់ទៅ ?

តើការយកស្រោមដៃមក ហើយស៊កដៃចូលទៅវិញ បង្ហាញអំពីអ្វី ? តើមានអ្វីកើតឡើងចំពោះព្រលឹង នៅពេលការរស់ឡើងវិញ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១៤, ១៦–១៧ ដោយស្វែងរករបៀបដែលព្រះអម្ចាស់ បានពិពណ៌នាអំពីការរស់ឡើងវិញ ។

សូមបញ្ចប់គោលលទ្ធិដូចតទៅនេះ ដែលបានបង្រៀននៅក្នុងខគម្ពីរទាំងនេះ ៖ **ព្រះយេស៊ូវគ្រីស្ទបានធ្វើឲ្យព្រលឹងរបស់យើងអាច ។**

នៅក្នុង ខទី ១៧ បន្ទាប់ពីយើងបានអានថា ព្រះយេស៊ូវគ្រីស្ទ បានប្រោសលោះព្រលឹងយើង នោះយើងរៀនថា អ្នកដែលមានចិត្តរាបសា និង ស្លូតបូតនឹងគ្រងផែនដីទុកជាមរតក ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១៨–២០ ដោយស្វែងរកអ្វីដែលនឹងកើតឡើងចំពោះផែនដី ពីមុនវាក្លាយទៅជានគរសេឡេស្ទាល ហើយព្រលឹងដែលព្រះបានប្រោសលោះនោះ គ្រងវាទុកជាមរតក ។

យោងតាម ខទី ១៩ តើវត្តមានរបស់អ្នកណាដែលនឹងមាននៅលើផែនដី ដែលបានញែកចេញជាបរិសុទ្ធនោះ ? សូមពិចារណាអំពីអ្វីដែលអ្នកនឹងថ្លែងទៅកាន់នរណាម្នាក់ ដែលបានសួរអ្នកនូវសំណួរដូចតទៅនេះ ៖ តើខ្ញុំត្រូវធ្វើអ្វីខ្លះ ដើម្បីសក្ដិសមរស់នៅក្នុងនគរសេឡេស្ទាល ហើយរីករាយនឹងវត្តមានរបស់ព្រះវរបិតាសួគ៌ ?

គឺដូចជាផែនដីនឹងទទួលបានសិរីល្អ បន្ទាប់ពីវាត្រូវបានញែកចេញជាបរិសុទ្ធ នោះរូបកាយរបស់យើងក៏នឹងត្រូវបានផ្លាស់ប្ដូរ ហើយទទួលបានសិរីល្អក្នុងការរស់ឡើងវិញដែរ ។ ទោះជាយ៉ាងណាក៏ដោយ មិនមែនមនុស្សទាំងអស់ នឹងទទួលបានកម្រិតនៃសិរីល្អស្មើៗគ្នានោះទេ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:២១–២៤ រួចស្វែងរកអ្វីដែលកំណត់អំពីកម្រិតនៃសិរីល្អ ដែលបុគ្គលម្នាក់ទទួលបានក្នុងការរស់ឡើងវិញ ។

នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:២៥–៣៣ សូមស្វែងរកពាក្យ និង ឃ្លាដែលគាំទ្រគោលលទ្ធិ ដែលមានបង្រៀននៅក្នុង ខទី ២១–២៤ ដែល **នៅក្នុងការរស់ឡើងវិញ យើងនឹងទទួលបានសិរីល្អដោយផ្អែកទៅលើក្រឹត្យវិន័យដែលយើងគោរពប្រតិបត្តិតាម ។**

ខទី ២៨ និយាយអំពី « ពួកអ្នកណា ដែលជាវិញ្ញាណនៃសេឡេស្ទាល » ។ អ្នកទាំងនេះគឺជាបុគ្គលទាំងឡាយ ដែលរស់នៅតាមក្រឹត្យវិន័យនៃនគរសេឡេស្ទាល ។ យើងដឹងចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦ ថា ក្រឹត្យវិន័យនៃនគរសេឡេស្ទាល រួមបញ្ចូលទាំងការធ្វើ និង ការរក្សាសេចក្ដីសញ្ញានៃដំណឹងល្អ ( សូមមើល គ. និង ស. ៧៦:៥០–៥៣, ៦៩–៧០ ) ។ បុគ្គលដែលរស់នៅតាមក្រឹត្យវិន័យសេឡេស្ទាលនៅលើផែនដីនេះ នឹងទទួលបានរូបកាយសេឡេស្ទាលក្នុងការរស់ឡើងវិញ ។ បើបុគ្គលម្នាក់គោរពប្រតិបត្តិតែក្រឹត្យវិន័យទេរេសទ្រាល ឬ ទេឡេស្ទាលនៅលើផែនដីនេះ នោះគាត់នឹងទទួលបានរូបកាយដែលមានសិរីល្អតិចជាង ដោយផ្អែកទៅលើក្រឹត្យវិន័យដែលគាត់បានគោរពប្រតិបត្តិ ។

ដើម្បីជួយអ្នកឲ្យយល់អំពីមូលហេតុ ដែលក្រឹត្យវិន័យទាំងឡាយរបស់ព្រះគឺជាពរជ័យសម្រាប់យើង នោះសូមគិតអំពីអត្ថប្រយោជន៍ដែលកើតចេញការគោរពច្បាប់ចរាចរណ៍ ។ ផ្ទុយទៅវិញ តើមានលទ្ធផលដូចម្ដេចខ្លះ ដែលកើតចេញពីការមិនគោរពតាមច្បាប់ចរាចរណ៍ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៣៤–៣៥ ដោយស្វែងរកលទ្ធផលនៃការរស់នៅតាម និង ការមិនរស់នៅតាមក្រឹត្យវិន័យនៃព្រះ ។

៥. សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤០ រួចស្វែងរកគុណសម្បត្តិនៃមនុស្ស ដែលនឹងចូលទៅក្នុងនគរសេឡេស្ទាល ។ បន្ទាប់មក សូមឆ្លើយសំណួរខាងក្រោមនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីបង្កើន ឬ ពង្រឹងគុណសម្បត្តិទាំងនេះនៅក្នុងជីវិតរបស់អ្នក ?

ខ. សូមជ្រើសរើសគុណសម្បត្តិមួយ ដែលអ្នករកឃើញ រួចដាក់គោលដៅដើម្បីបង្កើន ឬ ពង្រឹងគុណសម្បត្តិនោះនៅក្នុងជីវិតរបស់អ្នក ។

នៅពេលអ្នកសម្រេចបានគោលដៅរបស់អ្នក ហើយរស់នៅតាមក្រឹត្យវិន័យនៃព្រះយេស៊ូវគ្រីស្ទ នោះពន្លឺទ្រង់នឹងបំភ្លឺជីវិតរបស់អ្នក ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១–៤០ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៩ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤១–៦៩

## សេចក្ដីផ្ដើម

នេះគឺជាមេរៀនទីពីរក្នុងចំណោមមេរៀនទាំងបី ដែលផ្ដោតទៅលើវិវរណៈ មាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨ ។ ចំណែកនៃវិវរណៈដែលមានពាសពេញក្នុងមេរៀននេះ ត្រូវបានប្រទានឲ្យនៅក្នុងសន្និសីទរបស់ពួកសង្ឃជាន់ខ្ពស់នៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ នៅថ្ងៃទី ២៧ និង ២៨ ខែ ធ្នូ ឆ្នាំ ១៨៣២ ។ វាបូកបញ្ចូលទាំងការបកស្រាយរបស់ ព្រះយេស៊ូវគ្រីស្ទ អំពីរបៀបដែលព្រះគ្រប់គ្រងការបង្កបង្កើតរបស់ទ្រង់ និង ការអញ្ជើញយើងឲ្យខិតទៅជិតទ្រង់ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤១–៥០

*ព្រះអង្គសង្គ្រោះបើកសម្ដែងថា គ្រប់ការណ៍ទាំងអស់ត្រូវបានគ្រប់គ្រងដោយក្រឹត្យវិន័យដ៏ទេវភាព*



តើអ្នកធ្លាប់គយគន់ហ្វូងតារា ហើយគិតអំពីព្រះ និង ការបង្កបង្កើតរបស់ទ្រង់ដែរឬទេ ? តើសំណួរ ឬ គំនិតអ្វីខ្លះ ដែលអ្នកពិចារណានៅពេលអ្នកសម្លឹងមើលទៅមេឃ ។

នៅពេលមនុស្សគិតស្រមៃអំពីភាពធំធេងនៃការបង្កបង្កើតរបស់ព្រះ នោះជួនកាលពួកគេមានអារម្មណ៍ថាខ្លួនតូចតាច ហើយពុំសំខាន់ ។ ពួកគេអាចឆ្ងល់ ថាតើព្រះទ្រង់ស្គាល់ពួកគេដែរឬទេ ។ ខគម្ពីរជាច្រើន ដែលអ្នកសិក្សានៅថ្ងៃនេះក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨ បង្ហាញអំពីការស្គាល់របស់ព្រះ ចំពោះអ្នក និង ព្រះឆន្ទៈរបស់ទ្រង់ដើម្បីនាំអ្នកឲ្យទៅជិតទ្រង់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤១ ។ សូមគិតថាតើខគម្ពីរនេះ បង្ហាញយ៉ាងដូចម្ដេចថា ព្រះមានព្រះចេស្ដាដើម្បីស្គាល់អ្នក និង ជ្រាបអំពីសេចក្ដីត្រូវការរបស់អ្នក ។ បន្ទាប់មក សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤២–៤៥ រួចស្វែងរករបៀបដែលព្រះគ្រប់គ្រងការបង្កបង្កើតរបស់ទ្រង់ រួមបញ្ចូលទាំងព្រះអាទិត្យ ព្រះចន្ទ ហ្វូងតារា និង ពិភពទាំងឡាយ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

១. សូមគិតអំពីការបង្កបង្កើតមួយចំនួនរបស់ព្រះនៅឯស្ថានសួគ៌ និង នៅលើផែនដី ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីការបង្កបង្កើតរបស់ព្រះ ដែលធ្វើឲ្យអ្នកស្ញប់ស្ញែង ។ តើការបង្កបង្កើតនោះ បង្រៀនអ្នកអំពីព្រះដ៏បង្កបង្កើតយ៉ាងដូចម្ដេច ?

២. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤៦–៤៧ ដោយស្វែងរកថាតើព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ថា យើងនឹងមើលឃើញអ្វី នៅពេលយើងសង្កេតមើលការបង្កបង្កើតរបស់ព្រះ ។ រួចសូមឆ្លើយសំណួរខាងក្រោមនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើយើងនឹងមើលឃើញអ្វី នៅពេលយើងសង្កេតមើលការបង្កបង្កើតដ៏តូចមួយរបស់ទ្រង់ ?

ខ. តើការបង្កបង្កើតដែលអ្នកមើលឃើញនៅឯស្ថានសួគ៌ និង នៅលើផែនដី ជួយអ្នកបង្កើនទីបន្ទាល់អំពីព្រះយ៉ាងដូចម្ដេច ?

៣. សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤៨–៥០ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសង្ខេបខគម្ពីរទាំងនេះជាពាក្យពេចន៍ផ្ទាល់ខ្លួនរបស់អ្នក ។ តើខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះ អំពីព្រះយេស៊ូវគ្រីស្ទ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៥១–៦១

*ព្រះអម្ចាស់លើករឿងប្រដូចមួយឡើង អំពីបុរសទាំងឡាយធ្វើការនៅក្នុងចម្ការ ហើយត្រូវបានចៅហ្វាយត្រឡប់មកជួប*

គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៥១–៦០ មានរឿងប្រដូចមួយ ដែលជួយយើងយល់អំពីទំនាក់ទំនងរបស់ព្រះជាមួយនគរទាំងឡាយ ដែលទ្រង់បានបង្កើត ។ រឿងប្រដូច គឺជារឿងដែលប្រើប្រាស់ការប្រៀបធៀប ដើម្បីបង្រៀនអំពីសេចក្ដីពិត ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៥១–៥៥ ដោយស្វែងរកថាតើបុរសម្នាក់នៅក្នុងរឿងប្រដូចនេះ បានបញ្ជាដល់ពួកអ្នកបម្រើគាត់ឲ្យធ្វើអ្វី ហើយថាតើគាត់បានសន្យាដូចម្ដេចទៅកាន់ពួកគេម្នាក់ៗ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៥៦–៦០ យើងអានថា ម្ចាស់ចម្ការបានមកជួបពួកអ្នកបម្រើរបស់គាត់នៅពេលដល់វេនពួកគេ ៖ « ពួកគេទាំងអស់គ្នាបានទទួលរស្មី នៅលើមុខចៅហ្វាយរបស់ខ្លួន គឺមនុស្សម្នាក់ៗតាមម៉ោងរបស់ខ្លួន » ( គ. និង ស. ៨៨:៥៨ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦១ ដោយស្វែងរកអ្វីដែលរឿងប្រដូចបង្រៀនយើង អំពីរបៀបដែលព្រះទាក់ទងជាមួយនគរទាំងឡាយ ដែលទ្រង់បានបង្កើត ។

ផែនដីដែលយើងរស់នៅ គឺជានគរមួយក្នុងចំណោមនគរទាំងឡាយ ដែលព្រះអម្ចាស់បានសន្យាថានឹងយាងមកជួប ។ សេចក្ដីពិតមួយដែលយើង អាចរៀនចេញពីរឿងប្រដូចនេះគឺថា **ព្រះអម្ចាស់នឹងយាងទៅនគរទាំងឡាយរបស់ទ្រង់ និងទៅជួបនឹងបណ្ដាជនដែលគ្រងនគរទាំងនោះទៅតាមកាលវេលារបស់ទ្រង់** ។ អ្នកអាចនឹងចង់សរសេរសេចក្ដីពិតនេះនៅក្នុងព្រះគម្ពីររបស់អ្នក ។



យើងនឹងរីករាយក្នុងវត្តមានរបស់ព្រះអម្ចាស់នៅលើផែនដីនេះ អំឡុងពេលសហស្សវត្សរ៍ បន្ទាប់ពីការយាងមកជាលើកទីពីររបស់ទ្រង់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦២–៦៩

*ព្រះសន្យាថានឹងយាងចូលមកជិតយើង នៅពេលយើងចូលទៅជិតទ្រង់*

សូមពិចារណាអំពីសំណួរដូចតទៅនេះ ៖ តើអ្នកមានអារម្មណ៍ថា ស្និទ្ធស្នាលជាមួយព្រះអម្ចាស់ដល់កម្រិតណា ? តើអ្នកចង់ស្និទ្ធស្នាលជាមួយទ្រង់ កាន់តែខ្លាំងដែរឬទេ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦២–៦៣ ដោយស្វែងរកអ្វីដែលយើងអាចធ្វើ ដើម្បីអញ្ជើញព្រះអម្ចាស់ឲ្យយាងចូលមកជិតយើង ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

៤. សូម ធ្វើ ដូច ខាងក្រោម នេះ នៅក្នុង សៀវភៅ កំណត់ ហេតុ ការសិក្សា ព្រះគម្ពីរ របស់ អ្នក ៖

ក. សូមសរសេរគោលការណ៍ ដែលអ្នករៀនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦៣ អំពីការខិតចូលទៅជិតព្រះអម្ចាស់ ។

ខ. សូមសរសេរសកម្មភាពចំនួនបី ចេញពី ខទី ៦៣ ដែលផ្ដល់ការយល់ដឹងជ្រាលជ្រៅដល់អ្នកអំពីរបៀបដែលអ្នកអាចខិតចូលទៅកាន់តែជិតព្រះអម្ចាស់ ។

គ. សូមឆ្លើយសំណួរដូចតទៅនេះ ៖ តើអ្នកបានធ្វើអ្វីខ្លះក្នុងការស្វែងរក សូម និង គោះ ដើម្បីខិតចូលទៅកាន់តែជិតព្រះអម្ចាស់ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦៤ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានសន្យាដល់អ្នកទាំងឡាយ ដែលអធិស្ឋានដល់ព្រះវរបិតានៅក្នុងព្រះនាមរបស់ទ្រង់ ។

តើព្រះអង្គសង្គ្រោះបានបង្រៀនដូចម្ដេច អំពីរបៀបដែលព្រះវរបិតាសួគ៌ ឆ្លើយតបរាល់ការអធិស្ឋាន ? នៅក្នុងខគម្ពីរនេះ ឃ្លា « ជាការចាំបាច់សម្រាប់អ្នក » អាចនិយាយបានថា « ជាការប្រសើរបំផុតសម្រាប់អ្នក » ។ ហេតុដូច្នេះហើយ គោលការណ៍មួយ

ដែលយើងអាចរៀនចេញពីខគម្ពីរនេះ គឺថា **ព្រះ វរបិតា សួគ៌ឆ្លើយតបរាល់ការអធិស្ឋានរបស់យើង ទៅតាមអ្វីដែលទ្រង់ជ្រាបថាជាការប្រសើរបំផុតសម្រាប់យើង ។**



សេចក្ដីថ្លែងការណ៍ដូចតទៅនេះដោយ អែលឌើរ រីឆាដ ជី ស្កត ក្នុងកូរ៉ុមនៃពួកសាវកដប់ពីនាក់ អាចជួយអ្នកយល់អំពីមូលហេតុ ដែលអ្នកគួរតែមានអារម្មណ៍នៃការដឹងគុណ ទោះជាព្រះវរបិតាសួគ៌ឆ្លើយតបការអធិស្ឋានរបស់អ្នក ទៅតាមរបៀបមួយខុសពីអ្វី ដែលអ្នកសង្ឃឹម ឬ រំពឹងទុកយ៉ាងណាក៏ដោយ ៖ « វាពិតជារឿងមួយដ៏លំបាក នៅពេលការអធិស្ឋានដ៏ស្មោះដើម្បីបានអ្វីមួយ ដែលអ្នកប្រាថ្នាចង់បានខ្លាំងបំផុតនោះ ពុំត្រូវបានឆ្លើយតបទៅតាមរបៀបដែលអ្នកចង់បាននោះ ។ វាពិបាកដើម្បីយល់អំពីមូលហេតុ ដែលការអនុវត្តសេចក្ដីជំនឿដ៏ជ្រាលជ្រៅ និង ស្មោះរបស់អ្នកដោយរស់នៅក្នុងជីវិតមួយដែលមានការគោរពប្រតិបត្តិ បែរជាមិនបានទទួលលទ្ធផលដែលចង់បានទៅវិញ ។. . . ពេលខ្លះវាពិបាក ដើម្បីស្គាល់អំពីអ្វីដែលជា *ការប្រសើរបំផុត* ឬ *ការចាំបាច់* សម្រាប់អ្នកណាស់ ។ ជីវិតរបស់អ្នកនឹងកាន់តែងាយស្រួល នៅពេលអ្នកទទួលស្គាល់ថាអ្វីដែលព្រះបានធ្វើឲ្យមាននៅក្នុងជីវិតរបស់អ្នក គឺសម្រាប់សេចក្ដីល្អ*ដ៏អស់កល្បជានិច្ច* របស់អ្នក » (Using the Supernal Gift of Prayer » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ៩ ) ។

៥. តើអ្នកគួរតែធ្វើដូចម្ដេច នៅពេលចម្លើយចំពោះការអធិស្ឋានកើតឡើង តាមរបៀបដែលអ្នកពុំបានរំពឹងទុកនោះ ? សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីបទពិសោធន៍មួយ ដែលអ្នកធ្លាប់មាននៅពេលព្រះវរបិតាសួគ៌បានឆ្លើយតបការអធិស្ឋានរបស់អ្នក នៅតាមរបៀបដែលប្រសើរបំផុតសម្រាប់អ្នក ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦៦ យើងរៀនថា របៀបដែលព្រះទាក់ទងមកកាន់យើងគឺ « សំឡេងនៃមនុស្សម្នាក់កំពុងតែស្រែកនៅក្នុងទីរហោស្ថាន » ។ សូមអានខគម្ពីរនោះ ដោយស្វែងរករបៀបដែលព្រះសូរសៀងរបស់ព្រះបន្លឺមកកាន់យើង ។ សូមគិតអំពីគ្រាមួយ ដែលអ្នកធ្លាប់បានមានអារម្មណ៍ថា ព្រះបានយាងចូលមកជិតអ្នក ទោះជាអ្នកពុំអាចមើលឃើញទ្រង់យ៉ាងណាក្ដី ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦៧–៦៩ ដោយស្វែងរករបៀបបន្ថែម ដែលអ្នកអាចចូលទៅជិតព្រះអម្ចាស់បាន ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

ដោយប្រើខគម្ពីរទាំងនេះ សូមបញ្ចប់សេចក្ដីថ្លែងការណ៍ដូចតទៅនេះ ៖ **បើភ្នែករបស់ខ្ញុំស្មោះស្ម័គ្រទាំងស្រុង ទៅចំពោះសិរីល្អរបស់ព្រះ នោះ ។**

នៅក្នុង ខទី ៦៧ ឃ្លា « ភ្នែក . . . ស្មោះស្ម័គ្រទាំងស្រុងទៅចំពោះសិរីល្អរបស់យើង » មានន័យថា លះបង់ទាំងស្រុងចំពោះកិច្ចការ និង គោលបំណងរបស់ព្រះ ។

៦. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើនរណា ដែលអ្នកស្គាល់ ដែលមើលទៅហាក់ដូចជាពេញទៅដោយពន្លឺនៃព្រះអម្ចាស់ ?

ខ. តើអ្នកមើលឃើញពន្លឺនៃព្រះអម្ចាស់ ដែលបុគ្គលនោះមាន តាមរបៀបណា ?

នៅក្នុង ខទី ៦៨ សូមកត់ចំណាំថា ដើម្បីធ្វើឲ្យគំនិតរបស់អ្នកស្មោះស្ម័គ្រទាំងស្រុងចំពោះព្រះ អ្នកត្រូវញែកខ្លួនអ្នករាល់គ្នាចេញជាបរិសុទ្ធ ។ ឃ្លា « ញែកខ្លួនអ្នករាល់គ្នាចេញជាបរិសុទ្ធ » សំដៅទៅលើតម្រូវការធ្វើឲ្យបានបរិសុទ្ធ ហើយសម្អាតខ្លួនចេញពីអំពើបាប ។ អ្នកអាចបានញែកចេញជាបរិសុទ្ធបាន តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និង អានុភាពនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកប្រែចិត្តចេញពីអំពើបាបរបស់អ្នក ហើយទទួលពិធីបរិសុទ្ធនៃបព្វជិតភាព ថែមទាំងរក្សាសេចក្ដីសញ្ញា ។

៧. សូមរំឭកអំពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយ ដែលអ្នកបានរកឃើញនៅក្នុងមេរៀននេះ ។ រួចស្រមៃថា អ្នកកំពុងតយគន់ហ្វូងតារាជាមួយមិត្តភក្ដិម្នាក់ ដែលគិតថា ព្រះទ្រង់ពុំស្គាល់គាត់ឡើយ ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្វីដែលអ្នកនឹងថ្លែងទៅកាន់មិត្តភក្ដិរបស់អ្នក ។

សូមបញ្ចប់មេរៀននេះ ដោយអាន និង ពិចារណាលើសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយ ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ ក្នុងគណៈប្រធានទីមួយ ៖



« បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំអើយ វាជាការពិត ដែលមនុស្សគឺគ្មានជាអ្វីសោះ បើប្រៀបទៅនឹងភាពធំធេងនៃចក្រវាឡនេះ ។ ជួនកាល យើងអាចមានអារម្មណ៍ថាជាមនុស្សមិនសំខាន់ គ្មានគេកត់សម្គាល់ ឯកោ ឬ ត្រូវបានបំភ្លេចចោល ។ ប៉ុន្តែ សូមចងចាំជានិច្ចថា— អ្នកសំខាន់ចំពោះទ្រង់ !. . .

« ព្រះទតមើលអ្នក ពុំមែនគ្រាន់តែជាមនុស្សរមែងស្លាប់នៅក្នុងភពតូចមួយ ដែលយើងរស់នៅមួយរយៈនេះនោះទេ— ទ្រង់ទតមើលលើអ្នក ក្នុងនាមជាបុត្ររបស់ទ្រង់ ។ ទ្រង់ទតមើលអ្នកជាតួអង្គ ដែលមានសមត្ថភាព និងបានរៀបចំរចនាអ្នកឡើងឲ្យប្រែក្លាយទៅជាដូចនោះ ។ ទ្រង់ចង់ឲ្យអ្នកដឹងថា អ្នកសំខាន់ចំពោះទ្រង់ » (You Matter to Him » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១,ទំព័រ ២២ ) ។

៨. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៤១–៦៩ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៩ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧០–១៤១

## សេចក្ដីផ្ដើម

ចំណែកនៃវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨ ដែលមេរៀននេះផ្ដោតទៅលើ ប្តូកបញ្ចូលទាំងសេចក្ដីណែនាំរបស់ព្រះអម្ចាស់ទៅដល់ក្រុមថ្នាក់ដឹកនាំបព្វជិតភាព ថាពួកគាត់ត្រូវរៀនជាមួយគ្នាតាមរយៈការសិក្សា និង សេចក្ដីជំនឿ ហើយត្រូវបង្ហាញសេចក្ដីស្រឡាញ់ និង មិត្តភាពចំពោះគ្នាទៅវិញទៅមក ។ ព្រះអម្ចាស់ក៏មានព្រះបន្ទូលទុកជាមុន អំពីទីសម្គាល់នៃការយាងមកជាលើកទីពីរ លំដាប់លំដោយនៃការរស់ឡើងវិញ និង ព្រឹត្តិការណ៍នានាជុំវិញចម្បាំងដ៏ធំ និង ចុងក្រោយបង្អស់ជាមួយសាតាំង ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧០–១១៧

*ព្រះអម្ចាស់ត្រាស់បង្គាប់ពួកអែលឌើរនៃសាសនាចក្រ ឲ្យត្រៀមខ្លួនសម្រាប់ការបម្រើរបស់ពួកគាត់ ហើយទ្រង់បើកសម្ដែងព្រឹត្តិការណ៍នានាជុំវិញការយាងមកជាលើកទីពីររបស់ទ្រង់ ។*

នៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ នារដូវរងាឆ្នាំ ១៨៣២–៣៣ ព្រះអម្ចាស់បានត្រាស់បង្គាប់ឲ្យក្រុមថ្នាក់ដឹកនាំបព្វជិតភាព ជួបប្រជុំគ្នានៅក្នុងការប្រជុំមួយ ដែលត្រូវបានហៅថា សាលានៃពួកព្យាការី ដើម្បីរៀបចំខ្លួនប្រកាសដំណឹងល្អ ទៅក្នុងចំណោមជាតិសាសន៍ទាំងឡាយនៅលើផែនដី ។ ព្រះអម្ចាស់បានត្រាស់បង្គាប់ក្រុមនេះ ឲ្យបន្តនៅទីក្រុង ខឺតឡង់ ហើយរៀនពីគ្នាទីវិញទៅមក ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧៧–៨០ ដោយស្វែងរកការណ៍ ដែលព្រះអម្ចាស់បានត្រាស់បង្គាប់ឲ្យពួកអ្នកកាន់បព្វជិតភាពទាំងនេះធ្វើ នៅពេលពួកលោកមកជួបប្រជុំគ្នា ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នករកឃើញ ។



សាលានៃពួកព្យាការី បានប្រជុំគ្នានៅបន្ទប់ខាងលើនៃផ្សាររបស់ នូវែល ខេ វិតនី ហ្វេតដល់ព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ បានកសាងហើយ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៨១–១១៥ ព្រះអម្ចាស់បានបើកសម្ដែងព្រឹត្តិការណ៍ជាច្រើន ដែលនឹងកើតឡើងពីមុន និង ក្រោយពេលការយាងមកជាលើកទីពីររបស់ទ្រង់ ។ ទ្រង់ក៏បានបើកសម្ដែងអំពីព្រឹត្តិការណ៍នានាដែលនឹងកើតឡើងនៅចុងបញ្ចប់នៃសហស្សវត្សរ៍ដែរ ។

ព្រះអម្ចាស់បានបើកសម្ដែងថា មនុស្សស្លាប់នឹងបានរស់ឡើងវិញ ស្របទៅតាមភាពសុចរិតរបស់ខ្លួន ។ អ្នកទាំងឡាយដែលរស់ឡើងវិញដំបូងគេ គឺជាអ្នកដែលគ្រងនគរសេឡេស្ទាល ( សូមមើល គ. និង ស. ៨៨:៩៧–៩៨, ១០៧ ) ។ អ្នកទាំងឡាយដែលរស់ឡើងវិញទីពីរ គឺជាអ្នកដែលគ្រងនគរទេរេសស្ទ្រាល ( សូមមើល គ. និង ស. ៨៨:៩៩ ) ។ អ្នកទាំងឡាយ ដែលគ្រងនគរទេឡេស្ទាល នឹងរស់ឡើងវិញនៅបន្ទាប់ពីសហស្សវត្សរ៍ ( សូមមើល គ. និង ស. ៨៨:១០០–១០១ ) ។ ចុងក្រោយបំផុត « ពួកអ្នកដែលនៅសល់ »—គឺពួកអ្នកដែលកើតនៅលើផែនដីនេះ ក្លាយទៅជា កូនអន្តរធាន—នឹងរស់ឡើងវិញ ហើយត្រូវបានបោះទៅពិភពងងឹតខាងក្រៅ ( សូមមើល គ. និង ស. ៨៨:១០២, ១១៤ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨–២៦

*ព្រះអម្ចាស់ពិពណ៌នាអំពីគំរូនៃការរៀន*

១. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមរាយបញ្ជីការណ៍មួយចំនួន ដែលអ្នកបានរៀននាពេលថ្មីៗនេះ នៅឯសាលា និង នៅព្រះវិហារ ។ ក្រោយមកសូមឆ្លើយសំណួរដូចតទៅនេះ ៖ តើការរៀនអំពីមុខវិជ្ជានៅឯសាលាមានដូចជា គណិតវិទ្យា និង វិទ្យាសាស្ត្រ មានសភាពខុសគ្នាពីការសិក្សាមុខវិជ្ជាដំណឹងល្អយ៉ាងដូចម្ដេច ? តើវាមានសភាពដូចគ្នាយ៉ាងដូចម្ដេច ? ( សូមមើល គ. និង ស. ៨៨:៧៨–៧៩ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨ ដោយស្វែងរកថាតើអ្នកដែលចូលរៀននៅក្នុងសាលានៃពួកព្យាការីនោះត្រូវខំខ្នះខ្នែងរៀនអំពីអ្វី ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នករកឃើញ ។ តើអ្នកគិតថា ការរៀនសូត្រ « ដោយសេចក្ដីជំនឿ » មានន័យដូចម្ដេច ?

នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយ អែលឌើរ ដាវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ សូមគូសចំណាំពាក្យ ឬ ឃ្លា ដែលជួយអ្នកឲ្យយល់កាន់តែច្បាស់អំពីអត្ថន័យនៃការរៀនសូត្រដោយសេចក្ដីជំនឿ ៖



« ក្នុងនាមជាអ្នករៀន អ្នក និង ខ្ញុំ ត្រូវប្រព្រឹត្ត ហើយធ្វើជាអ្នកដែលប្រព្រឹត្តតាមព្រះបន្ទូល មិនមែនជាអ្នកស្ដាប់ដែលគ្រាន់តែទទួលសកម្មភាពតែប៉ុណ្ណោះទេ ។ តើអ្នក និង ខ្ញុំគឺជាភ្នាក់ងារដែលធ្វើសកម្មភាព ហើយព្យាយាមរៀនសូត្រដោយសេចក្ដីជំនឿ ឬ តើយើងកំពុងតែរង់ចាំឲ្យគេបង្រៀន ហើយទទួលសកម្មភាពឬ ?. . .

« . . . ការរៀនសូត្រដោយសេចក្ដីជំនឿ តម្រូវឲ្យមានកិច្ចខិតខំខាងវិញ្ញាណ ខាងសតិអារម្មណ៍ និង ខាងរូបកាយ ហើយពុំមែនជាការទទួលភាពអកម្មនោះទេ ។ វាគឺនៅក្នុងសេចក្ដីស្មោះត្រង់ និង ភាពខ្ជាប់ខ្ជួននៃសកម្មភាពដែលបានបំផុសគំនិតយើងឲ្យមានសេចក្ដីជំនឿនោះ ដែលយើងបង្ហាញចំពោះព្រះវរបិតាសួគ៌ និង ព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ជាការស្ម័គ្រចិត្តរបស់យើងដើម្បីរៀន និង ទទួលយកការបង្ហាត់បង្រៀនពីព្រះវិញ្ញាណបរិសុទ្ធ ។. . .

« . . . ការរៀនសូត្រដោយសេចក្ដីជំនឿ តម្រូវឲ្យមានទាំង ‹ ចិត្ត និង គំនិតដែលស្ម័គ្រតាម › ( គ. និង ស. ៦៤:៣៤ ) ។ ការរៀនសូត្រដោយសេចក្ដីជំនឿ គឺជាលទ្ធផលនៃព្រះវិញ្ញាណបរិសុទ្ធ ដែលនាំព្រះចេស្ដានៃព្រះបន្ទូលនៃព្រះមកកាន់ដួងចិត្តផង និង ចូលដល់ក្នុងដួងចិត្តផង ។ ការរៀនសូត្រដោយសេចក្ដីជំនឿ ពុំអាចត្រូវបានផ្ទេរពីអ្នកបង្រៀនទៅឲ្យសិស្សបានទេ. . .ផ្ទុយទៅវិញ សិស្សត្រូវអនុវត្តសេចក្ដីជំនឿ ហើយធ្វើសកម្មភាព ដើម្បីទទួលបានចំណេះដឹងសម្រាប់ខ្លួនឯង » ( « Seek Learning by Faith » *Ensign* ខែ កញ្ញា ឆ្នាំ ២០០៧ ទំព័រ ៦៤ ) ។

យើងអាចរៀនដោយសេចក្ដីជំនឿ នៅពេលយើងរួមចំណែកក្នុងការរៀនដំណឹងល្អដោយសកម្ម និង យកចិត្តទុកដាក់ ហើយបន្ទាប់មក ប្រព្រឹត្តតាមអ្វីដែលយើងរៀន ។

សូមកត់ចំណាំនៅដើម គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨ ថាព្រះអម្ចាស់បានមានព្រះបន្ទូលថា មនុស្សមួយចំនួនពុំមានសេចក្ដីជំនឿឡើយ ។ ចេញពីអ្វីដែលអ្នកបានរៀននៅក្នុងខគម្ពីរនេះ តើអ្នកនឹងបញ្ចប់គោលការណ៍ដូចតទៅនេះ អំពីរបៀបបង្កើនសេចក្ដីជំនឿតាមរបៀបណា ? **ប្រសិនបើយើង នោះសេចក្ដីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ នឹងកើនឡើង ។**

២. ដើម្បីជួយអ្នកឲ្យយល់អំពីរបៀបដែលគោលការណ៍នេះ អាចត្រូវបានអនុវត្តនៅក្នុងជីវិតរបស់អ្នក នោះសូមអានស្ថានភាពនីមួយៗដូចខាងក្រោមនេះ ។ បន្ទាប់មក សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបដែលបុគ្គលនៅក្នុងស្ថានភាពនីមួយៗ អាចកែប្រែបានដើម្បីរៀនដោយការសិក្សា និង ដោយសេចក្ដីជំនឿ ។ សូមសរសេរផងដែរអំពីរបៀបដែលសកម្មភាពរបស់បុគ្គល បានជួយបុគ្គលនោះបង្កើនសេចក្ដីជំនឿ ។

ក. យុវនារីម្នាក់អានព្រះគម្ពីរយ៉ាងទៀងទាត់ ប៉ុន្តែ នាងកម្រនឹងឈប់ដើម្បីគិតអំពីអ្វីដែលនាងអាន ។ នាងពុំមានអារម្មណ៍ថា ការអានព្រះគម្ពីរមានអត្ថប្រយោជន៍សម្រាប់នាងខ្លាំងនោះទេ ។

ខ. យុវជនម្នាក់ចូលរួមរាល់ការប្រជុំនៅព្រះវិហារ ហើយរីករាយនឹងការចូលរួមពិភាក្សាក្នុងថ្នាក់ ។ ជួនកាល គាត់មានអារម្មណ៍បំផុតគំនិតឲ្យកែប្រែជីវិតរបស់គាត់ទៅតាមអ្វី ដែលគាត់រៀន ប៉ុន្តែជាធម្មតា គាត់ពុំប្រព្រឹត្តតាមការបំផុសគំនិតទាំងនោះទេ ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើនៅពេលណាខ្លះ ដែលអ្នកបានមានអារម្មណ៍ថា សេចក្ដីជំនឿរបស់អ្នកកើនឡើង ដែលជាលទ្ធផលមកពីការព្យាយាមរៀនយ៉ាងសកម្មដោយការសិក្សា និង ដោយសេចក្ដីជំនឿ ?

ខ. តើសកម្មភាពរបស់អ្នក ជួយឲ្យសេចក្ដីជំនឿរបស់អ្នកកើនឡើងយ៉ាងដូចម្ដេច ?

គ. តើអ្នកមានអារម្មណ៍ថាអ្នកគួរតែធ្វើអ្វីនាពេលអនាគត ដើម្បីព្យាយាមរៀនដោយការសិក្សា និង ដោយសេចក្ដីជំនឿ ?

*ការសរសេរទុកនូវគំនិតដែលអ្នកទទួលបាន*

អែលឌើរ រីឆាដ ជី ស្កត ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានលើកទឹកចិត្តយើងឲ្យសរសេរទុកនូវអារម្មណ៍ ដែលយើងទទួលបាន ៖ « សូមសរសេរទុកនៅកន្លែងសុវត្ថិភាព នូវរឿងសំខាន់ៗ ដែលអ្នករៀនពីព្រះវិញ្ញាណ ។ អ្នកនឹងយល់ឃើញថា នៅពេលអ្នកសរសេរទុកនូវគំនិត ដែលមានតម្លៃនោះ នឹងមានគំនិតបន្ថែមកើតមកជាបន្តបន្ទាប់ទៀត ។ ចំណេះដឹងដែលអ្នកទទួលបាននេះ នឹងកើតមានពេញមួយជីវិតអ្នក ។ មិនថាពេលថ្ងៃ ឬ ពេលយប់ អ្នកនៅកន្លែងណា ឬ កំពុងធ្វើអ្វីនោះទេ សូមព្យាយាមទទួលស្គាល់ ហើយឆ្លើយតបទៅនឹងការដឹកនាំនៃព្រះវិញ្ញាណជានិច្ច » ( « To Acquire Knowledge and the Strength to Use It Wisely » *Ensign* ខែ មិថុនា ឆ្នាំ ២០០២ ទំព័រ ៣២ ) ។

ដើម្បីរៀនបន្ថែមអំពីសាលានៃពួកព្យាការី សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៩–២០ ដោយស្វែងរកថាតើព្រះអម្ចាស់ពិពណ៌នាយ៉ាងដូចម្ដេចអំពីទីតាំង ដែលសាលានៃពួកព្យាការីត្រូវជួបជុំគ្នានោះ ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នករកឃើញ ។

ដើម្បីឆ្លើយតបទៅនឹងព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ឲ្យកសាងដំណាក់ឡើង ដែលមានពិពណ៌នានៅក្នុង ខទី ១១៩ នោះទីបំផុតពួកបរិសុទ្ធ បានកសាងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។ នៅពេលព្រះវិហារបរិសុទ្ធកំពុងសាងសង់ សាលានៃពួកព្យាការីបានជួបប្រជុំគ្នា នៅបន្ទប់ខាងលើនៃផ្សាររបស់ នូវល ខេ វិតនី នៅទីក្រុង ខឺតឡង់ ។

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២១–២៦ រួចស្វែងរកថាតើព្រះអម្ចាស់រំពឹងឲ្យពួកបងប្អូនប្រុស នៅក្នុងសាលានៃពួកព្យាការីប្រព្រឹត្តយ៉ាងដូចម្ដេច ។ សូមពិចារណាអំពីរបៀបដែលឥរិយាបថនេះ អាចជួយអ្នកនៅពេលអ្នកសិក្សាដំណឹងល្អដោយខ្លួនឯង និង ជាមួយមនុស្សដទៃ ។ អ្នកអាចនឹងពិចារណាអំពី របៀបដែលឥរិយាបថនានា ដែលអ្នករកឃើញនោះអាចត្រូវបានអនុវត្តនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់អ្នក ។

៤. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថាវាន័យដូចម្ដេច ដែលត្រូវ « ឈប់ពីសម្ដីអសារឥតការទាំងអស់របស់អ្នក ពីសំណើចទាំងអស់ . . . និង គំនិតផ្ដេសផ្ដាសទាំងអស់របស់អ្នក » ( គ. និង ស. ៨៨:១២១ ) ?

សេចក្ដីណែនាំអំពីសំណើច និង គំនិតផ្ដេសផ្ដាសក្នុងការនិយាយស្ដី ត្រូវបានប្រទានឲ្យអ្នកដែលចូលរៀនក្នុងសាលានៃពួកព្យាការី ដែលមានន័យថា អ្នកដែលចូលរៀនក្នុងសាលានៃពួកព្យាការី ត្រូវមានគារវភាពចំពោះកិច្ចការដ៏ពិសិដ្ឋៗ ។ នៅទីបំផុតការប្រជុំទាំងនេះបានប្រព្រឹត្តទៅនៅក្នុងព្រះវិហារបរិសុទ្ធ ។

តើការគោរពប្រតិបត្តិតាមឱវាទនេះ អាចផ្ដល់អត្ថប្រយោជន៍ដល់កិច្ចខ្នះខ្នែងក្នុងការរៀនអ្វីដែលពិសិដ្ឋយ៉ាងដូចម្ដេច ?

ទោះជាយ៉ាងណាក៏ដោយ ឱវាទនេះពុំមានន័យថា សំណើចទាំងអស់សុទ្ធតែជាអំពើបាបនោះទេ ។ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានមានប្រសាសន៍ទៅកាន់ពួកយុវវ័យនៃសាសនាចក្រ អំពីសំណើច ៖



« ប្អូនៗអាចមានពេលដ៏រីករាយ ។ ប្រាកដណាស់ ប្អូនៗអាចមានវាបាន ! យើងចង់ឲ្យប្អូនៗ មានការសប្បាយ ។ យើងចង់ឲ្យប្អូនៗ រីករាយនឹងជីវិត ។. . . យើងចង់ឲ្យប្អូនៗរឹងមាំ និង អឹកធឹកឡើង ដើម្បីច្រៀង ហើយរាំ ដើម្បីសើច ហើយសប្បាយ ។

« ប៉ុន្តែពេលធ្វើដូច្នោះ ចូររាបសា និងប្រកបដោយការអធិស្ឋាន នោះស្នាមញញឹមនៅស្ថានសួគ៌ នឹងមានមកលើអ្នក » (A Prophet's Counsel and Prayer for Youth, » *Ensign* ខែ មករា ឆ្នាំ ២០០១ ទំព័រ ១១ ) ។

សូមកត់ចំណាំភាពស្ទួនដដែលៗនៃពាក្យ *ទាំងអស់* នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២២ ។ សូមគិតថាតើថ្នាក់រៀនមួយ អាចមានអានុភាពយ៉ាងដូចម្ដេច ប្រសិនបើសិស្ស *ទាំងអស់* ចូលរួមរៀនមេរៀននោះ ហើយព្យាយាមរៀនពីគ្នាទៅវិញទៅមក ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២៤ មាននូវសេចក្ដីណែនាំពីព្រះអម្ចាស់ អំពីការដេក ។ សូមពិចារណាអំពីរបៀបដែលការដេកយូរជាងតម្រូវការ អាចប៉ះពាល់ដល់សមត្ថភាពយើង ក្នុងការរៀន ឬ ទទួលអារម្មណ៍ពីព្រះវិញ្ញាណ ។ ( គ. និង ស. ៨៨:១២៤ គឺជាចំណេះចំណានខគម្ពីរមួយ ។ អ្នកអាចនឹងចង់គូសចំណាំវានៅក្នុងរបៀបមួយ ដែលជួយអ្នកអាចងាយរកវាឃើញនៅពេលខាងមុខ ) ។

តើអ្នកគិតថា ការដេកក្នុងចំនួនពេលវេលាត្រឹមត្រូវ និង ការក្រោកឲ្យបានឆាប់ អាចជួយយើងឲ្យរៀនកាន់តែប្រសើរតាមរបៀបណា ? គោលការណ៍មួយដែលអាចរកបានចេញពីសេចក្ដីណែនាំរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨–២៦ គឺថា **ការធ្វើសកម្មភាពសុចរិត និង ចៀសវាងពីសកម្មភាពទុច្ចរិត នឹងជួយយើងឲ្យរៀនចេះ និង បានស្អាងឡើង ។** សូមគិតអំពីការសរសេរគោលការណ៍នេះ នៅលើគែមព្រះគម្ពីររបស់អ្នក ។

៥. សូមរំពឹក គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២១–២៦ រួចកំណត់ថាតើ ប្រការមួយណានៃឱវាទនេះ ដែលអ្នកត្រូវអនុវត្តឲ្យបានកាន់តែពេញលេញនៅក្នុងជីវិតរបស់អ្នក ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលអ្នកគិតថា ការធ្វើតាមឱវាទរបស់ព្រះអម្ចាស់ និង ការប្រព្រឹត្តនូវការណ៍ទាំងនេះ មានសារៈសំខាន់ក្នុងការជួយអ្នកឲ្យរៀនចេះដំណឹងល្អ និង បានស្អាងឡើង ។

## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២៤

៦. ដើម្បីជួយអ្នកឲ្យទន្ទេញចាំ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២៤ សូមរាយបញ្ជីដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីឥរិយាបថចំនួនប្រាំមួយ ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថាត្រូវចៀសវាង ឬ ធ្វើតាម ។ សូមសូត្រឡើងវិញម្ដងហើយម្ដងទៀត នូវបញ្ជីឥរិយាបថទាំងនោះ រហូតដល់អ្នកទន្ទេញចាំមាត់ ។ ដើម្បីជួយអ្នកចងចាំ ហើយអនុវត្តតាមឱវាទដែលមាននៅក្នុងវគ្គចំណេះចំណានខគម្ពីរនេះ សូមគិតអំពីការសូត្រវានៅក្នុងចិត្តរាល់ពេលដែលអ្នកចូលរៀនថ្នាក់សិក្ខាសាលា ឬ ថ្នាក់នៅឯព្រះវិហារ ឬ កម្មវិធីរាត្រីជួបជុំក្រុមគ្រួសារនៅខែក្រោយ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២៧–៤១

*ព្រះអម្ចាស់រៀបចំសាលានៃពួកព្យាការី*



សូមគិតអំពីទីកន្លែងមួយចំនួន ដែលអ្នកសិក្សាដំណឹងល្អជាមួយមនុស្សដទៃ ។ សូមគិតប្រសិនបើមានមនុស្សដែលអ្នកពុំស្គាល់ច្បាស់ ឬ ព្យាយាមចុះសម្រុង ។ សូមគិតអំពីមនុស្សម្នាក់ នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២៧–៤១ ។ សូមពិចារណាសំណួរដូចតទៅនេះ ៖ តើទំនាក់ទំនងរបស់អ្នក ជាមួយមនុស្សដែលអ្នករៀនដំណឹងល្អជាមួយ មានឥទ្ធិពលលើសមត្ថភាពរបស់អ្នកក្នុងការរៀន ហើយបានស្អាងឡើងដោយព្រះវិញ្ញាណយ៉ាងដូចម្ដេច ?

ព្រះអម្ចាស់មានព្រះទ័យរំពឹងឲ្យសមាជិកក្នុងសាលានៃពួកព្យាការី បង្កើតទំនាក់ទំនងល្អជាមួយគ្នាទៅវិញទៅមក នៅពេលពួកគាត់រៀនជាមួយគ្នា ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១២៨–៣៤ ដោយស្វែងរកតួនាទីរបស់គ្រូបង្រៀន ក្នុងការបង្កើតបរិយាកាសខាងវិញ្ញាណនៃការរៀន នៅក្នុងសាលានៃពួកព្យាការី ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នករកឃើញ ។

កិច្ចស្វាគមន៍របស់គ្រូបង្រៀនដល់សមាជិកក្នុងថ្នាក់មានន័យថា គាត់ស្វាគមន៍នៅពេលពួកគេដើរចូលក្នុងថ្នាក់ ។ នេះគឺជាការទទួលរាក់ទាក់ដ៏ចាំបាច់ នៅក្នុងសាលានៃពួកព្យាការី ។ តើអ្នកកត់ចំណាំអ្វីខ្លះ អំពីកិច្ចស្វាគមន៍ និង ការទទួលរាក់ទាក់នៅក្នុង ខទី ១៣៣ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១៣៥–៣៧ ដោយស្វែងរកតួនាទីរបស់សិស្ស ក្នុងការបង្កើតបរិយាកាសនៃការរៀនដ៏ល្អ ។

តើទំនាក់ទំនងប្រភេទណា ដែលព្រះអម្ចាស់បានមានព្រះទ័យឲ្យសមាជិកក្នុងសាលានៃពួកព្យាការី មានចំពោះគ្នាទៅវិញទៅមក ? យោងតាម ខទី ១៣៧ តើព្រះអម្ចាស់បានសន្យាដូចម្ដេច ប្រសិនបើសមាជិកក្នុងសាលារបស់ពួកព្យាការី នឹងធ្វើតាមសេចក្ដីណែនាំនេះ ?

ខាងក្រោមនេះគឺជាគោលការណ៍ ដែលយើងរៀនចេញពីខគម្ពីរទាំងនេះ ៖ **បើយើងបង្ហាញមិត្តភាព និង សេចក្ដីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក នោះយើងអាចអញ្ជើញព្រះវិញ្ញាណ នៅពេលយើងសិក្សាដំណឹងល្អជាមួយគ្នា ។**

៧. សូមមើលកិច្ចស្វាគមន៍នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១៣៣ ឡើងវិញ ។ រួចសូមឆ្លើយសំណួរខាងក្រោមនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា អ្នកអាចបង្ហាញ « ការសម្រេចចិត្តដែលជាប់ ឥតកម្រើក ហើយឥតប្រែប្រួលដើម្បីជាមិត្ត » ទៅដល់សមាជិកក្នុងថ្នាក់ ឬ សមាជិកគ្រួសារ ដែលយើងពុំស្គាល់ច្បាស់ ឬ អាចនឹងព្យាយាមទទួលបានសេចក្ដីស្រឡាញ់តាមរបៀបណា ?

ខ. តើនៅពេលណាខ្លះ ដែលអ្នកធ្លាប់មានបទពិសោធន៍រៀនដំណឹងល្អនៅក្នុងបរិយាកាស ដែលមានមនុស្សគ្រប់គ្នាបានសម្រេចចិត្តធ្វើជាមិត្ត ? តើវាមានសភាពដូចម្ដេច ឬ តើអ្នកគិតថាវានឹងមានសភាពដូចម្ដេច ?

សូមគិតអំពីរបៀបដែលអ្នកអាចបង្កើនការសម្រេចចិត្ត ដើម្បីស្រឡាញ់មនុស្សដែលអ្នករៀនដំណឹងល្អជាមួយ ។ អ្នកអាចនឹងចង់កត់ត្រាការបំផុសគំនិតនានា ដែលអ្នកទទួលអារម្មណ៍ថាត្រូវបង្ហាញសណ្ដានចិត្ត និង សេចក្ដីស្រឡាញ់កាន់តែច្រើន ចំពោះសមាជិកក្នុងថ្នាក់ និង សមាជិកគ្រួសារ ។

៨. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧០–១៤១ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ១៩ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩

## សេចក្ដីផ្ដើម

នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៨៣៣ ដើម្បីឆ្លើយតបទៅនឹងការទូលសួររបស់ព្យាការី យ៉ូសែប ស្ម៊ីធ អំពីការប្រើប្រាស់ថ្នាំជក់របស់ពួកបងប្អូនប្រុសនៅក្នុងការប្រជុំទាំងឡាយរបស់ពួកគាត់ នោះព្រះអម្ចាស់បានប្រទានវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩ ដែលត្រូវបានស្គាល់ថាជា ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ។ នៅក្នុងវិវរណៈនោះ ព្រះអម្ចាស់បានព្រមានទាស់នឹងការប្រើប្រាស់សារធាតុដែលបណ្ដាលឲ្យអន្ដរាយ ហើយបានលើកទឹកចិត្តឲ្យទទួលទានអាហារដែលនាំឲ្យមានសុខភាពល្អវិញ ។ ព្រះអម្ចាស់ក៏បានសន្យាដែរថា មនុស្សទាំងឡាយដែលធ្វើតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ នឹងមានពរទាំងខាងសាច់ឈាម និង ខាងវិញ្ញាណ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១–៣

*យ៉ូសែប ស្ម៊ីធ បង្ហាញវិវរណៈ ដែលត្រូវបានស្គាល់ថាជា ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ*

តើអ្នកធ្លាប់ពន្យល់ប្រាប់នរណាម្នាក់ អំពីមូលហេតុដែលអ្នកមិនទទួលទានគ្រឿងស្រវឹង តែ ឬ កាហ្វេ ឬ ប្រើប្រាស់ថ្នាំជក់ដែរឬទេ ? បើអ្នកធ្លាប់ តើអ្នកចងចាំអំពីអ្វីដែលអ្នកបានថ្លែង និង ប្រតិកម្មរបស់បុគ្គលនោះដែរឬទេ ? មេរៀននេះនឹងជួយអ្នកយល់កាន់តែច្បាស់ អំពីពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ហើយត្រៀមខ្លួនដើម្បីពន្យល់វាទៅកាន់មនុស្សទូទៅ ។



នារដូវរងាឆ្នាំ ១៨៣៣ ពួកបងប្អូនប្រុសបព្វជិតភាពប្រមាណជា ២០ នាក់ បានចាប់ផ្ដើមប្រជុំគ្នានៅបន្ទប់ខាងលើនៃផ្សាររបស់ នូវល ខេ វិតនី នៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ដើម្បីចូលរួមសាលានៃពួកព្យាការី ។ « នៅក្នុងការប្រជុំនៃសាលានោះ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៨៣៣ ព្យាការីបានទទួលវិវរណៈដ៏សំខាន់មួយ ។ នៅជំនាន់ដំបូងនៃសាសនាចក្រ ការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជក់ កាហ្វេ និង តែ គឺជារឿងធម្មតានៅក្នុងសហគមន៍ និងចំណោមសមាជិកសាសនាចក្រ ។ នៅពេលព្យាការីបានឃើញពួកបងប្អូនប្រុស ប្រើប្រាស់ថ្នាំជក់នៅសាលា នោះលោកបានមានការព្រួយបារម្ភ ។ ព្រិកហាំ យ៉ង់ នៅចាំដូច្នេះ ៖ ‹ នៅពេលពួកគាត់ប្រជុំគ្នានៅក្នុងបន្ទប់នេះបន្ទាប់ពីស្រស់ស្រូបអាហារពេលព្រឹក [ កិច្ចការ ] ដំបូងដែលពួកគាត់ធ្វើ គឺអុជខ្សៀរបស់ពួកគាត់ ហើយកាលកំពុងតែជក់ នោះពួកគាត់ជជែកគ្នាអំពីកិច្ចការដ៏មហិមានៃនគរ ។. . . ជារឿយៗ នៅពេលព្យាការីចូលទៅក្នុងបន្ទប់ដើម្បីបង្រៀន នោះលោកបានឃើញថា ខ្លួនលោកហ៊ុំព័ទ្ធទៅដោយផ្សែងបារី ។ ការណ៍នេះបូករួមទាំងការត្អូញត្អែរពីសំណាក់ភរិយារបស់លោកអំពីការសម្អាតកម្រាលឥដ្ឋដ៏កខ្វក់ [ មកពីការទំពារថ្នាំជក់ ] ផងនោះ បានធ្វើឲ្យព្យាការីពិចារណាលើបញ្ហានេះ ហើយលោកបានទូលសួរព្រះអម្ចាស់ទាក់ទងទៅនឹងការប្រើប្រាស់ថ្នាំជក់របស់ពួកបងប្អូនប្រុស ហើយវិវរណៈនេះត្រូវបានស្គាល់ថាជា ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ដែលបានមកពីការទូលសួរនោះ › » (*ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* [ ឆ្នាំ ២០០៧ ] ទំព័រ ២៦៣) ។

សូមអានសេចក្ដី ណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩ ដោយស្វែងរកអ្វីដែលព្យាការី យ៉ូសែប ស្ម៊ីធ បានធ្វើក្នុងការឆ្លើយតបទៅកាន់ពួកបងប្អូនប្រុសអំពីការប្រើប្រាស់ថ្នាំជក់របស់ពួកគាត់ ។ បន្ទាប់មក សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១–៣ ដោយស្វែងរកពាក្យ និង ឃ្លា ដែលពិពណ៌នាអំពីគោលបំណងរបស់ព្រះអម្ចាស់ក្នុងការប្រទានវិវរណៈនេះ ។

អ្នកអាចនឹងរកឃើញថា គោលបំណងមួយនៃវិវរណៈនេះ ទាក់ទងនឹងការសង្គ្រោះខាងសាច់ឈាមរបស់យើង ។ ការសង្គ្រោះខាងសាច់ឈាម ត្រូវអនុវត្តជាមួយនឹងសុខុមាលភាពខាងរូបកាយរបស់យើង ។

សូមកត់ចំណាំនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:២ ថា ដំបូងឡើយ ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ពុំត្រូវបានប្រទានមកជាព្រះបញ្ញត្តិនៅឡើយទេ ។ ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ បានពន្យល់ ៖ « នៅគ្រានោះ . . .បើ [ ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ]

ត្រូវបានប្រទានជាព្រះបញ្ញត្តិ នោះវានឹងនាំឲ្យមនុស្ស ដែលញៀនក្នុងការប្រើប្រាស់សារធាតុពុលទាំងឡាយ ឲ្យធ្លាក់នៅក្រោមការកាត់ទោស ដូច្នេះ ព្រះអម្ចាស់បានមានសេចក្ដីមេត្តាករុណា ហើយប្រទានឱកាសឲ្យពួកគេយកឈ្នះជាមុនសិន ពីមុនទ្រង់ដាក់ឲ្យពួកគេស្ថិតនៅក្រោមច្បាប់ » ( នៅក្នុង របាយការណ៍សន្និសីទ ខែ តុលា ឆ្នាំ ១៩១៣ ទំព័រ ១៤ ) ។

ដោយសារតែហេតុនេះហើយ ទើបយើងគួរតែប្រុងប្រយ័ត្នកុំវិនិច្ឆ័យថ្នាក់ដឹកនាំសាសនាចក្រជំនាន់ដំបូងមួយចំនួន ដែលបន្ទាប់ពីពាក្យសម្ដីនៃប្រាជ្ញាវាងវៃត្រូវបានបើកសម្ដែងហើយ នៅតែប្រើប្រាស់សារធាតុដែលត្រូវបានហាមឃាត់នាពេលសព្វថ្ងៃនេះ ។ ពេញមួយប្រវត្តិសាសនាចក្រជំនាន់ដំបូង ថ្នាក់ដឹកនាំបានអញ្ជើញពួកបរិសុទ្ធឲ្យរស់នៅតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃឲ្យបានកាន់តែពេញលេញ ។ នៅសន្និសីទទូទៅនាសរទរដូវឆ្នាំ ១៨៥១ ប្រធាន ព្រិកហាំ យ៉ង់ បានស្នើឲ្យពួកបរិសុទ្ធទាំងអស់ចុះសេចក្ដីសញ្ញាជាផ្លូវការ ដើម្បីចៀសវាងពីតែ កាហ្វេ ថ្នាំជក់ និង ស្រាវិស្គី ។ នៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៨៨២ ព្រះអម្ចាស់បានបើកសម្ដែងដល់ប្រធាន ចន ថេលើរ ថា ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ត្រូវចាត់ទុកថាជាព្រះបញ្ញត្តិមួយ ។ ក្នុងឆ្នាំ ១៩១៩ គណៈប្រធានទីមួយនៅក្រោមការដឹកនាំរបស់ប្រធាន ហ៊ីប៊ើរ ចេ គ្រាន្ត បានដាក់ការគោរពប្រតិបត្តិពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ជាតម្រូវការដើម្បីទទួលបានបណ្ណចូលព្រះវិហារបរិសុទ្ធ ។ ពាក្យសម្ដីនៃប្រាជ្ញាវាងវៃបន្តធ្វើជាព្រះបញ្ញត្តិដ៏មានសារៈសំខាន់នាពេលសព្វថ្ងៃនេះ ហើយការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិនេះ គឺជាលក្ខខណ្ឌដែលតម្រូវឲ្យមានពីមុនពិធីបុណ្យជ្រមុជទឹក ការចូលរួមព្រះវិហារបរិសុទ្ធ កិច្ចការផ្សព្វផ្សាយសាសនា និង កិច្ចការដ៏សក្ដិសមផ្សេងៗទៀតនៅក្នុងសាសនាចក្រ ។

១. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរឃ្លា *គោលការណ៍ដោយសេចក្ដីសន្យា* ( ចេញពី គ. និង ស. ៨៩:៣ ) ដូចបានបង្ហាញខាងក្រោមនេះ ។ សូមទុកចន្លោះខ្លះ ដើម្បីសរសេរគោលការណ៍ និង សេចក្ដីសន្យានៃវិវរណៈនេះ នៅពីក្រោមពាក្យទាំងពីរនៃឃ្លានេះ ។ អ្នកអាចនឹងចង់គូសចំណាំឃ្លានេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។

| គោលការណ៍ | ដោយសេចក្ដីសន្យា |
|---|---|
| | |

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:៤–៩

*ព្រះអម្ចាស់ព្រមានពួកបរិសុទ្ធកុំឲ្យប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជក់ តែ ឬ កាហ្វេ*



តើអ្នកធ្លាប់ស្ទូចត្រីកាលពីមុនដែរឬទេ ?

តើអ្នកស្ទូចត្រីព្យាយាម បញ្ឆោតត្រីឲ្យស៊ីសន្ទូចតាមរបៀបណាខ្លះ ?

តើហេតុអ្វីបានជាមនុស្សមួយចំនួនព្យាយាម បញ្ចុះបញ្ចូលអ្នកឲ្យទទួលទានសារធាតុដែលព្រះអម្ចាស់បានហាមឃាត់ ? តើពួកគេប្រើនុយ ឬ វិធីសាស្ត្រអ្វីខ្លះ ដើម្បីព្យាយាមបញ្ចុះបញ្ចូលអ្នក និង មនុស្សទូទៅឲ្យប្រើប្រាស់សារធាតុទាំងនោះ ? សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:៤ ដោយស្វែងរកថាតើនរណា ដែលព្រះអម្ចាស់បានព្រមានថា នឹងប៉ុនប៉ងបញ្ឆោតពួកបរិសុទ្ធនៅថ្ងៃចុងក្រោយ ។



សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នៅក្រោមចំណងជើង « គោលការណ៍ » ៖ **ព្រោះតែអំពើអាក្រក់ទាំងឡាយនៃមនុស្សដែលរួមគំនិតប្រព្រឹត្តអំពើទុច្ចរិតនៅថ្ងៃចុងក្រោយ នោះព្រះអម្ចាស់ព្រមានយើងមិនឲ្យប្រើប្រាស់សារធាតុអន្តរាយនានា ។**

សេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន អ៊ែសរ៉ា ថាហ្វ បែនសឹន ជួយយើងឲ្យយល់ថា អំពើអាក្រក់មួយ និង មនុស្សដែលរួមគំនិតប្រព្រឹត្តអំពើទុច្ចរិត គឺទទួលបានផលប្រយោជន៍ដោយការជួញដូរសារធាតុញៀនដល់មនុស្សដទៃ ៖



« ព្រះអម្ចាស់បានទតឃើញជាមុននូវ ស្ថានភាពនាពេលសព្វថ្ងៃនេះ នៅពេលមនុស្សមានចិត្តចង់បានប្រាក់ នោះបានបណ្ដាលឲ្យមនុស្សរួមគំនិត ទាក់ទាញមនុស្សដទៃឲ្យសេពសារធាតុពុលទៅក្នុងរូបកាយរបស់ពួកគេ ។ ការផ្សាយពាណិជ្ជកម្មដែលផ្សព្វផ្សាយអំពីស្រាបៀរ ស្រាទំពាំងបាយជូរ គ្រឿងស្រវឹងនានា កាហ្វេ ថ្នាំជក់ និង សារធាតុអន្តរាយដទៃៗទៀត គឺជាគំរូនៃទង្វើដែលព្រះអម្ចាស់បានទតឃើញទុកជាមុន ។ ប៉ុន្តែ គំរូដ៏ប្រកបទៅដោយគ្រោះថ្នាក់បំផុតនៃការរួមគំនិតដ៏អាក្រក់នោះ នៅក្នុងជំនាន់របស់យើងនេះ គឺជាអ្នកដែលជំរុញចិត្តឲ្យពួកយុវវ័យធ្លាក់ចូលទៅក្នុងការប្រើប្រាស់គ្រឿងញៀន ។

> « ឱបងប្អូនប្រុសស្រីវ័យក្មេងរបស់ខ្ញុំអើយ យើងសូមព្រមានដល់បងប្អូនដោយសេចក្ដីស្រឡាញ់ទាំងស្រុងថា សាតាំង និងពួកពលបរិវាររបស់វា នឹងស្រវាស្រទេញក្នុងការជំរុញចិត្តអ្នកឲ្យប្រើប្រាស់សារធាតុពុលនានា ព្រោះពួកវាដឹងយ៉ាងប្រាកដថា បើអ្នកសេពសារធាតុទាំងនោះ អំណាចខាងវិញ្ញាណរបស់អ្នកនឹងចុះខ្សោយ ហើយអ្នកនឹងធ្លាក់ទៅក្នុងអំណាចរបស់អារក្ស ។ ចូរនៅឲ្យឆ្ងាយពីកន្លែង និងមនុស្សទាំងនោះ ដែលនឹងជះឥទ្ធិពលដល់អ្នកឲ្យល្មើសនឹងបទបញ្ញត្តិរបស់ព្រះ ។ ចូររក្សាបទបញ្ញត្តិនៃព្រះ ហើយអ្នកនឹងមានប្រាជ្ញាដើម្បីដឹង ហើយអាចញែកដឹងថា វាអាក្រក់ » (« A Principle with a Promise » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៣ ទំព័រ ៥៤–៥៥ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:៥–៩ ដោយស្វែងរកថាតើសារធាតុអ្វី ដែលព្រះអម្ចាស់បានព្រមានដល់ពួកបរិសុទ្ធមិនឲ្យទទួលទានចូលទៅក្នុងរូបកាយរបស់ពួកគេ ។ សូមគិតពីការគូសចំណាំអ្វីដែលអ្នករកឃើញ ។ ( ថ្នាក់ដឹកនាំសាសនាចក្របានថ្លែងថា វាក្យសព្ទ « ភេសជ្ជៈក្ដៅ » សំដៅទៅលើតែ និង កាហ្វេ ) ។ តើសារធាតុទាំងឡាយនៅក្នុង ខទី ៥–៩ មានសភាពអន្តរាយយ៉ាងដូចម្ដេច ?

សូមកត់ចំណាំថា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:៧–៨ ថ្លែងថា គ្រឿងស្រវឹង និង ថ្នាំជក់ ផ្ដល់ការប្រើប្រាស់ត្រឹមត្រូវផង និង មិនត្រឹមត្រូវផង ។ សព្វថ្ងៃនេះ មានសារធាតុផ្សេង ៗទៀត ដែលអាចត្រូវបានប្រើប្រាស់ដោយខុសឆ្គង ដូច្នេះ វាបានក្លាយទៅជាសារធាតុអន្តរាយ និង ញៀន ។ ថ្នាក់ដឹកនាំសាសនាចក្របានព្រមានទាស់នឹងការប្រើប្រាស់នៃ « ភេសជ្ជៈ គ្រឿងញៀន សារធាតុគីមី ឬ សកម្មភាពដ៏គ្រោះថ្នាក់ ដែលត្រូវបានប្រើ ដើម្បីបង្កើតឱ្យមាន ‹ អារម្មណ៍រំភើបរីករាយ › ឬ ឥទ្ធិពលបន្លំអារម្មណ៍ផ្សេងទៀត ដែលអាចបង្កឲ្យអន្តរាយដល់រូបកាយ ឬ គំនិតរបស់អ្នក ។ សារធាតុទាំងនេះមួយចំនួនរួមមាន កញ្ឆា ឱសថកម្រិតខ្លាំង វេជ្ជបញ្ជា ឱសថជាវដោយគ្មានវេជ្ជបញ្ជា និង សារធាតុគីមីដែលប្រើនៅតាមផ្ទះ » (*ដើម្បីកម្លាំងនៃយុវជន* [ កូនសៀវភៅ ឆ្នាំ ២០១១ ] ទំព័រ ២៦ ) ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

   ក. តើការញៀនមានសភាពដូចគ្នាទៅនឹងផ្លែសន្ទូច ដែលមនុស្សប្រើដើម្បីស្ទូចត្រីយ៉ាងដូចម្ដេច ?

   ខ. តើហេតុអ្វីបានជាការញៀន បំផ្លាញភាពរីកចម្រើនដ៏អស់កល្បរបស់យើង ?

   គ. តើការព្រមានឲ្យចៀសវាងពីសារធាតុញៀន និង អន្តរាយ បានប្រទានពរដល់ជីវិតរបស់អ្នកយ៉ាងដូចម្ដេច ?

អ្នកនឹងមានពរ ប្រសិនបើអ្នកសម្រេចចិត្តនាពេលឥឡូវនេះ ថានឹងមិនទទួលទានសារធាតុដែលផ្ទុយទៅនឹងពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១០–១៧

*ព្រះលើកទឹកចិត្តឲ្យយើងប្រើប្រាស់ រុក្ខជាតិ ផ្លែឈើ សាច់ និង ធញ្ញជាតិ*



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១០–១៧ ដោយស្វែងរកអាហារ ដែលព្រះអម្ចាស់បានលើកទឹកចិត្តយើងឲ្យទទួលទាន ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នករកឃើញ ។ យោងតាម ខទី ១១ តើយើងគួរមានឥរិយាបថបែបណា នៅពេលយើងទទួលទានអាហារដែលផ្ដល់សុខភាពល្អទាំងនេះ ?

វាអាចនឹងផ្ដល់អត្ថប្រយោជន៍ក្នុងការដឹងថា « ដោយការប្រុងប្រយ័ត្ន » មានន័យថា ដោយឈ្លាសវៃ និង យកចិត្តទុកដាក់ ។ របបអាហារលើសកម្រិត ឬ គ្មានតុល្យភាព ទោះជាអាហារល្អយ៉ាងណាក្ដី អាចជាអាហារដែលពុំនាំឲ្យមានសុខភាពល្អនោះទេ ។

៣. សូមសរសេរអំពីអាហារដែលនាំឲ្យមានសុខភាពល្អ នៅក្រោមចំណងជើង « គោលការណ៍ » នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

គំរូមួយនៃការប្រើប្រាស់អាហារដោយប្រុងប្រយ័ត្ន អាចឃើញមាននៅក្នុងសេចក្ដីណែនាំ ដែលព្រះអម្ចាស់បានប្រទានឲ្យអំពីសាច់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១២–១៣ ។ ពាក្យ *ដោយសំចៃ* ណែនាំថា សាច់ត្រូវប្រើប្រាស់តាមរបៀបដែលមិនខ្ជះខ្ជាយ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១៨–២១

*ព្រះអម្ចាស់សន្យាថានឹងប្រទានសុខភាពល្អ ប្រាជ្ញា និង ការការពារដល់អ្នកដែលគោរពតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ*

សូមសរសេរគោលការណ៍ខាងក្រោមនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នៅក្រោមចំណងជើង « សេចក្ដីសន្យា » ៖ **បើយើងធ្វើតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ នោះព្រះអម្ចាស់នឹងប្រទានពរឲ្យយើងដោយនូវ** . . .

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១៨–១៩ រួចស្វែងរកពរជ័យមួយចំនួន ដែលអ្នកអាចទទួលបានចំពោះការគោរពប្រតិបត្តិតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ។

៤. សូមប្រើអ្វីដែលអ្នកបានរៀនចេញពី ខទី ១៨–១៩ ដើម្បីបញ្ចប់ប្រយោគដែលអ្នកបានសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ ( សូមទុកចន្លោះដើម្បីសរសេរចូលទៅក្នុង ប្រយោគនេះនៅពេលក្រោយ ) ។ បន្ទាប់មក សូមឆ្លើយសំណួរដូចតទៅនេះ ៖ តើការគោរពតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ អាចជួយយើងឲ្យទទួលបានប្រាជ្ញា និង ចំណេះដឹងបានតាមរបៀបណា ?

ប្រធាន ប៊យដ៍ ឃេ ផាកកឺ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់អំពីគោលបំណងចម្បងមួយនៃពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ៖



« ខ្ញុំបានដឹង . . . ថា គោលបំណងចម្បងនៃពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ត្រូវកើតឡើងជាមួយនឹងវិវរណៈ ។. . .

« បើមនុស្សម្នាក់ ‹ នៅក្រោមឥទ្ធិពលនេះ › ស្ទើរតែមិនអាចស្ដាប់ការនិយាយធម្មតាផង តើពួកគេអាចឆ្លើយតបទៅនឹងការបំផុសគំនិតខាងវិញ្ញាណ ដែលធ្វើឲ្យអារម្មណ៍ដ៏ទន់ភ្លន់បំផុតរបស់គេរំជួលដោយរបៀបណា ?

« ‹ ពាក្យសម្ដីនៃប្រាជ្ញាវាងវៃ មានតម្លៃដូចជាក្រឹត្យវិន័យនៃសុខភាពដែរ វាអាចមានតម្លៃសម្រាប់វិញ្ញាណអ្នក ជាងសម្រាប់រាងកាយអ្នកទៅទៀត › (“Prayers and Answers,” *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ ទំព័រ ២០ ) ។

សូមគិតអំពីរបៀបដែលការគោរពប្រតិបត្តិតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ បាននាំឲ្យអ្នករីករាយនឹងភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ដែលបង្ហាញប្រាជ្ញា និង ចំណេះដឹងទៅដល់អ្នកដែលស្មោះត្រង់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:២០–២១ ដោយស្វែងរកពរជ័យបន្ថែម ដែលកើតឡើងពីការធ្វើតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ។ ( គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១៨–២១ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ អ្នកអាចនឹងចង់គូសចំណាំវានៅក្នុងរបៀបមួយ ដែលជួយអ្នកអាចងាយរកវាឃើញនៅពេលខាងមុខ ) ។

៥. ចេញពីអ្វីដែលអ្នកបានរៀនពីខគម្ពីរទាំងនេះ សូមសរសេរចូលទៅក្នុងប្រយោគដែលនៅក្រោមចំណងជើង « សេចក្ដីសន្យា » នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ ( សូមមើល លេខយោង ២១ *ក* ដើម្បីជួយអ្នកយល់ឃ្លា « ទេវតាដែលបំផ្លាញនឹងបង្ហួសពួកគេ » ។ សេចក្ដីសន្យានៃការថែរក្សាពីស្ថានសួគ៌នេះ អាចសំដៅទៅលើសុវត្ថិភាពខាងសាច់ឈាមផង និង ខាងវិញ្ញាណផង ) ។ បន្ទាប់មក សូមសរសេរចម្លើយចំពោះសំណួរដូចតទៅនេះ ៖ តើនៅពេលណាខ្លះ ដែលសេចក្ដីសន្យាដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១៨–២១ ត្រូវបានបំពេញនៅក្នុងជីវិតរបស់អ្នក ឬ ជីវិតរបស់មនុស្សដែលអ្នកស្គាល់ ?

សូមពិចារណាអំពីការដាក់គោលដៅ ដើម្បីរស់នៅតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃឲ្យបានកាន់តែប្រសើរ ។

## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩:១៨–២១

៦. សូមចម្លងចំណងជើង និង ខគម្ពីរយោងដែលមានរាយនៅខាងក្រោមនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

| សុខភាព | ប្រាជ្ញា | កម្លាំង | ការការពារ ។ |
|---|---|---|---|
| គ. និង ស. ៨៩:១៨ | គ. និង ស. ៨៩:១៩ | គ. និង ស. ៨៩:២០ | គ. និង ស. ៨៩:២១ |

សូមជ្រើសរើសខគម្ពីរមួយចំណោមខគម្ពីរទាំងនេះ ហើយព្យាយាមទន្ទេញវាបីប្អូននាទី ។ រង់ចាំមើលថាតើ អ្នកអាចសូត្រខគម្ពីរនេះឲ្យសមាជិកគ្រួសារ ឬ មិត្តភក្តិម្នាក់ស្ដាប់ដែរឬទេ ។ ដើម្បីទន្ទេញវគ្គបទគម្ពីរទាំងមូលឲ្យចាំ អ្នកអាចនឹងចង់ជ្រើសរើសខគម្ពីរដទៃទៀត ហើយកំណត់ពេលវេលាមួយដើម្បីព្យាយាមទន្ទេញខគម្ពីរទាំងនោះនៅថ្ងៃក្រោយ ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៩ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២០ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០–៩២

## សេចក្ដីផ្ដើម

នៅថ្ងៃទី ៨ ខែ មិនា ឆ្នាំ ១៨៣៣ ព្រះអម្ចាស់បានប្រទានវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០ ដែលមានចែងអំពីសេចក្ដីណែនាំទៅដល់គណៈប្រធានបព្វជិតភាពជាន់ខ្ពស់ ។ « វិវរណៈនេះគឺជាជំហានបន្តទៅទៀតអំពីការតាំងគណៈប្រធានទីមួយឡើង » ( គ. និង ស. ៩០ សេចក្ដីណែនាំអំពីកណ្ឌ ) ។ នៅថ្ងៃបន្ទាប់ ព្យាការី យ៉ូសែប ស្ម៊ីធ បានទូលសួរថាតើលោកគួរតែបកប្រែព្រះគម្ពីរអ័ប៉ូគ្រីផា ទុកជាផ្នែកនៃកំណែដ៏បំផុសគំនិតលើព្រះគម្ពីរប៊ីបដែរឬទេ ។ ព្រះអម្ចាស់បានមានបន្ទូលតបទៅនឹងការទូលសួររបស់លោក តាមរយៈវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩១ ហើយបានមានព្រះបន្ទូលប្រាប់ យ៉ូសែប ថាលោកមិនចាំបាច់បកប្រែព្រះគម្ពីរនោះទេ ។ ទើបតែពីរបីថ្ងៃក្រោយមក នៅថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៨៣៣ ព្យាការីបានទទួលវិវរណៈមួយ ( គ. និង ស. ៩២ ) ដែលបានបង្គាប់ឲ្យ ហ្វ្រេឌើរិក ជី វិលលាម្ស ដែលជាទីប្រឹក្សាមួយរូបរបស់ព្យាការី ទទួលយកករណីយកិច្ចរបស់លោកនៅក្នុងសហគ្រាសសាមគ្គីភាព ដែលត្រូវបានស្ថាបនាឡើង ដើម្បីគ្រប់គ្រងលើសុខុមាលភាព និងកិច្ចការជំនួញរបស់សាសនាចក្រ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:១–១៨

*ព្រះអម្ចាស់ត្រាស់ណែនាំដល់គណៈប្រធានបព្វជិតភាពជាន់ខ្ពស់ អំពីការទទួលខុសត្រូវរបស់ពួកលោក*

**តើអំណោយដ៏មានតម្លៃបំផុត ដែលអ្នកធ្លាប់ទទួលបាន គឺជាអ្វី ? ហេតុអ្វីបានជាវាមានតម្លៃ ?**

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:១–៣ ដោយស្វែងរកការណ៍ដ៏មានតម្លៃ ដែលព្យាការី យ៉ូសែប ស្ម៊ីធ បានទទួល ។ ស្របតាមខគម្ពីរទាំងនេះ តើអ្វីដែលព្យាការីកាន់ ?

ឃ្លា « កូនសោទាំងឡាយនៃនគរ » សំដៅទៅលើសិទ្ធិរបស់គណៈប្រធាន ឬ សិទ្ធិអំណាចដែលព្រះប្រទានឲ្យមនុស្សដើម្បីធ្វើអធិបតី គ្រប់គ្រង និង ដឹកនាំនគរទ្រង់នៅលើផែនដី ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:៤–៥ ដោយស្វែងរកការព្រមាន ដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធ ។ វាក្យសព្ទដែលបានប្រើនៅក្នុងខគម្ពីរនេះគឺ *ព្រះបន្ទូលទាំងឡាយ* សំដៅទៅលើវិវរណៈទាំងឡាយ ដែលបានមកពីព្រះតាមរយៈពួកព្យាការីរបស់ទ្រង់ ។



អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចតទៅនេះ នៅលើគែមព្រះគម្ពីររបស់អ្នកក្បែរ ខទី ៥ ៖ **បើយើងរាប់វិវរណៈទាំងឡាយដែលព្រះប្រទានឲ្យតាមរយៈពួកព្យាការីទ្រង់ទុកជាការឥតការ នោះយើងនឹងជំពប់ ហើយដួល ។**

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ការរាប់វិវរណៈទាំងឡាយដែលព្រះប្រទានឲ្យ តាមរយៈពួកព្យាការីរបស់ទ្រង់ « ជាការឥតការ » មានន័យដូចម្ដេច ( គ. និង ស. ៩០:៥ ) ?

ខ. តើគំរូមួយចំនួននៃវិវរណៈ ដែលមនុស្សអាចនឹងត្រូវបានល្បួងឲ្យរាប់ជាការឥតការមានអ្វីខ្លះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:៦ ដោយស្វែងរកថាតើនរណាទៀត ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ថា នឹងកាន់កូនសោទាំងឡាយនៃនគរ ។ អ្នកអាចនឹងចង់គូសចំណាំពាក្យ ឬ ឃ្លានៅក្នុងខគម្ពីរនេះ ដែលបង្រៀនសេចក្ដីពិតថា **គណៈប្រធានទីមួយ កាន់កូនសោទាំងឡាយនៃនគរ ។** ( សមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ក៏បានទទួលកូនសោទាំងឡាយនៃនគរដែរ នៅពេលកូរ៉ុមនោះត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៨៣៥ ។ ការប្រើប្រាស់កូនសោទាំងនេះ ស្ថិតនៅក្រោមការដឹកនាំរបស់ប្រធាននៃសាសនាចក្រ ) ។

នៅថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៨៣៣ គឺ ១០ ថ្ងៃបន្ទាប់ពីវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០ ត្រូវបានប្រទានឲ្យនោះ យ៉ូសែប ស្ម៊ីធ បានញែក ស៊ីឌនី រិកដុន និង ហ្វ្រេឌើរិក ជី វិលលាម្ស ចេញជាទីប្រឹក្សានៅក្នុងគណៈប្រធានបព្វជិតភាពជាន់ខ្ពស់ ដែលក្រោយមកបានស្គាល់ជាគណៈប្រធានទីមួយនៃសាសនាចក្រ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:៧–១០ មានសេចក្ដីណែនាំទៅដល់គណៈប្រធានទីមួយ ដើម្បីរៀបចំខ្លួនសមាជិកក្នុងសាលារបស់ពួកព្យាការី ឲ្យប្រកាសដំណឹងល្អពាសពេញពិភពលោក ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:១១ ហើយពិចារណាអំពីរបៀបដែលខគម្ពីរនេះ កំពុងតែត្រូវបានសម្រេចនាពេលសព្វថ្ងៃនេះ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:១២–១៨ ពិពណ៌នាអំពីការទទួលខុសត្រូវមួយចំនួនរបស់គណៈប្រធានទីមួយ ដែលរួមបញ្ចូលទាំងការរៀបចំកិច្ចការទាំងឡាយនៃសាសនាចក្រ ឲ្យមានរបៀបរៀបរយ ។ ដោយសារតែគណៈប្រធានទីមួយកាន់កូនសោទាំងឡាយនៃនគរ អ្នកនឹងមានពរនៅពេលអ្នកធ្វើតាមការបង្រៀនរបស់ពួកលោក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:១៩–៣៧

*ព្រះអម្ចាស់ណែនាំដល់ពួកបរិសុទ្ធនៅទីក្រុង ស៊ីយ៉ូន*

តើអ្នកធ្វើដូចម្ដេច នៅពេលស្ថានភាពក្នុងជីវិតរបស់អ្នក ធ្លាក់ដុនដាប ?

នៅពេលព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០ លោក និង ថ្នាក់ដឹកនាំឯទៀតនៃសាសនាចក្រ បានធ្លាក់ក្នុងស្ថានភាពដុនដាប ដោយសារតែកង្វះធនធានហិរញ្ញវត្ថុក្នុងសាសនាចក្រ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:១៩–៣៧ មានសេចក្ដីណែនាំពីព្រះអម្ចាស់ទៅដល់ ថ្នាក់ដឹកនាំសាសនាចក្រជំនាន់ដំបូង ស្ដីពីរបៀបទ្រាំទ្រនឹងស្ថានភាពដុនដាបដែលពួកលោកបានជួបប្រទះនោះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:២៤ រួចស្វែងរកឱវាទ ដែលអាចលួងលោមចិត្តដល់មនុស្ស ដែលអាចនឹងឆ្លងកាត់ស្ថានភាពដុនដាបមួយ ។

សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ដោយផ្ដោតទៅលើសេចក្ដីសន្យារបស់ព្រះអម្ចាស់ នៅក្នុង ខទី ២៤ ៖ **បើយើងនឹង ដោយព្យាយាម ជានិច្ច មាន ហើយនឹកចាំពី នោះគ្រប់ការណ៍ទាំងអស់នឹងផ្សំគ្នា សម្រាប់សេចក្ដីល្អដល់យើង ។**

ស្វែងរកដោយព្យាយាម គឺលើសជាងការអានព្រះគម្ពីរទៅទៀត ។ ប្រធាន ហារ៉ូល ប៊ី លី បានមានប្រសាសន៍ ៖ « ការព្យាយាមមានន័យថា ឧស្សាហ៍ ដែលផ្ទុយទៅនឹងខ្ជិលច្រអូស ឬ ធ្វេសប្រហែស ឬ មិនអើពើ ។ យើងអាចនិយាយបានម្យ៉ាងទៀតថា ពួកគេត្រូវច្បាស់ជាស្វែងរក ដើម្បីស្គាល់គោលលទ្ធិទាំងឡាយនៃសាសនាចក្រ » ( *Stand Ye in Holy Places: Selected Sermons and Writings of President Harold B. Lee* [ ឆ្នាំ ១៩៧៤ ] ទំព័រ ១៩៨ ) ។

តើអ្នកគិតថា « គ្រប់ការណ៍ទាំងអស់នឹងផ្សំគ្នា សម្រាប់សេចក្ដីល្អដល់អ្នក » ( គ. និង ស. ៩០:២៤ ) មានន័យដូចម្ដេច ?

ការណ៍នេះពុំមានន័យថា គ្មានរឿងអាក្រក់កើតឡើងចំពោះយើងនោះទេ ? ផ្ទុយទៅវិញ វាមានន័យថា ព្រះនឹងពង្រឹងយើងនៅអំឡុងពេលគ្រាដ៏ដុនដាប បើយើងមានចិត្តស្មោះត្រង់នោះ ហើយឧបសគ្គទាំងឡាយរបស់យើង អាចនាំមកឲ្យយើងនូវបទពិសោធន៍ និង ពរជ័យដ៏ចាំបាច់ៗ ។

២. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីបទពិសោធន៍មួយដែលអ្នកធ្លាប់មាន ឬ បានឃើញនៅក្នុងជីវិតនៃមនុស្សណាម្នាក់ទៀត ដែលបង្ហាញអំពីភាពពេញលេញនៃគោលការណ៍នេះ ។

សមាជិកសាសនាចក្រម្នាក់ ដែលបានបង្ហាញភាពស្មោះត្រង់ដ៏អស្ចារ្យ នៅអំឡុងគ្រាដុនដាបនោះគឺ វីអែនណា ចាកស៍ ។ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០:២៨–៣១ រួចស្វែងរកសេចក្ដីណែនាំ ដែលព្រះអម្ចាស់បានប្រទានដល់គាត់ ។ សូមសិក្សាព័ត៌មានខាងក្រោមនេះអំពីបងស្រី ចាកស៍ ដោយស្វែងរកថាតើគាត់មានចិត្តស្មោះត្រង់យ៉ាងណា ចំពោះសេចក្ដីណែនាំរបស់ព្រះអម្ចាស់ ។ នៅពេលអ្នកសិក្សាអំពីព័ត៌មាននេះ អ្នកអាចនឹងចង់គូសបន្ទាត់នៅពីក្រោមស្ថានភាពដុនដាបមួយចំនួនដែល វីអែនណា បានជួបប្រទះ ( សូមស្វែងរកឲ្យបានយ៉ាងហោចណាស់បី ) ។


វីអែនណា ចាកស៍

វីអែនណា ចាកស៍ គឺជាគំរូនៃមនុស្សមានចិត្តស្មោះត្រង់មួយរូប ក្នុងចំណោមពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើននៅជំនាន់ដំបូង ។ គាត់បានកើតនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៧៨៧ ។ បន្ទាប់ពីគាត់បានជួបជាមួយពួកអ្នកផ្សព្វផ្សាយសាសនានៅទីក្រុង បូស្តុន រដ្ឋ ម៉ាស្សាឈូសេត ស.រ.អា គាត់បានធ្វើដំណើរទៅកាន់ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ក្នុងឆ្នាំ ១៨៣១ ។ គាត់ស្នាក់នៅទីនោះប្រាំមួយសប្ដាហ៍ ហើយបានទទួលពិធីបុណ្យជ្រមុជទឹក ។ បន្ទាប់ពីបានត្រឡប់ទៅកាន់ទីក្រុង បូស្តុន វិញ វីអែនណា បាននាំសមាជិកគ្រួសាររបស់គាត់បីបួននាក់ ឲ្យចូលសាសនាចក្រដែរ ។ ក្រោយមក គាត់ « បានទូទាត់ទ្រព្យសម្បត្តិទាំងឡាយរបស់គាត់ ហើយបានត្រឡប់ទៅកាន់ទីក្រុង ខឺតឡង់ វិញ ដើម្បីចំណាយពេលវេលានៃជីវិតគាត់នៅក្នុងសាសនាចក្រជារៀងរហូត » ( « Home Affairs » *Woman's Exponent* ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ១៨៧៨ ទំព័រ ២១ ) ។ ក្នុងឆ្នាំ ១៨៣៣ វីអែនណា បានថ្វាយទ្រព្យសម្បត្តិទាំងអស់របស់គាត់ រួមទាំងប្រាក់ចំនួន ១,៤០០ ដុល្លារ ទៅដល់សាសនាចក្រ ក្នុងគ្រាដែលសាសនាចក្រត្រូវការប្រាក់ជាចាំបាច់ ។ រួចគាត់បានធ្វើដំណើរទៅកាន់រដ្ឋ មិសសួរី ដើម្បីទទួលកេរមរតករបស់គាត់នៅទីក្រុង ស៊ីយ៉ូន ។ ទោះជាយ៉ាងណាក៏ដោយ មិនយូប៉ុន្មានបន្ទាប់ពីគាត់ទៅដល់ទីនោះ គាត់បានរងទុក្ខសេចក្ដីបៀតបៀនជាមួយពួកបរិសុទ្ធ ។ បន្ទាប់ពីគាត់ត្រូវបានបណ្ដេញចេញពីផ្ទះនៅរដ្ឋ មិសសួរី គាត់បានចូលរួមមើលថែអ្នកជំងឺនៅក្នុងជំរុំ ស៊ីយ៉ូន ។ ហ៊ីប៊ើរ ស៊ី ឃិមប៊ល បានសរសេរថា « ខ្ញុំបានទទួលសណ្ដាណចិត្តដ៏ល្អបំផុត . . . ពីបងស្រី វីអែនណា ចាកស៍ ដែលបានបម្រើដល់សេចក្ដីត្រូវការរបស់ខ្ញុំ និង ដល់បងប្អូនប្រុសរបស់ខ្ញុំដែរ—សូមឲ្យព្រះអម្ចាស់ប្រទានរង្វាន់ដល់ [ គាត់ ] ចំពោះសណ្ដានចិត្ត [ របស់គាត់ ] ( « Extracts from H. C. Kimball's Journal » *Times and Seasons* ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៨៤៥ ទំព័រ ៨៣៩–៤០ ) ។

កាលកំពុងនៅរដ្ឋ មិសសួរី វីអែនណា ចាកស៍ បានរៀបអាពាហ៍ពិពាហ៍ជាមួយ ដានីយ៉ែល ស៊ៀរើ ។ ក្នុងឆ្នាំ ១៨៤៧ នៅអាយុ ៦០ ឆ្នាំ គាត់បានធ្វើដំណើរទៅភាគខាងលិចទៅកាន់រដ្ឋ យូថាហ៍ ដោយបររទេះរបស់គាត់កាត់តាមទីវាល ។ គាត់បានតាំងលំនៅនៅទីក្រុង សលត៍ លេក ហើយពេញមួយជីវិតរបស់គាត់ បានធ្វើការយ៉ាងសស្រាក់សស្រាំ ដើម្បីផ្គត់ផ្គង់ខ្លួនឯង និង សិក្សាព្រះគម្ពីរដោយព្យាយាម ។ បងស្រី ចាកស៍ បានទទួលមរណភាពនៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ១៨៨៤ នៅជន្មាយុ ៩៦ ឆ្នាំ ។ នៅក្នុងដំណឹងមរណភាពរបស់គាត់ បានប្រកាសថា « គាត់បានស្មោះត្រង់ទៅនឹងសេចក្ដីសញ្ញារបស់គាត់ ហើយបានឲ្យតម្លៃដល់ការស្ដារឡើងវិញនៃដំណឹងល្អថាជា រតនសម្បត្តិដែលមិនអាចកាត់ថ្លៃបាន » ( « In Memoriam » *Woman's Exponent* ថ្ងៃទី ១ ខែ មិនា ឆ្នាំ ១៨៨៤ ទំព័រ ១៥២ សូមមើលផងដែរ Susan Easton Black « Happiness in Womanhood » *Ensign* ខែ មិនា ឆ្នាំ ២០០២ ទំព័រ ១២, ១៤ ) ។

៣. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្វីដែលអ្នកបានរៀនអំពីទុក្ខលំបាក និង ភាពស្មោះត្រង់ ចេញពីគំរូរបស់ វីអែនណា ចាកស៍ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩១

*ព្រះអង្គសង្គ្រោះណែនាំ យ៉ូសែប ស្ម៊ីធ មិនឲ្យបកប្រែព្រះគម្ពីរអ័ប៉ូគ្រីផា*

តើអ្នកអាចដឹង ថាតើរឿងដែលអ្នកអាននៅលើទំព័រអ៊ិនធើរណែត ឬ កាសែត ឬ ទស្សនាវដ្ដីនោះពិត ឬ មិនពិតយ៉ាងដូចម្ដេច ? វិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩១ បានណែនាំ ព្យាការី យ៉ូសែប ស្ម៊ីធ អំពីរបៀបដឹង ថាតើរឿងដែលគាត់បានអាននោះពិត ឬ មិនពិត ។ សូមអានសេចក្ដីណែនាំអំពីកណ្ឌ ដោយស្វែងរកអ្វីដែល យ៉ូសែប ស្ម៊ីធ កំពុងតែធ្វើនៅគ្រាដែលលោកបានទទួលវិវរណៈនេះ ។

ព្រះគម្ពីរអ័ប៉ូគ្រីផា គឺជាការប្រមូលផ្ដុំនៃគម្ពីរពិសិដ្ឋៗរបស់ប្រជាជនសាសន៍យូដា ។ គម្ពីរទាំងនេះ មិនបានរួមបញ្ចូលនៅក្នុងព្រះគម្ពីរបរិសុទ្ធហេព្រើរដើមឡើយ ប៉ុន្តែត្រូវបានរួមបញ្ចូលនៅក្នុងការបកប្រែនៃព្រះគម្ពីរបរិសុទ្ធជាភាសាក្រិកនៅជំនាន់ព្រះគ្រីស្ទ ។ គម្ពីរមួយចំនួនមាននូវហេតុការណ៍កើតឡើងចន្លោះ ព្រះគម្ពីរសញ្ញាចាស់ និង ព្រះគម្ពីរសញ្ញាថ្មី ។ នៅពេលពួកគ្រីស្ដបរិស័ទជំនាន់បុរាណ បានចងក្រងគម្ពីរទាំងឡាយនៃព្រះគម្ពីរប៊ីបនៅច្រើនសតវត្សក្រោយមក ពួកគេបានដាក់បញ្ចូលគម្ពីរទាំងឡាយនៃព្រះគម្ពីរអ័ប៉ូគ្រីផា ប៉ុន្តែ មានចម្ងល់ជាច្រើន អំពីថាតើគម្ពីរទាំងនោះគឺជាផ្នែកនៃព្រះគម្ពីរដែរឬទេ ។ ព្រះគម្ពីរបរិសុទ្ធដែល យ៉ូសែប ស្ម៊ីធ បានប្រើដើម្បីបង្កើតការបកប្រែដ៏បំផុសគំនិតរបស់លោកនោះមាននូវគម្ពីរអ័ប៉ូគ្រីផាផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែសុពលភាពនៃគម្ពីរអ័ប៉ូគ្រីផាស្ថិតនៅក្នុងភាពសង្ស័យ នោះ យ៉ូសែប បានទូលសួរព្រះអម្ចាស់ ថាបើការបកប្រែរបស់លោកអំពីព្រះគម្ពីរប៊ីប គួររួមបញ្ចូលគម្ពីរទាំងនេះឬទេ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩១:១–៣ ដោយស្វែងរកអ្វីដែលព្យាការី យ៉ូសែប ស្ម៊ីធ បានរៀនអំពីគម្ពីរអ័ប៉ូគ្រីផា ។ *ពាក្យបញ្ចុះបញ្ចូល* គឺជាសេចក្ដីបន្ថែមទៅលើសំណៅ ដែលជួនកាលកែប្រែអត្ថន័យ ហើយបំប្លែងអត្ថបទដើម ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩១:៤–៦ រួចស្វែងរករបៀបដែលអ្នកសិក្សាគម្ពីរអ័ប៉ូគ្រីផា អាចស្គាល់អ្វីដែលជាការពិតនៅក្នុងគម្ពីរនេះ ។

យើងអាចរៀនចេញពីសេចក្ដីពិតដូចតទៅនេះ ៖ **ព្រះវិញ្ញាណបរិសុទ្ធអាចជួយយើងឲ្យស្គាល់បាន បើសិនជាការណ៍ដែលយើងអាននោះជាការពិត ។**

ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ក្នុងគណៈប្រធានទីមួយ បានបង្រៀន ៖



« គ្មានទេនៅក្នុងប្រវត្តិសាស្ត្រនៃពិភពលោកនេះ ដែលយើងងាយនឹងទទួលបានព័ត៌មានកាន់តែច្រើន—ព្រោះព័ត៌មានខ្លះពិត ខ្លះទៀតមិនពិត ហើយភាគច្រើននោះពិតខ្លះៗ ។

« ហេតុដូច្នេះហើយ គ្មានប្រវត្តិសាស្ត្រនៃពិភពលោកណា សំខាន់ជាងការរៀនឲ្យបានត្រឹមត្រូវ អំពីរបៀបដឹងរវាងសេចក្ដីពិត និង ការណ៍ក្លែងក្លាយឡើយ ។. . .

« ព្រះវិញ្ញាណបរិសុទ្ធ គឺជាអ្នកផ្ដល់វិវរណៈ ។ ទ្រង់ជាអង្គដ៏ជំនួយ ដែលបង្រៀនយើងអំពី ‹ សេចក្ដីពិតនៃគ្រប់ការណ៍ទាំងអស់ › ។. . .

« *សាក្សី* នៃសេចក្ដីពិតបានមកពីព្រះវិញ្ញាណបរិសុទ្ធ មានសម្រាប់មនុស្សទាំងអស់ គ្រប់ទីកន្លែង ពាសពេញពិភពលោក ។ មនុស្សទាំងអស់ដែលព្យាយាមស្គាល់សេចក្ដីពិត ដែលសិក្សាវានៅក្នុងគំនិត ហើយ ‹ សួរដោយចិត្តស្មោះស គឺដោយស្មោះអស់ពីចិត្ត ដោយមានសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ [ នឹងស្គាល់ ] សេចក្ដីពិត . . . ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ › ។ [ មរ៉ូណៃ ១០:៤ ] » ។ (« What Is Truth ? » [Church Educational System devotional address, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៣ ], ទំព័រ ៣, ៦; speeches.byu.edu) ។

៤. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីបទពិសោធន៍មួយ នៅពេលអ្នកបានទទួលអារម្មណ៍ព្រះវិញ្ញាណបរិសុទ្ធបញ្ជាក់ថា រឿងដែលអ្នកអាននោះជាការពិត ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩២

*ហ្វ្រេឌើរិក ជី វិលលាម្ស ត្រូវទទួលចូលទៅក្នុងសហគ្រាសសាមគ្គីភាព*

វិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩២ បានណែនាំដល់ថ្នាក់ដឹកនាំសាសនាចក្រ ដែលមានចំណែកក្នុងសហគ្រាសសាមគ្គីភាព ( ត្រូវបានហៅផងដែរ ជាសណ្ដាប់ធ្នាប់រួម ) ត្រូវទទួល ហ្វ្រេឌើរិក ជី វិលលាម្ស ចូលទៅក្នុងសហគ្រាសនោះ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩២:១–២ រួចស្វែងរករបៀប ដែលព្រះអម្ចាស់បានមានព្រះទ័យឲ្យបងប្រុស វិលលាម្ស ប្រព្រឹត្តក្នុងនាមជាសមាជិកម្នាក់នៅក្នុងសហគ្រាសសាមគ្គីភាព ។

៥. « សមាជិកសកម្មម្នាក់ » ក្នុងក្រុមមួយ គឺជាម្នាក់ដែលធ្វើសកម្មភាព ហើយប្ដេជ្ញាចិត្ត ។ សូមជ្រើសរើសស្ថានភាពខាងក្រោមនេះចំនួនពីរ ឬ ច្រើនជាងនោះ ហើយសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្វីដែល « សមាជិកសកម្មម្នាក់ » នៃសាសនាចក្រអាចធ្វើ នៅក្នុងស្ថានភាពទាំងនោះ ។

ក. យុវជនម្នាក់ត្រូវបានចាត់តាំង ឲ្យធ្វើជាគ្រូបង្រៀនតាមផ្ទះ ។

ខ. យុវនារីម្នាក់ត្រូវបានហៅបម្រើជា ប្រធានថ្នាក់យុវនារី ឬ ថ្នាក់ក្លូរ៉ុមបព្វជិតភាព ។

គ. យុវវ័យម្នាក់គឺជាសិស្ស នៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យ ។

ឃ. យុវវ័យម្នាក់គឺជាអ្នកជិតខាងរបស់គូស្វាមីភរិយាចំណាស់មួយគូ ។

សូមពិចារណាអំពីអ្វីដែលអ្នកអាចធ្វើ ដើម្បីធ្វើជាសមាជិកសកម្មម្នាក់ក្នុងសាសនាចក្រនាពេលសព្វថ្ងៃនេះ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩២:២ ព្រះអម្ចាស់បានបង្រៀន ហ្វ្រេឌើរិក ជី វិលលាម្ស អំពីអ្វីដែលលោកត្រូវធ្វើដើម្បី « បានពរជារៀងដរាបតទៅ » ។ អ្នកអាចនឹងចង់គូសចំណាំសេចក្ដីណែនាំនេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩០–៩២ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២០ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣

## បុព្វកថា

នៅថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ១៨៣៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣ ។ ព្រះយេស៊ូវគ្រីស្ទ បានពន្យល់អំពីគោលបំណងនៃផ្នែកទីមួយនៃវិវរណៈនេះ ( គ. និង ស. ៩៣:១–២០ ) ៖ « យើងប្រទានដល់អ្នកនូវពាក្យទាំងនេះ ដើម្បីឲ្យអ្នកអាចយល់ ហើយចេះថ្វាយបង្គំ ហើយស្គាល់នូវអ្វីដែលខ្លួនថ្វាយបង្គំ ប្រយោជន៍ឲ្យអ្នកអាចចូលមកឯព្រះវរបិតាដោយនូវព្រះនាមរបស់យើង ហើយនៅវេលាកំណត់ ឲ្យបានទទួលនូវភាពពោរពេញរបស់ទ្រង់ » ( គ. និង ស. ៩៣:១៩ ) ។ ខគម្ពីរទាំងនេះនឹងគ្របដណ្ដប់ដោយសេចក្ដីលំអិតកាន់តែច្បាស់ នៅពេលអ្នកជួបជាមួយគ្រូ រៀនមេរៀនប្រចាំសប្ដាហ៍ ។ មេរៀននេះផ្ដោតសំខាន់ជាចម្បងទៅលើ អ្វីដែលព្រះអម្ចាស់បានបើកសម្ដែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២១–៥៣ ។ ខគម្ពីរទាំងនេះរួមមានសេចក្ដីណែនាំពីព្រះអម្ចាស់ ស្ដីពីការស្វែងរកសេចក្ដីពិត និង ពន្លឺ និង តម្រូវការឲ្យ « មានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋាន » ( គ. និង ស. ៩៣:៥០ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១–២០

*ព្រះអម្ចាស់បើកសម្ដែងអំពីរបៀប ដែលយើងអាចប្រែក្លាយទៅដូចជាទ្រង់ និង ព្រះវរបិតាសួគ៌របស់យើង*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១–២០ យើងរៀនអំពី ព្រះយេស៊ូវគ្រីស្ទ ទំនាក់ទំនងរបស់ទ្រង់ជាមួយព្រះវរបិតាសួគ៌ និង អំពីរបៀបដែលយើងអាចទទួលបាន « ភាពពោរពេញនៃសិរីល្អរបស់ព្រះវរបិតា » ( គ. និង ស. ៩៣:១៦ ) ដូចដែលទ្រង់មាន ។

សាវក យ៉ូហាន គឺជាសិស្សរបស់យ៉ូហាន បាទីស្ទ នៅពេលព្រះយេស៊ូវគ្រីស្ទ បានចាប់ផ្ដើមការបម្រើរបស់ទ្រង់ក្នុងជីវិតរមែងស្លាប់ ។ លោកបានផ្ដល់បញ្ជីប្រវត្តិនៃទីបន្ទាល់របស់យ៉ូហាន បាទីស្ទ ដែលបានថ្លែងអំពីព្រះអង្គសង្គ្រោះ នៅក្នុងដំណឹងល្អរបស់ យ៉ូហាន នៃព្រះគម្ពីរសញ្ញាថ្មី ។ ទាក់ទងនឹងការដាក់បញ្ចូលទីបន្ទាល់របស់ យ៉ូហាន បាទីស្ទ នេះ អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ ៖



យ៉ូហាន បាទីស្ទ បានថ្លែងទីបន្ទាល់ដ៏រឹងមាំ អំពីព្រះយេស៊ូវគ្រីស្ទ ។



« យើងរៀនចេញពីវិវរណៈថ្ងៃចុងក្រោយថា រឿងរ៉ាវដែលមាននៅក្នុងផ្នែកដំបូងនៃដំណឹងល្អរបស់ យ៉ូហាន ( ជាសាវក អ្នកទទួលវិវរណៈ និង សិស្សស្ងួនភ្ងា ) ដើមឡើយត្រូវបានចារដោយ យ៉ូហាន បាទីស្ទ ។ តាមរយៈវិវរណៈ ព្រះអម្ចាស់បានស្ដារដល់ យ៉ូសែប ស្ម៊ីធ នូវចំណែកនៃការណ៍ដែល យ៉ូហាន បាទីស្ទ បានចារ ហើយបានសន្យាថានឹងបើកសម្ដែងចំណែកនោះដល់ពិភពលោក នៅពេលមនុស្សលោកមានចិត្តស្មោះត្រង់គ្រប់គ្រាន់នឹងទទួលបានចំណែកនោះ ។ ( គ. និង ស. ៩៣:៦–១៨ ) ។ [ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១៥ ] គឺជាគន្លឹះដើម្បីដឹងអំពីអ្វីដែល យ៉ូហាន បានថ្លែង ។. . .

« . . . ប្រាកដណាស់ថា សិស្សស្ងួនភ្ជា ( យ៉ូហាន ) បានមានបញ្ជីប្រវត្តិរបស់ យ៉ូហាន បាទីស នៅពេលលោកបានសរសេរដំណឹងល្អរបស់លោក ។ ក្រោយមក យ៉ូហាន បានចម្លងផង និង បកស្រាយផង នូវអ្វីដែលព្យាការីពីមុនដែលមានឈ្មោះដូចលោកនោះបានចារទុក ។ ភាពដែលអាចទៅរួចមួយទៀតនោះគឺ ព្រះអម្ចាស់បានបើកសម្ដែងដល់អ្នកចងក្រងដំណឹងល្អអំពីពាក្យពេចន៍ទាំងឡាយ ដែលបានកត់ត្រាដោយសារទូតសួគ៌ាពីមុន ជាអ្នកដែលបានរៀបចំផ្លូវថ្វាយទ្រង់ » ( *Doctrinal New Testament Commentary* វ៉ុល ៣ [ ឆ្នាំ ១៩៦៦–៧៣ ] ១:៧០–៧១ ) ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៦–១៧ ព្រះអម្ចាស់បានប្រទានការចេះដឹង អំពីបញ្ជីប្រវត្តិរបស់ យ៉ូហាន ដើម្បីជួយយើងឲ្យយល់កាន់តែច្បាស់អំពីទ្រង់ ។ យ៉ូហានបានបង្រៀនថា **ព្រះយេស៊ូវគ្រីស្ទបានចម្រើនឡើងពីព្រះគុណថែមលើព្រះគុណរហូតដល់ទ្រង់ទទួលបានភាពពេញលេញនៃសិរីល្អរបស់ព្រះវរបិតា ។**

យើងក៏អាចទទួលបានភាពពេញលេញនៃសិរីល្អរបស់ព្រះវរបិតាបានដែរ នៅពេលយើងធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ។ អ្នកអាចនឹងចង់គូសចំណាំឃ្លា ដែលបង្រៀនអំពីសេចក្ដីពិតនេះ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:១៩–២០ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២១–៣៩

*ព្រះអម្ចាស់ណែនាំពួកអ្នកបម្រើរបស់ទ្រង់ អំពីរបៀបទទួលបានសេចក្ដីពិត និង ពន្លឺ*

តើមានការទទួលខុសត្រូវអ្វីខ្លះ ចំពោះកូនច្បងនៅក្នុងក្រុមគ្រួសារ ?



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២១–២៣ ដោយស្វែងរកអ្វី ដែលព្រះយេស៊ូវគ្រីស្ទ បានបើកសម្ដែងអំពីអង្គទ្រង់ផ្ទាល់ ។

អ្នកអាចនឹងចង់គូសចំណាំពាក្យ ឬ ឃ្លានៅក្នុងខគម្ពីរទាំងនោះ ដែលបង្រៀនអំពីគោលលទ្ធិដូចតទៅនេះ ៖ **ព្រះយេស៊ូវគ្រីស្ទគឺជាកូនច្បងក្នុងចំណោមកូនវិញ្ញាណទាំងអស់ របស់ព្រះវរបិតាសួគ៌ ។**

ដោយសារតែព្រះយេស៊ូវគ្រីស្ទគឺជាកូនវិញ្ញាណច្បងរបស់ព្រះវរបិតា មានន័យថា ទ្រង់គឺជា « អ្នកដែលបានតម្រូវឲ្យគ្រង » ( ហេព្រើរ ១:២ ) គ្រប់អ្វីទាំងអស់ ដែលព្រះវរបិតាមាន ។ ទោះជាយ៉ាងណាក៏ដោយ ទ្រង់មានព្រះទ័យឲ្យកូនចៅរបស់ព្រះវរបិតាសួគ៌ទាំងអស់ មានចំណែកនៅក្នុងកេរមរតកនេះដែរ ។ យើងមានឱកាសធ្វើជា « អ្នកគ្រងមរតកនៃព្រះជាមួយព្រះគ្រីស្ទ » ( រ៉ូម ៨:១៧ ) ហើយត្រូវបានរាប់នៅក្នុងចំណោម « សាសនាចក្រនៃកូនច្បង » ( គ. និង ស. ៩៣:២២ សូមមើលផងដែរ គ. និង ស. ៧៦:៥១–៥៤ ) ។ អែលឌើរ ប្រ៊ូស អរ ម៉ាក់ខន់ឃី បានបង្រៀនថា « សមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយដែលបានថ្វាយខ្លួនគេចំពោះសេចក្ដីសុចរិត ដែលពួកគេបានទទួលពិធីបរិសុទ្ធនៃភាពតម្កើងឡើងកាន់តែខ្ពស់ នោះក្លាយទៅជាសមាជិកនៃ *សាសនាចក្រនៃកូនច្បង* » (*Mormon Doctrine* ការបោះពុម្ពលើកទី ២ [ ឆ្នាំ ១៩៦៦ ] ទំព័រ ១៣៩ ) ។ នៅតាមរបៀបនេះ យើងក៏អាចទទួលគ្រប់អ្វីទាំងអស់ដែលព្រះវរបិតាមានផងដែរ ( សូមមើល គ. និង ស. ៧៦:៥៥; ៨៤:៣៧–៣៨ ) ។

យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២២ យើងត្រូវតែកើតមកដោយសារព្រះយេស៊ូវគ្រីស្ទ ដើម្បីធ្វើជាអ្នកទទួលបានសិរីល្អនៃកូនច្បង ។ ការកើតមកដោយសារព្រះយេស៊ូវគ្រីស្ទ មានន័យថា ការកើតម្ដងទៀតខាងវិញ្ញាណ និង ស្អាតស្អំពីអស់ទាំងអំពើបាប តាមរយៈព្រះចេស្ដានៃដង្វាយធួន ។

១. សូមពន្យល់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលវាមានសារៈសំខាន់ចំពោះអ្នក ដែលត្រូវយល់អំពីតួនាទីរបស់ព្រះយេស៊ូវគ្រីស្ទ ថាជាកូនច្បងរបស់ព្រះវរបិតា ។ អ្នកអាចនឹងចង់កត់ត្រាអារម្មណ៍ ដែលអ្នកមានចំពោះព្រះយេស៊ូវគ្រីស្ទ នៅពេលអ្នកគិតថាតើតួនាទីរបស់ទ្រង់ជាកូនច្បងរបស់ព្រះវរបិតានោះមានន័យដូចម្ដេចចំពោះអ្នក ។

ចូរកត់ចំណាំនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២១ ថា ព្រះយេស៊ូវគ្រីស្ទ បានមានព្រះបន្ទូលថា « កាលដើមដំបូងយើងបានគង់នៅជាមួយព្រះវរបិតា » ។ ស្របតាម ខទី ២៣ តើនរណាទៀតដែល កាលដំបូងបាននៅជាមួយព្រះវរបិតា ?

គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២៣ អាចត្រូវចំពោះកូនវិញ្ញាណទាំងអស់របស់ព្រះវរបិតាសួគ៌ ។ អ្នកអាចដាក់ជំនួសពាក្យ *អ្នករាល់គ្នា* នៅក្នុងខគម្ពីរនេះ ដោយឈ្មោះរបស់អ្នកផ្ទាល់ ។ អ្នកអាចសរសេរឈ្មោះរបស់អ្នក នៅលើគែមព្រះគម្ពីរ ហើយគូសបន្ទាត់មួយចង្អុលទៅកាន់ពាក្យ *អ្នករាល់គ្នា* ។

ខណៈដែលយើងបានរស់នៅជាមួយព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ នៅក្នុងជីវិតមុនឆាកជីវិតនេះ នោះយើងត្រូវបានបង្រៀនដោយទ្រង់ទាំងពីរព្រះអង្គ ហើយបានមានឱកាសទទួលយក ឬ បដិសេធសេចក្ដីពិត ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២៤–២៦ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានបង្រៀន អំពីសេចក្ដីពិតនៅក្នុងខគម្ពីរទាំងនេះ ។

នៅក្នុងចន្លោះដែលមាន សូមសរសេរអំពីអ្វី ដែលអ្នកបានរៀនចេញមកពីនិយមន័យនៃសេចក្ដីពិតរបស់ព្រះអម្ចាស់នៅក្នុងខទី ២៤ ៖

សូមកត់ចំណាំថាតើសាតាំងត្រូវបានពិពណ៌នាយ៉ាងដូចម្ដេច នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២៥ ។ សូមកត់ចំណាំរបៀបដែលវា ខិតខំមានឥទ្ធិពលមកលើយើង ដោយការកុហក និង បន្ទាបចំណេះដឹងខាងសេចក្ដីពិតរបស់យើង ។ ដើម្បីធ្វើការប្រៀបធៀប សូមពិចារណាអំពីអ្វីដែលយើងរៀន អំពីព្រះអង្គសង្គ្រោះនៅក្នុង ខទី ២៦ ។

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៣៦–៣៧ រួចស្វែងរកសេចក្ដីពិតបន្ថែម ដែលព្រះអម្ចាស់បានបើកសម្ដែងអំពីពន្លឺ និង សេចក្ដីពិត ។ អ្នកអាចនឹងចង់គូសចំណាំឃ្លា « សិរីល្អនៃព្រះគឺជាបញ្ញា ឬក៏ម្យ៉ាងទៀត ជាពន្លឺ និង សេចក្ដីពិត » នៅក្នុង ខទី ៣៦ ។ សូមចងចាំថា ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ មានសិរីល្អពេញលេញ ដែលរួមបញ្ចូលទាំងភាពពោរពេញនៃបញ្ញា ឬ ជាពន្លឺ និង សេចក្ដីពិត ។ សូមពិចារណាអំពីរបៀប ដែលយើងទទួលបានប្រយោជន៍ដោយការទទួលបានពន្លឺ និង សេចក្ដីពិតនៅក្នុងជីវិតរបស់យើង ។ ប្រយោជន៍មួយគឺ **តាមរយៈការទទួលបានពន្លឺ និង សេចក្ដីពិត នោះយើងអាចក្លាយដូចជាព្រះយេស៊ូវគ្រីស្ទ និង ព្រះវរបិតាសួគ៌** ។ ( អ្នកអាចនឹងចង់សរសេរគោលការណ៍នេះ នៅលើគែមព្រះគម្ពីររបស់អ្នកក្បែរ ខទី ៣៦ ) ។

២. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលវាមានសារៈសំខាន់ចំពោះអ្នក ដែលត្រូវយល់ថា តាមរយៈការទទួលបានពន្លឺ និង សេចក្ដីពិត នោះយើងអាចក្លាយដូចជាព្រះយេស៊ូវគ្រីស្ទ និង ព្រះវរបិតាសួគ៌បាន ។



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២៧–២៨ ដោយស្វែងរកអ្វី ដែលយើងត្រូវតែធ្វើ ដើម្បីទទួលបានសេចក្ដីពិត និង ពន្លឺ ។ នៅក្នុងរង្វង់ពងក្រពើខាងស្ដាំនៃដ្យាក្រាមដែលមានមកជាមួយនេះ សូមសរសេរគោលការណ៍មួយ ដែលបង្រៀនអំពីរបៀបដែលយើងទទួលបានសេចក្ដីពិត និង ពន្លឺ ។

*ការដាក់ជំនួសឈ្មោះរបស់អ្នកក្នុងខគម្ពីរទាំងឡាយដែលអ្នកសិក្សា*

ការប្រើឈ្មោះរបស់អ្នក ឬ ដាក់ជំនួសដោយពាក្យ *ខ្ញុំ* ឬ *ទូលព្រះបង្គំ* នៅក្នុងកន្លែងសមរម្យក្នុងព្រះគម្ពីរ អាចជួយព្រះគម្ពីរឲ្យកាន់តែមានអត្ថន័យជ្រាលជ្រៅ ហើយជួយអ្នកឃើញថាតើវគ្គបទគម្ពីរមួយចំនួនអាចទាក់ទងនឹងរូបអ្នកយ៉ាងដូចម្ដេចខ្លះ ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិ ជួយយើងឲ្យទទួលបានសេចក្ដីពិត និង ពន្លឺយ៉ាងដូចម្ដេច ?

ខ. តើនៅពេលណា ដែលអ្នកមានអារម្មណ៍ថា បានទទួលសេចក្ដីពិត និង ពន្លឺ ដោយការគោរពព្រះបញ្ញត្តិ ?

នៅពេលយើងបានរស់នៅជាមួយព្រះ ពីមុនពេលយើងកើតមកលើផែនដីនេះ យើងបានមានសិទ្ធិជ្រើសរើស–ដែលជាលទ្ធភាពដើម្បីជ្រើសរើស និង ប្រព្រឹត្តដោយខ្លួនយើង ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២៩–៣២ ដោយស្វែងរកថាតើការប្រើសិទ្ធិជ្រើសរើសរបស់យើង មានឥទ្ធិពលលើលទ្ធភាពរបស់យើង ក្នុងការទទួលបានពន្លឺ និង សេចក្ដីពិតយ៉ាងដូចម្ដេច ។

ស្របតាម ខទី ៣១–៣២ តើមានផលវិបាកអ្វីខ្លះ បើយើងជ្រើសរើសពុំទទួលយកសេចក្ដីពិត និង ពន្លឺនោះ ?

ខគម្ពីរទាំងនេះជួយយើងឲ្យយល់ថា យើងធ្វើឲ្យខ្លួនយើងស្ថិតនៅក្រោមការដាក់ទោស ហើយរារាំងភាពរីកចម្រើនខាងវិញ្ញាណ ដោយបានបដិសេធមិនទទួលយកពន្លឺ ដែលមានសម្រាប់យើង ។



តាមរយៈការទទួលបានពន្លឺ និង សេចក្ដីពិត នោះយើងអាចក្លាយដូចជាព្រះយេស៊ូវគ្រីស្ទ និង ព្រះវរបិតាសួគ៌បាន ។

តើយើងអាចបាត់បង់ពន្លឺ និង សេចក្ដីពិត ដែលយើងបានទទួលរួចហើយដែរឬទេ ? សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៣៩ ដោយស្វែងរកចម្លើយចំពោះសំណួរនេះ ។

នៅក្នុងរង្វង់ពងក្រពើខាងឆ្វេងនៃដ្យាក្រាម សូមសរសេរគោលការណ៍មួយ ដែលថ្លែងអំពីបុព្វហេតុដែលបណ្ដាលឲ្យយើងបាត់បង់ពន្លឺ និង សេចក្ដីពិត ។

៤. សូមរាយបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគំរូមួយចំនួននៃសណ្ដាប់ ឬ សកម្មភាពទូទៅដែលមនុស្សជាច្រើនបានធ្វើ ដែលអាចបណ្ដាលឲ្យយើងបាត់បង់ពន្លឺ និង សេចក្ដីពិត ។ សូមសរសេរបីប្រយោគ ដោយពន្យល់អំពីរបៀបដែលការធ្វើតាមសណ្ដាប់ទាំងនេះ អាចប៉ះពាល់ដល់លទ្ធភាពរបស់យើងក្នុងការទទួលបាន ហើយថែរក្សាពន្លឺ និង សេចក្ដីពិត ដែលបានមកពីព្រះវរបិតាសួគ៌ ។

សកម្មភាពខាងក្រោមនេះ អាចជួយបង្ហាញអំពីរបៀបដែលជម្រើសផ្ទាល់ខ្លួនរបស់យើងក្នុងការគោរព ប្រតិបត្តិ ឬ មិនគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះ ជះឥទ្ធិពលលើលទ្ធភាពរបស់យើង ក្នុងការទទួលបានពន្លឺ និង សេចក្ដីពិត ឬ បាត់បង់វា ។ សូមអានសេចក្ដីអធិប្បាយខាងក្រោមនេះ អំពីរបៀបដែលជម្រើសរបស់ ម៉ារា មានឥទ្ធិពលលើលទ្ធភាពរបស់នាងក្នុងការទទួលបានពន្លឺ និង សេចក្ដីពិត ។ សូមឈប់បន្តិចសិនបន្ទាប់ពីបានអានកថាខណ្ឌនីមួយៗហើយ រួចគិតអំពីមូលហេតុដែលស្ថានភាពរបស់ ម៉ារា បានផ្លាស់ប្ដូរ ។

ម៉ារា អធិស្ឋានរៀងរាល់ព្រឹក និង ល្ងាច ។ នាងមានអារម្មណ៍សេចក្ដីអំណរដែលបានធ្វើការបម្រើ រក្សាសេចក្ដីសញ្ញារបស់នាង និង ស្រាវជ្រាវបទគម្ពីរជារៀងរាល់ថ្ងៃ ។ នាងបានជួយប្រមូលគ្រួសាររបស់នាងមកសិក្សាព្រះគម្ពីរ និង អធិស្ឋានជាគ្រួសារយ៉ាងទៀងទាត់ ។ នាងទន្ទឹងរង់ចាំទទួលទានសាក្រាម៉ង់ ជារៀងរាល់សប្ដាហ៍នៅព្រះវិហារ ។

ជីវិតរបស់ ម៉ារា បានមានសភាពកាន់តែរវល់ជាងមុន ។ ម៉ារា នៅតែអធិស្ឋាន ហើយសិក្សាព្រះគម្ពីរជាញឹកញាប់ ប៉ុន្តែ ពុំបានជារៀងរាល់ថ្ងៃនោះទេ ។ នាងចូលរួមក្នុងព្រះវិហារភាគច្រើនបំផុត ហើយតាមធម្មតា នាងស្ដាប់ដល់អ្នកទាំងឡាយដែលឡើងនិយាយ ឬ បង្រៀន ។ នាងទៅចូលរួមសកម្មភាពយុវនារី បើនាងដឹងថា មិត្តភក្ដិរបស់នាងនឹងទៅទីនោះ ។

ម៉ារា បានចូលរួមក្នុងសកម្មភាពជាមួយមិត្តភក្ដិរបស់នាងកាន់តែច្រើន ជាមិត្តភក្ដិដែលមិនគោរពតាមបទដ្ឋាននៃសាសនាចក្រ ។ ម៉ារា អធិស្ឋានតែនៅពេលដែលនាងមិនមានការអស់កម្លាំង ឬ មិនមានការប្រញាប់ ប្រញាល់ប៉ុណ្ណោះ ។ នាងជួយធុរៈការងារផ្ទះទាំងមិនពេញចិត្ត ហើយអានព្រះគម្ពីរជាមួយក្រុមគ្រួសារ តែនៅពេលដែលនាងចង់ប៉ុណ្ណោះ ។ ជាធម្មតា នាងគេចវេសពីការចូលរួមព្រះវិហារ និង សកម្មភាពយុវនារី ។ ជូនកាល នាងល្មើសនឹងពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ។

ម៉ារា ចំណាយពេលភាគច្រើនរបស់នាង ជាមួយមិត្តភក្ដិច្រើនជាងជាមួយក្រុមគ្រួសារ ។ ម៉ារា ពុំដែលអធិស្ឋាន អានព្រះគម្ពីរ ឬ ចូលរួមក្នុងការប្រជុំសាសនាចក្រទេ ។ ប៊ីស្សព បានសុំជួបនាង ប៉ុន្តែនាងនឹងពុំនិយាយជាមួយប៊ីស្សពទេ ។ នាងល្មើសនឹងពាក្យសម្ដីនៃប្រាជ្ញាវាងវៃជាញឹកញាប់ ។ នាងតែងឈ្លោះប្រកែកជាមួយសមាជិកគ្រួសារ ។ នាងមានអារម្មណ៍ឃ្លាតឆ្ងាយពីព្រះវរបិតាសួគ៌ ។

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីសារៈសំខាន់នៃការសម្រេចចិត្ត ដែលអ្នកធ្វើជារៀងរាល់ថ្ងៃ និង អំពីរបៀបដែលការសម្រេចចិត្តទាំងនោះ មានឥទ្ធិពលទៅលើពន្លឺ និង សេចក្ដីពិត ដែលអ្នកទទួលបាន និង ថែរក្សា ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៤០–៥៣

*ព្រះអម្ចាស់ប្រទានឱវាទដល់ពួកអ្នកបម្រើទ្រង់ ឲ្យតាំងគេហដ្ឋានឲ្យមានរបៀបរៀបរយ*



សូមពិចារណាអំពីរបៀប ដែលការប្រាស្រ័យទាក់ទងរបស់អ្នកជាមួយនឹងឪពុកម្ដាយអ្នក ឬ ជាមួយសមាជិកគ្រួសារដទៃទៀត ជួយអ្នកឲ្យរីកចម្រើននៅក្នុងពន្លឺ និង សេចក្ដីពិត ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៤០ រួចស្វែងរកការទទួលខុសត្រូវ ដែលព្រះបានប្រទានដល់ឪពុកម្ដាយទាំងឡាយ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៤១–៤៨ ព្រះអម្ចាស់បានណែនាំ ហ្វ្រេឌើរិក ជី វិលលាម្ស, ស៊ីឌនី រិកដុន និង យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ធ្វើឲ្យបានកាន់តែល្អប្រសើរ ក្នុងការបង្រៀនដល់កូនចៅខ្លួន អំពីពន្លឺ និង សេចក្ដីពិត និង តាមរបៀបដែលពួកគាត់ អាចរៀបចំគ្រួសារឡើងឲ្យមានរបៀបរៀបរយ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:៤៩–៥០ ដោយស្វែងរកការព្រមានពីព្រះអម្ចាស់ ដែលអនុវត្តដល់ក្រុមគ្រួសារទាំងអស់ ។ នៅពេលអ្នកសិក្សាខគម្ពីរទាំងនេះ អ្នកអាចនឹងចង់គូសចំណាំពាក្យ ឬ ឃ្លា ដែលបង្រៀនអំពីគោលការណ៍ដូចតទៅនេះ ៖ **យើងត្រូវតែអធិស្ឋានជានិច្ច ហើយមានចិត្តព្យាយាម និង គិតគូរអំពីគេហដ្ឋាន ក្រែងលោរាកំណាចនឹងមានអំណាចមកលើយើង ។**

ទោះជាការព្រមាននេះត្រូវបានប្រទានដល់ឪពុកក្ដី ក៏វាអនុវត្តចំពោះក្រុមគ្រួសារទាំងមូលរបស់ឪពុកនោះដែរ ។ អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់អំពីរបៀបដែលយើងអាច « មានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង » ៖

### « យោបល់ទីមួយ ៖ សម្ដែងសេចក្ដីស្រឡាញ់—ហើយបង្ហាញវា

« យើងអាចចាប់ផ្ដើមមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង ដោយប្រាប់ដល់មនុស្សដែលយើងស្រឡាញ់ថា យើងស្រឡាញ់ពួកគេ ។ អារម្មណ៍បែបនេះ ពុំត្រូវការឲ្យមានការស្ទាត់ជំនាញ ឬ ពេលវេលាច្រើនឡើយ ។ យើងគួរតែសម្ដែងសេចក្ដីស្រឡាញ់យ៉ាងសាមញ្ញដោយចិត្តស្មោះ និង ជាញឹកញាប់ ។. . .

« . . . កូនៗ តើពេលលើកមុនដែលអ្នកបានប្រាប់ដល់ឪពុកម្ដាយរបស់អ្នកថា អ្នកស្រឡាញ់ពួកគាត់នោះ គឺនៅពេលណា ?. . .

« យើងគួរតែចងចាំថា ការនិយាយថា ‹ ខ្ញុំស្រឡាញ់អ្នក › គឺគ្រាន់តែជាការចាប់ផ្ដើមប៉ុណ្ណោះ ។ យើងត្រូវតែនិយាយ យើងត្រូវតែមានចេតនាធ្វើវា ហើយដែលសំខាន់បំផុតនោះ យើងត្រូវតែបង្ហាញវាជានិច្ច ។ យើងត្រូវសម្ដែងសេចក្ដីស្រឡាញ់ផង បង្ហាញសេចក្ដីស្រឡាញ់ផង ។. . .

### « យោបល់ទីពីរ ៖ ថ្លែងទីបន្ទាល់—ហើយរស់នៅតាមទីបន្ទាល់នោះ ។

« យើងក៏អាចមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង ដោយការថ្លែងទីបន្ទាល់ទៅកាន់មនុស្សដែលយើងស្រឡាញ់អំពីការណ៍ដែលយើងដឹងថាជាការពិត តាមរយៈសាក្សីនៃព្រះវិញ្ញាណបរិសុទ្ធ ។ ការថ្លែងទីបន្ទាល់ពុំត្រូវការឲ្យមាន ពេលវេលាច្រើន ឬ ការស្ទាត់ជំនាញឡើយ ។. . .

« . . . កូនៗ តើពេលលើកមុនដែលអ្នកបានចែកចាយទីបន្ទាល់ដល់ឪពុកម្ដាយ និង ក្រុមគ្រួសាររបស់អ្នកនោះ គឺនៅពេលណា ?. . .

« យើងគួរតែចងចាំថា ការថ្លែងទីបន្ទាល់អស់ពីដួងចិត្ត គឺគ្រាន់តែជាការចាប់ផ្ដើមប៉ុណ្ណោះ ។ យើងត្រូវតែថ្លែងទីបន្ទាល់ យើងត្រូវតែមានចេតនាធ្វើវា ហើយដែលសំខាន់បំផុតនោះ យើងត្រូវតែរស់នៅតាមទីបន្ទាល់នោះជានិច្ច ។ យើងត្រូវប្រកាសអំពីទីបន្ទាល់ផង និង រស់នៅតាមទីបន្ទាល់ផង ។. . .

### « យោបល់ទីបី ៖ ប្រកាន់ភាពខ្ជាប់ខ្ជួន

« រាល់ការអធិស្ឋានជាគ្រួសារ រាល់ពេលសិក្សាព្រះគម្ពីរជាគ្រួសារ និង រាល់រាត្រីជួបជុំក្រុមគ្រួសារ គឺជាស្នាមដានគំនូសនៅលើក្រណាត់គំនូរនៃព្រលឹងយើង ។ គ្មានព្រឹត្តការណ៍ណាមួយអាចលេចឡើងជា ព្រឹត្តិការណ៍ដ៏អស្ចារ្យ ឬ គួរឲ្យចងចាំនោះទេ ។ ប៉ុន្តែ . . . ភាពខ្ជាប់ខ្ជួនរបស់យើង ក្នុងការធ្វើកិច្ចការតូចៗដោយច្បាស់លាស់ អាចដឹកនាំទៅរកលទ្ធផលខាងវិញ្ញាណដ៏អស្ចារ្យ » ។. . . ភាពខ្ជាប់ខ្ជួនគឺជាគោលការណ៍គ្រឹះ នៅពេលយើងដាក់គ្រឹះនៃកិច្ចការដ៏អស្ចារ្យក្នុងជីវិតបុគ្គលទាំងឡាយ និង នៅពេលយើងមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង » ( « More Diligent and Concerned at Home » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ១៧–២០ ) ។

៦. តើអ្នកគិតថា « ការមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង » ( គ. និង ស. ៩៣:៥០ ) មានន័យដូចម្ដេច ? សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីការណ៍មួយដែលអ្នកនឹងធ្វើដើម្បីមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២០ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤–៩៦

## បុព្វកថា

ព្រះអម្ចាស់បានប្រទានវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤ នៅថ្ងៃទី ២ ខែ សីហា ឆ្នាំ ១៨៣៣ ហើយបានដឹកនាំពួកបរិសុទ្ធឲ្យស្ថាបនាទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ឲ្យស្រដៀងគ្នាទៅនឹងទីក្រុង ស៊ីយ៉ូន នៅរដ្ឋ មិសសួរី ដែរ ។ ព្រះអម្ចាស់ក៏បានត្រាស់បង្គាប់ពួកបរិសុទ្ធ ឲ្យសាងសង់គេហដ្ឋានមួយឡើង ( អគាររដ្ឋបាលសាសនាចក្រ ) សម្រាប់គណៈប្រធានទីមួយ និង ជាកន្លែងសម្រាប់បោះពុម្ព ដែលជាកិច្ចការបន្ថែមពីលើព្រះវិហារបរិសុទ្ធ ដែលទ្រង់បានបង្គាប់ដល់ពួកបរិសុទ្ធឲ្យសាងសង់កាលពីលើកមុន ។ កាលពីពីរខែមុន នៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៨៣៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥ ដែលព្រះអម្ចាស់បានវាយផ្ចាលពួកបរិសុទ្ធ ចំពោះការពន្យារពេលការសាងសង់ព្រះវិហារបរិសុទ្ធ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៦ មានការណែនាំរបស់ព្រះអម្ចាស់ ឲ្យចាត់តាំង នូវល ខេ វិគនី ឲ្យ « កាន់កាប់ » ( គ. និង ស. ៩៦:២ ) អចលនទ្រព្យ ដែលព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ នឹងត្រូវបានសាងសង់លើ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤

*ព្រះអម្ចាស់ត្រាស់បង្គាប់ឲ្យពួកបរិសុទ្ធ សាងសង់គេហដ្ឋានពីរឡើង ហើយបញ្ជាក់បន្ថែមអំពីសេចក្ដីត្រូវការក្នុងការសាងសង់ព្រះវិហារបរិសុទ្ធ ។*



សូមស្រមៃថា អ្នកមានឱកាសធ្វើដំណើរឆ្លងកាត់ប្រទេសមួយ ដែលបានទៅដល់ទីក្រុងជាច្រើន ។ នៅពេលអ្នកធ្វើដំណើរ អ្នកបានកត់សម្គាល់ថា មានកីឡាដ្ឋានមួយ ស្ថិតនៅចំកណ្ដាលទីក្រុងនីមួយៗ ។ តើការណ៍នេះអាចប្រាប់យ៉ាងដូចម្ដេច អំពីមនុស្សនៅក្នុងប្រទេសនេះ ?

បើអ្នកគូរប្លង់ទីក្រុងដ៏ធំមួយ តើអ្នកនឹងដាក់អ្វីនៅចំកណ្ដាលទីក្រុង ? ហេតុអ្វី ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤:១–២ ដោយស្វែងរកថាតើព្រះអម្ចាស់ បានណែនាំឲ្យគូរប្លង់ទីក្រុងនៃស្តេកស៊ីយ៉ូនឡើងនៅក្នុងទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ យ៉ាងដូចម្ដេច ។

តើការណ៍នេះថ្លែងយ៉ាងដូចម្ដេច អំពីសារៈសំខាន់នៃព្រះវិហារបរិសុទ្ធចំពោះព្រះអម្ចាស់ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤:៣, ១០ រួចស្វែងរកអគារចំនួនពីរទៀត ដែលព្រះអម្ចាស់បានត្រាស់បង្គាប់ ឲ្យពួកបរិសុទ្ធសាងសង់នៅទីក្រុង ខឺតឡង់ ។

ព្រះបញ្ញត្តិដែលបង្គាប់ឲ្យសាងសង់អគារទាំងពីរនេះឡើង បង្ហាញអំពីសារៈសំខាន់ ដែលព្រះអម្ចាស់បានដាក់នៅក្នុង ពិធីបរិសុទ្ធទាំងឡាយក្នុងព្រះវិហារបរិសុទ្ធ កិច្ចការនៃគណៈប្រធានទីមួយក្នុងការទទួលបានវិវរណៈ និង ការបម្រើក្នុងសាសនាចក្រ និង ការបោះពុម្ពព្រះគម្ពីរ ព្រមទាំងកិច្ចការដទៃៗទៀត ដែលព្រះអម្ចាស់ត្រាស់បង្គាប់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤:៦–៨, ១២ ដោយស្វែងរកឃ្លា ដែលទាក់ទងទៅនឹងភាពពិសិដ្ឋនៃអគារទាំងនេះ ។

ព្រះអម្ចាស់បានណែនាំដល់ ហៃរុម ស្ម៊ីធ, រេយណុល្ឌ ខាហ៊ូន និង យ៉ារេឌ ខារតើរ ឲ្យបង្កើតគណៈកម្មាធិការសាងសង់ សម្រាប់ការសាងសង់អគារដែលបានលើកឡើងនៅក្នុងវិវរណៈនេះ ( សូមមើល គ. និង ស. ៩៤:១៣–១៧ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤:១៦ ដោយស្វែងរកការណ៍ ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ដល់ពួកបរិសុទ្ធ អំពីការសាងសង់អគារទាំងឡាយ សម្រាប់គណៈប្រធានទីមួយ និង សម្រាប់ការបោះពុម្ព ។

សូមពិចារណាអំពីមូលហេតុ ដែលវាមានសារៈសំខាន់ ដែលព្រះវិហារបរិសុទ្ធត្រូវតែបានសាងសង់ឡើង ឲ្យបានមុនអគារពីរផ្សេងទៀត ? តើការណ៍នេះអាចបង្រៀនយើង អំពីសារៈសំខាន់នៃព្រះវិហារបរិសុទ្ធដូចម្ដេចខ្លះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥

*ព្រះអម្ចាស់បានវាយផ្ចាលពួកបរិសុទ្ធ ចំពោះការផ្អាកការសាងសង់ព្រះវិហារបរិសុទ្ធ*

ដំបូង ព្រះអម្ចាស់ចេញព្រះបញ្ញត្តិឲ្យសាងសង់ព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៩ ដែលមានកត់ត្រានៅថ្ងៃទី ២៧–២៨ ខែ ធ្នូ ឆ្នាំ ១៨៣២ ។

សូមសិក្សាសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥ ដោយស្វែងរកកាលបរិច្ឆេទ ដែលវិវរណៈនេះត្រូវបានប្រទានឲ្យ ។ តើមានរយៈពេលប្រហែលប៉ុន្មាន នៅចន្លោះកាលបរិច្ឆេទទាំងពីរនេះ ?

អំឡុងគ្រានេះ ថ្នាក់ដឹកនាំសាសនាចក្រ បានទិញអចលនទ្រព្យនៅទីក្រុង ខឺតឡង់ ដែលត្រូវសាងសង់ព្រះវិហារបរិសុទ្ធ ។ ទោះជាយ៉ាងណាក៏ដោយ នៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៨៣៣ ពួកបរិសុទ្ធពុំបានចាប់ផ្ដើមសាងសង់ព្រះវិហារបរិសុទ្ធ ហើយក៏ពុំបានរៀបចំចាក់គ្រឹះដែរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥:១–៣ រួចស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ពួកបរិសុទ្ធ អំពីការពន្យារពេលរបស់ពួកគេនៅក្នុងការសាងសង់ព្រះវិហារបរិសុទ្ធ ។

សូមយោងទៅកាន់ ខទី ១ ដើម្បីបញ្ចប់សេចក្ដីថ្លែងការណ៍ដូចតទៅនេះ ៖ **ព្រះវាយផ្ចាល** ។



ការវាយផ្ចាលមានន័យថា ការណែនាំ ឬ ការកែតម្រូវ ។ នៅក្នុង ខទី ១ អ្នកអាចនឹងចង់គូសចំណាំមូលហេតុ ដែលព្រះវាយផ្ចាលមនុស្សដែលទ្រង់មានព្រះទ័យស្រឡាញ់ ។

សូមពិចារណាថាតើអ្នកមានប្រតិកម្មយ៉ាងដូចម្ដេច នៅពេលអ្នកត្រូវបានវាយផ្ចាល ឬ កែតម្រូវ ។ នៅពេលអ្នកអានសេចក្ដីអត្ថាធិប្បាយខាងក្រោមនេះ សូមស្វែងរករបៀបដែលពួកបងប្អូនប្រុសមួយចំនួន បានឆ្លើយតបទៅនឹងការវាយផ្ចាលរបស់ព្រះអម្ចាស់ ៖

បន្ទាប់ពី យ៉ូសែប ស៊្មីធ បានទទួលវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥ ថ្នាក់ដឹកនាំសាសនាចក្របានធ្វើសន្និសីទមួយ ដើម្បីពិភាក្សាអំពីការសាងសង់ព្រះវិហារបរិសុទ្ធ ។ « ពួកបងប្អូនប្រុសមួយចំនួន ចង់សាងសាង់ពីឈើសង់ផ្ទះ ហើយពួកបងប្អូនប្រុសឯទៀត ចង់សាងសង់ជាលក្ខណៈដាក់ឈើហ៊ុប ។ យ៉ូសែប បានរំឭកពួកគាត់ថា ពួកគាត់ពុំមែនសាងសង់ដំណាក់មួយឡើងសម្រាប់មនុស្សនោះទេ ប៉ុន្តែគឺសម្រាប់ព្រះ លោកបានមានប្រសាសន៍ថា ‹ បងប្អូនប្រុសទាំងឡាយអើយ តើយើងនឹងសាងសង់ដំណាក់សម្រាប់ព្រះរបស់យើងពីឈើហ៊ុបឬ ? ទេ ខ្ញុំមានផែនការល្អប្រសើរជាងនោះ ។ ខ្ញុំមានគម្រោងសាងសង់ដំណាក់របស់ព្រះអម្ចាស់ ដែលបានប្រទានមកពីទ្រង់ផ្ទាល់ ហើយឆាប់ៗនេះ បងប្អូននឹងឃើញ អំពីភាពខុសគ្នារវាង ការយល់ឃើញរបស់យើង និង អ្វីដែលទ្រង់ព្រះតម្រិះ › » ( លូស៊ី ម៉ាក ស៊្មីធ *History of Joseph Smith by His Mother* ed. Preston Nibley [ ឆ្នាំ ១៩៥៨ ] ទំព័រ ២៣០ ) ។ បន្ទាប់ពី យ៉ូសែប បានពន្យល់អំពី គំរូពេញលេញនៃព្រះវិហារបរិសុទ្ធ នោះពួកបងប្អូនប្រុសទាំងអស់មានចិត្តរំភើបរីករាយ ។ ពួកគាត់បានធ្វើដំណើរទៅកាន់ទីតាំងសាងសង់ ដករបង ហើយបានចាក់ដីបំពេញក្នុងស្រែ ដែលបានដាំដុះដោយគ្រួសារ ស៊្មីធ កាលពីមុន ។ បន្ទាប់ពីស្រូវត្រូវបានដកចេញហើយ ហៃរុម ស៊្មីធ « បានចាប់ផ្ដើមជីករណ្ដៅដាំបង្គោលគ្រឹះ ដែលគាត់បានប្រកាសថា គាត់នឹងចាប់ផ្ដើមសាងសង់គេហដ្ឋានទីមួយមុនគេ » ( លូស៊ី ម៉ាក ស៊្មីធ *History of Joseph Smith* ទំព័រ ២៣១ ) ។



១. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្វីដែលអ្នកអាចរៀនពីពួកបងប្អូនប្រុសទាំងនេះ ស្ដីពីរបៀបឆ្លើយតបទៅនឹងការកែតម្រូវ ឬ ការណែនាំ ។ បន្ថែមពីលើនោះ សូមសរសេរអំពីគ្រាមួយដែលអ្នកត្រូវបានវាយផ្ចាល ហើយបានឆ្លើយតបទៅវិញ ដើម្បីស្វែងរកភាពរីកចម្រើន ។

សូមកត់ចំណាំថា ព្រះអម្ចាស់បានមានព្រះបន្ទូល ហៅការពន្យារពេលរបស់ពួកបរិសុទ្ធក្នុងការសាង់សង់ព្រះវិហារបរិសុទ្ធថាជា « អំពើបាបដ៏ធ្ងន់ណាស់ » ( គ. និង ស. ៩៥:៣ ) ។ តើអ្នកគិតថា ហេតុអ្វីបានជាព្រះអម្ចាស់បានចាត់ទុកការពន្យារពេលក្នុងការសាងសង់ព្រះវិហារបរិសុទ្ធ ជាអំពើបាបដ៏ធ្ងន់ណាស់ ? សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥:៦ ដើម្បីឃើញថាតើព្រះអម្ចាស់បានប្រៀបធៀបអំពើបាបដ៏ធ្ងន់ណាស់នេះ ទៅនឹងអ្វី ។

សូមពិចារណាថាតើ ការមិនអើពើនឹងព្រះបញ្ញត្តិរបស់ព្រះអម្ចាស់—ជាពិសេសក្នុងការសាងសង់ព្រះវិហារបរិសុទ្ធ—អាចមានសភាពដូចជា ការដើរនៅក្នុងសេចក្ដីងងឹតនៅពេលថ្ងៃត្រង់ យ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥:៤, ៨–៩ រួចស្វែងរកមូលហេតុ ដែលព្រះអម្ចាស់បានត្រាស់បង្គាប់ ឲ្យពួកបរិសុទ្ធសាងសង់ព្រះវិហារបរិសុទ្ធនៅទីក្រុង ខឺតឡង់ ។ ( ឃ្លា « ប្រយោជន៍ឲ្យយើងអាចសម្រេចកិច្ចការប្លែក ៗរបស់យើងបាន » [ គ. និង ស. ៩៥:៤ ] សំដៅទៅលើកិច្ចការរបស់ព្រះអម្ចាស់នៅថ្ងៃចុងក្រោយ របៀបដែលមនុស្សពុំជឿទៅលើវិវរណៈ ការយាងមកជួបពីស្ថានសួគ៌ និង កិច្ចការខាងវិញ្ញាណដទៃ ៗទៀត ដែលអាចមើលឃើញថា ការស្ដារឡើងវិញនៃដំណឹងល្អគឺជារឿងចម្លែក ) ។

យើងរៀនចេញពីខគម្ពីរទាំងនេះថា **នៅក្នុងព្រះវិហារបរិសុទ្ធ ព្រះអម្ចាស់រៀបចំពួកអ្នកបម្រើទ្រង់ ឲ្យធ្វើកិច្ចការរបស់ទ្រង់ ហើយប្រទានអំណោយទានឲ្យពួកគាត់ដោយព្រះចេស្ដា ។**

ពាក្យ *ប្រទានអំណោយទាន* មានន័យថា ផ្ដល់ឲ្យនរណាម្នាក់នូវអំណោយមួយ ។ ការទទួលអំណោយទានពិសិដ្ឋនៅក្នុងព្រះវិហារបរិសុទ្ធ មានន័យថាទទួលបានអំណាច និង ចំណេះដឹងខាងវិញ្ញាណ ។ នៅក្នុងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ព្រះអម្ចាស់បានស្ដារកូនសោទាំងឡាយនៃបព្វជិតភាពឡើងវិញ ដែលចាំបាច់ដើម្បីធ្វើពិធីបរិសុទ្ធនៃការសង្គ្រោះ ដែលសព្វថ្ងៃនេះ យើងអាចទទួលបានតែនៅក្នុងព្រះវិហារបរិសុទ្ធប៉ុណ្ណោះ ៖ ការទទួលអំណោយទានពិសិដ្ឋនៅក្នុងព្រះវិហារបរិសុទ្ធ និង ពិធីផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ( សូមមើល គ. និង ស. ១១០ ) ។



ប្រធាន ថូម៉ាស អេស ម៉នសុន បានថ្លែងអំពីសារៈសំខាន់នៃការទទួលបានពរជ័យនៃព្រះវិហារបរិសុទ្ធទាំងនេះ ៖ « លុះត្រាតែអ្នកបានចូលក្នុងដំណាក់នៃព្រះអម្ចាស់ ហើយបានទទួលគ្រប់ពរជ័យ ដែលរង់ចាំអ្នកនៅទីនោះ បើមិនដូច្នោះទេ អ្នកមិនបានទទួលអ្វីៗទាំងអស់ ដែលសាសនាចក្របានផ្ដល់ឲ្យឡើយ ។ ពរជ័យសំខាន់ និងអស្ចារ្យបំផុតទាំងអស់ នៃសមាជិកភាពនៅក្នុងសាសនាចក្រ គឺជាពរជ័យទាំងឡាយណាដែលយើងបានទទួលនៅក្នុងដំណាក់នៃព្រះ » ( The Holy Temple—a Beacon to the World » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៩៣ ) ។

២. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរឿងមួយចំនួន ដែលអ្នកអាចធ្វើនាពេលឥឡូវនេះ ដើម្បីត្រៀមខ្លួនទទួលពិធីបរិសុទ្ធទាំងឡាយ និង ពរជ័យនៅក្នុងព្រះវិហារបរិសុទ្ធ ។

ការសាងសង់ព្រះវិហារបរិសុទ្ធ គឺជាកិច្ចការដ៏ធំមួយសម្រាប់ពួកបរិសុទ្ធ ។ នៅដើមឆ្នាំ ១៨៣៣ មានសមាជិកសាសនាចក្រតិចជាង ២០០ នាក់រស់នៅរដ្ឋ អូហៃអូ ហើយភាគច្រើនមានជីវភាពក្រីក្រ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥:១១–១២ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បានសន្យា ប្រសិនបើពួកបរិសុទ្ធគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

ពួកបរិសុទ្ធនៅរដ្ឋ អូហៃអូ បានបន្តដោយមានសេចក្ដីជំនឿទៅលើការសន្យារបស់ព្រះអម្ចាស់ ហើយបានសាងសង់ព្រះវិហារបរិសុទ្ធ ។ ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥:១១ យើងរៀនថា **ប្រសិនបើយើងរក្សាបទបញ្ញត្តិទាំងឡាយ នោះយើងនឹងមានអំណាចដើម្បីធ្វើអ្វីៗដែលព្រះអម្ចាស់បានសុំឲ្យយើងធ្វើ ។** អ្នកអាចសរសេរគោលការណ៍នេះ នៅគែមលើព្រះគម្ពីររបស់អ្នក ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើស្ថានភាពមួយចំនួន ដែលអ្នកអាចនឹងប្រឈមមុខ ជាស្ថានភាពដែលគោលការណ៍នេះអាចអនុវត្តនោះមានអ្វីខ្លះ ?

ខ. តើនៅពេលណាខ្លះ ដែលអ្នកបានមានអារម្មណ៍ថា បានទទួលជំនួយពីព្រះអម្ចាស់ ឲ្យធ្វើអ្វីមួយ ដោយសារតែអ្នកបានរក្សាព្រះបញ្ញត្តិទ្រង់ ?

សូមកត់ចំណាំថាឃ្លា « សេចក្ដីស្រឡាញ់នៃព្រះវរបិតា នឹងមិននៅជាមួយអ្នកឡើយ » នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥:១២ ។ នៅពេលយើងខកខានមិនគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយនៃដំណឹងល្អ នោះយើងបាត់បង់ពរជ័យមានដូចជាពន្លឺ និង ចំណេះដឹង ដែលជាផ្លែផ្កានៃសេចក្ដីស្រឡាញ់របស់ព្រះវរបិតា មានចំពោះមនុស្សទាំងឡាយ ដែលបង្ហាញសេចក្ដីស្រឡាញ់របស់ខ្លួនដោយការគោរពប្រតិបត្តិ ។



នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៥:១៣–១៧ យើងអានថា ព្រះអម្ចាស់បានប្រទានការណែនាំដល់ពួកបងប្អូនប្រុស អំពីទំហំ និង មុខងារនៃបន្ទប់ជាក់លាក់ៗនៃព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។ សូមអាន ខទី ១៤ ដោយស្វែងរកវិធីមួយដែលព្រះអម្ចាស់បានបង្ហាញប្រាប់ ថាទ្រង់នឹងបំពេញសេចក្ដីសន្យារបស់ទ្រង់ ដែលនឹងប្រទានដល់រាស្ត្រទ្រង់នូវអំណាចដើម្បីសាងសង់ព្រះវិហារបរិសុទ្ធ ។

បុរសទាំងបីរូប ដែលព្រះអម្ចាស់បានសន្យាថានឹងបង្ហាញអំពីរបៀបសាងសង់ព្រះវិហារបរិសុទ្ធ គឺជាគណៈប្រធានទីមួយ ។ ព័ត៌មានខាងក្រោមនេះ នឹងជួយអ្នកឲ្យឃើញអំពីរបៀប ដែលការសន្យានេះត្រូវបានបំពេញ ៖

យ៉ូសែប ស៊្មីធ, ស៊ីឌនី រិកដុន និង ហ្វ្រេឌើរិក ជី វិលលាម្ស បានអធិស្ឋានរួមគ្នា ហើយបានឃើញព្រះវិហារបរិសុទ្ធនៅក្នុងការនិមិត្ត ។ បន្ទាប់ពីបានឃើញផ្នែកខាងក្នុងយ៉ាងលម្អិត « អគារនោះហាក់ដូចជាប្រាកដខ្លួនយ៉ាងជាក់ស្ដែងដល់ [ ពួកគាត់ ] » ហើយពួកគាត់បានមើលឃើញផ្នែកខាងក្នុងនៃអគារនោះ ដូចជាពួកគាត់បានស្ថិតនៅខាងក្នុងអគារនោះដែរ ( សូមមើល *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស៊្មីធ* [ឆ្នាំ ២០០៧ ] ទំព័រ ២៧១) ។ ក្រោយមក នៅពេលព្រះវិហារបរិសុទ្ធបានសាងសង់ជិតរួចរាល់ហើយនោះ ហ្វ្រេឌើរិក ជី វិលលាម្ស បានវាចាឡើងថា វាមានរូបរាងដូចជាគំរូ ដែលគាត់បានមើលឃើញនៅក្នុងការនិមិត្ត សូម្បីតែផ្នែកតូចបំផុត ដែលគាត់ពុំអាចប្រាប់ពីភាពខុសគ្នាបានឡើយ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៦

*នូវែល ខេ វិតនី ត្រូវបានចាត់តាំងឲ្យកាន់កាប់អចលនទ្រព្យនៃព្រះវិហារបរិសុទ្ធរបស់សាសនាចក្រ*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៦ យើងអានថា ព្រះអម្ចាស់បានណែនាំឲ្យប៊ីស្សព នូវែល ខេ វិតនី កាន់កាប់អចលនទ្រព្យដែលព្រះវិហារបរិសុទ្ធនឹងត្រូវបានសាងសង់នៅលើនោះ ។ ព្រះអម្ចាស់ក៏បានត្រាស់បង្គាប់ប៊ីស្សព វិតនី បែងចែកអចលនទ្រព្យជាឡូដ៍ៗ សម្រាប់អ្នកដែលមកទទួលកេរមរតក ។ ដីឡូដ៍មួយចំនួន ត្រូវបានកំណត់ឲ្យថ្នាក់ដឹកនាំសាសនាចក្រមើលខុសត្រូវសម្រាប់ការបោះពុម្ពវិវរណៈនានា ។ ការទទួលបានកេរមរតកនេះ នឹងជួយពួកគាត់លះបង់ពេលវេលារបស់ខ្លួន ដើម្បីធ្វើកិច្ចការរបស់ព្រះអម្ចាស់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៦:៤–៥ ដោយស្វែងរកថាតើ ការបោះពុម្ពព្រះបន្ទូលរបស់ព្រះ ជួយដល់ពួកបរិសុទ្ធយ៉ាងដូចម្ដេច ។

នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់ក៏បានណែនាំដែរថា យ៉ូហាន ចនសុន នឹងត្រូវបានទទួលយកជាសមាជិកនៃសហគ្រាសសាមគ្គីភាព ដែលមើលខុសត្រូវលើហិរញ្ញវត្ថុរបស់សាសនាចក្រ ការបោះពុម្ព និង ប្រតិបត្តិការអាជីវកម្មទាំងឡាយ ។



៤. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៤–៩៦ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧

## បុព្វកថា

ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧ នៅថ្ងៃទី ២ ខែ សីហា ឆ្នាំ ១៨៣៣ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានប្រទានការណែនាំ និង ការលើក ទឹកចិត្តដល់ ប៉ាលី ភី ប្រាត្ត ដែលធ្វើជាអធិបតីលើសាលាសម្រាប់បងប្អូនប្រុសក្នុងបព្វជិតភាពនៅរដ្ឋ មិសសួរី និង សម្រាប់ពួកបងប្អូនប្រុស ដែលបានចូលរួមនៅក្នុងសាលានោះ ។ ព្រះអម្ចាស់ក៏បានគូសបញ្ជាក់អំពីព្រះឆន្ទៈរបស់ទ្រង់ ដែលមានព្រះទ័យឲ្យ ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី សាងសង់ព្រះវិហារបរិសុទ្ធ ។ ទ្រង់បានសន្យាថា បើពួកគេបានធ្វើដូច្នោះ ហើយបើដួងចិត្តរបស់ពួកគេបរិសុទ្ធ នោះសិរីល្អ និង វត្តមានរបស់ទ្រង់នឹងគង់សណ្ឋិតនៅទីនោះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:១–៩

*ព្រះអម្ចាស់បង្រៀនសមាជិកអំពី សាលានៃពួកអែលឌើរ នៅរដ្ឋ មិសសួរី អំពីអ្វីដែលពួកគាត់ត្រូវតែធ្វើដើម្បីទទួលយកទ្រង់*

បើអ្នកត្រូវបង្រៀនមិត្តភក្តិម្នាក់ អំពីរបៀបធ្វើជាសិស្សល្អ នោះតើឥរិយាបថ និង អាកប្បកិរិយាបែបណាខ្លះ ដែលអ្នកនឹងលើកទឹកចិត្តមិត្តភក្តិអ្នកឲ្យបង្កើន ?



សាលាសម្រាប់ពួកអែលឌើរ

នារដូវរងាក្នុងឆ្នាំ ១៨៣២–៣៣ ព្រះអម្ចាស់បានណែនាំថ្នាក់ដឹកនាំសាសនាចក្រ ឲ្យបង្កើតសាលានៃពួកព្យាការី នៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ។ នៅក្រោមការដឹកនាំរបស់ព្យាការី យ៉ូសែប ស្ម៊ីធ, ប៉ាលី ភី ប្រាត្ត ពួកលោកទាំងពីរបានដឹកនាំសាលាមួយដែលស្រដៀងនេះ នៅទីក្រុង អ៊ីនឌីប៉ែនដែនស៍ រដ្ឋ មិសសួរី ។ សាលានេះត្រូវបានហៅថា សាលានៃពួកអែលឌើរ ។ សមាជិកក្នុងសាលានៃពួកអែលឌើរនេះ បានសរសេរសំបុត្រជាច្រើនច្បាប់ទៅកាន់ យ៉ូសែប ស្ម៊ីធ ដែលនៅរដ្ឋ អូហៃអូ ។ ដើម្បីឆ្លើយតបទៅវិញ លោកបានផ្ញើសំបុត្រមួយច្បាប់ដែលមានវិវរណៈ ដែលសព្វថ្ងៃនេះត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:១ រួចស្វែងរកថាតើព្រះអម្ចាស់បានមានព្រះបន្ទូលពិពណ៌នាយ៉ាងដូចម្ដេចខ្លះ អំពីពួកបងប្អូនប្រុសជាច្រើននៅរដ្ឋ មិសសួរី ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:២ រួចស្វែងរកអ្វី ដែលព្រះអម្ចាស់បានសន្យាដល់បុរសទាំងនេះ ប្រសិនបើពួកគាត់បន្តមានចិត្តស្មោះត្រង់នោះ ។

ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:១–២ យើងរៀនថា **បើយើងបន្ទាបខ្លួន ហើយព្យាយាមស្វែងរក ដើម្បីរៀន នោះយើងនឹងទទួលបានប្រាជ្ញា និង សេចក្ដីពិត ។** អ្នកអាចនឹងចង់គូសចំណាំគោលការណ៍នេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីបានជាមានសារៈសំខាន់ចំពោះអ្នក ដែលត្រូវទទួលបានប្រាជ្ញា និង សេចក្ដីពិត ?

ខ. តើអ្នកគិតថា ការបន្ទាបខ្លួន និង ភាពឧស្សាហ៍ព្យាយាម នឹងជួយអ្នកទទួលបានប្រាជ្ញា និង សេចក្ដីពិតយ៉ាងដូចម្ដេច ?



### *អនុវត្តអ្វីដែលអ្នករៀន*

ប្រធាន ម៉ារ៉ុន ជី រ៉មនី ក្នុងគណៈប្រធានទីមួយ បានបង្រៀន ៖ « ការរៀនដំណឹងល្អចេញពីព្រះបន្ទូលដែលបានចារទុកនោះ . . . គឺមិនគ្រប់គ្រាន់ឡើយ ។ យើងត្រូវតែរស់នៅតាមនោះផងដែរ ។. . . មនុស្សម្នាក់ពុំអាចរៀនដំណឹងល្អបានពេញលេញដោយមិនរស់នៅតាមដំណឹងល្អនោះទេ » (Records of Great Worth » *Ensign* ខែ កញ្ញា ឆ្នាំ ១៩៨០ ទំព័រ ៤ ) ។ ក្នុងផ្នែកមួយចំនួនក្នុងមេរៀននេះ អ្នកនឹងត្រូវបានលើកទឹកចិត្ត ឲ្យអនុវត្តអ្វីដែលអ្នកបានរៀន ។ ការអនុវត្តន៍គួរតែជាផ្នែកមួយនៃការសិក្សាដំណឹងល្អរបស់អ្នក ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:៣–៥ ដើម្បីដឹងថាតើព្រះអម្ចាស់មានព្រះទ័យយ៉ាងដូចម្ដេច អំពីការបម្រើរបស់ ប៉ាលី ភី ប្រាត្ត និង អ្វីដែលព្រះអម្ចាស់បានសន្យានឹងបងប្រុស ប្រាត្ត ។

ដូចជា ប៉ាលី ភី ប្រាត្ត ដែរ ពួកគេអាចដឹងថា ព្រះអម្ចាស់សព្វព្រះទ័យនឹងអ្នក នៅពេលអ្នកបន្ដដើរតាមទ្រង់ ។

២. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:៧, ៩ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមគូររូបដើមឈើទាំងឡាយ ដែលមានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ ។ ( បើអ្នកពុំចង់គូរទេនោះ អ្នកអាចសរសេរកថាខណ្ឌចំនួនពីរ ដែលពិពណ៌នាអំពីដើមឈើទាំងនេះ ) ។

ដើមឈើទាំងពីរប្រភេទនោះ តំណាងឲ្យសមាជិកសាសនាចក្រ ចំណែកឯផ្លែនោះឯង គឺជាកិច្ចការ និង ទង្វើរបស់សមាជិក ។ សូមចងចាំថា ពួកបរិសុទ្ធជាច្រើននៅរដ្ឋ មិសសួរី បានបន្ទាបខ្លួន ហើយមានចិត្តស្មោះត្រង់ ។ ទោះជាយ៉ាងណាក៏ដោយ ពួកបរិសុទ្ធខ្លះទៀត បែរជាមានភាពឆ្មើងឆ្មៃ ហើយមិនគោរពប្រតិបត្តិ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:៦–៧ រួចពិចារណាលើសារលិខិតនានា ដែលអ្នករកឃើញនៅក្នុងខគម្ពីរទាំងនេះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:៨–៩ រួចពិចារណាលើសារលិខិតនានា ដែលអ្នករកឃើញនៅក្នុងខគម្ពីរទាំងនេះ ។

៣. តើព្រះអម្ចាស់បានសន្យាដល់ពួកបងប្អូនប្រុសទាំងនេះយ៉ាងដូចម្ដេច បើពួកគាត់បន្ដដើរតាមទ្រង់ ? នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរប្រយោគចំនួនពីរ ឬ បី ដោយពន្យល់ថាតើសេចក្ដីអត្ថាធិប្បាយអំពីដើមឈើ និង បរិយាកាសនៅជុំវិញវាក្នុង ខទី ៩ អាចលើកទឹកចិត្តអ្នកឲ្យមានចិត្តកាន់តែស្មោះត្រង់យ៉ាងដូចម្ដេច ។

យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:៨ តើលក្ខណៈសម្បត្តិមួយចំនួននៃបុគ្គល ដែលទទួលយកព្រះអម្ចាស់មានអ្វីខ្លះ ? ដើម្បីឆ្លើយសំណួរនេះ សូមសរសេរពាក្យ ដែលបញ្ចប់គោលការណ៍នេះ ៖ **ដើម្បីទទួលយកព្រះអម្ចាស់ យើងត្រូវតែ ។**

៤. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការលះបង់អ្វីខ្លះ ដែលអ្នកបានធ្វើដើម្បី « គោរពតាមសេចក្ដីសញ្ញា [ របស់អ្នក ] » ( គ. និង ស. ៩៧:៨ ) ?

សូមពិចារណាអំពីគោលជំហររបស់អ្នកនៅចំពោះព្រះ ។ សូមគិតអំពីរបៀប ដែលអ្នកអាចអនុវត្តគោលការណ៍នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:៨ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:១០–២១

*ព្រះអម្ចាស់គូសបញ្ជាក់អំពីព្រះឆន្ទៈរបស់ទ្រង់ ដែលមានព្រះទ័យឲ្យ ពួកបរិសុទ្ធនៅទីក្រុង ស៊ីយ៉ូន សាងសង់ព្រះវិហារបរិសុទ្ធ ។*

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:១០–១២ ដោយស្វែងរកការលះបង់ ដែលព្រះអម្ចាស់បានតម្រូវពីពួកបរិសុទ្ធនៅទីក្រុង ស៊ីយ៉ូន ( រដ្ឋ មិសសួរី ) ។ នៅក្នុងខគម្ពីរទាំងនេះ ពាក្យ *ដង្វាយមួយភាគដប់* សំដៅទៅលើដង្វាយនានាជាទូទៅ ពុំមែនសំដៅទៅលើ ១០ ភាគរយនៃប្រាក់ចំណូលប្រចាំឆ្នាំរបស់បុគ្គលម្នាក់ ដែលបានយល់ថាជាក្រឹត្យវិន័យដង្វាយមួយភាគក្នុងដប់ ដែលត្រូវបានបើកសម្ដែងក្រោយមកទៀតនោះទេ ( សូមមើល គ. និង ស. ១១៩ ) ។ បរិមាណច្រើនជាងមួយភាគដប់នៃធនធានរបស់ពួកបរិសុទ្ធ ត្រូវបានតម្រូវ ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធ រួមបញ្ចូលទាំងដង្វាយនៃពេលវេលា និង ការងាររបស់ពួកគេដែរ ។

សូមចងចាំថា ព្រះអម្ចាស់បានកំណត់ទីតាំងសម្រាប់សាងសង់ព្រះវិហារបរិសុទ្ធនៅទីក្រុង ស៊ីយ៉ូន រយៈពេលពីរឆ្នាំមុនដែលទ្រង់បានប្រទានវិវរណៈនេះ ( សូមមើល គ. និង ស. ៥៧:១–៣ ) ។ ក្នុងខែ មិថុនា ឆ្នាំ ១៨៣៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានសរសេរសំបុត្រទៅកាន់ថ្នាក់ដឹកនាំសាសនាចក្រនៅរដ្ឋ មិសសួរី ហើយបានណែនាំពួកគាត់ឲ្យចាប់ផ្ដើមការសាងសង់ព្រះវិហារបរិសុទ្ធជាបន្ទាន់ ( សូមមើល *History of the Church* ១:៣៦៣ ) ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលវិវរណៈដែលមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧ ត្រូវបានប្រទានឲ្យនៅថ្ងៃទី ២ ខែ សីហា ឆ្នាំ ១៨៣៣ នោះ ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ពុំទាន់បានចាប់ផ្ដើមការសាងសង់នៅឡើយទេ ។

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:១២–១៤ រួចស្វែងរកមូលហេតុនានា ដែលព្រះអម្ចាស់មានព្រះទ័យឲ្យពួកបរិសុទ្ធនៅរដ្ឋ មិសសួរី សាងសង់ព្រះវិហារបរិសុទ្ធ ។

ចំពោះអ្នក តើព្រះវិហារបរិសុទ្ធបានក្លាយទៅជា « កន្លែងនៃសេចក្ដីអំណរគុណ » ( គ. និង ស. ៩៧:១៣ ) តាមរបៀបណា ? តើព្រះវិហារបរិសុទ្ធបានក្លាយទៅជា « កន្លែងនៃការបង្គាប់ » ( គ. និង ស. ៩៧:១៣ ) តាមរបៀបណា ?

នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:១៥–២០ សូមស្វែងរកការសន្យាទាំងឡាយ ដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធ បើពួកគេសាងសង់ព្រះវិហារបរិសុទ្ធមួយឡើង ។



អែលឌើរ ដាវីឌ ប៊ី ហេត ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ថា ការសន្យាថានឹងបានឃើញព្រះនៅក្នុងព្រះវិហារបរិសុទ្ធ ( សូមមើល ខទី ១៥–១៦ )អាចរួមបញ្ចូលទាំង ភាពដែលលើសពីការមើលឃើញទ្រង់ដោយភ្នែកពីកំណើតរបស់យើងទៅទៀត ៖ « វាជាការពិតថា មានមនុស្សមួយចំនួនពិតជាបានឃើញព្រះអង្គសង្គ្រោះមែន ប៉ុន្តែ នៅពេលមនុស្សម្នាក់ស្រាវជ្រាវនៅក្នុងវចនានុក្រម នោះគាត់នឹងបានដឹងថា មានអត្ថន័យជាច្រើនទៀតចំពោះ ពាក្យ *មើលឃើញ*នេះ ដូចជាការមកស្គាល់ទ្រង់ ការញ្រាណដឹងអំពីទ្រង់ ការទទួលស្គាល់ទ្រង់ ថែមទាំងកិច្ចការរបស់ទ្រង់ ការស្គាល់អំពីសារៈសំខាន់នៃអង្គទ្រង់ ឬ ការបានយល់ដឹងអំពីទ្រង់ ( « Temples and Work Therein » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៦០ ទំព័រ ៦១ ) ។

ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:១៥–១៧ តើអ្នកអាចមានភាពសក្ដិសម ដើម្បីទទួលបទពិសោធន៍នៃសិរីល្អ និងវត្តមានរបស់ព្រះអម្ចាស់នៅក្នុងព្រះវិហារបរិសុទ្ធបានយ៉ាងដូចម្ដេច ? សូមគូសចំណាំពាក្យ ឬ ឃ្លានៅក្នុងខគម្ពីរទាំងនេះ ដែលបង្រៀនអំពីគោលការណ៍ ដែលថ្លែងថា **នៅក្នុងព្រះវិហារបរិសុទ្ធ ព្រះនឹងបង្ហាញព្រះកាយទ្រង់ទៅដល់មនុស្សទាំងឡាយណាដែលមានចិត្តបរិសុទ្ធ ។**

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ការមានចិត្តបរិសុទ្ធ មានន័យយ៉ាងដូចម្ដេច ?

ខ. តើយើងអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យចិត្តយើងបានបរិសុទ្ធ ដើម្បីយើងអាចទទួលបានពរជ័យនៃព្រះវិហារបរិសុទ្ធបាន ?

គ. តើអ្នកធ្លាប់មានអារម្មណ៍ថាមានពរតាមរបៀបណា នៅពេលអ្នកបានត្រៀមខ្លួន ចូលក្នុងព្រះវិហារបរិសុទ្ធ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:២១ រួចស្វែងរករបៀបដែលព្រះអម្ចាស់ បានកំណត់និយមន័យនៃពាក្យ *ស៊ីយ៉ូន ។* អ្នកអាចនឹងចង់សរសេរ ឬ គូសចំណាំ ឃ្លាដែលបង្រៀនអំពីសេចក្ដីពិតនេះ នៅក្នុងព្រះគម្ពីររបស់អ្នក ៖ **ស៊ីយ៉ូនគឺជាភាពបរិសុទ្ធនៅក្នុងចិត្ត ។**

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:២២–២៨

*ព្រះអម្ចាស់ពន្យល់អំពីអ្វី ដែលយើងត្រូវតែធ្វើ ដើម្បីចៀសផុតពីការពិរោធរបស់ទ្រង់ ហើយទទួលបានពរជ័យពីទ្រង់*



ដើម្បីយល់អំពីសារលិខិតរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:២២–២៤ សូមពិចារណាអំពីឃ្លាដូចតទៅនេះ ៖ ព្យុះសង្ឃរាកើតមានពាសពេញពិភពលោក ។ ព្យុះសង្ឃរាធំៗ អាចបង្វែរទៅជាខ្យល់ព្យុះកំបុតត្បូងដ៏សាហាវ ដែលបណ្ដាលឲ្យមានការខូចបង់យ៉ាងធ្ងន់ធ្ងរ ។ តើអ្នកធ្លាប់បានឃើញខ្យល់ព្យុះសង្ឃរា ឬ ខ្យល់ព្យុះកំបុតត្បូងដោយផ្ទាល់ ឬ បានឃើញតាមវីដេអូដែរឬទេ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:២២–២៤ រួចស្វែងរកអ្វី ដែលព្រះអម្ចាស់បានប្រៀបធៀបទៅនឹងខ្យល់ព្យុះសង្ឃរា ។

នៅក្នុង ខទី ២២ ពាក្យ *សេចក្ដីសងសឹក* សំដៅទៅលើផលវិបាក នៃការមិនគោរពប្រតិបត្តិព្រះអម្ចាស់ ។ នៅក្នុងចន្លោះដែលមាន សូមសរសេរអំពីរបៀប ដែលសេចក្ដីសងសឹករបស់ព្រះអម្ចាស់ អាចមានសភាពដូចជាខ្យល់ព្យុះសង្ឃរា ៖

សូមសិក្សានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧:២៥–២៨ ដើម្បីរកមើលអ្វីដែលយើងត្រូវធ្វើ ដើម្បីចៀសផុតពីសេចក្ដីសងសឹករបស់ព្រះអម្ចាស់ ហើយទទួលបានពរជ័យរបស់ទ្រង់ ។ អ្នកអាចនឹងចង់គូសចំណាំពាក្យ *បើសិនជា* នៅគ្រប់កន្លែងណាដែលអ្នកឃើញមាននៅក្នុងខគម្ពីរទាំងនេះ ។

សូមពិចារណាអំពីរបៀប ដែលសារលិខិតរបស់ព្រះអម្ចាស់នៅក្នុង ខទី ២៥–២៨ ទាក់ទងទៅនឹងរូបភាពនៃដើមឈើទាំងពីរប្រភេទ ដែលអ្នកបានសិក្សាមុននេះបន្តិច ។ តើ ខទី ២៧–២៨ បង្រៀនយ៉ាងដូចម្ដេច អំពីការប្រែចិត្ត និង ការអត់ទោស ?

យើងរៀនគោលការណ៍ចេញពីខគម្ពីរទាំងនេះថា **បើយើងគោរពប្រតិបត្តិ នោះយើងនឹងចៀសផុតពីសេចក្ដីសងសឹករបស់ព្រះអម្ចាស់ ហើយទទួលបានពរជ័យពីទ្រង់ជាច្រើនអនេក ។**

សូមពិចារណាអំពីអ្វីដែល អ្នកមានអារម្មណ៍ថាត្រូវបានបំផុសគំនិតឲ្យធ្វើ នៅពេលអ្នកបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧ ។ សូមធ្វើតាមការបំផុសគំនិតទាំងនោះ ដើម្បីអ្នកអាចទទួលបានពរជ័យទាំងឡាយពីព្រះអម្ចាស់ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៧ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២១ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨

## សេចក្ដីផ្ដើម

នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៨៣៣ អ្នកស្រុករដ្ឋ មិសសួរី មួយក្រុមចំនួន ៤០០–៥០០ នាក់ បានទាមទារមិនឲ្យមានពួកបរិសុទ្ធផ្លាស់ទីលំនៅទៅកាន់ឃុំចាកសុនទៀតឡើយ ហើយពួកបរិសុទ្ធដែលបានរស់នៅទីនោះហើយ ត្រូវតែចាកចេញភ្លាម ។ ពីមុនពួកបរិសុទ្ធអាចឆ្លើយតបទៅនឹងការទាមទារនោះ មនុស្សកំណាចមួយក្រុមបានចាប់ផ្ដើម បំផ្លាញទ្រព្យសម្បត្តិរបស់ពួកគេ ហើយគំរាមកំហែងដល់ជីវិតពួកគេ ។ នៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៨៣៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨ ជាវិវរណៈ ដែលព្រះអម្ចាស់បានណែនាំដល់ពួកបរិសុទ្ធ អំពីរបៀបឆ្លើយតបទៅនឹងសេចក្ដីបៀតបៀន ។ ទោះជាដំណឹងមួយចំនួនអំពីបញ្ហារំខាននៅរដ្ឋ មិសសួរី មុខជាត្រូវបានផ្ដល់ដល់ព្យាការីនៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ដែលមានចម្ងាយប្រមាណ ១,៤៥០ គីឡូម៉ែតយ៉ាងណាក្ដី ក៏លោកបានយល់អំពីភាពធ្ងន់ធ្ងរនៃស្ថានភាពនោះតាមតែរយៈវិវរណៈប៉ុណ្ណោះ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានជ្រាបអំពីទុក្ខវេទនារបស់ពួកបរិសុទ្ធ ហើយទ្រង់បានប្រទានឱវាទឲ្យពួកគេធ្វើតាមច្បាប់ភូមិបាល ថែមទាំងបានណែនាំពួកគេឲ្យរក្សាសេចក្ដីសញ្ញា ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១–២២

*ព្រះអម្ចាស់ប្រទានឱវាទឲ្យពួកបរិសុទ្ធ រក្សាសេចក្ដីសញ្ញារបស់ខ្លួននៅអំឡុងគ្រាដ៏លំបាក*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១–២២ ព្រះអម្ចាស់បានប្រទានឱវាទឲ្យពួកបរិសុទ្ធថ្លែងអំណរគុណសម្រាប់គ្រប់ការណ៍ទាំងអស់ ហើយត្រូវរង់ចាំព្រះអម្ចាស់ដោយចិត្តអត់ធ្មត់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១១–១២ រួចស្វែងរកព្រះបញ្ញត្តិ ដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:១៣–១៥ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ពួកបរិសុទ្ធអំពីការដែលត្រូវបានល្បងល ឬ ឲ្យបានឃើញថាសក្ដិសម ។ យើងរៀនចេញពីខគម្ពីរទាំងនេះថា **យើងបង្ហាញដល់ព្រះអម្ចាស់ថា ខ្លួនយើងសក្ដិសមតាមរយៈការរក្សាសេចក្ដីសញ្ញារបស់យើង ទោះជាមានភាពលំបាកក្នុងការធ្វើដូចនោះក្ដី ។**

សូមគិតអំពីមូលហេតុ ដែលអាចនឹងចាំបាច់ចំពោះពួកបរិសុទ្ធដែលរស់នៅរដ្ឋ មិសសួរី ក្នុងឆ្នាំ ១៨៣៣ ដែលពួកគេត្រូវចងចាំអំពីសារៈសំខាន់នៃការរក្សាសេចក្ដីសញ្ញារបស់ពួកគេ ទោះជាមានភាពលំបាកក្នុងការធ្វើដូចនោះក្ដី ។ តើអ្នកគិតថា ហេតុអ្វីបានជាវាអាចនឹងចាំបាច់ចំពោះយើងនាពេលបច្ចុប្បន្ននេះ ដែលត្រូវចងចាំអំពីសារៈសំខាន់នៃការរក្សាសេចក្ដីសញ្ញារបស់យើងអំឡុងគ្រាដ៏លំបាក ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:២៣–៣២

*ព្រះអម្ចាស់បើកសម្ដែងរបៀប ដែលពួកបរិសុទ្ធត្រូវឆ្លើយតបទៅនឹងសេចក្ដីបៀតបៀន*

១. សូមគូសប្រអប់ឈរចំនួនបី នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមដាក់ចំណងជើងប្រអប់ឈរទីមួយថា *ក្រឹត្យវិន័យរបស់ព្រះអម្ចាស់ស្ដីពីការសងសឹក ( គ. និង ស. ៩៨:២៣–៣២ )* ប្រអប់ឈរទីពីរថា *ក្រឹត្យវិន័យរបស់ព្រះអម្ចាស់ស្ដីពីសង្គ្រាម ( គ. និង ស. ៩៨:៣៣–៣៨ )* និង ប្រអប់ឈរទីបីថា *ក្រឹត្យវិន័យរបស់ព្រះអម្ចាស់ស្ដីពីការអត់ទោស ( គ. និង ស. ៩៨:៣៩–៤៨ )* ។ សូមទុកចន្លោះនៅលើប្រអប់ឈរនីមួយៗ ដើម្បីសរសេរគោលការណ៍ និង គោលលទ្ធិដែលអ្នករកឃើញនៅពេលអ្នកសិក្សាមេរៀននេះ ។ នៅពេលអ្នកសិក្សាពេញមួយមេរៀននេះ អ្នកនឹងរកឃើញសេចក្ដីណែនាំ អំពីអ្វីដែលត្រូវសរសេរនៅក្នុងប្រអប់ឈរទាំងនេះ ។

តើអ្នកនឹងមានអារម្មណ៍ដូចម្ដេច នៅពេលនរណាម្នាក់បានធ្វើឲ្យអ្នក ឬ ក្រុមគ្រួសាររបស់អ្នកមានការឈឺចាប់ ? តើអ្នកគិតថា ហេតុអ្វីបានជាមនុស្សមួយចំនួនអាចនឹងចង់សងសឹក ( តបត ) ទាស់នឹងបុគ្គល ដែលបានធ្វើឲ្យពួកគេឈឺចាប់ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:២៣–២៧ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលអំពីការតបត និង ការសងសឹក ។

អ្នកអាចនឹងចង់គូសចំណាំឃ្លា « មិនដេរប្រមាថ » និង « អត់ទ្រាំ » នៅក្នុងខគម្ពីរទាំងនេះ ។

យោងតាមអ្វីដែលព្រះអម្ចាស់ បានបង្រៀនដល់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី យើងរៀនថា **បើយើងអត់ទ្រាំនឹងការធ្វើបាប ដោយពុំមានការសងសឹក នោះព្រះអម្ចាស់នឹងប្រទានរង្វាន់ដល់យើង ។** សូមសរសេរគោលការណ៍នេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នៅពីក្រោមចំណងជើង « ក្រឹត្យវិន័យរបស់ព្រះអម្ចាស់ស្ដីពីការសងសឹក » ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ការសងសឹក ឬ ការព្យាយាមតបតទៅវិញ គឺជារឿងធ្វើឲ្យខូចប្រយោជន៍ តាមរបៀបណា ?

ខ. សូមគិតអំពីមនុស្សម្នាក់ ដែលអ្នកស្គាល់ ( ឬ បានអានអំពីមនុស្សម្នាក់ ) ដែលបានមានការអត់ធ្មត់ នៅអំឡុងពេលមានការធ្វើបាប ហើយពុំព្យាយាមសងសឹក ។ តើបុគ្គលម្នាក់នេះបានធ្វើដូចម្ដេច ដើម្បីមានការអត់ធ្មត់ ទោះជាមានគេធ្វើបាបដល់ខ្លួនគាត់នោះ ?

នៅពេលពួកមនុស្សកំណាចរួបរួមគ្នានៅឃុំចាកសុន រដ្ឋ មិសសួរី នៅថ្ងៃសៅរ៍ ទី ២០ ខែ កក្កដា ឆ្នាំ ១៨៣៣ ពួកគេមិនត្រឹមតែបានបំផ្លាញទ្រព្យសម្បត្តិនោះទេ ថែមទាំងបានប៉ុនប៉ងធ្វើទុក្ខទោសដល់ថ្នាក់ដឹកនាំសាសនាចក្រទៀតផង ។ ដំណើររឿងខាងក្រោមនេះ បង្ហាញអំពីរបៀបដែលប៊ីស្សព អែតវឺត ប៉ាទ្រិច និង ឆាលស៍ អេលែន ជាអ្នកប្រែចិត្តជឿវ័យ ២៧ ឆ្នាំម្នាក់មកពីរដ្ឋ ផែនសិលវេញ៉ា បានឆ្លើយតបទៅនឹងការធ្វើបាបពីសំណាក់ក្រុមមនុស្សកំណាចនៅរដ្ឋ មិសសួរី ។



មនុស្សកំណាចម្នាក់ គំរាមកំហែងថ្នាក់ដឹកនាំសាសនាចក្រនៅឃុំចាកសុន រដ្ឋ មិសសួរី ។

« មនុស្សកំណាចបានចាប់ប៊ីស្សព អែតវឺត ប៉ាទ្រិច និង ឆាលស៍ អេលែន ហើយបានអូសពួកគាត់កាត់ហ្វូងមនុស្សដែលកំពុងមានកំហឹងពុះកញ្ជ្រោល ហើយបានប្រមាថ ថែមទាំងបានធ្វើទុក្ខទោសដល់ពួកលោកនៅតាមផ្លូវទៅកាន់ទីលានសាធារណៈ ។ ជាជម្រើសទាំងពីរ ដែលបានផ្ដល់ដល់ពួកគាត់គឺ ពួកគាត់ត្រូវតែជ្រើសរើសបោះបង់ចោលសេចក្ដីជំនឿទៅលើ *ព្រះគម្ពីរមរមន* ឬ ជ្រើសរើសចាកចេញពីឃុំនោះ ។ ពួកគាត់ពុំបានជ្រើសរើសបដិសេធ *ព្រះគម្ពីរមរមន* ហើយក៏មិនបានជ្រើសរើសចាកចេញពីឃុំនោះដែរ ។ ដោយបានទទួលការអនុញ្ញាតឲ្យនិយាយ ប៊ីស្សព ប៉ាទ្រិច បានបន្លឺថា ពួកបរិសុទ្ធបានរងទុក្ខនឹងសេចក្ដីបៀតបៀននៅគ្រប់ជំនាន់ទាំងអស់ក្នុងប្រវត្តិសាស្ត្រពិភពលោក ហើយពួកគេមានឆន្ទៈដើម្បីរងទុក្ខដោយសារតែព្រះគ្រីស្ទ ដូចជាពួកបរិសុទ្ធនៅជំនាន់បុរាណបានធ្វើដែរ ដែលពួកគេពុំបានប្រព្រឹត្តអ្វីខុសទាល់តែសោះ ហើយបើសិនជាមនុស្សធ្វើទុក្ខទោសដល់ពួកគេ នោះនឹងបានធ្វើបាបដល់ជនឥតទោស ។ សំឡេងរបស់គាត់ត្រូវបាបលុបបាត់ដោយសារតែសូរកងរំពងនៃហ្វូងមនុស្ស ដែលពួកគេជាច្រើននាក់បានស្រែកឡើង ៖ ‹ អំពាវនាវទៅកាន់ព្រះរបស់ឯង ឲ្យចុះមកជួយឯងទៅ . . . ! › បងប្អូនប្រុសទាំងពីរនាក់ ប៉ាទ្រិច និង អេលែន ត្រូវបានគេសម្រាតសម្លៀកបំពាក់ ហើយបានលាបជ័រកៅស៊ូ [ ពាសពេញខ្លួន ] ដែលលាយជាមួយកំបោរស ឬ ផេះ ឬ សារធាតុអាស៊ីដផ្សេងៗដែលកាត់សាច់មនុស្ស និង ចាក់ស្លាបសត្វលើខ្លួនរបស់ពួកគាត់ ។ ពួកគាត់បានស៊ូទ្រាំនឹងទង្វើ និង ការធ្វើទុក្ខទោសដ៏សាហាវយង់ឃ្នងនេះដោយមានចិត្តរាបសា និង ទន់ទាប ខណៈដែលហ្វូងមនុស្សនៅតែបន្តប្រព្រឹត្តបែបនោះ ហើយពួកគេបានស្ងប់ស្ងែងនឹងអ្វីដែលពួកគេបានឃើញ ។ បងប្អូនប្រុសទាំងពីររូប ត្រូវបានដោះលែងដោយពុំមានការធ្វើទុក្ខទោសទៀតឡើយ » ( B. H. Roberts, *A Comprehensive History of the Church* ១:៣៣៣ សូមមើលផងដែរ *Church History in the Fulness of Times Student Manual* ការបោះពុម្ពលើកទី ២ [ Church Educational System manual ] ឆ្នាំ ២០០៣ ទំព័រ ១៣៣) ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើរបៀបដែលប៊ីស្សព ប៉ាទ្រិច និង ឆាលស៍ អេលែន បានឆ្លើយតបចំពោះសេចក្ដីបៀតបៀន ដែលពួកគាត់បានជួបប្រទះនោះ បានធ្វើឲ្យអ្នកស្ញប់ស្ញែងយ៉ាងដូចម្ដេច ?

ខ. តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីធ្វើតាមឱវាទរបស់ព្រះអម្ចាស់នៅក្នុងស្ថានភាពនេះ ឲ្យបានកាន់តែប្រសើរឡើង ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:២៨–៣២ ព្រះអម្ចាស់បានទូន្មានពួកបរិសុទ្ធថា បើសិនជាខ្មាំងសត្រូវបានធ្វើទុក្ខទោសដល់ពួកគេ ដោយបានគេចផុតពីការសឹងសឹករបស់ព្រះ នោះពួកគេគួរតែព្រមានខ្មាំងសត្រូវនោះនៅក្នុងព្រះនាមនៃព្រះអម្ចាស់ កុំឲ្យធ្វើទុក្ខទោសដល់ពួកគេទៀត ។ ព្រះអម្ចាស់បានពន្យល់បន្ថែមថា បើសិនជាខ្មាំងសត្រូវនោះបន្តធ្វើទុក្ខទោសបន្ទាប់ពីបានព្រមានហើយ នោះពួកបរិសុទ្ធត្រូវបានរាប់ជាសុចរិតក្នុង « ការសងអ្នកនោះតាមការណ៍ទាំងឡាយដែលគាត់ធ្វើ » ( គ. និង ស. ៩៨:៣១ ) ។ ទោះជាយ៉ាងណាក៏ដោយ ពួកបរិសុទ្ធក៏ត្រូវបានព្រះមានព្រះបន្ទូលប្រាប់ដែរថា បើសិនជាពួកគេប្រណីដល់ខ្មាំងសត្រូវខ្លួនដែលសមនឹងទទួលបានការសងសឹក នោះពួកគេនឹងទទួលបានរង្វាន់ចំពោះសេចក្ដីសុចរិតរបស់ពួកគេហើយ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៣៣–៣៨

*ព្រះអង្គសង្គ្រោះពន្យល់ អំពីពេលវេលាដែលសង្គ្រាមត្រូវបានរាប់ជាសុចរិត*

តើអ្នកមានញាតិសណ្ដាន ឬ មិត្តភក្ដិដែលធ្លាប់បានចូលច្បាំងក្នុងសង្គ្រាមដើម្បីប្រទេសជាតិរបស់ខ្លួនដែរឬទេ ? តើអ្នកធ្លាប់បានឆ្ងល់អំពី អ្វីដែលព្រះអម្ចាស់បានបង្រៀនអំពីសង្គ្រាមដែរឬទេ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៣៣–៣៤ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ពួកអ្នកដើរតាមទ្រង់ពីបុរាណ អំពីសង្គ្រាម ។

យោងតាមអ្វី ដែលអ្នកបានអាននៅក្នុង ខទី ៣៣ សូមបំពេញចន្លោះទាំងឡាយ ដើម្បីបញ្ចប់ឃ្លាដូចតទៅនេះ ៖ ពួកគេ ចេញទៅច្បាំងទាស់នឹងសាសន៍ ពូជមនុស្ស ភាសា ឬ ប្រជាជនណាមួយឡើយ ព្រះអម្ចាស់ ដល់ពួកគេប៉ុណ្ណោះ ។ អ្នកអាចនឹងចង់សរសេរសេចក្ដីពិតនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នៅពីក្រោមចំណងជើង « ក្រឹត្យវិន័យរបស់ព្រះអម្ចាស់ស្ដីពីសង្គ្រាម » ។ ( សូមចងចាំថា ព្រះអម្ចាស់បានប្រទានក្រឹត្យវិន័យនេះជាពិសេសទៅដល់ មនុស្សដែលរស់នៅក្នុងគ្រប់ជំនាន់ និង គ្រប់វប្បធម៌ ។ ទោះជាគោលការណ៍នៃក្រឹត្យវិន័យនេះជាការពិត ក៏សព្វថ្ងៃនេះយើងត្រូវបានតម្រូវឲ្យគោរពតាមច្បាប់នៃប្រទេស ដែលយើងរស់នៅដែរ [ សូមមើល មាត្រានៃសេចក្ដីជំនឿ ១:១២ ] ) ។

ស្របតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៣៤ តើពួកអ្នកដើរតាមទ្រង់កាលពីបុរាណ ត្រូវធ្វើដូចម្ដេចជាមុនសិន នៅពេលមាននរណាម្នាក់ប្រកាសសង្គ្រាមជាមួយពួកគេ ? ( សូមសរសេរចម្លើយចំពោះសំណួរនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នៅពីក្រោមចំណងជើង « ក្រឹត្យវិន័យរបស់ព្រះអម្ចាស់ស្ដីពីសង្គ្រាម » ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៣៥–៣៨ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ពួកអ្នកដើរតាមទ្រង់ពីបុរាណឲ្យធ្វើ នៅពេលដែលការផ្ដល់ជូនសន្តិភាពរបស់ពួកគេនោះ ពុំត្រូវបានទទួលយក ។

យើងរៀនចេញពីខគម្ពីរទាំងនេះថា **សង្គ្រាមអាចត្រូវបានរាប់ជាសុចរិត នៅក្នុងកាលៈទេសៈដែលត្រូវបានពិពណ៌នាដោយព្រះអម្ចាស់** ។ សូមសរសេរសេចក្ដីពិតនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នៅពីក្រោមចំណងជើង « ក្រឹត្យវិន័យរបស់ព្រះអម្ចាស់ស្ដីពីការសងសឹក » ។

នៅពេលប្រទេសនានាបានចូលរួមក្នុងសង្គ្រាមលោកលើកទី ២ ប្រធាន ដេវីឌ អូ មិកឃេ បានពន្យល់អំពីកាលៈទេសៈ ដែលពួកអ្នកដើរតាមព្រះអម្ចាស់ត្រូវបានរាប់ជាសុចរិត ក្នុងការចូលច្បាំង ៖



« សង្គ្រាមគឺជាបញ្ហាដែលមិនចុះសម្រុង ទៅនឹងការបង្រៀនរបស់ព្រះគ្រីស្ទ ។ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ គឺជាដំណឹងល្អនៃសន្តិភាព ។ សង្គ្រាមមានសភាពខុសគ្នាស្រឡះ [ ផ្ទុយគ្នា ] ទៅនឹងដំណឹងល្អ ហើយបង្កឲ្យមានសម្អប់ ។. . .

« ទោះជាយ៉ាងណាក៏ដោយ មានលក្ខខណ្ឌចំនួនពីរ ដែលអាចរាប់បុរសគ្រីស្តបរិស័ទដ៏ពិតជាសុចរិតឲ្យចូល—សូមកត់ចំណាំថា ខ្ញុំប្រើពាក្យសព្ទ *ចូល មិនមែនចាប់ផ្ដើម*—សង្គ្រាមនោះទេ ៖ (១) ការប៉ុនប៉ង [ ដោយនរណាម្នាក់ ] ដើម្បីគាបសង្កត់ ហើយដកហូតសិទ្ធិសេរីភាពរបស់គេ និង (២) កក្ដីភាពចំពោះប្រទេសរបស់គេ ។ អាចនឹងមានលក្ខខណ្ឌទីបី [ ពោលគឺ ] ការពារប្រទេសទន់ខ្សោយ ដែលកំពុងត្រូវបានសង្កត់សង្កិនដោយប្រទេសដែលមានអំណាចខ្លាំងជាងខ្លួន និង គ្មានមេត្តា »( នៅក្នុង Conference Report ខែមេសា ឆ្នាំ១៩៤២ ទំព័រ ៧១–៧២) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៣៩–៤៨

*ព្រះអម្ចាស់បង្រៀនពួកបរិសុទ្ធ អំពីរបៀបដែលពួកគេគួរតែឆ្លើយតបទៅនឹងខ្មាំងសត្រូវរបស់ខ្លួន*

អ្វីដែលទាក់ទងទៅនឹងក្រឹត្យវិន័យរបស់ព្រះអម្ចាស់ស្ដីពីសង្គ្រាម គឺជាក្រឹត្យវិន័យរបស់ព្រះអម្ចាស់ស្ដីពីការអត់ទោស នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៣៩–៤៨ ។ ដំណើររឿងខាងក្រោមនៃព្រឹត្តិការណ៍ ដែលបានកើតឡើងនៅបន្ទាប់ពីសង្គ្រាមលោកលើកទី ២ បង្ហាញអំពីក្រឹត្យវិន័យរបស់ព្រះអម្ចាស់ស្ដីពីការអត់ទោស ៖

« នៅប្រទេស ហូឡង់ អំឡុងពេលសង្គ្រាមលោកលើកទី ២ ក្រុមគ្រួសារ ខាស្ដើរ ផែន ប៊ូម បានប្រើប្រាស់ផ្ទះសម្បែងរបស់ខ្លួន ធ្វើជាទីកន្លែងលាក់ខ្លួនសម្រាប់អ្នកដែលត្រូវបានពួកសង្គមជាតិនិយម ណាស៊ី តាមចាប់ខ្លួន ។ នេះគឺជារបៀបដែលពួកគេបានរស់នៅ ឲ្យស្របទៅតាមជំនឿគ្រីស្ដសាសនារបស់ពួកគេ ។ សមាជិកបួននាក់នៃក្រុមគ្រួសារនោះ បានបាត់បង់ជីវិតដោយសារតែការផ្ដល់ជម្រកនេះ ។ ខូរី ផែន ប៊ូម និង បងស្រីរបស់នាង បែតស៊ី បានជាប់ក្នុងគុក រ៉ាវែនស្ប៊ូខ យ៉ាងវេទនា អស់រយៈពេលជាច្រើនខែ ។ បែតស៊ី បានបាត់បង់ជីវិតនៅក្នុងគុកនោះ—ហើយ ខូរី នៅរស់រានមានជីវិត ។

« នៅក្នុងគុក រ៉ាវែនស្ប៊ូខ នោះ ខូរី និង បែតស៊ី បានស្វែងយល់ថា ព្រះជួយពួកយើងឲ្យចេះអត់ទោស ។ ក្រោយពីសង្គ្រាមបានបញ្ចប់ទៅ ខូរី បានសម្រេចចិត្តចែកចាយសារលិខិតមួយនេះ ។ នៅក្នុងឱកាសមួយ នាងបានថ្លែងទៅកាន់មនុស្សមួយក្រុមនៅប្រទេស អាល្លឺម៉ង់ ដែលរងទុក្ខដោយសារការបំផ្លិចបំផ្លាញនៃសង្គ្រាម ។ សារលិខិតរបស់នាងមានចំណងជើងថា ‹ ព្រះទ្រង់អត់ទោស › ។ នៅពេលនោះហើយ ដែលភាពស្មោះត្រង់របស់ ខូរី ផែន ប៊ូម បាននាំឲ្យមានពរជ័យ ។

« មានបុរសម្នាក់បានដើរសំដៅមករកនាង ។ នាងបានស្គាល់បុរសនោះថាជា ឆ្មាំយាមគុកដ៏ឃោរឃៅបំផុត ។ គាត់បានវាចាថា ‹ បងស្រីបានថ្លែងអំពីគុក រ៉ាវែនស្ប៊ូខ នៅក្នុងសុន្ទរកថារបស់បងស្រី › ។ ‹ ខ្ញុំគឺជាឆ្មាំយាមនៅទីនោះ ។. . . ប៉ុន្តែបន្ទាប់ពីនោះមក . . . ខ្ញុំបានក្លាយទៅជាគ្រីស្ទបរិស័ទ ។ គាត់រៀបរាប់ថា គាត់បានស្វែងរកការអត់ទោសពីព្រះចំពោះទង្វើដ៏ឃោរឃៅ ដែលគាត់បានប្រព្រឹត្ត ។ គាត់បានហុចដៃរបស់គាត់ ហើយស្នើដូច្នេះថា ‹ តើបងស្រីនឹងអត់ទោសឲ្យខ្ញុំដែរឬទេ › ?

« ខូរី ផែន ប៊ូម បានបន្លឺ ៖

« ‹ វាគ្រាន់តែជាវេលាតែមួយភ្លែតប៉ុណ្ណោះ ដែលគាត់បានឈរនៅទីនោះ—ហើយហុចដៃរបស់គាត់មក—ប៉ុន្តែសម្រាប់ខ្ញុំវិញ វាហាក់ដូចជា ខ្ញុំបានពុះពារនៅក្នុងកិច្ចការដ៏លំបាកបំផុត ដែលខ្ញុំធ្លាប់បានធ្វើ ។

« ‹ . . . សារលិខិតដែលថា ព្រះទ្រង់អត់ទោសមាន. . . លក្ខខណ្ឌមួយ ៖ គឺយើងត្រូវអត់ទោសដល់ មនុស្សដែលបានព្យាបាទយើង ។. . .

“. . .‹ ជួយកូនផង ! › ខ្ញុំបានអធិស្ឋានដោយស្ងាត់ៗ ។ ទូលបង្គំអាចលើកដៃទូលបង្គំបាន ។ ទូលបង្គំអាចធ្វើដូច្នោះបាន ។ សូមព្រះអង្គប្រទានកម្លាំងចិត្តដល់ទូលបង្គំផង » ។

« ‹ . . . ខ្ញុំបានលើកដៃខ្ញុំ ទៅចាប់ដៃដែលបានហុចមកកាន់ខ្ញុំនោះ ទាំងលំបាក និង គ្មានកម្លាំងចិត្តអ្វីទាល់តែសោះ ។ នៅពេលខ្ញុំបានធ្វើដូចនោះ រឿងមួយដ៏អស្ចារ្យបានកើតឡើង ។ អារម្មណ៍មួយបានចាប់ផ្ដើមចេញពីស្មារបស់ខ្ញុំ រត់ទៅតាមដៃ ហើយចូលទៅក្នុងប្រអប់ដៃទាំងពីររបស់យើងដែលកំពុងចាប់នោះ ។ ភ្លាមនោះ អារម្មណ៍កក់ក្ដៅនៃភាពសះស្បើយនេះហាក់ដូចជាកែសាយពាសពេញរាងកាយខ្ញុំ ដោយបានធ្វើឲ្យខ្ញុំយំ ។

« ‹ ខ្ញុំអភ័យទោសឲ្យបងប្រុស ! › ខ្ញុំបានយំ ។ ‹ ដោយអស់ពីដួងចិត្តខ្ញុំ › ។

« ‹ យើងបានចាប់ដៃគ្នាអស់រយៈពេលយ៉ាងយូរ ក្នុងនាមជាអតីតឆ្មាំយាមគុក និង អតីតអ្នកជាប់គុក ។ នៅពេលខ្ញុំធ្វើនោះ ខ្ញុំពុំដែលបានស្គាល់សេចក្ដីស្រឡាញ់របស់ព្រះយ៉ាងសន្ធឹកសន្ធាប់ដូចនេះទេ › ។ [ ខូរី ផែន ប៊ូម *Tramp for the Lord* ( ឆ្នាំ ១៩៧៤ ) ទំព័រ ៥៤–៥៥ ] » ។ ( យើត ប៊ី ម៉ាក់ម៉ុលីន, Our Path of Duty » *Ensign* ឬ *លីអាហូណា*, ខែ ឧសភា ឆ្នាំ ២០១០,ទំព័រ ១៣ ) ។

តើដំណើររឿងនេះ បង្រៀនអ្នកអំពីការអត់ទោសយ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៣៩–៤០ ដោយស្វែងរកក្រឹត្យវិន័យរបស់ព្រះអម្ចាស់ស្ដីពីការអត់ទោស ។

ស្របតាមខគម្ពីរទាំងនេះ តើយើងគួរតែធ្វើអ្វីខ្លះ នៅពេលនរណាម្នាក់សុំការអត់ទោសពីយើង ?

ឃ្លា « រហូតដល់ប្រាំពីរចិតសិបដង » នៅក្នុង ខទី ៤០ ថ្លែងបញ្ជាក់ថា យើងគួរតែអត់ទោសដល់មនុស្សទូទៅឲ្យបានច្រើនដងតាមដែលអាចធ្វើទៅបាននៅពេលពួកគេប្រែចិត្ត ហើយស្វែងរកការអត់ទោសបន្ទាប់ពីបានប្រព្រឹត្តខុស ឬ ធ្វើឲ្យយើងឈឺចាប់ ។ ( ទោះជាយើងត្រូវបានបញ្ជាឲ្យអត់ទោសយ៉ាងណាក៏ដោយ ការណ៍នេះពុំមានន័យថា យើងគួរតែអនុញ្ញាតឲ្យមនុស្សទូទៅបន្តធ្វើទុក្ខទោសដល់យើងនោះទេ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៤១–៤៣ ដោយស្វែងរកសេចក្ដីពិតបន្ថែម ដែលព្រះអម្ចាស់បានបង្រៀនដល់ពួកបរិសុទ្ធ អំពីខ្មាំងសត្រូវដែលរំលោភបំពានលើពួកគេ ហើយពុំប្រែចិត្ត ។

សូមសរសេរសេចក្ដីសង្ខេបនៃក្រឹត្យវិន័យរបស់ព្រះអម្ចាស់ស្ដីពីការអត់ទោស ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នៅពីក្រោមចំណងជើង « ក្រឹត្យវិន័យរបស់ព្រះអម្ចាស់ស្ដីពីការអត់ទោស » ។

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ហេតុអ្វីបានជាយើងត្រូវបានបញ្ជាឲ្យអត់ទោសដល់មនុស្សដទៃ ទោះបីជាពួកគេពុំសុំការអត់ទោសផងនោះ ?

ខ. ហេតុអ្វីបានជាយើងត្រូវបានបញ្ជា ឲ្យអត់ទោសដល់ខ្មាំងសត្រូវរបស់យើង ?

សូមគិតអំពីអ្វី ដែលអ្នកអាចធ្វើនៅក្នុងជីវិត ដើម្បីធ្វើតាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់ស្ដីពីការអត់ទោស ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨:៤៤–៤៨ ព្រះអម្ចាស់បានសន្យាថា បើសិនជាខ្មាំងសត្រូវរបស់ពួកបរិសុទ្ធនឹងប្រែចិត្ត នោះពួកគេនឹងចៀសផុតពីការសងសឹករបស់ព្រះអម្ចាស់ ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩–១០០

## បុព្វកថា

ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩ នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៨៣២ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានហៅឲ្យ យ៉ូហាន មើដក់ បន្តកិច្ចការផ្សព្វផ្សាយរបស់គាត់ ហើយធ្វើដំណើរទៅភាគខាងកើតនៃសហរដ្ឋ ។ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០ នៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៨៣៣ កាលលោក និង ស៊ីឌនី រិកដុន បាននៅរដ្ឋ នូវ យ៉ោក កំពុងធ្វើការជាអ្នកផ្សព្វផ្សាយសាសនា ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានអះអាងដល់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី ថា ក្រុមគ្រួសាររបស់ពួកលោកនៅឯរដ្ឋ អូហៃអូ ឯណោះ គឺសុខសប្បាយទេ ។ ព្រះអម្ចាស់ក៏បានលួងលោមចិត្ត យ៉ូសែប អំពីពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ដែលកំពុងរងទុក្ខនឹងសេចក្ដីបៀតបៀនដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩

*ព្រះអម្ចាស់ត្រាស់ហៅ យ៉ូហាន មើដក់ ឲ្យប្រកាសដំណឹងល្អ*

សូមស្រមៃថា មានមិត្តភក្ដិម្នាក់ដែលមិនមែនជាសមាជិកសាសនាចក្រ មកសួរអ្នកអំពីមូលហេតុ ដែលយុវជន និង យុវនារីជាច្រើន មានឆន្ទៈលះបង់ ២ ឆ្នាំ ឬ ១៨ ខែ ក្នុងជីវិតរបស់ពួកគេ ទៅបម្រើបេសកកម្ម ។ តើអ្នកនឹងពន្យល់យ៉ាងដូចម្ដេច អំពីមូលហេតុដែលមនុស្សម្នាក់នឹងមានឆន្ទៈក្នុងការលះបង់បែបនោះ ដើម្បីបម្រើបេសកកម្ម ។



យ៉ូហាន មើដក់ គឺជាសមាជិកម្នាក់នៃសាសនាចក្រជំនាន់ដំបូង ។ នៅពេលអ្នកអានព័ត៌មានខាងក្រោមនេះ សូមកត់ចំណាំអំពីការលះបង់ ដែលគាត់បានធ្វើដើម្បីបម្រើព្រះអម្ចាស់ ៖

យ៉ូហាន មើដក់ បានសិក្សាអំពីសាសនាចក្រជាច្រើន ហើយបានសន្និដ្ឋានថា សាសនាចក្រទាំងអស់ពុំត្រឹមត្រូវឡើយ ។ ទោះជាយ៉ាងណាក៏ដោយ នៅចុងឆ្នាំ ១៨៣០ គាត់បានអានព្រះគម្ពីរមរមន ហើយបានទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ថ្លែងអំពីសេចក្ដីពិតនៃព្រះគម្ពីរនេះ ។ គាត់បានប្រែចិត្តជឿ ហើយបានរកឃើញសាសនាចក្រដ៏ពិតរបស់ព្រះគ្រីស្ទ ។ មិនយូរប៉ុន្មានបន្ទាប់ពីបានទទួលពិធីបុណ្យជ្រមុជទឹកនៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ១៨៣០ យ៉ូហាន មើដក់ បានបម្រើបេសកកម្ម ដោយបានធ្វើពិធីបុណ្យជ្រមុជទឹកឲ្យមនុស្សប្រមាណ ៧០ នាក់ក្នុងរយៈពេលបួនខែនៅ អ័រែន និង វើរិនស៊ីល រដ្ឋ អូហៃអូ ។

នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៨៣១ មិនយូរប៉ុន្មានបន្ទាប់ពី យ៉ូហាន បានត្រឡប់មកពីបេសកកម្មរបស់គាត់វិញ នោះភរិយារបស់គាត់ ជូលៀ បានបាត់បង់ជីវិតបន្ទាប់ពីបានផ្ដល់



យ៉ូហាន មើដក់

កំណើតឲ្យកូនភ្លោះ ។ ក្នុងខែ មិថុនា ឆ្នាំ ១៨៣១ ព្រះអម្ចាស់បានត្រាស់ហៅគាត់ឲ្យធ្វើដំណើរទៅរដ្ឋ មិសសួរី ហើយប្រកាសដំណឹងល្អនៅតាមផ្លូវ ( សូមមើល គ. និង ស. ៥២:៨–៩ ) ។ ពីមុន យ៉ូហាន អាចចាកចេញទៅ គាត់ត្រូវធ្វើឲ្យប្រាកដថា កូនៗទាំងប្រាំនាក់ ដែលសុទ្ធតែអាយុក្រោមប្រាំពីរឆ្នាំនោះ ត្រូវបានផ្គត់ផ្គង់ ។ គាត់បានចាត់ចែងឲ្យមានមនុស្សបីបួននាក់ មើលថែកូនច្បងៗរបស់គាត់ ហើយ យ៉ូសែប ស៊្មីធ និង អិមម៉ា ស៊្មីធ បានទទួលចិញ្ចឹមកូនភ្លោះ ។ រហូតដល់ចុងឆ្នាំ ១៨៣១ និង ពាក់កណ្តាលឆ្នាំដំបូងនៃ ១៨៣២ យ៉ូហាន មើដក់ បានប្រកាសដំណឹងល្អនៅក្នុងដែនដី មីឈីហ្គេន, អ៊ិនឌីអាណា, មិសសួរី និង អូហៃអូ ។ នៅពេលគាត់បានត្រឡប់ទៅកាន់ភូមិហៃរ៉ាំ រដ្ឋ អូហៃអូ វិញក្នុងខែ មិថុនា ឆ្នាំ ១៨៣២ គាត់បានរងទុក្ខដោយការឆ្លងជំងឺរ៉ាំរ៉ៃ ។ គាត់ក៏បានដឹងដែរថា កូនភ្លោះគាត់ម្នាក់បានស្លាប់ក្នុងខែមិនាមុន ហើយអ្នកដែលបានមើលថែកូនច្បងទាំងបីរបស់គាត់ បានទាមទារយកថ្លៃមើលថែរបស់ពួកគេ ។

ព្យាការី យ៉ូសែប ស៊្មីធ បានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ៩៩ ប្រមាណពីរខែបន្ទាប់ពី យ៉ូហាន មើដក់ បានត្រឡប់មកផ្ទះវិញ ពីបេសកកម្មទីពីររបស់គាត់ ។ សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៩៩:១ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បានត្រាស់ហៅ យ៉ូហាន មើដក់ ឲ្យធ្វើ ។

បន្ថែមពីលើការហៅឲ្យប្រកាសដំណឹងល្អ វិវរណៈនេះមាននូវការសន្យាជាច្រើនទាក់ទងទៅនឹងការបម្រើរបស់ យ៉ូហាន ។ សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៩៩:២–៣ ដោយស្វែងរកថាតើទាំង យ៉ូហាន មើដក់ និង មនុស្សដែលគាត់បានបង្រៀននោះ នឹងមានពរតាមរយៈការបម្រើរបស់គាត់យ៉ាងដូចម្តេច ។

ចេញពី ខទី ២–៣ យើងរៀនសេចក្តីពិតដូចតទៅនេះ ៖ **យើងតំណាងឲ្យព្រះអម្ចាស់ នៅពេលយើងបម្រើបេសកកម្ម ហើយអស់អ្នកដែលទទួលយកដំណឹងល្អដូចជាក្មេងនោះ នឹងទទួលបានសេចក្តីមេត្តាករុណា ។**

ពីមុន យ៉ូហាន មើដក់ បានចាកចេញទៅបម្រើបេសកកម្មនៅភាគខាងកើតនៃសហរដ្ឋគាត់បានចូលរៀននៅក្នុងសាលារបស់ពួកព្យាការី ដែលបានផ្តល់ដល់គាត់នូវភាពពិតមួយដ៏អស្ចារ្យ ។ « នៅក្នុង [ ការអធិស្ឋានសម្រាប់ការប្រជុំ ] មួយ ព្យាការីបានមានប្រសាសន៍ប្រាប់ថា បើសិនជាយើងបន្ទាបខ្លួនយើងនៅចំពោះព្រះ ហើយអនុវត្តសេចក្តីជំនឿដ៏រឹងមាំ នោះយើងនឹងឃើញព្រះភក្ត្ររបស់ព្រះអម្ចាស់ ។ ប្រហែលជាពាក់កណ្តាលថ្ងៃត្រង់ ការនិមិត្តបានបើកសម្តែងនៅក្នុងគំនិតរបស់ខ្ញុំ ហើយខ្ញុំត្រូវបានបំភ្លឺដោយការយល់ដឹង ហើយខ្ញុំបានឃើញរូបរាងបុរសម្នាក់ គួរឲ្យស្ញើចសរសើរ ផ្ទៃមុខរបស់គាត់បានភ្លឺចែងចាំងដូចរស្មីព្រះអាទិត្យ ។. . . ទឹកមុខរបស់គាត់បានសម្លឹងមករកខ្ញុំ ដែលគួរឲ្យគោរពស្រឡាញ់បំផុត ។ ហើយកាលខ្ញុំកំពុងព្យាយាមមើលឲ្យស្គាល់តួអង្គទាំងស្រុងពីក្បាលរហូតដល់ចុងជើង នោះការនិមិត្តក៏បានឃ្លាតឆ្ងាយ ហើយបញ្ចប់ទៅ ។ ប៉ុន្តែ វាបានបន្សល់ទុកនៅក្នុងគំនិតរបស់ខ្ញុំនូវសេចក្តីស្រឡាញ់ ដែលអស់រយៈពេលជាយូរខែខ្ញុំមិនដែលទទួលបានអារម្មណ៍ដល់កម្រិតនោះឡើយ » ( យ៉ូហាន មើដក់ autobiography and diary, ១៣, L. Tom Perry Special Collections, Harold B. Lee Library, សាកលវិទ្យាល័យ ព្រិកហាំ ទីក្រុង ប្រូវ៉ូ រដ្ឋ យូថាហ៍ ) ។

១. សូមស្វែងរកតួអង្គយ៉ាងហោចណាស់ឲ្យបានបី នៅក្នុងព្រះគម្ពីរ ឬ នៅក្នុងជីវិតរបស់អ្នក ដែលបានលះបង់បម្រើព្រះអម្ចាស់ ។ សូមសរសេរឈ្មោះតួអង្គទាំងនោះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ សូមសរសេរអំពីពរជ័យអ្វីខ្លះ ដែលមនុស្សទាំងនេះបានទទួលដោយសារតែការលះបង់ និង ការបម្រើរបស់ពួកគេ ។

សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៩៩:៤–៥ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលថានឹងកើតឡើង ចំពោះអ្នកដែលបានបដិសេធសារលិខិតដែល យ៉ូហាន មើដក់ នឹងបង្រៀនពួកគេ ។

សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៩៩:៦–៨ ដោយស្វែងរកភស្តុតាង ដែលព្រះអម្ចាស់បានមានព្រះទ័យទុកដាក់ចំពោះសេចក្តីត្រូវការរបស់ យ៉ូហាន មើដក់ និង ការលះបង់ដែលគាត់បានធ្វើ ។

យ៉ូហាន មើដក់ បានធ្វើតាមឱវាទរបស់ព្រះអម្ចាស់ ហើយបានរៀបចំផ្ញើកូនច្បងទាំងបីនាក់របស់គាត់ទៅឲ្យប៊ីស្សព ប៉ាទ្រិច នៅរដ្ឋ មិសសួរី ដែលពួកគេបានស្នាក់នៅជាមួយគ្រួសារផ្សេងៗពីគ្នា ។ យ៉ូហាន បានចេញទៅបម្រើបេសកកម្មក្នុងខែ កញ្ញា ឆ្នាំ ១៨៣២ ប្រហែលមួយខែបន្ទាប់ពីគាត់បានទទួលការហៅបម្រើរបស់គាត់ ។ គាត់បានបម្រើបេសកកម្មបីបួនទៀត ហើយបានរស់នៅជួបជុំនឹងកូនច្បងទាំងបីរបស់គាត់នៅរដ្ឋ មិសសួរី ។ ពេញមួយជីវិតរបស់គាត់ពីពេលនោះមក យ៉ូហាន មើដក់ បានបម្រើព្រះអម្ចាស់យ៉ាងស្មោះត្រង់នៅក្នុងការហៅបម្រើជាអ្នកផ្សព្វផ្សាយសាសនា ប៊ីស្សព និង ជាលោកអយ្យកោ ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ១០០:១–១២

*ព្រះអម្ចាស់បានប្រទានដល់ យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន នូវព្រះបន្ទូលនៃការលួងលោមចិត្ត និង ការណែនាំ*

តើកង្វល់មួយចំនួន ដែលអ្នកផ្សព្វផ្សាយសាសនាអាចនឹងមាននៅពេលពួកគេចាប់ផ្តើមបេសកកម្មរបស់ខ្លួន មានអ្វីខ្លះ ? សូមរក្សាការណ៍ទាំងនេះទុកនៅក្នុងគំនិត នៅពេលសិក្សា គោលលទ្ធិ និង សេចក្តីសញ្ញា ១០០ ។

ក្នុងខែ មេសា ឆ្នាំ ១៨៣៣ បុរសម្នាក់ឈ្មោះ ហ្វ្រីមែន នីកឃើរសុន បានចូលសាសនាចក្រនៅរដ្ឋ នូវ យ៉ោក ហើយបានធ្វើដំណើរទៅកាន់ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ។ នៅពេល ហ្វ្រីមែន បានជួបនឹង យ៉ូសែប ស្ម៊ីធ គាត់បានសុំឲ្យព្យាការីទៅលេងក្រុមគ្រួសារ នីកឃើរសុន នៅរដ្ឋ នូវ យ៉ោក និង ប្រទេស កាណាដា ។ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានយល់ព្រមទៅនឹងសំណើរបស់គាត់ ហើយពួកលោកបានចាកចេញពីទីក្រុង ខឺតឡង់ ទៅជាមួយគាត់នៅថ្ងៃទី ៥ ខែ តុលា ឆ្នាំ ១៨៣៣ ។ ក្រុមនោះបានប្រកាសដំណឹងល្អ នៅតាមផ្លូវធ្វើដំណើរ ។ នៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៨៣៣ ពួកគាត់បានទៅដល់ផ្ទះរបស់ក្រុមគ្រួសារ នីកឃើរសុន នៅភូមិ ផើរីស្បឺក រដ្ឋ នូវ យ៉ោក ហើយ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០ ។

សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០ ដោយស្វែងរកអ្វីដែល យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានព្រួយបារម្ភ នៅពេលពួកលោកបានមកដល់រដ្ឋ នូវ យ៉ោក ។

នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានឆ្លើយតបនឹងការព្រួយបារម្ភរបស់ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន អំពីក្រុមគ្រួសាររបស់ពួកលោក ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:១–២ ដោយស្វែងរកថាតើព្រះអង្គសង្គ្រោះ បានឆ្លើយតបនឹងការព្រួយបារម្ភរបស់ពួកលោកយ៉ាងដូចម្ដេច ។ អ្នកអាចនឹងចង់គូសចំណាំឃ្លា ដែលអាចនឹងលួងលោមចិត្តដល់ យ៉ូសែប និង ស៊ីឌនី ។

២. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមពិពណ៌នាអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:១–២ ដែលអាចនឹងជួយពួកអ្នកផ្សព្វផ្សាយសាសនានាពេលបច្ចុប្បន្ននេះ ជាមួយនឹងកង្វល់របស់ពួកគេអំពីក្រុមគ្រួសារ ។

បន្ថែមលើការអះអាងដល់ពួកគេអំពីក្រុមគ្រួសារ ព្រះអម្ចាស់បានធានាដល់ យ៉ូសែប និង ស៊ីឌនី ថា ពួកលោកនឹងមានពរនៅក្នុងកិច្ចការផ្សព្វផ្សាយសាសនារបស់ពួកលោក ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:៣–៤ រួចស្វែងរកការអះអាងទាំងនេះមួយចំនួន ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:៥–៨ ដោយស្វែងរកការសន្យាបន្ថែមពីព្រះអម្ចាស់ ។

ខទី ៥–៦ មាននូវការសន្យាដែលប្រាប់ថា **បើយើងបន្លឺសំឡេងចែកចាយដំណឹងល្អ នោះព្រះអម្ចាស់នឹងជួយយើងឲ្យដឹងអំពីអ្វីដែលត្រូវថ្លែង ។** ( សូមចងចាំថា ដើម្បីទទួលបានជំនួយដែលបានសន្យា យើងត្រូវតែរស់នៅដោយសុចរិត និង ត្រៀមខ្លួនដើម្បីបម្រើ ) ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:៧ យើងរៀនថា ពួកអ្នកផ្សព្វផ្សាយសាសនាគួរតែប្រកាសដំណឹងល្អ « ដោយនូវចិត្តម៉ឺងម៉ាត់ ដោយនូវវិញ្ញាណស្លូតបូត » ។ ឱវាទនេះបញ្ជាក់ឲ្យឃើញថា យើងគួរតែចែកចាយដំណឹងល្អដោយប្រាកដប្រជា និង មានចិត្តរាបសា ។



បើយើងបន្លឺសំឡេងចែកចាយដំណឹងល្អ នោះព្រះអម្ចាស់នឹងជួយយើងឲ្យដឹងអំពីអ្វីដែលត្រូវថ្លែង ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:៨ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានសន្យា បើយើងប្រកាសដំណឹងល្អនៅតាមរបៀបនេះនោះ ។ សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ៖ **បើយើងចែកចាយដំណឹងល្អជាមួយ មនុស្សទូទៅដោយនូវចិត្តម៉ឺងម៉ាត់ និង ដោយនូវវិញ្ញាណស្លូតបូត នោះព្រះវិញ្ញាណបរិសុទ្ធនឹង** ។

៣. សូមគិតអំពីគ្រាមួយ ដែលអ្នកបានទទួលព្រះវិញ្ញាណបរិសុទ្ធបញ្ជាក់ថា អ្វីដែលអ្នកបង្រៀន ឬ ថ្លែងនោះ គឺជាការពិត ។ ការណ៍នេះអាចនឹងរួមបញ្ចូលទាំងការជជែកអំពីដំណឹងល្អជាមួយមិត្តភក្តិ ឬ ក្រុមគ្រួសាររបស់អ្នក ការថ្លែងទីបន្ទាល់ ឬ ផ្ដល់សុន្ទរកថានៅក្នុងការប្រជុំសាសនាចក្រ ឬ ផ្ដល់យោបល់នៅក្នុងថ្នាក់រៀន ។ សូមពិពណ៌នាអំពីបទពិសោធន៍របស់អ្នក ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ អ្នកក៏អាចពិពណ៌នាអំពីបទពិសោធន៍មួយ នៅពេលអ្នកទទួលបានអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធថ្លែងសាក្សីថា អ្វីដែលបុគ្គលណាម្នាក់បានថ្លែងនោះ គឺជាការពិត ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:៩–១២ ដោយស្វែងរកសេចក្ដីណែនាំ និង ការសន្យា ដែលព្រះអម្ចាស់បានប្រទានដល់ព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ។

៤. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការសន្យាដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:១២ អាចនឹងមានន័យយ៉ាងដូចម្ដេចចំពោះអ្នក បើអ្នកកំពុងបម្រើបេសកកម្មនោះ ?

កិច្ចការផ្សព្វផ្សាយសាសនារបស់ព្យាការី យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានមានអានុភាពលើសាសនាចក្រជាយូរអង្វែង ។ ស៊ីឌនី រិកដុន បានប្រកាសដំណឹងល្អទៅកាន់ក្រុមដ៏ធំមួយ ដែលបានមកជួបជុំគ្នានៅផ្ទះរបស់ក្រុមគ្រួសារ នីកឃើរសុន ក្រោយមក បងប្អូនប្រុសទាំងបីរូបនេះបានបន្តដំណើរទៅកាន់ភាគខាងជើងទៅដល់ទីក្រុង អនទែរីយ៉ូ ប្រទេស កាណាដា ជាទីតាំងដែលពួកលោកបានប្រកាសទៅកាន់ក្រុមដទៃៗទៀត ។ នៅទីនោះ ពួកអ្នកផ្សព្វផ្សាយសាសនាបានធ្វើពិធីបុណ្យជ្រមុជទឹកឲ្យមនុស្សជិត ២០ នាក់ ហើយបានបង្កើតសាខាមួយនៃសាសនាចក្រឡើង ។ មិនយូរប៉ុន្មានក្រោយមក ប៉ាលី ភី ប្រាត្ត បានទៅធ្វើដំណើរទៅកាន់សាខានេះ ពេលគាត់បម្រើបេសកកម្មនៅក្នុងប្រទេសកាណាដា ។ ម៉ូសេ នីកឃើរសុន ដែលជាអ្នកប្រែចិត្តជឿក្នុងបេសកកម្មឆ្នាំ ១៨៣៣ បានណែនាំអែលឌើរ ប្រាត្ត ឲ្យស្គាល់ យ៉ូហាន ថេល័រ ជាអ្នកដែលបានក្លាយជាអ្នកផ្សព្វផ្សាយសាសនាដ៏មានជោគជ័យ ហើយក្រោយមកបានក្លាយទៅជាប្រធាននៃសាសនាចក្រ ។ ព្រឹត្តិការណ៍នេះគឺជាផ្នែកមួយ នៃការបំពេញតាមការសន្យារបស់ព្រះអម្ចាស់ដែលថា « ទ្វារដ៏មានផលប្រយោជន៍ [ នឹង ] ត្រូវបានបើកចំហ នៅភូមិភាគជុំវិញនៅដែនដីនៃទិសខាងកើតនេះ » ( គ. និង ស. ១០០:៣ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:១៣–១៧

*ព្រះអម្ចាស់លួងលោមចិត្ត យ៉ូសែប និង ស៊ីឌនី អំពីការល្បងលនៃពួកបរិសុទ្ធនៅរដ្ឋ មិសសួរី*

ក្នុងខែ សីហា ឆ្នាំ ១៨៣៣ នៅមិនយូរប៉ុន្មានពីមុនព្យាការី យ៉ូសែប ស្ម៊ីធ បានចាកចេញទៅបម្រើបេសកកម្មនេះ អូលីវើរ ខៅឌើរី បានជូនដំណឹងពីរដ្ឋ មិសសួរី ថា ខ្មាំងសត្រូវរបស់សាសនាចក្របានប្រព្រឹត្តអំពើព្រៃផ្សៃទៅលើពួកបរិសុទ្ធនៅទីនោះ ។ យ៉ូសែប បានបញ្ជូន អូរសុន ហៃឌ និង យ៉ូហាន ហ្គូដ ដើម្បីនាំយកដំបូន្មានពីលោក ទៅឲ្យពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ។ ការធ្វើដំណើរនេះនឹងប្រកបដោយគ្រោះថ្នាក់ ព្រោះពួកគាត់នឹងធ្វើដំណើរឆ្លងកាត់តំបន់នានាក្បែរ ទីតាំងរបស់ក្រុមមនុស្សកំណាចដែលប្រឆាំងនឹងពួកមរមន ។ កាលកំពុងបម្រើបេសកកម្មជាមួយ ស៊ីឌនី រិកដុន និង ហ្វ្រីមែន នីកឃើរសុន ព្យាការីបានព្រួយបារម្ភអំពី អូរសុន និង យ៉ូហាន ព្រមទាំងពួកបរិសុទ្ធ ដែលកំពុងត្រូវបានធ្វើទុក្ខទោសនៅរដ្ឋ មិសសួរី ។

៥. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០០:១៣–១៧ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ព្យាការី យ៉ូសែប ស្ម៊ីធ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. យោងតាមអ្វី ដែលអ្នកបានរៀននៅក្នុង ខទី ១៥ សូមបញ្ចប់គោលការណ៍នេះ ៖ **គ្រប់ការណ៍ទាំងអស់នឹងបានផ្សំគ្នាសម្រាប់សេចក្ដីល្អ បើយើង . . .**

ខ. ដើម្បី « ដើរដោយទៀងត្រង់ » នៅចំពោះព្រះអម្ចាស់ សំដៅទៅលើការមានភាពសុចរិត និង ការរក្សាព្រះបញ្ញត្តិទាំងឡាយ ។ សូមគិតអំពីការណ៍ដ៏ជាក់លាក់នានា ដែលអ្នកអាចធ្វើនៅក្នុងជីវិតរបស់អ្នក ដើម្បី « ដើរដោយទៀងត្រង់ » នៅចំពោះព្រះអម្ចាស់ ។ សូមដាក់ ហើយសរសេរគោលដៅមួយ ដើម្បីប្រព្រឹត្តតាមការណ៍មួយក្នុងចំណោមការណ៍ដ៏ជាក់លាក់ទាំងនេះ ហើយអញ្ជើញឲ្យមានពរជ័យនេះកើតមាននៅក្នុងជីវិតរបស់អ្នកឲ្យបានកាន់តែច្រើន ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៩–១០០ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២១ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១–១៦

## បុព្វកថា

នៅថ្ងៃទី ១៦ និង ១៧ ខែ ធ្នូ ឆ្នាំ ១៨៣៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈអំពីទុក្ខវេទនាទាំងឡាយ ដែលពួកបរិសុទ្ធបានមាននៅរដ្ឋ មិសសួរី ។ វិវរណៈនេះ ដែលត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១ នឹងត្រូវបានបំបែកជាបីមេរៀន ។ មេរៀនទីមួយនេះ រួមបញ្ចូលការបេកស្រាយរបស់ព្រះអម្ចាស់អំពីមូលហេតុ ដែលទ្រង់ទុកឲ្យពួកបរិសុទ្ធរងទុក្ខវេទនា ។ វាក៏រួមបញ្ចូលទាំងព្រះបន្ទូលទ្រង់នៃឱវាទ និង ការលួងលោមចិត្តទៅដល់ពួកបរិសុទ្ធដែលរងទុក្ខដែរ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១–៨

*ព្រះអម្ចាស់បកស្រាយអំពីមូលហេតុ ដែលទ្រង់ទុកឲ្យរាស្ត្ររបស់ទ្រង់ត្រូវជួបនឹងការសាកល្បង*




**ចេញពីអ្វីដែលអ្នកបានរៀន អំឡុងពេលសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៨ សូមចង្អុលបង្ហាញអំពីសេចក្ដីលំបាកខាងក្រោមនេះ ដែលពួកបរិសុទ្ធមាននៅឃុំចាកសុន រដ្ឋ មិសសួរី ក្នុងខែ កក្កដា ឆ្នាំ ១៨៣៣ ។ អ្នកអាចយោងទៅមេរៀននៅថ្ងៃទី ១ ដើម្បីជួយអ្នកចងចាំ ។**

| | |
|---|---|
| | ការិយាល័យរោងពុម្ពរបស់ពួកបរិសុទ្ធត្រូវបានបំផ្លាញ ។ |
| | ផ្សាររបស់ ស៊ីឌនី គិលប៊ឺត ត្រូវបានកំទេចចោល ហើយឥវ៉ាន់នានា ត្រូវបានលួច ។ |
| | ផ្ទះសម្បែងជាច្រើនខ្នងរបស់ពួកបរិសុទ្ធ និង ដំណាំជាច្រើនត្រូវបានដុតបំផ្លាញចោល ។ |
| | ពួកបរិសុទ្ធពីរនាក់ អែតវឺត ប៉ាទ្រិច និង ឆាលស៍ អេលែន ត្រូវបានគេលាបកៅស៊ូ ហើយចាក់រោមសត្វលើខ្លួននៅទីសាធារណៈ ។ |

### *ការរៀនអំពីទីតាំងភូមិសាស្ត្រ*

ពត៌មានសាមញ្ញអំពីទីតាំងភូមិសាស្ត្រនៃដំណើររឿងក្នុងព្រះគម្ពីរ អាចជួយអ្នកឲ្យយល់កាន់តែច្បាស់ អំពីបរិបទ និង មាតិកានៃព្រះគម្ពីរបាន ។ ផែនទីអាចជួយអ្នកឲ្យយល់ អំពីទំនាក់ទំនងរវាងទីតាំងខុសៗគ្នា ។

ដោយសារតែអំពើព្រៃផ្សៃរបស់ក្រុមមនុស្សកំណាចនៅឃុំចាកសុន រដ្ឋ មិសសួរី ក្នុងខែ កក្កដា ឆ្នាំ ១៨៣៣ នោះថ្នាក់ដឹកនាំសាសនាចក្របានយល់ព្រមចាកចេញពីឃុំនោះ ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងខែ សីហា ឆ្នាំ ១៨៣៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានទូន្មានកុំឲ្យពួកបរិសុទ្ធលក់ដីធ្លីរបស់ខ្លួនឡើយ ។ ថ្នាក់ដឹកនាំសាសនាចក្របានដាក់ញត្តិទាមទារដល់រដ្ឋាភិបាល ហើយបានប្រើប្រាស់បណ្ដាញស្របច្បាប់ដែលមាន ដើម្បីរក្សាដីធ្លីរបស់ខ្លួននៅរដ្ឋ មិសសួរី ហើយស្វែងរកភាពយុត្តិធម៌ពីអ្នកដែលទទួលខុសត្រូវលើអំពើព្រៃផ្សៃទាំងនោះ ។ បន្ទាប់ពីបានដឹងអំពីសកម្មភាពនេះ ហើយដោយជឿថា ពួកបរិសុទ្ធពុំមានផែនការណ៍ចាកចេញដូចដែលបានរំពឹងទុកទេនោះ អ្នកតាំងលំនៅដែលមិនមែនជាពួកបរិសុទ្ធថ្ងៃចុងក្រោយបានវាយប្រហារលើពួកបរិសុទ្ធសាជាថ្មី ។ នាយប់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៨៣៣ មនុស្សកំណាចមួយក្រុមមានអ្នកជិះសេះប្រមាណ ៥០ នាក់ បានវាយលុកលំនៅដ្ឋានរបស់កុម្រគ្រួសារ វិតមើរ ដែលមានទីតាំងនៅភាគខាងលិចនៃទីក្រុង អ៊ីនឌីប៉ែនដែនស៍ ។ ពួកគេបានរុះរើផ្ទះចំនួន ១៣ ខ្នង ហើយបានវាយបុរសបួនប្រាំនឹងរំពាត់ ដែលស្ទើរតែសម្លាប់ពួកគេបង់ទៅហើយ ។ ការវាយប្រហារនេះបានបន្តដល់ពីរយប់បន្ទាប់ នៅទីក្រុង អ៊ីនឌីប៉ែនដែនស៍ និង ទីតាំងផ្សេងទៀតដែលពួកបរិសុទ្ធបានរស់នៅ ។ បុរស ៗត្រូវបានគេវាយ ចំណែកឯស្ត្រីៗ និង កុមារត្រូវគេធ្វើឲ្យភ័យតក់ស្លុត ។ ពួកបរិសុទ្ធជាង ១,០០០ នាក់ត្រូវបានជម្លៀសចេញពីផ្ទះសម្បែងរបស់ខ្លួននៅឃុំចាកសុន ។

តើអ្នកគិតថា មានសំណួរអ្វីដែលពួកបរិសុទ្ធនៅរដ្ឋ មិសសួរី អាចនឹងចោទសួរនៅគ្រានេះ ? តើអ្នកធ្លាប់ឆ្ងល់ដែរឬទេថា ហេតុអ្វីបានជាព្រះអម្ចាស់បណ្ដោយឲ្យការណ៍អាក្រក់ៗ កើតឡើងចំពោះអ្នក ឬ មនុស្សដែលអ្នកស្គាល់ ?

សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១ ដើម្បីរៀនអំពីគ្រាដែលវិវរណៈនេះត្រូវបានប្រទានឲ្យ និង ការសាកល្បងមួយចំនួនបន្ថែមទៀត ដែលពួកបរិសុទ្ធនៅរដ្ឋ មិសសួរី បានជួបប្រទះនៅគ្រានេះ ។

នៅពេលពួកបរិសុទ្ធនៅរដ្ឋ មិសសួរី បានរងទុក្ខការសាកល្បងទាំងនេះ ព្រះអម្ចាស់បានបើកសម្ដែងសេចក្ដីពិតអំពីមូលហេតុដែលទ្រង់ទុកឲ្យរាស្ត្ររបស់ទ្រង់រងទុក្ខលំបាកបែបនេះ ។ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១–២ ដោយស្វែងរកមូលហេតុ ដែលព្រះអម្ចាស់បានទុកឲ្យពួកបរិសុទ្ធនៅឃុំចាកសុនត្រូវរងសេចក្ដីបៀតបៀន និង ការរងទុក្ខ ។

ចេញពី ខទី ២ យើងរៀនថា **នៅពេលយើងល្មើសនឹងព្រះបញ្ញត្តិ នោះព្រះនឹងទុកឲ្យយើងរងទុក្ខ ។**

១. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថា ហេតុអ្វីបានជាមានសារៈសំខាន់ដែលត្រូវយល់អំពីសេចក្ដីពិតនេះ ?

ទោះជាពួកបរិសុទ្ធជាច្រើននៅរដ្ឋ មិសសួរី មានចិត្តស្មោះត្រង់ និង គោរពប្រតិបត្តិក្ដី ក៏ពួកគេនៅតែរងទុក្ខ ដោយសារតែសេចក្ដីបៀតបៀនដែរ ។ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៣–៥ ដោយស្វែងរកមូលហេតុ ដែលព្រះអម្ចាស់បានទុកឲ្យទាំងពួកបរិសុទ្ធដ៏សុចរិតនៅឃុំចាកសុនត្រូវរងទុក្ខ ។ សូមកត់ចំណាំថា ពាក្យ *សេចក្ដីវាយផ្ចាល* មានន័យថា ការលុតដំ ឬ កែតម្រូវ ពាក្យ *សាកល្បង* មានន័យថា ការពិសោធន៍ និង ពាក្យ *ញែកចេញជាបរិសុទ្ធ* មានន័យថា ធ្វើឲ្យនរណាម្នាក់ ឬ អ្វីមួយទៅជាបរិសុទ្ធ ឬ ពិសិដ្ឋ ។

យោងតាម ខទី ៥ សូមបញ្ចប់សេចក្ដីថ្លែងការណ៍នៃសេចក្ដីពិតដូចតទៅនេះ ៖ **បើយើងមិនទ្រាំទ្រនឹងសេចក្ដីវាយផ្ចាលទេនោះ យើងមិនអាច** ។



អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនអំពីរបៀបដែលការដែលត្រូវបានវាយផ្ចាល និង ល្បងល ជួយយើងឲ្យបានញែកចេញជាបរិសុទ្ធ ៖ « បន្ថែមពីលើការដាស់តឿនយើងឲ្យប្រែចិត្ត នោះបទពិសោធន៍ដ៏មានសារៈសំខាន់នៃការទ្រាំទ្រសេចក្ដីវាយផ្ចាល អាចជុសខាត់ហើយរៀបចំយើងឲ្យទទួលបានឯកសិទ្ធិដ៏មហិមាខាងវិញ្ញាណ » ( As Many as I Love, I Rebuke and Chasten," *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៩៨ ) ។



នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤ ព្រះអម្ចាស់បានយក អ័ប្រាហាំ ធ្វើជាគំរូនៃមនុស្ស ដែលត្រូវបានវាយផ្ចាល និង ពិសោធន៍ ។ នៅពេលព្រះអម្ចាស់បានត្រាស់បង្គាប់ អ័ប្រាហាំ ឲ្យថ្វាយកូនប្រុសរបស់លោក អ៊ីសាក ជាយញ្ញបូជា នោះ អ័ប្រាហាំ បានបញ្ជាក់ការស្មោះត្រង់ ហើយបានបង្ហាញថា លោកបានត្រៀមខ្លួនទទួលពរជ័យដ៏មហិមាខាងវិញ្ញាណ ( សូមមើល លោកុប្បត្តិ ២២:១–១៨ ) ។

២. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការយល់អំពីសេចក្ដីពិត ដែលមានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៥ អាចជួយអ្នកនៅអំឡុងគ្រាលំបាកយ៉ាងដូចម្ដេច ?

៣. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៦–៨ រួចស្វែងរកកត្តាជាក់លាក់ៗ ដែលពួកបរិសុទ្ធមួយចំនួននៅរដ្ឋ មិសសួរី បានធ្វើ ដែលបណ្ដាលឲ្យមានទុក្ខវេទនាធ្លាក់មកលើពួកគេ ។ រួចសូមឆ្លើយសំណួរខាងក្រោមនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ស្របតាម ខទី ៧ តើលទ្ធផលនៃ « ការកម្រស្ដាប់តាមសំឡេងនៃព្រះអម្ចាស់ » គឺជាអ្វី ?

ខ. ស្របតាម ខទី ៨ តើមនុស្សមួយចំនួនចាប់ផ្ដើមធ្វើអ្វី នៅអំឡុងគ្រានៃទុក្ខវេទនា ? តើអ្នកគិតថា « ខំរាវរក » ព្រះអម្ចាស់ មានន័យដូចម្ដេច ?

សូមគិតអំពីបទពិសោធន៍មួយ នៅពេលអ្នកត្រូវបានវាយផ្ចាល ហើយអ្នកបានស្វែងរកព្រះអម្ចាស់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៩–១៦

*ព្រះអម្ចាស់បានប្រទានឱវាទ និង ការលួងលោមចិត្តដល់ពួកបរិសុទ្ធ*

នៅពេលអ្នកអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៩ សូមស្វែងរកសារលិខិតនៃសេចក្ដីសង្ឃឹម ដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធ ដែលរងទុក្ខនៅរដ្ឋ មិសសួរី ។ អ្នកអាចនឹងចង់គូសចំណាំពាក្យ ឬ ឃ្លា ដែលបង្រៀនគោលការណ៍ដូចតទៅនេះ ៖ **ទោះជានៅពេលយើងបានប្រព្រឹត្តបាប ព្រះអម្ចាស់ក៏នឹងមានសេចក្ដីមេត្តាករុណាចំពោះយើងដែរ ។**

៥. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការយល់ដឹងអំពីគោលលទ្ធិនេះ អាចនាំឲ្យអ្នកមានសេចក្ដីសង្ឃឹមយ៉ាងដូចម្ដេច ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១០–១១ យើងរៀនថា ទោះជាព្រះអម្ចាស់បានទុកឲ្យពួកបរិសុទ្ធរងសេចក្ដីបៀតបៀនក្ដី ក៏ទ្រង់បានមានព្រះបន្ទូលថា ទ្រង់នឹងដាក់ទោសមនុស្សដែលបៀតបៀនពួកគេដែរ ។



នៅពេលអ្នកអានកថាខណ្ឌខាងក្រោមនេះ សូមគូសចំណាំការបកស្រាយនៃការរងទុក្ខ ដែលអាចនឹងជាការលំបាកចំពោះអ្នក ក្នុងការមើលឃើញទិដ្ឋភាពនោះ ឬ ទទួលបទពិសោធន៍ ៖

ក្រុមមនុស្សកំណាចនៅឃុំចាកសុន រដ្ឋ មិសសួរី បានបន្តធ្វើបាបពួកបរិសុទ្ធ រហូតដល់សមាជិកទាំងអស់នៃសាសនាចក្រត្រូវបានជម្លៀសចេញពីឃុំនោះ ។ ឡាយមិន វ៉ាយ បានរាយការថា « ខ្ញុំបានឃើញស្ត្រី និង កុមារចំនួនមួយរយកៅសិបនាក់ ធ្វើដំណើរចម្ងាយ សែសិបប្រាំបីគីឡូម៉ែត្រ កាត់តាមទីវាល ដោយមានតែបុរសចាស់ជរាបីនាក់ប៉ុណ្ណោះក្នុងចំណោមពួកគេ ក្នុងខែ វិច្ឆិកា ផ្ទៃដីមានពាសពេញទៅដោយទឹកកក ហើយខ្ញុំអាចដើរតាមដានជើងរបស់ពួកគេដែលមាន *ឈាមហូរហាមចេញពីប្រអប់ជើងដាច់រហែក* ដោយគល់ជ្រាំងស្មៅ ! » ( នៅក្នុង *History of the Church* ៣:៤៣៩ ) ។

ពួកបរិសុទ្ធជាច្រើនបានភៀសខ្លួនទៅភាគខាងជើង ជាទីតាំងដែលពួកគេត្រូវឆ្លងកាត់ទន្លេ មិសសួរី ។ ច្រាំងទន្លេទាំងសងខាងក្បែរកំពង់ដរ បានពេញទៅដោយត្រសាលជំរុំ ។ ពួកបរិសុទ្ធមួយចំនួនមានសំណាង ដែលបានភៀសខ្លួនដោយនាំយកទ្រព្យសម្បត្តិក្នុងផ្ទះមកជាមួយ ប៉ុន្តែ ពួកបរិសុទ្ធជាច្រើនបានបាត់បង់អ្វីគ្រប់យ៉ាង ។ ប៉ាលី ភី ប្រាត្ត បានសរសេរ ៖ « ខ្ញុំបានឃើញមានមនុស្សរាប់រយនាក់នៅគ្រប់ទីកន្លែង ខ្លះជ្រកនៅក្នុងត្រសាល ហើយខ្លះនៅកណ្ដាលវាលអង្គុយជុំវិញភ្នក់ភ្លើង កាលមេឃកំពុងភ្លៀង ។ ស្វាមីជាច្រើនកំពុងមើលថែដល់ភរិយាខ្លួន ភរិយាជាច្រើនកំពុងមើលថែស្វាមីខ្លួន ឪពុកម្ដាយជាច្រើនកំពុងមើលថែកូនៗខ្លួន និង កូនៗជាច្រើនកំពុងមើលថែឪពុកម្ដាយខ្លួន ។. . . ទិដ្ឋភាពនេះគឺគួរឲ្យខ្លោចផ្សាបំផុត ខ្ញុំប្រាកដណាស់ថា ការណ៍នេះបានធ្វើឲ្យមនុស្សនៅលើផែនដីមានចិត្តអាណិតអាសូរ លើកលែងតែជនគៀបសង្កត់ដ៏ងងឹតងងល់ និង ក្រុមមនុស្សដែលល្ងង់ខ្លៅ និង អវិជ្ជាប៉ុណ្ណោះ » (*Autobiography of Parley P. Pratt,* ការបោះពុម្ពនៃ ប៉ាលី ភី ប្រាត្ត ជុញ្ញ័រ [ ឆ្នាំ ១៩៣៨ ] ទំព័រ ១០២ ) ។

តើអ្នកគិតថា អ្នកអាចនឹងធ្វើដូចម្ដេច បើអ្នកជួបប្រទះនឹងទុក្ខវេទនាប្រភេទទាំងនេះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១២–១៦ ដោយស្វែងរកការសន្យាពីព្រះអម្ចាស់ទៅកាន់ពួកបរិសុទ្ធដែលសុចរិត ។ ( វាអាចនឹងជួយអ្នក ក្នុងការដឹងថា នៅក្នុង ខទី ១២ ឃ្លា « អស់ទាំងពួកសាសន៍អ៊ីស្រាអែលរបស់យើង » សំដៅទៅលើអ្នកដែលស្មោះត្រង់ ចំពោះសេចក្ដីសញ្ញានៃដំណឹងល្អ ) ។

អ្នកអាចនឹងចង់សរសេរ គោលការណ៍ដូចតទៅនេះដាក់នៅក្នុងព្រះគម្ពីររបស់អ្នកក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១៦ ៖ **នៅពេលយើងរស់នៅដោយសុចរិត នោះយើងអាចរកឃើញការលួងលោមចិត្តនៅក្នុងការចេះដឹងមួយថា មនុស្សទាំងអស់ស្ថិតនៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ។**

៥. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរខាងក្រោមនេះដោយយោងតាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក ឬ អ្នកអាចពិភាក្សាអំពីសំណួរទាំងនេះ ជាមួយសមាជិកគ្រួសារ ឬ មិត្តភក្តិ រួចសរសេរអ្វីដែលអ្នករៀនចេញពីការសន្ទនានោះ ៖

   ក. នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១៦ តើអ្នកគិតថា « ចូរបង្អង់សិន ឲ្យបានដឹងថា យើងជាព្រះ » មានន័យដូចម្ដេច ?

   ខ. តើអ្នកធ្លាប់មានពរដោយនូវសេចក្ដីសុខសាន្ត អំឡុងពេលគ្រាលំបាកយ៉ាងដូចម្ដេច ?

   គ. តើការនៅបង្អង់ ឬ មិនមានភាពឆោឡោ អាចជួយអ្នកឲ្យទទួលបានការលួងលោមចិត្តពីព្រះអម្ចាស់យ៉ាងដូចម្ដេច ?

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

   *ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១–១៦ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

   *សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២១ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១៧–៤២

## សេចក្ដីផ្ដើម

នៅថ្ងៃទី ១៦ និង ១៧ ខែ ធ្នូ ឆ្នាំ ១៨៣៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈអំពីពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ដែលបានចាកចេញពីផ្ទះសម្បែងរបស់ខ្លួន ដើម្បីគៀសខ្លួនចេញពីសេចក្ដីបៀតបៀន ។ ពួកបរិសុទ្ធជាច្រើនត្រូវបានបង្ខំ ឲ្យទុកចោលទ្រព្យសម្បត្តិរបស់ខ្លួន ។ វិវរណៈដែលព្យាការីបានទទួល ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១ ត្រូវបានបំបែកជាបីមេរៀន ។ មេរៀនទីពីរនេះ រួមបញ្ចូលទាំងការបកស្រាយរបស់ព្រះអម្ចាស់ អំពីស្ថានភាពអំឡុងពេលសហស្សវត្សរ៍ ។ វាក៏រួមបញ្ចូលទាំងព្រះបន្ទូលនៃការលួងលោមចិត្ត និង ឱវាទ ទៅដល់ពួកបរិសុទ្ធផងដែរ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១៧–៣៤

*ព្រះអម្ចាស់ពិពណ៌នាអំពី ស្ថានភាពអំឡុងពេលសហស្សវត្សរ៍*

សូមគិតអំពីព្រឹត្តិការណ៍មួយចំនួននាពេលអនាគត ដែលអ្នករៀបចំខ្លួនចូលរួម ។ ហេតុអ្វីបានជាអ្នកខិតខំ ដើម្បីរៀបចំខ្លួនចូលរួមក្នុងព្រឹត្តិការណ៍ទាំងនោះ ?

គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១ មាននូវការបង្រៀនស្ដីពី ការរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ និង សម្រាប់សហស្សវត្សរ៍ ( រយៈពេលនៃសេចក្ដីសុខសាន្ត ដែលនឹងចាប់ផ្ដើម នៅពេលព្រះគ្រីស្ទយាងត្រឡប់មកសោយរាជ្យដោយអង្គទ្រង់ផ្ទាល់ នៅលើផែនដី ) ។ ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១៧–២១ យើងរៀនថា ការសន្យារបស់ព្រះអម្ចាស់ថានឹងប្រមូលពួកបរិសុទ្ធនៅទីក្រុង ស៊ីយ៉ូន ក្នុងឃុំចាកសុន រដ្ឋ មិសសួរី នោះ « ត្រូវបានពន្យាពេល [ ផ្អាកបណ្ដោះអាសន្ន ] ព្រោះមនុស្សកំពុងត្រូវបានញែកចេញជាបរិសុទ្ធ ដើម្បីទទួលបានអំណោយ និង ការទទួលខុសត្រូវដែលមានមកជាមួយអំណោយនោះ ។ នៅចន្លោះពេលនោះ ពួកអ្នកមានចិត្តទៀងត្រង់បានប្រមូលគ្នានៅច្រកភ្នំរ៉កគី [ និង នៅស្ដេកទូទាំងពិភពលោក ] ។. . . ព្រះវិហារបរិសុទ្ធត្រូវបានកសាងឡើង ។. . . ប៉ុន្តែទីក្រុង ស៊ីយ៉ូន នឹងត្រូវបានស្ថាបនាឡើងនៅទីតាំងដែលបានជ្រើសរើស » ( ជេម អ៊ី ថាល់មេហ្គ *មាត្រានៃសេចក្ដីជំនឿ* ការបោះពុម្ពលើក ១២ [ ឆ្នាំ ១៩២៤ ] ទំព័រ ៣៥៣ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:២២–២៣ ដោយស្វែងរកការណ៍ ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ពួកបរិសុទ្ធឲ្យធ្វើ ដើម្បីរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ។ ( នៅក្នុង ខទី ២៣ ឃ្លា « វិវរណៈដែលនឹងមកដល់ » សំដៅទៅលើការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ ។ សេចក្ដីយោងចំពោះពាក្យ វាំងននត្រូវបានបើកឡើង ក៏ទាក់ទងទៅនឹងការយាងមកជាលើកទីពីរដែរ—គឺនៅពេលដែលប្រជាជនទាំងអស់នៅលើផែនដី នឹងឃើញព្រះអង្គសង្គ្រោះ ) ។

សូមបញ្ចប់សេចក្ដីថ្លែងការណ៍ដូចតទៅនេះ ដោយយោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:២២–២៣ ៖ យើងអាចរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះដោយ ដល់ព្រះនាមទ្រង់ ដោយរស់នៅតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ នោះត្រូវប្រមូលគ្នា ហើយ នៅទីបរិសុទ្ធនានា ។



១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកមានអារម្មណ៍ថា អ្នកឈរនៅក្នុងទីបរិសុទ្ធ នៅពេលណាខ្លះ ?

ខ. តើការប្រមូលគ្នានៅទីបរិសុទ្ធនានា ជាមួយនឹងពួកបរិសុទ្ធដទៃទៀត ជួយអ្នកឲ្យរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?

គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:២៤–៣៤ សំដៅទៅលើការបំផ្លាញបង់នៃពួកទុច្ចរិត នៅគ្រានៃការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ និង ទៅលើស្ថានភាពដែលនឹងកើតឡើងនៅលើផែនដីអំឡុងពេលសហស្សវត្សរ៍ ។ ឧទាហរណ៍ នៅក្នុង ខទី ៣២–៣៤ យើងអានថា ព្រះអម្ចាស់នឹងបើកសម្ដែងគ្រប់ទាំងអស់អំពីផែនដីមានដូចជាការបង្កបង្កើតរបស់វា ព្រមទាំងអំពីស្ថានសួគ៌ដែរ ។ ( ពាក្យ *សេចក្ដីខ្មាំង* នៅក្នុង ខទី ២៦ សំដៅទៅលើសម្អប់ និង ការទាស់ទែងគ្នា ) ។

២. សូមរាយបញ្ជីនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីស្ថានភាពចំនួនពីរ ឬ បី នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:២៤–៣៤ ដែលអ្នកនឹងរង់ចាំជាពិសេស ដើម្បីឲ្យស្ថានភាពទាំងនោះកើតឡើង ។ សូមពន្យល់អំពីមូលហេតុ ដែលស្ថានភាពទាំងនេះមានអត្ថន័យចំពោះអ្នក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៣៥–៣៨

*ព្រះអម្ចាស់មានបន្ទូលអះអាងដល់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ថា បើពួកគេកាន់ខ្ជាប់នៅក្នុងសេចក្ដីជំនឿ នោះពួកគេនឹងទទួលបានសិរីល្អរបស់ទ្រង់នៅចុងបំផុត ។*

នៅពេលព្រះអម្ចាស់បានប្រទានវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:២៤–៣៤ ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី បានជួបប្រទះនឹងការលំបាកធំៗ រួមមានការរំលោភបំពានខាងរូបកាយ ការបាត់បង់ផ្ទះសម្បែង និង ទ្រព្យសម្បត្តិនានា ថែមទាំងអាកាសធាតុត្រជាក់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៣៥–៣៨ រួចស្វែងរកគោលការណ៍ និង ឱវាទដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ដើម្បីលួងលោមចិត្ត ហើយចម្រើនកម្លាំងពួកគេនៅក្នុងការល្បងលនេះ ។

៣. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរចំណុចមួយចេញពីឱវាទ ដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធនៅក្នុង ខទី ៣៥–៣៨ ។ បន្ទាប់មក សូមពន្យល់អំពីរបៀបដែលឱវាទនេះ អាចនឹងលួងលោមចិត្តដល់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ។

សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ដោយផ្អែកទៅលើអ្វីដែលអ្នកស្វែងយល់ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៣៥ ៖ **អស់អ្នកណាដែល ដោយព្រោះព្រះនាមនៃព្រះអង្គសង្គ្រោះ ហើយ គង់តែនឹងបានទទួលសិរីល្អរបស់ព្រះ ។**

សិស្សដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទ តែងតែធ្វើតាមទ្រង់ ទោះជានៅពេលពួកគេត្រូវគេបៀតបៀនដោយព្រោះតែសេចក្ដីជំនឿរបស់ខ្លួនយ៉ាងណាក្ដី ។ ប្រធាន ជេម អ៊ី ហ្វោស្ដ ក្នុងគណៈប្រធានទីមួយ បានចែកចាយដំណើររឿងខាងក្រោមនេះ អំពីពួកបរិសុទ្ធថ្ងៃចុងក្រោយពីរនាក់ ដែលបានរស់នៅប្រទេស ម៉ិកស៊ិក នៅដើមសតវត្សទី ១៩ ។ ក្នុងឆ្នាំ ១៩១៥ ពួកគេត្រូវបានចាប់ខ្លួនដោយពួកទាហានដ៏ឃោរឃៅមួយក្រុម ។ នៅពេលអ្នកអានដំណើររឿងនេះ សូមកត់ចំណាំអំពីរបៀបដែលពួកបរិសុទ្ធថ្ងៃចុងក្រោយទាំងពីរនាក់នេះ បានធ្វើជាគំរូនៃការទ្រាំទ្រនៅក្នុងសេចក្ដីបៀតបៀន ដោយមានសេចក្ដីជំនឿ ។



« រ៉ាហ្វាអែល ម៉ុនរ៉យ គឺជាប្រធានសាខានៃសាខាតូចមួយនៅទីក្រុង សាន់ ម៉ាកុស ប្រទេស ម៉ិកស៊ិក និង វីសិនទែ ម៉ូរ៉ាឡែស គឺជាទីប្រឹក្សាទីមួយរបស់គាត់ ។. . . គេបានប្រាប់ពួកគាត់ថា ពួកគាត់នឹងរួចជីវិតបើពួកគាត់ទម្លាក់អាវុធចុះ ហើយលះបង់សាសនាដ៏ចម្លែករបស់ពួកគេចោល ។ បងប្រុស ម៉ុនរ៉យ បានប្រាប់អ្នកចាប់ខ្លួនគាត់ថា គាត់ពុំមានអាវុធណាមួយឡើយ ហើយបានដកយកព្រះគម្ពីរមរមនចេញពីហោប៉ៅរបស់គាត់ដោយធម្មតា ។ គាត់បានស្រដីថា ‹ លោក អាវុធតែមួយគត់ ដែលខ្ញុំមាន វាគឺជាអាវុធនៃសេចក្ដីពិតដែលប្រឆាំងនឹងភាពខុសឆ្គងទាំងឡាយ › ។

« នៅពេលគេពុំឃើញមានអាវុធទេ នោះបងប្អូនប្រុសទាំងពីរនាក់នេះ ត្រូវបានគេវាយធ្វើបាបយ៉ាងឃោរឃៅ ដើម្បីឲ្យពួកគាត់ប្រាប់ពីកន្លែងដែលអាវុធត្រូវបានលាក់ទុក ។ ប៉ុន្តែ ពុំមានអាវុធដែលត្រូវបានលាក់ទុកឡើយ ។ ក្រោយមកពួកគាត់ត្រូវបានគេនាំយកទៅឃុំឃាំងនៅជាយក្រុង ជាកន្លែងដែលអ្នកចាប់ខ្លួនពួកគាត់ ចាប់ចងផ្ដោបពួកគាត់ទៅនឹងដើមឈើធំមួយ ដើម្បីធ្វើការប្រហារជីវិតនៅមុខពួកទាហាន ។ នាយទាហាននោះទទួលបន្ទុកដោះលែងពួកគាត់ បើពួកគាត់លះបង់ចោលសាសនារបស់ខ្លួន ហើយចូលរួមជាមួយ [ កងទាហាន ] ប៉ុន្តែ បងប្រុស ម៉ុនរ៉យ បានវាចាតបថា ‹ ខ្ញុំស្រឡាញ់សាសនារបស់ខ្ញុំជាងជីវិតរបស់ខ្ញុំទៅទៀត ហើយខ្ញុំមិនអាចលះបង់វាចោលបានឡើយ › ។

« លំដាប់នោះ គេបានប្រាប់ពួកគាត់ថា ពួកគាត់នឹងត្រូវគេបាញ់ប្រហារជីវិត ហើយបានសួរថាតើពួកគាត់មានសំណើអ្វីដែរឬទេ ។ បងប្រុស រ៉ាហ្វាអែល បានស្នើសុំឲ្យគាត់អាចអធិស្ឋាន ពីមុនគាត់ត្រូវបានប្រហារជីវិត ។ គាត់បានលុតជង្គង់ចុះនៅទីនោះ ក្នុងចំណោមពួកអ្នកប្រហារជីវិត អធិស្ឋានដោយបញ្ចេញសំឡេងឮៗ សូមឲ្យព្រះប្រទានពរ ហើយថែរក្សាមនុស្សដ៏ជាទីស្រឡាញ់ទាំងឡាយរបស់គាត់ ថែមទាំងថែរក្សាសាខាដ៏តូចដែលកំពុងពុះពារ ដែលនឹងត្រូវបាត់បង់អ្នកដឹកនាំនោះ ។ នៅពេលគាត់បានបញ្ចប់ការអធិស្ឋាន គាត់បានថ្លែងចេញព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ កាលទ្រង់ត្រូវបានដំដែកគោលភ្ជាប់លើឈើឆ្កាង ហើយបានអធិស្ឋានសម្រាប់ពួកអ្នកប្រហារជីវិតទ្រង់ ៖ ‹ ឱព្រះវរបិតាអើយ សូមអត់ទោសដល់អ្នកទាំងនេះផង ដ្បិតគេមិនដឹងជាគេធ្វើអ្វីទេ › ។ [លូកា ២៣:៣៤] ។ ក្រុមពេជ្ឈឃាដបានបាញ់សម្លាប់បងប្រុស ម៉ុនរ៉យ និង បងប្រុស ម៉ូរ៉ាល (Discipleship » *Ensign* ឬ *លីអាហូណា*,ខែ វិច្ឆិកា ឆ្នាំ ២០០៦,ទំព័រ ២១–២២; យោងតាម Rey L. Pratt, « A Latter–day Martyr » *Improvement Era,* ខែ មិថុនា ឆ្នាំ ១៩១៨,ទំព័រ ៧២០–២៦ ) ។

សូមគិតអំពីគ្រាដែលអ្នកត្រូវបានគេបៀតបៀន ( ឆាឆៅ ឬ ធ្វើបាប ) ដោយសារតែសេចក្ដីជំនឿរបស់អ្នកមានទៅលើព្រះយេស៊ូវគ្រីស្ទ និង លើសាសនាចក្ររបស់ទ្រង់ ។

៤. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ នៅពេលមនុស្សត្រូវបានគេបៀតបៀនដោយសារតែសេចក្ដីជំនឿរបស់ខ្លួនទៅលើព្រះយេស៊ូវគ្រីស្ទ និង លើសាសនាចក្ររបស់ទ្រង់ តើពួកគេអាចឆ្លើយតបដោយប្រើសេចក្ដីជំនឿយ៉ាងដូចម្ដេច ?



សូមគិតអំពីអត្ថប្រយោជន៍មួយចំនួន នៃអំបិល ។ ឧទាហរណ៍ វាអាចត្រូវបានប្រើប្រាស់ដើម្បីផ្ដល់ឱជារស និង រក្សាម្ហូបអាហារ និង ដើម្បីព្យាបាលរបួសជាសារធាតុរម្ងាប់មេរោគ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៣៩ ដោយស្វែងរកមនុស្ស ដែលព្រះអម្ចាស់បានប្រដូចទៅនឹងអំបិល ។

សូមពិចារណាអំពីមូលហេតុ ដែលមនុស្សដែលបានមករកដំណឹងល្អ ហើយធ្វើសេចក្ដីសញ្ញាជាមួយព្រះអម្ចាស់ អាចត្រូវបានហៅថា « អំបិលនៃផែនដី » ។

សូមកត់ចំណាំនៅក្នុង ខទី ៣៩ ថា ព្រះអម្ចាស់ក៏បានហៅសមាជិកសាសនាចក្រថា « ជាតិប្រៃនៃមនុស្ស » ដែរ ។ ពាក្យ *ជាតិប្រៃ* សំដៅទៅលើឱជារស ឬ គុណភាពខុសប្លែកពីគេ ។ តើអ្នកគិតថា ការធ្វើជាជាតិប្រៃនៃមនុស្ស មានន័យដូចម្ដេច ?



សេចក្ដីថ្លែងការណ៍ដូចតទៅនេះដោយ អែលឌើរ ខាឡូស អ៊ី អេសេយ នៃពួកចិតសិបនាក់ អាចជួយអ្នកឲ្យយល់កាន់តែច្បាស់ អំពីអត្ថន័យនៃជាតិប្រៃនៃមនុស្ស ៖ « នៅពេលព្រះអម្ចាស់បានប្រើពាក្យសព្ទ ‹ ជាតិប្រៃនៃមនុស្ស › គឺទ្រង់មានព្រះបន្ទូល អំពីអ្នកទាំងឡាយដែលតំណាងឲ្យទ្រង់ ។ ទ្រង់សំដៅទៅលើអ្នកទាំងឡាយ ដែលបានប្រែចិត្ត ដែលបានសម្អាតឲ្យជ្រះស្អាតនៅក្នុងទឹកនៃពិធីបុណ្យជ្រមុជ និងអ្នកទាំងឡាយដែលបានធ្វើសេចក្ដីសញ្ញា ដើម្បីលើកដាក់លើខ្លួនពួកគេនូវព្រះនាម និង ព្រះឆន្ទៈទ្រង់ ។ មួយវិញទៀត ទ្រង់មានព្រះបន្ទូលអំពីអ្នកទាំងឡាយ ដែលរួមចំណែកក្នុងអំណាចបព្វជិតភាពរបស់ខ្លួន តាមរយៈសេចក្ដីសញ្ញា ។ ទ្រង់មានបន្ទូលពីអ្នក និងខ្ញុំ » ( Salt of the Earth: Savor of Men and Saviors of Men » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៨០ ទំព័រ ៤២ ) ។

ឃ្លា « អំបិលនៃផែនដី » និង « ជាតិប្រៃនៃមនុស្ស » បង្រៀនថា ក្នុងនាមជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ យើងមានការទទួលខុសត្រូវដើម្បីជួយមនុស្សទាំងអស់ នៅលើផែនដីឲ្យទទួលបានពរជ័យពីព្រះ ( សូមមើល អ័ប្រាហាំ ២:៨–១១ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤០–៤២ ដោយស្វែងរកការព្រមាន និង ការសន្យារបស់ព្រះអម្ចាស់ ។



សូមកត់ចំណាំថា ខទី ៤០ មានចែងឃ្លា « បើសិនជាអំបិលនៃផែនដីបាត់ជាតិប្រៃហើយ » ។ អំបិលពុំបាត់ជាតិប្រៃឡើយ នៅពេលវាកាន់តែចាស់នោះ ។ វាបាត់បង់រសជាតិរបស់វា នៅពេល វាត្រូវបានលាយជាមួយសារធាតុដទៃទៀត ហើយត្រូវបានរំលាយដោយសារធាតុនោះ ។ អែលឌើរ អេសេយ បានបង្រៀនថា ៖ « ឱជារស និង គុណភាព បាត់បង់ពីមនុស្សទៅនៅពេលពួកគេធ្វើឲ្យគំនិតទៅជាកខ្វក់ដោយ ការគិតមិនបរិសុទ្ធ បន្ទាបការនិយាយស្ដីរបស់ខ្លួនដោយថ្លែងចេញនូវពាក្យមិនសុវពិត ហើយប្រើប្រាស់កម្លាំងខ្លួនទៅប្រព្រឹត្តអំពើអាក្រក់ » ( « Salt of the Earth » ទំព័រ ៤២ ) ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤០–៤២ ជួយយើងឲ្យរៀនថា **ដើម្បីជួយមនុស្សទាំងអស់ នៅលើផែនដីឲ្យទទួលបានពរជ័យពីព្រះ យើងត្រូវតែប្រែចិត្តពីអំពើបាបរបស់យើង ហើយបន្ទាបខ្លួន ។** អ្នកអាចនឹងចង់សរសេរសេចក្ដីពិតនេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការបង្រៀនរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៣៩–៤២ ជួយអ្នកយល់អំពីអ្វីដែលទ្រង់មានព្រះទ័យរំពឹងពីអ្នកយ៉ាងដូចម្ដេច ?

ខ. តើគំរូមួយចំនួននៃរបៀបដែលអំពើបាប អាចរារាំងយើងពីការធ្វើឲ្យមនុស្សនៅលើផែនដីមានពរនោះ មានអ្វីខ្លះ ?

គ. តើអ្នកនឹងធ្វើអ្វី ដើម្បីចៀសវាងពីការរំខានដោយអំពើបាប ?

សូមគិតថាតើ អំពើបាបកំពុងរំខានដល់ជីវិតរបស់អ្នកដែរឬទេ ។ សូមប្រែចិត្តពីអំពើបាបទាំងនោះ ដើម្បីអ្នកអាចបានបរិសុទ្ធនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ហើយដើម្បីអ្នកអាចមានអានុភាពកាន់តែខ្លាំងក្លាក្នុងការជួយដល់មនុស្សទូទៅឲ្យទទួលបានពរជ័យ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:១៧–៤២ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២២ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–១០១; ១០២

## បុព្វកថា

នៅថ្ងៃទី ១៦ និង ១៧ ខែ ធ្នូ ឆ្នាំ ១៨៣៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈអំពីពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ដែលបានចាកចេញពីផ្ទះសម្បែងរបស់ខ្លួនដើម្បីភៀសខ្លួនចេញពីសេចក្ដីបៀតបៀន ។ ពួកបរិសុទ្ធជាច្រើនត្រូវបានបង្ខំ ឲ្យទុកចោលទ្រព្យសម្បត្តិរបស់ខ្លួន ។ វិវរណៈដែលព្យាការីបានទទួល ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១ ត្រូវបានបំបែកជាបីមេរៀន ។ មេរៀនទីបីនេះ រួមបញ្ចូលការប្រដូចរបស់ព្រះអម្ចាស់អំពី បុរសត្រកូលខ្ពស់ និង ដើមអូលីវ ដែលជាការបង្រៀនអំពីព្រះឆន្ទៈទ្រង់អំពីការប្រោសលោះទីក្រុង ស៊ីយ៉ូន ។ វាក៏រួមបញ្ចូលទាំងឱវាទរបស់ព្រះអម្ចាស់ ដែលបានប្រាប់ឲ្យពួកបរិសុទ្ធបន្តប្រមូលគ្នា ហើយស្វែងរកយុត្តិធម៌ឲ្យអ្នកទាំងឡាយទទួលរងឧក្រិដ្ឋកម្មដែរ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–៦២

*ព្រះអម្ចាស់បានប្រទានរឿងប្រដូច អំពីបុរសត្រកូលខ្ពស់ និង ដើមអូលីវ*

រឿងប្រដូចគឺជា « រឿងសាមញ្ញដែលត្រូវបានប្រើប្រាស់ដើម្បីបង្ហាញ និង បង្រៀនអំពីសេចក្ដីពិតខាងវិញ្ញាណ ឬ គោលការណ៍ ។ រឿងប្រដូចយោងទៅលើការប្រៀបធៀបវត្ថុបំណងធម្មតា ឬ ព្រឹត្តិការណ៍មួយ ទៅនឹងសេចក្ដីពិត » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ រឿងប្រៀបប្រដូច » scriptures.lds.org) ។ អ្នកប្រហែលជាចងចាំរឿងប្រដូចទាំងឡាយដែលព្រះអង្គសង្គ្រោះបានបង្រៀនអំឡុងការបម្រើរបស់ទ្រង់ក្នុងជីវិតរមែងស្លាប់—ជារឿងប្រដូចអំពីសាសន៍សាម៉ារីដ៏សប្បុរស រឿងប្រដូចអំពីកូនប្រុសខ្ជះខ្ជាយ រឿងប្រដូចអំពីស្ត្រីព្រហ្មចារីទាំងដប់នាក់ និង រឿងប្រដូចផ្សេងៗទៀត ។

នៅក្នុងមេរៀននៅថ្ងៃនេះ អ្នកនឹងសិក្សារឿងប្រដូចអំពីបុរសត្រកូលខ្ពស់ និង ដើមអូលីវ ជារឿងប្រដូចដែលព្រះអង្គសង្គ្រោះបានប្រទានតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ។



នៅពេលអ្នកសិក្សារឿងប្រដូចនេះ សូមពិចារណាអំពីសេចក្ដីថ្លែងការណ៍ដូចតទៅនេះដោយ អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖ « រឿងប្រដូចទាំងឡាយ [ របស់ព្រះអង្គសង្គ្រោះ ] ស្តែងចេញក្នុងអត្ថន័យជាច្រើន ឬ ការអនុវត្តន៍នានា ដែលស្របទៅតាមភាពចាស់ទុំខាងវិញ្ញាណរបស់អ្នកស្ដាប់ ។ រឿងប្រដូចទាំងឡាយមាននូវសារលិខិតសម្រាប់កុមារផង និង អ្នកមានវិជ្ជាជ្រៅជ្រះខាងដំណឹងល្អផង » ( Scripture Reading and Revelation,” *Ensign* ខែ មករា ឆ្នាំ ១៩៩៥ ទំព័រ ៨ ) ។ សូមស្វែងរកអត្ថន័យ និង ការអនុវត្តន៍នៅក្នុងរឿងប្រដូចនេះ ( សូមមើលផងដែរ Bible Dictionary, “Parables” ) ។

ព្រះអម្ចាស់បានប្រទានរឿងប្រដូចអំពីបុរសត្រកូលខ្ពស់ និង ដើមអូលីវ ដើម្បីជួយរាស្ត្រទ្រង់យល់អំពី « ព្រះហឫទ័យរបស់ទ្រង់អំពីសេចក្ដីប្រោសលោះនៃស៊ីយ៉ូន » ( គ. និង ស. ១០១:៤៣ ) ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៤–៤៥ ដោយស្វែងរកការណ៍ ដែលបុរសត្រកូលខ្ពស់នៅក្នុងរឿងប្រដូចនេះ បានបង្គាប់ឲ្យពួកអ្នកបម្រើគាត់ធ្វើ ។



ហេតុអ្វីបានជាបុរសត្រកូលខ្ពស់រូបនោះ ចង់ឲ្យមានអ្នកយាមនៅក្នុងចម្ការនោះ ? ហេតុអ្វីបានជាគាត់ ចង់ឲ្យអ្នកយាមធ្វើការនៅលើប៉ម ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៦–៥០ រួចស្វែងរកថាតើ ពួកអ្នកបម្រើរបស់បុរសត្រកូលខ្ពស់រូបនោះ បានធ្វើតាមសេចក្ដីណែនាំរបស់គាត់បានដល់កម្រិតណា ។ ( នៅពេលអ្នកអាន ខទី ៥០ វាអាចនឹងផ្ដល់អត្ថប្រយោជន៍ក្នុងការដឹងថា ឃ្លា « កំពុងតែជជែកគ្នាទៅវិញទៅមក » មានន័យថា ពួកអ្នកបម្រើបានប្រកែកគ្នាទៅវិញទៅមក ឬ មានការខ្វែងគំនិតគ្នា ) ។

ហេតុអ្វីបានជាពួកអ្នកបម្រើទាំងនោះ ខកខានមិនមានសាងសង់ប៉មឡើង ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៥១ ដោយស្វែងរកអ្វីដែលបានកើតឡើង ដោយសារតែពួកអ្នកបម្រើពុំបានសាងសង់ប៉ម ?

សូមអានពាក្យពេចន៍របស់បុរសត្រកូលខ្ពស់ ទៅកាន់ពួកអ្នកបម្រើរបស់គាត់ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៥២–៥៤ ។ យោងតាម ខទី ៥៤ ហេតុអ្វីបានជាបុរសត្រកូលខ្ពស់រូបនោះ រកាំចិត្តដោយសារតែពួកអ្នកបម្រើរបស់គាត់ពុំបានសាងសង់ប៉ម ?

តើព្រឹត្តការណ៍ដែលបានពិពណ៌នានៅក្នុងរឿងប្រដូចនេះ ទាក់ទងទៅនឹងអ្វីដែលបានកើតឡើងដល់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី យ៉ាងដូចម្ដេច ?

១. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើប៉មនៅក្នុងរឿងប្រដូចនេះ ទាក់ទងទៅនឹងព្រះវិហារបរិសុទ្ធ ដែលពួកបរិសុទ្ធខកខានពុំបានស្ថាបនានៅឃុំចាកសុន រដ្ឋ មិសសួរី យ៉ាងដូចម្ដេចដែរ ?

២. សូមឆ្លើយសំណួរតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើមានគោលការណ៍មួយចំនួនណាខ្លះនៅក្នុងរឿងប្រដូចនេះ ដែលអនុវត្តនៅក្នុងជីវិតរបស់អ្នក ? ( នៅពេលអ្នកឆ្លើយសំណួរនេះ សូមពិចារណាអំពីគោលលទ្ធិ និង គោលការណ៍ដូចតទៅនេះ ៖ **នៅពេលយើងគោរពប្រតិបត្តិតាមព្រះបញ្ញត្តិ នោះយើងត្រូវបានចម្រើនកម្លាំងឲ្យតតាំងនឹងខ្មាំងសត្រូវខាងវិញ្ញាណ និង ខាងសាច់ឈាម ។ ពួកព្យាការីដើរតួជាអ្នកយាមនៅលើប៉ម ដោយព្រមានយើងអំពីគ្រោះថ្នាក់ដែលនឹងកើតឡើង ។ យើងត្រៀមខ្លួនតតាំងនឹងបច្ចាមិត្តតាមរយៈកិច្ចការព្រះវិហារបរិសុទ្ធ** ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៥៥ ជាខគម្ពីរដែលបុរសត្រកូលខ្ពស់នៅក្នុងរឿងប្រដូច ផ្ដល់ការណែនាំដល់អ្នកបម្រើម្នាក់ ។ បន្ទាប់មក សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:២១ ។ តើអ្នកបម្រើរូបនោះនៅក្នុងរឿងប្រដូច តំណាងឲ្យនរណា ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៥៦–៦២ ដោយស្វែងរកអ្វី ដែលបុរសត្រកូលខ្ពស់រូបនោះ បានបង្គាប់ឲ្យអ្នកបម្រើធ្វើ ដោយសារតែខ្មាំងសត្រូវបានបំផ្លិចបំផ្លាញផ្នែកជាច្រើននៃចម្ការហើយនោះ ។ យ៉ូសែប ស្ម៊ីធ បានធ្វើតាមសេចក្ដីណែនាំនៅក្នុងរឿងប្រដូចនេះ ។ លោកបានបង្កើតក្រុមមួយហៅថា កងទ័ពជំរំស៊ីយ៉ូន ដើម្បីសង្គ្រោះដែនដីស៊ីយ៉ូន ។ ពួកគេបានធ្វើដំណើរទៅដល់រដ្ឋ មិសសួរី នៅប្រាំមួយខែបន្ទាប់ពីរឿងប្រដូចនេះត្រូវបានប្រទានឲ្យ ។ អ្នកនឹងរៀនបន្ថែមអំពី កងទ័ពជំរំស៊ីយ៉ូន នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣ និង ១០៥ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៦៣–៧៥

*ព្រះអម្ចាស់បានត្រាស់ក្រើនរំឭកពួកបរិសុទ្ធ ឲ្យបន្តកិច្ចការប្រមូលផ្ដុំគ្នា*

ទោះជាពួកបរិសុទ្ធត្រូវបានបណ្ដេញចេញពីឃុំចាកសុន រដ្ឋ មិសសួរី យ៉ាងណាក្ដី ក៏ព្រះអម្ចាស់បានត្រាស់បង្គាប់ពួកគេឲ្យបន្តស្ថាបនានគរទ្រង់ឡើងដែរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៦៣–៦៤ ដោយស្វែងរកការណ៍ ដែលព្រះអម្ចាស់បានសន្យាថាទ្រង់នឹងបន្តធ្វើ ។



នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានយោងទៅលើរឿងប្រដូចអំពីស្រូវសាលី និង ស្រងៃ ជាវិវរណៈដែលទ្រង់បានពិពណ៌នាអំពីការប្រមូលវាស្រ្តរបស់ទ្រង់ ( សូមមើលផងដែរ ម៉ាថាយ ១៣:២៤–៣០, ៣៦–៤៣ ) ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៦៥–៦៦ រួចស្វែងរកធាតុសំខាន់ៗនៃរឿងប្រដូចនេះមានដូចជា ៖ ជង្រុក ស្រូវសាលី និង ស្រងៃ ។

កាលពីបុរាណ ជង្រុកគឺជាកន្លែងដែលស្រូវសាលី ត្រូវបានប្រមូលផ្ដុំ ហើយរក្សាទុកឲ្យមានសុវត្ថិភាព ។ អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានផ្ដល់អត្ថន័យនិមិត្តរូបនៃពាក្យ *ជង្រុក* នៅក្នុងរឿងប្រដូចនេះ ។ លោកបានមានប្រសាសន៍ថា « ជង្រុកគឺជាព្រះវិហារដ៏បរិសុទ្ធ » ( Honorably Hold a Name and Standing," *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៩៧ ) ។ ស្រងៃជាស្មៅចង្រៃ ដែលមើលទៅស្រដៀងនឹងស្រូវសាលីដែរ កាលវានៅខ្ចី ។

ដើម្បីជួយអ្នកយល់រឿងប្រដូចនេះ អ្នកអាចនឹងចង់សរសេរការបកស្រាយដូចតទៅនេះ ដាក់នៅក្នុងព្រះគម្ពីររបស់អ្នក ៖ *ជង្រុក = ព្រះវិហារដ៏បរិសុទ្ធ; ស្រូវសាលី = ពួកសុចរិត; ស្រងៃ = ពួកទុច្ចរិត ។*

នៅក្នុងរឿងប្រដូច ស្រូវសាលីត្រូវបានប្រមូលដាក់នៅក្នុងជង្រុក ។ តើយើងប្រមូលគ្នាទៅក្នុងព្រះវិហារបរិសុទ្ធតាមរបៀបណាខ្លះ ?

សូមបំពេញចន្លោះ ដើម្បីបង្ហាញគោលការណ៍មួយ ដែលរឿងប្រដូចនេះបង្រៀន ៖ **នៅពេលយើងប្រមូលគ្នានៅក្នុង នោះយើងទទួលបានការការពារ ហើយត្រៀមខ្លួនសម្រាប់** ។

៣. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើពិធីបរិសុទ្ធ និង សេចក្ដីសញ្ញានានាក្នុងព្រះវិហារបរិសុទ្ធ ផ្ដល់នូវការការពារសម្រាប់អ្នក ហើយរៀបចំអ្នកឲ្យទទួលជីវិតដ៏នៅអស់កល្បយ៉ាងដូចម្ដេច ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៦៧–៧៥ យើងអានថា ទោះជាពួកបរិសុទ្ធត្រូវបានបង្ខំឲ្យចាកចេញពីឃុំចាកសុន រដ្ឋ មិសសួរី យ៉ាងណាក្ដី ក៏ព្រះអម្ចាស់បានប្រទានឱវាទឲ្យពួកគេបន្តទិញដីធ្លីនៅទីនោះដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៧៦–១០១

*ព្រះអម្ចាស់ប្រទានឱវាទឲ្យពួកបរិសុទ្ធ បន្តស្វែងរកមធ្យោបាយដើម្បីត្រឡប់មកផ្ទះរបស់ពួកគេវិញនៅរដ្ឋ មិសសួរី*

បន្ថែមពីលើការណែនាំឲ្យពួកបរិសុទ្ធទិញដីធ្លី ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ពួកគេឲ្យ « កែសាទុក្ខ និង ការសង » ដោយសារតែទង្វើនៃអ្នកទាំងឡាយ ដែលបានបៀតបៀនពួកគេ ( សូមមើល គ. និង ស. ១០១:៧៦ ) ។ អាចនិយាយបានម្យ៉ាងទៀតថា ទ្រង់បានមានព្រះបន្ទូលប្រាប់ពួកគេឲ្យស្វែងរកយុត្តិធម៌ តាមរយៈប្រព័ន្ធស្របច្បាប់របស់រដ្ឋាភិបាល ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៧៦–៨០ រួចស្វែងរកប្រព័ន្ធច្បាប់ ដែលបានអនុញ្ញាតឲ្យពួកបរិសុទ្ធស្វែងរកជំនួយពីថ្នាក់ដឹកនាំរដ្ឋាភិបាល ។

ស្របតាមខគម្ពីរទាំងនេះ ហេតុអ្វីបានជាព្រះអម្ចាស់មានព្រះទ័យឲ្យ រដ្ឋធម្មនុញ្ញនៃសហរដ្ឋ ត្រូវបានតាំងឡើង ?

៤. សូមកត់ចំណាំនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៧៨ នូវឃ្លា « សិទ្ធិជ្រើសរើសខាងសីលធម៌ » និង « ទទួលការខុសត្រូវចំពោះអំពើបាបទាំងឡាយរបស់ខ្លួន » ។ សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីបានជាការទទួលខុសត្រូវ—ដែលជាទំនួលខុសត្រូវចំពោះរាល់ទង្វើរបស់យើង—គឺជាផ្នែកសំខាន់មួយនៃសិទ្ធិជ្រើសរើស ?

ខ. តើអ្នកនឹងថ្លែងដូចម្ដេចទៅកាន់នរណាម្នាក់ ដែលពោលថា « ខ្ញុំមានសិទ្ធិសេរីភាព ធ្វើអ្វីគ្រប់យ៉ាងដែលខ្ញុំចង់ធ្វើ ? »

សូមបញ្ចប់គោលលទ្ធិដូចតទៅនេះ ៖ **ព្រះបានប្រទានសិទ្ធិជ្រើសរើសឲ្យយើង ដែលជាអំណាចដើម្បីជ្រើសរើស ប៉ុន្តែ យើងត្រូវ ចំពោះជម្រើសរបស់យើង ។**

ព្រះអម្ចាស់បានប្រើប្រាស់រឿងប្រដូចទីបី ដើម្បីលើកទឹកចិត្តពួកបរិសុទ្ធឲ្យស្វែងរកជំនួយពីថ្នាក់ដឹកនាំរដ្ឋាភិបាលរបស់ពួកគេ ។ វាមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៨១–៨៤ ។ ( ទម្រង់មួយនៃរឿងប្រដូចនេះ មានចែងនៅក្នុង លូកា ១៨:១–៨ ) ។ នៅពេលអ្នកអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៨១–៨៤ សូមគិតអំពីរបៀបដែលរឿងប្រដូចនេះ បានអនុវត្តចំពោះពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ។ ដូចជារឿងប្រដូចដែលមាននៅក្នុងវិវរណៈនេះ ស្ត្រីរូបនោះតំណាងឲ្យសមាជិកនៃសាសនាចក្រ ។ ចៅក្រមអាចតំណាងឲ្យថ្នាក់ដឹកនាំរដ្ឋាភិបាល ដែលពួកបរិសុទ្ធបានសុំជំនួយ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៨៥–៨៨ ដើម្បីឃើញរបៀបដែលព្រះអង្គសង្គ្រោះបានអនុវត្ត រឿងប្រដូចនេះចំពោះពួកបរិសុទ្ធ ដែលត្រូវបានជម្លៀសចេញពីផ្ទះសម្បែងរបស់ខ្លួន ។

ពួកបរិសុទ្ធបានធ្វើតាមការក្រើនរំឭករបស់ព្រះអម្ចាស់ ។ ពួកគេបានស្នើ ដានីយ៉ែល ដាំងឃ្លីន ដែលជាអភិបាលរដ្ឋ មិសសួរី ឲ្យផ្ដល់កងកម្លាំងយោធាការពារពួកគេ នៅពេលពួកគេត្រឡប់ទៅកាន់ផ្ទះរបស់ពួកគេវិញ ។ គាត់បានច្រានចោលសំណើនោះ ដោយបានពោលថា ច្បាប់មិនអនុញ្ញាតឲ្យគាត់ធ្វើដូចនោះទេ ។ ពួកគេក៏បានស្នើ អាន់ឌ្រូ ចាកសុន ដែលជាប្រធានាធិបតីនៃសហរដ្ឋ ឲ្យជួសជុលផ្ទះសម្បែង និង ទ្រព្យសម្បត្តិរបស់ពួកគេ ហើយការពារដល់ពួកគេ ប៉ុន្តែ គាត់ពុំបានផ្ដល់ជំនួយឡើយ ។ នៅគ្រានោះ មន្ត្រីរដ្ឋាភិបាលនៃសហរដ្ឋបានគិតថា អភិបាលរដ្ឋ ត្រូវទទួលខុសត្រូវលើបញ្ហានេះ ។ ពួកបរិសុទ្ធក៏បានដាក់ញត្តិទៅកាន់នីតិកាលរបស់រដ្ឋផងដែរ ប៉ុន្តែ អ្នកនយោបាយទាំងនោះបានបដិសេធមិនព្រមជួយ ។

សូមអានគ្រួសៗនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៨៩–៩១ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលថាតើថ្នាក់ដឹកនាំរដ្ឋាភិបាលនឹងទទួលខុសត្រូវយ៉ាងដូចម្ដេចខ្លះ បើពួកគេបដិសេធពុំជួយពួកបរិសុទ្ធ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៩២–៩៥ ដោយស្វែងរកការណ៍ ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ពួកបរិសុទ្ធឲ្យធ្វើ សម្រាប់ថ្នាក់ដឹកនាំរដ្ឋាភិបាលរបស់ពួកគេ ។

៥. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៩២ បង្រៀនអ្នកអ្វីខ្លះ អំពីព្រះអម្ចាស់ ?

នៅពេលអ្នកពិនិត្យពិច័យលើខគម្ពីរទាំងនេះ ហើយសរសេរអំពី ខទី ៩២ សូមញែកពេលពិចារណាអំពីសេចក្ដីស្រឡាញ់ និង សេចក្ដីមេត្តារបស់ព្រះ ។ សូមកត់ចំណាំថា ទ្រង់ពុំមានព្រះទ័យដាក់ទោសរាស្ត្ររបស់ទ្រង់នោះទេ ។ ទ្រង់មានព្រះទ័យឲ្យរាស្ត្រទ្រង់ទាំងអស់គ្នាប្រែចិត្ត ដើម្បីទ្រង់អាចមានសេចក្ដីមេត្តាចំពោះពួកគេ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៩៦–១០១ យើងអានអំពីឱវាទរបស់ព្រះអម្ចាស់ប្រទានទៅដល់ពួកបរិសុទ្ធ ឲ្យរក្សាទុកទ្រព្យសម្បត្តិរបស់ខ្លួននៅឃុំចាកសុន ទោះជាពួកគេពុំត្រូវបានអនុញ្ញាតឲ្យរស់នៅទីនោះយ៉ាងណាក្ដី ។ ខគម្ពីរទាំងនេះក៏រួមបញ្ចូលទាំងការសន្យាពីព្រះអម្ចាស់ថា បើសិនជាពួកបរិសុទ្ធរស់នៅដោយមានភាពសក្ដិសម នោះពួកគេនឹងអាចរស់នៅទីនោះបាន នៅថ្ងៃណាមួយជាមិនខាន ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២

*ព្រះអម្ចាស់ត្រាស់បង្រៀនក្រុមប្រឹក្សាជាន់ខ្ពស់ ស្ដីពីរបៀបដោះស្រាយបញ្ហាលំបាកៗ*

គោលលទ្ធិ និង សេចក្ដីសញ្ញា ១០២ មានការបង្រៀនរបស់ព្រះអម្ចាស់ ស្ដីពីរបៀបដែលប្រធានស្ដេក ជួយដល់ទីប្រឹក្សា និង សមាជិកក្នុងក្រុមប្រឹក្សាជាន់ខ្ពស់របស់លោក ឲ្យដឹកនាំក្រុមប្រឹក្សាវិន័យ សម្រាប់អ្នកទាំងឡាយដែលបានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ ។ « គោលបំណងរបស់ក្រុមប្រឹក្សាវិន័យគឺត្រូវ (១) ជួយសង្គ្រោះព្រលឹងនៃអ្នកប្រព្រឹត្តរំលងច្បាប់ (២) ការពារជនឥតទោស និង (៣) ការពារភាពបរិសុទ្ធស្អាត ភាពថ្លៃថ្នូរ និង ឈ្មោះដ៏ល្អរបស់សាសនាចក្រ » (*ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* [ ឆ្នាំ ២០០៤ ] ទំព័រ ៧២–៧៣) ។ ព្រះអម្ចាស់បានបើកសម្ដែងព្រះឆន្ទៈរបស់ទ្រង់ ទៅដល់អ្នកដែលធ្វើអធិបតីលើក្រុមប្រឹក្សាវិន័យ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០១:៤៣–១០១; ១០២ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២២ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣

## សេចក្ដីផ្ដើម

នៅក្នុងការប្រជុំនៃក្រុមប្រឹក្សាជាន់ខ្ពស់នៅទីក្រុង ខឺតឡង់ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៨៣៤ ប៉ាលី ភី ប្រាត្ត និងឡាយមិន វ៉ាយ បានស្វែងរកការដឹកនាំពីការប្រជុំក្រុមប្រឹក្សា អំពីរបៀបដែលពួកបរិសុទ្ធនៅរដ្ឋ មិសសួរី អាចទទួលបានជំនួយខាងសាច់ឈាម ហើយទទួលបានកម្មសិទ្ធិដីធ្លីរបស់ខ្លួននៅឃុំចាកសុនមកវិញ ។ នៅថ្ងៃនោះដែរ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣ ជាវិវរណៈ ដែលព្រះអម្ចាស់បានសន្យាថា ដែនដីស៊ីយ៉ូននឹងត្រូវបានរំដោះមកវិញ ។ ព្រះអម្ចាស់បានត្រាស់បង្គាប់ថ្នាក់ដឹកនាំសាសនាចក្រ ឲ្យប្រមូលធនធាន និង កេណ្ឌទាហានទៅជួយពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ។ ក្រុមនេះត្រូវបានស្គាល់ថា កងទ័ពជំរំស៊ីយ៉ូន ។


កងទ័ពជំរំស៊ីយ៉ូន ធ្វើដំណើរទៅដល់រដ្ឋ មិសសួរី

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:១–២១

*ព្រះអម្ចាស់សន្យាថា ស៊ីយ៉ូននឹងត្រូវបានរំដោះ*

តើអ្វីខ្លះ ដែលជាខ្មាំងសត្រូវរបស់ពួកសុចរិត នាពេលសព្វថ្ងៃនេះ ?

សូមគិតអំពីរបៀបដែលពួកខ្មាំងសត្រូវរបស់ព្រះអម្ចាស់ព្យាយាមបង្អាក់ភាពល្អូតលាស់ខាងវិញ្ញាណ និង វឌ្ឍនភាពរបស់សាសនាចក្រ ។ នៅពេលអ្នកសិក្សាអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣ សូមស្វែងរកគោលលទ្ធិ និង គោលការណ៍ ដែលនឹងជួយអ្នកឲ្យយកឈ្នះលើខ្មាំងសត្រូវប្រភេទនេះ ។

ដូចបានពន្យល់នៅក្នុងសេចក្ដីណែនាំនៃមេរៀននេះ ព្រះអម្ចាស់បានប្រទានវិវរណៈដល់ព្យាការី យ៉ូសែប ស្ម៊ីធ ដើម្បីឆ្លើយតបទៅនឹងសំណួរ អំពីរបៀបជួយដល់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ។ នៅពេលចាប់ផ្ដើមវិវរណៈនេះ ព្រះអម្ចាស់បានពន្យល់អំពីមូលហេតុដែលទ្រង់ ទុកឲ្យពួកខ្មាំងសត្រូវរបស់ទ្រង់បៀតបៀនពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:១–៤ ដោយស្វែងរកមូលហេតុ ដែលព្រះអម្ចាស់បានទុកឲ្យរឿងដ៏អាក្រក់នេះ កើតឡើងដល់រាស្ត្ររបស់ទ្រង់ ។

សូមពិចារណាអំពីមូលហេតុដែលវាមានសារៈសំខាន់ដែលថា ព្រះអម្ចាស់បានចាត់ទុកអ្នកដែលបៀតបៀនពួកបរិសុទ្ធ ថាជាខ្មាំងសត្រូវរបស់ទ្រង់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:៥–៧ រួចស្វែងរកចម្លើយចំពោះសំណួរដូចតទៅនេះ ៖ បើពួកបរិសុទ្ធធ្វើតាមឱវាទព្រះអម្ចាស់ « ចាប់ពីម៉ោង | នេះ | ទៅ » តើពរជ័យអ្វីខ្លះ ដែលពួកគេទទួលបាន ? ( អ្នកអាចនឹងចង់គូសចំណាំចម្លើយទាំងនេះ ពេលអ្នករកវាឃើញ ។ សូមកត់ចំណាំថា ពាក្យ *ឈ្នះ* មានន័យថា ខ្លាំងជាងគូបដិបក្ខ ឬ មានជ័យជម្នះ ) ។

ខគម្ពីរទាំងនេះបង្រៀនគោលការណ៍មួយ ដែលអាចអនុវត្តចំពោះកិច្ចខិតខំរបស់អ្នក ក្នុងការយកឈ្នះលើអានុភាពនៃលោកិយ ៖ **នៅពេលយើងចាប់ផ្ដើមធ្វើតាមឱវាទព្រះអម្ចាស់ នោះយើងទទួលបានកម្លាំង ដើម្បីចាប់ផ្ដើមយកឈ្នះលើលោកិយ ។**

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:៨–១០ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បានព្រមានថានឹងកើតឡើង បើសិនជាពួកបរិសុទ្ធជ្រើសរើសមិនគោរពប្រតិបត្តិតាមព្រះបន្ទូលទាំងឡាយរបស់ទ្រង់ ។

តើគោលការណ៍អ្វីដែលព្រះអម្ចាស់បង្រៀននៅក្នុងខគម្ពីរទាំងនេះ អំពីការណ៍ដែលនឹងកើតឡើង បើសិនជាយើងមិនគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់នោះ ? សូមបញ្ចប់សេចក្ដីថ្លែងការណ៍ « បើសិនជា–នោះ » ដូចតទៅនេះ ៖ **បើសិនជាយើងគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ នោះ** ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:៩ ម្ដងទៀត ។ តើយើងអាចធ្វើជា « ពន្លឺដល់ពិភពលោក » បានតាមរបៀបណា ? តើអ្នកអាចធ្វើជាអ្នកសង្គ្រោះ បានតាមរបៀបណា ?

*ការស្គាល់គោលលទ្ធិ និង គោលការណ៍ទាំងឡាយ*
ចំណុចមួយនៃគោលបំណងសំខាន់របស់ព្រះគម្ពីរ គឺដើម្បីបង្រៀនគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ នៅពេលអ្នកសិក្សាបទគម្ពីរ អ្នកអាចធ្វើឲ្យគោលលទ្ធិ និង គោលការណ៍ទាំងនេះ មានសភាពច្បាស់លាស់នៅក្នុងគំនិតរបស់អ្នក ដោយសង្ខេបអ្វីដែលអ្នករៀននោះជាសេចក្ដីថ្លែងការណ៍មួយខ្លី ហើយច្បាស់លាស់ ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើមានគំរូមួយចំនួនណាខ្លះ នៃរបៀបដែលពួកខ្មាំងសត្រូវរបស់ព្រះអម្ចាស់ព្យាយាមយកឈ្នះលើ សមាជិកនៃសាសនាចក្រនាពេលបច្ចុប្បន្ននេះ ?

ខ. តើអ្នកគិតថា ហេតុអ្វីបានជាមនុស្សម្នាក់ដែលពុំគោរពប្រតិបត្តិព្រះអម្ចាស់ ឬ គោរពប្រតិបត្តិតែផ្នែកមួយចំនួនពុំអាចនឹងមានលទ្ធភាពយកឈ្នះលើពួកខ្មាំងសត្រូវរបស់ព្រះអម្ចាស់បាន ?

គ. តើនៅពេលណាខ្លះ ដែលអ្នកធ្លាប់បានឃើញមនុស្សណាម្នាក់ មានជ័យជម្នះលើខ្មាំងសត្រូវរបស់ព្រះអម្ចាស់ដោយព្យាយាមគោរពប្រតិបត្តិតាមព្រះបន្ទូលរបស់ទ្រង់ ? ( ឧទាហរណ៍ អ្នកអាចនឹងគិតអំពីមនុស្សណាម្នាក់ដែលបានយកឈ្នះលើការញៀន ឬ អ្នកដែលសព្វថ្ងៃនេះរស់នៅតាមដំណឹងល្អ បន្ទាប់ពីបានរស់នៅតាមជីវិតខាងលោកិយ ) ។

២. សូមសរសេរអ្វីមួយនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ដែលអ្នកអាចចាប់ផ្ដើមធ្វើ « ចាប់ពីម៉ោងនេះទៅ » ( គ. និង ស. ១០៣:៥ ) ដើម្បីស្ដាប់តាមឱវាទរបស់ព្រះអម្ចាស់ឲ្យបានកាន់តែប្រសើរឡើង ។ សូមសរសេរផែនការអំពីរបៀប ដែលអ្នកនឹងធ្វើវា ។

សូមចងចាំថា ខណៈពេលដែលអ្នកអាចនឹងមិនគោរពប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះអម្ចាស់បានយ៉ាងល្អឥតខ្ចោះ បើសិនជាអ្នកព្យាយាមគោរពប្រតិបត្តិទ្រង់ដោយចិត្តឧស្សាហ៍ ហើយបើសិនជានៅពេលអ្នកធ្លាក់ទៅក្នុងផ្លូវខុស អ្នកប្រែចិត្ត ហើយស្វែងរកការអត់ទោសដោយស្មោះពីចិត្តតាមរយៈដង្វាយធួនទ្រង់ នោះទ្រង់នឹងជួយអ្នក ឲ្យយកឈ្នះលើពួកខ្មាំងសត្រូវរបស់ទ្រង់ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:១១–២១ យើងអានអំពីការសន្យារបស់ព្រះអម្ចាស់ដែលមានព្រះបន្ទូលថា បន្ទាប់ពីពួកបរិសុទ្ធបានទទួលរងទុក្ខលំបាកហើយ នោះទីក្រុង ស៊ីយ៉ូន នឹងត្រូវបានរំដោះដោយព្រះចេស្ដារបស់ទ្រង់ ។ ប៉ុន្តែ ទ្រង់ក៏បានព្រមានពួកគេដែរថា បើសិនជាពួកបរិសុទ្ធបង្ខូចកេរមរតករបស់ខ្លួន នោះពួកគេនឹងត្រូវទម្លាក់ចុះ ។ លោកបានមានព្រះបន្ទូលអំពីព្យាការី យ៉ូសែប ស្ម៊ីធ ថាជាបុរសប្រៀបធៀបទៅនឹង ម៉ូសេ ដែលបានដឹកនាំប្រជារាស្ត្រ ( សូមមើល គ. និង ស. ១០៣:១៦, ២១ សូមមើលផងដែរ គ. និង ស. ២៨:២ ) ។ ការប្រៀបធៀបនេះគឺពិតប្រាកដណាស់ ចំពោះប្រធាននៃសាសនាចក្រគ្រប់រូប ( សូមមើល គ. និង ស. ១០៧:៩១ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:២២–៤០

*ព្រះអម្ចាស់បើកសម្ដែងអំពី របៀបដែលដែនដីស៊ីយ៉ូន ត្រូវបានរំដោះ*

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:២២–២៣ ។ ខគម្ពីរទាំងនេះមានសេចក្ដីណែនាំរបស់ព្រះអម្ចាស់ ដល់ថ្នាក់ដឹកនាំសាសនាចក្រនៅគ្រានោះ គឺក្នុងឆ្នាំ ១៨៣៤ ។ ទ្រង់បានត្រាស់បង្គាប់ពួកលោកឲ្យប្រមូលគ្នា ទៅដែនដីស៊ីយ៉ូន រដ្ឋមិសសួរី ហើយជួយពួកបរិសុទ្ធនៅទីនោះ ។ ក្រុមបុរសដែលមានថ្នាក់ដឹកនាំសាសនាចក្របានប្រមូលគ្នា ដើម្បីដឹកនាំដោយព្យាការី យ៉ូសែប ស្ម៊ីធ នោះ ត្រូវបានស្គាល់ថា កងទ័ពជំរំស៊ីយ៉ូន (*ជំរំ* គឺជាពាក្យមួយទៀតនៃពលទ័ព ) ។ សមាជិកនៃជំរំមរមន មានគោលបំណងចំនួនពីរ ។ ទីមួយ ពួកលោកត្រូវនាំយកធនធាននានា ទៅឲ្យពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ។ ដោយមានធនធានទាំងនេះ ពួកគេអាចផ្ដល់ជំនួយដល់ពួកបរិសុទ្ធ ហើយមានលទ្ធភាពជួយពួកគេអាចត្រឡប់ទៅផ្ទះសម្បែងវិញ ។ ពួកលោកក៏ប្រើធនធានទាំងនេះ ដើម្បីទិញដីធ្លីបន្ថែមដែរ ។ ទីពីរ ដោយបានទទួលការអនុញ្ញាតពីលោកអភិបាល ដានីយ៉ែល ដាំងឃ្លីន នៃរដ្ឋ មិសសួរី បន្ទាប់ពីកងជីវពលរដ្ឋ បានជួយការពារពួកបរិសុទ្ធឲ្យត្រឡប់ទៅកាន់យុំចាកសុនវិញ នោះកងទ័ពជំរំស៊ីយ៉ូន នឹងត្រូវបានទុកឲ្យទីនោះ ដើម្បីជួយការពារសណ្ដាប់ធ្នាប់ និងសន្តិភាព ។

ហ៊ីប៊ើរ ស៊ី ឃិមប៊ឹល គឺជាបងប្អូនប្រុសម្នាក់ ដែលបានឆ្លើយតបដោយស្មោះត្រង់ទៅនឹងការហៅឲ្យចូលរួមជំរំស៊ីយ៉ូន ។ ក្រោយមក គាត់បានបម្រើជា សមាជិកក្នុងគណៈប្រធានទីមួយ ។ គាត់បានរៀបរាប់អំពីអារម្មណ៍របស់គាត់ នៅពេលគាត់បានចាកចេញទៅជាមួយកងទ័ពជំរំស៊ីយ៉ូន ៖ « យើងបានចាប់ផ្ដើមនៅថ្ងៃទី ៥ ខែ ឧសភា ហើយនោះគឺជាវេលាព្រឹកដ៏ក្រៀមក្រំសម្រាប់ខ្ញុំ ។ ខ្ញុំបានចាកចេញពីភរិយា និងកូនៗ ព្រមទាំងមិត្តភក្ដិរបស់ខ្ញុំ ដោយមិនរំពឹងថានឹងបានជួបមុខពួកគេម្ដងទៀតឡើយ ព្រោះខ្លួនរូបខ្ញុំផ្ទាល់ រួមទាំងពួកបងប្អូនប្រុសផងនោះ ត្រូវបានគំរាមកំហែងទាំងនៅក្នុងប្រទេស និង នៅរដ្ឋ មិសសួរីពីសំណាក់ពួកខ្មាំងសត្រូវ ដែលពួកគេអាចនឹងបំផ្លាញយើងបង់ ហើយប្រល័យយើងចោលចេញពីដែនដី » ( នៅក្នុង "Extract from the Journal of Heber C. Kimball," *Times and Seasons,* ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៨៤៥ ទំព័រ ៧៧១ សូមមើលផងដែរ *Church History in the Fulness of Times Student Manual* ការបោះពុម្ពលើកទី ២ [Church Educational System manual, ២០០៣] ទំព័រ ១៤៣) ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. បើសិនជាអ្នកបានរស់នៅក្នុងគ្រានោះ តើអ្នកគិតថា អ្នកនឹងមានឆន្ទៈធ្វើដំណើរទៅកាន់ឃុំចាកសុន ដើម្បីជួយពួកបរិសុទ្ធដែរឬទេ ? ហេតុអ្វីអ្នកមានឆន្ទៈ ឬ ហេតុអ្វីអ្នកមិនមានឆន្ទៈ ?

ខ. ការចូលរួមក្នុងកងទ័ពជំរំស៊ីយ៉ូន តម្រូវឲ្យចាកចេញពីក្រុមគ្រួសារ និងការងារផ្សេងៗ ដើម្បីធ្វើដំណើរប្រមាណ ១,៤៥០ គីឡូម៉ែត្រ ឆ្លងកាត់ស្ថានភាពដ៏យ៉ាប់យ៉ឺន ចូលទៅកន្លែងដែលមានការប្រឆាំង និងប្រកបដោយគ្រោះថ្នាក់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:២០ ។ តើការសន្យានៅក្នុងខគម្ពីរនេះ មានអានុភាពទៅលើការសម្រេចចិត្តរបស់អ្នកក្នុងការស្ម័គ្រចិត្តយ៉ាងដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:២៧–២៨ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលទៅកាន់អ្នកដែលបានចូលរួមក្នុងកងទ័ពជំរំស៊ីយ៉ូន ។ អ្នកអាចនឹងពិចារណាអំពីការបង្កើតឃ្លា ដែលបង្រៀនសេចក្ដីពិតដូចតទៅនេះ ៖ **ពួកសិស្សនៃព្រះយេស៊ូវគ្រីស្ទ មានឆន្ទៈលះបង់ជីវិតពួកគេដើម្បីទ្រង់ ។**

ចំពោះពួកបរិសុទ្ធនៅក្នុងកងទ័ពជំរំស៊ីយ៉ូន សក្ដានុពលក្នុងការបាត់បង់ជីវិតរបស់ខ្លួនគឺមានច្រើន ។ ទោះជាអ្នកអាចនឹងមិនប្រឈមមុខចំពោះហានិភ័យដូចគ្នានេះក៏ដោយ ក៏សេចក្ដីពិតនេះនៅតែអាចអនុវត្តចំពោះអ្នកដែរ ។



ប្រធាន ជេម អ៊ី ហ្វោស្ដ ក្នុងគណៈប្រធានទីមួយ បានផ្ដល់មធ្យោបាយមួយទៀត ដើម្បីគិតអំពីការពលីជីវិតដើម្បីព្រះអម្ចាស់ ៖ « សម្រាប់យើងភាគច្រើន . . . អ្វីដែលតម្រូវឲ្យធ្វើនោះ គឺពុំចាំបាច់ *ស្លាប់* ដើម្បីសាសនាចក្រនោះទេ ប៉ុន្តែ គឺត្រូវ *រស់នៅ* ដើម្បីសាសនាចក្រ ។ សម្រាប់មនុស្សជាច្រើន ការរស់នៅដូចជាព្រះយេស៊ូវជារៀងរាល់ថ្ងៃ អាចមានការលំបាក ជាងការប្ដូរជីវិតខ្លួនទៅទៀត » ( Discipleship » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ២២ ) ។

៤. សូមធ្វើសកម្មភាពដូចខាងក្រោមនេះ ៖

ក. សូមចែកចាយសេចក្ដីថ្លែងការណ៍ដោយប្រធាន ហ្វោស្ដ ជាមួយសមាជិកគ្រួសារ ឬ មិត្តភក្ដិ រួចសួរពួកគេនូវសំណួរដូចតទៅ ៖ តើអ្នកគិតថា ហេតុអ្វីបានជាវាអាចនឹងមានសភាពលំបាកក្នុង *ការរស់នៅ* ដើម្បីព្រះអម្ចាស់ជាង *ការស្លាប់* ដើម្បីទ្រង់ ?

ខ. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមកត់ត្រាអំពីមនុស្សដែលអ្នកសួរ រួចសរសេរចម្លើយរបស់ពួកគេ ។ សូមសរសេរបញ្ចូលការយល់ដឹងផ្ទាល់ខ្លួនរបស់អ្នកអំពីសេចក្ដីថ្លែងការណ៍របស់ប្រធាន ហ្វោស្ដ និង សំណួរដែលចោទសួរនេះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:៣០–៣៤ ដោយស្វែងរកចំនួនអ្នកស្ម័គ្រចិត្ត ដែលព្រះអម្ចាស់បានមានព្រះទ័យឲ្យចូលរួមក្នុងកងទ័ពជំរំស៊ីយ៉ូន ។

តើព្រះអម្ចាស់មានព្រះទ័យ ឲ្យមានអ្នកស្ម័គ្រចិត្តប៉ុន្មាននាក់ ?

តើចំនួនអប្បបរមា ដែលព្រះអម្ចាស់បានតម្រូវឲ្យមាន គឺប៉ុន្មាន ?

នៅចុងបញ្ចប់នៃការប្រជុំក្រុមប្រឹក្សាជាន់ខ្ពស់ ដែលថ្នាក់ដឹកនាំសាសនាចក្របានពិភាក្សាអំពីស្ថានភាពនៃពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ព្យាការី យ៉ូសែប ស្ម៊ីធ បានប្រកាសថា លោកនឹងធ្វើដំណើរទៅរំដោះទីក្រុង ស៊ីយ៉ូន ។ មានបុរសប្រមាណ ៣០ ឬ ៤០ នាក់ ក៏បានលើកដៃស្ម័គ្រចិត្តដែរ ។ បន្ទាប់មក ព្រះអម្ចាស់បានចាត់តាំងបុរស ៨ នាក់ឲ្យចេញទៅជួបបណ្ដាជននៃសាសនាចក្រ ជ្រើសរើសអ្នកស្ម័គ្រចិត្តចូលរួមក្នុងកងទ័ពជំរំស៊ីយ៉ូន ហើយស្វែងរកមូលនិធិជាគ្រឿងឧបភោគបរិភោគ និង ប្រាក់កាសសម្រាប់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ( សូមមើល គ. និង ស. ១០៣:៣៧–៤០ ) ។



កងទ័ពជំរំស៊ីយ៉ូន

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:៣៥–៣៦ រួចស្វែងរកអ្វីដែលពួកបរិសុទ្ធត្រូវធ្វើ ដើម្បីជោគជ័យដល់ការខិតខំរបស់ពួកគេក្នុងការរំដោះទីក្រុង ស៊ីយ៉ូន ។ សូមពិចារណាអំពីសេចក្ដីពិត ដែលព្រះអម្ចាស់បានបង្រៀននៅក្នុង ខទី ៣៦ អំពីរបៀបដែលយើងអាចមានជ័យជម្នះ ក្នុងការបំពេញកិច្ចការរបស់ទ្រង់ ។

សូមគិតអំពីរបៀបដែលអារក្ស ព្យាយាមបង្អាក់ភាពរីកចម្រើនខាងវិញ្ញាណរបស់អ្នក ។ តើមានអំពើបាប ការល្បួង ឬ ឧបសគ្គណាមួយ ដែលកំពុងប្រឆាំងអ្នកក្នុងការខិតខំដើម្បីដើរតាមព្រះអម្ចាស់ដែរឬទេ ? សូមមើលទៅចម្លើយរបស់អ្នកចំពោះ លំហាត់ទី ២ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ តើចម្លើយរបស់អ្នក ទាក់ទងទៅនឹងការមានចិត្តឧស្សាហ៍ព្យាយាម និង ស្មោះត្រង់ និងការអធិស្ឋានដោយសេចក្ដីជំនឿយ៉ាងដូចម្ដេច ? សូមចងចាំថា ដូចជាពួកបរិសុទ្ធនៅជំនាន់យ៉ូសែប ស្ម៊ីធ ដែរ អ្នកមានលទ្ធភាពទទួលបានជ័យជម្នះលើពួកខ្មាំងសត្រូវនៃព្រះអម្ចាស់ ហើយសម្រេចគោលបំណងរបស់ព្រះអម្ចាស់ ដរាបណាអ្នកអធិស្ឋានដោយសេចក្ដីជំនឿ និងដរាបណាអ្នកគោរពប្រតិបត្តិតាមព្រះបន្ទូលទ្រង់ដោយមានចិត្តឧស្សាហ៍ព្យាយាម និងស្មោះត្រង់ ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤

## សេចក្ដីផ្ដើម

នៅត្រឹមនិទាឃរដូវឆ្នាំ ១៨៣៤ សាសនាចក្របានមានវិបត្តិផ្នែកហិរញ្ញវត្ថុ ចំណែកឯការខិតខំប្រមូលមូលនិធិសម្រាប់ជាការសង្គ្រោះនោះ បានបរាជ័យ ។ ក្នុងឆ្នាំ ១៨៣៤ ព្រះអម្ចាស់បានត្រាស់បង្គាប់ថ្នាក់ដឹកនាំសាសនាចក្រឲ្យ « បង្កើតអាជីវកម្ម និង ការបោះពុម្ពរបស់សាសនាចក្រ ដោយបង្កើតជា ‹ សហគ្រាស › មួយ ដែលនឹងមើលខុសត្រូវលើកិច្ចការទាំងនេះ ដោយបង្កើតឲ្យមានមូលនិធិសម្រាប់ការស្ថាបនាទីក្រុង ស៊ីយ៉ូន និង ដើម្បីជាប្រយោជន៍ដល់ជនក្រីក្រ ។ សហគ្រាសនេះ ត្រូវបានស្គាល់ថា សហគ្រាសសាមគ្គីភាព ដែលត្រូវបានបង្កើតឡើងនៅខែ មេសា ឆ្នាំ ១៨៣២ ហើយបានរំលាយទៅវិញនៅឆ្នាំ ១៨៣៤ ( សូមមើល កណ្ឌ ៨២ ) » ( គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៨ សេចក្ដីណែនាំអំពីកណ្ឌ ) ។ នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៨៣៤ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានបើកសម្ដែងថា សហគ្រាសសាមគ្គីភាពត្រូវតែបង្កើតឡើងវិញ ចំណែកឯទ្រព្យសម្បត្តិរបស់វានោះ ត្រូវបែងចែកក្នុងចំណោមសមាជិកនៃសហគ្រាសនោះតាមតំណែងរបស់ខ្លួន ។ នៅក្រោមការដឹកនាំរបស់ យ៉ូសែប ស្ម៊ីធ នៅពេលក្រោយមកទៀត វាក្យសព្ទ « សហគ្រាសសាមគ្គីភាព » ត្រូវបានជំនួសដោយ « សហសមាគម » នៅក្នុងវិវរណៈនេះ ។ មេរៀននេះប្រើប្រាស់វាក្យសព្ទ សហសមាគម ដើម្បីឲ្យត្រូវនឹងភាសាដែលប្រើនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤ ។ ព្រះអម្ចាស់ក៏បានណែនាំសមាជិកសាសនាចក្រផងដែរ អំពីរបៀបដែលពួកលោកត្រូវមើលថែជនក្រីក្រ ហើយបានប្រទានឱវាទដល់ថ្នាក់ដឹកនាំសាសនាចក្រអំពីបំណុលរបស់ពួកលោក ។ សមាជិកភាពនៃសហសមាគមរួមមាន យ៉ូសែប ស្ម៊ីធ, ស៊ីឌនី រិកដុន, អូលីវើរ ខៅឌើរី, វិលលាម ដ័បបុលយូ ហ្វែប្ស, អែតវឺត ប៉ាទ្រិច, យ៉ូហាន វិតមើរ, ស៊ីឌនី គិលបឺត, ម៉ាទិន ហារីស, នូវល ខេ វិតនី, យ៉ូហាន ចនសុន និង ហ្វ្រេឌើរិក ជី វិលលាម្ស ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១–១៨

*ព្រះអម្ចាស់ ប្រទានការណែនាំទាក់ទងនឹងសហសមាគម*

សូមស្រមៃថា ឪពុកម្ដាយរបស់អ្នកបានឲ្យកូនសោឡានរបស់ពួកគាត់មកដល់អ្នក ( ឬ សូមគិតអំពីអ្វីមួយផ្សេងទៀត ដែលតម្រូវឲ្យប្រើកូនសោដូចជា ផ្ទះរបស់អ្នក ) ។ តើការណ៍នេះធ្វើឲ្យអ្នក ក្លាយទៅជាម្ចាស់ឡាននោះដែរឬទេ ? តើអ្នកអាចប្រើប្រាស់ឡាននោះ សម្រាប់គោលបំណងទាំងឡាយណាដែលអ្នកចង់បានដែរឬទេ ? ហេតុអ្វីអាច ឬ ហេតុអ្វីមិនអាន ? តើការដឹងថា អ្នកនឹងទទួលខុសត្រូវចំពោះអ្វីដែលអ្នកធ្វើជាមួយវត្ថុនោះ នឹងមានឥទ្ធិពលមកលើអ្នកយ៉ាងដូចម្ដេច ?



ក្នុងខែ មិនា និង ខែ មេសា ឆ្នាំ ១៨៣២ ព្រះអម្ចាស់បានត្រាស់បង្គាប់ថ្នាក់ដឹកនាំនៃសាសនាចក្រ ឲ្យបង្កើតសហគ្រាសសាមគ្គីភាព ( ឬ សហសមាគម ) ដែលសមាជិកទាំងឡាយនៅក្នុងសហគ្រាសនោះ នឹងទទួលខុសត្រូវចំពោះការគ្រប់គ្រងលើអាជីវកម្ម និង ដំណើរការបោះពុម្ពរបស់សាសនាចក្រដើម្បីមើលថែដល់ជនក្រីក្រ និង ពង្រីកកិច្ចការរបស់ទ្រង់ ។ នានិទាឃរដូវឆ្នាំ ១៨៣៤ ថ្នាក់ដឹកនាំសាសនាចក្រ បានពិចារណាអំពីការរំលាយសហគ្រាសនេះវិញ យោងលើហេតុផលជាច្រើន ។ ទោះជាយ៉ាងណាក៏ដោយ ព្រះអម្ចាស់បានមានព្រះទ័យឲ្យពួកបងប្អូនប្រុស បង្កើតវាឡើងវិញ ហើយបែងចែកទ្រព្យសម្បត្តិ ក្នុងចំណោមសមាជិកនៃសហគ្រាសនោះតាមតំណែងរបស់ខ្លួន ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១–៤ រួចស្វែងរកមូលហេតុមួយ ដែលបង្កឲ្យមានបញ្ហាដល់សហសមាគម ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:៥–១០ មាននូវព្រះរាជឱង្ការពីព្រះអម្ចាស់ដែលប្រកាសថា លទ្ធផលនៃការល្មើសសេចក្ដីសញ្ញាដែលមានក្នុងសហសមាគម នឹងត្រូវបណ្ដាសា ហើយកាត់ចេញពីសាសនាចក្រ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១១–១៣ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថា សមាជិកគ្រប់រូបនៃសហសមាគមត្រូវទទួលបាន ។ ( វាអាចនឹងផ្ដល់អត្ថប្រយោជន៍ក្នុងការដឹងថា *អ្នកកាន់កាប់ត្រួតត្រា* គឺជាបុគ្គលដែលត្រូវបានផ្ដល់ឲ្យការទទួលខុសត្រូវ ចំពោះអ្វីមួយដែលជាកម្មសិទ្ធរបស់បុគ្គលម្នាក់ទៀត ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១៤ ដោយស្វែងរកថាតើនរណា ជាម្ចាស់កម្មសិទ្ធលើទ្រព្យសម្បត្តិដែលមាននៅក្នុងសហសមាគម ។ សូមគូសចំណាំឃ្លា ដែលបង្រៀនអំពីសេចក្ដីពិតដែលថា **ព្រះអម្ចាស់បានបង្កើតផែនដី និង គ្រប់ទាំងអស់ដែលមាននៅលើនោះ ។**

១. សូមបំពេញកិច្ចការខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមរាយបញ្ជីនៃទ្រព្យសម្បត្តិខាងលោកិយចំនួន ១០ ដែលអ្នកមាន ( ឧទាហរណ៍ ទីលំនៅ សម្លៀកបំពាក់ សួនច្បារ ម្ហូបអាហារ ) ។

ខ. សូមសរសេរអំពីរបៀបដែលគោលលទ្ធិ ដែលមានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១៤ អាចនឹងមានឥទ្ធិពលទៅលើអ្វី ដែលអ្នកគិតអំពីទ្រព្យសម្បត្តិទាំងនោះ ហើយប្រើប្រាស់ពួកវា ។

ការត្រាស់ក្រើនរំឭកពីព្រះអម្ចាស់ដល់ពួកបរិសុទ្ធថា គ្រប់របស់ទាំងឡាយនៅលើផែនដីនេះសុទ្ធតែជារបស់ផងទ្រង់ អាចអះអាងដល់ពួកគេបានថា ទ្រង់អាចផ្គត់ផ្គង់ដល់សេចក្ដីត្រូវការខាងសាច់ឈាមរបស់ពួកគេបាន ។ ទ្រង់បានបន្តមានព្រះបន្ទូលដោយពន្យល់ អំពីរបៀបដែលទ្រង់អាចទាញយកធនធាននានា មកផ្គត់ផ្គង់ដល់ពួកបរិសុទ្ធរបស់ទ្រង់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១៥–១៦ ដោយស្វែងរកថាតើព្រះអម្ចាស់បានមានព្រះបន្ទូល ថាទ្រង់នឹងផ្គត់ផ្គង់ដល់ពួកបរិសុទ្ធនោះយ៉ាងដូចម្ដេច ។

អែលឌើរ យ៉ូសែប ប៊ី វឺតលីន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានផ្ដល់ការយល់ដឹងជ្រៅជ្រះអំពីរបៀបដែលព្រះអម្ចាស់ផ្គត់ផ្គង់ដល់ពួកបរិសុទ្ធរបស់ទ្រង់ ៖ « របៀបរបស់ព្រះអម្ចាស់រួមមាន ការជួយដល់មនុស្សឲ្យចេះជួយខ្លួនឯង ។ ជនក្រីក្រត្រូវបានតម្កើងឡើង ដោយសារតែពួកគេខិតខំធ្វើការដើម្បីទទួលបានជំនួយខាងសាច់ឈាម ពួកគេបានរៀនគោលការណ៍ដ៏ត្រឹមត្រូវ ហើយពួកគេមានលទ្ធភាពលើកស្ទួយខ្លួនគេឡើងចេញពីភាពក្រីក្រទៅកាន់ភាពខ្លួនទីពឹងខ្លួន ។ អ្នកមានត្រូវបានបន្ទាបចុះ ដោយសារពួកគេមានភាពរាបទាប ក្នុងការចែករំលែកទ្រព្យសម្បត្តិពួកគេដល់មនុស្សទ័លក្រ ដោយសទ្ធា » ( Inspired Church Welfare » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៩៩ ទំព័រ ៧៧ ) ។ សព្វថ្ងៃនេះ « របៀបរបស់ព្រះអម្ចាស់ » ក្នុង « ការជួយដល់មនុស្សឲ្យចេះជួយខ្លួនឯង » មានបញ្ចូលទៅក្នុងកម្មវិធីសុខុមាលភាពសាសនាចក្រ និង ការប្រមូលដង្វាយតមអាហារ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១៧–១៨ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានណែនាំយើងឲ្យធ្វើ ជាមួយនឹងរបស់ដ៏បរិបូរដែលទ្រង់បានបង្កើតមក ។

យើងរៀនចេញពីខគម្ពីរទាំងនេះថា **យើងទទួលខុសត្រូវលើការប្រើប្រាស់របស់ ដែលព្រះអម្ចាស់បានប្រទានឲ្យយើង ដើម្បីជួយដល់មនុស្សទូទៅ ។**

សូមគិតត្រឡប់ទៅឧទាហរណ៍នៃកូនសោឡាន ដែលបានលើកឡើងនៅដើមមេរៀននេះ និង របៀបដែលអ្នកប្រើប្រាស់ឡាននោះ អាចមានឥទ្ធិពលដោយសារតែការទទួលខុសត្រូវរបស់អ្នក ដែលមានចំពោះវា ។ តើការណ៍នេះទាក់ទងទៅនឹងសេចក្ដីពិតដែលអ្នកបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១៤–១៨ យ៉ាងដូចម្ដេច ?

យើងអាចគិតអំពី « ជនក្រីក្រ និង អ្នកខ្វះខាត » ថា ពួកគាត់មិនគ្រាន់តែជាមនុស្សដែលមានសេចក្ដីត្រូវការខាងហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមនុស្សដែលមានសេចក្ដីត្រូវការខាងវិញ្ញាណ ខាងផ្លូវចិត្ត ខាងសតិអារម្មណ៍ និង ខាងសង្គមដែរ ។ ស្រដៀងគ្នានេះដែរ យើងអាចគិតអំពីភាពដ៏បរិបូររបស់យើងឲ្យបានច្រើនជាងការគិតតែអំពីប្រាក់កាស ឬ ភោគទ្រព្យដែលយើងមាននោះ ។ ភាពដ៏បរិបូររបស់យើងក៏រួមបញ្ចូលទាំងពេលវេលា ទេពកោសល្យ ចំណេះដឹង និង ជំនាញនានារបស់យើងដែរ ។



២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ហេតុអ្វីបានជាសំខាន់ដែលយើង ត្រូវចែករំលែកភាពបរិបូរដែលទទួលបានមកពីព្រះអម្ចាស់ ?

ខ. តើគំរូនៃតួអង្គមួយចំនួនណាខ្លះ នៅក្នុងព្រះគម្ពីរ ដែលបានជួយដល់អ្នកខ្វះខាត ? តើពួកគេបានជួយមនុស្សទូទៅ នៅតាមរបៀបរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេចខ្លះ ?

គ. តើអ្នកអាចជួយមនុស្សទូទៅ នៅតាមរបៀបរបស់ព្រះអម្ចាស់បានយ៉ាងដូចម្ដេចខ្លះ ? ( សូមសរសេរគោលដៅជាក់លាក់ដើម្បីធ្វើដូចនោះ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១៩–៧៧

*ព្រះអម្ចាស់ ប្រទានការណែនាំអំពីសហសមាគម កិច្ចត្រួតត្រា និង រតនាគារ*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:១៩–៥៣ ព្រះអម្ចាស់បានប្រទានសេចក្ដីណែនាំជាក់លាក់ៗ ស្ដីពីកិច្ចត្រួតត្រាផ្សេងៗ ដែលត្រូវបានចាត់តាំងដល់សមាជិកខុសៗគ្នាក្នុងសហសមាគម ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:២៣, ២៥, ៣១, ៣៣, ៣៥, ៣៨, ៤២, ៤៦ ដោយស្វែងរកគំរូមួយនៅក្នុងសេចក្ដីសន្យា ដែលព្រះអម្ចាស់បានធ្វើជាមួយសមាជិកនីមួយៗក្នុងសហសមាគម ។ វាអាចនឹងជួយអ្នក ដែលត្រូវដឹងថាឃ្លា « ដរាបណា » មានន័យថា « ល្គឹកណាតែ » ឬ « បើសិនជា » ។

*ការស្វែងរកការទំនាក់ទំនង លំនាំ និង គោលគំនិតទាំងឡាយ*

នៅពេលអ្នកសិក្សាព្រះគម្ពីរ សូមស្វែងរកទំនាក់ទំនង លំនាំ និង គោលគំនិតនៅក្នុងវគ្គបទគម្ពីរផ្សេងៗ ។ ការស្គាល់អំពីលំនាំនៅក្នុងសេចក្ដីណែនាំ និង ពរជ័យដែលបានសន្យា អាចជួយអ្នកគិតអំពី របៀបដែលសេចក្ដីណែនាំ និង ពរជ័យទាំងឡាយនោះ អនុវត្តនៅក្នុងជីវិតរបស់អ្នក ។

៣. យោងតាមអ្វីដែលអ្នកបានសិក្សានៅក្នុងខគម្ពីរទាំងនេះ សូមសរសេរគោលការណ៍មួយដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ដោយពន្យល់អំពីអ្វីដែលនឹងកើតឡើង ដរាបណាយើងបន្ទាបខ្លួន ហើយមានចិត្តស្មោះត្រង់ ។ បន្ទាប់មក សូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើអ្នកអាចរៀនអ្វីខ្លះ ចេញពីគោលការណ៍នេះ អំពីរបៀបដែលការគោរពប្រតិបត្តិ មានឥទ្ធិពលលើពរជ័យដែលអ្នកទទួលបាន ?

ខ. តើនៅពេលណាខ្លះ ដែលអ្នកធ្លាប់បានឃើញមនុស្សម្នាក់មានចិត្តស្មោះត្រង់ ក្នុងការទទួលខុសត្រូវរបស់ខ្លួនចំពោះព្រះអម្ចាស់ ហើយមានពរដោយសារតែការប្រព្រឹត្តបែបនោះ ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៤:៥៤–៧៧ ព្រះអម្ចាស់បានប្រទានសេចក្ដីណែនាំចំពោះការស្ថាបនារតនាគារឡើង ដែលមូលនិធិទទួលបានពីអ្នកកាន់កាប់ត្រួតត្រា អាចត្រូវបានដាក់ជំនួសដើម្បីជាប្រយោជន៍ដល់សាសនាចក្រមានដូចជាការបោះពុម្ពព្រះគម្ពីរមរមន ។

## គោលលទ្ធិ និង សេចក្តីសញ្ញា ១០៤:៧៨–៨៦

*ព្រះអម្ចាស់មានបន្ទូលណែនាំថ្នាក់ដឹកនាំសាសនាចក្រ អំពីបំណុលនៃសហសមាគម*

សូមគិតអំពីគ្រាមួយ ដែលអ្នកត្រូវបានស្នើឲ្យធ្វើអ្វីមួយដែលអ្នកគិតថាពុំអាចទៅរួច ឬ មានការលំបាកពេកពន់ ដើម្បីឲ្យអ្នកសម្រេចកិច្ចការនោះបាន ។

នៅពេលកំពុងគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ សហសមាគមបានធ្លាក់ទៅក្នុងបំណុលមួយដ៏ធំ ។ មានព្រឹត្តិការណ៍មួយចំនួន ដែលរារាំងសមាគមពីការសងបំណុល ។ ឧទាហរណ៍ ការបំផ្លិចបំផ្លាញរោងពុម្ពពីសំណាក់មនុស្សកំណាចនៅឃុំចាកសុន រដ្ឋ មិសសួរី បានរារាំងពួកបរិសុទ្ធពីការស្វែងរកប្រាក់ចំណូលពីការបោះពុម្ពព្រះគម្ពីរ និង ផលិតផលផ្សេងទៀត ហើយពួកមនុស្សកំណាចក៏បានរារាំងពួកបរិសុទ្ធពីការប្រើប្រាស់ឃ្លាំងនៅក្រុង អ៊ីនឌីប៉េនដែនស៍ ដែរ ។

សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១០៤:៧៨ ដោយគូសចំណាំសេចក្តីណែនាំពីព្រះអម្ចាស់ ស្តីពីបំណុលរបស់សាសនាចក្រ ។

ការសងបំណុលអាចជារឿងមិនអាចទៅរួចចំពោះពួកបរិសុទ្ធ ប៉ុន្តែ ព្រះអម្ចាស់បានប្រទានសេចក្តីណែនាំដើម្បីជួយដល់ពួកគេ ។

៤. នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់អ្នក សូមគូសបន្ទាត់ត្រង់ឈរពីរ—ម្ខាងដាក់ចំណងជើងថា *ប្រសិនបើ* ហើយម្ខាងទៀតដាក់ថា *នោះ*. សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១០៤:៨០–៨២។ នៅក្រោមប្រអប់ឈរ « បើសិនជា » សូមសរសេរអ្វីដែលព្រះអម្ចាស់បានបង្គាប់ឲ្យសមាជិកក្នុងសមាគមធ្វើ ដើម្បីទទួលបានជំនួយពីទ្រង់ក្នុងការសងបំណុលរបស់ពួកគេ ។ នៅក្រោមប្រអប់ឈរ « ខណៈនោះ » សូមសរសេរអ្វីដែលព្រះអម្ចាស់បានសន្យាថានឹងធ្វើ ដើម្បីជួយពួកបរិសុទ្ធឲ្យរួចពីបំណុល ។ យោងតាមអ្វីដែលអ្នកបានអាន និង កត់ត្រា សូមសរសេរអ្វីដែលយើងអាចរៀនចេញពីខគម្ពីរទាំងនេះ ។

៥. សូមធ្វើលំហាត់ពីរ ឬ ច្រើនជាងពីរនៃលំហាត់ទាំងឡាយខាងក្រោមនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមសរសេរអំពីតួអង្គមួយនៅក្នុងព្រះគម្ពីរ ឬ នរណាម្នាក់ដែលអ្នកស្គាល់ ដែលជាឧទាហរណ៍នៃគោលការណ៍ដែលអ្នកបានសរសេរនៅក្នុងលំហាត់ទី ៤ ។ សូមពិពណ៌នាអំពី ថាតើអ្នកមើលឃើញគោលការណ៍នេះនៅក្នុងជីវិតបុគ្គលនេះយ៉ាងដូចម្តេច ។ ឬ អ្នកអាចសរសេរអំពីរបៀបដែលអ្នកធ្លាប់បានឃើញ គោលការណ៍នេះនៅក្នុងជីវិតអ្នក ។

ខ. សូមឆ្លើយសំណួរដូចតទៅនេះ ៖ តើការណ៍មួយចំនួនដែលព្រះអម្ចាស់បានត្រាស់បង្គាប់ឲ្យសមាជិកសាសនាចក្រធ្វើ ដែលអាចនឹងចាត់ទុកថាជាឧបសគ្គនោះ គឺជាអ្វី ? តើការមានចិត្តរាបសា ស្មោះត្រង់ និង ការអធិស្ឋានមានតួនាទីអ្វីខ្លះ ក្នុងការសម្រេចបានការណ៍ដែលព្រះអម្ចាស់បានត្រាស់បង្គាប់ឲ្យអ្នកធ្វើ ?

គ. សូមសរសេររបៀបដែលអ្នកអាចមានចិត្តកាន់តែរាបសា ស្មោះត្រង់ ឬ ពេញដោយការអធិស្ឋាន ដើម្បីឲ្យព្រះអម្ចាស់អាចជួយអ្នក សម្រេចបានការណ៍ដែលទ្រង់បានត្រាស់បង្គាប់ឲ្យអ្នកធ្វើ ។ សូមសរសេរគោលដៅមួយដើម្បីធ្វើវា ។

៦. សូមសរសេរអ្វីដែលនៅខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្តីសញ្ញា ១០៤ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២២ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥

## បុព្វកថា

ដើម្បីគោរពប្រតិបត្តិតាមសេចក្ដីណែនាំរបស់ព្រះអម្ចាស់ នោះព្យាការី យ៉ូសែប ស្ម៊ីធ ថែមទាំងពួកអ្នកស្ម័គ្រចិត្ត និង អ្នកដែលត្រូវបានជ្រើសរើសប្រមាណ ២០០ នាក់ផ្សេងទៀត បានបង្កើតកងទ័ពជំរំស៊ីយ៉ូន ឡើង ដើម្បីផ្ដល់ជំនួយដល់ពួកបរិសុទ្ធដែលត្រូវបាននិរទេសចេញពីឃុំចាកសុន រដ្ឋមិសសួរី ។ នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៨៣៤ កាលកំពុងបោះជំរំនៅក្បែរទន្លេ ហ្វិស៊ីង ក្នុងរដ្ឋមិសសួរី នោះ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានប្រទានការណែនាំអំពីការរំដោះទីក្រុង ស៊ីយ៉ូន ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:១–១៩

*ព្រះអម្ចាស់ណែនាំពួកបរិសុទ្ធ ឲ្យទន្ទឹងរង់ចាំការរំដោះទីក្រុង ស៊ីយ៉ូន*



សូមស្រមៃថាអ្នកគឺជាតន្ត្រីករម្នាក់ ក្នុងវង្សភ្លេងមួយវង្ស ។ ស្រាប់តែនៅចំពាក់កណ្ដាលនៃការប្រគុំ អ្នកកូតវីយូឡុងពីរបីនាក់សម្រេចចិត្តលេងនៅលើទំព័រ ដែលខុសពីតន្ត្រីករឯទៀតនៅក្នុងវង្ស ។ ពួកគេមិនទាន់បានចាប់ផ្ដើមផង ស្រាប់តែអ្នកផ្លុំខ្លុយមួយចំនួនសម្រេចចិត្តលេងក្នុងល្បឿនកាន់តែលឿន ។ នៅខណៈពេលតែមួយនោះ ក្រុមផ្លុំត្រែទាំងមូលសម្រេចចិត្តឈប់លេងយ៉ាងដំណាលគ្នា ។

ក្នុងនាមជាតន្ត្រីករមួយរូបក្នុងវង្សភ្លេងនេះ តើអ្នកនឹងទទួលឥទ្ធិពលពីការសម្រេចចិត្តទាំងនេះយ៉ាងដូចម្ដេច ? តើលទ្ធផលនៃការប្រគុំដូចនេះ នឹងទៅជាយ៉ាងណា ? ហេតុអ្វីបានជាការមានភាពចុះសម្រុងក្នុងគោលបំណង និងការធ្វើការរួមគ្នាចាំបាច់ដើម្បីឲ្យវង្សភ្លេងអាចប្រគុំតន្ត្រីបានយ៉ាងពិរោះក្រអូនក្រអៅ ?

សូមចងចាំថា ក្នុងខែ កុម្ភៈ ឆ្នាំ ១៨៣៤ ព្រះអម្ចាស់បានត្រាស់បង្គាប់ព្យាការី យ៉ូសែប ស្ម៊ីធ និងសមាជិកដទៃទៀត ឲ្យប្រមូលធនធានខាងសាច់ឈាម ហើយជ្រើសរើសអ្នកស្ម័គ្រចិត្តដើម្បីទៅជួយដល់ពួកបរិសុទ្ធ ដែលត្រូវបានជម្លៀសចេញពីឃុំចាកសុន រដ្ឋមិសសួរី ដើម្បីទាមទារយកកម្មសិទ្ធដីធ្លីរបស់ខ្លួនមកវិញ ។ នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥ សូមស្វែងរកថាតើសាមគ្គីភាព ដើរតួយ៉ាងដូចម្ដេចនៅក្នុង កិច្ចខ្នះខ្នែងរបស់ពួកបរិសុទ្ធក្នុងការទាមទារយកដែនដីស៊ីយ៉ូនមកវិញ ។

នៅក្នុងវិវរណៈកាលពីមុន ( សូមមើល គ. និង ស. ១០៣:៣០–៣៤ ) ព្រះអម្ចាស់បានមានព្រះបន្ទូលថ្លែងថា ទ្រង់មានព្រះទ័យចង់ឲ្យមានអ្នកស្ម័គ្រចិត្តចំនួន ៥០០ នាក់ចូលរួមក្នុងកងទ័ពជំរំស៊ីយ៉ូន ។ បើសិនជាមិនមានមនុស្សដល់ ៥០០ នាក់ទេ ចំនួនអ្នកស្ម័គ្រចិត្តជាអប្បបរមាដែលទ្រង់តម្រូវឲ្យមានគឺ ១០០ នាក់ ។ លទ្ធផលចំពោះកិច្ចខិតខំរបស់ព្យាការី យ៉ូសែប ស្ម៊ីធ និងអ្នកដទៃទៀត ក្នុងការជ្រើសរើសអ្នកស្ម័គ្រចិត្ត និង ធនធានសម្រាប់កងទ័ពជំរំស៊ីយ៉ូននោះ ពុំបានជោគជ័យដូចដែលបានសង្ឃឹមទុកនោះទេ ។ នៅត្រឹមពេលដែលជំរំនោះបានចាប់ផ្ដើមចេញដំណើរនៅដើមខែ ឧសភា ឆ្នាំ ១៨៣៤ មានអ្នកស្ម័គ្រចិត្តចំនួនតែ ១២២ នាក់ប៉ុណ្ណោះ ។ ជំរំសីយ៉ូន បានជ្រើសរើសអ្នកស្ម័គ្រចិត្តបន្ថែម នៅតាមផ្លូវធ្វើដំណើរទៅកាន់រដ្ឋ មិសសួរី ។ នៅពេលក្រុមដែល ហៃរុម ស្ម៊ីធ និង ឡាយមិន វ៉ាយ ដែលបានជ្រើសរើសចេញពីដែនដី មីឈីហ្គេន បានមកជួបជាមួយក្រុមរបស់ យ៉ូសែប នៅដើមខែ មិថុនា ឆ្នាំ ១៨៣៤ នោះកងទ័ពជំរំស៊ីយ៉ូនមានបុរសចំនួនជាង ២០០ នាក់ ស្ត្រី ១២ នាក់ និង កុមារ ៩ នាក់ ( សូមមើល Alexander L. Baugh « Joseph Smith and Zion's Camp," *Ensign* ខែ មិថុនា ឆ្នាំ ២០០៥ ទំព័រ ៤៥ ) ។

អាយុជាមធ្យមរបស់បុរសនៅក្នុងកងទ័ពជំរំស៊ីយ៉ូនគឺ ២៩ ឆ្នាំ ។ សមាជិកនៃជំរំដែលមានវ័យក្មេងជាងគេគឺ ១៤ ឆ្នាំ ហើយចាស់ជាងគេគឺ ៧៩ ឆ្នាំ ។ យ៉ូសែប ស្ម៊ីធ ដែលត្រូវបានជ្រើសតាំងឲ្យធ្វើជា « មេបញ្ជាការដឹកនាំពលទ័ពអ៊ីស្រាអែល » ( នៅក្នុង *History of the Church* ២:៣៩ ) បានមានអាយុត្រឹមតែ ២៨ ឆ្នាំប៉ុណ្ណោះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:៧–៨ ដោយស្វែងរកមូលហេតុមួយ ដែលសមាជិកមួយចំនួននៃសាសនាចក្រ ពុំជ្រើសរើសទៅជួយមិត្តភក្ដិពួកបរិសុទ្ធរបស់ពួកគេនៅរដ្ឋ មិសសួរី ។

សមាជិកមួយចំនួននៃសាសនាចក្រ បានរង់ចាំមើលថាតើព្រះធ្វើអន្តរាគមន៍ ហើយជួយពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ដែរឬទេ ពីមុនពួកគេជួយ ឬ ផ្ដល់ជំនួយខាងហិរញ្ញវត្ថុ ទៅដល់មិត្តភក្ដិសមាជិកសាសនាចក្ររបស់ពួកគេនោះ ។ តើអ្នកគិតថា មានអ្វីខុសឆ្គងចំពោះឥរិយាបថនេះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:១–៦ ដោយស្វែងរកថាតើការមិនគោរពប្រតិបត្តិ និងការខ្វះសាមគ្គីភាពបានមានឥទ្ធិពលយ៉ាងដូចម្ដេច ចំពោះសមាជិកនៃសាសនាចក្រ ។ វាអាចនឹងផ្ដល់អត្ថប្រយោជន៍ក្នុងការដឹងថា « ក្រឹត្យវិន័យនៃនគរសេឡេស្ទាល » ដែលមានលើកឡើងនៅក្នុង ខទី ៤–៥ រួមបញ្ចូលទាំងក្រឹត្យវិន័យ និង គោលការណ៍ទាំងឡាយដែលយើងត្រូវគោរពប្រតិបត្តិ ពិធីបរិសុទ្ធដែលយើងត្រូវទទួល និងសេចក្ដីសញ្ញាដែលយើងត្រូវរក្សាដើម្បី គ្រងនគរសេឡេស្ទាល ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើគោលការណ៍មួយណា ដែលយើងអាចរៀនចេញពីខគម្ពីរទាំងនេះ អំពីអ្វីដែលយើងត្រូវធ្វើដើម្បីឲ្យទីក្រុងស៊ីយ៉ូនត្រូវបានស្ថាបនាឡើង ?

ខ. តើអ្នកគិតថា ហេតុអ្វីបានជាដើម្បីស្ថាបនាទីក្រុងស៊ីយ៉ូន តម្រូវឲ្យមានការរួបរួមគ្នា និងការគោរពប្រតិបត្តិ ?

គ. តើបទពិសោធន៍អ្វីខ្លះ ដែលបានជួយដល់អ្នក ឲ្យយល់អំពីសារៈសំខាន់នៃសមាជិកសាសនាចក្រដែលត្រូវមានការរួបរួមគ្នា ?

សមាជិកដែលបានស្ម័គ្រចិត្តចូលរួមក្នុងជំរុំស៊ីយ៉ូន បានជួបប្រទះនឹងឧបសគ្គ ហើយបានឃើញអព្ភូតហេតុជាច្រើនពេញមួយបេសកកម្មរបស់ខ្លួន ។ សូមពិចារណាថាតើអ្នកនឹងឆ្លើយតបយ៉ាងដូចម្ដេច ទៅកាន់ឧបសគ្គមួយចំនួនដូចខាងក្រោមនេះ ៖

កងទ័ពជំរុំស៊ីយ៉ូន បានធ្វើដំណើរប្រមាណ ១,៤៥០ គីឡូម៉ែត្រ ឆ្លងកាត់រដ្ឋចំនួនបី ដោយបានធ្វើដំណើរចន្លោះពី ៣២ ទៅ ៦៤ គីឡូម៉ែត្រ ក្នុងមួយថ្ងៃ និងអស់រយៈពេល ៤៥ ថ្ងៃ ។ សមាជិកក្នុងជំរំបានពងជើង អាកាសធាតុក្ដៅ និងស្អុះស្អាប់ កង្វះអាហារ និងទទួលទានអាហារមិនល្អ ។ ( សូមមើល Alexander L. Baugh, “Joseph Smith and Zion’s Camp,” ទំព័រ ៤៤ *Church History in the Fulness of Times Student Manual,* ការបោះពុម្ពលើកទី ២ [Church Educational System manual ឆ្នាំ ២០០៣ ] ទំព័រ ១៤៣–៤៤) ។ យូរៗម្ដង ដោយការស្រេកទឹកខ្លាំងពេក ជំរុញឲ្យសមាជិកក្នុងជំរំផឹកទឹកថ្លុក ដែលដង្កូវមូសបានបន្សល់មេរោគក្នុងនោះ ( ពេលខ្លះបានប្រើធ្មេញដើម្បីច្រោះទឹក ) ឬផឹកទឹកចេញពីដានសេះ បន្ទាប់ពីមានភ្លៀងខ្លាំង ។ ពេញមួយការធ្វើដំណើរនោះ កងទ័ពជំរំស៊ីយ៉ូនត្រូវបានគំរាមកំហែងជាញឹកញាប់ ដោយអំពើហិង្សាពីមនុស្សដទៃ ។ ( សូមមើល *Church History in the Fulness of Times,* ១៤៤–៤៥) ។

ទោះជាមានឧបសគ្គយ៉ាងណាក្ដី ក៏កងទ័ពជំរំស៊ីយ៉ូនត្រូវបានប្រទានពរឲ្យឃើញអព្ភូតហេតុជាច្រើន ពេញមួយការធ្វើដំណើរនោះដែរ ។ តួយ៉ាងនៅថ្ងៃដ៏ក្ដៅហួតហែងមួយក្នុងខែ មិថុនា ឆ្នាំ ១៨៣៤ ពួកក្នុងជំរំបានធ្វើដំណើរពេញមួយថ្ងៃ ហើយពុំមានទឹកផឹកតាំងពីព្រឹកមកម្ល៉េះ ។ បន្ទាប់ពីបានសង្កេតឃើញមានការរងទុក្ខជាច្រើននៃមនុស្ស ព្រមទាំងសត្វពាហនៈរបស់ពួកគេផងដែរនោះ ព្យាការីបានសួររកប៉ែល ហើយជ្រើសរើសចំណុចមួយ ហើយបានជីកអណ្ដូងដ៏រាក់មួយ ។ ភ្លាមនោះ ទឹកបានចេញពេញអណ្ដូង ហើយវានៅតែមានពេញដដែល ទោះជាក្រោយពីសមាជិកទាំងអស់ក្នុងជំរំ ព្រមទាំងសត្វពាហនៈរបស់ពួកគេផងដែរនោះ បានទទួលទានហើយទាំងអស់ក្ដី ។

នៅពាក់កណ្ដាលខែ មិថុនា ឆ្នាំ ១៨៣៤ កងទ័ពជំរំស៊ីយ៉ូន បានបោះជំរំនៅលើជ្រោយមួយនៃទន្លេ ហ្វិស៊ីង រដ្ឋ មិសសួរី ។ អ្នកស្រុក មិសសួរី ប្រដាប់ដោយអាវុធចំនួនប្រាំនាក់ បានធ្វើដំណើរទៅដល់ជំរំ ហើយបានស្បថថា សមាជិកទាំងឡាយនៃជំរំនឹង « មិនមានជីវិតរហូតដល់ព្រឹកស្អែកឡើយ » ( នៅក្នុង *History of the Church* ២:១០៣ ) ។ ពួកគេបាននិយាយថា ក្រុមមនុស្សកំណាចដែលមានបុរសជាង ៣០០ នាក់ បានប្រមូលគ្នាពីឃុំផ្សេងៗគ្នា ហើយបានត្រៀមខ្លួនធ្វើដំណើរឆ្លងកាត់ទន្លេមិសសួរី មកបំផ្លាញពួកគេបង់ ។ បុរសមួយចំនួននៅក្នុងជំរំបានចង់ប្រយុទ្ធតបត ប៉ុន្តែ ព្យាការីបានសន្យាថា ព្រះអម្ចាស់នឹងថែរក្សាពួកគេ ។ ព្យាការីបានប្រកាសថា « សូមឈរឲ្យស្ងៀម ហើយចាំមើលសេចក្ដីសង្គ្រោះរបស់ព្រះ » ( ដកស្រង់ចេញពី Joseph Holbrook « History of Joseph Holbrook ឆ្នាំ ១៨០៦–១៨៨៥ » ទំព័រ ១៥ នៅក្នុង *Church History in the Fulness of Times* ទំព័រ ១៤៨) ។



ទន្លេ ហ្វិស៊ីង រដ្ឋមិសសួរី

នៅប៉ុន្មាននាទីបន្ទាប់ពីអ្នកស្រុក មិសសួរី បានចាកចេញទៅ ដុំពពកខ្មៅមួយផ្ទាំងតូច បានលេចឡើងគ្របដណ្ដប់លើផ្ទៃមេឃ ។ វាបានរសាត់ទៅភាគខាងកើត លាតត្រដាងឡើងដូចជារមូរក្រដាសបានលាតឡើង បិតបាំងផ្ទៃមេឃដោយភាពងងឹត ។ ព្យុះភ្លៀង ព្រិល ខ្យល់ រន្ទះដ៏ធំ ព្រមទាំងផ្លេកបន្ទោរឆ្វេចឆ្វាចបានលេចឡើង ។ ពួកកងទ័ពជំរំស៊ីយ៉ូនបានរត់ចោលត្រសាលរបស់ខ្លួន ហើយបានរកឃើញជម្រកនៅក្នុងសាលាប្រជុំបាទីស្ទដ៏ចំណាស់មួយនៅក្បែរនោះ ។ នៅពេល យ៉ូសែប ស្ម៊ីធ បានរត់ចូលមកដល់ក្នុង លោកបានស្រែកឡើងថា « បងប្អូនប្រុសៗអើយ ការណ៍នេះមានអត្ថន័យជ្រាលជ្រៅបំផុត ។ ព្យុះនេះគឺជាទីសម្គាល់មកពីព្រះ » ។ ពួកមនុស្សកំណាចដែលប៉ុនប៉ងឆ្លងកាត់ទន្លេ មិសសួរី នោះ ត្រូវបានបញ្ឈប់ដោយសារព្យុះនោះទៅ ។ ព្យុះដ៏ខ្លាំងនោះ បានធ្វើឲ្យគ្រាប់រំសេវរបស់ពួកមនុស្សកំណាចទទឹកសើម ដោយធ្វើឲ្យវាមិនអាចប្រើការបានឡើយ ។ ព្យុះនោះក៏បានបំភ័យ ហើយធ្វើឲ្យសេះរបស់ពួកមនុស្សកំណាចរត់ផាយបែកខ្ញែកអស់រលីងទៅ ហើយបានធ្វើឲ្យកម្ពស់ទឹកទន្លេ ហ្វិស៊ីង កើនឡើងជិតមួយម៉ែត្រ ដែលបានរារាំងពួកគេពីការវាយប្រហារលើកងទ័ពជំរំស៊ីយ៉ូន ។ ( សូមមើល *Church History in the Fulness of Times* ទំព័រ ១៤៨ សូមមើលផងដែរ *History of the Church* ២:១០៤–៥ ) ។

២. បទពិសោធន៍ទាំងនេះបង្ហាញអំពី របៀបដ៏សំខាន់ និងអស្ចារ្យ ដែលព្រះអម្ចាស់បានជួយដល់កងទ័ពជំរំស៊ីយ៉ូន ។ ទ្រង់ក៏បានជួយពួកគេ តាមរបៀបដ៏សាមញ្ញៗដែរ ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគ្រាមួយដែលព្រះអម្ចាស់បានជួយអ្នក ឬ នរណាម្នាក់ដែលអ្នកស្គាល់ ឲ្យសម្រេចគោលបំណងរបស់ទ្រង់ ។

ពីមុនកងទ័ពជំរំស៊ីយ៉ូន បានចាកចេញពីទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ថ្នាក់ដឹកនាំសាសនចក្រ បានទទួលបានការសន្យាពីលោកអភិបាលរដ្ឋ ដានីយ៉ែល ដាំងឃ្លីន ថា បើក្រុមយុត្តិធម៌នៃសន្តិភាពប្រចាំឃុំចាកសុន ពុំធានាសុវត្ថិភាពដល់ពួកបរិសុទ្ធទេ នោះគាត់នឹងប្រើប្រាស់មធ្យោបាយផ្សេងទៀត ដើម្បីដាក់ឲ្យច្បាប់មានដំណើរការ ។ គាត់ក៏បានថ្លែងផងដែរថា កងជីវពលរដ្ឋនឹងចាំបាច់ត្រូវជួយពួកបរិសុទ្ធ ឲ្យត្រឡប់ទៅផ្ទះសម្បែងរៀងៗខ្លួនវិញ ។ បន្ទាប់ពីសមាជិកក្នុងកងទ័ពជំរំស៊ីយ៉ូន បានធ្វើដំណើរទៅដល់រដ្ឋ មិសសួរី ពួកគេបានដឹងថា លោកអភិបាលរដ្ឋ ដានីយ៉ែល ដាំងឃ្លីន ពុំបានរក្សាការសន្យារបស់ខ្លួនថានឹងជួយពួកបរិសុទ្ធនោះទេ ។ ( សូមមើល *Church History in the Fulness of Times* ទំព័រ ១៣៥, ១៤៦–៤៧) ។ ទោះជាមានដំណឹងដ៏ខកចិត្តយ៉ាងនេះក្ដី ក៏ពួកកងទ័ពជំរំស៊ីយ៉ូន នៅតែបានបន្តទៅឆ្ពោះទៅឃុំចាកសុនដែរ ដោយរង់ចាំការបង្ហាញផ្លូវបន្ថែមពីព្រះអម្ចាស់ ។

ការបង្ហាញផ្លូវដ៏ចាំបាច់នេះ បានកើតឡើងនៅក្នុងវិវរណៈពីព្រះអម្ចាស់នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៨៣៤ បន្ទាប់ពីពួកកងទ័ពជំរំស៊ីយ៉ូនបានធ្វើដំណើរជិតប្រាំពីរសប្ដាហ៍ ហើយបានត្រឹមចម្ងាយ ១៦–២០ គីឡូម៉ែត្រប៉ុណ្ណោះ ពីឃុំចាកសុន ។ វិវរណៈនេះ មានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ១០៥ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:៩–១៤ ដោយស្វែងរកការណ៍ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថាពួកគេត្រូវធ្វើ ទាក់ទងទៅនឹងការរំដោះទីក្រុង ស៊ីយ៉ូន ។



សូមស្រមៃថាអ្នកគឺជាសមាជិកម្នាក់ ក្នុងកងទ័ពជំរំស៊ីយ៉ូន ។ បន្ទាប់ពីបានធ្វើដំណើរចម្ងាយនេះមក អ្នកដឹងថា អ្នកនឹងត្រូវរង់ចាំ « មួយរដូវខ្លីសិន » ពីមុនទីក្រុង ស៊ីយ៉ូន នឹងត្រូវរំដោះ ។ តើអ្នកនឹងមានអារម្មណ៍ដូចម្ដេច ?

៣. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមធ្វើបញ្ជីរាយនាមហេតុផលចំនួនពីរ ដែលព្រះអម្ចាស់បានប្រទាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:៩–១៤ ចំពោះមូលហេតុដែលទីក្រុង ស៊ីយ៉ូន ពុំត្រូវបានរំដោះនៅគ្រានោះ ។ ចំពោះហេតុផលនីមួយៗទាំងនេះ សូមពន្យល់អំពីចំណុច ដែលត្រូវកែតម្រូវ ឬ កើតឡើងពីមុនទីក្រុង ស៊ីយ៉ូន អាចត្រូវបានរំដោះ និងអំពីមូលហេតុអ្វី ។

សូមចងចាំថា ការរំដោះទីក្រុង ស៊ីយ៉ូន ពុំគ្រាន់តែជាការទាមទារកម្មសិទ្ធដីធ្លីស៊ីយ៉ូនមកវិញនោះទេ ។ ទោះជាស៊ីយ៉ូនគឺជាទីតាំងខាងសាច់ឈាម ក៏វាជាសង្គមមួយ ដែលបង្កើតឡើងដោយមនុស្សប្រភេទមួយចំនួនដែរ ។ រាស្ត្ររបស់ព្រះអម្ចាស់ត្រូវតែបានញែកឲ្យបរិសុទ្ធ និងមានភាពសក្តិសម ដើម្បីទទួលបានកម្មសិទ្ធដីមកវិញ ហើយស្ថាបនាទីក្រុង ស៊ីយ៉ូន ឡើង ។

សមាជិកភាគច្រើនក្នុងកងទ័ពជំរំស៊ីយ៉ូន បានទទួលយកការណែនាំពីព្រះអម្ចាស់នៅក្នុងវិវរណៈនេះ ប៉ុន្តែ សមាជិកខ្លះបានរអ៊ូរទាំ ហើយពុំបានបន្តមានចិត្តស្មោះត្រង់ឡើយ បន្ទាប់ពីបានដឹងថា ពួកគេនឹងមិនច្បាំងនៅក្នុងរដ្ឋ មិសសួរី នោះ ។ ពួកគេពុំបានយល់ថា ចេតនាដ៏ជ្រៅជ្រះរបស់កងទ័ពជំរំស៊ីយ៉ូន គឺពុំមែនចូលរួមក្នុងចម្បាំង ឬ ទាមទារយកកម្មសិទ្ធដីធ្លីរបស់ពួកបរិសុទ្ធនៅឃុំចាកសុនមកវិញ ដោយប្រើកម្លាំងទ័ពនោះទេ ។ ពួកបុរសនៅក្នុងជំរំបានត្រៀមខ្លួនជាស្រេចដើម្បីធ្វើចម្បាំង បើសិនជាជីវិតរបស់ពួកគេត្រូវបានគំរាមកំហែងនោះ ប៉ុន្តែ ព្រះអម្ចាស់ពុំមានព្រះទ័យរំដោះស៊ីយ៉ូន ដោយកម្លាំងរបស់មនុស្សឡើយ ( សូមមើល គ. និង ស. ១០៣:១៥–១៨; ១០៥:១៤ ) ។ ជាលទ្ធផលនៃវិវរណៈនេះ ដែលត្រាស់បង្គាប់ឲ្យពួកគេរង់ចាំ ហើយពុំធ្វើចម្បាំងនោះ មានបុរសមួយចំនួនបានបះបោរឡើង ហើយក្រោយមកបានក្បត់សាសនា ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:១៨–១៩ ដោយស្វែងរកមូលហេតុដែលព្រះអម្ចាស់ បាននាំពួកកងទ័ពជំរំស៊ីយ៉ូនមកដល់រដ្ឋ មិសសួរី ហើយនៅពេលពួកគេបានធ្វើដំណើរមកដល់ ពួកគេពុំត្រូវធ្វើសកម្មភាពណា ដើម្បីទាមទារយកដីធ្លីឲ្យពួកបរិសុទ្ធនៅស៊ីយ៉ូន នៅគ្រានោះ ។ ( វាអាចនឹងផ្ដល់អត្ថប្រយោជន៍ក្នុងការយល់ថា ការសាកល្បងសេចក្ដីជំនឿ អាចសំដៅទៅលើការពិសោធន៍ថាតើយើងនឹងជ្រើសរើស ដើម្បីទុកចិត្ត ហើយគោរពប្រតិបត្តិតាមព្រះអម្ចាស់ដែរឬទេ ទោះជាស្ថិតនៅក្នុងកាលៈទេសៈបែបណាក៏ដោយនោះ ) ។

សូមពិចារណាអំពីការបង្កើតឃ្លានៅក្នុង ខទី ១៨–១៩ ដែលបង្រៀនសេចក្ដីពិតថា **ព្រះបានរៀបចំព្រះពរទុក សម្រាប់ពួកអ្នកដែលមានចិត្តស្មោះត្រង់ក្នុងការសាកល្បងរបស់ពួកគេ ។**

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើពេលណាដែលអ្នក ឬ នរណាម្នាក់ដែលអ្នកស្គាល់ ធ្លាប់បានទទួលបទពិសោធន៍នៃការសាកល្បងសេចក្ដីជំនឿ ?

ខ. តើការសាកល្បងសេចក្ដីជំនឿ គឺជាការត្រៀមខ្លួនទទួលបានពរជ័យនាពេលអនាគតយ៉ាងដូចម្ដេច ?

ពរជ័យមួយដែលសមាជិកក្នុងកងទ័ពជំរំស៊ីយ៉ូន បានទទួល គឺជាឱកាសបម្រើនៅក្នុងនគររបស់ព្រះអម្ចាស់ ។ ក្នុងខែ កុម្ភៈ ឆ្នាំ ១៨៣៥ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និង កូរ៉ុមទីមួយនៃពួកចិតសិបនាក់ ត្រូវបានបង្កើតឡើង ។ សាវកតាំងពីដំបូងទាំងប្រាំបួននាក់ និង សមាជិកក្នុងកូរ៉ុមទីមួយនៃពួកចិតសិបនាក់ទាំងអស់ បានបម្រើនៅក្នុងកងទ័ពជំរំស៊ីយ៉ូន ។ ( សូមមើល *Church History in the Fulness of Times* ទំព័រ ១៥១) ។



ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនអំពីតួនាទី ដែលកងទ័ពជំរំស៊ីយ៉ូនបានមាន ក្នុងការរៀបចំបុរសទាំងនេះឲ្យមានតំណែងជាអ្នកដឹកនាំ ៖ « ព្រះពុំមានព្រះទ័យឲ្យអ្នកធ្វើចម្បាំងឡើយ ។ ទ្រង់ពុំអាចស្ថាបនានគរទ្រង់ឡើង ដោយមានបុរសដប់ពីរនាក់ ដែលត្រូវបើកទ្វារដំណឹងល្អឲ្យជាតិសាសន៍ទាំងអស់នៅលើផែនដីនោះទេ និង ដោយមានបុរសចិតសិបនាក់ទៀត ស្ថិតនៅក្រោមការដឹកនាំរបស់ពួកគេដើម្បីបន្តកិច្ចការបានឡើយ លើកលែងតែទ្រង់ចម្រាញ់ពួកគេចេញមកពី ក្រុមបុរសដែលបានថ្វាយជីវិតខ្លួន និង ដែលបានលះបង់យ៉ាងធំធេងដូចដែលអ័ប្រាហាំបានធ្វើប៉ុណ្ណោះ » ( នៅក្នុង *History of the Church* ២:១៨២ ) ។

នៅពេលក្រោយមកទៀត ថ្នាក់ដឹកនាំសាសនាចក្រ បានសម្ដែងអំណរគុណចំពោះបទពិសោធន៍ ដែលពួកលោកបានមានក្នុងនាមជាសមាជិកក្នុងកងទ័ពជំរំស៊ីយ៉ូន ។ តួយ៉ាង នៅពេល ព្រិកហាំ យ៉ង់ បានត្រឡប់មកកាន់ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូវិញ មានបុរសម្នាក់បានសួរគាត់ថា « តើលោកបានទទួលប្រយោជន៍អ្វីខ្លះ ពីការធ្វើដំណើរដ៏ឥតប្រយោជន៍ទៅកាន់រដ្ឋ មិសសួរីជាមួយ យ៉ូសែប ស្ម៊ីធ » ? ព្រិកហាំ យ៉ង់ បានបន្លឺតបវិញថា « អ្វីទាំងអស់ ដែលយើងបានឆ្លងកាត់ » ។ គាត់បានបន្ថែមទៀតថា « ខ្ញុំនឹងមិនប្ដូរ *បទពិសោធន៍* ដ៏សែនលំបាក ដែលខ្ញុំបានមាននៅក្នុងការធ្វើដំណើរនោះ ជាមួយនឹងជាមួយនឹងភាពសុខសាន្តនៅឃុំហ្គីហ្គាឡើយ » ( នៅក្នុង B. H. Roberts, “Brigham Young: A Character Sketch,” *Improvement Era* ខែ មិថុនា ឆ្នាំ ១៩០៣ ទំព័រ ៥៦៧ ) ។ នៅជំនាន់នោះ ទីក្រុង ខឺតឡង់ ស្ថិតនៅក្នុងឃុំហ្គីហ្គា ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:២០–៤១

*ព្រះអម្ចាស់ត្រាស់បង្រៀនពួកបរិសុទ្ធ អំពីអ្វីដែលពួកគេត្រូវធ្វើ ពីមុនស៊ីយ៉ូនត្រូវបានរំដោះ*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:២០–៣៧ យើងអានថា ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ពួកបរិសុទ្ធនៅរដ្ឋមិសសួរី អំពីរបៀបដែលពួកគេត្រូវឆ្លើយតបចំពោះសេចក្ដីបៀតបៀន ដែលពួកគេកំពុងជួបប្រទះ ខណៈដែលពួកគេកំពុងរង់ចាំការរំដោះស៊ីយ៉ូននៅថ្ងៃខាងមុខនោះ ។ ទ្រង់បានប្រទានឱវាទឲ្យពួកគេ បន្ទាបខ្លួន ហើយចៀសវាងការមានទំនាស់ ។ ទ្រង់បានពន្យល់ថា ពួកគេត្រូវតែបានញែកចេញជាបរិសុទ្ធ ក្នុងការត្រៀមខ្លួនសម្រាប់ការរំដោះស៊ីយ៉ូននៅទីបំផុត ។ ដូចដែលទ្រង់បានមានព្រះបន្ទូលតាំងពីដំបូង នៅក្នុងវិវរណៈតែមួយនេះថា ពួកគេត្រូវ « បានបង្រៀនឲ្យបានល្អឥតខ្ចោះទៅទៀត ហើយមានការពិសោធន៍ ហើយចេះឲ្យបានល្អឥតខ្ចោះទៅទៀត អំពីកាតព្វកិច្ចរបស់ពួកគេ និងអ្វីៗដែលយើងតម្រូវពីដៃរបស់ពួកគេ » (គ. និង ស. ១០៥:១០ ) ។

ព្រះអម្ចាស់បានបញ្ចប់វិវរណៈនេះ ដោយបានណែនាំពួកបរិសុទ្ធឲ្យធ្វើអ្វីមួយ ដែលមិនមែនចំពោះតែអ្នកដែលបៀតបៀនពួកគេប៉ុណ្ណោះទេ ប៉ុន្តែ គឺសម្រាប់ពិភពលោកទាំងមូល ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:៣៨–៤១ ដោយស្វែងរកអ្វីដែលទ្រង់បានណែនាំឲ្យពួកគេធ្វើ ។ ( នៅពេលអ្នកអាន វាអាចនឹងផ្ដល់អត្ថប្រយោជន៍ក្នុងដឹងថា *ភាវ៉* មានន័យថា ស្វែងរក និង *ទង់ជ័យ* មានន័យថា ទង់ ឬ សញ្ញា ) ។

៥. សូមបំពេញកិច្ចការខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ដោយយោងតាមការបង្រៀនរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥:៣៨–៤១ សូមសរសេរគោលការណ៍មួយ អំពីពរជ័យដែលអាចកើតមាន បើសិនជាយើងព្យាយាមបង្កើតសន្តិភាពជាមួយមនុស្សទូទៅ ។

ខ. សូមរាយបញ្ជីកត្តាចំនួនបួន ឬ ប្រាំ ដែលសមាជិកសាសនាចក្រនៅជំនាន់យើងនេះអាចធ្វើ ដើម្បីព្យាយាមបង្កើតសន្តិភាពជាមួយមនុស្សទូទៅ ជាពិសេសជាមួយជនដែលអាចនឹងបៀតបៀនដល់ពួកគេ ។

គ. សូមជ្រើសរើសកត្តាមួយ ដែលអ្នកបានរាយក្នុងបញ្ជី រួចដាក់គោលដៅដើម្បីអនុវត្តកត្តានោះនៅក្នុងជីវិតអ្នក ។

៦. សូមសរសេរអ្វីដែលនៅខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៥ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៣ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦; ១០៧:១–២០

## បុព្វកថា

ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦ នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៨៣៤ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានហៅ វ៉ារិន ខៅឌើរី ឲ្យធ្វើអធិបតីលើសាសនាចក្រនៅដែនដី ហ្វ្រីដុម រដ្ឋនូវ យ៉ោក និងសហគមន៍ក្បែរៗនោះ ។ វិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧ ត្រូវបានកត់ត្រាក្នុងឆ្នាំ ១៨៣៥ ប៉ុន្តែ ព្រះអម្ចាស់បានប្រទានផ្នែកជាក់លាក់ៗនៃវិវរណៈនេះទៅដល់ យ៉ូសែប ស្ម៊ីធ នៅពេលខុសៗគ្នា ។ នៅគ្រាដែលវិវរណៈនេះត្រូវបានកត់ត្រា សមាជិកនៅក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ ដែលទើបតែបានបង្កើតឡើងនោះ បានត្រៀមខ្លួនចេញបម្រើបេសកកម្ម ។ នេះគឺជាមេរៀនទីមួយ ក្នុងចំណោមមេរៀនទាំងបីនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦

*ព្រះអម្ចាស់ត្រាស់ហៅ វ៉ារិន ខៅឌើរី ឲ្យធ្វើជាសង្ឃជាន់ខ្ពស់ជាអធិបតី នៅដែនដីហ្វ្រីដុម រដ្ឋនូវ យ៉ោក ។*

សូមគិតអំពីគ្រាមួយដែលប៊ីស្សព ឬ ប្រធានសាខាថ្មីមួយរូបត្រូវបានហៅ ។ តើអ្នកគិតថា បុគ្គលនោះមានអារម្មណ៍ដូចម្ដេច ?

ក្នុងឆ្នាំ ១៨៣៤ សាសនាចក្របានមានភាពរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងសហគមន៍នៃដែនដីហ្វ្រីដុម រដ្ឋនូវ យ៉ោក ដែលមានចម្ងាយមិនដល់ ៣២២ គីឡូម៉ែត្រពីទីក្រុង ខឺតឡង់ រដ្ឋអូហៃអូ ។ ព្រះអម្ចាស់បានត្រាស់ហៅអ្នកដឹកនាំបព្វជិតភាព ឲ្យធ្វើអធិបតីលើសមាជិកនៅទីនោះ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦:១ ដើម្បីឃើញរបៀបដែលព្រះអម្ចាស់បានចាត់តាំងឲ្យធ្វើអធិបតី ។




វ៉ារិន ខៅឌើរី គឺជាបងប្រុសរបស់ អូលីវើរ ខៅឌើរី ។ នៅពេល វ៉ារិន ខៅឌើរី ទទួលបានការហៅឲ្យបម្រើជាសង្ឃជាន់ខ្ពស់ជាអធិបតី គាត់អាចមានអារម្មណ៍ស្រដៀងគ្នាទៅនឹងប៊ីស្សព ឬ ប្រធានសាខា ដែលត្រូវបានហៅឲ្យបម្រើថ្មីៗដែរ ។ ព្រះអម្ចាស់បានមានព្រះបន្ទូលលួងលោមចិត្ត នៅពេលបងប្រុស ខៅឌើរី បានទទួលយកការហៅបម្រើថ្មីរបស់គាត់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦:២–៣ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បានត្រាស់បង្គាប់ឲ្យបងប្រុស ខៅឌើរី ធ្វើ នៅពេលគាត់ធ្វើអធិបតីលើសមាជិកសាសនាចក្រនៅក្នុងតំបន់នៃដែនដីហ្វ្រីដុម រដ្ឋនូវ យ៉ោក ។

សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១០៦:៦ រួចស្វែងរកអ្វីដែល វ៉ារិន ខៅឌើរី បានធ្វើ ដែលនាំទៅរកសេចក្តីអំណរនៅឯស្ថានសួគ៌ ។ នៅពេលអ្នកអាន សូមកត់ចំណាំថា ដំបងពេជ្រ គឺជាវត្ថុដែលព្រះមហាក្សត្រកាន់ ។ វាគឺជានិមិត្តរូបនៃសិទ្ធិអំណាច ។ នៅក្នុងខគម្ពីរនេះ ឃ្លា « ក្រាបចំពោះដំបងពេជ្ររបស់យើង » សំដៅទៅលើបងប្រុស ខៅឌើរី កំពុងតែបន្ទាបខ្លួនរបស់គាត់នៅចំពោះព្រះចេស្តារបស់ព្រះ និង ឃ្លា « បំបែកខ្លួនចេញពីកលល្បិចនៃមនុស្ស » ទំនងជាសំដៅទៅលើបងប្រុស ខៅឌើរី កំពុងដកខ្លួនរបស់គាត់ចេញពីអំពើដ៏ឥតបានការ និងទុច្ចរិតនានា ។

សូមពិចារណាអំពីអ្វីដែលអ្នកអាចធ្វើ ដើម្បីបន្ទាបខ្លួនរបស់អ្នក នៅចំពោះព្រះ ហើយបំបែកខ្លួនអ្នកចេញពីអំពើទុច្ចរិតនានា ។

នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១០៦:៧–៨ យើងអានឱវាទរបស់ព្រះអម្ចាស់ប្រទានទៅដល់ វ៉ារិន ខៅឌើរី និងសេចក្តីសន្យារបស់ទ្រង់ថានឹងប្រទានពរដល់ វ៉ារិន ចំពោះការធ្វើតាមឱវាទនោះ ។ សូមអានខគម្ពីរទាំងនេះ រួចសង្ខេបសេចក្តីសន្យារបស់ព្រះអម្ចាស់ ដោយបំពេញចន្លោះដូចតទៅនេះ ៖ **បើយើង ខ្លួនយើងនៅចំពោះព្រះអម្ចាស់ នោះទ្រង់នឹងមានសេចក្តីមេត្តាករុណាមកលើយើង យើងឡើង ហើយប្រទានដល់យើងនូវ ។**

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើព្រះអម្ចាស់លើកអ្នកទាំងឡាយ ដែលបន្ទាបខ្លួនចំពោះទ្រង់ឡើងតាមរបៀបណាខ្លះ ?

ខ. តើនៅពេលណាដែលអ្នកធ្លាប់ឃើញ នរណាម្នាក់ត្រូវបានលើកឡើង ដោយសារតែពួកគេបានបន្ទាបខ្លួនចំពោះព្រះអម្ចាស់ ?

## គោលលទ្ធិ និង សេចក្តីសញ្ញា ១០៧:១–២០

*ព្រះអម្ចាស់បង្រៀនអំពីបព្វជិតភាពមិលគីស្សាដែក និង អើរ៉ុន*

សូមព្យាយាមទាយថាតើព្យាការីមួយណានៃព្រះគម្ពីរសញ្ញាចាស់ ដែលត្រូវបានពិពណ៌នានៅក្នុងកថាខណ្ឌខាងក្រោមនេះ ៖

ព្យាការីរូបនេះ « គឺជាបុរសនៃសេចក្តីជំនឿ ដែលបានរស់នៅដោយសុចរិត ហើយកាលនៅជាកុមារ លោកបានកោតខ្លាចដល់ព្រះ ហើយបានចងមាត់សិង្ហ ថែមទាំងបានពន្លត់ភ្លើងដែលឆេះសន្ធោសន្ធៅ » (ការបកប្រែដោយយ៉ូសែប ស្ម៊ីធ លោកុប្បត្តិ ១៤:២៦ [ នៅក្នុងសេចក្តីបន្ថែមនៃព្រះគម្ពីរប៊ីប ] ) ។ ក្នុងនាមជាស្តេចក្រុងសាឡិម ទ្រង់ « បានបង្កើតសេចក្តីសុខសាន្តនៅក្នុងស្រុកនៅសម័យទ្រង់ ហេតុដូច្នេះហើយ ទ្រង់ត្រូវបានហៅថាជាម្ចាស់នៃសេចក្តីសុខសាន្ត » ( អាលម៉ា ១៣:១៨ ) ។ ព្យាការី អ័ប្រាហាំ បានថ្វាយដង្វាយមួយភាគក្នុងដប់ទៅកាន់លោក ( សូមមើល អាលម៉ា ១៣:១៥ ) ។



សូមមើល អាលម៉ា ១៣:១៤–១៨ ដើម្បីស្វែងរក ថាតើព្យាការីនោះគឺជានរណា ។ បន្ទាប់មកសូមសិក្សា គោលលទ្ធិ និង សេចក្តីសញ្ញា ១០៧:១–៤ រួចស្វែងរកមូលហេតុដែលបព្វជិតភាពមិលគីស្សាដែក ត្រូវបានដាក់ឈ្មោះតាមព្យាការី មិលគីស្សាដែក ។

តើបព្វជិតភាពមិលគីស្សាដែកត្រូវបានហៅថាដូចម្តេច ពីមុនជំនាន់របស់មិលគីស្សាដែក ?

សូមគិតអំពីការគូសចំណាំហេតុផលចំនួនពីរ ដែលបានធ្វើឲ្យសមាជិកសាសនាចក្រនៅជំនាន់បុរាណ ហៅបព្វជិតភាពនេះតាមឈ្មោះលោក មិលគីស្សាដែក ។

អ្នកក៏អាចនឹងគិតអំពីការគូសចំណាំ សេចក្តីថ្លែងការណ៍នៃគោលលទ្ធិដូចតទៅនេះនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១០៧:៣ ៖ **បព្វជិតភាពមិលគីស្សាដែកគឺតាមរបៀបនៃព្រះរាជបុត្រានៃព្រះ ។**



ប្រធាន បយ ដ៍ ខេ ផាកកឺ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់អំពីរបៀប ដែលគោលលទ្ធិនេះនឹងត្រូវបានបង្ហាញនៅក្នុងជីវិតរបស់អ្នកកាន់បព្វជិតភាព ៖ « នៅពេលសិទ្ធិអំណាចបព្វជិតភាពត្រូវបានប្រើប្រាស់យ៉ាងត្រឹមត្រូវ នោះអ្នកកាន់បព្វជិតភាពធ្វើនូវអ្វីដែលទ្រង់ [ ព្រះយេស៊ូវគ្រីស្ទ ] នឹងធ្វើ បើសិនជាទ្រង់មានវត្តមាននៅទីនេះ » ( « The Power of the Priesthood » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៧ ) ។

អ្នកអាចនឹងចង់សរសេរការពន្យល់នេះ ដាក់នៅក្នុងព្រះគម្ពីររបស់អ្នក ក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣ ។

២. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគ្រាមួយដែលអ្នកបានឃើញនរណាម្នាក់ប្រើប្រាស់បព្វជិតភាពយ៉ាងត្រឹមត្រូវ ដោយធ្វើនូវអ្វីដែលព្រះយេស៊ូវគ្រីស្ទនឹងធ្វើ ។

បើសិនជាគ្មានបព្វជិតភាពមិលគីស្សាដែកទេនោះ សាសនាចក្រពុំកើតមានឡើងឡើយ ។ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៥, ៨–៩ ដោយស្វែងរកពាក្យ ឬ ឃ្លាដែលបង្រៀនអំពីរបៀបដែលបព្វជិតភាពមិលគីស្សាដែក ទាក់ទងទៅនឹងអង្គការនានានៃសាសនាចក្រមានដូចជា ថ្នាក់បឋមសិក្សា ថ្នាក់សាលាថ្ងៃអាទិត្យ ថ្នាក់យុវជន ថ្នាក់យុវនារី និងថ្នាក់សមាគមសង្គ្រោះ ។ ( គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៨ គឺជាចំណេះចំណានខគម្ពីរ ។ អ្នកអាចនឹងចង់គូសចំណាំវានៅក្នុងរបៀបមួយដែលងាយសម្គាល់ ដើម្បីអ្នកអាចងាយរកវាឃើញកាន់តែស្រួល ) ។

សូមកត់ចំណាំនៅក្នុង ខទី ៥ ថា អង្គការទាំងនេះត្រូវបានហៅថា បន្ថោងបញ្ជាប់ ។ បន្ថោងបញ្ជាប់គឺជាផ្នែកនៃរូបរាងកាយមានដូចជា ដៃ ឬ ជើង ។

ដើម្បីយល់អំពីសិទ្ធិ និងសិទ្ធិអំណាចនៃបព្វជិតភាពមិលគីស្សាដែក សូមយោងទៅកាន់ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៨ ដើម្បីបំពេញសេចក្ដីថ្លែងការណ៍ដូចតទៅនេះ ៖ **បព្វជិតភាពមិលគីស្សាដែក មានសិទ្ធិខាង អំណាច និង សិទ្ធិអំណាចលើ និងសិទ្ធិអំណាចដើម្បីចាត់ចែង ការណ៍ទាំងឡាយ ។**

« ចាត់ចែងការណ៍ទាំងឡាយខាងវិញ្ញាណ » រួមបញ្ចូលទាំងពរជ័យ ពិធីបរិសុទ្ធ និងសេចក្ដីសញ្ញាទាំងឡាយ ។

៣. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគ្រាមួយដែលអ្នកមានពរ តាមរយៈសិទ្ធិអំណាចនៃបព្វជិតភាពមិលគីស្សាដែក ។ អ្នកអាចសរសេរអំពីគ្រាមួយ ដែលអ្នកបានទទួលពរជ័យ ដែលអ្នកបានចូលរួមក្នុងពិធីបរិសុទ្ធ ឬ ដែលអ្នកបានធ្វើសេចក្ដីសញ្ញា ។

« គណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ » ដែលមានលើកឡើងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៩ គឺជាគណៈប្រធានទីមួយ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:១០ ដោយស្វែងរកថាតើនរណា ដែលមានសិទ្ធិធ្វើការនៅក្រោមដឹកនាំនៃគណៈប្រធានទីមួយ ។

ប្រធានស្ដេក និងគណៈប៊ីស្សព គឺជាលំនាំមួយនៃពួកសង្ឃជាន់ខ្ពស់ធ្វើការ នៅក្នុងគោលជំហររបស់ខ្លួន នៅក្រោមការដឹកនាំនៃគណៈប្រធានទីមួយ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:១៥–១៧ សំដៅទៅលើប៊ីស្សពជាអធិបតីនៃសាសនាចក្រ ។ អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ ៖



« នេះគឺជាតំណែងដែល អើរ៉ុន បានកាន់កាលពីបុរាណ សិទ្ធិទទួលបានតំណែងនេះ គឺជាការស្នងវង្សត្រកូល វាត្រូវបានផ្ដល់ពីឪពុកដែលមានភាពសក្ដិសមទៅដល់កូនដែលមានភាពសក្ដិសម ។. . . ប៉ុន្តែនៅក្នុងវិវរណៈមួយប្រទានឲ្យប្រធាននៃសាសនាចក្រ ចំពោះការកំណត់ខ្សែស្រឡាយ និងបុគ្គលឲ្យកាន់តំណែងជាន់ខ្ពស់នៃគណៈប៊ីស្សព និងគណៈប្រធានលើ គឺគណៈប្រធានទីមួយជាអ្នកជ្រើសតាំង ‹ សង្ឃជាន់ខ្ពស់មួយរូបនៃបព្វជិតភាពមិលគីស្សាដែល › ឲ្យកាន់តំណែងនេះ ។ នៅក្នុងព្រឹត្តិការណ៍នេះដែរ ទីប្រឹក្សាចំនួនពីររូបក៏ត្រូវបានហៅឲ្យបម្រើនៅក្នុងគណៈប៊ីស្សពជាអធិបតីដែរ ។ (គ. និង ស. ៦៨:១៤–២១; ១០៧:១៥–១៧, ៦៨–៧៨ ) ។

« ក្នុងនាមជាអ្នកកាន់កូនសោនៃគណៈប្រធានលើបព្វជិតភាពអើរ៉ុននៃសាសនាចក្រ និងលើប៊ីស្សពដទៃទៀត នោះប៊ីស្សពជាអធិបតី គឺជាពួកអ្នកមានសិទ្ធិអំណាចទូទៅនៃសាសនាចក្រ ។ គាត់អង្គុយក្នុងតំណែងជាចៅក្រមនៅអ៊ីស្រាអែល ដែលទទួលខុសត្រូវលើកិច្ចការខាងអាណាចក្រនៃនគរ ( គ. និង ស. ១០៧:៦៨–៧៤ ) ទទួលដង្វាយដែលសម្រាប់ជួយដល់ជនក្រីក្ររបស់ព្រះអម្ចាស់ ( គ. និង ស. ៤២:៣១–៣៣; ៥១:៥, ១២–១៣ ) ហើយត្រូវបានហៅឲ្យធ្វើដំណើរ និងប្រកាសដំណឹងល្អដើម្បីជាជំនួយដល់ការស្ថាបនានគរឡើង ។ ( គ. និង ស. ៨៤:១១២–១១៦ ) » (*Mormon Doctrine* ការបោះពុម្ពលើកទី ២ [ ឆ្នាំ ១៩៦៦ ] ទំព័រ ៥៩២ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:១៨ រួចគូសចំណាំសេចក្ដីថ្លែងការណ៍នៃគោលលទ្ធិដូចតទៅនេះ ៖ **បព្វជិតភាពមិលគីស្សាដែក កាន់កូនសោនៃរាល់ពរជ័យខាងវិញ្ញាណនៃសាសនាចក្រ ។**

« កូនសោបព្វជិតភាពគឺជាសិទ្ធិអំណាចព្រះ ដែលបានប្រទានដល់ថ្នាក់ដឹកនាំបព្វជិតភាពដើម្បី ដឹកនាំ គ្រប់គ្រង និង ត្រួតត្រាការប្រើប្រាស់បព្វជិតភាពរបស់ទ្រង់នៅលើផែនដី ។ ការប្រើប្រាស់សិទ្ធិអំណាចបព្វជិតភាព គឺត្រូវបានគ្រប់គ្រងដោយអ្នក

ទាំងឡាយដែលកាន់កូនសោ ( សូមមើល គ. និង ស. ៦៥:២; ៨១:២; ១២៤:១២៣ ) ។ អ្នកទាំងឡាយដែលកាន់កូនសោមានសិទ្ធិដើម្បីធ្វើអធិបតី និងដឹកនាំសាសនាចក្រនៅក្នុងដែនកំណត់មួយ » (*ក្បួនខ្នាតភាគ ២ ៖ ការគ្រប់គ្រងសាសនាចក្រ* [ ឆ្នាំ ២០១០ ] ចំណុច ២.១.១) ។ ដែនកំណត់គឺជាតំបន់ភូមិសាស្ត្រមួយ ដែលមនុស្សមួយចំនួនក្នុងតំបន់នោះមាននូវសិទ្ធិអំណាច ។ តួយ៉ាង ដែនកំណត់របស់ប៊ីស្សព គឺជាវួដរបស់គាត់ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៨–៩, ១៨ យើងអានអំពីអំណាច សិទ្ធិអំណាច និងរបៀបរបបនៃបព្វជិតភាពមិលគីស្សាដែក ។ សិទ្ធិនៃគណៈប្រធាននេះ មានទំនាក់ទំនងជាមួយកូនសោនៃបព្វជិតភាព ។ វាក្យសព្ទ « កូនសោនៃបព្វជិតភាព » ត្រូវបានប្រើយ៉ាងហោចណាស់តាមរបៀបចំនួនបី ៖ កូនសោដែលត្រូវបានប្រគល់ដល់ពួកសាវក កូនសោនៃគណៈប្រធាន និងការប្រើប្រាស់ជាទូទៅនៃ « កូនសោបព្វជិតភាព » ។

**កូនសោដែលត្រូវបានប្រគល់ដល់ពួកសាវក ។** អ្នកដែលត្រូវបានតែងតាំងជាសាវកត្រូវបានប្រទានឲ្យនូវ (១) កូនសោនៃពួកសាវក ឬ កូនសោនៃនគរ—ដែលជាអំណាច និងសិទ្ធិអំណាចដើម្បីធ្វើអធិបតីលើសាសនាចក្រ និងនគរព្រះនៅលើផែនដី ( សូមមើល គ. និង ស. ២៧:១២–១៣ ); (២) កូនសោនៃការប្រមូលរាស្ត្រអ៊ីស្រាអែល ឬ កិច្ចការផ្សព្វផ្សាយសាសនា ( សូមមើល គ. និង ស. ១១០:១១ ); (៣) កូនសោនៃគ្រាកាន់កាប់ត្រួតត្រានៃដំណឹងល្អរបស់អ័ប្រាហាំ និងការស្ដារឡើងវិញគ្រប់អ្វីទាំងអស់ ( សូមមើល គ. និង ស. ១១០:១២ សូមមើលផងដែរ គ. និង ស. ២៧:៦–៧ ) និង (៤) កូនសោនៃអំណាចដើម្បីផ្សារភ្ជាប់ ( សូមមើល គ. និង ស. ១១០:១៣–១៥ ) ។ មានតែពួកសាវកប៉ុណ្ណោះ ទើបមានកូនសោបព្វជិតភាពទាំងនេះ ដ្បិតពួកលោកពុំប្រគល់កូនសោទាំងនេះទៅឲ្យមនុស្សដទៃឡើយ ។

« ព្រះយេស៊ូវគ្រីស្ទកាន់កូនសោបព្វជិតភាពទាំងអស់ សម្រាប់សាសនាចក្ររបស់ទ្រង់ ។ ទ្រង់បានប្រទានឲ្យពួកសាវករបស់ទ្រង់ម្នាក់ៗរាល់កូនសោ ដែលមានសម្រាប់នគរព្រះនៅលើផែនដី ។ សាវកច្បងដែលកំពុងរស់នៅ ដែលជាប្រធានសាសនាចក្រ គឺជាបុគ្គលតែម្នាក់គត់នៅលើផែនដីនេះ ដែលត្រូវបានប្រទានសិទ្ធិអំណាចឲ្យប្រើរាល់កូនសោបព្វជិតភាព ( សូមមើល គ. និង ស. ៤៣:១–៤; ៨១:២; ១០៧:៦៤–៦៧, ៩១–៩២; ១៣២:៧ ) ។

« ពួកចិតសិបនាក់ បម្រើតាមការចាត់តាំង និងតាមការផ្ទេរសិទ្ធិអំណាច ពីគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ប្រធានតំបន់ត្រូវបានចាត់តាំងឲ្យគ្រប់គ្រងលើតំបន់នានា ដោយមានការអនុញ្ញាតពីគណៈប្រធានទីមួយ និង ពួកដប់ពីរនាក់ ។ គណៈប្រធាននៃពួកចិតសិបនាក់ ត្រូវបានញែកចេញ និងប្រគល់កូនសោឲ្យធ្វើអធិបតីលើកូរ៉ុមនៃពួកចិតសិបនាក់ » (*ក្បួនខ្នាតភាគ ២* ចំណុច ២.១.១) ។

**កូនសោនៃគណៈប្រធាន ។** « ប្រធាននៃសាសនាចក្របែងចែកកូនសោនៃបព្វជិតភាពទៅថ្នាក់ដឹកនាំបព្វជិតភាពដទៃទៀត ដើម្បីពួកគាត់អាចធ្វើអធិបតីនៅក្នុងផ្នែកនៃការទទួលខុសត្រូវរបស់ខ្លួន ។ កូនសោបព្វជិតភាពត្រូវបានប្រគល់ឲ្យប្រធានព្រះវិហារបរិសុទ្ធ បេសកកម្ម ស្ដេក និងមណ្ឌល ប៊ីស្សព ប្រធានសាខា ព្រមទាំងប្រធានកូរ៉ុមនានា ។ សិទ្ធិអំណាចធ្វើជាអធិបតី មានកំណត់សម្រាប់តែការទទួលខុសត្រូវដែលបានចាត់តាំង និងនៅក្នុងដែនកំណត់ភូមិសាស្ត្រនៃការហៅបម្រើរបស់អ្នកដឹកនាំគ្រប់រូប » (*ក្បួនខ្នាតភាគ ២* ចំណុច ២.១.១) ។



ដោយបានទទួលកូនសោបព្វជិតភាពទាំងនេះ អ្នកដឹកនាំបព្វជិតភាពមានសិទ្ធិអំណាចដើម្បីបម្រើជា អ្នកកាន់តំណែងជាអធិបតី ។ តួយ៉ាង ប៊ីស្សពបម្រើជាសង្ឃជាន់ខ្ពស់ជាអធិបតីនៅក្នុងវួដ ហើយក៏ជាប្រធាននៃបព្វជិតភាពអើរ៉ុននៅក្នុងវួដដែរ ។ ថ្នាក់ដឹកនាំបព្វជិតភាព ដែលទទួលបានកូនសោក៏ត្រូវបានប្រទានឲ្យនូវសិទ្ធិទទួលអំណោយទាន និងអំណាចមានដូចជាអំណោយទាននៃការញាណដឹង ។ ឧទាហរណ៍ ប៊ីស្សពមួយរូបបម្រើជាចៅក្រមទូទៅ ហើយទទួលបានលទ្ធភាពខាងវិញ្ញាណ ដើម្បីជួយសមាជិកដែលត្រូវការដំបូន្មានសម្រាប់បញ្ហាចាំបាច់ផ្ទាល់ខ្លួនរួមមាន អំពើរំលងដ៏ធ្ងន់ធ្ងរ ។

« នៅពេលថ្នាក់ដឹកនាំបព្វជិតភាពត្រូវបានដោះលែងពីការហៅបម្រើរបស់ខ្លួន ពួកលោកពុំកាន់កូនសោដែលជាប់ទាក់ទងនឹងការហៅបម្រើនោះទៀតឡើយ ។

« ទីប្រឹក្សារបស់ថ្នាក់ដឹកនាំបព្វជិតភាព ពុំមានកូនសោនោះទេ ។ ពួកលោកត្រូវបានញែកចេញ ហើយធ្វើការហៅបម្រើរបស់ខ្លួន តាមការចាត់តាំង និងសិទ្ធិអំណាចដែលបានផ្ទេរឲ្យ ។

« អង្គការជំនួយរបស់វួដ និងស្តេកទាំងអស់ ប្រតិបត្តិការនៅក្រោមការដឹកនាំរបស់ប៊ីស្សព និងប្រធានស្តេក ដែលកាន់កូនសោ ដើម្បីធ្វើអធិបតី ។ ប្រធានអង្គការជំនួយ និងទីប្រឹក្សារបស់ពួកគាត់ ពុំមានកូនសោនោះទេ ។ ពួកគាត់មានសិទ្ធិអំណាចដែលបានផ្ទេរឲ្យ ដើម្បីបម្រើនៅក្នុងការហៅរបស់ខ្លួន » (*ក្បួនខ្នាតភាគ ២* ចំណុច ២.១.១) ។

**ការប្រើប្រាស់ជាទូទៅនៃ « កូនសោបព្វជិតភាព »** ។ ការប្រើប្រាស់ជាទូទៅនៃពាក្យសព្ទ « កូនសោបព្វជិតភាព » ឬ « កូនសោនៃបព្វជិតភាព » អាចត្រូវបានយល់ថាជា សិទ្ធិរបស់ថ្នាក់ដឹកនាំបព្វជិតភាព និងមានចំពោះពួកគាត់ ឬ ក្នុងករណីជាច្រើន មានចំពោះសមាជិក ។ សិទ្ធិទាំងនេះ ត្រូវតែបានកំណត់នៅក្នុងបរិបទរបស់វារៀងៗខ្លួន ។ ឧទាហរណ៍ កូនសោចំពោះការបម្រើនៃពួកទេវតា មានសម្រាប់អ្នកកាន់បព្វជិតភាពអើរ៉ុន តាមរយៈសិទ្ធិ ( សូមមើល គ. និង ស. ១៣:១ ) ។ កូនសោនៃសេចក្តីអាថ៌កំបាំងទាំងឡាយនៃនគរ ( សូមមើល គ. និង ស. ៨៤:១៩–២០; ១២៨:១៤ ) មានប្រើប្រាស់នៅក្នុងព្រះវិហារបរិសុទ្ធ ។ កូនសោនៃសេចក្តីសង្គ្រោះ គឺជាគោលលទ្ធិ និងពិធីបរិសុទ្ធនៃដំណឹងល្អ ហើយត្រូវបានផ្តល់ឲ្យអ្នកស្វែងរកសេចក្តីពិត និងភាពសុចរិត ។ បុគ្គលម្នាក់ៗ ត្រូវតែមានភាពសក្តិសម និង បានបំណងប្រាថ្នាចង់បានកូនសោនីមួយៗទាំងនេះ ទើបវាបើកបង្ហាញនៅក្នុងជីវិតរបស់ពួកគេ ។

នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១០៧:១៩ យើងអានអំពីពរជ័យមួយចំនួន ដែលកើតមានតាមរយៈបព្វជិតភាពមិលគីស្សាដែក ។ សូមអានខគម្ពីរនេះ រួចស្វែងរកពរជ័យទាំងនោះ ។



ព្យាការី យ៉ូសែប ស្ម៊ីធ បានពន្យល់អំពីសារៈសំខាន់នៃបព្វជិតភាពមិលគីស្សាដែក ក្នុងការផ្តល់ឲ្យមានពរជ័យ ៖ « បព្វជិតភាពមិលគីស្សាដែក . . . គឺជាបណ្តាញមួយ ដែលតាមរយៈបណ្តាញនោះ ចំណេះដឹង គោលលទ្ធិ ផែនការនៃសេចក្តីសង្គ្រោះ និង រាល់កត្តាសំខាន់ៗ ត្រូវបានបើកសម្តែងពីស្ថានសួគ៌ » ( នៅក្នុង *History of the Church* ៤:២០៧ ) ។

សមាជិកគ្រប់រូបនៃសាសនាចក្រ អាចទទួលបានពរជ័យ ដែលមានមកពីបព្វជិតភាពមិលគីស្សាដែក ។ ពរជ័យទាំងនេះមានដល់មនុស្សទាំងអស់ ដែលទទួលបានពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ ហើយបន្តមានចិត្តស្មោះត្រង់ចំពោះសេចក្តីសញ្ញារបស់ខ្លួន ។

សូមគិតអំពីនរណាម្នាក់ដែលអ្នកស្គាល់ ដែលកាន់បព្វជិតភាពអើរ៉ុន ។ សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១០៧:១៣–១៤, ២០ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បានបង្រៀន អំពីសិទ្ធិអំណាចបព្វជិតភាពអើរ៉ុន ។

យោងតាមអ្វីដែលអ្នកបានរៀនចេញពីខគម្ពីរទាំងនេះ សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ៖ **បព្វជិតភាពអើរ៉ុន កាន់កូនសោនៃ ហើយចាត់ចែងពិធីបរិសុទ្ធខាងក្រៅទាំងឡាយ ។**

តើមានពិធីបរិសុទ្ធអ្វីខ្លះ នៅក្នុង ខទី ២០ ? តើមានពិធីបរិសុទ្ធអ្វីខ្លះទៀត ដែលត្រូវបានចាត់ចែងដោយ សិទ្ធិអំណាចនៃបព្វជិតភាពអើរ៉ុន ?

អែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់អំពីទំនាក់ទំនងរវាងការបម្រើនៃពួកទេវតា និងពិធីបរិសុទ្ធនៃបុណ្យជ្រមុជទឹក និង សាក្រាម៉ង់ ៖



« ពិធីបរិសុទ្ធនៃបព្វជិតភាពអើរ៉ុនទាំងនេះ . . . មានសារៈសំខាន់ចំពោះការបម្រើនៃពួកទេវតា ។

« ‹ ពាក្យ « ទេវតា » គឺត្រូវបានប្រើក្នុងបទគម្ពីរសម្រាប់តួអង្គស្ថានសួគ៌គ្រប់អង្គ ដែលមានសារដំណឹងរបស់ព្រះ › ( ចច យូ ខានុន *Gospel Truth,* ជ្រើសរើសចេញពី Jerreld L. Newquist [ ឆ្នាំ ១៩៨៧ ] ទំព័រ ៥៤ ) ។ បទគម្ពីររៀបរាប់នូវឧទាហរណ៍យ៉ាងច្រើន ដែលពួកទេវតាបានលេចមកជាតួអង្គ ។. . . កាលខ្ញុំនៅក្មេង ខ្ញុំបានគិតថា លក្ខណៈដូចនោះ គ្រាន់តែជាភាពសំខាន់មួយប៉ុណ្ណោះ ដែលហៅថាជាការបម្រើនៃពួកទេវតានោះ ។ ក្នុងនាមជាអ្នកកាន់បព្វជិតភាពអើរ៉ុនវ័យក្មេង ខ្ញុំពុំដែលគិតថា ខ្ញុំនឹងឃើញទេវតាទេ ហើយខ្ញុំបានងឿងឆ្ងល់អំពីលក្ខណៈដូចនោះ មានទាក់ទងអ្វីនឹងបព្វជិតភាពអើរ៉ុន។

« ប៉ុន្តែការបម្រើនៃពួកទេវតា ក៏អាចត្រូវបានលាក់កំបាំងផងដែរ ។ សារលិខិតរបស់ទេវតា អាចត្រូវបានផ្តល់ឲ្យដោយសម្លេង ឬដោយគំនិត ឬអារម្មណ៍ទំនាក់ទំនងនៅក្នុងចិត្ត ។. . .

« . . . ទេវតាភាគច្រើនទំនាក់ទំនងតាមរយៈអារម្មណ៍ ឬ បានស្តាប់ឮ ជាជាងការបានឃើញ ។

« ជាទូទៅ ពរជ័យនៃការមានភាពជាដៃគូ និងទំនាក់ទំនងខាងវិញ្ញាណ គឺមានតែចំពោះអ្នកទាំងឡាយណាដែលស្អាតស្អំប៉ុណ្ណោះ ។. . . តាមរយៈពិធីបរិសុទ្ធបព្វជិតភាពអើរ៉ុននៃពិធីបុណ្យជ្រមុជទឹក និង ពិធីសាក្រាម៉ង់ នោះយើងត្រូវបានស្អាតស្អំពីអំពើបាបរបស់យើង ហើយបានសន្យាថា បើយើងរក្សាសេចក្ដីសញ្ញាទាំងឡាយរបស់យើង នោះយើងនឹងមានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយយើងជានិច្ច ។ ខ្ញុំជឿថា ការសន្យាពុំសំដៅតែទៅលើព្រះវិញ្ញាណបរិសុទ្ធទេ ប៉ុន្តែក៏សំដៅទៅលើការបម្រើនៃពួកទេវតាដែរ ដ្បិត ‹ ពួកទេវតានិយាយដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ហេតុដូច្នោះហើយពួកទេវតានិយាយអំពីព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ › (នីហ្វៃទី២ ៣២:៣ ) ។ ដូច្នេះ គឺអ្នកទាំងឡាយដែលកាន់បព្វជិតភាពអើរ៉ុន ដែលបើកទ្វារសម្រាប់សមាជិកសាសនាចក្រទាំងអស់ ដែលទទួលទានពិធីសាក្រាម៉ង់ដោយសក្ដិសម ដើម្បីរីករាយនឹងភាពជាដៃគូនៃព្រះវិញ្ញាណនៃព្រះអម្ចាស់ និងការបម្រើនៃពួកទេវតា » ។ ( « The Aaronic Priesthood and the Sacrament » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ទំព័រ ៣៨–៣៩ ) ។

៤. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបដែលអ្នកមានពរ តាមរយៈបព្វជិតភាពអើរ៉ុន ។ ( អ្នកអាចនឹងចង់គិតអំពីពិធីបុណ្យជ្រមុជទឹក និងបទពិសោធន៍របស់អ្នកក្នុងការទទួលទានសាក្រាម៉ង់ ) ។

សូមសរសេរតំណែងបព្វជិតភាពដូចតទៅនេះ ដាក់នៅក្រោមចំណងជើងត្រឹមត្រូវក្នុងតារាង ៖ អែលឌើរ សង្ឃជាន់ខ្ពស់ លោកអយ្យកោ ពួកចិតសិបនាក់ សាវក ឌីកុន គ្រូ សង្ឃ ប៊ីស្សព ។ ( តំណែងបព្វជិតភាពចំនួនពីរ សាវក និង ប៊ីស្សព ត្រូវបានដាក់បញ្ចូលទៅក្នុងទីតាំងត្រឹមត្រូវ ) ។

| បព្វជិតភាពមិលគីស្សាដែក | បព្វជិតភាពអើរ៉ុន |
|---|---|
| សាវក | ប៊ីស្សព |
| | |
| | |
| | |
| | |

អ្នកនឹងយោងទៅកាន់តារាង នៅក្នុងមេរៀនចំនួនពីបន្ទាប់ទៀត នៅពេលអ្នករៀនបន្ថែមអំពីតំណែងបព្វជិតភាព ។

## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៨

៥. ដើម្បីយល់អំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៨ ឲ្យបានកាន់តែច្បាស់ សូមអានពាក្យមួយម៉ាត់ដំបូងគេ « បព្វជិតភាព » ឲ្យឮៗ ។ បន្ទាប់មក សូមអានពាក្យពីរម៉ាត់ដំបូងគេ ៖ « បព្វជិតភាពមិលគីស្សាដែក » ។ សូមបន្តអនុវត្តតាមលំនាំនេះ រហូតដល់អ្នកទន្ទេញចាំខគម្ពីរទាំងមូល ។ សូមបិទព្រះគម្ពីររបស់អ្នក រួចព្យាយាមសូត្រខគម្ពីរទាំងមូលចេញពីការចងចាំ ។ បើអ្នកពុំអាចសូត្រចេញពីការចងចាំទេ សូមបើកព្រះគម្ពីររបស់អ្នកម្ដងទៀត ហើយធ្វើតាមលំនាំដដែល ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមកត់ត្រាអំពីកាលបរិច្ឆេទដែលអ្នកបានបញ្ចប់លំហាត់នេះ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៦; ១០៧:១–២០ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និងការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២១–៣៨

## សេចក្ដីផ្ដើម

ក្នុងខែ មេសា ឆ្នាំ ១៨៣៥ សមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ដែលត្រូវបានតែងតាំងថ្មីៗ បាននៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ដោយរៀបចំខ្លួនចេញដំណើរទៅកាន់បេសកកម្មកូរ៉ុមទីមួយ ។ ពីមុនពួកគាត់ចាកចេញទៅ ព្យាការី យ៉ូសែប ស្ម៊ីធ បានចែកចាយវិវរណៈមួយចំនួនដែលលោកទទួលបាន ទៅកាន់ពួកគាត់ ដែលសព្វថ្ងៃនេះមានចែងនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧ ។ នេះគឺជាមេរៀនទីពីរក្នុងចំណោមមេរៀនទាំងបី នៃកណ្ឌមួយនេះ ។ នៅក្នុងចំណែកនៃវិវរណៈនេះ ព្រះអម្ចាស់បានណែនាំអំពីករណីយកិច្ចរបស់កូរ៉ុមដែលជាអធិបតីនៃសាសនាចក្រ ៖ គណៈប្រធានទីមួយ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និង ពួកចិតសិបនាក់ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២១–២៦

*ព្រះអម្ចាស់ណែនាំអំពីករណីយកិច្ច និង សិទ្ធិអំណាចនៃកូរ៉ុមដែលជាអធិបតីនៃសាសនាចក្រ*

សូមគិតអំពីគ្រាមួយនៅពេលនរណាម្នាក់បានទ្រទ្រង់ គាំទ្រ ការពារ ហើយលើកទឹកចិត្តអ្នក ។ តើមានភាពខុសប្លែកយ៉ាងដូចម្ដេច នៅពេលមាននរណាម្នាក់ជួយអ្នកតាមរបៀបនេះ ?

នៅក្នុងបទគម្ពីរ *គាំទ្រ* នរណាម្នាក់ មានន័យថា យើងទ្រទ្រង់ គាំទ្រ ការពារ ឬ លើកទឹកចិត្តដល់បុគ្គលនោះ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២១–២២ ដោយស្វែងរកថាតើនរណា ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថា សមាជិកគួរតែគាំទ្រ ។

ស្របតាម ខទី ២២ តើយើងគាំទ្រគណៈប្រធានទីមួយតាមរបៀបណា ? សូមឆ្លើយសំណួរនេះ ដោយបំពេញសេចក្ដីថ្លែងការណ៍ដូចតទៅនេះ ៖ **គណៈប្រធានទីមួយត្រូវបានគាំទ្រដោយ, និង នៃសាសនាចក្រ ។** អ្នកអាចនឹងចង់គូសចំណាំពាក្យ ឬ ឃ្លាដែលបង្រៀនអំពីសេចក្ដីពិតនេះ ។ ( សូមកត់ចំណាំថា នៅក្នុង ខទី ២២ ឃ្លា « បានរើសឡើងដោយក្រុម » ពុំមានន័យថា សមាជិកសាសនាចក្រ ជ្រើសរើសអ្នកដែលត្រូវបម្រើនៅក្នុងគណៈប្រធានទីមួយនោះទេ ។ វាសំដៅទៅលើឆន្ទៈរបស់សមាជិកសាសនាចក្រ ដែលត្រូវគាំទ្រដល់ថ្នាក់ដឹកនាំទាំងនោះ ) ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

   ក. តើអ្នកគិតថាវាមានន័យដូចម្ដេច ដែលត្រូវគាំទ្រដល់គណៈប្រធានទីមួយ ដោយសេចក្ដីទុកចិត្ត សេចក្ដីជំនឿ និង សេចក្ដីអធិស្ឋាន ?

   ខ. ចេញពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក តើយើងមានពរតាមរបៀបណា នៅពេលយើងទ្រទ្រង់ ហើយគាំទ្រដល់គណៈប្រធានទីមួយនោះ ?

   គ. តើអ្នករៀនអ្វីខ្លះ ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២១–២២ អំពីគណៈប្រធានទីមួយ ?

នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន ហិនរី ប៊ី អាវរិង ក្នុងគណៈប្រធានទីមួយ សូមគូសបន្ទាត់ពីក្រោមអ្វី ដែលលោកបានមានប្រសាសន៍ថា យើងអាចធ្វើ ដើម្បីគាំទ្រថ្នាក់ដឹកនាំសាសនាចក្ររបស់យើង ៖



« ចំពោះយើង ដើម្បីគាំទ្រដល់អ្នកទាំងឡាយ ដែលត្រូវបានហៅ . . . យើងត្រូវតែពិនិត្យពិច័យលើជីវិតរបស់យើង ប្រែចិត្តបើចាំបាច់ សន្យាថានឹងគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ ហើយធ្វើតាមពួកអ្នកបម្រើរបស់ទ្រង់ ។. . .

« . . . វានឹងជារឿងឈ្លាសវៃក្នុងការប្ដេជ្ញាចិត្តថានឹងគាំទ្រដោយសេចក្ដីជំនឿ និង សេចក្ដីអធិស្ឋានរបស់យើង ដល់អ្នកទាំងឡាយដែលបម្រើយើងនៅក្នុងនគរ ។ ខ្ញុំយល់ច្បាស់ដោយខ្លួនខ្ញុំផ្ទាល់ អំពីអំណាចនៃសេចក្ដីជំនឿរបស់សមាជិកសាសនាចក្រ ក្នុងការគាំទ្រដល់អ្នកទាំងឡាយដែលត្រូវបានហៅ ។. . . ខ្ញុំបានមានអារម្មណ៍ពីការអធិស្ឋាន និងសេចក្ដីជំនឿរបស់មនុស្សដែលខ្ញុំមិនស្គាល់ ហើយពួកគេបានស្គាល់ខ្ញុំថាជាមនុស្សម្នាក់ដែលត្រូវបានហៅឲ្យបម្រើ តាមរយៈកូនសោបព្វជិតភាព » ( The True and Living Church » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៨,ទំព័រ ២១ ) ។

សូមគិតអំពីអ្វីដែលអ្នកកំពុងធ្វើនាពេលបច្ចុប្បន្ននេះ ក្នុងការគាំទ្រដល់គណៈប្រធានទីមួយ និង ថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រ ។ តើអ្នកអាចទ្រទ្រង់ គាំទ្រ ការពារ ឬ លើកទឹកចិត្តដល់ពួកលោកតាមរបៀបណា ?



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២៣ ដោយស្វែងរកថាតើព្រះអម្ចាស់បានមានព្រះបន្ទូលយ៉ាងដូចម្ដេចខ្លះអំពីករណីកិច្ចរបស់ពួកសាវកដប់ពីរនាក់ ។ តើពួកសាវកដប់ពីរនាក់ ត្រូវបានហៅឲ្យធ្វើអ្វី ?

អ្នកអាចនឹងចង់គូសចំណាំ ពាក្យ ឬ ឃ្លានៅក្នុងព្រះគម្ពីររបស់អ្នក ដែលបង្រៀនអំពីសេចក្ដីពិតដូចតទៅនេះ ៖ **ពួកសាវកគឺជាសាក្សីពិសេសអំពីព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ នៅពេញសព្វក្នុងពិភពលោក ។**

តើអ្នកគិតថាវាមានន័យដូចម្ដេចដែលថា ពួកសាវកគឺជាសាក្សីពិសេសអំពីព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ?

សូមសិក្សានៅក្នុង សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ឬ នៅក្នុង Bible Dictionary នូវអ្វីដែលប្រាប់អំពី ពាក្យ និងងារនៃ *សាវក ។*

ប្រធាននៃសាសនាចក្រ គឺជាសាវកច្បងនៅលើផែនដី ចំណែកឯទីប្រឹក្សានៅក្នុងគណៈប្រធានទីមួយ ក៏ជាសាវកផងដែរ ។ ហេតុដូច្នេះហើយ សមាជិកទាំងឡាយក្នុងគណៈប្រធានទីមួយ ក៏ត្រូវបានហៅថាសាក្សីពិសេសអំពីព្រះនាមនៃព្រះយេស៊ូវគ្រីស្ទដែរ ។



អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនអំពីអត្ថន័យនៃការធ្វើជាសាក្សីពិសេសនៃព្រះនាមនៃព្រះគ្រីស្ទ ៖ « តួនាទីរបស់សាវកនាពេលសព្វថ្ងៃនេះ គឺជាតួនាទីដូចគ្នាទៅនឹងសាវកពីបុរាណដែរ ( សូមមើល កិច្ចការ ១:២២; ៤:៣៣ ) ។ តួនាទីរបស់យើងគឺចេញទៅពាសពេញពិភពលោក ហើយប្រកាសអំពី ‹ ព្រះយេស៊ូវគ្រីស្ទ និង ទ្រង់ដែលត្រូវឆ្កាង › ( សូមមើល ម៉ាកុស ១៦:១៥; កូរិនថូស ទី១ ២:២ ) ។ សាវកម្នាក់គឺជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ និង ជាសាក្សីពិសេសអំពីព្រះនាមនៃព្រះគ្រីស្ទ ។ ‹ ព្រះនាមនៃព្រះគ្រីស្ទ › សំដៅទៅលើបេសកកម្ម ការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ—ដែលជាសិទ្ធិអំណាច គោលលទ្ធិ និង គុណសម្បត្តិសំខាន់ក្នុងនាមជាព្រះរាជបុត្រានៃព្រះ ដែលត្រូវធ្វើជាព្រះអង្គប្រោសលោះ និង ព្រះអង្គសង្គ្រោះរបស់យើង ។ ក្នុងនាមជាសាក្សីពិសេសអំពីព្រះនាមនៃព្រះគ្រីស្ទ យើងសូមថ្លែងទីបន្ទាល់អំពីភាពពិត ទេវភាព និង ការរស់ឡើងវិញនៃព្រះយេស៊ូវគ្រីស្ទ ដែលជាដង្វាយធួនដ៏និរន្តរ៍ និង អស់កល្បជានិច្ច និង ជាដំណឹងល្អរបស់ទ្រង់ » ( "Special Witnesses of the Name of Christ," *The Religious Educator: Perspectives on the Restored Gospel* វ៉ុល ១២ ទំព័រ ២ [ ឆ្នាំ ២០១១ ] ទំព័រ ១ ) ។

២. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីថាតើអ្នកមានអារម្មណ៍ដូចម្ដេច និងថាតើអ្នកបានរៀនអ្វីខ្លះ នៅពេលអ្នកបានស្ដាប់ ឬ អានសក្ខីភាព ឬ ទីបន្ទាល់ របស់ពួកសាវក ។ ( វាអាចនឹងផ្ដល់អត្ថប្រយោជន៍ ក្នុងការរំឭកអំពីសុន្ទរកថាសន្និសីទទូទៅរបស់ពួកសាវក នៅក្នុងទស្សនាវដ្ដីសាសនាចក្រ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២៤ ដោយស្វែងរកថាតើព្រះអម្ចាស់បានមានព្រះបន្ទូលយ៉ាងដូចម្ដេច អំពីសិទ្ធិអំណាច និង អំណាចរបស់កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។

នៅពេលបុរសទាំងឡាយត្រូវបានតែងតាំងជាសាវក នោះពួកលោកត្រូវបានប្រគល់ឲ្យនូវកូនសោបព្វជិតភាព ជាប្រធាននៃសាសនាចក្រ ។ ទោះជាយ៉ាងណាក៏ដោយ ចំពោះប្រធាននៃសាសនាចក្រ ក្នុងនាមជាសង្ឃជាន់ខ្ពស់ត្រួតត្រាលើបព្វជិតភាពមិលគីស្សាដែក លោកគឺជាបុរសតែម្នាក់គត់នៅលើផែនដីនេះ ដែលត្រូវបានអនុញ្ញាតឲ្យប្រើកូនសោទាំងឡាយនៃបព្វជិតភាព ។ ពួកសាវកដទៃទៀតប្រើកូនសោទាំងនេះ ដោយបានទទួលការអនុញ្ញាតពីប្រធាននៃសាសនាចក្រ ។ នៅពេលប្រធាននៃសាសនាចក្រទទួលមរណភាព គណៈប្រធានទីមួយត្រូវបានរំសាយ ចំណែកឯកូរ៉ុមនៃពួកដប់ពីរនាក់ ដែលមានសិទ្ធិអំណាច និង អំណាចស្មើគ្នាទៅនឹងគណៈប្រធានទីមួយដែរនោះ បានក្លាយទៅជាក្រុមដែលធ្វើអធិបតីលើសាសនាចក្រ ។ ក្នុងនាមជាប្រធានកូរ៉ុមនៃពួកដប់ពីរនាក់ សាវកច្បងដែលកំពុងរស់នៅ ត្រូវបានអនុញ្ញាតឲ្យប្រើកូនសោទាំងឡាយនៃបព្វជិតភាពចាប់ពីពេលនោះ ។

អែលឌើរ ដាវីឌ បី ហេត ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀន ៖



« នៅពេលប្រធាននៃសាសនាចក្របានទទួលមរណភាពទៅ តើប្រធានថ្មីត្រូវបានជ្រើសតាំងតាមរបៀបណា ។

« ក្នុងឆ្នាំ ១៨៣៥ ព្រះអម្ចាស់បានប្រទានវិវរណៈ ស្ដីពីកម្មវត្ថុមួយនេះ ដែលបង្ហាញអំពីរបៀបស្នងតំណែងដ៏ត្រឹមត្រូវ ។ វិវរណៈនេះថ្លែងថា កូរ៉ុមនៃពួកសាវកដប់ពីរនាក់ គឺជាក្រុមដែលមានសិទ្ធិអំណាចស្មើគ្នាទៅនឹងគណៈប្រធានទីមួយទីមួយដែរ ។ ( សូមមើល គ. និង ស. ១០៧:២៤ ) ។ « សេចក្ដីនេះមានន័យថា នៅពេលប្រធាននៃសាសនាចក្រទទួលមរណភាព គណៈប្រធានទីមួយត្រូវបានរំសាយ ចំណែកឯកូរ៉ុមនៃពួកដប់ពីរនាក់ ក្លាយទៅជាក្រុមដែលធ្វើអធិបតីលើសាសនាចក្រដោយស្វ័យប្រវត្តិ ។ លំនាំនោះត្រូវបានបង្កើតឡើង នៅពេលប្រធាននៃសាសនាចក្រ យ៉ូសែប ស្ម៊ីធ បានទទួលមរណៈភាព ។. . .

« ដំណើរការដ៏ទេវភាពដែលត្រូវបានបើកសម្ដែងសម្រាប់ការតែងតាំងគណៈប្រធានទីមួយថ្មីនៃសាសនាចក្រ—ដែលជាវិវរណៈមកពីព្រះអម្ចាស់ និង ជាការគាំទ្រដោយមនុស្សនោះ—ត្រូវបានប្រតិបត្តិរហូតដរាបមកដល់បច្ចុប្បន្ននេះ ។ គណៈប្រធានទីមួយត្រូវបាន ‹ គាំទ្រដោយសេចក្ដីទុកចិត្ត សេចក្ដីជំនឿ និង សេចក្ដីអធិស្ឋាននៃសាសនាចក្រ › ។ ( គ. និង ស. ១០៧:២២ ) » ( A Prophet Chosen of the Lord,” *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៦ ទំព័រ ៨ ) ។

បន្ថែមពីលើការពន្យល់អំពីករណីយកិច្ចរបស់គណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ នោះព្រះអម្ចាស់ក៏បានត្រាស់សម្ដែងអំពីករណីយកិច្ចរបស់ពួកចិតសិបនាក់ដែរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២៥ដោយស្វែងរកការណ៍ដែលព្រះអម្ចាស់បានមានព្រះបន្ទូលអំពីករណីយកិច្ចរបស់ពួកលោក ។

អ្នកអាចនឹងចង់គូសចំណាំ ពាក្យ ឬ ឃ្លានៅក្នុង ខទី ២៥ ដែលបង្រៀនអំពីសេចក្ដីពិតដូចតទៅនេះ ៖ **ពួកសាវកគឺជាសាក្សីពិសេសអំពីព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ នៅពេញសព្វក្នុងពិភពលោក ។**

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២៦ ដោយស្វែងរកថាតើព្រះអម្ចាស់បានមានព្រះបន្ទូលយ៉ាងដូចម្ដេច អំពីសិទ្ធិអំណាចរបស់កូរ៉ុមនៃពួកចិតសិបនាក់ ។



អែលឌើរ អើល ស៊ី ធីងឌី ក្នុងគណៈប្រធាននៃពួកចិតសិបនាក់ បានបង្រៀនអំពីសិទ្ធិអំណាចនៃពួកចិតសិបនាក់ ៖ « ពួកចិតសិបនាក់ពុំទទួលបានកូនសោបព្វជិតភាពបន្ថែមនោះទេ ប៉ុន្តែ ដោយមានការចាត់តាំងនីមួយៗ ដែលពួកលោកទទួលបានពីគណៈប្រធានទីមួយ ឬ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ នោះពួកលោកត្រូវបានផ្ទេរសិទ្ធិអំណាច ឲ្យបំពេញការចាត់តាំងដែលបានផ្ដល់ឲ្យ » ( «The Quorums of the Seventy» *Ensign* ខែ សីហា ឆ្នាំ ២០០៥ ទំព័រ ៤៨–៤៩ ) ។

សេចក្ដីថ្លែងការណ៍ខាងក្រោមនេះ អាចនឹងជួយអ្នកយល់អំពីទំនាក់ទំនងរវាងគណៈប្រធានទីមួយ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និង ពួកចិតសិបនាក់ ។

« ព្រះយេស៊ូវគ្រីស្ទកាន់កូនសោបព្វជិតភាពទាំងអស់ សម្រាប់សាសនាចក្ររបស់ទ្រង់ ។ ទ្រង់បានប្រទានឲ្យពួកសាវករបស់ទ្រង់ម្នាក់ៗរាល់កូនសោ ដែលមានសម្រាប់នគរព្រះនៅលើផែនដី ។ សាវកច្បងដែលកំពុងរស់នៅ ដែលជាប្រធានសាសនាចក្រ គឺជាបុគ្គលតែម្នាក់គត់នៅលើផែនដីនេះ ដែលត្រូវបានប្រទានសិទ្ធិអំណាចឲ្យប្រើរាល់កូនសោបព្វជិតភាព ។. . .

« ពួកចិតសិបនាក់ បម្រើតាមការចាត់តាំង និងតាមការផ្ទេរសិទ្ធិអំណាច ពីគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។. . . គណៈប្រធាននៃពួកចិតសិបនាក់ត្រូវបានញែកចេញ ហើយត្រូវបានផ្ដល់ឲ្យនូវកូនសោ ដើម្បីធ្វើជាអធិបតីលើកូរ៉ុមនៃពួកចិតសិបនាក់ » ( *ក្បួនខ្នាតភាគ ២ ៖ ការគ្រប់គ្រងសាសនាចក្រ* [ ឆ្នាំ ២០១០], ២.១.១) ។



ទោះជាព្រះអម្ចាស់បានមានព្រះបន្ទូលថា គណៈប្រធានទីមួយ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និង ពួកចិតសិបនាក់មាន « សិទ្ធិអំណាចស្មើគ្នា » ក្ដី ( គ. និង ស. ១០៧:២៤, ២៦ ) ក៏គណៈប្រធានទីមួយ ធ្វើអធិបតីលើកូរ៉ុមទាំងអស់ដែរ ។ កូរ៉ុមនៃគណៈប្រធានទីមួយ មានប្រធាននៃសាសនាចក្រ ហើយជាធម្មតាមានទីប្រឹក្សាទាំងពីររូប ។ ជាញឹកញាប់ ប៉ុន្តែមិនមែនជាដរាបនោះទេ ទីប្រឹក្សាទាំងពីររូបនោះត្រូវបានជ្រើសតាំងចេញពីកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ « ពួកសង្ឃជាន់ខ្ពស់ត្រួតត្រាបីនាក់ . . . បង្កើតជាកូរ៉ុមគណៈប្រធាននៃសាសនាចក្រ » ( គ. និង ស. ១០៧:២២ ) ។ ពួកលោកមានការទទួលខុសត្រូវ នៃការដឹកនាំនគរព្រះនៅលើផែនដី ( សូមមើល គ. និង ស. ៩០:១២–១៦ ) ។ ព្រះអម្ចាស់បានគូសបញ្ជាក់អំពី សារៈសំខាន់នៃគណៈប្រធានទីមួយ ដោយបានមានព្រះបន្ទូលប្រកាសថា « អស់អ្នកណាដែលទទួលយើង នោះទទួលពួកអ្នកទាំងនោះ គឺគណៈប្រធានទីមួយ ដែលយើងបានចាត់ឲ្យទៅ ដែលយើងបានធ្វើជាទីប្រឹក្សាទាំងឡាយដល់អ្នក ដោយយល់ដល់ព្រះនាមរបស់យើង » ( គ. និង ស. ១១២:២០ ) ។

ដូចបានពន្យល់នៅដើមមេរៀននេះ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ក្លាយទៅជាកូរ៉ុមជាអធិបតីនៅក្នុងសាសនាចក្រ តែនៅពេលប្រធាននៃសាសនាចក្រទទួលមរណៈភាពប៉ុណ្ណោះ ។ នៅពេលប្រធានថ្មីនៃសាសនាចក្រ និង ទីប្រឹក្សាទាំងពីររបស់លោកត្រូវបានញែកចេញ នោះគណៈប្រធានទីមួយក្លាយទៅជាកូរ៉ុមជាអធិបតីសាជាថ្មី ។



ប្រធាន ប៊ិយដ៏ យេ ផាកកឺ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍អំពីគណៈប្រធានទីមួយ ៖ « សូមអរព្រះគុណដល់ព្រះ ចំពោះគណៈប្រធានទីមួយ ។ ដូចជា [ ភ្នំទាំងបី ] ដែលខ្ពស់សន្លឹមដែរ ពួកលោកឈរដោយគ្មានអ្វីស្ថិតនៅពីលើឡើយ មានតែស្ថានសួគ៌ប៉ុណ្ណោះ ។ ពួកលោកត្រូវការមេតិគាំទ្រពីយើង ។ ជួនកាល ពួកលោកមានភាពឯកោនៅក្នុងការហៅដ៏ខ្ពស់នៃភាពជាអ្នកដឹកនាំនោះ—ដ្បិតការហៅរបស់ពួកលោកពុំមែនផ្គាប់ចិត្តមនុស្សនោះទេ ប៉ុន្តែ គឺផ្គាប់ព្រះហឫទ័យព្រះវិញ ។ សូមឲ្យព្រះប្រទានពរដល់បុរសដ៏ឆ្នើម និង ដ៏ប្រពៃទាំងបីរូបនេះ » ( «The Spirit Beareth Record» *Ensign* ខែ មិថុនា ឆ្នាំ ១៩៧១ ទំព័រ ៨៧ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២៧–៣២

*ព្រះអង្គសង្គ្រោះពន្យល់អំពី របៀបដែលកូរ៉ុមជាអធិបតីនៃសាសនាចក្រ ត្រូវសម្រេចចិត្ត*

សូមគិតអំពីគ្រាមួយ នៅពេលអ្នកត្រូវសម្រេចចិត្តនៅក្នុងក្រុម ។ តើអ្នកមានបទពិសោធន៍យ៉ាងដូចម្ដេច ?

ជាទូទៅ ក្រុមមនុស្សសម្រេចចិត្តយ៉ាងដូចម្ដេច ? តើអ្នកគិតថា ដំណើរការនៃការសម្រេចចិត្តទាំងនេះ ប្រៀបធៀបយ៉ាងដូចម្ដេចទៅនឹង របៀបនៃការសម្រេចចិត្តរបស់គណៈប្រធានទីមួយ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និង ពួកចិតសិបនាក់ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២៧–៣២ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានបង្រៀន អំពីរបៀបដែលកូរ៉ុមជាអធិបតីនៃសាសនាចក្រ ធ្វើការសម្រេចចិត្ត ។ អ្នកអាចនឹងចង់គូសចំណាំឃ្លា ដែលជួយអ្នកយល់អំពីរបៀប ដែលកូរ៉ុមទាំងនេះសម្រេចចិត្ត ។

យោងតាមខគម្ពីរទាំងនេះ តើការសម្រេចចិត្តរបស់កូរ៉ុមជាអធិបតី ត្រូវបានធ្វើឡើងយ៉ាងដូចម្ដេច ?

អ្នកអាចនឹងចង់សរសេរ សេចក្ដីថ្លែងការណ៍នៃគោលលទ្ធិដូចតទៅនេះ នៅក្នុងព្រះគម្ពីររបស់អ្នកក្បែរខគម្ពីរនេះ ៖ **ការសម្រេចចិត្តរបស់កូរ៉ុមជាអធិបតីនៃសាសនាចក្រ ត្រូវបានធ្វើឡើងដោយការរួបរួម និង សុចរិតភាព ។**

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការដឹងថា ការសន្យារបស់ព្រះអម្ចាស់ថានឹងប្រទានពរដល់គណៈប្រធានទីមួយ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និង ពួកចិតសិបនាក់ ដោយនូវព្រះតម្រិះរបស់ទ្រង់ ជួយអ្នកឲ្យគាំទ្រដល់ថ្នាក់ដឹកនាំទាំងនេះដោយទំនុកចិត្ត សេចក្ដីជំនឿ និង សេចក្ដីអធិស្ឋាន ហើយត្រេងត្រាប់តាមដំបូន្មានរបស់ពួកលោកយ៉ាងដូចម្ដេច ?

ខ. តើគុណសម្បត្តិមានរាយនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣០ ដែលពួកបងប្អូនប្រុសទាំងនេះចាំបាច់ត្រូវមាន ដើម្បីធ្វើការសម្រេចចិត្តដោយរួបរួមនោះ មានអ្វីខ្លះ ?

គ. យោងតាម ខទី ៣១ តើព្រះអម្ចាស់សន្យាដល់កូរ៉ុមជាអធិបតីនៃសាសនាចក្រថាដូចម្ដេច បើសិនជាពួកលោកធ្វើការសម្រេចចិត្តដោយរួបរួម និង ដោយសុចរិតភាពនោះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៣–៣៨

*ព្រះអម្ចាស់ប្រទានសេចក្ដីណែនាំបន្ថែម ទៅដល់កូរ៉ុមជាអធិបតីនៃសាសនាចក្រ*

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៣–៣៥ ដោយស្វែងរកសេចក្ដីពិតដូចខាងក្រោមនេះ ៖

- **ពួកសាវកដប់ពីរនាក់ ប្រព្រឹត្តនៅក្នុងព្រះនាមនៃព្រះអម្ចាស់ និង នៅក្រោមការដឹកនាំនៃគណៈប្រធានទីមួយក្នុងការស្ថាបនាសាសនាចក្រឡើង ។**
- **ពួកចិតសិបនាក់ ប្រព្រឹត្តនៅក្នុងព្រះនាមនៃព្រះអម្ចាស់ នៅក្រោមការដឹកនាំរបស់ពួកសាវកដប់ពីរនាក់ ។**
- **ពួកសាវកដប់ពីរនាក់ កាន់កូនសោទាំងឡាយនៃការប្រកាសដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។**

៤. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីកត្តាជាក់លាក់មួយចំនួន ដែលអ្នកនឹងធ្វើដើម្បីគាំទ្រ ( ទ្រទ្រង់ គាំទ្រ ការពារ និង លើកទឹកចិត្ត ) ដល់ពួកអ្នកបម្រើរបស់ព្រះអម្ចាស់ ហើយត្រេងត្រាប់តាមដំបូន្មានរបស់ពួកលោកឲ្យបានកាន់តែប្រសើរឡើង ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:២១–៣៨ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៣ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩–១០០; ១០៨

## សេចក្ដីផ្ដើម

ចំណែកទីមួយនៃមេរៀននេះ គ្របដណ្ដប់លើ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩–១០០ ។ ទោះជា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧ ត្រូវបានកត់ត្រានៅក្នុងខែ មេសា ឆ្នាំ ១៨៣៥ ក្ដី ក៏មាតិកាភាគច្រើននៅក្នុង ខទី ៦០–១០០ ត្រូវបានប្រទានឲ្យព្យាការី យ៉ូសែប ស្ម៊ីធ តាមរយៈវិវរណៈនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៨៣១ ។ ខគម្ពីរដែលយកមកពិភាក្សានៅក្នុងមេរៀននេះ មាននូវព្រះបន្ទូលរបស់ព្រះអម្ចាស់ អំពីរបៀបប្រគល់បព្វជិតភាពមិលគីស្សាដែកកាលពីជំនាន់បុរាណ ពីឪពុកទៅកាន់កូនប្រុស ។ ខគម្ពីរទាំងនោះក៏ផ្ដល់សេចក្ដីណែនាំអំពីករណីយកិច្ចរបស់ថ្នាក់ដឹកនាំបព្វជិតភាពជាច្រើនផ្នែកដែរ ។ មេរៀននេះក៏គ្របដណ្ដប់លើ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨ ជាកណ្ឌដែលព្រះអម្ចាស់បានប្រទានឱវាទ និង ការសន្យាដល់ ឡៃម៉ាន សើម៉ាន ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩–១០០

*ព្រះអម្ចាស់គ្រាស់សម្ដែងថា កាលពីបុរាណ បព្វជិតភាពមិលគីស្សាដែកត្រូវបានប្រគល់បន្តពីឪពុកទៅកាន់កូនប្រុស*

១. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីកាលៈទេសៈមួយចំនួនដែលអ្នកជួបប្រទះនាពេលបច្ចុប្បន្ននេះ ឬ នឹងជួបប្រទះនាពេលឆាប់ៗ ដែលនៅក្នុងកាលៈទេសៈនោះ អ្នកអាចទាញយកអត្ថប្រយោជន៍ពីការទទួលបានការដឹកនាំ ឬ ការលួងលោមចិត្តពីព្រះវរបិតាសួគ៌របស់អ្នក ។

នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩–១០០ សូមស្វែងរកសេចក្ដីពិតនានា ដែលអាចជួយអ្នកឲ្យទទួលបានការដឹកនាំ និង ការលួងលោមចិត្ត ពីព្រះវរបិតាសួគ៌ ។

នៅក្នុងមេរៀនមុន អ្នកបានសិក្សាអំពី ករណីយកិច្ចរបស់គណៈប្រធានទីមួយ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ និង ពួកចិតសិបនាក់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩ ដោយស្វែងរកករណីយកិច្ចមួយរបស់កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ វាក្យសព្ទ « ការងារបម្រើខាងការផ្សាយដំណឹងល្អ » សំដៅទៅលើអ្នកដែលកាន់តំណែងលោកអយ្យកោ នៅក្នុងបព្វជិតភាពមិលគីស្សាដែក ( សូមមើល Evangelist » scriptures.lds.org Bible Dictionary, “Evangelist” » ) ។

សូមបញ្ចប់ឃ្លាដូចតទៅនេះ ដោយផ្អែកទៅលើអ្វីដែលអ្នកស្វែងយល់ចេញពី ខទី ៣៩ ៖ **លោកអយ្យកោត្រូវបានហៅដោយ និង បានតែងតាំងនៅក្រោមការដឹកនាំរបស់ពួកសាវកដប់ពីរនាក់ ។**



អ្នកទាំងឡាយដែលកាន់តំណែងលោកអយ្យកោ ផ្ដល់ពរជ័យពិសេស ដែលត្រូវបានហៅថា ពររបស់លោកអយ្យកោ ទៅកាន់សមាជិកសាសនាចក្រដែលមានភាពសក្ដិសម ។ ពររបស់លោកអយ្យកោ មានឱវាទរបស់ព្រះអម្ចាស់ទៅកាន់បុគ្គលម្នាក់ ហើយប្រកាសអំពីខ្សែស្រឡាយរបស់បុគ្គលនោះនៅក្នុងវង្សអ៊ីស្រាអែល ( សូមមើល *True to the Faith: A Gospel Reference* [ឆ្នាំ ២០០៤ ] «Patriarchal Blessings» ទំព័រ ១១១–១៣ ) ។

នៅពេលសិក្សាពររបស់លោកអយ្យកោផ្ទាល់របស់ពួកគេ នោះពួកគេអាចទទួលបានការដឹកនាំ និង ការលួងលោមចិត្តពីព្រះវរបិតាសួគ៌ ។ បើសិនជាអ្នកពុំទាន់បានទទួលពររបស់លោកអយ្យកោទេនោះ សូមពិភាក្សាជាមួយឪពុកម្ដាយរបស់អ្នក និង ប៊ីស្សព ឬ ប្រធានសាខា អំពីពេលវេលាដ៏សមរម្យបំផុត ដើម្បីទទួលបានពររបស់លោកអយ្យកោ និង អ្វីដែលអ្នកត្រូវធ្វើ ក្នុងការរៀបចំខ្លួនទទួលបទពិសោធន៍នោះ ។

ពាក្យ *លោកអយ្យកោ* ក៏សំដៅទៅលើឪពុកផងដែរ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៤១–៥៧ បង្រៀនថា អ័ដាមគឺជាឪពុក និង លោកអយ្យកោដ៏សុចរិតម្នាក់ ។ សូមអាន ខទី ៤១–៥០ ព្រួសៗ រួចស្វែងរកលំនាំមួយ—មានកិច្ចការចំនួនពីរ ដែលអ័ដាមបានធ្វើដដែលៗ នៅពេលគាត់គ្រប់គ្រងគ្រួសាររបស់គាត់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៥៣ ។ នៅក្នុងខគម្ពីរនេះ យើងអានថា អ័ដាមបានប្រសិទ្ធពរដល់កូនចៅដ៏សុចរិតរបស់គាត់ ។

២. ចេញពីអ្វីដែលអ្នកបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៤១–៥៧ សូមឆ្លើយសំណួរខាងក្រោមនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើកិច្ចការចំនួនពីរ ដែលអ័ដាមបានធ្វើដដែលៗនៅពេលដែលគាត់គ្រប់គ្រងក្រុមគ្រួសាររបស់គាត់នោះមានអ្វីខ្លះ ?

ខ. តើបទពិសោធន៍របស់អ័ដាម ដើរតួជាលំនាំមួយចំពោះឪពុកគ្រប់រូបតាមរបៀបណា ?

សេចក្ដីពិតមួយដែល យើងអាចរៀនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៥៣ គឺថា **ឪពុកទាំងឡាយដែលកាន់បព្វជិតភាពមិលគីស្សាដែក មានសិទ្ធិអំណាចដើម្បីប្រសិទ្ធពរ ដល់កូនចៅរបស់ខ្លួន ។** បន្ថែមពីលើការតែងតាំងដល់កូនប្រុសឲ្យកាន់បព្វជិតភាព ឪពុកម្នាក់អាចនឹងផ្ដល់ពរជ័យនៃបព្វជិតភាព ទៅដល់កូនប្រុស ឬ កូនស្រីនៅពេលពួកគេមានជំងឺ ឬ ផ្ដល់ការដឹកនាំ និង ការលួងលោមចិត្ត ។

អ្នកកាន់បព្វជិតភាពមិលគីស្សាដែក មិនត្រឹមតែអាចប្រសិទ្ធពរដល់កូនៗរបស់ខ្លួនប៉ុណ្ណោះទេ ពួកគាត់អាចនឹងប្រសិទ្ធពរដល់សមាជិកដទៃទៀតនៃគ្រួសារ ឬ មនុស្សដទៃទៀតដែលស្នើដល់ពួកគាត់ ។ ប្រធាន ប៊ីយដ៏ ឃេ ផាកកឺ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ ៖ « គេហដ្ឋានទាំងឡាយណាដែលពុំមានអ្នកកាន់បព្វជិតភាព ត្រូវតែបានមើលថែ និង បម្រើដោយកូរ៉ុមបព្វជិតភាព ។ ការធ្វើបែបនេះ នឹងនាំឲ្យគ្មានការស្រេកឃ្លានពរជ័យក្នុងចំណោមសមាជិកនៃសាសនាចក្រឡើយ » ( The Power of the Priesthood » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១០,ទំព័រ ៩ ) ។

៣. សូមពិពណ៌នានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបដែលអ្នក ឬ មនុស្សដែលអ្នកស្គាល់ បានទាញយកអត្ថប្រយោជន៍ពីការទទួលបានពរជ័យពីឪពុក ឬ ពីអ្នកកាន់បព្វជិតភាពមិលគីស្សាដែកដទៃទៀត ។ បើសិនជាអ្នកពុំមានឱកាសទទួលបានពរជ័យនៃបព្វជិតភាពទេនោះ សូមសរសេរអំពីរបៀបដែលអ្នកអាចទាញយកអត្ថប្រយោជន៍ពីការស្វែងរកពរជ័យដូចនេះ ។

សូមគិតត្រឡប់ទៅកាលៈទេសៈ ដែលអ្នកបានសរសេរនៅក្នុងលំហាត់ទី ១ នៃមេរៀននេះ ។ សូមចងចាំថា អ្នកអាចស្វែងរកការដឹកនាំ និង ការលួងលោមចិត្តពីព្រះវរបិតាសួគ៌បាន តាមរយៈពររបស់លោកអយ្យកោ និង តាមរយៈពរជ័យនៃបព្វជិតភាពដែលបានផ្ដល់ឲ្យតាមរយៈឪពុករបស់អ្នក ឬ អ្នកកាន់បព្វជិតភាពមិលគីស្សាដែកដទៃទៀត ។

### *ការស្វែងរកលំនាំ*

លំនាំនានានៅក្នុងបទគម្ពីរ អាចដឹកនាំសកម្មភាពរបស់យើង ។ អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា « លំនាំគឺជាផែនការ គំរូ ឬ បទដ្ឋាន ដែលអាចប្រើប្រាស់ជាមគ្គុទ្ទេសក៍ សម្រាប់ការប្រព្រឹត្តដដែលៗ ឬ ធ្វើអ្វីមួយ ។ នៅក្នុងបទគម្ពីរគឺពោរពេញទៅដោយ លំនាំខាងវិញ្ញាណ » ( «A Reservoir of Living Water» [Church Educational System fireside for young adults, ២០០៧] ទំព័រ ៤ si.lds.org )។ នៅពេលអ្នកសិក្សាព្រះគម្ពីរ សូមស្វែងរកលំនាំនានា ដែលអាចផ្ដល់ការដឹកនាំនៅក្នុងជីវិតអ្នក ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៥៨–៩៨ យើងអានអំពីករណីយកិច្ចរបស់ថ្នាក់ដឹកនាំបព្វជិតភាពជាច្រើនផ្នែក ។ នៅពេលអ្នកសិក្សាខគម្ពីរទាំងនេះ សូមពិចារណាថាតើអ្នកដែលបំពេញករណីយកិច្ចទាំងនេះ អាចនាំពរជ័យទាំងឡាយនៃបព្វជិតភាព ឲ្យកើតមាននៅក្នុងជីវិតរបស់មនុស្សទូទៅយ៉ាងដូចម្ដេច ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៩៩–១០០ ដោយស្វែងរកសេចក្ដីណែនាំ ដែលព្រះអម្ចាស់បានប្រទានដល់អ្នកទាំងឡាយដែលកាន់បព្វជិតភាព ។



ប្រធាន ថូម៉ាស អេស ម៉នសុន បានបង្រៀន ៖ « បព្វជិតភាពគឺជាការទទួលខុសត្រូវឲ្យបម្រើដល់មនុស្សទូទៅ ច្រើនជាងគ្រាន់តែជាអំណោយទាន ព្រោះវាជាឯកសិទ្ធិដើម្បីតម្កើងឡើង និង ជាឱកាសដើម្បីប្រទានពរដល់ជីវិតនៃមនុស្សដទៃ » ( «Our Sacred Priesthood Trust» *Ensign* ឬ *Liahona* ខែឧសភា ឆ្នាំ ២០០៦ ទំព័រ ៥៧ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨

*ព្រះអម្ចាស់ប្រទានឱវាទ និង ពរជ័យដល់ ឡៃម៉ាន សើម៉ាន*

សូមគិតអំពីគ្រាមួយ ដែលអ្នកបានមានអារម្មណ៍ថា បានទទួលការបំផុសគំនិតពីព្រះវិញ្ញាណ ឲ្យធ្វើអ្វីមួយ ហើយអ្នកបានធ្វើតាមការបំផុសគំនិតនោះ ។ តើអ្នកបានទទួលពរជ័យអ្វីខ្លះ នៅពេលអ្នកបានគោរពប្រតិបត្តិតាមការបំផុសគំនិតពីព្រះវិញ្ញាណ ?

ឡៃម៉ាន សើម៉ាន គឺជាសមាជិកសាសនាចក្រដ៏ស្មោះត្រង់ម្នាក់ ដែលបានបម្រើនៅក្នុងកងទ័ពជំរំស៊ីយ៉ូន ហើយត្រូវបានហៅឲ្យបម្រើជាប្រធានមួយរូប ក្នុងចំណោមប្រធានទាំងប្រាំពីររូបនៃកូរ៉ុមនៃពួកចិតសិបនាក់ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានកត់ត្រានៅក្នុងកំណត់ហេតុរបស់លោកថា នៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៨៣៥ « បងប្រុស ឡៃម៉ាន សើម៉ាន បានដើរចូលមក ហើយបានស្នើសូមឲ្យព្រះអម្ចាស់មានព្រះបន្ទូលមកតាមរយៈរូបខ្ញុំ ហើយបានស្រដីថា ‹ ដ្បិតខ្ញុំត្រូវបានសណ្ឋិតដោយព្រះវិញ្ញាណ ដើម្បីប្រាប់លោកឲ្យដឹងអំពីអារម្មណ៍ និង បំណងប្រាថ្នារបស់ខ្ញុំ ហើយបានសន្យាថា ខ្ញុំនឹងទទួលបានវិវរណៈ ដែលប្រាប់ឲ្យខ្ញុំស្គាល់អំពីករណីយកិច្ចរបស់ខ្ញុំ › » ( នៅក្នុង *History of the Church* ២:៣៤៥ ) ។

នៅពេល ឡៃម៉ាន បានពោលថា គាត់ត្រូវបាន « សណ្ឋិតដោយព្រះវិញ្ញាណ » ឲ្យប្រាប់ព្យាការី យ៉ូសែប ស្ម៊ីធ នោះមានន័យថា គាត់ត្រូវបានបំផុសគំនិតដោយព្រះវិញ្ញាណបរិសុទ្ធ ។

ដើម្បីឆ្លើយតបទៅនឹងសំណើរបស់ ឡៃម៉ាន នោះ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:១ ដោយស្វែងរកពរជ័យ ដែលព្រះអម្ចាស់បានប្រទានដល់ ឡៃម៉ាន ដោយសារតែលោកបានគោរពប្រតិបត្តិតាមការបំផុសគំនិត ឲ្យប្រាប់ដល់ព្យាការី ។

ដោយយោងតាមអ្វី ដែលព្រះអម្ចាស់បានត្រាស់សម្ដែងដល់ ឡៃម៉ាន សើម៉ាន សូមបំពេញគោលការណ៍ដូចតទៅនេះ ៖ **នៅពេលយើង ព្រះសូរសៀងរបស់ព្រះអម្ចាស់ នោះយើងទទួលបានការអត់ទោសពីទ្រង់ ។**

៤. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថាហេតុអ្វីបានជាការគោរពប្រតិបត្តិតាមការបំផុសគំនិតពីព្រះអម្ចាស់ ទទួលបានការអត់ទោសពីទ្រង់ ?

ព្រះសូរសៀងរបស់ព្រះអម្ចាស់ អាចឮបានតាមរយៈព្រះគម្ពីរ ប្រសាសន៍របស់ព្យាការីទ្រង់ និង ការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ។ ការគោរពប្រតិបត្តិតាមព្រះ រួមមានការធ្វើឲ្យជីវិតរបស់អ្នកពេញទៅដោយទង្វើដ៏សុចរិត ដែលនាំឲ្យមានអំណាចខាងវិញ្ញាណ ។ ការគោរពប្រតិបត្តិទាំងស្រុង នាំឲ្យមានអានុភាពពេញលេញនៃដំណឹងល្អ ទៅក្នុងជីវិតរបស់អ្នក ។ ការគោរពប្រតិបត្តិរួមបញ្ចូលទាំងទង្វើ ដែលអ្នកមិនអាចគិតដល់ពីដំបូងថាជាផ្នែកនៃការប្រែចិត្តមានដូចជា ការចូលរួមការប្រជុំ ការថ្វាយដង្វាយមួយភាគក្នុងដប់ ការផ្ដល់ការបម្រើ និង ការអភ័យទោសដល់មនុស្សទូទៅ ។ ព្រះអម្ចាស់បានសន្យាថា « អ្នកណាដែលប្រែចិត្ត ហើយធ្វើតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ នោះនឹងបានអត់ទោស » ( គ. និង ស. ១:៣២ ) ។



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:២ ដោយស្វែងរកឱវាទរបស់ព្រះអម្ចាស់ប្រទានដល់ ឡៃម៉ាន ស៊ើម៉ាន បន្ទាប់ពីគាត់បានដឹងថា អំពើបាបទាំងឡាយរបស់គាត់ត្រូវបានអត់ទោសហើយ ។

តើអ្នកគិតថា « ចូរឲ្យព្រលឹងអ្នកបានស្ងប់ស្ងៀមអំពីជំហរខាងវិញ្ញាណរបស់អ្នកចុះ » មានន័យដូចម្ដេច ( គ. និង ស. ១០៨:២ ) ?

យើងរៀនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:១–២ ថា **ការអត់ទោសរបស់ព្រះអម្ចាស់ នាំឲ្យមានសេចក្ដីសុខសាន្តដល់ព្រលឹងរបស់យើង ។**

ពេលខ្លះ មនុស្សដែលបានប្រែចិត្តហើយបានឆ្ងល់ ថាតើពួកគេត្រូវបានអត់ទោសពីអំពើបាបរបស់ខ្លួនដែរឬទេ ។ នៅក្នុងសេចក្ដីថ្លែងការណ៍ខាងក្រោមនេះ សូមគូសចំណាំដំបូន្មាន ដែលបានផ្ដល់ឲ្យដល់អ្នកទាំងឡាយណា ដែលពុះពារដើម្បីឲ្យព្រលឹងខ្លួនទទួលបានសេចក្ដីសុខសាន្ត ។

ប្រធាន ប៊ យដ៍ ឃេ ផាកកឺ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀន ៖



ទិវានៃការអត់ទោសដ៏ធំនោះ មិនអាចប្រព្រឹត្តទៅក្នុងពេលតែមួយនោះទេ ។ សូមកុំចុះចាញ់ឡើយ នៅពេលអ្នកបរាជ័យជាលើកទីមួយនោះ ។ ជាញឹកញាប់ ចំណុចដ៏ពិបាកបំផុតនៃការប្រែចិត្ត គឺត្រូវអត់ទោសឲ្យខ្លួនឯង ។ ការបាក់ទឹកចិត្ត គឺជាចំណែកមួយនៃការសាកល្បងនោះ ។ សូមកុំចុះចាញ់ ។ ទិវាដ៏ចែងចាំងនឹងកើតឡើង ។

« យ៉ាងនោះ ‹ សេចក្ដីសុខសាន្តរបស់ព្រះ ដែលហួសលើសពី . . . គំនិត › នឹងកើតមាននៅក្នុងជីវិតរបស់អ្នកសាជាថ្មី ។ [ ភីលីព ៤:៧ ] ។ លំដាប់នោះ អ្នកនឹងពុំចាំអំពីអំពើបាបទាំងឡាយរបស់អ្នកទៀតទេ ដូចជាទ្រង់ពុំចាំអំពីអំពើបាបរបស់អ្នកដែរ ។ តើអ្នកនឹងដឹងដោយរបៀបណា ? អ្នកនឹងដឹង ! [ សូមមើល ម៉ូសាយ ៤:១–៣ ] » ។ (« The Brilliant Morning of Forgiveness » *Ensign*, ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ២០ ) ។



ប្រធាន ហារ៉ូល ប៊ី លី បានបង្រៀន ៖ « ប្រសិនបើពេលនោះមកដល់ ជាពេលដែលអ្នកបានធ្វើអ្វីៗគ្រប់យ៉ាង ដែលអ្នកអាចធ្វើដើម្បីប្រែចិត្តចេញពីអំពើបាបរបស់អ្នក មិនថាអ្នកជានរណា អ្នកនៅកន្លែងណា ហើយបានកែប្រែ ព្រមទាំងប៉ះប៉ូវដោយអស់ពីសមត្ថភាពរបស់អ្នកនោះទេ . . . អ្នកនឹងចង់ដឹងថាតើចំពោះចម្លើយបញ្ជាក់ប្រាប់នោះ ព្រះអម្ចាស់បានទទួលអ្នកហើយឬនៅ ។ នៅក្នុងព្រលឹងដែលខ្វាយខ្វល់របស់អ្នក ប្រសិនបើអ្នកស្រាវជ្រាវ ហើយស្វែងរកសេចក្ដីសុខសាន្តនៃសតិសម្បជញ្ញៈ ដោយការបញ្ជាក់នោះ អ្នកអាចដឹងថា ព្រះអម្ចាស់បានទទួលយកការប្រែចិត្តរបស់អ្នកហើយ » ( *Stand Ye in Holy Places* [ ឆ្នាំ ១៩៧៤ ] ទំព័រ ១៨៥ ) ។

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:៣ ដោយស្វែងរកឱវាទបន្ថែម ដែលព្រះអម្ចាស់បានប្រទានដល់ ឡៃម៉ាន ស៊ើម៉ាន ។ ( វាអាចនឹងផ្ដល់អត្ថប្រយោជន៍ ក្នុងការដឹងថាពាក្យ *គោរពតាម* នៅក្នុងខគម្ពីរនេះមានន័យថា អនុវត្តតាម ឬ គោរពប្រតិបត្តិតាម ។ *សម្បថ* គឺជាការសន្យា ឬ សេចក្ដីសញ្ញា ) ។

តើឱវាទដែលប្រាប់ថាឲ្យប្រុងប្រយ័ត្នកាន់តែខ្លាំង ក្នុងការគោរពតាមសម្បថ មានអត្ថប្រយោជន៍យ៉ាងដូចម្ដេច ចំពោះបុគ្គលដែលត្រូវបានអត់ទោសពីអំពើបាប ?

៥. សូមពន្យល់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីរបៀបសេចក្ដីពិត ដែលអ្នកបានរកឃើញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:១–៣ អាចលើកទឹកចិត្តមិត្តភក្ដិ ឬ សមាជិកគ្រួសារម្នាក់ ឲ្យគោរពតាមព្រះសូរសៀងរបស់ព្រះអម្ចាស់ ហើយទទួលបានការអត់ទោស ។

តើអ្នកធ្លាប់ឮពាក្យសព្ទ « ជំនុំមុតមាំ » ដែរឬទេ ? អែលឌើរ ដេវីឌ ប៊ី ហេត ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ ៖ « ជំនុំមុតមាំ ជាឈ្មោះដែលបង្ហាញ បញ្ជាក់អំពីភាពពិសិដ្ឋ ភាពហ្មត់ចត់ និង ជាឱកាសដ៏មានគារវភាព ដែលពួកបរិសុទ្ធជួបជុំគ្នានៅក្រោមការដឹកនាំរបស់គណៈប្រធានទីមួយ ។ ជំនុំមុតមាំ ត្រូវបានប្រើក្នុងគោលបំណងបីយ៉ាង ៖ ការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ ការណែនាំពិសេសចំពោះអ្នកដឹកនាំបព្វជិតភាព និងការគាំទ្រប្រធានសាសនាចក្រថ្មី » (Solemn Assemblies » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ទំព័រ ១៤ ) ។

ក្នុងខែ ធ្នូ ឆ្នាំ ១៨៣២ ព្រះអម្ចាស់បានសន្យានឹងពួកបរិសុទ្ធថា បើសិនជាពួកគេកសាងព្រះវិហារបរិសុទ្ធ ហើយប្រារព្ធជំនុំមុតមាំនោះទ្រង់នឹងចាក់បង្ហូរព្រះពរដ៏អស្ចារ្យៗមកលើពួកគេ ( សូមមើល គ. និង ស. ៨៨:៧០–៧៥, ១១៧–១៩ ) ។ ក្នុងខែ ធ្នូ ឆ្នាំ ១៨៣៥ នៅពេលវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨ ត្រូវបានប្រទានដល់ ឡៃម៉ាន សើម៉ាន នោះព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ នឹងត្រូវបានឧទ្ទិសឆ្លងក្នុងរយៈពេលតែបីខែទៀតប៉ុណ្ណោះ ។

នៅពេលអ្នកអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:៤–៦ សូមស្វែងរកការណ៍ ដែលព្រះអម្ចាស់បានសន្យាថា ឡៃម៉ាន នឹងទទួលបាននៅក្នុងជំនុំមុតមាំនោះ ។

បន្ទាប់មក សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:៧–៨ ដោយស្វែងរកសេចក្ដីណែនាំ ដែលព្រះអម្ចាស់បានប្រទានឲ្យ ឡៃម៉ាន ។ តើអ្នកអាចចម្រើនកម្លាំងមនុស្សទូទៅ « ដោយគ្រប់វាចារបស់អ្នក » ( គ. និង ស. ១០៨:៧ ) បានយ៉ាងដូចម្ដេច ? វាអាចនឹងផ្ដល់អត្ថប្រយោជន៍ ក្នុងការដឹងថា *សេចក្ដីតាស់តឿន* គឺជាពាក្យណែនាំ ឬ ការលើកទឹកចិត្តឲ្យប្រព្រឹត្តអំពើល្អ ។

៦. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា សេចក្ដីណែនាំនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៨:៧–៨ អាចជួយ ឡៃម៉ាន សើម៉ាន នៅពេលគាត់ប្រកាសដំណឹងល្អដល់មនុស្សទូទៅយ៉ាងដូចម្ដេច ?

ខ. តើអ្នកអាចអនុវត្តតាម ឱវាទរបស់ព្រះអម្ចាស់ដែលមាននៅក្នុង ខទី ៧ នៅក្នុងជីវិតរបស់អ្នកបានយ៉ាងដូចម្ដេច ?

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៧:៣៩–១០០; ១០៨ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧

## បុព្វកថា

នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៨៣៦ ព្យាការី យ៉ូសែប ស្ម៊ីធ បានប្រជុំជាមួយទីប្រឹក្សាទីមួយរបស់លោកនៅក្នុងគណៈប្រធានទីមួយ ព្រមទាំងឪពុករបស់លោក យ៉ូសែប ស្ម៊ីធ ស៊ីញ័រ នៅក្នុងបន្ទប់ជាន់លើនៃព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ដែលបានសាងសង់ជិតសព្វគ្រប់ហើយនោះ ។ នៅក្នុងឱកាសនេះ ព្យាការីបានទទួលការនិមិត្តអំពីនគរសេឡេស្ទាល ហើយបានស្ដាប់ព្រះអម្ចាស់មានព្រះបន្ទូលប្រាប់អំពី របៀបដែលទ្រង់នឹងជំនុំជម្រះ បុគ្គលទាំងឡាយណាដែលបានចែកឋានទៅដោយពុំស្គាល់ដំណឹងល្អ ។ វ៉ារិន ផារីស្ស ដែលជាស្មៀនរបស់ យ៉ូសែប ស្ម៊ីធ នៅគ្រានោះ បានកត់ត្រាការនិមិត្តនេះ ដាក់នៅក្នុងកំណត់ហេតុរបស់ព្យាការី ។ នាពេលក្រោយមកទៀត កំណត់ត្រានៃការនិមិត្តនេះ ត្រូវបានដាក់បញ្ចូលទៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ជា កណ្ឌទី ១៣៧ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:១–៦

*យ៉ូសែប ស្ម៊ីធ ទទួលបានវិវរណៈ អំពីនគរសេឡេស្ទាល*

សូមគិតអំពីបុគ្គលមួយចំនួន ដែលជាមនុស្សសំខាន់នៅក្នុងជីវិតរបស់អ្នក ។ ហេតុអ្វីបានជាពួកគេជាមនុស្សសំខាន់សម្រាប់អ្នក ?

១. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីមូលហេតុដែលវាចាំបាច់ចំពោះអ្នក ក្នុងការដឹងថា មនុស្សដែលអ្នកស្រឡាញ់ នឹងមានឱកាសរស់នៅក្នុងនគរសេឡេស្ទាល បន្ទាប់ពីអស់ជីវិតទៅ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧ មាននូវការពិពណ៌នាអំពីការនិមិត្តរបស់ព្យាការី យ៉ូសែប ស្ម៊ីធ នៃអ្វីដែលលោកបានឃើញអំពីនគរសេឡេស្ទាល ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:១–៤ ដោយស្វែងរកពាក្យ និង ឃ្លាទាំងឡាយ ដែលពិពណ៌នាអំពីនគរសេឡេស្ទាល ។ សូមសាកល្បងនឹកស្រមៃក្នុងចិត្ត ថាតើការរស់នៅក្នុងនគរសេឡេស្ទាល មានសភាពបែបណា ។

យ៉ូសែប ស្ម៊ីធ បានរីករាយនៅពេលបានឃើញសមាជិកក្រុមគ្រួសាររបស់លោករស់នៅក្នុងនគរសេឡេស្ទាល ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:៣, ៥–៦ រួចស្វែងរកថាតើនរណាដែល យ៉ូសែប ស្ម៊ីធ បានឃើញនៅក្នុងនគរសេឡេស្ទាល ។

ឪពុកម្ដាយរបស់ យ៉ូសែប នៅមានជីវិតនៅឡើយនៅគ្រានោះ ចំណែកឯឪពុករបស់លោកវិញ កំពុងនៅជាមួយលោកក្នុងបន្ទប់នោះ អំឡុងពេលលោកទទួលបានការនិមិត្តនេះ ។ ការណ៍នេះបង្ហាញថា ការនិមិត្តនេះពុំមែនសំដៅលើអ្នកដែលបានរស់នៅក្នុងនគរសេឡេស្ទាលនោះទេ ប៉ុន្តែ សំដៅលើអ្នកណាដែលនឹងរស់នៅក្នុងនគរនោះវិញ ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:៦ ហេតុអ្វីបានជា យ៉ូសែប ស្ម៊ីធ ឆ្ងល់ នៅពេលលោកបានឃើញបងប្រុសរបស់លោក អាលវិន នៅក្នុងនគរសេឡេស្ទាល ?

ខ. តើអ្នកគិតថា យ៉ូសែប បានមានអារម្មណ៍បែបណាទៀត នៅពេលលោកបានឃើញ អាលវិន នៅក្នុងនគរសេឡេស្ទាលនោះ ?

*ការនឹកស្រមៃក្នុងចិត្ត*

នៅពេលអ្នកសិក្សាបទគម្ពីរនានា សូមស្វែងរកការពិពណ៌នាលម្អិត ដែលអាចជួយអ្នកឲ្យបង្កើតរូបភាពក្នុងគំនិត នៅពេលអ្នកអាន ។ ការគិតស្រមៃក្នុងចិត្តថាមានវត្តមាននៅក្នុងព្រឹត្តិការណ៍ជាក់លាក់ៗ អាចជួយអ្នកឲ្យយល់កាន់តែច្បាស់ ហើយស្គាល់ព្រឹត្តិការណ៍នានា និង តួអង្គនៅក្នុងព្រះគម្ពីរ ។ ការធ្វើដូចនេះនឹងជួយពង្រឹងទីបន្ទាល់របស់អ្នកអំពីភាពពិតនៃអ្វីដែលអ្នកអានក្នុងព្រះគម្ពីរ ។

ព្យាការី យ៉ូសែប ស្ម៊ីធ ស្រឡាញ់ ហើយគោរពបងប្រុសរបស់លោកខ្លាំងបំផុត ។ អាលវិន ក៏ស្រឡាញ់ យ៉ូសែប ដែរ ហើយបានគាំទ្រ យ៉ូសែប ក្នុងការត្រៀមខ្លួនទទួលផ្ទាំងចំណារមាស ពីទេវតាមរ៉ូណៃ ។ ក្នុងខែ វិច្ឆិកា ឆ្នាំ ១៨២៣ ពេលអាលវីន អាយុ ២៥ ឆ្នាំ ហើយយ៉ូសែប អាយុ ១៧ ឆ្នាំ ស្រាប់តែ អាលវីនបានធ្លាក់ខ្លួនឈឺជាទម្ងន់ ។ នៅពេលស្ថានភាពជំងឺរបស់គាត់កាន់តែធ្ងន់ធ្ងរទៅៗ ហើយឃើញថាគាត់នឹងជិតស្លាប់ គាត់បានទូន្មាននឹងយ៉ូសែបថា ៖ « បងចង់ឲ្យប្អូនធ្វើជាក្មេងល្អ ហើយធ្វើអ្វីគ្រប់យ៉ាងក្នុងអំណាចប្អូន ដើម្បីទទួលបានកំណត់ត្រានោះ ។ ចូរមានចិត្តស្មោះត្រង់ ក្នុងការទទួលសេចក្ដីណែនាំ និង រក្សារាល់ព្រះបញ្ញត្តិដែលបានប្រទានដល់ឯង » ( ប្រសាសន៍ដកស្រង់នៅក្នុង *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* [ ឆ្នាំ ២០០៧ ] ទំព័រ ៤០១) ។



អាលវិន ស្ម៊ីធ ដែលជាបងប្រុសរបស់ព្យាការី បានទទួលមរណភាពនៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៨២៣ ពីមុនសាសនាចក្រត្រូវបានបង្កើតឡើង ។

មរណភាពរបស់ អាលវិន បាននាំឲ្យគ្រួសារ ស្ម៊ីធ មានទុក្ខជាទម្ងន់ ។ « គ្រួសារ ស្ម៊ីធ បានសុំឲ្យគ្រូគង្វាលប្រេសប៊ីធារានទីក្រុង ផាលម៉ៃរ៉ា រដ្ឋ នូវ យ៉ោក ធ្វើពិធីបុណ្យសពដល់លោក ។ ដោយសារ អាលវិន មិនមែនជាសមាជិកនៃក្រុមជំនុំរបស់គ្រូគង្វាលនោះ លោកអាចារ្យនោះបានពោលអះអាងនៅក្នុងទេសនកថារបស់គាត់ថា អាលវិន មិនអាចបានសង្គ្រោះឡើយ ។ វិល្លាម ស្ម៊ីធ ដែលជាប្អូនប្រុសរបស់ យ៉ូសែប បានចាំ ៖ ‹ [ គ្រូគង្វាលនោះ ] . . . បានប្រកាសដោយម៉ឺងម៉ាត់ថា [ អាលវិន ] បានចុះនរកហើយ ដោយសារ អាលវិន មិនមែនជាសមាជិកនៃសាសនាចក្រគាត់ឡើយ យ៉ាងណាក៏ដោយ គាត់ជាក្មេងដ៏ល្អម្នាក់ ហើយឪពុករបស់ខ្ញុំមិនពេញចិត្តនឹងការណ៍នេះទេ › » (*Teachings: Joseph Smith,* ៤០១ ទំព័រ ៤០៣) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:៧–១០

*ព្រះអម្ចាស់ត្រាស់សម្ដែង អំពីរបៀបដែលទ្រង់នឹងជំនុំជម្រះមនុស្ស ដែលបានចែកឋានទៅ ដោយពុំបានស្គាល់ដំណឹងល្អ*

នៅពេលព្យាការី យ៉ូសែប ស្ម៊ីធ បានឆ្ងល់ថាតើវាបានកើតឡើងតាមរបៀបណា ដែល អាលវិន អាចចូលទៅក្នុងនគរសេឡេស្ទាល ដោយពុំទាន់បានទទួលពិធីបុណ្យជ្រមុជទឹក នោះព្រះអម្ចាស់បានប្រទានចម្លើយមួយ ។ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:៧–៨ រួចស្វែងរកគោលលទ្ធិ ដែលព្រះអម្ចាស់បានបង្រៀន ដើម្បីជួយ យ៉ូសែប យល់អំពីមូលហេតុដែល អាលវិន អាចចូលទៅក្នុងនគរសេឡេស្ទាលបាន ។

៣. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមកត់ត្រាគោលលទ្ធិដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:៧–៨ រួចឆ្លើយសំណួរដូចតទៅនេះ ៖ តើគោលលទ្ធិនេះ លួងលោមចិត្តដល់អ្នកទាំងឡាយដែលមានមនុស្សជាទីស្រឡាញ់បានអស់ជីវិតទៅ ដោយពុំបានស្គាល់ដំណឹងល្អយ៉ាងដូចម្ដេច ?

ព្រះអម្ចាស់បានត្រាស់សម្ដែងគោលលទ្ធិនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:៧–៨ ពីមុនទ្រង់បានបើកសម្ដែងគោលលទ្ធិនៃពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជន ។ អ្នកនឹងសិក្សាវិវរណៈ អំពីពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជន នៅក្នុងមេរៀនបន្ទាប់ទៀត ។

ព្រះអម្ចាស់បានបង្រៀនអំពីរបៀប ដែលទ្រង់នឹងជំនុំជម្រះមនុស្សលោកទាំងអស់ ទុកជាផ្នែកមួយនៃវិវរណៈនេះ អំពីអ្នកដែលចែកឋានទៅ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:៩ រួចបំពេញសេចក្ដីថ្លែងការណ៍ដូចតទៅនេះ ៖ **ព្រះអម្ចាស់នឹងជំនុំជម្រះយើងស្របតាម និង** ។

៤. សូមពន្យល់នៅក្នុងព្រះគម្ពីររបស់អ្នក ដោយប្រើពាក្យសម្ដីរបស់អ្នកផ្ទាល់ថាតើ អ្នកគិតថា មូលហេតុអ្វីបានជាបំណងប្រាថ្នា និង កិច្ចការរបស់យើងមានសារៈសំខាន់ទាំងពីរ ។

ដើម្បីយល់ឲ្យបានកាន់តែច្បាស់ អំពីរបៀបដែលព្រះអម្ចាស់នឹងជំនុំជម្រះយើងស្របតាមកិច្ចការ និង បំណងប្រាថ្នា សូមសិក្សាសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« តើអ្នកប្រាកដដែរឬទេ ថានឹងពុំមានទោសនៅក្រោមក្រឹត្យវិន័យនៃព្រះ បើយើងគ្រាន់តែចៀសវាងចេញពីអំពើអាក្រក់នោះ ? ចុះបើសិនជាអ្នករីករាយនឹងគំនិត និង បំណងប្រាថ្នាដែលអាក្រក់ទៅវិញនោះ ?

« តើអារម្មណ៍សម្ងប់ នឹងមិនត្រូវបានលើកឡើងនៅថ្ងៃនៃការជំនុំជម្រះទេឬអី ? ចុះការច្រណែនវិញ ? ចុះការលោភចង់បាននោះ ?. . .

« ចម្លើយរបស់យើងទៅនឹងសំណួរទាំងនេះ បង្ហាញអំពីអ្វីដែលយើងហៅថាជាដំណឹងអាក្រក់ ជាអ្វីដែលយើងប្រព្រឹត្តអំពើបាបដោយពុំបើកចំហ [ ឲ្យឃើញច្បាស់ ] ដែលគ្រាន់តែជាអារម្មណ៍ និង បំណងប្រាថ្នានៃដួងចិត្តរបស់យើង ។

« វាក៏ជាដំណឹងល្អផងដែរ ។ នៅក្រោមក្រឹត្យវិន័យនៃព្រះ យើងអាចទទួលបានរង្វាន់សម្រាប់ភាពសុចរិតរបស់យើង ទោះជាយើងស្ថិតនៅក្នុងកាលៈទេសៈដែលយើងពុំអាចប្រព្រឹត្តទង្វើ ដែលជាធម្មតានាំឲ្យមានពរជ័យដូចនោះក្ដី ។

« នៅពេលមាននរណាម្នាក់ចង់ធ្វើអ្វីមួយដោយសប្បុរស សម្រាប់ឪពុកក្មេកខ្ញុំ ប៉ុន្តែត្រូវបានរាំងដោយកាលៈទេសៈផ្សេងៗ នោះគាត់នឹងពោល ៖ ‹ សូមអរគុណ ។ ខ្ញុំនឹងទទួលយកទង្វើល្អនោះ › ។ ស្រដៀងនេះដែរ ខ្ញុំជឿថា ព្រះវរបិតាគង់នៅស្ថានសួគ៌នឹងទទួលយកបំណងប្រាថ្នានៃដួងចិត្តយើង ជំនួសឲ្យទង្វើដែលតាមការជាក់ស្ដែងពុំអាចធ្វើទៅបាន » ( "The Desires of Our Hearts" [ Brigham Young University devotional ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ១៩៨៥ ] ទំព័រ ៤ speeches.byu.edu ) ។

៥. ឧទាហរណ៍ទាំងបួនដូចតទៅនេះ អាចជួយអ្នកយល់បានកាន់តែច្បាស់ អំពីគោលលទ្ធិដែលអ្នករកឃើញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:៧–៨ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរដូចតទៅនេះ សម្រាប់ឧទាហរណ៍នីមួយ ៖ តើឧទាហរណ៍នេះ បង្ហាញអំពីសារៈសំខាន់នៃបំណងប្រាថ្នារបស់យើង និង ការប្រព្រឹត្តរបស់យើងយ៉ាងដូចម្ដេច ?

ក. សមាជិកសាសនាចក្រម្នាក់ មានបំណងប្រាថ្នារៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ ។ បន្ទាប់ពីមួយជីវិតនៃការបម្រើដោយស្មោះត្រង់នៅក្នុងសាសនាចក្រ សមាជិករូបនេះបានស្លាប់ ដោយពុំមានឱកាសផ្សារភ្ជាប់ជាមួយស្វាមី/ភរិយានៅក្នុងព្រះវិហារបរិសុទ្ធឡើយ ។

ខ. យុវជនម្នាក់ រក្សាសេចក្ដីសញ្ញាពិធីបុណ្យជ្រមុជទឹករបស់ខ្លួនដោយក្លាហាន ហើយធ្វើតាមករណីយកិច្ចបព្វជិតភាពអើរ៉ុន ។ បន្ទាប់ពីបានបញ្ចប់ការសិក្សានៅវិទ្យាល័យ គាត់មានបំណងប្រាថ្នាយ៉ាងមុតមាំដើម្បីបម្រើបេសកកម្មពេញម៉ោង ប៉ុន្តែ ពុំមានលទ្ធភាពធ្វើដូច្នោះបាន ដោយសារតែអសមត្ថភាពខាងរូបកាយ ។

គ. យុវនារីម្នាក់ចងគំនុំជាមួយយុវនារីម្នាក់ទៀត ។ នាងធ្វើពុតជាមានភាពស្និទ្ធស្នាល ប៉ុន្តែ មានបំណងធ្វើឲ្យមានរឿងអាក្រក់កើតឡើងចំពោះយុវនារីម្នាក់ទៀតដោយសម្ងាត់ ។

ឃ. យុវជនម្នាក់មានគំនិតអសីលធម៌ គាត់ពុំបានស្វែងរកជំនួយពីព្រះអម្ចាស់ ដើម្បីលុបបំបាត់គំនិត និង អារម្មណ៍មិនសមរម្យនោះចេញឡើយ ។

សូមពិចារណា ថាតើការដឹងថា អ្នកនឹងត្រូវជំនុំជម្រះដោយទង្វើ និង រួមទាំងបំណងប្រាថ្នានៃដួងចិត្តនោះ មានន័យយ៉ាងណាចំពោះអ្នក ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:១០ រួចគូសចំណាំសេចក្ដីពិត ដែលខគម្ពីរបង្រៀនអំពីក្មេងៗដែលបានស្លាប់ពីមុនវ័យដែលមានការដឹងខុសត្រូវ ។



នៅពេលព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនេះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧:១០ លោក និង ភរិយារបស់លោក អិមម៉ា បានសោកសៅដោយសារតែមរណភាពរបស់កូនទាំងបួននាក់របស់ពួកលោក រួមទាំងកូនដែលពួកលោកទទួលមកចិញ្ចឹមផងដែរ ។ ក្រោយមកទៀត កូនរបស់លោកពីរនាក់ទៀត ក៏បានស្លាប់ទៅដែរ ។ សូមគិតថាតើគោលលទ្ធិដែលបានបើកសម្ដែងនៅក្នុងខគម្ពីរនេះ អាចលួងលោមចិត្តក្រុមគ្រួសារទាំងឡាយដែលសោកសៅដោយសារតែមរណភាពរបស់កូនតូចរបស់ពួកគេយ៉ាងដូចម្ដេចដែរ ។

តើគោលលទ្ធិនេះ អាចជួយបង្កើនសេចក្ដីជំនឿរបស់អ្នកទៅលើព្រះបានយ៉ាងដូចម្ដេច ? តើអ្នកគិតថា ហេតុអ្វីបានជាវាមានសារៈសំខាន់ក្នុងការជឿជាក់ទៅលើផែនការរបស់ព្រះ នៅពេលកូនតូចស្លាប់កាលពួកគេនៅជាទារកនៅឡើយនោះ ?



នៅពេលនិយាយអំពីមរណភាពរបស់កូនតូចៗ ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀន ៖ « ព្រះអម្ចាស់ដកយកមនុស្សជាច្រើនទៅ សូម្បីតែទារក ដើម្បីឲ្យពួកគេអាចចៀសផុតពីសេចក្ដីច្រណែន និង ទុក្ខសោក និង សេចក្ដីអាក្រក់នៃពិភពលោកនាពេលបច្ចុប្បន្ននេះ ដ្បិតពួកគេបរិសុទ្ធណាស់ គួរឲ្យស្រឡាញ់ណាស់ ដែលមិនអាចរស់នៅលើផែនដីនេះ ហេតុដូច្នេះហើយ បើសិនជាត្រូវបានពិចារណាដោយត្រឹមត្រូវនោះ ជាការជំនួសឲ្យការទួញសោក នោះយើងមានមូលហេតុដើម្បីរីករាយ នៅពេលពួកគេត្រូវបានរំដោះចេញពីសេចក្ដីអាក្រក់ ហើយយើងនឹងមានពួកគេម្ដងទៀតក្នុងពេលឆាប់ៗ » (*Teachings: Joseph Smith* ទំព័រ ១៧៦) ។



ប្រធាន វិលហ្វឺដ វូឌ្រុហ្វ បានបង្រៀន ៖ « សំណួរអាចចោទឡើងដោយខ្ញុំ និង ដោយអ្នកថា—‹ ហេតុអ្វីបានជាព្រះអម្ចាស់ ដកយកកូនពីខ្ញុំទៅ › ? ប៉ុន្តែការណ៍នោះមិនមែនខ្ញុំទេ ដែលជាអ្នកប្រាប់នោះ ព្រោះខ្ញុំពុំដឹងឡើយ ដ្បិតការណ៍នេះស្រេចតែព្រះអម្ចាស់ទេ ហើយវាបានកើតឡើងដូច្នេះចាប់តាំងពីកំណើតលោកិយដរាបរៀងមក ។ កូនតូចៗត្រូវបានដកយកទៅកាលនៅជាទារក ហើយពួកគេទៅឯពិភពវិញ្ញាណ ។ ពួកគេមកទីនេះ ហើយបំពេញគោលបំណងនៃការមកនោះ ដែលជាការរស់ក្នុងរូបកាយសាច់ឈាម ។ ពួកគេមកលើផែនដីនេះដើម្បីទទួលការពិសោធន៍មួយ និង កេរមរតកនៅលើផែនដី ដ្បិតពួកគេទទួលបានរូបកាយ ឬ ទីកន្លែងស្នាក់នៅ ហើយទីកន្លែងស្នាក់នៅនោះនឹងត្រូវបានថែរក្សាទុកឲ្យពួកគេ ហើយនៅទិវានៃការរស់ឡើងវិញ នោះវិញ្ញាណ និង រូបកាយនឹងបានផ្គុំគ្នាឡើងវិញ ដូចគ្នានៅលើផែនដីនេះដែរ យើងឃើញមានកូនគ្រប់អាយុនៅក្នុងក្រុមគ្រួសារ ចាប់ពីទារកដែលបៅដោះម្ដាយរហូតដល់មនុស្សពេញរូបរាងដើម្បីឲ្យក្លាយជាក្រុមគ្រួសារមួយនៅពិភពសេឡេស្ទាល ។ កូនៗរបស់យើងនឹងបានរស់ឡើងវិញនៅជាមួយយើងម្ដងទៀតនៅពេលដែលពួកគេត្រូវបញ្ចុះទៅក្នុងផ្នូរបើសិនជាយើង ដែលជាឪពុកម្ដាយបន្តស្មោះត្រង់ ហើយបង្ហាញភស្តុតាងថាខ្លួនយើងសក្ដិសមនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ហើយបើសិនជាយើងមិនធ្វើដូច្នោះទេ ក៏កូនៗយើងនឹងនៅតែអាចបានរក្សាទុក ហើយនឹងគ្រងមរតកនៃសិរីល្អសេឡេស្ទាលដែរ ។ នេះគឺជាទស្សនរបស់ខ្ញុំ ស្ដីពីទារកទាំងឡាយដែលស្លាប់ទៅ » (*Teachings of Presidents of the Church: Wilford Woodruff* [ ឆ្នាំ ២០០៤ ] ទំព័រ ៨៤–៨៥) ។

៦. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកបានសិក្សាអ្វីខ្លះ ចេញពីការសិក្សារបស់អ្នកនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧ អំពីការខិតខំរបស់ព្រះអម្ចាស់ ក្នុងការធ្វើឲ្យមនុស្សទាំងអស់មានឱកាសរស់នៅក្នុងនគរសេឡេស្ទាល ?

ខ. ហេតុអ្វីបានជាសេចក្ដីពិតទាំងនេះ មានសារៈសំខាន់ចំពោះអ្នក ?

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៧ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៤ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩

## បុព្វកថា

ពួកបរិសុទ្ធបានធ្វើការអស់រយៈពេលជិតបីឆ្នាំ ដើម្បីបញ្ចប់ការសាងសង់ព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។ នៅពេលការសាងសង់បានបញ្ចប់ ព្រះអម្ចាស់បានត្រាស់សម្ដែងដល់ព្យាការី យ៉ូសែប ស្ម៊ីធ អំពីសេចក្ដីអធិស្ឋាន ដែលត្រូវថ្វាយនៅឯការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ ។ ព្យាការីបានអានសេចក្ដីអធិស្ឋាននោះ នៅក្នុងពិធីឧទ្ទិសឆ្លងនៅថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ១៨៣៦ ។ លោកបានទូលសូមឲ្យព្រះអម្ចាស់ទទួលយកព្រះវិហារបរិសុទ្ធ ហើយបំពេញតាមការសន្យារបស់ទ្រង់ ដែលទ្រង់បានធ្វើអំពីព្រះវិហារបរិសុទ្ធរួមមានការការពារ និង ពរជ័យចំពោះអ្នកទាំងឡាយណាដែលមកថ្វាយបង្គំនៅទីនោះ ។ លោកបានអធិស្ឋានឲ្យពួកបរិសុទ្ធ ដែលត្រូវបានគេសង្កត់សង្កិននៅឃុំចាកសុន រដ្ឋ មិសសួរី ហើយលោកបានអធិស្ឋានឲ្យអ្នកដែលសង្កត់សង្កិនពួកគេផងដែរ ។ លោកក៏បានអធិស្ឋានសូមឲ្យមនុស្សទូទាំងពិភពលោក ជាពិសេសពួកអ៊ីស្រាអែលដែលបានខ្ចាត់ខ្ចាយ ទទួលយកភាពពោរពេញនៃដំណឹងល្អដែរ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:១–២៣

*យ៉ូសែប ស្ម៊ីធ បានទូលសូមឲ្យព្រះអម្ចាស់ទទួលយកព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ហើយប្រទានពរដល់អ្នកទាំងឡាយណាដែលមកថ្វាយបង្គំនៅទីនោះ*

តើអ្នកដឹងថាតើព្រះវិហារបរិសុទ្ធនីមួយៗនេះ មានទីតាំងស្ថិតនៅទីណាខ្លះ ? សូមផ្គូផ្គងរូបភាពនៃព្រះវិហារបរិសុទ្ធនីមួយៗទៅនឹងទីតាំងរបស់វា ។ ( ចម្លើយមាននៅចុងមេរៀននេះ ) ។

<table>
<tr><td>_____ ១.</td><td></td><td>ក. ទីក្រុង ហុងកុង ប្រទេសចិន</td></tr>
<tr><td>_____ ២.</td><td></td><td>ខ. ទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍</td></tr>
</table>

| | | |
|---|---|---|
| _____ ៤. |  | ឃ. ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ |
| _____ ៥. |  | ង. ទីក្រុងតៃហ្គូស៊ីហ្គាលផា ប្រទេស ហុងឌូរ៉ាស |

១. សូមសរសេរសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ *ហេតុអ្វីបានជាពួកបរិសុទ្ធថ្ងៃចុងក្រោយ កសាងព្រះវិហារបរិសុទ្ធ ?* សូមសរសេរចម្លើយពីរបី ចំពោះសំណួរនេះ ។ សូមទុកចន្លោះដើម្បីសរសេរចម្លើយបញ្ចូល នៅក្នុងមេរៀននេះ ។

អ្នកអាចរកបានចម្លើយចំពោះចំណួរនេះ ដោយសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩ ដែលមានសេចក្ដីអធិស្ឋាន ដែលព្យាការី យ៉ូសែប ស្ម៊ីធ បានថ្វាយនៅក្នុងពិធីឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ។

បន្ទាប់ពីបានធ្វើការ និង លះបង់អស់រយៈពេលជិតបីឆ្នាំ ក្នុងការកសាងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ពួកបរិសុទ្ធបានឃើញការបំពេញតាមសេចក្ដីសន្យាដែលថា បើសិនជាពួកគេគោរពតាមព្រះបញ្ញត្តិទាំងឡាយ នោះពួកគេនឹង « មានអំណាចដើម្បីកសាងគេហដ្ឋាននោះ » ( គ. និង ស. ៩៥:១១ ) ។ នៅថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ១៨៣៦ សមាជិកសាសនាចក្របានចូលរួមពិធីឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ ហើយព្យាការី យ៉ូសែប ស្ម៊ីធ បានថ្វាយពាក្យអធិស្ឋានឆ្លងនោះ ។ សមាជិកជិត ១,000 នាក់បានចូលរួមពិធីឧទ្ទិសឆ្លងនោះ ។ មានមនុស្សជាច្រើននាក់ទៀតដែលបានចូលរួម ប៉ុន្តែអគារទាំងមូលពុំអាចដាក់មនុស្សទាំងអស់បានឡើយ ។ ព្យាការីបានរៀបចំឲ្យពួកគេចូលរួមនៅក្នុងការប្រជុំមួយក្នុងបន្ទប់មួយផ្សេងទៀត ហើយពិធីឧទ្ទិសឆ្លងត្រូវបានប្រារព្ធឡើងវិញម្ដងទៀតសម្រាប់ពួកគេនៅប៉ុន្មានថ្ងៃក្រោយមក ។

តើអ្នកធ្លាប់បានចូលរួមនៅក្នុង ពិធីឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធដែរឬទេ ? សូមស្រមៃថាបានចូលរួមក្នុងពិធីឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ៖ នេះគឺជាព្រះវិហារបរិសុទ្ធដំបូងបង្អស់ ចាប់តាំងពីជំនាន់បូរាណមក ។ អ្នកបានទន្ទឹងរង់ចាំថ្ងៃនោះអស់រយៈពេលជាយូរមកហើយ ។ មានទំនុកតម្កើងបើកកម្មវិធីដោយក្រុមចម្រៀង ។ បន្ទាប់មក ស៊ីឌនី រិកដុន ដែលជាទីប្រឹក្សាក្នុងគណៈប្រធានទីមួយ ចែកចាយសុន្ទរកថា ។ បន្ទាប់ពីបានសម្រាកបន្តិចក្រោយមក អ្នកមានឱកាសគាំទ្រថ្នាក់ដឹកនាំសាសនាចក្រ ។ ក្រោយមក ព្យាការី យ៉ូសែប ស្ម៊ីធ ក្រោកឈរ ហើយអានពាក្យអធិស្ឋានឆ្លង ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:១–៤ ដោយស្វែងរកមូលហេតុចម្បង ដែលពួកបរិសុទ្ធកសាងព្រះវិហារបរិសុទ្ធ ។ សូមកត់ចំណាំថា សាសនាចក្រនាពេលបច្ចុប្បន្ននេះក៏ដូចជាកាលជំនាន់បូរាណដែរ **ព្រះអម្ចាស់ត្រាស់បង្គាប់យើងឲ្យកសាងព្រះវិហារបរិសុទ្ធ ។**

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៥ ដោយស្វែងរកឃ្លាដែល ពិពណ៌នាអំពីការលះបង់របស់ពួកបរិសុទ្ធក្នុងការកសាងព្រះវិហារបរិសុទ្ធ ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នករកឃើញ ។



នៅចន្លោះខែ មិថុនា ឆ្នាំ ១៨៣៣ និង ខែ មិនា ឆ្នាំ ១៨៣៦ សមាជិកសាសនាចក្របានលះបង់ពេលវេលា ប្រាក់កាស និង ទ្រព្យសម្បត្តិដើម្បីជួយកសាងព្រះដំណាក់នៃព្រះអម្ចាស់ឡើង ។ បុរសៗបានស្ម័គ្រចិត្តធ្វើការ នៅក្នុងការដ្ឋាន ។ ស្ត្រីៗបានកាត់ដេរសម្លៀកបំពាក់ ផ្ដល់ទីស្នាក់អាស្រ័យ ហើយនៅពេលបុរសជាច្រើនបានចាកចេញទៅជាមួយជំរុំស៊ីយ៉ូនដើម្បីជួយពួកបរិសុទ្ធដែលមានបញ្ហានៅក្នុងរដ្ឋ មិសសួរី នោះមានស្ត្រីមួយចំនួន បានបន្តធ្វើការងារសាងសង់ព្រះវិហារបរិសុទ្ធ ។ ពួកបរិសុទ្ធមួយចំនួនដូចជា ចន ថៃនើរ និង វ៉េនណា ចាក បានបរិច្ចាគទ្រព្យសម្បត្តិរបស់ខ្លួនយ៉ាងច្រើនសន្ធឹកសន្ធាប់ដល់ការសាងសង់ព្រះវិហារបរិសុទ្ធ ។

នៅពេលការសាងសង់បានរីកលូតលាស់ទៅមុខ នោះពួកបរិសុទ្ធបានដឹងថា ពួកគេត្រូវការលទ្ធភាពដើម្បីរៀបឥដ្ឋនៅផ្នែកខាងក្រៅនៃព្រះវិហារបរិសុទ្ធ ។ មានគេបានណែនាំថា ជាងសំណង់ម្នាក់ឈ្មោះ អាធីមើស មីឃេ មានជំនាញពិសេសអាចបញ្ចប់ការសាងសង់ផ្នែកខាងក្រៅបាន ដោយប្រើក្បួនសំណង់ថ្មបំណែក ។ ប៉ុន្តែ អាធីមើស រស់នៅប្រទេសកាណាដាងណោះ ហើយគាត់ពុំមែនជាសមាជិកសាសនាចក្រឡើយ ។ យ៉ូសែប ស្ម៊ីធ បានចាត់ឲ្យ ព្រិកហាំ យ៉ង់ ធ្វើដំណើរទៅប្រទេសកាណាដា ដើម្បីបង្រៀន ហើយធ្វើពិធីបុណ្យជ្រមុជទឹកឲ្យ អាធីមើស ហើយនាំគាត់មកទីក្រុង ខឺតឡង់ ដើម្បីជួយកសាងព្រះវិហារបរិសុទ្ធ ។ លំដាប់នោះព្យាការីបានមានប្រសាសន៍ថា « ហើយប្រាប់គាត់ឲ្យនាំយកប្រាក់មួយពាន់ដុល្លាមកតាមខ្លួនផង » ( ប្រសាសន៍ដកស្រង់នៅក្នុង អិម រ័សុល បាឡឺដ «What Came from Kirtland» | Brigham Young University devotional ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ | ទំព័រ ៨–៩ speeches.byu.edu ) ។ ព្រិកហាំ បានធ្វើតាមបណ្ដាំគ្រប់យ៉ាង ។ អាធីមើស បានសម្រេចចិត្តទទួលពិធីបុណ្យជ្រមុជទឹក ហើយបានចាកចេញពីផ្ទះសម្បែងរបស់គាត់នៅប្រទេសកាណាដាទុកជាការលះបង់មួយដ៏ធំ ដើម្បីមកជួយកសាងព្រះវិហារបរិសុទ្ធ ។

តម្លៃសរុបនៃព្រះវិហារបរិសុទ្ធគឺប្រមាណ ៦០,០០០ ដុល្លារ—ដែលជាបរិមាណដ៏ច្រើនលើសលុបនៅជំនាន់នោះ ជាពិសេសបើគិតអំពីភាពក្រខ្សត់ពួកបរិសុទ្ធ ។

២. តើអ្វីដែលធ្វើឲ្យអ្នកស្ញប់ស្ញែង អំពីការលះបង់ដែលពួកបរិសុទ្ធបានធ្វើ ដើម្បីកសាងព្រះវិហារបរិសុទ្ធ ? សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៥ ម្ដងទៀត ដោយស្វែងរកសេចក្ដីពិតមួយ អំពីព្រះវិហារបរិសុទ្ធ ដែលពន្យល់អំពីមូលហេតុដែលធ្វើឲ្យពួកបរិសុទ្ធមានឆន្ទៈលះបង់យ៉ាងច្រើនសន្ធឹកសន្ធាប់ដើម្បីកសាង ។ សូមសរសេរសេចក្ដីពិតនោះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

សូមគិតអំពីថាតើវាមានន័យដូចម្ដេច ដែលថាព្រះអម្ចាស់នឹង « សម្ដែងអង្គទ្រង់ដល់រាស្ត្ររបស់ទ្រង់ » ( គ. និង ស. ១០៩:៥ ) ។ ពាក្យ *សម្ដែង* មានន័យថា បង្ហាញ ឬ ធ្វើឲ្យគេដឹង ។ ចំពោះមនុស្សខ្លះ ពាក្យនេះរួមបញ្ចូលទាំងការបង្ហាញខ្លួនឲ្យឃើញ ។ ចំពោះអ្នកទាំងឡាយណាដែលចូលក្នុងព្រះវិហារបរិសុទ្ធដោយសក្ដិសម ទ្រង់សម្ដែងអង្គទ្រង់តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ និង គោលលទ្ធិនានា ដែលមានបង្រៀននៅទីនោះ ដែលជួយយើងឲ្យស្គាល់ទ្រង់ ។




ប្លង់មើលចំពីលើ នៃជាន់ខាងក្រោមក្នុងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់

ព្រះអម្ចាស់ក៏អាចសម្ដែងអង្គទ្រង់ទៅកាន់រាស្ត្ររបស់ទ្រង់នៅខាងក្រៅព្រះវិហារបរិសុទ្ធបានផងដែរ ប៉ុន្តែព្រះវិហារបរិសុទ្ធគឺជាទីកន្លែងដែលអ្នកទាំងឡាយដែលមានភាពសក្តិសម អាចទទួលបានអារម្មណ៍ពីព្រះចេស្ដាទ្រង់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:១២–១៣ ដោយស្វែងរកឃ្លាទាំងឡាយ ដែលជួយអ្នកយល់អំពីរបៀប ដែលព្រះអម្ចាស់អាចសម្ដែងអង្គទ្រង់ទៅដល់អ្នក នៅក្នុងព្រះវិហារបរិសុទ្ធ ។ សូមពិចារណាអំពីការគូសចំណាំឃ្លាទាំងឡាយណាដែលមានន័យជាពិសេសចំពោះអ្នក ។

៣. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគ្រាដែលអ្នកបានមានអារម្មណ៍ថានៅក្បែរព្រះអម្ចាស់នៅក្នុងព្រះវិហារបរិសុទ្ធ ? បើសិនជាអ្នកពុំទាន់បានទៅព្រះវិហារបរិសុទ្ធនៅឡើយទេនោះ សូមសរសេរអំពីអារម្មណ៍ដែលអ្នកសង្ឃឹមថានឹងទទួលបាន នៅពេលអ្នកមានឱកាសទៅព្រះវិហារបរិសុទ្ធ ។

សូមពិចារណាថាតើអារម្មណ៍នៃការស្ថិតនៅក្បែរព្រះអង្គសង្គ្រោះនៅក្នុងព្រះវិហារបរិសុទ្ធ អាចមានអានុភាពទៅលើជីវិតរបស់អ្នក នៅពេលអ្នកចេញមកក្រៅព្រះវិហារបរិសុទ្ធវិញយ៉ាងដូចម្ដេច ។ បន្ទាប់មក សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:១៤–២៣ ដោយស្វែងរកពរជ័យបន្ថែម ដែលបានសន្យាដល់អ្នកទាំងឡាយ ដែលមកថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធ ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នករកឃើញ ។

សេចក្ដីពិតមួយដែលយើងអាចរៀនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:២២–២៣ គឺ **ការទទួលបានពរជ័យក្នុងព្រះវិហារបរិសុទ្ធ ប្រដាប់យើងដោយព្រះចេស្ដា និង ជំនួយពីព្រះអម្ចាស់នៅពេលយើងបម្រើទ្រង់ ។** នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក អ្នកអាចនឹងចង់សរសេរបញ្ចូលសេចក្ដីពិតនេះទៅក្នុងបញ្ជីនៃមូលហេតុដែលយើងកសាងព្រះវិហារបរិសុទ្ធ ។

តើអ្នកគិតថា « ប្រដាប់ដោយព្រះចេស្ដា [ របស់ព្រះ ] » ( គ. និង ស. ១០៩:២២ ) មានន័យដូចម្ដេច ? សូមពិចារណាអំពីសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ យ៉ូសែប ប៊ី វឺតលីន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ រួចស្វែងរកព្រះចេស្ដាដែលអាចកើតមានចំពោះអ្នក នៅពេលអ្នកមកថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធ ៖ « នៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ សមាជិកសាសនាចក្រដែលស្មោះត្រង់ អាចត្រូវបានប្រទានឲ្យ ‹ ដោយព្រះចេស្ដាពីស្ថានលើ › [គ. និង ស. ៩៥:៨ ] ជាព្រះចេស្ដាដែលអាចឲ្យយើងតតាំងនឹងការល្បួង គោរពសេចក្ដីសញ្ញា គោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ហើយថ្លែងទីបន្ទាល់ អំពីដំណឹងល្អដោយមានចិត្តក្លៀវក្លា និង មិនមានការភ័យខ្លាចទៅដល់ក្រុមគ្រួសារ មិត្តភក្តិ និង អ្នកជិតខាង » ( «Cultivating Divine Attributes» *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ទំព័រ ២៧ ) ។

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើព្រះចេស្ដាប្រភេទនេះ អាចជាពរជ័យចំពោះអ្នក និង ក្រុមគ្រួសាររបស់អ្នកបានយ៉ាងដូចម្ដេច ?

ខ. តើវានឹងក្លាយជាពរជ័យ ចំពោះពួកអ្នកផ្សព្វផ្សាយសាសនាយ៉ាងដូចម្ដេច ?

### *ការពិចារណា*

ការពិចារណារួមបញ្ចូលទាំង ការគិត ការស្មឹងស្មាធ ការសួរសំណួរ និង ការវាយតម្លៃលើអ្វីៗដែលអ្នកដឹង និង អ្វីៗដែលអ្នកបានរៀន ។ ការពិចារណាអាចជួយអ្នកឲ្យយល់អំពីអ្វី ដែលយើងត្រូវធ្វើ ដើម្បីអនុវត្តតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ សូមពិចារណាអំពីពរជ័យមួយចំនួនដែលព្រះអម្ចាស់បានសន្យាដល់អ្នកទាំងឡាយ ដែលមកថ្វាយបង្គំ ហើយបម្រើនៅក្នុងព្រះវិហារបរិសុទ្ធ ។ សូមពិចារណាអំពីរបៀបរស់នៅដែលអ្នកត្រូវតែមាន ដើម្បីឲ្យការសន្យាទាំងនេះនឹងត្រូវបានបំពេញនៅក្នុងជីវិតរបស់អ្នក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:២៤–៣៤

*ព្យាការីអធិស្ឋានសូមឲ្យព្រះអម្ចាស់ថែរក្សា និង ប្រទានពរដល់អ្នកទាំងឡាយ ដែលមកថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធ*

សូមមើលទៅរូបភាពនៃស្លាបព្រាកំបោរ និង ដាវដែលភ្ជាប់មកជាមួយនេះ ។ ស្លាបព្រាកំបោរគឺជាសម្ភារប្រើដើម្បី បៀកស៊ីម៉ងត៍ភ្ជាប់ឥដ្ឋ និង ថ្ម ។ តើសម្ភារនីមួយៗទាំងនេះ អាចត្រូវបានប្រើសម្រាប់ការសាងសង់ព្រះវិហារបរិសុទ្ធយ៉ាងដូចម្ដេច ?



នៅអំឡុងពេលសាងសង់ព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ពួកមនុស្សកំណាចបានគំរាមកំហែងថានឹងកំទេចជញ្ជាំងព្រះវិហារបរិសុទ្ធចោល ។ ប្រធាន ព្រិកហាំ យ៉ង់ បានមានប្រសាសន៍ប្រាប់អំពី « កម្មករដែលធ្វើការសាងសង់ជញ្ជាំង បានកាន់ដាវនៅដៃម្ខាង ដើម្បីការពារខ្លួនពីមនុស្សកំណាច នៅពេលដែលពួកគេកំពុងតែតម្រៀបថ្ម ហើយហុចស្លាបព្រាកំបោរទៅឲ្យគ្នា » ( *Discourses of Brigham Young*, ជ្រើសរើសចេញពី John A. Widtsoe [ ឆ្នាំ ១៩៥៤ ] ទំព័រ ៤១៥ ) ។ យូរៗម្ដង បុរសដែលធ្វើការសាងសង់ព្រះវិហារបរិសុទ្ធនៅពេលថ្ងៃក៏ត្រូវយាមល្បាតនៅពេលយប់ដែរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:២៤–២៨ ដោយស្វែងរកការការពារដែលព្យាការី យ៉ូសែប ស្ម៊ីធ បានទូលសូមពីព្រះអម្ចាស់ ។

នៅក្នុង ខទី ២៤ សូមកត់ចំណាំឃ្លា « មានឈ្មោះ និង ជំហរដ៏ប្រសើរ » ។ ការណ៍នេះសំដៅទៅលើការតម្រូវឲ្យមានភាពសក្ដិសមក្នុងការថ្វាយបង្គំព្រះអម្ចាស់ នៅក្នុងព្រះវិហារបរិសុទ្ធ និង មានចិត្តស្មោះត្រង់ចំពោះសេចក្ដីសញ្ញាដែលយើងធ្វើនៅទីនោះ ។

ចេញពីអ្វីដែលអ្នកបានអាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:២៤–២៨ សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ៖ **បើសិនជាយើងមានភាពសក្ដិសម ហើយថ្វាយបង្គំព្រះអម្ចាស់នៅក្នុងព្រះវិហារបរិសុទ្ធ នោះ** ។ ( អ្នកនឹងប្រហែលជារកឃើញ របៀបជាច្រើនដើម្បីបញ្ចប់សេចក្ដីថ្លែងការណ៍នេះ ។ ឧទាហរណ៍ អ្នកអាចនឹងឃើញថា ពរជ័យមួយនៃការថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធគឺ « មិនមានគ្រឿងសាស្ត្រាវុធបានធ្វើឡើងទាស់នឹង [ យើង ] បានលូតលាស់ឡើយ » [ គ. និង ស. ១០៩:២៥ ] ។ អ្នកអាចនឹងចង់សរសេរបញ្ចូលគោលការណ៍នេះ និង គោលការណ៍ដទៃទៀត ទៅក្នុងបញ្ជីនៃមូលហេតុដែលយើងកសាងព្រះវិហារបរិសុទ្ធ ) ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:២៩–៣៤ យើងអានអំពីរបៀបដែលព្យាការី យ៉ូសែប ស្ម៊ីធ បានអធិស្ឋានសូមឲ្យជនដែលរាយការណ៍កុហកអំពីពួកបរិសុទ្ធត្រូវបំភាន់ ហើយសូមឲ្យសមាជិកសាសនាចក្រនឹងមានលទ្ធភាពក្រោកឈរឡើង ហើយធ្វើកិច្ចការរបស់ព្រះអម្ចាស់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៣៥–៧៦

*យ៉ូសែប ស្ម៊ីធ អធិស្ឋានសម្រាប់ថ្នាក់ដឹកនាំសាសនាចក្រ សម្រាប់ពួកបរិសុទ្ធនៅរដ្ឋ មិសសួរី សម្រាប់ពួកអ្នកសង្កត់សង្កិនដល់ពួកបរិសុទ្ធ និង សូមឲ្យជាតិសាសន៍ទាំងឡាយនៅលើផែនដី នឹងស្ដាប់ពួកអ្នកផ្សព្វផ្សាយសាសនា*

ពួកបរិសុទ្ធបានទន្ទឹងរង់ចាំការប្រទានព្រះចេស្ដា និង សិរីល្អ ដែលបានសន្យាដល់ពួកគេទុកជាផ្លែផ្កានៃការកសាងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៣៥–៤៦ ព្យាការី យ៉ូសែប ស្ម៊ីធ បានទូលអង្វរព្រះអម្ចាស់ឲ្យបំពេញព្រះវិហារបរិសុទ្ធដោយនូវសិរីល្អទ្រង់ ហើយប្រទានទីបន្ទាល់ និង អំណាចដល់ពួកអ្នកបម្រើទ្រង់ ដែលត្រូវនឹងត្រូវការដើម្បីប្រកាសដំណឹងល្អ ។



នៅល្ងាចថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ១៨៣៦ បន្ទាប់ពីពិធីឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធហើយ កូរ៉ុមបព្វជិតភាពបានជួបប្រជុំគ្នានៅក្នុងព្រះវិហារបរិសុទ្ធ ។ យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា លោក « បានប្រទានដល់ពួកគាត់នូវសេចក្ដីណែនាំអំពីវិញ្ញាណនៃការព្យាករណ៍ ហើយលោកបានចាត់ឲ្យអ្នកចូលរួមឡើងថ្លែង ។. . .

« បងប្រុស ចច អេ ស្ម៊ីធ បានក្រោកឈរឡើង ហើយបានចាប់ផ្ដើមព្យាករ នៅពេលសំឡេងមួយបានឮឡើងដូចជាសំឡេងខ្យល់បក់យ៉ាងខ្លាំង ដែលបានឮខ្ទរខ្ទារពេញព្រះវិហារបរិសុទ្ធ ហើយមនុស្សទាំងអស់បានក្រោកឈរឡើងទន្ទឹមគ្នាដោយបានទទួលអានុភាពពីព្រះវិញ្ញាណ នោះមនុស្សជាច្រើនបានចាប់ផ្ដើមថ្លែងចេញជាច្រើនភាសា និង ជាការព្យាករណ៍ ចំណែកមនុស្សខ្លះទៀតបានឃើញការនិមិត្តដ៏អស្ចារ្យៗ ហើយបានឃើញព្រះវិហារបរិសុទ្ធពេញទៅដោយពួកទេវតា ដែលជាព្រឹត្តិការណ៍មួយខ្ញុំបានប្រកាសទៅដល់បណ្ដាជន ។ ប្រជាជនដែលរស់នៅក្បែរខាង បានរត់មកទាំងអស់គ្នា ( ព្រោះបានឮសំឡេងចម្លែកនៅខាងក្នុង និង បានឃើញពន្លឺយ៉ាងភ្លឺដូចជាបង្គោលភ្លើងស្ថិតនៅក្នុងព្រះវិហារបរិសុទ្ធ ) ហើយពួកគេបានស្ងើចចំពោះអ្វីដែលបានកើតឡើងនោះ » ( នៅក្នុង *History of the Church* ២:៤២៨ ) ។ ព្រះគម្ពីរសញ្ញាថ្មីប្រាប់យើងអំពីព្រឹត្តិការណ៍មួយស្រដៀងនេះ ដែលកើតឡើងក្នុងចំណោមពួកបរិសុទ្ធស្មោះត្រង់ ដែលបានប្រមូលគ្នានៅមិនយូរប៉ុន្មាន បន្ទាប់ពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ ព្រឹត្តិការណ៍នោះ ដែលជាញឹកញាប់ត្រូវបានហៅថា បុណ្យថ្ងៃទីហាសិប មានកត់ត្រានៅក្នុង កិច្ចការ ២ ។ អ្នកអាចនឹងចង់ដាក់បទគម្ពីរយោង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៣៦–៣៧ ជាមួយនឹង កិច្ចការ ២:២–៣ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៤៧–៦៧ យើងអានថា យ៉ូសែប ស្ម៊ីធ បានអធិស្ឋានសម្រាប់ពួកបរិសុទ្ធ ដែលត្រូវបានបណ្ដេញចេញពីផ្ទះសម្បែងនៅរដ្ឋ មិសសួរី ហើយលោកបានអធិស្ឋានសម្រាប់អ្នកដែលបានសង្កត់សង្កិនពួកគេ ។ លោកក៏បានអធិស្ឋានសម្រាប់ព្រះអម្ចាស់ ឲ្យបន្ទន់ចិត្តមនុស្សនៅលើផែនដី ដើម្បីពួកគេទទួលពួកអ្នកបម្រើ ដែលចេញពីព្រះវិហារបរិសុទ្ធទៅប្រកាសដំណឹងល្អ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៦៨–៨០

*ព្យាការីអធិស្ឋានសម្រាប់សាសនាចក្រ ហើយសូមឲ្យព្រះអម្ចាស់ទទួលយកសេចក្ដីឧទ្ទិសព្រះវិហារបរិសុទ្ធ*

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩:៦៨–៦៩, ៧១–៧៣, ៧៨–៨០ ដោយស្វែងរកសំណូមពរបន្ថែមទៀត ដែលព្យាការីបានទូលនៅក្នុងពាក្យអធិស្ឋានឆ្លង ។

៥. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមរាយបញ្ជីសំណូមពរដែលព្យាការីបានទូលនៅក្នុងខគម្ពីរទាំងនេះ ។ បន្ទាប់មក សូមសរសេរថាតើអត្ថប្រយោជន៍អ្វីខ្លះ ដែលអ្នកគិតថាអាចកើតចេញពីសំណូមពរទាំងនេះ រួមទាំងសំណូមពរដូចនេះនៅក្នុងការអធិស្ឋានរបស់អ្នក ។

បើសិនជាអ្នកមានសៀវភៅទំនុកតម្កើង សូមបើកទៅ « ព្រះវិញ្ញាណនៃព្រះ » ( *ទំនុកតម្កើង* លេខ ២ ) ។ ទំនុកតម្កើងនេះត្រូវបានច្រៀងនៅឯពិធីឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ភ្លាមៗបន្ទាប់ពីពាក្យអធិស្ឋានឆ្លងត្រូវបានថ្លែង ( សូមមើលកំណត់ចំណាំនៅពីក្រោមទំនុកតម្កើងនេះ ) ។ ទំនុកតម្កើងនេះនៅតែបន្តច្រៀង នៅក្នុងពិធីឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធនាពេលសព្វថ្ងៃនេះដដែល ។ ស្ដាប់ អាន ឬ ច្រៀងទំនុកតម្កើង

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

ចម្លើយរបស់លំហាត់ផ្គូផ្គង ៖ (១) ខ, (២) ក, (៣) ង, (៤) គ, (៥) ឃ ។

## មេរៀនទី ២៤ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០

### បុព្វកថា

នៅថ្ងៃអាទិត្យ ទី ៣ ខែ មេសា ឆ្នាំ ១៨៣៦ ការប្រជុំសាក្រាម៉ង់មួយត្រូវបានប្រារព្ធធ្វើនៅក្នុងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។ នៅពេលកំពុងប្រជុំនោះព្យាការី យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី បានដកខ្លួនចេញពីក្រុមជំនុំដើម្បីទៅអធិស្ឋាន ។ ក្រោយពីបានក្រោកឈរឡើងពីអធិស្ឋាន ព្រះយេស៊ូវគ្រីស្ទបានបង្ហាញអង្គទ្រង់ទៅដល់ពួកលោក ហើយបានទទួលយកព្រះវិហារបរិសុទ្ធដែលបានឧទ្ទិសឆ្លងថ្មីនោះ ។ បន្ទាប់មក ម៉ូសេ អេលីយ៉ាស់ និង អេលីយ៉ា បានបង្ហាញខ្លួនដល់ពួកលោក ហើយកូនសោបព្វជិតភាពត្រូវបានស្ដារឡើងវិញ. គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០ គឺជាដំណើររឿងនៃការនិមិត្តទាំងនេះ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១–១០

*ព្រះអម្ចាស់បង្ហាញអង្គទ្រង់ ហើយទទួលយកព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់*




តើអ្នកធ្លាប់កត់ចំណាំឃ្លា ដែលបានឆ្លាក់នៅផ្នែកខាងក្រៅនៃគ្រប់ព្រះវិហារបរិសុទ្ធដែរឬទេ ? វាឆ្លាក់ថា « បរិសុទ្ធដល់ព្រះអម្ចាស់—ព្រះដំណាក់របស់ព្រះអម្ចាស់ » ។

ដោយសារតែព្រះវិហារបរិសុទ្ធគឺជាព្រះដំណាក់របស់ព្រះអម្ចាស់ តើអ្នកអាចគិតអំពីគ្រាមួយដែលព្រះអម្ចាស់បានយាងមកម្ដងនោះដែរឬទេ ?

ការយាងមកម្ដងនោះបានកើតឡើង នៅមិនយូរប៉ុន្មានបន្ទាប់ពី ការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ។ សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០ ដោយស្វែងរកថាតើនរណាខ្លះ ដែលមានវត្តមាននៅទីនោះ និង អ្វីខ្លះដែលពួកលោកបានធ្វើពីមុនឆ្លងកាត់បទពិសោធន៍បែបនេះ ។




សូមអានដំណើររឿងរបស់ព្យាការី យ៉ូសែប ស្ម៊ីធ អំពីការនិមិត្តនេះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១–៣ ។ សូមសាកល្បងគិតស្រមៃអំពីអ្វីដែលបានកើតឡើង និង ស្រមៃថាតើអ្នកអាចនឹងមានអារម្មណ៍ដូចម្ដេចបើសិនជាអ្នកមានវត្តមាននៅទីនោះ ។ បន្ទាប់មក សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:៤–៥ រួចស្វែងរកអ្វីដែលព្រះអង្គសង្គ្រោះបានមានព្រះបន្ទូលទៅកាន់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ។ អ្នកអាចនឹងចង់គូសចំណាំឃ្លាទាំងឡាយ ដែលមានអត្ថន័យចំពោះអ្នក ។

១. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្វីដែលមានអត្ថន័យចំពោះអ្នកនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:៤–៥ រួចពន្យល់អំពីមូលហេតុ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:៥ មាននូវសេចក្ដីណែនាំពីព្រះអម្ចាស់ចំពោះ យ៉ូសែប និង អូលីវើរ ដើម្បីឲ្យពួកលោកងើបមុខឡើង ហើយអរសប្បាយរីករាយចុះ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:៦–១០ រួចស្វែងរកមូលហេតុដែល យ៉ូសែប និង អូលីវើរ ថែមទាំងពួកបរិសុទ្ធ ត្រូវអរសប្បាយរីករាយ ។ សូមគិតពីការគូសចំណាំអ្វីដែលអ្នករកឃើញ ។

មូលហេតុមួយដែលពួកបរិសុទ្ធត្រូវអរសប្បាយរីករាយ មាននៅក្នុង ខទី ៧–៨ ។ ខគម្ពីរទាំងនេះបង្រៀនអំពីគោលការណ៍ដូចតទៅ ៖ **បើសិនជាយើងគោរពប្រតិបត្តិតាមព្រះបញ្ញត្តិ ហើយរក្សាព្រះដំណាក់ទ្រង់ឲ្យបានបរិសុទ្ធ នោះទ្រង់នឹងសម្ដែងអង្គទ្រង់ឲ្យយើងឃើញនៅក្នុងព្រះវិហារបរិសុទ្ធរបស់ទ្រង់ ។**

២. បើសិនជាអ្នកជាធ្លាប់មានឱកាសទៅ ឬ ចូលក្នុងព្រះវិហារបរិសុទ្ធ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគ្រាដែលអ្នកបានមានអារម្មណ៍ថានៅក្បែរព្រះអម្ចាស់នៅទីនោះ ។ បើសិនជាអ្នកពុំទាន់មានឱកាសទេនោះ សូមសរសេរអំពីអារម្មណ៍ដែលអ្នកអាចនឹងមាននៅទីនោះ ។ បន្ទាប់មកសូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើព្រះអម្ចាស់អាចសម្ដែងអង្គទ្រង់ ទៅកាន់មនុស្សនៅក្នុងព្រះវិហារបរិសុទ្ធបានយ៉ាងដូចម្ដេច ? ( ពាក្យ *សម្ដែង* មានន័យថា បង្ហាញ ឬ ធ្វើឲ្យគេដឹង ដូចបានពិភាក្សានៅក្នុងមេរៀននៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៩ ) ។

ខ. តើយើងអាចរក្សាព្រះដំណាក់របស់ព្រះអម្ចាស់ ឲ្យមានភាពបរិសុទ្ធ និង ស្អាតស្អំបានយ៉ាងដូចម្ដេច ?

គ. តើអ្នកគិតថា ហេតុអ្វីបានជាព្រះអម្ចាស់មានព្រះទ័យតម្រូវឲ្យយើងគោរពប្រតិបត្តិ និង ស្អាតស្អំ ពីមុនទ្រង់នឹងសម្ដែងអង្គទ្រង់ឲ្យយើងឃើញនៅក្នុងព្រះវិហារបរិសុទ្ធ ?

សូមរំឭក គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:៩–១០ រួចស្វែងរកថាតើនរណាដែលនឹងមានពរ តាមរយៈការស្ដារពរជ័យនៃព្រះវិហារបរិសុទ្ធឡើងវិញ ។

៣. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើពិភពលោកមានពរតាមរយៈព្រះវិហារបរិសុទ្ធ និង កិច្ចការនៃសេចក្ដីសង្គ្រោះសម្រាប់មនុស្សរស់ផង និងមនុស្សដែលបានអស់ជីវិតទៅហើយផងយ៉ាងដូចម្ដេច ?

ខ. តើព្រះវិហារបរិសុទ្ធ បានប្រទានពរជ័យដល់ជីវិតអ្នកយ៉ាងដូចម្ដេចខ្លះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១១–១៦

*ម៉ូសេ អេលីយ៉ាស និង អេលីយ៉ា បង្ហាញខ្លួន ហើយ កូនសោបព្វជិតភាពត្រូវបានស្ដារឡើងវិញដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី*



ម៉ូសេ



អេលីយ៉ា

សូមមើលនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១១–១៣ ស្វែងរកថាតើនរណាដែលបានបង្ហាញខ្លួនដល់ព្យាការី យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី បន្ទាប់ពីបានឃើញ ការនិមិត្តនៃព្រះអម្ចាស់ ។ អ្នកអាចចង់គូសចំណាំ ឈ្មោះទាំងនេះ ។

តើអ្នកស្គាល់ថាម៉ូសេ និង អេលីយ៉ាគឺជានរណា និង កិច្ចការដ៏អស្ចារ្យៗមួយចំនួន ដែលពួកលោកបានធ្វើ កាលពួកលោក បានរស់នៅលើផែនដីនេះដែរឬទេ ? ដើម្បីរៀនបន្ថែមអំពី ព្យាការីព្រះគម្ពីរសញ្ញាចាស់ទាំងពីររូបនេះ សូមស្វែងរកឈ្មោះ របស់ពួកលោកនៅក្នុង Bible Dictionary ឬ សេចក្ដីណែនាំ ដល់បទគម្ពីរទាំងឡាយ ។

អេលីយ៉ាសអាចជាព្យាការីមួយរូប ដែលបានរស់នៅជំនាន់ របស់អ័ប្រាហាំ ។ លើសពីឈ្មោះទៅទៀត *អេលីយ៉ាស* គឺជា ងារមួយដែលមានន័យថា អ្នកនាំមុខ ឬ អ្នកស្ដារឡើងវិញ ។ ( សូមមើល សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ អេលីយ៉ាស » scriptures.lds.org; Bible Dictionary, “Elias” » ) ។

សារទូតទាំងបីរូបដែលបានបង្ហាញខ្លួននៅក្នុងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ បានប្រទានកូនសោបព្វជិតភាពទៅដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ។

៤. សូមចម្លងតារាងខាងក្រោមនេះ ចូលទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ បន្ទាប់មក សូមសិក្សាវគ្គបទគម្ពីរដែលមានសរសេរពីក្រោមឈ្មោះព្យាការីម្នាក់ៗ រួចសរសេរអំពីអ្វីដែលពួកលោកម្នាក់ៗបានស្ដារឡើងវិញ ។

| ម៉ូសេ<br>( គ. និង ស. ១១០:១១ ) | អេលីយ៉ាស<br>( គ. និង ស. ១១០:១២ ) | អេលីយ៉ា<br>( គ. និង ស. ១១០:១៣–១៦ ) |
|---|---|---|
| | | |

ព័ត៌មានខាងក្រោមនេះ អាចជួយអ្នកយល់អំពីកូនសោ ឬ សិទ្ធិអំណាចដែលអ្នកឃើញមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១១–១៦ ។

### « កូនសោនៃការប្រមូលរាស្ត្រអ៊ីស្រាអែល »

ព្រះអម្ចាស់បានប្រទានឈ្មោះ អ៊ីស្រាអែល ទៅដល់ យ៉ាកុប ដែលជាកូនប្រុសរបស់ អ៊ីសាក និង ជាចៅប្រុសរបស់ អ័ប្រាហាំ ( សូមមើល លោកុប្បត្តិ ៣២:២៨ ) ។ ពូជអំបូររបស់យ៉ាកុប ដែលត្រូវបានស្គាល់ថាជា អាណាចក្រអ៊ីស្រាអែលនោះ គឺជារាស្ត្រនៃសេចក្ដីសញ្ញារបស់ព្រះ ។ អស់រយៈពេលជាយូរយារក្រោយមក រាស្ត្រអ៊ីស្រាអែល និង ពូជអំបូររបស់ពួកគេបានខ្ចាត់ខ្ចាយពាសពេញផែនដី ដោយសារតែភាពទុច្ចរិតរបស់ខ្លួន ។ ព្រះអម្ចាស់បានសន្យាថា នឹងប្រមូលរាស្ត្រនៃសេចក្ដីសញ្ញារបស់ទ្រង់ ( សូមមើល នីហ្វៃទី១ ១៥:១៣–១៤; នីហ្វៃទី៣ ៥:២៤; ១៦:៥; ២៩:១, ៣ ) ។ ពូជអំបូររបស់យ៉ាកុប និង រាស្ត្រដទៃទៀតត្រូវបានប្រមូលទៅកាន់អាណាចក្ររបស់ព្រះអម្ចាស់តាមរយៈកិច្ចការផ្សព្វផ្សាយសាសនា ។ កូនសោបព្វជិតភាពដែលម៉ូសេបានស្ដារឡើងវិញនោះ បានពង្រីកឡើងជាកិច្ចការផ្សព្វផ្សាយសាសនានៅក្នុងសាសនាចក្រនៅពាសពេញផ្ទៃផែនដី ។



អែលឌើរ រ័សុល អិម ណិលសុន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ ៖ « កិច្ចការផ្សព្វផ្សាយសាសនាគឺចាំបាច់ ក្នុងការប្រមូលពួកអ៊ីស្រាអែល ។. . . នៅក្នុងប្រទេសជាតិជាច្រើន អ្នកផ្សព្វផ្សាយសាសនារបស់យើងបានស្វែងរកកូនចៅនៃសាសន៍អ៊ីស្រាអែលដែលបានបែកខ្ញែក » ( The Gathering of Scattered Israel » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ៨១ ) ។



ប្រធាន ស្ពែនសើរ ដបុលយូ ឃីមបឹល បានបង្រៀន ៖ « ការប្រមូលផ្ដុំសាសន៍អ៊ីស្រាអែលរួមមានការចូលរួមក្នុងសាសនាចក្រដ៏ពិត និង ការស្គាល់ព្រះដ៏ពិត ។. . . ហេតុដូច្នេះហើយ បើសិនជាបុគ្គលណាម្នាក់ដែលបានទទួលយកដំណឹងល្អដែលបានស្ដារឡើងវិញ និង អស់អ្នកដែលឥឡូវនេះស្វែងរកការថ្វាយបង្គំព្រះអម្ចាស់ជាភាសារបស់ខ្លួន ព្រមទាំងជាមួយនឹងពួកបរិសុទ្ធនៅក្នុងប្រទេសដែលខ្លួនរស់នៅ នោះមានន័យថាបានអនុវត្តតាមក្រឹត្យវិន័យនៃការប្រមូលផ្ដុំសាសន៍អ៊ីស្រាអែល ហើយទទួលបានមរតកនៃពរជ័យទាំងអស់ ដែលបានសន្យាចំពោះពួកបរិសុទ្ធនៅក្នុងថ្ងៃចុងក្រោយបង្អស់ » (*The Teachings of Spencer W. Kimball* ការបោះពុម្ពរបស់ អ៊ីដ្វើត អិល ឃីមបឹល [ ឆ្នាំ ១៩៨២ ] ទំព័រ ៤៣៩ ) ។

**អ្នកអាចនឹងចង់សរសេរពាក្យ *កិច្ចការផ្សព្វផ្សាយសាសនា* នៅលើតារាង ក្នុងប្រអប់ឈរពីក្រោមចំណងជើង « ម៉ូសេ » ។**

## « សម័យកាន់កាប់ត្រួតត្រា នៃដំណឹងល្អនៃលោកអ័ប្រាហាំ »



សម័យកាន់កាប់ត្រួតត្រា នៃដំណឹងល្អនៃលោកអ័ប្រាហាំ ត្រូវបានប្រគល់ទៅឲ្យព្យាការី យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ដោយ អេលីយ៉ា ដែលបានបំពេញការសន្យាដែលព្រះអម្ចាស់បានធ្វើជាមួយអ័ប្រាហាំ ។ អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ ៖ « អេលីយ៉ាស បាននាំត្រឡប់មកវិញ នូវ ‹ ដំណឹងល្អនៃលោកអ័ប្រាហាំ › គឺជាសេចក្ដីសញ្ញានៃអ័ប្រាហាំដ៏អស្ចារ្យ ដែលពួកអ្នកស្មោះត្រង់ទទួលបានការសន្យាឲ្យមានការរីកចម្រើនដ៏អស់កល្បជានិច្ច គឺជាការសន្យាថា តាមរយៈអាពាហ៍ពិពាហ៍សេឡេស្ទាល នោះពូជពង្សដ៏អស់កល្បជានិច្ចរបស់ពួកគេនឹងមានចំនួនច្រើនដូចខ្សាច់នៅមាត់សមុទ្រ ឬ ដូចជាផ្កាយរាប់មិនអស់នៅលើមេឃ ។ អេលីយ៉ាស បានផ្ដល់ការសន្យា—ដែលទទួលបានដោយអ័ប្រាហាំ អ៊ីសាក និង យ៉ាកុបពីបូរាណ—ថាមនុស្សនៅសម័យថ្មី និង កូនចៅរបស់លោកគ្រប់ជំនាន់នឹងមានពរ ។ ហើយយើងកំពុងផ្ដល់ពរជ័យរបស់ អ័ប្រាហាំ អ៊ីសាក និងយ៉ាកុប ដល់អ្នកដែលនឹងទទួលយកវា » ( The Keys of the Kingdom » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៨៣ ទំព័រ ២២ ) ។

**អ្នកអាចនឹងចង់សរសេរពាក្យ *អាពាហ៍ពិពាហ៍សេឡេស្ទាល* និង *ពូជពង្សដ៏អស់កល្បជានិច្ច* នៅលើតារាង ក្នុងប្រអប់ឈរពីក្រោមចំណងជើង « អេលីយ៉ាស » ។**

## « កូនសោទាំងឡាយនៃគ្រាកាន់កាប់ត្រួតត្រានេះ »

**ដើម្បីជួយអ្នកយល់អំពីកូនសោបព្វជិតភាពដែល អេលីយ៉ាបានស្ដារឡើងវិញ សូមអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ៖**



ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានបង្រៀន ៖ « អំណាចនៃការផ្សារភ្ជាប់នេះបានប្រទានដល់អេលីយ៉ា គឺជាអំណាចដែលចងភ្ជាប់ស្វាមី និង ភរិយា ព្រមទាំងកូនចៅទៅនឹងឪពុកម្ដាយសម្រាប់ពេលនេះ និង ពេលដ៏នៅអស់កល្បជានិច្ច ។ វាគឺជាអំណាចនៃចងភ្ជាប់ ដែលមាននៅក្នុងគ្រប់ពិធីបរិសុទ្ធទាំងអស់នៃដំណឹងល្អ ។. . . ដោយសារតែអំណាចនេះហើយ ទើបគ្រប់ពិធីបរិសុទ្ធទាំងអស់ដែលទាក់ទងនឹងសេចក្ដីសង្គ្រោះត្រូវបានចងភ្ជាប់ ឬ ផ្សារភ្ជាប់ ហើយនោះគឺជាបេសកកម្មរបស់អេលីយ៉ាដែលត្រូវបង្ហាញខ្លួនមក ហើយស្ដារវាឡើងវិញ » (*Elijah the Prophet and His Mission* [ ឆ្នាំ ១៩៥៧ ] ទំព័រ ៥ ) ។

អែលឌើរ ដាវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ ៖



« ក្នុងនាមជាសមាជិកនៃសាសនាចក្រ ដែលត្រូវបានស្ដារឡើងវិញរបស់ព្រះគ្រីស្ទនេះ យើងមានទំនួលខុសត្រូវដោយសេចក្ដីសញ្ញាក្នុងការស្រាវជ្រាវរកជីដូនជីតារបស់យើង ហើយធ្វើពិធីបរិសុទ្ធការសង្គ្រោះនៃដំណឹងល្អសម្រាប់ពួកលោក ។ ‹ ដើម្បីមិនឲ្យអ្នកទាំងនោះបានគ្រប់លក្ខណ៍ ក្រៅពីយើងឡើយ › ( ហេព្រើរ ១១:៤០ . . . ) ។ ហើយ ‹ រីឯយើងក៏ពុំអាចបានល្អឥតខ្ចោះក្រៅពីមនុស្សស្លាប់របស់យើងដែរ › ( គ. និង ស. ១២៨:១៥ ) ។

« ដោយសារតែមូលហេតុនេះហើយ ទើបយើងធ្វើការស្រាវជ្រាវពង្សប្រវត្តិ កសាងព្រះវិហារបរិសុទ្ធ និង ធ្វើពិធីបរិសុទ្ធជំនួសមនុស្សដែលបានចែកឋានទៅ ។ ដោយសារហេតុផលនេះ អេលីយ៉ា ត្រូវបានបញ្ជូនឲ្យទៅស្ដារអំណាចផ្សារភ្ជាប់ ចំណងនៅលើផែនដី និងនៅស្ថានសួគ៌ » ( « The Hearts of the Children Shall Turn » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២៥–២៦ ) ។

យោងតាមការបកស្រាយទាំងនេះ តើអំណាច ឬ សិទ្ធិអំណាចអ្វីដែលអេលីយ៉ាបានស្ដារឡើងវិញ ? ( អ្នកអាចនឹងចង់សរសេរចម្លើយរបស់អ្នក នៅលើតារាងក្នុងប្រអប់ឈើ ពីខាងក្រោមចំណងជើង « អេលីយ៉ា » ) ។



នៅពេលអេលីយ៉ា បានបង្ហាញខ្លួននៅក្នុងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ លោកបានបំពេញការព្យាករណ៍ដែលថា អេលីយ៉ានឹងមក « មុនដែលថ្ងៃដ៏ធំ ហើយគួរស្ញែងខ្លាចរបស់ព្រះយេហូវ៉ាបានមកដល់ » ដើម្បី « នឹងបង្វែរចិត្តពួកឪពុកមកឯកូន និងចិត្តកូនមកឯឪពុកវិញ » ( ម៉ាឡាគី ៤:៥–៦ ) ។

៥. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីថាតើជីវិតរបស់អ្នកទទួលបានអត្ថប្រយោជន៍អ្វីខ្លះ តាមរយៈការស្ដារឡើងវិញនៃយ៉ាងហោចណាស់កូនសោបព្វជិតភាពមួយ ( កិច្ចការផ្សព្វផ្សាយសាសនា អាពាហ៍ពិពាហ៍សេឡេស្ទាល និង ពូជពង្សដ៏អស់កល្បជានិច្ច ឬ អំណាចនៃការផ្សារភ្ជាប់ រួមបញ្ចូលទាំងព្រះវិហារបរិសុទ្ធ និង កិច្ចការពង្សប្រវត្តិ ) ។

ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានកត់ត្រាថា ព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ « ត្រូវបានកសាងឡើងជាបឋម សម្រាប់ការស្ដារឡើងវិញនៃកូនសោសិទ្ធិអំណាច ។ នៅក្នុងការទទួលកូនសោទាំងនេះ នោះភាពពោរពេញនៃពិធីបរិសុទ្ធនៃដំណឹងល្អទាំងនេះ [ ត្រូវបាន ] សម្ដែងឡើង » (*Doctrines of Salvation,* comp . Bruce R. McConkie ៣ vols. [១៩៥៤–៥៦] ២:២៤២ ) ។ កូនសោនេះមាននៅដល់សព្វថ្ងៃនេះ ដែលកាន់ដោយប្រធាននៃសាសនាចក្រ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។

សូមបញ្ចប់សេចក្ដីថ្លែងការណ៍ដូចតទៅនេះ ៖ ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១១–១៦ យើងរៀនថា **កូនសោនៃកិច្ចការផ្សព្វផ្សាយសាសនា ក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ច និង កិច្ចការក្នុងព្រះវិហារបរិសុទ្ធ ជួយយើងត្រៀមខ្លួនសម្រាប់ ។**

អ្នករស់នៅក្នុងជំនាន់ដែលអ្នកអាចធ្វើកិច្ចការផ្សព្វផ្សាយសាសនា កិច្ចការពង្សប្រវត្តិ និង កិច្ចការក្នុងព្រះវិហារបរិសុទ្ធ និង ជាពេលដែលអ្នកអាចសម្លឹងមើលទៅមុខទៀតរួមបញ្ចូលទាំងពិធីបរិសុទ្ធនៃការផ្សារភ្ជាប់ផងដែរ ។ សូមគិតអំពីការដាក់គោលដៅដើម្បីរួមចំណែកក្នុងកិច្ចខិតខំខ្នែងទាំងនេះ ដើម្បីត្រៀមខ្លួនទទួលការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ។ អ្នកក៏អាចដាក់គោលដៅជាក់លាក់មួយ លើរបៀបដែលអ្នកនឹងត្រៀមខ្លួនរៀបអាពាហ៍ពិពាហ៍សេឡេស្ទាល ។ សូមទូលសូមព្រះវរបិតាសួគ៌ដើម្បីជួយអ្នកឲ្យសម្រេចបានគោលដៅនោះ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៤ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១

## បុព្វកថា

ក្នុងឆ្នាំ ១៨៣៦ សាសនាចក្របានជំពាក់បំណុលយ៉ាងច្រើន ។ ព្យាការី យ៉ូសែប ស្ម៊ីធ និង ថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រ បានធ្វើដំណើរទៅកាន់ក្រុង សាឡិម រដ្ឋ ម៉ាស្សាឈូសេត ដែលនៅទីនោះពួកលោកបានសង្ឃឹមថានឹងអាចទទួលបានប្រាក់ ដើម្បីសងបំណុលរបស់សាសនាចក្រ ។ នៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៨៣៦ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១ ជាកណ្ឌដែលព្រះអម្ចាស់បានធានាដល់លោក ទាក់ទងនឹងកង្វល់អំពីបំណុល និង សុខុមាលភាពរបស់ទីក្រុង ស៊ីយ៉ូន ។ ព្រះអម្ចាស់ក៏បានប្រទានសេចក្ដីណែនាំដល់ព្យាការីផងដែរ ដែលទាក់ទងនឹងការស្នាក់នៅរបស់ថ្នាក់ដឹកនាំសាសនាចក្រនៅក្រុង សាឡិម ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១

*ព្រះអម្ចាស់ប្រទានការអះអាង និង សេចក្ដីណែនាំដល់ យ៉ូសែប ស្ម៊ីធ និង ថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រ*

១. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមធ្វើបញ្ជីនៃបញ្ហាមួយចំនួន ដែលនាំឲ្យមានភាពតានតឹង ឬ កង្វល់នៅក្នុងជីវិតរបស់អ្នក ។

សូមគិតអំពីស្ថានភាពតានតឹនដែលព្យាការី យ៉ូសែប ស្ម៊ីធ និង ថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្របានជួបប្រទះ នៅពេលអ្នកអានព័ត៌មានខាងក្រោមនេះ ៖

នារដូវក្ដៅឆ្នាំ ១៨៣៦ ព្យាការី យ៉ូសែប ស្ម៊ីធ និង ថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រ បានព្រួយបារម្ភអំពីបញ្ហាហិរញ្ញវត្ថុរបស់សាសនាចក្រ ។ នៅឆ្នាំមុននេះ សាសនាចក្របានជាប់ជំពាក់បំណុលដ៏ធំ ដោយសារតែថ្នាក់ដឹកនាំសាសនាចក្របានគោរពប្រតិបត្តិតាមការត្រាស់បង្គាប់របស់ព្រះអម្ចាស់ ឲ្យកសាងព្រះវិហារបរិសុទ្ធទីក្រុង ខឺតឡង់ ដោយបានទិញដីនៅរដ្ឋ អូហៃអូ និង មិសសួរី ថែមទាំងផ្ដល់ជំនួយដល់កងទ័ពជំរំស៊ីយ៉ូនទៀត ។ សាសនាចក្រក៏បានត្រូវការប្រាក់ដើម្បីទិញដីឲ្យពួកបរិសុទ្ធនៅរដ្ឋ មិសសួរី ដែលត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះសម្បែងរបស់ខ្លួននោះដែរ ។ ក្នុងឆ្នាំ ១៨៣៤ ព្រះអម្ចាស់បានណែនាំ យ៉ូសែប ស្ម៊ីធ និង ថ្នាក់ដឹកនាំដទៃទៀតឲ្យ « បង់បំណុល [ របស់ពួកគេ ] ឲ្យអស់ » ( គ. និង ស. ១០៤:៧៨ ) ។ ទោះជាយ៉ាងណាក៏ដោយ កិច្ចខិតខំរបស់ពួកលោកក្នុងការសងបំណុលទាំងនេះត្រូវបានបង្អាក់ ដោយសារការបាត់បង់អាជីវកម្មដែលផ្ដល់ប្រាក់ចំណូលនៅរដ្ឋ មិសសួរី ។ ដូច្នេះ ថ្នាក់ដឹកនាំសាសនាចក្រពុំមានប្រាក់គ្រប់គ្រាន់ ដើម្បីបង្គ្រប់តាមការទាមទាររបស់ម្ចាស់បំណុលឡើយ ។

បើសិនជាអ្នកធ្វើជាថ្នាក់ដឹកនាំសាសនាចក្រនៅពេលនោះ ហេតុអ្វីបានជាស្ថានភាពនេះអាចជាការព្រួយបារម្ភចំពោះអ្នក ?

ព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ថ្នាក់ដឹកនាំសាសនាចក្រថា ទ្រង់នឹង « បញ្ជូនផ្លូវនានាដល់ [ ពួកលោក ] សម្រាប់ការរំដោះ [ របស់ពួកលោក ] » ( គ. និង ស. ១០៤:៨០ ) ចេញពីបញ្ហាបំណុលរបស់សាសនាចក្រ ។ ក្នុងឆ្នាំ ១៨៣៦ សមាជិកសាសនាចក្រម្នាក់ឈ្មោះ វិល្លាម បើហ្គែស បានធ្វើដំណើរមកដល់ទីក្រុង ខឺតឡង់ ហើយបានជម្រាបថ្នាក់ដឹកនាំសាសនាចក្រអំពីចំនួនទឹកប្រាក់ដ៏ច្រើនដែលមាននៅក្រុង សាឡិម រដ្ឋ ម៉ាស្សាឈូសេត ។ គាត់បានពោលថា ប្រាក់នោះស្ថិតនៅក្នុងបន្ទប់ក្រោមដីនៃផ្ទះមួយ ហើយគាត់គឺជាបុគ្គលតែម្នាក់គត់ ដែលបានដឹងអំពីទីតាំងនៃប្រាក់នោះ ។

បើសិនជាអ្នកធ្វើជាថ្នាក់ដឹកនាំសាសនាចក្រនៅពេលនោះ តើអ្នកនឹងឆ្លើយតបចំពោះដំណឹងនេះយ៉ាងដូចម្ដេច ?

យ៉ូសែប ស្ម៊ីធ, ស៊ីឌនី រិកដុន, ហៃរុម ស្ម៊ីធ និង អូលីវើរ ខៅឌើរី បានធ្វើដំណើរចេញពីទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៨៣៦ ដើម្បីទៅជួបនឹងម្ចាស់បំណុលរបស់សាសនាចក្រនៅរដ្ឋ ញូវ យ៉ោក ។ បន្ទាប់ពីបានស្នាក់នៅនៅរដ្ឋ ញូវ យ៉ោក ប៉ុន្មានថ្ងៃក្រោយមក ក្រុមរបស់លោកបានធ្វើដំណើរទៅកាន់ក្រុង សាឡិម រដ្ឋ ម៉ាស្សាឈូសេត ។ វិល្លាម បើហ្គែស បានជួបពួកលោកនៅក្រុង សាឡិម ប៉ុន្តែលោកបានវាចាថា ក្រុងនេះឥឡូវបានកែប្រែមុខមាត់ច្រើនណាស់ពីកាលដែលគាត់បានរស់នៅទីនោះ ដូច្នេះគាត់ពុំអាចរកផ្ទះដែលមានប្រាក់នោះឃើញទេ ។ ក្រោយមក បងប្រុស បើហ្គែស បានចាកចេញពីក្រុង សាឡិម ទៅ ។




តើអ្នកគិតថា អ្នកអាចនឹងមានអារម្មណ៍ដូចម្ដេច បន្ទាប់ពីបានធ្វើដំណើរទៅកាន់ក្រុង សាឡិម ដោយសង្ឃឹមថានឹងរកឃើញមធ្យោបាយដើម្បីជួយសងបំណុលរបស់សាសនាចក្រ ហើយពុំអាចរកបានដូចអ្វីដែលអ្នកបានរំពឹងទុកនោះ ? តើអ្នកអាចនឹងធ្វើអ្វីខ្លះ ?

ថ្នាក់ដឹកនាំសាសនាចក្របានចំណាយពេលខ្លះ ដើម្បីស្វែងរកផ្ទះដែលត្រូវបានប្រាប់ថាមានប្រាក់នោះ ។ នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៨៣៦ កាលពួកលោកកំពុងនៅក្រុង សាឡិម នៅឡើយនោះ ព្យាការី យ៉ូសែប ស៊្មីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១:១ ដោយស្វែងរកថាតើព្រះអម្ចាស់ បានមានព្រះទ័យយ៉ាងដូចម្ដេចអំពីការធ្វើដំណើរទៅកាន់ក្រុង សាឡិម នេះ ។ ពាក្យ *ភាពចម្កួត* អាចមានន័យថា « ទង្វើឆោតល្ងង់ ឬ លីលា ប៉ុន្ដែមិនមែនជាបទល្មើសធ្ងន់ធ្ងរនោះទេ គឺជាទង្វើមួយដែលមិនសមហេតុផល ឬ មិនមានការប្រុងប្រយ័ត្ន » ( *Noah Webster's First Edition of an American Dictionary of the English Language ១៨២៨* [ ឆ្នាំ ១៩៦៧ ] « folly » ) ។ ជួនកាលនៅពេលមនុស្សប្រព្រឹត្តអំពើចម្កួត ពួកគេមានចេតនាព្យាយាមធ្វើកិច្ចការល្អ ទោះជាសកម្មភាពរបស់ពួកគេពុំឆ្លាតវៃយ៉ាងណាក្ដី ។

ទោះជាការស្វែងរកប្រាក់នៅក្រុង សាឡិម បានបរាជ័យយ៉ាងណាក្ដី ក៏ព្រះអម្ចាស់បានបង្ហាញថា ការធ្វើដំណើរនេះអាចនៅតែជារឿងល្អសម្រាប់នគរទ្រង់ដែរ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១:២ រួចស្វែងរកអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលថា ទ្រង់មាននៅក្រុង សាឡិម ។

សូមកត់ចំណាំនៅក្នុង ខទី ២ ថាព្រះអម្ចាស់បានមានព្រះបន្ទូលថា ទ្រង់នឹងប្រមូលរាស្ដ្រដែលទ្រង់មាននៅក្រុង សាឡិម នៅពេលដែលបានកំណត់ ។ យ៉ូសែប ស៊្មីធ ព្រមទាំងអ្នកដែលបានធ្វើដំណើរទៅជាមួយលោក បានចំណាយពេលពីរបីសប្ដាហ៍នៅក្រុង សាឡិម ហើយពួកលោកបានប្រកាសដំណឹងល្អកាលកំពុងស្នាក់នៅទីនោះ ។ ប្រាំឆ្នាំក្រោយមក អ៊ីរ៉ាស្ទុស ស្នូវ ត្រូវបានហៅឲ្យបម្រើបេសកកម្មនៅក្រុង សាឡិម ហើយបានបង្កើតសាខាមួយដែលមានសមាជិក ១២០ នាក់ ( សូមមើល *Church History in the Fulness of Times Student Manual* ការបោះពុម្ពលើកទី ២ [ Church Educational System manual, ២០០៣ ] ទំព័រ ១៧០–៧១) ។

សេចក្ដីពិតដែលយើងអាចរៀនពី បទពិសោធន៍របស់ យ៉ូសែប ស៊្មីធ នៅក្រុង សាឡិម និង ការបង្រៀនរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១:១–២ គឺ **ព្រះអម្ចាស់អាចនាំឲ្យមានសេចក្ដីល្អ កើតចេញពីការខិតខំដ៏ស្មោះអស់ពីចិត្តរបស់យើងបាន ។**

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើព្រះអម្ចាស់អាចនាំឲ្យមានសេចក្ដីល្អ កើតចេញពីការខិតខំដ៏ស្មោះអស់ពីចិត្តរបស់យើងបានតាមរបៀបណា ទោះបីជាការខិតខំទាំងនោះពុំមែនជាការឆ្លាតវៃយ៉ាងណាក៏ដោយនោះ ?

ខ. តើការណ៍នេះមានអានុភាពចំពោះអ្នកយ៉ាងដូចម្ដេច ក្នុងការដឹងថាព្រះអម្ចាស់អាចនាំឲ្យមានសេចក្ដីល្អ កើតចេញពីការខិតខំដ៏ស្មោះអស់ពីចិត្តរបស់អ្នកនោះ ?

ព្រះអម្ចាស់បានប្រទានសេចក្ដីណែនាំទៅដល់ យ៉ូសែប ស្ម៊ីធ និង ដៃគូរបស់លោក ដើម្បីជួយពួកលោកឲ្យសម្រេចបានសេចក្ដីល្អ កាលពួកលោកស្នាក់នៅក្រុង សាឡិម រដ្ឋ ម៉ាស្សាឈូសេត ។ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១:៣–៨ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់ បានមានព្រះទ័យឲ្យពួកលោកធ្វើ ។ ( នៅក្នុង ខទី ៤ឃ្លា « ពួកគេនឹងមិនរកឃើញផ្នែកសម្ងាត់ទាំងឡាយរបស់អ្នក » មានន័យថា ប្រជាជនរស់នៅក្រុង សាឡិម នឹងមិនផ្ដល់ភាពអាម៉ាស់ដល់ថ្នាក់ដឹកនាំសាសនាចក្រឡើយ ) ។

ព្រះអម្ចាស់បានបង្រៀន យ៉ូសែប ស្ម៊ីធ និង ថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រនៅក្រុង សាឡិម អំពីរបៀបដែលពួកលោកស្វែងរកកន្លែងស្នាក់នៅនៅទីក្រុងនោះ ។ សូមប្រើព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុង ខទី ៨ ដើម្បីបញ្ចប់សេចក្ដីពិតនៃគោលលទ្ធិដូចតទៅ ៖ **យើងអាចទទួលបានការដឹកនាំពីព្រះអម្ចាស់ដោយ និង នៃព្រះវិញ្ញាណរបស់ទ្រង់ ។**

៣. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ថាតើការចងចាំអំពីគោលលទ្ធិនេះ អាចជួយអ្នកប្រឈមមុខនឹងការព្រួយបារម្ភ និង ឧបសគ្គនានាដែលអ្នកជួបប្រទះក្នុងជីវិតយ៉ាងដូចម្ដេច ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១:៩–១០ ដោយស្វែងរកកិច្ចការបន្ថែម ដែលព្រះអម្ចាស់បានប្រទានដល់ យ៉ូសែប ស្ម៊ីធ និង ដៃគូរបស់លោក ឲ្យធ្វើកាលកំពុងស្នាក់នៅនៅក្រុង សាឡិម ។

ព្យាការី យ៉ូសែប ស្ម៊ីធ និង បុរសដទៃទៀតបានធ្វើតាមឱវាទរបស់ព្រះអម្ចាស់ថាត្រូវ « ខំសាកសួរពីបណ្ដាជនពីបូរាណកាល និង ពួកអ្នកដែលរកឃើញទីក្រុងនេះ » ( គ.និង ស. ១១១:៩ ) ។ ពួកលោកបានទៅទស្សនាទីតាំងប្រវត្តិសាស្ត្រនានា កាលកំពុងស្នាក់នៅនៅក្រុង សាឡិម ។ ពួកលោកបានស្វែងយល់ចេញពីទស្សនកិច្ចនោះថា ពួកម្ចាស់ស្រុកក្រុងសាឡិម រដ្ឋម៉ាស្សាឈូសេត និង តំបន់ជុំវិញ នូវ អឹងឡេន ធ្លាប់បានគេបៀតបៀន ហើយសម្លាប់ចោល ដែលជាលទ្ធផលនៃការមិនចុះសម្រុង និង ការប្រកាន់សាសនា ។ ( សូមមើល *History of the Church* ២:៤៦៤–៦៥ ) ។ ព្រឹត្តិការណ៍នេះបាននាំឲ្យ យ៉ូសែប ស្ម៊ីធ សរសេរទុកនៅក្នុងប្រវត្តិរបស់លោកថា « តើដល់ពេលណាទៅ ទើបមនុស្សនឹងឈប់ធ្វើសង្គ្រាមជាមួយមនុស្ស ហើយរឹបអូស [ ដកយក ] សិទ្ធិដ៏ពិសិដ្ឋចេញពីលោក ក្នុងការថ្វាយបង្គំព្រះទៅតាមក្រឹត្យក្រមនៃសតិសម្បជញ្ញៈយ៉ាងនេះនោះ ? » ( នៅក្នុង *History of the Church* ២:៤៦៥ ) ។



ព័ត៌មានចេញពីប្រវត្តិរបស់ យ៉ូសែប ស្ម៊ីធ

ក្រោយមក ព្យាការីបានថ្លែងថា នេះគឺជាជំនឿគ្រឹះមួយរបស់សាសនាចក្រ ដែលអនុញ្ញាតឲ្យមនុស្សទាំងអស់ មានសិទ្ធិសេរីភាពខាងសាសនា ( សូមមើល មាត្រានៃសេចក្ដីជំនឿ ១:១១ ) ។

ទោះជា យ៉ូសែប ស្ម៊ីធ និង ដៃគូរបស់លោក ពុំទទួលបានប្រាក់ដែលពួកលោកបានរំពឹងថានឹងរកឃើញនៅក្រុង សាឡិម យ៉ាងណាក្ដី ក៏ពួកលោកទទួលបានរតនសម្បត្តិជាច្រើនទៀតមកពីការធ្វើដំណើរនេះដែរ ។ ការណ៍នេះរួមបញ្ចូលទាំងរតនសម្បត្តិនៃចំណេះដឹង និង នៃប្រជាជនដែលរស់នៅតំបន់នោះ ដែលក្រោយមកបានទទួលពិធីបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់ជាសមាជិកនៃសាសនាចក្រ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១:១១ ដោយស្វែងរកឱវាទចុងក្រោយ របស់ព្រះអម្ចាស់នៅក្នុងវិវរណៈនេះ ។ ( ពាក្យ *រៀបចំ* ដែលប្រើនៅក្នុង ខទី ១១ មានន័យថា ចាត់ចែង ) ។

សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ដោយផ្អែកទៅលើអ្វីដែលអ្នកស្វែងយល់ចេញពី ខទី ១១ ៖ **បើយើង តែ នោះព្រះអម្ចាស់នឹងរៀបចំគ្រប់អ្វីៗទាំងអស់ ។**

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើមានវិធីមួយចំនួនណាខ្លះ ដែលអ្នកអាចមានភាពឆ្លាតវៃនៅក្នុងជម្រើសរបស់អ្នកបាន ?

ខ. តើអ្នកគិតថា ព្រះអម្ចាស់ « នឹងរៀបចំគ្រប់អ្វីៗទាំងអស់ សម្រាប់សេចក្ដីល្អដល់អ្នក » ( គ. និង ស. ១១១:១១ ) មានន័យដូចម្ដេច ?

គ. តើអ្នកធ្លាប់បានឃើញ គំរូនៃគោលការណ៍នេះនៅពេលណា ?

៥. សូមមើលទៅលំហាត់ទី ១ ក្នុងមេរៀនថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក—ជាបញ្ជីនៃបញ្ហាដែលនាំឲ្យមានភាពតានតឹង និង កង្វល់នៅក្នុងជីវិតរបស់អ្នក ។ សូមសរសេរប្រយោគមួយ ឬ ពីរដែលពន្យល់អំពីអ្វីដែលអ្នកបានរៀនចេញពីការសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១ ដែលអាចជួយអ្នកប្រឈមមុខនឹងឧបសគ្គនានា ដែលអ្នកជួបប្រទះ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១១ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៤ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២

## សេចក្ដីផ្ដើម

នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៨៣៧ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២ ជំនួសឲ្យ ថូម៉ាស ប៊ី ម៉ាស ដែលជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ នៅក្នុងវិវរណៈនេះ ថូម៉ាស ប៊ី ម៉ាស ទទួលបានឱវាទអំពីការទទួលខុសត្រូវនៃខ្លួនគាត់ផ្ទាល់ និង នៃសមាជិកក្នុងកូរ៉ុមនៃពួកដប់ពីរនាក់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:១–១៣

*ព្រះអម្ចាស់ប្រទានឱវាទផ្ទាល់ខ្លួន ថែមទាំងសន្យាថានឹងប្រទានពរដល់ ថូម៉ាស ប៊ី ម៉ាស*

សូមគិតអំពីគ្រាដែលអ្នកធ្លាប់បានមានអារម្មណ៍ថា ខឹងសម្បា បាក់ទឹកចិត្ត ទាស់ចិត្ត ឬ ច្រណែននិន្ទា ដែលមកពីការប្រាស្រ័យជាមួយនឹងអ្នកផ្សេងទៀត ។ សាវកនៅជំនាន់ដំបូង ថូម៉ាស ប៊ី ម៉ាស បានជួបប្រទះនឹងស្ថានភាព ដែលប្រហែលជានាំគាត់ឲ្យធ្លាក់ខ្លួនមានអារម្មណ៍ស្រដៀងគ្នានេះ ។

នៅមិនយូរប៉ុន្មានបន្ទាប់ពីលោកត្រូវបានហៅឲ្យបម្រើជាសាវកក្នុងឆ្នាំ ១៨៣៥ នោះ ថូម៉ាស ប៊ី ម៉ាស្ស ត្រូវបានតែងតាំងជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ នារដូវក្ដៅរីកក្នុងឆ្នាំ ១៨៣៧ ប្រធាន ម៉ាស្ស បានដឹងថា សមាជិកម្នាក់នៃពួកសាវកដប់ពីរនាក់ គឺអែលឌើរ ប៉ាលី ភី ប្រាត្ត បានគ្រោងចេញបេសកកម្មទៅប្រទេសអង់គ្លេសដោយគ្មានការដឹកនាំពីប្រធាន ម៉ាស្ស ។ ប្រធាន ម៉ាស្ស ដែលបាននៅរដ្ឋ មីសសួរី បានសរសេរសំបុត្រទៅអែលឌើរ ប៉ាលី ភី ប្រាត្ត និង សមាជិកដទៃទៀតនៃពួកដប់ពីរនាក់ ហើយបានអញ្ជើញពួកលោកឲ្យមកជួបនឹងខ្លួននៅឯទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៨៣៧ ដើម្បីឲ្យពួកលោកអាចរួបរួមគ្នានៅក្នុងគម្រោងសម្រាប់បេសកកម្មនានា ។ ទោះជាយ៉ាងណាក្ដី ក៏មួយខែមុនពេលការប្រជុំបានប្រព្រឹត្តឡើង មានសមាជិកពីររូបនៃពួកដប់ពីរនាក់ គឺ ហ៊ីប៊ើរ ស៊ី ឃិមប៊ល និង អូរសុន ហៃឌ បានចេញទៅប្រទេសអង់គ្លេសបន្ទាប់ពីបានទទួលការហៅបម្រើបេសកកម្មពីព្យាការី យ៉ូសែប ស្ម៊ីធ ។ ពិតប្រាកដណាស់ ប្រធាន ម៉ាស្ស បានអន់ចិត្ត ដែលសមាជិកនៃពួកដប់ពីរនាក់បានបន្ដទៅផ្សព្វផ្សាយដំណឹងល្អនៅឯប្រទេសអង់គ្លេសដោយពុំមានការរួបរួមនៃកូរ៉ុម និង ពុំមានការយល់ព្រមពីលោក ។

នៅក្នុងស្ថានភាពនេះ តើប្រធាន ម៉ាស្ស អាចធ្វើអ្វីដើម្បីចៀសវាងពីអារម្មណ៍ខឹងសម្បា បាក់ទឹកចិត្ត ទាស់ចិត្ត ឬ ច្រណែននិន្ទា ? តើអ្វីខ្លះជាគ្រោះថ្នាក់នៃការអនុញ្ញាតឲ្យអារម្មណ៍បែបនេះគ្រប់គ្រងចិត្តគំនិត និង សកម្មភាពរបស់អ្នកនោះ ?

ព្រិកហាំ យ៉ង់ ដែលជាសមាជិកម្នាក់ក្នុងកូរ៉ុមនៃពួកដប់ពីរនាក់នៅគ្រានោះ បាននិយាយជាមួយប្រធាន ម៉ាស្ស ឲ្យទៅជួបប្រធាន យ៉ូសែប ស្ម៊ីធ ។ ដើម្បីឆ្លើយតបទៅនឹងកង្វល់របស់ប្រធាន ម៉ាស្ស ព្រះអម្ចាស់បានប្រទានវិវរណៈទៅកាន់ព្យាការី យ៉ូសែប ស្ម៊ីធ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:១–៣ ដោយស្វែងរកការព្រមានដែលព្រះអម្ចាស់បានប្រទានដល់ ថូម៉ាស ប៊ី ម៉ាស្ស ។ នៅពេលអ្នកអាន វាអាចនឹងផ្ដល់អត្ថប្រយោជន៍ក្នុងការដឹងថាពាក្យ *បន្ទាបខ្លួន* នៅក្នុង ខទី ៣ មានន័យថា ប្រធាន ម៉ាស្ស បានបន្ទាបខ្លួនរបស់លោក ។ តើការព្រមានអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានទៅដល់លោក ? តើមានរឿងល្អៗណាខ្លះដែលព្រះអម្ចាស់មានព្រះបន្ទូលថា ថូម៉ាស បានធ្វើ ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:៤–១០ ព្រះអម្ចាស់បានប្រទានឱវាទបន្ថែមទៅកាន់ ថូម៉ាស ប៊ី ម៉ាស្ស ហើយបានអះអាងដល់គាត់ថា គាត់អាចសម្រេចបានកិច្ចការអស្ចារ្យៗ ដោយមានជំនួយពីព្រះអម្ចាស់ ។

១. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:៤–១០ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមរាយបញ្ជីការសន្យាដែលព្រះអម្ចាស់បានធ្វើជាមួយ ថូម៉ាស ប៊ី ម៉ាស្ស ។ ( នៅក្នុង ខទី ៥ ពាក្យ *ខំប្រយុទ្ធ* ពុំមានន័យថា ខឹងសម្បា ឬ ជំទាស់នោះទេ ប៉ុន្តែ វាមានន័យថា ធ្វើការផ្សាយដំណឹងល្អដោយមានចិត្តឧស្សាហ៍ព្យាយាម ) ។

### *ការដាក់ជំនួសឈ្មោះ*

នៅពេលអ្នកអាន សូមសាកល្បងដាក់បញ្ចូលឈ្មោះរបស់អ្នកជំនួសឈ្មោះដែលមាននៅក្នុងបទគម្ពីរ ។ ការអនុវត្តន៍បែបនេះ អាចជួយអ្នកឲ្យមចំណែកនៅក្នុងការសិក្សាព្រះគម្ពីរប្រកបដោយអត្ថន័យ ហើយមើលឃើញថាតើវគ្គបទគម្ពីរជាក់លាក់នានា អាចទាក់ទងទៅនឹងអ្នកយ៉ាងដូចម្ដេច ។ នៅពេលអ្នកអានវគ្គបទគម្ពីរច្រើន អ្នកអាចអនុវត្តតាម សេចក្ដីថ្លែងការណ៍របស់ព្រះអម្ចាស់ដែលថា « អ្វីៗដែលយើងប្រាប់ដល់មនុស្សម្នាក់យ៉ាងណា នោះយើងប្រាប់ដល់មនុស្សទាំងអស់យ៉ាងនោះដែរ » ( គ. និង ស. ៩៣:៤៩ ) ។ ចូរសាកល្បងប្រើរបៀបសិក្សានេះជាមួយ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:១–១១ ។

សូមបំពេញសេចក្ដីថ្លែងការណ៍ « បើសិនជា–នោះ » ដូចតទៅនេះ ដោយផ្អែកទៅលើអ្វីដែលអ្នកស្វែងយល់ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:១០ ៖ **បើសិនជាយើង នោះព្រះអម្ចាស់នឹង** ។ ( អ្នកអាចនឹងចង់គូសចំណាំគោលការណ៍នេះ នៅក្នុងព្រះគម្ពីររបស់អ្នក ) ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ហេតុអ្វីបានជាការបន្ទាបខ្លួនជួយយើងឲ្យទទួលបានការដឹកនាំពីព្រះអម្ចាស់ ?

ខ. តើនៅពេលណាខ្លះ ដែលអ្នកធ្លាប់មានអារម្មណ៍ថា ត្រូវបានដឹកនាំដោយព្រះអម្ចាស់បន្ទាប់ពីបានបន្ទាបខ្លួន ?



នៅពេលព្រះអម្ចាស់បានប្រទានវិវរណៈនេះក្នុងខែ កក្កដា ឆ្នាំ ១៨៣៧ សាសនាចក្របានកំពុងតែជួបប្រទះនឹងការបែកបាក់សាមគ្គីភាព ការទាស់ទែងគ្នា និង ការក្បត់សាសនា ។ អំណួត និង សេចក្ដីលោភៈ បាននាំឲ្យសមាជិកមួយចំនួនក្នុងសាសនាចក្រ រិះគន់ព្យាការី យ៉ូសែប ស្ម៊ីធ ហើយបានសង្ស័យដល់សិទ្ធិអំណាចរបស់លោក ។ ឧបសគ្គទាំងនេះគឺជាលទ្ធផលមួយផ្នែកតូចមកពីវិបត្តិហិរញ្ញវត្ថុ ក្នុងចំណោមពួកបរិសុទ្ធនៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ។ ដោយសារតែមានវិបត្តិសេដ្ឋកិច្ចមួយដ៏សាកល ដែលក្រោយមកបានគេហៅថា ភាពស្លន់ស្លោនៃឆ្នាំ ១៨៣៧ នោះមានធនាគារជាច្រើនពាសពេញសហរដ្ឋបានក្ស័យធន ។ សមាគមសង្គមសុវត្ថិភាពទីក្រុង ខឺតឡង់ ដែលជាស្ថាប័នហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដោយថ្នាក់ដឹកនាំសាសនាចក្រ ក៏បានក្ស័យធនផងដែរនារដូវក្នុងឆ្នាំ ១៨៣៧ ។ អ្នកវិនិយោគពីរយនាក់បានខាតបង់អ្វីៗស្ទើរតែទាំងអស់ ដោយមាន យ៉ូសែប ស្ម៊ីធ ជួយទ្រទ្រង់ការខាតបង់ភាគច្រើនបំផុត ។ ទោះបីជាសមាគមសង្គមសុវត្ថិភាពទីក្រុង ខឺតឡង់ មិនត្រូវបានឧបត្ថម្ភដោយសាសនាចក្រក្ដី ក៏ពួកបរិសុទ្ធខ្លះបានគិតថា វាជាធនាគាររបស់សាសនាចក្រ ឬ ធនាគាររបស់ព្យាការី ហើយបានបន្ទោសដល់ យ៉ូសែប ស្ម៊ីធ ចំពោះវិបត្តិហិរញ្ញវត្ថុរបស់ពួកគេ ។ មនុស្សខ្លះថែមទាំងចាប់ផ្ដើមហៅលោកថាជាព្យាការីបរាជ័យ ។ ប៉ុន្តែ មានមនុស្សខ្លះទៀតបានបន្តសេចក្ដីជំនឿ ហើយនៅតែស្មោះត្រង់ចំពោះព្យាការី ទោះជាពួកគេត្រូវខាតបង់ប្រាក់កាសជាច្រើនដោយសារតែការដួលរលំរបស់សមាគមសង្គមសុវត្ថិភាពទីក្រុង ខឺតឡង់ យ៉ាងណាក្ដី ។ ( សូមមើល *Church History in the Fulness of Times Student Manual*, បោះពុម្ពទី ២ [Church Educational System manual, ឆ្នាំ ២០០៣], ទំព័រ ១៧១–៧៣) ។

សមាជិកមួយចំនួននៃសាសនាចក្រ រួមបញ្ចូលទាំងសមាជិកខ្លះក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ថែមទាំងព្យាយាមដោះលែង យ៉ូសែប ស្ម៊ីធ ចេញពីតំណែងជាប្រធាននៃសាសនាចក្រទៀតផង ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:១១–១៣ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បានណែនាំឲ្យ ថូម៉ាស ប៊ី ម៉ាស្ស ធ្វើដើម្បីជួយសមាជិកដទៃទៀតក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដែលកំពុងតែមានបញ្ហាបម្រុះនោះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:១៤–៣៤

*ព្រះអម្ចាស់បង្រៀន ថូម៉ាស ប៊ី ម៉ាស្ស អំពីករណីយកិច្ចនៃពួកសាវកដប់ពីរនាក់*

ប្រធាន ម៉ាស្ស កាន់តំណែងដ៏សំខាន់មួយ ហើយមានការទទួលខុសត្រូវជាច្រើនដែលបានប្រទានពីព្រះអម្ចាស់ ។

៣. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្វីដែលអាចជួយអ្នកឲ្យបន្ទាបខ្លួន នៅពេលអ្នកទទួលបានការទទួលស្គាល់ ឬ ការទទួលខុសត្រូវដ៏សំខាន់ៗ ?

កាលទ្រង់បន្តរំឭកគាត់ឲ្យបន្ទាបខ្លួន នោះអម្ចាស់បានជួយ ថូម៉ាស ប៊ី ម៉ាស្ស ឲ្យទទួលស្គាល់សារៈសំខាន់នៃការទទួលខុសត្រូវរបស់គាត់ ក្នុងនាមជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមបំពេញតារាងខាងក្រោមនេះ នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:១៤–២២, ២៨–៣៣ ។

| | គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:១៤–២២, ២៨–៣៣ |
|---|---|
| ឃ្លាទាំងឡាយគូសសម្គាល់អំពីសារៈសំខាន់នៃការទទួលខុសត្រូវរបស់ប្រធាន ម៉ាស្ស ៖ | |
| ឃ្លាទាំងឡាយដែលរំឭក ថូម៉ាស ម៉ាស្ស អំពីតម្រូវការឲ្យគាត់បន្ទាបខ្លួន ៖ | |

៤. សូមបំពេញកិច្ចការខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. យោងតាម ខទី ១៦–១៧តើកូនសោអ្វីខ្លះ ដែលត្រូវបានកាន់ដោយប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ? សូមគូសចំណាំនៅក្នុងព្រះគម្ពីររបស់អ្នកអំពីគោលលទ្ធិដែលអ្នកបានរៀន រួចសរសេរវាដាក់ទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

ខ. សូមសរសេរគោលការណ៍ ដែលអ្នករៀននៅក្នុង ខទី ៣០–៣២ អំពីកូនសោបព្វជិតភាព ដែលប្រធាន ម៉ាស្ស កាន់ ។

សូមគិតអំពីការគូសចំណាំ គោលលទ្ធិដូចតទៅនេះដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:៣០–៣២ ៖ **កូនសោបព្វជិតភាពត្រូវបានស្ដារឡើងវិញ ចុងក្រោយបង្អស់នៅក្នុងគ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ ។**

គ្រាកាន់កាប់ត្រួតត្រា គឺជាអំឡុងពេលដែលព្រះអម្ចាស់ត្រាស់សម្ដែងគោលលទ្ធិ ពិធីបរិសុទ្ធនានា និង បព្វជិតភាពរបស់ទ្រង់ ។ វាគឺជាអំឡុងពេលមួយ ដែលយ៉ាងហោចណាស់ ព្រះអម្ចាស់មានអ្នកបម្រើម្នាក់ដែលមានសិទ្ធិអំណាចនៅលើផែនដី ដែលកាន់បព្វជិតភាពដ៏បរិសុទ្ធ និង ជាអ្នកដែលមាននូវការអនុញ្ញាតពីព្រះដើម្បីចែកចាយដំណឹងល្អ និង ដើម្បីចាត់ចែងពិធីបរិសុទ្ធដែលមានក្នុងដំណឹងល្អនោះ ។ ( សូមមើល Bible Dictionary, « Dispensations » ) ។

សូមពិចារណាសំណួរដូចតទៅនេះ ៖ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:១៥, ៣០ តើព្រះអម្ចាស់មានព្រះបន្ទូលយ៉ាងដូចម្ដេច អំពីទំនាក់ទំនងរវាងការទទួលខុសត្រូវរបស់ ថូម៉ាស ម៉ាស្ស ក្នុងនាមជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ និងការទទួលខុសត្រូវរបស់ព្យាការី យ៉ូសែប ស៊្មីធ ?

ថូម៉ាស ប៊ី ម៉ាស្ស បានមានការលំបាកក្នុងការធ្វើតាមឱវាទ ដែលគាត់ទទួលបាននៅក្នុងវិវរណៈនេះ ។

នៅមិនយូរប៉ុន្មានបន្ទាប់ពីវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២ ត្រូវបានប្រទានឲ្យ នោះ ថូម៉ាស ប៊ី ម៉ាស្ស បានប្រាប់ដល់ វីឡាធី ឃីមបឹល ( ភរិយារបស់ ហ៊ីប៊ើរ ស៊ី ឃិមបឹល ) ថា ហ៊ីប៊ើរ នឹងពុំមានជោគជ័យនៅក្នុងបេសកកម្មរបស់គាត់ឡើយ ។ ប្រាកដណាស់ ប្រធាន ម៉ាស្ស បានមានអារម្មណ៍ថា ដោយសារតែការប្រកាសដំណឹងល្អនៅក្រៅប្រទេសគឺជាការទទួលខុសត្រូវរបស់លោក នោះចំណាប់ផ្ដើមនៃកិច្ចការផ្សព្វផ្សាយសាសនានៅប្រទេស អង់គ្លេស នឹងពុំកើតមានឡើយ ដរាបទាល់តែគាត់បញ្ជូននរណាម្នាក់ ឬ ទៅដោយខ្លួនគាត់ផ្ទាល់ ។

សូមគិតថាតើហេតុការណ៍នេះបង្ហាញយ៉ាងដូចម្ដេច ថាប្រធាន ម៉ាស្ស អាចនឹងមានការលំបាកក្នុងការបន្ទាបខ្លួន ។

ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ ក្នុងគណៈប្រធានទីមួយ បានពន្យល់អំពីរបៀបដែលយើងអាចបន្ទាបខ្លួនកាន់តែច្រើន និងចៀសវាងពីភាពឆ្មើងឆ្មៃ ៖



« ការបន្ទាបខ្លួនពុំមានន័យដល់ការប្រាប់ខ្លួងឯងថាយើងពុំមានតម្លៃ ឥតបានការ ឬ មិនសូវសំខាន់នោះទេ ។ វាក៏ពុំមានន័យដល់ការមិនទទួលយក ឬ ដកហូតទេពកោសល្យនានាដែលព្រះបានប្រទានឲ្យយើងនោះដែរ ។ យើងពុំអាចរកឃើញការបន្ទាបខ្លួននៅក្នុងការរំពឹងដោយបន្ទាបបន្ថោក *អំពី* ខ្លួនយើងនោះទេ ប៉ុន្តែ យើង រំពឹងដោយមិនគិត *អំពី* ខ្លួនឯង ។ វាកើតឡើងនៅពេលយើងធ្វើការរបស់យើងដោយមានផ្នត់គំនិតនៃការបម្រើព្រះ និង មនុស្សនៅជុំវិញខ្លួន ។

« ការបន្ទាបខ្លួនដឹកនាំស្មារតី និង សេចក្ដីស្រឡាញ់របស់យើងទៅកាន់មនុស្សដទៃ និង គោលបំណងរបស់ព្រះវរបិតាសួគ៌ ។ ភាពឆ្មើងឆ្មៃប្រព្រឹត្តទៅផ្ទុយពីនេះ ។ ភាពឆ្មើងឆ្មៃទាញយកថាមពល និង កម្លាំងរបស់វាចេញពីជម្រៅដ៏ជ្រៅនៃអត្តទត្ថភាព ។ « . . . នៅពេលដែលយើងឈប់ឈ្លក់វង្វេងនឹងខ្លួនយើង ហើយភ្លេចខ្លួនយើងក្នុងការបម្រើ នោះភាពអំណួតរបស់យើងនឹងថយចុះ ហើយចាប់ផ្ដើមបាត់បង់ទៅ » ( Pride and the Priesthood » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ៥៨ ) ។

៥. សូមពន្យល់ទៅកាន់សមាជិកគ្រួសារ ឬ មិត្តភក្ដិម្នាក់ អំពីអ្វីដែលអ្នកបានរៀនអំពីការបន្ទាបខ្លួន ។ សូមសរសេរឈ្មោះរបស់បុគ្គលនោះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:៣៤ ដោយស្វែងរកអ្វីដែល ថូម៉ាស ម៉ាស្ស ត្រូវធ្វើដើម្បីទទួលបានពរជ័យទាំងនេះ ។

សូមបញ្ចប់គោលការណ៍ដូចតទៅនេះ ៖ **យើងត្រូវតែ ដើម្បីទទួលបានពរជ័យដែលព្រះអម្ចាស់បានសន្យា ។**

ដំណើររឿងដូចតទៅនេះ សង្ខេបអំពីការធ្លាក់នៅទីបំផុតរបស់ ថូម៉ាស ប៊ី ម៉ាស្ស ចេញពីសាសនាចក្រ ហើយក៏បានត្រឡប់មកកាន់សាសនាចក្រវិញ ៖

គ្រាមួយ ប្រធាន ម៉ាស្ស បានធ្វើតាមឱវាទដែលគាត់ទទួលបាន ។ គាត់បានខិតខំពង្រឹងសាសនាចក្រ ហើយគាំទ្រ យ៉ូសែប ស៊្មីធ ។ ទោះជាយ៉ាងណាក៏ដោយ នៅមិនយូរប៉ុន្មានគាត់បានត្រឡប់ជាមានអារម្មណ៍ជំទាស់នឹងរបៀបដែលសាសនាចក្រត្រូវបានដឹកនាំទៅវិញ ។ អារម្មណ៍ទាំងនេះបូកផ្សំជាមួយនឹងកង្វល់អំពីទំនាស់រវាងសមាជិកសាសនាចក្រដែលពុំគោរពប្រតិបត្តិ និង ឈ្លានពាន ព្រមទាំងអ្នកជិតខាងរបស់ខ្លួននៅរដ្ឋ មិសសួរី ។ ក្នុងខែ កញ្ញា ឆ្នាំ ១៨៣៨ កាលគាត់ត្រូវបានជុំជិតដោយគំនិតក្បត់សាសនា នោះភរិយារបស់គាត់ អេលីសាបែត បានពាក់ព័ន្ធនឹងជម្លោះមួយ ។ គាត់ និង ស្ត្រីម្នាក់ទៀត ទាំងពីរនាក់គឺជាសមាជិកសាសនាចក្រ បានព្រមព្រៀងគ្នាដោះដូរទឹកដោះគោជាប្រចាំ ដើម្បីមានទឹកដោះគោគ្រប់គ្រាន់ក្នុងការធ្វើឈីស ប៉ុន្តែបងស្រី ម៉ាស្ស បានប្ដឹងគាត់ថាល្មើសនឹងកិច្ចព្រមព្រៀង ដោយបានទុកចំណែកទឹកដោះគោដែលមានសារធាតុខ្លាញ់ទឹកដោះច្រើន ។ បញ្ហានេះត្រូវបាននាំទៅដល់ថ្នាក់ដឹកនាំសាសនាចក្រ ជាច្រើនដង ។ វាក៏ត្រូវបាននាំទៅដល់ គណៈប្រធានទីមួយផងដែរ ។ រាល់ពេលនាំទៅដល់ម្ដងៗ វាត្រូវបានសម្រេចថាបងស្រី ម៉ាស្ស គឺជាអ្នកខុស ។ ប្រធាន ម៉ាស្ស បានខឹង ហើយពុំពេញចិត្តនឹងការសម្រេចទាំងនេះទេ ( សូមមើល George A. Smith, "Discourse," *Deseret News* ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៨៥៦ ទំព័រ ៤៤ ) ។ ទោះជាស្ថានភាពនេះពុំបានបណ្ដាលឲ្យគាត់ចាកចេញពីសាសនាចក្រក្ដី ក៏ស្ថានភាពរបស់គាត់កាន់តែធ្ងន់ធ្ងរឡើងដោយការខកចិត្តមួយទៀតដែរ ។ គាត់បែរជារិះគន់ដល់ថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រ ហើយនៅទីបំផុតបានប្រឆាំងនឹងពួកបរិសុទ្ធ ។ ក្រោយមកគាត់បាននៅចាំថា « ខ្ញុំបានប្រណែននិន្ទានឹងព្យាការី . . . ហើយបានមើលរំលងចំណុចល្អគ្រប់យ៉ាង ថែមទាំងបានចំណាយពេលពេញមួយជីវិតដើម្បីស្វែងរកចំណុចអាក្រក់ » ( "Remarks," *Deseret News* ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៨៥៧ ទំព័រ ២២០ ) ។

ដប់ប្រាំបីឆ្នាំក្រោយមកបន្ទាប់ពីបានចាកចេញពីសាសនាចក្រ ថូម៉ាស ម៉ាស្ស បានសរសេរសំបុត្រមួយច្បាប់ដោយរាបសាទៅកាន់ ហ៊ីប៊ើរ ស៊ី ឃិមប៊ល ដោយបានសុំការអភ័យទោស និង ការអនុញ្ញាតឲ្យចូលសាសនាចក្រវិញ ។ គាត់បានរៀបរាប់អំពីអ្វីដែលគាត់បានរៀនពីកំហុសរបស់គាត់ ៖ « ព្រះអម្ចាស់អាចបន្តទៅមុខបានយ៉ាងល្អដោយគ្មានរូបខ្ញុំ ហើយទ្រង់ពុំបានខាតបង់អ្វីបន្តិចដោយសារតែការធ្លាក់របស់ខ្ញុំចេញពីសាសនាចក្រនោះទេ ប៉ុន្តែ មើលចុះខ្ញុំបានខាតបង់អ្វីខ្លះ ?! » ( Thomas B. Marsh letter to Heber C. Kimball ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ១៨៥៧ Brigham Young Collection, Church History Library មានដកស្រង់នៅក្នុង Kay Darowski «The Faith and Fall of Thomas Marsh» *Revelations in Context* ថ្ងៃទី ១៩ ខែ មីនា [ឆ្នាំ ២០១៣ | history.lds.org ) ។

៦. សូមសង្ខេបនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្វីដែលអ្នកបានរៀននៅថ្ងៃនេះ ។ សូមជ្រើសរើសរបៀបមួយ ដែលអ្នកអាចបន្ទាបខ្លួន និង មានចិត្តស្មោះត្រង់កាន់តែច្រើន រួចសរសេរគោលដៅមួយដើម្បីប្រព្រឹត្តតាម ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៥ ៖ ថ្ងៃទី ១

# សាសនាចក្រប្ដូរទៅរដ្ឋ មិសសួរីភាគខាងជើង

## បុព្វកថា

ក្នុងឆ្នាំ ១៨៣៧ និង ១៨៣៨ ព្យាការី យ៉ូសែប ស្ម៊ីធ និង ថ្នាក់ដឹកនាំសាសនាចក្រដទៃទៀតបានដឹកនាំសាសនាចក្រឆ្លងកាត់ពេលលំបាកយ៉ាងថ្លៃថ្នូរ ។ ជាលទ្ធផលនៃវិបត្តិសេដ្ឋកិច្ច សេចក្ដីលោភលន់ ការចាប់កំហុស និង ការបៀតបៀន នោះ ពួកបរិសុទ្ធប្រហែល ១០ ទៅ ១៥ ភាគរយនៅក្នុងទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ បានក្បត់សាសនា រួមមានទាំងថ្នាក់ដឹកនាំសាសនាចក្រដែលលេចធ្លោមួយចំនួនផងដែរ ។ ពួកបរិសុទ្ធស្មោះត្រង់នៅ រដ្ឋ អូហៃអូ បានចាប់ផ្ដើមប្ដូរទីលំនៅទៅចូលរួមពួកអ្នកនៅរដ្ឋ មិសសួរីភាគខាងជើង ។ ក្រុងហ្វារវែស្ទ រដ្ឋ មីសសូរី ក្លាយជាទីស្នាក់ការកណ្ដាលរបស់សាសនាចក្រ រហូតដល់ពួកបរិសុទ្ធបានបង្ខំឲ្យចាកចេញពីទីក្រុងនោះនៅដើមឆ្នាំ ១៨៣៩ ។ មេរៀននេះអាចជួយអ្នកឲ្យយល់ និងរៀនពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនានា ហើយផ្ដល់ការយល់ដឹងដល់អ្នកអំពី វិវរណៈដែលបានទទួលអំឡុងពេលនោះ ។

## ការលំបាក និងការក្បត់សាសនានៅក្នុងទីក្រុងខឺតឡង់ រដ្ឋអូហៃអូ

សូមគិតពីសំណួរដូចតទៅនេះ ៖ តើការលំបាក និងការសាកល្បងជួយពង្រឹងសេចក្ដីជំនឿអ្នក ឬសេចក្ដីជំនឿអ្នកចុះខ្សោយនៅពេលជួបប្រទះនឹងបញ្ហាទាំងនោះ ?

ក្នុងឆ្នាំ ១៨៣៧ និង ១៨៣៨ ជារយៈពេលមួយនៃការសាកល្បងដែលបាននាំឲ្យពួកបរិសុទ្ធជាច្រើនប្រឈមមុខនឹងសំណួរនេះ ។ ពេលដែលការសាកល្បងមួយចំនួនរបស់ពួកគេ គឺជាលទ្ធផលនៃការបៀតបៀនពីសាសនាចក្រខាងក្រៅ ការល្បងជាច្រើនទៀតគឺជាលទ្ធផលនៃការឈ្លោះប្រកែកនៅក្នុងសាសនាចក្រ ។ នៅពេលអ្នកសិក្សាមេរៀននេះ សូមសញ្ជឹងគិតអំពីរបៀបដែលប្រតិកម្មរបស់យើងចំពោះការសាកល្បងអាចពង្រឹងសេចក្ដីជំនឿ ឬ ក៏ធ្វើឲ្យសេចក្ដីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទចុះខ្សោយ ។




ទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ និងកន្លែងដែលនៅភាគខាងជើងនៃរដ្ឋ មិសសួរី

នៅពេលអ្នកអានប្រវត្តិសាស្ត្រសង្ខេបដូចខាងក្រោម សូមពិចារណាថាតើគោលការណ៍អ្វីដែលអ្នកអាចរៀនពីព្រឹត្តិការណ៍ដែលបានរៀបរាប់ ៖

ក្នុងឆ្នាំ ១៨៣៧ ពួកបរិសុទ្ធនៅក្នុងទីក្រុងខឺតឡង់ រដ្ឋអូហៃអូបានជួបនឹងបញ្ហាហិរញ្ញវត្ថុខ្លះៗ ។ ដើម្បីជួយពួកបរិសុទ្ធឲ្យគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធិភាព នោះព្យាការី យ៉ូសែប ស៊្មីធ និងអ្នកដឹកនាំសាសនាចក្រដទៃទៀតបានស្ថាបនាសមាគមសង្គមសុវត្ថិភាពទីក្រុងខឺតឡង់ ជាក្រុមហ៊ុនមួយដែលស្រដៀងទៅនឹងធនាគារ ។ ដោយសារតែការរីករាលដាលនៃវិបត្តិសេដ្ឋកិច្ចអំឡុងពេលនោះ ធនាគារជាច្រើនបានដួលរលំទូទាំងសហរដ្ឋអាមេរិក ។ សមាគមសង្គមសុវត្ថិភាពទីក្រុងខឺតឡង់ ក៏បានដួលរលំនៅរដូវស្លឹកឈើជ្រុះក្នុងឆ្នាំ ១៨៣៧ ដែរ ។ អ្នកវិនិយោគពីររយនាក់នៅក្នុងធនាគារបានបាត់បង់អ្វីៗស្ទើរតែទាំងអស់ ដោយមាន យ៉ូសែប ស៊្មីធ ទទួលរងការការខូចខាតខ្លាំងជាងគេ ។ ទោះបីជាសមាគមសង្គមសុវត្ថិភាពទីក្រុងខឺតឡង់មិនត្រូវបានឧបត្ថម្ភដោយសាសនាចក្រក្ដី ក៏ពួកបរិសុទ្ធមួយចំនួនបានគិតថាវាជាធនាគាររបស់សាសនាចក្រ ឬជាធនាគាររបស់ព្យាការី ហើយបានបន្ទោសដល់ យ៉ូសែប ចំពោះបញ្ហាហិរញ្ញវត្ថុរបស់ពួកគេ ។ អ្នកខ្លះថែមទាំងចាប់ផ្ដើមហៅលោកថាជាព្យាការីបរាជ័យមួយរូប ។ ប៉ុន្តែ ទោះជាធនាគារបានដួលរលំក្ដី ក៏អ្នកដទៃផ្សេងទៀតជាច្រើន ដែលបានខាតលុយនោះ បានបន្តមានសេចក្ដីជំនឿ និងបន្តស្មោះត្រង់ចំពោះព្យាការីដែរ ។ ( សូមមើល *Church History in the Fulness of Times Student Manual,* បោះពុម្ពទី ២ [Church Educational System manual, ឆ្នាំ ២០០៣], ទំព័រ ១៧១–៧៣) ។

ស្មារតីនៃការក្បត់សាសនា និងការស្វែងរកកំហុស បានរីករាលដាលនៅក្នុងចំណោមពួកបរិសុទ្ធជាច្រើន ។ ព្រិកហាំ យ៉ង់ បានរៀបរាប់ពីគ្រាដែលសមាជិកសាសនាចក្រ រួមទាំងអ្នកដឹកនាំសាសនាចក្រមួយចំនួន បានជួបជុំគ្នាដើម្បីទម្លាក់ យ៉ូសែប ស៊្មីធ ហើយតែងតាំងព្យាការីថ្មីមួយរូប ៖ « សាវកពីរបីនាក់នៅក្នុងចំណោមសាវកដប់ពីរនាក់ សាក្សីនៃព្រះគម្ពីរមរមន និងអ្នកមានសិទ្ធិអំណាចនៅក្នុងសាសនាចក្រដទៃទៀត បានមានការប្រជុំប្រឹក្សានៅបន្ទប់ជាន់ខាងលើនៃព្រះវិហារបរិសុទ្ធ ។ សំណួរដែលចោទសួរនោះ គឺថាតើព្យាការី យ៉ូសែប អាចត្រូវទម្លាក់ ហើយតែងតាំង ដាវីឌ វិតមើរ ជាប្រធានសាសនាចក្រជំនួសវិញដោយរបៀបណា ។. . . ខ្ញុំបានក្រោកឈរឡើង ដោយប្រឡេត ហើយបានប្រាប់ទៅពួកគេថា ខ្ញុំដឹងថា យ៉ូសែប គឺជាព្យាការីម្នាក់ ហើយពួកគេអាចតិះដៀល និងនិយាយបង្ខូចលោកបានតាមពួកគេត្រូវការ ប៉ុន្តែពួកគេមិនអាចបំផ្លាញការជ្រើសតាំងរបស់ព្យាការីនៃព្រះបានទេ ពួកគេអាចត្រឹមតែបំផ្លាញសិទ្ធិអំណាចរបស់ខ្លួនឯង និងកាត់ចំណងដែលចងពួកគេទៅនឹងព្យាការី និងព្រះ ហើយពន្លិចខ្លួនទៅក្នុងនរកប៉ុណ្ណោះ » ( *Manuscript History of Brigham Young, 1801–1844,* ed. Elden Jay Watson [១៩៦៨], ទំព័រ ១៥–១៦ ) ។



១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើសេចក្ដីពិតអ្វីខ្លះ ដែលយើងអាចរៀនពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទាំងនេះ ?

ខ. តើអ្នកអាចធ្វើអ្វី ដើម្បីបន្តមានភាពស្មោះត្រង់ចំពោះព្យាការី ក្នុងពេលនៃការចាប់កំហុសនេះ ? តើនៅពេលណាដែលការស៊ូទ្រាំនឹងការសាកល្បងដោយសេចក្ដីជំនឿ បានពង្រឹងសេចក្ដីជំនឿរបស់អ្នកលើព្រះយេស៊ូវគ្រីស្ទ ?

គ. តើការធ្វើតាមព្យាការីអាចក្លាយជាការការពារខាងវិញ្ញាណ សម្រាប់អ្នកដោយរបៀបណា ?

នៅត្រឹមខែ មិថុនា ឆ្នាំ ១៨៣៨ មានអ្នកក្បត់សាសនាប្រហែលជា ២០០ ឬ ៣០០ នាក់បានចាកចេញពីសាសនាចក្រ រួមមានពួកសាវកបួនរូប ដែលជាសាក្សីបីនាក់នៃព្រះគម្ពីរមរមន និងសមាជិកនៃគណៈប្រធានទីមួយម្នាក់ ( សូមមើល *Church History in the Fulness of Times,* ទំព័រ ១៧៧) ។ ទោះជាយ៉ាងណាក្ដី ពួកបរិសុទ្ធភាគច្រើនបានឆ្លើយតបទៅនឹងរយៈពេលនៃការសាកល្បងនេះដោយសេចក្ដីជំនឿ ដូចជាព្រិកហាំ យ៉ង់ ដែរ ។ ពួកគេត្រូវបានពង្រឹងដោយព្រះអម្ចាស់ ហើយពួកគេនៅតែស្មោះចំពោះទីបន្ទាល់របស់ពួកគេ ។ មានមនុស្សបួនប្រាំនាក់នៃអស់អ្នកដែលបានចាកចេញពីសាសនាចក្រអំឡុងពេលនៃការក្បត់សាសនានេះ ក្រោយមកបានត្រឡប់មកវិញ និងបានស្នើសុំរួបរួមគ្នាជាថ្មីម្ដងទៀតជាមួយនឹងសាសនាចក្ររបស់ព្រះអម្ចាស់ ។ នៅក្នុងចំណោមពួកគេនោះគឺមាន អូលីវើរ ខៅឌើរី ម៉ាទីន ហារីស លូកា ចនសុន និងហ្វ្រេឌើរិក ជី វិលលាម្ស ។

នៅកណ្ដាលនៃការតស៊ូទាំងនេះនៅក្នុងទីក្រុងខឺតឡង់ មានអ្នកក្បត់សាសនាពីរបីនាក់បានប៉ុនប៉ងសម្លាប់ យ៉ូសែប ស្ម៊ីធ ។ លូក ចនសិន ដែលបានក្បត់ចេញពីសាសនាចក្រ មានសេចក្ដីសុចរិតគ្រប់គ្រាន់ដើម្បីព្រមានព្យាការីពីផែនការនោះ ។ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានចាកចេញពីទីក្រុង ខឺតឡង់នៅខែ មករា ឆ្នាំ ១៨៣៨ ។ ពួកលោកបានគេដេញតាមជាច្រើនថ្ងៃ ប៉ុន្តែព្រះអម្ចាស់បានការពារពួកលោក ។ ពួកលោកបានមកដល់ជួបជុំគ្រួសាររបស់ពួកលោកនៅក្រុងហ្វារវេស្ទ រដ្ឋមីសសួរី នៅខែ មីនា ឆ្នាំ ១៨៣៨ ។

## ភាគខាងជើងនៃរដ្ឋ មិសសួរី

សូមរកមើលរដ្ឋ មិសសួរី នៅលើផែនទីនៅខាងដើមនៃមេរៀននេះ ។ នៅពេលពួកបរិសុទ្ធត្រូវបានបណ្ដេញចេញពី ឃុំ ចាកសុន ខោនធី រដ្ឋ មិសសួរី នៅក្នុងឆ្នាំ ១៨៣៣ ប្រជាពលរដ្ឋនៃភូមិជិតខាងបានស្វាគមន៍ពួកគេ ហើយបានធ្វើឲ្យពួកគេធូរស្បើយ ដោយគិតថា ពួកបរិសុទ្ធនឹងស្នាក់នៅជាបណ្ដោះអាសន្នតែប៉ុណ្ណោះ ។ ប៉ុន្តែ បន្ទាប់ពីពួកបរិសុទ្ធបានរស់នៅទីនោះអស់រយៈពេលជិតបីឆ្នាំមក ប្រជាពលរដ្ឋទាំងនេះបានចាប់ផ្ដើមគៀបសង្កត់ឲ្យពួកគេចាកចេញពីភូមិនោះ ។

នៅពេលអ្នកអានពីប្រវត្តិសាស្ត្រសង្ខេបដូចខាងក្រោម សូមពិចារណាថាតើគោលការណ៍អ្វីដែលអ្នកអាចរៀនពីព្រឹត្តិការណ៍ដែលបានរៀបរាប់ ៖

ក្នុងឆ្នាំ ១៨៣៧ ចន វិតមើរ និង វិលាម ដំបុលយូ ហ្វែល្បស ជាទីប្រឹក្សាពីររូបក្នុងគណៈប្រធានស្តេក មិសសួរី បានប្រើមូលនិធិសាសនាចក្រទិញដីនៅកន្លែងដែលត្រូវបានស្គាល់ថា ក្រុងហ្វារវេស្ទ ក្នុងភាគខាងជើងនៃរដ្ឋ មិសសួរី ។ ប៉ុន្តែ ពេលពួកគេបានចែកចំណែកដីដល់ពួកបរិសុទ្ធដែលមកដល់ ពួកគេបានលក់ដីនោះយកប្រាក់ចំណេញតិចតួចទុកខ្លួនឯង ។ ទោះជាយ៉ាងនោះក្ដី ក្រុមប្រឹក្សាជាន់ខ្ពស់បានលើកទោសឲ្យពួកគេ ហើយបានចាត់ឲ្យអ្នកផ្សេងទៀតចែកចំណែកដីវិញ ។ ប៉ុន្តែ ចន និង វិល្លាម បន្តចង់បានបាក្រចំណេញពីការលក់ដី ។ ក្នុងឆ្នាំ ១៨៣៨ ក្រុមប្រឹក្សាជាន់ខ្ពស់បានកាត់កាលពួកគេចេញ ។ ( សូមមើល *Church History in the Fulness of Times,* ទំព័រ ១៨៣–៨៥) ។

យ៉ូសែប ស្ម៊ីធ បានគាំទ្រទង្វើរបស់ក្រុមប្រឹក្សា ដែលធ្វើឲ្យ វិល្លាមមានការថ្នាំងថ្នាក់ចិត្ត ។ ក្នុងខែ វិច្ឆិកា ឆ្នាំ ១៨៣៨ គាត់បានចុះហត្ថលេខាលើលិខិតថ្លែងសច្ចាទាស់នឹងព្យាការី ។ លិខិតថ្លែងសច្ចានេះ បាននាំឲ្យមានការចាប់ខ្លួន យ៉ូសែប និងអ្នកដទៃទៀត ហើយបានបញ្ជូនចូលគុកលីប៊ើធី នៅរដូវរងា ។

នៅក្នុងគុក ព្យាការី យ៉ូសែប ស្ម៊ីធ និងអ្នកនៅជាមួយលោក បានរងទុក្ខយ៉ាងមហិមា មិនត្រឹមតែពីស្ថានភាពដ៏យ៉ាបយ៉ឺនក្នុងគុកប៉ុណ្ណោះទេ ថែមទាំងពីរបាយការណ៍ស្ដីពីការបណ្ដេញពួកបរិសុទ្ធចេញពីផ្ទះសម្បែង និងធ្វើបាបសព្វបែបយ៉ាងផងដែរ ។ ពួកមនុស្សកំណាចក្នុងរដ្ឋ មិសសួរី ដោយមិនត្រូវបានពិនិត្យដោយរដ្ឋអំណាច បានបំផ្លាញ និងសម្លាប់មនុស្ស ១៧ នាក់ នៅរោងម៉ាស៊ីនកិនស្រូវមួយកន្លែងដែលកាន់កាប់ដោយបុរសម្នាក់មានឈ្មោះថា យ៉ាកុប ហន ។

វិលាម ដំបុលយូ ហ្វែល្បស បានរងទុក្ខខាងវិញ្ញាណសម្រាប់ទង្វើរបស់គាត់ ហើយគាត់បានសរសេរសំបុត្រសូមការអភ័យទោសពី យ៉ូសែប ។ ព្យាការីបានសរសេរតបវិញ ៖



« វាជាការពិតណាស់ថាយើងបានរងទុក្ខជាច្រើន ដោយសារលទ្ធផលនៃទង្វើរបស់អ្នក—[ ពែងល្វីង ] ពេញល្អមគ្រប់គ្រាន់សម្រាប់ឲ្យយើងផឹកហើយ ប៉ុន្តែវាបានហៀរពេលអ្នកបែរមកប្រឆាំងយើង ។. . .

« ប៉ុន្តែ ពែងនោះត្រូវបានផឹកហើយ ព្រះទ័យរបស់ព្រះវរបិតាត្រូវបានសម្រេច ហើយពួកយើងនៅមានជីវិតនៅឡើយ នោះហើយជាហេតុផលដែលយើងអរព្រះគុណដល់ព្រះអម្ចាស់ ។. . .

« ដោយជឿថាការសារភាពរបស់អ្នកពិត ហើយអ្នកប្រាកដជាប្រែចិត្តមែន ខ្ញុំមានភាពរីករាយក្នុងការផ្ដល់សិទ្ធិឲ្យអ្នកធ្វើជាសមាជិកម្ដងទៀត ហើយរីករាយចំពោះការត្រឡប់មកវិញរបស់កូនប្រុសខ្ជះខ្ជាយ ។. . .

« ‹ បងជាទីស្រឡាញ់អើយ សង្គ្រាមបានកន្លងហួសទៅហើយ មិត្តភក្តិមួយថ្ងៃ គឺមិត្តភក្តិមួយជីវិត › » ( នៅក្នុង *History of the Church,* ៤:១៦៣–៦៤ ) ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើហេតុអ្វីបានជាវាមានការលំបាកក្នុងការអភ័យទោសឲ្យមិត្តភក្ដិម្នាក់ ដែលបានក្បត់អ្នក ហើយបានធ្វើឲ្យអ្នករងទុក្ខ ?

ខ. តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីគំរូរបស់ យ៉ូសែប ស្ម៊ីធ ? ( គោលការណ៍នេះ អាចរំឭកអ្នកពីវគ្គចំណេះចំណានខគម្ពីរនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៩–១១ ។ អ្នកអាចរំឭកឡើងវិញនូវបទគម្ពីរ ដើម្បីឃើញថាវាទាក់ទងនឹងបទពិសោធន៍របស់ យ៉ូសែប ស្ម៊ីធ និង វិល្លាម ដ័បុលយូ ហ្វែប្ស ដោយរបៀបណា ) ។

គ. តើមេរៀនអ្វីផ្សេងទៀត ដែលយើងអាចរៀនពីរឿងនេះ ?



ផ្នែកមួយនៃសំបុត្ររបស់ យ៉ូសែប ស្ម៊ីធ សរសេរទៅកាន់ វិល្លាម ដ័បុលយូ ហ្វែប្ស

៣. សូមជ្រើសរើសគោលការណ៍មួយ ដែលអ្នកបានរកឃើញចេញពីប្រវត្តិសាស្ត្រសង្ខេបទាំងពីរនេះ ។ សូមសរសេរអំពីពេលដែលអ្នកបានឃើញគំរូរបស់វា នៅក្នុងជីវិតអ្នក ឬនៅក្នុងជីវិតរបស់អ្នកណាផ្សេងទៀតដែលអ្នកស្គាល់ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

## ព្រឹត្តិការណ៍ដែលនាំទៅរកការបណ្ដេញពួកបរិសុទ្ធចេញពីភាគខាងជើងនៃរដ្ឋ មិសសួរី

តើអ្នកធ្លាប់បានឃើញសមាជិកសាសនាចក្រ បានធ្វើការជ្រើសរើសដែលធ្វើឲ្យមនុស្សផ្សេងទៀតមានអារម្មណ៍អវិជ្ជមានចំពោះសាសនាចក្រដែរឬទេ ? អ្នកអាចនឹងចង់គិតពីរបៀបដែលទង្វើរបស់អ្នក បានជះឥទ្ធិពលលើអារម្មណ៍អ្នកដទៃអំពីសាសនាចក្រ ។

តើហេតុអ្វីបានជាវាមានសារៈសំខាន់សម្រាប់យើង ដើម្បីគិតអំពីរបៀបដែលទង្វើ ឬពាក្យសម្ដីរបស់យើងឆ្លុះបញ្ចាំងអំពីសាសនាចក្រ ?

ក្នុងឆ្នាំ ១៨៣៨ ទង្វើ និងពាក្យសម្ដីរបស់សមាជិកសាសនាចក្រមួយចំនួន បានបន្ថែមលើអារម្មណ៍អវិជ្ជមានរបស់ប្រជាពលរដ្ឋមួយចំនួននៅរដ្ឋ មិសសួរី ចំពោះពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ នៅពេលអ្នកអានអំពីប្រវត្តិសាស្ត្រសង្ខេបដូចខាងក្រោម សូមរកមើលអ្វីដែលពួកបរិសុទ្ធមួយចំនួនបាននិយាយ ឬបានធ្វើ ដែលធ្វើឲ្យសាសនាចក្រ និងសមាជិកខូចឈ្មោះ ។ សូមគិតពីការគូសចំណាំអ្វីដែលអ្នករកឃើញ ។

នៅក្នុងឆ្នាំ ១៨៣៧ និង ១៨៣៨ សមាជិកនៃសាសនាចក្រដែលខូចមិត្តភាព និងត្រូវបានកាត់កាលចេញពីសាសនាចក្រ ដែលរស់នៅក្នុងចំណោមពួកបរិសុទ្ធនៅក្នុងក្រុងហ្វារវេស្ទ រដ្ឋ មិសសួរី មួយចំនួនបានចាប់ផ្ដើមប្ដឹងផ្ដល់ទាស់នឹងសាសនាចក្រ និងដើម្បីវាយប្រហារលើសាសនាចក្រ ។ ពួកបរិសុទ្ធមួយចំនួនបានចាប់ផ្ដើមអស់ភាពអត់ធ្មត់នឹងពួកអ្នកប្រឆាំងទាំងនេះ ។ នៅក្នុងខែ មិថុនា ឆ្នាំ ១៨៣៨ ស៊ីឌនី រិកដុន បានថ្លែងដោយខឹងសម្បារ ដែលវាត្រូវបានគេស្គាល់ថាជា « ទេសនកថាអំបិល » ។ លោកបាននិយាយពី ម៉ាថាយ ៥:១៣ ហើយបានថ្លែងថា ប្រសិនបើអំបិលបាត់បង់រសជាតិរបស់វា នោះវាគ្មានប្រយោជន៍សោះ ហើយគួរតែកាត់ចេញទៅ ដោយបង្កប់ន័យថា អស់អ្នកដែលបានចាកចេញពីសាសនាចក្រគួរតែត្រូវបានកាត់ចេញពីក្នុង

ចំណោមពួកបរិសុទ្ធទៅ ។ បន្ថែមពីលើនោះ សមាជិកសាសនាចក្រ ៨៤នាក់បានចុះហត្ថលេខាលើឯកសារមួយ ដែលទាមទារឲ្យពួកអ្នកក្បត់សាសនាចាកចេញពីភូមិ ។ ពីរសប្ដាហ៍ក្រោយមក នៅថ្ងៃទី ៤ ខែ កក្កដា ស៊ីឌនី បានថ្លែងសុន្ទរកថាមួយ ដែលលោកបានសន្យាថា ពួកបរិសុទ្ធនឹងការពារខ្លួនគេថ្វីបើមាន « សង្គ្រាមនៃការបំផ្លាញចោល » កើតឡើងក្ដី ។ ទោះបីជាសុន្ទរកថាទាំងពីរនេះហាក់ដូចជាប្រឆាំងនឹងការណែនាំរបស់ព្រះអម្ចាស់ដើម្បី « តវ៉ាសូមសេចក្ដីសុខសាន្ត » ( គ. និង ស. ១០៥:៣៨ ) ក្ដី ក៏សុន្ទរកថាទាំងពីរនេះត្រូវបានបោះពុម្ព និងបានបណ្ដាលឲ្យមានការបង្អើលដល់ក្នុងចំណោមអ្នកមិនមែនជាពួកបរិសុទ្ធថ្ងៃចុងក្រោយដែរ ។ ( សូមមើល *Church History in the Fulness of Times,* ទំព័រ ១៩១–៩២) ។

នៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៨៣៨ ពួកបរិសុទ្ធមួយក្រុមបានព្យាយាមបោះឆ្នោតនៅទីក្រុង ហ្គាឡាទីន រដ្ឋ មិសសួរី ប៉ុន្តែត្រូវបានវាយប្រហារដោយប្រជាជនមិសសួរី ។ ពួកបរិសុទ្ធបានវាយតបវិញ ហើយមនុស្សនៅក្នុងក្រុមទាំងពីរបានរងរបួស ។ ឧបទ្ទវហេតុនេះ បាននាំទៅរកជម្លោះ និងការគំរាមកំហែងបន្ថែមទៀត ហើយបានបង្កើនការយល់ច្រឡំរវាងពួកបរិសុទ្ធថ្ងៃចុងក្រោយ និងអ្នកជិតខាងរបស់គេនៅរដ្ឋ មិសសួរី ។ ( សូមមើល *Journals, វ៉ុល ១ ៖ ឆ្នាំ ១៨៣២–១៨៣៩* វ៉ុល ១ នៃ the Journals series នៃ *The Joseph Smith Papers* [ ឆ្នាំ ២០០៨ ] ទំព័រ ២៩៨–៣០១ ) ។

អំឡុងពេលនេះ អ្នកប្រែចិត្តជឿម្នាក់ឈ្មោះ សេមសិន អាវើត បានធ្វើសម្បថសម្ងាត់ចំពោះអស់អ្នកដែលនឹងចូលរួមជាមួយនឹងគាត់ក្នុងការបង្កើតក្រុមចោរប្លន់មួយក្រុម ដែលហៅថា ពួកឌែណៃ ។ អាវើត បានណែនាំពួកគេឲ្យលួច និងប្លន់ពួកអ្នកនៅរដ្ឋ មិសសួរី ដោយនិយាយថា ការណ៍នេះនឹងជួយកសាងដល់នគររបស់ព្រះ ។

អាវើត បានបញ្ចុះបញ្ចូលដល់អ្នកដើរតាមខ្លួនថា ការដឹកនាំរបស់គាត់បានមកពីគណៈប្រធានទីមួយ ។ ក្រោយមក ការពិតត្រូវបានលាតត្រដាង ហើយអាវើតត្រូវបានកាត់កាល់ចេញ ។ សកម្មភាពរបស់អាវើត បានបណ្ដាលឲ្យមានការខូចខាតដ៏ខ្លាំងដល់កិត្តិនាមរបស់សាសនាចក្រ និងបានធ្វើឲ្យព្យាការីត្រូវគេចាប់ដាក់គុកលីប៊ើរធី ។

នៅខែ តុលា ឆ្នាំ ១៨៣៨ មានការប្រយុទ្ធតតាំងគ្នារវាងសមាជិកសាសនាចក្រមួយចំនួន និងពួកទាហានរដ្ឋ មិសសួរី ។ របាយការណ៍ពន្លើសនៃសង្គ្រាមនេះបានព្ទទៅដល់លោកអភិបាល ប៉ហ្គស៍ ជាអ្នកចេញដីកាបំផ្លាញចោល ៖ « ពួកមរមនត្រូវតែចាត់ទុកថាជាសត្រូវ និង *ត្រូវតែបំផ្លាញចោល* ឬបណ្ដេញចេញពីរដ្ឋនេះ ប្រសិនបើចាំបាច់ដើម្បីប្រយោជន៍សាធារណៈ » ( នៅក្នុង *History of the Church* ៣:១៧៥ ) ។ ភ្លាមៗនោះ ក្រុងហ្វារវេស្ទ ត្រូវបានឡោមព័ទ្ធដោយទាហានមួយក្រុម ដែលមានចំនួនច្រើនលើសលុបលើកម្លាំងរបស់ពួកបរិសុទ្ធប្រាំដង ។ ព្យាការី យ៉ូសែប ស៊្មីធ និងអ្នកដឹកនាំសាសនាចក្រផ្សេងទៀតត្រូវបានចាប់ដាក់គុកនៅក្នុងគុកលីប៊ើរធី ជាកន្លែងដែលពួកលោកបន្តនៅពេញមួយរដូវត្រជាក់ ។ ពួកបរិសុទ្ធទាំងឡាយផ្សេងទៀតត្រូវបានបង្ខំឲ្យចាកចេញពីរដ្ឋនេះ ។ ( សូមមើល *Church History in the Fulness of Times,* ទំព័រ ១៩៩–២០០, ២០៤, ២០៨) ។

គោលការណ៍មួយដែលយើងអាចរកឃើញ ពីពេលនោះគឺ **ទង្វើ និងពាក្យសម្ដីរបស់យើង អាចមានឥទ្ធិពលលើទស្សនៈអ្នកដទៃចំពោះសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។**


ពួកបរិសុទ្ធត្រូវបង្ខំឲ្យចាកចេញពីក្រុងហ្វារវេស្ទ រដ្ឋ មិសសួរី ។

តើអ្នកគិតថា ហេតុអ្វីវាសំខាន់ចំពោះយើងដើម្បីទទួលស្គាល់ថា ទង្វើរបស់សមាជិកសាសនាចក្រមួយចំនួននៅសម័យមុនរួមចំណែកដល់គំនិតអវិជ្ជមានដែលប្រជាជនរដ្ឋ មិសសួរី មានអំពីសាសនាចក្រ ?

ទោះជាជម្រើសមិនល្អរបស់យើងអាចមានឥទ្ធិពលលើអ្នកដទៃឲ្យមើលឃើញសាសនាចក្រក្នុងផ្លូវអាក្រក់ក៏ដោយ ក៏យើងអាចជួយអ្នកដទៃឲ្យមានទស្សនៈវិជ្ជមានចំពោះសាសនាចក្រតាមរយៈពាក្យសម្ដី និងទង្វើរបស់យើងបានដែរ ។

៤. សូមសរសេរអំពីពេលមួយដែលអ្នកបានឃើញពាក្យសម្ដី ឬទង្វើរបស់នរណាម្នាក់មានឥទ្ធិពលលើនរណាម្នាក់ឲ្យមានទស្សនៈវិជ្ជមានលើសាសនាចក្រ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

សូមរកមើលវិធីដើម្បីតំណាងយ៉ាងវិជ្ជមាន ឲ្យសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៅសប្ដាហ៍ក្រោយទៀត ។ នៅពេលដែលអ្នកធ្វើដូច្នោះ ព្រះអម្ចាស់នឹងប្រទានពរឲ្យអ្នក ។

គោលការណ៍សំខាន់មួយ ដែលយើងរៀនពីពេលនេះ នៅក្នុងប្រវត្តិសាសនាចក្រគឺ **នៅពេលយើងជ្រើសរើសឆ្លើយតបទៅនឹងការសាកល្បង ដោយសេចក្តីជំនឿជាជាងការសង្ស័យនោះ ទីបន្ទាល់របស់យើងអាចត្រូវបានពង្រឹង ។**

៥. សូមឆ្លើយសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើខ្ញុំនឹងធ្វើអ្វីខុសប្លែកពីមុន ដោយសារតែគោលលទ្ធិ និងគោលការណ៍ដែលខ្ញុំបានរៀននៅថ្ងៃនេះទៅ ?

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សាមេរៀន « សាសនាចក្រប្តូរទៅរដ្ឋមិសសួរីភាគខាងជើង » ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៥ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣–១១៤

## បុព្វកថា

បន្ទាប់ពីមកដល់ក្រុងហ្វាវេស្ទ រដ្ឋ មិសសួរី នៅខែ មិនា ឆ្នាំ ១៨៣៨ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣ ។ នៅក្នុងវិវរណៈនោះ ព្រះអម្ចាស់បានឆ្លើយតបនឹងសំណួរអំពីវគ្គគម្ពីរនៅក្នុងព្រះគម្ពីរ អេសាយ ។ យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៤ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៨៣៨ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានបញ្ជាឲ្យ ដាវីឌ ដ័បុលយូ ប៉ាទិន ដែលជាសមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ឲ្យរៀបចំខ្លួនបម្រើបេសសកម្ម ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣

*ព្រះអម្ចាស់ឆ្លើយតបចំពោះសំណួរ អំពីវគ្គគម្ពីរនៅក្នុងព្រះគម្ពីរអេសាយ*

តើអ្នកធ្លាប់មានបញ្ហាក្នុងការយល់អំពីអ្វីដែលអ្នកបានអាននៅក្នុងព្រះគម្ពីរឬទេ ?

ការព្យាករមួយចំនួននៅក្នុងព្រះគម្ពីរ ប្រើនិមិត្តរូបដែលពិបាកយល់ ។ នៅក្នុងក្រុងហ្វាវេស្ទ រដ្ឋ មិសសួរី បងប្អូនប្រុសមួយចំនួនបានសូមឲ្យព្យាការី យ៉ូសែប ស្ម៊ីធ បកស្រាយវគ្គគម្ពីរនៅក្នុងព្រះគម្ពីរអេសាយ ។ ចម្លើយរបស់ព្រះអម្ចាស់ចំពោះសំណួរទាំងនោះ ត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣ ។

**និមិត្តរូប**
អ្នកអាចសិក្សានិមិត្តរូបនៅក្នុងព្រះគម្ពីរ ដោយស្វែងយល់ពីធម្មជាតិរបស់វា ហើយពិចារណាពីចារិតលក្ខណៈរបស់វា ។ លេខយោង Bible Dictionary និង Topical Guide ឬសេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ អាចជួយបកប្រែនិមិត្តរូបបានមួយចំនួន ។ សូមសាកល្បងប្រើវិធីសាស្ត្រនេះ នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣ ។

១. សូមសរសេរសំណួរទាំងនេះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣ ក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ហើយសង្ខេបចម្លើយរបស់ព្រះអម្ចាស់ ។


អេសាយ

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣:១–២ គល់មានអត្ថន័យយ៉ាងច្បាស់ ។ ព័ត៌មានខាងក្រោមនេះ អាចជួយបង្កើនការយល់ដឹងរបស់អ្នកពីនិមិត្តរូប ៖ ព្រះយេស៊ូវគ្រីស្ទបានយាងចុះពីផ្ទះរបស់ អ៊ីសាយ ជាឪពុករបស់ ដាវីឌ ។ ពាក្យ *គល់* នៅក្នុង អេសាយ ១១:១ ត្រូវបានបកប្រែពីពាក្យហេព្រើរ ដែលមានន័យថាជាគល់ ឬជាឫសដើមឈើ—មាននៅក្នុងដើមឈើដែលត្រូវបានកាត់ចោល ឬក្នុងដើមឈើដែលត្រូវបានដាំ ។

សូមពិចារណាពីអត្ថន័យនៃពាក្យ លំពង់ ឫស ដែលបានលើកឡើងនៅ ក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣:៣–៦។ សូមគិតពីការបកប្រែខាងក្រោម ដែលចែកចាយដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « តើយើងនិយាយខុសឬ ដែលថាព្យាការីដែលបានលើកឡើងនៅទីនេះគឺជាយ៉ូសែប ស្ម៊ីធ ដែលបព្វជិតភាពមានមកតាមលោក ជាអ្នកដែលបានទទួលកូនសោទាំងឡាយនៃនគរ ហើយបានលើកទង់ដើម្បីប្រមូលរាស្ត្ររបស់ព្រះអម្ចាស់នៅក្នុងគ្រាកាន់កាប់ត្រួតត្រា ? ហើយតើលោកក៏មិនមែនជា ‹ អ្នកបម្រើនៅក្នុងព្រះហស្តនៃព្រះគ្រីស្ទ ដែលជាពូជពង្សរបស់ អ៊ីសាយ ខ្លះ និងពូជពង្សរបស់ អេប្រាអិម ខ្លះ ឬជាវង្សនៃ យ៉ូសែប ដែលមានអំណាចដ៏ខ្លាំង › ទេឬអី ? ( គ. និង ស. ១១៣:៤–៦ ) ។ អ្នកដែលយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការណ៍ដ៏ទេវភាពនោះនឹងដឹងអំពីអត្ថន័យនៃការណ៍ទាំងនេះ » ( *The Millennial Messiah: The Second Coming of the Son of Man* [ ឆ្នាំ ១៩៨២ ] ទំព័រ ៣៣៩–៤០ ) ។

តើ យ៉ូសែប ស្ម៊ីធ បានធ្វើអ្វីខ្លះក្នុងនាមជា « អ្នកបម្រើនៅក្នុងព្រះហស្តនៃព្រះគ្រីស្ទ » ( គ. និង ស. ១១៣:៤ ) ?

កាលអ្នកគិតអំពីអត្ថន័យនៃពាក្យ គល់ សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣:៥–៦ ។

តើគល់តំណាងឲ្យ យ៉ូសែប ស្ម៊ីធ យ៉ាងដូចម្ដេច ?

សូមបញ្ចប់សេចក្ដីថ្លែងការណ៍អំពីគោលលទ្ធិ ដោយផ្អែកលើអ្វីដែលអ្នកបានរៀនចេញពី ខ ៦ ៖ **យ៉ូសែប ស្ម៊ីធ ទទួលបានកូនសោនៃនគរសម្រាប់ និងសម្រាប់ នៅថ្ងៃចុងក្រោយបង្អស់** ។ អ្នកអាចនឹងចង់ធ្វើសេចក្ដីយោងបទគម្ពីរនៃ ខ ៦ ជាមួយ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១១ ។




បន្ទាប់ពីព្រះអម្ចាស់បានឆ្លើយតបចំពោះសំណួរអំពី អេសាយ ១១ អេលីយ៉ាស ហ៊ិកបី បានសួរសំណួរទាក់ទងនឹង អេសាយ ៥២ ។

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣:៧–១០ ហើយបំពេញតារាងខាងក្រោម ។

| គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣:៧–៨ | គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣:៩–១០ |
|---|---|
| តើអ្វីដែលយើងត្រូវ « ពាក់ » ? | តើព្រះអម្ចាស់សន្យាអ្វីចំពោះអ្នកដែលត្រឡប់មករកទ្រង់វិញ ? |
| តើអ្នកគិតថា វាមានន័យយ៉ាងណា ? | តើអ្នកគិតថា ការណ៍នេះមានន័យយ៉ាងណា ចំពោះប្រជាជនអ៊ីស្រាអែលដែលបានបែកខ្ញែក ? |

២. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរវិធីដែលព្រះអម្ចាស់អាចប្រទានការដឹកនាំ និងកម្លាំងដល់មនុស្សដែលព្យាយាមត្រឡប់មករកទ្រង់វិញ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៤

*ព្រះអម្ចាស់បានបញ្ជាឲ្យ ដាវីឌ ដ័បុលយូ ប៉ាទិន រៀបចំខ្លួនបម្រើបេសកកម្ម*

មនុស្សម្នាក់ដែលព្រះអម្ចាស់ជ្រើសរើស ដើម្បីជួយពង្រឹងទីក្រុងស៊ីយ៉ូន គឺជាបុរសម្នាក់ដែលមានឈ្មោះថា ដាវីឌ ដ័បុលយូ ប៉ាទិន ។

ដាវីឌ ដ័បុលយូ ប៉ាទិន បានចូលរួមក្នុងសាសនាចក្រនៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៨៣២ ។ គាត់ត្រូវបានតែងតាំងជាសាវកនៅឆ្នាំ ១៨៣៥ ។ គាត់មានអំណោយទាននៃការព្យាបាល ហើយលោកជាបុរសម្នាក់ដែលមានភាពក្លាហាន និងអំណាចយ៉ាងខ្លាំង ។ គាត់គ្មានការភ័យខ្លាចក្នុងការការពារសេចក្ដីជំនឿ និងព្យាការី យ៉ូសែប ស្ម៊ីធ ឡើយ ។ ក្នុងការការពារពួកបរិសុទ្ធពីពួកមនុស្សកំណាចនៅរដ្ឋ មិសសួរី ដាវីឌ ប៉ាទិន ត្រូវបានស្គាល់ថា « ប្រធានក្រុមអង់អាច » ។ ( សូមមើល Lycurgus A. Wilson, *Life of David W. Patten: The First Apostolic Martyr* [ ឆ្នាំ ១៩០០ ] ទំព័រ ៥–៨, ១៤–១៧, ៤៨–៤៩, ៦២ ) ។

អែលឌើរ ប៉ាទិន បានសូមឲ្យ ព្យាការី យ៉ូសែប ស្ម៊ីធ ស្វែងរកវិវរណៈឲ្យគាត់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៤:១ រកមើលអ្វីដែលព្រះអម្ចាស់មានព្រះទ័យចង់ឲ្យអែលឌើរ ប៉ាទិន ធ្វើ ។

នៅសរទរដូវក្នុងឆ្នាំ ១៨៣៨ ប្រាំមួយខែបន្ទាប់ពីវិវរណៈដែលបញ្ជាឲ្យអែលឌើរ ប៉ាទិន រៀបចំខ្លួនបម្រើបេសកកម្ម គាត់បានពាក់ព័ន្ធក្នុងការប្រយុទ្ធគ្នានៅទន្លេ ប្រុកឃិដ ដែលមានទីតាំងនៅជិតទីលំនៅរបស់ពួកបរិសុទ្ធនៅខាងលិចរដ្ឋ មិសសួរី ។ នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៨៣៨ ពួកមនុស្សកំណាចបានវាយប្រហារលើផ្ទះសម្បែងពួកបរិសុទ្ធមួយចំនួន និងបានបញ្ជាឲ្យសមាជិកចាកចេញពីរដ្ឋនោះ ហើយបានចាប់បុរសបីនាក់ជាអ្នកទោស ។ នៅពេលឮរបាយការណ៍ថាពួកមនុស្សកំណាចមានបំណងសម្លាប់ពួកអ្នកទោសនៅយប់នោះ កងជីវពលពួកបរិសុទ្ធបានរៀបចំជាពីរក្រុម ដើម្បីជួយសង្គ្រោះពួកអ្នកទោស ។ អែលឌើរ ដាវីឌ ដ័បុលយូ ប៉ាទិន បានដឹកនាំមួយក្រុម ។ នៅទៀបភ្លឺ ពេលដែលក្រុមរបស់អែលឌើរ ប៉ាទិន បានចូលមកដល់ទន្លេ ប្រុកឃិដ ដើម្បីឆ្លងទៅត្រើយម្ខាង សមាជិកក្រុមមនុស្សកំណាច ដែលបានលាក់ខ្លួននៅជិតនោះ បានចាប់ផ្ដើមបាញ់ ។ ការតតាំងដ៏ហ៊ឺសមួយបានផ្ទុះឡើង ហើយបុរសបីបួននាក់ពីក្រុមនីមួយៗបានរងរបួស រួមទាំងអែលឌើរ ប៉ាទិនផង ។



ការប្រយុទ្ធនៅទន្លេ ឃ្រុកឃិដ រដ្ឋ មិសសួរី

អែលឌើរ ប៉ាទិន បានស្លាប់បីបួនម៉ោងក្រោយមក ។ សេចក្ដីជំនឿរបស់គាត់នៅក្នុងដំណឹងល្អដែលបានស្ដារឡើងវិញមានយ៉ាងខ្លាំងក្លា ហើយមានម្ដងនោះ គាត់បានបញ្ជាក់ប្រាប់ព្យាការី យ៉ូសែប ស្ម៊ីធ ថាគាត់ចង់ស្លាប់ក្នុងការស្លាប់របស់ទុក្ករបុគ្គល ។ « ព្យាការី ដោយមានការរំជួលចិត្តជាខ្លាំង បាននិយាយទៅកាន់ ដាវីឌ ដោយទុក្ខព្រួយយ៉ាងខ្លាំងថា ‹ នៅពេលបុរសម្នាក់ដែលមានជំនឿដូចជាបងប្រុស សូមអ្វីមួយដល់ព្រះអម្ចាស់ នោះគេតែងនឹងទទួលបានវា › » ។ នៅឯពិធីបុណ្យសពរបស់អែលឌើរ ប៉ាទិន ក្នុងក្រុងហ្វារវេស្ទ បន្ទាប់ពីការប្រយុទ្ធនោះ យ៉ូសែប ស្ម៊ីធ បានកោតសរសើរគាត់ ៖ « នេះគឺជាបុរសដែលបានធ្វើដូចដែលគាត់បាននិយាយ—គាត់បានលះបង់ជីវិតរបស់គាត់ដោយសារមិត្តភក្ដិរបស់គាត់ » ។ ( សូមមើល *Church History in the Fulness of Times Student Manual*, ២nd ed. [Church Educational System manual ឆ្នាំ ២០០៣] ទំព័រ ១៩៩–២០០; សេចក្ដីសម្រង់ *Life of David W. Patten*, ទំព័រ ៥៣; *History of the Church*, ៣:១៧៥ ) ។

នៅពេលដែលអែលឌើរ ប៉ាទិន បានស្លាប់ គាត់បានរៀបចំខ្លួនដោយសេចក្ដីជំនឿរបស់គាត់ ដើម្បីបម្រើបេសកកម្ម ។ គាត់ក៏មានការព្រួយបារម្ភពីពួកបរិសុទ្ធដែលជាមិត្តភក្ដិរបស់គាត់ដែរ រួមទាំងសមាជិកមួយចំនួនក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដែលពុំស្មោះត្រង់ផងដែរ ។ នៅដង្ហើមចុងក្រោយរបស់គាត់ គាត់បានប្រកាសថា « ខ្ញុំបានលើកដាក់មកលើខ្លួនខ្ញុំ ! ខ្ញុំបានតយុទ្ធយ៉ាងល្អ ខ្ញុំបានរត់ប្រណាំងជាស្រេច ខ្ញុំបានរក្សាសេចក្ដីជំនឿទៅហើយ ពីនេះទៅមុខ នឹងមានមកុដនៃសេចក្ដីសុចរិត បម្រុងទុកឲ្យខ្ញុំដែលព្រះអម្ចាស់ដ៏ជាចៅក្រមសុចរិត [ សូមមើល ធីម៉ូថេ ទី២ ៤:៧–៨ ] » ។ គាត់បាននិយាយទៅកាន់ភរិយាគាត់ថា « ទោះជាអូនធ្វើអ្វីក៏ដោយ តែសូមកុំបោះបង់ចោលសេចក្ដីជំនឿឡើយ » ( សេចក្ដីសម្រង់ Heber C. Kimball, នៅក្នុង *Life of David W. Patten*, ទំព័រ ៦៩ ) ។

សេចក្ដីពិតមួយដែលយើងអាចរៀនពីបទពិសោធន៍របស់ ដាវីឌ ប៉ាទិន នោះគឺ **បើយើងស្ដាប់តាមការដឹកនាំរបស់ព្រះអម្ចាស់ នោះ យើងនឹងរៀបចំខ្លួនសម្រាប់អ្វីគ្រប់យ៉ាងដែលទ្រង់បានរៀបចំសម្រាប់យើង ។**

៣. សូមឆ្លើយនឹងសំណួរដូចតទៅនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើនៅពេលណាដែលអ្នកបានធ្វើតាមការទូន្មានរបស់ព្រះអម្ចាស់ ហើយបានឃើញថា វាបានរៀបចំអ្នកសម្រាប់អ្វីមួយដែលអ្នកមិនបានរំពឹងទុក ? បើអ្នកពុំធ្លាប់មានបទពិសោធន៍នេះទេ សូមពិភាក្សាសំណួរនេះជាមួយសមាជិកគ្រួសារ ឬមិត្តភក្ដិរបស់អ្នក ។ សូមសរសេរអ្វីដែលអ្នកបានរៀនពីគេ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៤:២ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានព្រះបន្ទូលប្រាប់ថានឹងកើតឡើងពេលមនុស្សមួយចំនួនបដិសេធព្រះនាមទ្រង់ ។ ( នៅក្នុងខគម្ពីរនេះ ពាក្យ *គណៈប៊ីស្សព* សំដៅទៅលើទំនួលខុសត្រូវរបស់មនុស្សម្នាក់ មិនមែនចំពោះប៊ីស្សព និងទីប្រឹក្សារបស់គាត់ទេ ។ សូមមើល ទំនុកដំកើង ១០៩:៨; កិច្ចការ ១:២០; Bible Dictionary, « Bishop » ) ។

នៅពេលសមាជិកមួយចំនួននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ មិនមានភាពស្មោះត្រង់ អ្នកដទៃទៀតត្រូវបានហៅឲ្យបម្រើជំនួសពួកគេ ។ សាវកថ្មីទាំងនេះ រួមមាន យ៉ូហាន ថេលើរ និង វិលហ្វូឌ វូឌដ្រុព្វ ជាអ្នកដែលបានបម្រើបេសកកម្មនៅប្រទេសអង់គ្លេសដោយស្មោះត្រង់ ហើយបាននាំមនុស្សជាច្រើនពាន់នាក់ឲ្យស្គាល់ដំណឹងល្អដែលបានស្ដារឡើងវិញ ។

៤. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវកថាខណ្ឌខ្លីមួយដែលរៀបរាប់ពីអ្វីដែលអ្នកអាចធ្វើបាន ដើម្បីធ្វើតាមការទូន្មានរបស់ព្រះអម្ចាស់ និងបំពេញការរំពឹងទុកដែលទ្រង់មានសម្រាប់អ្នក ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៣–១៤ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៥ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥–១៦

## បុព្វកថា

នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៨៣៨ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥ ។ នៅក្នុងនោះ ព្រះអម្ចាស់បានបើកសម្ដែងឈ្មោះរបស់សាសនាចក្រ និងបានបញ្ជាពួកបរិសុទ្ធឲ្យ « ក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ » ( គ និង ស ១១៥:៥ ) ហើយបានបើកសម្ដែងព្រះទ័យទ្រង់ទាក់ទងនឹងព្រះវិហារបរិសុទ្ធនៅក្នុងភូមិហ្វារវេសត៍ ។ នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៨៣៨ ព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៦ដែលប្រាប់ពីកន្លែងមួយដែលហៅថា ស្ព្រីង ហិល រដ្ឋ មិសសួរី ជាកន្លែង អ័ដាម–អុនដៃ–អាម៉ាន ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:១–៦

*ព្រះអម្ចាស់បញ្ជាសមាជិកនៃសាសនាចក្ររបស់ទ្រង់ឲ្យ « ក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ »*

តើអ្នកស្គាល់ឈ្មោះក្រុមហ៊ុន ឬឈ្មោះអង្គការអ្វីខ្លះ ? តើឈ្មោះរបស់អង្គការទាំងនេះ មានន័យយ៉ាងណា ? តើនរណាដឹកនាំអង្គការទាំងនេះ ? តើអង្គការទាំងនេះធ្វើអ្វីខ្លះ ?

សូមគិតពីឈ្មោះ និងរូបសញ្ញារបស់សាសនាចក្រ ។ នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥ សូមរកមើលថាតើឈ្មោះរបស់សាសនាចក្រប្រាប់ថា នរណាជាអ្នកដឹកនាំសាសនាចក្រ និងប្រាប់អ្វីពីសាសនាចក្រផ្ទាល់ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:១–៣ ប្រាប់យើងថា វិវរណៈនេះ ត្រូវបានប្រទានតាមរយៈ យ៉ូសែប ស្ម៊ីធ ដល់សមាជិកសាសនាចក្រទាំងអស់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:៤ រកមើលឈ្មោះដែលព្រះអម្ចាស់ បានរើសសម្រាប់សាសនាចក្ររបស់ទ្រង់ ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

សូមមើលពាក្យនីមួយៗនៅក្នុងឈ្មោះនៃសាសនាចក្រដោយប្រុងប្រយ័ត្ន ហើយគិតអំពីមូលហេតុដែលពាក្យនីមួយៗមានសារៈសំខាន់ ។

សូមអានការពន្យល់ដូចខាងក្រោយដោយអែលឌើរ អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ខ្ញុំបានគិតជាច្រើនអំពីមូលហេតុដែលព្រះអម្ចាស់បានប្រទានឈ្មោះដែលមានប្រាំបួនពាក្យដល់សាសនាចក្រដែលបានស្ដារឡើងវិញរបស់ទ្រង់ ។ វាហាក់ដូចជាវែង ប៉ុន្តែបើយើងគិតពីវាជាទិដ្ឋិភាពពិពណ៌នាទូទៅពីសាសនាចក្រ នោះវាខ្លី ត្រង់ និងច្បាស់ចំៗ ។ តើមានការរៀបរាប់ណាទៀតដែលចំ និងច្បាស់ ប៉ុន្តែបញ្ជាក់ន័យតែត្រឹមពាក្យបីបួនម៉ាត់ដូចពាក្យទាំងនេះ ?

« ពាក្យនីមួយៗច្បាស់ ហើយសំខាន់ ។ ពាក្យ *សាសនាចក្រ* បញ្ជាក់ពីគោលជំហរតែមួយរបស់សាសនាចក្រដែលបានស្ដារឡើងវិញ នៅក្នុងចំណោមសាសនាជាច្រើននៅលើពិភពលោក ។

« ពាក្យ *សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ* ប្រកាសថា វាជាសាសនាចក្ររបស់ទ្រង់ ។. . .

«*នៃថ្ងៃចុងក្រោយ* ពន្យល់ថា វាជាសាសនាចក្រតែមួយនឹងសាសនាចក្រដែលព្រះយេស៊ូវគ្រីស្ទបានបង្កើតឡើងក្នុងពេលនៃការគ្រប់គ្រងខាងសាច់ឈាមរបស់ទ្រង់ ហើយត្រូវបានស្ដារឡើងវិញនៅថ្ងៃចុងក្រោយនេះ ។. . .

*ពួកបរិសុទ្ធ* មានន័យថា សមាជិកសាសនាចក្រធ្វើតាមទ្រង់ ហើយព្យាយាមធ្វើតាមព្រះទ័យទ្រង់ រក្សាព្រះបញ្ញត្តិទ្រង់ ហើយរៀបចំខ្លួនម្ដងទៀត ដើម្បីរស់នៅជាមួយទ្រង់ និងព្រះវរបិតាសួគ៌យើងនៅពេលអនាគត ។ *ពួកបរិសុទ្ធ* សំដៅយ៉ាងសាមញ្ញលើអស់អ្នកណាដែលព្យាយាមធ្វើឲ្យជីវិតរបស់ខ្លួនបរិសុទ្ធដោយចុះសេចក្ដីសញ្ញាធ្វើតាមព្រះគ្រីស្ទ » (The Importance of a Name » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៨០ ) ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើសេចក្ដីពិតអ្វីខ្លះ ដែលបង្ហាញដោយឈ្មោះនៃសាសនាចក្រ ?

ខ តើនរណាគឺជាអ្នកដឹកនាំសាសនាចក្រ ? តើទ្រង់បានបញ្ជា និងបំផុសគំនិតនរណានៅលើផែនដីឲ្យដឹកនាំសាសនាចក្ររបស់ទ្រង់ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:៥ ដោយរកមើលអ្វីដែលព្រះអម្ចាស់មានព្រះទ័យរំពឹងពីអ្នក ដែលនៅក្នុងសាសនាចក្ររបស់ទ្រង់ ។

២. សូមឆ្លើយនឹងសំណួរដូចខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ ក្នុងនាមជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ តើអ្នកគិតថា « ក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ » ( គ និង ស.១១៥:៥ ) មានន័យដូចម្ដេច ?

តើពរជ័យអ្វីខ្លះនឹងកើតមាននៅពេលសមាជិកនៃសាសនាចក្រធ្វើតាមឱវាទរបស់ព្រះអម្ចាស់ឲ្យក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ ? ដើម្បីឆ្លើយសំណួរនេះ សូមប្រើ ខទី ៥ ដើម្បីជួយអ្នកឲ្យបំពេញឃ្លាខាងក្រោម ៖ **បើយើងក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ** . សូមពិចារណាអំពីការធ្វើគោលការណ៍នៅក្នុង ខ ៥ ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ពន្លឺ ឬគំរូរបស់យើង អាចក្លាយជា « បមាណីយដល់សាសន៍នានា » មានន័យយ៉ាងណា (គ. និង ស. ១១៥:៥ ) ? ( នៅពេលអ្នកឆ្លើយសំណួរនេះ វាអាចមានប្រយោជន៍ក្នុងការដឹងថា *បមាណីយ* គឺជាទង់ ឬបដាដែលធ្វើជាចំណុចរួបរួម ឬជានិមិត្តរូបបំផុសគំនិត ) ។

ខ. តើការធ្វើតាមព្រះបញ្ញត្តិរបស់ព្រះអង្គសង្គ្រោះឲ្យក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ ទាក់ទាញអ្នកដទៃមកកាន់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធ ដូចម្ដេច ?

ប្រធាន ជែមស៍ អ៊ី ហ្វោស្ដ នៃគណៈប្រធានទីមួយ បានចែកចាយរឿងដូចខាងក្រោមពីសមាជិកសាសនាចក្រម្នាក់ ដែលធ្វើតាមគោលការណ៍នេះ ៖



« ជាច្រើនឆ្នាំមុន ខនស្វែន ជានិសិត្សគិលានុបដ្ឋាម្នាក់ត្រូវបានចាត់ឲ្យព្យាយាមជួយស្ត្រីម្នាក់ដែលមានរបួសជើងនៅក្នុងគ្រោះថ្នាក់មួយ ។ ស្ត្រីម្នាក់នោះបានបដិសេធជំនួយផ្នែកពេទ្យ ដោយសារតែគាត់មានបទពិសោធន៍មិនល្អជាមួយនរណាម្នាក់នៅមន្ទីរពេទ្យ ។ គាត់មានការភ័យខ្លាច ហើយបានដកខ្លួនចេញពីសង្គម ។ លើកទីមួយដែល ខនស្វែន បានទៅផ្ទះគាត់ ស្ត្រីរងរបួសនោះបានបញ្ជាឲ្យនាងចេញ ។ ក្នុងការព្យាយាមលើកទីពីរ គាត់បានឲ្យ ខនស្វែន ចូល ។ ឥឡូវនេះជើងរបស់ស្ត្រីនោះមានដំបៅដ៏ធំ ហើយសាច់មួយចំនួនបានស្អុយខូចអស់ ។ ប៉ុន្តែ គាត់នៅតែមិនចង់ទទួលការព្យាបាល ។

« ខនស្វែន បានអធិស្ឋានពីរឿងនោះ ហើយមួយថ្ងៃ ឬពីរថ្ងៃក្រោយមក នាងបានទទួលចម្លើយ ។ នាងបានយកទឹកលាងបួស ទៅជាមួយនៅពេលនាងទៅលើកក្រោយ ។ ដោយសារតែវាមិនធ្វើឲ្យឈឺ ស្ដ្រីចំណាស់នោះបានព្រមឲ្យនាងប្រើវានៅលើជើងគាត់ ។ ហើយពួកគេបាននិយាយអំពីការព្យាបាលដែលប្រាកដប្រជាជាងនេះ ។ ខនស្វែន បានអះអាងនឹងគាត់ថា មន្ទីរពេទ្យនឹងព្យាយាមធ្វើឲ្យគាត់ស្នាក់នៅយ៉ាងសុខស្រួល ។ មួយថ្ងៃ ឬពីរថ្ងៃក្រោយមក ស្ដ្រីនោះមានចិត្តក្លាហានទៅមន្ទីរពេទ្យ ។ នៅពេល ខនស្វែន ទៅសួរសុខទុក្ខគាត់ ស្ដ្រីនោះបានញញឹម ហើយបាននិយាយថា ‹ ក្មួយបានធ្វើឲ្យខ្ញុំផ្លាស់ប្ដូរគំនិត › ។ ហើយគាត់បានសួរ ខនស្វែន ដោយមិនបានរំពឹងទុកថា ‹ តើក្មួយជាសមាជិករបស់សាសនាចក្រមួយណាដែរ ? › ខនស្វែន បានប្រាប់គាត់ថា នាងគឺជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ស្ដ្រីនោះបាននិយាយថា ៖ ‹ ខ្ញុំដឹងហើយ ។ ខ្ញុំដឹងថា ក្មួយត្រូវបានបញ្ជូនមកខ្ញុំ តាំងពីថ្ងៃទីមួយដែលខ្ញុំបានឃើញក្មួយ ។ មានពន្លឺមួយនៅលើមុខរបស់ក្មួយ ដែលខ្ញុំបានសម្គាល់ឃើញមាននៅលើមុខរបស់អ្នកដទៃទៀត ដែលមានជំនឿដូចក្មួយ ។ ខ្ញុំត្រូវទុកចិត្តលើក្មួយ › ។

« ជើងដំបៅរបស់គាត់បានជាសះស្បើយទាំងស្រុងក្នុងរយៈពេលបីខែ ។ សមាជិកក្នុងវួដដែលស្ដ្រីចំណាស់នោះរស់នៅបានជួសជុលផ្ទះរបស់គាត់ ហើយសម្អាតទីធ្លាឲ្យគាត់ ។ អ្នកផ្សព្វផ្សាយសាសនា បានជួបជាមួយគាត់ ហើយគាត់បានទទួលបុណ្យជ្រមុជទឹកមួយរយៈខ្លីបន្ទាប់ពីនោះ ។ [ សូមមើល Constance Polve, « A Battle Won » *New Era,* ខែ មេសា ឆ្នាំ ១៩៨០ ទំព័រ ៤៤–៤៥ ] ។ ការណ៍ទាំងនេះ ដោយសារតែគាត់បានកត់សម្គាល់ពីពន្លឺដែលមាននៅលើមុខរបស់និស្សិតគិលានុបដ្ឋាយិកាក្មេងនោះ » (The Light in Their Eyes » *Ensign* ឬ *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ២២ ) ។

តើ ខនស្វែន បានធ្វើអ្វីខ្លះ ដើម្បីក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ ? តើពន្លឺនៅលើមុខរបស់នាងជាបមាណីយសម្រាប់ស្ដ្រីនោះដូចម្ដេច ? តើស្ដ្រីនោះត្រូវបានប្រទានពរ ដោយសារពន្លឺដែលគាត់បានឃើញដូចម្ដេច ?

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

  ក. តើអ្នកស្គាល់នរណាដែលជាគំរូនៃការក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ ?

  ខ. តើគំរូរបស់គេក្លាយជាពរជ័យដល់អ្នកដូចម្ដេច ?

ព្យាការី យ៉ូសែប ស្ម៊ីធ គឺជាគំរូដ៏ល្អ ពីអ្វីដែលមានន័យថាក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ ។ មិនយូរប៉ុន្មានបន្ទាប់ពីវិវរណៈនេះត្រូវបានទទួល យ៉ូសែប បានចាប់ផ្ដើមសរសេរប្រវត្តិរបស់លោក ដែលមាននៅក្នុង មុក្ដាដ៏មានតម្លៃមហិមា ។

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

  ក. តើប្រវត្តិ យ៉ូសែប ស្ម៊ីធ ដែលរួមមានទីបន្ទាល់របស់លោកពីការនិមិត្តលើកដំបូងជាបមាណីយសម្រាប់ប្រជាជាតិដូចម្ដេច ?

  ខ. តើវាជាបមាណីយសម្រាប់អ្នកដូចម្ដេច ?



រឿងមួយសន្លឹកចេញពីប្រវត្តិរបស់ យ៉ូសែប ស្ម៊ីធ

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:៦ហើយរកមើលពរជ័យដែលត្រូវបានសន្យាដល់ពួកអ្នកដែលប្រមូលគ្នាជាមួយសាសនាចក្រនៅក្នុងស្តេកស៊ីយ៉ូន ។

សេចក្ដីពិតមួយដែលយើងរៀនចេញពីខគម្ពីរនេះ មានដូចតទៅនេះ ៖ **យើងប្រមូលគ្នានៅស្តេកស៊ីយ៉ូនដើម្បីមានកម្លាំងនិងការជ្រកកោន** ។ តើអ្នកគិតថា ការប្រមូលគ្នាជាពួកបរិសុទ្ធផ្ដល់ឲ្យយើងនូវការការពារ សុវត្ថិភាព ឬការជ្រកកោនដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:៧–១៩

*ព្រះអម្ចាស់បានត្រាស់បញ្ជាពួកបរិសុទ្ធបង្កើតក្រុងហ្វារ៉ែស្ទ និងឲ្យកសាងព្រះវិហារបរិសុទ្ធ*

វិធីមួយដែលយើងអាចទទួលបានការការពារពីព្រះអម្ចាស់ និងសុវត្ថិភាព គឺដោយការបម្រើ និងការថ្វាយបង្គំទ្រង់នៅក្នុងព្រះវិហារបរិសុទ្ធ ។ បន្ទាប់ពីពួកបរិសុទ្ធបានចាប់ផ្ដើមផ្លាស់ទៅក្រុងហ្វារ៉េស្វ រដ្ឋ មិសសួរី ក្នុងឆ្នាំ ១៨៣៦ អ្នកដឹកនាំសាសនាចក្របានរៀបចំផែនការកសាងព្រះវិហារបរិសុទ្ធដែលស្រដៀងទៅនឹងព្រះវិហារបរិសុទ្ធទីក្រុងខឺតឡង់ រដ្ឋ អូហៃអូដែរ ។ ទោះបីជាបានចាប់ផ្ដើមការចាក់គ្រឹះហើយខ្លះៗក៏ដោយ ក៏ការសាងសង់ត្រូវបានផ្អាករហូតដល់ យ៉ូសែប ស្ម៊ីធ អាចទទួលបានការណែនាំបន្ថែមទៀតពីព្រះអម្ចាស់ដែរ ។ ព្រះអម្ចាស់បានបើកសម្ដែងព្រះទ័យទ្រង់ទាក់ទងនឹងព្រះវិហារបរិសុទ្ធជាផ្នែកមួយនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:៧–១៦ ព្រះអម្ចាស់បានបើកសម្ដែងថា ព្រះវិហារបរិសុទ្ធគួរតែត្រូវសាងសង់ក្នុងក្រុងហ្វារ៉េស្វ តាមគំរូដែលទ្រង់បានប្រទានដល់គណៈប្រធានទីមួយ ។ ព្រះអម្ចាស់ក៏បានទូន្មានដល់អ្នកដឹកនាំសាសនាចក្រកុំឲ្យមានបំណុលក្នុងការសាងសង់ព្រះវិហារបរិសុទ្ធផងដែរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:១៧–១៩ រកមើលអ្វី ដែលព្រះអម្ចាស់មានព្រះទ័យចង់ឲ្យពួកបរិសុទ្ធធ្វើក្រោមការដឹកនាំរបស់ យ៉ូសែប ស្ម៊ីធ ក្នុងក្រុងហ្វារ៉េស្វ និងក្នុងតំបន់ជិតខាង ។

គោលការណ៍មួយដែលយើងរៀនពី ខ ១៩ គឺថា **ប្រធាននៃសាសនាចក្រ កាន់កូនសោដើម្បីដឹកនាំកិច្ចការរបស់ព្រះអម្ចាស់នៅលើផែនដី ។**

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៦

*ព្រះអម្ចាស់រើសទីតាំងនៅ អ័ដាម–អុនដៃ–អាម៉ាន*

ព្យាការី យ៉ូសែប ស្ម៊ីធ បានធ្វើតាមដំបូន្មានរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥:១៨ ហើយបានស្ទង់មើលតំបន់ដែលនៅជុំវិញក្រុងហ្វារ៉េស្វ ។ សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៦ រកមើលឈ្មោះនៃកន្លែងដែលព្យាការីបានស្ទង់មើល ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៦:១ ដោយរកមើលអ្វីដែលព្រះអម្ចាស់បានបើកសម្ដែងអំពី ស្ព្រីង ហិល ។ អ្នកអាចបើកមើលផែនទី និងរូបនៃកន្លែងអ័ដាម–អុនដៃ–អាម៉ាន នៅខាងក្រោយព្រះគម្ពីររបស់អ្នក ( សូមមើល ប្រវត្តិសាសនាចក្រ ផែនទី ទី៥ « តំបន់នៅរដ្ឋមិសសួរី រដ្ឋអិលលីណោយ រដ្ឋអៃអូវ៉ា នៅក្នុងសហរដ្ឋអាមេរិក » និងប្រវត្តិសាសនាចក្រ រូបថត ទី១០ នៃ អ័ដាម–អុនដៃ–អាម៉ាន ) ។



អ័ដាម–អុនដៃ–អាម៉ាន

វិវរណៈនេះ បង្ហាញពីទីតាំងនៃការបំពេញការព្យាករដែលបានធ្វើពីបុរាណសម្រាប់ពេលអនាគត ដោយព្យាការី ដានីយ៉ែល ( សូមមើល ដានីយ៉ែល ៧:៩–១០, ១៣–១៤ ) ។ វិវរណៈនោះពិពណ៌នាអំពីព្រឹត្តិការណ៍មួយនៅថ្ងៃចុងក្រោយ ដែលព្រះអង្គសង្គ្រោះ និងអ័ដាម នឹងយាងមកផែនដី ហើយធ្វើជាអធិបតីនៅក្នុងការប្រជុំមួយ មុនពេលនៃការយាងមកជាលើកទីពីរ ( សូមមើល គ. និង ស. ២៧:៥–១៤ ) ។

សូមពិចារណា ឬ ច្រៀងទំនុកតម្កើងបទ « Adam–ondi–Ahman » ( *ទំនុកតម្កើង* លេខ. ៤៩ នៅក្នុងទំនុកតម្កើងជាភាសា អង់គ្លេស ) ។

*ផែនដីនេះធ្លាប់ជាសួនច្បារមួយ*
*ដែលមានសិរីល្អជាទូទៅ*
*ហើយមនុស្សបានរស់នៅក្នុងទីដ៏បរិសុទ្ធ*
*ហើយថ្វាយបង្គំព្រះយេស៊ូវដោយផ្ទាល់*
*នៅកន្លែង អ័ដាម–អុនដៃ–អាម៉ាន ។*

យើងអានថា អេណុក បាននៅជាមួយព្រះ
*បានយកឈ្នះលើអំណាចទ្រព្យសម្បត្តិ*
*ព្រោះស៊ីយ៉ូនបានពង្រីកខ្លួនរបស់វា*
*ហើយពួកបរិសុទ្ធ និង ពួកទេវតាបន្លឺច្រៀងឡើង*
*នៅកន្លែង អ័ដាម–អុនដៃ–អាម៉ាន ។*
ដែនដីនោះជាដែនដីបវរ និង សុខដុម
*លើសជាងស្រុកកាណានដែនដីអ៊ីស្រាអែលទៅទៀត*
*កិត្តិសព្ទរបស់វារីកសុះសាយពីទិសខាងកើតទៅទិសខាងលិច*
*ភាពសុខសាន្តរបស់វាធំធេង និង បរិសុទ្ធ*
*នៃ អ័ដាម–អុនដៃ–អាម៉ាន ។*
ហូសានណាដល់ទិវាដែលនឹងមកដល់នោះ
*គឺការយាងមកវិញជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ*
*ជាពេលដែលផែនដីទាំងមូលស្ថិតក្នុងសិរីល្អ*
*ផ្ដល់ឲ្យពួកបរិសុទ្ធនូវផ្ទះមួយដ៏បរិសុទ្ធ*
*ដូចជា អ័ដាម–អុនដៃ–អាម៉ាន ។*

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៥–១៦ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៥ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧–២០

## បុព្វកថា

នៅថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៨៣៨ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈបួនដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧–២០ ។ នៅក្នុងវិវរណៈទីមួយក្នុងចំណោមវិវរណៈទាំងនេះ ( គ. និង ស. ១១៧ ) ព្រះអម្ចាស់បានត្រាស់បង្គាប់ឲ្យ វិលលាម ម៉ាក្ស និង នូវល ខេ វីតនី ឲ្យចាត់ចែងធុរកិច្ចរបស់ពួកគេនៅក្នុងទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ហើយចូលរួមជាមួយពួកបរិសុទ្ធដែលកំពុងប្រមូលផ្ដុំគ្នានៅក្នុងក្រុងហ្វារវេសត៍ ។ ព្រះអម្ចាស់ក៏បានបញ្ជា អូលីវើរ គ្រែងគើរ ឲ្យទៅទីក្រុង ខឺតឡង់ ធ្វើជាអ្នកតំណាងនៃគណៈប្រធានទីមួយ ។ នៅក្នុងវិវរណៈទីពីរ ( គ. និង ស. ១១៨ ) ព្រះអម្ចាស់បានហៅសាវកថ្មីឲ្យបំពេញកន្លែងរបស់អ្នកដែលបានក្បត់សាសនា ហើយទ្រង់បានហៅសមាជិកទាំងអស់នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ឲ្យបម្រើនៅចក្រភពអង់គ្លេស ។ នៅក្នុងវិវរណៈទីបី និងទីបួន បានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩ និង ១២០ ព្រះអម្ចាស់បានបង្រៀនគោលលទ្ធិនៃដង្វាយមួយភាគក្នុងដប់ ហើយទ្រង់បានបើកសម្ដែងគោលការណ៍ណែនាំ ដើម្បីឲ្យអ្នកដឹកនាំសាសនាចក្រសម្រេចថាតើត្រូវប្រើមូលនិធិដង្វាយមួយភាគដប់ដូចម្ដេច ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:១–១១

*ព្រះអម្ចាស់បានត្រាស់បញ្ជាឲ្យ វិលលាម ម៉ាក្ស និង នូវល ខេ វិតនី ចាត់ចែងធុរកិច្ចរបស់ពួកគេជាបន្ទាន់ ហើយចេញដំណើរពីដែនដីខឺតឡង់*

នៅក្នុងផ្នែកទីមួយនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧ ព្រះអម្ចាស់បានមានព្រះបន្ទូលទៅកាន់ វិលលាម ម៉ាក្ស និង នូវល ខេ វិតនី ។ វិលលាម ម៉ាក្ស គឺជាប្រធានស្តេកនៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ។ គាត់ជាម្ចាស់អាជីវកម្មលក់សៀវភៅម្នាក់ ។ នូវល ខេ វិតនី គឺជាប៊ីស្សពនៅទីក្រុង ខឺតឡង់ ។ គាត់គឺជាម្ចាស់អាជីវកម្មដ៏ជោគជ័យម្នាក់ ហើយគាត់បានបរិច្ចាគទ្រព្យសម្បត្តិរបស់គាត់ជាច្រើនដល់សាសនាចក្រ ។




នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៨៣៨ ព្រះអម្ចាស់បានបញ្ជាឲ្យពួកបរិសុទ្ធប្រមូលផ្ដុំក្នុងក្រុងហ្វារវែស្ទ រដ្ឋ មិសសួរី និងនៅកន្លែងផ្សេងៗទៀត ( សូមមើល គ. និង ស. ១១៥:១៧–១៨ ) ។ នៅថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ១៨៣៨ ក្រុមមួយដែលគេស្គាល់ថា ជំរំខឺតឡង់ ដែលមានពួកបរិសុទ្ធជាង ៥០០ នាក់ មកពីតំបន់ខឺតឡង់ បានចាកចេញទៅរដ្ឋ មិសសួរី ( សូមមើល *Church History in the Fulness of Times Student Manual,*ការបោះពុម្ពលើកទីពីរ [Church Educational System manual, ឆ្នាំ ២០០៣],ទំព័រ ១៧៩) ។ ប្រធាន ម៉ាក្ស និង ប៊ីស្សព វិតនី នៅតែនៅក្នុងក្រុង ខឺតឡង់ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:១–៣ យើងអានថា ព្រះអម្ចាស់បានត្រាស់បញ្ជាឲ្យប្រធាន ម៉ាក្ស និងប៊ីស្សព វិតនី ចាត់ចែងធុរកិច្ចរបស់ពួកលោកជាបន្ទាន់ ហើយចាកចេញពីដែនដីខឺតឡង់ ។ ពួកលោកត្រូវធ្វើដំណើរមុនពេលដែលព្រះអម្ចាស់នឹងបង្អុរព្រិលមកក្នុងតំបន់នោះ ។ ឬនិយាយម៉្យាងទៀតថា ពួកលោកត្រូវធ្វើដំណើរក្នុងរយៈពេលប្រហែលបួនខែ ។

នៅពេលអ្នកអានព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:៤–៥ អ្នកនឹងឃើញថា បុរសទាំងនេះមានការព្រួយបារម្ភហួសហេតុពីទ្រព្យសម្បត្តិរបស់ពួកគេនៅក្នុងទីក្រុង ខឺតឡង់ ។

សូមកត់សម្គាល់សំណួរដូចតទៅនេះនៅក្នុង ខ ៤ ៖ « តើអ្វីទៅជារបស់របរដល់យើង ? » សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:៥–៨ ដោយរកមើលហេតុផលដែលព្រះអម្ចាស់មានបន្ទូលដូច្នេះ ។ ( វាអាចនឹងផ្ដល់អត្ថប្រយោជន៍ក្នុងការដឹងថាឃ្លា « ច្រកភ្នំទាំងឡាយនៅអូឡាហាស៊ីនេហា » សំដៅទៅលើតំបន់នៅជុំវិញ អ័ដាម–អុនដៃ–អាម៉ាន ក្នុងរដ្ឋ មិសសួរី ។

សូមស្រមៃថាអ្នកមានភេសជ្ជៈមួយថូដែលអ្នកចូលចិត្តបំផុត និងកែវទឹកទទេមួយ នៅចំពីមុខអ្នក ។ ហើយសូមស្រមៃថា នរណាម្នាក់បានចាក់ភេសជ្ជៈនោះមួយដំណក់តូចទៅក្នុងកែវទឹកអ្នក ។ តើអ្នកចង់បានមួយកែវពេញ ឬមួយដំណក់ ? ហេតុអ្វី ?

តើអ្នកគិតថា « លោភចង់បាន . . . មួយដំណក់ ហើយចោលសេចក្ដីដែលមានទម្ងន់ជាង » មានន័យយ៉ាងណា ? ( គ. និង ស. ១១៧:៨ ) ។ ការលោភមានន័យថា ជាការចង់បានរបស់អ្នកដទៃ ។ តើអត្ថប្រយោជន៍នៃ ការរក្សាទ្រព្យសម្បត្តិក្នុងទីក្រុង ខឺតឡង់ គ្រាន់តែមួយ « តំណក់ » ប្រៀបធៀបទៅនឹងអត្ថប្រយោជន៍នៃការគោរពតាមព្រះបញ្ញត្តិនៃការប្រមូលផ្ដុំក្នុងរដ្ឋមិសសួរី ។

១. សូមសង្ខេបនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ពីអ្វីដែលព្រះអម្ចាស់បានបង្រៀនបុរសទាំងនេះ អំពីដីធ្លីដែលពួកគេលោភចង់បាន ប្រៀបធៀបទៅនឹងព្រះចេស្ដារបស់ទ្រង់ ដើម្បីប្រទានពរឲ្យពួកគេ ។

ចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:៥–៨ យើងអាចរកឃើញគោលការណ៍មួយអំពីអ្វីដែលកើតឡើង នៅពេលយើងលោភចង់បានរបស់ខាងលោកិយ ។ វិធីមួយដើម្បីបង្ហាញគោលការណ៍នេះគឺ **លោភចង់បានរបស់ខាងលោកិយ អាចធ្វើឲ្យយើងមិនយកចិត្តទុកដាក់នឹងអ្វីដែលសំខាន់ជាងនោះ ។**

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្វីខ្លះដែលជា « ដំណក់ » ខាងសាច់ឈាមក្នុងជីវិតអ្នក ដែលធ្វើឲ្យអ្នកមិនយកចិត្តទុកដាក់នឹងបញ្ហាដំណឹងល្អដែលជាការណ៍សំខាន់ជាងនោះ ?

ខ. តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីផ្ដោតលើអ្វីដែលមានសារៈសំខាន់យ៉ាងអស់កល្បឲ្យកាន់តែច្រើន ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:១០ យើងអានថាព្រះអម្ចាស់បានហៅ វិលលាម ម៉ាក្ស ឲ្យបន្តបម្រើជាអ្នកដឹកនាំសាសនាចក្រ ពេលគាត់មកដល់ ក្រុងហ្វារ៉េស្វ រដ្ឋ មិសសួរី ។ ព្រះអម្ចាស់ក៏បានមានព្រះបន្ទូលថា បើប្រធាន ម៉ាក្ស « មានចិត្តស្មោះនឹងត្រួតរបស់បន្តិច » នោះគាត់នឹង « ត្រួតលើរបស់ជាច្រើនទៅទៀត » ( សូមមើល ម៉ាថាយ ២៥:២៣ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:១១ ដោយរកមើលការស្ដីបន្ទោសដែលព្រះអម្ចាស់ស្ដីឲ្យ នូវល ខេ វិតនី ។ ពួកនីកូឡាស ដែលបានលើកឡើងនៅក្នុងខគម្ពីរនេះ គឺជាសមាជិកនៃនិកាយសាសនាពីបុរាណមួយ ។ ពួកគេបាននិយាយថា ពួកគេគឺជាពួកគ្រីស្ទាន ប៉ុន្តែពួកគេបានវង្វេងចេញពីគោលការណ៍ទាំងឡាយនៃដំណឹងល្អ ទៅប្រព្រឹត្តិតាមលោកិយវិញ ។ ឧទាហរណ៍ ការថ្វាយបង្គំរបស់ពួករូមមានការប្រព្រឹត្តអំពើបាបខាងផ្លូវភេទ ។ ( សូមមើល Bible Dictionary លើពាក្យ Nicolaitans »; *Doctrine and Covenants Student Manual,* ការបោះពុម្ពលើកទី ២ [ Church Educational System manual, ឆ្នាំ ២០០១ ], ២៩០) ។

បើ នូវល ខេ វិតនី បានសម្រេចថាផ្ដោតលើទ្រព្យសម្បត្តិនៅរដ្ឋ ខឺតឡង់ ជាជាងការប្រមូលផ្ដុំជាមួយពួកបរិសុទ្ធនោះ តើទង្វើរបស់គាត់ស្រដៀងគ្នាទៅនឹងពួកនីកូឡាសយ៉ាងដូចម្ដេចដែរ ?

ដោយសារតែការព្រួយបារម្ភរបស់ពួកគេ ពីទ្រព្យសម្បត្តិសាសនាចក្រនៅរដ្ឋ អូហៃអូ ហើយដោយសារការបៀតបៀននៅរដ្ឋមិសសួរី នោះ វិលលាម ម៉ាក្ស និង នូវល ខេ វិតនី មិនអាចប្រមូលផ្ដុំជាមួយពួកបរិសុទ្ធនៅក្រុងហ្វារ៉េស្វបានទេ ។ ទោះយ៉ាងណា ពួកគេបានធ្វើតាមដំបូន្មានរបស់ព្រះអម្ចាស់ និងនៅតែស្មោះត្រង់ ហើយក្រោយមកបានប្រមូលផ្ដុំជាមួយពួកបរិសុទ្ធនៅទីក្រុង ណៅវូ រដ្ឋ អិលលីណោយ ជាកន្លែងដែល វិលលាម ម៉ាក្ស បានបម្រើជាប្រធានស្តេក ហើយ នូវល ខេ វិតនី បានបម្រើជាប៊ីស្សព ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:១២–១៦

*ព្រះអម្ចាស់បញ្ជាឲ្យ អូលីវើរ គ្រែងគើរ ធ្វើជាតំណាងឲ្យគណៈប្រធានទីមួយក្នុងការចាត់ចែងអាជីវកម្មនៅរដ្ឋ ខឺតឡង់*

សូមគិតអំពីការហៅបម្រើក្នុងសាសនាចក្រ និងការចាត់តាំងដែលអ្នកអាចទទួលបាន ។ ការហៅបម្រើ និងការចាត់តាំងទាំងនេះ អាចរួមបញ្ចូលការបម្រើក្នុងកូរ៉ុម ឬគណៈប្រធានថ្នាក់ ការឡើងនិយាយនៅក្នុងការប្រជុំសាក្រាម៉ង់ ការបម្រើជាគ្រូបង្រៀនតាមផ្ទះ ការធ្វើមិត្តជាមួយនរណាម្នាក់ ឬការបម្រើបេសកកម្មពេញម៉ោង ។ តើការបម្រើទាំងនេះ តម្រូវឲ្យមានការលះបង់ប្រភេទណា ?

ព្រះអម្ចាស់បានបញ្ជាឲ្យបុរសម្នាក់ដែលមានឈ្មោះថា អូលីវើរ គ្រែងគើ ឲ្យចាកចេញពីក្រុងហ្វារ៉ែស្ទ រដ្ឋ មិសសួរី ហើយត្រឡប់ទៅទីក្រុងខឺតឡង់ រដ្ឋ អូហៃអូ ដើម្បី « សម្រេចក្ដីប្រោសលោះ នៃគណៈប្រធានទីមួយក្នុងសាសនាចក្ររបស់យើង » ( គ. និង ស. ១១៧:១៣ ) ។ ការចាត់តាំងនេះរួមមាន ការលក់ដីរបស់សាសនាចក្រ និងការចាត់ចែងធុរៈរបស់ យ៉ូសែប ស្ម៊ីធ ។ កិច្ចការនេះតម្រូវឲ្យ អូលីវើរ ដែលស្ទើរតែពិការភ្នែកនោះ ធ្វើការលះបង់ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧:១២–១៥ ដោយរកមើលពរជ័យដែលព្រះអម្ចាស់បានមានបន្ទូលថា អូលីវើរ នឹងទទួលបាន បើគាត់បំពេញតាមការចាត់តាំងនេះ ។


យុវជនដែលកាន់បព្វជិតភាពអើរ៉ុន អាចបម្រើជាគ្រូបង្រៀនតាមផ្ទះ ។

នៅក្នុង ខ ១៣ សូមកត់សម្គាល់ព្រះបន្ទូលព្រះអម្ចាស់ថា « ការបូជារបស់គាត់ នឹងបានរាប់ថាពិសិដ្ឋដល់យើង ជាងការតម្លើងរបស់គាត់ទៅទៀត » ។ ការណ៍នេះបញ្ជាក់ថា ព្រះអម្ចាស់មានព្រះទ័យយកចិត្តទុកដាក់លើការលះបង់របស់ អូលីវើរ ជាជាងប្រាក់កាសដែល អូលីវើរ នឹងទទួលបានពីការចាត់តាំងនេះទៅទៀត ។ ចេញពីខគម្ពីរនេះ យើងបានរៀនពីគោលការណ៍ដូចតទៅ ៖ **ការលះបង់ដែលយើងធ្វើក្នុងការបម្រើព្រះអម្ចាស់ គឺពិសិដ្ឋដល់ទ្រង់** ។ សូមគូសចំណាំពាក្យនៅក្នុង ខ ១៣ ដែលបង្រៀនពីគោលការណ៍នេះ ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីបានជាវាមានសារៈសំខាន់ ក្នុងការធ្វើអ្វីៗគ្រប់យ៉ាងអស់ពីលទ្ធភាពអ្នក ដើម្បីបំពេញការចាត់តាំង ឬការហៅបម្រើក្នុងសាសនាចក្រ ?

ខ. តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលអ្នកគិតថាការលះបង់ដែលអ្នកបានធ្វើ ក្នុងការបម្រើព្រះអម្ចាស់ ពិសិដ្ឋដល់ទ្រង់នោះ ?

អូលីវើរ គ្រែងគើ បានទទួលមរណភាពនៅទីក្រុង ខឺតឡង់ នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៨៤១ ។ នៅពេលនោះ គាត់នៅតែជាតំណាងគណៈប្រធានទីមួយនៅក្នុងធុរៈរបស់ពួកលោក ហើយគាត់ក៏ត្រូវបានហៅឲ្យធ្វើជាអធិបតីលើសាសនាចក្រនៅទីក្រុង ខឺតឡង់ ។ ទោះជាគាត់មិនជោគជ័យទាំងស្រុងក្នុងការចាត់ចែងធុរៈរបស់សាសនាចក្រក្ដី ក៏គាត់បានធ្វើការដើម្បីការពារភាពថ្លៃថ្នូរ និងឈ្មោះល្អរបស់សាសនាចក្រ ។ គាត់ស្មោះត្រង់ចំពោះព្រះអម្ចាស់ និងចំពោះព្យាការី យ៉ូសែប ស្ម៊ីធ ។

នៅក្នុងលិខិតផ្ដាំផ្ញើ យ៉ូសែប ស្ម៊ីធ និងសមាជិកនៃគណៈប្រធានទីមួយផ្សេងទៀត បានរៀបរាប់ពី អូលីវើរ គ្រែងគើ ថា « ជាបុរសសុចរិត មានគុណធម៌ និងមានសីលធម៌ខ្ពស់បំផុត ហើយ . . . ជាបុរសនៃព្រះ » ( នៅក្នុង *History of the Church,* ៣:៣៥០ ) ។ ប្រធាន ប៊យដ៍ ឃេ ផាកកឺ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ ៖



« តើ អូលីវើរ គ្រែងគើ បានធ្វើអ្វី បានជាឈ្មោះគាត់គួរត្រូវបានរំឭកយ៉ាងពិសិដ្ឋ ? គាត់មិនបានធ្វើអ្វីច្រើនទេ ។ វាមិនមែនជាអ្វីដែលគាត់បានធ្វើនោះទេ ប៉ុន្តែគឺខ្លួនគាត់ផ្ទាល់ទេតើ ។. . .

« ព្រះអម្ចាស់មិនបានរំពឹងឲ្យ អូលីវើ មានភាពឥតខ្ចោះនោះទេ ប្រហែលជាមិនរំពឹងឲ្យគាត់ជោគជ័យផងដែរ ។. . .

« យើងមិនអាចរំពឹងដើម្បីមានជោគជ័យជានិច្ចនោះទេ ប៉ុន្តែយើងគួរតែព្យាយាមឲ្យអស់ពីសមត្ថភាពដែលយើងអាចធ្វើបាន » (The Least of These » *Ensign* ឬ *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៤ ទំព័រ ៨៦ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៨

*ព្រះអម្ចាស់បានតែងតាំងសាវកថ្មី ហើយហៅសាវកទាំងអស់ឲ្យបម្រើបេសកកម្ម*

នៅថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៨៣៨ ព្រះអម្ចាស់បានហៅសាវកថ្មីឲ្យជំនួសអ្នកដែលបានក្បត់សាសនា ។ ព្រះអម្ចាស់បានហៅសាវកដប់ពីរនាក់ឲ្យប្រកាសដំណឹងល្អ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៨:៤–៥ ដោយរកមើលកន្លែងដែលព្រះអម្ចាស់បានបញ្ជាឲ្យសាវកដប់ពីរនាក់ទៅប្រកាសដំណឹងល្អ ។ ឃ្លា « លើទឹកដ៏ធំធេង » សំដៅលើការធ្វើដំណើរឆ្លងកាត់មហាសមុទ្រអាត្លង់ទិច ទៅកាន់ចក្រភពអង់គ្លេស ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៨:៥ សូមកត់សម្គាល់កន្លែងដែលពួកគេត្រូវប្រមូលផ្ដុំ មុនពេលចេញទៅបម្រើបេសកកម្ម ។ សូមកត់សម្គាល់ពីថ្ងៃដែលព្រះអម្ចាស់ បានមានបន្ទូលថាពួកគេត្រូវប្រមូលផ្ដុំនៅកន្លែងនោះ ។

ជាច្រើនខែក្រោយពីវិវរណៈនេះ ការបៀតបៀនបានកើនឡើងនៅរដ្ឋ មិសសួរី ។ នៅទីបំផុត ពួកបរិសុទ្ធត្រូវបានបណ្ដេញចេញពីរដ្ឋនោះ ។ ស្ថានការណ៍នេះបានបង្កគ្រោះថ្នាក់ដល់ពួកបរិសុទ្ធ ក្នុងការបំពេញព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដើម្បីទៅជួបជុំគ្នានៅក្រុងហ្វារវែស្ទ ។ ប្រជាជនរដ្ឋ មិសសួរី បានអួតអាងយ៉ាងបើកចំហរថា ពួកគេនឹងទប់ស្កាត់មិនឲ្យវិវរណៈរបស់ព្រះអម្ចាស់បានសម្រេច ។ ប៉ុន្តែ ពួកដប់ពីរនាក់បានប្ដេជ្ញាថាត្រូវធ្វើតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ។

នៅព្រឹកថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៨៣៩ សមាជិកនៃកូរ៉ុមនៃសាវកដប់ពីរនាក់បានប្រមូលផ្ដុំគ្នានៅទីធ្លាព្រះវិហារបរិសុទ្ធ ។ ( សមាជិកកូរ៉ុមស្មោះត្រង់ទាំងអស់មិនអាចមកជួបជុំនៅទីនោះបានទេ ។ អ្នកខ្លះត្រូវបានចាប់ដាក់គុក ) ។ ពួកគេចាប់ផ្ដើមសង់គ្រឹះនៃព្រះវិហារបរិសុទ្ធ ( សូមមើល គ. និង ស. ១១៥:១១ ) ដោយដាក់ថ្មដ៏ធំមួយដុំនៅជិតជ្រុងភាគអាគ្នេយ៍នៃដីសម្រាប់សង់ ។ ពួកគេបានតែងតាំងពួកសាវក ដើម្បីជំនួសកន្លែងទំនេររបស់កូរ៉ុមនៃពួកដប់ពីរនាក់ ។ ហើយពួកគេបានចាកចេញដោយមិនឲ្យដឹងដល់ពួកសត្រូវរបស់ពួកគេ ។ ( សម្រាប់ដំណើររឿងពេញលេញបន្ថែមទៀតអំពីបទពិសោធន៍នេះ សូមមើល *Teachings of Presidents of the Church: Wilford Woodruff* [ឆ្នាំ ២០០៤ ], ទំព័រ ១៣៩–៤១) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩–២០

*ព្រះអម្ចាស់បានបើកសម្ដែងពីក្រឹត្យវិន័យ នៃដង្វាយមួយភាគក្នុងដប់*



គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩ និង ១២០ មានវិវរណៈពីរស្ដីពីក្រឹត្យវិន័យនៃដង្វាយមួយភាគក្នុងដប់ ។ ក្នុងវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២០ ព្រះអម្ចាស់បានត្រាស់បញ្ជាថា ក្រុមប្រឹក្សាមួយនឹងត្រូវរៀបចំឡើង ដើម្បីដឹកនាំការប្រើប្រាស់នៃមូលនិធិដង្វាយមួយភាគក្នុងដប់របស់សាសនាចក្រ ។ សព្វថ្ងៃនេះ វួដ ឬសាខានីមួយៗបញ្ជូនមូលនិធិដង្វាយមួយភាគដប់របស់សមាជិកទៅកាន់ទីស្នាក់ការកណ្ដាលរបស់សាសនាចក្រ ដែលហៅថា ក្រុមប្រឹក្សារៀបចំដង្វាយមួយភាគក្នុងដប់ ។ អ្នកដឹកនាំក្នុងតំបន់ មិនសម្រេចថាមូលនិធិដង្វាយមួយភាគក្នុងដប់ត្រូវបានប្រើដោយរបៀបណានោះទេ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩:១–៤ ។ វាអាចមានអត្ថប្រយោជន៍ក្នុងការដឹងថា នៅក្នុង ខ ៤ ពាក្យ *ធនធាន* មានន័យថា ចំណូល ។



ប្រធាន ហាវើដ ដបុលយូ ហ៊ីនធើរ បានពន្យល់ ៖ « ក្រឹត្យវិន័យនោះបានចែងថា ‹ មួយភាគដប់នៃធនធានរបស់គេទាំងអស់ › ។ ធនធានមានន័យថា ប្រាក់ចំណេញ ប្រាក់សំណង ប្រាក់តម្លើង ។ វាគឺជាប្រាក់ខែរបស់និយោជិតមួយរូប ជាប្រាក់ចំណេញពីការធ្វើអាជីវកម្ម ជាប្រាក់កំណើនរបស់បុគ្គលម្នាក់ដែលរីកចម្រើន ឬ រកបាន ឬ ជាប្រាក់ចំណូលរបស់មនុស្សម្នាក់ទោះមកពីប្រភពណាក៏ដោយ ។ ព្រះអម្ចាស់បានមានបន្ទូលថា វាជាក្រឹត្យវិន័យដែលនៅ ‹ អចិន្ត្រៃយ › ដូចដែលវាមានពីបុរាណកាលផងដែរ » ( នៅក្នុង Conference Report, ខែ មេសា ឆ្នាំ ១៩៦៤, ទំព័រ ៣៥ ) ។

### *ការវាយតម្លៃជីវិតរបស់អ្នក*

នៅពេលអ្នកចំណាយពេល ដើម្បីវាយតម្លៃដោយស្មោះត្រង់ ថាតើអ្នកកំពុងរស់នៅតាមគោលការណ៍ជាក់លាក់មួយបានល្អប៉ុណ្ណា នោះអ្នកផ្ដល់ឱកាសដល់ព្រះវិញ្ញាណបរិសុទ្ធឲ្យជួយអ្នកដឹងថាតើអ្នកពូកែខាងអ្វី និងរបៀបដែលអ្នកអាចកែលម្អ ។ នៅពេលដែលអ្នកពិចារណាវិវរណៈទាំងឡាយ ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៩ និង ១២០ សូមសួរខ្លួនឯងថាតើអ្នកកំពុងរស់នៅតាមក្រឹត្យវិន័យបានល្អដល់កម្រិតណា ។

**នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាននៃសាសនាចក្រ សូមរកមើលពរជ័យដែលអ្នកអាចទទួលបានពេលអ្នកបង់ដង្វាយមួយភាគក្នុងដប់ ៖**



ប្រធាន ហារ៉ូល ប៊ី លី បានប្រៀបធៀបការសន្យារបស់ព្រះទៅនឹងការ « បើក . . . ទ្វារស្ថានសួគ៌ » ដើម្បីប្រទានពរដល់អ្នកបង់ដង្វាយ ( សូមមើល ម៉ាឡាគី ៣:៨–១១)ការបើកទ្វារស្ថានសួគ៌ មានន័យថាជាវិវរណៈមកពីព្រះដល់អ្នកដែលពេញចិត្តនឹងធ្វើការលះបង់ » ( « The Way to Eternal Life » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៧១ ទំព័រ ១៦ ) ។



ប្រធាន ហ៊ីប៊ើរ ចេ គ្រាន្ត បានមានប្រសាសន៍ពីពរជ័យខាងវិញ្ញាណដែលកើតមានដល់យើង នៅពេលយើងបង់ដង្វាយមួយភាគក្នុងដប់ ៖ « ភាពចម្រុងចម្រើនកើតមានដល់អ្នកដែលគោរពតាមក្រឹត្យវិន័យនៃដង្វាយមួយភាគក្នុងដប់ ។ « នៅពេលខ្ញុំនិយាយអំពីភាពចម្រុងចម្រើន ខ្ញុំមិនបានគិតអំពីវាថាទាក់ទងនឹងប្រាក់កាសតែម្យ៉ាងនោះទេ ។. . . ប៉ុន្តែអ្វីដែលខ្ញុំរាប់ថាជាចម្រុងចម្រើនពិតប្រាកដ ជារឿងមួយក្នុងចំណោមអ្វីៗផ្សេងទៀតទាំងអស់ដែលមានតម្លៃខ្លាំងចំពោះការរស់នៅរបស់បុរស និង ស្ត្រីគ្រប់គ្នា វាគឺជាការធំធាត់ខាងចំណេះដឹងអំពីព្រះ និង ក្នុងទីបន្ទាល់ និង អំណាចដើម្បីរស់នៅតាមដំណឹងល្អ និង ដើម្បីបំផុសគំនិតរបស់គ្រួសារយើងឲ្យធ្វើអ្វីដូចគ្នា ។ នោះគឺជាប្រភេទនៃការចម្រុងចម្រើនយ៉ាងពិតប្រាកដមួយ » ( *Teachings of Presidents of the Church: Heber J. Grant* [ ឆ្នាំ ២០០២ ] ទំព័រ ១២៤) ។

ប្រធាន គ្រាន្ត ក៏បានបង្រៀនផងដែរពីវិធីម្យ៉ាងដែលយើងអាចបានពរផ្នែកហិរញ្ញវត្ថុ នៅពេលយើងបង់ដង្វាយមួយភាគក្នុងដប់ ៖ « បើយើងបរិច្ចាគអ្វីដែលយើងមាន បើយើងបង់ដង្វាយមួយភាគក្នុងដប់ មិនថាវាតិចតួចប៉ុណ្ណានោះទេ . . . ព្រះដែលជាព្រះវរបិតាសួគ៌របស់យើង នឹងពង្រីកប្រាំបួនដុល្លារដែលនៅសល់ ឬកាក់សែសិបប្រាំបួនសេនដែលនៅសល់ពីហាសិបសេន ហើយអ្នកនឹងមានប្រាជ្ញាគ្រប់គ្រាន់ ក្នុងការប្រើវាឲ្យមានប្រយោជន៍ ដូច្នេះអ្នកនឹងមិនបាត់បង់អ្វីសោះឡើយក្នុងការស្មោះត្រង់ ( *Teachings: Heber J. Grant,* ទំព័រ ១២៤–២៥) ។

**៤. សូមឆ្លើយសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកបានទទួលពរជ័យអ្វីខ្លះ មកពីការគោរពតាមក្រឹត្យវិន័យនៃដង្វាយមួយភាគក្នុងដប់ ?**

**៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖**

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១១៧–២០ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៦ ៖ ថ្ងៃ ទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១–១០; ១២២

## សេចក្ដីផ្ដើម

គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១–២៣ មាននូវផ្នែកនៃសំបុត្រដែលបានជ្រើសរើស ដែលយ៉ូសែប ស្ម៊ីធ បានសរសេរទៅកាន់សាសនាចក្រ ចុះថ្ងៃទី ២០ ខែ មិនា ឆ្នាំ ១៨៣៩ ។ យ៉ូសែប ស្ម៊ីធ បានសរសេរសំបុត្រនេះ ខណៈដែលលោក និងដៃគូពីរបីនាក់របស់លោកត្រូវបានជាប់ឃុំឃាំងនៅក្នុងគុកលិបើធី ។ នៅក្នុងសំបុត្រនោះ យ៉ូសែបបានដាក់បញ្ចូលនូវការអធិស្ឋានមួយចំនួនរបស់លោកសម្រាប់ពួកបរិសុទ្ធដែលកំពុងរងទុក្ខ ដោយសារតែសកម្មភាពនៃមារសត្រូវរបស់ពួកគេ ។ លោកក៏បានដាក់បញ្ចូលនូវចម្លើយដែលលោកបានទទួលសម្រាប់ការអធិស្ឋានទាំងនោះផងដែរ ។ ( សូមមើល *History of the Church* ៣:២៨៩–៣០៥ ) ។ អ្នកនឹងសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១–២៣ នៅក្នុងមេរៀនប្រចាំថ្ងៃទាំងបួនថ្ងៃ នៅក្នុងសប្ដាហ៍នេះ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១–៦

*យ៉ូសែប ស្ម៊ីធ អធិស្ឋានសម្រាប់ពួកបរិសុទ្ធដែលបានរងទុក្ខ*

សូមនឹកស្រមៃថា មិត្តម្នាក់នឹងឆ្លងកាត់បទពិសោធន៍មួយដ៏លំបាក ។ មិត្តនោះប្រាប់អ្នកថា នាងមិនយល់ថាហេតុអ្វីបានជានាងជួបទុក្ខលំបាកបែបនេះ ហើយថានាងមានអារម្មណ៍ថាព្រះបានបោះបង់នាងចោល ។ តើអ្នកនឹងប្រាប់អ្វីខ្លះទៅមិត្តរបស់អ្នក ?

តើអ្នកនឹងធ្វើអ្វីខ្លះ ប្រសិនបើអ្នកគឺជាមនុស្សម្នាក់ដែលបានជួបទុក្ខលំបាកនោះ ?

នៅពេលអ្នកសិក្សាពីការអធិស្ឋានរបស់ព្យាការីយ៉ូសែប ស្ម៊ីធ នៅក្នុងគុកលិបើធី និងបន្ទូលទូន្មានរបស់ព្រះអម្ចាស់ចំពោះលោក សូមស្វែងរកគោលលទ្ធិ និង គោលការណ៍នានាដែលអាចជួយអ្នកឲ្យស៊ូទ្រាំការសាកល្បង និង ទុក្ខវេទនាដោយសេចក្ដីជំនឿ ។



នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៨៣៨ ចច ហ៊ីងខល ជាសមាជិកម្នាក់របស់សាសនាចក្រ និងជាវរសេនីយឯកម្នាក់នៅក្នុងជីវពលរដ្ឋមិសសួរី បានក្បត់នឹងយ៉ូសែប ស្ម៊ីធ ។ ហ៊ីងខល បានប្រាប់យ៉ូសែបថា ក្រុមមនុស្សដែលវាយធ្វើបាបដល់ពួកបរិសុទ្ធនៅក្នុងទីក្រុងហ្វារវែស្ទ រដ្ឋមិសសួរី ចង់ជួបសម្ភាសន៍ដោយសន្តិភាព ដើម្បីដោះស្រាយការមិនចុះសម្រុងនឹងគ្នា ។ នៅពេលយ៉ូសែប និង ថ្នាក់ដឹកនាំផ្សេងទៀតរបស់សាសនាចក្របានមកដល់សម្រាប់បទសម្ភាសន៍នោះ មានកងជីវពលបានចាប់ពួកលោកដោយបង្ខិតបង្ខំដូចជាអ្នកទោសសង្គ្រាម ។ នៅខែបន្ទាប់នោះ យ៉ូសែប ស្ម៊ីធ និងពួកសហការីរបស់លោកត្រូវបានគេធ្វើទុក្ខទោស ហើយជេរប្រមាថ ខណៈដែលមារសត្រូវរបស់ពួកលោកបានយកពួកលោកទៅដាក់គុកជាច្រើននៅក្នុងតំបន់នោះ ហើយបាននាំពួកលោកទៅមុខចៅក្រមជាច្រើន ។

ខណៈដែលព្យាការីយ៉ូសែប ស្ម៊ីធ អែលឌើរ ប៉ាលី ភី ប្រាត្ត និង ថ្នាក់ដឹកនាំផ្សេងទៀតរបស់សាសនាចក្រត្រូវបានឃុំខ្លួនយ៉ាងអយុត្តិធម៌ក្នុងគុកមួយនៅរីចម៉ុន្ត រដ្ឋមិសសួរី ពួកលោកបានឮពួកអ្នកយាមគុកនិយាយភាសាថោកទាប ដូចជាទង្វើអាក្រក់នៃការឆក់ប្លន់ ការចាប់រំលោភ និង ការកាប់សម្លាប់ដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ នៅក្នុងការពិពណ៌នារបស់លោកអំពីបទពិសោធន៍នោះ អែលឌើរ ប្រាត្ត បានសរសេរ ៖



« នៅយប់ដ៏ធុញទ្រាន់មួយនោះ យើងបានទម្រេតខ្លួន ដូចជាដេកលក់ រហូតដល់យប់ជ្រៅ តែត្រចៀក និងដួងចិត្តយើង ឈឺចាប់ ពេលយើងស្ដាប់ឮរាប់ម៉ោងនូវការចំអក ការស្បថអាក្រក់ៗ ការប្រមាថគួរឲ្យខ្លាច និងភាសាស្មោកគ្រោករបស់ពួកអ្នកយាម ។. . .

« ខ្ញុំបានស្ដាប់ឮរហូតដល់ខ្ញុំខ្ញើមឆ្អើម តក់ស្លុត រន្ធត់ និង ពេញដោយវិញ្ញាណដ៏ឈឺចាប់ ដែលវាពិបាកសម្រាប់ខ្ញុំដើម្បីទប់ខ្លួនកុំឲ្យឈរឡើង ហើយស្ដីបន្ទោសដល់ពួកអ្នកយាមនោះ ប៉ុន្តែ ខ្ញុំពុំនិយាយអ្វីទាំងអស់ទៅយ៉ូសែប . . . ទោះបីខ្ញុំដេកនៅជិតនឹងលោក ហើយបានដឹងថា លោកពុំទាន់ដេកក្តី ។ រំពេចនោះ លោកបានក្រោកឈរឡើង ហើយនិយាយដូចជាសំឡេងផ្គរលាន់ ឬដូចជាតោគ្រហឹម និយាយយ៉ាងច្បាស់ដែលខ្ញុំអាចនៅចាំបានថា ៖

« ‹ *ស្ងាត់ទៅ ! មនុស្សអាក្រក់ក្នុងរណ្ដៅដ៏អប្រិយអើយ ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ខ្ញុំស្ដីបន្ទោសដល់អ្នក ហើយបញ្ជាឲ្យអ្នកស្ងាត់ភ្លាម ដ្បិតខ្ញុំនឹងមិនរស់នៅមួយនាទីទៀត ហើយស្ដាប់ឮភាសាដូច្នេះឡើយ ។ ឈប់និយាយភ្លាម បើមិនដូច្នោះអ្នក ឬខ្ញុំនឹងស្លាប់ឥឡូវនេះ !* ›

« លោកបានឈប់វាចា ។ លោកបានឈរយ៉ាងមុតមាំនៅក្នុងមហិទ្ធានុភាពខ្លាំងណាស់ ។ ត្រូវគេដាក់ច្រវ៉ាក់ ហើយដោយគ្មានអាវុធ តែលោកស្ងប់ស្ងាត់ មិនក្រញេងក្រញាង ហើយថ្លៃថ្នូរប្រៀបដូចជាទេវតាមួយអង្គ នោះលោកបានមើលទៅអ្នកយាមដែលឱបជង្គង់រួញខ្លាចនៅគៀនជញ្ជាំង ឬក្រាបចុះនឹងជើងលោក បានសុំទោសដល់លោក ហើយនៅស្ងៀមរហូតដល់វេនផ្លាស់ប្ដូរអ្នកយាម ។

« ខ្ញុំធ្លាប់ឃើញពួករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពាក់រ៉ូបរបស់ចៅក្រម . . . ខណៈដែលជីវិតត្រូវបានពន្យារពេល នៅក្នុងតុលាការប្រទេសអង់គ្លេស ខ្ញុំធ្លាប់ឃើញសមាជិកមួយនៅក្នុងកិច្ចប្រជុំដ៏ឱឡារិកចេញច្បាប់សម្រាប់ប្រទេសជាតិ ខ្ញុំបានធ្លាប់ព្យាយាមគិតអំពីពួកស្ដេច ពួករាជវាំង បល្ល័ង្ក និង មកុដ និងអំពីពួកអធិរាជដែលបានប្រមូលផ្ដុំគ្នាដើម្បីសម្រេចពីជោគវាសនានៃនគរនានា ប៉ុន្តែសេចក្ដីថ្លៃថ្នូរ និង អានុភាពដ៏អស្ចារ្យដែលខ្ញុំធ្លាប់ឃើញគឺមាន*តែម្ដងគត់*គឺនៅពេលលោកឈរទាំងជាប់ច្រវ៉ាក់នៅពាក់កណ្ដាលអាធ្រាត្រក្នុងគុកមួយនៅភូមិដ៏ងងឹតនៃរដ្ឋមិសសួរី » ( *Autobiography of Parley P. Pratt* ed. Parley P. Pratt Jr. [ ឆ្នាំ ១៩៣៨ ] ទំព័រ ២១០–១១ ) ។

ខណៈនៅរង់ចាំវិនិច្ឆ័យកិច្ចដោយសារតែការចោទប្រកាន់ខុស ហើយដោយគ្មានវិនិច្ឆ័យកិច្ចត្រឹមត្រូវ យ៉ូសែប ស្ម៊ីធ និងថ្នាក់ដឹកនាំផ្សេងទៀតរបស់សាសនាចក្រត្រូវបានគេចាប់ខ្លួនដាក់គុកនៅក្នុងលិបើធី រដ្ឋមិសសួរី នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ។ ( សូមមើល *ប្រវត្តិនៃសាសនាចក្រ* ៣:១៨៨–៨៩, ២១៥ ) ។

នៅអំឡុងបួនខែបន្ទាប់មកទៀត ព្យាការី បងប្រុសលោក ហៃរុម អាឡិចសាន់ឌើរ ម៉ាក់រ៉ា ឡៃម៉ាន វ៉ៃត និង ខាលិប បលវិន ត្រូវបានគេយកទៅដាក់នៅជាន់ក្រោមនៃគុកលិបើធី នៅក្នុងរដូវរងារយ៉ាងល្វីងជូចត់ ។ ស៊ីឌនី រិកដុន ក៏បាននៅជាមួយនឹងពួកលោកមួយរយៈដែរ ប៉ុន្តែលោកត្រូវបានគេដោះលែងនៅដើមខែកុម្ភៈ ។ គុកក្រោមដីនោះមានទំហំប្រហែលជា ៤.៣ ម៉ែត្រគុណនឹង ៤.៣ ម៉ែត្រ ) ។ ពិដានមានកម្ពស់ចន្លោះពី ១.៨ ម៉ែត្រ និង ២ម៉ែត្រ ។ មានបង្អួចតូចពីរដែលផ្ដល់ពន្លឺព្រឹមៗ ហើយនៅពីខាងក្រៅបង្អួចចទាំងនេះ មានមនុស្សជាច្រើនបានចំអក ហើយប្រមាថដល់ពួកអ្នកជាប់ឃុំ ។ ពួកអ្នកជាប់ឃុំទាំងនោះបានដេកនៅលើចំបើងដែលកខ្វក់ ហើយមានពេលខ្លះយ៉ូសែបគ្មានភួយដណ្ដប់ឡើយ ។ ម្ដងម្កាលអាហារត្រូវបានគេដាក់ថ្នាំបំពុល ហើយពេលខ្លះទៀតវាគួរឲ្យខ្ពើមរអើមខ្លាំងណាស់ ប៉ុន្តែពួកលោកទទួលទានដោយសារតែភាពស្រេកឃ្លាន ។ ពួកលោកកម្រនឹងឲ្យមានអ្នកមកសួរសុខទុក្ខណាស់ ហើយមានទុក្ខជាទម្ងន់ដោយស្ដាប់ឮពីការរងទុក្ខរបស់ពួកបរិសុទ្ធដែលត្រូវបានបណ្ដេញចេញពីរដ្ឋមិសសួរីនៅពាក់កណ្ដាលរដូវរងារ ។



« សេចក្ដីថ្លៃថ្នូរ និង អានុភាពដ៏អស្ចារ្យ . . . ឈរទាំងជាប់ច្រវ៉ាក់ » ។



គុកលិបើធី រដ្ឋមិសសួរី

ខ្លឹមសារសំបុត្រនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១–២៣ មានបញ្ចូលនូវការអធិស្ឋានមួយចំនួនរបស់យ៉ូសែប ស្ម៊ីធ ទៅកាន់ព្រះអម្ចាស់ ។ ប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពរបស់ព្យាការី តើអ្នកនឹងអធិស្ឋានសុំអ្វីខ្លះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១–៦ ហើយកត់សម្គាល់ពីអ្វីដែលព្យាការីបានអធិស្ឋានសុំ រួមបញ្ចូលទាំងសំណួរដែលលោកបានសួរផងដែរ ។ អ្នកអាចនឹងចង់គូសចំណាំឃ្លាទាំងឡាយដែលមានអត្ថន័យចំពោះអ្នក ។ ( នៅពេលអ្នកអាន ខ ១ និង ៤ វាជាការល្អដើម្បីស្គាល់ថា ព្រះពន្លាគឺជាអគារមួយ ឬគ្រោងមួយទៀតដែលផ្ដល់ទីជម្រក ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៧–១០; ១២២

*ព្រះអម្ចាស់លួងលោមយ៉ូសែប ស៊្មីធ*

ចម្លើយរបស់ព្រះអម្ចាស់ចំពោះការអធិស្ឋានរបស់យ៉ូសែប ស៊្មីធ គឺមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៧–៤៦ និង ១២២:១–៩ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៧–៩ ដោយស្វែងរកសេចក្ដីពិតដែលបានជួយយ៉ូសែប និងពួកដៃគូរបស់លោកនៅក្នុងគុកលិប៊ើធី ។



១. នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៧–៩ សូមបំពេញកិច្ចការខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមសរសេរយ៉ាងហោចណាស់ឲ្យបានសេចក្ដីពិតចំនួនពីរដែលអ្នករកឃើញនៅក្នុងខគម្ពីរទាំងនេះ ។ សូមពន្យល់ពីរបៀបដែលគោលការណ៍ ឬគោលលទ្ធិទាំងនេះប្រហែលជាបានជួយដល់យ៉ូសែប និង ពួកដៃគូរបស់លោក ។

ខ. សូមឆ្លើយសំណួរដូចតទៅនេះ ៖ តើអ្នកគិតថាអ្វីទៅជាភាពខុសប្លែកគ្នារវាងការស៊ូទ្រាំនឹងការសាកល្បង និងការស៊ូទ្រាំនឹងការសាកល្បងបានល្អ ? ព្រះអម្ចាស់បានមានបន្ទូលថា សេចក្ដីទំនាស់ និង សេចក្ដីលំបាករបស់យ៉ូសែប ស៊្មីធ នោះ « គ្រាន់តែមួយភ្លែតប៉ុណ្ណោះទេ » ( គ. និង ស. ១២១:៧ ) ។ តើអ្នកគិតថា វាមានន័យយ៉ាងណា ? តើទស្សននេះជួយយើងឲ្យស៊ូទ្រាំនឹងការសាកល្បងរបស់យើងឲ្យល្អតាមរបៀបណា ?

គ. សូមសរសេរពាក្យពីរ ឬបីប្រយោគអំពីមនុស្សម្នាក់ដែលអ្នកស្គាល់ ហើយមានគំរូនៃការស៊ូទ្រាំនឹងការសាកល្បងបានល្អ ។

២. សូមគិតឡើងវិញពីស្ថានភាពដែលបានពិពណ៌នានៅដើមមេរៀននេះ—មិត្តម្នាក់ដែលកំពុងរងទុក្ខ ហើយគិតថាព្រះបានបោះបង់នាងចោល ។ សូមសរសេរសំបុត្រលួងលោមចិត្តមួយច្បាប់ទៅកាន់មិត្តម្នាក់នេះ ដោយប្រើសេចក្ដីពិតដែលអ្នករកឃើញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៧–៩ ។ សូមពន្យល់ពីរបៀបដែលសេចក្ដីពិតទាំងនេះអាចជួយដល់នាង ។ អ្នកអាចនឹងចង់ដកស្រង់ផ្នែកមួយចំនួន ឬផ្នែកទាំងស្រុងនៃ ខ ៩ ដាក់នៅក្នុងសំបុត្រនេះ ។

សូមសញ្ជឹងគិតពីកម្លាំងដែលអ្នកទទួលបានពីចំណេះដឹងរបស់អ្នកថា នៅពេលយើងអំពាវនាវដល់ព្រះអម្ចាស់នៅក្នុងគ្រានៃសេចក្ដីទំនាស់ និង សេចក្ដីទុក្ខលំបាក យើងអាចទទួលបានសេចក្ដីសុខសាន្តរបស់ទ្រង់ ហើយថាប្រសិនបើយើងស៊ូទ្រាំនឹងការសាកល្បងបានល្អនៅក្នុងជីវិតរមែងស្លាប់ ព្រះនឹងប្រទានពរដល់យើងនៅពេលនេះ និងនៅភាពអស់កល្បជានិច្ច ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២២ យើងអានពាក្យទូន្មាន និង ការលួងលោមបន្ថែមទៀតដែល ព្រះអម្ចាស់បានប្រទានដល់យ៉ូសែប ស៊្មីធ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២២:១–៤ ដោយស្វែងរកពរជ័យ ដែលព្រះអម្ចាស់បានសន្យាដល់យ៉ូសែប ស៊្មីធ ។ តើអ្នកគិតថា ការសន្យាទាំងនេះបានជួយព្យាការីនៅក្នុងគ្រាដ៏លំបាកនេះយ៉ាងណាខ្លះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២២:៥–៧ ដោយស្វែងរកគោលការណ៍មួយ ដែលព្រះអម្ចាស់បានបង្រៀន យ៉ូសែប ស៊្មីធ អំពីហេតុផលដែលយើងជួបសេចក្ដីទុក្ខលំបាក ។ អ្នកអាចនឹងចង់គូសចំណាំពាក្យ និងប្រយោគដែលសំខាន់ចំពោះអ្នក ។

តើយើងអាចរៀនអ្វីខ្លះពីខគម្ពីរទាំងនេះ អំពីគោលបំណងមួយនៃសេចក្ដីទុក្ខលំបាក ? សូមបំពេញប្រយោគដូចតទៅនេះ ៖ **សេចក្ដីទុក្ខលំបាកអាចផ្ដល់ឲ្យយើង ហើយទៅ** ជា។

អែលឌើរ យ៉ូសែប ប៊ី វ៉ឺតលីន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ពីរបៀបដែលសេចក្ដីទុក្ខលំបាកអាចផ្ដល់ការពិសោធន៍ដល់យើង ហើយទៅជាការល្អដល់យើង ។



« អ្នកប្រហែលជាមានអារម្មណ៍ឯកា នៅពេលសេចក្ដីទំនាស់ចូលមកក្នុងជីវិតអ្នក ។ អ្នកគ្រវីក្បាល ហើយនឹកឆ្ងល់ថា ‹ ហេតុអ្វីជារូបខ្ញុំ › ?

« ប៉ុន្ដែនៅទីបំផុតទុក្ខព្រួយនេះនឹងកើតមានចំពោះយើងម្នាក់ៗ ។ នៅពេលខុសៗគ្នា មនុស្សគ្រប់រូបត្រូវតែជួបនឹងទុក្ខព្រួយ ។ គ្មាននរណាម្នាក់ចៀសផុតឡើយ » ។. . .

« ការរៀនស៊ូទ្រាំក្នុងគ្រានៃការខកចិត្ត ការរងទុក្ខ និងសោកសៅ គឺជាផ្នែកនៃការបំពាក់បំប៉នការងាររបស់យើង ។ ជាញឹកញាប់ បទពិសោធន៍ទាំងនេះហាក់បីដូចជាពិបាកទ្រាំទ្រ តែវាក៏ជាប្រភេទនៃបទពិសោធន៍ជាក់លាក់ដែលពង្រីកការយល់ដឹងរបស់យើង ស្ថាបនាចរិកលក្ខណៈរបស់យើង ហើយបង្កើនសេចក្ដីមេត្តារបស់យើងចំពោះអ្នកដទៃ » (Come What May, and Love It » *Ensign* ឬ *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២៧ ) ។



អែលឌើរ អ្វសុន អែហ្វ វិតនី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ក៏បានបង្រៀនថា សេចក្ដីលំបាកនានាអាចទៅជាការល្អដល់យើង ៖ « គ្មានការឈឺចាប់ណាមួយដែលយើងរងទុក្ខ គ្មានការសាកល្បងណាមួយដែលយើងជួបជារឿងអាសារឥតការឡើយ » ។ វាបម្រើដល់ការអប់រំរបស់យើង ដល់ការអភិវឌ្ឍនៃគុណសម្បត្តិដូចជា ការអត់ធ្មត់ សេចក្ដីជំនឿ ការរឹងមាំ និង ការបន្ទាបខ្លួន ។ អ្វីទាំងអស់ដែលយើងរងទុក្ខ និងអ្វីទាំងអស់ដែលយើងស៊ូទ្រាំ ជាពិសេសនៅពេលយើងស៊ូទ្រាំវាដោយអត់ធ្មត់នោះ វានឹងពង្រឹងដល់អត្តចរិតរបស់យើង បន្សុទ្ធដួងចិត្តយើង ពង្រីកព្រលឹងយើង និង ធ្វើឲ្យយើងចេះស្រឡាញ់ និងសប្បុរសកាន់តែខ្លាំង កាន់តែសាកសមនឹងត្រូវបានហៅថាជាកូនចៅនៃព្រះ . . . ហើយវាគឺតាមរយៈសេចក្ដីសោកសៅ និងការរងទុក្ខ ការលំបាកនិង ទុក្ខព្រួយ ដែលយើងទទួលបានការអប់រំដែលយើងមកទីនេះដើម្បីទទួលបាន » ( នៅក្នុង ស្ពែនសើរ ដបុលយូ ឃីមបឹល *Faith Precedes the Miracle* [ ឆ្នាំ ១៩៧២ ] ទំព័រ ៩៨ ) ។

ព្យាការី យ៉ូសែប ស៊្មីធ បានជួបសេចក្ដីលំបាកច្រើនទៀតក្រោយពីលោកបានរងទុក្ខនៅក្នុងគុកលិបើធី ។ ប្រធាន ព្រិកហាំ យ៉ង់ បានមានថ្លែង ៖ « យ៉ូសែបមិនអាចល្អឥតខ្ចោះបានឡើយ ទោះជាលោកបានរស់នៅដល់រាប់ពាន់ឆ្នាំក្ដី ប្រសិនបើលោកគ្មានការបៀតបៀន ។ ប្រសិនបើលោករស់នៅបានរាប់ពាន់ឆ្នាំ ហើយដឹកនាំប្រជាជននេះ ហើយផ្សាយដំណឹងល្អដោយគ្មានការបៀតបៀន នោះលោកមិនអាចល្អឥតខ្ចោះដូចជាលោកបានរស់នៅត្រឹមតែ [ សាមសិបប្រាំបី ] ឆ្នាំឡើយ » ( *Teachings of Presidents of the Church: Brigham Young* [ ឆ្នាំ ១៩៩៧ ] ទំព័រ ២៦៤) ។

៣. នៅក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរអំពីបទពិសោធន៍ដ៏លំបាកមួយដែលបានក្លាយជាការល្អដល់អ្នក ។

តើអ្នកធ្លាប់ឮគេនិយាយថា គ្មាននរណាម្នាក់យល់ពីការសាកល្បងដែលពួកគេកំពុងជួបដែរឬទេ ? សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២២:៨ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់អាចមានបន្ទូលតបទៅនឹងមតិនេះ ។ ដើម្បីបង្កើនការយល់ដឹងរបស់អ្នកអំពីប្រយោគថា « បានចុះទាបជាងការណ៍ទាំងនោះទៅទៀត » សូមអាន នីហ្វៃទី២ ៩:២០–២១; អាលម៉ា ៧:១១; និង គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៥–៦ ។ អ្នកអាចពិចារណាសរសេរនូវគោលលទ្ធិដូចតទៅនេះនៅក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២២:៨ ៖ **ព្រះអង្គសង្គ្រោះបានរងទុក្ខការឈឺចាប់ និងសេចក្ដីលំបាករបស់មនុស្សទាំងអស់ ។**

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា គោលលទ្ធិនេះបានជួយព្យាការី យ៉ូសែប ស៊្មីធ និង ពួកដៃគូរបស់លោកនៅក្នុងគុកលិបើធីតាមរបៀបណាខ្លះ ?

ខ. តើគោលលទ្ធិនេះ អាចជួយអ្នក នៅពេលអ្នកជួបនឹងបញ្ហាយ៉ាងដូចម្ដេចខ្លះ ?



អែលឌើរ វ៉ីតលីន បានបង្រៀន ៖



« ដោយសារព្រះយេស៊ូវគ្រីស្ទបានរងទុក្ខយ៉ាងមហិមា ទ្រង់យល់ពីការរងទុក្ខរបស់យើង ។ ទ្រង់យល់ពីភាពសោកសៅរបស់យើង ។ យើងជួបរឿងលំបាកៗដើម្បីយើងអាចមានសេចក្ដីមេត្តាករុណា និងការយល់ដឹងកាន់តែច្រើនចំពោះមនុស្សផ្សេងទៀត ។

« សូមចងចាំបន្ទូលដ៏ឧត្តមរបស់ព្រះអង្គសង្គ្រោះទៅកាន់ព្យាការីយ៉ូសែប ស្ម៊ីធ នៅពេលលោកបានរងទុក្ខជាមួយនឹងពួកដៃគូរបស់លោកនៅក្នុងភាពងងឹតអាប់អួរនៃគុកលិបើធី ។

« ‹ បុត្រយើងអើយ ចូរមានសេចក្ដីសុខសាន្តដល់ព្រលឹងបុត្រចុះ សេចក្ដីទំនាស់ និងសេចក្ដីលំបាករបស់អ្នកនោះគ្រាន់តែមួយភ្លែតប៉ុណ្ណោះទេ

« ‹ ហើយខណៈនោះ បើសិនជាអ្នកស៊ូទ្រាំការណ៍នោះដោយហ្មត់ចត់ នោះព្រះទ្រង់នឹងតម្កើងអ្នកឡើងនៅស្ថានខ្ពស់ › ។ ( គ. និង ស. ១២១:៧–៨ ) ។

« ជាមួយនឹងទស្សនដ៏អស់កល្បនោះ យ៉ូសែបបានយកការលួងលោមពីបន្ទូលទាំងនេះ ហើយយើងក៏អាចធ្វើដូចគ្នាផងដែរ » ( « Come What May, and Love It » ទំព័រ ២៧ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២២:៩ ហើយគិតពីរបៀបដែលខគម្ពីរនេះមានទំនាក់ទំនងនឹងជីវិត និងការបម្រើរបស់ព្យាការីយ៉ូសែប ស្ម៊ីធ ។

៥. សូមឆ្លើយសំណួរដូចតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើបន្ទូលរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២២:៩ ពង្រឹងដល់អ្នកនៅក្នុងគ្រាដ៏លំបាកបានយ៉ាងដូចម្ដេច ?

បន្ទាប់ពីសំបុត្រនេះត្រូវបានសរសេរមិនយូរប៉ុន្មាន ព្រះអម្ចាស់បានបើកផ្លូវឲ្យយ៉ូសែប ស្ម៊ីធ និង ពួកដៃគូរបស់លោកទៅជួបជុំនឹងពួកបរិសុទ្ធនៅរដ្ឋអិលលីណោយ ។ ព្រះបានគង់នៅជាមួយនឹងអ្នកបម្រើរបស់ទ្រង់ យ៉ូសែប ស្ម៊ីធពេញមួយជីវិតរបស់យ៉ូសែប ។ ក្រោយមកទៀត មួយឆ្នាំកន្លះពីមុនលោកត្រូវបានគេធ្វើទុក្ករកម្ម យ៉ូសែប ស្ម៊ីធបានប្រកាស ៖ « ព្រះដ៏មានគ្រប់ព្រះចេស្ដាគឺជាខែលរបស់ខ្ញុំ ហើយតើមនុស្សអាចធ្វើអ្វីបាន ប្រសិនបើព្រះជាមិត្តរបស់ខ្ញុំ ? » ( នៅក្នុង *History of the Church* ៥:២៥៩ ) ។ ប្រសិនបើយើងបន្តស្មោះត្រង់នៅក្នុងសេចក្ដីលំបាករបស់យើង នោះព្រះក៏នឹងគង់នៅជិតយើង ដើម្បីពង្រឹង ហើយជ្រោមជ្រែងយើងជារៀងរហូត ។

៦. សូមសរសេរអ្វីដែលនៅខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១–១០; ១២២:១–៩ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៦ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១១–៣៣

## សេចក្ដីផ្ដើម

គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១ មាននូវផ្នែកនៃសំបុត្រដែល យ៉ូសែប ស្ម៊ីធ បានសរសេរនៅក្នុងគុកលិបើធីទៅកាន់ពួកបរិសុទ្ធ ចុះថ្ងៃទី ២០ ខែ មិនា ឆ្នាំ ១៨៣៩ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១១–៣៣ មាននូវការពិពណ៌នារបស់ព្រះអង្គសង្គ្រោះអំពីការជំនុំជម្រះដែលនឹងកើតមានទៅលើមនុស្សទុច្ចរិត និងការសន្យារបស់ទ្រង់អំពីវីរៈណៈទៅកាន់ពួកអ្នកក្លាហាន ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១១–២៥

*ព្រះអង្គសង្គ្រោះបានពិពណ៌នាពីការជំនុំជម្រះដែលនឹងកើតមានដល់មនុស្សដែលបៀតបៀនពួកបរិសុទ្ធ*

សូមនឹកស្រមៃថា មានព្រឹកមួយ នៅពេលអ្នកកំពុងចាកចេញពីផ្ទះ អ្នកបានកត់សម្គាល់ឃើញមានសេចក្ដីថ្លែងការណ៍បិតនៅខាងក្រៅទ្វារផ្ទះរបស់អ្នក ៖ « ត្រូវចាត់ទុកពួកមរមនជាសត្រូវ ហើយ *ត្រូវលុបបំបាត់ពួកគេចោល* » ។

តើអ្នកនឹងភ័យខ្លាចចាកចេញពីផ្ទះរបស់អ្នកដែរឬទេ ? តើអ្នកនឹងទៅរកជំនួយនៅកន្លែងណា ? តើអ្នកនឹងមានអារម្មណ៍បែបណា ប្រសិនបើអ្នកបានរកឃើញថា សេចក្ដីថ្លែងការណ៍នោះត្រូវបានធ្វើឡើងដោយមិត្តភក្ដិមួយចំនួនដែលអ្នកស្គាល់ពីមុន ?

ពីមុនព្យាការីយ៉ូសែប ស្ម៊ីធ ត្រូវបានចាប់ដាក់គុក មិត្តរបស់លោកមួយចំនួនដែលពេលមួយស្មោះត្រង់នឹងលោកបានងាកមកប្រឆាំងនឹងលោកវិញ ។ នៅក្នុងចំណោមនោះ មានមិត្តពីរនាក់គឺ ថូម៉ាស ប៊ី ម៉ាស និង អូរសុន ហៃឌ ធ្លាប់ជាសមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ បុរសទាំងពីរនាក់នេះបានចុះហត្ថលេខាលើសំបុត្របញ្ជាក់ ( លិខិតថ្លែងសច្ចា ) ដោយចោទប្រកាន់ខុសថា យ៉ូសែប ស្ម៊ីធ និង សមាជិកសាសនាចក្រដទៃទៀតកំពុងរៀបផែនការបណ្ដេញមារសត្រូវរបស់ខ្លួនចេញដោយការដុត និង បំផ្លាញទ្រព្យសម្បត្តិរបស់ពួកគេ ។ សំបុត្របញ្ជាក់នេះបានធ្វើឲ្យអភិបាលរដ្ឋមិសសួរីចេញសេចក្ដីថ្លែងការណ៍មួយត្រូវបានគេស្គាល់ថាជាដីកាការសម្លាប់គ្មានសល់ ដោយប្រកាសថា ពួកមរមនទាំងអស់ត្រូវតែសម្លាប់ចោល ឬបណ្ដេញចេញពីរដ្ឋ ។ សេចក្ដីថ្លែងការណ៍ដែលអ្នកនឹកស្រមៃថាបានបិទនៅទ្វាររបស់អ្នកគឺជាពាក្យដកស្រង់ចេញពីដីកាការសម្លាប់គ្មានសល់នោះ (សូមមើល *History of the Church* ៣:១៧៥) ។

សូមចងចាំថា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១–១២៣ មាននូវផ្នែកនៃសំបុត្រដ៏បំផុសគំនិតដែលយ៉ូសែប ស្ម៊ីធ បានសរសេរនៅក្នុងគុកលិបើធីទៅកាន់ពួកបរិសុទ្ធ ចុះខែ មិនា ឆ្នាំ ១៨៣៩ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១១–១៧ ដោយស្វែងរកអ្វីដែលព្យាការីរៀនពីព្រះអម្ចាស់ទាក់ទងនឹងអ្វីដែលនឹងកើតឡើងចំពោះអស់អ្នកដែលបានចោទប្រកាន់ពួកអ្នកបម្រើរបស់ព្រះអម្ចាស់អំពីអំពើរំលង ។

ប្រយោគដែលថា « សេចក្ដីសង្ឃឹមរបស់ពួកគេនឹងត្រូវបានបែកខ្ទេចខ្ទី ហើយសេចក្ដីប្រាថ្នារបស់ពួកគេនឹងត្រូវបានរលាយបាត់ទៅ » ( គ. និង ស. ១២១:១១ ) គូសបញ្ជាក់ថា ពួកអ្នកដែលច្បាំងទាស់នឹងពួកអ្នកបម្រើរបស់ព្រះអម្ចាស់ នៅទីបំផុតនឹងបរាជ័យនៅក្នុងការគ្រោងទុករបស់ពួកគេ ។

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១៨–២២ ដោយស្វែងរកលទ្ធផលបន្ថែមទៀតដែលនឹងកើតឡើងដល់ពួកអ្នកដែលចោទប្រកាន់ខុសឆ្គង ហើយច្បាំងទាស់នឹងពួកអ្នកបម្រើរបស់ព្រះអម្ចាស់ ។ ( នៅក្នុង ខ ១៩ ប្រយោគដែលថា « បានកាត់ចេញពីពិធីបរិសុទ្ធទាំងឡាយនៃដំណាក់ [ របស់ព្រះអម្ចាស់ ] »គឺមានន័យថា ការបាត់បង់ ឬផ្ដាច់ចេញពីពរជ័យដែលទាក់ទងជាមួយនឹងពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ) ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. នៅក្នុង ខ ១៣ និង ១៧ ហេតុផលអ្វីខ្លះដែលព្រះអម្ចាស់បានលើកឡើងពីមូលហេតុដែលមនុស្សមួយចំនួនបានចោទប្រកាន់ពួកអ្នកបម្រើរបស់ទ្រង់ថាជាអ្នកប្រព្រឹត្តអំពើបាប ?

ខ. ស្របតាម ខ ១៩–២២ តើមានគ្រោះថ្នាក់អ្វីខ្លះចំពោះការនិយាយខុសឆ្គងទាស់នឹងពួកអ្នកបម្រើរបស់ព្រះ ?

សេចក្ដីថ្លែងការណ៍ខុសដែលធ្វើឡើងដោយសមាជិកសាសនាចក្រដែលក្បត់សាសនា និងមនុស្សដទៃទៀត រួមផ្សំនឹងដីកាការសម្លាប់គ្មានសល់របស់អភិបាលរូបនោះ បានធ្វើឲ្យពួកមនុស្សកំណាចបង្កើនការបៀតបៀនរបស់ពួកគេទៅលើពួកបរិសុទ្ធនៅរដ្ឋមិសសួរី ។

នៅពេលអ្នកអានរឿងដូចតទៅនេះ សូមគូសចំណាំនូវគំរូមួយចំនួនស្ដីពីរបៀបដែលពួកបរិសុទ្ធត្រូវបានរងនូវអំពើអយុត្តិធម៌ ៖



ពួកមនុស្សកំណាចបានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់សមាជិកសាសនាចក្រនៅរដ្ឋមិសសួរី ។

នៅថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៨៣៨ គឺបីថ្ងៃបន្ទាប់ការចេញដីកាការសម្លាប់គ្មានសល់នោះមក មានបុរសប្រមាណជា ២៤០ នាក់បានធ្វើដំណើរទៅកាន់ទីតាំងលំនៅមួយរបស់ពួកមរមននៅត្រង់កន្លែងដែលហៅថា ហនស៍ មិល (ឬហោនស៍ មិល) ។ ពួកស្ត្រី និង ពួកក្មេង ៗបានរត់ចូលទៅក្នុងព្រៃ ខណៈដែលបុរស ៗខំការពារនៅហាងជាងដែក ។ ថ្នាក់ដឹកនាំម្នាក់របស់ពួកបរិសុទ្ធ គឺដេវីឌ អេវ៉ាន់ស៍ បានគ្រវីមួករបស់គាត់ ហើយស្រែកសុំសន្តិភាព ។ សំឡេងកាំភ្លើងរាប់រយបានឆ្លើយតបនឹងការសុំរបស់គាត់ ភាគច្រើនបាញ់តម្រង់ទៅហាងជាងដែកនោះ ។ ពួកមនុស្សកំណាចនោះបានលើកកាំភ្លើងបាញ់ដោយគ្មានក្ដីមេត្តាទៅលើមនុស្សគ្រប់គ្នាដែលពួកគេឃើញ រួមទាំងស្ត្រី បុរសចំណាស់ និងកុមារផងដែរ ។ អាមេនដា ស្ម៊ីធ បានឆក់កូនស្រីតូចពីរនាក់របស់ខ្លួន ហើយបានរត់ទៅជាមួយម៉ារី ស្ដេដវេល កាត់ទឹកតាមផ្លូវដើរ ។ អាមេនដា បាននៅចាំថា « ប៉ុន្តែទោះជាយើងជាមនុស្សស្រីដែលមានកូនតូច ៗ ដែលខំរត់គេចឲ្យរួចជីវិតក្ដី ក៏ពួកមនុស្សកំណាចទាំងនោះតាមសម្លាប់យើងពីភូមិមួយទៅភូមិមួយដែរ » (នៅក្នុង Andrew Jenson « Amanda Smith » *The Historical Record* ខែកក្កដា ឆ្នាំ ១៨៨៦ ទំព័រ ៨៤) ។

ក្រុមមនុស្សកំណាចបានចូលក្នុងហាងជាងដែកនោះ ហើយបានរកឃើញក្មេងប្រុសម្នាក់អាយុ ១០ ឆ្នាំ ឈ្មោះ សាដាស់ ស្ម៊ីធ ជាកូនប្រុសរបស់អាមេនដា ស្ម៊ីធ ហើយបានសម្លាប់វា កាលវាកំពុងលាក់ខ្លួននៅក្រោមស្នប់របស់ជាងដែក ។ ក្រោយមកបុរសនោះបានពន្យល់ថា « [កូនចៃ] នឹងក្លាយជាចៃ ហើយប្រសិនបើវានៅរស់វានឹងក្លាយជាពួកមរមន » ( នៅក្នុង Jenson « Haun's Mill Massacre » *Historical Record* ខែ ធ្នូ ឆ្នាំ ១៨៨៨ ទំព័រ ៦៧៣, សូមមើលផងដែរ B. H. Roberts, *A Comprehensive History of the Church,* ១:៤៨២) ។ អាលម៉ា ស្ម៊ីធ ជាប្អូនប្រុសរបស់សាដាស់ អាយុប្រាំពីរឆ្នាំ បានឃើញការស្លាប់របស់ឪពុក និង បងប្រុសខ្លួន ហើយត្រូវគេបាញ់ចំត្រគាក ។ ក្រុមមនុស្សកំណាចរកវាមិនឃើញឡើយ ហើយក្រោយមកត្រូវបានជាសះស្បើយយ៉ាងអព្ភូតហេតុតាមរយៈការអធិស្ឋាន និង សេចក្ដីជំនឿ ។ ទោះបីជាមានបុរសពីរបីនាក់នៅជាមួយនឹងពួកស្ត្រី និងក្មេង ៗរត់គេចខ្លួនឆ្លងកាត់ទន្លេចូលទៅជ្រលងភ្នំក្ដី ក៏យ៉ាងហោចណាស់មានមនុស្សចំនួន ១៧ នាក់ត្រូវបានគេសម្លាប់ ហើយប្រហែលជា ១៣ នាក់ត្រូវរងរបួស ។ ( សូមមើល *Church History in the Fulness of Times Student Manual* ការបោះពុម្ពលើកទី២ [ Church Educational System manual ឆ្នាំ ២០០៣ ] ទំព័រ ២០១, ២០៣–៤; សូមមើលផងដែរ *History of the Church* ៣:១៨៣–៨៦ ) ។

គ្មាននរណាម្នាក់នៅក្នុងក្រុមមនុស្សកំណាចឃោរឃៅទាំងនេះត្រូវបានទៅតុលាការរដ្ឋមិសសួរី ឬរដ្ឋអំណាចដើម្បីកាត់ទោសចំពោះឧក្រិដ្ឋកម្មរបស់ពួកគេឡើយ ។

តើអ្នកមានអារម្មណ៍យ៉ាងណាដែរ ប្រសិនបើអ្នកជួបនឹងភាពសាហាវឃោរឃៅទាំងនេះ ? តើអ្នកមានអារម្មណ៍បែបណាដែរ នៅពេលអ្នកបានដឹងថា ពួកអ្នកដែលវាយប្រហារមកលើអ្នកនឹងមិនបានឲ្យទទួលខុសត្រូវចំពោះទង្វើរបស់ពួកគេនោះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:២៣–២៥ ដោយស្វែងរកប្រយោគដែលគូសបញ្ជាក់ថា ព្រះនឹងធ្វើឲ្យមារសត្រូវរបស់ពួកបរិសុទ្ធទទួលខុសត្រូវចំពោះទង្វើរបស់ពួកគេ ។ ( យើងមិនដឹងពីពេលវេលាដែលការកាត់សេចក្ដីនេះនឹងកើតមានចំពោះពួកមារសត្រូវរបស់ពួកបរិសុទ្ធឡើយ ។ ផលខ្លះអាចនឹងមិនកើតឡើងក្នុងជីវិតនេះ ប៉ុន្តែរហូតដល់ជីវិតក្រោយ ) ។

សូមបំពេញសេចក្ដីថ្លែងការណ៍អំពីសេចក្ដីពិតដូចតទៅនេះ ដោយផ្អែកទៅលើអ្វីដែលអ្នកបានរៀននៅក្នុង ខ ២៤–២៥ ។

- **ព្រះអម្ចាស់ និង រាល់កិច្ចការរបស់យើង ។**
- **ពួកអ្នកដែលប្រឆាំងទាស់នឹងព្រះអម្ចាស់ និង រាស្ត្ររបស់ទ្រង់នឹងទទួលបាន នៅពេលកំណត់របស់ទ្រង់ ។**

២. សូមគិតពីពេលដែលអ្នកធ្លាប់ឃើញមនុស្សធ្វើខុស ហើយខំគេចពីផលកម្ម ។ នៅក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមឆ្លើយសំណួរដូចតទៅនេះ ៖ តើគោលការណ៍ដែលអ្នកបានរកឃើញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:២៤–២៥ ទាក់ទងនឹងស្ថានភាពសព្វថ្ងៃបែបណាខ្លះ នៅពេលមនុស្សហាក់ដូចជារត់គេចពីលទ្ធផលនៃកំហុសរបស់ពួកគេនោះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:២៦–៣៣

*ព្រះសន្យានឹងបើកសម្ដែងសេចក្ដីពិតដ៏អស់កល្បតាមរយៈព្រះវិញ្ញាណបរិសុទ្ធ*

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:២៦ ដោយរកមើលសេចក្ដីពិតមួយដែលព្យាការីយ៉ូសែបស្ម៊ីធ បានកត់ត្រាកាលលោកជាប់ឃុំនៅក្នុងគុកលិបើធី ។

សូមប្រើអ្វីដែលអ្នករៀននៅក្នុង ខ ២៦ ដើម្បីបំពេញឃ្លាដូចតទៅនេះ ៖ **ព្រះនឹង តាម រយៈ ។**



ជាន់ខាងក្រោយនៃគុកលិបើធី



នៅពេលអ្នកពិចារណាពីរបៀបដែលសេចក្ដីពិតនេះអាចមានទំនាក់ទំនងនឹងអ្នក នៅពេលអ្នកជួបការលំបាកនានា សូមសញ្ជឹងគិតពីសេចក្ដីថ្លែងការណ៍របស់អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖ « អ្នកអាចមានបទពិសោធន៍ដ៏ពិសិដ្ឋអស្ចារ្យ និងប្រកបដោយវិវរណៈជាមួយនឹងព្រះអម្ចាស់ *នៅក្នុងបទពិសោធន៍ដ៏ជូរចត់បំផុតនៃជីវិតរបស់អ្នក*—នៅក្នុងបរិយាកាសដ៏អាក្រក់បំផុត កាលកំពុងស៊ូទ្រាំនឹងភាពអយុត្តិធម៌ដ៏ឈឺចាប់បំផុត ពេលកំពុងជួបនឹងភាពមិនទៀងទាត់ និងសេចក្ដីទំនាស់ដែលពិបាកពុះពារបំផុតដែលធ្លាប់ជួប » ( « Lessons from Liberty Jail » [ Brigham Young University fireside ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៨ ] ទំព័រ ៤, speeches.byu.edu) ។

ដំណើររឿងតទៅនេះរបស់លូស៊ី ម៉ាក ស្ម៊ីធ ផ្ដល់នូវគំរូមួយអំពីរបៀបដែលព្រះអាចបើកសម្ដែងចំណេះដឹងដល់យើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ នៅពេលអ្នកអានដំណើររឿងនេះ សូមកត់សម្គាល់ពីរបៀបដែលចំណេះដឹងដែលគាត់បានទទួលតាមរយៈព្រះវិញ្ញាណបរិសុទ្ធបានលួងលោមគាត់អំពីការជាប់ឃុំឃាំងនៃកូនប្រុសរបស់គាត់ក្នុងគុកលិបើធី បន្ទាប់ពីយ៉ូសែប ហៃរុមត្រូវបានចាប់ខ្លួនជាអ្នកទោស ហើយគំរាមសម្លាប់ ។



« ផ្ទះរបស់យើងបានពោរពេញដោយការកាន់ទុក្ខ ការឡូញយំ និង សេចក្ដីវេទនាអស់មួយរយៈពេល ប៉ុន្តែនៅកណ្ដាលនៃទុក្ខព្រួយរបស់ខ្ញុំ ខ្ញុំបានរកឃើញការលួងលោមចិត្តដែលលើសលុបជាងការលួងលោមខាងលោកិយទាំងអស់ទៅទៀត ។ ខ្ញុំបានពោរពេញដោយព្រះវិញ្ញាណនៃព្រះ ហើយបានទទួលចំណេះដឹងដូចតទៅនេះតាមរយៈអំណោយទាននៃការព្យាករ ៖ ‹ ចូរឲ្យដួងចិត្តអ្នកទទួលបានការលួងលោមទាក់ទងនឹងរឿងកូនៗរបស់អ្នក មារសត្រូវរបស់ពួកគេនឹងមិនបៀតបៀនពួកគេឡើយ. . . ។ ការណ៍នេះបានធ្វើឲ្យចិត្តខ្ញុំធូរស្បើយ ហើយខ្ញុំរៀបចំខ្លួនជួបនឹងកូនៗរបស់ខ្ញុំ ។ ខ្ញុំបានប្រាប់ពួកគេពីអ្វីដែលបានបើកសម្ដែងមកខ្ញុំ ដែលវាបានលួងលោមចិត្តពួកគេយ៉ាងមហិមា » ( *History of Joseph Smith by His Mother* កែសម្រួលដោយ Preston Nibley [ ឆ្នាំ ១៩៥៨ ] ទំព័រ ២៩១ ) ។

៣. សូមឆ្លើយសំណួរមួយ ឬ សំណួរទាំងពីរខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការទទួលបានចំណេះដឹងតាមរយៈព្រះវិញ្ញាណបរិសុទ្ធអាចជួយអ្នក នៅពេលអ្នកជួបរឿងលំបាកៗបានដោយរបៀបណា ?

ខ. តើអ្នកធ្លាប់ទទួលបានចំណេះដឹងតាមរយៈព្រះវិញ្ញាណបរិសុទ្ធដែលបានជួយអ្នកឲ្យឆ្លងកាត់គ្រាលំបាកនៅពេលណាដែរ ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:២៦–៣៣ ព្រះអម្ចាស់បានសន្យានឹងបើកសម្ដែងចំណេះដឹងដែល « ពុំទាន់បានបើកសម្ដែងប្រាប់ចាប់តាំងពីកំណើតលោកិយ » ( គ. និង ស. ១២១:២៦ ) និងប្រទានពរជ័យដ៏រុងរឿងដល់អស់អ្នកដែល « ស៊ូទ្រាំដោយក្លាហានដើម្បីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ » ( គ. និង ស. ១២១:២៩ ) ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៣ ព្យាការីយ៉ូសែប ស្ម៊ីធ បានប្រើការប្រៀបធៀបដើម្បីជួយពួកបរិសុទ្ធឲ្យយល់ដឹងថា ព្រះអម្ចាស់មានមហិទ្ធិឫទ្ធិជាងអស់អ្នកកំពុងបៀតបៀនពួកបរិសុទ្ធ និងកំពុងចង់បញ្ឈប់កិច្ចការរបស់ព្រះ ។

សូមអាន ខទី ៣៣ ដោយស្វែងរកការប្រៀបធៀបដែលយ៉ូសែប ស្ម៊ីធ បានធ្វើ ដើម្បីចង្អុលបង្ហាញពីព្រះចេស្ដានៃព្រះ ។ ទន្លេមិសសួរីគឺជាទន្លេមួយដ៏ធំល្វឹងល្វើយដែលពួកបរិសុទ្ធកាលសម័យមុនបានរស់នៅក្បែរនោះ ហើយស្គាល់ ។


ទន្លេ មិសសួរី

តើវាមានប្រសិទ្ធិភាពប៉ុណ្ណា ដែលមនុស្សម្នាក់នឹងបញ្ឈប់ទិសដៅចរន្តទឹកហូរនៃទន្លេមួយដ៏ធំល្វឹងល្វើយដោយប្រើតែដៃម្ខាងនោះ ? តើអ្នកគិតថាព្រះអម្ចាស់កំពុងបង្រៀនអ្វីខ្លះដល់ព្យាការីអំពីវិវរណៈដែលទ្រង់នឹងបើកសម្ដែង ?

គោលលទ្ធិមួយដែលយើងរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៣ គឺថា **គ្មានអ្វីអាចបញ្ឈប់កិច្ចការរបស់ព្រះអម្ចាស់មិនឲ្យឆ្ពោះទៅមុខបានឡើយ ។**

៤. សូមឆ្លើយសំណួរដូចតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកមានអារម្មណ៍បែបណា ដោយដឹងថាកិច្ចការរបស់ព្រះអម្ចាស់នឹងបន្តមិនថាមានសេចក្ដីទំនាស់បែបណានោះ ?

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:១១–៣៣ ហើយបានបញ្ចប់មេរៀននេះនៅ ( កាលបរិច្ឆេទ ) ។*

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៦ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤–៤៦

## សេចក្ដីផ្ដើម

គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤–៤៦ គឺជាផ្នែកមួយនៃសំបុត្រដ៏បំផុសគំនិតរបស់ព្យាការី យ៉ូសែប ស្ម៊ីធ នៅក្នុងគុកលិបើធី ។ នៅក្នុងផ្នែកនេះនៃសំបុត្រ ព្យាការីបង្រៀននូវគោលការណ៍នានាអំពីអំណាច និង សិទ្ធិអំណាចនៃបព្វជិតភាព ។ លោកពន្យល់ពីហេតុផលដែលមនុស្សជាច្រើនត្រូវបានហៅ ប៉ុន្តែមានមនុស្សតែបន្តិចទេដែលត្រូវបានរើស និង អំពីរបៀបដែលអ្នកកាន់បព្វជិតភាពអាចទាញយកអំណាចទាំងឡាយនៃស្ថានសួគ៌ដើម្បីបម្រើដល់អ្នកដទៃទៀត ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤–៤០

*យ៉ូសែប ស្ម៊ីធ បង្រៀនថា សិទ្ធិនៃបព្វជិតភាពត្រូវបានភ្ជាប់ទៅនឹងអំណាចសួគ៌*

តើអ្នកគិតថា ការប្រើប្រាស់បព្វជិតភាពអាចប្រៀបបាននឹងការបើកចង្កៀងអគ្គិសនីមួយយ៉ាងដូចម្ដេចដែរ ?



សូមសរសេរពាក្យ *អ្នកកាន់បព្វជិតភាព* នៅក្បែររូបចង្កៀងអគ្គិសនីក្នុងរូបគំនូរ ។ នៅក្នុងមេរៀននេះ ពន្លឺចង្កៀងអគ្គិសនីតំណាងឲ្យពរជ័យដែលមនុស្សអាចទទួលបានពីព្រះតាមរយៈការបម្រើរបស់អ្នកកាន់បព្វជិតភាពម្នាក់ ។

សម្រាប់ការសិក្សារបស់អ្នកនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១ នាថ្ងៃនេះ សូមគិតពីរបៀបដែលភាពសុច្ចរិតរបស់អ្នកកាន់បព្វជិតភាពម្នាក់ ជះឥទ្ធិពលដល់សមត្ថភាពរបស់គាត់នៅក្នុងការជួយដល់មនុស្សដទៃទៀតឲ្យទទួលបានពរជ័យនៃបព្វជិតភាព ។ ទោះបីជាខគម្ពីរទាំងនេះសំដៅទៅលើពួកអ្នកកាន់បព្វជិតភាពក្ដី ក៏វាមាននូវគោលការណ៍ដែលអនុវត្តចំពោះសមាជិកសាសនាចក្រទាំងអស់ផងដែរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤ ដោយយកចិត្តទុកដាក់ទៅនឹងសំណួរនៅក្នុងខនេះ ។ អ្នកអាចនឹងចង់គូសចំណាំសួរសំណួរនេះ ៖



ដើម្បីបង្កើនការយល់ដឹងរបស់អ្នកអំពីអត្ថន័យដែលអ្នកកាន់បព្វជិតភាពម្នាក់ត្រូវបាន « ហៅ » និង « រើស » សូមអានសេចក្ដីថ្លែងការណ៍ដូចទៅនេះរបស់ប្រធាន ជេមស៍ អ៊ី ហ្វោស្ដ ក្នុងគណៈប្រធានទីមួយទៅកាន់ពួកអ្នកកាន់បព្វជិតភាព ៖ « យើងត្រូវបានហៅ នៅពេលដៃត្រូវបានដាក់លើក្បាលរបស់យើង ហើយយើងត្រូវបានប្រគល់ឲ្យបព្វជិតភាព ប៉ុន្តែយើងមិនត្រូវបានរើសឡើយរហូតយើងបានបង្ហាញសេចក្ដីសុចរិតរបស់យើង សេចក្ដីស្មោះត្រង់របស់យើង និង ការតាំងចិត្តរបស់យើងចំពោះព្រះ » ( « Called and Chosen » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ៥៥ ) ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៥–៣៨ យើងរៀនពីមូលហេតុដែលពួកអ្នកកាន់បព្វជិតភាពខ្លះមិនត្រូវបានរើស ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៥–៣៦ ដោយស្វែងរកនូវមេរៀនមួយដែលអ្នកកាន់បព្វជិតភាពគ្រប់រូបគួររៀនសូត្រ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

សូមសរសេរពាក្យ *អំណាចទាំងឡាយនៃស្ថានសួគ៌* នៅក្បែរព្រីភ្លើងក្នុងរូបគំនូរ ។ នៅក្នុងរឿងប្រៀបធៀបនេះ អគ្គិសនីតំណាងឲ្យអំណាចទាំងឡាយនៃស្ថានសួគ៌ ។

សូមកត់សម្គាល់ពីឃ្លាថា « សិទ្ធិទាំងឡាយនៃបព្វជិតភាព » នៅក្នុង ខទី ៣៦ ។ បុរសម្នាក់ទទួលបានសិទ្ធិដើម្បីអនុវត្តបព្វជិតភាពនៅពេលសិទ្ធិអំណាចបព្វជិតភាពត្រូវបានប្រគល់ដល់គាត់ដោយការដាក់ដៃលើក្បាល ។ សិទ្ធិដើម្បីធ្វើជាមួយនឹងសិទ្ធិអំណាចនេះពឹងផ្អែកលើភាពសក្ដិសមរបស់បុរសម្នាក់ ។ នៅក្នុងរូបគំនូរ សូមសរសេរនៅត្រង់ខ្សែភ្លើងថា *សិទ្ធិអំណាចបព្វជិតភាព* ។

សូមនឹកស្រមៃថា អ្នកដោតខ្សែភ្លើងចង្កៀងអគ្គិសនីនោះទៅក្នុងព្រីភ្លើង ប៉ុន្តែចង្កៀងនោះមិនភ្លឺ ។ អ្នកពិនិត្យមើលចង្កៀងនោះ ហើយរកឃើញថា កុងកាត់ភ្លើងមិនទាន់ « បើក » ។ នៅក្បែរកុងតាក់ភ្លើង ( លើខ្សែភ្លើងក្នុងរូបគំនូរ ) សូមសរសេរថា *គោលការណ៍នៃសេចក្ដីសុចរិត* ។

១. សូមបំពេញកិច្ចការខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. នៅក្នុងរឿងប្រៀបធៀបនេះ តើការធ្វើតាម « គោលការណ៍នៃសេចក្ដីសុចរិត » ដូចគ្នានឹងការបើកកុងតាក់ចង្កៀងតាមរបៀបណា ?

ខ. យោងតាមអ្វីដែលអ្នករៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៦ សូមបំពេញសេចក្ដីថ្លែងការណ៍ដូចតទៅនេះ ៖ **ពួកអ្នកកាន់បព្វជិតភាពអាចទាញយកអំណាចទាំងឡាយនៃស្ថានសួគ៌បាន ដរាបណាពួកគេ. . .**

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៧–៣៨ ដោយស្វែងរកអ្វីដែលកើតឡើងចំពោះសមត្ថភាពរបស់អ្នកកាន់បព្វជិតភាពម្នាក់ដើម្បីទាញយកអំណាចទាំងឡាយនៃស្ថានសួគ៌ ប្រសិនបើគាត់មិនរស់នៅដោយសុចរិតនោះ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។ ( នៅក្នុង ខទី ៣៨ « ធាក់ជល់នឹងជន្លួញ » សំដៅទៅលើសត្វមួយក្បាលដែលប្រឆាំងនឹងដំបងស្រួចមួយដែលធ្លាប់ប្រើនាំផ្លូវវាឆ្ពោះទៅទិសដៅដែលចង់ទៅ ។ ចំពោះយើង ឃ្លានេះសំដៅទៅលើការប្រឆាំងនឹងការដឹកនាំពីព្រះអម្ចាស់ និង ពួកអ្នកបម្រើរបស់ទ្រង់ ) ។

សូមពិនិត្យឡើងវិញនូវ ខទី ៣៥ និង ៣៧ ដោយរកមើលឥរិយាបថ និង ទង្វើទុច្ចរិតដែលធ្វើឲ្យទំនាក់ទំនងរបស់អ្នកកាន់បព្វជិតភាពម្នាក់នឹងអំណាចទាំងឡាយនៃស្ថានសួគ៌មានភាពទន់ខ្សោយ ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នកបានរកឃើញ ។ បន្ទាប់មកសូមអានឧទាហរណ៍ខាងក្រោម ។ សូមស្វែងរកឥរិយាបថ និង ទង្វើដែលត្រូវបានលើកឡើងនៅក្នុង ខទី ៣៥ និង ៣៧ ។ នៅក្នុងចន្លោះដែលបានផ្ដល់ឲ្យ សូមសរសេរឥរិយាបថ និង ទង្វើទាំងនោះ ។

- ដើម្បីសម្របខ្លួននឹងមិត្តភក្តិមួយចំនួនរបស់គាត់ដែលល្បី អ្នកកាន់បព្វជិតភាពម្នាក់ចូលរួមនឹងពួកគេសើចចំអកដល់មិត្តរួមថ្នាក់ម្នាក់នៅឯសាលារៀន ។

- ប្រធានកូរ៉ុមគ្រូម្នាក់ចូលចិត្តកីឡា ហើយបដិសេធដើម្បីចូលរួមនៅក្នុងការដាក់ផែនការធ្វើសកម្មភាពសម្រាប់កូរ៉ុមទាំងអស់ ដែលមិនទាក់ទងនឹងកីឡាបាល់ទាត់ ឬកីឡាបាល់បោះ ។ នៅពេលណាកូរ៉ុមចូលរួមក្នុងសកម្មភាព ឬការបម្រើមួយ គាត់តម្រូវឲ្យយុវជនផ្សេងទៀតធ្វើតាមគាត់ប្រាប់ ដោយសារគាត់គឺជាប្រធានកូរ៉ុម ។

នៅក្នុងទំនាក់ទំនងជាមួយនឹងការព្រមានស្ដីពីពួកអ្នកកាន់បព្វជិតភាពដែល « ខំរកផ្លូវដើម្បីលាក់អំពើបាបទាំងឡាយ[ របស់ពួកគេ ] » ( គ. និង ស. ១២១:៣៧ ) សូមពិចារណាពីដំណើររឿងរបស់ស្ដេចដាវីឌនៅក្នុង សាំយូអែល ទី២ ១១ ។ បន្ទាប់ដាវីដបានប្រព្រឹត្តអំពើបាបនៃសេចក្ដីកំផិតជាមួយនឹងនាង បាតសេបា ហើយនាងបានមានផ្ទៃពោះ នោះទ្រង់បានព្យាយាមលាក់អំពើបាបរបស់ទ្រង់ នៅទីបំផុតបានរៀបចំសម្លាប់ប្ដីរបស់ នាង ឈ្មោះ អ៊ូរី ។ តើអ្នកអាចគិតឃើញពីស្ថានភាពផ្សេងទៀតដែលមនុស្សព្យាយាមលាក់អំពើបាបរបស់ខ្លួនដែរឬទេ ?

តើគ្រោះថ្នាក់នៃការដាក់ដួងចិត្តទៅលើរឿងនៃលោកិយ និងការចង់បានកិត្តិយសនៃមនុស្សលោកមានអ្វីខ្លះ ?

២. សូមឆ្លើយសំណួរដូចទៅនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ ហេតុអ្វីបានជាអ្នកគិតថាឥរិយាបថ និង ទង្វើដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៥, ៣៧ រារាំងពួកអ្នកកាន់បព្វជិតភាពពីការទាញយកអំណាចទាំងឡាយនៃស្ថានសួគ៌ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៩–៤០ ដោយស្វែងរកហេតុផលដែលមនុស្សមួយចំនួនចាប់ផ្ដើមអនុវត្តអំណាចមិនសុចរិត( គ្រប់គ្រងមនុស្សដទៃ ) ។

៣. យោងតាមអ្វីដែលអ្នកបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤–៤០ សូមសង្ខេបដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកពីហេតុផលដែល« មនុស្សជាច្រើនដែលត្រូវបានហៅ ប៉ុន្តែមានមនុស្សតែបន្តិចទេដែលត្រូវបានរើស » ( គ. និង ស. ១២១:៤០ ) ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៤១–៤៦

*យ៉ូសែប ស្ម៊ីធបង្រៀនពីរបៀបដែលពួកអ្នកកាន់បព្វជិតភាពគួរប្រព្រឹត្ត*

បន្ទាប់ពីបង្រៀនអំពីឥរិយាបថ និង ទង្វើដែលធ្វើឲ្យទំនាក់ទំនងរវាងអ្នកកាន់បព្វជិតភាពម្នាក់ និងអំណាចទាំងឡាយនៃស្ថានសួគ៌មានភាពទន់ខ្សោយ ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនអំពីឥរិយាបថ និង ទង្វើដែលពង្រឹងដល់ទំនាក់ទំនងនោះ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៤១–៤៥ ដោយស្វែងរកឥរិយាបថ និង ទង្វើដែលជួយពួកអ្នកកាន់បព្វជិតភាពឲ្យទាញយកអំណាចទាំងឡាយនៃស្ថានសួគ៌ ។ សូមពិចារណាអំពីការគូសចំណាំឥរិយាបថ និង ទង្វើទាំងនេះនៅពេលអ្នកស្វែងរកពួកវា ។ នៅពេលអ្នកអាន វា មានប្រយោជន៍ដើម្បីដឹងថានៅក្នុង ខទី ៤១ ពាក្យថា *លើកលែងតែ* មានន័យថា « មានតែ » និងការធ្វើដោយសេចក្ដីស្រឡាញ់ស្មោះត្រង់ ហើយឥតលាក់ពុត ឬឥតបោក គឺជាការស្រឡាញ់មនុស្សដោយស្មោះពិតប្រាកដ ហើយមានការលើកទឹកចិត្តដ៏សុចរិត ។

៤. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរអំពីហេតុផលដែលគុណសម្បត្តិដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៤១–៤៥ សំខាន់ចំពោះពួកអ្នកកាន់បព្វជិតភាព ។ សូមឆ្លើយសំណួរដូចទៅនេះផងដែរ ៖ ហេតុអ្វីគុណសម្បត្តិទាំងនេះសំខាន់ចំពោះពួកបរិសុទ្ធថ្ងៃចុងក្រោយគ្រប់រូបត្រូវមាន ? សូមជ្រើសយកគោលការណ៍នៃសេចក្ដីសុចរិតមួយដែលបានលើកឡើងនៅក្នុងខទាំងនេះ ហើយដាក់គោលដៅមួយដើម្បីរស់នៅតាមគោលការណ៍នោះឲ្យបានប្រសើរ ។

នៅក្នុង ខទី ៤៣ ពាក្យ *ដោយស្ដីបន្ទោស* សំដៅលើការប្រាប់មនុស្សម្នាក់ថា គាត់កំពុងខុស ជាទូទៅដោយភាពទន់ភ្លន់ ឬចិត្តមេត្តា ។ ពាក្យ *សមពេលសមហេតុ* មានន័យថា « មុនពេល » ឬ « ទាន់ពេល » ។ ពាក្យ *ការតឹងរឹង* អាចសំដៅទៅលើសេចក្ដីត្រូវការដើម្បីបង្ហាញខ្លួនយើងឲ្យច្បាស់លាស់ ។ តើអ្នកគិតថា ហេតុអ្វីវាជាការសំខាន់សម្រាប់ថ្នាក់ដឹកនាំបព្វជិតភាពម្នាក់ដើម្បីស្ដីបន្ទោសឲ្យច្បាស់លាស់ ចំពេល ហើយស្របតាមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ ? តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីបង្ហាញសេចក្ដីស្រឡាញ់បន្ថែមទៀត បន្ទាប់ពីស្ដីបន្ទោសមនុស្សម្នាក់ ? តើអ្នកធ្លាប់ទទួលបានអត្ថប្រយោជន៍មកពីការកែតម្រូវបែបនេះនៅពេលណាដែរ ?

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ហេតុអ្វីវាជាការសំខាន់សម្រាប់ពួកអ្នកកាន់បព្វជិតភាពដើម្បីមានភាពទន់ភ្លន់ និងចិត្តមេត្តានៅក្នុងរបៀបដែលពួកគេទំនាក់ទំនងនឹងអ្នកដទៃ ?

ខ. តើអ្នកគិតថា ឃ្លា « សូមឲ្យគុណធម៌តុបតែងគំនិតអ្នកដោយឥតឈប់ឈរឡើយ » មានន័យដូចម្ដេច ( គ. និង ស. ១២១:៤៥ ) ? តើរឿងមួយចំនួន ដែលអ្នកអាចធ្វើដើម្បីរក្សាគំនិតរបស់អ្នកឲ្យមានគុណធម៌មានអ្វីខ្លះ ?

គ. តើគោលការណ៍ទាំងឡាយនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៤១–៤៥ អាចជួយយើងទាំងអស់គ្នា នៅពេលយើងទំនាក់ទំនងគ្នាយ៉ាងដូចម្ដេចដែរ ?



ការរស់នៅតាមគោលការណ៍នៃសេចក្ដីសុចរិតទាំងនេះជួយយើងឲ្យប្រែក្លាយកាន់តែដូចព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ហើយអាចផ្ដល់ពរដល់ជីវិតមនុស្សដទៃទៀតកាន់តែប្រសើរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៤៥–៤៦ ដោយស្វែងរកពរជ័យដែលកើតមានដល់ពួកអ្នកកាន់បព្វជិតភាពដែលទាញយកអំណាចទាំងឡាយនៃស្ថានសួគ៌តាមរយៈការរស់នៅដ៏សុចរិត ។ សូមពិចារណាអំពីការគូសចំណាំអ្វីដែលអ្នករកឃើញ ។

នៅពេលអ្នកអានខទាំងនេះ វាមានប្រយោជន៍ដើម្បីដឹងថា ដំបងរាជគឺជាវត្ថុមួយដែលស្ដេច ឬម្ចាស់ក្សត្រីកាន់ ។ វាគឺជានិមិត្តរូបមួយនៃសិទ្ធិអំណាច និង អំណាច ។

នៅពេលអ្នកសញ្ជឹងគិតពីពាក្យព្រាស់បង្គាប់ថា « សូមឲ្យគុណធម៌តុបតែងគំនិតអ្នកដោយឥតឈប់ឈរឡើយ » ( គ. និង ស. ១២១:៤៥ ) វាមានប្រយោជន៍ដើម្បីដឹងថា នៅពេលវិវរណៈនេះត្រូវបានប្រទានមក នោះអត្ថន័យមួយនៃពាក្យ *តុបតែ* គឺ « លម្អ » ដែលណែនាំឲ្យបង្កើតទំនាក់ទំនងជិតស្និទ្ធមួយ ។ អត្ថន័យមួយទៀតគឺ « ធ្វើឲ្យតាំងនៅជាប់ »—និយាយម្យ៉ាងទៀតគឺ « ទប់ចិត្ត » ។ ( សូមមើល Noah Webster, *An American Dictionary of the English Language,* សំណៅកិច្ចការនៃការបោះពុម្ពលើកទីមួយ [ ឆ្នាំ ១៨២៨ បោះពុម្ពឡើងវិញឆ្នាំ ១៩៦៧ ] « garnish » ) ។ នៅក្នុងនិយមន័យនេះ យើងរៀនថា យើងគួរអនុញ្ញាតឲ្យគុណធម៌នៅអែប ហើយគ្រប់គ្រងគំនិតរបស់យើង ។

៦. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរអំពីអ្នកកាន់បព្វជិតភាពម្នាក់ដែលអ្នកស្គាល់ ដែលគាត់បានរស់នៅតាមរបៀបដែលបានជួយគាត់ឲ្យទាញយកអំណាចទាំងឡាយនៃស្ថានសួគ៌ ។ តើអ្នកធ្លាប់បានទទួលពរជ័យ តាមរយៈការបម្រើរបស់គាត់យ៉ាងដូចម្ដេច ?

## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៦, ៤១–៤២

៧. សូមចំណាយពេលមួយចំនួនអានឡើងវិញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៦ ឲ្យឮៗរហូតអ្នកអាចសូត្រវាបាន ។ រួចសូត្រវាឲ្យសមាជិកគ្រួសារម្នាក់ស្ដាប់ ។ ដើម្បីជួយអ្នកឲ្យអនុវត្តគោលការណ៍នៅក្នុងខទី ៤១–៤២ សូមធ្វើបញ្ជីមួយអំពីឥរិយាបថដែលបានរៀបរាប់នៅក្នុងខទាំងនេះ ។ សូមដាក់បញ្ជីនោះត្រង់កន្លែងដែលអ្នកអាចអានវាបាន ។

៨. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៤–៤៦ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៦ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣; ការស្ដាបនាទីក្រុងណៅវូ

## សេចក្ដីផ្ដើម

ខណៈពេលដែលព្យាការី យ៉ូសែប ស្ម៊ីធ នៅក្នុងគុកលិបើធី នៅលិបើធី រដ្ឋមិសសួរី ពី ខែ ធ្នូ ឆ្នាំ ១៨៣៨ ដល់ខែ មេសា ឆ្នាំ ១៨៣៩ លោកបានសរសេរសំបុត្រនៃការលួងលោម និង ទូន្មានដល់ពួកបរិសុទ្ធ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣ គឺជាការដកស្រង់មួយចេញពីសំបុត្រនោះដែលចុះថ្ងៃទី ២០ ខែ មិនា ឆ្នា ១៨៣៩ ដែលលោកបានសរសេរទៅកាន់ពួកបរិសុទ្ធ ។ នៅក្នុងសេចក្ដីដកស្រង់នេះ យ៉ូសែប បានឲ្យដំបូន្មានទៅពួកបរិសុទ្ធដែលត្រូវបានគេបណ្ដេញចេញពីរដ្ឋមិសសួរី ។ បន្ទាប់ពីយ៉ូសែប ត្រូវបានអនុញ្ញាតឲ្យរួចពីការជាប់ឃុំ លោកបានមកជួបជុំនឹងពួកបរិសុទ្ធវិញ ហើយបានធ្វើការជាមួយពួកគេដើម្បីស្ថាបនាទីក្រុងណៅវូ រដ្ឋអិលលីណោយ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:១–៦

*យ៉ូសែប ស្ម៊ីធ ទូន្មានឲ្យពួកបរិសុទ្ធប្រមូល និង បោះពុម្ពដំណើររឿងនៃការបៀតបៀន និង ការរងទុក្ខរបស់ពួកគេ*

នៅខែ មិនា ឆ្នាំ ១៨៣៩ ពួកបរិសុទ្ធបានរងការបៀតបៀនយ៉ាងឃោរឃៅនៅមិសសួរី ។ ព្យាការី យ៉ូសែប ស្ម៊ីធ និងថ្នាក់ដឹកនាំសាសនាចក្រមួយចំនួនផ្សេងទៀតត្រូវបានគេចាប់ដាក់គុកនៅលិបើធី រដ្ឋមិសសួរី ហើយពួកបរិសុទ្ធត្រូវបានគេបណ្ដេញចេញពីរដ្ឋមិសសួរី អំឡុងខែរងាដ៏ត្រជាក់ខ្លាំង ដោយសារដីកាការសម្លាប់គ្មានសល់របស់លោកអភិបាល លីលបើន ដបុលយូ ប័ហ្គស៍ ។

> សូមអានសេចក្ដីថ្លែងការណ៍ដូចតទៅនេះ ដោយបានពិពណ៌នាពីការធ្វើខុសឆ្គងមួយចំនួនមកលើពួកបរិសុទ្ធ ៖ « នេះសូមបញ្ជាក់ថា ខ្ញុំ ឈ្មោះ ឌែលា រីដ បានប្ដូរមកនៅរដ្ឋ មិសសួរីនៅក្នុងឆ្នាំ ១៨៣៦ ។ ស្វាមីរបស់ខ្ញុំបានស្លាប់មិនយូរប៉ុន្មាន បន្ទាប់ពីយើងបានមកដល់ទីនេះ ហើយទុកកូនតូចៗប្រាំពីរនាក់ជាមួយខ្ញុំ ។ រួចខ្ញុំបានផ្លាស់ទៅភូមិខាលវែលដោយបានសង់កសិដ្ឋានមួយ [ហើយ]បន្តរស់នៅក្នុងកសិដ្ឋាននោះរហូតដល់រដូវស្លឹកឈើជ្រុះនាឆ្នាំ ១៨៣៨ ។ នៅពេលភាពច្របូកច្របល់បានកើតមានឡើងរវាងពួកប្រជាជន និង ពួកមរមន នោះខ្ញុំជាមួយនឹងសមាគមទាំងអស់របស់យើងត្រូវបានបង្ខំឲ្យចាកចេញពីរដ្ឋនោះ ។. . . ខ្ញុំត្រូវបានបង្ខំឲ្យលះបង់ទ្រព្យសម្បត្តិភាគច្រើន [ និង ] គ្រួសាររបស់ខ្ញុំ [ បាន ] ព្រាត់ប្រាស់គ្នា ហើយខ្ញុំត្រូវទទួលអាហារបន្តិចបន្តួចពី ជនដែលខ្ញុំមិនស្គាល់ » ( ឌែលា រីដ នៅក្នុង *Mormon Redress Petitions: Documents of the 1833–1838 Missouri Conflict,* បានបោះពុម្ពដោយ ខ្លាក វី ចនសុន [ ឆ្នាំ ១៩៩២ ] ទំព័រ ៥២៣ វណ្ណយុត្ត អក្សរធំ និង ការប្រកបពាក្យដែលមានបទដ្ឋាន ) ។

បងស្រី រីដ បានឲ្យសេចក្ដីថ្លែងការណ៍ជាផ្លូវការនេះទៅមន្ត្រីច្បាប់ម្នាក់ ។ សូមពិចារណាពីហេតុផលដែលគាត់ឲ្យសេចក្ដីថ្លែងការណ៍នេះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:១–៥ ដោយស្វែងរកអ្វីដែលព្យាការី យ៉ូសែប ស្ម៊ីធ បានទូន្មានឲ្យពួកបរិសុទ្ធដែលទទួលការបៀតបៀនធ្វើ ។ វាអាចមានប្រយោជន៍ដើម្បីដឹងថា នៅក្នុង ខទី ៥ ឃ្លា « ប្រជុំអំពើទុច្ចរិត » សំដៅទៅលើការប្រមូលផ្ដុំនៃអំពើកុហកទុច្ចរិត និងឃ្លា « ការបង្ខំដ៏អាក្រក់អាស្រូវ និងឃាតកម្មទាំងឡាយ » សំដៅលើអំពើអាក្រក់ និងហិង្សាទាំងឡាយ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:៦ ដោយស្វែងរកហេតុផលដែលពួកបរិសុទ្ធត្រូវបានប្រាប់ឲ្យប្រមូលដំណើររឿងនៃការបៀតបៀន និង ការរងទុក្ខរបស់ពួកគេ ។ ( នៅពេលអ្នកអាន វាមានប្រយោជន៍ដើម្បីដឹងថា ឃ្លា « ដែលតម្រូវពីយើង » មានន័យថា « តម្រូវឲ្យពួកយើង ») ។

មានពួកបរិសុទ្ធជាច្រើនបានធ្វើតាមពាក្យទូន្មានរបស់ព្យាការី ហើយបានប្រមូលដំណើររឿងនៃការបៀតបៀនរបស់ពួកគេបានយ៉ាងច្រើន ដែលវារួមបញ្ចូលការបំផ្លិចបំផ្លាញ និង ការបាត់បង់ផ្ទះសម្បែង សត្វពាហនៈ និង ទ្រព្យសម្បត្តិផ្សេងទៀតរបស់ពួកគេ ការរំលោភបំពានលើរូបកាយ ព្រមទាំងការបាត់បង់ជីវិតផងដែរ ។ តើអ្នកគិតថា ហេតុអ្វីវាជាការចាំបាច់ដើម្បីឲ្យពួកបរិសុទ្ធប្រមូលដំណើររឿងទាំងនេះ ហើយដាក់ស្នើទៅប្រមុខរដ្ឋាភិបាលជាជាងរង់ចាំ ឬសង្ឃឹមឲ្យព្រះដោះស្រាយបញ្ហារបស់

ពួកគេ ? សេចក្ដីពិតមួយដែលយើងអាចរៀនពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:៦ គឺថា **ព្រះអម្ចាស់នឹងបំពេញការសន្យារបស់ទ្រង់ បន្ទាប់ពីយើងធ្វើផ្នែករបស់យើងជាមុន ។** សូមពិចារណាហេតុអ្វីបានជាអ្នកគិតថា ព្រះអម្ចាស់រំពឹងឲ្យយើងធ្វើផ្នែករបស់យើង ពីមុនទ្រង់នឹងបំពេញការសន្យារបស់ទ្រង់ ។

១. សូមឆ្លើយសំណួរដូចទៅនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖តើអ្នកធ្លាប់ឃើញសេចក្ដីពិតត្រូវបានបំពេញនៅក្នុងជីវិតផ្ទាល់របស់អ្នក ឬនៅក្នុងជីវិតរបស់មនុស្សម្នាក់ដែលអ្នកស្គាល់នៅពេលណាដែរ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:៧–១៧

*យ៉ូសែប ស៊្មីធ ទូន្មានឲ្យពួកបរិសុទ្ធជួយដល់អស់អ្នកដែលចាញ់បោកដោយពាក្យកុហក*

សូមនឹកស្រមៃថាអ្នកត្រូវបានចាត់តាំងឲ្យសរសេររបាយការណ៍មួយអំពីសាសនាចក្រសម្រាប់មុខវិជ្ជាមួយនៅសាលារៀនរបស់អ្នក ។ ជាផ្នែកមួយនៃតម្រូវការនោះ អ្នកត្រូវរួមបញ្ចូលយ៉ាងហោចណាស់ប្រភពចំនួនបី ។ សូមគិតអំពីរបៀបដែលអ្នកនឹងឆ្លើយចំពោះសំណួរដូចតទៅនេះ ៖

- តើធនធានអ្វីដែលអ្នកអាចប្រើសម្រាប់របាយការណ៍របស់អ្នក ?
- ហេតុអ្វីបានជាវាសំខាន់ពីធនធានដែលអ្នកប្រើដើម្បីសរសេរអំពីសាសនាចក្រនោះ ?
- តើអ្នកដឹងបានដោយរបៀបណា ថាធនធានណាមួយដែលពិពណ៌នាយ៉ាងត្រឹមត្រូវពីសាសនាចក្រ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:៧–១០ ។ នៅពេលព្យាការីយ៉ូសែប ស៊្មីធ បានសរសេរសំបុត្រនេះ មានរឿងកុហកជាច្រើនអំពីសាសនាចក្រត្រូវបានរីកសាយភាយ ។ ពួកបរិសុទ្ធត្រូវបានប្រាប់ថា វាគឺជា « កាតព្វកិច្ចដ៏ចាំបាច់ » ( គ. និង ស. ១២៣:៧, ៩ ) ដើម្បីប្រមូល និង បោះពុម្ពដំណើររឿងនៃការបៀតបៀន និង ការរងទុក្ខរបស់ពួកគេដើម្បីឆ្លើយតបនឹងរឿងកុហកទាំងនេះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:១១–១២ ដោយស្វែងរកហេតុផលបន្ថែមទៀតដែលពួកបរិសុទ្ធត្រូវបានណែនាំឲ្យប្រមូល ហើយបោះពុម្ពដំណើររឿងទាំងនេះ ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:១២ តើមានមនុស្សប៉ុន្មាននាក់ដែលមានចិត្តបរិសុទ្ធដែលបានលាក់ពីសេចក្ដីពិត ?

ខ. តើការបោះពុម្ពសេចក្ដីពិតអំពីការបៀតបៀន និង ការរងទុក្ខរបស់ពួកបរិសុទ្ធនៅពេលនោះអាចជួយមនុស្សដទៃទៀតឲ្យរកសេចក្ដីពិតនៃដំណឹងល្អយ៉ាងដូចម្ដេច ?

គ. យោងតាម ខ ១២ ហេតុអ្វីមានមនុស្សជាច្រើននាក់នៅលើផែនដីនេះត្រូវបានលាក់ពីសេចក្ដីពិត ? សូមឆ្លើយសំណួរនេះដោយបំពេញសេចក្ដីពិតដូចតទៅ ៖ **មានមនុស្សជាច្រើនត្រូវបានលាក់ពីសេចក្ដីពិតដោយសារ . . .**

នៅតែមានមនុស្សជាច្រើននាពេលបច្ចុប្បន្ននេះ « ដែលបានខ្វាក់ដោយសារឧបាយកលដ៏ប្រសប់នៃមនុស្ស » ហើយដែលត្រូវបានលាក់ពីសេចក្ដីពិត ពីព្រោះពួកគេមិនដឹងជាទៅរកសេចក្ដីពិតឯណាទេ ( គ. និង ស. ១២៣:១២)។



នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍ដូចតទៅនេះរបស់អែលឌើរ អិម រ័សុល បាឡឺដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ សូមគូសបន្ទាត់ពីក្រោមនូវអ្វីដែលលោកបានលើកឡើង ដែលវាបានរារាំងមនុស្សមិនឲ្យស្គាល់សេចក្ដីពិតអំពីសាសនាចក្រនៅជំនាន់របស់យើង ៖ « មានមនុស្សជាច្រើន ដែលបានយល់តិចតួចអំពីសាសនាចក្រ ដោយសារតែព័ត៌មានភាគច្រើនដែលពួកគេបានឮអំពីយើង គឺមកពីព័ត៌មានប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលជាញឹកញាប់ជំរុញដោយការជំទាស់ ។ ការផ្ដោតចិត្តច្រើនពេកលើការជំទាស់បាននាំឲ្យជះឥទ្ធិពលអវិជ្ជមានលើការយល់ដឹងរបស់មនុស្សអំពីភាពពិត ដែលសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយមាន » (Sharing the Gospel Using the Internet » ខែ កក្កដា ឆ្នាំ ២០០៨ ទំព័រ ៦២ ) ។

ស្រដៀងគ្នានឹងពួកបរិសុទ្ធនាឆ្នាំ ១៨៣៩ ដែរ យើងត្រូវបានណែនាំឲ្យជួយមនុស្សដទៃឲ្យមានការយល់ដឹងត្រឹមត្រូវអំពីសាសនាចក្រនេះ—អំពីសមាជិក អ្នកដឹកនាំ ជំនឿ ប្រវត្តិ ការបង្រៀន និងការអនុវត្ត ។

៣. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរអ្វីដែលអ្នកអាចធ្វើដើម្បីជួយមនុស្សដទៃទៀតឲ្យទទួលបានការយល់ដឹងដ៏ត្រឹមត្រូវមួយអំពីសាសនាចក្រ និងដើម្បីជួយពួកគេឲ្យស្គាល់ពីទីកន្លែងដែលពួកគេអាចស្វែងរកសេចក្ដីពិតនោះ ។

នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍របស់អែលឌើរ បាឡឺដ ដូចតទៅនេះ សូមរកមើលវិធីមួយដែលលោកបានលើកឡើងដែលយើងអាចជួយមនុស្សដទៃទៀតឲ្យទទួលបានការយល់ដឹងដ៏ត្រឹមត្រូវអំពីសាសនាចក្រ ។



« មានការសន្ទនាជាច្រើនអំពីសាសនាចក្រឥតឈប់ឈរ ។ ការសន្ទនានោះនឹងបន្ត ទោះបីជាយើងជ្រើសរើសចូលរួម ឬ មិនចូលរួមក៏ដោយ ។ ប៉ុន្តែយើងមិនអាចឈរនៅស្ងៀម ខណៈដែលមនុស្សដទៃរួមទាំងអ្នករិះគន់របស់យើងព្យាយាមកំណត់ពីអ្វីដែលសាសនាចក្របង្រៀនឡើយ ។ ខណៈដែលការសន្ទនាមួយចំនួនមានអ្នកស្ដាប់រាប់ពាន់ ឬ រាប់លាននាក់ក៏ដោយ ការសន្ទនានោះគឺជារឿងតូចតាចទេ ។ ប៉ុន្តែការសន្ទនាទាំងនោះមានឥទ្ធិពលលើអស់អ្នកដែលចូលរួមក្នុងការសន្ទនានោះ ។ ការយល់ដឹងអំពីសាសនាចក្រត្រូវបានកកើតឡើងនៅក្នុងការសន្ទនាម្ដងៗ ។. . .

« ឥឡូវនេះខ្ញុំសូមឲ្យអ្នកចូលរួមសន្ទនាតាមរយៈ ការចូលរួមតាមអ៊ិនធើណែត ដើម្បីចែកចាយដំណឹងល្អ ហើយចូរពន្យល់នូវសារលិខិតដ៏សាមញ្ញ និងច្បាស់លាស់នៃការស្ដារឡើងវិញ ។. . . *ពិតមែនហើយ ការណ៍នេះតម្រូវឲ្យអ្នកយល់គោលការណ៍គ្រឹះរបស់ដំណឹងល្អសិន* ។ វាគឺជាការណ៍សំខាន់ដែលអ្នកអាចផ្ដល់ជាសាក្សីដ៏ *ច្បាស់*និង *ត្រឹមត្រូវ* អំពីសេចក្ដីពិត » ( « Sharing the Gospel Using the Internet » ទំព័រ ៦១–៦២ ) ។

៤. សូមបំពេញកិច្ចការខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមសរសេរពីគ្រាមួយដែលអ្នក ឬមនុស្សម្នាក់ដែលអ្នកស្គាល់បានជួយមនុស្សដទៃទៀតឲ្យយល់ដឹងបន្ថែមទៀតអំពីសាសនាចក្រ ។

ខ. សូមជ្រើសយកវិធីមួយដែលបានអ្នកបានសរសេរនៅក្នុងកិច្ចការទី ៣ ហើយសរសេរពីរបៀបដែលអ្នកនឹងធ្វើកិច្ចការនោះដើម្បីជួយមនុស្សដទៃទៀតរៀន ហើយស្វែងរកសេចក្ដីពិតអំពីសាសនាចក្រ និង ដំណឹងល្អ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:១៣–១៦ ដោយស្វែងរកអ្វីដែលពួកបរិសុទ្ធត្រូវបានប្រាប់អំពីកិច្ចខិតខំរបស់ពួកគេដើម្បីប្រាប់នូវដំណើររឿងដ៏ត្រឹមត្រូវមួយស្ដីពីបទពិសោធន៍របស់ពួកគេទៅកាន់មនុស្សដទៃទៀត ។ យោងតាម ខ ១៥ ហេតុអ្វីបានជាពួកគេត្រូវបានប្រាប់ថាកុំចាត់ទុកកិច្ចខិតខំរបស់ពួកគេថាជា « ការណ៍តូចឡើយ ? »

គោលការណ៍មួយដែលយើងអាចរៀនពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:១៥ គឺថា **ការសម្រេចចិត្តរបស់យើងដើម្បីធ្វើតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដែលហាក់បីដូចជាតូចតាច អាចមានឥទ្ធិពលធំធេងលើជីវិតរបស់យើងនាពេលអនាគត ។**

យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:១៦ តើវត្ថុដ៏តូចបែបនេះដូចជាដៃចង្កូតនាវា ( ចង្កូតដែលគ្រប់គ្រងដៃចង្កូត ) អាចជះឥទ្ធិពលទៅលើនាវាដ៏ធំមួយបានដោយរបៀបណា ? ( នៅក្នុងខនេះឃ្លា « ដោយសារដំណើរប្រក្រតី និង ខ្យល់ និង រលក » សំដៅលើការអាចបត់នាវាដើម្បីឲ្យវារក្សាលំនឹង ហើយមិនក្រលាប់នៅពេលខ្យល់ព្យុះ ) ។



៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការសម្រេចចិត្តតូចៗរបស់យើងប្រៀបបាននឹងដៃចង្កូតនាវាយ៉ាងដូចម្ដេចដែរ ?

ខ. តើការសម្រេចចិត្តទាំងនេះអាចជួយអ្នកឲ្យរក្សាលំនឹងរបស់អ្នកនៅពេលមានព្យុះភ្លៀងនៃជីវិតបានដោយរបៀបណា ?

គ. តើការសម្រេចចិត្តតូចៗអ្វីខ្លះ ដែលអ្នកកំពុងធ្វើនៅក្នុងជីវិតរបស់អ្នកនៅពេលនេះដែលអាចជះឥទ្ធិពលយ៉ាងខ្លាំងទៅលើអនាគតរបស់អ្នក ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣:១៧ ដោយស្វែងរកបៀបដែលខនេះទាក់ទងនឹងគោលការណ៍ដែលបានពន្យល់នៅក្នុង ខ ៦ ៖ **ព្រះអម្ចាស់នឹងបំពេញការសន្យារបស់ទ្រង់ បន្ទាប់ពីយើងធ្វើផ្នែករបស់យើងជាមុនសិន ។**

ផ្ដែកទៅលើអ្វីដែលព្យាការីយ៉ូសែប ស៊្មីធ បានសរសេរ យើងរៀនថា **បើយើងប្រព្រឹត្តិការណ៍ទាំងនេះដែលនៅក្នុងអំណាចយើង ដើម្បីគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ នោះយើងអាចទទួលការធានាអះអាងថា ព្រះនឹងប្រើព្រះចេស្ដារបស់ទ្រង់ ដើម្បីជួយយើងស្របតាមព្រះឆន្ទៈ និង ពេលវេលារបស់ទ្រង់ ។**

៦. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ហេតុអ្វីយើងត្រូវ « ប្រព្រឹត្តការណ៍ទាំងនេះដែលនៅក្នុងអំណាចយើង » ( គ. និង ស. ១២៣:១៧ ) ពីមុនយើងអាចមានការអះអាងថាព្រះនឹងជួយយើង ?

ខ. តើអ្នកគិតថា ហេតុអ្វីវាសំខាន់ដើម្បីប្រព្រឹត្តិការណ៍ទាំងនេះដែលនៅក្នុងអំណាចយើង *ដោយរីករាយចុះ* ?

អ្នកអាចមានទំនុកចិត្តថា នៅពេលអ្នកបានធ្វើអ្វីគ្រប់យ៉ាងដែលអ្នកអាចធ្វើបាន ដើម្បីគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះ នោះទ្រង់នឹងបំពេញការសន្យារបស់ទ្រង់ ។

## ការស្ថាបនាទីក្រុង ណៅវូ

បន្ទាប់ពី ការបណ្ដេញចេញរបស់ពួកគេពី រដ្ឋ មិសសួរី ពួកគេបានរកឃើញទីជម្រកនៅ ឃ្វីនស៊ី រដ្ឋ អិលលីណោយ និង តាមសហគមតូចៗផ្សេងទៀត ។ សូមរក ឃ្វីនស៊ី នៅលើផែនទីទី ៥នៃប្រវត្តិសាស្ត្រសាសនាចក្រ « តំបន់មិសសួរី, អិលលីណោយ និង អៃអូវ៉ា នៃស.រ.អា. » នៅក្នុងព្រះគម្ពីររបស់អ្នក ។

នៅខែ មេសា ឆ្នាំ ១៨៣៩ ពួកអ្នកយាមគុកនៅគុកនៅលិបើធី រដ្ឋមិសសួរី បានអនុញ្ញាតឲ្យយ៉ូសែប ស៊្មីធ រត់គេចខ្លួន ហើយបានជួបជុំនឹងគ្រួសារលោកនៅឃ្វីនស៊ី រដ្ឋអិលលីណោយ ។ ក្រោមការដឹកនាំរបស់ព្យាការី សាសនាចក្របានទិញដីមួយកន្លែងនៅទន្លេ មីស៊ីស៊ីបពី ភាគខាងជើងនៃឃ្វីនស៊ី ។ ភាគខាងលិចនៃទន្លេនោះគឺជាផ្នែកមួយនៃទឹកដីរដ្ឋ អៃអូវ៉ា ហើយភាគខាងកើតគឺផ្នែកមួយនៃរដ្ឋ អិលលីណោយ ។ ពួកបរិសុទ្ធបានកសាងទីស្នាក់ការកណ្ដាលថ្មីមួយរបស់សាសនាចក្រនៅផ្នែកខាងរដ្ឋ អិលលីណោយ នៅកន្លែងមួយដែលហៅថា ខំមើរស៍ ដែលពួកគេបានដាក់ឈ្មោះម្ដងទៀតថា ណៅវូ ។. *ណៅវូ* គឺជាភាសាហេព្រើមានន័យថា « ស្រស់ត្រកាល » ។



ខណៈដែលពួកបរិសុទ្ធបន្តរក្សាទីស្នាក់ការកណ្ដាលនៅក្នុងទីក្រុង ណៅវូ ព្យាការីយ៉ូសែប ស៊្មីធ ត្រូវបានបំផុសគំនិតឲ្យរៀបចំសមាគមសង្គ្រោះ ព្រះអម្ចាស់បានបើកសម្ដែងពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ អំណោយទានពិសិដ្ឋនៃព្រះវិហារបរិសុទ្ធ និង ការផ្សារភ្ជាប់អាពាហ៍ពិពាហ៍ ហើយកិច្ចការផ្សព្វផ្សាយសាសនាត្រូវបានលាតសន្ធឹងនៅទូទាំងពិភពលោក ។

៧. សូមស្នើឲ្យសមាជិកម្នាក់ក្នុងសមាគមសង្គ្រោះ ( ដូចជាសមាជិកគ្រួសារ ឬ មិត្តភក្ដិ ) ឲ្យប្រាប់អ្នកអំពីរបៀបមួយចំនួនដែលសមាគមសង្គ្រោះបានផ្ដល់ឱកាសដល់គាត់ចូលរួមក្នុងកិច្ចការរបស់ព្រះអម្ចាស់ ហើយបានប្រទានពរដល់ជីវិតគាត់ ។ សូមកត់ត្រាទុកនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវអ្វីដែលអ្នករៀនពីគាត់ ហើយត្រៀមខ្លួនចែកចាយនូវអ្វីដែលអ្នកបានកត់ត្រាទុកជាមួយនឹងសិស្សផ្សេងទៀតដែលសិក្សានៅផ្ទះ ។

៨. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៣ និង « ការស្ថាបនាទីក្រុងណៅវូ » ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៧ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១–៨៣

## បុព្វកថា

នៅក្នុងរដូវរងានាឆ្នាំ ១៨៣៨–៣៩ ពួកបរិសុទ្ធបានភៀសខ្លួនចេញពីរដ្ឋមិសសួរី ហើយបានតាំងលំនៅក្នុងរដ្ឋអិលលីណោយ តាមដងទន្លេមិស៊ីស៊ីបពី ។ នៅទីនោះ ពួកបរិសុទ្ធបានចាប់ផ្ដើមស្ថាបនាទីក្រុងមួយនៅក្នុងតំបន់តាំងទីលំនៅតូចឈ្មោះថា កូមិខូមើស ។ បន្ទាប់ការបៀតបៀន និង ទុក្ខវេទនាដែលពួកគេបានជួបមក ឥឡូវនេះពួកបរិសុទ្ធបានមានកន្លែងមួយដែលពួកគេអាចប្រមូលផ្ដុំ ហើយស្ថាបនាទីក្រុងមួយដោយភាពសុខសាន្ដ ។ ពួកគេបានបង្កើតសហគមន៍របស់ខ្លួន ហើយបានប្ដូរឈ្មោះវាទៅជាណៅវូ ។ នៅពេលព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤ នាថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៨៤១ ពួកបរិសុទ្ធបានរស់នៅក្នុងទីក្រុងណៅវូ ជិតពីរឆ្នាំ ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់បានបង្គាប់ឲ្យពួកបរិសុទ្ធសង់ព្រះវិហារបរិសុទ្ធមួយ ហើយបានពន្យល់ពីពរជ័យដែលមានសម្រាប់ពួកគេ ប្រសិនបើពួកគេមានភាពឧស្សាហ៍ព្យាយាមនៅក្នុងការសាងសង់ព្រះវិហារបរិសុទ្ធនេះ ។

### គោលលទ្ធិ និងសេចក្ដីសញ្ញា ១២៤:១–៤១, ៥៦–៨៣

*ព្រះអម្ចាស់ទ្រង់បញ្ជាឲ្យពួកបរិសុទ្ធសង់ព្រះវិហារបរិសុទ្ធ និង ផ្ទះមួយសម្រាប់អ្នកមកទស្សនកិច្ចនៅទីក្រុងណៅវូ ។*

តើកិច្ចការណាមួយដែលអ្នកធ្លាប់សម្រេចបាន ហើយវាតម្រូវឲ្យអ្នកចំណាយពេលវេលា កិច្ចការខិតខំ ឬការលះបង់ដ៏ច្រើន ? ហេតុអ្វីបានជាវាមានតម្លៃសក្ដិសមនឹងពេលវេលា កិច្ចខិតខំ ឬការលះបង់ដែលកិច្ចការតម្រូវឲ្យមាន ?



អាងជ្រមុជទឹកក្នុងព្រះវិហារបរិសុទ្ធ

ព្រះអម្ចាស់បានចាប់ផ្ដើមវិវរណៈនោះនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤ ដោយបញ្ជាឲ្យមានការប្រកាសមួយទៅកាន់ពួកអ្នកដឹកនាំនៃផែនដីអំពីការស្ដារឡើងវិញនៃដំណឹងល្អ ( សូមមើល គ. និង ស. ១២៤:១–១៤ ) ។ នៅក្នុងការបំពេញតាមបញ្ជានេះ កូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបោះពុម្ពការប្រកាសមួយនៅថ្ងៃទី ៦ ខែ មេសា ឆ្នា ១៨៤៥ ដែលបានចាប់ផ្ដើមថា

> « អ្នកករាល់គ្នាដឹងទេ ៖—
>
> « ថានគរព្រះបានមកដល់ហើយ ដូចដែលបានព្យាករដោយពួកព្យាការីពីបុរាណ ហើយបានអធិស្ឋានទូលសុំគ្រប់សម័យកាល ជានគរដែលនឹងមានពាសពេញផែនដីទាំងមូល ហើយនៅគង់វង្សជារៀងរហូត » ( នៅក្នុង ការបោះពុម្ព James R. Clark *Messages of the First Presidency of The Church of Jesus Christ of Latter–day Saints* វ៉ុល ៦ [ ឆ្នាំ ១៩៦៥–៧៥ ], ១:២៥៣) ។

រយៈពេលមួយរយសាមសិបឆ្នាំក្រោយមក ប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន នៅពេលនោះបម្រើជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានថ្លែងសុន្ទរកថានៅក្នុងសន្និសីទទូទៅមួយ ដោយលោកបានគូសបញ្ជាក់ឡើងវិញពីសារលិខិតនៃការប្រកាសនោះ ( សូមមើល « A Message to the World » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ទំព័រ ៣៣–៣៤ ) ។

បន្ថែមទៅលើការដាក់បញ្ជាឲ្យសរសេរការប្រកាសមួយ ព្រះអម្ចាស់បានប្រទានបញ្ញត្តិមួយទៅកាន់ពួកបរិសុទ្ធថាពួកគេនឹងតម្រូវឲ្យមានការលះបង់ដ៏ធំធេង ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:២៥–២៧ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានបញ្ជាឲ្យពួកបរិសុទ្ធនៅទីក្រុងណៅវូធ្វើ ។

តើព្រះអម្ចាស់សព្វព្រះទ័យឲ្យពួកបរិសុទ្ធប្រើអ្វីខ្លះដើម្បីសង់ព្រះវិហារបរិសុទ្ធនោះ ?

លុះដល់ពេលដែលពួកបរិសុទ្ធបានប្ដូរទីតាំងនៅទីក្រុងណៅវូ រដ្ឋអិលលីណោយ មានពួកបរិសុទ្ធជាច្រើនបានបាត់បង់ទ្រព្យសម្បត្តិ និង កម្មសិទ្ធិរបស់ខ្លួនស្ទើរតែទាំងអស់ ។ សូមពិចារណាថាតើការគោពតាមព្រះបញ្ញត្តិដើម្បីសង់ព្រះវិហារបរិសុទ្ធមួយទៀតអាចតម្រូវឲ្យមានសេចក្ដីជំនឿ និង ការលះបង់ពីពួកបរិសុទ្ធយ៉ាងដូចម្ដេចដែរ ។

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:២៨ ដោយស្វែងរកមូលហេតុដែលព្រះអម្ចាស់បានមានបន្ទូលថា ពួកបរិសុទ្ធត្រូវសាងសង់ព្រះវិហារបរិសុទ្ធមួយ ។ សូមគូសចំណាំអ្វីដែលអ្នករកឃើញនៅក្នុងព្រះគម្ពីររបស់អ្នក ។



ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានបង្រៀនអំពី « ភាពពេញលេញនៃបព្វជិតភាព » ដោយបានថ្លែង ៖ « មនុស្សគ្រប់រូបដែលស្មោះត្រង់ ហើយនឹងទទួលពិធីបរិសុទ្ធ និងពរជ័យទាំងនេះ ទទួលបានភាពពេញលេញនៃបព្វជិតភាព ហើយព្រះអម្ចាស់បានមានបន្ទូលថា ‹ ព្រះអង្គធ្វើឲ្យពួកគេបានស្មើគ្នានៅក្នុងអំណាច និងនៅក្នុងពលំ និងនៅក្នុងអាណាចក្រ › ។ [គ. និង ស. ៧៦:៩៥ សូមមើលផងដែរ គ. និង ស. ៨៨:១០៧] ។. . . ព្រះអម្ចាស់បានធ្វើឲ្យពរជ័យនេះអាចកើតមានចំពោះមនុស្សគ្រប់គ្នានៅក្នុងសាសនាចក្រនេះ តាមរយៈការគោរពប្រតិបត្តិរបស់គាត់ ដើម្បីទទួលបានភាពពេញលេញនៃបព្វជិតភាពតាមរយៈពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធរបស់ព្រះអម្ចាស់ ។ វាពុំអាចទទួលបានតាមវិធីណាទៀតឡើយ » (*Doctrines of Salvation*, comp ។ Bruce R. McConkie វ៉ុល៣ [១៩៥៤–៥៦], ៣:១៣២–៣៣ ) ។

សមាជិកសាសនាចក្រគ្រប់រូប—ទាំងបុរសទាំងស្ត្រី—អាចទទួលបានភាពពេញលេញនៃពរជ័យរបស់បព្វជិតភាពដោយការទទួលរាល់ពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ ។ តាមរយៈពិធីបរិសុទ្ធទាំងនេះយើងអាចទទួលបានរាល់ពរជ័យដែលព្រះវរបិតាសួគ៌មានព្រះរាជបំណងប្រោសប្រទានដល់កូនចៅរបស់ទ្រង់ ។ ការស្ដារឡើងវិញនៃពិធីបរិសុទ្ធ និង សេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធបានចាប់ផ្ដើមនៅក្នុងព្រះវិហារបរិសុទ្ធខឺតឡង់ ប៉ុន្តែវាពុំត្រូវបានបញ្ចប់នៅទីនោះទេ ។ ការសាងសង់ព្រះវិហារបរិសុទ្ធមួយនៅទីក្រុងណៅវូបានអនុញ្ញាតឲ្យការស្ដារឡើងវិញនៃពិធីបរិសុទ្ធ និង សេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធបានបន្តទៀត ( សូមមើល គ. និង ស. ១២៤:២៨, ៤០–៤១ ) ។



១. សូមអានឃ្លាពីរដំបូងនៅក្រោមប្រធានបទ ពិធីបរិសុទ្ធទាំងឡាយ » នៅក្នុងសេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ (scriptures.lds.org) ឬ *True to the Faith: A Gospel Reference* ([ ឆ្នាំ ២០០៤ | ទំព័រ ១០៩–១០) ។ រួចសូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើពិធីបរិសុទ្ធគឺជាអ្វី ?

ពិធីបរិសុទ្ធមួយចំនួនគឺចាំបាច់ចំពោះភាពលើកតម្កើងឡើង ហើយពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះទាំងនេះជាច្រើនអាចធ្វើឡើងតែនៅក្នុងព្រះវិហារបរិសុទ្ធប៉ុណ្ណោះ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:២៩ ដោយស្វែងរកពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធដ៏ ចាំបាច់មួយដែលបានគូសបញ្ជាក់ថាត្រូវស្ដារឡើងវិញ ។



**គោលលទ្ធិ គ្រឹះទាំងឡាយ**

នៅពេលអ្នកសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ហើយចេះចាំនូវបទគម្ពីរសំខាន់ៗ នោះអ្នកនឹងយល់ដឹងពីគោលលទ្ធិគ្រឹះទាំងឡាយនៃដំណឹងល្អ ។ ឧទាហរណ៍ នៅក្នុងមេរៀនផ្នែកនេះ សូមស្វែងរកចំណុចគោលលទ្ធិនៃពិធីបរិសុទ្ធទាំងឡាយដែលទាក់ទងនឹងអ្វីដែលព្រះអម្ចាស់បានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤ ។

នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៨៤០ ព្យាការីយ៉ូសែប ស្ម៊ីធ ដំបូងឡើយបានបង្រៀនថា ពួកបរិសុទ្ធអាចធ្វើពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះដូចជាបុណ្យជ្រមុជទឹកជំនួសឲ្យមិត្ត និង សមាជិកគ្រួសាររបស់ពួកដែលបានចែកឋានទៅ ដែលគ្មានឱកាសទទួលបានដំណឹងល្អ ( សូមមើល *Teachings of Presidents of the Church: Joseph Smith* [ ឆ្នាំ ២០០៧ | ទំព័រ ៤០៣ សូមមើលផងដែរ កូរិនថូស ទី១ ១៥:២៩) ។ បន្ទាប់ពីសេចក្ដីប្រកាសនេះ មានពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ជាច្រើនត្រូវធ្វើបានឡើងនៅក្នុងទន្លេមិស៊ីស៊ីបពី ឬនៅក្នុងអូរក្បែរនោះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៣០–៣៤ ហើយស្វែងរកបន្ទូលណែនាំរបស់ព្រះអម្ចាស់ទាក់ទងនឹងទីកន្លែងដែលពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ត្រូវធ្វើ ដើម្បីឲ្យទ្រង់អាចទទួលយកបាន ។

ទោះជាព្រះអម្ចាស់បានមានបន្ទូលថា ពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ត្រូវធ្វើនៅក្នុងព្រះវិហារបរិសុទ្ធក្ដី ហេតុអ្វីបានជាទ្រង់អនុញ្ញាតឲ្យពួកបរិសុទ្ធធ្វើពិធីបុណ្យជ្រមុជទឹកនៅខាងក្រៅព្រះវិហារបរិសុទ្ធជាបណ្ដោះអាសន្ន ?

បន្ទាប់ពី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤ នោះកិច្ចការសាងសង់ព្រះវិហារបរិសុទ្ធនៅណៅវូមានការរីកចម្រើនយ៉ាងឆាប់រហ័ស ។ នៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ១៨៤១ បន្ទាប់ពីជាន់ក្រោមដីនៃព្រះវិហារនោះត្រូវបានគេជីក យ៉ូសែប ស្ម៊ីធ បានប្រាប់ពួកបរិសុទ្ធថា « នឹងគ្មានពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ទៀតឡើយរហូតដល់ពិធីបរិសុទ្ធនេះអាចធ្វើឡើងនៅក្នុងដំណាក់របស់ព្រះអម្ចាស់ ។ . . . *ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះ !* » (*Teachings: Joseph Smith* ទំព័រ ៤៦៩) ។ នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៨៤១ បន្ទាប់ពីអាងជ្រមុជទឹកមួយត្រូវបានគេសង់ជាបណ្ដោះអាសន្ន ហើយបានឧទ្ទិសឆ្លងនៅជាន់ក្រោមដីនៃព្រះវិហារបរិសុទ្ធណៅវូ ពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់បានចាប់ផ្ដើមសារជាថ្មី ។ ( សូមមើល *Church History in the Fulness of Times Student Manual,* ការបោះពុម្ពលើកទី២ [Church Educational System manual ឆ្នាំ ២០០៣ ] ទំព័រ ២៥១–៥២, សូមមើលផងដែរ *Teachings of Presidents of the Church: Joseph Smith* ទំព័រ ៤៦៩–៧០) ។



គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤ បង្រៀនពីសេចក្ដីពិតដូចតទៅនេះ ៖ **ព្រះវិហារបរិសុទ្ធគឺជាទីកន្លែងតែមួយគត់ដែលយើងអាចទទួលបានភាពពេញលេញនៃពិធីបរិសុទ្ធនៃបព្វជិតភាពសម្រាប់ការប្រោសលោះដល់អ្នកនៅរស់ និង អ្នកស្លាប់ ។**

២. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរពីរបៀបដែលអ្នកគិតថាសេចក្ដីពិតនេះអាចលើកទឹកចិត្តពួកបរិសុទ្ធឲ្យធ្វើការលះបង់ដ៏ចាំបាច់ដើម្បីសង់ព្រះវិហារបរិសុទ្ធមួយនៅទីក្រុងណៅវូ ។



សូមគូសចំណាំត្រង់ពាក្យ ឬឃ្លាដែលអ្នកគិតថាសំខាន់នៅក្នុងការបង្រៀនដូចតទៅនេះមកពីប្រធាន ថូម៉ាស អេស ម៉នសុន ដែលលើកឡើងពីសារៈសំខាន់នៃសេចក្ដីពិតនេះ អំពីព្រះវិហារបរិសុទ្ធ ៖ « អស់អ្នកណាដែលយល់ដឹងពីពរជ័យដ៏នៅអស់កល្បជានិច្ចដែលកើតមាននៅក្នុងព្រះវិហារបរិសុទ្ធដឹងថា គ្មានការលះបង់ណាមួយធំធេងពេក គ្មានការបង់ថ្លៃណាមួយដែលធ្ងន់ធ្ងរពេក គ្មានឧបសគ្គណាមួយដែលលំបាកពេក ដើម្បីទទួលបានពរជ័យទាំងនោះឡើយ ។ ពួកគេនឹងធ្វើដំណើរទៅមិនថាឆ្ងាយប៉ុណ្ណានោះទេ មិនថាត្រូវយកឈ្នះឧបសគ្គច្រើនយ៉ាងណា ឬ ត្រូវស៊ូទ្រាំនឹងភាពមិនងាយស្រួលច្រើនប៉ុណ្ណានោះទេ ។ ពួកគេយល់ថាពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះទាំងឡាយ ដែលបានទទួលក្នុងព្រះវិហារបរិសុទ្ធ ដែលអនុញ្ញាតឲ្យយើងត្រឡប់ទៅព្រះវរបិតាសួគ៌នៅថ្ងៃមួយក្នុងទំនាក់ទំនងគ្រួសារអស់កល្បជានិច្ច និង ត្រូវបានប្រទានឲ្យនូវពរជ័យ និង អំណាចមកពីទីខ្ពស់ គឺមានតម្លៃគ្រប់ការពលិកម្ម និងការខិតខំទាំងអស់ ។ (The Holy Temple—a Beacon to the World » *Ensign* ឬ *Liahona,* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៩២ ) ។

៣. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរប្រយោគពីរបី ពិពណ៌នាពីហេតុផលដែលការទទួលពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធមានសារៈសំខាន់ចំពោះអ្នក ។

សូមពិចារណាពីអ្វីដែលអ្នកនឹងធ្វើនៅក្នុងជីវិតរបស់អ្នកដើម្បីរៀបចំខ្លួនឲ្យសក្ដិសមចូលទៅក្នុងព្រះវិហារបរិសុទ្ធ ហើយទទួលភាពពេញលេញនៃពិធីបរិសុទ្ធនៃបព្វជិតភាពសម្រាប់ខ្លួនឯង ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុផ្ទាល់ខ្លួន ឬលើក្រដាសអំពីអ្វីដែលអ្នកមានអារម្មណ៍ថាអ្នកត្រូវធ្វើនៅពេលនេះ ដើម្បីមានគុណសម្បត្តិគ្រប់គ្រាន់ទទួលពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៣៨–៤១ ដោយស្វែងរកហេតុផលដែលព្រះអម្ចាស់ទ្រង់បានបញ្ជាឲ្យម៉ូសេសង់ត្រសាលនៅក្នុងទីរហោស្ថាន ហើយបានណែនាំរាស្ត្ររបស់ទ្រង់ឲ្យសង់ព្រះវិហារបរិសុទ្ធមួយនៅដែនដីសន្យា ។

យោងតាមខទាំងនេះ សូមកត់សម្គាល់ថាតើពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះនៃព្រះវិហារបរិសុទ្ធកើតមានយូរប៉ុណ្ណាហើយ ។

៤. សូមនឹកស្រមៃថា អ្នកមានមិត្តម្នាក់សួរសំណួរដូចតទៅនេះដល់អ្នក រួចឆ្លើយសំណួរទាំងនោះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីបានជាសាសនាចក្រសាងសង់ព្រះវិហារបរិសុទ្ធ ?

ខ. ហេតុអ្វីព្រះវិហារបរិសុទ្ធសំខាន់ចំពោះអ្នក ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:២២–២៤, ៥៦–៨៣ ព្រះអម្ចាស់ក៏បានណែនាំពួកបរិសុទ្ធឲ្យសង់អគារមួយទៀត ដែលឲ្យឈ្មោះថា ទីសំណាក់ណៅវូ ជាកន្លែងសម្រាប់អ្នកដែលមកលេងទៅទីក្រុងណៅវូអាចស្នាក់នៅបាន ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៤២–៥៥

*ព្រះអម្ចាស់ពន្យល់ពីអ្វីដែលនឹងកើតឡើង ប្រសិនបើពួកបរិសុទ្ធថ្ងៃចុងក្រោយគោរពតាមព្រះបញ្ញត្តិដែលឲ្យសាងសង់ព្រះវិហារបរិសុទ្ធ ។*



អគារនេះត្រូវបានសាងសង់នៅផ្នែកមួយនៃគ្រឹះរបស់ទីសំណាក់ណៅវូដែលមិនទាន់សង់ចប់សព្វគ្រប់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៤២–៤៥ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បានមានបន្ទូលថានឹងកើតឡើង ប្រសិនបើពួកបរិសុទ្ធសង់ព្រះវិហារបរិសុទ្ធនៅណៅវូ រដ្ឋអិលលីណោយ ហើយស្ដាប់ព្រះសូរសៀងរបស់ទ្រង់ និង សំឡេងនៃពួកអ្នកបម្រើរបស់ទ្រង់ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៤៦–៥៤ ព្រះអម្ចាស់បានពន្យល់ពីអ្វីដែលនឹងកើតឡើង ប្រសិនបើពួកបរិសុទ្ធសង់ព្រះវិហារបរិសុទ្ធ ប៉ុន្ដែមិនស្ដាប់ព្រះសូរសៀងរបស់ទ្រង់ ឬសំឡេងនៃពួកអ្នកបម្រើរបស់ទ្រង់ ។ ទ្រង់ក៏បានពន្យល់ផងដែរថា ទ្រង់នឹងទទួលយកកិច្ចខិតខំរបស់ពួកបរិសុទ្ធក្នុងការសម្រេចកិច្ចការរបស់ទ្រង់ ( រួមបញ្ចូលទាំងការសង់ព្រះវិហារបរិសុទ្ធផងដែរ ) សូម្បីតែពួកគេត្រូវបានរារាំងមិនឲ្យធ្វើកិច្ចការនោះដោយសារការបៀតបៀនដែលពួកគេបានជួបក្ដី ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៥៥ ដោយស្វែងរកមើលអ្វីដែលព្រះអម្ចាស់បានប្រកាសថាពួកបរិសុទ្ធត្រូវបង្ហាញទ្រង់ដោយការគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ក្នុងការសង់ព្រះវិហារបរិសុទ្ធណៅវូ ។

យោងតាម ខ ៥៥ តើយើងបង្ហាញអ្វីខ្លះដល់ព្រះអម្ចាស់ នៅពេលយើងគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ?

អ្នកអាចនឹងចង់សរសេរគោលការណ៍ដូចតទៅនេះដាក់នៅក្នុងព្រះគម្ពីររបស់អ្នកក្បែរ ខ ៥៥ ៖ **តាមរយៈការគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ យើងបង្ហាញពីសេចក្ដីស្មោះត្រង់របស់យើង ។**

៥. សូមពិចារណាពីពេលវេលានៅក្នុងជីវិតរបស់អ្នក ពេលអ្នកធ្លាប់គោរពតាមព្រះបញ្ញត្តិមួយ ដោយស្ដែងចេញពីបំណងប្រាថ្នាមួយដើម្បីមានភក្ដីភាព និង ភាពស្មោះត្រង់ចំពោះព្រះវរបិតាសួគ៌ និង ព្រះអង្គសង្គ្រោះ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរអំពីបទពិសោធន៍មួយក្នុងចំណោមបទពិសោធន៍ទាំងនេះ ហើយអារម្មណ៍របស់អ្នកអំពីការបង្ហាញដល់ព្រះអម្ចាស់នូវភក្ដីភាព និង ភាពស្មោះត្រង់របស់អ្នកចំពោះទ្រង់ ។

យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៥៥ តើពរជ័យបន្ថែមទៀតដែលព្រះអម្ចាស់បានសន្យាដល់ពួកបរិសុទ្ធនោះមានអ្វីខ្លះ ប្រសិនបើពួកគេនឹងសង់ព្រះវិហារបរិសុទ្ធមួយនៅទីក្រុងណៅវូ ?

៦. ពរជ័យនៃកិត្តិយស អមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដែលបានសន្យានៅក្នុង ខ ៥៥ គឺមានភាពអស់កល្បជានិច្ច ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរពីហេតុផលដែលអ្នកគិតថា វាជាការចាំបាច់ដើម្បីយល់ដឹងថា ពរជ័យមួយចំនួនដែលយើងទទួលបានដោយសារតែភាពស្មោះត្រង់របស់យើងចំពោះព្រះអម្ចាស់អាចនឹងមិនប្រទានឲ្យភ្លាមៗនោះទេ ។

សូមល្បងខ្លួនឯងដើម្បីបង្ហាញពីភាពស្មោះត្រង់របស់អ្នកដល់ព្រះ តាមរយៈការគោរពព្រះបញ្ញត្តិរបស់ទ្រង់ដោយស្មោះត្រង់ ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១–៨៣ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៦ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤–១៤៥; ១២៥–២៦

## បុព្វកថា

គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤–១៤៥ បានទទួលនៅថ្ងៃ ទី ១៩ ខែ មករា ឆ្នាំ ១៨៤១ មានដំបូន្មានរបស់ព្រះអម្ចាស់ទៅកាន់សមាជិកសាសនាចក្រម្នាក់ៗ ។ ទ្រង់ក៏បានដាក់ឈ្មោះនៃអស់អ្នកដែលត្រូវបម្រើនៅក្នុងមុខងារផ្សេងៗនៃថ្នាក់ដឹកនាំបព្វជិតភាពផងដែរ ។ នៅក្នុងខែ មិនា ឆ្នាំ ១៨៤១ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៥ ដែលព្រះអម្ចាស់បានបើកសម្ដែងព្រះឆន្ទៈរបស់ទ្រង់ទាក់ទងនឹងការប្រមូលផ្ដុំពួកបរិសុទ្ធនៅក្នុងទឹកដី អៃអូវ៉ា ។ នៅថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ១៨៤១ ព្យាការីបានទទួលវិវរណៈដែលមាននៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ១២៦ ដែលព្រះអម្ចាស់បានប្រាប់ ព្រិកហាំ យ៉ង់ ថាលោកនឹងពុំតម្រូវឲ្យចាកចេញពីគ្រួសាររបស់លោកដើម្បីបម្រើបេសកកម្មទៀតឡើយ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤–១២២

*ព្រះអម្ចាស់បានប្រទានដំបូន្មានដល់បុគ្គលជាក់លាក់ទាំងឡាយ*

សូមគិតពីគ្រាមួយដែលអ្នកបានទទួលពាក្យទូន្មានមកពីមនុស្សម្នាក់ដែលចង់ជួយអ្នក ។ តើអ្នកបានធ្វើតាមពាក្យទូន្មាននោះដែរឬទេ ? ហេតុអ្វីធ្វើតាម ឬ ហេតុអ្វីអត់ធ្វើតាម ?



នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤–១១៨ ព្រះអម្ចាស់បានប្រទានពាក្យទូន្មានដោយផ្ទាល់ដល់សមាជិកសាសនាចក្រជាក់លាក់ម្នាក់ៗ បើសិនពួកគេធ្វើតាម នោះសន្យាថានឹងបានពរជ័យដ៏មហិមា ។ សូមអានសារលិខិតដូចតទៅនេះ ដោយរកមើលភាពស្រដៀងគ្នាមួយនៅក្នុងពាក្យទូន្មានដែលបានផ្ដល់ដល់បុគ្គលទាំងនេះ ។ ( វាអាចមានប្រយោជន៍ដើម្បីដឹងថា *ពាក្យទូន្មាន* សំដៅទៅលើការណែនាំ ការដឹកនាំ ឬសេចក្ដីបង្គាប់ ។ អ្នកគួរគូសចំណាំពាក្យទូន្មានដែលស្រដៀងគ្នា ) ។

- ខ ៨៩–៩០ ( វិលលាម ឡរ៍ )
- ខ ៩៤–៩៦ ( ហៃរុម ស្ម៊ីធ )
- ខ ១១១–១៤ ( អេម៉ុស ដាវីស )
- ខ ១១៥–១៨ ( រ៉ូប៊ើត ហ្វស្ទើរ )

សូមមើលខគម្ពីរដែលអ្នកបានអានឡើងវិញ ហើយរកមើលពរជ័យដែលព្រះអម្ចាស់បានសន្យានឹងប្រទានឲ្យ បើសិនពួកបុរសទាំងនេះធ្វើតាមការទូន្មានដែលទ្រង់បានប្រទានដល់ពួកគេ ។ នៅត្រង់ចន្លោះ សូមសរសេរពីពរជ័យដែលព្រះអម្ចាស់បានសន្យាដល់ពួកគេ ៖

គោលការណ៍មួយដែលយើងបានរៀនពីខគម្ពីរទាំងនេះ ដែលវាអនុវត្តចំពោះកូនចៅទាំងអស់របស់ព្រះគឺថា **ប្រសិនបើយើងស្ដាប់តាមពាក្យទូន្មានរបស់ពួកព្យាការី យើងនឹងបានសេចក្ដីសុខ ។**

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើពាក្យទូន្មានជាក់លាក់អ្វីខ្លះដែលប្រធានសាសនាចក្របានផ្ដល់នៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះ ?

ខ. តើពេលណាដែលអ្នកបានទទួលពរជ័យ ដោយការស្ដាប់តាមការទូន្មានរបស់ព្យាការី ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤ ហើយរកមើលអ្វីដែលព្រះអម្ចាស់មានបន្ទូលថា សមាជិកសាសនាចក្រម្នាក់ឈ្មោះ អាលម៉ុន បាបបិត បានកំពុងធ្វើ ជាជាងការធ្វើតាមការទូន្មានរបស់គណៈប្រធាននៃសាសនាចក្រ ។ វាអាចមានប្រយោជន៍ដើម្បីដឹងថា « រូបគោមាស » សំដៅទៅលើរូបបដិមា ឬព្រះក្លែងក្លាយដែលអើរ៉ុនបានធ្វើសម្រាប់កូនចៅអ៊ីស្រាអែលកាលព្យាការីម៉ូសេនៅលើភ្នំស៊ីណាយ ( សូមមើល និក្ខមនំ ៣២ ) ។ វាគឺជានិមិត្តរូបមួយនៃរឿងខាងលោកិយដែលអាចអូសទាញ ហើយរារាំងយើងមិនឲ្យបានពរជ័យខាងវិញ្ញាណ ។

យោងតាម ខ ៨៤ « រូបគោមាស »របស់អាលម៉ុន បាបបិត គឺថា គាត់បានប្រាថ្នាចង់បង្កើតការប្រឹក្សាផ្ទាល់ខ្លួនជាជាងការប្រឹក្សាមកពីគណៈប្រធានទីមួយ ។

សូមអាន ការព្រមានរបស់ប្រធាន ស្ពែនសឺរ ដបុលយូ឴ ឃឹមបឹល អំពីព្រះក្លែងក្លាយជាច្រើនដែលមនុស្សថ្វាយបង្គំនៅសព្វថ្ងៃនេះ ហើយពិចារណារូបបដិមាទាំងនេះនាសម័យទំនើបអាចជំនួសឲ្យការប្រឹក្សារបស់ពួកព្យាការីដែលនៅរស់ដូចតទៅ ៖



« រូបសំណាកសម័យទំនើប ឬ រូបព្រះខុសឆ្គងអាចមានទម្រង់ដូចជា សំលៀកបំពាក់ ផ្ទះ ជំនួញ ម៉ាស៊ីន រថយន្ត ទូកកំសាន្ត និង សម្ភារបួតផ្សេងទៀតជាច្រើនតាមផ្លូវទៅកាន់ភាពជាព្រះ ។ តើវាមានភាពខុសគ្នាយ៉ាងណាទៅ ប្រសិនបើវត្ថុដែលមានការព្រួយបារម្ភពុំមានរូបរាងដូចជារូបបដិមា ?. . .

« វត្ថុអរូបីយប្រៀបបានដូចជាពួកព្រះ ។ កម្រិតសញ្ញាបត្រ និង លិខិត ព្រមទាំងមុខងារអាចជារូបបដិមា ។. . . បរិញ្ញាបត្រ [ នៃមហាវិទ្យាល័យ ] និង ទ្រព្យសម្បត្តិ និង សន្តិសុខ ដែលកើតមានតាមរយៈរឿងទាំងនេះ លេចឡើងយ៉ាងទាក់ទាញរហូតធ្វើឲ្យ [ ការបម្រើ ] បេសកកម្មធ្លាក់មកលំដាប់ទីពីរ ។ មនុស្សខ្លះបានបោះបង់ការមកព្រះវិហារ ពេលរៀននៅមហាវិទ្យាល័យ ដោយផ្ដោតអារម្មណ៍ទៅលើការបំពាក់បំប៉នខាងលោកិយ ហើយប្រានចោលសេចក្ដីសញ្ញាខាងវិញ្ញាណដែលពួកគេបានធ្វើ ។. . .

« មនុស្សជាច្រើនគោរពការបរបាញ់ ដំណើរកំសាន្តស្ទូចត្រី វិស្សមកាល ពេលវេលាពិចនិចចុងសប្ដាហ៍ និង ការចេញទៅក្រៅ ។ អ្នកផ្សេងទៀតមានល្បែងកីឡា បាល់បោះ បាល់ទាត់ ល្បែងប្រកួតសត្វគោ ឬ ការលេងកូនហ្គោលជារូបព្រះរបស់ពួកគេ ។ ជាទូទៅ ការស្វែងរកទាំងនេះចូលឡុកឡំនឹងការថ្វាយបង្គំព្រះអម្ចាស់ និងការផ្ដល់ការបម្រើដើម្បីស្ថាបនានគរព្រះ ។ ចំពោះពួកអ្នកធ្វើកិច្ចការនេះ ការគូសបញ្ជាក់នេះទំនងប្រហែលពុំមែនជារឿងធំដុំនោះទេ ប៉ុន្តែវាចង្អុលបង្ហាញថាតើភាពទៀងត្រង់ និង ភាពស្មោះត្រង់របស់ ពួកគេស្ថិតនៅត្រង់ណា ។

« នៅមានរូបភាពមួយទៀតដែលមនុស្សថ្វាយបង្គំគឺអំណាច និង កិត្យានុភាព ។ មនុស្សជាច្រើននឹងជាន់ឈ្លីនៅក្រោមជើងនូវរឿងខាងវិញ្ញាណ ហើយជារឿយៗនូវតម្លៃសីលធម៌ដោយភាពឆ្មើងឆ្មៃដើម្បីចាប់យកភាពជោគជ័យរបស់ពួកគេ ។ ពួកព្រះទាំងនេះដែលរួមមាន អំណាច ទ្រព្យសម្បត្តិ និង ឥទ្ធិពលគឺជាអ្វីដែលគេចង់បានបំផុត ហើយវាពិតដូចជារូបគោមាសរបស់ពួកកូនចៅអ៊ីស្រាអែលនៅក្នុងទីរហោស្ថានដែរ » ( *The Miracle of Forgiveness* [ ឆ្នាំ ១៩៦៩ ] ទំព័រ ៤០–៤២ ) ។

២. សូមឆ្លើយសំណួរដូចទៅនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើវិធីមួយចំនួនដែលមនុស្សអាចដាក់ការប្រឹក្សារបស់ខ្លួនហួសពីការប្រឹក្សាដែលព្រះអម្ចាស់បានប្រទានឲ្យយើងនៅសព្វថ្ងៃនេះតាមរយៈពួកព្យាការីរបស់ទ្រង់មានអ្វីខ្លះ ?



សូមចងចាំថា អ្នកអាចមានភាពជឿជាក់នៅក្នុងការប្រឹក្សា និង ការណែនាំរបស់ពួកព្យាការីបាន ដោយសារពួកលោកថ្លែងនូវព្រះបន្ទូលរបស់ព្រះអម្ចាស់ ( សូមមើល គ. និង ស. ១:៣៨ ) ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១១៩–២២ មាននូវការណែនាំបន្ថែមដល់សាសនាចក្រទាក់ទងនឹងការណែនាំអំពីផ្ទះសំណាក់ណៅវូ ដែលក្លាយជាសណ្ឋាគារផ្ទាល់របស់សាសនាចក្រ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១២៣–៤៥

*ព្រះអម្ចាស់ប្រាប់ឈ្មោះនៃអស់អ្នកដែលត្រូវបម្រើនៅក្នុងមុខងារផ្សេងៗនៃថ្នាក់ដឹកនាំបព្វជិតភាព*

សូមសរសេរតួនាទីថ្នាក់ដឹកនាំបព្វជិតភាពមួយចំនួននៅក្នុងសាសនាចក្រ ៖

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១២៣–៤៥ ព្រះអម្ចាស់បានប្រាប់ឈ្មោះជាក់លាក់របស់មនុស្សមួយចំនួនដើម្បីបម្រើក្នុងមុខងារផ្សេងៗនៃថ្នាក់ដឹកនាំបព្វជិតភាព ។ សូមអាន ខ ១២៣–៤២ ដោយរកមើលតួនាទីថ្នាក់ដឹកនាំបព្វជិតភាពដែលព្រះអម្ចាស់បានលើកឡើង ។ សូមដាក់បន្ថែមនូវតួនាទីផ្សេងទៀតដែលអ្នកពុំមានសរសេរនៅក្នុងបញ្ជីរបស់អ្នក ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១៤៣ ដោយរកមើលពីហេតុផលដែលព្រះអម្ចាស់ហៅថ្នាក់ដឹកនាំបព្វជិតភាពហើយប្រទានកូនសោបព្វជិតភាព ។

យើងរៀនពីសេចក្ដីពិតដូចតទៅនៅក្នុងខគម្ពីរនេះ ៖ **ព្រះអម្ចាស់ហៅថ្នាក់ដឹកនាំបព្វជិភាពដើម្បីគ្រប់គ្រងកិច្ចការនៃការបម្រើហើយជួយធ្វើឲ្យពួកបរិសុទ្ធឲ្យបានគ្រប់លក្ខណ៍ ។** ( កិច្ចការនៃការបម្រើ និងការធ្វើឲ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍សំដៅទៅលើកិច្ចការនៃការជួយកូនចៅព្រះវរបិតាសួគ៌ទាំងអស់ឲ្យខិតមកជិតទ្រង់ ហើយត្រឡប់ទៅវត្តមានទ្រង់វិញដោយភាពសក្ដិសម ) ។ សូមពិចារណាក្នុងការគូសចំណាំពាក្យ ឬឃ្លាដែលបង្រៀនសេចក្ដីពិតនេះនៅក្នុងព្រះគម្ពីររបស់អ្នក ។

៣. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរអំពីវិធីមួយ ឬពីរដែលថ្នាក់ដឹកនាំបព្វជិតភាពរបស់អ្នកធ្លាប់ជួយអ្នកឲ្យខិតទៅជិតព្រះវរបិតាសួគ៌របស់អ្នក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៥

*ព្រះអម្ចាស់ដឹកនាំពួកបរិសុទ្ធឲ្យប្រមូលផ្ដុំគ្នាទៅកន្លែងនានាដែលទ្រង់បានកំណត់*

បន្ទាប់ពីពួកបរិសុទ្ធត្រូវបានបណ្ដេញចេញពីរដ្ឋ មិសសួរី នៅរដូវរងាឆ្នាំ ១៨៣៨–៣៩ ពួកគេបានធ្វើដំណើរចូលទៅ រដ្ឋ អិលលីណោយ និង អៃអូវ៉ា ជាកន្លែងដែលពួកគេបានតាំងទីលំនៅទាំងសងខាងលើច្រាំងទន្លេ មីស៊ីស៊ីបពី ។ វិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៥ ត្រូវបានទទួលនៅខែ មិនា ឆ្នាំ ១៨៤១ ហើយវាបើកសម្ដែងពីព្រះឆន្ទៈរបស់ព្រះអម្ចាស់ទាក់ទងនឹងពួកបរិសុទ្ធ ។ នៅពេលអ្នកអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៥ សូមស្វែងរកការណែនាំដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធទាំងនេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៦

*ព្រិកហាំ យ៉ង់ ពុំតម្រូវឲ្យចាកចេញពីគ្រួសាររបស់លោកដើម្បីបម្រើបេសកកម្មបន្ថែមទៀតឡើយ*

សូមស្រមៃថាតើវាមានទិដ្ឋភាពបែបណាដែរនៅពេលអ្នកចាកចេញពីគ្រួសារទៅបម្រើបេសកកម្មសម្រាប់ព្រះអម្ចាស់ក្នុងរយៈពេលរដូវក្ដៅប្រាំឆ្នាំបន្ទាប់ទៀត ហើយបន្ទាប់មកនឹងត្រូវបានហៅបម្រើបេសកកម្មមួយទៀតនៅបរទេសរយៈពេលជិតពីរឆ្នាំ ។ តើអ្នកនឹងមានអារម្មណ៍ដូចម្ដេច អំពីការចាកចេញពីគ្រួសារអ្នកច្រើនដងបែបនេះ ? តើអ្នកមានអារម្មណ៍យ៉ាងណាបើសិនអ្នកមានទំនួលខុសត្រូវចំពោះសេចក្ដីត្រូវការរបស់គ្រួសារអ្នក ?

បន្ទាប់ពី ព្រិកហាំ យ៉ង់ បានចូលរួមសាសនាចក្រនៅខែ មេសា ឆ្នាំ ១៨៣២ លោកបានបម្រើបេសកកម្មប្រាំពីរក្នុងរយៈពេលប្រាំបួនឆ្នាំ ។ បេសកកម្មដំបូងរបស់លោកគឺអំឡុងពេលនៃរដូវរងា បន្ទាប់ពីលោកបានទទួលបុណ្យជ្រមុជទឹករួច ។ ការបម្រើបេសកកម្មប្រាំផ្សេងទៀត រួមមានការចូលរួមរបស់លោកនៅក្នុង ជំរុំស៊ីយ៉ូន បានកើតឡើងរាល់រដូវក្ដៅពីឆ្នាំ ១៨៣៣ ដល់ ១៨៣៧ ។ បេសកកម្មទាំងនេះមានរយៈពេលចាប់ពីបី ទៅប្រាំខែ ។ ក្នុងឆ្នាំ ១៨៣៩ ព្រិកហាំ យ៉ង់ ជាមួយនឹងសាវកផ្សេងទៀតត្រូវបានហៅឲ្យបម្រើបេសកកម្មនៅចក្រភពអង់គ្លេស ។ ពួកគេបានធ្វើតាមការណែនាំរបស់ព្រះអម្ចាស់ ដើម្បីចាកចេញទៅបេសកកម្មនេះពី ហ្វាវែស្ទ រដ្ឋ មិសសួរី នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៨៣៩ ( សូមមើល គ. និង ស. ១១៨) ។ ព្រិកហាំ និង សាវកផ្សេងទៀតបានចំណាយពេលពីរបីខែបន្ទាប់នៅក្នុងរដ្ឋ អៃអូវ៉ា និង អិលលីណោយ ធ្វើការរៀបចំបន្ថែមទៀតដើម្បីធ្វើដំណើរទៅចក្រភពអង់គ្លេស ។ ការឆ្លងរោគគ្រុនចាញ់ បានកើតមាននៅក្នុងតំបន់នោះនារដូវក្ដៅឆ្នាំ ១៨៣៩ ហើយពួកគេក៏បានឆ្លងជំងឺនោះផងដែរ ។



សូមអានសេចក្ដីថ្លែងការណ៍ដូចតទៅនេះមកពីព្រិកហាំ យ៉ង់ ហើយរកមើលភស្ដុតាងនៃឥរិយាបថរបស់ព្រិកហាំចំពោះការបម្រើព្រះអម្ចាស់ថ្វីបើមានជំងឺជាទម្ងន់រហូតត្រូវមានគេជួយពេលឡើងជិះរទេះចេញទៅក៏ដោយ ៖« ខ្ញុំសម្រេចចិត្តទៅប្រទេស អង់គ្លេស ឬ ក៏ធ្វើការណ៍នោះរហូតដល់ស្លាប់ » ។ ខ្ញុំមានការតាំងចិត្តយ៉ាងមុតមាំថា ខ្ញុំនឹងធ្វើអ្វីដែលខ្ញុំបានតម្រូវឲ្យធ្វើនៅក្នុងដំណឹងល្អនៃជីវិត និង សេចក្ដីសង្គ្រោះ ឬ ខ្ញុំនឹងស្លាប់ដោយការព្យាយាមធ្វើការណ៍នេះ » (*Teachings of Presidents of the Church: Brigham Young* [ឆ្នាំ ១៩៩៧ ], ទំព័រ ៥) ។

ការបម្រើជាអ្នកផ្សព្វផ្សាយសាសនារបស់ព្រិកហាំ យ៉ង់ បានតម្រូវឲ្យមានការលះបង់ពីគ្រួសារគាត់ផងដែរ ។ សូមអានសេចក្ដីសង្ខេបខាងក្រោមនេះអំពីស្ថានភាពរបស់គ្រួសារព្រិកហាំ នៅពេលលោកបានចេញទៅបម្រើបេសកកម្មរបស់ខ្លួនទៅចក្រភពអង់គ្លេស ៖

ព្រិកហាំ យ៉ង់ បានចេញពី ម៉ុនទ្រូស រដ្ឋ អៃអូវ៉ា ទៅចក្រភពអង់គ្លេស នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៨៣៩ គឺដប់ថ្ងៃបន្ទាប់ពីភរិយារបស់លោក ម៉ារី អាន បានឆ្លងទន្លេកូនទីបួនរបស់ពួកគេ ។ ម៉ារី អាន បានរងទុក្ខដោយសារជំងឺគ្រុនចាញ់ ។ នេះគឺជាលើកទីប្រាំហើយតាំងពីពួកគេបានរៀបការដែលគាត់បានឲ្យព្រិកហាំចេញទៅបេសកកម្ម ។ បន្ទាប់ពីត្រូវបានបណ្ដេញចេញពីផ្ទះ និង បានបាត់បង់ទ្រព្យសម្បត្តិរបស់ពួកគេនៅក្នុងរដ្ឋ មិសសួរី កាលពីឆ្នាំមុន ពួកគេមានភាពក្រតោកយ៉ាក ។ ប្រធានព្រិកហាំបានបន្សល់ប្រាក់តែ ២.៧២ ដុល្លារ ឲ្យម៉ារី អាន សម្រាប់គ្រួសាររបស់ពួកគេ ។ ប្រធានព្រិកហាំ និង ម៉ារី អាន បានទុកចិត្តថា ព្រះអម្ចាស់នឹងប្រទានពរដល់ពួកគេ និង ពឹកផ្អែកលើការសន្យាពីព្រះអម្ចាស់ ដែលថា ក្រុមគ្រួសាររបស់ពួកសាវកនឹងទទួលបានការថែទាំសម្រាប់សេចក្ដីត្រូវការនានាខណៈដែលពួកសាវកទាំងនោះចេញទៅបម្រើបេសកកម្ម ( សូមមើល គ. និង ស. ១១៨:៣ ) ។

នៅពេលអៃលឌើរ ព្រិកហាំ យ៉ង់ ហ៊ីបឺរ ស៊ី គិមបុល និង ជួច អេ ស៊្មីធបានធ្វើដំណើរឆ្ពោះទៅភាគខាងកើតសហរដ្ឋសម្រាប់បេសកកម្មរបស់ពួកគេទៅចក្រភពអង់គ្លេស « ព្រិកហាំបានលូកដៃចូលទៅក្នុងហិបរបស់គាត់ ហើយតែងឃើញមានលុយគ្រប់គ្រាន់សម្រាប់ថ្លៃការបង្រៀនបន្ទាប់ទៀតរបស់ពួកលោក ។ លោកបានគិតថា ហ៊ីបឺរបានបន្ថែមប្រាក់ ប៉ុន្តែក្រោយក្រោយមកបានដឹងថាលោកពុំបានធ្វើដូច្នេះទេ ។ បងប្អូនប្រុសទាំងនេះបានចាប់ផ្ដើមធ្វើដំណើរមានតែប្រាក់ដង្វាយ ១៣.៥០ ដុល្លារ ប៉ុន្តែពួកលោកបានចំណាយច្រើនជាង ៨៧ ដុល្លារសម្រាប់ថ្លៃបង្រៀន ។ ពួកលោកពុំបានដឹងថា ប្រាក់នោះបាននៅក្នុងហិបរបស់ពួកលោកដោយរបៀបណាទេ ‹ លើកលែងតែទេវតានៅស្ថានសួគ៌បានដាក់ឲ្យដើម្បីបន្តការផ្សាយដំណឹងល្អ [ នៅក្នុង Leonard J. Arrington *Brigham Young: American Moses* [ ឆ្នាំ ១៩៨៥ ] ទំព័រ ៧៧ ] » ។ (*Church History in the Fulness of Times Student Manual* បោះពុម្ពទី ២ [ Church Educational System manual, ឆ្នាំ ២០០៣ ] ទំព័រ ២២៨) ។

នៅពេលលោក បានដឹកនាំពង្រីកកិច្ចការអ្នកផ្សព្វផ្សាយសាសនាទូទាំងកោះនៃប្រទេសអង់គ្លេស ព្រិកហាំ យ៉ង់ បានបង្ហាញសមត្ថភាពខាងវិញ្ញាណដ៏អស្ចារ្យ និង សមត្ថភាពនៃរដ្ឋបាល ។ ក្រោមការដឹកនាំរបស់ព្រិកហាំ យ៉ង់ និង សាវកផ្សេងទៀត សាសនាចក្របានរីកចម្រើនយ៉ាងខ្លាំងនៅក្នុងចក្រភពអង់គ្លេស ។ នៅពេលនោះសាវកស្ទើរតែទាំងអស់ បានបញ្ចប់បេសកកម្មរបស់ពួកលោកនៅលើកោះនានាក្នុងប្រទេសអង់គ្លេសនៅចុងខែ មេសា ឆ្នាំ ១៨៤១ មានមនុស្សច្រើនជាង ៥,០០០ នាក់បានចូលសាសនាចក្រ ដែលមានគ្នា ប្រហែល ១,០០០ នាក់បានធ្វើអន្តោប្រវេសន៍ទៅទីក្រុង ណៅវូ ពីរបីខែមុននោះ ។

« បេសកកម្មនេះគឺជាពេលសំខាន់មួយនៃការបំពាក់បំប៉ន និង មានភាពចាស់ទុំសម្រាប់កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ព្រិកហាំ យ៉ង់ បានពង្រឹងជំនាញនៃភាពដឹកនាំ ដែលមិនយូរមិនឆាប់នឹងត្រូវបានហៅដើម្បីប្រើវានៅក្នុងទីក្រុង ណៅវូ ។. . . តាមរយៈការសាកល្បង និង ការលះបង់នៅក្នុងប្រទេសអង់គ្លេស ព្រមទាំងការធ្វើការក្នុងគោលដៅរួម នោះពួកដប់ពីរនាក់បានរួមគ្នាក្នុងរបៀបមួយដែលធានាឲ្យមានភាពរឹងមាំក្នុងថ្នាក់ដឹកនាំសាសនាចក្រនៅក្នុងឆ្នាំបន្តបន្ទាប់ទៀត » ( *Church History in the Fulness of Times*,ទំព័រ ២៣៤) ។



ព្រិកហាំ យ៉ង់បានដឹកនាំកិច្ចការផ្សព្វផ្សាយសាសនានៅកោះនានាក្នុងប្រទេសអង់គ្លេស ។

បន្ទាប់ពីការដឹកនាំកិច្ចការអ្នកផ្សព្វផ្សាយសាសនារបស់សាសនាចក្រនៅក្នុងចក្រភពអង់គ្លេស ព្រិកហាំ យ៉ង់ បានទៅដល់ទីក្រុង ណៅវូ រដ្ឋ អិលលីណោយ នៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ១៨៤១ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈ ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៦ ប្រាំបីថ្ងៃក្រោយមក ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៦:១–៣ ដោយស្វែងរកអ្វី ដែលព្រះអម្ចាស់បានមានបន្ទូលប្រាប់ព្រិកហាំអំពីការបម្រើរបស់លោក ។ តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះអម្ចាស់បានសព្វព្រះទ័យនឹងការបម្រើរបស់អ្នក ?

សូមបំពេញគោលការណ៍ដូចតទៅស្ដីពីការបម្រើដែលយើងផ្ដល់ឲ្យមកពីអ្វីដែលអ្នកបានរៀននៅក្នុង ខ ១–២ ៖ **ប្រសិនបើយើងធ្វើការដោយឧស្សាហ៍ថ្វាយព្រះអម្ចាស់ ទ្រង់នឹង ការបូជាដ៏សុចរិតរបស់យើង**

« ក្រៅពីអាចចំណាយពេលច្រើនជាមួយគ្រួសាររបស់លោក ក្រោយពីវិវរណៈ នេះ [គ. និង ស. ១២៦] នោះព្រិកហាំ យ៉ង់ ក៏បាននៅក្បែរព្យាការី យ៉ូសែប ស្ម៊ីធ អស់ពេលជាច្រើនឆ្នាំជាងលោកអាចធ្វើបានកាលពីប៉ុន្មានឆ្នាំមុន ( ម្ភៃប្រាំបី ខែនៃសាមសិបប្រាំមួយខែចុងក្រោយនៃជីវិតរបស់យ៉ូសែប ) ។

« វាហាក់បីជាប្រាកដថាព្រះអម្ចាស់បានដឹងពីអនាគត ព្រិកហាំ យ៉ង់ និង អនាគតរបស់សាសនាចក្រ ដោយបានឲ្យ ព្រិកហាំ នៅក្បែរយ៉ូសែប ដូច្នេះលោកអាចរៀនអ្វីដែលចាំបាច់ដើម្បីដឹង ដើម្បីដឹកនាំសាសនាចក្របន្ទាប់ពីយ៉ូសែប ស្លាប់ » ( *Doctrine and Covenants Student Manual,* ការបោះពុម្ពលើកទី ២ [ Church Educational System manual ឆ្នាំ ២០០១ ] ទំព័រ ៣១៣) ។

ទោះបីជាព្រិកហាំ យ៉ង់ មិនតម្រូវឲ្យចាកចេញពីគ្រួសារលោកទៅបម្រើបេសកកម្មបន្ថែមទៀតក្ដី ក៏លោកបាននៅតែបម្រើបេសកកម្មរយៈពេលខ្លីៗមួយចំនួនពីមុនព្យាការីស្លាប់ ។ ព្រះអម្ចាស់បានទទួលយកការបូជាសុចរិត និងភាពឧស្សាហ៍ព្យាយាមនៅក្នុងកិច្ចការរបស់ទ្រង់របស់ព្រិកហាំ យ៉ង់ ។



ដោយសារទំនាក់ទំនងជិតស្និទ្ធរបស់លោកជាមួយនឹង ព្យាការី យ៉ូសែប ស្ម៊ីធ នោះ ព្រិកហាំ យ៉ង់ បានរៀនអ្វីដែលលោកត្រូវការដឹងដើម្បីដឹកនាំសាសនាចក្របន្ទាប់ពីមរណភាពរបស់យ៉ូសែប ។

៤. សូមគិតអំពីឱកាសនានាដែលអ្នកមានដើម្បីបម្រើព្រះអម្ចាស់ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរពាក្យពីរបីប្រយោគពន្យល់ពីរបៀបដែលអ្នកធ្វើតាមគំរូរបស់ថ្នាក់ដឹកនាំដូចជា ព្រិកហាំ យ៉ង់ ដើម្បីធ្វើការយ៉ាងឧស្សាហ៍នៅក្នុងឱកាសទាំងនេះ ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:៨៤–១៤៥; ១២៥–២៦ ហើយបានបញ្ចប់មេរៀននេះនៅ ( កាលបរិច្ឆេទ ) ។*

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៧ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧; ១២៨:១–១១

## សេចក្ដីផ្ដើម

គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧ មាននូវសំបុត្រមួយមកពីព្យាការី យ៉ូសែប ស្ម៊ីធ ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ១៨៤២ ដែលបានណែនាំពួកបរិសុទ្ធឲ្យរក្សាកំណត់ត្រាបុណ្យជ្រមុជទឹកដែលពួកគេបានធ្វើសម្រាប់អ្នកស្លាប់ ។ ប្រហែលជាមួយសប្ដាហ៍ក្រោយមក យ៉ូសែបបានសរសេរសំបុត្រមួយទៀតអំពីប្រធានបទនៃពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់. គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨ មាននូវសំបុត្រនេះ ដែលវាបង្រៀនពីមូលហេតុ ដែលយើងត្រូវរក្សាកំណត់ត្រានៃពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះដែលបានធ្វើឡើង ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧:១–៤

*យ៉ូសែប ស្ម៊ីធ មានសិរីល្អនៅក្នុងការបៀតបៀន និង សេចក្ដីឈឺចាប់*

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧:១ ដោយរកមើលសេចក្ដីឈឺចាប់អ្វីខ្លះដែលព្យាការី យ៉ូសែប ស្ម៊ីធ បានជួបនៅណៅវូ រដ្ឋ អិលលីណោយ ក្នុងឆ្នាំ ១៨៤២ ។

នៅខែ ឧសភា ឆ្នាំ ១៨៤២ លីលប៊ើន ដបុលយូ ប័ហ្គស៍ អតីតអភិបាលរដ្ឋមិសសួរីដែលបានចេញដីកាការសម្លាប់គ្មានសល់ទាស់នឹងពួកបរិសុទ្ធ ដែលបានរងរបួសដោយឃាតករមិនស្គាល់មុខ ។ អជ្ញាធររដ្ឋ មិសសួរី បានចោទប្រកាន់ព្យាការី យ៉ូសែប ស្ម៊ីធ ថាបានរៀបចំមនុស្សឲ្យមកសម្លាប់ ប័ហ្គស៍ ហើយបានព្យាយាមនាំព្យាការីទៅកាត់ទោសនៅមិសសួរីវិញ ។ យ៉ូសែប ស្ម៊ីធ បានចាកចេញពីមិសសួរីកាលពីប៉ុន្មានឆ្នាំមុន ហើយរស់នៅក្នុងតំបន់ណៅវូ អិលលីណោយ នៅពេលនោះ ។ ដោយដឹងថា ប្រសិនបើលោកត្រឡប់ទៅមិសសួរីវិញ លោកនឹងត្រូវគេសម្លាប់ នោះព្យាការីបានគេចខ្លួនពីពួកមន្ត្រីមិសសួរីមួយរយៈពេលដើម្បីចៀសវាងពីការចាប់ខ្លួនដោយអយុត្តិធម៌ ។ នៅខែ មករា ឆ្នាំ ១៨៤៣ ការតាមចាប់ខ្លួនយ៉ូសែប ស្ម៊ីធ ហើយចាប់លោកជាឈ្លើយសឹកទៅកាន់មិសសួរីវិញ ត្រូវបានគេកំណត់ថាជារឿងខុសច្បាប់ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧ គឺជាសំបុត្រមួយ ចុះថ្ងៃទី ១ ខែកញ្ញា ឆ្នាំ ១៨៤២ ដែលព្យាការី យ៉ូសែប ស្ម៊ីធ បានសរសេរទៅកាន់សាសនាចក្រ កាលលោកគេចខ្លួនដើម្បីចៀសវាងពីការចាប់ខ្លួនដោយអយុត្តិធម៌ពីសំណាក់ពួកមន្ត្រីមិសសួរី ។ សំបុត្រនេះត្រូវបានអានទៅកាន់ពួកបរិសុទ្ធនៅក្នុងទីក្រុងណៅវូប៉ុន្មានថ្ងៃក្រោយមក ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧:២ ដោយស្វែងរករបៀប ដែលយ៉ូសែបបានឆ្លើយតបនឹងសេចក្ដីឈឺចាប់ ។ នៅពេលអ្នកអាន វាអាចមានប្រយោជន៍ដើម្បីដឹងថា ពាក្យ *ឆ្លាប់* មានន័យថា ការសុំទៅនឹងអ្វីមួយ ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើឥរិយាបថរបស់យ៉ូសែប ស្ម៊ីធ ចំពោះសេចក្ដីឈឺចាប់គឺជាអ្វីទៅ ?

ខ. តើគំរូរបស់លោកអាចជួយយើងបានតាមរបៀបណា ?

យោងតាមអ្វីដែលព្យាការីបានសរសេរទៅកាន់ពួកបរិសុទ្ធ យើងអាចរៀនបានថា **ការទុកចិត្តលើព្រះវរបិតាសួគ៌អាចជួយយើងឲ្យស៊ូទ្រាំនឹងសេចក្ដីឈឺចាប់** ។ សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧:២ ឡើងវិញ ហើយពិចារណាអំពីការគូសចំណាំលើពាក្យ ឬឃ្លាដែលបង្រៀនពីសេចក្ដីពិតនេះ ។

២. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរឈ្មោះមនុស្សម្នាក់ដែលអ្នកស្គាល់( ឬបានរៀនអំពីគាត់ ) ដែលអាចស៊ូទ្រាំនឹងសេចក្ដីឈឺចាប់ ដោយសារគាត់បានទុកចិត្តលើព្រះវរបិតាសួគ៌ ។ តើការទុកចិត្តលើព្រះវរបិតាសួគ៌បានជួយបុគ្គលនេះឲ្យស៊ូទ្រាំនឹងសេចក្ដីឈឺចាប់យ៉ាងណាដែរ ?



ព្យាការី យ៉ូសែប ស្ម៊ីធ បានអះអាងដល់ពួកបរិសុទ្ធថា ពួកគេអាចរីករាយបាន ដោយសារ « ព្រះរបស់អ៊ីស្រាអែលគឺជាព្រះរបស់ពួកគេ » ( គ. និង ស. ១២៧:៣ ) ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧:៤ ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បានសន្យាដល់អ្នកទាំងឡាយ ដែលស៊ូទ្រាំនឹងការបៀតបៀន ។

សូមសញ្ជឹងគិតពីសេចក្ដីជំនឿរបស់ពួកបរិសុទ្ធដែលបានបន្តសាងសង់ព្រះវិហារបរិសុទ្ធណៅវូ ទោះជាពួកគេស្ថិតនៅក្រោមការគំរាមកំហែងនៃការបៀតបៀនក៏ដោយ ។ តើគំរូរបស់ពួកគេជះឥទ្ធិពលដល់អ្នកយ៉ាងណាដែរ នៅពេលអ្នកជួបនឹងឧបសគ្គលំបាកៗនោះ ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧:៥–១២

*ព្យាការី យ៉ូសែប ស្ម៊ីធ ទូន្មានដល់ពួកបរិសុទ្ធឲ្យរក្សាទុកកំណត់ត្រានៃពិធីបុណ្យជ្រមុជទឹកដែលពួកគេបានធ្វើសម្រាប់អ្នកស្លាប់ ។*

សូមចងចាំថា ប្រហែលជាមួយឆ្នាំកន្លះពីមុន យ៉ូសែប ស្ម៊ីធសរសេរសំបុត្រនោះដែលឥឡូវនេះត្រូវកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧ ព្រះអម្ចាស់បានមានបន្ទូលប្រាប់ពួកបរិសុទ្ធថា ពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់នេះមានតែនៅក្នុងព្រះវិហារបរិសុទ្ធប៉ុណ្ណោះ ( សូមមើល គ. និង ស. ១២៤:៣០ ) ។ ទោះជាយ៉ាងក៏ដោយ ព្រះអម្ចាស់បានអនុញ្ញាតឲ្យពួកបរិសុទ្ធធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់អ្នកសម្លាប់នៅក្នុងទន្លេ និង បឹងដែលនៅក្បែរៗរហូតដល់អាងជ្រមុជទឹកសង់រួចរាល់នៅក្នុងព្រះវិហារបរិសុទ្ធ ។ នៅពេលអាងមួយបានសង់រួចរាល់ហើយ ពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ទទួលយកបានតែនៅក្នុងព្រះវិហារបរិសុទ្ធប៉ុណ្ណោះ ។ ពួកបរិសុទ្ធបានចាប់ផ្ដើមធ្វើពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់នៅព្រះវិហារបរិសុទ្ធណៅវូក្នុងខែ វិច្ឆិកា ឆ្នាំ ១៨៤១ ។



តើអ្នកធ្លាប់ទៅព្រះវិហារបរិសុទ្ធ ហើយធ្វើពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ដែរឬទេ ? ប្រសិនបើធ្លាប់ តើអ្នកបានគាត់សម្គាល់ថាតើមាននរណាម្នាក់កំពុងអង្គុយនៅក្បែរអាងបុណ្យជ្រមុជទឹកនោះដែរឬទេ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧:៥–៩ ដោយរកមើលអ្នកដែលត្រូវមានវត្តមាននៅពេលពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ត្រូវបានធ្វើឡើង ។

យោងតាម ខ ៧ ហេតុអ្វីបានជាចាំបាច់ត្រូវមានអ្នកកត់ត្រាម្នាក់ធ្វើសាក្សីសម្រាប់ពិធីបុណ្យជ្រមុជទឹកនេះ ?

ក្រៅពីការត្រូវការអ្នកកត់ត្រាម្នាក់ យើងក៏អាចរៀននៅក្នុង ខ ៧ ផងដែរថា **ពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធដែលធ្វើនៅលើផែនដីនឹងចងភ្ជាប់នៅឯស្ថានសួគ៌ដែរ ។** អ្នកគួរគូសចំណាំពាក្យ ឬ ឃ្លា ដែលបង្រៀនអំពីគោលលទ្ធិនេះ ។ ការចងភ្ជាប់នៅឯស្ថានសួគ៌មានន័យថា ពិធីបរិសុទ្ធទាំងនោះមានសុពលភាពនៅក្នុងព្រះនេត្រនៃព្រះវរបិតាសួគ៌ ។

៣. សូមឆ្លើយសំណួរដូចទៅនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើគោលលទ្ធិនេះអាចជះឥទ្ធិពលដល់អ្នកដោយរបៀបណា នៅពេលអ្នកកំពុងចូលរួមនៅក្នុងពិធីបរិសុទ្ធនានាជំនួសឲ្យអ្នកស្លាប់ ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧:១០–១២ យើងរៀនថា យ៉ូសែប ស្ម៊ីធចង់បង្រៀនបន្ថែមទៀតដល់ពួកបរិសុទ្ធអំពីពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ ប៉ុន្តែដោយសារលោកកំពុងលាក់ខ្លួន នោះលោកមិនអាចធ្វើដូច្នោះបានទេ ។ លោកបានសន្យានឹងសរសេរសំបុត្របន្ថែមទៀតទៅពួកបរិសុទ្ធអំពីពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ និង ប្រធានបទសំខាន់ៗផ្សេងទៀត ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១–១១

*យ៉ូសែប ស៊្មីធ ពន្យល់ពីហេតុផលដែលយើងរក្សាកំណត់ត្រាសម្រាប់ពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ ។*

ប្រមាណជាមួយសប្ដាហ៍បន្ទាប់ពីលោកបានសរសេរលិខិតដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧ ព្យាការី យ៉ូសែប ស៊្មីធបានសរសេរសំបុត្រមួយទៀតទៅពួកបរិសុទ្ធអំពីពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ ។ មាតិកានៃសំបុត្រនេះ មាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១–៥ យ៉ូសែប ស៊្មីធ បានបង្រៀនថា ពួកអ្នកកត់កំណត់ត្រានៅក្នុងមូលដ្ឋានគួរត្រូវបានចាត់តាំងឲ្យធ្វើសាក្សី ហើយកត់ត្រាពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ ។ លោកក៏បានបង្រៀនដែរថា អ្នកកត់ត្រាទូទៅម្នាក់គួរត្រូវបានចាត់តាំងឲ្យចងក្រងកំណត់ត្រាមូលដ្ឋានទៅជាកំណត់ត្រាទូទៅមួយរបស់សាសនាចក្រ ។

តើអ្នកធ្លាប់ឃើញលិខិតឆ្លងដែនដែរឬទេ ? តើឯកសិទ្ធិបែបណាខ្លះដែលអ្នកកាន់លិខិតឆ្លងដែនមួយមាន ? ហេតុអ្វីបានជាលិខិតឆ្លងដែនរបស់មនុស្សម្នាក់ទៀត *មិន* អនុញ្ញាតឲ្យអ្នកចូលទៅក្នុងប្រទេសមួយទៀតបាន ? តើមានអ្វីកើតឡើង ប្រសិនបើអ្នកបានព្យាយាមចូលទៅប្រទេសមួយទៀត ប៉ុន្ដែព័ត៌មាននៅក្នុងលិខិតឆ្លងដែនរបស់អ្នកមិនពេញលេញ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:៦–៧ ដោយស្វែងរកកំណត់ហេតុអ្វីដែលនឹងត្រូវបានប្រើដើម្បីកំណត់ថាតើយើងមានគុណសម្បត្តិដើម្បីចូលទៅក្នុងវត្តមានរបស់ព្រះ ។ សូមកត់សម្គាល់ថា សាវក យ៉ូហាន និង ព្យាការី យ៉ូសែប ស៊្មីធ បានលើកឡើងច្រើនជាងកំណត់ត្រាមួយ ។ លោកបានប្រាប់ពី « បញ្ជី [ បាន ] បើកឡើង ហើយបញ្ជីមួយទៀត . . . ជាបញ្ជីជីវិត » ( គ. និង ស. ១២៨:៦ សូមមើលផងដែរ វិវរណៈ ២០:១២ ) ។ បញ្ជីដំបូងដែលបានលើកឡើងដោយយ៉ូហានគឺជាកំណត់ត្រាដែលបានរក្សាទុកនៅលើផែនដី ហើយបញ្ជីជីវិតគឺជាកំណត់ត្រាដែលបានរក្សាទុកនៅស្ថានសួគ៌ ។ បញ្ជីទាំងនេះមាននូវកំណត់ត្រាមួយអំពីកិច្ចការរបស់យើង ។

ដូចជាមនុស្សម្នាក់ត្រូវការឲ្យមានព័ត៌មានជាក់លាក់កត់ត្រាទុកនៅក្នុងលិខិតឆ្លងដែនរបស់ខ្លួន ដើម្បីគេអនុញ្ញាតឲ្យចូលទៅក្នុងប្រទេសមួយទៀត យើងត្រូវការឲ្យមានព័ត៌មានជាក់លាក់កត់ត្រានៅក្នុងបញ្ជីទាំងនេះ ដើម្បីត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងវត្តមានរបស់ព្រះ ។

ប្រធាន ប៊យដ៍ ឃេ. ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀន ៖



« មិនថាសញ្ជាតិ ឬជាតិសាសន៍ណាទេ មិនថាប្រុស ឬស្រី មិនថាការងារ មិនថាការអប់រំរបស់អ្នកបែបណាទេ មិនថាអ្នករស់នៅក្នុងជំនាន់ណានោះទេ ជីវិតគឺជាដំណើរមួយឆ្ពោះទៅផ្ទះសម្រាប់យើងគ្រប់គ្នា ដើម្បីត្រឡប់ទៅវត្តមានរបស់ព្រះនៅក្នុងនគរសេឡេស្ទាលរបស់ទ្រង់ ។

« ពិធីបរិសុទ្ធ និងសេចក្ដីសញ្ញាទាំងឡាយ ក្លាយទៅជារាជសាសន៍របស់យើង សម្រាប់ការទទួលឲ្យចូលទៅក្នុងទីវត្តមានរបស់ព្រះ ។ ការទទួលពិធីបរិសុទ្ធ និងសេចក្ដីសញ្ញាទាំងឡាយ ដោយភាពសក្ដិសម គឺជាដំណើរស្វែងរកនៃធាកជីវិតមួយ ហើយ ហើយការរក្សាសេចក្ដីសញ្ញាទាំងឡាយ បន្ទាប់ពីនេះទៅ គឺជាឧបសគ្គនៃជីវិតរមែងស្លាប់នេះ » ( "Covenants," *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៧ ទំព័រ ២៤ ) ។

សូមពិចារណាអំពីការគូសចំណាំឃ្លាដែលចែងថា « អ្វីក៏ដោយដែលអ្នកចងនៅផែនដី នោះនឹងត្រូវបានចងនៅស្ថានសួគ៌ដែរ » នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:៨ ។ រួចអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:៨ ម្ដងទៀត ដោយរកមើល « ការបកប្រែផ្សេងទៀត » ដែលយ៉ូសែប ស៊្មីធបានធ្វើចំពោះសេចក្ដីថ្លែងការណ៍នេះ ។ អ្នកអាចនឹងចង់គូសចំណាំឃ្លានោះផងដែរ ។

នៅពេលអ្នកអាន ខ ៨ វាអាចមានប្រយោជន៍ដើម្បីដឹងថាពាក្យ *ខ្លួនគេ* មានន័យថា ការធ្វើសម្រាប់ប្រយោជន៍ផ្ទាល់ខ្លួនរបស់នរណាម្នាក់ ហើយវាសំដៅទៅលើមនុស្សដែលបានទទួលបុណ្យជ្រមុជទឹកសម្រាប់ខ្លួនឯង ។ ឃ្លាថា « ភ្នាក់ងាររបស់គេផ្ទាល់ » សំដៅលើអស់អ្នកដែលមិនអាចទទួលពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹកសម្រាប់សេចក្ដីសង្គ្រោះនៅក្នុងជីវិតរមែងស្លាប់ ហើយត្រូវការភ្នាក់ងារ—ជាមនុស្សផ្សេងទៀត—ដើម្បីទទួលបុណ្យជ្រមុជទឹកជំនួសពួកគេ ។

យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:៨ តើអ្វីទៅជាកិច្ចការពីរយ៉ាងដែលត្រូវកើតឡើងដើម្បីឲ្យពិធីបរិសុទ្ធនានាត្រូវបានចងនៅផែនដី និង នៅស្ថានសួគ៌ ? ដើម្បីឆ្លើយនឹងសំណួរនេះ សូមបំពេញចន្លោះនៃគោលលទ្ធិដូចតទៅនេះ ៖ **នៅពេលពិធីបរិសុទ្ធមួយត្រូវបានធ្វើដោយបព្វជិតភាព និងត្រឹមត្រូវ ត្រូវបានរក្សាទុក នោះពិធីបរិសុទ្ធនោះនឹងចងនៅផែនដី និង ស្ថានសួគ៌ ។**

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ដើម្បីឲ្យពិធីបរិសុទ្ធមួយបានចងនៅស្ថានសួគ៌មានន័យយ៉ាងដូចម្ដេច ?

ខ. តើអ្នកមានអារម្មណ៍បែបណាដែរ នៅពេលអ្នកគិតអំពីការចូលរួមរបស់អ្នកនៅក្នុងពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹក និង ពិធីបញ្ចាក់ក្នុងព្រះវិហារបរិសុទ្ធនឹងនាំយកពរជ័យទៅឲ្យមនុស្សនៅក្នុងពិភពវិញ្ញាណ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:៩ ដោយស្វែងរកអ្វីដែលព្យាការី យ៉ូសែប ស្ម៊ីធ បានថ្លែងពីគោលការណ៍នេះ ។

រឿងមួយដែលយើងរៀននៅក្នុង ខ ៩ គឺថានៅគ្រប់គ្រាកាន់កាប់ត្រួតត្រានៃបព្វជិតភាព ព្រះអម្ចាស់បានប្រទានសិទ្ធិអនុញ្ញាតដល់ពួកអ្នកបម្រើរបស់ទ្រង់ យ៉ាងហោចណាស់ម្នាក់ដើម្បីកាន់ ហើយប្រើកូនសោបព្វជិតភាពសម្រាប់ការផ្សារភ្ជាប់ ។



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១០–១១ ដោយស្វែងរកអ្វី ដែលព្រះអង្គសង្គ្រោះបានប្រទានដល់ពេត្រុស ។

ដូចជាព្រះអង្គសង្គ្រោះបានប្រទានកូនសោបព្វជិតភាពសម្រាប់ការផ្សារភ្ជាប់ដល់ពេត្រុស នោះទ្រង់ក៏បានប្រទានកូនសោទាំងនោះម្ដងទៀតនៅជំនាន់របស់យើងផងដែរ ។

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីបានជាពិធីបរិសុទ្ធ ដូចជាពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ចាំបាច់ត្រូវធ្វើឡើងជាមួយនឹងសិទ្ធិអំណាចត្រឹមត្រូវ ?

ខ. តើអ្នកនឹងធ្វើអ្វីខ្លះ ដោយសារតែអ្វីដែលអ្នកបានរៀននៅថ្ងៃនេះ ?

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៧; ១២៨:១–១១ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៧ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១២–២៥

## សេចក្ដីផ្ដើម

មេរៀននេះមាននូវផ្នែកទាំងអស់នៃសំបុត្រដែលព្យាការីយ៉ូសែប ស្ម៊ីធ បានសរសេរឲ្យពួកបរិសុទ្ធនៅដើមខែ កញ្ញា ឆ្នាំ ១៨៤២ ។ នៅក្នុងផ្នែកនៃសំបុត្រនេះ ព្យាការីបង្រៀនអំពីសេចក្ដីសង្គ្រោះរបស់អ្នកនៅរស់ និង មរណជន ។ លោកក៏បានលើកទឹកចិត្តពួកបរិសុទ្ធឲ្យស្មោះត្រង់ចំពោះកិច្ចការរបស់ខ្លួនសម្រាប់មរណជន ហើយបង្ហាញសេចក្ដីអំណររបស់លោកនៅក្នុងការស្ដារឡើងវិញនៃដំណឹងល្អផងដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១២–១៨

*យ៉ូសែប ស្ម៊ីធ បង្រៀនអំពីសេចក្ដីសង្គ្រោះរបស់អ្នកនៅរស់ និង មរណជន ។*

សូមនឹកស្រមៃថាអ្នកកំពុងចូលរួមការសម្ពោធបើកឲ្យប្រើប្រាស់ព្រះវិហារបរិសុទ្ធជាមួយមិត្តម្នាក់ដែលមិនមែនជាសមាជិកសាសនាចក្រ ។ នៅពេលអ្នកដើរកាត់កន្លែងធ្វើពិធីបុណ្យជ្រមុជទឹក មិត្តរបស់អ្នកបានសួរថា « ហេតុអ្វីបានជាអ្នកធ្វើពិធីបុណ្យជ្រមុជទឹកឲ្យអ្នកស្លាប់ ? » មិត្តរបស់អ្នកសួរទៀតថា « តើពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់នេះមាននៅក្នុងព្រះគម្ពីរប៊ីបដែរឬទេ ? »



នៅពេលអ្នកសិក្សាមេរៀនសម្រាប់ថ្ងៃនេះ អ្នកនឹងរកឃើញគោលការណ៍ដែលអាចជួយអ្នកឲ្យឆ្លើយតបនឹងសំណួរទាំងនេះ ។

អ្នកអាចនឹកចាំពីមេរៀនមុនៗថា នៅក្នុងខែ កញ្ញា ឆ្នាំ ១៨៤២ ព្យាការីយ៉ូសែប ស្ម៊ីធ បានលាក់ខ្លួនពីក្រុមមនុស្សដែលតាមចាប់ខ្លួនលោកដោយខុសច្បាប់ ។ កាលកំពុងលាក់ខ្លួននោះ លោកបានសរសេរសំបុត្រមួយទៅកាន់ពួកបរិសុទ្ធ ។ នៅក្នុងសំបុត្រនោះ លោកបានបង្រៀនពួកគេអំពីពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១២–១៣ ដោយស្វែងរកអ្វី ដែលយ៉ូសែប ស្ម៊ីធ បានបង្រៀន អំពីនិមិត្តរូបនៃពិធីបុណ្យជ្រមុជទឹក ។

១. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរពាក្យពីរបីបន្ទាត់ដោយពន្យល់ពីរបៀបដែលអ្នកអាចប្រើការបង្រៀននៅក្នុង ខ ១២–១៣ ដើម្បីជួយមនុស្សម្នាក់ឲ្យយល់ពីហេតុផលដែលពិធីបុណ្យជ្រមុជទឹកត្រូវធ្វើឡើងដោយការជ្រមុជទៅក្នុងទឹក ។

នៅពេលអ្នកអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១៤ សូមកត់ចំណាំពីរបៀបដែល យ៉ូសែប ស្ម៊ីធ បានគូសបញ្ជាក់ពីសារៈសំខាន់នៃការរក្សាកំណត់ត្រាដែលអាចទទួលយកបាននៅចំពោះព្រះអម្ចាស់ទាក់ទិននឹងកិច្ចការនៃសេចក្ដីសង្គ្រោះសម្រាប់អ្នកស្លាប់ ។

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១៥ ដោយរកមើលហេតុផលដែលយើងធ្វើពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ ។

នៅក្នុង ខទី ១៥ ឃ្លាថា « ពួកគេក៏មិនអាចបានល្អឥតខ្ចោះ ក្រៅពីយើងដែរ »មានន័យថា **ដូនតារបស់យើងដែលបានចែកឋានដោយគ្មានដំណឹងល្អពុំអាចរីកចម្រើនឆ្ពោះទៅរកភាពល្អឥតខ្ចោះបានឡើយរហូតដល់ពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះនៃដំណឹងល្អត្រូវបានធ្វើឡើងជំនួសឲ្យពួកគេ ។**

សូមអានព័ត៌មានខាងក្រោមនេះ ដោយគូសចំណាំលើឃ្លាដែលគូសបញ្ជាក់ពីរបៀបដែលអ្នកអាចជួយពួកជីដូនជីតារបស់អ្នកដែលបានចែកឋានទៅដោយពុំបានទទួលដំណឹងល្អ ។

> « ជីដូនជីតាដែលស្លាប់របស់អ្នករស់នៅកន្លែងមួយដែលហៅថា ពិភពវិញ្ញាណ ។ នៅទីនោះពួកគេមានឱកាសដើម្បីស្ដាប់ និង ទទួលយកដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេមិនអាចទទួលពិធីបរិសុទ្ធនៃដំណឹងសម្រាប់ខ្លួនពួកគេឡើយ ហើយពួកគេពុំអាចរីកចម្រើនឡើងលើកលែងតែមានមនុស្សដទៃទៀតផ្ដល់ពិធីបរិសុទ្ធទាំងនេះសម្រាប់ពួកគេ ។
>
> « ឯកសិទ្ធិ និង ទំនួលខុសត្រូវរបស់អ្នកគឺត្រូវផ្ដល់អំណោយនេះដល់ពួកគេដោយការស្វែងរកពួកគេ ហើយធានាថាពិធីបរិសុទ្ធទាំងនេះត្រូវបានធ្វើឡើងជំនួសពួកគេនៅក្នុងព្រះវិហារបរិសុទ្ធ ។ បន្ទាប់មក ពួកគេអាចជ្រើសរើសថាព្រមទទួលយកកិច្ចការដែលបានធ្វើនេះឬក៏ អត់ » ( *Member's Guide to Temple and Family History Work* [ ឆ្នាំ ២០០៩ ] ទំព័រ ២ ) ។

២. សូមឆ្លើយសំណួរដូចទៅនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថា ជីដូនជីតារបស់អ្នកអាចមានអារម្មណ៍មកលើអ្នកយ៉ាងណាដែរ នៅពេលអ្នកបានជ្រមុជទឹកជំនួសពួកគាត់នោះ ? ប្រសិនបើអ្នកមានឱកាសចូលរួមនៅក្នុងពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ ក៏សូមសរសេរផងដែរអំពីអារម្មណ៍ដែលមានអ្នកមានអំឡុងពេលធ្វើពិធីនោះ ។

សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១៥ ឡើងវិញ ដោយរកមើលហេតុផលមួយទៀតដែលយើងធ្វើពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ ។ យោងតាមអ្វីដែលអ្នកបានរៀន សូមបំពេញគោលលទ្ធិដូចតទៅ ៖ **សេចក្ដីសង្គ្រោះរបស់ជីដូនជីតាយើងដែលបានចែកឋានទៅគឺ ចំពោះសេចក្ដីសង្គ្រោះរបស់យើង ។**

នៅពេលអ្នកបន្តសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨ សូមពិចារណាពីហេតុផលដែលការធ្វើកិច្ចការពង្សប្រវត្តិ និង កិច្ចការព្រះវិហារបរិសុទ្ធជំនួសឲ្យជីដូនជីតារបស់យើងដែលបានចែកឋានទៅគឺជារឿងដ៏ចាំបាច់ចំពោះសេចក្ដីសង្គ្រោះរបស់យើង ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១៦–១៧ ដោយរកមើលការបង្រៀនមកពីសាវកម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី និងព្យាការីម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ ហេតុអ្វីបានជាការដឹងថា ព្រះគម្ពីរមានបញ្ចូលនូវការបង្រៀនអំពីកិច្ចការជំនួសឲ្យអ្នកស្លាប់ជារឿងដ៏មានប្រយោជន៍ ?

តើអ្នកធ្លាប់មើលច្រវាក់ដែកឲ្យជិតនឹងភ្នែកដែរឬទេ ? ដើម្បីធ្វើច្រវាក់មួយដ៏រឹងមាំតំណនីមួយៗត្រូវបានភ្ជាប់គ្នាដោយគ្មានមុខតំណបន្ទាប់ពីបានភ្ជាប់នឹងតំណមួយទៀត ។



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១៨ ដោយរកមើលរបៀបដែលតំណនៃច្រវាក់មួយទាក់ទងនឹងការបង្រៀនរបស់ព្យាការី យ៉ូសែប ស្ម៊ីធ អំពីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ ។ ( សូមចងចាំថា *គ្រាកាន់កាប់ត្រួតត្រា* មួយគឺជាពេលដែលព្រះអម្ចាស់បើកសម្ដែងគោលលទ្ធិ ពិធីបរិសុទ្ធ និង បព្វជិតភាពរបស់ទ្រង់ [ សូមមើល Bible Dictionary « Dispensations »] ។ នៅក្នុងខគម្ពីរនេះពាក្យថា *កូនៗ* សំដៅលើពួកយើង ហើយពាក្យថា *ឪពុក* សំដៅលើជីដូនជីតារបស់យើង ) ។

អ្នកអាចនឹងចង់សរសេរគោលលទ្ធិដូចតទៅនៅក្នុងព្រះគម្ពីររបស់អ្នកក្បែរ ខ ១៨ ៖ **ពិធីបុណ្យជ្រមុជទឹកជំនួសឲ្យអ្នកស្លាប់ជួយតភ្ជាប់យើងទៅនឹងជីដូនជីតាយើងសម្រាប់ភាពដ៏នៅអស់កល្បជានិច្ច ។**

ក្រៅពីបុណ្យជ្រមុជទឹក ពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះផ្សេងទៀត—ពិធីបញ្ជាក់ ការតែងតាំងបព្វជិតភាពមិលគីស្សាដែក ( សម្រាប់បុរស ) ពិធីអំណោយទានពិសិដ្ឋនៃព្រះវិហារបរិសុទ្ធ និង ពិធីបរិសុទ្ធនៃការផ្សារភ្ជាប់—ក៏សំខាន់ដើម្បីធ្វើឲ្យតំណនៃការផ្សារភ្ជាប់គ្នារវាងជីដូនជីតារបស់យើង និង ខ្លួនយើងបានរឹងមាំផងដែរ ។

ដើម្បីបង្កើនការយល់ដឹងរបស់អ្នកអំពីសេចក្ដីពិតនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨ សូមសិក្សាសេចក្ដីថ្លែងការណ៍ដូចតទៅមកពីប្រធានយ៉ូសែប ហ្វីលឌីង ស្ម៊ីធ ៖



« សមាជិកសាសនាចក្រមួយចំនួនធ្លាប់ងឿងឆ្ងល់ពីអត្ថន័យនៃប្រសាសន៍របស់ព្យាការីដែលថ្លែងថា យើងពុំអាចធ្វើឲ្យល្អឥតខ្ចោះដោយគ្មានជីដូនជីតារបស់យើងបានឡើយ ។ តើមនុស្សម្នាក់ដែលគោរពព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ជាអ្នកដែលស្មោះត្រង់ ហើយមានកក្ដីភាពនឹងមិនទទួលបានភាពល្អឥតខ្ចោះទេឬ ? ពិតណាស់ គាត់ត្រូវផ្ដល់ឯកសិទ្ធិដូចគ្នាទៅដល់ជីដូនជីតារបស់គាត់ដែលបានចែកឋានទៅ ដោយសារត្រូវតែមានអង្គការគ្រួសារមួយ ជាអង្គភាពក្រុមគ្រួសារមួយ ហើយជំនាន់នីមួយៗត្រូវតែផ្សារភ្ជាប់ជាមួយនឹងច្រវ៉ាក់ដែលបានទៅមុន ដើម្បីនាំនូវភាពល្អឥតខ្ចោះនៅក្នុងអង្គភាពគ្រួសារ ។ ដូច្នេះនៅទីបំផុត យើងនឹងក្លាយជាគ្រួសារដ៏ធំមួយជាមួយនឹងអ័ដាម ដែលជាមេ មៃឃើល មេទ័ពពួកទេវតា ធ្វើជាអធិបតីលើពូជពង្សរបស់លោក » ( *Doctrines of Salvation*,comp ។ Bruce R. McConkie, 3 vols. [១៩៥៤–៥៦] ២:១៧៥ ) ។

យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១៨ ហេតុអ្វីបានជាការធ្វើជាផ្នែកមួយនៃតំណមនុស្សដែលបានតភ្ជាប់គ្នា ឬបានផ្សារភ្ជាប់នឹងគ្នាមានសារៈសំខាន់ ?

សេចក្ដីថ្លែងការណ៍ដូចតទៅអាចជួយអ្នកឲ្យយល់ពីបណ្ដាសារអ្វីដែលនៅក្នុង ខ ១៨ សំដៅទៅលើ ៖



ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានថ្លែង ៖« បើសិនគ្មានតំណភ្ជាប់គ្នារវាងពួកឪពុក និងកូនៗ—ដែលជាកិច្ចការសម្រាប់មនុស្សស្លាប់ទេ—នោះយើងទាំងអស់គ្នានឹងត្រូវកំទេចចោល ហើយកិច្ចការរបស់ព្រះទាំងមូលនឹងបរាជ័យ និង ត្រូវកំទេចចោលសូន្យឈឹង » (*Doctrines of Salvation* ២:១២២ ) ។



អែលឌើរអិល ថម ភែរី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖ « គ្រួសារដ៏នៅអស់កល្បជានិច្ចគឺជាកត្តាដ៏សំខាន់ចំពោះដំណឹងល្អនៃព្រះអង្គសង្គ្រោះរបស់យើង ។ វាគ្មានហេតុផលដែលទ្រង់ត្រូវត្រឡប់មកផែនដីវិញដើម្បីដឹកនាំ ហើយគ្រងរាជនៅលើនគរទ្រង់ឡើយ លើកលែងតែក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ចត្រូវបានស្ថាបនាឡើងសម្រាប់កូនចៅរបស់ព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ ។ នៅពេលយើងយល់ពីតួនាទីដ៏អស់កល្បជានិច្ចរបស់គ្រួសារ នោះការចិញ្ចឹមបីបាច់ និង ការបង្កើតចំណងក្រុមគ្រួសារដ៏រឹងមាំគឺជារឿងដ៏សំខាន់បំផុត » ( « Youth of the Noble Birthright » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ទំព័រ ៧៤ ) ។

៣. សូមឆ្លើយសំណួរដូចតទៅនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ យោងតាមអ្វីដែលអ្នកបានរៀននៅក្នុងការសិក្សារបស់អ្នកអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨ ហេតុអ្វីកិច្ចការពង្សប្រវត្តិ និង កិច្ចការព្រះវិហារបរិសុទ្ធចាំបាច់ចំពោះសេចក្ដីសង្គ្រោះរបស់យើង ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១៩–២៥

*យ៉ូសែប ស្ម៊ីធ បង្ហាញពីសេចក្ដីអំណរនៅក្នុងស្ដារឡើងវិញនៃដំណឹងល្អ ហើយលើកទឹកចិត្តដល់ពួកបរិសុទ្ធឲ្យស្មោះត្រង់ នៅពេលពួកគេធ្វើកិច្ចការសម្រាប់សេចក្ដីសង្គ្រោះដល់មរណជន*

សូមគិតអំពីពេលមួយ ដែលអ្នកមានភាពរីករាយដោយបានឮដំណឹងដ៏ល្អ ។ នៅពេលអ្នកបានឮពីរឿងនេះ តើអ្នកចង់ចែកចាយវានឹងអ្នកដទៃដែរឬទេ ? ហេតុអ្វី ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១៩ ។ ពាក្យ *ដំណឹងល្អ* នៅក្នុងខនេះគឺជាពាក្យមួយទៀតសម្រាប់ *ដំណឹង* ។ សូមរកមើលដំណឹងល្អដែលព្យាការី យ៉ូសែប ស្ម៊ីធ បានថ្លែងថា យើងនឹងបានទទួល ។

តើដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទគឺជាសំឡេងរីករាយសម្រាប់ទាំងអ្នករស់ និង មរណជនយ៉ាងដូចម្ដេច ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:២០–២១ យើងអានអំពីបទពិសោធន៍មួយចំនួនដែលព្យាការី យ៉ូសែប ស្ម៊ីធ មានជាមួយនឹងសារទូតសួគ៌ា នៅពេលដំណឹងល្អត្រូវបានស្ដារឡើងវិញតាមរយៈលោក ។

សេចក្ដីពិតមួយដែលយើងរៀនពីខគម្ពីរទាំងនេះគឺថា **កូនសោ អំណាច និង សិទ្ធិអំណាចនៃគ្រាកាន់កាប់ត្រួតត្រាកាលពីមុនត្រូវបានស្ដារឡើងវិញនៅក្នុងគ្រាកាន់កាប់ត្រួតត្រានៃកំណត់កាលដ៏ពោរពេញ** ។ សូមពិចារណាអំពីការសរសេរសេចក្ដីពិតនេះនៅក្នុងព្រះគម្ពីររបស់អ្នក ឬ ក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។



ប្រធាន យ៉ូហាន ថេល័រ បានមានប្រសាសន៍ ៖ « បើសិនអ្នកសួរយ៉ូសែបពីលក្ខណៈរបស់អ័ដាម នោះលោកនឹងប្រាប់អ្នកភ្លាម លោកនឹងប្រាប់អ្នកពីទំហំ និង រូបរាង ព្រមទាំងអ្វីៗទាំងអស់ពីអ័ដាម ។ អ្នកអាចសួរលោកពីលក្ខណៈរបស់ ពេត្រុស យ៉ាកុប និង យ៉ូហាន នោះលោកអាចប្រាប់អ្នកបានទាំងអស់ ។ ហេតុអ្វី ? ដោយសារលោកបានឃើញពួកគេ » ( នៅក្នុង *Teachings of Presidents of the Church: Joseph Smith* [ ឆ្នាំ ២០០៧ ] ទំព័រ ១០៣) ។

៤. សូមឆ្លើយសំណួរដូចតទៅនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការដឹងថាដំណឹងល្អត្រូវបានស្ដារឡើងវិញលើផែនដីតាមរយៈពួកសារទូតសួគ៌ា ជះឥទ្ធិពលដល់សេចក្ដីជំនឿរបស់អ្នក និងទីបន្ទាល់របស់អ្នកអំពីការស្ដារឡើងវិញយ៉ាងណាដែរ ?

គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:២២–២៣ មានការបង្ហាញពីសេចក្ដីអំណរដែលព្យាការីយ៉ូសែប ស្ម៊ីធ មានដោយសារកូនសោនៃបព្វជិតភាពត្រូវបានស្ដារឡើងវិញ ហើយដោយសារពួកបរិសុទ្ធអាចជួយសង្គ្រោះដល់មរណជន ។ នៅពេលអ្នកសិក្សាខគម្ពីរទាំងនេះ អ្នកគួរគូសចំណាំឃ្លាទាំងឡាយដែលមានន័យចំពោះអ្នក ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:២៤ ដោយរកមើលការបូជាមួយដែលព្យាការីបានណែនាំដល់ពួកបរិសុទ្ធឲ្យថ្វាយដល់ព្រះអម្ចាស់ ។ តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីរួមចំណែកនៅក្នុង « បញ្ជី » នេះ ?

សូមពិចារណាពីសេចក្ដីពិតដូចតទៅនេះ ៖ **នៅពេលយើងធ្វើកិច្ចការពង្សប្រវត្តិ ហើយទទួលពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធសម្រាប់ដីដូនជីតារបស់យើង នោះយើងធ្វើការថ្វាយដង្វាយដោយសុច្ចរិតដល់ព្រះអម្ចាស់ហើយ** ។ នៅពេលអ្នកគិតអំពីសេចក្ដីពិតនេះ សូមអានសេចក្ដីថ្លែងការណ៍ដូចតទៅ ដែលអែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃ ពួកសាវកដប់ពីរនាក់បានរៀបរាប់ពីតួនាទីរបស់អ្នកនៅក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះរបស់មរណជន ៖



« មានអ្នករាល់គ្នាជាច្រើនប្រហែលជាគិតថាកិច្ចការពង្សប្រវត្តិគឺត្រូវតែធ្វើឡើងដោយពួកមនុស្សវ័យចំណាស់ ។ ប៉ុន្តែ ខ្ញុំដឹងថាគ្មានការកំណត់អាយុណាមួយបានរៀបរាប់នៅក្នុងព្រះគម្ពីរ ឬសេចក្ដីណែនាំណាមួយដែលបានប្រកាសដោយពួកអ្នកដឹកនាំសាសនាចក្រដោយបានដាក់កំហិតនូវការបម្រើដ៏សំខាន់នេះទៅលើមនុស្សវ័យចំណាស់ឡើយ ។ អ្នកគឺជាបុត្រាបុត្រីនៃព្រះ ជាកូនចៅនៃសេចក្ដីសញ្ញា និងជាអ្នកស្ថាបនានគរ ។ អ្នកពុំត្រូវចាំហូតអ្នកមានអាយុគ្រប់គ្រាន់ដើម្បីបំពេញទំនួលខុសត្រូវរបស់អ្នកក្នុងការជួយដល់កិច្ចការនៃសេចក្ដីសង្គ្រោះសម្រាប់គ្រួសារមនុស្សឡើយ ។. . .

« វាមិនមែនជាការចៃដន្យទេ ដែលកម្មវិធីស្រាវជ្រាវពង្សប្រវត្តិ. . .ឧបករណ៍ទាំងឡាយដទៃទៀតត្រូវបង្កើតឡើងនៅចំពេលដែលមនុស្សវ័យក្មេងមានការចេះដឹងយ៉ាងទូលំទូលាយអំពីបច្ចេកវិជ្ជាព័ត៌មាន និង ទំនាក់ទំនងនោះ ។. . . ជំនាញ និងភាពឆ្លាតវៃក្នុងចំណោមពួកយុវវ័យជាច្រើនរបស់យើងសព្វថ្ងៃនេះ រៀបចំដើម្បីចូលរួមចំណែកជួយដល់កិច្ចការនៃសេចក្ដីសង្គ្រោះ ។

« ខ្ញុំសូមអញ្ជើញយុវជននៃសាសនាចក្រឲ្យរៀន ហើយមានបទពិសោធន៍ពីវិញ្ញាណនៃអេលីយ៉ា ។ ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យសិក្សា ស្វែងរកជីដូនជីតារបស់អ្នក ហើយត្រៀមខ្លួនរបស់អ្នកដើម្បីធ្វើបុណ្យជ្រមុជទឹកជំនួសនៅក្នុងព្រះដំណាក់នៃព្រះអម្ចាស់ សម្រាប់ញាតិសន្តានដែលស្លាប់ *របស់អ្នក* ( សូមមើល គ. និង ស. ១២៤:២៨–៣៦ ) ។ យើងខ្ញុំសូមជម្រុញអ្នកឲ្យជួយមនុស្សដទៃស្វែងរកពង្សប្រវត្តិរបស់ពួកគេ » ( « The Hearts of the Children Shall Turn » *Ensign* ឬ *Liahona* ខែវិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២៦–២៧ ) ។

៥. ដើម្បីអនុវត្តអ្វីដែលអ្នកបានរៀននៅថ្ងៃនេះ សូមដាក់ផែនការមួយដើម្បីជួយជីដូនជីតាមួយចំនួនរបស់អ្នកឲ្យទទួលបានពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ ។ អ្នកគួរធ្វើការជាមួយនឹងឪពុកម្ដាយរបស់អ្នក ឬអ្នកផ្ដល់ប្រឹក្សាខាងពង្សប្រវត្តិក្នុងវួដ ឬសាខារបស់អ្នក នៅពេលអ្នកដាក់ផែនការនេះ ។ សូមសរសេរចម្លើយរបស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរដូចខាងក្រោមនេះ ៖

ក. *ផែនការរបស់ខ្ញុំដើម្បីរកឈ្មោះជីដូនជីតាដែលត្រូវការពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ ៖*

ខ. *ផែនការរបស់ខ្ញុំដើម្បីសម្រេចកិច្ចការព្រះវិហារបរិសុទ្ធសម្រាប់ជីដូនជីតារបស់ខ្ញុំ ៖* ( ប្រសិនបើអាចធ្វើបាន សូមដាក់ផែនការមួយដើម្បីទៅព្រះវិហារបរិសុទ្ធទទួលពិធីបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់ជំនួសជីដូនជីតាដែលអ្នកបានរកឃើញ ) ។



### *អនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងឡាយ*

ការអនុវត្តមាននៅពេលអ្នកគិត និយាយ និង រស់នៅ ស្របតាមគោលលទ្ធិ និង គោលការណ៍ទាំងឡាយ ដែលអ្នកបានរៀន ។ នៅពេលអ្នកអនុវត្តគោលលទ្ធិ និង គោលការណ៍នៅក្នុងជីវិតរបស់អ្នក អ្នកនឹងទទួលបានពរជ័យ ។ អ្នកនឹងកើនការយល់ដឹង និង ទីបន្ទាល់ជ្រៅជាង អំពីគោលលទ្ធិ និង គោលការណ៍ដែលអ្នកបានអនុវត្ត ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១២–២៥ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៨ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩; ១៣០:១–១១, ២២–២៣

## សេចក្ដីផ្ដើម

នៅថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ១៨៤៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានប្រាប់ឲ្យដឹងពី « កូសោបីយ៉ាង » ( គ. និង ស. ១២៩:៩ ) ដើម្បីស្គាល់ពីលក្ខណៈនៃការបម្រើរបស់ពួកទេវតា និង វិញ្ញាណទាំងឡាយ ។ សេចក្ដីណែនាំទាំងនេះត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ១២៩ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០ មានការបង្រៀនរបស់ព្យាការីអំពីគោលលទ្ធិផ្សេងៗ ខណៈកំពុងជួបនឹងពួកបរិសុទ្ធនៅ រ៉ាមុស រដ្ឋ អិលលីណោយ នៅថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៨៤៣ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩

*ព្យាការី យ៉ូសែប ស្ម៊ីធ បានផ្ដល់ការណែនាំទាក់ទងនឹងលក្ខណៈនៃការបម្រើរបស់ពួកទេវតា និង វិញ្ញាណទាំងឡាយ ។*

ប្រសិនបើមានមនុស្សម្នាក់មកសួរអ្នកថាតើពួកបរិសុទ្ធថ្ងៃចុងក្រោយជឿលើពួកទេវតាដែរឬអត់ តើអ្នកនឹងប្រាប់ពួកគេបែបណា ?

សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ចាប់តាំងពីការចាប់ផ្ដើម រហូតមកដល់គ្រប់ការកាន់កាប់ត្រួតត្រាទាំងអស់ ព្រះបានប្រើពួកទេវតាជាអ្នកផ្សព្វផ្សាយរបស់ទ្រង់នៅក្នុងការបង្ហាញសេចក្ដីស្រឡាញ់ និង ការខ្វល់ខ្វាយចំពោះកូនចៅរបស់ទ្រង់ ។. . .

« ជាទូទៅទេវតាទាំងនោះគឺមនុស្សមើល *មិន* ឃើញឡើយ ។ ពេលខ្លះមើលឃើញ ។ ប៉ុន្តែទោះបីឃើញ ឬ មិនឃើញក្ដីពួកគេគឺ *តែង* នៅក្បែរជានិច្ច ។ ពេលខ្លះការចាត់តាំងរបស់ពួកគេគឺធំអស្ចារ្យ ហើយមានសារៈសំខាន់ចំពោះពិភពលោកទាំងមូល ។ ពេលខ្លះ សារលិខិតនោះគឺសម្ងាត់ណាស់ ។ ម្ដងម្កាលគោលបំណងនៃទេវតាគឺមកដើម្បីព្រមាន ។ ប៉ុន្តែជាទូទៅវាគឺជាការលួងលោមចិត្ត ការផ្ដល់ជាទម្រង់នៃការយកចិត្តទុកដាក់មួយចំនួន ការដឹកនាំនៅក្នុងគ្រាដ៏លំបាក » ( « The Ministry of Angels » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២៩ ) ។

នៅដើមឆ្នាំ ១៨៣៩ និង បន្តរហូតដល់ ឆ្នាំ ១៨៤៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានផ្ដល់ការណែនាំដល់មនុស្សជាច្រើនដើម្បីជួយឲ្យពួកគេដឹងពីភាពខុសប្លែកគ្នានៃលក្ខណៈនៃការបម្រើរបស់ពួកទេវតា និង វិញ្ញាណទាំងឡាយ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩:១–៣ ដោយស្វែងរកភាពខុសគ្នាដ៏សំខាន់មួយរវាងពួកទេវភាព និង ពួកវិញ្ញាណ ។ ( វាអាចមានប្រយោជន៍ដោយដឹងថា ពាក្យ *សុចរិត* មានន័យថា បរិសុទ្ធ ) ។ តើពួកទេវតាខុសពីវិញ្ញាណទាំងឡាយដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩:៤–៧ ដោយស្វែងរករបៀបមួយដើម្បីញែកចេញរវាងភាពខុសគ្នានៃពួកទេវភាព និង ពួកវិញ្ញាណ ។

ដើម្បីយល់ដឹងទាំងស្រុងពី ខ ៧ សូមចងចាំថា ដោយសារវិញ្ញាណទាំងឡាយគ្មានរូបកាយនៃសាច់ និង ឆ្អឹង នោះពួកគេមិនអាចចាប់ដៃជាមួយនឹងមនុស្សបានឡើយ ។ ប្រសិនបើវិញ្ញាណធ្វើពុតថាមានសមត្ថភាពមួយ ដែលពួកគេគ្មានការណ៍នោះនឹងក្លាយជាការបញ្ឆោត ហើយវិញ្ញាណដែលល្បងធ្វើការណ៍នេះពុំមែនជា « មនុស្សសុចរិត » ឡើយ ។ ហេតុដូច្នេះហើយ វិញ្ញាណនៃមនុស្សសុចរិតដែលបានធ្វើឲ្យល្អឥតខ្ចោះនឹងពុំព្យាយាមចាប់ដៃនៅពេលមានដៃមួយហុចមករកពួកគេនោះទេ ។ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩:៧ យើងរៀនថា **សារទូតពិតដែលព្រះវរបិតាសួគ៌បានបញ្ជូនមកនឹងមិនឆបោកយើងឡើយ ។**

ពេលខ្លះអារក្សព្យាយាមក្លែងខ្លួនជា « ទេវតានៃពន្លឺ » ដើម្បីបោកប្រាស់មនុស្ស ( សូមមើល គ. និង ស. ១២៩:៨ ) ។ លើសពីនោះ« ព្រះគម្ពីរបាននិយាយផងដែរអំពីទេវតានៃអារក្ស ។ ទាំងនោះគឺជាពួកវិញ្ញាណណាដែលបានធ្វើតាមលូស៊ីហ្វើ ហើយត្រូវបានបណ្ដេញចេញពីវត្តមានរបស់ព្រះនៅក្នុងជីវិតមុនឆាកជីវិតនេះ ហើយដេញចុះទៅផែនដីនេះ ( វិវរណៈ ១២:១–៩ នីហ្វៃទី២ ៩:៩, ១៦ គ. និង ស. ២៩:៣៦–៣៧)(សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ពួកទេវតា » scriptures.lds.org) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩:៨–៩ ដោយស្វែងរករបៀបដើម្បីស្គាល់វិញ្ញាណអាក្រក់ដែលស្វែងរកបោកប្រាស់ដោយការក្លែងខ្លួនជាទេវតានៃពន្លឺ ។ ( វាអាចមានប្រយោជន៍ដោយដឹងថា ពាក្យ *ចាត់ចែង* នៅក្នុង ខ ៩ សំដៅលើការបង្ហាញ ឬ ការមកជួបពីទេវតា ឬ វិញ្ញាណ ) ។



សេចក្ដីថ្លែងការណ៍តទៅនេះរបស់ព្យាការី យ៉ូសែប ស្ម៊ីធ អាចជួយអ្នកឲ្យយល់ពីហេតុផលដែលពួកវិញ្ញាណអាក្រក់តែងតែធ្វើតាមសេចក្ដីណែនាំនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩ ៖ « វាទំនង . . . ដូចជាវិញ្ញាណទុច្ចរិតមានចំណង មានភាពកំណត់ និង ក្រឹត្យវិន័យរបស់គេ ដើម្បីគ្រប់គ្រង ហើយត្រួតត្រាពួកវា ហើយពួកគេដឹងពីជោគវាសនានាពេលអនាគតរបស់ខ្លួន » ( នៅក្នុង *History of the Church* ៤:៥៧៦ ) ។

១. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសង្ខេបពីអ្វីដែលអ្នកបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩ អំពីភាពខុសគ្នារវាងពួកទេវតា វិញ្ញាណសុចរិត និង ពួកវិញ្ញាណអាក្រក់ ។ បន្ថែមពីលើសេចក្ដីណែនាំនៅក្នុងខគម្ពីរទាំងនេះ សូមពន្យល់ថាតើអ្វីខ្លះទៀតដែលព្រះវរបិតាសួគ៌បានប្រទានដល់អ្នកដើម្បីជួយអ្នកឲ្យដឹងពីការបោកប្រាស់របស់សាតាំង ។

## គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣០:១–១១, ២២–២៣

*ព្យាការី យ៉ូសែប ស្ម៊ីធ បានបញ្ជាក់ពីគោលលទ្ធិផ្សេងៗ*

នៅថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៨៤៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានប្រារព្ធធ្វើសន្និសីទស្តេកជាមួយពួកបរិសុទ្ធនៅ រ៉ាមុស រដ្ឋ អិលលីណោយ ដែលមានចម្ងាយប្រហែល ៣២ គីឡូម៉ែត្រភាគអាគ្នេយ៍នៃទីក្រុង ណេវូ ។ អំឡុងពេលប្រជុំពេលព្រឹក អែលឌើរ អូរសុន ហៃឌ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានផ្សព្វផ្សាយទេសកថាមួយ ហើយបានបង្រៀនពីការបកស្រាយព្រះគម្ពីរដែលមិនត្រឹមត្រូវដែលលោកបានរៀនកាលពីមុនជាមួយព្រះវិហារផ្សេង ។ តើទំនួលខុសត្រូវអ្វីខ្លះដែលព្យាការីមាននៅក្នុងស្ថានភាពនេះ ?

ពួកថ្នាក់ដឹកនាំជាអធិបតីក្នុងសាសនាចក្រដូចជាព្យាការី ប្រធានស្តេក និង ប៊ីស្សពមានទំនួលខុសត្រូវដើម្បីប្រាកដថាគោលលទ្ធិត្រឹមត្រូវត្រូវបានបង្រៀននៅក្នុងការប្រជុំសាសនាចក្រ ។ បន្ទាប់ពីការប្រជុំនៅពេលព្រឹកនោះ យ៉ូសែប ស្ម៊ីធ អូរសុន ហៃឌ និង មនុស្សពីរបីនាក់ផ្សេងទៀត បានទទួលទានអាហារថ្ងៃត្រង់នៅផ្ទះ សូហ្វ្រូនៀ ជាប្អូនស្រីរបស់យ៉ូសែប ស្ម៊ីធ ។ អំឡុងពេលអាហារថ្ងៃត្រង់នោះ ព្យាការី បានប្រាប់អែលឌើរ ហៃឌ ថា លោក « នឹងផ្ដល់ការកែតម្រូវចំពោះការបង្រៀនរបស់គាត់ » ។ អែលឌើរ ហៃឌ បានឆ្លើយថា « ខ្ញុំនឹងទទួលដោយអំណរគុណ » ( នៅក្នុង *History of the Church* ៥:៣២៣ ) ។

សូមពន្យល់ថា នៅក្នុងការនិយាយនាព្រឹកនោះ អូរសុន ហៃឌ បានបកស្រាយខុសនូវខគម្ពីរ យ៉ូហាន ១៤:២៣ ។ សូមចំណាយពេលមួយភ្លែតដើម្បីសិក្សាខនេះ ។

បន្ទាប់ពី អូរសុន ហៃឌ បាននិយាយពីខគម្ពីរនេះហើយ លោកបានប្រាប់មនុស្សថា « វាគឺជាឯកសិទ្ធិរបស់យើងដើម្បីមានព្រះវរបិតា និង ព្រះរាជបុត្រាគង់នៅក្នុងដួងចិត្តរបស់យើង » ( នៅក្នុង *History of the Church* ៥:៣២៣ ) ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០ មានការកែប្រែរបស់ យ៉ូសែប ស្ម៊ីធ អំពីគំនិតនេះ ។ វាក៏មានការបង្រៀនបន្ថែមមួយចំនួនទៀតផងដែរ ។



អូរសុន ហៃឌ

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១–៣ ដោយស្វែងរកអ្វីដែលជាសេចក្ដីថ្លែងការណ៍របស់ អូរសុន ហៃឌ ទាក់ទងនឹងអត្ថន័យនៃ យ៉ូហាន ១៤:២៣ គឺខុសឆ្គង ។

មនុស្សជាច្រើនសព្វថ្ងៃនេះ ពុំមានគំនិតអំពីព្រះ ឬ ប្រហែលជាដូចជា អូរសុន ហៃឌ ដែលធ្លាប់ជាគ្រូបង្រៀនពួក ខេមប៊ែលីត មានទស្សនខុសពីលក្ខណៈនៃអទិទេព ដោយសារតែទំនៀមទម្លាប់ក្លែងក្លាយនានា ។ យើងអាចជួយមនុស្សដទៃឲ្យយល់ពីលក្ខណៈពិតរបស់ព្រះវរបិតាសួគ៌ និង ទំនាក់ទំនងរបស់ពួកគេជាមួយទ្រង់ ។

២. សូមឆ្លើយសំណួរដូចទៅនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ នៅក្នុងការសន្ទនាជាមួយក្រុមមនុស្សដែលមានប្រពៃណី ឬជំនឿខុសឆ្គងអំពីព្រះ តើអ្នកអាចមានចិត្តសណ្ដោស និង ការយល់ដឹងដោយរបៀបណា នៅពេលអ្នកចែកចាយអ្វីដែលអ្នកដឹងអំពីលក្ខណៈពិតរបស់ព្រះ—ថាទ្រង់មានលក្ខណៈបែបណានោះ ?

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២២–២៣ ដោយស្វែងរកសេចក្ដីពិតដែលព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនអំពីក្រុមព្រះ ។ ( គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២២–២៣ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ អ្នកអាចនឹងចង់គូសចំណាំវានៅក្នុងរបៀបមួយ ដែលជួយអ្នកអាចងាយរកវាឃើញនៅពេលខាងមុខ) ។

៣. សូមបំពេញកិច្ចការខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ចេញពីអ្វីដែលអ្នករៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២២–២៣ សូមសរសេរគោលលទ្ធិពីរ ឬបីអំពីក្រុមព្រះ ។

ខ. សូមសរសេរប្រយោគមួយ ឬពីរ ដោយពន្យល់ពីរបៀបដែលអ្នកអាចប្រើសេចក្ដីពិតដែលបានបង្រៀននៅក្នុង ខ ២២–២៣ ដើម្បីបង្រៀនមនុស្សដទៃទៀតអំពីក្រុមព្រះ ។

គ. តើអ្នកគិតថា ហេតុអ្វីវាសំខាន់ដើម្បីយល់ថា ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ជាអង្គពីរខុសគ្នាដោយមានរូបរាងកាយនៃសាច់ និងឆ្អឹង ?

ប្រពៃណីជាច្រើនអំពីព្រះជាព្រះវរបិតា ព្រះយេស៊ូវគ្រីស្ទ និង ព្រះវិញ្ញាណបរិសុទ្ធគឺផ្អែកទៅលើគំនិតរបស់មនុស្សប្រុសស្រីខាងសាច់ឈាម ។ គំនិតទាំងនេះមួយចំនួនត្រូវបានបង្កើតជាលទ្ធផលមួយនៃកិច្ចពិភាក្សាតទល់រវាងពួកអ្នកដឹកនាំសាសនា ។ ចំណេះដឹងរបស់យើងអំពីក្រុមព្រះកើតមានតាមរយៈវិវរណៈមកពីព្រះទៅកាន់ពួកព្យាការីរបស់ទ្រង់ ។ សេចក្ដីសង្ខេបនៃសេចក្ដីថ្លែងការណ៍ខាងក្រោមបានបើកសម្ដែងអំពីក្រុមព្រះ ។ នៅពេលអ្នកអាន សូមគូសចំណាំពាក្យ ឬ ឃ្លាណាដែលលេចធ្លោចំពោះអ្នក ។



« *ព្រះជាព្រះវរបិតា* ៖ ជាទូទៅគឺជាព្រះវរបិតា ឬ អឺឡូហិម ដែលត្រូវបានហៅថាដោយព្រះនាមព្រះ ។ ទ្រង់ត្រូវបានហៅថាជាព្រះវរបិតាដោយសារទ្រង់គឺជាព្រះវរបិតាខាងវិញ្ញាណរបស់យើង ។. . . ព្រះវរបិតាគឺជាអង្គគ្រប់គ្រងដ៏ខ្ពស់បំផុតនៃសាកលលោកនេះ ។ ទ្រង់មានព្រះចេស្ដាទាំងអស់ . . . ត្រាស់ដឹងអ្វីៗទាំងអស់ . . . ហើយទ្រង់មានវត្តមានគ្រប់ទីន្លែងតាមរយៈព្រះវិញ្ញាណរបស់ទ្រង់ ។. . . មនុស្សមានទំនាក់ទំនងពិសេសជាមួយព្រះ ដែលបានញែកមនុស្សចេញពីការបង្កើតអ្វីៗផ្សេងទៀតទាំងអស់ ៖ បុរស និង ស្ត្រីគឺជាបុត្រាបុត្រីខាងវិញ្ញាណរបស់ព្រះ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ព្រះ, ក្រុមព្រះ » scriptures.lds.org) ។

«*ព្រះដែលជាព្រះរាជាបុត្រា* ៖ ព្រះដែលបានស្គាល់ថាជាព្រះយេហូវ៉ា គឺជាព្រះរាជបុត្រា គឺព្រះយេស៊ូវគ្រីស្ទ ។. . . ព្រះយេស៊ូវធ្វើការក្រោមការដឹកនាំរបស់ព្រះវរបិតា ហើយចុះសម្រុងទាំងស្រុងជាមួយទ្រង់ ។ មនុស្សលោកទាំងអស់គឺជាបងប្អូនប្រុសស្រីរបស់ទ្រង់ ដ្បិតទ្រង់គឺជាបងបង្អស់របស់កូនចៅខាងវិញ្ញាណរបស់ អេឡូហិម ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ព្រះ, ក្រុមព្រះ » scriptures.lds.org) ។ ទ្រង់គឺជាអង្គប្រោសលោះ ហើយទ្រង់បានរងទុក្ខនូវអំពើបាប និង ការឈឺចាប់របស់មនុស្សលោកទាំងអស់ ហើយបានយកឈ្នះលើសេចក្ដីស្លាប់ខាងរូបកាយសម្រាប់មនុស្សទាំងអស់ ។

« *ព្រះដែលជាព្រះវិញ្ញាណបរិសុទ្ធ* ៖ ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះមួយអង្គផងដែរ ហើយត្រូវបានហៅថា ព្រះវិញ្ញាណបរិសុទ្ធ ព្រះវិញ្ញាណ ព្រះវិញ្ញាណនៃព្រះ ក្នុងចំណោមឈ្មោះ និង ព្រះនាមស្រដៀងនេះ [ មានដូចជា អង្គលួងលោម ] ។ ដោយមានជំនួយពីព្រះវិញ្ញាណបរិសុទ្ធ មនុស្សអាចដឹងពីព្រះឆន្ទៈរបស់ព្រះជាព្រះវរបិតា ហើយដឹងថាព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ព្រះ ក្រុមព្រះ » scriptures.lds.org) ។ តួនាទីចម្បងរបស់ព្រះវិញ្ញាណបរិសុទ្ធគឺដើម្បីថ្លែងទីបន្ទាល់អំពីព្រះជាព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទ ។ ព្រះវិញ្ញាណបរិសុទ្ធបង្រៀន និង បញ្ជាក់ពីសេចក្ដីពិត ។

៤. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរប្រយោគពីរបី ដោយសង្ខេបពីអ្វីដែលអ្នកបានរៀនអំពីក្រុមព្រះ ។ សូមពន្យល់ថាតើសេចក្ដីពិតមួយដែលជាប់ក្នុងចិត្តអ្នក និងពីហេតុផល ។ អ្នកក៏អាចនឹងចង់ដាក់បញ្ចូលទីបន្ទាល់របស់អ្នកអំពីក្រុមព្រះផងដែរ ។

សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២ ឡើងវិញ ។ នៅពេលអ្នកធ្វើដូច្នេះ អ្នកអាចនឹងចង់គូសចំណាំពាក្យដែលបង្រៀនពីសេចក្ដីថ្លែងការណ៍ខាងគោលលទ្ធិដូចតទៅនេះ ៖ **ទំនាក់ទំនងដែលយើងអាចមាននៅក្នុងឋានសួគ៌គឺដូចគ្នាទៅនឹងទំនាក់ទំនងទាំងអស់ដែលយើងរីករាយនៅលើផែនដីនេះ ប៉ុន្តែវានឹងរួមបញ្ចូលជាមួយសិរីរុងរឿងនៃភាពអស់កល្បជានិច្ច** ។ ( ពាក្យ *ទំនាក់ទំនង* ក្នុង ខ ២ សំដៅទៅលើលក្ខណៈនៃការប្រាស្រ័យគ្នា និង ការទាក់ទងផ្ទាល់ខ្លួន ) ។



ប្រធាន ហិនរី ប៊ី អាវរិង ក្នុងគណៈប្រធានទីមួយបានចែកចាយទីបន្ទាល់របស់លោកអំពីទំនាក់ទំនងដ៏នៅអស់កល្បទាំងនេះ ៖ « ដោយសារការស្ដារឡើងវិញនៃចំណេះដឹងអំពីក្រុមគ្រួសារអស់កល្បជានិច្ច នោះយើងមានសង្ឃឹម និង មានចិត្តសប្បុរសកាន់តែច្រើននៅក្នុងទំនាក់ទំនងគ្រួសាររបស់យើងទាំងអស់ ។ សេចក្ដីអំណរដ៏អស្ចារ្យបំផុតនៅក្នុងជីវិតនេះគឺនៅក្នុងក្រុមគ្រួសារ នៅពេលពួកគេនឹងនៅក្នុងពិភពខាងមុខទៀត ។ ខ្ញុំមានអំណរគុណយ៉ាងខ្លាំងចំពោះការអះអាង ដែលខ្ញុំមាន បើសិនយើងស្មោះត្រង់ នោះទំនាក់ទំនងដដែលនោះដែលយើងរីករាយនៅទីនេះ នៅក្នុងជីវិតនេះ នឹងបន្តនៅអស់កល្បជាមួយយើងនៅក្នុងពិភពខាងមុខ នៅក្នុងសិរីរុងរឿងដ៏អស់កល្ប ។ [ សូមមើល គ. និង ស. ១៣០:២ ] » ។ ( « The True and Living Church » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ២២ ) ។

៥. សូមបំពេញកិច្ចការខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមឆ្លើយសំណួរដូចទៅនេះ ៖ តើការដឹងថាទំនាក់ទំនងយើងនៅលើផែនដីអាចបន្តនៅក្នុងសិរីល្អដ៏នៅអស់កល្បជានិច្ចនៅស្ថានសួគ៌ ជះឥទ្ធិពលចំពោះការប្រព្រឹត្តរបស់យើងចំពោះគ្នាយ៉ាងដូចម្ដេចខ្លះ ?

ខ. សូមគិតពីកិច្ចការមួយដែលអ្នកអាចធ្វើដើម្បីពង្រឹងទំនាក់ទំនងរបស់អ្នកជាមួយនឹងអ្នកដទៃ ជាពិសេសសមាជិកគ្រួសាររបស់អ្នក ។ រួចសរសេរគោលដៅមួយដើម្បីធ្វើវា ។

គោលលទ្ធិបន្ថែមមួយចំនួនទៀតបានបង្រៀនដោយព្យាការី យ៉ូសែប ស្ម៊ីធ នៅក្នុងរ៉ាមូស រដ្ឋ អិលលីណោយ មាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:៤–១១ ។ សូមអានខទាំងនេះ ដោយស្វែងរកការបង្រៀនរបស់ព្យាការីអំពីពួកទេវតា និងអំពីអនាគតនៃផែនដី ។ យោងតាម ខ ១០–១១ អស់អ្នកដែលគ្រងមរតកនៃនគរសេឡេស្ទាលនឹងទទួល យូរីម និង ធូមីម មួយដើម្បីជួយពួកគេឲ្យរៀន និង យល់អំពីអ្វីៗនៃស្ថានសួគ៌ ។ ព្យាការី ពុំបានបរិយាយល្អិតល្អន់អំពីការបង្រៀននេះឡើយ ។

## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២២–២៣

៦. អែលឌើរ ជែហ្វ្រី អ័រ ហូឡិន បានថ្លែងថា « យើងសូមប្រកាសថា វាគឺជាភស្ដុតាងផ្ទាល់ខ្លួនមកពីព្រះគម្ពីរដែលថា ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធគឺមានតួអង្គផ្សេងគ្នា ជាតួអង្គដ៏ទេវភាពបីផ្សេងគ្នា » ( « The Only True God and Jesus Christ Whom He Hath Sent » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៤១ ) ។ ដើម្បីឃើញពីរបៀបដែលគោលលទ្ធិនៃក្រុមព្រះត្រូវបានបង្រៀនយ៉ាងច្បាស់លាស់នៅក្នុងព្រះគម្ពីរ សូមស្វែងរកសារលិខិតនៅក្នុងព្រះគម្ពីរសញ្ញាថ្មីយ៉ាងហោចណាស់ឲ្យបានបី ដែលបង្រៀនពីគោលលទ្ធិដែលអែលឌើរ ហូឡិន បានពិពណ៌នា ។ វាមានប្រយោជន៍ក្នុងការប្រើសម្ភារជំនួយសម្រាប់ការសិក្សាព្រះគម្ពីរ ដូចជា Topical Guide លិបិក្រមនៅក្នុងព្រះគម្ពីរ និងសេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ។ សូមសរសេរសេចក្ដីយោងសម្រាប់វគ្គបទគម្ពីរដែលអ្នករកឃើញ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ អ្នកក៏អាចនឹងចង់សរសេរសេចក្ដីពិតនេះនៅក្នុងព្រះគម្ពីររបស់អ្នក ក្បែរ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២២–២៣ ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩; ១៣០:១–១១, ២២–២៣ ហើយបានបញ្ចប់មេរៀននេះនៅ ( កាលបរិច្ឆេទ ) ។*

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៨ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១២–២១

## បុព្វកថា

មេរៀននេះរួមមានគោលលទ្ធិដែលព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀននៅការប្រជុំសាសនាចក្រមួយនៅរ៉ាមូស រដ្ឋអិលលីណោយ នៅថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៨៤៣ ។ សេចក្ដីណែនាំទាំងនេះត្រូវបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០ ។ ព្យាការីបានបង្រៀនអំពីព្រឹត្តិការណ៍នាអនាគត រួមមានទាំងការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទផងដែរ ។ លោកក៏បានបង្រៀនអំពីសមត្ថភាពរបស់យើងដើម្បីរក្សាទុកចំណេះដឹង និងប្រាជ្ញាបន្ទាប់ពីយើងស្លាប់ ហើយបានពន្យល់ពីរបៀបដែលយើងអាចទទួលបានពរជ័យរបស់ព្រះ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១២–១៧

*យ៉ូសែប ស្ម៊ីធ បង្រៀនអំពីការយាងមកជាលើកទីពីរ*

តើអ្នកធ្លាប់ចង់ដឹងថាការយាងមកជាលើកទីពីរនឹងកើតឡើងនៅពេលណាដែរទេ ?

មានមនុស្សផ្សេងទៀតជាច្រើននាក់បានងឿងឆ្ងល់ពីរឿងនេះដូចគ្នា ។ នៅក្នុងសម័យរបស់យ៉ូសែប ស្ម៊ីធ មានគ្រូគង្វាលម្នាក់ដែលមានឋានៈខ្ពស់ឈ្មោះ វិល្លាម មិល្លើ បានប្រកាសថា ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់នឹងកើតឡើងនៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៨៤៣ ។ ពីមុនថ្ងៃដែលមិល្លើ បានទស្សន៍ទាយពីការយាងមកជាលើកទីពីរមួយថ្ងៃ ព្យាការី យ៉ូសែប ស្ម៊ីធ បានថ្លែងទៅពួកបរិសុទ្ធនៅរ៉ាមូស រដ្ឋអិលលីណោយ ហើយបានលើកឡើងថា លោកបានអធិស្ឋានដើម្បីឲ្យដឹងពីពេលវេលានៃការយាងមកជាលើកទីពីរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១៤–១៧ ដោយស្វែងរកអ្វីដែលយ៉ូសែប ស្ម៊ីធ បានដឹងពេលលោកបានអធិស្ឋានអំពីកាលវេលានៃការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។

សូមកត់ចំណាំថា ព្រះអម្ចាស់មិនបានបើកសម្ដែងដល់យ៉ូសែប ស្ម៊ីធ ពីកាលបរិច្ឆេទនៃការយាងមកជាលើកទីពីរឡើយ ។ លើសពីនេះទៀត ទ្រង់បានណែនាំដល់យ៉ូសែប ថា « ចូរកុំរំខានយើងពីការណ៍នេះទៀតឡើយ » ( គ. និង ស. ១៣០:១៥ ) ។ សូមមើលសេចក្ដីយោងបទគម្ពីរនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១៥ លេខយោង *ក* ។ វគ្គទាំងនេះបានគូសបញ្ជាក់បន្ថែមទៀតថា គ្មាននរណាម្នាក់ដឹងប្រាកដពីពេលដែលព្រះអង្គសង្គ្រោះនឹងយាងមកវិញឡើយ ។

នៅក្នុងសេចក្ដីថ្លែងតទៅនេះ សូមគូសបន្ទាត់ពីក្រោមនូវអ្វីដែលអែលឌើរ អិម រ័សុល បាឡឺដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានថ្លែងអំពីអ្នកដែលដឹងពីពេលដែលការយាងមកជាលើកទីពីរនឹងកើតឡើង ៖



« ខ្ញុំត្រូវបានហៅជាសាវកមួយរូបដើម្បីធ្វើជាសាក្សីពិសេសរបស់ព្រះគ្រីស្ទនៅក្នុងគ្រាដ៏រំភើប ហើយតានតឹងទាំងនេះ ហើយខ្ញុំមិនដឹងថាពេលណាទ្រង់នឹងយាងមកម្ដងទៀតឡើយ ។ អ្វីដែលខ្ញុំអាចដឹងគឺគ្មានបងប្អូនប្រុសរបស់ខ្ញុំណាម្នាក់នៅក្នុងកូរ៉ុមនៃពួកដប់ពីរនាក់ ឬសូម្បីតែគណៈប្រធានទីមួយបានដឹងដែរ ។ ហើយខ្ញុំសូមណែនាំដោយរាបសារថា ប្រសិនបើយើងមិនដឹង នោះគ្មាននរណាម្នាក់ដឹងឡើយមិនថាការលើកហេតុផលរបស់ពួកគេមានការបង្ខិតបង្ខំបែបណា ឬការគណនារបស់ពួកគេសមហេតុសមផលយ៉ាងណានោះទេ ។ ព្រះអង្គសង្គ្រោះបានមានបន្ទូលថា ‹ អំពីថ្ងៃ និង កាលវេលានោះ គឺគ្មាននរណាម្នាក់ដឹងឡើយ សូម្បីតែពួកទេវតានៃព្រះនៅឯស្ថានសួគ៌ ប៉ុន្តែមានតែព្រះវរបិតាយើងមួយអង្គគត់ › [ Joseph Smith—Matthew ១:៤០ ] ។

« ខ្ញុំជឿថា នៅពេលព្រះអម្ចាស់មានបន្ទូលថា ‹ គ្មាននរណាម្នាក់ ›ដឹងឡើយ នោះទ្រង់ពិតជាមានន័យថាគ្មាននរណាម្នាក់ដឹងឡើយ ។ យើងគួរតែប្រុងប្រយ័ត្នក្រៃលែងចំពោះជនណាមួយដែលប្រកាសថាមានករណីលើកលែងចំពោះបញ្ញត្តិនៃព្រះ » ( « When Shall These Things Be? » *Ensign* ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៥៦) ។

យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១៤–១៧ និង សេចក្ដីថ្លែងការណ៍របស់អែលឌើរ បាឡឺដ យើងបានរៀនថា **មានតែព្រះទេដែលដឹងពីពេលវេលាជាក់លាក់ដែលការយាងមកជាលើកទីពីរនឹងកើតឡើង ។**

១. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការចងចាំអំពីសេចក្ដីពិតនេះ អាចជួយអ្នកកុំឲ្យភ័ន្តច្រឡំចំពោះការប្រកាសខុសនានាដោយរបៀបណា ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១៨–១៩

*យ៉ូសែប ស៊្មីធ បង្រៀនអំពីសារៈសំខាន់នៃការទទួលបានចំណេះដឹង និង ប្រាជ្ញានៅក្នុងជីវិតនេះ*

សូមនឹកស្រមៃថា អ្នកកំពុងចាកចេញពីផ្ទះទៅកន្លែងមួយដែលអ្នកពុំធ្លាប់ទៅពីមុនសោះ ។ អ្នកត្រូវបានអនុញ្ញាតឲ្យយកឥវ៉ាន់តែមួយវ៉ាលីប៉ុណ្ណោះ ។ តើឥវ៉ាន់អ្វីខ្លះដែលអ្នកចង់ដាក់ក្នុងវ៉ាលីរបស់អ្នក ?



ចុះប្រសិនបើកន្លែងដែលអ្នកទៅជាពិភពវិញ្ញាណវិញ ( កន្លែងដែលវិញ្ញាណយើងទៅក្រោយពីយើងស្លាប់ ) ? តើរបស់ណាមួយដែលអ្នកជ្រើសដាក់នៅក្នុងវ៉ាលីរបស់អ្នកដែលអ្នកអាចយកវាទៅជាមួយនៅពេលអ្នកស្លាប់ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១៨–១៩ ដោយស្វែងរកអ្វីដែលយើងអាចយកទៅជាមួយនឹងយើងបានពេលយើងស្លាប់ទៅ ។

យោងតាម ខ ១៨–១៩ តើអ្វីនឹងនៅជាមួយយើងក្រោយពេលយើងស្លាប់ទៅ ? ដើម្បីឆ្លើយសំណួរនេះ សូមបំពេញគោលការណ៍ដូចតទៅនេះ ៖ **និង ដែលយើងទទួលបាននៅក្នុងជីវិតនេះ នោះនឹងនៅជាប់ជាមួយយើងក្នុងដំណើររស់ឡើងវិញ ។**



អែលឌើរ នែល អេ ម៉ាក់ស្វែល ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានជួយយើងឲ្យយល់ពីអត្ថន័យនៃពាក្យ *ប្រាជ្ញា* នៅក្នុងខគម្ពីរទាំងនេះ ៖ « ប្រសិនបើយើងសញ្ជឹងគិតពីអ្វីដែលនឹងនៅក្រោកឡើងជាមួយនឹងយើងនៅក្នុងការរស់ឡើងវិញ វាសបញ្ជាក់យ៉ាងច្បាស់ថា ប្រាជ្ញាយើងនឹងក្រោកឡើងជាមួយនឹងយើង គឺពុំមែនតែការសាកល្បងប្រាជ្ញារបស់យើងប៉ុណ្ណោះទេ ប៉ុន្តែជាសមត្ថភាពរបស់យើងដើម្បីទទួល ហើយអនុវត្តសេចក្ដីពិតផងដែរ ។ ទេពកោសល្យ លក្ខណៈ និងជំនាញរបស់យើងនឹងក្រោកឡើងជាមួយយើង ពិតណាស់រួមទាំងសមត្ថភាពរបស់យើងដើម្បីរៀន កម្រិតនៃទំនុកចិត្តរបស់យើង និង សមត្ថភាពធ្វើការរបស់យើងផងដែរ » ( *We Will Prove Them Herewith* [ ឆ្នាំ ១៩៨២ ] ទំព័រ ១២ ) ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១៩ តើយើងអាចទទួលចំណេះដឹង និង ប្រាជ្ញាច្រើនជាងមុនបានដោយរបៀបណា ?

ខ. តើអ្នកធ្លាប់ទទួលបានចំណេះដឹង ឬប្រាជ្ញាតាមរយៈភាពឧស្សាហ៍ និង ការស្ដាប់បង្គាប់របស់អ្នកនៅពេលណាដែរ ? តើអ្នកបានជួបបទពិសោធន៍អ្វីខ្លះ ?

សូមកត់សម្គាល់ថា យោងតាម ខ ១៩ ពួកអ្នកដែលទទួលបានចំណេះដឹង និង ប្រាជ្ញាច្រើននៅក្នុងជីវិតនេះនឹងមានឧត្តមភាពនៅក្នុងលោកខាងមុខ ។ នេះមានន័យថា អ្វីដែលយើងរៀននៅក្នុងជីវិតនេះ ទាំងខាងសាច់ឈាម និង ខាងវិញ្ញាណ នឹងជាប្រយោជន៍ដល់យើងនៅក្នុងភាពអស់កល្បជានិច្ច ។ យើងនឹងប្រើចំណេះដឹងដែលយើងទទួលបាននៅក្នុងជីវិតនេះដើម្បីប្រែក្លាយកាន់តែដូចជាព្រះវរបិតាសួគ៌ ។

៣. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរគោលដៅមួយ ដែលអាចជួយអ្នកទទួលបានចំណេះដឹង និង ប្រាជ្ញាច្រើន ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២០–២១

*យ៉ូសែប ស៊្មីធ ពន្យល់ពីរបៀបដែលយើងទទួលពរជ័យ*

សូមនឹកស្រមៃថា អ្នកចង់កែលម្អសិល្បៈក្នុងការសរសេររបស់អ្នក ដូច្នេះអ្នកសម្រេចចិត្តរត់ប្រហែលជាប្រាំគីឡូម៉ែត្រ ប្រាំថ្ងៃក្នុងមួយសប្ដាហ៍រយៈពេលមួយខែ ។ តើការហ្វឹកហាត់នេះជះឥទ្ធិពលទៅលើសិល្បៈនៃការសរសេររបស់អ្នកបានដោយរបៀបណា ?



ប្រសិនបើអ្នកចង់កែលម្អសិល្បៈក្នុងការសរសេររបស់អ្នក តើអ្នកត្រូវធ្វើអ្វីខ្លះ ?

ដូចជាយើងត្រូវយល់ដឹងពីរបៀបដើម្បីទទួលបានលទ្ធផលដែលយើងចង់បានផងដែរ នោះយើងត្រូវយល់ដឹងពីរបៀបដើម្បីទទួលបានពរជ័យដែលព្រះវរបិតាសួគ៌មានព្រះរាជបំណងចង់ប្រទានដល់យើង ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:២០–២១ ដោយស្វែងរករបៀបដែលយើងអាចទទួលបានពរជ័យដែលព្រះវរបិតាសួគ៌ មានព្រះរាជបំណងចង់ប្រទានដល់យើង ។ វាអាចមានប្រយោជន៍ដើម្បីដឹងថា ពាក្យ *ផ្អែកទៅលើ* មានន័យថា « សំអាងលើ » និងឃ្លា « ដ៏ពុំអាចដកចេញបាន » មានន័យថាច្បាប់មួយមានភាពជាអចិន្ត្រៃយ៍ ហើយមិនអាចផ្លាស់ប្ដូរបាន ។

ដោយយោងទៅលើអ្វីដែលអ្នកបានរៀននៅក្នុង ខ ២០–២១ សូមបំពេញគោលការណ៍ដូចតទៅនេះ ៖ **ប្រសិនបើយើងចង់ទទួលបាន នោះយើងត្រូវ** ។

ដើម្បីជួយអ្នកឲ្យយល់បន្ថែមទៀតពីគោលការណ៍នេះ សូមបំពេញតារាងខាងក្រោម ។ សូមអានបទគម្ពីរទាំងនោះ រួចរកមើលពីច្បាប់ និងពរជ័យដែលភ្ជាប់មកជាមួយដែលបានពិពណ៌នានៅក្នុងបទគម្ពីរនីមួយៗ ។

| វគ្គបទគម្ពីរ | ច្បាប់ | ពរជ័យ |
|---|---|---|
| គ. និង ស. ១០:៥ | | |
| នីហ្វៃទី២ ៣២:៣ | | |
| ម៉ាឡាគី ៣:៨–១០;<br>គ. និង ស. ៦៤:២៣ | | |
| គ. និង ស. ៨៩:១៨–២១ | | |

៤. សូមបំពេញកិច្ចការខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមឆ្លើយសំណួរដូចតទៅនេះ ៖ តើពរជ័យអ្វីខ្លះដែលអ្នកធ្លាប់ទទួលដោយសារអ្នកគោរពតាមច្បាប់មួយ ?

ខ. សូមគិតអំពីពរជ័យដែលអ្នកចង់ទទួលបាន ។ សូមសរសេរពីអ្វីដែលច្បាប់ ឬច្បាប់នានាដែលអ្នកត្រូវគោរពតាម ដើម្បីអ្នកអាចទទួលបានពរជ័យទាំងនោះ ។ ( អ្នកអាចប្រើជំនួយសម្រាប់ការសិក្សាព្រះគម្ពីរដូចជា សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ឬ Topical Guide ( ការណែនាំតាមប្រធានបទ ) ដើម្បីជួយអ្នកឲ្យស្វែងរកច្បាប់នានាដែលជួយនាំមកនូវពរជ័យ ។ ត្រូវចងចាំថា ច្បាប់ និង ពរជ័យខ្លះគឺមានភាពជាក់លាក់ខ្លាំងណាស់ កាលដែលច្បាប់ដទៃទៀតគឺជាលក្ខណៈទូទៅ ។ វាក៏សំខាន់ផងដែរដើម្បីចងចាំថា ពរជ័យខ្លះដែលបានសន្យាអាចកើតមានបន្ទាប់ពីជីវិតរមែងស្លាប់ ) ។

សូមរំឭកអំពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយ ដែលអ្នកបានរកឃើញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០ ។ សូមពិចារណាពីគោលលទ្ធិ និង គោលការណ៍នានា នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍ដូចតទៅនេះរបស់ប្រធាន ព្រិកហាំ យ៉ង់ ស្ដីពីសមត្ថភាពរបស់ព្យាការី យ៉ូសែប ស៊្មីធ ក្នុងការពន្យល់ពីរឿងរបស់ព្រះ ៖ « ភាពរុងរឿងដ៏ឧត្តមនៃចរិកលក្ខណៈរបស់បងប្រុស យ៉ូសែប ស៊្មីធ គឺថា លោកអាចធ្វើឲ្យមនុស្សដែលមានការយល់ដឹងមានកំណត់អាចយល់ដឹងពីរឿងសួគ៌ាបាន ។ នៅពេលលោកបង្រៀនដល់មនុស្សទូទៅ—ដោយបើកសម្ដែងពីរឿងរបស់ព្រះ ព្រះទ័យនៃព្រះ ផែនការនៃសេចក្ដីសង្គ្រោះ

ព្រះរាជបំណងនៃព្រះយេហូវ៉ា ទំនាក់ទំនងដែលយើងមានជាមួយនឹងទ្រង់ និង តួអង្គសួគ៌ាទាំងអស់—លោកបានសម្របការបង្រៀនរបស់លោកទៅនឹងសមត្ថភាពរបស់បុរស ស្ត្រី និង កុមារគ្រប់រូប ដោយគូសបញ្ជាក់វាយ៉ាងច្បាស់ ។ ការណ៍នេះគួរតែធ្វើឲ្យមនុស្សគ្រប់គ្នាដែលស្ដាប់លោកហើយបានដឹងពីសិទ្ធិអំណាច និង អំណាចដ៏ទេវភាពរបស់លោក ពីព្រោះគ្មាននរណាផ្សេងទៀតអាចបើកសម្ដែងរឿងនៃព្រះបានឡើយ មានតែតាមរយៈវិវរណៈរបស់ព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ » ( *Teachings of Presidents of the Church: Brigham Young* [ឆ្នាំ ១៩៩៧ | ទំព័រ ៣៤៧) ។

៥. សូមឆ្លើយសំណួរដូចតទៅនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើគោលការណ៍នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៩–៣០ ពង្រឹងទីបន្ទាល់អ្នកចំពោះការហៅបម្រើរបស់យ៉ូសែប ស្ម៊ីធ យ៉ាងដូចម្ដេច ?

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣០:១២–២១ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៨ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១

## សេចក្ដីផ្ដើម

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១ រួមមាននូវការបកស្រាយមួយអំពីគោលការណ៍ ដែលព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនកាលនៅរ៉ាមូស រដ្ឋ អិលលីណោយ នៅ ថ្ងៃទី ១៦–១៧ ខែ ឧសភា ឆ្នាំ ១៨៤៣ ។ លោកបានបង្រៀនអំពីសេចក្ដីសញ្ញា ថ្មី ហើយអស់កល្បជានិច្ចនៃអាពាហ៍ពិពាហ៍ និង ការសន្យានៃជីវិតដ៏នៅអស់កល្ប ជានិច្ចសម្រាប់អ្នកស្មោះត្រង់ ។ លោកក៏បានបង្រៀនផងដែរថា គ្រប់អស់ទាំង វិញ្ញាណសុទ្ធតែជាធាតុ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:១–៤

*យ៉ូសែប ស្ម៊ីធ បង្រៀនអំពីសារៈសំខាន់នៃសេចក្ដីសញ្ញាអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច*



ហេតុអ្វីព្រះអម្ចាស់ និង ថ្នាក់ដឹកនាំសាសនាចក្រធ្វើការ គូសបញ្ជាក់យ៉ាងខ្លាំងពីការរៀបការនៅក្នុងព្រះវិហារ បរិសុទ្ធ ? គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១ ជួយ យើងឲ្យឆ្លើយសំណួរនោះ ។ ដូចគ្នានឹង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២ ដែលអ្នកនឹងសិក្សានៅមេរៀនបន្ទាប់ ។

នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៨៤៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានធ្វើដំណើរទៅកាន់ រ៉ាមូស រដ្ឋអិលលីណយ ។ កាលស្នាក់ នៅក្នុងផ្ទះរបស់បេនយ៉ាមីន និង មិលីហ្សា ចនសុន លោក បានផ្សារភ្ជាប់ពួកគេជាស្វាមី ភរិយាដ៏នៅអស់កល្បជានិច្ច ( ពិធីបរិសុទ្ធនេះបានផ្ដល់សិទ្ធិបណ្ដោះអាសន្នរហូតដល់ ព្រះវិហារបរិសុទ្ធបានសង់រួចរាល់ ) ។ លោកក៏បានបង្រៀន ផងដែរពីរបៀបដែលអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច ទាក់ទងនឹងនគរសេឡេស្ទាល ។ សេចក្ដីពិតទាំងនេះត្រូវបាន កត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣១:១–៤ ។ ( សូមមើល *History of the Church* ៥:៣៩១–៩២ )។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:១ ដោយ ស្វែងរកសេចក្ដីពិតមួយ ដែលព្យាការីបានបើកសម្ដែងអំពីនគរ សេឡេស្ទាល ។ បន្ទាប់មក សូមបំពេញគោលការណ៍ដូចតទៅ នេះ ៖ មាន ស្ថានសួគ៌ ឬកម្រិតនៅក្នុងនគរសេឡេស្ទាល ។

ជារឿយៗ យើងយោងទៅការទទួលបានកម្រិតខ្ពស់បំផុតនៃ សិរីល្អនៅក្នុងនគរសេឡេស្ទាលជាភាពតម្កើងឡើង ឬជីវិតដ៏នៅអស់កល្បជានិច្ច ។ អស់អ្នកដែលទទួលកម្រិតនេះនៅក្នុងសិរីល្អ សេឡេស្ទាលនឹងរស់នៅក្នុងជីវិតដូចគ្នាដែលព្រះវរបិតាសួគ៌យើងមាន ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:២–៤ ដោយស្វែងរកអ្វី ដែលយើងត្រូវធ្វើ ដើម្បីទទួលបានកម្រិតខ្ពស់បំផុតនៃ នគរសេឡេស្ទាល ។ ( គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:១–៤ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ អ្នកអាចនឹងចង់គូសចំណាំ ខគម្ពីរទាំងនេះនៅក្នុងរបៀបមួយដែលងាយសម្គាល់ ដើម្បីអ្នកអាចងាយរកវាឃើញនៅពេលខាងមុខ ) ។

យោងតាមអ្វីដែលអ្នករៀននៅក្នុង ខ ២ សូមបំពេញសេចក្ដីថ្លែងការណ៍ខាងគោលលទ្ធិដូចតទៅនេះ ៖ **ដើម្បីទទួលបានកម្រិត ខ្ពស់បំផុតនៃនគរសេឡេស្ទាល យើងត្រូវចូល** ទៅក្នុង។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:៤ យើងរៀនថា ប្រសិនបើយើងមិនបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធដោយ សិទ្ធិអំណាចត្រឹមត្រូវទេ នោះយើង « ពុំអាចបានភាពចម្រើនឡើយ » ។ *ភាពចម្រើន* សំដៅទៅលើឱកាសដើម្បីបន្តមានកូនចៅ នៅក្នុងនគរសេឡេស្ទាល ។

សូមកត់សម្គាល់ឃ្លា « សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចខាងអាពាហ៍ពិពាហ៍ » នៅក្នុង ខ ២ ។ ពាក្យ *ថ្មី* នៅក្នុងបរិបទនេះមានន័យថា សេចក្ដីសញ្ញានេះត្រូវបានស្ដារឡើងវិញថ្មីនៅក្នុងសម័យកាន់កាប់ត្រួតត្រារបស់យើង ។ ពាក្យ *អស់កល្បអស់កាលជានិច្ច* មានន័យថា សេចក្ដីសញ្ញាដ៏សំខាន់នេះនឹងបន្តនៅក្នុងភាពអស់កល្បជានិច្ច ។ យើងចូលទៅក្នុងសេចក្ដីសញ្ញានៃអាពាហ៍ពិពាហ៍សេឡេស្ទាលនេះតែនៅក្នុងព្រះវិហារបរិសុទ្ធប៉ុណ្ណោះ ។

តើអ្នកគិតថា អាពាហ៍ពិពាហ៍សេឡេស្ទាលរវាងបុរស និងស្ត្រីរៀបចំពួកគេសម្រាប់ភាពតម្កើងឡើងដោយរបៀបណា ? អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានផ្ដល់ជាទស្សនដ៏សំខាន់មួយចំនួនចំពោះសំណួរនេះ ។ នៅពេលអ្នកអានអ្វីដែលលោកបានបង្រៀន សូមគូសចំណាំពាក្យ ឬឃ្លាដែលពន្យល់ពីរបៀបដែលអាពាហ៍ពិពាហ៍សេឡេស្ទាលជួយរៀបចំយើងសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ។



« ហេតុផលខាងគោលលទ្ធិពីរជួយយើងឲ្យយល់ដឹងពីហេតុផលដែលអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចគឺជារឿងដ៏សំខាន់នៅក្នុងផែនការរបស់ព្រះវរបិតា ។

«**ហេតុផលទី ១ ៖** *ធម្មជាតិនៃវិញ្ញាណបុរស និង ស្ត្រីបំពេញ ហើយធ្វើឲ្យទាំងសងខាងបានល្អឥតខ្ចោះ ហេតុដូច្នេះហើយ បុរស និង ស្ត្រីត្រូវតាំងចិត្តដើម្បីរីកចម្រើនរួមគ្នាឆ្ពោះទៅកាន់ភាពតម្កើងឡើង ។. . .*

« តាមរយៈការរចនាដ៏ទេវភាពបុរស និង ស្ត្រី ត្រូវបានតាំងចិត្តដើម្បីរីកចម្រើនជាមួយគ្នាឆ្ពោះទៅកាន់ភាពល្អឥតខ្ចោះ និង ភាពដ៏ពេញលេញនៃសិរីល្អ ។ ដោយសារភាពខុសគ្នានៃនិស្ស័យ និង សមត្ថភាពរបស់ខ្លួន បុរស និង ស្ត្រីគ្រប់រូបនាំមកកាន់ទំនាក់ទំនងអាពាហ៍ពិពាហ៍នូវទស្សនវិស័យ និង បទពិសោធន៍ដ៏ពិសេស ។ បុរស និង ស្ត្រី មានលក្ខណៈផ្សេងគ្នា ប៉ុន្តែមានភាពស្មើគ្នាតែមួយ និង សាមគ្គីភាព ដែលកិច្ចការទាំងនេះមិនអាចទទួលបានជោគជ័យបានតាមវិធីផ្សេងឡើយ ។ បុរសបំពេញ និងធ្វើឲ្យស្ត្រីបានគ្រប់លក្ខណ៍ ហើយស្ត្រីបំពេញ និងធ្វើឲ្យបុរសបានគ្រប់លក្ខណ៍ នៅពេលពួកគេរៀនពីគ្នា ហើយពង្រឹង និងប្រទានពរដល់គ្នាទៅវិញទៅមកនោះ ។. . .

« **ហេតុផលទី ២ ៖** *តាមរយៈការរៀបចំរបស់ព្រះ ទាំងបុរស និង ស្ត្រីត្រូវនាំយកកូនចៅមកក្នុងជីវិតរមែងស្លាប់ ហើយផ្ដល់មជ្ឈដ្ឋានដ៏ល្អបំផុតសម្រាប់ការចិញ្ចឹមបីបាច់កូនចៅ . . .*

« គេហដ្ឋានមួយដែលមានស្វាមីភរិយាដែលស្មោះត្រង់ ហើយចេះស្រឡាញ់គ្នាគឺជាមជ្ឈដ្ឋានដ៏ល្អបំផុតដែលកូនចៅអាចត្រូវបានចិញ្ចឹមដោយសេចក្ដីស្រឡាញ់ និង សេចក្ដីសុចរិត ហើយដែលសេចក្ដីត្រូវការខាងវិញ្ញាណ និង ខាងសាច់ឈាមរបស់កូនចៅអាចត្រូវបានបំពេញ ។ ដូចជាបុគ្គលិកលក្ខណៈដាច់ពីគ្នារបស់បុរស និង ស្ត្រីធ្វើវិភាគទានចំពោះភាពពេញលេញនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ដែរ ដូច្នេះបុគ្គលិកលក្ខណៈដូចគ្នានោះមានសារៈសំខាន់ដើម្បីចិញ្ចឹមបីបាច់ ហើយបង្រៀនដល់កូនចៅ » ( « Marriage Is Essential to His Eternal Plan » *Ensign* ខែ មិថុនា ឆ្នាំ ២០០៦ ទំព័រ ៨៣–៨៤ ឬ *Liahona* ខែ មិថុនា ឆ្នាំ ២០០៦ ទំព័រ ៥១–៥២ ) ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការយល់ដឹងគោលលទ្ធិថាអាពាហ៍ពិពាហ៍សេឡេស្ទាលគឺចាំបាច់សម្រាប់ភាពតម្កើងឡើងអាចជះឥទ្ធិពលលើអ្វីដែលអ្នកស្វែងរកនៅក្នុងស្វាមី ឬភរិយានាពេលអនាគតយ៉ាងដូចម្ដេច ?

ខ. ហេតុអ្វីបានវាសំខាន់ដើម្បដាក់អាទិភាពមួយដើម្បីរៀបចំខ្លួនទទួល « សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចខាងអាពាហ៍ពិពាហ៍ » នៅវ័យរបស់អ្នក ( គ. និង ស. ១៣១:២ ) នៅក្នុងព្រះវិហារបរិសុទ្ធ ?

ពរជ័យនៃភាពតម្កើងឡើងគឺមានចំពោះអស់អ្នកដែលគ្មានឱកាសសម្រាប់អាពាហ៍ពិពាហ៍សេឡេស្ទាលនៅក្នុងជីវិតនេះ ៖ « សមាជិកសាសនាចក្រមួយចំនួននៅលីវហួតដែលពុំមែនជាកំហុសរបស់ពួកគេ ទោះជាពួកគេចង់រៀបការក្ដី ។ ប្រសិនបើអ្នកឃើញខ្លួនអ្នកស្ថិតនៅក្នុងស្ថានភាពនេះ សូមប្រាកដថា ‹ គ្រប់ការណ៍ទាំងអស់ផ្សំគ្នាសម្រាប់សេចក្ដីល្អ ដល់ពួកអ្នកដែលស្រឡាញ់ព្រះ › ( រ៉ូម ៨:២៨ ) ។ នៅពេលអ្នកបន្តមានភាពសក្ដិសម នោះនៅថ្ងៃណាមួយ នៅក្នុងជីវិតនេះ ឬជីវិតបន្ទាប់ អ្នកនឹងបានពរជ័យទាំងឡាយនៃទំនាក់ទំនងគ្រួសារដ៏អស់កល្ប ។ ព្រះអម្ចាស់បានធ្វើការសន្យានេះម្ដងហើយម្ដងទៀតតាមរយៈពួកព្យាការីថ្ងៃចុងក្រោយរបស់ទ្រង់ » ( *ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងដំណឹងល្អ*[ឆ្នាំ ២០០៤ ] ទំព័រ ៩៩) ។

## ចំណេះចំណានខគម្ពីរ—គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:១–៤

២. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:១–៤ បីដង ។ សូមគូររូបភាពមួយដែលជួយពន្យល់ពីសេចក្ដីនៅក្នុងខគម្ពីរទាំងនេះ ។ សូមស្វែងរកឱកាសមួយដើម្បីបង្រៀនចំណេះចំណានខគម្ពីរទៅដល់សមាជិកគ្រួសារ ឬមិត្តភក្តិម្នាក់ ។ សូមពិចារណាអំពីការប្រើរូបភាពរបស់អ្នកដើម្បីជួយអ្នកពន្យល់ពីសេចក្ដីពិតនោះ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរថាមនុស្សណាដែលអ្នកបានបង្រៀន ហើយនៅពេលណា ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:៥–៦

*យ៉ូសែប ស្ម៊ីធ ពន្យល់ពី « ពាក្យទំនាយដ៏ពិតជាង »*

ការធានាអះអាងមួយគឺជាការសន្យា ឬការអះអាងថាអ្វីមួយនឹងកើតមាននៅពេលអនាគត ។

សូមពិចារណាពីសំណួរដូចតទៅនេះ ៖ តើការមានការធានាអះអាង មានអត្ថប្រយោជន៍អ្វីខ្លះ? ហេតុអ្វីបានជាការធានាអះអាងពីព្រះវរបិតាសួគ៌មានតម្លៃជាពិសេស ?

នៅរ៉ាមូស រដ្ឋអិលលីណោយ គឺនៅព្រឹកថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៨៤៣ ព្យាការី យ៉ូសែប ស្ម៊ីធ បានធ្វើការបង្រៀនអំពីឃ្លាមួយដែលនៅក្នុង ពេត្រុស ទី២ ១:១៩ ដែលតំណាងឲ្យការអះអាងមួយមកពីព្រះ ( សូមមើល *History of the Church* ៥:៣៩២ ) ។ សូមបើកទៅ ពេត្រុស ទី២ ១:១៩ ហើយរកឃ្លា « ពាក្យទំនាយដ៏ពិតជាង » ។ រួចអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:៥ ដើម្បីរៀនថាតើ « ពាក្យទំនាយដ៏ពិតជាង »មានន័យយ៉ាងណា ។

៣. យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:៥ តើព្រះវរបិតាសួគ៌ធានាអះអាងអ្វីខ្លះចំពោះមនុស្សម្នាក់តាមរយៈពាក្យទំនាយដ៏ពិតជាងនោះ ? នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរអំពីអារម្មណ៍ដែលអ្នកមាន ប្រសិនបើអ្នកបានទទួលការធានាអះអាងបែបនោះ ។

អ្នកខ្លះទទួលការធានានៃជីវិតដ៏នៅអស់កល្បនេះ កាលរស់នៅក្នុងជីវិតរមែងស្លាប់ ។ ពេលខ្លះ យើងឃើញប្រយោគនៅក្នុងបទគម្ពីរដែលតំណាងឲ្យព្រះអម្ចាស់ប្រទានការធានាអះអាងនេះទៅកាន់បុគ្គលជាក់លាក់ ។ ឧទាហរណ៍ ព្រះអម្ចាស់បានបង្ហាញការធានានេះដល់យ៉ូសែប ស្ម៊ីធ នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៤៩ និង ដល់អាលម៉ានៅក្នុង ម៉ូសាយ ២៦:២០ ។ ទោះជាយ៉ាងណា នេះគឺជារឿងឯកជនមួយរវាងបុគ្គលនោះនឹងព្រះអម្ចាស់ យើងមិនគួរស្មានអំពីបុគ្គលដែលបានទទួល « ពាក្យទំនាយដ៏ពិតជាង »នោះឡើយ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:៦ ដោយស្វែងរកអ្វីមួយដែលនឹងរារាំងមនុស្សម្នាក់ពីការទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

តើព្យាការី យ៉ូសែប ស្ម៊ីធបានថ្លែងអ្វីខ្លះ ដែលថាមនុស្សម្នាក់អាចត្រូវបានសង្គ្រោះ ឬទទួលជីវិតដ៏នៅអស់កល្បជានិច្ច ? សូមបំពេញគោលការណ៍ដូចតទៅ ៖ **យើងមិនអាចត្រូវបានសង្គ្រោះ** ឡើយ។



ប្រធាន ម៉ារ៉ុន ជី រ៉មនី ក្នុងគណៈប្រធានទីមួយបានផ្ដល់ការបកស្រាយមួយអំពីអត្ថន័យនៃគោលការណ៍នេះ ៖ « ចំណេះដឹងនៃ ‹ ព្រះពិតតែមួយ និងព្រះយេស៊ូវគ្រីស្ទ › ( យ៉ូហាន ១៧:៣ ) គឺជាចំណេះដឹងដ៏សំខាន់បំផុតនៅក្នុងសាកលលោក វាគឺជាចំណេះដឹងដែលព្យាការីយ៉ូសែប ស្ម៊ីធ ថ្លែងថា គ្មាននរណាម្នាក់អាចត្រូវបានសង្គ្រោះដោយពុំមានចំណេះដឹងនេះឡើយ ។ ការខ្វះចំណេះដឹងនេះគឺជាភាពល្ងង់ខ្លៅដែលបានលើកឡើងនៅក្នុងវិវរណៈដែលត្រូវបានចែងទុក ៖ ‹ គឺគ្មានផ្លូវទេសម្រាប់ឲ្យមនុស្សបានសង្គ្រោះក្នុងការល្ងង់ខ្លៅ › ។ ( គ. និង ស. ១៣១:៦ ) » ។ (« Except a Man Be Born Again » *Ensign*, ខែ វិច្ឆិកា ឆ្នាំ ១៩៨១ ទំព័រ ១៤ ) ។

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើចំណេះដឹងប្រភេទណាខ្លះដែលយើងត្រូវមានដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ? តើអ្នកគិតថាហេតុអ្វីបានជាចំណេះដឹងនេះចាំបាច់សម្រាប់សេចក្ដីសង្គ្រោះ ?

ខ. តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីបង្កើនចំណេះដឹងរបស់អ្នកអំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ?

*រៀនពីរបៀបដើម្បីធ្វើសេចក្ដីយោងបទគម្ពីរ*

សេចក្ដីយោងបទគម្ពីរភ្ជាប់សារបទគម្ពីរតាមរបៀបដែលអាចជួយអ្នកឲ្យយល់ពីគោលលទ្ធិ និង គោលការណ៍នៅក្នុងសាលិខិតទាំងនោះ ។ សេចក្ដីយោងបទគម្ពីរល្អអាចរកបាននៅក្នុងលេខយោង និងជំនួយសម្រាប់ការសិក្សាព្រះគម្ពីរផ្សេងទៀត ។ អ្នកក៏អាចរកឃើញសេចក្ដីយោងបទគម្ពីរនៅក្នុងការសិក្សាផ្ទាល់របស់អ្នកផងដែរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:៧–៨

*យ៉ូសែប ស្ម៊ីធ បង្រៀនថា គ្រប់អស់ទាំងវិញ្ញាណសុទ្ធតែជាធាតុ*

**សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១:៧–៨ ដោយស្វែងរកថាតើវិញ្ញាណត្រូវបានឡើងដោយធាតុអ្វីខ្លះ ។**

ខគម្ពីរទាំងនេះបង្រៀនថា គ្រប់អស់ការបង្កបង្កើតត្រូវបានបង្កើតឡើងដោយធាតុ ប៉ុន្តែធាតុនៃវិញ្ញាណ « ហ្មត់ ឬសុទ្ធសាធជាង » ( គ. និង ស. ១៣១:៧ ) ។ ធាតុគឺជារូបធាតុដែលបង្កើតវត្ថុនានា ។ ព្យាការី យ៉ូសែប ស្ម៊ីធបានពន្យល់ថា វិញ្ញាណរបស់យើងត្រូវបានបង្កើតឡើងពីធាតុដែលហ្មត់ ឬសុទ្ធសាធជាង ដែលយើងមិនអាចមើលឃើញនឹងភ្នែកទទេបានឡើយ បើគ្មានជំនួយរបស់ព្រះអម្ចាស់នោះ ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣១ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៨ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១–៣៣

## សេចក្ដីផ្ដើម

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២ មានវិវរណៈមួយអំពីសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍ ។ ទោះបីជាវិវរណៈនេះត្រូវបានកត់ត្រាទុកនៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៨៤៣ ក្ដី សេចក្ដីពិតមួយចំនួននៅក្នុងវិវរណៈនេះត្រូវបានដឹង ហើយបង្រៀនដោយព្យាការី យ៉ូសែប ស្ម៊ីធ នៅដើមឆ្នាំ ១៨៣១ ។ នៅក្នុងមេរៀននេះអ្នកនឹងរៀនអំពី លក្ខខណ្ឌនៃសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍ និង ការសន្យាដែលប្រទានដល់អស់អ្នកដែលគោរពវា ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១–១៨

*ព្រះអម្ចាស់កំណត់ពីលក្ខខណ្ឌនៃសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច*



នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១–២ យើងបានអានថា ព្យាការី យ៉ូសែប ស្ម៊ីធ បានទូលសួរព្រះអម្ចាស់ ហេតុអ្វីលោកអ័ប្រាហាំ អ៊ីសាក យ៉ាកុប និងព្យាការីដទៃទៀតនៅក្នុងព្រះគម្ពីរសញ្ញាចាស់មានភរិយាច្រើន ។ សំណួរនេះបានដឹកនាំទៅរកវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២ ដែលរួមបញ្ចូលនូវសេចក្ដីណែនាំអំពីការអនុវត្តនៃពហុពន្ធភាព ។ ព្រះគម្ពីរប៊ីប និង ព្រះគម្ពីរមរមន បង្រៀនថា បទដ្ឋានរបស់ព្រះសម្រាប់អាពាហ៍ពិពាហ៍គឺឲ្យបុរសម្នាក់រៀបការនឹងស្ត្រីម្នាក់ លើកលែងតែទ្រង់បានប្រកាសផ្សេងពីនោះ ( សូមមើល សាំយូអែល ទី២ ១២:៧–៨ និង យ៉ាកុប ២:២៧, ៣០ ) ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២ មាននូវវិវរណៈដែលបានស្ថាបនាការអនុវត្តនៃពហុពន្ធភាពនៅក្នុងចំណោមសមាជិកសាសនាចក្រចាប់តាំងពីដើមទសវត្សរ៍ ១៨៤០ រហូតដល់ទសវត្សរ៍ ១៨៩០ ពេលដែលព្រះអម្ចាស់បានបើកសម្ដែងថា ពួកបរិសុទ្ធមិនគួរមានពហុពន្ធភាពទៀតឡើយ ។

នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២ សូមស្វែងរកចម្លើយសម្រាប់សំណួរខាងក្រោមនេះ ៖

- តើអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចមួយ នឹងផ្ដល់ពរអ្នកនៅក្នុងជីវិតនេះ និងជារៀងរហូតតទៅយ៉ាងណាដែរ ?
- ហេតុអ្វីសេចក្ដីសញ្ញានៃអាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធមានសារៈសំខាន់ម្ល៉េះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣–៦ ដោយស្វែងរកលទ្ធផលនៃការចូលទៅក្នុងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍ និងលទ្ធផលនៃការបដិសេធសេចក្ដីសញ្ញានោះ ។ ពាក្យ *ជាប់ទោស* ដែលមាននៅក្នុង ខ ៤ និង ៦ មានន័យថា បុគ្គលម្នាក់ត្រូវបញ្ឈប់នៅក្នុងការរីកចម្រើនដ៏នៅអស់ជានិច្ចរបស់គាត់ ។

យោងតាម ខ ៦ តើពរជ័យមួយដែលមនុស្សទទួលបានពេលពួកគេគោរពតាម ឬទទួលយកក្រឹត្យវិន័យនៃអាពាហ៍ពិពាហ៍របស់ព្រះអម្ចាស់នោះគឺជាអ្វី ?



ប្រធានយ៉ូសែប ហ្វីលឌីង ស្ម៊ីធបានយោងទៅ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៧ ពេលលោកបានបង្រៀនអំពីអត្ថន័យនៃ « សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច » ៖ « ឥឡូវនេះ [ នៅក្នុង គ. និង ស. ១៣២:៧ ] គឺជានិយមន័យយ៉ាងច្បាស់មួយអំពីសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ។ វាគឺជាអ្វីគ្រប់យ៉ាង—ភាពពោរពេញនៃដំណឹងល្អ ។ ដូច្នេះអាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវ ពិធីបុណ្យជ្រមុជទឹក ពិធីតែងតាំងបព្វជិតភាព អ្វីគ្រប់យ៉ាងផ្សេងទៀត—គ្រប់កិច្ចសន្យា កាតព្វកិច្ច ការធ្វើពិធី នានាដែលទាក់ទងនឹងដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ដែលត្រូវបានផ្សារភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា យោងតាមក្រឹត្យវិន័យរបស់ទ្រង់ដែលបានប្រទានមក គឺជាផ្នែកមួយនៃសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច » ( *Doctrines of Salvation,* និពន្ធដោយ ។ Bruce R. McConkie វ៉ុល៣[១៩៥៤–៥៦] ១:១៥៨ ) ។

ជាញឹកញាប់មនុស្សធ្វើកិច្ចសន្យា ឬ កិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៧ ដោយស្វែងរកអ្វីដែលកើតឡើងចំពោះកិច្ចសន្យាដែលមនុស្សធ្វើ នៅពេលយើងស្លាប់ ។ ក៏សូមរកមើលផងដែរនូវលក្ខខណ្ឌចំនួនពីរដែលត្រូវមានដើម្បីឲ្យសេចក្ដីសញ្ញាមួយត្រូវបានចងភ្ជាប់បន្ទាប់ពីយើងស្លាប់ ។

នៅក្នុង ខ ៧ យើងបានរៀនពីសេចក្ដីពិតដូចតទៅ ៖ **នៅពេលសេចក្ដីសញ្ញាមួយត្រូវបានធ្វើឡើងតាមរយៈសិទ្ធិអំណាចបព្វជិតភាពដ៏ត្រឹមត្រូវ និងបានផ្សារភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា វានឹងបន្តនៅជារៀងរហូត ។**

អ្នកអាចងឿងឆ្ងល់ថាតើឃ្លា « ភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា »មានន័យដូចម្ដេចទៅ ។ សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយផ្ដល់នូវការពន្យល់ដូចតទៅ ៖ « ព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា ( កិច្ចការ ២:៣៣ ) ។ ទ្រង់បញ្ជាក់ថា ទង្វើ ពិធីបរិសុទ្ធ និងសេចក្ដីសញ្ញាដ៏សុចរិតរបស់មនុស្ស គឺអាចទទួលយកបានចំពោះព្រះ ។ ព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យាធ្វើជាសាក្សីដល់ព្រះវរបិតាថា ពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវ ហើយថាសេចក្ដីសញ្ញាដែលបានទាក់ទងជាមួយនឹងពួកគេត្រូវបានរក្សាទុក » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា » scriptures.lds.org) ។

១. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៥–១៨ ដោយរកមើលរបៀបពីរយ៉ាងដែលបុរស និង ស្ត្រីអាចចូលទៅក្នុងអាពាហ៍ពិពាហ៍ជាមួយគ្នា ។ រួចពិចារណាពីឧទាហរណ៍ខាងក្រោម ហើយសូមឆ្លើយសំណួរទាំងនោះស្របតាមការយល់ដឹងរបស់អ្នកនៅក្នុងខដែលអ្នកបានអាន នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

ក. *ឧទាហរណ៍ ទី ១ ៖* បុរស និង ស្ត្រីស្រឡាញ់គ្នា គោរពច្បាប់ព្រហ្មចារីភាព ហើយរៀបការយ៉ាងរីករាយដោយអ្នកដឹកនាំរដ្ឋាភិបាលក្នុងមូលដ្ឋាន ។ ពួកគេពុំបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធឡើយ ។ ពិធីរៀបអាពាហ៍ពិពាហ៍របស់ពួកគេមានពាក្យ « រហូតទាល់តែសេចក្ដីស្លាប់បំបែកអ្នកចេញ » ។ ពីរបីឆ្នាំក្រោយមក ស្វាមីម្នាក់នោះបានស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ ។ យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៥–១៧ នៅពេលស្វាមីស្លាប់ តើមានអ្វីកើតឡើងចំពោះអាពាហ៍ពិពាហ៍ ?

ខ. *ឧទាហរណ៍ទី ២ ៖* បុរស និង ស្ត្រីបានរៀបការហើយ ។ ពួកគេសន្យានឹងគ្នាថា ពួកគេនឹងស្រឡាញ់គ្នាជានិច្ច ហើយថាពួកគេនឹងនៅជាមួយគ្នារហូត ប៉ុន្តែ ពួកគេពុំបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធឡើយ ។ ពួកគេជឿថា ដោយសារសេចក្ដីស្រឡាញ់របស់ពួកគេ នោះព្រះ នឹងអនុញ្ញាតឲ្យពួកគេនៅជាមួយគ្នាជានិរន្តរ៍ ។ យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៨ នៅពេលក្នុងចំណោមពួកគេមានម្នាក់ស្លាប់ តើមានអ្វីកើតឡើងចំពោះអាពាហ៍ពិពាហ៍របស់ពួកគេ ?

នៅពេលអ្នកពិចារណាអំពីឧទាហរណ៍ទាំងនេះ សូមចងចាំថា យើងធ្វើពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធសម្រាប់អ្នកដែលចែកឋានទៅដែលគ្មានឱកាសទទួលពិធីបរិសុទ្ធនៃបព្វជិតភាពសម្រាប់ការសង្គ្រោះ ។ អ្នកអាចធ្លាប់ធ្វើបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ជំនួសឲ្យអ្នកស្លាប់ ។ សមាជិកនៃសាសនាចក្រដែលសក្ដិសមដែលធ្លាប់ទទួលបានអំណោយទានពិសិដ្ឋអាចទទួលអំណោយទានពិសិដ្ឋ និង ពិធីបរិសុទ្ធនៃការផ្សារភ្ជាប់ជំនួសឲ្យអ្នកដែលបានចែកឋានទៅដែលមិនបានទទួលពិធីបរិសុទ្ធទាំងនោះសម្រាប់ខ្លួនឯង ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៩–៣៣

*ព្រះអម្ចាស់សន្យាប្រទានពរជ័យដល់អស់អ្នកដែលគោរពតាមក្រឹត្យវិន័យនៃអាពាហ៍ពិពាហ៍សេឡេស្ទាល*

**អែលឌើរ អ៊ីនរីហ្គ អរ ហ្វេទ្បាបែលទ្បា ក្នុងកូរ៉ុមនៃពួកចិតសិបនាក់បានចែកចាយបទពិសោធន៍ដូចទៅនេះ ។ នៅពេលអ្នកអាន វា សូមគូសចំណាំពីហេតុផលដែលលោក និង ភរិយារបស់លោកមានអារម្មណ៍សោកសៅ និង ហេតុផលដែលពួកគាត់មាន អារម្មណ៍រីករាយ ។**



« នៅពេលខ្ញុំត្រឡប់មកពីបេសកកម្មវិញ ខ្ញុំបានជួបនឹងយុវនារីដ៏ស្រស់ស្អាតម្នាក់ ។. . . . . .នាងបាន ធ្វើឲ្យខ្ញុំជាប់ចិត្ត តាំងពីគ្រាដំបូងដែលខ្ញុំបានជួបនាង ។

« ភរិយារបស់ខ្ញុំ បានដាក់គោលដៅរៀបការនៅព្រះវិហារបរិសុទ្ធ ទោះជាកាលនោះព្រះវិហារបរិសុទ្ធ ដែលជិតបំផុតតម្រូវឲ្យយើងធ្វើដំណើរច្រើនជាង ៦,៤០០ គីឡូម៉ែត្រក៏ដោយ ។

« ពិធីរៀបការស៊ីវិលរបស់យើងមានទាំងរឿងរីករាយ និង កើតទុក្ខ ដ្បិតយើងបានរៀបការដោយមាន កាលបរិច្ឆេទពេលយើងបញ្ចប់ជីវិតនេះ ។ មន្ត្រីនោះបានប្រកាសពាក្យថា ‹ ហើយឥឡូវនេះខ្ញុំសូមប្រកាសថាអ្នកគឺជាស្វាមី និង ភរិយា › ប៉ុន្តែបន្តិចក្រោយមកគាត់បាននិយាយថា ‹ រហូតទាល់តែសេចក្ដីស្លាប់បំបែកអ្នកចេញ › ។

« ដូច្នេះដោយមានការលះបង់នោះយើងបានទិញសំបុត្រយន្តហោះទៅព្រះវិហារបរិសុទ្ធ មេសា អារីហ្សូណា ។

« នៅពេលយើងលុតជង្គង់ចុះលើអាសនានៃព្រះវិហារបរិសុទ្ធ អ្នកបម្រើដែលមានសិទ្ធិអំណាចម្នាក់បានប្រកាស ពាក្យដែលខ្ញុំចង់ស្ដាប់យូរមកហើយ ដែលបានប្រកាសថាពួកយើងគឺជាស្វាមី និង ភរិយាសម្រាប់វេលាកាលនេះ និង រហូតដល់ភាពអស់កល្បជានិច្ច » (The Home: The School of Life, » *Ensign* ឬ *Liahona,* ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ១០២ ) ។



ហេតុអ្វីគ្រួសារហ្វាទ្បាប៊ែទ្បា ពុំពេញចិត្តជាមួយនឹងអាពាហ៍ពិពាហ៍ស៊ីវិល របស់ពួកគាត់ ?

២. សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៩–២១ ដោយរកមើលពរជ័យដែលព្រះអម្ចាស់សន្យាដល់អស់អ្នក ដែលពិតចំពោះ សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាល ជានិច្ច ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ របស់អ្នក សូមសរសេរគំនិតរបស់អ្នកអំពីខទាំងនេះ ។

នៅពេលអ្នកសិក្សាខទាំងនេះ ព័ត៌មានដូចតទៅនេះអាចជួយអ្នកបាន ៖
ពាក្យ *នៅជាប់* មានន័យថា ទទួល ឬ បន្ត ដូច្នេះឃ្លា « នៅជាប់ក្នុងសេចក្ដីសញ្ញារបស់យើង » (ខ ១៩) និង « នៅជាប់នឹង ក្រឹត្យវិន័យរបស់យើង »( ខ ២១ ) មានន័យថាបន្តនៅពិតចំពោះសេចក្ដីសញ្ញា និង ក្រឹត្យវិន័យរបស់ព្រះអម្ចាស់ ។ អ្នកអាចនឹង ចង់គូសចំណាំឃ្លាទាំងនេះ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៩ មានការសន្យាដែលថា បើសិនបុរស និង ស្ត្រីរៀបការនៅក្នុង « សេចក្ដីសញ្ញាថ្មី និង ដ៏នៅអស់កល្បអស់កាលជានិច្ច ហើយសេចក្ដីសញ្ញានោះបានភ្ជាប់ដល់ពួកគេដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា » នោះ ពួកគេ « នឹងត្រូវបានក្រោកឡើងនៅក្នុងដំណើររស់ឡើងវិញលើកទីមួយ ហើយ. . .គ្រងបល្ល័ង្កទាំងឡាយ នគរទាំងឡាយ ក្សត្របុរីទាំងឡាយ និង អំណាចទាំងឡាយ » ដរាបណាពួកគេ « នៅជាប់ក្នុងសេចក្ដីសញ្ញារបស់យើង ហើយមិនប្រព្រឹត្តិ ឃាតកម្ម ដោយការកំចាយឈាមអ្នកដែលគ្មានទោសនោះ » ( សូមមើលផងដែរ គ. និង ស. ១៣២:២៧ ) ។

ឃ្លា « ពូជដ៏បរិបូរ និង បន្តបន្ទាប់ជារៀងដរាបតទៅ » ( ខ ១៩ ) និង « ពួកគេមានបន្តទៅ » ( ខ ២០ ) សំដៅលើការសន្យា ដែលគ្រួសារ និង ពូជពង្សរបស់យើងអាចបន្តរហូតអស់កល្បជានិច្ច ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៩–២១ យើងរៀននូវគោលការណ៍ដូចខាងក្រោម ៖

- **បើសិនបុរសម្នាក់ និងស្ត្រីម្នាក់រស់នៅតាមសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍ នោះពួកគេនឹងទទួលបានភាពលើកតម្កើង និងសិរីល្អ ។**
- **បើសិនបុរសម្នាក់ និងស្ត្រីម្នាក់នៅជាប់នឹងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍ នោះពួកគេនឹងមានការកើនឡើងនៃពូជពង្សដ៏អស់កល្បជានិច្ច ។**
- **បើសិនបុរសម្នាក់ និងស្ត្រីម្នាក់នៅជាប់នឹងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍ នោះអាពាហ៍ពិពាហ៍របស់ពួកគេនឹងមានប្រសិទ្ធិភាពរហូតដល់អស់កល្បអស់កាលជានិច្ច ។**
- **បើសិនបុរសម្នាក់ និងស្ត្រីម្នាក់នៅជាប់នឹងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃអាពាហ៍ពិពាហ៍ នោះពួកគេនឹងប្រែក្លាយដូចជាព្រះ ។**

សូមពិចារណាឧទាហរណ៍ខាងក្រោម ៖ សូមឆ្លើយសំណួរនោះស្របតាមការយល់ដឹងរបស់អ្នកអំពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១៩–២១ ។



*ឧទាហរណ៍ទី ៣ ៖* យុវជន និង យុវនារីម្នាក់បានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធដោយសិទ្ធិអំណាចបព្វជិតភាព ។ ពួកគេទាំងពីររស់នៅ ដោយស្មោះត្រង់ ហើយគោរពសេចក្ដីសញ្ញារបស់ខ្លួន ។ តើនឹងមានអ្វីកើតឡើងចំពោះអាពាហ៍ពិពាហ៍របស់ពួកគេបន្ទាប់ពីពួកគេស្លាប់?

៣. សូមឆ្លើយសំណួរដូចទៅនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថា ស្វាមី និង ភរិយាត្រូវតែធ្វើអ្វីខ្លះ ដើម្បីនៅជាប់នឹងសេចក្ដីសញ្ញានៃអាពាហ៍ពិពាហ៍ ? ( នៅពេលអ្នកឆ្លើយសំណួរនេះ សូមគិតពីទំនាក់ទំនងរបស់ពួកគេ ចំពោះគ្នារួមទាំងទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះផងដែរ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:២២–២៥ ដោយផ្ដោតចិត្តទុកដាក់ជាពិសេសចំពោះការពិពណ៌នារបស់ព្រះអម្ចាស់អំពីពាក្យ « ទ្វារ » និង ពាក្យ « ផ្លូវ » ដែលនាំទៅរកភាពតម្កើងឡើង ។ ពាក្យ *ចង្អៀត* នៅក្នុង ខ ២២ មានន័យថាតូច ឬ យ៉ាងប្រិតប្រៀន ដែលមិនឲ្យអ្វីមួយឆ្លងកាត់បាន ។

៤. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមគូររូបទ្វារ និង ផ្លូវមួយដែលបានពិពណ៌នានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:២២–២៥ រួចឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើរូបភាពនៃទ្វារដ៏ធំ និង ផ្លូវដ៏ទូលាយអាចតំណាងឲ្យទស្សនៈនៅក្នុងសង្គមបច្ចុប្បន្នអំពីទំនាក់ទំនងគូស្វាមីភរិយា និង អាពាហ៍ពិពាហ៍តាមរបៀបណាខ្លះ ?

ខ. តើទស្សនៈទាំងនេះផ្ទុយទៅនឹងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចខាងអាពាហ៍ពិពាហ៍យ៉ាងដូចម្ដេច ?

យោងតាម ខ ២២ និង ២៥ មានមនុស្សជាច្រើនមិនអាចចូលទៅក្នុងផ្លូវចង្អៀតដែលនាំទៅរកភាពតម្កើងឡើងបានទេ ដោយសារពួកគេខកខាននៅក្នុងការទទួលយកព្រះយេស៊ូវគ្រីស្ទ ហើយរស់នៅតាមក្រឹត្យវិន័យរបស់ទ្រង់ រាប់បញ្ចូលទាំងអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចផងដែរ ។



យើងរៀនពីខទាំងនេះថា **ដើម្បីទទួលបានភាពតម្កើងឡើង និង ជីវិតអស់កល្បជានិច្ច យើងត្រូវតែស្គាល់ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ប្រែក្លាយដូចជាពួកទ្រង់ ហើយនៅជាប់ជាមួយក្រឹត្យវិន័យរបស់ទ្រង់ ។** នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:២៩–៣៣ យើងឃើញពីគំរូមួយនៃគោលការណ៍នេះ ។ យើងអានថា អ័ប្រាហាំស្មោះត្រង់ និង គោរពតាមក្រឹត្យវិន័យនៃអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចរបស់ព្រះអម្ចាស់ ហើយថាលោកបានទទួលការសន្យានៃការកើនឡើងនៃពូជពង្សដ៏នៅអស់កល្បជានិច្ច ។

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីក្រឹត្យវិន័យនៃអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ចសំខាន់ចំពោះអ្នក ?

ខ. ដោយចាប់ផ្ដើមពីថ្ងៃនេះ តើអ្នកនឹងធ្វើអ្វីខ្លះ ដើម្បី រៀបចំខ្លួនចូលទៅព្រះវិហារបរិសុទ្ធ ហើយរៀបអាពាហ៍ពិពាហ៍ចំពោះវេលាកាល និង ភាពអស់កល្បជានិច្ច ?

គ. តើពរជ័យអ្វីខ្លះដែលអាចត្រូវបានទទួលនៅក្នុងជីវិតនេះចំពោះអស់អ្នកដែលធ្វើតាមក្រឹត្យវិន័យរបស់ព្រះ ដើម្បីត្រូវបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ?

សូមរៀបចំខ្លួននៅពេលនេះដើម្បីមានភាពសក្ដិសមចូលទៅក្នុងព្រះវិហារបរិសុទ្ធ ហើយរៀបការសម្រាប់ភាពនៅអស់កល្បជានិច្ច ដើម្បីអ្នកអាចរីករាយនឹងពរជ័យដែលព្រះវរបិតាសួគ៌បានរៀបចំសម្រាប់អ្នក ។

សប្ដាហ៍នេះអ្នកនឹងសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:៣៤–៦៦ ជាមួយនឹងគ្រូបង្រៀនរបស់អ្នក ។ ខទាំងនោះលើកឡើងពីគោលលទ្ធិនៃពហុអាពាហ៍ពិពាហ៍ ។ នៅថ្ងៃនេះ អ្នកនឹងពិភាក្សាជាមួយនឹងគ្រូបង្រៀនរបស់អ្នកអំពីបទដ្ឋានរបស់ព្រះអម្ចាស់ចំពោះអាពាហ៍ពិពាហ៍—ថា « អាពាហ៍ពិពាហ៍រវាងបុរសម្នាក់ និង ស្ត្រីម្នាក់គឺត្រូវបានតែងតាំងឡើងដោយព្រះ » ( « The Family: A Proclamation to the World » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២៩ ) ។ អ្នកក៏នឹងពិភាក្សាពីការបង្គាប់របស់ព្រះអម្ចាស់នៅពេលជាក់លាក់ថាឲ្យរាស្ត្ររបស់ទ្រង់មួយចំនួនរស់នៅតាមក្រឹត្យវិន័យនៃពហុពន្ធភាព ( សូមមើល យ៉ាកុប ២:២៧, ៣០ ) ។ អ្នកនឹងរៀនអំពីការបង្គាប់របស់ព្រះអម្ចាស់ឲ្យរស់នៅតាមក្រឹត្យវិន័យនៃពហុពន្ធភាពនៅថ្ងៃចុងក្រោយ ជាផ្នែកនៃការ « តាំងរបស់ទាំងអស់ឡើងវិញ » ( កិច្ចការ ៣:២១ ) និង អំពីការបង្គាប់របស់ទ្រង់ក្រោយមកទៀតឲ្យបញ្ឈប់ការអនុវត្តនោះ ( សូមមើល សេចក្ដីប្រកាសជាផ្លូវការទី ១ ) ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:១–៣៣ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៩ ៖ ថ្ងៃទី ១

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១–៣៥

## បុព្វកថា

នៅថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ១៨៣១ គឺពីរថ្ងៃបន្ទាប់ពី ព្រះអម្ចាស់បានណែនាំ យ៉ូសែប ស្ម៊ីធ ឲ្យបោះពុម្ពព្រះគម្ពីរនៃបទបញ្ញត្តិ ( សូមមើល គ. និង ស. ១ ក្បាលកណ្ឌ ) ព្យាការីបានទទួលវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣ ។ វិវរណៈនេះត្រូវបានបញ្ចូលទៅក្នុងការបោះពុម្ពឆ្នាំ ១៨៣៥ នៃគោលលទ្ធិ និង សេចក្ដីសញ្ញា ទុកជាសេចក្ដីបន្ថែម ហើយក្រោយមកត្រូវបានទុកជាលេខកណ្ឌ ។ អ្នកដែលបានធ្វើការជាមួយសំណៅដើមនោះ មានបំណងឲ្យវិវរណៈនេះត្រូវបានដាក់បញ្ចូលជាមួយនឹង កណ្ឌទី ១ ទៅក្នុងវិវរណៈដែលត្រូវបានដាក់បញ្ចូលទៅក្នុងការបោះពុម្ពនាឆ្នាំ ១៨៣៥ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣ នឹងត្រូវបានបំបែកជាពីរមេរៀន ។ មេរៀននេះមាននូវការត្រាស់បង្គាប់ពីព្រះអម្ចាស់ ដែលប្រាប់ឲ្យរាស្ត្ររបស់ទ្រង់ និង មនុស្សទូទៅត្រៀមខ្លួនទទួលការយាងមកជាលើកទីពីររបស់ទ្រង់ ។ វាក៏មាននូវការព្យាករណ៍អំពីព្រឹត្តិការណ៍នានា ដែលទាក់ទងនឹងការយាងមកជាលើកទីពីរ និង រជ្ជកាលនៃសហស្សវត្សរ៍របស់ទ្រង់ផងដែរ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១–១៥

*ព្រះអម្ចាស់ត្រាស់បង្គាប់ឲ្យរាស្ត្រទ្រង់ ត្រៀមខ្លួនទទួលការយាងមកជាលើកទីពីររបស់ទ្រង់*

តើអ្នកធ្លាប់ទៅសាលា ហើយដឹងខ្លួនថាអ្នកភ្លេចត្រៀមខ្លួនប្រឡងដែរឬទេ ? តើអ្នកបានមានអារម្មណ៍ដូចម្ដេច ឬ តើអ្នកអាចនឹងមានអារម្មណ៍ដូចម្ដេច ?

តើអ្នកមានអារម្មណ៍ដូចម្ដេច នៅពេលអ្នកដឹងថាបានត្រៀមខ្លួនយ៉ាងល្អសម្រាប់ការប្រឡង ?

សូមគិតអំពីព្រឹត្តិការណ៍មួយចំនួននាពេលអនាគត ដែលអ្នកគួរតែត្រៀមខ្លួនពីឥឡូវនេះទៅ ។



សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១–៣ ដោយស្វែងរកព្រឹត្តិការណ៍មួយ ដែលយើងត្រូវតែត្រៀមខ្លួនទទួល និង មូលហេតុរបស់វា ។

វាអាចនឹងផ្ដល់អត្ថប្រយោជន៍ក្នុងការដឹងថា « យាងចុះមកលើពិភពលោក ដោយសេចក្ដីបណ្ដាសាដើម្បីជំនុំជម្រះ » ( គ. និង ស. ១៣៣:២ ) សំដៅទៅលើការដាក់ទណ្ឌកម្មលើពួកទុច្ចរិត នៅពេលដែលទ្រង់យាងមកជាលើកទីពីរ ។ ឃ្លា « លាតព្រះពាហុបរិសុទ្ធរបស់ទ្រង់ » ( គ. និង ស. ១៣៣:៣ ) សំដៅទៅលើព្រះអម្ចាស់ បង្ហាញអានុភាព និង ព្រះចេស្ដារបស់ទ្រង់ទៅកាន់ពិភពលោក ។ ឃ្លា « អស់ទាំងចុងផែនដី នឹងបានឃើញសេចក្ដីសង្គ្រោះនៃព្រះរបស់ពួកគេ » ( គ. និង ស. ១៣៣:៣ ) មានន័យថា មនុស្សទាំងអស់នឹងឃើញការរំដោះ ដែលព្រះនឹងនាំមកដល់អស់អ្នកដែលធ្វើតាមទ្រង់ ។

នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣ សូមគិតអំពីមូលហេតុដែលការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ និង ការត្រៀមខ្លួនរបស់យើងមានសារៈសំខាន់បំផុត ។

យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:២ តើនឹងមានអ្វីកើតឡើងចំពោះពួកមនុស្សអាក្រក់ ឬ ពួកទុច្ចរិត នៅពេលព្រះយេស៊ូវគ្រីស្ទយាងមកជាលើកទីពីរ ? សូមឆ្លើយសំណួរនេះ ដោយបញ្ចប់គោលលទ្ធិដូចតទៅ ដោយប្រើអ្វីមួយដែលអ្នកបានរៀនចេញពីខគម្ពីរនេះ ៖ **នៅពេលទ្រង់យាងមកជាលើកទីពីរ ព្រះយេស៊ូវគ្រីស្ទនឹងយាងមក** ។

យើងរៀនចេញពីខគម្ពីរទាំងនេះថា ពួកទុច្ចរិត និង ពួកមនុស្សអាក្រក់នឹងមិនបានត្រៀមខ្លួនរួចរាល់សម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទនោះទេ ។ តើយើងអាចធ្វើអ្វីខ្លះ ដើម្បីប្រាកដថា យើងបានត្រៀមខ្លួនរួចរាល់ ?

១. សូមបំពេញកិច្ចការខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមសរសេរឃ្លាខាងក្រោមនេះ ៖ **ជួយរៀបចំយើង ទទួលការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។** សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤–១៦ ដោយស្វែងរកឃ្លាទាំងឡាយដែលអាចត្រូវបានប្រើដើម្បីបំពេញចន្លោះ ។ សូមសរសេរឃ្លាយ៉ាងតិចចំនួនប្រាំ ពីក្រោមចន្លោះទទេនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

ខ. សូមជ្រើសរើសឃ្លាដែលអ្នកបានរកឃើញនៅក្នុងលំហាត់ ក ។ សូមពន្យល់អំពីមូលហេតុដែលទង្វើទាំងនេះមានសារៈសំខាន់ក្នុងការរៀបចំខ្លួនយើង ដើម្បីទទួលការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។

គ. សូមពន្យល់អំពីពរជ័យនានា ដែលអ្នកនឹងទទួលបាននាពេលឥឡូវនេះ តាមរយៈការអនុវត្តតាមទង្វើដែលអ្នកបានរកឃើញនៅក្នុងលំហាត់ ខ ។

សូមមើលឡើងវិញនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៥, ៧, ១៤ ។ សូមគិតអំពីការគូសចំណាំឃ្លាស្រដៀងគ្នានេះដែលអ្នកបានកត់ចំណាំនៅក្នុងខគម្ពីរនីមួយៗ ។

នៅជំនាន់ព្រះគម្ពីរសញ្ញាចាស់ ទីក្រុង បាប៊ីឡូន គឺជាទីក្រុងទុច្ចរិតបំផុត ។ នៅក្នុងខគម្ពីរទាំងនេះ ទីក្រុង បាប៊ីឡូន អាចត្រូវបានឃើញថាជានិមិត្តរូបនៃសេចក្ដីទុច្ចរិត និងលោកិយ ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើវាអាចមានន័យដូចម្ដេច នៅពេលព្រះអម្ចាស់ត្រាស់បង្គាប់ឲ្យយើងរត់ភៀសពីទីក្រុង បាប៊ីឡូន ?

ខ. តើយើងអាចរត់ភៀសពីទីក្រុង បាប៊ីឡូន បានដោយរបៀបណា ? តើការណ៍ទាំងនេះអាចនឹងរៀបចំខ្លួនយើងទទួលការយាងមកជាលើកទីពីរបានយ៉ាងដូចម្ដេច ?

សូមកត់ចំណាំអ្វីដែលព្រះអម្ចាស់បានបង្រៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១៥ អំពីរបៀបដែលយើងត្រូវរត់ភៀសខ្លួនពីទីក្រុង បាប៊ីឡូន ។ ព្រះអម្ចាស់មានព្រះបន្ទូលថា នៅពេលប្ដីថ្មោងថ្មីមកដល់ ( សូមមើល ខទី ១០ ) នោះនឹងពុំមានពេលបម្រើយកិច្ចការយ៉ាងរួសរាន់ ដែលគួរតែបានបម្រើយតាំងពីយូរណាស់មកហើយនោះទេ ។ ការណ៍នេះមានសភាពស្រដៀងគ្នាទៅនឹងសារលិខិតដែលត្រូវបានបង្រៀននៅក្នុងរឿងប្រដូចនៃស្ត្រីព្រហ្មចារិយទាំងដប់នាក់ ( សូមមើល ម៉ាថាយ ២៥:១–១៣ សូមមើលផងដែរ គ. និង ស. ៤៥:៥៦–៥៧ ) ។ ស្ត្រីព្រហ្មចារិយប្រាំនាក់បានព្យាយាមបម្រើយកិច្ចការយ៉ាងរួសរាន់ នៅពេលបានឮសេចក្ដីប្រកាសថា ប្ដីថ្មោងថ្មីបានមកដល់ ប៉ុន្តែ វាយឺតពេលណាស់ទៅហើយ ។

សូមកត់ចំណាំផងដែរនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១៥ អំពីការណ៍ ដែលព្រះអម្ចាស់បានព្រមានមិនឲ្យយើងធ្វើនៅពេលយើងរត់ភៀសពីទីក្រុង បាប៊ីឡូន ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នករកឃើញ ។

សូមពិចារណាអំពីអត្ថន័យនៃឃ្លា « កុំឲ្យគេងាកមើលក្រោយ » ( គ. និង ស. ១៣៣:១៥ ) បន្ទាប់ពីយើងបានដកខ្លួនចេញពីអានុភាពដែលពេញដោយអំពើបាប និង ខាងលោកិយហើយ ។ បរិបទនៃឃ្លា *កុំឲ្យគេងាកមើលក្រោយ* សំដៅទៅលើការប្រឹងប្រែងលះបង់ចោលសេចក្ដីទុច្ចរិត និង ភាពខាងលោកិយទាំងស្រុង ហើយពុំត្រឡប់ទៅផ្លូវកាលពីមុនទៀតឡើយ ។ ខគម្ពីរនេះគឺជាការព្រមានយើងកុំឲ្យមានបំណង ហើយត្រឡប់ទៅរកជីវិតកាលពីមុនរបស់យើងទៀត ។

សូមគិតអំពីការសរសេរសេចក្តីពិតដូចតទៅ ដាក់នៅលើគែមព្រះគម្ពីររបស់អ្នកក្បែរ ខទី ១៥ ៖ **បើសិនជាយើងងាកទៅរកសេចក្តីទុច្ចរិត និង អំពើបាបកាលពីមុនរបស់យើង នោះយើងនឹងពុំបានត្រៀមខ្លួនជាស្រេច ដើម្បីទទួលការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះឡើយ ។**

៣. សូមឆ្លើយសំណួរដូចតទៅនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើយុវវ័យពួកបរិសុទ្ធថ្ងៃចុងក្រោយអាចធ្វើអ្វីខ្លះដើម្បី « កុំឲ្យគេងាកមើលក្រោយ » នៅពេលពួកគេព្យាយាមរីកចម្រើនខាងវិញ្ញាណ ហើយមកឲ្យកាន់តែជិតព្រះអង្គសង្គ្រោះ ?

សូមកត់ចំណាំនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៣:៩ ថាព្រះអម្ចាស់បានដឹកនាំរាស្ត្ររបស់ទ្រង់ ឲ្យប្រមូលគ្នានៅក្នុងដែនដីស៊ីយ៉ូន ។ សូមចងចាំថា ដែនដីស៊ីយ៉ូនក៏តំណាងឲ្យមនុស្សសុចរិតដែរ—គឺអស់អ្នកដែលមានចិត្តបរិសុទ្ធ រួបរួម និងលះបង់ចំពោះព្រះរាជបំណងរបស់ព្រះ ។



ព្រះអម្ចាស់បានត្រាស់បង្គាប់ដល់យើង ឲ្យចាកចេញពីសេចក្តីទុច្ចរិត និង កុំងាកមើលក្រោយឡើយ ។

៤. សូមឆ្លើយសំណួរដូចតទៅនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការលើកទឹកចិត្តបែបណាខ្លះ ដែលអ្នកនឹងផ្តល់ឲ្យដល់អស់អ្នកដែលបានរត់ភៀសខ្លួនពីទីក្រុងបាប៊ីឡូន ( សេចក្តីទុច្ចរិត និង ភាពខាងលោកិយ ) ហើយកំពុងពុះពារឆ្ពោះទៅកាន់ទីក្រុង ស៊ីយ៉ូន ( សេចក្តីសុចរិត ) ដើម្បីជួយគាត់ឲ្យបន្តមានចិត្តស្មោះត្រង់ ?

បើសិនជាអ្នកអវត្តមាននៅចំថ្ងៃ ដែលគ្រូប្រកាសអំពីការប្រឡងមួយដ៏ធំនាថ្ងៃខាងមុខ តើអ្នកនឹងសង្ឃឹមថា មិត្តរួមថ្នាក់របស់អ្នកនឹងធ្វើអ្វីសម្រាប់អ្នក ?

នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៣:៤–១៥ ព្រះអម្ចាស់ក៏បានបង្រៀនពួកបរិសុទ្ធផងដែរថា ការត្រៀមខ្លួនរបស់ពួកគេទទួលការយាងមកជាលើកទីពីរ រួមបញ្ចូលទាំងការជួយមនុស្សដទៃឲ្យត្រៀមខ្លួនផងដែរ ។ តើកិច្ចការប្រភេទណាខ្លះដែលព្រះអម្ចាស់បានមានបន្ទូលរៀបរាប់នៅក្នុង ខទី ៨–១០ ?

នៅពេលថ្លែងសុន្ទរកថាទៅកាន់ពួកអ្នកផ្សព្វផ្សាយសាសនា អែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនអំពីការទទួលខុសត្រូវដ៏មានសារៈសំខាន់មួយ ដែលក៏អនុវត្តចំពោះសមាជិកសាសនាចក្រផងដែរ ៖



« ការទទួលខុសត្រូវដ៏ចាំបាច់មួយរបស់អ្នក គឺត្រូវជួយរៀបចំមនុស្សទទួលការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។. . .

« បេសកកម្មរបស់អ្នកនឹងក្លាយជាឱកាសមួយដ៏ពិសិដ្ឋក្នុងការនាំមនុស្សទូទៅមករកព្រះគ្រីស្ទ ហើយជួយរៀបចំពួកគេទទួលការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។. . .

« . . . ពិភពលោកកំពុងត្រូវបានរៀបចំទទួលការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះនៅក្នុងទ្រង់ទ្រាយដ៏ធំមួយ តាមរយៈកិច្ចការរបស់ព្រះអម្ចាស់ ពីសំណាក់អ្នកផ្សព្វផ្សាយសាសនារបស់ទ្រង់ » ( «Preparing the World for the Second Coming» *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៤៩–៥១ ) ។

៥. សូមបំពេញកិច្ចការខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមឆ្លើយសំណួរដូចតទៅនេះ ៖ តើអ្នកគិតថា ការជួយមនុស្សទូទៅ ត្រៀមខ្លួនទទួលការយាងមកជាលើកទីពីរ ក៏នឹងជួយអ្នកឲ្យត្រៀមខ្លួនដូចគ្នាដោយរបៀបណា ? តើពរជ័យបន្ថែមមួយចំនួន ដែលអ្នកនឹងរីករាយនៅក្នុងជីវិតរបស់អ្នកតាមរយៈការជួយមនុស្សទូទៅ ឲ្យត្រៀមខ្លួនទទួលការយាងមកជាលើកទីពីរនោះមានអ្វីខ្លះ ?

ខ. សូមរំឭកពីអ្វីដែលអ្នកបានសរសេរ អំពីការត្រៀមខ្លួនទទួលការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមសរសេរអ្វីមួយដែលអ្នកមានអារម្មណ៍បំផុសឲ្យធ្វើ ដើម្បីត្រៀមខ្លួនអ្នកឲ្យបានកាន់តែប្រសើរ ឬ ជួយរៀបចំមនុស្សទូទៅទទួលការយាងមកជាលើកទីពីរ ។ សូមសរសេរផែនការមួយ អំពីរបៀបដែលអ្នកនឹងសម្រេចគោលដៅនេះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១៦ រួចស្វែងរកអ្វីដែលនឹងជួយយើង ឲ្យត្រៀមខ្លួនជួបព្រះអម្ចាស់ នៅពេលដែលទ្រង់យាងមក ។ សូមបំពេញគោលការណ៍ដូចតទៅនេះ ដោយសរសេរនៅក្នុងចន្លោះទទេដោយប្រើពាក្យដែលអ្នករកឃើញ ៖ **នៅពេលយើង នោះយើងបានត្រៀមខ្លួនដើម្បីជួបព្រះហើយ ។**

៦. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការប្រែចិត្តជួយរៀបចំយើង ទទួលការយាងមកជាលើកទីពីរយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១៧–៣៥

*ព្រះអម្ចាស់ត្រាស់សម្ដែងព្រឹត្តិការណ៍មួយចំនួន ដែលទាក់ទងទៅនឹងការយាងមកជាលើកទីពីរ និង រជ្ជកាលនៃសហស្សវត្សរ៍របស់ទ្រង់ ។*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១៧–៣៥ ព្រះអម្ចាស់បានមានព្រះបន្ទូលអំពីព្រឹត្តិការណ៍មួយចំនួន ដែលទាក់ទងនឹងការយាងមកជាលើកទីពីរ និង រជ្ជកាលនៃសហស្សវត្សរ៍របស់ទ្រង់នៅលើផែនដី ។ សូមអានខគម្ពីរទាំងនេះ ហើយគិតអំពីការគូសចំណាំព្រឹត្តិការណ៍នានា ដែលអ្នករកឃើញ ។ តើព្រឹត្តិការណ៍មួយណា ដែលអ្នកចាប់អារម្មណ៍ចង់ឃើញជាងគេ ?

ព្រឹត្តិការណ៍មួយដែលមាននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:២១–២៩ គឺជាការត្រឡប់ទៅវិញនៃអំបូរអ៊ីស្រាអែលមួយ ដែលបានបាត់បង់ ។ អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ ៖ « អំបូរទាំងដប់នឹងត្រឡប់មកវិញក៏បានដូចជាអំបូរដទៃទៀតដែរ ៖ តាមរយៈការទទួលយកព្រះគម្ពីរមរមន និង ការជឿលើដំណឹងល្អដែលបានស្ដារឡើងវិញ ។ ពុំអាចមានអង្គការសាសនាចក្រពីរដាច់ពីគ្នា និង ឯករាជ្យនៅលើផែនដីដូចគ្នា ក្នុងពេលតែមួយបានទេ យ៉ាងណាក៏ដោយ ក្នុងរយៈពេលមួយថ្ងៃមិនអាចគ្រប់គ្រងសាសនាចក្រចេញពីកន្លែងតែមួយបានទេ ។ ប្រធាននៃសាសនាចក្រកាន់កូនសោទាំងឡាយ អំបូរទាំងដប់នឹងត្រូវបាននាំចេញពីដែនដីភាគខាងជើង ទៅកាន់មាតុភូមិប៉ាឡេស្ទីនរបស់ពួកគេវិញ ។ គឺទ្រង់ មិនមែនពួកគេទេ ដែលនឹងដឹកនាំពួកគេឲ្យត្រឡប់មកវិញនោះ » ( *A New Witness for the Articles of Faith* [ ឆ្នាំ ១៩៨៥ ] ទំព័រ ៥២០–២១ ) ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៣០–៣៥ ប្រាប់អំពីពរជ័យមួយចំនួន ដែលរាស្ត្រក្នុងសេចក្ដីសញ្ញារបស់ព្រះអម្ចាស់ទទួលបាន ជាពរជ័យដែលទាក់ទងទៅនឹងការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ។ ដោយសារតែការសន្យារបស់ព្រះអម្ចាស់ត្រូវបានធ្វើជាមួយ អេប្រាអិម ( ជាកូនប្រុសរបស់ យ៉ូសែប ) និង ជាអំបូររបស់លោក នោះកូនចៅរបស់ អេប្រាអិម នឹងត្រូវបានប្រមូលមុនគេនៅថ្ងៃចុងក្រោយបង្អស់ ។ ពួកគេត្រូវបានផ្ដល់ឲ្យនូវការស្ដារឡើងវិញនៃដំណឹងល្អ និង សិទ្ធិអំណាចបព្វជិតភាព ព្រមទាំងកូនសោដែលអនុញ្ញាតឲ្យពួកគេដឹកនាំកិច្ចការនៃការប្រមូលផ្ដុំវង្សអ៊ីស្រាអែល ។ ព្រះរាជបំណងដ៏ធំបំផុតរបស់ព្រះអម្ចាស់ គឺត្រូវជួយក្រុមគ្រួសារទាំងមូលរបស់ព្រះ ឲ្យបានពាក់មកុដដោយនូវសិរីល្អ ហើយទទួលបានពរជ័យដែលមានតាមរយៈពិធីបរិសុទ្ធនានានៃដំណឹងល្អ ។

តាមរយៈការប្រែចិត្ត និង ការត្រៀមខ្លួនរបស់យើង និង ការរៀបចំមនុស្សទូទៅទទួលការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ នោះយើងអាចទន្ទឹងរង់ចាំការយាងមករបស់ទ្រង់ដោយសេចក្ដីអំណរ ហើយក៏រីករាយនឹងពរជ័យដែលកើតមានពីការរស់នៅប្រកបដោយសុចរិតភាពក្នុងពេលនេះដែរ ។

៧. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:១–៣៥ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៩ ៖ ថ្ងៃទី ២

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៣៦–៧៤

## បុព្វកថា

នេះគឺជាមេរៀនទីពីរ ដែលមានវិវរណៈកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈនេះ នៅថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ១៨៣១ ។ វាឆ្លើយសំណួរទាំងឡាយដែលពួកអ្នកផ្សព្វផ្សាយសាសនាបានមានអំពីការប្រកាសដំណឹងល្អ និង ការប្រមូលផ្ដុំសាសន៍អ៊ីស្រាអែល ។ វាក៏ប្រាប់អំពីការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ និង អំពីអ្វីដែលយើងត្រូវធ្វើដើម្បីត្រៀមខ្លួនទទួលព្រឹត្តិការណ៍នោះដែរ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៣៦–៤០

*ព្រះអម្ចាស់មានព្រះបន្ទូលប្រកាសថា ដំណឹងល្អដែលបានស្ដារឡើងវិញ នឹងត្រូវបានប្រកាសទៅដល់ពិភពលោកទាំងមូល*

១. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរអំពីអារម្មណ៍របស់អ្នក នៅពេលអ្នកពិចារណាអំពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ តើអ្នកមានអារម្មណ៍សប្បាយរីករាយ និង មានសង្ឃឹមដែរឬទេ កាលបានឃើញព្រះអង្គសង្គ្រោះនៅពេលទ្រង់យាងមកជាលើកទីពីរនោះ ? តើការត្រៀមខ្លួនរបស់យើងទទួលការយាងមកជាលើកទីពីរ អាចជួយយើងយកឈ្នះលើសេចក្ដីភ័យខ្លាចបានយ៉ាងដូចម្ដេច ?



ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ នឹងជាបទពិសោធន៍មួយដ៏ផ្អែមល្ហែម និង អស្ចារ្យសម្រាប់មនុស្សមួយចំនួន តែក៏ជាបទពិសោធន៍មួយដ៏តក់ស្លុតសម្រាប់មួយចំនួនទៀតដែរ—ដោយផ្អែកទៅលើការត្រៀមខ្លួន និង ភាពសក្ដិសមផ្ទាល់ខ្លួនរបស់ពួកគេ ។

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៣៦–៣៩ ដោយស្វែងរកភស្ដុតាងដែលបង្ហាញថា ព្រះអង្គសង្គ្រោះមានព្រះទ័យចង់ឲ្យមនុស្សទាំងពួង ត្រៀមខ្លួនជាស្រេចទទួលការយាងមកជាលើកទីពីររបស់ទ្រង់ ។

យើងមានតួនាទីជួយរៀបចំពិភពលោក ទទួលការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ យោងតាមអ្វីដែលអ្នករៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៣៧–៣៨ សូមបញ្ចប់សេចក្ដីពិតដូចតទៅនេះ ៖ **ក្នុងនាមជាអ្នកបម្រើរបស់ព្រះ យើងអាចជួយរៀបចំមនុស្សទូទៅ ទទួលការយាងមកជាលើកទីពីរតាមរយៈ** ។

យោងតាម ខទី ៣៨ យើងត្រូវប្រកាសដំណឹងល្អ « ដោយបន្លឺសំឡេងយ៉ាងខ្លាំង » ។ តើអ្នកគិតថា ការណ៍នេះមានន័យដូចម្ដេច ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤០ ដោយស្វែងរកកិច្ចការមួយទៀត ដែលពួកអ្នកបម្រើរបស់ព្រះនឹងត្រូវធ្វើពីមុនការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ តើខគម្ពីរនេះណែនាំអ្វីខ្លះ ទាក់ទងនឹងអារម្មណ៍របស់ពួកសុចរិតអំពីការយាងមករបស់ព្រះអង្គសង្គ្រោះ ?

នៅក្នុង ខទី ៤០ តើពាក្យណាខ្លះ ដែលបង្ហាញអំពីបំណងប្រាថ្នារបស់ពួកសុចរិត ដែលចង់ឃើញព្រះអម្ចាស់នៅពេលទ្រង់យាងមកជាលើកទីពីរ ? អ្នកអាចនឹងចង់គូសចំណាំពាក្យទាំងនេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤១–៥៦

*ព្រះយេស៊ូវគ្រីស្ទមានព្រះបន្ទូលប្រាប់ អំពីការយាងមកជាលើកទីពីររបស់ទ្រង់*

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤១–៤៥ ដោយស្វែងរកពរជ័យនានា ដែលនឹងកើតមានដល់អ្នកទាំងឡាយដែលអធិស្ឋាន ហើយទន្ទឹងរង់ចាំទទួលការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នករកឃើញ ។

ចេញពី ខទី ៤៥ យើងរៀនថា **ព្រះអម្ចាស់បានរៀបចំពរជ័យដ៏អស្ចារ្យៗ ទុកសម្រាប់អ្នកទាំងឡាយដែលទន្ទឹងរង់ចាំទ្រង់ ។** អ្នកអាចនឹងចង់សរសេរគោលការណ៍នេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។

នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ សូមគូសបន្ទាត់ពីក្រោមការណ៍ ដែលយើងត្រូវធ្វើដើម្បីទន្ទឹងរង់ចាំព្រះអម្ចាស់ដោយមានចិត្តស្មោះត្រង់ ៖



« យើង *មិនត្រូវ* អនុញ្ញាតឲ្យសេចក្ដីភ័យខ្លាច និង បិតានៃសេចក្ដីភ័យខ្លាច ( សាតាំងខ្លួនវា ) បង្វែរយើងចេញពីសេចក្ដីជំនឿ និង ការរស់នៅដោយមានចិត្តស្មោះត្រង់ទៅតាមស្ថានភាព *ណាមួយ* ឲ្យសោះ ។ វា *តែងតែ* មានការចោទសួរអំពីអនាគតកាលជានិច្ច ។ បុគ្គលវ័យក្មេង ឬ គូស្វាមីភរិយាវ័យក្មេងគ្រប់រូបនៅគ្រប់ជំនាន់ ត្រូវដើរដោយសេចក្ដីជំនឿទៅរកអ្វីមួយដែល *តែងតែ* ជារឿងមិនប្រាកដប្រជា—ចាប់ផ្ដើមដោយ អ័ដាម និង អេវ៉ា នៅក្នុងជំហានដំបូងដ៏ញញើតញញើម ចេញពីសួនច្បារអេដែន ។ ប៉ុន្តែ ការណ៍នោះពុំមែនជាបញ្ហានោះទេ ។ នេះគឺជាផែនការណ៍ ។ វានឹងពុំមានបញ្ហាឡើយ ។ សូមមានចិត្តស្មោះត្រង់ ។ ព្រះទ្រង់ទទួលយកបន្ទុកនោះហើយ ។ ទ្រង់ជ្រាបអំពីឈ្មោះរបស់អ្នក ហើយជ្រាបអំពីសេចក្ដីត្រូវការរបស់អ្នក ។. . .

« ព្រះមានព្រះទ័យរំពឹងឲ្យអ្នកមានសេចក្ដីជំនឿគ្រប់គ្រាន់ និង ការប្ដេជ្ញាចិត្ត ហើយទុកចិត្តលើទ្រង់ ដើម្បីបន្តទៅមុខ បន្តរស់នៅ និងបន្តមានចិត្តរីករាយ ។ ប្រាកដណាស់ ទ្រង់មិនមានព្រះទ័យរំពឹងឲ្យអ្នក *ប្រឈមមុខ* នឹងអនាគតកាលដោយធម្មតា ( ដែលហាក់ដូចជាក្រៀមក្រំ និង បណ្ដោយតាមវាសនា ) នោះទេ ដ្បិតទ្រង់មានព្រះទ័យរំពឹងឲ្យអ្នកឱបក្រសោបយក ហើយ *រៀបចំ* អនាគតកាល—ដើម្បីចេះស្រឡាញ់ ហើយអរសប្បាយនឹងអនាគតកាល ហើយធ្វើឲ្យរីករាយឡើងនៅក្នុងជីវិតរបស់អ្នក ។

« ព្រះទ្រង់ទន្ទឹងរង់ចាំដោយអន្ទះសា ចំពោះឱកាសដើម្បីឆ្លើយតបការអធិស្ឋានរបស់អ្នក ហើយបំពេញតាមសេចក្ដីប្រាថ្នាដែលអ្នកមាន ដូចដែលទ្រង់ធ្លាប់បានធ្វើរួចមកហើយ ។ ប៉ុន្តែ ទ្រង់ពុំអាចធ្វើយ៉ាងនោះបានទេបើសិនជាអ្នកពុំអធិស្ឋាន ហើយពុំមានសេចក្ដីប្រាថ្នានោះ ។ និយាយឲ្យខ្លី ទ្រង់ពុំអាចធ្វើយ៉ាងនោះបានទេ បើសិនជាអ្នកពុំជឿទេនោះ » ( Terror, Triumph, and a Wedding Feast» [ Brigham Young University fireside address ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៤ ] ទំព័រ ៣ speeches.byu.edu

សូមពិចារណាសំណួរដូចតទៅនេះ ៖ តើមនុស្សគ្រប់គ្នានឹងស្គាល់ព្រះយេស៊ូវគ្រីស្ទជានរណាដែរឬទេ នៅពេលទ្រង់យាងមកជាលើកទីពីរនោះ ? សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤៦–៤៧ ដើម្បីស្វែងរកចម្លើយចំពោះសំណួរនេះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤៨–៤៩ ដោយការពិពណ៌នាដែលប្រាប់អំពីរូបរាងរបស់ព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់នឹងយាងមកជាលើកទីពីរ ។

ដើម្បីយល់អំពីនិមិត្តរូបនៃព្រះពស្ត្រពណ៌ក្រហមរបស់ព្រះអង្គសង្គ្រោះ វានឹងផ្ដល់អត្ថប្រយោជន៍ក្នុងការដឹងអំពីអត្ថន័យនៃវាក្យសព្ទ « ធុងទំពាំងបាយជូរ » នៅក្នុង ខទី ៤៨ ។ ធុងទំពាំងបាយជូរក៏ត្រូវបានហៅថា ប្រដាប់គាបទឹកទំពាំងបាយជូរដែរ ដែលជាធុងមួយដ៏ធំផ្ទុកទៅដោយផ្លែទំពាំងបាយជូរ ។ មនុស្សជាន់លើផ្លែទំពាំងបាយជូរ ដើម្បីគាបយកទឹក ដូច្នេះវាអាចត្រូវបានផ្ទុកនៅក្នុងធុងតែមួយ ។ នៅពេលមនុស្សឈាន់លើផ្លែទំពាំងបាយជូរ នោះទឹករបស់វាបានខ្ទាតប្រឡាក់សម្លៀកបំពាក់ពួកគេដែលមានពណ៌ឡើងក្រហមទែង ។

សូមសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៤៨–៥១ ។ ចេញពីខគម្ពីរទាំងនេះ យើងរៀនអំពីសេចក្ដីយុត្តិធម៌ និង ការសងសឹកពេលទ្រង់យាងមកជាលើកទីពីរ ។


ផ្លែទំពាំងបាយជូរត្រូវបានជាន់នៅក្នុងធុងទំពាំងបាយជូរ ឬ ប្រដាប់គាបទឹកទំពាំងបាយជូរ ។

ចំពោះនិមិត្តរូបនៃប្រដាប់គាបទឹកទំពាំងបាយជូរ ផ្លែទំពាំងបាយជូរតំណាងឲ្យពួកទុច្ចរិត ដែលនឹងត្រូវបានបំផ្លាញចោលនៅពេលព្រះអង្គសង្គ្រោះយាងមកជាលើកទីពីរ ។ ព្រះពស្ត្រពណ៌ក្រហមរបស់ទ្រង់ អាចត្រូវបានចាត់ទុកជានិមិត្តរូបនៃសេចក្ដីយុត្តិធម៌របស់ទ្រង់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៥២–៥៣ ដោយស្វែងរកអ្វីដែលពួកសុចរិត នឹងចងចាំ ហើយថ្លែង « ឆ្នាំកំណត់នៃពួកប្រោសលោះរបស់យើង » ( គ. និង ស. ១៣៣:៥២ ) ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នករកឃើញ ។

២. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគ្រាដែលអ្នកបានមានអារម្មណ៍អំពីសណ្ដានព្រះទ័យនៃសេចក្ដីស្រឡាញ់របស់ព្រះអម្ចាស់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៥៤–៥៦ ដោយស្វែងរកអ្វីដែលនឹងកើតឡើងចំពោះពួកបរិសុទ្ធសុចរិតដែលបានស្លាប់ពីមុនការយាងមកជាលើកទីពីរ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៥៧–៧៤

*ដំណឹងល្អត្រូវបានបញ្ជូនទៅ ដើម្បីរៀបចំពិភពលោកទទួលការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ*

សូមគោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៥៧–៦២ ដោយស្វែងរកសេចក្ដីពិតអំពីមូលហេតុ ដែលដំណឹងល្អត្រូវតែបានបញ្ជូនទៅ ពីមុនព្រះអម្ចាស់យាងមកជាលើកទីពីរ ។

នៅពេលអ្នករៀនចេះដឹងអំពីដំណឹងល្អ ហើយរស់នៅតាម អ្នកនឹងត្រៀមខ្លួនជាស្រេចទទួលការយាងមកជាលើកទីពីរ ។ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៦២ បង្ហាញអំពីពរជ័យមួយទៀត ដែលអ្នកអាចទទួលបាន ។ សូមយោងទៅកាន់ខគម្ពីរនេះ ដើម្បីបញ្ចប់សេចក្ដីថ្លែងការណ៍ដូចតទៅនេះ ៖ **អ្នកទាំងឡាយដែល ហើយញែកខ្លួនចេញជាបរិសុទ្ធ នោះនឹងត្រូវបាន** ។

អ្នកអាចនឹងឃើញទំនាក់ទំនង រវាងគោលការណ៍នៅក្នុង ខទី ៦២ និង គោលការណ៍ដែលអ្នករកឃើញមុននេះនៅក្នុង ខទី ៤៥—ដែលប្រាប់ថា ព្រះអម្ចាស់បានរៀបចំពរជ័យអស្ចារ្យៗ ទុកសម្រាប់អ្នកទាំងឡាយដែលទន្ទឹងរង់ចាំទ្រង់ ។

៣. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើគោលការណ៍នៅក្នុង ខទី ៦២ ទាក់ទងនឹងគោលការណ៍ដែលអ្នករកឃើញនៅក្នុង ខទី ៤៥ យ៉ាងដូចម្ដេច ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៦៣–៧៤ យើងអានអំពីលទ្ធផលនានា កើតឡើងចំពោះអស់អ្នកទាំងឡាយដែលមិនប្រែចិត្ត ហើយមិនត្រៀមខ្លួនទទួលការយាងមកជាលើកទីពីរ ។ លទ្ធផលមួយចំនួនទាំងនេះ រួមបញ្ចូលទាំងការត្រូវបានកាត់ចេញពីព្រះអម្ចាស់ និង ការ « ត្រូវបានប្រគល់ទៅឯសេចក្ដីងងឹត » ( គ. និង ស. ១៣៣:៧២ ) ។

៤. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៦៦–៦៧, ៧០–៧១ ម្ដងទៀត ជាខគម្ពីរដែលមានព្រះបន្ទូលរបស់ព្រះអម្ចាស់ ទៅកាន់មនុស្សដែលពុំទទួលទ្រង់ ។ បន្ទាប់មក សូមសង្ខេបនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីជម្រើសនានារបស់មនុស្ស ដែលមានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ ។

ចំពោះអ្នកទាំងឡាយដែលបានមានឱកាសទទួលព្រះអម្ចាស់ហើយ ប៉ុន្តែ ពុំទទួលទ្រង់ទេនោះការយាងមកជាលើកទីពីរ នឹងជាពេលមួយដ៏ក្រៀមក្រំ ។ ប៉ុន្តែ បើសិនជាយើងទទួលយកការអញ្ជើញរបស់ព្រះអម្ចាស់ឲ្យទទួលទ្រង់ ស្ដាប់តាមព្រះសូរសៀងទ្រង់ ព្រមទាំងជឿ ហើយទទួលពួកអ្នកបម្រើរបស់ទ្រង់ផងនោះ ការយាងមកជាលើកទីពីរ នឹងជាទិវាមួយដ៏រុងរឿងសម្រាប់យើង ។

*ការស្វែងទំនាក់ទំនងនៅក្នុងបទគម្ពីរ*

អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា « ការភ្ជាប់គ្នាគឺជាទំនាក់ទំនង ឬ តំណរវាងគំនិត មនុស្ស វត្ថុ ឬ ព្រឹត្តិការណ៍នានា ហើយបទគម្ពីរមានពេញទៅដោយការភ្ជាប់គ្នានេះ ។. . . ការស្វែងរកប្រកបដោយការអធិស្ឋាន ការរៀន និង ការពិចារណាអំពីការភ្ជាប់គ្នានេះ—ឧទាហរណ៍ដូចជាភាពស្រដៀងគ្នា និង ភាពខុសគ្នានានា—គឺជាធនធានសំខាន់នៃទឹករស់ ថែមទាំងផ្ដល់ការយល់ដឹងដ៏បំផុសគំនិត និង ជារតនសម្បត្តិនៃចំណេះវិជ្ជាដែលបានកប់លាក់ទុក » ( «A Reservoir of Living Water» [ សន្និកថាការប្រជុំពិសេសនៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៧ ] ទំព័រ ៤ speeches.byu.edu ) ។ សូមសាកល្បងប្រើវិធីសាស្ត្រសិក្សានេះ នៅក្នុងការសិក្សាផ្ទាល់ខ្លួនរបស់អ្នក ។

៥. សូមស្រមៃថា ព្រះអង្គសង្គ្រោះបានយាងត្រឡប់មកកាន់ផែនដីវិញនៅថ្ងៃនេះ ។ តើអ្នកនឹងអរសប្បាយនៅក្នុងវត្តមានទ្រង់ ជាមួយអ្នកទាំងឡាយដែលបានទទួលនឹងរង់ចាំទ្រង់ដែរឬទេ ? សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវកិច្ចការមួយដែលអ្នកនឹងធ្វើ ដើម្បីឲ្យការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ នឹងក្លាយជាបទពិសោធន៍មួយដែលពោរពេញទៅដោយសេចក្ដីអំណរសម្រាប់អ្នក ។

៦. សូមសរសេរអ្វីដែលនៅខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៣:៣៦–៧៤ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤

## បុព្វកថា

នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៨៣៥ ការប្រជុំទូទៅមួយនៃសាសនាចក្របាន ធ្វើឡើងនៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ដើម្បីពិចារណាលើមាតិកាដែលបានស្នើ សម្រាប់ការបោះពុម្ពលើកដំបូងនៃគោលលទ្ធិ និង សេចក្ដីសញ្ញា ។ ដោយសារតែ ព្យាការី យ៉ូសែប ស្ម៊ីធ បានកំពុងតែសួរសុខទុក្ខពួកបរិសុទ្ធនៅទីក្រុង មីឈីហ្គេន ម្លោះហើយទើប អូលីវើរ ខៅឌើរី បានធ្វើអធិបតីលើការប្រជុំ ។ នៅក្នុងការប្រជុំនេះ ពួកបរិសុទ្ធបានបោះឆ្នោតដោយឯកច្ឆន្ទ ឲ្យដាក់បញ្ចូលសេចក្ដីប្រកាសដែល អូលីវើរ ខៅឌើរី បានសរសេរអំពីជំនឿរបស់សាសនាចក្រទាក់ទងនឹងរដ្ឋាភិបាល និង ច្បាប់ ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤ មាននូវពាក្យ ឬ ឃ្លា ដែលអាចនឹងពិបាកយល់ ។ បញ្ជី និយមន័យនានាខាងក្រោមនេះ អាចនឹងផ្ដល់អត្ថប្រយោជន៍នៅពេលអ្នកសិក្សាកណ្ឌនេះ ៖

*ទ្រទ្រង់* ( ខទី ២ ) ៖ សុវត្ថិភាព មិនត្រូវបានបំពាន

*ពួកចៅក្រម* ( ខទី ៣, ៦ ) ៖ មន្ត្រីសាធារណៈ ដែលគ្រប់គ្រងច្បាប់

*សាធារណៈរដ្ឋ* ( ខទី ៣ ) ៖ រដ្ឋាភិបាលដែលមានប្រជាពលរដ្ឋ បោះឆ្នោត ជ្រើសតាំងឲ្យធ្វើជាតំណាងពួកគេ

*មហាក្សត្រ* ( ខទី ៣ ) ៖ អ្នកគ្រប់គ្រងកំពូលមានដូចជា ព្រះរាជា ឬ ព្រះរាជនី

*ទទួលខុសត្រូវ* ( ខទី ៤ ) ៖ មានភារកិច្ច

*រំលោភទៅលើ* ( ខទី ៤ ) ៖ បង្ខាក់ ដាក់កំហិត បំពានទៅលើ

*ការដាក់ច្បាប់* ( ខទី ៤, ៦ ) ៖ ការបង្កើតច្បាប់

*ដាក់បញ្ជា* ( ខទី ៤ ) ៖ បង្គាប់ប្រជាពលរដ្ឋឲ្យធ្វើអ្វីមួយ តាមវិធីជាក់លាក់មួយ

*ហាមប្រាម* ( ខទី ៤ ) ៖ ដាក់កំហិត រឹតបន្តឹង

*ឥតដកចេញបាន* ( ខទី ៥ ) ៖ ពុំអាចបដិសេធ ពុំអាចយកចេញបាន

*ការចាក់រុក* ( ខទី ៥, ៧ ) ៖ ការបះបោរប្រឆាំងនឹងថ្នាក់ដឹកនាំរដ្ឋាភិបាល

*ព្រមធ្វើតាម* ( ខទី ៦ ) ៖ ការព្រមព្រៀង ការចុះចូល

*បានជំនួសដោយ* ( ខទី ៦ ) ៖ បានប្ដូរដោយ

*អនាធិបតេយ្យ* ( ខទី ៦ ) ៖ ភាពគ្មានសណ្ដាប់ធ្នាប់—អវត្តមាននៃច្បាប់ និង រដ្ឋាភិបាល ឬ ការបះបោរប្រឆាំងនឹងច្បាប់ ឬ រដ្ឋាភិបាល

*ហាមប្រាម* ( ខទី ៧, ៩ ) ៖ ឃាត់ឃាំង

*ការរួមគំនិតធ្វើអំពើទុច្ចរិត* (ខទី ៧ ) ៖ សកម្មភាពនៃការធ្វើការរួមគ្នា ដើម្បីផ្ដួលរំលំរដ្ឋាភិបាល ឬ អង្គការដទៃទៀត

*អំពើបំបែកបំបាក់* ( ខទី ៨ ) ៖ ល្មើស ឬ បំពាន

*កែ* ( ខទី ១១ ) ៖ ធ្វើអ្វីមួយឲ្យត្រឹមត្រូវឡើងវិញ

*ការបំពានល្មើសច្បាប់* ( ខទី ១១ ) ៖ ការឈ្លានពានខុសច្បាប់

*គ្រោះអាសន្ន* ( ខទី ១១ ) ៖ សេចក្ដីត្រូវការជាបន្ទាន់

*ទាសភាព* ( ខទី ១២ ) ៖ សេវកភាព ភាពជាអ្នកបម្រើ

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:១–៤

*ការទទួលខុសត្រូវរបស់រដ្ឋាភិបាល ត្រូវបានដាក់ឲ្យមាន*

១. សូមស្រមៃថា ក្រុមគ្រួសាររបស់អ្នកកំពុងចូលរួម ជាមួយគ្រួសារដទៃទៀត ដើម្បីបង្កើតជាប្រទេសថ្មី មួយ ដោយមានរដ្ឋាភិបាលថ្មី ។ សូមឆ្លើយសំណួរ ខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សា ព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថារដ្ឋាភិបាលមានគោលបំណងអ្វី ?

ខ. បើសិនជាអ្នកគឺជាអ្នកដឹកនាំប្រទេសថ្មីមួយ តើមានច្បាប់មួយចំនួនណាខ្លះ ដែលអ្នកនឹង បង្កើត ?



សូមរំឭកអំពីបុព្វកថានៃមេរៀននេះ និង សេចក្ដីណែនាំអំពីកណ្ឌឡើងវិញសម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤ ។ សូមស្វែងរកមូលហេតុដែលពួកបរិសុទ្ធ បានទទួលអារម្មណ៍ថាត្រូវបោះពុម្ពសេចក្ដីប្រកាសអំពីរដ្ឋាភិបាល និង ច្បាប់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:១ ដោយស្វែងរកថាតើនរណា ជាអ្នករដ្ឋាភិបាល ។ ដោយផ្អែកទៅលើអ្វីដែលអ្នកស្វែងយល់ចេញពីខគម្ពីរនេះ សូមបំពេញសេចក្ដីពិតដូចតទៅនេះ ៖ **រដ្ឋាភិបាលត្រូវបានឡើងដោយ សម្រាប់ផលប្រយោជន៍** ។

ចេញពី ខទី ១ យើងក៏រៀនស្វែងយល់អំពីសេចក្ដីពិតដូចតទៅនេះដែរ ៖ **មន្ត្រីរដ្ឋាភិបាលមានការទទួលខុសត្រូវចំពោះព្រះក្នុងការប្រព្រឹត្ត « សម្រាប់ការល្អ និង សន្តិសុខដល់សង្គម »** ។

២. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមធ្វើដូចខាងក្រោមនេះ ៖

ក. សូមរាយបញ្ជីនៃរបៀបដែលថ្នាក់ដឹកនាំរដ្ឋាភិបាល អាចប្រព្រឹត្ត « សម្រាប់ការល្អ និង សន្តិសុខដល់សង្គម » ។

ខ. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:២ ដោយស្វែងរកសិទ្ធិទាំងបី ដែលរដ្ឋាភិបាលគួរតែគាំពារ ។ សូមរាយបញ្ជីនៃសិទ្ធិទាំងបីនេះ ។

គ. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:៤ រួចកត់ត្រាសិទ្ធិមួយទៀត ដែលរដ្ឋាភិបាលគួរតែគាំពារ ។

ប្រធាន អែសរ៉ា ថាហ្វ បែនសឹន បានថ្លែងទីបន្ទាល់អំពីសារៈសំខាន់នៃអ្វីដែលលោកបានហៅថា « សិទ្ធិសំខាន់ៗទាំងបីរបស់មនុស្សជាតិ » ។ នៅក្នុងសេចក្ដីថ្លែងការណ៍របស់លោកខាងក្រោមនេះ ឃ្លា « ពួកអយ្យកោដើម » សំដៅទៅលើអ្នកទាំងឡាយដែលបានបង្កើតរដ្ឋាភិបាលនៃសហរដ្ឋអាមេរិកឡើង ។



« សេចក្ដីប្រកាសអំពីឯករាជ្យភាព បានបញ្ជាក់អំពីជំនឿ និង ទំនុកចិត្តរបស់ពួកអយ្យកោដើមទៅលើព្រះដោយពាក្យពេចន៍ទាំងនេះ ៖ ‹ យើងសូមប្រកាន់ខ្ជាប់ថា សេចក្ដីពិតទាំងនេះគឺជារឿងពិត ដែលថា មនុស្សទាំងអស់ត្រូវបានបង្កើតឡើងឲ្យមានសិទ្ធិស្មើគ្នា ដែលពួកគេត្រូវបានប្រទានឲ្យនូវសិទ្ធិផ្ទាល់ខ្លួនពីព្រះដ៏បង្កបង្កើតរបស់ខ្លួន ដែលក្នុងនោះមាន សិទ្ធិរស់រានមានជីវិត សិទ្ធិមានសេរីភាព និង សិទ្ធិស្វែងរកសុភមង្គល › ។

« គោលលទ្ធិ និង សេចក្ដីសញ្ញា ថ្លែងថា ‹ យើងខ្ញុំជឿថា គ្មានរដ្ឋាភិបាលណាអាចនៅក្នុងសេចក្ដីសុខសាន្តបានឡើយ លើកលែងតែច្បាប់ទាំងឡាយត្រូវបានបង្កើតឡើង ហើយទ្រទ្រង់ ដែលនឹងធានាដល់បុគ្គលម្នាក់ៗ នូវសេរីភាពខាងសតិសម្បជញ្ញៈ › (គ. និង ស. ១៣៤:២ ) ។ សិទ្ធិរស់រានមានជីវិត សិទ្ធិមានសេរីភាព សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ—គឺជាសិទ្ធិសំខាន់ៗទាំងបីរបស់មនុស្សជាតិ » ( «Our Divine Constitution» *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៧ ទំព័រ ៤ ) ។

៣. សូមកត់ត្រានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគំរូមួយចំនួននៃរបៀបដែលរដ្ឋាភិបាលអាចគាំពារសិទ្ធិនានា ដែលមានរាយបញ្ជីនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:២ ។ បន្ទាប់មក សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:៣ ដោយស្វែងរកអ្វីមួយ ដែលប្រជាពលរដ្ឋនៅក្នុងប្រទេសមួយចំនួនអាចធ្វើដើម្បីប្រាកដថា ថ្នាក់ដឹកនាំរដ្ឋាភិបាលរបស់ខ្លួននឹងអនុវត្តច្បាប់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:៥–៦, ៨

*ការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋ ត្រូវបានដាក់ឲ្យមាន*

សូមស្រមៃថាអ្នករស់នៅក្នុងប្រទេសមួយ ដែលជាធម្មតារដ្ឋាភិបាលប្រទេសនេះគាំពារសិទ្ធិរបស់ប្រជាពលរដ្ឋខ្លួន ប៉ុន្តែថ្មីៗនេះបានអនុមតិច្បាប់ដែលអ្នកពុំយល់ស្របតាម ។ តើរបៀបឆ្លើយតបណាមួយខាងក្រោមនេះ ដែលសមស្រប ? ( សូមគូសរង្វង់មួយ ) ។

- ប្រកាសជំទាស់ដោយសម្រេចថាមិនធ្វើតាម ច្បាប់ណាមួយរបស់រដ្ឋាភិបាលឡើយ ។
- គំរាមកំហែង ឬ បង្ករបួសស្នាមដល់មន្ត្រីរដ្ឋាភិបាល ដែលបានបង្កើតច្បាប់នោះឡើង ។
- ប្រមូលគ្នីគ្នាផ្ដួលរំលំរដ្ឋាភិបាល ។
- បង្ហាញទស្សន ឬ កង្វល់របស់អ្នកទៅតាមផ្លូវច្បាប់ ប៉ុន្តែ គាំទ្រ និង ប្រព្រឹត្តតាមរដ្ឋាភិបាលដោយគោរពតាមច្បាប់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:៥–៦ ដោយស្វែងរកមើលថាតើអ្វីខ្លះ ដែលជាការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋ ។

គោលការណ៍មួយដែល ខគម្ពីរនេះបង្រៀនគឺថា **យើងត្រូវគាំទ្រ ហើយគោរពតាមច្បាប់រដ្ឋាភិបាលដែលយើងរស់នៅក្រោមការគ្រប់គ្រង ។**

តើគោលការណ៍នេះរំឭកអ្នកអំពីមាត្រានៃសេចក្ដីជំនឿទីប៉ុន្មាន ? ( សូមមើលមាត្រានៃសេចក្ដីជំនឿ នៅក្នុងមុក្ដាដ៏មានតម្លៃមហិមា ដើម្បីផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក ) ។

៤. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថាហេតុអ្វីបានជាវាមានសារៈសំខាន់ ដែលប្រជាពលរដ្ឋត្រូវគាំទ្រ ហើយគោរពរដ្ឋាភិបាល ?

យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:៦ **ព្រះសព្វព្រះទ័យឲ្យយើងគោរព ហើយធ្វើតាមច្បាប់របស់ព្រះ និង ច្បាប់របស់មនុស្ស ។** តើអ្នកគិតថា យើងគួរតែធ្វើអ្វីខ្លះនៅពេលច្បាប់ភូមិបាល ដំណើរការទៅជំទាស់នឹងជំនឿរបស់យើង ?

នៅពេលអ្នកគិតអំពីសំណួរនេះ សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្ទហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« នៅក្នុងករណីមានទំនាស់រវាងការទាមទារដែលធ្វើឡើងពីព្រះបន្ទូលនៃព្រះដែលបានបើកសម្ដែង និងពីស្ថានភាពដែលត្រូវបានបង្ខំដោយច្បាប់លោកិយ តើភាគីណាមួយដែលសមាជិកសាសនាចក្រត្រូវគោរពតាម ? ដើម្បីឆ្លើយសំណួរនេះ ព្រះបន្ទូលនៃព្រះអាចនឹងត្រូវបានអនុវត្ត—ដ្បិតវាគឺជាករណីយកិច្ចរបស់មនុស្ស ដែលត្រូវថ្វាយរបស់សេសារ ទៅសេសារ ឯរបស់ព្រះ ចូរថ្វាយទៅព្រះវិញ [ សូមមើល លូកា ២០:២១–២៥ ] . . .

« ទន្ទឹមនឹងការរង់ចាំ [ ព្រះ ] ទ្រង់គ្រប់គ្រងលើអ្វីទាំងអស់ ដើម្បីមានសេរីភាពខាងសាសនានោះ វាគឺជាករណីយកិច្ចរបស់ពួកបរិសុទ្ធ ដែលត្រូវចុះចូលទៅនឹងច្បាប់នៃប្រទេសរបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេគួរតែប្រើប្រាស់គ្រប់វិធីក្នុងនាមជាប្រជាពលរដ្ឋ ឬ ដាក់សំណើទៅកាន់រដ្ឋាភិបាលរបស់ខ្លួន ដើម្បីធានាដល់ពួកគេ និង ដល់មនុស្សទាំងពួង ឲ្យទទួលបានគុណប្រយោជន៍នៃសេរីភាពខាងកិច្ចការសាសនា ។ ពួកគេពុំត្រូវបានតម្រូវឲ្យរងទុក្ខ ដោយគ្មានការប្រកាសជំទាស់ទៅនឹងការដាក់កំហិតឲ្យបង់ពន្ធដោយអ្នកបៀតបៀនខុសច្បាប់ ឬ តាមរយៈប្រតិបត្តិការនៃច្បាប់មិនស្មើភាពនោះទេ ប៉ុន្តែ ការប្រកាសជំទាស់របស់ពួកគេគួរតែត្រូវបានធ្វើឡើងទៅតាមបទបញ្ញាស្របច្បាប់ និង ត្រឹមត្រូវ ។ ពួកបរិសុទ្ធបានបង្ហាញការធ្វើតាមរបស់ខ្លួនដោយមានចិត្តប្រតិបត្តិថា វាជារឿងប្រសើរជាង ដែលត្រូវរងទុក្ខនឹងសេចក្ដីអាក្រក់ ជាជាងប្រព្រឹត្តអំពើខុសឆ្គងតាមរយៈការប្រឆាំងដែលធ្វើឡើងដោយមនុស្សល្អបរិសុទ្ធ ទៅកាន់អាជ្ញាធរមិនយុត្តិធម៌នោះ » ( *The Articles of Faith,* ការបោះពុម្ពលើកទី ១២ [ ឆ្នាំ ១៩២៤ ] ទំព័រ ៤២២–២៣ ) ។

៥. សូមគិតអំពីមនុស្សដែលអ្នកស្គាល់ ជាអ្នកដែលគាំទ្រ ហើយប្រព្រឹត្តតាមរដ្ឋាភិបាល និង ច្បាប់របស់ខ្លួន ។ សូមសរសេរអំពីពួកគេម្នាក់ ឬ ពីរនាក់ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។ តើអ្នកបានឃើញពួកគេធ្វើដូចម្ដេចខ្លះ ដើម្បីគាំទ្រ ហើយប្រព្រឹត្តតាមរដ្ឋាភិបាល និង ច្បាប់ ?

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:៨ យើងអានថា រដ្ឋាភិបាលមានការទទួលខុសត្រូវមួយក្នុងការដាក់ទោសដល់អ្នកទាំងឡាយ ដែលប្រព្រឹត្តបទឧក្រិដ្ឋ ហើយប្រជាពលរដ្ឋមានការទទួលខុសត្រូវមួយក្នុងការជួយ « នាំអ្នកមានទោសទាស់នឹងច្បាប់ល្អ មកដាក់ទោស » ។

៦. សូមសរសេរកថាខណ្ឌខ្លីមួយ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ដោយពិពណ៌នាអំពីអ្វីដែលអ្នកនឹងធ្វើ ដើម្បីគាំទ្រ ហើយប្រព្រឹត្តតាមរដ្ឋាភិបាលរបស់អ្នក ព្រមទាំងច្បាប់របស់វា ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:៧, ៩–១០, ១២

*ទំនាក់ទំនងរវាងសាសនា និង រដ្ឋាភិបាល*

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:៧, ៩–១០, ១២ យើងអានថា រដ្ឋាភិបាលគួរតែបង្កើតច្បាប់នានាដែលគាំពារការគោរពសាសនា ប៉ុន្តែ ពុំគួរផ្គាប់ចិត្តសាសនាមួយជាងសាសនាមួយផ្សេងទៀតឡើយ ។ យើងក៏អានថា អង្គការសាសនានានាមានសិទ្ធិដាក់ទោសដល់សមាជិករបស់ខ្លួន ដែលពុំគោរពតាមច្បាប់ ដោយការកាត់កាលចេញ ឬ ដកយកសមាជិកភាពរបស់ពួកគេចេញ ប៉ុន្តែ អង្គការទាំងនោះពុំមានសិទ្ធិអំណាចក្នុងការវិនិច្ឆ័យ ឬ បង្ខំដាក់ទោស ដែលនឹងដកយកទ្រព្យសម្បត្តិរបស់សមាជិក ឬ បង្ករបួសស្នាមដល់រូបរាងកាយរបស់ពួកគេឡើយ ។



ប្រធាន ថូម៉ាស អេស ម៉នសុន និង ប្រធានាធិបតីនៃសហរដ្ឋអាមេរិក រ៉ូណល រីហ្គាន

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:១១ ។

*សិទ្ធិអំពាវនាវសុំជំនួយពីរដ្ឋាភិបាល ត្រូវបានពន្យល់*

យោងតាម គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤:១១ ប្រជាពលរដ្ឋគួរតែត្រូវបានអនុញ្ញាតឲ្យ អំពាវនាវសុំជំនួយពីរដ្ឋាភិបាល ថាតើពួកគេបានប្រព្រឹត្តខុសឆ្គងដែរឬទេ ។ ខគម្ពីរទាំងនេះក៏បានបូកបញ្ចូលសេចក្ដីប្រកាសមួយដែលប្រាប់ថា ប្រជាពលរដ្ឋត្រូវបានបង្ហាញថាមិនមានកំហុស ដើម្បីការពារខ្លួនគេ និង មនុស្សទូទៅ នៅពេលមានសេចក្ដីត្រូវការបន្ទាន់ដែលរដ្ឋាភិបាលពុំអាចជួយពួកគេបាននោះ ។

សូមគិតអំពីអ្វីដែលអ្នកមានអំណរគុណ ចំពោះប្រទេស ឬ សហគមន៍របស់អ្នក ។

៧. សូមសរសេរអ្វីដែលនៅខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៤ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ២៩ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥

## បុព្វកថា

នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៨៤៤ ព្យាការី យ៉ូសែប ស្ម៊ីធ និង បងប្រុស ហៃរុម ដែលជាជំនួយការប្រធាន និង ជាលោកអយ្យកោនៃសាសនាចក្រនោះ ត្រូវគេធ្វើឃាតនៅក្រុងកាតធេច រដ្ឋ អិលលីណោយ ។ ក្រុមនៃពួកសាវកដប់ពីរនាក់ បានអនុមតិចេញសេចក្ដីប្រកាសមួយអំពី ទុក្ករកម្មនោះដើម្បីបញ្ចូលទៅក្នុងសេចក្ដីបញ្ចប់នៃគោលលទ្ធិ និង សេចក្ដីសញ្ញាដែលបោះពុម្ពក្នុងឆ្នាំ ១៨៤៤ ដែលបានហៀបនឹងបោះពុម្ពរួចរាល់ហើយនោះ ។ សេចក្ដីប្រកាសនោះសរសេរតាមដំណើររឿងដែលអែលឌើរ យ៉ូហាន ថេល័រ និង វិលឡើឌ រិចឆើត្ស ជាសមាជិកក្នុងក្រុមនៃពួកដប់ពីរនាក់ បានឃើញដោយផ្ទាល់ភ្នែក ។ សព្វថ្ងៃ វិវរណៈនេះមានកត់ត្រានៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥

*ទុក្ករកម្មរបស់យ៉ូសែប និង ហៃរុម ស្ម៊ីធ ត្រូវបានប្រកាស*

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:១ ។ សូមស្រមៃថា អ្នកគឺជាសមាជិកសាសនាចក្រម្នាក់រស់នៅទីក្រុង ណៅវូ រដ្ឋ អិលលីណោយ ក្នុងឆ្នាំ ១៨៤៤ រួចសូមគិតថាតើអ្នកអាចនឹងមានអារម្មណ៍ដូចម្ដេច នៅពេលបានឮដំណឹងដ៏ខ្លោចផ្សានេះ ។

ពួកបរិសុទ្ធជាច្រើនបានសោកសៅជាខ្លាំងពន់ពេក នៅពេលបានទទួលដំណឹងអំពីមរណភាពរបស់ យ៉ូសែប និង ហៃរុម ស្ម៊ីធ ។ សូមគិតអំពីអារម្មណ៍ និង ទីបន្ទាល់ផ្ទាល់ខ្លួនរបស់អ្នកអំពីព្យាការី យ៉ូសែប ស្ម៊ីធ នៅពេលអ្នកទទួលដំណឹងអំពីថ្ងៃចុងក្រោយនៃជីវិតរបស់លោក ។

យ៉ូសែប ស្ម៊ីធ និង ពួកបរិសុទ្ធបានរស់នៅយ៉ាងសុខសាន្តនៅរដ្ឋ អិលលីណោយ អស់រយៈពេលប្រហែលបីឆ្នាំ ។ ទោះជាយ៉ាងណាក៏ដោយ ត្រឹមឆ្នាំ ១៨៤២ ពួកគាត់បានចាប់ផ្ដើមជួបប្រទះនឹងសេចក្ដីទំនាស់សាជាថ្មី ។ អ្នកប្រឆាំងនៅក្នុងសាសនាចក្រ និង បក្សប្រឆាំងនៅខាងក្រៅសាសនាចក្របានរួមកម្លាំងគ្នាប្រឆាំងនឹងព្យាការី ព្រមទាំងសាសនាចក្រ ។ ប្រជាពលរដ្ឋទីក្រុង អិលលីណោយ បានចាប់ផ្ដើមភ័យខ្លាច ហើយស្អប់ឥទ្ធិពលនយោបាយរបស់ពួកបរិសុទ្ធ ។ ប្រជាពលរដ្ឋបានបែរជាច្រណែននឹងការរីកចម្រើនខាងសេដ្ឋកិច្ចរបស់សាសនាចក្រនៅទីក្រុង ណៅវូ ហើយបានរិះគន់នឹងអំណាចរបស់អភិបាលក្រុងណៅវូ និងក្រុមជីវពលរបស់ក្រុង ។ ប្រជាពលរដ្ឋខ្លះទៀត បានស្អប់ពួកបរិសុទ្ធដោយសារតែការយល់ខុសរវាងគោលលទ្ធិដ៏ចម្លែករបស់សាសនាចក្រដូចជាពហុអាពាហ៍ពិពាហ៍ និងការអនុវត្តផ្សេងទៀត ដែលបានប្រព្រឹត្តដោយខុសឆ្គងពីសំណាក់សមាជិកសាសនាចក្រក្បត់សាសនា ។ ( សូមមើល *Church History in the Fulness of Times Student Manual* | Church Educational System manual ឆ្នាំ ២០០៣ | ទំព័រ ២៦៣–៦៦, ២៧០–៧១) ។

ត្រឹមខែ មិថុនា ឆ្នាំ ១៨៤៤ អនាមិកភាពប្រឆាំងនឹងសាសនាចក្របានមានភាពតានតឹងជាខ្លាំង ។ ប្រជាពលរដ្ឋខ្លះនៅរដ្ឋ អិលលីណោយ បានពិភាក្សាអំពីការបណ្ដេញពួកបរិសុទ្ធចេញពីរដ្ឋ ទន្ទឹមនឹងពេលមនុស្សផ្សេងទៀតបានគ្រោងសម្លាប់ យ៉ូសែប ស្ម៊ីធ ។ អ្នកខ្លះដែលបានរួមគំនិតក្បត់នឹងព្យាការី និង សាសនាចក្រ ជាអតីតសមាជិកនៃសាសនាចក្រ ដែលបានក្បត់សាសនា ។ នៅថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ១៨៤៤ វិល្លាម ឡ ដែលបានបម្រើជាទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ និង អ្នកក្បត់សាសនាផ្សេងទៀត បានបោះពុម្ពកាសែតទីមួយដែលហៅថា *Nauvoo Expositor* ។ ដោយមានបំណងចង់បញ្ឆេះកំហឹងសាធារណជនឲ្យប្រឆាំងនឹងព្យាការី ព្រមទាំង សាសនាចក្រផងនោះ បុរសទាំងនេះបានប្រើកាសែតនេះ ដើម្បីនិយាយបង្ខូចអំពី យ៉ូសែប ស្ម៊ីធ ព្រមទាំងថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រ ។ យ៉ូសែប ស្ម៊ីធ និង ក្រុមប្រឹក្សាទីក្រុង ណៅវូ បានដឹងថា កាសែតអុជអាលនេះ នឹងនាំទៅរកអំពើហិង្សាឥតសណ្ដាប់ធ្នាប់ប្រឆាំងនឹង ទីក្រុងនេះ ។ ពួកគាត់បានប្រកាសថាក្រុមកាសែតនេះជាភាពសៅហ្មងដល់សាធារណជន ហើយបានបញ្ជាឲ្យកាសែត *Nauvoo Expositor* ត្រូវតែបានបំផ្លាញចោល ។


NAUVOO EXPOSITOR.

[illegible]

ពួកអ្នកក្បត់សាសនាបានប្រើ *Nauvoo Expositor* ដើម្បីនិយាយបង្ខូចអំពី យ៉ូសែប ស្ម៊ីធ ព្រមទាំងថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រ ហើយបញ្ឆេះកំហឹងសាធារណជនទាស់នឹងសាសនាចក្រ ។

មាតិកានៃ *Nauvoo Expositor* ព្រមជាមួយនឹងការបំផ្លាញកាសែតនោះចោល បានបណ្ដាលឲ្យកំហឹងរបស់ពួកប្រឆាំងនឹងពួកមរមននេះកាន់តែខ្លាំងឡើង ។ ចាងហ្វាងកាសែតនោះ បានចោទប្រកាន់តាមផ្លូវច្បាប់ប្រឆាំងនឹង យ៉ូសែប ស្ម៊ីធ ព្រមទាំងថ្នាក់ដឹកនាំក្រុងដទៃទៀត ដោយចោទពួកគាត់អំពីបទបង្កភាពចលាចល ។ យ៉ូសែប ស្ម៊ីធ ត្រូវបានប្រកាសថាមិនមានទោសចំពោះការចោទប្រកាន់នេះដោយចៅក្រមដែលជាពួកបរិសុទ្ធថ្ងៃចុងក្រោយ និង ចៅក្រមដែលមិនមែនជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ប៉ុន្តែការណ៍នេះបានត្រឹមតែធ្វើឲ្យខ្មាំងសត្រូវរបស់លោកមានកំហឹងកាន់តែខ្លាំងប៉ុណ្ណោះ ។ នៅពេលពត៌មានបែកធ្លាយថា ពួកមនុស្សកំណាចបានប្រមូលគ្នាដើម្បីទៅវាយប្រហារទីក្រុង ណៅវូ នោះក្នុងនាមជាអភិបាលក្រុង យ៉ូសែប ស្ម៊ីធ បានប្រកាសថា ទីក្រុង ណៅវូ ត្រូវស្ថិតនៅក្រោមច្បាប់អាជ្ញាសឹក ( ច្បាប់យោធាបណ្ដោះអាសន្ន ) ហើយដោយមានការដឹកនាំពីអភិបាលរដ្ឋ ថូម៉ាស ហ្វដ នៃរដ្ឋ អិលលីណោយ នោះយ៉ូសែប បានបញ្ជាឲ្យមានកងកម្លាំងការពារទីក្រុង ។

បញ្ហាតានតឹងនៅក្នុងតំបន់នេះ បានកើនឡើងជាខ្លាំងដែលបណ្ដាលឲ្យលោកអភិបាល ហ្វដ ទៅដល់ទីក្រុង កាតធេច ដែលជាចំណុចគ្រប់គ្រងកណ្ដាលនៃភូមិភាគ ដើម្បីកែប្រែស្ថានភាពតានតឹងនេះ ។ គាត់បានសរសេរសំបុត្រទៅកាន់ យ៉ូសែប ស្ម៊ីធ ថា មានតែតាមរយៈការសម្រេចក្ដីរបស់ព្យាការី និង ថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រត្រូវបានធ្វើឡើងដោយក្រុមចៅក្រមមិនមែនជាពួកមរមន នៅក្រុងកាតធេចទេ ទើបអាចធ្វើឲ្យប្រជាពលរដ្ឋស្ងប់ចិត្តបាន ។ លោកអភិបាល ហ្វដ ក៏បានសន្យាជាមួយពួកលោកថានឹងការពារ ហើយផ្ដល់ការជំនុំជម្រះមួយដ៏យុត្តិធម៌ ប្រសិនបើពួកលោកស្ម័គ្រចិត្តឡើងតុលាការ ។ យ៉ូសែប បានសរសេរតបទៅវិញថា ជីវិតរបស់លោកនឹងស្ថិតនៅក្នុងគ្រោះថ្នាក់នៅតាមផ្លូវ ដូច្នេះលោកសម្រេចថានឹងមិនទៅឡើយ ។

នៅអំឡុងគ្រាដ៏លំបាកនេះ ហើយបន្ទាប់ពីបានប្រឹក្សាជាមួយគ្នា ព្យាការីបានទទួលអារម្មណ៍ថា បើសិនជាលោក និង ហៃរុម ចាកចេញពីទីក្រុង ណៅវូ ហើយធ្វើដំណើរទៅកាន់ភាគខាងលិច នោះពួកបរិសុទ្ធនៅទីក្រុង ណៅវូ នឹងពុំត្រូវគេធ្វើទុក្ខទោសឡើយ ។ ដោយធ្វើតាមការបំផុសគំនិតនេះ យ៉ូសែប និង ហៃរុម បានធ្វើដំណើរឆ្លងកាត់ទន្លេ មីស៊ីស៊ីពី ទៅកាន់រដ្ឋ អៃអូវ៉ា ។ ទោះជាយ៉ាងណាក៏ដោយ សមាជិកមួយចំនួននៃសាសនាចក្រនៅទីក្រុង ណៅវូ បានឆ្ងល់អំពីផែនការរបស់ព្យាការី ។ សមាជិកខ្លះបានមកជួបលោក ហើយបានចោទប្រកាន់លោកថាជាមនុស្សកំសាកដោយស្រដីថា លោកកំពុងតែបោះបង់ពួកបរិសុទ្ធចោល ហើយទុកឲ្យពួកគេប្រឈមមុខនឹងសេចក្ដីបៀតបៀនតែឯង ។ ព្យាការីបានមានប្រសាសន៍ថា « ប្រសិនបើជីវិតរបស់ខ្ញុំ ពុំមានតម្លៃចំពោះមិត្តទាំងឡាយរបស់ខ្ញុំទេនោះ វាក៏ពុំមានតម្លៃចំពោះខ្លួនខ្ញុំផ្ទាល់ដែរ » ( នៅក្នុង *History of the Church* ៦:៥៤៩ ) ។ បន្ទាប់ពីបានប្រឹក្សាជាមួយគ្នាហើយ យ៉ូសែប និង ហៃរុម បានត្រឡប់មកទីក្រុង ណៅវូ វិញ ។ នៅព្រឹកព្រហាមថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៨៤៤ ពួកលោកបានចេញដំណើរទៅកាន់ក្រុង កាតធេច ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:៤ ដោយស្វែងរកការព្យាករណ៍ដែល យ៉ូសែប ស្ម៊ីធ បានធ្វើនៅក្បែរក្រុង កាតធេច ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ការណ៍នោះមានសភាពដូចម្ដេចសម្រាប់ យ៉ូសែប ស្ម៊ីធ ដែលត្រូវចាកចេញពីក្រុមគ្រួសាររបស់លោក ដោយដឹងថាលោកនឹងពុំវិលវិញសោះឡើយនោះ ?

ខ. តើអ្នកគិតថាហេតុអ្វីបានជាព្យាការី « ស្ងប់ចិត្តដូចជាព្រឹកព្រលឹមនារដូវក្ដៅ » នៅពេលលោកដឹងថា លោកនឹង « ទៅដូចជាចៀមដឹកទៅសម្លាប់ » ?

ព្យាការីបានដឹងថា មរណភាពរបស់លោកនឹងការពារជីវិតរបស់ពួកបរិសុទ្ធជាច្រើននាក់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:៥ រួចកត់ចំណាំអំពីអ្វីដែល ហៃរុម បានអាន និង គូសចំណាំពីមុនដែលលោកបានចាកចេញទៅកាន់ក្រុង កាតធេច ។

២. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថា ហេតុអ្វីបានជាខគម្ពីរ ចេញពីព្រះគម្ពីរអេធើរទាំងនេះ ( អេធើរ ១២:៣៦–៣៨ ) អាចនឹងមានអត្ថន័យជាពិសេសសម្រាប់ ហៃរុម ដែលត្រូវអាននៅពេលនោះ ?



ហៃរុម ស្ម៊ីធ បានអាន ហើយគូសចំណាំសន្លឹកទំព័រព្រះគម្ពីរមរមននៅក្នុងព្រះគម្ពីរមួយក្បាលនេះ ពីមុនចាកចេញទៅកាន់ក្រុង កាតធេច ។ សូមកត់ចំណាំកន្លែងដែលជ្រុងនៃទំព័រនេះត្រូវបានបត់ ។

នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៨៤៤ យ៉ូសែប, ហៃរុម និង ថ្នាក់ដឹកនាំដទៃទៀត បាននៅក្រៅឃុំរហូតដល់ការជំនុំជំម្រះជាផ្លូវការមួយបានធ្វើឡើង ដើម្បីដោះស្រាយបញ្ហាចោទប្រកាន់អំពីបទបង្កចលាចល ។ ទោះជាយ៉ាងណាក៏ដោយ នៅល្ងាចនោះ យ៉ូសែប និង ហៃរុម ត្រូវគេចាប់ដាក់គុក កាតធេច អំពីបទអំពើក្បត់ជាតិ ដែល យ៉ូសែប ស៊្មីធ និង ក្រុមមេធាវីរបស់លោកបានប្រកាសជំទាស់ថាខុសច្បាប់ ព្រោះការចោទប្រកាន់នោះពុំបានលើកឡើងកាលពីនៅក្រៅឃុំទេ ហើយអំពើក្បត់ជាតិពុំមានការដាក់ឲ្យនៅក្រៅឃុំនោះទេ ដូច្នេះគឺតម្រូវឲ្យពួកលោកស្នាក់នៅក្រុង កាតធេច ហើយ ស្ថិតក្នុងគ្រោះថ្នាក់ ។

នៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៨៤៤ យ៉ូសែប បានជួបជាមួយលោកអភិបាល ហ្វដ នៅក្នុងគុក ។ លោកអភិបាល ហ្វដ បានគិតអំពីការធ្វើដំណើរទៅទីក្រុង ណៅវូ ហើយ យ៉ូសែប បានសុំទៅជាមួយ ដោយមានអារម្មណ៍ថាលោកពុំមានសុវត្ថិភាពនៅក្នុងគុក កាតធេច នេះឡើយ ។ លោកអភិបាល ហ្វដ បានសន្យាថា ប្រសិនជាលោកចាកចេញពីក្រុង កាតធេច នោះគាត់នឹងនាំ យ៉ូសែប និង ហៃរុម ទៅជាមួយ ។ នៅល្ងាចនោះ ព្យាការីបានថ្លែងទីបន្ទាល់អំពីភាពពិតនៃព្រះគម្ពីរមរមន និង ការស្ដារឡើងវិញនៃដំណឹងល្អ ទៅកាន់អ្នកយាមគុក ។

នាព្រលឹមថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៨៤៤ យ៉ូសែប បានសរសេរនៅក្នុងសំបុត្រមួយច្បាប់ទៅកាន់ភរិយារបស់លោក អិមម៉ា ៖ « បងពិតជាស្កប់ចិត្តនឹងជោគវាសនារបស់បង ដោយដឹងថាបងត្រូវបានបង្ហាញថាគ្មានទោស ហើយបានធ្វើដោយអស់ពីចិត្តតាមដែលអាចធ្វើទៅបាន ។ សូមផ្ញើសេចក្ដីស្រឡាញ់របស់បង ទៅដល់កូនៗ និង មិត្តទាំងអស់របស់បងផង » ( នៅក្នុង *History of the Church* ៦:៦០៥ ) ។ ក្រោយមកនៅថ្ងៃដដែលនោះ ទោះជាមានការព្រមានថានឹងមានការវាយលុកចូលក្នុងគុក ហើយសម្លាប់អ្នកនៅក្នុងគុកទាំងអស់យ៉ាងណាក្ដី ក៏លោកអភិបាល ហ្វដ បានចាកចេញពីក្រុង កាតធេច ទៅនិយាយជាមួយនឹងប្រជាពលរដ្ឋនៅទីក្រុង ណៅវូ ដែរ ។ គាត់បានក្បត់ពាក្យសន្យា ហើយពុំបាននាំ យ៉ូសែប និង ហៃរុម ទៅជាមួយឡើយ ។ មុនពេលចាកចេញទៅ អភិបាល ហ្វដ បានដាក់ក្រុមទាហានកាតធេច–ជាពួកទាហានឃោរឃៅបំផុតបានប្រមូលផ្ដុំគ្នានៅទីក្រុងកាតធេច– មកទទួលបន្ទុកយាមគុក ហើយបានបណ្ដេញទាហានផ្សេងទៀតឲ្យត្រឡប់ទៅផ្ទះវិញ ។

នារសៀលដ៏ក្ដៅ និង ស្អុះស្អាប់ថ្ងៃទី ២៧ ខែ មិថុនា សាវក យ៉ូហាន ថេលើរ និង វិលឡឺឌ រិចឺត្ស បាននៅជាមួយ យ៉ូសែប និង ហៃរុម ក្នុងគុក កាតធេច ។ អារម្មណ៍នៃភាពអស់សង្ឃឹមបានគ្របដណ្ដប់លើព្យាការី និង អ្នកដែលមានវត្តមានជាមួយលោកនៅពេលពួកលោកអង្គុយនៅក្នុងបន្ទប់គុកនៅជាន់ទីពីរ ។ ព្យាការីបានបង្គាប់ឲ្យ យ៉ូហាន ថេលើរ ច្រៀងបទ « អ្នកធ្វើដំណើរដ៏ក្រតោកយ៉ាក » ( សូមមើល *ទំនុកតម្កើង* លេខ ១៧ ) ។ បើសិនជាអ្នកមានទំនុកតម្កើងនេះ ( ឬបើអ្នកអាចចូលទៅ lds.org/music/text/hymns/a–poor–wayfaring–man–of–grief ) សូមស្ដាប់ ច្រៀង ឬ អានទំនុកបទ រួចគិតអំពីមូលហេតុដែលទំនុកតម្កើងនេះ មានអត្ថន័យជ្រាលជ្រៅចំពោះព្យាការីនៅគ្រានោះក្នុងជីវិតរបស់លោក ។

សូមព្យាយាមស្រមៃក្នុងចិត្ត អំពីព្រឹត្តិការណ៍នានាដូចខាងក្រោមថាអ្នកបានមានវត្តមានជាមួយព្យាការី យ៉ូសែប ស្ម៊ីធ នៅក្នុងគុក កាតធេច ៖

មិនយូរប៉ុន្មានប្រហែលម៉ោង ៥:០០ រសៀល នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៨៤៤ ក្រុមមនុស្សកំណាចប្រមាណ ១៥០–២០០ នាក់ ដែលលាបមុខខ្មៅមិនឲ្យស្គាល់អត្តសញ្ញាណ បានមកឡោមព័ទ្ធគុក ។ អ្នកយាមគុកបានទប់ទល់បន្តិចស្រាប់តែមនុស្សកំណាចបីបួននាក់ បានប្រញាប់ប្រញាល់ឡើងទៅជាន់លើដល់បន្ទប់ដែលព្យាការី បងប្រុសរបស់លោក និង មិត្តភក្តិរបស់លោកបានស្នាក់នៅ ។


បន្ទប់ដេករបស់ពិរុទ្ធជនក្នុងគុក កាតធេច ជាកន្លែងដែលក្រុមមនុស្សកំណាចបានវាយប្រហារលើព្យាការី បងប្រុសរបស់លោក ហៃរុម, យ៉ូហាន ថេលើរ និង វិលឡឺឌ រិចឺត្យ

យ៉ូសែប និង អ្នកឯទៀតក្នុងបន្ទប់បានរុញទ្វារទល់មិនឲ្យក្រុមមនុស្សកំណាចចូលមកបាន ។ មានម្នាក់ក្នុងក្រុមមនុស្សកំណាចបានបាញ់កាំភ្លើងទៅផ្នែកខាងលើនៃទ្វារ ដោយបានទម្លុះច្រមុះរបស់ហៃរុមផ្នែកខាងឆ្វេង ។ គាត់បានដួលផ្ងារក្រោយ ដោយបានស្រែកថា « ខ្ញុំស្លាប់ហើយ ! » ( នៅក្នុង *History of the Church* ៦:៦១៧ ) ។ ក្រោយមក យ៉ូហាន ថេលើរ បានសរសេរថា « ខ្ញុំនឹងមិនអាចបំភ្លេចអារម្មណ៍អាណិតអាសូរ និង សេចក្ដីគោរពដ៏ជ្រាលជ្រៅដែលបានបង្ហាញឲ្យឃើញនៅលើទឹកមុខរបស់បងប្រុស យ៉ូសែប ស្ម៊ីធ នៅពេលលោកបានរត់ទៅរកហៃរុម ហើយបានទ្រោបទៅលើគាត់ ដោយស្រែកថា ‹ ឱ បងប្រុស ហៃរុម ដ៏គួរឲ្យអាណិតអើយ ! » ( នៅក្នុង B. H. Roberts, *The Rise and Fall of Nauvoo* [ ឆ្នាំ ១៩៦៥ ] ទំព័រ ៤៤៣ ) ។

ពីមុនព្រឹត្តិការណ៍កើតឡើងនៅថ្ងៃនោះ មានអ្នកមកសួរសុខទុក្ខម្នាក់បានឲ្យកាំភ្លើងខ្លីមួយដើមដល់យ៉ូសែប ។ ដោយដើរតួជាអ្នកការពារដល់មនុស្សគ្រប់រូបនៅក្នុងបន្ទប់ យ៉ូសែប បានរត់ទៅមាត់ទ្វារ ហើយឈោងទៅតោងគ្រោងទ្វារដើម្បីបាញ់តបទៅក្រៅ ។ មានតែបីគ្រាប់ប៉ុណ្ណោះក្នុងចំណោមប្រាំមួយគ្រាប់ ដែលបានធ្វើឲ្យមនុស្សបីនាក់នៃពួកមនុស្សកំណាចរងរបួស ។ រំពេចនោះ ពួកមនុស្សកំណាចបានរុញកាំភ្លើងរបស់គេទម្លុះចូលពាក់កណ្ដាលទ្វារដែលបិទ ហើយ យ៉ូហាន ថេលើរ បានព្យាយាមវាយកាណុងកាំភ្លើងរបស់ពួកគេនឹងឈើច្រត់ឲ្យដកថយវិញ ។

នៅពេលចលាចលនៅឯទ្វារនោះមានកាន់តែខ្លាំងឡើង នោះយ៉ូហាន ថេលើរ បានព្យាយាមរត់គេចពីបន្ទប់តាមបង្អួច ។ នៅពេលលោកចង់លោតចេញពីបង្អួច លោកត្រូវគេបាញ់ចំភ្លៅ មកពីមាត់ទ្វារ ហើយក៏ត្រូវគេបាញ់មកពីខាងក្រៅផងដែរ ។ លោកបានដួលទៅលើកម្រាលឥដ្ឋ ហើយខណៈដែលខំវារទៅក្រោមគ្រែក្បែរបង្អួចនោះ លោកត្រូវគេបាញ់របួសបីគ្រាប់យ៉ាងដំណំ ។ នៅពេលតែមួយនោះ វិលឡឺឌ រិចឺត្យ បានចាប់ផ្ដើមវាយកាំភ្លើងដែលរុញមកតាមច្រកទ្វារដោយដំបងរបស់គាត់ ។

ក្រោយមក យ៉ូសែប ស្ម៊ីធ បានសម្រេចចិត្តសាកល្បងរត់ចេញតាមបង្អួច ជាការសម្រេចចិត្តដែល វិលឡឺឌ រិចឺត្យ បានជឿថានឹងជួយលោក ថែមទាំង យ៉ូហាន ថេលើរ ឲ្យបានរួចជីវិត ។ នៅពេល វិលឡឺឌ រិចឺត្យ បានបន្តវាយត្រឡប់ទៅពួកមនុស្សកំណាចនៅឯមាត់ទ្វារ នោះព្យាការីបានទៅឯបង្អួចដែលបើកចំហរ ហើយបានស្រែក ៖ « ឱព្រះអម្ចាស់ដ៏ជាព្រះខ្ញុំអើយ ! » ( នៅក្នុង *History of the Church* ៦:៦១៨ ) ។ នៅពេលលោកធ្វើដូចនោះ ស្រាប់តែមានគ្រាប់កាំភ្លើងបាញ់ចេញមកពីក្នុងគុកផង និងមកពីក្រៅគុកផងបាញ់ចំព្យាការី ហើយលោកបានធ្លាក់ពីបង្អួចទៅលើដីជាន់ខាងក្រោម ។ ពួកមនុស្សកំណាចដែលនៅខាងក្នុងគុក បានរត់ចេញទៅក្រៅមើលដើម្បីបញ្ជាក់ឲ្យច្បាស់ថា យ៉ូសែប បានស្លាប់មែន ។ ទោះបីជាគ្មានសមាជិកណាម្នាក់នៃសាសនាចក្រនៅក្បែរនោះយ៉ាងណាក្ដី ក៏មានមនុស្សម្នាក់បានស្រែកឡើងថា « ពួកមរមនមកហើយ ! » ហើយហ្វូងមនុស្សកំណាចទាំងមូលក៏រត់គេចចេញអស់ទៅ ។ ( សូមមើល *History of the Church* ៦:៦១៨, ៦២០–២១ សូមមើលផងដែរ *Church History in the Fulness of Times Student Manual* ២៨៣) ។

### *ការប្រើប្រាស់តន្ត្រី នៅពេលអ្នកសិក្សាដំណឹងល្អ*

ទំនុកតម្កើងរបស់សាសនាចក្រ អាចដើរតួយ៉ាងសំខាន់មួយ ក្នុងការជួយយើងឲ្យទទួលអារម្មណ៍ដឹងអំពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងបទពិសោធន៍របស់យើងនៃការរៀនសូត្រអំពីដំណឹងល្អ ។ ការស្ដាប់ ការច្រៀង ឬ ការអានទំនុកបទទំនុកតម្កើង ដែលទាក់ទងចំៗទៅនឹងអ្វីដែលត្រូវបានបង្រៀននៅក្នុងបទគម្ពីរ អាចជួយយើងរំឭកឡើងវិញអំពីគោលការណ៍ទាំងឡាយនៃដំណឹងល្អ ហើយពិចារណាអំពីចំណេះដឹងដែលមានបន្ថែមទៀត ។

៣. សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:៣ ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមកត់ត្រាគំនិត ឬ អារម្មណ៍នានា ដែលអ្នកមានបន្ទាប់ពីបានអានដំណើររឿងនៃទុក្ករកម្មរបស់ យ៉ូសែប និង ហៃរុម ស្ម៊ីធ ។


បង្អួចដែលព្យាការី យ៉ូសែប ស្ម៊ីធ បានធ្លាក់ចុះមក

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:២ រួចកត់ចំណាំការពិពណ៌នាអំពីជោគវាសនារបស់ យ៉ូហាន ថេលើរ និង វិលឡឺឌ រិចឺត្ស ។

គ្រាប់កាំភ្លើងបានគ្រាន់តែប្លោងមកក្បែរត្រចៀកឆ្វេងរបស់ វិលឡឺឌ រិចឺត្ស ប៉ុណ្ណោះ ដែលបានបំពេញតាមការព្យាករណ៍ ដែល យ៉ូសែប បានព្យាករកាលពីមួយជាងមួយឆ្នាំមុនថា « គ្រានោះនឹងមកដល់ កាលគ្រាប់កាំភ្លើងនឹងហោះជុំវិញខ្លួនគាត់ដូចជាខ្យល់ព្យុះ ហើយគាត់នឹងឃើញមិត្តរបស់គាត់ដួលចុះពាសពេញ ប៉ុន្តែ នឹងពុំមានប្រហោងនៅក្នុងអាវគាត់ឡើយ » ( នៅក្នុង *History of the Church* ៦:៦១៩ ) ។

សូមកត់ចំណាំឃ្លា « ដើម្បីបិទទីបន្ទាល់អំពីព្រះគម្ពីរនេះ និង ព្រះគម្ពីរមរមន » នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:១ ។ នៅក្នុងបរិបទនេះ ឃ្លា « បិទ » គឺបង្កើតជាអ្វីមួយនៅជាអចិន្ត្រៃយ៍ដូចជា ទីបន្ទាល់មួយជាដើម ។ សូមគិតសរសេរអំពីការពន្យល់នេះ ដាក់ក្នុងព្រះគម្ពីររបស់អ្នក ។ អ្នកក៏អាចនឹងចង់កត់ចំណាំពាក្យ *ទុក្ករកម្ម* នៅក្នុង ខទី ១ ដែរ ។ ទុក្ករបុគ្គលគឺជាបុគ្គលដែលរងទុក្ខដល់ស្លាប់ ដោយឈរជាសាក្សីចំពោះសេចក្ដីពិតនៃជំនឿ ឬ បុព្វហេតុរបស់ខ្លួន ។ ពាក្យ *ទុក្ករបុគ្គល* ចេញ « មកពីពាក្យភាសាក្រិក ដែលមានន័យថា ‹ សាក្សី › » ( Bible Dictionary, « Martyr » ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥:៧ ដោយស្វែងរកថាតើទុក្ករកម្មរបស់ព្យាការី យ៉ូសែប និង ហៃរុម ស្ម៊ីធ បានធ្វើសាក្សីចំពោះអ្វីខ្លះ ។


រូបសំណាក យ៉ូសែប និង ហៃរុម ស្ម៊ីធ នៅទីក្រុង ណៅវូ រដ្ឋ អិលលីណោយ

៤. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការដឹងថា **យ៉ូសែប និង ហៃរុម ស្ម៊ីធ បានបិទទីបន្ទាល់របស់ពួកលោក អំពីភាពពោរពេញនៃដំណឹងល្អដែលបានស្ដារឡើងវិញដោយប្រើជីវិតរបស់ខ្លួន** អាចមានឥទ្ធិពលលើទីបន្ទាល់របស់អ្នកអំពីដំណឹងល្អយ៉ាងដូចម្ដេច ?

៥. សូមសរសេរអ្វីដែលនៅខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៥ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៣០ ៖ ថ្ងៃទី ១

# ការស្នងតំណែងនៅក្នុងគណៈប្រធានទីមួយ

## បុព្វកថា

បន្ទាប់ពីទុក្ករកម្មរបស់ព្យាការី យ៉ូសែប ស្ម៊ីធ នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៨៤៤ មនុស្សជាច្រើនបានច្របូកច្របល់អំពីអ្នកដែលនឹងដឹកនាំ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ប៉ុន្តែពីមុនលោកបានទទួលមរណភាពទៅ ព្យាការីបានរៀបចំការផ្ទេរភាពជាអ្នកដឹកនាំនេះ ដោយការប្រគល់កូនសោ និង អំណាចនៃបព្វជិតភាពទាំងអស់ទៅឲ្យកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។

នៅពេល ព្រិកហាំ យ៉ង់ ដែលជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានថ្លែងទៅកាន់ពួកបរិសុទ្ធនៅថ្ងៃទី ៨ ខែសីហា ឆ្នាំ ១៨៤៤ មានសមាជិកសាសនាចក្រជាច្រើនបានទទួលសាក្សីខាងវិញ្ញាណមួយថា លោកត្រូវបានហៅ និង រៀបចំដោយព្រះដើម្បីដឹកនាំសាសនាចក្រ ។

| ពេលវេលាដ៏ត្រឹមត្រូវក្នុងការស្នងតំណែងនៅក្នុងគណៈប្រធានទីមួយ បន្ទាប់ពីទុក្ករកម្មរបស់ យ៉ូសែប ស្ម៊ីធ | |
|---|---|
| **កាលបរិច្ឆេទ** | **ព្រឹត្តិការណ៍** |
| ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៨៤៤ | យ៉ូសែប និង ហៃរុម ស្ម៊ីធ ត្រូវបានគេធ្វើទុក្ករកម្មនៅក្រុង កាតធេច រដ្ឋ អិលលីណោយ ។ |
| ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៨៤៤ | ពិធីបើកមុខសាកសពជាសាធារណៈរបស់ យ៉ូសែប និង ហៃរុម ស្ម៊ីធ ។ |
| ពីថ្ងៃទី ២៧ ខែ មិថុនា ដល់ ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ១៨៤៤ | វិលឡឺដ រិចឆឺត្ស និង យ៉ូហាន ថេល័រ ដែលរងរបួស គឺជាសាវកតែពីរនាក់គត់នៅទីក្រុង ណៅវូ រដ្ឋ អិលលីណោយ ។ |
| ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៨៤៤ | ប៉ាលី ភី ប្រាត្ត ត្រឡប់ទៅទីក្រុង ណៅវូ វិញ ហើយបានជួយ វិលឡឺដ រិចឆឺត្ស និង យ៉ូហាន ថេល័រ រក្សារបៀបរៀបរយនៅក្នុងសាសនាចក្រ ។ |
| ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៨៤៤ | ស៊ីឌនី រិកដុន បានទៅដល់ទីក្រុង ណៅវូ ពីទីក្រុង ភិតស្ប៊ឺក រដ្ឋ ផែនស៊ីលវេញ៉ា ។ |
| ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ១៨៤៤ | ស៊ីឌនី រិកដុន បានប្រាប់ដល់ពួកបរិសុទ្ធមួយក្រុមថា គាត់គួរតែធ្វើការជាអាណាព្យាបាលរបស់សាសនាចក្រ ហើយចង់មានការប្រជុំពិសេសមួយត្រូវធ្វើឡើងនៅថ្ងៃទី ៦ ខែ សីហា ដើម្បីអនុមតិដល់ការតែងតាំងរបស់គាត់ ។ ការប្រជុំត្រូវបានធ្វើឡើងនៅថ្ងៃព្រហស្បតិ៍ ទី ៨ ខែ សីហា ។ |
| ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៨៤៤ | ពួកសាវកផ្សេងទៀតភាគច្រើនព្រមទាំង ព្រិកហាំ យ៉ង់ បានត្រឡប់មកទីក្រុង ណៅវូ ពីបេសកកម្មរបស់ខ្លួន ។ |
| ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៨៤៤ | លុះព្រឹកឡើង ពួកសាវកបានជួបជុំគ្នានៅក្នុងផ្ទះរបស់ យ៉ូហាន ថេល័រ ដែលរងរបួសនោះ ។<br>ក្នុងការប្រជុំពេលល្ងាចមួយរបស់ពួកសាវក ក្រុមប្រឹក្សាជាន់ខ្ពស់ និង សង្ឃជាន់ខ្ពស់ នោះ ស៊ីឌនី រិកដុន បានអះអាងជាថ្មីទៀតថា គាត់គួរតែធ្វើជាអាណាព្យាបាលរបស់សាសនាចក្រ ។ ព្រិកហាំ យ៉ង់ បានថ្លែងថា គាត់កាន់កូនសោទាំងឡាយ ហើយចង់ធ្វើតាមព្រះហឫទ័យរបស់ព្រះអម្ចាស់នៅក្នុងកិច្ចការដ៏សំខាន់នេះ ។ |

| ពេលវេលាដ៏ត្រឹមត្រូវក្នុងការស្នងតំណែងនៅក្នុងគណៈប្រធានទីមួយ បន្ទាប់ពីទុក្ករកម្មរបស់ យ៉ូសែប ស្ម៊ីធ | |
|---|---|
| កាលបរិច្ឆេទ | ព្រឹត្តិការណ៍ |
| ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៨៤៤ | អំឡុងការប្រជុំវេលាម៉ោង ១០ ព្រឹក ស៊ីឌនី រិកដុន បានថ្លែងរយៈពេលមួយម៉ោងកន្លះ ទៅកាន់ពួកបរិសុទ្ធរាប់ពាន់នាក់ ដែលកំពុងជួបជុំគ្នា ដោយពន្យល់អំពីមូលហេតុដែលគាត់គួរតែធ្វើជាអាណាព្យាបាលរបស់សាសនាចក្រ ។ ព្រិកហាំ យ៉ង់ ក៏បានថ្លែងផងដែរ ហើយបានហៅពួកបរិសុទ្ធមកជួបជុំគ្នាម្ដងទៀត ដើម្បីធ្វើការប្រជុំនៅម៉ោង ២ រសៀល ។<br>ពេញមួយថ្ងៃ មានសមាជិកជាច្រើននៃសាសនាចក្រ បានឃើញការគ្របបាំង ឬ សិទ្ធិអំណាចរបស់ព្យាការី យ៉ូសែប ស្ម៊ីធ មកលើ ព្រិកហាំ យ៉ង់ ។ អំឡុងការប្រជុំវេលាម៉ោង ២ រសៀលនោះ ពួកបរិសុទ្ធបានគាំទ្រ ព្រិកហាំ យ៉ង់ និង ពួកសាវកដប់ពីរនាក់ ឲ្យធ្វើជាអ្នកដឹកនាំសាសនាចក្រ ។<br>អំឡុងការប្រជុំទាំងពីរលើកនោះ ពួកបរិសុទ្ធជាច្រើនបានឃើញ ព្រិកហាំ យ៉ង់ បង្ហាញរូបរាង និងសំឡេងមួយភ្លែតដូចជាព្យាការី យ៉ូសែប ស្ម៊ីធ ដូច្នោះដែរ ។ |

## បន្ទាប់ពីទុក្ករកម្មរបស់ យ៉ូសែប និង ហៃរ៉ុម ស្ម៊ីធ សមាជិកមួយចំនួនបានអះអាងអំពីសិទ្ធិរបស់ខ្លួនដើម្បីដឹកនាំសាសនាចក្រ

សូមស្រមៃថា អ្នកបានដឹងថាប្រធាននៃសាសនាចក្រ បានទទួលមរណភាពកាលពីយប់មិញ ។ តើនរណានឹងក្លាយទៅជាប្រធាននៃសាសនាចក្របន្ទាប់នោះ ? តើលោកនឹងត្រូវបានជ្រើសតាំងយ៉ាងដូចម្ដេច ? តើកូនសោបព្វជិតភាពដើម្បីធ្វើអធិបតីលើសាសនាចក្រ ត្រូវបានប្រគល់ទៅឲ្យប្រធាននៃសាសនាចក្របន្ទាប់មកទៀតតាមរបៀបណា ?

បន្ទាប់ពីព្យាការី យ៉ូសែប ស្ម៊ីធ ត្រូវបានគេធ្វើទុក្ករកម្ម ពួកបរិសុទ្ធបានកើតទុក្ខជាទម្ងន់ ហើយសមាជិកជាច្រើននៃសាសនាចក្របានច្របូកច្របល់អំពីអ្នកដែលនឹងដឹកនាំសាសនាចក្រ ។ អំឡុងពេលនេះ មានសមាជិកជាច្រើនអះអាងអំពីសិទ្ធិរបស់ខ្លួនដើម្បីដឹកនាំសាសនាចក្រ ។ ក្នុងចំណោមពួកគាត់មាន ស៊ីឌនី រិកដុន ជេម ស្ត្រាង និង ព្រិកហាំ យ៉ង់ ។

នៅពេលអ្នកអានកថាខណ្ឌខាងក្រោមនេះ សូមស្វែងរកមូលហេតុដែល ស៊ីឌនី រិកដុន ដែលបានធ្វើជាអ្នកដឹកនាំដ៏សំខាន់មួយរូបនៅក្នុងសាសនាចក្រអស់រយៈពេលជាច្រើនឆ្នាំមកហើយនោះ បានគិតថា គាត់គួរតែដឹកនាំសាសនាចក្រ ៖

« ស៊ីឌនី រិកដុន ជាទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ បានមកដល់ [ ទីក្រុង ណៅវូ ] ពីទីក្រុង ភិតស្បឺក រដ្ឋផែនស៊ីលវេញ៉ា នៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៨៤៤ ។ នៅក្នុងឆ្នាំមុននេះ គាត់បានចាប់ផ្ដើមដើរលើផ្លូវផ្សេងពីដំបូន្មានរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ហើយបានក្លាយទៅជា [ ឃ្លាតឆ្ងាយ ] ពីសាសនាចក្រ ។ គាត់បានបដិសេធមិនជួបជាមួយសមាជិកបីរូបនៃពួកដប់ពីរនាក់រួចទៅហើយ កាលនៅទីក្រុង ណៅវូ ហើយជំនួសឲ្យការមកជួបនោះ គាត់បែរជាទៅថ្លែងទៅកាន់ពួកបរិសុទ្ធមួយក្រុមធំ ដែលមកជួបជុំគ្នាថ្វាយបង្គំនៅថ្ងៃអាទិត្យ » ( *គេហដំណើររបស់យើង ៖ ប្រវត្តិសង្ខេបរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ* [ ឆ្នាំ ១៩៩៦ ] ទំព័រ ៦៦ ) ។

ស៊ីឌនី រិកដុន បានកោះឲ្យមានការប្រជុំជាពិសេសមួយនៅថ្ងៃអង្គារ ទី ៦ ខែ សីហា ដើម្បីឲ្យសមាជិកសាសនាចក្រអាចជ្រើសតាំងអាណាព្យាបាលនៃសាសនាចក្រម្នាក់ ។ មើលទៅហាក់ដូចជាគាត់បានព្យាយាមដឹកនាំការប្រជុំនេះ ដើម្បីឲ្យសមាជិកសាសនាចក្រអនុមតិឲ្យគាត់មានតំណែងជាអាណាព្យាបាលនៃសាសនាចក្រ មុនពេលពួកសាវកដប់ពីរនាក់ទាំងអស់ ត្រឡប់មកពីបេសកកម្មរបស់ខ្លួនវិញពីភាគខាងកើតនៃសហរដ្ឋ ។ អ្នកដឹកនាំសាសនាចក្រមួយចំនួនបានដឹងថា បងប្រុស រិកដុន អាចនឹងគ្រោង « ឆ្លៀតយកឱកាសពីស្ថានភាពរបស់ពួកបរិសុទ្ធ » ( *History of the Church* ៧:២២៥ ) ។ សំណាងល្អ ដោយសារតែមានការខិតខំរបស់អែលឌើរ វិលឡឺឌ រិចឆើត និង អែលឌើរ ប៉ាលី ភី ប្រាត្ត ការប្រជុំនោះត្រូវលើកទៅថ្ងៃ ព្រហស្បតិ៍ ទី ៨ ខែ សីហា ដែលជាពេលដែលពួកសាវកភាគច្រើនបានត្រឡប់មកដល់ទីក្រុង ណៅវូ វិញ ។

បងប្រុស រិកដុន បានអះអាងថា ដោយសារគាត់ត្រូវបានហៅ និង តែងតាំងជាអ្នកនាំពាក្យរបស់ យ៉ូសែប ស្ម៊ីធ ពីមុនមក នោះវាជាទំនួលខុសត្រូវរបស់គាត់ដើម្បី « ដឹងថា សាសនាចក្រនេះត្រូវបានដឹកនាំតាមរបៀបត្រឹមត្រូវដែរឬទេ » ( នៅក្នុង *History of the Church* ៧:២២៩ ) ។ គាត់ក៏បានអះអាងដែរថា គាត់គួរតែធ្វើជា « អាណាព្យាបាលនៃប្រជាជននេះ » ហើយនៅក្នុងការបំពេញទំនួលខុសត្រូវនេះ នោះគាត់កំពុងធ្វើតាមអ្វីដែលព្រះបានត្រាស់បង្គាប់ឲ្យគាត់ធ្វើ ( សូមមើល *History of the Church* ៧:២៣០ ) ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. បើអ្នកបានទៅទីក្រុង ណៅវូ ក្នុងគ្រានោះ តើអ្នកនឹងគិតដូចម្ដេចចំពោះការអះអាងរបស់ ស៊ីឌនី រិកដុន ?

ខ. តើអ្នកអាចនឹងមានការបារម្ភអ្វីខ្លះអំពីបងប្រុស រិកដុន ?


ស៊ីឌនី រិកដុន

នៅពេលអ្នកអានកថាខណ្ឌខាងក្រោមនេះ សូមស្វែងរកមូលហេតុដែល ជេម ស្ត្រាង បានអះអាងថាគាត់គួរតែដឹកនាំសាសនាចក្រ ៖

ជេម ស្ត្រាង ដែលបានទទួលបុណ្យជ្រមុជទឹកនៅខែ កុម្ភៈ ឆ្នាំ ១៨៤៤ បានរកឃើញទីតាំងមួយ សម្រាប់ពួកបរិសុទ្ធនៅវីស្កុនស៊ីន ក្នុងនិទារយរដូវ ឆ្នាំ ១៨៤៤ ។ បន្ទាប់ពីទុក្ករកម្ម បងប្រុស ជេម ស្ត្រាង បានអះអាងថា បានទទួលវិវរណៈមួយនៅក្នុងសំបុត្រមកពី យ៉ូសែប ស៊្មីធ ដោយថ្លែងថា គាត់ត្រូវបានតែងតាំងឲ្យធ្វើជាអ្នកស្នងតំណែងពី យ៉ូសែប ។ សំបុត្ររបស់បងប្រុស ជេម ស្ត្រាង ដែលគាត់បានបង្ហាញដល់សមាជិកសាសនាចក្រ មានហត្ថលេខារបស់ យ៉ូសែប ស៊្មីធ ។ បងប្រុស ជេម ស្ត្រាង បានអះអាងថាខ្លួនត្រូវធ្វើជាព្យាការីបន្ទាប់ ហើយបានប្រកាសតំណែងរបស់គាត់នៅក្នុងសន្និសីទមួយរបស់សាសនាចក្រនៅទីក្រុង មីឈីហ្គែន ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ១៨៤៤ ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. បើអ្នកបាននៅជាមួយនឹងពួកបរិសុទ្ធនៅទីក្រុង មីឈីហ្គែន តើអ្នកគិតថា អ្នកអាចនឹងជឿទៅលើសេចក្ដីអះអាងរបស់ ជេម ស្ត្រាង ដែរឬទេ ?

ខ. តើអ្នកអាចនឹងមានការបារម្ភអ្វីខ្លះ អំពីសេចក្ដីអះអាងរបស់គាត់ ?

នៅពេលអ្នកអានកថាខណ្ឌខាងក្រោមនេះ សូមស្វែងរកអ្វីដែល ព្រិកហាំ យ៉ង់ បានប្រាប់ដល់អ្នកដឹកនាំបព្វជិតភាពដទៃទៀត រួមទាំងសមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដែលនៅទីក្រុង ណៅវូ អំពីអ្នកដែលគួរតែដឹកនាំសាសនាចក្រ ៖

អែលឌើរ យ៉ូហាន ថេល័រ, វិលឡឺដ រីចឹត្ស , ប៉ាលី ភី ប្រាត្ត បាននៅទីក្រុង ណៅវូ ស្រាប់ នៅពេល ស៊ីឌនី រិកដុន បានមកដល់ ។ ពួកសាវកឯទៀតភាគច្រើនព្រមទាំង ព្រិកហាំ យ៉ង់ បានត្រឡប់មកដល់ទីក្រុង ណៅវូ វិញនាល្ងាចថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៨៤៤ ។ នៅថ្ងៃបន្ទាប់ គឺថ្ងៃទី ៧ ខែ សីហា ពួកសាវកបានជួបជុំក្នុងការប្រជុំក្រុមប្រឹក្សានៅផ្ទះរបស់ យ៉ូហាន ថេល័រ ។ វេលាបន្ទាប់មកទៀតនៅថ្ងៃដដែលនោះ ពួកសាវកដប់ពីរនាក់ ក្រុមប្រឹក្សាជាន់ខ្ពស់ និង ពួកសង្ឃជាន់ខ្ពស់បានជួបជុំគ្នានៅក្នុងការប្រជុំនាពេលរសៀលមួយនៅទីក្រុង ណៅវូ ។ ប្រធាន យ៉ង់ ដែលជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានសូមឲ្យ ស៊ីឌនី រិកដុន ថ្លែងសារលិខិតរបស់គាត់ទៅកាន់ពួកបរិសុទ្ធ ។ ស៊ីឌនី រិកដុន បានប្រកាសដោយអង់អាចថា លោកបានឃើញការនិមិត្តមួយ ហើយថាគ្មានបុរសណាអាចស្នងតំណែងពី យ៉ូសែប ស៊្មីធ ជាប្រធាននៃសាសនាចក្របានទេ ។ ភ្លាមនោះលោកបានស្នើថា លោកត្រូវបានតែងតាំងជាអាណាព្យាបាលនៃប្រជាជននេះ ។

ក្រោយពី ស៊ីឌនី រិកដុន បានបញ្ចប់សុន្ទរកថារបស់គាត់ ព្រិកហាំ យ៉ង់ បានមានប្រសាសន៍ ៖



« ខ្ញុំមិនខ្វល់ថានរណាដឹកនាំសាសនាចក្រនោះទេ . . . ប៉ុន្តែមានរឿងមួយដែលខ្ញុំត្រូវតែដឹង ហើយថា នោះជាអ្វីដែលព្រះមានបន្ទូលអំពីវា ។ ខ្ញុំមានកូនសោ និង មានវិធីជាច្រើនក្នុងការទទួលបានព្រះឆន្ទៈនៃព្រះលើការងារនេះ ។. . .

« យ៉ូសែប បានប្រគល់មកលើក្បាលយើង [ សំដៅទៅលើកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ] នូវកូនសោ និង អំណាចទាំងអស់ ដែលជារបស់ផងសាវក ដែលលោកផ្ទាល់បានកាន់ មុនពេលលោកលាចាកលោកនេះទៅ។. . .

« តើយ៉ូសែប បាននិយាយប៉ុន្មានដងដល់ពួកសាវកថា ‹ ខ្ញុំបានចាក់គ្រឹះហើយអ្នកត្រូវតែកសាងបន្ត ដ្បិតនៅលើស្មាអ្នកបានដាក់នគរនោះហើយ › » ( នៅក្នុង *History of the Church* ៧:២៣០ ) ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើបំណងប្រាថ្នារបស់ប្រធាន យ៉ង់ មើលទៅហាក់ដូចជាមានសភាពខុសពី ស៊ីឌនី រិកដុន និង ជេម ស្រ្ទាង យ៉ាងដូចម្ដេច ?

ខ. ហេតុអ្វីបានជាទីបន្ទាល់របស់ ព្រិកហាំ យ៉ង់ អំពីកូនសោនៃបព្វជិតភាព មានសារៈសំខាន់ដល់ម្ល៉េះ ?

ប្រធាន ព្រិកហាំ យ៉ង់ និង សមាជិកដទៃទៀតក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនអំពីសេចក្ដីពិតដូចតទៅនេះ ៖ **ពួកសាវកកាន់កូនសោទាំងឡាយនៃបព្វជិតភាព ដែលចាំបាច់ចំពោះការធ្វើអធិបតីលើសាសនាចក្រ ។**

អំណាច និង កូនសោទាំងឡាយនៃបព្វជិតភាពដដែលនោះ ត្រូវបានកាន់ដោយពួកសាវកនាពេលបច្ចុប្បន្ននេះ ។ នៅពេលសាវកមួយរូបត្រូវបានតែងតាំង នោះគាត់ទទួលបានរាល់កូនសោចាំបាច់ៗទាំងអស់នៃបព្វជិតភាពនៅលើផែនដីនេះ ( សូមមើល គ. និង ស. ១១២:៣០–៣២ ) ប៉ុន្តែសិទ្ធិអំណាចដើម្បីប្រើប្រាស់កូនសោទាំងនោះ ត្រូវបានកំណត់ចំពោះតែសាវករៀមច្បង ដែលជាប្រធាននៃសាសនាចក្រតែប៉ុណ្ណោះ ។

ក្នុងខែ មករា ឆ្នាំ ១៨៣៦ គឺជាងប្រាំបីឆ្នាំពីមុនលោកបានទទួលមរណភាព ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនដល់កូរ៉ុមនៃពួកសាវកដប់ពីរនាក់ថា « ពួកដប់ពីរនាក់ ពុំស្ថិតនៅក្រោមអ្នកផ្សេងក្រៅពី គណៈប្រធានទីមួយនោះឡើយ » រួចលោកបានមានប្រសាសន៍ថា. . .« ពេលណាដែលគ្មានខ្ញុំ នោះគ្មានគណៈប្រធានទីមួយ ធ្វើជាអធិបតីលើពួកដប់ពីរនាក់ឡើយ ( នៅក្នុង *History of the Church* ២:៣៧៤ ) ។

ដោយផ្អែកទៅលើការបង្រៀនមកពីព្យាការី យ៉ូសែប ស្ម៊ីធ តើមានអ្វីកើតឡើងចំពោះគណៈប្រធានទីមួយ នៅពេលប្រធាននៃសាសនាចក្រទទួលមរណភាព ?

តើនរណាដែលអាចដឹកនាំសាសនាចក្របាន នៅពេលគណៈប្រធានទីមួយត្រូវបានរំសាយ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៤:១២៧–២៨ ដោយស្វែងរកថាតើនរណាដែលជាសាវករៀមច្បង និង ជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នៅពេលដែល យ៉ូសែប ស្ម៊ីធ ទទួលមរណភាព ។

ព្រិកហាំ យ៉ង់ គឺជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ព្រោះគាត់គឺជាសាវករៀមច្បង ។ នៅពេលកូរ៉ុមត្រូវបានបង្កើតឡើងដំបូងក្នុងឆ្នាំ ១៨៣៥ នោះភាពជារៀមច្បង ត្រូវបានសម្រេចដោយផ្អែកទៅលើវ័យ ។ នៅពេលបន្ថែមសមាជិកក្នុងកូរ៉ុម ភាពជារៀមច្បងត្រូវបានកំណត់ដោយកាលបរិច្ឆេទនៃការតែងតាំង ។ ហេតុដូច្នោះហើយ ទើបនៅជំនាន់យើងនេះ ភាពជារៀមច្បងត្រូវបានកំណត់ដោយកាលបរិច្ឆេទ និង លំដាប់លំដោយដែលសាវកមួយរូបត្រូវបានតែងតាំង ។. **នៅពេលប្រធានសាសនាចក្រទទួលមរណភាព គណៈប្រធានទីមួយត្រូវបានរំលាយ ហើយកូរ៉ុមនៃពួកសាវកដប់ពីរនាក់ក្លាយជាកូរ៉ុមជាអធិបតីក្រោមការណែនាំរបស់សាវកច្បង ។**

ការស្នងតំណែងនៅក្នុងគណៈប្រធានទីមួយនៃសាសនាចក្រ ត្រូវបានបង្កើតឡើងដោយព្រះអម្ចាស់ ដើម្បីឲ្យសាសនាចក្រអាចមានការដឹកនាំដ៏បំផុសគំនិតជានិច្ច ហើយគ្មានហេតុផលណាដែលត្រូវមានពាក្យចចាមអារាម ឬ ការវិវាទអំពីអ្នកដែលនឹងក្លាយជាប្រធានបន្ទាប់នៃសាសនាចក្រនោះទេ ។ ប្រធាន ហារ៉ូល ប៊ី លី បានពន្យល់ ៖ « [ ព្រះអម្ចាស់ ] ជ្រាបអំពីអ្នកដែលទ្រង់សព្វព្រះទ័យឲ្យធ្វើអធិបតីលើសាសនាចក្រ ហើយទ្រង់នឹងពុំជ្រើសមនុស្សខុសឡើយ ។ ព្រះអម្ចាស់ពុំធ្វើកិច្ចការដោយចៃដន្យនោះទេ ។ ទ្រង់ពុំដែលធ្វើកិច្ចការណាមួយ ដោយចៃដន្យឡើយ » ( នៅក្នុង របាយការណ៍សន្និសីទ ខែ តុលា ឆ្នាំ ១៩៧០ ទំព័រ ១៥៣ ) ។

សរុបសេចក្តីមក កូនសោនៃព្រះនគរត្រូវបានប្រគល់ដល់សមាជិកគ្រប់រូបក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នៅពេលដែលពួកគាត់ត្រូវបានតែងតាំងឲ្យធ្វើជាសាវក ។ សាវករៀមច្បង ដែលធ្វើអធិបតីក្នុងចំណោមកូរ៉ុមនៃពួកដប់ពីរនាក់ ត្រូវបានកំណត់ដោយកាលបរិច្ឆេទ និង លំដាប់លំដោយនៃការតែងតាំងរបស់គាត់ ។ នៅពេលប្រធាននៃសាសនាចក្រទទួលមរណភាព កូរ៉ុមនៃគណៈប្រធានទីមួយត្រូវបានរំសាយ ចំណែកឯទីប្រឹក្សាទាំងពីររូប បើសិនជាពួកគាត់ធ្លាប់នៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់នោះពួកគាត់ត្រូវត្រឡប់ទៅកាន់តំណែងនៃភាពជារៀមច្បងរបស់ខ្លួននៅក្នុងកូរ៉ុមនោះវិញ ។ បន្ទាប់មក កូរ៉ុមនៃពួកសាវកដប់ពីរនាក់ក្លាយទៅជា កូរ៉ុមអធិបតីក្នុងការដឹកនាំសាសនាចក្រ ។ សាវករៀមច្បង ដែលជាប្រធាននៃពួកសាវកដប់ពីរនាក់ កាន់ហើយប្រើប្រាស់កូនសោទាំងអស់នៃនគរដោយស្វ័យប្រវត្តិ ហើយធ្វើអធិបតីលើសាសនាចក្រទាំងមូល ។ ក្នុងនាមជាអ្នកកាន់តំណែងជាអធិបតីនៃសាសនាចក្រ ប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ មានសិទ្ធិទទួលបានវិវរណៈអំពីវេលាដែលត្រូវបង្កើតគណៈប្រធានទីមួយ ។ អ្វីសព្វសារពើនៅក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ ត្រូវបានធ្វើឡើងដោយប្រាជ្ញា និង របៀបរៀបរយ ។

## ពួកបរិសុទ្ធជាច្រើន បានទទួលសាក្សីមួយថា ព្រិកហាំ យ៉ង់ គួរតែដឹកនាំសាសនាចក្រ

នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៨៤៤ ពួកបរិសុទ្ធនៅទីក្រុង ណៅវូ រដ្ឋ អិលលីណោយ បានប្រជុំគ្នានៅម៉ោង ១០ ព្រឹក ដើម្បីស្តាប់ ស៊ីឌនី រិកដុន ធ្វើការអះអាងថាខ្លួនជាអាណាព្យាបាលនៃសាសនាចក្រ ។ ដោយសារតែខ្យល់បានបោកបក់ទៅចំវេទិកា ទើបបងប្រុស រិកដុន បានទៅឈរត្រង់កន្លែងរទេះសេះមួយ ពីខាងក្រោយក្រុមជំនុំដែលបានជួបជុំគ្នា ដូច្នេះ ប្រជាជនពុំអាចឮសំឡេងរបស់គាត់បានច្បាស់ឡើយ ។ ក្រុមជំនុំត្រូវបែរក្រោយ ទើបពួកគេអាចមើលឃើញបងប្រុស រិកដុន នៅពេលគាត់ថ្លែងនោះ ។ គាត់បានថ្លែងទៅកាន់ពួកបរិសុទ្ធដែលមកប្រជុំរាប់ពាន់នាក់អស់រយៈពេលមួយម៉ោងកន្លះ ដោយបកស្រាយអំពីមូលហេតុដែលគាត់គួរតែធ្វើជាអាណាព្យាបាលនៃសាសនាចក្រ ។ មនុស្សបីបួននាក់បាននិយាយថា សុន្ទរកថារបស់គាត់មិនមែនជាការបំផុសគំនិតនោះទេ ។

ប្រធាន ព្រិកហាំ យ៉ង់ និង អ្នកដឹកនាំសាសនាចក្រដទៃទៀត បានមកចូលរួម ហើយអង្គុយនៅលើវេទិកាប្រទល់មុខនឹង ស៊ីឌនី រិកដុន ដែលកំពុងតែថ្លែងនោះ ។ ខ្យល់បានស្ងប់ទៅវិញចំពេលនេះ ។ បន្ទាប់ពី ស៊ីឌនី រិកដុនបានបញ្ចប់ ប្រធាន ព្រិកហាំ យ៉ង់ បានមានប្រសាសន៍ ។ អ្នកស្តាប់ទាំងឡាយបានងាកត្រឡប់មកស្តាប់ ព្រិកហាំ យ៉ង់ មានប្រសាសន៍ ហើយបែរខ្នងទៅរទេះសេះដែលស៊ីនឌី រិកដុន ឈរនោះវិញ ។ ( សូមមើល «Discourse by President Geo. Q. Cannon » *Deseret News* ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៨៨៣ ទំព័រ ៦៧ ) ។ ប្រធាន យ៉ង់ បានមានប្រសាសន៍ដោយសង្ខេប ហើយបានថ្លែងថា លោកចង់ត្រឡប់មកទីក្រុង ណៅវូ ដើម្បីចូលរួមកាន់ទុក្ខដល់ព្យាការី ខ្លាំងជាងមកតែងតាំងអ្នកដឹកនាំថ្មី ។ លោកបានប្រកាសថា ការជួបប្រជុំថ្នាក់ដឹកនាំ និងសមាជិកសាសនាចក្រនឹងធ្វើឡើងពេលក្រោយនៅថ្ងៃនោះនៅម៉ោង ២ រសៀល ។ នៅពេលលោកនិយាយ សមាជិកមួយចំនួនបានឃើញទឹកមុខរបស់ ព្រិក ហាំ យ៉ង់ និងសំឡេងរបស់លោកផ្លាស់ប្តូរដូចជាព្យាការី យ៉ូសែប ស្ម៊ីធ ។ ព្រឹត្តការណ៍ដ៏អស្ចារ្យនេះ បានជួយឲ្យពួកបរិសុទ្ធជាច្រើនបានដឹងថា ព្រះអម្ចាស់សព្វព្រះទ័យឲ្យ ព្រិកហាំ យ៉ង់ ដឹកនាំសាសនាចក្រ ។

នៅពេលអ្នកអានបទពិសោធន៍ខាងក្រោមនេះ សូមស្វែងរករបៀបដែលព្រះអម្ចាស់បានប្រទានពរដល់ពួកបរិសុទ្ធ ឲ្យដឹងថានរណាដែលទ្រង់បានតែងតាំងឲ្យដឹកនាំសាសនាចក្រ ។ វាក្យសព្ទ « ការគ្របបាំង » សំដៅទៅលើសិទ្ធិអំណាច ផ្តល់បន្តពីព្យាការី និង ប្រធាននៃសាសនាចក្រ ( យ៉ូសែប ស្ម៊ីធ ) ទៅដល់អ្នកស្នងតំណែងរបស់លោក ( ព្រិកហាំ យ៉ង់ ) ។



បេនយ៉ាមីន អេហ្វ ចនសុន នៅចាំថា « ប្រធាន ព្រិកហាំ យ៉ង់ បានក្រោកឈរឡើង ហើយថ្លែង ។ ខ្ញុំបានឃើញគាត់ក្រោកឈរឡើង ប៉ុន្តែ រំពេចដែលលោកបានមានប្រសាសន៍ភ្លាម នោះខ្ញុំបានក្រោកឈរឡើង ដ្បិតវាគឺជាសំឡេងរបស់ យ៉ូសែប គ្រប់ម៉ាត់ ហើយរាយកាយលោកផ្ទាល់ ទាំងអាកប្បកិរិយា សម្លៀកបំពាក់ និង រូបរាង គឺដូចជា យ៉ូសែប ផ្ទាល់នៅរស់រវើក ហើយខ្ញុំដឹងរំពេចនោះថាវិញ្ញាណ និង ការគ្របបាំងរបស់ យ៉ូសែប បានមកគ្របដណ្ដប់លើរូបលោក » ( *My Life's Review* [ ឆ្នាំ ១៩៤៧ ] ទំព័រ ១០៣–៤ ) ។

វិលលាម សី ស្ដេន បានពិពណ៌នាថា ព្រិកហាំ យ៉ង់ នៅពេលកំពុងតែនិយាយ « សំឡេងគាត់គឺដូចជាសំឡេងរបស់ព្យាការី យ៉ូសែប ។ ខ្ញុំបានគិតនោះគឺ យ៉ូសែប ហើយមានមនុស្សរាប់ពាន់បានស្ដាប់ឮដូចគ្នានេះដែរ » ( នៅក្នុង *History of the Church* ៧:២៣៦ ) ។



វិលហ្វូឌ វូឌដ្រុព្វ បានសរសេរថា « បើខ្ញុំពុំធ្លាប់បានឃើញ ព្រិកហាំ យ៉ង់ ដោយផ្ទាល់ភ្នែករបស់ខ្ញុំទេ នោះគ្មាននរណាម្នាក់ ដែលអាចមកបញ្ចុះបញ្ចូលខ្ញុំឲ្យជឿថាអ្នកដែលឡើងនិយាយនោះពុំមែនជា យ៉ូសែប ស្ម៊ីធ នោះឡើយ ហើយមនុស្សគ្រប់រូបដែលបានស្គាល់បុរសទាំងពីររូបនេះ អាចថ្លែងទីបន្ទាល់ចំពោះព្រឹត្តិការណ៍នេះបាន ( នៅក្នុង *History of the Church* ៧:២៣៦ ) ។

ប្រធាន ព្រិកហាំ យ៉ង់ និង សមាជិកដទៃទៀតក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានថ្លែងនៅក្នុងការប្រជុំពេលរសៀល ។ មានមនុស្សជាច្រើនបាននិយាយថា ពួកគេឃើញ និង ស្ដាប់ឮ ព្រិកហាំ យ៉ង់ ដូចជា យ៉ូសែប ស្ម៊ីធ ។ ចច យ្យូ ខានុន ដែលមានអាយុ ១៧ ឆ្នាំ ក្នុងឆ្នាំ ១៨៤៤ បានចាំថា « បើ យ៉ូសែប បានរស់ពីសេចក្ដីស្លាប់ឡើងវិញ ហើយថ្លែងទៅកាន់បណ្ដាជនសាជាថ្មី វានឹងមានការភ្ញាក់ផ្អើលកាន់តែខ្លាំង ជាងអ្វីដែលបានកើតឡើងទៅទៀត ដ្បិតវាគឺជាសំឡេងរបស់ យ៉ូសែប ផ្ទាល់ ហើយវាពុំគ្រាន់តែជាសំឡេងរបស់ យ៉ូសែប ដែលគេបានឮនោះទេ ប៉ុន្តែ វាហាក់ដូចជាបានឃើញដោយផ្ទាល់ភ្នែកប្រជាជនដូចជា យ៉ូសែប បានឈរនៅចំពោះមុខពួកគេដែរ ។. . . ព្រះអម្ចាស់បានប្រទានទីបន្ទាល់មួយដល់រាស្ត្ររបស់ទ្រង់ថា គ្មានចន្លោះណាមួយទុកសម្រាប់ភាពសង្ស័យនោះទេ អំពីបុរសដែលត្រូវបានជ្រើសរើសឲ្យដឹកនាំពួកគេនោះ » ( នៅក្នុង *History of the Church* ៧:២៣៦ ) ។

បន្ថែមលើអព្ភូតហេតុនោះ ពួកបរិសុទ្ធជាច្រើនក៏បានទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធធ្វើជាសាក្សីដល់ពួកគេថា ព្រិកហាំ យ៉ង់ និង កូរ៉ុមនៃពួកដប់ពីរនាក់ ត្រូវបានហៅដោយព្រះដើម្បីដឹកនាំសាសនាចក្រ ។ នៅពេលបញ្ចប់ការប្រជុំនេះ ពួកបរិសុទ្ធនៅទីក្រុង ណៅវូ បានបោះឆ្នោតដោយមានមតិភាគច្រើនគាំទ្រដល់កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដោយមាន ព្រិកហាំ យ៉ង់ ជាប្រធាន ដើម្បីដឹកនាំសាសនាចក្រ ។ ទោះជាយ៉ាងណាក្ដី នៅទីបញ្ចប់ពុំមែនសមាជិកគ្រប់រូបនៃសាសនាចក្រ បានជ្រើសរើសធ្វើតាមពួកសាវកនោះទេ ។ ប្រជាជនខ្លះបានជ្រើសរើសធ្វើតាមបុគ្គលដទៃទៀតដូចជា ស៊ីឌនី រិកដុន និង ជេម ស្ត្រាង ដែលបានបង្កើតសាសនាចក្រផ្ទាល់ខ្លួនរបស់ពួកគេទៅវិញ ។

ប្រសិនបើអ្នកបានមានវត្តមាននៅក្នុងការប្រជុំទាំងអស់នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៨៤៤ តើសេចក្ដីសម្រេចណាមួយដែលអ្នកនឹងធ្វើ អំពីបុគ្គលដែលព្រះបានហៅឲ្យដឹកនាំសាសនាចក្រ ?

នៅពេល យ៉ូសែប ស្ម៊ីធ បានទទួលមរណភាព សាវកវៀមធ្បង ( ព្រិកហាំ យ៉ង់ ) អាចប្រើប្រាស់កូនសោទាំងឡាយនៃបព្វជិតភាពបានភ្លាមៗ ។ លោកមានសិទ្ធិទទួលវិវរណៈ ស្ដីពីពេលវេលាដែលត្រូវបង្កើតគណៈប្រធានទីមួយថ្មី ។ នៅក្នុងឆ្នាំ ១៨៤៧ – មានរយៈពេលជាងពីរឆ្នាំ បន្ទាប់ពីទុក្ករកម្ម– ព្រិកហាំ យ៉ង់ ត្រូវបានបំផុសគំនិតឲ្យបង្កើតគណៈប្រធានទីមួយប្រសើរជាងបន្តដឹកនាំសាសនាចក្រក្នុងនាមជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ដោយសារតែសាសនាចក្របន្តរីកចម្រើន និង រីកធំធាត់ វាជាការសំខាន់ក្នុងការចងចាំថា **តាមរយៈព្រះវិញ្ញាណបរិសុទ្ធ យើងអាចទទួលបានសាក្សីថា បុគ្គលទាំងឡាយដែលដឹកនាំសាសនាចក្រ ត្រូវបានហៅដោយព្រះ ។**


គណៈប្រធានទីមួយ ឆ្នាំ ២០១៣

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ហេតុអ្វីបានវាមានសារៈសំខាន់ក្នុងការទទួលបានទីបន្ទាល់មួយថា ថ្នាក់ដឹកនាំសាសនាចក្ររបស់យើង ត្រូវបានហៅពីព្រះ ?

ខ. សូមគិតអំពីគ្រាដែលអ្នកបានទទួលសាក្សីមួយថា អ្នកដឹកនាំនៃសាសនាចក្រម្នាក់ត្រូវបានហៅពីព្រះ ? ប្រសិនបើអ្នកធ្លាប់បានទទួលបទពិសោធន៍នោះ តើអ្នកបានធ្វើដូចម្ដេចដើម្បីទទួលបានសាក្សីនោះ ? ប្រសិនបើអ្នកពុំធ្លាប់ទទួលបានសាក្សីអំពីថ្នាក់ដឹកនាំសាសនាចក្រទេ សូមសរសេរអំពីកិច្ចការ ដែលអ្នកអាចធ្វើ ដើម្បីទទួលបានបទពិសោធន៍មួយ ?

៥. សូមស្នើឲ្យសមាជិកគ្រួសារ ឬ មិត្តភក្ដិម្នាក់ចែកចាយជាមួយអ្នកអំពីបទពិសោធន៍របស់ពួកគេ អំពីការទទួលបានសាក្សីពីព្រះវិញ្ញាណបរិសុទ្ធថា អ្នកដឹកនាំសាសនាចក្រម្នាក់ត្រូវបានហៅពីព្រះ ។ អ្នកក៏អាចនឹងចែកចាយអំពីអ្វី ដែលអ្នកបានសរសេរនៅក្នុងកិច្ចការមុននោះជាមួយពួកគេដែរ ។ សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្វីដែលអ្នកបានរៀនពីបទពិសោធន៍របស់បុគ្គលនេះ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សាមេរៀនអំពី « ការស្នងតំណែងនៅក្នុងគណៈប្រធានទីមួយ » ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# មេរៀនទី ៣០ ៖ ថ្ងៃទី ២ ការចាកចេញពីទីក្រុង ណៅវូ ការធ្វើដំណើរឆ្លងកាត់រដ្ឋ អៃអូវ៉ា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១–១៨

## បុព្វកថា

បន្ទាប់ពីព្យាការី យ៉ូសែប ស្ម៊ីធ ត្រូវគេធ្វើទុក្ករកម្ម នោះកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នៅក្រោមការដឹកនាំរបស់ ព្រិកហាំ យ៉ង់ ប្រធានកូរ៉ុមនៃពួកដប់ពីរនាក់ បានដឹកនាំសាសនាចក្រ ហើយបន្តធ្វើកិច្ចការរបស់ព្រះអម្ចាស់ ។ ពួកលោកបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យបញ្ចប់ការសាងសង់ព្រះវិហារបរិសុទ្ធ ហើយផ្លាស់ទីលំនៅទៅកាន់ភាគខាងលិច ។

### ពួកបរិសុទ្ធបានធ្វើការដោយឧស្សាហ៍ព្យាយាម ដើម្បីទទួលពរជ័យនៃព្រះវិហារបរិសុទ្ធ

សូមគិតអំពីគ្រាមួយ ដែលអ្នកបានធ្វើអ្វីមួយដ៏លំបាក ដោយសារតែអ្នកបានដឹងថា លទ្ធផលនឹងមានតម្លៃក្នុងការខិតខំនោះ ។

កិច្ចការដ៏លំបាកដែលពួកបរិសុទ្ធត្រូវបានបង្គាប់ឲ្យធ្វើបន្ទាប់ពីមរណភាពរបស់ព្យាការី យ៉ូសែប ស្ម៊ីធ គឺត្រូវបញ្ចប់ការសាងសង់ព្រះវិហារបរិសុទ្ធទីក្រុង ណៅវូ ។ វាត្រូវការពលិកម្មដ៏ធំពីសំណាក់ពួកបរិសុទ្ធ ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធទីក្រុង ណៅវូ ។ នៅពេលអ្នកអានកថាខណ្ឌខាងក្រោមនេះ សូមគូសបន្ទាត់ពីក្រោមពលិកម្មទាំងឡាយ ដែលពួកបរិសុទ្ធបានធ្វើ ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធទីមួយនៅទីក្រុង ណៅវូ ។

នៅក្នុងសន្និសីទទូទៅខែ តុលា ឆ្នាំ ១៨៤៤ ប្រធាន ព្រិកហាំ យ៉ង់ បានសុំឲ្យពួកបរិសុទ្ធថ្វាយដង្វាយមួយភាគក្នុងដប់ និងដង្វាយផ្សេង ៗរបស់ពួកគេ ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធ ។ ក្នុងការឆ្លើយតប សមាជិកសមាគមសង្គ្រោះម្នាក់ៗ បានបរិច្ចាគប្រាក់មួយសេនរាល់សប្ដាហ៍ ដើម្បីផ្គត់ផ្គង់ដល់ការសាងសង់ ។ បុរសជាច្រើនបានថ្វាយដង្វាយមួយភាគដប់ជាពេលវេលារបស់ខ្លួន ដោយធ្វើការសាងសង់ព្រះវិហារបរិសុទ្ធមួយថ្ងៃក្នុងរយៈពេលដប់ថ្ងៃម្ដង ។ អ្នកផ្សេងទៀតបានថ្វាយច្រើនជាងមួយភាគក្នុងដប់ទៅតាមមធ្យោបាយរបស់ពួកគេផ្ទាល់ ។ យ៉ូសែប តូរ៉ុនតូ បានប្រគល់មាសគិតជាទឹកប្រាក់ស្មើនឹងចំនួន ២៥០០ ដុល្លារ ឲ្យព្រិកហាំ យ៉ង់ ហើយបាននិយាយថា គាត់ចង់ថ្វាយអ្វីៗទាំងអស់ដែលគាត់មាន ដើម្បីស្ថាបនានគរនៃព្រះ ។

តើអ្នកគិតថា ហេតុអ្វីបានជាពួកបរិសុទ្ធស្ម័គ្រចិត្តលះបង់យ៉ាងច្រើន ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធយ៉ាងដូច្នេះ ?


ព្រះវិហារបរិសុទ្ធទីក្រុង ណៅវូ ពីដើម

ទោះជាពួកបរិសុទ្ធបានលះបង់ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធទីកុង្រ ណៅវូ យ៉ាងណាក្ដី ក៏សេចក្ដីបៀតបៀនបានបង្កឲ្យមានការលំបាកដល់ការបញ្ចប់ការសាងសង់ដែរ ។ ខ្មាំងសត្រូវជាច្រើនរបស់សាសនាចក្របានគិតថា នៅពេលព្យាការី យ៉ូសែប ស្ម៊ីធ ត្រូវគេសម្លាប់ហើយ នោះសាសនាចក្រនឹងដួលរលំ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលសមាជិកសាសនាចក្របន្តមានចិត្តស្មោះត្រង់ ហើយសាសនាចក្របន្តរីកចម្រើន នោះពួកខ្មាំងសត្រូវនៃសាសនាចក្របានពង្រឹងការខិតខំរបស់ពួកគេដើម្បីបណ្ដេញពួកបរិសុទ្ធចេញពីរដ្ឋ អិលលីណោយ ។

នៅពេលអ្នកអានកថាខណ្ឌខាងក្រោមនេះ សូមស្វែងរកអ្វីដែលពួកខ្មាំងសត្រូវនៃសាសនាចក្របានធ្វើ ដើម្បីព្យាយាមបំផ្លាញសាសនាចក្រចោល ៖

ក្នុងខែ កញ្ញា ឆ្នាំ ១៨៤៤ វរសេនីឯក លេវី វិលលាម ជាមនុស្សម្នាក់ក្នុងចំណោមអ្នកទាំងនោះ ដែលបានធ្វើឃាត យ៉ូសែប និង ហៃរុម ស្ម៊ីធ បានរៀបចំបង្កើតក្រុមកងទ័ពមួយដ៏ធំដើម្បីបង្ខំពួកបរិសុទ្ធថ្ងៃចុងក្រោយឲ្យចេញពីរដ្ឋ អិលលីណោយ ។ វាត្រូវបានផ្សព្វផ្សាយថា « ឆ្កែចចកដ៏ធំប្រមាញ់នៅក្នុងឃុំ ហែនខក » ( David E. Miller and Della S. Miller,*Nauvoo: The City of Joseph* [ ឆ្នាំ ១៩៧៤ ] ទំព័រ ១៨៦ ) ។ ពេលបានឮអំពីដំណឹងនេះ លោកអភិបាល ថូម៉ាស ហ្វត នៃរដ្ឋ អិលលីណោយ បានបញ្ជូនឧត្ដមសេនី ចន ហាឌីន ដែលជាកងទ័ពរដ្ឋឲ្យទៅកាន់ឃុំនោះ ដើម្បីរក្សាភាពស្ងប់ស្ងៀម ។

មួយឆ្នាំក្រោយមក នៅខែកញ្ញា ឆ្នាំ ១៨៤៥ វរសេនីឯក វិលលាម បានដឹកនាំក្រុមមនុស្សអាក្រក់មួយក្រុមដែលមានមនុស្ស ៣០០ នាក់ ទៅវាយប្រហារដល់ជម្រករបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅតំបន់ជាយៗ ដោយការដុតផ្ទះជាច្រើនខ្នង និងដុតអគារកសិដ្ឋាន រោងកិនស្រូវ និងស្រូវអង្ករអស់ជាច្រើន ។ នៅពាក់កណ្ដាលខែកញ្ញា ប្រធាន ព្រិកហាំ យ៉ង់ បានស្វែងរកអ្នកស្ម័គ្រចិត្តដើម្បីទៅជួយសង្គ្រោះពួកបរិសុទ្ធទាំងនោះ ។ ពួកបរិសុទ្ធនៅទីក្រុង ណៅវូ បានត្រៀមរទេះសេះចំនួន ១៣៤ រទេះ ដើម្បីដឹកក្រុមគ្រួសារដែលរស់នៅតំបន់ឆ្ងាយៗមកទីក្រុង ណៅវូ តាំងទីលំនៅដោយសុវត្ថិភាព ។

តើការវាយប្រហារទាំងនេះ បានធ្វើឲ្យវាមានការលំបាកដើម្បីបន្តធ្វើការសាងសង់ព្រះវិហារបរិសុទ្ធយ៉ាងដូចម្ដេច ?

មានប្រជាជនជាច្រើនដែលរស់នៅរដ្ឋ អិលលីណោយ បានភ័យខ្លាចថា វត្តមានរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយ អាចនាំឲ្យកើតមានសង្គ្រាមស៊ីវិល ។ ពួកគេបានសុំឲ្យពួកបរិសុទ្ធចាកចេញពីរដ្ឋ ។ នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៨៤៥ កូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានសន្យាថា សាសនាចក្រនឹងចាកចេញនៅនិទារឃរដូវក្រោយ ។

សូមពិចារណាអំពីមូលហេតុដែលការសម្រេចចិត្តចាកចេញពីរដ្ឋ អិលលីណោយ អាចមានការលំបាកក្នុងការធ្វើឡើង ។ សូមគិតផងដែរ ថាតើការសម្រេចចិត្តចាកចេញពីទីក្រុងណៅវូ អាចមានផលប៉ះពាល់ដល់ការខិតខំប្រឹងប្រែងរបស់ពួកបរិសុទ្ធដើម្បីបញ្ចប់ការសង់ព្រះវិហារបរិសុទ្ធយ៉ាងដូចម្ដេច ។

ទោះជាពួកបរិសុទ្ធបានដឹងថា ពួកគេនឹងត្រូវចាកចេញពីរដ្ឋ អិលលីណោយក្ដី ក៏ពួកគេបានបន្តសាងសង់ព្រះវិហារបរិសុទ្ធទីក្រុង ណៅវូ ដែរ ។

១. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថា ហេតុអ្វីបានជាពួកបរិសុទ្ធបានបន្តសាងសង់ព្រះវិហារបរិសុទ្ធ ទោះជាពួកគេដឹងថា ពួកគេនឹងចាកចេញទៅយ៉ាងនេះក្ដី ?

នៅគ្រានោះ ពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ ដែលចាំបាច់សម្រាប់ការតម្កើងឡើង ពុំទាន់អាចប្រារព្ធឡើងចំពោះសមាជិកទូទៅនៃសាសនាចក្រនៅឡើយទេ ។ នៅក្នុងវិវរណៈមួយនាឆ្នាំ ១៨៤១ ព្រះអម្ចាស់បានសន្យានឹងពួកបរិសុទ្ធថា បើពួកគេសាងសង់ព្រះវិហារបរិសុទ្ធ ណៅវូ នោះពួកគេអាចនឹងទទួលបានពិធីបរិសុទ្ធទាំងនោះ ( សូមមើល គ. និង ស. ១២៤:២២–៤៤ ) ។

ពួកបរិសុទ្ធទាំងនេះមានជំនឿថា ពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ នឹងរៀបចំពួកគេឲ្យរស់នៅក្នុងវត្តមាននៃព្រះវរបិតាសួគ៌នៅក្នុងភាពដ៏នៅអស់កល្បជានិច្ច ហើយក្រុមគ្រួសាររបស់ពួកគេអាចផ្សារភ្ជាប់ជាមួយគ្នាដ៏នៅអស់កល្បជានិច្ចផងដែរ ។ ដំណើរពលិកម្មរបស់ពួកបរិសុទ្ធ និង សេចក្ដីលំបាកនានាដែលពួកគេយកកល្បះ ដើម្បីសាងសង់ព្រះវិហារបរិសុទ្ធ បង្រៀនយើងអំពីសេចក្ដីពិតដូចតទៅនេះ ៖**ការទទួលបានពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ មានតម្លៃចំពោះរាល់ការខិតខំ និង ពលិកម្មដ៏សុចរិតរបស់យើង ។**

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា ហេតុអ្វីបានជាការទទួលពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ មានតម្លៃចំពោះការខិតខំ និង ពលិកម្មដ៏ធំ ?

ខ. តើអ្នកចាំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីអ្នកអាចទទួលបានពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ ?

សូមពិចារណាថាតើមានអ្វីណាមួយ ដែលអ្នកត្រូវឈប់ធ្វើ ឬ ចាប់ផ្ដើមធ្វើ ដើម្បីទទួលបានពរជ័យទាំងឡាយនៃព្រះវិហារបរិសុទ្ធ ។



ប្រធាន ថូម៉ាស អេស ម៉នសុន បានពិពណ៌នាអំពីពលិកម្មនានា ដែលពួកបរិសុទ្ធសម័យថ្មីបានធ្វើដើម្បីទទួលបានពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ ៖ « អស់រយៈពេលជាច្រើនឆ្នាំកន្លងទៅ ខ្ញុំបានអានអំពីក្រុមសមាជិកជាងមួយរយនាក់ ដែលបានចាកចេញពី មេណូស [ ប្រេស៊ីល ] ដែលស្ថិតនៅកណ្ដាលព្រៃលិចទឹកអាម៉ាហ្សូន ធ្វើដំណើរទៅកាន់ព្រះវិហារបរិសុទ្ធដែលនៅជិតបំផុត ស្ថិតនៅក្នុងទីក្រុង សៅ ផាឡូ ប្រទេសប្រេស៊ីល –ចម្ងាយប្រហែល ៤០០០ គីឡូម៉ែត្រពី មេណូស ។ ពួកបរិសុទ្ធស្មោះត្រង់ទាំងនោះ បានធ្វើដំណើរតាមទូកអស់រយៈពេលបួនថ្ងៃ តាមទន្លេអាម៉ាហ្សូន និង តាមដៃទន្លេនោះ ។ បន្ទាប់ពីបានបញ្ចប់ការធ្វើដំណើរតាមទឹកនេះ ពួកគេបានឡើងជិះឡានក្រុង ធ្វើដំណើររយៈពេលបីថ្ងៃទៀត តាមផ្លូវលំាក់ ហើយមានអាហារបរិភោគបន្តិចបន្តួចប៉ុណ្ណោះ ហើយគ្មានកន្លែងសម្រាកស្រួលបួលនោះទេ ។ ប្រាំពីរយប់ប្រាំពីរថ្ងៃក្រោយមក ពួកគេបានមក ដល់ព្រះវិហារបរិសុទ្ធនៅ សៅ ផាឡូ ដែលនៅទីនោះពិធីបរិសុទ្ធដ៏អស់កល្បទាំងឡាយត្រូវបានធ្វើឡើង ។ ប្រាកដណាស់ ការធ្វើដំណើរត្រឡប់មកវិញរបស់ពួកគេ មានការលំបាកដូចនឹងពេលធ្វើដំណើរទៅដែរ ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបានទទួលពិធីបរិសុទ្ធ និងពរជ័យនៃព្រះវិហារបរិសុទ្ធ ហើយទោះបីជាក្នុងសំពាយ របស់ពួកគេគ្មាននៅសល់ប្រាក់ក្ដី ក៏ពួកគេបានពោរពេញទៅដោយអារម្មណ៍ នៃព្រះវិហារបរិសុទ្ធ ហើយមានអំណរ គុណចំពោះពរជ័យទាំងឡាយដែលពួកគេបានទទួលផងដែរ » (The Holy Temple—a Beacon to the World, » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១១, ទំព័រ ៩១) ។

តើគំរូរបស់ពួកបរិសុទ្ធទាំងនេះ អាចបំផុសឲ្យអ្នកត្រៀមខ្លួនទទួលពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធបានយ៉ាងដូចម្ដេច ?

សូមអានកថាខណ្ឌខាងក្រោមនេះ រួចគូសបន្ទាត់ពីក្រោមគំរូនៃកិច្ចខិតខំដ៏សុចរិតរបស់ពួកបរិសុទ្ធនៅទីក្រុង ណៅវូ ដើម្បីទទួលបានពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ ៖

ថ្នាក់ដឹកនាំសាសនាចក្របានឧទ្ទិសឆ្លងបន្ទប់ទាំងឡាយក្នុងព្រះវិហារបរិសុទ្ធ នៅពេលដែលបានការសាងសង់បានចប់សព្វគ្រប់ ដើម្បីឲ្យកិច្ចការនៃពិធីបរិសុទ្ធអាចចាប់ផ្ដើមធ្វើឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។ បន្ទប់ខាងលើនៃព្រះវិហារបរិសុទ្ធ ត្រូវបានឧទ្ទិសឆ្លងសម្រាប់កិច្ចការនៃពិធីបរិសុទ្ធនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៨៤៥ ។ ពួកបរិសុទ្ធបានចាប់ផ្ដើមទទួលអំណោយទានពិសិដ្ឋរបស់ពួកគេនៅពេលល្ងាចថ្ងៃទី ១០ ខែ ធ្នូ ដែលមានវគ្គពិធីអំណោយទានពិសិដ្ឋបានបន្តរហូតដល់ម៉ោង ៣ ព្រឹក នៅថ្ងៃទី ១១ ខែ ធ្នូ ។

ត្រឹមចុងឆ្នាំ ១៨៤៥ មានសមាជិកជាង ១000 នាក់ បានទទួលពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ ។ ក្នុងខែ មករា ឆ្នាំ ១៨៤៦ ប្រធាន ព្រិកហាំ យ៉ង់ បានកត់ត្រាថា « ការណ៍បែបនោះបានបង្ហាញឲ្យឃើញពីភាពអន្ទះសាតាមរយៈពួកបរិសុទ្ធដើម្បីទទួលបានពិធីបរិសុទ្ធ [ នៅក្នុងព្រះវិហារបរិសុទ្ធ ] ចំណែកឯភាពអន្ទះសារបស់យើងវិញ គឺបម្រើដល់ពួកគេ រហូតដល់ខ្ញុំបានលះបង់ខ្លួនខ្ញុំទាំងស្រុងចំពោះកិច្ចការរបស់ព្រះអម្ចាស់នៅក្នុងព្រះវិហារបរិសុទ្ធទាំងយប់ទាំងថ្ងៃ ដោយចូលសម្រាកជាមធ្យមមិនលើសពីបួនម៉ោងក្នុងមួយថ្ងៃទេ ហើយទៅផ្ទះតែម្ដងប៉ុណ្ណោះក្នុងមួយសប្ដាហ៍ » ( នៅក្នុង *History of the Church* ៧:៥៦៧ ) ។ សមាជិកជាច្រើន បានរួមចំណែកដោយការបោកគក់សម្លៀកបំពាក់ព្រះវិហារបរិសុទ្ធរាល់យប់ ដើម្បីឲ្យកិច្ចការអាចបន្តមាននៅព្រឹកស្អែកឡើងដោយពុំមានការបង្អង់ឡើយ ។



ប្រធាន ព្រិកហាំ យ៉ង់ បានធ្វើការដោយមិនគិតពីភាពនឿយហត់ ដើម្បីផ្ដល់ពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធសម្រាប់ពួកបរិសុទ្ធ ពីមុនពួកគេត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុង ណៅវូ រដ្ឋ អិលលីណោយ ។

នៅថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ១៨៤៦ ប្រធាន យ៉ង់ បានចាកចេញពីព្រះវិហារបរិសុទ្ធ ដើម្បីលោកអាចត្រៀមខ្លួនចាកចេញពីទីក្រុង ណៅវូ នៅថ្ងៃបន្ទាប់ ។ ទោះជាយ៉ាងណាក៏ដោយ មានបណ្ដាជនជាច្រើនបានមកប្រជុំគ្នាដើម្បីទទួលអំណោយទានពិសិដ្ឋ រួចលោកក៏បានត្រឡប់ទៅបម្រើពួកគេវិញដោយក្ដីមេត្តា។ ការណ៍នេះបានពន្យាពេលនៃការចាកចេញរបស់លោក ដល់ទៅពីរសប្ដាហ៍ក្រោយ ។ យោងតាមកំណត់ត្រាព្រះវិហារបរិសុទ្ធបានបង្ហាញថា មានពួកបរិសុទ្ធចំនួន ៥៦១៥ នាក់បានទទួលអំណោយទានពិសិដ្ឋមុនពេលធ្វើដំណើរទៅភាគខាងលិច ។ ( សូមមើល *Church History in the Fulness of Times Student Manual* ការបោះពុម្ពលើកទី ២ [ Church Educational System manual ឆ្នាំ ២០០៣ ] ទំព័រ ៣០៣–៤) ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្វីដែលធ្វើឲ្យអ្នកចាប់អារម្មណ៍ អំពីកិច្ចខិតខំរបស់ពួកបរិសុទ្ធ ក្នុងការទទួលពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ ?

ខ. តើកិច្ចខិតខំ និង ពលិកម្មអ្វីខ្លះ ដែលយើងត្រូវធ្វើ ដើម្បីទទួលបានពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ ?

## ពួកបរិសុទ្ធចាកចេញពីទីក្រុង ណៅវូ

បន្ទាប់ពីបានទទួលពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធហើយ ពួកបរិសុទ្ធបានចាប់ផ្ដើមចាកចេញពីទីក្រុង ណៅវូ នៅខែ កុម្ភៈ ឆ្នាំ ១៨៤៦ ។ ទោះជាយ៉ាងណាក៏ដោយ មិនមែនសមាជិកទាំងអស់បានចាកចេញទៅជាមួយក្រុមធំនៃពួកបរិសុទ្ធនោះទេ ។ មានពួកបរិសុទ្ធមួយចំនួនតូចពុំបានត្រៀមខ្លួនចាកចេញនៅពេលនោះទេ ចំណែកឯមួយចំនួនទៀតបានសម្រេចចិត្តរស់នៅបន្ត ។

ពួកបរិសុទ្ធជាច្រើនដែលបន្តរស់នៅទីក្រុង ណៅវូ បានបន្តទទួលសេចក្ដីបៀតបៀន ។ ក្នុងខែ កញ្ញា ឆ្នាំ ១៨៤៦ ប្រាំពីរខែក្រោយមកបន្ទាប់ពីក្រុមធំនៃពួកបរិសុទ្ធបានចាកចេញទៅ មានប្រជាពលរដ្ឋប្រមាណ ៨០០ នាក់ ប្រដាប់ដោយកាំភ្លើងប្រាំមួយដើម បានត្រៀមខ្លួនវាយប្រហារទីក្រុង ណៅវូ ។ ពួកបរិសុទ្ធដែលនៅសេសសល់ និង ពលរដ្ឋថ្មីៗមួយចំនួន ដែលមានបុរសចំនួនប្រហែលជា ១៥០ នាក់ បានត្រៀមខ្លួនប្រយុទ្ធការពារទីក្រុង ។

បន្ទាប់ពីមានការប្រយុទ្ធគ្នាអស់រយៈពេលពីរបីថ្ងៃ នោះពួកបរិសុទ្ធជាច្រើនត្រូវបានបង្ខំឲ្យចុះចាញ់ ហើយត្រូវបានប្រាប់ថា ឲ្យចាកចេញពីទីក្រុងជាបន្ទាន់ ។ បន្ទាប់មក ពួកមនុស្សអាក្រក់ បានចូលមកក្នុងទីក្រុង ឆក់ប្លន់តាមផ្ទះ ហើយបានបំផ្លាញព្រះវិហារបរិសុទ្ធចោល ។ ពួកបរិសុទ្ធមួយចំនួន ដែលពុំអាចភៀសខ្លួនបានលឿន ត្រូវគេវាយធ្វើបាប ឬ បោះចូលទៅក្នុងទន្លេមីស៊ីស៊ីពី ។ បន្ទាប់ពីពួកបរិសុទ្ធដែលនៅសល់ទាំងនេះ ត្រូវបានគេបង្ខំឲ្យចេញពីទីក្រុង ណៅវូ ហើយ នោះពួកគេបានបោះជំរំជនភៀសខ្លួន នៅតាមដងទន្លេខាងលិច ។ ពួកគេភាគច្រើនពុំមានអាហារ ឬ បរិក្ខារទំនុកបម្រុងគ្រប់គ្រាន់សម្រាប់ខ្លួនគេនោះទេ ។

ថ្នាក់ដឹកនាំសាសនាចក្របានបញ្ជូនក្រុមជួយសង្គ្រោះឲ្យធ្វើដំណើរឆ្លងកាត់រដ្ឋ អៃអូវ៉ា ត្រឡប់មកជួយដល់ពួកបរិសុទ្ធដែលកំពុងរងទុក្ខ ។

៤. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថាអ្នកអាចនឹងមានអារម្មណ៍ដូចម្ដេច បើសិនជាអ្នកត្រូវបានហៅឲ្យត្រឡប់ទៅជួយពួកបរិសុទ្ធដែលកំពុងរងទុក្ខទាំងនោះ ?

សូមអានសារលិខិតរបស់ប្រធាន ព្រិកហាំ យ៉ង់ ដែលបានផ្ដល់ដល់បុរស ៗដែលគ្រប់គ្រងក្នុងការជ្រើសរើសក្រុមជួយសង្គ្រោះនោះ ៖



« ចូរឲ្យភ្លើងនៃសេចក្ដីសញ្ញា ដែលអ្នកបានធ្វើនៅក្នុងដំណាក់នៃព្រះអម្ចាស់ បានដុតរោលរាលក្នុងដួងចិត្តអ្នក ដូចជាអណ្ដាតភ្លើងដែលពុំអាចពន្លត់បាន រហូតដល់អ្នកបាន . . . ជួយដល់មនុស្សគ្រប់រូប. . . ដែល [ អាចចាកចេញមកបាន ] ហើយចែកភ្លើងនោះទៅដល់ព្រលឹងរបស់គាត់ រហូតដល់គាត់អាចក្រោកឡើង. . . ហើយចេញទៅភ្លាម ហើយនាំក្រុមមនុស្សក្រីក្រចេញពីទីក្រុង ណៅវូ ។. . .

« . . . នេះគឺជាពេលដែលត្រូវធ្វើសកម្មភាព » ( Journal History of The Church of Jesus Christ of Latter–day Saints ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៨៤៦ ទំព័រ ៥–៦ Church History Library, Salt Lake City ) ។

សេចក្ដីថ្លែងការណ៍របស់ ព្រិកហាំ យ៉ង់ បង្រៀនយើងថា **ព្រះអម្ចាស់តម្រូវឲ្យយើងរស់នៅតាម សេចក្ដីសញ្ញាទាំងឡាយដែលយើងធ្វើ ។**

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើពលិកម្មអ្វីខ្លះដែលអ្នកបានធ្វើ ដើម្បីរក្សាសេចក្ដីសញ្ញាទាំងឡាយ ?

ខ. តើពរជ័យអ្វីខ្លះដែលអ្នកបានទទួល ដោយសារតែអ្នកបានរស់នៅស្របតាមសេចក្ដីសញ្ញាទាំងឡាយដែលអ្នកបានធ្វើនោះ ?

## ពួកបរិសុទ្ធថ្ងៃចុងក្រោយ ធ្វើដំណើរឆ្លងកាត់រដ្ឋ អៃអូវ៉ា ហើយបង្កើតទីស្នាក់ការកណ្ដាលនៅវិនទើរ ខ្វាទើរ្ស

នៅពេលក្រុមធំនៃពួកបរិសុទ្ធបានចាប់ផ្ដើមចាកចេញពីទីក្រុង ណៅវូ ក្នុងខែ កុម្ភៈ ឆ្នាំ ១៨៤៦ ពួកគេបានធ្វើដំណើរទៅទិសខាងលិចឆ្លងកាត់រដ្ឋ អៃអូវ៉ា ។ « ការចាកចេញពីទីក្រុង ណៅវូ គឺជាទង្វើនៃសេចក្ដីជំនឿចំពោះពួកបរិសុទ្ធ ។ ពួកគេបានចាកចេញទៅដោយពុំដឹងពីទីកន្លែងពិតប្រាកដថានឹងទៅទីណា ឬ នៅពេលណាពួកគេនឹងទៅដល់កន្លែងមួយដែលពួកគេអាចបោះទីតាំងរស់នៅបានឡើយ ។ ពួកគេគ្រាន់តែដឹងថា ពួកគេកំពុងត្រូវគេបង្ខំឲ្យចាកចេញពីរដ្ឋ អិលលីណោយ ដោយពួកខ្មាំងសត្រូវរបស់ពួកគេ ហើយថ្នាក់ដឹកនាំរបស់ពួកគេបានទទួលវិវរណៈឲ្យទៅបោះទីតាំងនៅកន្លែងមួយក្នុងតំបន់ភ្នំ រ៉ក់ឃី » (*Church History in the Fulness of Times Student Manual* ៣០៩) ។

នៅពេលអ្នកអានដំណើររឿងរបស់ អូរសុន និង ខាធើរិន ស្ពែនសើរ សូមស្វែងរកគំរូនៃសេចក្ដីជំនឿ និង ទំនុកចិត្តរបស់ពួកគេ ៖

« បន្ទាប់ពីបានចាកចេញពីទីក្រុង ណៅវូ [ ខាធើរិន ] ទន់ខ្សោយ ហើយបានធ្លាក់ខ្លួនឈឺ ដោយសារតែការលំបាកជាច្រើនដែលនាងបានជួបប្រទះ ។ ស្វាមីដ៏ប្រកបដោយទុក្ខព្រួយ បានសរសេរសំបុត្រអង្វរករដល់ឪពុកម្ដាយរបស់ភរិយា សុំឲ្យពួកគាត់ទទួលនាងទៅនៅនឹងពួកគាត់ ទម្រាំតែពួកបរិសុទ្ធរកបានកន្លែងនឹងនរមួយ ។ ចម្លើយបានតបមកថា ‹ ចូរឲ្យនាងបោះបង់ចោលជំនឿដ៏គួរខ្មាស់អៀនរបស់នាងនោះចោលទៅ ទើបនាងអាចត្រឡប់មកនៅជាមួយយើងវិញ បើមិនដូច្នោះទេ នាងពុំអាចមកវិញឡើយ › ។

« នៅពេលសំបុត្រត្រូវបានអានឲ្យនាងស្ដាប់ នោះនាងបានសុំឲ្យស្វាមីនាងបើកព្រះគម្ពីរប៊ីបរបស់គាត់ទៅគម្ពីរនាងរស់ ហើយអានជំពូកទីមួយ ខទីដប់ប្រាំមួយ និងដប់ប្រាំពីរ ៖ ‹ សូមកុំទទូចឲ្យខ្ញុំទៅចោលអ្នកម្ដាយនឹងវិលទៅវិញ លែងតាមអ្នកម្ដាយនោះឡើយ ដ្បិតកន្លែងណាដែលអ្នកម្ដាយអញ្ជើញទៅ នោះខ្ញុំនឹងទៅតាម ហើយកន្លែងដែលអ្នកម្ដាយស្នាក់នៅ នោះខ្ញុំក៏នឹងទៅដែរ ។ សាសន៍របស់អ្នកម្ដាយនឹងបានជាសាសន៍របស់ខ្ញុំ ហើយព្រះរបស់អ្នកម្ដាយ នឹងបានជាព្រះរបស់ខ្ញុំដែរ › » ( *Memoirs of John R. Young: Utah Pioneer ១៨៤៧* [ ឆ្នាំ ១៩២០ ] ទំព័រ ១៧–១៨ ) ។ មិនយូរប៉ុន្មាន ខាធើរិន ស្ពែនសើរ បានស្លាប់ទៅ។

ពួកបរិសុទ្ធបានជួបប្រទះសេចក្ដីលំបាក នៅពេលធ្វើដំណើរ ។ ដោយសារតែភ្លៀងធ្លាក់ខ្លាំង និង ការផ្គត់ផ្គង់មិនគ្រប់គ្រាន់ នោះពួកបរិសុទ្ធបានចំណាយពេលបួនខែធ្វើដំណើរឆ្លងកាត់រដ្ឋ អៃអូវ៉ា ដែលមានចម្ងាយ ៤៨០ គីឡូម៉ែត្រ ។ ចូរពិចារណាអំពីការធ្វើដំណើរយឺតៗនេះ ថ្នាក់ដឹកនាំសាសនាចក្របានសម្រេចថាពុំបន្តដំណើរទៅភាគខាងលិចដើម្បីទៅកាន់ជួរភ្នំ រ៉ក់ឃី ទៀតទេ ចាំរហូតដល់និទាឃរដូវឆ្នាំ ១៨៤៧ សិន ។ ពួកលោកបានទូន្មានឲ្យពួកបរិសុទ្ធ តាំងលំនៅសម្រាប់រដូវរងារ ។ កន្លែងតាំងលំនៅដ៏ធំបំផុតមួយ គឺនៅ វិនទើរ ខ្វរទើរ្ស ដែលមានទីតាំងនៅភាគខាងលិចនៃទន្លេមិសសួរី ដែលបច្ចុប្បន្ននេះគឺ រដ្ឋ នេប្រាស្កា ។



ការតាំងលំនៅជាបណ្ដោះអាសន្ននៅ វិនទើរ ខ្វរទើរ្ស

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១–១៨

*ព្រះអម្ចាស់ប្រទានឱវាទឲ្យពួកបរិសុទ្ធរៀបចំ ហើយត្រៀមខ្លួនបន្តដំណើរទៅកាន់ភាគខាងលិច*

ប្រធាន ព្រិកហាំ យ៉ង់ បានទទួលវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦ នៅ វិនទើរ ខ្វរទើរ្ស ក្នុងខែ មករា ឆ្នាំ ១៨៤៧ ។

នៅពេលអ្នកសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១–១៨ សូមកត់ចំណាំឱវាទរបស់ព្រះអម្ចាស់អំពីរបៀប ដែលពួកបរិសុទ្ធត្រូវរៀបចំខ្លួន ហើយត្រៀមខ្លួនដើម្បីបន្តធ្វើដំណើរទៅកាន់ភាគខាងលិច ។

អ្នកនឹងរៀនបន្ថែមជាមួយគ្រូរបស់អ្នកនៅក្នុងមេរៀននេះ អំពីការធ្វើដំណើរទៅកាន់ភាគខាងលិច ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា « ការចាកចេញពីទីក្រុង ណៅវូ » « ការធ្វើដំណើរឆ្លងកាត់រដ្ឋ អៃអូវ៉ា » និង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១–១៨ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៣០ ៖ ថ្ងៃទី ៣

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១៩–៤២

## សេចក្ដីផ្ដើម

ក្នុងខែ មករា ឆ្នាំ ១៨៤៧ ប្រធាន ព្រិកហាំ យ៉ង់ បានទទួលវិវរណៈដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦ នៅ វិនទើរ ខ្វរទើរ្ស រដ្ឋ នេប្រាស្កា ។ មេរៀននេះគ្របដណ្ដប់លើ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១៩–៤២ ដែលរួមបញ្ចូលទាំងឱវាទរបស់ព្រះអម្ចាស់ដល់ពួកបរិសុទ្ធ ស្ដីពីរបៀបដែលពួកគេត្រូវប្រព្រឹត្តនៅពេលធ្វើដំណើរ ទ្រង់ប្រទានការអះអាង ហើយត្រាស់បង្គាប់ពួកគេឲ្យគោរពតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១៩–២៩

*ព្រះអម្ចាស់ប្រទានឱវាទដល់ពួកបរិសុទ្ធ ស្ដីពីរបៀបដែលពួកគេត្រូវប្រព្រឹត្តនៅពេលធ្វើដំណើរ*

សូមគិតអំពីឱកាសមួយ ដែលអ្នកធ្លាប់មាន ក្នុងការប្រាស្រ័យទាក់ទងជាមួយមនុស្សដទៃនៅក្នុងក្រុម ។ តើទិដ្ឋភាពវិជ្ជមានមួយចំនួន នៃការធ្វើការជាមួយមនុស្សដទៃនៅក្នុងក្រុមមានអ្វីខ្លះ ?

នៅពេលពួកបរិសុទ្ធត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុង ណៅវូ នៅដើមឆ្នាំ ១៨៤៦ ហើយបានចាប់ផ្ដើមធ្វើដំណើរទៅភាគខាងលិច នោះមានមនុស្សជាច្រើនពុំបានត្រៀមខ្លួនធ្វើដំណើរទេ ។ ក្រុមពួកបរិសុទ្ធដំបូងគេ បានចេញទៅជាច្រើនគីឡូម៉ែត្រ ដែលធ្វើឲ្យពួកគេពុំអាចជួយគ្នាទៅវិញទៅមកបានទេ ។ នៅក្នុងវិវរណៈមួយដែលប្រធាន ព្រិកហាំ យ៉ង់ បានទទួលនៅ វិនទើរ ខ្វរទើរ្ស រដ្ឋ នេប្រាស្កា ប្រហែលជាមួយឆ្នាំក្រោយមក ព្រះអម្ចាស់បានណែនាំឲ្យពួកបរិសុទ្ធរៀបចំខ្លួនដើម្បីពួកគេអាចជួយគ្នាទៅវិញទៅមក នៅពេលពួកគេបន្តការធ្វើដំណើរ ។

សូមរំពឹក គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:២, ៨–១០ ដោយស្វែងរកសេចក្ដីណែនាំពីព្រះអម្ចាស់ អំពីរបៀបដែលពួកបរិសុទ្ធត្រូវជួយគ្នាទៅវិញទៅមក ។

ទោះបីជាការធ្វើការជាក្រុមអនុញ្ញាតឲ្យយើងជួយគ្នាទៅវិញទៅមកក្ដី ក៏វាអាចបង្កើតជាបញ្ហាច្រើនផងដែរ ។ សូមគិតអំពីឧបសគ្គមួយចំនួន ដែលអាចកើតឡើងនៅពេលធ្វើការជាមួយគ្នា ?


ការធ្វើការជាក្រុម អនុញ្ញាតឲ្យយើងជួយគ្នាទៅវិញទៅមក ប៉ុន្តែ វាក៏អាចបង្កើតជាបញ្ហាច្រើនដែរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១៩–២៧ ដោយស្វែងរកឱវាទពីព្រះអម្ចាស់ទៅដល់ពួកបរិសុទ្ធ នៅពេលពួកគេធ្វើដំណើរ និង ធ្វើការរួមគ្នា ។


១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើឱវាទអ្វីខ្លះដែលអ្នកបានអាន ដែលបានជួយដល់ពួកបរិសុទ្ធធ្វើដំណើរ និង ធ្វើការរួមគ្នា ?

ខ. តើអ្នកគិតថា ហេតុអ្វីបានជាឱវាទនេះមានប្រយោជន៍ ?

គ. តើអ្នកអាចអនុវត្តតាមឱវាទនេះ នៅពេលអ្នកប្រាស្រ័យទាក់ទង ហើយធ្វើការជាមួយមនុស្សទូទៅតាមរបៀបណា ?

សូមរំឭក ខទី ២៣–២៤ ។ សូមកត់ចំណាំថា ព្រះអម្ចាស់បានប្រទានឱវាទដល់ពួកបរិសុទ្ធឲ្យ « ឈប់ការផឹកប្រមឹក » ( គ. និង ស. ១៣៦:២៤ ) ទោះជាវិវរណៈនេះបានប្រទានមកបន្ទាប់ពី ពួកបរិសុទ្ធបានទទួលពាក្យសម្តីនៃប្រាជ្ញាវាងវៃយ៉ាងណាក្តី ។ ពួកបរិសុទ្ធបានរីកចម្រើនបន្តិចម្តងៗ នៅពេលគោរពប្រតិបត្តិតាមពាក្យសម្តីនៃប្រាជ្ញាវាងវៃ ។ នៅពេលវិវរណៈនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៦ បានប្រទានឲ្យ កាលនោះពួកបរិសុទ្ធថ្ងៃចុងក្រោយ មិនត្រូវបានហាមឃាត់ពីការប្រើគ្រឿងស្រវឹងទាំងអស់ ដូចជាយើងនៅសព្វថ្ងៃនេះទេ ។

ស្របតាម គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៦:២៤ តើពាក្យសម្តីទាំងឡាយរបស់យើងគួរតែស្តែងចេញយ៉ាងដូចម្តេច ចំពោះមនុស្សនៅជុំវិញខ្លួន ? ដើម្បីឆ្លើយសំណួរនេះ សូមបញ្ចប់គោលការណ៍ដូចតទៅ ៖ **ពាក្យសម្តីទាំងឡាយរបស់យើងគួរតែ** . សូមគិតអំពីការគូសចំណាំឃ្លា ដែលបង្រៀនគោលការណ៍នេះនៅក្នុងព្រះគម្ពីររបស់អ្នក ។

អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ដើម្បីស្អាងគ្នា មានន័យថា ស្ថាបនានរណាម្នាក់ឡើងខាងវិញ្ញាណ ឬ ខាងសតិអារម្មណ៍ ។

២. សូមបំពេញកិច្ចការខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមឆ្លើយសំណួរដូចតទៅនេះ ៖ តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ចំពោះពួកបរិសុទ្ធ ដើម្បីប្រើពាក្យស្អាងគ្នា នៅពេលពួកគេធ្វើដំណើរជាមួយគ្នានោះ ?

ខ. សូមអធិប្បាយអំពីគ្រាដែលអ្នកធ្លាប់បានឃើញនរណាម្នាក់ ប្រើពាក្យសម្តីស្អាងដល់មនុស្សដទៃ ?

សូមគិតអំពីពាក្យសម្តីអ្នកអាចនិយាយ ដែលនឹងស្អាងមនុស្សជុំវិញខ្លួនអ្នកឡើង ។

នៅពេលអ្នកអានដំណើររឿងខាងក្រោម អំពីបទពិសោធន៍នានារបស់ពួកបរិសុទ្ធនៅពេលពួកគេបានចាប់ផ្តើមការធ្វើដំណើរឆ្ពោះទៅភាគខាងលិច សូមគិតថាតើអ្នកអាចនឹងមានអារម្មណ៍ដូចម្តេច និង អំពីមូលហេតុដែលពួកបរិសុទ្ធដ៏ស្មោះត្រង់ទាំងនេះ បានមានឆន្ទៈឆ្លងកាត់ការសាកល្បងដូចនេះ ៖

ម៉ារី អាណា វេស្តុន មូហាន បានសរសេរ ៖ « យើងត្រូវបានហៅឲ្យទៅបញ្ចុះសពមនុស្សពីរនាក់ក្នុងក្រុមយើង ដែលបានស្លាប់នៅព្រឹកនេះដោយសារតែជំងឺអាសន្នរោគ បុរសនោះឈ្មោះ ប្រោណ និង កុមារតូចម្នាក់ ។ មានអ្នកជំងឺច្រើនទៀតនៅក្នុងជំរំ ។ ដោយបានទៅដល់ ទន្លេ ប្លាត ពេញមួយថ្ងៃ ។ បានធ្វើដំណើរ ២៤ គីឡូម៉ែត្រ បានបោះជំរំនៅ សលត៍ ក្រិក ។ មិនយូរប៉ុន្មាន ក្មេងម្នាក់ទៀតក្នុងជំរំយើងបានស្លាប់ ។ ពួកគេបានបញ្ចុះសពនៅពេលថ្ងៃលិច តាមច្រាំងទន្លេក្រិក ។ មានមនុស្សច្រើនទៀតឈឺ ។ វាធ្វើឲ្យយើងមានអារម្មណ៍សោកសៅ ដែលត្រូវបញ្ចុះសពមិត្តរបស់យើងនៅតាមផ្លូវ ។ អាកាសធាតុក្តៅខ្លាំង » ( Mary Ann Weston Maughan journal វ៉ុល ៣ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៨៥០ ២:១ Family History Library, Salt Lake City; spelling, capitalization, and punctuation modernized ) ។



ក្លារីសា យ៉ង់ ស្ពែនសើរ ( កូនស្រីរបស់ ព្រិកហាំ យ៉ង់ ) បានសរសេរ ៖ « គុណសម្បត្តិលេចធ្លោបំផុតរបស់លោកឪពុកក្នុងនាមជាអ្នកដឹកនាំម្នាក់ គឺជាឥរិយាបថដែលលោកបានមើលថែដល់សុខុមាលភាពរបស់ប្រជាជនលោកទាំងខាងសាច់ឈាម និង ខាងសង្គម ព្រមទាំងដឹកនាំពួកគេ ចំពោះសេចក្តីត្រូវការខាងវិញ្ញាណរបស់ពួកគេផងដែរ ។ នៅក្នុងការធ្វើដំណើរដ៏អស្ចារ្យឆ្លងកាត់ទីវាលទំនាប ពេលដែលមនុស្សគ្រប់គ្នាដើរដោយទន់ល្មើយក្នុងផ្លូវដ៏វែងឆ្ងាយ បើសិនជាអាកាសធាតុអំណោយផលនោះពួកបរិសុទ្ធបានជួបជុំគ្នាជុំគុក្នក់ភ្លើងរាំកម្សាន្តនៅពេលល្ងាច ។ មានចម្រៀងបានបន្លឺឡើង តន្ត្រីប្រគុំដោយអ្នកលេងវីយូឡុង ហើយពួកបុរសស្ត្រីបានបំភ្លេចភាពនឿយហត់ក្នុងការដើរអស់ចម្ងាយម្ភៃប្អូនគីឡូម៉ែត្រជាដើមនៅលើវាលខ្សាច់ល្វល្វេវ ខណៈដែលពួកគេចូលរួមនៅក្នុងការរាំជារង្វង់ ។ នេះជារបៀបរបស់លោកក្នុងការជួយមនុស្សឲ្យរក្សា ‹ លីសធម៌ › មុនពេលលោកបានថ្លែងចេញអ្វីមួយ » ( ជាមួយ Mabel Harmer *One Who Was Valiant* [ ឆ្នាំ ១៩៤០ ] ទំព័រ ១៦២ ) ។

យោងតាមដំណើររឿងទាំងនេះ តើអ្នកនឹងពិពណ៌នាអំពីបទពិសោធន៍នៃពួកបរិសុទ្ធថ្ងៃចុងក្រោយដែលជាអ្នកត្រួសត្រាយផ្លូវយ៉ាងដូចម្តេច ?

៣. សូមអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៦:២៨–២៩ ដោយស្វែងរកឱវាទ ដែលមាននៅក្នុងខគម្ពីរទាំងនេះ ។ ក្រោយមក សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក នូវគោលការណ៍មួយដែលប្រាប់អំពីអ្វីយើងគួរធ្វើនៅពេលយើងរីករាយ និង គោលការណ៍មួយដែលប្រាប់អំពីអ្វីយើងគួរធ្វើនៅពេលមានទុក្ខព្រួយ ។

សូមគិតអំពីគ្រាដែលព្រះវរបិតាសួគ៌ បានឆ្លើយតបការអធិស្ឋានរបស់អ្នក ដោយបានជួយអ្នកឲ្យមានភាពរីករាយ ។ សូមពិចារណាក្នុងការចែកចាយបទពិសោធន៍មួយ ទៅកាន់សមាជិកគ្រួសារ ឬ មិត្តភក្តិម្នាក់ ។

សូមចងចាំថាត្រូវសរសើរតម្កើង ហើយថ្លែងអំណរគុណដល់ព្រះអម្ចាស់ នៅពេលអ្នករីករាយ និង អធិស្ឋានសុំជំនួយ នៅពេលអ្នកមានទុក្ខព្រួយ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:៣០–៤២

*ព្រះអម្ចាស់អះអាងដល់ពួកបរិសុទ្ធ ហើយប្រទានឱវាទឲ្យពួកគេឧស្សាហ៍ព្យាយាម ក្នុងការរក្សាព្រះបញ្ញត្តិទាំងអស់របស់ទ្រង់*

ពួកបរិសុទ្ធបានស៊ូទ្រាំនឹងការសាកល្បងដ៏ធំ ហើយពួកគេបានដឹងថា ការធ្វើដំណើរបន្តទៅភាគខាងលិចរបស់ពួកគេ គឺជាការលំបាកដ៏ខ្លាំង ។

តើអ្នកគិតថា មានអ្វីខ្លះដែលបានជួយពួកបរិសុទ្ធឲ្យបន្តនៅស្មោះត្រង់ ទោះជាស្ថិតនៅក្រោមស្ថានភាពដ៏លំបាកដូច្នេះក្ដីនោះ ?

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:៣០–៤០ ដោយស្វែងរកគោលលទ្ធិ និង គោលការណ៍ទាំងឡាយ ដែលបានលើកទឹកចិត្តដល់ពួកបរិសុទ្ធ ។

អ្នកអាចនឹងរកឃើញគោលលទ្ធិ និង គោលការណ៍ទាំងឡាយដូចខាងក្រោម ៖

- **យើងពុំគួរខ្លាចមារសត្រូវរបស់យើងទេ ពីព្រោះពួកវាស្ថិតនៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ។**
- **ការសាកល្បងរបស់យើង អាចរៀបចំយើងឲ្យទទួលបានសិរីល្អដែលព្រះមានសម្រាប់យើង ។**
- **បើយើងបន្ទាបខ្លួន ហើយអំពាវនាវដល់ព្រះ នោះព្រះវិញ្ញាណនឹងបំភ្លឺចិត្តយើង ។**
- **បើយើងមានចិត្តស្មោះត្រង់នៅក្នុងការធ្វើតាមព្រះបន្ទូលទាំងអស់ ដែលព្រះអម្ចាស់ប្រទានដល់យើង នោះយើងនឹងមើលឃើញសិរីល្អទ្រង់នៅថ្ងៃណាមួយ ។**
- **ព្រះអម្ចាស់ប្រទានដល់យើងនូវព្រះបន្ទូលទ្រង់ តាមរយៈពួកព្យាការីរបស់ទ្រង់ ។**
- **ព្រះអម្ចាស់អាចរំដោះយើងពីមារសត្រូវរបស់យើង ។**

៤. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអ្នកគិតថា គោលលទ្ធិ និង គោលការណ៍ទាំងនេះ បានជួយដល់ពួកបរិសុទ្ធ ឲ្យបន្តមានចិត្តស្មោះត្រង់ដោយរបៀបណា ?

ខ. តើគោលការណ៍ទាំងនេះ អាចជួយយើងបន្តមានចិត្តស្មោះត្រង់អំឡុងពេលដែលអ្នកជួបបទពិសោធន៍លំបាកផ្ទាល់ខ្លួនរបស់យើងបានយ៉ាងដូចម្ដេច ?

សូមពិចារណាអំពីសារលិខិតទាំងស្រុង ដែលអ្នកគិតថាពួកបរិសុទ្ធអាចបានរៀនពីព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:៣០–៤០ ។

ទោះជាអ្នកបានរកឃើញគោលលទ្ធិ និង គោលការណ៍ផ្សេងៗនៅក្នុងខគម្ពីរទាំងនេះក្ដី ក៏ព្រះអម្ចាស់បានប្រទានការអះអាងដល់ពួកបរិសុទ្ធថា អ្វីៗទាំងឡាយនឹងដោះស្រាយបាន ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:៤១–៤២ ដោយស្វែងរកការអះអាង និង ឱវាទបន្ថែមពីព្រះអម្ចាស់ ។

សូមប្រើអ្វីដែលអ្នកបានរៀន ចេញពីឱវាទរបស់ព្រះអម្ចាស់នៅក្នុង ខទី ៤២ ដើម្បីបញ្ចប់គោលការណ៍ដូចតទៅនេះ ៖ **បើយើងមានចិត្តព្យាយាម នោះសេចក្ដីជំនុំជម្រះរបស់ព្រះអម្ចាស់នឹងមិនធ្លាក់មកលើយើងឡើយ ចំណែកឯសេចក្ដីជំនឿយើងនឹងរឹងមាំ ហើយនៅទីបញ្ចប់ពួកមារសត្រូវនឹងមិនអាចមានជ័យជំនះលើយើងបាននោះទេ ។**

៥. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើគោលការណ៍នេះ អាចជួយអ្នកយ៉ាងដូចម្ដេច ?

ពួកបរិសុទ្ធបានគោរពប្រតិបត្តិ ដល់ព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ ។ ក្រុមទីមួយនៃអ្នកត្រួសត្រាយផ្លូវ បានចាកចេញពី វិនធើរខ្វរទើរ្ស នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ១៨៤៧ ។ ពួកគេបានធ្វើដំណើរជាង ១៦០០ គីឡូម៉ែត្រ និង បានមកដល់ច្រកភ្នំ សលត៍ លេក នៅចុងខែ កក្កដា ឆ្នាំ ១៨៤៧ ។ នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៨៤៧ នៅពេលប្រធាន ព្រិកហាំ យ៉ង់ បានធ្វើដំណើរហួសច្រកភ្នំ សលត៍ លេក លោកបានទទួលការបញ្ជាក់ពីព្រះវិញ្ញាណថា ពួកបរិសុទ្ធបានរកឃើញលំនៅដ្ឋានថ្មីរបស់ពួកគេហើយ ។ នៅពេលនោះលោកបានជិះពីខាងក្រោយរទេះរបស់ វិលហ្វូឌ វូឌរ៉ុព្វ ដោយសារតែលោកមានជំងឺគ្រុនក្ដៅ ។



ប្រធាន វិលហ្វូឌ វូឌរ៉ុព្វ បានតំណាលប្រាប់អំពីដំណើររឿង នៃការយល់ឃើញរបស់ប្រធាន យ៉ង់ ចំពោះជ្រលងភ្នំ សលត៍ លេក ៖ « នៅពេលយើងបានមកដល់. . . មើលឃើញទិដ្ឋភាពទាំងមូលនៃជ្រលងភ្នំ ខ្ញុំបានបង្វែររទេះរបស់ខ្ញុំមួយជុំ ឲ្យបែរទៅទិសខាងលិច ហើយប្រធាន ព្រិកហាំ យ៉ង់ បានក្រោកឡើងពីគ្រែរបស់លោក រួចបានសម្លឹងមើលទៅជុំវិញ ។ នៅពេលកំពុងមើលទៅទិដ្ឋភាពពីខាងមុខយើង លោកបានស្លុងទៅក្នុងការនិមិត្ត អស់មួយសន្ទុះធំ ។ លោកបានឃើញជ្រលងភ្នំនេះពីមុននៅក្នុងការនិមិត្ត ហើយនៅពេលនេះ លោកបានឃើញអនាគតដ៏រុងរឿងនៃស៊ីយ៉ូន និងនៃសាសន៍អ៊ីស្រាអែល ។. . . នៅពេលការនិមិត្តបានបញ្ចប់ទៅ នោះលោកបានមានប្រសាសន៍ថា ‹ វាគ្រប់គ្រាន់ហើយ ។ នេះគឺជាកន្លែងត្រឹមត្រូវហើយ ។ ចូរបន្តទៅមុខទៀត › ។ ដូច្នេះខ្ញុំក៏បានបររទេះទៅកាន់ជុំរំ ដែលបានបោះដោយពួកបរិសុទ្ធបានធ្វើដំណើរទៅពីមុនយើង » (*Teaching of Presidents of the Church: Wilford Woodruff* [ ឆ្នាំ ២០០៤ ] ទំព័រ ១៤៦) ។

ហេតុអ្វីបានជាវាមានសារៈសំខាន់ចំពោះ ព្រិកហាំ យ៉ង់ និង ពួកបរិសុទ្ធ ដែលត្រូវទទួលបានការបញ្ជាក់ថា ជ្រលងភ្នំ សលត៍ លេក គឺជាកន្លែងដែលត្រឹមត្រូវដើម្បីតាំងលំនៅ ? ហេតុអ្វីបានជាវាមានសារៈសំខាន់ចំពោះអ្នក ដែលត្រូវមានការអះអាងថាអ្នកកំពុងតែធ្វើអ្វីដែលព្រះអម្ចាស់សព្វព្រះទ័យឲ្យអ្នកធ្វើហើយនោះ ?

សូមព្យាយាមគោរពតាមរាល់ព្រះបញ្ញត្តិ ហើយស្ដាប់ការអះអាងរបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់អ្នក ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៦:១៩–៤២ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៣០ ៖ ថ្ងៃទី ៤

# ក្រុមអ្នកត្រួតត្រាយរទេះអូស ឆ្នាំ ១៨៥៦–៦០

## បុព្វកថា

ពួកបរិសុទ្ធដែលបានមកដល់ជ្រលងភ្នំ សលត៍ លេក ក្នុងឆ្នាំ ១៨៤៧ បានចេញទៅធ្វើការដាំដុះដាកសិកម្ម និង បង្កើតធនធានដទៃទៀត សម្រាប់អ្នកធ្វើអន្តោប្រវេសន៍នាពេលអនាគត ។ ក្នុងខែ កញ្ញា ឆ្នាំ ១៨៥១ ប្រធាន ព្រិកហាំ យ៉ង់ ព្រមទាំងទីប្រឹក្សារបស់លោក នៅក្នុងគណៈប្រធានទីមួយ បានអំពាវនាវឡើងវិញដល់ពួកបរិសុទ្ធទាំងអស់នៅរដ្ឋ អៃអូវ៉ា និងនៅជុំវិញពិភពលោក មកជួបជុំគ្នានៅជ្រលងភ្នំ សលត៍ លេក ។ មានពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើននាក់បានឆ្លើយតបចំពោះសេចក្ដីអំពាវនាវរបស់ប្រធាន យ៉ង់ ដោយមានការលះបង់ដ៏លើសលប់ ។ សមាជិកក្នុងកូរ៉ុមនៃពួកដប់ពីរនាក់ ត្រូវបានបញ្ជូនឲ្យទៅមើលអ្នកធ្វើអន្តោប្រវេសន៍ ហើយក្នុងឆ្នាំ ១៨៥២ មានពួកបរិសុទ្ធកាន់តែច្រើនបានធ្វើដំណើរដោយការអូសរទេះ ទៅកាន់ជ្រលងភ្នំ សលត៍ លេក ដែលមានចំនួនច្រើនជាងឆ្នាំណាៗទាំងអស់ ។ បន្ថែមពីលើនោះ មានពួកបរិសុទ្ធជាច្រើនធ្វើដំណើរទៅជ្រលងភ្នំ សលត៍ លេក នៅក្នុងក្រុមរទេះរុញ ចន្លោះឆ្នាំ ១៨៥៦ និង ឆ្នាំ ១៨៦០ ។

### ពួកបរិសុទ្ធបានធ្វើតាមដំបូន្មានឲ្យប្រមូលផ្ដុំគ្នានៅ ជ្រលងភ្នំ សលត៍ លេក

សូមស្រមៃថា អ្នកត្រូវបានសុំឲ្យធ្វើដំណើរចម្ងាយប្រមាណ ២០៩០ គីឡូម៉ែត្រ ដោយថ្មើរជើង ខណៈដែលត្រូវអូសរទេះផងដែរ ហើយពួកគេត្រូវបានអនុញ្ញាតឲ្យយករបស់របរផ្ទាល់ខ្លួនតាមខ្លួនតែ ៧.៧ គីឡូក្រាមប៉ុណ្ណោះ ។ តើអ្នកនឹងស្ម័គ្រចិត្តធ្វើដំណើរបែបនេះដែរឬទេ ?

នៅចន្លោះឆ្នាំ ១៨៥៦ និង ១៨៦០ មានពួកបរិសុទ្ធជិត ៣០០០ នាក់បានជ្រើសរើសធ្វើដំណើរទៅទិសខាងលិច កាត់វាលទំនាបនៃសហរដ្ឋអាមេរិកទៅកាន់រដ្ឋ យូថាហ៍ ដោយអូសរបស់របរពួកគេនៅក្នុងរទេះ ។ ក្រុមរទេះរុញច្រើនបំផុតបានដាក់ស្បៀងអាហារ និងសម្ភារផ្ទាល់ខ្លួន និងអាហារខ្លះៗនៅក្នុងរទេះ ហើយដើរពីទីក្រុង អៃអូវ៉ា រដ្ឋ អៃអូវ៉ា ធ្វើដំណើរទៅកាន់ទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍ ។ បីក្រុមចុងក្រោយគេ បានចាប់ផ្ដើមការធ្វើដំណើរនៅទីក្រុង ហ្វ្លរិន រដ្ឋ នេប្រាស្កា ។

បើអាចធ្វើទៅបាន សូមប្រមូលរបស់របរមួយចំនួននៅក្នុងផ្ទះរបស់អ្នក ដែលអ្នកគិតថាអ្នកនឹងយកអ្វីទៅជាមួយ បើសិនជាអ្នកមានវត្តមានក្នុងចំណោមពួកត្រួសត្រាយផ្លូវរទេះអូសទាំងនេះ ។ សូមថ្លឹងរបស់របរដើម្បីដឹង ថាតើអ្នកអាចយករបស់របរអ្វីខ្លះទៅបានក្នុងទម្ងន់ដែលបានកំណត់ ៧.៧ គីឡូក្រាម នោះ ។

នៅពេលអ្នកសិក្សាមេរៀននេះ សូមគិតអំពីសំណួរដូចតទៅ ៖ តើអ្នកគិតថា ហេតុអ្វីបានជាពួកបរិសុទ្ធស្ម័គ្រចិត្តលះបង់យ៉ាងច្រើន ដើម្បីបានទៅដល់រដ្ឋ យូថាហ៍ដូច្នេះ ?



សមាជិកភាគច្រើននៃសាសនាចក្រ រួមទាំងសមាជិកដែលរស់នៅក្រៅសហរដ្ឋផងដែរ បានចង់ទៅជួបជុំជាមួយពួកបរិសុទ្ធនៅរដ្ឋ យូថាហ៍ ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេភាគច្រើនពុំមានប្រាក់កាស ឬ បរិក្ខា ទំនុកបម្រុងគ្រប់គ្រាន់សម្រាប់ខ្លួនគេក្ដី ។ ដោយសារមូលហេតុនេះ ទើបប្រធាន ព្រិកហាំ យ៉ង់ បានបង្កើតមូលនិធិអន្តោប្រវេសន៍អចិន្ត្រៃយ៍ក្នុងឆ្នាំ ១៨៤៩ ។ មូលនិធិនេះបានផ្ដល់ប្រាក់កម្ចីដល់អ្នកធ្វើអន្តោប្រវេសន៍ ដើម្បីជួយពួកគេបង់ថ្លៃការធ្វើដំណើរ និង បរិក្ខារទំនុកបម្រុង ។ ដោយសារតែមានបញ្ហាខាងហិរញ្ញវត្ថុគ្រប់ជំពូក នោះមូលនិធិបានចុះថយ ក្នុងឆ្នាំ ១៨៥៥ ហើយប្រធាន យ៉ង់ បានបារម្ភខ្លាចថានឹងមិនមានប្រាក់គ្រប់គ្រាន់ ដើម្បីជួយដល់ពួកបរិសុទ្ធដែលចង់ធ្វើអន្តោប្រវេសន៍ក្នុងឆ្នាំ ១៨៥៦ បន្តទៀត ។ លោកបានសំណូមពរឲ្យអ្នកធ្វើអន្តោប្រវេសន៍ ដែលត្រូវការជំនួយពីមូលនិធិ គួរតែធ្វើដំណើរដោយអូសរទេះ ជំនួសដោយការដឹកជញ្ជូនតាមរទេះសេះ ។ ក្រុមរទេះអូស ពុំសូវចំណាយច្រើនទេ ហើយអនុញ្ញាតឲ្យពួកបរិសុទ្ធធ្វើអន្តោប្រវេសន៍បានច្រើន ។







ទោះជាការធ្វើដំណើរមានសភាពលំបាកយ៉ាងណាក្តី ក៏ក្រុមអ្នកត្រួតត្រាយរទេះអូសចំនួន ៨ ទៅ ១០ រទេះក្នុងចន្លោះឆ្នាំ ១៨៥៦ និង ១៨៦០ បានបញ្ចប់ការធ្វើដំណើរដោយជោគជ័យ ដោយអត្រាមនុស្សស្លាប់មានប្រមាណ ៣ ភាគរយ បើធៀបទៅនឹងក្រុមធ្វើដំណើរតាមរទេះសេះ ។ ប៉ុន្តែក្នុងឆ្នាំ ១៨៥៦ មានក្រុមរទេះអូសទីបួន និង ទីប្រាំ បានចេញដំណើរយឺតពេលក្នុងរដូវ ហើយបានជួបនឹងការលំបាកដ៏ធ្ងន់ធ្ងរ ។ ពួកគេគឺជាក្រុមរទេះអូស វីលី ដែលដឹកនាំដោយ ជេម ជី វីលី និង ក្រុមរទេះអូស ម៉ាទីន ដែលដឹកនាំដោយ អែតវើត ម៉ាទីន ។ បន្ទាប់ពីបានធ្វើដំណើរប្រមាណ ១៦០០ គីឡូម៉ែត្រ ទៅភាគខាងលិចពីរដ្ឋ អៃអូវ៉ា ក្រុមរទេះអូសទាំងឡាយ បានខ្វះខាតបរិក្ខាទំនុកបម្រុង និង ស្បៀងអាហារជាខ្លាំង ។ ក្រុមទាំងពីរនេះក៏បានជួបនឹងព្យុះរដូវរងា ដែលបានបង្អាក់ដល់ការធ្វើដំណើរទៅមុខរបស់ពួកគេដែរ ។ ពួកបរិសុទ្ធទាំងនេះបានរងទុក្ខយ៉ាងលំបាកនៅក្នុងភាពត្រជាក់ និង ទឹកកកដ៏ច្រើនសន្ធឹកនោះ ។

នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៨៥៦ សមាជិកក្នុងក្រុមរទេះអូសរបស់ ម៉ាទីន ត្រូវឆ្លងកាត់ទន្លេដ៏ធំមួយ អំឡុងពេលព្យុះទឹកកកមួយ ។ សមាជិកក្នុងក្រុមនោះជាច្រើននាក់ រួមមានទាំង អើរ៉ុន ចាកសុន ផងដែរ បានទន់ខ្សោយ ហើយបានធ្លាក់ខ្លួនឈឺ រីឯការធ្វើដំណើរឆ្លងកាត់ទន្លេ គឺមានឥទ្ធិពលកាន់តែអាក្រក់លើពួកគេ ។ អេលីស្សាប៊ែត ចាកសុន បានពិពណ៌នាអំពីអ្វីដែលបានកើតឡើងចំពោះស្វាមីរបស់គាត់នៅពីរបីថ្ងៃក្រោយមក ៖

« ខ្ញុំបានចូលដេក នៅម៉ោងប្រហែលជាប្រាំបួន ។. . . វាដូចជា ខ្ញុំបានដេករហូតដល់ម៉ោងប្រហែលជាពាក់កណ្ដាលអធ្រាត្រ ។ ខ្ញុំត្រជាក់យ៉ាងខ្លាំង ។ អាកាសធាតុកាន់តែត្រជាក់ខ្លាំង ។ ខ្ញុំបានស្ដាប់ថាតើស្វាមីរបស់ខ្ញុំនៅមានដង្ហើមឬទេ–ព្រោះគាត់ដេកនឹងថ្កល់ ។ ខ្ញុំស្ដាប់ពុំឮដង្ហើមរបស់គាត់ទេ ។ ខ្ញុំបានដឹងភ្លាម ។ ខ្ញុំបានដាក់ដៃខ្ញុំលើខ្លួនគាត់ នៅពេលនោះបានដឹងដោយរន្ធត់ចិត្តជាខ្លាំង ហើយភាពភ័យខ្លាចបំផុតរបស់ខ្ញុំបានចាប់ផ្ដើម ។ ស្វាមីរបស់ខ្ញុំបាន *ស្លាប់ហើយ* ។. . . ខ្ញុំបានស្រែកហៅរកជំនួយពីមនុស្សដែលនៅក្នុងតង់ផ្សេងទៀត ។ ពួកគេពុំអាចជួយខ្ញុំ អ្វីបានទេ ។. . . នៅពេលព្រឹកឡើង នោះបុរសមួយចំនួនមកពីក្នុងក្រុម បានរៀបចំបញ្ចុះសពរបស់គាត់ ។. . . ពួកគេបានរុំសពគាត់នៅក្នុងភួយមួយ ហើយបានដាក់គាត់នៅក្នុងគំនរនៃមនុស្សស្លាប់ដប់បីនាក់ទៀត រួចក៏គ្របដណ្ដប់គាត់ដោយពំនូកទឹកកក ។ ដីមានសភាពកករឹងដែលបណ្ដាលឲ្យពួកគេពុំអាចជីករណ្ដៅផ្នូរបានឡើយ » ( *Leaves from the Life of Elizabeth Horrocks Jackson Kingsford* [ ឆ្នាំ ១៩០៨ ] ទំព័រ ៦–៧ សូមមើលផងដែរ history.lds.org ) ។

១. បើអ្នកអាចសរសេរសំបុត្រទៅកាន់ អេលីស្សាប៊ែត ចាកសុន នៅអំឡុងគ្រាដ៏លំបាកនេះ តើអ្នកនឹងនិយាយអ្វីខ្លះ ដើម្បីលើកទឹកចិត្តកុំឲ្យគាត់បោះបង់ចោលការធ្វើដំណើរនេះ ? សូមសរសេរសំបុត្រខ្លីមួយទៅកាន់ អេលីស្សាប៊ែត ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។



សូមស្វែងរកភស្ដុតាងនៃសេចក្ដីជំនឿរបស់ អេលីស្សាប៊ែត នៅក្នុងដំណើររឿងរបស់គាត់ ៖

« សាកសពរបស់គាត់ត្រូវបានទុកនៅទីនោះ ដើម្បីសម្រាកក្នុងភាពស្ងប់ស្ងាត់ដរាបដល់ត្រែរបស់ព្រះអម្ចាស់នឹងបន្លឺឡើង ហើយមនុស្សដែលស្លាប់ទៅក្នុងព្រះគ្រីស្ទនឹងក្រោកឡើង ហើយឆ្ពោះទៅរកព្រឹកនៃការរស់ឡើងវិញទីមួយ ។ លំដាប់នោះ យើងនឹងរួបរួមចិត្ត និង ជីវិតសាជាថ្មី ចំណែកឯភាពអស់កល្បជានិច្ចនឹងផ្ដល់ជីវិតឲ្យយើងរស់នៅជានិរន្តរ ។

« ខ្ញុំពុំចង់ពិពណ៌នាអំពីអារម្មណ៍របស់ខ្ញុំ ពេលឃើញថាខ្លួនត្រូវបានបន្សល់ទុកឲ្យនៅជាស្ត្រីមេម៉ាយជាមួយនឹងកូនបីនាក់ ស្ថិតនៅក្រោមស្ថានភាពដ៏ឈឺចាប់ដូច្នេះទេ ។ ខ្ញុំពុំអាចធ្វើបានទេ ។ ប៉ុន្តែខ្ញុំជឿទៅលើកំណត់ត្រាទេវតា ដែលបានពិពណ៌នាក្នុងកំណត់ត្រានៅឯស្ថានលើ ហើយថាការរងទុក្ខរបស់ខ្ញុំដោយសារតែដំណឹងល្អ នឹងញែកចេញជាបរិសុទ្ធចំពោះខ្ញុំ សម្រាប់ជាសេចក្ដីល្អរបស់ខ្ញុំ » ( *Leaves,*ខទី ៧ សូមមើលផងដែរ history.lds.org ) ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ចេញពីកំណត់ត្រារបស់ អេលីស្សាប៊ែត តើអ្វីដែលជាគោលបំណងមួយចំពោះការរងទុក្ខ និង ការលះបង់ចំពោះដំណឹងល្អ ?

ខ. ឃ្លា « ញែកចេញជាបរិសុទ្ធចំពោះខ្ញុំ សម្រាប់ជាសេចក្ដីល្អរបស់ខ្ញុំ » មានន័យថា ការរងទុក្ខរបស់ អេលីស្សាប៊ែត នឹងត្រូវបានធ្វើឲ្យពិសិដ្ឋ និង បរិសុទ្ធសម្រាប់ជាផលប្រយោជន៍ដល់គាត់ ។ ទោះជាអ្នកពុំរងទុក្ខដូចជាគាត់យ៉ាងណាក្ដី តើអ្នកអាចនឹងត្រូវរងទុក្ខដោយសារតែដំណឹងល្អតាមរបៀបណាខ្លះ ? តើអ្នកអាចនឹងទទួលពរ តាមរយៈបទពិសោធន៍ទាំងនេះយ៉ាងដូចម្ដេច ?

អំឡុងពេលពីរបីថ្ងៃក្រោយបន្ទាប់ពី អើរ៉ុន ចាកសុន បានស្លាប់ នោះក្រុមរទេះអូស ម៉ាទីន បានធ្វើដំណើរឆ្ពោះទៅមុខទៀតបានប្រមាណ ១៦ គីឡូម៉ែត្រ ។ មនុស្សជាច្រើនបានស្លាប់អំឡុងពេលនេះ ។ នាយប់មួយ អំឡុងពេលធ្វើដំណើរនេះ គ្មាននរណាម្នាក់មានកម្លាំងគ្រប់គ្រាន់ដើម្បីបោះតង់នោះទេ ។ អេលីស្សាប៊ែត ចាកសុន បានអង្គុយនៅលើថ្មមួយដុំ ដែលកូនម្នាក់អង្គុយនៅលើភ្លៅ ហើយកូនម្នាក់ទៀតអង្គុយនៅសងខាងគាត់ ។ គាត់បាននៅអង្គុយដូច្នោះរហូតដល់ព្រឹក ។ អេលីស្សាប៊ែត បាក់ទឹកចិត្តយ៉ាងខ្លាំង។ ក្រោយមក នាយប់ថ្ងៃទី ២៧ ខែ តុលា គាត់បានទទួលបទពិសោធន៍មួយ ដែលផ្ដល់សេចក្ដីសង្ឃឹមនៃការសង្គ្រោះដល់គាត់ ៖

« មនុស្សនឹងអាចយល់ភ្លាមថា នៅក្រោមស្ថានភាពដ៏អាក្រក់ដូច្នេះ ខ្ញុំអស់សង្ឃឹមជាខ្លាំង ។ ខ្ញុំនៅចម្ងាយប្រាំបួនពាន់ប្រាំរយ ឬ មួយម៉ឺនមួយពាន់គីឡូម៉ែតពីដែនដីកំណើតរបស់ខ្ញុំ នៅក្នុងតំបន់ព្រៃភ្នំក្រោមថ្ម នៅក្នុងស្ថានភាពដ៏អស់សង្ឃឹម ដែលផ្ទៃដីគ្របដណ្ដប់ដោយព្រិល ទឹកត្រូវបានគ្របដណ្ដប់ដោយទឹកកក ហើយខ្ញុំនៅជាមួយនឹងកូនបីនាក់ដែលគ្មានឪពុក គ្មានអ្វីជួយការពារពួកគេពីព្យុះដ៏កំណាចឡើយ ។ ពេលខ្ញុំចូលដេកនៅពេលយប់ នៅថ្ងៃទី ២៧ ខែ តុលា នោះខ្ញុំបានមានវិវរណៈយ៉ាងអស្ចារ្យមួយ ។ នៅក្នុងសុបិនរបស់ខ្ញុំ ប្ដីរបស់ខ្ញុំបានឈរនៅជិតខ្ញុំ ហើយបាននិយាយថា— « ចូររីករាយឡើង អែលីស្សាប៉ែត ការជួយសង្គ្រោះជិតមកដល់ហើយ › » ( *Leaves,* ៨ សូមមើលផងដែរ history.lds.org ) ។

ក្ដីសុបិនរបស់ អែលីស្សាប៉ែត ត្រូវបានបំពេញ ។ ស្អែកឡើង ក្រុមជួយសង្គ្រោះទីមួយមកពីទីក្រុង សលត៍ លេក បានរកឃើញក្រុមរទេះអូស ម៉ាទីន ។

នៅថ្ងៃទី ៤ ខែ តុលា ឆ្នាំ ១៨៥៦ អស់ជាច្រើនសប្ដាហ៍មុនពេលមានព្យុះទឹកកក បានវាយប្រហារលើក្រុមរទេះអូស នោះពួកអ្នកធ្វើដំណើរបានរាយការណ៍ទៅប្រធាន ព្រិកហាំ យ៉ង់ ថា ក្រុមត្រួសត្រាយផ្លូវ កំពុងស្ថិតនៅលើទីវាលទំនាបនៅឡើយ ហើយនៅចម្ងាយផ្លូវរាប់រយគីឡូម៉ែតទៀតឯណោះ ។ នៅថ្ងៃស្អែកឡើង ក្នុងការប្រជុំថ្ងៃអាទិត្យ ព្រិកហាំ យ៉ង់ បានថ្លែងអំពីការជួយសង្គ្រោះដល់ពួកត្រួសត្រាយផ្លូវរទេះអូសទាំងនេះ ៖



« ពួកបងប្អូនប្រុសស្រីរបស់យើងជាច្រើននាក់កំពុងស្ថិតនៅតំបន់វាលទំនាបដោយមានរទេះអូសជាច្រើន ហើយប្រហែលជាពួកគេជាច្រើន ឥឡូវនេះស្ថិតនៅចម្ងាយប្រមាណ ១១០០ គីឡូម៉ែត្រពីទីកន្លែងនេះ យើងត្រូវនាំពួកគេមកទីនេះ ដូច្នេះយើងត្រូវតែបញ្ជូនជំនួយដល់ពួកគេ ។. . .

« នោះជាសាសនារបស់ខ្ញុំ នេះជាការបង្ហាញប្រាប់ដល់ខ្ញុំពីព្រះវិញ្ញាណបរិសុទ្ធ ថាត្រូវសង្គ្រោះដល់មនុស្ស ។. . . នេះគឺជាសេចក្ដីសង្គ្រោះ ដែលខ្ញុំកំពុងស្វែងរកនាពេលនេះ ដើម្បីសង្គ្រោះបងប្អូនប្រុសរបស់យើង ដែលនឹងត្រូវវិនាស ឬ រងទុក្ខដ៏ធ្ងន់ធ្ងរ បើសិនជាយើងមិនបញ្ជូនជំនួយដល់ពួកគេទេនោះ ។

« ខ្ញុំនឹងពុំរង់ចាំរហូតដល់ថ្ងៃស្អែក ឬ រហូតដល់ថ្ងៃស្អែកឡើយ ខ្ញុំនឹងហៅឲ្យពួកប៊ីស្សពនៅថ្ងៃនេះ រកគោល្អៗចំនួន ៦០ ក្បាល និង រទេះ ១២ ឬ ១៥ រទេះ. . . [ ព្រមទាំង ] ម្សៅ ១២ តោន និង មនុស្សបររទេះរឹងមាំ ៤០ នាក់ ក្រៅពីអ្នកទាំងឡាយដែលដឹកនាំក្រុម ។. . .

« ខ្ញុំនឹងប្រាប់អ្នកទាំងអស់គ្នាថា សេចក្ដីជំនឿ សាសនា និង កិច្ចការសាសនារបស់អ្នក នឹងពុំសង្គ្រោះដល់ព្រលឹងអ្នកនៅក្នុងនគរសេឡេស្ទាលនៃព្រះរបស់យើងឡើយ លុះត្រាតែអ្នកអនុវត្តនូវគោលការណ៍ទាំងឡាយនេះ ដែលខ្ញុំកំពុងតែបង្រៀនអ្នកនាពេលនេះប៉ុណ្ណោះ ។ ចូរចេញទៅ ហើយនាំអ្នកទាំងឡាយដែលកំពុងតែនៅលើវាលទំនាបនាពេលឥឡូវនេះ » ( « Remarks » *Deseret News* ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៨៥៦ ទំព័រ ២៥២ ) ។

តើអ្វីជាគោលការណ៍មួយដែលប្រធាន ព្រិកហាំ យ៉ង់ បានបង្រៀនដល់ពួកបរិសុទ្ធ ?

មានបុរស និង ស្ត្រីជាច្រើនបានឆ្លើយតបទៅនឹងការស្នើសុំរបស់ព្យាការី ឲ្យជួយដល់ពួកបរិសុទ្ធដែលកំពុងតែរងទុក្ខ ។ អំឡុងពេលពីរថ្ងៃបន្ទាប់ពីទេសនកថារបស់ប្រធាន យ៉ង់ នោះមានបុរសៗបានចេញទៅរកពួកអន្តោប្រវេសន៍ ដោយបររទេះគោដឹកជញ្ជូនសម្ភារជាច្រើន ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើកិច្ចខិតខំជួយសង្គ្រោះនេះ អាចជាការលះបង់មួយចំពោះពួកបរិសុទ្ធនៅជ្រលងភ្នំ សលត៍ លេក យ៉ាងដូចម្ដេច ?

ខ. តើការលះបង់មួយចំនួនដែលយើងអាចធ្វើ ដើម្បីជួយដល់អ្នកទាំងឡាយដែលមានសេចក្ដីត្រូវការខាងរូបកាយមានអ្វីខ្លះ ?

គ. តើការលះបង់មួយចំនួនដែលយើងអាចធ្វើ ដើម្បីជួយដល់អ្នកទាំងឡាយដែលមានសេចក្ដីត្រូវការខាងវិញ្ញាណមានអ្វីខ្លះ ?

នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៨៥៦ ក្រុមរទេះសេះជួយសង្គ្រោះទីមួយ បានរកឃើញក្រុមរបស់ វីលី ។ ក្រុមរទេះសេះមួយចំនួនបានបន្តនៅជាមួយនឹងក្រុម វីលី ប៉ុន្តែពួកគេភាគច្រើន បានបន្តទៅជួយដល់ក្រុម ម៉ាទីន ។ នៅថ្ងៃទី ២៣ ខែ តុលា ក្រុមវីលីបានធ្វើដំណើរ ២៤ គីឡូម៉ែត្រ ឆ្លងកាត់ស្ថានភាពមានព្យុះជាខ្លាំង ។ ក្នុងចម្ងាយ ៥ គីឡូម៉ែត្រ មានទាំងការឡើងភ្នំ ដែលឈ្មោះថា រ៉កគី រីដ ដែលមានកម្ពស់ ១៨០ ម៉ែត្រ ផងដែរ ។

ប្រធាន ជែមស៍ អ៊ី ហ្វៅស្ត ក្នុងគណៈប្រធានទីមួយ បានពិពណ៌នាអំពីភាពក្លាហានរបស់កុមារត្រួសត្រាយផ្លូវក្នុងក្រុម វីលី ៖



« សមាជិកនៃក្រុមវីលីដប់បីនាក់ ដែលបានស្លាប់ដោយសារភាពត្រជាក់ខ្លាំង ការនឿយហត់ និង ការស្រេកឃ្លាន ត្រូវបានកប់នៅក្នុងផ្នូររួមនៅ រ៉ក ក្រិក ហូឡូ ។. . . មានមនុស្សពីរនាក់នៃអ្នកទាំងនោះ ដែលបានកប់នៅ រ៉ក ក្រិក ហូឡូ គឺជាកុមារដ៏ក្លាហានដែលមានវ័យនៅទន់ខ្ចី ៖ បូឌីល [ ម៉ូធិនសិន ] អាយុ [ ដប់មួយឆ្នាំ ] មកពីប្រទេស ដាណាម៉ាក និង ជេម ខឺតវូឌ អាយុដប់មួយឆ្នាំ មកពីប្រទេស ស្កុតឡង់ ។

« ជាក់ស្ដែង បូឌីល ត្រូវបានចាត់ឲ្យមើលថែកុមារតូចៗមួយចំនួន នៅពេលពួកគេដើរឆ្លងកាត់ រ៉កគី រីជ ។ នៅពេលពួកគេបានមកដល់ នាងត្រូវបានចាត់ឲ្យទៅប្រមូលឧសមកបង្កាត់ភ្លើង ។ គេបានឃើញនាងរងាស្លាប់នៅលើកង់រទេះអូសរបស់នាង ដោយដៃក្ដាប់ស្មៅជាប់ ។

« ខ្ញុំនឹងប្រាប់អ្នកអំពី ជេម ខឺតវូឌ ។ ជេម មកពី ហ្គ្លាសហ្គោ ប្រទេស ស្កុតឡង់ ។ នៅក្នុងការធ្វើដំណើរទៅភាគខាងលិច ជេម បានទៅជាមួយម្ដាយមេម៉ាយរបស់គាត់ និង បងប្អូនប្រុសបីនាក់ ដែលក្នុងនោះគឺ ថូម៉ាស ដែលមានអាយុដប់ប្រាំបួនឆ្នាំ ជាមនុស្សពិការ ដែលត្រូវជិះនៅលើរទេះរុញ ។ ទំនួលខុសត្រូវចម្បងរបស់ ជេម នៅក្នុងការធ្វើដំណើរនោះ គឺត្រូវមើលថែប្អូនប្រុសអាយុបួនឆ្នាំគាត់ឈ្មោះ យ៉ូសែប ខណៈដែលម្ដាយរបស់គាត់ និងបងប្រុសច្បងរបស់គាត់ រ៉ូប៊ើត ត្រូវអូសរទេះ ។ នៅពេលពួកគេបានឡើងទៅដល់ រ៉កគី រីជ វាមានធ្លាក់ព្រិល ហើយខ្យល់បក់ត្រជាក់យ៉ាងខ្លាំង ។ វាបាននាំឲ្យក្រុមទាំងមូលធ្វើដំណើរ [ ម្ភៃ ] ម៉ោងក្នុងចម្ងាយម្ភៃបួនគីឡូម៉ែត្រ ។ នៅពេលប្អូនប្រុស យ៉ូសែប ខ្សោយពេក ពុំអាចដើរបាន នោះ ជេម ដែលជាបងប្រុស ត្រូវលើកអៀវប្អូន ដោយគ្មានជម្រើសណាផ្សេងទេ ។ ជេម និង យ៉ូសែប បានធ្វើដំណើរដោយយឺតៗទៅកាន់ជំរុំមុន ទុកឲ្យក្រុមធំនោះមកតាមក្រោយ ។ ទីបំផុត នៅពេលអ្នកទាំងពីរបានមកដល់កន្លែងភ្នក់ភ្លើង នោះជេម ‹ ដោយបានអនុវត្តនូវកិច្ចការរបស់ខ្លួនស្មោះត្រង់យ៉ាងខ្លាំងបានដួលចុះ រួចក៏ស្លាប់ទៅ ដោយសារតែការរងនឹងធាតុត្រជាក់ខ្លាំង និងខំប្រឹងហួសកម្លាំងពេកនោះ › » ( « A Priceless Heritage » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩២ ទំព័រ ៨៤–៨៥ ) ។

ប្រធាន ថូម៉ាស អេស ម៉នសុន បានពន្យល់អំពីរបៀបយើងអាចរស់នៅតាមគោលការណ៍នៃការជួយមនុស្សដែលមានសេចក្ដីត្រូវការនាពេលបច្ចុប្បន្ននេះ ។ នៅពេលអ្នកអានអ្វីដែលគាត់បានបង្រៀន សូមស្វែងរកមធ្យោបាយបន្ថែមទៀតដែលយើងអាចជួយមនុស្សទូទៅបាននាពេលសព្វថ្ងៃនេះ ។



« អស់រយៈពេលជាច្រើនឆ្នាំក្នុងនាមជាពួកអ្នកមានសិទ្ធិអំណាចទូទៅមួយរូប ខ្ញុំបានគូសសម្គាល់អំពីសេចក្ដីត្រូវការដើម្បី ‹ ជួយសង្គ្រោះ › បងប្អូនប្រុសស្រីយើងពីស្ថានភាពខុសគ្នាជាច្រើន ដែលអាចនឹងដកយកពរជ័យទាំងអស់ ដែលដំណឹងល្អអាចផ្ដល់ឲ្យ ។ ចាប់តាំងពីខ្ញុំបានក្លាយជាប្រធាននៃសាសនាចក្រមក ខ្ញុំបានទទួលអារម្មណ៍នៃភាពបន្ទាន់មានកាន់តែខ្លាំងឡើងចំពោះយើង ដែលត្រូវរួមចំណែកនៅក្នុងកិច្ចខិតខំសង្គ្រោះនេះ ។ ក្នុងនាមជាសមាជិកដ៏ស្មោះត្រង់នៃសាសនាចក្រត្រូវឈោងទៅជួយមនុស្សដោយសេចក្ដីស្រឡាញ់ និង ការយោគយល់ នោះមានមនុស្សជាច្រើនបានត្រឡប់មកសកម្មទាំងស្រុងឡើងវិញ ហើយរីករាយនឹងពរជ័យដែលបានផ្ដល់ឲ្យបន្ថែមទៀតនៅក្នុងជីវិតរបស់ពួកគេ ។ មានអ្វីជាច្រើនដែលត្រូវធ្វើនៅក្នុងចក្ខុវិស័យនេះស្រេចទៅហើយ ហើយខ្ញុំសូមលើកទឹកចិត្តមនុស្សទាំងអស់ ឲ្យបន្តឈោងទៅជួយមនុស្សទូទៅ ។ ព្រះអម្ចាស់បានមានព្រះបន្ទូលថា ‹ កាលណាអ្នកបានប្រែចិត្តវិលមកវិញ នោះចូរចម្រើនឲ្យបងប្អូនអ្នកបានខ្ជាប់ខ្ជួនឡើង › (លូកា ២២:៣២ ) Reach Out to Rescue »; (“Reach Out to Rescue”; LDS.org) ។

៤. សូមសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នកអំពីគ្រាមួយដែលអ្នកបានឃើញមនុស្សណាម្នាក់ ជួយមនុស្សដែលមានសេចក្ដីត្រូវការខាងវិញ្ញាណ និង ខាងសាច់ឈាម ។ តើមនុស្សម្នាក់នោះ បានជួយតាមរបៀបណា ? តើការបម្រើនោះបានប្រទានពរទាំងមនុស្សដែលបម្រើគេ និង មនុស្សដែលទទួលបានការបម្រើនោះយ៉ាងដូចម្ដេច ?

សូមយកពេលបន្តិចដើម្បីពិចារណា ថាតើនរណានៅជុំវិញខ្លួនអ្នកដែលត្រូវការជំនួយខាងវិញ្ញាណ និង ខាងសាច់ឈាម ។ តើអ្នកអាចជួយពួកគេបាន តាមរបៀបណាខ្លះ ?

ដំណើររឿងខាងក្រោមនេះ អាចជួយអ្នករកឃើញពរជ័យមួយចំនួន ដែលពួកបរិសុទ្ធទទួល ដោយសារតែពួកគេបានតស៊ូនៅក្នុងការរងទុក្ខដោយមានចិត្តស្មោះត្រង់ ៖



ក្នុងឆ្នាំ ១៨៥៦ ហ្វ្រែនស៊ីស និង បេតស៊ី វិបស្ទើរ មានប្រាក់គ្រប់គ្រាន់ដើម្បីធ្វើដំណើរទៅរដ្ឋ យូថាហ៍ តាមរទេះសេះ ប៉ុន្តែពួកគេបានបរិច្ចាគប្រាក់របស់ពួកគេចូលមូលនិធិអន្តោប្រវេសន៍អចិន្ត្រៃយ៍ ។ ការបរិច្ចាគរបស់ពួកគេបានអនុញ្ញាតឲ្យមនុស្សប្រាំបួននាក់បន្ថែមទៀត អាចធ្វើដំណើរតាមរទេះអូស ។ បងប្រុង និងបងស្រី វិបស្ទើរ ដែលកំពុងមានកូននោះ បានធ្វើដំណើរទៅទីក្រុង សលត៍ លេក ជាមួយក្រុមរទេះអូស ម៉ាទីន ហើយបានរងទុក្ខលំបាកនៅតាមផ្លូវជាមួយនឹងមនុស្សក្នុងក្រុមផ្សេង ៗទៀត ។

ប៉ុន្មានឆ្នាំក្រោយមក នៅពេលបងប្រុស វិបស្ទើរ អង្គុយនៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យ នោះគាត់បានស្ដាប់ពួសមាជិកសាសនាចក្រមួយចំនួន រិះគន់ដល់ថ្នាក់ដឹកនាំសាសនាចក្រ ចំពោះទុក្ខលំបាករបស់ក្រុមរទេះអូស ។ ដោយពុំអាចទប់បាន គាត់បានក្រោកឈរឡើង រួចថ្លែងទីបន្ទាល់អំពីពរជ័យកាលនៅជាមួយក្រុមរទេះអូស ម៉ាទីន ៖

> « ខ្ញុំសូមឲ្យអ្នកបញ្ឈប់ការរិះគន់នេះ ដ្បិតអ្នកកំពុងតែពិភាក្សាអំពីរឿងមួយដែលអ្នកពុំដឹងអ្វីបន្តិចសោះ ។ អង្គហេតុជាប្រវត្តិសាស្ត្រ ពុំមានន័យអ្វីទេនៅទីនេះ ដ្បិតវាពុំបានផ្ដល់នូវការបកប្រែត្រឹមត្រូវចំពោះសំណួរដែលជាប់ពាក់ព័ន្ធទេ ។ តើវាជាកំហុសឆ្គងទេ ដែលបញ្ជូនក្រុមរទេះអូសចេញទៅយឺតពេលនៅក្នុងពេលនោះ ? មែនហើយ ។ ប៉ុន្តែខ្ញុំបាននៅក្នុងក្រុមនោះ ហើយភរិយារបស់ខ្ញុំក៏នៅទីនោះដែរ ។. . . យើងបានរងទុក្ខហួសពីអ្វីដែល អ្នកគិតឃើញទៅទៀត ហើយមានមនុស្សជាច្រើនបានស្លាប់ដោយ ហេវហត់ និងសេចក្ដីស្រេកឃ្លាន ។ តើអ្នកធ្លាប់ឮមនុស្សដែលនៅមានជីវិតពីក្រុមនោះថ្លែងពាក្យរិះគន់ឬទេ ?. . . យើងគ្រប់គ្នាបានឆ្លងកាត់ដោយមានចំណេះដឹងដ៏ពិតថា ព្រះមានព្រះជន្មរស់ ដ្បិតយើងបានស្គាល់ទ្រង់នៅក្នុងគ្រាដ៏លំបាក [ ក្នុងគ្រាដែលត្រូវការដ៏ខ្លាំងបំផុត ] របស់យើង ។
>
> « ខ្ញុំបានទាញរទេះខ្ញុំពេលខ្ញុំខ្សោយកម្លាំង ហើយល្ហិតល្ហៃដោយសារជំងឺ និង កង្វះអាហារ ដែលធ្វើឲ្យខ្ញុំពិបាកនឹងបោះជំហានទៅមុខបំផុត ។ ខ្ញុំបានសម្លឹងទៅមុខ ហើយឃើញវាលខ្សាច់ ឬ ទីទួល ហើយបាននិយាយថាខ្ញុំអាចដើរទៅបានតែប៉ុណ្ណេះទេ ហើយខ្ញុំត្រូវតែបញ្ឈប់ការធ្វើដំណើរនៅត្រង់នេះ ដ្បិតខ្ញុំមិនអាចទាញរទេះខ្ញុំឆ្លងកាត់ទីនោះឡើយ ។ ខ្ញុំបានដើរទៅវាលខ្សាច់នោះ ហើយកាលខ្ញុំបានទៅដល់ហើយនោះ រទេះបានចាប់ផ្ដើមរុញខ្ញុំ ។ ខ្ញុំបានងាកមើលក្រោយជាច្រើនដង ដើម្បីមើលថាតើនរណាដែលបានរុញរទេះរបស់ខ្ញុំ តែខ្ញុំមើលពុំឃើញថាមាននរណាម្នាក់ទេ ។ រួចហើយខ្ញុំដឹងថា ពួកទេវតានៃព្រះគង់នៅទីនោះ ។
>
> « តើខ្ញុំសោកស្ដាយដែលខ្ញុំបានជ្រើសរើសធ្វើដំណើរមកដោយការអូសរទេះឬទេ ? អត់ទេ ។ ទេ ។ គ្មានសោះឡើយនៅក្នុងជីវិតរបស់ខ្ញុំ ទាំងនាពេលនោះ ហើយពេលនេះ ក៏គ្មានដែរ ។ តម្លៃដែលយើងបានបង់ថ្លៃ ដើម្បីស្គាល់ព្រះ គឺជាឯកសិទ្ធិដើម្បីបង់ថ្លៃ ហើយខ្ញុំមានអំណរគុណដែលខ្ញុំមានឯកសិទ្ធិដើម្បីមកដល់ស៊ីយ៉ូន នៅក្នុងក្រុមរទេះអូស ម៉ាទីន » ( នៅក្នុង William R. Palmer, « Pioneers of Southern Utah, » *The Instructor* ខែ ឧសភា ឆ្នាំ ១៩៤៤ ទំព័រ ២១៧–១៨ ) ។

គោលការណ៍មួយដែលយើងអាចរៀនចេញពីទីបន្ទាល់របស់ ហ្វ្រែនស៊ីស វិបស្ទើរ គឺ **បើសិនជាយើងតស៊ូក្នុងការរងទុក្ខដោយមានចិត្តស្មោះត្រង់ នោះយើងអាចស្គាល់ព្រះ ។**

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើឥរិយាបទ ឬ អាកប្បកិរិយាប្រភេទណាខ្លះ ដែលអ្នកបានឃើញមាននៅក្នុងខ្លួនមនុស្សទាំងឡាយ ដែលស៊ូទ្រាំក្នុងការរងទុក្ខដោយមានចិត្តស្មោះត្រង់នោះ ?

ខ. តើអ្នកបានស្គាល់ព្រះតាមរយៈការសាកល្បងដែលអ្នកបានជួបប្រទះដោយរបៀបណា ?

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សាមេរៀនអំពី « ក្រុមអ្នកត្រួតត្រាយរទេះអូស ឆ្នាំ ១៨៥៦–៦០ » ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៣១ ៖ ថ្ងៃទី ១

# សង្គ្រាមនៅរដ្ឋ យូថាហ៍ និង ការសម្លាប់រង្គាលនៅភ្នំម៉េដូ

## បុព្វកថា

អំឡុងទសវត្សរ៍ឆ្នាំ ១៨៥០ ភាពតានតឹង និង ទំនាក់ទំនងយល់ច្រឡំរវាងពួកបរិសុទ្ធថ្ងៃចុងក្រោយ និង ពួកមន្ត្រីរដ្ឋាភិបាលសហរដ្ឋអាមេរិកបាននាំឲ្យមានសង្គ្រាមនៅរដ្ឋយូថាហ៍នាឆ្នាំ ១៨៥៧–៥៨ ។ ក្នុងខែ កញ្ញា ឆ្នាំ ១៨៥៧ មានជម្លោះមួយកើតឡើងផងដែររវាងពួកបរិសុទ្ធមួយចំនួន និង សមាជិកក្រុមរទេះសេះដែលបានធ្វើអន្តោប្រវេសន៍ឆ្លងកាត់រដ្ឋ យូថាហ៍ ។ ដោយសារតែបានជំរុញដោយកំហឹង និង ភាពភ័យខ្លាច នោះពួកបរិសុទ្ធថ្ងៃចុងក្រោយមួយចំនួននៅខាងត្បូងរដ្ឋយូថាហ៍ បានរៀបផែនការ ហើយអនុវត្តការសម្លាប់រង្គាលពួកអន្តោប្រវេសន៍ប្រមាណជា ១២០ នាក់ ដែលធ្វើដំណើរទៅរដ្ឋ កាលីហ្វញ៉ា ។ ភាពសាហាវយ៉ង់ឃ្នងនេះត្រូវបានគេហៅពេលនេះថាជាការសម្លាប់រង្គាលនៅភ្នំម៉េដូ ។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅ LDS.org ជ្រើសរើស Gospel Topics រួចស្វែងរក Mountain Meadows Massacre ។

### ភាពតានតឹងដែលបានកើតឡើងរវាងពួកបរិសុទ្ធថ្ងៃចុងក្រោយ និង រដ្ឋាភិបាលសហរដ្ឋអាមេរិក

នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៨៥៧ ប្រធាន ព្រិកហាំ យ៉ង់ បានមានវត្តមានជាមួយនឹងក្រុមពួកបរិសុទ្ធមួយក្រុម ដែលកំពុងប្រារព្ធខួបរំឭក១០ ឆ្នាំនៃការមកដល់របស់ពួកគេនៅក្នុងជ្រលងភ្នំ សលត៍ លេក ពេលនោះហើយដែលលោកបានទទួលដំណឹងទាន់ហេតុការណ៍ថា កងទ័ពមួយក្រុមកំពុងមកកាន់ទីក្រុង សលត៍ លេក ។ កាលពីប៉ុន្មានឆ្នាំមុន មានការមិនយល់ព្រម និង ការខ្វែងគំនិតគ្នាដែលបន្សល់ទុកការកើនឡើងនូវភាពតានតឹងរវាងពួកបរិសុទ្ធថ្ងៃចុងក្រោយ និង ពួកមន្ត្រីរាជការនៃរដ្ឋាភិបាលសហរដ្ឋ ។ ពួកបរិសុទ្ធចង់បានអ្នកដឹកនាំដែលពួកគេបានជ្រើសរើស ហើយបានបដិសេធនូវការចាត់តាំងរបស់សហពន្ធ័ ដែលមិនបានឲ្យតម្លៃដល់ពួកគេ ។ នោះនាំឲ្យមន្ត្រីសហព័ន្ធមួយចំនួនបានគិតថា ពួកគេបានបះបោរទាស់នឹងរដ្ឋាភិបាលអាមេរិក ។ ដោយគ្មានការអនុមតិមកពីសភា នោះប្រធានាធិបតី ជេម ប៊ុជរាណា បានបញ្ជូនកងទ័ពប្រមាណ ១៥០០ នាក់ទៅកាន់ទីក្រុង សលត៍ លេក ដើម្បីបង្ខំឲ្យពួកយូថាហ៍ទទួលស្គាល់មន្ត្រីរាជការថ្មី ។

ប្រសិនបើអ្នកជាពួកបរិសុទ្ធថ្ងៃចុងក្រោយម្នាក់ ក្នុងឆ្នាំ ១៨៥៧ ហើយបានឮថា កងទ័ពដ៏ធំមួយក្រុមនឹងមកដល់ទីក្រុងរបស់អ្នក តើអ្នកអាចនឹងមានការបារម្ភអ្វីខ្លះ ? សូមចងចាំថា អនុស្សាវរីយនៃការត្រូវគេបណ្ដេញចេញយ៉ាងឃោរឃៅពីរដ្ឋ អូហៃអូ រដ្ឋ មិសសួរី និង រដ្ឋ អិលលីណោយ នៅតែដិតដានថ្មីៗក្នុងគំនិតរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើននាក់នៅឡើយ ។ ពួកបរិសុទ្ធជាច្រើនបានបាត់បង់ទ្រព្យសម្បត្តិដ៏មានតម្លៃ និង ដីធ្លី ចំណែកឯសមាជិកមួយចំនួននៃសាសនាចក្រត្រូវគេសម្លាប់ ឬ បាត់បង់ជីវិតដោយសារបុព្វហេតុនានា ទាក់ទងទៅនឹងសេចក្ដីបៀតបៀនទាំងនេះ ។ ដំណឹងនៃការមកដល់របស់កងទ័ពបានបណ្ដាលឲ្យពួកបរិសុទ្ធខ្លះបារម្ភថា ព្រឹត្តិការណ៍បែបនោះក៏អាចនឹងកើតឡើងនៅក្នុងរដ្ឋយូដាហ៍ដែរ ។

នៅក្នុងទេសនកថាទៅកាន់ពួកបរិសុទ្ធ ប្រធាន យ៉ង់ ព្រមទាំងថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រ បានចាត់ទុកកងទ័ពដែលនឹងមកនោះថាជាសត្រូវ ។ ប្រធាន យ៉ង់ ដែលបានសុំឲ្យពួកបរិសុទ្ធសន្សំទុកគ្រាប់ធញ្ញជាតិអស់រយៈពេលជាច្រើនឆ្នាំមកហើយ បានផ្ដល់ការណែនាំជាថ្មីរបស់លោកដើម្បីឲ្យពួកគេនឹងមានអាហារបរិភោគ ក្នុងករណីពួកគេត្រូវរត់គេចពីកងទ័ពនេះ ។ ក្នុងនាមជាអភិបាលរដ្ឋយូថាហ៍ លោកក៏បានដឹកនាំឲ្យកងជីវពលដែនដីរៀបចំការពារដល់បូរណភាពទឹកដីដែរ ។ ( កងជីវពលគឺជាប្រជាពលរដ្ឋមួយក្រុម ដែលអាចបង្កើតបានជាកងទាហានបម្រើក្នុងពេលមានអាសន្ន ) ។

## ជម្លោះបានកើតឡើងរវាងពួកបរិសុទ្ធថ្ងៃចុងក្រោយមួយចំនួន និងសមាជិកនៃពួកអន្តោប្រវេសន៍ក្រុមរទេះសេះ




ពួកអន្តោប្រវេសន៍ក្រុមរទេះមួយដែលបានធ្វើដំណើរមកភាគខាងលិចពីរដ្ឋ អាកាន់សាស ទៅកាន់រដ្ឋ កាលីហ្វញ៉ា បានចូលមក រដ្ឋ យូថាហ៍ ចំពេលដែលពួកបរិសុទ្ធថ្ងៃចុងក្រោយកំពុងរៀបចំការពារដែនដី ប្រឆាំងនឹងការមកដល់នៃកងទ័ពរបស់សហរដ្ឋ ។ នៅពេលអ្នកអានកថាខណ្ឌខាងក្រោមនេះ សូមគូសបន្ទាប់ពីក្រោមមូលហេតុនានា ដែលបណ្ដាលឲ្យមានអារម្មណ៍គ្រោតគ្រាត កើតមានរវាងសមាជិកមួយចំនួននៃក្រុមរទេះសេះ និង ពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

សមាជិកនៃក្រុមរទេះខ្លះបានតប់ប្រមល់ ដោយសារតែពួកគេពិបាកនឹងទិញគ្រាប់ធុញ្ញជាតិដែលត្រូវការជាខ្លាំងពីពួកបរិសុទ្ធ ដែលត្រូវបានណែនាំឲ្យរក្សាគ្រាប់ធុញ្ញជាតិនោះទុក ។ ពួកជនអន្តោប្រវេសន៍នោះក៏បានមានជម្លោះជាមួយនឹងពួកបរិសុទ្ធ ដែលមិនចង់ឲ្យសេះ និង គោរបស់ក្រុមរទេះនេះស៊ីអាហារ និង ផឹកទឹកដែលពួកបរិសុទ្ធត្រូវការសម្រាប់សត្វរបស់ពួកគេផ្ទាល់ដែរ ។

ទំនាស់បានផ្ទុះឡើងនៅទីក្រុងសេដា ជាទីតាំងចុងក្រោយគេនៅក្នុងរដ្ឋ យូថាហ៍តាមដងផ្លូវទៅកាន់រដ្ឋកាលីហ្វ័រញ៉ា ។ ការប្រឈមមុខជាច្រើនបានកើតឡើង រវាងសមាជិកនៃក្រុមរទេះសេះខ្លះ និង ពួកបរិសុទ្ធថ្ងៃចុងក្រោយខ្លះ ។ សមាជិកក្រុមរទេះសេះខ្លះបានគំរាមកំហែងថា នឹងចូលរួមក្នុងកងទ័ពរដ្ឋាភិបាលដែលកំពុងតែចេញដំណើរមកប្រឆាំងនឹងពួកបរិសុទ្ធនោះ ។ ទោះបីជាមេបញ្ជាការនៃក្រុមរទេះសេះនេះបានស្ដីបន្ទោសដល់ដៃគូរបស់លោកដោយសារបានធ្វើការគំរាមកំហែងទាំងនេះក្ដី ក៏អ្នកដឹកនាំទីក្រុងសេដាខ្លះ និង អ្នករស់នៅទីនោះបានចាត់ទុកថាជនអន្តោប្រវេសន៍ទាំងនោះគឺជាសត្រូវដែរ ។ ក្រុមរទេះនេះបានចាកចេញពីទីក្រុងក្រោយពីបានមកដល់តែត្រឹមប្រហែលមួយម៉ោងប៉ុណ្ណោះ ប៉ុន្តែប្រជាជន និង ថ្នាក់ដឹកនាំខ្លះនៅទីក្រុងសេដា បានចង់ដេញតាម និង ដាក់ទោសដល់មនុស្សទាំងឡាយដែលបានមើលងាយដល់ពួកគេ ។

សូមគិតអំពីពេល ដែលអ្នកបានជួបនឹងជម្លោះជាមួយនឹងមនុស្សម្នាក់ទៀត ឬ មនុស្សមួយក្រុមទៀត ។ សូមអាន នីហ្វៃទី៣ ១២:២៥ ដោយស្វែងរកគោលការណ៍មួយដែលព្រះយេស៊ូវគ្រីស្ទបានបង្រៀនថា អាចដឹកនាំយើងនៅពេលយើងមានទំនាស់ជាមួយមនុស្សទូទៅ ។

តើអ្នកគិតថា វាមានន័យដូចម្ដេចក្នុងឃ្លា « ព្រមព្រៀងជាមួយនឹងអ្នកដើមចោទអ្នកជាប្រញាប់ » ? អែលឌើរ ដេវីឌ អ៊ី ស៊្វិនសិន នៃពួកចិតសិបនាក់ បានបង្រៀនថាឃ្លានេះមានន័យថា « ដោះស្រាយភាពមិនចុះសម្រុងរបស់យើងឲ្យបានរហ័ស បើមិនដូច្នោះទេ កំហឹងមួយគ្រានោះនឹងកើនឡើងទៅជាហិង្សាខាងរាងកាយ ឬ សតិអារម្មណ៍ ហើយយើងបានជាប់ឃុំក្នុងកំហឹងរបស់យើង » ( «Forgiveness Will Change Bitterness to Love» *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៣ ទំព័រ ១១ ) ។

យោងតាមការបង្រៀនរបស់ព្រះអម្ចាស់នៅក្នុង នីហ្វៃទី៣ ១២:២៥ ព្រមទាំងការបកស្រាយរបស់អែលឌើរ ស៊្វិនសិន យើងរៀនថា **បើសិនជាយើងដោះស្រាយជម្លោះជាមួយមនុស្សទូទៅនៅតាមរបៀបរបស់អម្ចាស់ នោះយើងអាចចៀសវាងពីឥទ្ធិពលដ៏អន្តរាយនៃទំនាស់បាន ។**

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការគោរពតាមគោលការណ៍នៅក្នុង នីហ្វៃទី៣ ១២:២៥ បានជួយពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលបានអាក់អន់ចិត្តនឹងសមាជិកនៃក្រុមរទេះសេះ យ៉ាងដូចម្ដេច ?

ខ. តើការព្យាយាមដោះស្រាយភាពមិនចុះសម្រុងទៅតាមរបៀបរបស់អម្ចាស់ បានជួយអ្នក ឬ នរណាម្នាក់ដែលអ្នកស្គាល់ឲ្យចៀសវាងពីឥទ្ធិពលដ៏អន្តរាយនៃទំនាស់យ៉ាងដូចម្ដេច ?

ដោយសារតែពលរដ្ឋដែលរស់នៅទីក្រុងសេដាមួយចំនួន ពុំបានដោះស្រាយជម្លោះរបស់ពួកគេជាមួយនឹងជនអន្តោប្រវេសន៍តាមរបៀបរបស់ព្រះអម្ចាស់ ទើបស្ថានការណ៍នេះបានក្លាយទៅជាកាន់តែធ្ងន់ទៅៗ ។ នៅពេលអ្នកបន្តសិក្សា សូមពិចារណាអំពីគ្រោះថ្នាក់នៃការប្រព្រឹត្តដោយកំហឹង ឬ ការសងសឹក ។

អ៊ីសាក ហេត ជាអភិបាលក្រុងសេដា ជាវរសេនីយត្រីជីវពល និង ជាប្រធានស្ដេក បានស្នើសុំការអនុញ្ញាតពីមេបញ្ជាការជីវពលដែលបានរស់នៅក្បែរដារ៉ូវ៉ាន់ ឲ្យកោះហៅជីវពលឲ្យជួយបង្ក្រាបពួកអ្នកមើលងាយពួកគេ នៅក្នុងក្រុមរទេះនោះ ។ មេបញ្ជាការជីវពលឈ្មោះ វិល្លាម ដេម បានផ្ដល់យោបល់ដល់ អ៊ីសាក ហេត កុំឲ្យខ្វល់នឹងការគំរាមកំហែងរបស់ពួកអន្តោប្រវេសន៍នោះ ។ ដោយមិនបានស្ដាប់តាមយោបល់នេះ អ៊ីសាក ហេត និងថ្នាក់ដឹកនាំផងទៀតនៃទីក្រុងសេដា បានសម្រេចចិត្តទៅបញ្ចុះបញ្ចូលពួកសាសន៍អាមេរិកាំងដើមក្នុងតំបន់ខ្លះ ឲ្យវាយប្រហារក្រុមរទេះសេះ និង ទៅលួចគោរបស់ពួកគេ ដើម្បីទុកជាការដាក់ទោសដល់ពួកជនអន្តោប្រវេសន៍នោះ ។ អ៊ីសាក ហេត បានសុំឲ្យ ចន ឌី លី ជាសមាជិកសាសនាចក្រក្នុងតំបន់ម្នាក់ និង ជាវរសេនីយត្រី ដឹកនាំការវាយលុកនេះ ហើយបុរសទាំងពីររូបនេះបានគ្រោងទម្លាក់កំហុសទៅលើពួកសាសន៍អាមេរិកាំងដើមចំពោះទង្វើនេះ ។

តើថ្នាក់ដឹកនាំទីក្រុងសេដា គួរតែបានធ្វើអ្វីខ្លះ នៅពេលវិល្លាម ដេម បានផ្ដល់យោបល់ដល់ពួកគេកុំឲ្យប្រើក្រុមជីវពល ? តើការមិនធ្វើយោបល់នាពេលនោះ បាននាំពួកគេឲ្យធ្វើអ្វីខ្លះ ?

គោលការណ៍មួយដែលយើងរៀនពីគំរូរបស់ថ្នាក់ដឹកនាំទីក្រុងសេដាទាំងនេះគឺ ៖ **បើសិនជាយើងមិនព្រមស្ដាប់តាមយោបល់ឲ្យធ្វើអ្វីដែលត្រូវទេ នោះយើងនឹងកាន់តែងាយរងរងក្នុងការជ្រើសរើសអ្វីដែលមិនល្អ** ។ សូមមើលភស្ដុតាងនៃគោលការណ៍នេះ នៅពេលអ្នកបន្តរៀនអំពីសកម្មភាពរបស់ថ្នាក់ដឹកនាំទាំងនេះ ។ នៅពេលអ្នកអានកថាខណ្ឌខាងក្រោមនេះ សូមគូសបន្ទាត់ពីក្រោមរបៀបនានា ដែលថ្នាក់ដឹកនាំនៅទីក្រុងសេដា បានបន្តធ្វើការជ្រើសរើសពុំល្អ បន្ទាប់ពីពុំស្ដាប់តាមយោបល់ដែលពួកគេបានទទួលនោះ ៖

អ៊ីសាក ហេត បានបង្ហាញគម្រោងវាយលុកក្រុមរទេះសេះនេះដល់ក្រុមប្រឹក្សាថ្នាក់ដឹកនាំក្នុងតំបន់នៃសាសនាចក្រ សហគមន៍ និង ជីវពល ។ សមាជិកក្រុមប្រឹក្សាខ្លះមិនយល់ព្រមសោះឡើយ ចំពោះគម្រោងនេះ ហើយបានសួរ ហេត ថាតើលោកបានប្រឹក្សាជាមួយនឹងប្រធាន ព្រិកហាំ យ៉ង់ អំពីបញ្ហានេះហើយឬនៅ ។ ដោយបាននិយាយថា លោកមិនទាន់បានសួរនៅឡើយ លោក ហេត ក៏បានយល់ព្រមបញ្ជូនសារទូតម្នាក់ គឺលោកជេម ហេសឡេម ទៅកាន់ទីក្រុង សលត៍ លេក អមដោយសំបុត្រមួយច្បាប់ពន្យល់អំពីស្ថានការណ៍ និងសួរថាតើត្រូវធ្វើអ្វី ។ ទោះជាយ៉ាងណាក្ដី ដោយសារទីក្រុង សលត៍ លេក មានរយៈចម្ងាយប្រមាណ ៤០០ គីឡូម៉ែត្រ ពីទីក្រុងសេដា វាត្រូវការប្រហែលជាមួយសប្ដាហ៍ក្នុងការជិះសេះយ៉ាងលឿនដើម្បីទៅដល់ទីក្រុង សលត៍ លេក និងត្រឡប់មកទីក្រុងសេដាវិញដោយមានដំបូន្មានពីប្រធាន យ៉ង់ ជាមួយនឹងសារទូតនោះ ។

មុននេះបន្តិច មុនពេលអ៊ីសាក ហេត បានបញ្ជូនសំបុត្ររបស់លោកជាមួយនឹងសារទូត ចន ឌី លី ទន្ទឹមនឹងនោះពួកឥណ្ឌាសាសន៍អាមេរិកាំងដើមមួយក្រុមបានវាយលុកជុំវិញជនអន្តោប្រវេសន៍នៅកន្លែងមួយដែលហៅថា ភ្នំម៉េដូ ។ លី បានដឹកនាំការវាយប្រហារនេះ ប៉ុន្តែបានលាក់អត្តសញ្ញាណរបស់លោក ដើម្បីឲ្យវាមើលទៅមានតែពួកអាមេរិកកាំងស្បែកក្រហមប៉ុណ្ណោះដែលបានពាក់ព័ន្ធក្នុងរឿងនេះ ។ ជនអន្តោប្រវេសន៍ខ្លះត្រូវបានគេសម្លាប់ ឬ រងរបួស ប៉ុន្តែអ្នកនៅសេសសល់បានបណ្ដេញពួកអ្នកវាយលុកពួកគេ ដោយបង្ខំ លី និង ពួកឥណ្ឌាសាសន៍អាមេរិកាំងដើមឲ្យដកថយ ។ ជនអន្តោប្រវេសន៍បានទាញរទេះរបស់ខ្លួនជារង្វង់ ឬ ក្រោលមួយយ៉ាងមាំភ្លាមៗដើម្បីការពារខ្លួន ។ ការវាយលុកពីដេងទៀតបានកើតឡើង អំឡុងពេលការឡោមព័ទ្ធក្រុមរទេះបានប្រាំថ្ងៃ ។



នៅពេលមួយ ពួកជីវពលទីក្រុងសេដា បានដឹងថាមានជនអន្តោប្រវេសន៍ពីរនាក់បានចេញពីក្រោលរទេះសេះនោះ ។ ពួកជីវពលបានបាញ់ពួកគេ ដោយបានសម្លាប់គេម្នាក់ ។ បុរសម្នាក់ទៀតបានរត់គេចផុត ហើយបាននាំដំណឹងនេះទៅដល់ជុំរំរទេះសេះថា មានបុរសស្បែកសពាក់ព័ន្ធនឹងការវាយលុកប្រឆាំងនឹងពួកគេ ។ ឥឡូវនេះ អស់អ្នកដែលបានគ្រោងការវាយប្រហារនេះត្រូវបានគេដឹងពីល្បិចកលខ្លួន ។ ប្រសិនបើជនអន្តោប្រវេសន៍ត្រូវបានអនុញ្ញាតឲ្យបន្តធ្វើដំណើរទៅរដ្ឋកាលីហ្វ័រញ៉ា នោះដំណឹងនេះនឹងលេចឮថា ពួកបរិសុទ្ធថ្ងៃចុងក្រោយបានទាក់ទងនឹងការវាយប្រហារលើពួកក្រុមរទេះសេះនេះ ។ ពួកអ្នករួមគំនិតក្បត់ បានខ្លាចថាដំណឹងនេះនឹងនាំឲ្យមានលទ្ធផលអវិជ្ជមានមកដល់ខ្លួនគេ និងប្រជាជនរបស់ពួកគេ ។

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. នៅចំណុចនេះ តើជម្រើសណាខ្លះ ដែលជាទំនួលខុសត្រូវរបស់អស់អ្នកដែលបានធ្វើការវាយប្រហារទៅលើជនអន្តោប្រវេសន៍ ?

ខ. តើពួកគេគួរតែបានធ្វើអ្វីខ្លះ ? ហេតុអ្វី ?

ដោយបានធ្វើជម្រើសខុស បុរសទាំងនេះ បានធ្វើផ្ទុយទៅនឹងការទទួលខុសត្រូវខាងបព្វជិតភាពរបស់ពួកគេ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១:៣៦–៣៧ រួចគូសចំណាំការព្រមានពីព្រះអម្ចាស់ ទៅដល់ពួកអ្នកកាន់បព្វជិតភាពដែលប្រព្រឹត្ត ទុច្ចរិត។

សូមគិតអំពីអ្វីដែលអ្នកធ្វើ បន្ទាប់ពីអ្នកបានធ្វើអ្វីមួយខុសឆ្គង ។ តើអ្នកសារភាពអំពីអ្វីដែលអ្នកបានធ្វើខុសឆ្គង ហើយទទួលយកលទ្ធផលឬតើអ្នកព្យាយាមលាក់បាំងនូវអំពើបាបទាំងនោះតាមរយៈការបោកបញ្ឆោត ?

## ពួកបរិសុទ្ធថ្ងៃចុងក្រោយខ្លះ បានគ្រោងសម្លាប់រង្គាលនៅភ្នំម៉េដូ

សមាជិកសាសនាចក្រដែលជាប់ពាក់ព័ន្ធនៅក្នុងការវាយប្រហារពួកអន្តោប្រវេសន៍នេះ បានជ្រើសរើសយកការព្យាយាមលាក់បាំងអំពើបាបរបស់ខ្លួន ។ នៅក្នុងគោលបំណងដើម្បីរារាំងដំណឹងនេះកុំឲ្យលេចឮ ថា ពួកបរិសុទ្ធថ្ងៃចុងក្រោយបានចូលរួមនៅក្នុងការវាយប្រហារលើក្រុមរទេះសេះនេះ នោះ អ៊ីសាក ហេត, ចន ឌី លី និងថ្នាក់ដឹកនាំដទៃទៀតនៃសាសនាចក្រក្នុងតំបន់ ព្រមទាំងក្រុមជីវពល បានបង្កើតគម្រោងមួយដើម្បីសម្លាប់អ្នកនៅរស់ទាំងអស់ លើកលែងតែកូនក្មេងតូចៗប៉ុណ្ណោះ ។ ក្នុងការអនុម័តគម្រោងការនេះ ចន ឌី លី បានទៅដល់ពួកអន្តោប្រវេសន៍ ហើយបាននិយាយថា ពួកជីវពលនឹងការពារពួកគេកុំឲ្យរងការវាយប្រហារផ្សេងទៀត ដោយនឹងជួយនាំពួកគេត្រឡប់ទៅកាន់ទីក្រុងសេដាវិញដោយសុវត្ថិភាព ។ នៅពេលពួកអន្តោប្រវេសន៍បានដើរទៅកាន់ទីក្រុងសេដា ពួកជីវពលបានត្រឡប់ក្រោយ និងបានបាញ់ពួកគេ ។ ពួកសាសន៍អាមេរិកាំងដើមខ្លះដែលបានចូលរួមនឹងពួកប្រជាជននោះ បានរត់ចេញពីកន្លែងលាក់ខ្លួនមកដើម្បីជួយបាញ់បន្ថែម ។ មានជនអន្តោប្រវេសន៍ប្រហែល ១៤០ នាក់ដែលបានចូលរួមនៅក្នុងក្រុមរទេះសេះនេះ មានតែកូនក្មេង ១៧ នាក់ប៉ុណ្ណោះដែលនៅរស់ ។




បូជនីយស្ថានរំឭកសោកនាដកម្មនៅភ្នំមេដូ

ពីរថ្ងៃបន្ទាប់ពីការសម្លាប់រង្គាលនោះ ជេម ហេលឡេម បានមកដល់ទីក្រុងសេដា ដោយមានសារឆ្លើយតបរបស់ប្រធាន យ៉ង់ មកផង ដែលបានណែនាំថ្នាក់ដឹកនាំក្នុងតំបន់ឲ្យអនុញ្ញាតឲ្យក្រុមរទេះសេះនោះ បន្តធ្វើដំណើរប្រកបដោយសន្តិភាព ។ « នៅពេលហេត បានអានពាក្យរបស់ប្រធាន យ៉ង់ លោកបានយំដូចជាកូនក្មេង ហើយអាចនិយាយចេញតែពាក្យ ‹ យឺតពេលហើយ យឺតពេលហើយ › » ( Richard E. Turley Jr., The Mountain Meadows Massacre » *Ensign* ខែ កញ្ញា ឆ្នាំ ២០០៧ ទំព័រ ២០ ) ។

ជម្រើសរបស់ថ្នាក់ដឹកនាំ និង ពលរដ្ឋ មួយចំនួនដែលជាពួកបរិសុទ្ធថ្ងៃចុងក្រោយនៅក្នុងដែនដីរដ្ឋ យូថាហ៍ភាគខាងត្បូងនោះ បាននាំឲ្យមានការសម្លាប់រង្គាលដ៏សោកនាដកម្មមួយនៅភ្នំម៉េដូ ។ ផ្ទុយទៅវិញ ថ្នាក់ដឹកនាំសាសនាចក្រ និងថ្នាក់ដឹកនាំដែនដីនៅក្នុងទីក្រុង សលត៍ លេក បានដោះស្រាយជម្លោះជាមួយនឹងរដ្ឋាភិបាលសហរដ្ឋតាមរយៈការនិយាយ និងការចរចារដោយសន្តិភាពនៅក្នុងឆ្នាំ ១៨៥៨ ។ អំឡុងពេលនៃជម្លោះនេះ —ដែលក្រោយមកត្រូវបានហៅថា សង្គ្រាមរដ្ឋយូថាហ៍ — ពួកទាហានសហរដ្ឋ និងពួកជីវពលរដ្ឋយូថាហ៍បានប្រទ្បូកនឹងសកម្មភាពនៃការឈ្លានពាន ប៉ុន្តែមិនដែលចូលរួមក្នុងចម្បាំងឡើយ ។



ប្រធាន ហិនរី ប៊ី អាវរិង បានមានប្រសាសន៍អំពីការសម្លាប់រង្គាលនៅភ្នំម៉េដូ ៖ « ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលយើងកាន់ ស្អប់ខ្ពើមការសម្លាប់ដ៏ឃោរឃៅដល់បុរស ស្ត្រី និង កូនក្មេងណាស់ ។ តែតាមពិតទៅ វាលើកទឹកចិត្តឲ្យមានសេចក្ដីសុខសាន្ត និង ការអភ័យទោស ។ អ្វីដែលបានធ្វើដោយសមាជិកនៃសាសនាចក្ររបស់ [នៅភ្នំម៉េដូ] ជាយូរលង់មកនោះ តំណាងឲ្យការឃ្លាតចេញពីការបង្រៀន និងទង្វើជាពួកគ្រីស្ទានដ៏អាក្រក់ និងពុំអាចដោះសារបានឡើយ » (« 150th Anniversary of Mountain Meadows Massacre, » ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០៧, mormonnewsroom.org/article/150th–anniversary–of–mountain–meadows–massacre ) ។

ការសម្លាប់រង្គាលនៅភ្នំម៉េដូ មិនត្រឹមតែបន្សល់ទុកនូវការស្លាប់របស់ជនរងគ្រោះប្រហែល ១២០ នាក់ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងបណ្ដាលឲ្យមានការរងទុក្ខជាខ្លាំងផងដែរចំពោះកូនក្មេងដែលនៅរស់រានមានជីវិត និង សាច់ញាតិផ្សេងទៀតរបស់ជនរងគ្រោះទាំងនោះ ។ សាសន៍អាមេរិកាំងដើមឈ្មោះ ផៃយូត ក៏បានរងនូវការស្ដីបន្ទោសដ៏អយុត្តិធម៌ចំពោះបទឧក្រិដ្ឋកម្មនេះដែរ ។ បន្ថែមពីលើនោះ ពួកអ្នកទាំងឡាយ « ដែលបានចូលរួមក្នុងការសម្លាប់រង្គាលនេះ បានរស់នៅក្នុងជីវិតមួយស្ថិតនៅក្រោមអារម្មណ៍ជាប់ទោសដ៏អាប់អួរ និង បានមានបទពិសោធន៍យ៉ាងអាក្រក់ចំពោះអ្វីដែលពួកគេបានធ្វើ និង បានឃើញ » ( Richard E. Turley Jr The Mountain Meadows Massacre» ទំព័រ ២០ ) ។

៣. សូមបំពេញកិច្ចការខាងក្រោមនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមសង្ខេបគំនិតភាន់ច្រឡំនានា ដែលបាននាំទៅរកការសម្លាប់រង្គាលនៅភ្នំម៉េដូ ។

ខ. សូមសរសេរគោលការណ៍ ឬ មេរៀនមួយ ដែលយើងអាចរៀនចេញពីសោកនាដកម្មនេះ អំពីការសម្រេចចិត្តលាក់បាំងអំពើបាបរបស់យើង ។

គ. សូមឆ្លើយសំណួរដូចតទៅនេះ ៖ តើអ្នកអាចធ្វើដូចម្ដេចនាពេលអនាគត ដើម្បីប្រាកដថាអ្នកធ្វើតាមដំបូន្មានរបស់ថ្នាក់ដឹកនាំ ហើយចៀសវាងពីការលាក់បាំងអំពើបាបដែលអ្នកអាចនឹងបានប្រព្រឹត្ត ? តើពរជ័យអ្វីខ្លះដែលអ្នកទទួលបានពីការមានទំនួលខុសត្រូវចំពោះកំហុសរបស់អ្នក ហើយពុំព្យាយាមលាក់បាំងអំពើបាបរបស់អ្នក ?

ប្រសិនបើអ្នកបានចាប់ផ្ដើមដើរលើផ្លូវខុស និង ផ្លូវនៃអំពើបាបហើយ នោះអ្នកអាចការពារមិនឲ្យមាននូវការឈឺចិត្ត និងការសោកស្ដាយនាពេលអនាគតបាន ដោយការបែរទៅរកព្រះអម្ចាស់ និងការប្រែចិត្តពីអំពើបាបរបស់អ្នកក្នុងពេលនេះ។



ដោយសារពួកបរិសុទ្ធថ្ងៃចុងក្រោយក្នុងតំបន់មួយចំនួន ត្រូវទទួលខុសត្រូវលើការរៀបចំផែនការ និងចូលរួមក្នុងការសម្លាប់រង្គាលនៅលើភ្នំម៉េដូ នោះប្រជាជនខ្លះបានអនុញ្ញាតឲ្យហេតុការណ៍នេះជះឥទ្ធិពលអវិជ្ជមានលើការគិតអំពីសាសនាចក្រទាំងមូលរបស់ពួកគេ ។ រឿងស្រដៀងគ្នានេះបានកើតឡើងក្នុងព្រះគម្ពីរមរមន កាលអាលម៉ាដែលជាអ្នកផ្សព្វផ្សាយសាសនាមួយរូប ហើយលោកមានកូនប្រុសដែលបានល្មើសនឹងច្បាប់ព្រហ្មចារីភាព នោះមនុស្សដទៃពុំបានជឿលើប្រសាសន៍របស់អាលម៉ាឡើយ ដោយសារតែការប្រព្រឹត្តរបស់កូនប្រុសគាត់ ( សូមមើល អាលម៉ា ៣៩:១១ ) ។

៤. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ ហេតុអ្វីបានជាមានសារៈសំខាន់ដែលត្រូវដឹងថា ការធ្វើខុសរបស់សមាជិកសាសនាចក្រខ្លះ ពុំកំណត់សេចក្ដីពិតពេញលេញទាំងមូលនៃដំណឹងល្អទេ ?

សូមអាន ហេលេមិន ៥:១២ ដោយស្វែងរកអ្វីដែលយើងអាចធ្វើបានដើម្បីអភិវឌ្ឍ និងរក្សាទីបន្ទាល់របស់យើង ដើម្បីពេលណាយើងជួបនឹងគ្រាលំបាកនានា ដូចជានៅពេលយើងរៀនពីគំរូនៃសមាជិកសាសនាចក្រដែលបានខកខានមិនបានរស់នៅស្របតាមការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ នោះសេចក្ដីជំនឿរបស់យើងនឹងមិនរង្គោះរង្គើឡើយ ។ សូមសង្ខេបអ្វីដែលអ្នកបានរកឃើញ ៖

គោលការណ៍មួយដែលយើងអាចរៀនចេញពី ហេលេមិន ៥:១២ គឺ **យើងអាចអភិវឌ្ឍទីបន្ទាល់រឹងមាំបាន ដោយការសង់គ្រឹះនៃសេចក្ដីជំនឿរបស់យើងនៅលើព្រះយេស៊ូវគ្រីស្ទ ។**

ឧទាហរណ៍ខាងក្រោម ចង្អុលបង្ហាញអំពីគោលការណ៍នេះ ៖ « ជេម សេនឌើរ គឺជាចៅទួតប្រុសរបស់. . . ដែលជាក្មេងម្នាក់ដែលបាននៅរស់ពីការសម្លាប់រង្គាល [ ហើយក៏ជាសមាជិកម្នាក់នៃសាសនាចក្រផងដែរ ] ។ បងប្រុស សេនឌើរ បានពោលថា ‹ ខ្ញុំនៅតែមានអារម្មណ៍ខ្លោចផ្សា ដ្បិតខ្ញុំនៅតែមានអារម្មណ៍ខឹង និង ក្រៀមក្រំដែលការសម្លាប់រង្គាលនោះបានកើតឡើង ។ ‹ ប៉ុន្តែខ្ញុំដឹងថា មនុស្សដែលបានប្រព្រឹត្តអំពើនេះ នឹងទទួលខុសត្រូវចំពោះព្រះអម្ចាស់ ហើយការណ៍នោះនាំឲ្យខ្ញុំមានភាពសុខសាន្ត › ។ [ គាត់ ] បានមាននិយាយថា ការដឹងពីជូនតារបស់លោកថាត្រូវបានគេសម្លាប់នៅក្នុងការសម្លាប់រង្គាល ‹ មិនបានប៉ះពាល់ដល់សេចក្ដីជំនឿរបស់ខ្ញុំនោះទេ ដ្បិតសេចក្ដីជំនឿនេះផ្អែកលើព្រះយេស៊ូវគ្រីស្ទ មិនមែនលើមនុស្សនៅក្នុងសាសនាចក្រនោះទេ › » ( Richard E. Turley Jr « The Mountain Meadows Massacre » ទំព័រ ២១) ។

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើសេចក្ដីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ អាចធ្វើឲ្យយើងរឹងមាំបានយ៉ាងដូចម្ដេច នៅពេលយើងរៀនពីគំរូនានា ដែលក្នុងនោះមានសមាជិកសាសនាចក្រខ្លះខកខានមិនបានរស់នៅស្របតាមការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ?

ខ. តើសកម្មភាពអ្វីខ្លះដែលអ្នកធ្វើ ដែលជួយអ្នកសង់គ្រឹះនៃសេចក្ដីជំនឿនៅលើព្រះយេស៊ូវគ្រីស្ទ ?

គ. តើសកម្មភាពអ្វីខ្លះអ្នកនឹងធ្វើនៅសប្ដាហ៍នេះ ដែលជួយអ្នកឲ្យសង់គ្រឹះនៃសេចក្ដីជំនឿអ្នកទៅលើព្រះយេស៊ូវគ្រីស្ទ ? ( អ្នកអាចនឹងសរសេរចំណុចច្រើនជាងមួយ ដែលអ្នកនឹងធ្វើ ) ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សាមេរៀនអំពី « សង្គ្រាមនៅរដ្ឋ យូថាហ៍ និង ការសម្លាប់រង្គាលនៅភ្នំម៉េដូ » ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៣១ ៖ ថ្ងៃទី ២

# ការលេចចេញមកនៃព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា

## បុព្វកថា

ក្នុងឆ្នាំ ១៨៥១ អែលឌើរ ហ្វ្រែងគ្លីន ឌី រីឆាដ ជាសមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ និង ជាប្រធានបេសកកម្មអង់គ្លេស បានបោះពុម្ពវិវរណៈ ការបកប្រែ និង ការសរសេរមួយចំនួនរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ហើយត្រូវបានហៅថា ការជ្រើសរើសនៃមុក្តាដ៏មានតម្លៃមហិមា ដែលក្រោយមកត្រូវបានបញ្ចូលទៅក្នុងបទដ្ឋានព្រះគម្ពីរ ។ « ព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា គឺជាការជ្រើសរើសនូវឯកសាដ៏សំខាន់ទាំងឡាយ ដែលទាក់ទងទៅនឹងចំណុចសំខាន់ៗជាច្រើន អំពីសេចក្តីជំនឿ និងគោលលទ្ធិនៃសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទបរិសុទ្ធថ្ងៃចុងក្រោយ » ( បុព្វកថាមុក្តាដ៏មានតម្លៃមហិមា) ។ ឃ្លា « មុក្តាដ៏មានតម្លៃមហិមា » បានមកពីរឿងប្រដូចមួយរបស់ព្រះយេស៊ូវគ្រីស្ទ ( សូមមើល ម៉ាថាយ ១៣:៤៥–៤៦ ) ។ នៅក្នុងរឿងប្រដូចនេះ ឈ្មួញម្នាក់បានលក់របស់ទ្រព្យខ្លួនទាំងអស់ ដើម្បីទិញមុក្តាដ៏មានតម្លៃនោះ ។

### ការលេចចេញមកនៃព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា



តើអ្នកដឹងថា មុក្តាត្រូវបានបង្កើតឡើងតាមរបៀបណាដែរឬទេ ? មុក្តាមួយគ្រាប់ត្រូវបានបង្កបង្កើតឡើងនៅក្នុងមាត់ខ្យងសមុទ្រ ចំពោះខ្យងសមុទ្រវាគិតថាជាគ្រាប់ខ្សាច់ដ៏រំខានមួយគ្រាប់ប៉ុណ្ណោះ ។ ខ្យងសមុទ្របង្កើតជាសារធាតុមួយ ដែលរុំជុំវិញគ្រាប់ខ្សាច់ដែលយូរៗទៅបង្កើតបានជាគុជ ។ គុជធម្មជាតិ គឺកម្រមានណាស់ ហើយវាត្រូវបានចាត់ទុកថាមានតម្លៃខ្ពស់ ។

នៅក្នុងមេរៀននេះ អ្នកនឹងរៀនអំពីធាតុដើមនៃគុជមួយទៀត—ដែលជាសៀវភៅមួយក្នុងព្រះគម្ពីរមានចំណងជើងថា មុក្តាដ៏មានតម្លៃមហិមា ។ នៅពេលអ្នកសិក្សាថាតើព្រះគម្ពីរនេះចេញមកតាមរបៀបណា នោះសូមស្វែងរកមូលហេតុមួយចំនួនដែលមុក្តាដ៏មានតម្លៃមហិមា មានតម្លៃសម្រាប់យើង ។

សូមអានកថាខណ្ឌផ្នែកទីមួយនៅក្នុងបុព្វកថានៃមុក្តាដ៏មានតម្លៃមហិមា ដោយស្វែងរកអ្វីដែលមានសរសេរនៅក្នុងមុក្តាដ៏មានតម្លៃមហិមា ។ ពាក្យ *ទស្សនាវដ្តី* សំដៅទៅលើកាសែត ឬទស្សនាវដ្តី—ជាការបោះពុម្ពទាំងឡាយ ដែលត្រូវបានចែកចាយជាទៀងទាត់ ដូចជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ឬប្រចាំខែ ។

នៅក្នុងកថាខណ្ឌផ្នែកទីពីរនៃបុព្វកថា យើងរៀនថា ក្នុងឆ្នាំ ១៨៥១ អែលឌើរ ហ្វ្រាំងក្លិន ឌី រិចឺត្ស ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានប្រមូលផ្តុំការជ្រើសរើសនៃឯកសារនានាមកពីព្យាការី យ៉ូសែប ស្ម៊ីធ ហើយបានបោះពុម្ពឯកសារទាំងនោះជាមុក្តាដ៏មានតម្លៃមហិមា ។ ពីមុនឯកសារទាំងនោះអាចក្លាយទៅជាផ្នែកមួយនៃបទដ្ឋានព្រះគម្ពីរ គណៈប្រធានទីមួយត្រូវតែអនុមតិ ហើយបង្ហាញព្រះគម្ពីរទាំងនោះទៅដល់សមាជិកសាសនាចក្រ នៅក្នុងសន្និសីទទូទៅ ដើម្បីទទួលការគាំទ្រ ។ ក្នុងអំឡុងពេលនៃសន្និសីទទូទៅមួយរបស់សាសនាចក្រក្នុងខែ តុលា ឆ្នាំ ១៨៨០ សមាជិកសាសនាចក្របានទទួលយកមុក្តាដ៏មានតម្លៃមហិមាជាព្រះគម្ពីរ—ជាចំណែកនៃព្រះគម្ពីរបទដ្ឋាន ។

នៅក្នុងកថាកណ្ឌទីបីនៃបុព្វកថា យើងរៀនថា ចាប់តាំងពីការបោះពុម្ពគម្ពីរមុក្ដាដ៏មានតម្លៃមហិមាជាលើកដំបូង មាតិកាមួយចំនួនត្រូវបានបន្ថែម ឬ បានដកចេញ ។ មាតិកាមួយចំនួនត្រូវបានបន្ថែម ហើយក្រោយមកត្រូវបានដកចេញទៅដាក់ក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ។

សូមអានផ្នែកចុងក្រោយនៃបុព្វកថា រួចស្វែងរកមាតិកានៃមុក្ដាដ៏មានតម្លៃមហិមា នាពេលបច្ចុប្បន្ននេះ ។



អែលឌើរ ហ្វ្រាំងក្លិន ឌី រិចឺត្ស

## គម្ពីរម៉ូសេ និង យ៉ូសែប ស៊្មីធ—ម៉ាថាយ

គម្ពីរម៉ូសេ និង យ៉ូសែប ស៊្មីធ—ម៉ាថាយ គឺជាផ្នែកនៃការបកប្រែដោយ យ៉ូសែប ស៊្មីធ នៃព្រះគម្ពីរប៊ីប ។ ការបកប្រែដោយ យ៉ូសែប ស៊្មីធ គឺជា « ការពិនិត្យឡើងវិញ ឬ កំណែបកប្រែរបស់ស្ដេចជេមស៍ នៃព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេស ដែលព្យាការី យ៉ូសែប ស៊្មីធ បានចាប់ផ្ដើមក្នុងខែមិថុនា ឆ្នាំ ១៨៣០ ។ លោកត្រូវបានព្រះត្រាស់បង្គាប់ ឲ្យធ្វើការបកប្រែ និង ចាត់ទុកថាវាជាផ្នែកមួយនៃការហៅបម្រើរបស់លោក ក្នុងនាមជាព្យាការីមួយរូប » ( Guide to the Scriptures, Joseph Smith Translation" scriptures.lds.org) ។ ព្រះអម្ចាស់បានត្រាស់សម្ដែងពាក្យពេចន៍នៃគម្ពីរម៉ូសេទៅកាន់ យ៉ូសែប ស៊្មីធ នៅពេល យ៉ូសែប បានសរសេរបន្ថែម កែប្រែ ហើយលុបជំពូកមួយចំនួនក្នុងគម្ពីរលោកុប្បត្តិ អំឡុងពេលលោកបកប្រែព្រះគម្ពីរប៊ីប ។ គម្ពីរម៉ូសេ មាននូវសេចក្ដីពិតដ៏មានតម្លៃ អំពីផែនការនៃសេចក្ដីសង្គ្រោះរបស់ព្រះវរបិតាសួគ៌ ។

១. សូមអានគម្ពីរម៉ូសេត្រួសៗ ហើយរកមើលខគម្ពីរមួយយ៉ាងតិច ដែលមាននូវសេចក្ដីពិតមួយ ដែលអ្នកចាត់ទុកថាមានតម្លៃ ។ សូមសរសេរខគម្ពីរដែលអ្នកបានជ្រើសរើស ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក រួចសរសេរអំពីមូលហេតុដែលវាមានអត្ថន័យចំពោះអ្នក ។

## គម្ពីរអ័ប្រាហាំ

ដូចជាគម្ពីរម៉ូសេដែរ គម្ពីរអ័ប្រាហាំស្ដារឡើងវិញនូវសេចក្ដីពិតដ៏មានតម្លៃ ។ វាបង្រៀនអំពីជីវិតមុនឆាកជីវិតនេះ ថែមទាំងផ្ដល់ការយល់ដឹងកាន់តែច្បាស់អំពីជីវិត និង ការបម្រើរបស់អ័ប្រាហាំ និង សេចក្ដីសញ្ញា ដែលព្រះអម្ចាស់បានធ្វើជាមួយលោក ។ វាគឺជារតនសម្បត្តិមួយដែលមានគម្ពីរអ័ប្រាហាំ ហើយមើលឃើញអំពីរបៀបដែលលោកបានគោរពប្រតិបត្តិព្រះនៅគ្រប់វេលាទាំងអស់ និង របៀបដែលព្រះបានប្រទានកិត្តិយសដល់លោក ។

កថាខណ្ឌខាងក្រោមនេះគឺជាការបកស្រាយ អំពីរបៀបដែលព្យាការី យ៉ូសែប ស៊្មីធ បានទទួលអត្ថបទពីបុរាណនៅក្នុងគម្ពីរអ័ប្រាហាំ ៖ « នៅថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ១៨៣៥ មានបុរសម្នាក់ឈ្មោះ ម៉ៃឃែល ចានឡើរ បាននាំយកសាកសពម៉ូមីអេហ្ស៊ីបចំនួនបួន និង ផ្ទាំងរមូរជាច្រើន ដែលមានអក្សរអេហ្ស៊ីបបុរាណយកទៅទីក្រុង ខឺតឡង់ រដ្ឋ អូហៃអូ ។ សាកសពម៉ូមី និង ផ្ទាំងរមូរ ត្រូវគេរកឃើញនៅប្រទេសអេហ្ស៊ីបជាច្រើនឆ្នាំមុនដោយ អានតូនីញ៉ូ លីបូឡូ ។ ទីក្រុង ខឺតឡង់ គឺជាកន្លែងដែលរដ្ឋជាច្រើនចូលសំចត នៃសហរដ្ឋអាមេរិកប៉ែកខាងកើត ដើម្បីមើលការតាំងពិពណ៌សាកសពម៉ូមីរបស់ចានឡើរ ។ ចានឡើរ បានដាក់លក់សាកសពម៉ូមី និង ផ្ទាំងរមូរទាំងឡាយ ហើយដោយមានការជម្រុញពីព្យាការី យ៉ូសែប ស៊្មីធ នោះសមាជិកមួយចំនួននៃសាសនាចក្រ បានបរិច្ចាគប្រាក់ដើម្បីទិញវា ។ នៅក្នុងសេចក្ដីថ្លែងការមួយចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ១៨៣៥ យ៉ូសែប ស៊្មីធ បានប្រកាសអំពីសារៈសំខាន់នៃអត្ថបទរបស់ជនជាតិអេហ្ស៊ីបពីបុរាណទាំងនេះ ដែលបានកត់ត្រា ៖ ‹ ខ្ញុំបានចាប់ផ្ដើមបកប្រែតួអក្សរ ឬ អក្សរសញ្ញាសម្គាល់មួយចំនួន ហើយសេចក្ដីអំណររបស់យើងគឺមានដ៏លើសលប់ដែលរកឃើញថា ផ្ទាំងរមូរមួយមាននូវការសរសេររបស់អ័ប្រាហាំ ។. . . ពិតណាស់ យើងអាចនិយាយបានថា ព្រះអម្ចាស់បានចាប់ផ្ដើមត្រាស់សម្ដែងភាពសុខសាន្ត និង សេចក្ដីពិតដ៏ពេញបរិបូរហើយ › (*History of the Church,* ២:២៣៦ ) » ។ ( *The Pearl of Great Price Student Manual* [ Church Educational System manual ឆ្នាំ ២០០០ ] ទំព័រ ២៨) ។

មនុស្សមួយចំនួនបានងឿងឆ្ងល់ ថាតើព្យាការីបានបកប្រែអត្ថបទពីបុរាណនោះដោយរបៀបណា ។ យ៉ូសែប ស្ម៊ីធ ពុំដែលប្រាប់ឲ្យគេដឹងអំពីរបៀបដែលលោកបកប្រែកំណត់ត្រាទាំងនេះទេ ប៉ុន្តែ លោកបានបកប្រែអត្ថបទទាំងនេះដោយអំណោយទាន និង ព្រះចេស្ដានៃព្រះ ។ សាសនាចក្រ អ្នកប្រាជ្ញ និង ប្រវត្តិវិទូជាច្រើននាក់ បន្តព្យាយាមយល់អត្ថបទដើមនៃគម្ពីរនេះ ។ គម្ពីរនេះក៏ដូចជាគម្ពីរដទៃទៀតដែរ អត្ថន័យដ៏ជ្រាលជ្រៅនៃការទទួលបានទីបន្ទាល់អំពីភាពពេញលេញនៃគម្ពីរអ័ប្រាហាំ គឺជាការសិក្សាប្រកដដោយការអធិស្ឋានអំពីគម្ពីរនេះ ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ LDS.org ជ្រើសរើស Gospel Topics រួចស្វែងរក book of Abraham ។

២. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ ហេតុអ្វីបានជាវាមានសារៈសំខាន់ ដែលត្រូវទទួលបានសាក្សីខាងវិញ្ញាណអំពីសេចក្ដីពិតពេញលេញនៃគម្ពីរអ័ប្រាហាំ ?

ខាងក្រោមនេះគឺជាបញ្ជីសំណួរដែលធ្លាប់បានសួរជាទូទៅ ដោយភ្ជាប់មកជាមួយចម្លើយអំពីការលេចចេញមកនៃគម្ពីរអ័ប្រាហាំ ៖

**សំណួរ** ៖ ហេតុអ្វីបានជា យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា លោកបានបកប្រែអត្ថបទនៃគម្ពីរអ័ប្រាហាំ ទោះជាសំណៅនៃអត្ថបទនេះ ពុំមានកាលបរិច្ឆេទចាប់តាំងពីជំនាន់អ័ប្រាហាំផងនោះ ?

**ចម្លើយ** ៖ ព្យាការី យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា គម្ពីរអ័ប្រាហាំ គឺជា « ការបកប្រែនៃកំណត់ត្រាពីបុរាណមួយចំនួនដែលបានធ្លាក់ក្នុងដៃរបស់យើងបានមកពី ផ្នូរខេតខូមស៍របស់អេស៊ីព្ទ ដែលការណ៍នេះអះអាងថាជាអត្ថបទរបស់អ័ប្រាហាំខណៈដែលលោកនៅប្រទេសអេស៊ីព្ទ » ( *Times and Seasons* ថ្ងៃទី ១ ខែ មិនា ឆ្នាំ ១៨៤២ ទំព័រ ៧០៤ ) ។

ក្នុងឆ្នាំ ១៩៦៦ បំណែកនៃផ្ទាំងរមូរចំនួនដប់មួយបំណែកដែលធ្លាប់ជាកម្មសិទ្ធិរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ត្រូវបានរកឃើញនៅក្នុងសារៈមន្ទីរសិល្បៈ មេត្រូប៉ូលីតាន នៅទីក្រុង ញូវ យ៉ក ។ ផ្ទាំងរមូរទាំងនេះមាននូវអត្ថបទដ៏ពិតរបស់ពួកអេហ្ស៊ីប ប៉ុន្តែវាពុំកំណត់អំពីកាលបរិច្ឆេទនៃជំនាន់របស់អ័ប្រាហាំឡើយ ហើយវាក៏មិនមាននូវដំណើររឿងផ្ទាល់ខ្លួនដ៏ពិតប្រាកដរបស់អ័ប្រាហាំដែរ ។ វាជាការសំខាន់ដែលត្រូវដឹងថា ផ្ទាំងរមូរដែលបានរកឃើញនោះមានតែពីរបីបំណែកតែប៉ុណ្ណោះ និងពុំមែនជាផ្ទាំងរមូរទាំងអស់ដែល យ៉ូសែប ស្ម៊ីធ ធ្លាប់មាននោះទេ ។ គម្ពីរអ័ប្រាហាំអាចត្រូវបានបកប្រែចេញមកពី ផ្ទាំងរមូរដែលពុំត្រូវបានរកឃើញ ។ ផ្ទាំងរមូរដែលបានបាត់បង់នេះ អាចនឹងមានអត្ថបទសរសេរដោយអ័ប្រាហាំ ។



ច្បាប់ចម្លងទី ១ នៃបំណែកផ្ទាំងរមូរ

នៅពេលបច្ចុប្បន្ននេះ ជាធម្មតាយើងពុំដឹងអំពីលក្ខណៈពិតប្រាកដនៃទំនាក់ទំនងរវាងគម្ពីរអ័ប្រាហាំ និង ផ្ទាំងរមូរដែល យ៉ូសែប ស្ម៊ីធ បានមាននោះទេ ។ មានទ្រឹស្ដីជាច្រើនដែលចោទសួរអំពីរបៀបដែលព្យាការីបានបកប្រែអត្ថបទទាំងនេះ ប៉ុន្តែ ជាធម្មតាយើងពុំដឹងអំពីសេចក្ដីពិស្ដារឡើយ ។ យើងពិតជាដឹងថា ព្យាការី យ៉ូសែប ស្ម៊ីធ បានបកប្រែគម្ពីរអ័ប្រាហាំ ដោយអំណោយទាន និង ព្រះចេស្ដានៃព្រះ ។

**សំណួរ** ៖ តើ យ៉ូសែប ស្ម៊ីធ បានធ្វើអ្វីខ្លះ នៅក្នុងការបកប្រែរបស់លោក ?

**ចម្លើយ** ៖ « គម្ពីរអ័ប្រាហាំ ត្រូវបានបោះពុម្ពជាលើកដំបូងដោយមានការដកស្រង់តែចំនួនពីរបីប៉ុណ្ណោះក្នុងមួយលើកៗនៅក្នុងកាសែត *Times and Seasons* ដែលជាការបោះពុម្ពផ្សាយរបស់សាសនាចក្រ ចាប់ផ្ដើមក្នុងខែ មិនា ឆ្នាំ ១៨៤២ នៅទីក្រុងណៅវូ រដ្ឋ អិលលីណោយ [ សូមមើល បុព្វកថានៃមុក្ដាដ៏មានតម្លៃមហិមា ] ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានចង្អុលបង្ហាញថា លោកនឹងបោះពុម្ពគម្ពីរអ័ប្រាហាំបន្ថែមទៀតនៅពេលក្រោយ ប៉ុន្តែលោកត្រូវបានគេធ្វើឃាត មុនពេលលោកអាចបោះពុម្ពបន្ថែមទៀត ។ ស្ដីអំពីរយៈពេលជាចម្បងនៃការបកប្រែបានបញ្ចប់ អូលីវើរ ខៅឌើរី បានមានប្រសាសន៍ម្ដងនោះថា ‹ ភាគនានា › ចាំបាច់ត្រូវមានដាក់នៅក្នុងនោះ ( សូមមើល *Messenger and Advocate* ខែ ធ្នូ ឆ្នាំ ១៨៣៥ ទំព័រ ២៣៦ ) ។

« បន្ថែមពីលើអត្ថបទសរសេរជាអក្សរសញ្ញាសម្គាល់ សំណៅនោះក៏មានគំនូរផ្សេងៗនៃពួកអេហ្ស៊ីបផងដែរ ។ នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៨៤២ ព្យាការី យ៉ូសែប ស្ម៊ីធ បានសុំ រ៉ូប៊ិន ហែតឡាក់ ជាអ្នកឆ្លាក់ឈើដ៏ជំនាញមួយរូប និងជាសមាជិកនៃសាសនាចក្រ ឲ្យរៀបចំកាត់ឈើឆ្លាក់ជាពុម្ពចំនួនបី ដើម្បីពួកគេអាចបោះពុម្ពបាន ។ ហែតឡាក់ បានបញ្ចប់ការឆ្លាក់ក្នុងមួយសប្ដាហ៍ ហើយ យ៉ូសែប ស្ម៊ីធ បានបោះពុម្ពច្បាប់ចម្លង ( សំណៅ ) ព្រមជាមួយនឹងគម្ពីរអ័ប្រាហាំ ។ ការពន្យល់របស់ យ៉ូសែប ស្ម៊ីធ អំពីគំនូរព្រមជាមួយនឹងសំណៅទាំងឡាយ » (*The Pearl of Great Price Student Manual* ទំព័រ ២៨–២៩) ។

**សំណួរ** ៖ តើមានអ្វីកើតឡើងចំពោះសាកសពម៉ូមី និង ផ្ទាំងរមូរនោះ ?

**ចម្លើយ** ៖ « បន្ទាប់ពីមរណភាពរបស់ព្យាការី យ៉ូសែប ស្ម៊ីធ នោះមានសាកសពម៉ូមីចំនួនបួន និង ផ្ទាំងរមូរ បានក្លាយទៅជាសម្បត្តិរបស់ម្ដាយ យ៉ូសែប ដែលជាស្ត្រីមេម៉ាយឈ្មោះ លូស៊ី ម៉ាក ស្ម៊ីធ ។ នៅពេល លូស៊ី ទទួលមរណភាព ក្នុងឆ្នាំ ១៨៥៦ទៅ អិមម៉ា ស្ម៊ីធ ដែលជាភរិយារបស់ព្យាការី បានលក់របស់ទាំងនោះទៅឲ្យលោក អេ ខូម ។ ទ្រឹស្តីមួយចំនួនត្រូវបានលើកឡើង ស្តីអំពីអ្វីដែលបានកើតឡើងចំពោះសាកសពម៉ូមី និង ផ្ទាំងរមូរ ។ វាបានលេចឡើងថា មានសាកសពយ៉ាងហោចណាស់ចំនួនពីរ ត្រូវបានដុតឆេះនៅក្នុងពេលមានអគ្គីភ័យដ៏ធំឆាបឆេះនៅរដ្ឋ ឈីកាហ្គោ ក្នុងឆ្នាំ ១៨៧១ ( សូមមើល B. H. Roberts, *New Witnesses for God* វ៉ុល ៣ [ ឆ្នាំ ១៩០៩–១១ ] ២:៣៨០–៣៨២ ) ។



ពុម្ពឆ្លាក់ត្រូវបានបង្កើតឡើង ដើម្បីបោះពុម្ពច្បាប់ចម្លងនៅក្នុងគម្ពីរអ័ប្រាហាំ

« នៅដើមនិទាឃរដូវឆ្នាំ ១៩៦៦ វេជ្ជ. អាហ្ស៊ីស អេស អាទីយ៉ា ជាសាស្ត្រាចារ្យសាកលវិទ្យាល័យយូថាហ៍ បានរកឃើញបំណែកមួយចំនួននៃផ្ទាំងរមូរគម្ពីរអ័ប្រាហាំ កាលលោកកំពុងសិក្សាស្រាវជ្រាវនៅសារៈមន្ទីរសិល្បៈ មេត្រូប៉ូលីតាន នៅទីក្រុង ញូវ យ៉ក ។ បំណែកទាំងនេះ ត្រូវបានបង្ហាញដល់សាសនាចក្រ ដោយនាយកសារៈមន្ទីរ នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៦៧ ។ ពុំមានដំណឹងអំពីទីតាំងបច្ចុប្បន្នរបស់សាកសពម៉ូមីផ្សេងទៀត និង បំណែកផ្សេងទៀតនៃផ្ទាំងរមូរនោះទេ ( សូមមើល H. Donl Peterson, “Some Joseph Smith Papyri Rediscovered ( ឆ្នាំ ១៩៦៧ )” នៅក្នុង *Studies in Scripture វ៉ុល ពីរ* ទំព័រ ១៨៣–៨៥ )” (*The Pearl of Great Price Student Manual* ទំព័រ ២៩) ។

បន្ថែមពីលើការបង្រៀនអំពីគោលលទ្ធិ និង គោលការណ៍ដ៏មានតម្លៃ **មុក្តាដ៏មានតម្លៃមហិមា គឺជាភស្តុតាងដែលបង្ហាញថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីរបស់ព្រះ ។**

៣. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថា មុក្តាដ៏មានតម្លៃមហិមា គឺជាភស្តុតាងអំពីការហៅបម្រើរបស់ យ៉ូសែប ស្ម៊ីធ ជាព្យាការី ដោយរបៀបណា ?

## មាត្រានៃសេចក្តីជំនឿ

នៅថ្ងៃទី ១ ខែ មិនា ឆ្នាំ ១៨៤២ ព្យាការី យ៉ូសែប ស្ម៊ីធ បានបោះពុម្ពសំបុត្រមួយច្បាប់ដែលលោកបានសរសេរទៅកាន់ ចន វ៉េនវើស ជាអ្នកសរសេរកាសែត ដោយពន្យល់ប្រាប់អំពីប្រវត្តិ និង ជំនឿនៃសាសនាចក្រ ។ រឿងនេះត្រូវបានគេស្គាល់ជាទូទៅថា សំបុត្ររបស់ វ៉េនវើស ។ នៅក្នុងសំបុត្រនោះ យ៉ូសែប បានប្រកាសគោលការណ៍គ្រឹះនៃដំណឹងល្អចំនួន ១៣ ។ ជំនឿទាំងនេះ ត្រូវបានដាក់បញ្ចូលនៅក្នុង មុក្តាដ៏មានតម្លៃមហិមា ជាមាត្រានៃសេចក្តីជំនឿ ។ ទោះបីជាអ្វីទាំងនោះពុំមែនជាសេចក្តីថ្លែងការណ៍មួយអំពីសេចក្តីជំនឿរបស់យើងទាំងអស់ក្តី តែវាជាកញ្ចប់គោលលទ្ធិ និង គោលការណ៍ដ៏សំខាន់ ។

សូមបើកទៅ ហើយអាន មាត្រានៃសេចក្តីជំនឿ នៅក្នុងមុក្តាដ៏មានតម្លៃមហិមា ។

៤. សូមជ្រើសរើសមាត្រានៃសេចក្តីជំនឿចំនួនពីរ ។ សូមធ្វើលំហាត់ខាងក្រោមនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមសរសេរដោយប្រើពាក្យពេចន៍របស់អ្នកផ្ទាល់ អំពីគោលលទ្ធិ ឬ គោលការណ៍ដែលមាត្រានៃសេចក្តីសញ្ញាបង្រៀន ។

ខ. សូមស្វែងរកបទគម្ពីរមួយ ដែលគាំទ្រ ឬ ពន្យល់អំពីគោលលទ្ធិ ឬ គោលការណ៍នៅក្នុងមាត្រានៃសេចក្តីជំនឿនោះ ។ សូមសរសេរអំពីចំណេះដឹងដែលបទគម្ពីរនេះបន្ថែម ទៅក្នុងការយល់ដឹងរបស់អ្នកអំពីគោលលទ្ធិ ឬ គោលការណ៍នេះ ។

គ. សូមសរសេរអំពីវិធីមួយ ដែលការយល់ដឹង និង ការជឿលើមាត្រានៃសេចក្តីជំនឿនេះ អាចនាំពរជ័យចូលមកក្នុងជីវិតរបស់បុគ្គលម្នាក់ ។

### *ការអនុវត្តពន្យល់អំពីសេចក្តីពិតនៃដំណឹងល្អ*

ពេញមួយជីវិតអ្នក អ្នកអាចនឹងមានឱកាសពន្យល់អំពីជំនឿរបស់អ្នកទាក់ទងនឹងដំណឹងល្អ—ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ក្នុងការហៅបម្រើក្នុងសាសនាចក្រ ឬ បង្រៀនទៅដល់ក្រុមគ្រួសារ មិត្តភក្តិ និង មនុស្សដែលអ្នកទើបតែស្គាល់ ។ ការសរសេរចម្លើយចំពោះសំណួរខាងដំណឹងល្អ គឺជាវិធីដ៏ប្រសើរមួយ ដើម្បីរៀនអំពីរបៀបឆ្លើយតបទៅវិញដោយច្បាស់លាស់ និង ដោយសង្ខេប ។ នៅពេលអ្នកអនុវត្តការពន្យល់អំពីដំណឹងល្អដោយការសរសេរ នោះវាអាចនឹងផ្តល់អត្ថប្រយោជន៍ ប្រសិនបើអ្នកស្រមៃថា អ្នកកំពុងសរសេរទៅកាន់បុគ្គលជាក់លាក់ណាម្នាក់ ។

អែលឌើរ អិល ថម ភើរី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានតំណាលអំពីរបៀបដែលមាត្រានៃសេចក្ដីជំនឿ អាចមានប្រយោជន៍ជាពិសេសសម្រាប់សមាជិកនៃសាសនាចក្រ ៖



« ខ្ញុំបានធ្វើការសន្និដ្ឋានថា ប្រសិនបើខ្ញុំបានសិក្សាមាតិការបស់មាត្រានៃសេចក្ដីជំនឿនីមួយៗ ខ្ញុំអាចពន្យល់ ហើយការពាររាល់គោលការណ៍ទាំងឡាយនៃដំណឹងល្អ ដែលខ្ញុំអាចមានឱកាសដើម្បីបង្រៀនទៅដល់បុគ្គលដែលកំពុងស្វែងរកសេចក្ដីពិតដែលបានស្ដារឡើងវិញ ។

« តើវាគឺជាពរជ័យដ៏មហិមាយ៉ាងណាទៅ ប្រសិនបើសមាជិកគ្រប់រូបនៃសាសនាចក្រ ទន្ទេញចាំមាត្រានៃសេចក្ដីជំនឿ ហើយក្លាយជាមានការចេះដឹងច្រើនអំពីគោលការណ៍ទាំងឡាយដែលមាននៅក្នុងមាត្រានីមួយៗនោះ ។ លំដាប់នោះ យើងនឹងត្រៀមខ្លួនបានយ៉ាងល្អប្រសើរ ដើម្បីចែកចាយដំណឹងល្អជាមួយមនុស្សទូទៅ ។. . .

« មាត្រានៃសេចក្ដីជំនឿ ពុំមែនជាស្នាដៃរបស់ក្រុមនៃពួកអ្នកប្រាជ្ញនោះទេ ប៉ុន្តែ វាត្រូវបានចងក្រងឡើងដោយបុរសតែម្នាក់គត់ ដែលមានការបំផុសគំនិត ជាបុរសដែលបានប្រកាសដោយទូលំទូលាយ និង ដោយសង្ខេប អំពីសារៈសំខាន់នៃគោលលទ្ធិទាំងឡាយនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ វាមាននូវសេចក្ដីថ្លែងការណ៍ត្រង់ៗ និង សាមញ្ញៗ អំពីគោលការណ៍ទាំងឡាយនៃសាសនារបស់យើង ហើយវារួមគ្នាបង្កើតឡើងជាការបំផុសគំនិតដ៏ទេវភាព ដែលមានលើរូបព្យាការី យ៉ូសែប ស្ម៊ីធ » ( «The Articles of Faith,» *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៨ ទំព័រ ២៣–២៤ ) ។

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើសេចក្ដីថ្លែងការណ៍ត្រង់ៗ និង សាមញ្ញៗ អំពីគោលការណ៍ទាំងឡាយ អាចមានអត្ថប្រយោជន៍ក្នុងការពន្យល់ និង បង្រៀនអំពីដំណឹងល្អយ៉ាងដូចម្ដេច ?

ខ. សូមសរសេរអំពីបទពិសោធន៍មួយ ដែលអ្នកបានមាននៅពេលមាត្រានៃសេចក្ដីជំនឿ ឬ សេចក្ដីពិតទាំងឡាយដែលមាននៅក្នុងនោះ បានជួយដល់អ្នកក្នុងការពន្យល់ដំណឹងល្អដល់បុគ្គលណាមួយ ។ ប្រសិនបើអ្នកពុំធ្លាប់មានបទពិសោធន៍ដូចនោះទេ សូមសរសេរសំណួរទាំងឡាយ ដែលមនុស្សដទៃអាចនឹងសួរអំពីសាសនារបស់យើង ដែលអាចឆ្លើយបានដោយប្រើមាត្រានៃសេចក្ដីជំនឿ ។

អ្នកអាចនឹងចង់ដាក់គោលដៅមួយ ដើម្បីសិក្សា ហើយទន្ទេញឲ្យចាំមាត្រានៃសេចក្ដីជំនឿទាំងអស់ ។ ការធ្វើដូច្នេះនឹងបង្កើនសមត្ថភាពរបស់អ្នក ក្នុងការពន្យល់ប្រាប់អំពីគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សាមេរៀនអំពី « ការលេចចេញមកនៃព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា » ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៣១ ៖ ថ្ងៃទី ៣

# សេចក្តីប្រកាសជាផ្លូវការទី ១និងការអភិវឌ្ឍកិច្ចការព្រះវិហារបរិសុទ្ធជាបន្តបន្ទាប់

## បុព្វកថា

អាពាហ៍ពិពាហ៍ពហុពន្ធភាពត្រូវបានអនុញ្ញាតតែក្នុងករណី ដែលត្រូវបានត្រាស់បង្គាប់ដោយព្រះអម្ចាស់ ដើម្បីបង្កើតកូនចៅក្នុងការបំពេញតាមគោលបំណងទ្រង់ប៉ុណ្ណោះ ( សូមមើល យ៉ាកុប ២:២៧–៣០ ) ។ បន្ទាប់ពីព្យាការី យ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈដឹកនាំលោកឲ្យបង្រៀនគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាព នោះលោកក៏បានអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ហើយសមាជិកសាសនាចក្រមួយចំនួន ក៏បានចាប់ផ្តើមអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពនៅដើមឆ្នាំ ១៨៤០ ។ នៅអំឡុងជាច្រើនទសវត្សរ៍ក្រោយមក សាសនាចក្របានជួបប្រទះនឹងការជំទាស់ពីសំណាក់សាធារណជន ដោយសារតែការអនុវត្តនេះ ។ « បន្ទាប់ពីទទួលបានវិវរណៈ នោះប្រធាន វិលហ្វូឌ វូឌ្រុព្វ បានចេញ. . . [ សេចក្តីប្រកាសជាផ្លូវការទី ១ ] ដែលត្រូវបានទទួលយកដោយសាសនាចក្រ ជាការអនុញ្ញាតជាផ្លូវការ ហើយគោរពតាមនៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៨៩០ ។ សេចក្តីថ្លែងការណ៍នេះ បាននាំទៅរកការបញ្ចប់នូវការអនុវត្តន៍អាពាហ៍ពិពាហ៍ពហុពន្ធភាពនៅក្នុងសាសនាចក្រ ( សេចក្តីប្រកាសជាផ្លូវការទី ១ បុព្វកថា ) ។ នៅអំឡុងពេលតែមួយនោះ ពួកបរិសុទ្ធបានធ្វើការដោយឧស្សាហ៍ព្យាយាមដើម្បីសាងសង់ព្រះវិហារបរិសុទ្ធជាកន្លែងដែលពួកគេបានទទួលពីធីបរិសុទ្ធនៃសេចក្តីសង្គ្រោះសម្រាប់ខ្លួនគេ និងសម្រាប់មរណជន ។

### ព្រះអម្ចាស់បានត្រាស់សម្តែងថា ពួកបរិសុទ្ធថ្ងៃចុងក្រោយគួរតែបញ្ឈប់នូវការអនុវត្តន៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាព

តើអ្នកអាចគិតអំពីគំរូមួយចំនួននៃបុគ្គលសុចរិតទាំងឡាយ ដែលត្រូវបានចាប់ខ្លួន ឬ ដាក់គុកដោយសារតែបានធ្វើអ្វី ដែលព្រះបានត្រាស់បង្គាប់ពួកគេឲ្យធ្វើដែរឬទេ ?

មានបុរស ៗនៃពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើនរូប ត្រូវបានចាប់ខ្លួន ហើយដាក់គុក ដោយសារតែពួកគេបានបន្តគោរពបទបញ្ញត្តិដើម្បីអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព បន្ទាប់ពីរដ្ឋាភិបាលសហរដ្ឋអាមេរិក បានអនុមតិច្បាប់ធ្វើឲ្យការអនុវត្តនេះខុសនឹងច្បាប់ ។ ស្រ្តីមួយចំនួនត្រូវបានចាប់ខ្លួនផងដែរ ជាធម្មតាដោយសារតែពួកគេពុំព្រមប្រាប់ពីកន្លែងលាក់ខ្លួនរបស់ប្តីពួកគេដែលបានរត់ទៅលាក់ខ្លួនពីការតាមចាប់ខ្លួននោះ ។

នៅពេលអ្នកអានកថាខណ្ឌខាងក្រោមនេះ សូមគូសចំណាំសេចក្តីលំបាកនានា ដែលសមាជិកសាសនាចក្រមួយចំនួនកាលពីជំនាន់ដំបូងបានជួបប្រទះ នៅពេលពួកគេបានគោរពតាមបទបញ្ជារបស់ព្រះអម្ចាស់ ឲ្យអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។

ក្នុងខែ សីហា ឆ្នាំ ១៨៥២ ជាចំណែកនៃសន្និសីទមួយនៅទីក្រុង សលត៍ លេក ថ្នាក់ដឹកនាំសាសនាចក្រ បានប្រកាសជាសាធារណៈថា ដោយគោរពតាមបទបញ្ញត្តិនៃព្រះ នោះសមាជិកសាសនាចក្រមួយចំនួន កំពុងតែអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ មានថ្នាក់ដឹកនាំសាសនា និង ថ្នាក់ដឹកនាំនយោបាយជាច្រើននៅក្នុងសហរដ្ឋ បានប្រឆាំងទៅនឹងប្រព័ន្ធអាពាហ៍ពិពាហ៍ពហុពន្ធភាព ដែលពួកគេចាត់ទុកថាប្រព័ន្ធនេះគឺអសីលធម៌ និង គ្មានអរិយធម៌ ។ ពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើនរូបត្រូវបានគេសើចចំអកក្នុងទីសាធារណៈនៅក្នុងសុន្ទរកថា សៀវភៅ ទស្សនាវដ្តី និង កាសែតនានា ។ សភាសហរដ្ឋបានចេញច្បាប់ជាច្រើនដែលដាក់កម្រិតដល់សេរីភាពរបស់សមាជិកសាសនាចក្រ ហើយបានសង្កត់សង្កិនដល់សាសនាចក្រខាងសេដ្ឋកិច្ចដោយរឹតបន្តឹងចំនួនអចលនទ្រព្យដែលសាសនាចក្រអាចកាន់កាប់បាន ។ ច្បាប់ទាំងនេះ នៅទីបំផុតនាំទៅរកការចាប់

ខ្លួន និងការដាក់គុកបុរសៗដែលមានប្រពន្ធច្រើនជាងមួយ ។ បុរសទាំងនេះត្រូវបានគេបដិសេធ « មិនឲ្យមានសិទ្ធិបោះឆ្នោត គ្មានសិទ្ធិឯកជននៅក្នុងផ្ទះរបស់ពួកគេ ហើយគ្មានសិទ្ធិរីករាយនឹងសេរីភាពស៊ីវិលដទៃទៀតឡើយ » (*កេរដំណែលរបស់យើង ៖ ប្រវត្តិសង្ខេបរបស់សាសនាចក្រនៃព្រះ យេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ* [ ឆ្នាំ ១៩៩៦ ] ទំព័រ ៩៧ ) ។ នៅត្រឹមឆ្នាំ ១៨៩០ មានពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏ស្មោះត្រង់ជាច្រើនរយនាក់បានជាប់គុក ដោយព្រោះតែអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ អ្នកផ្សេងទៀតបានរត់គេចលាក់ខ្លួនដើម្បីចៀសវាងពីការចាប់ខ្លួន និងដាក់គុក ។ នៅក្នុងស្ថានភាពបែបនេះ មានគ្រួសារជាច្រើនបានរងទុក្ខដោយភាពតានតឹង ទុក្ខសោក ភាពក្រីក្រ និង ការអត់ឃ្លាន ។

កាលៈទេសៈដ៏លំបាកទាំងនេះបាននាំឲ្យប្រធាន វិលហ្វូឌ វូឌរ៉ុហ្វ ស្វែងរកការដឹកនាំពីព្រះអម្ចាស់ប្រកបដោយការអធិស្ឋានពាក់ព័ន្ធទៅនឹងការអនុវត្តន៍អាពាហ៍ពិពាហ៍ពហុពន្ធភាពរបស់ពួកបរិសុទ្ធទាំងឡាយ ។ ក្នុងឆ្នាំ ១៨៨៩ ប្រធាន វូដរ៉ុហ្វ បានណែនាំថ្នាក់ដឹកនាំសាសនាចក្រ ឲ្យបញ្ឈប់ការបង្រៀនគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពនេះទៀត ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានមនុស្សខ្លះបានចេញផ្សាយរបាយការណ៍ជាច្រើនថា សាសនាចក្រនៅតែបន្តឲ្យមានការអនុវត្តន៍ពហុអាពាហ៍ពិពាហ៍ដដែល ។ របាយការណ៍ទាំងនេះ បានបង្កើតជាការរុកគួនដល់សាសនាចក្រ ។ ក្នុងឆ្នាំ ១៨៩០ ប្រធាន វូឌ រ៉ុហ្វ បានចេញជាសេចក្ដីប្រកាសមួយដែលពេលនេះត្រូវបានគេស្គាល់ថាជាសេចក្ដីប្រកាសជាផ្លូវការទី ១ ដែលមាននៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ។


ប្រធាន វិលហ្វូឌ វូឌរ៉ុហ្វ

នៅក្នុងកថាកណ្ឌបីដំបូងនៃ សេចក្ដីប្រកាសជាផ្លូវការទី ១ប្រធាន វូឌរ៉ុហ្វ បានអះអាងថា របាយការណ៍ចោទប្រកាន់ថា សាសនាចក្រនៅតែលើកទឹកចិត្តឲ្យអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព គឺជារឿងមិនត្រឹមត្រូវទេ ។

សូមអានកថាកណ្ឌទីបួន និង ទីប្រាំនៃ សេចក្ដីប្រកាសជាផ្លូវការទី ១ ( ចាប់ផ្ដើមនៅត្រង់ « ដរាបណាដែលមានច្បាប់ » ) និងសេចក្ដីថ្លែងការណ៍ជាបន្តបន្ទាប់ដោយប្រធាន ឡូរ៉េនសូ ស្នូ ដែលពេលនោះជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមស្វែងរក ហើយគូសចំណាំអ្វីដែលប្រធាន វូឌរ៉ុហ្វ បានណែនាំពួកបរិសុទ្ធឲ្យធ្វើ ។

យោងតាមសេចក្ដីថ្លែងការណ៍ដោយប្រធាន ឡូរ៉េនសូ ស្នូ ហេតុអ្វីបានជាមានសារៈសំខាន់ដែលការដឹកនាំឲ្យចៀសវាងពីការចុះកិច្ចព្រមព្រៀងលើអាពាហ៍ពិពាហ៍ពហុពន្ធភាពតទៅទៀត ត្រូវចេញមកពីប្រធាននៃសាសនាចក្រ ?

វាជាការសំខាន់ដែលត្រូវយល់ថា ប្រធាននៃសាសនាចក្រ គឺជាបុគ្គលតែម្នាក់គត់នៅលើផែនដីនេះ ដែលកាន់កូនសោទាំងឡាយនៃពិធីបរិសុទ្ធនៃការសង្គ្រោះ ។ អាពាហ៍ពិពាហ៍ពហុពន្ធភាព អាចត្រូវបានអនុញ្ញាតតែតាមរយៈកូនសោបព្វជិតភាព ដែលត្រូវបានប្រទានឲ្យដល់ប្រធាននៃសាសនាចក្រប៉ុណ្ណោះ ( សូមមើល គ. និង ស. ១៣២:៧, ៤៨ ) ។

សូមអានកថាកណ្ឌទីមួយនៃ « ការដកស្រង់មកពីប្រសាសន៍ចំនួនបី ដោយប្រធាន វិលហ្វូឌ វូឌរ៉ុហ្វ ទាក់ទងនឹងសេចក្ដីប្រកាស » ដែលយកតាមអត្ថបទនៃសេចក្ដីប្រកាសនោះ ។ សូមស្វែងរក ហើយគូសចំណាំគោលការណ៍មួយ ដែលប្រធាន វូឌរ៉ុហ្វ បានណែនាំពួកបរិសុទ្ធឲ្យធ្វើ ។

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

   ក. តើប្រធាន វិលហ្វូឌ វូឌរ៉ុហ្វ បានបង្រៀនគោលការណ៍អ្វីដល់ពួកបរិសុទ្ធ ?

   ខ. តើអ្នកគិតថា ហេតុអ្វីបានជាវាមានសារៈសំខាន់ ដែលយើងត្រូវមានទីបន្ទាល់ថា **ព្រះអម្ចាស់នឹងមិនដែលអនុញ្ញាតឲ្យប្រធាននៃសាសនាចក្រ ដឹកនាំសាសនាចក្រឲ្យដើរតាមផ្លូវខុសទេនោះ ?**

សមាជិកសាសនាចក្រមួយចំនួន បានងឿងឆ្ងល់ថា ហេតុអ្វីក៏ពួកគេត្រូវបានដឹកនាំឲ្យរស់នៅតាមគោលការណ៍នៃអាពាហ៍ពិពាហ៍ពហុពន្ធភាពហើយ បែរជាមកដឹកនាំឲ្យបញ្ឈប់ទៅវិញដូច្នេះ ។ ព្រះអម្ចាស់បានណែនាំប្រធាន វូឌ្រុព្វ ឲ្យចោទជាសំណួរដល់ពួកបរិសុទ្ធ ។ សូមអានកថាកណ្ឌទីបី ទីបួន និង ទីប្រាំនៃ « ការដកស្រង់ចេញមកពីប្រសាសន៍ទាំងបីរបស់ប្រធាន វិលហ្វូឌ វូឌ្រុព្វ » ( ចាប់ផ្ដើមត្រង់ « ខ្ញុំមានវិវរណៈមួយចំនួន » ) ដោយស្វែងរកសំណួរដែលប្រធាន វូឌ្រុហ្វ បានសួរដល់ពួកបរិសុទ្ធ ។

ពួកបរិសុទ្ធគឺស្ថិតនៅក្នុងគ្រោះថ្នាក់នៃការបាត់បង់ព្រះវិហារបរិសុទ្ធទីក្រុង សេន្ត ចច រដ្ឋ យូថាហ៍ ព្រះវិហារបរិសុទ្ធទីក្រុង ឡូហ្គិន រដ្ឋ យូថាហ៍ ព្រះវិហារបរិសុទ្ធទីក្រុង ម៉ាន់ធៃ រដ្ឋ យូថាហ៍ និង ព្រះវិហារបរិសុទ្ធទីក្រុង សលត៍ លេក ដែលសាងសង់ហៀបនឹងបញ្ចប់ហើយនោះ ។ តើកិច្ចការដ៏សំខាន់មួយណាដែលនឹងបាត់បង់ទៅ ប្រសិនបើរដ្ឋាភិបាលសហរដ្ឋអាមេរិក រឹបអូសយកព្រះវិហារបរិសុទ្ធនោះ ?


ពួកបរិសុទ្ធបានស្ថិតនៅក្នុងគ្រោះថ្នាក់នៃការបាត់បង់ព្រះវិហារបរិសុទ្ធ

សូមអានកថាខណ្ឌទីប្រាំពីរនៃ « ការដកស្រង់ចេញមកពីប្រសាសន៍ទាំងបីរបស់ប្រធាន វិលហ្វូឌ វូឌ្រុព្វ » ( ចាប់ផ្ដើមត្រង់ « ខ្ញុំបានឃើញយ៉ាងច្បាស់ » ) ដោយស្វែងរកអ្វីដែលប្រធាន វូឌ្រុហ្វ នឹងធ្វើ ប្រសិនបើព្រះមិនបានត្រាស់បង្គាប់ឲ្យលោកណែនាំដល់ថ្នាក់ដឹកនាំសាសនាចក្រ មិនឲ្យបន្តអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។

តើយើងអាចរៀនអ្វីខ្លះមកពីសេចក្ដីថ្លែងការណ៍របស់ប្រធាន វូឌ្រុព្វ ដែលថា « ខ្ញុំបានសរសេរនូវអ្វីដែលព្រះអម្ចាស់បានប្រាប់ឲ្យខ្ញុំសរសេរ » ?

គោលលទ្ធិមួយដែលយើងអាចរៀនចេញពីការដកស្រង់នេះគឺ **ព្រះអម្ចាស់ដឹកនាំសាសនាចក្រទ្រង់ តាមរយៈវិវរណៈទៅដល់ប្រធាននៃសាសនាចក្រ ។**

២. សូមធ្វើលំហាត់ពីរ ឬ ច្រើនជាងពីរនៃលំហាត់ទាំងឡាយខាងក្រោមនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. សូមគិតអំពីគ្រាទាំងឡាយដែលអ្នកបានឃើញ ព្រះអម្ចាស់ដឹកនាំសាសនាចក្រទ្រង់ តាមរយៈវិវរណៈទៅដល់ប្រធាននៃសាសនាចក្រ ។ សូមពិពណ៌នាអំពីឧទាហរណ៍ចំនួនពីរ ដែលអ្នកគិតឃើញ ។

ខ. សូមសរសេរ ២–៣ ប្រយោគអំពីរបៀបដែលសេចក្ដីជំនឿរបស់អ្នកនៅក្នុងគោលលទ្ធិនេះ បានមានឥទ្ធិពលលើជម្រើសដែលអ្នកបានធ្វើ ។

គ. សូមសួរសមាជិកគ្រួសារ ឬ មិត្តភក្ដិម្នាក់ អំពីរបៀបដែលគាត់ដឹងថា ព្រះអម្ចាស់ទ្រង់ដឹកនាំសាសនាចក្ររបស់ទ្រង់ តាមរយៈវិវរណៈទៅដល់ប្រធាននៃសាសនាចក្រ ។ សូមសរសេរអំពីអ្វី ដែលអ្នកបានរៀនចេញពីការសន្ទនាជាមួយគាត់ ។

ពួកបរិសុទ្ធថ្ងៃចុងក្រោយមួយចំនួនតូច បានបន្តអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពជាថ្មី បន្ទាប់ពីសេចក្ដីប្រកាសត្រូវបានផ្ដល់ឲ្យ ។ ក្នុងឆ្នាំ ១៩០៤ ប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ បានធ្វើសេចក្ដីប្រកាសជាផ្លូវការ ៖ « រាល់អាពាហ៍ពិពាហ៍ [ ពហុពន្ធភាព ] គឺត្រូវបានហាមឃាត់ ហើយបើមានអ្នកកាន់តំណែងណាមួយ ឬសមាជិកនៃសាសនាចក្រណាម្នាក់ ទទួលយកដោយគោរព ឬ អនុវត្តអាពាហ៍ពិពាហ៍ប្រភេទនេះ នោះគាត់នឹងត្រូវ [ ចាត់ទុកថា ] ប្រព្រឹត្តអំពើរំលងប្រឆាំង នឹងសាសនាចក្រ . . . ហើយត្រូវតែកាត់កាលចេញពីសាសនាចក្រ » ( នៅក្នុង របាយការណ៍សន្និសីទ ខែ មេសា ឆ្នាំ ១៩០៤ ទំព័រ ៧៥ ) ។ គោលនយោបាយនេះបន្តនៅមានដល់សព្វថ្ងៃនេះ ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ LDS.org ជ្រើសរើស Gospel Topics រួចស្វែងរក plural marriage ។

សេចក្ដីថ្លែងការណ៍ខាងក្រោម ដែលធ្វើជា សេចក្ដីផ្ដើមនៃសេចក្ដីប្រកាសជាផ្លូវការទី ១ នៅក្នុងកំណែថ្មីនៃព្រះគម្ពីរឆ្នាំ ២០១៣ អាចជួយអ្នកឲ្យឆ្លើយសំណួរអំពីការអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅឆ្នាំ ១៨០០ ។



រូបថតប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ ( កណ្ដាល ) និង ក្រុមគ្រួសាររបស់លោក

> « ព្រះគម្ពីរប៊ីប និង ព្រះគម្ពីរមរមន បង្រៀនថា ការរៀបអាពាហ៍ពិពាហ៍ដែលមានស្វាមីម្នាក់ និង ភរិយាម្នាក់ គឺជាបទដ្ឋានរបស់ព្រះសម្រាប់អាពាហ៍ពិពាហ៍ លើកលែងតែទ្រង់បានប្រកាសផ្សេងពីនោះ ( សូមមើល សាំយូអែល ទី២ ១២:៧–៨ និង យ៉ាកុប ២:២៧, ៣០ ) ។ នៅបន្ទាប់ពីវិវរណៈមួយទៅកាន់ យ៉ូសែប ស្ម៊ីធ ការអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ត្រូវបានធ្វើឡើងនៅក្នុងចំណោមសមាជិកសាសនាចក្រនៅដើមឆ្នាំ ១៨៤០ ( សូមមើល កណ្ឌ ១៣២ ) ។ ចាប់តាំងពីឆ្នាំ ១៨៦០ ដល់ឆ្នាំ ១៨៨០ រដ្ឋាភិបាលសហរដ្ឋអាមេរិក បានបង្កើតច្បាប់ទាំងឡាយដែលធ្វើឲ្យការអនុវត្តខាងសាសនានេះខុសច្បាប់ ។ ទីបំផុត ច្បាប់ទាំងនេះត្រូវបានគាំទ្រ ដោយតុលាការកំពូលស.រ.អា ។ បន្ទាប់ពីទទួលបានវិវរណៈ នោះប្រធាន វិលហ្វូឌ វូឌរ្រុព្វ បានចេញគោលនយោបាយខាងក្រោម ដែលត្រូវបានទទួលយកដោយសាសនាចក្រ ជាការអនុញ្ញាតជាផ្លូវការ ហើយគោរពតាម នៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៨៩០ ។ សេចក្ដីថ្លែងការណ៍នេះ បានបញ្ចប់នូវការអនុវត្តន៍អាពាហ៍ពិពាហ៍ពហុពន្ធភាពនៅក្នុងសាសនាចក្រ » ។

៣. យោងតាមអ្វីដែលអ្នកបានរៀនថ្ងៃនេះ តើអ្នកនឹងឆ្លើយតបយ៉ាងដូចម្ដេច បើសិនជានរណាម្នាក់បានសួរថាតើពួកបរិសុទ្ធថ្ងៃចុងក្រោយពិតជាបានអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពមែនដែរឬទេ ? សូមសរសេរចម្លើយរបស់អ្នក នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

## កិច្ចការព្រះវិហារបរិសុទ្ធបន្តឆ្ពោះទៅមុខ

បន្ទាប់ពីសេចក្ដីប្រកាសត្រូវបានប្រគល់ឲ្យមក ការគំរាមគំហែងរឹបអូសយកព្រះវិហារបរិសុទ្ធ និង សម្បត្តិរបស់សាសនាចក្រពីសំណាក់រដ្ឋាភិបាលសហព័ន្ធ ត្រូវបានបញ្ចប់ ។ បើគ្មានការរំខានដូច្នោះទេ នោះពួកបរិសុទ្ធអាចនឹងត្រូវបានផ្ដោតអារម្មណ៍កាន់តែខ្លាំងទៅលើកិច្ចការព្រះវិហារបរិសុទ្ធ ។ ក្នុងឆ្នាំ ១៨៩៣ គឺរយៈពេល ៤០ ឆ្នាំ បន្ទាប់ពីថ្មជ្រុងនៃព្រះវិហារបរិសុទ្ធទីក្រុងសលត៍ លេក ត្រូវបានបញ្ចុះ ប្រធាន វិលហ្វូឌ វូឌរ្រុព្វ បានឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធនោះ ដែលក្នុងនោះព្រះវិហារបរិសុទ្ធចំនួនបួនបានដំណើរការ ។



ក្នុងខែ មេសា ឆ្នាំ ១៨៩៤ គឺរយៈពេលមួយឆ្នាំ បន្ទាប់ពីការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធទីក្រុង សលត៍ លេក ប្រធាន វិលហ្វឺដ វ៉ូឌ្រុហ្វ បានប្រកាសថា លោកបានទទួលវិវរណៈ ដែលបញ្ជាក់កាន់តែច្បាស់អំពីពិធីបរិសុទ្ធនៃការផ្សារភ្ជាប់ ឬ ពិធីផ្សារភ្ជាប់ដ៏អស់កល្បជានិច្ច ។ មុនពេលវិវរណៈនេះ សមាជិកសាសនាចក្រ បានធ្វើតាមចំណេះដឹងដែលពួកគេមាន ដោយពួកគេបានផ្សារភ្ជាប់ខ្លួនពួកគេ ឬ « បានផ្សារភ្ជាប់ទៅសាច់ញាតិចិញ្ចឹម » ទៅនឹងថ្នាក់ដឹកនាំសាសនាចក្រ ជាជាងផ្សារភ្ជាប់ទៅនឹងឪពុកម្ដាយខ្លួន ។ ប្រធាន វ៉ូឌ្រុហ្វ បានណែនាំដល់ពួកបរិសុទ្ធ ដោយផ្អែកលើវិវរណៈថ្មីលោកបានថ្លែងទីបន្ទាល់ថា « ព្រះឆន្ទៈរបស់ព្រះអម្ចាស់ចំពោះប្រជាជននេះ គឺពួកគេត្រូវស្រាវជ្រាវពង្សាវលីរបស់ខ្លួនឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន រួចផ្សារភ្ជាប់ទៅនឹងឪពុក និង ម្ដាយរបស់ខ្លួន ។ ចូរឲ្យកូនៗផ្សារភ្ជាប់នឹងឪពុកម្ដាយរបស់ពួកគេ ហើយបន្តការផ្សារភ្ជាប់នេះ ទៅកាន់ជំនាន់ដើមបំផុតតាមដែលអ្នកអាចធ្វើបាន » (*ការបង្រៀនរបស់ប្រធាននៃសាសនាចក្រ ៖ វិលហ្វឺដ វ៉ូឌ្រុហ្វ* [ ឆ្នាំ ២០០៤ ] ទំព័រ xxxiv–xxxv) ។

យោងតាមសេចក្ដីថ្លែងការណ៍ដោយប្រធាន វ៉ូឌ្រុហ្វ យើងរៀនគោលការណ៍ដូចតទៅនេះ ៖ **យើងអាចត្រូវបានផ្សារភ្ជាប់ទៅនឹងសមាជិកគ្រួសាររបស់យើង រួមមានទាំងអស់អ្នកដែលបានមកកើតពីមុនយើង និង អ្នកដែលកើតក្រោយយើងផងដែរ តាមរយៈពិធីបរិសុទ្ធនៃការផ្សារភ្ជាប់ ។**

៤. សូមឆ្លើយសំណួរដូចតទៅនេះ ដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើពិធីបរិសុទ្ធនៃការផ្សារភ្ជាប់ អាចជាពរជ័យដល់អ្នក និង ក្រុមគ្រួសាររបស់អ្នក អំឡុងពេលនៃជីវិតនេះ និង បន្ទាប់ពីជីវិតនេះ យ៉ាងដូចម្ដេច ?

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា « សេចក្ដីប្រកាសជាផ្លូវការទី ១ និង ការអភិវឌ្ឍកិច្ចការព្រះវិហារបរិសុទ្ធជាបន្តបន្ទាប់ » ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*



ពិធីបរិសុទ្ធនៃការផ្សារភ្ជាប់ដើម្បីបង្រួបបង្រួមក្រុមគ្រួសារសម្រាប់ភាពអស់កល្បជានិច្ច ត្រូវបានធ្វើឡើងតែក្នុងព្រះវិហារបរិសុទ្ធប៉ុណ្ណោះ ។

មេរៀនទី ៣១ ៖ ថ្ងៃទី ៤

# គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨

## សេចក្ដីផ្ដើម

នៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ១៩១៨ ប្រធាន យ៉ូសែប អេហ្វ ស៊្មីធ បានទទួលការនិមិត្ត ដែលមានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨ ។ នៅក្នុងការនិមិត្តនេះ លោកបានឃើញព្រះអង្គសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ បម្រើដល់វិញ្ញាណសុចរិត ដែលកំពុងរង់ចាំការរំដោះឲ្យរួចពីសេចក្ដីស្លាប់ ។

### គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១–១១

*ប្រធាន យ៉ូសែប អេហ្វ ស៊្មីធ ពិចារណាអំពីបទគម្ពីរទាំងឡាយ និង ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ*

តើអ្នកធ្លាប់មានមនុស្សជាទីស្រឡាញ់ស្លាប់ ឬ តើអ្នកស្គាល់នរណាម្នាក់ ដែលមានមនុស្សជាទីស្រឡាញ់ស្លាប់ដែរឬទេ ? នៅពេលមនុស្សម្នាក់ស្លាប់ វិញ្ញាណ និង រូបកាយបែកចេញពីគ្នា ហើយវិញ្ញាណរបស់មនុស្សនោះនឹងទៅពិភពវិញ្ញាណ ។ តើអ្នកនឹកគិតថា ពិភពវិញ្ញាណមានសភាពដូចម្ដេច ?

ប្រធាន យ៉ូសែប អេហ្វ ស៊្មីធ ជាប្រធានទីប្រាំមួយនៃសាសនាចក្រ បានទទួលវិវរណៈមួយអំពីពិភពវិញ្ញាណ ។ សូមអានសេចក្ដីណែនាំអំពីកណ្ឌនៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨ ដោយស្វែងរកអ្វីដែលប្រធាន ស៊្មីធ បានទទួលបទពិសោធន៍នៅក្នុងពេលជាច្រើនខែពីមុនសន្និសីទទូទៅខែ តុលា ឆ្នាំ ១៩១៨ ។


ប្រធាន យ៉ូសែប អេហ្វ ស៊្មីធ

នៅក្នុងខែទាំងនោះ ប្រធាន យ៉ូសែប អេហ្វ ស៊្មីធ កំពុងកាន់ទុក្ខចំពោះការបាត់បង់កូនប្រុសរបស់លោកគឺ ហៃរ៉ុម ម៉ាក ស៊្មីធ ដែលបានបម្រើជាសមាជិកមួយរូបក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ហៃរ៉ុម ម៉ាក ស៊្មីធ បានទទួលមរណភាពនៅដើមឆ្នាំនោះដោយសារធ្លាយពោះវៀនដុះខ្នែងនៅក្នុងវ័យ ៤៥ ឆ្នាំ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១–៤ ដោយស្វែងរកគោលលទ្ធិដែលប្រធាន យ៉ូសែប អេហ្វ ស៊្មីធ បានសញ្ជឹងគិតនៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ១៩១៨ ។

នៅក្នុង ខទី ៤ យើងរៀនថា **តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និង តាមរយៈការគោរពប្រតិបត្តិចំពោះគោលការណ៍ទាំងឡាយនៃដំណឹងល្អ មនុស្សទាំងអស់អាចបានសង្គ្រោះ ។**

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៥ ដោយស្វែងរកអ្វីដែលប្រធាន ស៊្មីធ បានរកឃើញ នៅពេលលោកពិចារណាអំពីដង្វាយធួន ។

តើអ្នកធ្លាប់មានបទគម្ពីរណាមួយប្រាកដឡើងនៅក្នុងគំនិតរបស់អ្នក នៅពេលអ្នកបានពិចារណាអំពីទិដ្ឋភាពនៃដំណឹងល្អដែរឬទេ ? តាមរយៈការបន្តការសិក្សាព្រះបន្ទូលរបស់ព្រះ និង បទគម្ពីរគន្លឹះ នោះអ្នកនឹងឃើញថា ព្រះវិញ្ញាណបរិសុទ្ធអាចនាំខគម្ពីរទាំងនោះចូលមកក្នុងគំនិតរបស់អ្នកបាន នៅពេលដែលចាំបាច់ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៦–១០ ដោយស្វែងរកការបង្រៀននានា ដែលបានធ្វើឲ្យប្រធាន ស៊្មីធ មានសេចក្ដីស្ងប់ស្ងែង ។

ប្រធាន ស៊្មីធ បានបើកព្រះគម្ពីររបស់លោក ហើយបានអានវគ្គបទគម្ពីរនៅក្នុង ពេត្រុស ទី១ ខទី ៣ និង ៤ ។ នៅក្នុងវគ្គបទគម្ពីរទាំងនេះ ពេត្រុស បានពន្យល់ថា ព្រះយេស៊ូវគ្រីស្ទបានយាងទៅពិភពវិញ្ញាណបន្ទាប់ពីទ្រង់សុគត ។ ព្រះអង្គសង្គ្រោះបានបង្រៀនដំណឹងល្អនៅក្នុងពិភពវិញ្ញាណ ដើម្បីឲ្យមនុស្សគ្រប់គ្នាត្រូវបានជំនុំជម្រះដោយយុត្តិធម៌ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១១ ដោយស្វែងរកអ្វីដែលប្រធាន ស្ម៊ីធ បានមើលឃើញ នៅពេលលោកពិចារណាអំពីបទគម្ពីរទាំងនេះ។

ពីមុនអ្នករៀនអំពីការនិមិត្តរបស់ប្រធាន ស្ម៊ីធ អំពីពិភពវិញ្ញាណ សូមកត់ចំណាំអំពីដំណើរការនៃវិវរណៈដែលលោកបានពិពណ៌នា ៖ នៅពេលលោកពិចារណាអំពីបទគម្ពីរ លោកបាននឹកគិតដល់គោលលទ្ធិនៃដង្វាយធួន និង សេចក្ដីស្រឡាញ់ ដែលស្ដែងចេញដោយព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ នៅក្នុងការយាងមកប្រសូតរបស់ព្រះអង្គសង្គ្រោះនៅលើពិភពលោកនេះ ។ គំនិតទាំងនេះ បាននាំឲ្យលោកនឹងដល់ពាក្យសម្ដីរបស់ពេត្រុស ។ បន្ទាប់មក ពេលលោកពិចារណាអំពីពាក្យសម្ដីរបស់ពេត្រុស « ភ្នែកនៃយោបល់របស់ខ្ញុំ [ លោក ] ត្រូវបានបើក » ( គ. និង ស. ១៣៨:១១ ) ព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតលើលោក ហើយលោកបានឃើញពិភពវិញ្ញាណ ។ គោលការណ៍មួយដែលយើង អាចរៀនចេញពីដំណើររឿងនេះគឺ **នៅពេលយើងអាន ហើយពិចារណាអំពីបទគម្ពីរ នោះយើងនឹងត្រៀមខ្លួនឯងដើម្បីទទួលបានវិវរណៈ ។**

១. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើការអាន និង ការពិចារណាបទគម្ពីរ ជួយអ្នកអញ្ជើញឲ្យមានវិវរណៈយ៉ាងដូចម្ដេច ?

ខ. សូមពិពណ៌នាអំពីពេលដែលអ្នក បានធ្វើតាមគំរូនេះ នៅក្នុងការសិក្សាព្រះគម្ពីររបស់អ្នក ។ តើការធ្វើតាមគំរូនេះ បានផ្លាស់ប្ដូរបទពិសោធន៍នៃការសិក្សាព្រះគម្ពីររបស់អ្នកយ៉ាងដូចម្ដេច ?

អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនអំពីមូលហេតុដែលយើងគួរតែសិក្សាព្រះគម្ពីរ ។ នៅពេលអ្នកអានអំពីការបកស្រាយនេះ សូមគូសចំណាំគំនិតនានា ដែលអ្នកអាចអនុវត្តនៅក្នុងការសិក្សាព្រះគម្ពីររបស់អ្នក ។



« នៅពេលដែលខ្ញុំនិយាយថា ‹ សិក្សា › ខ្ញុំមានន័យថាជាអ្វីមួយ ដែលពិសេសជាងការគ្រាន់តែអានទៅទៀត ។. . . ខ្ញុំឃើញថា ពេលខ្លះអ្នកអានខគម្ពីរមួយចំនួន រួចហើយឈប់ ដើម្បីសញ្ជឹងគិតអំពីខគម្ពីរនោះ សូមអានខគម្ពីរនេះម្ដងទៀតដោយយកចិត្តទុកដាក់ ហើយនៅពេលអ្នកគិតពីន័យរបស់វា សូមអធិស្ឋានសម្រាប់ការយល់ដឹង សួរសំណួរនៅក្នុងគំនិតរបស់អ្នក រង់ចាំការបំផុសគំនិតខាងវិញ្ញាណ និង សរសេរទុកនូវការបំផុសគំនិត និង ទស្សនៈវិស័យជ្រៅជ្រះដែលនឹងមក ដូច្នេះអ្នកអាចចងចាំ និង រៀនបានច្រើនជាង » (When Thou Art Converted, » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៤, ទំព័រ ១១) ។

សូមដាក់គោលដៅមួយដើម្បីអាន និង ពិចារណាបទគម្ពីរតាមរបៀបដែល អែលឌើរ គ្រីស្តូហ្វឺសិន បានពិពណ៌នា នៅក្នុងសប្ដាហ៍នេះ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១២–២៤, ៣៨–៥០

*យ៉ូសែប អេហ្វ ស្ម៊ីធ មើលឃើញមរណជនសុចរិតកំពុងរង់ចាំការរស់ឡើងវិញរបស់ពួកគេ*

តើព្រឹត្តការណ៍ណាខ្លះនាពេលអនាគត ដែលអ្នកកំពុងទន្ទឹងរង់ចាំខ្លាំងបំផុតនោះ ? ហេតុអ្វីអ្នករំភើបចិត្តចំពោះវា ?

នៅពេលប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ បានឃើញពិភពវិញ្ញាណនៅក្នុងការនិមិត្ត នោះលោកបានឃើញការប្រមូលផ្ដុំគ្នាដ៏ធំនៃវិញ្ញាណទាំងឡាយ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១២–១៣ ដោយស្វែងរកថាតើវិញ្ញាណប្រភេទណាខ្លះដែលត្រូវបានប្រមូលផ្ដុំ ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នករកឃើញ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៣៨–៤៩ ដោយស្វែងរកឈ្មោះនៃបុគ្គលមួយចំនួន ដែលបានប្រមូលផ្ដុំគ្នា។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១៥–១៦, ៥០ ។ តើការរំដោះប្រភេទណា ដែលវិញ្ញាណសុចរិតទាំងនេះកំពុងទន្ទឹងរង់ចាំ ? សូមគិតមួយសន្ទុះ អំពីមូលហេតុដែលការផ្ដុំឡើងវិញនៃវិញ្ញាណ និង រូបកាយ នឹងនាំមកនូវការរំដោះចំពោះពួកវិញ្ញាណសុចរិតទាំងនេះ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១៧ ដើម្បីស្វែងរកពរជ័យទាំងឡាយ ដែលព្រលឹងសុចរិត ទទួលបានបន្ទាប់ពីវិញ្ញាណ និង រូបកាយរបស់ពួកគេផ្ដុំឡើងវិញ ។

យើងរៀនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១៦–១៧ អំពីគោលលទ្ធិដូចតទៅនេះ ៖ **តាមរយៈព្រះគុណនៃព្រះជាព្រះវរបិតា និង ព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងត្រូវបានរំដោះឲ្យរួចពីចំណងនៃសេចក្ដីស្លាប់ ។ យើងអាចទទួលបានសេចក្ដីអំណរពេញលេញ តាមរយៈការរស់ឡើងវិញ ។**

នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយ អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ សូមស្វែងរកមូលហេតុដែលរូបកាយរបស់យើងចាំបាច់ ត្រូវទទួលបានសេចក្ដីអំណរពេញលេញ ៖



« រូបកាយសាច់ឈាមរបស់យើង ធ្វើឲ្យមានបទពិសោធន៍ទូលំទូលាយ ជ្រាលជ្រៅ និង កម្លាំង ដែលជាធម្មតាពុំអាចទទួលបាននៅក្នុងរូបកាយមុនជីវិតរមែងស្លាប់របស់យើងបានឡើយ ។ ដូច្នេះ ទំនាក់ទំនងរបស់យើងជាមួយមនុស្សទូទៅ សមត្ថភាពរបស់យើងដើម្បីស្គាល់ និង ប្រព្រឹត្តស្របតាមសេចក្ដីពិត និង លទ្ធភាពរបស់យើងដើម្បីគោរពតាមគោលការណ៍ និង ពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ត្រូវបានពង្រីកឲ្យកាន់តែល្អឡើងតាមរយៈរូបកាយសាច់ឈាមរបស់យើង ។. . .

« ផែនការរបស់ព្រះវរបិតា ត្រូវបានគ្រោងឡើងដើម្បីផ្ដល់ការដឹកនាំចំពោះកូនចៅរបស់ទ្រង់ ដើម្បីជួយពួកគេឲ្យរីករាយ ហើយនាំពួកគេត្រឡប់ទៅផ្ទះវិញ ទៅឯទ្រង់ដោយសុវត្ថិភាព ជាមួយនឹងរូបកាយដែលរស់ឡើងវិញ និងតម្កើងឡើង » (We Believe in Being Chaste, » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ៤១, ៤៣ ) ។

សូមគិតអំពីសំណួរដូចតទៅនេះមួយសន្ទុះ ៖ ហេតុអ្វីបានជាយើងត្រូវការរូបកាយដែលត្រូវទទួលសេចក្ដីអំណរពេញលេញ ?

សេចក្ដីអំណរពេញលេញ គឺជាសេចក្ដីអំណរដែលព្រះវរបិតាសួគ៌មាន ។ ព្រះវរបិតាសួគ៌ មានរូបកាយជា សាច់ និងឆ្អឹង ( សូមមើល គ. និង ស. ១៣០:២២ ) ។ នៅពេលវិញ្ញាណ និង រូបកាយរបស់យើងត្រូវបានបំបែកចេញពីគ្នា គឺយើងពុំមានលក្ខណៈដូចជាទ្រង់នោះទេ ហើយយើងពុំអាចទទួលភាពពេញលេញនៃសេចក្ដីអំណរបានឡើយ ( សូមមើល គ. និង ស. ៩៣:៣៣–៣៤ ) ។ នៅពេលយើងប្រែក្លាយដូចជាទ្រង់ យើងអាចមានពរជ័យ សេចក្ដីសុខសាន្ត និង សេចក្ដីអំណរ ដែលទ្រង់មាន ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៥១–៥២ ដោយស្វែងរកឃ្លាបន្ថែម ដែលពិពណ៌នាថាតើការរស់ឡើងវិញនឹងអនុញ្ញាតឲ្យព្រលឹងសុចរិតធ្វើអ្វី ។ សូមគិតពីការគូសចំណាំអ្វីដែលអ្នករកឃើញ ។

២. សូមស្រមៃថា មិត្តភក្ដិរបស់អ្នកម្នាក់ បានសុំឲ្យអ្នកពន្យល់អំពីមូលហេតុដែលការរស់ឡើងវិញមានសារៈសំខាន់នៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌ ។ ដោយប្រើអ្វីដែលអ្នកបានរៀននៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨ និង សេចក្ដីថ្លែងការណ៍ពីអែលឌើរ បែដណា សូមសរសេរការពន្យល់មួយសម្រាប់មិត្តភក្ដិរបស់អ្នក នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ។

ពួកសុចរិតនៅក្នុងពិភពវិញ្ញាណ កំពុងរង់ចាំ « ការយាងមក » ឬ ការយាងមកដល់របស់ព្រះរាជបុត្រានៃព្រះ ដើម្បីរំដោះពួកគេ ហើយស្ដារពួកគេឡើងនៅក្នុង « រូបរាងពេញខ្នាត » ( គ. និង ស. ១៣៨:១៦–១៧ ) ។ សូមស្រមៃក្នុងចិត្តនូវអ្វីដែលនឹងកើតឡើងនៅលើផែនដី ខណៈដែលពួកវិញ្ញាណសុចរិតទាំងនេះ ត្រូវបានរួបរួមគ្នា ។ ព្រះយេស៊ូវគ្រីស្ទ បានរងការឈឺចាប់នៅក្នុងសួនច្បារគេតសេម៉ានី និង នៅលើឈើឆ្កាង ។ ពួកវិញ្ញាណសុចរិតមួយចំនួន ដែលនៅក្នុងពិភពវិញ្ញាណ បានរង់ចាំអស់រាប់ពាន់ឆ្នាំ សម្រាប់ការរំដោះរបស់ពួកគេពីសេចក្ដីស្លាប់ ។ ពលិកម្មរបស់ព្រះយេស៊ូវគ្រីស្ទ បានផ្ដល់ឲ្យនូវសេចក្ដីសង្គ្រោះពីសេចក្ដីស្លាប់ខាងសាច់ឈាមដល់ពួកគេ និង ចុងក្រោយបំផុតសម្រាប់មនុស្សទាំងពួង ។

*ការនឹកគិតក្នុងចិត្ត*

សូមស្វែងរកការពិពណ៌នាលម្អិត ដែលអាចជួយអ្នកស្រមៃឃើញរូបភាព នៅពេលអ្នកអាន ។ សូមស្រមៃថាអ្នកមានវត្តមាន ក្នុងព្រឹត្តិការណ៍ជាក់លាក់មួយ ដែលអាចជួយពង្រឹងទីបន្ទាល់របស់អ្នកអំពីភាពពិតនៃការណ៍ ដែលអ្នកអានក្នុងបទព្រះគម្ពីរ ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:១៨–២៤ រួចស្រមៃអំពីព្រឹត្តិការណ៍ ដែលបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះថាមានសភាពយ៉ាងដូចម្ដេច ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ប្រសិនបើអ្នកមានវត្តមាននៅទីនោះ បានស្ដាប់ព្រះអង្គសង្គ្រោះផ្សព្វផ្សាយនៅឯពិភពវិញ្ញាណ តើអ្នកអាចនឹងគិត ឬ មានអារម្មណ៍យ៉ាងដូចម្ដេច ?

ខ. តើអ្នកអាចនឹងឆ្លើយតបទៅព្រះអង្គសង្គ្រោះ ដែលជាអង្គដែលទើបតែបានធ្វើដង្វាយធួនសម្រាប់អ្នកវិញយ៉ាងដូចម្ដេច ?

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:២៥–៣៧

*ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ បានរៀនអំពីរបៀបដែលដំណឹងត្រូវបានផ្សាយនៅក្នុងពិភពវិញ្ញាណ*

អ្នកអាចនឹងកត់ចំណាំនៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:២០–២២ ថា មានវិញ្ញាណមួយចំនួនដែលពុំអាចមើលឃើញព្រះអង្គសង្គ្រោះបានឡើយ កាលទ្រង់យាងទៅឯពិភពវិញ្ញាណនោះ ។ ខណៈដែលប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ ពិចារណាអំពីខគម្ពីរនៅក្នុងពេត្រុស ទី១ នោះព្រះអម្ចាស់បានត្រាស់សម្ដែងដល់លោក អំពីរបៀបដែលអ្នកនៅក្នុងស្ថានឃុំព្រលឹងនឹងមាន

ឱកាសដើម្បីទទួលពរជ័យទាំងឡាយនៃដំណឹងល្អ ។ សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:២៩–៣១ ដោយស្វែងរករបៀបដែលវិញ្ញាណទាំងឡាយនៅឯពិភពវិញ្ញាណ នឹងទទួលបានពរជ័យនៃដំណឹងល្អ ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នករកឃើញ ។

៤. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមប្រើអ្វីដែលអ្នកបានរៀននៅក្នុង ខទី ២៩–៣១ ដើម្បីសរសេរសេចក្ដីអត្ថាធិប្បាយខ្លីមួយ អំពីរបៀបដែលដំណឹងល្អ ត្រូវបានបង្រៀននៅក្នុងពិភពវិញ្ញាណ ។

នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៣២–៣៧ ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ បានសរសេរថា លោកបានឃើញដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ត្រូវបានបង្រៀនទៅដល់វិញ្ញាណពីរប្រភេទនៅក្នុងស្ថានឃុំវិញ្ញាណ ៖ អ្នកដែលបានស្លាប់ទៅដោយពុំបានស្គាល់ដំណឹងល្អ និង អ្នកដែលបានស្លាប់ទៅដោយបានបដិសេធព្យាការី កាលនៅក្នុងជីវិតរមែងស្លាប់ ។ វិញ្ញាណទាំងនេះ ដែលបានស្ថិតនៅក្នុងពិភពវិញ្ញាណ នឹងទទួលបានឱកាសមួយដើម្បីប្រែចិត្ត ហើយទទួលយកដំណឹងល្អ តាមរយៈការបង្រៀនពីសារទូតដែលបានជ្រើសតាំងដោយព្រះអម្ចាស់ ។

## គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៥៣–៦០

*ប្រធាន ស្ម៊ីធ បានមើលឃើញវិញ្ញាណដែលថ្លៃថ្នូ និង អស្ចារ្យៗ បានផ្សាយដំណឹងល្អនៅស្ថានឃុំវិញ្ញាណ ។*

សូមគិតអំពីសមាជិកគ្រួសារ ឬ ជីដូនជីតាសុចរិតរបស់អ្នក ដែលបានចែកឋានទៅ ។ តើអ្នកធ្លាប់ងឿងឆ្ងល់ ថាតើពួកគេកំពុងធ្វើអ្វីនៅក្នុងពិភពវិញ្ញាណដែរឬទេ ?

នៅក្នុងផ្នែកមួយនៃការនិមិត្តនេះ ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ បានឃើញឪពុករបស់លោកគឺ ហៃរុម ស្ម៊ីធ និង ឪពុកមារបស់លោកគឺ យ៉ូសែប ស្ម៊ីធ និង វិញ្ញាណជម្រើសដទៃទៀត ។ វិញ្ញាណដ៏ថ្លៃថ្នូទាំងនេះ បានចូលរួមធ្វើកិច្ចការរបស់ព្រះអម្ចាស់នៅក្នុងជីវិតរមែងស្លាប់ ។ ពួកគេ និង វិញ្ញាណដទៃទៀតត្រូវបានរៀបចំទុក ពីមុនពួកគេបានចាប់កំណើតមកដើម្បីសម្រេចកិច្ចការអស្ចារ្យៗនៅលើផែនដី ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៥៧ ដោយស្វែងរកអ្វីដែលពួកអែលឌើរស្មោះត្រង់នឹងបន្តធ្វើ បន្ទាប់ពីពួកគេបានស្លាប់ទៅនោះ ។ អ្នកអាចនឹងចង់គូសចំណាំអ្វីដែលអ្នករកឃើញ ។



ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ ក៏បានពន្យល់ថា កិច្ចការនៅឯពិភពវិញ្ញាណ ពុំកំណត់ចំពោះអ្នកដែលកាន់បព្វជិតភាពមិលគីស្សាដែកឡើយ ៖ « ស្ត្រីល្អៗ ត្រូវបានញែកចេញ តែងតាំងចំពោះកិច្ចការ [ និង ] ត្រូវបានហៅឲ្យធ្វើ. . . ត្រូវបានផ្ដល់សិទ្ធិ និង អំណាចពេញលេញ ដើម្បីផ្សាយដំណឹងល្អ » (*Gospel Doctrine* ការបោះពុម្ពលើកទី ៥ [ ឆ្នាំ ១៩៣៩ ] ទំព័រ ៤៦១ ) ។

សេចក្ដីពិតមួយដែលយើងរៀនចេញពី គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៥៧ និង សេចក្ដីថ្លែងការណ៍របស់ប្រធាន ស្ម៊ីធ គឺថា **បន្ទាប់ពីបានចាកចេញពីជីវិតរមែងស្លាប់ នោះពួកបរិសុទ្ធស្មោះត្រង់នឹងបន្តកិច្ចការរបស់ខ្លួន ក្នុងការប្រកាសដំណឹងល្អ ។**

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨:៦០ ដោយស្វែងរកទីបន្ទាល់របស់ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ អំពីសេចក្ដីពិតទាំងឡាយ ដែលលោកបានកត់ត្រា ។

វាគឺជាពរជ័យមួយដ៏អស្ចារ្យ ដែលត្រូវដឹងថា កូនចៅទាំងអស់របស់ព្រះវរបិតាសួគ៌ នឹងទទួលបានឱកាសទទួលយក ហើយរស់នៅតាមដំណឹងល្អ ។ កិច្ចការដែលយើងធ្វើសម្រាប់មរណជន នៅក្នុងព្រះវិហារបរិសុទ្ធ ផ្ដល់ឲ្យពួកគេនូវលទ្ធភាពបានស្អាតពីអំពើបាបទាំងឡាយរបស់ខ្លួន ត្រូវបានប្រោសលោះពីស្ថានឃុំវិញ្ញាណ និង ចូលរួមក្នុងកិច្ចការនៃការប្រោសលោះដ៏ធំនៅក្នុងពិភពវិញ្ញាណ ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣៨ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និង ការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៣២ ៖ ថ្ងៃទី ១

# កម្មវិធី និង អង្គការសាសនាចក្រ

## បុព្វកថា

នៅពេលសាសនាចក្របន្តរីកចម្រើន ព្រះអម្ចាស់បានបំផុសគំនិតដល់អ្នកដឹកនាំសាសនាចក្រ និងសមាជិកឲ្យអនុវត្តអង្គការ និង កម្មវិធីនៅក្នុងសាសនាចក្រដើម្បីប្រទានពរដល់ពួកបរិសុទ្ធ ។ នៅពេលអង្គការ និងកម្មវិធីទាំងនេះ ត្រូវបានស្ថាបនាជាលើកដំបូង នោះវាពុំមែនជាតម្រូវការចាំបាច់ដូចពេលបច្ចុប្បន្នទេ ប៉ុន្តែខណៈសាសនាចក្រលូតលាស់ នោះវាក្លាយទៅជាផ្នែកដ៏សំខាន់នៅក្នុងកិច្ចការរបស់សាសនាចក្រដើម្បីសេចក្ដីសង្គ្រោះនៃកូនចៅរបស់ព្រះ ។

### អង្គការ និងកម្មវិធីសាសនាចក្រ ជួយយើងរៀបចំខ្លួន និងលូតលាស់ឆ្ពោះទៅរកជីវិតដ៏អស់កល្បជានិច្ច

ចូរគិតអំពីរបៀបដែលអង្គការ និងកម្មវិធីសាសនាចក្រ បានប្រទានពរដល់ជីវិតរបស់អ្នក ។

តើអ្នកនឹងនិយាយអ្វីខ្លះអំពីគោលបំណងនៃអង្គការសាសនាចក្រ ដូចជាអង្គការយុវជន និងយុវនារី ? តើការដឹងអំពីគោលបំណងនៃអង្គការមួយ អាចជួយដល់អស់អ្នកដែលរួមចំណែកយ៉ាងដូចម្ដេច ?

សូមអានម៉ូសេ ១:៣៩ ស្វែងរកអ្វីដែលជាគោលបំណងរបស់ព្រះវរបិតាសួគ៌ គឺស្ថិតនៅក្នុងគ្រប់អ្វីដែលទ្រង់ធ្វើ ។ សូមចងចាំថា *ជីវិតអមត* សំដៅទៅលើការរស់នៅជារៀងរហូតនៅក្នុងស្ថានភាពដែលរស់ឡើងវិញ ។ តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ មនុស្សទាំងអស់នឹងត្រូវបានរស់ឡើងវិញ ដោយមិនគិតអំពីអំពើទុច្ចរិត ឬសុចរិតរបស់ពួកគេនៅក្នុងជីវិតនេះទេ ។. *ជីវិតដ៏នៅអស់កល្បជានិច្ច* សំដៅទៅលើ ការរស់នៅជានិរន្តរ៍ជាមួយក្រុមគ្រួសារក្នុងវត្តមានរបស់ព្រះវរបិតាសួគ៌ និងការប្រែក្លាយដូចជាទ្រង់ ។

ចូរពិចារណាថា គោលបំណងរបស់ព្រះវរបិតាសួគ៌ គឺដើម្បីនាំមកនូវអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់កូនចៅរបស់ទ្រង់ ចុះតើគោលបំណងនៃសាសនាចក្រនេះគឺជាអ្វី ?

ដោយសារតែគោលបំណងរបស់ព្រះវរបិតាសួគ៌ គឺដើម្បីនាំមកនូវអតមភាព និងជីវិតអស់កល្បជានិច្ចមកដល់កូនចៅរបស់ទ្រង់ នោះគោលបំណងនៃសាសនាចក្ររបស់ទ្រង់ គឺដូចគ្នា ។ **ព្រះវរបិតាសួគ៌បានស្ថាបនាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយដើម្បីជួយកូនចៅរបស់ទ្រង់ទទួលបានជីវិតអស់កល្បជានិច្ច ។**

១. នៅក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរនូវវិធីនានាមួយចំនួនដែលសាសនាចក្របានជួយព្រះវរបិតាសួគ៌ក្នុងការនាំមកនូវអមតភាព និងជីវិតអស់កល្បជានិច្ចមកដល់កូនចៅរបស់ទ្រង់ ។

សាសនាចក្រមានអង្គការជាច្រើន–ដែលហៅថា អង្គការជំនួយចំពោះបព្វជិតភាព–ហើយនិងកម្មវិធីផ្សេងៗ ដែលជួយយើងឲ្យរីកចម្រើនឆ្ពោះទៅរកជីវិតអស់កល្បជានិច្ច ។ សូមព្យាយាមរៀបរាប់ឈ្មោះអង្គការមួយចំនួននោះ ។

អ្នកអាចរៀបរាប់ឈ្មោះដូចជា អង្គការយុវជន អង្គការយុវនារី អង្គការបឋមសិក្សា អង្គការសមាគមសង្គ្រោះ និងថ្នាក់សាលាថ្ងៃអាទិត្យ និងកម្មវិធីនានា ដូចជាថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា និងរាត្រីជួបជុំក្រុមគ្រួសារ ។

ដើម្បីមើលឃើញពីរបៀបដែលអង្គការសាសនាចក្រ និងកម្មវិធីទាំងឡាយជួយយើងឲ្យរៀន និងរីកចម្រើននៅក្នុងដំណឹងល្អ ដើម្បីយើងអាចទទួលបានជីវិតអស់កល្បជានិច្ច សូមអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ប៊ិយដ៍ ឃេ ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សេចក្ដីថ្លែងការណ៍នេះ គឺអំពីកម្មវិធីថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាន ប៉ុន្តែគោលការណ៍ដែលវាបង្រៀនក៏អាចយកមកអនុវត្តចំពោះអង្គការជំនួយសាសនាចក្រដទៃទៀត និងកម្មវិធីទាំងឡាយផងដែរ។



« នៅក្នុងប្រវត្តិសាស្ត្រសាសនាចក្រ គឺគ្មានការចង្អុលបង្ហាញណា អំពីការរៀបចំប្រជាជននេះដោយការព្យាករ ប្រសើរជាងការចាប់ផ្ដើមនៃកម្មវិធីថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាននោះទេ ។ កម្មវិធីទាំងនេះត្រូវបានចាប់ផ្ដើមជាការល្អ ប៉ុន្តែវាពុំត្រូវការជាចាំបាច់នោះទេ ។ វាផ្ដល់នូវរដូវកាលមួយដើម្បីចម្រើន និងលូតលាស់ទៅជាកំផែងការពារ គ្រឿងការពារសម្រាប់សាសនាចក្រ ។ ឥឡូវនេះ អង្គការទាំងនេះក្លាយទៅជាការបញ្ជូនមកពីព្រះ សម្រាប់សេចក្ដីសង្គ្រោះដល់សាសន៍អ៊ីស្រាអែលសម័យទំនើប នៅក្នុងគ្រាដ៏លំបាកបំផុតមួយ » (« Teach the Scriptures » [address to CES religious educators, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៧៧] ទំព័រ ៣, si.lds.org) ។

ព្រះអម្ចាស់បានបំផុសគំនិតអ្នកដឹកនាំរបស់ទ្រង់ដើម្បីស្ថាបនាកម្មវិធី និងអង្គការនៅក្នុងសាសនាចក្រជាច្រើន ដើម្បីរៀបចំយើងសម្រាប់ការសាកល្បង និងឧបសគ្គទាំងឡាយ ដែលយើងជួបប្រទះ អំឡុងពេលជីវិតរមែងស្លាប់នេះ និងដើម្បីជួយយើងរីកចម្រើនឆ្ពោះទៅរកជីវិតអស់កល្បជានិច្ច ។

នៅពេលអ្នកអានសេចក្ដីសង្ខេបនៃប្រវត្តិសាស្ត្រនីមួយៗដូចខាងក្រោម សូមរកមើលចម្លើយចំពោះសំណួរដូចតទៅនេះ ៖

- តើអង្គការ ឬកម្មវិធីបានចាប់ផ្ដើមមានឡើងយ៉ាងដូចម្ដេច ? ( សូមពិចារណាធ្វើការគូសចំណាំចម្លើយចំពោះសំណួរនេះ ) ។
- តើអ្នកគិតថា វារៀបចំយើងដើម្បីប្រឈមមុខនឹងការសាកល្បង ព្រមទាំងឧបសគ្គនានាក្នុងជំនាន់របស់យើងយ៉ាងដូចម្ដេច ?
- តើអ្នកគិតថា វាជួយយើងរីកចម្រើនឆ្ពោះទៅរកជីវិតអស់កល្បជានិច្ចយ៉ាងដូចម្ដេច ?

## ថ្នាក់សាលាថ្ងៃអាទិត្យ



នៅឆ្នាំ ១៨៤៩ សមាជិកសាសនាចក្រម្នាក់ ឈ្មោះ រីឆាដ បាឡាទីន មានអារម្មណ៍ថា កុមារតូចៗត្រូវការកន្លែងមួយដើម្បីរៀនដំណឹងល្អនៅថ្ងៃបរិសុទ្ធ ។ ពួកបរិសុទ្ធនៅចក្រភពអង់គ្លេស មានថ្នាក់សាលាថ្ងៃអាទិត្យរួចទៅហើយ ហើយបងប្រុស បាឡាទីន បានចាប់ផ្ដើមថ្នាក់សាលាថ្ងៃអាទិត្យដំបូងគេនៅរដ្ឋ យូថាហ៍ នៅក្នុងវួដទីក្រុងសលត៍ លេករបស់គាត់ នៅខែធ្នូ ឆ្នាំ ១៨៤៩ ។ មិនយូរប៉ុន្មានក្រោយមក វួដផ្សេងទៀតបានចាប់ផ្ដើមទទួលយកការអនុវត្តដូចគ្នានេះ ដោយវួដនីមួយៗប្រើកម្មវិធីសិក្សារៀងៗខ្លួន ។ ក្នុងឆ្នាំ ១៨៦៧ ថ្នាក់អ្នកដឹកនាំសាសនាចក្របានបង្កើតសហព័ន្ធសាលាថ្ងៃអាទិត្យដេសេរ៉េត ដែលលើកទឹកចិត្តឲ្យមានភាពរួបរួមគ្នាក្នុងកម្មវិធីសិក្សាតែមួយ ។ ត្រឹមឆ្នាំ ១៨៧០ នោះមានថ្នាក់សាលាថ្ងៃអាទិត្យច្រើនជាង ២០០ ថ្នាក់ ត្រូវបានបង្កើតឡើង ។ សព្វថ្ងៃនេះ វួដ និងសាខាទាំងឡាយ មានថ្នាក់សាលាថ្ងៃអាទិត្យចម្រុះ ។

## យុវនារី



ប្រធាន ព្រិកហាំ យ៉ង់ បានជួបនឹងកូនស្រីទាំងឡាយរបស់លោកនៅក្នុងផ្ទះរបស់លោកនៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ១៨៦៩ ហើយបានសុំពួកគេឲ្យធ្វើជាអ្នកដឹកនាំ ដើម្បីជួយដល់មិត្តភក្តិដែលមានអាយុប្រហាក់ប្រហែលនឹងពួកគេទទួលបានទីបន្ទាល់នៃដំណឹងល្អ ដើម្បីមានភាពរមទម្យនៅក្នុងការស្លៀកពាក់ និងទង្វើរបស់ពួកគេ ហើយចៀសវាងពីទំនោរ និងអាកប្បកិរិយាខាងលោកិយ ។ នៅឆ្នាំ ១៨៧០ អង្គការយុវនារីជាផ្លូវការមួយ ត្រូវបានរៀបចំឡើងដើម្បីលើកស្ទួយដល់គោលបំណងទាំងនេះ ។ នៅទីបំផុត អង្គការនេះត្រូវបានស្គាល់ថាជា សមាគមកែលម្អគ្នាទៅវិញទៅមករបស់ក្រុមយុវនារី (វ៉ាយ.ដបុលយូ.អិម.អាយ.អេ ) ដែលក្រោយមកបានផ្លាស់ប្ដូរទៅជាអង្គការយុវនារី ។ នៅដើមឆ្នាំ ១៩៧០ ពួកអ្នកដឹកនាំបានណែនាំអំពីកម្មវិធីអភិវឌ្ឍខ្លួន ។ នៅឆ្នាំ ១៩៨៥ ពួកគាត់បានណែនាំអំពីគុណសម្បត្តិ និងបាវចនាយុវនារី ។

## យុវជន



សមាគមកែលម្អគ្នាទៅវិញទៅមករបស់ក្រុមយុវជន ( វ៉ាយ.អិម.អិម.អាយ.អេ ) ត្រូវបានបង្កើតឡើងនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៨៧៥ នៅក្រោមការដឹកនាំរបស់ប្រធាន ព្រិកហាំ យ៉ង់ ។ អង្គការនេះ គឺមានបំណងដើម្បីជួយដល់ក្រុមយុវជន អភិវឌ្ឍខាងវិញ្ញាណ និងខាងបញ្ញាស្មារតី ក៏ដូចជាផ្ដល់ដល់ពួកគេ នូវសកម្មភាពផ្នែកប្រឌិតផងដែរ ។ នៅឆ្នាំ ១៩១៣ សាសនាចក្រ បានចូលសហការជាមួយនឹងក្រុមកាយឫទ្ធិអាមេរិកកាំងនៅ ក្នុងសហរដ្ឋអាមេរិក ។ ការចាប់ដៃគូក្នុងកម្មវិធីក្រុមកាយឫទ្ធិ ផ្សេងទៀត ត្រូវបានបង្កើតឡើងជាអន្តរជាតិ នៅកន្លែងណា ដែលអាចធ្វើទៅបាន ។ ឈ្មោះរបស់អង្គការត្រូវបានផ្លាស់ប្ដូរ ផងដែរ ដែលដំបូងឡើងបានផ្លាស់ប្ដូរទៅជា បព្វជិតភាពអើរ៉ុន–អិម.អាយ.អេ បន្ទាប់មកក្លាយទៅជាបព្វជិតភាពអើរ៉ុន ហើយ បន្ទាប់មកទៀតទៅជាក្រុមយុវជន ។ នៅឆ្នាំ ២០០១ ពួកអ្នកដឹកនាំសាសនាចក្រ បានណែនាំកម្មវិធីកាតព្វកិច្ចចំពោះព្រះ ។

## អង្គការបឋមសិក្សា



នៅឆ្នាំ ១៨៧៧ អូរេលៀ ស្ពែនស៊ើរ រ៉ូជើរ « ទទួលអារម្មណ៍យ៉ាង ខ្លាំងថា មានអ្វីមួយត្រូវធ្វើឡើង អំពីឥរិយាបទរបស់ក្មេងប្រុស នៅជិតខាងដែលរត់លេងដោយសេរីពេញទីក្រុងទាំងថ្ងៃទាំង យប់ ។ នាងមានអារម្មណ៍ថា កុមារទាំងនេះ ពុំត្រូវបានបង្រៀននូវ គោលការណ៍ និងគុណតម្លៃជាមូលដ្ឋាន [ដើម្បីរៀបចំពួកគេ] ទាំង ខាងចំណេះដឹង ឬឥរិយាបទ ដើម្បីនាំយកដំណឹងល្អឆ្ពោះទៅមុខ ឬដើម្បីក្លាយជាឪពុកម្ដាយ ឬពលរដ្ឋល្អ » (« History of Primary » lds.org/callings/primary/getting–started/history–of–primary) ។ នាងបានជួបនឹង អេលីស្សា អ ស្នូ ដែលពេលនោះបម្រើជាប្រធានសមាគមសង្គ្រោះទូទៅ ហើយ ពួកគេបានទទួលការអនុញ្ញាតមកពីប្រធាន យ៉ូហាន ថេល័រ ដើម្បី រៀបចំអង្គការបឋមសិក្សានៅក្នុងក្រុង ហ្វាមីងតុន រដ្ឋយូថាហ៍ នៅក្រោមការដឹកនាំរបស់ប៊ីស្សព យ៉ូហាន ហេស្ស ។ ការប្រជុំ អង្គការបឋមសិក្សាដំបូង បានធ្វើឡើងនៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ ១៨៧៨ ដែលមានកុមារ និងកុមារីចំនួន ២២៤ នាក់ ។ នៅឆ្នាំ ១៨៨០ ប្រធានអង្គការបឋមសិក្សាទូទៅត្រូវបានហៅ ហើយថ្នាក់អង្គការបឋមសិក្សាបានចាប់ផ្ដើមរៀបចំឡើងនៅក្នុងវួដ ជាច្រើន ។

## ថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាននៃសាសនា



នៅឆ្នាំ ១៨៨៨ សាសនាចក្របានបង្កើតគណៈកម្មការអប់រំ និង វិទ្យាស្ថានសាសនាចក្រ ហើយបានបង្កើតថ្នាក់ខាងសាសនា ដើម្បី ផ្ដល់គ្រឹះខាងវិញ្ញាណសម្រាប់ការរៀនសូត្រដែលមិនទាក់ទងនឹង សាសនាសម្រាប់អ្នកទាំងឡាយដែលពុំបានចូលរួមក្នុងវិទ្យាស្ថាន សាសនាចក្រ ។ នៅឆ្នាំ ១៩១២ យ៉ូសែប អែហ្វ មើរីល ជា សាស្ត្រាចារ្យម្នាក់ និងជាសមាជិកនៃសាសនាចក្រ បានដាក់ស្នើ សុំផែនការមួយ ដើម្បីអនុញ្ញាតឲ្យសិស្សនៅក្នុងសាលារដ្ឋមកចូល រួមថ្នាក់សាសនាជាផ្នែកមួយនៃការសិក្សារាល់ថ្ងៃរបស់ពួកគេ ។ វាត្រូវបានហៅថាថ្នាក់សិក្ខាសាលា ហើយថ្នាក់ដំបូងត្រូវបាន បង្រៀននៅជិតវិទ្យាល័យហ្គ្រេនិត នៅទីក្រុងសលត៍ លេក រដ្ឋ យូថាហ៍ ហើយមានសិស្សចុះឈ្មោះចំនួន ៧០ នាក់ ។ នៅពេល កម្មវិធីថ្នាក់សិក្ខាសាលាបានរីកសុះសាយ នោះកម្មវិធីស្រដៀងគ្នាមួយត្រូវបានបង្កើតឡើងសម្រាប់យុវវ័យដែលស្ថិតក្នុងវ័យ រៀននៅសាកលវិទ្យាល័យ ។ វាត្រូវបានដាក់ឈ្មោះថា វិទ្យាស្ថានសាសនាពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយថ្នាក់វិទ្យាស្ថានបានចាប់ ផ្ដើមនៅក្នុងឆ្នាំ ១៩២៦ នៅក្នុងទីក្រុង ម៉ូស្កូ រដ្ឋ អៃដាហូ ។ នៅដើមឆ្នាំ ១៩៥០ កម្មវិធីថ្នាក់សិក្ខាសាលានៅពេលព្រឹកព្រលឹម បានចាប់ផ្ដើមនៅក្នុងរដ្ឋ កាលីហ្វូញ៉ា កម្មវិធីថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះ បានចាប់ផ្ដើមនៅឆ្នាំ ១៩៦០ ហើយថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា បានចាប់ផ្ដើមនៅក្នុងអំឡុងបណ្ដាឆ្នាំ ១៩៦០ ហើយថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា បានបន្តពង្រីកនៅទូទាំងពិភពលោក ។

## រាត្រីជួបជុំក្រុមគ្រួសារ



ប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ បានបង្រៀនថា កម្មវិធីសាសនាចក្រ គឺប្បី « បន្ថែមទៅក្នុងការបង្រៀន និងការបំពាក់បំប៉នរបស់យើងនៅក្នុងគេហដ្ឋាន ។ បើបរិដ្ឋាន គំរូ និង ការបំពាក់បំប៉ននៅក្នុងគេហដ្ឋាន មានភាពចុះសម្រុងនឹងសេចក្ដីពិតនៅក្នុងដំណឹងល្អនៃព្រះគ្រីស្ទ នោះគឺគ្មានកុមារណាម្នាក់ក្នុងចំនួនមួយរយនាក់នឹងត្រូវវង្វេងឡើយ » (« Worship in the Home, » *Improvement Era* ខែ ធ្នូ ឆ្នាំ ១៩០៣ ទំព័រ ១៣៨ ) ។ នៅក្នុងឆ្នាំ ១៩០៩ ស្តេកហ្គ្រែនិតនៅក្នុងទីក្រុងសលត៍ លេក រដ្ឋយូថាហ៍ បានចាប់ផ្ដើមកម្មវិធីរាត្រីជួបជុំក្រុមគ្រួសារប្រចាំសប្ដាហ៍ ដែលប្រសាសន៍របស់ប្រធាន ស្ម៊ីធ ត្រូវបានបំផុសគំនិត ។ នៅក្នុងឆ្នាំ ១៩១៥ គណៈប្រធានទីមួយ បានចេញអនុសាសន៍ថា រាត្រីជួបជុំក្រុមគ្រួសារប្រចាំខែត្រូវបានអនុវត្តទូទាំងសាសនាចក្រ ។ គណៈប្រធានទីមួយបានសន្យា ៖ « បើពួកបរិសុទ្ធគោរពតាមដំបូន្មាននេះ [ ដើម្បីរក្សារាត្រីជួបជុំក្រុមគ្រួសារ ] នោះយើងសន្យាថា ពរជ័យដ៏មហិមា នឹងកើតមានឡើង ។ សេចក្ដីស្រឡាញ់ក្នុងផ្ទះ និង ការគោរពប្រតិបត្តិដល់ឪពុកម្ដាយនឹងកើនឡើង ។ សេចក្ដីជំនឿ នឹងបង្កើតឡើងនៅក្នុងដួងចិត្តរបស់យុវវ័យនៃអ៊ីស្រាអែល ហើយពួកគេនឹងទទួលបានអំណាចដើម្បីទប់ទល់នឹងឥទ្ធិពលអាក្រក់ និង ការល្បួងរបស់អារក្សដែលឡោមព័ទ្ធពួកគេ » ( នៅក្នុង James R. Clark, comp., *Messages of the First Presidency of The Church of Jesus Christ of Latter–day Saints,* វ៉ុលទី ៦ [១៩៦៥–៧៥] ៤:៣៣៩ ) ។ ហាសិបឆ្នាំក្រោយមក សាសនាចក្របានបោះពុម្ពសៀវភៅសិក្សាសម្រាប់ក្រុមគ្រួសារឲ្យប្រើប្រាស់នៅក្នុងការបង្រៀនដំណឹងល្អប្រចាំសប្ដាហ៍ ។ នៅក្នុងឆ្នាំ ១៩៧០ អ្នកដឹកនាំសាសនាចក្រ បានជ្រើសរើសល្ងាចថ្ងៃចន្ទសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ហើយបានប្រកាសថា សកម្មភាពសាសនាចក្រដទៃទៀត ពុំត្រូវធ្វើឡើងនៅល្ងាចនោះទេ ។

អង្គការ និង កម្មវិធីសាសនាចក្រនីមួយៗ បានប្រតិបត្តិការឡើងដោយឯករាជ្យ ។ នៅពេលសាសនាចក្រពង្រីកកាន់តែធំនៅក្នុងឆ្នាំ ១៩៥០ នោះពួកអ្នកដឹកនាំសាសនាចក្របានឃើញពីតម្រូវការដើម្បីធ្វើការវាយតម្លៃទៅលើរបៀបដែលអង្គការសាសនាចក្របំពេញតាមគោលបំណងរបស់សាសនាចក្រ ។ ពួកគាត់បានសម្រេចចិត្តដើម្បីប្រមូល ហើយសម្របសម្រួលគ្រប់អង្គការ និងកម្មវិធីសាសនាចក្រទាំងអស់ ទាំងនៅក្នុងការគ្រប់គ្រង និងនៅក្នុងការជ្រើសរើសកម្មវិធីសិក្សា ។ ការផ្លាស់ប្ដូរទាំងនេះបានជួយអង្គការ និងកម្មវិធីនានា ឲ្យបំពេញតាមតម្រូវការនៃការលូតលាស់របស់សាសនាចក្រ និងដើម្បីពង្រឹងក្រុមគ្រួសារកាន់តែល្អប្រសើរ ។ នៅក្រោមកិច្ចខិតខំសហសម្ព័ន្ធនេះ**អង្គការសាសនាចក្រទាំងអស់ បានប្រតិបត្តិនៅក្រោមការដឹកនាំរបស់អ្នកដឹកនាំបព្វជិតភាព ដែលកាន់កូនសោជាអធិបតី ។**

បន្ថែមពីលើនោះ នៅក្រោមការដឹកនាំនៃគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ការិយាល័យសហសម្ព័ន្ធមួយ ត្រូវបានបង្កើតឡើង ដើម្បីពិនិត្យមើល វាយតម្លៃ និងធ្វើសហសម្ព័ន្ធគ្រប់សម្ភារដែលបានបោះពុម្ពដោយសាសនាចក្រទាំងអស់ ។ ការណ៍នេះត្រូវបានធ្វើឡើងដើម្បីរក្សាគោលលទ្ធិឲ្យនៅបរិសុទ្ធ ដើម្បីឲ្យការបង្រៀនរបស់សាសនាចក្រ មិនត្រូវបានគេយល់ខុស ។

ចូរពិចារណាអំពីរបៀបដែលអង្គការជំនួយទាំងឡាយរបស់សាសនាចក្រ បានរួមសាមគ្គីភាពគ្នា ហើយធ្វើសហសម្ព័ន្ធនឹងគ្នាក្រោមការដឹកនាំរបស់អ្នកកាន់បព្វជិតភាព អាចជួយសម្រេចគោលបំណងរបស់ព្រះវរបិតាសួគ៌សម្រាប់កូនចៅរបស់ទ្រង់ឲ្យបានកាន់តែល្អប្រសើរ ។

២. សូមពិចារណាអំពីគោលការណ៍ដូចខាងក្រោម ៖**នៅពេលយើងចូលរួមនៅក្នុងអង្គការ និងកម្មវិធីនានារបស់សាសនាចក្រ នោះយើងទទួលបានពរជ័យដែលមាននៅក្នុងកម្មវិធី និងអង្គការទាំងនោះ ។** សូមឆ្លើយសំណួរខាងក្រោមនេះដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើអង្គការ និងកម្មវិធីនានារបស់សាសនាចក្រ បានប្រទានពរដល់ជីវិតរបស់អ្នកយ៉ាងដូចម្ដេច ?

ខ. តើកម្មវិធីកាតព្វកិច្ចចំពោះព្រះ ឬកម្មវិធីអភិវឌ្ឍខ្លួន បានប្រទានពរដល់ជីវិតរបស់អ្នកយ៉ាងដូចម្ដេច ?

៣. នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់អ្នក ចូរសរសេរគោលដៅមួយ ឬពីរដើម្បីកែលម្អការចូលរួមរបស់អ្នកក្នុងអង្គការ និងកម្មវិធីនានានៃសាសនាចក្រ ។ សំណួរដូចខាងក្រោមនេះ អាចជួយអ្នកគិត អំពីអ្វីដែលជាគោលដៅត្រូវដាក់ ៖ តើអ្នកនឹងចូលរួមបានកាន់តែពេញលេញនៅក្នុងអង្គការយុវជន និងអង្គការយុវនារីយ៉ាងដូចម្ដេច ? នៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យ ? ក្នុងរាត្រីជួបជុំក្រុមគ្រួសារ ? នៅក្នុងថ្នាក់សិក្ខាសាលា ?

៤. សូមឆ្លើយសំណួរដូចខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់អ្នក ៖ តើការចូលរួមនៅក្នុងអង្គការជំនួយ និងកម្មវិធីនានា អាចជួយអ្នករៀបចំខ្លួនដើម្បីទទួលបព្វជិតភាពមិលគីស្សាដែក ឬចូលទៅថ្នាក់សមាគមសង្គ្រោះបានយ៉ាងដូចម្ដេច ?

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សាមេរៀនអំពី « អង្គការ និងកម្មវិធីនានារបស់សាសនាចក្រ » ហើយបានបញ្ចប់វានៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និងការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៣២ ៖ ថ្ងៃទី ២

# សេចក្ដីប្រកាសជាផ្លូវការទី ២

## សេចក្ដីផ្ដើម

អំឡុងសតវត្សរ៍ទី ២០ កិច្ចការផ្សព្វផ្សាយសាសនា បានសាយភាយទៅទូទាំងផែនដី ។ អ្នកដឹកនាំសាសនាចក្រ បានអធិស្ឋានសុំការដឹកនាំពាក់ព័ន្ធទៅនឹងលក្ខខណ្ឌចំពោះការតែងតាំងបព្វជិតភាព និងពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធសម្រាប់សមាជិកសាសនាចក្រដែលជាកូនចៅរបស់ជនជាតិអាហ្រ្វិក ។ វិវរណៈដ៏ជាក់លាក់មួយបានប្រទានដល់ប្រធាន ស្ពែនស៊ើរ ដបុលយូ ឃឹមបឹល ហើយត្រូវបានអះអាងបញ្ជាក់ដល់ទីប្រឹក្សារបស់លោកនៅក្នុងគណៈប្រធានទីមួយ និង សមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់នៅក្នុងព្រះវិហារបរិសុទ្ធសលត៍ លេក នៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៧៨ ។ នៅក្នុងសំបុត្រមួយដែលចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៨ ពួកលោកបានប្រកាសវិវរណៈនោះ ។

## សេចក្ដីប្រកាសជាផ្លូវការទី ២

*ព្រះអម្ចាស់បើកសម្ដែងថា ពរជ័យបព្វជិតភាព និងពរជ័យនៃព្រះវិហារបរិសុទ្ធ អាចផ្ដល់ទៅឲ្យសមាជិកនៃសាសនាចក្រដែលមានភាពសក្ដិសមគ្រប់រូប ។*

សូមស្រមៃថាអ្នកមានមិត្តម្នាក់ដែលជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយកំពុងតែស្មុគស្មាញនឹងសំណួរខ្លះៗអំពី គោលលទ្ធិ គោលនយោបាយ ឬការអនុវត្តនានារបស់សាសនាចក្រ ។

១. សូមឆ្លើយសំណួរដូចខាងក្រោម ដាក់នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកនឹងលើកទឹកចិត្តមិត្តរបស់អ្នកឲ្យធ្វើអ្វីខ្លះ ?

នៅក្នុងសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរ អេស្វ អុជដូហ្វ នៃគណៈប្រធានទីមួយ សូមគូសចំណាំផ្នែកណាដែលមានប្រយោជន៍ជាពិសេសចំពោះអ្នក ៖



« ចុះការសង្ស័យ និង សំណួរវិញ ? តើអ្នកឃើញថា ដំណឹងល្អនេះពិតដោយរបៀបណា ? តើវាមិនអីទេឬដែលមានសំណួរអំពីសាសនាចក្រ ឬ គោលលទ្ធិរបស់សាសនាចក្រនោះ ? មិត្តភក្ដិវ័យក្មេងជាទីស្រឡាញ់របស់ខ្ញុំអើយ យើងគឺជាមនុស្សដែលសួរសំណួរ ដោយសារយើងដឹងថាសំណួរនាំទៅរកសេចក្ដីពិត ។ នោះគឺជារបៀបដែលសាសនាចក្រនេះចាប់ផ្ដើមឡើង–មកពីយុវជនម្នាក់ដែលមានសំណួរនោះ ។ តាមពិត ខ្ញុំមិនប្រាកដពីរបៀបដែលមនុស្សម្នាក់អានរកឃើញសេចក្ដីពិត ដោយគ្មានការសួរសំណួរនោះទេ ។ នៅក្នុងព្រះគម្ពីរ អ្នកនឹងកម្ររកឃើញវិវរណៈមួយដែលមក ដោយមិនបានឆ្លើយតបទៅនឹងសំណួរណាស់ ។ នៅពេលណាដែលមានសំណួរមួយលេចឡើង ហើយយ៉ូសែប ស្ម៊ីធ មិនបានប្រាកដពីចម្លើយនោះ គាត់បានទៅរកព្រះអម្ចាស់ ហើយលទ្ធផលគឺជាវិវរណៈដ៏អស្ចារ្យនៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ។ ជាញឹកញាប់ ចំណេះដឹងដែលយ៉ូសែប បានទទួលនោះបានលាតសន្ធឹងឆ្ងាយលើសពីសំណួរដើមទៅទៀត ។ នេះគឺដោយសារមិនត្រឹមតែព្រះអម្ចាស់អាចឆ្លើយនឹងសំណួរដែលយើងសួរប៉ុណ្ណោះទេ ប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺ ទ្រង់អាចផ្ដល់ចម្លើយឲ្យយើងចំពោះសំណួរទាំងឡាយដែលយើងគួរតែបានសួរនោះ ។ ចូរយើងស្ដាប់តាមចម្លើយទាំងនោះ ។

« ការខិតខំរបស់អ្នកផ្សព្វផ្សាយសាសនានៃសាសនាចក្រនេះ គឺមាននៅលើអ្នករៀនថ្មីដ៏ស្មោះត្រង់ ដែលសួរសំណួរដោយអស់ពីចិត្ត ។ ការសួរគឺជាទីកំណើតនៃទីបន្ទាល់ ។ អ្នកខ្លះអាចមានអារម្មណ៍អៀនខ្មាស់ ឬ ថាមិនស័ក្ដិសម ដោយសារពួកគេបានរកសំណួរដែលទាក់ទងទៅនឹងដំណឹងល្អ ប៉ុន្តែពួកគេមិនចាំបាច់មានអារម្មណ៍បែបនោះទេ ។ ការសួរសំណួរមិនមែនជាសញ្ញានៃភាពទន់ខ្សោយនោះទេ វាគឺជាប្រផ្នូលមួយនៃការរីកចម្រើន ។

« ព្រះបានបញ្ជាយើងឲ្យស្វែងរកចម្លើយចំពោះសំណួររបស់យើង ( សូមមើល យ៉ាកុប ១: ៥–៦ ) ហើយសួរតែអ្វីដែលយើងស្វែងរក ‹ ដោយចិត្តស្មោះស គឺដោយស្មោះអស់ពីចិត្ត ដោយមានសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ › ( មរ៉ូណៃ ១០:៤ ) ។ នៅពេលយើងធ្វើដូច្នោះ សេចក្ដីពិតនៃការណ៍ទាំងអស់អាចត្រូវបានបង្ហាញដល់យើង ‹ ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ › (មរ៉ូណៃ ១០:៥) ។

« ចូរកុំខ្លាចឡើយ សូមសួរសំណួរ ។ ចូរឆ្ងល់ ប៉ុន្ដែកុំសង្ស័យឡើយ ! សូមកាន់ខ្ជាប់ទៅនឹងសេចក្ដីជំនឿ និង ពន្លឺដែលអ្នកបានទទួលរួចហើយនោះជានិច្ច ។ ដោយសារយើងឃើញភាពមិនឥតខ្ចោះនៅក្នុងជីវិតរមែងស្លាប់នេះ នោះមិនមែនអ្វីៗទាំងអស់នឹងយល់នាពេលឥឡូវនេះទេ ។. . .

« . . .ការស្វែងរកចម្លើយចំពោះសំណួររបស់អ្នកអាចនាំអ្នកឲ្យកាន់តែខិតទៅជិតព្រះ ដោយការពង្រឹងទីបន្ទាល់របស់អ្នកជាជាងបោះបង់វាចោល ។ ពិតណាស់ ‹ សេចក្ដីជំនឿគឺពុំមែនជា . . . ដំរិះដ៏ឥតខ្ចោះនោះទេ › ( អាលម៉ា ៣២:២១ ) ប៉ុន្ដែនៅពេលអ្នកអនុវត្តសេចក្ដីជំនឿរបស់អ្នក ដោយការអនុវត្តគោលការណ៍ទាំងឡាយនៃដំណឹងល្អរាល់ថ្ងៃទោះស្ថិតក្រោមកាលៈទេសៈណាក៏ដោយនោះ អ្នកនឹងភ្លក់នូវផ្លែឈើដ៏ផ្អែមនៃដំណឹងល្អ ហើយតាមរយៈផ្លែនេះ អ្នកនឹងដឹងពីសេចក្ដីពិតរបស់វា ( សូមមើល ម៉ាថាយ ៧:១៦–២០ យ៉ូហាន ៧:១៧ អាលម៉ា ៣២:៤១–៤៣ ) » ( "The Reflection in the Water" [ Church Educational System fireside address ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ] LDS.org ) ។

ដំណើររឿងដូចខាងក្រោម បង្ហាញអំពីរបៀបដែលបុគ្គលពីរនាក់ឈ្មោះ ហេលវេស៊ីអូ ម៉ាទិន និង រូដា ម៉ាទិន បានព្យាយាមដើម្បីទទួល និងយល់ពីសេចក្ដីពិត តាមរយៈការសួរសំណួរ ៖

« នៅយប់ភ្លឺថ្លាខែមេសា ឆ្នាំ ១៩៧២ . . . ហេលវេស៊ីអូ ម៉ាទិន បានសញ្ជឹងគិតអំពីការស្វែងរកសេចក្ដីពិតរបស់គ្រួសារគាត់ ។ គាត់ និងភរិយា រូដា បានស៊ើបអង្កេតអំពីសាសនាជាច្រើន ប៉ុន្ដែហាក់ដូចជាគ្មានបំពេញនូវភាពទទេស្អាតខាងវិញ្ញាណរបស់ពួកគេសោះ ។ គាត់និយាយថា ‹ ខ្ញុំបានសន្ទនាជាមួយព្រះនាយប់នោះ ដោយទូលសុំជំនួយ › » (Elder Helvécio Martins of the Seventy » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩០ ទំព័រ ១៦០ ) ។


អែលឌើរ ហេលវេស៊ីអូ ម៉ាទិន

ប៉ុន្មានថ្ងៃក្រោយមក ពួកអ្នកផ្សព្វផ្សាយសាសនាបានមកដល់ផ្ទះរបស់ពួកគេនៅ រីយ៉ូ ដេ ចានេរូ ប្រទេសប្រេស៊ីល ។ អែលឌើរ ម៉ាទីន បាននឹកចាំថា « នៅគ្រាដែលយុវជនទាំងពីរនាក់នោះ បានបោះជំហានចូលមកក្នុងផ្ទះរបស់យើងភ្លាម នោះភាពងងឹត និងភាពរសាប់រសល់ខាងវិញ្ញាណទាំងអស់របស់ខ្ញុំត្រូវបានរលាយបាត់មួយរំពេច ហើយត្រូវបានដាក់ជំនួសវិញដោយភាពស្ងប់ស្ងាត់ ដែលឥឡូវខ្ញុំដឹងថា វាបានមកពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ » ( ដោយ Mark Grover, *The Autobiography of Elder Helvécio Martins* [ឆ្នាំ ១៩៩៤] ទំព័រ ៤៣ ) ។

នៅពេល ហេលវេស៊ីអូ និង រូដា ដែលជាកូនចៅជនជាតិអាហ្វ្រិក បានសន្ទនាជាមួយអ្នកផ្សព្វផ្សាយសាសនានោះ ហេលវេស៊ីអូ បានសួរអំពីតួនាទីរបស់ប្រជាជនស្បែកខ្មៅនៅក្នុងសាសនាចក្រ ។ ម៉ាទិនបានដឹងថា នៅគ្រានោះ គោលនយោបាយសាសនាចក្រ បានដាក់កំហិតចំពោះបុរសស្បែកខ្មៅដែលជាកូនចៅជនជាតិអាហ្វ្រិក ពីការត្រូវបានតែងតាំងបព្វជិតភាព ។ រឿងនេះបាននាំឲ្យពួកគេសួរសំណួរបន្ថែមទៀតដល់ពួកអ្នកផ្សព្វផ្សាយសាសនា ។

បើអ្នកស្ថិតនៅក្នុងស្ថានភាពគ្រួសារម៉ាទិន តើសំណួរអ្វីខ្លះដែលអ្នកអាចនឹងសួរ នៅពេលអ្នកបានដឹងអំពីការដាក់កំហិតចំពោះបព្វជិតភាព ?

សេចក្ដីថ្លែងការណ៍ដូចខាងក្រោម គឺជាសេចក្ដីណែនាំទៅកាន់ សេចក្ដីប្រកាសជាផ្លូវការទី ២ នៅក្នុងការបោះពុម្ពនៃព្រះគម្ពីរឆ្នាំ ២០១៣ ។ នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍ សូមរកមើលចម្លើយចំពោះសំណួរទាំងឡាយ ដែលបុគ្គលម្នាក់ៗ អាចមានអំពីការដាក់កំហិតចំពោះបព្វជិតភាព ។

« ព្រះគម្ពីរមរមនបង្រៀនថាគ្រប់ ‹ មនុស្សទាំងអស់ក៏ដូចគ្នានៅចំពោះព្រះ › រួម ‹ ទាំងខ្មៅ និងស ទាំងបាវគេ និងសេរី ទាំងប្រុស និងស្រី › ( នីហ្វៃទី ២ ២៦:៣៣ ) ។ ពេញទាំងប្រវត្តិសាស្ត្រនៃសាសនាចក្រ មនុស្សទាំងអស់នៃអស់ទាំងសាសន៍ និងជាតិពន្ធនៅក្នុងប្រទេសជាច្រើន បានជ្រមុជទឹក និងបានរស់នៅជាសមាជិកដ៏ស្មោះត្រង់នៃសាសនាចក្រ ។ អំឡុងពេល យ៉ូសែប ស្ម៊ីធ នៅមានជីវិត មានបុរសស្បែកខ្មៅពីរបីនាក់ដែលជាសមាជិកនៃសាសនាចក្រ ត្រូវបានតែងតាំងឲ្យមានបព្វជិតភាព ។ កាលពីដើមនៅក្នុងប្រវត្តិសាស្ត្រ ថ្នាក់ដឹកនាំសាសនាចក្របានបញ្ឈប់ការអនុញ្ញាតឲ្យមានបព្វជិតភាពដល់បុរសស្បែកខ្មៅដែលមានពូជអំបូរអាហ្វ្រិក ។ កំណត់ត្រាសាសនាចក្រ ពុំបានផ្ដល់នូវការយល់ដឹងច្បាស់លាស់ នៅក្នុងច្បាប់ដើមនៃការអនុវត្តនេះទេ ។ អ្នកដឹកនាំសាសនាចក្រជឿថា វិវរណៈមួយមកពីព្រះ គឺចាំបាច់ត្រូវផ្លាស់ប្ដូរការអនុវត្តនេះ ហើយស្វែងរកការណែនាំប្រកបដោយការអធិស្ឋាន ។ វិវរណៈបានផ្ដល់ទៅឲ្យប្រធានសាសនាចក្រ ស្ពែនសើរ ដបុលយូ ឃីមបឹល ហើយត្រូវបានបញ្ជាក់អះអាងទៅអ្នកដឹកនាំសាសនាចក្រដទៃទៀតនៅក្នុងព្រះវិហារបរិសុទ្ធ សលត៍ លេក នៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ១៩៧៨ ។ វិវរណៈបានដកចេញនូវរាល់ការដាក់កំហិតដែលទាក់ទងនឹងជាតិសាសន៍ ដែលធ្លាប់បានអនុវត្តចំពោះបព្វជិតភាពនាពេលនោះ ។

២. សូមឆ្លើយសំណួរដូចខាងក្រោម ដាក់នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់អ្នក ៖ តើសំណួរអំពីការដាក់កំហិតបព្វជិតភាព អាចត្រូវបានឆ្លើយតាមរយៈសេចក្ដីថ្លែងការណ៍នេះមានអ្វីខ្លះ ?

សូមកត់ចំណាំផ្លូវខាងក្រោមនៅក្នុងសេចក្ដីថ្លែងការណ៍ពីខាងលើ « កំណត់ត្រានៃសាសនាចក្រ ពុំបានផ្ដល់នូវការយល់ដឹងច្បាស់លាស់អំពីការអនុវត្តបែបនេះពីដើមដំបូងឡើយ » ។ ទោះជាមនុស្សខ្លះចមានមូលហេតុចំពោះការណ៍ដែលបុរសអំបូរពីអាហ្វ្រិកមិនត្រូវបានតែងតាំងឲ្យមានបព្វជិតភាពមួយរយៈ តែមូលហេតុទាំងនោះពុំទំនងជាត្រឹមត្រូវឡើយ ។ សេចក្ដីថ្លែងការណ៍នៅក្នុងសេចក្ដីណែនាំទៅកាន់ សេចក្ដីប្រកាសជាផ្លូវការទី ២ តំណាងឲ្យជំហរជាផ្លូវការរបស់សាសនាចក្រ ។

នៅពេលអ្នកអាននូវកថាកណ្ឌដូចខាងក្រោម សូមរកមើលអ្វីដែលគ្រួសារម៉ាទីន បានធ្វើ បន្ទាប់ពីពួកគេបានដឹងអំពីដំណឹងល្អដែលបានស្ដារឡើងវិញនោះ ៖

គ្រួសារម៉ាទិន បានទទួលបុណ្យជ្រមុជទឹកនៅថ្ងៃទី ២ ខែកក្កដា ឆ្នាំ ១៩៧២ ហើយបានបម្រើដោយស្មោះត្រង់នៅក្នុងសាសនាចក្រ ។ នៅពេលកូនប្រុសច្បងរបស់ពួកគេ ម៉ាគឹស បានទទួលពររបស់លោកអយ្យកោរបស់គាត់ ក្នុងនោះបានសន្យាថាគាត់នឹងផ្សាយដំណឹងល្អ ។ ទោះជាមានការដាក់កំហិតបព្វជិតភាពនៅគ្រានោះដែលបានរាំង ម៉ាគឹសមិនឲ្យបម្រើបេសកកម្មពេញម៉ោងក្ដី ក៏ឪពុកម្ដាយគាត់ បានបើកគណនីសន្សំប្រាក់ចេញផ្សាយសាសនាឲ្យគាត់ដែរ ។ នៅឆ្នាំ ១៩៧៥ សាសនាចក្របានប្រកាសថា ព្រះវិហារបរិសុទ្ធនឹងត្រូវសាងសង់នៅក្នុងទីក្រុង សៅ ផាឡូ ប្រទេសប្រេស៊ីល ។ ដើម្បីជួយដល់ការរៃអង្គាសបងស្រីម៉ាទិន បានលក់គ្រឿងអលង្ការរបស់គាត់ ។ បងប្រុស ម៉ាទិន បានបម្រើដោយស្មោះត្រង់ជាសមាជិកនៃគណៈកម្មការសាធារណៈសម្រាប់ព្រះវិហារបរិសុទ្ធ ។ គ្រួសារម៉ាទិន បានធ្វើការលះបង់ទាំងនេះ ទោះជាពួកគេបានដឹងថា ពួកគេនឹងពុំមានឱកាសទទួលពិធីបរិសុទ្ធបព្វជិតភាពនៅក្នុងព្រះវិហារបរិសុទ្ធក្ដី ។

៣. សូមឆ្លើយសំណួរដូចខាងក្រោម ដាក់នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់អ្នក ៖ ហេតុអ្វីអ្នកគិតថាគ្រួសារម៉ាទិន មានឆន្ទៈទទួលបុណ្យជ្រមុជទឹក ហើយបម្រើដោយស្មោះត្រង់នៅក្នុងសាសនាចក្រ ទោះជាពួកគេរងឥទ្ធិពលដោយការដាក់កំហិតចំពោះបព្វជិតភាពនៅគ្រានោះក្ដី ?

ចូរប្រៀបធៀបចម្លើយរបស់អ្នកជាមួយនឹងសេចក្ដីថ្លែងការណ៍ដែលអែលឌើរ ម៉ាទិន បានផ្ដល់ឲ្យដូចតទៅ ៖ « យើងបានរកឃើញសេចក្ដីពិត ហើយគ្មានអ្វីដែលអាចបញ្ឈប់យើងមិនឲ្យរស់នៅតាមនោះទេ ។. . . នៅពេលព្រះវិញ្ញាណប្រាប់អ្នកថាដំណឹងល្អពិត . . .តើអ្នកអាចបដិសេធដោយរបៀបណា ? » (នៅក្នុង « Elder Helvécio Martins of the Seventy, » ទំព័រ ១០៦) ។

ដោយសារតែគ្រួសារម៉ាទីន បានទទួលទីបន្ទាល់តាមរយៈព្រះវិញ្ញាណបរិសុទ្ធ នោះពួកគេអាចដើរឆ្ពោះទៅមុខ ទុកចិត្តលើព្រះអម្ចាស់ ដោយមិនខ្វល់ពីអ្វីដែលពួកគេពុំយល់នោះឡើយ ។

បន្ថែមពីលើគ្រួសារម៉ាទិន ពូជអំបូរអាហ្វ្រិករាប់ពាន់ទៀត នៅក្នុងជាតិសាសន៍ជាច្រើនប្រភេទ បានមកស្គាល់សេចក្ដីពិតពេញលេញនៃដំណឹងល្អដែលបានស្ដារឡើងវិញនៅក្នុងបណ្ដាទស្សវត្សរ៍មុននឹងបានទទួលវិវរណៈនាឆ្នាំ ១៩៧៨ ទៅទៀត ។ ថ្នាក់ដឹកនាំសាសនាចក្រនៅក្នុងទីក្រុងសលត៍ លេក បានទទួលសំបុត្រជាច្រើនមកពីអ្នកប្រែចិត្តជឿដែលមិនទាន់បានជ្រមុជទឹកនៅក្នុងប្រទេសនីហ្សេរីយ៉ា និងហ្គាណាស្នើសុំឲ្យមានអ្នកផ្សព្វផ្សាយសាសនាជាច្រើនបញ្ជូនទៅកាន់អាហ្វ្រិក ។ អស់រយៈពេលជាច្រើនឆ្នាំ ពួកអ្នកដឹកនាំសាសនាចក្របានពិចារណាប្រកបដោយការអធិស្ឋានអំពីរឿងនោះ ប៉ុន្តែពួកលោកបានមានអារម្មណ៍ថា ពេលវេលាពុំទាន់មកដល់នៅឡើយ ដើម្បីបញ្ជូនពួកអ្នកផ្សព្វផ្សាយសាសនាទៅអាហ្វ្រិកជាកន្លែងដែលសមាជិកក្នុងមូលដ្ឋាននឹងពុំអាចធ្វើជាអធិបតី ឬធ្វើពិធីបរិសុទ្ធនៅឡើយនោះ ។



ប្រធាន ស្ពែនស៊ើរ ដបុលយូឃឹមបឹល

សេចក្ដីប្រកាសជាផ្លូវការទី ២ មាននូវការប្រកាសជាផ្លូវការអំពីវិវរណៈមួយដែល ប្រធាន ស្ពែនស៊ើរ ដបុលយូ ឃឹមបឹល បានទទួលនៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ១៩៧៨ ។ សូមអានកថាកណ្ឌទីមួយនៅក្រោមឃ្លា « ជូនចំពោះបងប្អូនប្រុសទាំងឡាយ » ហើយស្វែងរកមើលនូវអ្វីដែលអ្នកដឹកនាំសាសនាចក្របានថ្លែងថាពួកលោកបានធ្វើជាសាក្សី ។

តើថ្នាក់ដឹកនាំសាសនាចក្រត្រូវបានបំផុសគំនិតអ្វីខ្លះ នៅពេលពួកលោកបានធ្វើជាសាក្សីអំពីការរីកចម្រើននៃកិច្ចការរបស់ព្រះអម្ចាស់ ?

សូមអានកថាកណ្ឌដែលចាប់ផ្ដើម « ដោយយល់ពីសេចក្ដីសន្យាទាំងឡាយ » ។ ចូរស្វែងរកមើលរបៀបដែលថ្នាក់ដឹកនាំសាសនាចក្របានធ្វើសកម្មភាពលើបំណងប្រាថ្នាដ៏បំផុសគំនិតរបស់ពួកលោក ។

តើប្រធាន ឃឹមបឹល និងថ្នាក់ដឹកនាំសាសនាចក្រផ្សេងទៀតបានធ្វើសកម្មភាពលើបំណងប្រាថ្នាដ៏បំផុសគំនិតរបស់ពួកលោកដោយរបៀបណា ?

កថាកណ្ឌនេះ ជួយយើងយល់ដឹងថា**ពួកព្យាការីស្វែងរកការដឹកនាំរបស់ព្រះអម្ចាស់នៅក្នុងការដឹកនាំសាសនាចក្រ ។** អ្នកអាចនឹងចង់គូសចំណាំគោលការណ៍នេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។

ចូរកត់សម្គាល់ថា នៅដើមដំបូងនៃកថាកណ្ឌទីពីរនោះ ចាប់ផ្ដើមជាមួយនឹងឃ្លាថា « ដោយយល់ពីសេចក្ដីសន្យាទាំងឡាយដែលបានធ្វើដោយពួកព្យាការី » ។ ឃ្លានេះ បង្រៀនយើងថា អ្នកដឹកនាំសាសនាចក្របានដឹងថា នៅពេលមួយ បុរសសក្ដិសមទាំងឡាយនឹងមានឱកាសដើម្បីទទួលបានបព្វជិតភាព ។ អស់ជាច្រើនឆ្នាំពីមុនឆ្នាំ ១៩៧៨ គណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពិភាក្សា ហើយអធិស្ឋានអំពីការដាក់កំហិតចំពោះបព្វជិតភាពនេះ ។ ពួកអ្នកដឹកនាំមានអារម្មណ៍ថា វិវរណៈ គឺចាំបាច់ត្រូវមានដើម្បីមានការផ្លាស់ប្ដូរនូវការដាក់កំហិតនេះ ដែលបានស្ថាបនាឡើងជាយូរមកអស់ច្រើនជាងមួយសតវត្សន៍ហើយនោះ ។ ពេលខ្លះ សំណួរនេះ បានដិតជាប់យ៉ាងខ្លាំងក្នុងចិត្តរបស់ប្រធាន ឃឹមបឹល ហើយជាញឹកញាប់លោកបានចេញទៅព្រះវិហារបរិសុទ្ធតែម្នាក់ឯងដើម្បីអធិស្ឋានអំពីរឿងនោះ ។

សូមអានកថាកណ្ឌនៅក្នុង សេចក្ដីប្រកាសជាផ្លូវការទី ២ ដែលចាប់ផ្ដើមជាមួយនឹង « ទ្រង់បានឮពាក្យអធិស្ឋានទាំងឡាយរបស់យើង » ហើយ « យើងសូមប្រកាស » រួចស្វែងរកមើលចម្លើយរបស់ព្រះអម្ចាស់ចំពោះការអធិស្ឋានរបស់ប្រធាន ឃឹមបឹល ទីប្រឹក្សារបស់លោកនៅក្នុងគណៈប្រធានទីមួយ និងសមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ អ្នកអាចនឹងចង់គូសចំណាំនូវអ្វីដែលអ្នករកឃើញ ។

កថាកណ្ឌទាំងនេះ ជួយយើងយល់ថា**ព្រះអម្ចាស់ដឹកនាំសាសនាចក្ររបស់ទ្រង់តាមរយៈវិវរណៈទៅកាន់ពួកព្យាការីរបស់ទ្រង់ ។** អ្នកអាចនឹងចង់សរសេរគោលលទ្ធិនេះ នៅក្នុងព្រះគម្ពីររបស់អ្នក ។

វិវរណៈនេះមានឥទ្ធិពលយ៉ាងខ្លាំងលើមនុស្សនៅទូទាំងពិភពលោក ។ សូមអានប្រតិកម្មរបស់ ហេលវេស៊ីអូ ម៉ាទិន និងភរិយារបស់លោក ឈ្មោះ រូដា នៅពេលពួកគាត់បានដឹងអំពីវិវរណៈ ៖ « ខ្ញុំពុំអាចទប់អារម្មណ៍បានទេ ។ រូដា និងខ្ញុំបានចូលទៅបន្ទប់ដេករបស់យើង លុតជង្គង់ចុះ ហើយបានអធិស្ឋាន ។ យើងបានយំ ខណៈដែលយើងអរគុណដល់ព្រះវរបិតាសួគ៌ ចំពោះព្រឹត្តិការណ៍មួយ ដែលយើងបានគ្រាន់តែសុបិនចង់បានប៉ុណ្ណោះ ។ ថ្ងៃនោះបានមកដល់យ៉ាងពិត ហើយវានៅក្នុងជីវិតរមែងស្លាប់*របស់យើង* » (*Autobiography* ទំព័រ ៦៩–៧០ ) ។

គ្រួសារម៉ាទិន បានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ។ កូនប្រុសរបស់ពួកគាត់ ម៉ាគីស គឺជាសមាជិកសាសនាចក្រជនជាតិអាហ្វ្រិកដំបូងគេបំផុត ដែលបម្រើបេសកកម្មបន្ទាប់ពីទទួលវិវរណៈ ដើម្បីបញ្ចប់នូវការដាក់កំហិតចំពោះបព្វជិតភាព ។ ហេលវេស៊ីអូ ម៉ាទិន បានក្លាយជាអ្នកកាន់បព្វជិតភាពក្នុងមូលដ្ឋាន ហើយទីបំផុត ត្រូវបានហៅឲ្យបម្រើជាសមាជិកម្នាក់នៃកូរ៉ុមទីពីរនៃពួកចិតសិបនាក់ ។

ក្នុងអំឡុងពេលយ៉ាងខ្លីក្រោយពីវិវរណៈដែលបានបញ្ចប់ការដាក់កំហិតបព្វជិតភាពត្រូវបានទទួល នោះពួកអ្នកផ្សព្វផ្សាយសាសនាជាច្រើនត្រូវបានបញ្ជូនទៅកាន់ទ្វីបអាហ្វ្រិក ។ ព្រះវិហារបរិសុទ្ធជាច្រើនត្រូវបានសាងសង់នៅលើទ្វីបនោះ ហើយមនុស្សរាប់រយរាប់ពាន់នាក់បានទទួលពិធីបរិសុទ្ធនៃដំណឹងល្អសម្រាប់ខ្លួនគេ និងសម្រាប់ដូនតាដែលចែកឋានទៅរបស់ពួកគេ ។

អ្នកអាចសួរថា ហេតុអ្វីសាសនាចក្រពុំតែងតាំងបុរសជនជាតិអាហ្វ្រិកឲ្យ មានបព្វជិតភាពក្នុងមួយរយៈពេលនោះ ។ សូមពិចារណា ថាតើអ្នកអាចនឹងឆ្លើយសំណួរនេះយ៉ាងណា ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ LDS.org ជ្រើសរើស Gospel Topics ហើយស្វែងរក race and the priesthood ។

៤. វាជាការសមរម្យដើម្បីពន្យល់ដល់អ្នកដទៃថា យើងពុំដឹងថាហេតុអ្វីបានជាចាប់ផ្ដើមមានការដាក់កំហិតចំពោះបព្វជិតភាពដូច្នោះទេ ។ បន្ថែមពីលើនោះ អ្នកអាចចែកចាយ និងថ្លែងទីបន្ទាល់អំពីសេចក្ដីពិតដែលយើងបានដឹងដូចជាអ្នកទាំងឡាយដែលអ្នកបានរៀននៅក្នុងមេរៀននេះ ។ នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់អ្នក ចូរសរសេរអំពីរបៀបដែលអ្នកអាចនឹងឆ្លើយសំណួរថា ហេតុអ្វីសាសនាចក្រពុំតែងតាំងបព្វជិតភាពដល់បុរសនៃអំបូរអាហ្វ្រិកសម្រាប់មួយរយៈនោះ ។ នៅពេលអ្នកបង្កើតចម្លើយរបស់អ្នក អ្នកអាចនឹងចង់ប្រើឧទាហរណ៍អំពីគ្រួសារ ម៉ាទិន ក៏ដូចជាសេចក្ដីណែនាំទៅកាន់ សេចក្ដីប្រកាសជាផ្លូវការទី ២ នៅក្នុងការបោះពុម្ពនៃព្រះគម្ពីរឆ្នាំ ២០១៣ ផងដែរ ។

៥. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សា សេចក្ដីប្រកាសជាផ្លូវការទី ២ ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និងការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៣២ ៖ ថ្ងៃទី ៣

# ការពន្លឿនកិច្ចការនៃសេចក្ដីសង្គ្រោះ

## បុព្វកថា

តាំងពីការចាប់ផ្ដើមនៃការស្ដារឡើងវិញ កិច្ចការនៃព្រះអម្ចាស់បានពង្រីកទៅទូទាំងពិភពលោក ។ យើងរស់នៅក្នុងជំនាន់មួយ ដែលព្រះអម្ចាស់កំពុងពន្លឿនកិច្ចការរបស់ទ្រង់ ។ អ្នកមានធនធាន និង ឱកាសជាច្រើនដើម្បីចូលរួមចំណែកក្នុងការពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ ។

## ព្រះអម្ចាស់កំពុងពន្លឿនកិច្ចការរបស់ទ្រង់

តើមានមូលហេតុបែបណាខ្លះដែលមនុស្សអាចនឹងពន្លឿន ឬបង្កើនល្បឿនការងារនោះ ? សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៨:៧៣ ស្វែងរកមើលនូវអ្វីដែលព្រះអម្ចាស់បានមានបន្ទូលថា ទ្រង់នឹងពន្លឿន ( សូមមើលផងដែរ យ៉ាកុប ៥:៦១–៦២, ៧០–៧១) ។

យោងទៅលើ គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៧៣ អែលឌើរ រ័សុល អិម ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា « ពេលវេលានៃការពន្លឿននោះ គឺជាពេលឥឡូវនេះហើយ » (Thus Shall My Church Be Called » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩០ ទំព័រ ១៧ ) ។

**យើងរស់នៅក្នុងជំនាន់មួយ ដែលព្រះអម្ចាស់កំពុងពន្លឿនកិច្ចការរបស់ទ្រង់ ។** តាមរយៈការពន្លឿនកិច្ចការរបស់ទ្រង់ ព្រះអម្ចាស់លើកកម្ពស់ ហើយបន្ថែមល្បឿនកិច្ចខិតខំរបស់ទ្រង់ដើម្បីនាំមកនូវសេចក្ដីសង្គ្រោះដល់មនុស្សលោក ។

១. សូមឆ្លើយសំណួរដូចខាងក្រោម ដាក់នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកធ្វើជាសាក្សីថា ព្រះអម្ចាស់កំពុងពន្លឿនកិច្ចការរបស់ទ្រង់ របៀបណា ?

អំឡុងពេលការបម្រើរបស់ប្រធាន ស្ពែនសើរ ដបុលយូ឴ ឃឹមបឹល ក្នុងនាមជាប្រធានសាសនាចក្រ ព្រះអម្ចាស់បានពន្លឿនកិច្ចការរបស់ទ្រង់ ។ ឧទាហរណ៍ កិច្ចការផ្សព្វផ្សាយសាសនាបានពង្រីក ហើយសាសនាចក្របានបោះពុម្ពកំណែថ្មីនៃព្រះគម្ពីរ ។ នៅពេលលោកលើកទឹកចិត្តដល់សមាជិកសាសនាចក្រឲ្យឆ្ពោះទៅមុខ នោះប្រធាន ឃឹមបឹល បានមានប្រសាសន៍ថា សាសនាចក្រ « បានបង្អង់នៅត្រង់កន្លែងខ្លះយូរល្មមគ្រប់គ្រាន់ហើយ ។ ចូរយើងបន្តការធ្វើដំណើររបស់យើងឆ្ពោះទៅមុខ ហើយឡើងទៅលើ » ( « Let Us Move Forward and Upward » *Ensign* ខែ ឧសភា ឆ្នាំ ១៩៧៩ ទំព័រ ៨២ ) ។ លោកក៏បានបង្រៀនផងដែរថា « យើងត្រូវតែពង្រីកការបោះជំហានរបស់យើង ហើយត្រូវតែធ្វើវាឥឡូវនេះ » (Always a Convert Church: Some Lessons to Learn and Apply This Year, » *Ensign* ខែកញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៣ ) ។

នៅពេលសមាជិកសាសនាចក្រ « ពង្រីកការបោះជំហានរបស់ពួកគេ » នោះពួកគេបង្កើនកិច្ចខិតខំរបស់ពួកគេដើម្បីចូលរួមក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។ ឧទាហរណ៍ ពួកគេធ្វើការកាន់តែមានភាពឧស្សាហ៍ព្យាយាមដើម្បីចែកចាយដំណឹងល្អ សិក្សាព្រះគម្ពីរ ហើយធ្វើកិច្ចការព្រះវិហារបរិសុទ្ធ និងកិច្ចការពង្សប្រវត្តិ ។

## ការពន្លឿនកិច្ចការផ្សព្វផ្សាយសាសនា

ប្រធាន ស្ពែនសើរ ដបុលយូ ឃឹមបឹល បានប្រាប់ពួកបរិសុទ្ធថា ព្រះអម្ចាស់បានរៀបចំដើម្បីបើកទ្វារសម្រាប់ពួកគេឲ្យចែកចាយដំណឹងល្អ រួមទាំងនៅក្នុងជាតិសាសន៍ដែលពុំអនុញ្ញាតឲ្យមានកិច្ចការផ្សព្វផ្សាយសាសនាផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ លោកក៏បានមានប្រសាសន៍ថា ពួកបរិសុទ្ធចាំបាច់ត្រូវត្រៀមខ្លួនឯងដើម្បីទទួលយកឱកាសនោះផងដែរ ។ ប្រធាន ឃឹមបឹលក៏បានថ្លែងទីបន្ទាល់ថា បើយុវជនគ្រប់រូបត្រៀមខ្លួនបម្រើបេសកកម្មពេញម៉ោង នោះព្រះអម្ចាស់នឹងបើកទ្វារ ហើយផ្ដល់មធ្យោបាយមួយសម្រាប់កិច្ចការផ្សព្វផ្សាយសាសនា ដើម្បីចេញទៅពេញពិភពលោកទាំងមូល ៖



« ខ្ញុំគិតអំពីជាតិសាសន៍ជាច្រើនដែលនៅពុំទាន់បានទំនាក់ទំនង ។ ខ្ញុំដឹងថា ពួកគេមានរាំងនន [ ការដាក់កំហិតទប់ទល់នឹងឥទ្ធិពលពីខាងក្រៅ ] ដូចជារាំងននដែក និងរាំងននឫស្សី ។ ខ្ញុំដឹងថា វាលំបាកខ្លាំង ដោយសារយើងបានខិតខំបញ្ចេញសមត្ថភាពខ្លះហើយ ។. . .

« ប៉ុន្តែខ្ញុំអាចមើលឃើញថា វាគ្មានហេតុផលល្អទេ ដែលព្រះអម្ចាស់នឹងបើកទ្វារ ដែលយើងពុំបានត្រៀមខ្លួនដើរចូលទៅនោះ ។ ហេតុអ្វីក៏ទ្រង់គប្បីបំបាក់រាំងននដែក ឬរាំងននឫស្សី ឬរាំងននផ្សេងទៀត បើយើងពុំត្រៀមខ្លួនដើម្បីដើរចូលផងនោះ ? (« When the World Will Be Converted, » *Ensign* ខែ តុលា ឆ្នាំ ១៩៧៤ ទំព័រ ៥, ៧ ) ។

សមាជិកនៃសាសនាចក្របានធ្វើតាមការទូន្មានរបស់ប្រធាន ឃឹមបឹល ហើយបានត្រៀមខ្លួនដើម្បីចែកចាយដំណឹងល្អ ។ អំឡុងការដឹកនាំរបស់ប្រធាន ឃឹមបឹល នោះចំនួនអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង បានកើនឡើងច្រើនជាង ៥០ ភាគរយ ។ នៅចុងឆ្នាំ ១៩៨០ និងដើមឆ្នាំ ១៩៩០ រដ្ឋាភិបាលអាល្លឺម៉ង់ខាងកើត ប្រទេសជាតិទាំងឡាយនៅក្នុងសហភាពសូវៀតពីដើម និងប្រទេសជាតិនានាឯទៀត ជាទីកន្លែងដែលកិច្ចការផ្សព្វផ្សាយសាសនាត្រូវបានដាក់កំហិតពីមុននោះ បានចាប់ផ្ដើមអនុញ្ញាតឲ្យអ្នកផ្សព្វផ្សាយសាសនាចូលទៅចែកចាយដំណឹងល្អនៅក្នុងប្រទេសទាំងនេះ ។ ការព្យាករណ៍របស់ប្រធាន ឃឹមបឹល ត្រូវបានបំពេញ ហើយវាបន្តបំពេញនៅពេលកិច្ចការផ្សព្វផ្សាយសាសនាបានពង្រីកកាន់តែធំ ។



នៅពេលប្រធាន ឃឹមបឹល បានលើកទឹកចិត្តដល់សមាជិកសាសនាចក្រឲ្យពង្រីកការបោះជំហានរបស់ពួកគេ នោះលោកបានបញ្ជាក់អំពីទំនួលខុសត្រូវមួយរបស់យុវជនគ្រប់រូបក្នុងសាសនាចក្រ ៖ « សំណួរត្រូវបានសួរជាញឹកញាប់ ៖ តើយុវជនគ្រប់រូបគួរបំពេញបេសកកម្មឬទេ ? ហើយចម្លើយត្រូវបានប្រទានឲ្យដោយព្រះអម្ចាស់ ។ គឺ ‹ ពិតមែនហើយ › ។ យុវជនគ្រប់រូបគប្បីបំពេញបេសកកម្ម » (« When the World Will Be Converted » ទំព័រ ៨ )។

ចាប់តាំងពីពេលនោះមក ពួកព្យាការីបានបន្តលើកទឹកចិត្តយុវជនដែលសក្តិសម និងមានសមត្ថភាពគ្រប់រូប ឲ្យបម្រើបេសកកម្មពេញម៉ោង ។ ពួកព្យាការីក៏ស្វាគមន៍ដល់យុវនារីឲ្យបម្រើបេសកកម្មពេញម៉ោងផងដែរ បើពួកគេមានបំណងចង់ធ្វើ ។ នៅខែតុលា ឆ្នាំ ២០១២ ប្រធាន ថូម៉ាស អេស ម៉នសុន បានប្រកាសអំពីការផ្លាស់ប្ដូរអាយុដែលតម្រូវឲ្យចេញផ្សព្វផ្សាយសាសនាដោយអនុញ្ញាតឲ្យយុវជនចាប់ផ្ដើមការបម្រើផ្សព្វផ្សាយសាសនានៅវ័យ ១៨ ឆ្នាំ ហើយយុវនារីនៅវ័យ ១៩ ឆ្នាំ. **យុវជនគ្រប់រូបគួរតែត្រៀមខ្លួនដើម្បីបម្រើបេសកកម្មពេញម៉ោង ហើយរក្សាខ្លួនឲ្យមានភាពសក្តិសមដើម្បីបម្រើ ។**

២. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីក៏យុវជនគ្រប់រូបគប្បីត្រៀមខ្លួនបម្រើបេសកកម្មពេញម៉ោងយ៉ាងដូច្នេះ ?

ខ. តើការត្រៀមខ្លួនសម្រាប់បេសកកម្មនាពេលឥឡូវនេះ អាចជួយអ្នករួមចំណែកក្នុងកិច្ចការរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?

គ. តើអ្នកគិតថា ការផ្លាស់ប្ដូរចំពោះតម្រូវការអាយុសម្រាប់ការចេញផ្សព្វផ្សាយសាសនាពេញម៉ោងដ៏បំផុសគំនិត បានរួមចំណែកចំពោះការពន្លឿនកិច្ចការរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?



## កំណែថ្មីនៃព្រះគម្ពីរ

តើអ្នកនឹងនិយាយអ្វីខ្លះ បើមិត្តជិតស្និតម្នាក់របស់អ្នកនិយាយមកកាន់អ្នកថា « ខ្ញុំចង់ខិតទៅកាន់តែជិតព្រះ ។ តើខ្ញុំគួរតែធ្វើយ៉ាងដូចម្ដេច ? »



សូមអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ស្ពេនស៊ើរ ដបុលយូ.ឃឹមបឹល ៖ « ខ្ញុំយល់ឃើញថា នៅពេលខ្ញុំមិនសូវចាប់អារម្មណ៍ក្នុងការទំនាក់ទំនងទាំងឡាយរបស់ខ្ញុំជាមួយនឹងព្រះដ៏ទេវភាព ហើយនៅពេលដែលវាហាក់បីដូចជាបង្ហាញថា គ្មានត្រចៀកដ៏ទេវភាពណាកំពុងស្ដាប់ និង គ្មានសម្លេងដ៏ទេវភាពណាកំពុងនិយាយ ពេលនោះហើយដែលធ្វើឲ្យខ្ញុំកាន់តែឃ្លាតឆ្ងាយទៅៗ ។ ប្រសិនបើខ្ញុំផ្ដោតយកចិត្តទុកដាក់ទាំងស្រុងលើព្រះគម្ពីរ នោះផ្លូវឆ្ងាយនឹងត្រូវបានបង្រួញ ហើយជីវភាពខាងវិញ្ញាណនឹងត្រឡប់មកវិញ » (*Teachings of Presidents of the Church: Spencer W. Kimball* [ឆ្នាំ ២០០៦ ] ទំព័រ ៦៧ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១:៦, ២៤–៣០ រួចប្រាប់ថា ហេតុអ្វីព្រះអម្ចាស់សព្វព្រះទ័យឲ្យពួកអ្នកដឹកនាំបោះពុម្ពវិវរណៈ ។ តើព្រះគម្ពីរអាចជួយយើងពង្រីកជំហានរបស់យើង ហើយរួមចំណែកក្នុងការពន្លឿនកិច្ចការរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?

នៅដើមឆ្នាំ ១៩៧០ អ្នកដឹកនាំសាសនាចក្រទទួលស្គាល់ពីតម្រូវការ ដែលសមាជិកសាសនាចក្រត្រូវចេះបទគម្ពីរឲ្យបានកាន់តែស្ទាត់ជំនាញ ហើយឲ្យមានកំណែថ្មីនៃព្រះគម្ពីរប៊ីបជាបទដ្ឋានមួយដើម្បីសិក្សា និងបង្រៀន ។ នៅឆ្នាំ ១៩៧៩ បន្ទាប់ពីរយៈពេលជាច្រើនឆ្នាំនៃកិច្ចខិតខំ ដ៏បំផុសគំនិត និងឧស្សាហ៍ព្យាយាម នោះសាសនាចក្រ បានបោះពុម្ពកំណែថ្មីនៃព្រះគម្ពីរប៊ីបរបស់ស្ដេចជេមស៍ អិល.ឌី.អេស ជាផ្លូវការជាភាសាអង់គ្លេស ។ កំណែថ្មីនៃគម្ពីរប៊ីបនេះ មាននូវជំនួយការសិក្សាដ៏ច្រើន ដែលពុំធ្លាប់មានពីមុន រួមមានទាំងលេខយោងជាមួយនឹងសេចក្ដីយោងបទគម្ពីរ និងជំនួយដទៃៗទៀតត្រូវបានពង្រីកកាន់តែច្រើន ហើយបានកែលម្អដើមជំពូក ដកស្រង់ចេញមកពីការបកប្រែរបស់យ៉ូសែប ស៊្មីធ Topical Guide និង Bible Dictionary ។ នៅឆ្នាំ ១៩៨១ សាសនាចក្របានបោះពុម្ពកំណែថ្មី នៃបណ្ដុំព្រះគម្ពីរទាំងបីជាភាសាអង់គ្លេស– ព្រះគម្ពីរមរមន គោលលទ្ធិ និងសេចក្ដីសញ្ញា និង មុក្ដាដ៏មានតម្លៃមហិមា– ដែលរួមមានទាំងការកែលម្អលេខយោង ដើមជំពូក ផែនទី និងមាតិកា ។ នៅឆ្នាំ ២០០៩ សាសនាចក្របានបោះពុម្ពកំណែថ្មីនៃព្រះគម្ពីរប៊ីបនៃ រីណា វ៉ាឡេរ៉ា អិល.ឌី.អេស ជាភាសាអេស្ប៉ាញ ។

សូមអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ប៊យដ៏ ឃេ ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដែលបានធ្វើឡើង នៅរយៈពេលមួយឆ្នាំ បន្ទាប់ពីបានចេញបណ្ដុំព្រះគម្ពីរទាំងបីជាភាសាអង់គ្លេសនៅឆ្នាំ ១៩៨១ ។ ចូររកមើលរបៀបដែលលោកបានមើលឃើញជាមុនថា កំណែថ្មីនៃព្រះគម្ពីរទាំងនេះ នឹងប្រទានពរដល់ជីវិតជាច្រើន ហើយរំកិលកិច្ចការរបស់ព្រះឆ្ពោះទៅមុខ ។



« រយៈពេលជាច្រើនឆ្នាំបានកន្លងផុតទៅ ព្រះគម្ពីរទាំងនេះនឹងបង្កើតផលជាជំនាន់នៃពួកគ្រីស្ទានស្មោះត្រង់ជាបន្តបន្ទាប់ ដែលស្គាល់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ហើយដែលចង់គោរពតាមព្រះទ័យទ្រង់ ។

« . . . វិវរណៈ នឹងបើកសម្ដែងដល់ពួកគេ ដែលគ្មានវិធីណាផ្សេងឡើយនៅក្នុងប្រវត្តិសាស្ត្រនៃពិភពលោក ។. . . ពួកគេនឹងអភិវឌ្ឍចំណេះវិជ្ជានៃដំណឹងល្អ លើសហួសជីដូនជីតារបស់ពួកគេអាចសម្រេចបានទៅទៀត ។ ពួកគេនឹងមានទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ហើយអាចប្រកាសអំពីទ្រង់ និងការពារទ្រង់ » ( « Scriptures » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨២ ទំព័រ ៥៣ ) ។

**ព្រះគម្ពីរថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ។** ការសិក្សាបទគម្ពីរអាចជួយយើងទទួលបានទីបន្ទាល់អំពី ព្រះយេស៊ូវគ្រីស្ទ ហើយជួយបំពេញជីវិតរបស់យើងដោយព្រះវិញ្ញាណបរិសុទ្ធ ។ កិច្ចខិតខំដ៏អស្ចារ្យ បានមាន និងបន្តធ្វើឡើងដើម្បីផ្ដល់ឲ្យសមាជិកសាសនាចក្រនូវព្រះគម្ពីរ ហើយផ្ដល់ជំនួយសម្រាប់ការសិក្សាជាភាសាកំណើតរបស់ពួកគេ ។

៣. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីក៏ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃសំខាន់ ?

ខ. តើការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់អ្នក បានជួយអ្នក ឲ្យជួយក្នុងកិច្ចការរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេច ?

## ការពន្លឿនកិច្ចការព្រះវិហារបរិសុទ្ធ និងកិច្ចការពង្សប្រវត្តិ

ការសាងសង់ព្រះវិហារបរិសុទ្ធបានកើនឡើងយ៉ាងច្រើនក្រៃលែង នៅក្រោមការដឹកនាំរបស់ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ។ នៅក្នុងឆ្នាំ ១៩៩៥ នៅពេលដែលមានព្រះវិហារបរិសុទ្ធតិចជាង ៥០ កំពុងដំណើរការ នៅទូទាំងពិភពលោក លោកបានមានប្រសាសន៍ ៖ « ខ្ញុំមានបំណងប្រាថ្នាដ៏ខ្លាំងមួយថា ព្រះវិហារបរិសុទ្ធមួយ ត្រូវតាំងឡើងនៅក្នុងកន្លែងមួយដែលពួកបរិសុទ្ធថ្ងៃចុងក្រោយនៅទូទាំងពិភពលោកអាចចូលរួមបានដោយសមហេតុផល ។. . . . . . កិច្ចការកំពុងឆ្ពោះទៅមុខយ៉ាងលឿនតាមដែលយើងអាចធ្វើទៅបាន ។ វាគឺជាការអធិស្ឋានដ៏ខ្ជាប់ខ្ជួនរបស់ខ្ញុំសុំឲ្យវាអាចត្រូវបានពន្លឿនល្បឿនឡើង ដើម្បីឲ្យប្រជាជនរបស់យើងកាន់តែច្រើននាក់អាចចូលទៅក្នុងដំណាក់ដ៏ពិសិដ្ឋរបស់ព្រះអម្ចាស់បានកាន់តែងាយស្រួល » (Of Missions, Temples, and Stewardship » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ៥២, ៥៣ ) ។

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ១២៨:១៥, ១៧ ដោយស្វែងរកមើលនូវទំនួលខុសត្រូវដែលយើងមានចំពោះជីដូនជីតារបស់យើង ។ អែលឌើរ ដាវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានថ្លែងគោលការណ៍ដូចខាងក្រោម ៖**យើងមានទំនួលខុសត្រូវដែលភ្ជាប់ជាមួយសេចក្ដីសញ្ញា ដើម្បីនឹងស្រាវជ្រាវស្វែងរកដូនតារបស់យើង ហើយធ្វើពិធីបរិសុទ្ធនៃការសង្គ្រោះក្នុងដំណឹងល្អដល់ពួកលោក** » (The Hearts of the Children Shall Turn » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២៥ ) ។

សំណង់ព្រះវិហារបរិសុទ្ធ និងការរីកចម្រើននៃកិច្ចការពង្សប្រវត្តិ គឺជាភស្តុតាងដែលព្រះកំពុងពន្លឿនកិច្ចការរបស់ទ្រង់ នៅផ្នែកម្ខាងទៀតនៃវាំងនន ។



សូមអានសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ បែដណា រួចរកមើលរបៀបដែលអ្នកអាចចូលរួមក្នុងកិច្ចការរបស់ព្រះអម្ចាស់ ៖ « វាមិនមែនជាការចៃដន្យទេដែលកម្មវិធី FamilySearch និងឧបករណ៍ទាំងឡាយដទៃទៀតត្រូវបង្កើតឡើងនៅចំពេលដែលមនុស្សវ័យក្មេង មានការចេះដឹងយ៉ាងទូលំទូលាយ អំពីបច្ចេកវិជ្ជាព័ត៌មាន និងបណ្ដាញទំនាក់ទំនងទាំងនោះ។ ម្រាមដៃរបស់អ្នកត្រូវបានបង្រៀនឲ្យវាយសារ ដើម្បីបង្កើនល្បឿន និងជំរុញកិច្ចការរបស់ព្រះអម្ចាស់–ពុំគ្រាន់តែជាទំនាក់ទំនងបានឆាប់ជាមួយមិត្តរបស់អ្នកប៉ុណ្ណោះទេ ។ ជំនាញ និងសមត្ថភាព ដែលជាភស្តុតាងនៅក្នុងចំណោមមនុស្សវ័យក្មេងជាច្រើនសព្វថ្ងៃនេះ គឺជាការឲរៀបចំមួយដើម្បីរួមចំណែកក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះ » (« The Hearts of the Children » ទំព័រ ២៦ ) ។

៤. សូមឆ្លើយសំណួរដូចខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់អ្នក ៖ តើបទពិសោធន៍វិជ្ជមានអ្វីខ្លះដែលអ្នកមាន នៅក្នុងការធ្វើកិច្ចការពង្សប្រវត្តិរបស់អ្នក ឬការទៅព្រះវិហារបរិសុទ្ធដើម្បីចូលរួមក្នុងពិធីបរិសុទ្ធសម្រាប់មរណជន ?

## ទំនួលខុសត្រូវរបស់យើងក្នុងការជម្រុញកិច្ចការឲ្យឆ្ពោះទៅមុខ

នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយ ដេវីឌ ប៊ី ហេត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ គូសចំណាំពរជ័យមួយដែលមានចំពោះយើងម្នាក់ៗ ៖



« បងប្អូនប្រុសស្រី ព្រះអម្ចាស់កំពុងបើកផ្លូវ ហើយធ្វើឲ្យមានលទ្ធភាពដើម្បីពង្រីកកិច្ចការរបស់ទ្រង់នៅទូទាំងពិភពលោក ហើយនោះជាពរជ័យមួយសម្រាប់យើងទាំងអស់គ្នា– ដែលបុគ្គលម្នាក់ៗត្រូវចូលរួមចំណែក–តាមរបៀបផ្ទាល់ខ្លួន ។. . .

« តើមាននរណាក្រៅពីពួកព្យាការីនៃព្រះ អាចមើលឃើញជាមុនអំពីអព្ភូតហេតុនៃការរីកចម្រើនយ៉ាងលឿននៃកិច្ចការរបស់ព្រះអម្ចាស់ ? ពិតណាស់ ដូចដែលព្រះអម្ចាស់បានប្រាប់ជាមុននៅក្នុងកណ្ឌ ៨៨ អំពី គោលលទ្ធិ និង សេចក្ដីសញ្ញា នោះទ្រង់កំពុងពន្លឿនកិច្ចការរបស់ទ្រង់តាមពេលវា ( សូមមើលគ និង ស ៨៨:៧៣)» («Missionary Work—Our Responsibility » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៣, ទំព័រ ៦១, ៦២ ) ។

**យើងអាចត្រូវបានប្រទានពរនៅក្នុងការចូលរួមចំណែកនៅក្នុងការពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ ។** ចូរពិចារណាអំពីឱកាសទាំងឡាយ ដែលអ្នករួមចំណែកដើម្បីពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ ។

៥. សូមឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. តើមានវិធីមួយចំនួនណាខ្លះ ដែលអ្នកអាចរួមចំណែកដើម្បីពន្លឿនដល់កិច្ចការរបស់ព្រះអម្ចាស់ ?

ខ. តើពរជ័យអ្វីខ្លះដែលអ្នកបានទទួលពិសោធន៍ នៅពេលអ្នកបានចូលរួមក្នុងការពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ ?

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សាមេរៀនអំពី « ការពន្លឿនកិច្ចការនៃសេចក្ដីសង្គ្រោះ » ហើយបានបញ្ចប់មេរៀននេះនៅ ( កាលបរិច្ឆេទ ) ។*

*សំណួរ គំនិត និងការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

មេរៀនទី ៣២ ៖ ថ្ងៃទី ៤

# ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក

### បុព្វកថា

នៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ១៩៩៥ នៅក្នុងការប្រជុំសមាគមសង្គ្រោះទូទៅមួយ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានណែនាំអំពី « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ។ សេចក្ដីប្រកាសនេះ ចេញមកពីគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ប្រកាសទៅកាន់ពិភពលោកអំពីបទដ្ឋាន និងគោលលទ្ធិរបស់ព្រះអម្ចាស់អំពីក្រុមគ្រួសារ ។ សេចក្ដីប្រកាសក៏ផ្ដល់នូវការទូន្មានផងដែរ សម្រាប់ជាការពង្រឹងដល់ក្រុមគ្រួសារ និងការព្រមានអំពីលទ្ធផលនៃការបែកបាក់ក្រុមគ្រួសារ ។ ( ច្បាប់ចម្លងនៃការប្រកាសអំពីគ្រួសារនេះគឺមាននៅចុងមេរៀននេះ ) ។

## គណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានចេញសេចក្ដីប្រកាសមួយទៅកាន់ពិភពលោកអំពីក្រុមគ្រួសារ

តើអ្នកធ្លាប់មានសំណួរ ឬស្គាល់នរណាម្នាក់ដែលមានសំណួរទាក់ទងនឹងបញ្ហាមួយដូចខាងក្រោមនេះឬទេ ?

- សារៈសំខាន់នៃអាពាហ៍ពិពាហ៍ និងគ្រួសារ
- ការលែងលះគ្នា
- អាពាហ៍ពិពាហ៍ភេទដូចគ្នា
- ភេទ
- ឪពុកម្ដាយដែលពុំបានរៀបការនឹងគ្នា
- ការមានកូន
- ទំនាក់ទំនងផ្លូវភេទក្រៅចំណងអាពាហ៍ពិពាហ៍
- តួនាទីរបស់ម្ដាយ
- តួនាទីរបស់ឪពុក
- ការពន្លូតកូន

សំណួរជាច្រើនអំពីបញ្ហាទាំងនេះ និងបញ្ហាគ្រួសារផ្សេង ៗទៀត អាចត្រូវបានឆ្លើយ តាមរយៈការប្រើឯកសារ« ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ។

មុនពេលប្រធានហ្គរដិន ប៊ី ហ៊ិងគ្លី អានការប្រកាសនេះ លោកបានថ្លែងអំពីមូលហេតុមួយចំនួនថាហេតុអ្វីក៏ពិភពលោកត្រូវការសេចក្ដីពិតទាំងឡាយក្នុងសេចក្ដីប្រកាសនេះ ។ នៅពេលអ្នកអានសេចក្ដីថ្លែងការណ៍របស់លោក សូមស្វែងរកមើល ហើយគូសបន្ទាត់ពីក្រោមមូលហេតុទាំងនេះ ។



« ជាមួយនឹងការបោកបញ្ឆោតដ៏ឈ្លាសវៃជាច្រើនដែលបន្លំថាជាសេចក្ដីពិត ជាមួយនឹងការបំភាន់ជាច្រើនអំពីបទដ្ឋាន និងគុណតម្លៃ ជាមួយនឹងការធ្វើឲ្យស្រើបស្រាល និងការរំភើបក្នុងការទទួលយកនូវស្នាមប្រឡាក់បន្តិចម្ដងៗនៃពិភពលោក នោះយើងមានអារម្មណ៍បំផុសថា ត្រូវព្រមាន និងហាមទុកជាមុន ។ បន្ថែមពីលើនេះ យើងជាគណៈប្រធានទីមួយ និងក្រុមប្រឹក្សានៃពួកសាវកដប់ពីរនាក់ ឥឡូវនេះបានចេញនូវសេចក្ដីប្រកាសមួយចំពោះសាសនាចក្រ និងពិភពលោក ជាសេចក្ដីប្រកាស និងការបញ្ជាក់ជាថ្មីអំពីបទដ្ឋាន គោលលទ្ធិ និងការអនុវត្តទាំងឡាយ ដែលទាក់ទងទៅនឹងក្រុមគ្រួសារដែលពួកព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈនៃសាសនាចក្រ បានថ្លែងដដែលៗនៅពេញប្រវត្តិសាសនាចក្រ » (Stand Strong against the Wiles of the World, » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ១០០ ) ។

**១. ដើម្បីជួយអ្នកស្គាល់គោលលទ្ធិ និង គោលការណ៍ទាំងឡាយ ដែលឆ្លើយតបនឹងសំណួរអំពីបញ្ហាដែលបានរៀបរាប់នៅខាងដើមមេរៀន សូមចម្លងតារាងដូចខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ដោយទុកកន្លែងដើម្បីសរសេរចម្លើយរបស់អ្នកផងដែរ ។ ( អ្នកអាចនឹងចង់ដាក់លេខតាមកថាខណ្ឌក្នុងច្បាប់ចម្លងនៃការប្រកាសនៅចុងមេរៀននេះ ) ។**

| បញ្ហាទាំងឡាយទាក់ទងនឹងគ្រួសារ | គោលលទ្ធិ និងគោលការណ៍ទាំងឡាយចេញមកពីការប្រកាសអំពីគ្រួសារ | បានបង្រៀនកថាខណ្ឌមួយណានៅក្នុងការប្រកាស ? |
|---|---|---|
| សារៈសំខាន់នៃអាពាហ៍ពិពាហ៍ និងគ្រួសារ | | |
| ការលែងលះគ្នា | | |
| អាពាហ៍ពិពាហ៍ភេទដូចគ្នា | | |
| ភេទ | **ភេទប្រុសស្រី គឺជាលក្ខណៈពិសេស នៃអត្តសញ្ញាណ និងគោលបំណងរបស់បុគ្គលម្នាក់ៗនៅជីវិតមុនផែនដី ជីវិតរមែងស្លាប់ និង នៅអស់កល្បជានិច្ច ។** | កថាខណ្ឌទី ២ |
| ការមានកូន | | |
| តួនាទីរបស់ឪពុក | | |
| តួនាទីរបស់ម្ដាយ | | |
| ទំនាក់ទំនងផ្លូវភេទក្រៅចំណងអាពាហ៍ពិពាហ៍ | | |
| ការពន្លូតកូន | **ការបង្កបង្កើតជីវិតរមែងស្លាប់ គឺជាផ្នែកមួយដ៏ពិសិដ្ឋ និងសំខាន់នៃផែនការរបស់ព្រះវរបិតាសួគ៌ ។** | កថាខណ្ឌទី ៣ និង ៥ |

**សូមអានកថាខណ្ឌ ១–៥ នៃការប្រកាសអំពីគ្រួសារ រួចរកមើលគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលទាក់ទងទៅនឹងបញ្ហាគ្រួសារទាំងនេះ ។ ចេញមកពីអ្វីដែលអ្នករកបាននៅក្នុងការប្រកាសអំពីគ្រួសារ ចូរប្រាប់អំពីគោលលទ្ធិ ឬគោលការណ៍ដែលទាក់ទងនឹងបញ្ហានីមួយៗ នៅក្នុងតារាង ។ ចូរសរសេរអ្វីទាំងនេះនៅក្នុងកូឡោនត្រឹមត្រូវ នៅជិតនឹងបញ្ហាក្នុងតារាងនៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ។ ចូរសរសេរផងដែរថា កថាខណ្ឌមួយណា ឬកថាខណ្ឌទាំងឡាយណា នៃការប្រកាសអំពីគ្រួសារ ដែលអ្នកប្រើដើម្បីជួយអ្នកស្គាល់គោលលទ្ធិ ឬគោលការណ៍នីមួយៗ ។ ( ព័ត៌មានពីរជួរក្នុងតារាងត្រូវបានបំពេញឲ្យអ្នក សម្រាប់ជាឧទាហរណ៍ ) ។**

២. សូមជ្រើសរើសគោលលទ្ធិ ឬគោលការណ៍ចំនួនពីរ ដែលអ្នកបានប្រាប់នៅក្នុងតារាងរបស់អ្នក ។ សូមឆ្លើយនឹងសំណួរខាងក្រោមនេះចំពោះគោលលទ្ធិ ឬគោលការណ៍នីមួយ ៗដែលអ្នកបានជ្រើសរើសដាក់នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

ក. ហេតុអ្វីក៏អ្នកគិតថា វាសំខាន់ដើម្បីយល់អំពីគោលលទ្ធិ ឬគោលការណ៍នេះ ?

ខ. តើការយល់ដឹង និងការជឿទៅលើគោលលទ្ធិ ឬគោលការណ៍នេះ អាចមានឥទ្ធិពលទៅលើការសម្រេចចិត្តរបស់អ្នកយ៉ាងដូចម្ដេច ?

### *ការអនុវត្តគោលការណ៍ទាំងឡាយ*

គោលការណ៍មួយ គឺជាសេចក្ដីពិតស្ថិតស្ថេរមួយ ឬជាច្បាប់ ដែលអ្នកអាចទទួលយក ដើម្បីដឹកនាំអ្នកនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ។ អ្នកអាចប្រើគោលការណ៍ទាំងឡាយ ដែលមាននៅក្នុងការប្រកាសអំពីគ្រួសារ ដើម្បីដឹកនាំអ្នកក្នុងការធ្វើការសម្រេចចិត្តអំពីគ្រួសារដែលអ្នកនឹងបង្កើតឡើង ។

## ការប្រកាសអំពីក្រុមគ្រួសារ ជួយយើងស្ថាបនាក្រុមគ្រួសារដោយជោគជ័យ



សូមអានកថាខណ្ឌទី ៦–៧ នៃ « គ្រួសារ ៖ ការប្រកាសដល់ពិភពលោក » រកមើលនូវអ្វីដែលអាចជួយអ្នកសម្រេចបាននូវសុភមង្គលក្នុងគ្រួសាររបស់អ្នក ។

គោលការណ៍មួយដែលយើងរៀនចេញមកពីការប្រកាសអំពីគ្រួសារ គឺថា ៖ **សុភមង្គលនៅក្នុងជីវិតគ្រួសារអាចសម្រេចទៅបានល្អបំផុតនៅពេលផ្ដោតទៅលើការបង្រៀនរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។**

៣. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ចូរសរសេរគោលការណ៍ដែលមាននៅក្នុងកថាខណ្ឌទី ៧ នៃការប្រកាសអំពីគ្រួសារ ដែលជួយដល់ក្រុមគ្រួសាររកឃើញសុភមង្គល ។ ( អ្នកអាចនឹងចង់គូសចំណាំគោលកាណ៍នេះនៅក្នុងច្បាប់នៃសេចក្ដីប្រកាសអំពីក្រុមគ្រួសាររបស់អ្នក ) ។ បន្ទាប់មកសូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើគំរូអ្វីខ្លះដែលអ្នកបានមើលឃើញក្រុមគ្រួសារបានធ្វើតាមការបង្រៀនទាំងនេះ ?

ខ. ហេតុអ្វីអ្នកគិតថាក្រុមគ្រួសារដែលធ្វើតាមការបង្រៀនទាំងនេះ គឺហាក់ដូចជាមានក្ដីរីករាយជាងដូច្នេះ?

៤. ចូរគិតអំពីរបៀបដែលការបង្រៀនទាំងនេះអាចបន្ថែមទៅលើសុភមង្គលក្នុងគ្រួសារមួយ ។ ចូរគិតពិចារណាថាតើការបង្រៀនណាមួយ ដែលអ្នកអាចរស់នៅតាមបានល្អប្រសើរ ដើម្បីនាំមកនូវសុភមង្គលកាន់តែខ្លាំងចំពោះអ្នក និងគ្រួសាររបស់អ្នក ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ចូរសរសេរគោលដៅមួយដើម្បីជួយអ្នកឲ្យរស់នៅកាន់តែល្អតាមការបង្រៀនទាំងនេះឲ្យបានមួយ ឬច្រើននៅក្នុងគ្រួសាររបស់អ្នក ។

នៅពាក់កណ្ដាលចុងក្រោយនៃឃ្លា ទី ៧ នៃការប្រកាសអំពីគ្រួសារ តើការទទួលខុសត្រូវរបស់ឪពុកមានអ្វីខ្លះ ?

ចូរគិតអំពីរបៀបដែលអ្នកបានមើលឃើញឪពុកអ្នក ឬឪពុកដទៃទៀត បានបំពេញតាមការទទួលខុសត្រូវទាំងនេះ ។

នៅពាក់កណ្ដាលចុងក្រោយនៃឃ្លា ទី ៧ តើការទទួលខុសត្រូវចម្បងរបស់ម្ដាយមានអ្វីខ្លះ ?

ចូរគិតអំពីរបៀបដែលអ្នកបានមើលឃើញអ្នកម្ដាយអ្នក ឬអ្នកម្ដាយដទៃទៀត បានបំពេញតាមតួនាទីនេះ ?

យោងតាមឃ្លា ទី ៧ ទំនួលខុសត្រូវ ឬតួនាទីរបស់ម្ដាយ និងឪពុក គឺ « តាមផែនការរបស់ព្រះ » ។ នេះមានន័យថាការណ៍នេះបង្កើតឡើងដោយព្រះវរបិតាសួគ៌របស់យើង ។ ហេតុអ្វីក៏អ្នកគិតថា កិច្ចការនេះសំខាន់ដើម្បីយល់ដឹង ?

នៅក្នុងឃ្លា ទី ៧ យើងក៏រៀនផងដែរថា **ឪពុក និងម្ដាយមានកាតព្វកិច្ចដើម្បីជួយគ្នាទៅវិញទៅមក ជាដៃគូស្មើភាពគ្នានៅក្នុងការទទួលខុសត្រូវក្នុងគ្រួសាររបស់ពួកគេ។** ចូរគិតអំពីគ្រាដែលអ្នកបានឃើញម្ដាយ និងឪពុកធ្វើការជាមួយគ្នាដើម្បីជួយគ្នាទៅវិញទៅមក ជាដៃគូស្មើភាពគ្នានៅក្នុងទំនួលខុសត្រូវដ៏ពិសិដ្ឋទាំងនេះ ។

ប្រយោគដូចខាងក្រោមមាននៅជិតចុងបញ្ចប់នៃឃ្លាទី ៧ ៖ « អសមត្ថភាព មរណភាព ឬកាលៈទេសៈផ្សេង ៗទៀត អាចនឹងត្រូវសម្របទៅតាមស្ថានភាពចាំបាច់របស់បុគ្គលម្នាក់ ៗ » ។ ព្រះអម្ចាស់បានញាណដឹងអំពីស្ថានភាពទាំងនេះ ហើយទ្រង់ប្រទានពរដល់ឪពុកម្ដាយ និងក្រុមគ្រួសារ នៅពេលពួកគេព្យាយាមដើម្បីបំពេញនូវកាតព្វកិច្ចរបស់ពួកគេដោយអស់ពីសមត្ថភាពរបស់ពួកគេ ។

សូមអានឡើងវិញនូវប្រយោគចុងក្រោយនៃឃ្លាទី ៧ នៃការប្រកាសអំពីគ្រួសារ រួចរកមើលថានរណាផ្សេងទៀតដែលអាចជួយម្ដាយ និងឪពុកនៅក្នុងទំនួលខុសត្រូវរបស់ពួកគេ ។ កូន ៗក៏អាចជួយឪពុកម្ដាយពួកគេបំពេញទំនួលខុសត្រូវបានផងដែរ ។

គ្រប់ក្រុមគ្រួសារមានការលំបាក និងកាលៈទេសៈជាក់លាក់ផ្ទាល់ខ្លួន ប៉ុន្តែគ្រប់ក្រុមគ្រួសារអាចរស់នៅតាមការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ និងរកឃើញសុភមង្គល ។

៥. នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរនូវអ្វីដែលអ្នកថ្លែងអំណរគុណចំពោះឪពុកម្ដាយ ឬ អាណាព្យាបាលរបស់អ្នក ។

សូមអានឃ្លាទី ៨–៩ នៃការប្រកាសអំពីគ្រួសារ រួចរកមើលអ្វីដែលនឹងកើតឡើង ប្រសិនបើយើងពុំបំពេញតាមទំនួលខុសត្រូវរបស់យើងនៅក្នុងក្រុមគ្រួសារយើងទេនោះ ។

គោលការណ៍មួយក្នុងឃ្លាទាំងនេះ បង្រៀនថា **ព្រះអម្ចាស់នឹងធ្វើឲ្យយើងទទួលខុសត្រូវ បើយើងពុំបំពេញតាមទំនួលខុសត្រូវរបស់យើងនៅក្នុងក្រុមគ្រួសារនោះទេ ។** អ្នកអាចនឹងចង់សរសេរសេចក្ដីពិតនេះនៅលើច្បាប់ចម្លងនៃការប្រកាសអំពីគ្រួសាររបស់អ្នក ។

ចូរពិចារណាអំពីរបៀបដែលអ្នកបំពេញទំនួលខុសត្រូវរបស់អ្នកនៅក្នុងគ្រួសាររបស់អ្នក ។ ចូរចងចាំក្នុងការស្វែងរកជំនួយពីព្រះអម្ចាស់ នៅពេលអ្នកធ្វើការឆ្ពោះទៅរកគោលដៅរបស់អ្នក ដើម្បីរស់នៅឲ្យបានកាន់តែប្រសើរតាមការបង្រៀនមួយរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងគ្រួសាររបស់អ្នក ។

៦. សូមសរសេរឃ្លាខាងក្រោមនេះ ពីខាងក្រោមកិច្ចការថ្ងៃនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ៖

*ខ្ញុំបានសិក្សាមេរៀនអំពី « គ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ហើយបានបញ្ចប់មេរៀននេះនៅ* ( កាលបរិច្ឆេទ ) ។

*សំណួរ គំនិត និងការយល់ដឹងបន្ថែម ដែលខ្ញុំចង់ចែកចាយជាមួយគ្រូរបស់ខ្ញុំ ៖*

# ក្រុមគ្រួសារ

## ការប្រកាស ដល់ពិភពលោក

គណៈប្រធានទីមួយ និងក្រុមប្រឹក្សានៃពួកសាវកដប់ពីរនាក់ នៃសាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

យើងជាគណៈប្រធានទីមួយ និងក្រុមប្រឹក្សានៃពួកសាវកដប់ពីរនាក់ នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ សូមប្រកាសជាឧឡារិកថា អាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី គឺត្រូវបានតែងតាំងឡើងដោយព្រះ ហើយថាគ្រួសារជាផ្នែកដ៏សំខាន់មួយ នៅក្នុងផែនការរបស់ព្រះដ៏បង្កបង្កើត សំរាប់គោលដៅដ៏នៅអស់កល្បជានិច្ចនៃកូនចៅរបស់ទ្រង់។

មនុស្សទាំងអស់—ទាំងប្រុសទាំងស្រី—ត្រូវបានបង្កើតឡើងតាមរូបភាពនៃព្រះ។ មនុស្សម្នាក់ៗសុទ្ធតែជាបុត្រា និងបុត្រីខាងវិញ្ញាណរបស់ព្រះមាតាបិតាសួគ៌ ដូច្នេះហើយមនុស្សម្នាក់ៗមានចរិត និងគោលដៅនៃព្រះ។ ភេទប្រុសស្រី គឺជាលក្ខណៈពិសេសនៃអត្តសញ្ញាណ និងគោលបំណងរបស់បុគ្គលម្នាក់ៗ នៅជីវិតមុនផែនដី ជីវិតរមែងស្លាប់ និងនៅអស់កល្បជានិច្ច។

នៅជីវិតមុនផែនដី បុត្រា និងបុត្រីខាងវិញ្ញាណទាំងឡាយបានស្គាល់ ហើយបានថ្វាយបង្គំព្រះជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ចរបស់ពួកគេ ហើយបានទទួលផែនការរបស់ទ្រង់ ដែលនាំឱ្យកូនចៅទាំងឡាយ អាចទទួលរូបកាយ ហើយនឹងទទួលបទពិសោធន៍នៅលើផែនដី ដើម្បីរីកចំរើនទៅរកភាពល្អឥតខ្ចោះ ហើយនៅទីបញ្ចប់ នឹងដឹងពីគោលបំណងដ៏ទេវភាពរបស់ពួកគេ ដោយទទួលជីវិតដ៏នៅអស់កល្បទុកជាមរតក។ ផែនការនៃសុភមង្គលដ៏ទេវភាពនេះ ផ្តល់លទ្ធភាពដល់ទំនាក់ទំនងក្រុមគ្រួសារចេះតែបន្តមានរហូតហួសពីសេចក្តីស្លាប់។ ពិធីបរិសុទ្ធ និងសេចក្តីសញ្ញាពិសិដ្ឋនានា ដែលមាននៅក្នុងព្រះវិហារបរិសុទ្ធ អាចធ្វើឱ្យបុគ្គលម្នាក់ៗត្រឡប់ទៅកាន់វត្តមាននៃព្រះវិញ ហើយដើម្បីឱ្យក្រុមគ្រួសារអាចត្រូវបានរួបរួមគ្នាដ៏អស់កល្បជានិច្ច។

ព្រះបញ្ញត្តិ ទីមួយ ដែលព្រះបានប្រទានដល់លោកអ័ដាម និងនាងអេវ៉ា ទាក់ទងទៅនឹងសមត្ថភាពរបស់ពួកគេ សំរាប់ភាពជាឪពុកម្តាយ ក្នុងនាមជាស្វាមី និងភរិយា។ យើងសូមប្រកាសថា ព្រះបញ្ញត្តិរបស់ព្រះសំរាប់កូនចៅរបស់ទ្រង់ ដើម្បីបង្កើតកូនចៅឱ្យចំរើនជាច្រើនឡើងឱ្យមានពាសពេញលើផែនដី នោះនៅតែឱ្យប្រតិបត្តិនៅឡើយ។ យើងសូមប្រកាសថែមទៀតថា ព្រះបានបញ្ជាថា អំណាចពិសិដ្ឋនៃការបង្កើតកូន គឺត្រូវបានប្រើរវាងតែបុរស និងស្ត្រី ដែលបានរៀបអាពាហ៍ពិពាហ៍យ៉ាងស្របច្បាប់ជាប្តី និងប្រពន្ធប៉ុណ្ណោះ។

យើងសូមប្រកាសថា មធ្យោបាយដើម្បីបង្កើតជីវិតរមែងស្លាប់នេះ គឺត្រូវបានតែងតាំងឡើងដោយព្រះ។ យើងសូមបញ្ជាក់នូវការញែកចេញជាបរិសុទ្ធនៃជីវិត និងសារៈសំខាន់នៃជីវិតនៅក្នុងផែនការដ៏អស់កល្បជានិច្ចរបស់ព្រះ។

ស្វាមី និងភរិយា មានការទទួលខុសត្រូវដ៏ឧឡារិកដើម្បីស្រឡាញ់ និងថែរក្សាគ្នាទៅវិញទៅមក ព្រមទាំងកូនចៅរបស់ខ្លួនផងដែរ។ “កូនចៅជាមរតកពីព្រះយេហូវ៉ា” (ទំនុកដំកើង 127:3)។ ឪពុកម្តាយមានកាតព្វកិច្ចដ៏ពិសិដ្ឋ ដើម្បីចិញ្ចឹមបីបាច់កូនចៅរបស់ខ្លួនដោយក្តីស្រឡាញ់ និងសេចក្តីសុចរិត ផ្គត់ផ្គង់សេចក្តីត្រូវការ ទាំងខាងរូបកាយនិងខាងវិញ្ញាណរបស់ពួកគេ និងបង្រៀនពួកគេឱ្យចេះស្រឡាញ់ និងបំរើគ្នាទៅវិញទៅមក ចេះគោរពព្រះបញ្ញត្តិទាំងឡាយនៃព្រះ ហើយធ្វើជាពលរដ្ឋល្អ ចេះគោរពច្បាប់គ្រប់ទីកន្លែង ដែលពួកគេរស់នៅ។ ស្វាមី និងភរិយា—ម្តាយ និងឪពុក—នឹងទទួលខុសត្រូវនៅចំពោះព្រះភ័ក្ត្រព្រះ តាមការប្រតិបត្តិនៃភារកិច្ចទាំងឡាយនេះ។

ក្រុមគ្រួសារ ត្រូវបានតែងតាំងឡើងដោយព្រះ។ អាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី គឺជាផ្នែកមួយដ៏សំខាន់ក្នុងផែនការដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់។ កូនចៅមានសិទ្ធនឹងទទួលកំណើតមកក្នុងចំណងនៃអាពាហ៍ពិពាហ៍ ហើយនឹងត្រូវបានចិញ្ចឹមបីបាច់ដោយឪពុកម្តាយ ដែលគោរពប្រតិបត្តិតាមសច្ចានៃអាពាហ៍ពិពាហ៍ដោយស្មោះត្រង់ទាំងស្រុង។ សុភមង្គលនៅក្នុងជីវិតគ្រួសារអាចកើតមានឡើងបាន នៅពេលធ្វើតាមការបង្រៀនរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ។ អាពាហ៍ពិពាហ៍ និងគ្រួសារដែលមានជោគជ័យ នោះគឺត្រូវស្ថាបនា និងថែរក្សានៅលើគោលការណ៍នៃសេចក្តីជំនឿ ការអធិស្ឋាន ការប្រែចិត្ត ការអភ័យទោស ការគោរពគ្នា សេចក្តីស្រឡាញ់ សេចក្តីមេត្តាករុណា ការងារ និងកម្មវិធីកំសាន្តល្អៗនានា។ តាមការរៀបចំដ៏ទេវភាពនេះ ឪពុកត្រូវបានចាត់ឱ្យធ្វើជាអ្នកដឹកនាំនៅក្នុងគ្រួសាររបស់ខ្លួន ដោយសេចក្តីស្រឡាញ់ និងសេចក្តីសុចរិត ហើយមានភារកិច្ចក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងជីវិត ព្រមទាំងការពារក្រុមគ្រួសារខ្លួនផង។ ម្តាយមានភារកិច្ចសំខាន់ដើម្បីថែរក្សាបីបាច់កូនចៅរបស់ខ្លួន។ នៅក្នុងការទទួលខុសត្រូវដ៏ពិសិដ្ឋទាំងនេះ ឪពុក និងម្តាយ មានកាតព្វកិច្ចដើម្បីជួយគ្នាទៅវិញទៅមកជាដៃគូស្មើគ្នា។ ពិការភាព មរណភាព ឬកាលៈទេសៈផ្សេងៗទៀត អាចនឹងត្រូវសម្របទៅតាមស្ថានភាពចាំបាច់របស់បុគ្គលម្នាក់ៗ។ ញាតិសន្តានក្រុមគ្រួសារ គួរតែជួយគាំទ្រ នៅពេលមានសេចក្តីត្រូវការ។

យើងសូមព្រមានថា បុគ្គលណាដែលបំពានលើសេចក្តីសញ្ញានៃព្រហ្មចារីភាព ដោយបានធ្វើបាបភរិយា ឬកូនចៅ ឬមិនបានបំពេញការទទួលខុសត្រូវក្នុងគ្រួសារ គង់តែថ្ងៃណាមួយនឹងទទួលខុសត្រូវនៅចំពោះព្រះ។ លើសពីនេះទៅទៀត យើងសូមព្រមានថា ការបែកបាក់នៅក្នុងគ្រួសារនឹងនាំមកនូវមហន្តរាយដល់បុគ្គលនោះ សហគមន៍ និងជាតិសាសន៍ ដូចដែលបានទាយទុកជាមុនដោយពួកព្យាការីសម័យបុរាណ និងពួកព្យាការីសម័យទំនើប។

យើងសូមអំពាវនាវដល់ ប្រជាពលរដ្ឋ និងមន្ត្រីរាជការទាំងឡាយនៅក្នុងរដ្ឋាភិបាល ដែលទទួលខុសត្រូវនៅគ្រប់ទីកន្លែងទាំងអស់ សូមឱ្យគាំទ្រនូវអ្វីៗទាំងនេះ ដែលបានរៀបរាប់ឡើង ដើម្បីទ្រទ្រង់ និងធ្វើឱ្យក្រុមគ្រួសារមាំមួន ដូចជាអង្គភាពមួយដ៏សំខាន់នៃសង្គម។

*ការប្រកាសនេះត្រូវបានអាន ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ជាផ្នែកនៃសារលិខិតរបស់លោក នៅក្នុងការប្រជុំសមាគមសង្គ្រោះទូទៅ ដែលបានធ្វើឡើងនៅថ្ងៃទី 23 ខែ កញ្ញា ឆ្នាំ 1995 នៅក្នុងទីក្រុងសលត៍ លេក រដ្ឋយូថាហ៍។*

សាសនាចក្រនៃ

ព្រះយេស៊ូវគ្រីស្ទ

នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

CAMBODIAN

4 02105 89258 8

10589 258